

# គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ

## សៀវភៅគ្រូបង្រៀនថ្នាក់សិក្ខាសាលា

# សៀវភៅសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ សម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលា

បោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍

សូមថ្លែងអំណរគុណចំពោះយោបល់ និង ការកែលម្អ ។ សូមផ្ញើយោបល់ និង ការកែលម្អទាំងនោះ រួមទាំងកំហុសឆ្គងទាំងឡាយមកកាន់ ៖

Seminaries and Institutes of Religion Curriculum Services
50 East North Temple Street
Salt Lake City,  UT  84150–0008
USA
អ៊ីម៉ែល ៖ ces–manuals@ldschurch.org

សូមសរសេរឈ្មោះពេញ អាសយដ្ឋានរួជ និងស្ដេករបស់អ្នក ។

សូមកុំភ្លេចសរសេរចំណងជើងសៀវភៅសិក្សានោះ ។ បន្ទាប់មក សូមផ្ដល់មតិយោបល់របស់អ្នក ។

© 2013 by Intellectual Reserve, Inc ។
All rights reserved.
បោះពុម្ពនៅសហរដ្ឋអាមេរិក
កំណែថ្មីទី ២ ៧/១៧

អនុមតិជាភាសាអង់គ្លេស ៖ ៨/១២
អនុមតិការបកបកប្រែ ៖ ៨/១២
ការបកប្រែនៃ *Doctrine and Covenants and Church History Seminary Teacher Manual*
Cambodian
10590 258

# មាតិកា


បុព្វកថានៃសៀវភៅសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលា . . . . . . x

ផែនការនៃសេចក្ដីសង្គ្រោះ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១

បុព្វកថាព្រះគម្ពីរគោលលទ្ធិ និងសេចក្តីសញ្ញា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦

ការក្បត់សាសនាដ៏ធំ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩

គោលលទ្ធិ និង សេចក្ដីសញ្ញា ១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៣

ការសិក្សាព្រះគម្ពីរ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៦

ផែនការនៃសេចក្ដីសង្គ្រោះ–ការសិក្សាព្រះគម្ពីរ ( មេរៀនទី ១ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២០

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៤

តួនាទីរបស់សិស្ស . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៨

យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:២១–២៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៣២

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–៥៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ២ . . . . . . . . . . . . . . . . . . . . . . . . . . . ៣៥

យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៥៥–៥៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤០

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–៦៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ២ ( មេរៀនទី ២ ) . . . . . . . . . . . . . . . . . . . . ៤៤

គោលលទ្ធិ និង សេចក្ដីសញ្ញា ៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៨

គោលលទ្ធិ និង សេចក្ដីសញ្ញា១០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥២

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៥

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៩

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧ . . . . . . . . . . . . . . . . . . . . . . . . . . ៦៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ៣–៧; ១០; យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៦–៦៧ ( មេរៀនទី ៣ ) . . . . . . . . . . . . . . ៦៧

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧០

គោលលទ្ធិ និង សេចក្ដីសញ្ញា ៩ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៤

គោលលទ្ធិ និង សេចក្ដីសញ្ញា១១:–១២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៨

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ១:៦៨–៧៥,គោលលទ្ធិ និង សេចក្ដីសញ្ញា១៣ . . . . . . . . . . . . . . . . . . . . . . . . . . . ៨១

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៨៥

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩; ១១–១៦; យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៨–៧៥ ( មេរៀនទី ៤ ) . . . . . . . . . . . ៨៩

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១–១៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩៧

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១៧–៤៧ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០០

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០៤

គោលលទ្ធិ និងសេចក្ដីសញ្ញា ១៩:២៣–៤១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០៨

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧–១៩ ( មេរៀនទី ៥ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១១២

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១១៦

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១២០

គោលលទ្ធិ និង សេចក្តីសញ្ញា ១២២:៦៨–៨៤ . . . . . . . . . . ១២៤

គោលលទ្ធិ និង សេចក្តីសញ្ញា ២១ . . . . . . . . . . ១២៨

គោលលទ្ធិ និង សេចក្តីសញ្ញា ២២– ២៣ . . . . . . . . . . ១៣២

គោលលទ្ធិ និង សេចក្តីសញ្ញា ២០–២៣ ( មេរៀនទី ៦ ) . . . . . . . . . . ១៣៥

គោលលទ្ធិ និង សេចក្តីសញ្ញា ២៤ និង ១២៦ . . . . . . . . . . ១៣៨

គោលលទ្ធិ និង សេចក្តីសញ្ញា ២៥ . . . . . . . . . . ១៤២

គោលលទ្ធិ និង សេចក្តីសញ្ញា ២៧ . . . . . . . . . . ១៤៦

គោលលទ្ធិ និង សេចក្តី សញ្ញា ២៨ . . . . . . . . . . ១៥២

គោលលទ្ធិ និង សេចក្តីសញ្ញា ២៩:១–២៩ . . . . . . . . . . ១៥៦

គោលលទ្ធិ និង សេចក្តីសញ្ញា ២៤–២៩:៣០ ( មេរៀនទី ៧ ) . . . . . . . . . . ១៦០

គោលលទ្ធិ និង សេចក្តីសញ្ញា ២៩:៣០–៥០ . . . . . . . . . . ១៦៤

គោលលទ្ធិ និង សេចក្តីសញ្ញា ៣០ . . . . . . . . . . ១៦៨

គោលលទ្ធិ និង សេចក្តីសញ្ញា ៣១–៣២ . . . . . . . . . . ១៧១

គោលលទ្ធិ និង សេចក្តីសញ្ញា ៣៣–៣៤ . . . . . . . . . . ១៧៥

គោលលទ្ធិ និង សេចក្តីសញ្ញា ៣៥ . . . . . . . . . . ១៧៩

គោលលទ្ធិ និង សេចក្តីសញ្ញា ២៩:៣១–៥០; ៣០–៣៥ ( មេរៀនទី ៨ ) . . . . . . . . . . ១៨៣

គោលលទ្ធិ និង សេចក្តីសញ្ញា ៣៦–៣៧ . . . . . . . . . . ១៨៧

គោលលទ្ធិ និង សេចក្តីសញ្ញា ៣៨:១–១៦ . . . . . . . . . . ១៩១

គោលលទ្ធិ និង សេចក្តីសញ្ញា ៣៨:១៧–៤២ . . . . . . . . . . ១៩៥

គោលលទ្ធិ និង សេចក្តីសញ្ញា ៣៩–៤០ . . . . . . . . . . ១៩៩

នៅរដ្ឋ អូហៃអូ . . . . . . . . . . ២០៣

គោលលទ្ធិ និង សេចក្តីសញ្ញា ៣៦–៤០; នៅរដ្ឋអូហៃអូ ( មេរៀនទី ៩ ) . . . . . . . . . . ២០៧

គោលលទ្ធិ និង សេចក្តីសញ្ញា ៤១ . . . . . . . . . . ២១១

គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:១–២៩ . . . . . . . . . . ២១៥

គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៣០–៤២ . . . . . . . . . . ២១៩

គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៤៣–៩៣ . . . . . . . . . . ២២៣

គោលលទ្ធិ និង សេចក្តីសញ្ញា ៤៣–៤៤ . . . . . . . . . . ២២៧

គោលលទ្ធិ និង សេចក្តីសញ្ញា ៤១–៤៤ ( មេរៀនទី ១០ ) . . . . . . . . . . ២៣១

គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:១–១៥ . . . . . . . . . . ២៣៥

គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:១៦–៥៩ . . . . . . . . . . ២៣៩

គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:៦០–៧៥ . . . . . . . . . . ២៤៤

គោលលទ្ធិ និង សេចក្តីសញ្ញា ៤៦ . . . . . . . . . . ២៤៨

គោលលទ្ធិ និង សេចក្តីសញ្ញា ៤៧–៤៨ . . . . . . . . . . ២៥២

គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥–៤៨ មេរៀនទី ១១ . . . . . . . . . . ២៥៦

គោលលទ្ធិ និង សេចក្តី សញ្ញា ៤៩ . . . . . . . . . . ២៦០

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ . . . . ២៦៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១–៥២ . . . . ២៦៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៥ . . . . ២៧២
គោលលទ្ធិ និង សេចក្ដី សញ្ញា ៥៦ . . . . ២៧៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩–៥៦ ( មេរៀនទី ១២ ) . . . . ២៨០
កន្លែងកណ្ដាលនៃស៊ីយ៉ូន . . . . ២៨៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ . . . . ២៨៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–៣៣ . . . . ២៩១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៤–៦៥ . . . . ២៩៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ . . . . ២៩៩
កន្លែងកណ្ដាលនៃស៊ីយ៉ូន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧–៥៩ ( មេរៀនទី ១៣ ) . . . . ៣០៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២ . . . . ៣០៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១–២១ . . . . ៣១១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២២–៦៦ . . . . ៣១៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩ . . . . ៣១៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣ . . . . ៣២៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦៤ ( មេរៀនទី ១៤ ) . . . . ៣២៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ . . . . ៣៣១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦ . . . . ៣៣៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧ . . . . ៣៣៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨ . . . . ៣៤២
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១ . . . . ៣៤៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៧១ ( មេរៀនទី ១៥ ) . . . . ៣៥០
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៤ . . . . ៣៥៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ . . . . ៣៥៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–១៩ . . . . ៣៦២
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–៤៩ . . . . ៣៦៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០ . . . . ៣៧០
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៦:៨០ ( មេរៀនទី ១៦ ) . . . . ៣៧៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩ . . . . ៣៧៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ . . . . ៣៨២
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨–៨០ . . . . ៣៨៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ . . . . ៣៨៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២–៨៣ . . . . ៣៩៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧–៨៣ ( មេរៀនទី ១៧ ) . . . . ៣៩៧

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤០១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–៦១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤០៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦២–១២០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤០៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤១៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤១៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤–៨៧ ( មេរៀនទី ១៨ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤២១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–៤០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤២៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៦៩. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤២៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១១៧ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៣៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១៤១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៣៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៤១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨–៨៩ ( មេរៀនទី ១៩ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៤៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៤៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–២០. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៥៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–៥៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៥៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៦១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៦៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩៧ ( មេរៀនទី ២០ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៦៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–២២. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៧៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៣–៤៨ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៧៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៨១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៨៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៨៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨–១០១:៤២ ( មេរៀនទី ២១ ). . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៩៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៩៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥០១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥០៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥០៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥១៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២–១០៥ ( មេរៀនទី ២២ ). . . . . . . . . . . . . . . . . . . . ៥១៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:១–១០៧:២០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥២១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥២៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥២៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៣៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៣៦

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦–១០៨; ១៣៧ ( មេរៀនទី ២៣ ) . . . . . . . . . . . . . . . . . . . . . . . . . . .៥៤១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១–៤៦. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៤៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៨០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៤៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៥២
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៥៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៦១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩–១១២ ( មេរៀនទី ២៤ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៦៥
សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៦៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១១៤. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៧៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥–១១៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៧៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–១១៨. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៨២
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩–១២០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៨៦
សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១២០ ( មេរៀនទី ២៥ ) . . . . .៥៩០
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៩៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៩៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦០២
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦០៦
ការកសាងទីក្រុង ណៅវូ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦១០
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣ការស្ថាបនាទីក្រុងណៅវូ ( មេរៀនទី ២៦ ) . . . . . . . . . . . . . . . . .៦១៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–២១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦១៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២២–៨៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦២៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–១២៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦២៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៣១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៣៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤–១២៨ ( មេរៀនទី ២៧ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៣៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៤៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៤៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦៥១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣–៣៣. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦៥៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–២, ៣៤–៦៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦៥៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩–១៣១; ១៣២:១–៣៣ ( មេរៀនទី ២៨) . . . . . . . . . . . . . . . . . . . . . . ៦៦៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៦៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៧៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៧១
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៧៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ ភាគ ១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៧៩

គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៥ ភាគ ២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦៨៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣–១៣៥ ( មេរៀនទី ២៩ ) . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៨៧
ការស្វែងតំណែងបន្តនៅក្នុងគណៈប្រធានទីមួយ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦៩១
ការចាកចេញពីទីក្រុងណៅវូ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៦៩៦
មេរៀនទី ១៤៨ ៖ ការធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨ . . . . . . . . . . . ៧០១
គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៦:១៩–៤២. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧០៥
ក្រុមអ្នកត្រួសត្រាយរទេះអូស ឆ្នាំ ១៨៥៦–១៨៦០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧០៩
ការស្វែងតំណែងបន្តនៅក្នុងគណៈប្រធាន ការចាកចេញពីទីក្រុងណៅវូ និង ការធ្វើដំណើរទៅទិសខាងលិច ( មេរៀនទី ៣០ ). . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧១៤
សង្គ្រាមនៅយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧១៨
ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៧២៣
សេចក្ដីប្រកាសជាផ្លូវការទី ១និងការអភិវឌ្ឍកិច្ចការព្រះវិហារបរិសុទ្ធជាបន្តបន្ទាប់. . . . . . . . . . . . . . . . . . . . . ៧២៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–២៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៧៣២
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៧–៦០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៣៦
សង្គ្រាមនៅយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា សេចក្ដីប្រកាសជាផ្លូវការទី ១, និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ ( មេរៀនទី ៣១ ) . . . . . . . . . . ៧៤០
កម្មវិធី និងអង្គការសាសនាចក្រ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៤៤
សេចក្ដីប្រកាសជាផ្លូវការទី ២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៤៨
ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៥២
ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៥៧
ព្យាការីនៅរស់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៦១
កម្មវិធី និង អង្គការសាសនាចក្រ សេចក្ដីប្រកាសជាផ្លូវការទី ២, ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ, ការប្រកាសអំពីក្រុមគ្រួសារ និង ព្យាការីនៅរស់ ( មេរៀនទី ៣២ ) . . . . . . . . . . . . . . . . . . . . . . . . . . ៧៦៤
ឧបសម្ព័ន្ធ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៦៩
តារាងអានព្រះគម្ពីរ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៧៧០
ការណែនាំពីល្បឿនបង្រៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៧១
យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៧៧៨
ការណែនាំពីល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនមេរៀននៅផ្ទះ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៨០
ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៨៥

# បុព្វកថានៃសៀវភៅសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ សម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលា

## គោលបំណងរបស់យើង

គោលបំណងរបស់ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនា ៖

« គោលបំណងរបស់យើងគឺ ដើម្បីជួយយុវវ័យ និង យុវមជ្ឈិមវ័យឲ្យយល់ និង ពឹងផ្អែកលើការបង្រៀន និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ឲ្យមានភាពសក្ដិសមសម្រាប់ពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ ហើយរៀបចំខ្លួន ក្រុមគ្រួសាររបស់ពួកគេ និង អ្នកដទៃទៀត សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ជាមួយនឹងព្រះវរបិតារបស់ពួកគេដែលគង់នៅឋានសួគ៌ » ។

ដើម្បីសម្រេចបាននូវគោលលបំណងរបស់យើង នោះយើងបង្រៀនសិស្សអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ដូចដែលមាននៅក្នុងព្រះគម្ពីរ និង ពាក្យសម្ដីរបស់ព្យាការីទាំងឡាយ ។ គោលលទ្ធិ និង គោលការណ៍ទាំងនេះគឺត្រូវបានបង្រៀនតាមរបៀបមួយដែលដឹកនាំឲ្យមានការយល់ដឹង និង ការស្អាងឡើង ។ យើងជួយសិស្សទាំងឡាយ ឲ្យបំពេញតួនាទីរបស់ពួកគេនៅក្នុងដំណើរការនៃការរៀនសូត្រ និង រៀបចំពួកគេឲ្យបង្រៀនដំណឹងល្អដល់អ្នកដទៃទៀត ។

ដើម្បីជួយសម្រេចបានគោលបំណងទាំងនេះ នោះអ្នក និង សិស្សដែលអ្នកបង្រៀនត្រូវបានលើកទឹកចិត្តឲ្យសហការ ធ្វើតាមមូលដ្ឋានគ្រឹះនៃការបង្រៀន និង ការរៀនដំណឹងល្អ នៅពេលអ្នកសិក្សាព្រះគម្ពីររួមគ្នាដូចខាងក្រោម ៖

- បង្រៀន និង រៀនសូត្រដោយព្រះវិញ្ញាណ ។
- បង្កើតបរិយាកាសរៀនសូត្រដែលពោរពេញដោយសេចក្ដីស្រឡាញ់ ការគោរព និង មានគោលបំណង ។
- សិក្សាព្រះគម្ពីរ និង អានមេរៀននៃវគ្គសិក្សារៀងរាល់ថ្ងៃ ។ ( តារាងសម្រាប់តាមដានការអានព្រះគម្ពីរ អាចរកបាននៅក្នុងឧបសម្ព័ន្ធនៅខាងចុងនៃសៀវភៅសិក្សានេះនៅគេហទំព័រ LDS.org, និង store.lds.org [ សៀវភៅលេខ ១០៤៩៤ ] ) ។
- យល់ពីបរិបទ និង មាតិកានៃព្រះគម្ពីរ ព្រមទាំងពាក្យសម្ដីរបស់ព្យាការីទាំងឡាយ ។
- ស្វែងរក យល់ ដឹងពីសេចក្ដីពិត និង សារៈសំខាន់នៃដំណឹងល្អ ហើយអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។
- ពន្យល់ ចែកចាយ និង ថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។
- ចាំស្ទាត់នូវខគម្ពីរសំខាន់ៗ និង គោលលទ្ធិគ្រឹះទាំងឡាយ។

សៀវភៅសម្រាប់គ្រូបង្រៀននេះបានរៀបចំឡើង ដើម្បីជួយដល់អ្នកឲ្យទទួលបានជោគជ័យក្នុងការសម្រេចនូវគោលបំណងទាំងនេះ ។

## កម្មវិធីសិក្សារបស់យុវវ័យនៅថ្នាក់សិក្ខាសាលា និង នៅថ្ងៃអាទិត្យ

*ការជួយយុវវ័យឲ្យកាន់តែប្រែចិត្តជឿចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ*



### ការរួមបញ្ចូលគ្នា

គណៈប្រធានទីមួយបានអំពាវនាវឪពុកម្ដាយ គ្រូបង្រៀន និង ថ្នាក់ដឹកនាំឲ្យ « យុវវ័យឲ្យដំណឹងល្អតាមរយៈការសិក្សា និង

សេចក្ដីជំនឿផ្ទាល់ខ្លួនពួកគេ រកឃើញភាពពោរពេញនៃសេចក្ដីពិតអំពីដំណឹងល្អសម្រាប់ខ្លួនពួកគេ ហើយពង្រឹងគ្រួសាររបស់ពួកគេ និង មនុស្សដទៃតាមរយៈការចែកចាយបទពិសោធន ការយល់ដឹង និង ទីបន្ទាល់របស់ខ្លួន » ។ ការធ្វើដូច្នេះនឹងជួយពួកគេឲ្យធ្វើតាមផ្លូវដែល « នឹងនាំពួកគេឲ្យប្រែចិត្តជឿ » (*Teaching the Gospel in the Savior's Way* [ ឆ្នាំ ២០១២ ] ទំព័រ ២ ) ។

នៅក្រោមការដឹកនាំបព្វជិតភាពអង្គការ យុវជន យុវនារី សាលាថ្ងៃអាទិត្យ និង ថ្នាក់សិក្ខាសាលា ធ្វើការសហការគ្នាដោយបានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីជួយយុវវ័យឲ្យសម្រេចបាននូវគោលបំណងទាំងនេះ ។ ខណៈដែលអង្គការនិមួយៗមានតួនាទីពិសេសក្នុងការពង្រឹងយុវវ័យ នោះគោលបំណងសំខាន់នៃកម្មវិធីសិក្សាទាំងអស់របស់យុវវ័យគឺដើម្បីដឹកនាំយុវវ័យឆ្ពោះទៅកាន់ព្រះអង្គសង្គ្រោះ ហើយនាំឲ្យមានការប្រែចិត្តជឿលើដំណឹងល្អរបស់ទ្រង់ ។ កម្មវិធីសិក្សាសម្រាប់អង្គការយុវវ័យនិមួយៗគឺត្រូវបានរៀបចំឡើងដើម្បីធ្វើការឲ្យស៊ីសង្វាក់គ្នាជាមួយនឹងអង្គការយុវវ័យដទៃទៀត ។ ឧទាហរណ៍ ៖

- « Teaching in the Savior's Way » ( គឺជាការបោះពុម្ពដែលបានជ្រើសរើសទាំងមេរៀនសម្រាប់ថ្នាក់សិក្ខាសាលា និង កម្មវិធីសិក្សារបស់យុវវ័យនៅថ្ងៃអាទិត្យ ) ត្រូវបានដាក់បញ្ចូលគ្នាដោយអង្គការយុវវ័យ ដើម្បីជួយគ្រូបង្រៀន ឪពុកម្ដាយ និង ថ្នាក់ដឹកនាំរៀនអំពីរបៀបដែលព្រះអង្គសង្គ្រោះបានបង្រៀន ( សូមមើល *ការបង្រៀន និង ការរៀនសូត្រដំណឹងល្អ ៖ ក្បួនខ្នាតណែនាំសម្រាប់គ្រូបង្រៀន និង ថ្នាក់ដឹកនាំនៅក្នុងថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនា* [ ឆ្នាំ ២០១២ ] ទំព័រ v–vii *Teaching the Gospel in the Savior's Way* [ ឆ្នាំ ២០១២ ] ទំព័រ ៤–៥ ) ។ « Teaching in the Savior's Way » បង្ហាញពីរបៀបដែលព្រះអង្គសង្គ្រោះបានជួយមនុស្សដទៃវិភាគឲ្យស៊ីជម្រៅអំពីសេចក្ដីពិតដ៏ពិសិដ្ឋដែលទ្រង់បានបង្រៀនតាមរយៈការលើកទឹកចិត្តពួកគេឲ្យអនុវត្តដោយសេចក្ដីជំនឿ ហើយធ្វើការយ៉ាងសកម្មនៅក្នុងដំណើរការរៀនសូត្រ ។ គោលការណ៍នៃការបង្រៀន និង ការរៀនសូត្រដំណឹងល្អទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសម្រាប់អង្គការយុវវ័យទាំងអស់ ។

- កម្មវិធីសិក្សាសម្រាប់អង្គការយុវវ័យទាំងអស់ សង្កត់ធ្ងន់លើគោលលទ្ធិគ្រឹះដូចគ្នានេះផងដែរ ។ គោលលទ្ធិគ្រឹះបានសង្កត់ធ្ងន់នៅក្នុងកម្មវិធីសិក្សាថ្នាក់សិក្ខាសាលាដែលត្រូវនឹង គោលការណ៍នៃគោលលទ្ធិគ្រឹះ ដែលបានបង្រៀននៅក្នុងកម្មវិធីសិក្សារបស់យុវវ័យ ។ នៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យនានា កម្មវិធីសិក្សារបស់យុវវ័យផ្ដោតលើគោលលទ្ធិទាំងនេះរៀងរាល់ខែ ។ នៅក្នុងថ្នាក់សិក្ខាសាលា គោលលទ្ធិទាំងនេះត្រូវបានសង្កត់ធ្ងន់ នៅពេលយុវវ័យសិក្សាបទដ្ឋានព្រះគម្ពីរនិមួយៗ ។ ការរួមបញ្ចូលគ្នានេះជួយពង្រឹងសេចក្ដីពិតដែលយុវវ័យបានរៀននៅថ្ងៃអាទិត្យ ជាមួយនឹងអ្វីដែលពួកគេកំពុងរៀននៅក្នុងថ្នាក់សិក្ខាសាលា ហើយដូចគ្នាផងដែរនឹងអ្វីដែលយុវវ័យរៀននៅក្នុងថ្នាក់សិក្ខាសាលានឹងជួយពង្រឹងពួកគេនូវអ្វីដែលពួកគេរៀននៅថ្ងៃអាទិត្យផងដែរ ។ ការសង្កត់ធ្ងន់លើគោលលទ្ធិខ្លឹមដូចគ្នានេះនៅក្នុងកម្មវិធីសិក្សាទាំងអស់របស់យុវវ័យ ធ្វើឲ្យមានបទពិសោធន៍កាន់តែល្អឥតខ្ចោះសម្រាប់យុវវ័យ គ្រូបង្រៀន និង ឪពុកម្ដាយ ។

- កម្មវិធីសិក្សាសម្រាប់អង្គការនិមួយៗត្រូវបានរៀបចំឡើង ដើម្បីជួយយុវវ័យឲ្យពង្រីកការយល់ដឹង និង ទីបន្ទាល់របស់ពួកគេកាន់តែជ្រៅជ្រះ អំពីដំណឹងល្អ ព្រមទាំងរៀនពីរបៀបដើម្បីបង្រៀនវាដល់អ្នកដទៃ ។ ដើម្បីសម្រេចបាននូវលទ្ធផលនេះ ទាំងមេរៀនថ្នាក់សិក្ខាសាលា និង កម្មវិធីសិក្សារបស់យុវវ័យគឺមានបំណងជួយយុវវ័យ ឲ្យអនុវត្តនូវតួនាទីរបស់ខ្លួនឲ្យកាន់តែសកម្មឡើងក្នុងនាមជាអ្នកសិក្សាដំណឹងល្អ ស្វែងរកសេចក្ដពិតនៃដំណឹងល្អសម្រាប់ខ្លួនពួកគេ ហើយពន្យល់ចែកចាយ និង ថ្លែងទីបន្ទាល់អំពីសេចក្ដីពិតទាំងនេះទៅកាន់មនុស្សដទៃទៀត ។

- អស់អ្នកដែលត្រូវបានហៅឲ្យបង្រៀននៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ យុវជន យុវនារី ឬ ថ្នាក់សិក្ខាសាលា នឹងអាចមើលឃើញពីវិធីសាស្ត្រដែលស្រដៀងគ្នានេះដើម្បីបង្រៀន និង រៀនដំណឹងល្អ ។ ទាំងមេរៀនថ្នាក់សិក្ខាសាលា និង កម្មវិធីសិក្សាយុវវ័យផ្ដោតលើការជួយយុវវ័យឲ្យពង្រីកការប្រែចិត្តជឿរបស់ពួកគេឲ្យកាន់តែជ្រាលជ្រៅ ។ ជាលទ្ធផលនៃគោលបំណងដែលបានចែកចាយនេះ មានឯកសារបំពាក់បំប៉ន និង ប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានបង្កើតឡើងសម្រាប់គ្រូបង្រៀន ប្រើប្រាស់កម្មវិធីសិក្សាថ្ងៃអាទិត្យរបស់យុវវ័យដែលបានចែកចាយដោយថ្នាក់សិក្ខាសាលា និង រួមមាននៅលើគេហទំព័រ LDS.org។

## លក្ខណៈពិសេសៗ

អង្គការយុវវ័យនិមួយៗមានតួនាទីពិសេស ក្នុងការជួយយុវវ័យឲ្យកាន់តែប្រែចិត្តជឿចំពោះដំណឹងល្អ ( សូមមើល *Teaching the Gospel in the Savior's Way*, ទំព័រ ១២–១៣ ) ។ ឧទាហរណ៍ កម្មវិធីសិក្សាដែលបានប្រើនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ យុវជន និង យុវនារីផ្ដោតលើគោលការណ៍នៃគោលលទ្ធិគ្រឹះមួយជារៀងរាល់ខែ ។ ផ្ទុយទៅវិញ សិស្សនៅក្នុងថ្នាក់សិក្ខាសាលារៀនគោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អ នៅពេលពួកគេសិក្សាបទដ្ឋានព្រះគម្ពីរតាំងពីដើមរហូតដល់ចប់ ។

តាមរយៈការសិក្សាដំណឹងល្អ តាមប្រធានបទនៅក្នុងថ្នាក់ថ្ងៃអាទិត្យ នោះយុវវ័យអាចធ្វើឲ្យការយល់ដឹងរបស់ខ្លួនអំពីគោលលទ្ធិជាក់លាក់នានាកាន់តែជ្រាលជ្រៅ តាមរយៈការរកមើលលក្ខណៈខុសៗគ្នានៃសេចក្ដីពិតទាំងនោះ និង ការបង្រៀនគោលលទ្ធិទាំងនោះដល់គ្នាទៅវិញទៅមក ។ នៅក្នុងថ្នាក់សិក្ខាសាលាយុវវ័យអាចឃើញ និង យល់នូវគោលលទ្ធិដូចគ្នាទាំងនោះ នៅក្នុងបរិបទដែលទាក់ទងនឹងសេចក្ដពិតនៅក្នុងព្រះគម្ពីរ ហើយមើលឃើញពីគោលលទ្ធិទាំងនោះបង្ហាញនៅក្នុងជីវិត និង ការបង្រៀនរបស់បុគ្គលម្នាក់ៗនៅក្នុងព្រះគម្ពីរ ។ លើសពីនេះទៀត តាមរយៈការសិក្សាព្រះគម្ពីរតាំងពីដើមរហូតដល់ចប់ នោះយុវវ័យអាច

រីកចម្រើនលើទំនុកចិត្តរបស់ខ្លួនថា « ព្រះវរបិតាសួគ៌កំពុងមានព្រះបន្ទូលយ៉ាងពិតប្រាកដទៅកាន់ពួកគេតាម រយៈព្រះគម្ពីរ និង [ ទទួលបាន ] ទំនុកចិត្តដែលពួកគេអាចបែរទៅអានព្រះគម្ពីរ ហើយស្វែងរកចម្លើយចំពោះបញ្ហា និង ការអធិស្ឋាននានារបស់គេ » ( ហារ៉ើដ ដបុលយូ ហ៊ីនឃើរ « Eternal Investments » [ address to Church Educational System religious educators ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ [ ១៩៨៩ ] ទំព័រ ២ គេហទំព័រ LDS.org ) ។ យុវវ័យក៏នឹងកាន់តែយល់ដឹងជាមួយព្រះគម្ពីរ ដូច្នេះពួកគេអាចប្រើវាយ៉ាងមានប្រសិទ្ធិភាព ក្នុងពេលខាងមុខក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា អ្នកដឹកនាំ និង ឪពុកម្ដាយ ។ របៀបទាំងពីរនៃការសិក្សាគោលលទ្ធិនៃដំណឹងល្អធ្វើការរួមគ្នា ដើម្បីជួយយុវវ័យឲ្យពង្រីកការយល់ដឹងរបស់ពួកគេអំពីដំណឹងល្អ ហើយរៀបចំពួកគេដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ។

## ការរៀបចំមេរៀន

ព្រះអម្ចាស់បានបញ្ជាដល់អស់អ្នកដែលបង្រៀនដំណឹងល្អរបស់ទ្រង់ឲ្យ « បង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរប៊ីប និង ព្រះគម្ពីរមរមន គឺជាភាពពោរពេញនៃដំណឹងល្អ » (គ. និង ស. ៤២:១២) ។ ទ្រង់បានត្រាស់បង្គាប់បន្ថែមទៀតថា សេចក្ដីពិតទាំងនេះគួរតែត្រូវបានបង្រៀនដូចដែល « ត្រូវបានដឹកនាំពីព្រះវិញ្ញាណ » ដែល « ត្រូវបានប្រទានដល់អ្នក . . . ដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ » (គ. និង ស. ៤២:១៣–១៤) ។ នៅពេលរៀបចំមេរៀននិមួយៗ សូមអធិស្ឋានស្វែងរកការដឹកនាំពីព្រះវិញ្ញាណ ដើម្បីជួយអ្នកយល់ព្រះគម្ពីរ និង គោលលទ្ធិ ព្រមទាំងគោលការណ៍នានាដែលមាននៅក្នុងគម្ពីរ ។ ដូចគ្នានេះផងដែរ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណ នៅពេលដាក់ផែនការពីរបៀបដើម្បីជួយសិស្សឲ្យយល់ពីបទគម្ពីរ ដែលត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ និង ទទួលមានឆន្ទៈដើម្បីអនុវត្តអ្វីដែលពួកគេរៀន ។

នៅក្នុងវគ្គសិក្សានេះ គោលលទ្ធិ និង សេចក្ដីសញ្ញាគឺជាអត្ថបទចម្បងរបស់អ្នក នៅពេលអ្នករៀបចំ និង បង្រៀន ។ សូមសិក្សាកណ្ឌ ឬ ខគម្ពីរនានាដែលអ្នកនឹងបង្រៀនដោយការអធិស្ឋាន ។ សូមព្យាយាមយល់ពីបរិបទ និង មាតិកានៃបណ្ដុំបទគម្ពីរ រួមទាំងខ្សែរឿង មនុស្ស ទីកន្លែង និង ព្រឹត្តិការណ៍នានា ។ នៅពេលអ្នកកាន់តែស្គាល់បរិបទ និង មាតិកានៃបណ្ដុំបទគម្ពីរនិមួយៗ នោះសូមព្យាយាមស្វែងរកគោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងខគម្ពីរនោះ ហើយសម្រេចចិត្តថាសេចក្ដីពិតណាមួយដែលសំខាន់សម្រាប់សិស្សរបស់អ្នកដើម្បីយល់ ហើយអនុវត្តវានោះ ។ កាលណាអ្នកបានរកឃើញ អ្វីដែលផ្ដោតចិត្តទុកដាក់ហើយនោះ នោះអ្នកអាចសម្រេចពីវិធីសាស្ត្រ យុទ្ធសាស្ត្រ និង សកម្មភាពណាមួយដែលជួយសិស្សរបស់អ្នកបានល្អបំផុតឲ្យរៀន និង អនុវត្តសេចក្ដីពិតដ៏ពិសិដ្ឋដែលមាននៅក្នុងព្រះគម្ពីរ ។

សៀវភៅសិក្សានេះ ត្រូវបានរៀបចំឡើងដើម្បីជួយអ្នកក្នុងដំណើរការនេះ ។ សូមរំឭកមេរៀនដោយយកចិត្តទុកដាក់ ឲ្យស្រប ទៅនឹងបណ្ដុំបទគម្ពីរដែលអ្នកនឹងបង្រៀន ។ អ្នកអាចជ្រើសប្រើប្រាស់យោបល់ណែនាំទាំងអស់ ឬមួយចំនួនសម្រាប់បណ្ដុំបទគម្ពីរ ឬ អ្នកអាចសម្របសម្រួលទៅតាមគំនិត ដែលបានណែនាំទៅតាមតម្រូវការ និង ស្ថានភាពសិស្សដែលអ្នកបង្រៀន ។

វាសំខាន់ថា អ្នកជួយសិស្សឲ្យសិក្សាបណ្ដុំបទគម្ពីរទាំងមូលនៅក្នុងមេរៀននីមួយៗ ។ ការធ្វើដូច្នេះនឹងជួយសិស្សឲ្យចាប់យកសារលិខិតពេញលេញ ដែលអ្នកសរសេរព្រះគម្ពីរមានបំណងចង់បង្ហាញ ។ ប៉ុន្តែ នៅពេលអ្នកគ្រោងមេរៀនរបស់ខ្លួន អ្នកអាចរកឃើញថា អ្នកពុំមានពេលគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន ដើម្បីប្រើគ្រប់អស់ទាំងយោបល់នៃការបង្រៀននៅក្នុងសៀវភៅសិក្សានេះឡើយ ។ សូមស្វែងរកការណែនាំពីព្រះវិញ្ញាណ ហើយពិចារណាដោយការអធិស្ឋានអំពីតម្រូវការនៃសិស្សរបស់អ្នក នៅពេលអ្នកសម្រេចចិត្តដើម្បីបញ្ជាក់អត្ថន័យលើផ្នែកណាមួយនៃបណ្ដុំបទគម្ពីរ ដើម្បីជួយសិស្សឲ្យទទួលអារម្មណ៍នៃសេចក្ដីពិត និង សារៈសំខាន់របស់សេចក្ដីពិតនៃដំណឹងល្អ ហើយអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ។ ប្រសិនបើពេលវេលាខ្លី អ្នកត្រូវតែសម្របសម្រួលផ្នែកដទៃទៀតនៃមេរៀន ដោយសង្ខេបក្រុមខគម្ពីរនោះឲ្យខ្លី ឬ តាមរយៈការនាំសិស្សឲ្យរកឃើញគោលការណ៍ ឬ គោលលទ្ធិមួយយ៉ាងលឿន ពីមុនបន្តទៅក្រុមខគម្ពីរបន្ទាប់ទៀត ។

នៅពេលអ្នកពិចារណាអំពីរបៀបដើម្បីសម្របសម្រួលមេរៀន សូមប្រាកដថាបានធ្វើតាមការប្រឹក្សានេះ ពីអែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ខ្ញុំស្ដាប់ឮប្រធាន ផាកកឺ បានបង្រៀនជាញឹកញាប់ថា ដំបូងយើងត្រូវទទួលយក បន្ទាប់មកសម្រប តាមវា ។ ប្រសិនបើយើងចេះច្បាស់នៅក្នុងមេរៀនដែលបានពិពណ៌នា ដែលយើងត្រូវបង្រៀន នោះ យើងអាចធ្វើតាមព្រះវិញ្ញាណដើម្បីកែសម្រួលវា » (A Panel Discussion with Elder Dallin H. Oaks » Seminaries and Institutes of Religion satellite broadcast ថ្ងៃទី ៧ ខែ សីហា ឆ្នាំ [ ២០១២ ] គេហទំព័រ sis.lds.org

នៅពេលអ្នករៀបចំបង្រៀន សូមនឹកគិតដល់សិស្សដែលមានតម្រូវការជាពិសេសផង ។ សូមសម្របសម្រួលសកម្មភាពនានា និងការរំពឹងទុកទាំងឡាយដើម្បីជួយសិស្សឲ្យទទួលបានជោគជ័យ ។ ទំនាក់ទំនងជាមួយនឹងឪពុកម្ដាយ និង អ្នកដឹកនាំដែល

នឹងជួយអ្នកឲ្យដឹងពីតម្រូវការរបស់សិស្ស ហើយជួយអ្នកឲ្យបានជោគជ័យ ក្នុងការផ្តល់នូវបទពិសោធន៍ដ៏មានន័យសម្រាប់ពួកគេ ។

អំឡុងពេលនៃការរៀបចំមេរៀនរបស់អ្នក អ្នកអាចជ្រើសរើសប្រើប្រាស់ឧបករណ៍កំណត់ចំណាំ និង សៀវភៅកំណត់ហេតុនៅលើគេហទំព័រ LDS.org ឬ នៅក្នុង Gospel Library សម្រាប់ឧបករណ៍ចល័តរបស់អ្នក ។ អ្នកអាចប្រើប្រាស់ឧបករណ៍ទាំងនេះដើម្បីគូសចំណាំព្រះគម្ពីរ សុន្ទរកថាសន្និសីទ អត្ថបទទស្សនាវដ្ដីនៃសាសនាចក្រ និង មេរៀននានា ។ អ្នកអាចបន្ថែម ឬ រក្សាទុកកំណត់ចំណាំនោះសម្រាប់ប្រើវាអំឡុងពេលអ្នកបង្រៀន ។ ដើម្បីរៀនបន្ថែមពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនេះ សូមមើល Notes and Journal Help នៅគេហទំព័រ LDS.org។

## ការប្រើសៀវភៅសិក្សាសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ

### សេចក្តីណែនាំនៃបណ្ដុំបទគម្ពីរ

សេចក្តីណែនាំនៃបណ្ដុំបទគម្ពីរផ្តល់នូវទិដ្ឋភាពទូទៅដ៏ខ្លីមួយនៃបរិបទ និង មាតិកានៃបណ្ដុំបទគម្ពីរសម្រាប់មេរៀននីមួយៗ ។

### សេចក្តីសង្ខេបនៃក្រុមខគម្ពីរ និង បរិបទ

ជាញឹកញាប់ បណ្ដុំបទគម្ពីរត្រូវបានបែងចែកចេញទៅជាវគ្គតូចៗ ឬ ក្រុមខគម្ពីរដែលផ្ដោតលើប្រធានបទ ឬ សកម្មភាពជាក់លាក់មួយ ។ សេចក្តីយោងនៃក្រុមខគម្ពីរនីមួយៗ ត្រូវបានបន្តដោយសេចក្តីសង្ខេបខ្លីនៃហេតុការណ៍ ឬការបង្រៀននៅក្នុងក្រុមខគម្ពីរនោះ ។

### ជំនួយក្នុងការបង្រៀន

ជំនួយក្នុងការបង្រៀននឹងពន្យល់អំពីគោលការណ៍ និង វិធីបង្រៀនដំណឹងល្អ ។ វាអាចជួយអ្នកនៅក្នុងការខិតខំ ដើម្បីកែលម្អក្នុងនាមជាគ្រូបង្រៀនម្នាក់ ។

### តួសេចក្តីនៃមេរៀន

តួសេចក្តីនៃមេរៀនមានសេចក្តីណែនាំសម្រាប់អ្នក នៅពេលអ្នកសិក្សា និង បង្រៀន ។ វាផ្តល់គំនិតបង្រៀន រួមមានសំណួរ សកម្មភាព ការដកស្រង់ ដ្យាក្រាម និង តារាងនានា ។

### គោលលទ្ធិ និង គោលការណ៍

ជាធម្មតានៅពេលគោលលទ្ធិ និង គោលការណ៍នានាបង្ហាញចេញមកពីការសិក្សានៃអត្ថបទព្រះគម្ពីរ វាត្រូវបានគូសចំណាំជាអក្សរក្រាស់ខ្មៅដើម្បីជួយដល់អ្នកឲ្យរកឃើញ និង សង្កត់ធ្ងន់ លើវា នៅក្នុងការពិភាក្សារបស់អ្នកជាមួយសិស្ស ។

### រូបភាព

រូបភាពនៃអ្នកដឹកនាំសាសនាចក្រ និង ព្រឹត្តិការណ៍នានាអំពីព្រះគម្ពីរ តំណាងឲ្យជំនួយចក្ខុវិស័យ ដែលអ្នកអាចបង្ហាញ ប្រសិនបើវាមាននៅពេលអ្នកបង្រៀន ។

### ចន្លោះជួរឈរ

ចន្លោះជួរឈរអាចត្រូវបានប្រើ សម្រាប់ការរៀបចំមេរៀនរួមមានការសរសេរកត់ចំណាំ គោលការណ៍ បទពិសោធន៍ ឬ គំនិតផ្សេងទៀតនៅពេលអ្នកទទួលបានការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។

### សេចក្តីអធិប្បាយ និង ព័ត៌មានសាច់រឿង

ការដកស្រង់ និង ការពន្យល់បន្ថែមត្រូវបានផ្តល់ឲ្យនៅចុងបញ្ចប់មេរៀនមួយចំនួន ដើម្បីផ្តល់ដល់អ្នកនូវការយល់ដឹងបន្ថែមនៃប្រវត្តិបរិបទ សិក្ខាបទជាក់លាក់ ឬ វគ្គបទគម្ពីរ ។ សូមប្រើព័ត៌មាននៅក្នុងផ្នែកនេះ ដើម្បីរៀបចំឆ្លើយនឹងសំណួរ ឬ ផ្តល់ការយល់ដឹងបន្ថែមនៅពេលអ្នកបង្រៀន ។ សេចក្តីអធិប្បាយបន្ថែមផ្សេងទៀត អាចរកបាននៅក្នុងទម្រង់អេឡិចត្រូនិចនៃសៀវភៅសិក្សានេះនៅគេហទំព័រ LDS.org។

### គំនិតបន្ថែមសម្រាប់ការបង្រៀន

គំនិតបន្ថែមនានាសម្រាប់ការបង្រៀន មាននៅខាងចុងនៃមេរៀនមួយចំនួន ។ គំនិតនេះផ្តល់យោបល់សម្រាប់ការបង្រៀនគោលលទ្ធិ និង គោលការណ៍ដែលពុំអាចរកឃើញ ឬ សង្កត់ធ្ងន់នៅក្នុងតួមេរៀន ។ ពួកគេក៏ផ្តល់ផងដែរនូវយោបល់ស្ដីពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍ ដូចជាឌី.វី.ឌី.បទបង្ហាញ និង វីដេអូនៅលើគេហទំព័រ LDS.org។ គំនិតបន្ថែមនានាសម្រាប់ការបង្រៀន អាចរកបាននៅក្នុងទម្រង់អេឡិចត្រូនិចនៃសៀវភៅសិក្សានេះនៅគេហទំព័រ LDS.org។

## កម្មវិធីសិក្សាថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ ( ម៉ោងសិក្សាអំពីសាសនា និង ម៉ោងព្រឹកព្រលឹម )

សៀវភៅសិក្សានេះ រួមមានមូលដ្ឋានគ្រឹះដូចខាងក្រោមសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ ៖ មេរៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀនចំនួន ១៦០មេរៀន ជំនួយក្នុងការបង្រៀន និង ធនធានសម្រាប់ការបង្រៀនចំណេះចំណានខគម្ពីរ និង គោលលទ្ធិគ្រឹះទាំងឡាយ ។

### មេរៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀន

#### ទម្រង់នៃមេរៀន

មេរៀននីមួយៗនៅក្នុងសៀវភៅសិក្សានេះផ្ដោតលើបណ្ដុំបទគម្ពីរមួយ ជាជាងផ្ដោតទៅលើគំនិត គោលលទ្ធិ ឬ គោលការណ៍ពិសេសណាមួយ ។ ទម្រង់នៃមេរៀននេះជួយអ្នក និង សិស្សរបស់អ្នកឲ្យសិក្សាព្រះគម្ពីរតាមលំដាប់លំដោយ ហើយពិភាក្សាពីគោលលទ្ធិ និង គោលការណ៍ដែលវាមាននៅក្នុងអត្ថបទព្រះគម្ពីរ ។ នៅពេលសិស្សរៀនមាតិកានៅក្នុងគោលលទ្ធិ ឬ គោលការណ៍ដែលរកឃើញ នោះការយល់ដឹងរបស់ពួកគេអំពីសេចក្ដីពិតនោះនឹងកាន់តែជ្រាលជ្រៅ ។ លើសពីនេះទៅទៀត សិស្សនឹងមើលឃើញ ហើយយល់កាន់តែប្រសើរឡើងអំពីវិសាលភាពទាំងមូលនៃសារលិខិតដែលបំផុសគំនិតដល់អ្នកសរសេរគម្ពីរ ដែលមានបំណងចង់បង្ហាញ ។ ការបង្រៀនព្រះគម្ពីរតាមរបៀបនេះក៏នឹងជួយសិស្សឲ្យរៀនផងដែរ ពីរបៀបស្វែងរក និង អនុវត្តសេចក្ដីពិតដ៏អស់កល្បនានានៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

នៅក្នុងមេរៀននីមួយៗគ្រប់ផ្នែកទាំងអស់នៃបណ្ដុំបទគម្ពីរពុំត្រូវបានសង្កត់ធ្ងន់ឡើយ ។ ផ្នែកមួយចំនួនត្រូវបានផ្ដោតលើតិចតួចដោយសារវាពុំសូវផ្ដោតសំខាន់លើសារលិខិតទាំងមូល នូវការបំផុសគំនិតរបស់អ្នកសរសេរ ឬ ដោយសារវាពុំសូវពាក់ព័ន្ធចំពោះយុវវ័យទេ ។ អ្នកមានទំនួលខុសត្រូវដើម្បីកែសម្រួលមេរៀនទាំងនេះទៅតាមតម្រូវការ និង ការចាប់អារម្មណ៍របស់សិស្សដែលអ្នកបង្រៀន ។ អ្នកអាចសម្របសម្រួលគំនិតនៃមេរៀននៅក្នុងសៀវភៅសិក្សានេះ ដោយជ្រើសយកការសង្កត់ធ្ងន់កាន់តែខ្លាំងចំពោះគោលលទ្ធិ ឬ គោលការណ៍ពិសេសៗ ជាជាងគំនិតនានាដែលត្រូវបានផ្ដល់ឲ្យក្នុងមេរៀន ឬ ដោយជ្រើសយកការសង្កត់ធ្ងន់តែបន្តិចបន្តួចលើផ្នែកមួយនៃបណ្ដុំបទគម្ពីរ ដែលត្រូវបានបង្កើតឡើងឲ្យយល់កាន់តែច្បាស់នៅក្នុងសៀវភៅសិក្សានេះ ។ សូមស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយអ្នកឲ្យធ្វើការកែសម្រួលនេះ នៅពេលអ្នករៀបចំ និង បង្រៀន ។

#### គោលលទ្ធិ និង គោលការណ៍

នៅក្នុងតួសេចក្ដីនៃមេរៀននិមួយៗ អ្នកនឹងឃើញគោលលទ្ធិ និង គោលការណ៍គន្លឹះមួយចំនួននោះដែលត្រូវបានគូសចំណាំជាអក្សរដិតខ្មៅ ។ គោលលទ្ធិ និង គោលការណ៍ទាំងនេះត្រូវបានរកឃើញនៅក្នុងកម្មវិធីសិក្សាដោយសារ (១) វាឆ្លុះបញ្ចាំងពីសារលិខិតសំខាន់នៃបណ្ដុំបទគម្ពីរ (២) វាអាចត្រូវបានអនុវត្តបានចំពោះសេចក្ដីត្រូវការ និង ស្ថានភាពនានារបស់សិស្ស (៣) វាគឺជាសេចក្ដីពិតគន្លឹះដែលអាចជួយសិស្សឲ្យមានទំនាក់ទំនងកាន់តែខ្លាំងឡើងជាមួយព្រះអម្ចាស់ ។ សូមដឹងថាគោលលទ្ធិ និង សេចក្ដីសញ្ញាបង្រៀនសេចក្ដីពិតមួយចំនួន ហួសពីសេចក្ដីពិតទាំងអស់ដែលមាននៅក្នុងកម្មវិធីសិក្សា ។ ប្រធាន ប៊យដ៍ ឃេ ផាកកឺ បានបង្រៀនថាព្រះគម្ពីរមាននូវ « បណ្ដុំនៃសេចក្ដីពិតដ៏អស់កល្បដែលនឹងបំពេញនូវសេចក្ដីត្រូវការនៃផនគ្រប់រូបនៅក្នុងគ្រប់ស្ថានភាពទាំងអស់ » (« The Great Plan of Happiness » ។ CES Symposium on the Doctrine and Covenants/Church History, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣ ។ គេហទំព័រ LDS.org; សូមមើលផងដែរ *Teaching Seminary: Preservice Readings* ។ ឆ្នាំ ២០០៤ ។ ទំព័រ ៦៩ គេហទំព័រ LDS.org) ។

នៅពេលអ្នកបង្រៀន សូមផ្ដល់ឱកាសឲ្យសិស្សជានិច្ចដើម្បីស្វែងរកគោលលទ្ធិ និង គោលការណ៍នានានៅក្នុងព្រះគម្ពីរ ។ នៅពេលសិស្សបង្ហាញសេចក្ដីពិតដែលពួកគេរកឃើញ នោះជាញឹកញាប់ពួកគេអាចប្រើពាក្យ ដែលខុសគ្នាអំពីរបៀបដែលគោលលទ្ធិ ឬ គោលការណ៍នោះបានថ្លែងនៅក្នុងសៀវភៅសិក្សានោះ ។ ពួកគេក៏អាចរកឃើញផងដែរ នូវសេចក្ដីពិតដែលពុំមាននៅក្នុងគម្រោងមេរៀន ។ សូមប្រុងប្រយ័ត្ន កុំផ្ដល់យោបល់ដោយងាយៗថា ចម្លើយរបស់សិស្សគឺខុស ដោយសារតែពាក្យដែលពួកគេប្រើដើម្បីបង្ហាញពីសេចក្ដីពិត ខុសពីអ្វីដែលបានប្រើនៅក្នុងសៀវភៅសិក្សា ឬ ដោយសារពួកគេបានរកឃើញសេចក្ដីពិតមួយ ដែលពុំបានលើកឡើងនៅក្នុងកម្មវិធីសិក្សានោះ ។ ទោះជាយ៉ាងណាក្ដី ប្រសិនបើប្រយោគរបស់សិស្សម្នាក់ខុសពីគោលលទ្ធិ នោះវាជាទំនួលខុសត្រូវរបស់អ្នកដើម្បីជួយសិស្សដោយឥរិយាបទទន់ភ្លន់ ដើម្បីជួយកែតម្រូវសេចក្ដីថ្លែងការណ៍របស់គាត់ ដោយធ្វើការនេះដោយសេចក្ដីស្រឡាញ់ និង ការទុកចិត្ត ។ ការធ្វើដូច្នោះអាចផ្ដល់នូវបទពិសោធន៍រៀនសូត្រយ៉ាងសំខាន់ដល់សិស្សក្នុងថ្នាក់របស់អ្នក ។

#### ល្បឿនបង្រៀន

សៀវភៅសិក្សានេះមានមេរៀនថ្នាក់សិក្ខាសាលាប្រចាំថ្ងៃចំនួន ១៦០ មេរៀន ។ អ្នកអាចសម្របសម្រួលមេរៀននេះ និង ល្បឿននៃការបង្រៀនទៅតាមតម្រូវការនៃរយៈពេលដែលអ្នកមានដើម្បីបង្រៀនវគ្គសិក្សានេះ ។ សូមមើលឧបសម្ព័ន្ធ

នៅចុងបញ្ចប់នៃសៀវភៅសិក្សានេះ សម្រាប់សេចក្ដីណែនាំគំរូនៃល្បឿនបង្រៀន ។ សេចក្ដីណែនាំនៃល្បឿនបង្រៀនគឺផ្ដោតលើ ៣៦សប្ដាហ៍ ឬ ១៨០ថ្ងៃនៃឆ្នាំសិក្សា និង ២០ថ្ងៃ « ដែលអាចផ្លាស់ប្ដូរបាន » ដែលអ្នកអាចប្រើដើម្បីសម្រួលមេរៀនប្រចាំថ្ងៃ ជួយសិស្សឲ្យស្ទាត់ជំនាញចំណេះចំណានខគម្ពីរ និង គោលលទ្ធិគ្រឹះ រំឭកមេរៀនពីមុនៗ និង ទុកពេលសម្រាប់កាលវិភាគដែលរំខាននានា ។

### កិច្ចការជំនួសអវត្តមាន

*សៀវភៅមគ្គុទេសន៍ការសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ* អាចត្រូវបានប្រើប្រាស់ក្នុងកម្មវិធីសិក្សាថ្នាក់សិក្ខាសាលាប្រចាំថ្ងៃជាធនធាន ដើម្បីផ្ដល់កិច្ចការជំនួសអវត្តមានដល់សិស្ស ។ មេរៀននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សដែលសិក្សានៅផ្ទះវាស្របនឹងមេរៀនដែលមាននៅក្នុងសៀវភៅសិក្សានេះ ។ សិស្សដែលអវត្តមានច្រើនលើសលុបអាចត្រូវបានចាត់ឲ្យបំពេញនូវកិច្ចការនានានៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សាដែលត្រូវគ្នានឹងមាតិកាដែលពួកគេខកខានពុំបានមករៀន ។ កិច្ចការនោះអាចបោះពុម្ពចេញពីគេហទំព័រ LDS.org. ដូច្នេះអ្នកពុំចាំបាច់ត្រូវផ្ដល់សៀវភៅសិក្សាទាំងមូលនេះដល់សិស្ស ដែលត្រូវធ្វើកិច្ចការជំនួសអវត្តមានឡើយ ។ ព័ត៌មានបន្ថែមទាក់ទងនឹង *សៀវភៅមគ្គុទេសន៍ការសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ* គឺត្រូវបានផ្ដល់ឲ្យនៅក្នុងវគ្គចំណងជើង « កម្មវិធីសិក្សាថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ » នៅក្នុងឯកសារណែនាំទាំងនេះ ។

### ជំនួយក្នុងការបង្រៀន

ជំនួយក្នុងការបង្រៀនមាននៅគែមទំព័រនៃសៀវភៅសិក្សានេះ ។ ការបង្រៀនទាំងនេះជួយពន្យល់ និង បង្ហាញពីរបៀបដែលអ្នក និង សិស្សដែលអ្នកបង្រៀនអាចអនុវត្តការបង្រៀន និង ការរៀនសូត្រមូលដ្ឋានគ្រឹះនៃដំណឹងល្អ នៅក្នុងការសិក្សារបស់អ្នក អំពីគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ ។ វាក៏ផ្ដល់ផងដែរនូវយោបល់នានាស្ដីអំពីរបៀបដ៏មានប្រសិទ្ធភាព ដើម្បីប្រើវិធីសាស្ត្រ ជំនាញ និង យុទ្ធសាស្ត្របង្រៀនផ្សេងៗ ។ នៅពេលអ្នកយល់គោលការណ៍ដែលមាននៅក្នុងជំនួយក្នុងការបង្រៀន សូមរកមើលរបៀបនានាដើម្បីអនុវត្ត ហើយប្រើវាឲ្យបានជាប់លាប់នៅក្នុងការបង្រៀនរបស់អ្នក ។

## ការប្រើប្រាស់មេរៀនដែលសិក្សានៅផ្ទះ

### សេចក្ដីសង្ខេបនៃមេរៀនរបស់សិស្ស

សេចក្ដីសង្ខេបនេះនឹងជួយអ្នកឲ្យស្គាល់បរិបទ និង គោលលទ្ធិ ព្រមទាំងគោលការណ៍នានា ដែលសិស្សបានសិក្សាក្នុងមួយសប្ដាហ៍ នៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ។

### សេចក្ដីផ្ដើមនៃមេរៀន

សេចក្ដីផ្ដើមនៃមេរៀននេះនឹងជួយអ្នកឲ្យស្គាល់ពីផ្នែកខ្លះៗនៃបណ្ដុំបទគម្ពីរណាមួយ ដែលនឹងត្រូវសង្កត់ធ្ងន់នៅក្នុងមេរៀននេះ ។

### តួសេចក្ដីនៃមេរៀន

តួសេចក្ដីនៃមេរៀនផ្ដល់នូវសេចក្ដីណែនាំសម្រាប់អ្នក នៅពេលអ្នកសិក្សា និង បង្រៀន ។ វាផ្ដល់គំនិតបង្រៀន រួមមានសំណួរ សកម្មភាព ការដកស្រង់ គូររូបភាព និង តារាងនានា ។

### សេចក្ដីសង្ខេបនៃក្រុមខគម្ពីរ និង បរិបទ

ខគម្ពីរត្រូវបានដាក់ជាក្រុម ស្របតាមទីតាំងដែលផ្លាស់ប្ដូរនៅក្នុងបរិបទ ឬ មាតិកាដែលមានពាសពេញទាំងបណ្ដុំបទគម្ពីរ ។ សេចក្ដីយោងនៃក្រុមខគម្ពីរនិមួយៗ ត្រូវបានបន្តដោយសេចក្ដីសង្ខេបខ្លីនៃហេតុការណ៍ ឬ ការបង្រៀននៅក្នុងក្រុមខគម្ពីរនោះ ។

### គោលលទ្ធិ និង គោលការណ៍

នៅពេលគោលលទ្ធិ និង គោលការណ៍នានាមាននៅក្នុងការសិក្សាអត្ថបទព្រះគម្ពីរ នោះវាត្រូវបានគូសចំណាំ ជាអក្សរខ្មៅដិត ដើម្បីជួយអ្នកឲ្យរកឃើញ និង សង្កត់ធ្ងន់លើវានៅក្នុងការពិភាក្សារបស់អ្នកជាមួយសិស្ស ។

### សេចក្ដីណែនាំនៃមេរៀនបន្ទាប់

កថាខណ្ឌចុងក្រោយនៃមេរៀននីមួយៗផ្ដល់ការចង្អុលបង្ហាញមួយទៅមេរៀនបន្ទាប់ ។ សូមចែកចាយកថាខណ្ឌនេះជាមួយសិស្សរបស់អ្នក នៅពេលបញ្ចប់មេរៀននីមួយៗ ដើម្បីជួយពួកគេឲ្យខ្នះខ្នែងសិក្សាព្រះគម្ពីរអំឡុងពេលនៃសប្ដាហ៍ក្រោយ ។

## កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ

ក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំបព្វជិតភាពក្នុងមូលដ្ឋាន និង អ្នកតំណាង ស&វ នោះថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះអាចត្រូវបានរៀបចំឡើងនៅកន្លែងណា ដែលសិស្សពុំអាចចូលរួមរៀននៅក្នុងថ្នាក់រៀងរាល់ថ្ងៃបាន ដោយសារតែចម្ងាយធ្វើដំណើរ ឬ កត្តាផ្សេង ៗទៀត ( ដូចជាពិការភាពជាដើម ) ។ ថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះជាទូទៅពុំមានដូចថ្នាក់រៀនដែលបង្រៀនរៀងរាល់ថ្ងៃ ( ថ្ងៃនៃសប្ដាហ៍ ) នៅពេលព្រឹកព្រលឹម ឬ ម៉ោងសិក្សាអំពីសាសនាឡើយ ។

កម្មវិធីសិក្សានៅផ្ទះអនុញ្ញាតឲ្យសិស្សទទួលក្រេឌីតនៅក្នុងថ្នាក់សិក្ខាសាលា តាមរយៈការបំពេញមេរៀននិមួយ ៗនៅផ្ទះជាជាងចូលរួមរៀននៅក្នុងថ្នាក់រាល់ថ្ងៃនៃសប្ដាហ៍ ។ មេរៀនទាំងនេះមាននៅក្នុងសៀវភៅសិក្សាផ្សេងមួយទៀត *សៀវភៅមគ្គុទេសន៍ការសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រសម្រាប់សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ* ។ មួយសប្ដាហ៍ម្ដង សិស្សនឹងជួបជាមួយគ្រូបង្រៀនថ្នាក់សិក្ខាសាលា ដើម្បីប្រគល់កិច្ចការរបស់ពួកគេ និង ចូលរួមក្នុងមេរៀនប្រចាំសប្ដាហ៍ ។ សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស និង មេរៀនប្រចាំសប្ដាហ៍ ត្រូវបានពន្យល់បន្ថែមទៀតនៅខាងក្រោមនេះ ។

### សៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សសិក្សានៅផ្ទះ

*សៀវភៅមគ្គុទេសន៍ការសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ* ត្រូវបានរៀបចំឡើងដើម្បីជួយសិស្សដែលសិក្សានៅផ្ទះទទួលនូវបទពិសោធន៍នៅក្នុងការសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រស្រដៀងនឹងសិស្សដែលចូលរៀននៅក្នុងថ្នាក់រៀនរៀងរាល់ថ្ងៃនៃសប្ដាហ៍ ។ ហេតុដូច្នោះហើយ ល្បឿនបង្រៀននៃសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ព្រមទាំងគោលលទ្ធិ និង គោលការណ៍ដែលវាសង្កត់ធ្ងន់នោះ វាស្របទៅនឹងមេរៀននៅក្នុងសៀវភៅសិក្សានេះ ។ សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ក៏រួមមាននូវសេចក្ដីណែនាំអំពីចំណេះចំណានខគម្ពីរផងដែរ ។ វគ្គចំណេះចំណានខគម្ពីរត្រូវបានរៀបរាប់នៅក្នុងបរិបទ ដូចដែលវាមាននៅក្នុងអត្ថបទព្រះគម្ពីរ ហើយជាញឹកញាប់សកម្មភាពសរសេរនានា ត្រូវបានផ្ដល់ឲ្យនៅក្នុងមេរៀននានាដែលមានវគ្គបទគម្ពីរនោះ ។

រៀងរាល់សប្ដាហ៍ សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ ត្រូវបញ្ចប់មេរៀនបួនមកពីសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ហើយចូលរួមនៅក្នុងមេរៀនប្រចាំសប្ដាហ៍មួយ ដែលបង្រៀនដោយគ្រូថ្នាក់សិក្ខាសាលារបស់ពួកគេ ។ សិស្សបំពេញកិច្ចការមួយចំនួនពីសៀវភៅមគ្គុទេសន៍ការសិក្សា នៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សិស្សគួរតែមានសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរពីរក្បាល ដូច្នេះពួកគេអាចទុកមួយនៅជាមួយគ្រូ ហើយទុកមួយទៀតសម្រាប់សរសេរខ្លួនឯង ។ នៅពេលសិស្សជួបជាមួយគ្រូរបស់ខ្លួនរាល់សប្ដាហ៍ សៀវភៅកំណត់ហេតុមួយដែលសិក្សានៅផ្ទះត្រូវឲ្យទៅគ្រូ ហើយសៀវភៅមួយក្បាលទៀតត្រូវប្រគល់ឲ្យសិស្សវិញដើម្បីប្រើសរសេរមេរៀនបន្ទាប់ ។ ( ឧទាហរណ៍ អំឡុងមួយសប្ដាហ៍ សិស្សបញ្ចប់កិច្ចការនៅក្នុងសៀវភៅកំណត់ហេតុទី ១ ។ បន្ទាប់មកសិស្សយកសៀវភៅកំណត់ហេតុនោះទៅថ្នាក់រៀន ហើយប្រគល់វាទៅឲ្យគ្រូបង្រៀន ។ អំឡុងសប្ដាហ៍បន្ទាប់ សិស្សបញ្ចប់កិច្ចការនៅក្នុងសៀវភៅកំណត់ហេតុទី ២ ។ នៅពេលសិស្សប្រគល់សៀវភៅកំណត់ទី ២ឲ្យគ្រូ នោះគ្រូនឹងឲ្យសៀវភៅកំណត់ហេតុទី ១មកវិញ ។ បន្ទាប់មកសិស្សប្រើសៀវភៅកំណត់ហេតុទី ១ ដើម្បីបំពេញកិច្ចការនៅសប្ដាហ៍បន្ទាប់ ) ។

សិស្សថ្នាក់សិក្ខាសាលាទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ហើយអានមេរៀននានា ប៉ុន្តែសិស្សសិក្សានៅផ្ទះគួរយល់ថា ពួកគេត្រូវបានរំពឹងឲ្យចំណាយពេលពី ៣០ ទៅ ៤០នាទីបន្ថែមទៀត សម្រាប់មេរៀននិមួយនៅក្នុងមេរៀនទាំងបួន សម្រាប់ការសិក្សានៅផ្ទះនៅក្នុងមេរៀននិមួយ ៗ ហើយចូលរួមនៅក្នុងថ្នាក់សិក្សានៅផ្ទះប្រចាំសប្ដាហ៍ ។

### មេរៀនប្រចាំសប្ដាហ៍សម្រាប់គ្រូបង្រៀនដែលបង្រៀនសិស្សដែលសិក្សានៅផ្ទះ

មេរៀននិមួយ ៗនៅក្នុង *សៀវភៅមគ្គុទេសន៍ការសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រសម្រាប់ សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ* ត្រូវគ្នានឹងមេរៀនប្រាំនៅក្នុងសៀវភៅសិក្សាប្រចាំរបស់គ្រូបង្រៀន ។ នៅចុងបញ្ចប់នៃមេរៀនទាំងប្រាំនេះនៅក្នុងសៀវភៅសិក្សានេះ អ្នកនឹងឃើញមានមេរៀនប្រចាំសប្ដាហ៍មួយ សម្រាប់គ្រូបង្រៀនដែលបង្រៀនសិស្សនៅផ្ទះ ។ មេរៀនសិក្សានៅផ្ទះនឹងជួយសិស្សរំឭក ពង្រីកការយល់ដឹងរបស់ពួកគេ និង អនុវត្តគោលលទ្ធិ និង គោលការណ៍ដែលពួកគេបានរៀននៅពេលពួកគេបញ្ចប់មេរៀននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សអំឡុងសប្ដាហ៍នោះ ។ មេរៀនទាំងនេះអាចបង្ហាញនូវសេចក្ដីពិតបន្ថែមដែលពុំមាននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សឡើយ ។ ( សម្រាប់ជំនួយនៅក្នុងការរៀបចំកាលវិភាគមេរៀនរបស់អ្នក សូមមើលសេចក្ដីណែនាំពីល្បឿននៃការបង្រៀនសម្រាប់គ្រូបង្រៀនសិស្សដែលសិក្សានៅផ្ទះនៅក្នុងឧបសម្ព័ន្ធដែលនៅចុងបញ្ចប់នៃសៀវភៅសិក្សានេះ ) ។

ក្នុងនាមជាគ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ អ្នកអាចមានការយល់ដឹងទាំងស្រុងពីអ្វីដែលសិស្សរបស់អ្នកកំពុងសិក្សានៅផ្ទះរាល់សប្ដាហ៍ ដូច្នេះអ្នកអាចឆ្លើយសំណួរ និង បង្កើតការពិភាក្សានានាដ៏មានអត្ថន័យនៅពេលអ្នកជួបជាមួយពួកគេ ។ សូមឲ្យសិស្សយកព្រះគម្ពីរ សៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ និង សៀវភៅមគ្គុទេសន៍ការសិក្សាសិស្ស របស់ពួកគេមកថ្នាក់រៀនរាល់សប្ដាហ៍ ដូច្នេះពួកគេអាចប្រើប្រាស់វាពេលកំពុងរៀន ។ សូមសម្របសម្រួលមេរៀននានាស្របទៅតាមតម្រូវការរបស់សិស្ស នៅពេលអ្នកបង្រៀន និង ស្របទៅតាមការណែនាំនៃព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកក៏អាចប្រើប្រាស់មេរៀនប្រចាំថ្ងៃរបស់គ្រូបង្រៀននៅក្នុងសៀវភៅសិក្សានេះ នៅពេលអ្នករៀបចំ និង បង្រៀនផងដែរ ។ ការសិក្សាពីជំនួយក្នុងការបង្រៀន និង វិធីសាស្ត្រនានា ដែលបានប្រើនៅក្នុងមេរៀនប្រចាំថ្ងៃ អាចជួយពង្រីកការបង្រៀនប្រចាំសប្ដាហ៍របស់អ្នក ។ សូមតម្រូវទៅតាមសេចក្ដីត្រូវការពិសេសនានានៃសិស្សដែលអ្នកបង្រៀន ។ ឧទាហរណ៍ ប្រសិនបើសិស្សម្នាក់មានការលំបាកក្នុងការសរសេរ សូមឲ្យគាត់ប្រើម៉ាស៊ីនថតសំឡេង ឬ និយាយគំនិតនោះទៅសមាជិកគ្រួសារ ឬ មិត្តភក្ដិ ដែលអាចសរសេរចម្លើយរបស់គាត់ទុក ។

នៅចុងបញ្ចប់នៃមេរៀនរាល់សប្ដាហ៍ សូមប្រមូលសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់សិស្ស ហើយលើកទឹកចិត្តពួកគេឲ្យបន្តសិក្សារបស់ពួកគេ ។ សូមផ្ដល់សៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរសម្រាប់កិច្ចការសប្ដាហ៍បន្ទាប់ ដូចដែលបានពន្យល់មកពីខាងលើនៅក្នុងវគ្គដែលហៅថា « សៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សដែលសិក្សានៅផ្ទះ » ។ ( ក្រោមការដឹកនាំថ្នាក់ដឹកនាំបព្វជិតភាព និង ឪពុកម្ដាយ ស្ដេក [ ដែលបានហៅ ] គ្រូបង្រៀនថ្នាក់សិក្ខាសាលាអាចទាក់ទងសិស្សថ្នាក់សិក្ខាសាលាតាមប្រព័ន្ធអេឡិចត្រូនិចជាមួយសិស្សដែលចុះឈ្មោះចូលរៀនថ្នាក់សិក្ខាសាលានៅផ្ទះ ) ។

នៅពេលអ្នកអានកិច្ចការរបស់សិស្សសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់សិស្សចប់ហើយ សូមឆ្លើយតបចំពោះកិច្ចការរបស់ពួកគេរៀងរាល់ខែ ដោយសរសេរកំណត់ចំណាំ ឬ មូលវាចារណ៍ខ្លីមួយនៅពេលអ្នកជួបពួកគេលើកក្រោយ ។ អ្នកក៏អាចស្វែងរកវិធីនានាដើម្បីផ្ដល់ការគាំទ្រ និង ផ្ដល់មតិកែលម្អដ៏មានអត្ថន័យផងដែរ ។ ការណ៍នេះនឹងជួយសិស្សឲ្យដឹងថា អ្នកខ្វល់អំពីកិច្ចការរបស់ពួកគេ និង ជួយជំរុញទឹកចិត្តពួកគេឲ្យធ្វើកិច្ចការរបស់ពួកគេបានកាន់តែហ្មត់ចត់ ។

កិច្ចខិតខំភាគច្រើនរបស់សិស្ស ដើម្បីសូត្រវគ្គបទគម្ពីរគន្លឹះឲ្យចាំស្ទាត់នឹងអាចធ្វើបាន នៅពេលពួកគេបំពេញមេរៀនសិក្សានៅផ្ទះរបស់ខ្លួន។ គ្រូបង្រៀនដែលបង្រៀនសិស្សនៅផ្ទះ អាចតាមដានកិច្ចខិតខំរបស់សិស្ស អំឡុងពេលមេរៀនសិក្សានៅផ្ទះ ដោយអញ្ជើញសិស្សឲ្យសូត្រ ឬ រំឭកវគ្គចំណេះចំណានខគម្ពីរ ដែលមាននៅក្នុងអត្ថបទសម្រាប់មេរៀនសិក្សានៅសប្ដាហ៍នោះ ។

## ធនធានផ្សេងទៀត

### Joseph Smith Papers Project ( គម្រោងឯកសាររបស់យ៉ូសែប ស្ម៊ីធ )

ព័ត៌មានប្រវត្តិសាស្ត្រភាគច្រើននៅក្នុងសៀវភៅសិក្សានេះបានដកស្រង់ចេញពី *History of the Church* និង Joseph Smith Papers Project ( គម្រោងឯកសាររបស់យ៉ូសែប ស្ម៊ីធ ) ។ ជាពិសេសគឺភាគទី ១ និង ២នៃ Documents series of *The Joseph Smith Papers ( គម្រោងឯកសាររបស់យ៉ូសែប ស្ម៊ីធ )* ដែលបានបោះពុម្ពដោយកាសែតប្រវត្តិសាស្ត្ររបស់សាសនាចក្រ ( ការបោះពុម្ពនៃនាយកដ្ឋានប្រវត្តិសាស្ត្រសាសនាចក្រនៃ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ) ។ ដើម្បីមើលរូបភាពជាអេឡិចត្រូនិច និង អានអត្ថបទនៃឯកសារដើមនៅក្នុង Joseph Smith Papers Project ( គម្រោងឯកសាររបស់យ៉ូសែប ស្ម៊ីធ ) សូមមើលគេហទំព័រ josephsmithpapers.org។

### Notes and Journal Tools ( ឧបករណ៍កំណត់ចំណាំ និង កំណត់ហេតុ )

សៀវភៅសិក្សាថ្នាក់សិក្ខាសាលារបស់គ្រូបង្រៀន និង សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សមាននៅគេហទំព័រ LDS.org និង នៅក្នុង Gospel Library សម្រាប់ឧបករណ៍ចល័តនានា ។ គ្រូបង្រៀន និង សិស្សអាចប្រើ Notes and Journal tools ( ឧបករណ៍កំណត់ចំណាំ និង កំណត់ហេតុ ) តាមអ៊ិនធើរណែត និង ឧបករណ៍ចល័ត ដើម្បីគូសចំណាំ និង បន្ថែមកំណត់ចំណាំលើសៀវភៅសិក្សាទាំងនេះតាមអ៊ិនធើរណែត នៅពេលពួកគេរៀបចំមេរៀន និង សិក្សាព្រះគម្ពីរ ។ សៀវភៅសិក្សារបស់គ្រូបង្រៀន និង សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សក៏មាន សម្រាប់ការទាញយក ជាទម្រង់នានា ( ដូចជាឯកសារជា PDF, ePub, និង mobi [Kindle] ) នៅលើគេហទំព័រ LDS.org។

## សម្ភារបន្ថែម

ធនធានខាងក្រោមនេះមាននៅលើអ៊ិនធើរណែត តាមរយៈអ្នកគ្រប់គ្រងរបស់អ្នក តាមរយៈមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រនៅក្នុងមូលដ្ឋាន និង តាមរយៈហាងទំនិញតាមអ៊ិនធើរណែតរបស់សាសនាចក្រនៅគេហទំព័រ (store.lds.org) ៖



*Doctrine and Covenants and Church History Visual Resource DVDs* ទំនិញលេខ.០៨០៤២ មានតែភាសាអង់គ្លេស អេស្ប៉ាញ និង ព័រទុយហ្គាយ ប៉ុណ្ណោះ )



*Doctrine and Covenants and Church History DVD* ទំនិញលេខ.៥៤០១២)



Media Library នៅគេហទំព័រ LDS.org



*សៀវភៅសិល្បៈដំណឹងល្អ* ទំនិញលេខ. ០៦០៤៨ )



*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងដំណឹងល្អ* ទំនិញលេខ. ៣៦៨៦៣ )



ប្រធានបទនៃដំណឹងល្អនៅលើគេហទំព័រ LDS.org



*ដើម្បីកម្លាំងនៃយុវជន* កូនសៀវភៅ ( ទំនិញលេខ. ០៩៤០៣ )

មេរៀនទី ១

# ផែនការនៃសេចក្ដីសង្គ្រោះ

## សេចក្ដីផ្ដើម

ប្រធាន បិយ យេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានណែនាំដល់គ្រូបង្រៀនថ្នាក់សិក្ខាសាលាឲ្យបង្ហាញដោយសង្ខេបពីទិដ្ឋភាពទូទៅអំពីផែនការនៃសេចក្ដីសង្គ្រោះនៅពេលចាប់ផ្ដើមថ្នាក់ក្នុងឆ្នាំនីមួយៗ ៖

« ទិដ្ឋភាពទូទៅសង្ខេបអំពី ‹ ផែនការនៃសុភមង្គល › . . . បើត្រូវបានផ្ដល់ឲ្យនៅពេលចាប់ផ្ដើម ហើយត្រឡប់ទៅមើលជាញឹកញាប់ នោះវានឹងមានតម្លៃមហិមាចំពោះសិស្សរបស់អ្នក ។. . .

« មនុស្សវ័យក្មេងងឿងឆ្ងល់ថា ‹ ហេតុអ្វី ? › – ហេតុអ្វីក៏យើងត្រូវបានបញ្ជាឲ្យ *ធ្វើ* រឿងមួយចំនួន ហើយរឿងមួយចំនួនទៀត *មិន* តម្រូវឲ្យធ្វើដូច្នេះ ? ចំណេះដឹងអំពីផែនការនៃសុភមង្គល ទោះជាក្នុងទម្រង់យ៉ាងសង្ខេប ក៏វាអាចធ្វើឲ្យគំនិតមនុស្សវ័យក្មេងឆ្ងល់ថា ‹ ហេតុអ្វី › » ដែរ ( « ផែនការនៃសុភមង្គលដ៏មហិមា » [ សុន្ទរកថាទៅកាន់គ្រូបង្រៀនសាសនាស៊ី.អ៊ី.អែស ថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៣ ] LDS.org) ។

មេរៀននេះផ្ដល់ជាទិដ្ឋភាពទូទៅសង្ខេបមួយអំពី ផែនការនៃសេចក្ដីសង្គ្រោះ ។ វាផ្ដោតទៅលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែល « ជាកត្តាចម្បង និងជាគ្រឹះដ៏សំខាន់ ហើយជាគោលលទ្ធិមេនៃផែនការនៃសេចក្ដីសង្គ្រោះដ៏មហិមា និងអស់កល្បជានិច្ច » ( ជែហ្វ្រី អ័រ ហូឡិន Missionary Work and the Atonement» *Ensign* ខែមិនា ឆ្នាំ ២០០១ ទំព័រ ៨ ) ។

## យោបល់សម្រាប់ការបង្រៀន

### ផែនការរបស់ព្រះវរបិតាសួគ៌គឺជាផែនការនៃសុភមង្គល

អញ្ជើញសិស្សឲ្យអាន ម៉ូសេ ១:៣៩ ឮៗ ។ ( ឬសិស្សអាចសូត្រវា បើពួកគេទន្ទេញចាំហើយ ) ។ សូមឲ្យសិស្សមើលតាម និងរកមើលនូវអ្វីដែលព្រះវរបិតាសួគ៌បានមានបន្ទូល ដែលជាគោលបំណងនៃកិច្ចការរបស់ទ្រង់ ។ សូមសរសេរសេចក្ដីថ្លែងដូចខាងក្រោមនៅលើក្ដារខៀន ៖ **គោលបំណងនៃផែនការរបស់ព្រះវរបិតាសួគ៌ គឺដើម្បីផ្ដល់មាគ៌ាមួយសម្រាប់យើង ទទួលបានជីវិតអមតៈ និងជីវិតដ៏នៅអស់កល្បជានិច្ច ។**

- តើជីវិតអមតៈ និងជីវិតអស់កល្បជានិច្ចខុសគ្នាយ៉ាងដូចម្ដេច ? ( ជីវិតអមតៈ គឺជាការរស់នៅជារៀងរហូតក្នុងស្ថានភាពដែលរស់ឡើងវិញមួយ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ដែលមនុស្សគ្រប់រូប នឹងទទួលបានអំណោយទាននេះ ។ ជីវិតដ៏នៅអស់កល្បជានិច្ច ឬភាពតម្កើងឡើង គឺជាការរស់នៅក្នុងវត្តមានរបស់ព្រះជារៀងរហូតជាមួយនឹងក្រុមគ្រួសាររបស់យើង អំណោយទាននេះក៏បានមកតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទដែរ ប៉ុន្តែមានតែចំពោះអ្នកទាំងឡាយដែលគោរពតាមច្បាប់ និងពិធីបរិសុទ្ធនានានៃដំណឹងល្អប៉ុណ្ណោះ ) ។

ដើម្បីជួយសិស្សឲ្យយល់ពាក្យ « ជីវិតដ៏នៅអស់កល្បជានិច្ច » សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការដូចខាងក្រោមដោយអែលឌើរ ប្រ៊ូស អរ ម៉ាក់ខនគី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



*«ជីវិតរបស់ព្រះ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដែលជីវិតដ៏នៅអស់កល្បជានិច្ច គឺជាជីវិតរបស់ព្រះការបញ្ជាក់នេះ គឺមានន័យដូចគ្នា »* (*Mormon Doctrine* បោះពុម្ពជាលើកទី ២ [ ឆ្នាំ ១៩៦៦ ] ទំព័រ ២៣៧ ) ។

- តើពរជ័យមួយចំនួនដែលត្រូវបានប្រទានឲ្យអ្នកទាំងឡាយដែលទទួលជីវិតដ៏នៅអស់កល្បជានិច្ចមានអ្វីខ្លះ ?

សូមគូស ឌីយ៉ាក្រាមខាងក្រោមនេះលើក្ដារខៀន ។ សូមអញ្ជើញសិស្សឲ្យចម្លងឌីយ៉ាក្រាម ឬកត់ត្រាក្នុងសៀវភៅកត់ចំណាំរបស់ពួកគេ ឬ សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ នៅពេលពួកគេរៀនអំពីផែនការនៃសេចក្ដីសង្គ្រោះក្នុងមេរៀននេះ ។

### *បង្រៀនអំពីផែនការនៃសេចក្ដីសង្គ្រោះពេញមួយឆ្នាំ*

នៅពេញមួយឆ្នាំ អ្នកអាចនឹងចង់បង្ហាញឌីយ៉ាក្រាមអំពីផែនការនៃសេចក្ដីសង្គ្រោះដែលមាននៅក្នុងមេរៀននេះយូរៗម្ដង ។ សូមជួយសិស្សឲ្យស្គាល់ទីតាំងដែលវិវរណៈទាំងឡាយនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា បន្ថែមទៅលើការយល់ដឹងរបស់យើងអំពីផែនការនៃសេចក្ដីសង្គ្រោះ ។ បន្ទាប់មកសុំឲ្យសិស្សពន្យល់អំពីរបៀបបង្រៀនចេញមកពីវិវរណៈទាំងនោះដែលត្រូវនឹងឌីយ៉ាក្រាម ។

## ផែនការនៃសេចក្ដីសង្គ្រោះ




### *សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ*

សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អាចជាសៀវភៅកំណត់ហេតុកងមួយ ឬជាសៀវភៅកំណត់ចំណាំ ឬជាក្រដាសសៀវភៅកងមួយចោះភ្ជាប់គ្នា ។ វាអាចជាឧបករណ៍កំណត់ចំណាំ ឬសៀវភៅកំណត់ហេតុនៅលើ LDS.org ឬកម្មវិធីកត់ចំណាំមួយនៅលើទូរសព្ទទំនើប ឬឧបករណ៍ Tablet ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ សិស្សអាចកត់ចំណាំ ឬកត់ត្រាចំណាប់អារម្មណ៍ អំឡុងពេលមេរៀនថ្នាក់សិក្ខាសាលា អំឡុងពេលសិក្សាផ្ទាល់ខ្លួន និងអំឡុងពេលការប្រជុំសាសនាចក្រ។ នៅពេលពួកគេកត់ត្រា ហើយរៀបចំគំនិត និងចំណាប់អារម្មណ៍របស់ពួកគេ នោះពួកគេនឹងបង្កើនការចេះដឹងអំពីដំណឹងល្អ ទទួលវិវរណៈផ្ទាល់ខ្លួន ហើយត្រៀមខ្លួនកាន់តែល្អដើម្បីចូលរៀនក្នុងថ្នាក់ ។

សូមពន្យល់ថា នៅក្នុងជីវិតមុនជីវិតលើផែនដីរបស់យើង យើងរស់នៅជាវិញ្ញាណក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌របស់យើង ។ នៅទីនោះយើងរៀនអំពីផែនការរបស់ព្រះវរបិតាសួគ៌ សម្រាប់សុភមង្គលរបស់យើង និងរៀនអំពីរបៀបដែលផែនការនឹងជួយយើង សម្រេចគោលបំណងរបស់ទ្រង់សម្រាប់យើង ( សូមមើល គ&ស ១៣៨:៥៥–៥៦; អ័ប្រាហាំ ៣:២២–២៨) ។

- តើយើងខុសគ្នាពីព្រះវរបិតាសួគ៌យើងកាលពីជីវិតមុនកើតលើផែនដីដីយ៉ាងដូចម្ដេចខ្លះ ? ( ទ្រង់មានរូបកាយ និងលក្ខណៈសម្បត្តិដ៏ល្អឥតខ្ចោះមួយ ។ យើងពុំមាន ) ។

- នៅក្នុងជីវិតមុនកើតលើផែនដី តើព្រះវរបិតាសួគ៌ បានបង្ហាញដល់យើងអ្វីខ្លះ ដើម្បីជួយយើងទទួលបានជីវិតអមតៈ និងជីវិតដ៏នៅអស់កល្បជានិច្ចនោះ ? ( ផែនការនៃសេចក្ដីសង្គ្រោះ ) ។

សូមពន្យល់ថា យើងប្រើពាក្យ *ជីវិតរមែងស្លាប់* សំដៅទៅលើជីវិតរបស់យើងនៅលើផែនដី ។ ដូចបានបង្ហាញនៅក្នុងឌីយ៉ាក្រាមអប បន្ថែមទៅលើក្ដារខៀន រូបពងក្រពើរតំណាងឲ្យជីវិតលើផែនដី ហើយដាក់ស្លាកវាដោយពាក្យ *ជីវិតរមែងស្លាប់* ។ គូរសញ្ញាព្រួញពី *ជីវិតមុនជីវិតលើផែនដី* ទៅរក *ជីវិតរមែងស្លាប់* ។

## ផែនការនៃសេចក្ដីសង្គ្រោះ




សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោម ៖

- តើហេតុអ្វីក៏យើងចាំបាច់ត្រូវចាកចេញពីវត្តមានរបស់ព្រះ ដើម្បីប្រែក្លាយឲ្យកាន់តែដូចជាទ្រង់យ៉ាងដូច្នេះ ? ( ចម្លើយរបស់សិស្សអាចរួមមានដូចខាងក្រោម ៖ ដើម្បីទទួលរូបកាយ ដើម្បីរៀន និងដើម្បីរីកចម្រើន តាមរយៈការប្រើសិទ្ធិជ្រើសរើសរបស់យើង ) ។

បន្ទាប់ពីសិស្សពីរបីនាក់បានឆ្លើយរួចហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការពន្យល់ដូចខាងក្រោមនេះ ដោយប្រធាន ស្ពែនសើរ ដបុលយូ឴ ឃីមបឹល ថា ៖



« ព្រះបានប្រទានផែនការមួយឲ្យយើង ។ ទ្រង់បានបញ្ជូនយើងទាំងអស់គ្នាមកកាន់ផែនដី ដើម្បីទទួលរូបកាយ និងដើម្បីទទួលបទពិសោធន៍ ហើយរីកចម្រើន » (*The Teachings of Spencer W. Kimball,* ed. Edward L. Kimball [ ឆ្នាំ ១៩៨២ ] ទំព័រ ២៥ ) ។

- យោងតាមប្រធាន ឃីមបឹល តើមានមូលហេតុអ្វីខ្លះបានជាព្រះបញ្ជូនយើងមកកាន់ផែនដី ? ( ពេលសិស្សឆ្លើយ ពួកគេគួរតែប្រាប់ពីសេចក្ដីពិតដូចខាងក្រោម ៖ **ព្រះបានបញ្ជូនយើងមកកាន់ផែនដី ដើម្បីទទួលរូបរាងកាយ និងដើម្បីទទួលបទពិសោធន៍ ហើយរីកចម្រើនឡើង** )។

- តើឧបសគ្គនៃការល្បួង ជំងឺ ភាពសោកសៅ ការឈឺចាប់ ការបាក់ទឹកចិត្ត អសមត្ថភាព និងការលំបាកក្នុងជីវិតរមែងស្លាប់ដទៃទៀត ដើរតួក្នុងកិច្ចខិតខំរបស់យើង ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៩–២០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់អានតាម និងប្រាប់អំពីឧបសគ្គនានា ដែលអាចរាំងយើងមិនឲ្យទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

- តើឧបសគ្គអ្វីខ្លះ ដែលយើងជួបប្រទះក្នុងជីវិតរមែងស្លាប់ ដែលអាចរាំងយើងមិនឲ្យទទួលជីវិតដ៏នៅអស់កល្បជានិច្ច ? ( ពេលសិស្សឆ្លើយ សូមជួយពួកគេឲ្យប្រាប់ពីសេចក្ដីពិតដូចខាងក្រោម ៖ **អំពើបាប រាំងយើងមិនឲ្យប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ហើយមិនឲ្យត្រឡប់ទៅរស់នៅជាមួយទ្រង់។** សូមមើលផងដែរ ម៉ូសេ ៦:៥៧ ដែលបង្រៀនថា តាមរយៈការប្រែចិត្ត នោះយើងអាចត្រឡប់មករស់នៅជាមួយនឹងព្រះ ) ។

នៅលើក្ដារខៀន សូមសរសេរពាក្យ *អំពើបាប* នៅលើឌីយ៉ាក្រាម ជិតនឹងពាក្យ *ជីវិតរមែងស្លាប់* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ១០:២១ ឲ្យសិស្សផ្សេងទៀតអាន ម៉ូសេ ៦:៥៧ ហើយសិស្សម្នាក់ទៀតអាន អាលម៉ា ៤១:១០–១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់តាមដាន រកមើលមូលហេតុដែលអំពើបាបរាំងយើងមិនឲ្យប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ហើយទទួលជីវិតដ៏នៅអស់កល្បជានិច្ច ។

- ស្របតាមខគម្ពីរទាំងនេះ តើហេតុអ្វីបានជាអំពើបាបរាំងយើងមិនឲ្យប្រែក្លាយដូចជាព្រះវរបិតាសួគ៌ និងមិនឲ្យទទួលជីវិតដ៏នៅអស់កល្បជានិច្ចដូច្នេះ ? ( សិស្សអាចផ្ដល់ចម្លើយផ្សេងៗគ្នា ។ សូមជួយពួកគេឲ្យស្គាល់ពីសេចក្ដីពិតដូចខាងក្រោម ៖ **គ្មានអ្វីដែលមិនស្អាតអាចអាស្រ័យនៅក្នុងវត្តមានរបស់ព្រះបានឡើយ**) ។

សូមឲ្យសិស្សពីរនាក់ឡើងមកខាងមុខថ្នាក់ ។ សូមឲ្យសិស្សម្នាក់កាន់រូបភាពរបស់ព្រះយេស៊ូវ កំពុងនៅក្នុងសួនច្បារគេតសេម៉ានីឡើង (*សៀវភៅរូបភាពដំណឹងល្អ* [ ឆ្នាំ ២០០៩ ] ទំព័រ  ៥៦ សូមមើលផងដែរ LDS.org) ហើយសិស្សម្នាក់ទៀតកាន់រូបភាពនៃការឆ្កាង ( ទំព័រ ៥៧ ) ។ សូមអញ្ជើញសិស្សទីបីអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៤០–៤២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីអ្វីដែលព្រះវរបិតាសួគ៌ បានប្រទានដល់យើង ដើម្បីយើងអាចយកឈ្នះលើអំពើបាប ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៤០–៤២ តើអ្វីខ្លះ ដែលធ្វើឲ្យយើងអាចយកឈ្នះលើអំពើបាបបាន ? ( សិស្សអាចឆ្លើយពាក្យផ្សេងៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់សេចក្ដីពិតដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយត្រូវបានឆ្កាងដើម្បីអំពើបាបនៃមនុស្សគ្រប់រូប** ) ។

សូមអញ្ជើញសិស្សដែលកាន់រូបភាពឲ្យពន្យល់អំពីព្រឹត្តការអ្វីក្នុងរូបភាពរបស់ពួកគេ ទាក់ទងនឹងលទ្ធភាពរបស់យើងដើម្បីយកឈ្នះលើឥទ្ធិពលនៃអំពើបាប ។ សូមបង្ហាញរូបភាពនៅលើក្ដារខៀន ដូចបង្ហាញនៅក្នុងឌីយ៉ាក្រាមអមនោះ ។




សូមសរសេរសេចក្ដីយោងបទគម្ពីរដូចខាងក្រោមនៅលើក្ដារខៀន ៖ *គ. និង ស. ១៨:២២–២៣; គ. និង ស. ២៥:១៣, ១៥* ។ សូមឲ្យសិស្សធ្វើការជាគូៗ ។ សូមឲ្យដៃគូម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២២–២៣ ហើយសុំឲ្យដៃគូម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៣,១៥ ។ សូមឲ្យពួកគេទាំងពីរនាក់រកមើលអ្វីដែលយើងត្រូវតែធ្វើដើម្បីអាចទទួលបានព្រះចេស្ដាលាងសម្អាតនៃដង្វាយធួន ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមអញ្ជើញពួកគេឲ្យចែកចាយនឹងដៃគូរបស់ខ្លួនអំពីអ្វីដែលពួកគេរកឃើញ ។

- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលពរជ័យនៃពលិកម្មធួនរបស់ទ្រង់ ? ( ចម្លើយ អាចរួមមាន ការបង្ហាញសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ការទទួលបុណ្យជ្រមុជទឹក ការទទួលព្រះវិញ្ញាណបរិសុទ្ធ ការស៊ូទ្រាំនៅក្នុងសេចក្ដីជំនឿ ការរក្សាសេចក្ដីសញ្ញា និងការគោរពបទបញ្ញត្តិ ។ ដូចបានបង្ហាញនៅក្នុងឌីយ៉ាក្រាមបន្ទាប់ សូមគូរព្រួញចេញពីឆ្វេងទៅស្ដាំ កាត់ពីខាងក្រោមរង្វង់ពងក្រពើរ ។ សូមសរសេរចម្លើយរបស់សិស្សឲ្យស្របនឹងព្រួញនោះ ) ។

សូមសង្ខេបចម្លើយរបស់សិស្ស តាមរយៈការថ្លែងទីបន្ទាល់ថា **បើយើងគោរពប្រតិបត្តិចំពោះគោលការណ៍ និងពិធីបរិសុទ្ធនានានៃដំណឹងល្អ នោះយើងអាចយកឈ្នះលើអំពើបាប តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ** ។ សូមពន្យល់ថា នៅពេលយើងធ្វើ និងរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក នោះយើងត្រូវបានអភ័យទោសដោយក្ដីមេត្តាពីអំពើបាបរបស់យើង បើយើងប្រែចិត្ត ។ បន្ថែមពីលើនោះ តាមរយៈអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចមានជំនួយជាប្រចាំថ្ងៃក្នុងការដើរនៅលើផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ។

- តើព្រះបានជួយអ្នក តាមរយៈព្រះវិញ្ញាណបរិសុទ្ធនៅក្នុងកិច្ចខិតខំប្រចាំថ្ងៃរបស់អ្នក ដើម្បីរស់នៅតាមដំណឹងល្អយ៉ាងដូចម្ដេច ?

ចូរពន្យល់ថា បន្ថែមពីលើអំពើបាប នោះមានឧបសគ្គទីពីរ ដែលយើងត្រូវតែយកឈ្នះ ដើម្បីយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមសួរសិស្ស បើពួកគេអាចប្រាប់អំពីឧបសគ្គទីពីរនោះបាន ។

បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមសរសេរ *សេចក្ដីស្លាប់ខាងរូបកាយ* នៅលើឌីយ៉ាក្រាមនៅជិតនឹងពាក្យ *អំពើបាប ។* សូមអញ្ជើញសិស្សម្នាក់ឲ្យពន្យល់ពីអ្វីកើតឡើងចំពោះវិញ្ញាណ និងរូបកាយរបស់យើង បន្ទាប់ពីយើងស្លាប់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៣៣–៣៤ ឲ្យឮៗ ហើយឲ្យសិស្សម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២ ឮៗ ។ សូមសួរសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលចម្លើយចំពោះសំណួរដូចខាងក្រោម ៖

- តើការបំបែកជានិរន្ដន៍នៃវិញ្ញាណ និងរូបកាយរបស់យើង នឹងក្លាយជាឧបសគ្គមួយ ពុំឲ្យយើងប្រែក្លាយដូចជាព្រះយ៉ាងដូចម្ដេច ? ( សិស្សគួរតែប្រាប់ពីគោលលទ្ធិដូចខាងក្រោម ៖ **យើងពុំអាចក្លាយដូចជាព្រះវរបិតាសួគ៌ដោយគ្មានរូបកាយជាសាច់ និងឆ្អឹងនោះទេ** ) ។

សូមបង្ហាញសិស្សក្នុងថ្នាក់នូវរូបភាពរបស់ ម៉ារា និងព្រះយេស៊ូវគ្រីស្ទ ដែលមានព្រះជន្មរស់ (*សៀវភៅរូបភាពសិល្បៈដំណឹងល្អ* លេខ ៥៩ សូមមើលផងដែរ LDS.org) ហើយសុំសិស្សម្នាក់ឲ្យពន្យល់នូវអ្វីដែលកំពុងកើតឡើងនៅក្នុងរូបភាព ។ បន្ទាប់មកសុំឲ្យសិស្សម្នាក់អាន អាលម៉ា ១១:៤២–៤៤ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយប្រាប់នូវអ្វីដែលព្រះយេស៊ូវគ្រីស្ទបានធ្វើដើម្បីយើងអាចយកឈ្នះលើឧបសគ្គនៃសេចក្ដីស្លាប់ខាងរូបកាយ ។

- ស្របតាមខគម្ពីរទាំងនេះ តើព្រះយេស៊ូវគ្រីស្ទ បានធ្វើអ្វីខ្លះ ដើម្បីប្រាកដថា យើងអាចយកឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយ ? ( ជួយសិស្សឲ្យប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ដោយសារតែការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ នោះមនុស្សគ្រប់រូប នឹងបានរស់ឡើងវិញ ហើយនឹងរស់នៅជារៀងរហូត** ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៤–១៧ ។

- តើ « សេចក្ដីសង្ឃឹមនៃការរស់ឡើងវិញដ៏រុងរឿង » អាចនាំសេចក្ដីអំណរមកដល់អ្នក និងគ្រួសារអ្នកយ៉ាងដូចម្ដេចខ្លះ ?

សូមរំឭកសិស្សថា ជីវិតអមតៈ គឺជាអំណោយទានមួយ ដែលមនុស្សគ្រប់រូបនឹងទទួលបាន ។ ទោះជាយ៉ាងណា ជីវិតអស់កល្បជានិច្ច គឺជាអំណោយទានរបស់ព្រះអម្ចាស់ ចំពោះតែអ្នកទាំងឡាយណាដែលគោរពតាមច្បាប់ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អទ្រង់ប៉ុណ្ណោះ ។ សូមដាក់រូបភាព ម៉ារា និងព្រះយេស៊ូវគ្រីស្ទដែលបានមានព្រះជន្មរស់ នៅលើក្ដារខៀនជិតនឹងរូបភាពផ្សេងទៀត ។ សូមសរសេរ *ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ* នៅពីខាងលើរូបភាពទាំងបី ។

សូមគូសរង្វង់មួយទៀត នៅពីខាងលើរង្វង់ពងក្រពើរ ហើយដាក់ស្លាកវាថា *ជីវិតដ៏នៅអស់កល្បជានិច្ច* ។ សូមគូរព្រួញបញ្ឈរមួយចេញពីចុងព្រួញនៅខាងក្រោមឌីយ៉ាក្រាមទៅរកពាក្យ *ជីវិតដ៏នៅអស់កល្បជានិច្ច* ។

## ផែនការនៃសេចក្ដីសង្គ្រោះ




សូមឲ្យសិស្សសង្ខេបនូវអ្វីដែលពួកគេបានរៀនអំពីផែនការរបស់ព្រះវរបិតាសួគ៌ ដើម្បីសុភមង្គលរបស់យើង ។ សូមអញ្ជើញពួកគេឲ្យស្វែងរកឱកាសមួយ ដើម្បីបង្រៀនអំពីផែនការនៃសុភមង្គលទៅកាន់សមាជិកគ្រួសារ ឬមិត្តម្នាក់ ។

ដើម្បីបញ្ចប់មេរៀន សូមពន្យល់សិស្សថា នៅក្នុងការសិក្សារបស់ពួកគេអំពីគោលលទ្ធិ និងសេចក្ដីសញ្ញា នោះពួកគេនឹងរៀនសេចក្ដីពិតជាច្រើនទៀត ដែលទាក់ទងទៅនឹងផែនការនៃសុភមង្គល ។ មេរៀននេះ ត្រូវបានបង្ហាញតែទិដ្ឋភាពទូទៅសង្ខេបមួយប៉ុណ្ណោះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិតដែលសិស្សក្នុងថ្នាក់បានពិភាក្សាគ្នានៅក្នុងមេរៀននេះ ។

មេរៀនទី ២

# បុព្វកថាព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា មាននូវ « វិវរណៈ និងការប្រកាសដ៏បំផុសគំនិតរបស់ព្រះ ដែលបានប្រទានឲ្យសម្រាប់ការស្ថាបនា និងច្បាប់នៃនគរព្រះនៅលើផែនដី ក្នុងថ្ងៃចុងក្រោយ » (បុព្វកថាព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា)។

តាមរយៈការសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា ដោយការអធិស្ឋាន នោះសិស្សអាចពង្រឹងទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ហើយទទួលវិវរណៈផ្ទាល់ខ្លួន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា មាននូវវិវរណៈដែលបានទទួលដោយព្យាការីយ៉ូសែប ស្ម៊ីធ និងអ្នកស្នងតំណែងទាំងឡាយរបស់លោក ។

*អញ្ជើញព្រះវិញ្ញាណតាមរយៈការប្រជុំធម្មនិដ្ឋានប្រកបដោយប្រសិទ្ធភាព ។*

ការប្រជុំធម្មនិដ្ឋាននៅពេលចាប់ផ្ដើមថ្នាក់ អាចជារបៀបអស្ចារ្យបំផុត ដើម្បី ប្រមូលសិស្សទាំងឡាយដោយការបង្វែរគំនិត និង ចិត្ត របស់ពួកគេទៅកាន់កិច្ចការខាងព្រលឹងវិញ្ញាណ ។ វាអាចជួយគ្រូបង្រៀន និង សិស្សទាំងឡាយទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយ ត្រៀមខ្លួនជាស្រេចដើម្បីរៀនសូត្រ ។ ជាទូទៅការប្រជុំធម្មនិដ្ឋានត្រូវមាននូវទំនុកតម្កើងមួយ ការអធិស្ឋានមួយ និង គំនិតមួយពីព្រះគម្ពីរ ។ វាគឺមានប្រសិទ្ធភាពបំផុត នៅពេលសិស្សទាំងឡាយ ចែកចាយពីអារម្មណ៍ និង គំនិត ដែលគេមាននៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់គេ និង នៅពេលពួកគេថ្លែងទីបន្ទាល់ ។

សូមចាប់ផ្ដើមមេរៀនដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា សៀវភៅមួយណា ដែលពិភពលោកទាំងមូលនឹងទទួលបានអត្ថប្រយោជន៍មកពីការអានសៀវភៅនោះ ? ហេតុអ្វី ? (សូមពិចារណាធ្វើការដាក់បង្ហាញសៀវភៅពីរបីក្បាល ដែលអ្នកនឹងឲ្យគំនិតដល់គេ។)

បន្ទាប់ពីសិស្សបានឆ្លើយរួច សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងដោយយ៉ូសែប ស្ម៊ីធ ដូចខាងក្រោម៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវអ្វីដែលព្យាការីបានបង្រៀន ស្ដីអំពីគោលលទ្ធិ និងសេចក្ដីសញ្ញា ។



«[គោលលទ្ធិ និង សេចក្ដីសញ្ញាគឺជា] គ្រឹះនៃសាសនាចក្រនៅក្នុងថ្ងៃចុងក្រោយនេះ ហើយជាប្រយោជន៍ចំពោះពិភពលោក ដែលបង្ហាញថាកូនសោអាថ៌កំបាំងនៃនគររបស់ព្រះអង្គសង្គ្រោះរបស់យើង ត្រូវបានផ្ដល់ដល់មនុស្សម្ដងទៀត» (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ៖ យ៉ូសែប ស្ម៊ីធ* ឆ្នាំ ២០០៧]១៩៤

សូមពន្យល់ថា គម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា គឺមានប្រយោជន៍ដ៏សំខាន់ចំពោះលោកិយ ដែលប្រធាន យ៉ូសែប ហ្វីលឌិង ស្ម៊ីធ បានប្រកាសថា « វាមានតម្លៃយ៉ាងច្រើនចំពោះយើង ជាងអ្នកមានទ្រព្យសម្បត្តិនៅលើផែនដី» (*Doctrines of Salvation*, ចងក្រងដោយ ប្រ៊ូស អរ ម៉ាក់ខនគី វ៉ុល ៣ [ឆ្នាំ ១៩៥៤–៥៦], ៣:១៩៨)។ ក្នុងពេលរៀនមេរៀនថ្ងៃនេះ សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកមើលនូវវិធី ដែលការសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា អាចមានប្រយោជន៍ដល់ជីវិតរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យបើកទៅទំព័រចំណងជើង នៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ សូមពន្យល់ថា ដើម្បីធ្វើឲ្យគោលលទ្ធិ និងសេចក្ដីសញ្ញាជាប្រយោជន៍ នោះយើងត្រូវតែយល់ថាគោលលទ្ធិ និងសេចក្ដីសញ្ញាជាអ្វីជាមុនសិន ។ សូមឲ្យសិស្សអានត្រង់ទំព័រចំណងជើង និងប្រយោគដំបូងនៃបុព្វកថាឲ្យបានឮៗ ។

- តើអ្នកឲ្យនិយមន័យពាក្យ *គោលលទ្ធិ* យ៉ាងដូចម្ដេច? តើ *សេចក្ដីសញ្ញា* គឺជាអ្វី ? តើ *វិវរណៈ* គឺជាអ្វី ? (អ្នកចាំបាច់ត្រូវពន្យល់ថា *គោលលទ្ធិ* គឺជាគ្រឹះ នៃសេចក្ដីពិតដ៏អស់កល្បនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ឯ *សេចក្ដីសញ្ញា* គឺជាកិច្ចព្រមព្រៀងដ៏ពិសិដ្ឋមួយ រវាងព្រះ និងកូនចៅរបស់ទ្រង់ និង *វិវរណៈ* គឺជាទំនាក់ទំនងមកពីព្រះទៅកាន់កូនចៅរបស់ទ្រង់ ។ អ្នកអាចនឹងចង់សរសេរអំពីនិយមន័យទាំងនេះនៅលើក្ដារខៀន ហើយសុំឲ្យ សិស្សចម្លងពីទំព័រចំណងជើងចូលក្នុងគម្ពីររបស់ពួកគេ )។

សូមសិស្សឲ្យបើកទៅកថាកណ្ឌទីប្រាំបីនៃបុព្វកថាព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ( ដោយចាប់ផ្ដើមជាមួយនឹង « នៅក្នុងវិវរណៈ. . .»)។ សូមពន្យល់ថា កថាកណ្ឌនេះ មានរៀបរាប់ឧទាហរណ៍អំពីគោលលទ្ធិមួយចំនួនដែលមាននៅក្នុងគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ។ សូមអញ្ជើញសិស្សឲ្យអានប្រយោគទីមួយដោយស្ងាត់ៗ ហើយប្រាប់អំពីគោលលទ្ធិមួយ ឬច្រើន ដែលពួកគេចាប់អារម្មណ៍ចង់រៀនបានកាន់តែច្រើន ។

- តើគោលលទ្ធិណាមួយណា ដែលអ្នកចាប់អារម្មណ៍ចង់រៀនច្រើនបំផុត ? តើអ្នកគិតថា អ្នកនឹងទទួលប្រយោជន៍ពីចំណេះដឹង និងការយល់ដឹងអំពីសេចក្ដីពិតទាំងនោះកាន់តែច្រើនដោយរបៀបណា ?

សូមពន្យល់ថា ទោះជាចំណេះដឹងអំពីគោលលទ្ធិទាំងនេះ មានសារៈសំខាន់យ៉ាងខ្លាំងក្ដី ក៏តម្លៃធំបំផុតនៃគោលលទ្ធិ និងសេចក្ដីសញ្ញា គឺមាននៅក្នុងសេចក្ដីពិតដ៏សំខាន់បំផុត ដែលវាមានផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានប្រយោគចុងក្រោយនៃកថាកណ្ឌទីប្រាំបីឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលសេចក្ដីពិតដែលធ្វើឲ្យគោលលទ្ធិ និងសេចក្ដីសញ្ញាមានតម្លៃយ៉ាងខ្លាំង ។

- តើអ្វី ដែលធ្វើឲ្យគោលលទ្ធិ និងសេចក្ដីសញ្ញា « មានតម្លៃយ៉ាងខ្លាំង» ? ហេតុអ្វីក៏ទីបន្ទាល់អំពីព្រះអង្គសង្គ្រោះមានតម្លៃយ៉ាងខ្លាំងដូច្នេះ ?

- តើការសិក្សាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា បង្កើនទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច?

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀនថា៖**តាមរយៈការសិក្សាវិវរណៈនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា នោះយើងអាចពង្រឹងទីបន្ទាល់របស់យើងអំពីព្រះយេស៊ូវគ្រីស្ទ។**

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបរស់នៅរបស់ពួកគេ អាចទាញយកអត្ថប្រយោជន៍ពីទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទកាន់តែរឹងមាំនោះ ។ សូមពិចារណាពីការចែកចាយអំពីរបៀបដែលការសិក្សាព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា បានពង្រឹងទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ ។

ដើម្បីជួយសិស្សឲ្យយល់អំពីរបៀបដែលការសិក្សាព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា អាចពង្រឹងទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវប្រយោគទីពីរក្នុងកថាកណ្ឌមួយក្នុងសេចក្ដីផ្ដើម ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ថា តើជាសំឡេងអ្នកណា ដែលពួកគេនឹងស្ដាប់ឮតាមរយៈគោលលទ្ធិ និងសេចក្ដីសញ្ញា ។ បន្ទាប់ពីសិស្សបានឆ្លើយតបហើយ សូមសរសេរនូវគោលការណ៍ខាងក្រោមនៅលើក្ដារខៀន៖**នៅពេលយើងសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា នោះយើងអាចស្ដាប់ឮសំឡេងរបស់ព្រះអង្គសង្គ្រោះ ។**

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១៨:៣៤–៣៦ ឲ្យឮៗ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្វែងរករបៀបដែលយើងអាចស្ដាប់ឮសំឡេងរបស់ព្រះអម្ចាស់ នៅពេលយើងសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា ។

- តើយើងអាចថ្លែងទីបន្ទាល់អំពីអ្វីខ្លះ បើយើងសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា ?

យើងអាចចង់ពន្យល់ថា នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ពាក្យដូចជា « ព្រះអម្ចាស់» ឬ « ព្រះ» ជាទូទៅសំដៅទៅលើព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់គឺជាអ្នកថ្លែងនៅពាសពេញគោលលទ្ធិ និងសេចក្ដីសញ្ញា ទាំងមូល ។

សូមឲ្យសិស្សម្នាក់អានកថាកណ្ឌទីបីនៃបុព្វកថាឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយស្វែងរកពាក្យដែលពិពណ៌នាសំឡេងរបស់ព្រះអង្គសង្គ្រោះ ។ (អ្នកអាចផ្ដល់យោបល់ឲ្យ សិស្សគូសចំណាំអ្វីដែលពួកគេរកឃើញ )។

- តើពាក្យណាខ្លះដែលត្រូវបានប្រើដើម្បីពិពណ៌នាអំពីសំឡេងរបស់ព្រះអង្គសង្គ្រោះ ?

- តើការដែលអ្នកអាចស្ដាប់ ហើយស្គាល់សំឡេងរបស់ព្រះអម្ចាស់នោះ មានផលប្រយោជន៍អ្វីខ្លះ មកក្នុងជីវិតរបស់អ្នក ? ( សូមពន្យល់ថា នៅសប្ដាហ៍ក្រោយ សិស្សនឹងរៀនអំពីវិធីផ្សេងទៀត ដើម្បីស្ដាប់សំឡេងរបស់ព្រះអម្ចាស់ ហើយស្គាល់សំឡេងទ្រង់ ពេលទ្រង់កំពុងមានបន្ទូលទៅកាន់ពួកគេ ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀត អំពីរបៀបដែលការសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា អាចមានប្រយោជន៍ក្នុងជីវិតពួកគេ សូមពិចារណាពីការដាក់តាំងរូបភាពមនុស្សមួយចំនួន ដែលទាក់ទងនឹងវិវរណៈទាំងឡាយនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា៖បងប្រុស យ៉ូសែប (*សៀវភៅសិល្បៈដំណឹងល្អ* [២០០៩], ទំព័រ ៨៧ សូមមើលផងដែរ LDS.org) អិមម៉ា ស្ម៊ីធ (ទំព័រ ៨៨) យ៉ូហាន បាទីស្ទ ប្រគល់បព្វជិតភាពអើរ៉ុន (ទំព័រ ៩៣) ការស្ដារបព្វជិតភាពមិលគិស្សាដែកឡើងវិញ (ទំព័រ ៩៤ អេលីយ៉ាលេចមកនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ (ទំព័រ ៩៥) ។ សូមពន្យល់ថា នៅពេលពួកគេសិក្សាអំពីវិវរណៈទាំងឡាយនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា នោះពួកគេនឹងរៀនរឿងសំខាន់ៗ ទាក់ទងនឹងមនុស្សទាំងនេះ ។ សូមឲ្យសិស្សអានប្រយោគពីរដំបូងនៃកថាកណ្ឌទីប្រាំមួយនៃសេចក្ដីផ្ដើម ( ដែលចាប់ផ្ដើមជាមួយ « វិវរណៈពិសិដ្ឋទាំងនេះ. . .»)។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម និងប្រាប់អំពីស្ថានភាពដែលវិវរណៈទាំងឡាយក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ដែលបានទទួល ។

- តើឃ្លាអ្វីខ្លះ ក្នុងកថាកណ្ឌនេះ ពិពណ៌នាអំពីស្ថានភាពដែលវិវរណៈទាំងនេះ ត្រូវបានទទួល? («នៅក្នុងចម្លើយចំពោះការអធិស្ឋាន» « នៅក្នុងគ្រាចាំបាច់» និង « ស្ថានភាពជីវិតពិត»)។

ដាក់បង្ហាញក្រដាសមួយសន្លឹកដែលមានសរសេរពាក្យ *អ្នក* នៅលើនោះ ។ សូមចង្អុលបង្ហាញថា ដូចជាបុគ្គលម្នាក់ៗ ដកស្រង់ចេញពីប្រវត្តិសាសនាចក្រ នោះយើងក៏ឆ្លងកាត់ស្ថានភាពជាច្រើនផងដែរ ដែលយើងត្រូវការការណែនាំពីព្រះ ។ សូមអញ្ជើញសិស្សឲ្យពិពណ៌នាអំពី ស្ថានភាពដែលអាចកើតមានអំឡុងពេលឆ្នាំសិក្សា ដែលពួកគេអាចទទួលប្រយោជន៍មកពីការណែនាំរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។

សូមពន្យល់ថា វិវរណៈនីមួយៗ ដែលសិស្សនឹងសិក្សាក្នុងឆ្នាំនេះ គឺជាសាក្សីបន្ថែមមួយថា ព្រះពិតជាមានព្រះជន្មរស់ ថាទ្រង់មានបន្ទូលទៅកាន់កូនចៅរបស់ទ្រង់ ហើយថាទ្រង់ដឹកនាំសាសនាចក្ររបស់ទ្រង់ ។

- តើសាក្សីបន្ថែមទាំងនេះ ជួយអ្នកយ៉ាងដូចម្ដេច ពេលអ្នកស្ថិតនៅក្នុងស្ថានភាពលំបាក ?
- ផ្អែកទៅលើអ្វីដែលអ្នកបានអាននៅក្នុងកថាកណ្ឌប្រាំមួយនៃសេចក្ដីផ្ដើម តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានការណែនាំដ៏ទេវភាពនៅក្នុងគ្រាចាំបាច់របស់យើង ?

សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍មួយមកពីកថាកណ្ឌប្រាំមួយ ដោយការសរសេរនូវសេចក្ដីថ្លែងមិនពេញលេញនៅលើក្ដារខៀន៖*បើយើង* ______________________________ *នោះព្រះអម្ចាស់នឹង* ______________________________.

សូមអញ្ជើញសិស្សឲ្យសង្ខេបនូវអ្វីដែលពួកគេបានរៀន តាមរយៈការបំពេញបញ្ចប់សេចក្ដីថ្លែងនេះ។ សិស្សអាចប្រើពាក្យផ្សេងៗ ប៉ុន្តែចម្លើយរបស់ពួកគេ គួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម៖**បើយើងអធិស្ឋានសុំជំនួយក្នុងគ្រាចាំបាច់របស់យើង នោះព្រះអម្ចាស់នឹងផ្ដល់ការណែនាំដល់យើង។**

សូមសិស្សឲ្យបើកទៅកថាកណ្ឌទីបួន និង ទីប្រាំនៃសេចក្ដីផ្ដើម ។ សូមសង្ខេបកថាកណ្ឌទាំងនេះ ដោយការពន្យល់ថា ពួកគេផ្ដល់នូវទិដ្ឋភាពរួមអំពីព្រឹត្តការណ៍សំខាន់ក្នុងការស្ដារឡើងវិញអំពីសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទនៅលើផែនដី រួមទាំងការនិមិត្តដំបូង និងការបើកបង្ហាញដ៏ទេវភាពដទៃទៀត ការបកប្រែព្រះគម្ពីរមរមន ការស្ដារឡើងវិញនូវសិទ្ធិអំណាច និងកូនសោបព្វជិតភាព និងការបង្កើតសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ សូមប្រាប់សិស្សថា ពួកគេនឹងរៀនច្រើនទៀតអំពីព្រឹត្តការណ៍ពិសិដ្ឋទាំងនេះ អំឡុងពេលវគ្គសិក្សារបស់ពួកគេ ។ សូមពន្យល់ថា បទពិសោធន៍ដ៏ទេវភាពទាំងនេះកើតមាន ពេលព្យាការីយ៉ូសែប ស្ម៊ីធ និងអ្នកដទៃទៀត ស្វែងរកជំនួយ និងការណែនាំរបស់ព្រះអម្ចាស់ ។

- តើអ្នកជួបនឹងស្ថានភាពមួយ ដែលអ្នកត្រូវការជំនួយ ឬការណែនាំរបស់ព្រះអម្ចាស់ ហើយអ្នកបានទទួល នៅពេលណា?

សូមអញ្ជើញសិស្សឲ្យបើកទៅ « ទីបន្ទាល់អំពីពួកសាវកដប់ពីរនាក់ ចំពោះសេចក្ដីពិតអំពីព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា» ដែលមាននៅក្នុងបុព្វកថា ។ សូមឲ្យសិស្សអានកថាកណ្ឌពីរដំបូងឲ្យឮៗ ( ចាប់ផ្ដើមត្រង់ឃ្លា « ដូច្នេះ យើងយល់ព្រមនឹង. . . » ) ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ឃ្លាដែលផ្ដល់ចំណាប់អារម្មណ៍ដល់ពួកគេ ។

- តើឃ្លាណាខ្លះ ចេញមកពីទីបន្ទាល់របស់សាវកដប់ពីរនាក់អំពីគោលលទ្ធិ និងសេចក្ដីសញ្ញាដែលអ្នកចាប់អារម្មណ៍? ហេតុអ្វី ?

បន្ទាប់ពីសិស្សបានឆ្លើយតប សូមរំឭកពួកគេថា នៅដើមមេរៀន នោះពួកគេត្រូវបានលើកទឹកចិត្តឲ្យស្វែងរកវិធីដែលការសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា អាចជាប្រយោជន៍ក្នុងជីវិតរបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យសរសេរក្នុងសៀវភៅកំណត់ចំណាំរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីរបៀបដែលពួកគេសង្ឃឹមថា គោលលទ្ធិ និង សេចក្ដីសញ្ញា នឹងជាប្រយោជន៍ដល់ជីវិតរបស់ពួកគេ និងអ្វីដែលពួកគេនឹងធ្វើដើម្បីជួយកិច្ចការនេះឲ្យកើតឡើងបាន ។

នៅពេលសិស្សបានបញ្ចប់ការសរសេរហើយ សូមសំណូមពរពួកគេឲ្យសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញាប្រកបដោយការអធិស្ឋានរាល់ថ្ងៃក្នុងឆ្នាំសិក្សានេះ ជាមធ្យោបាយមួយដើម្បីជួយពួកគេស្ដាប់សំឡេងរបស់ព្រះអង្គសង្គ្រោះ ហើយទទួលបានការណែនាំមកពីទ្រង់ ។ អ្នកអាចនឹងចង់បញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីរបៀបដែលការសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា បានជួយអ្នកឲ្យទទួលបទពិសោធន៍ពរជ័យទាំងនេះ នៅក្នុងជីវិតអ្នក ។

*ស្គាល់ឈ្មោះរបស់សិស្ស ។*

សិស្សនឹងទទួលអារម្មណ៍នៃក្ដីស្រឡាញ់ និងការគោរព នៅពេលអ្នកហៅឈ្មោះរបស់ពួកគេ ។ ស្វាគមន៍សិស្សម្នាក់ៗមកថ្នាក់រៀន ហើយហៅឈ្មោះរបស់ពួកគេ នៅពេលពួកគេចូលរួមក្នុងមេរៀន ។ បន្ថែមពីលើនោះ សូមជួយសិស្សឲ្យរៀន និងប្រើឈ្មោះរបស់អ្នកដទៃម្នាក់ៗ ។

មេរៀនទី ៣

# ការក្បត់សាសនាដ៏ធំ

## បុព្វកថា

ព្រះយេស៊ូវគ្រីស្ទ បានស្ថាបនាសាសនាចក្ររបស់ទ្រង់ អំឡុងការបម្រើនៅលើផែនដីរបស់ទ្រង់ ។ « បន្ទាប់ពីការយាងឡើងទៅរបស់ព្រះគ្រីស្ទ ពួកសាវក បានបន្តអនុវត្តកូនសោទាំងឡាយដែលទ្រង់បានបន្សល់ទុកនឹងពួកគេ ។ ប៉ុន្តែ ដោយសារការមិនគោរពប្រតិបត្តិ និងការបាត់បង់សេចក្ដីជំនឿរបស់សមាជិក នោះពួកសាវកបានស្លាប់ដោយមិនបានប្រគល់កូនសោឲ្យអ្នកស្នងនោះទេ ។ យើងហៅហេតុការណ៍នោះថាជាសោកនាដកម្ម ‹ ការក្បត់សាសនា › » ( ហ៊ិនរី ប៊ី អាវិង « សាសនាចក្រពិត ហើយសកម្ម » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ២១ ) ។ ដោយសារតែការក្បត់សាសនានេះបានរីកសាយភាយ នោះព្រះអម្ចាស់បានដកសិទ្ធិអំណាចបព្វជិតភាពចេញពីមនុស្ស ។ ការយល់ដឹងអំពីការក្បត់សាសនាដ៏ធំ ជួយយើងយល់កាន់តែច្រើនអំពីតម្រូវការដើម្បីមានការស្ដារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នៅក្នុងថ្ងៃចុងក្រោយ ។

## យោបល់សម្រាប់ការបង្រៀន

*កំណត់ចំណាំ ៖* ដោយសារមេរៀននេះ ផ្ដល់យោបល់ឲ្យប្រើវត្ថុ និងរូបភាពច្រើន ជាជំនួយក្នុងការបង្រៀន នោះអ្នកអាចនឹងចង់ប្រមូលវត្ថុមួយចំនួនមកទុកជាមុន ។ ទាំងនេះ រួមមាន វត្ថុខាងមេកានិចមួយចំនួន និងរូបភាពដូចខាងក្រោម ៖ព្រះគ្រីស្ទកំពុងតែងតាំងពួកសាវក (*សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] ទំព័រ ៣៨ សូមមើលផងដែរ LDS.org) យុវជនកំពុងទទួលបុណ្យជ្រមុជទឹក ( លេខ ១០៣ ) អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ( លេខ ១០៥ ) ការប្រសិទ្ធពរនំបុ័ង និងទឹក ( លេខ ១០៧ ) និង គូស្វាមីភរិយាវ័យក្មេងទៅព្រះវិហារបរិសុទ្ធ ( លេខ ១២០ ) ។

> *ស្គាល់គ្នាទៅវិញទៅមក*
>
> នៅពេលវគ្គសិក្សាចាប់ផ្ដើម សូមស្វែងរកវិធីនានាដើម្បីបណ្ដុះបរិយាកាសរៀនសូត្រមួយដោយក្ដីស្រឡាញ់ ការគោរព និងមានគោលបំណង ។ ជួយសិស្សឲ្យមានអារម្មណ៍ល្អជាមួយគ្នា និងជាមួយអ្នក តាមរយៈការរៀនឈ្មោះរបស់គ្នាទៅវិញទៅមក និងរៀនអំពីចំណាប់អារម្មណ៍ ទេពកោសល្យ ឧបសគ្គ និងលទ្ធភាពរបស់គ្នាទៅវិញទៅមក ។

### ព្រះយេស៊ូវគ្រីស្ទ បានស្ថាបនាសាសនាចក្ររបស់ទ្រង់ អំឡុងការបម្រើនៅលើផែនដីរបស់ទ្រង់

សូមនាំយកផ្នែកគ្រឿងម៉ាស៊ីន ដែលចាំបាច់សម្រាប់ម៉ាស៊ីនមួយ ឬជាចំណែកនៃឧបករណ៍ដើម្បីធ្វើការ ( ដូចជាខ្សែភ្លើងពីឧបករណ៍ប្រើប្រាស់ ឬកុំព្យូទ័រ ប្រវ៉ាក់ ឬសំបកកង់ ឬក្បាលប៊ិចស៊ីឡាន) ។ សូមបង្ហាញផ្នែកទាំងនោះដល់សិស្ស ហើយសួរពួកគេថា តើវាត្រូវនឹងផ្នែកណា  ហើយវាមានមុខងារធ្វើអ្វី ។ ( បើអ្នកពុំមានគ្រឿងមេកានិចមួយទេ សូមគូសរូបនៅលើក្ដារខៀន ) ។

- តើមានអ្វីកើតឡើង នៅពេលរបស់នេះបានបាត់ពីឧបករណ៍ ?
- តើឧទាហរណ៍នេះអាចប្រៀបប្រដូចទៅនឹងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ? ( សាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ មានសមាសភាគសំខាន់ៗ បើគ្មាន សមាសភាគសំខាន់ៗទាំងនេះទេ វាពុំអាចដំណើរការ ឬមានវានោះឡើយ ) ។

សូមសិស្សឲ្យគិតអំពីផ្នែកនានាក្នុងសាសនាចក្រដែលសំខាន់ ដើម្បីឲ្យសាសនាចក្រមានដំណើរការនៃការផ្ដល់សេចក្ដីសង្គ្រោះដល់ពិភពលោក ។ សូមសរសេរក្បាលរឿង *ធាតុសំខាន់ៗនៃសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ* នៅលើក្ដារខៀន ។

សូមអញ្ជើញសិស្សឲ្យអាន អេភេសូរ ២:១៩–២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម និងប្រាប់អំពីគ្រឹះដែលព្រះយេស៊ូវគ្រីស្ទបានស្ថាបនាសាសនាចក្ររបស់ទ្រង់ អំឡុងការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ។ ( អ្នកអាចឲ្យលេខទំព័រដល់សិស្សដើម្បីជួយពួកគេរកខគម្ពីរក្នុងគម្ពីរសញ្ញាចាស់ ដែលពួកគេនឹងអានក្នុងមេរៀននេះ) ។ នៅពេលពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ សូមសរសេរសេចក្ដីពិតដូចខាងក្រោម នៅពីក្រោមក្បាលរឿង នៅលើក្ដារខៀន ៖ **ពួកសាវក និងពួកព្យាការី ជាគ្រឹះនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។** សូមឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំឃ្លានៅក្នុង អេភេសូរ ២:២០ ដែលបង្រៀនពីសេចក្ដីពិតនេះ ។

- តើហេតុអ្វីបានជាអ្នកគិតថា ពួកសាវក និងពួកព្យាការី ត្រូវបានចាត់ទុកជា « គ្រឹះ » នៃសាសនាចក្រដូច្នេះ ?

ដើម្បីជួយសិស្សស្គាល់ធាតុសំខាន់ដទៃទៀតនៃសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ សូមដាក់បង្ហាញរូបភាពព្រះគ្រីស្ទ កំពុងតែងតាំងពួកសាវក (*សៀវភៅសិល្បៈដំណឹងល្អ* លេខ ៣៨ ) ។ សូមឲ្យសិស្សពិពណ៌នាអ្វីដែលបានកើតឡើងនៅក្នុងរូបភាពនោះ ។ បន្ទាប់មកអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាកុស ៣:១៣–១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ធាតុនៃសាសនាចក្រដទៃទៀត ដែលវាសំខាន់ចំពោះសេចក្ដីសង្គ្រោះរបស់កូនចៅព្រះ ។ បន្ទាប់ពីសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **សិទ្ធិអំណាចបព្វជិតភាព គឺចាំបាច់ដើម្បីទទួលបានពិធីបរិសុទ្ធ និងសេចក្ដីសញ្ញានៃសេចក្ដីសង្គ្រោះ ។**

សូមពន្យល់ថា មុនពេលព្រះអង្គសង្គ្រោះចាកចេញពីផែនដី នោះទ្រង់បានប្រទានដល់ពួកសាវកររបស់ទ្រង់នូវសិទ្ធិអំណាចដើម្បីដឹកនាំសាសនាចក្រ និងធ្វើកិច្ចការក្នុងព្រះនាមរបស់ព្រះសម្រាប់សេចក្ដីសង្គ្រោះនៃកូនចៅរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ប្រាប់ពីធាតុសំខាន់ដទៃទៀតនៃសាសនាចក្រពិត ៖



« សេចក្ដីពិត និងគោលលទ្ធិ ដែលយើងបានទទួល បានមក ហើយនឹងបន្តមានមក តាមរយៈវិវរណៈរបស់ព្រះ ។ នៅក្នុងទំនៀមទំលាប់ជំនឿមួយចំនួន. . .បញ្ហាខាងគោលលទ្ធិ អាចក្លាយជាការខ្វែងមតិយោបល់គ្នា ។ . . .ប៉ុន្តែ នៅក្នុងសាសនាចក្រសព្វថ្ងៃ ក៏ដូចជាជំនាន់បុរាណ ការស្ថាបនាគោលលទ្ធិនៃព្រះគ្រីស្ទ ឬការកែគំនិតក័ន្តច្រឡំខាងគោលលទ្ធិ គឺជារឿងមួយនៃវិវរណៈរបស់ព្រះចំពោះអ្នកទាំងឡាយណាដែលព្រះអម្ចាស់ បានប្រគល់ឲ្យនូវសិទ្ធិអំណាចជាសាវក» ( គោលលទ្ធិនៃព្រះគ្រីស្ទ » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៨៦ ) ។

- យោងតាមអែលឌើរ គ្រីស្តូហ្វឺសិន តើតួនាទីសំខាន់មួយរបស់ព្យាការី និងពួកសាវកគឺជាអ្វី ? ( សិស្សអាចប្រើពាក្យផ្សេងពីគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់អំពីសេចក្ដីពិតដូចខាងក្រោម ៖ **ពួកសាវក និងពួកព្យាការី ស្ថាបនាគោលលទ្ធិត្រឹមត្រូវតាមរយៈវិវរណៈរបស់ព្រះ ។** អ្នកអាចនឹងត្រូវការរំឭកដល់សិស្សថា *គោលលទ្ធិ* សំដៅទៅលើសេចក្ដីពិតជាគ្រឹះ និងអស់កល្បនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ សូមបន្ថែមសេចក្ដីពិតនេះទៅលើបញ្ជីនៅលើក្ដារខៀន ) ។

សូមបង្ហាញសិស្សនូវបញ្ជីគោលលទ្ធិគ្រឹះ ដែលបានរកឃើញនៅក្នុងសេចក្ដីបន្ថែមនៃសៀវភៅសិក្សានេះ ឬនៅក្នុងសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរ ។ សូមពន្យល់ថាសិស្សថ្នាក់សិក្ខាសាលា ត្រូវបានលើកទឹកចិត្តដើម្បីទទួលបាននូវការយល់ដឹងកាន់តែជ្រៅជ្រះអំពីគោលលទ្ធិគ្រឹះ ក្នុងពេលសិក្សាថ្នាក់សិក្ខាសាលារបស់ពួកគេទាំងមូល ។ ការធ្វើដូច្នេះ នឹងជួយពួកគេពង្រឹងទីបន្ទាល់របស់ពួកគេ ហើយរៀបចំពួកគេដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ សូមអញ្ជើញសិស្សឲ្យមើលគោលលទ្ធិទាំងនេះអំឡុងពេលនៃការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញានាឆ្នាំនេះ ។

សូមអញ្ជើញសិស្សឲ្យជ្រើសរើសគោលលទ្ធិគ្រឹះមួយ ដែលមានអត្ថន័យចំពោះពួកគេ ហើយសួរពួកគេមួយចំនួនឲ្យពន្យល់ដោយសង្ខេបអំពីមូលហេតុដែលពួកគេជ្រើសរើសវា ។

- ហេតុអ្វីក៏វាសំខាន់ថា គោលលទ្ធិពិត ត្រូវបានបង្រៀន ហើយត្រូវយល់ដឹងឲ្យបានត្រឹមត្រូវនៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ដូច្នេះ ? ( ពេលសិស្សឆ្លើយតប នោះអ្នកអាចចែកចាយសេចក្ដីថ្លែងដូចខាងក្រោមដោយប្រធានប៊ិយដ៍ ឃេ ផាកកឺ ជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « ពេលយល់គោលលទ្ធិពិត នោះវាផ្លាស់ប្ដូរអាកប្បកិរិយា និងអត្តចរិក » [« Little Children » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ១៧ ) ។

ដើម្បីជួយសិស្សគិតអំពីធាតុសំខាន់ៗដទៃទៀតនៃសាសនាចក្ររបស់ព្រះអម្ចាស់ សូមបង្ហាញរូបភាព យុវជនកំពុងទទួលបុណ្យជ្រមុជទឹក (*សៀវភៅសិល្បៈដំណឹងល្អ* លេខ ១០៣ ) អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ( លេខ ១០៥ ) ការប្រសិទ្ធពរនំប៉័ង និងទឹក ( លេខ ១០៧ ) និង គូស្វាមីភរិយាវ័យក្មេងកំពុងទៅព្រះវិហារបរិសុទ្ធ ( លេខ ១២០ ) ។ សូមសួរសិស្សអំពីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ ពិធីប្រសិទ្ធពរនំប៉័ង និងទឹក និងការផ្សារភ្ជាប់ជាទូទៅ ។ ( ទាំងអស់នេះជាពិធីបរិសុទ្ធ ) ។

- តើពិធីបរិសុទ្ធជាអ្វី ? ( ជាកិច្ចការដ៏ពិសិដ្ឋ និងជាផ្លូវការមួយ ដែលបានធ្វើឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាព ) ។

- ហេតុអ្វីក៏អ្នកគិតថា ពិធីបរិសុទ្ធនានា គឺជាផ្នែកសំខាន់មួយនៃសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ ? ( ដើម្បីជួយសិស្សឆ្លើយសំណួរនេះ អ្នកអាចអញ្ជើញពួកគេឲ្យអាន យ៉ូហាន ៣:៥ រួចហើយសួរពួកគេថាតើអ្វីនឹងកើតឡើង បើពួកគេគ្មានវិធីណាអាចជ្រមុជទឹកបាននោះ ។ សូមគូសបញ្ជាក់ថា រាល់ពិធីបរិសុទ្ធនៃការសង្គ្រោះទាំងអស់នៃបព្វជិតភាព គឺមានអមជាមួយនឹងសេចក្ដីសញ្ញា ដែលជាការព្រមព្រៀងដ៏ពិសិដ្ឋជាមួយព្រះ ) ។

សូមថ្លែងទីបន្ទាល់ថា **នៅក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលបានពិធីបរិសុទ្ធនានា ដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។** សូមបន្ថែមសេចក្ដីពិតនេះទៅលើបញ្ជីនៅលើក្ដារខៀន ) ។

សូមពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវគ្រីស្ទសុគត នោះទ្រង់បានរស់ឡើងវិញ ហើយទ្រង់បានយាងឡើងទៅស្ថានសួគ៌ ។ ទ្រង់ឈប់មានវត្តមានជារូបកាយសាច់ឈាម ដើម្បីដឹកនាំសាសនាចក្រនៅលើផែនដីទៀតហើយ ។ ទោះជាទ្រង់ពុំមានវត្តមានជារូបកាយសាច់ឈាមនៅលើផែនដីក្ដី **ក៏ព្រះយេស៊ូវគ្រីស្ទ ដឹកនាំ និងណែនាំដល់ពួកសាវកររបស់ទ្រង់ តាមរយៈវិវរណៈដែរ ។** នៅក្រោមការដឹកនាំរបស់ពួកសាវកទ្រង់ នោះសាសនាចក្រពីបុរាណ បានរីកសាយយ៉ាងឆាប់ ហើយមានមនុស្សរាប់ពាន់នាក់បានទទួលបុណ្យជ្រមុជទឹក ។ ក្រុមជំនុំពួកបរិសុទ្ធ ភាគច្រើនត្រូវបានបង្កើតឡើងនៅអាណាចក្ររ៉ូម ។ អែលឌើរ ប៊ីស្សព ឌីកុន សង្ឃ គ្រូ និងគ្រូផ្សាយដំណឹងល្អ ( អយ្យកោ ) ត្រូវបានហៅ និងផ្ដល់សិទ្ធិអំណាចបព្វជិតភាពដោយពួកសាវក ។

## ការក្បត់សាសនាដ៏ធំ បានកើតឡើង អំឡុងជាច្រើនសតវត្សន៍ បន្ទាប់ពីការបម្រើក្នុងជីវិតមែងស្លាប់របស់ព្រះអម្ចាស់

សូមសរសេរសេចក្តីពិតដូចខាងក្រោមនៅលើក្តារខៀន ៖ **ការក្បត់សាសនា កើតឡើងនៅពេលមនុស្សងាកចេញពីគោលលទ្ធិពិតនៃដំណឹងល្អ ហើយបដិសេធពួកអ្នកបម្រើដែលមានសិទ្ធិអំណាចរបស់ព្រះអម្ចាស់ ។**

សូមពន្យល់ថា គ្រានៃការក្បត់សាសនាទូទៅ បានកើតឡើងនៅពេញទាំងប្រវត្តិសាសនានៃពិភពលោក ។ ឧទាហរណ៍មួយនៃការក្បត់សាសនាដ៏ធំ ដែលបានកើតឡើងបន្ទាប់ពីព្រះអង្គសង្គ្រោះបានស្ថាបនាសាសនាចក្ររបស់ទ្រង់ (សូមមើល ថែស្សាឡូនិចទី ២ ២:១–៣) ។ បន្ទាប់ពីការស្លាប់នៃពួកសាវករបស់ព្រះអង្គសង្គ្រោះ នោះគោលការណ៍ទាំងឡាយនៃដំណឹងល្អត្រូវបានខូចបង់ ហើយនឹងមានការផ្លាស់ប្តូរដែលមិនមានការអនុញ្ញាតកើតឡើងនៅក្នុងអង្គការសាសនាចក្រ និង ពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាព ។ ( សូមមើល *ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* | ឆ្នាំ ២០០៤ | ទំព័រ ១៣–១៤ ) ។

សូមសរសេរសេចក្តីយោងបទគម្ពីរដូចខាងក្រោមនៅលើក្តារខៀន ៖ *កិច្ចការ ១២:១–៣; ធីម៉ូថេទី ២ ៤:៣–៤; ពេត្រុសទី ២ ២:១–២ ។*

សូមពន្យល់ថា ក្រៅពីកិច្ចខិតខំរបស់ពួកសាវក នោះសាសនាចក្រជំនាន់មុន បានជួបនឹងការគំរាមគំហែង ។ សូមបែងចែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ សូមអញ្ជើញក្រុមនីមួយៗឲ្យសិក្សាវគ្គបទគម្ពីរមួយនៅលើក្តារខៀន ដោយស្វែងរកអ្វីមួយ ដែលបានគំរាមគំហែងសាសនាចក្រ ។ ( សម្រាប់អ្នកទាំងឡាយដែលកំពុងអាន កិច្ចការ ១២:១–៣ នោះអ្នកអាចចាំបាច់ត្រូវបញ្ជាក់ថា យ៉ាកុប និង ពេត្រុស គឺជាពួកសាវក ) ។ បន្ទាប់ពីផ្តល់ពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗរាយការណ៍នូវអ្វីដែលក្រុមបានរកឃើញ ។

- ហេតុអ្វីអ្នកគិតថា ការគំរាមគំហែងទាំងនេះ គ្រោះថ្នាក់ខ្លាំងចំពោះសាសនាចក្រ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងដូចខាងក្រោម ដោយប្រធាន ប៊យដ៍ ឃេ ផាកកឺ ជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលថ្លែងអំពីការបាត់បង់ដ៏ធំនូវសេក្តីបទថ្មី ដែលសាសនាចក្របានជួបអំឡុងគ្រានេះថា ៖



« យ៉ាកុបត្រូវបានសម្លាប់នៅក្រុងយេរូសាឡិមដោយស្តេចហេរ៉ូឌ ។ ពេត្រុស និង ប៉ុល ស្លាប់នៅក្រុងរ៉ូម ។ ទំនៀមទំលាប់បានប្រាប់ថា ភីលីព បានចេញទៅភាគខាងកើត ។ មានរឿងជាច្រើនទៀតដែលយើងពុំដឹង ។

« ពួកលោកបានបំបែកគ្នា ពួកលោកបានបង្រៀន ថ្លែងទីបន្ទាល់ ហើយបានស្ថាបនាសាសនាចក្រឡើង ។ ហើយពួកគេបានស្លាប់ដើម្បីជំនឿរបស់ពួកគេ ហើយដោយការស្លាប់របស់ពួកគេ នោះកើតមាននូវភាពងងឹតនៃការក្បត់សាសនាជាច្រើនសតវត្សន៍ » (ពួកដប់ពីរនាក់ » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៨៤ ) ។

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យបន្តអានការពន្យល់របស់ប្រធានផាកកឺ អំពីការបាត់បង់ដ៏ធំបំផុត នាំឲ្យមានការក្បត់សាសនាដ៏ធំ ៖



« របស់ដ៏មានតម្លៃបំផុតដែលបានបាត់បង់នៅក្នុងការក្បត់សាសនា គឺសិទ្ធិអំណាចដែលពួកសាវកកាន់–គឺកូនសោបព្វជិតភាព ។ ដើម្បីឲ្យសាសនាចក្រនេះ ជាសាសនាចក្រ*របស់ទ្រង់* សាសនាចក្រនេះត្រូវតែមានកូរ៉ុមមួយនៃពួកសាវកដប់ពីរនាក់ ដែលកាន់កូនសោទាំងឡាយនៃបព្វជិតភាព ហើយប្រគល់វាទៅដល់មនុស្សដទៃទៀត » (« The Twelves » ទំព័រ ៨៤ ) ។

- តើការបាត់បង់សិទ្ធិអំណាចបព្វជិតភាព នឹងជះឥទ្ធិពលដល់ធាតុសំខាន់ៗដទៃទៀតនៃសាសនាចក្រយ៉ាងដូចម្តេច ?
- តើមានវិធីណា ដែលមនុស្សអាចដឹកនាំសាសនាចក្រ ដោយគ្មានពួកសាវក និងពួកព្យាការី សិទ្ធិអំណាចបព្វជិតភាព ឬចំណេះដឹងត្រឹមត្រូវអំពីគោលលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទឬទេ ? ហេតុអ្វីយល់ស្រប ឬ ហេតុអ្វីមិនយល់ស្រប ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ផាកកឺ ៖



« នៅពេលជាច្រើនសតវត្សន៍បានកន្លងផុតទៅ នោះអណ្ដាតភ្លើងនៃគោលលទ្ធិ បានភ្លឺព្រឹមៗ ហើយស្រអាប់ងងឹតទៅ ។ ពិធីបរិសុទ្ធនានា ត្រូវបានផ្លាស់ប្ដូរ ឬបោះបង់ចោល ។ ខ្សែតំណត្រូវបានផ្ដាច់ ហើយសិទ្ធិអំណាចដើម្បីប្រគល់ព្រះវិញ្ញាណបរិសុទ្ធ ដែលជាអំណោយទានមួយត្រូវបានបាត់ ។ យុគសម័យដ៏ខ្មៅងងឹតនៃការក្បត់សាសនា បានរីកសាយពេញលើពិភពលោក » (« The Cloven Tongues of Fire » *Ensign* ខែ ឧសភា ឆ្នាំ ២០០២,ទំព័រ ៨ ) ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់អំពី ការក្បត់សាសនាដ៏ធំ និងផលវិបាករបស់វាដូច្នេះ ? (ទោះជាសិស្សអាចប្រាប់ពីមូលហេតុផ្សេងៗក្ដី សូមគូសបញ្ជាក់ថា ការយល់ដឹងអំពី ការធ្លាក់ចុះដ៏ធំនេះ ជួយយើងដឹងថា **ការស្ដារឡើងវិញនៃគោលលទ្ធិ និងសិទ្ធិអំណាចរបស់ព្រះយេស៊ូវគ្រីស្ទ គឺចាំបាច់ដើម្បីយកឈ្នះលើឥទ្ធិពលនៃការក្បត់សាសនាដ៏ធំ ) ។**

សូមពន្យល់ថា ទោះជាវានឹងពុំមានការក្បត់សាសនាពីសេចក្ដីពិតជាទូទៅមួយទៀតក្ដី ក៏យើងម្នាក់ៗ ត្រូវតែការពារទប់ទល់នឹងការក្បត់សាសនាផ្ទាល់ខ្លួន តាមរយៈការរក្សាសេចក្ដីសញ្ញា ការគោរពព្រះបញ្ញត្តិ ការធ្វើតាមអ្នកដឹកនាំសាសនាចក្រ ការទទួលទានសាក្រាម៉ង់ និងការពង្រឹងទីបន្ទាល់របស់យើងដោយខ្ជាប់ខ្ជួន តាមរយៈការសិក្សាព្រះគម្ពីរ ការអធិស្ឋាន និងការបម្រើ ( សូមមើល *ពិតចំពោះសេចក្ដីជំនឿ* ទំព័រ ១៣–១៤) ។ សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះ កូនចៅរបស់ទ្រង់ ភាពពិតនៃការក្បត់សាសនាដ៏ធំ និងអំណោយទានដ៏មហិមានៃការស្ដារឡើងវិញនៃដំណឹងល្អ ។

មេរៀន ទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១

## បុព្វកថា

ត្រឹមខែវិច្ឆិកា ឆ្នាំ ១៨៣១ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈច្រើនជាង ៦០ ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកសាសនាចក្រភាគច្រើន ពុំមានវិធីចូលទៅប្រើច្បាប់ចម្លងនៃវិវរណៈទាំងនោះឡើយ ។ ព្យាការីយ៉ូសែប បានកោះហៅឲ្យមានសន្និសីទមួយនៅ ហៃរ៉ុម អូហៃអូ ដើម្បីពិភាក្សាអំពីការបោះពុម្ពវិវរណៈទាំងឡាយ ជាសៀវភៅមួយ ដែលនឹងហៅថា សៀវភៅនៃព្រះបញ្ញត្តិ ។ គណៈកម្មការនៃពួកអែលឌើរ បានព្រាងបុព្វកថាមួយចំពោះសៀវភៅនោះ ។ ដោយពុំពេញចិត្តនឹងការពង្រាងនេះ អ្នកទាំងឡាយដែលចូលរួមក្នុងសន្និសីទ បានស្នើសុំឲ្យយ៉ូសែប ស៊្មីធ សួរដល់ព្រះអម្ចាស់សុំបុព្វកថាមួយ ។ បន្ទាប់ពីការទូលអង្វរដល់ព្រះអម្ចាស់ក្នុងការអធិស្ឋាន យ៉ូសែប បានទទួលបុព្វកថាដោយវិវរណៈ ។ បុព្វកថារបស់ព្រះអម្ចាស់ ចំពោះសៀវភៅនៃព្រះបញ្ញត្តិក្លាយជាកណ្ឌទី ១ នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១–១៦

*ព្រះអម្ចាស់ព្រមានអំពីការវិនិច្ឆ័យ ដែលនឹងកើតមានមកលើអ្នកបះបោរ នៅពេលការយាងមកជាលើកទីពីរ ។*

អ្នកអាចនឹងចាប់ផ្ដើមមេរៀននេះ ដោយការសុំដល់សិស្សក្នុងថ្នាក់ឲ្យ ពិចារណាពីសំណួរនានាដូចខាងក្រោម ពេលអ្នកអានវាឮៗ ។ បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ដល់សិស្សហើយ សូមអញ្ជើញសិស្សម្នាក់ ឬពីរនាក់ចែកចាយចម្លើយរបស់ពួកគេ ។

- តើមាននរណាម្នាក់ធ្វើឲ្យអ្នកចាប់ចំណាប់អារម្មណ៍ ហើយព្រមានអ្នកអំពីអ្វីមួយនៅពេលណាដែរឬទេ ? តើអ្នកឆ្លើយតបដោយរបៀបណា ?
- តើអ្នកមានអារម្មណ៍ដឹងថាមនុស្សម្នាក់ ខំព្រមានដល់អ្នកយ៉ាងដូចម្ដេច ? ហេតុអ្វីអ្នកមានអារម្មណ៍បែបនោះ ?

សូមដាក់បង្ហាញគម្ពីរ គោលលទ្ធិ និង សេចក្ដីសញ្ញា របស់អ្នក ហើយពន្យល់ថា នៅក្នុងគម្ពីរនេះ ព្រះអម្ចាស់បានផ្ដល់នូវការព្រមាន ជាក់បទបញ្ញត្តិ និងការណែនាំជាច្រើន ដែលសំខាន់សម្រាប់សុភមង្គល និងសេចក្ដីសង្គ្រោះរបស់យើង ។ សូមប្រាប់សិស្សថា ព្រះអម្ចាស់ បានបើកសម្ដែងកណ្ឌទី ១ ជាបុព្វកថា ចំពោះវិវរណៈដទៃទៀត នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។ បុព្វកថា រៀបចំអ្នកអានសម្រាប់មាតិកានៃសៀវភៅមួយ ដោយសង្ខេបសារ និងគោលបំណងរបស់អ្នកនិពន្ធ ។ ដើម្បីជួយសិស្សឲ្យយល់អំពីបរិបទប្រវត្តិសាស្ត្រសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ១ អ្នកអាចនឹងចង់រៀបរាប់ពីព័ត៌មានមួយចំនួនមកពីបុព្វកថានៃមេរៀននេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម និងប្រាប់អំពីពាក្យ ឬឃ្លានានាដែលព្រះអម្ចាស់ បានប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍អ្នកទាំងឡាយដែលនឹងអានបន្ទូលទ្រង់ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេរកឃើញ ។ ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់ពន្យល់ថា *ការស្ដាប់* មានន័យថា ស្ដាប់ដោយយកចិត្តទុកដាក់ ។ នៅពេលយើងពិតជាស្ដាប់ព្រះអម្ចាស់ នោះយើងនឹងដើរតាមការប្រឹក្សារបស់ទ្រង់ ហើយគោរពតាមបទបញ្ញត្តិរបស់ទ្រង់ ) ។

- តើព្រះអម្ចាស់កំពុងមានបន្ទូលទៅកាន់នរណា ក្នុងខគម្ពីរទាំងនេះ ? ( ព្រះអម្ចាស់ កំពុងមានបន្ទូលទៅកាន់កូនចៅមនុស្សទាំងអស់លើផែនដី ពុំគ្រាន់តែសមាជិកនៃសាសនាចក្រប៉ុណ្ណោះទេ ) ។
- តើអ្នកគិតថាវាមានន័យយ៉ាងណា ត្រង់ឃ្លាថា « សេចក្ដីទុច្ចរិតរបស់ពួកគេនឹងត្រូវថ្លែងប្រាប់ពីលើដំបូលផ្ទះ ហើយអំពើស្ងាត់កំបាំងរបស់ពួកគេ នឹងត្រូវបើកសម្ដែងមកឲ្យឃើញ» នោះ? (គ និង ស ១:៣) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៤–៧ ឲ្យឮៗ ហើយសួរដល់សិស្សក្នុងថ្នាក់ឲ្យប្រាប់ពីរបៀបដែលព្រះអម្ចាស់បានមានបន្ទូលថា ទ្រង់នឹងផ្ដល់ការព្រមានរបស់ទ្រង់ដល់មនុស្សទាំងអស់តាមរបៀបណា ។

- តើព្រះអម្ចាស់មានបន្ទូលថា ទ្រង់នឹងផ្ដល់ការព្រមានរបស់ទ្រង់ដល់មនុស្សទាំងអស់តាមរបៀបណា ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់ពីគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអម្ចាស់ មានបន្ទូលការព្រមានរបស់ទ្រង់ដល់មនុស្ស**

#### *ល្បឿនមេរៀនសមរម្យ*

សូមកំណត់ល្បឿនមេរៀននិមួយៗ ដើម្បីអ្នកបានចំណាយពេលគ្រប់គ្រាន់ពិភាក្សាអំពីធាតុសំខាន់ៗបំផុត ។ បើអ្នកចំណាយពេលច្រើនពេកទៅលើផ្នែកដំបូងនៃមេរៀន នោះអ្នកនឹងមានអារម្មណ៍ថា ត្រូវប្រញាប់បញ្ចប់នៅផ្នែកចុងក្រោយនៃមេរៀន ។ នៅពេលអ្នករៀបចំដើម្បីបង្រៀន សូមស្មានពីពេលវេលាដែលនឹងចំណាយ ដើម្បីបង្រៀនដោយមានប្រសិទ្ធភាពលើផ្នែកនីមួយៗនៃមេរៀន ។ សូមកំណត់ថា ផ្នែកណាមួយអាចត្រូវការពេលច្រើនបំផុត ឲ្យសិស្សពិភាក្សាអំពីគោលលទ្ធិ និងគោលការណ៍នានា ហើយនឹងចែកចាយបទពិសោធន៍ដែលទាក់ទងនោះ ។

**ទាំងអស់ តាមរយៈពួកសិស្សជម្រើសរបស់ទ្រង់** ។ អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំគោលលទ្ធិនេះ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៤ ឬសរសេរវានៅរឹមខគម្ពីររបស់ពួកគេ ) ។

- តើព្រះអម្ចាស់ នឹងមានបន្ទូល ហើយបោះពុម្ពការព្រមានរបស់ទ្រង់ តាមរយៈពួកសិស្សណាខ្លះ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៨–១០ ដោយការពន្យល់ថា ព្រះអម្ចាស់ បានប្រកាសថា ទ្រង់នឹងជំនុំជម្រះមនុស្សទាំងអស់ ស្របតាមទង្វើរបស់ពួកគេ និងរបៀបដែលពួកគេប្រព្រឹត្តនឹងអ្នកដទៃ ។ សូមសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១១–១៤ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម និងប្រាប់ការព្រមានបន្ថែមទៀត ។

- ស្របតាមលេខយោង ១២ *ខ* តើព្រះអម្ចាស់សំដៅទៅលើព្រឹត្តការណ៍អ្វីខ្លះ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១២?
- នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៤ តើអ្នកគិតថាព្រះអម្ចាស់ចង់មានន័យយ៉ាងណា នៅពេលទ្រង់បានព្រមានថា អ្នកទាំងឡាយដែលពុំស្ដាប់តាមពួកព្យាការី និងពួកសាវករបស់ទ្រង់ នឹងត្រូវកាត់ចេញ ? ( ពួកគេនឹងត្រូវបំបែកចេញពីពួកសុចរិត ហើយបាត់បង់ពរជ័យ ដែលមានតាមរយៈពិធីបរិសុទ្ធ និងសេចក្ដីសញ្ញានានានៃដំណឹងល្អ ) ។

សូមពន្យល់ថា ការព្រមានទាំងនេះ គឺចាំបាច់ណាស់ ដោយសារតែមានអំពើទុច្ចរិត និងការក្បត់សាសនានៅទូទាំងពិភពលោក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១៥–១៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពាក្យ ឬឃ្លានានា ដែលបង្ហាញពីសេចក្ដីទុច្ចរិត ឬការក្បត់សាសនា ។ សូមឲ្យសិស្សពីរបីនាក់ប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើមនុស្សនៅក្នុងជំនាន់របស់យើងដើរ « តាមវិធីផ្ទាល់ខ្លួន [ ពួកគេ ] ហើយដើរតាមរូបភាពនៃព្រះផ្ទាល់ខ្លួន [ ពួកគេ ] តាមរបៀបណាខ្លះ ? (គ និង ស ១:១៦) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៧–៣៣

*ដំណឹងល្អត្រូវបានស្ដារឡើងវិញតាមរយៈយ៉ូសែប ស៊្មីធ ដើម្បីរៀបចំពិភពលោកសម្រាប់គ្រោះមហន្តរាយនៃថ្ងៃចុងក្រោយ*

សូមឲ្យសិស្សក្នុងថ្នាក់មើលត្រួសៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៧ ហើយប្រាប់ពាក្យ ដែលព្រះអម្ចាស់បានប្រើសំដៅទៅលើសេចក្ដីទុច្ចរិត ការក្បត់សាសនា និងការបំផ្លិចបំផ្លាញ ដែលនឹងកើតឡើងនៅថ្ងៃចុងក្រោយ ។ នៅពេលសិស្សប្រាប់ពាក្យ *គ្រោះមហន្តរាយ* សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៧–៣៣ ព្រះអម្ចាស់ បានផ្ដល់ដំណោះស្រាយដើម្បីជួយយើងឆ្លងកាត់គ្រោះមហន្តរាយនៃថ្ងៃចុងក្រោយនោះ ។ ( អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ *គ្រោះមហន្តរាយ* គឺសំដៅទៅលើព្រឹត្តការណ៍ប្រកបដោយគ្រោះថ្នាក់ ដែលមានជាមួយនូវការបាត់បង់ដ៏ធំ ការឈឺចាប់ និងការរងទុក្ខ) ។

សូមចម្លងតារាងខាងក្រោម ដាក់លើក្ដារខៀន ឬ រៀបចំវាជាក្រដាសសម្រាប់ចែកឲ្យសិស្ស ៖

| | តើដំណោះស្រាយ ដែលព្រះអម្ចាស់បានប្រទានសម្រាប់គ្រោះមហន្តរាយ ដែលនឹងកើតមានមកលើផែនដី មានអ្វីខ្លះ ? | តើដំណោះស្រាយនេះ ជួយយើងប្រឈមមុខនឹងគ្រោះមហន្តរាយនៃថ្ងៃចុងក្រោយយ៉ាងដូចម្ដេច? |
|---|---|---|
| គ និង ស ១:១៧ | | |
| គ និង ស ១:១៨–២៣ | | |
| គ និង ស ១:២៩ | | |
| គ និង ស ១:៣០ | | |

អ្នកអាចនឹងចង់សុំឲ្យសិស្សបំពេញតារាងខ្លួនឯង ឬជាដៃគូ ។ សូមសិស្សឲ្យអានវគ្គបទគម្ពីរ នៅផ្នែកខាងឆ្វេងនៃតារាង ហើយប្រាប់ពីដំណោះស្រាយ ដែលព្រះអម្ចាស់បានប្រទានឲ្យ ដើម្បីជួយយើងពេលគ្រោះមហន្តរាយនៃថ្ងៃចុងក្រោយ ។ សូមឲ្យពួកគេសរសេរពិពណ៌នា ឬគូររូបភាពអំពីអ្វីដែលពួកគេរកឃើញនៅក្នុងកូឡោនកណ្ដាលនៃតារាងនោះ ។ នៅក្នុងប្រអប់ខាងស្ដាំ សូមពួកគេឲ្យសរសេរការពន្យល់សង្ខេបៗ អំពីរបៀបដែលដំណោះស្រាយនិមួយៗរបស់ព្រះអម្ចាស់ អាចជួយយើងក្នុងគ្រាគ្រោះមហន្តរាយនៃថ្ងៃចុងក្រោយ ។

ក្រោយពីឲ្យពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានកត់ត្រានៅក្នុងតារាង ។ ចម្លើយនៅក្នុងកូឡោនកណ្ដាល គួរតែមានដូចខាងក្រោម ៖ ព្រះអម្ចាស់ បានហៅយ៉ូសែប ស៊្មីធ ហើយបានប្រទានវិវរណៈ និងបទបញ្ញត្តិដល់លោក ( សូមមើល គ និង ស ១:១៧) ព្រះអម្ចាស់ បានបញ្ជាពួកអ្នកបម្រើទ្រង់ឲ្យទៅទូទាំងផែនដី ដើម្បីប្រកាសដំណឹងល្អរបស់ទ្រង់ ហើយស្ថាបនាសេចក្ដីសញ្ញារបស់ទ្រង់ ( សូមមើល គ និង ស ១:១៨–២៣) ព្រះអម្ចាស់ បានបើកសម្ដែងព្រះគម្ពីរមរមន ( សូមមើល គ និង ស ១:២៩) ហើយព្រះអម្ចាស់បានស្ដារសាសនាចក្ររបស់ទ្រង់នៅលើផែនដី ( សូមមើល

គ និង ស ១:៣០) ។ ចម្លើយនៅក្នុងក្ដារខៀនខាងស្ដាំអាចមានផ្សេងៗគ្នា ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

ដើម្បីជួយសិស្សគិតបន្ថែមអំពី ការប្រកាសរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣០ អ្នកអាចនឹងចង់ឲ្យយោបល់ដល់ពួកគេឲ្យគូសចំណាំពាក្យក្នុងខគម្ពីរនេះ ដែលបង្ហាញពីសេចក្ដីពិតដូចខាងក្រោម ៖ **សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាសាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផ្ទៃផែនដី ។**

- ផ្អែកទៅលើអ្វីដែលអ្នកបានរៀននៅមេរៀនមុន អំពីការក្បត់សាសនាដ៏ធំ តើអ្នកនឹងពន្យល់ដល់នរណាម្នាក់ អំពីមូលហេតុដែល សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាសាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផ្ទៃផែនដីដោយរបៀបណា ?

- តើអ្វីដែលធ្វើឲ្យសាសនាចក្រនេះ « សកម្ម » ?

សូមពន្យល់ថា តាមរយៈអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអម្ចាស់អាចដឹកនាំសាសនាចក្ររបស់ទ្រង់ ជាមួយនឹងការបន្តផ្ដល់វិវរណៈ ។ វិវរណៈដែលមានជាបន្តបន្ទាប់នេះ គឺជាឧទាហរណ៍មួយពីរបៀបដែលសាសនាចក្រនេះសកម្ម ។

- ហេតុអ្វីក៏វាសំខាន់ចំពោះអ្នក ដើម្បីដឹងថាអ្នកស្ថិតនៅក្នុងសាសនាចក្រតែមួយ ដែលពិត ហើយសកម្មនៅលើផ្ទៃផែនដី ?

- តើអ្នកគិតថា ព្រះអម្ចាស់ចង់មានន័យយ៉ាងណា ពេលទ្រង់មានបន្ទូលថ្លែងថា ទ្រង់សព្វព្រះទ័យនឹងសាសនាចក្ររបស់ទ្រង់ « ទាំងស្រុង ហើយមិនមែននិមួយៗទេ » នោះ ? (គ និង ស ១:៣០) ។ ( ទោះជាសាសនាចក្រពិត ហើយសាសនាចក្រទាំងស្រុង គឺជាទីសព្វព្រះទ័យដល់ព្រះអម្ចាស់ក្ដី ក៏មានសមាជិកមួយចំនួនក្នុងសាសនាចក្រ អាចនឹងមិនរស់នៅតាមរបៀបមួយដែលសព្វព្រះទ័យចំពោះទ្រង់ដែរ) ។

សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣១–៣៣ ហើយប្រាប់អំពីអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីអំពើបាប និងការប្រែចិត្ត ។

- តើព្រះអម្ចាស់ទតមើលអំពើបាបយ៉ាងដូចម្ដេច ? តើយើងអាចត្រូវបានអភ័យទោសដោយរបៀបណា ?

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៣ តើអ្វីខ្លះកើតឡើងចំពោះ អ្នកទាំងឡាយដែលមិនប្រែចិត្ត ?

- តើវាមានន័យយ៉ាងណាដែលថា « ពន្លឺ » ត្រូវបានដកចេញនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៤–៣៩

*ព្រះអម្ចាស់ ដឹកនាំយើងឲ្យស្រាវជ្រាវទំនាក់ទំនង និងបទបញ្ញត្តិ ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ។*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៤–៣៦ ដោយពន្យល់ថា ព្រះអម្ចាស់ បានបង្ហាញព្រះរាជបំណងរបស់ទ្រង់ម្ដងទៀត ដើម្បីព្រមានដល់មនុស្សទាំងអស់ឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៩ ឲ្យឮៗ ។ សូមដល់សិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលសេចក្ដីពិតដែលព្រះអម្ចាស់បានគូសបញ្ជាក់នៅក្នុងសេចក្ដីបញ្ចប់នៃបុព្វកថារបស់ទ្រង់ ចំពោះ គោលលទ្ធិ និង សេចក្ដីសញ្ញា ។

- តើសេចក្ដីពិតអ្វីខ្លះ ដែលព្រះអម្ចាស់គូសបញ្ជាក់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៩? ( នៅពេលសិស្សចែកចាយសេចក្ដីពិតដែលពួកគេបានប្រាប់ សូមប្រាកដថា សេចក្ដីតទៅនេះគឺច្បាស់លាស់ ៖ **យើងត្រូវស្រាវជ្រាវបទបញ្ញត្តិដែលព្រះអម្ចាស់បានប្រទានឲ្យ ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់ នឹងត្រូវបានបំពេញទាំងអស់ ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់គឺពិត ទោះជាវាត្រូវបានមានបន្ទូលដោយទ្រង់ផ្ទាល់ ឬដោយពួកអ្នកបម្រើទ្រង់ក្ដី**) ។

- ផ្អែកទៅលើអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ តើអ្នកអាចត្រូវបានប្រទានពរយ៉ាងដូចម្ដេច បើអ្នកស្រាវជ្រាវបទបញ្ញត្តិ និងវិវរណៈទាំងឡាយ ដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញានោះ ?

សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយពីរបៀបដែលការស្រាវជ្រាវបទគម្ពីរ បានប្រទានពរដល់ជីវិតរបស់ពួកគេ ។ អ្នកក៏អាចចង់អញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវគោលដៅដើម្បីសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញាប្រចាំថ្ងៃ អំឡុងឆ្នាំសិក្សា ។ សូមឲ្យពួកគេពិចារណាអំពីពេលវេលា ទីកន្លែង និងរយៈពេលដែលពួកគេនឹងសិក្សារាល់ថ្ងៃនោះ ។ សូមប្រាប់ពួកគេថា អ្នកនឹងធ្វើការតាមដានជារឿយៗ ដើម្បីជួយពួកគេទទួលជោគជ័យក្នុងការសិក្សាប្រចាំថ្ងៃរបស់ពួកគេ ។

មេរៀន ទី ៥

# ការសិក្សាព្រះគម្ពីរ

## សេចក្តីផ្តើម

មេរៀននេះនឹងជួយសិស្សឲ្យរៀនរបៀបយល់ដឹងបរិបទ និងមាតិកាបទគម្ពីរកាន់តែប្រសើរ ស្គាល់គោលលទ្ធិ និងគោលការណ៍ដំណឹងល្អ ដែលមានក្នុងបទគម្ពីរ ហើយអនុវត្តសេចក្តីពិតទាំងនោះក្នុងជីវិតរបស់ពួកគេ ។ នៅពេលសិស្សរកឃើញ ហើយធ្វើតាមសេចក្តីពិតដ៏អស់កល្បជានិច្ច ដែលមាននៅក្នុងបទគម្ពីរទាំងឡាយ នោះដំណឹងល្អអាចចាក់ចូលកាន់តែជ្រៅទៅក្នុងដួងចិត្តរបស់ពួកគេ ។ សូមពិចារណាអំពីរបៀបនានា ដើម្បីមើលសម្ភារក្នុងមេរៀននេះនៅពេញមួយឆ្នាំ ។

## យោបល់សម្រាប់ការបង្រៀន

### គោលបំណងនៃការសិក្សាបទគម្ពីរ

មុនពេលចូលរៀន សូមដាក់វត្ថុសាមញ្ញមួយនៅក្នុងថ្នាក់ ដូចជា ខ្មៅដៃ សៀវភៅកត់ចំណាំ ឬសៀវភៅទំនុកដំកើង នៅកន្លែងណាមួយក្នុងបន្ទប់ ដែលមើលឃើញច្បាស់ ។ សូមជ្រើសរើសកន្លែងមួយដែលវត្ថុនោះ នឹងពុំរញ៉េរញ៉ៃ ឬដាក់នៅកន្លែងដែលសិស្សងាយឃើញ ។ សូមចាប់ផ្តើមមេរៀនដោយប្រាប់សិស្សថា អ្នកបានបាត់អ្វីមួយ ហើយអ្នកត្រូវការជំនួយពីពួកគេឲ្យជួយរក ។ សូមឲ្យពួកគេរកមើលក្នុងបន្ទប់ ប៉ុន្តែកុំប្រាប់ពួកគេនូវអ្វីដែលពួកគេត្រូវរកនោះឡើយ ។ បន្ទាប់ពីសិស្សរកមិនឃើញក្នុងរយៈពេលខ្លីមក សូមពិពណ៌នាអំពីអ្វីដែលពួកគេគួរស្វែងរក ហើយសុំឲ្យពួកគេព្យាយាមរកម្តងទៀត ។

- ហេតុអ្វីបានជាវាងាយស្រួលជាង ដើម្បីរកអ្វីដែលអ្នកកំពុងរកជាលើកទីពីរនេះ ?

លើកគម្ពីរអ្នកឡើង ។ សូមចង្អុលបង្ហាញថា វាងាយស្រួលជាងដើម្បីរកអ្វីមួយ ដែលយើងដឹងថាត្រូវរកអ្វី ការសិក្សាព្រះគម្ពីររបស់យើង អាចកាន់តែមានអត្ថន័យ ពេលយើងថាត្រូវរកអ្វី ពេលយើងសិក្សានោះ ។

ដើម្បីជួយសិស្សស្គាល់នូវអ្វីដែលយើងគួរតែស្រាវជ្រាវ ពេលយើងសិក្សាបទគម្ពីរ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងដូចខាងក្រោម ដោយប្រធាន ម៉ារ៉ុន ជី រ៉មនី នៃគណៈប្រធានទីមួយ ។ មុនពេលសិស្សអាន សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងស្តាប់រកអ្វីដែលពួកគេគួរតែអាចរកបានជានិច្ចនៅក្នុងបទគម្ពីរ ពេលពួកគេស្វែងរកវា ។ ( អ្នកអាចនឹងចង់ផ្តល់ដល់សិស្សនូវច្បាប់ចម្លងនៃសេចក្តីថ្លែងរបស់ព្យាការីមួយនេះ និងសេចក្តីថ្លែងដទៃៗទៀត នៅក្នុងមេរៀននេះ ) ។



« មនុស្សម្នាក់ពុំអាចសិក្សាបទគម្ពីរដោយស្មោះ ដោយពុំរៀនគោលការណ៍នានានៃដំណឹងល្អទេ ដោយសារតែបទគម្ពីរ ត្រូវបានសរសេរទុក ដើម្បីរក្សាគោលការណ៍នានានោះ» ( « The Message of the Old Testament » [ address to CES religious educators ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៧៩ ] ទំព័រ ៣ LDS.org) ។

- ផ្អែកទៅលើការពន្យល់របស់ប្រធាន រ៉មនី តើយើងគួរស្វែងរកអ្វី នៅពេលយើងសិក្សាបទគម្ពីរ ?

- តើគោលការណ៍មួយគឺជាអ្វី ?

សូមបញ្ជាក់ ឬបំពេញបន្ថែមចម្លើយរបស់សិស្ស តាមរយៈការអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការពន្យល់ដូចខាងក្រោម ដោយ អែលឌើរ រីឆាដ ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ មុនពេលសិស្សអាន សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ស្តាប់ថា គោលការណ៍គឺជាអ្វី ។ សូមសិស្សពាក់កណ្តាលថ្នាក់ទៀត ស្តាប់ពីមូលហេតុនៃការស្រាវជ្រាវគោលការណ៍នានាក្នុងបទគម្ពីរគឺសំខាន់ខ្លាំងណាស់ ។



« គោលការណ៍ទាំងឡាយ ជាសេចក្ដីពិតបរិសុទ្ធ បានរៀបចំសម្រាប់ការអនុវត្តចំពោះស្ថានភាពផ្សេងៗគ្នាដ៏ទូលំទូលាយ ។ គោលការណ៍ពិត ធ្វើឲ្យការសម្រេចចិត្តច្បាស់លាស់ ទោះជាស្ថិតនៅក្រោមស្ថានភាពច្របូកច្របល់ និងការបង្ខិតបង្ខំដ៏ខ្លាំងបំផុតក្ដី » ( Acquiring Spiritual Knowledge » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ទំព័រ ៨៦ ) ។

- ស្របតាមអែលឌើរ ស្កត តើគោលការណ៍គឺជាអ្វី ? ហេតុអ្វីការស្វែងរកគោលការណ៍នៅក្នុងបទគម្ពីរសំខាន់ខ្លាំងម្ល៉េះ ?

សូមពន្យល់ថា គោលការណ៍ និងគោលលទ្ធិទាំងឡាយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាសេចក្ដីពិតគ្រឹះ ពុំផ្លាស់ប្ដូរ ដែលផ្ដល់ការដឹកនាំនៅក្នុងជីវិតរស់នៅរបស់យើង ។ គោលលទ្ធិ និងគោលការណ៍ គឺជាអ្វីដែលព្រះអម្ចាស់ និងពួកព្យាការីរបស់ទ្រង់មានបំណងចង់ឲ្យយើងរៀនមកពីវិវរណៈ ទេសនកថា និងព្រឹត្តការណ៍នានាដែលបានកត់ត្រានៅក្នុងបទគម្ពីរ ។

ដើម្បីជួយសិស្សរកឃើញគំរូមួយនៃគោលលទ្ធិ និងគោលការណ៍ ដែលបានបង្រៀននៅក្នុងបទគម្ពីរ សូមអញ្ជើញពួកគេឲ្យនឹកគិតទៅលើការនិមិត្តដំបូងរបស់យ៉ូសែប ស៊្មីធ ។ សូមសួរដល់ពួកគេ បើពួកគេអាចប្រាប់សេចក្ដីពិតសាមញ្ញមួយ ដែលយើងអាចរៀនមកពីបទពិសោធន៍របស់យ៉ូសែប ស៊្មីធបានឬទេ ។ សិស្សអាចនឹងប្រាប់ពីគោលលទ្ធិ និងគោលការណ៍ផ្សេងៗ ។ សេចក្ដីពិតដូចខាងក្រោម គឺជាគំរូមួយ ៖ **បើយើងអធិស្ឋានដោយសេចក្ដីជំនឿ នោះព្រះនឹងឆ្លើយតបការអធិស្ឋានរបស់យើង ។**

## ការយល់ដឹងអំពីបរិបទ និង មាតិកានៃបទគម្ពីរ

សូមបង្ហាញចំណិតផ្លែឈើ ដែលត្រូវតែបកសំបកពីមុនអាចបរិភោគបាន ( ឧទាហរណ៍ ផ្លែចេក ឬផ្លែក្រូច ) ។

- តើអ្នកត្រូវធ្វើអ្វីខ្លះ ពីមុនអ្នកអាចប្រើវត្ថុនេះ សម្រាប់គោលបំណងដែលចង់បាន ? ( បកសំបកចេញ ) ។

- បើផ្នែកសំខាន់ និងមានប្រយោជន៍របស់វា គឺស្ថិតនៅផ្នែកខាងក្នុង តើគោលបំណងនៃសំបកផ្នែកខាងក្រៅគឺជាអ្វី ? ( ដើម្បីរក្សា និងបញ្ជូនមាតិកា ) ។

សូមពន្យល់ថា ផ្លែឈើនៅក្នុងសំបក អាចប្រៀបដូចជាគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលមាននៅក្នុងបទគម្ពីរដែរ ។ សំបកខាងក្រៅ អាចប្រៀបទៅនឹងព្រឹត្តការណ៍ មនុស្ស និងទេសនកថាបទគម្ពីរ ។ ក៏ដូចជាសំបកដែលរក្សា និងជួយបញ្ជូនសាច់ផ្លែឈើនៅខាងក្នុងដែរ ដំណើររឿងបទគម្ពីរទាំងនេះ បញ្ជូនគោលលទ្ធិ និងគោលការណ៍នៃដំណឹងល្អដល់យើង តាមរបៀបមួយ ដែលជួយយើងឲ្យយល់ ចងចាំ និងអនុវត្តវាក្នុងជីវិតរបស់យើង ។

សូមឲ្យសិស្សចែកចាយនូវអ្វីដែលពួកគេបានធ្វើ ដើម្បីជួយពួកគេទទួលបានការយល់ដឹងកាន់តែប្រសើរអំពីទីតាំង តំណររឿង ព្រឹត្តការណ៍ និងព័ត៌មានលម្អិតដទៃទៀតនៃបទគម្ពីរ ។ ( អ្នកអាចរៀបរាប់គំនិតមួយចំនួនរបស់ពួកគេនៅលើក្ដារខៀន ) ។ បន្ទាប់ពីសិស្សបានចែកចាយគំនិតមួយចំនួនហើយ សូមពន្យល់អំពីជំនាញការសិក្សាបទគម្ពីរដូចខាងក្រោមទៅដល់សិស្សក្នុងថ្នាក់ ហើយចំណាយពេលពីរបីនាទីដើម្បីអនុវត្តវា ។

**ទីតាំងប្រវត្តិសាស្ត្រ** ៖ សូមពន្យល់ថា កណ្ឌនីមួយៗនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា រួមមាននូវបុព្វកថាមួយ ដែលពិពណ៌នាអំពីកង្វល់ សំណួរ ឬព្រឹត្តការណ៍ជាប្រវត្តិសាស្ត្រ ដែលទាក់ទងនឹងវិវរណៈក្នុងកណ្ឌនោះ ។ ការដឹងអំពីព័ត៌មានលម្អិតទាំងនេះ អាចជួយយើងឲ្យយល់វិវរណៈ ។

ដើម្បីបង្ហាញពីរបៀបដែលការដឹងអំពីព័ត៌មានលម្អិតទាំងនេះ អាចបង្កើនការយល់ដឹងអំពីវិវរណៈមួយ សូមអញ្ជើញសិស្សមួយចំនួនដើម្បីផ្លាស់វេណគ្នាអានឲ្យឮៗដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–៨ ។ បន្ទាប់មកសុំសិស្សឲ្យអានផ្នែកបុព្វកថាដោយស្ងៀមស្ងាត់ ស្វែងរកព័ត៌មានដែលជួយពួកគេយល់អំពីខទាំងនេះ ។

- តើការដឹងថាយ៉ូសែប ស៊្មីធ ត្រូវបានជាប់ក្នុងគុកលីបឺធីអស់ជាច្រើនខែ ជួយយើងឲ្យយល់ខទាំងនេះកាន់តែប្រសើរដោយរបៀបណា ?

**និយមន័យពាក្យ** ៖ សូមចង្អុលបង្ហាញថា ពាក្យខ្លះ បានប្រើនៅក្នុងបទគម្ពីរ អាចនឹងមិនដែលស្គាល់ ។ វចនានុក្រមព្រះគម្ពីរប៊ីបសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ លេខយោងបទគម្ពីរ និងវចនានុក្រមធម្មតា អាចជួយយើងរៀននិយមន័យនៃពាក្យនានា ហើយយល់ពីអត្ថន័យរបស់វាបាន ។

ដើម្បីបង្ហាញឧទាហរណ៍ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២ ដោយស្ងាត់ស្ងៀម ។ សូមពន្យល់ថា ពាក្យ *ស្នាក់នៅ* អាចមានន័យថា ពន្យាពេល ឬផ្អាក ។

- តើការដឹងនិយមន័យនេះ ជួយយើងឲ្យយល់ខនេះកាន់តែច្បាស់យ៉ាងដូចម្ដេច ?

## ការស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

សូមពន្យល់ថា នៅពេលយើងបង្កើនការយល់ដឹងរបស់យើងអំពីបរិបទ និងមាតិកានៃវគ្គបទគម្ពីរ នោះយើងត្រូវបានត្រៀមខ្លួនដើម្បីស្គាល់សេចក្តីពិតនៃដំណឹងល្អ ដែលមាននៅក្នុងនោះហើយ ។ សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយអែលឌើរ រីឆាដ ជី ស្កត ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលឃ្លាដែលពិពណ៌នាអំពីអ្វី ដែលយើងគួរធ្វើដើម្បីស្គាល់សេចក្តីពិតនានា ពេលយើងសិក្សាបទគម្ពីរ ។



« នៅពេលអ្នកស្វែងរកចំណេះដឹងខាងវិញ្ញាណ សូមស្វែងរកគោលការណ៍នានា ។ សូមបែងចែកវាចេញពីព័ត៌មានលម្អិត ដែលបានប្រើដើម្បីពន្យល់វានោះដោយប្រុងប្រយ័ត្ន ។. . .វាសក្តិសមនឹងកិច្ចខិតខំដ៏មហិមាដើម្បីរៀបចំសេចក្តីពិតដែលយើងប្រមូលផ្តុំ ដើម្បីបង្កើតសេចក្តីថ្លែងការណ៍សាមញ្ញអំពីគោលការណ៍ »(« Acquiring Spiritual Knowledge » ទំព័រ ៨៦ ) ។

- តើឃ្លាដែលអែលឌើរ ស្កត បានប្រើដើម្បីពិពណ៌នាអំពីការស្គាល់សេចក្តីពិតនៅក្នុងបទគម្ពីរមានអ្វីខ្លះ ? ( «សូមញែកវាចេញពីព័ត៌មានលម្អិតដែលបានប្រើដើម្បីពន្យល់វានោះដោយប្រុងប្រយ័ត្ន » « រៀបចំសេចក្តីពិតដែលយើងប្រមូលផ្តុំដើម្បីបង្កើតជាសេចក្តីថ្លែងការណ៍សាមញ្ញៗអំពីគោលការណ៍ » ) ។

- ហេតុអ្វីក៏អ្នកគិតថាវាសំខាន់ដើម្បី « រៀបចំសេចក្តីពិត » ដែលយើងរៀនមកពីវគ្គបទគម្ពីរឲ្យទៅជាសេចក្តីថ្លែងការសាមញ្ញមួយអំពីគោលលទ្ធិ ឬ គោលការណ៍ដូច្នេះ ?

សូមចង្អុលបង្ហាញថា គោលលទ្ធិ និងគោលការណ៍ដំណឹងល្អមួយចំនួន គឺងាយស្រួលដើម្បីស្គាល់ ដោយសារវាត្រូវបានថ្លែងដោយចំៗនៅក្នុងបទគម្ពីរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២១ :៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម និងប្រាប់សេចក្តីពិតនានា ដែលត្រូវបានថ្លែងដោយចំៗនៅក្នុងខគម្ពីរទាំងនេះ ។ សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងស៊ូទ្រាំការណ៍នេះដោយហ្មត់ចត់ នោះព្រះនឹងដំកើងយើងឡើង ហើយជួយយើងឲ្យមានជ័យជំនះលើពួកខ្មាំងសត្រូវរបស់យើង ។**

សូមពន្យល់ថា គោលលទ្ធិ និងគោលការណ៍ជាច្រើន ពុំបានថ្លែងចំៗនៅក្នុងអត្ថបទគម្ពីរទេ ប៉ុន្តែផ្ទុយទៅវិញត្រូវបានបង្ហាញ ឬពិពណ៌នាទៅក្នុងខគម្ពីរជាច្រើនទៀត ។ ការស្គាល់ប្រភេទនៃគោលលទ្ធិ និងគោលការណ៍នេះ តម្រូវឲ្យមានការស្គាល់សេចក្តីពិត ដែលបានបង្ហាញនៅក្នុងវគ្គបទគម្ពីរ ហើយថ្លែងសេចក្តីពិតទាំងនោះតាមរបៀបដ៏ច្បាស់លាស់ និងសាមញ្ញ ។ ដើម្បីជួយសិស្សឲ្យរៀនស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលពុំបានថ្លែងដោយចំៗ សូមផ្តល់យោបល់ឲ្យពួកគេសួរសំណួរដូចជា « តើខ្ញុំអាចរៀនអ្វីខ្លះមកពីរឿងនេះ ? » « តើសារលិខិត ឬចំនុចសំខាន់នៃខគម្ពីរទាំងនេះជាអ្វី ? » ឬ « តើព្រះអម្ចាស់ មានបំណងចង់ឲ្យខ្ញុំរៀនអ្វីខ្លះមកពីរឿងនេះ ? »

សូមអញ្ជើញសិស្សឲ្យហាត់រៀនស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដោយការមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១២១:១–៨ ។ សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ចំណាំរបស់ពួកគេ ឬសៀវភៅកំណត់ត្រាការសិក្សាបទគម្ពីរនូវសេចក្តីពិតដំណឹងល្អមួយ ដែលយើងអាចរៀនមកពីការអធិស្ឋានរបស់យ៉ូសែប និងចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋាននោះ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សមួយចំនួនឲ្យអានគោលលទ្ធិ ឬគោលការណ៍ ដែលពួកគេបានស្គាល់ចេញមកពីខគម្ពីរទាំងនេះ ។ សេចក្តីពិតទាំងឡាយ ដែលសិស្សបានប្រាប់ អាចរួមមានដូចខាងក្រោម ៖

**ព្រះស្តាប់ឮការអធិស្ឋានរបស់យើង ។**

**បើយើងទូលហៅទ្រង់នៅក្នុងគ្រាលំបាក នោះទ្រង់អាចប្រទានក្តីសុខសាន្តដល់យើង ។**

## ការអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយក្នុងជីវិតរបស់យើង

សូមយោងទៅរឿងចំណិតផ្លែឈើ ដែលសិស្សក្នុងថ្នាក់បានពិភាក្សាកាលពីមុនក្នុងមេរៀនម្តងទៀត ។

- តើផ្លែឈើមានតម្លៃទេ បើវាពុំដែលបកសំបកមកបរិភោគផងនោះ ?

- បើគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលយើងស្គាល់ក្នុងបទគម្ពីរ អាចប្រៀបប្រដូចទៅនឹងចំណិតផ្លែឈើ ដែលយើងបានបក តើយើងគួរធ្វើអ្វីខ្លះ នៅពេលយើងស្គាល់សេចក្តីពិតទាំងនោះ ? ( អនុវត្តវាក្នុងជីវិតរបស់យើង ) ។

សូមពន្យល់ថា នៅពេលយើងដឹងពីសេចក្តីពិត និងសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលយើងបានស្គាល់នៅក្នុងបទគម្ពីរ នោះយើងនឹងមានបំណងប្រាថ្នាដើម្បីអនុវត្តវាក្នុងជីវិតរបស់យើង ។ សូមអញ្ជើញសិស្សឲ្យចែកចាយជាមួយដៃគូ អំពីរបៀបដែលពួកគេអាចអនុវត្តសេចក្តីពិតមួយ ដែលពួកគេបានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១២១:១–៨ ។

សូមអញ្ជើញឲ្យសិស្សម្នាក់ អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊យដ៏ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយប្រាប់ឃ្លានានា ដែលមានអត្ថន័យចំពោះពួកគេ ។



« បើ [ អ្នក ] បានស្គាល់វិវរណៈ នោះអ្នកគ្មានការសង្ស័យទេ–ទោះជាផ្ទាល់ខ្លួន ជាសង្គម ឬនយោបាយ ឬវិជ្ជាជីវៈ– ដែលចាំបាច់ត្រូវទៅដោយគ្មានចម្លើយនោះឡើយ ។ វាមាននូវភាពពោរពេញនៃដំណឹងល្អដ៏អស់កល្បជានិច្ច ។ នៅក្នុងនោះ យើងរកឃើញគោលការណ៍នៃសេចក្ដីពិត ដែលនឹងដោះស្រាយរាល់ការប្របូកប្របល់ និងរាល់បញ្ហា និងរាល់ទ្វេគ្រោះ ដែលនឹងប្រឈមមុខចំពោះគ្រួសារមនុស្ស ឬបុគ្គលម្នាក់ៗ » ( « Teach the Scriptures » [ address to CES religious educators ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៧៧ ] ទំព័រ ៣–៤ » LDS.org ។

- តើឃ្លាណាដែលអ្នកចាប់អារម្មណ៍ ? ហេតុអ្វី ?

សូមបញ្ចប់មេរៀនដោយការចែកចាយអំពីរបៀបដែលគោលលទ្ធិ និងគោលការណ៍ទាំងឡាយក្នុងបទគម្ពីរ បានប្រទានពរដល់ជីវិតរបស់អ្នក ពេលអ្នកបានរកឃើញ ហើយអនុវត្តវាក្នុងជីវិត ។ សូមពិចារណាធ្វើការអញ្ជើញដល់សិស្សឲ្យចែកចាយគោលលទ្ធិ ឬគោលការណ៍មួយ ដែលពួកគេបានរកឃើញនៅក្នុងបទគម្ពីរ និងរបៀបដែលវាបានប្រទានពរដល់ជីវិតរបស់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកសេចក្តីពិតដ៏អស់កល្បជានិច្ចទាំងនេះដោយឧស្សាហ៍ព្យាយាម  នៅពេលពួកគេសិក្សាបទគម្ពីរ ហើយអនុវត្តវាក្នុងជីវិតរបស់ពួកគេ ។

មេរៀនសិក្សានៅផ្ទះ

# ផែនការនៃសេចក្ដីសង្គ្រោះ–ការសិក្សាព្រះគម្ពីរ ( មេរៀនទី ១ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបញ្ចប់មេរៀនទី ១នៃមេរៀនសិស្សដែលសិក្សានៅផ្ទះដែលមានបួនមេរៀននោះ ។ ការដឹងពីអ្វីដែលសិស្សកំពុងសិក្សានឹងជួយអ្នករៀបចំមេរៀនសម្រាប់បង្រៀន ។ សេចក្ដីសង្ខេបមិនមែនជាផ្នែកមួយនៃមេរៀនទេ ហើយក៏ពុំមែនដើម្បីចែកចាយជាមួយសិស្សដែរ ។ ដោយសារមេរៀនដែលអ្នកនឹងបង្រៀនសម្រាប់មេរៀនទី១ ផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីប៉ុណ្ណោះ មានពេលខ្លះអ្នកអាចមានអារម្មណ៍បំផុសឡើងដើម្បីរំឭក ឬ ពិភាក្សាគោលលទ្ធិ និង គោលការណ៍ផ្សេងទៀតតាមការបំផុសគំនិតពីព្រះវិញ្ញាណ និង ទៅតាមតម្រូវការនៃសិស្សរបស់អ្នក ។

### ថ្ងៃទី ១ ( ផែនការនៃសេចក្ដីសង្គ្រោះ )

ការសិក្សាពីផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ បានជួយសិស្សឲ្យស្គាល់ថាគោលបំណងនៃផែនការនេះ គឺដើម្បីផ្ដល់ផ្លូវមួយដល់យើងទទួលបានជីវិតអមតៈ និង ជីវិតដ៏នៅអស់កល្បជានិច្ច ។ សិស្សបានរៀនថាព្រះវរបិតាសួគ៌ បានបញ្ជូនយើងមកកាន់ផែនដីដើម្បីទទួលរូបរាងកាយ និងដើម្បីទទួលបទពិសោធន៍ ហើយរីកចម្រើនឡើង ។ ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ធ្វើឲ្យយើងអាចយកឈ្នះលើឥទ្ធិពលនៃអំពើបាប និង សេចក្ដីស្លាប់ ។

### ថ្ងៃទី ២ ( ការក្បត់សាសនាដ៏ធំ )

អំឡុងពេលរៀនអំពីការក្បត់សាសនាដ៏ធំ សិស្សបានឃើញថាព្យាការី និង សាវកបង្កើតជាគ្រឹះនៃសាសានាចក្ររបស់ព្រះគ្រីស្ទ ហើយជួយរក្សាឲ្យព្រះវិហារបានបរិសុទ្ធ ដោយការបង្រៀននូវគោលលទ្ធិត្រឹមត្រូវ ។ លើពីនេះ សិទ្ធិអំណាច និង កូនសោបព្វជិតភាពគឺចាំបាច់ដើម្បីទទួលសេចក្ដីសញ្ញា និង ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ដែលទាំងអស់នេះត្រូវបានទទួលនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ ការក្បត់សាសនាកើតឡើងនៅពេលមនុស្សបែរចេញឆ្ងាយពីសេចក្ដីពិតនៃដំណឹងល្អ ហើយបដិសេធចោលពួកអ្នកបម្រើដែលមានសិទ្ធិអំណាចរបស់ព្រះអម្ចាស់ ។ ការស្ដារឡើងវិញនៃសេចក្ដីពិត និង សិទ្ធិអំណាច និង កូនសោបព្វជិតភាពគឺចាំបាច់ដើម្បីយកឈ្នះឥទ្ធិពលនៃការក្បត់សាសនាដ៏ធំ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១)

នៅក្នុងការសិក្សារបស់ពួកគេអំពីបុព្វកថារបស់ព្រះអម្ចាស់អំពីព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា នោះសិស្សបានរៀនថាព្រះអម្ចាស់មានព្រះបន្ទូលពីការប្រមានរបស់ទ្រង់ ទៅកាន់មនុស្សទាំងអស់ តាមរយៈកូនសិស្សជម្រើសរបស់ទ្រង់ ហើយថាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាសាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផែនដីនេះ ។ សិស្សបានឃើញថា ពួកគេត្រូវស្រាវជ្រាវព្រះបញ្ញត្តិទាំងឡាយដែលព្រះអម្ចាស់បានប្រទានមក ព្រះបន្ទូលរបស់ព្រះអម្ចាស់នឹងត្រូវបានសម្រេចទាំងអស់ ហើយព្រះបន្ទូលរបស់ព្រះអម្ចាស់គឺពិតទោះបីជាវាត្រូវបានមានព្រះបន្ទូលពីទ្រង់ផ្ទាល់ ឬ ពីអ្នកបម្រើរបស់ទ្រង់ក្ដី ។

### ថ្ងៃទី ៤ ( ការសិក្សាព្រះគម្ពីរ )

នៅក្នុងមេរៀននេះ សិស្សបានរៀនថាព្រះគម្ពីរត្រូវបានសរសេរឡើងដើម្បីរក្សាទុកនូវសេចក្ដីពិតដ៏អស់កល្ប ដែលបានស្គាល់ថាជាគោលលទ្ធិ និង គោលការណ៍ ។ ពួកគេបានរៀនថា ដើម្បីរកឲ្យឃើញសេចក្ដីពិតដ៏អស់កល្បទាំងនេះ នោះវាសំខាន់ថាយើងត្រូវយល់នូវបរិបទ និង មាតិកានៃអត្ថបទព្រះគម្ពីរជាមុនសិន ។ សិស្សបានរៀនថា នៅពេលណាដែលពួកគេយល់បរិបទ និង មាតិកាវាហើយនោះវាសំខាន់ណាស់ដើម្បីបង្ហាញគោលលទ្ធិ និង គោលការណ៍ ដែលពួកគេរកឃើញជាសេចក្ដីថ្លែងការណ៍ដ៏ច្បាស់ សាមញ្ញអំពីសេចក្ដីពិត ។ ជាចុងក្រោយ សិស្សបានរៀនថាតម្លៃនៃសេចក្ដីពិតនៃការសិក្សាព្រះគម្ពីរបានមកពី ការអនុវត្តនូវគោលលទ្ធិ និង គោលការណ៍ទាំងនោះក្នុងជីវិតផ្ទាល់ខ្លួន ដែលពួកគេឃើញនៅក្នុងព្រះគម្ពីរ ។

## សេចក្ដីផ្ដើម

មេរៀននេះនឹងណែនាំសិស្សឲ្យស្គាល់ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ដោយប្រើបុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា និង កណ្ឌទី ១ ។ សិស្សនឹងរៀនថា គោលលទ្ធិ និង សេចក្ដីសញ្ញាមាននូវ « វិវរណៈ និង ការប្រកាសដ៏បំផុស គំនិតរបស់ព្រះ ដែលបានប្រទានឲ្យសម្រាប់ការស្ថាបនា និងប្រតិបត្តិច្បាប់នៃនគរព្រះនៅលើផែនដីក្នុងថ្ងៃចុងក្រោយ » ( បុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ) ។ ការសិក្សាព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាស្ត្រ សាសនាចក្រអាចពង្រឹងទីបន្ទាល់របស់សិស្សអំពីព្រះយេស៊ូវគ្រីស្ទ ។

*កំណត់ចំណាំ ៖* ដោយសារថ្ងៃនេះជាថ្ងៃដំបូងនៃថ្នាក់រៀន អ្នកអាចអញ្ជើញពួកគេឲ្យសួរសំណួរ ដែលពួកគេមានអំពីកម្មវិធីសិក្សា នៅផ្ទះ និង របៀបសិក្សាព្រះគម្ពីរដោយខ្លួនឯងឲ្យមានប្រសិទ្ធិភាព ។

## យោបល់សម្រាប់ការបង្រៀន

### បុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ

*គោលលទ្ធិ និង សេចក្ដីសញ្ញា មាននូវវិវរណៈដែលបានទទួលដោយព្យាការីយ៉ូសែប ស្ម៊ីធ និងអ្នក ស្នងតំណែងទាំងឡាយរបស់លោក ។*

អ្នកអាចចាប់ផ្ដើមមេរៀនដោយសួរសិស្សថា ពួកគេគិតថាសៀវភៅអ្វីខ្លះនៅក្នុងពិភពលោកទាំងមូលនេះ ដែលមានប្រយោជន៍ ប្រសិនបើយើងអានវានោះ ហើយប្រាប់ពីមូលហេតុនោះ ។ ( សូមគិតយកសៀវភៅពីរបីក្បាល ដែលអ្នកចង់ផ្ដល់យោបល់ឲ្យគេ អាន ) ។ បន្ទាប់ពីសិស្សឆ្លើយហើយ សូមឲ្យសិស្សអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ដោយព្យាការី យ៉ូសែប ស្ម៊ីធ ហើយ អញ្ជើញសិស្សឲ្យស្ដាប់រកមើលអ្វីដែលព្យាការីបានបង្រៀនអំពីព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ៖



« [ វិវរណៈក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញាគឺជា ] គ្រឹះនៃសាសនាចក្រនៅក្នុងថ្ងៃចុងក្រោយ នេះ ហើយជាប្រយោជន៍ដល់ពិភពលោក ដែលបង្ហាញថាកូនសោអាថ៌កំបាំងនៃនគររបស់ព្រះអង្គសង្គ្រោះ របស់យើង ត្រូវបានផ្ដល់ដល់មនុស្សម្ដងទៀត » (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ១៩៤) ។

ក្នុងពេលរៀនមេរៀនថ្ងៃនេះ សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកវិធីនានា ដែលការសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា អាចផ្ដល់ ប្រយោជន៍ដល់ពិភពលោក និង អាចមានប្រយោជន៍ដល់ជីវិតរបស់ពួកគេផ្ទាល់ ។

សូមសិស្សឲ្យបើកទៅទំព័រចំណងជើងនៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ សូមពន្យល់ថាដើម្បីធ្វើឲ្យគោលលទ្ធិ និងសេចក្ដី សញ្ញាមានប្រយោជន៍ ដំបូងយើងត្រូវតែយល់ពីគោលលទ្ធិ និងសេចក្ដីសញ្ញាថាជាអ្វីសិន ។ សូមប្រាប់សិស្សម្នាក់ឲ្យអានទំព័រ ចំណងជើងនោះឮៗ ។ បន្ទាប់មក សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកនឹងឲ្យនិយមន័យពាក្យ *គោលលទ្ធិ* យ៉ាងដូចម្ដេច?
- តើសេចក្ដីសញ្ញាគឺជាអ្វី ?
- តើវិវរណៈគឺជាអ្វី ?

បើចាំបាច់ សូមពន្យល់ថា *គោលលទ្ធិ* គឺជាគ្រឹះនៃសេចក្ដីពិតដ៏អស់កល្បនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលពុំអាចផ្លាស់ប្ដូរ បាន ឯ *សេចក្ដីសញ្ញា* គឺជាកិច្ចព្រមព្រៀងដ៏ពិសិដ្ឋមួយរវាងព្រះ និងកូនចៅរបស់ទ្រង់ ដែលព្រះទ្រង់ដាក់នូវគ្រប់លក្ខខណ្ឌនៃ ការសន្យា ហើយ *វិវរណៈ* គឺជាទំនាក់ទំនងមកពីព្រះទៅកាន់កូនចៅរបស់ទ្រង់ ។ អ្នកអាចស្នើថា សិស្សគួរតែសរសេរនិយមន័យ ទាំងនេះនៅលើទំព័រចំណងជើងនោះ ។

សូមឲ្យសិស្សបើកទៅកថាខណ្ឌទីប្រាំបី នៃបុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ( ដោយចាប់ផ្ដើមជាមួយនឹង « នៅក្នុងវិវរណៈ. . .» ) ។ សូមពន្យល់ថា កថាខណ្ឌនេះ មានរៀបរាប់ឧទាហរណ៍អំពីប្រធានបទនៃគោលលទ្ធិមួយចំនួនដែល មាននៅក្នុងគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ។ សូមអញ្ជើញសិស្សឲ្យអានប្រយោគទីមួយដោយស្ងាត់ៗ ហើយប្រាប់អំពី គោលលទ្ធិមួយ ឬច្រើន ដែលពួកគេចាប់អារម្មណ៍រៀនបន្ថែមទៀត ។ បន្ទាប់មក សួរពួកគេនូវសំណួរខាងក្រោមនេះ ៖

- តើប្រធានបទនៃគោលលទ្ធិណាមួយ ដែលអ្នកចាប់អារម្មណ៍ខ្លាំងបំផុតដើម្បីរៀនបន្ថែមទៀត ?
- តើការចេះ និងការយល់ដឹងពីសេចក្ដីពិតទាំងនោះកាន់តែប្រសើរឡើងអាចផ្ដល់ប្រយោជន៍ ដល់អ្នកយ៉ាងដូចម្ដេចខ្លះ ?

សូមឲ្យសិស្សអានប្រយោជន៍ចុងក្រោយនៃកថាខណ្ឌទីប្រាំបីឲ្យឮ ( វាចាប់ផ្ដើមដោយ « នៅទីបញ្ចប់ ទីបន្ទាល់ដែលបានថ្លែង. . . » ) ហើយអញ្ជើញសិស្ស ឲ្យរកមើលអ្វី ដែលធ្វើឲ្យគោលលទ្ធិ និង សេចក្ដីសញ្ញាមានតម្លៃខ្លាំងម្ល៉េះ ។ បន្ទាប់មក សួរពួកគេនូវសំណួរខាងក្រោមនេះ ៖

- តើអ្វីដែលធ្វើឲ្យគោលលទ្ធិ និងសេចក្ដីសញ្ញា « មានតម្លៃធំ » ?
- ហេតុអ្វីក៏ទីបន្ទាល់អំពីព្រះអង្គសង្គ្រោះមានតម្លៃយ៉ាងខ្លាំងដូច្នេះ ?
- តើអ្នកគិតថានឹងមានអ្វីកើតឡើងចំពោះទីបន្ទាល់ *របស់អ្នក* អំពីព្រះយេស៊ូវគ្រីស្ទ នៅពេលអ្នកសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញានោះ ?

សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀនថា ៖ **តាមរយៈការសិក្សាវិវរណៈនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា នោះយើងអាចពង្រឹងទីបន្ទាល់របស់យើងអំពីព្រះយេស៊ូវគ្រីស្ទ ។** សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលទីបន្ទាល់ដ៏រឹងមាំមួយអំពី ព្រះអង្គសង្គ្រោះអាចជះឥទ្ធិពលលើជីវិតរបស់ពួកគេ ។ សូមគិតពីការចែកចាយអំពីរបៀបដែលការសិក្សាព្រះគម្ពីរ គោលលទ្ធិ និងសេចក្ដីសញ្ញា បានពង្រឹងទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ ។

សូមឲ្យសិស្សអានកថាខណ្ឌទីមួយ នៃបុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាឲ្យឮៗ ខណៈដែលសិស្សទាំងអស់នៅក្នុងថ្នាក់ផ្ទៀងតាម ។ បន្ទាប់មកសូមសួរ ៖ នៅពេលយើងសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា តើយើងនឹងឮសំឡេងរបស់នរណា ?

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **នៅពេលយើងសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា នោះយើងអាចស្ដាប់ឮសំឡេងរបស់ព្រះអង្គសង្គ្រោះ ។** បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:–៣៤–៣៦ ឲ្យសិស្សស្ដាប់ ។

សូមឲ្យសិស្សអានកថាខណ្ឌទីបី នៃបុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាឲ្យឮ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយស្វែងរកពាក្យដែលពិពណ៌នាសំឡេងរបស់ព្រះអង្គសង្គ្រោះ ។ ( អ្នកអាចផ្ដល់យោបល់ឲ្យ សិស្សគូសចំណាំអ្វីដែលពួកគេរកឃើញ ) ។ បន្ទាប់មក សួរពួកគេនូវសំណួរខាងក្រោមនេះ ៖

- តើពាក្យណាខ្លះដែលត្រូវបានប្រើដើម្បីពិពណ៌នាអំពីសំឡេងរបស់ព្រះអង្គសង្គ្រោះ ?
- តើអ្នកអាចទទួលបានប្រយោជន៍អ្វីខ្លះនៅក្នុងជីវិតអ្នក នៅពេលអ្នកស្ដាប់ ហើយស្គាល់សំឡេងរបស់ទ្រង់ ?

សូមដាក់តាំងរូបភាពមនុស្សមួយចំនួន ដែលវិវរណៈនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញាសរសេរសម្រាប់ពួកគេ និង សរសេរអំពី ពួកគេ ( សូមមើល *សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ], លេខ. ៨៧, ៨៨, ៩៣, ៩៤,៩៥; សូមមើលផងដែរ គេហទំព័រ LDS.org) ។ នៅពេលអ្នកបង្ហាញរូបភាពទាំងនេះ សូមពន្យល់ថាសិស្សនឹងរៀនអំពីមនុស្សទាំងនេះពេលកំពុងសិក្សាព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ។

សូមឲ្យសិស្សអានប្រយោគពីរដំបូងនៃកថាខណ្ឌទីប្រាំមួយនៃបុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាឲ្យឮៗ ( វាចាប់ផ្ដើមពី « វិវរណៈពិសិដ្ឋទាំងនេះ. . .» ) ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម និង រកមើលស្ថានភាពនានាដែលវិវរណៈនេះ ត្រូវបានទទួល ។ ( អ្នកអាចផ្ដល់យោបល់ឲ្យ សិស្សគូសចំណាំអ្វីដែលពួកគេរកឃើញ ) ។

- តើឃ្លាអ្វីខ្លះក្នុងប្រយោគទាំងនេះដែល ពិពណ៌នាអំពីស្ថានភាពដែលវិវរណៈទាំងនេះ ត្រូវបានទទួល ?

សូមបង្ហាញក្រដាសមួយសន្លឹកដែលមានសរសេរពាក្យ *អ្នក* នៅលើនោះ ។ សូមចង្អុលបង្ហាញថា ដូចជាបុគ្គលម្នាក់ៗដែលដកស្រង់ចេញពីប្រវត្តិសាសនាចក្រ នោះយើងក៏ឆ្លងកាត់ស្ថានភាពជាច្រើនផងដែរ ដែលយើងត្រូវការការណែនាំដ៏ទេវភាព ។

- ប្រសិនបើយើងត្រូវធ្វើតាមគំរូរបស់ពួកបរិសុទ្ធជំនាន់ដើមទាំងនេះ តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានការណែនាំដ៏ទេវភាព ? ( អធិស្ឋាន និង ស្វែងរកវា ) ។

សូមពន្យល់ថារបៀបមួយដើម្បីស្វែងរកការណែនាំដ៏ទេវភាពគឺត្រូវសិក្សាព្រះគម្ពីរ ។ សូមឲ្យសិស្សបើកទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៨, ដែលជាចំណេះចំណានខគម្ពីរមួយ ។ សូមរំឭកពួកគេថា ព្រះអម្ចាស់បានប្រទានវិវរណៈទុកជាអារម្ភកថារបស់ទ្រង់ចំពោះព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:–៣៧–៣៨ ឲ្យឮៗ ខណៈដែលសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយ រកមើលព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ចំពោះពួកយើងដែលទាក់ទងនឹងព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ។

- តើព្រះអម្ចាស់បានបញ្ជាយើងឲ្យធ្វើអ្វីជាមួយនឹងព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **យើងត្រូវពិចារណាមើលព្រះបញ្ញត្តិដែលព្រះអម្ចាស់បានប្រទានឲ្យ ។**)

សូមអញ្ជើញសិស្សឲ្យចែកចាយរបៀបដែលពួកគេទទួលបានប្រយោជន៍ ពីការស្រាវជ្រាវព្រះគម្ពីរអំឡុងពេលសិក្សានៃសប្ដាហ៍ របស់ពួកគេ ។ សូមតាមដានសិស្ស ពីគោលដៅដែលពួកគេបានដាក់ដើម្បីសិក្សាព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ជារៀងរាល់ថ្ងៃអំឡុងពេលឆ្នាំសិក្សានេះ ។ សូមសួរពួកគេអំពីផែនការរបស់ខ្លួន ដើម្បីធ្វើតាមការបញ្ជារបស់ព្រះអម្ចាស់ដើម្បី « សូមពិចារណាមើលព្រះព្រះបញ្ញត្តិទាំងនេះចុះ » (គ. និង ស. ១:៣៧) ។ អ្នកអាចបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការស្ដាប់តាមសំឡេងរបស់ព្រះអម្ចាស់ និង ការទទួលការណែនាំពីទ្រង់ តាមរយៈការសិក្សាព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ។

## មេរៀនបន្ទាប់ (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១; គោលលទ្ធិ និង សេចក្ដីសញ្ញា ២)

ព្រះស្ដាប់ ហើយឆ្លើយតបការអធិស្ឋាន ។ ការនិមិត្តដំបូងគឺជាលទ្ធផលមួយនៃការអធិស្ឋានដ៏រាបទាបរបស់យ៉ូសែប ស្ម៊ីធ ។ មិនយូរប៉ុន្មានក្រោយមក ទេវតាបានណែនាំព្យាការី យ៉ូសែប ស្ម៊ីធអំពីការចេញមកនៃព្រះគម្ពីរមរមន និង ការស្ដារឡើងវិញនៃបព្វជិតភាព ។ បន្ទាប់ពីយ៉ូហានបាទីស្ទ បានបង្ហាញខ្លួនដល់យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី នោះអូលីវើរ បានសរសេរថា « គិតមួយសន្ទុះមក ដួងចិត្តយើងពោរពេញដោយក្ដីអំណរអ្វីម៉្លេះ. . . នៅពេលយើងទទួលបព្វជិតភាពដ៏បរិសុទ្ធក្រោមព្រះហស្ដរបស់លោក » (យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៧១, កំណត់ចំណាំ ) ។

មេរៀន ទី ៦

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២០

## បុព្វកថា

នៅឆ្នាំ ១៨៣៨ យ៉ូសែប ស្ម៊ីធ បានចាប់ផ្ដើមធ្វើការអំពីប្រវត្តិនៃគ្រួសារលោកជាផ្លូវការ ។ នៅក្នុងនោះ លោកបានពិពណ៌នាអំពីក្រុមគ្រួសារលោក និងទីកន្លែងទាំងឡាយដែលពួកលោកបានរស់នៅ ។ លោកក៏ប្រាប់លម្អិតអំពីក្ដីកើបខុសប្រក្រតី អំពីសាសនាដែលមាននៅរដ្ឋនូវយ៉ោកខាងលិចនៅក្នុងឆ្នាំ ១៨២០ ។ ចំណង់ខាងសាសនានេះ បាននាំលោកឲ្យ « គិតពិចារណាដ៏ជ្រាលជ្រៅ ហើយមានចិត្តខ្វល់ខ្វាយជាខ្លាំង » ថាត្រូវចូលរួមនឹងព្រះវិហារណាមួយ (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៨) ។ បន្ទាប់ពីការស្រាវជ្រាវបទគម្ពីរ ជាពិសេស នៅក្នុងយ៉ាកុប ១:៥ យ៉ូសែប បានសម្រេចចិត្តថាសូមសួរដល់ព្រះ នៅក្នុងការអធិស្ឋានរកចម្លើយចំពោះចម្ងល់ទាំងឡាយរបស់លោក ។ នៅក្នុងចម្លើយចំពោះការអធិស្ឋានរបស់លោក ព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានលេចមកជួបលោក ។

## យោបល់សម្រាប់ការបង្រៀន

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–៤

*យ៉ូសែប ស្ម៊ីធ សរសេរប្រវត្តិសាស្ត្រនៃសាសនាចក្រ*

សូមឲ្យសិស្សម្នាក់អានឲ្យឮៗនូវបទពិសោធន៍ដូចខាងក្រោមអំពីអ្នកផ្សព្វផ្សាយសាសនាពីររូបនៅក្នុងប្រទេសកាណាដា ដូចបានរាយការណ៍ដោយប្រធាន ថូម៉ាស អេស ម៉នសុន ( ដំណើររឿងដែលនៅសល់ នឹងប្រាប់នៅក្នុងមេរៀនពេលក្រោយទៀត ) ៖



« [ អ្នកផ្សព្វផ្សាយសាសនា ] ពីររូប បានហៅឲ្យទៅផ្ទះរបស់លោក អែលមើរ ផូឡាត ។. . . ពួកគេបានបង្ហាញសារលិខិតរបស់ពួកគេ ហើយសួរគាត់ បើគាត់នឹងចូលរួមក្នុងការអធិស្ឋានជាមួយពួកគេ ។ គាត់បានយល់ព្រម តែទាល់តែគាត់ជាអ្នកធ្វើការអធិស្ឋាន ។

« ការអធិស្ឋានរបស់គាត់ បានធ្វើឲ្យអ្នកផ្សព្វផ្សាយសាសនាមានការភ្ញាក់ផ្អើលជាខ្លាំង ។ គាត់អធិស្ឋានថា ‹ ព្រះវរបិតាសួគ៌អើយ សូមប្រទានពរដល់អ្នកផ្សព្វផ្សាយសាសនាដ៏អភ័ព្វ និងល្ងិតល្ងង់ពីនាក់នេះផង ដើម្បីពួកគេអាចត្រឡប់ទៅផ្ទះវិញ ហើយកុំខ្ជះខ្ជាយពេលវេលាដើរនិយាយប្រាប់ប្រជាជនកាណាដា អំពីសារលិខិតដែលមិនគួរឲ្យជឿនេះ ហើយដែលពួកគេចេះតែបន្តិចបន្តួចនេះឡើយ › ។

« នៅពេលពួកគេក្រោកឡើង នោះលោក ផូឡាត បានសុំឲ្យអ្នកផ្សព្វផ្សាយសាសនាកុំត្រឡប់មកផ្ទះគាត់ទៀតឡើយ ។ នៅពេលពួកគេចាកចេញទៅ គាត់បាននិយាយចំអកដាក់ពួកគេ ‹ អ្នកមិនអាចនឹងប្រាប់ខ្ញុំថា អ្នកពិតជាជឿថា យ៉ូសែប ស្ម៊ីធ ជាព្យាការីម្នាក់របស់ព្រះផងហ្នឹង ណាស់ហើយចុះ › ហើយគាត់បានញ្ញទ្វារបិទយ៉ាងខ្លាំង » (The Prophet Joseph Smith: Teacher by Example » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៦៩ ) ។

- បើអ្នកជាអ្នកផ្សព្វផ្សាយម្នាក់ក្នុងចំណោមអ្នកផ្សព្វផ្សាយទាំងពីរនោះ តើអ្នកនឹងនិយាយទៅលោក ផូឡាត យ៉ាងណាដែរ ?
- តើមនុស្សម្នាក់អាចដឹងដោយខ្លួនឯងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ —ប្រវត្តិ ១:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលមូលហេតុដែលយ៉ូសែប ស្ម៊ីធ បានប្រាប់ក្នុងការសរសេរពីប្រវត្តិគ្រួសារលោក និងប្រវត្តិសាស្ត្រនៃសាសនាចក្រនោះ ។

- ស្របតាម ខទី ១ តើមានការបោះពុម្ពផ្សាយអ្វីខ្លះ នៅក្នុងចំណោយប្រជាជនអំឡុងសម័យសាសនាចក្រជំនាន់ដើម ? ( មានការរាយការណ៍ខុសឆ្គងជាច្រើន ដែលបង្វែរចិត្តមនុស្សឲ្យទាស់នឹងសាសនាចក្រ ) ។
- តើមូលហេតុអ្វីខ្លះ ដែលយ៉ូសែប ស្ម៊ីធ បានប្រាប់ក្នុងការសរសេរប្រវត្តិរបស់លោក ? ( ដើម្បីផ្ដល់ទៅឲ្យសាធារណៈជននូវដំណើររឿងពិត និងត្រឹមត្រូវអំពីព្រឹត្តការណ៍នានា អំពីការនិមិត្តដំបូង និងការស្ដារឡើងវិញ ) ។

សូមពន្យល់ថា នៅមានបុគ្គល និងក្រុមជាច្រើននាសព្វថ្ងៃនេះ ដែលបានផ្សាយព័ត៌មានខុសឆ្គង និងបោកបញ្ឆោត អំពីសាសនាចក្រ ដោយមានបំណងដើម្បីបំផ្លាញសេចក្ដីជំនឿ ។

- តើយើងអាចរៀនអ្វីខ្លះ ចេញមកពីមូលហេតុដែលយ៉ូសែប ស្ម៊ីធ បានសរសេរនៅក្នុងប្រវត្តិរបស់លោក ដែលអាចជួយយើងឲ្យចៀសវាងពីការបញ្ឆោត ដោយព័ត៌មានខុសឆ្គង និងបោកបញ្ឆោតនោះ ? ( អ្នកទាំងឡាយដែលចង់បានសេចក្តីពិតដោយស្មោះ គួរតែស្វែងរកដោយឧស្សាហ៍ព្យាយាមនូវប្រភពព័ត៌មានពិតអំពីសាសនាចក្រ និងប្រវត្តិវាជាជាងគ្រាន់តែទទួលយកព័ត៌មាននានាដែលគេស្តាប់ឮ រួមទាំងអ្វីៗដែលមាននៅលើអ៊ីនធើរណិតនោះឡើយ ) ។
- ហេតុអ្វីបានជាវាសំខាន់ ដើម្បី « ស្វែងរកសេចក្តីពិត » អំពីការស្តារឡើងវិញ រហូតទៅដល់ដំណើររឿងរបស់យ៉ូសែប ស្ម៊ីធដូច្នេះ ? ( អាស្រ័យទៅលើ ដំណើររឿងរបស់ព្យាការី អាចជួយបុគ្គលម្នាក់ៗចៀសវាងពីការបោកបញ្ឆោត ដោយព័ត៌មានខុសឆ្គង ឬបោកបញ្ឆោតបាន ) ។
- តើការអានពាក្យសម្តីផ្ទាល់របស់យ៉ូសែប ស្ម៊ីធ ជួយនរណាម្នាក់ឲ្យដឹងសេចក្តីពិតអំពីបទពិសោធន៍របស់លោកយ៉ាងដូចម្តេច ?

សូមចែកចាយនូវការព្រមានដូចខាងក្រោម មកពីអែលឌើរ ណិល អិល អាន់ឌើរសិន ៖



« វាតែងតែមានមនុស្សមួយចំនួនតូច ដែលចង់បំផ្លាញកេរ្តិ៍ឈ្មោះរបស់សាសនាចក្រ និង ដើម្បីបំផ្លាញសេចក្តីជំនឿ ។ សព្វថ្ងៃនេះ ពួកគេប្រើអ៊ីនធើណិត ។

« ព័ត៌មានមួយចំនួនអំពីសាសនាចក្រ មិនថាវាមានការបញ្ចុះបញ្ចូលយ៉ាងណាទេ វាមិនពិតឡើយ » (« ការសាកលសេចក្តីជំនឿនៃអ្នកគាល់គ្នា », *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៤១ ) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្តាប់អំពីរបៀបដែលយើងគួរតែវាយតម្លៃនូវអ្វីដែលយើងអានអំពីសាសនាចក្រ និងប្រវត្តិរបស់វា ។ ( អ្នកអាចផ្តល់ច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍ ឲ្យទៅសិស្សម្នាក់ៗ ដើម្បីពួកគេអាចផ្ទៀងតាម ) ។



« អ្នកអានពួកបរិសុទ្ធថ្ងៃចុងក្រោយ គួរតែ. . .ឆ្លាតវៃ. . . នៅក្នុងការវាយតម្លៃរបស់ពួកគេទៅលើអ្វីដែលពួកគេអាន ។

« ទីបន្ទាល់ផ្ទាល់ខ្លួនយើងម្នាក់ៗផ្អែកលើសាក្សីនៃព្រះវិញ្ញាណ ពុំមែននៅលើបណ្តុំ ឬការផ្គុំនូវហេតុការណ៍ខាងប្រវត្តិសាស្ត្រណាមួយនោះទេ ។ បើយើងផ្តោតជីវិតយើងទៅលើសាក្សីនៃព្រះវិញ្ញាណនោះគ្មានហេតុការណ៍ខាងប្រវត្តិសាស្ត្រណា អាចធ្វើឲ្យយើងសង្ស័យនឹងទីបន្ទាល់របស់យើងឡើយ ។ ព្រះវរបិតាសួគ៌របស់យើង ប្រទានដល់យើងនូវអំណាចនៃហេតុផល ហើយយើងត្រូវបានរំពឹងថាចេះប្រើវាពេញលេញបំផុត ។ ប៉ុន្តែទ្រង់ក៏ប្រទានដល់យើងនូវអង្គលួងលោមចិត្ត ដែលទ្រង់មានបន្ទូលថា នឹងដឹកនាំយើងនៅក្នុងសេចក្តីពិត ហើយដោយអំណាចនោះហើយ ដែលយើងអាចដឹងសេចក្តីពិតនៃរឿងគ្រប់យ៉ាង ។ នោះជាមគ្គុទេសន៍ដ៏គ្មានទីបំផុតសម្រាប់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលសក្តិសម និងមានឆន្ទៈពឹងផ្អែកទៅលើនោះ » (« Reading Church History » [ address to CES religious educators ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ១៩៨៥ ], ទំព័រ ៧, LDS.org) ។

សូមអញ្ជើញសិស្សឲ្យចែកចាយនូវអ្វីដែលផុសក្នុងអារម្មណ៍របស់ពួកគេចំពោះដំបូន្មានរបស់អែលឌើរ អូក ហើយហេតុអ្វីក៏វាជាជំនួយដល់គេ ។

អ្នកអាចពន្យល់ថា យ៉ូសែប ស្ម៊ីធ បានសរសេរដំណើររឿងអំពីការនិមិត្តដំបូងនេះ នៅក្នុងឆ្នាំ ១៨៣៨ ជាផ្នែកនៃប្រវត្តិសាស្ត្រនៃសាសនាចក្រជាផ្លូវការមួយ ដើម្បីបោះពុម្ពទៅកាន់ពិភពលោក ។ មានដំណើររឿងដែលគេស្គាល់ចំនួនប្រាំបួនអំពីការនិមិត្តដំបូង–ដែលដំណើររឿងចំនួនបួន ត្រូវបានសរសេរ ឬនិពន្ធដោយយ៉ូសែប ស្ម៊ីធ ហើយការសរសេរចំនួនប្រាំទៀត ត្រូវបានសរសេរដោយអ្នកដទៃ ដែលប្រាប់ឡើងវិញអំពីបទពិសោធន៍របស់លោក ។ « សម្រាប់ព័ត៌មានបន្ថែម អំពីដំណើររឿងចំនួនបួនអំពីការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ សូមមើល Milton V. Backman Jr « Joseph Smith's Recitals of the First Vision » *Ensign* ខែ មករា ឆ្នាំ ១៩៨៥ ទំព័រ ៨–១៧ ) ។

អ្នកក៏អាចពន្យល់ថា ដំណើររឿងជាច្រើនអំពីការនិមិត្ត ត្រូវបានរៀបចំនៅក្នុងគ្រាផ្សេងៗ និងសម្រាប់អ្នកស្តាប់ផ្សេងៗគ្នា ។ នៅក្នុងដំណើររឿងទាំងនេះ យ៉ូសែប ស្ម៊ីធ បានគូសបញ្ជាក់អំពីទិដ្ឋភាពផ្សេងនៃបទពិសោធន៍លោកអំពី ការនិមិត្តដំបូង ប៉ុន្តែដំណើររឿងទាំងអស់ ព្រមព្រៀងគ្នានៅក្នុងសេចក្តីពិតដ៏សំខាន់ ថាយ៉ូសែប ស្ម៊ីធ ពិតជាត្រូវបានស្ថានសួគ៌បើកបង្ហាញមកកាន់លោក ហើយលោកបានឃើញសារទូតរបស់ព្រះ រួមទាំង ព្រះជាព្រះវរបិតា និងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ ដោយសារដំណើររឿងនៅឆ្នាំ ១៨៣៨ ជាចំណែកក្នុងប្រវត្តិសាស្ត្រជាផ្លូវការរបស់យ៉ូសែប ស្ម៊ីធ និងទីបន្ទាល់លោកទៅកាន់ពិភពលោក នោះវាក៏ត្រូវបានបញ្ចូលទៅក្នុងមុក្តាដ៏មានតម្លៃមហិមា ជាគម្ពីរផងដែរ ។

- ដូចដែលយ៉ូសែប ស្ម៊ីធ បានគូសបញ្ជាក់អំពីទិដ្ឋភាពផ្សេងគ្នានៃការនិមិត្តរបស់លោក នៅក្នុងដំណើររឿងជាច្រើនរបស់លោក នោះសាវកប៉ុល បានគូសបញ្ជាក់អំពីទិដ្ឋភាពផ្សេងគ្នានៃការនិមិត្តរបស់គាត់ អំពីព្រះអង្គសង្គ្រោះទៅដល់អ្នកស្ដាប់ផ្សេងគ្នាផងដែរ ( សូមមើល កិច្ចការ ៩:១–៩ កិច្ចការ ២២:៥–១១ កិច្ចការ ២៦:១២–២០ ) ។ ហេតុអ្វីក៏អ្នកគិតថា យ៉ូសែប ស្ម៊ីធ និង ប៉ុល បានគូសបញ្ជាក់រឿងផ្សេងគ្នានៅរាល់លើក ដែលពួកលោករៀបរាប់ដំណើររឿងអំពីការនិមិត្តរបស់ពួកលោកដូច្នេះ ?

សូមសង្ខេប យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣–៤ ដោយការពន្យល់ថា យ៉ូសែប បានកើតនៅភូមិ វើរម៉ុន្ត ប៉ុន្តែផ្លាស់ទៅ ភូមិ ប៉ាល់ម៉ៃរ៉ា រដ្ឋនូវយោក ពេលដែលលោកមានអាយុ ១០ ឆ្នាំ ។

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥–១៣

*នៅកណ្ដាលភាពចលាចលខាងសាសនា យ៉ូសែប ស្ម៊ីធ បានប្ដេជ្ញាចិត្តថាសូមសួរដល់ព្រះ ថាព្រះវិហារណាមួយត្រូវ ។*

សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ បានរស់នៅអំឡុងគ្រានៃការរំជើបរំជួលដ៏អស្ចារ្យអំពីសាសនា ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេណគ្នាអានឲ្យឮៗមកពី យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥–៧ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យ ឬឃ្លា ពិពណ៌នាអំពីស្ថានភាព ដែលយ៉ូសែបបានជួបប្រទះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរនៅលើក្ដារខៀននូវពាក្យ ឬឃ្លាដែលពួកគេរកឃើញ ។ បន្ទាប់មក អញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៨,១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកការពិពណ៌នារបស់យ៉ូសែប ស្ម៊ីធ ថាលោកមានអារម្មណ៍ដូចម្ដេចអំឡុងគ្រានោះ ។

- តើយ៉ូសែប មានអារម្មណ៍ដូចម្ដេច មកពីការរំភើបខាងសាសនាដែលនៅជុំវិញរូបលោកនោះ ?
- តើលោកពុះពារនឹងសំណួរមួយចំនួនយ៉ាងណាខ្លះ ?
- តើអ្នកមានធ្លាប់ត្រូវបានសួរសំណួរស្រដៀងគ្នានេះដែរឬទេ ? តើអ្នកបានធ្វើអ្វីដើម្បីដោះស្រាយវា ?

សូមអញ្ជើញសិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១១ ដោយស្ងាត់ស្ងៀម ហើយស្វែងរកអ្វី ដែលយ៉ូសែបស្ម៊ីធ បានធ្វើដើម្បីរកចម្លើយចំពោះសំណួររបស់លោក ។

- តើយ៉ូសែប បានងាកទៅទីណា ដើម្បីសុំជំនួយរកចម្លើយចំពោះសំណួរទាំងឡាយរបស់លោក ?
- តើគោលការណ៍ ដែលបានបង្រៀននៅក្នុង យ៉ាកុប ១:៥ ដែលបានជួយយ៉ូសែប ស្ម៊ីធ មានទំនុកចិត្តថា លោកអាចរកបានចម្លើយចំពោះសំណួរដែលលោកមាននោះអ្វីខ្លះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេរកឃើញគោលការណ៍ដូចតទៅនេះ ៖ **បើយើងសូមដល់ព្រះដោយសេចក្ដីជំនឿ នោះព្រះនឹងឆ្លើយតបការអធិស្ឋានរបស់យើង ។** អ្នកអាចពន្យល់ថា ព្រះនឹងឆ្លើយតបការអធិស្ឋានរបស់យើងតាមពេលវេលា និងតាមរបៀបរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១២–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ប្រាប់អំពីរបៀបដែលគោលការណ៍ បង្រៀននៅក្នុង យ៉ាកុប ១:៥ មានឥទ្ធិពលលើយ៉ូសែប ស្ម៊ីធ ។

## យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:១៤–២០

*យ៉ូសែប ស្ម៊ីធ ឃើញព្រះដ៏ជាព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់ គឺ ព្រះយេស៊ូវគ្រីស្ទ។*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៤–១៥ ឲ្យឮៗ ។

- តើអ្នកគិតថា ហេតុអ្វីសាតាំងបានព្យាយាមបញ្ឈប់យ៉ូសែប ស្ម៊ីធ កុំឲ្យអធិស្ឋានដូច្នេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៦–១៧ ឲ្យឮៗ។ សូមឲ្យសិស្សនៅក្នុងថ្នាក់ប្រាប់អំពីរបៀបឆ្លើយតបរបស់យ៉ូសែប ស្ម៊ីធ ចំពោះរឿងផ្ទុយដែលលោកមានបទពិសោធន៍នោះ ។ សូមឲ្យពួកគេកត់ចំណាំឃ្លាមកពីទីបន្ទាល់របស់យ៉ូសែប ដែលមានអត្ថន័យចំពោះពួកគេ ឬដែលពួកគេអាចប្រើនៅក្នុងការបង្រៀនដល់អ្នកដទៃអំពីការនិមិត្តដំបូងផងដែរ ។

- តើឃ្លាណាមួយក្នុងខគម្ពីរទាំងនេះ មានអត្ថន័យចំពោះអ្នក ? ហេតុអ្វី ?

សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **យ៉ូសែប ស្ម៊ីធ បានឃើញព្រះដ៏ជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។**

- ហេតុអ្វីបានជាវាសំខាន់ដើម្បីមានទីបន្ទាល់មួយថា យ៉ូសែប ស្ម៊ីធ បានឃើញព្រះដ៏ជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទដូច្នេះ ?
- តើអ្នកដឹង ថា យ៉ូសែប ស្ម៊ីធ បានឃើញព្រះដ៏ជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

បន្ទាប់ពីសិស្សមួយចំនួនបានចែកចាយទីបន្ទាល់របស់ពួកគេហើយ សូមពន្យល់ថា ការនិមិត្តដំបូង គឺជាព្រឹត្តការណ៍គ្រឹះនៃការស្ដារឡើងវិញ ។ ការនិមិត្តដំបូង ក៏ផ្ដល់ចម្លើយចំពោះសំណួរខាងគោលលទ្ធិសំខាន់ផងដែរ ។ សូមអញ្ជើញសិស្សឲ្យមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–១៧ ដោយស្ងាត់ស្ងៀម ស្វែងរកសេចក្ដីពិតដែលយើងអាចរៀនមកពីដំណើររឿងនេះ ។ អ្នកអាចចង់សួរសំណួរដូចខាងក្រោម ៖

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពី យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–១៦ ដែលអាចជួយយើងយកឈ្នះលើការល្បួង ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងស្វែងរកសុំជំនួយពីព្រះដោយឧស្សាហ៍ព្យាយាម ពេលសាតាំងព្យាយាមបំបាក់ទឹកចិត្តយើង នោះព្រះអាចជួយសង្គ្រោះយើង** ) ។

- តើខគម្ពីរទាំងនេះបង្រៀនអំពីលក្ខណៈរបស់ព្រះ ជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទអ្វីខ្លះ ? ( ចម្លើយអាចរួមមានដូចខាងក្រោម ៖ **ព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ មានព្រះជន្មរស់ ។ ព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ជាតួអង្គផ្សេងពីគ្នា ហើយដាច់ដោយឡែក** ) ។

- តើបន្ទូលដំបូង ដែលព្រះមានបន្ទូលទៅយ៉ូសែប ស្ម៊ីធ គឺជាអ្វី ? ( យ៉ូសែប ) ។ ហេតុអ្វីការណ៍នេះសំខាន់ដើម្បីដឹង ? តើយើងអាចរៀនសេចក្ដីពិតអ្វីខ្លះចេញមកការណ៍នេះ ? ( ចម្លើយអាចរួមមានដូចខាងក្រោម ៖ **ព្រះវរបិតាសួគ៌ ស្គាល់ឈ្មោះយើងម្នាក់ៗ ។ ព្រះឆ្លើយតបការអធិស្ឋានរបស់យើង** ) ។

ដើម្បីជួយសិស្សឲ្យយល់ និងដឹងពីសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ ដែលពួកគេបានប្រាប់ក្នុងមេរៀននេះ នោះអ្នកអាចសួរនូវសំណួរដូចខាងក្រោម ៖

- ហេតុអ្វីក៏សេចក្ដីពិតទាំងនេះអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ សំខាន់ត្រូវចេះដឹង និងយល់ដូច្នេះ ?

- តើនៅពេលណាដែលសេចក្ដីពិតមួយ ឬច្រើន បានប្រទានពរដល់ជីវិតអ្នក ? (សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួនគឺពិសិដ្ឋ ឬផ្ទាល់ខ្លួនពេក ពុំគួរចែកចាយទេ ) ។

សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ ក៏បានទទួលចម្លើយចំពោះសំណួររបស់លោកផងដែរ ក្នុងអំឡុងការនិមិត្តដំបូងនោះ ។ សូមអញ្ជើញសិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៨–២០ ដោយស្ងៀមស្ងាត់ ។

- តើយ៉ូសែប បានរៀនអ្វីខ្លះ ចំពោះចម្លើយសម្រាប់ការអធិស្ឋានរបស់លោកនោះ ?

សូមរំឭកសិស្សអំពី ដំណើររឿងនៃពួកអ្នកផ្សព្វផ្សាយសាសនា ដែលបានអាននៅដើមដំបូងក្នុងមេរៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងបញ្ចប់ ៖



« អ្នកទាំងពីរបានត្រឡប់មកគោះទ្វាររបស់ លោក ផូឡាត វិញ ។ លោក ផូឡាត បានបើកទ្វាដោយខឹងរួចនិយាយថា ‹ ខ្ញុំគិតថា ខ្ញុំបានប្រាប់ឯងរួចហើយថាកុំឲ្យត្រឡប់មកវិញទៀត ! ›

« ដៃគូជុញ្ញ័រ ពេលនោះបាននិយាយដោយភាពក្លាហានរបស់ខ្លួនថា ‹ លោក ផូឡាត នៅពេលដែលយើងបានដើរចេញពីទ្វារផ្ទះលោក លោកបាននិយាយថា យើងពុំបានជឿពិតថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ ។ ខ្ញុំចង់ថ្លែងទីបន្ទាល់ទៅ លោក ផូឡាត ថា ខ្ញុំ *ដឹង* ថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ ថាតាមរយៈការបំផុសគំនិត លោកបានបកប្រែកំណត់ត្រាពិសិដ្ឋ ដែលស្គាល់ថាជាព្រះគម្ពីរមរមន ថាលោកបានឃើញព្រះជាព្រះវរបិតា និងព្រះយេស៊ូវ ជាព្រះរាជបុត្រា › ។ រួចហើយពួកអ្នកផ្សព្វផ្សាយសាសនាក៏បានដើរចេញពីមាត់ទ្វាទៅ ។

« [ ក្រោយមកលោក ផូឡា បានថ្លែងទីបន្ទាល់ថា ៖ ] ‹ នាល្ងាចនោះ ខ្ញុំគេងពុំលក់សោះ ។ ខ្ញុំប្រែខ្លួនចុះឡើងរហូត ។ ខ្ញុំបានឮពាក្យសម្ដីដែលថា « យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ ម្ដងហើយម្ដងទៀតក្នុងគំនិតរហូត ។ ខ្ញុំដឹងពីរឿងនេះ ។. . . ខ្ញុំដឹងពីរឿងនេះ ។. . . ខ្ញុំដឹងពីរឿងនេះ » ។ ខ្ញុំរង់ចាំដល់ព្រឹកឡើងដោយអន្ទះសារ ។ ខ្ញុំបានទូរស័ព្ទទៅអ្នកផ្សព្វផ្សាយសាសនា ។. . . ពួកគេបានត្រឡប់មកវិញ ហើយគ្រានេះ ភរិយាខ្ញុំ គ្រួសារខ្ញុំ និងខ្ញុំ បានចូលរួមក្នុងការពិភាក្សាក្នុងនាមជាអ្នកស្វែងរកសេចក្ដីពិតដោយអស់ពីចិត្ត ។ ជាលទ្ធផល យើងបានឱបក្រសោបយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ › » (« The Prophet Joseph Smith: Teacher by Example » ទំព័រ ៦៩ ) ។

សូមលើកទឹកចិត្តដល់សិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ដោយខ្លួនឯង ហើយទូលសូមដល់ព្រះវរបិតាសួគ៌ឲ្យជួយពួកគេពង្រឹងទីបន្ទាល់របស់ខ្លួនថា ដំណើររឿងរបស់យ៉ូសែប ស្ម៊ីធ អំពីការនិមិត្តដំបូងគឺជាការពិត ។ អ្នកក៏អាចលើកទឹកចិត្តដល់ពួកគេឲ្យស្វែងរកឱកាសដើម្បីចែកចាយសារលិខិតនៃការនិមិត្តដំបូងជាមួយនឹងអ្នកផ្សេងផងដែរ ។ សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សានៅថ្ងៃនេះ ។

### *សូមអញ្ជើញឲ្យសិស្សថ្លែងទីបន្ទាល់*

ប្រធាន បិយដ៏ ឃេ ផាកកឺ ជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា មានពរជ័យមួយ ដែលអាចកើតចេញមកពីការផ្ដល់ឱកាសដល់សិស្សដើម្បីចែកចាយទីបន្ទាល់របស់ពួកគេថា ៖

« ឱ ខ្ញុំចង់ដឹងថា បើខ្ញុំអាចបង្រៀនអ្នកនូវគោលការណ៍មួយនេះ ។ ទីបន្ទាល់មួយគឺត្រូវបាន *រកឃើញ* នៅក្នុង *ការថ្លែង* ពីវា ! . . .

« វាគឺជាបទពិសោធន៍មួយដើម្បីទទួលបានសាក្សីមួយមកពីអ្វីដែលបានអាន ឬពីអ្វីដែលអ្នកផ្សេងទៀតបាននិយាយ ។. . . វាជាបទពិសោធន៍មួយទៀត ដើម្បីមានព្រះវិញ្ញាណអាចបញ្ជាក់នៅក្នុងដួងចិត្តអ្នកថា អ្វីដែល *អ្នក* បានថ្លែងទីបន្ទាល់ គឺជាការពិត » (« The Candle of the Lord » *Ensign* ខែ មករា ឆ្នាំ ១៩៨៣ ទំព័រ ៥៤–៥៥ ) ។

មេរៀនទី ៧

# តួនាទីរបស់សិស្ស

## សេចក្ដីផ្ដើម

គោលបំណងនៃមេរៀននេះ គឺដើម្បីជួយសិស្សឲ្យរៀនអំពីរបៀបបំពេញតួនាទីរបស់ពួកគេក្នុងការរៀនសូត្រដំណឹងល្អ ។ ប្រធាន ហិនរី ប៊ី អារិង នៃគណៈប្រធានទីមួយ បានមានប្រសាសន៍ថា « ការផ្លាស់ប្រែចិត្តជឿពិត អាស្រ័យលើការស្វែងរកសេចក្ដីជំនឿរបស់សិស្សដោយសេរី និងដោយកិច្ចខិតខំដ៏ខ្លាំង » ( « We Must Raise Our Sights » [ address to CES religious educators ] ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០១ ] ទំព័រ ៤ LDS.org ) ។ នៅពេលអ្នកជួយសិស្សឲ្យបំពេញតួនាទីរបស់ពួកគេក្នុងដំណើរការរៀនសូត្រ នោះពួកគេនឹងរៀនពីរបៀបដើម្បីអញ្ជើញឲ្យមានវិវរណៈផ្ទាល់ខ្លួន ហើយមានការផ្លាស់ប្រែចិត្តជឿកាន់តែខ្លាំងទៅលើព្រះអម្ចាស់ ។ អ្នកអាចនឹងត្រូវការរំឭកគោលការណ៍នានា ដែលបានបង្រៀននៅក្នុងមេរៀននេះជាទៀងទាត់ ដើម្បីរំឭកសិស្សអំពីតួនាទីរបស់ពួកគេក្នុងការរៀនសូត្រដំណឹងល្អ ។

## យោបល់សម្រាប់ការបង្រៀន

### តួនាទីរបស់គ្រូបង្រៀន អ្នករៀន និងព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការរៀនសូត្រដំណឹងល្អ ។

សូមនាំយកអាហារ ឬទឹកមកថ្នាក់រៀន ( ដូចជា ចំណិតផ្លែឈើ ឬចំណិតនំប៉័ង ឬទឹកមួយកែវ ) ។ សូមអញ្ជើញសិស្សពីរនាក់ឡើងមកខាងមុខថ្នាក់ ។ សូមឲ្យសិស្សម្នាក់បរិភោគអាហារនោះមួយម៉ាត់ ឬផឹកទឹកមួយក្រេប ។ សូមសុំឲ្យសិស្សទីមួយរៀបរាប់អំពីរសជាតិអាហារ ( ឬទឹក ) ទៅសិស្សទីពីរ ។ សូមលើកទឹកចិត្តគាត់ រៀបរាប់វាឲ្យបានល្អ ដើម្បីឲ្យការរៀបរាប់នោះបានជួយបំពេញ ឬបំបាត់ការស្រេកឃ្លានរបស់សិស្សទីពីរ។ បន្ទាប់មកសួរសិស្សទីពីរនូវសំណួរដូចខាងក្រោម ៖

- តើអ្នកទទួលបានប្រយោជន៍អ្វីមកពីអាហារ ( ឬទឹក ) ដែលសិស្សម្នាក់ទៀតបានរៀបរាប់នោះ ?
- តើការរៀបរាប់របស់សិស្ស ជួយបំបាត់ការស្រេកឃ្លាន ( ឬការស្រេកទឹក ) របស់អ្នកបានល្អយ៉ាងណា ?
- តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានកម្លាំង ឬប្រយោជន៍មកពីអាហារ ( ឬទឹក )នេះ ?

សូមសួរសិស្សក្នុងថ្នាក់អំពីរបៀបដែលឧទាហរណ៍នេះ នៃការបំពេញតម្រូវការខាងរូបកាយរបស់យើង អាចទាក់ទងនឹងការទទួលខុសត្រូវរបស់យើង ដើម្បីរៀន និងរីកចម្រើនខាងវិញ្ញាណយ៉ាងដូចម្ដេច ។

សូមចង្អុលបង្ហាញថា មនុស្សខ្លះគិតថា ការទទួលខុសត្រូវចំពោះការរៀនដំណឹងល្អផ្អែកជាចម្បងទៅលើគ្រូបង្រៀន ។ ទោះជាយ៉ាងណា ក៏ដូចជាឧទាហរណ៍អំពីអាហារ ឬទឹក មនុស្សម្នាក់ពុំអាចទទួលយកសេចក្ដីពិតខាងវិញ្ញាណជំនួសមនុស្សម្នាក់ទៀតបានឡើយ ។ យើងម្នាក់ៗត្រូវតែរៀន និងអនុវត្តសេចក្ដីពិតនៃដំណឹងល្អសម្រាប់ខ្លួនយើង ដើម្បីទទួលបានកម្លាំង និងការរីកចម្រើនខាងវិញ្ញាណ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨ ឲ្យឮៗ ។ សូមលើកទឹកចិត្តសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពាក្យ ឬឃ្លាដែលពិពណ៌នាអំពី ការទទួលខុសត្រូវរបស់យើងក្នុងការរៀនដំណឹងល្អ ។

- តើពាក្យ ឬឃ្លាណា ដែលពិពណ៌នាអំពីការទទួលខុសត្រូវរបស់យើងក្នុងការរៀនដំណឹងល្អ ? ( « ព្យាយាមស្វែងរក » « បង្រៀនគ្នាទៅវិញទៅមក » « ស្វែងរកការរៀន គឺដោយការសិក្សា និងដោយសេចក្ដីជំនឿផង » ។ អ្នកអាចនឹងចង់អញ្ជើញឲ្យសិស្សម្នាក់សរសេរឃ្លាទាំងនេះ នៅលើក្ដារខៀន ដូចដែលសិស្សបាននិយាយប្រាប់ ) ។
- យើងស្គាល់អត្ថន័យស្វែងរកការរៀនសូត្រគឺ « ដោយសារការសិក្សា » ។ តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីស្វែងរកការរៀនសូត្រ « ដោយសារសេចក្ដីជំនឿផង » ?

ដើម្បីជួយសិស្សឲ្យកាន់តែយល់អំពីអត្ថន័យនៃឃ្លានេះ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ បើអាចធ្វើទៅបាន សូមផ្ដល់ច្បាប់ចម្លងដល់សិស្សម្នាក់មួយច្បាប់ៗ ឬសរសេរសេចក្ដីថ្លែងនោះនៅលើក្ដារខៀនមុនពេលចាប់ផ្ដើមថ្នាក់រៀន ។ សូមសិស្សឲ្យស្វែងរកពាក្យ ឬឃ្លា ដែលជួយពួកគេឲ្យយល់បទបញ្ញត្តិរបស់ព្រះអម្ចាស់ ដើម្បីស្វែងរកការរៀនសូត្រដោយសេចក្ដីជំនឿ ។



« ការរៀនសូត្រដោយសេចក្ដីជំនឿ តម្រូវឲ្យមានកិច្ចខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និង ខាងរូបកាយ ហើយពុំមែនគ្រាន់តែជាការទទួលភាពអកម្មនោះទេ ។. . .

«. . . សិស្សត្រូវតែអនុវត្តសេចក្ដីជំនឿ ហើយធ្វើសកម្មភាពដើម្បីទទួលបានចំណេះដឹងសម្រាប់ខ្លួនពួកគេ » ( « Seek Learning by Faith » [ address to CES religious educators ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០៦ ] ទំព័រ ៣ LDS.org ) ។

សូមសរសេរសេចក្ដីថ្លែងការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ *ការរៀនសូត្រខាងវិញ្ញាណ តម្រូវឲ្យ . . .*

សូមដល់សិស្សឲ្យប្រើការពន្យល់ដោយអែលឌើរ បេដណា និងអ្វីដែលពួកគេបានរៀនអំពីការទទួលខុសត្រូវរបស់យើង ជាអ្នករៀនសូត្រដើម្បីបំពេញសេចក្ដីថ្លែងការណ៍នេះ ។ ចម្លើយដែលឆ្លើយ អាចនឹងមាន ដូចខាងក្រោម ៖ **ការរៀនសូត្រខាងវិញ្ញាណតម្រូវឲ្យមានការខិតខំពីខ្លួនយើង ។ ការរៀនសូត្រខាងវិញ្ញាណ តម្រូវឲ្យយើងអនុវត្តសេចក្ដីជំនឿ និងធ្វើសកម្មភាព ។**

ដើម្បីជួយសិស្សឲ្យយល់អំពីឥទ្ធិពលដែលការខិតខំផ្ទាល់ខ្លួន អាចមានទៅលើការរៀនសូត្រខាងវិញ្ញាណរបស់ពួកគេ សូមគូរឌីយ៉ាក្រាមដែលមានអមជាមួយ នៅលើក្ដារខៀន ។ សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ ព្រះអម្ចាស់ជួយយើងឲ្យយល់កាន់តែច្បាស់ អំពីតួនាទីរបស់យើងនៅក្នុងការរៀនសូត្រដំណឹងល្អ ។ ដើម្បីធ្វើដូច្នេះ ដំបូងទ្រង់ពន្យល់អំពីតួនាទីរបស់គ្រូបង្រៀន និងព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងការរៀនសូត្រដំណឹងល្អ ។

*សូមឲ្យសិស្សប្រើពាក្យផ្ទាល់ខ្លួនរបស់ពួកគេ*

នៅពេលសិស្សប្រាប់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលពួកគេរកឃើញនៅក្នុងព្រះគម្ពីរ សូមកុំនិយាយថាចម្លើយរបស់ពួកគេខុស ដោយសារតែចម្លើយនោះខុសពីពាក្យដែលបានប្រើនៅក្នុងសៀវភៅណែនាំនេះនោះឡើយ ។ ទោះជាយ៉ាងណាក្ដី ប្រសិនបើប្រយោគរបស់សិស្សម្នាក់ខុសពីគោលលទ្ធិ វាជាការទទួលខុសត្រូវរបស់អ្នកដើម្បីជួយគេដោយទន់ភ្លន់ក្នុងការកែតម្រូវប្រយោគនោះ ។ ការធ្វើដូច្នោះអាចផ្ដល់នូវបទពិសោធន៍ក្នុងការសិក្សាដ៏សំខាន់ ដោយសារយើងបានរក្សាបរិយាកាសប្រកបដោយក្ដីស្រឡាញ់ និង ទំនុកចិត្ត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៣–១៤ ឲ្យឮៗ ។ មុនពេលសិស្សអាន សូមពន្យល់ថា ខទាំងនេះ ត្រូវបានផ្ដល់ទៅឲ្យពួកបរិសុទ្ធជំនាន់មុនដែលត្រូវបានតែងតាំងឲ្យបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ ឲ្យរកមើលពាក្យដែលពិពណ៌នាអំពីការទទួលខុសត្រូវរបស់គ្រូបង្រៀន ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ទៀត ឲ្យរកមើលពាក្យដែលពិពណ៌នាអំពីការទទួលខុសត្រូវរបស់ព្រះវិញ្ញាណ ។




- ស្របតាមខទាំងនេះ តើការទទួលខុសត្រូវរបស់គ្រូបង្រៀន គឺជាអ្វី ? ( ដើម្បីផ្សាយដំណឹងល្អដោយព្រះវិញ្ញាណ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរ *ផ្សាយដំណឹងល្អដោយព្រះវិញ្ញាណ* នៅខាងក្រោមពាក្យ *គ្រូបង្រៀន* នៅលើឌីយ៉ាក្រាម ) ។

- តើតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ ឬព្រះដ៏ជាជំនួយ គឺជាអ្វី ? ( ដើម្បីបង្រៀនពីសេចក្ដីពិត ។ សូមឲ្យសិស្សម្នាក់បន្ថែមពាក្យ *បង្រៀនពីសេចក្ដីពិត* នៅខាងក្រោមពាក្យ *ព្រះវិញ្ញាណបរិសុទ្ធ* នៅលើឌីយ៉ាក្រាម ) ។

សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះវិញ្ញាណបរិសុទ្ធគឺជាគ្រូបង្រៀនពិត ។** សូមពន្យល់ថា ខណៈពេលដែលគ្រូបង្រៀន អ្នកផ្សព្វផ្សាយសាសនា ឬថ្នាក់ដឹកនាំក្នុងសាសនាចក្រ មានការទទួលខុសត្រូវដើម្បីផ្សាយដំណឹងល្អដោយព្រះវិញ្ញាណ វាគឺជាព្រះវិញ្ញាណបរិសុទ្ធទេតើ ដែលបើកសម្ដែង បំភ្លឺ និងនាំសេចក្ដីពិតនៃដំណឹងល្អមកក្នុងដួងចិត្តរបស់យើង ។

- តើនៅពេលណា ដែលអ្នកមានអារម្មណ៍ដឹងថា ព្រះវិញ្ញាណបរិសុទ្ធ កំពុងបង្រៀនអ្នក ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៩–២១ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលពាក្យដែលពិពណ៌នាអំពីការទទួលខុសត្រូវរបស់អ្នករៀនសូត្រ ។

- ស្របតាមខទាំងនេះ តើការទទួលខុសត្រូវរបស់អ្នករៀនសូត្រគឺជាអ្វី ? ( ដើម្បីទទួលព្រះបន្ទូលនៃសេចក្ដីពិតដោយព្រះវិញ្ញាណ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរពាក្យ *ទទួលដោយព្រះវិញ្ញាណ* នៅខាងក្រោមពាក្យ *អ្នករៀនសូត្រ* នៅលើឌីយ៉ាក្រាម ) ។

ដើម្បីជួយសិស្សយល់កាន់តែច្បាស់អំពីអត្ថន័យដើម្បីទទួលដោយព្រះវិញ្ញាណ សូមសុំពួកគេឲ្យពិចារណាថា តើមនុស្សម្នាក់តម្រូវឲ្យមានអ្វី ដើម្បីទទួលបានបាល់ពីមនុស្សម្នាក់ទៀត ដែលកំពុងទាត់ ឬកំពុងបោះវាទៅពួកគេនោះ ។

- តើមនុស្សម្នាក់ចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានបាល់ ? ( លើកដៃរបស់ខ្លួនឡើង ហើយចាប់វា ) ។ តើវាដូចគ្នាទៅនឹងការខិតខំរបស់អ្នករៀនសូត្រម្នាក់ ត្រូវធ្វើ ដើម្បីទទួលបានព្រះបន្ទូលនៃសេចក្ដីពិតដោយព្រះវិញ្ញាណយ៉ាងដូចម្ដេចដែរ ? ( ដើម្បីទទួលបានបាល់ មនុស្សម្នាក់ ត្រូវត្រៀមចាំចាប់បាល់ ។ ដូចគ្នានេះដែរ យើងត្រូវតែត្រៀមដួងចិត្ត និងគំនិតរបស់យើង ដើម្បីទទួលសេចក្ដីពិតដោយព្រះវិញ្ញាណ ) ។

សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២២ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលកើតឡើង ពេលយើងធ្វើការខិតខំនេះ ដើម្បីទទួលបានដំណឹងល្អ ហើយរៀនសូត្រដោយសេចក្ដីជំនឿ ។ ពីមុនសិស្សអាន សូមពន្យល់ថា ពាក្យ *បានស្អាងឡើង* សំដៅទៅលើការដែលត្រូវបានលើកឡើង ឬស្ថាបនាឡើងខាងវិញ្ញាណ ។

- ស្របតាមខនេះ តើមានពរជ័យអ្វីខ្លះ ដែលគ្រូបង្រៀន និងអ្នករៀនទទួលបានតាមរយៈព្រះវិញ្ញាណ បើពួកគេបំពេញការទទួលខុសត្រូវរបស់ពួកគេក្នុងការបង្រៀន និងការរៀនសូត្រដំណឹងល្អនោះ ? ( ការយល់ដឹង, ការស្អាងឡើង និង សេចក្ដីអំណរ) ។

សូមប្រាប់សិស្សថា អែលឌើរ រីឆាដ ជី ស្កត បានថ្លែងទីបន្ទាល់អំពីទំនាក់ទំនងរវាងអ្នករៀនសូត្រដែលបំពេញតួនាទីរបស់ពួកគេ និងឱកាសរបស់ព្រះវិញ្ញាណដើម្បីបង្រៀន និងថ្លែងទីបន្ទាល់ ។ បើអាចធ្វើទៅបាន សូមចែកដល់សិស្សម្នាក់ៗនូវច្បាប់ចម្លងសេចក្ដីថ្លែងការណ៍មួយដូចខាងក្រោម ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលពន្យល់អំពីឥទ្ធិពលនៃកិច្ចខិតខំរបស់អ្នករៀនសូត្រ មានចំពោះឱកាសរបស់ព្រះវិញ្ញាណបរិសុទ្ធដើម្បីបង្រៀន ។



« ការសម្រេចចិត្តរបស់ [ អ្នករៀនសូត្រ ] ដើម្បីចូលរួម គឺជាការអនុវត្តនូវសិទ្ធិជ្រើសរើស ដែលអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធ បញ្ជូនសារលិខិតផ្ទាល់ខ្លួន មួយ ដែលត្រូវនឹងសេចក្ដីត្រូវការផ្ទាល់ខ្លួន [ របស់ពួកគេ ] ។ ការបង្កើតបរិយាកាសនៃការចូលរួម ពង្រីកឱកាសដែលព្រះវិញ្ញាណនឹងបង្រៀនមេរៀនកាន់តែសំខាន់ជាង [ គ្រូបង្រៀន ] អាចទំនាក់ទំនង » (« To Learn and to Teach More Effectively » [ BYU Campus Education Week devotional ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ ] ទំព័រ ៤–៥ speeches.byu.edu ) ។

- ស្របតាមសេចក្ដីថ្លែងការរបស់អែលឌើរ ស្កត តើយើងអាចអញ្ជើញព្រះវិញ្ញាណបរិសុទ្ធដើម្បីបង្រៀនយើងតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសង្ខេបអំពីរបៀបដែលកិច្ចខិតខំរបស់ពួកគេ ក្នុងនាមជាអ្នករៀនសូត្រ មានឥទ្ធិពលយ៉ាងណាចំពោះឱកាសរបស់ព្រះវិញ្ញាណបរិសុទ្ធដើម្បីបង្រៀន ។ សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងអនុវត្តសិទ្ធិជ្រើសរើសរបស់យើងដើម្បីចូលរួមក្នុងដំណើរការរៀនសូត្រ នោះយើងអាចអញ្ជើញព្រះវិញ្ញាណដើម្បីបង្រៀន និងថ្លែងទីបន្ទាល់ពីសេចក្ដីពិត** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន នៅខាងក្រោមពាក្យទាំងឡាយដែលបានប្រាប់ពីមុនៗ ។

ដើម្បីផ្ដល់ឧទាហរណ៍មួយដល់សិស្ស អំពីនរណាម្នាក់ដែលអនុវត្តសិទ្ធិជ្រើសរើសរបស់គាត់ ដើម្បីរៀនសូត្រតាមរយៈការសិក្សា និងសេចក្ដីជំនឿ សូមអញ្ជើញពួកគេឲ្យនឹកគិតអំពីដំណើររឿងនៃការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ ។ សូមចាត់តាំងសិស្សជាគូៗ ហើយចាត់តាំងគូនីមួយៗ អានខគម្ពីរខាងក្រោមមួយ ឬច្រើន ៖ យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៨, ១០, ១១, ១២, ១៣, ១៤, ១៥, ១៦, ១៨ ។ ( អ្នកអាចសរសេរខទាំងនេះលើក្ដារខៀន ) ។ សូមអញ្ជើញសិស្សឲ្យអានខដែលបានចាត់ឲ្យពួកគេនោះ ហើយពិភាក្សានូវសំណួរដូចខាងក្រោម ៖

- តើយ៉ូសែបបានខិតខំ ដើម្បីរៀនសេចក្ដីពិតខាងវិញ្ញាណយ៉ាងដូចម្ដេច ?

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញគូនិមួយៗប្រាប់ពីឃ្លា ដែលបង្ហាញអំពីកិច្ចខិតខំរបស់យ៉ូសែប ចេញមកពីខគម្ពីរដែលបានចាត់តាំងឲ្យពួកគេនោះ ។

សូមថ្លែងទីបន្ទាល់អំពីឆន្ទៈរបស់យ៉ូសែប ក្នុងការសិក្សាព្រះបន្ទូលរបស់ព្រះ ហើយធ្វើសកម្មភាពដោយសេចក្ដីជំនឿ ទៅលើអ្វីដែលលោកបានរៀន ដែលនាំឲ្យមានចំណេះដឹងដ៏ធំកើតឡើង ហើយជាពរជ័យមួយ មានសម្រាប់យើងទាំងអស់គ្នា ។

សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវ យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:២០ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលយ៉ូសែប បានថ្លែងទៅម្ដាយរបស់លោក ពេលលោកបានត្រឡប់មកផ្ទះវិញ បន្ទាប់ពីទទួលបានការនិមិត្តដំបូង ។

- តើឃ្លាណា នៅក្នុងសេចក្ដីថ្លែងរបស់យ៉ូសែប ចំពោះម្ដាយរបស់លោកឆ្លុះបញ្ចាំងថា លោកបានរៀនសេចក្ដីពិតដោយខ្លួនលោក ? ( « ខ្ញុំបានចេះដឹងដោយខ្លួនខ្ញុំ » ) ។

សូមអញ្ជើញសិស្សឲ្យប្រាប់គោលការណ៍មួយ ដែលយើងអាចរៀនមកពីបទពិសោធន៍របស់យ៉ូសែប ។ សូមលើកទឹកចិត្តពួកគេឲ្យបង្ហាញពីយោបល់របស់ពួកគេជា សេចក្ដីថ្លែង « បើសិនជា –នោះ » ។ ខាងក្រោមនេះ គឺជាវិធីមួយដែលសិស្សអាចបង្ហាញគោលការណ៍នេះ ៖ **បើយើងសិក្សាព្រះបន្ទូលរបស់ព្រះដោយឧស្សាហ៍ព្យាយាម ហើយធ្វើសកម្មភាពដោយសេចក្ដីជំនឿ នោះយើងអាចដឹងសេចក្ដីពិតនៃដំណឹងល្អដោយខ្លួនយើងផ្ទាល់ ។** (អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យសរសេរគោលការណ៍នេះ ជាពាក្យរបស់គេផ្ទាល់នៅជិតនឹង យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:២០) ។

យោងទៅលើសកម្មភាពអាហារ ឬទឹក អ្នកអាចប្រើនៅពេលចាប់ផ្ដើមថ្នាក់ ។ សូមរំឭកសិស្សថា ការទទួលទាននូវការចិញ្ចឹមបីបាច់ខាងរូបកាយ តម្រូវឲ្យមានការខិតខំពីខ្លួនយើង ហើយថាយើងអាចទទួលប្រយោជន៍ពីអាហារ ឬទឹក បានតែតាមរយៈការទទួលទាន ឬការផឹកវាចូលមកក្នុងខ្លួនយើងប៉ុណ្ណោះ ។ សូមថ្លែងទីបន្ទាល់ថា វាដូចគ្នានឹងខាងវិញ្ញាណដែរ ៖ ដំណឹងល្អអាចចូលមកក្នុងដួងចិត្តរបស់យើង ហើយក្លាយជាចំណែករបស់យើង តែនៅពេលយើងខិតខំរៀនសូត្រសេចក្ដីពិតនៃដំណឹងល្អ ហើយអនុវត្តវានៅក្នុងជីវិតយើងផ្ទាល់ប៉ុណ្ណោះ ។

- តើសកម្មភាពអ្វីខ្លះ ដែលអ្នកនឹងធ្វើនៅឆ្នាំនេះ ដើម្បីអញ្ជើញព្រះវិញ្ញាណ ដើម្បីបង្រៀនអ្នក ហើយនាំសេចក្ដីពិតនៃដំណឹងល្អចូលមកក្នុងដួងចិត្តអ្នកនោះ ? ( ចម្លើយ អាចរួមមាន ការចូលរួមក្នុងការប្រជុំសាសនាចក្រ និងថ្នាក់រៀន រួមមានថ្នាក់សិក្ខាសាលា ការចូលរួមក្នុងការប្រជុំ និងថ្នាក់រៀន តាមរយៈការច្រៀងទំនុកដំកើង ការគូសចំណាំខគម្ពីរ ការកត់ត្រាការបំផុសគំនិត ការឆ្លើយសំណួរ ការចែកចាយបទពិសោធន៍ និងការថ្លែងទីបន្ទាល់ និងការបង្រៀនអ្នកដទៃ ការចូលរួមក្នុងរាត្រីជួបជុំក្រុមគ្រួសារ និងការសិក្សាបទគម្ពីរជាគ្រួសារ មានការសិក្សាព្រះគម្ពីរ និងការអធិស្ឋានផ្ទាល់ខ្លួនជាប្រចាំ និងការអនុវត្តគោលការណ៍ដំណឹងល្អក្នុងជីវិតរបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយ ឬច្រើន ) ។

សូមបញ្ចប់ដោយការសុំឲ្យសិស្សនឹកគិតអំពីទីបន្ទាល់របស់ពួកគេចំពោះដំណឹងល្អ និងអ្វីដែលពួកគេដឹងដោយខ្លួនគេថាជាការពិត ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីរបៀបដែលការខិតខំផ្ទាល់ខ្លួនរបស់ពួកគេក្នុងការរៀនសូត្រដំណឹងល្អមានឥទ្ធិពលទៅលើទីបន្ទាល់ និងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះអម្ចាស់ ។ សូមបន្ថែមទីបន្ទាល់របស់អ្នកអំពីកម្លាំង និងការណែនាំ ដែលយើងអាចទទួលបានមកពីព្រះអម្ចាស់ នៅក្នុងការឆ្លើយតបចំពោះការខិតខំរបស់យើង ដើម្បីរៀនសូត្រ និងរស់នៅតាមគោលការណ៍ដំណឹងល្អ ។

មេរៀនទី ៨

# យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:២១–២៦

## បុព្វកថា

បន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានទទួលការនិមិត្តដំបូងក្នុងឆ្នាំ ១៨២០ នោះលោកបានចែកចាយបទពិសោធន៍របស់លោក ជាមួយនឹងអាចារ្យម្នាក់ ដែលបានបដិសេធទីបន្ទាល់របស់លោក ។ បន្ថែមពីលើនោះ មនុស្សផ្សេងទៀតនៅក្នុងសហគមន៍ បានធ្វើទុក្ខបុកម្នេញ ដល់យុវជនយ៉ូសែប ស្ម៊ីធ ។ មនុស្សដែលមានឥទ្ធិពលបានចេញទៅរិះគន់ដល់លោកជាសាធារណៈ ។ ទោះជាមានការផ្ទុយកើតឡើងក្ដី ក៏យ៉ូសែប ស្ម៊ីធ បានបន្តនៅពិតត្រង់ចំពោះទីបន្ទាល់របស់លោកដែរ ។

## យោបល់សម្រាប់ការបង្រៀន

### យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:២១–២៣

*ពួកអាចារ្យ និងមនុស្សផ្សេងទៀតដែលមានឥទ្ធិពល ញុះញង់ឲ្យមានការបៀតបៀនទាស់នឹងយ៉ូសែប ស្ម៊ីធ*

សូមចាប់ផ្ដើមថ្នាក់រៀនដោយការអានឮៗនូវដំណើររឿងដូចខាងក្រោម ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី អំពីការសន្ទនាមួយដែលលោកមានជាមួយនឹងយុវជនម្នាក់នៅក្នុងទីក្រុងឡុង ប្រទេសអង់គ្លេស ។ មុនពេលអ្នកអានផ្នែកដំបូងនៃដំណើររឿងនេះ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យពិចារណាអំពីអ្វីដែលពួកគេអាចធ្វើ បើពួកគេស្ថិតនៅក្នុងស្ថានភាពរបស់យុវជនរូបនេះ ។ ( អ្នកអាចនឹងប្រាប់សិស្សក្នុងថ្នាក់ថា ទីបញ្ចប់នៃដំណើររឿងនេះ នឹងប្រាប់នៅពេលក្រោយក្នុងមេរៀន ) ។



« គាត់ប្រាប់ថា ‹ ខ្ញុំត្រូវការនិយាយជាមួយនឹងនរណាម្នាក់ ។ ខ្ញុំឯកោណាស់. . . › ។

« រួចខ្ញុំពោលថា ‹ តើប្អូនមានបញ្ហាអ្វី ? ›

« រួចគាត់និយាយថា ‹ នៅពេលខ្ញុំចូលរួមក្នុងព្រះវិហារមិនបានមួយឆ្នាំផង នោះឪពុកខ្ញុំបានដេញខ្ញុំចេញពីផ្ទះរបស់គាត់ និងឲ្យត្រឡប់ទៅវិញឡើយ › ។ ហើយខ្ញុំពុំដែលបានទៅវិញទេ › ។

« គាត់បានបន្តថា ‹ ប៉ុន្មានខែក្រោយមក ក្រុមកីឡាក្រិកខិត ដែលខ្ញុំជាសមាជិក បានដកខ្ញុំចេញពីក្រុមរាំងខ្ញុំមិនឲ្យមានទំនាក់ទំនងនឹងយុវជនដែលខ្ញុំបានធំឡើងជាមួយ និងពីមិត្តភក្តិជិតស្និតរបស់ខ្ញុំ › ។

« រួចគាត់និយាយថា ‹ កាលពីខែមុន ចៅហ្វាយខ្ញុំ បានបណ្ដេញខ្ញុំចេញ ដោយសារតែខ្ញុំជាសមាជិកនៃព្រះវិហារនេះ ហើយខ្ញុំពុំអាចរកការងារផ្សេងធ្វើបានទេ› ។. . .

« ‹ ហើយយប់មិញ មិត្តស្រីដែលខ្ញុំបានស្រឡាញ់ មួយឆ្នាំកន្លះមកហើយនោះ បាននិយាយថា នាងនឹងពុំរៀបការនឹងខ្ញុំឡើយ ដោយសារខ្ញុំជាមរមន › » ( « The Loneliness of Leadership » [ Brigham Young University devotional address ស ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៦៩ ],ទំព័រ ៣, speeches.byu.edu ) ។

បន្ទាប់ពីបានអានដំណើររឿងនេះ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លើយចំពោះសំណួរដូចខាងក្រោម ៖

- តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកត្រូវបានគេប្រព្រឹត្តដោយចិត្តអាក្រក់ ឬរិះគន់ ដោយសារតែជំនឿសាសនារបស់អ្នកឬទេ ? តើវាមានស្ថានភាពយ៉ាងណា ? (អ្នកក៏អាចចង់ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយជាមួយនឹងសិស្សក្នុងថ្នាក់) ។

សូមដាក់បង្ហាញរូបភាព ការនិមិត្តដំបូង (*សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] ទំព័រ ៩០ សូមមើលផងដែរ LDS.org ) ។ សូមពន្យល់ថា ថ្វីត្បិតតែយ៉ូសែបស្ម៊ីធ ត្រូវបានប្រទានពរយ៉ាងច្រើន ដោយសារតែទីបន្ទាល់ដែលលោកបានទទួល មកពីការនិមិត្តដំបូងក្ដី ក៏លោកត្រូវបានសាកល្បងយ៉ាងធំធំដែរ ។ សូមលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេអាចរៀនពីការឆ្លើយតបចំពោះការផ្ទុយរបស់ យ៉ូសែប ស្ម៊ីធ ដែលលោកបានជួបប្រទះ ដោយសារតែទីបន្ទាល់របស់លោកនោះ ។



សូមចាត់សិស្សឲ្យធ្វើការជាគូៗ ។ សូមអញ្ជើញសិស្សមួយគូរៗផ្លាស់វេនគ្នាអាន យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២១–២៣ ឲ្យឮៗ ។ សូមឲ្យពួកគេរកមើលពាក្យ និងឃ្លាដែលបានពិពណ៌នាអំពីការជុំទាស់ ដែលយ៉ូសែប ស៊្មីធ បានជួបប្រទះ ដោយសារតែទីបន្ទាល់របស់លោក ។ ( អ្នកអាចឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំពាក្យ និងឃ្លាដែលពួកគេរកឃើញ ) ។ បន្ទាប់ពីសិស្សបានបញ្ចប់ការអាន សូមសួរសំណួរដូចខាងក្រោម ៖

- តើពាក្យ ឬឃ្លាណាដែលអ្នកចាប់អារម្មណ៍ ?
- តើនរណាដែលផ្ដើមការបៀតបៀនជាច្រើន ទាស់នឹងយ៉ូសែប ស៊្មីធ នៅគ្រានេះ ? ( មនុស្សដែលមានឥទ្ធិពលនៅក្នុងសហគមន៍ ដែលអះអាងខ្លួនថាជាគ្រីស្ទាន ) ។
- នៅពេលអ្នកពិចារណាអំពីវ័យ និងស្ថានភាពក្នុងជីវិតរបស់ យ៉ូសែប ស៊្មីធ តើការបៀតបៀនមកពីពួកមនុស្សទាំងនេះ មានការពិបាកដល់លោកខ្លាំងជាពិសេសយ៉ាងដូចម្ដេចខ្លះ ?

សូមចង្អុលបង្ហាញអំពីប្រយោគដែលនៅជិតចុងបញ្ចប់នៃ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២០ ដែលចាប់ផ្ដើមថា « មើលទៅហាក់បីដូចជា . . .» ។ សូមឲ្យសិស្សចាប់ផ្ដើមជាមួយពាក្យទាំងនេះ ហើយអានខគម្ពីរទាំងអស់ដែលនៅសល់ដោយស្ងាត់ៗ ដោយរកមើលហេតុផលដែលយ៉ូសែប ស៊្មីធ ផ្ដល់ឲ្យអំពីមូលហេតុដែលលោកបានជួបនឹងការបៀតបៀននេះនៅក្នុងភាពវ័យក្មេងបែបនេះ ។

ស្របតាម យ៉ូសែប ស៊្មីធ ហេតុអ្វីបានជាលោកទទួលបទពិសោធន៍នៃការបៀតបៀននេះ តាំងពីវ័យក្មេងដូច្នេះ ? ( សាតាំងបានទទួលស្គាល់ថា យ៉ូសែប ស៊្មីធ នឹងក្លាយជា « អ្នករំខាន និងជាអ្នករំខាននគររបស់វា » [យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២០ ] ) ។

សូមពន្យល់ថា នៅពេលសិស្សបន្តការសិក្សារបស់ពួកគេអំពីយ៉ូសែប ស៊្មីធ—ប្រវត្តិ នោះពួកគេនឹងរៀនពីសេចក្ដីពិតសំខាន់ ដែលនឹងជួយពួកគេឲ្យទប់ទល់នឹងការជុំទាស់ និងការបៀតបៀន ដែលពួកគេអាចជួបប្រទះ ដោយសារតែជំនឿ និងសកម្មភាពសុចរិតរបស់ពួកគេ ។

## យ៉ូសែប ស៊្មីធ – ប្រវត្តិ ១:២៤–២៦

*ទោះបីជា យ៉ូសែប ស៊្មីធ ត្រូវបានគេស្អប់ និងបៀតបៀនក្ដី ក៏លោកបន្តនៅស្មោះពិតចំពោះទីបន្ទាល់របស់លោកដែរ*

សូមលើកគម្ពីររបស់អ្នកឡើង ហើយសួរសំណួរដូចខាងក្រោម ៖

- តើនរណាម្នាក់ ដែលនៅក្នុងគម្ពីរនេះ ដែលអ្នកសរសើរ ដោយសារតែអត្តចរិក ឬភាពរឹងមាំនៃគំរូរបស់គាត់ ? (សូមអញ្ជើញសិស្សឲ្យពន្យល់ដោយសង្ខេបអំពីចម្លើយរបស់ពួកគេ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២៤ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលឈ្មោះមនុស្សម្នាក់ ដែលមានបទពិសោធន៍ស្រដៀងនឹងបទពិសោធន៍របស់យ៉ូសែប ស៊្មីធ ។

- ហេតុអ្វីយ៉ូសែប ស៊្មីធ អាចក្រឡេកទៅមើលបទពិសោធន៍របស់លោក ហើយយល់ពីអារម្មណ៍របស់សាវកប៉ុលដូច្នេះ ? ( ប៉ុល ត្រូវបានគេចំអកចំពោះទីបន្ទាល់របស់លោក អំពីព្រះយេស៊ូវគ្រីស្ទ តែលោកបន្តនៅពិតត្រង់ចំពោះទីបន្ទាល់នោះ ) ។
- អ្នកគិតថា តើវាអាចជាជំនួយដល់ យ៉ូសែប ស៊្មីធ យ៉ាងដូចម្ដេចដើម្បីមើលទៅរឿងទាំងឡាយ ដែលលោកមានស្រដៀងគ្នាទៅនឹងសាវកប៉ុលនោះ ? ( សូមមើល កូរិនថូសទី ២ ១១:២៣–២៧ សម្រាប់ការពិពណ៌នាអំពីការរងទុក្ខរបស់ប៉ុល ) ។
- តើយើងអាចរៀនមេរៀនអ្វីខ្លះ មកពីគំរូនៃការសិក្សា និងការពិចារណាអំពីបទពិសោធន៍របស់ប៉ុលពីយ៉ូសែប ស៊្មីធនោះ ? ( សូមជួយសិស្សប្រាប់គោលការណ៍ដូចខាងក្រោម ៖ **អំឡុងគ្រាលំបាក យើងអាចទាញយកកម្លាំងមកពីគំរូរបស់បុគ្គលស្មោះត្រង់នៅក្នុងបទគម្ពីរ**) ។

សូមសរសេរសេចក្ដីពិតនេះ នៅលើក្ដារខៀន ហើយពន្យល់ថា វាគឺជាឧទាហរណ៍មួយអំពីគោលការណ៍មួយ ។ អ្នកអាចរំឭកសិស្សថា គោលលទ្ធិ និងគោលការណ៍នៃដំណឹងល្អ គឺជាសេចក្ដីពិតគ្រឹះ ពុំផ្លាស់ប្ដូរ ដែលផ្ដល់នូវការណែនាំសម្រាប់ជីវិតរបស់យើង ។ ដើម្បីជួយសិស្សភ្ជាប់គោលការណ៍នេះទៅនឹងជីវិតរបស់ពួកគេ ហើយដឹងពីសេចក្ដីពិត និងសារៈសំខាន់របស់វា សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកត្រូវបានពង្រឹងតាមរយៈការសិក្សាពីបទពិសោធន៍របស់បុគ្គលស្មោះត្រង់ក្នុងបទគម្ពីរនៅពេលណា ? ( អ្នកក៏អាចចែកចាយបទពិសោធន៍មួយផងដែរ ) ។

សូមលើកទឹកចិត្តដល់សិស្សឲ្យបែរទៅរកគម្ពីរជាកម្លាំង ពេលណាពួកគេជួបនឹងការលំបាក ។

សូមសរសេរសេចក្ដីថ្លែងការណ៍ដូចខាងក្រោម នៅលើក្ដារខៀន ៖ *« ដ្បិតខ្ញុំបានឃើញការនិមិត្ត ខ្ញុំដឹងថា ខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំដឹងថា ព្រះទ្រង់ក៏ដឹងថា ខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាចបដិសេធរឿងនេះឡើយ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៥ ) ។*

- តើឃ្លានេះបង្រៀនអ្នកអ្វីខ្លះអំពីទីបន្ទាល់របស់ យ៉ូសែប ស្ម៊ីធ អំពីការនិមិត្តដំបូង ?
- តើអ្នកអាចទទួលបានសាក្សីមួយ ថាយ៉ូសែប ស្ម៊ីធ ពិតជាបានឃើញព្រះជាព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៣–២៥ ដោយស្ងៀមស្ងាត់។ សូមឲ្យពួកគេស្វែងរកគោលលទ្ធិ ឬគោលការណ៍ដែលអាចជួយយើង នៅពេលយើងជួបនឹងការផ្ទុយ ឬកំពុងមានទីបន្ទាល់ពុំរឹងមាំ ។អញ្ជើញពួកគេឲ្យកត់ត្រានូវអ្វីដែលពួកគេរកឃើញចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ឧទាហរណ៍អំពីសេចក្ដីពិត ដែលសិស្សអាចប្រាប់ រួមមានដូចខាងក្រោម ៖

**ចំណេះដឹងដែលយើងទទួលបានមកពីព្រះ គឺពិត ទោះជាពិភពលោកបដិសេធវាក្ដី ។**

**យើងគួរតែខ្វល់ខ្វាយអំពីអ្វីដែលព្រះគិតអំពីយើងឲ្យច្រើនជាងអ្វីដែលមនុស្សគិតពីយើង ។**

**ទោះជាយើងត្រូវគេស្អប់ ហើយបៀតបៀនចំពោះទីបន្ទាល់របស់យើងក្ដី ក៏យើងត្រូវតែនៅពិតស្មោះត្រង់ចំពោះទីបន្ទាល់របស់យើងដែរ ។**

### *ផ្ដល់ឱកាសដល់សិស្សឲ្យកត់ត្រាអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ*

វាចំណាយនូវកិច្ចខិតខំ និងការអនុវត្តដោយហ្មត់ចត់ ដើម្បីរៀនអំពីរបៀបដើម្បីស្គាល់គោលលទ្ធិ និងគោលការណ៍ដំណឹងល្អនៅក្នុងបទគម្ពីរ ហើយថ្លែងវាដោយច្បាស់លាស់ និងសាមញ្ញ ។ អ្នកអាចជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីគោលលទ្ធិ និងគោលការណ៍ដែលពួកគេរកឃើញ ដោយការសុំឲ្យពួកគេសរសេរសេចក្ដីពិតទាំងនេះនៅលើក្ដារខៀន នៅគែមទំព័រព្រះគម្ពីររបស់ពួកគេ ឬនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

សូមអញ្ជើញសិស្សឲ្យចែកចាយសេចក្ដីពិត ដែលពួកគេបានស្គាល់ ។ សូមលើកទឹកចិត្តពួកគេឲ្យស្ដាប់ដោយប្រុងប្រយ័ត្នចំពោះគ្នាទៅវិញទៅមក ។ អ្នកអាចឲ្យយោបល់ថា ពួកគេកត់ត្រាសេចក្ដីពិត ដែលពួកគេបានរៀនពីមួយទៅមួយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរ ។ ពេលសិស្សចែកចាយសេចក្ដីពិត ដែលពួកគេបានរកឃើញ សូមសួរសំណួរដូចខាងក្រោម ៖

- តើ យ៉ូសែប ស្ម៊ីធ ជាគំរូនៃសេចក្ដីពិតនោះដោយរបៀបណា ?
- តើសេចក្ដីពិតនោះ អាចជាប្រយោជន៍ដល់អ្នកយ៉ាងដូចម្ដេច ?
- តើការរស់នៅតាមសេចក្ដីពិតនោះ មានឥទ្ធិពលលើការជ្រើសរើសរបស់យើងយ៉ាងដូចម្ដេច ?

សូមអានដំណើររឿងដែលនៅសល់ ដែលបានថ្លែងប្រាប់ដោយប្រធាន ហ៊ិងគ្លី អំពីយុវជននៅទីក្រុងឡុង ប្រទេសអង់គ្លេស ដែលប្រឈមមុខនឹងរឿងផ្ទុយយ៉ាងខ្លាំង ដោយសារតែជំនឿសាសនារបស់គាត់នោះឲ្យឮៗ ៖



« ខ្ញុំបាននិយាយថា ‹ បើរឿងនេះ ធ្វើឲ្យអ្នកត្រូវបាត់បង់ច្រើនយ៉ាងនេះ ហេតុអ្វីក៏អ្នកមិនចាកចេញពីសាសនាចក្រនេះ ហើយត្រឡប់ទៅផ្ទះរកឪពុកអ្នកវិញ ទៅរកក្រុមកីឡាក្រិកខិតរបស់អ្នក និងទៅរកកន្លែងការងារ ដែលមានន័យយ៉ាងខ្លាំងចំពោះអ្នក និង ទៅរកមិត្តស្រី ដែលអ្នកគិតថាអ្នកស្រឡាញ់នោះវិញទៅ ? ›

« គាត់ពុំបាននិយាយអ្វីជាយូរ ។ រួចហើយគាត់យកដៃអោបក្បាលចុះ គាត់យំខ្សឹកខ្សួលយ៉ាងខ្លាំង ។ ទីបំផុត គាត់បានងើបឡើងនិយាយទាំងទឹកភ្នែកថា ‹ ខ្ញុំមិនអាចធ្វើដូច្នោះបានទេ ។ ខ្ញុំដឹងថា សាសនាចក្រនេះពិត ហើយបើវាត្រូវចំណាយទាំងជីវិតខ្ញុំក្ដី ក៏ខ្ញុំពុំអាចលះបង់វាចោលឡើយ › » ( « The Loneliness of Leadership » ទំព័រ ៣–៤ ) ។

សូមអញ្ជើញសិស្សឲ្យជ្រើសរើសសេចក្ដីពិតមួយ ដែលពួកគេបានសរសេរ ហើយកត់នូវអ្វីដែលពួកគេនឹងធ្វើដើម្បីអនុវត្តសេចក្ដីពិតនោះនៅក្នុងជីវិតរបស់ពួកគេ ។

សូមបញ្ចប់មេរៀនដោយការអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៦ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយប្រាប់នូវគោលការណ៍ដែល យ៉ូសែប ស្ម៊ីធ បានរកឃើញថាជាការពិត ។

- តើយ៉ូសែប ស្ម៊ីធ មានពរជ័យអ្វីខ្លះ ដោយសារតែលោកបានជឿលើការសន្យារបស់យ៉ាកុប ? ( លោកបានរៀនថា នៅពេលយើងសូមប្រាជ្ញាពីព្រះដោយសេចក្ដីជំនឿ នោះទ្រង់នឹងប្រទានដល់យើងដោយសទ្ធាឥតបន្ទោសផង ។ លោកក៏បានរៀនផងដែរថា នៅពេលយើងធ្វើតាមការសន្យាក្នុងព្រះគម្ពីរ នោះយើងអាចទទួលបានទីបន្ទាល់មួយនៃសេចក្ដីពិត ) ។

សូមចែកចាយទីបន្ទាល់របស់អ្នកថា នៅពេលយើងទុកចិត្តលើព្រះ ហើយជឿ និងធ្វើតាមការសន្យាទាំងឡាយក្នុងព្រះគម្ពីរ នោះយើងនឹងទទួលបានចម្លើយមកពីព្រះ ហើយទទួលកម្លាំងដើម្បីយកឈ្នះលើបញ្ហានានាដែលយើងជួប ។

មេរៀនទី ៩

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–៥៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ២

## បុព្វកថា

យុវជន យ៉ូសែប ស្ម៊ីធ បានបន្តបញ្ជាក់អះអាងថា លោកបានឃើញការនិមិត្តមួយ ហើយលោកត្រូវបានបៀតបៀនជាបន្តបន្ទាប់ ។ ក្រោយមក លោកបានមានប្រសាសន៍ថា អំឡុងពេលនេះ លោក « ធ្លាក់ទៅក្នុងការខុសឆ្គងជាច្រើន ហើយបានសម្ដែងនូវភាពទន់ខ្សោយនៃយុវវ័យ » (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៨ ) ។ នាល្ងាចមួយ នៅពេលលោកមានអាយុ ១៧ ឆ្នាំ លោកបានអធិស្ឋានសុំការអភ័យទោស ហើយបានសូមដើម្បីដឹងពីគោលជំហររបស់លោកនៅចំពោះព្រះ ។ ទេវតាមួយអង្គនាម មរ៉ូណៃ បានលេចមក ហើយបានប្រកាសថា ព្រះមានកិច្ចការមួយសម្រាប់យ៉ូសែបធ្វើ រួមមានទាំងការបកប្រែបញ្ជីកំណត់ត្រាបុរាណមួយនៅលើផ្ទាំងមាស ។ ខណៈដែលកំពុងតែពន្យល់អំពីតួនាទីរបស់ យ៉ូសែប នៅក្នុងការស្ដារឡើងវិញនៃដំណឹងល្អនោះ មរ៉ូណៃ បានដកស្រង់ពាក្យព្យាករណ៍មួយចំនួនចេញពីព្រះគម្ពីរប៊ីប រួមទាំងការព្យាករណ៍របស់ម៉ាឡាគីអំពីការត្រឡប់មកវិញនៃអេលីយ៉ា ។ នៅថ្ងៃបន្ទាប់ យ៉ូសែប ស្ម៊ីធ បានចេញទៅកូនភ្នំ ដែល មរ៉ូណៃ បានប្រាប់ថា ផ្ទាំងមាសត្រូវបានកប់ទុកនោះ ។ នៅទីនោះ លោកបានទទួលការណែនាំបន្ថែមទៀតមកពីមរ៉ូណៃ ។

## យោបល់សម្រាប់ការបង្រៀន

### យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:២៧–២៩

*យ៉ូសែប ស្ម៊ីធ អធិស្ឋានសុំការអភ័យទោស*

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីដែលពួកគេបានរៀនមកពីគំរូរបស់ យ៉ូសែប ស្ម៊ីធ កាលពីនៅក្មេង ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយសង្ខេបអំពីគោលការណ៍ដែលពួកគេបានរៀន ដែលមានឥទ្ធិពលចំពោះពួកគេ ។ បន្ទាប់មកសុំសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–២៩ ឲ្យឮៗ ។ មុនពេលឲ្យពួកគេអាន សូមចង្អុលបង្ហាញថា ព្រឹត្តការណ៍ដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ បានកើតឡើងនៅពេលយ៉ូសែប មានអាយុចន្លោះពី ១៤ ទៅ ១៧ ឆ្នាំ ។ សូមអញ្ជើញសិស្សឲ្យ ប្រដូចខគម្ពីរទាំងនេះ ទៅនឹងខ្លួនពួកគេ ដោយប្រាប់អំពីបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធ ដែលស្រដៀងគ្នានឹងបទពិសោធន៍ដែលពួកគេមាន ។

- តើបទពិសោធន៍មួយចំនួនដែលយ៉ូសែប ស្ម៊ីធ មានកាលពីនៅក្មេង ដែលអ្នកអាចមានដូចគ្នានោះ មានអ្វីខ្លះ ? ( សូមរំឭកសិស្សថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ឬ រឿងផ្ទាល់ខ្លួនខ្លាំងពេកនោះទេ ) ។
- យោងទៅតាមចុងបញ្ចប់នៃ យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:២៨ តើយ៉ូសែប ស្ម៊ីធបាននិយាយអ្វីខ្លះអំពីការល្បួង និងកំហុសឆ្គងដែលលោកបានធ្លាក់ចូលនោះ ? ( លោកពុំបានធ្វើខុសចំពោះអំពើបាបធ្ងន់ធ្ងរណាមួយទេ ប៉ុន្ដែពេលខ្លះ លោកមានអារម្មណ៍ថា លោកពុំបានធ្វើចរិយាសមរម្យ ជាអ្នកដែលត្រូវបានហៅដោយព្រះគួរធ្វើនោះឡើយ ) ។
- តើយ៉ូសែប ស្ម៊ីធ បានធ្វើអ្វីខ្លះ ចំពោះកំហុសឆ្គងដែលលោកមានអារម្មណ៍ចំពោះអំពើបាបរបស់លោក ? ( លោកបានអធិស្ឋានសុំការអភ័យទោស ហើយបានសុំសួរដើម្បីដឹងពីគោលជំហររបស់លោកនៅចំពោះព្រះ ) ។
- តើសេចក្ដីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីគំរូរបស់យ៉ូសែប ស្ម៊ីធ ?

នៅពេលសិស្សពិភាក្សាអំពីគំនិតរបស់ពួកគេ សូមជួយពួកគេឲ្យប្រាប់ពីសេចក្ដីពិតដូចខាងក្រោម ៖

**នៅពេលយើងទទួលស្គាល់អំពើបាបរបស់យើង ហើយមានអារម្មណ៍សោកស្ដាយចំពោះវា នោះយើងអាចអធិស្ឋានទៅព្រះវរបិតាសួគ៌សុំការអភ័យទោស ។**

**យើងអាចអធិស្ឋានដើម្បីដឹងពីគោលជំហររបស់យើងចំពោះព្រះ ។**

***បង្រៀនសិស្សឲ្យប្រដូចព្រះគម្ពីរទៅនឹងខ្លួនពួកគេ***

សូមលើកទឹកចិត្តសិស្សឲ្យសួរខ្លួនគេថា « តើកាលៈទេសៈ និងស្ថានភាពអ្វីខ្លះក្នុងជីវិតរបស់ខ្ញុំ ដូចគ្នានឹងស្ថានភាព និងកាលៈទេសៈដែលមាននៅក្នុងវគ្គបទគម្ពីរនេះ ? » ឬ « តើខ្ញុំដូចជាមនុស្សដែលយើងកំពុងសិក្សាក្នុងបទគម្ពីរនេះយ៉ាងដូចម្ដេច ? » នៅពេលសិស្សឃើញភាពស្រដៀងគ្នារវាងបទពិសោធន៍របស់ពួកគេ និងបទពិសោធន៍របស់មនុស្សក្នុងបទគម្ពីរ នោះពួកគេនឹងអាចស្គាល់គោលលទ្ធិ និងគោលការណ៍កាន់តែច្បាស់ ហើយមើលឃើញពីរបៀបដែលសេចក្ដីពិតទាំងនោះអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។

- តើអ្នកគិតថា ការដឹងពីគោលជំហររបស់អ្នកនៅចំពោះព្រះមានន័យដូចម្ដេច ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ដើម្បីដឹងពីគោលជំហររបអ្នកចំពោះព្រះ មានន័យថា ដឹងថាតើព្រះសព្វព្រះទ័យនឹងយើងឬអត់ ) ។
- ហេតុអ្វីក៏វាសំខាន់សម្រាប់យើង ដើម្បីដឹងពីគោលជំហររបស់យើងនៅចំពោះព្រះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន កូរ៉ុមនៃពួកសាវក ដប់ពីរនាក់ ។ សូមពន្យល់ថា ការប្រឹក្សារបស់អែលឌើរ អាន់ឌើរសិន អាចជួយយើងឲ្យដឹងពីរបៀបដែលយើងអាចដឹងពី គោលជំហររបស់យើងនៅចំពោះព្រះ ។



« [ យើងអាច ] ទូលអង្វរដល់ព្រះអម្ចាស់ដោយរាបសារ ៖ ‹ ព្រះវរបិតាអើយ តើទ្រង់សព្វព្រះទ័យ ចង់ឲ្យទូលបង្គំធ្វើអ្វីខ្លះ ? › ចម្លើយបានមក ។ យើងមានអារម្មណ៍ត្រូវធ្វើការផ្លាស់ប្ដូរជាចាំបាច់ ។ ព្រះអម្ចាស់ប្រាប់យើងនៅក្នុងគំនិត និងដួងចិត្តយើង » (ប្រែចិត្ត. . . ដើម្បីយើងអាចជួយដល់ អ្នកបាន » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤១ ) ។

សូមថ្លែងទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិតដែលសិស្សបានពិភាក្សា ។ សូមអះអាងនឹងសិស្សថា ព្រះវរបិតាសួគ៌ មានព្រះឆន្ទៈ អភ័យទោសដល់យើង នៅពេលយើងអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយធ្វើអ្វីៗទាំងអស់ ដែលចាំបាច់ដើម្បី ប្រែចិត្តពីអំពើបាបរបស់យើង ។

## យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:៣០–៣៥

*ទេវតាមរ៉ូណៃ លេចមកឯយ៉ូសែប ស្ម៊ីធ*

សូមអញ្ជើញសិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ– ប្រវត្តិ ១:៣០ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលបានកើតឡើង នៅពេលយ៉ូសែប ស្ម៊ីធ បានអធិស្ឋានសុំការអភ័យទោស ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ សូមដាក់បង្ហាញរូបភាព មរ៉ូណៃ លេចមកឯយ៉ូសែប ស្ម៊ីធ ក្នុងបន្ទប់របស់លោក(*សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] ទំព័រ ៩១ សូមមើលផងដែរ LDS.org ) ។



សូមឲ្យសិស្សអាន យ៉ូសែប ស្ម៊ីធ– ប្រវត្តិ ១:៣២–៣៣ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ស្វែងរកសារលិខិតដំបូងរបស់ មរ៉ូណៃទៅកាន់យ៉ូសែប ស្ម៊ីធ ។

- តើមរ៉ូណៃនិយាយអ្វីខ្លះ អំពីអនាគតរបស់ យ៉ូសែប ស្ម៊ីធ ? ( សិស្សគួរតែបង្ហាញថា **ព្រះមានកិច្ចការមួយឲ្យយ៉ូសែប ស្ម៊ីធ ធ្វើ**) ។
- មរ៉ូណៃ បាននិយាយថា ឈ្មោះរបស់យ៉ូសែប ស្ម៊ីធ នឹង « ត្រូវបានស្គាល់សម្រាប់សេចក្ដីល្អ និងសេចក្ដីអាក្រក់ក្នុង ចំណោមគ្រប់សាសន៍ទាំងអស់ » ។ តើអ្នកបានឃើញ គំរូដូច្នេះនៅពេលណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៤–៣៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម ប្រាប់ អំពីអ្វីដែល មរ៉ូណៃ បានបង្រៀនអំពីកិច្ចការដែល យ៉ូសែប នឹងធ្វើ ។

- តើព្រះគម្ពីរនឹងត្រូវបកប្រែដោយរបៀបណា ? ( តាមរយៈ ការប្រើត្បូងពិសេស ដែលបានហៅថា យូរីម និងធូមីម ដែលព្រះបានរៀបចំទុក ) ។

សូមពន្យល់ថា នៅក្នុងមេរៀនខាងមុខ សិស្សនឹងរៀនអំពីការខិតខំរបស់យ៉ូសែប ស្ម៊ីធ ដើម្បីបកប្រែ និងបោះពុម្ព ព្រះគម្ពីរមរមន ។

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៦–៤៩; គោលលទ្ធិ និង សេចក្ដីសញ្ញា ២ ។

*ម៉ូរ៉ូណៃបង្រៀនដល់យ៉ូសែប ស្ម៊ីធ*

សូមសង្ខេប យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៦–៤២ ដោយការពន្យល់ថា ម៉ូរ៉ូណៃ បានដកស្រង់ការព្យាករណ៍មកពី ព្រះគម្ពីរប៊ីប ដើម្បីពន្យល់អំពីតួនាទីរបស់ យ៉ូសែប ស្ម៊ីធ នៅក្នុងការនាំមកនូវការស្ដារឡើងវិញនៃដំណឹងល្អ ។ ( សូមពិចារណាឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំសេចក្ដីយោងខគម្ពីរ ដែលបានប្រាប់នៅក្នុងវគ្គទាំងនោះ ) ។ ឧទាហរណ៍ នៅក្នុង ខ ៤០ សិស្សអាចគូសចំណាំឃ្លា « ជំពូកដប់មួយនៃគម្ពីរអេសាយ » ) ។

សូមចង្អុលបង្ហាញថា ពាក្យនៅក្នុងការព្យាករណ៍ ដែលបានដកស្រង់នៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៨–៣៩ ក៏មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២ ផងដែរ ។ នេះគឺជាវិវរណៈមួយដំបូងបំផុត នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ដែលបានប្រគល់ដល់ យ៉ូសែប ស្ម៊ីធ នៅពេលលោកមានអាយុ ១៧ ឆ្នាំ ។

អ្នកអាចនឹងចង់ប្រាប់ថា ការព្យាករណ៍នេះ គឺមានសារៈសំខាន់ដូចដែលវាបានមាននៅក្នុងគម្ពីរសញ្ញាចាស់ផងដែរ ( សូមមើល ម៉ាឡាគី ៤:៥–៦) គម្ពីរសញ្ញាថ្មី ( សូមមើល លូកា ១:១៧) និងព្រះគម្ពីរមរមន ( សូមមើល នីហ្វៃទី ៣ ២៥:៥–៦ ) ។

មុនពេលចាប់ផ្ដើមថ្នាក់ សូមថតចម្លងតារាងដូចខាងក្រោម ។ កាត់វាជាបីចំរៀកដើម្បីចែកឲ្យសិស្ស ។ សូមបំបែកសិស្សក្នុងថ្នាក់ជាបីក្រុម ហើយឲ្យក្រុមនិមួយៗនូវក្រដាសមួយសន្លឹក ។ សូមឲ្យក្រុមនីមួយៗសិក្សាអំពីខគម្ពីរ និងការពន្យល់អំពីការព្យាករណ៍ដែលមានមកតាមក្រោយវា ដែលបានដាក់ឲ្យពួកគេធ្វើនោះ ។ បន្ថែមពីលើនោះ សូមឲ្យក្រុមនីមួយៗ សង្ខេបសារលិខិតក្នុងខគម្ពីរដែលបានចាត់ឲ្យពួកគេនោះតាមពាក្យសម្ដីខ្លួនគេ ហើយឆ្លើយសំណួរ ឬសួរសំណួរនៅលើក្រដាសរបស់ពួកគេ ។

### ក្រុមទី ១

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:១– តើអេលីយ៉ាជានរណា ? តើអំណាចបព្វជិតភាពដែល ម៉ូរ៉ូណៃ បាននិយាយថា អេលីយ៉ា នឹងស្ដារឡើងវិញជាអ្វី ?



« អេលីយ៉ា គឺជាព្យាការីដ៏អស្ចារ្យម្នាក់ដែលព្រះបានប្រទានអំណាចដ៏មហិមាដល់លោក ។ លោកកាន់អំណាចដ៏ធំបំផុត ដែលព្រះបានប្រទានដល់កូនចៅរបស់ទ្រង់ ៖ លោក កាន់អំណាចនៃការផ្សារភ្ជាប់ អំណាចដើម្បីចងអ្វីៗនៅលើផែនដី និងវាចងអ្វីៗនៅលើស្ថានសួគ៌ » ( ប្រធាន ហិនរី ប៊ី អាវរិង Hearts Bound Together » *Ensign* ឬ *លីអាហូណា* ខែឧសភា ឆ្នាំ ២០០៥ ទំព័រ ៧៨ ) ។

### ក្រុមទី ២

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:២–តើឪពុក និងកូន ដែលនិយាយនៅក្នុងខនេះ សំដៅទៅលើនរណា ?



នៅក្នុងការព្យាករណ៍ថា « លោកនឹងដាក់នៅក្នុងចិត្តនៃកូនចៅ នូវសេចក្ដីសន្យាដែលបានធ្វើដល់ពួកឪពុក » ឃ្លា « ឪពុក » សំដៅទៅលើ « អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប ដែលសេចក្ដីសន្យាទាំងឡាយបានធ្វើឡើង ។ តើការសន្យាមានអ្វីខ្លះ ? វាគឺជាការសន្យាទាំងឡាយនៃការបន្តមានក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច » ( អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *Millennial Messiah* [ ឆ្នាំ ១៩៨២ ] ទំព័រ ២៦៧ ) ។



នៅក្នុងការព្យាករណ៍ថា « ចិត្តនៃកូនចៅនឹងបានបង្វែរមករកពួកឪពុករបស់ពួកគេ » ឃ្លា « ពួកឪពុករបស់ពួកគេ » សំដៅទៅលើ « ជីដូនជីតាដែលចែកឋានទៅរបស់យើង ដែលបានទទួលមរណកាលទៅដោយគ្មានឯកសិទ្ធិដើម្បីទទួលដំណឹងល្អ ប៉ុន្តែបានទទួលការសន្យាថាពេលវេលានឹងមកដល់ ដែលឯកសិទ្ធិនោះនឹងផ្ដល់ដល់ពួកគាត់ ។ កូនចៅគឺជាអ្នកទាំងឡាយដែលកំពុងរស់នៅឥឡូវនេះ ដែលកំពុងរៀបចំទិន្នន័យពង្សាវលី ហើយដែលកំពុងធ្វើពិធីបរិសុទ្ធជំនួសនៅក្នុងព្រះវិហារបរិសុទ្ធ » ( President Joseph Fielding Smith *Doctrines of Salvation* បានបោះពុម្ពដោយ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី វ៉ុល ៣ [ ឆ្នាំ ១៩៥៤–៥៦ ] ២:១២៧ ) ។

### ក្រុមទី ៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:៣–ហេតុអ្វីផែនដីនឹងត្រូវកំទេចចោលសូន្យឈឹង បើអំណាចនៃការផ្សារភ្ជាប់មិនត្រូវបានស្ដារឡើងវិញនោះ ?



« ហេតុអ្វីផែនដីនឹងត្រូវកំទេចចោលដូច្នេះ ? ធម្មតាប្រសិនបើវាពុំមានបណ្ដាញវេញចូលគ្នាមួយរវាងពួកឪពុក និងកូនចៅ–ដែលជាកិច្ចការសម្រាប់មរណជនទេ–នោះយើងទាំងអស់គ្នានឹងត្រូវចំទេចចោល ហើយកិច្ចការរបស់ព្រះទាំងមូល នឹងបរាជ័យ ហើយកំទេចចោលសូន្យឈឹង » ( ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ *Doctrines of Salvation* បានបោះពុម្ពដោយ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី វ៉ុល ៣ [ ឆ្នាំ ១៩៥៤–៥៦ ] ២:១២២ ) ។

បន្ទាប់ពីក្រុមមានពេលគ្រប់គ្រាន់ដើម្បីរៀបចំ សូមអញ្ជើញសិស្សមកពីក្រុមទាំងឡាយ រាយការណ៍អំពីការសង្ខេប និងចម្លើយរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។ ចម្លើយរបស់សិស្ស គួរឆ្លុះបញ្ចាំងពីសេចក្ដីពិតដូចខាងក្រោម ៖

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:១—**ព្រះនឹងបញ្ជូនអេលីយ៉ាឲ្យមកស្ដារអំណាចនៃការផ្សារភ្ជាប់នៅលើផែនដី មុនពេលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។**

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:២—**ដួងចិត្តរបស់យើង អាចបង្វែរទៅរកជីដូនជីតារបស់យើង ហើយយើងអាចធ្វើពិធីបរិសុទ្ធនានាជំនួសពួកគាត់ក្នុងព្រះវិហារបរិសុទ្ធ ។**

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:៣—**បើគ្មានអំណាចដើម្បីប្រមូលក្រុមគ្រួសារសម្រាប់ភាពដ៏នៅអស់កល្បជានិច្ចទេ នោះផែនដីនឹងត្រូវបំផ្លាញចោលនៅការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។**

បើអ្នកបានផ្សារភ្ជាប់ហើយក្នុងព្រះវិហារបរិសុទ្ធ អ្នកអាចនឹងបង្ហាញរូបភាពមួយអំពីក្រុមគ្រួសាររបស់អ្នក ។ បើអ្នកពុំទាន់បានផ្សារភ្ជាប់ទេ សូមប្រាប់អំពីក្ដីរំភើបរបស់អ្នកដើម្បីទទួលបានការផ្សារភ្ជាប់ ។ សូមពន្យល់ដោយសង្ខេបថា នៅពេលសិស្សសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ នោះពួកគេនឹងរៀនអំពី អេលីយ៉ាប្រគល់អំណាចនៃការផ្សារភ្ជាប់ទៅឲ្យព្យាការី យ៉ូសែប ស្ម៊ីធ ។

សូមបង្វែរអារម្មណ៍សិស្សឲ្យផ្ដោតលើរឿងនិទាននៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ វិញដោយពន្យល់ថា បន្ទាប់ពី មរ៉ូណៃ បានដកស្រង់ការព្យាករណ៍អំពីការត្រឡប់មកវិញរបស់ អេលីយ៉ា នោះលោកបានដកស្រង់ការព្យាករណ៍ផ្សេងទៀត អំពីការស្ដារឡើងវិញ ។ បន្ទាប់មក លោកបានផ្ដល់ការណែនាំបន្ថែម អំពីផ្ទាំងមាស ហើយក៏ចេញទៅ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៤២–៤៣ ) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៤៤–៤៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីអ្វីដែលបានកើតឡើង បន្ទាប់ពីមរ៉ូណៃបានចាកចេញទៅ ។ នៅពេលសិស្សស្គាល់ថា មរ៉ូណៃបានត្រឡប់មកយប់នោះ ហើយរំឭកសារលិខិតដដែល សូមអញ្ជើញពួកគេឲ្យមើលត្រួសៗ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៤៦–៤៩ ហើយស្វែងរកចំនួនដងដែលមរ៉ូណៃ បាននាំសារលិខិតដូចគ្នាទៅដល់យ៉ូសែប ស្ម៊ីធ ។

- តើទេវតាមរ៉ូណៃបាននាំសារមកកាន់ យ៉ូសែប ស្ម៊ីធ រយៈពេលប៉ុន្មានដង ? ( បួនដង ) ។
- តើសារលិខិតមួយចំនួន ដែលបានផ្ដល់ដដែលៗនៅក្នុងបទគម្ពីរ នៅក្នុងមេរៀនសាសនាចក្រ និងនៅក្នុងសុន្ទរកថាសន្និសីទទូទៅមានអ្វីខ្លះ ?
- តើយើងអាចទទួលប្រយោជន៍ នៅពេលព្រះអម្ចាស់ និងពួកអ្នកបម្រើទ្រង់ បានថ្លែងសារលិខិតរបស់ពួកលោកឡើងវិញតាមវិធីណា ?

សូមលើកទឹកចិត្តដល់សិស្សឲ្យរកមើលការបង្រៀនដដែលៗ នៅពេលពួកគេសិក្សាបទគម្ពីរដោយខ្លួនឯង ហើយពិចារណាអំពីសារៈសំខាន់នៃការបង្រៀនទាំងនោះ ។

### យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:៥០–៥៤

*យ៉ូសែប បានទៅកាន់កូនភ្នំនោះ ហើយបានបើកយក កំណត់ត្រា យ៉ូរីម និងធូមីម និងប្រដាប់បាំងទ្រូង ។*

សូមសង្ខេប យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥០–៥១ ដោយពន្យល់ថា យ៉ូសែប បានគោរពតាមបញ្ជារបស់ មរ៉ូណៃ ហើយបានប្រាប់ដល់ឪពុករបស់លោក អំពីបទពិសោធន៍នាយប់មុនរបស់លោក ។ ឪពុករបស់លោកជឿដល់លោក ហើយបានទូន្មានដល់លោកឲ្យធ្វើតាមអ្វីដែល មរ៉ូណៃបានប្រាប់ឲ្យលោកធ្វើ ។ ដូច្នេះយ៉ូសែប បានទៅកូនភ្នំជាកន្លែងដែលផ្ទាំងមាសកប់នៅទីនោះ ។

សូមឲ្យសិស្សបីនាក់ ផ្លាស់វេនគ្នាអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥២–៥៤ ឲ្យឮៗ ខណៈដែលសិស្សក្នុងថ្នាក់ផ្ទៀងតាម ។ ដើម្បីប្រាកដថាសិស្សយល់បានច្បាស់អំពីព្រឹត្តការណ៍នានា ដែលបានពិពណ៌នានៅក្នុងខទាំងនេះ សូមឲ្យសិស្សម្នាក់ថ្លែងឡើងវិញពីអ្វីដែលបានកើតឡើងតាមពាក្យរបស់គេផ្ទាល់ ។ សូមប្រាប់ដល់សិស្សថា នៅក្នុងមេរៀនក្រោយ ពួកគេនឹងពិភាក្សាអំពីព្រឹត្តការណ៍នានាដែលកើតឡើងនៅជុំវិញពេលដែលយ៉ូសែប ត្រូវបានអនុញ្ញាតឲ្យទទួលផ្ទាំងចំណារ ។

អ្នកក៏អាចចង់បញ្ចប់មេរៀនដោយការថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សានៅក្នុងមេរៀននេះ និងដោយការអញ្ជើញសិស្សឲ្យអនុវត្តតាមការបំផុសគំនិតទាំងឡាយណា ដែលពួកគេបានទទួល ដើម្បីអនុវត្តសេចក្ដីពិតទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

មេរៀនទី ១០

# យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៥៥–៥៦

## បុព្វកថា

ព្យាការី យ៉ូសែប ស្ម៊ីធ បានពិពណ៌នាអំពីព្រឹត្តការណ៍សំខាន់មួយចំនួន ដែលលោកបានទទួលបទពិសោធន៍ នៅចន្លោះអាយុ ១៧ និង ២២ ឆ្នាំ ។ ព្រឹត្តការណ៍ទាំងនេះ រួមមានការងាររបស់លោកដើម្បីជួយផ្គត់ផ្គង់គ្រួសាររបស់លោក ការស្លាប់របស់បងប្រុសលោក ឈ្មោះ អាល់វិន និងអាពាហ៍ពិពាហ៍របស់លោក ជាមួយនិង អិមម៉ា ហេល ។ យ៉ូសែប ក៏បានសរសេរផងដែរថា បន្ទាប់ពីអស់រយៈពេលជាច្រើនឆ្នាំក្នុងការទទួលការបង្រៀនមកពីទេវតា មរ៉ូណៃ នោះលោក ផ្ដល់ នូវ ការទទួលខុសត្រូវលើផ្ទាំងចំណារ ហើយបានចាប់ផ្ដើមបកប្រែព្រះគម្ពីរមរមន ។

ម៉ាទីន ហារីស បានបង្ហាញច្បាប់ចម្លងនៃអក្សរមួយចំនួនចេញមកពីផ្ទាំងចំណារ និងការបកប្រែរបស់ពួកលោកទៅលំពួកបណ្ឌិតនៅរដ្ឋនូវយ៉ោក ។ បណ្ឌិតទាំងនេះ បានអះអាងពីភាពត្រឹមត្រូវនៃតួអក្សរទាំងឡាយ និងភាពត្រឹមត្រូវនៃការបកប្រែរបស់ពួកលោក ។ ទោះជាយ៉ាងណាក៏ដោយ មានបណ្ឌិតម្នាក់ បានបដិសេធដំណើររឿងដែលយ៉ូសែប ស្ម៊ីធ បានទទួលផ្ទាំងចំណារ ដែលបំពេញតាមការព្យាករណ៍មួយមកពីគម្ពីរអេសាយ ( សូមមើល អេសាយ ២៩:១១–១២ និង នីហ្វៃទី ២ ២៧:១៥–២០ ) ។

## យោបល់សម្រាប់ការបង្រៀន

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៥៨

*យ៉ូសែប ស្ម៊ីធ ធ្វើការឲ្យ យ៉ូសៀស ស្ដោល ហើយបានរៀបការជាមួយ អិមម៉ា ហេល*

*កំណត់ចំណាំ ៖* នៅក្នុងយ៉ូសែប ស្ម៊ីធ–ប្រវត្តិ ព្យាការីសំដៅទៅលើ យ៉ូសៀស ស្ទូល ។ នៅក្នុងកំណត់ត្រាខាងប្រវត្តិសាស្ត្រមួយចំនួន *ស្ដោល* ក៏លេចចេញជា *ស្ទូវែល* ឬពាក្យក្លាយផ្សេងៗទៀតផងដែរ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីព្រឹត្តការណ៍សំខាន់មួយ ដែលបានកើតឡើងនៅក្នុងជីវិតរបស់ពួកគេ អំឡុងប៉ុន្មានឆ្នាំមុន ។ សូមឲ្យពួកគេពន្យល់អំពីរបៀបដែលព្រឹត្តការណ៍នេះ មានឥទ្ធិពលទៅលើចរិយា និងអនាគតរបស់ពួកគេ ។ បន្ទាប់មកសុំឲ្យសិស្សក្នុងថ្នាក់ ប្រាប់ពីព្រឹត្តការណ៍សំខាន់មួយចំនួន ដែលពួកគេរំពឹងថាកើតឡើងនៅក្នុងជីវិតរបស់ពួកគេ អំឡុងប្រាំឆ្នាំទៀត ។ សូមពន្យល់ថា នៅក្នុងមេរៀនថ្ងៃនេះថា ពួកគេនឹងរៀនអំពីព្រឹត្តការណ៍សំខាន់ៗនៅក្នុងរយៈពេលប្រាំឆ្នាំនៃជីវិតរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។ សូមចង្អុលបង្ហាញថា នៅក្នុងដំណើររឿងដែលបានកត់ត្រានៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៦៥ យ៉ូសែប ស្ម៊ីធ គឺមានអាយុចន្លោះពី ១៧ និង ២២ ឆ្នាំ –គឺស្រករនឹងអាយុរបស់សិស្សថ្នាក់សិក្ខាសាលាជាច្រើន ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៥៨ ដោយស្ងាត់ស្ងៀម រកមើលព្រឹត្តការណ៍សំខាន់ៗនៅក្នុងជីវិតរបស់យ៉ូសែប ស្ម៊ីធ ។

- តើព្រឹត្តការណ៍សំខាន់អ្វីខ្លះ ដែលបានកើតឡើងអំឡុងពេលនេះក្នុងជីវិតរបស់យ៉ូសែប ស្ម៊ីធ ? ( ចម្លើយរបស់សិស្សអាចរួមមានដូចខាងក្រោម ៖ ការស្លាប់បងប្រុសរបស់យ៉ូសែប ឈ្មោះ អាល់វិន, យ៉ូសែប ស្ម៊ីធ បានចេញទៅធ្វើការឲ្យ យ៉ូសៀស ស្ដោល, យ៉ូសែប បានរៀបការជាមួយ អិមម៉ា ហេល ) ។

### យ៉ូសែប ស្ម៊ីធ – ប្រវត្តិ ១:៥៩–៦២

*យ៉ូសែប បានទទួលផ្ទាំងចំណារ ហើយបានចាប់ផ្ដើមធ្វើការបកប្រែ*

សូមយកវត្ថុមួយមកពីផ្ទះ ( ឬប្រាប់ពីវត្ថុមួយនៅក្នុងថ្នាក់រៀនរបស់អ្នក ) ដែលអ្នកដឹងថាមានតម្លៃខ្ពស់ ហើយអ្នកចង់ថែរទាំវាដោយយកចិត្តទុកដាក់ ។ សូមពន្យល់អំពីសារៈសំខាន់នៃវត្ថុនោះ ហើយហេតុអ្វីក៏អ្នកថែរទាំវាយ៉ាងយកចិត្តទុកដាក់ដូច្នេះ ។

- តើអ្នកធ្លាប់ឃើញនរណាម្នាក់ ដែលធ្វេសប្រហែស ឬពុំយកចិត្តទុកដាក់មើលថែអ្វីមួយដែលមានតម្លៃដែរឬទេ ? ហេតុអ្វីក៏មនុស្សមួយចំនួន ធ្វើដូច្នេះ ?

សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ ត្រូវបានទុកចិត្តឲ្យមើលថែវត្ថុដ៏សំខាន់បំផុត ។ សូមលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេបានរៀនមកពីគំរូលោក នៅពេលពួកគេសិក្សា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៩–៦២ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៩ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយប្រាប់ពីវត្ថុសំខាន់ដែលទេវតា មរ៉ូណៃ បានប្រគល់ទៅឲ្យយ៉ូសែប ស្ម៊ីធ ។

- តើវត្ថុអ្វីខ្លះ ដែលមរ៉ូណៃ បានទុកចិត្តឲ្យយ៉ូសែប ស្ម៊ីធ មើលថែ ? ( ផ្ទាំងចំណារមាស, យ៉ូរីម និងធូមីម និងប្រដាប់បាំងទ្រូង ។ សូមពន្យល់ថា យ៉ូរីម និងធូមីម គឺជាឧបករណ៍ដែលបានរៀបចំដ៏ទេវភាព ដើម្បីជួយអ្នកមើលឆុតនៅក្នុងកិច្ចការបកប្រែ និងក្នុងការទទួលវិវរណៈ ) ។

- តើការទទួលខុសត្រូវអ្វីខ្លះ ដែលមរ៉ូណៃប្រគល់ទៅឲ្យ យ៉ូសែប ស្ម៊ីធ ទាក់ទងនឹងផ្ទាំងចំណារទាំងឡាយនោះ ? ( អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំឃ្លា « ខំប្រើសេចក្ដីព្យាយាមដ៏អស់ពីចិត្តខ្ញុំដែលនឹងរក្សាវត្ថុទាំងនោះទុក » ) ។

សូមសរសេរសេចក្ដីថ្លែងការដូចខាងក្រោមនៅលើក្ដារខៀន ៖ *នៅពេលយើងមានការទទួលខុសត្រូវហើយថែរក្សានូវអ្វីដែលព្រះអម្ចាស់បានប្រទានដល់យើង នោះទ្រង់នឹង* ______________________________.

- តើព្រះអម្ចាស់សន្យាអ្វីខ្លះដល់យ៉ូសែប បើលោកនឹងទទួលខុសត្រូវមើលថែផ្ទាំងចំណានោះ ?

សូមអញ្ជើញសិស្សឲ្យផ្ដល់យោបល់ពីវិធី ដើម្បីបំពេញសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ។ នៅខាងក្រោមនេះ គឺជាវិធីមួយដែលពួកគេអាចឆ្លើយ ៖ **នៅពេលយើងមានការទទួលខុសត្រូវហើយថែរក្សានូវអ្វីដែលព្រះអម្ចាស់បានប្រទានដល់យើង នោះទ្រង់នឹងផ្ដល់ការការពារ និងជំនួយរបស់ទ្រង់ដល់យើង ។**

ដើម្បីជួយសិស្សឲ្យប្រដូចបទពិសោធន៍របស់យ៉ូសែប ទៅនឹងស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ សូមសួរសំណួរដូចខាងក្រោម ៖

- តើគំរូមួយចំនួននៃការទុកចិត្តដ៏ពិសិដ្ឋ ដែលព្រះអម្ចាស់បានប្រទានដល់យើង មានអ្វីខ្លះ ? ( ចម្លើយ អាចរួមមាន ការមើលថែរូបកាយយើងដោយគារវភាព, សេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក និងសេចក្ដីសញ្ញាក្នុងព្រះវិហារបរិសុទ្ធ ,ភាតព្វកិច្ច និងសិទ្ធិអំណាចបព្វជិតភាព, ការហៅបម្រើក្នុងសាសនាចក្រ, ការទទួលខុសត្រូវរបស់យើងដើម្បីចិញ្ចឹមបីបាច់គំនិត និងវិញ្ញាណរបស់យើង, ការទទួលខុសត្រូវ និងទំនាក់ទំនងក្នុងគ្រួសាររបស់យើង និងទីបន្ទាល់របស់យើង ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ —ប្រវត្តិ ១:៦០ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយប្រាប់នូវប្រយោគមួយ ដែលបង្ហាញថា ព្រះអម្ចាស់ បានបំពេញការសន្យារបស់ទ្រង់ ពេលយ៉ូសែប ស្មោះត្រង់ចំពោះទំនុកចិត្តដែលបានផ្ដល់ឲ្យលោក ។ ( « ប៉ុន្ដែដោយសារប្រាជ្ញារបស់ព្រះ របស់ទាំងនោះបាននៅក្នុងកណ្ដាប់ដៃរបស់ខ្ញុំដោយផុតអន្ដរាយ លុះត្រាខ្ញុំបានសម្រេចភារកិច្ច ដោយវត្ថុនោះដែលត្រូវការធ្វើពីដៃរបស់ខ្ញុំ » ។

ដើម្បីបង្ហាញពីរបៀបដែលព្រះអម្ចាស់បានផ្ដល់ការការពារនិងជំនួយរបស់ទ្រង់ នៅពេលយ៉ូសែប ស្ម៊ីធ បានព្យាយាមដោយឧស្សាហ៍ព្យាយាមដើម្បីថែរក្សាផ្ទាំងទាំងឡាយ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោមឲ្យឮៗ ។ មុនពេលសិស្សអាន ចូរពន្យល់ថា វាគឺជាការដកចេញមួយមកពីដំណើររឿងមួយ ដោយម្ដាយរបស់យ៉ូសែប ស្ម៊ីធ គឺ លូស៊ី ម៉ាក ស្ម៊ីធ អំពីអ្វីដែលបានកើតឡើងមិនយូរប៉ុន្មានបន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានទទួលផ្ទាំងចំណារមកពី មរ៉ូណៃ នៅកូនភ្នំកូម៉ូរ៉ា ។ សូមពន្យល់ផងដែរថា នៅពេលយ៉ូសែប ស្ម៊ីធ បានទទួលផ្ទាំងចំណារទាំងឡាយមកពីមរ៉ូណៃ ដំបូងគេគឺលោកបានលាក់វាទុកក្នុងឈើពុក ដែលមានចម្ងាយប្រហែលជា ៣ ម៉ែលពីផ្ទះរបស់លោក ។ ម្ដាយរបស់ យ៉ូសែប ស្ម៊ីធ បានកត់ត្រាពីអ្វីដែលបានកើតឡើង ដែលក្រោយមកលោកបានទៅយកផ្ទាំងចំណារពីកន្លែងលាក់ទុករបស់លោក ហើយបាននាំមកផ្ទះវិញ ។



« យ៉ូសែប ស្ម៊ីធ បានទៅ ហើយបានយកចេញពីកន្លែងសម្ងាត់មក ហើយបានរុំវានៅក្នុងក្រណាត់អាវរងារ ដាក់វាក្លៀតនៅនឹងដៃ រួចដើរមកផ្ទះ ។

« បន្ទាប់ពីដើរបានបន្ដិចមក លោកបានគិតថា វានឹងមានសុវត្ថិភាពជាងដើម្បីកុំដើរតាមផ្លូវ ហើយទៅដើរកាត់តាមព្រៃវិញ ។ បន្ទាប់ពីដើរចុះពីផ្លូវ បានបន្ដិចមក នោះលោកបានទៅជួបនឹងខ្យល់បក់យ៉ាងខ្លាំងមួយ ហើយពេលលោកលោតរំលងគល់ឈើមួយ នោះមានមនុស្សម្នាក់បានលេចចេញមកពីក្រោយ ហើយបានវាយលោកយ៉ាងខ្លាំងនឹងកាំភ្លើង ។ យ៉ូសែប បានងាកក្រោយ ហើយវាយមនុស្សម្នាក់នោះដួល រួចរត់យ៉ាងលឿនបំផុតតាមដែលលោកអាចធ្វើបាន ។ ពេលទៅបានប្រហែលជាកន្លះម៉ាយល៍ទៀត លោកត្រូវបានគេវាយប្រហារម្ដងទៀតតាមរបៀបដូចមុនដែរ លោកបានវាយមនុស្សនោះដួល ដូចមុន ហើយក៏បានរត់ម្ដងទៀត ហើយពីមុនលោកបានទៅដល់ផ្ទះ នោះលោកត្រូវបានគេវាយជាលើកទីបី ។ នៅក្នុងការវាយប្រហារចុងក្រោយនេះ លោកបានភ្លាត់ឆ្អឹងមេដៃ តែទោះជាយ៉ាងណា លោកពុំបានដឹងទេ រហូតទាល់តែលោកបានមកជិតដល់ផ្ទះ ពេលលោកបានទម្លាក់ខ្លួនចុះនៅជិតនឹងកាច់ជ្រុងរបងផ្ទះ ដើម្បីឈប់ឲ្យបាត់ហត់ ។ ពេលលោកមានកម្លាំងភ្លាម នោះលោកបានក្រោកឡើង ហើយចូលទៅក្នុងផ្ទះ ។ លោកនៅតែពុំទាន់អាចនិយាយបានទេ ដោយសារតែការវាយប្រហារ និងការហត់មកពីការរត់នោះ » ( នៅក្នុង លូស៊ី ម៉ាក ស្ម៊ីធ *History of Joseph Smith by His Mother,* បានបោះពុម្ពដោយ Preston Nibley [ ឆ្នាំ ១៩៥៨ ], ទំព័រ ១០៨ ) ។

- តើនៅពេលណា ដែលអ្នក ( ឬនរណាម្នាក់ដែលអ្នកស្គាល់ ) បានទទួលការការពារ និងបានជួយមកពីព្រះអម្ចាស់ នៅពេលអ្នកព្យាយាមដោយឧស្សាហ៍ព្យាយាម ដើម្បីនៅស្មោះត្រង់ចំពោះការទុកចិត្តដ៏ពិសិដ្ឋមួយមកពីព្រះអម្ចាស់ ?

ដើម្បីជួយសិស្សគិតអំពីបំណងប្រាថ្នារបស់ពួកគេ ដើម្បីរក្សាទំនុកចិត្តដ៏ពិសិដ្ឋដែលព្រះអម្ចាស់បានប្រទានដល់ពួកគេ សូមឲ្យសិស្សម្នាក់អាន នូវសេចក្ដីថ្លែងដូចខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ចូរឈ្លាសវៃជាមួយអ្វីដែលព្រះអម្ចាស់បានប្រទានដល់អ្នក ។ វាគឺជាទំនុកចិត្តមួយ ។ . . .

« ជាជាងធ្លាក់ចុះទៅក្នុងភាពធ្វេសប្រហែស សូមឲ្យជីវិតរបស់អ្នក ធ្វើជាមនុស្សម្នាក់ដែលបង្កើនភាពត្រឹមត្រូវច្បាស់លាស់ក្នុងការគោរពប្រតិបត្តិ ។ ខ្ញុំសង្ឃឹមថា អ្នកនឹងគិត ទទួលអារម្មណ៍ ស្លៀកពាក់ និងធ្វើសកម្មភាពតាមរបៀប ដែលបង្ហាញគារវភាព និងការគោរពដល់វត្ថុពិសិដ្ឋ កន្លែងពិសិដ្ឋ ឱកាសពិសិដ្ឋ » ( « A Sense of the Sacred » [ Church Educational System fireside for young adults, ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០០៤], ៩, ១០; speeches.byu.edu ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦១–៦២ ឲ្យឮៗ ។ សូមសិស្សនៅក្នុងថ្នាក់ឲ្យផ្ទៀងតាម និងរកមើលគំរូពីរបៀបដែលព្រះអម្ចាស់បានប្រទានពរដល់យ៉ូសែប និង អិមម៉ា ស្ម៊ីធ ចំពោះភាពស្មោះត្រង់របស់ពួកគេ នៅក្នុងការទទួលខុសត្រូវចំពោះវត្ថុពិសិដ្ឋ ។

- តើព្រះអម្ចាស់ប្រទានពរដល់ព្យាការី និងភរិយារបស់លោកនៅគ្រានេះយ៉ាងដូចម្ដេច ? ( ជួយសិស្សឲ្យមើលឃើញថា ព្រះអម្ចាស់ បានជួយយ៉ូសែប សម្រេចនូវព្រះទ័យទ្រង់ តាមរយៈជំនួយរបស់ ម៉ាទីន ហារីស ) ។

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៣–៦៥

*ម៉ាទីន ហារីស បង្ហាញតួអក្សរលើផ្ទាំងចំណារទៅឲ្យបណ្ឌិតនៅរដ្ឋនូវយ៉ោកមើល*

បើអាចធ្វើទៅបាន សូមបង្ហាញសិស្សនូវ រូបភាពដែលអមមកជាមួយ ដែលបង្ហាញនូវគំរូតួអក្សរដែលត្រូវបានសរសេរនៅលើផ្ទាំងចំណារមាស ។ នៅក្នុងឆ្នាំ ១៨២៨ យ៉ូសែប ស្ម៊ីធ បានថតចម្លងតួរអក្សរខ្លះៗដាក់នៅលើសន្លឹកក្រដាស ។ ម៉ាទីន ហារីស បានសុំបើសិនជាលោកអាចបង្ហាញច្បាប់ចម្លងនៃតួរអក្សរមួយចំនួនចេញមកពីផ្ទាំងចំណារនេះទៅឲ្យពួកបណ្ឌិតនៅរដ្ឋនូវយ៉ោក ដែលមានចំណេះដឹងផ្នែកអក្សរសាស្ត្រនិងអារ្យធម៌បុរាណបានដែរឬទេ ។ ( នៅពេលអ្នកបង្ហាញរូបភាព នោះអ្នកអាចនឹងចង់ប្រាប់ថា មានច្បាប់ចម្លងនៃតួរអក្សរមួយចំនួនត្រូវបានថតចម្លង ។ តែវាមិនដឹងថា នេះគឺជាច្បាប់ចម្លងពិត ដែល ម៉ាទីន ហារីស បានបង្ហាញទៅឲ្យពួកបណ្ឌិតមើលនោះទេ ។




សូមសរសេរ *យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៣–៦៥* និង *អេសាយ ២៩:១០–១២* នៅលើក្ដារខៀន ។ សូមពន្យល់ថា ឯកសារយោងមកពី យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ពិពណ៌នាអំពីការប្រជុំរបស់ម៉ាទីន ហារីស ជាមួយពួកបណ្ឌិត ។ ឯកសារយោងរបស់អេសាយ មាននូវការព្យាករណ៍ អំពីថ្ងៃចុងក្រោយ ។ សូមអញ្ជើញសិស្សឲ្យធ្វើការជាគូ ហើយផ្លាស់វេណគ្នាអានវគ្គបទគម្ពីរទាំងនេះឲ្យឮៗម្នាក់ម្ដង ។ សូមណែនាំពួកគេឲ្យអាន យ៉ូសែប ស្ម៊ីធ – ប្រវត្តិ វគ្គទីមួយ ។ អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យអានក្បាលជំពូកទៅ អេសាយ ២៩ មុនពេលពួកគេអានវគ្គបទគម្ពីរអេសាយ ។ នៅពេលពួកគេអានខគម្ពីរនៅក្នុង អេសាយ ២៩ សូមឲ្យពួកគេរកមើលភាពស្រដៀងគ្នាទៅនឹងដំណើររឿងរបស់ម៉ាទីន ហារីស ។ បន្ទាប់ពីសិស្ស បានបញ្ចប់ការអាន និងការពិភាក្សាវគ្គបទគម្ពីរទាំងពីរហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើសេចក្តីពិតអ្វីខ្លះ ដែលវគ្គបទគម្ពីរទាំងនេះ បង្រៀនយើងអំពីបុរាណវិទ្យា របស់ព្រះអម្ចាស់ និងការព្យាករណ៍ទាំងឡាយរបស់ពួកអ្នកបម្រើរបស់ទ្រង់ ? ( អ្នកនឹងអាចចង់ប្រាប់ថា នៅពេល ម៉ាទីន បានបង្ហាញតួរអក្សរចេញមកពីផ្ទាំងចំណារដល់ពួកបណ្ឌិតនៅរដ្ឋនូវយ៉ោកហើយ នោះលោកបានជួយបំពេញតាមការព្យាករណ៍ដែលបានកត់ត្រានៅក្នុង អេសាយ ២៩:១១–១២ ) ។

ថ្វីបើសិស្សអាចប្រើពាក្យផ្សេងក៏ដោយ ក៏ពួកគេគួរតែប្រាប់ពីសេចក្តីពិតដូចខាងក្រោម ៖ **ការព្យាករណ៍ទាំងឡាយរបស់ពួកអ្នកបម្រើនៃព្រះអម្ចាស់ នឹងបានសម្រេច ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។ អ្នកក៏អាចនឹងឲ្យយោបល់ដល់សិស្សឲ្យសរសេរវានៅក្នុងបទគម្ពីររបស់ពួកគេ ជិតនឹង យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៥ ។ សូមសួរដល់សិស្សបើសិនជាពួកគេអាចគិតអំពី ចំណេះចំណានខគម្ពីរ ដែលបង្រៀនពីសេចក្តីពិតដូចគ្នានេះ ( ឧទាហរណ៍ សូមមើល គ. និង ស. ១:៣៧–៣៨ និង អេម៉ុស ៣:៧ ) ។ អ្នកអាចនឹងឲ្យយោបល់ដល់ពួកគេឲ្យសរសេរសេចក្តីយោងទាំងនេះនៅជិតនឹង យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៥ ។

- តើការបំពេញសេចក្តីសន្យារបស់ព្រះ និងសេចក្តីថ្លែងការណ៍របស់ព្យាការី ជួយពង្រឹងដល់សេចក្តីជំនឿរបស់យើងយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសរសេរប្រយោគមួយចំនួននៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ដើម្បីសង្ខេបអំពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនថ្ងៃនេះ ហើយហេតុអ្វីបានជាវាសំខាន់ចំពោះពួកគេ ។ ដើម្បីផ្តល់ឱកាសដល់សិស្សឲ្យពន្យល់ និងថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលពួកគេបានរៀន សូមអញ្ជើញពួកគេពីរបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេបានសរសេរនៅក្នុងថ្នាក់ ។

មេរៀនសិក្សានៅផ្ទះ

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–៦៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ២ ( មេរៀនទី ២ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ ដែលសិស្សបានរៀននៅពេលពួកគេសិក្សា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–៦៥ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ២ ( មេរៀនទី ២ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២០)

សិស្សបានរៀនពីបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធនៅក្នុងការព្យាយាមចង់ដឹងថាសាសនាចក្រណាមួយដែលពិត បើសិនយើងសូមដល់ព្រះក្នុងសេចក្ដីជំនឿ នោះទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់យើង ។ ពួកគេបានផ្ដោតលើសេចក្ដីពិតដែលថា យ៉ូសែប ស្ម៊ីធ បានឃើញព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ ចេញពីបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធ សិស្សក៏បានរៀនផងដែរថា ព្រះគឺជាព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ មានព្រះជន្មរស់ ហើយថាព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទមានព្រះកាយដាច់ដោយឡែក និង ទីទៃពីគ្នា ។ ក្រៅពីនោះ សិស្សបានឃើញថា ប្រសិនបើយើងស្វែងរកយ៉ាងស្មោះត្រង់នូវជំនួយពីព្រះ កាលសាតាំងព្យាយាមបំបាក់ទឹកចិត្តយើង នោះព្រះអាចជួយរំដោះយើងបាន ។

### ថ្ងៃទី ២ (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២១–២៦)

ចេញពីបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធ សិស្សបានរៀនថា អំឡុងពេលលំបាក យើងអាចទាញយកភាពរឹងមាំចេញពីគំរូនៃបុគ្គលស្មោះត្រង់ជាច្រើននៅក្នុងព្រះគម្ពីរ ។ តាមរយៈការសិក្សាអំពីរបៀបដែល យ៉ូសែប ស្ម៊ីធ បានដោះស្រាយនឹងការបៀតបៀន ដែលលោកបានជួបប្រទះបន្ទាប់ពីការនិមិត្តលើកដំបូង នោះសិស្សបានរៀនពីគោលលទ្ធិ និង គោលការណ៍ដែលអាចជួយពួកគេ នៅពេលពួកគេប្រឈមមុខនឹងឧបសគ្គ ដោយសារទីបន្ទាល់របស់ពួកគេ ។ ក្រៅពីនោះសិស្សបានរៀនថា តាមរយៈការអនុវត្តតាមគោលការណ៍ដែលបានបង្រៀននៅក្នុងព្រះគម្ពីរ នោះយើងអាចទទួលបានទីបន្ទាល់មួយនៃសេចក្ដីពិត ។

### ថ្ងៃទី ៣ (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–៥៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ២)

យ៉ូសែប ស្ម៊ីធមានបំណងប្រាថ្នាចង់ដឹងពីគោលជំហររបស់លោកចំពោះព្រះ ។ លោកបានទទួលស្គាល់កំហុស និង ភាពទន់ខ្សោយរបស់ខ្លួន ហើយមានការសោកស្ដាយ ។ ដូចយ៉ូសែប ស្ម៊ីធ ដែរ នៅពេលយើងទទួលស្គាល់អំពើបាបរបស់យើង ហើយមានអារម្មណ៍សោកស្ដាយចំពោះវា នោះយើងអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ទូលសុំការអភ័យទោសបាន ។ សិស្សបានរៀនពី ទស្សនកិច្ចរបស់មរ៉ូណៃជាមួយយ៉ូសែប ស្ម៊ីធ ហើយបានរៀនថាព្រះមានកិច្ចការមួយឲ្យយ៉ូសែប ស្ម៊ីធ ធ្វើដែលនឹងផ្សព្វផ្សាយទូទាំងផែនដី ។ កិច្ចការនោះរួមមាន ការស្ដារអំណាចផ្សារភ្ជាប់របស់អេលីយ៉ាឡើងវិញនៅលើផែនដីពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

### ថ្ងៃទី ៤ (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៦៥)

សិស្សបានពិចារណាពីការសន្យារបស់មរ៉ូណៃចំពោះ យ៉ូសែប ស្ម៊ីធ ថាផ្ទាំងទាំងនោះនឹងត្រូវបានការពារ ហើយពួកគេបានរៀនថានៅពេលយើងមានទំនួលខុសត្រូវ និង រក្សាទំនួលខុសត្រូវដែលព្រះអម្ចាស់បានប្រទានដល់យើង នោះទ្រង់នឹងប្រទានការការពារ និង ជំនួយរបស់ទ្រង់ ។ នៅពេលសិស្សបានសិក្សាដំណើររឿងរបស់ ម៉ាទីន ហារីស បានចម្លងតួអក្សរនៅផ្ទាំងមាស និង ការបកប្រែទៅឲ្យសាស្ត្រាចារ្យ អ័នថុន និង បណ្ឌិតមិចឆែល នោះពួកគេបានរៀនថា ការព្យាករណ៍របស់អ្នកបម្រើនៃព្រះអម្ចាស់នឹងកើតឡើង ។

## សេចក្ដីផ្ដើម

មេរៀននេះអាចជួយសិស្សឲ្យយល់កាន់តែស៊ីជម្រៅ ពីការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ ។ វាក៏បានផ្ដល់ឱកាសមួយដល់ពួកគេឲ្យរៀនពីការខំប្រឹងប្រែង ដើម្បីស្វែករកចម្លើយចំពោះសំណួរ ហើយមានអំណរគុណចំពោះតួនាទីរបស់ខ្លួននៅក្នុងការរៀនសូត្រដំណឹងល្អផងដែរ ។ សិស្សនឹងរៀនពីរបៀបដើម្បីពង្រឹងទីបន្ទាប់របស់ពួកគេ ប្រឆាំងនឹងការបៀតបៀន និង ឧបសគ្គនានាដែលពួកគេអាចជួប ។

## យោបល់សម្រាប់ការបង្រៀន

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥–២០

*ព្រះជាព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានបង្ហាញអង្គទ្រង់ដល់យ៉ូសែប ស្ម៊ីធ*

សូមឲ្យសិស្សគិតអំពីពេលមួយដែលពួកគេចង់បានចម្លើយខាងវិញ្ញាណ ឬ សំណួរដែលទាក់ទងនឹងដំណឹងល្អ ។ បន្ទាប់មកសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកបានធ្វើអ្វីខ្លះដើម្បីស្វែងរកចម្លើយចំពោះសំណួររបស់អ្នក ?

សូមរំឭកថាកាលនោះយ៉ូសែប ស្ម៊ីធមានអាយុប្រហែលសិស្សថ្នាក់សិក្ខាសាលាដែរ នៅពេលលោកបានមានកង្វល់ពីសំណួរដ៏សំខាន់ ហើយបានចាប់ផ្ដើមស្វែងរកចម្លើយ ។ ដោយសារបទពិសោធន៍របស់យ៉ូសែបពិតជាពិសេស នោះព្រឹត្តិការណ៍ដែលនាំឲ្យវាកើតឡើងនោះគឺជាគំរូមួយដល់ពួកយើងថា យើងអាចធ្វើតាមលោកដើម្បីទទួលជំនួយ និង ចម្លើយពីព្រះ ។

អ្នកអាចផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំឃ្លា « ខ្ញុំបានចេះដឹងដោយខ្លួនខ្ញុំថា » យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២០។

សូមចែកសិស្សជាក្រុម ដែលមួយក្រុមៗមានគ្នាពីរ ឬ បីនាក់ ។ សូមឲ្យក្រុមនិមួយៗអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៨, ១១–១២, ១៤–១៥, ដោយរកមើលអ្វីដែលយ៉ូសែប ស្ម៊ីធ បានធ្វើដើម្បីទទួលបានចម្លើយចំពោះសំណួររបស់លោក ។ សូមអញ្ជើញក្រុមនិមួយៗឲ្យផ្ដល់អ្នកតំណាងក្រុមមកមុខក្ដារខៀន ដើម្បីសរសេរពីចំណុចសំខាន់មួយដែលក្រុមរបស់ខ្លួនរកឃើញ ។ សូមប្រាប់សិស្សកុំឲ្យសរសេរអ្វីដែលមានដូចគ្នានៅលើក្ដារខៀនឡើយ ។ ប្រសិនបើសិស្សមានការលំបាកក្នុងការស្វែងរកអ្វីដែលយ៉ូសែប ស្ម៊ីធ បានធ្វើ នោះអ្នកអាចជួយពួកគេ ដោយផ្ដល់យោបល់មួយចំនួនខាងក្រោមនេះ ៖ យ៉ូសែប បានគិតពិចារណាយ៉ាងម៉ត់ចត់ ( គិត ) បានចូលរួមការប្រជុំសាសនាចក្រ បានសិក្សាការបង្រៀនពីបក្សនិកាយផ្សេងៗ បានសិក្សាព្រះគម្ពីរ បានអធិស្ឋានដោយការប្ដេជ្ញាចិត្ត ។

សូមសួរសំណួរខាងក្រោម ៖

- តើគោលការណ៍អ្វីខ្លះដែលអ្នកអាចរៀនពីយ៉ូសែប ស្ម៊ីធ អំពីអ្វីដែលតម្រូវឲ្យធ្វើ ដើម្បីរៀនកិច្ចការខាងវិញ្ញាណនោះ ? ( ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងៗពីគ្នាក្ដី ពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **ការរៀនសូត្រខាងវិញ្ញាណតម្រូវឲ្យមានការខិតខំផ្ទាល់ខ្លួនរបស់យើង ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- ហេតុអ្វីអ្នកគិតថាវាសំខាន់សម្រាប់យើងដើម្បីខិតខំអស់ពីចិត្តដើម្បី រៀនសេចក្ដីពិតខាងវិញ្ញាណ ?
- តើការអនុវត្តគោលការណ៍នេះអាចជួយអ្នកនៅក្នុងការសិក្សាព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញានាផ្ទាល់ខ្លួនបានដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ– ប្រវត្តិ ១:១៦–១៧ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមក្នុងព្រះគម្ពីររបស់ខ្លួន ហើយរកមើលអ្វីដែលយ៉ូសែបបានជួបប្រទះនៅពេលលោកបានខិតខំដើម្បីទទួលបានចំណេះដឹងនោះ ។

- យោងតាម ខ ១៧ តើយ៉ូសែប ស្ម៊ីធបានឃើញនរណា ? ( សូមប្រាកដថា **យ៉ូសែប ស្ម៊ីធ បានឃើញព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ**) ។
- តើលោកបានរៀនអ្វីខ្លះអំឡុងពេលនៃការនិមិត្តនេះអំពីតួអង្គទាំងពីរនេះ ?

សូមឲ្យសិស្សម្នាក់អានឮនូវសេចក្ដីថ្លែងការណ៍ខាងក្រោមពីប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ ដែលបានពន្យល់ពីសារៈសំខាន់នៃការនិមិត្តដំបូងនេះ ៖



« ព្រឹត្តការណ៍ដ៏ធំបំផុត ដែលបានកើតឡើងនៅក្នុងពិភពលោក ចាប់តាំងពីការរស់ឡើងវិញនៃព្រះរាជបុត្រារបស់ព្រះ ដែលយាងចេញពីផ្នូរ និងការយាងឡើងទៅស្ថានសួគ៌វិញ នោះគឺការយាងមករបស់ព្រះវរបិតា និងព្រះរាជបុត្រាមកជួបក្មេងប្រុស យ៉ូសែប ស្ម៊ីធ » (*Gospel Doctrine,* ការបោះពុម្ពទី ៥ [ ឆ្នាំ ១៩៣៩ ] ទំព័រ ៤៩៥ )

- តើហេតុអ្វីអ្នកគិតថាវាសំខាន់ ដើម្បីមានទីបន្ទាល់ថាព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទពិតបានបង្ហាញអង្គទ្រង់ដល់ យ៉ូសែប ស្ម៊ីធមែន ?

សូមអញ្ជើញសិស្សឲ្យអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៨–២០ ឲ្យឮៗ ហើយសូមឲ្យសិស្សស្វែងរកអ្វីដែលយ៉ូសែប ស្ម៊ីធ បានរៀនសម្រាប់ខ្លួនលោក ដោយសារតែការខិតខំរបស់លោកដើម្បីធ្វើវាដោយសេចក្ដីជំនឿ ។ បន្ទាប់មក សួរសំណួរខាងក្រោមនេះ ៖

- តើយ៉ូសែបបានរៀនអ្វីខ្លះសម្រាប់ខ្លួនលោក ?
- តើយើងអាចរៀនអ្វីខ្លះពីបទពិសោធន៍របស់ យ៉ូសែប ស្ម៊ីធ អំពីអ្វីដែលអាចកើតឡើងនៅពេលយើងសិក្សាព្រះបន្ទូលរបស់ព្រះ ហើយបន្ទាប់មកអនុវត្តតាមអ្វីដែលយើងបានអាន ? ( ចម្លើយអាចរួមមានសេចក្ដីពិតខាងក្រោមនេះ ៖ **ប្រសិនបើយើងសិក្សាព្រះបន្ទូលរបស់ព្រះដោយឧស្សាហ៍ព្យាយាម ហើយធ្វើសកម្មភាពដោយសេចក្ដីជំនឿ នោះយើងអាចដឹងសេចក្ដីពិតនៃដំណឹងល្អដោយខ្លួនយើងផ្ទាល់** ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន ហើយអញ្ជើញឲ្យសិស្សសរសេរវាចូលក្នុងគែមព្រះគម្ពីររបស់ពួកគេ ) ។
- តើសេចក្ដីពិតនេះអាចជួយមិត្តម្នាក់ ឬ សមាជិកគ្រួសារដែលមានសំណួរអំពី ដំណឹងល្អដោយរបៀបណា ?
- តើសេចក្ដពិតនេះអាចជួយអ្នកឆ្លើយនឹងសំណួរ និង កង្វល់នានាដោយរបៀបណា ?

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២០–៦៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ២

*យ៉ូសែប ស្ម៊ីធ បានរៀបការជាមួយអិមម៉ា ហែល ទទួលផ្ទាំងមាស ហើយបានចាប់ផ្ដើមការបកប្រែ*

សូមឲ្យសិស្សរំឭកពីអ្វីដែលបានកើតឡើងចំពោះយ៉ូសែប ស្ម៊ីធ បន្ទាប់ពីការនិមិត្តដំបូងរបស់លោក ។ សូមប្រាកដថាពួកគេយល់ថាបទពិសោធន៍ដែលព្យាការីបានជួបការបៀតបៀនដ៏ធ្ងន់ធ្ងរបន្ទាប់ពីប្រាប់មនុស្សដទៃពីការនិមិត្តនោះ ។ សូមអញ្ជើញពួកគេឲ្យអានឃ្លាចុងបញ្ចប់នៃ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២០ ដោយខ្លួនពួកគេផ្ទាល់ ដែលចាប់ផ្ដើមជាមួយឃ្លា « មើលទៅហាក់បីដូចជា ។. . .» ។ បន្ទាប់មកសូមសួរសំណួរខាងក្រោមដល់សិស្ស ៖

- តាមរយៈយ៉ូសែប ស្ម៊ីធ ហេតុអ្វីបានជាលោកទទួលបទពិសោធន៍នៃការបៀតបៀនដ៏ធំនេះ តាំងពីវ័យក្មេងដូច្នេះ ? ( ការបៀតបៀនចេញមកពីអំណាចសាតាំង ដោយសារវាស្គាល់ថាយ៉ូសែប ស្ម៊ីធ ជា « អ្នករំខាន និងជាអ្នករំខាននគររបស់ [ សាតាំង ] ») ។
- តើមានស្ថានភាពមួយចំនួនណាខ្លះដែលអ្នក ឬ មនុស្សដទៃដែលអ្នកស្គាល់អាចមានបទពិសោធន៍នៃការបៀតបៀននៅសព្វថ្ងៃនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:២៤–២៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយស្វែងរកអ្វីដែលយើងអាចធ្វើ ដើម្បីទទួលកម្លាំងអំឡុងគ្រាលំបាកទាំងនោះ ។

- តើយើងអាចធ្វើអ្វីខ្លះអំឡុងគ្រាលំបាក ដើម្បីទទួលបានកម្លាំងបន្តនៅស្មោះត្រង់នោះ ? ( សិស្សអាចផ្ដល់ចម្លើយផ្សេងៗគ្នា ។ សូមប្រាកដថាពួកគេរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **អំឡុងគ្រាលំបាក យើងអាចទាញយកកម្លាំងមកពីគំរូរបស់បុគ្គលស្មោះត្រង់នានានៅក្នុងបទគម្ពីរ**) ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន ហើយអញ្ជើញឲ្យសិស្សសរសេរវាចូលក្នុងគែមព្រះគម្ពីររបស់ពួកគេ ) ។

សូមអញ្ជើញសិស្សឲ្យរំឭក យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៤–២៥, ដោយស្វែងរកមើលពាក្យ ឬ ឃ្លា ដែលអាចផ្ដល់ក្ដីក្លាហាន ឬ កម្លាំងដល់ពួកគេ ដើម្បីធ្វើអ្វីដែលត្រឹមត្រូវក្នុងពេលមានការបៀតបៀន ។ បន្ទាប់ពីសិស្សប្រាប់ពីឃ្លាដែលពួកគេរកឃើញអ្នកអាចផ្ដល់យោបល់ថាពួកគេអាចគូសចំណាំឃ្លា « ខ្ញុំបានឃើញការនិមិត្ត ខ្ញុំដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំដឹងថា ព្រះទ្រង់ក៏ដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាចបដិសេធរឿងនេះ » ។

សូមសួរសិស្សនូវសំណួរដូចខាងក្រោម ៖

- តើឃ្លានេះបង្រៀនអ្នកអ្វីខ្លះអំពីទីបន្ទាល់របស់ យ៉ូសែប ស្ម៊ីធ អំពីការនិមិត្តដំបូង ?
- តើឃ្លានេះអាចជួយអ្នកដោយរបៀបណា នៅពេលមាននរណាម្នាក់ធ្វើឲ្យអ្នកមានឧបសគ្គចំពោះទីបន្ទាល់ ឬ បៀតបៀនអ្នកដោយសារតែសេចក្ដីជំនឿរបស់អ្នក ?

សូមបញ្ចប់មេរៀននេះ ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀននេះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយពីបទពិសោធន៍ ឬ អារម្មណ៍របស់ខ្លួនអំពីសេចក្ដីពិតនេះ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣–៧; ១០; យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៦៧)

តើឯកសារទាំង ១១៦ ទំព័រនៃព្រះគម្ពីរមរមនដែលយ៉ូសែប ស្ម៊ីធ បានបកប្រែរួចបានបាត់ ហើយពុំបានទទួលវិញដោយរបៀបណា ? នៅពេលសិស្សសិក្សាមេរៀនបន្ទាប់ នោះពួកគេនឹងរៀនអំពីម៉ាទីន ហារីស និង ការបាត់ឯកសារសរសេរដោយដៃ ។ ពួកគេក៏នឹងរៀនផងដែរអំពីព្រះឱវាទរបស់ព្រះអម្ចាស់ដល់អស់អ្នកដែលមានបំណងបម្រើព្រះ ។

មេរៀនទី ១១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣

## បុព្វកថា

យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣ បន្ទាប់មកម៉ាទីន ហារីស បានធ្វើឲ្យបាត់ ១១៦ ទំព័រនៃកំណត់ត្រាសរសេរដោយដៃដែលយ៉ូសែប បានបកប្រែចេញមកពីផ្ទាំងចំណារមាស ។ នៅក្នុងវិវរណៈនេះព្រះអម្ចាស់មានបន្ទូលថា កិច្ចការរបស់ទ្រង់ នឹងទទួលបានជោគជ័យលើសេចក្ដីទុច្ចរិតរបស់មនុស្ស ។ ព្រះអម្ចាស់ ក៏បានបន្ទោសដល់យ៉ូសែប ហើយបានព្រមានលោកអំពីអ្វីនឹងកើតឡើង បើលោកពុំប្រែចិត្ត ។ ទីបំផុត ព្រះអម្ចាស់បានពន្យល់អំពី គោលបំណងរបស់ទ្រង់ក្នុងការនាំមកនូវព្រះគម្ពីរមរមន ។

## យោបល់សម្រាប់ការបង្រៀន

*សូមបង្កើតបរិយាកាសសម្រាប់ការរៀនសូត្រ ។*

បរិយាកាសជុំវិញខាងរាងកាយ អាចមានឥទ្ធិពលមួយ ចំពោះអ្វីដែលសិស្សមានបទពិសោធន៍ នៅក្នុងការរៀនសូត្រអំពីដំណឹងល្អ ។ សូមរៀបចំថ្នាក់រៀន ដើម្បីសិស្សអាចមានអារម្មណ៍ល្អ ហើយអាចផ្ដោតទៅលើមេរៀន ។ អ្នកក៏អាចនឹងគិតចង់រៀបចំកៅអីអង្គុយ វត្ថុដែលមានការរំខានខ្លាំង លក្ខណៈថ្នាក់រៀន និងលក្ខណៈគ្រូបង្រៀន នៅក្នុងការរៀបចំរបស់អ្នក ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១–៣

*យ៉ូសែប ស៊្មីធ បានរៀនថា កិច្ចការរបស់ព្រះ ពុំមែនជាកិច្ចការស្មុគស្មាញទេ*

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីស្ថានភាពដែលពួកគេអាចត្រូវបានល្បួងឲ្យស្ដាប់តាមមិត្តភក្ដិ ជាជាងធ្វើតាមបទបញ្ញត្តិ ឬការប្រឹក្សារបស់ឪពុកម្ដាយ ឬថ្នាក់ដឹកនាំរបស់ពួកគេ ។

- ហេតុអ្វីបានជាពេលខ្លះវាពិបាកដើម្បីបដិសេធនឹងមិត្តភក្ដិ នៅពេលពួកគេព្យាយាមមានឥទ្ធិពលមកលើយើងឲ្យធ្វើអ្វីដែលខុស ?

សូមសិស្សឲ្យចែកចាយនូវអ្វីដែលពួកគេដឹងអំពីព្រឹត្តការ ដែលនាំទៅរកការបាត់បង់ព្រះគម្ពីរមរមន ចំនួន ១១៦ សន្លឹកដែលជាការបកប្រែសរសេរដោយដៃនោះ ។

នៅពេលសិស្សឆ្លើយតប នោះអ្នកអាចបន្ថែមពីលើចម្លើយរបស់ពួកគេជាមួយនឹងព័ត៌មានលម្អិតមួយចំនួនដូចខាងក្រោម ៖

ចាប់តាំងពីពាក់កណ្ដាលខែ មេសា ឆ្នាំ ១៨២៨ រហូតដល់ពាក់កណ្ដាលខែមិថុនា ឆ្នាំ ១៨២៨ នោះព្យាការី យ៉ូសែប ស៊្មីធ កំពុងបកប្រែផ្ទាំងចំណារ ខណៈដែលកំពុងរស់នៅក្នុងភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ។ កសិករ អ្នកជំនួញស្ដុកស្ដមម្នាក់ឈ្មោះ ម៉ាទីន ហារិស បានធ្វើជាអ្នកសរសេរឲ្យយ៉ូសែប ខណៈពេលដែលលោកបកប្រែ ។ ម៉ាទីន មានវ័យចាស់ជាង យ៉ូសែប ២២ ឆ្នាំ ហើយបានឲ្យប្រាក់ដល់ យ៉ូសែប និង អិមម៉ា ៥០ ដុល្លារ ( ជាចំនួនទឹកប្រាក់ដ៏ច្រើននៅជំនាន់នោះ ) ដើម្បីជួយពួកគេឲ្យផ្លាស់ទៅកាន់ភូមិ ហាម៉ូនី រដ្ឋផែនផែនសិលវេញ៉ា ( ជាកន្លែងដែលគ្រួសារអិមម៉ារស់នៅ) ដូច្នេះវាបានជួយគាំទ្រដល់យ៉ូសែប ខណៈពេលលោកបកប្រែផ្ទាំងចំណារ ។ នៅខែ កុម្ភៈ ឆ្នាំ ១៨២៨ យ៉ូសែប បានលើកទឹកចិត្តឲ្យម៉ាទីន យកច្បាប់ចម្លងនៃតួអក្សរមកពីផ្ទាំងមាសទៅជួបសាស្ត្រាចារ្យនៅរដ្ឋ នូវ យ៉ោក ( សូមមើល យ៉ូសែប ស៊្មីធ–ប្រវត្តិ ១:៦៣–៦៥ ) ។ លូស៊ី ហារិស ជាភរិយារបស់ម៉ាទីន បានខ្វល់ខ្វាយយ៉ាងខ្លាំងអំពីចំណាប់អារម្មណ៍របស់ម៉ាទីន និងការចូលរួមខាងហិរញ្ញវត្ថុនៅក្នុងការបកប្រែផ្ទាំងចំណារ ។ គាត់ និងអ្នកដទៃទៀត បានចាប់ផ្ដើមបង្ខំឲ្យម៉ាទីន រកភស្ដុតានៃវត្តមានរបស់ផ្ទាំងចំណារនោះ ។ ដើម្បីរម្ងាប់កង្វល់របស់ពួកគេ នោះនៅពាក់កណ្ដាលខែមិថុនា ម៉ាទីន បានស្នើរសុំដល់យ៉ូសែប ដើម្បីអនុញ្ញាតឲ្យគាត់យកការបកប្រែដែលសរសេរដោយដៃចំនួន ១១៦ ទំព័រ ដែលពួកគេបានបញ្ចប់នោះ ទៅបង្ហាញជាភស្ដុតាង ។

សូមអញ្ជើញសិស្សឲ្យនឹកគិតអំពីស្ថានភាពលំបាកដែលព្យាការីមាន ពេលម៉ាទីន ហារិស បានសុំដើម្បីយកឯកសារសរសេរដោយដៃទៅនោះ ។ ដើម្បីជួយជាមួយនឹងបរិបទ សូមពិចារណាអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោម ចេញមកពីប្រវត្តិរបស់ព្យាការី យ៉ូសែប ស៊្មីធ ៖



« [ ម៉ាទីន ] មានបំណងចង់ឲ្យខ្ញុំសូមដល់ព្រះអម្ចាស់តាមរយៈយូរីម និងធូមីម បើគាត់មិនអាច [ យកឯកសារសរសេរដោយដៃនោះទៅផ្ទះ ហើយបង្ហាញវាដល់គេ ] នោះទេ ។ ខ្ញុំបានទូលសូមហើយចម្លើយគឺថា គាត់មិនត្រូវយកទៅទេ ។ ទោះជាយ៉ាងណាក៏ដោយ គាត់ពុំស្កប់ចិត្តនឹងចម្លើយនេះឡើយ ហើយប្រាថ្នាចង់ឲ្យខ្ញុំសូមម្ដងទៀត ។ ខ្ញុំបានទូលសូមហើយចម្លើយគឺដូចគ្នានឹងលើកមុន ។ តែគាត់នៅតែពុំអាចស្កប់ចិត្ត ហើយនៅតែទទូចថាឲ្យខ្ញុំទូលសូមម្ដងទៀត » ( នៅក្នុង *ប្រវត្តិសាស្ត្រនៃសាសនាចក្រ* ១:២១ ) ។

- ហេតុអ្វីបានជាអ្នកគិតថា យ៉ូសែប ស៊្មីធ បានទូលសូមដល់ព្រះនូវសំណួរដដែលៗទោះជាបានទទួលចម្លើយយ៉ាងច្បាស់ហើយដូច្នោះ ?

សូមពន្យល់ថា បន្ទាប់ពីការទទូចអង្វរជាច្រើនដងមកពី ម៉ាទីន នោះយ៉ូសែប បានសូមដល់ព្រះអម្ចាស់ជាលើកទីបី ហើយព្រះអម្ចាស់បានអនុញ្ញាតឲ្យម៉ាទីន យកឯកសារសរសេរដោយដៃនោះ « នៅឱកាសជាក់លាក់ » ( *ប្រវត្តិសាស្ត្រ នៃសាសនាចក្រ* ១:២១ ) ។ ម៉ាទីន បានសន្យាថា គាត់នឹងបង្ហាញឯកសារសរសេរដោយដៃនោះ តែចំពោះភរិយារបស់គាត់ និងសមាជិកគ្រួសារតែប៉ុន្មាននាក់ទៀតប៉ុណ្ណោះ ។ ម៉ាទីន បានត្រឡប់ទៅរដ្ឋ នូវ យ៉ោក ជាមួយនឹងឯកសារសរសេរដោយដៃនោះ ។ ក្រោយពី ម៉ាទីន បានចេញទៅមិនយូរប៉ុន្មានអិមម៉ា ស៊្មីធ បានផ្ដល់កំណើតកូនប្រុសម្នាក់ ឈ្មោះ អាលវិន ដែលបានស្លាប់នៅមិនយូរប៉ុន្មានបន្ទាប់ពីបានកើតមក ។ អិមម៉ា ស្ទើរតែស្លាប់ហើយយ៉ូសែប បាននៅជិតនាងអស់រយៈពេលពីរសប្ដាហ៍ ។ ពេលនេះ ម៉ាទីន បានទៅអស់រយៈពេលបីសប្ដាហ៍ ហើយពួកគេពុំបានឮដំណឹងអ្វីពីគាត់សោះ ។ អិមម៉ា បានជាសះស្បើយឡើងវិញបន្តិច ហើយបានបញ្ចុះបញ្ចូលយ៉ូសែប ឲ្យទៅរដ្ឋ នូវ យ៉ោក ដើម្បីមើលថាហេតុអ្វីក៏ ម៉ាទីន ពុំប្រាប់ដំណឹងអ្វីមួយម៉ាត់មកវិញសោះនោះ ។ យ៉ូសែប បានធ្វើដំណើរទៅផ្ទះរបស់ឪពុកម្ដាយលោក ហើយពេលទៅដល់ទីនោះ លោកបានហៅម៉ាទីនឲ្យមក ។ ម៉ាទីន បានចំណាយពេលពេញមួយព្រឹកដើម្បីធ្វើដំណើរមក ។ នៅពេលគាត់បានមកដល់ គាត់បានបរិភោគអាហារជាមួយគ្រួសារស៊្មីធប៉ុន្តែរំពេចនោះបានទម្លាក់ស្លាបព្រាចុះ ។ នៅពេលដែលគេសួរថា លោកមានរឿងអ្វី លោកបានយំ ហើយទីបំផុតបានសារភាពថា លោកបានធ្វើឲ្យបាត់ឯកសារដែលសរសេរដោយដៃចំនួន ១១៦ ទំព័រនោះហើយ ។ ( សូមមើល *History of Joseph Smith by His Mother,* បានបោះពុម្ពដោយ Preston Nibley [ ឆ្នាំ១៩៥៨ ], ១២៤–២៩ សម្រាប់ព័ត៌មានលម្អិតអំពីដំណើររឿងនេះ ) ។

- សូមពិចារណាអំពីស្ថានភាពលំបាកទាំងនេះចំពោះព្យាការី យ៉ូសែប ស៊្មីធ ។ តើអ្នកគិតថា អ្នកនឹងមានអារម្មណ៍ដូចម្ដេចក្នុងស្ថានភាពបែបនេះ ?

សូមប្រាប់ដល់សិស្សថា នៅពេលត្រឡប់មកដល់ភូមិ ហាម៉ូនីវិញដោយគ្មានឯកសារសរសេរដោយដៃចំនួន ១១៦ ទំព័រនោះ យ៉ូសែប ស៊្មីធ បានអធិស្ឋានសុំការអភ័យទោស ។ ដោយសារយ៉ូសែប បាន« ធ្វើឲ្យព្រះអម្ចាស់ធុញថប់ ចំពោះការទទូចសុំឯកសិទ្ធិឲ្យ ម៉ាទីន ហារិស យកការសរសេរនោះទៅ » ( *History of the Church,*១:២១ ) ម្រ៉ូណៃ បានដកយក យ៉ូរីម និងធូមីម ហើយយ៉ូសែប បានបាត់បង់អំណោយទាននៃការបកប្រែ ។ ទោះជាយ៉ាងណាក៏ដោយ ម្រ៉ូណៃ បានសន្យាថា យ៉ូសែប អាចទទួលបានវាម្ដងទៀត បើលោកនឹង « រាបសារ ហើយភ្ញាក់ខ្លួន » *History of Joseph Smith by His Mother,* ១៣៤ ) ។ ក្រោយមក យ៉ូសែប បានទទួលវិវរណៈ ដែលឥឡូវត្រូវបានគេស្គាល់ថាជាគោលលទ្ធិ និង សេចក្ដីសញ្ញា ៣ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១–៣ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលនូវអ្វីដែលព្រះអម្ចាស់ចង់ឲ្យព្យាការី យ៉ូសែប ស៊្មីធ យល់ ។

- តើអ្នកនឹងសង្ខេបអំពីសារលិខិតរបស់ព្រះអម្ចាស់ ចំពោះយ៉ូសែប ស៊្មីធ ក្នុងខទាំងនេះយ៉ាងដូចម្ដេច ? ( នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមគូសបញ្ជាក់នូវគោលលទ្ធិដូចខាងក្រោម ៖ **គោលបំណងនៃព្រះ ពុំអាចស្មុគស្មាញទេ** ។ អ្នកអាចនឹងឲ្យយោបល់សិស្សគូសចំណាំសេចក្ដីពិតនេះនៅក្នុង ខ១ ។ វាអាចនឹងជាជំនួយដើម្បីពន្យល់ថា នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១ ពាក្យ *ស្មុគស្មាញ* មានន័យថា រារាំងមិនឲ្យសម្រេចជោគជ័យ ) ។

- តើការពិតនេះ បានជួយដល់យ៉ូសែប ស៊្មីធ អំឡុងគ្រាលំបាកនេះយ៉ាងដូចម្ដេច ? ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងទាំងអស់គ្នា ដើម្បីយល់ពីសេចក្ដីពិតនេះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៤–១៥

### *ព្រះអម្ចាស់ បន្ទោសដល់យ៉ូសែប ស៊្មីធ ហើយបានដាស់តឿនលោកឲ្យប្រែចិត្ត*

សូមពន្យល់ថា ទោះបីជាព្រះ មានបន្ទូលថា កិច្ចការរបស់ទ្រង់ពុំអាចស្មុគស្មាញក្ដី ក៏ទ្រង់ចង់ឲ្យព្យាការី ដឹងផងដែរអំពីកំហុសដែលលោកបានធ្វើ ហើយនឹងលទ្ធផលនៃកំហុសទាំងឡាយនោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៤–៦ ឲ្យឮៗ ។ សូមដល់សិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ប្រាប់ពាក្យ និងឃ្លា ដែលអាចនឹងពិបាកដើម្បីឲ្យយ៉ូសែប ស៊្មីធស្ដាប់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវពាក្យ និងឃ្លាទាំងឡាយដែលពួកគេរកឃើញ ហើយហេតុអ្វី ។

- តើយ៉ូសែប « បានទៅតាមការបញ្ចុះបញ្ចូលទាំងឡាយនៃមនុស្សលោក » តាមរបៀបណា ? ( គ. និង ស. ៣:៦ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១២–១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលឃ្លាទាំងឡាយ ដែលគូសបញ្ជាក់ពីមូលហេតុដែលសកម្មភាពរបស់យ៉ូសែប គឺធ្ងន់ធ្ងរបំផុតនោះ ។ បន្ទាប់មកសូមអញ្ជើញសិស្សឲ្យរាយការណ៍នូវអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៧ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ប្រាប់នូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទៅយ៉ូសែប ស៊្មីធ គួរតែធ្វើ នៅពេលលោក ស្ថិតនៅក្រោមសម្ពាធរបស់ម៉ាទីន ហារិស ។ ( មុនពេលសិស្សអាន

អ្នកអាចនឹងពន្យល់ថា នៅក្នុងវគ្គបទគម្ពីរនេះ ពាក្យ *មនុស្សលោក* គឺសំដៅទៅមនុស្សលោកទាំងអស់ ) ។ បន្ទាប់ពីសិស្សប្រាប់អំពីការទូន្មានរបស់ព្រះអម្ចាស់ សូមសរសេរនូវគោលការណ៍ដូចខាងក្រោម នៅលើក្ដារខៀន ៖ **យើងគួរតែខ្លាចព្រះជាជាងខ្លាចមនុស្ស ។** ( អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំពាក្យ ឬឃ្លានៅក្នុង ខទី ៧ ដែលបង្រៀនពីគោលការណ៍នេះ ) ។

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីខ្លាចព្រះ ជាជាងខ្លាចមនុស្សនោះ ?

ដើម្បីជួយសិស្សឲ្យយល់អំពីអត្ថន័យនៃការខ្លាចព្រះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពន្យល់ដូចខាងក្រោម ដោយអែលឌើរ ឌី ថដ គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« មានកន្លែងជាច្រើនក្នុងព្រះគម្ពីរ ដែលទូន្មានរបស់មនុស្សឲ្យខ្លាចដល់ព្រះ ។ នៅជំនាន់របស់យើង ជាទូទៅយើងបានបកប្រែពាក្យ *ខ្លាច* ថាជា « គោរព » ឬ « គារវភាព » ឬ « ស្រឡាញ់ » ដែលថា ការខ្លាចដល់ព្រះ មានន័យថា ស្រឡាញ់ព្រះ ឬគោរពដល់ទ្រង់ និងក្រឹត្យវិន័យរបស់ទ្រង់ ។ ជាញឹកញាប់ នោះអាចជាការអានដ៏ត្រឹមត្រូវមួយ ប៉ុន្តែខ្ញុំឆ្ងល់ពេលខ្លះ បើពាក្យ *ខ្លាច* ពុំមានន័យពិតថាជា *ខ្លាច* នៅពេលពួកព្យាការីនិយាយអំពីការភ័យខ្លាចធ្វើឲ្យព្រះអាក់អន់ព្រះទ័យ ដោយការមិនគោរពបទបញ្ញត្តិរបស់ទ្រង់នោះ ។. . .

« . . .យើងគួរតែស្រឡាញ់ និងមានគារវភាពចំពោះទ្រង់ ដែលយើងខ្លាចក្នុងការធ្វើអ្វីមួយខុសនៅចំពោះព្រះនេត្រទ្រង់ មិនថាអាចនឹងមានទស្សនៈ ឬសម្ពាធមកពីអ្នកដទៃយ៉ាងណានោះទេ » ( « A Sense of the Sacred » [ CES fireside for young adults, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ], ៦–៧, LDS.org សូមមើល ផងដែរ speeches.byu.edu ) ។

- ស្របតាមអែលឌើរ គ្រីស្តូហ្វឺសិន តើការខ្លាចព្រះមានន័យយ៉ាងណា ?
- តើការខ្លាចព្រះ ដូចដែលអែលឌើរ គ្រីស្តូហ្វឺសិន បានពន្យល់ អាចជួយយើងធ្វើការសម្រេចចិត្តត្រូវ ទោះជាពេលយើងមានការដាក់សម្ពាធមកពីមិត្តភក្តិយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៨ ដោយស្ងាត់ស្ងៀម ស្វែងរកមើលអ្វីដែលព្រះ នឹងបានធ្វើ បើ យ៉ូសែប ស៊្មីធ បានស្ដាប់តាមចម្លើយពីដំបូងចំពោះការសុំរបស់ ម៉ាទីន នោះ ។ សូមអញ្ជើញសិស្សឲ្យសង្ខេបនូវអ្វីដែលយើងអាចរៀនមកពីខនេះ ។ សិស្សអាចប្រើពាក្យផ្សេង ប៉ុន្តែត្រូវប្រាកដថា ពួកគេយល់ថា **បើយើងមានភាពស្មោះត្រង់ចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះទ្រង់នឹងគាំទ្រយើង អំឡុងគ្រាលំបាកទាំងឡាយ ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀន ។

សូមឲ្យសិស្សគិតអំពីគ្រាមួយ ពេលដែលពួកគេធ្វើតាមបញ្ញត្តិរបស់ព្រះអម្ចាស់ ជាជាងធ្វើតាមការដាក់សម្ពាធ ឬឥទ្ធិពលរបស់មនុស្សដទៃទៀត ។ សូមអញ្ជើញសិស្សមួយចំនួនឲ្យចែកចាយអំពីរបៀបដែលពួកគេបានទទួលការគាំទ្ររបស់ព្រះអម្ចាស់ចំពោះការគោរពប្រតិបត្តិរបស់ពួកគេ ។

សូមរំឭកសិស្សថា នៅដើមមេរៀន អ្នកបានសុំឲ្យពួកគេគិតអំពីស្ថានភាពដែលពួកគេអាចនឹងត្រូវបានល្បួងឲ្យស្ដាប់មិត្តភក្តិជាជាងការគោរពប្រតិបត្តិ ។ សូមទាញចំណាប់អារម្មណ៍របស់សិស្សផ្ដោតទៅលើសេចក្ដីពិត ដែលអ្នកបានសរសេរនៅលើក្ដារខៀន ។

- តើសេចក្ដីពិតនេះ ជួយអ្នកនៅពេលអ្នកត្រូវបានល្បួងដោយមិត្តភក្តិម្នាក់ឲ្យធ្វើនូវរឿងមួយដែលអ្នកដឹងថាមិនត្រឹមត្រូវយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យសរសេរក្នុងសៀវភៅ សរសេររបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីរបៀបដែលពួកគេអាចអនុវត្តសេចក្ដីពិតនេះចំពោះទំនាក់ទំនងបច្ចុប្បន្នរបស់ពួកគេជាមួយនឹងមិត្តភក្តិ និងគ្រួសារ ។

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៩–១០ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលការសន្យាដែលព្រះអម្ចាស់ បានប្រទានដល់ យ៉ូសែប ស៊្មីធ ទោះជាយ៉ូសែប បានធ្វើកំហុសធ្ងន់ធ្ងរក្ដី ។ ( អ្នកអាចនឹងផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំអ្វីដែលពួកគេរកឃើញ ) ។

- តើការសន្យាអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស៊្មីធ ? តើការសន្យានេះអនុវត្តចំពោះយើងយ៉ាងដូចម្ដេច ? ( សិស្សអាចឲ្យយោបល់នូវគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវបាក្រដគូសបញ្ជាក់ថា **ប្រសិនបើយើងប្រែចិត្តពីអំពើបាបរបស់យើង នោះយើងនឹងទទួលបានសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់** ) ។
- សូមចាំក្នុងចិត្តនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់យ៉ូសែប នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៤–៦ តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច បន្ទាប់ពីស្ដាប់ឮការសន្យានេះមកពីព្រះអម្ចាស់ បើអ្នកគឺជាយ៉ូសែបវិញ ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៣:៩, ១១ ដោយស្ងាត់ស្ងៀម ហើយប្រាប់ពីការព្រមានដែលព្រះអម្ចាស់ បានផ្តល់ឲ្យព្យាការី យ៉ូសែប ស្ម៊ីធ ។

- ហេតុអ្វីក៏ការព្រមានទាំងនេះ សំខាន់ដើម្បីរំឭកយើង នៅពេលយើងប្រែចិត្តពីអំពើបាបរបស់យើង ហើយស្វែងរកសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់នោះ ?

## គោលលទ្ធិ និង សេចក្តីសញ្ញា ៣:១៦–២០

*ព្រះអម្ចាស់ ពន្យល់អំពី គោលបំណងរបស់ទ្រង់ក្នុងការនាំមកនូវព្រះគម្ពីរមរមន*

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៣:១៦–២០ ដោយស្ងាត់ស្ងៀម រួចប្រាប់អំពីគោលបំណងដែលព្រះអម្ចាស់ប្រទានព្រះគម្ពីរមរមនមកនោះ ។

- ហេតុអ្វីក៏កិច្ចការដែលយ៉ូសែប ស្ម៊ីធ និង ម៉ាទីន ហារិស កំពុងធ្វើនោះ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះព្រះអម្ចាស់ និងរាស្ត្រទ្រង់ដូច្នេះ ?

សូមបញ្ចប់មេរៀននេះ ដោយការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវអ្វី ដែលពួកគេបានរៀន ហើយទទួលអារម្មណ៍នៅថ្ងៃនេះ និងរបៀបដែលពួកគេអាចអនុវត្តសេចក្តីពិត ដែលពួកគេបានរៀន ។ សូមចែកចាយទីបន្ទាល់របស់អ្នកផ្ទាល់អំពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ នៅពេលយើងប្រែចិត្តពីអំពើបាបរបស់យើង ។ អ្នកក៏អាចប្រាប់ដល់សិស្សទាំងអស់ថា នៅក្នុងមេរៀនក្រោយ ពួកគេនឹងរៀនអំពីរបៀបដែលព្រះអម្ចាស់បានសងនូវការបាត់បង់នៃឯកសារសរសេរដោយដៃចំនួន ១១៦ ទំព័រ ។

មេរៀនទី១២

# គោលលទ្ធិ និង សេចក្ដីសញ្ញា១០

## បុព្វកថា

បន្ទាប់ពីបាត់ឯកសារដែលសរសេរដោយដៃចំនួន១១៦ ទំព័រមក ព្យាការីបានបាត់បង់អំណាចដើម្បីបកប្រែ ។ ក្រោយពីការអធិស្ឋានដោយរាបសារ និងការប្រែចិត្តអស់មួយរយៈពេលមកនោះផ្ទាំងចំណារនិង យូរីម និងធូមីម ត្រូវបានប្រគល់មកឲ្យ យ៉ូសែប វិញ ។ ព្រះអម្ចាស់ បានបញ្ជាយ៉ូសែបមិនឲ្យបកប្រែឡើងវិញនូវផ្នែកនៃផ្ទាំងចំណារដែលបានបាត់ទាំង១១៦ ទំព័រនោះទេ ហើយទ្រង់បានបើកសម្ដែងអំពីផែនការសម្ងាត់របស់សាតាំង ដើម្បីបំផ្លាញកិច្ចការរបស់ព្រះ ។ រួចហើយព្រះអម្ចាស់បានបញ្ជាឲ្យយ៉ូសែប ស្ម៊ីធ បកប្រែផ្ទាំងតូចរបស់នីហ្វៃ ។ ទ្រង់ក៏បានពន្យល់អំពី គោលបំណងនៃព្រះគម្ពីរមរមន ហើយនឹងតួនាទីវានៅក្នុងការស្ថាបនាសាសនាចក្ររបស់ទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា១០:១–៤

*ព្រះអម្ចាស់ បានស្ដារអំណោយទានដើម្បីបកប្រែរបស់យ៉ូសែប ឡើងវិញ*

សូមឲ្យសិស្សមើលសង្ខេបៗនូវអ្វីដែលពួកគេរៀនមកពីមេរៀនមុន អំពីការបាត់ឯកសារដែលសរសេរដោយដៃចំនួន១១៦ ទំព័រឡើងវិញ ( សូមមើល គ. និង ស. ៣ ) ។ សូមរំឭកសិស្សថា ដោយសារតែការទទូចសុំដដែលៗរបស់ព្យាការីដើម្បីអនុញ្ញាតឲ្យម៉ាទីន ហារិស យកឯកសារដែលបានសរសេរដោយដៃទៅ ជាលទ្ធផលនាំឲ្យបាត់ទំព័រទាំងនោះ មរ៉ូណៃក៏បានដកយកផ្ទាំងចំណារមាស និងយូរីម និងធូមីម ចេញពី យ៉ូសែប ស្ម៊ីធ ។

ក្រោយមកមរ៉ូណៃ បានប្រគល់ផ្ទាំងចំណារ និង យូរីម និងធូមីមឲ្យវិញ ។ មួយរយៈកាល បន្ទាប់ពីទទួលបានរបស់ទាំងនេះមកវិញ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០ ។ នៅក្នុងវិវរណៈនេះព្រះអម្ចាស់ បានណែនាំយ៉ូសែប អំពីអ្វីដែលត្រូវធ្វើជាមួយនឹងផ្នែកនៃផ្ទាំងចំណារ ដែលបានសរសេរដោយដៃ ដែលបានបាត់នោះ ។ ( សូមមើល លូស៊ី ម៉ាក ស្ម៊ីធ *History of Joseph Smith by His Mother,* បានបោះពុម្ពដោយ Preston Nibley [ ឆ្នាំ១៩៥៨ ], ទំព័រ១៣៣–៣៦ ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា១០:១–២ ដោយពន្យល់ថា ព្រះអម្ចាស់បានរំឭកយ៉ូសែប ពីមូលហេតុដែលអំណាចដើម្បីបកប្រែត្រូវបានដកចេញពីលោក និងអ្វីដែលបានកើតឡើងជាលទ្ធផលមកពីកំហុសរបស់លោក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៣–៤ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការប្រឹក្សាដែលព្រះអម្ចាស់បានផ្ដល់ឲ្យ ពេលយ៉ូសែប ស្ម៊ីធ ចាប់ផ្ដើមបកប្រែម្ដងទៀតនោះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- ហេតុអ្វីបានជាអ្នកគិតថា យ៉ូសែប ស្ម៊ីធ ចាំបាច់ត្រូវទទួលបានការប្រឹក្សាកុំឲ្យធ្វើការ ឬបកប្រែហួសពីកម្លាំងដែលលោកមានដូច្នេះ ?
- តើការប្រឹក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៤ ណែនាំយើង នៅពេលយើងបម្រើព្រះអម្ចាស់យ៉ាងដូចម្ដេចខ្លះ ?

### គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៥–៣៧

*ព្រះអម្ចាស់ព្រមានអំពីផែនការរបស់សាតាំងក្នុងការបំផ្លាញយ៉ូសែប ស្ម៊ីធ និងកិច្ចការរបស់ព្រះ*

សូមបង្ហាញអង្គប់ ឬអន្ទាក់មួយ ( ឬ គូររូបភាពមួយនៅលើក្ដារខៀន ) ។

- តើឧបករណ៍ដូច្នេះ តំណាងឲ្យបំណងរបស់សាតាំងចំពោះយើងយ៉ាងដូចម្ដេច ?



សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៥ ឲ្យឮៗ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យ ព្យាការីយ៉ូសែប ស្ម៊ីធ ធ្វើដើម្បីគេចចេញពីសាតាំង ។

- តើយើងអាចរៀនអ្វីខ្លះចេញមកពីខនេះ ? ( សិស្សអាចប្រាប់គោលការណ៍ផ្សេងមួយ ប៉ុន្តែសូមប្រាកដថា អ្នកគួសបញ្ជាក់ប្រាប់ថា **នៅពេលយើងអធិស្ឋានជានិច្ច នោះយើងនឹងមានអំណាចដើម្បីយកឈ្នះលើសាតាំង និងអ្នកទាំងឡាយដែលបម្រើវា ។** សូមពិចារណាសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។

- តើការអធិស្ឋានជួយយើង « យកឈ្នះលើសាតាំង ហើយ. . .គេចចេញ [ ពីអ្នកទាំងឡាយ ]ដែលជួយកិច្ចការរបស់វា យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយឧទាហរណ៍អំពីរបៀបដែលការអធិស្ឋានបានជួយពួកគេឲ្យទប់ទល់នឹងការល្បួងរបស់សាតាំង ។ ( សូមរំឭកសិស្សថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ ឬ រឿងផ្ទាល់ខ្លួនច្រើនពេកនោះទេ ) ។

សូមពន្យល់ថា ព្រះអម្ចាស់ បានព្រមានដល់យ៉ូសែប អំពីអន្ទាក់មួយដែលសាតាំងបានដាក់ ដើម្បីព្យាយាមបំផ្លាញដល់ព្យាការី និងកិច្ចការរបស់ព្រះ ។ សូមអញ្ជើញសិស្សបួនប្រាំនាក់ឲ្យផ្លាស់វេនគ្នាអានឲ្យឮៗមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៨–១៩ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីផែនការរបស់បុគ្គលទុច្ចរិត ដែលកាន់កាប់ឯកសារសរសេរដោយដៃនោះ ។

- តើផែនការរបស់បុគ្គលទុច្ចរិត ដែលមានឯកសារសរសេរដោយដៃជាអ្វី ? ( ដើម្បីបង្ខូចកិត្តិយសព្យាការី និងកិច្ចការរបស់ព្រះអម្ចាស់ តាមរយៈការផ្លាស់ប្ដូរពាក្យនៃឯកសារសរសេរដោយដៃនោះ ។ បើយ៉ូសែប បានបកប្រែឯកសារដូចគ្នាម្ដងទៀត ពួកគេនឹងនិយាយថា លោកពុំអាចធ្វើវាដូចគ្នាពីរដងទេ ហេតុដូច្នោះពុំមានអំណោយទានទេ ) ។

សូមលើកអន្ទាក់ ឬអង្គប់ ដែលអ្នកដាក់បង្ហាញកាលពីមុនឡើង ( ឬសំដៅទៅលើរូបភាពដែលបានគូរនៅលើក្ដារខៀន ) ។ សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១០:២០–២៩ ព្រះអម្ចាស់ បាននិយាយអំពីឥទ្ធិពលរបស់សាតាំងចំពោះមនុស្សទុច្ចរិត ដែលទទួលបានឯកសារសរសេរដោយដៃចំនួន១១៦ទំព័រនោះ និងរបៀបដែលសាតាំងសម្រេចគោលបំណងទុច្ចរិតរបស់វា ។ សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យសិស្សម្នាក់ក្នុងចំណោមដៃគូនីមួយៗអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១០:២០–២៩ ដោយស្ងាត់ស្ងៀម ស្វែងរកអ្វីដែលខទាំងនេះ បង្រៀនអំពីគោលបំណងរបស់សាតាំង ។ សូមឲ្យសិស្សម្នាក់ទៀត អានខដូចគ្នា ស្វែងរកមើលយុទ្ធសាស្ត្រដែលសាតាំងប្រើដើម្បីសម្រេចគោលបំណងវា ។ ក្រោយពីឲ្យពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សចែកចាយពីអ្វីដែលពួកគេបានរកឃើញជាមួយនឹងដៃគូរបស់ពួកគេ ។

- តើយើងរៀនអ្វីខ្លះ អំពីគោលបំណងរបស់សាតាំងមកពីខទាំងនេះ ? ( សិស្សអាចរកឃើញគោលការណ៍ផ្សេងមួយ ប៉ុន្តែសូមប្រាកដថា ពួកគេបានប្រាប់ពីសេចក្ដីពិតដូចខាងក្រោម ៖ **សាតាំងមានបំណងបំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និងព្រលឹងរបស់យើង ។** អ្នកអាចសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ។ អ្នកក៏អាចឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំពាក្យ ឬឃ្លាដែលបង្រៀនសេចក្ដីពិតនេះនៅក្នុង ខ ២២–២៣ និង ២៧ ) ។

- ចេញមកពីអ្វីដែលអ្នកអាននៅក្នុងខទាំងនេះ តើសាតាំងព្យាយាមបំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និងព្រលឹងរបស់យើងយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់ និងដឹងពីសារៈសំខាន់នៃសេចក្ដីពិតនេះ សូមសួរសំណួរដូចខាងក្រោម ។ សូមអញ្ជើញសិស្សដែលចាប់ដៃគូគ្នាពិភាក្សាពីចម្លើយរបស់ពួកគេ ។

- តើអ្នកបានឃើញភស្តុតាងអ្វីខ្លះ ដែលសាតាំងបានប្រើដើម្បីបោកបញ្ឆោត ញុះញង់កំហឹង បញ្ឆោរ និងកុហក ដើម្បីបំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និងព្រលឹងរបស់យើងនោះ ?

- តើការដឹងជាមុនអំពីបំណងរបស់សាតាំង និងវិធីសាស្ត្ររបស់វា ជួយយើងចៀសវាងនិងគេចចេញពីអន្ទាក់របស់វាយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទី សរសេរក្នុងសៀវភៅកំណត់ចំណាំ ក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីវិធីសាស្ត្ររបស់មារសត្រូវដែលបានសរសេរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:២០–២៩ ដែលពួកគេបានឃើញឬដឹងនោះ ។ សូមពួកគេឲ្យសរសេរអំពីអ្វីដែលពួកគេអាចធ្វើ ដើម្បីចៀសវាង ឬគេចចេញពីអន្ទាក់របស់សាតាំងផងដែរ ។

បន្ទាប់ពីសិស្សមានពេលសរសេរគ្រប់គ្រាន់ហើយ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៣០–៣៧ ដោយពន្យល់ថា ដោយសារតែផែនការរបស់មនុស្សទុច្ចរិត ដើម្បីបំផ្លាញកិច្ចការរបស់ព្រះ និងកេរ្តិ៍ឈ្មោះរបស់យ៉ូសែប ស្ម៊ីធ នោះព្រះអម្ចាស់បានបញ្ជាយ៉ូសែបកុំឲ្យបកប្រែឡើងវិញនូវផ្នែកនោះក្នុងផ្ទាំងចំណារដែលបានបាត់ចំនួន១១៦ ទំព័រដែលបានបកប្រែហើយនោះឡើយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៣៨–៤៥

*ព្រះអម្ចាស់បានបញ្ជាឲ្យយ៉ូសែប ស៊្មីធ បកប្រែផ្ទាំងតូចរបស់នីហ្វៃ ។*

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៣៨–៤២ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់ បានបញ្ជាឲ្យយ៉ូសែបបកប្រែជំនួសឲ្យការបកប្រែឡើងវិញនូវចំណែកនៃផ្ទាំងចំណារដែលបានបាត់ចំនួន១១៦ ទំព័រ ដែលបានបកប្រែហើយនោះ ។

- តើព្រះអម្ចាស់បានបញ្ជាយ៉ូសែបឲ្យបកប្រែអ្វី ? ហេតុអ្វី ?

សូមជួយសិស្សឲ្យយល់អំពីរបៀបដែលព្រះអម្ចាស់បានរៀបចំសម្រាប់ឯកសារសរសេរដោយដៃដែលបានបាត់ចំនួន១១៦ ទំព័រនោះ ។ សូមពន្យល់ថា ការបាត់ឯកសារដែលមានការបកប្រែនៃគម្ពីរលីហៃ គឺមាននៅក្នុងសេចក្ដីសង្ខេបរបស់មរមន អំពីផ្ទាំងធំរបស់នីហ្វៃ ។ មរមនត្រូវបានបំផុសឲ្យភ្ជាប់ផ្ទាំងតូចរបស់នីហ្វៃទៅនឹងកំណត់ត្រារបស់លោក « សម្រាប់គោលបំណងដ៏ឆ្លាតវៃមួយ » ដែលពេលនោះលោកពុំយល់ឡើយ ( សូមមើល ពាក្យសម្ដីនៃមរមន១:៣–៧ ) ។ ផ្ទាំងតូចរបស់នីហ្វៃ បានមានប្រហែលជាក្នុងរយៈពេលដូចគ្នានឹងគម្ពីរលីហៃ ។ បន្ទាប់ពីការបាត់ចំនួន១១៦ ទំព័រនោះមក ព្រះអម្ចាស់បានបញ្ជាព្យាការី យ៉ូសែប ស៊្មីធ ឲ្យបកប្រែឯកសារមកពីផ្ទាំងតូចរបស់នីហ្វៃ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៤៣ ដោយស្ងាត់ស្ងៀម ហើយរកមើលសេចក្ដីពិតដ៏សំខាន់មួយដែលព្រះអម្ចាស់បានចង់ឲ្យយ៉ូសែប ស៊្មីធ យល់ ។ ( នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ប្រាជ្ញារបស់ព្រះមហិមាជាងកលល្បិចនៃអារក្សទៅទៀត ។** អ្នកអាចនឹងត្រូវការពន្យល់ថា *កលល្បិច* សំដៅទៅលើការប្រើល្បិចដើម្បីបញ្ឆោតមនុស្ស ) ។

- តើផែនការរបស់ព្រះអម្ចាស់ ជំនួសឯកសារសរសេរដោយដៃដែលបានបាត់ បង្ហាញពីសេចក្ដីពិតនេះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៤៤–៤៥ ដោយស្ងាត់ស្ងៀម ស្វែងរកមើលភស្ដុតាងនៃសេចក្ដីពិតនៅក្នុងខ ៤៣ ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៤៤–៤៥ ហេតុអ្វីផ្ទាំងតូចរបស់នីហ្វៃមានតម្លៃជាងឯកសារដែលបានបាត់ចំនួន ១១៦ ទំព័រនោះដូច្នេះ ?
- តើការដឹងថា ព្រះបានរៀបចំផ្លូវមួយដើម្បីសងថ្លៃ ឯកសារសរសេរដោយដៃដែលបានបាត់ចំនួន១១៦ ទំព័រ ជួយអ្នកយល់កាន់តែពេញលេញពីទំនុកចិត្តរបស់ទ្រង់យ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៤៦–៧០

*ព្រះអម្ចាស់ក៏បានពន្យល់អំពី គោលបំណងនៃព្រះគម្ពីរមរមន ហើយនឹងតួនាទីវានៅក្នុងការស្ថាបនាសាសនាចក្ររបស់ទ្រង់*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៤៦–៦១ ដោយការពន្យល់ថា នៅក្នុងខទាំងនេះ ព្រះអម្ចាស់បានថ្លែងទីបន្ទាល់ថា ទ្រង់បានឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកសិស្សនីហ្វៃរបស់ទ្រង់ ដោយការរក្សា និងការនាំព្រះគម្ពីរមរមនឲ្យចេញមកនៅជំនាន់របស់យើង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១០:៦២–៦៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា ព្រះគម្ពីរមរមន នឹងនាំមកនូវពន្លឺ ។

- តើព្រះគម្ពីរមរមននឹងនាំអ្វីខ្លះទៅកាន់ពន្លឺ ? ( ចំណុចពិតនៃគោលលទ្ធិរបស់ព្រះគ្រីស្ទ ) ។
- ស្របតាម ខ ៦៣ តើព្រះអម្ចាស់ប្រើចំណុចពិតនៃគោលលទ្ធិរបស់ទ្រង់ ដើម្បីយកឈ្នះលើកិច្ចការរបស់សាតាំងយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗអំពីការសន្យាចុងក្រោយរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៦៧, ៦៩–៧០ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយកត់ចំណាំឃ្លាដែលមានអត្ថន័យចំពោះពួកគេ ក្នុងពន្លឺនៃអ្វីដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមអញ្ជើញពួកគេឲ្យចែកចាយឃ្លា ដែលមានអត្ថន័យចំពោះពួកគេ និង ហេតុអ្វី ។ សូមបញ្ចប់ដោយទីបន្ទាល់របស់អ្នក ។

មេរៀនទី១៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤

## បុព្វកថា

វិវរណៈនេះ ត្រូវបានផ្ដល់ឲ្យទៅ យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ នៅខែកុម្ភៈ ឆ្នាំ១៨២៩ ដែលត្រូវជាឪពុករបស់ព្យាការី គឺជាវិវរណៈដំបូងគេមួយនៃវិវរណៈដំបូងគេមួយចំនួន បានប្រទានទៅដល់បុគ្គលជាច្រើន ដែលមានបំណងប្រាថ្នាដើម្បីជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់ ( សូមមើលផងដែរ គ. និង ស.១១–១២; ១៤–១៦; ២៥ ) ។ ក្នុងវិវរណៈនោះ យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ ត្រូវបានហៅឲ្យធ្វើកិច្ចការនៅក្នុងការបម្រើរបស់ព្រះ ។ បន្ថែមពីលើនោះ ព្រះអម្ចាស់ បានចែងពីគុណសម្បត្តិ និងលក្ខណៈសម្បត្តិគន្លឹះសម្រាប់អ្នកទាំងឡាយណាដែលបម្រើទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:១–៣

*យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ ត្រូវបានហៅឲ្យធ្វើកិច្ចការនៅក្នុងការបម្រើរបស់ព្រះ ។*

សូមចាប់ផ្ដើមដោយការសុំឲ្យសិស្សពិចារណាអំពីសំណួរខាងក្រោម ៖

- តើអ្នកធ្លាប់មានអារម្មណ៍ប្រាថ្នាចង់បម្រើព្រះ ហើយចង់ដឹងពីព្រះឆន្ទៈទ្រង់ ទាក់ទងនឹងរបៀបដែលអ្នកអាចជួយក្នុងការធ្វើកិច្ចការរបស់ទ្រង់បានល្អបំផុតដែរឬទេ ?

សូមពន្យល់ថា ឪពុករបស់យ៉ូសែប ស្ម៊ីធ មានបំណងយ៉ាងខ្លាំង ប៉ុន្តែគាត់ពុំដឹងថាតើព្រះអម្ចាស់មានព្រះទ័យឲ្យគាត់ធ្វើអ្វីឡើយ ។ ក្នុងខែ កុម្ភៈ ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ និង លូស៊ី ជាភរិយារបស់លោក បានទៅសួរសុខទុក្ខកូនប្រុសរបស់ពួកលោក យ៉ូសែប ស្ម៊ីធ ជុញ៉័រ នៅភូមិ ហាម៉ូនី រដ្ឋ ប៉ែនសិលវេញ៉ា ។ អំឡុងការសួរសុខទុក្ខនោះ យ៉ូសែប ស្ម៊ីធ ជុញ៉័រ បានទទួលវិវរណៈមួយដែលឆ្លើយទៅនឹងសំណួររបស់ឪពុករបស់លោក ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤ គឺជាចម្លើយរបស់ព្រះអម្ចាស់ ដែលទ្រង់បានចែងពីគុណសម្បត្តិនានា ដែលទ្រង់រំពឹងចង់បានពីសំណាក់អ្នកទាំងឡាយដែលជួយនៅក្នុងកិច្ចការរបស់ទ្រង់ ។

សូមរំឭកសិស្សថា នៅគ្រានៃវិវរណៈនេះ សាសនាចក្រ ពុំទាន់ត្រូវបានរៀបចំឡើង ហើយបព្វជិតភាពពុំទាន់ត្រូវបានស្ដារឡើងវិញនៅឡើយទេ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:១ ដោយស្ងាត់ស្ងៀម ស្វែងរកមើលរបៀបដែលព្រះអម្ចាស់ បានពិពណ៌នាអំពីការស្ដារឡើងវិញថា ជាការណ៍ដែលទើបតែចាប់ផ្ដើមបង្កើតឡើង ។

- តើព្រះអម្ចាស់ប្រើព្រះបន្ទូលអ្វីដើម្បី ពិពណ៌នាអំពីការស្ដារឡើងវិញនៃដំណឹងល្អនៅក្នុងថ្ងៃចុងក្រោយ ?
- តើការស្ដារឡើងវិញនៃដំណឹងល្អ « អស្ចារ្យ » ដោយវិធីណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់សុំពីអ្នកទាំងឡាយដែលចាប់ផ្ដើមធ្វើការបម្រើរបស់ទ្រង់ ។ ( អ្នកអាចនឹងពន្យល់ថាពាក្យ *ចាប់ផ្ដើមធ្វើការ* មានន័យថា ផ្ដើមធ្វើ ) ។

- ស្របតាមខគម្ពីរនេះ តើព្រះអម្ចាស់រំពឹងអ្វីខ្លះ ពីអ្នកទាំងឡាយដែលបម្រើទ្រង់ ?
- តើវាមានន័យដូចម្ដេច ដើម្បីធ្វើអ្វីមួយ « ដោយអស់ពីចិត្តអស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង » នោះ ?

ដើម្បីជួយសិស្សយល់បានកាន់តែច្បាស់អំពីឃ្លានេះ សូមឲ្យពួកគេពិពណ៌នាអំពីសកម្មភាព ឬលក្ខណៈសម្បត្តិអ្វីខ្លះ ដែលពួកគេរំពឹងថាមាននៅក្នុងខ្លួនមនុស្សម្នាក់ ដែលកំពុងព្យាយាមដើម្បីបម្រើព្រះដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់ពួកគាត់នោះ ។ អ្នកក៏អាចអញ្ជើញពួកគេឲ្យផ្ដល់ឧទាហរណ៍អំពីមនុស្សទាំងឡាយដែលពួកគេដឹងថាបានបម្រើព្រះអម្ចាស់តាមរបៀបនេះផងដែរ ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងបម្រើព្រះដោយអស់ពីចិត្តអស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់យើង* ________________________________.

ដើម្បីជួយសិស្សប្រាប់ពីគោលការណ៍មួយដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២ សូមសួរសំណួរដូចខាងក្រោម ៖

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២ តើមានពរជ័យអ្វីខ្លះ ដែលកើតចេញមកពីការបម្រើព្រះ « ដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង [ របស់យើង ] នោះ ? ( នៅពេលសិស្សឆ្លើយសូមសិស្សម្នាក់ឲ្យបំពេញសេចក្ដីថ្លែងការណ៍បញ្ចប់នៅលើក្ដារខៀន ។ វាគួរតែអានស្រដៀងគ្នានឹងឃ្លាដូចខាងក្រោមនេះ ៖ **បើយើងបម្រើព្រះដោយអស់ពីចិត្តអស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់យើង នោះយើងអាចបានឈរដោយឥតទោសនៅចំពោះព្រះនៅថ្ងៃចុងក្រោយបំផុត ។** អ្នកអាចផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។
- ហេតុអ្វីអ្នកគិតថា ការបម្រើព្រះដោយអស់ពីចិត្តអស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់យើង នឹងអនុញ្ញាតឲ្យយើងឈរដោយឥតទោសនៅចំពោះព្រះដូច្នេះ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យធ្វើការពិចារណាថា តើមានអារម្មណ៍យ៉ាងណាដើម្បីឈរនៅក្នុងវត្តមានរបស់ព្រះ ហើយ « ឥតទោស » នោះ ។ អ្នកអាចអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ ឲ្យចែកចាយគំនិតរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៣ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលលក្ខណៈសម្បត្តិមួយ ដែលបុគ្គលម្នាក់ៗ ចាំបាច់ត្រូវមានដើម្បីជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់ ។

- តើលក្ខណៈសម្បត្តិអ្វីខ្លះ ដែលមនុស្សម្នាក់ចាំបាច់ត្រូវមាន ដើម្បីជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់នោះ ? ( មានបំណងចង់បម្រើព្រះ ) ។

អ្នកអាចនឹងពន្យល់ថា មនុស្សមួយចំនួនគិតថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤ គឺជាការហៅឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងតែប៉ុណ្ណោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ឪពុករបស់យ៉ូសែប ស្ម៊ីធ ដែលវិវរណៈនេះត្រូវបានប្រទានឲ្យគាត់ គឺពុំត្រូវបានហៅជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនោះទេ ។ ទោះជាយ៉ាងណា គាត់បានធ្វើតាមការប្រឹក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២–៣ អស់មួយជីវិតរបស់គាត់ និងបម្រើដោយការតាំងចិត្ត នៅគ្រប់ទីកន្លែង និងគ្រប់ពេលដែលគាត់ត្រូវបានហៅឲ្យបម្រើ ។ គាត់គឺជាសាក្សីម្នាក់នៃសាក្សីប្រាំបីនាក់អំពីព្រះគម្ពីរមរមន ហើយជាមនុស្សម្នាក់នៃមនុស្សដំបូងដែលត្រូវបានជ្រមុជទឹក នៅពេលសាសនាចក្រ ត្រូវបានរៀបចំឡើងជាផ្លូវការនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ១៨៣០ ។ គាត់ក៏បានបម្រើជាលោកអយ្យកោដំបូងគេបង្អស់ក្នុងសាសនាចក្រ និងជាទីប្រឹក្សាជំនួយក្នុងគណៈប្រធានទីមួយ ។

ការប្រឹក្សាដែលបានប្រទានឲ្យនៅក្នុងកណ្ឌនេះ អាចអនុវត្តចំពោះមនុស្សទាំងអស់ដែលមានបំណងចង់បម្រើព្រះអម្ចាស់ និងតាមរបៀបជាច្រើនដែលយើងអាចស្ដាបនានគររបស់ព្រះ ។

- ជាការបន្ថែមទៅលើកិច្ចការផ្សព្វផ្សាយសាសនាពេញម៉ោង តើវិធីមួយចំនួនដែលយើងអាចជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់មានអ្វីខ្លះ ?

ដើម្បីផ្ដល់ជាគំនិតដល់សិស្ស អំពីរបៀបដែលពួកគេអាចធ្វើតាមបំណងប្រាថ្នារបស់ពួកគេដើម្បីជួយនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់នាពេលឥឡូវនេះ សូមអញ្ជើញសិស្សក្នុងថ្នាក់ម្នាក់ ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដកចេញមកពី *ដើម្បីកម្លាំងនៃយុវជន* ៖

> « ការបម្រើដ៏សំខាន់បំផុតមួយចំនួន ដែលអ្នកអាចផ្ដល់ឲ្យ គឺនៅក្នុងផ្ទះរបស់អ្នកផ្ទាល់ ។ អ្នកអាចបម្រើនៅក្នុងការចាត់តាំងពីសាសនាចក្រ សាលារៀន និង សហគមន៍របស់អ្នកបានផងដែរ ។ អ្នកអាចបម្រើដោយការធ្វើកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។ អ្នកអាចបម្រើដោយការចែកចាយដំណឹងល្អ ជាមួយនឹងអ្នកដទៃឥឡូវនេះ និងក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនាពេលអនាគត ។ ជាញឹកញាប់ ការបម្រើដ៏មានអត្ថន័យបំផុត គឺត្រូវបានបង្ហាញតាមរយៈការធ្វើកិច្ចការល្អៗសាមញ្ញជារៀងរាល់ថ្ងៃ ។ សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធជារៀងរាល់ថ្ងៃ ដើម្បីដឹងថាតើត្រូវបម្រើនរណា និងពីរបៀបដើម្បីជួយស្របទៅតាមតម្រូវការទាំងឡាយរបស់ពួកគេ ។ សូមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះនៅពេលអ្នកបម្រើដល់អ្នកដទៃ » ( *ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ៣២ ) ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរនូវរបៀបជាក់លាក់មួយ ដែលពួកគេចង់ជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់ នៅគ្រានេះក្នុងជីវិតរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៤

*ស្រែសស្កុះព្រះល្មមច្រូតហើយ*

បើអាចធ្វើទៅបាន សូមយកគ្រាប់ស្រូវមកថ្នាក់រៀន ។ បើពុំមានទេ សូមបង្ហាញសិស្សនូវរូបភាពវាលស្រែ ឬ គូររូបសាមញ្ញមួយ អំពីគួរស្រូវ នៅលើក្ដារខៀន ។ សូមពន្យល់ថា ស្រូវ ដូចជាស្រូវសាឡី វាប្រែពណ៌ពេលវាដុះធំឡើង ។ នៅពេលដើមស្រូវនៅខ្ចី វាមានពណ៌បៃតង ប៉ុន្តែពេលវាធំឡើងវានឹងប្រែទៅជាពណ៌លឿងព្រលែត ។ នៅពេលស្រូវវាទុំល្មមច្រូតកាត់ ជាញឹកញាប់ វាត្រូវបានពិពណ៌នាថាជា « ពណ៌លឿងទុំ » ។

សូមសរសេរពាក្យដូចខាងក្រោមនៅលើក្ដារខៀន ៖ *វាលស្រូវ, ចម្រូត, កណ្ដៀវ* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៤ ឲ្យឮៗ ។ មុនពេលគាត់អាន សូមពន្យល់ថា នៅក្នុងខនេះ ព្រះអម្ចាស់ បានប្រៀបប្រដូចមនុស្សក្នុងលោកិយ ទៅនឹងវាលស្រែមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលព្រះអម្ចាស់បានពិពណ៌នាអំពីវាលស្រែ ( ឬមនុស្សក្នុងលោកិយ ) ។

- តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ អំពីវាលស្រែរបស់ទ្រង់ ( ឬមនុស្សក្នុងលោកិយ ) ?
- តើអ្នកគិតថាឃ្លា « ស្រែសស្កុះព្រះល្មមច្រូតហើយ » មានន័យយ៉ាងណា ? ( មនុស្សក្នុងលោកិយ ត្រូវបានរៀបចំដើម្បីប្រមូលទៅកាន់ព្រះ និងសាសនាចក្ររបស់ទ្រង់ ) ។

សូមសួរបើសិនជាមាននរណាម្នាក់អាចពន្យល់អំពីកណ្ដៀវថាជាអ្វី ហើយគេប្រើវាដើម្បីធ្វើអ្វី ។ ( កណ្ដៀវ គឺជាកាំបិតមុខកោង ហើយប្រើសម្រាប់ច្រូតស្រូវ ។ អ្នកអាចនឹងចង់ គូររូបកណ្ដៀវសាមញ្ញមួយនៅលើក្ដារខៀន ) ។

- តើអ្នកគិតថា ការច្រូតកាត់នឹងកណ្ដៀវដោយអស់ពីកម្លាំងរបស់ខ្លួននោះ វាមានន័យយ៉ាងណា ? ( ធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីនាំអ្នកដទៃមកកាន់ព្រះយេស៊ូវគ្រីស្ទ ) ។
- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៤ តើពរជ័យអ្វីខ្លះនឹងកើតមានចំពោះអ្នកទាំងឡាយដែលធ្វើការដោយឧស្សាហ៍ព្យាយាម ដើម្បីនាំអ្នកដទៃមកកាន់ព្រះយេស៊ូវគ្រីស្ទ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់អំពីសេចក្ដីពិតដូចខាងក្រោម ៖ **នៅពេលយើងធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីនាំអ្នកដទៃមកកាន់ព្រះយេស៊ូវគ្រីស្ទ នោះយើងក៏អាចទទួលបានសេចក្ដីសង្គ្រោះសម្រាប់ខ្លួនយើងផងដែរ** ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។
- តើការជួយអ្នកដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទ ក៏ដូចជាជួយយើងឲ្យមកកាន់ទ្រង់ផងដែរ បានយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សពង្រឹងទីបន្ទាល់របស់ពួកគេអំពីគោលការណ៍នេះ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្ដល់ជាឧទាហរណ៍ អំពីរបៀបដែលពួកគេមានអារម្មណ៍កាន់តែជិតស្និទជាមួយនឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេបានធ្វើការជួយដល់អ្នកដទៃឲ្យមកកាន់តែជិតទ្រង់នោះ ។ អ្នកក៏អាចចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន ឬសាក្សីរបស់អ្នកអំពីគោលការណ៍នេះផងដែរ ។





***ការចែកចាយពីការយល់ដឹង***

នៅពេលសិស្សចែកចាយពីការយល់ដឹង និងបទពិសោធន៍ដូចគ្នា នោះពួកគេអាចពង្រឹងដល់ទីបន្ទាល់ និងការយល់ដឹងរបស់ពួកគេអំពីសេចក្ដីពិតនៃដំណឹងល្អ ។ នៅពេលពួកគេចែកចាយ នោះព្រះវិញ្ញាណបរិសុទ្ធដឹកនាំពួកគេឲ្យមានការអះអាងកាន់តែជ្រាលជ្រៅអំពីសេចក្ដីពិតដែលពួកគេកំពុងតែថ្លែងទីបន្ទាល់ ។ ទាំងគ្រូបង្រៀន និងសិស្សគួរតែមានឱកាសដើម្បីចែកចាយការយល់ដឹងរបស់ខ្លួន ទាក់ទងនឹងគោលលទ្ធិ និងគោលការណ៍ដំណឹងល្អ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៥–៧

*ព្រះអម្ចាស់ បានចែងពីគុណសម្បត្តិ និងលក្ខណៈសម្បត្តិគន្លឹះសម្រាប់ការបម្រើទ្រង់ ។*

សូមឲ្យសិស្សប្រាប់អំពីមុខរបរមួយចំនួន ។ សូមជ្រើសរើសមុខរបរមួយ ឬពីរ ដែលពួកគេបានប្រាប់ ហើយសុំពួកគេឲ្យប្រាប់ពីគុណសម្បត្តិ និងលក្ខណៈសម្បត្តិចាំបាច់ ដែលមនុស្សម្នាក់ចាំបាច់ត្រូវមានដើម្បីទទួលបានជោគជ័យនៅក្នុងមុខរបរនោះ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៥ ដោយស្ងាត់ស្ងៀម រកមើលលក្ខណៈសម្បត្តិដែលមនុស្សម្នាក់មានដើម្បីជួយនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ ( អ្នកអាចអញ្ជើញឲ្យសិស្សម្នាក់សរសេរលក្ខណៈសម្បត្តិទាំងនេះ នៅលើក្ដារខៀន នៅពេលសិស្សក្នុងថ្នាក់បានឆ្លើយ ) ។ អ្នកក៏អាចឲ្យយោបល់ដល់សិស្សគូសចំណាំវានៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៦ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម កត់ចំណាំលក្ខណៈសម្បត្តិបន្ថែម ដែលព្រះអម្ចាស់បានផ្ដល់ការប្រឹក្សាឲ្យអ្នកបម្រើរបស់ទ្រង់ « ចងចាំ » ។ ( អ្នកអាចសុំឲ្យសិស្សម្នាក់សរសេរលក្ខណៈសម្បត្តិទាំងនេះនៅលើក្ដារខៀន នៅជិតនឹងលក្ខណៈសម្បត្តិដែលដកស្រង់ចេញពី ខ ៥ ) ។

សូមឲ្យសិស្សរកមើលសេចក្ដីពិតពី ខទី ៥–៦ ថាតើមានលក្ខណៈសម្បត្តិដ៏ទេវភាពអ្វីខ្លះដែលអនុញ្ញាតឲ្យយើងអភិវឌ្ឍ ។ សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញសេចក្ដីពិតដូចតទៅនេះ ៖ **ការខិតខំរបស់យើងដើម្បីអភិវឌ្ឍលក្ខណៈសម្បត្តិដ៏ទេវភាពនឹងជួយយើងឲ្យមានគុណសម្បត្តិជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។** ( អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។ អ្នកក៏អាចឲ្យយោបល់ដល់សិស្សឲ្យសរសេរវានៅក្នុងបទគម្ពីររបស់ពួកគេ ជិតនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៥–៦ ផងដែរ ។

- តើការអភិវឌ្ឍលក្ខណៈសម្បត្តិនីមួយៗ នៅក្នុង ខ ៥–៦ ជួយយើងកាន់តែមានប្រសិទ្ធភាពក្នុងការជួយដល់កិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- តើលក្ខណៈសម្បត្តិណាមួយ ដែលសរសេរនៅក្នុងខទាំងនេះ ដែលអ្នកចង់អភិវឌ្ឍវាឲ្យបានកាន់តែពេញលេញ ? ហេតុអ្វី ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៧ ឲ្យឮៗ ខណៈដែលសិស្សក្នុងថ្នាក់ស្វែងរករបៀបដែលយើងអាចព្យាយាមធ្វើតាម និងអភិវឌ្ឍលក្ខណៈសម្បត្តិទាំងនេះ ។

- តើពាក្យ « សុំ » និង « គោះ » មានន័យយ៉ាងណា ?
- តើអ្នកគិតថា ការអធិស្ឋានអាចជួយយើងឲ្យអភិវឌ្ឍលក្ខណៈសម្បត្តិដ៏ទេវភាពបានយ៉ាងដូចម្ដេច ?

ដើម្បីបញ្ចប់មេរៀន អ្នកអាចអញ្ជើញសិស្សឲ្យថ្លែងទីបន្ទាល់អំពី ពរជ័យទាំងឡាយដែលពួកគេបានទទួល នៅពេលពួកគេបានជួយនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។

មេរៀនទី១៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥

## បុព្វកថា

ទោះជាម៉ាទីន ហារិស បានធ្វើឲ្យបាត់ឯកសារសរសេរដោយដៃចំនួន១១៦ ទំព័រក្ដី ក៏អំឡុងពេលនៃរដូវក្ដៅ នៃឆ្នាំ១៨២៨ លោកបានបន្ដចង់ជួយនៅក្នុងការនាំចេញមកនៃព្រះគម្ពីរមរមនដែរ ។ នៅខែមិនា ឆ្នាំ១៨២៩ ម៉ាទីន បានធ្វើដំណើរពីផ្ទះរបស់លោក នៅរដ្ឋនូវយ៉ោក ដើម្បីសួរសុខទុក្ខយ៉ូសែប និងអិមម៉ា ស្ម៊ីធ នៅភូមិហាម៉ូនី រដ្ឋផេនសិលវេញ៉ា ។ ខណៈដែលនៅទីនោះ ម៉ាទីន បានស្នើសុំធ្វើជាសាក្សីម្នាក់ថា យ៉ូសែប មានផ្ទាំងចំណារមាស ។ យ៉ូសែប ស្ម៊ីធ បានទូលសួរទៅព្រះអម្ចាស់ ហើយបានទទួលវិវរណៈ ដែលឥឡូវនេះត្រូវបានគេស្គាល់ថាជា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ បានប្រកាសថា សាក្សីបីនាក់ នឹងត្រូវបានហៅឲ្យថ្លែងទីបន្ទាល់អំពីព្រះគម្ពីរមរមន ហើយបានប្រាប់ដល់ម៉ាទីន អំពីអ្វី ដែលគាត់ត្រូវធ្វើ ដើម្បីសមនឹងក្លាយជាសាក្សីម្នាក់នៃសាក្សីទាំងនេះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១–២២

*ព្រះអម្ចាស់នឹងនាំព្រះបន្ទូលរបស់ទ្រង់ចេញមកនៅថ្ងៃចុងក្រោយ ហើយសាក្សីទាំងឡាយ នឹងថ្លែងទីបន្ទាល់*

សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរខាងក្រោមនេះ ៖

- តើមានអ្វីមួយ ដែលអ្នកបានគ្រាន់តែឮអំពីវា ប៉ុន្ដែចង់មើលឃើញដោយផ្ទាល់ភ្នែកឬទេ ? ហេតុអ្វីអ្នកចង់មើលឃើញផ្ទាល់ភ្នែក ?

បន្ទាប់ពីសិស្សពីរបីនាក់បានឆ្លើយរួច សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលម៉ាទីន ហារិស ចង់មើលឃើញដោយខ្លួនគាត់ ។ បន្ទាប់ពីសិស្សបានប្រាប់នូវអ្វីដែលម៉ាទីន ចង់មើលឃើញហើយ នោះអ្នកអាចនឹងសួរពួកគេ ប្រសិនបើពួកគេចង់មើលឃើញផ្ទាំងចំណារមាសឬទេ ។ សូមឲ្យសិស្សម្នាក់ ឬ ពីរនាក់ ពន្យល់អំពីចម្លើយរបស់ពួកគេ ។

ដើម្បីជួយសិស្សយល់ពីមូលហេតុដែល ម៉ាទីន ស្វែងរកសាក្សីបន្ថែមអំពីផ្ទាំងចំណារដែលមាននោះ សូមពន្យល់ថា នៅខែមិនា ឆ្នាំ១៨២៩ ម៉ាទីន បានរៀបចំធ្វើដំណើរពីផ្ទះរបស់គាត់នៅរដ្ឋនូវយ៉ោក ទៅសួរសុខទុក្ខយ៉ូសែប និង អិមម៉ា ស្ម៊ីធ នៅភូមិហាម៉ូនី រដ្ឋផេនសិលវេញ៉ា ។ ទោះជាយ៉ាងណាក៏ដោយ ភរិយារបស់គាត់ លូស៊ី ហារិស ពុំសប្បាយចិត្តចំពោះពេលវេលា និងប្រាក់កាសដែលប្ដីរបស់គាត់ បានផ្ដល់សម្រាប់ការបោះពុម្ពព្រះគម្ពីរមរមនទេ ។ គាត់ខឹងនឹងយ៉ូសែប ស្ម៊ីធ ដែលបានបដិសេធនឹងសំណើរពីខាងដើមរបស់គាត់ដើម្បីមើលផ្ទាំងចំណារមាសផងដែរ ។ គាត់បានធ្វើសំណុំឯកសារច្បាប់ប្ដឹងទាស់នឹងយ៉ូសែប ហើយបានប្រមូលមនុស្សមួយក្រុមដែលស្ម័គ្រចិត្តធ្វើទីបន្ទាល់ថា លោកកុហកអំពីរឿងផ្ទាំងចំណារ ។ បន្ថែមពីលើការគំរាមគំហែងប្ដឹងទាស់នឹងយ៉ូសែប មនុស្សទាំងនោះ បានព្រមានម៉ាទីនថា បើគាត់ពុំចូលរួមនឹងពួកគេធ្វើទីបន្ទាល់សង្ស័យអំពីការបោកបញ្ឆោត និងការក្លែងបន្លំរបស់យ៉ូសែប ស្ម៊ីធ ទេនោះម៉ាទីននឹងជាប់ទោសជាមួយយ៉ូសែប ហើយនឹងត្រូវជាប់គុគជាមួយយ៉ូសែបដែរ ។ ស្របនឹងពេលនោះម៉ាទីន ពុំធ្លាប់ឃើញផ្ទាំងចំណារមាសផ្ទាល់ផង ទោះជាគាត់បានធ្វើជាអ្នកសរសេរឲ្យយ៉ូសែបក្ដី ។ បន្ទាប់ពីបានធ្វើដំណើរទៅដល់ផ្ទះរបស់យ៉ូសែប ម៉ាទីន បានបង្ហាញពីបំណងរបស់គាត់ដើម្បីទទួលបានសាក្សីបន្ថែមមួយអំពីភាពពិតប្រាកដនៃផ្ទាំងចំណារមាស ។ គាត់អាចនឹងជឿថា បើគាត់អាចមើលឃើញផ្ទាំងចំណារផ្ទាល់ នោះ គាត់នឹងត្រៀមខ្លួនដើម្បីថ្លែងទីបន្ទាល់នៅក្នុងតុលាការអំពីវត្តមានរបស់ផ្ទាំងចំណារ ហើយស្រាយបំភ្លឺកេរ្ដិ៍ឈ្មោះរបស់គាត់ និងយ៉ូសែប ស្ម៊ីធ ដែលឥតជាប់ជំពាក់នឹងការបោកបញ្ឆោតអ្វីនោះទេ ។ បន្ទាប់ពីយ៉ូសែប បានស្ដាប់ចំពោះសំណើររបស់ម៉ាទីន ដើម្បីឃើញផ្ទាំងចំណារនោះលោកបានទូលសូមព្រះអម្ចាស់ ហើយបានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះអម្ចាស់ បានប្រាប់យ៉ូសែប ស្ម៊ីធ ឲ្យតបនឹងសំណើររបស់ម៉ាទីន ហារិស ។

- តើព្រះអម្ចាស់បានប្រាប់យ៉ូសែប ឆ្លើយតបនឹងម៉ាទីន យ៉ាងដូចម្ដេច ?

- ហេតុអ្វីក៏យ៉ូសែប ស្ម៊ីធ ពុំអាចបង្ហាញផ្ទាំងចំណារដល់ ម៉ាទីន ហារិស ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីមូលហេតុដែលព្រះអម្ចាស់ ពុំអនុញ្ញាតឲ្យបង្ហាញផ្ទាំងចំណារមាសចំពោះពិភពលោក ។ សូមអញ្ជើញសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយប្រធានយ៉ូសែប ហ្វីលឌិង ស្ម៊ីធ ៖



« ជាញឹកញាប់ នៅពេល [ មនុស្ស ]. . . ស្ដាប់រឿងអំពីការចេញមកនៃព្រះគម្ពីរមរមន នោះពួកគេសួរបើផ្ទាំងចំណារមាននៅក្នុងសារមន្ទីរខ្លះ ដែលអាចឲ្យពួកគេអាចមើលឃើញដែរឬទេ ។ មនុស្សដែលមានការបំពាក់បំប៉នខាងវិទ្យាសាស្ត្រមួយចំនួន [ ស្មាន ] ថាបើមានអ្នកប្រាជ្ញអាចមើលឃើញនិងពិសោធន៍ អាន ហើយរៀនពីផ្ទាំងចំណារ នោះពួកគេនឹងថ្លែងទីបន្ទាល់ពីសេចក្ដីពិត និងសច្ចៈសីលភាពរបស់យ៉ូសែប ស្ម៊ីធ ហើយពិភពលោកទាំងមូលនឹងបានផ្លាស់ប្រែចិត្តជឿ » ( *Church History and Modern Revelation, 2 vols.* [១៩៥៣ ],១:៤០ ) ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមអញ្ជើញដៃគូនីមួយៗ ផ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:៥–១០ ឲ្យឮៗ រកមើលមូលហេតុដែលព្រះអម្ចាស់បានប្រាប់យ៉ូសែប ស្ម៊ីធ កុំឲ្យបង្ហាញផ្ទាំងចំណារដល់លោកិយ ។

- តើព្រះអម្ចាស់មានហេតុផលអ្វី ដែលយ៉ូសែប ស្ម៊ីធ ពុំគួរបង្ហាញផ្ទាំងចំណារដល់លោកិយនោះ ? ( បើមនុស្សមិនជឿព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលបានបើកសម្ដែងតាមរយៈយ៉ូសែប ស្ម៊ីធ នោះពួកគេនឹងមិនជឿ ទោះជាពួកគេបានឃើញផ្ទាំងចំណារក្ដី [ សូមមើល គ. និង ស. ៥:៧ ]; ព្រះអម្ចាស់ រក្សាផ្ទាំងចំណារកុំឲ្យពិភពលោកឃើញសម្រាប់គោលបំណងដ៏ឈ្លាសវៃ [ សូមមើល គ. និង ស. ៥:៩ ] ) ។

- តើអ្នករៀនអ្វីខ្លះមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១០ អំពីការហៅជាពិសេសរបស់យ៉ូសែប ស្ម៊ីធ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់សេចក្ដីពិតដូចខាងក្រោម ៖ **ព្រះអម្ចាស់ បានហៅយ៉ូសែប ស្ម៊ីធ ឲ្យនាំព្រះបន្ទូលទ្រង់ទៅកាន់ពិភពលោក ។** អ្នកអាចឲ្យយោបល់សិស្សឲ្យសរសេរសេចក្ដីពិតនេះ នៅក្នុងគម្ពីររបស់ពួកគេនៅជិតនឹងគោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១០ ) ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់សម្រាប់យើងដើម្បីមានទីបន្ទាល់អំពីសេចក្ដីពិតនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់មានបន្ទូលថា ទ្រង់នឹងធ្វើដើម្បីគាំទ្រដល់ទីបន្ទាល់របស់យ៉ូសែប ស្ម៊ីធ អំពីព្រះគម្ពីរមរមន ។ បន្ទាប់ពីសិស្សរាយការណ៍នូវអ្វីដែលពួកគេបានរៀន សូមសរសេរសេចក្ដីពិតនៅលើក្ដារខៀន ៖ **ទីបន្ទាល់នៃពួកសាក្សីបីនាក់ នឹងឈរជាភស្ដុតាងអំពីសេចក្ដីពិតពេញលេញនៃព្រះគម្ពីរមរមន ។**

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១១–១៥ ដោយស្ងៀមស្ងាត់ រកមើលនូវអ្វីដែលពួកសាក្សីបីនាក់នឹងស្ដាប់ឮ មើលឃើញ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- តើវាជាប្រយោជន៍យ៉ាងដូចម្ដេច ដើម្បីដឹងថា បន្ថែមពីលើ យ៉ូសែប ស្ម៊ីធ ព្រះអម្ចាស់បានហៅសាក្សីបីនាក់ ដែលបានឃើញផ្ទាំងចំណារហើយបានស្ដាប់ឮព្រះអម្ចាស់ប្រកាសពីសេចក្ដីពិតពេញលេញនោះ ?

សូមពន្យល់ថា បន្ថែមពីលើការដឹកនាំយ៉ូសែប ស្ម៊ីធ និងសាក្សីបីនាក់ឲ្យថ្លែងទីបន្ទាល់ នោះព្រះអម្ចាស់បានផ្ដល់មធ្យោបាយផ្សេងទៀត ដែលយើងអាចដឹងពីសេចក្ដីពិតពេញលេញនៃព្រះគម្ពីរមរមន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១៦–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានសន្យានឹងអ្នកទាំងឡាយដែលជឿទៅលើព្រះគម្ពីរមរមន ។

- តើព្រះអម្ចាស់មានបន្ទូលថា ទ្រង់នឹងបញ្ជូនអ្វីខ្លះ មកដល់ពួកអ្នកទាំងឡាយដែលជឿតាមព្រះបន្ទូលទ្រង់នោះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់ពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងនឹងជឿលើព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះទ្រង់នឹងបញ្ជាក់ពីសេចក្ដីពិតតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ )** ។

ដើម្បីជួយដល់សិស្សក្នុងថ្នាក់មើលឃើញពីរបៀបដែលពួកគេអាចអនុវត្តសេចក្ដីពិតដែលបានបង្ហាញនៅខាងលើ សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធានអែសរ៉ា ថាហ្វ បែនសឹន ។ សូមឲ្យសិស្សស្ដាប់អ្វីដែលយើងគួរធ្វើ ពេលយើងបានទទួលទីបន្ទាល់មួយអំពីព្រះគម្ពីរមរមន ។



« យើងម្នាក់ៗត្រូវការមានទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើង អំពីព្រះគម្ពីរមរមន តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ បន្ទាប់មកទីបន្ទាល់របស់យើង ផ្ដួបជាមួយនឹងព្រះគម្ពីរមរមន គួរតែចែកចាយជាមួយនឹងអ្នកដទៃដើម្បីពួកគេអាចដឹងតាមរយៈព្រះវិញ្ញាណបរិសុទ្ធផងដែរអំពីសេចក្ដីពិតពេញលេញរបស់វា » ( The Book of Mormon and the Doctrine and Covenants, » *Ensign* ខែ ឧសភា ឆ្នាំ១៩៨៧, ទំព័រ ៨៤ ) ។

សូមឲ្យពេលដល់សិស្សពីរបីនាទីដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរមរមន (១) ទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេអំពីព្រះគម្ពីរមរមន ឬ (២) អ្វីដែលពួកគេអាចធ្វើ ដើម្បីទទួលបាន ឬពង្រឹងភាពជាសាក្សីរបស់ពួកគេ ថាព្រះគម្ពីរមរមនពិត ។ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេបានសរសេរជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២១–២២ ឲ្យឮៗ ដោយដាក់ជំនួសឈ្មោះ « យ៉ូសែប » ជាឈ្មោះផ្ទាល់របស់ពួកគេ ។ សូមឲ្យសិស្សទន្ទេញចាំនូវអ្វីដែលព្រះអម្ចាស់កំពុងបង្រៀននៅក្នុងគម្ពីរទាំងនេះ ។

- តើមនុស្សម្នាក់ អាចចៀសវាងពីការស្ដាប់តាម« ការបញ្ចុះបញ្ចូលរបស់មនុស្ស » ដោយរបៀបណា ?
- តើព្រះអម្ចាស់បានសន្យាដល់យ៉ូសែប ស្ម៊ីធ ថា លោកនឹងទទួលបានអ្វីបើលោកស្មោះត្រង់– ទោះបីជាលោក ត្រូវគេ « សម្លាប់ » ក៏ដោយនោះ ? ( ជីវិតដ៏នៅអស់កល្បជានិច្ច ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៣–៣៥

*ម៉ាទីន ហារិស អាចត្រូវបានហៅជាសាក្សីម្នាក់នៃសាក្សីទាំងបីនាក់ បើគាត់ប្រែចិត្ត*

បើអាចធ្វើទៅបាន សូមបង្ហាញសិស្សនូវអំពូលភ្លើងមួយ ( ឬគូររូបអំពូលភ្លើងនៅលើក្ដារខៀន ) ។ សូមសួរថាយើងត្រូវធ្វើអ្វីខ្លះដើម្បីធ្វើឲ្យអំពូលភ្លើងភ្លឺ ។ បន្ទាប់មកដាក់អំពូលភ្លើងក្នុងចង្កៀងភ្លើង ។ ដោតភ្លើងរួចចុចកុងតាក់បើក ។ សូមពន្យល់ថា វាក៏ដូចជាជំហានមួយចំនួនដើម្បីបើកភ្លើងឲ្យអំពូលភ្លើងភ្លឺដែរ ម៉ាទីន ហារិស បានដឹងថា នឹងមានជំហានមួយចំនួនដើម្បីទទួលសាក្សីអំពីផ្ទាំងចំណារ ដែលលោកមានបំណងប្រាថ្នាចង់បានពីព្រះអម្ចាស់ ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៣–២៤ ដោយស្ងៀមស្ងាត់ រកមើលការសន្យាបន្ថែមដែលព្រះអម្ចាស់បានប្រទានដល់ម៉ាទីន ហារិស ដោយប្រើពាក្យ *បើ* និងពាក្យ *ខណៈនោះ* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរអ្វីដែលពួកគេរកឃើញនៅលើក្ដារខៀន ។ សិស្សអាចសរសេរអ្វីដូចជា « បើម៉ាទីន ហារិស នឹងអធិស្ឋានដោយរាបសារ សេចក្ដីជំនឿ និងដោយស្មោះត្រង់ ខណៈនោះ ព្រះអម្ចាស់នឹងប្រទានឲ្យគាត់មើលផ្ទាំងចំណារ ដូចដែលគាត់ប្រាថ្នាចង់មើលហើយ » ។ សូមចង្អុលបង្ហាញថា តាមរយៈការសន្យានេះ ព្រះអម្ចាស់ បានផ្ដល់ឱកាសដល់ ម៉ាទីន ហារិស ដើម្បីធ្វើជាសាក្សីម្នាក់អំពីព្រះគម្ពីរមរមន ។

- តើអ្នកគិតថា ការអធិស្ឋានដោយរាបសារ សេចក្ដីជំនឿ និងដោយស្មោះត្រង់ មានន័យយ៉ាងណា ?

ដើម្បីជួយសិស្សស្គាល់សេចក្ដីពិតមួយ ចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៤ សូមឲ្យពួកគេឡើងវិញនូវសេចក្ដីថ្លែងការ « បើ–ខណៈនោះ » នៅលើក្ដារខៀន តាមរបៀបមួយដែលអាចអនុវត្តចំពោះ យើងទាំងអស់គ្នា ។ សិស្សគួរតែបង្ហាញអ្វីមួយដែលស្រដៀងគ្នាទៅនឹងសេចក្ដីពិតដូចខាងក្រោម ៖ **បើយើងអធិស្ឋានដោយស្មោះដោយរាបសារ និងសេចក្ដីជំនឿ ខណៈនោះយើងអាចទទួលបានចម្លើយស្របតាមបំណងប្រាថ្នាសុចរិតរបស់យើង ។**

- តើអ្នកគិតថា ការអធិស្ឋានដោយរាបសារ សេចក្ដីជំនឿ និងដោយស្មោះត្រង់ អាចរៀបចំយើងទទួលចម្លើយមកពីព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- តើនៅពេលណា ដែលអ្នកស្ដាប់ ឬផ្ដល់ការអធិស្ឋានមួយ ដែលអ្នកមានអារម្មណ៍ថា ត្រូវបានផ្ដល់ឲ្យដោយភាពរាបសារ សេចក្ដីជំនឿ និងដោយស្មោះត្រង់នោះ ? តើអ្វីដែលធ្វើឲ្យការអធិស្ឋាននេះ ខុសពីការអធិស្ឋានផ្សេងទៀត ដែលអ្នកបានស្ដាប់ឮ ឬផ្ដល់ការអធិស្ឋាននោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៥–២៦ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលនូវអ្វីដែលព្រះអម្ចាស់ បានរំពឹងឲ្យម៉ាទីន ហារិស ធ្វើបន្ទាប់ពីការក្លាយជាសាក្សីម្នាក់ចំពោះព្រះគម្ពីរមរមន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៧–២៨, ៣២ ដោយស្ងៀមស្ងាត់ រកមើលការប្រឹក្សានិងការព្រមានបន្ថែមដែលព្រះអម្ចាស់បានប្រទានដល់ម៉ាទីន ហារិស ។

### *ការស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយ*

នៅពេលអ្នកជួយសិស្សឲ្យដឹងពីរបៀបស្គាល់គោលលទ្ធិ និង គោលការណ៍នៅក្នុងព្រះគម្ពីរ ពួកគេនឹងអាចសិក្សាព្រះគម្ពីរមានប្រសិទ្ធភាពជាងនេះដោយខ្លួនឯង ។ សូមបង្រៀនសិស្សឲ្យរកមើលឃ្លាដូចជា « ម្លោះហើយយើងឃើញ » « ហេតុដូច្នេះហើយ » « ហេតុដូច្នេះហើយ » « ដ្បិតមើលចុះ » ឬ « ប្រសិនបើ . . . នោះ . . . » ដែលជាញឹកញាប់ វាបង្ហាញពីគោលការណ៍ ឬ សេចក្ដីថ្លែងការនៃគោលលទ្ធិ ។

- តើព្រះអម្ចាស់ប្រឹក្សា និងព្រមានអ្វីខ្លះ ដល់ម៉ាទីន ហារិសឲ្យធ្វើ ?
- តើព្រះអម្ចាស់ មានបន្ទូលថាអ្វីខ្លះ នឹងកើតឡើងចំពោះ ម៉ាទីន ហារិស បើគាត់ពុំបន្ទាបខ្លួន និង « ទទួលសាក្សីមួយ » ( គ. និង ស. ៥:៣២) មកពីព្រះអម្ចាស់ទេនោះ ?
- តើយើងអាចប្រៀបធៀបការប្រឹក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:៣២ ទៅនឹងខ្លួនយើងយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យកត់ត្រានៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរនូវរាល់អារម្មណ៍ដែលកើតមានដល់ពួកគេ អំឡុងមេរៀននាថ្ងៃនេះ ។ អ្នកអាចនឹងលើកទឹកចិត្តពួកគេឲ្យផ្ដោតទៅលើការផ្លាស់ប្ដូរជាក់លាក់ ដែលពួកគេទទួលអារម្មណ៍ថា ពួកគេចាំបាច់ត្រូវធ្វើការផ្លាស់ប្ដូរ ដើម្បីអធិស្ឋានឲ្យកាន់តែរាបសារ ដោយសេចក្ដីជំនឿ និងកាន់តែស្មោះ ដើម្បីពួកគេអាចទទួលបានចម្លើយមកពីព្រះអម្ចាស់កាន់តែល្អប្រសើរ ។

មេរៀនទី១៥

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧

### បុព្វកថា

នៅដើមនិទារឃរដូវ ឆ្នាំ១៨២៩ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលអារម្មណ៍ជម្រុញមួយយ៉ាងខ្លាំងអំពីការបកប្រែនៃព្រះគម្ពីរមរមន ។ លោកបានឃើញថាពេលវេលារបស់លោកដើម្បីធ្វើការបកប្រែគឺមានពេលកំណត់យ៉ាងខ្លាំង ដោយសារលោកចាំបាច់ត្រូវធ្វើការដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់លោក ។ បងប្រុសរបស់អិមម៉ា និង យ៉ូសែប ឈ្មោះ សាំយូអែល បានជួយធ្វើជាស្មៀនប៉ុន្តែពួកគេពុំអាចសរសេរឲ្យលោកពេញម៉ោងទេ ។ យ៉ូសែបបានមានផ្ទាំងចំណារអស់រយៈពេលច្រើនជាងមួយឆ្នាំកន្លះ ព្រមជាមួយនឹងការបាត់ឯកសារសរសេរដោយដៃចំនួន ១១៦ ទំព័រ នោះលោកមានតែពីរបីទំព័រប៉ុណ្ណោះនៃឯកសារដែលបានបកប្រែហើយនោះ ។ យ៉ូសែបបានអធិស្ឋានទូលសូមព្រះអម្ចាស់ឲ្យបញ្ជូននរណាម្នាក់ដែលអាចជួយលោកនៅក្នុងកិច្ចការបកប្រែ ។ ក្នុងការឆ្លើយតបចំពោះការអធិស្ឋានរបស់យ៉ូសែប នោះព្រះអម្ចាស់បានបញ្ជូនអូលីវើរ ខៅឌើរី ឲ្យមកធ្វើជាស្មៀន ។

វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦ និង ៧ ត្រូវបានផ្ដល់ឲ្យមិនយូរប៉ុន្មានបន្ទាប់ពីការមកដល់របស់ អូលីវើរ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦ មាននូវការប្រឹក្សាដល់អូលីវើរ ស្ដីអំពីតួនាទីរបស់លោក នៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧ មាននូវកំណែថ្មីនៃការសរសេរមួយចំនួនដែលបានបកប្រែរួចដោយ យ៉ូហាន ដែលបង្រៀនថា ព្រះអម្ចាស់ បានប្រទានតាមបំណងរបស់ យ៉ូហាន ជាសិស្សដ៏ជាទីស្រឡាញ់ដែលចង់នៅរស់ និងនាំព្រលឹងជាច្រើនមកកាន់ព្រះយេស៊ូវគ្រីស្ទ រហូតដល់ការយាងមកជាលើកទីពីរ ។

## យោបល់សម្រាប់ការបង្រៀន

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:១–៩ ។

*អូលីវើរ ខៅឌើរី បានក្លាយជាស្មៀនរបស់ យ៉ូសែប ស្ម៊ីធ*

សូមគូររូប អំពូលភ្លើង និង ព្រះអាទិត្យរះ នៅលើក្ដារខៀន ។




- តើការបើកអំពូលភ្លើងឲ្យភ្លឺ ខុសគ្នាពីការមើលព្រះអាទិត្យរះយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងផ្ដល់យោបល់ផ្សេង ៗគ្នាជាច្រើន ប៉ុន្តែសូមចង្អុលបង្ហាញថា មួយ អ្នកមើលឃើញពន្លឺភ្លាម ៗ ហើយមួយទៀត អ្នកមើលឃើញវាបន្តិចម្ដង ៗ ) ។

សូមពន្យល់ថា អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានប្រើភាពស្រដៀងគ្នាដើម្បីបង្រៀនអំពីវិវរណៈផ្ទាល់ខ្លួន ។ លោកបានបង្រៀនថា ពេលខ្លះវិវរណៈកើតឡើង « ភ្លាម ៗ ទាំងស្រុង និងតែម្ដងក្នុងពេលតែមួយ [ ដូចជាការបើកភ្លើងនៅក្នុងបន្ទប់ងងឹតដូច្នោះដែរ ] ។ . . .[ ប៉ុន្តែ ] ជាញឹកញាប់បំផុត វិវរណៈកើតមានមកច្រើនឡើង ៗតាមពេលវេលា » ( The Spirit of Revelation, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១,ទំព័រ ៨៨ ) ។ សូមអញ្ជើញសិស្ស

ឲ្យពិចារណាអំពីគ្រានានាដែលព្រះអម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់ពួកគេភ្លាមៗ និងគ្រាដែលទ្រង់បានឆ្លើយដោយសន្សឹមៗ ។ នៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦ នៅថ្ងៃនេះ សូមលើកទឹកចិត្តពួកគេឲ្យរកមើលសេចក្ដីពិតដែលនឹងជួយពួកគេឲ្យស្គាល់ថា ពេលណាព្រះកំពុងប្រទានវិវរណៈដល់ពួកគេ ។

ដើម្បីជួយសិស្សយល់អំពីបរិបទជាប្រវត្តិសាស្ត្រសម្រាប់វិវរណៈនេះ សូមអញ្ជើញសិស្សឲ្យអានឮៗនូវកថាកណ្ឌទីមួយនៃបុព្វកថាមេរៀននេះ ។ បន្ទាប់មកអញ្ជើញសិស្សទាំងអស់ឲ្យអាន យ៉ូសែប ស្ម៊ីធ –ប្រវត្តិ១:៦៦–៦៧ ដោយស្ងៀមស្ងាត់ ហើយប្រាប់ពីរបៀបដែលព្រះវរបិតាសួគ៌ បានជួយយ៉ូសែប នៅក្នុងកិច្ចខិតខំរបស់លោកដើម្បីបកប្រែកាន់តែឆាប់ដោយរបៀបណា ។

- តើព្រះអម្ចាស់បានធ្វើអ្វីខ្លះ នៅក្នុងការឆ្លើយតបចំពោះការទូលអង្វររបស់ យ៉ូសែប សូមមនុស្សម្នាក់មកជួយដល់ការបកប្រែរបស់លោកនោះ ?

បន្ទាប់ពីសិស្សរាយការណ៍នូវអ្វីដែលពួកគេបានរកឃើញ សូមពន្យល់ថា អូលីវើរ ខៅឌើរី បានមកពី ប៉ាលម៉ៃរ៉ា រដ្ឋ នូវ យ៉ោក មានចម្ងាយជាង ២២៥ គីឡូម៉ែត្រ ដើម្បីមកជួបនឹងយ៉ូសែប នៅភូមិ ហាម៉ូនី រដ្ឋ ផែនសិលវេញ៉ា ( សូមមើល ផែនទីប្រវត្តិសាស្ត្រសាសនាចក្រ ផែនទី ទី១ « សហរដ្ឋប៉ែកឦសាន » ) ហើយថាលោកបានមកដល់នៅពីរបីថ្ងៃក្រោយពេល យ៉ូសែប បានអធិស្ឋានសុំជំនួយ ។

សូមពន្យល់ថា នៅមិនយូរប៉ុន្មានបន្ទាប់ពី អូលីវើរបានធ្វើជាស្មៀនរបស់យ៉ូសែប នោះយ៉ូសែប បានទទួលវិវរណៈមួយដែលព្រះអម្ចាស់មានបន្ទូលទៅអូលីវើរ ។ វិវរណៈនេះបានថ្លែងពីបំណងរបស់អូលីវើរ ហើយជាក់ស្ដែងបានឆ្លើយសំណួរ ដែលគាត់បានអធិស្ឋានប៉ុន្តែពុំបានបង្ហាញប្រាប់ដល់យ៉ូសែប ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៥–៦, ៨ ដោយស្ងៀមស្ងាត់ ហើយរកមើលការបង្ហាញដែលព្រះអម្ចាស់ បានដឹងពីបំណងប្រាថ្នារបស់អូលីវើរ ។

- តើខគម្ពីរទាំងនេះ និងកិច្ចកិតខំរបស់អូលីវើរ ដើម្បីធ្វើដំណើរ ២២៥ គីឡូម៉ែត្រមកជួយយ៉ូសែប ស្ម៊ីធ ប្រាប់យើងអំពីអូលីវើរយ៉ាងណាខ្លះ ?

*កំណត់ចំណាំ ៖* ខ១–៩ ត្រូវបានកើតមានម្ដងទៀតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១១ ជាវិវរណៈមួយដែលនិយាយចំៗទៅហៃរ៉ុម ស្ម៊ីធ ហើយនឹងពិភាក្សាបន្ថែមនៅក្នុងមេរៀននោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:១០–២៤

*ព្រះអម្ចាស់ អះអាងដល់អូលីវើរ ខៅឌើរី អំពីសេចក្ដីពិតពេញលេញនៃកិច្ចការនោះ*

សូមឲ្យសិស្សពិចារណាពីសំណួរខាងក្រោម ៖

- តើអ្នកធ្លាប់បានទទួលចម្លើយមួយមកពីព្រះ ហើយក្រោយមកជួបនឹងកង្វល់ ឬការច្របូកច្របល់អំពីចម្លើយនោះឬទេ ? ( សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់គេ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយរបស់អ្នកផ្ទាល់ផងដែរ ។ សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ពុំគួរចែកចាយទេ ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:១០–១៣ ដោយការពន្យល់ថា ព្រះអម្ចាស់ បានប្រាប់ដល់អូលីវើរ ខៅឌើរី ថា អូលីវើរ មានអំណោយទានមួយនៃវិវរណៈ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:១៤–១៧, ២០ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់ បានបង្រៀនដល់អូលីវើរ អំពីការទទួល និងការស្គាល់វិវរណៈ ។

- តើសេចក្ដីពិតអ្វី ដែលព្រះអម្ចាស់បង្រៀនដល់ អូលីវើរ អំពីការទទួល និងការស្គាល់វិវរណៈនោះ ?

សិស្សអាចប្រាប់នូវគោលការណ៍ដូចខាងក្រោម ។ អ្នកអាចសរសេរវានៅលើក្ដារខៀន នៅពេលសិស្សប្រាប់ ។ អ្នកក៏អាចឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំឃ្លា ដែលមានអត្ថន័យចំពោះពួកគេនៅក្នុងខគម្ពីរទាំងនេះផងដែរ ។

**នៅពេលយើងស្វែងរកចម្លើយមកពីព្រះវរបិតាសួគ៌ នោះទ្រង់នឹងប្រទានដល់យើងនូវការណែនាំ ។**

**ព្រះអម្ចាស់ នឹងបំភ្លឺគំនិតរបស់យើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។**

**ព្រះដឹងពីគំនិត និងបំណងនៃដួងចិត្តរបស់យើង ។**

**នៅពេលយើងបានទទួលវិវរណៈ នោះយើងគួរតែរក្សាវាទុកនៅក្នុងដួងចិត្តរបស់យើង ។**

- ហេតុអ្វីក៏វាសំខាន់សម្រាប់យើង ដើម្បីដឹងថា ព្រះអម្ចាស់ស្ដាប់ឮ និងឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ?

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដែលថា ព្រះអម្ចាស់ នឹង « បំភ្លឺ » ដល់គំនិតរបស់យើងនោះ ? ( អ្នកអាចពន្យល់ថាតាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអម្ចាស់ នឹងប្រទានគំនិត និងការយល់ដឹងមកដល់យើង ) ។

- ហេតុអ្វីក៏វាសំខាន់ដើម្បីដឹងថា មានតែព្រះប៉ុណ្ណោះដែលដឹងពីគំនិត និងបំណងប្រាថ្នានៃដួងចិត្តរបស់យើង ?
- តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បី « រក្សា » ព្រះបន្ទូលរបស់ព្រះអម្ចាស់នោះ ? ( ដើម្បីសិក្សា ពិចារណា និងធ្វើនូវរឿងទាំងឡាយដែលព្រះអម្ចាស់បើកសម្ដែង និងមានទំនុកចិត្តទៅលើវិវរណៈដែលយើងបានទទួល ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២១–២៤ ឲ្យឮៗ ហើយសុំសិស្សឲ្យស្វែងរករបៀបផ្សេងទៀតដែលព្រះអម្ចាស់បានទំនាក់ទំនងនឹងយើង ។

- តើយើងអាចរៀនមកពីខទាំងនេះអ្វីខ្លះ អំពីរបៀបផ្សេងទៀតដែលព្រះអម្ចាស់មានបន្ទូលមកកាន់យើងនោះ ? ( **ព្រះអម្ចាស់មានបន្ទូលនូវភាពសុខសាន្តដល់គំនិតយើង ជាសាក្សីមួយអំពីសេចក្ដីពិត ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំឃ្លា « ភាពសុខសាន្តដល់គំនិតរបស់អ្នក » [ គ. និង ស. ៦:២៣ ] ) ។
- ចេញមកពីបទពិសោធន៍របស់អ្នក តើអ្នកមានអារម្មណ៍យ៉ាងណា ដែលព្រះអម្ចាស់មានបន្ទូលពីសេចក្ដីសុខសាន្តកើតមានក្នុងគំនិតយើងនោះ ?

ដើម្បីជួយសិស្សឲ្យកាន់តែយល់អំពីរបៀបដែលវិវរណៈមានមកកាន់ពួកគេ សូមចង្អុលបង្ហាញថា ការទទួលស្គាល់ពេលដែលព្រះអម្ចាស់កំពុងមានបន្ទូលមកកាន់យើង ពេលខ្លះអាចមានការលំបាក សូមពន្យល់ថា អែលឌើរ បេដណា បានប្រាប់ពីភាពស្រដៀងគ្នានៃព្រះអាទិត្យរះទៅដល់កម្រិតមួយទៀត ដើម្បីបញ្ជាក់បន្ថែមឲ្យច្បាស់ អំពីរបៀបទំនាក់ទំនងមកពីព្រះដែលកើតមានជាញឹកញាប់នោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមឲ្យឮៗ ៖



« ពេលខ្លះ ព្រះអាទិត្យរះនៅពេលព្រឹកមួយ ដែលមានពពកច្រើន ឬចុះអ័ព្ទ ។ ដោយសារតែអាកាសធាតុមិនល្អ ការទទួលបានពន្លឺគឺមានភាពលំបាកជាង ហើយការប្រាប់ដោយត្រឹមត្រូវអំពីពេលដែលព្រះអាទិត្យរះលើមេឃ គឺពុំអាចធ្វើទៅបានទេ ។

« ស្រដៀងគ្នានឹងនេះដែរ ភាគច្រើនយើងទទួលបានវិវរណៈដោយពុំបានដឹងពីរបៀប ឬ ពេលវេលាដែលយើងទទួលបានវិវរណៈនោះទេ » ( « The Spirit of Revelation, » ទំព័រ ៨៩ ) ។

- តើពេលខ្លះយើងមើលរំលង ឬបដិសេធចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់យើងយ៉ាងដូចម្ដេច ?
- តើអ្នកនឹងផ្ដល់ឱវាទអ្វីខ្លះ ដល់នរណាម្នាក់ដែលចង់រៀនឲ្យស្គាល់ថា ពេលណាព្រះអម្ចាស់កំពុងមានបន្ទូលទៅកាន់ពួកគេឲ្យបានកាន់តែប្រសើរនោះ ?

សូមពន្យល់ថា វាពុំមានទេ រហូតទាល់តែបន្ទាប់ពីវិវរណៈនេះ ត្រូវបានទទួល ដែលអូលីវើរ បានប្រាប់យ៉ូសែប អំពី « យប់ » ដែលព្រះអម្ចាស់បានសំដៅទៅ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២២ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវអ្វីដែលព្យាការី យ៉ូសែប បានរៀនបន្ទាប់ពីការទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦ ៖



« បន្ទាប់ពីយើងបានទទួលវិវរណៈនេះ អូលីវើរ ខៅឌើរី បានថ្លែងមកកាន់ខ្ញុំថា បន្ទាប់ពីគាត់បានទៅរកឪពុកខ្ញុំដើម្បីរស់នៅក្នុងផ្ទះរបស់គាត់ បន្ទាប់មក គ្រួសារខ្ញុំ បានទំនាក់ទំនងនឹងគាត់អំពីខ្ញុំដែលមានផ្ទាំងចំណារ ហើយនៅយប់មួយបន្ទាប់ពីគាត់ចូលដេកនៅលើគ្រែ គាត់បានអធិស្ឋានទៅព្រះអម្ចាស់ដើម្បីដឹង បើរឿងទាំងនេះ គឺពិតដូច្នោះមែន រួចព្រះអម្ចាស់បានបង្ហាញដល់គាត់ថា វាពិតមែន ប៉ុន្តែគាត់បានទុករឿងនោះជាសម្ងាត់បំផុត ហើយពុំបាប្រាប់ទៅនរណាម្នាក់ទេ ដូច្នេះបន្ទាប់ពីវិវរណៈនេះត្រូវបានប្រទានឲ្យ នោះគាត់បានដឹងថា កិច្ចការនេះគឺពិតមែន ដោយសារគ្មានមនុស្សណា បានដឹងអំពីរឿងដែលបានប្រាប់នៅក្នុងវិវរណៈទេ ក្រៅពីព្រះ និងខ្លួនគាត់ផ្ទាល់ប៉ុណ្ណោះ » ( *History of the Church* ១:៣៥ ) ។

ចូរអញ្ជើញសិស្សឲ្យនឹកគិតពីគ្រាដែលព្រះបានបំភ្លឺគំនិតរបស់ពួកគេ ឬផ្ដល់ភាពសុខសាន្តដល់ពួកគេ ។ សូមពិចារណាពីការអញ្ជើញពួកគេឲ្យសរសេរទុកពីការចងចាំមួយចំនួនទាំងនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យទុកចិត្តទៅលើវិវរណៈផ្ទាល់ខ្លួន កាលដែលពួកគេបានទទួលកាលពីអតីតកាលមកនោះ ។ សូមពន្យល់ថា នៅមេរៀនពីរក្រោយទៀត នឹងជួយពួកគេរៀនស្គាល់អំពីចម្លើយចំពោះការអធិស្ឋានរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២៥–៣៧

*ព្រះអម្ចាស់ បានប្រឹក្សាដល់យ៉ូសែប និងអូលីវើរ ឲ្យបកប្រែ ហើយកុំសង្ស័យ ឬខ្លាចឡើយ*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២៥–៣១ ដោយពន្យល់ថា ព្រះអម្ចាស់ បានប្រាប់ដល់អូលីវើរថា បើលោកមានបំណង នោះលោកអាចមានអំណោយទាននៃការបកប្រែ ហើយឈរជាមួយយ៉ូសែប ធ្វើជាសាក្សីទីពីរអំពីព្រះគម្ពីរមរមន ។

- បើអ្នកជាអូលីវើរវិញ តើអ្នកនឹងមានអារម្មណ៍យ៉ាងណា ពេលអ្នកបានឮពីការទទួលខុសត្រូវ ដែលព្រះអម្ចាស់ដាក់មកលើអ្នកដូច្នេះ ?

សូមឲ្យសិស្សគិតអំពីគ្រានានា ពេលពួកគេមានអារម្មណ៍សង្ស័យ ឬភ័យខ្លាចអំពីអ្វីដែលព្រះអម្ចាស់ចង់ឲ្យពួកគេធ្វើ ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣២–៣៧ ដោយស្ងៀមស្ងាត់ ហើយរកមើលរបៀបដែលព្រះអម្ចាស់បានទូន្មានដល់យ៉ូសែប និងអូលីវើរ ឲ្យយកឈ្នះលើការសង្ស័យ និងការភ័យខ្លាច ពេលពួកលោកបន្តធ្វើកិច្ចការរបស់ទ្រង់ ។

- តើសេចក្ដីពិត ឬគោលការណ៍អ្វីខ្លះ ចេញមកពីការប្រឹក្សានេះ ដែលយើងអាចអនុវត្តនៅក្នុងជីវិតបាន ? ( សិស្សអាចផ្ដល់យោបល់អំពីគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថាគូសចំណាំថា **នៅពេលយើងមើលទៅព្រះយេស៊ូវគ្រីស្ទ នោះយើងអាចយកឈ្នះលើការសង្ស័យ និងភាពភ័យខ្លាច** ) ។
- តើគំរូមួយចំនួនអំពីរបៀបដែលមនុស្សម្នាក់ អាចមើលទៅព្រះគ្រីស្ទនៅគ្រប់គំនិតមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍ដែលពួកគេមាន នៅពេលចំណេះដឹងរបស់ពួកគេអំពីព្រះអង្គសង្គ្រោះបានជួយពួកគេយកឈ្នះលើការសង្ស័យ ឬភាពភ័យខ្លាច ។ អ្នកក៏អាចចង់ចែកចាយពីបទពិសោធន៍មួយរបស់អ្នកដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧

*យ៉ូហានជាទីស្រឡាញ់ ត្រូវបានសន្យាថា លោកនឹងរស់នៅ ហើយនាំព្រលឹងជាច្រើនមកកាន់ព្រះគ្រីស្ទ រហូតដល់ការយាងមកជាលើកទីពីរ*

*កំណត់ចំណាំ* ៖ គ្មានអ្វីត្រូវបានបើកបង្ហាញអំពីកិច្ចការបម្រើដ៏ជាក់លាក់របស់យ៉ូហាន ជាតួអង្គប្រែរូបនោះទេ ។ សូមកុំប៉ាន់ស្មានអំពីកន្លែង ឬកិច្ចការសម្រេចរបស់យ៉ូហាននោះឡើយ ។

សូមពន្យល់ថា ពេលមួយ នៅអំឡុងខែមេសា ឆ្នាំ១៨២៩ ខណៈដែល អូលីវើរ កំពុងជួយយ៉ូសែប ជាមួយនឹងការបកប្រែ នោះលោក និងយ៉ូសែប បានមាន « គំនិតផ្សេងមួយ. . . អំពីដំណើររឿងរបស់យ៉ូហាន ជាសាវក ដែលបានប្រាប់នៅក្នុងគម្ពីរសញ្ញាថ្មី [ សូមមើល យ៉ូហាន ២១:២០–២៣ ]. . . ថាតើលោកស្លាប់ ឬលោកបន្ត [ នៅរស់ ] » ( *Histories, Volume ១:១៨៣២–១៨៤៤,* វ៉ុលទី១ នៃ the Histories series of *The Joseph Smith Papers* [ ឆ្នាំ ២០១២ ], ទំព័រ ២៨៤ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧:១–៣ ដើម្បីរកមើលចម្លើយចំពោះសំណួររបស់ យ៉ូសែប និងអូលីវើរ ។ ( បើសិស្សមានការពិបាកក្នុងការប្រាប់ចម្លើយ អ្នកអាចផ្ដល់យោបល់ថា ពួកគេអានកណ្ឌសង្ខេបសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧:១–៣ ) ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣–៧; ១០; យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៦–៦៧ ( មេរៀនទី ៣ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀននៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣–៧; ១០; យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៦៧ ( មេរៀនទី ៣ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣; ១០)

នៅពេលសិស្សបានរៀនពីស្ថានភាពជុំវិញការបាត់ឯកសារ ១១៦សន្លឹកនៃព្រះគម្ពីរមរមន នោះ ពួកគេបានឃើញថាគម្រោងការណ៍ទាំងឡាយនៃព្រះនោះពុំអាចធ្វើឲ្យស្មុគស្មាញបានឡើយ ។ ព្រះអម្ចាស់ស្ដីបន្ទោសយ៉ូសែប ស្ម៊ីធ សម្រាប់ការទុកលអង្វរដដែលៗ ដើម្បីផ្ដល់ឯកសារសរសេរដោយដៃនោះឲ្យទៅម៉ាទីន ហារីស នោះសិស្សបានរៀនថាពួកគេគួរតែខ្លាចព្រះជាជាងខ្លាចការបញ្ចុះបញ្ចូលរបស់មនុស្ស ហើយថាប្រសិនបើយើងស្មោះត្រង់ចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះទ្រង់នឹងគាំទ្រយើង ក្នុងអំឡុងគ្រាលំបាកនានា ។ បន្ទាប់ពីផ្ទាំងទាំងនោះត្រូវបានប្រគល់ឲ្យយ៉ូសែប ស្ម៊ីធវិញ នោះព្រះអម្ចាស់បានបង្រៀនលោកថាសាតាំងមានបំណងចង់បំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និង ព្រលឹងរបស់យើង ប៉ុន្តែនៅពេលយើងអធិស្ឋានជានិច្ច នោះយើងនឹងមានអំណាចដើម្បីយកឈ្នះលើសាតាំង និងអ្នកទាំងឡាយដែលបម្រើវា ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤)

ចេញពីការឆ្លើយតបរបស់ព្រះអម្ចាស់ចំពោះបំណងប្រាថ្នារបស់យ៉ូសែប ស្ម៊ីធ ស៊ីញ័រ ដើម្បីដឹងពីអ្វីដែលព្រះអម្ចាស់ចង់ឲ្យលោកធ្វើនោះសិស្សបានរៀនថា ប្រសិនបើពួកគេបម្រើព្រះដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់ខ្លួន នោះពួកគេនឹងអាចបានឈរដោយឥតទោសនៅចំពោះព្រះនៅថ្ងៃចុងក្រោយ ។ ពួកគេក៏បានរៀនផងដែរថា នៅពេលពួកគេធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីនាំអ្នកដទៃមកកាន់ព្រះយេស៊ូវគ្រីស្ទ នោះពួកគេក៏អាចទទួលបានសេចក្ដីសង្គ្រោះសម្រាប់ខ្លួនផងដែរ ។ ជាចុងក្រោយ សិស្សបានរកឃើញពីលក្ខណៈដ៏ទេវភាពដែលធ្វើឲ្យបុគ្គលម្នាក់សក្ដិសមជួយដល់កិច្ចការរបស់ព្រះអម្ចាស់ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥)

នៅពេលម៉ាទីន ហារីស បានស្វែងរកសាក្សីនៃផ្ទាំងបន្ថែមទៀតលើសាក្សីដែលមាន នោះព្រះអម្ចាស់បានបង្រៀនម៉ាទីនថា ទ្រង់បានហៅយ៉ូសែប ស្ម៊ីធ ឲ្យផ្សព្វផ្សាយព្រះបន្ទូលរបស់ទ្រង់ទៅកាន់ពិភពលោក ប៉ុន្តែទីបន្ទាល់នៃសាក្សីបីនាក់នឹងឈរជាកស្ដុតាងចំពោះសេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមន ។ សិស្សបានរៀនថា ប្រសិនបើពួកគេនឹងជឿលើព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះព្រះវិញ្ញាណនឹងបញ្ជាក់ពីសេចក្ដីពិតរបស់ពួកគេ ។ កណ្ឌនេះក៏បានជួយសិស្សឲ្យយល់ផងដែរថា បើសិនយើងអធិស្ឋានដោយស្មោះ ដោយរាបសារ និងសេចក្ដីជំនឿខណៈនោះយើងអាចទទួលបានចម្លើយស្របតាមបំណងប្រាថ្នាសុចរិតរបស់យើង ។

### ថ្ងៃទី ៤ (យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧)

ព្រះអម្ចាស់បានបង្រៀន អូលីវើរ ខៅឌើរី អំពីសេចក្ដីពិតនានាដ៏សំខាន់នៃការទទួល និង ការស្គាល់វិវរណៈ ។ សិស្សបានត្រិះរិះគិតពីរបៀបដែលសេចក្ដីពិតទាំងនេះត្រូវបានអនុវត្តចំពោះពួកគេ ។ លើសពីនេះទៅទៀតពួកគេបានរៀនថា ព្រះអម្ចាស់មានបន្ទូលនូវភាពសុខសាន្តចំពោះគំនិតយើង ទុកជាសាក្សីមួយអំពីសេចក្ដីពិត ។ សិស្សក៏បានរៀនផងដែរថា នៅពេលយើងបែរទៅរកព្រះយេស៊ូវគ្រីស្ទ នោះយើងអាចយកឈ្នះលើភាពសង្ស័យ និង ភាពភ័យខ្លាច ។

## សេចក្ដីផ្ដើម

អំឡុងពេលនៃមេរៀននេះ សិស្សនឹងសិក្សាយ៉ាងច្រើនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០, ដែលបានបើកសម្ដែងដល់ព្យាការីយ៉ូសែប ស្ម៊ីធ បន្ទាប់ពីបាត់បង់ឯកសារដែលសរសេរដោយដៃនៃព្រះគម្ពីរមរមនទាំង ១១៦ទំព័រ ។ ពីមុនវិវរណៈនេះមរ៉ូណៃបានយកផ្ទាំងព្រមទាំងយូរីម និង ធូមីមពីយ៉ូសែប ស្ម៊ីធវិញ ហើយព្យាការីបានបាត់បង់អំណាចដើម្បីបកប្រែមួយរយៈ ។ បន្ទាប់ពី

ផ្ទាំងត្រូវបានប្រគល់ឲ្យគាត់វិញ ព្រះអម្ចាស់បានបញ្ជាកុំឲ្យយ៉ូសែបបកប្រែឡើងវិញនូវចំណែកនៃផ្ទាំងដែលបានបាត់ទាំង ១១៦ ទំព័រ នោះឡើយ ។ ព្រះអម្ចាស់ក៏បានបើកសម្ដែងអំពីផែនការរបស់សាតាំងក្នុងការបំផ្លាញកិច្ចការនេះ ហើយបានបង្រៀនពីរបៀបដែលយើងអាចយកឈ្នះលើសាតាំង ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣; ១០

*សាតាំងព្យាយាមបំផ្លាញយ៉ូសែប ស្ម៊ីធ និង កិច្ចការរបស់ព្រះ*

សូមអញ្ជើញសិស្សឲ្យពន្យល់ពីស្ថានភាពជុំវិញការបាត់បង់ឯកសារដែលសរសេរដោយដៃទាំង ១១៦ទំព័រនោះ ។ បន្ទាប់មក សូមពិភាក្សាសំណួរខាងក្រោមនេះ ៖

- ចេញពីអ្វីដែលអ្នកបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣, ហេតុអ្វីអ្នកគិតថា យ៉ូសែប ស្ម៊ីធ បានទូលសុំដល់ព្រះនូវសំណួរដដែលៗ ទោះជាបានទទួលចម្លើយយ៉ាងច្បាស់ហើយដូច្នោះ ?
- តើអ្នកគិតថា យ៉ូសែប ស្ម៊ីធ បានរៀនអ្វីខ្លះពីបទពិសោធន៍នេះ ?
- តើសេចក្ដីពិតអ្វីខ្លះដែលអ្នកបានរៀនពី បទពិសោធន៍របស់យ៉ូសែបដែលអាចជួយអ្នក នៅពេលអ្នកជួបនូវការរងសម្ពាធពីមនុស្សដទៃឲ្យធ្វើអ្វីមួយដែលមិនត្រឹមត្រូវនោះ ?

សូមបង្ហាញអង្គប់ ឬអន្ទាក់មួយ ( ឬ គូររូបភាព នេះមួយនៅលើក្ដារខៀន ) ។ សូមឲ្យសិស្សពីរបីនាក់សង្ខេបពីអ្វី ដែលពួកគេបានរៀនពីការសិក្សានៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០ អំពីរបៀបដែលសាតាំងមានបំណងដាក់អន្ទាក់យ៉ូសែបជាមួយនឹងឯកសារ ១១៦សន្លឹកដែលបាត់នោះ ។



សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:២០–២៩ ព្រះអម្ចាស់ បានពិពណ៌នាពីអស់អ្នកដែលបណ្ដោយខ្លួនទៅតាមឥទ្ធិពលសាតាំង ដើម្បីយកឯកសារ ១១៦សន្លឹក និង របៀបដែលសាតាំងអាចដាក់អន្ទាក់ពួកគេ ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យសិស្សម្នាក់ក្នុងមួយគូៗ អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:២០–២៩ ដោយស្ងាត់ស្ងៀម ស្វែងរកអ្វីដែលខគម្ពីរទាំងនេះ បង្រៀនអំពីគោលបំណងរបស់សាតាំង ។ សូមឲ្យសិស្សម្នាក់ទៀត អានខគម្ពីរដូចគ្នានោះ ស្វែងរកមើលវិធីសាស្ត្រដែលសាតាំងប្រើដើម្បីសម្រេចគោលបំណងវា ។ នៅពេលពួកគេអានចប់ សូមអញ្ជើញសិស្សក្នុងគូនិមួយៗរាយការណ៍ប្រាប់គ្នាទៅវិញទៅមក ។ បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយនោះ សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើយើងអាចរៀនអ្វីខ្លះពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:២០–២៩ អំពីគោលបំណងរបស់សាតាំង ? ( សិស្សអាចរកឃើញគោលការណ៍ផ្សេងមួយ ប៉ុន្តែសូមប្រាកដថាពួកគេយល់ថា **សាតាំងមានបំណងបំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និងព្រលឹងរបស់យើង** ។ អ្នកអាចសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ។ អ្នកក៏អាចឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំពាក្យ ឬឃ្លាទាំងឡាយដែលបង្រៀនសេចក្ដីពិតនេះនៅក្នុង ខ ២២–២៣ និង ២៧) ។
- ចេញពីអ្វីដែលអ្នកអាននៅក្នុងខគម្ពីរទាំងនេះ តើសាតាំងព្យាយាមបំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និងព្រលឹងរបស់យើងយ៉ាងដូចម្ដេច ? ( វាប្រើមធ្យោបាយដូចជា ការបោកប្រាស់ កំហឹង ការបញ្ឆោរ និង ការកុហក ។ អ្នកអាចផ្ដល់យោបល់ឲ្យសិស្សគូសចំណាំនូវ មធ្យោបាយទាំងនេះរបស់ពួកមារសត្រូវ នៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។

ដើម្បីជួយសិស្សឲ្យយល់ និង យល់ពីសារៈសំខាន់នៃសេចក្ដីពិតនេះ សូមអញ្ជើញពួកគេឲ្យពិភាក្សាសំណួរខាងក្រោមជាមួយដៃគូរបស់ពួកគេ ( អ្នកគួរតែសរសេរសំណួរទាំងនេះនៅលើក្ដារខៀន ឬ រៀបចំក្រដាសចែកមុនពេលចាប់ផ្ដើមបង្រៀន ) ៖

- តើអ្នកបានឃើញភស្ដុតាងអ្វីខ្លះ ដែលសាតាំងនៅតែប្រើ ការបោកបញ្ឆោត កំហឹង ការបញ្ឆោរ និង ការកុហក ដើម្បីបំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និង ព្រលឹងរបស់មនុស្សនោះ ?
- តើការដឹងជាមុនអំពីបំណងរបស់សាតាំង និង វិធីសាស្ត្ររបស់វាជួយយើងចៀសវាង និង គេចផុតពីអន្ទាក់របស់វាយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីវិធីសាស្ត្ររបស់សាតាំងដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:២០–២៩ ពួកគេបានទទួលអារម្មណ៍ ឬ បានឃើញ ព្រមទាំងអ្វី ដែលពួកគេអាចធ្វើដើម្បីចៀសវាង ឬ គេចផុតពីអន្ទាក់របស់សាតាំង ។

សូមពន្យល់ថា នៅក្នុងវិវរណៈនេះព្រះអម្ចាស់បានប្រទានព្រះបញ្ញត្តិ និងការសន្យាមួយដែលទាក់ទងនឹងកិច្ចខិតខំរបស់យើង ដើម្បីចៀសវាងពីឥទ្ធិពលរបស់សាតាំង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥ ឲ្យឮៗ ហើយ សូមឲ្យសិស្សរកមើលទាំងព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ និង ការសន្យារបស់ទ្រង់ ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ *នៅពេលយើង* ______________________ *នោះយើងនឹងមានអំណាច ដើម្បី* ____________________________________________________________.

សូមសួរសិស្សថា ៖ តើអ្នកនឹងបំពេញគោលការណ៍នេះយ៉ាងណាដោយផ្អែកលើ ខ ៥? ( សិស្សអាចរកឃើញគោលការណ៍ផ្សេងៗ ប៉ុន្ដែសូមប្រាកដថា អ្នកគួរបញ្ជាក់ប្រាប់ថា **នៅពេលយើងអធិស្ឋានជានិច្ច នោះយើងនឹងមានអំណាចដើម្បីយកឈ្នះលើសាតាំង និងអ្នកទាំងឡាយដែលបម្រើវា**) ។

សូមឲ្យសិស្សរំឭកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៣៨–៤៥ ឡើងវិញ ។ បន្ទាប់មក សូមអញ្ជើញសិស្សម្នាក់ឲ្យពន្យល់ពីរបៀបដែលព្រះអម្ចាស់ប៉ះប៉ូវនូវការបាត់ឯកសារ ១១៦សន្លឹកនោះ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៤៣ ដោយស្ងាត់ស្ងៀម ហើយរកមើលសេចក្ដីពិតដ៏សំខាន់មួយដែលព្រះអម្ចាស់បានចង់ឲ្យយ៉ូសែប ស្ម៊ីធ យល់ ។ ( នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមសរសេរសេចក្ដីពិតខាងក្រោមនៅលើក្ដារខៀន ៖ **ប្រាជ្ញារបស់ព្រះមហិមាជាងកលល្បិចនៃអារក្សទៅទៀត** ។ អ្នកអាចត្រូវការពន្យល់ថា *កលល្បិច* សំដៅទៅលើការប្រើល្បិចដើម្បីបញ្ឆោតមនុស្ស ) ។

សូមសួរសំណួរខាងក្រោម ៖

- តើផែនការរបស់ព្រះអម្ចាស់ ជំនួសឯកសារសរសេរដោយដៃដែលបានបាត់ បង្ហាញពីសេចក្ដីពិតនេះយ៉ាងដូចម្ដេច ?
- តើវាជួយអ្នកឲ្យដឹងថាប្រាជ្ញារបស់ព្រះមហិមាជាងកលល្បិចនៃអារក្សយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៤៤–៤៥, ដោយស្ងាត់ស្ងៀម រកមើលភស្ដុតាងបន្ថែមទៀតនៃសេចក្ដីពិតដែលបានសរសេរលើក្ដារខៀន ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៤៤–៤៥, ហេតុអ្វីក៏ផ្ទាំងតូចមានតម្លៃជាងការសង្ខេបរបស់មរមនពី ផ្ទាំងធំដែលមាននៅក្នុង ១១៦សន្លឹកដែលបាត់នោះ ? ( ផ្ទាំងតូចមាននូវដំណើររឿងសំខាន់ៗខាងវិញ្ញាណ ។ ឯកសារ ១១៦សន្លឹកដែលបាត់នោះមាននូវដំណើររឿងសង្ខេបនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ) ។
- តើការដឹងថាព្រះបានរៀបចំផ្លូវមួយដើម្បីប៉ះប៉ូវឯកសារ ១១៦សន្លឹកដែលបាត់នោះជួយអ្នកឲ្យកាន់តែទុកចិត្តទាំងស្រុងលើទ្រង់យ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤–៧

*ព្រះអម្ចាស់ប្រទានព្រះឱវាទដល់យ៉ូសែប និងអូលីវើរកុំឲ្យសង្ស័យ ឬខ្លាចឡើយ*

សូមអញ្ជើញសិស្សឲ្យប្រាប់ខ្លីៗពីសេចក្ដីពិតមួយចំនួនអំពីវិវរណៈផ្ទាល់ខ្លួន ដែលពួកគេបានដឹងពេលសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦ ។ សូមអញ្ជើញពួកគេឲ្យពិចារណាបទពិសោធន៍ នៅពេលពួកគេបានទទួលអារម្មណ៍ថាគំនិតរបស់ពួកគេត្រូវបានបំភ្លឺ ហើយពេញដោយភាពសុខសាន្ដចំពោះអ្វីដែលពួកគេបានអធិស្ឋាន ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមរំឭកសិស្សថា ផ្នែកមួយនៃការសិក្សារបស់ពួកគេនៃវគ្គចំណេះចំណានខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣៦, នោះពួកគេបានសរសេរការឡើងនិយាយខ្លីមួយដែលរៀបរាប់ពីវិធីនានាដើម្បីរស់នៅតាមព្រះឱវាទរបស់ព្រះអម្ចាស់ដែលបានប្រទានឲ្យក្នុងខគម្ពីរនោះ ។ សូមអញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣៦ ឲ្យឮៗទាំងអស់គ្នា ។ អ្នកអាចធ្វើវាម្ដងទៀតដើម្បីជួយពួកគេទន្ទេញឲ្យចាំវា ។ បន្ទាប់មក សូមឲ្យសិស្សពីរបីនាក់ដែលចង់ចែកចាយការនិយាយរបស់ពួកគេឡើងមកចែកចាយ ។ អ្នកអាចចង់ចែកចាយទីបន្ទាល់របស់ខ្លួនអំពី របៀបដែលព្រះអម្ចាស់បានជួយអ្នកឲ្យយកឈ្នះលើការសង្ស័យ ឬ ការភ័យខ្លាចកាលពីអតីតកាល ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩; ១១–១៦)

តើវិញ្ញាណនៃវិវរណៈគឺជាអ្វី ? តើអ្នកដឹងថាអ្នកកំពុងទទួលវិវរណៈពីព្រះដោយរបៀបណា ? សូមពន្យល់ថា នៅក្នុងមេរៀនបន្ទាប់សិស្សនឹងរៀនអំពីគោលការណ៍នៃវិវរណៈដែលនឹងប្រទានដល់ពួកគេ នៅពេលពួកគេស្វែងរកការណែនាំពីព្រះនៅក្នុងជីវិតរបស់ពួកគេ ។

មេរៀនទី ១៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨

## បុព្វកថា

នៅខែមេសា ឆ្នាំ ១៨២៩ អូលីវើរ ខៅឌើរី បានចាប់ផ្ដើមជួយព្យាការីយ៉ូសែប ស្ម៊ីធ ជាមួយនឹងការបកប្រែនៃផ្ទាំងចំណារមាស ដោយធ្វើជាស្មៀន ។ ដោយសារ ព្រះអម្ចាស់ បានផ្ដល់ដល់ អូលីវើរ នូវអំណោយទាននៃការបកប្រែ បើលោកមាន បំណងដូច្នោះ ( សូមមើល គ. និង ស. ៦:២៥) នោះអូលីវើរ « មានចិត្តរំភើប ជាខ្លាំងដើម្បីមានអំណាចនៃការបកប្រែប្រទានមកដល់គាត់ » ( យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* ១:៣៦ ) ។ ក្នុងការឆ្លើយតប ព្រះអម្ចាស់ បាន មានបន្ទូលថា ទ្រង់នឹងផ្ដល់ដល់អូលីវើរ នូវសមត្ថភាពដើម្បីបកប្រែ ស្របតាម សេចក្ដីជំនឿរបស់អូលីវើរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១–៥

*ព្រះអម្ចាស់សន្យានឹងអូលីវើរ ខៅឌើរី នូវអំណោយទាននៃវិវរណៈ*

មុនចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ ដាក់ឲ្យសិស្សក្នុងថ្នាក់នូវសំណួរនីមួយៗដើម្បីសរសេរ អំពីគោលការណ៍នានា ដែលសិស្សនឹងប្រាប់អំឡុងមេរៀន ។

> *តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យការអធិស្ឋានរបស់យើងកាន់តែមានន័យ ?*
>
> *តើយើងអាចដឹងថា នៅពេលណាព្រះមានបន្ទូលមកកាន់យើងយ៉ាងដូចម្ដេច ?*

សូមឲ្យសិស្សមើលទៅសំណួរនៅលើក្ដារខៀន ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីយល់អំពីចម្លើយចំពោះសំណួរទាំងនេះ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨ មាននូវវិវរណៈមួយ ដែលព្រះអម្ចាស់បានប្រទានទៅឲ្យ អូលីវើរ ខៅឌើរី តាមរយៈ យ៉ូសែប ស្ម៊ីធ ។ នៅក្នុងវិវរណៈនេះ យើងអាចរកការណែនាំមកពីព្រះអម្ចាស់ ដែលជួយឆ្លើយសំណួរនៅលើ ក្ដារខៀន ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១ ដោយស្ងៀមស្ងាត់ រកមើលរបៀបដែលព្រះអម្ចាស់បានណែនាំឲ្យ អូលីវើរ អធិស្ឋាន ។

- តើការណែនាំអ្វីខ្លះ ដែលព្រះអម្ចាស់ប្រទានដល់អូលីវើរ អំពីរបៀបអធិស្ឋាន ?
- តើអ្នកគិតថា វាមានអត្ថន័យដូចម្ដេចដើម្បី « សុំដោយមានជំនឿ ដោយមានចិត្តទៀងត្រង់ »នោះ ?

នៅក្រោមសំណួរទីមួយនៅលើក្ដារខៀន សូមសរសេរដូចខាងក្រោមថា ៖ *បើយើងអធិស្ឋាន* ________________*យើងអាច ទទួល* ________________________________________________.

ផ្អែកទៅលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១ តើអ្នកនឹងបំពេញប្រយោគនេះយ៉ាងដូចម្ដេច ? ( ទោះជាសិស្សអាចបង្ហាញ វាផ្សេងក្ដី ចម្លើយរបស់ពួកគេ គួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដែលថា **បើយើងអធិស្ឋានដោយមានជំនឿ និងដោយ មានចិត្តទៀងត្រង់ នោះយើងអាចទទួលបានចំណេះដឹងមកពីព្រះ** ។ សូមប្រើពាក្យសម្ដីរបស់ពួកគេ បំពេញប្រយោគនៅលើ ក្ដារខៀន ) ។

- ហេតុអ្វីអ្នកគិតថា សេចក្ដីជំនឿ និងភាពទៀងត្រង់របស់យើង មានឥទ្ធិពលទៅលើលទ្ធភាពរបស់យើង ដើម្បីទទួល ចំណេះដឹងមកពីព្រះដូច្នេះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីគ្រាមួយ ពេលពួកគេបានទទួលបទពិសោធន៍ទទួលនូវពរជ័យ ពេលពួកគេអធិស្ឋាន ដោយមានជំនឿ និងដោយដួងចិត្តទៀងត្រង់ ។

ដើម្បីជួយសិស្សទទួលបានការយល់ដឹងនៅក្នុងសំណួរទីពីរនៅលើក្ដារខៀន សូមអញ្ជើញសិស្សម្នាក់ឲ្យរៀបរាប់ដំណើររឿង អំពី ម៉ូសេ ដឹកនាំកូនចៅអ៊ីស្រាអែល ចេញពីទាសភាពក្រោមការដេញតាមពីសំណាក់កងទ័ពអេស៊ីព្ទដោយសង្ខេបឡើងវិញ ( សូមមើល និក្ខមនំ១៤ ) ។



សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២–៣ ឲ្យឮៗ ។ សូមលើកទឹកចិត្តដល់សិស្សក្នុងថ្នាក់ឲ្យរកមើលរបៀបដែលព្រះបើកសម្ដែងដល់ម៉ូសេថា លោកគួរនាំកូនចៅអ៊ីស្រាអែលឆ្លងកាន់សមុទ្រក្រហម ។

- តើព្រះបំផុសគំនិតម៉ូសេឲ្យញែកទឹកសមុទ្រក្រហមចេញបានយ៉ាងដូចម្ដេច ? ( ដោយវិញ្ញាណនៃវិវរណៈ ) ។

- តើសេចក្ដីពិតអ្វីខ្លះ ដែលយើងបានរៀនមកពីខគម្ពីរទាំងនេះ អំពីរបៀបដែលព្រះអម្ចាស់អាចមានបន្ទូលមកកាន់យើង ? ( សិស្សគួរតែបង្ហាញថា **ព្រះអម្ចាស់ ថ្លែងមកកាន់គំនិត និងដួងចិត្តរបស់យើងតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ** ។ សូមសរសេរសេចក្ដីពិតនេះនៅក្រោមសំណួរទីពីរនៅលើក្ដារខៀន ) ។




សូមគូស ឌីយ៉ាក្រាមដែលអមជាមួយខាងក្រោមនេះដាក់លើក្ដារខៀន ។ បន្ថែមចំណុចព្រួញចង្អុលទៅរក គំនិត និង ដួងចិត្ត ។

- តើព្រះអម្ចាស់មានបន្ទូលមកកាន់គំនិតរបស់យើងតាមវិធីណាខ្លះ ? តើទ្រង់មានបន្ទូលមកកាន់ចិត្តរបស់យើងតាមវិធីណាខ្លះ ?

ដើម្បីជួយសិស្សឲ្យកាន់តែយល់អំពីរបៀបទទួលអារម្មណ៍ដឹងអំពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រធាន ប៊ិយដ៏ ឃេ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



អ្នកអាចរៀនឥឡូវនេះ នៅក្នុងយុវវ័យរបស់អ្នក ដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ។

« ក្នុងនាមជាសាវកម្នាក់ ខ្ញុំស្ដាប់ឥឡូវនេះ ចំពោះការបំផុសគំនិតដូចគ្នា ដែលចេញមកពីប្រភពដូចគ្នា តាមវិធីដូចគ្នា ដែលខ្ញុំបានស្ដាប់កាលពីនៅក្មេង ។ សញ្ញាគឺមានកាន់តែច្បាស់ក្នុងពេលឥឡូវនេះ » ( Prayers and Answers, » *Ensign* ខែវិច្ឆិកា ឆ្នាំ១៩៧៩, ទំព័រ ២១ ) ។

រួចហើយសូមអញ្ជើញសិស្សម្នាក់ទៀត ឲ្យអាននូវសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយអែលឌើរ រីឆាដ ជី ស្កត កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ចំណាប់អារម្មណ៍ចំពោះ *គំនិត* គឺជាក់លាក់ណាស់ ។

« ពាក្យលម្អិតអាចនឹងត្រូវបានស្ដាប់ឮ ឬទទួលអារម្មណ៍ ហើយសរសេរទុក ដូចជាការណែនាំត្រូវបានសរសេរតាមដូច្នោះដែរ ។

« ទំនាក់ទំនងទៅកាន់ *ចិត្ត* គឺកាន់តែទូទៅជាង ។ ជាញឹកញាប់ ព្រះអម្ចាស់ ចាប់ផ្ដើមដោយការផ្ដល់នូវចំណាប់អារម្មណ៍ ។ ពេលដែលមាននូវការទទួលស្គាល់ពីសារៈសំខាន់របស់វា ហើយពួកគេបានគោរពតាម នោះអ្នកទទួលបានសមត្ថភាពកាន់តែច្រើន ដើម្បីទទួលការណែនាំលម្អិតកាន់តែច្រើននៅក្នុង *គំនិត* ។ ចំណាប់អារម្មណ៍ក្នុងចិត្ត បើធ្វើតាម គឺត្រូវបានបន្ថែមដោយការណែនាំកាន់តែជាក់លាក់ទៅដល់គំនិត » ( « “Helping Others to Be Spiritually Led” [ address to CES religious educators, ថ្ងៃ ទី ១១ ខែ សីហា ឆ្នាំ១៩៩៨ ], ទំព័រ ៣–៤, » LDS.org ) ។

អ្នកអាចពន្យល់ថា សម្រាប់មនុស្សមួយចំនួន ចំណាប់អារម្មណ៍ក្នុងចិត្ត អាចនឹងជាក់លាក់ដូចជាចំណាប់អារម្មណ៍ក្នុងគំនិត ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ និងទទួលស្គាល់របៀបដែលព្រះអម្ចាស់ទំនាក់ទំនងនឹងយើងម្នាក់ៗដូច្នេះ ?

សូមអញ្ជើញសិស្សឲ្យសរសេរក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរអំពី (១) គ្រាមួយដែលព្រះវរបិតាសួគ៌បានមានបន្ទូលមកកាន់គំនិតនិងដួងចិត្តរបស់ពួកគេ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ឬ (២) គ្រាមួយដែលពួកគេមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកអាចសុំដល់សិស្សពីរបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេបានសរសេរទុក បើពួកគេមានអារម្មណ៍ថាចង់ចែកចាយវា ។ អ្នកក៏អាចចែកចាយអារម្មណ៍មួយ ដែលអ្នកបានទទួលថាព្រះអម្ចាស់កំពុងមានបន្ទូលមកកាន់អ្នកផងដែរ ។

សូមពន្យល់ថា លទ្ធភាពដើម្បីស្វែងរក និងទទួលបានវិវរណៈផ្ទាល់ខ្លួន គឺមានចំពោះកូនចៅគ្រប់រូបទាំងអស់របស់ព្រះ ។

សូមទាញចំណាប់អារម្មណ៍របស់សិស្សមក គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:៤ ។ សូមអាននូវចំណែកខគម្ពីរដូចខាងក្រោមឲ្យឮៗទៅដល់សិស្សក្នុងថ្នាក់ ៖ « ហេតុដូច្នោះហើយ នេះជាអំណោយទានរបស់អ្នក សូមអនុវត្តចុះ ហើយអ្នកមានពរហើយ » ។ សូមពន្យល់ថា ខគម្ពីរនេះ ពាក្យ *អំណោយទាន* សំដៅទៅលើលទ្ធភាពរបស់អូលីវើរ ដើម្បីទទួលបានវិវរណៈ ។

- តើអ្នកគិតថា « សូមអនុវត្ត » ព្រះវិញ្ញាណនៃវិវរណៈ មានន័យដូចម្ដេចដែរ ? ( សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ) ។

សូមឲ្យសិស្សពិចារណាអំពីរបៀបដែលពួកគេអាចអនុវត្តព្រះវិញ្ញាណនៃវិវរណៈកាន់តែល្អប្រសើរនៅក្នុងជីវិតរបស់ពួកគេ ។ សូមសរសេរដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងអនុវត្តព្រះវិញ្ញាណនៃវិវរណៈ* ______________________.

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:៤–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់បានសន្យានឹងអូលីវើរ បើលោកនឹង « អនុវត្ត » ព្រះវិញ្ញាណនៃវិវរណៈ ។ បន្ទាប់ពីសិស្សឆ្លើយរួច សូមឲ្យយោបល់ថា របៀបមួយដើម្បីបំពេញបញ្ចប់នៅក្នុងប្រយោគអាចជា ៖ **បើយើងអនុវត្តព្រះវិញ្ញាណនៃវិវរណៈ នោះយើងអាចរំដោះពីសេចក្ដីអាក្រក់ និងគ្រោះថ្នាក់** ។ សូមបំពេញសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ។

- តើព្រះអម្ចាស់ប្រើអំណាចនៃវិវរណៈដើម្បីការពារអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ពីសេចក្ដីអាក្រក់ ឬគ្រោះថ្នាក់យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្ដារខៀននូវវិធីមួយចំនួន ដែលយើងអាចនឹង « អនុវត្ត » អំណោយទាននៃវិវរណៈ ដើម្បីទទួលបានការការពារពីសេចក្ដីអាក្រក់ ។ សូមសួរពួកគេអំពីរបៀបដែលយោបល់របស់ពួកគេ អាចបង្កើតលទ្ធភាពរបស់យើងដើម្បីទទួល និងទទួលស្គាល់វិវរណៈ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរនូវគោលដៅមួយ ដើម្បីធ្វើតាមយោបល់មួយនៃយោបល់ទាំងនេះ ។

អ្នកអាចចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការព្យាយាមឲ្យមានព្រះវិញ្ញាណ នៃវិវរណៈ ហើយប្រាប់សិស្សអំពីរបៀបដែលការធ្វើដូច្នេះ បានប្រទានពរដល់ជីវិតរបស់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:៦–៩

*អូលីវើរ ខៅឌើរី មាន « អំណោយទាននៃអើរ៉ុន »*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:៦–៩ ដោយការប្រាប់ដល់សិស្សថា ព្រះអម្ចាស់ប្រទានពរដល់អូលីវើរ ខៅឌើរី ជាមួយនឹងអំណោយទានដែលនឹងជួយលោកឲ្យបំពេញតួនាទីរបស់លោកនៅក្នុងការស្ដារដំណឹងល្អឡើងវិញ ។ នៅក្នុងចំណោមអំណោយទានទាំងនេះ គឺជា « អំណោយទាននៃអើរ៉ុន » ដែលព្រះអម្ចាស់បានប្រាប់ដល់អូលីវើរថា លោកនឹងធ្វើ « កិច្ចការដ៏អស្ចារ្យ » ។ យើងពុំដឹងច្បាស់នូវអ្វីដែលមានក្នុង « អំណោយទាននៃអើរ៉ុន »នោះទេ ។ សូមរំឭកសិស្សថា អើរ៉ុនគឺជាបងប្រុសរបស់ម៉ូសេ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយថាលោកបានជួយម៉ូសេបំពេញតាមការទទួលខុសត្រូវដែលលោកបានព្យាករណ៍ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:៧–៨ ដោយស្ងៀមស្ងាត់ រកមើលអំណាចដែលនៅពីក្រោយអំណោយទានខាងវិញ្ញាណទាំងអស់ ។ សូមពន្យល់ថា នៅពេលណាដែលព្រះអម្ចាស់ហៅ ឬបញ្ជាយើងឲ្យធ្វើកិច្ចការជាក់លាក់មួយ នោះទ្រង់នឹងប្រទានពរដល់យើងជាមួយនឹងអំណោយទាននិងសមត្ថភាពដើម្បីសម្រេចវាហើយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១០–១២

*ព្រះអម្ចាស់ សន្យានឹងអូលីវើរ ខៅឌើរី នូវអំណោយទានដើម្បីបកប្រែ បើលោកអនុវត្តសេចក្ដីជំនឿ ។*

សូមទាញចំណាប់អារម្មណ៍របស់សិស្សទៅកាន់គោលការណ៍ដែលបានសរសេរនៅលើក្ដារខៀន ៖ **បើយើងអធិស្ឋានដោយមានជំនឿ និងដោយចិត្តទៀងត្រង់ នោះយើងអាចទទួលចំណេះមកពីព្រះ** » ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១០–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលគំនិតបន្ថែមអំពីការអធិស្ឋាន ។ បន្ទាប់ពី

សិស្សរាយការណ៍នូវអ្វីដែលពួកគេបានរកឃើញ សូមសួរសំណួរដូចខាងក្រោម ៖ សូមឲ្យយោបល់ដល់សិស្សឲ្យពិចារណាអំពីសំណួរមួយសន្ទុះសិនមុនពេលពួកគេឆ្លើយ ៖

- បើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់អូលីវើរ តើអ្នកគិតថា ការប្រឹក្សានេះនឹងជួយអ្នកយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរនូវសំណួរពីរបីដែលពួកគេព្យាយាមស្វែងរកចម្លើយដោយស្មោះ ។ ពួកគេក៏អាចនឹងចង់សរសេរនូវការផ្លាស់ប្ដូរជាក់លាក់ខ្លះៗដែលពួកគេចង់ធ្វើនៅក្នុងរបៀបដែលពួកគេអធិស្ឋានសុំចម្លើយទាំងនោះផងដែរ ។

សូមថ្លែងទីបន្ទាល់ដល់សិស្សអំពីសេចក្ដីស្រឡាញ់របស់ព្រះនិងការចង់ឆ្លើយដល់ការអធិស្ឋានរបស់ពួកគេ ហើយនឹងការចង់ផ្ដល់វិវរណៈរបស់ទ្រង់ដល់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យសួរសំណួររបស់ពួកគេដល់ព្រះវរបិតាសួគ៌ដោយសេចក្ដីជំនឿ ហើយដើម្បីធ្វើតាមចម្លើយដែលពួកគេទទួលបានដោយបំណងស្មោះត្រង់ ។

មេរៀនទី១៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩

## បុព្វកថា

នៅក្នុងខែ មេសា ឆ្នាំ១៨២៩ អូលីវើរ ខៅឌើរី ក៏ត្រូវបានសន្យាផងដែរថា លោកអាចមានអំណោយទាននៃការបកប្រែ ( សូមមើល គ. និង ស. ៦:២៥–២៨ ) ។ ក្រោយមក អូលីវើរ ត្រូវបានណែនាំអំពីការទទួលវិវរណៈនៅក្នុងដំណើរការនៃការបកប្រែ ( សូមមើល គ. និង ស. ៨:១–៤) ហើយលោកបានព្យាយាមបកប្រែ ។ ទោះជាការចាប់ផ្ដើមរបស់លោកល្អក្ដី ក៏លោកពុំបាន « ធ្វើតទៅទៀត ដូចជា [ លោក ] បានចាប់ផ្ដើម » ( គ. និង ស. ៩:៥) ដែរ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយ ពន្យល់ពីមូលហេតុដែលការខិតខំរបស់អូលីវើរ ដើម្បីបកប្រែពុំមានជោគជ័យ ។ នៅក្នុងវិវរណៈ ព្រះអម្ចាស់ មានបន្ទូលថា វាពុំសមគួរនឹងឲ្យអូលីវើរ បកប្រែតទៅទៀតឡើយ ។ ព្រះអម្ចាស់ ក៏ប្រទានការប្រឹក្សាបន្ថែមផងដែរ អំពីការទទួលវិវរណៈ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:១–៦,១១

*ព្រះអម្ចាស់ ពន្យល់ពីមូលហេតុដែលអូលីវើរ ខៅឌើរី មានបញ្ហាលំបាកដើម្បីបកប្រែ*

សូមឲ្យសិស្សប្រាប់អំពីការសម្រេចចិត្តសំខាន់ៗមួយចំនួន ដែលពួកគេនឹងធ្វើការសម្រេចចិត្តនៅឆ្នាំក្រោយ ។ បន្ទាប់មកសុំឲ្យពួកគេសរសេរការសម្រេចចិត្តសំខាន់ៗដែលពួកគេនឹងធ្វើនៅ ៥ ទៅ១០ ឆ្នាំក្រោយទៀត ។ ពេលសិស្សឆ្លើយតប នោះអ្នកអាចកត់ត្រាចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ សូមឲ្យសិស្សគិតអំពីការសម្រេចចិត្តមួយនៃការសម្រេចចិត្តទាំងនេះ ទាក់ទងនឹងសំណួរដូចខាងក្រោម ។

- តើការស្វែងរកការណែនាំពីព្រះអម្ចាស់ ជួយអ្នកធ្វើការសម្រេចចិត្តនេះយ៉ាងដូចម្ដេច ?

បន្ទាប់ពីសិស្សម្នាក់ ឬពីរនាក់បានឆ្លើយតប សូមប្រាប់ដល់សិស្សថា នៅក្នុងមេរៀននេះ ពួកគេនឹងរៀនអំពីបទពិសោធន៍ដែលអូលីវើរ ខៅឌើរី មានពេលលោកព្យាយាមធ្វើការបកប្រែ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលគោលលទ្ធិ និងគោលការណ៍នានាពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩ ដែលអាចជួយពួកគេទទួលបាន និងស្គាល់ការណែនាំរបស់ព្រះអម្ចាស់ពេលពួកគេធ្វើការសម្រេចចិត្តសំខាន់ៗ ។

សូមរំឭកសិស្សថា ព្រះអម្ចាស់ បានប្រទានអំណោយទាននៃការបកប្រែដល់ អូលីវើរ ហើយអនុញ្ញាតឲ្យលោកបកប្រែបើលោកមានបំណងចង់ធ្វើដូច្នោះ ( សូមមើល គ. និង ស. ៦:២៥–២៨ ) ។ ព្រះអម្ចាស់ បានប្រាប់ដល់អូលីវើរ ថាអំណោយទាននៃការបកប្រែនេះ នឹងកើតមានតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល គ. និង ស. ៨:១–២ ) ។ បំណងរបស់អូលីវើរ ដើម្បីបកប្រែពីដំបូងបានចាប់ផ្ដើមយ៉ាងល្អ ប៉ុន្តែនៅទីបញ្ចប់ លោកពុំទទួលបានជោគជ័យទេ ។ បន្ទាប់ពីការមានបំណងចង់បកប្រែរបស់អូលីវើរ នោះយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:១–៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលកិច្ចការដែលព្រះអម្ចាស់ បានហៅឲ្យអូលីវើរ ឲ្យធ្វើជំនួសការបកប្រែ ។

- តើកិច្ចការអ្វីខ្លះ ដែលព្រះអម្ចាស់សុំឲ្យអូលីវើរ ធ្វើ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៥–៦,១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលមូលហេតុដែលអូលីវើរ ពុំទទួលបានជោគជ័យ ពេលលោកមានបំណងចង់បកប្រែ ។

ដើម្បីជួយសិស្សឲ្យកាន់តែយល់ឃ្លាដែលថា ‹ អ្នកពុំបានធ្វើតទៅទៀត ដូចជាអ្នកបានចាប់ផ្ដើម › ( គ. និង ស. ៩:៥) សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពន្យល់ដូចខាងក្រោម ដោយប្រធានយ៉ូសែប ហ្វីលឌិង ស្ម៊ីធថា ៖

> **យល់ដឹងអំពីបរិបទនៃបទគម្ពីរ**
>
> ការយល់ដឹងអំពីបរិបទនៃបទគម្ពីររៀបចំគ្រូបង្រៀន និងសិស្សទទួលស្គាល់សារលិខិតទាំងឡាយរបស់អ្នកនិពន្ធដ៏បំផុសគំនិត ។ បរិបទ រួមមានទាំងស្ថានភាព ដែលនៅជុំវិញ ឬផ្ដល់ជាផ្ទៃរឿងអំពីវគ្គបទគម្ពីរព្រឹត្តការណ៍ និងដំណើររឿងជាក់លាក់មួយ ។ ដើម្បីយល់អំពីការបង្រៀននៅក្នុងបទគម្ពីរ នោះគ្រូបង្រៀន និងសិស្សគួរព្យាយាមយល់ពីស្ថានភាព ដូចដែលអ្នកនិពន្ធបទគម្ពីរបានមើលឃើញ ។



« ការបរាជ័យរបស់អូលីវើរ កើតឡើងដោយសារតែលោកពុំបន្ដធ្វើដូចដែលលោកបានចាប់ផ្ដើម ហើយដោយសារការងារវាលំបាក នោះលោកបានបោះបង់សេចក្ដីជំនឿចោល » ( *Church History and Modern Revelation* ឆ្នាំ១៩៥៣ ],១:៥១ ) ។

- ស្របតាមប្រធាន ស្ម៊ីធ ហេតុអ្វីអូលីវើរ ពុំអាចបន្តធ្វើល្អតទៅទៀត ដូចដែលពេលលោកបានចាប់ផ្ដើមយ៉ាងដូច្នេះ ? ( សេចក្ដីជំនឿរបស់លោកត្រូវបានធ្លាក់ចុះ ) ។
- តើការភ័យខ្លាច ឬ ការខ្វះសេចក្ដីជំនឿ អាចរារាំងយើងពីការទទួល ឬការធ្វើតាមវិវរណៈមកពីព្រះអម្ចាស់តាមរបៀបណាខ្លះ ?
- តើបទពិសោធន៍របស់អូលីវើរ អាចបង្រៀនយើងអ្វីខ្លះ អំពីរបៀបដើម្បីទទួលវិវរណៈមកពីព្រះអម្ចាស់ ? ( គោលការណ៍មួយ ដែលសិស្សអាចប្រាប់គឺថា **ដើម្បីទទួលវិវរណៈ នោះ យើងត្រូវតែធ្វើកិច្ចការនៅក្នុងសេចក្ដីជំនឿ ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែល្អពីសេចក្ដីពិតនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅក្នុងដំណើរការនៃវិវរណៈ និង ការធ្វើការសម្រេចចិត្ត នោះភាពភ័យខ្លាចដើរតួនាទីជាការបំផ្លាញពេលខ្លះធ្វើឲ្យស្លន់ ។ ចំពោះអូលីវើរ ខៅឌើរី ដែលបាត់បង់ឱកាសមានតែម្ដងក្នុងមួយជីវិត ដោយសារលោកពុំចាប់យកឱកាសនោះ ព្រះអម្ចាស់បានមានបន្ទូលថា ‹ អ្នកពុំបានធ្វើតទៅទៀត ដូចជាអ្នកបានចាប់ផ្ដើមឡើយ › ។ តើនោះវាស្រដៀងគ្នាទៅនឹងអ្នកទាំងឡាយដែលបានទទួលការណែនាំហើយតែបែរជាបោះបង់ចោលដោយសារតែគំនិតទីពីរ និងការសង្ស័យកើតមាននោះយ៉ាងដូចម្ដេច ?. . .

« . . . បន្ទាប់ពីអ្នកបានទទួលសារលិខិត បន្ទាប់ពីអ្នកបានបង់ថ្លៃដើម្បីដឹងពីក្ដីស្រឡាញ់របស់ទ្រង់ ហើយស្ដាប់តាមព្រះបន្ទូលទ្រង់ហើយ សូមបន្ដឆ្ពោះទៅមុខ ។ សូមកុំខ្លាច កុំស្ទាក់ស្ទើរ កុំគិតលើរឿងដែលពុំសំខាន់ កុំរអ៊ូរទាំ ។. . . សូមលះចោលនូវភាពភ័យខ្លាចរបស់អ្នក ហើយដើរដោយក្លាហានដោយជើងទាំងពីររបស់អ្នក » ( Cast Not Away Therefore Your Confidence, » *Ensign,* ខែ មិនា ឆ្នាំ ២០០០, ទំព័រ១០ ) ។

- តើនៅពេលណា ដែលអ្នកបានទទួលចម្លើយមួយមកពីព្រះអម្ចាស់ ហើយបានធ្វើតាមដោយពុំស្ទាក់ស្ទើរនោះ ? ( សូមប្រាកដថាសិស្សយល់ថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ ។ )

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៧–១០

*ព្រះអម្ចាស់បើកសម្ដែងគោលការណ៍នៃការគ្រប់គ្រងវិវរណៈ*

សូមពន្យល់ថា ព្រះអម្ចាស់ បានបើកសម្ដែងនូវគោលការណ៍សំខាន់មួយ ស្ដីអំពីរបៀបដើម្បីស្វែងរកការដឹកនាំរបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៧–៨ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលមូលហេតុផ្សេងទៀតដែលអូលីវើរ បានមានបញ្ហាដើម្បីទទួលជំនួយរបស់ព្រះអម្ចាស់ក្នុងកិច្ចខិតខំបកប្រែរបស់លោក ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៧ តើអូលីវើរបានសន្និដ្ឋានអ្វី ដែលជារឿងតែមួយគត់ ដែលលោកចាំបាច់ត្រូវធ្វើដើម្បីទទួលបានវិវរណៈ ខណៈដែលលោកបកប្រែនោះ ?
- តើព្រះអម្ចាស់បង្រៀនដល់អូលីវើរ ថាលោកគួរធ្វើអ្វីខ្លះ មុនពេលសុំការណែនាំ ?

នៅពេលសិស្សឆ្លើយ អ្នកអាចផ្ដល់យោបល់ឲ្យពួកគេគូសចំណាំការប្រឹក្សារបស់ព្រះអម្ចាស់ នៅក្នុងបទគម្ពីររបស់ពួកគេ ។ ដើម្បីជួយសិស្សឲ្យវិភាគពីអត្ថន័យនៃខគម្ពីរទាំងនេះ សូមសួរសំណួរដូចតទៅនេះ ៖

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បី « ត្រូវសិក្សាក្នុងគំនិតរបស់អ្នក » នោះ ? ( ដើម្បីពិចារណាអំពីការសម្រេចចិត្ត និងជម្រើសនានា សូមធ្វើការថ្លឹងថ្លែងពីជម្រើសដោយប្រុងប្រយ័ត្ន ) ។ តើអ្នកបានធ្វើការនេះយ៉ាងដូចម្ដេច ពេលអ្នកចាំបាច់ត្រូវធ្វើការសម្រេចចិត្តនោះ ?

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៨ តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះ បន្ទាប់ពីយើងបានសិក្សាអំពីរឿងដែលយើងកំពុងពិចារណានោះ ? ( សូមសម្រេចថាតើជម្រើសមួយណា ដែលយើងជឿថាត្រូវ រួចហើយនាំយកការសម្រេចចិត្តរបស់យើងនោះទៅកាន់ព្រះវរបិតាសួគ៌ក្នុងការអធិស្ឋាន ) ។
- តើមេរៀនអ្វីខ្លះ ដែលយើងអាចរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៨ អំពីអ្វីដែលព្រះអម្ចាស់ រំពឹងឲ្យយើងធ្វើ ពេលយើងស្វែងរកការដឹកនាំ និងការណែនាំរបស់ទ្រង់នោះ ? ( សិស្សអាចនឹងឆ្លើយតបសេចក្ដីពិតមួយចំនួនដូចខាងក្រោម ៖ **ការទទួល និងការទទួលស្គាល់វិវរណៈ តម្រូវឲ្យមានការខិតខំពីផ្នែករបស់យើង ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ។

ដើម្បីជួយសិស្សយល់ពីសេចក្ដីពិតនេះ សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា ការសិក្សាអំពីរឿងមួយក្នុងគំនិតរបស់អ្នក អាចជួយអ្នកឲ្យទទួលវិវរណៈយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់អំពីរបៀបដែលសេចក្ដីពិតនេះ អាចទាក់ទងទៅនឹងស្ថានភាពនានាក្នុងជីវិតរបស់ពួកគេ សូមអានឧទាហរណ៍ដូចខាងក្រោម ។ បន្ទាប់ពីអានវានីមួយៗហើយ សូមអញ្ជើញសិស្សឲ្យពន្យល់ពីរបៀបដែលម្នាក់ៗបានពិពណ៌នាអាចប្រើសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៧–៨ ដើម្បីទទួលវិវរណៈ ៖ ។

១. យុវជនម្នាក់បានទទួលការងារល្អមួយ ប៉ុន្តែតម្រូវឲ្យគាត់ធ្វើការនៅថ្ងៃអាទិត្យ ។ គាត់ព្យាយាមសម្រេចចិត្តថាតើគួរទទួលការងារឬអត់ ។

២. យុវនារីម្នាក់បានគិតអំពីមិត្តដែលនាងសេពគប់ និងឥទ្ធិពលអវិជ្ជមានដែលពួកគេមានមកលើនាង ។ នាងចង់ឈប់ដើរលេងជាមួយពួកគេ ប៉ុន្តែនាងពុំដឹងរបៀបដែលល្អបំផុតដើម្បីដកខ្លួនចេញពីពួកគេនោះទេ ។

៣. យុវនារីម្នាក់ កំពុងគិតនូវអ្វីដែលនាងគួរធ្វើ បន្ទាប់ពីនាងបញ្ចប់វិទ្យាល័យ ។ នាងដឹងថា នាងចង់បន្តការសិក្សា ប៉ុន្តែពុំប្រាកដថា វិទ្យាស្ថានសិក្សាណាមួយ ដែលនាងគួរទៅរៀននោះទេ ។

បន្ទាប់ពីការពិភាក្សាអំពីឧទាហរណ៍ទាំងនេះជាមួយសិស្សក្នុងថ្នាក់ហើយ សូមអនុញ្ញាតឲ្យសិស្សគិតពីបទពិសោធន៍របស់ពួកគេជាមួយនឹងគោលការណ៍នេះ តាមរយៈការសរសេរសំណួរដូចខាងក្រោម នៅលើក្ដារខៀន ៖ *តើអ្នកបានដឹងពីការខិតខំនៅផ្នែករបស់អ្នក បានជួយអ្នកឲ្យទទួលវិវរណៈមកពីព្រះអម្ចាស់នៅពេលណា ?*

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីសំណួរនេះមួយសន្ទុះ ។ បន្ទាប់មក សុំសិស្សពីរបីនាក់ដែលស្ម័គ្រចិត្តចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សដទៃទៀតក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៨ ឡើងវិញ រកមើលរបៀបដែលអូលីវើរ អាចដឹងថាតើការសន្និដ្ឋាន ឬការសម្រេចចិត្តរបស់លោកត្រឹមត្រូវឬអត់នោះ ។

- តើយើងអាចរៀនមកពី ខ ៨ អំពីរបៀបដែលព្រះអម្ចាស់ឆ្លើយសំណួររបស់យើងយ៉ាងដូចម្ដេច ? (**វិវរណៈ អាចកើតមានមក តាមរយៈអារម្មណ៍របស់យើង ពេលយើងសូមការដឹកនាំពីព្រះអម្ចាស់ ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ។

អ្នកអាចបញ្ជាក់ថា ការបណ្ដាលឲ្យទ្រូងខ្លួនខ្មាញ់ ដែលបានសន្យាដល់អូលីវើរ គឺជាវិធីតែមួយគត់ដែលព្រះវិញ្ញាណអាចបញ្ជាក់ជម្រើសត្រឹមត្រូវមួយ ។ ការបញ្ជាក់ពីព្រះវិញ្ញាណ អាចកើតមានតាមវិធីផ្សេងៗ ដែលផ្ទាល់ខ្លួន និងបំភ្លឺគំនិត ។

ដើម្បីជួយសិស្សយល់ពីរបៀបដែលព្រះអម្ចាស់ អាចបណ្ដាលឲ្យយើង « មានអារម្មណ៍ថា [ ការសម្រេចចិត្តមួយ ] ត្រឹមត្រូវ » ( គ. និង ស. ៩:៨) សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពន្យល់ដូចខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កុត ៖



« អារម្មណ៍សុខសាន្ត គឺជាសាក្សីបញ្ជាក់ដ៏សាមញ្ញបំផុតដែលខ្ញុំបានទទួលបទពិសោធន៍ផ្ទាល់ខ្លួន ។ ពេលខ្ញុំខ្វល់ខ្វាយខ្លាំងអំពីរឿងសំខាន់មួយ លំបាកក្នុងការដោះស្រាយវាដោយគ្មានជោគជ័យ ខ្ញុំបានបន្តកិច្ចខិតខំទាំងនោះដោយសេចក្ដីជំនឿ ។ ក្រោយមកភាពសុខសាន្តប្រកបដោយអានុភាពបំផុតមួយបានកើតមាន ម្រាប់កង្វល់របស់ខ្ញុំ ដូចដែលទ្រង់បានសន្យាដូច្នោះមែន » ( Using the Supernal Gift of Prayer » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ១០ ) ។

- តើអ្នកបានទទួលអារម្មណ៍ថាព្រះអម្ចាស់បានបញ្ជាក់ពីការសម្រេចចិត្តមួយ ដែលអ្នកបានធ្វើនៅពេលណា ? តើការបញ្ជាក់នោះធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ? ( សូមរំឭកសិស្សថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ ឬរឿងផ្ទាល់ខ្លួនច្រើនពេកនោះទេ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៩ ឲ្យឮៗ ។ សូមឲ្យសិស្សប្រាប់ឃ្លា ដែលពិពណ៌នាអំពីរបៀប ដែលយើងអាចដឹង បើសិនជាការសម្រេចចិត្តមួយ ដែលយើងបានធ្វើពុំត្រឹមត្រូវ ។ ដើម្បីជួយសិស្សយល់ឃ្លា « អាប់គំនិត » សូមអញ្ជើញសិស្សម្នាក់អានសេចក្ដីថ្លែងដូចខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កត ដែលលោកបានពន្យល់ពីបទពិសោធន៍មួយ ដែលជាការអាប់គំនិត ៖



« [ ការអាប់គំនិត ] នោះ សម្រាប់ខ្ញុំគឺជាអារម្មណ៍ពុំសុខស្រួល ពុំស្ងប់ » ( « Using the Supernal Gift of Prayer, » ទំព័រ១០ ) ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ នូវអ្វីដែលពួកគេបានរៀន អំពីការទទួលវិវរណៈ ដែលអាចជួយពួកគេធ្វើការសម្រេចចិត្តសំខាន់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩ :១២–១៤

*ព្រះអម្ចាស់ លើកទឹកចិត្តដល់អូលីវើរ ដើម្បីបន្តនៅក្នុងកិច្ចការដែលលោកត្រូវបានហៅឲ្យធ្វើ*

សូមរំឭកសិស្សអំពីការហៅបម្រើរបស់អូលីវើរ ដើម្បីធ្វើជាស្មៀនសម្រាប់ព្យាការី ( សូមមើល គ. និង ស. ៩:១, ៤ ) ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:១២–១៤ ដោយស្ងាត់ស្ងៀម រកមើលពាក្យឬឃ្លា ដែលយ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី អាចរកឃើញថាជាការលើកទឹកចិត្តនៅពេលនេះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយពាក្យ និងឃ្លានានា ដែលពួកគេរកឃើញថាមានអត្ថន័យ ហើយពន្យល់ពីមូលហេតុ ។

ដើម្បីបញ្ចប់មេរៀននេះ អ្នកអាចចែកចាយទីបន្ទាល់របស់អ្នក ដែលយើងអាចទទួលវិវរណៈផ្ទាល់ខ្លួន ពេលយើងធ្វើតាម គោលការណ៍ដែលបានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩ ។

មេរៀនទី១៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា១១:–១២

## បុព្វកថា

មិនយូរប៉ុន្មានបន្ទាប់ពីការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន ក្នុងខែ ឧសភា ឆ្នាំ១៨២៩ បុរសពីរនាក់បានមកជួបនឹងព្យាការី យ៉ូសែប ស្ម៊ីធ នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ៖ បងប្រុសរបស់យ៉ូសែប ស្ម៊ីធ ឈ្មោះហៃរ៉ុម និង យ៉ូសែប ណៃត សីញ៉័រ ។ បុរសទាំងពីរនាក់បានបង្ហាញពីបំណងដើម្បីបម្រើព្រះ ហើយជួយនៅក្នុងការស្ដារឡើងវិញនៃដំណឹងល្អ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា១១ កត់ត្រាវិវរណៈរបស់ព្រះអម្ចាស់ទៅកាន់ហៃរុមស្ម៊ីធ ស្ដីអំពីរបៀបដែលគាត់អាចស្ថាបនាបុព្វហេតុនៃក្រុងស៊ីយ៉ូន ។ គោលលទ្ធិ និង សេចក្ដីសញ្ញា១២ កត់ត្រាវិវរណៈរបស់ព្រះអម្ចាស់ទៅកាន់យ៉ូសែបណៃត សីញ៉័រ និងរបៀបដែលគាត់អាចជួយស្ថាបនាបុព្វហេតុនៃក្រុងស៊ីយ៉ូនផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១–១៤

*ហៃរុម ស្ម៊ីធ បានរៀនអំពីរបៀបដែលគាត់ អាចជួយស្ថាបនាបុព្វហេតុនៃក្រុងស៊ីយ៉ូន*

សូមឲ្យសិស្សគិតអំពី គ្រាមួយដែលពួកគេចង់ចូលរួម ឬរួមចំណែកនៅក្នុងសកម្មភាពឬបុព្វហេតុដ៏មានប្រយោជន៍មួយ ដូចជាការរៀបចំផែនការសកម្មភាពសាសនាចក្រមួយ ការធ្វើការបម្រើដល់នរណាម្នាក់ដែលខ្វះខាត ឬការចូលរួមចំណែកនៅក្នុងក្លឹបសាលា ឬអង្គការមួយ ។

- តើអ្នកចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីចូលរួមនៅក្នុងសកម្មភាព ឬបុព្វហេតុនោះ ? ( សិស្សអាចឲ្យយោបល់រឿងដូចជាចុះឈ្មោះ បំពេញទម្រង់បែបបទ និយាយទៅនរណាម្នាក់ដែលគ្រប់គ្រង ឬសកម្មភាពដទៃទៀតដែលបង្ហាញពីបំណងចូលរួមរបស់ពួកគេ ) ។

សូមអញ្ជើញសិស្សឲ្យអានក្បាលកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា១១ និង ១២ រកមើលឈ្មោះរបស់បុគ្គលពីររូបដែលមានបំណងចង់ចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ បន្ទាប់មកអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១១:២៧ និង ១២:៧ ដោយស្ងាត់ស្ងៀម ហើយចង្អុលបង្ហាញនរណាផ្សេងទៀតដែលព្រះអម្ចាស់បានអញ្ជើញឲ្យមកជួយកិច្ចការរបស់ទ្រង់ ។

- តើនរណាផ្សេងទៀត ដែលព្រះអម្ចាស់បានអញ្ជើញឲ្យមកជួយកិច្ចការរបស់ទ្រង់ ? ( គឺអស់អ្នកទាំងឡាយដែលមានបំណងជួយទ្រង់ ) ។

ដើម្បីជួយសិស្សយល់បរិបទនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា១១ សូមពន្យល់ថា វិវរណៈក្នុងកណ្ឌនេះ ត្រូវបានផ្ដល់ទៅកាន់ហៃរុម ស្ម៊ីធ ដែលមកពីប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក ទៅកាន់ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ដើម្បីជួបនឹងប្អូនប្រុសរបស់លោកយ៉ូសែប ។ ហៃរុមទំនងជាបានដឹងជាមុនអំពីព្រឹត្តការថ្មីៗ ដូចជាការរីកចម្រើននៅក្នុងការបកប្រែព្រះគម្ពីរមរមន ។ គាត់ចង់ដឹងអំពីរបៀបដែលគាត់អាចជួយយ៉ូសែបនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ យ៉ូសែប បានទូលសូមដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈនេះ ។ ( ដើម្បីជួយសិស្សស្គាល់ពីសារៈសំខាន់ នៃបំណងប្រាថ្នា ដែលដើរតួយ៉ាងសំខាន់ក្នុងកិច្ចការរបស់ព្រះអម្ចាស់ នោះអ្នកអាចនឹងចង់ឲ្យយោបល់ដល់ពួកគេឲ្យគូសចំណាំពាក្យ *បំណងចង់*, *ប្រាថ្នា* និង *ចង់បាន* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១១:៣, ៨,១០,១៤,១៧, ២១, ២៧ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១១:៥–៩ ដោយស្ងាត់ស្ងៀម ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់ប្រាប់អំពីពរជ័យទាំងឡាយដែលព្រះអម្ចាស់បានសន្យាដល់ហៃរុម ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ទៀត ឲ្យប្រាប់អំពីអ្វីដែលហៃរុម នឹងត្រូវធ្វើដើម្បីទាមទារពរជ័យទាំងនេះ ។ ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចាំបាច់ត្រូវបញ្ជាក់ថា « សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ » [ គ. និង ស.១១:៧ ] គឺជាសេចក្ដីពិតខាងវិញ្ញាណដែលត្រូវបានស្គាល់តែតាមរយៈវិវរណៈប៉ុណ្ណោះ ) ។

- តើសេចក្ដីពិតអ្វីខ្លះដែលយើងអាចរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា១១:៨ អំពីបំណងចង់ធ្វើកិច្ចការរបស់ព្រះអម្ចាស់ ? ( នៅពេលសិស្សឆ្លើយតប សូមគូសបញ្ជាក់នូវសេចក្ដីពិតដូចខាងក្រោម ៖ **(១) យើងអាចទទួលបានពរជ័យមកពីព្រះ ស្របតាមបំណងប្រាថ្នាសុចរិតរបស់យើង ។ (២) បើយើងមានបំណងចង់ធ្វើកិច្ចការរបស់ព្រះ នោះយើងនឹងទៅជាមធ្យោបាយនៃការធ្វើល្អដ៏ច្រើន ។**

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បី « នឹងក្លាយទៅជាមធ្យោបាយនៃការធ្វើល្អដ៏ច្រើន » ក្នុងជំនាន់របស់ខ្ញុំ ?*

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១០–១៤ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការប្រឹក្សាដែលព្រះអម្ចាស់បានប្រទានដល់ហៃរុម ដែលនឹងជួយទ្រង់សម្រេចការល្អដ៏ច្រើននេះ ។ នៅពេលសិស្សបញ្ចប់ការអាន សូមអញ្ជើញសិស្សពីរបីនាក់ឲ្យសរសេរអ្វីដែលពួកគេរកឃើញ តាមសំណួរលើក្ដារខៀន ។ ( អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យចម្លងបញ្ជីនេះដាក់ក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ) ។ ( ពួកគេនឹងបន្ថែមក្នុងបញ្ជីពេលបន្តមេរៀនទៅមុខទៀត ) ។

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បីដាក់ទីទុកចិត្តរបស់អ្នកលើព្រះវិញ្ញាណ ?

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១២–១៣ តើអ្នកអាចស្គាល់ឥទ្ធិពលនៃព្រះវិញ្ញាណបានយ៉ាងដូចម្ដេច ? ( សិស្សអាចប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្ដីពិតដូចខាងក្រោម ៖ **(១) ព្រះវិញ្ញាណនៃព្រះអម្ចាស់ ដឹកនាំយើងឲ្យធ្វើល្អ រាបសារ និងវិនិច្ឆ័យដោយសុចរិត ។ ( (២) ព្រះវិញ្ញាណបំភ្លឺគំនិតរបស់យើង ហើយបំពេញព្រលឹងរបស់យើងដោយសេចក្ដីអំណរ ) ។**

នៅពេលអ្នកពិភាក្សាពីសេចក្ដីពិតទាំងនេះ អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យរំឭកចំណេះចំណានខគម្ពីរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣ ។ អ្នកអាចនឹងចង់ឲ្យយោបល់សិស្សឲ្យសរសេរសេចក្ដីយោងចំណេះចំណានខគម្ពីរ នៅក្នុងរឹមទំព័រជិតនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១២–១៤ ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១២–១៣ តើព្រះវិញ្ញាណអាចមានឥទ្ធិពលមកលើគំនិតនិងដួងចិត្តយើងតាមរបៀបមួយចំនួនអ្វីខ្លះ ?

- តើអ្នកធ្លាប់មានបទពិសោធន៍ពីឥទ្ធិពលនៃព្រះវិញ្ញាណតាមរបៀបមួយនៃរបៀបទាំងនេះនៅពេលណា ? តើបទពិសោធន៍នេះនាំអ្នកឲ្យ « ធ្វើល្អ » យ៉ាងដូចម្ដេចខ្លះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា១១ :១៥–៣០

*ព្រះអម្ចាស់ បញ្ជាហៃរុម ស្មឺធ ឲ្យរៀបចំខ្លួនសម្រាប់ការហៅឲ្យផ្សព្វផ្សាយ*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១៥–១៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យ យ៉ូសែប ស្មឺធ និងដៃគូរបស់លោកធ្វើ ។ សូមជួយសិស្សឲ្យយល់ថា ហៃរុម ស្មឺធ ពុំត្រូវបានបញ្ជាឲ្យផ្សព្វផ្សាយឡើយរហូតដល់លោកត្រូវបានហៅឲ្យធ្វើកិច្ចការនោះសិន ។

- ស្របតាមខគម្ពីរនេះ ហេតុអ្វីហៃរុម ស្មឺធ ត្រូវ « ចាំបន្តិច » មុនពេលគាត់ត្រូវបានហៅឲ្យផ្សព្វផ្សាយដំណឹងល្អដូច្នេះ ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ឃ្លា « លុះត្រាអ្នកនឹងបានព្រះបន្ទូលរបស់យើង ថ្មដារបស់យើង សាសនាចក្ររបស់យើង និងដំណឹងល្អរបស់យើង » សំដៅទៅលើកត្ដាពិតថា សាសនាចក្រពុំទាន់ត្រូវបានរៀបចំ ហើយព្រះគម្ពីរមរមនពុំទាន់បានឃើញមានបោះពុម្ពនៅឡើយ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១៧–២០ ឲ្យឮៗ នៅពេលសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទៅហៃរុម ថាចាំបាច់ត្រូវធ្វើដើម្បីក្លាយជាអ្នកផ្សព្វផ្សាយដំណឹងល្អដ៏មានប្រសិទ្ធភាព ។ អ្នកអាចនឹងចង់បន្ថែមពីលើចម្លើយរបស់សិស្ស ចូលក្នុងតារាងនៅលើក្ដារខៀន ។ អ្នកអាចចង់អញ្ជើញសិស្សដើម្បីសរសេរចម្លើយរបស់ពួកគេទុក ។

- តើអ្នកគិតថា ការនៅជាប់នឹងព្រះអម្ចាស់ដោយអស់ពីដួងចិត្តរបស់អ្នកនោះ វាមានន័យយ៉ាងណា ? ( អ្នកអាចចាំបាច់ត្រូវពន្យល់ថា បរិបទនេះ ពាក្យ *នៅជាប់* មានន័យថា គោរពតាមអ្វីមួយដោយម៉ឺងម៉ាត់ ឬពុំរារែក ) ។

- តើឃ្លាអ្វីខ្លះ ត្រូវបានថ្លែងដដែលៗនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១១:១៨ និង ២០ ? ( អ្នកអាចនឹងចង្អុលបង្ហាញផងដែរថា ឃ្លា « ការរក្សាបទបញ្ញត្តិរបស់ខ្ញុំ » ក៏មាននៅក្នុង ខ ៦ និង ៩ ផងដែរ ) ។

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ការរក្សាបទបញ្ញត្តិរៀបចំយើងខាងវិញ្ញាណដើម្បីធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។**

- តើការរក្សាបទបញ្ញត្តិនៅថ្ងៃនេះ រៀបចំអ្នកសម្រាប់ការបម្រើផ្សព្វផ្សាយសាសនា អាពាហ៍ពិពាហ៍ និងការបម្រើក្នុងសាសនាចក្រនៅឆ្នាំខាងមុខៗយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១១:២១–២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីផ្សេងទៀតដែល ហៃរុម ចាំបាច់ត្រូវធ្វើដើម្បីជួយគាត់អាចក្លាយជាអ្នកផ្សព្វផ្សាយដំណឹងល្អកាន់តែមានប្រសិទ្ធភាព ។

- តើព្រះអម្ចាស់ប្រាប់ហៃរុមថា គាត់នឹងត្រូវការធ្វើអ្វីខ្លះ ដើម្បីអាចប្រកាសព្រះបន្ទូលទ្រង់ចំពោះប្រជាជន ? ( អ្នកអាចនឹងចង់បន្ថែម *ការសិក្សាព្រះគម្ពីរ* ចូលក្នុងតារាងនៅលើក្ដារខៀន) ។
- តើការសិក្សាព្រះគម្ពីរដើម្បីស្គាល់ព្រះបន្ទូលព្រះ ខុសគ្នាពីការគ្រាន់តែអានព្រះគម្ពីរយ៉ាងណា ?
- តើព្រះអម្ចាស់បានសន្យាជាមួយហៃរុម និងអ្នកដទៃដែលធ្វើតាមគំរូ ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១១:២១–២២ អ្វីខ្លះ ? ( សិស្សគួរតែប្រាប់គោលការណ៍ដូចខាងក្រោម ៖ **អ្នកទាំងឡាយដែលសិក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ នឹងទទួលព្រះវិញ្ញាណទ្រង់ និងអំណាចដើម្បីបញ្ចុះបញ្ចូលអ្នកដទៃឲ្យជឿសេចក្ដីពិតនៃដំណឹងល្អ** ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា១២

*ព្រះអម្ចាស់ ប្រឹក្សាដល់យ៉ូសែប ណៃត អំពីរបៀបស្ថាបនាបុព្វហេតុនៃក្រុងស៊ីយ៉ូន*

បង្ហាញសិស្សនូវឈ្មោះរបស់បុគ្គលល្បីៗពីរបីនាក់ ។ សួរប្រសិនបើពួកគេធ្លាប់ឮអំពីបុគ្គលម្នាក់ៗដែលអ្នកបានប្រាប់ ហើយពន្យល់សង្ខេបៗអំពីមូលហេតុដែលពួកគេល្បីល្បាញ ។ រួចសួរប្រសិនបើពួកគេធ្លាប់ឮឈ្មោះបុរសម្នាក់ឈ្មោះ យ៉ូសែប ណៃត ស៊ីញ៉រ ។

- សូមគិតអំពីបុគ្គលម្នាក់ៗក្នុងវួដឬសាខារបស់អ្នកដែលបម្រើដោយស្មោះត្រង់ និងដោយស្ងប់ស្ងាត់ ។ តើពួកគេកំពុងជួយយ៉ាងដូចម្ដេច ដើម្បីស្ថាបនានគររបស់ព្រះ ?

ដើម្បីជួយសិស្សរៀនអំពីយ៉ូសែប ណៃត ស៊ីញ៉រ និងការបរិច្ចាគរបស់គាត់ ចំពោះការស្ដារឡើងវិញនៃដំណឹងល្អ សូមអញ្ជើញសិស្សឲ្យអានឮៗក្នុងសេចក្ដីផ្ដើមកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា១២ ។ សូមពន្យល់ថា យ៉ូសែប ណៃត ស៊ីញ៉រ ពុំសូវមានគេស្គាល់នៅសព្វថ្ងៃនេះទេ ប៉ុន្តែគាត់បានផ្គត់ផ្គង់ដល់ព្យាការី យ៉ូសែប ស្ម៊ីធ នូវម្ហូបអាហារ និងសម្ភារដទៃទៀត អំឡុងពេលធ្វើការដ៏សំខាន់នៃការបកប្រែព្រះគម្ពីរមរមន ។ គោលលទ្ធិ និង សេចក្ដីសញ្ញា១២ កត់ត្រាវិវរណៈមួយដែលព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស៊្មីធ សម្រាប់យ៉ូសែប ណៃត ស៊ីញ៉រ ក្នុងខែឧសភា ឆ្នាំ១៨២៩ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១២:៦–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ប្រាប់អំពីលក្ខណៈសម្បត្តិសុចរិតនៃអ្នកទាំងឡាយដែលចង់ជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់ គួរតែមាន ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា១២:៨ តើលក្ខណៈសម្បត្តិអ្វីខ្លះ ដែលព្រះអម្ចាស់តម្រូវឲ្យមានចំពោះអ្នកទាំងឡាយដែលចង់ជួយក្នុងកិច្ចការរបស់ទ្រង់ ?
- តើអ្នកអភិវឌ្ឍលក្ខណៈសម្បត្តិទាំងនេះក្នុងជីវិតរបស់អ្នកដូចម្ដេច ?

សូមប្រាប់សិស្សថា យ៉ូសែប ណៃត ស៊ីញ៉រ បានព្យាយាមយ៉ាងខ្ជាប់ខ្ជួនដើម្បីអភិវឌ្ឍ និងអនុវត្តលក្ខណៈសម្បត្តិសុចរិតទាំងនេះ ។ គាត់បានផ្ដល់ជំនួយខាងសាច់ឈាម និងខាងវិញ្ញាណដល់យ៉ូសែប ស៊្មីធ ក្នុងអំឡុងពេលនៃការបម្រើរបស់ព្យាការី ។ ជាច្រើនឆ្នាំបន្ទាប់ពី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១២ លោកបានកត់ត្រាដូចខាងក្រោម ស្ដីអំពីសេចក្ដីស្មោះត្រង់របស់ យ៉ូសែប ណៃត ៖



« យ៉ូសែប ណៃត ស៊ីនញ៉រ. . . បានស្មោះ ហើយពិត ហើយជាគំរូល្អ និងល្អចំពោះមនុស្សគ្រប់រូប ប្រកបដោយគុណធម៌ និងចិត្តល្អ ពុំដែលងាករេឡើយ ។. . . គាត់ជាមនុស្សសុចរិតម្នាក់ » ( *History of the Church*, ៥:១២៤ ) ។

ដើម្បីលើកទឹកចិត្តដល់សិស្សឲ្យនឹកគិត និងអនុវត្តនូវអ្វីដែលពួកគេបានរៀននៅថ្ងៃនេះ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវរបៀបដែលពួកគេបញ្ចប់ឃ្លាដូចខាងក្រោមនេះ ៖ « ដើម្បីជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់ ខ្ញុំនឹង. . . »

អ្នកក៏អាចចង់បញ្ចប់ដោយការបង្ហាញពីរបៀបដែលអ្នកនឹងបញ្ចប់ឃ្លានេះ ។

មេរៀនទី១៩

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ១:៦៨–៧៥, គោលលទ្ធិ និង សេចក្ដីសញ្ញា១៣

## បុព្វកថា

នៅថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី បានទៅក្នុងព្រៃជិតចម្ការរបស់យ៉ូសែប នៅហាម៉ូនី រដ្ឋផែនសិលវេញ៉ា ដើម្បីទូលសូមសួរដល់ព្រះអម្ចាស់បន្ទាប់ពីការបកប្រែវគ្គគម្ពីរមួយ ក្នុងព្រះគម្ពីរមរមន ដែលគូសបញ្ជាក់ពីសារៈសំខាន់នៃពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក ។ ខណៈដែលកំពុងតែអធិស្ឋាន នោះយ៉ូហាន បាទីស្ទ បានលេចមកឯពួកលោក ក្នុងនាមជាតួអង្គដែលបានរស់ឡើងវិញ ។ លោកបានប្រទានបព្វជិតភាពអើរ៉ុនមកលើពួកលោក បានដឹកនាំពួកលោកឲ្យជ្រមុជទឹកគ្នាទៅវិញទៅមកក្នុងទន្លេ សុសគ្វីហាណានៅជិតនោះ រួចហើយបានដឹកនាំពួកលោកឲ្យតែងតាំងអំណាចបព្វជិតភាពអើរ៉ុនដល់គ្នាទៅវិញទៅមក ។ ពាក្យរបស់យ៉ូហានទៅកាន់យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា១៣ ។ បន្ទាប់ពីបុណ្យជ្រមុជទឹករបស់ពួកលោក យ៉ូសែប និង អូលីវើរ ត្រូវបានពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបានទទួលបទពិសោធន៍ពរជ័យដ៏មហិមា ។

## យោបល់សម្រាប់ការបង្រៀន

### យ៉ូសែប ស្ម៊ីធ –ប្រវត្តិ១:៦៨–៧២; គោលលទ្ធិ និង សេចក្ដីសញ្ញា១៣

*យ៉ូហាន បាទីស្ទ ប្រគល់បព្វជិតភាពអើរ៉ុនមកឲ្យយ៉ូសែប ស្ម៊ីធ និង អូលីវើរខៅឌើរី*

សូមសរសេរ សំណួរដូចខាងក្រោមនៅលើក្ដារខៀនមុនពេលរៀន ឬចែកក្រដាសសំណួរដល់សិស្សម្នាក់ៗ ( សូមកុំសរសេរចម្លើយឡើយ ) ។ នៅពេលសិស្សមកដល់ថ្នាក់រៀន សូមអញ្ជើញពួកគេឲ្យឆ្លើយសំណួរនៅលើក្រដាសមួយសន្លឹក ឬនៅលើក្រដាសដែលចែកឲ្យពួកគេនោះ ។ បើចាំបាច់ សូមឲ្យយោបល់ដល់ពួកគេឲ្យប្រើលិបិក្រមនៃបណ្ដុំព្រះគម្ពីរ ( សូមមើល « បព្វជិតភាព អើរ៉ុន » ) ឬ សេចក្ដីណែនាំដល់បទគម្ពីរ ( សូមមើល « បព្វជិតភាព អើរ៉ុន » ) ដើម្បីរកចម្លើយត្រឹមត្រូវ ។ អ្នកអាចនឹងចង់រង់ចាំរហូតដល់ សិស្សបានកត់ត្រាចម្លើយរបស់ពួកគេរួច មុនពេលអ្នកចាប់ផ្ដើមការប្រជុំធម្មនិដ្ឋាន ។

> ១. *តើនៅកន្លែងណាក្នុងបទគម្ពីរ ដែលយើងអាចរៀនអំពីការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន ?*
>
> ២. *តើបព្វជិតភាពអើរ៉ុនបានស្ដារឡើងវិញនៅថ្ងៃខែឆ្នាំណា ?*
>
> ៣. *តើទេវតាដែលស្ដារបព្វជិតភាពអើរ៉ុនមកកាន់ផែនដីវិញ តាមរយៈការប្រគល់វាទៅឲ្យយ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី ឈ្មោះអ្វី ?*
>
> ៤. *តើបព្វជិតភាពអើរ៉ុនបានប្រគល់ទៅដល់ពួកលោកដោយរបៀបណា ?*
>
> ៥. *តើទេវតាបានសន្យានឹងយ៉ូសែប និង អូលីវើរ ថាពួកគេនឹងទទួលបានអ្វីខ្លះទៀត ? តើពួកគេនឹងទទួលវាមកពីនរណា ?*

( ចម្លើយ ៖ (១) យ៉ូសែប ស្ម៊ីធ –ប្រវត្តិ ឬ គោលលទ្ធិ និង សេចក្ដីសញ្ញា១៣, (២) ថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ១៨២៩ [ សូមមើល យ៉ូសែប ស្ម៊ីធ –ប្រវត្តិ១:៧២ ]; (៣) យ៉ូហាន បាទីស្ទ [ សូមមើល យ៉ូសែប ស្ម៊ីធ –ប្រវត្តិ១:៧២ ]; (៤) ដោយការដាក់ដៃលើ [ សូមមើល យ៉ូសែប ស្ម៊ីធ –ប្រវត្តិ១:៦៨, ៧១ ]; (៥) យ៉ូហាន បាទីស្ទ បានប្រាប់ពួកគាត់ថា ថ្ងៃក្រោយពួកគាត់នឹងទទួលបព្វជិតភាពមិលគីស្សាដែកមកពីសាវក ពេត្រុស យ៉ាកុប និងយ៉ូហាន [ សូមមើល យ៉ូសែប ស្ម៊ីធ–ប្រវត្តិ១:៧២ ] ) ។

បន្ទាប់ពីការប្រជុំធម្មនិដ្ឋាន សូមឲ្យសិស្សចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរទីមួយ ។ បន្ទាប់ពីពួកគេបានឆ្លើយសំណួរនេះដោយត្រឹមត្រូវ សូមចាត់តាំងសិស្សឲ្យធ្វើការជាគូៗ ហើយពិនិត្យចម្លើយរបស់ពួកគេជាមួយសំណួរទាំងឡាយដែលនៅសល់ ។ ណែនាំពួកគេឲ្យប្រើ យ៉ូសែប ស្ម៊ីធ –ប្រវត្តិ១:៦៨–៧២ និងការពិពណ៌នាដោយ អូលីវើរ ខៅឌើរី បន្ទាប់ពីយ៉ូសែប ស្ម៊ីធ –ប្រវត្តិ ។ អ្នកក៏អាចផ្លាស់វេនគ្នាទូទាំងថ្នាក់រៀន ដើម្បីជួយសិស្សស្វែករកចម្លើយត្រឹមត្រូវ ។

បន្ទាប់ពីមានពេលគ្រប់គ្រាន់ សូមរំឭកចម្លើយជាមួយគ្នាក្នុងថ្នាក់ ។ នៅពេលអ្នកមើលចម្លើយទាំងនោះជាមួយគ្នា សូមជួយសិស្សប្រាប់ និងយល់នូវគោលលទ្ធិដូចខាងក្រោម ៖ **យ៉ូហាន បាទីស្ទ បានស្ដារបព្វជិតភាពអើរ៉ុនមកកាន់ផែនដីវិញ**( សូមមើល យ៉ូសែប ស្ម៊ីធ —ប្រវត្តិ១:៧២ ) ។ **បព្វជិតភាព គឺត្រូវបានប្រគល់ដោយការដាក់ដៃលើ**( សូមមើល យ៉ូសែប ស្ម៊ីធ —ប្រវត្តិ១:៦៨, ៧១ ) ។ ផងដែរ នៅពេលអ្នកពិនិត្យមើលចម្លើយរបស់សិស្ស សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរ បានទទួលបព្វជិតភាពមិលគីស្សាដែកពី ពេត្រុស យ៉ាកុប និង យ៉ូហាន ក្រោយមកនៅខែ ឧសភា ឆ្នាំ១៨២៩ ( សូមមើល ឡារី ស៊ី ផតធើរ« The Restoration of the Aaronic and Melchizedek Priesthoods, » *Ensign* ខែ ធ្នូ ឆ្នាំ១៩៩៦, ទំព័រ ៣០–៤៧ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស្ម៊ីធ —ប្រវត្តិ១:៦៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែល យ៉ូសែប និងអូលីវើរ កំពុងធ្វើ ដែលដឹកនាំពួកលោកឲ្យទូលសួរដល់ព្រះអម្ចាស់ អំពីពិធីបុណ្យជ្រមុជទឹកសម្រាប់ការផ្ដាច់បាប ។

- ស្របតាមខគម្ពីរនេះ តើអ្វីខ្លះដែលបាននាំឲ្យ យ៉ូសែប និង អូលីវើរ សួរអំពីពិធីបុណ្យជ្រមុជទឹកសម្រាប់ការផ្ដាច់បាប ? ( ពួកគេកំពុងបកប្រែព្រះគម្ពីរមរមន ហើយបានមកឃើញការបង្រៀនស្ដីអំពីពិធីបុណ្យជ្រមុជទឹក សម្រាប់ការផ្ដាច់បាប ) ។

សូមចង្អុលបង្ហាញថា ការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន គឺសំខាន់យ៉ាងខ្លាំង ដែលពាក្យរបស់យ៉ូហានបាទីស្ទ ត្រូវបានដាក់បញ្ចូលនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ជាកណ្ឌទី១៣ ។ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីរបៀបដែលការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន បានឆ្លើយតបដល់ការអធិស្ឋានរបស់ យ៉ូសែប និង អូលីវើរ ដើម្បីដឹងច្រើនទៀតអំពីពិធីបុណ្យជ្រមុជទឹក សម្រាប់ការផ្ដាច់បាប ។

- តើការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុនឆ្លើយតបចំពោះការអធិស្ឋានរបស់យ៉ូសែប និង អូលីវើរ ដើម្បីដឹងច្រើនទៀតអំពីពិធីបុណ្យជ្រមុជទឹក សម្រាប់ការផ្ដាច់បាប យ៉ាងដូចម្ដេចខ្លះណា ?

នៅលើក្ដារខៀន សូមគូររូបភាពទ្វារដែលមានរន្ធសោ ។





- តើគោលបំណងនៃទ្វារមួយនេះជាអ្វី ? ( នៅពេលសិស្សពិភាក្សាអំពីសំណួរនេះ សូមជួយពួកគេមើលឃើញថា ទ្វារបានបើកឲ្យឃើញកន្លែងមួយទៀត ) ។ បន្ថែមពីលើនោះ ទ្វារអាចបិទឃាំងយើងឬបើកឲ្យយើងចូល ) ។

បង្ហាញសិស្សនូវកូនសោមួយ ( ឬគូររូប កូនសោដ៏សាមញ្ញមួយ នៅលើក្ដារខៀន) ហើយសួរសំណួរដូចខាងក្រោម ៖

- តើកូនសោមួយទាក់ទងទៅនឹងដំណើរការរបស់ទ្វាយ៉ាងដូចម្ដេច ? ( ចាក់សោបិទ ឬចាក់សោបើកទ្វារ ។ នៅពេលយើងប្រើកូនសោមួយចាក់បើកទ្វារ នោះវាអាចឲ្យយើងដើរឆ្លងកាត់ ហើយជួបអ្វីដែលនៅឯម្ខាងទៀត ) ។

សូមពន្យល់ថា ព្រះអម្ចាស់ប្រើកូនសោជានិមិត្តរូបមួយ ដើម្បីតំណាងនូវសិទ្ធិអំណាចនៃបព្វជិតភាព ដែលចាក់បើកទ្វារសម្រាប់យើងទទួលនូវឱកាសនិងពរជ័យដ៏អស់កល្បជានិច្ច ។ សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣:១ រកមើលកូនសោដែលជាប់ទាក់ទងទៅនឹងបព្វជិតភាពអើរ៉ុន ។ អ្នកអាចនឹងចង់ស្នើឲ្យសិស្សគូសចំណាំកូនសោទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ពេលពួកគេស្វែងរកវា ។

- តើយ៉ូហានបាទីស្ទ ប្រាប់ថាបព្វជិតភាពអើរ៉ុនកាន់កូនសោអ្វីខ្លះ ? ( **បព្វជិតភាពអើរ៉ុន កាន់កូនសោនៃការបម្រើនៃពួកទេវតា និងនៃដំណឹងល្អនៃការប្រែចិត្ត និង នៃពិធីបុណ្យជ្រមុជទឹកដោយការពន្លិចសម្រាប់ការផ្ដាច់បាប ។** អ្នកអាចនឹងចង់អញ្ជើញសិស្សម្នាក់ឲ្យសរសេរសេចក្ដីថ្លែងការនេះនៅក្រោមរូបភាពនៃទ្វារនៅលើក្ដារខៀន ) ។

ដើម្បីជួយសិស្សយល់កាន់តែប្រសើរអំពីកូនសោនៃបព្វជិតភាពអើរ៉ុនទាំងនេះ និងពរជ័យទាំងឡាយ ដែលវាមានសម្រាប់សមាជិកនៃសាសនាចក្រ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវការពន្យល់ដូចខាងក្រោម ដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ( សូមពិចារណាធ្វើការថតចម្លងសេចក្ដីថ្លែងការណ៍នេះតូចៗសម្រាប់សិស្សម្នាក់ៗ ដើម្បីរក្សានៅក្នុងគម្ពីររបស់ពួកគេ ) ។



« តើបព្វជិតភាពអើរ៉ុនកាន់ [ កូនសោនៃ ] ‹ ដំណឹងល្អនៃការប្រែចិត្ត និងពិធីបុណ្យជ្រមុជទឹក និងការផ្ដាច់បាប › មានន័យយ៉ាងណាខ្លះ ? អត្ថន័យ គឺអាចរកបាននៅក្នុងពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក និងនៅក្នុងពិធីសាក្រាម៉ង់ ។ ពិធីបុណ្យជ្រមុជទឹក គឺសម្រាប់ការផ្ដាច់បាប ហើយពិធីសាក្រាម៉ង់ គឺរំឭកសេចក្ដីសញ្ញា និងពរជ័យទាំងឡាយនៃពិធីបុណ្យជ្រមុជទឹក ។ ទាំងពីរ គួរតែដើរឈានមុខដោយការប្រែចិត្ត ។

« គ្មាន [ យើង ] ណាម្នាក់ បានរស់នៅដោយគ្មានអំពើបាបសោះ ចាប់តាំងពីពិធីបុណ្យជ្រមុជទឹក [ របស់យើង ] ទៅនោះទេ ។ បើគ្មានការផ្ដល់នូវការលាងសម្អាតបន្ថែមខ្លះៗ ក្រោយពីពិធីបុណ្យជ្រមុជទឹកយើងទេ នោះយើងម្នាក់ៗនឹងត្រូវវង្វេងនូវរឿងខាងវិញ្ញាណមិនខាន ។

« យើងត្រូវបានបញ្ជាឲ្យប្រែចិត្តពីអំពើបាបរបស់យើង ហើយមករកព្រះអម្ចាស់ដោយដួងចិត្តសង្រេង និងវិញ្ញាណទន់ទាប ហើយទទួលទានសាក្រាម៉ង់ដោយការគោរពតាមសេចក្ដីសញ្ញានានានៃពិធីសាក្រាម៉ង់ ។ នៅពេលយើងរំឭកពីសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់យើងតាមវិធីនេះ នោះព្រះអម្ចាស់នឹងរំឭកឥទ្ធិពលនៃការលាងសម្អាតនៃពិធីបុណ្យជ្រមុជទឹករបស់យើង ។

« យើងពុំអាចថ្លែងបំផ្លើសពីសារៈសំខាន់នៃបព្វជិតភាពអើរ៉ុនក្នុងនេះនោះទេ ។ ជំហានសំខាន់ៗទាំងអស់នេះ មាននូវការផ្ដាច់បាប ដែលត្រូវធ្វើឡើងតាមរយៈពិធីបរិសុទ្ធនៃការសង្គ្រោះនៃពិធីបុណ្យជ្រមុជទឹក និងការរំឭកពិធីបរិសុទ្ធនៃពិធីសាក្រាម៉ង់ ។ ពិធីបរិសុទ្ធទាំងពីរនេះ គឺត្រូវបានធ្វើឡើងដោយអ្នកកាន់បព្វជិតភាពអើរ៉ុន ក្រោមការដឹកនាំរបស់គណៈប៊ីស្សព ដែលអនុវត្តកូនសោនៃដំណឹងល្អនៃការប្រែចិត្ត និងនៃពិធីបុណ្យជ្រមុជទឹក និងសម្រាប់ការផ្ដាច់បាប » ( « The Aaronic Priesthood and the Sacrament, » *Ensign* ខែ វិច្ឆិកា ឆ្នាំ១៩៩៨, ទំព័រ ៣៧–៣៨ ) ។

- តើកូនសោនៃបព្វជិតភាពអើរ៉ុន ជួយយើងឲ្យទទួលពរជ័យនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

- ស្របតាម អែលឌើរ អូក តើនរណាដឹកនាំកូនសោនៃដំណឹងល្អនៃការប្រែចិត្ត និងពិធីបុណ្យជ្រមុជទឹកនៅក្នុងវួដនីមួយៗ ?

ដើម្បីជួយសិស្សយល់កាន់តែច្បាស់អំពី កូនសោនៃការបម្រើនៃពួកទេវតា សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវការពន្យល់ដូចខាងក្រោម ដោយអែលឌើរ អូក ៖



« ក្នុងនាមជាអ្នកកាន់បព្វជិតភាពអើរ៉ុនវ័យក្មេង ខ្ញុំពុំដែលគិតថា ខ្ញុំនឹងឃើញទេវតាទេ ហើយខ្ញុំបានងឿងឆ្ងល់អំពីលក្ខណៈដូចនោះ មានទាក់ទងអ្វីនឹងបព្វជិតភាពអើរ៉ុន ។

« ប៉ុន្តែការបម្រើនៃពួកទេវតា ក៏អាចជារឿងអាថ៌កំបាំង ។ សារលិខិតរបស់ទេវតា អាចត្រូវបានផ្ដល់ឲ្យដោយសម្លេង ឬដោយគំនិត ឬអារម្មណ៍ទំនាក់ទំនងនៅក្នុងចិត្ត » ( « The Aaronic Priesthood and the Sacrament, » ៣៩ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យមកខាងមុខថ្នាក់ ហើយកាន់រូបភាព យុវជនកំពុងទទួលបុណ្យជ្រមុជទឹក ( *រូបភាពសិល្បៈដំណឹងល្អ* [ ២០០៩ ] លេខ ១០៣ សូមមើលផងដែរ LDS.org) និងការប្រសិទ្ធពរនៃពិធីសាក្រាម៉ង់ ( លេខ ១០៧ ) បើមាន ។





- តើការយល់ដឹងអំពីកូនសោបព្វជិតភាពអើរ៉ុន អាចមានឥទ្ធិពលលើគំនិតនិងសកម្មភាពរបស់អ្នក នៅពេលអ្នកត្រៀមខ្លួនបម្រើ និងទទួលទានសាក្រាម៉ង់រាល់សប្តាហ៍យ៉ាងដូចម្តេចខ្លះ ?

សូមអញ្ជើញយុវនារីម្នាក់ក្នុងថ្នាក់ឲ្យចែកចាយអារម្មណ៍របស់ពួកគេអំពីបព្វជិតភាពអើរ៉ុន និងពរជ័យដែលកើតមាននៅក្នុងជីវិតរបស់ពួកគេ ។ អ្នកក៏អាចចង់ចែកចាយពីមូលហេតុដែលអ្នកមានអំណរគុណចំពោះ ការស្តារឡើងវិញនៃបព្វជិតភាពអើរ៉ុនផងដែរ ។

## យ៉ូសែប ស៊្មីធ—ប្រវត្តិ១:៧៣–៧៥

*យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី បានទទួលបទពិសោធន៍នៃពរជ័យដ៏មហិមា បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់ពួកលោក*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស៊្មីធ —ប្រវត្តិ១:៧៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពាក្យ ឬឃ្លាដែលពិពណ៌នាថា យ៉ូសែប និង អូលីវើរ បានទទួលបទពិសោធន៍អ្វី បន្ទាប់ពីពួកគាត់បានទទួលបុណ្យជ្រមុជទឹករួចហើយនោះ ។ អ្នកអាចស្នើឲ្យសិស្សគូសចំណាំពាក្យ និង ឃ្លាទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- តើមានអ្វីមកសណ្ឋិតលើយ៉ូសែប និងអូលីវើរ បន្ទាប់ពីពួកលោកបានទទួលបុណ្យជ្រមុជទឹក ?

ដោយសារយ៉ូសែប និង អូលីវើរ ពុំទាន់បានទទួល *អំណោយទាន* នៃព្រះវិញ្ញាណបរិសុទ្ធនៅឡើយ នោះអ្វីដែលពួកលោកបានជួបក្នុងស្ថានភាពនេះ គឺជា *ព្រះចេស្តា* នៃព្រះវិញ្ញាណបរិសុទ្ធ ។ យ៉ូសែប និង អូលីវើរ នឹងទទួលបព្វជិតភាពមិលគីស្សាដែកដើម្បីការប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃក្រោយ ( សូមមើល យ៉ូសែប ស៊្មីធ —ប្រវត្តិ១:៧០ សូមមើលផងដែរ Bible Dictionary ឬសេចក្តីណែនាំដល់បទគម្ពីរ « ព្រះវិញ្ញាណបរិសុទ្ធ » scriptures.lds.org ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូសែប ស៊្មីធ —ប្រវត្តិ១:៧៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពរជ័យជាក់លាក់មួយ ដែលយ៉ូសែប និងអូលីវើរ បានទទួលតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ បន្ទាប់ពីសិស្សបានរាយការណ៍នូវអ្វីដែលពួកគេបានរកឃើញហើយ សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្តារខៀន ៖ **ព្រះវិញ្ញាណបរិសុទ្ធជួយយើងយល់អំពីអត្ថន័យ និងបំណងនៃព្រះគម្ពីរ ។**

- ហេតុអ្វីក៏អ្នកគិតថា យើងត្រូវការព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយយើងយល់បទគម្ពីរដូច្នេះ ?

- តើពេលណា ដែលមានព្រះវិញ្ញាណបរិសុទ្ធបានជួយអ្នកឲ្យយល់ « អត្ថន័យនិងបំណងពិត » នៃបទគម្ពីរ ?

អញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទី សរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីអញ្ជើញឲ្យមានការជួយពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលពួកគេសិក្សាព្រះគម្ពីរ ។

មេរៀនទី ២០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦

## បុព្វកថា

នៅចុងខែ ឧសភា ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានស៊ូទ្រាំនឹងការគំរាមគំហែងពីមនុស្សកំណាច ខណៈដែលកំពុងតែបញ្ចប់ការបកប្រែព្រះគម្ពីរមរមន ។ ដេវីឌ វិតមើរ បានជួយពួកគេផ្លាស់ពី ហាម៉ូនី រដ្ឋផែនសិលវេញ៉ា ទៅផ្ទះរបស់វិតមើរ នៅហ្វាយ៉ែត រដ្ឋនូវយ៉ោក ដូច្នេះពួកលោកអាចគេចចេញពីការបៀតបៀន ហើយពួកលោកអាចបង្រៀនដំណឹងល្អដែលបានស្ដារឡើងវិញដល់គ្រួសារ វិតមើរ និងអ្នកជិតខាងពួកគេផងដែរ ។ គ្រួសារ វិតមើរ បានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើព្រឹត្តការណ៍ដែលបានបើកបង្ហាញអំពីការស្ដារឡើងវិញ ។ យ៉ូសែប ស្ម៊ីធ បានពិពណ៌នាអំពី ដេវីឌ វិតមើរ ចន វិតមើរ និង ពេត្រុស វិតមើរ ជុញ្ញ័រ ថាជា « មិត្ត និងជំនួយការដ៏មោះមុតបំផុត នៅក្នុងកិច្ចការ ហើយ. . . រំភើបដើម្បីដឹងអំពីកាតព្វកិច្ចរបស់ពួកគេម្នាក់ៗ » ( *History of the Church,* ១:៤៨–៤៩) ។ ព្យាការីបានអធិស្ឋាន ហើយបានទទួលវិវរណៈសម្រាប់ ដេវីឌ វិតមើរ និង បងប្អូនប្រុសគាត់ ចន និង ពេត្រុស ។ បងប្អូនប្រុសទាំងនេះ បានរៀនអំពីតួនាទីរបស់ពួកគាត់នៅក្នុងការនាំចេញមកនូវកិច្ចការរបស់ព្រះអម្ចាស់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤

*ព្រះអម្ចាស់បានហៅដេវីឌ វិតមើរ ឲ្យជួយនៅក្នុងកិច្ចការនៅថ្ងៃចុងក្រោយ*

ដើម្បីជួយសិស្សយល់អំពីប្រវត្តិខាងប្រវត្តិសាស្ត្រនៃវិវរណៈទាំងឡាយ ដែលពួកគេនឹងសិក្សានៅថ្ងៃនេះ សូមសង្ខេបព័ត៌មាននៅក្នុងបុព្វកថានៃមេរៀននេះ ។ បន្ថែមពីលើនោះ អ្នកអាចនឹងចង់សុំឲ្យសិស្សម្នាក់អានដំណើររឿងដូចខាងក្រោម ។ មុនពេលសិស្សអាន សូមពន្យល់ថា ដេវីឌ វិតមើរ ត្រូវដាំដុះស្រូវនៅលើកដីកសិដ្ឋានគ្រួសារ ហើយបានបាចកំបោរខ្លះៗ ដើម្បីធ្វើឲ្យដីមានជីវជាតិ ។ គាត់បានទទួលអារម្មណ៍បំផុសគំនិតថា គាត់គួរតែជួយយ៉ូសែប និងអូលីវើរ បន្ទាប់ពីគាត់បានបញ្ចប់កិច្ចការទាំងនោះ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្ដាប់អព្ភូតហេតុនានា ដែលអនុញ្ញាតឲ្យ ដាវីឌ វិតមើរ ជួយដល់អូលីវើរ ខៅឌើរី និង យ៉ូសែប ស្ម៊ីធ គេចចេញពីអ្នកបៀតបៀនពួកគេ ៖



« ដេវីឌ បានទៅចម្ការ ហើយបានឃើញថា គាត់មានការងារយ៉ាងច្រើនដែលត្រូវធ្វើការសម្រាប់រយៈពេលពីរថ្ងៃឯណោះ ។. . . រួចហើយគាត់បានចងសេះភ្ជាប់រនាស់ ហើយជំនួសឲ្យការបែកចែងចម្ការជារងៗ តាមដែលកសិករធ្លាប់ធ្វើ នោះគាត់បានទៅរាស់ជុំវិញចម្ការទាំងមូល គាត់បានបន្តរហូតថ្ងៃត្រង់ គាត់បានសម្រាកសម្រាប់អាហារពេលល្ងាច គាត់បានមើលជុំវិញ ហើយបានមានការភ្ញាក់ផ្អើលថា គាត់បានរាស់បានពាក់កណ្ដាលស្រែរួចទៅហើយ ។ បន្ទាប់ពីអាហារពេលល្ងាច គាត់បានទៅធ្វើដូចពីមុន ហើយដល់ល្ងាចឡើង គាត់បានបង្ហើយអស់ការងារ ដែលត្រូវធ្វើសម្រាប់រយៈពេលពីរថ្ងៃនោះ ។

« ឪពុកគាត់ ពេលបានទៅចម្ការនៅល្ងាចនោះដែរ បានឃើញនូវអ្វីដែលបានធ្វើរួច ហើយគាត់បានស្រែកឡើងថា ‹ ច្បាស់ជាមានអំណាចពីស្ថានខ្ពស់ ជួយនៅក្នុងកិច្ចការនេះហើយ ហើយឪពុកគិតថា កូនត្រូវទៅរដ្ឋផែនសិលវេញ៉ាភ្លាម ពេលកូនបានបាចជីរួចរាល់ហើយនោះ › ។

« នាព្រឹកឡើង ដេវីឌ បានយកម៉ែត្រឈើមួយកាន់នឹងដៃ ហើយបានចេញទៅបាចជី ដែលគាត់បានទុកចោល កាលពីពីរថ្ងៃមុន គរទុកនៅជិតផ្ទះរបស់បងស្រីគាត់ ប៉ុន្តែពេលគាត់ទៅដល់ទីនោះ គាត់បានឃើញថា វាបានបាត់អស់រលីង ! រួចគាត់បានរត់ទៅរកបងស្រីរបស់គាត់ ហើយសួរគាត់ថា តើគាត់មានដឹងថាវាទៅណាទេ ។ គាត់បាននិយាយដោយភ្ញាក់ផ្អើលថា ‹ ហេតុអ្វីមកសួរបងអញ្ចឹង តើវាពុំត្រូវបានបាចកាលពីម្សិលមិញទេឬអី?›

ដេវីឌ បានឆ្លើយថា «‹ទេ តាមដែលខ្ញុំដឹងនោះ› ។

បងស្រីគាត់បានឆ្លើយថា «‹បងភ្ញាក់ផ្អើលនឹងរឿងនោះណាស់ ព្រោះក្មេងៗមករកបងកាលព្រឹកមិញ ហើយបានសុំអង្វរឲ្យបងចេញទៅមើល បុរសៗដែលបានបាចជីនៅក្នុងស្រែ ដោយនិយាយថា ពួកគេពុំធ្លាប់ឃើញនរណា បាចជីលឿនដូច្នេះក្នុងជីវិតពួកគេនោះទេ ។ បងបានទៅមើល ហើយបានឃើញបុរសបីនាក់នៅធ្វើការក្នុងចម្ការ ដូចជាក្មេងបាននិយាយមែន

> ប៉ុន្តែបងស្មានថា ប្អូនបានជួលមនុស្សឲ្យមកជួយ ព្រោះប្អូនព្យាយាមចង់ធ្វើការនោះឲ្យហើយឆាប់នោះអី បងក៏បានទៅចូលក្នុងវិញដោយពុំនិយាយអ្វីទៀតពីរឿងនោះ › ។
>
> « ដាវីឌបានដេញដោលសាកសួរពីរឿងដែលបានកើតឡើងនោះ ទាំងនៅក្នុងចំណោមសាច់ញាតិ និងអ្នកជិតខាងរបស់គាត់ ប៉ុន្តែគ្មាននរណាដឹងថាអ្នកណាបានធ្វើនោះទេ » ( លូស៊ី ម៉ាក ស្ម៊ីធ *History of Joseph Smith by His Mother*, ed. Preston Nibley [ ឆ្នាំ ១៩៥៨ ], ១៤៨–៤៩ ) ។

- តើអ្នកគិតថាបទពិសោធន៍ទាំងនេះ អាចមានឥទ្ធិពលលើដេវីឌ វិតមើរ យ៉ាងដូចម្ដេចខ្លះ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:១–៥ ដោយពន្យល់ថា ព្រះអម្ចាស់ បានប្រកាសអំពីការលេចចេញមកនៃកិច្ចការរបស់ទ្រង់ និងពរជ័យដែលបានសន្យាដល់អ្នកទាំងឡាយដែលចូលរួមចំណែកក្នុងកិច្ចការនេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការដឹកនាំរបស់ព្រះអម្ចាស់ចំពោះដេវីឌ និងពរជ័យដែលដេវីឌ នឹងទទួល ដែលជាលទ្ធផលមកពីការស្ដាប់តាមការណែនាំរបស់ព្រះអម្ចាស់ ។

- តើព្រះអម្ចាស់សន្យាអ្វីខ្លះដល់ដេវីឌ វិតមើរ ? តើដេវីឌ បានតម្រូវឲ្យធ្វើអ្វីខ្លះ ដើម្បីការសន្យានេះត្រូវបានបំពេញ ?

សូមឲ្យសិស្សថ្លែងឡើងវិញអំពីគោលការណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:៧ ជាពាក្យរបស់ពួកគេផ្ទាល់ ។ នៅពេលសិស្សបានឆ្លើយតប សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើសិនជាយើងរក្សាបទបញ្ញត្តិរបស់ព្រះ ហើយស៊ូទ្រាំរហូតដល់ទីបំផុត នោះយើងនឹងទទួលបានជីវិតដ៏អស់កល្បជានិច្ច ។**

- តើវាមានន័យយ៉ាងម៉េច ដើម្បីទទួលបានជីវិតអស់កល្បជានិច្ចនោះ ? ( ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច គឺដើម្បីរស់នៅជារៀងរហូតជាមួយនឹងក្រុមគ្រួសាររបស់យើងនៅក្នុងវត្តមានរបស់ព្រះ ។ ជីវិតអស់កល្បជានិច្ច គឺជាប្រភេទជីវិតដែលព្រះទ្រង់មានព្រះជន្មនៅ ) ។

- តើការសន្យានៃជីវិតអស់កល្បជានិច្ច លើកទឹកចិត្តយើងឲ្យរក្សាបទបញ្ញត្តិរបស់ព្រះ ហើយស៊ូទ្រាំដល់ចុងបំផុតយ៉ាងដូចម្ដេចខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:៨ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាមរកមើលពរជ័យផ្សេងទៀត ដែលដេវីឌ វិតមើរ អាចទទួលបានបើគាត់គោរពប្រតិបត្តិ ។ បន្ទាប់ពីសិស្សបានរាយការណ៍នូវអ្វីដែលពួកគេរកឃើញហើយនោះ សូមពន្យល់ថា មិនយូរប៉ុន្មានបន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈសម្រាប់ ដេវីឌ នោះដេវីឌ បានក្លាយទៅជាសាក្សីម្នាក់នៃសាក្សីបីនាក់អំពីព្រះគម្ពីរមរមន ។ គាត់បានឃើញទេវតាម៉ូរ៉ូណៃ និងផ្ទាំងចំណារមាស ហើយបានស្ដាប់ឮសំឡេងរបស់ព្រះ ថ្លែងទីបន្ទាល់អំពីសេចក្ដីពិតពេញលេញនៃកំណត់ត្រានោះ ។

សូមពន្យល់ថា ព្រះអម្ចាស់ បានប្រទានដល់ ដេវីឌ វិតមើរ នូវការសន្យាមួយទៀត អាស្រ័យទៅលើសេចក្ដីស្មោះត្រង់របស់ដេវីឌ ។ ដើម្បីរៀបចំសិស្សឲ្យប្រាប់អំពីគោលការណ៍មួយនៅក្នុងបន្ទូលរបស់ព្រះអម្ចាស់ ទៅដល់ ដេវីឌ សូមសរសេរដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើង* ______________________________ *ព្រះអម្ចាស់នឹង* ______________________________.

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:៩–១១ ដោយស្ងាត់ស្ងៀម ។ សូមអញ្ជើញពួកគេឲ្យប្រាប់អំពីគោលការណ៍មួយ ដែលត្រូវនឹងគំរូនៅលើក្ដារខៀន ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេបានរកឃើញ ។ សិស្សអាចនឹងផ្ដល់យោបល់នូវគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា វាច្បាស់លាស់ **បើយើងជួយកិច្ចការរបស់ទ្រង់ដោយស្មោះត្រង់ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ។**

- តើព្រះអម្ចាស់សុំឲ្យអ្នកជួយនៅក្នុងកិច្ចការរបស់ទ្រង់តាមវិធីណាខ្លះ ? តើមានពរជ័យអ្វីខ្លះដែលកើតមានក្នុងជីវិតរបស់អ្នកពេលអ្នកបានជួយនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ?

> ***សូមឲ្យសិស្សប្រើពាក្យផ្ទាល់ខ្លួនរបស់ពួកគេ***
>
> នៅពេលសិស្សបង្ហាញពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលពួកគេរកឃើញនៅក្នុងព្រះគម្ពីរ សូមកុំថាចម្លើយរបស់ពួកគេខុស ដោយសារតែពួកគេមានចម្លើយខុសពីពាក្យដែលបានប្រើនៅក្នុងសៀវភៅណែនាំនេះនោះឡើយ ។ ទោះជាយ៉ាងណាក្ដី ប្រសិនបើប្រយោគរបស់សិស្សម្នាក់ខុសពីគោលលទ្ធិ វាជាការទទួលខុសត្រូវរបស់អ្នកដើម្បីជួយគេដោយទន់ភ្លន់ក្នុងការកែតម្រូវប្រយោគនោះ ។ ការធ្វើដូច្នោះអាចផ្ដល់នូវបទពិសោធន៍ក្នុងការសិក្សាដ៏សំខាន់មួយ ដោយសារយើងបានរក្សាបរិយាកាសប្រកបដោយក្ដីស្រឡាញ់ និង ទំនុកចិត្ត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥–១៦

*ព្រះយេស៊ូវគ្រីស្ទ បង្រៀនចន វិតមើរ និងពេត្រុស វិតមើរ ជុញ្ញ័រ អំពីអ្វីដែលមានតម្លៃបំផុតចំពោះពួកគេ*

សូមអញ្ជើញសិស្សពីរនាក់ឲ្យឡើងមកខាងមុខថ្នាក់ ។ សូមឲ្យដៃគូម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥: ១ ឲ្យឮៗ ហើយសុំឲ្យដៃគូម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៦:១ ឲ្យឮៗ ។ សូមឲ្យសិស្សទាំងនេះអានខ ២–៦ នៃកណ្ឌទាំងនេះតាមរបៀបដូចគ្នា ។

សូមអញ្ជើញសិស្សឲ្យប្រាប់ពីបំណងប្រាថ្នាដែល ចន វិតមើរ និងពេត្រុស វិតមើរ ជុញ្ញ័រ មានដូចគ្នានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥:៣–៤ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៦:៣–៤ ។

- តើ ចន វិតមើរ និង ពេត្រុស វិតមើរ ជុញ៉រ ទាំងពីរនាក់មានបំណងប្រាថ្នាអ្វី ? ( ដើម្បីដឹងនូវអ្វីដែលពួកគេអាចធ្វើ ដែលមានតម្លៃមហិមាបំផុតចំពោះពួកគេ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥:៦ និង ១៦:៦ ដោយស្ងាត់ស្ងៀម ។ សូមសួរពួកគេឲ្យប្រាប់ចម្លើយដែលព្រះអម្ចាស់បានប្រទានដល់បុរសទាំងនេះ ។

- តើព្រះអម្ចាស់បានឆ្លើយនឹងសំណួររបស់ពួកគេយ៉ាងដូចម្ដេច ? តើគោលការណ៍អ្វីដែលយើងអាចរៀនមកពីចម្លើយរបស់ព្រះអម្ចាស់នោះ ? ( ទោះជាសិស្សអាចប្រើពាក្យផ្សេងគ្នា សូមប្រាកដថា ពួកគេយល់ថា **កិច្ចខិតខំរបស់យើងដើម្បីនាំអ្នកដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទ គឺមានតម្លៃមហិមាណាស់ចំពោះយើង** ) ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជួយអ្នកដទៃឲ្យមករកព្រះគ្រីស្ទ ?

- ហេតុអ្វីក៏កិច្ចខិតខំទាំងនេះមហិមាខ្លាំងម្ល៉េះចំពោះយើង ?

សូមអញ្ជើញសិស្សឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥ និង ១៦ ស្វែងរករបៀបដែលវិវរណៈទាំងពីរនេះ មានភាពខុសពីគ្នា ។ ( ភាពខុសគ្នាតែមួយគត់គឺថា មួយបានថ្លែងទៅកាន់ចន ហើយមួយទៀតគឺថ្លែងទៅកាន់ ពេត្រុស ) ។

សូមពន្យល់ថា ជួនកាល ព្រះអម្ចាស់បើកសម្ដែងសារលិខិតដូចគ្នាទៅកាន់មនុស្សផ្សេងគ្នា ដោយសារពួកគេមានតម្រូវការស្ថានភាព ឬបំណងប្រាថ្នាស្រដៀងគ្នា ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចប្រាកដថា ទ្រង់ស្គាល់យើងម្នាក់ៗ ។ នៅក្នុងឧទាហរណ៍នេះទ្រង់បានហៅ ចន វិតមើរ និង ពេត្រុស វិតមើរ ជុញ៉រ ដោយឈ្មោះ ហើយបានបើកសម្ដែងព្រះឆន្ទៈទ្រង់ដល់ពួកគេម្ដងម្នាក់ៗ ។

- តើពរជ័យបព្វជិតភាព និងការហៅបម្រើបេសកកម្ម អាចបង្ហាញថា ព្រះស្គាល់យើងផ្ទាល់ ទោះជាពរជ័យ ឬការហៅបម្រើបេសកកម្មនោះ មាននូវពាក្យស្រដៀងគ្នា ចំពោះពាក្យដែលផ្ដល់ទៅអ្នកដទៃទៀត យ៉ាងដូចម្ដេច ?

ដើម្បីផ្ដល់ឧទាហរណ៍មួយទៀត ថាព្រះស្គាល់យើងដោយផ្ទាល់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោមដោយ អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« កាលលើកមុន ខ្ញុំបាននិយាយទៅកាន់អ្នកដឹកនាំបព្វជិតភាពម្នាក់ ដែលបានលើកទឹកចិត្តឲ្យទន្ទេញចាំឈ្មោះរបស់យុវវ័យទាំងអស់ដែលមានអាយុ ១៣ ទៅ ២១ ឆ្នាំ នៅក្នុងស្តេករបស់គាត់ ។ ការប្រើរូបថតដែលមិនដឹងខ្លួនរបស់យុវជន និងយុវនារី គាត់បានបង្កើតជាកាតបញ្ចាំង ដើម្បីគាត់អាចមើលពេលធ្វើដំណើរទៅធ្វើការ និងនៅពេលផ្សេងៗទៀត ។ អ្នកដឹកនាំបព្វជិតភាពនេះ បានរៀនយ៉ាងឆាប់អំពីឈ្មោះរបស់យុវវ័យទាំងអស់ ។

« នៅយប់មួយអ្នកដឹកនាំបព្វជិតភាពនោះ បានសុបិនអំពីយុវជនម្នាក់ដែលគាត់បានស្គាល់តែក្នុងរូបថត ។ នៅក្នុងការសុបិននោះ គាត់បានឃើញយុវជននោះ ស្លៀកពាក់អាវពណ៌ស ហើយពាក់ស្លាកឈ្មោះអ្នកផ្សព្វផ្សាយសាសនា ។ យុវជននោះ កំពុងបង្រៀនដល់គ្រួសារមួយ ដោយមានដៃគូអង្គុយជិតគាត់ ។ យុវជននោះ កាន់ព្រះគម្ពីរមរមននៅក្នុងដៃគាត់ ហើយគាត់បានមើលទៅដូចជា គាត់កំពុងថ្លែងទីបន្ទាល់អំពីភាពពេញលេញនៃព្រះគម្ពីរ ។ រួចហើយអ្នកដឹកនាំបព្វជិតភាពនោះបានភ្ញាក់ដឹងខ្លួនពីសុបិន ។

« នៅក្នុងការជួបជុំបព្វជិតភាពមួយ អ្នកដឹកនាំរូបនោះបានទៅជួបនឹងយុវជនដែលគាត់បានឃើញក្នុងសុបិន ហើយបានសុំនិយាយនឹងយុវជននោះរយៈពេលពីរបីនាទី ។ បន្ទាប់ពីការណែនាំសង្ខេបៗមក អ្នកដឹកនាំបានហៅយុវជននោះដោយឈ្មោះ ហើយបាននិយាយថា ៖ ‹ ខ្ញុំពុំមែនជាមនុស្សរើរវាយទេ ។ ខ្ញុំពុំដែលសុបិនឃើញសមាជិកនៅលីវណាម្នាក់ក្នុងស្តេកនេះទេ ក្រៅពីអ្នក ។ ខ្ញុំចង់ប្រាប់អ្នកអំពីសុបិនរបស់ខ្ញុំ រួចហើយខ្ញុំចង់ឲ្យអ្នកជួយខ្ញុំយល់អំពីអត្ថន័យរបស់វា › ។

« អ្នកដឹកនាំបព្វជិតភាពបានរៀបរាប់ប្រាប់ពីសុបិននោះ ហើយបានសួរដល់យុវជននោះ អំពីអត្ថន័យនៃសុបិន ។ ដោយនិយាយទាំងអួលដើមក យុវជននោះបានឆ្លើយតបដោយសាមញ្ញថា ‹ នោះមានន័យថា ព្រះស្គាល់ខ្ញុំជានរណា › ។ ការសន្ទនាបន្ទាប់ទៀត រវាងយុវជននេះ និងអ្នកដឹកនាំបព្វជិតភាព គឺមានអត្ថន័យបំផុត ហើយពួកគាត់បានយល់ព្រមដើម្បីជួប ហើយប្រឹក្សាជាមួយគ្នាពីមួយគ្រាទៅមួយគ្រា អំឡុងពេលជាច្រើនខែបន្តបន្ទាប់មក » ( The Tender Mercies of the Lord » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៥, ទំព័រ១០០ ) ។

- ហេតុអ្វីក៏វាមានប្រយោជន៍សម្រាប់យើង ដើម្បីដឹងថា ព្រះស្គាល់យើងដោយផ្ទាល់ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីរបៀបដែលពួកគេដឹងថា ព្រះស្គាល់ពួកគេដោយផ្ទាល់ ។ ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ឧទាហរណ៍របស់សិស្ស ពុំចាំបាច់ថាវាត្រូវតែអស្ចារ្យពេកនោះទេ ។ សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយពីបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ ) ។

- តើចំណេះដឹងដែលថា ព្រះស្គាល់អ្នកដោយផ្ទាល់អាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកជាប្រចាំថ្ងៃយ៉ាងដូចម្ដេច ? តើចំណេះដឹងនេះ មានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកយ៉ាងដូចម្ដេច ?

អ្នកអាចនឹងចង់បញ្ចប់មេរៀននេះ ដោយការថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សា ហើយអញ្ជើញសិស្សឲ្យធ្វើតាមសេចក្ដីពិតទាំងនេះ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩; ១១–១៦; យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៨–៧៥ ( មេរៀនទី ៤ )

## ការរៀបចំមេរៀនសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសម្រាប់សិស្សសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩; ១១–១៦; និង យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៨–៧៥ ( មេរៀនទី ៤ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩)

នៅពេលពួកគេបានសិក្សាពី ការព្យាយាមរបស់អូលីវើរ ខៅឌើរី ដើម្បីបកប្រែផ្ទាំង នោះសិស្សបានរៀនថាការទទួល និង ការស្គាល់វិវរណៈតម្រូវឲ្យមានការខិតខំក្នុងផ្នែករបស់ពួកគេ ។ ( ពួកគេក៏បានរៀនផងដែរថា ប្រសិនបើពួកគេនឹងសិក្សា ហើយទូលសុំដោយសេចក្ដីជំនឿ នោះព្រះអម្ចាស់នឹងមានបន្ទូលមកកាន់គំនិត និង ដួងចិត្តរបស់យើង តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១១–១២)

ហៃរ៉ុម ដែលជាបងប្រុសរបស់ព្យាការីបាន បង្ហាញបំណងប្រាថ្នាដើម្បីជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ ចេញពីវិវរណៈចំពោះហៃរ៉ុម សិស្សបានរៀនថាពួកគេទទួលពរជ័យពីព្រះស្របតាមបំណងប្រាថ្នារបស់ពួកគេ ហើយថាប្រសិនបើពួកគេមានបំណងប្រាថ្នាធ្វើកិច្ចការរបស់ព្រះ នោះពួកគេគឺជាមធ្យោបាយនៃការធ្វើកិច្ចការល្អៗជាច្រើន ។ សិស្សក៏មានឱកាសដើម្បីពិចារណាផងដែរពីរបៀបដែលពួកគេអាចសិក្សា និង ទទួលបានព្រះបន្ទូលរបស់ព្រះអម្ចាស់ ដើម្បីទទួលបាននូវព្រះវិញ្ញាណ និង ព្រះចេស្ដារបស់ទ្រង់ ។

### ថ្ងៃទី ៣ (យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៦៨–៧៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣)

សិស្សបានរៀនថា យ៉ូហាន បាទីស្ទ បានប្រគល់បព្វជិតភាពអើរ៉ុនមកឲ្យយ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ដោយការដាក់ដៃលើ ។ កូនសោនៃបព្វជិតភាពអើរ៉ុន ដែលរួមមានការបម្រើនៃពួកទេវតា ដំណឹងល្អនៃការប្រែចិត្ត និង នៃពិធីបុណ្យជ្រមុជទឹកដោយការពន្លិចសម្រាប់ការផ្ដាច់បាប ត្រូវបានស្ដារម្ដងទៀតលើផែនដីនេះ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦)

ដាវីឌ វិតមើរ បានជួយយ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ប្ដូរលំនៅទៅ នូវ យ៉ោក ដើម្បីគេចផុតពីការបៀតបៀននៅក្នុងរដ្ឋផែនសីលវេញ៉ា ។ ចេញពីព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះដាវីឌ វិតមើរ សិស្សបានរៀនថា ប្រសិនបើពួកគេរក្សាបទបញ្ញត្តិរបស់ព្រះ ហើយស៊ូទ្រាំរហូតដល់ទីបំផុត នោះពួកគេនឹងទទួលបានជីវិតដ៏អស់កល្បជានិច្ច ។ ពួកគេក៏បានរៀនផងដែរថា នៅពេលពួកគេស្មោះត្រង់ក្នុងការជួយកិច្ចការរបស់ព្រះអម្ចាស់ នោះពួកគេនឹងទទួលពរទាំងខាងវិញ្ញាណ និង ខាងសាច់ឈាម ។ តាមរយៈការសិក្សាវិវរណៈនេះដែលបានប្រទានដល់យ៉ូហាន និង ពេត្រុស វិតមើរ នោះសិស្សបានឃើញថា កិច្ចខិតខំរបស់យើងដើម្បីនាំមនុស្សដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទ គឺមានតម្លៃយ៉ាងធំចំពោះយើង ហើយថាព្រះស្គាល់ពួកយើងម្នាក់ៗ ។

## សេចក្ដីផ្ដើម

អូលីវើរ ខៅឌើរី ហៃរ៉ុម ស្ម៊ីធ យ៉ូសែប ណៃ ស៊ីញ៉រ ដាវីឌ វិតមើរ យ៉ូហាន វិតមើរ និង ពេត្រុស វិតមើរ អ្នកទាំងអស់នេះទទួលស្គាល់ថាយ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ព្រះ ហើយពួកគេមានចិត្តរំភើបក្នុងការជួយការស្ដារឡើងវិញ ។ ព្រះអម្ចាស់បានបង្រៀនពួកគេអំពីវិញ្ញាណនៃវិវរណៈ ហើយពីអ្វីដែលបុគ្គលម្នាក់គួរតែធ្វើពីមុននឹងព្យាយាមប្រកាសដំណឹងល្អ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩

*ព្រះអម្ចាស់បង្រៀន អូលីវើរ ខៅឌើរី និង ហៃរ៉ុម ស្ម៊ីធអំពីវិញ្ញាណនៃវិវរណៈ*

សូមឲ្យសិស្សលើកដៃឡើង ប្រសិនបើពួកគេឆ្ងល់ពីរបៀបដើម្បី ដឹងថាពួកគេបានទទួលវិវរណៈមកពីព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សឲ្យរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៨ និង ៩ ឡើងវិញ ព្រមទាំងពីអ្វីដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីជំពូកទាំងនោះនៅក្នុងមេរៀននៃថ្ងៃទី ១សម្រាប់មេរៀននេះ ។ សូមឲ្យសិស្សស្វែងរកអ្វីដែលពួកគេបានរៀនអំពីការទទួល និង ការស្គាល់ពីចម្លើយចំពោះ ការអធិស្ឋាន ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេបានរៀន ។

- តើឧបសគ្គអ្វីខ្លះដែលអ្នកបានជួបប្រទះ នៅពេលអ្នកព្យាយាមស្គាល់ថាអ្នកកំពុងទទួលការបំផុសគំនិត ឬ ការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ?

សូមរំឭកសិស្សថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨ និង ៩ មាននូវការណែនាំរបស់ព្រះអម្ចាស់សម្រាប់អូលីវើរ ខៅឌើរី នៅពេលអូលីវើរបានព្យាយាមបកប្រែផ្ទាំងមាសនោះ ។ ចេញពីវិវរណៈទាំងនេះ នោះយើងអាចរៀនពីរបៀបដើម្បីទទួល និង ស្គាល់វិវរណៈ ។ សូមឲ្យសិស្សបើកទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣ ( ដែលជាចំណេះចំណានខគម្ពីរមួយ ) ហើយសូត្រវគ្គបទគម្ពីរនោះរួមគ្នា ។ ( សូមសរសេរសេចក្ដីពិតខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ថ្លែងមកកាន់គំនិត និងដួងចិត្តរបស់យើងតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។**

- តើការយល់ពីសេចក្ដីពិតនេះ អាចជួយអ្នកដោយរបៀបណា នៅពេលអ្នកព្យាយាមទទួលស្គាល់វិវរណៈមកពីព្រះអម្ចាស់ ?

សូមពន្យល់ថា លទ្ធភាពដើម្បីស្វែងរក និងទទួលបានវិវរណៈផ្ទាល់ខ្លួន គឺជាអំណោយទានមួយមកពីព្រះដែលមានចំពោះកូនចៅរបស់ទ្រង់ទាំងអស់ ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:៤ ឲ្យឮៗ ហើយសូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានសន្យានឹងអូលីវើរ ប្រសិនបើលោកនឹង « អនុវត្ត » អំណោយទាននៃវិវរណៈនេះ ។ បន្ទាប់មក សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា « សូមអនុវត្ត » ព្រះវិញ្ញាណនៃវិវរណៈមានន័យដូចម្ដេចដែរ ? ( ស្វែងរកចម្លើយចំពោះ ការអធិស្ឋាន ហើយរស់នៅដោយសក្ដិសមដើម្បីទទួលវិវរណៈទាំងនេះ ) ។
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨ :៤ ? ( ទោះជាសិស្សអាចប្រាប់នូវគោលការណ៍ផ្សេងៗគ្នាក្ដី សូមប្រាកដថាពួកគេរកឃើញគោលការណ៍នេះ **ប្រសិនបើយើងអនុវត្តព្រះវិញ្ញាណនៃវិវរណៈ នោះយើងអាចត្រូវបានរំដោះពីសេចក្ដីអាក្រក់ និងគ្រោះថ្នាក់ ។** សូមគោលការណ៍នេះនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយ នៅពេលព្រះអម្ចាស់បានការពារពួកគេ ឬ នរណាម្នាក់ដែលពួកគេស្គាល់ដោយសារពួកគេបានស្វែងរក និង ស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១ ដោយស្ងាត់ស្ងៀម ហើយរកមើលវិធីនានា ដែលយើងអាចកែលម្អការអធិស្ឋានរបស់យើង ដើម្បី « អនុវត្ត » វិញ្ញាណនៃវិវរណៈ ។

ប្រសិនបើអាចធ្វើបាន សូមផ្ដល់ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍ខាងក្រោមរបស់អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដល់សិស្ស ( ឬ សរសេរវានៅលើក្ដារខៀនមុននឹងចាប់ផ្ដើមថ្នាក់ ៖ )



« . . . ដោយសារតែវិញ្ញាណខ្សឹបមកកាន់យើងដោយស្រទន់ និងផ្អែមល្ហែម នោះវាងាយដើម្បីយល់ថាហេតុអ្វីយើងគួរតែគេចចេញពីប្រព័ន្ធផ្សព្វផ្សាយដែលពុំសមរម្យ ការណ៍អាសគ្រាម និង ចៀសវាងពីវត្ថុឬសកម្មភាពដែលនាំឲ្យញៀន និងគ្រោះថ្នាក់នានា ។ មធ្យោបាយរបស់មារសត្រូវទាំងនេះ អាចធ្វើឲ្យទន់ខ្សោយ និងបំផ្លាញដល់សមត្ថភាពរបស់យើងបន្តិចម្ដងៗ ក្នុងការទទួលស្គាល់ និងឆ្លើយតបចំពោះសារលិខិតដ៏ប៉ិនប្រសប់មកពីព្រះ ដែលបានផ្ដល់ឲ្យដោយព្រះចេស្ដានៃព្រះវិញ្ញាណរបស់ទ្រង់ ។ យើងម្នាក់ៗ គួរតែគិតដោយហ្មត់ចត់ និងមានការពិចារណាប្រកបដោយការអធិស្ឋានអំពីរបៀបដែលយើងអាចបដិសេធនឹងការល្បួងរបស់អារក្ស ហើយ ‹ អនុវត្ត › ដោយសុចរិត រួមទាំងវិញ្ញាណនៃវិវរណៈនៅក្នុងជីវិតយើងផ្ទាល់ និងជីវិតក្រុមគ្រួសាររបស់យើង » (« The Spirit of Revelation » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៨៨ ) ។

សូមអញ្ជើញសិស្សឲ្យអានសេចក្ដីថ្លែងការណ៍របស់អែលឌើរ បែដណាដោយស្ងៀមស្ងាត់ ហើយរកមើលឃ្លាដែលជួយពួកគេឲ្យយល់ពីរបៀបដើម្បី « អនុវត្ត » ឬ ស្វែងរកវិញ្ញាណនៃវិវរណៈឲ្យបានកាន់តែល្អប្រសើរ ។ អ្នកអាចស្នើថា ពួកគេគូសចំណាំឃ្លាទាំងនេះ ។ បន្ទាប់មក សូមសួរសំណួរខាងក្រោមនេះ ៖

- តើឃ្លាណាខ្លះដែលអ្នកបានកត់សម្គាល់ ហើយហេតុអ្វីអ្នកចាប់អារម្មណ៍ឃ្លាទាំងនោះ ?
- យោងតាមអែលឌើរ បែដណាហេតុអ្វីបាន ជាសំខាន់ដើម្បីគេចផុតចេញពី អំពើអាក្រក់ ប្រសិនបើយើងប្រាថ្នាទទួល និងស្គាល់វិវរណៈនោះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីវិធីមួយចំនួនដែលពួកគេអាច « អនុវត្ត » អំណោយទាននៃវិវរណៈ ដើម្បីទទួលបានការការពារពីសេចក្ដីអាក្រក់ ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យសរសេរគោលដៅពីរបៀបដែលពួកគេចង់ « អនុវត្ត » ចំពោះអំណោយទាននេះឲ្យកាន់តែពេញលេញនៅក្នុងជីវិតរបស់ពួកគេ ។

ដើម្បីជួយសិស្សឲ្យយល់ពីវិធីមួយទៀតដើម្បីស្វែងរកវិវរណៈ សូមរំឭកពួកគេថាអូលីវើរ ខៅឌើរី ត្រូវបានប្រទាននូវការអនុញ្ញាតដើម្បីបកប្រែ ប៉ុន្តែក្រោយមកគាត់បានចាប់ផ្ដើម « ពុំបានធ្វើតទៅទៀត ដូចជា ‌| លោកបាន | ចាប់ផ្ដើម » ( គ. និង ស. ៩:៥ ) ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៧–៨ ឲ្យឮៗ ហើយសូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់បានប្រាប់អូលីវើរ ពីអ្វី ដែលគាត់ចាំបាច់ត្រូវធ្វើដើម្បីទទួលបានវិវរណៈ ។

- ផ្អែកលើការទូន្មានរបស់ព្រះអម្ចាស់ចំពោះអូលីវើរ ខៅឌើរី តើយើងរៀនអ្វីខ្លះដែលជាផ្នែករបស់យើងដើម្បីទទួលបានវិវរណៈ ? ( គោលការណ៍មួយដែលសិស្សអាចស្វែងរកឃើញនោះគឺ **ការទទួល និង ការស្គាល់វិវរណៈ តម្រូវឲ្យមានការខិតខំក្នុងផ្នែករបស់យើង ។** អ្នកអាចសរសេរសេចក្ដីពិតនេះ ឬ ស្រដៀងគ្នានេះដែលបង្ហាញដោយសិស្សនៅលើក្ដារខៀន ) ។
- សូមប្រើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៨, តើអ្នកចង់ផ្ដល់ដំបូន្មានអ្វីខ្លះដល់មិត្តអ្នកដែលកំពុងព្យាយាមធ្វើការសម្រេចចិត្តមួយដ៏សំខាន់ ?

អ្នកអាចសូមឲ្យសិស្សចែកចាយបទពិសោធន៍ផងដែរ នៅពេលពួកគេចាំបាច់ត្រូវអនុវត្តកិច្ចខិតខំដើម្បីធ្វើការសម្រេចចិត្តលំបាកៗ ហើយសួរព្រះវរបិតាសួគ៌ ប្រសិនបើពួកគេបានជ្រើសរើសត្រូវ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១–១២; ១៤–១៦

*ព្រះអម្ចាស់ណែនាំហៃរ៉ុម ស្ម៊ីធ យ៉ូសែប ណៃ សឺញ៉រ និង បងប្អូនប្រុស វិតមើរអំពីតួនាទីរបស់ពួកគេនៅក្នុងកិច្ចការរបស់ព្រះ*

សូមឲ្យសិស្សគិតស្រមៃថាពួកគេត្រូវបានសុំ ឲ្យចូលរួមនៅក្នុងបុព្វហេតុដ៏ធំមហិមាមួយដែលកើតឡើងនៅលើផែនដីនេះ ។ សូមប្រាប់ពួកគេថានៅក្នុងខែ ឧសភា និង ខែ មិថុនា ឆ្នាំ ១៨២៩ មានបុរសប្រាំនាក់ត្រូវបានណែនាំដោយផ្ទាល់ទាក់ទងនឹងព្រះឆន្ទៈរបស់ព្រះអម្ចាស់សម្រាប់ពួកគេ នៅក្នុងការស្ដារដំណឹងល្អឡើងវិញ ។

សូមសរសេរ ក្បាលជំពូក និង ខគម្ពីរយោងខាងក្រោម នៅលើក្ដារខៀន ។ សូមឲ្យសិស្សអានខគម្ពីរទាំងនេះ ដើម្បីស្វែងរកអ្វីដែលព្រះអម្ចាស់ទូន្មានបុរសទាំងនោះឲ្យធ្វើ ដើម្បីជួយកសាងនគររបស់ព្រះនៅលើផែនដីនេះ ។ សូមអញ្ជើញឲ្យសិស្សអានខគម្ពីរទាំងបួននេះ ។ ( ប្រសិនបើមានពេលខ្លី សូមចែកសេចក្ដីយោងទាំងនេះឲ្យសិស្ស ហើយសូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ) ។

| ហៃរ៉ុម ស្ម៊ីធ | យ៉ូសែប ណៃត សឺញ៉រ | ដាវីឌ វិតមើរ | យ៉ូហាន និង ពេត្រុស វិតមើរ |
|---|---|---|---|
| គ. និង ស. ១១:១៦, ១៨–១៩, ២១ | គ. និង ស. ១២:៦–៩ | គ. និង ស. ១៤:៦–៨, ១១ | គ. និង ស. ១៥:៤–៦; ១៦:៤–៦ |

បន្ទាប់ពីសិស្សបានសិក្សាសេចក្ដីសង្ខេបរួចហើយ សូមសួរសំណួរខាងក្រោម ៖

- តើអ្នកបានកត់សម្គាល់ឃើញមានភាពស្រដៀងគ្នាអ្វីខ្លះក្នុងការបញ្ជារបស់ព្រះអម្ចាស់ចំពោះបុរសទាំងប្រាំនោះ ? តើអ្នកមើលឃើញមានភាពខុសគ្នាអ្វីខ្លះ ?
- ចេញពីអ្វីដែលអ្នកបានរៀនពីខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១, ហេតុអ្វីបានជាព្រះអម្ចាស់ចង់ឲ្យហៃរ៉ុម ស្ម៊ីធ « ចាំបន្តិច » (គ. និង ស. ១១:១៦) ដើម្បីផ្សព្វផ្សាយដំណឹងល្អ ?

- តើការទូន្មានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ហៃរ៉ុមនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:២១ ដែលនឹងមានប្រយោជន៍ចំពោះយុវជន ឬ យុវនារីដែលរៀបចំដើម្បីបម្រើបេសកកម្ម ? ( ចេញពីចម្លើយរបស់ពួកគេ សូមជួយសិស្សឲ្យរកឃើញគោលការណ៍ខាងក្រោម ៖ **អ្នកទាំងឡាយដែលសិក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ នឹងទទួលព្រះវិញ្ញាណទ្រង់ និងអំណាចដើម្បីបញ្ចុះបញ្ចូលអ្នកដទៃឲ្យជឿសេចក្ដីពិតនៃដំណឹងល្អ**) ។ អ្នកអាចសរសេរវានៅលើក្ដារខៀន ។

សូមអញ្ជើញសិស្សពិចារណាអំពីអ្វីដែលពួកគេអាចធ្វើ ដើម្បីមានបំណងកាន់តែខិតខំក្នុងការសិក្សា និង ទទួលបាននូវព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយដាក់គោលដៅអនុវត្តតាមការបំផុសគំនិតដែល ពួកគេបានទទួលពេលពួកគេសញ្ជឹងគិត ។

ដើម្បីជួយសិស្សឲ្យសូត្រចាំចំណេះចំណានខគម្ពីរនេះបន្ថែមទៀតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣:១ សូមអញ្ជើញពួកគេឲ្យសូត្រវាជាមួយគ្នាពីអ្វីដែលពួកគេចាំ ។ សូមឲ្យពួកគេប្រើព្រះគម្ពីរប្រសិនបើចាំបាច់ ។ បន្ទាប់មកសូមចែកសិស្សជាគូៗ ហើយសូមឲ្យពួកគេប្រើប្រាស់វគ្គបទគម្ពីរនេះដើម្បីពន្យល់ដៃគូរបស់ខ្លួន ពីរបៀបដែលកូនសោនៃបព្វជិតភាពអើរ៉ុនជួយនាំមនុស្សឲ្យមករកព្រះគ្រីស្ទ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧–១៩)

សូមប្រាប់សិស្សថា នៅពេលពួកគេសិក្សាមេរៀនបន្ទាប់នោះពួកគេនឹងរៀនអំពីមនុស្សដែលត្រូវបានជ្រើសរើសដើម្បីធ្វើជាសាក្សីមើលឃើញផ្ទាំងមាស លីអាហូណា និង វត្ថុពិសិដ្ឋៗផ្សេងទៀត ។ ពួកគេនឹងអានដំណើររឿងរបស់ព្រះអង្គសង្គ្រោះ អំពីការរងទុក្ខរបស់ទ្រង់នៅក្នុងសួនគេតសាម៉ានី និង នៅលើឈើឆ្កាង ។ ពួកគេក៏នឹងបានអានការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីរបៀបដែលពួកយើងអាចចៀសវាងពីការរងទុក្ខបែបនោះ ។

មេរៀនទី ២១

# គោលលទ្ធិ និង សេចក្តីសញ្ញា ១៧

## បុព្វកថា

ខណៈពេលដែល យ៉ូសែប ស្ម៊ីធ កំពុងបកប្រែព្រះគម្ពីរមរមន លោកបានរៀនថា សាក្សីបីនាក់ នឹងត្រូវបានអនុញ្ញាតឲ្យមើលផ្ទាំងចំណារ ( សូមមើល នីហ្វៃទី ២ ២៧:១២–១៤; អេធើរ ៥:២–៤; គ. និង ស. ៥:១១–១៥, ១៨ ) ។ នៅពេល អូលីវើរ ខៅឌើរី និងដាវីឌ វិតមើរ បានដឹងអំពីរឿងនេះ ពួកលោកទាំងពីរនាក់ បានទទួលអារម្មណ៍នៃបំណងប្រាថ្នាដ៏បំផុសគំនិតមួយ ដើម្បីធ្វើជាសាក្សី ។ ពីមុនហេតុការណ៍នេះ ព្រះអម្ចាស់ បានមានបន្ទូលថា បើម៉ាទីន ហារិស ចេះបន្ទាបខ្លួន និង គោរពប្រតិបត្តិល្អមគ្រប់គ្រាន់ នោះគាត់នឹងត្រូវបានអនុញ្ញាតឲ្យមើលឃើញផ្ទាំងចំណារ ( សូមមើល គ. និង ស. ៥:២៣–២៨ ) ។ អូលីវើរ ខៅឌើរី, ដាវីឌ វិតមើរ និង ម៉ាទីន ហារិស បានសុំដល់ព្យាការីឲ្យសួរដល់ព្រះអម្ចាស់ ថាតើពួកគេនឹងអនុញ្ញាតឲ្យមានឱកាសនេះឬទេ ។ ព្រះអម្ចាស់ បានបញ្ជាក់ថា បុរសទាំងបីនាក់នេះនឹងត្រូវបានអនុញ្ញាតឲ្យមើលផ្ទាំងចំណារ ហើយនឹងវត្ថុផ្សេងៗទៀត បើពួកគេអនុវត្តសេចក្តីជំនឿល្អមគ្រប់គ្រាន់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ១៧:១–២

*ព្រះអម្ចាស់ ប្រាប់ដល់អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ និង ម៉ាទីន ហារិស ថាបើពួកគេមានសេចក្តីជំនឿល្អមគ្រប់គ្រាន់ នោះពួកគេនឹងអនុញ្ញាតឲ្យមើលឃើញផ្ទាំងចំណារ និងវត្ថុពិសិដ្ឋដទៃទៀត ។*

នៅលើក្តារខៀន សូមសរសេរលេខ ១ ដល់លេខ ៥ បញ្ឈរពីលើចុះក្រោម ។ សូមសរសេរ *ផ្ទាំងចំណារមាស* នៅជិតនឹងលេខ ១ ។ សូមអញ្ជើញពួកគេឲ្យកត់ត្រានូវចំនួនលេខក្នុងបញ្ជី នោះចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមឲ្យសិស្សបំពេញក្នុងបញ្ជីនោះ ដោយសរសេរនូវវត្ថុផ្សេងទៀត ដែលសាក្សីបីនាក់បានមើលឃើញ នៅពេលមរ៉ូណៃបានបង្ហាញផ្ទាំងចំណារដល់ពួកលោក ។ បន្ទាប់ពីឲ្យពេលល្មមគ្រប់គ្រាន់ សូមសួរដល់សិស្សឲ្យប្រៀបធៀបបញ្ជីរបស់ពួកគេជាមួយនឹងវត្ថុដែលមានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៧:១ ។

- តើវត្ថុណាខ្លះ ដែលមានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៧:១ ដែលអ្នកចង់មើលឃើញបំផុត ? ហេតុអ្វី ?
- តើការមើលឃើញវត្ថុទាំងនេះ បានពង្រឹងដល់ទីបន្ទាល់របស់សាក្សីបីនាក់យ៉ាងដូចម្តេច ? ហេតុអ្វី ?
- តើការមើលឃើញដាវរបស់ឡាបាន់ និងលីអាហូណា ផ្តល់ជាសាក្សីបន្ថែមអំពីព្រះគម្ពីរមរមនដោយរបៀបណា ?

ដើម្បីជួយសិស្សយល់ដឹងអំពីប្រវត្តិជាប្រវត្តិសាស្ត្រនៃវិវរណៈ ដែលពួកគេនឹងសិក្សានៅថ្ងៃនេះ សូមសង្ខេបបុព្វកថានៃមេរៀននេះ ។ ព្រះអម្ចាស់ បានប្រាប់យ៉ូសែប ស្ម៊ីធ ថា ម៉ាទីន ហារិស អូលីវើ ខៅឌើរី និង ដាវីឌ វិតមើរ នឹងត្រូវបានអនុញ្ញាតឲ្យមើលឃើញផ្ទាំងចំណារ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់ បានតម្រូវឲ្យពួកគេធ្វើកិច្ចការមួយចំនួនជាមុនសិន ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៧:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់តាមជាមួយ រកមើលនូវអ្វីដែលសាក្សីបីនាក់ចាំបាច់ត្រូវធ្វើដើម្បីមើលផ្ទាំងចំណារបាន ។ ក្រោយពីសិស្សបានរាយការណ៍អំពីអ្វីដែលពួកគេបានរកឃើញ ហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីពឹងផ្អែកទៅលើព្រះបន្ទូលរបស់ព្រះ « ដោយស្មោះអស់ពីចិត្ត » នោះ ? ( អត្ថន័យមួយអាចថា យើងគោរពព្រះ ឬធ្វើតាមព្រះបន្ទូលរបស់ទ្រង់ដោយអស់ពីដួងចិត្តរបស់យើង ) ។
- ហេតុអ្វីក៏អ្នកគិតថា បុរសទាំងនេះចាំបាច់ត្រូវបង្ហាញសេចក្តីជំនឿ ដូចជាពួកព្យាការីជំនាន់ដើម ពីមុនព្រះអម្ចាស់នឹងអនុញ្ញាតឲ្យពួកគេមើលផ្ទាំងចំណារនោះដូច្នោះ ?

ទោះជាយ៉ាងណា យើងអាចនឹងគ្មានឱកាសមើលឃើញវត្ថុទាំងឡាយ ដូចដែលពួកសាក្សីបីនាក់មើលឃើញដោយផ្ទាល់ក៏ដោយ តែយើងអាចទទួលបានសាក្សីមួយអំពីសេចក្តីពិតនៃដំណឹងល្អដែរ ។ សូមសរសេរសេចក្តីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោម នៅលើក្តារខៀន ៖ *បើយើងគោរព ហើយ* __________ *យើងអាចទទួលបានសាក្សីមួយអំពីសេចក្តីពិតនៃដំណឹងល្អ ។*

### *ការស្អាងដល់ការបង្រៀន*

នៅពេលអ្នកសម្រេចថាត្រូវបង្រៀនអ្វីចេញមកពីគម្ពីរមួយ និងរបៀបដើម្បីបង្រៀនវា សូមជ្រើសរើសសេចក្តីពិត និងវិធីសាស្ត្រនៃការបង្រៀន ដែលស្អាងដល់សិស្ស ហើយអនុញ្ញាតឲ្យពួកគេត្រូវបានលើកឡើងដោយព្រះវិញ្ញាណបរិសុទ្ធ ។ សូមជួយសិស្សឲ្យអនុវត្តសេចក្តីពិតនៅក្នុងជីវិតផ្ទាល់របស់ពួកគេ ហើយយល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងផែនការនៃសេចក្តីសង្គ្រោះ ។

សូមអញ្ជើញសិស្សឲ្យប្រាប់ពាក្យ ដើម្បីបំពេញសេចក្ដីថ្លែងការណ៍នេះ ។ ( សិស្សអាចនឹងឆ្លើយតបជាមួយអ្វីដូចនេះថា ៖ **បើយើងគោរព ហើយអនុវត្តសេចក្ដីជំនឿទៅលើព្រះ នោះយើងអាចទទួលបានសាក្សីមួយអំពីសេចក្ដីពិត នៃដំណឹងល្អ ។** សូមសរសេរគោលការណ៍ពេញលេញនៅលើក្ដារខៀន ដោយប្រើពាក្យរបស់សិស្ស ) ។

- តើអ្នកអនុវត្តសេចក្ដីជំនឿទៅលើព្រះ ដើម្បីទទួលបានសាក្សីមួយអំពីព្រះគម្ពីរមរមនយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់អំពីរបៀបដែលយ៉ូសែប ស្ម៊ីធ បានជួយដល់ ម៉ាទីន ហារិស អនុវត្តគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដោយម្ដាយរបស់យ៉ូសែប ស្ម៊ីធ ឈ្មោះ លូស៊ី ម៉ាក ស្ម៊ីធ ដូចខាងក្រោមថា ៖



« ព្រឹកស្អែកឡើង បន្ទាប់ពីការចូលរួមក្នុងកម្មវិធីប្រជុំតាមធម្មតារួចហើយ ដែលមានដូចជា ការអាន ការច្រៀង និងការអធិស្ឋាន នោះយ៉ូសែប បានក្រោកឡើងពីការលុតជង្គង់របស់គាត់ ហើយបានដើរទៅរក ម៉ាទីន ហារិស ដោយមុតមាំ ដែលធ្វើឲ្យនឹកចាំយ៉ាងស៊ើបសរសើររហូតមកដល់ពេលនេះ ដោយមានប្រសាសន៍ថា ‹ ម៉ាទិន ហារិស អ្នកត្រូវរាបសារនៅចំពោះព្រះថ្ងៃនេះ ដើម្បីអ្នកអាចទទួលបានការអភ័យទោសចំពោះអំពើបាបរបស់អ្នក ។ បើអ្នកធ្វើដូច្នោះ ព្រះឆន្ទៈរបស់ព្រះ ចង់ឲ្យអ្នកមើលឃើញផ្ទាំងចំណារ ព្រមជាមួយនឹងអូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ » ( *History of Joseph Smith by His Mother,* បានបោះពុម្ពដោយ Preston Nibley [ ឆ្នាំ ១៩៥៨ ], ១៥១–៥២ ) ។

- តើម៉ាទីន ចាំបាច់ត្រូវកែប្រែខ្លួន ដើម្បីធ្វើជាសាក្សីម្នាក់អំពីផ្ទាំងចំណារមាសតាមរបៀបណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៣–៩

*ព្រះអម្ចាស់ បើកបង្ហាញអំពីទំនួលខុសត្រូវរបស់ពួកសាក្សីបីនាក់ ដើម្បីថ្លែងទីបន្ទាល់អំពីផ្ទាំងចំណារ*

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៣–៥ ដោយខ្លួនគេ រកមើលទំនួលខុសត្រូវដែលសាក្សីបីនាក់នឹងមាន បន្ទាប់ពីមើលឃើញផ្ទាំងចំណាររួច ។ ( ពួកគេនឹងមានទំនួលខុសត្រូវដើម្បីថ្លែងទីបន្ទាល់អំពីអ្វីដែលពួកគេបានធ្វើជាសាក្សីផ្ទាល់ភ្នែក ) ។

- តើយើងមានទំនួលខុសត្រូវអ្វីខ្លះ ពេលព្រះអម្ចាស់ប្រទានដល់យើងនូវសាក្សីអំពីសេចក្ដីពិតដ៏ទេវភាព ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បន្ទាប់ពីយើងទទួលបានសាក្សីមួយអំពីសេចក្ដីពិត យើងមានទំនួលខុសត្រូវដើម្បីថ្លែងទីបន្ទាល់អំពីវា ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំឃ្លានៅក្នុងគម្ពីររបស់ពួកគេ ដែលបង្រៀនពីគោលការណ៍នេះ ) ។

- តើការមានឆន្ទៈរបស់យើងដើម្បីថ្លែងទីបន្ទាល់អំពីសេចក្ដីពិត បង្ហាញពីសេចក្ដីជំនឿរបស់យើងយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់អំពីដំណើររឿងនៃសាក្សីបីនាក់ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗអំពីដំណើររឿងដូចខាងក្រោម ដោយយ៉ូសែប ស្ម៊ីធ ៖



« ម៉ាទីន ហារិស, ដាវីឌ វិតមើរ, អូលីវើរ ខៅឌើរី និង [ ខ្ញុំ ] . . . បានចូលទៅ [ កាន់ព្រៃដែលនៅជិតនឹងផ្ទះរបស់ វិតមើរ ] ហើយបានលុតជង្គង់ចុះ រួចពួកយើងបានចាប់ផ្ដើមអធិស្ឋានដោយសេចក្ដីជំនឿយ៉ាងខ្លាំងចំពោះព្រះដ៏មានមហិទ្ធិឫទ្ធិ ។. . .

« យោងតាមការរៀបចំពីមុន ខ្ញុំបានចាប់ផ្ដើមដោយការអធិស្ឋានជាសំឡេងទៅកាន់ព្រះវរបិតាសួគ៌ ហើយអ្នកដទៃទៀតម្នាក់ៗក៏បានធ្វើតាមតាមលេខរៀងផងដែរ ។ ទោះជាយ៉ាងណា តាំងពីគ្រាដំបូងមក យើងពុំបានទទួលចម្លើយ ឬការបើកសម្ដែងពីព្រះជំនួសឲ្យយើងនោះទេ ។ យើងបានសង្កេតមើលនូវរបៀបដូចគ្នានៃការអធិស្ឋាន. . . ប៉ុន្តែមានលទ្ធផលដូចគ្នានឹងពីមុន ។

« យើងបានបរាជ័យជាលើកទីពីរ ចំពោះរឿងនេះ ម៉ាទីន ហារិស បានស្នើសុំថា គាត់គួរតែដកខ្លួនចេញពីយើង តាមដែលគាត់បានបង្ហាញប្រាប់ដោយខ្លួនគាត់ថា គាត់ជឿថាវត្តមានរបស់គាត់ គឺជាមូលហេតុដែលយើងពុំអាចទទួលបានចម្លើយតាមដែលយើងប៉ងប្រាថ្នាសុំនោះទេ ។ រួចគាត់ក៏បានដកខ្លួនចេញពីយើងទៅ ហើយយើងបានលុតជង្គង់ចុះម្ដងទៀត ហើយមិនបានប៉ុន្មាននាទីផង នៅក្នុងការអធិស្ឋាននោះ យើងបានឃើញពន្លឺមួយនៅចំពីលើយើងក្នុងអាកាសដែលភ្លឺចែងចាំងយ៉ាងខ្លាំង ហើយមើលចុះ មានទេវតាមួយអង្គឈរនៅចំពោះយើង ។ នៅក្នុងដៃរបស់លោក លោកមានផ្ទាំងចំណារដែលយើងកំពុងអធិស្ឋានសុំឲ្យអ្នកទាំងឡាយនោះបានមើលឃើញ ។ លោកបានបើកមួយសន្លឹកម្ដងៗ ដើម្បីយើងអាចមើលឃើញវា ហើយយល់អំពីការឆ្លាក់ត្រានៅក្នុងនោះបានយ៉ាងច្បាស់ ។. . . យើងបានស្ដាប់ឮសំឡេងមួយចេញមកពីក្នុងពន្លឺនៅខាងលើយើង ដោយថ្លែងថា ‹ ផ្ទាំងចំណារទាំងនេះ ត្រូវបានបើកសម្ដែងឡើងដោយព្រះចេស្ដានៃព្រះ

ហើយវាត្រូវបានបកប្រែដោយព្រះចេស្ដានៃព្រះ ។ ការបកប្រែរបស់វា ដែលអ្នកបានមើលឃើញគឺត្រឹមត្រូវ ហើយខ្ញុំបញ្ជាដល់អ្នកឲ្យថ្លែងទីបន្ទាល់អំពីអ្វីដែលឥឡូវអ្នកបានឃើញ និងស្ដាប់ឮនោះ › ។

« ឥឡូវខ្ញុំបានចាកចេញពីដេវីឌ និងអូលីវើរ ហើយបានទៅរកម៉ាទីន ហារិស ដែលខ្ញុំបានឃើញថា គាត់កំពុងតែអធិស្ឋានយ៉ាងក្លៀវក្លានៅកន្លែងឆ្ងាយមួយ ។ ទោះជាយ៉ាងណា មិនយូរប៉ុន្មាន គាត់បានប្រាប់ខ្ញុំថា គាត់ពុំទាន់បានទទួលជោគជ័យជាមួយព្រះអម្ចាស់នៅឡើយទេ ហើយបានស្នើសុំយ៉ាងក្លៀវក្លា ដើម្បីខ្ញុំចូលរួមនឹងគាត់ក្នុងការអធិស្ឋាន ដើម្បីគាត់អាចបានដឹងនូវពរជ័យដូចគ្នាដែលយើងបានទើបតែទទួលនោះផងដែរ ។ យើងបានចូលរួមក្នុងការអធិស្ឋាន ហើយទីបំផុតបានទទួលតាមបំណងរបស់យើង ដ្បិតមុនពេលយើងបានបញ្ចប់ការអធិស្ឋាន នោះមានការនិមិត្តដូចគ្នា ត្រូវបានបើកសម្ដែងឲ្យយើងឃើញ ហើយទីបំផុតវាត្រូវបានបើកឲ្យឃើញម្ដងទៀតចំពោះខ្ញុំ ហើយខ្ញុំបានមើលឃើញ និងស្ដាប់ឮនូវរឿងដូចគ្នាម្ដងទៀត ហើយក្នុងគ្រានោះ ម៉ាទីន ហារិស បានស្រែកឡើង ដោយក្ដីអំណរយ៉ាងខ្លាំងថា « ‹ គ្រប់គ្រាន់ហើយ គ្រប់គ្រាន់ហើយ ភ្នែករបស់ខ្ញុំផ្ទាល់បានមើលឃើញ ភ្នែករបស់ខ្ញុំផ្ទាល់បានមើលឃើញ› » ( នៅក្នុង *History of the Church* ១:៥៤–៥៥ ) ។

- ហេតុអ្វីក៏អ្នកគិតថា ច្បាប់នៃសាក្សីភាព ឬការមានសាក្សីច្រើន សំខាន់យ៉ាងខ្លាំងនៅក្នុងការស្ដារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដូច្នេះ ?

សូមពិចារណាសុំដល់សិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដែលប្រាប់លម្អិតអំពីអារម្មណ៍របស់យ៉ូសែប ស្ម៊ីធ នូវបទពិសោធន៍នោះថា ៖



« នៅពេលពួកលោកត្រឡប់មកផ្ទះវិញ គឺនៅចន្លោះម៉ោងបីទៅបួនល្ងាច នោះលោក វិតមើរ លោក ស្ម៊ីធ និង រូបខ្ញុំ អង្គុយនៅក្នុងបន្ទប់គេងមួយ នាគ្រានោះ ។ ពេលមកដល់ផ្ទះ យ៉ូសែប បានទម្លាក់ខ្លួននៅជិតខ្ញុំ ហើយប្រកាសថា ‹ពុកអើយ ម៉ែអើយ លោកទាំងពីរពុំដឹងទេថាខ្ញុំសប្បាយចិត្តខ្លាំងយ៉ាងណា ៖ ឥឡូវ ព្រះអម្ចាស់បានបង្ហាញផ្ទាំងចំណារទៅដល់បុរសបីនាក់ផ្សេងទៀតក្រៅពីរូបខ្ញុំ ។ ពួកគេបានមើលឃើញទេវតា ដែលបានថ្លែងទីបន្ទាល់ដល់ពួកគេ ហើយពួកគេនឹងធ្វើជាសាក្សីចំពោះសេចក្ដីពិតនៃអ្វីដែលខ្ញុំបាននិយាយ ដ្បិតឥឡូវនេះ ពួកគេបានដឹងដោយផ្ទាល់ខ្លួនគេហើយថា ខ្ញុំពុំបានទៅបោកបញ្ឆោតមនុស្សទេ ហើយខ្ញុំមានអារម្មណ៍ដូចជាខ្ញុំត្រូវបានរួចពីបន្ទុកមួយ ដែលធ្ងន់យ៉ាងខ្លាំងស្ទើរតែខ្ញុំពុំអាចរែកបាននោះ ហើយវាធ្វើឲ្យព្រលឹងរបស់ខ្ញុំរីករាយ ដែលខ្ញុំឈប់ជាអ្នកដឹងតែឯងក្នុងលោកិយនេះទៀតហើយ› ។ ចំពោះរឿងនេះ ម៉ាទីន ហារិស បានចូលមក ៖ គាត់ហាក់ដូចជាគ្របដណ្ដប់ដោយក្ដីអំណរ ហើយថ្លែងទីបន្ទាល់យ៉ាងម៉ឺងម៉ាត់ចំពោះអ្វីដែលគាត់បានទាំងមើលឃើញ និងស្ដាប់ឮនោះ ។ ហើយក៏ដូចគ្នានឹង ដាវីឌ វិតមើរផងដែរ បានបន្ថែមថា គ្មានអណ្ដាតណាអាចបង្ហាញប្រាប់ពីក្ដីអំណរនៃដួងចិត្តរបស់ពួកលោកឡើយ និងភាពមហិមានៃរឿងទាំងឡាយដែលពួកលោកបានទាំងមើលឃើញ និងស្ដាប់ឮនោះ » ( *History of Joseph Smith by His Mother* ១៥២ ) ។

- តើអ្នកមានអារម្មណ៍យ៉ាងណា ពេលអ្នកស្ថិតនៅជាមួយនឹងអ្នកទាំងឡាយដែលដឹងថាដំណឹងល្អគឺជាការពិតនោះ ? តើទីបន្ទាល់របស់ពួកគេ ជួយដល់អ្នកដូចម្ដេចដែរ ?

សូមបែងចែកសិស្សជាដៃគូ ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអាន « ទីបន្ទាល់នៃសាក្សីបីនាក់ » ឲ្យឮៗ ( មាននៅបន្ទាប់ពីបុព្វកថានៃព្រះគម្ពីរមរមន ) ។ នៅពេលសិស្សអាន សូមអញ្ជើញពួកគេឲ្យរកមើលពាក្យ ឬឃ្លាដែលពង្រឹងដល់ទីបន្ទាល់របស់ពួកគេ ។

សូមពន្យល់ទៅដល់សិស្សថា ទោះបីជាសាក្សីទាំងបីនាក់ ដែលម្នាក់ៗបានធ្លាក់ចេញពីសាសនាចក្រក្ដី ( អូលីវើរ ខៅឌើរី និង ម៉ាទីន ហារិស ដែលក្រោយមកបានទទួលបុណ្យជ្រមុជទឹកឡើងវិញ ) នោះគ្មានពួកគេណាម្នាក់បានបដិសេធភាពជាសាក្សីរបស់ពួកគេអំពីព្រះគម្ពីរមរមននោះទេ ។

សូមឲ្យសិស្សនឹកគិតថា ទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេអំពីព្រះគម្ពីរមរមន អាចបន្ថែមទៅក្នុងច្បាប់នីមួយៗនៃព្រះគម្ពីរមរមន ។ សូមអញ្ជើញឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ នូវអ្វីដែលពួកគេនឹងចង់ដាក់បញ្ចូលទៅក្នុងទីបន្ទាល់របស់ពួកគេ ។ សូមពិចារណាធ្វើការអញ្ជើញដល់សិស្សមួយចំនួនឲ្យចែកចាយនូវអ្វីដែលពួកគេបានសរសេរ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៦ ដោយស្ងាត់ស្ងៀម រកមើលទីបន្ទាល់របស់ព្រះយេស៊ូវគ្រីស្ទអំពីព្រះគម្ពីរមរមន ។ **ព្រះយេស៊ូវគ្រីស្ទ ក៏បានថ្លែងទីបន្ទាល់ផងដែរថា ព្រះគម្ពីរមរមនពិត !**

- តើទីបន្ទាល់របស់ព្រះអម្ចាស់អំពី ព្រះគម្ពីរមរមន ជួយពង្រឹងដល់ទីបន្ទាល់របស់អ្នកយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៧–៩ ឲ្យឮៗ ។ សូមឲ្យសិស្សតាមជាមួយ រកមើលនូវការសន្យាទាំងឡាយដែលបានផ្ដល់ទៅឲ្យពួកសាក្សីបីនាក់ ។ សូមនាំការផ្ដោតយកចិត្តទុកដាក់របស់សិស្សទៅលើឃ្លា « គោលបំណងដ៏សុចរិត » នៅក្នុង ខ ៩ ។

- តើគោលបំណងរបស់ព្រះអម្ចាស់មួយចំនួន ដើម្បីមានសាក្សីបីនាក់មានអ្វីខ្លះ ? ( អ្នកអាចនឹងចង់ឲ្យសិស្សរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៤ ដើម្បីឆ្លើយសំណួរនេះផងដែរ ) ។
- តើ « គោលបំណងដ៏សុចរិត » មួយ ដើម្បីផ្ដល់នូវសាក្សីនៃសេចក្ដីពិតដល់អ្នក ដែលអ្នកប្រាថ្នាចង់ដឹងគឺជាអ្វី ?

សូមរំឭកសិស្សថា យើងអាចទទួលបាន ឬពង្រឹងទីបន្ទាល់មួយ នៅពេលយើងចែកចាយវា ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ពិចារណាអំពីនរណាដែលពួកគេអាចចែកចាយទីបន្ទាល់របស់ពួកគេជាមួយ ដែលអាចទទួលបានផលប្រយោជន៍មកពីការស្ដាប់ឮវានោះ ។ សូមលើកទឹកចិត្តពួកគេឲ្យចែកចាយទីបន្ទាល់របស់ពួកគេជាមួយនឹងមនុស្សម្នាក់នោះក្នុងសប្ដាហ៍នេះ ។

មេរៀនទី ២២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១–១៦

### បុព្វកថា

យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ សម្រាប់ខ្លួនលោក សម្រាប់អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ នៅខែមិថុនា ឆ្នាំ ១៨២៩ មិនយូរប៉ុន្មានបន្ទាប់ពី ពេត្រុស យ៉ាកុប និង យ៉ូហាន បានប្រគល់បព្វជិតភាពមិលគីស្សាដែកមកលើ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។

នៅដើមដំបូងនៃវិវរណៈ ព្រះអម្ចាស់ បានបង្រៀនអូលីវើរ ខៅឌើរី អំពីការស្ថាបនាសាសនាចក្រឡើង ។ បន្ទាប់មក ទ្រង់បានហៅអូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ឲ្យផ្សាយការប្រែចិត្ត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១–៥

*ព្រះអម្ចាស់ បង្រៀនអំពីរបៀបដើម្បីស្ថាបនាសាសនាចក្ររបស់ទ្រង់ឡើង*

សូមគូសរូបភាពដែលមានអមមកជាមួយ នៅលើក្ដារខៀនឲ្យសិស្ស ។




សូមពិចារណាធ្វើការអានព័ត៌មានដូចខាងក្រោម ឬចែកចាយព័ត៌មានស្រដៀងគ្នានោះអំពីការរញ្ជួយដី ដែលបានកើតឡើងថ្មីៗនេះ ឬដែលកើតឡើងនៅជិតនឹងកន្លែងដែលអ្នករស់នៅ៖

នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៨៩ វេលាម៉ោង ៥:០៤ ល្ងាច នោះមានការរញ្ជួយដីមួយ ដែលមានរង្វាស់ ៦.៩ រិកទ័រ វាយប្រហារនៅ សាន់ហ្វ្រាន់ស៊ីស្កូ រដ្ឋកាលីហ្វូញ៉ា នៅតំបន់នៃសហរដ្ឋអាមេរិក ។ មានអគាររាប់ពាន់ត្រូវបានខូចខាត ឬបំផ្លិចបំផ្លាញ ។ គ្រឹះនៃអគារជាច្រើនត្រូវបានប្រេះស្រាំដែលបណ្ដាលឲ្យអគារទាំងឡាយត្រូវបានប្រកាសថាពុំមានសុវត្ថិភាព ។

- តើអ្នកនឹងមានកង្វល់អ្វីខ្លះ ចំពោះការរស់នៅក្នុងផ្ទះមួយដែលមានគ្រឹះពុំរឹងមាំនោះ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ បានកត់ត្រាវិវរណៈរបស់ព្រះអម្ចាស់ទៅកាន់យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី ស្ដីអំពីរបៀបដើម្បីស្ថាបនាសាសនាចក្ររបស់ទ្រង់នៅលើគ្រឹះដ៏សុវត្ថិភាពមួយ ។ នៅដើមដំបូងនៃវិវរណៈនេះ ព្រះអម្ចាស់ បានយោងទៅលើអ្វីដែល អូលីវើរ ខៅឌើរី បានសរសេរ ជាអត្ថន័យនៃព្រះបន្ទូលក្នុងព្រះគម្ពីរមរមន ដែលអូលីវើរ បានកត់ត្រាខណៈដែលធ្វើជាស្មៀនរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១–៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលរឿងនានាត្រូវបានសរសេរនៅក្នុងព្រះគម្ពីរមរមន ដែលនឹងជួយនៅក្នុងការស្ថាបនាសាសនាចក្រឡើងវិញ ។

- តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ នៅក្នុងព្រះគម្ពីរមរមន ? តើការបង្រៀននៅក្នុងព្រះគម្ពីរមរមនអាចជួយនៅក្នុងការស្ថាបនាឡើងនៃសាសនាចក្រយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ប្រាប់នូវអ្វីដែលព្រះអង្គសង្គ្រោះ បានសន្យា បើយើងនឹងស្ថាបនាសាសនាចក្ររបស់ទ្រង់ឡើងនៅលើគ្រឹះនៃដំណឹងល្អរបស់ទ្រង់ ។

- ស្របតាម ខ ៥ តើសាសនាចក្រពិតរបស់ព្រះត្រូវស្ថាបនាឡើងនៅលើអ្វីខ្លះ ? ( ចម្លើយរបស់សិស្ស គួរតែឆ្លុះបញ្ចាំងនូវគោលលទ្ធិដូចខាងក្រោម ៖ **សាសនាចក្រពិត គឺស្ថាបនាឡើងនៅលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់** ) ។

- តើព្រះអម្ចាស់សន្យាយើងអ្វីខ្លះ នៅពេលយើងស្ថាបនាសាសនាចក្ររបស់ទ្រង់នៅលើគ្រឹះនៃដំណឹងល្អរបស់ទ្រង់នោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៦–១៦

*ព្រះអម្ចាស់បានហៅអូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ឲ្យផ្សាយការប្រែចិត្ត*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះអម្ចាស់បានពិពណ៌នាអំពីពិភពលោកដែលយើងកំពុងរស់នៅ ។ បន្ទាប់ពីសិស្សបានរាយការណ៍អំពីអ្វីដែលពួកគេរកឃើញហើយ សូមឲ្យពួកគេអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ១៨:៩ ដើម្បីរៀនអំពីអ្វីដែលព្រះអម្ចាស់បានត្រាស់បញ្ជានៅក្នុងការឆ្លើយតបចំពោះការកើនឡើងនូវសេចក្ដីទុច្ចរិតនៅក្នុងពិភពលោកនេះ ។

- តើចម្លើយរបស់ព្រះអម្ចាស់ចំពោះ ការកើនឡើងនៃអំពើទុច្ចរិតក្នុងលោកិយមានអ្វីខ្លះ ? ( ទ្រង់បានហៅពួកអ្នកបម្រើឲ្យផ្សាយពីការប្រែចិត្ត ) ។

សូមចង្អុលបង្ហាញថាព្រះអម្ចាស់បានហៅអូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ឲ្យផ្សាយពីការប្រែចិត្ត ដូចទ្រង់បានហៅសាវកប៉ុលពីបុរាណឲ្យធ្វើកិច្ចការនោះផងដែរ ។ ដោយសារ អូលីវើរ និងដាវីឌ ពុំត្រូវបានហៅឲ្យធ្វើជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីនាក់ នោះពួកគេមានតួនាទីនៅក្នុងការស្ថាបនាកូរ៉ុមនេះនៅថ្ងៃចុងក្រោយ ។ សូមពន្យល់ថា សិស្សនឹងរៀនច្រើនទៀតអំពីតួនាទីរបស់ អូលីវើរ ខៅឌើរី និងដាវីឌ វិតមើរ នៅក្នុងមេរៀនបន្ទាប់ ។

ដើម្បីជួយសិស្សរៀបចំសិក្សាអំពីការបង្រៀនរបស់ព្រះអម្ចាស់ ចំពោះតម្លៃនៃព្រលឹង សូមបង្ហាញវត្ថុមួយចំនួន ដែលអ្នកគិតថាអាចមានតម្លៃចំពោះសិស្សរបស់អ្នក ។ សូមសួរដល់ពួកគេថា តើពួកគេនឹងបង់ថ្លៃអស់ប៉ុន្មានសម្រាប់វត្ថុនីមួយៗទាំងនេះ ។ សូមពន្យល់ថា របៀបមួយដើម្បីកំណត់អំពីតម្លៃរបស់វត្ថុមួយ គឺត្រូវរកឲ្យឃើញនូវអ្វីដែលមនុស្សស្ម័គ្រចិត្តនឹងបង់ថ្លៃសម្រាប់វានោះ ។ មនុស្សម្នាក់អាចប្រកាសថា វត្ថុជាក់លាក់មួយ មានតម្លៃក្នុងចំនួនទឹកប្រាក់ជាក់លាក់មួយ ប៉ុន្តែតម្លៃនេះ គឺត្រឹមត្រូវតែបើសិនជាមនុស្សម្នាក់ទៀត នឹងស្ម័គ្រចិត្តដើម្បីបង់ថ្លៃទៅតាមចំនួន សម្រាប់វត្ថុនោះតែប៉ុណ្ណោះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០ ឲ្យឮៗ សូមអញ្ជើញសិស្សឲ្យប្រើខគម្ពីរនេះពន្យល់អំពីតម្លៃរបស់ពួកគេនៅក្នុងព្រះនេត្រនៃព្រះ ។ សិស្សអាចនឹងផ្ដល់យោបល់ជាគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវគូសបញ្ជាក់ឲ្យបាក្រដថា **តម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ** ។

- ហេតុអ្វីអ្នកគិតថា អ្នកមានតម្លៃដ៏មហិមានៅចំពោះព្រះដូច្នេះ ?

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ នៃគណៈប្រធានទីមួយ ៖



« ព្រះទតមើលអ្នក ពុំមែនគ្រាន់តែជាមនុស្សរមែងស្លាប់នៅក្នុងភពតូចមួយ ដែលយើងរស់នៅមួយរយៈនោះទេ— ទ្រង់ទតមើលលើអ្នក ក្នុងនាមជាបុត្ររបស់ទ្រង់ ។ ទ្រង់ទតមើលអ្នកជាតួអង្គ ដែលមានសមត្ថភាព និង បានរៀបចំរចនាអ្នកឡើងឲ្យប្រែក្លាយទៅជាដូចនោះ ។ ទ្រង់ចង់ឲ្យអ្នកដឹងថា អ្នកសំខាន់ចំពោះទ្រង់ » ( You Matter to Him » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១,ទំព័រ ២២ ) ។

សូមរំឭកសិស្សអំពីសកម្មភាព ដែលអ្នកបានបង្ហាញថា តម្លៃនៃវត្ថុមួយ គឺអាស្រ័យទៅលើអ្វីដែលមនុស្សម្នាក់ ស្ម័គ្រចិត្តដើម្បីបង់ថ្លៃសម្រាប់វាទៅវិញទេ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១១–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់តាមជាមួយ ហើយប្រាប់នូវអ្វីដែលព្រះអង្គសង្គ្រោះបានស្ម័គ្រព្រះទ័យដើម្បីបង់ថ្លៃសម្រាប់យើង ។

- តើព្រះអង្គសង្គ្រោះបង់ថ្លៃសម្រាប់ព្រលឹងយើងថ្លៃប៉ុន្មាន ? ( អ្នកអាចនឹងចង់រំឭកសិស្សថា នៅក្នុងខគម្ពីរទាំងនេះឃ្លាថា « មនុស្សលោកទាំងអស់ » គឺសំដៅទៅលើមនុស្សទាំងអស់ ។

- តើយើងអាចបង្ហាញនូវការដឹងគុណចំពោះពលិកម្ម ដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់យើងយ៉ាងដូចម្ដេច ? ( ទោះជាចម្លើយផ្សេងៗគ្នាត្រឹមត្រូវ សូមបញ្ជាក់ថា របៀបមួយដ៏ល្អបំផុត ដែលយើងអាចបង្ហាញការដឹងគុណរបស់យើង គឺតាមរយៈការប្រែចិត្ត ) ។

សូមសរសេរនូវសេចក្ដីថ្លែងដូចខាងក្រោមនៅលើក្ដារខៀន ៖ **តម្លៃខ្លួនខ្ញុំគឺថ្លៃខ្លាំងណាស់ ដែលធ្វើឲ្យព្រះយេស៊ូវគ្រីស្ទ បានរងទុក្ខ ហើយបានសុគត ដូច្នេះខ្ញុំអាចបានប្រែចិត្ត ។**

អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យសរសេរគោលការណ៍នេះនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬ សៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

- តើសេចក្ដីពិតនេះ មានឥទ្ធិពលលើរបៀបដែលយើងមើលមកខ្លួនឯងយ៉ាងដូចម្ដេចខ្លះ ?
- តើសេចក្ដីពិតនេះ មានឥទ្ធិពលលើរបៀបដែលអ្នកប្រព្រឹត្តនឹងអ្នកដទៃយ៉ាងដូចម្ដេចខ្លះ ?

សូមថ្លែងទីបន្ទាល់អំពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ និងការសុគតរបស់ទ្រង់ ដើម្បីយើងម្នាក់ៗ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៣ ដោយស្ងាត់ស្ងៀម ។

- ហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់មានក្ដីអំណរយ៉ាងខ្លាំងពេលយើងប្រែចិត្តដូច្នេះ ?
- បើនរណាម្នាក់ជឿថា តម្លៃនៃព្រលឹងគឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ នោះតើជំនឿរបស់ពួកគេនឹងដឹកនាំពួកគេឲ្យធ្វើអ្វីខ្លះ ? ( ចម្លើយអាចមានដូចជា ៖ ការប្រព្រឹត្តនឹងអ្នកដទៃដោយគោរព បម្រើអ្នកដទៃ ឬរៀបចំខ្លួនដើម្បីបម្រើបេសកកម្ម ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៤ ដោយស្ងាត់ស្ងៀម ដើម្បីរៀនអំពីអ្វីដែលព្រះអម្ចាស់បានហៅអូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរឲ្យធ្វើ ។

- តើអ្នកគិតថា វាមានន័យដូចម្ដេចក្នុងការ « ស្រែកប្រាប់ពីការប្រែចិត្ត » ?

ដើម្បីជួយសិស្សយល់ឃ្លានេះកាន់តែប្រសើរ សូមអានសេចក្ដីថ្លែងការដោយអែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ថា ៖ « ការស្រែកប្រាប់ពីការប្រែចិត្ត ជាធម្មតាមានន័យថា ការជួយមនុស្សឲ្យត្រឡប់មករកព្រះ » ( «Preparing for Your Spiritual Destiny » [ CES fireside address, ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១០ ], ៧, speeches.byu.edu ) ។

- តើយើងអាចជួយអ្នកដទៃទៀតឲ្យប្រែចិត្តតាមវិធីណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យ អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៥–១៦ ដើម្បីរៀនអំពីបទពិសោធន៍របស់បុគ្គលម្នាក់ៗពេលពួកគេជួយដល់នរណាម្នាក់ឲ្យមករកព្រះយេស៊ូវគ្រីស្ទ ។

- តើមានពរជ័យអ្វីខ្លះដែលត្រូវបានប្រទានឲ្យ អ្នកទាំងឡាយដែល ជួយអ្នកដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទនោះ ? ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងជួយអ្នកដទៃឲ្យប្រែចិត្ត ហើយមករកព្រះអម្ចាស់ នោះយើងនឹងទទួលអារម្មណ៍នៃក្ដីអំណរ ជាមួយពួកគេនៅក្នុងនគរនៃព្រះ**
- ហេតុអ្វីក៏អ្នកគិតថា អ្នកនឹងមានអារម្មណ៍នៃក្ដីអំណរ បើអ្នកនាំអ្នកដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទនោះ ?

សូមអញ្ជើញសិស្សឲ្យ ចែកចាយបទពិសោធន៍មួយ ដែលពួកគេ ឬនរណាម្នាក់ដែលពួកគេស្គាល់ បានមានអារម្មណ៍ក្ដីអំណរដោយសារតែពួកគេបានជួយនរណាម្នាក់ឲ្យរីកចម្រើនឡើងខិតទៅកាន់តែជិតព្រះអម្ចាស់ ។ អ្នកក៏អាចចង់ចែកចាយពីបទពិសោធន៍មួយរបស់អ្នកផងដែរ ។

សូមអញ្ជើញសិស្សឲ្យសរសេរអ្វីមួយដែលពួកគេអាចធ្វើ ដើម្បីជួយនៅក្នុងកិច្ចការនៃការសង្គ្រោះព្រលឹង ។ សូមពួកគេឲ្យពិចារណាទៅលើមនុស្សជាក់លាក់ ដែលពួកគេអាចជួយ ។

### *សូមអញ្ជើញសិស្សឲ្យចែកចាយពីបទពិសោធន៍នានា*

នៅពេលសិស្សចែកចាយពីបទពិសោធន៍ដ៏បំផុសទាំងឡាយ វាអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់មកក្នុងថ្នាក់រៀន ។ នៅពេលសិស្សស្ដាប់ពីបទពិសោធន៍ និង ទីបន្ទាល់របស់មិត្តភក្ដិរបស់ពួកគេ នោះទីបន្ទាល់របស់ពួកគេត្រូវបានពង្រឹង ហើយពួកគេរៀនពីរបៀបថ្មីដើម្បីអនុវត្តគោលការណ៍ដំណឹងល្អនៅក្នុងជីវិតរបស់ពួកគេ ។ ជាធម្មតា វាគ្រប់គ្រាន់ដើម្បីមានសិស្សពីម្នាក់ទៅបីនាក់ឲ្យចែកចាយបទពិសោធន៍នេះ ។ សូមពន្យល់ដល់សិស្សថា ពួកគេពុំគួរចែកចាយបទពិសោធន៍ដែលពិសិដ្ឋ ឯកជន និងផ្ទាល់ខ្លួនខ្លាំងពេករបស់ពួកគេនោះទេ ។ សូមចៀសវាងការហៅសិស្សពីរបីនាក់ដដែលៗឲ្យចែកចាយរាល់ថ្ងៃ សូមព្យាយាមឲ្យគ្រប់គ្នាបានចូលរួម ។

មេរៀនទី ២៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១៧–៤៧

## បុព្វកថា

យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះសម្រាប់ខ្លួនលោក អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ក្នុងខែមិថុនា ឆ្នាំ ១៨២៩ ។ បន្ទាប់ពីការហៅបុរសពីរនាក់ដើម្បីប្រកាសពីការកែប្រែចិត្ត ព្រះអង្គសង្គ្រោះបានបង្រៀនពួកគេអំពីសារៈសំខាន់នៃការទទួលយកព្រះនាមទ្រង់ដាក់មកលើខ្លួនពួកគេ ។ លោកបានប្រាប់អំពីការចេញមកនូវការហៅពួកសាវកដប់ពីរនាក់ និងបំណងប្រាថ្នា ដែលពួកគេនឹងត្រូវទទួលមកដាក់លើខ្លួនពួកគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ដោយ « បំណងចិត្តដ៏ពោរពេញ » ( គ. និង ស. ១៨:២៧ ) ។ រួចហើយព្រះអម្ចាស់បានប្រទានដល់ អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ នូវការទទួលខុសត្រូវដើម្បីស្វែងរកបុរស ដែលអាចបម្រើជាសមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១៧–២៥

*ព្រះយេស៊ូវគ្រីស្ទបង្រៀនថា ព្រះនាមរបស់ទ្រង់ គឺជានាមតែមួយគត់ ដែលយើងអាចត្រូវបានសង្គ្រោះ*

សូមអញ្ជើញសិស្សម្នាក់ ឬពីរនាក់ឲ្យសរសេរគោត្តនាមរបស់ពួកគេនៅលើក្ដារខៀន ។ សូមសួរពួកគេនូវសំណួរខាងក្រោម ៖

- តើគោត្តនាមរបស់អ្នកមានអត្ថន័យយ៉ាងណាចំពោះអ្នក ?
- តើមាននូវឯកសិទ្ធិ និងការទទួលខុសត្រូវអ្វីខ្លះ ជាមួយនឹងនាមនោះ ? ( ឯកសិទ្ធិអាចរាប់បញ្ចូលទាំងទីកន្លែងមួយដើម្បីរស់នៅ ក្ដីស្រឡាញ់ពីគ្រួសារ សុវត្ថិភាព និងការត្រូវបានចិញ្ចឹមនៅក្នុងសាសនាចក្រ ។ ការទទួលខុសត្រូវ អាចរាប់បញ្ចូលទាំង ការជួយរក្សាផ្ទះឲ្យមានសុវត្ថិភាព ការប្រព្រឹត្តនឹងសមាជិកគ្រួសារដោយគោរព ការធ្វើកិច្ចការផ្ទះ និងការនាំកិត្តិយសមកដល់ឈ្មោះគ្រួសារ ) ។

សូមរំឭកសិស្សថា ព្រះអម្ចាស់ បានហៅអូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ឲ្យស្រែកប្រាប់ពីការប្រែចិត្ត ( សូមមើលគ. និង ស. ១៨:៦, ៩, ១៤ ) ។ សូមពន្យល់ថា បន្ទាប់ពីព្រះអម្ចាស់បានប្រទានការណែនាំនេះដល់ពួកគេ នោះទ្រង់មានបន្ទូលទៅកាន់ពួកគេអំពីឯកសិទ្ធិ និងការទទួលខុសត្រូវដើម្បី លើកដាក់មកលើខ្លួនពួកគេនូវព្រះនាមរបស់ទ្រង់ ។

សូមចម្លងតារាងខាងក្រោម ដាក់លើក្ដារខៀន ប៉ុន្តែសូមកុំចម្លងចម្លើយនៅបន្ទាត់ខាងក្រោមឡើយ ។ សូមអញ្ជើញពួកគេឲ្យចម្លងតារាងចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ បន្ទាប់មក សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៧–២៥ ដោយស្ងាត់ស្ងៀម ហើយប្រាប់អំពីឯកសិទ្ធិ និងទំនួលខុសត្រូវដែលកើតមានមកជាមួយនឹងការទទួលយកមកដាក់លើខ្លួនពួកគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទនោះ ។ សូមឲ្យពួកគេសរសេរនូវអ្វីដែលពួកគេបានរកឃើញនៅក្នុងជួរខាងក្រោមនៃតារាង ។

| ឯកសិទ្ធិ | ទំនួលខុសត្រូវ |
|---|---|
| ទទួលយក និងត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ<br>សូមអញ្ជើញអ្នកដទៃឲ្យទទួលបុណ្យជ្រមុជទឹក ហើយកាន់ខ្ជាប់ដល់ចុងបំផុត<br>ទទួលយកសេចក្ដីសង្គ្រោះនៅក្នុងនគរនៃព្រះវរបិតា | មានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស<br>ចៀសវាងពីការទាស់ទែងនឹងព្រះវិហារផ្សេងទៀត<br>និយាយសេចក្ដីពិតដោយស្លូតត្រង់<br>ប្រែចិត្ត ហើយបានកាន់ខ្ជាប់ដល់ចុងបញ្ចប់ ។ |

- យោងទៅតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៣ ហេតុអ្វីបានជាវាសំខាន់ចំពោះយើង ដើម្បីលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ? ( សិស្សគួរតែប្រាប់អំពីគោលលទ្ធិខាងក្រោម ៖ **ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ គឺជាព្រះនាមតែមួយគត់ ដែលយើងអាចត្រូវបានសង្គ្រោះ** ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមដល់សិស្សក្នុងថ្នាក់ឲ្យស្ដាប់ការប្រឹក្សារបស់អែលឌើរ បាឡឺដ អំពីរបៀបដែលយើងត្រូវលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ៖



« យើងនឹងលើកដាក់លើខ្លួនយើងនូវព្រះនាមនៃព្រះគ្រីស្ទនៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹក ។ យើងរំឭកប្រសិទ្ធភាពនៃពិធីបុណ្យជ្រមុជទឹកនោះរាល់សប្ដាហ៍ នៅពេលយើងទទួលទាននៃពិធីសាក្រាម៉ង់ ដែលបង្ហាញពីឆន្ទៈរបស់យើងដើម្បីលើកដាក់ព្រះនាមទ្រង់មកលើយើង ហើយសន្យាថាចងចាំទ្រង់ជានិច្ច ( សូមមើល គ. និង ស. ២០:៧៧, ៧៩) ។. . .

« យើងត្រូវបានសុំឲ្យឈរជាសាក្សីម្នាក់នៃទ្រង់ ។. . . នេះមានន័យថា យើងត្រូវតែមានឆន្ទៈដើម្បីប្រាប់ឲ្យអ្នកដទៃដឹងថា យើងដើរតាមនរណា ហើយយើងស្ថិតនៅក្នុងសាសនាចក្ររបស់នរណា ៖ ជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ យើងច្បាស់ជាចង់ធ្វើនូវកិច្ចការនេះដោយអារម្មណ៍នៃក្ដីស្រឡាញ់ និងទីបន្ទាល់ ។ យើងចង់ធ្វើតាមព្រះអង្គសង្គ្រោះ ដោយសាមញ្ញ និងដោយច្បាស់លាស់ ប៉ុន្តែដោយរាបសារ ដែលប្រកាសថា យើងជាសមាជិកនៃសាសនាចក្ររបស់ទ្រង់ » ( «The Importance of a Name, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៧៩–៨០ ។

- តើអែលឌើរ បាឡឺដ ឲ្យយោបល់ថា យើងត្រូវប្រាប់ឲ្យអ្នកដទៃដឹងថា យើងដើរតាមព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ?
- នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៩–២០ ព្រះអម្ចាស់ បានបញ្ជាអូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ឲ្យមានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ហើយចៀសវាងពីការឈ្លោះទាស់ទែងជាមួយនឹងព្រះវិហារដទៃទៀត និងសមាជិករបស់ពួកគេ ។ ហេតុអ្វីក៏អ្នកគិតថា វាសំខាន់សម្រាប់យើងដើម្បីធ្វើនូវរឿងទាំងនេះ ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ?

អ្នកអាចនឹងចង់ជួយដល់សិស្សឲ្យយល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២០ ឃ្លា « សាសនាចក្រនៃអារក្ស » ពុំសំដៅទៅលើព្រះវិហារជាក់លាក់ណាមួយទេ ។ វាសំដៅទៅលើបុគ្គល ក្រុម អង្គការ ឬទស្សនវិជ្ជាណាដែលធ្វើការប្រឆាំងទាស់នឹងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ និងសេចក្ដីសង្គ្រោះនៃកូនចៅរបស់ព្រះ ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីរបៀបមួយ ដែលពួកគេប្រាប់អ្នកដទៃឲ្យដឹងថា ពួកគេដើរតាមព្រះយេស៊ូវគ្រីស្ទ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៦–៤៧

*ព្រះអម្ចាស់បើកសម្ដែងការហៅ និងបេសកកម្មរបស់ពួកសាវកដប់ពីរនាក់*

សូមពន្យល់ថា ព្រះម្ចាស់មានបន្ទូលអំពីបុរស ៗ ក្រៅពីអូលីវើរ ខៅឌើរី និងដាវិត វិតមើរ ដែលនឹងលើកដាក់មកលើខ្លួនពួកគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយប្រកាសដំណឹងល្អរបស់ទ្រង់ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៧–៣២ ដោយស្ងាត់ស្ងៀម ហើយសរសេរចម្លើយរបស់ពួកគេចំពោះសំណួរដូចខាងក្រោម ។ ( សូមសរសេរសំណួរទាំងនេះនៅលើក្ដារខៀន ពីមុនពេលចាប់ផ្ដើមថ្នាក់ ឬ សូមរៀបចំវាជាក្រដាសចែកឲ្យសិស្សម្នាក់ៗ) ។

1. *តើពួកសិស្សដប់ពីរនាក់ទាំងនេះមានបំណងប្រាថ្នាអ្វីខ្លះ ?*
2. *តើបុរសទាំងនេះត្រូវបានហៅឲ្យធ្វើអ្វីខ្លះ ? ( រកមើលគំនិតផ្សេង ៗឲ្យបាន ៣–៥ ) ។*
3. *តើសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បច្ចុប្បន្នរូបណា ដែលអ្នកអាចនៅចាំ ? ( សូមសរសេរឈ្មោះពួកគាត់ ) ។*

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សរាយការណ៍ចម្លើយរបស់ពួកគេចំពោះសំណួរទីមួយដែលបានសរសេរនៅលើក្ដារខៀន ។ បន្ទាប់មក សួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទដោយស្មោះអស់ពីចិត្តនោះ ?

សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យរាយការណ៍ពីចម្លើយរបស់ពួកគេចំពោះសំណួរទីពីរដែលបានសរសេរនៅលើក្ដារខៀន ។ គោលការណ៍មួយ ដែលសិស្សគួរប្រាប់មកគឺថា **ពួកសាវកដប់ពីរនាក់របស់ព្រះអម្ចាស់ គឺត្រូវបានហៅឲ្យផ្សាយ និងបម្រើដំណឹងល្អទៅដល់ពិភពលោកទាំងមូល ។** សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៣៧–៣៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលទំនួលខុសត្រូវដែលព្រះបានប្រទានដល់អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ។

- តើព្រះអម្ចាស់បានបញ្ជាឲ្យអូលីវើរ និងដាវិតធ្វើអ្វីខ្លះ ? ( ស្វែងរកបុរស ដែលព្រះអម្ចាស់នឹងហៅឲ្យធ្វើជាសមាជិកនៃកូរ៉ុមនៃពួកសាវកទាំងដប់ពីរទីមួយនៅក្នុងថ្ងៃចុងក្រោយ ) ។

- តើពួកគេអាចដឹងថានរណាគួរត្រូវបានហៅឲ្យធ្វើជាសាវកបានយ៉ាងដូចម្ដេច ? ( ពួកសាវកនាពេលអនាគត នឹងបង្ហាញពីបំណងប្រាថ្នា និងកិច្ចការដែលព្រះអម្ចាស់បានមានបន្ទូល ) ។

សូមពន្យល់ថា ម៉ាទីន ហារិស ក៏បានទទួលទំនួលខុសត្រូវឲ្យស្វែងរកពួកសាវកដប់ពីរនាក់ផងដែរ ។ សមាជិកនៃកូរ៉ុមនៃពួកសាវកទាំងដប់ពីរទីមួយនៅក្នុងថ្ងៃចុងក្រោយ ត្រូវបានហៅនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ១៨៣៥ ជិតនឹងរយៈពេលប្រាំឆ្នាំបន្ទាប់ពីការរៀបចំសាសនាចក្រឡើងជាផ្លូវការនោះ ។ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ ជួយយើងយល់អំពីសារៈសំខាន់នៃកូរ៉ុមតាមរយៈការចែងពីតួនាទីនៃពួកសាវកនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សឲ្យរាយការណ៍ចម្លើយរបស់ពួកគេ ចំពោះសំណួរទីបីដែលសរសេរនៅលើក្ដារខៀន ដោយការសួរពួកគេឲ្យប្រាប់ឈ្មោះរបស់សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បច្ចុប្បន្ននេះ ។ បើអាចធ្វើទៅបាន សូមបង្ហាញរូបភាពនៃបុរសទាំងនេះ ។ រូបថតមាននៅក្នុងច្បាប់ទស្សនាវដ្ដី *Ensign* និង *លីអាហូណា* ខែឧសភា និងខែវិច្ឆិកា ព្រមទាំងនៅក្នុង lds.org/church/leaders ។

*សូមបង្ហាញរូបភាពនៃពួកអ្នកដឹកនាំសាសនាចក្រ*

ការបង្ហាញរូបភាពនៃពួកអ្នកដឹកនាំសាសនាចក្រ នៅពេលអ្នកបង្រៀនប្រសាសន៍របស់ពួកលោកនឹងជួយសិស្សឲ្យស្គាល់អ្នកទាំងឡាយណាដែលព្រះអម្ចាស់បានហៅឲ្យធ្វើជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ វាក៏នឹងជួយបង្កើនចំណាប់អារម្មណ៍របស់សិស្សទៅលើប្រសាសន៍របស់ពួកលោកផងដែរ ។ ម្ដងម្កាល អ្នកអាចនឹងចង់បង្ហាញពីសេចក្ដីថ្លែងការណ៍ដកស្រង់ចេញមកពីសុន្ទរកថាសន្និសីទទូទៅដោយប្រើវីដេអូឌីជីថល ឬឯកសារសោតកម្ម ( មាននៅ LDS.org ) ។ សូមប្រយ័ត្នកុំឲ្យប្រើវីដេអូ និងសោតកម្មច្រើនហួសហេតុពេក ព្រោះវាពុំមែនជាវិធីដ៏មានប្រសិទ្ធភាពបំផុតដើម្បីបង្ហាញសេចក្ដីថ្លែងការមកពីពួកអ្នកដឹកនាំសាសនាចក្រជានិច្ចកាលនោះទេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជែហ្វ្រីអ័រ.ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ មុនពេលសិស្សអាន សូមពន្យល់ថា អែលឌើរ ហូឡិន បានផ្ដល់ប្រសាសន៍ទាំងនេះនៅក្នុងសុន្ទរកថាសន្និសីទទូទៅដំបូងរបស់លោក ក្នុងនាមជាសាវកត្រូវបានហៅថ្មីម្នាក់ ។



« ប្រាកដណាស់ វាគឺជាសេចក្ដីកើប និង សេចក្ដីអំណរដ៏ធំដែលខ្ញុំមានឱកាសដូចជានីហ្វៃបានថ្លែងដើម្បី ‹ និយាយអំពីព្រះគ្រីស្ទ. . .អររីករាយក្នុងព្រះគ្រីស្ទ. . .ផ្សាយអំពីព្រះគ្រីស្ទ [ និង ] ព្យាករអំពីព្រះគ្រីស្ទ › ( នីហ្វៃទី២ ២៥:២៦) នៅគ្រប់ទីកន្លែងដែលខ្ញុំនឹងទៅ និង គ្រប់មនុស្សដែលខ្ញុំនឹងជួបដរាបដល់ខ្ញុំឃើញថា នេះជាវិនាទីចុងក្រោយនៃដង្ហើមជីវិតរបស់ខ្ញុំ ។ ប្រាកដណាស់ គ្មានគោលបំណង ឬ ឯកសិទ្ធិណាប្រសើរជាង ‹ [ សាក្សី ] ពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទនៅពេញសព្វក្នុងពិភពលោក › នោះទេ ( គ. និង ស. ១០៧:២៣) ។

« . . .លើសពីពាក្យសម្ដី និង ការបង្រៀន និង ទីបន្ទាល់ដែលបានថ្លែងរបស់ខ្ញុំ នោះជីវិតរបស់ខ្ញុំក៏ត្រូវតែជាផ្នែកក្នុងទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទនោះដែរ ។ គួរអង្គរបស់ខ្ញុំ ត្រូវតែឆ្លុះបញ្ចាំងអំពីទេវភាពនៃកិច្ចការនេះ ។ ខ្ញុំពុំអាចទទួលវាបានទេ បើអ្វីណាមួយដែលខ្ញុំនិយាយ ឬធ្វើ ដែលនឹងបង្អាក់សេចក្ដីជំនឿរបស់អ្នកទៅលើព្រះគ្រីស្ទ បង្អាក់សេចក្ដីស្រឡាញ់របស់អ្នកចំពោះសាសនាចក្រនេះ ឬបង្អាក់ការគោរពរបស់អ្នកចំពោះភាពជាសាវកដ៏បរិសុទ្ធនោះ ។

« ខ្ញុំសន្យានឹងអ្នក– ដូចខ្ញុំបានសន្យានឹងព្រះអម្ចាស់ និងបុរសទាំងនេះ–ថា ខ្ញុំនឹងព្យាយាមដើម្បីរស់នៅដ៏សក្ដិសមតាមទំនុកចិត្តនេះ ហើយបម្រើដោយពេញងង្វាស់នៃសមត្ថភាពរបស់ខ្ញុំ » ( Miracles of the Restoration » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤, ៣១ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៧ ឲ្យឮៗ ។

- តើវាជួយអ្នកឲ្យស្គាល់ថា អ្នកទាំងឡាយដែលបម្រើជាពួកសាវក បានលើកដាក់មកលើខ្លួនពួកគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ដោយបំណងចិត្តដ៏ពោរពេញយ៉ាងដូចម្ដេច ? តើយើងអាចធ្វើតាមគំរូរបស់ពួកគាត់ដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ ឬពីរនាក់ ឲ្យជួយអ្នកក្នុងសកម្មភាពមួយ ។ សូមបិទភ្នែកសិស្សទាំងនេះ ឬសុំឲ្យពួកគេបិទភ្នែក ។ សូមអញ្ជើញសិស្សមួយចំនួនផ្សេងទៀត ឲ្យផ្លាស់វេណគ្នានិយាយដោយសំឡេងធម្មតាមួយ ។ សូមសុំឲ្យសិស្សដែលបិទភ្នែកនោះប្រាប់ឈ្មោះអ្នកដែលនិយាយ ។ បន្ទាប់មក សួរសំណួរដូចខាងក្រោមនេះ ៖

- ហេតុអ្វីក៏មានសំឡេងមនុស្សខ្លះ ងាយស្រួលស្គាល់ជាងមនុស្សខ្លះទៀត ? ( សិស្សអាចនឹងចង្អុលបង្ហាញថា កាលណាយើងស្ដាប់ឮសំឡេងមួយកាន់តែញឹកញាប់ នោះយើងកាន់តែស្គាល់ ហើយកាន់តែដឹងច្បាស់ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៣៤–៣៦, ៣៧ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយប្រាប់អំពីវិធីមួយដែលព្រះអម្ចាស់បានមានបន្ទូលថា យើងអាចស្ដាប់ឮសំឡេងទ្រង់ ។ ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា នៅក្នុង ខ ៣៤ ឃ្លា « ព្រះបន្ទូលទាំងនេះ » សំដៅទៅលើវិវរណៈទាំងឡាយនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ) ។

- ស្របតាមខគម្ពីរទាំងនេះ តើយើងអាចស្ដាប់ឮសំឡេងរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ? ( សិស្សអាចផ្ដល់នូវចម្លើយផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា គោលការណ៍ដូចខាងក្រោម ប្រាប់បានច្បាស់លាស់ ៖ **យើងអាចស្ដាប់ឮសំឡេងនៃព្រះយេស៊ូវគ្រីស្ទ នៅពេលយើងអានបទគម្ពីរដោយព្រះចេស្ដានៃព្រះវិញ្ញាណ ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

- តើការសិក្សាព្រះគម្ពីរជួយយើងស្ដាប់ឮសំឡេងរបស់ព្រះយេស៊ូវគ្រីស្ទតាមវិធីណាខ្លះ ?

សូមជួយសិស្សឲ្យយល់ថា យើងអាចស្ដាប់ឮសំឡេងរបស់ព្រះអម្ចាស់តាមរបៀបជាច្រើន ដែលពុំមែនស្ដាប់ឮដោយត្រចៀករបស់យើងនោះទេ ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចទទួលអារម្មណ៍ និងសារលិខិតមកកាន់ដួងចិត្ត និងគំនិតរបស់យើង ( សូមមើល គ. និង ស. ៨:២–៣ ) ។

សូមយោងទៅលើសេចក្ដីពិត ដែលអ្នកបានសរសេរនៅលើក្ដារខៀន ។

- តើសេចក្ដីពិតនេះ មានឥទ្ធិពលលើរបៀបដែលអ្នកគិតអំពីព្រះគម្ពីរយ៉ាងដូចម្ដេចខ្លះ ? តើវាអាចដឹកនាំអ្នកយ៉ាងដូចម្ដេច នៅពេលអ្នកជ្រើសរើសពេលវេលា និងទីកន្លែងដែលអ្នកអានព្រះគម្ពីរនោះ ?

- នៅពេលណា ដែលអ្នកបានទទួលអារម្មណ៍ថា ព្រះអម្ចាស់ បានបំផុសគំនិតអ្នក នៅពេលអ្នកបានអាន ឬពិចារណាបទគម្ពីរនោះ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យស្រាវជ្រាវបទគម្ពីរជាប្រចាំថ្ងៃ ហើយមានភាពឧស្សាហ៍ព្យាយាមក្នុងការស្វែងរក និងការយល់ដឹងអំពីសំឡេងរបស់ព្រះអម្ចាស់ ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៤០–៤៧ ដោយពន្យល់ថា ព្រះអម្ចាស់បានបញ្ជាក់ថា អូលីវើរ ខៅឌើរី, ដាវីឌ វិតមើរ និងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់នាពេលអនាគត នឹងទទួលពរជ័យដ៏មហិមា បើសិនជាពួកគេស្មោះត្រង់នៅក្នុងការគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ អ្នកអាចនឹងចង់បញ្ចប់មេរៀននេះដោយការថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សាជាមួយសិស្ស ។

មេរៀនទី ២៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២

## បុព្វកថា

នៅក្នុងខែមិថុនា ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ បានជួលម្ចាស់រោងពុម្ព ឈ្មោះ អែហ្គបឺត ប៊ី ហ្គ្រានឌីន ដើម្បីបោះពុម្ពព្រះគម្ពីរចំនួន ៥០០០ ក្បាលក្នុងតម្លៃ ៣០០០ ដុល្លារ ។ ទោះជាយ៉ាងណាក៏ដោយ ហ្គ្រានឌីន នឹងមិនចាប់ផ្ដើមបោះពុម្ព ឬសូម្បីតែទិញក្រដាសបោះពុម្ពឡើយ ទាល់តែគាត់ត្រូវបានអះអាងថា ទទួលបានប្រាក់បង់ថ្លៃសម្រាប់ការងារមុនសិន ។ នៅក្នុងវិវរណៈ ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩ ដែលទំនងជាត្រូវបានប្រទានឲ្យនៅរដូវក្ដៅឆ្នាំ ១៨២៩ នោះព្រះអម្ចាស់បានបញ្ជាម៉ាទិន ហារិសឲ្យ « ចំណាយផ្នែកនៃទ្រព្យសម្បត្តិរបស់អ្នក . . . [ ហើយ ] សងបំណុលដែលអ្នកបានយល់ព្រមជាមួយនឹងអ្នកបោះពុម្ព » ( គ. និង ស. ១៩:៣៤–៣៥ ) ។ ដោយការប្រើចម្ការខ្លះៗរបស់គាត់ដាក់បញ្ចាំ នោះម៉ាទិន ហារិសផ្ទាល់បានអះអាងថា បង់ថ្លៃការចំណាយលើការបោះពុម្ព បើការលក់ព្រះគម្ពីរមរមន មិនអាចទូទាត់សងថ្លៃការចំណាយបានទេនោះ ។

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានពិពណ៌នាអំពីវិវរណៈនេះ ជាមួយនឹងការបង្រៀនរបស់វាអំពីដង្វាយធួនជា « វិវរណៈដ៏មហិមាមួយ ដែលត្រូវបានប្រទានឲ្យនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ដែលមានសារៈសំខាន់មួយចំនួនច្រើនជាងនេះ » ( *Church History and Modern Revelation,* វ៉ុលទី ២ [ឆ្នាំ ១៩៥៣], ១:៨៥ ) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–៣

*ព្រះអង្គសង្គ្រោះប្រកាសថា ទ្រង់បានសម្រេចតាមព្រះឆន្ទៈរបស់ព្រះបិតាហើយ*

នៅពេលចាប់ផ្ដើមថ្នាក់ សូមឲ្យសិស្សគិតអំពីអ្វីៗមួយចំនួន ដែលពួកគេត្រូវបានសុំឲ្យធ្វើ ឬនឹងត្រូវបានសុំឲ្យធ្វើ ដោយសារពួកគេជាសមាជិកនៃសាសនាចក្រ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ បន្ទាប់មក សូមឲ្យសិស្សមើលបញ្ជីនៅលើក្ដារខៀន ហើយជ្រើសរើសវត្ថុមួយចំនួន ដែលគិតថាពិបាក ។ ( ឧទាហរណ៍ អាចប្រួមទាំង ការថ្វាយដង្វាយមួយភាគក្នុងដប់ ការបម្រើបេសកកម្ម និងការប្រែចិត្ត ) ។

- ហេតុអ្វីក៏រឿងទាំងនេះ ពិបាកសម្រាប់មនុស្សមួយចំនួនដើម្បីធ្វើ ?

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទជាប្រវត្តិសាស្ត្រអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩ សូមអានបុព្វកថាចំពោះមេរៀននេះឲ្យឮៗ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–៣ ដោយស្ងាត់ស្ងៀម រកមើលសេចក្ដីពិតអំពីព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេ ។ ជាផ្នែកនៃការពិភាក្សា សូមប្រាកដថាសិស្សប្រាប់នូវគោលលទ្ធិដូចខាងក្រោ ៖ **ព្រះយេស៊ូវគ្រីស្ទ បានបំពេញតាមព្រះទ័យរបស់ព្រះវរបិតាទ្រង់ ។ ព្រះយេស៊ូវគ្រីស្ទ នឹងជំនុំជម្រះយើង ស្របតាមកិច្ចការរបស់យើង ។**. សូមចម្លងតារាងដូចខាងក្រោម នៅលើក្ដារខៀន ដោយប្រើសេចក្ដីពិតទាំងនេះ ជាចំណងជើងសម្រាប់ក្ងឡោនទាំងពីរ ។ សូមអញ្ជើញសិស្សដើម្បីធ្វើតារាងស្រដៀងគ្នាមួយនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ហើយបំពេញវានៅអំឡុងមេរៀន ។ សូមទុកកន្លែងទំនេរនៅលើក្ដារខៀនឲ្យបានច្រើន ដើម្បីបំពេញតារាង ដូចបានបង្ហាញនៅពេលក្រោយក្នុងមេរៀន ។

| ព្រះយេស៊ូវគ្រីស្ទ បានបំពេញតាមព្រះទ័យរបស់ព្រះបិតារបស់ទ្រង់ ។ | ព្រះយេស៊ូវគ្រីស្ទ នឹងជំនុំជំរះយើង ស្របតាមកិច្ចការរបស់យើង ។ |
|---|---|
| | |

- តើការដឹងអំពីសេចក្ដីពិតទាំងនេះអំពីព្រះអង្គសង្គ្រោះ បានជួយដល់ ម៉ាទីន ហារិស ឲ្យមានអារម្មណ៍សុខសាន្ត ក្នុងការសម្រេចចិត្តរបស់គាត់ ដើម្បីលក់ចំណែកដ៏ធំនៃចម្ការរបស់គាត់យ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៤–១២

*ព្រះយេស៊ូវគ្រីស្ទ ពន្យល់អំពីទារុណកម្មដ៏អស់កល្ប និងមិនចេះចប់*

នៅក្នុងតារាងនៅលើក្ដារខៀន សូមសរសេរ *គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៤–១២* ពីខាងក្រោមចំណងជើង « ព្រះយេស៊ូវគ្រីស្ទ នឹងជំនុំជម្រះយើង ស្របតាមកិច្ចការរបស់យើង » ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៤ ដោយស្ងាត់ស្ងៀម រកមើលសេចក្ដីពិតមួយ អំពីសេចក្ដីជំនុំជម្រះ ដែលយើងទាំងអស់គ្នាគួរតែគិតពិចារណា ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **គ្រប់រូបត្រូវតែប្រែចិត្ត បើពុំនោះសោតទេនឹងត្រូវរងទុក្ខ** សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរគោលលទ្ធិនេះ នៅលើក្ដារខៀនពីខាងក្រោម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៤–១២ » ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៥ មាននូវការពន្យល់របស់ព្រះអង្គសង្គ្រោះ ដែលទ្រង់នឹងមិនដកសេចក្ដីជំនុំជម្រះរបស់ទ្រង់ឡើយ ។ ការណ៍នេះតម្រូវថា អ្នកទាំងឡាយណាដែលពុំប្រែចិត្ត នឹងត្រូវរងទុក្ខចំពោះទោសអំពើបាបរបស់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះអង្គសង្គ្រោះ បានពិពណ៌នាអំពីស្ថានភាពនៃអ្នកទាំងឡាយណាដែលពុំប្រែចិត្ត ហើយហេតុដូច្នោះនឹងទទួលការជំនុំជម្រះរបស់ទ្រង់ ។

- តើអ្នកទាំងឡាយដែលពុំប្រែចិត្តនឹងមានបទពិសោធន៍អ្វីខ្លះ ?
- តើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៥ អាចលើកទឹកចិត្តដល់យើងឲ្យប្រែចិត្តយ៉ាងដូចម្ដេច ?

សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្ដារខៀន នៅពីក្រោម « មនុស្សគ្រប់រូបត្រូវតែប្រែចិត្ត បើពុំនោះសោតទេនឹងត្រូវរងទុក្ខ » ៖ *ទោសដ៏អស់កល្ប ឬមិនចេះចប់* ។

- តើអ្នកគិតយ៉ាងដូចម្ដេច ពេលអ្នកស្ដាប់ឮ ឬអានឃ្លា « ទោសដ៏អស់កល្ប ឬមិនចេះចប់មិនចេះហើយ » នេះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៦–១២ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលព្រះអម្ចាស់កំណត់ទោសដ៏អស់កល្ប ឬមិនចេះចប់មិនចេះហើយនោះ ។ បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមលុបពាក្យ *ដ៏អស់កល្ប ឬមិនចេះចប់* ពីលើក្ដារខៀន ហើយជំនួសដោយពាក្យ *របស់ព្រះ* ។

- តើអ្នកគិតយ៉ាងដូចម្ដេច ពេលអ្នកស្ដាប់ឮ ឬអានឃ្លា « ទោសមកពីព្រះ » នេះ ?

អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា នៅក្នុងបទគម្ពីរ ពាក្យ *ទោសដ៏អស់កល្ប* និង *ទោសមិនចេះចប់មិនចេះហើយ* ពុំសំដៅទៅលើប្រវែងនៃពេលវេលាដែលមនុស្សនឹងរងទុក្ខចំពោះអំពើបាបរបស់ពួកគេនោះទេ ។ ព្រះអង្គសង្គ្រោះ បានមានបន្ទូលថា « យើងមិនចេះសាបសូន្យឡើយ ហើយទោសដែលយើងធ្វើចេញពីព្រះហស្តរបស់យើងទៅ គឺជាទោសដ៏មិនចេះចប់មិនចេះហើយ ដ្បិតមិនចេះសូន្យឡើយ គឺជាព្រះនាមរបស់យើង » ( គ និង ស ១៩:១០ ) ។ ហេតុដូច្នោះហើយ នៅពេលទ្រង់សំដៅទៅលើទោសដ៏មិនចេះចប់មិនចេះហើយ ឬដ៏អស់កល្ប នោះទ្រង់កំពុងមានបន្ទូលអំពីទណ្ឌកម្មដែលទ្រង់នឹងដាក់ ស្របតាមច្បាប់ព្រះ និងតម្រូវការនៃសេចក្ដីយុត្តិធម៌ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–២២

*ព្រះអង្គសង្គ្រោះមានបន្ទូលអំពីការរងទុក្ខចំពោះអំពើបាបរបស់ទ្រង់*

នៅក្នុងតារាងនៅលើក្ដារខៀន សូមសរសេរ *គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–១៧* ក្នុងកូឡោនចំណងជើងថា « ព្រះយេស៊ូវគ្រីស្ទ នឹងជំនុំជម្រះយើង ស្របតាមកិច្ចការរបស់យើង » ។ សូមពន្យល់ថា ខ ១៣–១៧ មាននូវការព្រមានមួយចំពោះសមាជិកនៃសាសនាចក្រ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–១៧ ដោយស្ងាត់ស្ងៀម រកមើលលទ្ធផលចំពោះអ្នកទាំងឡាយដែលជ្រើសរើសមិនប្រែចិត្ត ។

- តើមានអ្វីខ្លះនឹងកើតឡើង ចំពោះអ្នកទាំងឡាយដែលជ្រើសរើសមិនប្រែចិត្តពីអំពើបាបរបស់ពួកគេនោះ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **អ្នកទាំងឡាយណាដែលជ្រើសរើសពុំប្រែចិត្ត នឹងត្រូវរងទុក្ខចំពោះទោសនៃអំពើបាបរបស់ពួកគេ** ។ សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន នៅក្រោម «គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–១៧ » ) ។

សូមសរសេរ *គោលលទ្ធិ និង សេចក្ដីសញ្ញា១៩:១៦–១៩* នៅក្នុងកូឡោនចំណងជើងថា « ព្រះយេស៊ូវគ្រីស្ទ នឹងជំនុំជម្រះយើង ស្របតាមកិច្ចការរបស់យើង » ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៦–១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលព្រះអង្គសង្គ្រោះបានប្រាប់ថាហេតុអ្វីបានជាទ្រង់រងទុក្ខចំពោះអំពើបាបរបស់យើងដូច្នេះ ។

- តើព្រះអង្គសង្គ្រោះបានប្រាប់ថាមានមូលហេតុអ្វីខ្លះ ដែលទ្រង់បានរងទុក្ខចំពោះអំពើបាបរបស់យើងនោះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអង្គសង្គ្រោះ បានរងទុក្ខចំពោះអំពើបាបរបស់យើង ដូច្នេះយើងអាចប្រែចិត្ត ហើយពុំរងទុក្ខដូចជាទ្រង់បានរងទុក្ខ** ) ។
- ស្របតាមខគម្ពីរទាំងនេះ តើអ្វីដែលបានធ្វើឲ្យអំពើបាបរបស់យើងអាចត្រូវបានអភ័យទោស ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរសេចក្ដីថ្លែងការដូចខាងក្រោមក្នុងតារាងនៅលើក្ដារខៀន ពីក្រោម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៦–១៩ » ៖ **សេចក្ដីរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទ និងលោហិតដង្វាយធួនរបស់ទ្រង់ បានស្កប់ស្កល់ដល់តម្រូវការនៃសេចក្ដីយុត្តិធម៌ ។ ហេតុដូច្នោះហើយ សេចក្ដីមេត្តាករុណាត្រូវបានផ្ដល់ទៅឲ្យអ្នកទាំងឡាយដែលប្រែចិត្ត**) ។
- តើការស្គាល់សេចក្ដីពិត ដែលយើងបានលើកឡើងមកនៅថ្ងៃនេះ មានឥទ្ធិពលលើបំណងប្រាថ្នាដើម្បីធ្វើការប្រែចិត្តរបស់យើងយ៉ាងដូចម្ដេចខ្លះ ?

ដើម្បីជួយសិស្សឲ្យយល់អំពីការជ្រើសរើសដែលយើងទាំងអស់គ្នាត្រូវតែប្រែចិត្ត ឬក៏រងទុក្ខចំពោះទោសនៃអំពើបាបរបស់យើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការដូចខាងក្រោមដោយអែលឌើរ នែល អេ ម៉ាក់ស្វែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅទីបញ្ចប់យើងនឹងត្រូវជ្រើសរើសលក្ខណៈនៃការរស់នៅរបស់ព្រះគ្រីស្ទ ឬលក្ខណៈនៃការរងទុក្ខរបស់ទ្រង់! វាអាចនឹង ‹ ត្រូវរងទុក្ខដូចជាយើង › ( គ. និង ស. ១៩:១៦–១៧) ឬយកឈ្នះ ‹ដូចជា [ ទ្រង់ ] . . . បានឈ្នះ› ( វិវរណៈ ៣:២១Overcome . . . Even As I Also Overcame, » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៧, ទំព័រ ៧២ ) ។

នៅក្នុងតារាងនៅលើក្ដារខៀន សូមសរសេរ *គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៥, ១៨–១៩* ពីក្រោមចំណងជើង « ព្រះយេស៊ូវគ្រីស្ទ បានបំពេញតាមព្រះទ័យរបស់ព្រះបិតារបស់ទ្រង់ » ។

សូមពន្យល់ថា ដំណើររឿងភាគច្រើនអំពីសេចក្ដីរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានផ្ដល់ឲ្យដោយមនុស្សផ្សេងទៀត ក្រៅពីព្រះអង្គទ្រង់ ( សូមមើល ម៉ាថាយ ២៦:៣៦–៣៩; លូកា ២២:៣៩–៤៤ ) ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩ មាននូវដំណើររឿងផ្ទាល់របស់ព្រះអង្គសង្គ្រោះអំពីសេចក្ដីរងទុក្ខរបស់ទ្រង់ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៥, ១៨–១៩ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលព្រះអង្គសង្គ្រោះ បានពិពណ៌នាអំពីសេចក្ដីរងទុក្ខ ដែលទ្រង់បានជួបអំឡុងពេលធ្វើដង្វាយធួន ។ អ្នកអាចផ្ដល់យោបល់ឲ្យសិស្សថា ពួកគេគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ សូមបន្ថែមចម្លើយរបស់សិស្សទៅលើក្ដារខៀន ក្រោម «គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៥, ១៨–១៩ » ។ តារាងចុងក្រោយ អាចសរសេរដូចជាអ្វីខាងក្រោមនេះ ៖

| ព្រះយេស៊ូវគ្រីស្ទ បានបំពេញតាមព្រះទ័យរបស់ព្រះបិតារបស់ទ្រង់ ។ | ព្រះយេស៊ូវគ្រីស្ទ នឹងជំនុំជម្រះយើង ស្របតាមកិច្ចការរបស់យើង ។ |
|---|---|
| គ. និង ស. ១៩:១៥, ១៨–១៩<br>សេចក្ដីរងទុក្ខរបស់ព្រះអង្គសង្គ្រោះ គឺឈឺចាប់ ខ្លាំងបំផុត ហើយពិបាកទ្រាំទ្រ ។<br>សេចក្ដីរងទុក្ខរបស់ព្រះអង្គសង្គ្រោះ បានបណ្ដាលឲ្យទ្រង់ឈឺញ័ររន្ធត់ ដោយសារតែការឈឺចាប់ ហើយនឹងការហូរលោហិតពីគ្រប់គល់រោម ។<br>ព្រះយេស៊ូវគ្រីស្ទ បានរងទុក្ខទាំងខាងសាច់ឈាម និងខាងសាច់ឈាម ។<br>ព្រះអង្គសង្គ្រោះ បានអធិស្ឋានថា សុំឲ្យទ្រង់បានរួចពីការទទួលទានពែងល្វីងនេះ បើអាចទៅរួច ។<br>ព្រះអង្គសង្គ្រោះ បានបំពេញតាមព្រះហឫទ័យរបស់ព្រះបិតា ហើយ «បានសម្រេចការរៀបចំ [ របស់ទ្រង់ ] ចំពោះកូនចៅមនុស្ស » ( គ. និង ស. ១៩:១៩ ) ។ | គ. និង ស. ១៩:៤–១២<br>មនុស្សទាំងអស់ត្រូវតែប្រែចិត្ត ឬត្រូវរងទុក្ខវេទនា ។<br>ទោសមកពីព្រះ<br>គ. និង ស. ១៩:១៣–១៧<br>អ្នកទាំងឡាយដែលជ្រើសរើសពុំប្រែចិត្ត នឹងរងទុក្ខនូវទោសនៃអំពើបាបរបស់ពួកគេ ។<br>គ. និង ស. ១៩:១៦–១៩<br>សេចក្ដីរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទ និងលោហិតនៃដង្វាយធួនរបស់ទ្រង់ បានធ្វើឲ្យស្កប់ស្កល់ដល់សេចក្ដីយុត្តិធម៌ ។ ហេតុដូច្នោះហើយ សេចក្ដីមេត្តាករុណាត្រូវបានផ្ដល់ទៅឲ្យអ្នកទាំងឡាយដែលប្រែចិត្ត ។ |

- តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចអំពីព្រះអង្គសង្គ្រោះរងទុក្ខនូវទោសនៃអំពើបាបរបស់យើងនោះ ?
- តើការយល់ដឹងអំពីសេចក្ដីរងទុក្ខរបស់ព្រះអង្គសង្គ្រោះ បានជួយដល់ ម៉ាទីន ហារិស នៅពេលគាត់គិតពិចារណាអំពីរឿងដូចជាការបាត់បង់ឯកសារសរសេរដោយដៃ ១១៦ ទំព័រ ឬការលះបង់ចំណែកនៃទ្រព្យរបស់គាត់ដើម្បីបង់ថ្លៃការបោះពុម្ពព្រះគម្ពីរមរមនយ៉ាងដូចម្ដេច ?
- តើពេលណា ដែលចំណេះដឹងរបស់អ្នកអំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ បានជួយអ្នកឲ្យប្រឈមមុខនឹងការលំបាកនោះ ? ( សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ដែលពុំគួរចែកចាយ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២០ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលនូវឃ្លាមួយដែលសំដៅទៅលើគ្រាមួយ ដែលម៉ាទិន ហារិស ជួបនឹងការរងទុក្ខចំពោះអំពើបាបរបស់គាត់ ។

- ហេតុអ្វីក៏អ្នកគិតថា ការគ្មានព្រះវិញ្ញាណបរិសុទ្ធ នឹងដឹកនាំទៅរកការរងទុក្ខដូច្នេះ ?

សូមអញ្ជើញសិស្សឲ្យអានឡើងវិញ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣, ១៥, ២០ ដោយស្ងាត់ស្ងៀម រកមើលបញ្ញានៅក្នុងខនីមួយៗ និងការព្រមាននៅក្នុង ខ ១៥ និង ២០ ។

- តើបទបញ្ញត្តិរបស់ព្រះអម្ចាស់ឲ្យប្រែចិត្ត ជាភស្តុតាងនៃសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើងតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរនូវទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍មួយដែលពួកគេបានរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២ ។

មេរៀនទី ២៥

# គោលលទ្ធិ និងសេចក្តីសញ្ញា ១៩:២៣–៤១

## បុព្វកថា

ដើម្បីធានាអះអាងដល់ អ៊ី. ប៊ី. ហ្គ្រានឌិន ចំពោះការបង់ថ្លៃនៃការបោះពុម្ពព្រះគម្ពីរមរមន ម៉ាទីន ហារិស បានចុះហត្ថលេខាកិច្ចសន្យាបញ្ចាំចម្ការរបស់គាត់មួយ នៅខែសីហា ឆ្នាំ ១៨២៩ ។ នៅក្នុងវិវរណៈ ដែលបានមាននៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៩ ព្រះអម្ចាស់ បានដាស់តឿនដល់ ម៉ាទីន ឲ្យចំណាយទ្រព្យសម្បត្តិរបស់គាត់ដោយសេរីសម្រាប់ការបោះពុម្ពព្រះគម្ពីរមរមន ( សូមមើល គ. និង ស. ១៩:២៦). ទីបំផុត ម៉ាទីនបានលក់ចម្ការរបស់គាត់ អស់ ១៥១ ហិចតា ដើម្បីបង់ថ្លៃការបោះពុម្ព ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:២៣–២៤

*ព្រះអង្គសង្គ្រោះ ថ្លែងទីបន្ទាល់ថា ទ្រង់បានសម្រេចតាមព្រះឆន្ទៈរបស់ព្រះបិតាហើយ*

មុនពេល ថ្នាក់រៀន សូមសរសេរសំណួរដូចខាងក្រោមនៅលើក្តារខៀន ៖ *តើមានពេលណា ដែលអ្នកត្រូវធ្វើនូវរឿងអ្វីមួយ ដែលអ្នកដឹងថាត្រូវ ប៉ុន្តែអ្នកពុំប្រាកដ ឬភ័យខ្លាចអំពីលទ្ធផលដែលវានឹងកើតឡើងដែរឬទេ ?*

សូមចាប់ផ្តើមថ្នាក់រៀន ដោយការសុំឲ្យសិស្សឆ្លើយនឹងសំណួរនេះ ។ ( សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ពុំគួរចែកចាយទេ ) ។

ក្រោយពីសិស្សបានចែកចាយគ្រប់គ្រាន់ហើយ សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- បើអ្នកនឹងជួបប្រទះថាអ្នកត្រូវធ្វើនូវរឿងអ្វីមួយ ដែលអ្នកដឹងថាត្រូវ ប៉ុន្តែអ្នកពុំប្រាកដ ឬភ័យខ្លាចអំពីលទ្ធផលដែលវានឹងកើតឡើងនោះ តើមានអ្វីខ្លះ នឹងជួយអ្នកឲ្យមានសេចក្តីជំនឿដើម្បីធ្វើកិច្ចការនោះ ទោះជាវាលំបាកក្តី ?

- តើប្រតិកម្មរបស់អ្នកនឹងផ្លាស់ប្តូរ អាស្រ័យទៅលើមនុស្សដែលសុំឲ្យអ្នកធ្វើនូវរឿងលំបាកនោះឬទេ ? ហេតុអ្វីផ្លាស់ប្តូរ ឬ ហេតុអ្វីមិនផ្លាស់ប្តូរ ?

ដើម្បីរំឭកដល់សិស្សអំពីបរិបទជាប្រវត្តិសាស្ត្រសម្រាប់ គោលលទ្ធិ និង សេចក្តីសញ្ញា ១៩ សូមអានបុព្វកថាមេរៀនឲ្យឮៗ ។ បន្ទាប់មកអញ្ជើញឲ្យសិស្សអានសេចក្តីផ្តើមនៃកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្តីសញ្ញា ១៩ និង គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:២៦ ដោយស្ងាត់ស្ងៀម រកមើលនរណាដែលបានបញ្ជា ម៉ាទីន ហារិស ឲ្យបញ្ចាំចម្ការរបស់គាត់ ។

- បើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់ ម៉ាទីន តើការដឹងថា បញ្ញត្តិនេះ មកពីព្រះ នឹងជួយដល់អ្នកយ៉ាងដូចម្តេច ?

សូមពន្យល់ថា ការសម្រេចចិត្តដើម្បី ចំណាយទ្រព្យសម្បត្តិរបស់គាត់ ដើម្បីផ្តល់ថវិការសម្រាប់ការបោះពុម្ពនៃព្រះគម្ពីរមរមន គឺជាការលំបាកមួយសម្រាប់ ម៉ាទីន ហារិស ( សូមមើល *Documents, Volume ១: ខែ កក្កដា ឆ្នាំ ១៨២៨– ខែមិថុនា ឆ្នាំ ១៨៣១*, វ៉ុលទី ១ នៃ the Documents series of *The Joseph Smith Papers* [ ឆ្នាំ ២០១៣ ], ទំព័រ ៨៦, ៨៨ ) ។ ព្រះអម្ចាស់ បានឆ្លើយតបចំពោះកង្វល់របស់ម៉ាទីន ដោយការបើកសម្តែងរឿងមួយចំនួន ដែលគាត់ចាំបាច់ត្រូវធ្វើ និងអ្វីមួយចំនួនដែលគាត់ចាំបាច់ត្រូវដឹង ។សូមបង្កើតកូឡោនពីរនៅលើក្តារខៀនហើយដាក់ជាពាក្យស្លាកថា *ត្រូវធ្វើ* និង *ត្រូវដឹង* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:២៣–២៤ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់ចង់ឲ្យម៉ាទីន ហារិស ធ្វើ និង ដឹង ។ នៅពេលសិស្សពិភាក្សាអំពីការស្វែងរករបស់ពួកគេ សូមសរសេរចម្លើយរបស់ពួកគេនៅក្នុងកូឡោនត្រឹមត្រូវនៅលើក្តារខៀន ។ តារាងគួរមើលទៅដូចជាអ្វីដែលនៅខាងក្រោមនេះ ៖

| ត្រូវធ្វើ | ត្រូវដឹង |
|---|---|
| រៀនអំពីព្រះយេស៊ូវគ្រីស្ទ<br>ស្ដាប់តាមព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ<br>ដើរនៅក្នុងភាពរាបសានៃព្រះវិញ្ញាណ | វិរេណៈនេះមកពីព្រះយេស៊ូវគ្រីស្ទ<br>ព្រះយេស៊ូវគ្រីស្ទ បានគោរពតាមព្រះហឫទ័យរបស់ព្រះវរបិតាសួគ៌ |

សូមចង្អុលទៅពាក្យ *រៀន ស្ដាប់* និង *ដើរ* នៅក្នុងកូឡោន «ត្រូវធ្វើ» ។

- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីរៀនអំពីព្រះគ្រីស្ទ ស្ដាប់តាមបន្ទូលទ្រង់ ហើយដើរនៅក្នុងភាពរាបសានៃព្រះវិញ្ញាណរបស់ទ្រង់ ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា *ភាពរាបសា* បង្ហាញនូវភាពចុះចូល ) ។
- តើអ្នកគិតថា ការធ្វើនូវរឿងទាំងនេះ អាចជួយដល់ ម៉ាទីន ធ្វើការសម្រេចចិត្តលំបាកៗ ក្នុងការបញ្ចាំទ្រព្យសម្បត្តិរបស់គាត់ ដើម្បីផ្ដល់ថវិការសម្រាប់ការបោះពុម្ពព្រះគម្ពីរមរមនយ៉ាងដូចម្ដេចខ្លះ ?

សូមអញ្ជើញសិស្សអានសារឡើងវិញនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣ ដោយស្ងាត់ស្ងៀម រកមើលនូវការសន្យារបស់ព្រះអម្ចាស់ចំពោះ ម៉ាទីន ហារិស ។

- តើសេចក្ដីពិតអ្វីខ្លះ ដែលព្រះអម្ចាស់បង្រៀនដល់ ម៉ាទីន ហារិស ដែលយើងក៏អាចអនុវត្តនៅក្នុងជីវិតរបស់យើងផ្ទាល់ផងដែរ ? ( នៅពេលសិស្សប្រាប់អំពី គោលការណ៍ដូចខាងក្រោម សូមសរសេរវានៅលើក្ដារខៀន ៖ **បើយើងរៀនអំពីព្រះគ្រីស្ទ ស្ដាប់តាមបន្ទូលរបស់ទ្រង់ ហើយដើរដោយភាពរាបសានៃព្រះវិញ្ញាណទ្រង់ នោះយើងនឹងមានភាពសុខសាន្ត)**

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើមានពួកគេ ឬនរណាម្នាក់ដែលពួកគេស្គាល់បានរកឃើញកម្លាំង ដើម្បីធ្វើការសម្រេចចិត្តដែលលំបាកៗ ដោយសារតែព្រះវិញ្ញាណដែលបានប្រទាននូវអារម្មណ៍សុខសាន្តដល់ពួកគេឬទេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

- តើអារម្មណ៍នៃភាពសុខសាន្តអាចជួយអ្នកធ្វើការសម្រេចចិត្តត្រឹមត្រូវ ទោះជាពេលអ្នកមានទុក្ខព្រួយ ឬភាពភ័យខ្លាចចំពោះលទ្ធផលដែលវានឹងកើតឡើងដូចម្ដេចខ្លះ ? ( ពីមុនសិស្សឆ្លើយចំពោះសំណួរនេះ អ្នកអាចនឹងចង់ពន្យល់ថា « នៅក្នុងបទគម្ពីរ ភាពសុខសាន្តអាចមានន័យថា ជាសេរីភាព ដែលគ្មានជម្លោះ និងភាពច្របូកច្របល់ ឬ ជាភាពសុខសាន្តក្នុងខ្លួន និងជាការលួងលោមចិត្តដែលកើតមកពីព្រះវិញ្ញាណ ដែលព្រះប្រទានដល់ពួកបរិសុទ្ធស្មោះត្រង់របស់ទ្រង់ » ( Guide to the Scriptures, «Peace » scriptures.lds.org ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៥–៣៥

*ព្រះអម្ចាស់ បានបញ្ជា ម៉ាទីន ហារិស ឲ្យលក់ទ្រព្យសម្បត្តិរបស់គាត់សម្រាប់ការបោះពុម្ពព្រះគម្ពីរមរមន*

សូមប្រាប់សិស្សថា ព្រះអម្ចាស់ បានប្រទានដល់ម៉ាទីន ហារិស នូវបទបញ្ញត្តិ និងការទូន្មានបន្ថែម ។ សូមបែងចែកសិស្សជាដៃគូ ។ សូមឲ្យគូរនីមួយៗ ស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៥–៣៥ រកមើលបទបញ្ញត្តិ និងការទូន្មានដែលបានផ្ដល់ដល់ ម៉ាទីន ។ ( អ្នកអាចនឹងចង់ឲ្យយោបល់ថា ពួកគេរកមើល និងពិចារណាធ្វើការគូសចំណាំឃ្លា «យើងបញ្ជា » និង « សូមអ្នក » ) ។

- តើបទបញ្ញត្តិ និងការទូន្មានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ ម៉ាទីន ហារិស ?

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់ ខ្វល់ព្រះទ័យនឹង ម៉ាទីន ហារិស ហើយបានប្រទានបញ្ញត្តិជាក់លាក់តាមស្ថានភាពផ្ទាល់ខ្លួនរបស់គាត់ ។ យើងពុំមានព័ត៌មានគ្រប់គ្រាន់ដើម្បីយល់ពីមូលហេតុដែលព្រះអម្ចាស់ បានប្រទានបទបញ្ញត្តិជាក់លាក់ដល់ ម៉ាទីន ហារិស នោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់បានប្រាប់យ៉ាងច្បាស់នូវអ្វីដែលបានកើតឡើង បើ ម៉ាទីន ពុំគោរពតាមបទបញ្ញត្តិទាំងឡាយទេនោះ ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៣ តើព្រះអម្ចាស់មានបន្ទូលថាអ្វីនឹងកើតឡើង បើ ម៉ាទីន «មិនអើពើ » នឹងបទបញ្ញត្តិរបស់ព្រះនោះ ? ( សូមពន្យល់ថា នៅក្នុងបរិបទនេះ ពាក្យ *មិនអើពើ* មានន័យថា ពុំគោរពដល់អ្វីមួយ ដោយសារតែវាហាក់ដូចជាមិនសូវសំខាន់ ឬមានតម្លៃតិច ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីបទបញ្ញត្តិមួយចំនួន ដែលពួកគេបានទទួលមកពីព្រះអម្ចាស់ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យបញ្ចូលបទបញ្ញត្តិ និងដំបូន្មាន ដែលពួកគេបានទទួលម្នាក់ៗ តាមរយៈពរជ័យនៃបព្វជិតភាព និងអ្នកដឹកនាំបព្វជិតភាពនោះ ។

- តើបទបញ្ញត្តិ និងដំបូន្មានដែលយើងបានទទួល ជាភស្តុតាងថាព្រះអម្ចាស់ ស្គាល់ និង ស្រឡាញ់យើងយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ដែលពួកគេ ឬនរណាម្នាក់ដែលគេស្គាល់ មានបទពិសោធន៍អាក្រក់ ដោយសារតែពួកគេពុំគោរពតាមបទបញ្ញត្តិរបស់ព្រះ ។

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវដំបូន្មានដូចខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« [ អ្នក ] នឹងជួបមនុស្សដែលរើសថា បទបញ្ញត្តិមួយណាដែលពួកគេនឹងរក្សា ហើយមិនអើពើនឹងបទបញ្ញត្តិផ្សេងទៀត ដែលពួកគេជ្រើសរើសមិនគោរពតាម ។ ខ្ញុំហៅការណ៍នេះថាអាហារប៊ូហ្វេ ដែលឈានទៅរកការមិនគោរពប្រតិបត្តិ ។ ការអនុវត្តនៃការរើសពេក និងការជ្រើសរើសនេះ នឹងគ្មានបានការទេ ។ វានឹងនាំទៅរកសេចក្ដីវេទនា ។ ដើម្បីត្រៀមខ្លួនទៅជួបនឹងព្រះ នោះមនុស្សម្នាក់រក្សា *រាល់*បទបញ្ញត្តិរបស់ទ្រង់ » ( Face the Future with Faith, »*Ensign*ឬ *លីអាហូណា*ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ៣៤ ) ។

- តើ « ហាង អាហារប៊ូហ្វេ ដែលឈានទៅរកការមិនគោរពប្រតិបត្តិ » ដែលអែលឌើរ ណិលសុន បានពិពណ៌នា ជាភស្តុតាងថា មនុស្សម្នាក់កំពុងមិនអើពើនឹងបទបញ្ញត្តិរបស់ព្រះយ៉ាងដូចម្ដេច ?

សូមអះអាងនឹងសិស្សថា ព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ ដូចជាទ្រង់ស្គាល់ ម៉ាទីន ហារិសដែរ ។ ហើយព្រះអម្ចាស់ប្រទានបញ្ញត្តិ និងដំបូន្មានដើម្បីជួយយើង ក៏ដូចជាទ្រង់បានប្រទានដល់បទបញ្ញត្តិ និងដំបូន្មានដល់ ម៉ាទីន ដើម្បីជួយគាត់ផងដែរ ។ សូមឲ្យសិស្សគិតពិចារណាថាតើ ពួកគេមានទំនោរដើម្បីមិនអើពើ ឬមិនគោរពចំពោះបទបញ្ញត្តិណាមួយ ដែលព្រះអម្ចាស់បានប្រទានដល់ពួកគេ ឬតើមានបទបញ្ញត្តិជាក់លាក់ណាមួយ ដែលពួកគេអាចគោរពដោយមានការលះបង់កាន់តែច្រើនឬទេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៦–៤១

### *ព្រះអម្ចាស់ទូន្មានដល់ ម៉ាទីន ហារិស ស្ដីអំពីការបម្រើរបស់គាត់*

សូមពន្យល់ថា ក៏ដូចជាម៉ាទីន ហារិស ផងដែរ យើងទាំងអស់គ្នាត្រូវតែសម្រេចចិត្តថាតើយើងនឹងចុះចូលឆន្ទៈរបស់យើងទៅតាមព្រះហឫទ័យរបស់ព្រះវរបិតាឬក៏អត់ ទោះជាអ្វីដែលទ្រង់បានសុំឲ្យធ្វើនោះមានការលំបាកក៏ដោយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានផ្នែកដំបូងនៃដំណើររឿងដូចខាងក្រោម ដែលបានចែកចាយដោយប្រធាន ថូម៉ាស អេស ម៉នសុន ។



« កើតមកក្នុងភាពក្រីក្រ ប៉ុន្តែបានបីបាច់ដោយសេចក្ដីជំនឿ ចូស [ ហ្គាសា ] បានត្រៀមខ្លួនសម្រាប់ការហៅបម្រើបេសកកម្មមួយ ។ ខ្ញុំមានវត្តមាននៅថ្ងៃ ដែលគាត់ទទួលបាននូវអនុសាសន៍ ។ នោះមានសេចក្ដីថ្លែងការណ៍ថា ៖ ‹បងប្រុស ហ្គាសា នឹងបម្រើដោយការលះបង់ដ៏ធំធេងចំពោះគ្រួសាររបស់គាត់ ព្រោះគាត់ជាអ្នកផ្គត់ផ្គង់គ្រួសារ ។ គាត់មានតែទ្រព្យមួយប៉ុណ្ណោះ–ជាការសន្សំតែមទុក– ដែលគាត់យល់ព្រមលក់វា បើចាំបាច់ ដើម្បីជួយដល់សម្រាប់ចំណាយលើបេសកកម្មរបស់គាត់› ។

« ប្រធាន [ ស្ពែនសើរ ដបុលយូ ]ឃីមបឹល បានស្ដាប់ដោយយកចិត្តទុកដាក់ពេលសេចក្ដីថ្លែងនេះបានអានឲ្យលោកស្ដាប់ រួចហើយលោកបានតបថា ៖ ‹សូមឲ្យគាត់លក់តែមសន្សំទុករបស់គាត់ចុះ› ។ ការលះបង់ដូច្នេះនឹងនាំមកនូវពរជ័យដល់គាត់ » ( Profiles of Faith » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៨, ទំព័រ ៥៦ ) ។

- តើការសម្រេចចិត្តដ៏លំបាកដូចជា ចូស នឹងងាយស្រួល បើយើងធ្លាប់ទទួលអារម្មណ៍សុខសាន្ត ដែលជាលទ្ធផលចេញមកពីការគោរពប្រតិបត្តិចំពោះបទបញ្ញត្តិរបស់ព្រះអម្ចាស់រួចហើយនោះ យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៦–៤១ ដោយស្ងាត់ស្ងៀម រកមើលគោលការណ៍ដែលអាចនឹងជួយលើកទឹកចិត្តដល់ ម៉ាទីន ហារិស ឲ្យគោរពប្រតិបត្តិចំពោះបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ សូមជួយ សិស្ស ឲ្យប្រាប់នូវគោលការណ៍ដូចខាងក្រោមនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៨ ៖ **បើយើងធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរជ័យដល់យើង ដែលមានតម្លៃថ្លៃជាងទ្រព្យសម្បត្តិលើផែនដីទៅទៀត** ។ អ្នកអាចនឹងចង់ឲ្យយោបល់សិស្សឲ្យសរសេរសេចក្ដីពិតនេះ នៅក្នុងគែមគម្ពីរជិតនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៨ ) ។

- តើគោលការណ៍នេះ ទាក់ទងនឹងសេចក្ដីពិតផ្សេងទៀតដែលអ្នកបានរៀននៅក្នុងមេរៀននេះយ៉ាងដូចម្ដេច ?

សូមអាននូវសេចក្ដីបញ្ចប់នៃដំណើររឿងដោយប្រធាន ម៉នសុន ហើយសុំឲ្យសិស្សស្ដាប់អំពីរបៀបដែល ចូស ត្រូវបានប្រទានពរចំពោះការលក់តែមសន្សំរបស់គាត់ ៖



« បន្ទាប់មក ដោយមានស្នាមញញឹមលើទឹកមុខ និងការព្រិចភ្នែក នោះព្យាការីជាទីស្រឡាញ់រូបនេះ បានមានប្រសាសន៍ថា ‹រាល់ខែនៅវិសាលនដ្ឋាននៃព្រះវិហារ នោះយើងទទួលបានសំបុត្ររាប់លាន មកពីគ្រប់ទីកន្លែងទាំងអស់លើពិភពលោក ។ យើងបានសន្សំតែមនោះទុក ហើយប្រគល់វាទៅឲ្យ ចូស នៅពេលគាត់បញ្ចប់បេសកកម្មរបស់គាត់ ។ គាត់នឹងមានតែមសន្សំដ៏ស្អាតបំផុតជាងយុវជនណាៗទាំងអស់ក្នុងប្រទេស មិកស៊ីក ដោយពុំត្រូវចំណាយប្រាក់ › » ( «Profiles of Faith, »ទំព័រ ៥៦ ) ។

ម៉ាទីន ហារិស បានគោរពតាមបទបញ្ជាឲ្យលក់ទ្រព្យសម្បត្តិរបស់គាត់ ដើម្បីផ្ដល់ថវិកាសម្រាប់ការបោះពុម្ពព្រះគម្ពីរមរមន តាមរយៈការបញ្ចាំ ហើយនៅទីបំផុត បានលក់ចម្ការរបស់គាត់ចំនួន អស់ប្រវែង ១៥១ ហិចតា ។ ដោយសារតែជម្រើសរបស់ម៉ាទីន នោះមានជីវិតមនុស្សរាប់លាននាក់ ត្រូវបានប្រទានពរ ហើយនឹងនៅតែបន្តប្រទានពរ ។

ដើម្បីបញ្ចប់មេរៀននេះ សូមពិចារណាធ្វើការអញ្ជើញដល់សិស្សឲ្យពិចារណានូវអ្វីដែលពួកគេអាចធ្វើបានកាន់តែល្អប្រសើរ ក្នុងការចុះចូលឆន្ទៈរបស់ពួកគេស្របទៅតាមព្រះហឫទ័យរបស់ព្រះវរបិតា ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧–១៩ ( មេរៀនទី ៥ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧–១៩ ( មេរៀនទី ៥ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧)

តាមរយៈព្រះឱវាទរបស់ព្រះអម្ចាស់ដល់សាក្សីបីនាក់នៃព្រះគម្ពីរមរមន នោះសិស្សបានរៀនថា ប្រសិនបើយើងអនុវត្តសេចក្ដីជំនឿលើព្រះ នោះយើងអាចទទួលបានសាក្សីមួយអំពីសេចក្ដីពិត ដែលយើងចង់ដឹង ។ អស់អ្នកដែលទទួលបានសាក្សីអំពីសេចក្ដីពិតមានទំនួលខុសត្រូវ ដើម្បីថ្លែងទីបន្ទាល់អំពីវា ។ ព្រះអង្គសង្គ្រោះទ្រង់ផ្ទាល់ក៏បានថ្លែងទីបន្ទាល់ផងដែរថា ព្រះគម្ពីរមរមនពិត ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨)

នៅក្នុងមេរៀននេះ សិស្សបានរៀនថាតម្លៃនៃព្រលឹងគឺមហិមាណាស់ដែលធ្វើឲ្យព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយបានសុគតដូច្នេះមនុស្សអាចប្រែចិត្ត ហើយត្រឡប់ទៅនៅជាមួយព្រះវរបិតាសួគ៌វិញ ។ សិស្សក៏បានរកឃើញផងដែរថា ប្រសិនបើយើងជួយអ្នកដទៃឲ្យប្រែចិត្ត ហើយមករកព្រះអម្ចាស់ នោះ យើងនឹងទទួលអារម្មណ៍នៃក្ដីអំណរ ជាមួយពួកគេនៅក្នុងនគរនៃព្រះ ។ យើងអាចឮសំឡេងរបស់ព្រះយេស៊ូវគ្រីស្ទ បាននៅពេលយើងអានព្រះគម្ពីរដោយនូវព្រះចេស្ដានៃព្រះវិញ្ញាណ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២)

ចេញពីព្រះឱវាទរបស់ព្រះអង្គសង្គ្រោះដល់ម៉ាទីន ហារីស សិស្សអាចរៀនថាព្រះយេស៊ូវគ្រីស្ទបានបំពេញតាមព្រះហឫទ័យនៃព្រះវរបិតាទ្រង់ ហើយថាព្រះយេស៊ូវគ្រីស្ទនឹងជំនុំជម្រះយើងតាមកិច្ចការទាំងឡាយរបស់យើង ។ សិស្សក៏បានរៀនផងដែរថាយើងត្រូវតែប្រែចិត្តចេញពីអំពើបាប ឬ ការរងទុក្ខរបស់យើង ។ អ្នកទាំងឡាយដែលជ្រើសរើសពុំប្រែចិត្ត នឹងត្រូវរងទុក្ខនូវទោសនៃអំពើបាបរបស់ខ្លួន ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៤១)

សិស្សបានរៀនអំពីការសន្យារបស់ព្រះអម្ចាស់ចំពោះម៉ាទីន ហារីស ៖ ប្រសិនបើម៉ាទីនរៀនពីទ្រង់ ស្ដាប់តាមបន្ទូលរបស់ទ្រង់ ហើយដើរដោយភាពរាបសារនៃព្រះវិញ្ញាណរបស់ទ្រង់ នោះគាត់នឹងមានភាពសុខសាន្ត ។ ការសន្យានេះក៏អនុវត្តចំពោះយើងផងដែរ ។ មេរៀននេះក៏បានជួយសិស្សឲ្យរៀនថា ប្រសិនបើយើងធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរជ័យដល់យើង ដែលមានតម្លៃថ្លៃជាងទ្រព្យសម្បត្តិលើផែនដីទៅទៀត ។

## សេចក្ដីផ្ដើម

មេរៀននេះនឹងជួយសិស្សរៀនពី មូលហេតុដែលការប្រែចិត្តមានភាពចាំបាច់ ។ វានឹងជួយពង្រីកការយល់ដឹងរបស់ពួកគេអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ កាលណាយើងយល់កាន់តែច្រើនអំពីការបូជា និង ការគោរពប្រតិបត្តិរបស់ព្រះយេស៊ូវគ្រីស្ទ នោះ ការសង្ស័យពីសមត្ថភាពរបស់យើងដើម្បីជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់នឹងកាត់បន្ថយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដី សញ្ញា ១៧

*ព្រះអម្ចាស់សន្យាដល់ពួកសាក្សីបីនាក់ថា ពួកគេនឹងអនុញ្ញាតឲ្យមើលឃើញផ្ទាំងចំណារ និងវត្ថុពិសិដ្ឋដទៃទៀត*

សូមយកវត្ថុមួយដែលគួរឲ្យចាប់អារម្មណ៍មកថ្នាក់រៀន ប៉ុន្តែសូមកុំឲ្យសិស្សមើលឃើញឡើយ ។ នៅពេលថ្នាក់ចាប់ផ្ដើម សូមប្រាប់សិស្សថាអ្នកបានយកវត្ថុមួយមក ។ សូមសួរសិស្ស ប្រសិនបើពួកគេជឿថាអ្នកមានវត្ថុនោះ ទោះបីជាពួកគេពុំបានឃើញវាក្ដី ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលសាក្សីបីនាក់ចាំបាច់ត្រូវមានពីមុនពួកគេអាចមើលផ្ទាំងមាសបាន ។

- ហេតុអ្វីអ្នកគិតថា សាក្សីបីនាក់ត្រូវមានសេចក្ដីជំនឿមុននឹងពួកគេអាចឃើញផ្ទាំងចំណារបានយ៉ាងដូច្នេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៣–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានតម្រូវឲ្យសាក្សីបីនាក់ធ្វើ បន្ទាប់ពីពួកគេបានឃើញផ្ទាំងមាស និង វត្ថុពិសិដ្ឋៗផ្សេងទៀត ។

- តើព្រះអម្ចាស់បានប្រាប់សាក្សីបីនាក់ឲ្យពួកគេត្រូវធ្វើអ្វីខ្លះ បន្ទាប់ពីពួកគេបានឃើញផ្ទាំងមាស និង វត្ថុពិសិដ្ឋៗផ្សេងទៀត ?
- តើព្រះអម្ចាស់រំពឹងអ្វីខ្លះពីយើង បន្ទាប់ពីយើងទទួលបានសាក្សីនៃសេចក្ដីពិតនោះ ? **( បន្ទាប់ពីយើងទទួលបានសាក្សីនៃសេចក្ដីពិត នោះយើងមានទំនួលខុសត្រូវដើម្បីថ្លែងទីបន្ទាល់អំពីវា )** ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីអ្វីដែលពួកគេបានដឹងថាពិត និង របៀបដែលពួកគេបានថ្លែងទីបន្ទាល់ពីវត្ថុទាំងនោះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨–១៩

*ព្រះអម្ចាស់បានមានព្រះបន្ទូលពីការរងទុក្ខរបស់ទ្រង់ ហើយបង្រៀនពីសារៈសំខាន់នៃការប្រែចិត្ត*

សូមបង្ហាញផ្លែឈើមួយចំណិតដល់សិស្ស ឬ បង្ហាញរូបភាពនៃផ្លែឈើមួយចំណិត ។ សូមសួរពួកគេថា តើពួកគេដឹងដោយរបៀបណាថាផ្លែឈើនេះអាចហូបបាន ។ ( រូបរាងរបស់វា ឬ លក្ខណៈពិសេសផ្សេងទៀតដែលបង្ហាញថាវាទុំ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពី អ្វីដែលទុំស្រុះនៅក្នុងសេចក្ដីទុច្ចរិត ។

- តើអ្នកគិតថា « ពិភពលោកលោកកំពុងតែទុំស្រុះនៅក្នុងសេចក្ដីទុច្ចរិត » មានន័យយ៉ាងណា ?
- តើភស្តុតាងអ្វីខ្លះដែលអ្នកឃើញថាការណ៍នេះកំពុងតែកើតឡើង ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨០:១០ ( ដែលជាផ្នែកមួយនៃវគ្គចំណេះចំណានខគម្ពីរ ) ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលព្រះអម្ចាស់មានព្រះទ័យចំពោះមនុស្សទាំងអស់ ទោះទាំងអស់អ្នកដែលទុំស្រុះនៅក្នុងសេចក្ដីទុច្ចរិត ។ បន្ទាប់មក សូមឲ្យពួកគេអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០ ឲ្យឮៗ រួមគ្នា ជាច្រើនដង រហូតទាល់តែសមាជិកម្នាក់ៗនៃថ្នាក់អាចសូត្រចាំ ។

- តើព្រះអម្ចាស់មានព្រះទ័យយ៉ាងណាចំពោះកូនចៅរបស់ទ្រង់ ?
- តើការដឹងពីការណ៍នេះ អាចជះឥទ្ធិពលលើរបៀបដែលអ្នកប្រព្រឹត្តចំពោះមនុស្សនៅជុំខ្លួនអ្នកដោយរបៀបណា ?
- តើមនុស្សម្នាក់អាចដឹងថាខ្លួនគេមានតម្លៃមហិមាចំពោះព្រះដោយរបៀបណា ?

សូមចង្អុលបង្ហាញថា នៅក្នុងស្ថានភាពជាច្រើនតម្លៃនៃវត្ថុមួយគឺត្រូវបានកំណត់ដោយឆន្ទៈដ៏អនេករបស់បុគ្គលម្នាក់ដែលចង់បង់ថ្លៃសម្រាប់វា ។ អ្នកអាចនឹងចង់ដាក់បង្ហាញវត្ថុពីរបីដែលមានតម្លៃផ្សេងៗពីគ្នាដើម្បីបង្ហាញពីចំណុចនេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១១–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលតម្លៃដែលព្រះអង្គសង្គ្រោះបានបង់ថ្លៃចំពោះព្រលឹងរបស់យើង ។

- តើតម្លៃអ្វីខ្លះត្រូវបានបង់សម្រាប់ព្រលឹងរបស់យើង ? ហេតុអ្វីបានជាវាត្រូវបានបង់ថ្លៃឲ្យ ? ( អ្នកអាចសរសេរនូវគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **តម្លៃនៃបុគ្គលម្នាក់ គឺធំមហិមាអ្វីម្ល៉េះ ដែលធ្វើឲ្យព្រះយេស៊ូវគ្រីស្ទ បានរងទុក្ខ ហើយបានសុគត ដូច្នេះខ្ញុំអាចបានប្រែចិត្ត ហើយត្រឡប់ទៅព្រះវរបិតាសួគ៌វិញ**) ។
- តើការប្រែចិត្តត្រូវតែធ្វើអ្វីជាមួយនឹងការមកកាន់ព្រះអង្គសង្គ្រោះ ?

ដើម្បីជួយសិស្សយល់កាន់តែប្រសើរពីរបៀបជួយយើងមកកាន់ព្រះអង្គសង្គ្រោះ សូមឲ្យសិស្សម្នាក់អានឃ្លាខាងក្រោមមកពីកូនសៀវភៅ *ពិតចំពោះសេចក្ដីជំនឿ* ៖

> « ការប្រែចិត្តគឺវាសំខាន់ជាងការគ្រាន់តែដឹងពីការធ្វើខុស ។ វាគឺជាការផ្លាស់ប្ដូរនៃគំនិត និង ចិត្តដែលផ្ដល់ដល់យើងនូវការយល់ដឹងថ្មីអំពីព្រះ អំពីខ្លួនរបស់យើងផ្ទាល់ និង អំពីពិភពលោកនេះ ។ វារួមមានការបែរចេញពីអំពើបាប ហើយបែរទៅរកព្រះសម្រាប់ការអភ័យទោស ។ វាត្រូវបានជម្រុញដោយសេចក្ដីស្រឡាញ់ដល់ព្រះ និង បំណងដ៏ស្មោះត្រង់ក្នុងការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់» *ពិតចំពោះសេចក្ដីជំនឿ ៖ សេចក្ដីយោងនៃដំណឹងល្អ* ឆ្នាំ ២០០៤], ទំព័រ ១៣២ ) ។

សូមលើកទឹកចិត្តឲ្យសិស្សគិតពិចារណាពី អំពើបាប អកប្បកិរិយា និង បុគ្គលលក្ខណៈណាមួយ ដែលពួកគេត្រូវការដកខ្លួនចេញពីវាដើម្បីប្រែចិត្ត ហើយមកកាន់ព្រះគ្រីស្ទ ។

សូមសរសេរសេចក្ដីយោងបទគម្ពីរខាងក្រោមនៅលើក្ដារខៀន ៖ *គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៣–១៦ ។*

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេនគ្នាអានខគម្ពីរទាំងនេះឲ្យឮៗ ខណៈដែលសិស្សទាំងអស់ទៀតផ្ទៀងតាម ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំពាក្យណាស្រដៀងនឹង *ការប្រែចិត្ត* នៅក្នុងខគម្ពីរទាំងនេះ (*ប្រែចិត្ត* និង *ការប្រែចិត្ត*) ។ បន្ទាប់ពីអានខគម្ពីរនេះហើយ សូមសួរសិស្សពីអ្វីដែលខគម្ពីរទាំងនេះបានបង្រៀនអំពី ការប្រែចិត្ត ។ អ្នកអាចចង្អុលបង្ហាញថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៥–១៦ ជាវគ្គចំណេះចំណានខគម្ពីរមួយ ។

សូមបន្ថែមសេចក្ដីពិត ដែលសិស្សស្វែងរកដាក់លើក្ដារខៀន ។ សិស្សអាចរកឃើញគោលការណ៍ផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដឲ្យច្បាស់ថា **ប្រសិនបើយើងជួយអ្នកដទៃឲ្យប្រែចិត្ត ហើយមករកព្រះអម្ចាស់ នោះ យើងនឹងទទួលអារម្មណ៍នៃក្ដីអំណរ ជាមួយពួកគេនៅក្នុងនគរនៃព្រះ ។**

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីអ្វីដែលនឹងទទួលបាន នៅពេលពួកគេត្រឡប់ទៅកាន់ទីវត្តមានរបស់ព្រះដើម្បីទទួលការកាត់ទោស ។ សូមសួរពួកគេពីរបៀបដែលពួកគេដាក់ផែនការសម្រាប់ប្រព្រឹត្តិការណ៍ដ៏ធំនោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលហើយគួរធ្វើដើម្បីរៀបចំខ្លួនសម្រាប់ថ្ងៃនោះ ។

- យោងតាមខគម្ពីរនេះ តើមានអ្វីកើតឡើងប្រសិនបើយើងជ្រើសរើសពុំប្រែចិត្តនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–១៩ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលលទ្ធផលសម្រាប់អស់អ្នកដែលជ្រើសរើសពុំប្រែចិត្ត ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៦–១៩, តើមានមូលហេតុអ្វីខ្លះ ដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យចំពោះហេតុផលដែលទ្រង់រងទុក្ខចំពោះអំពើបាបរបស់យើងនោះ ? ( អ្នកអាចបន្ថែមគោលលទ្ធិខាងក្រោមលើគោលលទ្ធិផ្សេងៗនៅលើក្ដារខៀន ៖ **ព្រះអង្គសង្គ្រោះបានរងទុក្ខចំពោះអំពើបាបរបស់យើង ដូច្នេះយើងអាចប្រែចិត្តហើយពុំរងទុក្ខដូចជាទ្រង់បានរងទុក្ខឡើយ**) ។

សូមបង្ហាញរូបភាពព្រះអង្គសង្គ្រោះនៅក្នុងច្បារគែតសេម៉ានី ដូចជារូបភាពដែលព្រះយេស៊ូវអធិស្ឋាននៅក្នុងច្បារគែតសេម៉ានី (*សៀវភៅរូបភាពដំណឹងល្អ* [ ឆ្នាំ ២០០៩ ], លេខ ៥៦ សូមមើលផងដែរគេហទំព័រ LDS.org) ។ សូមពន្យល់ថា ដំណើររឿងភាគច្រើនអំពីសេចក្ដីរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានផ្ដល់ឲ្យដោយមនុស្សផ្សេងទៀតក្រៅពីព្រះអង្គទ្រង់ ( សូមមើល ម៉ាថាយ ២៦:៣៦–៣៩; លូកា ២២:៣៩–៤៤) ប៉ុន្តែ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩ មាននូវដំណើររឿងនៃការរងទុក្ខរបស់ព្រះអង្គសង្គ្រោះផ្ទាល់ ។

សូមអញ្ជើញសិស្សឲ្យរំពឹក គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៨–១៩ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលព្រះអង្គសង្គ្រោះបានពិពណ៌នាអំពីសេចក្ដីរងទុក្ខ ដែលទ្រង់បានជួបអំឡុងពេលធ្វើដង្វាយធួន ។

សូមសរសេរ សំណួរពីរខាងក្រោម នៅលើក្ដារខៀន ៖

> *តើផ្នែកមួយណានៃការពិពណ៌នារបស់ព្រះអង្គសង្គ្រោះ អំពីការរងទុក្ខរបស់ទ្រង់ដែលមានន័យ បំផុតចំពោះអ្នក ? ហេតុអ្វី ?*
>
> *តើមានអ្វីខ្លះនៅក្នុងការពិពណ៌នារបស់ព្រះអង្គសង្គ្រោះ ដែលជួយបង្កើនបំណងប្រាថ្នារបស់អ្នក ដើម្បីប្រែចិត្ត ហើយត្រឡប់ទៅកាន់ទ្រង់វិញនោះ ?*

សូមអញ្ជើញសិស្សឲ្យជ្រើសរើសសំណួរមួយ ហើយពិភាក្សាចម្លើយរបស់ពួកគេជាមួយដៃគូ ។

សូមអញ្ជើញសិស្សឲ្យច្រៀង ឬ ស្ដាប់ទំនុកបទនៃទំនុកតម្កើង « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ »(*ទំនុកតម្កើង*, លេខ ១១៥ ) ។ សូមឲ្យពួកគេសញ្ជឹងគិតពីទំនុកបទនៃទំនុកតម្កើងនេះ ហើយគិតអំពីអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់ពួកគេ ។

ប្រសិនបើមានពេល សូមអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ និង ពរជ័យនៃការប្រែចិត្ត ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមអារម្មណ៍ ឬ ការបំផុសគំនិតដែលពួកគេមានដើម្បីប្រែចិត្ត ហើយត្រឡប់មករកព្រះអង្គសង្គ្រោះវិញ ។

ដើម្បីបញ្ចប់មេរៀននេះ សូមអញ្ជើញសិស្សឲ្យសូត្រ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣ ពីការចងចាំ ឬ អានវារួមគ្នាពីព្រះគម្ពីររបស់ពួកគេ ។ សូមសួរពួកគេពីរបៀបដែលពួកគេគិតអំពីចំណោះចំណានខគម្ពីរនេះ ទាក់ទងនឹងការប្រែចិត្ត និង សេចក្ដីសង្ឃឹមនៃការអភ័យទោស ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២០–២៣)

តើយើងធ្វើអ្វីខ្លះនៅក្នុងសាសនាចក្រសព្វថ្ងៃនេះ ដែលដូចគ្នាក្នុងសម័យដែលសាសនាចក្រត្រូវបានស្ថាបនាឡើងនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០នោះ ? តើអ្វីខ្លះជាតម្រូវការនៃបុណ្យជ្រមុជទឹក ? តើការណែនាំរបស់អ្នកកាន់បព្វជិតភាពដើម្បីប្រសិទ្ធិពរសាក្រាម៉ង់យ៉ាងដូចម្ដេចដែរ ? តើកាតព្វកិច្ចរបស់គ្រូ ឬ សង្ឃមានអ្វីខ្លះ ? សិស្សនឹងរៀនឆ្លើយសំណួរទាំងនេះនៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០–២៣ ។

មេរៀនទី ២៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦

## បុព្វកថា

នៅក្នុងវិវរណៈមួយទៅកាន់ ព្យាការីយ៉ូសែប ស្ម៊ីធ ព្រះអម្ចាស់បានបញ្ជាថា សាសនាចក្រដែលបានស្ដារឡើងវិញរបស់ទ្រង់ ត្រូវរៀបចំឡើងនៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣០ ។ ទ្រង់ក៏បានបង្រៀនអំពីសារៈសំខាន់នៃព្រះគម្ពីរមរមន ហើយបានប្រទានការណែនាំជាច្រើនអំពីការគ្រប់គ្រងសាសនាចក្ររបស់ទ្រង់ រួមទាំង តំណែងបព្វជិតភាព ពិធីបរិសុទ្ធ និងទម្រង់ការនានានៃសាសនាចក្រដែលបានស្ដារឡើងវិញថ្មីនោះ ។ វិវរណៈនេះត្រូវបានហៅថា « មាត្រា និងសេចក្ដីសញ្ញា » កាលពីជំនាន់មុនក្នុងសាសនាចក្រ ឥឡូវមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ។ វិវរណៈនេះត្រូវបានកត់ត្រានៅក្នុងរយៈពេលពីបីថ្ងៃក្រោយពីថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣០ ប៉ុន្តែព្រះអម្ចាស់ប្រហែលជាបានបើកសម្ដែងតែផ្នែកៗទេ ទៅកាន់ព្យាការីនៅដើមរដូវក្ដៅនៃឆ្នាំ ១៨២៩ ។ ដោយសារវាវែង នោះ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ត្រូវបានបែងចែកទៅជាបីមេរៀននៅក្នុងសៀវភៅសិក្សានេះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៤

*ព្រះបញ្ជាថា សាសនាចក្រត្រូវតែបានស្ថាបនាឡើងវិញ*

សូមអញ្ជើញសិស្សឲ្យគិតអំពីការប្រជុំលើកមុន ដែលពួកគេបានចូលរួម ដែលមានការចែកចាយទីបន្ទាល់ ។ សូមពួកគេឲ្យពិពណ៌នាអំពីរបៀបដែលការថ្លែងទីបន្ទាល់ គឺមានភាពខុសគ្នាពីការប្រាប់រឿង ឬការបង្ហាញនូវអំណរគុណ ។

សូមសូមឲ្យសិស្សម្នាក់អាននិយមន័យដូចខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ទីបន្ទាល់អំពីដំណឹងល្អគឺជាសាក្សីផ្ទាល់ខ្លួនមួយ ដែលថ្លែងដល់ព្រលឹងយើងដោយព្រះវិញ្ញាណបរិសុទ្ធថា ភាពពិតជាក់លាក់នៃសារៈសំខាន់ដ៏អស់កល្ប គឺជាការពិត ហើយដែលយើងដឹងថាវាជាការពិត » ( Testimony » *Ensign* ឬ *លីអាហូណា* ខែឧសភា ឆ្នាំ ២០០៨, ២៦ ) ។

សូមសរសេរនៅលើក្ដារខៀនដូចខាងក្រោម ៖ *យើងដឹងថា* . . .

សូមអញ្ជើញសិស្សឲ្យបើកទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ។ សូមពន្យល់ថា ពួកអ្នកដឹកនាំសាសនាចក្រអានកណ្ឌនេះឮៗនៅក្នុងសន្និសីទសាសនាចក្រ ដែលបានធ្វើឡើងនៅថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ១៨៣០ និងថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២៨៣០ ដែលបានជួយរំឭកដល់សមាជិកនៃសាសនាចក្រថ្មីអំពីសារៈសំខាន់ជាច្រើននៃសេចក្ដីពិតដំណឹងល្អ ។ សូមលើកទឹកចិត្តដល់សិស្សឲ្យស្រាវជ្រាវរកគោលលទ្ធិ និងគោលការណ៍ទាំងឡាយក្នុងកណ្ឌនេះ ដែលអាចត្រូវបានចាប់ផ្ដើមដោយឃ្លា « យើងដឹងថា. . . »

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–២ ដោយស្ងាត់ស្ងៀម រកមើលគំនិតបំភ្លឺអំពីការស្ដារឡើងវិញនៃដំណឹងល្អ ។

- តើខគម្ពីរទាំងនេះ បានថ្លែងទីបន្ទាល់អំពីសេចក្ដីពិតស្ដីអំពីការស្ដារឡើងវិញនៃដំណឹងល្អអ្វីខ្លះ ? ( គោលលទ្ធិមួយ ដែលសិស្សអាចប្រាប់គឺថា **យ៉ូសែប ស្ម៊ីធ ត្រូវបានហៅពីព្រះ ហើយបានបញ្ជាឲ្យរៀបចំសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។** សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរគោលលទ្ធិនេះ ព្រមទាំងឲ្យសិស្សផ្សេងទៀតប្រាប់អំពីអ្វីនៅលើក្ដារខៀន ក្រោមឃ្លាថា « យើងដឹងថា . . . » សិស្សទាំងឡាយអាចនឹងបង្កើតបញ្ជីស្រដៀងគ្នាមួយ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ) ។

ដើម្បីជួយសិស្សយល់អំពីសារៈសំខាន់នៃសេចក្ដីពិតទាំងនេះ សូមលើកទឹកចិត្តពួកគេឲ្យពិចារណាអំពីទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេអំពីការហៅដ៏ទេវភាពរបស់យ៉ូសែប ស៊្មីធ និងសេចក្ដីពិតពេញលេញនៃសាសនាចក្រ ។ អ្នកអាចនឹងចង់ សុំឲ្យសិស្សចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់ អំពីរបៀបដែលពួកគេបានមកដឹងថារឿងទាំងនេះថាជាការពិត ។

- តើអ្នកគិតថាពាក្យ « ការតាំងឡើង » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១ មានន័យយ៉ាងណា ទាក់ទងទៅនឹងការរៀបចំសាសនាចក្រ ? ( អ្នកអាចនឹងចាំបាច់ត្រូវរំឭកដល់សិស្សអំពីការក្បត់សាសនា និងតម្រូវការសម្រាប់ការស្ដារឡើងវិញ ) ។
- តើយើងអាចជួយសាសនាចក្ររបស់ព្រះអម្ចាស់ បន្ត «ការតាំងឡើង » នៅជំនាន់របស់យើងយ៉ាងដូចម្ដេច ?

*សូមអញ្ជើញសិស្សឲ្យថ្លែងទីបន្ទាល់*

គ្រូបង្រៀនអាចលើកទឹកចិត្តសិស្សឲ្យថ្លែងទីបន្ទាល់អំពី សេចក្ដីពិតដំណឹងល្អតាមរយៈការសួរសំណួរដែលអញ្ជើញពួកគេឲ្យចែកចាយបទពិសោធន៍ និងជំនឿរបស់ពួកគេ ។ នៅពេលសិស្សថ្លែងទីបន្ទាល់អំពីអារម្មណ៍ និងការផ្លាស់ប្រែចិត្តជឿរបស់ពួកគេ នោះជាញឹកញាប់ ព្រះវិញ្ញាណបរិសុទ្ធអាចថ្លែងទីបន្ទាល់កាន់តែមានអានុភាពអំពីសេចក្ដីពិតទាំងនេះដល់ពួកគេ ដែលជួយសិស្សអភិវឌ្ឍទីបន្ទាល់កាន់តែជ្រាលជ្រៅអំពីរឿងដែលពួកគេបានបង្ហាញប្រាប់ ។ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណ នោះពាក្យសម្ដីរបស់ពួកគេក៏អាចមានឥទ្ធិពលសំខាន់ទៅលើដួងចិត្តមិត្តភក្តិរបស់ពួកគេផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៥–១៦

*ព្រះអម្ចាស់បានរៀបរាប់សង្ខេបអំពីព្រឹត្តការណ៍មួយចំនួននៃការស្ដារឡើងវិញ*

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៥–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវរឿងទាំងឡាយដែលបានរៀបចំយ៉ូសែប ស៊្មីធ ឲ្យរៀបចំសាសនាចក្រម្ដងទៀតនៅលើផែនដី ។

- តើយ៉ូសែប មានបទពិសោធន៍អ្វីខ្លះ ដែលអាចឲ្យលោករៀបចំសាសនាចក្រពិតម្ដងទៀតនៅលើផែនដី ? ( លោកត្រូវបានណែនាំដោយព្រះ និងពួកទេវតា ហើយត្រូវបានប្រទានអំណាចឲ្យបកប្រែព្រះគម្ពីរមរមន ) ។

សូមពន្យល់ថា នៅពេលសាសនាចក្រត្រូវបានរៀបចំឡើងនៅខែមេសា ឆ្នាំ ១៨៣០ នោះព្រះគម្ពីរមរមនទើបតែបានបោះពុម្ពរួច ។ សូមសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៩–១២ ដោយស្ងាត់ស្ងៀម រកមើលសេចក្ដីពិតដែលព្រះគម្ពីរមរមនបង្រៀន ។ អ្នកអាចផ្ដល់យោបល់ថា សិស្សគួរគូសចំណាំនូវអ្វីដែលពួកគេរកឃើញ ។ បន្ទាប់ពីមានពេលគ្រប់គ្រាន់ សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *ព្រះគម្ពីរមរមន បង្ហាញដល់ពិភពលោកថា . . .*

សូមអញ្ជើញសិស្សមួយចំនួនឲ្យឡើងមកក្ដារខៀន ហើយបញ្ចប់ប្រយោគដោយប្រើឃ្លានានា ដែលពួកគេបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៩–១២ ។ អ្នកអាចចង្អុលទៅបញ្ចីចម្លើយរបស់ពួកគេ ហើយសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីក៏វាសំខាន់ដល់ម្ល៉េះដើម្បីទទួលបានទីបន្ទាល់មួយថា ព្រះគម្ពីរមរមន គឺជាការពិតនោះ ?
- បើព្រះគម្ពីរមរមន គឺជាការពិត ចុះតើវាបង្ហាញអ្វីខ្លះអំពីយ៉ូសែប ស៊្មីធ ?

សូមថ្លែងទីបន្ទាល់ថា **ព្រះគម្ពីរមរមន គឺជាភស្តុតាងថា ព្រះបានស្ដារដំណឹងល្អនៅក្នុងជំនាន់របស់យើងឡើងវិញ ។** សេចក្ដីពិតនេះអាចត្រូវបានសរសេរនៅលើក្ដារខៀនក្រោមពាក្យ « យើងដឹងថា . . . »

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៤–១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកនូវអ្វីដែលព្រះអម្ចាស់ សន្យាដល់អ្នកទាំងឡាយដែលទទួលព្រះគម្ពីរមរមន ហើយរស់នៅតាមការបង្រៀនក្នុងព្រះគម្ពីរនោះ ។

- តើព្រះអម្ចាស់សន្យាពរជ័យអ្វីខ្លះ ចំពោះអ្នកទាំងឡាយដែលទទួលបានព្រះគម្ពីរមរមនដោយសេចក្ដីជំនឿ ?
- តើមានអ្វីខ្លះនឹងកើតឡើងដល់អ្នកទាំងឡាយដែលមានចិត្តរឹងរូសក្នុងការឥតជំនឿ ហើយបដិសេធព្រះគម្ពីរមរមននោះ ?
- តើមានវិធីអ្វីខ្លះ ដែលអ្នកអាចទទួលបានព្រះគម្ពីរមរមនដោយសេចក្ដីជំនឿ ?
- តើព្រះគម្ពីរមរមនអាចដឹកនាំមនុស្សម្នាក់ឲ្យ « ធ្វើការសុចរិត » យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សពិចារណាអំពី (១) របៀបដែលទីបន្ទាល់របស់ពួកគេអំពីព្រះគម្ពីរមរមន បានជួយពួកគេកាន់តែគោរពបទបញ្ញត្តិរបស់ព្រះ និង (២) អ្វីខ្លះដែលពួកគេអាចធ្វើ ដើម្បីពង្រឹងដល់ទីបន្ទាល់របស់ពួកគេអំពីវានោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧–៣៦

*ព្រះគម្ពីរមរមន បង្រៀន និងបញ្ជាក់អំពីគោលលទ្ធិសំខាន់ៗនៃដំណឹងល្អ*

អ្នកអាចនឹងអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន ៖



« នៅក្នុងកណ្ឌទី ២០ នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ព្រះម្ចាស់បានប្រទានខគម្ពីរជាច្រើន ដើម្បីសង្ខេបអំពីសេចក្ដីពិតដ៏សំខាន់ ដែលព្រះគម្ពីរមរមនបង្រៀន ។ ( សូមមើល ខ ១៧–៣៦ ) ។ វាថ្លែងអំពីព្រះ ការបង្កបង្កើតនៃមនុស្ស ការធ្លាក់ ដង្វាយធួន ការយាងឡើងទៅស្ថានសួគ៌វិញរបស់ព្រះគ្រីស្ទ ពួកព្យាការី សេចក្ដីជំនឿ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក ព្រះវិញ្ញាណបរិសុទ្ធ ការកាន់ខ្ជាប់ ការអធិស្ឋាន ភាពយុត្តិធម៌ និងការញែកចេញឲ្យបរិសុទ្ធ តាមរយៈព្រះគុណ និងសេចក្ដីស្រឡាញ់ និងការបម្រើព្រះ » ( A New Witness for Christ, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៤, ទំព័រ ៧ ) ។

សូមអញ្ជើញសិស្សឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧, ២៩, ៣០, ៣១, ៣៥ ហើយប្រាប់ឃ្លាដែលត្រូវបានថ្លែងដដែលៗនៅជិតនឹងការចាប់ផ្ដើមខគម្ពីរនីមួយៗ ។ ( សិស្សគួរតែប្រាប់ឃ្លាថា « យើងដឹងថា » ឬ ការផ្សេងៗអំពីវា ) ។ សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧–៣៦ យើងអាចរកឃើញគោលលទ្ធិសំខាន់មួយចំនួនដែលសាសនាចក្ររបស់ព្រះអម្ចាស់ បានប្រកាសដល់ពិភពលោក ជាលទ្ធផលមួយអំពីការនិមិត្តដំបូង និងការចេញមកនៃព្រះគម្ពីរមរមន ។ នៅក្នុងចំណោមសេចក្ដីពិតទាំងនេះអំពីព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ និងអ្វីដែលយើងត្រូវតែធ្វើដើម្បីត្រូវបានសង្គ្រោះនៅក្នុងនគរនៃព្រះ ។

សូមសរសេរសេចក្ដីយោងដូចខាងក្រោមនៅលើក្ដារខៀន ៖ *គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧–១៩, គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២១–២៥, គោលលទ្ធិ និងសេចក្ដីសញ្ញា ២០:២៦–២៨* ។

ដើម្បីជួយសិស្សឲ្យបំពេញតួនាទីរបស់ពួកគេនៅក្នុងដំណើរការរៀនសូត្រ ហើយរៀបចំពួកគេឲ្យប្រាប់អំពីសេចក្ដីពិតដំណឹងល្អ ដោយបំបែកពួកគេជាគូៗ ហើយចាត់គូនីមួយៗនូវវគ្គគម្ពីរមួយនៅលើក្ដារខៀន ។ សូមអញ្ជើញពួកគេឲ្យសិក្សាខគម្ពីរដែលបានចាត់ឲ្យពួកគេជាមួយគ្នា រកមើលសេចក្ដីពិតអំពីព្រះបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ និងអ្វីដែលពួកទ្រង់បានធ្វើសម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។

បន្ទាប់ពីផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សមួយចំនួនឲ្យចែកចាយសេចក្ដីពិតមួយដែលពួកគេបានប្រាប់អំពីព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ ឬ ព្រះវិញ្ញាណបរិសុទ្ធ ហើយពន្យល់ពីមូលហេតុដែលវាសំខាន់ចំពោះពួកគេ ។ អ្នកអាចនឹងលើកទឹកចិត្តសិស្សឲ្យសរសេរសេចក្ដីពិត ដែលមានអត្ថន័យជាក់លាក់ចំពោះពួកគេនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ និងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

នៅពេលសិស្សរកឃើញសេចក្ដីពិតទាំងនេះ អ្នកអាចបន្ថែមសេចក្ដីពិតទាំងនោះទៅលើបញ្ជីនៅលើក្ដារខៀនក្រោមពាក្យ « យើងដឹងថា. . .» ។ គោលលទ្ធិមួយចំនួនដែលសិស្សអាចរកឃើញរួមមានដូចតទៅនេះ ៖

**មានព្រះមួយអង្គ ដែលនៅជានិរន្តរ៍ និងអស់កល្បជានិច្ច ឥតប្រែប្រួល** ( ខ ១៧ ) ។

**យើងត្រូវបានបង្កើតឡើងតាមរូបអង្គទ្រង់ និងដូចជារូបរបស់ព្រះ** ( ខ ១៨ ) ។

**ព្រះប្រទានព្រះរាជបុត្រាសំណប់តែមួយគត់របស់ទ្រង់ ដើម្បីត្រូវគេឆ្កាង ហើយរស់ឡើងវិញម្ដងទៀត ដើម្បីមនុស្សទាំងអស់ដែលជឿ ត្រូវបានជ្រមុជទឹក និងកាន់ខ្ជាប់នៅក្នុងសេចក្ដីជំនឿ អាចត្រូវបានសង្គ្រោះ** ( ខ ២១–២៥ ) ។

**ព្រះវិញ្ញាណបរិសុទ្ធ ថ្លែងទីបន្ទាល់អំពីព្រះបិតា និងព្រះរាជបុត្រា** ( ខ ២៧ ) ។

**ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ធ្វើការរួមគ្នាដើម្បីរៀបចំយើងសម្រាប់ជីវិតដ៏អស់កល្បជានិច្ច** ( ខ ១៧–២៨ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២៩–៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការទទួលខុសត្រូវ ដែលយើងមាន បើយើងចង់ទទួលបានជីវិតដ៏អស់កល្បជានិច្ចជាមរតក ។ ដើម្បីជួយសិស្សឲ្យយល់ខទាំងនេះ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា *យុត្តិធម៌* ( ខ ៣០) មានន័យថា ត្រូវបានអភ័យទោស អត់ទោស ហើយប្រកាសថា គ្មានកំហុស ។ *ការញែកជាបរិសុទ្ធ* ( ខ ៣១) មានន័យថាក្លាយជាស្អាតស្អំ បរិសុទ្ធ ពិសិដ្ឋ និងមានលក្ខណៈដូចជាព្រះគ្រីស្ទ ។

- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ ដែលយើងត្រូវធ្វើដើម្បីបានសង្គ្រោះនៅក្នុងនគរនៃព្រះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៥–៣៦ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យរកមើលនូវអ្វីដែលពួកគេអាចធ្វើដើម្បីបង្ហាញថា ពួកគេដឹងថារឿងទាំងនេះគឺជាការពិត ។

- តើយើងអាចថ្វាយព្រះកិត្តិយស និងសិរីល្អដល់ព្រះនាមដល់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សមើលបញ្ជីនៅលើក្ដារខៀនឡើងវិញក្រោមពាក្យ « យើងដឹងថា. . . » ។ សូមឲ្យពួកគេពិចារណាដោយស្ងៀមស្ងាត់ថា តើគោលការណ៍ណាមួយដែលពួកគេដឹងថាពិត ។ បើពួកគេបានសរសេរបញ្ជីស្រដៀងគ្នានៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ នោះអ្នកអាចអញ្ជើញពួកគេឲ្យដាក់សញ្ញាគូសធីក នៅជិតនឹងសេចក្ដីពិតទាំងនោះ ។

សូមបញ្ចប់មេរៀនដោយការអញ្ជើញឲ្យសិស្សជ្រើសរើសគោលការណ៍ដែលបានលើកឡើងមួយ ហើយចែកចាយពីរបៀបដែលពួកគេបានដឹងអំពីសេចក្ដីពិតពេញលេញរបស់គោលការណ៍នោះ ។

មេរៀនទី ២៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧

## បុព្វកថា

នៅក្នុងវិវរណៈទៅកាន់ព្យាការី យ៉ូសែប ស្ម៊ីធ ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ព្រះអម្ចាស់បានបញ្ជាថា សាសនាចក្រដែលបានស្ដារឡើងវិញរបស់ទ្រង់ គឺត្រូវរៀបចំឡើងនៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣០ ។ ទ្រង់ក៏ប្រទានការណែនាំអំពីការគ្រប់គ្រងសាសនាចក្ររបស់ទ្រង់ផងដែរ រួមមាននូវការពន្យល់មួយអំពីតំណែងបព្វជិតភាពផ្សេងៗ និងកាតព្វកិច្ចនៃអ្នកទាំងឡាយដែលនឹងកាន់តំណែងទាំងនេះ ។ ដោយមានតំណែងទាំងនេះ កូនៗរបស់ព្រះវរបិតាសួគ៌ អាចទទួលបានពិធីបរិសុទ្ធបព្វជិតភាព ហើយធ្វើសេចក្ដីសញ្ញានានា ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៥៩

*កាតព្វកិច្ចនៃតំណែងបព្វជិតភាព ត្រូវបានតាំងឡើង*

សូមសរសេរពាក្យដូចខាងក្រោម នៅលើក្ដារខៀនក្នុងថ្នាក់ ៖ *ផ្សាយ បង្រៀន ពន្យល់ ដាស់តឿន ព្រមាន អញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ*

នៅពេលចាប់ផ្ដើមថ្នាក់រៀនដំបូង សូមយោងទៅពាក្យនៅលើក្ដារខៀន ហើយសួរសំណួរដូចខាងក្រោម ៖

- តើនរណាមានទំនួលខុសត្រូវទាំងនេះ ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យ *ពន្យល់* មានន័យថា បង្រៀនអ្វីមួយដោយមានភាពលម្អិតយ៉ាងខ្លាំង ហើយថាពាក្យ *ដាស់តឿន* មានន័យថាជាការលើកទឹកចិត្តយ៉ាងខ្លាំងដល់នរណាម្នាក់ឲ្យធ្វើអ្វីមួយ ។

សិស្សអាចចង្អុលបង្ហាញថា ពួកព្យាការី ពួកសាវក អ្នកដឹកនាំសាសនាចក្រផ្សេងទៀត និងពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង មានទំនួលខុសត្រូវទាំងនេះ ។ ពួកគេក៏អាចចង្អុលបង្ហាញផងដែរថា ទាំងនេះជាកាតព្វកិច្ចដែលអ្នកកាន់បព្វជិតភាពទាំងអស់មាន រួមទាំងអ្នកកាន់បព្វជិតភាពអើរ៉ុន ដែលអាចអនុវត្ត ។ បើពួកគេពុំបានប្រាប់អំពីអ្នកកាន់បព្វជិតភាពអើរ៉ុនទេ នោះវានឹងប្រាប់ពីសេចក្ដីពិតដោយខ្លួនឯង ។ សូមគូសបញ្ជាក់ថា អ្នកកាន់បព្វជិតភាពអើរ៉ុន នៅក្នុងថ្នាក់របស់អ្នក ត្រូវបានទុកចិត្តជាមួយនឹងឱកាសសំខាន់ដើម្បីបម្រើ ។

សូមបែងចែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ សូមពន្យល់ថា នៅក្នុងទំនាក់ទំនងជាមួយនឹងអង្គភាពនៃសាសនាចក្រ នោះព្រះអម្ចាស់បានបើកសម្ដែងដល់យ៉ូសែប ស្ម៊ីធ នូវកាតព្វកិច្ចជាច្រើនអំពីអ្នកកាន់បព្វជិតភាព ។ សូមឲ្យក្រុមមួយសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៤៥ រកមើលកាតព្វកិច្ចរបស់ពួកអែលឌើរ ។ សូមអញ្ជើញក្រុមទីពីរឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៤៦–៥២ រកមើលកាតព្វកិច្ចរបស់ពួកសង្ឃ ។ សូមអញ្ជើញក្រុមទីបីឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៥៣–៥៩ រកមើលកាតព្វកិច្ចរបស់គ្រូបង្រៀន និងឌីកុន ។ នៅពេលពួកគេសិក្សា សូមសរសេរពាក្យដូចខាងក្រោមនៅផ្នែកខាងលើនៃក្ដារខៀន ៖

| អែលឌើរ | ពួកសង្ឃ | គ្រូបង្រៀន និងឌីកុន |
|---|---|---|
| គ. និង ស. ២០:៣៨–៤៥ | គ. និង ស. ២០:៤៦–៥២ | គ. និង ស. ២០:៥៣–៥៩ |

បន្ទាប់ពីផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមអញ្ជើញអ្នកតំណាងម្នាក់ ឬពីរនាក់មកពីក្រុមនីមួយៗមកលើក្ដារខៀន ហើយសរសេរកាតព្វកិច្ចនៃតំណែង ឬតំណែងនានា ដែលពួកគេបានសិក្សា ។

- តើអ្នកកត់សម្គាល់ឃើញភាពខុសគ្នាអ្វីខ្លះរវាង កាតព្វកិច្ចនៃពួកអែលឌើរ ពួកសង្ឃ ពួកគ្រូ និងពួកឌីកុន ? តើអ្នកមើលឃើញមានភាពស្រដៀងគ្នាអ្វីខ្លះ ?

- តើតំណែងណាមួយ ដែលមានសិទ្ធិដើម្បីប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ? ( អែលឌើរ សូមមើល ខ ៤១ ) ។ តើតំណែងណាមួយ ដែលមានសិទ្ធិអំណាចដើម្បីបម្រើសាក្រាម៉ង់ ? ( អែលឌើរ និងសង្ឃ សូមមើល ខ ៤០ និង ៤៦ ) ។ តើតំណែងណាមួយ ដែលមានសិទ្ធិអំណាចដើម្បីតែងតាំងសង្ឃ គ្រូ និងឌីកុន ? ( អែលឌើរ និង សង្ឃ សូមមើល ខ ៣៩ និង ៤៨ ) ។ តើតំណែងណាមួយ ដែលមានសិទ្ធិអំណាចដើម្បីពន្យល់ ដាស់តឿន និងបង្រៀន ? ( អែលឌើរ សង្ឃ គ្រូ និង ឌីកុន សូមមើល ខ ៤២, ៤៦ និង ៥៩ ) ។

- តើសេចក្ដីពិតណាខ្លះ ដែលយើងអាចរៀនអំពីតំណែងបព្វជិតភាព តាមរយៈការប្រៀបធៀប និងការដាក់ភាពផ្ទុយគ្នានៃកាតព្វកិច្ចរបស់ពួកគេ ?

សិស្សអាចនឹងប្រាប់គោលការណ៍ផ្សេងៗ ប៉ុន្ដែត្រូវប្រាកដថា អ្នកគូសបញ្ជាក់ដូចខាងក្រោម ៖

**នៅពេលកូនប្រុសទាំងឡាយរបស់ព្រះវរបិតាសួគ៌ ទទួលតំណែងនៃបព្វជិតភាពកាន់តែខ្ពស់ នោះពួកគេទទួលបាននូវទំនួលខុសត្រូវ និងឱកាសកាន់តែច្រើនដើម្បីបម្រើអ្នកដទៃ ។**

**នៅពេលអ្នកកាន់បព្វជិតភាពម្នាក់ត្រូវបានតែងតាំងតំណែងនៃបព្វជិតភាពបន្ថែម នោះគាត់រក្សានូវតំណែងដែលទាបជាង និងទំនួលខុសត្រូវដែលជាប់ទាក់ទងរបស់ពួកគេដដែល ។**

**អ្នកកាន់បព្វជិតភាពទាំងអស់ មានទំនួលខុសត្រូវដើម្បីធ្វើពិធីបរិសុទ្ធ និងមើលការខុសត្រូវទៅលើសមាជិកនៃសាសនាចក្រ ហើយបម្រើដល់ពួកគេ ។**

បន្ទាប់ពីអ្នកជួយដល់សិស្សឲ្យប្រាប់សេចក្ដីពិតចុងក្រោយនៅលើបញ្ជី សូមសរសេរវានៅលើក្ដារខៀន ក្រោមបញ្ជីទំនួលខុសត្រូវនៃបព្វជិតភាព ។ អ្នកអាចនឹងចាំបាច់ត្រូវចង្អុលបង្ហាញថា ពាក្យ *បម្រើ* មានន័យថា ផ្ដល់ការបម្រើ ។

ដើម្បីជួយសិស្សយល់អំពីទំនួលខុសត្រូវរបស់អ្នកកាន់បព្វជិតភាព សូមនាំចំណាប់អារម្មណ៍របស់ពួកគេផ្ដោតទៅលើបញ្ជីនៅលើក្ដារខៀន ហើយសួរសំណួរដូចខាងក្រោម ៖

- តើវិធីមួយចំនួនណាខ្លះ ដែលអ្នកកាន់បព្វជិតភាពអើរ៉ុន អាច « មើលការខុសត្រូវលើព្រះវិហារ » និង « នៅជាមួយ ហើយពង្រឹងដល់ពួកគេ » ? ( ឧទាហរណ៍ អាចរួមមាន ការបង្រៀនតាមផ្ទះ ការមើលថែដល់អ្នកក្រីក្រ និងអ្នកខ្វះខាត ការមើលថែសាលាប្រជុំ និងបរិវេណ និងការបំពេញតាមការចាត់តាំងផ្សេងទៀតមកពីប៊ីស្សព និងកូរ៉ុមអែលឌើរ ) ។

- តើវិធីមួយចំនួនណាខ្លះ ដែលអ្នកកាន់បព្វជិតភាពអើរ៉ុនអាច « អញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ » បាន ?

នៅពេលសិស្សក្នុងថ្នាក់ពិភាក្សាអំពីសំណួរនេះ អ្នកអាចនឹងចង់សុំឲ្យសិស្សម្នាក់អាននូវការប្រឹក្សាដូចខាងក្រោម ៖

> « ប្រសិនបើអ្នកជាអ្នកកាន់បព្វជិតភាព សូមចងចាំថា បព្វជិតភាពគួរជាផ្នែកមួយរបស់អ្នកគ្រប់ពេល និងគ្រប់កាលៈទេសៈទាំងអស់ ។ វាមិនដូចជាអាវពាក់ដណ្ដប់ ដែលអ្នកអាចពាក់ ហើយដោះចេញតាមចិត្តបាននោះទេ ។ រាល់ការតែងតាំងណាមួយចំពោះតំណែងបព្វជិតភាព ជាការហៅឲ្យបម្រើមួយដើម្បីបម្រើពេញមួយជីវិតជាមួយនឹងសេចក្ដីសន្យាថា ព្រះអម្ចាស់នឹងបញ្ជាក់ថា អ្នកមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការរបស់ទ្រង់ស្របតាមភាពស្មោះត្រង់របស់អ្នក ។
>
> « អ្នកត្រូវមានភាពសក្ដិសមដើម្បីទទួល និងអនុវត្តអំណាចបព្វជិតភាព ។ ពាក្យសម្ដីដែលអ្នកនិយាយ និងឥរិយាបទរាល់ថ្ងៃរបស់អ្នក ជះឥទ្ធិពលដល់សមត្ថភាពរបស់អ្នកដើម្បីបម្រើ ។ ឥរិយាបទរបស់អ្នកជាសាធារណៈ ត្រូវតែមានកម្រិតខ្ពស់ ។ ឥរិយាបទរបស់អ្នកនៅទីកំបាំងក៏រឹតតែសំខាន់ខ្លាំងផងដែរ » ( *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* ឆ្នាំ ២០០៤ ], ទំព័រ ១២៧ ) ។

សូមសរសេរនៅលើក្ដារខៀននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ រ៉ូឆាដ ជី ស្កុត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយអញ្ជើញសិស្សឲ្យអានវាឮៗ ។ ( សេចក្ដីថ្លែងការនេះ គឺមាននៅក្នុង «Honor the Priesthood and Use It Well, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨, ៤៦ ) ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យសរសេរវានៅគែមទំព័រព្រះគម្ពីររបស់ពួកគេនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ឬ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

> *« គោលបំណងនៃសិទ្ធិអំណាចបព្វជិតភាព គឺត្រូវផ្ដល់ឲ្យ បម្រើ លើកតម្កើង បំផុសគំនិត »*
> *( អែលឌើរ រ៉ូឆាដ ជី ស្កុត ) ។*

សូមឲ្យសិស្សប្រាប់អំពីពេលវេលាដែលពួកគេបានមើលឃើញអ្នកកាន់បព្វជិតភាពផ្ដល់ឲ្យ បម្រើ លើកតម្កើង និងបំផុសគំនិត ។ អ្នកអាចនឹងបន្ថែមនូវការសង្កេតឃើញផ្ទាល់ខ្លួនរបស់អ្នកផងដែរ ។

ជាចំណែកនៃការពិភាក្សានេះ សូមចង្អុលបង្ហាញថា ខណៈដែលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ គឺនិយាយអំពីអ្នកកាន់បព្វជិតភាព នោះសមាជិកទាំងអស់នៃសាសនាចក្រ មានទំនួលខុសត្រូវ និងឯកសិទ្ធិដើម្បីបម្រើដល់អ្នកដទៃ ។ យុវនារីម្នាក់មានឱកាសជាច្រើនដើម្បីបម្រើ ។ មនុស្សមួយចំនួនអាចជ្រើសរើសបម្រើបេសកកម្ម ហើយថ្ងៃណាមួយពួកគេនឹងមានឱកាសធ្វើជាសមាជិកក្នុងសមាគមសង្គ្រោះ « ធ្វើ [ការ] ព្រមគ្នាជាមួយនឹងបុរសដែលកាន់បព្វជិតភាព ដើម្បីបង្កើនសេចក្ដីជំនឿ និងសេចក្ដីសុចរិតផ្ទាល់ខ្លួន ពង្រឹងដល់ក្រុមគ្រួសារ និងគេហដ្ឋាន ហើយស្វែងរក និងជួយដល់អ្នកទាំងឡាយដែលខ្វះខាត » ( *Daughters in My Kingdom: The History and Work of Relief Society* ឆ្នាំ២០១១ [, ទំព័រ ៧ ) ។

សូមផ្ដល់ឱកាសដល់សិស្សពីរបីនាទី ដើម្បីសរសេរអំពីអ្វីដែលពួកគេបានរៀន ចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៥៩ ។ សូមលើកទឹកចិត្តយុវជនម្នាក់ឲ្យគិត ហើយសរសេរគោលដៅមួយ ដែលនឹងជួយពួកគេមើលថែ និងពង្រឹងដល់សមាជិកនៃសាសនាចក្រដោយស្មោះត្រង់ ។ ការណ៍នេះអាចនឹងត្រូវធ្វើឡើង ជាផ្នែកនៃកិច្ចខិតខំរបស់ពួកគេក្នុងការធ្វើសៀវភៅ កាតព្វកិច្ចចំពោះព្រះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦០–៦៧

*សេចក្ដីណែនាំអំពីការតែងតាំងបព្វជិតភាព ត្រូវបានផ្ដល់ឲ្យ*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦០ ឮៗ ហើយសុំឲ្យសមាជិកក្នុងថ្នាក់រកមើលតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ ពេលនរណាម្នាក់ ត្រូវបានតែងតាំងនូវតំណែងបព្វជិតភាពមួយ ។

សូមឲ្យសិស្សលើកដៃឡើង បើពួកគេបានធ្វើជាសាក្សីក្នុងការតែងតាំងបព្វជិតភាពមួយ ឬត្រូវបានតែងតាំងនូវតំណែងមួយក្នុងបព្វជិតភាព ។ សូមអញ្ជើញមនុស្សមួយចំនួនឲ្យលើកដៃរបស់ពួកគេដើម្បីចែកចាយបទពិសោធន៍របស់ពួកគេ និងអារម្មណ៍ដែលពួកគេមាន អំឡុងពេលតែងតាំង ។ អ្នកក៏អាចនឹងសួរសំណួរដូចខាងក្រោម ៖

- តើព្រះវិញ្ញាណបរិសុទ្ធមានចំណែកនៃការតែងតាំងយ៉ាងដូចម្ដេច ?

សូមសរសេរនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ *អ្នកកាន់បព្វជិតភាព ត្រូវការព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនៅជាមួយពួកគេ ពេលពួកគេបំពេញកាតព្វកិច្ចរបស់ពួកគេ ។*

ដើម្បីជួយដល់យុវជនឲ្យគិតអំពីភាពសក្ដិសមរបស់ពួកគេ នៅពេលធ្វើពិធីបរិសុទ្ធនៃបព្វជិតភាព សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ប៊យដ៍ ឃេ ផាកកឺ នៃពួកសាវកដប់ពីរនាក់ ៖



« សិទ្ធិអំណាចរបស់អ្នក បានមកតាមរយៈការតែងតាំងរបស់អ្នក អំណាចរបស់អ្នក បានមកតាមរយៈការគោរពប្រតិបត្តិ និង ភាពសក្ដិសម ។ . . .

« អំណាចនៅក្នុងបព្វជិតភាព កើតមកពីការអនុវត្តកាតព្វកិច្ចរបស់អ្នក នៅក្នុងកិច្ចការសាមញ្ញទាំងឡាយដូចជា ៖ ការចូលរួមការប្រជុំនានា ការទទួលយកការចាត់តាំង ការអានព្រះគម្ពីរ ការគោរពពាក្យនៃប្រាជ្ញាវាងវៃ » ( «The Aaronic Priesthood, » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨១, ៣២–៣៣ ) ។

សូមអញ្ជើញយុវជនឲ្យពិចារណាប្រកបដោយការអធិស្ឋាននូវអ្វីដែលព្រះអម្ចាស់នឹងឲ្យពួកគេធ្វើ ដើម្បីអញ្ជើញអំណាចនៃព្រះវិញ្ញាណបរិសុទ្ធឲ្យមាននៅជាមួយពួកគេ ពេលពួកគេធ្វើតាមកាតព្វកិច្ចបព្វជិតភាពនាពេលបច្ចុប្បន្ន ឬនាពេលអនាគតរបស់ពួកគេ ។ សូមគូសបញ្ជាក់ថា យុវនារី ក៏មានទំនួលខុសត្រូវសំខាន់ផងដែរក្នុងសាសនាចក្រ ។ សូមអញ្ជើញពួកគេឲ្យពិចារណានូវអ្វីដែលព្រះអម្ចាស់ នឹងឲ្យពួកគេធ្វើ ដើម្បីអញ្ជើញឲ្យមានអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ពេលពួកគេបំពេញតួនាទីទាំងឡាយនោះ ។

អ្នកអាចនឹងពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦១–៦៣ ប្រាប់អំពីគោលបំណងមួយចំនួននៃការធ្វើសន្និសីទសាសនាចក្រ ដូចជាការដឹកនាំកិច្ចការសាសនាចក្រដោយបើកចំហរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦៥ ឮៗ ។ សូមពន្យល់ថា នៅក្នុងខនេះ ពាក្យ *គាំទ្រ* សំដៅទៅលើការគាំទ្រនរណាម្នាក់ឲ្យទទួលតំណែងមួយក្នុងបព្វជិតភាព ពីមុនពេលត្រូវបានតែងតាំងក្នុងតំណែងនោះ ។ សូមឲ្យយុវជននៅក្នុងថ្នាក់នឹកគិតពីគ្រាមុន ដែលពួកគេត្រូវបានគាំទ្រដោយសមាជិកនៃវួដ ឬសាខារបស់ពួកគេ ដើម្បីត្រូវបានតែងតាំងក្នុងតំណែងបព្វជិតភាពមួយ ។

*ការចែកចាយគំនិត និង អារម្មណ៍*

នៅពេលយុវជនបង្ហាញគំនិត និង អារម្មណ៍របស់ពួកគេអំពីគោលការណ៍នៃដំណឹងល្អ នោះពួកគេអញ្ជើញព្រះវិញ្ញាណបរិសុទ្ធ ជួយដល់ការយល់ដឹងរបស់ពួកគេបានជ្រៅជ្រះ និង ពង្រឹងនូវទីបន្ទាល់របស់ពួកគេ ។ អ្នកក៏អាចជួយរឿងនេះឲ្យកើតមានឡើងដោយការអញ្ជើញសិស្សឲ្យចែកចាយនូវបទពិសោធន៍ដែលទាក់ទង ពេលពួកគេមានអារម្មណ៍ព្រះវិញ្ញាណ ឬពេលព្រះអម្ចាស់បានប្រទានពរដល់ពួកគេ ។ អែលឌើរ រីឆាដ ជី ស្កុត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « កិច្ចខិតខំដើម្បីចែកចាយចំណេះដឹងគឺជាញឹកញាប់ ត្រូវបានផ្ដល់ផ្ទាន់ជាការចេះដឹងកាន់តែច្រើន ដូចជាពន្លឺបន្ថែមដែលហូរចូលទៅក្នុងគំនិត និងដួងចិត្តរបស់អ្នក ( សូមមើលគ. និង ស. ៨:២–៣ Acquiring Spiritual Knowledge, »*Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, ទំព័រ ៨៨ ) ។

- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកបានឃើញថា សមាជិកនៃវួដ ( ឬសាខា) របស់អ្នក បានគាំទ្រដល់ការតែងតាំងរបស់អ្នក ? តើការចងចាំពីការលើកដៃគាំទ្ររបស់ពួកគេ អាចជួយអ្នកនៅក្នុងការបម្រើបព្វជិតភាពរបស់អ្នកយ៉ាងដូចម្ដេច ? ( ចម្លើយអាចរួមមានដូចជា ពួកគេនឹងមានអារម្មណ៍ល្អចំពោះសមាជិកក្នុងវួដ ដើម្បីធ្វើការបម្រើក្នុងវួដ និងថាពួកគេនឹងមានអារម្មណ៍គាំទ្រពីសមាជិកក្នុងវួដ ) ។

អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីមូលហេតុដែលពួកគេ មានអំណរគុណចំពោះសិទ្ធិអំណាចបព្វជិតភាព ។ សូមចែកចាយទីបន្ទាល់របស់អ្នក អំពីសេចក្ដីពិតទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀននេះផងដែរ ។

មេរៀនទី ២៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៦៨–៨៤

## បុព្វកថា

នៅក្នុងផ្នែកនៃកណ្ឌទី ២០ នេះ ព្រះអម្ចាស់ បានប្រទានការណែនាំអំពីការគ្រប់គ្រងសាសនាចក្ររបស់ទ្រង់ រួមមានទាំងការពន្យល់អំពីតម្រូវការសម្រាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ហើយនឹងវិធីត្រឹមត្រូវដើម្បីបម្រើពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ និង ពិធីសាក្រាម៉ង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៧៤

*ព្រះអម្ចាស់ បើកសម្ដែងពីតម្រូវការសម្រាប់បុគ្គលម្នាក់ៗមាន មុនពេល និងក្រោយពេលពិធីបុណ្យជ្រមុជទឹក ។*

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីដែលពួកគេអាចនិយាយនៅក្នុងស្ថានភាពខាងក្រោមនេះ ៖

មិត្តម្នាក់ដែលនៅក្នុងព្រះវិហារផ្សេង ទទួលបានទីបន្ទាល់មួយអំពីដំណឹងល្អដែលបានស្ដារឡើងវិញ ។ នាងបានសួរមកកាន់អ្នកថា « តើខ្ញុំចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីខ្ញុំអាចទទួលបានបុណ្យជ្រមុជទឹក ហើយក្លាយជាសមាជិកនៃសាសនាចក្ររបស់អ្នក ? »

សូមអញ្ជើញសិស្សពួកគេឲ្យសរសេរចម្លើយរបស់ពួកគេចំពោះសំណួរនេះចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ រួចអញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ រកមើលតម្រូវការសម្រាប់អ្នកទាំងឡាយណាដែលមានបំណងប្រាថ្នាដើម្បីបានជ្រមុជទឹក ។ អ្នកអាចឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំនូវតម្រូវការនីមួយៗដែលពួកគេបានរកឃើញ ។ ដើម្បីជួយសិស្សយល់កាន់តែល្អប្រសើរអំពីអត្ថន័យនៃខគម្ពីរនេះ អ្នកអាចនឹងចង់ពន្យល់ថា មនុស្សដែលមាន « ចិត្តសង្រេង និងវិញ្ញាណទន់ទាប » គឺរាបសា ហើយទទួលយកព្រះឆន្ទៈរបស់ព្រះ ។ ពួកគេមានអារម្មណ៍សោកស្ដាយយ៉ាងខ្លាំងចំពោះអំពើបាប និង មានបំណងចង់ប្រែចិត្តដោយអស់ពីចិត្ត ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖*មុនពេលមនុស្សអាចទទួលបុណ្យជ្រមុជទឹក នោះពួកគេត្រូវតែ. . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យមកកាន់ក្ដារខៀន ហើយធ្វើជាស្មៀន ។ សូមសួរសិស្សក្នុងថ្នាក់នូវសំណួរខាងក្រោម ៖

- យោងទៅតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ តើមនុស្សម្នាក់ត្រូវបង្ហាញថាធ្វើអ្វីខ្លះ មុនពេលពួកគេអាចទទួលបានជ្រមុជទឹក ? ( នៅពេលសិស្សឆ្លើយសំណួរនេះ សូមឲ្យអ្នកសរសេរបំពេញនូវសេចក្ដីថ្លែងការនៅលើក្ដារខៀន ។ អ្នកសរសេរអាចសរសេរនូវអ្វីដូចនេះថា ៖ **មុនពេលមនុស្សអាចទទួលបុណ្យជ្រមុជទឹក នោះពួកគេត្រូវតែបន្ទាបខ្លួន ប្រែចិត្ត ស្ម័គ្រចិត្តដើម្បីលើកដាក់លើខ្លួនគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយតាំងចិត្តដើម្បីបម្រើទ្រង់រហូតដល់ទីបំផុត**) ។
- ហេតុអ្វីក៏អ្នកគិតថាមនុស្សម្នាក់ចាំបាច់ត្រូវបំពេញតាមតម្រូវការទាំងនេះ មុនពេលទទួលបុណ្យជ្រមុជទឹក ?

សូមចង្អុលបង្ហាញថា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ ក៏មានចែងអំពីសេចក្ដីសញ្ញាដែលយើងបានធ្វើ នៅពេលយើងទទួលបុណ្យជ្រមុជទឹកផងដែរ ។ សូមអញ្ជើញសិស្សឲ្យពិចារណានូវអ្វីដែលពួកគេកំពុងធ្វើនាពេលនេះ ដើម្បីរស់នៅស្របតាមសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យស្រមៃថា មិត្តដដែលនោះ បានសួរអំពីអ្វីដែលត្រូវធ្វើ នៅពេលនរណាម្នាក់បានទទួលបុណ្យជ្រមុជទឹក ។ បន្ទាប់ពីសិស្សពីរបីនាក់បានឆ្លើយតបហើយ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧២–៧៤ ឮៗ ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំលក្ខណៈនៃពិធីបុណ្យជ្រមុជទឹកដែលបានពិពណ៌នាដោយព្រះអម្ចាស់ ។

- យោងតាមខ ៧២–៧៤តើព្រះអម្ចាស់សព្វព្រះទ័យឲ្យពិធីបុណ្យជ្រមុជទឹកត្រូវបានធ្វើឡើងតាមរបៀបណា ? ( ចម្លើយរបស់សិស្ស គួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖**ពិធីបុណ្យជ្រមុជទឹក ត្រូវតែធ្វើឡើងដោយការជ្រមុជ និងបានធ្វើឡើងដោយអ្នកកាន់សិទ្ធិអំណាចត្រឹមត្រូវម្នាក់** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន នៅខាងក្រោមគោលការណ៍ដែលបានប្រាប់ពីមុន ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ២០:៦៨–៦៩ ដោយស្ងាត់ស្ងៀម ដោយប្រាប់អំពីការរំពឹងទុករបស់ព្រះអម្ចាស់ចំពោះយើងម្នាក់ៗ បន្ទាប់ពីយើងបានទទួលបុណ្យជ្រមុជទឹក ។ អ្នកអាចស្នើឲ្យសិស្សគូសចំណាំការរំពឹងទុកទាំងនេះ ។

- តើរឿងមួយចំនួនណាខ្លះ ដែលអ្នកបានរកឃើញថា ព្រះអម្ចាស់រំពឹងទុកពីយើង បន្ទាប់ពីយើងបានទទួលបុណ្យជ្រមុជទឹក ?

*កំណត់ចំណាំ* ៖ សិស្សអាចនឹងសួរអំពីតម្រូវការនៅក្នុង ខ ៦៨ ដែលសមាជិកបានទទួលបុណ្យជ្រមុជទឹកថ្មីៗ ត្រូវតែបានបង្រៀនដោយអែលឌើរ មុនពេលពួកគេអាចត្រូវបានទទួលពិធីបញ្ជាក់ ។ សូមពន្យល់ថា ការអនុវត្តបច្ចុប្បន្នក្នុងការបង្រៀនមេរៀនអ្នកផ្សាយសាសនាដល់អ្នករៀន មុនពេលពិធីបុណ្យជ្រមុជទឹក អនុញ្ញាតឲ្យមនុស្សត្រូវបានបញ្ជាក់ និងទទួលព្រះវិញ្ញាណបរិសុទ្ធភ្លាមបន្ទាប់ពីពួកគេបានទទួលបុណ្យជ្រមុជទឹក ។

- ដកស្រង់មកពី ខ ៦៩ តើអ្នករៀនអ្វីខ្លះ អំពីរបៀបដែលយើងបង្ហាញដល់ព្រះអម្ចាស់ អំពីភាពសក្តិសមរបស់យើង បន្ទាប់ពីយើងទទួលបុណ្យជ្រមុជទឹក ? ( ចម្លើយរបស់សិស្សអាចនឹងមានផ្សេងៗ ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក យើងបង្ហាញដល់ព្រះអម្ចាស់នូវភាពសក្តិសមរបស់យើង តាមរយៈការដើរ និងវាចាដ៏សុចរិតរបស់យើង** ។ សូមសរសេរគោលសេចក្តីពិតនៅលើក្ដារខៀន នៅខាងក្រោមគោលការណ៍ពីរដែលប្រាប់ពីមុនមកហើយនោះ ។

- តើអ្នកគិតថាវាមានន័យយ៉ាងណាដើម្បី « បង្ហាញពី. . . ការដើរ និងវាចាដ៏សុចរិត » នោះ ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា មនុស្សម្នាក់ បង្ហាញ ឬសម្ដែងចេញ « នូវដំណើរ និងវាចាដ៏សុចរិត » តាមរយៈសកម្មភាព អាកប្បកិរិយា និងការនិយាយ ដែលសុខដុមនឹងព្រះ ) ។

ផ្អែកទៅលើតម្រូវការរបស់សិស្សអ្នក សូមពិចារណាដើម្បីសុំឲ្យពួកគេបើកទៅវគ្គមួយនៃកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន*សម្រាប់ការប្រឹក្សាកាន់តែជាក់លាក់បន្ថែមទៀត អំពីរបៀបដែលយុវវ័យម្នាក់ អាចបង្ហាញនូវ « ដំណើរ និងវាចាដ៏សុចរិត » ។

- តើនៅពេលណាដែលអ្នកបានមើលឃើញអ្នកដទៃ « បង្ហាញនូវ. . .ការដើរ និងវាចាដ៏សុចរិត » ? តើអ្នកគិតថាសកម្មភាព និងអាកប្បកិរិយារបស់ពួកគេ មានឥទ្ធិពលដល់អ្នកដទៃដែលនៅជុំវិញខ្លួនពួកគេយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សអនុវត្តគោលការណ៍នេះ សូមលើកទឹកចិត្តពួកគេឲ្យពិចារណាអំពីរបៀបដែលពួកគេអាចកាន់តែបង្ហាញដោយពេញលេញនូវ « ដំណើរ និងវាចាដ៏សុចរិត » នៅក្នុងពីរបីថ្ងៃខាងមុខ ។ បើសិស្សមានអារម្មណ៍ល្អក្នុងការចែកចាយអំពីរបៀបដែលពួកគេដាក់ផែនការធ្វើដូចនេះ សូមអញ្ជើញពួកគេឲ្យចែកចាយគំនិតរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។ អ្នកក៏អាចចង់ធ្វើដូចគ្នានេះ ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យទាំងឡាយ ដែលកើតមាន នៅពេលយើងគោរពតាមសេចក្តីសញ្ញាបុណ្យជ្រមុជទឹករបស់យើង ។

> *សូមសម្របមេរៀននេះទៅតាមតម្រូវការរបស់សិស្ស*
>
> នៅពេលអ្នកអធិស្ឋានសុំការណែនាំដើម្បីជួយដល់សិស្សរបស់អ្នក ព្រះអម្ចាស់អាចបំផុសគំនិតអ្នកឲ្យសម្របមេរៀនដើម្បីបំពេញតាមតម្រូវការរបស់ពួកគេ ។ ឧទាហរណ៍ នៅក្នុងការពិភាក្សានេះអំពីការបង្ហាញនូវ « ការដើរ និងវាចាដ៏សុចរិត » សូមរកមើលវិធីដើម្បីសម្របមេរៀន ដោយផ្អែកទៅលើតម្រូវការរបស់សិស្ស និងការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ២០:៧៥–៧៩

### *ព្រះអម្ចាស់ ប្រទានការណែនាំស្ដីអំពីការបម្រើពិធីសាក្រាម៉ង់*

សូមអញ្ជើញសិស្សមួយគូឲ្យឡើងមកខាងមុខថ្នាក់ ។ សូមឲ្យសិស្សម្នាក់តំណាងឲ្យមិត្តម្នាក់ ដែលមកចូលរួមការប្រជុំសាក្រាម៉ង់ជាលើកទីមួយ ហើយចង់ដឹងពីមូលហេតុដែលគេចែកនំប៉័ង និងទឹកដល់ក្រុមជំនុំ ។ សូមសិស្សម្នាក់ទៀតឲ្យពន្យល់អំពីពិធីបរិសុទ្ធនៃសាក្រាម៉ង់ដល់មិត្តនោះ ។ បន្ទាប់ពីសិស្សបានចែកចាយគំនិតរបស់ពួកគេហើយ សូមលើកទឹកចិត្តសិស្សក្នុងថ្នាក់ឲ្យរកមើលបទគម្ពីរដែលគាំទ្រនូវអ្វីដែលសិស្សបានពន្យល់ ក៏ដូចជាគំនិតបន្ថែមផ្សេងទៀត ដែលពួកគេអាចប្រើដើម្បីពន្យល់អំពីពិធីសាក្រាម៉ង់ នៅពេលពួកគេសិក្សាខគម្ពីរជាច្រើនក្រោយមកទៀត ។

សូមសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ២០:៧៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ។ ( អ្នកអាចនឹងចង់ចង្អុលបង្ហាញថា សព្វថ្ងៃនេះ យើងប្រើទឹកជំនួសឲ្យស្រានៅក្នុងពិធីសាក្រាម៉ង់ ។ សូមមើល គ. និង ស. ២៧:១–២) ។

- ហេតុអ្វីក៏អ្នកគិតថា យើងត្រូវបានណែនាំឲ្យទទួលទានសាក្រាម៉ង់ជាមួយគ្នាញឹកញាប់ដូច្នេះ ?

ជាចំណែកនៃការពិភាក្សានេះ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ មែលវិន ជេ បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ( អ្នកអាចនឹងចង់ពន្យល់ថា នៅពេលអែលឌើរ បាឡឺដ មានប្រសាសន៍អំពី « ការមាន| មុខ | នៅតុសាក្រាម៉ង់ » គឺលោកចង់សំដៅទៅលើការអនុវត្តនៃការទទួលទានសាក្រាម៉ង់ ) ។



« រឿងមួយដែលនឹងផ្ដល់សុវត្ថិភាពដល់បុរស និងស្ត្រីគ្រប់រូប នោះគឺជាការមានមុខនៅតុសាក្រាម៉ង់ជារៀងរាល់ថ្ងៃបរិសុទ្ធ ។ យើងនឹងមិននៅឆ្ងាយពីព្រះមួយសប្ដាហ៍—គឺមិននៅឆ្ងាយពេកឡើយ បើមិនតាមរយៈដំណើរការនៃការសង្កេតមើលខ្លួនឯងទេ នោះយើងពុំអាចនឹងកំហុសឆ្គងនានា ដែលយើងបានប្រព្រឹត្តឡើយ ។. . . ផ្លូវទៅកាន់តុសាក្រាម៉ង់ គឺជាផ្លូវនៃសុវត្ថិភាពសម្រាប់ពួកបរិសុទ្ធថ្ងៃចុងក្រោយ » ( នៅក្នុង Bryant S. Hinckley *Sermons and Missionary Services of Melvin Joseph Ballard* [ ឆ្នាំ ១៩៤៩ ], ទំព័រ ១៥១ ) ។

សូមសរសេរក្បាលរឿង ដូចខាងក្រោម នៅលើក្ដារខៀន ៖

*អ្វីដែលយើងសន្យា អ្វីដែលព្រះអម្ចាស់សន្យា*

សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧៧–៧៩ រកមើលអ្វីដែលយើងសន្យា នៅពេលយើងទទួលទានសាក្រាម៉ង់ ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ទៀត ឲ្យអានខដូចគ្នា រកមើលអ្វីដែលព្រះអម្ចាស់សន្យា ។ បន្ទាប់ពីសិស្សមានពេលសរសេរគ្រប់គ្រាន់ ដើម្បីសិក្សាវគ្គគម្ពីរហើយ សូមពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ក្រោមក្បាលរឿងត្រឹមត្រូវ ។ ពេលសិស្សបានបញ្ចប់បញ្ជីទាំងនេះហើយ នោះពួកគេនឹងប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖

**នៅពេលយើងទទួលទានសាក្រាម៉ង់ នោះយើងធ្វើជាសាក្សីថា យើងនឹងមានឆន្ទៈលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ថាយើងនឹងចងចាំទ្រង់ជានិច្ច ហើយថាយើងនឹងរក្សាបទបញ្ញត្តិរបស់ទ្រង់ ។**

**នៅពេលយើងស្មោះត្រង់ចំពោះការសន្យាទាំងឡាយ ដែលយើងបានធ្វើអំឡុងពេលពិធីសាក្រាម៉ង់ នោះយើងអាចមានព្រះវិញ្ញាណគង់នៅជាមួយយើងជានិច្ច ។**

អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំសេចក្ដីពិតទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- សូមប្រៀបធៀបបញ្ជីនៅលើក្ដារខៀនជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ តើអ្នកឃើញមានភាពស្រដៀងគ្នាអ្វីខ្លះ នៅក្នុងការសន្យាដែលបានធ្វើឡើងអំឡុងពេលសាក្រាម៉ង់ និងសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ?

សូមពន្យល់ថា នៅពេលយើងទទួលទានសាក្រាម៉ង់ នោះយើងរំឭកសេចក្ដីសញ្ញា ដែលយើងធ្វើ ពេលយើងត្រូវបានជ្រមុជទឹក និងបញ្ជាក់ ។

- តើយើង អាចបង្ហាញពីឆន្ទៈរបស់យើងដើម្បីលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ? ( ចម្លើយអាចរួមមាន ការឈរសម្រាប់អ្វីដែលត្រូវ ការប្រាប់អ្នកដទៃថា យើងគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ការចែកចាយជំនឿរបស់យើងទៅលើទ្រង់ និងការចូលរួមក្នុងកិច្ចការរបស់ទ្រង់ ) ។
- តើរឿងមួយចំនួនណាខ្លះ ដែលយើងអាចធ្វើដើម្បីចងចាំព្រះអង្គសង្គ្រោះជានិច្ច ?
- តើការទទួលទានសាក្រាម៉ង់ ជួយយើង « បង្ហាញនូវ. . . ការដើរ និងវាចាដ៏សុចរិត » យ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់អំពីតម្លៃនៃការមានព្រះវិញ្ញាណគង់នៅជាមួយយើង សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមមកពីកូនសៀវភៅ*ពិតចំពោះសេចក្ដីជំនឿ* ។ សូមសិស្សក្នុងថ្នាក់ស្ដាប់នូវពរជ័យទាំងឡាយ អំពីការរំឭកសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់យើង ។

« អ្នកបានទទួលពរជ័យដ៏មហិមា ពេលអ្នករក្សាសេចក្ដីសញ្ញាបុណ្យជ្រមុជទឹក ។ នៅពេលអ្នករំឭកវា នោះព្រះអម្ចាស់រំឭកការសន្យាដែលបានធ្វើដើម្បីផ្ដាច់បាបរបស់អ្នក ។ បានស្អាតពីអំពើបាប អ្នកអាច ‹ មានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹង [ អ្នក ] ជាដរាប › ( គ. និង ស. ២០:៧៧ ) ។ ការមានភាពជាដៃគូនៃព្រះវិញ្ញាណដ៏ខ្ជាប់ខ្ជួនគឺជាអំណោយដ៏ធំបំផុតមួយ ដែលអ្នកអាចទទួលបានក្នុងជីវិតរមែងស្លាប់ ។ ព្រះវិញ្ញាណនឹងដឹកនាំអ្នកនៅលើផ្លូវនៃសេចក្ដីសុចរិត និងភាពសុខសាន្ត ដែលដឹកនាំអ្នកទៅកាន់ជីវិតដ៏នៅអស់កល្ប ជាមួយនឹងព្រះវរបិតាសួគ៌របស់អ្នក និងព្រះយេស៊ូវគ្រីស្ទ » ( *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ], ទំព័រ ១៤៨ ) ។

សូមអញ្ជើញសិស្សឲ្យពិចារណា ( ឬសរសេរ ) អំពីរបៀបដែលពួកគេនឹងរៀបចំខ្លួនដើម្បីទទួលទានសាក្រាម៉ង់ក្នុងសប្ដាហ៍នេះ ។ អ្នកអាចនឹងចង់ចែកចាយទីបន្ទាល់របស់អ្នកអំពីតម្លៃនៃការរំឭកសេចក្ដីសញ្ញាបុណ្យជ្រមុជទឹកប្រចាំសប្ដាហ៍របស់យើង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៨០–៨៤

*ព្រះអម្ចាស់ណែនាំដល់ថ្នាក់ដឹកនាំសាសនាចក្រឲ្យរក្សាកំណត់ត្រាសមាជិកភាពសាសនាចក្រត្រឹមត្រូវ*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៨១–៨៤ ដោយការជូនដំណឹងដល់សិស្សថា អ្នកកាន់បព្វជិតភាពនៅក្នុងសាសនាចក្រជំនាន់មុន ត្រូវបានណែនាំឲ្យកត់ត្រាឈ្មោះរបស់មនុស្សដែលបានចូលរួមក្នុងសាសនាចក្រ ។ ពួកគេរក្សាទុកឈ្មោះទាំងឡាយនៅក្នុងសៀវភៅមួយ ។ ឈ្មោះរបស់អ្នកទាំងឡាយដែលបានចាកចេញពីសាសនាចក្រ ត្រូវបានដកចេញពីសៀវភៅនោះ ។ បន្ថែមពីលើនោះ សមាជិកនៃសាសនាចក្រ ដែលបានផ្លាស់ពីទីតាំងមួយទៅទីតាំងមួយទៀត គឺត្រូវយកវិញ្ញាបនបត្រនៃសមាជិកភាពរបស់ពួកគេទៅជាមួយ ដើម្បីប្រគល់ទៅឲ្យអ្នកដឹកនាំបព្វជិតភាពថ្មីរបស់ពួកគេ ។ នៅជំនាន់របស់យើង អ្នកដឹកនាំសាសនាចក្រ បន្តរក្សាកំណត់ត្រាសមាជិកភាពត្រឹមត្រូវ ប៉ុន្តែវិធីសាស្ត្រនៃការធ្វើវា គឺមានភាពងាយស្រួលច្រើន ។

អ្នកអាចបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀន ។

មេរៀនទី ២៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២១

## បុព្វកថា

នៅក្រោមការដឹកនាំរបស់ព្យាការី យ៉ូសែប ស្ម៊ីធ សាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានរៀបចំឡើងជាផ្លូវការនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ នៅផ្ទះរបស់ ពេត្រុស វិតមើរ ស៊ីញ៉័រ ក្នុងហ្វាយ៉េត រដ្ឋនូវយ៉ោក ។ មានមនុស្សជិត ៦០ នាក់បានមកចូលរួមការប្រជុំ ដែលមានការអធិស្ឋាន ការគាំទ្រ ការតែងតាំង ការបម្រើសាក្រាម៉ង់ និងពិធីបញ្ជាក់ ។ នៅក្នុងការប្រជុំនេះ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលឥឡូវ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២១ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រកាសអំពី ការហៅបម្រើ និង ទំនួលខុសត្រូវរបស់ យ៉ូសែប ស្ម៊ីធ ហើយបានណែនាំដល់សមាជិកសាសនាចក្រឲ្យស្ដាប់តាមពាក្យសម្ដីរបស់លោក ។

### *បង្រៀនដោយព្រះវិញ្ញាណ ហើយថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ*

សូមអ្នកខំឲ្យអស់ពីលទ្ធភាពដើម្បីបង្កើតបរិយាកាសមួយ ដែលសិស្សអាចត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ ។ វិធីដ៏មានអត្ថន័យបំផុតមួយ ដើម្បីបង្កើតបរិយាកាសមួយដូច្នេះគឺ ផ្ដោតឧទាហរណ៍ និងការពិភាក្សារបស់អ្នកទៅលើព្រះអង្គសង្គ្រោះ ថ្លែងទីបន្ទាល់អំពីទ្រង់ឲ្យញឹកញាប់ ហើយផ្ដល់ឱកាសឲ្យសិស្សថ្លែងទីបន្ទាល់អំពីទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:១–៣

*យ៉ូសែប ស្ម៊ីធ ត្រូវបានតាំងឲ្យធ្វើជាព្យាការី និងអ្នកមើលឆុតនៃសាសនាចក្រ*

សូមគិតសុំសិស្សក្នុងថ្នាក់ឲ្យច្រៀងបទ « យើងសូមអរគុណទ្រង់ចំពោះព្យាការី » ( *ទំនុកតម្កើង* លេខ ១៩ ) ជាផ្នែកនៃការប្រជុំធម្មនិដ្ឋានប្រចាំថ្ងៃ ។ នៅពេលអ្នកចាប់ផ្ដើមមេរៀន សូមប្រាប់អំពីទំនុកតម្កើងនេះ ហើយសួរសំណួរដូចខាងក្រោម ៖

- តើមូលហេតុមួយចំនួនអ្វីខ្លះ ដែលអ្នកមានអារម្មណ៍ថ្លែងអំណរគុណចំពោះព្យាការីម្នាក់ ?

សូមពន្យល់ដល់សិស្សថា នៅក្នុងការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២១ ពួកគេនឹងរៀនពីសេចក្ដីពិតដែលអាចបង្កើនការយល់ដឹងរបស់ពួកគេអំពីតួនាទីរបស់ពួកព្យាការី ។ ដើម្បីផ្ដល់ដល់សិស្សនូវបរិបទជាប្រវត្តិសាស្ត្រមួយចំនួនសម្រាប់វិវរណៈនេះ សូមសង្ខេបព័ត៌មានដែលបានផ្ដល់ឲ្យនៅក្នុងបុព្វកថាមេរៀននេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:១ ឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលតំណែង ដែលយ៉ូសែបស្ម៊ីធ នឹងត្រូវបានគេស្គាល់ ។ បន្ទាប់មកសូមអញ្ជើញសិស្សឲ្យរាយការណ៍នូវអ្វីដែលពួកគេរកឃើញ ។

- តើវាមានន័យយ៉ាងណា ដែលព្រះអម្ចាស់បានហៅយ៉ូសែប ស្ម៊ីធ ឲ្យធ្វើជាអ្នកមើលឆុតនោះ ?
- តើវាមានន័យយ៉ាងណា ដែលព្រះអម្ចាស់បានហៅយ៉ូសែប ស្ម៊ីធ ឲ្យធ្វើជាព្យាការីនោះ ?

ដើម្បីជួយសិស្សយល់នូវតំណែងទាំងនេះ និងទំនួលខុសត្រូវដែលមានក្នុងនោះ សូមអញ្ជើញសិស្សពីរនាក់ឲ្យអានការពិពណ៌នាអំពីអ្នកមើលឆុត និងព្យាការីម្នាក់ ដូចខាងក្រោមនេះឲ្យឮៗ ។ សូមឲ្យពួកគេអានសេចក្ដីថ្លែងការណ៍និមួយៗយឺតៗ ឈប់បន្តិចនៅពេលបញ្ចប់ប្រយោគនីមួយៗ ។ សូមសិស្សផ្សេងទៀតក្នុងថ្នាក់ឲ្យស្ដាប់មើលប្រយោគទាំងឡាយ ដែលមានអត្ថន័យដល់ពួកគេ ហើយត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុ ។



« អ្នកមើលឆុត គឺជាអ្នកដែលមើលឃើញដោយភ្នែកខាងវិញ្ញាណ ។ លោកដឹងពីអត្ថន័យនៃអ្វីដែលហាក់ដូចជា [ ស្រពិចស្រពិល ឬលាក់កំបាំង ] ចំពោះអ្នកដទៃ ហេតុដូច្នេះហើយលោកគឺជាអ្នកបកប្រែ និង អ្នកបញ្ជាក់ពីសេចក្ដីពិតដ៏អស់កល្បជានិច្ច ។ គាត់ព្យាករណ៍អនាគតកាលពីអតីតកាល និង បច្ចុប្បន្នកាល ។ ការណ៍នេះ គាត់ធ្វើដោយអំណាចនៃព្រះអម្ចាស់ដែលប្រតិបត្តិការតាមរយៈគាត់ដោយផ្ទាល់ ឬ មិនផ្ទាល់ជាមួយនឹងជំនួយនៃឧបករណ៍ដ៏ទេវភាពដូចជា យូរីម និង ធូមីម ។ និយាយរួមលោកគឺជាមនុស្សម្នាក់ដែលមើលឃើញ ដែលដើរនៅក្នុងពន្លឺរបស់ព្រះអម្ចាស់ ទាំងបើកភ្នែក »
( John A. Widtsoe, *Evidences and Reconciliations,* arr. G. Homer Durham, ៣ vols. in ១ [ ១៩៦០ ], ២៥៨ ) ។

ព្យាការី គឺជា « បុរសម្នាក់ដែលត្រូវបានហៅដោយព្រះ ដើម្បីនិយាយជំនួស ព្រះ ។ ក្នុងនាមជាសារទូតរបស់ព្រះ ព្យាការីម្នាក់ ទទួលបទបញ្ញត្តិ ព្យាករ ហើយទទួលវិវរណៈមកពីព្រះ ។ ទំនួលខុសត្រូវរបស់លោក គឺដើម្បីបង្ហាញពីព្រះហឫទ័យរបស់ព្រះ និងលក្ខណៈពិតរបស់ព្រះចំពោះមនុស្សលោក ហើយបង្ហាញពីអត្ថន័យនៃការទំនាក់ទំនងរបស់ទ្រង់ជាមួយពួកគេ ។ ព្យាការីម្នាក់ ប្រកាសបដិសេធអំពើបាបទាំងស្រុង ហើយទាយទុកពីផលវិបាករបស់វា ។ លោកគឺជាអ្នកផ្សាយអំពីសេចក្ដីសុចរិត ។ ក្នុងឱកាសខ្លះ ពួកព្យាការីអាចនឹងត្រូវបានបំផុសគំនិតឲ្យទាយទុកជាមុនអំពី អនាគតកាលសម្រាប់ជាប្រយោជន៍ដល់មនុស្សលោក ។ ទោះជាយ៉ាងណា ទំនួលខុសត្រូវចម្បងរបស់លោក គឺត្រូវថ្លែងជាសាក្សីអំពីព្រះគ្រីស្ទ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ព្យាការី » scriptures.lds.org ) ។

បន្ទាប់ពីនិយមន័យនីមួយៗបានអានហើយ សូមអញ្ជើញសិស្សមួយចំនួនឲ្យពន្យល់ថាប្រយោគណាដែលពួកគេមានចំណាប់អារម្មណ៍ ។

មុនពេលបន្ត វាអាចនឹងជាប្រយោជន៍ដើម្បីពិភាក្សាជាមួយសិស្សដោយសង្ខេបអំពីនិយមន័យនៃតំណែងផ្សេងៗទៀតដូចខាងក្រោម ដែលបានផ្ដល់ឲ្យនៅក្នុងខទីមួយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២១ ៖

*អ្នកបកប្រែ ៖* ជាមនុស្សម្នាក់ដែល (១) បកប្រែពាក្យសម្ដីក្នុងការសរសេរ ឬការនិយាយ ទៅជាភាសាផ្សេងទៀត ឬ (២) ផ្ដល់អត្ថន័យកាន់តែច្បាស់ចំពោះការបកប្រែរួចហើយ តាមរយៈការកែលម្អ ឬការកែតម្រូវបា ឬដោយការស្ដារនូវឯកសារដែលបានបាត់បង់ទៅ ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ, « ការបកប្រែ » scriptures.lds.org ) ។

*ពួកសាវក ៖* ជាសាក្សីពិសេសម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ដល់ពិភពលោក ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ« សាវក » ) ។

*អែលឌើរ ៖* « ជាតំណែងត្រឹមត្រូវ ដែលបានផ្ដល់ទៅឲ្យអ្នកកាន់បព្វជិតភាពមិលគីស្សាដែកទាំងអស់ » និងផ្ដល់ចំពោះនរណាម្នាក់ ដែលត្រូវបានហៅឲ្យបម្រើកិច្ចការព្រះយេស៊ូវគ្រីស្ទពេញម៉ោង ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « អែលឌើរ » ) ។

- តើតំណែងដែលបានផ្ដល់ទៅឲ្យ យ៉ូសែប ស្ម៊ីធ ជួយអ្នកយល់អំពីតួនាទីសំខាន់របស់លោកក្នុងការស្ដារឡើងវិញយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:២–៣ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះបានបំផុសគំនិតដល់ យ៉ូសែប ស្ម៊ីធ ឲ្យធ្វើ ។ សូមសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរៀន ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។ ( សិស្សគួរតែបង្ហាញពីសេចក្ដីពិតថា **ព្រះបានដឹកនាំ យ៉ូសែប ស្ម៊ីធ ឲ្យស្ដារសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ** ) ។

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់សម្រាប់យើងដើម្បីដឹងថា យ៉ូសែប ស្ម៊ីធ ត្រូវបានហៅដោយព្រះ ដើម្បីស្ដារឡើងវិញ និងដឹកនាំសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទដូច្នេះ ?



សូមបង្ហាញដល់សិស្សនូវរូបភាព បងប្រុស យ៉ូសែប ( *សៀវភៅសិល្បៈនៃដំណឹងល្អ* [ ឆ្នាំ ២០០៩ ], លេខ ៨៦; សូមមើលផងដែរ LDS.org) ហើយថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សាខាងលើ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៤–៩

*សមាជិកនៃសាសនាចក្រ គួរតែស្ដាប់តាមពាក្យសម្ដីរបស់ យ៉ូសែប ស្ម៊ីធ*

សូមរំឭកសិស្សថា ព្រះអម្ចាស់ បានប្រទាននូវវិវរណៈនេះនៅថ្ងៃដែលសាសនាចក្រត្រូវបានរៀបចំឡើង ។ វិវរណៈនេះត្រូវបានប្រគល់ឲ្យនៅថ្ងៃពិសេសនេះ គឺផ្ដល់នូវភាពសំខាន់ជាពិសេសអំពីវា ។

សូមសរសេរនូវពាក្យ ឬឃ្លាទាំងឡាយដូចខាងក្រោមដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៤–៥ នៅលើក្ដារខៀន ( សូមកុំដាក់បញ្ចូលទាំងនិយមន័យនៅក្នុងវង់ក្រចកនោះឡើយ) ៖

*សាសនាចក្រ* ( សមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅក្នុងជំនាន់របស់ យ៉ូសែប ស៊្មីធ ក៏ដូចជានៅក្នុងជំនាន់យើងផ្ទាល់ផងដែរ ) ។

*របស់លោក* ( ជាពិសេសចំពោះ យ៉ូសែប ស៊្មីធ ប៉ុន្តែក៏អាចសំដៅទៅលើប្រធានសាសនាចក្របច្ចុប្បន្នផងដែរ )

*ពាក្យសម្ដី និងបញ្ញត្តិទាំងឡាយ* ( អាចសំដៅទៅលើការបង្រៀន និងដំបូន្មានរបស់ព្យាការីម្នាក់ រួមមានទាំងការណែនាំជាក់លាក់ ដែលត្រូវបានប្រទានឲ្យដោយព្រះអម្ចាស់ តាមរយៈព្យាការី ផងដែរ)

*ដោយសេចក្ដីអត់ធន់ និងសេចក្ដីជំនឿគ្រប់យ៉ាង* ( អាចមានន័យថា យើងអាចទុកចិត្តទាំងស្រុងទៅលើការបង្រៀនរបស់ព្យាការី ថាយើងពុំគួររិះគន់លោក ថាយើងគួរតែធ្វើតាមដំបូន្មានរបស់លោក ដោយពុំគិតអំពីការធ្លាក់ចុះផ្ទាល់ខ្លួន ដែលលោកអាចមាន ហើយថាយើងគួរតែរង់ចាំពរជ័យដែលបានសន្យាដោយអត់ធន់ )

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៤–៥ ដោយស្ងាត់ស្ងៀម ហើយពិចារណាអំពីអត្ថន័យនៃពាក្យ ឬឃ្លានៅលើក្ដារខៀន ។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមសួរដល់សិស្សថា តើពួកគេនឹងកំណត់ពាក្យ និងឃ្លាទាំងនេះ យ៉ាងដូចម្ដេច ។ អ្នកអាចនឹងចង់ប្រើនិយមន័យនៅក្នុងរង្វង់ក្រចកដើម្បីដឹកនាំការពិភាក្សា ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៤–៥ តើការបង្រៀនរបស់ព្យាការីណាមួយ ដែលយើងត្រូវស្ដាប់ ? ( យើងត្រូវស្ដាប់ « រាល់ពាក្យសម្ដីរបស់លោក និងបទបញ្ញត្តិទាំងឡាយ » ) ។
- ហេតុអ្វីពេលខ្លះវាតម្រូវឲ្យមានការអត់ធន់ និងសេចក្ដីជំនឿដើម្បីស្ដាប់ពាក្យសម្ដីរបស់ព្យាការី ?
- តើការដឹងថា ព្យាការី ទទួលបានដំបូន្មាន និងបទបញ្ញត្តិមកពីព្រះអម្ចាស់ ជួយដល់អ្នកទទួលយកពាក្យសម្ដីរបស់លោក « ដោយសេចក្ដីអត់ធន់ និងសេចក្ដីជំនឿគ្រប់យ៉ាង » តាមរបៀបណា ? ( គ. និង ស. ២១:៥ ) ។

សូមអញ្ជើញសិស្សម្នាក់ៗឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៦ ដោយស្ងាត់ស្ងៀម រកមើលពរជ័យបីយ៉ាងដែលបាន ផ្ដល់ដល់អ្នកទាំងឡាយ ដែលទទួលបានពាក្យសម្ដីរបស់ព្យាការីដោយសេចក្ដីអត់ធន់ និងសេចក្ដីជំនឿ ។ ( អ្នកអាចពន្យល់ ថា អត្ថន័យមួយនៃពាក្យ *ញាប់ញ័រ* គឺធ្វើឲ្យរបូត ឬដាច់ចេញពីអ្វីមួយដែលទ្រទ្រង់វា ឬដាច់ចេញពីប្រអប់មួយ ។ ដូច្នេះការ បកប្រែមួយនៃខគម្ពីរនេះ អាចថា នៅពេលស្ថានសួគ៌ញាប់ញ័រ « ដើម្បីសេចក្ដីល្អដល់ [ យើង ] » នោះវិវរណៈ និងពរជ័យ ទាំងឡាយ គឺត្រូវបាន « ដាច់ចេញមក » ហើយចាក់ស្រោចមកលើអ្នកទាំងឡាយដែលធ្វើតាមពួកព្យាការីនៅរស់ ) ។

- តើអ្នកនឹងសង្ខេបការសន្យាដែលបានប្រទានឲ្យដល់អ្នកទាំងឡាយណាដែលបានស្ដាប់តាមពាក្យសម្ដីរបស់ព្យាការីយ៉ាង ដូចម្ដេច ? ( សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងស្ដាប់តាមពាក្យសម្ដីរបស់ព្យាការី នោះយើងនឹងត្រូវបានការពារទាស់នឹងមារសត្រូវ** ។ អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើ ក្ដារខៀន ) ។
- តើការស្ដាប់តាមពាក្យសម្ដីរបស់ព្យាការី « កម្ចាត់អំណាចនៃសេចក្ដីងងឹតចេញ » យ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់គោលការណ៍ ដែលពួកគេទើបនឹងបានប្រាប់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវការដកស្រង់ដូចខាង ក្រោមនេះ ស្ដីអំពី ការដើរលេងជាគូ ( ឬការដកស្រង់មួយទៀត អំពី ជម្រើសរបស់អ្នក ) ចេញមកពីកូនសៀវភៅ *ដើម្បីកម្លាំង នៃយុវជន* ។ សូមឲ្យសិស្សផ្សេងទៀតក្នុងថ្នាក់ស្ដាប់ដោយយកចិត្តទុកដាក់ ហើយប្រាប់អំពីដំបូន្មានរបស់ព្យាការី និងពរជ័យ ដែលបានសន្យា ។ បន្ទាប់ពីសិស្សបានបញ្ចប់ការអានរួចហើយ សូមអញ្ជើញសិស្សឲ្យរាយការណ៍នូវអ្វីដែលពួកគេបានប្រាប់ ។

> « ការដើរលេងជាគូ គឺជាសកម្មភាពមួយដែលបានដាក់ ដើម្បីអនុញ្ញាតឲ្យយុវជនម្នាក់ និង យុវនារីម្នាក់ ចាប់ផ្ដើមស្គាល់ គ្នាបានប្រសើរជាង ។ នៅក្នុងវប្បធម៌ ដែលការដើរលេងជាគូ អាចទទួលយកបាន វាអាចជួយអ្នកឲ្យរៀន និង អនុវត្តនូវ ជំនាញខាងសង្គម អភិវឌ្ឍមិត្តភាព មានភាពសប្បាយរីករាយ និង ទីបំផុតរកឃើញដៃគូដ៏អស់កល្បជានិច្ចម្នាក់ ។
>
> « អ្នកមិនគួរដើរលេងជាគូឡើយ រហូតដល់អ្នកមានអាយុយ៉ាងតិច ១៦ ឆ្នាំសិន ។ នៅពេលដែលអ្នកចាប់ផ្ដើមដើរ លេងជាគូ សូមទៅជាមួយនឹងគូផ្សេងទៀត ។ សូមចៀសវាងពីការដើរលេងជាគូ ញឹកញាប់ជាមួយនឹងដៃគូដដែលៗ ។ ការអភិវឌ្ឍន៍ទំនាក់ទំនងស្និទ្ធស្នាលតាំងពីវ័យក្មេងពេក អាចរាំងអ្នកមិនឲ្យមានឱកាសស្គាល់មនុស្សផ្សេងទៀត ដែលអ្នក ជួប ហើយប្រហែលជាអាចនាំទៅរកភាពអសីលធម៌ ។ សូមអញ្ជើញឪពុកម្ដាយរបស់អ្នកឲ្យស្គាល់មនុស្ស ដែលអ្នកដើរលេង ជាគូជាមួយ ។
>
> « សូមជ្រើសរើសដើរលេងតែជាមួយអ្នកទាំងឡាយណា ដែលមានបទដ្ឋានសីលធម៌ខ្ពស់ ហើយនឹងនៅក្នុងក្រុម ដែលអ្នក អាចរក្សានូវបទដ្ឋានរបស់អ្នកបាន ។ សូមចងចាំថា យុវជនម្នាក់ និងយុវនារីម្នាក់ដើរលេងជាគូ គឺមានទំនួលខុសត្រូវដើម្បី ការពារកិត្តិយស និងគុណធម៌ឲ្យគ្នាទៅវិញទៅមក » ( *ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ ២០១១ ], ៤; សូមមើល ផងដែរ LDS.org) ។

- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ ទទួលបានពរជ័យពីការស្ដាប់តាមពាក្យសម្ដី និងបទបញ្ញត្តិទាំងឡាយនៃព្យាការីនៅរស់នៅពេលណា ?

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេត្រូវធ្វើ ដើម្បីប្រកាសអំពីពរជ័យដែលបានសន្យានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៦ ។ សូមអះអាងនឹងពួកគេថា នៅពេលពួកគេស្ដាប់តាមពាក្យសម្ដីរបស់ព្យាការីដោយយកចិត្តទុកដាក់ នោះពួកគេនឹងទទួលបានពរជ័យដ៏អស្ចារ្យក្នុងពេលនេះ និងដ៏អស់កល្បជានិច្ច ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៧–៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវបំណងប្រាថ្នា និងឥរិយាបទសុចរិតរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។

- តើយើងរៀនបានអ្វីខ្លះអំពីព្យាការី យ៉ូសែប ស្ម៊ីធ ចេញមកពីខគម្ពីរទាំងនេះ ?

- តើអ្នកគិតថា ខគម្ពីរទាំងនេះក៏អាចអនុវត្តចំពោះប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយបច្ចុប្បន្ននេះយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១០–១២

*អូលីវើរ ខៅឌើរី ត្រូវបានទទួលស្គាល់ជាអែលឌើរ និងអ្នកផ្សាយម្នាក់*

សូមប្រាប់សិស្សថា នៅក្នុងការប្រជុំដំបូងរបស់សាសនាចក្រ អូលីវើរ ខៅឌើរី ត្រូវបានតែងតាំងជាអែលឌើរម្នាក់ ដោយព្យាការី យ៉ូសែប ស្ម៊ីធ ហើយព្យាការី ត្រូវបានតែងតាំងជាអែលឌើរ ដោយអូលីវើរ ខៅឌើរី ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេណគ្នាអានឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:១០–១២ ។

អ្នកក៏អាចចង់ចង្អុលបង្ហាញថា នៅក្នុង ខ ១០ ព្រះអម្ចាស់សំដៅទៅលើ អូលីវើរ ខៅឌើរី ថាជា «សាវករបស់យើង » ( សូមមើលផងដែរ គ. និង ស. ២០:២–៣ ) ។ សូមពន្យល់ថា នៅក្នុងភាសាក្រិច ពាក្យថា *សាវក* មានន័យថា « ជាមនុស្សម្នាក់ដែលត្រូវបានបញ្ជូន » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « សាវក » scriptures.lds.org ) ។ អូលីវើរ ខៅឌើរី ត្រូវបានបញ្ជូនមកដោយព្រះយេស៊ូវគ្រីស្ទ ហើយបានបញ្ជាឲ្យថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ ។ ទោះបីជាអូលីវើរ ត្រូវបានផ្ដល់ឲ្យនូវទំនួលខុសត្រូវជាសាវកក្ដី ក៏លោកពុំមែនជាសមាជិកនៃ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ដែរ ។ ទោះជាយ៉ាងណាក៏ដោយ លោកបានជួយនៅក្នុងការស្វែងរកបុរស ដែលត្រូវបានហៅថាជាសមាជិកនៃកូរ៉ុមនោះ ពេលវាត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ ១៨៣៥ ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:១១ តើអូលីវើរ ខៅឌើរី ត្រូវបានសុំឲ្យធ្វើអ្វីខ្លះ ? ( ថ្លែងពីព្រះនាមរបស់ព្រះអម្ចាស់ ) ។

- តើការថ្លែងអំពីព្រះនាមរបស់ព្រះអម្ចាស់ មានន័យយ៉ាងណាចំពោះអ្នក ?

សូមបញ្ចប់មេរៀនថ្ងៃនេះ ដោយការលើកទឹកចិត្តសិស្សឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួលស្ដីអំពីរបៀបដែលពួកគេអាចថ្លែងពីព្រះនាមរបស់ព្រះអម្ចាស់ ហើយធ្វើជាតំណាងឲ្យសាសនាចក្រ នៅក្នុងគ្រួសាររបស់ពួកគេ សហគមន៍របស់ពួកគេ និងពិភពលោក ។

មេរៀនទី ៣០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២២–២៣

## បុព្វកថា

អំឡុងការក្បត់សាសនាដ៏ធំ ពិធីបរិសុទ្ធនៃសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានផ្លាស់ប្ដូរ លុបបំបាត់ ឬធ្វើឡើងដោយគ្មានសិទ្ធិអំណាចត្រឹមត្រូវ ។ នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២២ ព្រះអម្ចាស់បានបញ្ជាក់ថា ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក ត្រូវបានធ្វើឡើងដោយអ្នកទាំងឡាយណាដែលមានសិទ្ធិអំណាចដើម្បីផ្ដល់សមាជិកភាពសាសនាចក្រដល់បុគ្គលម្នាក់ៗ ហើយអាចចូលទៅក្នុងនគររបស់ព្រះ ។ កណ្ឌ ២៣ នៃគោលលទ្ធិ និងសេចក្ដីសញ្ញា រួមទាំងវិវរណៈមួយ ដែលបានទទួលដោយ យ៉ូសែប ស្ម៊ីធ សម្រាប់បុរសប្រាំនាក់ ដែលមានបំណងប្រាថ្នាយ៉ាងខ្លាំង ដើម្បីដឹងអំពីព្រះឆន្ទៈរបស់ព្រះអំពីពួកគេ ៖ អូលីវើរ ខៅឌើរី, ហៃរ៉ុម ស្ម៊ីធ, សាំយូអែល ស្ម៊ីធ, យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ និង យ៉ូសែប ណៃត៍ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដី សញ្ញា ២២

*ពិធីបុណ្យជ្រមុជទឹក ត្រូវតែធ្វើឡើងដោយអ្នកទាំងឡាយ ដែលមានសិទ្ធិអំណាចត្រឹមត្រូវ ។*

សូមអញ្ជើញសិស្សបីនាក់ឲ្យ ដើរតួក្នុងការសម្ដែងមួយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យដើរតួជាអ្នករៀន ដែលជឿថា សាសនាចក្រពិត ។ អ្នករៀនបានទទួលបុណ្យជ្រមុជទឹក ដោយការពន្លិចទៅក្នុងទឹក នៅព្រះវិហារផ្សេងរួចហើយ ហើយពុំយល់ថា ហេតុអ្វីក៏ចាំបាច់ត្រូវទទួលបុណ្យជ្រមុជទឹកម្ដងទៀតនោះទេ ។ សូមសិស្សពីរនាក់ផ្សេងទៀត ឲ្យដើរតួជាអ្នកផ្សព្វផ្សាយសាសនា ដែលព្យាយាមឆ្លើយតបចំពោះសំណួររបស់អ្នករៀន ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យគិតពីរបៀបដែលពួកគេអាចឆ្លើយតប បើពួកគេស្ថិតនៅក្នុងស្ថានភាពដូចគ្នានេះ ។

**ការសម្ដែង**

ការសម្ដែងនឹងជួយសិស្សឲ្យអនុវត្តដំណោះស្រាយដំណឹងល្អទៅក្នុងស្ថានភាពជីវិតពិត ។ ការសម្ដែងនឹងកាន់តែមានជោគជ័យ បើអ្នកផ្ដល់ទៅដល់អ្នកចូលរួមសម្ដែងនូវព័ត៌មានគ្រប់គ្រាន់ ហើយផ្ដល់ពេលឲ្យរៀបចំខ្លួន ។ នៅពេលសិស្សសម្ដែង ពួកគេនឹងមានកំហុសឆ្គង ។ សូមបង្ហាញនូវការយល់ចំពោះអារម្មណ៍ និងអាកប្បកិរិយារបស់ពួកគេ ហើយមិនត្រូវរិះគន់ចំពោះកំហុសឆ្គងរបស់ពួកគេទេ ។ នៅចុងបញ្ចប់នៃការសម្ដែង វាអាចនឹងមានប្រយោជន៍ ដើម្បីសួរឲ្យអ្នកមើល បើមានគំនិតផ្សេងដែលពួកគេអាចនឹងនិយាយ បើពួកគេជាសម្ដែងវិញនោះ ។

បន្ទាប់ពីការសម្ដែង សូមពន្យល់ថា វិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២២ ត្រូវបានបំផុសគំនិតដោយស្ថានភាពស្រដៀងគ្នាមួយ ។ មានមនុស្សជាច្រើនដែលចង់ក្លាយជាសមាជិកសាសនាចក្រ បានទទួលបុណ្យជ្រមុជទឹកនៅក្នុងជំនឿពីមុនរបស់ពួកគេហើយ ។ ពួកគេងឿងឆ្ងល់ថា ហេតុអ្វីក៏ពួកគេត្រូវទទួលបុណ្យជ្រមុជទឹកម្ដងទៀត ។

យ៉ូសែប ស្ម៊ីធ បានសួរដល់ព្រះអម្ចាស់អំពីសំណួររបស់ពួកគេ ។ ក្នុងចម្លើយ ព្រះអម្ចាស់បានបង្រៀននូវគោលលទ្ធិដ៏សំខាន់មួយនៃការស្ដារឡើងវិញនៃដំណឹងល្អ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២២: ១ ២២:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាមួយដែលទាក់ទងទៅនឹងការស្ដារឡើងវិញនៃដំណឹងល្អ ។

- តើឃ្លាណា ក្នុងខគម្ពីរនេះ ដែលទាក់ទងនឹងការស្ដារឡើងវិញនៃដំណឹងល្អ ? ( « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ) ។

ដើម្បីជួយសិស្សយល់នូវឃ្លានេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការដូចខាងក្រោមឲ្យឮៗ ។



« *សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច* គឺជាភាពពេញលេញនៃដំណឹងល្អ ។ [ សូមមើល គ. និង ស.៦៦:២] ។ វាមាននូវ ‹ សេចក្ដីសញ្ញា កិច្ចសន្យា សំបុត្រជានា កាតព្វកិច្ច សម្បថ ការសច្ចា ការប្រព្រឹត្តិ ការរួបរួម ការចូលរួម ឬការសង្ឃឹម › ដែលភ្ជាប់មកលើសមាជិកនៃសាសនាចក្រ ដោយព្រះវិញ្ញាណបរិសុទ្ធនៃការសន្យា ឬព្រះវិញ្ញាណបរិសុទ្ធ ដោយសិទ្ធិអំណាចនៃប្រធានសាសនាចក្រដែលកាន់កូនសោទាំងឡាយ ។ [សូមមើល គ. និង ស. ១៣២:៧ ] ។ ប្រធាននៃសាសនាចក្រកាន់កូនសោទាំងឡាយនៃបព្វជិតភាពមិលគីស្សាដែក ។ លោកផ្ទេរសិទ្ធិអំណាចដល់អ្នកដទៃ ហើយផ្ដល់សិទ្ធិឲ្យពួកគេធ្វើពិធីបរិសុទ្ធដ៏ពិសិដ្ឋនៃបព្វជិតភាព ។

« អាពាហ៍ពិពាហ៍សម្រាប់ភាពអស់កល្បគឺជាសេចក្ដីសញ្ញាអស់កល្បអស់កាលជានិច្ច *មួយ* ។ ពិធីបុណ្យជ្រមុជទឹក ក៏ជាសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច *មួយ* [ សូមមើល គ និង ស ១៣២: ២២ ] ហើយក៏ដូចជាការតែងតាំងបព្វជិតភាពដែរ ហើយសេចក្ដីសញ្ញាដទៃទៀតទាំងអស់ គឺអស់កល្បអស់កាលជានិច្ច ហើយជាផ្នែកមួយនៃ *សេចក្ដី សញ្ញាថ្មី* ហើយអស់កល្បអស់កាលជានិច្ច ដែលឱបក្រសោបនូវរឿងគ្រប់យ៉ាង » ( *Answers to Gospel Questions,* ចងក្រងដោយ Joseph Fielding Smith Jr., វ៉ុលទី៥ [ ឆ្នាំ១៩៥៧– ៦៦ ១:៦៥ ) ។

សូមឲ្យសិស្សសង្ខេបតាមសម្ដីផ្ទាល់របស់ពួកគេអំពីអត្ថន័យនៃឃ្លាថា *សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច* ។

- តើការរៀនសូត្រអំពីសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច អាចជាជំនួយដល់អ្នកទាំងឡាយដែលត្រូវបានទទួលបុណ្យជ្រមុជទឹក ដោយគ្មានសិទ្ធិអំណាចបព្វជិតភាពយ៉ាងដូចម្ដេច ?
- តើពិធីបរិសុទ្ធ នៅក្រោមសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ដែលបានធ្វើឡើងដោយសិទ្ធិអំណាចអ្វី ? ( សិទ្ធិអំណាចបព្វជិតភាព ) ។

សូមសរសេរនូវគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖ **ពិធីបុណ្យជ្រមុជទឹក ត្រូវតែធ្វើឡើងដោយមនុស្សម្នាក់ ដែលមានសិទ្ធិអំណាចមកពីព្រះ ។**

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២២:២–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីឃ្លាដែលចង្អុលបង្ហាញថា ព្រះអម្ចាស់ពុំទទួលយកពិធីបុណ្យជ្រមុជទឹក ដែលបានធ្វើឡើងដោយគ្មានសិទ្ធិអំណាចបព្វជិតភាពនោះទេ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ បានសំដៅពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក ជាការចូលទៅក្នុង « ទ្វារចង្អៀត » ( សូមមើល គ និង ស ២២: ២ ) ។ បន្ទាប់មកសូមអញ្ជើញសិស្សឲ្យប្រាប់នូវអ្វីដែលពួកគេរកឃើញ ។

- តើពិធីបុណ្យជ្រមុជទឹកដោយគ្មានសិទ្ធិអំណាច អាចជា « កិច្ចការគ្មានន័យ » របៀបណា ? ( វាពុំផ្ដល់ប្រយោជន៍ដ៏អស់កល្បដល់អ្នកទាំងឡាយដែលបានធ្វើកិច្ចការនោះទេ ) ។
- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣: ៣ តើព្រះអម្ចាស់បានធ្វើអ្វីខ្លះ ព្រោះតែកិច្ចការដ៏គ្មានន័យ ដែលត្រូវបានធ្វើឡើងនៅគ្រានោះ ? ( ទ្រង់បានធ្វើឲ្យសេចក្ដីសញ្ញារបស់ទ្រង់ ស្ដាបនាឡើងវិញ ហើយសាសនាចក្ររបស់ទ្រង់ ត្រូវបានស្ដាបនាឡើង ) ។
- តើអ្នកត្រូវបានប្រទានពរយ៉ាងដូចម្ដេច ដោយសារតែអ្នកបានក្លាយជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ– ជាព្រះវិហារតែមួយគត់ ដែលមានសិទ្ធិអំណាចដើម្បីធ្វើពិធីបរិសុទ្ធសំខាន់ៗ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣

*បុរសប្រាំនាក់ត្រូវបានហៅឲ្យពង្រឹងដល់សាសនាចក្រ*

សូមឲ្យសិស្សគិតអំពីគ្រាមួយ ដែលពួកគេត្រូវការពាក្យសម្ដីនៃការលើកទឹកចិត្ត ឬការដឹកនាំមកពីមនុស្សផ្សេងទៀត ។ អ្នកអាចនឹងសុំឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យមើលសេចក្ដីណែនាំ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ ហើយប្រាប់ពីបុរសប្រាំនាក់ដែលបានថ្លែងនៅក្នុងកណ្ឌនេះ ។ សូមពន្យល់ថា នៅក្នុងវិវរណៈនេះបុរសទាំងនេះម្នាក់ៗបានទទួលការណែនាំជាក់លាក់មកពីព្រះអម្ចាស់ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលមេរៀនដែលពួកគេអាចរៀន នៅពេលពួកគេសិក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់បុរសទាំងនេះ ។ ជីវប្រវត្តិខ្លីៗដូចខាងក្រោម ផ្ដល់បរិបទដ៏ជាជំនួយសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ ។

*ហៃរ៉ុម ស្ម៊ីធ* ជាបងប្រុសរបស់ ព្យាការី បានជួយក្នុងការបោះពុម្ពព្រះគម្ពីរមរមនដោយការធ្វើការដោយផ្ទាល់ជាមួយនឹងអ្នកបោះពុម្ព ។ គាត់បានបម្រើជាប្រធាននៃសាខាទីមួយរបស់សាសនាចក្រនៅ ខូស្វីល រដ្ឋនូវយ៉ោក ។ ហៃរ៉ុម ស្មោះត្រង់ចំពោះព្រះអម្ចាស់ និងសាសនាចក្រពេញមួយជីវិតរបស់គាត់ ។

*សាំយូអែល ស្ម៊ីធ* ជាប្អូនប្រុសរបស់ព្យាការី បានជ្រមុជទឹកនៅក្នុងខែឧសភា ឆ្នាំ ១៨២៩ ។ នៅក្នុងខែមិថុនា ឆ្នាំ ១៨៣០ គាត់បានធ្វើដំណើរទៅបេសកកម្មមួយ ហើយបានដាក់លក់ព្រះគម្ពីរមរមន ដែលទីបំផុតបាននាំឲ្យមានការផ្លាស់ប្រែចិត្តជឿដល់ ព្រីហ្គាំ យ៉ង់ និងសមាជិកគ្រួសារគាត់ជាច្រើន ។ សាំយូអែល មានភក្ដីចំពោះព្រះគ្រួសារគាត់ និងសាសនាចក្រពេញមួយជីវិតរបស់គាត់ ។ សាំយូអែល ពុំទាន់បានត្រៀមខ្លួនដើម្បីផ្សព្វផ្សាយទេ ពេលវិវរណៈនេះ ត្រូវបានផ្ដល់ឲ្យ ប៉ុន្តែរយៈពេលពីរខែក្រោយមក គាត់បានចាប់ផ្ដើមការបម្រើបេសកកម្មរបស់គាត់ ។

*យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ* ជាឪពុករបស់ព្យាការី បានចូលរួមក្នុងសាសនាក្រ នៅថ្ងៃដែលសាសនាចក្របានរៀបចំឡើង ។ នៅរដូវក្ដៅក្រោយមក គាត់ និងកូនប្រុសរបស់គាត់ ដុន ខាឡុស បានចាប់ផ្ដើមបេសកកម្មមួយទៅដល់គ្រួសារសាច់ញាតិនៅរដ្ឋនូវយ៉ោក ។ គាត់បានក្លាយជាសង្ឃជាន់ខ្ពស់ម្នាក់ ហើយជាអយ្យកោទីមួយនៃសាសនាចក្រ ។ យ៉ូសែប ស្ម៊ីធ ជុញ៉័រ បានពិពណ៌នាអំពីឪពុកលោកថាជា « បុរសស្មោះត្រង់ចំពោះព្រះរបស់គាត់ និងចំពោះសាសនាចក្រ គ្រប់ស្ថានភាពទាំងអស់ និងក្រោមកាលៈទេសៈទាំងអស់ ដែលគាត់បានឆ្លងកាត់ » ( *History of the Church,* ) ។

*យ៉ូសែប ណៃត ស៊ីញ៉័រ* គឺជាមិត្តជិតស្និតម្នាក់របស់ យ៉ូសែប ស្ម៊ីធ ជុញ៉័រ ហើយបានបង្ហាញដល់លោកនូវសន្ដានចិត្តដ៏ល្អ ។ គាត់បានផ្ដល់សម្ភារទៅដល់ព្យាការី ខណៈដែលលោកធ្វើការបកប្រែព្រះគម្ពីរមរមន ។ គាត់មានបំណងប្រាថ្នាចង់ទទួលបុណ្យជ្រមុជទឹកជាមួយអ្នកដទៃទៀត នៅថ្ងៃដែលសាសនាចក្រត្រូវបានរៀបចំឡើង ប៉ុន្តែគាត់បានរង់ចាំសិន ដោយសារគាត់ចង់សិក្សាព្រះគម្ពីរមរមនបន្ថែម ។ ក្រោយមក គាត់បានសរសេរថា « ខ្ញុំនឹង [ មាន ]អារម្មណ៍ល្អជាង បើខ្ញុំ. . . បានដើរទៅមុខ » ដើម្បីទទួលបុណ្យជ្រមុជទឹកនោះ ( ដូចបានដកស្រង់នៅក្នុង Larry Porter, « The Joseph Knight Family » *Ensign,* ខែ តុលា ឆ្នាំ១៩៧៨,ទំព័រ ៤០ ការប្រកបពាក្យ និងការដាក់អក្សរធំ ត្រូវបានធ្វើឡើងតាមបទដ្ឋាន ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣: ១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមានមួយ ដែលព្រះអម្ចាស់បានផ្ដល់ទៅឲ្យអូលីវើរ ខៅឌើរី ។

- តើការព្រមានអ្វីខ្លះ ដែលព្រះអម្ចាស់បានផ្ដល់ទៅឲ្យអូលីវើរ ? តើភាពឆ្មើងឆ្មៃនាំទៅរកការល្បួងយ៉ាងដូចម្ដេច ?
- តើវិធីមួយចំនួនណាខ្លះ ដែលយើងអាចចៀសពីអារម្មណ៍នៃភាពឆ្មើងឆ្មៃ ដែលនឹងនាំយើងទៅរកការល្បួងនោះ ?
- ស្របតាម ខ ២ តើអូលីវើរ នឹងមានពរជ័យអ្វីខ្លះ ? ( សមត្ថភាពដើម្បី « ផ្សព្វផ្សាយពីសេចក្ដីពិត » ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ :៣–៥ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលភាពស្រដៀងគ្នានៅក្នុងការណែនាំ ដែលព្រះអម្ចាស់បានផ្ដល់ទៅឲ្យ ហៃរ៉ុម ស្ម៊ីធ, សាំយូអែល ស្ម៊ីធ និង យ៉ូសែបស្ម៊ីធ ស៊ីញ៉័រ ។

- តើការណែនាំរបស់ព្រះអម្ចាស់ចំពោះបុរសទាំងនេះស្រដៀងគ្នាយ៉ាងដូចម្ដេច ? ( ម្នាក់ៗត្រូវបានហៅឲ្យដាស់តឿន និងពង្រឹងដល់សាសនាចក្រ ។ អ្នកក៏អាចពន្យល់ថា ការហៅឲ្យដាស់តឿន សំដៅទៅលើទំនួលខុសត្រូវដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ) ។

សូមអញ្ជើញសិស្សបីនាក់ឲ្យបើកទៅអានជីវប្រវត្តិសង្ខេបរបស់ ហៃរ៉ុម ស្ម៊ីធ, សាំយូអែល ស្ម៊ីធ និង យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ ឲ្យឮៗ ។ ពីមុននឹងអាន សូមឲ្យសិស្សស្ដាប់រកមើលរបៀបដែលបុរសទាំងនេះ បានបំពេញតាមការហៅឲ្យដាស់តឿន និងពង្រឹងដល់សាសនាចក្រ ។ បន្ទាប់ពីអានជីវប្រវត្តិនីមួយៗហើយ សូមឲ្យសិស្សចែកចាយនូវអ្វីដែលពួកគេបានរៀន ។

- តើមានភាពស្រដៀងគ្នា និងភាពខុសគ្នាមានអ្វីខ្លះ រវាងការណែនាំទៅដល់ ហៃរ៉ុម ស្ម៊ីធ និង សាំយូអែល ស្ម៊ីធ ?
- តើវិធីមួយចំនួនណាខ្លះ ដែលយើងអាចដាស់តឿន និងពង្រឹងដល់សាសនាចក្រ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវជីវប្រវត្តិសង្ខេបរបស់ យ៉ូសែប ណៃត ស៊ីញ៉័រ រួចហើយសុំឲ្យសិស្សផ្សេងទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣:៦–៧ដែលមាននូវពាក្យទូន្មានរបស់ព្រះអម្ចាស់ ចំពោះ យ៉ូសែប ណៃត ស៊ីញ៉័រ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើព្រះអម្ចាស់បានបញ្ជាដល់គាត់ឲ្យធ្វើអ្វីខ្លះ ។

- តើយ៉ូសែប ណៃត បានបញ្ជាឲ្យធ្វើអ្វីខ្លះ ? ( ឲ្យអធិស្ឋានឮៗនៅក្នុងទីកំបាំង ជាមួយនឹងគ្រួសារ និងមិត្តភក្ដិគាត់ និងនៅចំពោះពិភពលោក ដើម្បីចូលរួមក្នុងសាសនាចក្រ ហើយដើម្បីដាស់តឿនដល់អ្នកដទៃ ) ។
- តើមានភស្ដុតាងអ្វីខ្លះ ដែលអ្នកបានឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣: ៧ ដែលព្រះអម្ចាស់មានព្រះទ័យដើម្បីប្រទានពរដល់ យ៉ូសែប ណៃត ស៊ីញ៉័រ ?

សូមពន្យល់ថា ក្នុងរយៈពេលខ្លីមួយ បន្ទាប់ពីព្រះអម្ចាស់បានប្រទានវិវរណៈនេះ យ៉ូសែប ណៃត ស៊ីញ៉័រ បានជ្រើសរើសទទួលបុណ្យជ្រមុជទឹក ។ គាត់បាននៅស្មោះត្រង់ចំពោះសាសនាចក្រពេញមួយជីវិតរបស់គាត់ ការពារដល់ព្យាការី យ៉ូសែប ស្ម៊ីធ ដោយសម្ងាត់ និងបើកចំហរ ។ ព្យាការី ក្រោយមកបានពិពណ៌នាអំពី យ៉ូសែប ណៃត ស៊ីញ៉័រ ថាជា « មនុស្សស្មោះ និងពិតត្រង់ ហើយជាជំនួយ និងជាគំរូ ហើយប្រកបដោយគុណធម៌ និងសន្ដានចិត្តល្អ ពុំដែលងាកបេរទៅឆ្វេង ឬទៅស្ដាំឡើយ » ( *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ ២០០៧ ] ៤៦២ ) ។

សូមអញ្ជើញសិស្សឲ្យថ្លែងគោលការណ៍មួយ ដែលពួកគេបានរៀនមកពីការសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ ។ សិស្សអាចនឹងបង្ហាញអំពីគោលការណ៍ដូចខាងក្រោមនេះ ៖

**នៅពេលយើងមានបំណងប្រាថ្នាដើម្បីបម្រើព្រះអម្ចាស់ យើងអាចទទួលបានការដឹកនាំផ្ទាល់ខ្លួនមកពីទ្រង់ ។**

**ព្រះអម្ចាស់ នឹងប្រទានពរដល់យើង នៅពេលយើងធ្វើតាមការណែនាំដែលទ្រង់បានប្រទានដល់យើង ។**

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីការណែនាំដែលពួកគេបានទទួលមកពីព្រះអម្ចាស់ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ពាក្យសម្ដីរបស់ព្យាការីនៅរស់ ឬព្រះគម្ពីរ ។ សូមឲ្យពេលពួកគេពីរបីនាទី ដើម្បីនឹកគិតអំពីរបៀបដែលពួកគេនឹងគោរពតាមដំបូន្មានដែលពួកគេបានទទួល ។ អ្នកអាចអញ្ជើញពួកគេឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ រាល់ចំណាប់អារម្មណ៍ដែលពួកគេបានទទួល ។ សូមអះអាងនឹងពួកគេថា ពួកគេនឹងទទួលបានពរជ័យជាមួយនឹងជំនួយ និងការណែនាំមកពីព្រះអម្ចាស់ នៅពេលពួកគេធ្វើតាមអ្វីដែលទ្រង់បានសុំឲ្យពួកគេធ្វើ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២០–២៣ ( មេរៀនទី ៦ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០–២៣ ( មេរៀនទី ៦ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦)

មេរៀននេះគូសបញ្ជាក់ពីការហៅបម្រើរបស់យ៉ូសែប ស្ម៊ីធ មកពីព្រះដើម្បីរៀបចំសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ វាជួយសិស្សឲ្យយល់ថាការលេចចេញមកនៃព្រះគម្ពីរមរមន គឺជាភស្ដុតាងមួយនៃសេចក្ដីពិតដ៏ពេញលេញនៃការស្ដារឡើងវិញ ។ សិស្សក៏អាចរកឃើញនូវសេចក្ដីពិតគ្រឹះអំពីលក្ខណៈ និង និស្ស័យរបស់ក្រុមព្រះផងដែរ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧)

សិស្សបានសិក្សាពីកាតព្វកិច្ចនៃតំណែងបព្វជិតភាព ហើយបានរៀនថានៅពេលកូនប្រុសទាំងឡាយរបស់ព្រះវរបិតាសួគ៌ ទទួលតំណែងនៃបព្វជិតភាពកាន់តែខ្ពស់ នោះពួកគេទទួលបាននូវទំនួលខុសត្រូវ និងឱកាសកាន់តែច្រើនដើម្បីបម្រើអ្នកដទៃ ។ សិស្សក៏អាចសិក្សាពីទំនួលខុសត្រូវរបស់អ្នកកាន់បព្វជិតភាព ដែលមានដើម្បីចាត់ចែងពិធីបរិសុទ្ធនៃដំណឹងល្អ ហើយមើលថែទាំព្រមទាំងបម្រើដល់សមាជិកសាសនាចក្រ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៨៤)

សិស្សបានរៀនអំពីពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹក និង ពិធីសាក្រាម៉ង់ ។ ដ្បិតពិធីបុណជ្រមុជទឹកត្រូវតែធ្វើឡើងដោយបុគ្គលមួយរូប ដែលកាន់សិទ្ធិអំណាចត្រឹមត្រូវ ហើយត្រូវបានធ្វើឡើងនៅក្នុងលក្ខណៈត្រឹមត្រូវ ទើបពីធីបុណ្យជ្រមុជទឹកនោះនឹងត្រូវទទួលស្គាល់ដោយព្រះ ។ សិស្សក៏បានពិចារណាអំពីការសន្យាដែលថា ប្រសិនបើពួកគេស្មោះត្រង់ចំពោះសេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹករបស់ពួកគេ ហើយទទួលទានសាក្រាម៉ង់ដោយសក្ដិសម នោះពួកគេនឹងមានព្រះវិញ្ញាណគង់នៅជាមួយពួកគេជានិច្ច ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២១–២៣)

នៅពេលសិស្សបានរៀនអំពីព្រឹត្តិការណ៍ជុំវិញការស្ថាបនាសាសនាចក្រជាផ្លូវការ នោះពួកគេបានសិក្សាពីសេចក្ដីពិតខាងក្រោមនេះ ៖ ព្រះបានបំផុសគំនិតយ៉ូសែប ស្ម៊ីធ ឲ្យស្ដារសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ ។ ប្រសិនបើបុគ្គលម្នាក់ៗស្ដាប់តាមប្រសាសន៍របស់ព្យាការី នោះពួកគេនឹងត្រូវបានការពារប្រឆាំងនឹងអារក្ស ហើយទទួលបាននូវពរជ័យពីស្ថានសួគ៌ ។ ពិធីបុណ្យជ្រមុជទឹក ត្រូវតែធ្វើឡើងដោយមនុស្សម្នាក់ដែលមានសិទ្ធិអំណាចមកពីព្រះ ។ នៅពេលយើងមានបំណងប្រាថ្នាដើម្បីបម្រើព្រះអម្ចាស់ នោះយើងអាចទទួលការណែនាំពិសេសមកពីទ្រង់ ហើយព្រះអម្ចាស់នឹងប្រទានពរដល់ពួកយើងនៅពេលយើងធ្វើតាមការណែនាំដែលទ្រង់បានប្រទានឲ្យយើង ។

## សេចក្ដីផ្ដើម

សាសនាចក្រត្រូវបានរៀបចំឡើងដោយផ្អែកលើវិវរណៈដែលព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស្ម៊ីធ ។ មេរៀននេះគូសបញ្ជាក់ពីសារៈសំខាន់នៃវិវរណៈរបស់ព្រះអម្ចាស់ចំពោះព្យាការីរបស់ទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២០–២១

*ព្រះអម្ចាស់រៀបចំសាសនាចក្ររបស់ទ្រង់*

សូមរៀបចំ រូបភាពដែលទាក់ទង ដាក់លើក្រដាសពីរសន្លឹងផ្សេងគ្នា ។ សូមកុំឲ្យសិស្សមើលឃើញរូបភាពទាំងនោះឡើយ ហូតដល់អ្នកធ្វើតាមការណែនាំខាងក្រោម ។



សូមប្រាប់សិស្សថា អ្នកនឹងបង្ហាញពួកគេនូវរូបភាពពីរ ហើយថាពួកគេគួរតែព្យាយាមគូរនូវអ្វីដែលពួកគេមើលឃើញ ។ សូមពន្យល់ថាពួកគេនឹងឃើញរូបភាពនិមួយៗតែមួយវិនាទីប៉ុណ្ណោះ ដូច្នេះពួកគេគួរតែយកចិត្តទុកដាក់ឲ្យបានម៉ត់ចត់ ។ សូមបង្ហាញរូបភាពទីមួយដល់ពួកគេ សូមទុកពេលឲ្យពួកគេគូររូបនោះ ហើយក្រោយមកបង្ហាញរូបភាពទីពីរដល់ពួកគេ ហើយទុកពេលខ្លះឲ្យពួកគេគូររូបនោះ ។

- តើរូបភាពមួយណាងាយគូរជាងគេ ?

សូមបង្ហាញរូបភាពទាំងពីរក្នុងពេលតែមួយ ។ សូមចង្អុលបង្ហាញថា រូបភាពទាំងពីរនេះ មានចំនួនខ្សែបន្ទាត់ដូចគ្នា ។

- ហេតុអ្វីបានជារូបភាពទីពីរស្រួលគូរជាង ? ( ខ្សែបន្ទាត់ដប់ពីរដែលមានសណ្ដាប់ធ្នាប់ងាយគូរជាង ) ។
- តើមេរៀនអ្វីខ្លះដែលយើងរៀនពីការគូររូបភាពទាំងពីរនេះ ?

សូមពន្យល់ថា នៅពេលព្រះយេស៊ូវគ្រីស្ទបានស្ដារសាសនាចក្ររបស់ទ្រង់ឡើងវិញ នោះទ្រង់បានប្រទានវិវរណៈមួយចំនួនស្ដីអំពីរបៀបដែលសាសនាចក្រត្រូវបានរៀបចំ ហើយថានរណាគួរតែដឹកនាំសាសនាចក្រ ។

- តើការមានព្យាការីម្នាក់ និង សាវក ១២នាក់រក្សាសណ្ដាប់ធ្នាប់នៅក្នុងសាសនាចក្រដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–២ ឲ្យឮៗ ហើយឲ្យសិស្សម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលបណ្ដាជំហានដំបូង ដែលព្រះយេស៊ូវគ្រីស្ទបានធ្វើដើម្បីស្ថាបនាសណ្ដាប់ធ្នាប់នៅក្នុងសាសនាចក្ររបស់ទ្រង់ ។

- យោងតាមខគម្ពីរទាំងនេះ តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះដើម្បីស្ថាបនាសណ្ដាប់ធ្នាប់ និង ជួយរៀបចំសាសនាចក្ររបស់ទ្រង់នោះ ? ( ទ្រង់បានហៅយ៉ូសែប ស្ម៊ីធ ឲ្យធ្វើជាព្យាការី បានផ្ដល់ព្រះបញ្ញត្តិដល់លោក ហើយបានផ្ដល់ការណែនាំអំពីរបៀបរៀបចំសាសនាចក្ររបស់ទ្រង់ ) ។

សូមសង្ខេបចម្លើយរបស់សិស្សដោយសរសេរថា **ព្រះបានណែនាំយ៉ូសែប ស្ម៊ីធ ឲ្យស្ដារសាសនាចក្ររបស់ទ្រង់ឡើងវិញ** នៅលើក្ដារខៀន ។

- តើអ្នកគិតថា ហេតុអ្វីវាចាំបាច់មានព្យាការីដើម្បីស្ដារសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទឡើងវិញ ?

សូមអញ្ជើញសិស្សឲ្យចែកចាយរបៀបដែលការសិក្សារបស់ពួកគេ អំឡុងសប្ដាហ៍នេះជួយពួកគេឲ្យមានអំណរគុណកាន់តែខ្លាំងចំពោះ យ៉ូសែប ស្ម៊ីធ និង តួនាទីរបស់លោកក្នុងការស្ដារសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា យ៉ូសែប ស្ម៊ីធបានទទួលវិវរណៈ និង ការណែនាំឲ្យស្ថាបនាសាសនាចក្ររបស់ព្រះអម្ចាស់ ហើយថាតាមរយៈយ៉ូសែប ស្ម៊ីធ នោះព្រះអម្ចាស់បាននាំមកនូវរបៀបរៀបរយមកកាន់នគរទ្រង់លើផែនដីនេះ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៥–៦ ដោយស្ងាត់ស្ងៀម រកមើលពរជ័យបីដែលបានផ្ដល់ដល់អ្នកទាំងឡាយណា ដែលទទួលយកពាក្យសម្ដីរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ដោយសេចក្ដីអត់ធន់ និង សេចក្ដីជំនឿ ។ បន្ទាប់ពីអានរួច សូមពន្យល់ថាការសន្យាទាំងនេះក៏អនុវត្តផងដែរចំពោះព្យាការីនៅរស់សព្វថ្ងៃនេះផងដែរ ។

- តើអ្នកនឹងសង្ខេបពរជ័យដែលបានសន្យាដល់អ្នកទាំងឡាយណា ដែលបានស្ដាប់តាមពាក្យសម្ដីរបស់ព្យាការីយ៉ាងដូចម្ដេច ? ( ខាងក្រោមនេះគឺជារបៀបមួយ ដើម្បីថ្លែងពីគោលការណ៍នេះ ៖ **បើយើងស្ដាប់តាមពាក្យសម្ដីរបស់ព្យាការីនោះយើងនឹងត្រូវបានការពារទាស់នឹងមារសត្រូវ ហើយទទួលពរជ័យពីឋានសួគ៌** ) ។

- ហេតុអ្វីបានជាការស្ដាប់តាម ( ការទទួលយក ហើយរស់នៅតាម ) និង ការដែលពុំគ្រាន់តែស្ដាប់ឮប្រសាសន៍របស់ព្យាការី វាសំខាន់ដើម្បីទទួលបានពរជ័យទាំងនេះយ៉ាងដូច្នេះ ?
- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ ត្រូវបានការពារប្រឆាំងនឹងមាសត្រូវតាមរយៈការធ្វើតាមប្រសាសន៍របស់ព្យាការីដែលនៅរស់នៅពេលណា ?

សូមឲ្យសិស្សគិតអំពីការបង្រៀនរបស់ព្យាការីនៅរស់ ដើម្បីពួកគេអាចចាំបាច់ស្ដាប់តាម ឬ រស់នៅតាមកាន់តែឲ្យប្រសើរឡើង ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើអ្វីមួយដើម្បីអនុវត្តតាមការបង្រៀនសព្វថ្ងៃនេះ ។

សូមសរសេរឃ្លានេះ « *យើងដឹងថា . . .* » នៅលើក្ដារខៀន ។

សូមរំឭកសិស្សថា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ត្រូវបានអានឮៗនៅក្នុងសន្និសីទមួយចំនួនរបស់សាសនាចក្រកាលពីជំនាន់មុន ដើម្បីរំឭកដល់សមាជិកនៃសាសនាចក្រថ្មីនេះ អំពីសេចក្ដីពិតដ៏ចាំបាច់ជាច្រើននៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមចែកសិស្សជាបួនក្រុម ។ សូមចាត់ឲ្យក្រុមនីមួយៗអានសេចក្ដីយោងខាងក្រោម ដោយរកមើលគោលលទ្ធិនានាដែលអាចត្រូវបានបញ្ចូលខាងក្រោមឃ្លា « យើងដឹងថា. . . »

- គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧
- គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៨–១៩
- គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២១–២៣
- គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២៥, ២៩

បន្ទាប់ពីសិស្សមានពេលសិក្សាវគ្គគម្ពីររបស់ខ្លួនហើយ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីគោលលទ្ធិដែលពួកគេបានរកឃើញ ។ ( សូមឲ្យសិស្សម្នាក់ធ្វើជាអ្នកសរសេរ ហើយសរសេរសេចក្ដីពិតទាំងនេះនៅលើក្ដារខៀន នៅពេលសិស្សក្នុងថ្នាក់រកឃើញសេចក្ដីពិតទាំងនោះ ) ។

គោលលទ្ធិទាំងឡាយ ដែលសិស្សរកឃើញ អាចរួមមានដូចខាងក្រោម ៖

**មានព្រះមួយអង្គដែលនៅជានិរន្តរ៍ និងអស់កល្បជានិច្ច ឥតប្រែប្រួល** (ខ ១៧) ។

**យើងត្រូវបានបង្កើតឡើងតាមរូបអង្គទ្រង់ និងដូចជារូបរបស់ព្រះ** (ខ ១៨) ។

**ព្រះប្រទានព្រះរាជបុត្រាសំណប់តែមួយគត់របស់ទ្រង់ ដើម្បីត្រូវគេឆ្កាង ហើយរស់ឡើងវិញម្ដងទៀត** (ខ ២១–២៣) ។

**មនុស្សទាំងអស់ត្រូវតែប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទ ត្រូវជ្រមុជទឹក និង កាន់ខ្ជាប់ដោយសេចក្ដីជំនឿ ដើម្បីត្រូវបានសង្គ្រោះ** (ខ ២៥, ២៩) ។

នៅពេលសិស្សបានបញ្ចប់ធ្វើបញ្ជីនៃសេចក្ដីពិត ដែលពួកគេបានរកឃើញនៅក្នុងខគម្ពីរទាំងនេះ សូមឲ្យពួកគេជ្រើសរើសសេចក្ដីពិតមួយដែលមានអត្ថន័យចំពោះពួកគេ ហើយថាពួកគេដឹងដោយផ្ទាល់ខ្លួនថាវាគឺជាការពិត ។ សូមអញ្ជើញសិស្សមួយចំនួនឲ្យចែកចាយទីបន្ទាល់របស់ខ្លួនអំពីសេចក្ដីពិតដែលពួកគេបានជ្រើសរើស ហើយពន្យល់ពីមូលហេតុដែលសេចក្ដីពិតនោះសំខាន់ចំពោះពួកគេ ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នក អំពីសេចក្ដីពិតនានាដែលបានពិភាក្សាថ្ងៃនេះ និង អំណរគុណរបស់អ្នកចំពោះការធ្វើជាសមាជិកនៃសាសនាចក្ររបស់ព្រះអម្ចាស់ ដែលបានស្ដារឡើងវិញ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៩)

តើយ៉ាងម៉េចដែរ ប្រសិនបើអ្នកជួបនរណាម្នាក់ដែលមិនមែនជាព្យាការី ប៉ុន្តែបានប្រកាសថាទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល ? នៅក្នុងមេរៀនបន្ទាប់ សិស្សនឹងរៀនពីរបៀបដែលព្យាការីយ៉ូសែប ស្ម៊ីធដោះស្រាយនូវបញ្ហានេះ ។ ពួកគេក៏នឹងរៀនផងដែរអំពី ទីសម្គាល់ទាំងឡាយនៃការយាងមកជាលើកទីពីរ ?

មេរៀនទី ៣១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤ និង ២៦

## បុព្វកថា

នៅក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ ១៨៣០ យ៉ូសែប ស្ម៊ីធ និងសមាជិកសាសនាចក្រផ្សេងទៀត បានប្រឈមមុខនឹងការបៀតបៀនដ៏ខ្លាំងក្លា ។ អំឡុងគ្រានៃការលំបាកនេះ ព្រះអម្ចាស់ បានពង្រឹងដល់ យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី ហើយបានណែនាំពួកគេស្ដីអំពីទំនួលខុសត្រូវរបស់ពួកគេ តាមរយៈវិវរណៈដែលមាននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ២៤ ។ ព្រះអម្ចាស់ បានប្រទានការដឹកនាំចំពោះការអនុវត្តនូវការយល់ព្រមទូទៅនៅក្នុងសាសនាចក្រផងដែរ ដែលមាននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ២៦ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១–១២

*យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ទទួលបានការប្រឹក្សាស្ដីអំពីការហៅរបស់ពួកលោក*

មុនពេលថ្នាក់ចាប់ផ្ដើម សូមសរសេរនូវសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើអ្នកធ្វើអ្វីខ្លះ នៅពេលជីវិតជួបការលំបាក ?*

សូមសិស្សឲ្យគិតអំពីគ្រាលំបាក ឬគ្រាស្មុគស្មាញមួយ ដែលពួកគេបានជួប និងរបៀបដែលពួកគេប្រឈមមុខនឹងការលំបាក ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។ ( សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ដែលពុំគួរចែកចាយ ) ។

សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ បានជួបនឹងគ្រាលំបាកជាច្រើននៅក្នុងជីវិតរបស់លោក ។ សូមឲ្យសិស្សម្នាក់អានក្បាលរឿងនៃកណ្ឌ ២៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម និងប្រាប់អំពីស្ថានភាពដែលវិវរណៈនេះ និងវិវរណៈពីរទៀតត្រូវបានទទួលមក ។

ដើម្បីបង្ហាញពីការបៀតបៀនដែល យ៉ូសែប ស្ម៊ីធ និងអ្នកផ្សេងទៀត បានប្រឈមមុខនៅគ្រានេះ សូមគិតធ្វើការសុំដល់សិស្សឲ្យសង្ខេបអំពីជីវប្រវត្តិជាប្រវត្តិសាស្ត្រដូចខាងក្រោមឲ្យឮៗ ( អ្នកអាចនឹងត្រូវការផ្ដល់ព័ត៌មាននេះពីមុនចាប់ផ្ដើមថ្នាក់រៀនដើម្បីទុកពេលឲ្យសិស្សបានរៀបចំខ្លួន ) ៖

នៅក្នុងខែ មិថុនា ឆ្នាំ ១៨៣០ យ៉ូសែប ស្ម៊ីធ និងសហការីពីរបីនាក់ បានចេញទៅ ខូលស៊ីល រដ្ឋនូវយ៉ោក ដើម្បីជួបនឹងមនុស្សដែលចាប់អារម្មណ៍ក្នុងការទទួលបុណ្យជ្រមុជទឹក ។ ទឹកអូរមួយ ត្រូវបានទប់ទំនប់ឡើងដើម្បីរៀបចំសម្រាប់ពិធីបុណ្យជ្រមុជទឹកនៅថ្ងៃបន្ទាប់ ( ថ្ងៃអាទិត្យ ) ប៉ុន្តែពួកមនុស្សអាក្រក់បានបំផ្លាញទំនប់ទឹកនោះ នៅពេលយប់ ។ នៅព្រឹកថ្ងៃចន្ទ ទំនប់ទឹកត្រូវបានសង់ឡើងវិញ ហើយមនុស្សចំនួន ១៣ នាក់ត្រូវបានទទួលបុណ្យជ្រមុជទឹក រួមទាំង អិមម៉ា ស្ម៊ីធ ផង ។ ទោះជាយ៉ាងណា នៅពេលដែលពិធីបុណ្យជ្រមុជទឹកត្រូវបានបញ្ចប់ នោះពួកមនុស្សអាក្រក់ ជិត ៥០ នាក់បានប្រមូលផ្ដុំគ្នាដេរប្រមាថ ហើយគំរាមគំហែងដើម្បីធ្វើទុក្ខទោសដល់ពួកបរិសុទ្ធ ។ នាល្ងាចនោះ ពួកបរិសុទ្ធ បានជួបជុំគ្នាដើម្បីធ្វើពិធីបញ្ជាក់ដល់អ្នកទាំងឡាយដែលបានជ្រមុជទឹកពីព្រឹកមិញ ប៉ុន្តែមុនពេលដែលពិធីបញ្ជាក់ត្រូវបានធ្វើឡើង នោះយ៉ូសែប ត្រូវបានគេចាប់ខ្លួន ដោយចោទប្រកាន់ថា « ជាអ្នកធ្វើឲ្យច្របូកច្របល់ ដែលធ្វើឲ្យទីក្រុងមានភាពវឹកវរដោយការផ្សាយព្រះគម្ពីរមរមន » ។ ( សូមមើល *History of the Church,* ១:៨៦–៨៨ ) ។

នៅតាមផ្លូវទៅកាន់កន្លែងកាត់ក្ដី នោះយ៉ូសែប បានគេចខ្លួនពីមនុស្សអាក្រក់ ដោយមានជំនួយពីមន្ត្រីចិត្តល្អម្នាក់ ដែលអមដំណើរលោក ។ បន្ទាប់ពីបានកាត់ក្ដី ហើយរកឃើញថា គ្មានទោសកំហុសអ្វីសោះ នោះយ៉ូសែប ត្រូវបានចាប់ខ្លួនម្ដងទៀតភ្លាមៗ ដោយការពួកទាហានមកពីទីក្រុងផ្សេង ។ នៅយប់នោះ យ៉ូសែប ត្រូវបានគេរិះគន់ ហើយរំលោភបំពានដោយ « មនុស្សមួយហ្វូង » ហើយនៅព្រឹកឡើង លោកត្រូវបានកាត់ក្ដី ។ យ៉ូសែប ស្ម៊ីធ ត្រូវបានរកឃើញថា គ្មានទោសកំហុសអ្វីសោះម្ដងទៀត ហើយក៏បានគេចខ្លួនពីពួកមនុស្សអាក្រក់ផ្សេងទៀត ពេលលោកបានធ្វើដំណើរមកផ្ទះ ។ ( សូមមើល *History of the Church,* ១:៨៨–៩៦ ) ។

យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានព្យាយាមម្ដងទៀត ដើម្បីទៅជួបនឹងសមាជិកដែលបានជ្រមុជទឹកថ្មីៗនៅ ខូលស្វីល ប៉ុន្តែពួកមនុស្សអាក្រក់ បានផ្ដុំគ្នាមិនយូរប៉ុន្មានបន្ទាប់ពីពួកលោកបានទៅដល់ ។ យ៉ូសែប និង អូលីវើរ ត្រូវបានបង្ខំឲ្យរត់គេចខ្លួន គេចខ្លួនផុតបន្តិច ពេលមនុស្សអាក្រក់បានដេញតាមពួកលោកនាយប់នោះ ( សូមមើល *History of the Church,* ១:៩៧ ) ។ យ៉ូសែប បាននិយាយអំពីការព្យាយាមនេះថា « ក្រៅពីការក្រោធខឹងរបស់ពួកសត្រូវរបស់យើងទាំងអស់ នោះយើងបានទទួលការលួងលោមចិត្តយ៉ាងច្រើន ហើយរឿងជាច្រើនបានកើតឡើង ដើម្បីពង្រឹងដល់សេចក្ដីជំនឿរបស់យើង ហើយធ្វើឲ្យដួងចិត្តយើងរីករាយ » ( នៅក្នុង *History of the Church* ១:១០១ ) ។

សូមឲ្យសិស្សម្នាក់អានឲ្យឮៗនូវប្រយោគចុងក្រោយ នៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤ ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំប្រយោគនេះទុក ។ សូមអញ្ជើញពួកគេឲ្យពិចារណាអំឡុងមេរៀនអំពីរបៀបដែលពាក្យទូន្មានរបស់ព្រះអម្ចាស់ដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ក៏អាចជួយពួកគេ នៅពេលពួកគេជួបនឹងគ្រាលំបាកផងដែរ ។

សូមសរសេរប្រយោគខាងក្រោមនៅលើក្ដារខៀន ៖

| ការពង្រឹង និងការលើកទឹកចិត្ត | ការណែនាំ |
|---|---|
| | |

សូមចាត់សិស្សឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១–១ ២ ជាគូៗ ។ សូមអញ្ជើញសិស្សម្នាក់អានខដោយស្ងាត់ស្ងៀម រកមើលឃ្លាដែលអាចនឹងពង្រឹង ហើយលើកទឹកចិត្តដល់ព្យាការី និង អូលីវើរ ខៅឌើរី ។ សូមអញ្ជើញសិស្សទីពីរឲ្យអានខគម្ពីរស្វែងរកការណែនាំដែលព្រះអម្ចាស់បានប្រទានឲ្យ ។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមនាំសិស្សឲ្យចែកចាយជាមួយនឹងដៃគូរបស់ពួកគេអំពីអ្វីដែលពួកគេបានរកឃើញ ។ សូមអញ្ជើញដៃគូទាំងពីរឲ្យជ្រើសរើសឃ្លាមួយ ដែលមានអត្ថន័យចំពោះពួកគេ ហើយបញ្ចូលទៅក្នុងការពិភាក្សារបស់ពួកគេ អំពីរបៀបដែលពួកគេគិតថាការលើកទឹកចិត្ត ឬការណែនាំជាក់លាក់មកពីព្រះអម្ចាស់ អាចបានជួយដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។

> ***សូមធ្វើការជាដៃគូៗ***
> ការធ្វើការជាដៃគូ អាចផ្ដល់ឱកាសឲ្យសិស្សដើម្បី « បង្រៀនគ្នាទៅវិញទៅមកអំពីគោលលទ្ធិនៃនគរ » ( គ និង ស ៨៨:៧៧ ) ។ សូមគិតដោយប្រុងប្រយ័ត្ននៅក្នុងការសម្រេចចិត្តរបស់អ្នក អំពីសិស្សដែលអ្នកចាត់ឲ្យធ្វើការជាមួយគ្នា ។ សិស្សខ្លះអាចនឹងទទួលបានជំនួយ ឬជាការរំខានដល់គេ ពេលពួកគេមានដៃគូ ។

បន្ទាប់ពីដៃគូនីមួយៗបានពិភាក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១–១២ រួចហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យរាយការណ៍អំពីអ្វីដែលពួកគេបានរៀន ។ នៅពេលសិស្សផ្ដល់គំនិតរបស់ពួកគេ សូមផ្ដល់ពាក្យនៃការលើកទឹកចិត្ត និងការណែនាំ ដែលពួកគេរកឃើញដាក់នៅក្រោមក្បាលរឿងដែលត្រឹមត្រូវនៅលើក្ដារខៀន ។

- តើគោលការណ៍ណាខ្លះ ដែលយើងអាចរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:៨ ទាក់ទងនឹងអ្វីដែលអាចជួយយើងនៅក្នុងគ្រាទុក្ខលំបាករបស់យើង ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា *ទុក្ខលំបាក* គឺជាបុព្វហេតុ ឬស្ថានភាពមួយ នៃការឈឺចាប់ ការអស់សង្ឃឹម ឬ ការវេទនា ។ សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងអត់ធ្មត់ ហើយទ្រាំទ្រក្នុងទុក្ខលំបាករបស់យើង នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

ដើម្បីជួយសិស្សយល់នូវគោលការណ៍នេះ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ នូវការពន្យល់ដោយសង្ខេបអំពីអ្វីដែលពួកគេដឹងថាវាមានន័យយ៉ាងណា ដើម្បីមានភាពអត់ធ្មត់ និងស៊ូទ្រាំ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យអានការពិពណ៌នារបស់ពួកគេឲ្យឮៗ ។ បន្ថែមពីលើគំនិតរបស់ពួកគេ ដោយការពន្យល់ថា នៅក្នុងបរិបទដំណឹងល្អ ដើម្បីស៊ូទ្រាំការលំបាក អាចមានន័យថា នៅបន្តស្មោះត្រង់ចំពោះព្រះអម្ចាស់ ហើយទប់ទល់រាល់ការសាកល្បងដោយភាពក្លាហាន ។

- ហេតុអ្វីក៏វាពិបាកដើម្បីអត់ធ្មត់អំឡុងពេលមានទុក្ខលំបាក ?

- តើអ្នកបានឃើញមនុស្សអនុវត្តភាពអត់ធន់ ហើយបន្តស្មោះត្រង់អំឡុងពេលមានទុក្ខលំបាកនៅពេលណា ?

- តើព្រះអម្ចាស់បង្ហាញដល់អ្នកទាំងអស់នោះថា ទ្រង់គង់នៅជាមួយពួកគេយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យស្គាល់សេចក្ដីពិតមួយ ទាក់ទងទៅនឹងគោលការណ៍ ដែលបានសរសេរលើក្ដារខៀន សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១០–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីពរជ័យដែលព្រះអម្ចាស់ បានសន្យាដល់ អូលីវើរ ខៅឌើរី បើគាត់នឹងបន្តស្មោះត្រង់នៅក្នុងការហៅរបស់គាត់ ដើម្បីប្រកាសដំណឹងល្អ ។

- តើពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់សន្យានឹង អូលីវើរ ខៅឌើរី បើគាត់នឹងបន្តនៅស្មោះត្រង់ក្នុងការធ្វើនូវអ្វីដែលព្រះអម្ចាស់សុំឲ្យគាត់ធ្វើ ? ( ជួយសិស្សឲ្យមើលឃើញការសន្យាដូចខាងក្រោម ៖ « យើងនៅជាមួយនឹងលោកដរាបដល់ចុងបំផុត » [ ខ ១០ ] ។ « នៅក្នុងយើង នោះលោកនឹងបានសិរីល្អ » [ ខ ១១ ] ។ « យើងនឹងប្រទានដល់លោកនូវកម្លាំងដូចជាពុំដែលស្គាល់នៅក្នុងចំណោមមនុស្សមកឡើយ » [ ខ ១២ ] ។

សូមសរសេរដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើ . . . នោះ . . .* ] ។

សូមអញ្ជើញសិស្សឲ្យប្រាប់សេចក្ដីថ្លែងការណ៍ « បើ –នោះ » ដែលបង្ហាញពីគោលការណ៍ ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១០–១២ ។ ( សិស្សអាចនឹងប្រាប់គោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា គូសបញ្ជាក់អំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងស្មោះត្រង់ធ្វើនូវអ្វីដែលព្រះអម្ចាស់សុំឲ្យយើងធ្វើ នោះទ្រង់នឹងចម្រើនកម្លាំងយើង** ។ សូមបំពេញក្នុងកន្លែងទំនេរនៅលើក្ដារខៀន ដើម្បីបំពេញគោលការណ៍ ។

- តើព្រះអម្ចាស់បានចម្រើនកម្លាំងដល់អ្នក នៅពេលអ្នកស្មោះត្រង់ចំពោះទ្រង់យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យសរសេរនូវអ្វីមួយ ដែលពួកគេអាចធ្វើដើម្បីអត់ធ្មត់ ហើយបន្តស្មោះត្រង់ចំពោះព្រះអម្ចាស់ នៅពេលពួកគេប្រឈមមុខនឹងការលំបាកក្នុងជីវិតរបស់ពួកគេ ។ សូមពិចារណាធ្វើការចែកចាយអំពីរបៀបដែលអ្នកត្រូវបានចម្រើនកម្លាំង ហើយមានព្រះអម្ចាស់គង់នៅជាមួយអ្នក ដោយសារភាពអត់ធ្មត់ដោយស្មោះត្រង់របស់អ្នកនៅក្នុងគ្រាលំបាក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១៣–១៩

*ព្រះអម្ចាស់ណែនាំដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី អំពីកិច្ចការរបស់ពួកលោក និង អំពីអ្នកទាំងឡាយដែលប្រឆាំងជំទាស់នឹងពួកលោក*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១៣–១៩ ដោយពន្យល់ថា ព្រះអម្ចាស់ បានណែនាំដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ទាក់ទងនឹងអព្ភូតហេតុទាំងឡាយ ដែលពួកគេអាចធ្វើនៅក្នុងព្រះនាមរបស់ទ្រង់ ។ ទ្រង់ក៏បានប្រាប់ដល់ពួកគេអំពីការការពារ ដែលពួកគេអាចទទួលបាន នៅពេលមនុស្សប្រឆាំងជំទាស់នឹងពួកគេ ។ អ្នកក៏អាចនឹងចង់ពន្យល់ថា ព្រះអម្ចាស់បានប្រទានដល់ពួកលោកនូវការណែនាំមួយចំនួន ដែលខុសគ្នាពីការណែនាំដែលពួកអ្នកផ្សព្វផ្សាយសាសនាទទួលបាននៅសព្វថ្ងៃនេះ ។ ឧទាហរណ៍ ទ្រង់បានប្រទានដល់ពួកលោកនូវការអនុញ្ញាតដើម្បី « រលាស់ធូលីដីបាតជើង [ ពួកលោក ] ចេញ » ទុកជាទីបន្ទាល់ទាស់នឹងអ្នកទាំងឡាយដែលពុំទទួលពួកលោក ( គ និង ស ២៤:១៥ ) ។ ការអនុវត្តនេះ ត្រូវបានរក្សាទុកសម្រាប់ស្ថានភាពដ៏លើសលប់ ។ ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ពុំអនុញ្ញាតឲ្យធ្វើដូច្នេះទេសព្វថ្ងៃនេះ ។ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ក៏ត្រូវបានបញ្ជា « កុំឲ្យយកការបូប ឬយាម » ទៅជាមួយឡើយ ( គ និង ស ២៤:១៨ ) នោះមានន័យថា ពួកលោកបានធ្វើដំណើរដោយគ្មានប្រាក់ទេ ដោយពឹងផ្អែកលើសេចក្ដីល្អរបស់សមាជិកសាសនាចក្រ និងអ្នកដទៃដែលផ្ដល់អាហារ និងទីជម្រកដល់ពួកលោក ។ សព្វថ្ងៃនេះ ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ពុំត្រូវបានបញ្ជាឲ្យទៅដោយគ្មានយកការបូប ឬយាមទៅជាមួយនោះឡើយ ។

## គោលលទ្ធិ និង សេចក្ដី សញ្ញា ២៦

*ព្រះអម្ចាស់ ណែនាំយ៉ូសែប ស្ម៊ីធ, អូលីវើរ ខៅឌើរី និង យ៉ូហាន វិតមើរ*

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៦:១ មាននូវការណែនាំបន្ថែមដល់ យ៉ូសែប ស្ម៊ីធ, អូលីវើរ ខៅឌើរី និង យ៉ូហាន វិតមើរ ទាក់ទងនឹងកិច្ចការខាងវិញ្ញាណ និងខាងរាងកាយ ដែលពួកលោកត្រូវធ្វើ ។ រួចព្រះអម្ចាស់ បានគូសបញ្ជាក់ឡើងវិញអំពីសារៈសំខាន់នៃគោលការណ៍មួយដែលទាក់ទងនឹងការគ្រប់គ្រងសាសនាចក្រ ។ ដើម្បីណែនាំអំពីគោលការណ៍នេះ សូមលើកទឹកចិត្តដល់សិស្សឲ្យនឹកគិតថា មានមិត្តម្នាក់ដែលមានជំនឿផ្សេងបានទៅជាមួយពួកគេ ក្នុងការប្រជុំមួយ ដែលអ្នកកាន់តំណែងសាសនាចក្រ ត្រូវបានគាំទ្រ ។ សូមសួរដល់ពួកគេថា តើពួកគេនឹងពន្យល់ដល់មិត្តរបស់ពួកគេអំពី ការអនុវត្តនូវការគាំទ្រនេះយ៉ាងដូចម្ដេច ។ ( សូមគិតធ្វើការអញ្ជើញដល់សិស្សពីរនាក់ឲ្យសម្ដែងសីណារីយ៉ូនេះ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៦:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាមួយដែលទាក់ទងទៅនឹងការអនុវត្តនូវការគាំទ្រ ។ បន្ទាប់ពីអានខគម្ពីរនេះ សូមសួរសិស្សឲ្យប្រាប់វា ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យពួកគេគូសចំណាំពាក្យ ដែលបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **អ្វីៗគ្រប់យ៉ាងនៅក្នុងសាសនាចក្រ នឹងត្រូវធ្វើឡើងដោយការយល់ព្រមទូទៅ** ។

- តើអ្នកគិតថា « ការយល់ព្រមទូទៅ » មានន័យដូចម្ដេច ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា « ការយល់ព្រមទូទៅ » សំដៅទៅលើសមាជិកសាសនាចក្រដែលប្រើសិទ្ធិជ្រើសរើសរបស់ពួកគេ ដើម្បីបង្ហាញពីការស្ម័គ្រចិត្ត ឬការមិនស្ម័គ្រចិត្តរបស់ពួកគេ ក្នុងការគាំទ្រដល់ការដាក់ស្នើសុំមកពីអ្នកដឹកនាំសាសនាចក្រ ។ នៅក្នុងការប្រជុំសាក្រាម៉ង់ និងសន្និសីទស្តេក និងសន្និសីទទូទៅ យើងត្រូវបានសុំឲ្យយល់ព្រមដោយការលើកដៃស្ដាំរបស់យើងជាសញ្ញា ) ។

- តើការគាំទ្រដោយការយល់ព្រមទូទៅ និងការបោះឆ្នោតខុសគ្នាយ៉ាងណាខ្លះ ?

អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា នៅក្នុងនគររបស់ព្រះអម្ចាស់ ជាញឹកញាប់ ព្រះអម្ចាស់បានបើកសម្ដែងពីការសម្រេចព្រះទ័យរបស់ទ្រង់ចំពោះអ្នកដឹកនាំទាំងឡាយដែលបានតែងតាំងពីទ្រង់ ។ ទោះជាយ៉ាងណា ក្នុងករណីមួយចំនួន ទ្រង់អនុញ្ញាតឲ្យអ្នកដឹកនាំធ្វើការសម្រេចចិត្ត តាមរយៈសិទ្ធិអំណាចដែលបានប្រគល់ឲ្យពួកគាត់ ។ ព្រះវិញ្ញាណបរិសុទ្ធ បញ្ជាក់អំពីការសម្រេចចិត្តទាំងនេះ ហើយសមាជិកសាសនាចក្រ ប្រើសិទ្ធិជ្រើសរើសរបស់ពួកគេ ដើម្បីបង្ហាញពីការស្មគ្រ័ចិត្តគាំទ្រដល់ការសម្រេចចិត្តនោះជាសញ្ញាលើកដៃ ។ ច្បាប់នៃការយល់ព្រមទូទៅ អនុវត្តចំពោះការហៅបម្រើក្នុងសាសនាចក្រ ការតែងតាំង

បព្វជិតភាព និងវិវរណៈ ។ យើងចូលរួមក្នុងច្បាប់នៃការយល់ព្រមទូទៅរាល់ពេល ដែលយើងលើកដៃរបស់យើង ដើម្បីគាំទ្រមនុស្សម្នាក់ ឬការសម្រេចចិត្តមួយក្នុងការប្រជុំសាសនាចក្រនោះ ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមពីអត្ថន័យ ពេលដែលយើងគាំទ្រអ្នកដទៃ សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការដូចខាងក្រោម ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្ដាប់នូវរឿងបីយ៉ាង ដែលយើងតាំងចិត្តធ្វើ នៅពេលយើងគាំទ្រអ្នកដទៃដោយការយល់ព្រមទូទៅ ។



« ទម្រង់ការនៃការគាំទ្រ គឺមានន័យច្រើនជាងការលើកដៃជាផ្លូវការមួយ ។ វាគឺជាការតាំងចិត្តមួយដើម្បីលើកស្ទួយ គាំទ្រ ជួយដល់អ្នកទាំងឡាយ ដែលត្រូវបានជ្រើសរើស » ( « This Work Is Concerned with People » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៥ ទំព័រ ៥១ ) ។

- តើយើងត្រូវតាំងចិត្តធ្វើអ្វីខ្លះ ពេលយើងលើកដៃរបស់យើងដើម្បីគាំទ្រដល់អ្នកដទៃ ?

សូមសួរដល់សិស្ស បើពួកគេធ្លាប់ត្រូវបានគាំទ្រសម្រាប់ការតែងតាំងមួយ ការរីកចម្រើន ឬការហៅបម្រើមួយដែរឬទេ ។

- តើអ្នកមានអារម្មណ៍បែបណាអំពីការដែលត្រូវបានគេគាំទ្រនោះ ?
- តើយើងអាចគាំទ្រអ្នកដទៃតាមវិធីបីយ៉ាង ដែលប្រធាន ហ៊ិងគ្លី បានពិពណ៌នាយ៉ាងដូចម្ដេច ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សឲ្យសរសេរឈ្មោះរបស់បុគ្គលម្នាក់ ដែលពួកគេបានគាំទ្រដោយការលើកដៃរបស់ពួកគេ ( ឧទាហរណ៍ ព្យាការី ពួកសាវក ប៊ីស្សព ឬអ្នកដឹកនាំយុវវ័យ ) ។ សូមឲ្យសិស្សសរសេរនូវសកម្មភាពមួយ ដែលពួកគេនឹងធ្វើ ដើម្បីគាំទ្រដល់បុគ្គលនេះបានកាន់តែល្អប្រសើរ ។ សូមបង្ហាញទីបន្ទាល់របស់អ្នកអំពី ពរជ័យដែលកើតមាន តាមរយៈការគាំទ្រដល់អ្នកដឹកនាំសាសនាចក្រ ។

មេរៀន ទី ៣២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥

## បុព្វកថា

ការបៀតបៀនទាស់នឹងព្យាការី យ៉ូសែប ស្ម៊ីធ និងសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានបន្តអំឡុងរដូវក្ដៅនៃឆ្នាំ ១៨៣០ ។ ភរិយារបស់យ៉ូសែប ឈ្មោះ អិមម៉ា បានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃទី ២៨ ខែមិថុនា ប៉ុន្តែការបៀតបៀននៃសមាជិកបានពន្យាពេលពិធីបញ្ជាក់របស់គាត់ រហូតដល់ខែសីហា ឆ្នាំ ១៨៣០ ។ នៅចុងខែមិថុនា ក្នុងចន្លោះពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់របស់ អិមម៉ា នោះ យ៉ូសែប បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ ។ នៅក្នុងនោះ ព្រះអម្ចាស់ បានផ្ដល់នូវពាក្យលួងលោមដល់ អិមម៉ា ក៏ដូចជាផ្ដល់ការណែនាំ ទាក់ទងនឹងគ្រួសារនាង និងទំនួលខុសត្រូវក្នុងសាសនាចក្រ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១–៣

*ព្រះអម្ចាស់ បានថ្លែងពី អិមម៉ា ស្ម៊ីធ ថាជាស្ត្រីជម្រើស*

មុនពេលចាប់ផ្ដើមថ្នាក់រៀន សូមអញ្ជើញសិស្សបីនាក់ឲ្យសិក្សាខ្លួនឯងឲ្យចេះរឿង ហើយសង្ខេបរឿងអំពីជីវិត និងចរិកលក្ខណៈរបស់ អិមម៉ា ស្ម៊ីធ ដែលជាភរិយារបស់ ព្យាការីយ៉ូសែប ដូចខាងក្រោម ។ សូមចាប់ផ្ដើមថ្នាក់រៀន ដោយការអញ្ជើញឲ្យសិស្សទាំងបីនាក់នេះ ប្រាប់ដល់សិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានរៀនអំពី អិមម៉ា ស្ម៊ីធ ។ អ្នកអាចនឹងចង់បង្ហាញរូបភាពរបស់ អិមម៉ា ស្ម៊ីធ ( *សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] លេខ ៨៨ សូមមើលផងដែរ LDS.org ) ។



១. អិមម៉ា បានជួយ យ៉ូសែប ស្ម៊ីធ អំឡុងការបកប្រែនៃព្រះគម្ពីរមរមន

មិនយូរប៉ុន្មានបន្ទាប់ពី អិមម៉ា ហេល បានរៀបការនឹង យ៉ូសែប ស្ម៊ីធ នោះទេវតាមរ៉ូណៃបានប្រាប់ដល់ យ៉ូសែប ថា ពេលវេលាបានមកដល់ហើយ ដើម្បីលោកទទួលយកផ្ទាំងចំណារមាស ។ នៅព្រឹកព្រលឹម ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៨២៧ យ៉ូសែប និង អិមម៉ា បានជិះរទេះសេះជាមួយគ្នាទៅកាន់កូនភ្នំ គូម៉ូរ៉ា ជាកន្លែងដែល យ៉ូសែប បានទទួលផ្ទាំងចំណារ ។ ដោយសារតែការបៀតបៀននៅក្នុងរដ្ឋ នូវ យ៉ោក នោះ យ៉ូសែប និង អិមម៉ា ក្រោយមកបានផ្លាស់ទៅកាន់ ហាម៉ូនី រដ្ឋផែនស៊ីលវេញ៉ា ជាកន្លែងដែលក្រោយមកពួកគេបានទិញដីពីឪពុកម្ដាយរបស់ អិមម៉ា ។ នៅហាម៉ូនីនោះ ព្យាការី បានចាប់ផ្ដើមបកប្រែផ្ទាំងចំណារ ។ អិមម៉ា បានធ្វើជាស្មៀនខណៈដែលយ៉ូសែប បានបកប្រែអស់មួយរយៈកាល ។ មកដល់ពេលនេះ យ៉ូសែប ត្រូវបានបញ្ជាថា លោកពុំគួរបង្ហាញផ្ទាំងចំណារទៅដល់នរណាម្នាក់ឡើង សូម្បីតែ អិមម៉ា ផងដែរ ។ ទោះជា អិមម៉ា បានមើលឃើញផ្ទាំងចំណារដាក់នៅលើតុដោយមានគ្របក្រណាត់ក្ដី ក៏នាងពុំដែលបានបើកក្រណាត់ឡើងដើម្បីមើលផ្ទាំងចំណារដែរ ។

២. អិមម៉ា បានជួបនឹងសោកនាកដកម្ម ការឈឺចាប់ និងការបៀតបៀន ។

ខណៈពេលកំពុងរស់នៅក្នុងហាម៉ូនី រដ្ឋផែនស៊ីលវេញ៉ា អិមម៉ា បានបង្កើតកូនប្រុសម្នាក់ ដាក់ឈ្មោះថា អាល់វិន ដែលមានអាយុខ្លី ។ អិមម៉ាផ្ទាល់បានធ្លាក់ខ្លួនឈឺជាទម្ងន់ ហើយ យ៉ូសែប ខ្លាចថានាងនឹងពុំអាចរស់ផងដែរ ។ នៅពេលនាង

បានជាសះស្បើយ នាងបានឮដំណឹងដ៏អាក្រក់ថា ឯកសារសរសេរដោយដៃដែលបានបកប្រែចំនួន ១១៦ ទំព័រ ត្រូវបានបាត់នៅក្នុងដៃមិត្តរបស់យ៉ូសែប ឈ្មោះ ម៉ាទីន ហារិស ។ ទោះជានាងមានសុខភាពមិនល្អក្ដី ក៏អិមម៉ា បានលួងលោមចិត្តស្វាមីដែលបាក់ទឹកចិត្តរបស់នាង ដែលបានបាត់បង់អំណាចដើម្បីបកប្រែដែរ ។ ពួកគាត់បានរង់ចាំជាមួយគ្នា ដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ ចំពោះការបកប្រែផ្ទាំងចំណារ ។ ក្រោយមក នាងត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះនាងនៅភូមិហាម៉ូនី ដោយសារតែការគំរាមគំហែងមកពីមនុស្សឃោរឃៅ ។

៣. នៅថ្ងៃដែល អិមម៉ា ទទួលបុណ្យជ្រមុជទឹក នោះ យ៉ូសែប ត្រូវបានគេចាប់ខ្លួន ។

នៅក្នុងខែ មិថុនា ឆ្នាំ ១៨៣០ យ៉ូសែប និងក្រុមអ្នកជឿមួយចំនួនតូចបានសង់ទំនប់ទឹកមួយ នៅក្នុងស្ទឹងមួយជិតនឹងខូលស្វីល រដ្ឋនូវយ៉ោក ដើម្បីបង្កើតជាអាងជ្រៅល្មមដើម្បីធ្វើពិធីបុណ្យជ្រមុជទឹក ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សអាក្រក់បានទម្លាយទំនប់ទឹក មុនពេលពិធីបុណ្យជ្រមុជទឹកអាចធ្វើឡើង ។ ថ្ងៃស្អែកឡើង ពួកបរិសុទ្ធបានសង់ទំនប់ទឹកឡើងវិញ ហើយបានធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មនុស្ស ១៣ នាក់ រួមទាំង អិមម៉ា ស្ម៊ីធផងដែរ ។ នៅយប់នោះមុនពេលដែលពិធីបញ្ជាក់ត្រូវបានធ្វើឡើង នោះយ៉ូសែប ត្រូវបានគេចាប់ខ្លួន ដោយចោទប្រកាន់ថា « ជាអ្នកធ្វើឲ្យច្របូកច្របល់ » ( *History of the Church* ១:៨៨ ) ។ លោកត្រូវបានកាត់ក្តី ហើយរកឃើញថា គ្មានទោសកំហុសអ្វីសោះ នោះយ៉ូសែប ត្រូវបានចាប់ខ្លួនម្តងទៀតភ្លាមៗ ដោយការចោទប្រកាន់ដូចគ្នា ដោយពួកទាហានមកពីទីក្រុងផ្សេង ។ លោកត្រូវបានដោះលែងម្ដងទៀត ។ ដោយសារតែមានការជំទាស់ជាបន្តបន្ទាប់ទៅនឹងកិច្ចខិតខំផ្សព្វផ្សាយសាសនារបស់ពួកគាត់ នោះសមាជិកសាសនាចក្រ ត្រូវពន្យាពេលការប្រជុំធ្វើពិធីបញ្ជាក់របស់ពួកគាត់ ។ អិមម៉ា ពុំត្រូវបានធ្វើពិធីបញ្ជាក់ជាសមាជិកសាសនាចក្រ ហើយប្រទានឲ្យនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធទេ រហូតដល់ដើមខែសីហា ។ នៅចុងខែមិថុនា ចន្លោះពេលនៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់របស់នាង យ៉ូសែប បានទទួលវិវរណៈមួយសម្រាប់អិមម៉ា ដែលឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ ។

- តើអ្វីខ្លះ ដែលធ្វើឲ្យអ្នកចាប់អារម្មណ៍អំពី អិមម៉ា ស្ម៊ីធ នៅពេលអ្នករៀនអំពីបទពិសោធន៍មួយចំនួនរបស់នាងនោះ ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១–៣ ដោយស្ងាត់ស្ងៀម រកមើលពាក្យ ឬឃ្លាទាំងឡាយ ដែលអាចជាការលួងលោមចិត្តដល់ អិមម៉ា ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីអ្វី ដែលពួកគេរកឃើញ ហើយពន្យល់អំពី មូលហេតុដែលពួកគេគិតថាពាក្យ ឬឃ្លាទាំងនោះ អាចជាការលួងលោមចិត្តដល់នាង ។

- តើការដឹងថា អ្នកជាបុត្រា ឬបុត្រីម្នាក់ នៅក្នុងនគររបស់ព្រះអម្ចាស់ ជួយដល់អ្នក អំឡុងគ្រាលំបាកយ៉ាងដូចម្តេច ?
- តើព្រះអម្ចាស់សន្យា អិមម៉ា អ្វីខ្លះ បើនាងនឹងនៅស្មោះត្រង់ ហើយ « ដើរតាមផ្លូវគុណធម៌ » នោះ ?
- តើអ្នកគិតថា « ដើរតាមផ្លូវគុណធម៌ » មានន័យដូចម្តេច ? តើមនុស្សដែលដើរតាមផ្លូវគុណធម៌អាចត្រូវបានការពារដោយរបៀបណា ?

សូមបង្វែរចំណាប់អារម្មណ៍របស់សិស្សទៅលើឃ្លា « ស្ត្រីជម្រើស » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:៣ ។ អ្នកអាចនឹងចង់ស្នើឲ្យពួកគេគូសចំណាំឃ្លានេះ ។ សូមពន្យល់ថា នៅពេលសមាគមសង្គ្រោះ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៨៤២ ( ច្រើនជាងមួយទស្សវត្ស បន្ទាប់ពីវិវរណៈត្រូវបានប្រគល់ឲ្យ » អិមម៉ា ស្ម៊ីធ ត្រូវបានហៅឲ្យធ្វើជាប្រធានទីមួយនៃអង្គការនេះ ។ នៅក្នុងគ្រាដដែលនោះ ព្យាការីយ៉ូសែប ស្ម៊ីធ បានអានវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ ។ រួចលោកបានពន្យល់ថា អិមម៉ា គឺជាស្ត្រី « ជម្រើស » ដោយសារនាងត្រូវបាន « ជ្រើសរើសឲ្យធ្វើកិច្ចការជាក់លាក់មួយ. . . ហើយវិវរណៈនោះត្រូវបានបំពេញដោយសារ ការជ្រើសរើស [ របស់នាង ] ឲ្យធ្វើជាគណៈប្រធាននៃសមាគមសង្គ្រោះ ដែលនាងត្រូវបានតែងតាំងពីមុនមកឲ្យពន្យល់បទគម្ពីរ » ( នៅក្នុង *History of the Church* ៤:៥៥២–៥៣ ) ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ២៥:៤–១៦

*អិមម៉ា ស្ម៊ីធ បានទទួលការទូន្មានទាក់ទងនឹងគ្រួសាររបស់នាង និងកាតព្វកិច្ចក្នុងសាសនាចក្រ*

សូមសរសេរពាក្យដូចខាងក្រោមនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យចម្លងវាដាក់ទៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

| ការទូន្មាន | ការហៅ | ការសន្យា |
| --- | --- | --- |
| | | |

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ២៥:៤–១៦ ដោយស្ងាត់ស្ងៀម ហើយរកមើលឃ្លា ឬគំនិត ដែលទាក់ទងទៅនឹងផ្នែកទាំងបី ដែលបានសរសេរនៅលើក្ដារខៀន ។ ( ពួកគេអាចធ្វើដូចនេះតែឯង ឬជាមួយនឹងដៃគូម្នាក់ ) ។ សូមពួកគេឲ្យសរសេរនូវអ្វីដែលពួកគេរកឃើញ ដាក់នៅក្រោមផ្នែកត្រឹមត្រូវ ។ ( ឧទាហរណ៍ នៅក្នុងខ៤ ការណែនាំរបស់ព្រះអម្ចាស់ចំពោះ អិមម៉ា « កុំរអ៊ូរទាំ » ដោយសារតែនាងពុំបានមើលឃើញផ្ទាំងចំណារ អាចចាត់ជាដំបូន្មានវិញ ) ។

បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមចាត់សិស្សឲ្យពិភាក្សាអំពីសំណួរដូចខាងក្រោមជាក្រុមតូចៗ ។ អ្នកអាចសរសេរសំណួរនៅលើក្ដារខៀន ឬរៀបចំវានៅលើក្រដាសសម្រាប់ចែកដល់ក្រុមនីមួយៗ ។ អ្នកអាចនឹងចង់ចាត់ឲ្យមានអ្នកដឹកនាំការពិភាក្សាម្នាក់ នៅក្នុងក្រុមនិមួយៗ ដើម្បីសួរសំណួរ និងលើកទឹកចិត្តឲ្យមានការរួមចំណែកពីសិស្សម្នាក់ៗ ។

- តើឃ្លា ឬគំនិតណាមួយ ដែលអ្នកបានស្គាល់ ដែលបង្ហាញថា ព្រះអម្ចាស់ស្គាល់ និងស្រឡាញ់ចំពោះ អិមម៉ា ស្ម៊ីធ ? សូមពន្យល់អំពីរបៀបដែលឃ្លា ឬគំនិតនីមួយៗ គឺជាភស្តុតាងនៃសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ ។
- គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៦ មាននូវសេចក្ដីប្រកាសរបស់ព្រះអម្ចាស់ ដែលទ្រង់មានព្រះទ័យផ្ដល់ការទូន្មាន និងការសន្យានៅក្នុងកណ្ឌនេះ ក៏អនុវត្តចំពោះយើងផងដែរ ។ តើមេរៀនមួយចំនួនដែលអ្នករៀនមកពីព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅដល់ អិមម៉ា ស្ម៊ីធ មានអ្វីខ្លះ ? ( នៅពេលអ្នកប្រាប់អំពីសេចក្ដីពិតទាំងនេះ សូមសរសេរវាទុក ) ។

បន្ទាប់ពីក្រុមពិភាក្សាអំពីចម្លើយរបស់ពួកគេចំពោះសំណួរទាំងនេះ សូមឲ្យពួកគេប្រាប់ដល់សិស្សក្នុងថ្នាក់អំពីគោលការណ៍ទាំងឡាយ ដែលពួកគេបានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:៤–១៦ ។ ចម្លើយរបស់ពួកគេអាចនឹងរួមមានចម្លើយមួយចំនួន ឬទាំងអស់ដូចខាងក្រោម ( ទោះជាយ៉ាងណា ពួកគេអាចនឹងនិយាយពាក្យផ្សេងៗគ្នាក្ដី ) ៖

**យើងត្រូវទុកចោលនូវរឿងនៃលោកិយ ហើយស្វែងរកអ្វីដែលអស់កល្បជានិច្ចវិញ ។**

**នៅពេលយើងថ្វាយបង្គំព្រះអម្ចាស់ តាមរយៈតន្ត្រីសុចរិត នោះទ្រង់នឹងប្រទានពរដល់យើង ។**

**យើងអាចរកបានក្ដីអំណរ និង ការកម្សាន្តចិត្តនៅក្នុងការនៅជាប់នឹងសេចក្ដីសញ្ញា ដែលយើងបានចុះជាមួយព្រះអម្ចាស់ ។**

**បើយើងនឹងរក្សាបទបញ្ញត្តិរបស់ព្រះដោយខ្ជាប់ខ្ជួន នោះយើងនឹងទទួលបានមកុដនៃសេចក្ដីសុចរិត ។**

នៅពេលសិស្សរាយការណ៍អំពីសេចក្ដីពិតដែលពួកគេបានចង្អុលប្រាប់ សូមពិភាក្សាចម្លើយរបស់ពួកគេនឹងសិស្សក្នុងថ្នាក់ ។ សូមធ្វើតាមការដឹកនាំរបស់ព្រះវិញ្ញាណ នៅពេលអ្នកអញ្ជើញសិស្សឲ្យពន្យល់អំពីអ្វីដែលពួកគេបានរកឃើញ ហើយចែកចាយអំពីការយល់ដឹង និងគំនិតទាំងឡាយ ។ សំណួរ និងការណែនាំទាំងឡាយនៅខាងក្រោម អាចនឹងជាប្រយោជន៍នៅពេលអ្នកដឹកនាំការពិភាក្សានេះ ។

**យើងត្រូវទុកចោលរឿងនៃលោកិយ ហើយស្វែងរកអ្វីដែលអស់កល្បជានិច្ចវិញ**( សូមមើល គ និង ស ២៥:១០ ) ។

- តើអ្នកគិតថាការទូន្មានឲ្យដាក់រឿងអស់កល្បជានិច្ចមុនរឿងនៃលោកិយនេះ អាចនឹងជាប្រយោជន៍ដល់ អិមម៉ា ជាពិសេសក្នុងនាមជាភរិយារបស់ យ៉ូសែប ស្ម៊ីធ យ៉ាងដូចម្ដេច ? ( វាអាចនឹងជាប្រយោជន៍ដើម្បីពន្យល់ថា អិមម៉ា ហេល ត្រូវបានចិញ្ចឹមបីបាច់ធំឡើងនៅក្នុងគ្រួសារមានស្ដុកស្ដម ប៉ុន្តែ បន្ទាប់ពីរៀបការ បានរស់នៅក្នុងស្ថានភាពក៏ក្រខ្សត់បំផុត ) ។
- តើការទូន្មានឲ្យដាក់រឿងអស់កល្បជានិច្ច មុនរឿងនៃលោកិយ ជាប្រយោជន៍ដល់យើងសព្វថ្ងៃនេះយ៉ាងដូចម្ដេច ?
- តើរឿងមួយចំនួននៃលោកិយ ដែលមនុស្សមានទំនោរដាក់មុនព្រះមានអ្វីខ្លះ ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីស្វែងរកអ្វីដែលអស់កល្បជានិច្ច ?

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពួកគេកំពុងដាក់រឿងខាងលោកិយមុនព្រះដែរឬទេ ។

**នៅពេលយើងថ្វាយបង្គំព្រះអម្ចាស់តាមរយៈតន្ត្រីដ៏សុចរិត នោះទ្រង់នឹងប្រទានពរយើង**( សូមមើលគ និង ស ២៥:១២ ) ។

- យោងតាមខគម្ពីរនេះ តើរឿងមួយដែលព្រះសព្វព្រះទ័យគឺជាអ្វី ? តើទ្រង់មានបន្ទូលអំពីពរជ័យអ្វីខ្លះ ដែលកើតមានតាមរយៈ « ចម្រៀងនៃពួកសុចរិត » នោះ ?
- តើពរជ័យអ្វីខ្លះ ដែលអ្នកបានទទួលជាលទ្ធផលនៃការថ្វាយបង្គំដល់ព្រះអម្ចាស់ តាមរយៈតន្ត្រីត្រឹមត្រូវនោះ ?

សូមពិចារណាធ្វើការអញ្ជើញសិស្សឲ្យដាក់គោលដៅមួយ ដើម្បីស្ដាប់ដន្ត្រីសក្ដិសម និងត្រឹមត្រូវ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យរកមើលពរជ័យដែលនឹងកើតមាន នៅពេលពួកគេព្យាយាមសម្រេចគោលដៅនេះ ។

**យើងអាចរកបានក្ដីអំណរ និង ការកម្សាន្តចិត្ត ដោយការនៅជាប់ក្នុងសេចក្ដីសញ្ញា ដែលយើងបានចុះជាមួយព្រះអម្ចាស់** ( សូមមើល គ និង ស ២៥:១៣ ) ។

អ្នកអាចនឹងចង់ពន្យល់ថា ឃ្លាថា « នៅជាប់នឹងសេចក្ដីសញ្ញា » មានន័យថា គោរពតាមយ៉ាងជិតដល់ ឬកាន់ខ្ជាប់ទៅនឹងការសន្យា ដែលយើងបានធ្វើជាមួយនឹងព្រះ ។

សូមគិតអំពី នរណាម្នាក់ដែលអ្នកស្គាល់ ដែលបានបន្តនៅស្មោះត្រង់ចំពោះសេចក្ដីសញ្ញារបស់ពួកគេ ទោះជាអំឡុងពេលមានគ្រាលំបាកក្ដី ។

### *ការដឹកនាំការពិភាក្សាក្នុងថ្នាក់*

ការពិភាក្សាក្នុងថ្នាក់ អាចជួយសិស្សរៀនពីគ្នាទៅវិញទៅមក ទទួលបានការយល់ដឹងកាន់តែជ្រៅជ្រះអំពីសេចក្ដីពិតដែលបានពិភាក្សា ហើយមានបំណងប្រាថ្នាដើម្បីអនុវត្តនូវអ្វីដែលពួកគេរៀន ។ តាមរយៈការស្ដាប់ដោយយកចិត្តទុកដាក់ចំពោះសិស្ស ហើយសួរសំណួរតាមដាន នោះអ្នកអាចយល់ពីតម្រូវការពួកគេ ហើយដឹកនាំការពិភាក្សានៅក្រោមការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។ សូមពិចារណាដើម្បីសួរសំណួរដូចជា « តើអ្នកអាចជួយខ្ញុំឲ្យយល់ពីអ្វីដែលអ្នកចង់មានន័យបានឬទេ ? » ឬ សូមសួរដល់សមាជិកថ្នាក់ដទៃទៀតថា « តើអ្នកនឹងបន្ថែមអ្វីខ្លះចំពោះយោបល់នោះ ? »

- តើភាពស្មោះត្រង់គឺជាពរជ័យមួយចំពោះគាត់យ៉ាងដូចម្ដេច ?
- តើអ្នកបានទទួលពរជ័យនៅពេលណា ដោយសារតែអ្នកនៅស្មោះត្រង់ចំពោះសេចក្ដីសញ្ញា ដែលអ្នកបានធ្វើនោះ ?

សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលពួកគេអាចនឹងលើកដួងចិត្តឡើង ហើយនៅពិតស្មោះចំពោះសេចក្ដីសញ្ញារបស់ពួកគេ ។

**បើយើងនឹងរក្សាបទបញ្ញត្តិរបស់ព្រះជាបន្តបន្ទាប់ នោះយើងនឹងទទួលបានមកុដនៃសេចក្ដីសុចរិត**( សូមមើល គ និង ស ២៥:១៥ ) ។

សូមពន្យល់ថា ឃ្លា « មកុដនៃសេចក្ដីសុចរិត នោះអ្នកនឹងបានទទួល » សំដៅទៅលើការទទួលបានការលើកតម្កើងនៅក្នុងនគរសេឡេស្ទាល ( សូមមើលផងដែរ គ និង ស ២៩:១៣ ) ។

- តើការសន្យានេះ អាចជួយដល់នរណាម្នាក់ ដែលបានឆ្លងកាត់ ឬកំពុងដើរឆ្លងកាត់គ្រាលំបាកយ៉ាងដូចម្ដេច ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីគោរពប្រតិបត្តិជាបន្តបន្ទាប់ ហើយពុំមែនម្ដងម្កាលនោះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេអាចកែលម្អនៅក្នុងការគោរពប្រតិបត្តិជាបន្តបន្ទាប់ ។ អ្នកអាចនឹងចង់សុំឲ្យពួកគេសរសេរគំនិតរបស់ពួកគេទុកនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

បន្ទាប់ពីអ្នកបានពិភាក្សារឿងទាំងនេះ ដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ ជាមួយសិស្សក្នុងថ្នាក់ហើយ សូមអញ្ជើញសិស្សឲ្យគិតប្រកបដោយអធិស្ឋាន រួចសរសេរនូវអ្វីដែលពួកគេទទួលអារម្មណ៍មកពីព្រះអម្ចាស់ ដើម្បីឲ្យពួកគេធ្វើផ្អែកទៅលើអ្វីដែលបានរៀនមកពីក្នុងថ្នាក់នេះ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការដឹកនាំទាំងនេះ ។

មេរៀនទី ៣៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧

## បុព្វកថា

នៅក្នុងខែសីហា ឆ្នាំ ១៨៣០ នូវែល ណៃត និងភរិយារបស់គាត់ សាលី បានធ្វើដំណើរទៅ ភូមិ ហាម៉ូនី រដ្ឋផែនស៊ីលវេញ៉ា ដើម្បីសួរសុខទុក្ខ ព្យាការីយ៉ូសែប ស៊្មីធ ។ សាលី ណៃត និង អិមម៉ា ស៊្មីធ បានទទួលបុណ្យជ្រមុជទឹកនៅដើមខែមិថុនា ប៉ុន្តែពុំទាន់បានទទួលពិធីបញ្ជាក់ ដោយសារតែមានការបៀតបៀនពីពួកមនុស្សអាក្រក់ ។ អំឡុងការទៅសួរសុខទុក្ខរបស់ គ្រួសារ ណៃត នៅភូមិហាម៉ូនី នោះត្រូវបានកំណត់ថា សាលី និង អិមម៉ា គួរទទួលបានពិធីបញ្ជាក់ ហើយថាក្រុមដែលមកជាមួយយ៉ូហាន វិតមើរក៏នឹងបានទទួលទានសាក្រាម៉ង់ជុំគ្នាផងដែរ ។ នៅពេល យ៉ូសែប ចេញទៅក្រៅដើម្បីទទួលយកស្រាទំពាំងបាយជូរសម្រាប់ពិធីសាក្រាម៉ង់ នោះលោកបានជួបនឹងសារទូតសួគ៌ ដែលបានទំនាក់ទំនងនូវវិវរណៈ ដែលឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១–៤

*ព្រះអម្ចាស់ បានប្រទានការណែនាំអំពីនិមិត្តសញ្ញានៃពិធីសាក្រាម៉ង់*

បើអាចធ្វើទៅរួច សូមបង្ហាញសំបកជំឡូងបារាំងខ្លះៗ ហើយសុំឲ្យសិស្សទាយស្មានពីគោលបំណងខាងវិញ្ញាណអ្វី ដែលពួកគេអាចប្រើជាការប្រៀបធៀប ។ បន្ទាប់ពីសិស្សឆ្លើយបានពីរបីនាក់ សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវសេចក្ដីថ្លែងការដូចខាងក្រោមដកស្រង់ចេញពីការនឹកចាំរបស់ ប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន អំពីការទៅទស្សនាទីបអឺរ៉ុបដែលត្រូវបំផ្លាញដោយសង្គ្រាម បន្ទាប់ពីសង្គ្រាមលោកលើកទី ២ ៖



« ខ្ញុំពុំអាចភ្លេចអំពីពួកបរិសុទ្ធជនជាតិបារាំង ដែលពុំអាចទទួលបាននំប៉័ង តែបានប្រើសំបកជំឡូងបារាំងធ្វើជាតំណាងនៃពិធីសាក្រាម៉ង់ជំនួសវិញ » ( Prepare for the Days of Tribulation » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨០, ៣៣–៣៤ ) ។

- តើអ្នកនឹងគិតយ៉ាងណា បើអ្នកបានឃើញសំបកជំឡូងបារាំងត្រូវបានប្រើជំនួសនំប៉័ងសម្រាប់ពិធីសាក្រាម៉ង់នោះ ?
- ហេតុអ្វីក៏អ្នកគិតថា វាអាចទទួលយកបានសម្រាប់ពួកបរិសុទ្ធជនជាតិបារាំងប្រើអ្វីមួយផ្សេងក្រៅពីនំប៉័ង ដើម្បីជាតំណាងនៃពិធីសាក្រាម៉ង់ដូច្នេះ ?

ដើម្បីផ្ដល់ដល់សិស្សនូវបរិបទខាងប្រវត្តិសាស្ត្រសម្រាប់វិវរណៈដែលបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧ សូមសង្ខេបព័ត៌មានដែលបានផ្ដល់ឲ្យនៅក្នុងបុព្វកថាមេរៀន ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលទេវតាបានប្រាប់ដល់ យ៉ូសែប ស៊្មីធ អំពីការតំណាងនៃពិធីសាក្រាម៉ង់ ។

- តើសារទូតបានបង្រៀនអ្វីខ្លះដល់ យ៉ូសែប ស៊្មីធ ចំពោះអ្វីដែលយើងគួរទទួលទាន ឬផឹក នៅពេលយើងទទួលទានសាក្រាម៉ង់នោះ ? ( អ្វីដែលយើងប្រើជាតំណាងនៃពិធីសាក្រាម៉ង់ គឺពុំសំខាន់ដូចជាអ្វីដែលរបស់ទាំងនោះតំណាងឲ្យ ដែលជួយយើងឲ្យចងចាំនោះទេ ) ។
- ស្របតាមខគម្ពីរទាំងនេះ តើយើងគួរផ្ដោតទៅលើអ្វីខ្លះ ពេលយើងទទួលទានសាក្រាម៉ង់ ? ( សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងទទួលទានពិធីសាក្រាម៉ង់ នោះយើងត្រូវចងចាំអំពីពលិកម្មធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។** អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សគូសចំណាំសេចក្ដីពិតនេះនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:២ ។ ជាចំណែកនៃការពិភាក្សា អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា យើងមាន « ភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ [ ព្រះអម្ចាស់ ] » នៅពេលយើងផ្ដោតទៅលើទ្រង់ ហើយដាក់ឆន្ទៈរបស់យើងឲ្យស្របនឹងឆន្ទៈរបស់ទ្រង់ ) ។

ដើម្បីជួយដល់សិស្សដឹងពីសារៈសំខាន់នៃសេចក្ដីពិតនេះ ហើយពិចារណាអំពីរបៀបដែលវាអាចអនុវត្តនៅក្នុងជីវិតរបស់ពួកគេ សូមពិភាក្សាអំពីសំណួរដូចខាងក្រោម ៖

- តើអ្នកមានបទពិសោធន៍អ្វីខ្លះ ពេលអ្នកបាននឹកគិតអំពីពលិកម្មធួនរបស់ព្រះអង្គសង្គ្រោះ អំឡុងពេលធ្វើពិធីសាក្រាម៉ង់នោះ ?

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីកែលម្អលទ្ធភាពរបស់យើងដើម្បីចងចាំពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ហើយទទួលទានសាក្រាម៉ង់ « ភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ [ ទ្រង់ ] » ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីរៀបចំទទួលទានសាក្រាម៉ង់រាល់សប្ដាហ៍ ។ សូមលើកទឹកចិត្តពួកគេឲ្យពិចារណាអំពីវិធីនានាដើម្បីចងចាំព្រះយេស៊ូវគ្រីស្ទ និងអត្ថន័យដែលមានបង្កប់នៅក្នុងការតំណាងនៃពិធីសាក្រាម៉ង់ ។ អ្នកអាចនឹងចង់អញ្ជើញពួកគេពីរបីនាក់ឲ្យចែកចាយអ្វីដែលពួកគេបានសរសេរ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:៣–៤ តាមរយៈការពន្យល់ថា ព្រះអម្ចាស់ បានព្រមានដល់ យ៉ូសែប ស្ម៊ីធ កុំឲ្យទិញស្រា ឬភេសជ្ជៈខ្លាំង ( ភេសជ្ជៈទាំងអស់ណា ដែលមានជាតិធ្វើឲ្យស្រវឹង ) មកពីពួកសត្រូវរបស់សាសនាចក្រ ហើយប្រើប្រាស់នៅក្នុងពិធីសាក្រាម៉ង់ឡើយ ។ ពួកគេត្រូវប្រើតែស្រាដែល « បានធ្វើថ្មី » ដោយពួកបរិសុទ្ធប៉ុណ្ណោះ ។ វាអាចនឹងជាប្រយោជន៍ដល់សិស្សរបស់អ្នក ដើម្បីដឹងថា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ មិនត្រូវបានបើកសម្ដែងសម្រាប់រយៈពេលពីរឆ្នាំកន្លះ ( សូមមើល គ និង ស ៨៩ ) ហើយថានៅក្នុងសាសនាចក្រសព្វថ្ងៃ យើងប្រើទឹកសម្រាប់ពិធីសាក្រាម៉ង់ ។

> ***ការអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ***
>
> មេរៀនដំណឹងល្អប្រកបដោយប្រសិទ្ធភាព អាចបង្កើនបំណងប្រាថ្នា និងលទ្ធភាពរបស់សិស្សដើម្បីអនុវត្តសេចក្ដីពិត ដែលពួកគេបានរៀនតាមរបៀបមួយប្រកបដោយអត្ថន័យ ។ របៀបមួយដែលគ្រូបង្រៀនអាចជួយសម្រេចការណ៍នេះ គឺតាមរយៈការអញ្ជើញសិស្សឲ្យពិចារណាតាមវិធីជាក់លាក់មួយ ដែលពួកគេអាចអនុវត្តគោលលទ្ធិ ឬគោលការណ៍មួយនៅក្នុងស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:៥–១៤

*ព្រះអម្ចាស់ នឹងទទួលទានសាក្រាម៉ងម្ដងទៀតនៅលើផែនដី*

សូមឲ្យសិស្សពិចារណាអំពីរបៀបដែលបទពិសោធន៍នៃការទទួលទានសាក្រាម៉ង់របស់ពួកគេអាចនឹងផ្លាស់ប្ដូរយ៉ាងដូចម្ដេច បើពួកគេត្រូវទទួលទាននៅចំពោះវត្តមានរបស់ព្រះអង្គសង្គ្រោះវិញនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិតរបស់ពួកគេ ។

សូមរំឭកដល់សិស្សថា ព្រះអង្គសង្គ្រោះ បានណែនាំពិធីបរិសុទ្ធនៃសាក្រាម៉ង់ដល់ពួកសាវករបស់ទ្រង់នៅយប់អាហារចុងក្រោយ ។ នៅក្នុងស្ថានភាពនេះ ព្រះយេស៊ូវគ្រីស្ទ បានព្យាករអំពីគ្រាមួយ ពេលដែលទ្រង់នឹងត្រឡប់មកកាន់ផែនដីវិញ ហើយទទួលទានសាក្រាម៉ង់ម្ដងទៀតជាមួយនឹងពួកសិស្សរបស់ទ្រង់ ( សូមមើល ម៉ាថាយ ២៦:២៦–២៩ ) ។

សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:៥–១២ ព្រះអម្ចាស់បានប្រាប់ឈ្មោះរបស់បុគ្គលមួយចំនួន ដែលនឹងចូលរួមក្នុងការប្រជុំនេះដោយជាក់លាក់ ។ សូមអញ្ជើញសិស្សឲ្យមើលខគម្ពីរទាំងនេះត្រួសៗ ហើយប្រាប់ ( ១ ) បុគ្គលម្នាក់ៗទាំងនេះជានរណា និង ( ២ ) បើបានប្រាប់ហើយ តើពួកគេមានកូនសោ ឬ ទំនួលខុសត្រូវអ្វីខ្លះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរព័ត៌មាននេះនៅលើក្ដារខៀន ពេលដែលសិស្សផ្សេងទៀតក្នុងថ្នាក់រាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ ( អ្នកអាចនឹងចង់ពន្យល់ថា នៅក្នុងប្រវត្តិសាស្ត្រផែនដីទាំងមូល ព្រះអម្ចាស់បានប្រទានសិទ្ធិអំណាចបព្វជិតភាពដល់បុរសសុចរិតដើម្បីជួយបម្រើដំណឹងល្អរបស់ទ្រង់ ។ ទ្រង់ក៏បានប្រទានឲ្យនូវកូនសោបព្វជិតភាពដល់អ្នកដឹកនាំបព្វជិតភាពផងដែរ ដើម្បីពួកគាត់អាចដឹកនាំ ត្រួតត្រា និងគ្រប់គ្រងលើការប្រើបព្វជិតភាពរបស់ទ្រង់នៅលើផែនដី ) ។

នៅពេលបញ្ជីត្រូវបានបំពេញហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១២–១៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីកូនសោដែលព្រះអម្ចាស់បានប្រទានដល់ ព្យាការីយ៉ូសែប ស្ម៊ីធ ។

- តើកូនសោអ្វីខ្លះ ដែលព្រះអម្ចាស់បានតាំងចិត្តដល់ ឬផ្ដល់ទៅដល់ព្យាការី យ៉ូសែប ស្ម៊ីធ ? ( សូមអញ្ជើញសិស្សម្នាក់ឲ្យបន្ថែម *យ៉ូសែប ស្ម៊ីធ* និង *កូនសោទាំងឡាយនៃនគររបស់ព្រះអម្ចាស់* ចូលក្នុងបញ្ជីលើក្ដារខៀន ) ។

សូមចង្អុលបង្ហាញថា ព្យាការីជាច្រើន ដែលមានឈ្មោះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧ បានមកជួបនឹង យ៉ូសែប ស្ម៊ីធ ដើម្បីប្រគល់កូនសោមកឲ្យលោក ។

អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំឃ្លា « នៃការកាន់កាប់ត្រួតត្រានៃដំណឹងល្អសម្រាប់ពេលចុងក្រោយបង្អស់ និងសម្រាប់កំណត់កាលដ៏ពោរពេញ » នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៣ ។

- យោងតាមខគម្ពីរនេះ តើព្រះអម្ចាស់មានបន្ទូលថាទ្រង់នឹងធ្វើអ្វីខ្លះ អំឡុងគ្រាកាន់កាប់ត្រួតត្រាសម្រាប់ពេលចុងក្រោយបង្អស់នោះ ? ( « ប្រមូលរបស់របរទាំងអស់ទៅតែមួយ » ) ។

សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ក្រោមបញ្ជីថា ៖ **ការកាន់កាប់ត្រួតត្រានៃដំណឹងល្អសម្រាប់កំណត់កាលដ៏ពោរពេញ ជាពេលដែលនឹងប្រមូលកូនសោដំណឹងល្អទាំងអស់ ពិធីបរិសុទ្ធ និងសេចក្ដីពិតនៃការកាន់កាប់ត្រួតត្រាកាលពីអតីតកាលមកតែមួយ ។**

សូមពន្យល់ថា ការកាន់កាប់ត្រួតត្រា « គឺជាអំឡុងពេលមួយ ដែលយ៉ាងហោចណាស់ ព្រះអម្ចាស់មានអ្នកបម្រើដែលមាននូវសិទ្ធិអំណាចម្នាក់នៅលើផែនដី ដែលកាន់ [ កូនសោ ] បព្វជិតភាពបរិសុទ្ធ. . . និង ជាអ្នកដែលមាននូវការអនុញ្ញាតពីព្រះដើម្បីចែកចាយដំណឹងល្អ » ( Bible Dictionary, « Dispensations » ) និងដើម្បីចាត់ចែងពិធីបរិសុទ្ធដែលមានក្នុងដំណឹងល្អនោះ ។ នៅពេលព្រះអម្ចាស់រៀបចំការកាន់កាប់ត្រួតត្រាមួយ « ដំណឹងល្អត្រូវបានបើកសម្ដែងជាថ្មី ដើម្បីឲ្យមនុស្សនៃគ្រាកាន់កាប់ត្រួតត្រានោះ ពុំចាំបាច់ត្រូវពឹងផ្អែកទាំងស្រុងទៅលើគ្រាកាន់កាប់ត្រួតត្រាកាលពីអតីតកាល សម្រាប់ចំណេះដឹងអំពីផែនការនៃសេចក្ដីសង្គ្រោះ » ( Bible Dictionary « Dispensations » ) ។ អ័ដាម, ហេណុក, ណូអេ, ម៉ូសេ និងអ្នកដទៃទៀតគឺជាអ្នកដឹកនាំនៃគ្រាកាន់កាប់ត្រួតត្រាដំណឹងល្អ ។ យ៉ូសែប ស្ម៊ីធ គឺជាអ្នកដឹកនាំនៃគ្រាកាន់កាប់ត្រួតត្រាដែលយើងរស់នៅ– ជាគ្រាកាន់កាប់ត្រួតត្រានៃកំណត់កាលដ៏ពោរពេញ ។ នៅគ្រាកាន់កាប់ចុងក្រោយនេះ បានចាប់ផ្ដើមជាមួយនឹងការស្ដារដំណឹងល្អតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ វាត្រូវបានហៅថាជាគ្រាកាន់កាប់ត្រួតត្រានៃកំណត់កាលដ៏ពោរពេញ ដោយសារតែរាល់កូនសោទាំងអស់ ដែលព្រះអម្ចាស់បានបើកសម្ដែងសម្រាប់ពរជ័យនៃកូនចៅរបស់ទ្រង់ ត្រូវបានស្ដារឡើងវិញ ហើយរាល់ផែនការ និងសេចក្ដីសន្យាទាំងឡាយរបស់ព្រះអម្ចាស់ ចាប់តាំងពីការកកើតពិភពលោក នឹងត្រូវបានបំពេញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៤ ឲ្យឮៗ ។ សូមឲ្យសិស្សនៅក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយប្រាប់ថានរណាផ្សេងទៀតនឹងមានវត្តមាននៅក្នុងការប្រជុំសាក្រាម៉ង់ ដែលបានពិពណ៌នានៅក្នុងកណ្ឌនេះ ។

- តើអ្នកគិតថា ឃ្លា « អស់អ្នកណាដែលព្រះវរបិតារបស់យើង បានប្រទានដល់យើង ចេញពីលោកិយផង » សំដៅទៅលើនរណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ. ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« រាល់អ្នកស្មោះត្រង់នៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោកទាំងមូល រាល់បុគ្គលដែលបានរស់នៅដើម្បីសមនឹងជីវិតដ៏អស់កល្បជានិច្ច នៅក្នុងនគរនៃព្រះវរបិតា នឹងមានវត្តមាន ហើយនឹងទទួលទានសាក្រាម៉ង់ជាមួយព្រះអម្ចាស់ » ( *The Promised Messiah: The First Coming of Christ* ឆ្នាំ ១៩៧៨ ], ទំព័រ៥៩៥ ) ។

សូមបន្ថែម *អ្នក និង ខ្ញុំ* ចូលទៅក្នុងបញ្ជីនៅលើក្ដារខៀន ។

- យោងទៅតាម អែលឌើរ ម៉ាក់ខន់ឃី តើយើងត្រូវរស់នៅយ៉ាងដូចម្ដេច ដើម្បីមានវត្តមាននៅក្នុងការប្រជុំសាក្រាម៉ង់ដ៏ពិសេសនេះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨

### *ព្រះអម្ចាស់បញ្ជារាស្ត្ររបស់ទ្រង់ឲ្យពាក់អាវក្រោះនៃព្រះ*

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨ មាននូវពាក្យទូន្មានដែលនឹងជួយយើងឲ្យមានភាពសក្ដិសមដើម្បីទទួលបានពរជ័យទាំងឡាយរបស់ព្រះអម្ចាស់ រួមទាំងពរជ័យនៃការចូលរួមការប្រជុំសាក្រាម៉ង់ដែលបានប្រាប់នៅក្នុងខ ៤–១៤ ។

សូមសួរដល់សិស្សថា តើពួកគេចង់ស្លៀកពាក់អ្វី បើពួកគេដឹងថាពួកគេនឹងទៅធ្វើសង្គ្រាមនោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើល ( ១ ) អ្វីដែលព្រះអម្ចាស់ដឹកនាំឲ្យយើងធ្វើដើម្បីរៀងចំខ្លួនសម្រាប់ចម្បាំងខាងវិញ្ញាណ និង ( ២ ) តើទ្រង់សន្យាប្រទានពរជ័យអ្វីខ្លះ បើយើងធ្វើតាមការដឹកនាំរបស់ទ្រង់នោះ ។

- តើព្រះអម្ចាស់ទូន្មានយើងឲ្យធ្វើអ្វីខ្លះដើម្បីរៀបចំខ្លួនសម្រាប់ចម្បាំងខាងវិញ្ញាណ ? ( សូមសង្ខេបចម្លើយរបស់សិស្សដោយការសរសេរដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងពាក់លើខ្លួនយើងនូវអាវក្រោះទាំងមូលរបស់ព្រះ. . .*

- តើព្រះអម្ចាស់សន្យាប្រទានពរជ័យអ្វីខ្លះ ចំពោះអ្នកទាំងឡាយដែលពាក់អាវក្រោះទាំងមូលរបស់ព្រះនោះ ? ( នៅពេលសិស្សឆ្លើយ សូមបំពេញគោលការណ៍នៅលើក្ដារខៀន ៖ **បើយើងលើកដាក់មកលើខ្លួនយើងនូវអាវក្រោះទាំងមូលនៃព្រះនោះយើងនឹងអាចទប់ទល់នឹងអារក្ស** )



សូមចម្លងរូបភាពនៅលើក្ដារខៀន ដោយមានគូសបន្ទាត់ភ្ជាប់ទៅចំណែកនៃអាវក្រោះនីមួយៗ ដែលបានប្រាប់នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨ ។ សូមបំបែកសិស្សក្នុងថ្នាក់ជាក្រុមតូចៗ ហើយចាត់តាំងក្រុមនិមួយៗនូវចំណែកមួយនៃអាវក្រោះ ។ សូមផ្ដល់ដល់ក្រុមនិមួយៗនូវសេចក្ដីថ្លែងការដោយប្រធាន ហារ៉ូល ប៊ី លី ដូចខាងក្រោម និងព័ត៌មាន និងសំណួរនៅក្នុងវគ្គខាងក្រោមទាក់ទងទៅនឹងចំណែកនៃអាវក្រោះដែលបានចាត់ទៅឲ្យគេនោះ ។ សូមអញ្ជើញសិស្សឲ្យធ្វើការនៅក្នុងក្រុមពួកគេ ដើម្បីឆ្លើយសំណួរសម្រាប់ចំណែកអាវក្រោះដែលបានចាត់តាំងទៅឲ្យពួកគេ ហើយត្រៀមខ្លួនដើម្បីចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។



« យើងមានផ្នែកបួននៃរាងកាយ ដែលសាវកប៉ុលបានមានប្រសាសន៍ថា [ គឺជា ] ផ្នែកដ៏ទន់ខ្សោយបំផុតចំពោះអំណាចនៃសេចក្ដីងងឹត ។ ចង្កេះ ជាតួយ៉ាងនៃគុណធម៌ព្រហ្មចារីយភាព ។ បេះដូង ជាតួយ៉ាងនៃទង្វើរបស់យើង ។ ជើងរបស់យើង ជាគោលដៅឬគោលបំណងនៅក្នុងជីវិតរបស់យើង ហើយចុងក្រោយ គឺជាក្បាលរបស់យើង គំនិតរបស់យើង » ( ហារ៉ូល ប៊ី លី *Feet Shod with the Preparation of the Gospel of Peace* Brigham Young University Speeches of the Year [ ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ១៩៥៤],ទំព័រ ២ ) ។

« **ក្រវាត់ចង្កេះដោយសេចក្ដីពិត** » ( សូមមើលគ និង ស ២៧:១៥–១៦ ) ៖

ប្រធាន លី បានមានប្រសាសន៍ថា « ចង្កេះគឺជាផ្នែងនៃរាងកាយ ដែលនៅ ចន្លោះឆ្អឹងជំនី និងត្រគៀក ដែលអ្នកនឹងស្គាល់ គឺជាសរីរាង្គដ៏សំខាន់ ដែលត្រូវតែមានសម្រាប់ការបន្តពូជ » ( *ជាស្បែកជើង* ២ ) ។ ដើម្បី *ក្រវាត់* គឺជាការចងយ៉ាងតឹងដោយខ្សែក្រវាត់មួយ ។

- ហេតុអ្វីក៏អ្នកគិតថាសាតាំងវាយប្រហារទៅលើបរិសុទ្ធភាព គុណធម៌ និងព្រហ្មចារីយភាពដូច្នេះ ?
- តើអ្នកគិតថា ការស្គាល់បទដ្ឋានរបស់ព្រះអំពីសីលធម៌ អាចជួយអ្នកស្ថិតនៅបរិសុទ្ធ ប្រកបដោយគុណធម៌ និងព្រហ្មចារីភាពយ៉ាងដូចម្ដេច ?

ការសិក្សាព្រះគម្ពីរជួយក្រវ៉ាត់យើងនៅក្នុងសេចក្ដីពិត ហើយជួយការពារគុណធម៌ និងព្រហ្មចារីយភាពរបស់យើង ។

**« ប្រដាប់បាំងដើមទ្រូងនៃសេចក្ដីសុចរិត »** ( គ និង ស ២៧:១៦ ) ៖

- យោងតាមប្រធាន លី តើប្រដាប់បាំងដើមទ្រូងការពារអ្វីខ្លះ ?
- តើអ្នកគិតថា សេចក្ដីសុចរិតនៃដួងចិត្តរបស់យើង ( ទង្វើរបស់យើង និងបំណងប្រាថ្នារបស់យើង ) មានឥទ្ធិពលលើលទ្ធផលរបស់យើង ដើម្បីច្បាំងក្នុងចម្បាំងខាងវិញ្ញាណរបស់យើងយ៉ាងដូចម្ដេច ?

**« ពាក់សេចក្ដីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្ដីសុខសាន្តទុកជាស្បែកជើង »** ( គ និង ស ២៧:១៦ ) ៖

ការ « ពាក់ស្បែក » ជើងរបស់អ្នក មានន័យថា ជាការពាក់ស្បែកជើង ឬការការពារជើងយើង ។

- យោងតាមប្រធាន លី តើជើងរបស់យើងតំណាងឲ្យអ្វី ?
- តើសាតាំងវាយប្រហារលើគោលដៅ និងគោលបំណងក្នុងជីវិតរបស់យើងយ៉ាងដូចម្ដេច ?
- តើព្រះប្រទានអ្វីខ្លះដល់យើងឲ្យ « តោងជាប់ » ដើម្បីជួយយើងរក្សាជើងរបស់យើង ដើរតាមផ្លូវនៃជីវិតឆ្ពោះទៅកាន់គោលដៅរបស់យើង ? ( សូមមើល នីហ្វៃទី ១ ៨:២៤ ) ។
- តើការផ្ដោតទៅលើគោលដៅ និងគោលបំណងសុចរិត ជួយយើងយកឈ្នះការល្បួងយ៉ាងដូចម្ដេច ?

**« សេចក្ដីជំនឿទុកជាខែល »** ( គ និង ស ២៧:១៧ ) ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « រលត់អស់ទាំងព្រួញឆេះរបស់ពួកទុច្ចរិត » ?
- តើសេចក្ដីជំនឿរបស់អ្នកទុកជាខែល ហើយការពារដល់អ្នកយ៉ាងដូចម្ដេច ?

**« សេចក្ដីសង្គ្រោះទុកជាមួកសឹក »** ( គ និង ស ២៧:១៨ ) ៖

- យោងតាមប្រធានលី នៅពេលក្បាលរបស់យើងត្រូវបានគ្របបាំង តើវាការពារដល់អ្វីខ្លះ ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីការពារដល់គំនិតរបស់យើង ?
- តើសាតាំងវាយប្រហារដល់គំនិតរបស់យើងយ៉ាងដូចម្ដេច ?
- តើរឿងជាក់លាក់អ្វីខ្លះ ដែលយើងអាចធ្វើ ដើម្បីការពារគំនិតរបស់យើង ?

**« ដាវរបស់ព្រះវិញ្ញាណរបស់ខ្ញុំ »** ( គ និង ស ២៧:១៨ ) ៖

- តើព្រះវិញ្ញាណអាចជួយយើងយកឈ្នះលើការវាយប្រហាររបស់សាតាំងយ៉ាងដូចម្ដេច ?
- តើការមានព្រះវិញ្ញាណផ្ដល់អត្ថប្រយោជន៍អ្វីខ្លះដល់យើង នៅក្នុងការប្រយុទ្ធរបស់យើងទាស់នឹងអំពើអាក្រក់ ?
- តើព្រះបន្ទូលនៃព្រះ ជួយយើងប្រើដាវរបស់ព្រះវិញ្ញាណយ៉ាងដូចម្ដេច ?
- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីអញ្ជើញព្រះវិញ្ញាណឲ្យចូលក្នុងជីវិតរបស់អ្នកកាន់តែច្រើន ?

បន្ទាប់ពីសិស្សបានរាយការណ៍ពីចម្លើយរបស់ពួកគេហើយ សូមអាននូវសេចក្ដីថ្លែងការខាងក្រោមដោយ អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយសុំឲ្យសិស្សស្ដាប់ពីរបៀបដែលយើងពាក់គ្រឿងសឹក និងពង្រឹងដល់គ្រឿងសឹករបស់ព្រះ ៖



« ខ្ញុំចូលចិត្តគិតអំពីអាវក្រោះខាងវិញ្ញាណនេះ ដែលពុំប្រៀបដូចជាបំណែកនៃលោហៈធាតុដែលសូន្យឡើងមួយដុំ ដើម្បីពាក់ឲ្យត្រូវរូបកាយនោះទេ ប៉ុន្តែវាដូចជាច្រវ៉ាក់ប្រទាក់គ្នាទៅវិញ ។ ច្រវ៉ាក់ប្រទាក់គ្នាមានជាបំណែកតូចៗជាច្រើនផែនតភ្ជាប់នឹងគ្នា ដើម្បីអនុញ្ញាតឲ្យអ្នកប្រើអាចបត់បែនបានកាន់តែងាយស្រួលដោយមិនបាត់បង់នូវការការពារ ។ ខ្ញុំនិយាយដូច្នោះ ដោយសារវាជាបទពិសោធន៍របស់ខ្ញុំថាគ្មានអ្វីតែមួយដ៏ធំ ហើយអស្ចារ្យដែលយើងអាចធ្វើ ដើម្បីការពារខ្លួនយើងខាងវិញ្ញាណបាននោះឡើយ ។ អំណាចខាងវិញ្ញាណពិត ពឹងលើទង្វើតូចៗជាច្រើនវេញបញ្ចូលគ្នានៅក្នុងសាច់ក្រណាត់នៃការការពារខាងវិញ្ញាណ ដែលការពារ និងជាខែលទាស់នឹងរាល់សេចក្ដីអាក្រក់ » ( « Be Strong in the Lord » *Ensign* ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៨ ) ។

- តើទង្វើរតូចៗមួយចំនួនអ្វីខ្លះ ដែលបានប្រមូលផ្ដុំជាកម្លាំងរបស់វា នឹងជួយការពារយើងទាស់នឹងការល្បួង និងអំពើអាក្រក់ ?

សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅមើលនៅដើមបន្ទាត់នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥ ។ បន្ទាប់មក សួរសំណួរដូចខាងក្រោមនេះ ៖

- តើយើងគួរមានអាកប្បកិរិយាយ៉ាងណា ពេលយើងពាក់គ្រឿងសឹករបស់ព្រះ ? ( យើងគួរតែ « លើកទឹកចិត្ត [ របស់យើង ] ឡើងហើយអរសប្បាយ » ) ។ ហេតុអ្វីក៏យើងគួរតែមានអាកប្បកិរិយាបែបនេះ ?

សូមឲ្យសិស្សពិចារណាអំពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនថ្ងៃនេះ ហើយអញ្ជើញពួកគេឲ្យជ្រើសរើសរឿងជាក់លាក់មួយដែលពួកគេអាចធ្វើដើម្បីពាក់អាវក្រោះនៃព្រះបានកាន់តែល្អប្រសើរ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរនូវអ្វីដែលពួកគេនឹងធ្វើនៅលើក្រដាសមួយសន្លឹក ដែលពួកគេអាចមើលជាញឹកញាប់ ទុកជាការរំឭកមួយអំពីការតាំងចិត្តរបស់ពួកគេ ។

ដើម្បីបញ្ចប់មេរៀននេះ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីសេចក្ដីពិត ដែលបានបង្រៀននៅក្នុងមេរៀន ។

មេរៀនទី ៣៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨

## បុព្វកថា

នៅក្នុងឆ្នាំ ១៨៣០ ព្យាការីយ៉ូសែប ស្ម៊ីធ បានជួបនឹងបញ្ហាមួយ ដោយសារសមាជិកសាសនាចក្រពុំយល់អំពីលំដាប់នៃវិវរណៈនៅក្នុងសាសនាចក្រ ។ ហៃរ៉ាំ  ភេច បានប្រកាសថាទទួលវិវរណៈសម្រាប់សាសនាចក្រ តាមរយៈរូបអារក្សនៃថ្មពិសេសមួយ ហើយសមាជិកសាសនាចក្រមួយចំនួន រួមទាំង អូលីវើរ ខៅឌើរី ផងក៏បានជឿគាត់ផងដែរ ។ មិនយូរប៉ុន្មានមុនពេលសន្និសីទសាសនាចក្រមួយដែលធ្វើឡើងនៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៨៣០ នោះព្រះអម្ចាស់បានបើកសម្ដែងសេចក្ដីពិត ដែលបានជួយអូលីវើរ ខៅឌើរី និងអ្នកដទៃទៀតឲ្យយល់អំពីលំដាប់នៃវិវរណៈនៅក្នុងសាសនាចក្រ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១–៧

*ព្រះអម្ចាស់ ប្រកាសថា ប្រធាននៃសាសនាចក្រ គឺជាមនុស្សតែម្នាក់គត់ ដែលអាចទទួលវិវរណៈដើម្បីគ្រប់គ្រងសាសនាចក្រ ។*

សូមសរសេរពាក្យ *ក្លែងក្លាយ* នៅលើក្ដារខៀន ។

- តើឧទាហរណ៍មួយចំនួននៃរឿងដែលគ្រាន់តែជាការក្លែងក្លាយមានអ្វីខ្លះ ? ( ជាចំណែកនៃការពិភាក្សានេះ អ្នកអាចនឹងចង់បង្ហាញឧទាហរណ៍មួយអំពីវត្ថុមួយដែលក្លែងក្លាយ ដូចជារូបគំនូរថតចម្លង លុយក្លែងក្លាយ ឬផ្លែឈើជ័រមួយចំណិតជាដើម ) ។

- ហេតុអ្វីក៏ការយល់ខុសថា វត្ថុក្លែងក្លាយជាវត្ថុពិត អាចជារឿងប្រកបដោយគ្រោះថ្នាក់ដូច្នេះ ?

សូមឲ្យសិស្សម្នាក់អានការព្រមានដូចខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« អារក្សគឺជាបិតានៃការកុហក ហើយវាអន្ទះសារធ្វើឲ្យស្មុគស្មាញដល់កិច្ចការរបស់ព្រះ តាមរយៈការក្លែងបន្លំដ៏ ឆ្លាតវៃរបស់វា » ( Two Lines of Communication, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៨៤ ) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឲ្យឮៗនូវការណែនាំ នៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីរឿងក្លែងក្លាយដែលសាតាំងបានប្រើដើម្បីបញ្ឆោតដល់សមាជិកមួយ ចំនួនក្នុងសាសនាចក្រកាលពីជំនាន់មុន ។

- តើរឿងក្លែងក្លាយដែលសាតាំងបានប្រើដើម្បីបញ្ឆោតដល់សមាជិកសាសនាចក្រគឺជាអ្វី ? ( បើសិស្សពុំបានប្រាប់ពីភាពស្រដៀងគ្នារវាងថ្មរបស់ហៃរ៉ាំ ជាមួយយូរិម និងធូមីម ដែលយ៉ូសែបស្ម៊ីធ បានប្រើពេលខ្លះនោះ សូមចង្អុលបង្ហាញពីភាពស្រដៀងគ្នានេះ ) ។

សូមពន្យល់ថា សមាជិកសាសនាចក្រមួយចំនួនបានជឿវិវរណៈក្លែងក្លាយដែលសាតាំងបានបញ្ឆោត ហៃរ៉ាំ ភេច ។ នៅពេលសិស្សសិក្សា ហើយពិភាក្សាអំពីវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ សូមលើកទឹកចិត្តដល់ពួកគេឲ្យរកមើលសេចក្ដីពិតដែលអាចជួយពួកគេចៀសវាងពីការបញ្ឆោត ដោយសារការក្លែងបន្លំរបស់សាតាំង ។ សូមប្រាប់សិស្សថា អ្នកនឹងសរសេរសេចក្ដីពិតទាំងនេះនៅលើក្ដារខៀន នៅពេលពួកគេរកឃើញវានៅក្នុងមេរៀន ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សសរសេរសេចក្ដីពិតទាំងនេះនៅគែមព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១–៤ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យប្រាប់អំពីទំនួលខុសត្រូវរបស់អូលីវើរ ខៅឌើរី នៅក្នុងសាសនាចក្រគឺខុសពីទំនួលខុសត្រូវរបស់ យ៉ូសែប ស៊្មីធ ដោយរបៀបណា ។

- តើទំនួលខុសត្រូវរបស់អូលីវើរ ខៅឌើរី ខុសពីយ៉ូសែប ស៊្មីធ យ៉ាងដូចម្ដេច ? ( យ៉ូសែប គឺទទួលខុសត្រូវដើម្បីទទួលបញ្ញត្តិ និងវិវរណៈសម្រាប់សាសនាចក្រ ) ។ អូលីវើរ គឺទទួលខុសត្រូវដើម្បីបង្រៀនតាមរយៈអង្គលួងលោមចិត្ត ទាក់ទងនឹងបទបញ្ញត្តិ និងវិវរណៈទាំងឡាយ ដែលយ៉ូសែប បានទទួល ) ។

- តើសេចក្ដីពិតសំខាន់អំពី ប្រធានសាសនាចក្រដែលយើងអាចរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:២ មានអ្វីខ្លះ ? ( សិស្សគួរប្រាប់អំពីគោលលទ្ធិដូចខាងក្រោម ៖ **ប្រធាននៃសាសនាចក្រគឺជាមនុស្សតែម្នាក់គត់ដែលអាចទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល** ។ សូមសរសេរសេចក្ដីថ្លែងការនេះនៅលើក្ដារខៀន ) ។

- តើចំណេះដឹងរបស់យើងអំពីសេចក្ដីពិតនេះ ជួយយើងចៀសវាងពីការត្រូវបានបោកបញ្ឆោតយ៉ាងដូចម្ដេច ?

នៅពេលសិស្សពិភាក្សាអំពីសំណួរទាំងនេះ អ្នកអាចនឹងចង់មើលឲ្យប្រាកដថាពួកគេអាចទុកចិត្តជានិច្ចទៅលើការបង្រៀន និងការទូន្មានរបស់ប្រធាននៃសាសនាចក្រ ដោយសារតែព្រះអម្ចាស់នឹងពុំដែលអនុញ្ញាតឲ្យប្រធានដឹកនាំយើងឲ្យវង្វេងនោះទេ ។ ( កំណត់ចំណាំថា ការសន្យានេះគឺរកបាននៅក្នុងសេចក្ដីថ្លែងការមួយដោយប្រធាន វិលហ្វូឌ វូឌរ៉ុហ្វ ។ សេចក្ដីថ្លែងការណ៍នោះគឺមានបញ្ចូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា នៅក្នុងឯកសារបន្ថែមបន្ទាប់ពី ការប្រកាសជាផ្លូវការទី ១ ) ។

សូមពន្យល់ថា មិនយូរប៉ុន្មាន ពីមុនពេលព្រះអម្ចាស់បើកសម្ដែងសេចក្ដីពិត ដែលឥឡូវនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ អូលីវើរ ខៅឌើរី បានធ្វើអ្វីមួយ ដែលបង្ហាញថា គាត់ពុំទាន់យល់ដឹងពេញលេញអំពីភាពខុសគ្នា រវាងទំនួលខុសត្រូវរបស់គាត់នៅក្នុងសាសនាចក្រ និងទំនួលខុសត្រូវរបស់យ៉ូសែប ស៊្មីធ ក្នុងនាមជាប្រធាននៃសាសនាចក្រនៅឡើយទេ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោម ៖

យ៉ូសែប ស៊្មីធ រស់នៅក្នុងភូមិ ហាម៉ូនី រដ្ឋផែនស៊ីលវេញ៉ា នៅពេលលោកបានទទួលសំបុត្រមួយមកពី អូលីវើរ ខៅឌើរី ដែលនៅភូមិហ្វាយ៉េត រដ្ឋនូវយ៉ោក ដែលមានចម្ងាយប្រហែលជា ១០០ ម៉ែល ( ១៦០ គ.ម ) ពីគ្នា ។ អូលីវើរ បានមានប្រសាសន៍ថា គាត់បានរកឃើញកំហុសឆ្គងមួយនៅក្នុងវិវរណៈ ដែលយើងឥឡូវហៅថា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ។ អូលីវើរ បានសរសេរថា ៖ « ខ្ញុំបញ្ជាអ្នកនៅក្នុងនាមនៃព្រះឲ្យលុបពាក្យទាំងឡាយនោះចោល » ។ យ៉ូសែប បានធ្វើដំណើរទៅភូមិហ្វាយ៉េត ហើយបានដឹងថា គ្រួសារ វិតមើរ បានយល់ព្រមជាមួយនឹង អូលីវើរ អំពីកំហុសឆ្គងដែលគិតស្មាននៅក្នុងវិវរណៈ ។ យ៉ូសែប បានសរសេរថា « បើគ្មានការខិតខំធ្វើការ និងការអត់ធន់នោះទេ ខ្ញុំពុំអាចយកឈ្នះលើពួកគេណាម្នាក់ ឲ្យគិតអំពីហេតុផលដោយស្ងប់ស្ងាត់អំពីប្រធានបទនោះទេ » ។ នៅទីបំផុត ព្យាការី « បានទទួលជោគជ័យក្នុងការនាំគ្រួសារ វិតមើរ ថែមទាំង. . .អូលីវើរ ខៅឌើរី ផង មកកាន់ចំណេះដឹងដែលពួកគេបានមានកំហុសឆ្គងនោះ » ( *Histories, វ៉ុលទី ១: ឆ្នាំ ១៨៣២–១៨៤៤*, វ៉ុលទី ១ of the Histories series of *The Joseph Smith Papers* [ ឆ្នាំ ២០១២], ទំព័រ ៤២៦; សូមមើលផងដែរទំព័រ ៤២៤–២៥ ) ។

សូមសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៦–៧ ដោយស្ងាត់ស្ងៀម រកមើលការដឹកនាំរបស់ព្រះអម្ចាស់ទៅកាន់អូលីវើរ ខៅឌើរី ។

- តើព្រះអម្ចាស់បានបង្រៀនដល់ អូលីវើរ ខៅឌើរី អ្វីខ្លះ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោម នៅលើក្ដារខៀន ៖ **នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ បុគ្គលម្នាក់ៗពុំទទួលវិវរណៈដើម្បីដឹកនាំនរណាម្នាក់ ដែលធ្វើជាអធិបតីលើពួកគេឡើយ** ) ។

- តើសេចក្ដីពិតនេះ ទាក់ទងនឹងដំណើររឿងដែលយើងទើបតែអានយ៉ាងដូចម្ដេច ?

- តើសេចក្ដីពិតនេះ អាចជួយយើងនៅសព្វថ្ងៃយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨–១០

*ព្រះអម្ចាស់ បានហៅអូលីវើរ ខៅឌើរី ឲ្យផ្សព្វផ្សាយដំណឹងល្អទៅកាន់ពួកសាសន៍លេមិន*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨–១០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ ប្រាប់ពីអ្វីដែលព្រះអម្ចាស់ បានហៅឲ្យអូលីវើរឲ្យធ្វើនោះ ។

- តើព្រះអម្ចាស់ហៅឲ្យអូលីវើរ ឲ្យធ្វើអ្វីខ្លះ ? ( ផ្សាយដំណឹងល្អនៅក្នុងចំណោមពួកសាសន៍លេមិន ) ។

- តើយើងអាចរៀនវិវរណៈផ្ទាល់ខ្លួនអ្វីខ្លះមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨ ? ( បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរនូវគោលលទ្ធិដូចខាងក្រោម នៅលើក្ដារខៀន ៖ **យើងអាចទទួលវិវរណៈសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនរបស់យើង និងដើម្បីជួយយើងនៅក្នុងការហៅបម្រើ និងការចាត់តាំងដែលបានប្រគល់ដល់យើង** ) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ប៊ិយដ៏ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« យើងអាចទទួលបានវិវរណៈផ្ទាល់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ លុះត្រាតែយើងត្រូវបានញែកចេញទៅតំណែងអធិបតីមួយចំនួនប៉ុណ្ណោះ នោះយើងនឹងពុំទទួលបានវិវរណៈទាក់ទងនឹងអ្វីដែលអ្នកដទៃគួរធ្វើនោះឡើយ . . . ។

« បទពិសោធន៍ខាងវិញ្ញាណខុសប្រក្រតីមួយ ពុំគួរគិតថាជាការហៅផ្ទាល់ខ្លួនឲ្យដឹកនាំអ្នកដទៃនោះទេ ។ ការជឿជាក់របស់ខ្ញុំគឺថា បទពិសោធន៍ពិសេសមួយ ដែលមានលក្ខណៈពិសិដ្ឋគឺជាលក្ខណៈបុគ្គល ហើយគួរតែរក្សាទុកសម្រាប់ខ្លួនឯង » ( « Revelation in a Changing World, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ទំព័រ ១៤–១៥ ) ។

ពីមុនចាប់ផ្តើមថ្នាក់រៀន សូមសរសេរតួនាទី និងការហៅដូចខាងក្រោម នៅលើសន្លឹកក្រដាសផ្សេងគ្នា ៖ *ឪពុកម្តាយ អ្នកដែលមានសិទ្ធិអំណាចទូទៅ ប៊ីស្សប អ្នកផ្សព្វផ្សាយសាសនា គ្រូបង្រៀនសាលាថ្ងៃអាទិត្យ ប្រធានម៉េម៉េត គ្រូបង្រៀនតាមផ្ទះ គ្រូបង្រៀនសួរសុខទុក្ខ* ។ ដាក់ក្រដាសចូលក្នុងប្រអប់មួយ ។

សូមអញ្ជើញសិស្សឲ្យជ្រើសរើសក្រដាសមកពីប្រអប់ ហើយអានវាទៅកាន់សិស្សក្នុងថ្នាក់ម្តងមួយៗ ។ នៅពេលក្រដាសនិមួយៗត្រូវបានអាន សូមឲ្យសិស្សផ្តល់យោបល់អំពីប្រភេទនៃវិវរណៈ ដែលបុគ្គលម្នាក់ៗអាចទទួលបាន ដើម្បីជួយពួកគេបំពេញនូវតួនាទី ឬការហៅបម្រើនោះ ។

អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ ដែលពួកគេបានទទួលវិវរណៈនៅក្នុងការចាត់តាំង ឬការទទួលខុសត្រូវមួយ ។ អ្នកក៏អាចនឹងចង់ចែកចាយបទពិសោធន៍មួយ ដែលអ្នកបានទទួលវិវរណៈដើម្បីជួយអ្នកនៅក្នុងការហៅ ឬការចាត់តាំងមួយ ។ សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ពុំគួរចែកចាយ ។

សូមលើកទឹកចិត្តដល់សិស្សឲ្យអធិស្ឋានសូមវិវរណៈ ដើម្បីជួយពួកគេនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គេ និងនៅក្នុងការហៅបម្រើក្នុងសាសនាចក្រ និងការចាត់តាំងទាំងឡាយរបស់ពួកគេ ។ ក៏សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋានសូមឲ្យអ្នកដឹកនាំសាសនាចក្រនឹងត្រូវបានប្រទានពរឲ្យមានសុខភាពល្អ និងសុវត្ថិភាព ហើយមានការបំផុសគំនិត ដែលពួកលោកត្រូវការ ដើម្បីបំពេញទំនួលខុសត្រូវរបស់ពួកលោក ។

> ## *ការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន*
> កាលណាអ្នកចែកចាយបទពិសោធន៍ដែលអ្នកមាន នៅពេលអ្នកព្យាយាមរស់នៅតាមគោលការណ៍ដំណឹងល្អ នោះអ្នកអាចជួយសិស្សយល់អំពីរបៀបដើម្បីអនុវត្តគោលការណ៍ទាំងឡាយដោយខ្លួនគេ ។ សូមរក្សាឲ្យរឿងអ្នកខ្លី ហើយតែងតែមានបញ្ចូលនូវសេចក្តីថ្លែងការណ៍អំពីទីបន្ទាល់ ដែលនាំទៅរកអ្វីដែលអ្នកបានរៀន ឬរបៀបដែលអ្នកត្រូវបានប្រទានពរ តាមរយៈបទពិសោធន៍របស់អ្នកនោះ ។ ការណ៍នេះ នឹងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យថ្លែងជាសាក្សីពីសេចក្តីពិត ដែលអ្នកចែកចាយ ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ២៨:១១–១៦

*ព្រះអម្ចាស់ដឹកនាំ អូលីវើរ ខៅឌើរី ឲ្យកែតម្រូវ ហៃរ៉ាំ ភេច ហើយជួយរៀបចំសាសនាចក្រឲ្យមានរបៀបរៀបរយ*

សូមរំឭកសិស្សអំពីវិវរណៈក្លែងក្លាយ ដែលហៃរ៉ាំ ភេច បានបង្ហាញដល់សមាជិកសាសនាចក្រមួយចំនួន ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ២៨:១១–១៤ ដោយស្ងាត់ស្ងៀម ដើម្បីរកមើលអ្វីដែលព្រះអម្ចាស់បានដឹកនាំ អូលីវើរ ខៅឌើរី ឲ្យធ្វើ ដើម្បីជួយដោះស្រាយបញ្ហាលំបាកនេះ ។

- តើព្រះអម្ចាស់បញ្ជាឲ្យ អូលីវើរ ធ្វើអ្វីខ្លះ ដើម្បីជួយដោះស្រាយបញ្ហាជាមួយនឹង ហៃរ៉ាំ ភេច ?

- តើយើងអាចរៀនអ្វីបានខ្លះពីខគម្ពីរទាំងនេះ អំពី ការទទួលខុសត្រូវរបស់អ្នកដឹកនាំសាសនាចក្រ ? ( សិស្សអាចប្រាប់អំពីគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា អ្នកគូសបញ្ជាក់ដូចខាងក្រោមនេះ ៖ **អ្នកដឹកនាំសាសនាចក្រ មានទំនួលខុសត្រូវដើម្បីកែតម្រូវអ្នកទាំងឡាយណា ដែលកំពុងដឹកនាំអ្នកដទៃឲ្យវង្វេង ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ) ។

- តើយើងអាចរៀនអ្វីខ្លះ មកពី គោលលទ្ធិ និង សេចក្តីសញ្ញា ២៨:១៣ អំពីរបៀបដែលព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេប្រាប់អំពី គោលការណ៍ដូចខាងក្រោម ៖ **នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ អ្វីៗគ្រប់យ៉ាង ត្រូវតែមានរបៀបរៀបរយ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ) ។

សូមពន្យល់ថា របៀបមួយដែលយើងធ្វើគ្រប់ការណ៍ទាំងអស់ « តាមរបៀបរៀបរយ និងតាមការយល់ព្រមទូទៅ » គឺថាយើងគាំទ្រដល់បុគ្គលម្នាក់ៗជាសាធារណៈនៅក្នុងការហៅបម្រើសាសនាចក្រ ។

- ហេតុអ្វីក៏អ្នកគិតថាវាសំខាន់ ចំពោះបុគ្គលម្នាក់ៗ ត្រូវបានគាំទ្រជាសាធារណៈនៅក្នុងការហៅបម្រើរបស់ពួកគេដូច្នេះ ?

ដើម្បីជួយសិស្សក្នុងថ្នាក់យល់អំពីរបៀបយល់ព្រមទូទៅ ផ្តល់នូវរបៀបរៀបរយ និងការការពារដល់សាសនាចក្រ សូមឲ្យសិស្សម្នាក់អាននូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ផាកកឺ ៖



« វិវរណៈក្នុងសាសនាចក្រ កើតមានដល់អ្នកទាំងឡាយដែលត្រូវបានហៅ បានគាំទ្រ បានតែងតាំង ឬបានញែកចេញដោយត្រឹមត្រូវ ។ ឧទាហរណ៍ ប៊ីស្សពម្នាក់ នឹងពុំទទួលវិវរណៈណាទាក់ទងនឹងវួដជិតខាងទេ ដោយសារវាស្ថិតនៅក្រៅតំបន់របស់គាត់ ។

« កម្រមានមនុស្សម្នាក់ណា នឹងប្រកាសខ្លួនថាបានទទួលសិទ្ធិអំណាចដើម្បីបង្រៀន និងប្រទានពរ ដោយពុំត្រូវបានហៅ និងញែកចេញណាស់ ។. . .

« នោះជាមូលហេតុដែលដំណើរការនៃការគាំទ្រដល់អ្នកទាំងឡាយ បានហៅឲ្យកាន់តំណែង គឺត្រូវបានការពារយ៉ាងខ្លាំងបំផុតក្នុងសាសនាចក្រ– ដើម្បីឲ្យមនុស្សអាចដឹងថា នរណាមានសិទ្ធិអំណាចដើម្បីបង្រៀន និងប្រទានពរ » ( « Revelation in a Changing World, » ទំព័រ ១៥ ) ។

- យោងតាម ប្រធាន ផាកកឺ ហេតុអ្វីក៏យើងគាំទ្រអ្នកទាំងឡាយដែលបានទទួលការហៅបម្រើក្នុងសាសនាចក្រជាសាធារណៈដូច្នេះ ?
- បន្ទាប់ពីយើងបានលើកដៃដើម្បីនិយាយថា យើងនឹងគាំទ្រដល់អ្នកទាំងឡាយក្នុងការហៅបម្រើរបស់ពួកគេ តើយើងគួរធ្វើអ្វីខ្លះ ដើម្បីបង្ហាញថាពិតជាបានគាំទ្រដល់ពួកគេពិតមែន ?

ដើម្បីជួយសិស្សអនុវត្តគោលការណ៍ដែលពួកគេបានរៀននៅក្នុងមេរៀនថ្ងៃនេះ សូមអានស្ថានភាពដូចខាងក្រោមឲ្យឮៗ ហើយសួរពួកគេអំពីរបៀបដែលពួកគេនឹងឆ្លើយតបទៅនឹងគោលការណ៍នីមួយៗ ៖

១. អ្នកទទួលបានសារទំនាក់ទំនងអេឡិចត្រូនិចមួយ ប្រកាសថាជាវិវរណៈថ្មី ។ វាមាននូវការបង្រៀនដែលពុំត្រូវតាមបទគម្ពីរ ឬពាក្យសម្ដីរបស់ព្យាការីនៅរស់ ។

២. អ្នកកត់សម្គាល់ឃើញថា សមាជិកម្នាក់ក្នុងវួដរបស់អ្នក បានធ្វើសេចក្ដីថ្លែងការណ៍មួយ ដែលពុំត្រឹមត្រូវតាមគោលលទ្ធិ នៅពេលនាងថ្លែងទីបន្ទាល់របស់នាង អំឡុងការប្រជុំសាក្រាម៉ង់ ។ អ្នកបារម្ភបើសិនជាសារលិខិតនោះខុសពីសេចក្ដីពិត វាអាចនឹងមានឥទ្ធិពលប៉ះពាល់បំផ្លាញអ្នកដទៃ ។ តើនរណាគួរកែតម្រូវសមាជិកដែលកំពុងនិយាយខុសឆ្គងនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១៥–១៦ ឲ្យឮៗ ហើយសួរដល់សិស្សក្នុងថ្នាក់ឲ្យប្រាប់អំពីការទូន្មានចុងក្រោយរបស់ព្រះអម្ចាស់ ទៅកាន់អូលីវើរ ខៅឌើរី នៅក្នុងវិវរណៈ ។

ចូរពន្យល់ថា បន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះ លោកបានចាប់ផ្ដើមធ្វើសន្និសីទមួយ ហើយបានរៀបចំសាសនាចក្រតាមរបៀបរៀបរយ ។ នៅក្នុងសន្និសីទ « បងប្រុស ភេច ក៏ដូចជាសាសនាចក្រទាំងមូល ដែលមានវត្តមាននៅទីនោះ បានបដិសេធនឹងថ្មចេះនិយាយ ព្រមទាំងអ្វីៗទាំងអស់ ដែលបានជាប់ទាក់ទងនឹងរឿងនោះ » ( *Histories, វ៉ុលទី ១:១៨៣២–១៨៤៤*, ៤៥២ ) ។ ដើម្បីបញ្ចប់មេរៀននេះ សូមថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សា និងតម្លៃរបស់ពួកគេក្នុងការជួយយើងឲ្យចៀសផុតពីការបញ្ឆោត ។

មេរៀនទី ៣៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–២៩

## បុព្វកថា

មិនយូរប៉ុន្មានពីមុនពេលសន្និសីទសាសនាចក្រ ដែលបានធ្វើឡើងនៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៨៣០ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយនៅក្នុងវត្តមានរបស់អែលឌើរប្រាំមួយរូប ។ តាមរយៈវិវរណៈ ពួកអែលឌើរទាំងនេះ បានរៀនអំពីការប្រមូលផ្ដុំនៃពួកជម្រើសរបស់ព្រះអង្គសង្គ្រោះ មុនការយាងមកជាលើកទីពីររបស់ទ្រង់ ។

### *សូមអញ្ជើញព្រះវិញ្ញាណបរិសុទ្ធ*

សូមលើកទឹកចិត្តសិស្សឲ្យអញ្ជើញឲ្យមានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធខណៈពេលពួកគេសិក្សាព្រះគម្ពីររួមគ្នា ។ សកម្មភាពមួយចំនួនដែលអញ្ជើញឲ្យមានព្រះវិញ្ញាណគឺការអធិស្ឋានដោយស្មោះ ការបង្រៀនមកពីព្រះគម្ពីរ ការថ្លែងទីបន្ទាល់ ការសួរសំណួរបំផុសគំនិត ការបង្ហាញនូវសេចក្ដីស្រឡាញ់ចំពោះព្រះនិងអ្នកដទៃ ព្រមទាំងការចែកចាយបទពិសោធន៍ខាងវិញ្ញាណ ។ ក្នុងឱកាសខ្លះ អ្នកអាចនឹងទទួលបានការបំផុសគំនិតដើម្បីជួយសិស្សទទួលស្គាល់ពីឥទ្ធិពលរបស់ព្រះវិញ្ញាណបរិសុទ្ធ អំឡុងមេរៀនទាំងឡាយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–១៣

*ព្រះអម្ចាស់ បានថ្លែងទីបន្ទាល់អំពីដង្វាយធួនរបស់ទ្រង់ និងព្រះទ័យរបស់ទ្រង់ក្នុងការប្រមូលរាស្ត្ររបស់ទ្រង់*

ពីមុនចាប់ផ្ដើមថ្នាក់រៀន សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ « *សូមលើកចិត្តអ្នកឡើង ហើយអរសប្បាយចុះ* » *( គ និង ស ២៩:៥ ) ។*

- ហេតុអ្វីក៏ពេលខ្លះវាពិបាកដើម្បីគោរពតាមការទូន្មាននេះ ? តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកបានរកឃើញដើម្បីគោរពតាមការទូន្មាននេះ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៣ មាននូវព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ដែលអាចជួយយើង « សូមលើកចិត្ត [ យើង ]ឡើង ហើយអរសប្បាយចុះ » ។



សូមដាក់បង្ហាញរូបភាពព្រះយេស៊ូវគ្រីស្ទជាមួយនឹងកុមារតូចៗ ( *សៀវភៅសិល្បៈដំណឹងល្អ* [ ២០០៩ ] ទំព័រ ៤៧ សូមមើលផងដែរ LDS.org ) ហើយ បើអាចធ្វើទៅបាន សូមបង្ហាញរូបភាពមេមាន់កំពុងក្រុងកូនៗវា ។ សូមសួរថាតើមាននរណាម្នាក់ អាចពិពណ៌នាអំពី របៀប និង មូលហេតុដែលមេមាន់ក្រុងកូនវា ។ ( បើសិស្សពុំដឹងទេ សូមពន្យល់ថានៅពេលមេមាន់ដឹងពីគ្រោះថ្នាក់ នោះវានឹងហៅកូនៗវាមក ។ នៅពេលពួកវាមករកមេវា មេមាន់ក្រុងពួកវានៅក្រោមស្លាបដើម្បីការពារពួកវា ) ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២ ឲ្យឮៗ ។

- តើព្រះអង្គសង្គ្រោះ ដូចជាមេមាន់ដែលក្រុងការពារកូនវាយ៉ាងដូចម្ដេច ?

- តើកូនមាន់ត្រូវធ្វើអ្វីខ្លះ ដើម្បីត្រូវបានក្រុងដោយសុវត្ថិភាពនៅក្រោមស្លាបការពាររបស់មេវា ? ( បើចាំបាច់ សូមចង្អុលបង្ហាញថា កូនមាន់ត្រូវខំរត់ទៅរកមេរបស់វា ) ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ *ព្រះយេស៊ូវគ្រីស្ទនឹងប្រមូលយើង ពេលយើង . . .*

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២ តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីត្រូវបានប្រមូលផ្ដុំដោយព្រះអង្គសង្គ្រោះ ? ( សូមប្រើចម្លើយរបស់សិស្សដើម្បីបំពេញគោលការណ៍នៅលើក្ដារខៀន ៖ **ព្រះយេស៊ូវគ្រីស្ទ នឹងប្រមូលយើង ពេលយើងស្ដាប់តាមសំឡេងទ្រង់ដោយរាបសារ ហើយទូលហៅទ្រង់ក្នុងការអធិស្ឋាន** ) ។

សូមពន្យល់ថា ចាប់តាំងពីការចាប់ផ្ដើមមក ពួកព្យាការីបានព្យាករអំពីការប្រមូលផ្ដុំនៃពួកអ៊ីស្រាអែល ។ ដំណាក់នៃអ៊ីស្រាអែល–វាស្រ្តនៃសេចក្ដីសញ្ញារបស់ព្រះអម្ចាស់–នឹងត្រូវបានប្រមូលផ្ដុំនៅក្នុងថ្ងៃចុងក្រោយ មុនការយាងមករបស់ព្រះគ្រីស្ទ ( សូមមើល មាត្រានៃសេចក្ដីជំនឿ ១:១០ ) ។ ព្រះអម្ចាស់ ប្រមូលរាស្ត្រទ្រង់ នៅពេលពួកគេអនុវត្តសេចក្ដីជំនឿទៅលើទ្រង់ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ ។

ដើម្បីជួយសិស្សយល់ និងដឹងពីសេចក្ដីពិត និងសារៈសំខាន់នៃគោលការណ៍នេះ សូមពិភាក្សាចំពោះសំណួរដូចខាងក្រោម ៖

- តើវិធីមួយចំនួនដែលយើងស្ដាប់សំឡេងរបស់ព្រះអង្គសង្គ្រោះមានអ្វីខ្លះ ? ( ចម្លើយអាចរួមមានថា យើងអាចស្ដាប់ឮសំឡេងរបស់ទ្រង់តាមរយៈព្រះគម្ពីរ ការបង្រៀនរបស់ពួកព្យាការីនៅរស់ និងពួកសាវក និងការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ ) ។

- តើការស្ដាប់តាមសំឡេងរបស់ព្រះអង្គសង្គ្រោះ ខុសពីការគ្រាន់តែឮសំឡេងរបស់ទ្រង់យ៉ាងដូចម្ដេច ?

- ហេតុអ្វីក៏អ្នកគិតថា យើងចាំបាច់ត្រូវបន្ទាបខ្លួន ដើម្បីត្រូវបានប្រមូលដោយព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាដែលពួកគេបានទទួលអារម្មណ៍ថា នៅជិតនឹងព្រះអង្គសង្គ្រោះ តាមរយៈការសិក្សាព្រះគម្ពីរ ការធ្វើតាមពាក្យសម្ដីរបស់ព្យាការីនៅរស់ ឬការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ។ សូមផ្ដល់ឱកាសដល់សិស្សពីរបីនាក់ ឲ្យចែកចាយបទពិសោធន៍ទាំងនេះ សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ពុំគួរចែកចាយទេ ។

យោងទៅបទគម្ពីរដែលអ្នកបានសរសេរនៅលើក្ដារខៀនពីមុនចាប់ផ្ដើមថ្នាក់រៀន ។

- តើគំនិតដែលត្រូវបានប្រមូលផ្ដុំដោយព្រះអង្គសង្គ្រោះ ជួយអ្នកលើកចិត្តអ្នកឡើង ហើយអរសប្បាយយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១, ៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុមួយ ដើម្បីលើកចិត្តយើងឡើង ហើយអរសប្បាយ ។ បន្ទាប់មក សូមឲ្យសិស្សប្រាប់អំពីគោលការណ៍មួយមកពីខគម្ពីរទាំងនេះ ដែលពន្យល់ពីមូលហេតុដែលយើងអាចលើកចិត្តខ្លួនឯងឡើង ហើយអរសប្បាយ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីគោលការណ៍ដែលពួកគេបានប្រាប់នោះ ។ ( ចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងពីគោលការណ៍ដូចខាងក្រោម ៖ **ដោយសារតែព្រះអង្គសង្គ្រោះបានធួនសម្រាប់អំពើបាបរបស់យើង នោះយើងអាចលើកចិត្តយើងឡើង ហើយអរសប្បាយ** ) ។

- តើទីបន្ទាល់របស់អ្នកអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទបាននាំសុភមង្គលមកក្នុងជីវិតរបស់អ្នកយ៉ាងដូចម្ដេច ? ( បន្ទាប់ពីសិស្សបានឆ្លើយតបចំពោះសំណួរនេះ អ្នកអាចនឹងចង់ចែកចាយចម្លើយរបស់អ្នកផងដែរ ) ។

សូមពន្យល់ថា របៀបមួយដែលព្រះអង្គសង្គ្រោះប្រមូលរាស្ត្រទ្រង់ គឺតាមរយៈការខិតខំរបស់យើងដើម្បីចែកចាយដំណឹងល្អ ។ នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ ទ្រង់មានបន្ទូលតាមរយៈ យ៉ូសែប ស្ម៊ីធ ទៅកាន់អែលឌើរទាំងប្រាំមួយរូប ហើយបានបញ្ជាពួកគេដើម្បីប្រកាសដំណឹងល្អរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤–៦ ដោយស្ងាត់ស្ងៀម ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលពាក្យ និងឃ្លាទាំងឡាយដែលទាក់ទងនឹងកិច្ចការអ្នកផ្សព្វផ្សាយសាសនា ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- តើពាក្យ និង ឃ្លាអ្វីខ្លះ ដែលអ្នកបានរកឃើញ ? តើពាក្យ ឬឃ្លាទាំងឡាយនេះ បង្រៀនអំពីបទពិសោធន៍នៃការចែកចាយដំណឹងល្អយ៉ាងណាខ្លះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការពន្យល់របស់ព្រះអង្គសង្គ្រោះអំពីអ្វីដែលអែលឌើរទាំងប្រាំមួយនាក់នេះ ត្រូវបានហៅឲ្យធ្វើ និងហេតុអ្វី ។

- តើព្រះអង្គសង្គ្រោះបានហៅពួកអែលឌើរទាំងនេះឲ្យធ្វើអ្វីខ្លះ ? ( « ដើម្បីនាំឲ្យមានការប្រមូលផ្ដុំនៃពួកជម្រើស [ របស់ទ្រង់ ] » ) ។ តើព្រះអង្គសង្គ្រោះពិពណ៌នាអំពីពួកជម្រើសរបស់ទ្រង់យ៉ាងដូចម្ដេច ? ( អ្នកទាំងឡាយដែល « ស្ដាប់សំឡេងរបស់ទ្រង់ ហើយពុំរឹងរូសក្នុងដួងចិត្តរបស់ពួកគេ » ) ។

- តើអ្នកផ្សព្វផ្សាយសាសនាជួយនាំមកនូវការប្រមូលផ្ដុំនៃពួកជម្រើសយ៉ាងដូចម្ដេច ?

ចូរពន្យល់ថា កាលវិវរណៈនេះត្រូវបានផ្ដល់ឲ្យ សមាជិកភាពក្នុងសាសនាចក្រមានចំនួនតិច ។ ពួកបរិសុទ្ធអាច « ត្រូវបានប្រមូលនៅកន្លែងមួយ » ( គ. និង ស. ២៩:៨ ) ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលសាសនាចក្ររីកចម្រើន ព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធប្រមូលផ្ដុំគ្នាពីកន្លែងផ្សេងៗ ។ សព្វថ្ងៃនេះ យើងប្រមូលផ្ដុំគ្នានៅក្នុងស្ដេកនៃស៊ីយ៉ូន ត្រង់កន្លែងដែលយើងរស់នៅ ។

- តើយើងប្រមូលផ្ដុំគ្នានាសព្វថ្ងៃនេះត្រង់កន្លែងណា ? ( ចម្លើយអាចរួមមាន នៅគេហដ្ឋាន សាលាប្រជុំ និង ព្រះវិហារបរិសុទ្ធ ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៩–១៣ ដោយការពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះ ព្រះអង្គសង្គ្រោះបានប្រកាសថា ទ្រង់នឹងយាងមកម្ដងទៀតនៅលើផែនដីដោយព្រះចេស្ដា និងសិរីល្អ ។ ពួកពលបរិវារដែលនឹងមកជាមួយព្រះអង្គសង្គ្រោះក្នុងសិរីល្អនៅការយាងមកជាលើកទីពីររបស់ទ្រង់ នឹងជាពួកបរិសុទ្ធស្មោះត្រង់ ដែលបានរស់នៅពីគ្រប់ជំនាន់នៃប្រវត្តិសាស្ត្រផែនដី ។ ពួកសុចរិតដែលបានស្លាប់ទៅ នឹងត្រូវបានរស់ឡើងវិញ ហើយពួកទុច្ចរិតនឹងត្រូវបំផ្លាញចោល ។ ព្រះយេស៊ូវគ្រីស្ទ នឹង « ស្ថិតនៅក្នុងសេចក្ដីសុចរិតជាមួយមនុស្សលោកនៅលើផែនដីអស់មួយពាន់ឆ្នាំ » ( គ និង ស ២៩:១១ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៤–២១

*ព្រះយេស៊ូវគ្រីស្ទ ពិពណ៌នាអំពីទីសម្គាល់មួយចំនួនដែលនឹងមានមុនការយាងមកជាលើកទីពីររបស់ទ្រង់*

សូមពន្យល់ថា ការប្រមូលផ្ដុំនៃពួកអ៊ីស្រាអែល គឺជាចំណែកនៃការរៀបចំខ្លួនរបស់យើងសម្រាប់ការយាងត្រឡប់មកវិញរបស់ព្រះអង្គសង្គ្រោះ ។ ព្រះអម្ចាស់ បានបើកសម្ដែងទីសម្គាល់ដទៃៗទៀត ដែលនឹងកើតឡើង ពីមុនការយាងមកជាលើកទីពីររបស់ទ្រង់ ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៤–២១ ដោយស្ងាត់ស្ងៀម រកមើលទីសម្គាល់ដែលនឹងកើតឡើង ពីមុនការយាងមកជាលើកទីពីរ ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំទីសម្គាល់ទាំងនេះនៅក្នុងបទគម្ពីររបស់ពួកគេ ឬសរសេរវានៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

ពីមុនសិស្សអានខគម្ពីរទាំងនេះ សូមគូសបញ្ជាក់ថា យើងពុំដឹងពីរបៀប ឬនៅពេលណាដែលការព្យាករណ៍ទាំងនេះនឹងត្រូវបានបំពេញនោះទេ ។

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីសិក្សាខគម្ពីរទាំងនេះហើយ សូមចង្អុលបង្ហាញថា ទោះបីជាទីសម្គាល់ទាំងនេះនឹងកើតមាន ដោយសារតែសេចក្ដីទុច្ចរិតក្ដី នោះវានឹងមានឥទ្ធិពលលើមនុស្សទាំងអស់នៅលើផែនដី ទោះជាពួកសុចរិតក្ដី ។ អ្នកអាចនឹងចង់អានសេចក្ដីថ្លែងការដូចខាងក្រោម ដោយព្យាការី យ៉ូសែប ស្ម៊ីធ ៖



« អំពីការយាងមករបស់កូនមនុស្ស. . . វាក៏ជាគំនិតខុសឆ្គងផងដែរ ដែលថាពួកបរិសុទ្ធ នឹងចៀសផុតពីគ្រប់ការជំនុំជម្រះ ខណៈពេលដែលមនុស្សទុច្ចរិតរងទុក្ខ ដ្បិតគ្រប់សាច់ឈាម គឺស្ថិតនៅក្រោមការរងទុក្ខ ហើយ ‹ ពួកសុចរិតវិះនឹងគៀសខ្លួនមិនរួចដែរ › [ សូមមើល គ និង ស ៦៣:៣៤ប៉ុន្តែពួកបរិសុទ្ធជាច្រើននឹងបានគៀសខ្លួន ដ្បិតមនុស្សសុចរិតនឹងរស់នៅដោយសេចក្ដីជំនឿរបស់ខ្លួន [ សូមមើល ហាបាគុក ២:៤] ប៉ុន្តែពួកសុចរិតជាច្រើន នឹងរងគ្រោះដោយសារជម្ងឺ គ្រោះចង្រៃជាដើម ។ ដោយសារតែមូលហេតុនៃភាពទន់ខ្សោយខាងសាច់ឈាម ហើយប៉ុន្តែនឹងត្រូវបានសង្គ្រោះនៅក្នុងនគរព្រះ » ( *Teachings of Presidents of the Church: Joseph Smith* ឆ្នាំ ២០០៧], ២៥៣ ) ។

- ហេតុអ្វីក៏អ្នកចង់ត្រូវបានប្រមូលផ្ដុំជាមនុស្សជម្រើសម្នាក់របស់ព្រះអង្គសង្គ្រោះ នៅពេលរឿងទាំងនេះកើតឡើងដូច្នេះ ?

សូមចង្អុលបង្ហាញថា បើយើងមានសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយធ្វើតាមទ្រង់ នោះយើងអាចមានភាពសុខសាន្តជានិច្ច ទោះជានៅក្នុងគ្រាទាំងឡាយ ដែលបានពិពណ៌នានៅក្នុងវិវរណៈនេះក្ដី ។ ដើម្បីគូសបញ្ជាក់អំពីសេចក្ដីពិតនេះ អ្នកអាចអញ្ជើញសិស្សឲ្យអាននូវខមួយចំនួន ឬខទាំងអស់ដូចខាងក្រោម ៖ យ៉ូហាន ១៤:២៧, ១៦:៣៣, គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២៣ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលផលវិបាកនៃការបដិសេធក្នុងការប្រែចិត្ត ។

- តើផលវិបាកនៃការបដិសេធក្នុងការប្រែចិត្តមានអ្វីខ្លះ ? ( សិស្សគួរតែបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងមិនប្រែចិត្តទេ នោះលោហិតនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នឹងពុំលាងជម្រះយើងឡើយ ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំគោលការណ៍នេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៧ ) ។

សូមអះអាងនឹងសិស្សថា ការរៀបចំខ្លួនដ៏សំខាន់បំផុត ដែលយើងអាចធ្វើសម្រាប់ការយាងមកជាលើកទីពីរគឺ ការមករកព្រះអង្គសង្គ្រោះ ប្រែចិត្ត ហើយត្រូវបានលាងជម្រះពីអំពើបាបរបស់យើង ។ សូមអញ្ជើញសិស្សឲ្យគិតថា តើពួកគេចាំបាច់ត្រូវប្រែចិត្តអ្វីខ្លះ ហើយអ្វីខ្លះដែលពួកគេត្រូវធ្វើ ដើម្បីឲ្យបានជ្រះស្អាតពីអំពើបាប ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២២–២៩

*ព្រះអង្គសង្គ្រោះ បើកសម្ដែងសេចក្ដីពិតអំពីអ្វីដែលនឹងកើតមានឡើង បន្ទាប់ពីសហសវត្ស រួមទាំងការជំនុំជម្រះចុងក្រោយផងដែរ*

សូមចាត់ឲ្យសិស្សម្នាក់ៗនូវវគ្គបទគម្ពីរដូចខាងក្រោមមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ ៖ ខ ២២, ខ ២៦ ឬ ខ ២៧–២៨ ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរដែលបានចាត់ទៅឲ្យពួកគេ ឬអានខគម្ពីរនោះដោយស្ងាត់ស្ងៀម ហើយប្រាប់នូវរឿងមួយដែលនឹងកើតឡើងនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ។ ( សម្រាប់សិស្សទាំងឡាយដែលត្រូវបានចាត់តាំងឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២៦ អ្នកអាចនឹងចង់ពន្យល់ថា មីកែលដែលជាមហាទេវតា គឺជាលោកអ័ដាម ។ សូមមើល គ. និង ស. ១០៧:៥៤ ) ។ បន្ទាប់ពីសិស្សមានពេលស្រាវជ្រាវខគម្ពីរដែលបានចាត់ទៅឲ្យពួកគេឬខគម្ពីរទាំងឡាយរួចហើយ សូមឲ្យពួកគេរាយការណ៍អំពីអ្វីដែលពួកគេបានរកឃើញ ចាប់ផ្ដើមពី ខ ២២ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២៧ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវពរជ័យដែលបានប្រទានដល់ពួកសុចរិតនៅក្នុងការជំនុំជម្រះចុងក្រោយ ។

- តើនឹងមានពរជ័យអ្វីខ្លះកើតមានដល់យើង បើយើងត្រូវបានប្រមូលផ្ដុំទៅជួបព្រះអង្គសង្គ្រោះ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **អ្នកទាំងឡាយដែលបានរស់នៅដោយសុចរិត ហើយមករកព្រះយេស៊ូវគ្រីស្ទនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។** អ្នកអាចចង់លើកទឹកចិត្តពួកគេឲ្យគូសចំណាំសេចក្ដីពិតនេះ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២៧ ) ។

សូមបញ្ចប់ដោយការដាក់រូបភាពនៃព្រះយេស៊ូវគ្រីស្ទជាមួយនឹងកុមារតូចៗនៅលើក្ដារខៀន ។ សូមសរសេរពាក្យ *ខ្ញុំ* នៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សឲ្យគិតអំពីកន្លែងដែលពួកគេនឹងដាក់ពាក្យ *ខ្ញុំ* បើសិនជាការដាក់ជំនួសវានោះ តំណាងឲ្យភាពជិតស្និតបំផុតរបស់ពួកគេចំពោះព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សចែកចាយបទពិសោធន៍ដែលពួកគេមាន នៅពេលពួកគេបានធ្វើតាមការបំផុសគំនិតដែលបាននាំពួកគេទៅកាន់តែជិតនឹងព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញពួកគេឲ្យជ្រើសរើសអ្វីមួយ ដែលពួកគេនឹងធ្វើ ដើម្បីធ្វើនូវអ្វីដែលពួកគេបានរៀននៅថ្ងៃនេះ ហើយខិតទៅកាន់តែជិតនឹងទ្រង់ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៩:៣០ ( មេរៀនទី ៧ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៩:៣០ ( មេរៀនទី ៧ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៦)

តាមរយៈព្រះឱវាទរបស់ព្រះអម្ចាស់ដល់យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី អំពីការឆ្លើយតបទៅនឹងការសាកល្បង នោះសិស្សបានរៀនថាយើងគួរតែមានចិត្តអត់ធ្មត់ ហើយស៊ូទ្រាំនឹងទុក្ខវេទនារបស់យើង ដោយសារព្រះអម្ចាស់គង់នៅជាមួយយើង ។ នៅពេលសិស្សបានសិក្សាព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះ អិមម៉ា ស្ម៊ីធ អំពីតួនាទីរបស់គាត់នៅក្នុងសាសនាចក្រ នោះពួកគេបានរកឃើញគោលការណ៍មួយចំនួន ហើយបានជ្រើសរើសយកគោលការណ៍មួយដើម្បីផ្ដោតយកចិត្តទុកដាក់លើវា នោះពួកគេនឹងមានអារម្មណ៍ថា អាចអនុវត្តបាននៅក្នុងជីវិតផ្ទាល់ខ្លួន ។ ជាចុងក្រោយ សិស្សបានសិក្សាពីការប្រកាសរបស់ព្រះអម្ចាស់ ដែលថារបស់ទាំងអស់នឹងត្រូវបានសម្រេច ដោយសារការយល់ព្រមទូទៅនៅក្នុងសាសនាចក្រ ហើយបានពិចារណាពី របៀបដែលពួកគេអាចធ្វើការតាំងចិត្តខ្លួនបានកាន់តែប្រសើរ ដើម្បីគាំទ្រអស់អ្នកដែលត្រូវបានហៅ ហើយគាំទ្រឲ្យបម្រើនៅក្នុងវួដ ឬ សាខារបស់ខ្លួន ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧)

( នៅពេលសិស្សបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧ នោះពួកគេបានរៀនថា នៅពេលយើងទទួលទានពិធីសាក្រាម៉ង់ នោះយើងត្រូវចងចាំអំពីពលិកម្មធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេក៏បានរៀនផងដែរថា យើងកំពុងរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រានៃកំណត់កាលដ៏ពោរពេញ ដែលនាំមករួមគ្នានូវកូនសោទាំងអស់នៃដំណឹងល្អ ពិធីបរិសុទ្ធ និង សេចក្ដីពិតនៃគ្រាកាន់កាប់ត្រួតត្រាដែលបានកន្លងហួសទៅ ។ ដើម្បីអាចទប់ទល់នឹងអំពើអាក្រក់នៅជំនាន់របស់យើងនេះ សិស្សត្រូវបានលើកទឹកចិត្តឲ្យពាក់លើខ្លួនពួកគេនូវគ្រប់គ្រឿងសឹករបស់ព្រះ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨)

ចេញពីព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះ អូលីវើរ ខៅឌើរី សិស្សបានរៀនថានៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ សមាជិកម្នាក់ៗពុំទទួលវិវរណៈ ដើម្បីដឹកនាំនរណាម្នាក់ដែលធ្វើជាអធិបតីលើពួកគេឡើយ ហើយថាមានតែប្រធានសាសនាចក្រតែម្នាក់ប៉ុណ្ណោះដែលនឹងទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចនឹងទទួលបានវិវរណៈសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន និង ដើម្បីជួយយើងបំពេញការហៅ និង ការចាត់តាំងដែលបានប្រគល់ដល់យើង ។ ( សិស្សក៏បានរៀនផងដែរថា អ្នកដឹកនាំសាសនាចក្រមានទំនួលខុសត្រូវ ដើម្បីនឹងកែតម្រូវដល់អស់អ្នកដែលកំពុងដឹកនាំអ្នកដទៃទៀតឲ្យវង្វេង ហើយថាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ អ្វីៗគ្រប់យ៉ាងត្រូវតែមានរបៀបរៀបរយ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៣០)

ចេញពីការណែនាំរបស់ព្រះអង្គសង្គ្រោះអំពី ការយាងមកជាលើកទីពីរ និង ព្រឹត្តិការណ៍ក្រោយពីសហស្សវត្សរ៍ នោះសិស្សបានរៀនថា អស់អ្នកដែលមករកព្រះអង្គសង្គ្រោះ នឹងត្រូវបានរៀបចំសម្រាប់ការសាកល្បង និង សេចក្ដីទុក្ខលំបាកនៃថ្ងៃចុងក្រោយ ហើយនឹងទទួលជីវិតអស់កល្បជានិច្ច ។ មេរៀននេះក៏បានជួយសិស្សឲ្យយល់ថា ដោយសារព្រះយេស៊ូវគ្រីស្ទ បានធ្វើឲ្យធួននឹងអំពើបាបទាំងឡាយរបស់យើង និង ជាព្រះដ៏គាំទ្រចំពោះព្រះវរបិតា នោះយើងអាចលើកចិត្តយើងឡើង ហើយបានអរសប្បាយ ។

## សេចក្ដីផ្ដើម

មេរៀននេះផ្ដល់ឱកាសឲ្យសិស្សពង្រីកនូវការយល់របស់ខ្លួនកាន់តែជ្រាលជ្រៅអំពី សារៈសំខាន់នៃការពាក់លើខ្លួននូវគ្រប់គ្រឿងសឹករបស់ព្រះ ។ នៅពេលសិស្សរៀនអំពីផ្នែកនិមួយ ៗនៃគ្រឿងសឹកទាំងមូលរបស់ព្រះ នោះពួកគេនឹងមានឱកាសវាយតម្លៃកម្លាំងនៃគ្រឿងសឹករបស់ពួកគេ ហើយធ្វើការផ្លាស់ប្ដូរនានាតាមការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨

*ព្រះអម្ចាស់ត្រាស់បញ្ជារាស្ត្ររបស់ទ្រង់ឲ្យពាក់គ្រប់គ្រឿងសឹករបស់ព្រះ*

សូមយកឧបករណ៍ការពារមួយចំនួនមកថ្នាក់រៀន ដូចជាឧបករណ៍ការពារសម្រាប់កីឡា វ៉ែនតាសុវត្ថិភាព ស្រោមដៃវិជ្ជាសាស្ត្រ មួកសុវត្ថិភាពសម្រាប់ការសាងសង់ ឬ អាវក្រោះ ។ សូមឲ្យសិស្សពន្យល់ពីគោលបំណងនៃឧបករណ៍នោះ និង របៀបដែលវាប្រើដើម្បីការពារអ្នកពាក់វា ។ សូមពន្យល់ថា ខណៈដែលឧបករណ៍ទាំងនេះការពារពួកយើងខាងរាងកាយ នោះព្រះអម្ចាស់បានផ្ដល់ព្រះឱវាទដើម្បីជួយការពារយើងខាងវិញ្ញាណ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថាយើងត្រូវតែធ្វើដើម្បីត្រូវបានការពារខាងវិញ្ញាណ ។

- តើយើងត្រូវតែធ្វើអ្វីដើម្បីត្រូវបានការពារខាងវិញ្ញាណ ?
- យោងតាមខគម្ពីរនេះ តើព្រះអម្ចាស់បានសន្យាអ្វីខ្លះ ចំពោះអស់អ្នកដែលពាក់គ្រប់គ្រឿងសឹករបស់ព្រះនោះ ?

សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **ប្រសិនបើយើងពាក់គ្រប់គ្រឿងសឹករបស់ព្រះ នោះយើងនឹងអាចទប់ទល់នឹងអំពើអាក្រក់បាន ។**

- តើអ្នកគិតថាហេតុអ្វីបានជាវាសំខាន់ដើម្បីពាក់ *គ្រប់* គ្រឿងសឹកនៃព្រះ ហើយកុំគ្រាន់តែពាក់តែមួយផ្នែកនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៦–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយស្វែងរកផ្នែកនិមួយៗនៃគ្រឿងសឹកខាងវិញ្ញាណ ដែលយើងត្រូវពាក់ដើម្បីអាចទប់ទល់នឹងសេចក្ដីអាក្រក់បាន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាអ្នកសរសេរ ហើយសរសេរ ( ឬ គូរ ) ផ្នែកនៃគ្រឿងសឹកនៅក្ដារខៀននៅពេលសិស្សរកឃើញវា ។ ( អ្នកអាចចង្អុលបង្ហាញថាសាវក ប៉ុល ក៏បានបង្រៀនផងដែរអំពីគ្រប់គ្រឿងសឹករបស់ព្រះ [ សូមមើល អេភេសូ ៦:១១–១៧] ) ។

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃការការពារខាងវិញ្ញាណនេះ ដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ សូមចែកសិស្សជាក្រុមតូចៗ ហើយចាត់តាំងក្រុមនិមួយៗនូវចំណែកមួយនៃគ្រឿងសឹក ។ សូមផ្ដល់ដល់ក្រុមនិមួយៗនូវសេចក្ដីថ្លែងការមួយច្បាប់ ដោយប្រធាន ហារ៉ូល ប៊ី លី ដូចខាងក្រោម និង ព័ត៌មាន និងសំណួរនៅក្នុងវគ្គខាងក្រោមទាក់ទងទៅនឹងផ្នែកនានានៃគ្រឿងសឹកដែលបានចាត់ទៅឲ្យគេនោះ ។ សូមអញ្ជើញសិស្សឲ្យធ្វើការនៅក្នុងក្រុមពួកគេ ដើម្បីឆ្លើយសំណួរអំពីផ្នែកនៃគ្រឿងសឹកដែលបានចាត់តាំងទៅឲ្យពួកគេ ហើយត្រៀមខ្លួនដើម្បីចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។



« យើងមានផ្នែកបួននៃរាងកាយ ដែលសាវកប៉ុលបានមានប្រសាសន៍ថា [ គឺជា ] ផ្នែកដ៏ទន់ខ្សោយបំផុតចំពោះអំណាចនៃសេចក្ដីងងឹត ។ ចង្កេះជាតួយ៉ាងនៃគុណធម៌ ព្រហ្មចារីយភាព ។ បេះដូងជាតួយ៉ាងនៃទង្វើរបស់យើង ។ ជើងរបស់យើងជាគោលដៅ ឬ គោលបំណងនៅក្នុងជីវិតរបស់យើង ហើយចុងក្រោយគឺជាក្បាលរបស់យើង គំនិតរបស់យើង » ( ហារ៉ូល ប៊ី លី, *Feet Shod with the Preparation of the Gospel of Peace,* Brigham Young University Speeches of the Year [ ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៤ ] ទំព័រទី ២ ) ។

« **ក្រវាត់ចង្កេះដោយសេចក្ដីពិត** » ( សូមមើលគ. និង ស. ២៧:១៥–១៦) ៖

ប្រធាន លី បានមានប្រសាសន៍ថា « ចង្កេះគឺជាផ្នែងនៃរាងកាយ ដែលនៅ ចន្លោះឆ្អឹងជំនី និងត្រកៀក ដែលអ្នកនឹងស្គាល់ គឺជាសរីរាង្គដ៏សំខាន់ ដែលត្រូវតែមានសម្រាប់ការបន្តពូជ » (*ជាស្បែកជើង*២ ) ។ ដើម្បី *ក្រវាត់* គឺជាការចងយ៉ាងតឹងដោយខ្សែក្រវាត់មួយ ។

- ហេតុអ្វីក៏អ្នកគិតថាសាតាំងវាយប្រហារទៅលើបរិសុទ្ធភាព គុណធម៌ និងព្រហ្មចារីយភាពដូច្នេះ ?
- តើអ្នកគិតថាការស្គាល់បទដ្ឋានរបស់ព្រះអំពីសីលធម៌ អាចជួយអ្នកស្ថិតនៅបរិសុទ្ធ ប្រកបដោយគុណធម៌ និងព្រហ្មចារីភាពយ៉ាងដូចម្ដេច ?

ការសិក្សាព្រះគម្ពីរជួយក្រវ៉ាត់យើងនៅក្នុងសេចក្ដីពិត ហើយជួយការពារសេចក្ដីពិត និងព្រហ្មចារីយភាពរបស់យើង ។

« **ប្រដាប់បាំងដើមទ្រូងនៃសេចក្ដីសុចរិត** » (គ. និង ស. ២៧:១៦) ៖

- យោងតាមប្រធាន លី តើប្រដាប់បាំងដើមទ្រូងការពារអ្វីខ្លះ ?
- តើអ្នកគិតថាសេចក្ដីសុចរិតនៃដួងចិត្តរបស់យើង ( បំណងប្រាថ្នារបស់យើង ) មានឥទ្ធិពលលើលទ្ធផលរបស់យើង ដើម្បីច្បាំងក្នុងចម្បាំងខាងវិញ្ញាណរបស់យើងយ៉ាងដូចម្ដេច ?

« **ពាក់សេចក្ដីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្ដីសុខសាន្តទុកជាស្បែកជើង** » (គ. និង ស. ២៧:១៦) ៖

ការ « ពាក់ស្បែក » ជើងរបស់អ្នក មានន័យថា ជាការពាក់ស្បែកជើង ឬការការពារជើងយើង ។

- យោងតាមប្រធាន លី តើជើងរបស់យើងតំណាងឲ្យអ្វី ?
- តើសាតាំងវាយប្រហារលើគោលដៅ និងគោលបំណងក្នុងជីវិតរបស់យើងយ៉ាងដូចម្ដេច ?
- តើព្រះប្រទានអ្វីខ្លះដល់យើងឲ្យ « តោងជាប់ » ដើម្បីជួយយើងរក្សាជើងរបស់យើង ដើរតាមផ្លូវនៃជីវិតឆ្ពោះទៅកាន់គោលដៅរបស់យើង ? ( សូមមើល នីហ្វៃទី ១ ៨:២៤) ។
- តើការផ្ដោតទៅលើគោលដៅ និងគោលបំណងសុចរិត ជួយយើងយកឈ្នះការល្បួងយ៉ាងដូចម្ដេច ?

« **សេចក្ដីជំនឿទុកជាខែល** » (គ. និង ស. ២៧:១៧) ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « រលត់អស់ទាំងព្រួញឆេះ [ ការល្បួង ] របស់ពួកទុច្ចរិត ? »
- តើសេចក្ដីជំនឿរបស់អ្នកទុកជាខែល ហើយការពារដល់អ្នកយ៉ាងដូចម្ដេច ?

« **សេចក្ដីសង្គ្រោះទុកជាមួកសឹក** (គ. និង ស. ២៧:១៨) ៖

- យោងតាមប្រធានលី នៅពេលក្បាលរបស់យើងត្រូវបានគ្របបាំង តើវាការពារដល់អ្វីខ្លះ ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីការពារដល់គំនិតរបស់យើង ?
- តើសាតាំងវាយប្រហារដល់គំនិតរបស់យើងយ៉ាងដូចម្ដេច ?
- តើរឿងជាក់លាក់អ្វីខ្លះ ដែលយើងអាចធ្វើ ដើម្បីការពារគំនិតរបស់យើង ?

« **ដាវរបស់ព្រះវិញ្ញាណរបស់ខ្ញុំ**» (គ. និង ស. ២៧:១៨) ៖

- តើព្រះវិញ្ញាណអាចជួយយើងយកឈ្នះលើការវាយប្រហាររបស់សាតាំងយ៉ាងដូចម្ដេច ?
- តើការមានព្រះវិញ្ញាណផ្ដល់អត្ថប្រយោជន៍អ្វីខ្លះដល់យើង នៅក្នុងការប្រយុទ្ធរបស់យើងទាស់នឹងអំពើអាក្រក់ ?
- តើព្រះបន្ទូលនៃព្រះ ជួយយើងប្រើដាវរបស់ព្រះវិញ្ញាណយ៉ាងដូចម្ដេច ?
- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីអញ្ជើញព្រះវិញ្ញាណឲ្យចូលក្នុងជីវិតរបស់អ្នកកាន់តែច្រើន ?

**បន្ទាប់ពីសិស្សបានរាយការណ៍ពីចម្លើយរបស់ពួកគេហើយ សូមអាននូវសេចក្ដីថ្លែងការខាងក្រោមដោយ អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយសុំឲ្យសិស្សស្ដាប់ពីរបៀបដែលយើងពាក់គ្រឿងសឹក និងពង្រឹងដល់គ្រឿងសឹករបស់ព្រះ ៖**



« ខ្ញុំចូលចិត្តគិតអំពីអាវក្រោះខាងវិញ្ញាណនេះ ដែលពុំប្រៀបដូចជាបំណែកនៃលោហៈធាតុដែលសូន្យឡើងមួយដុំ ដើម្បីពាក់ឲ្យត្រូវរូបកាយនោះទេ ប៉ុន្តែវាដូចជាច្រវ៉ាក់ប្រទាក់គ្នាទៅវិញ ។ ច្រវ៉ាក់ប្រទាក់គ្នាមានជាបំណែកតូចៗជាច្រើនផែនតភ្ជាប់នឹងគ្នា ដើម្បីអនុញ្ញាតឲ្យអ្នកប្រើអាចបត់បែនបានកាន់តែងាយស្រួលដោយមិនបាត់បង់នូវការការពារ ។ ខ្ញុំនិយាយដូច្នោះ ដោយសារវាជាបទពិសោធន៍របស់ខ្ញុំ ថា គ្មានអ្វីតែមួយដ៏ធំ ហើយអស្ចារ្យដែលយើងអាចធ្វើ ដើម្បីការពារខ្លួនយើងខាងវិញ្ញាណបាននោះឡើយ ។ អំណាចខាងវិញ្ញាណពិត ពឹងលើទង្វើតូចៗជាច្រើនវេញបញ្ចូលគ្នានៅក្នុងសាច់ក្រណាត់នៃការការពារខាងវិញ្ញាណ ដែលការពារ និងជាខែលទាស់នឹងរាល់សេចក្ដីអាក្រក់ » (« Be Strong in the Lord »*Ensign* ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៨ ) ។

- **តើទង្វើរតូចៗមួយចំនួនអ្វីខ្លះ ដែលបានប្រមូលផ្ដុំជាកម្លាំងរបស់វា នឹងជួយការពារយើងទាស់នឹងការល្បួង និងអំពើអាក្រក់ ?**

**សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅមើលនៅដើមបន្ទាត់នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥ ។**

- តើយើងគួរមានអាកប្បកិរិយាយ៉ាងណា ពេលយើងពាក់គ្រឿងសឹករបស់ព្រះ ? ( យើងគួរតែ « លើកទឹកចិត្ត [ របស់យើង ] ឡើងហើយអរសប្បាយ » ) ។ ហេតុអ្វីក៏យើងគួរតែមានអាកប្បកិរិយាបែបនេះ ?
- តើវគ្គចំណេះចំណានខគម្ពីរណាខ្លះដែលអ្នករៀនក្នុងសប្ដាហ៍នេះ ដែលទូន្មានយើងឲ្យលើកចិត្តរបស់យើងឡើង ហើយអរសប្បាយផងដែរនោះ ? (គ. និង ស. ២៥:១៣) ។ សូមគិតពីការអញ្ជើញសិស្សឲ្យអានវាម្ដងទៀត ឬ សូត្រវាតាមការចាំ ) ។
- តើការធ្វើតាមការបញ្ជានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៣ ឲ្យយើងនៅជាប់នឹងសេចក្ដីសញ្ញារបស់យើងជាមួយព្រះវរបិតាសួគ៌អាចការពារយើងពី សាតាំងយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សពិចារណាអំពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនថ្ងៃនេះ ហើយអញ្ជើញពួកគេឲ្យជ្រើសរើសអ្វីមួយជាក់លាក់ដែលពួកគេអាចធ្វើ ដើម្បីពាក់គ្រឿងសឹកនៃព្រះបានកាន់តែល្អប្រសើរ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរនូវអ្វីដែលពួកគេនឹងធ្វើនៅលើក្រដាសមួយសន្លឹក ដែលពួកគេអាចមើលជាញឹកញាប់ ទុកជាការរំឭកមួយអំពីការតាំងចិត្តរបស់ពួកគេ ។

ដើម្បីបញ្ចប់មេរៀននេះ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីសេចក្ដីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០; ៣០–៣៥)

តើកូនចៅរបស់ព្រះវរបិតាសួគ៌ប៉ុន្មាននាក់ដែលត្រូវបានបណ្ដេញចេញពីឋានសួគ៌នៅក្នុងជីវិតមុនជីវិតនេះ ? ហេតុអ្វីពួកគេត្រូវបានបណ្ដេញចេញ ? តើឃ្លាថា « បញ្ឆោត [ បានបញ្ឆោត ] សាសន៍ទាំងឡាយ » មានន័យដូចម្ដេច ? នៅក្នុងមេរៀនបន្ទាប់សិស្សនឹងរៀនអំពីចម្លើយចំពោះសំណួរទាំងនេះ ។ ពួកគេក៏នឹងរៀនផងដែរអំពីសមាជិកកាលពីជំនាន់មុន ដែលត្រូវបានហៅឲ្យ « បញ្ឆោត [ បានបញ្ឆោត ] សាសន៍ទាំងឡាយដោយព្រះចេស្ដានៃព្រះវិញ្ញាណ[ នោះ ] » (គ. និង ស. ៣៥:១៣) ។

មេរៀនទី ៣៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣០–៥០

## បុព្វកថា

មិនយូរប៉ុន្មានពីមុនពេលសន្និសីទសាសនាចក្រ ដែលបានធ្វើឡើងនៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៨៣០ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយនៅក្នុងវត្តមានរបស់អែលឌើរប្រាំមួយរូប ។ តាមរយៈវិវរណៈ ពួកអែលឌើរទាំងនេះ បានរៀនអំពី ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា និងអំពីការប្រោសលោះពីការធ្លាក់ ដោយសារតែដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣០–៤៥

*ព្រះអង្គសង្គ្រោះ ប្រកាសថា ទ្រង់បានប្រោសលោះយើងពីការធ្លាក់ ហើយថាទ្រង់បានផ្ដល់សេចក្ដីសង្គ្រោះពីអំពើបាបរបស់យើង*

សូមចែកចាយស្ថានភាពដូចខាងក្រោមជាមួយសិស្សរបស់អ្នក រួចហើយសួរសំណួរដែលមានដូចខាងក្រោម ៖

សូមនឹកស្រមៃថា មិត្តម្នាក់របស់អ្នកមករកអ្នក ហើយមានអារម្មណ៍បាក់ទឹកចិត្តបន្តិចបន្តួច ។ នៅពេលអ្នកសួរថា ហេតុអ្វីក៏នាងបាក់ទឹកចិត្ត នាងប្រាប់អ្នកថា នាងពុំដឹងថាបើការធ្វើជាមនុស្សល្អនោះតើមានតម្លៃដើម្បីខំប្រឹងឬក៏អត់នោះទេ ។ នាងពន្យល់ថា ទោះជានាងបានព្យាយាមគោរពតាមព្រះបញ្ញត្តិនានាក្ដី ក៏នាងពុំឃើញថាជីវិតរបស់នាងបានល្អប្រសើរជាងជីវិតរបស់មិត្តភក្តិនាង ដែលជ្រើសរើសធ្វើអំពើបាបនោះដែរ ។ បន្ថែមពីលើនោះ នាងបានចង្អុលបង្ហាញថា គ្មានអ្វីដែលអាក្រក់បានកើតឡើងដល់មិត្តភក្តិរបស់នាង ដោយសារតែការជ្រើសរើសខុសរបស់ពួកគេផងហ្នឹង ។

- តើអ្នកអាចឆ្លើយតបចំពោះកង្វល់របស់មិត្តអ្នកយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលលទ្ធិ និងគោលការណ៍ទាំងឡាយ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ ដែលអាចជួយពួកគេឆ្លើយតបចំពោះកង្វល់របស់មិត្តពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៣២ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ។ ដើម្បីជួយសិស្សយល់អំពីការបង្រៀននៅក្នុងខគម្ពីរទាំងនេះ សូមពន្យល់ដូចខាងក្រោម មុនពេលសិស្សអានវាឮៗ ៖

នៅការបង្កបង្កើត អ័ដាម អេវ៉ា ផែនដី និងវត្ថុសព្វសារពើរនៅលើផែនដី គឺស្ថិតនៅក្នុងសភាពខាងវិញ្ញាណ ។ ទោះជាអ័ដាម និងអេវ៉ា មានរូបកាយក្តី ក៏ពួកគាត់ពុំស្ថិតនៅក្រោមសេចក្ដីស្លាប់ដែរ ហើយអាចរស់នៅក្នុងវត្តមានរបស់ព្រះជានិរន្តរ៍ ។ ទោះជាយ៉ាងណាក៏ដោយ ជាចំណែកនៃផែនការរបស់ព្រះវរបិតាសួគ៌ រាល់ការបង្កបង្កើតរបស់ទ្រង់ នឹងក្លាយទៅជាខាងសាច់ឈាម ។ ជាពាក្យម្យ៉ាងទៀតគឺថា ពួកគេនឹងក្លាយជាបណ្ដោះអាសន្ន ហើយស្ថិតនៅក្រោមសេចក្ដីស្លាប់ ។ បន្ទាប់ពីការរស់ឡើងវិញ នោះពួកគេនឹងត្រឡប់ទៅសភាពជាវិញ្ញាណ– មានរូបកាយ តែមានជីវិតអមតផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៤–៣៥ ។ សូមឲ្យសិស្សរកមើលវិធីដែលព្រះអម្ចាស់ទតមើលបទបញ្ញត្តិ ដែលទ្រង់ប្រទានដល់យើង ។

- តើព្រះអម្ចាស់បានពិពណ៌នាអំពីបទបញ្ញត្តិរបស់ទ្រង់យ៉ាងដូចម្ដេច ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងនូវគោលលទ្ធិដូចខាងក្រោម ៖ **រាល់បទបញ្ញត្តិរបស់ព្រះទាំងអស់ គឺខាងវិញ្ញាណ** ។ សូមសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។
- តើអ្នកនឹងពន្យល់អំពីការប្រកាសរបស់ព្រះអម្ចាស់ថា រាល់បទបញ្ញត្តិទាំងអស់របស់ទ្រង់ គឺខាងវិញ្ញាណដោយរបៀបណា ? តើគុំរូមួយចំនួននៃពរជ័យខាងវិញ្ញាណ ដែលកើតមាន នៅពេលយើងរក្សាបទបញ្ញត្តិមានអ្វីខ្លះ ?

*ការបង្ហាញរបស់គ្រូបង្រៀន*

ខណៈដែលវាសំខាន់សម្រាប់សិស្ស ដើម្បីទទួលនូវតួនាទីដ៏សកម្មនៅក្នុងដំណើរការនៃការរៀនសូត្រ ការណ៍នេះពុំជំនួសតម្រូវការសម្រាប់គ្រូបង្រៀន ដើម្បីធ្វើការបង្ហាញដ៏ច្បាស់លាស់ អំពីព័ត៌មានដែលអាចនឹងថ្មីចំពោះសិស្សនោះទេ ។ នៅក្នុងករណីដូច្នេះ សិស្សចូលរួមដោយការស្ដាប់ដោយយកចិត្តទុកដាក់ និងការសួរសំណួរ ។ អ្នកអាចចាំបាច់ត្រូវធ្វើបទបង្ហាញដូច្នេះ ពេលអ្នកសង្ខេបវគ្គបទគម្ពីរ បង្ហាញព័ត៌មានថ្មីអំពីគោលលទ្ធិ គោលការណ៍ ឬបរិបទជាប្រវត្តិសាស្ត្រ ធ្វើការផ្លាស់ប្ដូររវាងផ្នែកផ្សេងៗនៃមេរៀន និងធ្វើការសន្និដ្ឋាន ។

នៅពេលសិស្សឆ្លើយតបចំពោះសំណួរទាំងនេះ អ្នកអាចនឹងចង់ចង្អុលបង្ហាញថា បទបញ្ញត្តិជាច្រើន ដូចជាពាក្យសម្ដីនៃប្រាជ្ញាវាងវៃ និងច្បាប់ដង្វាយមួយភាគក្នុងដប់ ដឹកនាំទៅរកពរជ័យខាងសាច់ឈាម ។ ទោះជាយ៉ាងណាក៏ដោយ វាដឹកនាំទៅរកពរជ័យខាងវិញ្ញាណកាន់តែខ្លាំង ។ ខណៈដែលពរជ័យខាងសាច់ឈាមនឹងបញ្ចប់នៅទីបំផុតនោះ នោះពរជ័យខាងវិញ្ញាណនឹងនៅមានជារៀងរហូត ។

- តើគោលលទ្ធិដែលបានសរសេរនៅលើក្ដារខៀន អាចជួយមិត្តរបស់អ្នកនៅក្នុងស្ថានភាពដែលបានពិភាក្សានៅដើមមេរៀនយ៉ាងដូចម្ដេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៦–៣៩ ដោយការពន្យល់ថា ពួកអារក្ស បានបះបោរទាស់នឹងព្រះនៅក្នុងពិភពជាវិញ្ញាណមុនជីវិតនេះ ហើយនាំ « បំបែរមួយភាគបីនៃពួកពលបរិវារស្ថានសួគ៌ចេញ » ។ ដោយសារតែអារក្ស និងពួកអ្នកដើរតាមវា បានបះបោរទាស់ នោះពួកវាត្រូវបានបណ្ដេញចេញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៩ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ឲ្យរកមើលមូលហេតុ ដែលព្រះអម្ចាស់អនុញ្ញាតឲ្យពួកអារក្សល្បួងយើង ។

- ហេតុអ្វីក៏ព្រះអម្ចាស់អនុញ្ញាតឲ្យអារក្សល្បួងយើងដូច្នេះ ? ហេតុអ្វីក៏វាសំខាន់សម្រាប់យើង ដើម្បីមានការជ្រើសរើសរវាងសេចក្ដីល្អ និងសេចក្ដីអាក្រក់ ?

ដើម្បីរៀបចំសិស្សឲ្យពិភាក្សាអំពីសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤០–៤៥ សូមចង្អុលបង្ហាញថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៥ ព្រះអម្ចាស់បានប្រាប់អំពីបទបញ្ញត្តិមួយ ដែលទ្រង់បានប្រទានដល់អ័ដាមនៅក្នុងសួនច្បារអេដែន ( សូមមើលផងដែរ គ និង ស ២៩:៤០ ) ។ សូមអញ្ជើញសិស្សឲ្យអានបទបញ្ញត្តិនេះដោយស្ងាត់ស្ងៀមនៅក្នុង ម៉ូសេ ៣:១៦–១៧ ។

- តើបទបញ្ញត្តិអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់អ័ដាម ? ( ព្រះអម្ចាស់បានបញ្ជាអ័ដាម មិនឲ្យបរិភោគផ្លែឈើនៃដើមដឹងខុសត្រូវឡើយ ) ។ តើព្រះអម្ចាស់មានបន្ទូលថាអ្វីខ្លះនឹងកើតឡើង បើអ័ដាមរំលងក្រិត្យវិន័យនេះ ? ( អ័ដាម នឹងស្លាប់ ។ ចាប់តាំងពីថ្ងៃនៃការរំលងរបស់លោក អ័ដាម បានស្ថិតក្រោមការស្លាប់ខាងរូបកាយ និងការស្លាប់ខាងវិញ្ញាណ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤០–៤១ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអត្ថន័យនៃឃ្លា « សេចក្ដីស្លាប់ខាងវិញ្ញាណ » ។

- យោងតាមខគម្ពីរនេះ តើសេចក្ដីស្លាប់ខាងវិញ្ញាណជាអ្វី ? ( សិស្សគួរតែបង្ហាញនូវគោលលទ្ធិដូចខាងក្រោម ៖ **សេចក្ដីស្លាប់ខាងវិញ្ញាណគឺជាការត្រូវបានដកចេញពីវត្តមានរបស់ព្រះ** ) ។

ដើម្បីជួយសិស្សយល់អត្ថន័យនៃឃ្លា « សេចក្ដីស្លាប់ទីមួយ » នៅក្នុងខ ៤១ សូមពន្យល់ថា មានសេចក្ដីស្លាប់ខាងវិញ្ញាណពីរ ។ ទីមួយ គឺជាលទ្ធផលមកពីការធ្លាក់ និងជាការបណ្ដេញអាសន្ន ។ ទីពីរ គឺលទ្ធផលមួយនៃការមិនប្រែចិត្តពីអំពើបាប ហើយនឹងនៅជាប់ជាមួយ អ្នកទាំងឡាយដែលធ្លាក់ចុះ មិនប្រែចិត្ត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤២ ។ សូមសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្វែងរកប្រភេទនៃសេចក្ដីស្លាប់ផ្សេងទៀត ដែលកើតមាន ដោយសារតែការរំលងរបស់អ័ដាម ។

- តើប្រភេទនៃសេចក្ដីស្លាប់ផ្សេងទៀត កើតមានមកដោយសារតែការរំលងរបស់អ័ដាមមានអ្វីខ្លះ ? ( សេចក្ដីស្លាប់ខាងសាច់ឈាម ឬជាពាក្យម្យ៉ាងទៀតថាជា សេចក្ដីស្លាប់ខាងរូបកាយ ។ សេចក្ដីស្លាប់ គឺជាការបំបែកវិញ្ញាណ និងរូបកាយចេញពីគ្នា ។

ដើម្បីជួយសិស្សយល់អំពីលទ្ធផលនៃការធ្លាក់សម្រាប់មនុស្សលោកទាំងអស់ សូមអញ្ជើញពួកគេឲ្យអាន ហេលេមិន ១៤:១៦ ដោយស្ងាត់ស្ងៀម ។ សូមពួកគេឲ្យប្រាប់ថានរណាដែលទទួលបទពិសោធន៍ពីលទ្ធផលនៃការរំលងរបស់អ័ដាម ។

- តើនរណាទទួលបទពិសោធន៍មកពីការធ្លាក់របស់លោកអ័ដាម ? ( មនុស្សលោកទាំងអស់ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេលេមិន ១៤:១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលខនេះ បាននិយាយអំពីរបៀបដែលលទ្ធផលនៃការធ្លាក់របស់អ័ដាមនឹងត្រូវបានយកឈ្នះ ។

- តើលទ្ធផលនៃការធ្លាក់របស់អ័ដាមនឹងត្រូវបានយកឈ្នះយ៉ាងដូចម្ដេច ? តើនរណានឹងទទួលបានពរជ័យទាំងនេះ ?

សូមសរសេរសេចក្ដីយោងបទគម្ពីរដូចខាងក្រោមនៅលើក្ដារខៀន ៖ *អាលម៉ា ៣៣:២២, ៤២:២៣* ។ សូមពន្យល់ថា មនុស្សទាំងអស់នឹងត្រឡប់ទៅកាន់វត្តមានរបស់ព្រះសម្រាប់ការជំនុំជម្រះ ប៉ុន្តែពុំមែនមនុស្សទាំងអស់នឹងសក្ដិសមដើម្បីរស់នៅក្នុងវត្តមានរបស់ទ្រង់ជារៀងរហូតនោះទេ ។ រួចហើយអញ្ជើញសិស្សឲ្យអានដោយស្ងាត់ស្ងៀមនូវវគ្គបទគម្ពីរដែលអ្នកបានសរសេរ

នៅលើក្ដារខៀន រកមើលភស្ដុតាងនៃសេចក្ដីពិតនេះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៣–៤៤ ឲ្យឮៗ ។ សូមចង្អុលបង្ហាញអំពីការប្រកាសថា អ្នកទាំងឡាយដែល « ពុំជឿ » ទៅលើព្រះគ្រីស្ទ « ពុំអាចត្រូវបានប្រោសលោះពីការធ្លាក់ខាងវិញ្ញាណរបស់ពួកគេឡើយ » ។ ចូរពន្យល់ថា ថ្វីដ្បិតតែមនុស្សទាំងអស់នឹងត្រូវបានប្រោសលោះពីការធ្លាក់នៃលោកអ័ដាម និងអេវ៉ាក្ដី ក៏អ្នកទាំងឡាយដែលបដិសេធពុំអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តទេ នោះនឹងពុំត្រូវបានសង្គ្រោះពីការធ្លាក់ខាងវិញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤២–៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលវិធីដែលយើងអាចត្រូវបានសង្គ្រោះពីលទ្ធផលនៃអំពើបាបផ្ទាល់ខ្លួនរបស់យើង ។

- ស្របតាមខគម្ពីរទាំងនេះ តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីត្រូវបានសង្គ្រោះពីលទ្ធផលនៃអំពើបាបរបស់យើងផ្ទាល់បាន ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែបង្ហាញនូវគោលលទ្ធិដូចខាងក្រោម ៖ **តាមរយៈដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ផ្ដល់ការអភ័យទោស និងជីវិតអស់កល្បជានិច្ចចំពោះមនុស្សទាំងអស់ ដែលអនុវត្តសេចក្ដីជំនឿទៅលើទ្រង់ ហើយប្រែចិត្តពីអំពើបាបរបស់ពួកគេ ។** សូមសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។

សូមថ្លែងទីបន្ទាល់ថា ការធ្លាក់នៃលោកអ័ដាម និងអេវ៉ា គឺមានចំណែកនៃផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់សុភមង្គលរបស់យើង ។ ថ្វីដ្បិតតែយើងបានរស់នៅក្នុងវត្តមានរបស់ព្រះពីមុនយើងកើតមកក្ដី ក៏យើងម្នាក់ៗចាំបាច់ត្រូវមកកាន់ផែនដីទទួលរូបកាយខាងសាច់ឈាម ហើយរៀនតាមរយៈបទពិសោធន៍ដើម្បីប្រើសិទ្ធិជ្រើសរើសធ្វើតាមព្រះយេស៊ូវគ្រីស្ទផងដែរ ។ ស្ថានភាពខាងវិញ្ញាណរបស់យើង នៅពេលយើងទទួលជីវិតដ៏អស់កល្បជានិច្ច នឹងមានសភាពអស្ចារ្យជាងស្ថានភាពខាងវិញ្ញាណដែលយើងបានទទួលពិសោធន៍នៅក្នុងពិភពជាវិញ្ញាណក្នុងជីវិតមុនឆាកជីវិតនេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពន្យល់ដូចខាងក្រោម មកពីកូនសៀវភៅ *ពិតចំពោះសេចក្ដីជំនឿ* ៖

> « អមតភាព គឺជាជីវិតដែលអាចរស់នៅជានិរន្តរ៍ក្នុងស្ថានភាពដែលបានរស់ឡើងវិញ ។ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ មនុស្សគ្រប់រូបនឹងទទួលបានអំណោយនេះ ។ ជីវិតដ៏អស់កល្បជានិច្ច ឬភាពលើកតម្កើង គឺដើម្បីទទួលកន្លែងមួយនៅក្នុងកម្រិតដ៏ខ្ពស់បំផុតនៃនគរសេឡេស្ទាល ដែលយើងនឹងរស់នៅក្នុងវត្តមានរបស់ព្រះ ហើយបន្តជាក្រុមគ្រួសារ ( សូមមើល គ និង ស ១៣១:១–៤ ) ។ ដូចជាជីវិតអមតភាពផងដែរ អំណោយទាននេះ នឹងត្រូវបានធ្វើឲ្យកើតមានឡើងតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ទោះជាយ៉ាងណាក៏ដោយ វាតម្រូវឲ្យមាន ‹ ការគោរពតាមក្រិត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ › ( មាត្រានៃសេចក្ដីជំនឿ ១:៣) » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ២០០៤ ], ៥២ ) ។

ដើម្បីជួយសិស្សយល់ពីសារៈសំខាន់នៃការធ្វើការជ្រើសរើសដែលនឹងជួយពួកគេទទួលពរជ័យនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការទូន្មានដូចខាងក្រោមមកពី ប្រធាន ថូម៉ាស អេស ម៉នសុន ៖



> « សូមកុំដាក់ជីវិតដ៏អស់កល្បជានិច្ចរបស់អ្នកក្នុងគ្រោះថ្នាក់ឡើយ ។ ប្រសិនបើអ្នកមានបាប កាលណាអ្នកត្រឡប់មកវិញរកផ្លូវវិញកាន់តែឆាប់ នោះអ្នកនឹងរកឃើញនូវភាពសុខសាន្តដ៏ផ្អែមល្ហែម និងក្ដីអំណរដែលកើតមានមកជាមួយនឹងអព្ភូតហេតុនៃការអភ័យទោស ។
>
> « . . .អ្នកមាននូវអំណាចមរតកកូនច្បងដ៏ថ្លៃថ្លាមួយ ។ ជីវិតដ៏នៅអស់កល្បជានិច្ចក្នុងនគររបស់ព្រះវរបិតាយើង គឺជាគោលដៅរបស់អ្នក ។ គោលដៅបែបនោះ ពុំអាចសម្រេចបាន តាមរយៈការខិតខំប្រឹងប្រែងលើភាពរុងរឿងម្យ៉ាងនោះទេ ប៉ុន្តែវាជាលទ្ធផលនៃសេចក្ដីសុចរិតពេញមួយជីវិត ដែលមានរួមចំណែកទាំងការជ្រើសរើសដ៏ឈ្លាសវៃ ព្រមទាំងមានគោលបំណងដ៏ខ្ជាប់ខ្ជួន និង ឧត្ដមគតិដ៏ខ្ពង់ខ្ពស់ផងដែរ ។ វាគឺដូចជាអ្វីគ្រប់យ៉ាងដែលមានតម្លៃបំផុតផងដែរ ផ្លូវទៅកាន់សម្រាប់ភាពអស់កល្បជានិច្ច គឺទាមទារឲ្យមានការប្រឹងប្រែង ។
>
> « . . . សូមយើងពោរពេញដោយអំណរគុណចំពោះការជ្រើសរើស *ត្រឹមត្រូវ* និងទទួលយក *ការទទួលខុសត្រូវ* ទៅលើជម្រើស និងសូមគិតអំពី *លទ្ធផល* នៃការជ្រើសរើស » ( « ជម្រើសទាំងបីនៃអក្សរ ក » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ៦៩–៧០ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៦–៥០

*ព្រះអង្គសង្គ្រោះ ប្រកាសថា កុមារតូចៗ និងអ្នកទាំងឡាយដែលពុំមានការយល់ដឹង គឺត្រូវបានសង្គ្រោះតាមរយៈ ដង្វាយធួនរបស់ទ្រង់ ។*

សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៦–៥០ យើងមើលឃើញថា លទ្ធផលនៃការរំលងក្រិត្យវិន័យរបស់ព្រះ គឺខុសគ្នាពីកុមារតូចៗ និងអ្នកទាំងឡាយដែលពុំដឹងខុសត្រូវនៅចំពោះព្រះភក្ត្រព្រះ ។ យើងក៏មើលឃើញពីព្រះចេស្ដារដ៏មហិមា និងក្ដីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៦–៤៧ ឲ្យឮៗ ។

- តើការណ៍នេះមានន័យយ៉ាងណា ចំពោះកុមារតូចៗដែលស្លាប់ទៅ មុនពេលពួកគេមានអាយុប្រាំបីឆ្នាំនោះ ? ( ពួកគេត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល ។ សូមមើលផងដរ គ និង ស ១៣៧:១០ ។ អ្នកអាចនឹងចង់ចង្អុលបង្ហាញថា យោងតាមការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ លោកុប្បត្តិ ១៧:១១ [ នៅក្នុង Bible appendix ] និង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៥ កុមារតូចៗចាប់ផ្ដើមក្លាយជាមនុស្សដឹងខុសត្រូវនៅចំពោះព្រះអម្ចាស់ ពេលពួកគេមានអាយុប្រាំបីឆ្នាំ ។ សម្រាប់ការបង្រៀនបន្ថែមស្ដីអំពីប្រធានបទនេះ សូមមើល ម៉ូរ៉ូណៃ ៨ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១០ ) ។

- តើវគ្គបទគម្ពីរនេះ ពង្រីកការយល់ដឹងរបស់អ្នកអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

ដើម្បីបញ្ចប់មេរៀន សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៩ ដោយស្ងាត់ស្ងៀម ហើយពិចារណាអំពីការរំពឹងទុករបស់ព្រះអម្ចាស់ចំពោះពួកគេដោយផ្ទាល់ ។ សូមអញ្ជើញសិស្សពីរបីនាក់ ដើម្បីចែកចាយថាវាមានន័យយ៉ាងណាចំពោះពួកគេដើម្បីអាចត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌ ហើយបន្តនៅទីនោះដ៏អស់កល្បជានិច្ច ។ បន្ទាប់ពីសិស្សពីរបីនាក់បានឆ្លើយតបហើយ សូមលើកទឹកចិត្តដល់សិស្សឲ្យធ្វើការជ្រើសរើស ដែលនឹងអាចជួយពួកគេឲ្យរស់នៅក្នុងវត្តមានរបស់ព្រះអម្ចាស់ដ៏អស់កល្បជានិច្ច ។

មេរៀនទី ៣៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០

## បុព្វកថា

នៅក្នុងខែកញ្ញា ឆ្នាំ ១៨៣០ មិនយូរប៉ុន្មានបន្ទាប់ពីសន្និសីទសាសនាចក្រមួយនៅ ហ្វាយ៉េត រដ្ឋនូវយ៉ោក នោះយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈសម្រាប់ ដាវីឌ វិតមើរ, ពេត្រុស វិតមើរ ជុញ៉័រ និង ចន វិតមើរ ។ វិវរណៈទាំងនេះ ត្រូវបានបោះពុម្ព ដាច់ដោយឡែកពីខាងដើម ប៉ុន្តែយ៉ូសែប ស្ម៊ីធ បានបញ្ចូលវាទៅជាកណ្ឌតែមួយ នៅក្នុងការបោះពុម្ពឆ្នាំ ១៨៣៥ នៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។

## យោបល់សម្រាប់ការបង្រៀន

*សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ*

គ្មានរឿងតូចតាចណា ដែលមានឥទ្ធិពលយូរអង្វែងឲ្យធ្វើការល្អ ជាងការជួយសិស្សឲ្យអភិវឌ្ឍនូវទម្លាប់នៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃនោះទេ ។ សូមលើកទឹកចិត្តសិស្ស ឲ្យញែកពេលវេលារាល់ថ្ងៃ សម្រាប់ការសិក្សាព្រះគម្ពីរ ។ សូមផ្ដល់ដល់សិស្សនូវឱកាសជាទៀងទាត់នៅក្នុងថ្នាក់ ដើម្បីចែកចាយនូវអ្វីដែលពួកគេកំពុងរៀន និង មានអារម្មណ៍ ពេលពួកគេសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនផងដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១–៤

*ព្រះអម្ចាស់ បានវាយផ្ចាល ដេវីឌ វិតមើរ ចំពោះការមិនស្ដាប់តាមព្រះវិញ្ញាណ និងអ្នកបម្រើដែលបានតែងតាំងរបស់ព្រះអម្ចាស់*

សូមឲ្យសិស្សពិចារណាដោយស្ងៀមស្ងាត់ចំពោះសំណួរខាងក្រោម ៖

១. យុវជនម្នាក់បានស្ដាប់តន្ត្រី ដែលពុំត្រូវតាមបទដ្ឋានដូចមានចែងនៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។ ទោះជាគាត់ចូលចិត្តស្ដាប់តន្ត្រីនេះក្ដី ក៏គាត់បានចាប់ផ្ដើមដឹងថា សាររបស់ចម្រៀងនោះ បានបណ្ដាលឲ្យគាត់បាត់បង់ព្រះវិញ្ញាណ ហើយឃ្លាតឆ្ងាយពីគ្រួសារ មិត្តភក្តិ និងសាសនាចក្ររបស់ខ្លួន ។

២. បន្ទាប់ពីមានការដើរលេងជាគូជាមួយនឹងយុវជនម្នាក់ជាច្រើនដងមក មានយុវនារីម្នាក់នោះបានចាប់ផ្ដើមទទួលស្គាល់ដោយការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ថាយុវជននោះបានប៉ុនប៉ងដើម្បីបញ្ចុះបញ្ចូលនាងឲ្យរំលងច្បាប់ព្រហ្មចារីយភាពបន្តិចម្ដងៗ ។

សូមចង្អុលបង្ហាញថា ព្រះវិញ្ញាណបរិសុទ្ធ នឹងព្រមានយើង ពេលយើងស្ថិតនៅក្នុងគ្រោះថ្នាក់ខាងវិញ្ញាណ ។ ទោះជាយ៉ាងណាក៏ដោយ បើយើងពុំស្ដាប់ការព្រមានរបស់ទ្រង់ទេ នោះព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងយាងដកថយពីយើង ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ មានគោលលទ្ធិ និងគោលការណ៍ដែលអាចជួយយើងរៀបចំខ្លួនដើម្បីទទួល និងធ្វើតាមការព្រមានមកពីព្រះវិញ្ញាណ ។

សូមពន្យល់ថា ផ្នែកដំបូងនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ គឺជាវិវរណៈមួយ ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលសម្រាប់ ដាវីឌ វិតមើរ ។

- តើអ្នកបានដឹងអ្វីខ្លះអំពី ដេវីឌ វិតមើរ ? ( ចម្លើយអាចរួមមានថា គាត់ និងឪពុកម្ដាយគាត់ បានផ្ដល់កន្លែងមួយសម្រាប់ យ៉ូសែប ស្ម៊ីធ ដើម្បីបកប្រែព្រះគម្ពីរមរមន ថាគាត់គឺជាសាក្សីម្នាក់ នៃសាក្សីបីនាក់អំពីព្រះគម្ពីរមរមន ហើយថា គាត់គឺជាសមាជិកម្នាក់នៃសមាជិកប្រាំមួយនាក់ដំបូងរបស់សាសនាចក្រ ) ។

សូមពន្យល់ថា ទោះបីជា ដេវីឌ វិតមើរ ស្មោះត្រង់ក្នុងរបៀបជាច្រើនក្ដី ក៏ព្រះអម្ចាស់បានវាយផ្ចាលគាត់ អំពីការធ្វេសប្រហែសចំពោះការទទួលខុសត្រូវរបស់គាត់ នៅក្នុងសាសនាចក្រដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១–២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីការវាយផ្ចាល ។

- ហេតុអ្វីបានជាព្រះអម្ចាស់វាយផ្ចាល ដេវីឌ វិតមើរ ដូច្នេះ ? ( អ្នកអាចនឹងចង់កត់ត្រាចម្លើយរបស់សិស្សនៅលើក្ដារខៀន ។ ចម្លើយអាចរួមមានថា ដេវីឌ ខ្លាចមនុស្ស ហើយពុំពឹងផ្អែកទៅលើព្រះអម្ចាស់សុំកម្លាំង បានដាក់ក្នុងគំនិតរបស់គាត់នូវរឿងខាងលោកិយច្រើនជាងរឿងរបស់ព្រះអម្ចាស់ ពុំបានធ្វើតាមការដឹកនាំរបស់ព្រះវិញ្ញាណ និងអ្នកដឹកនាំសាសនាចក្រ ហើយត្រូវបានបញ្ចុះបញ្ចូលដោយមនុស្សដែលព្រះអម្ចាស់ពុំបានហៅបម្រើ ) ។

សូមអញ្ជើញសិស្សឲ្យផ្ដល់យោបល់នូវគោលការណ៍ ដែលយើងអាចរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១–២ ។ ពួកគេអាចផ្ដល់យោបល់មួយចំនួន ឬគោលការណ៍ទាំងអស់ដូចខាងក្រោម ៖

**ជាជាងយើងភ័យខ្លាចមនុស្ស យើងគួរតែពឹងផ្អែកលើព្រះអម្ចាស់សុំកម្លាំង ។**

**យើងគួរតែដាក់គំនិតរបស់យើងទៅលើរបស់ផងទាំងឡាយនៃព្រះ ច្រើនជាងទៅលើរបស់ផងទាំងឡាយខាងលោកិយ ។**

**យើងគួរតែធ្វើតាមព្រះវិញ្ញាណ និងពាក្យទូន្មានរបស់ថ្នាក់ដឹកនាំសាសនាចក្រ ជាជាងត្រូវបានបញ្ចុះបញ្ចូលដោយមនុស្សដែលព្រះអម្ចាស់ពុំបានហៅឲ្យបម្រើ ) ។**

ដើម្បីជួយសិស្សយល់ និងដឹងពីសារៈសំខាន់នៃគោលការណ៍ទាំងនេះ សូមសួរសំណួរមួយចំនួន ឬទាំងអស់ដូចខាងក្រោម ៖

- តើអ្នកគិតថា ការខ្លាចមនុស្ស វាមានន័យដូចម្ដេច ? ( ចម្លើយអាចរួមមានដូចជា វាន័យថា ជាការអនុញ្ញាតឲ្យការបង្រៀនរបស់មនុស្សដទៃដឹកនាំយើងចេញពីការបង្រៀនរបស់ព្រះ ) ។
- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីពឹងផ្អែកទៅលើព្រះអម្ចាស់ ដើម្បីសុំកម្លាំងនោះ ? តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានពង្រឹងដល់អ្នក ?
- តើអ្នកគិតថា វាន័យយ៉ាងណា ដែលដាក់ឲ្យគំនិតរបស់យើងផ្ដោតទៅលើរឿងលោកិយ ច្រើនជាងផ្ដោតទៅលើរឿងរបស់ព្រះអម្ចាស់ ? តើគ្រោះថ្នាក់មួយចំនួន ដែលកើតមកពីកំហុសនៃរឿងទាំងនេះ មានអ្វីខ្លះ ?
- តើអ្នកត្រូវបានប្រទានពរយ៉ាងដូចម្ដេច នៅពេលអ្នកធ្វើតាមព្រះវិញ្ញាណ និងពាក្យទូន្មានរបស់អ្នកដឹកនាំសាសនាចក្រ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៣–៤ ឮៗ ។ សូមលើកទឹកចិត្តសិស្សក្នុងថ្នាក់ស្វែងរកដំបូន្មានដែលព្រះអម្ចាស់បានប្រទានដល់ ដេវីឌ វិតមើរ ។

- បន្ទាប់ពីការវាយផ្ចាលដល់ ដេវីឌ តើព្រះអម្ចាស់បញ្ជាឲ្យ ដេវីឌ ធ្វើអ្វីខ្លះ ? ( ឲ្យពិចារណាទៅលើរឿងដែលគាត់បានទទួល ហើយចូលរួមនៅក្នុងកាតព្វកិច្ចក្នុងសាសនាចក្ររបស់គាត់ ) ។
- តើការពិចារណាអំពីរឿងដែលយើងបានទទួលមកពីព្រះ ជួយយើងឲ្យបន្តស្មោះត្រង់យ៉ាងដូចម្ដេចខ្លះ ?
- តើយើងមានឥទ្ធិពលយ៉ាងណាសម្រាប់សេចក្ដីល្អ នៅពេលយើងលះបង់ខ្លួនយើងទៅក្នុងការបម្រើ ដែលយើងបានទទួលនោះ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១–៤ ដោយស្ងាត់ស្ងៀម រកមើលការប្រឹក្សាដែលអនុវត្តបានយ៉ាងល្អជាក់លាក់នៅក្នុងជីវិតរបស់យើង ។ សូមឲ្យពួកគេពិចារណានូវអ្វីដែលពួកគេអាចធ្វើដើម្បីធ្វើតាមការទូន្មាននោះផងដែរ ។ សូមអញ្ជើញពួកគេឲ្យកត់ត្រាគំនិតរបស់ពួកគេចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៥–៨

*ពេត្រុស វិតមើរ ជុញ្ញ័រ ត្រូវបានហៅឲ្យទៅជាមួយ អូលីវើរ ខៅឌើរី ក្នុងបេសកកម្មមួយ ទៅកាន់ប្រជាជនលេមិន ។*

សូមយកវត្ថុធ្ងន់មួយ ឬកាបូបមួយដែលដាក់វត្ថុធ្ងន់ៗយ៉ាងណែន ដូចជាសៀវភៅ ឬថ្ម មកថ្នាក់រៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យកាន់វត្ថុនោះ នៅពីមុខគាត់ ។ ខណៈដែលសិស្សកំពុងកាន់វត្ថុនោះ សូមពន្យល់ថា ជាការបន្ថែមទៅលើវិវរណៈដល់ ដេវីឌ វិតមើរ ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ នោះមានវិវរណៈពីរបន្ថែមទៀត ដែលថ្លែងទៅកាន់ប្អូនប្រុសរបស់ ដេវីឌ គឺ ពេត្រុស និង យ៉ូហាន ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា៣០:៥ ដោយខ្លួនឯង ហើយស្វែងរកអ្វីដែលព្រះអម្ចាស់ បានហៅ ពេត្រុស វិតមើរ ជុញ្ញ័រ ឲ្យធ្វើ ។

- តើព្រះអម្ចាស់ ហៅ ពេត្រុស វិតមើរ ជុញ្ញ័រ ឲ្យធ្វើអ្វីខ្លះ ? ( ប្រកាសដំណឹងល្អ ) ។ តើនរណាជាអ្នកដឹកនាំរបស់ពេត្រុស នៅក្នុងកិច្ចខិតខំនេះ ? ( អូលីវើរ ខៅឌើរី ) ។

សូមអញ្ជើញសិស្សទីពីរ ឲ្យជួយសិស្សដែលកំពុងកាន់វត្ថុធ្ងន់នោះ ។ សូមឲ្យសិស្សទីមួយ ពិពណ៌នាអំពីភាពខុសគ្នាដែលគាត់បានដឹងក្នុងការមានការគាំទ្រពីមនុស្សម្នាក់ទៀត ។ សូមពន្យល់ថា ព្រះអម្ចាស់ ប្រទានដំបូន្មានដល់ ពេត្រុស ដែលពិពណ៌នាអំពីរបៀបដែលគាត់ត្រូវគាំទ្រដល់ អូលីវើរ ខៅឌើរី ។ សូមអញ្ជើញសិស្សឲ្យស្វែងរក គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៥–៨ ស្វែងរកឃ្លាដែលពិពណ៌នាអំពីរបៀបដែលពេត្រុស ត្រូវគាំទ្រដល់ អូលីវើរ ។ អ្នកអាចនឹងចង់ស្នើឲ្យ សិស្សគួរតែគូសចំណាំឃ្លាទាំងនេះ ។

- តើអ្នករកឃើញឃ្លាអ្វីខ្លះ ? ( អ្នកអាចនឹងចង់អញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- តើអ្នកគិតថាវាន័យយ៉ាងណា សម្រាប់ពេត្រុសឲ្យ « រងទុក្ខនៅក្នុងគ្រប់ទាំងសេចក្ដីវេទនារបស់ [ អូលីវើរ ] » នោះ ? ( ពេត្រុស ត្រូវឈរនៅជិតនឹង អូលីវើរ ទោះជាក្នុងគ្រាលំបាកក្ដី ) ។
- ស្របតាម ខ ៦ តើការអធិស្ឋានដើរតួយ៉ាងណា នៅក្នុងការគាំទ្រដល់អ្នកដឹកនាំសាសនាចក្ររបស់យើង ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៩–១១

*យ៉ូហាន វិតមើរ ត្រូវបានហៅឲ្យផ្សាយដំណឹងល្អ*

សូមពន្យល់ថាគោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៩–១១ មាននូវវិវរណៈមួយសម្រាប់ យ៉ូហាន វិតមើរ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៩–១០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានហៅ យ៉ូហាន វិតមើរឲ្យធ្វើ ។ ( វាអាចនឹងជាប្រយោជន៍ដើម្បីពន្យល់ថា ភរិយារបស់ ភីលីព បើរោ គឺជាសមាជិកម្នាក់ក្នុងសាសនាចក្រ ។ គ្រួសារ បើរោ រស់នៅប្រហែលជាប្រាំពីរម៉ែល ខាងជើងគ្រួសារ វិតមើរ ក្នុង សេនីកា ហ្វល រដ្ឋ នូវ យ៉ោក ។ ទោះជា ភីលីព បើរោ ត្រូវបានហៅថាជា « បងប្អូន » នៅក្នុង ខ ១០ ក្ដី ក៏គ្មានកំណត់ត្រាថា គាត់បានចូលរួមក្នុងសាសនាចក្រដែរ ) ។

បន្ទាប់ពីសិស្សរាយការណ៍នូវអ្វីដែលពួកគេបានរកឃើញ សូមឲ្យពួកគេស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១១ រកមើលគោលការណ៍មួយអំពីរបៀបដែលយើងគួរតែបម្រើព្រះអម្ចាស់ ។ សូមលើកទឹកចិត្តពួកគេឲ្យបង្ហាញនូវអ្វីដែលពួកគេរៀននៅក្នុងប្រយោគ « បើសិនជា– នោះ ) ។

- តើគោលការណ៍អ្វី ដែលអ្នកឃើញនៅក្នុង ខ ១១ ? ( សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងបម្រើព្រះអម្ចាស់ដោយអស់ពីព្រលឹងរបស់យើង នោះទ្រង់នឹងគង់នៅជាមួយនឹងយើង** ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយនូវបទពិសោធន៍មួយ ដែលពួកគេមាន ដោយសារពួកគេបានដឹងថា ព្រះអម្ចាស់គង់នៅជាមួយពួកគេ ពេលពួកគេបានបម្រើទ្រង់ ) ។ ( អ្នកក៏អាចចង់ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនអំពីគោលការណ៍នេះផងដែរ ) ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលឱកាសដើម្បីខិតទៅកាន់តែជិតនឹងព្រះអម្ចាស់ តាមរយៈការបម្រើទ្រង់ ។

មេរៀនទី ៣៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១–៣២

## បុព្វកថា

នៅខែ កញ្ញា ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានហៅ ថូម៉ាស ប៊ី ម៉ាស ឲ្យផ្សាយដំណឹងល្អ ហើយជួយស្ថាបនាសាសនាចក្រ ។ ការហៅនេះ មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១ ក៏មានរួមទាំងការសន្យា និងការទូន្មាន ដើម្បីដឹកនាំ ថូម៉ាស នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គាត់ និងជាអ្នកផ្សព្វផ្សាយសាសនាមួយរូប ។ នៅក្នុង ខែ តុលា ឆ្នាំ ១៨៣០ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈ ដែលឥឡូវមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២ ដែលព្រះអម្ចាស់បានហៅ ប៉ាលី ភី ប្រាត្ត និង សែបា ភីតើសុន ឲ្យចូលរួមនឹង អូលីវើរ ខៅឌើរី និង ពេត្រុស វិតមើរ ជុញ្ញ័រ ចំពោះបេសកកម្មមួយទៅពួកសាសន៍លេមិន នៅប៉ែកខាងលិចរដ្ឋមីសសួរី ។ ព្រះអម្ចាស់បានសន្យាថាគង់នៅជាមួយនឹងបុរសទាំងនេះក្នុងកិច្ចការផ្សព្វផ្សាយសាសនារបស់ពួកគាត់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១–៨

*ព្រះអម្ចាស់បានហៅ ថូម៉ាស ប៊ី ម៉ាស ឲ្យផ្សាយដំណឹងល្អ ហើយជួយស្ថាបនាសាសនាចក្រ*

សូមអញ្ជើញសិស្សឲ្យគិតអំពីសមាជិកគ្រួសាររបស់ពួកគេ និងអារម្មណ៍ដែលពួកគេមានអំពីពួកគាត់ ។ អ្នកអាចនឹងដាក់តាំងរូបថតគ្រួសាររបស់អ្នក ហើយរៀបរាប់ដោយសង្ខេបអំពីក្ដីស្រឡាញ់របស់អ្នកចំពោះពួកគាត់ ។ សូមឲ្យសិស្សពិចារណាថា តើមាននរណាម្នាក់ក្នុងគ្រួសារពួកគេ ដែលពុំមែនជាសមាជិកនៃសាសនាចក្រ ឬបច្ចុប្បន្ននេះពុំបានរស់នៅតាមសេចក្ដីសញ្ញារបស់ពួកគេ ជាមួយនឹងព្រះអម្ចាស់ដែរឬទេ ។ អ្នកក៏អាចនឹងអញ្ជើញសិស្សឲ្យពិចារណាអំពីក្ដីសង្ឃឹមរបស់ពួកគេចំពោះសមាជិកគ្រួសារ ។

សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១ ព្រះអម្ចាស់ បានថ្លែងប្រាប់អំពី អ្នកផ្លាស់ប្រែចិត្តជឿថ្មីម្នាក់ ឈ្មោះ ថូម៉ាស ប៊ី ម៉ាស ហើយបាននិយាយទៅកាន់គាត់អំពីគ្រួសាររបស់គាត់ ។

ដើម្បីជួយឲ្យសិស្សក្នុងថ្នាក់យល់អំពីប្រវត្តិនៃកណ្ឌនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវការពិពណ៌នាដូចខាងក្រោមអំពីរបៀបដែលថូម៉ាស ប៊ី ម៉ាស បានក្លាយជាសមាជិកនៃសាសនាចក្រ ។

ខណៈដែលកំពុងរស់នៅក្នុងទីក្រុង បូស្តុន រដ្ឋម៉ាស្សាឈូសេត ក្នុងឆ្នាំ ១៨២៩ ថូម៉ាស ប៊ី ម៉ាស បានសន្និដ្ឋានថា គ្មានព្រះវិហារណា ដែលគាត់ធ្លាប់ស្គាល់ មានភាពត្រូវគ្នានឹងការបង្រៀននៃព្រះគម្ពីរប៊ីបទេ ។ គាត់បានសរសេរថា « ខ្ញុំបានជឿថា ព្រះវិញ្ញាណរបស់ព្រះបានដឹកនាំខ្ញុំឲ្យធ្វើដំណើរទៅភាគខាងលិច » ។ គាត់បានចាកចេញពីភរិយារបស់គាត់ អេលីស្សាប៊ែត និងកូនៗរបស់គាត់ដើម្បីស្វែងរកសេចក្ដីពិត ។ បន្ទាប់ពីការធ្វើដំណើរអស់រយៈពេលបីខែ នោះថូម៉ាស បានធ្វើដំណើរត្រឡប់មកផ្ទះវិញ នៅពេលគាត់ « បានស្ដាប់ឮអំពីសៀវភៅមាស [ មួយ ] ដែលរកឃើញដោយយុវជនម្នាក់ ឈ្មោះ យ៉ូសែប ស៊្មីធ » ។ គាត់បានធ្វើដំណើរទៅកាន់ភូមិ បាល់ម៉ៃរ៉ា រដ្ឋនូវយ៉ោក ជាកន្លែងដែលគាត់បានជួបនឹង ម៉ាទីន ហារិស ។ អ្នកបោះពុម្ពបានឲ្យឯកសារដប់ប្រាំមួយសន្លឹកដំបូង នៃព្រះគម្ពីរមរមន ដែលហៀបនឹងបោះពុម្ពដល់ថូម៉ាស ។ ក្រោយមក ថូម៉ាស បានសរសេរថា « បន្ទាប់ពីមកដល់ផ្ទះវិញ . . . ខ្ញុំបានបង្ហាញដល់ភរិយាខ្ញុំនូវឯកសារដប់ប្រាំមួយទំព័រនៃព្រះគម្ពីរមរមន . . . ដែលនាងសប្បាយចិត្តយ៉ាងខ្លាំង ហើយជឿថាវាគឺជាកិច្ចការរបស់ព្រះ » ។ ប្រហែលមួយឆ្នាំក្រោយមក បន្ទាប់ពីដឹងអំពីការរៀបចំសាសនាចក្រ នោះថូម៉ាស និងគ្រួសាររបស់គាត់ បានផ្លាស់ទៅកាន់ ប៉ាល់ម៉ៃរ៉ា ។ ខណៈដែលកំពុងរស់នៅក្នុងតំបន់ដែលគាត់ត្រូវបានជ្រមុជទឹក ជិតភូមិហ្វាយ៉ែត ហើយបានតែងតាំងជាអែលឌើរ ដោយ អូលីវើរ ខៅឌើរី ក្នុងខែកញ្ញា ឆ្នាំ ១៨៣០ ( សូមមើល ថូម៉ាស ប៊ី ម៉ាស « History of Thomas Baldwin Marsh » *Millennial Star* ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៨៦៤, ទំព័រ ៣៧៥ ) ។

- តើអ្នកមានចំណាប់អារម្មណ៍យ៉ាងណា អំពីការស្វែងរកសេចក្ដីពិតរបស់ ថូម៉ាស ប៊ី ម៉ាស ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១–២ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលឃ្លាទាំងឡាយដែលព្រះអម្ចាស់បានប្រើដើម្បីលើកទឹកចិត្តដល់ ថូម៉ាស បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់គាត់ ។

- តើការលើកទឹកចិត្ត ដែលព្រះអម្ចាស់បានផ្ដល់ដល់ ថូម៉ាស នៅក្នុង ខទាំងនេះ មានអ្វីខ្លះ ?

### សូមសម្រេចចិត្តសម្រាប់អ្វីដែលត្រូវបង្រៀន

មេរៀននេះ មាននូវឯកសារច្រើនជាងពេលវេលាដែលអ្នកមានដើម្បីបង្រៀន ។ សូមពិចារណាប្រកបដោយការអធិស្ឋានថា គោលលទ្ធិ គោលការណ៍ ឬគំនិតបង្រៀនណាមួយ ដែលជាប្រយោជន៍ល្អបំផុតសម្រាប់សិស្សនៅក្នុងថ្នាក់របស់អ្នក ។ សូមសម្របមេរៀនទៅតាមអារម្មណ៍ដែលអ្នកបានទទួលការបំផុសគំនិត ។

- តើព្រះអម្ចាស់ប្រទានការសន្យាអ្វីខ្លះ ដល់ ថូម៉ាស ទាក់ទងនឹងគ្រួសារគាត់ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១–២ ដែលអាចជួយយើង បើយើងមានសមាជិកគ្រួសារ ដែលពុំមែនជាសមាជិកនៃសាសនាចក្រ ឬ ដែលពុំបានរស់នៅដោយស្មោះត្រង់ស្របទៅតាមសេចក្ដីសញ្ញារបស់ពួកគេនោះ ? ( ទោះជា សិស្សអាចនឹងប្រើពាក្យផ្សេងៗក្ដី ក៏ពួកគេគប្បីប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **តាមរយៈសេចក្ដីស្មោះត្រង់របស់យើង សមាជិកគ្រួសាររបស់យើង អាចនឹងត្រូវបានប្រទានពរឲ្យជឿ និងស្គាល់សេចក្ដីពិត ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- តើបុគ្គលម្នាក់ៗអាចត្រូវបានប្រទានពរតាមរយៈសេចក្ដីស្មោះត្រង់នៃសមាជិកគ្រួសារគេ តាមវិធីណាខ្លះ ? តើអ្នកបានឃើញគំរូណាខ្លះ ?

សូមឲ្យសិស្សមើលត្រួសៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៣–៤ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានត្រាស់ហៅឲ្យ ថូម៉ាស ប៊ី ម៉ាស ធ្វើ ។ សុំឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ស្ដីអំពីពរជ័យទាំងឡាយ ដែលកើតមានដល់អ្នកទាំងឡាយណា ដែលបម្រើជាអ្នកផ្សព្វផ្សាយសាសនាដោយស្មោះត្រង់ ។ ( អ្នកអាចនឹងចង់ផ្ដល់ច្បាប់ចម្លងនៃសេចក្ដីថ្លែងការនេះដល់សិស្សម្នាក់មួយច្បាប់ដើម្បីរក្សាទុកក្នុងព្រះគម្ពីររបស់ពួកគេ ) ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្ដាប់មើលថា តើនរណាត្រូវបានប្រទានពរតាមរយៈការបម្រើផ្សព្វផ្សាយសាសនា ។



« អ្នកនឹងប្រទានពរដល់ជីវិតនៃអ្នកទាំងឡាយដែលអ្នកបង្រៀន និងកូនចៅតំណរក្រោយរបស់ពួកគេ ។ អ្នកនឹងប្រទានពរដល់ជីវិតរបស់អ្នកផ្ទាល់ ។ អ្នកនឹងប្រទានពរដល់ជីវិតនៃគ្រួសារអ្នកដែលនឹងគាំទ្រអ្នក ហើយអធិស្ឋានសម្រាប់អ្នក » ( Of Missions, Temples, and Stewardship, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, ៥២ ។

- តើនរណាត្រូវបានប្រទានពរតាមរយៈការបម្រើផ្សព្វផ្សាយសាសនា ?

សូមបែងចែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដី ៣១:៥–៨ ឲ្យឮៗ ។ សូមឲ្យក្រុមមួយរកមើលពរជ័យ ដែលនឹងកើតមានដល់អ្នកទាំងឡាយណា ដែល ថូម៉ាស ប៊ី ម៉ាស នឹងបង្រៀន ។ សូមឲ្យក្រុមទីពីររកមើលពរជ័យដែលនឹងកើតមានដល់ ថូម៉ាស ពេលគាត់បានបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ សូមឲ្យក្រុមទីបី រកមើលពរជ័យដែលនឹងកើតមានដល់គ្រួសាររបស់ថូម៉ាស ពេលគាត់ឃ្លាតទៅឆ្ងាយពីពួកគេ ។ បន្ទាប់ពីសិស្សបានអានរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើពរជ័យអ្វីខ្លះដែលនឹងកើតមានដល់អ្នកទាំងឡាយដែល ថូម៉ាស បានបង្រៀន ?
- តើថូម៉ាស នឹងត្រូវបានប្រទានពរចំពោះការបម្រើផ្សព្វផ្សាយសាសនារបស់គាត់យ៉ាងដូចម្ដេច ?
- តើគ្រួសារគាត់នឹងត្រូវបានប្រទានពរឲ្យយ៉ាងដូចម្ដេច ?
- តើការបម្រើផ្សព្វផ្សាយសាសនារបស់មនុស្សដទៃ បានប្រទានពរដល់ជីវិតរបស់អ្នក ឬជីវិតរបស់នរណាម្នាក់ដែលអ្នកស្គាល់យ៉ាងដូចម្ដេច ?

អ្នកអាចនឹងចង់ចែកចាយអំពីឧទាហរណ៍នៃរបៀបដែលអ្នកបានឃើញការបម្រើផ្សព្វផ្សាយសាសនា ប្រទានពរដល់ជីវិតរបស់មនុស្ស ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៩–១៣

*ព្រះយេស៊ូវគ្រីស្ទ បានប្រទានការទូន្មានដោយផ្ទាល់ទៅដល់ ថូម៉ាស ប៊ី ម៉ាស*

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៩–១៣ មាននូវការទូន្មានដែលព្រះអម្ចាស់ប្រទានឲ្យ ដើម្បីជួយដល់ថូម៉ាស ប៊ី ម៉ាស នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គាត់ និងក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ។ មុនថ្នាក់ចាប់ផ្ដើម សូមសរសេរការណែនាំដូចខាងក្រោម នៅលើក្ដារខៀន ឬរៀបចំវានៅលើក្រដាសមួយដើម្បីចែកចាយដល់សិស្ស ៖

*សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៩–១២ ហើយប្រាប់អំពីចំនុចមួយនៃការទូន្មាន ដែលអ្នកមានអារម្មណ៍ថានឹងសំខាន់សម្រាប់យើងដើម្បីធ្វើតាមនៅថ្ងៃនេះ ។ សូមរៀបចំខ្លួនដើម្បីឆ្លើយសំណួរដូចខាងក្រោម ៖*

1. *តើអ្នកបានជ្រើសរើសចំនុចមួយណានៃការទូន្មាននោះ ? ហេតុអ្វីក៏អ្នកគិតថា ការទូន្មាននេះសំខាន់សម្រាប់យើងនៅសព្វថ្ងៃនេះ ?*
2. *តើយើងអាចអនុវត្តការទូន្មាននេះនៅក្នុងជីវិតរបស់យើង តាមវិធីមួយយ៉ាងដូចម្ដេច ?*
3. *តើយើងអាចទទួលប្រយោជន៍មកពីការធ្វើតាមដំបូន្មាននេះយ៉ាងដូចម្ដេច ?*

សូមចាត់សិស្សឲ្យធ្វើការជាគូៗ ។ សូមឲ្យពួកគេម្នាក់ៗសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៩–១២ រួចហើយចែកចាយចម្លើយចំពោះសំណួរទាំងនោះ ម្នាក់មួយជាមួយនឹងដៃគូរបស់ពួកគេ ។

បន្ទាប់ពីសិស្សបានចែកចាយ សូមអញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១៣ ដោយស្ងាត់ស្ងៀម ហើយប្រាប់ពីពរជ័យដែលព្រះអម្ចាស់បានសន្យាចំពោះ ថូម៉ាស ប៊ី ម៉ាស បើគាត់នឹងនៅស្មោះត្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យមកកាន់ក្ដារខៀន ហើយសរសេរការសន្យានេះនៅក្នុងទម្រង់នៃគោលការណ៍មួយ ដោយប្រើពាក្យ *បើសិនជា នោះ* ។ សូមលើកទឹកចិត្តសិស្សផ្សេងទៀតក្នុងថ្នាក់ឲ្យជួយសិស្សនោះ បើចាំបាច់ ។ ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងក្ដី ក៏គោលការណ៍ដូចខាងក្រោមនេះ គួរតែប្រាប់ច្បាស់ថា ៖ **បើយើងស្មោះត្រង់ដល់ទីបំផុត នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង** ។ សូមចង្អុលបង្ហាញថា សេចក្ដីពិតនេះ អនុវត្តចំពោះយើង នៅពេលយើងព្យាយាមចែកចាយដំណឹងល្អជាមួយអ្នកដទៃ ក៏ដូចជានៅក្នុងស្ថានភាពដទៃផងដែរ ។

- តើនៅពេលណា ដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់ គង់នៅជាមួយអ្នក ពេលអ្នកព្យាយាមស្មោះត្រង់ចំពោះទ្រង់ ? ( សូមឲ្យពេលសិស្សដើម្បីពិចារណាសំណួរនេះ មុនពេលពួកគេឆ្លើយ ។ សូមគិតពីការចែកចាយនូវបទពិសោធន៍ផ្ទាល់ខ្លួនអ្នក ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២

*ព្រះអម្ចាស់ ហៅ ប៉ាលី ភី ប្រាត្ត និង សេបា ភីតើសុន ឲ្យចូលរួមក្នុងបេសកកម្មផ្សព្វផ្សាយទៅកាន់សាសនាលេមិន*

សូមឲ្យសិស្សមើលទៅផែនទីក្នុងគម្ពីររបស់ពួកគេ ដែលមានចំណងជើងថា « ដំណើរនៃសាសនាចក្រទៅទិសខាងលិច » ( សូមមើល ផែនទីប្រវត្តិសាស្ត្រសាសនាចក្រ ផែនទីទី ៦ ) ។ ឬអ្នកអាចនឹងដាក់តាំងផែនដីធំមួយ បង្ហាញអំពីចម្ងាយផ្លូវចន្លោះពីរដ្ឋនូវ យ៉ោក និងរដ្ឋមីសសួរី ស.រ.អា ។

- តើអូលីវើរ ខៅឌើរី និង ពេត្រុស វិតមើរ ជុញ្ញ័រ ត្រូវបានហៅឲ្យផ្សាយដំណឹងល្អនៅកន្លែងណា ? ( បើសិស្សពុំចាំទេ សូមអញ្ជើញពួកគេឲ្យយោងទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨–៩, ៣០:៥ ។ អ្នកផ្សព្វផ្សាយសាសនាទាំងនេះត្រូវបានហៅឲ្យផ្សាយ « ទៅកាន់សាសន៍លេមិន » នៅភាគខាងលិចត្រង់ព្រំប្រទល់នៃរដ្ឋមីសសួរី ។ សូមជួយសិស្សឲ្យរកមើលទីតាំងនេះនៅផែនទី ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការណែនាំក្បាលកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីសំណួរមួយចំនួនដែលពួកអែលឌើរនៃសាសនាចក្រ មានកង្វល់អំពីបេសកកម្ម ដែល អូលីវើរ ខៅឌើរី និង ពេត្រុស វិតមើរ ជុញ្ញ័រ ត្រូវបានហៅឲ្យធ្វើនោះ ។

- តើសំណួរ ដែលអែលឌើរមួយចំនួននៃសាសនាចក្រ មានកង្វល់អំពីបេសកកម្មទៅកាន់ពួកសាសន៍លេមិន មានអ្វីខ្លះ ? ( ពួកគេចង់ដឹង បើមានអ្នកផ្សព្វផ្សាយសាសនាបន្ថែមទៀត អាចនឹងត្រូវបានហៅឲ្យបង្រៀនដល់ពួកសាសន៍លេមិន ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែល ប៉ាលី ភី ប្រាត្ត និង សេបា ភីតើសុន ត្រូវបានហៅឲ្យធ្វើ និងអ្វីដែលព្រះអម្ចាស់បានសន្យានឹងពួកគេ ។

- តើ ប៉ាលី និង សេបា ត្រូវបានហៅឲ្យធ្វើអ្វីខ្លះ ?
- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះជាមួយពួកគាត់ ?

អ្នកអាចនឹងចង់ចង្អុលបង្ហាញពីភាពស្រដៀងគ្នា រវាងការសន្យាដែលត្រូវបានប្រទានឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២:៣ និងគោលការណ៍ដែលបានសរសេរនៅលើក្ដារខៀនថា ៖ *បើយើងស្មោះត្រង់ដល់ទីបំផុត នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង ។*

អ្នកអាចនឹងចង់ពន្យល់ថា អំឡុងសរទរដូវ ឆ្នាំ ១៨៣០ និងសិសិររដូវ ឆ្នាំ ១៨៣០–៣១ ក្រុមអ្នកផ្សព្វផ្សាយសាសនាតូចនេះ ( ក្រោយមកបានចូលរួមដោយអ្នកផ្លាស់ប្រែចិត្តជឿមកពី អូហៃអូ ឈ្មោះថា ហ្វ្រេដឌើរីក ជី វិល្លាម ) បានធ្វើដំណើរជិត ១៥០០ ម៉ៃល ( ប្រហែលជា ២៤០០ គីឡូម៉ែត្រ ) ពីភូមិ ហ្វាយ៉ែត រដ្ឋ នូវ យ៉ោក ទៅកាន់ អ៊ិនឌីប៉ែនដែន្ស រដ្ឋមីសសួរី ដែលភាគច្រើនដើរថ្មើជើង ។ អ្នកផ្សព្វផ្សាយសាសនាទាំងបួននាក់នេះ បានធ្វើដំណើរទៅដល់ អ៊ិនឌីប៉ែនដែន្ស នៅពាក់កណ្ដាលខែមករា ឆ្នាំ ១៨៣១ ។ ក្នុងការធ្វើដំណើររបស់ពួកគាត់ នោះពួកគាត់បានស៊ូទ្រាំនឹងភាពត្រជាក់ខ្លាំង ខ្យល់បោកបក់ និងនឿយហត់ជាខ្លាំង ដែលការរស់នៅបរិភោគនំប៉ុងកកធ្វើពីពោត និងសាច់ជ្រូកឆៅជាចម្បង ។ នៅកន្លែងខ្លះ ពួកគាត់បានដើរកាត់ព្រិលជម្រៅ បី ហ្វីត ។ ដោយពុំគិតអំពីការលំបាកទាំងនេះ អ្នកផ្សព្វផ្សាយសាសនាទាំងនោះទទួលបានជោគជ័យក្នុងការណែនាំដំណឹងល្អដល់ពួកអាមេរិកកាំងស្បែកក្រហម ដែលរស់នៅក្នុងដែនដីពួកស្បែកក្រហម ជិតនឹងប៉ែកខាងលិចព្រំប្រទល់រដ្ឋមីសសួរី ។ ពួកគេក៏បានផ្សាយដំណឹងល្អនៅក្នុង មែនទ័រ និង ខឺតឡង់ រដ្ឋអូហៃអូ ទៅដល់ក្រុមជំនុំនៃមនុស្សដែលកំពុងស្វែងរកការស្ដារឡើងវិញនៃគ្រីស្ទនិកជនសញ្ញាថ្មី ។ ( សិស្សនឹងរៀនច្រើនអំពីប្រជាជនទាំងនេះ និងអ្នកដឹកនាំរបស់ពួកគេ ស៊ីឌនី រិកដុន នៅក្នុងការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ ) ។ ព្រះអម្ចាស់បានបំពេញសេចក្ដីសន្យារបស់ទ្រង់ថា ទ្រង់នឹងគង់នៅជាមួយអ្នកផ្សព្វផ្សាយសាសនាទាំងនេះ ហើយថាគ្មានអ្វីនឹងយកឈ្នះលើពួកគាត់បានទេ ។ ( សូមមើល *Church History in the Fulness of Times Student Manual,* បោះពុម្ពទី ២ [ Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ៨៤–៨៥ ) ។

អ្នកអាចនឹងចង់បញ្ចប់មេរៀននេះ ដោយការថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សា ។

មេរៀនទី ៣៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣–៣៤

## បុព្វកថា

នៅខែតុលា ឆ្នាំ ១៨៣០ ព្រះអម្ចាស់ បានហៅ អែសរ៉ា ធេយ័រ និង ណូរត្រុព ស៊្មីត ឲ្យប្រកាសដំណឹងល្អ ។ វិវរណៈនេះ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣ រួមមាននូវការណែនាំអំពីរបៀបដែលបុរសទាំងនេះ ត្រូវបានបង្រៀនដំណឹងល្អ ។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ នៅក្នុងវិវរណៈបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤ ព្រះអម្ចាស់ បានសរសើរ អួរសុន ប្រាត្ត ចំពោះ សេចក្ដីជំនឿរបស់គាត់ ហើយបានបញ្ជាឲ្យគាត់ទៅផ្សាយដំណឹងល្អផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១–៦

*ព្រះអម្ចាស់ បានហៅ អែសរ៉ា ធេយ័រ និង ណូរត្រុព ស៊្មីត ឲ្យប្រកាសដំណឹងល្អ*

មុនពេលថ្នាក់ចាប់ផ្ដើម សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្ដារខៀន ៖ *ត្រែ, មាត់, ត្រចៀក វាលស្រែស្រូវទុំល្អមច្រូតកាត់* ។ ( បើអាចធ្វើទៅបាន សូមបង្ហាញរូបភាពនៃវត្ថុទាំងនេះ ) ។ នៅពេលចាប់ផ្ដើមថ្នាក់ សូមសួរសំណួរដូចខាងក្រោម ៖

- តើវត្ថុទាំងនេះ ទាក់ទងនឹងកិច្ចការផ្សព្វផ្សាយសាសនាយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់បរិបទចំពោះ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣ សូមពន្យល់ថា អែសរ៉ា ធេយ័រ បានរស់នៅជិតនឹងគ្រួសាររបស់ យ៉ូសែប ស៊្មីធ ជុញ្ញ័រ ។ គាត់បានស្គាល់សមាជិកនៃគ្រួសារស៊្មីធ តាមរយៈកិច្ចការដែលពួកគេបានធ្វើសម្រាប់គាត់ក្នុងពេលផ្សេងៗ ។ នៅក្នុងខែ តុលា ឆ្នាំ ១៨៣០ អែសរ៉ា ធេយ័រ និងអ្នករស់នៅប៉ាល់ម៉ែរា ឈ្មោះ ណូរត្រុព ស៊្មីត ត្រូវបានទទួលបុណ្យជ្រមុជទឹកចូលក្នុងសាសនាចក្រ ។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ ព្យាការីយ៉ូសែប ស៊្មីធ បានទទួលវិវរណៈមួយដែលថ្លែងទៅកាន់បុរសទាំងពីរនាក់នេះ ដែលឥឡូវត្រូវបានកត់ត្រាទុកនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១–២ ដោយស្ងាត់ស្ងៀម រកមើលពាក្យ ឬឃ្លាដែលទាក់ទងទៅនឹងគំនូរ ( ឬពាក្យ ) នៅលើក្ដារខៀន ។ ( រូបភាពមាត់ នឹងប្រាប់នៅពេលក្រោយក្នុងមេរៀននេះ ) ។ ក្រោយពីសិស្សបានរាយការណ៍អំពីអ្វីដែលពួកគេបានរកឃើញហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « បើក. . . ត្រចៀករបស់អ្នក ហើយស្ដាប់តាមសំឡេងនៃ. . . ព្រះ » នោះ ? តើយើងអាចបង្ហាញដល់ព្រះអម្ចាស់ថា ត្រចៀករបស់យើងត្រូវបានបើកដើម្បីស្ដាប់តាមសំឡេងរបស់ទ្រង់យ៉ាងដូចម្ដេច ?

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីប្រកាសដំណឹងល្អ « ហាក់ដូចជាដោយសំឡេងត្រែ » ?

សូមពន្យល់ថា ជាញឹកញាប់ ព្រះអម្ចាស់ បានប្រើវត្ថុស្រដៀងគ្នា ដូចជា ត្រែ ជានិមិត្តរូប ដើម្បីបង្រៀនដំណឹងល្អរបស់ទ្រង់ និងដើម្បីជួយយើងយល់អំពីសេចក្ដីពិតដ៏អស់កល្បជានិច្ច ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនិមិត្តរូបបន្ថែម ដែលព្រះអម្ចាស់បានប្រើនៅក្នុងវិវរណៈនេះ ។

- តើអ្នកគិតថាចម្ការទំពាំងបាយជូររបស់ព្រះអម្ចាស់តំណាងឲ្យអ្វី ? ( ពិភពលោក ) ។

- តើអ្នកដែលធ្វើការក្នុងចម្ការទំពាំងបាយជូររបស់ព្រះអម្ចាស់ តំណាងឲ្យនរណា ? ( សមាជិកនៃសាសនាចក្ររបស់ព្រះអម្ចាស់ ) ។

- តើអ្នកគិតថាឃ្លា « ត្រូវជាម៉ោងទី ១១ » មានន័យយ៉ាងណា ? ( នេះគឺជាគ្រាកាន់កាប់ត្រួតត្រាចុងក្រោយនៃដំណឹងល្អ និងជាគ្រាចុងក្រោយ ដែលព្រះអម្ចាស់នឹងរៀបចំនគររបស់ទ្រង់ឡើងនៅលើផែនដី មុនពេលការយាងមកជាលើកទីពីររបស់ទ្រង់ ) ។

*សូមអញ្ជើញសិស្សទាំងអស់ឲ្យចូលរួម*

សូមកៅធីអញ្ជើញសិស្សទាំងអស់ឲ្យចូលរួមនៅក្នុងការពិភាក្សាដ៏មានអត្ថន័យដោយសមរម្យ ទោះជាអ្នកទាំងឡាយមានការស្ទាក់ស្ទើរក្នុងការចូលរួមក្ដី ។ វិធីមួយដើម្បីធ្វើការនេះ គឺត្រូវសួរសំណួរដែលចាប់ផ្ដើមជាមួយនឹងឃ្លាថា « តើអ្នកគិតយ៉ាងណា. . . ? » សំណួរដូច្នេះជួយសិស្សឲ្យយល់ថា គំនិតរបស់ពួកគេគឺមានតម្លៃ ហើយថាអ្នកពុំចង់បានចម្លើយជាក់លាក់តែមួយនោះទេ ។

សូមសុំសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៤ ដោយស្ងាត់ស្ងៀមរកមើលរបៀបដែលព្រះអម្ចាស់ បានពិពណ៌នាអំពីស្ថានភាពនៃលោកិយក្នុងឆ្នាំ ១៨៣០ ។

- តើឃ្លាណាមួយក្នុងខគម្ពីរនេះ ដែលលេចធ្លោចំពោះអ្នក ? ហេតុអ្វី ? តើយើងអាចធ្វើអ្វីខ្លះ ដើម្បីពង្រឹងខ្លួនយើងទប់ទល់នឹងឥទ្ធិពលពុករលួយនៃលោកិយ ?

សូមសរសេរដូចខាងក្រោមនៅលើក្ដារខៀន ៖ *ព្រះអម្ចាស់មាន ____________________ ហើយគឺជា ____________________ ។*

សូមឲ្យពេលដល់សិស្សពីរបីនាទី ដើម្បីពិចារណាពីអ្វីដែលព្រះអម្ចាស់បានធ្វើ ឬកំពុងធ្វើដើម្បីជួយពង្រឹងពួកគេទប់ទល់នឹងភាពពុករលួយនៃលោកិយ ។ សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៥–៦ ព្រះអម្ចាស់ បានប្រកាសអ្វីមួយដែលទ្រង់បានធ្វើ ហើយនឹងរឿងមួយដែលទ្រង់កំពុងធ្វើដើម្បីជួយពង្រឹងយើង ទប់ទល់នឹងភាពពុករលួយនៃលោកិយ ។ សូមសុំឲ្យសិស្សម្នាក់អានខគម្ពីរទាំងនេះឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់នូវអ្វីដែលព្រះអម្ចាស់បានធ្វើ ហើយនឹងធ្វើដើម្បីពង្រឹងដល់យើង ។

- យោងតាមខគម្ពីរទាំងនេះ តើអ្វីមួយដែលព្រះបានធ្វើ ហើយអ្វីមួយដែលទ្រង់កំពុងធ្វើក្នុងពេលឥឡូវនេះ ដែលអាចជួយពង្រឹងយើងទប់ទល់នឹងភាពពុករលួយនៃលោកិយនេះ ? ( នៅពេលសិស្សឆ្លើយតប សូមអញ្ជើញសិស្សម្នាក់ឲ្យបំពេញនៅក្នុងចន្លោះ នៅក្នុងសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ) ។ ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់ បានស្ដាបនាសាសនាចក្ររបស់ទ្រង់ ហើយកំពុងតែប្រមូលផ្ដុំពួកជម្រើសរបស់ទ្រង់នៅថ្ងៃចុងក្រោយ** ) ។

ដើម្បីជួយសិស្សយល់បន្ថែមអំពីសេចក្ដីពិតនេះ ហើយមានអារម្មណ៍ដឹងពីសារៈសំខាន់របស់វា សូមចាត់ឲ្យពួកគេធ្វើការជាគូៗ ហើយពិភាក្សាអំពី ចម្លើយរបស់ពួកគេចំពោះសំណួរដូចខាងក្រោម ។ អ្នកអាចអានសំណួរទាំងនេះឲ្យឮៗ សូមសរសេរវានៅលើក្ដារខៀន ឬចែកវានៅក្នុងក្រដាសទៅឲ្យសិស្ស ។ ( សូមកុំសរសេរចម្លើយនៅក្នុងវង់ក្រចក ) ។

1. *យោងតាម ខ ៦ តើនរណាជាពួកជម្រើស ? ( អ្នកទាំងឡាយដែលនឹងជឿលើព្រះ ហើយស្ដាប់តាមសំឡេងទ្រង់ ) ។*
2. *សូមពិចារណាអំពីភាពពុករលួយនៃលោកិយ ហេតុអ្វីក៏វាសំខាន់ដើម្បីប្រមូលផ្ដុំពួកជម្រើសរបស់ព្រះអម្ចាស់ ?*
3. *តើសមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានពង្រឹងដល់អ្នកទប់ទល់នឹងភាពពុករលួយនៃលោកិយនេះយ៉ាងដូចម្ដេច ?*

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៧–១៨

*ព្រះអម្ចាស់ បានប្រទានការណែនាំដល់ អ៊ែសរ៉ា ធេយ័រ និង ណូរត្រុព ស្វ៊ីត ឲ្យបង្រៀនដំណឹងល្អ*

យោងទៅលើរូបភាព មាត់ ( ឬពាក្យ *មាត់* ) នៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៧–១០ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះអម្ចាស់បានបង្រៀនដល់ អ៊ែសរ៉ា ធេយ័រ និង ណូរត្រុព ស្វ៊ីត ពីអ្វីដែលពួកគេត្រូវធ្វើ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងបើកមាត់របស់យើងប្រកាសដំណឹងល្អ . . .*

សូមឲ្យសិស្សប្រើនូវអ្វីដែលពួកគេបានរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៧–១០ ដើម្បីបំពេញសេចក្ដីថ្លែងការណ៍នេះ ។ អ្នកអាចនឹងចង់អញ្ជើញសិស្សម្នាក់ឲ្យមកកាន់ក្ដារខៀន ដើម្បីសរសេរបញ្ចប់គោលការណ៍នេះ ។ វាអាចត្រូវបានសរសេរដូចតទៅ ៖ **បើយើងបើកមាត់របស់យើងប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹងបំផុសយើងអំពីអ្វីដែលត្រូវនិយាយ ។**

- តើស្ថានភាពមួយចំនួនដែលយើងអាចនឹងស្ទាក់ស្ទើរដើម្បីបើកមាត់របស់យើងប្រាប់អំពីដំណឹងល្អមានអ្វីខ្លះ ?
- តើអ្នកបានសម្រេចចិត្តបើកមាត់របស់អ្នក និយាយអំពីដំណឹងល្អ និងទទួលអារម្មណ៍បំផុសគំនិតឲ្យដឹងនូវអ្វីដែលត្រូវនិយាយនៅពេលណា ? តើនៅពេលណាអ្នកបានឃើញនរណាម្នាក់ទៀត ដែលចែកចាយដំណឹងល្អ ហើយមានអារម្មណ៍ថាពួកគេត្រូវបានបំផុសគំនិតនៅក្នុងអ្វីដែលពួកគេនិយាយនោះ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១១–១៥ តាមរយៈការពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះ ព្រះអម្ចាស់បានណែនាំ អ៊ែសរ៉ា ធេយ័រ និង ណូរត្រុព ស្វីត ដើម្បីផ្សាយគោលការណ៍ទីមួយ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ–សេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមយោងទៅគោលការណ៍ដែលបានសរសេរលើក្ដារខៀនម្ដងទៀត ។ សូមឲ្យសិស្សពិចារណាអំពីអ្វីដែលយើងចាំបាច់ត្រូវធ្វើ បន្ថែមពីលើការបើកមាត់របស់យើង ដូច្នេះព្រះអម្ចាស់អាចបំផុសគំនិតយើងឲ្យដឹងនូវអ្វីដែលត្រូវនិយាយ ពេលយើងចែកចាយដំណឹងល្អជាមួយអ្នកដទៃ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១៦–១៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីការទូន្មានជាក់លាក់ដែលព្រះអម្ចាស់បានប្រទានដល់ អ៊ែសរ៉ា និង ណូរត្រុព ដែលនឹងជួយពួកគេដឹងនូវអ្វីដែលត្រូវនិយាយក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។

- តើព្រះអម្ចាស់បានប្រទានការទូន្មានអ្វីខ្លះ ដល់អ៊ែសរ៉ា និង ណូរត្រុព ដែលអាចជួយពួកគេឲ្យដឹងនូវអ្វីដែលត្រូវនិយាយក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ? ( សូមគិតពីការសរសេរចម្លើយរបស់សិស្សដាក់លើក្ដារខៀន ។ )

- តើអ្នកគិតថា វាមានន័យយ៉ាងណាចំពោះការទូន្មានរបស់ព្រះអម្ចាស់ ឲ្យមាន « ចង្កៀងបង្កាត់ ហើយឆេះ ហើយមានប្រេងនៅជាមួយអ្នកផង » នោះ ? ( គ និង ស ៣៣:១៧ ) ។ ( ដើម្បីត្រូវបានត្រៀមខ្លួនខាងវិញ្ញាណ ហើយត្រៀមខ្លួនជាស្រេចគ្រប់ពេលសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ខគម្ពីរនេះ ជាប់ទាក់ទងនឹងរឿងប្រៀបធៀបនៃស្ត្រីក្រមុំព្រហ្មចារីយភាពទាំងដប់នាក់ ដែលមាននៅក្នុង ម៉ាថាយ ២៥:១–១៣ ហើយមានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៥៦–៥៧ ) ។

- តើការទូន្មានរបស់ព្រះអម្ចាស់នៅក្នុងខទាំងនេះជួយយើងត្រៀមខ្លួនដើម្បីបើកមាត់ចែកចាយដំណឹងល្អនៅគ្រប់ពេល និងគ្រប់ស្ថានភាពយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤

*ព្រះអម្ចាស់ បានសរសើរដល់ អូរសុន ប្រាត្ត ចំពោះសេចក្ដីជំនឿរបស់គាត់ ហើយបានបញ្ជាឲ្យគាត់ផ្សាយដំណឹងល្អ*

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤ ដើម្បីរកមើលឧទាហរណ៍មួយរបស់មនុស្សម្នាក់ ដែលត្រូវបានប្រទានពរនៅពេលនរណាម្នាក់ទៀត បានបើកមាត់របស់គាត់ចែកចាយដំណឹងល្អ ។

- តើនរណាត្រូវបានទទួលពរជ័យនៅក្នុងឧទាហរណ៍នេះ ? តើ អូរសុន ប្រាត្ត មានអាយុប៉ុន្មាន ពេលគាត់ទទួលបុណ្យជ្រមុជទឹក ? តើគាត់បានរៀនអំពីដំណឹងល្អយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើព្រះអម្ចាស់មានបន្ទូលសំដៅទៅលើអូរសុនយ៉ាងណាខ្លះ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។ បន្ទាប់មក ឲ្យសិស្សក្នុងថ្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:២–៣ ដោយស្ងាត់ស្ងៀម ដើម្បីរកមើលមូលហេតុដែលព្រះអម្ចាស់បានហៅគាត់ថា « បុត្ររបស់យើង » ។

- ហេតុអ្វីក៏ព្រះអម្ចាស់ហៅ អូរសុន ជាបុត្ររបស់ទ្រង់ដូច្នេះ ? ( ដោយសារជំនឿរបស់ អូរសុន មានទៅលើព្រះអម្ចាស់ ) ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:៣ តើព្រះអម្ចាស់បានធ្វើអ្វីខ្លះ សម្រាប់ « អស់អ្នកណា » ដែលជឿទៅលើទ្រង់ ? ( ដើម្បីជួយសិស្សយល់ថា សេចក្ដីពិតនៅក្នុងខគម្ពីរនេះ អនុវត្តដូចគ្នាចំពោះស្ត្រី អ្នកអាចនឹងចង់ផ្ដល់យោបល់ថាពួកគេអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:៤–៦ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ អូរសុន ដែលនឹងនាំមកនូវពរជ័យកាន់តែច្រើនក្នុងជីវិតរបស់គាត់នោះ ។

- តើអ្នកគិតថា ហេតុអ្វីយើងត្រូវបាន « ប្រទានពរកាន់តែច្រើន » នៅពេលយើងបង្រៀនដំណឹងល្អដល់អ្នកដទៃដូច្នេះ ?

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:១០–១១ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលពរជ័យដែលត្រូវបានប្រទានដល់អ្នកទាំងឡាយដែលចែកចាយដំណឹងល្អជាមួយអ្នកដទៃដោយឧស្សាហ៍ព្យាយាម ។

- តើមានពរជ័យអ្វីខ្លះ ដែលត្រូវបានប្រទានឲ្យអ្នកទាំងឡាយដែលបង្រៀនដំណឹងល្អដោយឧស្សាហ៍ព្យាយាមនោះ ? ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចខាងក្រោម នៅលើក្ដារខៀន ៖ **អ្នកទាំងឡាយដែលបង្រៀនដំណឹងល្អដោយឧស្សាហ៍ព្យាយាម នឹងធ្វើឡើងដូច្នោះដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ**

- តើមានពរជ័យអ្វីខ្លះដែលត្រូវបានសន្យាដល់អ្នកទាំងឡាយដែលស្មោះត្រង់ ? ( អ្នកក៏អាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀនផងដែរ ៖ **បើយើងស្មោះត្រង់ នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង** ) ។
- តើសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:១១ អាចជួយយើងនៅក្នុងគ្រាដែលបាក់ទឹកចិត្តយ៉ាងដូចម្ដេច ?

អ្នកអាចនឹងចង់បញ្ចប់មេរៀនដោយការចែកចាយអំពីគ្រាមួយដែលអ្នកបានមានអារម្មណ៍ថា ព្រះអម្ចាស់ គង់នៅជាមួយអ្នកពេលអ្នកស្មោះត្រង់នឹងទ្រង់ ។ អ្នកក៏អាចនឹងចង់ថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលបានពិភាក្សានៅក្នុងមេរៀននេះផងដែរ ។

មេរៀនទី ៤០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥

## បុព្វកថា

អំឡុងប្រាំមួយខែនៃការរៀបចំសាសនាចក្រឡើង អូលីវើរ ខៅឌើរី និង ពេត្រុស វិតមើរ ជុញ្ញ័រ ត្រូវបានហៅឲ្យផ្សាយដំណឹងល្អទៅដល់ពួកអាមេរិកកាំងស្បែកក្រហម ( សូមមើល គ. និង ស. ២៨:៨, ៣០:៥) ។ សេបា ភីតើសុន និង ប៉ាលី ភី ប្រាត្ត ត្រូវបានហៅបន្ទាប់មកនោះ ដើម្បីរួមដំណើរជាមួយពួកគាត់ ( សូមមើល គ. និង ស. ៣២) ។ នៅតាមផ្លូវរបស់ពួកគាត់ទៅកាន់ព្រំប្រទល់រដ្ឋមីសសួរីភាគខាងលិច ពួកគាត់បានឈប់នៅ មែនទ័រ អូហៃអូ និង ខឺតឡង់ អូហៃអូ ជាកន្លែងដែលពួកគេបានចែកចាយសារលិខិតនៃដំណឹងល្អដែលបានស្ដារឡើងវិញ ជាមួយនឹងមិត្តរបស់ អែលឌើរ ប្រាត្ត និងគ្រូគង្វាលចាស់របស់ ស៊ីឌនី រិកដុន ។ ក្នុងរយៈពេលដ៏ខ្លី មានមនុស្សច្រើនជាង ១០០ នាក់ រួមទាំង ស៊ីឌនី រិកដុន និងសមាជិកជាច្រើនទៀតនៃក្រុមជំនុំរបស់គាត់ បានទទួលបុណ្យជ្រមុជទឹក ។ នេះគឺមានចំនួនទ្វេដងច្រើនជាងចំនួនសមាជិកភាពសរុបរបស់សាសនាចក្រទៅទៀត ។

បន្ទាប់ពីពួកអែលឌើរ បានចាកចេញពីតំបន់ទីក្រុង ខឺតឡង់ ដើម្បីបន្តដំណើររបស់ពួកគាត់ នោះស៊ីឌនី រិកដុន និងមិត្តម្នាក់ ឈ្មោះ អែតវឺត ប៉ាទ្រិច បានធ្វើដំណើរទៅ ហ្វាយ៉ែត រដ្ឋ នូវយ៉ោក ដើម្បីជួបនឹងព្យាការី យ៉ូសែប ស្ម៊ីធ ។ មិនយូរប៉ុន្មានបន្ទាប់ពីពួកគាត់ទៅដល់ យ៉ូសែប បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥។ ក្នុងវិវរណៈនោះ ព្រះអម្ចាស់ បានប្រទានទំនួលខុសត្រូវជាក់លាក់ដល់ ស៊ីឌនី ក្នុងអំឡុងសាសនាចក្រដែលបានស្ដារឡើងវិញថ្មីៗ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១–១២

*ព្រះអម្ចាស់ បានមានបន្ទូលថា ទ្រង់បានរៀបចំ ស៊ីឌនី រិកដុន សម្រាប់កិច្ចការងារ ដ៏មហិមា*

មុនពេលចាប់ផ្ដើមថ្នាក់ ចូរសរសេរនូវសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើអ្នកមានបទពិសោធន៍អ្វីខ្លះ ដែលជួយអ្នកដឹងថា ព្រះស្គាល់អ្នក ហើយមានផែនការមួយសម្រាប់ជីវិតអ្នក ?*

ដើម្បីចាប់ផ្ដើមមេរៀន សូមអញ្ជើញសិស្សឲ្យចែកចាយចម្លើយចំពោះសំណួរនេះ បើពួកគេមានអារម្មណ៍ល្អក្នុងការធ្វើដូច្នោះបាន ។

សូមពន្យល់ថា នៅក្នុងវិវរណៈដែលឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ ព្រះអម្ចាស់ បានថ្លែងអំពីបុរសម្នាក់ឈ្មោះ ស៊ីឌនី រិកដុន ដែលទើបតែបានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ថ្មីៗ ។ ព្រះអម្ចាស់ បានមានបន្ទូលទៅកាន់ ស៊ីឌនី អំពីតួនាទីរបស់គាត់ក្នុងការជួយដល់ ព្យាការីយ៉ូសែប ស្ម៊ីធ ។ សូមលើកទឹកចិត្តសិស្សឲ្យបន្តគិតអំពីសំណួរនៅលើក្ដារខៀន នៅពេលពួកគេសិក្សាអំពីការណែនាំរបស់ព្រះអម្ចាស់ទៅដល់ ស៊ីឌនី ។

ដើម្បីជួយឲ្យសិស្សយល់អំពីប្រវត្តិរូបរបស់ ស៊ីឌនី រិកដុន មួយចំនួន សូមឲ្យសិស្សម្នាក់អានឮៗ នូវបុព្វកថានៃមេរៀននេះ ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលភស្ដុតាងដែលព្រះអម្ចាស់ បានដឹងជាមុនអំពី ស៊ីឌនី រិកដុន និងកិច្ចការងាររបស់គាត់ ។

- តើមានភស្ដុតាងអ្វីខ្លះ ដែលអ្នកបានរកឃើញថា ព្រះអម្ចាស់ បានដឹងជាមុនអំពី ស៊ីឌនី រិកដុន ?
- តើខគម្ពីរទាំងនេះ ផ្ដល់យោបល់អ្វីខ្លះអំពីទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយយើង ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ ស្គាល់យើង ហើយមានកិច្ចការមួយសម្រាប់ឲ្យយើងម្នាក់ៗធ្វើ** ) ។
- ហេតុអ្វីសេចក្ដីពិតនេះសំខាន់ចំពោះអ្នក ?

ដើម្បីបញ្ជាក់ថា ព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ នែល អេ ម៉ាក់ស្វែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ខ្ញុំសូមថ្លែងទីបន្ទាល់ទៅអ្នកថា ព្រះស្គាល់អ្នកម្នាក់ៗ . . . តាំងពីយូរលង់មកហើយ ( សូមមើល គ. និង ស. ៩៣:២៣) ។ ទ្រង់ស្រឡាញ់អ្នកជាយូរលង់មកហើយ ។. . . ទ្រង់ស្គាល់ឈ្មោះរបស់អ្នក និងការឈឺចាប់ទាំងអស់របស់អ្នក និងក្ដីអំណររបស់អ្នក ! » (« Remember How Merciful the Lord Hath Been, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ៤៦ ) ។



សូមដាក់តាំងរូបភាពរបស់ យ៉ូហាន បាទីស្ទ កំពុងផ្សាយ ឬរូបភាព យ៉ូហាន កំពុងជ្រមុជទឹកឲ្យព្រះអង្គសង្គ្រោះ ( សូមមើល យ៉ូហាន បាទីស្ទ កំពុងជ្រមុជទឹកព្រះយេស៊ូវ, *សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ], លេខ ៣៥; សូមមើលផងដែរ LDS.org ) ។ សូមឲ្យសិស្សប្រាប់ថា យ៉ូហាន បាទីស្ទ ជានរណា ហើយតើគាត់រៀបចំអ្នកដទៃសម្រាប់ការយាងមកនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៤–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែល ស៊ីឌនី រិកដុន គឺដូចជា យ៉ូហាន បាទីស្ទ ។

- យោងតាម ខ ៤ តើស៊ីឌនី ដូចជា យ៉ូហាន បាទីស្ទ យ៉ាងដូចម្ដេច ? ( គាត់បានរៀបចំអ្នកដទៃដើម្បីទទួលភាពពេញលេញនៃដំណឹងល្អ ) ។

- ព្រះអម្ចាស់ បានមានបន្ទូលថា ស៊ីឌនី នឹងធ្វើ « កិច្ចការដ៏ធំ » ជាងកិច្ចការដែលគាត់បានធ្វើរួចទៅហើយនោះ ( គ. និង ស. ៣៥:៣) ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៦ តើអ្វីដែលជាចំណែកនៃ « កិច្ចការដ៏ធំ » នេះ ? ( គាត់នឹងជួយអ្នកដទៃទទួលបុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ តាមរយៈសិទ្ធិអំណាចត្រឹមត្រូវ ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលបទពិសោធន៍ និងស្ថានភាពនានានៅក្នុងជីវិតរបស់ពួកគេឥឡូវនេះ កំពុងរៀបចំពួកគេសម្រាប់ « កិច្ចការដ៏ធំ » នាពេលអនាគត ។ អ្នកអាចនឹងចង់ផ្ដល់ពេលឲ្យពួកគេពីរបីនាទី ដើម្បីសរសេរការណ៍នេះទុកនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

សូមចង្អុលបង្ហាញពីឃ្លា « អ្នកពុំបានដឹងសោះឡើយ » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៤ ។ សូមពន្យល់ថា មុនពេល ស៊ីឌនី បានរៀនអំពីសាសនាចក្រដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ គាត់បានរៀបចំខ្លួនឯង និងអ្នកដទៃដើម្បីទទួលយក ។ គាត់បានធ្វើដូច្នេះ តាមរយៈការប្រើព្រះគម្ពីរប៊ីប ដើម្បីបង្រៀនដល់មនុស្សនៅក្នុងព្រះវិហាររបស់គាត់នៅរដ្ឋអូហៃអូ ។ សូមថ្លែងទីបន្ទាល់ថា ទោះជាយើងពុំស្គាល់កិច្ចការជាក់លាក់ ដែលព្រះអម្ចាស់បានរៀបទុកសម្រាប់យើងក្ដី ក៏យើងអាចមានទំនុកចិត្តថា ទ្រង់បានដឹងជាមុនអំពីយើង ។ នៅពេលយើងព្យាយាមដើម្បីធ្វើតាមទ្រង់ នោះទ្រង់នឹងជួយយើងសម្រេចកិច្ចការ ដែលទ្រង់ចង់ឲ្យយើងធ្វើ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៧–១១ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលនូវអ្វីដែលនឹងកើតឡើងនៅក្នុងជីវិតរបស់អ្នកទាំងឡាយ ដែលជឿ ហើយអនុវត្តសេចក្ដីជំនឿទៅលើព្រះ នៅក្នុងថ្ងៃចុងក្រោយ ។

- យោងតាមខទាំងនេះ តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់អ្នកទាំងឡាយ ដែលធ្វើតាមទ្រង់នៅក្នុងសេចក្ដីជំនឿ ? ( ទោះជាសិស្សអាចនឹងប្រើពាក្យសម្ដីផ្សេងក្ដី ពួកគេគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអម្ចាស់នឹងបង្កើតអព្ភូតហេតុ ផ្ដល់ទីសម្គាល់ និងភាពអស្ចារ្យ ស្របតាមសេចក្ដីជំនឿនៃអ្នកទាំងឡាយដែលជឿលើព្រះនាមទ្រង់** ) ។

- ហេតុអ្វីក៏អ្នកគិតថា អព្ភូតហេតុ ទីសម្គាល់ និងភាពអស្ចារ្យ ត្រូវបានភ្ជាប់យ៉ាងជិតស្និតបំផុតទៅនឹងសេចក្ដីជំនឿដូច្នេះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៣–១៩

*ព្រះអម្ចាស់សន្យានឹងជួយដល់អ្នកទាំងឡាយណា ដែលទ្រង់ហៅឲ្យធ្វើកិច្ចការរបស់ទ្រង់*

សូមអញ្ជើញសិស្សឲ្យស្រមៃថា ពួកគេកំពុងប្រមូលផ្ដុំក្រុមកីឡាមួយក្រុម ។ សូមឲ្យពួកគេពិពណ៌នាអំពីភាពខ្លាំង និងជំនាញ ដែលពួកគេប្រាថ្នាចង់បានពីកីឡាករក្នុងក្រុមរបស់ពួកគេ ។

សូមពន្យល់ថា នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ បានពិពណ៌នាអំពីអ្នកទាំងឡាយដែលទ្រង់បានហៅឲ្យជួយនៅក្នុងកិច្ចការថ្ងៃចុងក្រោយនៃការកសាងនគររបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ប្រាប់អំពីចរិតលក្ខណៈនៃអ្នកទាំងឡាយដែលព្រះអម្ចាស់បានជ្រើសរើសឲ្យជួយនៅក្នុងកិច្ចការរបស់ទ្រង់ ។

- តើឃ្លាណាមួយនៅក្នុងខគម្ពីរនេះ ពិពណ៌នាអំពីអ្នកទាំងឡាយដែលព្រះអម្ចាស់ហៅឲ្យជួយនៅក្នុងកិច្ចការរបស់ទ្រង់ ?
- តើអ្នកទាំងឡាយដែលព្រះអម្ចាស់ហៅឲ្យជួយនៅក្នុងកិច្ចការរបស់ទ្រង់ ត្រូវបានគិតថាជា « ពួកកំសោយនៅលោកីយ៍នេះ » តាមរបៀបណា ?
- ហេតុអ្វីក៏អ្នកទាំងឡាយដែលពិភពលោក គិតថាជាពួកកំសោយ គឺជាបេក្ខជនដ៏ល្អក្នុងការជួយដល់ព្រះអម្ចាស់សម្រេចកិច្ចការរបស់ទ្រង់ដូច្នេះ ?

សូមពន្យល់ថា ពាក្យថា *លាន* ( ឬ *លានស្រូវ*) នៅក្នុងខគម្ពីរនេះសំដៅទៅលើការអនុវត្តនៃលានស្រូវ ។ លានស្រូវ គឺជាដំណើរការដែលធុញ្ញជាតិ ដូចជាស្រូវសាឡី ត្រូវបានញែកចេញពីដើម និងសំបក ។ ស្រូវត្រូវបានរក្សាទុក ហើយដើម និងសំបកវាត្រូវបានបោះចោល ។

- តើអ្នកគិតថាឃ្លា « បញ្ជាន់សាសន៍ទាំងឡាយដោយសារព្រះចេស្ដានៃព្រះវិញ្ញាណរបស់យើង » មានន័យយ៉ាងណា ? ( អ្នកអាចនឹងចាំបាច់ត្រូវជួយសិស្សឲ្យយល់ថា ការណ៍នេះសំដៅទៅលើកិច្ចខិតខំរបស់ព្រះអម្ចាស់ ដើម្បីញែក ហើយប្រមូលអ្នកទាំងឡាយដែលត្រៀមខ្លួនជាស្រេចដើម្បីទទួលដំណឹងល្អ ចេញពីអ្នកទាំងឡាយដែលមិនទទួល ) ។
- តើយើងអាចរៀនសេចក្ដីពិតអ្វីខ្លះនៅក្នុង ខទី ១៣ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះហៅពួកកំសោយនៅលោកិយ៍ដើម្បីឲ្យសម្រេចកិច្ចការរបស់ទ្រង់តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណរបស់ទ្រង់ ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។
- តើសេចក្ដីពិតនេះ អាចជួយនរណាម្នាក់ដែលមានអារម្មណ៍ភិតភ័យអំពីការបម្រើបេសកកម្មយ៉ាងដូចម្ដេច ? តើវាអាចជួយនរណាម្នាក់ដែលត្រូវបានសុំឲ្យបង្រៀននៅព្រះវិហារ ប៉ុន្តែមានអារម្មណ៍ថាខ្លួនពុំល្អគ្រប់គ្រាន់យ៉ាងដូចម្ដេច ? តើវាអាចជួយនរណាម្នាក់ដែលមានអារម្មណ៍បំផុសគំនិតឲ្យចែកចាយដំណឹងល្អ ប៉ុន្តែពុំដឹងថាត្រូវនិយាយអ្វីឲ្យប្រាកដដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៤–១៥ ដោយស្ងាត់ស្ងៀម ហើយរកមើលវិធីដែលព្រះអម្ចាស់បានសន្យាដើម្បីពង្រឹងដល់អ្នកទាំងឡាយ ដែលជួយនៅក្នុងកិច្ចការរបស់ទ្រង់ ។

- តើឃ្លាមួយចំនួននៅក្នុងខគម្ពីទាំងនេះ ដែលពិពណ៌នាអំពីរបៀបដែលព្រះអម្ចាស់នឹងប្រទានពរយើង នៅពេលយើងជួយនៅក្នុងកិច្ចការរបស់ទ្រង់ មានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៧–១៩, ២២ ឲ្យឮៗ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវការទូន្មានរបស់ព្រះអម្ចាស់ទៅកាន់ស៊ីឌនី រិកដុន ស្ដីអំពីព្យាការី យ៉ូសែប ស្ម៊ីធ ។

- តើការទូន្មានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ស៊ីឌនី រិកដុន ស្ដីអំពីព្យាការី យ៉ូសែប ស្ម៊ីធ នោះ ? ( « សូមមើលលោកដើម្បីកុំឲ្យសេចក្ដីជំនឿរបស់លោកវិនាសបាត់ឡើយ » « សូមនៅជាមួយនឹងលោកចុះ » ហើយ « សូមកុំបោះបង់លោកចោលឡើយ » ) ។
- តើយើងអាចអនុវត្តការទូន្មាននេះ ទាក់ទងទៅនឹងអ្នកដឹកនាំសព្វថ្ងៃរបស់យើងយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២០–២៧

*ព្រះអម្ចាស់បានបញ្ជា ស៊ីឌនី រិកដុន ឲ្យធ្វើជាស្មៀន យ៉ូសែប ស្ម៊ីធ ឲ្យ ផ្សាយដំណឹងល្អ ហើយរក្សាសេចក្ដីសញ្ញាដែលគាត់បានធ្វើ ។*

សូមឲ្យសិស្សពិពណ៌នាអំពីការហៅបម្រើ ឬកាតព្វកិច្ចរបស់ពួកគេនៅក្នុងសាសនាចក្រ ។ បន្ទាប់មក សូមឲ្យសិស្សមើលត្រួសៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២០–២៣ ដោយស្ងាត់ស្ងៀម រកមើលកាតព្វកិច្ចជាក់លាក់ ដែលព្រះអម្ចាស់បានហៅឲ្យ ស៊ីឌនី រិកដុន ធ្វើ ។

- តើកាតព្វកិច្ចមួយចំនួន ដែលព្រះអម្ចាស់បានហៅ ស៊ីឌនី រិកដុន ធ្វើមានអ្វីខ្លះ ?

សូមចង្អុលបង្ហាញថា កាតព្វកិច្ចមួយរបស់ស៊ីឌនី គឺត្រូវធ្វើជាស្មៀនរបស់ យ៉ូសែប ស្ម៊ីធ ។ ស្មៀនពីមុនរបស់ យ៉ូសែប គឺ អូលីវើរ ខៅឌើរី និង យ៉ូសែប វិតមើរ ត្រូវបានហៅឲ្យបម្រើបេសកកម្ម ។ ការបកប្រែព្រះគម្ពីរមរមន គឺត្រូវបានបញ្ចប់នៅត្រឹមពេលនេះ ប៉ុន្តែព្រះអម្ចាស់បានបញ្ជាយ៉ូសែបឲ្យ ស្ដារ ឬធ្វើកំណែថ្មីនូវផ្នែកជាច្រើននៃកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ ដែលត្រូវបានបាត់បង់ ឬផ្លាស់ប្ដូរនោះ ។ យ៉ូសែប ត្រូវការស្មៀនម្នាក់ដើម្បីជួយក្នុងកិច្ចការនេះ ។ ( សូមមើល Bible Dictionary « Joseph Smith Translation » ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២៤–២៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យដែលព្រះអម្ចាស់បានសន្យាដល់ ស៊ីឌនី បើគាត់នឹងរក្សាសេចក្ដីសញ្ញាទាំងឡាយ ដែលគាត់បានធ្វើជាមួយព្រះអម្ចាស់ ។ អ្នកអាចផ្ដល់យោបល់ថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដែលថា ព្រះអម្ចាស់នឹងបណ្ដាលឲ្យផ្ទៃមេឃញាប់ញ័រដើម្បីសេចក្ដីល្អដល់អ្នកនោះ ? ( អត្ថន័យដែលអាចមានមួយ គឺថា ព្រះអម្ចាស់ នឹងបញ្ជូនពរជ័យ និងអំណាចនៃស្ថានសួគ៌ ដើម្បីជួយអ្នកសម្រេចកិច្ចការរបស់ទ្រង់ ហើយយកឈ្នះលើអារក្ស ) ។ សូមមើលផងដរ គ. និង ស. ២១:៦ ) ។

សូមអញ្ជើញសិស្សឲ្យសង្ខេបខគម្ពីរទាំងនេះ ដោយប្រាប់គោលការណ៍មួយ អំពីរបៀបដែលយើងអាចទទួលបានជោគជ័យនៅក្នុងការសម្រេចកិច្ចការរបស់ព្រះដែលមានសម្រាប់យើង ។ ទោះជាសិស្សអាចនឹងថ្លែងវាតាមរបៀបផ្សេង ក៏ចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងរក្សាបទបញ្ញត្តិទាំងឡាយ ហើយគោរពសេចក្ដីសញ្ញារបស់យើង នោះព្រះអម្ចាស់នឹងជួយយើងសម្រេចកិច្ចការរបស់ទ្រង់** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។

សូមទាញយកចំណាប់អារម្មណ៍របស់សិស្សលើសេចក្ដីពិតទាំងបីដែលបានសរសេរនៅលើក្ដារខៀន ។

> *ព្រះអម្ចាស់ស្គាល់យើង ហើយមានកិច្ចការមួយសម្រាប់យើងម្នាក់ៗធ្វើ ។*
>
> *ព្រះហៅអ្នកទាំងឡាយដែលទន់ខ្សោយដើម្បីសម្រេចកិច្ចការរបស់ទ្រង់ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណរបស់ទ្រង់ ។*
>
> *នៅពេលយើងរក្សាបទបញ្ញត្តិ ហើយគោរពសេចក្ដីសញ្ញារបស់យើង នោះព្រះអម្ចាស់នឹងជួយយើងសម្រេចកិច្ចការរបស់ទ្រង់ ។*

- តើសេចក្ដីពិតទាំងបីនៅលើក្ដារខៀនទាក់ទងនឹងគ្នាទៅវិញទៅមកយ៉ាងដូចម្ដេច ?

- តើអ្នក ( ឬនរណាម្នាក់ដែលអ្នកស្គាល់ ) បានទទួលជំនួយរបស់ព្រះអម្ចាស់ ខណៈដែលកំពុងព្យាយាមដើម្បីសម្រេចកិច្ចការរបស់ទ្រង់ នៅពេលណា ?

ដើម្បីបញ្ចប់ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២៦–២៧ ឲ្យ ឮៗ ។

- ផ្ដោតទៅលើអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ តើមានមូលហេតុអ្វីខ្លះដែលអ្នកគិតថា ស៊ីឌនី រិកដុន និង យ៉ូសែប ស្ម៊ីធ ត្រូវតែលើកដួងចិត្តឡើង ហើយអរសប្បាយនោះ ?

សូមអញ្ជើញសិស្សឲ្យចែកចាយមូលហេតុដែលពួកគេត្រូវលើកដួងចិត្តគេឡើង ហើយអរសប្បាយនោះ ។ អ្នកអាចនឹងចង់បន្ថែមទីបន្ទាល់របស់អ្នកអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ដើម្បីជួយដល់យើង ក្នុងកិច្ចខិតខំរបស់យើង ដើម្បីជួយក្នុងកិច្ចការរបស់ទ្រង់ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០; ៣០–៣៥ ( មេរៀនទី ៨ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០; ៣០–៣៥ ( មេរៀនទី ៨ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០)

នៅពេលសិស្សបានរៀនអំពីផែនការនៃសេចក្ដីសង្គ្រោះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩, នោះពួកគេបានឃើញថា គ្រប់ព្រះបញ្ញត្តិទាំងអស់របស់ព្រះគឺខាងវិញ្ញាណ ហើយថាព្រះបានប្រទានអំណោយនៃសិទ្ធិជ្រើសរើសដល់យើង ដើម្បីធ្វើការជ្រើសរើស ហើយមានបទពិសោធន៍ជាមួយនឹងលទ្ធផលនៃជម្រើសទាំងនោះ ។ នៅពេលសិស្សបានគិតអំពីរបៀបនៃការធ្លាក់របស់អ័ដាមបាននាំមកនូវការស្លាប់ខាងវិញ្ញាណ នោះពួកគេបានរៀនថា តាមរយៈដង្វាយធួន ព្រះយេស៊ូវគ្រីស្ទផ្ដល់ការអភ័យទោស និងជីវិតអស់កល្បជានិច្ចដល់មនុស្សទាំងអស់ណាដែលអនុវត្តសេចក្ដីជំនឿលើទ្រង់ ហើយប្រែចិត្តពីអំពើបាបរបស់ពួកគេ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០–៣២)

នៅក្នុងមេរៀននេះសិស្សបានអានពីព្រះឱវាទ និង ការសន្យានានាដែលព្រះអម្ចាស់បានប្រទានដល់បុរសប្រាំមួយនាក់ ដែលទ្រង់បានហៅឲ្យប្រកាសដំណឹងល្អ ។ មេរៀននេះបានគូសបញ្ជាក់ថា យើងគួរតែបម្រើព្រះអម្ចាស់ឲ្យអស់ពីព្រលឹងរបស់យើង ហើយទ្រង់នឹងគង់នៅជាមួយនឹងយើង ។ សិស្សក៏បានរៀនផងដែរថា តាមរយៈសេចក្ដីស្មោះត្រង់របស់យើង នោះសមាជិកគ្រួសាររបស់យើង អាចនឹងត្រូវបានប្រទានពរឲ្យជឿ ហើយស្គាល់សេចក្ដីពិត ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣–៣៤)

សិស្សបានសិក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ដល់អ្នកផ្សព្វផ្សាយសាសនាពីរនាក់ អែសរ៉ា ធេយ័រ និង ណូរត្រុត ស្វ៊ីត ។ សិស្សបានឃើញថា ប្រសិនបើយើងបើកមាត់របស់យើងប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹងបំផុសគំនិតដល់យើងនូវអ្វីដែលត្រូវនិយាយ ។ តាមរយៈព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះ អ័រសុន ប្រាត្ត នោះសិស្សបានរៀនថាអស់អ្នកដែលបង្រៀនដំណឹងល្អដោយត្រឹមត្រូវ និង ដោយឧស្សាហ៍ព្យាយាម នោះនឹងធ្វើកិច្ចការដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥)

សិស្សបានអានអំពីការប្រែចិត្តជឿរបស់ ស៊ីឌនី រិកដុន ហើយបានសិក្សាព្រះបន្ទូលរបស់ព្រះចំពោះលោក ។ ពួកគេបានរៀនថា ព្រះអម្ចាស់ជ្រាបដឹងពីពួកយើង ហើយមានកិច្ចការមួយសម្រាប់ពួកយើងម្នាក់ៗឲ្យធ្វើ ហើយថាព្រះត្រាស់ហៅ មនុស្សទន់ខ្សោយឲ្យបំពេញកិច្ចការរបស់ទ្រង់ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណទ្រង់ ។ សិស្សក៏បានឃើញថា នៅពេលយើងរក្សាបទបញ្ញត្តិ ហើយគោរពសេចក្ដីសញ្ញារបស់យើង នោះព្រះអម្ចាស់នឹងជួយយើងសម្រេចកិច្ចការរបស់ទ្រង់ ។

## សេចក្ដីផ្ដើម

មេរៀននេះផ្ដោតជាពិសេសលើព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះ ដាវីឌ និង ពេត្រុស វិតមើរ បន្ទាប់ពីសន្និសីទមួយរបស់សាសនាចក្រនៅក្នុងខែ កញ្ញា ឆ្នាំ ១៨៣០ ។ អំឡុងពេលនៃសន្និសីទនោះ ព្រះអម្ចាស់បានបើកបង្ហាញឲ្យវិវរណៈនានាមកពី ហៃរ៉ាំ ភេច ថាគឺជាការបោកបញ្ឆោត ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០, ព្រះអម្ចាស់ស្ដីបន្ទោសដល់ ដាវីឌ វិតមើរ ចំពោះសេចក្ដីជំនឿរបស់គាត់លើត្បូង ហើយបានហៅពេត្រុត វិតមើរឲ្យអមដំណើរជាមួយ អូលីវើរ ខៅឌើរីទៅបេសកកម្មរបស់លោក ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១–៤

*ដាវីឌ វិតមើរ ត្រូវបានស្ដីបន្ទោសចំពោះការស្ដាប់តាមការបញ្ចុះបញ្ចូលរបស់មនុស្ស*

សូមឲ្យសិស្សពិចារណាដោយស្ងៀមស្ងាត់ចំពោះសំណួរខាងក្រោម ៖

១. យុវជនម្នាក់បានស្ដាប់តន្ត្រី ដែលពុំត្រូវតាមបទដ្ឋានដូចមានចែងនៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។ ទោះជាគាត់ចូលចិត្តស្ដាប់តន្ត្រីនេះក្ដី ក៏គាត់បានចាប់ផ្ដើមដឹងថា សាររបស់ចម្រៀងនោះ បានបណ្ដាលឲ្យគាត់បាត់បង់ព្រះវិញ្ញាណ ហើយឃ្លាតឆ្ងាយពីគ្រួសារ មិត្តភក្ដិ និងសាសនាចក្ររបស់ខ្លួន។

២. បន្ទាប់ពីមានការដើរលេងជាគូជាមួយនឹងយុវជនម្នាក់ជាច្រើនដងមក យុវនារីម្នាក់នោះបានដឹង តាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធថា យុវជននោះបានប៉ុនប៉ងដើម្បីបញ្ចុះបញ្ចូលនាងឲ្យរំលងច្បាប់ព្រហ្មចារីយភាពបន្តិចម្ដងៗ ។

បន្ទាប់មក សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើយើងអាចដឹងដោយរបៀបណាថា នៅពេលណាដែលយើងត្រូវបានបោកបញ្ឆោតដូចជាបុគ្គលទាំងឡាយនៅក្នុងស្ថានភាពទាំងនោះ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ មានសេចក្ដីពិតនានាដែលអាចជួយយើងរៀបចំខ្លួនដើម្បីទទួល និងធ្វើតាមការព្រមានមកពីព្រះវិញ្ញាណ ហើយជួយយើងឲ្យចៀសផុតពីការបោកបញ្ឆោត ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្ដីពិតទាំងនេះ នៅពេលពួកគេសិក្សាកណ្ឌនេះនៅថ្ងៃនេះ ។

ដើម្បីជួយសិស្សឲ្យយល់បរិបទនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ សូមឲ្យពួកគេរំឭកពីអ្វីដែលពួកគេបានរៀនអំពី ដាវីឌ វិតមើរ តាំងតែពីពួកគេបានសិក្សានៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រមក ។ ( គាត់គឺជាសាក្សីម្នាក់នៃសាក្សីបីនាក់អំពីព្រះគម្ពីរមរមន ហើយបានជួយផ្ដល់គ្រឿងបរិក្ខារនានាអំឡុងពេលនៃការបកប្រែព្រះគម្ពីរមរមន ) ។

សូមប្រាប់សិស្សថា បងប្រុសថ្លៃរបស់ដាវីឌ វិតមើរ គឺ ហៃរ៉ាំ ភេច ។ អ្នកអាចសួរសិស្សពីអ្វីដែលពួកគេបានចាំអំពី ហៃរ៉ាំ ភេច មកពីការសិក្សារបស់ពួកគេនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ ។ ( គាត់គឺជាសាក្សីម្នាក់នៃសាក្សីប្រាំបីនាក់អំពីព្រះគម្ពីរមរមន ហើយបានរកឃើញត្បូងមួយគ្រាប់ ដែលតាមរយៈត្បូងនោះ គាត់បានប្រកាសថាគាត់អាចទទួលវិវរណៈបាន ) ។ សូមពន្យល់ថា នៅពេល ហៃរ៉ាំ ភេច ណែនាំត្បូងអ្នកមើលឆុតក្លែងក្លាយរបស់ខ្លួន ហើយបានប្រកាសថាវិវរណៈនានាត្រូវបានទទួលមកពីត្បូងនោះ នោះ អូលីវើរ ខៅឌើរី គ្រួសារ វិតមើរ និង មនុស្សដទៃទៀតនៅតំបន់ ហ្វាយែត បានចាប់ផ្ដើមជឿលើការប្រកាសរបស់ហៃរ៉ាំ ។

- ហេតុអ្វីបានជាដាវីឌ វិតមើរ ត្រូវបានបញ្ចុះបញ្ចូលដោយ ហៃរ៉ាំ ភេច យ៉ាងងាយស្រួលបែបនេះ ?

សូមឲ្យសិស្សស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១–២ រួចឆ្លើយនឹងសំណួរខាងក្រោមនេះ ៖

- តើព្រះអម្ចាស់បានមានព្រះបន្ទូលថា ដាវីឌ វិតមើរបានធ្វើអ្វីខ្លះ ដែលអាចធ្វើឲ្យគាត់ទន់ខ្សោយចំពោះការបោកបញ្ឆោតនោះ ?

- តើព្រះអម្ចាស់បានមានបន្ទូលថាដាវីឌពុំបានធ្វើអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យផ្ដល់យោបល់នូវគោលការណ៍ ដែលយើងអាចរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១–២ ។ ពួកគេអាចផ្ដល់យោបល់មួយចំនួន ឬទាំងអស់ខាងក្រោមនេះ ៖

**ជាជាងភ័យខ្លាចដល់មនុស្ស យើងគួរតែពឹងផ្អែកលើព្រះអម្ចាស់សម្រាប់កម្លាំង។**

**យើងគួរតែដាក់គំនិតរបស់យើងទៅលើរបស់ផងទាំងឡាយនៃព្រះ ច្រើនជាងទៅលើរបស់ផងទាំងឡាយខាងលោកិយ។**

**យើងគួរតែធ្វើតាមព្រះវិញ្ញាណ និងពាក្យទូន្មានរបស់ថ្នាក់ដឹកនាំសាសនាចក្រ ជាជាងត្រូវបានបញ្ចុះបញ្ចូលដោយមនុស្សដែលព្រះអម្ចាស់ពុំបានហៅឲ្យបម្រើ ។**

សូមសួរសំណួរខាងក្រោម ៖

- តើអ្នកគិតថា វាមានន័យដូចម្ដេច ដែលដាក់ឲ្យគំនិតរបស់យើងផ្ដោតទៅលើរបស់ផងទាំងឡាយនៃលោកិយ ច្រើនជាងផ្ដោតទៅលើរបស់ផងទាំងឡាយនៃព្រះអម្ចាស់? តើមានមធ្យោបាយណាខ្លះ ដែលយើងអាចត្រូវបានល្បួងឲ្យធ្វើការណ៍នេះ ?

- តើការផ្ដោតលើរបស់ផងខាងលោកិយច្រើនជាងរបស់ផងនៃព្រះអម្ចាស់នោះ អាចបណ្ដាលឲ្យយើងងាយនឹងត្រូវបានបោកបញ្ឆោតដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន សេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌិង ស្ម៊ីធឲ្យឮៗ ៖



« វាហាក់ដូចជាចម្លែកបន្ដិចថា មិនយូរប៉ុន្មានបន្ទាប់ពីការបើកសម្ដែងដ៏អស្ចារ្យដែល [ ដាវីឌ វិតមើរ ] បានទទួល និង សាក្សីនៃការចាក់ស្រោចនៃព្រះវិញ្ញាណនៅពេលក្រោយៗទៀតនោះ គាត់បានភ្លេច ប៉ុន្ដែធម្មជាតិនៃមនុស្សគឺថាពួកយើងគ្រប់គ្នាត្រូវតែ រំឭកចាំឲ្យខ្ជាប់ខ្លួនអំពីទំនួលខុសត្រូវរបស់យើង ឬ យើងទំនងជាភ្លាត់ចូលទៅក្នុងភាពព្រងើយកន្ដើយមួយចំនួននោះ ។ តម្រូវការនៃការអធិស្ឋានយ៉ាងខ្ជាប់ខ្លួន និង ការផ្ចង់គំនិតរបស់យើង លើរបស់ផងនៃនគរព្រះ និង ការផ្ដោតអារម្មណ៍ដោយស្មោះសរចំពោះកាតព្វកិច្ច គឺភាគច្រើនវាអាចមើលឃើញជាមួយនឹងយើង ក្រែងលោយើងបានប្រព្រឹត្ដខុស ។ ព្រះអម្ចាស់បានព្រមានប្រជារាស្ត្រទ្រង់ជាញឹកញាប់ជំទាស់នឹងភាពកំសោយនៃសាច់ឈាមនោះ ! » (*Church History and Modern Revelation*, ភាគ ២. [ ឆ្នាំ ១៩៥៣ ] ១:១៤៦ ) ។

- យោងតាមប្រធាន ស្ម៊ីធ តើយើងត្រូវតែធ្វើអ្វីដើម្បីប្រាកដថា យើងនឹងមិនភ្លេចទំនួលខុសត្រូវខាងវិញ្ញាណរបស់យើងដូចជា ដាវីឌ វិតមើរ បានធ្វើនោះ ?

អ្នកអាចប្រើឱកាសនេះដើម្បី រំឭកសិស្សអំពី ភាពចាំបាច់នៃការសិក្សាព្រះគម្ពីរប្រចាំថ្ងៃរបស់ពួកគេ—មិនមែនគ្រាន់តែបំពេញតាមការចាត់ឲ្យអានប៉ុណ្ណោះទេ ប៉ុន្ដែជួយពួកគេឲ្យរៀនដំណឹងល្អ បង្កើនទីបន្ទាល់នៃដំណឹងល្អ ហើយស្ដាប់សំឡេងរបស់ព្រះអម្ចាស់ ។ អ្នកក៏អាចសូមឲ្យសិស្សចែកចាយពី អ្វីដែលបានជួយពួកគេឲ្យសិក្សាព្រះគម្ពីរតាមរបៀបមួយដ៏មានអត្ថន័យផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៣–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការណែនាំរបស់ព្រះអម្ចាស់ដល់ ដាវីឌ វិតមើរ ។

- បន្ទាប់ពីត្រូវបានបោកបញ្ឆោតដោយហៃរ៉ាំ ភេច មក តើព្រឹត្តិការណ៍នេះអាចជួយដាវីត វិតមើរ ដោយរបៀបណា ឲ្យពិចារណាពីរឿង ៗនានាដែលព្រះអម្ចាស់បានបើកសម្ដែងដល់គាត់នោះ ?

សូមលើកទឹកចិត្តសិស្សឲ្យពិចារណា ប្រសិនបើមានស្ថានភាពនានានៅក្នុងជីវិតរបស់ពួកគេដែលពួកគេអាចផ្ដែកលើ ឬ ផ្ដោតចិត្តច្រើនលើ « របស់ផងទាំងឡាយលើផែនដី » ជាជាងរបស់ផងទាំងឡាយនៃព្រះ និង របៀបដែលការធ្វើបែបនោះអាចធ្វើឲ្យពួកគេងាយនឹងត្រូវបានបោកបញ្ឆោត ។ សូមអញ្ជើញពួកគេឲ្យសម្រេចចិត្តពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីពឹងផ្អែកលើព្រះអម្ចាស់ឲ្យកាន់តែច្រើននៅក្នុងគ្រប់ស្ថានភាពទាំងនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៥–៨

*ពេត្រុស វិតមើរ ត្រូវបានហៅឲ្យទៅជាមួយ អូលីវើរ ខៅឌើរី ក្នុងបេសកកម្មទៅកាន់ពួកសាសន៍លេមិន*

សូមបង្ហាញវត្ថុដែលធ្ងន់មួយ ឬកាបូបមួយដែលដាក់ឥវ៉ាន់ធ្ងន់ៗ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យមកមុខក្ដារខៀន ហើយលើកវត្ថុនោះចេញមកដាក់ខាងមុខខ្លួន ។ ខណៈដែលសិស្សនោះ កំពុងលើកវត្ថុនោះ សូមអញ្ជើញសិស្សផ្សេងទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៥ ដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីដែលព្រះអម្ចាស់បានហៅឲ្យពេត្រុស វិតមើរ ឲ្យធ្វើ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

- តើនរណាជាអ្នកដឹកនាំអធិបតីលើបេសកកម្មរបស់ពេត្រុស វិតមើរទៅកាន់សាសន៍លេមិននោះ ?

សូមអញ្ជើញសិស្សទីពីរ ឲ្យជួយសិស្សដែលកំពុងកាន់វត្ថុធ្ងន់នោះ ។ សូមឲ្យសិស្សទីមួយពិពណ៌នាអំពីភាពខុសគ្នា ដែលគាត់បានទទួលអារម្មណ៍ពីការមានការគាំទ្រពីមនុស្សម្នាក់ទៀត ។ សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:៥–៧ កត់ត្រាអំពីព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះពេត្រុស វិតមើរ អំពីរបៀបដែលពេត្រុសគាំទ្រដល់អូលីវើរ ខៅឌើរីនៅក្នុងតំណែងនៃថ្នាក់ដឹកនាំរបស់លោក ។ សូមឲ្យសិស្សស្រាវជ្រាវខគម្ពីរទាំងនេះ ហើយស្វែងរកឃ្លាជាក់លាក់នានាដែលពិពណ៌នាអំពីរបៀបដែលពេត្រុសគាំទ្រដល់អូលីវើរ ។

- តើព្រះអម្ចាស់បានប្រើឃ្លាអ្វីខ្លះ ដើម្បីបង្រៀនពេត្រុសពីរបៀបដែលលោកគួរតែគាំទ្រដល់អូលីវើរ ? ( សូមមើល ខ ៦; ពេត្រុសត្រូវរួមសុខ រួមទុក្ខជាមួយនឹងអូលីវើរ អធិស្ឋានឲ្យអូលីវើរ និង ទទួលស្គាល់សិទ្ធិអំណាចរបស់អូលីវើរ ) ។
- តើអ្នកគិតថា « នៅក្នុងគ្រប់សេចក្ដីទុក្ខវេទនារបស់គាត់ » មានន័យដូចម្ដេច ( គ. និង ស. ៣០:៦ ? )
- តើមេរៀនអ្វីដែលយើងអាចរៀនពីព្រះឱវាទរបស់ព្រះអម្ចាស់ ចំពោះពេត្រុស ដែលអនុវត្តចំពោះយើងផងដែរនោះ ?

សេចក្ដីពិតមួយដែលសិស្សអាចបង្ហាញនោះគឺថា **យើងត្រូវគាំទ្រ ហើយទ្រទ្រង់ អ្នកទាំងឡាយណា ដែលព្រះអម្ចាស់បានហៅឲ្យដឹកនាំកិច្ចការរបស់ទ្រង់ ។** សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។

សូមឲ្យសិស្សពន្យល់ ពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់ខ្លួន ប្រហែលនៅក្នុងការគាំទ្រអ្នកដឹកនាំនៅក្នុងវួដ ឬ សាខារបស់ខ្លួន ។ សូមអញ្ជើញឲ្យសិស្សចែកចាយទីបន្ទាល់របស់ខ្លួនអំពីពរជ័យនានា ដែលបានទទួលពីការគាំទ្រដល់អស់អ្នកដែលព្រះអម្ចាស់បានហៅបម្រើ ។ សូមលើកទឹកចិត្តពួកគេឲ្យបន្តរស់នៅតាមគោលការណ៍នេះ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៤០)

សូមសួរសិស្ស ប្រសិនបើពួកគេធ្លាប់ត្រូវបានសុំឲ្យធ្វើតាមព្រះបញ្ញត្តិមួយ ប៉ុន្តែពួកគេពុំយល់ពីមូលហេតុនោះទាំងស្រុងឡើយ ។ តើវាយ៉ាងម៉េចដែរ ប្រសិនបើអ្នកត្រូវបានសន្យានូវពរជ័យនានា ផ្ដោតលើការគោរពប្រតិបត្តិរបស់អ្នក ប៉ុន្តែក្រោយមកអ្នកពុំបានរស់នៅតាមព្រះបញ្ញត្តិនោះទៅវិញ ? នៅក្នុងមេរៀនក្រោយ សិស្សនឹងរៀនអំពីសមាជិកសាសនាចក្រ ដែលបានឃើញថាពួកគេនៅក្នុងស្ថានភាពនេះ និង អ្វីដែលព្រះអម្ចាស់បានបង្រៀនពួកគេ ។

មេរៀនទី ៤១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៧

### បុព្វកថា

នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៨៣០ រយៈពេលពីរថ្ងៃពីមុន អែតវឺត ប៉ាទ្រិច បានទទួលបុណ្យជ្រមុជទឹក នោះ ព្រះអម្ចាស់បានប្រទានដល់គាត់នូវវិវរណៈមួយ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ នៅក្នុងវិវរណៈនេះ ដែលឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៣៦ ព្រះអម្ចាស់បានអភ័យទោសដល់ អែតវឺត ប៉ាទ្រិច ពីអំពើបាបរបស់គាត់ ហើយបានហៅគាត់ឲ្យផ្សាយដំណឹងល្អ ។ ព្រះអម្ចាស់ក៏បានចេញបទបញ្ញត្តិមួយសម្រាប់អ្នកកាន់ បព្វជិតភាពទាំងអស់ឲ្យផ្សាយដំណឹងល្អផងដែរ ។ មិនយូរប៉ុន្មាន បន្ទាប់ពីទទួលបានវិវរណៈនេះ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៣៧ដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធចាកចេញពី រដ្ឋនូវ យ៉ោក ហើយទៅប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:១–៣

*ព្រះអម្ចាស់បានអត់ទោសឲ្យ អែតវឺត ប៉ាទ្រិច ពីអំពើបាបរបស់គាត់ ហើយហៅគាត់ឲ្យផ្សាយដំណឹងល្អ*

សូមនាំយកវ៉ាលី ( ឬកាបូបស្ពាយ ) មួយមកថ្នាក់ ដែលមាននូវសម្ភារ ដែលអ្នកផ្សព្វផ្សាយសាសនាអាចនឹងត្រូវការនៅពេលកំពុងបម្រើបេសកកម្មពេញម៉ោងមួយ ។ ឧទាហរណ៍ អ្នកអាចដាក់ព្រះគម្ពីរ អាវ–ស ក្រវ៉ាត់ក សំលៀកបំពាក់ ស្បែកជើង និងសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង*មួយក្បាល ។ សូមបង្ហាញដល់សិស្សនូវវ៉ាលីដែលបិទជិតមួយ ហើយអញ្ជើញឲ្យពួកគេនឹកគិតថា វាបានដាក់អ្វីខ្លះសម្រាប់អ្នកផ្សព្វផ្សាយ សាសនា ដែលកំពុងត្រៀមខ្លួនទៅបម្រើបេសកកម្មពេញម៉ោង ។ សូមសួរថាតើពួកគេរំពឹងទុកថាមានអ្វីខ្លះនៅក្នុងវ៉ាលីនេះ ។ បន្ទាប់មក បើកវ៉ាលី ហើយបង្ហាញវត្ថុដែលមានក្នុងនោះ ។ ( ឬ អ្នកអាចអញ្ជើញសិស្សឲ្យធ្វើការជាគូ ដើម្បីបង្កើតជាបញ្ជីមួយ ឬគូររូបរាងវត្ថុទាំងឡាយ ដែលអ្នកផ្សព្វផ្សាយសាសនាអាចនឹងត្រូវការក្នុងបេសកកម្មរបស់ពួកគេ ) ។

សូមពន្យល់ថា មានអ្វីៗផ្សេងទៀតជាច្រើន ដែលពួកអ្នក ផ្សព្វផ្សាយសាសនាត្រូវការ ដែលពុំចាំបាច់ត្រូវវេចខ្ចប់ក្នុងវ៉ាលី (ឬកាបូបស្ពាយ ) ។ ព្រះអម្ចាស់បានប្រាប់នូវរឿងមួយចំនួននេះ នៅក្នុងវិវរណៈមួយ ដែលបានថ្លែងទៅកាន់ អែតវឺត ប៉ាទ្រិច ។ វិវរណៈនោះ ឥឡូវគឺសរសេរនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៣៦ ។ សូមអញ្ជើញសិស្សឲ្យរកមើលនូវអ្វីដែលអ្នកផ្សព្វផ្សាយសាសនាម្នាក់ត្រូវការ ពីមុនពេលគាត់ត្រូវបានរៀបចំខ្លួនដើម្បីបម្រើបេសកកម្ម ខណៈពេលដែលពួកគេសិក្សាអំពីវិវរណៈនេះ ។ ( នៅពេលសិស្សប្រាប់អំពីសេចក្ដីពិតទាំងឡាយ អំឡុងពេលរៀនមេរៀននេះ នោះអ្នកអាចនឹងចង់សរសេរសេចក្ដីពិតទាំងនោះនៅលើក្រដាសមួយសន្លឹក ។ បន្ទាប់មកបិទ ឬដោតជាមួយម្ជុលខ្ទាស់ក្រដាសនោះទៅនឹងផ្នែកខាងក្រៅនៃវ៉ាលី ឬកាបូបស្ពាយ ដើម្បីឲ្យសិស្សមើលឃើញ ។ អ្នកក៏អាចរៀបរាប់វាដោយសាមញ្ញនៅលើក្ដារខៀនផងដែរ ) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឲ្យឮៗនូវព័ត៌មាននៃប្រវត្តិ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦ ដូចខាងក្រោម ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវអ្វីដែលបានជួយដល់ អែតវឺត ប៉ាទ្រិច ធ្វើការសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។

អំឡុងពីរបីសប្ដាហ៍នៃការមកដល់របស់អែលឌើរ អូលីវើរ ខៅឌើរី និងដៃគូរបស់គាត់ នៅប៉ែកឮសាននៃរដ្ឋអូហៃអូ នោះមានមនុស្សជាច្រើនបានទទួលបុណ្យជ្រមុជទឹកចូលក្នុងសាសនាចក្រដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ទោះបីជាភរិយារបស់ អែតវឺត ប៉ាទ្រិច លីឌា ស្ថិតនៅក្នុងចំណោមអ្នកទាំងឡាយដែលបានផ្លាស់ប្រែចិត្តជឿ និងទទួលបុណ្យជ្រមុជទឹកដោយពួកអ្នកផ្សព្វផ្សាយសាសនាក្ដី ក៏អែតវឺត នៅពុំទាន់ជឿពេញលេញនោះដែរ ។ គាត់មានបំណងដើម្បីទៅជួបព្យាការី យ៉ូសែប ស្ម៊ីធ មុនពេលគាត់សម្រេចចិត្ត ។ គាត់ និងស៊ីឌនី រិកដុន បានទៅដល់ វ៉ែតធើរលូ រដ្ឋ នូវយ៉ោក ចំពេលដែល យ៉ូសែប ស្ម៊ីធ កំពុងធ្វើទេសនកថាមួយ ។ នៅពេលព្យាការី បានបញ្ចប់ការនិយាយហើយ នោះអែតវឺត បានក្រោកឈរឡើងនិយាយ ។ គាត់បានរៀបរាប់ថា នៅតាមផ្លូវទៅកាន់ វ៉ែតធើរលូ គាត់បាននិយាយជាមួយនឹងអ្នកជិតខាង ដែលនៅជិតចម្កាគ្រួសារ ស្ម៊ីធ នៅ ម៉ានឆែសស្ទើរ អំពីចរិកលក្ខណៈរបស់គ្រួសារ ស្ម៊ីធ ។ ដោយបានស្ដាប់ស្គាល់នឹងអ្វីដែលគាត់បានដឹង នោះអែតវឺត បានសួរថា តើយ៉ូសែប អាចនឹងជ្រមុជទឹកឲ្យគាត់បានឬទេ ។ ( សូមមើល *Documents, Volume ១: ខែ កក្កដា ឆ្នាំ ១៨២៨–ខែ មិថុនា ឆ្នាំ ១៨៣១*, វ៉ុលទី ១ of the Documents series of *The Joseph Smith Papers* [ឆ្នាំ ២០១៣], ទំព័រ ១៩៧, ១៩៩, ២២៤ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:១ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់ បានប្រាប់ដល់ អែតវឺត ប៉ាទ្រិច បន្ទាប់ពីគាត់បានទទួលបុណ្យជ្រមុជទឹកហើយ ។

- តើពរជ័យអ្វីខ្លះ ដែលអែតវឺត ប៉ាទ្រិច បានទទួល ដែលជាលទ្ធផលបានមកពីពិធីបុណ្យជ្រមុជទឹករបស់គាត់នោះ ? ( ព្រះអម្ចាស់អត់ទោសអំពើបាបរបស់គាត់ ) ។
- តើទំនួលខុសត្រូវអ្វីខ្លះ ដែល អែតវឺត មាន បន្ទាប់ពីគាត់បានទទួលបុណ្យជ្រមុជទឹករួច ?
- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់សម្រាប់អ្នកទាំងឡាយដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ត្រូវប្រែចិត្ត ហើយត្រូវបានអត់ទោសអំពើបាបរបស់ពួកគេដូច្នេះ ?

ដើម្បីជួយសិស្សយល់ពីមូលហេតុដែលវាសំខាន់ចំពោះអ្នកដែលត្រៀមធ្វើជាអ្នកផ្សព្វផ្សាយសាសនា ត្រូវប្រែចិត្តពីអំពើបាបរបស់ពួកគេនោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយ អែលឌើរ ជែហ្វ្រី អរ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ( អ្នកអាចនឹងចង់ចង្អុលបង្ហាញថា នៅពេលអែលឌើរ ហូឡិន ប្រើឃ្លាថា « លេងឲ្យខាងមារសត្រូវ » ហើយ « ត្រូវខាងព្រះអង្គសង្គ្រោះ » នោះគាត់កំពុងប្រៀបប្រដូចទៅនឹងការប្រកួតរវាងសេចក្ដីល្អ និងសេចក្ដីអាក្រក់នៅក្នុងការប្រកួតប្រជែងអត្តពលកម្មមួយ ) ។ សូមពិចារណាធ្វើការរៀបចំច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍នេះសម្រាប់សិស្សម្នាក់ៗ ។



« នៅក្នុងការប្រកួតរវាងសេចក្ដីល្អ និងសេចក្ដីអាក្រក់នេះ អ្នកពុំអាចលេងឲ្យខាងមារសត្រូវ នៅពេលណាមានការល្បួងកើតឡើង រួចមករំពឹងទុកថា ខ្លួនបែរត្រូវខាងព្រះអង្គសង្គ្រោះវិញ នៅឯព្រះវិហារបរិសុទ្ធ និងនៅពេលចេញបេសកកម្ម ដែលហាក់ដូចជាគ្មានអ្វីបានកើតឡើងបាននោះទេ ។. . . ព្រះនឹងពុំត្រូវចំអកឡើយ ។

« . . . ព្រះអម្ចាស់ បានគូសបន្ទាត់ភាពសក្តិសមសម្រាប់អ្នកទាំងឡាយ ដែលត្រូវបានហៅឲ្យធ្វើការជាមួយទ្រង់ក្នុងកិច្ចការរបស់ទ្រង់ ។ គ្មានអ្នកផ្សព្វផ្សាយសាសនាណា អាចមិនប្រែចិត្តពីអំពើរំលងខាងផ្លូវភេទ ឬភាសាអាសគ្រាម ឬបណ្ដោយខ្លួនតាមភាពអាសគ្រាម ហើយមករំពឹងឲ្យអ្នកដទៃប្រែចិត្តពីរឿងទាំងអស់នេះនោះទេ !. . . ព្រះវិញ្ញាណនឹងពុំគង់នៅជាមួយអ្នកឡើយ ហើយពាក្យទាំងឡាយនឹងត្រូវស្លាក់នៅក្នុងបំពង់កអ្នក ពេលអ្នកថ្លែងវាចេញមក ។ អ្នកពុំអាចធ្វើដំណើរតាមផ្លូវដែល លីហៃ បានហៅថា ‹ ផ្លូវហាមឃាត់ › នោះឡើយ នីហ្វៃទី ១ ៨:២៨ហើយរំពឹងថាដឹកនាំអ្នកដទៃឲ្យដើរលើ ‹ ផ្លូវត្រង់ និងចង្អៀត › នោះឡើយ នីហ្វៃទី ២ ៣១:១៨ វាពុំអាចធ្វើទៅរួចទេ » ( We Are All Enlisted » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១,ទំព័រ ៤៥ ) ។

ដើម្បីជួយសិស្សឲ្យយល់អំពីអ្វីដែលពួកគេអាចធ្វើនៅពេលឥឡូវនេះ ដើម្បីបានស្អាតស្អំចំពោះការបម្រើផ្សព្វផ្សាយសាសនា សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការអញ្ជើញឲ្យប្រែចិត្តដូចខាងក្រោម មកពីអែលឌើរ ហូឡិន ផងដែរថា ៖



« មិនថាអ្នកជានរណា ឬអ្នកបានធ្វើអ្វីនោះទេ អ្នកអាចត្រូវបានអភ័យទោសឲ្យ ។ អ្នករាល់គ្នាគ្រប់រូប . . . អាចទុកចោលអំពើរំលងសព្វបែបយ៉ាង ដែលអ្នកអាចនឹងមានបញ្ហា ។ វាគឺជាអព្ភូតហេតុនៃការអភ័យទោស វាគឺជាអព្ភូតហេតុនៃដង្វាយធួនរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ប៉ុន្តែអ្នកពុំអាចធ្វើវាបានដោយគ្មានការតាំងចិត្តដ៏សកម្មមួយចំពោះដំណឹងល្អនោះទេ ហើយអ្នកពុំអាចធ្វើវាបានដោយគ្មានការប្រែចិត្ត ពេលដែលវាចាំបាច់តម្រូវឲ្យមាននោះឡើយ ។ ខ្ញុំសុំឲ្យអ្នក. . . សកម្ម ហើយស្អាតស្អំ ។ បើវាតម្រូវឲ្យខ្ញុំធ្វើដូច្នោះ នោះខ្ញុំសំណូមពរដល់អ្នកឲ្យ *ទទួលបាន*ការសកម្ម ហើយ *ទទួលបាន* ភាពស្អាតស្អំ » ( We Are All Enlisted » ទំព័រ៤៥ ) ។

សូមពន្យល់ថា ទោះជា អែតវឺត ប៉ាទ្រិច បានទទួលបុណ្យជ្រមុជទឹកពីមុនទទួលវិវរណៈនេះក្ដី តែគាត់ពុំទាន់ទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធនៅឡើយទេ ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:២–៣ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់ប្រាប់ ដល់អែតវឺត អំពីអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- ផ្អែកទៅលើអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់អែតវឺត ប៉ាទ្រិច ហេតុអ្វីក៏អ្នកផ្សព្វផ្សាយសាសនាត្រូវការព្រះវិញ្ញាណបរិសុទ្ធជាដៃគូរបស់ពួកគេដូច្នេះ ?
- ស្របតាម ខ ២ តើព្រះវិញ្ញាណបរិសុទ្ធនឹងបង្រៀន អែតវឺត ប៉ាទ្រិច អ្វីខ្លះ ? តើអ្នកគិតថាវាមានន័យយ៉ាងដូចម្ដេចដើម្បីរៀន « ការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្តនៃនគរ » ? ( ដើម្បីជួយសិស្សឆ្លើយសំណួរនេះ សូមឲ្យពួកគេអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៦១) ។

អ្នកអាចអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍នានា ដែលពួកគេមាន នៅពេលព្រះវិញ្ញាណបរិសុទ្ធ បានបង្រៀនពួកគេនូវការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្តនៃនគរ ។ ( សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ដែលពុំគួរចែកចាយ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៤–៨

*ព្រះអម្ចាស់ចេញបទបញ្ញត្តិមួយ ស្ដីអំពីអ្នកទាំងឡាយដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៤–៥, ៧ ឲ្យឮៗ ។ មុនពេលសិស្សអាន សូមចង្អុលបង្ហាញថា នៅក្នុងខទាំងនេះ ព្រះអម្ចាស់ កំពុងមានបន្ទូលទៅកាន់ « ពួកអែលឌើរនៃសាសនាចក្រ [ របស់ទ្រង់ ] » (គ. និង ស. ៣៦:៧) ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវទំនួលខុសត្រូវមួយ ដែលព្រះអម្ចាស់បានផ្ដល់ទៅឲ្យពួកអ្នកកាន់បព្វជិតភាព ។

- តើទំនួលខុសត្រូវអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រគល់ទៅឲ្យអ្នកកាន់បព្វជិតភាព ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **អ្នកកាន់បព្វជិតភាព ត្រូវបានហៅឲ្យផ្សាយដំណឹងល្អ** ) ។

ដើម្បីជួយសិស្សយល់អំពីសារៈសំខាន់នៃសេចក្ដីពិតនេះ និងរបៀបដែលវាអនុវត្តនៅក្នុងជីវិតរបស់យើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានអំពីសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ថូម៉ាស អេស ម៉នសុន ។



« ខ្ញុំរំឭកឡើងវិញនូវអ្វីដែលពួកព្យាការីបានបង្រៀនជាយូរលង់មកហើយ—ថារាល់យុវជនដែលមានលក្ខណៈសម្បត្តិសក្ដិសម និងមានសមត្ថភាពគ្រប់រូប គួរតែត្រៀមខ្លួនបម្រើបេសកកម្ម ។ កិច្ចការផ្សព្វផ្សាយសាសនា គឺជាកាតព្វកិច្ចបព្វជិតភាពមួយ–ជាកាតព្វកិច្ចមួយ ដែលព្រះអម្ចាស់រំពឹងពីយើង ដែលត្រូវបានប្រទានឲ្យយ៉ាងច្រើននោះ » (As We Meet Together Again, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ៥–៦ ) ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៥ តើអ្នកកាន់បព្វជិតភាពចាំបាច់ត្រូវធ្វើអ្វីខ្លះ មុនពេលពួកគេត្រូវបានតែងតាំង ហើយបញ្ជូនទៅផ្សាយដំណឹងល្អនោះ ?
- តើយុវជនម្នាក់អាចបង្ហាញដល់ព្រះអម្ចាស់ថា គាត់ឱបក្រសោបយកបទបញ្ញត្តិដើម្បីផ្សាយដំណឹងល្អដោយរបៀបណា ?
- តើនរណាដែលអ្នកស្គាល់ ថាបានឱបក្រសោបយកបទបញ្ញត្តិដើម្បីផ្សាយដំណឹងល្អ ? តើគំរូរបស់បុគ្គលនេះ មានឥទ្ធិពលមកលើអ្នកយ៉ាងណាខ្លះ ?

អ្នកអាចនឹងចង់ពន្យល់ថា ទោះជាការបម្រើអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង គឺជាកាតព្វកិច្ចបព្វជិតភាពក្ដី ក៏យុវនារីអាចបម្រើបានផងដែរ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ៖



« ពាក្យសម្ដីទៅកាន់យុវនារីទាំងឡាយ ខណៈដែលអ្នកពុំមាននូវទំនួលខុសត្រូវ បព្វជិតភាព ដូចយុវជនដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងក្ដី ក៏អ្នកអាចធ្វើការចូលរួមចំណែកដ៏មានតម្លៃជាពួកអ្នកផ្សព្វ ផ្សាយសាសនាបានផងដែរ ហើយយើងស្វាគមន៍ចំពោះការបម្រើរបស់អ្នក » ( As We Meet Together Again »៦ ) ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៦ ដោយស្ងាត់ស្ងៀម រកមើលសារលិខិតជាមូលដ្ឋាន ដែលព្រះអម្ចាស់បញ្ជាដល់ពួកអ្នកផ្សព្វផ្សាយសាសនារបស់ទ្រង់ឲ្យបង្រៀន ។ ដើម្បីជួយសិស្សយល់ឃ្លាថា « អាវដែលត្រូវស្មោកគ្រោកដោយសាច់ឈាមផង » នោះសូមពន្យល់ថា នៅក្នុងសាសន៍អ៊ីស្រាអែលបុរាណ សំលៀកបំពាក់ដែលមានមេរោគឆ្លង គឺត្រូវដុតចោល ដើម្បីការពារកុំឲ្យជំងឺឆ្លងរាតត្បាត ។ នៅក្នុងខនេះ ព្រះអម្ចាស់ ប្រៀបធៀបជំងឺទៅនឹងអំពើបាប ដូច្នេះហើយទ្រង់បានបញ្ជាដល់យើងឲ្យចៀសវាងនូវអ្វីៗទាំងអស់ដែលទាក់ទងនឹងអំពើបាប ។ ( សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *Doctrinal New Testament Commentary,* វ៉ុលទី ៣ [ឆ្នាំ ១៩៦៥–៧៣], ៣:៤២៨ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៧ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលលក្ខណៈដែលអ្នកកាន់បព្វជិតភាព គួរឱបក្រសោបនៅក្នុងការហៅរបស់ពួកគេ ។

- តើអ្នកកាន់បព្វជិតភាពម្នាក់អាច « ឱបក្រសោប [ ការហៅបម្រើរបស់គាត់ ] ដោយមានចិត្តព្រមព្រៀង » យ៉ាងដូចម្ដេច ? ( ចម្លើយអាចរួមមានទាំងការចាប់ផ្ដើមតាំងចិត្តចំពោះការហៅបម្រើរបស់គាត់ ហើយបម្រើដោយស្មោះ និងដោយសេចក្ដីសុចរិត ) ។

បើអ្នកបានបម្រើបេសកកម្មពេញម៉ោងមួយ សូមពិចារណាធ្វើការចែកចាយបទពិសោធន៍របស់អ្នកអំពីការឱបក្រសោបយកការហៅឲ្យផ្សាយដំណឹងល្អ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៧

*ព្រះអម្ចាស់បញ្ជាសាសនាចក្ររបស់ទ្រង់ឲ្យប្រមូលគ្នីគ្នាទៅឯរដ្ឋ អូហៃអូ*

សូមពន្យល់ថា ខណៈដែលស៊ីឌនី រិកដុន និង អែតវឺត ប៉ាទ្រិច កំពុងសង្កេតមើលសាសនាចក្រនៅរដ្ឋអូហៃអូ នោះការបៀតបៀនដល់ពួកបរិសុទ្ធនៅក្នុង រដ្ឋនូវយ៉ោក បានកើនឡើង ។ ក្នុងករណីមួយចំនួន ការគំរាមគំហែងទាំងឡាយបានកើតឡើងដល់ជីវិតរបស់អ្នកដឹកនាំសាសនាចក្រ ហើយខ្មាំងសត្រូវរបស់ពួកគេ បានប្រជុំនៅក្នុងកន្លែងសម្ងាត់ដើម្បីដាក់ផែនការការបំផ្លាញរបស់ពួកគេ ( សូមមើល គ. និង ស. ៣៨:១៣, ២៨–២៩ ) ។ នៅជិតចុងខែធ្នូ ឆ្នាំ ១៨៣០ ប៉ុន្មានសប្ដាហ៍បន្ទាប់ពីស៊ីឌនី រិកដុន និង អែតវឺត ប៉ាទ្រិច បានមកដល់រដ្ឋ នូវ យ៉ោក នោះយ៉ូសែប ស៊្មីធ បានទទួលវិវរណៈមួយ ដែលព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធ ឲ្យគេចចេញពីខ្មាំងសត្រូវរបស់ពួកគេ ហើយផ្លាស់ទៅរដ្ឋ អូហៃអូ ។

សូមអញ្ជើញសិស្សបីនាក់ឲ្យឆ្លាស់វេណគ្នាអានឲ្យឮៗដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៧:២–៤ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលនូវការរៀបចំ ដែលព្រះអម្ចាស់ចង់ឲ្យ យ៉ូសែប ធ្វើមុនពេលលោកទៅកាន់រដ្ឋអូហៃអូ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- ហេតុអ្វី ព្រះអម្ចាស់ បញ្ជាឲ្យ យ៉ូសែប ស៊្មីធ ទៅរកពួកបរិសុទ្ធនៅ ខូលស្វិល ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរទាំងនេះ អំពីការអធិស្ឋាន ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងអធិស្ឋានដោយសេចក្ដីជំនឿ នោះព្រះអម្ចាស់នឹងឆ្លើយតបរាល់ការអធិស្ឋានរបស់យើង ។ ព្រះអម្ចាស់ ជាញឹកញាប់ប្រើអ្នកដទៃឲ្យឆ្លើយតបនឹងការអធិស្ឋានរបស់យើង** ) ។
- តើនរណាម្នាក់បានឆ្លើយចំពោះការអធិស្ឋានរបស់អ្នកនៅពេលណា ?

ពេលបានបំផុសគំនិតដោយព្រះវិញ្ញាណ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀននេះ ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមអ្វីដែលពួកគេបានទទួលអារម្មណ៍ ពេលពួកគេបានសិក្សាវិវរណៈទាំងនេះ ។

មេរៀនទី ៤២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១–១៦

## បុព្វកថា

នៅក្នុងខែ ធ្នូ ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានបើកសម្ដែងដល់ព្យាការី យ៉ូសែប ស៊្មីធ នូវបទបញ្ញត្តិមួយ ដើម្បីឲ្យសាសនាចក្រមកប្រមូលផ្ដុំគ្នាទៅឯរដ្ឋអូហៃអូ ( សូមមើល គ. និង ស. ៣៧ ) ។ នៅក្នុងឆ្នាំ ១៨៣១ ព្រះអម្ចាស់ បានប្រទានវិវរណៈ ដែលឥឡូវនេះ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ដែលបានពន្យល់អំពីមូលហេតុមួយចំនួនថា ហេតុអ្វីពួកបរិសុទ្ធគួរប្រមូលផ្ដុំគ្នាទៅរដ្ឋអូហៃអូ ។ ទ្រង់ក៏បានប្រទានបញ្ញត្តិដើម្បីដឹកនាំពួកគេនៅក្នុងការប្រមូលផ្ដុំនោះផងដែរ ។ មេរៀននេះ មានគម្របដណ្ដប់ខគម្ពីរចំនួន ១៦ ខដំបូងនៃកណ្ឌទី ៣៨ ។ នៅក្នុងវិវរណៈនេះ ព្រះយេស៊ូវគ្រីស្ទ បានប្រាប់ដល់សមាជិកនៃសាសនាចក្រថា ទ្រង់ស្ថិតនៅក្នុងចំណោមពួកគេ ។ ទ្រង់ក៏បានពិពណ៌នាផងដែរថានរណានឹងអត់ទ្រាំនៅក្នុងការយាងមកជាលើកទីពីររបស់ទ្រង់ ទ្រង់បានព្រមានដល់ពួកបរិសុទ្ធអំពីគ្រោះថ្នាក់ និងប្រទាននូវការលើកទឹកចិត្តដល់ពួកបរិសុទ្ធ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១–៧

*ព្រះយេស៊ូវគ្រីស្ទ ប្រាប់ដល់សមាជិកនៃសាសនាចក្ររបស់ទ្រង់ថា ទ្រង់គឺស្ថិតនៅក្នុងចំណោមពួកគេ ។*

សូមអញ្ជើញសិស្សឲ្យសរសេរក្នុងសៀវភៅកំណត់ត្រាក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ នូវបទបញ្ញត្តិមួយចំនួន ដែលពួកគេមានអារម្មណ៍ថា ងាយស្រួលដើម្បីពួកគេគោរពតាម ។ បន្ទាប់មកអញ្ជើញ ពួកគេឲ្យពិចារណាថា បទបញ្ញត្តិមួយណា ដែលលំបាកសម្រាប់ពួកគេក្នុងការគោរពតាម ហើយហេតុអ្វី ។ ( សិស្សអាចនឹងសរសេរនូវគំនិតទាំងនេះទុកផងដែរ បើពួកគេមានអារម្មណ៍ថាល្អក្នុងការធ្វើដូច្នោះ ) ។

- តើហេតុអ្វីបានជាបទបញ្ញត្តិមួយចំនួនពិបាកសម្រាប់យើងគោរពតាម ?
- តើចំណុចអ្វីខ្លះដែលលើកទឹកចិត្តដល់អ្នកឲ្យរក្សាបទបញ្ញត្តិទាំងឡាយ ទោះបីលំបាកសម្រាប់អ្នកគោរពតាមក៏ដោយ ?

សូមរំឭកសិស្សថា នៅខែធ្នូ ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធនៅរដ្ឋ នូវ យ៉ោក ឲ្យប្រមូលផ្ដុំគ្នាមកឯរដ្ឋ អូហៃអូ ( សូមមើល គ. និង ស. ៣៧) ។ សម្រាប់សមាជិកសាសនាចក្រមួយចំនួននេះ បទបញ្ញត្តិមួយនេះ គឺពិបាកខ្លាំងណាស់ដើម្បីគោរពតាម ។ នៅថ្ងៃទី ២ ខែមករា ឆ្នាំ ១៨៣១ ពួកបរិសុទ្ធមកពីសាខាផ្សេងៗ នៅរដ្ឋ នូវ យ៉ោក បានជួបគ្នានៅផ្ទះរបស់ពេត្រុស វិតមើរ ស៊ីញ៉័រ សម្រាប់សន្និសីទសាសនាចក្រលើកទី ៣ ។ អំឡុងសន្និសីទ មានសមាជិកសាសនាចក្រមួយចំនួនបានសួរអំពីបទបញ្ញត្តិនៃការផ្លាស់ទៅកាន់រដ្ឋអូហៃអូ ។

- ហេតុអ្វីអ្នកគិតថា វាអាចមានការលំបាក សម្រាប់ពួកបរិសុទ្ធមួយចំនួនដើម្បីគោរពតាមបទបញ្ញត្តិឲ្យចាកចេញពីរដ្ឋនូវយ៉ោក ហើយប្រមូលផ្ដុំគ្នានៅឯរដ្ឋ អូហៃអូ យ៉ាងដូច្នេះ?

អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា មិនមែនមនុស្សគ្រប់គ្នាដែលនៅក្នុងសន្និសីទនោះសុទ្ធតែយល់ពីប្រាជ្ញានៃបទបញ្ញត្តិនេះទាំងអស់នោះទេ។ មនុស្សមួយចំនួននឹងមិនទទួលយកថា វាជាព្រះបន្ទូលរបស់ព្រះអម្ចាស់ទេ ហើយអ្នកផ្សេងទៀតបានស្ទាក់ស្ទើរក្នុងការចាកចោលកសិដ្ឋានដ៏រុងរឿង និងស្ថានភាពសុខស្រួលរបស់ពួកគេ ដើម្បីទៅកាន់កន្លែងថ្មីដែលមិនប្រាកដប្រជា ។ ជាការពិតណាស់មនុស្សជាច្រើននឹងបាត់បង់ថវិកា ទៅលើអចលនទ្រព្យរបស់ពួកគេ ហើយមនុស្សខ្លះទៀត អាចនឹងពុំអាចលក់អចលនទ្រព្យរបស់ពួកគេជាច់បានទេ ។

សូមពន្យល់ថា អំឡុងសន្និសីទខែមករា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ បានអធិស្ឋានទៅកាន់ព្រះអម្ចាស់សុំរៀនបន្ថែមទៀតអំពីបទបញ្ញត្តិដើម្បីប្រមូលផ្ដុំគ្នាទៅឯរដ្ឋ អូហៃអូ ។ ព្រះអម្ចាស់ បានឆ្លើយតបជាមួយនឹងវិវរណៈ ដែលឥឡូវនេះកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ។ សូមជូនដំណឹងដល់សិស្សថា នៅពេលពួកគេសិក្សាវិវរណៈនេះ នោះពួកគេនឹងរៀនពីសេចក្ដីពិតទាំងឡាយ ដែលអាចជួយពួកគេ នៅពេលពួកគេធ្វើការជ្រើសរើស ទាក់ទងនឹងបទបញ្ញត្តិនានា ដែលពួកគេឃើញថាពិបាកនឹងគោរពតាម ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីពិតដែលយើងអាចរៀនអំពីព្រះយេស៊ូវគ្រីស្ទ ។ នៅពេលសិស្សឆ្លើយតប នោះអ្នកអាចនឹងផ្ដល់យោបល់ឲ្យពួកគេគូសចំណាំពាក្យ និង ឃ្លាដែលទាក់ទងជាមួយនឹងចម្លើយរបស់ពួកគេ ។

- តើសេចក្ដីពិតអ្វីខ្លះ ដែលយើងអាចរៀនអំពីព្រះយេស៊ូវគ្រីស្ទ មកពីខគម្ពីរទាំងនេះ ? ( នៅពេលសិស្សឆ្លើយតប សូមជួយពួកគេឲ្យប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទ ដឹងរឿងគ្រប់យ៉ាង** ) ។
- តើការយល់ដឹងថា ព្រះយេស៊ូវគ្រីស្ទ ដឹងនូវរឿងគ្រប់យ៉ាង អាចជួយដល់ពួកបរិសុទ្ធដែលត្រូវបានបញ្ជាឲ្យផ្លាស់ទៅរដ្ឋអូហៃអូយ៉ាងដូចម្ដេច ?
- តើសេចក្ដីពិតនេះ អាចជួយយើងនៅគ្រាដែលយើងមានការលំបាកក្នុងការគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

សូមពន្យល់ថា ពីមុនពេលទទួលវិវរណៈនេះ យ៉ូសែប ស្ម៊ីធ បានធ្វើការនៅក្នុងកំណែថ្មីដ៏បំផុសគំនិតនៃព្រះគម្ពីរប៊ីប ហើយបានទទួលនូវអ្វីដែលឥឡូវមាននៅក្នុង ម៉ូសេ ៦–៧ នៅក្នុងមុក្ដាដ៏មានតម្លៃមហិមា ។ ជំពូកទាំងនេះ ផ្ដល់នូវដំណើររឿងអំពីព្យាការីម្នាក់ ដែលមានឈ្មោះថា ហេណុក និងប្រជាជនរបស់លោក ។ ដោយសារតែសេចក្ដីសុចរិត និងសាមគ្គីភាពរបស់ពួកគេ នោះព្រះអម្ចាស់បានហៅប្រជាជនទាំងនេះថា *ស៊ីយ៉ូន* ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៤ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់ ហេណុក និងប្រជាជនរបស់លោក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា នៅពេលព្រះអម្ចាស់បានប្រើឃ្លាថា « នៅក្នុងឱរារបស់យើងផ្ទាល់ » នោះទ្រង់កំពុងសំដៅទៅលើវត្តមានរបស់ទ្រង់ ។

- ស្របតាម ខ ៤ តើរឿងមួយដែលប្រជាជនហេណុកបានធ្វើ ដែលបណ្ដាលឲ្យព្រះអម្ចាស់យកពួកគេឡើងទៅស្ថានសួគ៌គឺជាអ្វី ? ( ពួកគេជឿទៅលើព្រះនាមទ្រង់ ) ។
- តើព្រះអង្គសង្គ្រោះបានមានបន្ទូល ថាទ្រង់បានធ្វើអ្វីខ្លះ សម្រាប់អ្នកទាំងឡាយដែលបានជឿដល់ព្រះនាមរបស់ទ្រង់ ? តើរឿងនោះធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច អំពីព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៥–៧ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវគ្រីស្ទ បានមានបន្ទូលអំពីទីកន្លែងរបស់ទ្រង់ ។

- តើព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលថាទ្រង់គង់នៅកន្លែងណា ?
- តើអ្នកមានអារម្មណ៍ថា ព្រះអង្គសង្គ្រោះ គង់នៅជិត ទោះជាអ្នកមើលមិនឃើញទ្រង់ដោយផ្ទាល់ភ្នែក នៅពេលណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៨–១២

*ព្រះអម្ចាស់ពិពណ៌នាអំពីនរណាដែលនឹងអត់ទ្រាំនៅក្នុងការយាងមកជាលើកទីពីរ*

សូមដាក់បង្ហាញរូបភាព ការយាងមកជាលើកទីពីរ (*សៀវភៅសិល្បៈដំណឹងល្អ* | ឆ្នាំ ២០០៩ | ទំព័រ ៦៦, សូមមើលផងដែរ LDS.org)។ សូមពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះកំពុងជួយដល់ពួកបរិសុទ្ធនៅរដ្ឋ នូវ យ៉ោក យល់អំពីសារៈសំខាន់នៃការប្រមូលផ្ដុំគ្នាទៅឯរដ្ឋ អូហៃអូ នោះទ្រង់បានមានបន្ទូលអំពីការយាងមកជាលើកទីពីរ ។



សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៨–១០។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានបើកសម្ដែងអំពីការយាងមកជាលើកទីពីររបស់ទ្រង់ ។ វាអាចជួយពន្យល់ថា អ្នកទាំងឡាយណាដែល « ធន់នៅថ្ងៃនោះ » ( គ. និង ស. ៣៨:៨ ) នៃការយាងមកជាលើកទីពីរ គឺអ្នកទាំងឡាយ ដែលនឹងអាចបន្តនៅលើផែនដីជាមួយនឹងព្រះអង្គសង្គ្រោះនៅពេលទ្រង់យាងមក ជាជាងត្រូវបានបំផ្លាញចោល ។

- តើខគម្ពីរទាំងនេះជួយយើងយល់អំពីសារៈសំខាន់នៃការធ្វើឲ្យបរិសុទ្ធ និងស្អាតស្អំ មុនការយាងមកជាលើកទីពីរយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១១–១២ ដោយស្ងាត់ស្ងៀម ហើយរកមើលការពិពណ៌នារបស់ព្រះអម្ចាស់អំពីស្ថានភាព ដែលនឹងមាននៅលើផែនដីមុនការយាងមកជាលើកទីពីរ ។ រួចហើយឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។ ( ដើម្បីជួយសិស្សយល់អំពី ខគម្ពីរទាំងនេះ អ្នកអាចពន្យល់ថា ការពិពណ៌នាអំពីពួកទេវតានៅរង់ចាំដើម្បី « ច្រូតកាត់ផែនដី » គឺជាសេចក្ដីយោងមួយទៅរឿងប្រៀបធៀបក្នុងព្រះគម្ពីរសញ្ញាថ្មី អំពីស្រូវសាឡី និងស្រងែ [សូមមើល ម៉ាថាយ ១៣:២៤–៣០, គ. និង ស. ៨៦:១–៧] ដែលស្រូវសាឡី [ ជាអ្នកទាំងឡាយដែលសុចរិត ] គឺត្រូវបានប្រមូលផ្ដុំ មុនពេលដុតស្រងែ [ អ្នកទាំងឡាយដែលទុច្ចរិត ] ) ។

- តើមានភស្តុតាងអ្វីខ្លះ ដែលអ្នកមើលឃើញថាស្ថានភាពទាំងឡាយ បានពិពណ៌នានៅក្នុង ខ ១១ មាននៅសព្វថ្ងៃនេះ ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីបន្តមានភាពបរិសុទ្ធនៅក្នុងកណ្ដាលស្ថានភាពទាំងឡាយនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៣–១៦

*ព្រះអម្ចាស់ ព្រមានពួកបរិសុទ្ធអំពីគ្រោះថ្នាក់ ហើយផ្ដល់ការលើកទឹកចិត្តដល់ពួកគេ*

សូមពន្យល់ថា បន្ថែមពីលើការមានបន្ទូលអំពីការយាងមកជាលើកទីពីរ នោះព្រះអម្ចាស់បានផ្ដល់ការព្រមានមួយស្ដីអំពីគ្រោះថ្នាក់ដែលពួកបរិសុទ្ធជួបប្រទះ ។ សូមនាំសិស្សទៅកាន់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១២ ហើយសួរសំណួរដូចខាងក្រោម ៖

- នៅចុង ខ ១២ តើព្រះអម្ចាស់បានបង្រៀនអ្វីខ្លះ អំពីខ្មាំងសត្រូវរបស់ពួកបរិសុទ្ធ ?

សូមជួយសិស្សឲ្យយល់ថា ឃ្លា « ខ្មាំងសត្រូវ កំពុងរួមគ្នា » ជាទូទៅ អាចនឹងសំដៅទៅលើភាពពិត ដែលសាតាំង និងពលបរិវាររបស់វាបានប្រមូលផ្ដុំដើម្បីទាស់នឹងពួកបរិសុទ្ធនៅក្នុងថ្ងៃចុងក្រោយ ។ វាក៏អាចសំដៅទៅលើមនុស្សដែលជាខ្មាំងសត្រូវនឹងពួកបរិសុទ្ធ នៅគ្រាដែលវិវរណៈនេះត្រូវបានប្រទានឲ្យផងដែរ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៣ ឲ្យឮៗ ហើយអញ្ជើញសិស្សឲ្យរកមើលអ្វីដែលជាបំណងរបស់ខ្មាំងសត្រូវបានប្រមូលផ្ដុំគ្នានេះ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- តើព្រះអម្ចាស់អាចធ្វើអ្វីខ្លះ នៅពេលយើងស្ថិតនៅក្នុងគ្រោះថ្នាក់ ? ( សិស្សអាចផ្ដល់ចម្លើយផ្សេងៗគ្នា ។ សូមប្រាកដថា គូសបញ្ជាក់នូវគោលការណ៍ដូចខាងក្រោម ហើយសរសេរវានៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ អាចព្រមានយើងអំពីគ្រោះថ្នាក់ )**

សូមទុកពេលឲ្យសិស្សមួយសន្ទុះពិចារណាអំពីសារលិខិតដែលពួកព្យាការីរបស់ព្រះអម្ចាស់ បានប្រទានដល់យើងនៅក្នុងសន្និសីទទូទៅ ហើយនឹងតាមរយៈឯកសារបោះពុម្ពរបស់សាសនាចក្រ ។

- តើសារលិខិតទាំងនេះ ជាការព្រមានមកពីព្រះអម្ចាស់ អំពីគ្រោះថ្នាក់ខាងវិញ្ញាណ ឬខាងសាច់ឈាម ដែលយើងជួបប្រទះតាមរបៀបណាខ្លះ ?
- តើអ្នកត្រូវបានព្រមានអំពីគ្រោះថ្នាក់ខាងវិញ្ញាណ ឬខាងសាច់ឈាម តាមវិធីណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៤–១៥ ដោយស្ងាត់ស្ងៀម ហើយរកមើលរបៀបដែលព្រះអម្ចាស់បានលើកទឹកចិត្តដល់ពួកបរិសុទ្ធអំឡុងគ្រានៃគ្រោះថ្នាក់ និងភាពពុំពិតប្រាកដនេះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធសម្រាប់សេចក្ដីសង្គ្រោះរបស់ពួកគេ ។ សូមជួយសិស្សឲ្យយល់ថា បទបញ្ញត្តិដែលសំដៅទៅលើនោះ គឺជាបទបញ្ញត្តិឲ្យផ្លាស់ទីពីទីក្រុង នូវ យ៉ោក ទៅកាន់ រដ្ឋ អូហៃអូ ។

- តើបទបញ្ញត្តិឲ្យផ្លាស់ទីពីទីក្រុង នូវ យ៉ោក អាចជាសេចក្ដីសង្គ្រោះខាងសាច់ឈាមរបស់ពួកបរិសុទ្ធតាមរបៀបណា ?
- តើបទបញ្ញត្តិឲ្យប្រមូលគ្នីគ្នាទៅឯរដ្ឋ អូហៃអូ អាចជាសេចក្ដីសង្គ្រោះខាងវិញ្ញាណតាមរបៀបណា ?

សូមបន្ថែមទៅលើគោលការណ៍ដែលមាននៅលើក្ដារខៀន ដូច្នេះវាអានដូចតទៅនេះ ៖ **ព្រះអម្ចាស់ អាចព្រមានយើងអំពីគ្រោះថ្នាក់ ហើយប្រទានបញ្ញត្តិដល់យើងដើម្បីការពារយើង ។**

- តើការរក្សាបទបញ្ញត្តិរបស់ព្រះអម្ចាស់អាចការពារយើងយ៉ាងដូចម្ដេច ?
- តើអ្នកមានអារម្មណ៍ដឹងថា អ្នកត្រូវបានការពារ តាមរយៈការរក្សាបទបញ្ញត្តិនៅពេលណា ? ( អ្នកអាចទុកពេល ដល់សិស្សឲ្យពិចារណា អំពីសំណួរនេះ មុនពេលឲ្យពួកគេឆ្លើយ ) ។

សូមអញ្ជើញសិស្សឲ្យនឹកគិតអំពីសកម្មភាពនៅពេលចាប់ផ្ដើមថ្នាក់រៀន ដែលពួកគេបានគិតអំពីបទបញ្ញត្តិដែលលំបាកចំពោះពួកគេគោរពតាម ។ សូមឲ្យពួកគេគិតពិចារណាអំពីរបៀបដែលបទបញ្ញត្តិទាំងនេះ អាចជាពរជ័យមកពីព្រះអម្ចាស់ដើម្បីការពារពួកគេពីគ្រោះថ្នាក់ខាងវិញ្ញាណ ឬខាងសាច់ឈាម ។

- តើការយល់ដឹងអំពីសេចក្ដីពិត ដែលបានសរសេរនៅលើក្ដារខៀន លើកទឹកចិត្តអ្នកឲ្យគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ជាពិសេសនៅពេលការគោរពតាមបទបញ្ញត្តិទាំងនេះ មើលទៅហាក់ដូចជាលំបាកនោះ ?

សូមបញ្ចប់មេរៀនដោយការអញ្ជើញសិស្សចែកចាយទីបន្ទាល់របស់ពួកគេអំពីលទ្ធភាពរបស់ព្រះអម្ចាស់ ដើម្បីព្រមានយើងអំពីគ្រោះថ្នាក់ ហើយប្រទានបទបញ្ញត្តិ ដែលនឹងជួយការពារដល់យើង បើយើងគោរពតាមនោះ ។ អ្នកក៏អាចថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនេះផងដែរ ។

*សូមទុកពេលឲ្យសិស្សពិចារណា*

ដើម្បីជួយសិស្សស្គាល់នូវគ្រានានា ពេលដែលពួកគេបានទទួលបទពិសោធន៍អំពីភាពពិតពេញលេញនៃគោលការណ៍ដំណឹងល្អ សូមសួរសំណួរដែលនឹងធ្វើឲ្យពួកគេនឹកចាំពីក្នុងការចងចាំរបស់ពួកគេ ។ បន្ទាប់មកទុកពេលឲ្យពួកគេគ្រប់គ្រាន់ដើម្បីពិចារណាអំពីចម្លើយរបស់ពួកគេ ។ បើសិស្សបន្តនៅស្ងាត់ស្ងៀម បន្ទាប់ពីអ្នកបានសួរសំណួរមួយ នោះវាចង្អុលបង្ហាញថា ពួកគេកំពុងពិចារណាអំពីសំណួរនោះដោយយកចិត្តទុកដាក់ហើយ ។ នៅពេលសិស្សពិចារណា សូមកុំបន្ថែមសំណួរ ការណែនាំ ឬការសន្ទានដែលនឹងរំខានដល់ពួកគេ ។

មេរៀនទី ៤៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៧–៤២

## បុព្វកថា

មេរៀនមុន បានគ្របដណ្ដប់ខគម្ពីរចំនួន ១៦ ខដំបូងនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ។ មេរៀននេះបង្រៀននូវផ្នែកដែលនៅសេសសល់ទាំងប៉ុន្មាននៃកណ្ឌនោះ ។ នៅក្នុងការឆ្លើយតបចំពោះបំណងប្រាថ្នារបស់ពួកបរិសុទ្ធ ដើម្បីដឹងបន្ថែមអំពីបទបញ្ញត្តិដើម្បីប្រមូលគ្នីគ្នាទៅឯរដ្ឋ អូហៃអូ នោះព្រះអម្ចាស់បានបើកសម្ដែងនូវពរជ័យមួយចំនួនដែលនឹងកើតមានចំពោះពួកសុចរិត អំឡុងពេលសហស្សវត្សរ៍ ។ រួចទ្រង់បានបង្រៀនពួកបរិសុទ្ធឲ្យមានសាមគ្គីភាព ហើយបានពន្យល់ពីមូលហេតុដែលទ្រង់បានបញ្ជាពួកគេឲ្យប្រមូលគ្នីគ្នាទៅឯរដ្ឋ អូហៃអូ ។ ទីបំផុត ព្រះអម្ចាស់បានប្រទានបទបញ្ញត្តិដើម្បីជួយដល់ពួកបរិសុទ្ធឲ្យដឹងរបៀបដើម្បីចាប់ផ្ដើមការប្រមូលគ្នីគ្នា ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៧–២២

*ព្រះអម្ចាស់ បើកសម្ដែងពរជ័យមួយចំនួនដែលនឹងកើតមានចំពោះពួកសុចរិតក្នុងពេលឥឡូវនេះ និងអំឡុងពេលសហស្សវត្សរ៍ ។*

សូមសួរដល់សិស្សថាតើមរតកមួយគឺជាអ្វី ហើយជាធម្មតាតើនរណាទទួលបានវា ។

- ហេតុអ្វីអ្នកចង់បានមរតកមួយដូច្នេះ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៧–២២ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីមរតកដែលព្រះអម្ចាស់បានសន្យានឹងប្រទានឲ្យរាស្ត្ររបស់ទ្រង់ ។

- តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ ទៅកាន់រាស្ត្រទ្រង់ដែលនឹងចាំបាច់ត្រូវធ្វើ ដើម្បីទទួលបានមរតក ដែលបានថ្លែងនៅក្នុងខគម្ពីរទាំងនេះ ? ( សូមស្វែងរកវាដោយអស់ពីដួងចិត្តរបស់ពួកគេ [ សូមមើល គ. និង ស. ៣៨:១៩] ស្ដាប់សំឡេងទ្រង់ ហើយធ្វើតាមទ្រង់ [ គ. និង ស. ៣៨:២២] ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យរៀបរាប់ពីប្រវត្តិនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ដែលពួកគេបានរៀនអំឡុងមេរៀនមុន ។ បើចាំបាច់ សូមរំឭកសិស្សថា ពួកបរិសុទ្ធមួយចំនួននៅរដ្ឋ នូវ យ៉ោក បានស្នើសុំព័ត៌មានបន្ថែមស្ដីអំពីបទបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីផ្លាស់ទៅកាន់រដ្ឋ អូហៃអូ ។

- តើអ្នកគិតថា ការបង្រៀនដល់ពួកបរិសុទ្ធអំពីមរតកដ៏អស់កល្បរបស់ពួកគេ អាចមានឥទ្ធិពលលើអារម្មណ៍របស់ពួកគេអំពីបទបញ្ជាឲ្យផ្លាស់ទៅរដ្ឋ អូហៃអូ យ៉ាងដូចម្ដេច ?

សូមលើកទឹកចិត្តដល់សិស្សឲ្យស្វែងរកមូលហេតុបន្ថែមថា ហេតុអ្វីព្រះអម្ចាស់បានប្រទានបទបញ្ញត្តិដល់ពួកបរិសុទ្ធឲ្យប្រមូលគ្នីគ្នាទៅរដ្ឋ អូហៃអូ នៅពេលពួកគេសិក្សាអ្វីដែលនៅសល់ទាំងប៉ុន្មានក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៣–២៧

*ព្រះអម្ចាស់ បញ្ជាពួកបរិសុទ្ធឲ្យមានសាមគ្គីភាព*

មុនចាប់ផ្ដើមថ្នាក់រៀន សូមគូររូបភាពផ្នែកខាងក្រៅនៃអគារមួយ ដែលមាននៅក្នុងតំបន់របស់អ្នកដោយសាមញ្ញនៅលើក្ដារខៀន ។ ឬគូររូប ផ្ទះដ៏សាមញ្ញមួយដូចបានបង្ហាញនៅទីនេះ ។ សូមបញ្ចូលនូវធាតុសំខាន់ៗនៃអគារ រួមមានទាំងច្រកទ្វារចូល បង្អួច ជញ្ជាំង និងតំបូល ។ សូមសួរដល់សិស្សថា ផ្នែកណាមួយនៃអគារដែលសំខាន់បំផុត ។ នៅពេលសិស្សឆ្លើយ សូមជួយពួកគេមើលឃើញថា ផ្នែកនីមួយៗនៃអគារធ្វើឡើងសម្រាប់គោលបំណងចាំបាច់មួយ ។



- តើផ្នែកទាំងឡាយនៃអគារមួយ អាចប្រៀបធៀប ទៅនឹងសមាជិកក្នុងគ្រួសារមួយ ឬសមាជិកនៅក្នុងវួដ ឬ សាខាមួយបានយ៉ាងដូចម្ដេច ? ( ក៏ដូចជាផ្នែកនីមួយៗ នៃអគារមួយគឺវាសំខាន់ នោះសមាជិកម្នាក់ៗក្នុងគ្រួសារ ឬវួដ ឬសាខាមួយ គឺមានតម្លៃ ហើយអាចប្រើក្នុងតួនាទី សំខាន់មួយ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៣–២៥ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវឃ្លា មួយ ដែលបង្រៀនពីរបៀប ដែលយើងអាចមើលទៅមនុស្ស ដទៃយ៉ាងណា ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេ រៀន ។

- តើអ្នកគិតថា វាមានន័យយ៉ាងណា ចំពោះមនុស្សម្នាក់ ឲ្យ « គោរពបងប្អូនខ្លួន ឲ្យដូចជាខ្លួនឯង » ? ( បន្ទាប់ពី សិស្សបានឆ្លើយហើយ សូមសរសេរគោលការណ៍ខាង ក្រោមនៅលើក្ដារខៀន ៖ **យើងត្រូវឲ្យតម្លៃអ្នកដទៃឲ្យបានច្រើនដូចជាយើងឲ្យតម្លៃដល់ខ្លួនយើងដែរ** )

ដើម្បីជួយសិស្សចងចាំគោលការណ៍នេះ សូមសរសេរ សេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ប៊ិយដ៏ យេ ដាកកឹ នៃ កូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅលើក្ដារខៀន ។ អ្នកអាចឲ្យយោបល់ដល់សិស្សឲ្យចម្លងវាដាក់ក្នុងព្រះគម្ពីរសៀវភៅកត់ចំណាំ ក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។ ( សេចក្ដីថ្លែងការណ៍ រកបាននៅក្នុង « The Weak and the Simple of the Church » *Ensign* ឬ ***លីអាហូណា*** ខែ វិច្ឆិកា ឆ្នាំ ២០០៧,ទំព័រ ៧ ) ។

> *« មានភាពស្មើគ្នាដ៏ពិសេសមួយនៅក្នុងចំណោមសមាជិក [ នៃសាសនាចក្រ ] ។ គ្មានយើងណាម្នាក់ ចាត់ទុកថាខ្លួន ឯងមានតម្លៃច្រើនជាងអ្នកដទៃនោះទេ ( សូមមើល គ. និង ស. ៣៨:២៤–២៥ ) » ( ប្រធាន ប៊ិយដ៏ យេ ដាកកឹ ) ។*

- តើមានអ្វីកើតឡើងខ្លះពេលមនុស្សគិតថា ខ្លួនគេមានតម្លៃច្រើនជាង ឬល្អប្រសើរជាងអ្នកដទៃនោះ ?
- តើសាសនាចក្រ ត្រូវបានប្រទានពរយ៉ាងដូចម្ដេច នៅពេលយើងពុំចាត់ទុកខ្លួនយើងថាមានតម្លៃជាងអ្នកដទៃនោះ ?

សូមប្រាប់ដល់សិស្សថា ព្រះអង្គសង្គ្រោះ បានបង្រៀននូវរឿងប្រៀបធៀបមួយ ដែលបង្ហាញពីមូលហេតុដែលយើងគួរតែគោរព ដល់អ្នកដទៃឲ្យដូចជាខ្លួនយើង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានរឿងប្រៀបធៀបនេះចេញមកពី គោលលទ្ធិ និង សេចក្ដី សញ្ញា ៣៨:២៦ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយរកមើលរបៀបដែលបុរសក្នុងរឿងប្រៀបធៀបនេះ បានប្រព្រឹត្តចំពោះ កូនប្រុសៗរបស់គាត់ ។

- តើអ្នកមានអារម្មណ៍យ៉ាងណា បើអ្នកជាកូនប្រុសដែលបានពាក់កន្ទបនៅក្នុងរឿងប្រៀបធៀបនេះ ?
- តើកូនប្រុសដែលពាក់ខោអាវអាចធ្វើអ្វីខ្លះដើម្បីកែលម្អស្ថានភាពនេះ ?
- តើអ្នកគិតថា សារលិខិតរបស់ព្រះអម្ចាស់មួយនេះ បង្កប់ន័យអ្វីខ្លះនៅក្នុងរឿងប្រៀបធៀបនេះចំពោះយើង ?

សូមសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៧ ដោយស្ងាត់ស្ងៀម ហើយរកមើលគោលការណ៍មួយ ដែលព្រះអម្ចាស់ចង់ឲ្យយើងយល់ដកស្រង់ចេញពីរឿងប្រៀបធៀបនេះ ។ ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរ តែបង្ហាញពីអ្វីមួយ ដែលមានលក្ខណៈដូចខាងក្រោមនេះ ៖ **បើសិនជាអ្នករាល់គ្នាមិនរួមគ្នាតែមួយទេ ឈ្មោះថាអ្នករាល់គ្នា ពុំមែនជារបស់ផងព្រះអម្ចាស់ឡើយ** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ក្បែរនឹងគោលការណ៍ដែលអ្នកបាន សរសេរពីដំបូង ។ អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សគូសចំណាំពាក្យនៅក្នុងគម្ពីររបស់ពួកគេ ដែលបង្រៀនពីគោលការណ៍ នេះ ) ។

- នៅក្នុងបរិបទនៃ ខ ២៧ តើវាមានន័យយ៉ាងណាដើម្បីបាន « រួមគ្នាតែមួយ » ? ( ដើម្បីមានសាមគ្គីភាពនឹងអ្នកដទៃ ហើយនឹងជាមួយព្រះអម្ចាស់នៅក្នុងសេចក្ដីសុចរិត ) ។
- តើការឲ្យតម្លៃអ្នកដទៃឲ្យច្រើនដូចជាយើងឲ្យតម្លៃលើខ្លួនយើង អាចជួយយើងឲ្យប្រែក្លាយទៅជារួមគ្នាតែមួយយ៉ាង ដូចម្ដេច ? តើការណ៍នេះអាចជួយយើងក្លាយទៅជារួមគ្នាតែមួយនឹងព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- ហេតុអ្វីក៏អ្នកគិតថា យើងពុំអាចក្លាយជារាស្ត្ររបស់ព្រះអម្ចាស់បានឡើយ ប្រសិនបើយើងពុំបានរួមគ្នាតែមួយនោះ ?

សូមពន្យល់ថា សមាជិកសាសនាចក្រជំនាន់មុន ដែលត្រូវបានហៅឲ្យប្រមូលផ្ដុំគ្នាទៅឯរដ្ឋ អូហៃអូ គឺមានជីវប្រវត្តិផ្សេងៗគ្នា ។ អ្នកខ្លះជាម្ចាស់ចម្ការដ៏មានជោគជ័យ ហើយត្រូវបានគេគោរពរាប់អាននៅក្នុងសហគមន៍របស់ពួកគេ ខណៈដែលអ្នកដទៃទៀតមានទ្រព្យបន្តិចបន្តួច ហើយត្រូវបានចាត់ទុកថាមានវណ្ណៈទាបក្នុងសង្គម ។

- តើគោលការណ៍ទាំងឡាយនៅលើក្ដារខៀន បានប្រទានពរដល់ពួកបរិសុទ្ធ នៅពេលដែលពួកគេប្រមូលផ្ដុំគ្នាជាមួយនឹងសមាជិកដទៃទៀតនៃសាសនាចក្រនៅក្នុងរដ្ឋ អូហៃអូ យ៉ាងដូចម្ដេច ?

ពីមុនចាប់ផ្ដើមថ្នាក់រៀន អ្នកអាចរៀបចំដើម្បីចែកក្រដាសមួយដល់សិស្សម្នាក់ៗ ដែលមាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍នេះឲ្យឮៗ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលវិធីដែលបទបញ្ញត្តិឲ្យរួមគ្នាតែមួយ ដែលមានជាប់ទាក់ទងទៅនឹងបទបញ្ញត្តិរបស់ព្រះសម្រាប់រាស្ត្ររបស់ទ្រង់ឲ្យប្រមូលផ្ដុំគ្នា ។



« យើងបានដឹងមកពីបទពិសោធន៍ដែលថាក្ដីអំណរកើតមាន នៅពេលយើងត្រូវបានប្រទានពរជាមួយនឹងភាពសាមគ្គីគ្នា ។. . . បំណងប្រាថ្នា [ ព្រះវរបិតាសួគ៌របស់យើង ] គឺត្រូវបានប្រទានដល់យើងនូវបំណងដ៏ពិសិដ្ឋឲ្យមានសាមគ្គីភាពដែលវាចេញមកពីក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើង ។

« ទ្រង់ពុំអាចប្រទានវាដល់យើងម្នាក់ៗនោះទេ ។ ក្ដីអំណរនៃសាមគ្គីភាព ដែលទ្រង់ចង់ប្រទានឲ្យយើងយ៉ាងខ្លាំងនោះ គឺមិនឲ្យយើងតែម្នាក់ឯងទេ ។ យើងត្រូវតែស្វែងរកវា ហើយនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់មានវា ជាមួយនឹងអ្នកផ្សេងទៀត ។ វាមិនគួរឲ្យភ្ញាក់ផ្អើលទេដែលព្រះជម្រុញយើងឲ្យប្រមូលផ្ដុំគ្នា ដូច្នេះទើបទ្រង់អាចប្រទានពរដល់យើង ។ ទ្រង់ចង់ឲ្យយើងរួបរួមគ្នានៅក្នុងក្រុមគ្រួសារ ។ ទ្រង់បានបង្កើតថ្នាក់ វួដ និងសាខាជាច្រើន ហើយបានបញ្ជាយើងឲ្យជួបជុំគ្នាជារឿយៗ ។ នៅក្នុងការរួបរួមគ្នាទាំងនោះ ដែលព្រះបានរៀបចំសម្រាប់យើង នោះជាឱកាសដ៏អស្ចារ្យរបស់យើង ។ យើងអាចអធិស្ឋានហើយធ្វើការស្វែងរកភាពសាមគ្គី ដែលនឹងនាំយើងនូវសេចក្ដីអំណរ និងពង្រីកអំណាចរបស់យើងដើម្បីបម្រើ » (« Our Hearts Knit as One » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៦៩ ) ។

- យោងតាមប្រធាន អាវរិង ហេតុអ្វីព្រះអម្ចាស់ចង់ឲ្យយើងប្រមូលផ្ដុំគ្នា ? ( ដូច្នេះទ្រង់អាចប្រទានពរដល់យើង ហើយជួយយើងឲ្យធ្វើការរួមគ្នាឆ្ពោះទៅរកសាមគ្គីភាព ) ។ តើពរជ័យនៃសាមគ្គីភាពមានន័យយ៉ាងណា ? ( ក្ដីអំណរ និងអំណាចទ្វេភាគដើម្បីបម្រើរបស់យើង ) ។

- តើសេចក្ដីថ្លែងការរបស់ប្រធាន អាវរិង ជួយយើងឲ្យយល់ពីមូលហេតុដែលយើងត្រូវរួបរួមគ្នាជាក្រុមគ្រួសារយ៉ាងដូចម្ដេច ? ជាសមាជិកសាសនាចក្រយ៉ាងដូចម្ដេច ? ជាសិស្សថ្នាក់សិក្ខាសាលាមួយយ៉ាងដូចម្ដេច ?

- តើអ្នកមានបទពិសោធន៍នៃការទទួលពរជ័យទាំងឡាយ ដែលកើតមានមកពីការរួបរួមគ្នានឹងអ្នកដទៃទៀតនៅពេលណា ?

សូមអញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទីសរសេរ នៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ អំពីអ្វីដែលពួកគេអាចធ្វើដើម្បីរួមគ្នាតែមួយជាមួយនឹងក្រុមគ្រួសាររបស់ពួកគេ ជាមួយយុវជន និងយុវនារីនៅក្នុងកូរ៉ុម និងថ្នាក់រៀននៅព្រះវិហាររបស់ពួកគេ ហើយនឹងជាមួយព្រះអម្ចាស់ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៨–៣៣

*ព្រះអម្ចាស់ពន្យល់ពីមូលហេតុដែលទ្រង់បានបញ្ជាឲ្យសាសនាចក្ររបស់ទ្រង់ត្រូវប្រមូលផ្ដុំគ្នានៅឯរដ្ឋ អូហៃអូ*

សូមពន្យល់ថា ព្រះអម្ចាស់ បានបើកបង្ហាញនូវមូលហេតុផ្សេងទៀតថា ហេតុអ្វីបានជាទ្រង់បញ្ជាឲ្យពួកបរិសុទ្ធចាកចេញពីរដ្ឋ នូវយ៉ោក ហើយប្រមូលផ្ដុំគ្នាទៅឯរដ្ឋ អូហៃអូ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៨–៣០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុផ្សេងទៀត ដែលពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យប្រមូលផ្ដុំគ្នាទៅឯរដ្ឋ អូហៃអូ ។

- តើព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធអំពីអ្វីខ្លះ ?

- ស្របតាម ខ ៣០ តើរាស្ត្ររបស់ព្រះអម្ចាស់អាចធ្វើអ្វីខ្លះ ដើម្បីកុំឲ្យភ័យខ្លាចពួកខ្មាំងសត្រូវរបស់ពួកគេ ? ( អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សគូសចំណាំពាក្យដែលបង្រៀនគោលការណ៍ដូចខាងក្រោម ៖ **បើយើងបានត្រៀមខ្លួន នោះយើងនឹងពុំភ័យខ្លាចឡើយ** )។

### *សូមព្យាយាមដើម្បីបង្កើតបរិយាកាសនៃក្ដីស្រឡាញ់ និងការគោរព*

សិស្សទាំងឡាយណាដែលទទួលអារម្មណ៍នូវក្ដីស្រឡាញ់ ទុកចិត្ត និង ឲ្យតម្លៃដោយគ្រូបង្រៀនរបស់គេ និងសិស្សដទៃ ផ្សេងទៀត នោះនឹងមកកាន់ថ្នាក់រៀនដោយបើកទូលាយចំពោះ ឥទ្ធិពលនៃព្រះវិញ្ញាណ និងមានបំណងប្រាថ្នាកាន់តែមុតមាំក្នុងការចូលរួម ។ អ្នកអាចនឹងចង់ឈ្លាតពេលនេះ ដើម្បីពិភាក្សាជាមួយនឹងសិស្សពីអ្វីដែលអាចត្រូវបានធ្វើឡើង ដើម្បីពង្រីកអារម្មណ៍នៃក្ដីស្រឡាញ់ ការគោរព និងសាមគ្គីភាព នៅក្នុងចំណោមសមាជិកនៃថ្នាក់សិក្ខាសាលារបស់អ្នក ។

ដើម្បីជួយសិស្សយល់ ហើយអនុវត្តសេចក្ដីពិតដែលពួកគេទើបតែប្រាប់ សូមបំបែកពួកគេជាគូៗ ហើយអញ្ជើញឲ្យគូនីមួយៗពិភាក្សារកចម្លើយចំពោះសំណួរដូចខាងក្រោម ។ ( អ្នកអាចនឹងចង់សរសេរសំណួរទាំងនេះលើក្ដារខៀន ) ។

- ហេតុអ្វីក៏អ្នកគិតថា ការរៀបចំខ្លួនផ្ដល់នូវទំនុកចិត្តដល់យើង នៅពេលប្រឈមមុខនឹងភាពអវិជ្ជមាន ឬគ្រោះថ្នាក់ ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនទប់ទល់នឹងកម្លាំងរបស់ខ្មាំងសត្រូវដែលចង់បំផ្លាញយើងនោះ ?

សូមរំឭកសិស្សថា នៅក្នុងឆ្នាំ ១៨៣១ ពួកបរិសុទ្ធមួយចំនួននៅរដ្ឋនូវយ៉ោក បានមានចម្ងល់ថាហេតុអ្វីក៏ពួកគេត្រូវបានបញ្ជាឲ្យទៅរដ្ឋ អូហៃអូ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣១–៣៣ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយប្រាប់ពីរបៀបដែលពួកបរិសុទ្ធត្រូវបានប្រទានពរ បើពួកគេបានគោរពតាមបទបញ្ញត្តិឲ្យប្រមូលផ្ដុំគ្នានៅឯរដ្ឋអូហៃអូ នោះ ។ សិស្សគួរតែប្រាប់អំពីពរជ័យចំនួនបួន ៖ ( ១ ) ពួកគេ « អាចនឹងគេចផុតពីអំណាចរបស់ខ្មាំងសត្រូវ » ( ២ ) ពួកគេនឹង « ត្រូវបានប្រមូលគ្នាទៅរក [ ព្រះ ] ជារាស្ត្រសុចរិតមួយ » ( ៣ ) ពួកគេនឹងទទួលបានក្រឹត្យវិន័យរបស់ព្រះ ហើយ ( ៤ ) ពួកគេនឹង « ប្រទានឲ្យនូវព្រះចេស្ដាមកពីស្ថានលើ » ។

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ប្រមូលរាស្ត្ររបស់ទ្រង់ ដើម្បីការពារពួកគេ ហើយពង្រឹងដល់ពួកគេខាងវិញ្ញាណ ។**

- តើការប្រមូលផ្ដុំជាមួយនឹងអ្នកទាំងឡាយដែលចែកចាយបទដ្ឋានរបស់អ្នក ជួយអ្នកមានអារម្មណ៍ថាត្រូវបានការពារពីអំណាចរបស់សាតាំងយ៉ាងដូចម្ដេច ?
- តើការទទួលក្រឹត្យវិន័យរបស់ព្រះ ជួយពង្រឹងយើងខាងវិញ្ញាណដូចម្ដេចខ្លះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣៤–៤២

*សាសនាចក្រត្រូវបានផ្ដល់ឲ្យនូវបទបញ្ញត្តិទាំងឡាយទាក់ទងនឹងការប្រមូលផ្ដុំទៅឯរដ្ឋអូហៃអូ*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣៤–៤២ ដោយការពន្យល់ថា ព្រះអម្ចាស់បានប្រទានបទបញ្ញត្តិមួយចំនួន ហើយប្រឹក្សាដល់ពួកបរិសុទ្ធថា បញ្ញត្តិទាំងនោះនឹងជួយពួកគេនៅក្នុងការផ្លាស់លំនៅទៅកាន់រដ្ឋអូហៃអូ ។ សូមពន្យល់ផងដែរថា សម្រាប់ពួកបរិសុទ្ធភាគច្រើន ប្រភពនៃការចិញ្ចឹមជីវិតរបស់ពួកគេ គឺចម្ការរបស់ពួកគេ ។ ដោយមានសមាជិកជាច្រើនក្នុងសាសនាចក្រត្រូវលក់ទ្រព្យសម្បត្តិរបស់ខ្លួននៅក្នុងពេលតែមួយ នោះមានពួកបរិសុទ្ធជាច្រើន បានប្រឈមមុខនឹងការខាតបង់ប្រាក់ទៅលើចម្ការរបស់ពួកគេ ឬពួកគេពុំអាចលក់វាដាច់ទាល់តែសោះ ។ ដោយមានដីជាច្រើនត្រូវលក់ នោះវានឹងនាំឲ្យថ្លៃធ្លាក់ចុះ ហើយអនុញ្ញាតឲ្យពួកអ្នកទិញចម្ការរបស់ពួកបរិសុទ្ធទិញបានក្នុងតម្លៃថោកបំផុត ។

សូមអញ្ជើញសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣៧, ៣៩ ដោយស្ងាត់ស្ងៀម ហើយរកមើលដំបូន្មានរបស់ព្រះអម្ចាស់ ទាក់ទងទៅនឹងចម្ការ និងភាពមានបានរបស់ពួកបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- តើការដឹងពីការសន្យាដ៏អស់កល្បជានិច្ច ដែលព្រះអម្ចាស់បានប្រទានដល់អ្នក ជួយអ្នកឲ្យគោរពតាមបទបញ្ញត្តិរបស់ទ្រង់យ៉ាងដូចម្ដេច ?

សូមពន្យល់ថា មានពួកបរិសុទ្ធមួយចំនួនមានការលំបាកក្នុងការលក់ចម្ការរបស់ពួកគេ បន្ទាប់ពីបទបញ្ញត្តិត្រូវបានប្រទានឲ្យ ។ មួយចំនួនបានលក់ចម្ការរបស់ពួកគេខាត អ្នកដទៃទៀតពុំអាចលក់អចលនទ្រព្យដាច់តែម្ដង ។ មានសមាជិកស្មោះត្រង់មួយចំនួនត្រូវ បានចាកចោលផ្ទះ និងទ្រព្យសម្បត្តិដែលលក់មិនដាច់ ហើយចេញដំណើរទៅរដ្ឋអូហៃអូ ។

អ្នកអាចបញ្ចប់មេរៀន ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិត ដែលបានប្រាប់នៅក្នុងមេរៀន ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមរឿងទាំងឡាយដែលពួកគេបានទទួលអារម្មណ៍ និងបានកត់ត្រានៅក្នុងអំឡុងពេលមេរៀន ។

មេរៀនទី ៤៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០

## បុព្វកថា

នៅក្នុង ខែ មករា ឆ្នាំ ១៨៣១ អ្នកបង្រៀនសាសនាប្រូតេស្តង់ ឈ្មោះ យ៉េមស៍ ខូវិល បានជួបនឹង យ៉ូសែប ស្ម៊ីធ នៅភូមិ ហ្វាយ៉ែត នូវយ៉ោក ហើយ « បានចុះសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់ថា គាត់នឹងគោរពតាមបទបញ្ញត្តិទាំងឡាយ ដែលព្រះអម្ចាស់នឹងប្រទានឲ្យតាមរយៈអ្នកបម្រើរបស់ទ្រង់ យ៉ូសែប » ( សូមមើល *Documents, Volume ១: ខែ កក្កដា ឆ្នាំ ១៨២៨–ខែ មិថុនា ឆ្នាំ ១៨៣១* វ៉ុលទី ១ of the Documents series of *The Joseph Smith Papers* [ ឆ្នាំ ២០១៣ ], ទំព័រ ២៣៣–៣៤ ) ។ ចម្លើយរបស់ព្រះអម្ចាស់ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩ ។ នៅវិវរណៈ ព្រះអម្ចាស់បានហៅ យ៉េមស៍ ខូវិល ឲ្យទទួលបុណ្យជ្រមុជទឹក ហើយឲ្យផ្សាយភាពពេញលេញនៃដំណឹងល្អនៅក្នុងរដ្ឋអូហៃអូ ។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃបន្ទាប់ពីវិវរណៈត្រូវបានសរសេរទុកថា យ៉េមស៍ ខូវិល បានចាកចេញពីភូមិហ្វាយ៉ែត ហើយ « ត្រឡប់ទៅកាន់គោលការណ៍ចាស់ និងមិត្តចាស់របស់គាត់ » (*History of the Church* ១:១៤៥ ) ។ រួចហើយ ព្រះអម្ចាស់បានប្រទានវិវរណៈមួយដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ពន្យល់ពីមូលហេតុដែល ខូវិល ពុំបានគោរពតាមបទបញ្ញត្តិដែលបានប្រទានឲ្យគាត់ ។ វិវរណៈនោះ គឺត្រូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៤០ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១–១២

*ព្រះយេស៊ូវគ្រីស្ទ អញ្ជើញ យ៉េមស៍ ខូវិល ឲ្យទទួលដំណឹងល្អរបស់ទ្រង់ ហើយទទួលបុណ្យជ្រមុជទឹក*

សូមឲ្យសិស្សនឹកគិតថា ពួកគេទើបត្រូវបានប្រទានអំណោយមួយ មកពីឪពុកម្ដាយ ឬមនុស្សជាទីស្រឡាញ់ផ្សេងទៀត ។ នៅពេលពួកគេបើកអំណោយ នោះពួកគេឃើញថា ជាអ្វីមួយដែលពួកគេពិតជាចង់បាន ។

- តើអ្នកនឹងទទួលអំណោយនោះឬទេ ? តើមានមូលហេតុអ្វីផ្សេង ថាហេតុអ្វីអ្នកនឹងជ្រើសរើសមិនទទួលអំណោយនោះឬដែរទេ ?
- តើអ្នកអាចគិតអំពីអំណោយ ឬការផ្ដល់ឲ្យណាផ្សេងទៀត មកពីព្រះវរបិតាសួគ៌ ដែលកូនចៅរបស់ទ្រង់បានជ្រើសរើសមិនព្រមទទួលយកដែរឬទេ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលមនុស្សមួយចំនួនបានជ្រើសរើសធ្វើពុំព្រមទទួល ។

- តើមនុស្សទាំងនេះជ្រើសរើសមិនទទួលយកអ្វីខ្លះ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីទទួលព្រះយេស៊ូវគ្រីស្ទ ?
- មកពីអ្វីដែលអ្នកដឹងអំពីការបម្រើរបស់ព្រះអង្គសង្គ្រោះនៅលើផែនដី តើមូលហេតុមួយចំនួនដែលរាស្ត្រទ្រង់ពុំទទួលយកទ្រង់មានអ្វីខ្លះ ?

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោម នៅលើក្ដារខៀន ៖ *បើយើងទទួលយកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹង . . .*

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម រកមើលថាតើសេចក្ដីថ្លែងការនៅលើក្ដារខៀន អាចត្រូវបានបំពេញមកពីគោលការណ៍មួយដោយរបៀបណា ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។

សូមចង្អុលបង្ហាញថា ទោះជាខគម្ពីរ និយាយថា « បុត្រា » ក្ដី ក៏ព្រះអម្ចាស់បានបង្រៀនថា ស្ត្រីអាចក្លាយជាបុត្រីនៃព្រះយេស៊ូវគ្រីស្ទផងដែរ ( សូមមើល គ. និង ស. ២៥:១ ) ។ បន្ទាប់មក បញ្ចប់សេចក្ដីថ្លែងការនៅលើក្ដារខៀន ដូចខាងក្រោម ៖ **បើយើងទទួលព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងប្រទានអំណាចដល់យើងដើម្បីក្លាយជាកូនចៅរបស់ទ្រង់ ។**

### *សូមសរសេរគោលការណ៍ និងគោលលទ្ធិទាំងឡាយនៅលើក្ដារខៀន*

នៅពេលសិស្សប្រាប់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ សូមប្រាកដថាជួយពួកគេឲ្យថ្លែងសេចក្ដីពិតឲ្យច្បាស់លាស់ និងសាមញ្ញៗ ។ សូមសរសេរសេចក្ដីពិតនៅលើក្ដារខៀន ឬអញ្ជើញសិស្សឲ្យសរសេរវា ឬគូសចំណាំវានៅក្នុងព្រះគម្ពីរ នោះវានឹងជួយសិស្សឲ្យបញ្ជាក់ពីសេចក្ដីពិតទាំងនេះ នៅក្នុងគំនិតរបស់ពួកគេ ។ សូមសរសេរគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅលើក្ដារខៀន ក៏រំឭកសិស្សឲ្យផ្ដោតទៅលើបទគម្ពីរដែលពួកគេកំពុងសិក្សាផងដែរ ។

ដើម្បីជួយសិស្សយល់នូវអត្ថន័យដើម្បីក្លាយជាកូនចៅនៃព្រះគ្រីស្ទ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងដូចខាងក្រោមដោយ ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ។ ( អ្នកអាចសរសេរសេចក្ដីថ្លែងនេះនៅលើក្ដារខៀន ពីមុនចាប់ផ្ដើមថ្នាក់រៀន ឬផ្ដល់ជាក្រដាសចែកឲ្យសិស្ស ) ។



« ព្រះអង្គសង្គ្រោះ ក្លាយជាព្រះបិតារបស់យើង ក្នុងន័យដែលឃ្លានេះ ត្រូវបានប្រើនៅក្នុងបទគម្ពីរ គឺដោយសារទ្រង់បានប្រទានជីវិតដល់យើង ជីវិតដ៏អស់កល្បជានិច្ច តាមរយៈដង្វាយធួន ដែលទ្រង់បានធ្វើសម្រាប់យើង » ( *Doctrines of Salvation,*comp. Bruce R. McConkie, 3vols. [ឆ្នាំ ១៩៥៤–៥៦], ១:២៩) ។

សូមពន្យល់ថា នៅក្នុងព្រះគម្ពីរមរមន យើងបានរៀនថា អ្នកទាំងឡាយណាដែលបានផ្លាស់ប្ដូរដួងចិត្តរបស់ពួកគេតាមរយៈសេចក្ដីជំនឿទៅលើព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាបុត្រសំណប់ខាងវិញ្ញាណរបស់ទ្រង់ ។ ពួកគេក្លាយជាបុត្រា និងបុត្រីរបស់ទ្រង់ ( សូមមើល ម៉ូសាយ ៥:៧) ។ សូមថ្លែងដោយសាមញ្ញថា បុត្រា និងបុត្រីរបស់ព្រះគ្រីស្ទ គឺជា « អ្នកទាំងឡាយណាដែលបានទទួលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » ( សេចក្ដីណែនាំដល់បទគម្ពីរ « កូនចៅនៃព្រះគ្រីស្ទ » scriptures.lds.org ) ។

- យោងតាមសេចក្ដីថ្លែងការរបស់ប្រធាន ស្ម៊ីធ ហេតុអ្វីក៏យើងអាចក្លាយជាកូនចៅរបស់ព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៥–៦ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលយើងអាចទទួលព្រះយេស៊ូវគ្រីស្ទ ហើយទទួលយកប្រយោជន៍ពីអ្វីដែលទ្រង់បានប្រទានដល់យើង ដើម្បីយើងអាចក្លាយជាកូនចៅរបស់ទ្រង់ ។

- ផ្អែកទៅលើអ្វីដែលអ្នកបានរៀនមកពីខគម្ពីរទាំងនេះ តើអ្នកនឹងពន្យល់នូវអ្វីដែលយើងត្រូវធ្វើដើម្បីក្លាយជាកូនរបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

សូមពន្យល់ថា ព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះ ត្រូវបានដឹកនាំទៅ យ៉េមស៍ ខូវិល ដែលជាអ្នកគង្វាលពួកមេតូឌីស ដែលមានការគោរពម្នាក់ អស់រយៈពេលប្រហែលជា ៤០ ឆ្នាំ ។ មុនពេល យ៉ូសែប ស៊្មីធ បានទទួលវិវរណៈនេះ យ៉េមស៍ ខូវិល បានរៀនអំពីការស្ដារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ទោះជាគាត់ពុំមែនជាសមាជិកនៃសាសនាចក្រក្ដី ក៏គាត់បានចុះសេចក្ដីសញ្ញាថាគោរពតាមរាល់បទបញ្ញត្តិដែលគាត់បានទទួលតាមរយៈយ៉ូសែប ស៊្មីធដែរ ។ ( កំណត់ចំណាំថា តាមការស្រាវជ្រាវថ្មីៗនេះ បានបង្ហាញពីពន្លឺទៅលើការស្គាល់បុរសដែលបានទទួលវិវរណៈនេះ ។ បើសិស្សពុំមានកំណែថ្មីនៃព្រះគម្ពីរចុងក្រោយបំផុតទេ នោះសេចក្ដីណែនាំកណ្ឌនឹងពុំឆ្លុះបញ្ចាំងពីព័ត៌មានថ្មីៗបំផុតនោះទេ ) ។

- ការដឹងថា យ៉េមស៍ ខូវិល ពុំមែនជាសមាជិកនៃសាសនាចក្រ ពេលវិវរណៈនេះត្រូវបានទទួល តើការបង្រៀននៅក្នុង ខ ៥–៦ អាចអនុវត្តចំពោះគាត់យ៉ាងដូចម្ដេច ?

- ហេតុអ្វីវាតម្រូវឲ្យមានសេចក្ដីជំនឿដ៏ខ្លាំងចំពោះ យ៉េមស៍ ខូវិល ដើម្បីទទួលយកព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ហើយទទួលបុណ្យជ្រមុជទឹកដូច្នេះ ? ( ក្នុងនាមជាគ្រូគង្វាលម្នាក់ បើ យ៉េមស៍ ខូវិល បានទទួលបុណ្យជ្រមុជទឹក នោះគាត់នឹងលះបង់តំណែង អ្នករាប់អាន និងប្រាក់ចំណូលរបស់គាត់ ដែលគាត់បានស្ថាបនាឡើងជាង ៤០ ឆ្នាំមកហើយនោះជាពុំខាន ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៧–៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលភស្តុតាងដែលថាព្រះអម្ចាស់បានស្គាល់ យ៉េមស៍ ខូវិល ។ បន្ទាប់ពីសិស្សរៀបរាប់នូវអ្វីដែលពួកគេបានរៀនរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- បើអ្នកស្ថិតនៅក្នុងតំណែងរបស់ យ៉េមស៍ ខូវិល តើអ្នកអាចមានអារម្មណ៍យ៉ាងណា បន្ទាប់ពីបានស្ដាប់ឮពាក្យទាំងនេះ ? ហេតុអ្វី ?

- តើព្រះអម្ចាស់បានមានបន្ទូលអ្វីខ្លះ អំពីស្ថានភាពនៃដួងចិត្តរបស់ យ៉េមស៍ ខូវិលនៅក្នុងគ្រានេះ ? តើអ្នកគិតថា វាមានន័យយ៉ាងណា ដែលដួងចិត្តរបស់គាត់ « ត្រឹមត្រូវនៅចំពោះ » ព្រះអម្ចាស់ នៅពេលវេលានេះ ? ( អ្នកអាចអញ្ជើញសិស្សឲ្យគូសចំណាំពាក្យ *ពេលវេលានេះ* នៅក្នុង ខ ៨ ) ។

- យោងតាម ខ ៩ ហេតុអ្វីក៏ យ៉េមស៍ ខូវិល បានបដិសេធព្រះអម្ចាស់ជាច្រើនលើកច្រើនគ្រាដូច្នេះ ?

សូមចម្លង តារាងខាងក្រោម ដាក់លើក្ដារខៀន ។

| បើអ្នកនឹង. . . | នោះ . . . |
|---|---|
| | |

សូមអញ្ជើញសិស្សបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១០–១២ ។ ពីមុនពួកគេចាប់ផ្ដើមអាន សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បង្គាប់ យ៉េម្ស ខូវិល ឲ្យធ្វើ ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់ទៀតស្វែងរកអ្វីដែលព្រះអម្ចាស់បានសន្យាជាមួយ យ៉េម្ស ខូវិល ថាគាត់នឹងទទួលបាន បើគាត់គោរពប្រតិបត្តិតាមព្រះអម្ចាស់ ។

នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន សូមសរសេរចម្លើយរបស់ពួកគេនៅក្រោមក្បាលរឿងត្រឹមត្រូវនៅក្នុងតារាង ។ ដើម្បីជួយសិស្សឲ្យវិភាគខគម្ពីរទាំងនេះ សូមសួរសំណួរដូចតទៅនេះ ៖

- តើតាមរបៀបណា ដែលយ៉េមស៍ ខូវិល ទទួលបានពរជ័យកាន់តែមហិមា ហើយធ្វើកិច្ចការកាន់តែអស្ចារ្យមួយ បើគាត់បានទទួលការអញ្ជើញរបស់ព្រះអម្ចាស់ឲ្យជ្រមុជទឹកនោះ ? ( សូមជួយសិស្សឲ្យមើលឃើញថា ព្រះអម្ចាស់ បានផ្ដល់ដល់ យ៉េមស៍ នូវភាពពេញលេញនៃដំណឹងល្អ ដែលរួមមានទាំងទំនួលខុសត្រូវ និងពរជ័យទាំងឡាយ ដែលគាត់ពុំមានពីមុនមកដូចជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងការតែងតាំងបព្វជិតភាព ) ។

សូមចង្អុលបង្ហាញនូវពាក្យ *បើសិន* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១០ និង ១១ ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំពាក្យនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- តើពាក្យ *បើសិនជា* នៅក្នុងខគម្ពីរទាំងនេះ សំខាន់អ្វីខ្លះ ? ( ពរជ័យដែលបានសន្យារបស់ព្រះអម្ចាស់ចំពោះ យ៉េមស៍ ខូវិល គឺស្ថិតលើ យ៉េមស៍ បានស្ដាប់តាមសំឡេងរបស់ព្រះអម្ចាស់ ) ។
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីការប្រើពាក្យ *បើសិនជា* របស់ព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះ ? ( ទោះបីជាសិស្សអាចប្រើពាក្យផ្សេងគ្នាក្ដី ក៏ពួកគេគួរប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ពរជ័យដែលបានសន្យារបស់ព្រះអម្ចាស់ គឺស្ថិតនៅលើការស្ដាប់តាមរបស់យើងចំពោះសំឡេងរបស់ទ្រង់** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

សូមឲ្យសិស្សពិចារណាដោយស្ងាត់ស្ងៀម អំពីពរជ័យទាំងឡាយ ដែលព្រះអម្ចាស់បានសន្យានឹងពួកគេ ។ បន្ទាប់មក សូមសុំឲ្យពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖

- តើមានលក្ខណខណ្ឌអ្វីខ្លះ ដែលព្រះអម្ចាស់បានដាក់មកលើអ្នក ពីមុនអ្នកអាចទទួលបានពរជ័យទាំងនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១៣–២៤

*ជេម ខូវែល ត្រូវបានហៅឲ្យផ្សាយភាពពេញលេញនៃដំណឹងល្អនៅរដ្ឋ អូហៃអូ*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១៣–២៤ ដោយការប្រាប់ដល់សិស្សថា ព្រះអម្ចាស់ បានហៅយ៉េមស៍ ខូវិល ឲ្យផ្សាយដំណឹងល្អនៅរដ្ឋ អូហៃអូ ។ ព្រះអម្ចាស់ បានប្រទានការណែនាំដល់គាត់អំពីអ្វីដែលត្រូវបង្រៀន និងរបៀបដើម្បីបង្រៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលខគម្ពីរនេះ ទាក់ទងទៅនឹងគោលការណ៍ទាំងឡាយ ដែលអ្នកបានពិភាក្សារួចហើយនៅក្នុងមេរៀននេះ ។

- តើអ្នកគិតថា អ្នកអាចឆ្លើយតបយ៉ាងដូចម្ដេច បើអ្នកពុំមែនជាសមាជិកនៃសាសនាចក្រ ហើយមានការណែនាំនៅក្នុងវិវរណៈនេះ ត្រូវបានប្រទានឲ្យដល់អ្នកនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០

*ព្រះអម្ចាស់ បើកសម្ដែងពីមូលហេតុដែល យ៉េមស៍ ខូវិល បានបដិសេធព្រះបន្ទូលរបស់ទ្រង់*

សូមប្រាប់សិស្សថា នៅថ្ងៃបន្ទាប់ពីវិវរណៈដែលបានស្គាល់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩ ត្រូវបានសរសេរទុក នោះ យ៉េមស៍ ខូវិល បានចាកចេញពីភូមិ ហ្វាយ៉ែត រដ្ឋ នូវ យ៉ោក ហើយ « បានត្រឡប់ទៅគោលការណ៍ចាស់ និងមិត្តរបស់គាត់ *History of the Church* ១:១៤៥ ) ។ ព្រះអម្ចាស់ បានបើកសម្ដែងដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ថាហេតុអ្វីបានជា យ៉េមស៍ ខូវិល ពុំគោរពតាមការណែនាំរបស់ព្រះអម្ចាស់ ហើយពុំទទួលពរជ័យដែលមានចែងនៅក្នុង កណ្ឌទី ៣៩ ។

សូមអញ្ជើញសិស្សបីនាក់ឲ្យឆ្លាស់វេនគ្នាអានឮៗមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០:១–៣ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែល យ៉េមស៍ ខូវិល ពុំស្ដាប់តាមសំឡេងរបស់ព្រះអម្ចាស់ ។

- សូមប្រៀបធៀប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០:១ ជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៨ ។ តើដួងចិត្ត របស់ យ៉េមស៍ ខូវិល បានផ្លាស់ប្ដូរយ៉ាងដូចម្ដេច ?
- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០:២តើនៅទីបំផុត មានអ្វីដែលនាំឲ្យ យ៉េមស៍ខូវិល បដិសេធព្រះបន្ទូល របស់ព្រះអម្ចាស់ ?
- តើគោលការណ៍អ្វីខ្លះ ដែលអ្នកប្រាប់នៅក្នុង ខ ២? ( សិស្សអាចនឹងប្រាប់ អំពីគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់ថា **ភាពភ័យខ្លាច និងភាពខ្វល់ខ្វាយនៃលោកិយ អាចបណ្ដាលឲ្យយើងបដិសេធព្រះបន្ទូលរបស់ព្រះ ។** សូម សរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ។ អ្នកអាចផ្ដល់យោបល់ថា សិស្សគួរតែកត់ត្រាវានៅក្នុងព្រះគម្ពីររបស់ពួកគេ) ។
- តើភាពខ្វល់ខ្វាយនៃលោកិយអ្វីខ្លះ ដែលអាចរារាំងមនុស្សមិនឲ្យធ្វើតាមព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ មួយភាពភ័យខ្លាច ឬភាពខ្វល់ខ្វាយនៃលោកិយ ដែលអាចរារាំងពួកគេមិនឲ្យធ្វើតាមព្រះយេស៊ូវគ្រីស្ទ និងរស់នៅតាមដំណឹងល្អ ទ្រង់ ។ បន្ទាប់មកសូមឲ្យពួកគេសរសេរនូវអ្វីដែលពួកគេអាចធ្វើ ដើម្បីមានសេចក្ដីជំនឿដើម្បីយកឈ្នះលើភាពភ័យខ្លាច និង ភាពខ្វល់ខ្វាយទាំងឡាយរបស់ពួកគេ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យធ្វើតាមអ្វីដែលពួកគេបានសរសេរ ។

ដើម្បីជួយសិស្សសង្ខេបនូវអ្វីដែលពួកគេបានរៀន សូមសរសេរពាក្យ *បើសិនជា* នៅលើក្ដារខៀន ។ បន្ទាប់មក សូមសួរសំណួរ ដូចខាងក្រោមនេះ ៖

- តើពាក្យនេះ ទាក់ទងនឹង យ៉េមស៍ ខូវិល យ៉ាងដូចម្ដេច ?
- តើវាទាក់ទងនឹងយើងយ៉ាងដូចម្ដេច ?

ដើម្បីបញ្ចប់មេរៀន សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីគ្រាដែលពួកគេបានទទួលពរជ័យមួយ មកពីព្រះអម្ចាស់ ដោយសារពួកគេបានគោរពតាមលក្ខខណ្ឌ ដែលមានភ្ជាប់នឹងពរជ័យនោះ ។ អ្នកក៏អាចនឹងចង់ចែកចាយនូវទីបន្ទាល់របស់អ្នក អំពីពរជ័យទាំងឡាយ ដែលយើងទទួល នៅពេលយើងរក្សាបទបញ្ញត្តិទាំងឡាយផងដែរ ។

មេរៀនទី ៤៥

# នៅរដ្ឋអូហៃអូ

## បុព្វកថា

មេរៀននេះនឹងផ្ដល់ដល់សិស្សនូវសេចក្ដីសង្ខេបខ្លីអំពីបទពិសោធន៍របស់ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ។ នៅក្នុងខែធ្នូ ឆ្នាំ ១៨៣០ ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យផ្លាស់ទៅរដ្ឋ អូហៃអូ ( សូមមើល គ. និង ស. ៣៧:៣) ហើយនៅក្នុងខែមករា ឆ្នាំ ១៨៣១ នោះពួកគេត្រូវបានសន្យាថា ពួកគេនឹងត្រូវបាន « ទទួលព្រះចេស្ដាមកពីស្ថានលើ » បើពួកគេនឹងគោរពតាម (គ. និង ស. ៣៨:៣២) ។

អ្នកទាំងឡាយដែលបានប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ត្រូវបានប្រទានពរយ៉ាងមហិមា ។ វិវរណៈជាបន្ដបន្ទាប់ បានដឹកនាំ ពួកបរិសុទ្ធឲ្យយល់ដឹងកាន់តែជ្រៅជ្រះអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ បន្ថែមពីលើនោះ ពួកគេបានទទួលពរជ័យទាំងឡាយដែលកើតមកពីការស្ថាបនាព្រះវិហារបរិសុទ្ធ និងការផ្សាយដំណឹងល្អ ។ ខណៈដែលសាសនាចក្រមានចំនួនសមាជិក ហើយកម្លាំងខាងវិញ្ញាណកាន់តែច្រើននៅក្នុងរដ្ឋ អូហៃអូ នោះការធ្វើទុក្ខបៀតបៀនក៏កើនឡើងទាស់នឹងសាសនាចក្រ និងអ្នកដឹកនាំផងដែរ ។ ព្យាការី យ៉ូសែប ស៊្មីធ បានរស់នៅក្នុងទីក្រុង ខឺតឡង់ ចាប់ពីខែមករា ឆ្នាំ ១៨៣១ ទៅដល់ ខែ មករា ឆ្នាំ ១៨៣៨ ។

## យោបល់សម្រាប់ការបង្រៀន

### សេចក្ដីសង្ខេបអំពីទីក្រុងខឺតឡង់

សូមពន្យល់ថា នៅក្នុងខែ មករា ឆ្នាំ ១៨៣១ ព្យាការីយ៉ូសែប ស៊្មីធ និង ភរិយារបស់លោក អិមម៉ា ក៏ដូចជា ស៊ីឌនី រិកដុន និង អែតវឺត ប៉ាទ្រិច បានចាកចេញពីរដ្ឋនូវ យ៉ោក ទៅកាន់រដ្ឋ អូហៃអូ ។ ពួកបរិសុទ្ធនៅ នូវ យ៉ោក ភាគច្រើន បានមកតាមប្រាំខែក្រោយ ។ មេរៀនតូច ៗចំនួនបួនដូចខាងក្រោម មាននូវសេចក្ដីសង្ខេបមួយអំពីព្រឹត្តការណ៍សំខាន់នៃរយៈពេលនៃប្រវត្តិសាស្ត្រសាសនាចក្រនៅរដ្ឋ អូហៃអូ ។ សូមបំបែកសិស្សក្នុងថ្នាក់ជាបួនក្រុម ហើយចាត់មេរៀនតូចមួយឲ្យក្រុមនិមួយ ៗ ។ ( បើចំនួនសិស្សក្នុងថ្នាក់របស់អ្នកពុំអាចធ្វើដូចនេះបាន អ្នកអាចបំបែកសិស្សក្នុងថ្នាក់របស់អ្នកជាក្រុមសិស្សពីរបីនាក់ ហើយចាត់មេរៀនតូច ៗច្រើនជាងមួយ ដល់ក្រុមនិមួយ ៗ ) ។ សូមអញ្ជើញសិស្សឲ្យសិក្សាអំពីគម្រោងរបស់ពួកគេ ហើយរៀបចំដើម្បីបង្រៀនឯកសារដល់សិស្សក្នុងថ្នាក់ ។ បន្ទាប់ពីសិស្សមានពេលដើម្បីរៀបចំគ្រប់គ្រាន់ហើយ សូមអញ្ជើញក្រុមនិមួយ ៗឲ្យជ្រើសរើសសមាជិកម្នាក់ដើម្បីបង្រៀនដល់សិស្សក្នុងថ្នាក់ ។ មេរៀននីមួយ ៗគួរតែចំណាយពេលបីទៅបួននាទី ។

*ការប្រើជំនួយការសិក្សាព្រះគម្ពីរ*

សេចក្ដីសង្ខេបកណ្ឌ ផែនទី និងតារាងលំដាប់មាតិកា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា អាចពង្រីកការយល់ដឹងរបស់សិស្សអំពីបទគម្ពីរ និងបរិបទខាងប្រវត្តិសាស្ត្ររបស់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យយោងទៅធនធានទាំងឡាយ ពេលពួកគេសិក្សា ដើម្បីជួយពួកគេយល់អំពីបរិបទខាងប្រវត្តិសាស្ត្រនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ។

### មេរៀនតូច ៗទី ១–ក្រឹត្យវិន័យនៃសាសនាចក្រ

សូមចាប់ផ្ដើមថ្នាក់ដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- ហេតុអ្វីក្រឹត្យវិន័យសំខាន់ ?
- ហេតុអ្វីក្រឹត្យវិន័យសំខាន់នៅក្នុងសាសនាចក្រ ?

សូមរំឭកសិស្សក្នុងថ្នាក់ថា ព្រះអម្ចាស់ បានសន្យាថា ទ្រង់នឹង « ប្រទានក្រឹត្យវិន័យដល់ [ ពួកបរិសុទ្ធ ] មួយ » នៅពេលពួកគេចេញទៅរដ្ឋ អូហៃអូ ( គ. និង ស. ៣៨:៣២ ) ។ សូមពន្យល់ថា នៅពេលពួកបរិសុទ្ធបានទៅដល់រដ្ឋ អូហៃអូ នោះព្រះអម្ចាស់បានបំពេញ ហើយបានប្រទានវិវរណៈមួយ ទាក់ទងនឹងក្រិតវិន័យនៃសាសនាចក្រ ។ នៅក្នុងក្រឹត្យវិន័យនេះ ដែលត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ រួមមាននូវបទបញ្ញត្តិ និងការណែនាំទាំងឡាយ ដែលដឹកនាំដំណើរការក្នុងសាសនាចក្រ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យមើលត្រួសៗនូវសេចក្ដីសង្ខេបកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ ( មាននៅពីមុនខគម្ពីរដំបូងគេ ) សូមរកមើលក្រឹត្យវិន័យមួយចំនួន ដែលព្រះអម្ចាស់ប្រទានដល់ពួកបរិសុទ្ធ ។

សូមអញ្ជើញសិស្សឲ្យគូសចំណាំឃ្លា « ក្រឹត្យវិន័យគ្រប់គ្រងលើការថ្វាយជាទ្រព្យសម្បត្តិ គឺត្រូវបានបង្កើតឡើង » នៅក្នុងសេចក្ដីសង្ខេបកណ្ឌ ។

សូមពន្យល់ថា នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ បានប្រទានក្រឹត្យវិន័យនៃការថ្វាយ ដែលជា « គោលការណ៍ដ៏ទេវភាពមួយ ដែលបុរសនិងស្ត្រី លះបង់ពេលវេលា ទេពកោសល្យ និងទ្រព្យសម្បត្តិខាងសម្ភាររបស់ពួកគេដោយស្ម័គ្រចិត្ត ដើម្បីស្ថាបនា និងកសាងឡើងនូវនគររបស់ព្រះ » ( សេចក្ដីណែនាំដល់បទគម្ពីរ « “Consecrate, Law of Consecration, »scriptures.lds.org) ។ គោលបំណងនៃក្រឹត្យវិន័យនៃការថ្វាយមួយចំនួន បានរួមមានទាំងការមើលថែដល់អ្នកទាល់ក្រ លុបបំបាត់ភាពកំណាញ់ ហើយបង្កើតសាមគ្គីភាពនៅក្នុងចំណោមពួកបរិសុទ្ធ ។

ប្រហែលជាលើសពីមួយឆ្នាំបន្តិច បន្ទាប់ពីព្រះអម្ចាស់បើកសម្ដែងក្រឹត្យវិន័យនៃការថ្វាយ ដែលទ្រង់បានបញ្ជាឲ្យអ្នកដឹកនាំនៃសាសនាចក្រស្ថាបនាជាក្រុមហ៊ុនសាមគ្គីភាព ។ គោលបំណងមួយនៃក្រុមហ៊ុនសាមគ្គីភាព គឺផ្ដោតទៅលើគោលការណ៍ទាំងឡាយនៃក្រឹត្យវិន័យនៃការថ្វាយ គឺត្រូវស្ថាបនាឃ្លាំងដើម្បីជួយចំពោះតម្រូវការបណ្ដោះអាសន្ន របស់សមាជិកនៃសាសនាចក្រ ជាពិសេសអ្នកទាំងឡាយណាដែលក្រីក្រ ។ នេះគឺជាពរជ័យមួយចំពោះពួកបរិសុទ្ធនៅគ្រានេះ ដោយសារសមាជិកសាសនាចក្រជាច្រើន ដែលបានផ្លាស់ទីលំនៅមកពីរដ្ឋ នូវ យ៉ោក ទៅកាន់រដ្ឋ អូហៃអូ ដែលត្រូវទុកចោលផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់ពួកគេ ។ ក្រុមហ៊ុនសាមគ្គីភាព ក៏មានផ្ដល់ជាមូលនិធិ ដើម្បីចំណាយលើកិច្ចការរបស់សាសនាចក្រផ្សេងៗដូចជា កិច្ចការអ្នកផ្សព្វផ្សាយសាសនា និង ការបោះពុម្ព ។ យើងនឹងរៀនច្រើនទៀតអំពីក្រឹត្យវិន័យនៃការថ្វាយ និងឥទ្ធិពលរបស់វាទៅលើពួកបរិសុទ្ធនៅក្នុងមេរៀនក្រោយ ។

## មេរៀនតូចៗទី ២–ព្រះវិហារបរិសុទ្ធខឺតឡង់

សូមរំឭកសិស្សអំពីសេចក្ដីសន្យារបស់ព្រះអម្ចាស់ដើម្បីប្រទានដល់ពួកបរិសុទ្ធ « ព្រះចេស្ដាមកពីស្ថានលើ » នៅពេលពួកគេមកដល់រដ្ឋ អូហៃអូ ( សូមមើល គ. និង ស. ៣៨:៣២ ) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលបទបញ្ញត្តិ ដែលព្រះអម្ចាស់បានប្រទានដល់ពួកអ្នកបរិសុទ្ធ ។ បន្ទាប់ពីពួកគេបានប្រាប់ថា ព្រះអម្ចាស់បានបញ្ជាពួកគេឲ្យស្ថាបនាដំណាក់មួយឡើង ចូរពន្យល់ថា « ដំណាក់ » នោះ ព្រះអម្ចាស់សំដៅទៅលើព្រះវិហារបរិសុទ្ធ ។ ព្រះវិហារបរិសុទ្ធ ខឺតឡង់ គឺជាព្រះវិហារបរិសុទ្ធដំបូងគេ ដែលបានសាងសង់នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ។

សូមអញ្ជើញសិស្សឲ្យបើករូបថតនៃព្រះវិហារបរិសុទ្ធខឺតឡង់ នៅក្នុងព្រះគម្ពីររបស់ពួកគេ ( រូបថតប្រវត្តិសាស្ត្រសាសនាចក្រ រូបថតទី ៩ « ព្រះវិហារបរិសុទ្ធខឺតឡង់ » ) ។

សូមពន្យល់ថា ព្រះវិហារបរិសុទ្ធខឺតឡង់ចំណាយពេលប្រហែលជាបីឆ្នាំដើម្បីសាងសង់ ។ បន្ទាប់ពីព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងនៅថ្ងៃទី ២៧ ខែមិនា ឆ្នាំ ១៨៣៦ ព្រះអម្ចាស់បានចាប់ផ្ដើមបំពេញការសន្យារបស់ទ្រង់ដើម្បីប្រទានឲ្យពួកបរិសុទ្ធដោយអំណាច ហើយពួកគេបានទទួលបទពិសោធន៍នៃពរជ័យខាងវិញ្ញាណដ៏អស្ចារ្យ ។ ឧទាហរណ៍ ព្រះអម្ចាស់បានលេចមកយ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរ ដោយផ្ទាល់នៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ហើយបានប្រកាសថា គាត់បាន « បានទទួលដំណាក់នេះ » (គ. និង ស. ១១០:៧) ។ ទ្រង់បានបញ្ជូនសាទូតសួគ៌បីអង្គមកផងដែរគឺ– ម៉ូសេ អេលីយ៉ា និង អេលីយ៉ាស– ដើម្បីស្ដារឡើងវិញនូវកូនសោបព្វជិតភាពសំខាន់លើផែនដី ។ កូនសោទាំងនេះ នឹងផ្ដល់ដល់ពួកបរិសុទ្ធនូវសិទ្ធិអំណាចដើម្បីធ្វើពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ហើយផ្សាភ្ជាប់គ្រួសារសម្រាប់ភាពអស់កល្បជានិច្ច ។ បន្ថែមពីលើនោះ « បានប្រគល់ដល់យើងនូវកូនសោទាំងឡាយនៃការប្រមូលសាសន៍អ៊ីស្រាអែល » ត្រូវបានស្ដារឡើងវិញក្នុងគ្រានេះ (គ. និង ស. ១១០:១១) ។ ជាលទ្ធផល អ្នកផ្សព្វផ្សាយសាសនាត្រូវបានហៅ ហើយផ្ដល់សិទ្ធិអំណាចដើម្បីបង្រៀនដំណឹងល្អនៅទូទាំងផែនដី ។

## មេរៀនតូចៗទី ៣– កិច្ចការផ្សព្វផ្សាយសាសនា

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៦–៧ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលបទបញ្ញត្តិដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ បន្ទាប់ពីពួកគេបានមកដល់រដ្ឋ អូហៃអូ ។ បន្ទាប់ពីសិស្សបានអានខទាំងឡាយហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើបទបញ្ញត្តិអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ?
- យោងតាម ខ ៦ តើអ្នកផ្សព្វផ្សាយសាសនាទាំងនេះផ្សាយដំណឹងល្អយ៉ាងដូចម្ដេច ?
- តើការណ៍នេះស្រដៀងគ្នាទៅនឹងរបៀបដែលអ្នកផ្សព្វផ្សាយសាសនា ផ្សាយដំណឹងល្អនៅសព្វថ្ងៃយ៉ាងដូចម្ដេច ?

សូមពន្យល់ថា នៅពេលព្រះវិហារបរិសុទ្ធខឺតឡង់ត្រូវបានឧទ្ទិសឆ្លង ហើយកូនសោនៃការប្រមូលផ្ដុំនៃសាសន៍អ៊ីស្រាអែលត្រូវបានស្ដារឡើងវិញ នោះសមាជិកនៃសាសនាចក្រ បានចាប់ផ្ដើមផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនៅច្រើនកន្លែងទៀត ។ សូមអញ្ជើញសិស្សឲ្យបើកបទគម្ពីររបស់ពួកគេទៅ ផែនទី ទី៣ នៅក្នុងវគ្គផែនទីប្រវត្តិសាស្ត្រសាសនាចក្រក្នុងគម្ពីររបស់ពួកគេ ( « The New York, Pennsylvania, and Ohio Area of the USA » ) ។

នៅពេលសិស្សមើលទៅផែនទី សូមរំឭកពួកគេថា ព្រះអម្ចាស់ បានសន្យានឹងពួកបរិសុទ្ធថា ទ្រង់នឹងបញ្ជូនពួកគេឲ្យចេញទៅផ្សាយ « នៅក្នុងចំណោមគ្រប់អស់ទាំងសាសន៍ » (គ. និង ស. ៣៨:៣៣ ) ។ សូមពន្យល់ថា ទីក្រុងខឺតឡង់ គឺជាកន្លែងពិសេសមួយ ដើម្បីចាប់ផ្ដើមបញ្ជូនអ្នកផ្សព្វផ្សាយសាសនាទៅទូទាំងពិភពលោក ។ ទីក្រុងខឺតឡង់ គឺនៅជិតនឹងផ្លូវសំខាន់មួយចំនួនសម្រាប់ការធ្វើដំណើរនៅក្នុងសហរដ្ឋ ។ ចេញពីទីក្រុងខឺតឡង់ អ្នកផ្សព្វផ្សាយសាសនាត្រូវធ្វើដំណើរក្នុងរយៈពេលខ្លីដើម្បីទៅជិះទូកនៅទន្លេធំៗ និងព្រែក អ៊ីរីន របស់អាមេរិក ។ ពួកគេក៏អាចចេញចូលទៅប្រព័ន្ធផ្លូវជាតិនៅខាងត្បូង ហើយប្រព័ន្ធព្រែកជីកនៅខាងជើងផងដែរ ។ ដោយសារតែការណ៍នេះ ទីក្រុងខឺតឡង់ គឺជាកន្លែងចេញដំណើរបេសកកម្មទៅប្រទេសកាណាដា ទៅផ្នែកផ្សេងៗទៀតនៃសហរដ្ឋ និងអាណាចក្រប្រទេសអង់គ្លេស ។

សូមពន្យល់ថា ដោយសារតែកិច្ចការផ្សព្វផ្សាយសាសនា អំឡុងគ្រានេះ សមាជិកភាពនៃសាសនាចក្រ នៅទូទាំងពិភពលោកបានកើនឡើងដល់រាប់ពាន់នាក់ ។ នៅក្នុងឆ្នាំ ១៨៣៧ អែលឌើរ ហ៊ីប៊ើ ស៊ី឴ ឃីមបឹល និង អូរសុន ហៃឌ ត្រូវបានហៅទៅជាមួយនឹងមនុស្សប្រាំនាក់ទៀតក្នុងបេសកកម្មមួយទៅអាណាចក្រប្រទេសអង់គ្លេស ជាកន្លែងដែលពួកគេបានធ្វើបុណ្យជ្រមុជទឹកឲ្យប្រជាជនប្រហែលជា ២,០០០ នាក់ ។ ត្រឹមឆ្នាំ ១៨៣៨ នៅពេលពួកបរិសុទ្ធចាកចេញពីក្រុងខឺតឡង់ ដោយសារតែការបៀតបៀន នោះមានសមាជិកសាសនាចក្រប្រហែលជា ២,០០០ នាក់ រស់នៅក្នុងទីក្រុងខឺតឡង់ ហើយមានជិតដល់ ១, ៨០០០ នាក់នៅទូទាំងពិភពលោក ។

### មេរៀនតូចៗទី ៤– វិវរណៈ និងព្រឹត្តការណ៍សំខាន់ដទៃទៀត

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៦១ ដោយស្ងាត់ស្ងៀម ។ បន្ទាប់ពីពួកគេបានបញ្ចប់ការអាន សូមចង្អុលបង្ហាញថា បន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានមកដល់រដ្ឋ អូហៃអូ ព្រះអម្ចាស់បានមានបន្ទូលប្រាប់លោកថា គាត់នឹង « ទទួលវិវរណៈថែមទៅលើវិវរណៈ » បើលោកនឹងសូមដល់ព្រះ ។ បន្ទាប់មក សូមអញ្ជើញសិស្សឲ្យបើកទៅតារាងលំដាប់មាតិកានៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ( មាននៅបន្ទាប់ពីសេចក្ដីផ្ដើម ) ។ សូមឲ្យពួកគេកំណត់ទីតាំងដែលវិវរណៈភាគច្រើនបំផុតបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ត្រូវបានទទួល ។ បន្ទាប់ពីពួកគេបានរកឃើញថា វិវរណៈភាគច្រើនត្រូវបានទទួលនៅក្នុងរដ្ឋ អូហៃអូ សូមពន្យល់ថា វិវរណៈយ៉ាងច្រើននៅរដ្ឋ អូហៃអូ បានបំពេញតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ។

ដើម្បីបង្ហាញសិស្សក្នុងថ្នាក់នូវវិវរណៈសំខាន់ៗមួយចំនួន ដែលបានទទួលនៅក្នុងរដ្ឋ អូហៃអូ សូមចាត់តាំងកណ្ឌ ដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ដូចខាងក្រោមមួយ ឬពីរ ដល់សិស្សម្នាក់ៗ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦, ៨៩, ១០៧, ១៣៧ ។

សម្រាប់កណ្ឌនិមួយៗ សូមឲ្យសិស្សដែលបានចាត់អានសេចក្ដីណែនាំកណ្ឌ និងមើលត្រួសៗពីសេចក្ដីសង្ខេបកណ្ឌ ដែលមាននៅមុនខទីមួយ ។ បន្ទាប់មក អញ្ជើញសិស្សម្នាក់ៗឲ្យរៀបរាប់អំពី មូលហេតុដែលកណ្ឌដែលបានចាត់ដល់ពួកគេគឺសំខាន់ ។ នៅពេលពួកគេពិពណ៌នា សូមប្រាកដថា ពួកគេរៀបរាប់ដូចខាងក្រោម ៖

គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦, ១៣៧ ( វិវរណៈអំពីកម្រិតទាំងបីនៃសិរីល្អ និងការនិមិត្តអំពីនគរស្ថានសួគ៌ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ( ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ( វិវរណៈអំពីបព្វជិតភាព )

បន្ទាប់ពីសិស្សម្នាក់ៗអាចបានរាយការណ៍ សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថាវាយ៉ាងណាដែរចំពោះពួកបរិសុទ្ធនៅក្នុងរដ្ឋ អូហៃអូ ដើម្បីស្ដាប់ឮសេចក្ដីពិតទាំងនេះខ្លះៗជាលើកដំបូង ?

សូមពន្យល់ថា បន្ថែមទៅលើសេចក្ដីពិតដែលបានបើកសម្ដែងទាំងនេះ ព្រះអម្ចាស់ ក៏បានណែនាំយ៉ូសែប ស្ម៊ីធ ឲ្យរៀបចំថ្នាក់ដឹកនាំសាសនាចក្រអំឡុងគ្រានេះផងដែរ ។ គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងកូរ៉ុមនៃពួកចិតសិបនាក់ ត្រូវបានបង្កើតឡើងជាផ្លូវការ ខណៈពេលដែលពួកបរិសុទ្ធបានរស់នៅក្នុងរដ្ឋ អូហៃអូ ។ បន្ថែមពីលើនោះ យ៉ូសែប ស្ម៊ីធ បានបន្តកិច្ចការរបស់លោកនៅក្នុងការបកប្រែព្រះគម្ពីរប៊ីប ។

### ការផ្ដុយ និងការក្បត់សាសនា រុកគួនពួកបរិសុទ្ធនៅរដ្ឋអូហៃអូ

បន្ទាប់ពីសិស្សបានបញ្ចប់សកម្មភាពខាងលើហើយ សូមពន្យល់ថា ទន្ទឹមនឹងពួកបរិសុទ្ធត្រូវបានប្រទានពរយ៉ាងច្រើន មកពីព្រះអម្ចាស់នៅក្នុងរដ្ឋ អូហៃអូ នោះសាតាំងក៏បានបង្កើនការផ្ទុយទាស់នឹងសាសនាចក្រដំណាលគ្នានោះផងដែរ ។ ពេលពួកបរិសុទ្ធបានមកដល់ទីក្រុងខឺតឡង់ភ្លាម នោះពួកអ្នកប្រឆាំងនឹងពួកមរមន បានចាប់ផ្ដើមវាយប្រហារមកលើសាសនាចក្រ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ យ៉ូសែប ស្ម៊ីធ ទាក់ទងនឹងស្ថានភាពទាំងនេះ ៖



« មានរបាយការណ៍ខុសឆ្គង ការកុហក និងរឿងឆ្កួតលីលាជាច្រើន ត្រូវបានបោះពុម្ពនៅក្នុងកាសែត ហើយផ្សាយទៅគ្រប់ទិសទី ដើម្បីរាំងមនុស្សកុំឲ្យរៀនពីកិច្ចការនេះ ឬឱបក្រសោបយកសេចក្ដីជំនឿ » ( នៅក្នុង *History of the Church,* ១:១៥៨ ) ។

សូមពន្យល់ថា របាយការណ៍អវិជ្ជមានទាំងនេះមួយចំនួន ត្រូវបានចាប់ផ្ដើមដោយមនុស្សមួយចំនួនដែលបានចាកចេញពីសាសនាចក្រសម្រាប់មូលហេតុផ្សេងៗ ។ ឧទាហរណ៍ នៅក្នុងខែកញ្ញា ឆ្នាំ ១៨៣១ សមាជិកចាស់របស់សាសនាចក្រម្នាក់ឈ្មោះ អែសរ៉ា ប៊ូស បានព្យាយាមឃាត់មនុស្សកុំឲ្យចូលរួមនៅក្នុងសាសនាចក្រ ហើយបានបោះពុម្ពសំបុត្រចំនួនប្រាំបួនច្បាប់ដែលប្រាប់លម្អិតអំពីការរិះគន់របស់គាត់អំពីសាសនាចក្រ ( សូមមើល *Documents, Volume ១: ខែ កក្កដា ឆ្នាំ ១៨២៨–ខែមិថុនា ឆ្នាំ ១៨៣១* vol. ១ of the Documents series of*The Joseph Smith Papers* [ឆ្នាំ ២០១៣], ២០៣–៤; សូមមើលផងដែរ *Church History in the Fulness of Times Student Manual* បានបោះពុម្ពជាលើកទី ២ ។ [ Church Educational System manual, ឆ្នាំ ២០០៣ ], ១១៣–១៥ ) ។ សំបុត្រទាំងនេះ បានបង្កើតជាការរុកគួនដល់សាសនាចក្រ ។ ការបៀតបៀន ដែលជាលទ្ធផលមកពីឥទ្ធិពលដូច្នេះ ជួនកាលធ្វើឲ្យមានអំពើហិង្សាជាពិសេសចំពោះព្យាការី និងអ្នកដឹកនាំសាសនាចក្រដទៃទៀត ។

នៅក្នុងឧប្បទ្ទវហេតុដ៏ធ្ងន់ធ្ងរមួយ នៅយប់ថ្ងៃទី ២៤ ខែមិនា ឆ្នាំ ១៨៣២ មានពួកមនុស្សកំណាចចំនួន ២៥ ទៅ ៣០ នាក់ បានវាយប្រហារលើផ្ទះរបស់ ចន ចនសុន នៅហៃរ៉ាំ រដ្ឋ អូហៃអូ ជាកន្លែងដែល យ៉ូសែប និង អិមម៉ា កំពុងស្នាក់នៅ ។

បុរសទាំងនោះបានចូលទៅចាប់ យ៉ូសែប ស៊្មីធ ហើយបានទាញលោកចេញមកក្រៅផ្ទះទាំងយប់ ។ ពួកគេបានច្របាច់កលោក បានវាយលោក ហើយបានព្យាយាមចាក់អាសុីតមួយដបតូចចូលទៅក្នុងមាត់របស់លោក ដែលធ្វើឲ្យបាក់ធ្មេញរបស់លោកមួយ បណ្ដាលឲ្យលោកក្រោយមកនិយាយចេញតែសំឡេងខ្សាវៗ។ បន្ទាប់មកពួកគេបានចាក់ជ័រកៅស៊ូ និងបិទរោមសត្វពេញខ្លួនលោក ហើយទុកលោកចោល ។ នៅពេលយ៉ូសែប មានកម្លាំងបន្តិចមកវិញ  លោកបានខិតខំត្រឡប់ទៅផ្ទះវិញ ។ នៅពេលលោកបានទៅដល់មាត់ទ្វា ហើយអិមម៉ាបានឃើញលោកមានសុទ្ធតែជ័រកៅស៊ូពេញខ្លួន ដែលបានមើលទៅដូចជាឈាម នោះនាងបានសន្លប់បាត់ស្មារតី ។ មិត្តភក្ដិជាច្រើន បានចំណាយពេលពេញមួយយប់ ដើម្បីជួយលាងសម្អាតជ័រកៅស៊ូនោះ ។ នៅថ្ងៃស្អែកឡើង ដែលត្រូវជាថ្ងៃអាទិត្យ នោះ យ៉ូសែប បានផ្សាយទេសនកថាមួយ ដែលក្នុងនោះមានពួកមនុស្សកំណាចមួយចំនួនបានមកចូលរួមផងដែរ ។ បន្ទាប់ពីទេសនកថា នោះយ៉ូសែប បានធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សបីនាក់ ។ (សូមមើល *ប្រវត្តិនៃសាសនាចក្រ* ១:២៦១–៦៥)។

អំឡុងពេលដែលមានបញ្ហា និងការច្របូកច្របល់ក្នុងការវាយប្រហារនេះ ទ្វាផ្ទះបានបើកចំហរចោល ។ ដែលជាលទ្ធផលបណ្ដាលឲ្យកូនប្រុសរបស់ យ៉ូសែប ឈ្មោះយ៉ូសែប មើរដក់ ស៊្មីធ ដែលកំពុងមានជំងឺកញ្ជ្រិលនោះ កើតជម្ងឺ « គ្រុនផ្ដាសសាយធំ » ហើយបានស្លាប់ក្នុងរយៈពេលប្រាំថ្ងៃក្រោយមក ។ នៅយប់ដដែលនោះ ស៊ីឌនី រិកដុន បានដើរអូសជើងរបស់គាត់មកពីផ្ទះ ។ ក្បាលរបស់គាត់បានត្រូវបែកយ៉ាងដំណំ ដោយសារតែដួលទៅបោកលើដីរឹងនោះ ហើយគាត់ត្រូវវង្វេងវង្វាន់អស់ជាច្រើនថ្ងៃ ។ ( សូមមើល *History of the Church* ១:២៦៥ ) ។

សូមពន្យល់ថា មិនថាមានការលំបាកដូចនេះ និងការលំបាកផ្សេងៗទៀតប៉ុណ្ណោះទេ ពួកបរិសុទ្ធបានបន្តប្រមូលផ្ដុំគ្នានៅទីក្រុងខឺតឡង់ ជាពិសេសចាប់ពីឆ្នាំ ១៨៣៦ ទៅដល់ឆ្នាំ ១៨៣៨ ។ ទោះជាយ៉ាងណាក៏ដោយ ការបៀតបៀនបានមានកាន់តែធ្ងន់ធ្ងរឡើងៗ អំឡុងនិទាឃរដូវ ឆ្នាំ ១៨៣៨ ដែលពួកបរិសុទ្ធភាគច្រើន ត្រូវបានបង្ខំឲ្យចាកចេញពីរដ្ឋ អូហៃអូ ។ អ្នកដឹកនាំសាសនាចក្រមួយចំនួន រួមមានទាំង យ៉ូសែប ស៊្មីធ, ស៊ីឌនី រិកដុន និង ព្រិកហាំ យ៉ង់ ត្រូវរត់ភៀសខ្លួនពីទីក្រុងខឺតឡង់ ដើម្បីសុវត្ថិភាពជីវិតរបស់ពួកលោក ។

សូមបញ្ចប់មេរៀនដោយការថ្លែងទីបន្ទាល់ថា ទោះជាសាសនាចក្របានជួបនឹងការសាកល្បង ព្រមទាំងការបៀតបៀនយ៉ាងខ្លាំងនៅក្នុងទីក្រុងខឺតឡង់ក្ដី ក៏ព្រះអម្ចាស់បានប្រទានពរដល់អ្នកទាំងឡាយដែលបន្តនៅស្មោះត្រង់យ៉ាងច្រើនអនេកផងដែរ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៤០; នៅរដ្ឋអូហៃអូ ( មេរៀនទី ៩ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៤០ និង « នៅរដ្ឋ អូហៃអូ » ( មេរៀនទី ៩ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៧)

តាមរយៈវិវរណៈមួយទៅកាន់ អែតវើត ប៉ាទ្រិច ពីមុនបុណ្យជ្រមុជទឹករបស់គាត់ សិស្សបានរៀនថាអ្នកកាន់បព្វជិតភាព ត្រូវបានហៅឲ្យផ្សព្វផ្សាយដំណឹងល្អ ហើយត្រូវតែមានភាពស្អាតស្អំ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨)

នៅពេលសិស្សបានសិក្សាព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ដែលឲ្យពួកបរិសុទ្ធប្រមូលគ្នីគ្នាទៅរដ្ឋ អូហៃអូ នោះពួកគេបានឃើញថាព្រះអម្ចាស់ជ្រាបដឹងការណ៍គ្រប់យ៉ាង ថាទ្រង់អាចព្រមានយើងអំពីគ្រោះថ្នាក់ ហើយថាទ្រង់ប្រទានបទបញ្ញត្តិដល់យើងសម្រាប់ជាការការពារខ្លួនយើង ។ ពួកគេក៏បានរៀនផងដែរថា ព្រះអម្ចាស់បានសន្យាដល់ពួកបរិសុទ្ធថា ប្រសិនបើពួកគេធ្វើតាមព្រះបញ្ញត្តិរបស់ទ្រង់ ពួកគេនឹងត្រូវបានរៀបចំ ហើយនឹងពុំខ្លាចឡើយ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០)

ព្រះអម្ចាស់បានដឹកនាំអាចារ្យប្រូតេស្តង់ឈ្មោះ យ៉េម្ស ខូវ៉ល ឲ្យទទួលពិធីបុណ្យជ្រមុជទឹក ហើយផ្សាយអំពីភាពពោរពេញនៃដំណឹងល្អ ។ ចេញពីការណែនាំនេះ សិស្សបានរៀនថា ប្រសិនបើយើងទទួលយកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងប្រទានឲ្យយើងនូវអំណាចដើម្បីក្លាយទៅជាបុត្រា និង បុត្រីរបស់ទ្រង់ ។ សិស្សក៏បានឃើញផងដែរថាពរជ័យដែលបានសន្យារបស់ព្រះអម្ចាស់ គឺស្របទៅតាមការស្ដាប់តាមសំឡេងរបស់ទ្រង់ ។ យ៉េម្ស ខូវ៉ល បានបដិសេធការអញ្ជើញរបស់ព្រះអង្គសង្គ្រោះដើម្បីជ្រមុជទឹក ។ សិស្សបានរៀនថា ភាពភ័យខ្លាច និង ភាពខ្វល់ខ្វាយនៃលោកិយ អាចបណ្ដាលឲ្យយើងបដិសេធព្រះបន្ទូលរបស់ព្រះ ។

### មេរៀនទី ៤ ( នៅរដ្ឋអូហៃអូ )

មេរៀននេះនឹងផ្ដល់ទស្សនៈមួយដល់សិស្ស អំពីបទពិសោធន៍របស់ពួកបរិសុទ្ធនៅក្នុងរដ្ឋអូហៃអូ ពីឆ្នាំ ១៨៣១ ដល់ ឆ្នាំ ១៨៣៨ ។ សិស្សបានរៀនថា ព្រះអម្ចាស់បានសន្យាដល់ពួកបរិសុទ្ធនៅក្នុងរដ្ឋអូហៃអូថា ទ្រង់នឹងបើកសម្ដែងក្រឹត្យវិន័យរបស់ទ្រង់ និង ប្រទានអំណាចពីស្ថានខ្ពស់ដល់ពួកគេ ។ ក្រៅពីនោះ ព្រះអម្ចាស់បានប្រកាសថាទ្រង់នឹងហៅពួកបរិសុទ្ធឲ្យផ្សព្វផ្សាយដំណឹងល្អនៅទូទាំងពិភពលោក ។ សិស្សបានរៀនពី របៀបដែលព្រះអម្ចាស់បានប្រទានវិវរណៈជាច្រើនដល់ពួកបរិសុទ្ធ ហើយបានបំពេញសេចក្ដីសន្យារបស់ទ្រង់ ទោះបីជាមានសេចក្ដីទំនាស់ និង ការបៀតបៀនក៏ដោយ ។ ពួកគេក៏បានរៀនផងដែរអំពីព្រឹត្តិការណ៍ និង សេចក្ដីទំនាស់ដ៏អកុសលមួយចំនួន ដែលពួកបរិសុទ្ធបានជួបប្រទះអំឡុងពេលនៅក្នុងរដ្ឋអូហៃអូ ។

## សេចក្ដីផ្ដើម

ព្រះអម្ចាស់ពុំគ្រាន់តែណែនាំពួកបរិសុទ្ធឲ្យប្ដូរទីលំនៅទៅរដ្ឋអូហៃអូតែប៉ុណ្ណោះទេ ទ្រង់ក៏បានប្រទានព្រះឱវាទដល់ពួកគេនូវរបៀបប្រាស្រ័យទាក់ទងគ្នានឹងគ្នា ។ នៅក្នុងមេរៀននេះ សិស្សនឹងរៀនអំពីការបញ្ជារបស់ព្រះយេស៊ូវគ្រីស្ទឲ្យមានសាមគ្គីភាព ហើយផ្ដល់តម្លៃឲ្យមនុស្សដទៃដូចយើងផ្ដល់តម្លៃដល់ខ្លួនឯងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៨

*ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យមានសាមគ្គីភាព*

សូមចែកសិស្សជាពីរក្រុម ហើយឲ្យវត្ថុចម្រុះផ្សេងគ្នាដល់ក្រុមនិមួយៗ ដែលអាចប្រើវាដើម្បីសាងសង់អគារ ( វត្ថុទាំងនោះរួមមានដូចជា ឈើដុំតូចៗ ពែងក្រដាស ឬ ប្រអប់ទទេតូចៗ ) ។ សូមប្រាកដថាមានមួយក្រុមត្រូវទទួលវត្ថុទាំងនោះច្រើនជាង ឬ ធំជាងក្រុមផ្សេងទៀត ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ *សូមធ្វើប៉មមួយឲ្យខ្ពស់តាមដែលអាចធ្វើបានដោយប្រើវត្ថុទាំងនេះ ។* សូមកុំនិយាយថាសកម្មភាពនេះគឺជាការប្រកួត ឬ និយាយឲ្យពួកគេសាងសង់ប៉មពីរឡើយ ។ សិស្សទំនងជាគិតថា ក្រុមទាំងពីរកំពុងប្រកួតប្រជែងគ្នា ។ ប្រសិនបើពួកគេសួរសំណួរថា តើពួកគេគួរតែធ្វើការរួមគ្នា ឬ ធ្វើការតែតាមក្រុមរៀងៗខ្លួន នោះគ្រាន់តែប្រាប់ពួកគេថានូវគោលបំណងនោះម្ដងទៀតថា ៖ ពួកគេត្រូវសាងសង់ប៉មមួយឲ្យបានខ្ពស់តាមតែអាចធ្វើបាន ។

សូមទុកពេលមួយនាទីដើម្បីឲ្យពួកគេបញ្ចប់កិច្ចការនេះ ។ បន្ទាប់ពីសកម្មភាពនេះ សូមឲ្យពួកគេវាយតម្លៃថាតើនរណាគឺជា « អ្នកឈ្នះ » ។ បន្ទាប់ពីសិស្សបានចែកចាយគំនិតរបស់ខ្លួនហើយ សូមប្រាប់ពួកគេថា ដើម្បីកំណត់ថាពួកគេបានជោគជ័យ ប៉ុណ្ណែនៅក្នុងសកម្មភាពនេះ នោះពួកគេនឹងត្រូវតែសិក្សាឱវាទរបស់ព្រះអម្ចាស់ដែលបានប្រទានឲ្យពួកបរិសុទ្ធ នៅពេលពួកគេត្រូវបានរៀបចំខ្លួនឲ្យប្ដូរទីលំនៅទៅរដ្ឋ អូហៃអូ ។ សូមអញ្ជើញសិស្សឲ្យរកមើលការយល់ដឹងពីសកម្មភាពនេះ ទៅនឹងជីវិតរបស់ពួកគេផងដែរ នៅពេលពួកគេសិក្សាការណែនាំរបស់ព្រះអម្ចាស់ ចំពោះពួកបរិសុទ្ធកាលពីជំនាន់មុន ។

សូមឲ្យសិស្សនឹកឡើងវិញអំពីមូលហេតុ ដែលព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធឲ្យប្រមូលផ្ដុំគ្នាទៅរដ្ឋអូហៃអូ ។ ( ប្រសិនបើចាំបាច់ សូមលើកទឹកចិត្តពួកគេឲ្យរំឭកការកត់ចំណាំរបស់ខ្លួននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៧–៣៨ និង នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ) ។ ចម្លើយរបស់សិស្សគួរតែរួមមានទាក់ទងនឹង គ្រោះថ្នាក់ដែលពួកបរិសុទ្ធកំពុងជួបប្រទះនៅទីក្រុងនូវ យ៉ោក ព្រមទាំងពរជ័យដែលព្រះអម្ចាស់បានសន្យាថា ប្រទានដល់ប្រជារាស្ត្ររបស់ទ្រង់នៅពេលពួកគេបានប្រមូលផ្ដុំគ្នារដ្ឋអូហៃអូ ។

សូមពន្យល់ថា ព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធទាក់ទងនឹងការប្ដូរទីលំនៅរបស់ពួកគេទៅរដ្ឋអូហៃអូ នោះទ្រង់បានប្រទានព្រះឱវាទដល់ពួកគេស្ដីពីរបៀបដែលពួកគេត្រូវប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៣–២៥ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវឃ្លាមួយ ដែលបង្រៀនពីរបៀប ដែលយើងអាចប្រព្រឹត្តិចំពោះមនុស្សដទៃទៀត ។

- តើព្រះអម្ចាស់បានមានព្រះបន្ទូលថា ឲ្យយើងគួរតែប្រព្រឹត្តិចំពោះមនុស្សដទៃយ៉ាងដូចម្ដេច ?
- តើអ្នកគិតថា ការគោរពបងប្អូនខ្លួនដូចជាខ្លួនឯងផ្ទាល់ មានន័យយ៉ាងដូចម្ដេច ? ( បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **យើងត្រូវឲ្យតម្លៃអ្នកដទៃឲ្យបានច្រើនដូចជាយើងឲ្យតម្លៃដល់ខ្លួនយើងដែរ )**
- តើមានអ្វីកើតឡើងខ្លះពេលមនុស្សគិតថា ខ្លួនគេមានតម្លៃច្រើនជាង ឬល្អប្រសើរជាងអ្នកដទៃនោះ ?
- តើពរជ័យអ្វីខ្លះអាចត្រូវបានប្រទានមកដល់យើង ក្នុងនាមជាសាសនាចក្រទាំងមូល ឬ ជាបុគ្គលផ្ទាល់ នៅពេលយើងពុំចាត់ទុកខ្លួនយើងថាមានតម្លៃជាងអ្នកដទៃនោះ ?

សូមលើកក្រណាត់ស្អាត និង កន្ទបមួយដុំឡើង ។ សូមសួរសិស្សថា តើពួកគេចង់យកក្រណាត់ណាមួយមកស្លៀក ? សូមពន្យល់ថា ដើម្បីជួយពួកបរិសុទ្ធឲ្យយល់ពីគោលការណ៍នេះ ព្រះអម្ចាស់បានប្រទានបានប្រទាននូវរឿងប្រៀបប្រដូចមួយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៦ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយរកមើលរបៀបដែលបុរសក្នុងរឿងប្រដូចនេះ បានប្រព្រឹត្តចំពោះកូនប្រុសៗរបស់ខ្លួន ។

- តើអ្នកមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកគឺជាកូនប្រុសដែលទទួលបានកន្ទបនោះ ?
- តើកូនប្រុសដែលទទួលបានសម្លៀកបំពាក់អាចធ្វើអ្វីខ្លះដើម្បីកែលម្អស្ថានភាពនេះបាន ? ( គាត់គួរតែចែករំលែកនូវអ្វីដែលគាត់មានជាមួយនឹងកូនប្រុសដែលទទួលបានតិចជាងខ្លួន ) ។
- តើអ្នកគិតថាមានសារលិខិតអ្វីដែលព្រះអម្ចាស់បង្រៀនពួកយើងនៅក្នុងរឿងប្រដូចនេះ ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៧ ដោយស្ងាត់ស្ងៀម ហើយរកមើលគោលការណ៍មួយដែលព្រះអម្ចាស់ចង់ឲ្យយើងយល់ចេញពីរឿងប្រដូចនេះ ។ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ក្បែរ

គោលការណ៍ទីមួយដែលអ្នកបានសរសេរ ៖ **ប្រសិនបើយើងមិនរួមគ្នាតែមួយទេ នោះយើងមិនមែនជាប្រជារាស្ត្ររបស់ទ្រង់ឡើយ ។** អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សគូសចំណាំ ពាក្យនៅក្នុងគម្ពីររបស់ពួកគេ ដែលបង្រៀនពីគោលការណ៍នេះ ។

- នៅក្នុងបរិបទនៃ ខ ២៧ តើពាក្យ « រួមគ្នាតែមួយ » មានន័យយ៉ាងណា ? ( ដើម្បីមានសាមគ្គីភាពនឹងមនុស្សដទៃនឹងជាមួយព្រះអម្ចាស់នៅក្នុងសេចក្តីសុចរិត ) ។
- តើការឲ្យតម្លៃអ្នកដទៃឲ្យច្រើនដូចជាយើងឲ្យតម្លៃលើខ្លួនយើង អាចជួយយើងឲ្យប្រែក្លាយទៅជារួមគ្នាតែមួយយ៉ាងដូចម្តេច ? តើការណ៍នេះអាចជួយយើងក្លាយទៅជារួមគ្នាតែមួយនឹងព្រះអម្ចាស់យ៉ាងដូចម្តេច ?
- ហេតុអ្វីក៏អ្នកគិតថា យើងពុំអាចក្លាយជារាស្ត្ររបស់ព្រះអម្ចាស់បានឡើយ ប្រសិនបើយើងពុំបានរួមគ្នាតែមួយនោះ ?

សូមពន្យល់ថា សមាជិកសាសនាចក្រជំនាន់មុន ដែលត្រូវបានហៅឲ្យប្រមូលផ្តុំគ្នាទៅឯរដ្ឋ អូហៃអូ គឺមានជីវប្រវត្តិផ្សេងៗគ្នា ។ អ្នកខ្លះជាម្ចាស់ចម្ការដ៏មានជោគជ័យ ហើយត្រូវបានគេគោរពរាប់អាននៅក្នុងសហគមន៍របស់ពួកគេ ខណៈដែលអ្នកដទៃទៀតមានទ្រព្យបន្តិចបន្តួច ហើយត្រូវបានចាត់ទុកថាមានវណ្ណៈទាបក្នុងសង្គម ។

- តើគោលការណ៍ទាំងឡាយនៅលើក្តារខៀន បានប្រទានពរដល់ពួកបរិសុទ្ធនៅពេលដែលពួកគេប្រមូលផ្តុំគ្នាជាមួយនឹងសមាជិកដទៃទៀតនៃសាសនាចក្រនៅក្នុងរដ្ឋអូហៃអូ យ៉ាងដូចម្តេច ?

សូមនិយាយពីសកម្មភាពនៃការសាងសង់ប៉ម នៅពេលចាប់ផ្តើមមេរៀន ។ សូមឲ្យសិស្សនិយាយពីគោលបំណងនៃការសាងសង់ប៉មនោះឡើងវិញ ( សាងសង់ប៉មឲ្យខ្ពស់តាមដែលពួកគេអាចធ្វើបាន ) ។

- តើយើងបានសាងសង់ប៉ម ឲ្យខ្ពស់តាមដែលយើងអាចធ្វើបានដែរឬទេ ? ( ប្រសិនបើក្រុមទាំងពីរបញ្ចូលបំណែករបស់ខ្លួនចូលគ្នា នោះពួកគេអាចសង់ប៉មបានខ្ពស់មែន ។ ប្រសិនបើក្រុមមួយៗធ្វើការរៀងខ្លួន នោះពួកគេប្រហែលជាអះអាងថាពួកគេបានសាងសង់ប៉មរបស់ខ្លួនបានខ្ពស់តាមដែលពួកគេអាចធ្វើបាន ) ។
- ផ្អែកលើព្រះឱវាទរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៣៨, តើរបៀបដ៏ល្អបំផុតអ្វីខ្លះដែលប្រើប្រាស់ដើម្បីសាងសង់ប៉មឲ្យខ្ពស់តាមដែលអាចធ្វើបាន ? ( ចូលរួមគ្នាជាក្រុមតែមួយ ហើយបញ្ចូលនូវអ្វីៗដែលយើងត្រូវបានផ្តល់ឲ្យ ដើម្បីកសាងប៉មមួយ ) ។
- តើស្ថានភាពមួយចំនួនណាខ្លះនៅក្នុងជីវិតនេះ ដែលយើងអាចត្រូវបានល្បួងឲ្យគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ជាជាងស្វែងរកការស្ថាបនា និង លើកស្ទួយមនុស្សដទៃដែលនៅជុំវិញខ្លួនយើង ?

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ពីរបៀបដែលបទបញ្ញត្តិឲ្យរួមគ្នាតែមួយ ទាក់ទងទៅនឹងបទបញ្ញត្តិរបស់ព្រះសម្រាប់រាស្ត្ររបស់ទ្រង់ឲ្យប្រមូលផ្តុំគ្នា ។ អ្នកអាចផ្តល់ច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍នេះ ឲ្យសិស្សម្នាក់ៗដើម្បីពួកគេអាចផ្ទៀងតាម ។



« យើងបានដឹងមកពីបទពិសោធន៍ដែលថាក្តីអំណរកើតមាន នៅពេលយើងត្រូវបានប្រទានពរជាមួយនឹងភាពសាមគ្គីគ្នា ។. . . បំណងប្រាថ្នា [ ព្រះវរបិតាសួគ៌របស់យើង ] គឺត្រូវបានប្រទានដល់យើងនូវបំណងដ៏ពិសិដ្ឋឲ្យមានសាមគ្គីភាពដែលវាចេញមកពីក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង ។

« ទ្រង់ពុំអាចប្រទានវាដល់យើងម្នាក់ៗនោះទេ ។ ក្តីអំណរនៃសាមគ្គីភាព ដែលទ្រង់ចង់ប្រទានឲ្យយើងយ៉ាងខ្លាំងនោះ គឺមិនឲ្យយើងតែម្នាក់ឯងទេ ។ យើងត្រូវតែស្វែងរកវា ហើយនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់មានវា ជាមួយនឹងអ្នកផ្សេងទៀត ។ វាមិនគួរឲ្យភ្ញាក់ផ្អើលទេដែលព្រះជម្រុញយើងឲ្យប្រមូលផ្តុំគ្នា ដូច្នេះទើបទ្រង់អាចប្រទានពរដល់យើង ។ ទ្រង់ចង់ឲ្យយើងរួបរួមគ្នានៅក្នុងក្រុមគ្រួសារ ។ ទ្រង់បានបង្កើតថ្នាក់ វួដ និងសាខាជាច្រើន ហើយបានបញ្ជាយើងឲ្យជួបជុំគ្នាជារឿយៗ ។ នៅក្នុងការរួបរួមគ្នាទាំងនោះ ដែលព្រះបានរៀបចំសម្រាប់យើង នោះជាឱកាសដ៏អស្ចារ្យរបស់យើង ។ យើងអាចអធិស្ឋានហើយធ្វើការស្វែងរកភាពសាមគ្គី ដែលនឹងនាំយើងនូវសេចក្តីអំណរ និងពង្រីកអំណាចរបស់យើងដើម្បីបម្រើ » (« Our Hearts Knit as One » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៦៩ ) ។

- យោងតាមប្រធាន អាវរិង ហេតុអ្វីព្រះអម្ចាស់ចង់ឲ្យយើងរួបរួមគ្នា ?
- តើលោកបានមានប្រសាសន៍ថាសាមគ្គីភាពនាំពរជ័យអ្វីខ្លះមកកាន់យើង ?

- តើសេចក្ដីថ្លែងការរបស់ប្រធាន អាវរិង ជួយយើងឲ្យយល់ពីមូលហេតុដែលយើងត្រូវរួបរួមគ្នាជាក្រុមគ្រួសារយ៉ាងដូចម្ដេច ? ជាសមាជិកសាសនាចក្រយ៉ាងដូចម្ដេច ? ជាសិស្សថ្នាក់សិក្ខាសាលាមួយយ៉ាងដូចម្ដេច ?
- តើពរជ័យអ្វីខ្លះ ដែលកើតមានមកពីការប្រមូលផ្ដុំគ្នាជាមួយមនុស្សដទៃដែលអ្នកបានទទួលនោះ ?

សូមអញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទី ដើម្បីសរសេរនៅក្នុងសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ខ្លួន អំពីអ្វីដែលពួកគេអាចធ្វើ ដើម្បីរួមគ្នាតែមួយជាមួយនឹងក្រុមគ្រួសាររបស់ពួកគេ ជាមួយយុវជន និងយុវនារីនៅក្នុងកូរ៉ុម និងថ្នាក់រៀននៅព្រះវិហាររបស់ពួកគេ ហើយនឹងជាមួយព្រះអម្ចាស់ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ អ្នកអាចនឹងចង់ចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យនៃការរួបរួមគ្នាតែមួយជាមួយគ្នា និង ការផ្ដល់តម្លៃដល់មនុស្សដទៃ ដូចដែលយើងផ្ដល់តម្លៃឲ្យខ្លួនយើង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០

*ព្រះអម្ចាស់ផ្ដល់ការអញ្ជើញទៅដល់ យ៉េម្ស ខូវិល*

សូមអញ្ជើញសិស្សឲ្យរំឭកឡើងវិញថា នរណាគឺជាយ៉េម្ស ខូវិល ហើយថាតើមានអ្វីបានកើតឡើងចំពោះគាត់ ដោយការអានក្បាលកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩ និង ៤០ ។ នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៨៣១ យ៉េម្ស ខូវិល ត្រូវបានបញ្ជាដោយព្រះអម្ចាស់ឲ្យទទួលបុណ្យជ្រមុជទឹក ( សូមមើល គ. និង ស. ៣៩:១០) ។ ប៉ុន្តែគាត់ពុំបានគោរពតាមការសន្យារបស់ខ្លួនដើម្បីធ្វើតាមការបញ្ជារបស់ព្រះឡើយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សនិយាយពីមូលហេតុដែលយ៉េម្ស ខូវិល បានបដិសេធការអញ្ជើញរបស់ព្រះអម្ចាស់ចំពោះគាត់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយ ពីអ្វីដែលពួកគេបានរៀនចេញពីខគម្ពីរទាំងនេះអំពីសារៈសំខាន់នៃការរក្សាសេចក្ដីសញ្ញា ដែលពួកគេបានធ្វើជាមួយព្រះអម្ចាស់ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១–៤៤)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួននៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១–៤៤, អ្នកក៏អាចអញ្ជើញពួកគេឲ្យពិចារណាសំណួរខាងក្រោម ៖ តើគ្រោះថ្នាក់នៃការតម្រេកសម្រើបចង់បានមានអ្វីខ្លះ ? តើយើងគួរតែបង្រៀននៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ដោយរបៀបណា ? តើសេចក្ដីស្លាប់នឹងមានរសជាតិយ៉ាងដូចម្ដេចចំពោះអស់អ្នកដែលសុចរិត ? សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ សិស្សនឹងមានឱកាសរៀនពីចម្លើយរបស់ព្រះអម្ចាស់ ចំពោះសំណួរទាំងនេះ ព្រមទាំងរៀនអំពីក្រឹត្យវិន័យនៃការថ្វាយរបស់ព្រះអម្ចាស់ ។

មេរៀនទី ៤៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១

## បុព្វកថា

នៅក្នុងខែធ្នូ ឆ្នាំ ១៨៣០ ព្រះអម្ចាស់ បានបញ្ជាដល់ពួកបរិសុទ្ធឲ្យផ្លាស់ទៅរដ្ឋ អូហៃអូ ជាកន្លែងដែលពួកគេនឹងទទួលក្រឹត្យវិន័យរបស់ទ្រង់ ( សូមមើល គ. និង ស. ៣៧:៣, ៣៨:៣២ ) ។ លីម៉ាន ខុព្លី ជាសមាជិកម្នាក់នៃសាសនាចក្រ ក្នុងរដ្ឋ អូហៃអូ បានផ្ដល់ឲ្យដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន និងក្រុមគ្រួសាររបស់ពួកគេនូវ « ផ្ទះ និងស្បៀងអាហារ » ( សេចក្ដីផ្ដើម កណ្ឌ គ. និង ស. ៤១ ) ។ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១ នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ១៨៣១ មិនយូរប៉ុន្មានបន្ទាប់ពីលោកបានមកដល់រដ្ឋ អូហៃអូ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ បានណែនាំព្យាការី និងអ្នកដឹកនាំសាសនាចក្រដទៃទៀតឲ្យអធិស្ឋានដើម្បីទទួលក្រឹត្យវិន័យរបស់ទ្រង់ ។ បន្ថែមពីលើនោះ ទ្រង់បានបញ្ជាក់ពីកន្លែងដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន គួររស់នៅ ហើយបានហៅ អែតវឺត ប៉ាទ្រិច ឲ្យធ្វើជាប៊ីស្សពទីមួយនៃសាសនាចក្រ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១–៦

*ព្រះអម្ចាស់បង្រៀនថា ពួកសិស្សដ៏ពិតនឹងរក្សាក្រឹត្យវិន័យរបស់ទ្រង់*

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលនាំមកនូវក្ដីរីករាយ ឬស្វែងរកសេចក្ដីអំណរនៅក្នុងការធ្វើរឿងអ្វីមួយ ។

- តើអ្នករីករាយ ឬពេញចិត្តក្នុងការធ្វើអ្វីខ្លះ ?
- តើអ្នកគិតថាព្រះអម្ចាស់សព្វព្រះហឫទ័យនៅក្នុងការធ្វើអ្វី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីអ្វីដែលព្រះអម្ចាស់ សព្វព្រះហឫទ័យនៅក្នុងការធ្វើនោះ ។

- តើព្រះអម្ចាស់មានបន្ទូលថា ទ្រង់សព្វព្រះហឫទ័យក្នុងការធ្វើអ្វី ? ( ប្រទានពរដល់រាស្ត្រទ្រង់ « ព្រះពរដ៏ប្រសើរបំផុត ជាងព្រះពរទាំងអស់ » ) ។

នៅពេលសិស្សឆ្លើយតប សូមសរសេរសេចក្ដីថ្លែងការមិនពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *ព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានពរដល់យើង នៅពេល. . .*

- យោងតាម ខ ១ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលពរជ័យទាំងឡាយ ដែលព្រះអម្ចាស់មានព្រះទ័យប្រទានដល់យើង ? ( អ្នកអាចចាំបាច់ត្រូវពន្យល់ថា *ប្រុងស្ដាប់* មានន័យថា ស្ដាប់ដោយយកចិត្តទុកដាក់ ហើយគោរពតាម ។ សូមប្រើចម្លើយរបស់សិស្ស បំពេញគោលការណ៍នៅលើក្ដារខៀន ៖ **ព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានពរដល់យើង នៅពេលយើងស្ដាប់ ហើយគោរពតាមទ្រង់** ។ អ្នកអាចនឹងចង់លើកទឹកចិត្តសិស្សឲ្យគូសចំណាំពាក្យ ឬឃ្លាទាំងឡាយ ដែលបង្រៀននូវគោលការណ៍នេះនៅក្នុងគម្ពីររបស់ពួកគេ ) ។

សូមឲ្យសិស្សពិចារណាថាតើពួកគេធ្លាប់មានបទពិសោធន៍នៃក្ដីអំណរ ជាលទ្ធផលមកពីការធ្វើអ្វីមួយសម្រាប់អ្នកដទៃម្នាក់ទៀតដែរឬទេ ។ សូមអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ចែកចាយពីបទពិសោធន៍របស់ពួកគេ ។

- តើវាមានន័យយ៉ាងណាចំពោះអ្នក ដែលព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានពរដល់អ្នក ចំពោះការស្ដាប់តាមទ្រង់នោះ ?

សូមរំឭកសិស្សថា ព្រះអម្ចាស់ បានបញ្ជាឲ្យពួកបរិសុទ្ធទៅប្រមូលគ្នានៅក្នុងរដ្ឋ អូហៃអូ ។ ពួកបរិសុទ្ធមួយចំនួនដែលផ្លាស់ទៅរដ្ឋ អូហៃអូ បានធ្វើដំណើរដោយការលះបង់ ។ ពួកគេបានលក់ទ្រព្យសម្បត្តិរបស់ពួកគេក្នុងតម្លៃថោក ឬចាកចេញពីផ្ទះ និងទ្រព្យសម្បត្តិដោយពុំបានលក់ដូរសោះ ហើយចេញទៅរដ្ឋអូហៃអូ ដោយការគោរពប្រតិបត្តិតាមបញ្ជា ដែលព្រះអម្ចាស់បានប្រទានឲ្យ តាមរយៈព្យាការីរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវដំណើររឿងដូចខាងក្រោម អំពី លូស៊ី ម៉ាក ស៊្មីធ ( ម្ដាយរបស់ព្យាការី យ៉ូសែប ស៊្មីធ ) ហើយនឹងក្រុមមួយនៃសមាជិកសាសនាចក្រ ដែលគាត់បានដឹកនាំទៅកាន់រដ្ឋ អូហៃអូ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់មើលគំរូមួយអំពីរបៀបដែលព្រះអម្ចាស់ប្រទានពរដល់ពួកបរិសុទ្ធ នៅពេលពួកគេបានស្ដាប់តាមបញ្ញារបស់ទ្រង់ ដើម្បីផ្លាស់ទីទៅរដ្ឋ អូហៃអូ ៖

លូស៊ី ម៉ាក ស៊្មីធ បានដឹកនាំក្រុមមួយដែលមានសមាជិកសាសនាចក្រចំនួន ៨០ នាក់ចេញពី ភូមិ ហ្វាយ៉េត រដ្ឋ នូវ យ៉ោក ទៅកាន់រដ្ឋ អូហៃអូ ។ នៅពេលពួកគេធ្វើដំណើរតាមទូកនៅតាមព្រែកជីក កាយូកា និង សេនីកា ទៅ បាហ្វាឡូ រដ្ឋ នូវ យ៉ោក នោះលូស៊ី បានរំឭកដល់ពួកបរិសុទ្ធថា ពួកគេកំពុងធ្វើដំណើរតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ ដូចជាលីហៃពីជំនាន់ដើម ពេលគាត់បានចាកចេញពីយេរូសាឡិម ។ គាត់បានឲ្យដំបូន្មានដល់ពួកបរិសុទ្ធថា បើពួកគេនឹងស្មោះត្រង់ នោះពួកគេ « មានមូលហេតុដូចគ្នា ដើម្បីរំពឹងទុកនូវពរជ័យទាំងឡាយនៃព្រះ » ( សូមមើល *History of Joseph Smith by His Mother,* បានបោះពុម្ពដោយ Preston Nibley [ឆ្នាំ ១៩៥៨], ទំព័រ ១៩៥–៩៦; *Church History in the Fulness of Times Student Manual,* បានបោះពុម្ពជាលើកទី ២ [Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ៩១ ) ។

នៅពេលពួកគេបានធ្វើដំណើរទៅដល់ បាហ្វាឡូ ពួកគេបានរកឃើញថាកំពង់ផែត្រូវបានស្ទះដោយទឹកកក រាំងមិនឲ្យទូកចេញចូលបាន ។ « បន្ទាប់ពីអស់រយៈពេលដ៏រន្ធត់ជាច្រើនថ្ងៃនៅ បាហ្វាឡូ នោះកុមារតូចៗមួយចំនួនចាប់ផ្ដើមឈឺ ហើយមនុស្សជាច្រើនក្នុងក្រុមបានស្រេកឃ្លាន ហើយបាក់ទឹកចិត្ត ។ ពួកគេបានបង់ថ្លៃដើម្បីអង្គុយនៅលើដំបូលទូក ដោយដាក់ឥវ៉ាន់របស់ពួកគេនៅលើទូក ហើយបានទទួលកន្លែងជ្រកបណ្ដោះអាសន្ន សម្រាប់ស្ត្រី និងកុមារតូចៗ រហូតដល់ព្រឹកស្អែកឡើង ។ នៅពេលពួកគេត្រឡប់មកទូកវិញ លូស៊ី បានបញ្ចុះបញ្ចូលដល់ក្រុមដែលកំពុងតែនៅទួញសោក សុំឲ្យព្រះអម្ចាស់បំបាក់ផ្ទាំងទឹកកកកម្រាស់ម្ភៃហ្វីត ដែលកកនៅកំពង់ផែនោះ » (*Church History in the Fulness of Times Student Manual,* ៩២ ) ។

លូស៊ី បានដាស់តឿនដល់ក្រុមរបស់គាត់ឲ្យមានសេចក្ដីជំនឿទៅលើព្រះ ហើយបានសន្យាថា បើពួកគេនឹងមានសាមគ្គីភាពនៅក្នុងការអធិស្ឋាន ហើយសុំឲ្យព្រះបំបែកផ្ទាំងទឹកកក ដែលកកកំពង់ផែនោះ នោះវានឹងបានសម្រេច ។ លូស៊ី បានពិពណ៌នាអំពីអ្វីដែលបានកើតឡើងបន្ទាប់ទៀតថា ៖ « រំពេចនោះ មានសំឡេងមួយបន្លឺឡើង ដូចជាផ្គរលាន់ ។ អ្នកបើកទូកបានស្រែកថា ‹ អ្នកគ្រប់គ្នាសូមទៅកាន់កន្លែង › ។ ដុំទឹកកកនោះបានបែកប្រេះចេញ ដោយទុកច្រកតូចមួយសម្រាប់ទូក ហើយនៅពេលទូកបានឆ្លងកាត់តាមផ្លូវតូចចង្អៀតនោះ ពោងទឹកបានហែកដោយសារតែទង្គិចនឹងមុខបែករបស់ទឹកកក ។. . . យើងបានឆ្លងផុតតែបន្តិច មុនពេលដែលទឹកកកមកជាប់គ្នាវិញម្ដងទៀតនោះ » ( សូមមើល *History of Joseph Smith by His Mother,* ទំព័រ ១៩៧–២០៥ ) ។

- តើពួកបរិសុទ្ធទាំងនេះបង្ហាញសេចក្ដីជំនឿទៅលើព្រះអម្ចាស់នៅក្នុងស្ថានភាពលំបាកនេះយ៉ាងដូចម្ដេច ? តើស្ថានភាពនេះបង្ហាញថា ព្រះអម្ចាស់បានដឹងជាមុនអំពីយើង ហើយនឹងជួយយើងយកឈ្នះលើការលំបាកទាំងនោះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:២–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវការណែនាំ ដែលព្រះអម្ចាស់បានប្រទានដល់ពួកអែលឌើរនៃសាសនាចក្រ ។

- តើព្រះអម្ចាស់បញ្ជាឲ្យពួកអែលឌើរនៃសាសនាចក្រធ្វើអ្វីខ្លះ ? ( ទ្រង់បានបញ្ជាពួកគេឲ្យជួបជុំគ្នា ដើម្បីធ្វើសេចក្ដីព្រមព្រៀងគ្នា អធិស្ឋានដោយសេចក្ដីជំនឿ ទទួលក្រឹត្យវិន័យរបស់ទ្រង់ ហើយមើលថាក្រឹត្យវិន័យរបស់ទ្រង់ត្រូវបានរក្សាដោយសមាជិកនៃសាសនាចក្រ ) ។

- យោងតាម ខ ៣ តើគោលបំណងនៃក្រឹត្យវិន័យដែលពួកអែលឌើរត្រូវទទួលគឺជាអ្វី ?

- តើការទទួលក្រឹត្យវិន័យរបស់ព្រះអម្ចាស់ អាចជាពរជ័យមួយចំពោះពួកបរិសុទ្ធនៅក្នុងរដ្ឋ អូហៃអូ យ៉ាងដូចម្ដេច ?

សូមចង្អុលបង្ហាញថា « ក្រឹត្យវិន័យ » ដែលព្រះអម្ចាស់សំដៅទៅលើនោះ គឺក្រិត្យវិន័យដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ ជាក្រឹត្យវិន័យ នៃព្រះអម្ចាស់ចំពោះសាសនាចក្រ ។ សូមពន្យល់ដល់សិស្សថា ពួកគេនឹងសិក្សាក្រឹត្យវិន័យនេះលម្អិតនៅក្នុងមេរៀនក្រោយ ។

ដើម្បីរៀបចំសិស្សឲ្យពិពណ៌នាអំពីសេចក្ដីពិតសំខាន់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៥ សូមសរសេរពាក្យដូចខាងក្រោមនៅលើក្ដារខៀន ៖ *អ្នកជឿ* និង *ពួកសិស្ស* ។

- តើគោលគំនិតទាំងពីរនេះដូចគ្នាតាមរបៀបណា ? តើវាអាចខុសគ្នាតាមរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៥ ឲ្យឮៗ ។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលអំពីពួកសិស្សរបស់ទ្រង់ ។

- យោងតាមខគម្ពីរនេះ តើលក្ខណៈមួយរបស់ពួកសិស្សនៃព្រះអង្គសង្គ្រោះគឺជាអ្វី ? ( អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំពាក្យ ឬឃ្លាទាំងឡាយ ដែលបង្រៀននូវគោលការណ៍ដូចខាងក្រោម ៖ **ពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទ ទទួលបានក្រឹត្យវិន័យរបស់ទ្រង់ ហើយគោរពតាម** ) ។

- ហេតុអ្វីបានជាវាសំខាន់ ដែលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវថែរក្សាបទបញ្ញត្តិ ហើយពុំគ្រាន់តែបានដឹងពីបទបញ្ញត្តិនោះ ?

ដើម្បីជួយសិស្សអនុវត្តគោលការណ៍នេះ សូមអញ្ជើញពួកគេឲ្យរំឭកបទដ្ឋាននៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ដោយខ្លួនគេផ្ទាល់ ។ សូមឲ្យពួកគេជ្រើសរើសបទដ្ឋានមួយ ហើយសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ អំពីអ្វីដែលពួកគេចង់ធ្វើដើម្បីរស់នៅតាមបទដ្ឋាននោះបានកាន់តែប្រសើរជាងមុនបន្តិច ។ ( សូមអះអាងនឹងសិស្សថា នេះគឺជាសកម្មភាពផ្ទាល់ខ្លួនមួយ ហើយពួកគេនឹងពុំសុំឲ្យចែកចាយចម្លើយរបស់ពួកគេជាមួយអ្នកដទៃទេ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៧–៨

*ព្រះអម្ចាស់ ណែនាំពួកបរិសុទ្ធឲ្យស្ថាបនាគេហដ្ឋានមួយ ដែលព្យាការីអាចរស់នៅ ហើយបកប្រែ*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៧–៨ ដោយការពន្យល់ថា ព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធឲ្យផ្គត់ផ្គង់គេហដ្ឋានមួយ ដែលព្យាការី និងគ្រួសាររបស់លោក អាចរស់នៅ ហើយយ៉ូសែប អាចបន្តកិច្ចការរបស់លោកក្នុងការបកប្រែព្រះគម្ពីរប៊ីប ។ ព្រះអម្ចាស់ក៏ផ្ដល់នូវការណែនាំសង្ខេបផងដែរចំពោះស៊ីឌនី រិកដុន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៩–១២

*ព្រះអម្ចាស់ហៅ អែតវើត ប៉ាទ្រិច ឲ្យធ្វើជាប៊ីស្សពទីមួយនៃសាសនាចក្រ*

សូមអញ្ជើញសិស្សឲ្យនឹកស្រម៉ៃថា វួដរបស់ពួកគេត្រូវការប៊ីស្សពថ្មីម្នាក់ ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៩–១០ ដោយខ្លួនគេ រកមើលអ្វីដែលជាប់ទាក់ទងនៅក្នុងការហៅបម្រើជាប៊ីស្សពម្នាក់ ។

- យោងតាមខគម្ពីរនេះ តើមានអ្វីខ្លះ ដែលជាប់ទាក់ទងនឹងការហៅបម្រើនៃប៊ីស្សពថ្មី ? ( **ប៊ីស្សព ត្រូវបានហៅដោយព្រះ បានគាំទ្រដោយសំឡេងរបស់សមាជិក ហើយបានតែងតាំងដោយសិទ្ធិអំណាចត្រឹមត្រូវ** ។ អ្នកអាចនឹងចង់សរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ប៊ីស្សពក្នុងវួដសព្វថ្ងៃនេះ ពុំត្រូវបានបញ្ជាឲ្យចំណាយពេលទាំងអស់របស់ពួកគាត់ « ធ្វើការឲ្យព្រះវិហារ » ដូចដែលព្រះអម្ចាស់បានហៅ អែតវើត ប៉ាទ្រិចឲ្យធ្វើនោះទេ ) ។

- តើដែលត្រូវបាន « តែងតាំងដោយសំឡេងនៃសាសនាចក្រ » មានន័យយ៉ាងណា ? ( វាមានន័យថា សមាជិកនៃសាសនាចក្រ បានផ្ដល់ការគាំទ្ររបស់ពួកគេ ឬគាំទ្រមនុស្សដែលត្រូវបានហៅដោយព្រះ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលលក្ខណៈដែលអែតវើត ប៉ាទ្រិច មាន ដែលនឹងជួយគាត់នៅក្នុងការហៅរបស់គាត់ ។

- តើមានលក្ខណៈអ្វីខ្លះ ដែលអែតវើត ប៉ាទ្រិច មាន ដែលអាចជួយគាត់នៅក្នុងការហៅបម្រើរបស់គាត់ ? ( នៅពេលសិស្សឆ្លើយ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា *ឧបាយកល* គឺប្រកបដោយការបោកបញ្ឆោត ឬការលាក់ពុត ។ ហេតុដូច្នោះហើយការ « គ្មានឧបាយកល » មានន័យថាជាការស្មោះត្រង់ និងដោយស្មោះអស់ពីចិត្ត ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមាន ដែលព្រះអម្ចាស់បានប្រទានឲ្យនៅចុងបញ្ចប់នៃវិវរណៈនេះ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីប្រយ័ត្នក្នុងរបៀបដែលយើងកាន់ភ្ជាប់នូវព្រះបន្ទូលទាំងឡាយរបស់ព្រះអង្គសង្គ្រោះនោះ? ( អ្នកអាចនឹងចង់ពន្យល់ថា ចំពោះយ៉ូសែប ស្ម៊ីធ និងអ្នកដទៃ នេះគឺជាបទបញ្ញត្តិមួយដើម្បីរក្សាបទគម្ពីរ ) ។ តើការណ៍នេះទាក់ទងនឹងអ្វីដែលយើងបានរៀនអំពីពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

### *សូមជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយ*

ការអនុវត្តមាននៅពេលសិស្សទាំងឡាយគិត និយាយ និង រស់នៅ ស្របតាមគោលការណ៍ទាំងឡាយ ដែលពួកគេបានរៀន ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ៖ « គោលដៅនៃការបង្រៀនដំណឹងល្អ . . .គឺមិនមែនដើម្បី ‹ ចាក់ព័ត៌មាន › ចូលទៅក្នុងចិត្តនៃ [អ្នករៀន] នោះទេ ។ . . . *គោលដៅនោះគឺដើម្បីបំផុសគំនិតដល់បុគ្គលម្នាក់ៗឲ្យគិត ឲ្យដឹង ហើយបន្ទាប់មក ឲ្យធ្វើអ្វីម្យ៉ាងអំពីការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ* » ( នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៧០ ទំព័រ ១០៧ ) ។ នៅពេលសិស្សសរសេរអំពីអារម្មណ៍របស់ពួកគេ ហើយពិចារណាទៅលើសកម្មភាពជាក់លាក់ដែលពួកគេគួរធ្វើ នោះ ព្រះវិញ្ញាណបរិសុទ្ធ អាចបំផុសគំនិតដល់ពួកគេអំពីវិធីជាក់លាក់ ដើម្បីអនុវត្តសេចក្ដីពិតដែលពួកគេបានរៀន ។



សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ នែល អេ ម៉ាក់ស្វែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ « រាល់ថ្ងៃយើងសម្រេចចិត្តទៅលើកម្រិតនៃភាពជាសិស្សរបស់យើង » (My Servant Joseph, » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩២, ទំព័រ ៣៩ ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយអំពីរបៀបដែលសេចក្ដីពិតទាំងឡាយ ដែលពួកគេបានរៀននៅក្នុងមេរៀននេះ អាចជួយពួកគេក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទកាន់តែល្អ ។

មេរៀនទី ៤៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–២៩

## បុព្វកថា

សូមរំឭកសិស្សថា នៅខែធ្នូ ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធនៅរដ្ឋ នូវ យ៉ោក ឲ្យប្រមូលផ្ដុំគ្នាមកឯរដ្ឋ អូហៃអូ ( សូមមើល គ. និង ស. ៣៧) ។ នៅក្នុងខែមករា ឆ្នាំ ១៨៣១ ទ្រង់បានសន្យាថា ពួកគេនឹងទទួលបានក្រឹត្យវិន័យរបស់ទ្រង់ ( សូមមើល គ. និង ស. ៣៨:៣២) ។ នៅថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ១៨៣១ មិនយូរប៉ុន្មានបន្ទាប់ពីការមកដល់ទីក្រុងខឺតឡង់ នោះមានអែលឌើរ ១២ នាក់នៃសាសនាចក្រ បានប្រមូលផ្ដុំគ្នា ហើយបានអធិស្ឋានរួមគ្នា ដូចដែលព្រះអម្ចាស់បានបញ្ជាដល់ពួកគេ ( សូមមើល គ. និង ស. ៤១:២–៣ ) ។ នៅក្នុងស្ថានភាពនេះ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយ ដែលឥឡូវនេះ បានបញ្ចូលជា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–៧៣ ។ លោកបានទទួលការណែនាំបន្ថែមនៅថ្ងៃទី ២៣ ខែកុម្ភៈ ( សូមមើល គ. និង ស. ៤២:៧៤–៩៣ ) ។ ដោយបញ្ចូលវិវរណៈទាំងនេះរួមគ្នា ត្រូវបានស្គាល់ថាជា « ក្រឹត្យវិន័យនៃសាសនាចក្រ » ( គ. និង ស. ៤២ ក្បាលកណ្ឌ ) ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ នឹងត្រូវបានបំបែកជាបីមេរៀន ។ មេរៀននេះគ្រប់ដណ្ដប់ ខ ១–២៩ ដែលបានផ្ដល់ការណែនាំអំពីការបង្រៀនដំណឹងល្អ និងការបង្កើតច្បាប់នៃការប្រព្រឹត្តទូទៅសម្រាប់សមាជិកនៃសាសនាចក្រ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–១០

*ព្រះអម្ចាស់បានហៅពួកអែលឌើរ ឲ្យបង្រៀនដំណឹងល្អ ហើយស្ថាបនាសាសនាចក្ររបស់ទ្រង់ឡើង*

នៅលើក្ដារខៀនផ្នែកខាងលើ សូមសរសេរថា *ក្រឹត្យវិន័យ និងបទបញ្ញត្តិទាំងឡាយ* ។

នៅផ្នែកខាងក្រោម សូមសរសេរពាក្យដូចខាងក្រោម ៖

> *ការដាក់កំហិត ពរជ័យ បន្ទុក ធុញទ្រាន់ អំណោយទាន ព្រំដែន រង្វាន់*

សូមចាប់ផ្ដើមដោយការសុំឲ្យសិស្សពិចារណាថា ពាក្យណាមួយនៅលើក្ដារខៀន ដែលពួកគេអាចជ្រើសរើសដើម្បីយកមកពិពណ៌នាអំពីក្រឹត្យវិន័យ និងបទបញ្ញត្តិទាំងឡាយ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវពាក្យ និងពាក្យទាំងឡាយដែលពួកគេជ្រើសរើស ហើយពន្យល់ថាហេតុអ្វី ។ បន្ទាប់ពីសិស្សបានចែកចាយគំនិតរបស់ពួកគេរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីក៏ពេលខ្លះវាពិបាកដើម្បីរក្សាបទបញ្ញត្តិទាំងឡាយ ?
- ហេតុអ្វី ក៏មនុស្សមួយចំនួនមានអារម្មណ៍ថា ក្រឹត្យវិន័យ ឬបទបញ្ញត្តិទាំងឡាយ គឺជាអំណោយ ឬពរជ័យមួយដូច្នេះ ?

សូមរំឭកសិស្សថា បន្ទាប់ពីព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធនៅក្នុង រដ្ឋ នូវ យ៉ោក ឲ្យទៅកាន់រដ្ឋ អូហៃអូ នោះទ្រង់បានសន្យាថា នៅពេលពួកគេនៅទីនោះ នោះទ្រង់នឹងប្រទានដល់ពួកគេនូវក្រឹត្យវិន័យរបស់ទ្រង់ ( សូមមើល គ. និង ស. ៣៨:៣២) ។ ពួកបរិសុទ្ធនៅរដ្ឋ នូវ យ៉ោក ភាគច្រើនបានគោរពតាមបញ្ញាឲ្យប្រមូលផ្ដុំគ្នាទៅឯរដ្ឋ អូហៃអូ ។ បន្ទាប់ពីពួកគេមួយចំនួនបានទៅដល់ទីក្រុងខឺតឡង់ហើយ នោះអែលឌើរ ១២ នាក់បានជួបជាមួយនឹងព្យាការី យ៉ូសែប ស្ម៊ីធ ហើយបានអធិស្ឋានទៅកាន់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–៣ ឮៗ ។ សូមលើកទឹកចិត្តដល់សិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលមូលហេតុថាហេតុអ្វីបានជាពួកអែលឌើរបានជួបជុំគ្នា ។

- ហេតុអ្វីបានជាពួកអែលឌើរជួបជុំគ្នានៅពេលនេះ ? ( ព្រះអម្ចាស់បានបញ្ជាពួកគេឲ្យជួបជុំគ្នាដើម្បីទទួលក្រឹត្យវិន័យរបស់ទ្រង់ ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤–១០ ដោយការពន្យល់ថា ព្រះអម្ចាស់ បានណែនាំឲ្យពួកអែលឌើរចេញទៅពីរៗនាក់ ធ្វើជាអ្នកផ្សព្វផ្សាយសាសនាដើម្បីផ្សាយដំណឹងល្អ ហើយស្ថាបនាសាសនាចក្រនៅគ្រប់ភូមិភាគដែលពួកគេត្រូវបានហៅឲ្យទៅ រហូតដល់មនុស្សទាំងអស់ត្រូវបានហៅឲ្យជួបជុំគ្នាជាក្រុមតែមួយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១១–១៧

*ព្រះអម្ចាស់បានបង្កើតគោលការណ៍នៃការបង្រៀនដំណឹងល្អ*

សូមឲ្យសិស្សនឹកស្រមៃថា ពួកគេកំពុងអង្គុយនៅក្នុងសាលាជំនុំរង់ចាំការប្រជុំសាក្រាម៉ង់ចាប់ផ្ដើម ។ សមាជិកនៃគណៈប៊ីស្សពឬគណៈប្រធានសាខា បានពន្យាពេល ហើយពុំទាន់បានមកដល់នៅឡើយ ។ មានមនុស្សម្នាក់មកពីក្រុមជំនុំបានក្រោកឈរឡើង ហើយពន្យល់ថា គាត់ចង់ផ្ដល់ការហៅបម្រើមួយចំនួន ហើយបង្រៀននូវគោលលទ្ធិថ្មីមួយចំនួន ដែលត្រូវបានបើកសម្ដែងដល់គាត់ ។

- តើអ្នកនឹងមានប្រតិកម្មយ៉ាងណាចំពោះស្ថានភាពនេះ ? ហេតុអ្វី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១១ ឲ្យឮៗ ហើយសួរដល់សិស្សក្នុងថ្នាក់ឲ្យរកមើលថា តើនរណាដែលព្រះអម្ចាស់ បានអនុញ្ញាតឲ្យបង្រៀន និងស្ថាបនាសាសនាចក្ររបស់ទ្រង់ ។

- តើនរណាដែលព្រះអម្ចាស់មានបន្ទូលថា ត្រូវបានអនុញ្ញាតឲ្យបង្រៀន និងស្ថាបនាសាសនាចក្ររបស់ទ្រង់ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **អ្នកទាំងឡាយដែលបង្រៀន និងស្ថាបនាសាសនាចក្រ ត្រូវតែបានហៅដោយព្រះ និងបានតែងតាំង ឬញែកចេញដោយពួកអ្នកដឹកនាំដែលមានសិទ្ធិអំណាចនៃសាសនាចក្រ** ) ។

- យោងតាម ខ ១១ អ្នកទាំងឡាយណាដែលត្រូវបានហៅឲ្យបង្រៀនដំណឹងល្អ គឺត្រូវការហៅរបស់ពួកគេ ត្រូវបានគេស្គាល់នៅក្នុងសាសនាចក្រ ។ តើសមាជិកសាសនាចក្រសព្វថ្ងៃនេះ ដឹងថា មនុស្សម្នាក់បានទទួលការហៅបម្រើនៅក្នុងវួដ ឬស្តេក ហើយនឹងបានញែកចេញ ឬបានតែងតាំងដោយពួកអ្នកដឹកនាំសាសនាចក្រដោយរបៀបណា ? ( ឈ្មោះរបស់អ្នកទាំងឡាយដែលត្រូវបានហៅនោះ ត្រូវបានបង្ហាញទៅកាន់សមាជិកភាពនៃសាសនាចក្រសម្រាប់ការបោះឆ្នោតគាំទ្រ ។ នេះត្រូវបានស្គាល់ថាជា គោលការណ៍នៃការយល់ព្រមជាទូទៅ ។ សូមមើល គ. និង ស. ២៦:២ ) ។

- តើទម្រង់ការនៃការគាំទ្រដល់ពួកអ្នកដឹកនាំសាសនាចក្រ និងពួកគ្រូបង្រៀន អាចការពារដល់សាសនាចក្រ និងសមាជិកយ៉ាងដូចម្ដេច ? ( ការគាំទ្រដល់ពួកអ្នកដឹកនាំសាសនាចក្រ ជួយយើងដឹងថា នរណាត្រូវបានហៅឲ្យដឹកនាំ និងបង្រៀននៅក្នុងសាសនាចក្រ ) ។ វាក៏អាចជួយការពារបុគ្គលម្នាក់ៗពីការសន្មត់ស្មានៗចំពោះ ការទទួលខុសត្រូវទាំងឡាយ ដែលពុំបានចាត់ទៅឲ្យពួកគេ ហើយថាតើមួយណាដែលពួកគេគ្មានសិទ្ធិអំណាចដើម្បីធ្វើនោះ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១២–១៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលទំនួលខុសត្រូវដែលបានផ្ដល់ឲ្យមនុស្ស ដែលបង្រៀន និងដឹកនាំនៅក្នុងសាសនាចក្រ រួមទាំងពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងផងដែរ ។

- យោងតាមខគម្ពីរទាំងនេះ តើទំនួលខុសត្រូវ ដែលព្រះអម្ចាស់ប្រទានដល់អ្នកទាំងឡាយដែលទ្រង់ហៅឲ្យបង្រៀន ឬដឹកនាំនៅក្នុងសាសនាចក្រមានអ្វីខ្លះ ?

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់សម្រាប់គ្រូបង្រៀន និងអ្នកដឹកនាំ បង្រៀនអំពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ដូចមាននៅក្នុងបទគម្ពីរ ?

- តើអ្នកត្រូវបានប្រទានពរជ័យយ៉ាងដូចម្ដេច នៅពេលគ្រូបង្រៀន ឬពួកអ្នកដឹកនាំរបស់អ្នក បានរស់នៅតាមគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលពួកគេបានបង្រៀននោះ ?

សូមឲ្យសិស្សរំពឹក គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៣ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលគួរតែដឹកនាំយើង នៅពេលយើងបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ បន្ទាប់ពីសិស្សរាយការណ៍នូវអ្វីដែលពួកគេរកឃើញហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលអ្នកទាំងឡាយ ដែលបង្រៀនដំណឹងល្អគួរធ្វើដើម្បីទទួលបានឥទ្ធិពលនៃព្រះវិញ្ញាណ ។

- តើយើងអាចទទួលបានឥទ្ធិពលនៃព្រះវិញ្ញាណដើម្បីជួយយើងបង្រៀនដល់អ្នកដទៃអំពីដំណឹងល្អយ៉ាងដូចម្ដេច ? (**បើសិនជាយើងអធិស្ឋានដោយសេចក្ដីជំនឿ នោះយើងអាចទទួលបានព្រះវិញ្ញាណជួយយើងបង្រៀនដល់អ្នកដទៃ ។** ( អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំពាក្យនៅក្នុង ខទី ១៤ ដែលបង្រៀនពីគោលការណ៍នេះ។ សូមចង្អុលបង្ហាញថា បន្ថែមពីលើការអធិស្ឋានដោយសេចក្ដីជំនឿ យើងចាំបាច់ត្រូវមានភាពសក្តិសមដើម្បីទទួលព្រះវិញ្ញាណ ) ។

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជេហ្វ្រីអ័រ.ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« បទគម្ពីរបានចែងថា ‹ ព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នក ដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ ហើយបើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀនឡើយ › (គ. និង ស. ៤២:១៤) ។ ការណ៍នេះបង្រៀនថា វាពុំគ្រាន់តែថា អ្នកនឹងមិនបង្រៀន ឬថាអ្នកពុំអាចបង្រៀន ឬថាវានឹងជាការបង្រៀនមិនល្អនោះទេ ទេ វាខ្លាំងជាងនោះទៅទៀត ។ វាគឺជាទម្រង់កិរិយាសព្ទបញ្ជា ។ ‹ អ្នករាល់គ្នា*មិនត្រូវ*បង្រៀនឡើយ › ។ សូមដាក់ពាក្យ*អ្នក*នៅទីនោះ ជំនួសឲ្យ*អ្នករាល់គ្នា*មានភាសាភ្នំស៊ីណាយ ។ នេះគឺជាបទបញ្ញត្តិមួយ » (Teaching, Preaching, Healing » *Ensign* ខែ មករា ឆ្នាំ ២០០៣, ទំព័រ ៤១ ) ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៤ និងសេចក្ដីថ្លែងការណ៍របស់អែលឌើរ ហូឡិន តើនរណាគឺជាគ្រូបង្រៀនពិតនៅក្នុងថ្នាក់រៀនរបស់សាសនាចក្រ ? ( ព្រះវិញ្ញាណ ) ។
- តើវិធីមួយចំនួនណាខ្លះ ដែលសិស្សអាចជួយបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៦–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ មុនពេលសិស្សអាន វានឹងជាជំនួយដើម្បីរំឭកសិស្សថា ពាក្យ*អង្គលួងលោមចិត្ត* ដែលបានប្រើនៅក្នុងខទាំងនេះ គឺជាឈ្មោះមួយទៀតសម្រាប់ព្រះវិញ្ញាណបរិសុទ្ធ ។

- ស្របតាម ខ ១៧ តើព្រះវិញ្ញាណបរិសុទ្ធនឹងដឹង ហើយធ្វើអ្វីខ្លះ ? ( អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំគោលលទ្ធិនៅក្នុងព្រះគម្ពីររបស់ពួកគេដូចខាងក្រោម ៖ **ព្រះវិញ្ញាណបរិសុទ្ធ ដឹងនូវរឿងគ្រប់យ៉ាង ហើយថ្លែងទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា** ) ។
- ផ្ដោតទៅលើគោលលទ្ធិនេះ ហេតុអ្វីក៏វាសំខាន់សម្រាប់យើងដើម្បីមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយយើង នៅពេលយើងបង្រៀនដំណឹងល្អ ?
- តើការមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយអ្នក អាចជួយដល់អ្នកទាំងឡាយដែលអ្នកបង្រៀនយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យនឹកគិតអំពីសំណួរដូចខាងក្រោម ( អ្នកអាចនឹងចង់សរសេរសំណួរទាំងនេះនៅលើក្ដារខៀន មុនចាប់ផ្ដើមថ្នាក់រៀន ឬរៀបចំដាក់នៅក្នុងក្រដាសសម្រាប់ចែកចាយ ) ៖

> *តើពេលណាដែលអ្នកមានបទពិសោធន៍អំពី ព្រះចេស្ដា និងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ពេលអ្នកកំពុងបង្រៀន ( ចែកចាយ, ពន្យល់ ឬថ្លែងទីបន្ទាល់អំពី ) ដំណឹងល្អ ?*
>
> *តើពេលណាខ្លះ ដែលអ្នកដឹងថា ព្រះវិញ្ញាណបរិសុទ្ធ ថ្លែងទីបន្ទាល់មកកាន់អ្នកអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ?*

បន្ទាប់ពីផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យជ្រើសរើសសំណួរមួយក្នុងសំណួរទាំងឡាយ ហើយចែកចាយពីបទពិសោធន៍របស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។ អ្នកអាចនឹងចង់បន្ថែមទីបន្ទាល់របស់អ្នកអំពីតួនាទីដ៏សំខាន់ដែលព្រះវិញ្ញាណមាន នៅក្នុងការបង្រៀន និងការរៀនដំណឹងល្អ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៨–២៩

*ព្រះអម្ចាស់បើកសម្ដែងក្រឹត្យវិន័យ និងបទបញ្ញត្តិទាំងឡាយសម្រាប់សមាជិកនៃសាសនាចក្រ*

សូមសរសេរសេចក្ដីយោងព្រះគម្ពីរដូចខាងក្រោមនៅលើក្ដារខៀន ៖ ( សូមកុំបញ្ចូលពាក្យនៅក្នុងវង់ក្រចក ) ៖

> *គ. និង ស. ៤២:១៨–១៩ ( ការសំលាប់ ) គ. និង ស. ៤២:២០ ( ការលួច ) គ. និង ស. ៤២:២១ ( ការកុហក )*
> *គ. និង ស. ៤២:២២–២៣ ( ការលោភចង់បានរបស់អ្នកដទៃ ) គ. និង ស. ៤២:២៤–២៦ ( អំពើផិតក្បត់ )*
> *គ. និង ស. ៤២:២៧ ( ការនិយាយអាក្រក់ពីអ្នកដទៃ )*

សូមពន្យល់ថា នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបើកសម្ដែងក្រឹត្យវិន័យ និងបទបញ្ញត្តិនានាដែលទាក់ទងទៅនឹងសមាជិកទាំងអស់នៃសាសនាចក្រ ។ សូមបែងចែកសិស្សជាបីក្រុម ឬប្រាំមួយក្រុម ។ សូមចាត់ឲ្យសិស្សម្នាក់ៗនូវសេចក្ដីយោងព្រះគម្ពីរមួយ ឬពីរ ដែលសរសេរនៅលើក្ដារខៀន ហើយពន្យល់ថា វគ្គបទគម្ពីរនិមួយៗ មាននូវការណែនាំរបស់ព្រះអម្ចាស់ អំពីបទបញ្ញត្តិជាក់លាក់មួយ ។ សូមឲ្យសិស្សសិក្សានូវវគ្គបទគម្ពីរដែលបានចាត់ទៅឲ្យពួកគេ រួចហើយប្រើគម្រោងខាងក្រោមដើម្បីរៀបចំបង្រៀនដល់ក្រុមរបស់ពួកគេនូវអ្វីដែលពួកគេបានរកឃើញ ។ ( អ្នកអាចបង្ហាញគម្រោងនៅលើក្ដារខៀន ឬ រៀបចំ

ចែកជាវានៅលើក្រដាសដល់ពួកគេ ។ ) អ្នកអាចនឹងចង់លើកទឹកចិត្តដល់សិស្សឲ្យប្រើកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ឬសេចក្ដីណែនាំទៅបទគម្ពីរសម្រាប់ជំនួយបន្ថែម ។ បើសិស្សក្នុងថ្នាក់របស់អ្នកមានចំនួនតិច អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យបង្រៀនដល់សិស្សក្នុងថ្នាក់ទាំងមូល ជាជាងបង្រៀនទៅដល់ក្រុមរបស់ពួកគេ ) ។

១. សូមអញ្ជើញសិស្សម្នាក់ពីក្រុមរបស់អ្នកឲ្យអាននូវបទគម្ពីរដែលបានចាត់ទៅឲ្យពួកគេឮៗ ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សមាជិកនៃក្រុមរបស់អ្នក ឲ្យគូសចំណាំបញ្ញត្តិ ឬក្រឹត្យវិន័យ នៅក្នុងវគ្គបទគម្ពីរ ។

២. សូមប្រាប់អំពីគោលលទ្ធិ ឬគោលការណ៍មួយ ដែលយើងអាចរៀនចេញមកពីខគម្ពីរ ។

៣. សូមពន្យល់ថា ហេតុអ្វីក៏អ្នកមានអារម្មណ៍ថា បទបញ្ញត្តិនេះ សំខាន់ និងរបៀបដែលការគោរពប្រតិបត្តិរបស់យើងចំពោះបទបញ្ញត្តិ អាចជះឥទ្ធិពលដល់សុខុមាលភាពខាងវិញ្ញាណរបស់យើង ។

៤. សូមចែកចាយគំនិតមួយអំពីអ្វីដែលយើងទាំងអស់គ្នាអាចធ្វើកាន់តែពេញលេញក្នុងការរក្សាបទបញ្ញត្តិនេះ ( ឬការពារកុំឲ្យបំបាក់បទបញ្ញត្តិនេះ ) ។ អ្នកក៏អាចនឹងចង់អញ្ជើញសមាជិកក្រុមរបស់អ្នកឲ្យចែកចាយគំនិតរបស់ពួកគេផងដែរ ។

***សិស្សបង្រៀនគ្នាទៅវិញទៅមក***

នៅពេលពួកគេសិក្សា និង បង្រៀនគ្នានូវគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ដែលបានស្ដារឡើងវិញដល់គ្នាទៅវិញទៅមក នោះពួកគេនឹងមាននូវការយល់ដឹងកាន់តែអស្ចារ្យ ហើយពង្រឹងដល់ទីបន្ទាល់របស់ពួកគេ ។ សូមជ្រើសរើសឱកាសដោយយកចិត្តទុកដាក់ដើម្បីឲ្យសិស្សបង្រៀនគ្នាទៅវិញទៅមក ហើយផ្ដល់នូវការណែនាំច្បាស់លាស់ដល់ពួកគេ ដើម្បីពួកគេអាចធ្វើបានជោគជ័យ ។ ជាទូទៅ ការចាត់ឲ្យសិស្សបង្រៀនបទគម្ពីរមួយ ដោយគ្មានផ្ដល់នូវការណែនាំច្បាស់លាស់ ពុំអាចផ្ដល់ផលជាការបង្រៀនល្អទេ ។ សូមលើកទឹកចិត្តសិស្សឲ្យគិត និងអធិស្ឋានពេលពួកគេរៀបចំខ្លួនដើម្បីបង្រៀន ។

សូមប្រាកដថា អ្នកឲ្យពេលពួកគេគ្រប់គ្រាន់ដើម្បីសិស្សអាចត្រៀមខ្លួន រួចហើយបង្រៀនដល់ក្រុមរបស់ពួកគេ ។ នៅពេលសិស្សបង្រៀនគ្នាទៅវិញទៅមក សូមដើរមើលជុំវិញ ហើយផ្ដល់ជាជំនួយ និងការលើកទឹកចិត្ត ពេលចាំបាច់ ។

បន្ទាប់ពីសិស្សបានបញ្ចប់ការបង្រៀនដល់ក្រុមរបស់ពួកគេហើយ សូមសរសេរនូវសេចក្ដីថ្លែងការណ៍ដែលពុំពេញលេញដូចខាងក្រោម នៅលើក្ដារខៀន ៖ *តាមរយៈការបម្រើព្រះ និងការរក្សាបទបញ្ញត្តិរបស់ទ្រង់ នោះយើងបង្ហាញ. . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:២៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ ឬឃ្លាទាំងឡាយដែលបំពេញគោលការណ៍នេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យបំពេញចន្លោះទំនេរនៅលើក្ដារខៀន ដើម្បីឲ្យសេចក្ដីថ្លែងការណ៍មានលក្ខណៈស្រដៀងនឹងគោលការណ៍ដូចខាងក្រោម ៖ **តាមរយៈការបម្រើព្រះ និងការរក្សាបទបញ្ញត្តិរបស់ទ្រង់ នោះយើងបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះ ។** ( អ្នកអាចផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំគោលកាណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។

- តើការរក្សាក្រឹត្យវិន័យ និងបទបញ្ញត្តិរបស់ព្រះ បង្ហាញពីសេចក្ដីស្រឡាញ់របស់យើងចំពោះទ្រង់យ៉ាងដូចម្ដេច ?

- តើការរក្សាបទបញ្ញត្តិបាននាំអ្នកឲ្យខិតទៅកាន់តែជិតព្រះអម្ចាស់យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សនឹកគិតអំពីអាកប្បកិរិយារបស់ពួកគេចំពោះក្រឹត្យវិន័យ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញពួកគេឲ្យជ្រើសរើសបទបញ្ញត្តិមួយ ដែលពួកគេនឹងព្យាយាមដើម្បីរក្សាឲ្យបានកាន់តែពេញលេញ ដែលជារបៀបមួយដើម្បីបង្ហាញពីសេចក្ដីស្រឡាញ់របស់ពួកគេចំពោះព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះ ។ សូមបញ្ចប់ដោយការចែកចចាយអំពីរបៀបដែលការរក្សាបទបញ្ញត្តិទាំងឡាយ បានជួយពង្រឹងដល់ទំនាក់ទំនងរបស់អ្នកជាមួយព្រះអម្ចាស់ ។

មេរៀនទី ៤៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៤២

## បុព្វកថា

នៅដើមឆ្នាំ ១៨៣១ ពួកបរិសុទ្ធភាគច្រើនដែលរស់នៅក្នុងរដ្ឋនូវយ៉ោក រួមទាំង យ៉ូសែប ស្ម៊ីធ បានផ្លាស់ទីលំនៅទៅកាន់រដ្ឋ ហូហៃអូ ដើម្បីចូលរួមនឹងក្រុមធំមួយ ដែលបានផ្លាស់ប្រែចិត្តជឿទទួលបុណ្យជ្រមុជទឹកថ្មីៗនៅទីនោះ ។ អ្នកដឹកនាំ សាសនាចក្រ ស្វែងរកការដឹកនាំមកពីព្រះអម្ចាស់ ទាក់ទងនឹងការរីកចម្រើន នៃសាសនាចក្រ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយ ដែលឥឡូវត្រូវ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–៧៣ នៅក្នុងវត្តមាន នៃពួកអែលឌើរ ១២ នាក់ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានណែនាំអំពី ក្រឹត្យវិន័យខាងវិញ្ញាណ ខាងសេដ្ឋកិច្ច និងខាងសាច់ឈាម ដើម្បីដឹកនាំសមាជិក សាសនាចក្រ ឲ្យជួយដល់អ្នកក្រីក្រ ផ្ដល់ហិរញ្ញវត្ថុសម្រាប់បន្ទុកផ្សេងៗក្នុង សាសនាចក្រ ហើយជួយដល់ពួកបរិសុទ្ធផ្សេងទៀតដែលមកដល់រដ្ឋ អូហៃអូ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៤២

*ព្រះអម្ចាស់បានដាក់ក្រឹត្យវិន័យនៃការថ្វាយ*

មុនពេលចាប់ផ្ដើមថ្នាក់រៀន សូមប្រើបង់ស្គិត ឬហ្វឺត ដើម្បីគូសបន្ទាត់មួយ នៅលើកែវទឹកថ្លាចំនួនប្រាំមួយ ។ សូមគូសបន្ទាត់ ក្នុងកម្រិតកម្ពស់ផ្សេងៗគ្នានៅលើកែវទឹកនិមួយៗ ។ សូមយកកែវទឹកមកថ្នាក់រៀន ។ សូមនាំយកថូទឹកមួយដែលមានទឹកច្រើន ល្មមគ្រប់គ្រាន់ដើម្បីចាក់បំពេញក្នុងកែវទឹកទាំងអស់ត្រឹមបន្ទាត់ដែលបានគូសនៅលើកែវទឹកទាំងនោះ ។ ( អ្នកអាចនឹងចង់ លាយពណ៌នៅក្នុងទឹក ដើម្បីសិស្សនឹងអាចមើលឃើញវាដោយងាយ ) ។

នៅដើមមេរៀន សូមបង្ហាញថូទឹក ។ សូមប្រាប់ដល់សិស្សថា ទឹកតំណាងឲ្យទ្រព្យសម្បត្តិ និងធនធានទាំងអស់ក្នុងសហគមន៍ មួយ ។

សូមពន្យល់ថា នៅក្នុងខែកុម្ភៈ ឆ្នាំ ១៨៣១ សមាជិកនៃសាសនាចក្រនៅទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ បានត្រូវការជំនួយ ដើម្បីមើលថែដល់អ្នកទាល់ក្រ ជួយដល់អ្នកមកតាំងលំនៅថ្មី ដែលបានលះបង់យ៉ាងច្រើន ដើម្បីមកប្រមូលផ្ដុំនៅរដ្ឋ អូហៃអូ ហើយជួយផ្នែកហិរញ្ញវត្ថុដើម្បីប្រតិបត្តិការលើសាសនាចក្រផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលបទបញ្ញត្តិ ដែលព្រះអម្ចាស់បានបើកសម្ដែងទាក់ទងនឹងអ្នកទាល់ក្រ ។

- តើអ្នកគិតថា « សូមនឹកដល់មនុស្សទាល់ក្រ » មានន័យយ៉ាងណា ?

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធឲ្យថ្វាយទ្រព្យសម្បត្តិរបស់ពួកគេ ដើម្បីគាំទ្រដល់មនុស្សទាល់ក្រ ។ សូមសរសេរពាក្យ*ការថ្វាយ*នៅលើក្ដារខៀន ។ សូមឲ្យសិស្សពិចារណាអំពីសំណួរខាងក្រោម ៖

- តើអ្នកគិតថា ការថ្វាយមានន័យដូចម្ដេច ?

សូមសរសេរនៅលើក្ដារខៀននូវនិយមន័យដូចខាងក្រោមនៃពាក្យ *ការថ្វាយ* ដែលបានផ្ដល់ឲ្យដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ អ្នកអាចនឹងចង់ស្នើឲ្យសិស្សសរសេរនិយមន័យនេះនៅក្នុងគែមទំព័រនៃបទគម្ពីរ របស់ពួកគេ នៅជិតនឹង ខ ៣០ ។

*ឧបករណ៍សម្រាប់មេរៀន*

ឧបករណ៍សម្រាប់មេរៀន អាចជាវិធីដ៏មានប្រសិទ្ធភាពមួយ ដើម្បីជួយសិស្សយល់គោលការណ៍ខាងវិញ្ញាណ ។ ជាញឹកញាប់វត្ថុមួយ អាចជួយទាក់ទាញចំណាប់អារម្មណ៍របស់សិស្ស ហើយជួយពួកគេឲ្យផ្ដោតទៅលើបទពិសោធន៍រៀនសូត្រ ។ នៅពេលណាអ្នកមើលឃើញកម្មវត្ថុនៃមេរៀនមួយ សូមប្រាកដថា វាជួយជម្រុញដល់គោលបំណងនៃមេរៀនជាជាងការរំខានចំពោះមេរៀនទៅវិញ ។



« ដើម្បីថ្វាយ គឺញែកចេញ ឬលះបង់អ្វីមួយដើម្បីគោលបំណងបរិសុទ្ធ ពិសិដ្ឋ ដោយលះបង់ » (Reflections on a Consecrated Life, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ១៦ ) ។

- តើអ្នកគិតថានិយមន័យនេះ ទាក់ទងនឹងទង្វើនៃការផ្ដល់អ្វីមួយដើម្បីជួយដល់មនុស្សដែលខ្វះខាតយ៉ាងដូចម្ដេច ?

- តើអ្នកអាចសង្ខេបបទបញ្ញត្តិរបស់ព្រះអម្ចាស់ នៅក្នុង ខ ៣០ ទាក់ទងនឹងមនុស្សទាល់ក្រយ៉ាងដូចម្ដេច ? ( ទោះជាសិស្សអាចប្រើពាក្យផ្សេងក្ដី ក៏ចម្លើយរបស់ពួកគេ គួរតែបង្ហាញពីគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអម្ចាស់ បញ្ជាឲ្យយើងមើលថែដល់អ្នកទាល់ក្រ និងអ្នកខ្វះខាត ។** ជាចំណែកនៃការពិភាក្សានេះ អ្នកនឹងចង់អាចអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨: ១៦, ៣៤–៣៦ ) ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ មានគោលការណ៍នៃក្រឹត្យវិន័យមួយ ដែលហៅថា ក្រឹត្យវិន័យនៃការថ្វាយ ។ ដើម្បីជួយសិស្សយល់អំពីគោលការណ៍មូលដ្ឋានគ្រឹះទាំងនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការពន្យល់ដូចខាងក្រោម ដោយប្រធាន ម៉ារុន ជី រ៉ូមនី នៃគណៈប្រធានទីមួយ ។



« គោលការណ៍គ្រឹះ និងការកែសម្រួលសម្រាប់ក្រឹត្យវិន័យនៃការថ្វាយ ‹ គឺថាអ្វីៗគ្រប់យ៉ាងដែលយើងមានជារបស់ផងព្រះអម្ចាស់ ហេតុដូច្នោះហើយ ព្រះអម្ចាស់អាចហៅឲ្យយើងលះបង់រាល់ទ្រព្យសម្បត្តិដែលយើងមាន ដោយសារវាជារបស់ផងទ្រង់ ។ គ. និង ស. ១០៤:១៤–១៧, ៥៤–៥៧ J. Reuben Clark, Jr., in Conference Report, ខែ តុលា ឆ្នាំ ១៩៤២, ទំព័រ ៥៥ » ) (Living the Principles of the Law of Consecration, » *Ensign* ខែ កុម្ភៈ ឆ្នាំ ១៩៧៩, ទំព័រ ៣ ) ។

*កំណត់ចំណាំ ៖* ឧបករណ៍សម្រាប់មេរៀនដូចខាងក្រោម គឺជាការសម្រាយមួយអំពីក្រឹត្យវិន័យនៃការថ្វាយ ដូចដែលមាននៅក្នុងសាសនាចក្រប្រហែលនៅឆ្នាំ ១៨៣៣ ។ បន្ទាប់ពីគ្រានេះមក សាសនាចក្របានកែការអនុវត្តនេះ ។ មានឃ្លាមួយចំនួននៃការអនុវត្តក្រឹត្យវិន័យនៃការថ្វាយ និងការកែសម្រួលការអនុវត្តនៅក្នុងឆ្នាំក្រោយៗមកទៀត ។

សូមអញ្ជើញឲ្យសិស្សប្រាំមួយនាក់ឡើងមកខាងមុខថ្នាក់ ។ សូមឲ្យពួកគេម្នាក់ៗកាន់កែវទឹកទំនេរមួយ ។ សូមចាក់ទឹកពីក្នុងថូចូលក្នុងកែវ ។ សូមបំពេញកែវទឹកមួយដល់ត្រឹមខ្សែបន្ទាត់ ដែលអ្នកបានគូស ហើយសូមបំពេញកែវទឹកបីទៀតនៅខាងលើបន្ទាត់ដែលអ្នកបានគូស ហើយបំពេញកែវទឹកពីរទៀតនៅខាងក្រោមបន្ទាត់ដែលអ្នកបានគូស ។ សូមពន្យល់ថា កែវទឹកនិមួយៗតំណាងឲ្យគ្រួសារមួយ ហើយថាបន្ទាត់នៅលើកែវទឹកនិមួយៗតំណាងឲ្យសេចក្ដីត្រូវការ និងបំណងប្រាថ្នាសុចរិតរបស់គ្រួសារនោះ ។ កែវទឹកដែលមានទឹកនៅខាងក្រោមបន្ទាត់ តំណាងឲ្យគ្រួសារដែលពុំមានប្រាក់កាសគ្រប់គ្រាន់ ឬសម្ភារដើម្បីផ្គត់ផ្គង់តម្រូវការរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលជំហានទីមួយ ដែលពួកបរិសុទ្ធទាំងនេះ បានចាប់ផ្ដើមដើម្បីរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។

- សម្រាប់ពួកបរិសុទ្ធទាំងនេះ តើជំហានទីមួយនៅក្នុងការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយគឺជាអ្វី ? ( សម្ភាររបស់ពួកគេគឺត្រូវបាន « ដាក់ទ្រព្យទាំងនោះនៅចំពោះមុខប៊ីស្សពនៃសាសនាចក្រ និងទីប្រឹក្សាទាំងឡាយរបស់គាត់ » ។ ជាពាក្យម្យ៉ាងទៀតថា ពួកគេត្រូវបង្ហាញនូវការស្ម័គ្រចិត្តរបស់ពួកគេដើម្បីថ្វាយប្រាក់ និងទ្រព្យសម្បត្តិរបស់ពួកគេដល់សាសនាចក្រ ) ។

- តើប៊ីស្សពតំណាងឲ្យនរណា ? ( ព្រះអម្ចាស់ ) ។

ដើម្បីជាតំណាងឲ្យសាសនាចក្រ នោះសមាជិកបានថ្វាយទ្រព្យរបស់ខ្លួនដល់សាសនាចក្រ សូមឲ្យសិស្សប្រាំមួយនាក់មកចាក់ទឹកចេញពីកែវរបស់ពួកគេចូលទៅក្នុងថូ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣២ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលជំហានទីពីរ ដែលពួកបរិសុទ្ធទាំងនេះ ត្រូវធ្វើដើម្បីរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។

សូមពន្យល់ថា គ្រប់គ្រួសារបានធ្វើការជាមួយប៊ីស្សព និងបានទទួលនូវអ្វីដែលហៅថា « ការកាន់កាប់ត្រួតត្រា » (គ. និង ស. ៤២:៧២) ។ នេះមានន័យថា គ្រួសារនិមួយៗត្រូវបានប្រគល់ទ្រព្យ និងធនធាននានាមកពីព្រះអម្ចាស់ ។ ក្រុមគ្រួសារ មានឯកសិទ្ធិធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ និងធនធាននានា ដែលពួកគេបានទទួល ហើយពួកគេត្រូវប្រើសិទ្ធិជ្រើសរើសរបស់ពួកគេ ដើម្បីគ្រប់គ្រងលើការកាន់កាប់ត្រួតត្រារបស់ពួកគេ ។ ក្នុងនាមជាអ្នកកាន់កាប់ត្រួតត្រាទ្រព្យសម្បត្តិ និងធនធាននានារបស់ព្រះអម្ចាស់ នោះពួកគេមានទំនួលខុសត្រូវចំពោះទ្រង់ ហើយទទួលខុសត្រូវទាំងស្រុងចំពោះអ្វីដែលទ្រង់បានប្រគល់ដល់ពួកគេ ។

សូមចាក់ទឹកចេញពីថូ បំពេញក្នុងកែវទឹកនិមួយៗត្រឹមបន្ទាត់ដែលគូសនោះ ។

ដើម្បីជួយសិស្សឲ្យយល់អំពីរបៀបដែលប៊ីស្សពចែកធនធានដល់ក្រុមគ្រួសារ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលប៊ីស្សព ( ដែលនៅក្នុងករណីនេះ គឺជា អែតវឺត ប៉ាទ្រិច ) បានប្រគល់ចំណែកមួយដល់គ្រួសារនិមួយៗ ។ អ្នកក៏អាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យសរសេរ *គ. និង ស. ៥១:៣* នៅក្នុងគម្ពីររបស់ពួកគេជិតនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣៣ ។

- តើប៊ីស្សពប្រគល់ចំណែកមួយដល់គ្រប់ក្រុមគ្រួសារយ៉ាងដូចម្ដេច ? ( ការចែកចំណែក គឺអាស្រ័យទៅលើស្ថានភាព ចំណង់ និងតម្រូវការរបស់គ្រួសារនិមួយៗ ) ។

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះអម្ចាស់កំណត់អំពីចំណង់ និងតម្រូវការរបស់មនុស្សតាមរបៀបណា ។ អ្នកក៏អាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យសរសេរ *គ. និង ស. ៨២:១៧* នៅក្នុងបទគម្ពីររបស់ពួកគេ ជិតនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣៣។

- យោងតាមខនេះ តើព្រះអម្ចាស់មានតម្រូវការអ្វីខ្លះពីរាស្ត្រ ដែលប្រកាសពីបំណងប្រាថ្នា និងតម្រូវការរបស់ពួកគេចំពោះប៊ីស្សពនោះ ? ( ពួកគេត្រូវមានយុត្តិធម៌ ឬជាពាក្យម៉្យាងទៀតថា ស្មើភាព និងទៀងត្រង់ ) ។

សូមបង្ហាញទឹកដែលនៅសល់ក្នុងថូដល់សិស្ស ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣៣–៣៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានណែនាំដល់ពួកបរិសុទ្ធឲ្យធ្វើជាមួយនឹងទ្រព្យសម្បត្តិដែលបានថ្វាយ ដែលនៅសេសសល់បន្ទាប់ពីចែកឲ្យកាន់កាប់ត្រួតត្រាហើយនោះ ។

- តើព្រះអម្ចាស់បានមានព្រះបន្ទូលណែនាំពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ជាមួយនឹងទ្រព្យសម្បត្តិដែលនៅសល់ ឬ « របស់ដែលនៅសល់ទាំងប៉ុន្មាន » នោះ ? ( ពួកគេគឺត្រូវប្រើដើម្បីជួយដល់អ្នកទាល់ក្រ ផ្ដល់ហិរញ្ញវត្ថុដល់ការសាងសង់សាសនាចក្រ និងជួយសមាជិកដែលខ្វះខាត ) ។ តើអ្នកគិតថា ថូ តំណាងឲ្យអ្វី នៅក្នុងខទាំងនេះ ? ( ឃ្លាំង ) ។
- តើការថ្វាយជួយក្នុងការមើលថែដល់មនុស្សទាល់ក្រ និងអ្នកទាំងឡាយដែលខ្វះខាតយ៉ាងដូចម្ដេច ?
- តើក្រឹត្យវិន័យនៃការថ្វាយ អាចជាពរជ័យមួយដល់សាសនាចក្រយ៉ាងដូចម្ដេច ?
- តើវានឹងលំបាកយ៉ាងណា ដើម្បីរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលការណ៍មួយ ដែលព្រះអម្ចាស់បង្រៀនទាក់ទងនឹងការធ្វើល្អចំពោះអ្នកដទៃ ។

- តើគោលការណ៍អ្វីខ្លះដែលព្រះអម្ចាស់បានបង្រៀនអំពីការធ្វើល្អដល់អ្នកដទៃ ? ( សិស្សគួរតែបង្ហាញថា**នៅពេលយើងធ្វើល្អដល់អ្នកដទៃ ក៏ដូចជាយើងធ្វើល្អដល់ព្រះអម្ចាស់ដែរ** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- តើសេចក្ដីពិតនេះ បានជួយដល់ពួកបរិសុទ្ធ មានឆន្ទៈដើម្បីលះបង់ទ្រព្យសម្បត្តិរបស់ពួកគេយ៉ាងដូចម្ដេច ? តើការចងចាំសេចក្ដីពិតនេះ ជួយអ្នកយ៉ាងដូចម្ដេច ?
- តើនៅពេលណា ដែលអ្នកបានដឹងថា អ្នកកំពុងបម្រើព្រះអម្ចាស់ នៅពេលអ្នកបានធ្វើអ្វីមួយដើម្បីជួយដល់អ្នកដទៃនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤០–៤២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលលក្ខណៈរបស់មនុស្សម្នាក់ ត្រូវតែមាន ដើម្បីរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ ( ដើម្បីជួយសិស្សយល់អំពីរបៀបដែល ខ ៤០ អនុវត្តនៅក្នុងជីវិតរបស់ពួកគេ នោះអ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ព្រះអម្ចាស់ ពុំរំពឹងឲ្យយើងដេរខោអាវខ្លួនយើងទេ ។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់ចង់ឲ្យយើងមានភាពស្អាតបាត និងស្អាតខាងរាងកាយរបស់យើងផង ) ។

- នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤២ ពាក្យ *ខ្ជិលច្រអូស* មានន័យថាខ្ជិល ។ ហេតុអ្វីក៏វាពិបាកសម្រាប់មនុស្សខ្ជិលម្នាក់រស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ?

សូមបែងចែកសិស្សជាក្រុម ៗ ដែលមានគ្នាពីរ ឬបីនាក់ក្នុងមួយក្រុម ៗ ។ សូមពន្យល់ថា ទោះបីជាយើងពុំបានបញ្ជាឲ្យរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយតាមរបៀបដូចគ្នានឹងពួកបរិសុទ្ធជំនាន់មុនក្ដី ក៏ក្រឹត្យវិន័យគឺនៅតែមានសម្រាប់ពេលសព្វថ្ងៃនេះផងដែរ ។ សូមអញ្ជើញក្រុមនិមួយ ៗអាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអេលឌើរ ស្ពែនស៊ើរ ដបុលយូ ឃីមបឹលឲ្យឮ ៗ ហើយស្ដាប់នូវអត្ថន័យដែលវាមានចំពោះយើងនាសព្វថ្ងៃនេះ ដើម្បីរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ បន្ទាប់មកអញ្ជើញសមាជិកក្រុមនិមួយ ៗពិភាក្សាចម្លើយរបស់ពួកគេចំពោះសំណួរដែលមានតាមក្រោយសេចក្ដីថ្លែងការណ៍នោះ ។ ( អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សសរសេរសេចក្ដីថ្លែងការណ៍នេះនៅគែមព្រះគម្ពីររបស់ពួកគេជិត ខ ៣០ ) ។



« ការថ្វាយគឺជាការផ្ដល់ពេលវេលា ទេពកោសល្យ និងធម្យោបាយនានារបស់មនុស្សម្នាក់ ដើម្បីមើលថែដល់អ្នកទាំងឡាយដែលខ្វះខាត– ទោះជាខាងវិញ្ញាណ ឬខាងសាច់ឈាមក្ដី– ហើយនៅក្នុងការស្ថាបនានគររបស់ព្រះអម្ចាស់ » (Welfare Services: The Gospel in Action, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៧, ទំព័រ ៧៨ ) ។

- តើមនុស្សម្នាក់ដែលនៅជិតអ្នក អាចនឹងខ្វះខាតតាមមធ្យោបាយមួយចំនួន ( ក្រៅពីហិរញ្ញវត្ថុ ) មានអ្វីខ្លះ ?
- តើពេលវេលា ទេពកោសល្យ និងមធ្យោបាយ នានាអ្វីខ្លះ ដែលអ្នកមាន ដែលអាចប្រើដើម្បីជួយដល់អ្នកទាំងឡាយដែលខ្វះខាត ?
- តើពេលណាដែលអ្នកត្រូវបានប្រទានពរ ដោយមនុស្សម្នាក់ផ្សេងទៀត ដែលបានលះបង់ពេលវេលា ទេពកោសល្យ ឬមធ្យោបាយរបស់ពួកគេដើម្បីជួយអ្នកនោះ ?

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

មេរៀនទី ៤៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៣–៩៣

## បុព្វកថា

ផ្នែកខាងក្រោយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ គឺជាការបន្តនូវអ្វីដែលត្រូវបានស្គាល់ថាជា ក្រឹត្យវិន័យនៃសាសនាចក្រ ។ វារួមមានទាំងការបង្រៀនរបស់ព្រះអម្ចាស់ទាក់ទងនឹងសេចក្ដីស្លាប់ និងការព្យាបាល ។ វាក៏មាននូវការទូន្មានរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធ ទាក់ទងនឹងរបៀបត្រូវដោះស្រាយជាមួយនឹងអំពើបាបដ៏ធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្ម និងរបៀបគ្រប់គ្រងស្ថានភាពដោយត្រឹមត្រូវដែលយើងត្រូវបានអាក់អន់ចិត្ត ឬបានធ្វើឲ្យគេអាក់អន់ចិត្ត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៣–៥៥

*ព្រះអម្ចាស់ប្រទានការទូន្មានទាក់ទងនឹងសេចក្ដីស្លាប់ និងការព្យាបាល*

សូមយកដៃម្ខាងលើកដបប្រេងអូលីវតូចមួយ សម្រាប់ធ្វើការប្រសិទ្ធិពរដល់អ្នកឈឺ ហើយយកដៃម្ខាងទៀតកាន់ដបថ្នាំ ។

- តើវត្ថុទាំងពីរនេះប្រើសម្រាប់ធ្វើអ្វី ? តើវត្ថុមួយណាដែលយើងគួរតែពឹងផ្អែកនៅលើពេលមានជម្ងឺ ?

បន្ទាប់ពីសិស្សបានចែកចាយដោយសង្ខេបនូវគំនិតរបស់ពួកគេហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៣–៤៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការណែនាំរបស់ព្រះអម្ចាស់ ទាក់ទងនឹងអ្វីដែលយើងគួរតែពឹងផ្អែកលើវាពេលមានជំងឺ ។ ដើម្បីជួយសិស្សយល់នូវខគម្ពីរទាំងនេះ វាអាចជាប្រយោជន៍ដើម្បីពន្យល់ថា រុក្ខជាតិ និងអាហារស្រាលៗ ដែលបានប្រាប់នៅក្នុង ខ ៤៣ នេះសំដៅទៅលើការព្យាបាលខាងវេជ្ជសាស្ត្រ ដែលត្រូវបានគេប្រើជាទូទៅអំឡុងពេលដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ។

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់អំពីរបៀបដែលការព្យាបាលអាចកើតមានមកតាមរយៈ ទាំងសេចក្ដីជំនឿផង *និង* ការព្យាបាលខាងវេជ្ជសាស្ត្រផង ។



« ពួកបរិសុទ្ធថ្ងៃចុងក្រោយ ជឿទៅលើការអនុវត្តចំណេះដឹង និងបច្ចេកវិទ្យាខាងវិទ្យាសាស្ត្រដ៏ល្អបំផុតដែលមាន ។ យើងប្រើអាហាររូបត្ថម្ភ លំហាត់ប្រាណ និងការអនុវត្តដទៃទៀត ដើម្បីថែទាំសុខភាព ហើយយើងចូលរួមបម្រើ ក្នុងការព្យាបាលរបស់គ្រូពេទ្យជំនាញ ដូចជាវេជ្ជបណ្ឌិត និង គ្រូពេទ្យវះកាត់ ដើម្បីទទួលបានសុខភាពល្អឡើងវិញផងដែរ ។

« ការប្រើប្រាស់វិទ្យាសាស្ត្រវេជ្ជសាស្ត្រ គឺពុំមែនជាការជំទាស់នឹងការអធិស្ឋានដោយសេចក្ដីជំនឿរបស់យើង និងការពឹងផ្អែករបស់យើងទៅលើការប្រសិទ្ធពរនៃបព្វជិតភាពនោះទេ ។. . .

« ប្រាកដណាស់ថា យើងពុំរង់ចាំរហូតដល់វិធីសាស្ត្រដទៃទៀតទាំងអស់ប្រើការលែងបាន ទើបយើងអធិស្ឋានដោយសេចក្ដីជំនឿ ឬផ្ដល់ការប្រសិទ្ធពរបព្វជិតភាពសម្រាប់ការជាសះស្បើយនោះទេ ។ ក្នុងពេលអាសន្ន ការអធិស្ឋាន និងការប្រសិទ្ធពរត្រូវធ្វើឡើងដំបូងគេបង្អស់ ។ ជាញឹកញាប់ណាស់ ដែលយើងខិតខំធ្វើអ្វីៗគ្រប់យ៉ាងក្នុងពេលដំណាលគ្នា » (Healing the Sick » *Ensign* ឬ *Liahona*, ខែ ឧសភា ឆ្នាំ ២០១០, ទំព័រ ៤៧ ) ។

*សូមសម្រេចចិត្តសម្រាប់អ្វីដែលត្រូវបង្រៀន*

មេរៀននេះ មាននូវឯកសារច្រើនជាងពេលវេលាដែលអ្នកមានដើម្បីបង្រៀន។ សូមពិចារណាប្រកបដោយការអធិស្ឋានថា គោលលទ្ធិ គោលការណ៍ ឬគំនិតបង្រៀនណាមួយ ដែលជាប្រយោជន៍ល្អបំផុតសម្រាប់សិស្សនៅក្នុងថ្នាក់របស់អ្នក ។ សូមសម្របមេរៀន ពេលអ្នកបានទទួលអារម្មណ៍បំផុសគំនិតដោយព្រះវិញ្ញាណបរិសុទ្ធ ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់សម្រាប់យើងដើម្បីប្រើការអធិស្ឋាន និងពរជ័យនៃបព្វជិតភាព ក៏ដូចជាការព្យាបាលខាងវេជ្ជសាស្ត្រសម្រាប់ធ្វើការព្យាបាលក្នុងពេលមានជំងឺយ៉ាងដូច្នេះ ?

- ស្របតាម ខ ៤៤ តើមនុស្សមានជម្ងឺគ្រប់គ្នា ដែលបានទទួលពរជ័យបព្វជិតភាព នឹងត្រូវបានព្យាបាលជាឬ ?

សូមប្រាប់សិស្សថា ព្រះអម្ចាស់ បានពន្យល់ពីមូលហេតុដែលមនុស្សមួយចំនួន ដែលបានទទួលពរជ័យបព្វជិតភាព អាចនឹងពុំបានជាសះស្បើយផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៤៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលការណ៍ទាំងឡាយដែលគ្រប់គ្រង ថាតើនរណានឹងត្រូវបានជាសះស្បើយ ឬអត់ ដោយសារការប្រសិទ្ធពរពីបព្វជិតភាព ។

- យោងតាម ខ ៤៨ តើកត្តាចម្បងដែលកំណត់ពីលទ្ធផលនៃការប្រសិទ្ធពរពីបព្វជិតភាពគឺជាអ្វី ? ( នៅពេលសិស្សឆ្លើយតប អ្នកអាចពន្យល់ថា « ដែលពុំបានកំណត់ឲ្យស្លាប់ » សំដៅទៅលើកត្តាដែលសេចក្តីស្លាប់ ឬការព្យាបាល នឹងត្រូវធ្វើឡើងស្របតាមពេលវេលា ប្រាជ្ញា និងព្រះទ័យរបស់ព្រះអម្ចាស់ ) ។

- ហេតុអ្វីក៏មនុស្សគ្រប់គ្នាដែលមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នឹងពុំបានជាសះស្បើយដូច្នេះ ?

- ហេតុអ្វីក៏វាសំខាន់ដើម្បីមានសេចក្តីជំនឿទៅលើព្រះឆន្ទៈរបស់ព្រះ និងពេលវេលាសម្រាប់យើងម្នាក់ៗ ?

សូមអញ្ជើញសិស្សឲ្យប្រាប់គោលការណ៍មួយដែលយើងអាចរៀនចេញមកពី គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៤៨ អំពីការព្យាបាលពីអស់ទាំងរោគារបស់យើង ។ ចម្លើយរបស់សិស្សអាចនឹងឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានព្យាបាលតាមព្រះឆន្ទៈរបស់ទ្រង់** ។ អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សគូសចំណាំពាក្យ ឬឃ្លានៅក្នុង ខទី ៤៨ ដែលបង្រៀនពីគោលការណ៍នេះ។

ដើម្បីជួយសិស្សឲ្យយល់ថា សេចក្តីជំនឿរបស់យើង ត្រូវតែផ្តោតទៅលើព្រះយេស៊ូវគ្រីស្ទ ជាជាងផ្តោតទៅលើលទ្ធផលជាក់លាក់នានា ដែលយើងប្រាថ្នាចង់បាន សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្តាប់រកមូលហេតុមួយថា ហេតុអ្វីក៏វាសំខាន់ដើម្បីផ្តោតសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ។



« ក្នុងនាមជាបុត្ររបស់ព្រះ ដោយដឹងពីសេចក្តីស្រឡាញ់ដ៏មហិមារបស់ទ្រង់ និងចំណេះដឹងដ៏គ្មានកម្រិតរបស់ទ្រង់អំពីអ្វីដែលល្អបំផុតសម្រាប់សុខុមាលភាពដ៏អស់កល្បរបស់យើង នោះយើងនឹងទុកចិត្តលើទ្រង់ ។ គោលការណ៍ទីមួយនៃដំណឹងល្អគឺជាសេចក្តីជំនឿទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ហើយសេចក្តីជំនឿមានន័យថាការទុកចិត្ត ។ ខ្ញុំបានទទួលអារម្មណ៍ដឹងពីទំនុកចិត្តនោះ នៅក្នុងការនិយាយដែលបងប្អូនជីដូនមួយរបស់ខ្ញុំបានថ្លែងនៅពិធីបុណ្យសពរបស់ក្មេងស្រីជំទង់ម្នាក់ ដែលបានស្លាប់ដោយសារមានជំងឺធ្ងន់ ។ គាត់បាននិយាយពាក្យទាំងនេះ ដែលដំបូងវាធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ហើយបន្ទាប់មកវាបានធ្វើឲ្យខ្ញុំបានស្ងប់ចិត្ត ៖ ‹ ខ្ញុំដឹងថា វាគឺជាព្រះឆន្ទៈរបស់ព្រះអម្ចាស់ ដែលថានាងត្រូវស្លាប់ ។ នាងបានទទួលនូវការយកចិត្តទុកដាក់ពីវេជ្ជសាស្ត្រដ៏ល្អ ។ នាងបានទទួលការប្រសិទ្ធពរបព្វជិតភាព ។ ឈ្មោះនាងត្រូវបានដាក់នៅក្នុងបញ្ជីអធិស្ឋានក្នុងព្រះវិហារបរិសុទ្ធ ។ នាងគឺជាប្រធានបទនៃការអធិស្ឋានរបស់មនុស្សរាប់រយនាក់ ដែលសុំឲ្យនាងមានសុខភាពល្អប្រសើរវិញ ។ ហើយខ្ញុំដឹងថា គ្រួសារនេះមានជំនឿល្មមគ្រប់គ្រាន់ដើម្បីឲ្យនាងនឹងបានជាសះស្បើយ តែវាគឺជាព្រះទ័យរបស់ព្រះអម្ចាស់ ដើម្បីនាំនាងត្រឡប់ទៅផ្ទះវិញនាពេលនេះ › ។ ខ្ញុំបានមានអារម្មណ៍ពីទំនុកចិត្តដូចគ្នានេះទៅលើពាក្យរបស់ឪពុករបស់ក្មេងស្រីជម្រើសម្នាក់ទៀត ដែលបានស្លាប់ដោយសារមហារីក ក្នុងវ័យជំទង់របស់នាង ។ គាត់បានប្រកាសថា ‹ សេចក្តីជំនឿរបស់គ្រួសារយើង គឺនៅលើព្រះយេស៊ូវគ្រីស្ទ ហើយវាមិនពឹងផ្អែកទៅលើលទ្ធផលណាមួយនោះទេ › ។ ការបង្រៀនទាំងនោះស្តាប់ទៅពិតណាស់ចំពោះខ្ញុំ ។ យើងធ្វើនូវអ្វីៗទាំងអស់ដែលយើងអាចធ្វើ ដើម្បីព្យាបាលដល់មនុស្សជាទីស្រឡាញ់របស់យើង រួចហើយយើងទុកចិត្តទៅលើព្រះអម្ចាស់ចំពោះលទ្ធផលនោះ » (« Healing the Sick » ទំព័រ ៥០ ) ។

- តើបុគ្គលម្នាក់ៗដែលអែលឌើរ អូក មានប្រសាសន៍បានអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

- ពេលខ្លះវាតម្រូវឲ្យមានសេចក្តីជំនឿកាន់តែខ្លាំង ដើម្បីមើលឃើញមនុស្សជាទីស្រឡាញ់ត្រូវស្លាប់ ឬរងទុក្ខនឹងជំងឺរ៉ាំរ៉ៃជាជាងមើលឃើញពួកគេរស់នៅ ឬត្រូវបានជាសះស្បើយ ។ ហេតុអ្វីអ្នកគិតថាការណ៍នេះអាចប្រែក្លាយជាដូច្នេះ ?

- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ទោះជាយើងពុំទទួលបានលទ្ធផលដែលយើងចង់បានក្តី ?

សូមសួរសិស្សប្រសិនបើជាពួកគេស្គាល់នរណាដែលបានទទួលមរណភាព ទោះជាគាត់បានធ្វើតាមដំបូន្មានខាងវេជ្ជសាស្ត្រត្រឹមត្រូវ ហើយស្វែងរកការព្យាបាលតាមរយៈការអធិស្ឋាន និងការប្រសិទ្ធពរពីបព្វជិតភាពក៏ដោយ ។ ( សូមប្រយ័ត្នជាពិសេសចំពោះអារម្មណ៍របស់អ្នកដែលអាចនឹងជួបស្ថានភាពដូចនេះ ) ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៥–៤៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ ឬឃ្លាដែលអាចនាំមកនូវការលួងលោមចិត្តដល់នរណាម្នាក់ដែលធ្លាប់មានមនុស្សជាទីស្រឡាញ់របស់ខ្លួនទទួលរមណភាព ។

- ខ ៤៥ ប្រាប់យើងថា យើងនឹងយំសោកទៅតាមធម្មជាតិ ចំពោះការបាត់បង់មនុស្សដែលយើងស្រឡាញ់ ។ តើគោលការណ៍អ្វីខ្លះ បានបង្រៀននៅក្នុង ខ ៤៦ ដែលអាចនាំមកនូវការលួងលោមចិត្តដល់អ្នកទាំងឡាយដែលយំសោកចំពោះការបាត់បង់មនុស្សជាទីស្រឡាញ់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **សេចក្ដីស្លាប់ គឺផ្អែមល្ហែមចំពោះអ្នកទាំងឡាយដែលស្លាប់នៅក្នុងព្រះអម្ចាស់** ) ។
- តើអ្នកគិតថាសេចក្ដីស្លាប់នៅក្នុងព្រះអម្ចាស់ វាមានន័យយ៉ាងណា ?
- តើអ្នកគិតថាវាមានន័យយ៉ាងណា ដែលថាសេចក្ដីស្លាប់នឹង « ផ្អែមល្ហែម » ចំពោះអ្នកទាំងឡាយដែលស្លាប់នៅក្នុងព្រះអម្ចាស់នោះ ? ( អ្នកចាំបាច់ត្រូវពន្យល់ថា សូម្បីតែមនុស្សស្មោះត្រង់ម្នាក់ដែលស្លាប់ ក៏អាចនឹងរងនូវការឈឺចាប់ខាងរូបកាយដែរ ការសន្យានេះសំដៅទៅលើភាពសុខសាន្ត និងការឈប់សម្រាក ដែលបុគ្គលនោះ នឹងទទួលនៅក្នុងពិភពវិញ្ញាណ ) ។

សូមអញ្ជើញសិស្សឲ្យគិតពិចារណាថាតើពួកគេកំពុងរស់នៅក្នុងជីវិតតាមរបៀបដែលនឹងធ្វើឲ្យសេចក្ដីស្លាប់ « ផ្អែមល្ហែម » ចំពោះពួកគេ ប្រសិនបើវានឹងកើតឡើងនៅក្នុងថ្ងៃនេះបុទេ ។ ( អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសរសេរគំនិតរបស់ពួកគេទុកនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៥៦–៧៣

*ព្រះអម្ចាស់សន្យាថាបើកសម្ដែងបទគម្ពីរ និង វិវរណៈបន្ថែមទៅកាន់អ្នកទាំងឡាយណាដែលសុំ*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៥៦–៥៨ ដោយការពន្យល់ថា ខគម្ពីរទាំងនេះ យោងទៅលើការបកប្រែព្រះគម្ពីរប៊ីបរបស់យ៉ូសែប ស្ម៊ីធ។ ព្រះអម្ចាស់បានប្រាប់ដល់ពួកបរិសុទ្ធថា ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ គួរតែត្រូវបានបង្រៀនដល់មនុស្សទាំងអស់ ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៥៩–៦៩ ដោយការពន្យល់ថា ខគម្ពីរទាំងនេះ មាននូវការណែនាំមកពីព្រះអម្ចាស់ ទៅកាន់ យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀត ទាក់ទងនឹងពេលវេលា និង នរណាដែលពួកគេគប្បីផ្សាយដំណឹងល្អទៅ ។ ព្រះអម្ចាស់ បានដាស់តឿនពួកគេឲ្យរស់នៅតាមក្រឹត្យវិន័យទាំងឡាយដែលពួកគេត្រូវបានប្រគល់ឲ្យ ហើយទ្រង់បានពន្យល់ថា ពួកគេនឹងទទួលការដឹកនាំបន្ថែម ដែលនឹងជួយពួកគេស្ថាបនាសាសនាចក្រ ហើយរៀបចំពួកបរិសុទ្ធឲ្យរស់នៅក្នុងទីក្រុងយេរូសាឡិមថ្មីនាពេលអនាគត ។ បន្ថែមពីលើនោះ ព្រះអម្ចាស់បានបង្រៀនពួកគេអំពីគោលការណ៍ទាំងឡាយដែលទាក់ទងនឹងរបៀបដែលពួកគេអាចបន្តទទួលវិវរណៈពីព្រះ ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៧០–៧៣ ដោយពន្យល់ថា នៅក្រោមក្រឹត្យវិន័យនៃការថ្វាយ នោះអ្នកទាំងឡាយដែលផ្ដល់ការបម្រើពេញម៉ោង ឬក្រៅម៉ោងដល់សាសនាចក្រ គឺត្រូវបានផ្ដល់ជំនួយខាងហិរញ្ញវត្ថុ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៦១, ៦៨ ដោយស្ងាត់ស្ងៀម រកមើលគោលការណ៍ទាំងឡាយអំពីការទទួលវិវរណៈ ។ ចម្លើយសិស្សអាចរួមមានដូចខាងក្រោម ៖

**បើយើងសូម នោះព្រះអម្ចាស់នឹងប្រទានចំណេះដឹងដល់យើង ដែលនឹងនាំមកយើងនូវសេចក្ដីសុខសាន្ត សេចក្ដីអំណរ និងជីវិតដ៏អស់កល្បជានិច្ច ។**

**បើយើងសូមប្រាជ្ញា នោះព្រះអម្ចាស់នឹងប្រទានដល់យើងដោយសទ្ធា ដោយឥតបន្ទោសផង ។**

- ពេលទូលសុំវិវរណៈពីព្រះអម្ចាស់ដោយឧស្សាហ៍ព្យាយាមតើនឹងមានពរជ័យអ្វីខ្លះ ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា អ្នកដឹកនាំសាសនាចក្ររបស់យើងដឹកនាំ និងណែនាំយើងតាមរយៈគោលការណ៍នៃវិវរណៈជាបន្តបន្ទាប់នេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៧៤–៨៧

*ថ្នាក់ដឹកនាំបព្វជិតភាព ទទួលបានសេចក្ដីណែនាំ ស្ដីពីការដោះស្រាយជាមួយសមាជិកសាសនាចក្រ ដែលបានប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរ*

សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៧៤–៨៧ ព្រះអម្ចាស់បានពិពណ៌នាអំពីក្រឹត្យវិន័យមួយចំនួនដើម្បីគ្រប់គ្រងការដាក់វិន័យសាសនាចក្រ ។ ទ្រង់បានប្រទានការដឹកនាំដ៏ជាក់លាក់ដល់ពួកអ្នកដឹកនាំបព្វជិតភាព ទាក់ទងនឹងរបៀបដើម្បីបម្រើដល់អ្នកទាំងឡាយដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ រួមទាំងអំពើបាបខាងផ្លូវភេទ ការលួច ការកុហក ឬ « ការប្រព្រឹត្តសេចក្ដីទុច្ចរិតណាមួយ » (គ. និង ស. ៤២:៨៧) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៨៨–៩៣

*ព្រះអម្ចាស់ណែនាំពួកបរិសុទ្ធ អំពីរបៀបដោះស្រាយជាមួយហេតុទាស់ផ្ទាល់ខ្លួន*

- តើពេលណា ដែលអ្នកបានឃើញនរណាម្នាក់ មានហេតុទាស់នឹងពាក្យសម្ដី ឬ ទង្វើនៃមនុស្សម្នាក់ទៀត ? តើអ្នកធ្លាប់មានអារម្មណ៍ឈឺចាប់ ឬហេតុទាស់នឹងពាក្យសម្ដី ឬទង្វើរបស់មនុស្សម្នាក់ទៀតឬទេ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៨៨–៨៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការណែនាំរបស់ព្រះអម្ចាស់ សម្រាប់អ្វីដែលត្រូវធ្វើ បើនរណាម្នាក់មានហេតុទាស់នឹងយើង ។

- តើយើងនឹងធ្វើអ្វី ចំពោះនរណាម្នាក់ដែលមានហេតុទាស់នឹងយើង ? ( ផ្សះផ្សារជាមួយនឹងគាត់ ឬនាង ជាសម្ងាត់ ) ។ អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ *ផ្សះផ្សារ* មានន័យថា ដោះស្រាយនូវភាពខុសគ្នា ហើយស្ដារឲ្យមានភាពសុខុដុមឡើងវិញ ។

- ហេតុអ្វីអ្នកគិតថា ការធ្វើបែបនេះ អាចមានប្រយោជន៍ ?

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅផ្នែកម្ខាងនៃក្ដារខៀន ៖

> *ហេតុទាស់ដែលមានក្នុងទីសម្ងាត់ គួរតែត្រូវ. . .*
>
> *ហេតុទាស់ដែលមានក្នុងទីសាធារណៈ គួរតែត្រូវ. . .*

នៅលើក្ដារខៀនម្ខាងទៀត សូមសរសេរបញ្ចប់នូវសេចក្ដីថ្លែងការណ៍កាលពីមុននិមួយៗ ៖

> *. . . បានដោះស្រាយជាសាធារណៈ ។*
>
> *. . . បានដោះស្រាយដោយសម្ងាត់ ។*

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៩០–៩៣ ដោយស្ងាត់ស្ងៀម ហើយដឹកនាំពួកគេឲ្យផ្គូរផ្គងសេចក្ដីថ្លែងការណ៍ដែលពុំពេញលេញនិមួយៗជាមួយនឹងឃ្លាបញ្ចប់ដែលត្រឹមត្រូវ ។ ( **ហេតុទាស់ដោយសម្ងាត់ គួរតែត្រូវបានដោះស្រាយដោយសម្ងាត់** ) ។ ( **ហេតុទាស់ដែលជាសាធារណៈ គួរតែត្រូវបានដោះស្រាយជាសាធារណៈវិញ** ) ។

- ហេតុអ្វីបានជាវាមិនសមរម្យចំពោះហេតុទាស់ដោយសម្ងាត់ ត្រូវដោះស្រាយជាសាធារណៈនោះ ?

- ហេតុអ្វីក៏ជួនកាលវាជារឿងឆ្លាតវៃដើម្បីដោះស្រាយហេតុទាស់ជាសាធារណៈនៅទីសាធារណៈ ?

សូមឲ្យសិស្សគិតអំពីស្ថានភាពទាំងឡាយ ដែលបង្ហាញ ទាំងការអនុវត្តត្រឹមត្រូវ និងការអនុវត្តមិនត្រឹមត្រូវនៃសេចក្ដីពិតទាំងនេះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិតរបស់ពួកគេ ។ ( នៅពេលសិស្សចែកចាយ សូមគូសបញ្ជាក់ថា ការដោះស្រាយហេតុទាស់តាមវិធីរបស់ព្រះអម្ចាស់ មានជាប់ទាក់ទងនឹងការប្រែចិត្ត និងការអភ័យទោស ) ។

- តើអ្នកគិតថាការដោះស្រាយហេតុទាស់ដោយត្រឹមត្រូវ អាចប្រទានពរដល់គ្រួសារមួយយ៉ាងដូចម្ដេច ? វួដ ឬ សាខាយ៉ាងដូចម្ដេច ? ក្រុមមួយនៃមិត្តរួមថ្នាក់យ៉ាងដូចម្ដេច ?

អ្នកអាចនឹងចង់ចង្អុលបង្ហាញថា យើងត្រូវការភាពក្លាហានដើម្បីទៅកាន់មនុស្សដែលបានធ្វើហេតុទាស់នឹងយើង ។ សូមអញ្ជើញសិស្សឲ្យអធិស្ឋានសុំជំនួយមកពីព្រះវរបិតាសួគ៌ នៅពេលពួកគេព្យាយាមដោះស្រាយបញ្ហានៃភាពខុសគ្នាជាមួយអ្នកដទៃដោយត្រឹមត្រូវនោះ ។

មេរៀនទី ៥០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៤

## បុព្វកថា

នៅក្នុងខែកុម្ភៈ ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ បានមកដល់ទីក្រុងខឺតឡង់ រដ្ឋអូហៃអូ ។ ពេលលោកមកដល់ លោកបានឃើញថា ពួកបរិសុទ្ធនៅទីក្រុងខឺតឡង់ត្រូវបានបញ្ឆោតដោយវិវរណៈក្លែងក្លាយ ។ ឧទាហរណ៍ ស្ត្រីម្នាក់ឈ្មោះ អ្នកស្រី ហ៊ើបបិល បានអះអាងថាជាព្យាការីស្រី ហើយទទួលវិវរណៈសម្រាប់សាសនាចក្រ ។ ដោយបារម្ភអំពីឥទ្ធិពលដែលកើតមាននៅក្នុងចំណោមពួកបរិសុទ្ធនៅទីក្រុងខឺតឡង់ នោះយ៉ូសែបបានទូលសួរដល់ព្រះអម្ចាស់អំពីអ្វីដែលគួរតែធ្វើ ។ ជាការឆ្លើយតប លោកបានទទួលវិវរណៈដែលឥឡូវនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់ បានណែនាំដល់ពួកបរិសុទ្ធអំពីអ្វីដែលពួកគេត្រូវធ្វើ ដើម្បីចៀសវាងពីការបោកបញ្ឆោត ។ វិវរណៈ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៤ ក៏ត្រូវបានទទួលនៅក្នុងខែកុម្ភៈ ឆ្នាំ ១៨៣១ ផងដែរ ដែលផ្ដល់នូវការណែនាំដល់ពួកបព្វជិតភាពឲ្យផ្សាយដំណឹងល្អ ហើយបម្រើដល់មនុស្សទាល់ក្រ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១–៧

*ព្រះអម្ចាស់ប្រកាសថា វិវរណៈ និង ព្រះបញ្ញត្តិទាំងឡាយ គឺមានតាមតែរយៈព្យាការីដែលត្រូវបានតែងតាំងរបស់ទ្រង់ប៉ុណ្ណោះ*

សូមជ្រើសរើសទំនុកតម្កើងពីរសម្រាប់ឲ្យសិស្សច្រៀង ។ ដើម្បីជួយសិស្សឲ្យយល់ពីការលំបាកក្នុងការធ្វើតាមអ្នកដឹកនាំពីរនាក់ផ្សេងគ្នាក្នុងពេលតែមួយ សូមសួរដល់សិស្សពីរនាក់ឲ្យឈរនៅខាងមុខ ហើយនាំសិស្សឲ្យច្រៀងទំនុកតម្កើងពីរក្នុងពេលតែមួយ ។ បន្ទាប់ពីច្រៀងបានពីរបីជួរចេញពី ទំនុកតម្កើងទាំងពីរនោះហើយ សូមឈប់ច្រៀង ហើយសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីបានជាវាលំបាកដើម្បីធ្វើតាមអ្នកដឹកនាំ ឬច្រៀងចម្រៀងពីរផ្សេងគ្នាក្នុងពេលតែមួយដូច្នេះ ?

សូមពន្យល់ថា នៅខែកុម្ភៈ ឆ្នាំ ១៨៣១ មានស្ត្រីម្នាក់ឈ្មោះ ហ៊ើបបិល បានមកក្នុងចំណោមពួកបរិសុទ្ធនៅខឺតឡង់ រដ្ឋអូហៃអូ ។ នាងបានអះអាងថា នាងគឺជាព្យាការីស្រីម្នាក់ ដែលនាងបានទទួលវិវរណៈសម្រាប់សាសនាចក្រ នាងបានដឹងថាព្រះគម្ពីរមរមនពិត ហើយថានាងគួរតែក្លាយជាគ្រូបង្រៀនម្នាក់នៅក្នុងសាសនាចក្រ ។ នាងអាចបោកបញ្ឆោតដល់ពួកបរិសុទ្ធមួយចំនួន ។ យ៉ូសែប ស្ម៊ីធ និងអ្នកដទៃទៀត បានបារម្ភអំពីឥទ្ធិពលរបស់នាង និងអំពីវិវរណៈក្លែងក្លាយផ្សេងទៀត នៅក្នុងចំណោមពួកបរិសុទ្ធ ។ ព្យាការី បានសម្រេចចិត្តទូលសួរដល់ព្រះអម្ចាស់អំពីអ្វីដែលត្រូវធ្វើ ហើយលោកបានទទួលវិវរណៈ ។ យ៉ូហាន វិតមើរ ដែលបានមកដល់ទីក្រុងក្នុងពេលថ្មីៗផងដែរនោះ បានសរសេរថា « ព្រះអម្ចាស់បានប្រទានវិវរណៈ [នេះ] ថាពួកបរិសុទ្ធមិនអាចត្រូវបានបោកបញ្ឆោតឡើយ » (*Documents, Volume ១: ខែ កក្កដា ឆ្នាំ ១៨២៨–ខែ មិថុនា ឆ្នាំ ១៨៣១* វ៉ុលទី ១ of the Documents series of *The Joseph Smith Papers* [ ឆ្នាំ ២០១៣ ],ទំព័រ ២៥៧ ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១–៥។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការពន្យល់របស់ព្រះអម្ចាស់ អំពីនរណាដែលអាចទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល ។

- តើនរណាត្រូវបានតែងតាំងនៅគ្រានោះដើម្បីទទួលបទបញ្ញត្តិ និងវិវរណៈសម្រាប់សាសនាចក្រទាំងមូល ? ( យ៉ូសែប ស្ម៊ីធ ) ។ តើនរណាត្រូវបានតែងតាំងតំណែងនោះនាសព្វថ្ងៃនេះ ? ( ប្រធាននៃសាសនាចក្រ ) ។

- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរទាំងនេះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់អំពី គោលលទ្ធិដូចខាងក្រោម ៖ **មានតែប្រធាននៃសាសនាចក្រប៉ុណ្ណោះ ដែលអាចទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល** ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ថា សិស្សគួរសរសេរសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ខ ៣–៤ ។ ដើម្បីគូសបញ្ជាក់អំពីសារៈសំខាន់នៃគោលលទ្ធិនេះ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៤–៦, ២៨:២–៧ ) ។

សូមចង្អុលបង្ហាញថា ដូចជាអ្នកស្រី ហ៊ើបបិល និងអ្នកផ្សេងទៀតនៅក្នុងសាសនាចក្រជំនាន់មុន មនុស្សមួយចំនួននៅក្នុងជំនាន់របស់យើងក៏ព្យាយាមដើម្បីបញ្ចុះបញ្ចូលអ្នកដទៃឲ្យធ្វើតាមពួកគេ ហើយទទួលយកការបង្រៀនរបស់ពួកគេផងដែរ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ពិពណ៌នាអំពីគំរូ ដែល

### *សូមចែកចាយពីការញាណដឹងមួយអំពីគោលបំណង*

នៅពេលអ្នក និងសិស្សចែកចាយពីការញាណដឹងមួយអំពីគោលបំណង នោះអ្នកនឹងរកឃើញថា សេចក្ដីជំនឿនឹងបង្កើនឡើង ហើយថា បទពិសោធន៍ក្នុងថ្នាក់រៀននឹងមានការដឹកនាំកាន់តែច្រើន ហើយកាន់តែមានអត្ថន័យ ។ អ្នកអាចបីបាច់នូវការញាណដឹងពីគោលបំណងដូច្នេះ ដោយការទុកចិត្តឲ្យសិស្សចែកចាយតាមរបៀបដ៏សំខាន់– ដោយពឹងទុកឲ្យពួកគេបំពេញនូវតួនាទីរបស់ពួកគេក្នុងនាមជាអ្នករៀនសូត្រ ហើយជួយពួកគេក្នុងការធ្វើដូច្នេះ ។

ព្រះអម្ចាស់បានបើកសម្ដែងបានការពារយើងពីការបោកបញ្ឆោតដោយពួកអ្នកទាំងឡាយដែលពុំមានសិទ្ធិអំណាចដើម្បីដឹកនាំសាសនាចក្រ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:៨–១៦

*ពួកអែលឌើរ ត្រូវបានបញ្ជាឲ្យណែនាំ និងស្អាងដល់គ្នាទៅវិញទៅមក ហើយក្លាយជាបរិសុទ្ធ*

សូមឲ្យសិស្សរៀបរាប់នៅលើក្ដារខៀនអំពីការប្រជុំមួយចំនួនដែលពួកគេបានចូលរួមក្នុងនាមជាសមាជិកនៃសាសនាចក្រ ។ បន្ទាប់មក អញ្ជើញសិស្សឲ្យបំបែកជាគូៗ ហើយពិភាក្សាអំពីសំណួរដូចខាងក្រោម ៖

- តើគោលបំណងមួយចំនួននៃការប្រជុំទាំងនេះ គឺជាអ្វី ?

បន្ទាប់ពីសិស្សបានពិភាក្សាអំពីសំណួរទាំងនេះ អ្នកអាចនឹងចង់សុំពួកគេមួយចំនួនឲ្យចែកចាយនូវចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ទាំងមូល ។ បន្ទាប់មកសុំឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:៨ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យប្រាប់នូវអ្វីដែលខគម្ពីរនេះ បង្រៀនអំពីគោលបំណងនៃការប្រជុំក្នុងសាសនាចក្រ ។

- តើព្រះអម្ចាស់បានមានបន្ទូលទៅពួកអែលឌើរនៃសាសនាចក្រឲ្យធ្វើអ្វីខ្លះ នៅពេលពួកគេប្រជុំគ្នា ? តើការស្អាងគ្នាទៅវិញទៅមកមានន័យដូចម្ដេច ? ( ដើម្បីស្ថាបនាគ្នាទៅវិញទៅមក ហើយពង្រឹងដល់គ្នាទៅវិញទៅមក ) ។

- ស្របតាម ខ ៨ តើយើងនឹងរៀនអ្វីខ្លះ នៅពេលយើងណែនាំ និងស្អាងគ្នាទៅវិញទៅមកនោះ ? ( ចម្លើយរបស់សិស្សអាចមានផ្សេងៗគ្នា ប៉ុន្ដែពួកគេគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងប្រជុំគ្នា យើងត្រូវណែនាំ ហើយស្អាងគ្នាទៅវិញទៅមក ដើម្បីយើងអាចរៀនអំពីរបៀបប្រព្រឹត្ត និង ដឹកនាំសាសនាចក្រ** ) ។

ចូរអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:៩, ១១ ដោយស្ងាត់ស្ងៀម ហើយប្រាប់ពីអ្វីដែលយើងត្រូវធ្វើបន្ទាប់ពីយើងរៀនអំពីរបៀបប្រព្រឹត្ត ។

- តើយើងត្រូវធ្វើអ្វីខ្លះ បន្ទាប់ពីយើងត្រូវបានណែនាំនៅក្នុងការប្រជុំក្នុងសាសនាចក្ររបស់យើង ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **យើងត្រូវមានកាតព្វកិច្ចធ្វើតាមចំណេះដឹងដែលយើងបានទទួលនោះ ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំសេចក្ដីពិតនេះនៅក្នុង ខ ៩) ។

- ស្របតាមខគម្ពីរទាំងនេះ តើយើងត្រូវបានប្រទានពរយ៉ាងដូចម្ដេច នៅពេលយើងទទួលចំណេះដឹង ហើយប្រព្រឹត្តតាមនោះ ? ( នៅពេលសិស្សពិភាក្សាអំពីសំណួរនេះ សូមប្រាកដថាគូសបញ្ជាក់អំពីគោលការណ៍ដូចខាងក្រោម ៖ **យើងប្រែក្លាយជាបរិសុទ្ធ នៅពេលយើងប្រព្រឹត្តតាមសេចក្ដីពិត ដែលយើងរៀន ។** យើងក៏អាចនឹងចង់ពន្យល់ថា ដើម្បីបានញែកជាបរិសុទ្ធ គឺត្រូវបានធ្វើឲ្យបរិសុទ្ធ ស្អាតពីអំពើបាប ) ។

សូមគូស ឌីយ៉ាក្រាមដែលអមជាមួយខាងក្រោមនេះនៅលើក្ដារខៀន ។

- តើអ្នកគិតថា « ត្រូវមាន| កាតព្វកិច្ច | ធ្វើតាម » មានន័យយ៉ាងណា ?

- តើចំណេះដឹងដែលយើងបានទទួលនៅក្នុងការប្រជុំនៃសាសនាចក្រ ជួយយើងបានញែកចេញជាបរិសុទ្ធយ៉ាងដូចម្ដេច ?




សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យគិតអំពីពរជ័យទាំងឡាយដែលពួកគេបានទទួល នៅពេលពួកគេបានធ្វើតាមអ្វីដែលពួកគេបានរៀននៅក្នុងការប្រជុំសាសនាចក្រ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយនូវបទពិសោធន៍ទាំងនេះ ហើយពន្យល់អំពីរបៀបដែលពួកគេត្រូវបានប្រទានពរដើម្បីប្រព្រឹត្តនូវអ្វីដែលពួកគេបានរៀននោះ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១២–១៤ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រាប់ដល់ពួកបរិសុទ្ធថា បើពួកគេចង់ទទួលសេចក្ដីពិតនៃដំណឹងល្អ នោះពួកគេចាំបាច់ត្រូវគាំទ្រដល់ យ៉ូសែប ស្ម៊ីធ នៅក្នុងការហៅរបស់លោក ។

សូមពន្យល់ថា ព្រះអម្ចាស់ បានបើកសម្ដែងសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១៥–១៦ ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលកំពុងរៀបចំខ្លួនចេញបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ បន្ទាប់មក សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឲ្យឮៗ ។

- តើអ្នកគិតថា ខគម្ពីរទាំងនេះ អនុវត្តចំពោះកិច្ចការ នៃអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១៧–៣៥

*ពួកអ្នកបម្រើរបស់ព្រះ ត្រូវផ្សាយអំពីការប្រែចិត្ត ក្នុងការប្រុងប្រៀបខ្លួនសម្រាប់ការយាងមកជាលើកទីពីរ និង សហស្សវត្សរ៍*

សូមឲ្យសិស្សរៀបរាប់អំពីសកម្មភាព ឬព្រឹត្តការណ៍ទាំងឡាយ ដែលតម្រូវឲ្យមានការរៀបចំដោយប្រុងប្រយ័ត្ន ។ សិស្សអាចចែកចាយនូវឧទាហរណ៍មួយចំនួន ដូចជាបេសកកម្មពេញម៉ោង ព្រឹត្តការណ៍កីឡា ផលិតកម្មតន្ត្រី ការចាត់តាំងឲ្យបង្រៀននៅព្រះវិហារ និងការប្រឡងនៅសាលារៀនជាដើម ។

- តើអ្នកគិតថាមនុស្សនឹងមានអារម្មណ៍យ៉ាងណា បើពួកគេពុំបានរៀបចំ នៅពេលដល់ពេលវេលាត្រូវសម្ដែងក្នុងសកម្មភាពដូច្នេះនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១៧–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រឹត្តការណ៍មួយ ដែលតម្រូវឲ្យយើងមានការរៀបចំ ។ ( « ថ្ងៃដ៏ធំនៃព្រះអម្ចាស់ » ឬជាពាក្យម្យ៉ាងទៀតថា ការយាងមកជាលើកទីពីរ ) ។

សូមបែងចែកសិស្សជាគូ ។ សូមឲ្យដៃគូនិមួយៗអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១៧–២២ ជាមួយគ្នា រកមើលអ្វីដែលព្រះអម្ចាស់បានណែនាំដល់ពួកអែលឌើរឲ្យធ្វើ ដើម្បីជួយមនុស្សរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ នៅពេលសិស្សបានអានហើយ សូមសួរសិស្សក្នុងថ្នាក់នូវសំណួរដូចខាងក្រោម ៖

- តើព្រះអម្ចាស់ណែនាំពួកអែលឌើរឲ្យបង្រៀនអ្វីខ្លះ ? តើសេចក្ដីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? ( សិស្សគួរតែបង្ហាញថា**ដើម្បីរៀបចំខ្លួនយើងសម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ យើងត្រូវតែប្រែចិត្ត ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។

សូមរំឭកសិស្សថា ព្រះអម្ចាស់បានសន្យាថានឹងប្រមូលរាស្ត្រទ្រង់ដូចជាមេមាន់ប្រមូលកូនវានៅក្រោមស្លាបដូច្នោះដែរ ប៉ុន្តែមានមនុស្សជាច្រើនបានបដិសេធប្រែចិត្ត ឬរៀបចំខ្លួនគេសម្រាប់ការយាងមកជាលើកទីពីរ ( សូមមើល គ. និង ស. ៤៣:២៣–២៤ សូមមើលផងដែរ គ. និង ស. ២៩:១–២ និងមេរៀនទី ៣៥ នៅក្នុងសៀវភៅសិក្សានេះ ) ។

សូមដៃគូទាំងឡាយអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:២៥–២៧ ជាមួយគ្នា រកមើល « សំឡេង » ផ្សេងៗ ដែលព្រះអម្ចាស់បានប្រើដើម្បីហៅរាស្ត្រឲ្យមកទ្រង់ ។ បន្ទាប់ពីសិស្សបានបញ្ចប់ការអាន សូមសួរសំណួរដូចខាងក្រោម ៖

- តើ « សំឡេង » អ្វីដែលអ្នកស្គាល់ ? ហេតុអ្វីក៏សំឡេងខុសៗគ្នាទាំងនេះ ត្រូវការជាចាំបាច់ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរឿងជាក់លាក់ដែលពួកគេចាំបាច់ត្រូវធ្វើ ដើម្បីប្រែចិត្ត ហើយរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ រួចអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:២៨–៣១ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលព្រឹត្តការណ៍ធំៗដែលបានព្យាករនៅក្នុងខគម្ពីរទាំងនេះ ។

- តើព្រឹត្តការណ៍ដ៏ធំ ដែលបានព្យាករនៅក្នុងខគម្ពីរទាំងនេះគឺជាអ្វី ? ( សហស្សវត្សរ៍ ) ។

- តើមានអ្វីខ្លះនឹងកើតឡើងនៅក្នុងអំឡុងពេលសហស្សវត្សរ៍ ? ( សិស្សគួរតែប្រាប់គោលលទ្ធិដូចខាងក្រោម ៖ **អំឡុងពេលសហស្សវត្សរ៍ សាតាំងនឹងត្រូវបានចង ហើយព្រះយេស៊ូវគ្រីស្ទ នឹងសោយរាជ្យជាមួយនឹងរាស្ត្រទ្រង់នៅលើផែនដី ។** អ្នកក៏អាចឲ្យយោបល់សិស្សឲ្យគូសចំណាំពាក្យ ឬឃ្លាដែលបង្រៀនសេចក្ដីពិតនេះ នៅ ខ ២៨–៣១ ) ។ ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ អំពីរបៀបដែលសាតាំងនឹងត្រូវចង សូមពិចារណាធ្វើការអញ្ជើញពួកគេឲ្យអាន នីហ្វៃទី១ ២២:២៦ ) ។

សូមអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយ ប្រធាន ចច ឃ្យូ ខានុន នៃគណៈប្រធានទីមួយ ដែលពន្យល់អំពីរបៀបដែលសាតាំងនឹងត្រូវចង អំឡុងសហស្សវត្សរ៍ថា ៖



« យើងនិយាយអំពីសាតាំងដែលនឹងត្រូវចង ។ សាតាំងនឹងត្រូវចងដោយព្រះចេស្ដានៃព្រះ ប៉ុន្តែ វាក៏នឹងត្រូវបានចងផងដែរ ដោយការប្ដេជ្ញាចិត្តរបស់រាស្ត្រនៃព្រះ មិនស្ដាប់តាមវា ដោយមិនអនុញ្ញាតឲ្យវាគ្រប់គ្រងលើបាន » ( *Gospel Truth: Discourses and Writings of President George Q. Cannon* ជ្រើសរើសដោយ Jerreld L. Newquist វ៉ុល ២ [ ឆ្នាំ ១៩៥៧–៧៤ ] ១:៨៦ ) ។

- តើយើងអាចត្រូវបានរៀបចំខ្លួននាពេលឥឡូវនេះ ដើម្បីត្រូវបានរាប់នៅក្នុងចំណោមមនុស្សសុចរិត ពេលព្រះអង្គសង្គ្រោះយាងមកម្តងទៀតដោយរបៀបណា ? ( នៅពេលសិស្សឆ្លើយតបចំពោះសំណួរនេះ អ្នកអាចនឹងចង់រំឭក ហើយធ្វើទីបន្ទាល់អំពីសេចក្តីពិត ដែលបានពិភាក្សានៅក្នុងមេរៀននេះ ) ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៤៤

*ព្រះអម្ចាស់ បញ្ជាពួកអ្នកបម្រើទ្រង់ឲ្យជួបជុំគ្នា*

សូមសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ៤៤:១–៦ ដោយពន្យល់ថា ព្រះអម្ចាស់បានដឹកនាំពួកអែលឌើរឲ្យជួបជុំគ្នាសម្រាប់សន្និសីទមួយ ។ ព្រះអម្ចាស់បានសន្យានឹងពួកអែលឌើរថា បើពួកគេនឹងនៅស្មោះត្រង់ ហើយអនុវត្តសេចក្តីជំនឿទៅលើទ្រង់ នោះទ្រង់នឹងចាក់ស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើពួកគេ ហើយប្រទានពរដល់ពួកគេ ដើម្បីកុំឲ្យមារសត្រូវរបស់ពួកគេ មានអំណាចលើពួកគេឡើយ ។ ព្រះអម្ចាស់បានដឹកនាំពួកគេឲ្យផ្សាយ ពីការប្រែចិត្ត បម្រើដើម្បីជួយសង្គ្រោះដល់មនុស្សទ័លក្រ ហើយរៀបចំខ្លួនគេស្របតាមច្បាប់នៃដែនដី ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១–៤៤ ( មេរៀនទី ១០ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១–៤៤ ( មេរៀនទី ១០ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១)

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១, សិស្សបានរៀនថា ព្រះអម្ចាស់សព្វព្រះទ័យនឹងប្រទានពរដល់ពួកយើង នៅពេលយើងស្ដាប់ និង គោរពតាមទ្រង់ ហើយថាយើងនឹងក្លាយជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលយើងទទួលក្រឹត្យវិន័យទ្រង់ ហើយធ្វើតាមក្រឹត្យវិន័យទាំងនោះ ។ តាមរយៈការសិក្សាពីការហៅបម្រើរបស់អែតវើត ប៉ាទ្រិច ឲ្យធ្វើជាប៊ីស្សពទីមួយនៃសាសនាចក្រ នោះសិស្សក៏បានរៀនផងដែរថា ប៊ីស្សពត្រូវបានហៅដោយព្រះ គាំទ្រដោយសំឡេងនៃសមាជិក និង ត្រូវបានតែងតាំងដោយសិទ្ធិអំណាចត្រឹមត្រូវ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–២៩)

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ គឺត្រូវបានរាប់ទុកជា « ក្រឹត្យវិន័យនៃសាសនាចក្រ » ។ នៅពេលសិស្សបានសិក្សាពីផ្នែកទីមួយនៃក្រឹត្យវិន័យនៃសាសនាចក្រ នោះពួកគេបានរៀនថា ប្រសិនបើយើងអធិស្ឋានដោយសេចក្ដីជំនឿ នោះយើងអាចទទួលបានព្រះវិញ្ញាណជួយយើងបង្រៀនដល់អ្នកដទៃ ។ លើសពីនោះទៀត សិស្សបានរៀនថា ព្រះវិញ្ញាណបរិសុទ្ធជ្រាបដឹងនូវការណ៍គ្រប់យ៉ាង ហើយថ្លែងទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា ។ នៅក្នុងចំណោមក្រឹត្យវិន័យ និង បទបញ្ញត្តិជាច្រើនដែលបានសិក្សានៅក្នុងផ្នែកនេះ នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២, សិស្សបានសិក្សាអំពីសេចក្ដីពិតថា ប្រសិនបើយើងមានតម្រេកសម្រើបចង់បានបុគ្គលណាមួយ នោះយើងនឹងបោះបង់ចោលសេចក្ដីជំនឿ ហើយនឹងមិនមានព្រះវិញ្ញាណឡើយ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៩៣)

នៅពេលពួកគេបានសិក្សា ហើយបានបង្រៀនពីក្រឹត្យវិន័យនៃការថ្វាយរបស់ព្រះអម្ចាស់ នោះសិស្សបានរៀនថា នៅពេលយើងយកចិត្តទុកដាក់ចំពោះជនទ័លក្រ និង អស់អ្នកដែលខ្វះខាត ហើយថាប្រសិនបើយើងធ្វើល្អចំពោះមនុស្សដទៃ នោះយើងធ្វើការណ៍នេះដល់ព្រះអម្ចាស់ហើយ ។ សិស្សក៏រកឃើញគោលការណ៍នេះថា ប្រសិនបើយើងទូលសួរ នោះព្រះអម្ចាស់នឹងប្រទានចំណេះដឹងដល់យើង ដែលនឹងនាំមកយើងនូវសេចក្ដីសុខសាន្ត សេចក្ដីអំណរ ។ ពួកគេបានបញ្ចប់មេរៀននេះដោយការរៀនថា ទង្វើខុសដែលបានធ្វើឡើងដោយសម្ងាត់គួរតែត្រូវបានដោះស្រាយដោយសម្ងាត់ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៤)

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣, សិស្សបានរៀនថា មានតែព្យាការីនៃសាសនាចក្រតែប៉ុណ្ណោះ ដែលនឹងទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល ។ សិស្សក៏យល់ផងដែរថា គោលបំណងនៃការប្រជុំរបស់សាសនាចក្រគឺដើម្បីបង្ហាប់ និង ស្អាងគ្នាទៅវិញទៅមក ហើយថាយើងត្រូវភ្ជាប់ខ្លួនយើង ទៅនឹងការប្រព្រឹត្តតាមសេចក្ដីពិត ដែលយើងរៀន ។ បន្ទាប់ពីការសិក្សាពីរបៀបដែលព្រះអម្ចាស់បានបញ្ជាកូនចៅរបស់ទ្រង់ឲ្យប្រែចិត្ត ហើយរៀបចំខ្លួនពួកគេសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នោះសិស្សបានរៀនផងដែរថា អំឡុងពេលសហស្សវត្សរ៍ សាតាំងនឹងត្រូវបានចង ហើយព្រះយេស៊ូវគ្រីស្ទ នឹងសោយរាជ្យជាមួយរាស្ត្រទ្រង់នៅលើផែនដី ។

## សេចក្តីផ្តើម

នៅក្នុងមេរៀននេះ សិស្សនឹងផ្តោតលើការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤២ ទាក់ទងនឹងសេចក្តីស្លាប់ និង ការជាសះស្បើយ ដែលនឹងពុំមាននៅក្នុងមេរៀនរបស់សិស្សដែលសិក្សានៅផ្ទះឡើយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៤៣–៥២

*ព្រះអម្ចាស់ប្រទានឱវាទទាក់ទងនឹងសេចក្តីស្លាប់ និង ការជាសះស្បើយ*

សូមយកដៃម្ខាងលើកដបប្រេងអូលីវតូចមួយ សម្រាប់ធ្វើការប្រសិទ្ធិពរដល់អ្នកឈឺ ហើយយកដៃម្ខាងទៀតកាន់ដបថ្នាំ ។

- តើវត្ថុទាំងពីរនេះប្រើសម្រាប់ធ្វើអ្វី ?
- តើវត្ថុមួយណាដែលយើងគួរតែពឹងផ្អែកទៅលើ ពេលមានជំងឺនោះ ?

បន្ទាប់ពីសិស្សបានចែកចាយដោយសង្ខេបនូវគំនិតរបស់ពួកគេហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៤៣–៤៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការណែនាំរបស់ព្រះអម្ចាស់ ទាក់ទងនឹងអ្វីដែលយើងគួរតែពឹងផ្អែកលើវាពេលមានជំងឺ ។ ដើម្បីជួយសិស្សយល់នូវខគម្ពីរទាំងនេះ វាអាចជាប្រយោជន៍ដើម្បីពន្យល់ថា រុក្ខជាតិ និង អាហារសាប ៗដែលបានប្រាប់នៅក្នុង ខ ៤៣ នេះសំដៅទៅលើការព្យាបាលខាងវេជ្ជសាស្ត្រ ដែលត្រូវបានគេប្រើជាទូទៅ អំឡុងពេលដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ។

ដើម្បីជួយសិស្សយល់ថា ការជាស្បើយអាចត្រូវបានប្រទានមកដោយសារសេចក្តីជំនឿ *និង* ថ្នាំពេទ្យព្យាបាលនោះ សូមឲ្យសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ នៅពេលសិស្សអាន សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្តាប់អំពីរបៀបដែលការជាសះស្បើយ អាចកើតមានមកតាមរយៈទាំងសេចក្តីជំនឿផង និង ការព្យាបាលខាងវេជ្ជសាស្ត្រផង ។



« ពួកបរិសុទ្ធថ្ងៃចុងក្រោយ ជឿទៅលើការអនុវត្តចំណេះដឹង និងបច្ចេកវិទ្យាខាងវិទ្យាសាស្ត្រដ៏ល្អបំផុតដែលមាន ។ យើងប្រើអាហាររូបត្ថម្ភ លំហាត់ប្រាណ និងការអនុវត្តដទៃទៀត ដើម្បីថែទាំសុខភាព ហើយយើងចូលរួមបម្រើ ក្នុងការព្យាបាលរបស់គ្រូពេទ្យជំនាញ ដូចជាវេជ្ជបណ្ឌិត និង គ្រូពេទ្យវះកាត់ ដើម្បីទទួលបានសុខភាពល្អឡើងវិញផងដែរ ។

« ការប្រើប្រាស់វិទ្យាសាស្ត្រវេជ្ជសាស្ត្រ គឺពុំមែនជាការជំទាស់នឹងការអធិស្ឋានដោយសេចក្តីជំនឿរបស់យើង និងការពឹងផ្អែករបស់យើងទៅលើការប្រសិទ្ធពរនៃបព្វជិតភាពនោះទេ ។. . .

« ប្រាកដណាស់ថា យើងពុំរង់ចាំរហូតដល់វិធីសាស្ត្រដទៃទៀតទាំងអស់ប្រើការលែងបាន ទើបយើងអធិស្ឋានដោយសេចក្តីជំនឿ ឬផ្តល់ការប្រសិទ្ធពរបព្វជិតភាពសម្រាប់ការជាសះស្បើយនោះទេ ។ ក្នុងពេលអាសន្ន ការអធិស្ឋាន និងការប្រសិទ្ធពរត្រូវធ្វើឡើងដំបូងគេបង្អស់ ។ ជាញឹកញាប់ណាស់ ដែលយើងខិតខំធ្វើអ្វីៗគ្រប់យ៉ាងក្នុងពេលដំណាលគ្នា » (Healing the Sick » *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០១០, ទំព័រ ៤៧ ) ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់សម្រាប់យើងដើម្បីប្រើការអធិស្ឋាន និងពរជ័យនៃបព្វជិតភាព ក៏ដូចជាការព្យាបាលខាងវេជ្ជសាស្ត្រសម្រាប់ធ្វើការព្យាបាលក្នុងពេលមានជំងឺយ៉ាងដូច្នេះ ?
- ស្របតាម ខ ៤៤, តើមនុស្សមានជំងឺគ្រប់គ្នា ដែលបានទទួលពរជ័យបព្វជិតភាពនឹងត្រូវបានជាសះស្បើយដែរឬទេ ?

សូមប្រាប់សិស្សថា ព្រះអម្ចាស់បានពន្យល់ពីមូលហេតុដែលមនុស្សមួយចំនួន ដែលបានទទួលពរជ័យបព្វជិតភាព អាចនឹងពុំបានជាសះស្បើយផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៤៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលការណ៍ទាំងឡាយដែលគ្រប់គ្រង ថាតើនរណានឹងត្រូវបានជាសះស្បើយ ឬអត់ ដោយសារការប្រសិទ្ធពរពីបព្វជិតភាព ។

- យោងតាម ខ ៤៨ តើកត្តាចម្បងដែលកំណត់ពីលទ្ធផលនៃការប្រសិទ្ធពរពីបព្វជិតភាពគឺជាអ្វី ? ( ប្រសិនបើបុគ្គលម្នាក់មានសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយពុំត្រូវបានកំណត់ឲ្យស្លាប់ នោះបុគ្គលនោះនឹងត្រូវបានជាសះស្បើយ ។ អ្នកអាចត្រូវពន្យល់ឃ្លា « ដែលពុំបានកំណត់ឲ្យស្លាប់ » សំដៅទៅលើកត្តាដែលសេចក្ដីស្លាប់ ឬការជាសះស្បើយនឹងកើតឡើងស្របតាមពេលវេលា ប្រាជ្ញា និងព្រះទ័យរបស់ព្រះអម្ចាស់ ) ។
- ហេតុអ្វីក៏មនុស្សគ្រប់គ្នាដែលមានសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នឹងពុំបានជាសះស្បើយដូច្នេះ ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីមានសេចក្ដីជំនឿទៅលើព្រះឆន្ទៈរបស់ព្រះ និងពេលវេលាសម្រាប់យើងម្នាក់ៗ ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយដែលយើងអាចរៀនចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៨ អំពីការជាសះស្បើយពីអស់ទាំងរោគារបស់យើង ។ ទោះបីជាសិស្សអាចប្រើពាក្យផ្សេងគ្នាក្ដី ចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងមានសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានជាសះស្បើយតាមព្រះឆន្ទៈរបស់ទ្រង់ ។** អ្នកអាចឲ្យយោបល់ដល់សិស្សគូសចំណាំពាក្យ ឬឃ្លានៅក្នុង ខទី ៤៨ ដែលបង្រៀនពីគោលការណ៍នេះ ។

ដើម្បីជួយសិស្សឲ្យយល់ថា សេចក្ដីជំនឿរបស់យើង ត្រូវតែផ្ដោតទៅលើព្រះយេស៊ូវគ្រីស្ទ ជាជាងផ្ដោតទៅលើលទ្ធផលជាក់លាក់នានា ដែលយើងប្រាថ្នាចង់បាន សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្ដាប់រកមូលហេតុមួយថា ហេតុអ្វីក៏វាសំខាន់ដើម្បីផ្ដោតសេចក្ដីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ។



« ក្នុងនាមជាបុត្ររបស់ព្រះ ដោយដឹងពីសេចក្ដីស្រឡាញ់ដ៏មហិមារបស់ទ្រង់ និងចំណេះដឹងដ៏គ្មានកម្រិតរបស់ទ្រង់អំពីអ្វីដែលល្អបំផុតសម្រាប់សុខុមាលភាពដ៏អស់កល្បរបស់យើង នោះយើងនឹងទុកចិត្តលើទ្រង់ ។ គោលការណ៍ទីមួយនៃដំណឹងល្អគឺជាសេចក្ដីជំនឿទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ហើយសេចក្ដីជំនឿមានន័យថាការទុកចិត្ត ។ ខ្ញុំបានទទួលអារម្មណ៍ដឹងពីទំនុកចិត្តនោះ នៅក្នុងការនិយាយដែលបងប្អូនជីដូនមួយរបស់ខ្ញុំបានផ្ដល់នៅពិធីបុណ្យសពរបស់ក្មេងស្រីជំទង់ម្នាក់ ដែលបានស្លាប់ដោយសារមានជំងឺធ្ងន់ ។ គាត់បាននិយាយពាក្យទាំងនេះ ដែលដំបូងវាធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ហើយបន្ទាប់មកវាបានធ្វើខ្ញុំបានស្កប់ចិត្ត ៖ ‹ ខ្ញុំដឹងថា វាគឺជាព្រះឆន្ទៈរបស់ព្រះអម្ចាស់ ដែលថានាងត្រូវស្លាប់ ។ នាងបានទទួលនូវការយកចិត្តទុកដាក់ពីវេជ្ជសាស្ត្រដ៏ល្អ ។ នាងបានទទួលការប្រសិទ្ធពរបព្វជិតភាព ។ ឈ្មោះនាងត្រូវបានដាក់នៅក្នុងបញ្ជីអធិស្ឋានក្នុងព្រះវិហារបរិសុទ្ធ ។ នាងគឺជាប្រធានបទនៃការអធិស្ឋានរបស់មនុស្សរាប់រយនាក់ ដែលសុំឲ្យនាងមានសុខភាពល្អប្រសើរវិញ ។ ហើយខ្ញុំដឹងថា គ្រួសារនេះមានជំនឿល្មមគ្រប់គ្រាន់ដើម្បីឲ្យនាងនឹងបានជាសះស្បើយ តែវាគឺជាព្រះទ័យរបស់ព្រះអម្ចាស់ ដើម្បីនាំនាងត្រឡប់ទៅផ្ទះវិញនាពេលនេះ › ។ ខ្ញុំបានមានអារម្មណ៍ពីទំនុកចិត្តដូចគ្នានេះទៅលើពាក្យរបស់ឪពុករបស់ក្មេងស្រីជម្រើសម្នាក់ទៀត ដែលបានស្លាប់ដោយសារមហារីក ក្នុងវ័យជំទង់របស់នាង ។ គាត់បានប្រកាសថា ‹ សេចក្ដីជំនឿរបស់គ្រួសារយើង គឺនៅលើព្រះយេស៊ូវគ្រីស្ទ ហើយវាមិនពឹងផ្អែកទៅលើលទ្ធផលណាមួយនោះទេ › ។ ការបង្រៀនទាំងនោះស្ដាប់ទៅពិតណាស់ចំពោះខ្ញុំ ។ យើងធ្វើនូវអ្វីៗទាំងអស់ដែលយើងអាចធ្វើ ដើម្បីព្យាបាលដល់មនុស្សជាទីស្រឡាញ់របស់យើង រួចហើយយើងទុកចិត្តទៅលើព្រះអម្ចាស់ចំពោះលទ្ធផលនោះ » (« Healing the Sick » ទំព័រ ៥០ ) ។

- តើបុគ្គលម្នាក់ៗដែលអែលឌើរ អូក មានប្រសាសន៍បានអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?
- ពេលខ្លះវាតម្រូវឲ្យមានសេចក្ដីជំនឿកាន់តែខ្លាំង ដើម្បីមើលឃើញមនុស្សជាទីស្រឡាញ់ត្រូវស្លាប់ ឬរងទុក្ខនឹងជំងឺដ៏រ៉ាំរ៉ៃជាជាងមើលឃើញពួកគេរស់នៅ ឬត្រូវបានជាសះស្បើយ ។ ហេតុអ្វីអ្នកគិតថាការណ៍នេះអាចប្រែក្លាយជាដូច្នេះ ?
- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ទោះជាយើងពុំទទួលបានលទ្ធផលដែលយើងចង់បានក្ដី ?

សូមសួរសិស្សប្រសិនបើជាពួកគេស្គាល់នរណាដែលបានទទួលមរណភាព ទោះជាគាត់បានធ្វើតាមដំបូន្មានខាងវេជ្ជសាស្ត្រត្រឹមត្រូវ ហើយស្វែងរកការព្យាបាលតាមរយៈការអធិស្ឋាន និងការប្រសិទ្ធពរពីបព្វជិតភាពក៏ដោយ ។ ( សូមប្រយ័ត្នជាពិសេសចំពោះអារម្មណ៍របស់អ្នកដែលអាចនឹងជួបស្ថានភាពដូចនេះ ) ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៥–៤៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ ឬឃ្លាដែលអាចនាំមកនូវការលួងលោមចិត្តដល់នរណាម្នាក់ដែលធ្លាប់មានមនុស្សជាទីស្រឡាញ់របស់ខ្លួនទទួលមរណភាព ។

- ខ ៤៥ ប្រាប់យើងថា យើងនឹងយំសោកទៅតាមធម្មជាតិ ចំពោះការបាត់បង់មនុស្សដែលយើងស្រឡាញ់ ។ តើគោលការណ៍អ្វីខ្លះបានបង្រៀននៅក្នុង ខ ៤៦ ដែលអាចនាំមកនូវការលួងលោមចិត្តដល់អស់អ្នកដែលទួញយំចំពោះការបាត់បង់មនុស្សជាទីស្រឡាញ់ ? (**សេចក្ដីស្លាប់គឺផ្អែមល្ហែមចំពោះអ្នកទាំងឡាយណាដែលស្លាប់នៅក្នុងព្រះអម្ចាស់ ។** អ្នកអាចឲ្យយោបល់សិស្សគូសចំណាំពាក្យ ឬ ឃ្លានានាដែលបង្រៀនពីសេចក្ដីពិតនេះ ) ។

- តើអ្នកគិតថាសេចក្ដីស្លាប់នៅក្នុងព្រះអម្ចាស់ វាមានន័យដូចម្ដេច ? ( របៀបមួយដើម្បីពន្យល់ការណ៍នេះថាបុគ្គលនេះមានការស៊ូទ្រាំយ៉ាងស្មោះត្រង់ ហើយបានរក្សាសេចក្ដីសញ្ញាពិសិដ្ឋរហូតដល់ស្លាប់ ) ។

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដែលថាសេចក្ដីស្លាប់នឹង « ផ្អែមល្ហែម » ចំពោះអ្នកទាំងឡាយដែលស្លាប់នៅក្នុងព្រះអម្ចាស់នោះ ? ( អ្នកចាំបាច់ត្រូវពន្យល់ថា សូម្បីតែមនុស្សស្មោះត្រង់ម្នាក់ដែលស្លាប់ ក៏អាចនឹងរងនូវការឈឺចាប់ខាងរូបកាយដែរ ការសន្យានេះសំដៅទៅលើភាពសុខសាន្ត និងការឈប់សម្រាក ដែលបុគ្គលនោះ នឹងទទួលនៅក្នុងពិភពវិញ្ញាណ ) ។

សូមអញ្ជើញសិស្សឲ្យគិតពិចារណាថាតើពួកគេកំពុងរស់នៅក្នុងជីវិតតាមរបៀបដែលនឹងធ្វើឲ្យសេចក្ដីស្លាប់ « ផ្អែមល្ហែម » ចំពោះពួកគេ ប្រសិនបើវានឹងកើតឡើងនៅក្នុងថ្ងៃនេះឬទេ ។ ( អ្នកអាចអញ្ជើញសិស្សឲ្យសរសេរគំនិតរបស់ពួកគេទុកនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ) ។

សូមបញ្ចប់មេរៀន ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិតនានា ដែលបានបង្រៀននៅក្នុងមេរៀនថ្ងៃនេះ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥–៤៨)

សូមសួរសិស្សប្រសិនបើពួកគេធ្លាប់មានអារម្មណ៍ច្របូកច្របល់ ឬ ខ្វល់ខ្វាយពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងរៀនបន្ថែមទៀតអំពីទីសម្គាល់នានានៃការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ តើមានអ្វីខ្លះនឹងកើតឡើងនៅពេលព្រះយេស៊ូវគ្រីស្ទយាងមក ? តើយើងអាចធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលនោះ ?

មេរៀនទី ៥១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៥

## បុព្វកថា

នៅខែមិនា ឆ្នាំ ១៨៣១ សាសនាចក្របានបន្តរីកចម្រើននៅក្នុងទីក្រុងខឺតឡង់ ។ ការប្រឆាំងទាស់នឹងសាសនាចក្រក៏នៅតែបន្តផងដែរ ។ ព្យាការី យ៉ូសែប ស៊្មីធ បានសរសេរថា ៖ « មានរបាយការណ៍ខុសឆ្គង ការកុហក និងរឿងឆ្កួតលីលាជាច្រើន ត្រូវបានបោះពុម្ពនៅលើទំព័រកាសែត ហើយផ្សាយទៅគ្រប់ទិសទី ដើម្បីរារាំងមនុស្សកុំឲ្យរៀនពីកិច្ចការនេះ ឬឱបក្រសោបយកសេចក្ដីជំនឿ » ។ នៅក្នុងគ្រាដែលមានការរីកចម្រើន និងការប្រឆាំងនេះ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈមួយ ដែលក្រោយមកលោកបានមានប្រសាសន៍ដែលនាំឲ្យ « ពួកបរិសុទ្ធដែលត្រូវតស៊ូទាស់នឹងអ្វីៗគ្រប់យ៉ាង មានក្ដីអំណរ ដែលការពិសេសអើង និងសេចក្ដីអាក្រក់ អាចកែប្រែមុខមាត់ថ្មី » ( នៅក្នុង *History of the Church* ១:១៥៨ ) ។ វិវរណៈនេះ ឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ដែលចាប់ផ្ដើមជាមួយនឹងសេចក្ដីប្រកាសមកពីព្រះអង្គសង្គ្រោះ អំពីតួនាទីរបស់ទ្រង់នៅក្នុងសេចក្ដីសង្គ្រោះរបស់យើង ។ មេរៀនថ្ងៃនេះ គឺជាមេរៀនដំបូងគេនៃមេរៀនទាំងបី ដែលផ្ដោតទៅលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–៥

*ព្រះយេស៊ូវគ្រីស្ទ បានគូសបញ្ជាក់អំពីតួនាទីរបស់ទ្រង់ ជាអង្គបង្កបង្កើត និងជាអង្គគាំទ្រ*

សូមឲ្យសិស្សនឹកស្រមៃថា ពួកគេកំពុងស្វែងរកទិសដៅអំពីអ្វីមួយ ដែលសំខាន់ចំពោះពួកគេ ហើយដែលមនុស្សផ្សេងៗមួយចំនួនចង់ផ្ដល់ដំបូន្មានឲ្យពួកគេ ។

- តើមនុស្សម្នាក់ចាំបាច់ត្រូវមានគុណសម្បត្តិអ្វីខ្លះ មុនពេលអ្នកនឹងស្ដាប់តាមដំបូន្មានរបស់គាត់ ? ( សិស្សអាចនឹងចែកចាយចម្លើយផ្សេងៗគ្នាជាច្រើនចំពោះសំណួរនេះ ។ បើចាំបាច់ អ្នកអាចនឹងចង់ផ្ដល់យោបល់ថា ពួកគេនឹងទំនងជាចង់ស្ដាប់នរណាម្នាក់ដែលយកចិត្តទុកដាក់ចំពោះពួកគេដោយផ្ទាល់ ហើយដែលមានជោគជ័យនៅក្នុងប្រធានបទដែលពួកគេកំពុងផ្ដល់យោបល់ឲ្យនោះ ) ។

សូមពន្យល់ថា វិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ បានកើតឡើងនៅចំគ្រា ដែលពួកបរិសុទ្ធថ្ងៃចុងក្រោយ និង មនុស្សដទៃទៀត បានស្ដាប់ និង អានសារលិខិតដែលប្រឆាំងទាស់នឹងសាសនាចក្រ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការណែនាំក្បាលកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលស្ថានភាពដែលពួកបរិសុទ្ធកំពុងតែប្រឈមមុខ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានព្រះបន្ទូលដំបូងគេរបស់ព្រះអម្ចាស់នៅក្នុងវិវរណៈ ។

សូមរំឭកសិស្សថា *ប្រុងស្ដាប់* មានន័យថា ស្ដាប់ដោយយកចិត្តទុកដាក់ ហើយគោរពតាម ។ នៅពេលយើងស្ដាប់ព្រះអម្ចាស់យ៉ាងពិតប្រាកដ នោះយើងនឹងធ្វើតាមឱវាទ និងព្រះបញ្ញត្តិរបស់ទ្រង់។ សូមពន្យល់ថា នៅដើមដំបូងនៃវិវរណៈនេះ ព្រះអម្ចាស់បានធ្វើការប្រកាសអំពីតួនាទីរបស់ទ្រង់មួយចំនួន និង កិច្ចខិតខំខ្នែងរបស់ទ្រង់ក្នុងការជួយដល់យើង ។ នៅពេលយើងអានសេចក្ដីប្រកាសទាំងនេះ យើងអាចរកឃើញមូលហេតុ ដែលយើងត្រូវស្ដាប់តាមព្រះបន្ទូលទ្រង់ ។ សូមលើកទឹកចិត្តដល់សិស្សឲ្យរកមើលពាក្យ *ប្រុងស្ដាប់* និង *ស្ដាប់* នៅក្នុងខគម្ពីរទាំងឡាយ ពេលពួកគេសិក្សានៅថ្ងៃនេះ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូល អំពីព្រះអង្គទ្រង់ ។ សូមសុំឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ នៅពេលពួកគេឆ្លើយតប សូមសរសេរគោលលទ្ធិខាងក្រោមនៅលើក្ដារខៀន ៖**ព្រះយេស៊ូវគ្រីស្ទ បានបង្កើតផ្ទៃមេឃ និងផែនដី ។**

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលត្រូវប្រុងស្ដាប់ព្រះអង្គសង្គ្រោះ ។

**ការធ្វើទីបន្ទាល់**

អ្នកគួរតែថ្លែងទីបន្ទាល់អំពីគោលលទ្ធិជាក់លាក់ដែលអ្នកបង្រៀននៅក្នុងមេរៀននិមួយៗ មិនមែនគ្រាន់តែពីសេចក្ដីពិតនៃដំណឹងល្អទូទៅនោះទេ ។ នៅពេលអ្នកថ្លែងទីបន្ទាល់ សូមចាំការប្រឹក្សានេះមកពីអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « សូមថ្លែងទីបន្ទាល់របស់អ្នក ដោយចេញពីជម្រៅនៃដួងចិត្តរបស់អ្នក ។ វានឹងជារឿងដែលសំខាន់បំផុតដែលអ្នកនិយាយទៅកាន់ពួកគេពេញមួយម៉ោងពេញ ។. . . ប្រសិនបើយើងថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដែលយើងបានបង្រៀន ព្រះនឹងបញ្ជាក់ដល់ដួងចិត្តយើង និង ដល់ដួងចិត្តនៃសិស្សរបស់យើងនូវសារលិខិតនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ » Teaching and Learning in the Church, » *Ensign* ខែ មិថុនា ឆ្នាំ ២០០៧, ទំព័រ ១០៤, ១០៥ ) ។

- យោងតាមខគម្ពីរនេះ ហេតុអ្វីក៏យើងគួរតែប្រុងស្ដាប់តាមព្រះអង្គសង្គ្រោះ ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ឃ្លា « នៅវេលាដែលអ្នករាល់គ្នាមិនគិត នោះរដូវក្ដៅនឹងកន្លង » សំដៅទៅលើគំនិតដែលរដូវក្ដៅ អាចនឹងជាវេលាមួយ ដើម្បីធ្វើការ ហើយត្រៀមសម្រាប់ច្រូតកាត់ នៅចុងរដូវ ។ ខគម្ពីរនេះ បង្រៀនថាយើងចាំបាច់ត្រូវប្រុងស្ដាប់ព្រះអង្គសង្គ្រោះក្នុងពេលឥឡូវនេះ ហើយប្រែចិត្តពីអំពើបាបរបស់យើង ខណៈដែលយើងនៅតែមានពេលដើម្បីធ្វើការសម្រាប់សេចក្ដីសង្គ្រោះនៃព្រលឹងរបស់យើង ) ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣ រួមមានទាំងពាក្យ *អ្នកគាំទ្រ* ។ អ្នកគាំទ្រ គឺជាមនុស្សម្នាក់ ដែលទូលអង្វរសម្រាប់បុព្វហេតុនៃមនុស្សម្នាក់ទៀត ។ ពេលខ្លះ រឿងនេះកើតឡើងនៅក្នុងតុលាការ ជាកន្លែងដែលមេធាវី បង្ហាញនូវភស្ដុតាងទៅដល់ចៅក្រម ជំនួសឲ្យនរណាម្នាក់ ដែលត្រូវបានទទួលការផ្ដន្ទាទោស ។

មុនពេលចាប់ផ្ដើមថ្នាក់ សូមរៀបចំស្លាកសញ្ញាបីដូចខាងក្រោម ៖

| | | |
|---|---|---|
| ចៅក្រម | ព្រះអង្គគាំទ្រ | អ្នកជាប់ចោទ |

រៀបចំនៅខ្នងខាងក្រោយស្លាកសញ្ញាទាំងនេះដូចខាងក្រោម ៖

| | | |
|---|---|---|
| ព្រះវរបិតាសួគ៌ | ព្រះយេស៊ូវគ្រីស្ទ | ពួកយើង |

សូមអញ្ជើញសិស្សបីនាក់ឡើងមកខាងមុខថ្នាក់ ។ សូមឲ្យស្លាកសញ្ញាមួយទៅដល់សិស្សម្នាក់ៗ ។ សូមឲ្យពួកគេលើកសញ្ញាទាំងឡាយឡើង ដែលបង្ហាញនូវពាក្យ *ចៅក្រម មេធាវី* និង *ចុងចោទ ។* សូមឲ្យសិស្សលើកសញ្ញាដែលមានស្លាកថា *មេធាវី* ឈរនៅចម្លោះសិស្សពីរនាក់ទៀតនោះ ។

សូមឲ្យសិស្សក្នុងថ្នាក់នឹកស្រម៉ៃថា ពួកគេនៅក្នុងតុលាការ ដែលមានចៅក្រម មេធាវី និងចុងចោទ ដែលត្រូវបានគេចោទប្រកាន់ថា បានធ្វើបទឧក្រិដ្ឋមួយ ។

- តើតួនាទីរបស់ចៅក្រមគឺជាអ្វី ?
- តើមេធាវីអាចជួយដល់ជនដែលត្រូវគេចោទប្រកាន់បានយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣ ឲ្យឮៗ ។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលខគម្ពីរនេះបង្រៀនអំពីព្រះអង្គសង្គ្រោះ ។

- នៅក្នុងខគម្ពីរនេះ តើនរណាគឺជាចៅក្រម ? ( នៅពេលសិស្សឆ្លើយសំណួរនេះ សូមឲ្យសិស្សកាន់ស្លាកសញ្ញាដែលមានពាក្យថា *ចៅក្រម* បង្វិលសញ្ញានោះមើលនៅខ្នងខាងក្រោយវិញ ) ។ តើនរណាជាចុងចោទ ? ( សូមឲ្យសិស្សកាន់សញ្ញាដែលមានស្លា ក *ចុងចោទ* បង្វិលសញ្ញានោះមើលនៅខ្នងខាងក្រោយវិញ ) ។ តើនរណាជាមេធាវី ? ( សូមឲ្យសិស្សកាន់សញ្ញាដែលមានស្លាក *អ្នកគាំទ្រ* បង្វិលសញ្ញានោះមើលនៅខ្នងខាងក្រោយវិញ ) ។ បន្ទាប់មកសរសេរនូវគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន **៖ព្រះយេស៊ូវគ្រីស្ទ គឺជាមេធាវីរបស់យើងនៅចំពោះព្រះភក្ត្រព្រះវរបិតាសួគ៌ ) ។**
- ហេតុអ្វីក៏យើងត្រូវការអ្នកគាំទ្រម្នាក់នៅចំពោះព្រះភក្ត្រព្រះវរបិតាសួគ៌ ? ( យើងមានកំហុសនៃអំពើបាប ។ ស្របតាមសេចក្ដីយុត្តិធម៌របស់ព្រះ គ្មានវត្ថុមិនស្អាតណា អាចរស់នៅក្នុងវត្តមានរបស់ទ្រង់បានទេ ។ ហេតុដូច្នោះហើយ យើងត្រូវការអ្នកគាំទ្រម្នាក់ ដើម្បីទូលអង្វរពីបុព្វហេតុរបស់យើង នៅចំពោះព្រះភក្ត្ររបស់ព្រះបិតា ហើយជួយយើងឲ្យផ្សះផ្សានឹងទ្រង់ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានទូលអង្វរពីបុព្វហេតុរបស់យើងចំពោះព្រះវរបិតា ។

- ស្របតាម ខ ៤ តើព្រះយេស៊ូវគ្រីស្ទបានទូលសូមដល់ព្រះវរបិតាឲ្យទ្រង់ញាណអ្វីខ្លះ ? ( ព្រះអង្គសង្គ្រោះបានប្រាប់អំពីជីវិតដែលគ្មានអំពើបាបរបស់ទ្រង់ និងការរងទុក្ខ និងការសុគតរបស់ទ្រង់ ) ។

- ស្របតាម ខ ៥ តើព្រះអង្គសង្គ្រោះបានទូលសុំឲ្យព្រះវរបិតាទ្រង់ញាណអ្វីខ្លះទៀត ? ( សេចក្ដីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេត្រូវការព្រះយេស៊ូវគ្រីស្ទដើម្បីធ្វើជាអង្គគាំទ្ររបស់ពួកគេនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។ សូមផ្ដល់ពេលដល់ពួកគេឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរនូវអារម្មណ៍របស់ពួកគេ អំពីព្រះអង្គសង្គ្រោះជាអង្គគាំទ្ររបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យសរសេរនូវអ្វីដែលពួកគេមានអារម្មណ៍ដឹងថាទ្រង់នឹងឲ្យពួកគេធ្វើ ដើម្បីបង្ហាញពីជំនឿរបស់ពួកគេទៅលើព្រះនាមរបស់ទ្រង់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦–១០

*ព្រះអង្គសង្គ្រោះ ប្រកាសថា ទ្រង់គឺជាពន្លឺ និងជាជីវិតនៃលោកិយ ហើយថា ទ្រង់បានបញ្ជូនសេចក្ដីសញ្ញាដ៏អស់កល្បអស់កាលជានិច្ចរបស់ទ្រង់ទៅដល់ពិភពលោក ។*

សូមបំបែកសិស្សជាគូៗ ហើយសុំឲ្យដៃគូទាំងឡាយអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦–១០ ជាមួយគ្នា ។ ក្រោយពីសិស្សមានពេលអានគ្រប់គ្រាន់ហើយ សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- ស្របតាម ខ ៦–៧ តើមូលហេតុអ្វីខ្លះ ដែលព្រះអង្គសង្គ្រោះបានប្រទានដល់យើងឲ្យប្រុងស្ដាប់ដល់ទ្រង់ ? តើវាមានន័យយ៉ាងណាចំពោះអ្នក ដែលថាទ្រង់គឺជា « ដើម និងជាចុង » ? តើទ្រង់នាំពន្លឺ និងជីវិតមកលើពិភពលោកតាមវិធីណា ?

សូមសរសេរ ការពិពណ៌នាដូចខាងក្រោមអំពីព្រះអង្គសង្គ្រោះ នៅលើក្ដារខៀន ៖

> *ព្រះយេស៊ូវគ្រីស្ទ គឺជាដើម និងជាចុង ។*
>
> *ព្រះយេស៊ូវ គ្រីស្ទ គឺជាពន្លឺ និងជាជីវិតនៃពិភពលោក ។*

- ស្របតាម ខ ៨ តើព្រះអង្គសង្គ្រោះបានសន្យាអ្វីខ្លះ ដល់អ្នកទាំងឡាយដែលទទួលយកទ្រង់ ?

សូមចង្អុលបង្ហាញថា នៅក្នុង ខ ៩ យើងអានថា ព្រះយេស៊ូវគ្រីស្ទ បានបញ្ជូន « សេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ចរបស់ទ្រង់. . . ដើម្បីធ្វើជាពន្លឺដល់មនុស្សលោក ហើយដើម្បីធ្វើជាបមាណីយដល់រាស្ត្រ [ របស់ទ្រង់ ] » ។ នៅក្នុងវិវរណៈមួយទៀត ទ្រង់បានមានបន្ទូលថា សេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ចរបស់ទ្រង់ គឺជា « ភាពពោរពេញនៃដំណឹងល្អ [ របស់ទ្រង់ ] » ( គ. និង ស. ៦៦:២ ) ។

- តើអ្នកគិតថា « ស្វែងរក » ដំណឹងល្អមានន័យយ៉ាងណា ?

- តើអ្នកធ្លាប់បានឃើញដំណឹងល្អគឺជាពន្លឺដល់ពិភពលោកតាមរបៀបណាខ្លះ ? តើដំណឹងល្អគឺជាបទដ្ឋានមួយសម្រាប់យើងដែលបានធ្វើសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់ ដោយវិធីណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១១–១៥

*ព្រះអង្គសង្គ្រោះប្រកាសថា ទ្រង់គឺជាព្រះនៃលោកហេណុក*

សូមដាក់បង្ហាញរូបភាពទីក្រុងស៊ីយ៉ូនត្រូវបានលើកឡើងទៅស្ថានសួគ៌ (*សៀវភៅសិល្បៈដំណឹងល្អ* [ឆ្នាំ ២០០៩ ] ទំព័រ ៦, សូមមើលផងដែរ LDS.org ) ។ សូមពន្យល់ថា នេះគឺជាសិល្បៈនៃការពិពណ៌នាអំពីហេណុក និងរាស្ត្ររបស់ទ្រង់ ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១១ ឲ្យឮៗ ។ សូមចង្អុលបង្ហាញថា នៅក្នុងខគម្ពីរនេះ ព្រះអម្ចាស់បានមានបន្ទូលថា មនុស្សមួយចំនួនហៅទ្រង់ថា « ព្រះនៃលោកហេណុក » ។



សូមអញ្ជើញសិស្សឲ្យប្រាប់ដល់សិស្សក្នុងថ្នាក់នូវអ្វីដែលពួកគេដឹងអំពីព្យាការី ហេណុក ។ បើចាំបាច់ សូមផ្ដល់ព័ត៌មានដូចខាងក្រោមថា ៖ ហេណុក បានរស់នៅពីមុនជំនាន់របស់ណូអេ ។ ផែនដីនៅក្នុងជំនាន់របស់លោកហេណុក ត្រូវបានគ្របដណ្ដប់ដោយសេចក្ដីទុច្ចរិត ប៉ុន្តែលោកបានដឹកនាំមនុស្សសុចរិតមួយក្រុម ដែលបានរស់នៅក្នុងទីក្រុងមួយដែលហៅថា ស៊ីយ៉ូន ។ នៅទីបំផុត ប្រជារាស្ត្រទីក្រុង ស៊ីយ៉ូន ត្រូវបាន « បែកចេញពីផែនដី » (គ. និង ស. ៤៥:១២)—ត្រូវបានលើកឡើងទៅស្ថានសួគ៌ ដោយសារតែសេចក្ដីសុចរិតរបស់ពួកគេ ( សូមមើល ម៉ូសេ ៧:៦៩) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១២–១៤ ដោយការពន្យល់ថា ព្រះអម្ចាស់បានទទួលប្រជារាស្ត្រទីក្រុង ស៊ីយ៉ូន ឡើងទៅឯទ្រង់ ហើយថាទ្រង់នឹងរក្សាពួកគេទុក « រហូតដល់ថ្ងៃនៃសេចក្ដីសុចរិតនឹងមកដល់ » ។ នៅថ្ងៃនោះ ហេណុក និង រាស្ត្ររបស់លោក នឹងត្រឡប់មកផែនដីវិញ ដើម្បីជួបជាមួយពួកបរិសុទ្ធថ្ងៃចុងក្រោយស្មោះត្រង់ នៅទីក្រុងយេរ៉ូសាឡិមថ្មី ដែលក៏នឹងត្រូវបានហៅថា ទីក្រុង ស៊ីយ៉ូន ដែរ ( សូមមើល ម៉ូសេ ៧:៦២–៦៤ ) ។ ព្យាការីទាំងអស់បានទន្ទឹងរង់ចាំថ្ងៃនោះ ។ ដោយសារតែអំពើទុច្ចរិតនៃប្រជាជនដែលរស់នៅលើផែនដី ទើបថ្ងៃនោះមិនទាន់បានមកដល់នៅឡើយ ប៉ុន្តែអ្នកទាំងឡាយដែលបានទន្ទឹងរង់ចាំថ្ងៃនោះ នឹងបានឃើញជាប្រាកដនៅថ្ងៃណាមួយ ។

សូមអញ្ជើញសិស្សឲ្យរំឭកសេចក្ដីថ្លែងការណ៍ដែលអ្នកបានសរសេរនៅលើក្ដារខៀនដែលពិពណ៌នាអំពីតួនាទី និងចរិតលក្ខណៈមួយចំនួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សពិចារណាអំពីសេចក្ដីថ្លែងការណ៍ទាំងនេះ ហើយជ្រើសរើសចរិតលក្ខណៈមួយដែលមានអត្ថន័យជាពិសេសចំពោះពួកគេ ។ បន្ទាប់ពីផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យរៀបរាប់អំពីតួនាទី ឬចរិតលក្ខណៈ ដែលពួកគេបានជ្រើសរើស ហើយពន្យល់ថាហេតុអ្វីក៏វាមានអត្ថន័យចំពោះពួកគេ ។ បន្ទាប់ពីសិស្សបានពន្យល់អំពីគំនិតរបស់ពួកគេរួចហើយ ចូរសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **នៅពេលយើងរៀនអំពីតួនាទី និងចរិតលក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ នោះបំណងប្រាថ្នារបស់យើងដើម្បីធ្វើតាមទ្រង់នឹងកើនឡើង ។**

- តើអ្នកបានរៀនអ្វីខ្លះ អំពីព្រះអង្គសង្គ្រោះនៅថ្ងៃនេះ ដែលជួយអ្នកឲ្យមានបំណងប្រុងស្ដាប់តាមទ្រង់ដោយប្រុងប្រយ័ត្ននោះ ?

អ្នកអាចនឹងចង់ចែកចាយនូវគំនិតរបស់អ្នកអំពីតួនាទី ឬចរិតលក្ខណៈមួយរបស់ព្រះអង្គសង្គ្រោះ និងអំពីរបៀបដែលចំណេះដឹងរបស់អ្នកអំពីតួនាទី និងចរិតលក្ខណៈ បានជួយអ្នកឲ្យមានបំណងប្រាថ្នាដើម្បីធ្វើតាមទ្រង់យ៉ាងដូចម្ដេច ។ សូមពិចារណាធ្វើការបញ្ចប់មេរៀនដោយការថ្លែងទីបន្ទាល់អំពីពរជ័យនៃការស្ដាប់តាមព្រះយេស៊ូវគ្រីស្ទ និងការគោរពតាមដំបូន្មាន និងបទបញ្ញត្តិរបស់ទ្រង់ ។

មេរៀនទី ៥២

# គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:១៦–៥៩

### បុព្វកថា

ព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន ព្យាករអំពីស្ថានភាព និងព្រឹត្តការណ៍ទាំងឡាយ ដែលនឹងកើតមានឡើងពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ មិនយូរប៉ុន្មាន បន្ទាប់ពីសាសនាចក្របានផ្លាស់ពីរដ្ឋនូវ យ៉ោក ទៅរដ្ឋ អូហៃអូ នោះ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥ ។ នៅក្នុងចំណែកនៃវិវរណៈ ដែលត្រូវបានគ្របដណ្តប់នៅក្នុងមេរៀននេះ ព្រះអង្គសង្គ្រោះ បានផ្តល់នូវរឿងលម្អិតអំពី គ្រាដែលកើតមានពីមុនការយាងមកជាលើកទីពីរ ។ ទ្រង់បានលាតសន្ធឹងសេចក្តីពិត ដែលទ្រង់បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់នៅលើភ្នំអូលីវ ( សូមមើល ម៉ាថាយ ២៤ ) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:១៦–៤៦

*ព្រះអង្គសង្គ្រោះ បើកសម្តែងទីសម្គាល់ទាំងឡាយ ដែលនឹងកើតមានពីមុនការយាងមកជាលើកទីពីររបស់ទ្រង់*

សូមចាប់ផ្តើមមេរៀនដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកអាចប្រាប់ពីពេល ដែលអាចនឹងមានភ្លៀងធ្លាក់យ៉ាងដូចម្តេច ?

សូមពន្យល់ថា ក៏ដូចជាឧបករណ៍ឧតុនិយម ជួយយើងឲ្យដឹងថា ពេលណាភ្លៀងនឹងបង្អុរចុះមក នោះក៏មានឧបករណ៍ឧតុនិយម ឬទីសម្គាល់ ដែលជួយយើងឲ្យដឹងថា ពេលណាដែលការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ នឹងកើតឡើងផងដែរ ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ទីសម្គាល់នៃការយាងមកជាលើកទីពីរ ។*

សូមពន្យល់ថា នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥ ព្រះអម្ចាស់ បានពិពណ៌នាអំពីទីសម្គាល់មួយចំនួនដែលនឹងប្រាប់យើងជាមុន អំពីការមកដល់ជាលើកទីពីររបស់ទ្រង់ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:១៦–១៧ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលពួកសិស្សរបស់ព្រះអម្ចាស់ បានសួរទ្រង់ និងអ្វីដែលទ្រង់បានមានបន្ទូលថានឹងបង្ហាញដល់ពួកគេ ។

- តើពួកសិស្សបានសូមដល់ព្រះអម្ចាស់ឲ្យបង្រៀនពួកគេអំពីអ្វីខ្លះ ?
- តើព្រះអម្ចាស់មានបន្ទូលថា ទ្រង់នឹងបង្ហាញដល់ពួកសិស្សរបស់ទ្រង់អ្វីខ្លះ ? ( តើថ្ងៃនៃការប្រោសលោះនឹងមកដល់របៀបណា ហើយការប្រមូលពួកសាសន៍អ៊ីស្រាអែលដែលបានខ្ចាត់ព្រាត់ដោយរបៀបណា ) ។

ដើម្បីជួយសិស្សឲ្យប្រាប់ពីទីសម្គាល់ទាំងឡាយ ដែលព្រះអម្ចាស់បានមានបន្ទូលថានឹងកើតមាននៅពីមុនការយាងមកជាលើកទីពីររបស់ទ្រង់ សូមសរសេរសេចក្តីយោងដូចខាងក្រោមនៅលើក្តារខៀន ៖

> *គ. និង ស. ៤៥:១៨–២៤*
>
> *គ. និង ស. ៤៥:២៥–២៧*
>
> *គ. និង ស. ៤៥:២៨–៣១, ៣៣*
>
> *គ. និង ស. ៤៥:៤០–៤៣*

សូមបែងចែកសិស្សជាគូរ ៗ ហើយចាត់ឲ្យគូនិមួយ ៗនូវវគ្គបទគម្ពីរមួយនៅលើក្ដារខៀន ។ សូមសុំឲ្យពួកគេអានខទាំងឡាយជាមួយគ្នា រកមើលទីសម្គាល់ដែលបានប្រាប់នៅក្នុងខគម្ពីរទាំងនោះ ។ ពីមុនពួកគេចាប់ផ្ដើម អ្នកអាចចង្អុលបង្ហាញថាទីសម្គាល់មួយចំនួនត្រូវបានបំពេញរួចទៅហើយ ។

បន្ទាប់ពីផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមឲ្យដៃគូនិមួយ ៗ រៀបរាប់អំពីការរកឃើញរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅខាងក្រោមក្បាលរឿង « ទីសម្គាល់នៃការយាងមកជាលើកទីពីរ » នៅលើក្ដារខៀន ។ បើចាំបាច់ សូមប្រើព័ត៌មាននៅក្នុងកថាកណ្ឌពីរបន្ទាប់ដើម្បីជួយសិស្សយល់អំពីការព្យាករណ៍ទាំងឡាយ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៨–២៤ យើងអានអំពីការព្យាករណ៍ទាំងឡាយដែលត្រូវបានបំពេញរួចហើយនោះ ។ ព្រឹត្តការណ៍ទាំងឡាយដែលបានព្យាករនៅក្នុងខគម្ពីរទាំងនេះ បានកើតឡើងនៅក្នុងពេលមិនយូរប៉ុន្មានបន្ទាប់ពីការសុគត និងការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ។ សូមកត់ចំណាំថា ខ ២០ សំដៅទៅលើព្រះវិហារបរិសុទ្ធ ដែលបានសង់ឡើងដោយស្ដេចហេរ៉ូឌ នៅក្នុងក្រុងយេរូសាឡិម ។ វាត្រូវបានបំផ្លាញដោយជនជាតិរ៉ូម នៅ គ.ស ឆ្នាំ ៧០ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:២៥–៤៦ យើងអានអំពីការព្យាករណ៍ទាំងឡាយដែលបានបំពេញនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ មុនពេលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ នៅក្នុងវគ្គបទគម្ពីរនេះ ឃ្លាថា « ពេលវេលានៃពួកសាសន៍ដទៃ » (គ. និង ស. ៤៥:២៥,២៨, ៣០) សំដៅទៅលើដំណឹងល្អដែលត្រូវបានផ្សាយជាលើកដំបូងទៅកាន់សាសន៍ដទៃនៅក្នុងថ្ងៃចុងក្រោយ ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា យ៉ូសែប ស្ម៊ីធ « គឺជាសាសន៍ដទៃមានន័យថា លោកគឺជាពលរដ្ឋនៃជាតិសាសន៍ដទៃ ហើយលោកក៏ពុំមែនជាពួកសាសន៍យូដាដែរ ។. . . ប្រាកដណាស់ ដំណឹងល្អបានលេចចេញមកនៅថ្ងៃចុងក្រោយនៅ *ជំនាន់នៃពួកសាសន៍ដទៃ* ហើយ នឹងមិនទៅកាន់ពួកយូដាទេ ទាល់តែ *ពួកសាសន៍ដទៃទាំងអស់* មកកាន់ដំណឹងល្អសិន (គ និង ស. ៤៥:២៨–៣០) » ។ ( *Mormon Doctrine* កំណែលើកទីពីរ | ឆ្នាំ ១៩៦៦ | ទំព័រ ៣១១ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលពួកសិស្សនៅក្នុងជំនាន់របស់ព្រះយេស៊ូវគ្រីស្ទមានអារម្មណ៍យ៉ាងដូចម្ដេច នៅពេលទ្រង់បានប្រាប់ពួកគេអំពីទីសម្គាល់នៃការយាងមកជាលើកទីពីររបស់ទ្រង់ ។

- តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច នៅពេលអ្នកគិតពិចារណាអំពីទីសម្គាល់ទាំងឡាយនៃការយាងមកជាលើកទីពីរ ?

សូមពន្យល់ថា ការដឹងអំពីទីសម្គាល់ទាំងឡាយនៃការយាងមកជាលើកទីពីរ អាចជួយយើងរស់នៅដោយគ្មានភាពភ័យខ្លាចភាពសង្ស័យ ឬភាពវង្វេងស្មារតីឡើយ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣៥–៣៨ ដោយស្ងាត់ស្ងៀម ដើម្បីរៀនពីមូលហេតុដែលព្រះអម្ចាស់ប្រទាននូវទីសម្គាល់ទាំងនេះ ។ ( ពីមុនសិស្សអាន អ្នកអាចនឹងចង់ពន្យល់ថា នៅក្នុងអ៊ីស្រាអែល ដើមល្វាគឺជាដើមឈើចុងក្រោយគេបំផុត ដែលនឹងដុះត្រួយនៅនិទាឃរដូវ ហើយលាស់ត្រួយនៅចុងរដូវ ) ។

- ហេតុអ្វីក៏វាសំខាន់ដើម្បីអាចស្គាល់អំពីពេលវេលា « ម៉ោងជិតដល់ហើយ » ឬថាការយាងមកជាលើកទីពីរនឹងមកដល់ជាប្រាកដនោះ ?

សូមសរសេរនៅលើក្ដារខៀន *គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣២, ៣៩* ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរទាំងនេះជាមួយនឹងដៃគូរបស់ពួកគេ ហើយពិពណ៌នានូវអ្វីដែលពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទនឹងធ្វើ ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមករបស់ទ្រង់ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីត្រៀមខ្លួនសម្រាប់ការយាងមករបស់ព្រះអម្ចាស់ ?

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើសិនជាយើងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយទន្ទឹងចាំទីសម្គាល់ នោះយើងនឹង . . .*

- ផ្អែកទៅលើអ្វីដែលយើងបានសិក្សាកន្លងមក តើអ្នកនឹងបំពេញសេចក្ដីថ្លែងការណ៍នេះយ៉ាងដូចម្ដេច ? ( នៅខាងក្រោមនេះគឺជាវិធីមួយដែលសិស្សអាចបំពេញនូវគោលការណ៍នោះ ៖ **បើសិនជាយើងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយទន្ទឹងចាំទីសម្គាល់ នោះយើងនឹងត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់** ។ សូមបញ្ចប់ការសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើអ្នកគិតថា អ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ អាច « ឈរនៅក្នុងទីបរិសុទ្ធ » យ៉ាងដូចម្ដេច ? តើទីកន្លែងណាខ្លះនៅក្នុងជីវិតរបស់អ្នក ដែលអ្នកគិតថាជា « ទីបរិសុទ្ធ » ?

ដើម្បីជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីអ្វីដែលជាអត្ថន័យដើម្បីឈរនៅក្នុងទីបរិសុទ្ធ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមឲ្យឮៗ ។ សូមលើកទឹកចិត្តសិស្សក្នុងថ្នាក់ឲ្យស្ដាប់នូវអ្វីដែលជាអត្ថន័យដើម្បីឈរនៅក្នុងទីបរិសុទ្ធ ៖

> « ‹ ទីបរិសុទ្ធ › អាចមានកត្តាជាច្រើនតម្រូវឲ្យធ្វើជាមួយនឹង *របៀប* ដែលបុគ្គលម្នាក់រស់នៅ ប្រសើរជាង *ទីកន្លែង* ដែលបុគ្គលនោះរស់នៅ ។ ប្រសិនបើយើងរស់នៅដោយស្អាតស្អំដោយមានដៃគូជាព្រះវិញ្ញាណបរិសុទ្ធឥតដាច់នោះ យើងនឹងឈរនៅក្នុងទីបរិសុទ្ធមួយហើយ ។. . . « ទីបរិសុទ្ធស្ថិតនៅគ្រប់ទីកន្លែងទាំងអស់ ជាទីដែលបុគ្គលម្នាក់រីករាយនឹងព្រះវិញ្ញាណនៃព្រះ » (*គោលលទ្ធិ និង សេចក្ដីសញ្ញា សៀវភៅសិក្សារបស់សិស្ស* ការបោះពុម្ពជាលើកទី ២ [ សៀវភៅសិក្សារបស់ប្រព័ន្ធអប់រំសាសនាចក្រ ឆ្នាំ ២០០១ ] ទំព័រ ១៩៦ ) ។

- តើយើងអាចឈរនៅក្នុងទីបរិសុទ្ធ ខណៈដែលយើងត្រូវបានហ៊ុំព័ទ្ធដោយសេចក្ដីទុច្ចរិតនៃលោកិយបានយ៉ាងដូចម្ដេច ?

សូមពិចារណាធ្វើការដាក់បង្ហាញរូបភាពការយាងមកជាលើកទីពីរ (*សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] ទំព័រ ៦៦, សូមមើលផងដែរ LDS.org) ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៤–៤៦ ដោយការពន្យល់ថា អ្នកទាំងឡាយដែលត្រូវបានត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ នឹងបានឃើញទ្រង់យាងមកក្នុងសិរីល្អ ។ មនុស្សសុចរិត ដែលបានស្លាប់ទៅមុនពេលការយាងមករបស់ទ្រង់ នឹងត្រូវបានរស់ឡើងវិញ ហើយក្រោកឡើងមកជួបនឹងទ្រង់ ។ ពួកបរិសុទ្ធស្មោះត្រង់ដែលនៅរស់នៅលើផែនដី ក៏នឹងត្រូវបាននាំយកទៅជួបនឹងទ្រង់ផងដែរ ( សូមមើល គ. និង ស. ៨៨:៩៦–៩៨) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៧–៥៩

*ព្រះអង្គសង្គ្រោះបើកសម្ដែងទីសម្គាល់ និង ការអស្ចារ្យជាច្រើន ដែលនឹងមានចំណែកក្នុងការយាងមកជាលើកទីពីររបស់ទ្រង់ ។*



សូមដាក់តាំង ឬអញ្ជើញសិស្សឲ្យបើកទៅទំព័រ ផែនទី ១ ( « Physical Map of the Holy Land » ) នៅក្នុងវគ្គផែនទីក្នុងព្រះគម្ពីរប៊ីបរបស់ពួកគេ ។ សូមចង្អុលបង្ហាញពីទីតាំងដែលភ្នំអូលីវ គឺនៅជិតនឹងទីក្រុងយេរូសាឡិម ហើយពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៨ សំដៅទៅលើទីកន្លែងសំខាន់នេះនៅក្នុងអ៊ីស្រាអែល ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលនឹងកើតឡើងចំពោះភ្នំនេះ និងចំពោះផែនដី នៅពេលព្រះអង្គសង្គ្រោះយាងត្រឡប់មកវិញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៩–៥០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយស្វែងរកមើលអ្វីផ្សេងទៀត ដែលនឹងកើតមានឡើងនៅក្នុងការយាងមកជាលើកទីពីរ ។

- តើនឹងមានអ្វីកើតឡើងចំពោះសាសន៍ទាំងឡាយនៃផែនដី នៅគ្រានៃការយាងមកជាលើកទីពីរ ?
- តើនរណាដែលអ្នកគិតថាសំដៅទៅលើ « ពួកគេដែលបានសើចដាក់ » នោះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៥១–៥៣ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលពួកសាសន៍យូដានឹងឆ្លើយតប នៅពេលព្រះអម្ចាស់យាងមកភ្នំអូលីវ ។

- ហេតុអ្វីបានជាពួកសាសន៍យូដានឹងយំ នៅពេលព្រះអម្ចាស់យាងត្រឡប់មកវិញ ?

ដើម្បីជួយសិស្សយល់របៀបបន្ថែមទៀតដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ សូមបង្ហាញរូបភាពរឿងប្រៀបធៀបនៃស្ត្រីព្រហ្មចារីដប់នាក់ (*សៀវភៅរូបភាពដំណឹងល្អ* [ ឆ្នាំ ២០០៩ ] លេខ ៥៣ សូមមើលផងដែរ LDS.org) ។ សូមសួរដល់សិស្សបើមាននរណាម្នាក់ អាចរៀបរាប់ឡើងវិញអំពីរឿងប្រៀបធៀបនៃស្ត្រីព្រហ្មចារីដប់នាក់បានទេ ។ បើចាំបាច់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានរឿងប្រៀបធៀបនោះឲ្យឮៗ ចេញមកពី ម៉ាថាយ ២៥:១–១៣ ។

**ជំនួយចក្ខុ**

វត្ថុ និង រូបភាពទាំងឡាយ រួមមាន ផែនទី និង តារាង អាចជួយសិស្សមើលឃើញនឹងភ្នែក, វិភាគ ហើយយល់អំពីបទគម្ពីរ ជាពិសេស នៅពេលវាត្រូវបានប្រើប្រាស់ ដើម្បីជម្រុញឲ្យមាន ការពិភាក្សាមួយ ។ វត្ថុជំនួយចក្ខុដូចនេះ ក៏អាចជួយលើកទឹកចិត្តដល់សិស្សចង់ដឹង និងជួយពួកគេឲ្យចង់រៀនបន្ថែមផងដែរ ។



- តើស្ត្រីព្រហ្មចារីយ ប្រាំនាក់មានគំនិតដូចម្ដេចខ្លះ ?
- តើរឿងប្រៀបធៀបនេះ ទាក់ទងនឹងការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៥៦–៥៧ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលរឿងប្រៀបធៀបនៃស្ត្រីព្រហ្មចារីយដប់នាក់ នឹងបំពេញយ៉ាងដូចម្ដេចខ្លះ ។

- តើរឿងប្រៀបធៀបនេះនឹងត្រូវបានបំពេញនៅក្នុងការយាងមកជាលើកទីពីរយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យកាន់តែយល់បន្ថែមអំពីអត្ថន័យនៃរឿងប្រៀបធៀបស្ត្រីព្រហ្មចារីយដប់នាក់នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវអ្វីដែលស្ត្រីព្រហ្មចារីយដប់នាក់តំណាងឲ្យ ៖



« ការគិតអំពីរឿងប្រៀបធៀបនេះ គឺព្រឺសម្បុរ ។ ស្រីព្រហ្មចារីទាំងដប់នាក់ ពិតជាតំណាងឲ្យសមាជិកនៃសាសនាចក្ររបស់ព្រះគ្រីស្ទ ដោយសារមនុស្សទាំងអស់ត្រូវបានអញ្ជើញឲ្យមកពិធីមង្គលការ ហើយមនុស្សទាំងអស់បានដឹងពីតម្រូវការដើម្បីបានចូល នៅពេលកូនកំលោះបានមក ។ ប៉ុន្តែមានតែសមាជិកពាក់កណ្ដាលប៉ុណ្ណោះ ដែលត្រៀមខ្លួនជាស្រេច នៅពេលកូនកម្លោះបានមកដល់នោះ » ( Preparation for the Second Coming, » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៨ ) ។

- យោងតាម ខ ៥៧ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីបានត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ? ( សិស្សគួរតែពិពណ៌នាប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងទទួលសេចក្ដីពិត ហើយទទួលយកព្រះវិញ្ញាណបរិសុទ្ធធ្វើជាអង្គដឹកនាំយើង នោះយើងនឹងនៅខ្ជាប់ខ្ជួនក្នុងការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។** សូមសរសេរគោលការណ៍នៅលើក្ដារខៀន។

សូមអញ្ជើញសិស្សឲ្យគិតអំពី គោលការណ៍នៅលើក្ដារខៀន ហើយពិចារណាអំពីពេលវេលា ដែលពួកគេបានទទួលសេចក្ដីពិតឬបានធ្វើតាមព្រះវិញ្ញាណបរិសុទ្ធ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

- តើអ្នកគិតថាបទពិសោធន៍របស់អ្នកជាមួយនឹងការទទួលយកសេចក្ដីពិត និងការធ្វើតាមព្រះវិញ្ញាណបរិសុទ្ធ អាចជួយអ្នកត្រៀមខ្លួនដើម្បីជួបនឹងព្រះអម្ចាស់ នៅក្នុងការយាងមកជាលើកទីពីររបស់ទ្រង់ឬទេ ?

សូមអញ្ជើញសិស្សឲ្យប្រើគោលការណ៍ទាំងឡាយដែលបានសរសេរនៅលើក្ដារខៀន ដើម្បីដាក់គោលដៅមួយ ដែលនឹងជួយពួកគេត្រៀមខ្លួនសម្រាប់ការយាងមករបស់ព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៥៥, ៥៨–៥៩ ដោយស្ងាត់ស្ងៀម ដើម្បីរកមើលពរជ័យបន្ថែមដែលនឹងកើតមានមកលើអ្នកទាំងឡាយណាដែលបានត្រៀមខ្លួន ហើយនៅខ្ជាប់ខ្ជួនក្នុងថ្ងៃនៃការយាងមកជាលើកទីពីរនោះ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ។

សូមពន្យល់ថា ប្រធាន ប៊យដ៏ ឃេ ផាកកឺ នៃពួកសាវកដប់ពីរនាក់ បានគូសបញ្ជាក់ អំពីសារៈសំខាន់នៃការមានព្រះវិញ្ញាណគង់នៅជាមួយក្នុងគ្រាលំបាក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្ដាប់អំពីរបៀបដែលប្រធាន ផាកកឺ បានមានប្រសាសន៍ ដើម្បីយើងអាចដឹងអំពីការរស់នៅក្នុងគ្រាដែលនឹងកើតមានមុនការយាងមកជាលើកទីពីរ ៖



« យើងរស់នៅក្នុងគ្រាដ៏លំបាក—ដែលជាគ្រាដ៏លំបាកពេកពន់ ។ យើងសង្ឃឹម យើងអធិស្ឋាន សូមឲ្យស្ថានភាពកាន់តែប្រសើរឡើង ។ ប៉ុន្តែការណ៍នោះមិនកើតឡើងទាល់តែសោះ ។ ការព្យាករណ៍បានប្រាប់យើងថាដូច្នោះ ។ យើងនឹងមិនធ្វើជាមនុស្ស ក្រុមគ្រួសារ ឬ បុគ្គល ដែលរួចចាកផុតពីការសាកល្បងដែលនឹងកើតឡើងនោះទេ ។. . .

« យើងមិនត្រូវរស់នៅដោយភិតភ័យនឹងអនាគតឡើយ ។ យើងមានគ្រប់ហេតុផលដើម្បីបានរីករាយ និង ហេតុផលតូចបំផុតដើម្បីនឹងភិតភ័យ ។ បើយើងធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ នោះយើងនឹងមានសុខសុវត្ថិភាព ទោះជាអនាគតទៅជាយ៉ាងក៏ដោយ ។ យើងនឹងត្រូវបានបង្ហាញនូវអ្វីដែលត្រូវធ្វើ » ( « The Cloven Tongues of Fire,» *Ensign* ខែ ឧសភា ឆ្នាំ ២០០០ ទំព័រ ៨ ) ។

**សូមឲ្យសិស្សចែកចាយនូវអ្វីមួយដែលពួកគេបានរៀនអំពីការយាងមកជាលើកទីពីរចេញមកពីមេរៀននេះ ។ អ្នកអាចចង់ចែកចាយពីអារម្មណ៍របស់អ្នកផងដែរ ។**

មេរៀនទី ៥៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦០–៧៥

## បុព្វកថា

នៅពេលពួកបរិសុទ្ធបានប្រមូលគ្នីគ្នានៅក្នុងក្រុងខឺតឡង់ នោះមានដំណើររឿង និង ពាក្យចចាមអារាមតាមការសែតក្លែងបន្លំជាច្រើន ដែលរាយការណ៍ខុស និង និយាយបង្កាច់បង្ខូចសាសនាចក្រ ។ នៅក្នុងវិវរណៈបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ព្រះអម្ចាស់ បានចាប់ផ្ដើមបើកសម្ដែងលម្អិតអំពីទីកន្លែងប្រមូលផ្ដុំដែលបានកំណត់ទុក ជាកន្លែងដែលមានសេចក្ដីសុខសាន្ត និងសុវត្ថិភាព នៅក្នុងថ្ងៃចុងក្រោយ ដែលត្រូវបានសន្យានៅក្នុងព្រះគម្ពីរមរមន និងបានរៀបរាប់ប្រាប់ពីដំបូងនៅក្នុងវិវរណៈឆ្នាំ ១៨៣០ ( សូមមើល គ. និង ស. ២៨ ) ។ ព្រះអម្ចាស់បានពិពណ៌នាលម្អិតអំពីដែនដីនៃការប្រមូលផ្ដុំគ្នានេះ ដែលត្រូវបានស្គាល់ថា ជា ទីក្រុងយេរូសាឡិមថ្មី ឬ ស៊ីយ៉ូន ។ ព្រះអម្ចាស់ក៏បានណែនាំព្យាការី យ៉ូសែប ស្ម៊ីធ ឲ្យចាប់ផ្ដើមផ្ដោតយកចិត្តទុកដាក់ទៅលើកិច្ចខិតខំធ្វើការបកប្រែព្រះគម្ពីរសញ្ញាថ្មីរបស់លោក ដើម្បីត្រៀមខ្លួនពួកបរិសុទ្ធចំពោះអ្វីដែលនឹងកើតឡើង ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦០–៦១

*ព្រះអម្ចាស់ណែនាំព្យាការី យ៉ូសែប ស្ម៊ីធ ឲ្យចាប់ផ្ដើមការបកប្រែព្រះគម្ពីរសញ្ញាថ្មីរបស់លោក*

សូមសួរដល់សិស្ស បើសិនជាពួកគេណាម្នាក់អាចសូត្រមាត្រានៃសេចក្ដីជំនឿទីប្រាំបីបាន ។ បើពួកគេត្រូវការជំនួយ សូមឲ្យសិស្សម្នាក់ឲ្យបើកទៅមាត្រានៃសេចក្ដីជំនឿ ហើយអានខទីប្រាំបីឲ្យឮៗ ។

- តើឃ្លា « បើសិនជាបានបកប្រែត្រឹមត្រូវ » បានផ្ដល់ជាយោបល់អ្វីខ្លះដល់យើង អំពីព្រះគម្ពីរប៊ីប ?

សូមរំឭកដល់សិស្សថា យ៉ូសែប ចូលចិត្តការសិក្សាព្រះគម្ពីរប៊ីប ហើយបានរកឃើញនូវការលួងលោមចិត្តដ៏អស្ចារ្យពីព្រះបន្ទូលទាំងឡាយនៅក្នុង ព្រះគម្ពីរនោះ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលលោកបានសិក្សាវា លោកបានកត់សម្គាល់ឃើញមាននូវកំហុសជាច្រើន ហើយលោកមានអារម្មណ៍ថា ព័ត៌មានមួយចំនួនត្រូវបានបាត់ ឬមានពុំពេញលេញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយព្យាការី យ៉ូសែប ស្ម៊ីធ ស្ដីអំពីព្រះគម្ពីរប៊ីបឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវអ្វីដែលបានបណ្ដាលឲ្យមានបញ្ហាជាច្រើន ដែលយ៉ូសែប បានកត់សម្គាល់នោះ ៖



« វាបង្ហាញឲ្យឃើញថា មានចំណុចសំខាន់ៗជាច្រើន ដែលមានឥទ្ធិពលដល់សេចក្ដីសង្គ្រោះរបស់មនុស្ស ត្រូវបានដកចេញពីព្រះគម្ពីរបរិសុទ្ធ ឬ ត្រូវបានបាត់ មុនពេលវាត្រូវបានគេចងក្រង » ( *ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ឆ្នាំ ២០០៧ ]ទំព័រ ២១៧



លោកក៏បានមានប្រសាសន៍ផងដែរថា ៖ « ខ្ញុំជឿលើព្រះគម្ពីរប៊ីប បើសិនជាវាត្រូវបានសរសេរដោយដងប៉ាកានៃអ្នកនិពន្ធដើម ។ អ្នកបកប្រែដែលគ្មានវិជ្ជាជីវៈ អ្នកចម្លងខ្ជីខ្ជា ឬ ពួកសង្ឃដែលក្លែងបន្លំ និង ពុករលួយ បានបង្កើតឲ្យមានកំហុសជាច្រើន » ( *Teachings: Joseph Smith*, ទំព័រ ២០៧) ។

- ស្របតាម យ៉ូសែប ស្ម៊ីធ តើមូលហេតុ យ៉ាងហោចណាស់ចំនួនបី ដែលបណ្ដាលឲ្យព្រះគម្ពីរបរិសុទ្ធ មានកំហុសឆ្គង គឺអ្វីខ្លះ ?

សូមរំឭកសិស្សថា នៅក្នុងមេរៀន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៥៩ ពួកគេបានសិក្សានូវអ្វីដែលព្រះយេស៊ូវគ្រីស្ទ បានប្រាប់ដល់ពួកសិស្សរបស់ទ្រង់ អំពីការយាងមកជាលើកទីពីររបស់ទ្រង់ ។ វិវរណៈ បានរៀបរាប់នូវអ្វីៗជាច្រើន ដែលត្រូវបានកត់ត្រានៅក្នុង ម៉ាថាយ ២៤ ។ នៅពេលវិវរណៈនេះត្រូវបានសរសេរឡើងវិញនៅក្នុងឆ្នាំ ១៨៣១ នោះយ៉ូសែបស្ម៊ីធ កំពុងធ្វើការកែកំណែថ្មីដ៏បំផុសគំនិត ទៅលើព្រះគម្ពីរសញ្ញាចាស់ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦០–៦១ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់ចង់ឲ្យព្យាការីមានចំណាប់អារម្មណ៍ទៅលើនោះ ។

- តើព្រះអម្ចាស់បានមានបន្ទូលថា ការបកប្រែនៃព្រះគម្ពីរសញ្ញាថ្មី នឹងប្រទានពរដល់ពួកបរិសុទ្ធយ៉ាងដូចម្ដេច ? ( វានឹងបើកសម្ដែងច្រើនអំពីព្រះឆន្ទៈរបស់ព្រះ ដើម្បីរៀបចំពួកបរិសុទ្ធ ) ។

សូមឲ្យសិស្សម្នាក់សង្ខេបនូវព័ត៌មានដូចខាងក្រោមដល់សិស្សក្នុងថ្នាក់ ។ ( ដើម្បីទុកពេលឲ្យសិស្សបានរៀបចំខ្លួន សូមផ្ដល់ព័ត៌មានដល់គាត់ មុនចាប់ផ្ដើមថ្នាក់រៀន ) ។ អ្នកអាចនឹងចង់បំពេញព័ត៌មានលម្អិត ដែលសិស្សពុំបានផ្ដល់ព័ត៌មាន ។

នៅក្នុងរដូវស្លឹកឈើជ្រុះ ឆ្នាំ ១៨៣០ យ៉ូសែប ស្ម៊ីធ ត្រូវបានបញ្ជាដោយព្រះអម្ចាស់បកប្រែព្រះគម្ពីរប៊ីប ។ លោកពុំបានបកប្រែព្រះគម្ពីរប៊ីបចេញពីភាសាមួយទៅភាសាមួយទៀតនោះទេ ហើយលោកក៏ពុំមានឯកសារសរសេរដោយដៃនៃព្រះគម្ពីរប៊ីបដើមមកធ្វើការបកប្រែដែរ ។ ផ្ទុយទៅវិញ លោកបានអាន ហើយសិក្សាវគ្គបទគម្ពីរចេញមកពីកំណែថ្មីនៃព្រះគម្ពីរប៊ីបដោយស្ដេចជេមស៍ ហើយបានធ្វើកំណែ និងបន្ថែម ទៅតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ ដូច្នេះ ការបកប្រែកំណែថ្មីនោះគឺកាន់តែមានការបំផុសគំនិតខ្លាំងជាងការបកប្រែតាមទម្លាប់ ។

ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ត្រូវបានប៉ាន់ស្មានថា បានរងឥទ្ធិពលយ៉ាងហោចណាស់ចំនួន ៣៤០០ ខគម្ពីរ នៅក្នុងកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ ។ ភាពខុសគ្នាទាំងនេះ មានរួមទាំង ការបន្ថែម ( ដើម្បីបញ្ជាក់ពីអត្ថន័យ ឬបរិបទឲ្យច្បាស់ ) ការលុបចោល ការរៀបចំខគម្ពីរឡើងវិញ និងការរៀបចំរចនាសម្ព័ន្ធនៃជំពូកជាក់លាក់ឲ្យបានពេញលេញ ។ ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ បានបញ្ជាក់យ៉ាងច្បាស់អំពីមាតិកាខាងគោលលទ្ធិ ជាពិសេស បេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ និស្ស័យនៃព្រះលក្ខណៈធម្មជាតិរបស់មនុស្ស សេចក្ដីសញ្ញារបស់អ័ប្រាហាំ បព្វជិតភាព និងការស្ដារឡើងវិញនៃដំណឹងល្អ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយ បានកែសម្រួលកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ ដែលបានបោះពុម្ពបន្ទាប់ពីឆ្នាំ ១៩៧៩ រួមមានទាំងការផ្លាស់ប្ដូរច្រើនជាង ៦០០ កន្លែងមកពីការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ។ ការផ្លាស់ប្ដូរខ្លីៗ ត្រូវបានកត់ចំណាំនៅលេខយោង និងការជ្រើសរើសកាន់តែធំ គឺត្រូវបានរកឃើញនៅក្នុងសេចក្ដីបន្ថែមនៃព្រះគម្ពីរប៊ីប ។

សូមអញ្ជើញសិស្សឲ្យរកមើល យ៉ូសែប ស្ម៊ីធ–ម៉ាថាយ នៅក្នុងព្រះគម្ពីរមុក្ដាដ៏មានតម្លៃមហិមា ។ សូមពន្យល់ថា ចំណែកនៃការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ មាននូវព័ត៌មានច្រើនចេញមកពី ម៉ាថាយ ២៤ អំពីការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ហើយត្រូវបានបំពេញតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦០–៦១ ។

អ្នកអាចចង់សុំឲ្យសិស្សម្នាក់ដើម្បីថាឡើងវិញឲ្យឮៗនូវអ្វីដែលគាត់យល់អំពីការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ។ បើសិស្សរបស់អ្នកមានកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ របស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ នោះអ្នកអាចបង្ហាញដល់ពួកគេនូវគំរូនៃលេខយោងការបកប្រែរបស់យ៉ូសែប ស្ម៊ីធ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ឬជម្រើសដ៏ធំនៅក្នុងសេចក្ដីបន្ថែមនៃព្រះគម្ពីរប៊ីប ។ ឧទាហរណ៍ ម៉ាថាយ ៤:១ លេខយោង *ខ* ថ្លែងថា ព្រះយេស៊ូវបានយាង « ទៅគង់នៅជាមួយនឹងព្រះ » ជាជាង « ឲ្យត្រូវអារក្សល្បួង » ។ បន្ទាប់ពីបានបង្ហាញដល់សិស្សនូវឧទាហរណ៍មួយចំនួនរួចហើយ សូមសួរដល់ពួកគេអំពីរបៀបដែលការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ អាចបានជួយដល់ការសិក្សា និងការយល់ដឹងរបស់ពួកគេ អំពីព្រះគម្ពីរប៊ីប ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦២–៦៥

*ពួកបរិសុទ្ធត្រូវបានព្រមានទុកជាមុន ឲ្យទៅជួបជុំគ្នានៅភូមិភាគខាងលិចនៃប្រទេស*

សូមពន្យល់ថា ព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធផ្លាស់ទៅភូមិភាគខាងលិច« ពីដែនដីខាងកើត » ( គ. និង ស. ៤៥:៦៤ ) ។ ដើម្បីជួយសិស្សមើលឃើញនឹងភ្នែកអំពីការផ្លាស់លំនៅឆ្ពោះទៅកាន់ទិសខាងលិច របស់ពួកសមាជិកនៃសាសនាចក្រនៅគ្រាដែលវិវរណៈនេះ ត្រូវបានផ្ដល់ឲ្យ (ចេញពីរដ្ឋ នូវ យ៉ោក ទៅរដ្ឋ អូហៃអូ ) អ្នកអាចនឹងសុំឲ្យពួកគេបើកទៅទំព័រ ផែនទី ៣ (« រដ្ឋនូវយ៉ោក ផែនស៊ីលវេញ៉ា និងតំបន់អូហៃអូនៃសហរដ្ឋអាមេរិក ») នៅក្នុងផ្នែកនៃផែនទីប្រវត្តិសាស្ត្រសាសនាចក្រក្នុងព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦២–៦៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីមូលហេតុដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធប្រមូលគ្នីគ្នាឆ្ពោះទៅ « ភាគខាងលិចនៃប្រទេស » (គ. និង ស. ៤៥:៦៤) ។

- តើព្រះអម្ចាស់មានព្រះបន្ទូលអំពីអ្វី « នៅមាត់ទ្វារ » ? តើអ្នកគិតថា រូបភាពនេះមានន័យដូចម្ដេចដែរ ?

សូមពន្យល់ថា នៅក្នុងឆ្នាំ ១៨៦១ ជិតរយៈពេល ១៧ ឆ្នាំ បន្ទាប់ពីការស្លាប់របស់ យ៉ូសែប ស្ម៊ីធ នោះសង្គ្រាមស៊ីវិលមួយបានចាប់ផ្ដើមកើតមានឡើងនៅក្នុងសហរដ្ឋអាមេរិក ។ វាត្រូវបានធ្វើការប៉ាន់ស្មានថា សង្គ្រាមនេះបានបណ្ដាលឲ្យប្រជាជនជាង ១ លាននាក់ រងរបួស និងស្លាប់ ហើយទ្រព្យសម្បត្តិជាច្រើនក៏ត្រូវបានបំផ្លិចបំផ្លាញផងដែរ ដែលធ្វើឲ្យក្រុមគ្រួសាររងទុក្ខលំបាក និងសហគមន៍ជាច្រើននៅទូទាំងប្រទេស ។ ពួកបរិសុទ្ធទាំងឡាយដែលបានបន្តធ្វើតាមដំបូន្មានរបស់ព្រះអម្ចាស់ ឲ្យប្រមូលផ្ដុំគ្នាចេញពីភាគខាងកើត ត្រូវបានប្រទានពរដោយមានសេចក្ដីសុខសាន្ត និងសុវត្ថិភាពជាមួយសាច់ញាតិនៅក្នុងរដ្ឋយូថាហ៍ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់ចង់ឲ្យពួកបរិសុទ្ធធ្វើ នៅពេលពួកគេប្រជុំគ្នានៅភាគខាងលិចនៃប្រទេស ។

*បទបង្ហាញអំពីសម្ភាររបស់គ្រូបង្រៀន*

ខណៈដែលសិស្សចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការរៀនសូត្រ នោះគឺជាការចាំបាច់ណាស់ដែលពួកគេត្រូវយល់ និង អនុវត្តខគម្ពីរទាំងឡាយ ប៉ុន្តែវាពុំបានជំនួសឲ្យតម្រូវការ ដែល គ្រូបង្រៀនត្រូវប្រាប់អំពីព័ត៌មានក្នុងពេលផ្សេងៗគ្នា ខណៈដែល សិស្សស្ដាប់នោះឡើយ ។ ការធ្វើបទបង្ហាញរបស់គ្រូបង្រៀនដោយសង្ខេបខ្លីៗ អាចនឹងមានប្រសិទ្ធភាពខណៈដែលយើងត្រូវការសង្ខេបឯកសារក្នុងមេរៀនដែលមាននូវដំណើររឿងដ៏វែង ដើម្បីបង្ហាញព័ត៌មានដែលថ្មីសម្រាប់សិស្ស ធ្វើការផ្លាស់ប្ដូរនៅក្នុងមេរៀន ឬឈានទៅដល់ការធ្វើការសន្និដ្ឋាន ។

- ហេតុអ្វីពួកគេត្រូវប្រមូលនូវទ្រព្យសម្បត្តិរបស់ពួកគេ ? ( ដើម្បីទិញដីដែលពួកបរិសុទ្ធអាចរស់នៅក្នុងសាមគ្គីភាព សេចក្ដីសុខសាន្ត និងសុវត្ថិភាព ) ។ សូមពន្យល់ថា *មរតក* សំដៅទៅលើទឹកដីដែលពួកបរិសុទ្ធ អាចរស់នៅ ហើយថ្វាយបង្គំដល់ព្រះអម្ចាស់ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៦–៧៥

*ព្រះអម្ចាស់ពិពណ៌នាអំពីទីក្រុង យេរូសាឡិមថ្មី ឬទីក្រុង ស៊ីយ៉ូន*

សូមឲ្យសិស្សគិតពិចារណាអំពីសំណួរខាងក្រោម ៖

- បើអ្នកអាចជ្រើសរើសកន្លែងណាមួយក្នុងពិភពលោកដើម្បីរស់នៅ តើអ្នកនឹងរើសយកកន្លែងណា ? ហេតុអ្វីអ្នកចង់រស់នៅទីនោះ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លើយនឹងសំណួរ ។ នៅពេលពួកគេឆ្លើយ សូមគូសបន្ទាត់មួយនៅពាក់កណ្ដាលក្ដារខៀន បង្កើតជាពីរកូឡោន ។ នៅផ្នែកខាងលើនៃកូឡោនមួយ សូមសរសេរឈ្មោះទីតាំងមួយចំនួនដែលសិស្សបានប្រាប់ ។ នៅក្នុងកូឡោនដដែលនោះ សូមសរសេរនូវមូលហេតុដែលពួកគេចង់រស់នៅក្នុងទីតាំងទាំងនោះនៅក្រោមឈ្មោះទីតាំងទាំងនោះ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៦–៦៧ ដោយស្ងាត់ស្ងៀម រកមើលឈ្មោះនៃដែនដីកេរអាករ និង មូលហេតុនានារបស់ពួកបរិសុទ្ធ ដែលជាដែនដីដែលគួរឲ្យចង់រស់នៅ ។ អ្នកអាចផ្ដល់យោបល់ថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើដែនដីកេរអាកររបស់ពួកបរិសុទ្ធត្រូវបានហៅថាអ្វី ? ( ទីក្រុងយេរូសាឡិមថ្មី ឬទីក្រុងស៊ីយ៉ូន ។ សូមសរសេរនៅផ្នែកខាងលើនៃកូឡោនទីពីរនៅលើក្ដារខៀន ) ។

សូមពន្យល់ថា នៅក្នុងព្រះគម្ពីរ ពាក្យ *ស៊ីយ៉ូន* ពេលខ្លះ ត្រូវបានប្រើជាន័យផ្សេងៗពីគ្នាបន្តិច ។ ពេលខ្លះ ពាក្យនោះសំដៅទៅលើប្រជាជននៃស៊ីយ៉ូន ហើយពិពណ៌នាវាថាជា « ចិត្តល្អសុទ្ធសាធ » (គ. និង ស. ៩៧:២១) ។ កន្លែងផ្សេងទៀត ពាក្យ *ស៊ីយ៉ូន* សំដៅទៅលើសាសនាចក្រទាំងមូល និងស្តេកទាំងអស់នៅទូទាំងពិភពលោក ( សូមមើល គ. និង ស. ៨២:១៤) ។ ពាក្យ *ស៊ីយ៉ូន* ក៏អាចសំដៅទៅលើទីតាំងភូមិសាស្ត្រជាក់លាក់ផងដែរ ។ នៅក្នុងវិវរណៈនេះ ពាក្យ *ស៊ីយ៉ូន* សំដៅទៅលើទីក្រុងខាងសាច់ឈាមមួយ ដែលពួកបរិសុទ្ធនឹងស្ថាបនាឡើង ហើយប្រមូលផ្ដុំគ្នា ។

- តើព្រះអម្ចាស់បានពិពណ៌នាអំពីទីក្រុង យេរូសាឡិមថ្មី ( ទីក្រុង ស៊ីយ៉ូន ) យ៉ាងដូចម្ដេច ? ( សូមសរសេរចម្លើយរបស់សិស្សនៅក្នុងកូឡោនទីពីរ នៅលើក្ដារខៀន ) ។ ពួកគេអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ទីក្រុងយេរូសាឡិមថ្មី នឹងជាកន្លែងនៃសេចក្ដីសុខសាន្ត និងសុវត្ថិភាព ហើយសិរីល្អរបស់ព្រះអម្ចាស់ នឹងគង់នៅទីនោះ**) ។

សូមអញ្ជើញសិស្សឲ្យប្រៀបធៀបទីតាំងដែលពួកគេបានជ្រើសរើសសម្រាប់គេហដ្ឋានអនាគតដ៏ល្អរបស់ពួកគេទៅតាមការពិពណ៌នាអំពីទីក្រុងស៊ីយ៉ូននោះ ។

- ផ្អែកទៅលើការពិពណ៌នារបស់ព្រះអម្ចាស់អំពីទីក្រុងស៊ីយ៉ូន ហេតុអ្វីក៏អ្នកចង់មានចំណែកនៅក្នុងទីក្រុងនេះ ?

- តើអ្នកធ្លាប់បានទទួលបទពិសោធន៍នៃសេចក្ដីសុខសាន្ត និងសុវត្ថិភាពនៅកន្លែងណា ? ហេតុអ្វីក៏វាសំខាន់ដើម្បីមានកន្លែងជាច្រើន ដែលអ្នកអាចមានសុវត្ថិភាព និងសេចក្ដីសុខសាន្តនោះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៨–៧១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុបន្ថែម ដែលពួកគេអាចនឹងចង់រស់នៅក្នុងទីក្រុងយេរូសាឡិមថ្មី ។ អ្នកអាចផ្ដល់យោបល់ឲ្យសិស្សថា ពួកគេគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ សូមឲ្យពួកគេរៀបរាប់អំពីអ្វីដែលពួកគេបានរកឃើញ ហើយបន្ថែមចម្លើយរបស់ពួកគេចូលទៅក្នុងកូឡោនទីពីរនៅលើក្ដារខៀន ។

- តើពួកទុច្ចរិតនឹងមានអារម្មណ៍យ៉ាងណាអំពីទីក្រុងស៊ីយ៉ូន ?
- ស្របតាម ខ ៧១ តើមនុស្សសុចរិតនៃទីក្រុងស៊ីយ៉ូននឹងចេញមកពីកន្លែងណា ? ( បើវាពុំទាន់បានពិពណ៌នាទេ សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅក្នុងកូឡោនទីពីរនៅលើក្ដារខៀន ៖ **មនុស្សសុចរិតមកពីគ្រប់ជាតិសាសន៍នឹងប្រមូលផ្ដុំគ្នាទៅកាន់ស៊ីយ៉ូន ។** អ្នកអាចនឹងចង់ពន្យល់ថា នេះគឺជាការពិតចំពោះទីក្រុងស៊ីយ៉ូន ដែលបានសំដៅទៅលើ នៅក្នុងវិវរណៈនេះ ហើយគឺជាការពិតចំពោះស្តេកនៃស៊ីយ៉ូន ដែលត្រូវបានស្ថាបនាឡើងនៅទូទាំងពិភពលោកសព្វថ្ងៃនេះ ) ។

សូមអាននូវសេចក្ដីថ្លែងការដូចខាងក្រោម ដោយព្យាការី យ៉ូសែប ស្ម៊ីធ អំពីប្រធានបទនៃស៊ីយ៉ូន ៖



« ស៊ីយ៉ូន . . . គឺជាកន្លែងរបស់ពួកសុចរិត ហើយមនុស្សទាំងអស់ ដែលស្ថាបនានៅលើនោះ គឺត្រូវថ្វាយបង្គំដល់ព្រះពិត និងមានព្រះជន្មរស់ ហើយជាអស់អ្នកដែលជឿទៅលើគោលលទ្ធិមួយ ជាគោលលទ្ធិនៃព្រះអម្ចាស់របស់យើង និងព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ » ( នៅក្នុង *History of the Church* ២:២៥៤ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៧២–៧៣ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធកុំឲ្យធ្វើ ។ បន្ទាប់មក សូមសង្ខេបខគម្ពីរពីរចុងក្រោយនៃវិវរណៈនេះ ដោយពន្យល់ថា ព្រះអម្ចាស់រំឭកពួកបរិសុទ្ធថា ការយាងមកជាលើកទីពីរនឹងធ្វើឲ្យពួកមារសត្រូវរបស់ពួកគេជួបនូវបញ្ហាធំ ។

អ្នកអាចនឹងរំឭកដល់សិស្សថា ព្រះអម្ចាស់បានជម្រុញឲ្យពួកបរិសុទ្ធជំនាន់មុន និងពួកយើងឲ្យ « ប្រុងស្ដាប់ » តាមសំឡេងរបស់ទ្រង់នៅក្នុងវិវរណៈនេះ ។ សូមអញ្ជើញសិស្សឲ្យមើលត្រឡប់ទៅក្រោយវិញ ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ហើយរំឭកនូវអ្វីដែលព្រះអម្ចាស់ បានបើកសម្ដែងដល់ពួកបរិសុទ្ធ អំពីការយាងមកជាលើកទីពីររបស់ទ្រង់ និងទីក្រុងយេរូសាឡិមថ្មី ។ អ្នកអាចនឹងលើកទឹកចិត្តពួកគេឲ្យបំពេញសេចក្ដីថ្លែងការណ៍ដូចខាងក្រោមនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេថា ៖ « ដោយសារតែអ្វីដែលយើងរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ខ្ញុំនឹងរៀបចំខ្លួនចំពោះរឿងទាំងឡាយដែលនឹងកើតមាន ដោយ . . . » សូមបញ្ចប់ដោយការលើកទឹកចិត្តដល់សិស្សឲ្យពិភាក្សានូវអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនសព្វថ្ងៃនេះ ជាមួយនឹងសមាជិកគ្រួសារ ។

មេរៀនទី ៥៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦

## បុព្វកថា

នៅខែមិនា ឆ្នាំ ១៨៣១ ជិតរយៈពេលមួយឆ្នាំ បន្ទាប់ពីការរៀបចំសាសនាចក្រឡើង នោះព្រះអម្ចាស់បានពិគ្រោះពួកបរិសុទ្ធថា ការប្រជុំក្នុងសាសនាចក្រ គឺត្រូវដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ។ នៅក្នុងវិវរណៈដដែលនេះ ទ្រង់បានគូសបញ្ជាក់ថា មនុស្សដែលមិនមែនជាសមាជិកនៃសាសនាចក្រ ពុំត្រូវបណ្ដេញចេញពីការប្រជុំជាសាធារណៈនោះឡើយ ។ បន្ថែមពីលើការកែតម្រូវចំពោះការអនុវត្តដែលពុំរាប់បញ្ចូលនូវអ្នកឥតជឿនៅក្នុងការប្រជុំ នោះព្រះអម្ចាស់បានបង្រៀនអំពីអំណោយទាននៃព្រះវិញ្ញាណ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:១–៦

*ព្រះអម្ចាស់ បង្រៀនដល់ពួកបរិសុទ្ធអំពីការប្រជុំក្នុងសាសនាចក្ររបស់ពួកគេ*

សូមឲ្យសិស្សនឹកស្រម៉ៃថា ពួកគេកំពុងដឹកនាំផែនការនៃការប្រជុំសាក្រាម៉ង់ ។

- តើអ្នកដឹងថា អ្នកត្រូវរាប់បញ្ចូលអ្វីខ្លះនៅក្នុងការប្រជុំតាមរបៀបណា ? តើអ្នកនឹងជ្រើសរើសតន្ត្រី ហើយសម្រេចចិត្តថានរណានឹងឡើងនិយាយដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការណែនាំដែលព្រះអម្ចាស់បានប្រទានឲ្យ អំពីរបៀបដែលការប្រជុំសាសនាចក្រគួរត្រូវបានដឹកនាំ ។ អ្នកអាចនឹងចង់ចង្អុលបង្ហាញថា ទំនួលខុសត្រូវដើម្បីដឹកនាំការប្រជុំ រួមមានទាំងទំនួលខុសត្រូវក្នុងការរៀបចំសម្រាប់ការប្រជុំទាំងនោះផងដែរ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ចម្លើយរបស់ពួកគេអាចនឹងមានផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖**អ្នកដឹកនាំសាសនាចក្រ គឺត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ នៅពេលពួកគាត់ដឹកនាំការប្រជុំ ។**

- តើនៅពេលណា ដែលអ្នកមានអារម្មណ៍ដឹងថា ពួកអ្នកដឹកនាំត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការប្រជុំមួយនោះ ?

- តើសមាជិកសាសនាចក្រអាចអញ្ជើញឲ្យមានឥទ្ធិពលពីព្រះវិញ្ញាណនៅក្នុងការប្រជុំសាសនាចក្រដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅ កំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីរបៀបមួយ ដែលពួកគេនឹងកែលម្អនូវការចូលរួមរបស់ពួកគេនៅក្នុងការប្រជុំសាសនាចក្រទាំងឡាយ ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន *សូមស្វាគមន៍ភ្ញៀវទេសចរ* ។ សូមឲ្យសិស្សប្រាប់ពីទីកន្លែងដែលពួកគេធ្លាប់បានឃើញឃ្លានេះបានដាក់នៅកន្លែងណាមួយ ។ សូមសួរពួកគេបើសិនជាពួកគេធ្លាប់ឃើញវានៅខាងក្រៅសាលាប្រជុំសាសនាចក្រ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាននូវការណែនាំ នៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមនៅក្នុងព្រះគម្ពីររបស់ពួកគេ ហើយរកមើលថាពួកបរិសុទ្ធជំនាន់មុនរូបណា ដែលបានអនុញ្ញាតឲ្យចូលរួមក្នុងការប្រជុំរបស់ពួកគេ ។ សូមអញ្ជើញពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ បន្ទាប់មកសូមឲ្យពួកគេអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៣–៦ ដោយស្ងាត់ស្ងៀម រកមើលឃ្លាដែលបានកែតម្រូវចំពោះការអនុវត្តកាលពីដើមនេះ ។

- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរទាំងនេះ អំពីរបៀបដែលព្រះអម្ចាស់ចង់ឲ្យយើងប្រព្រឹត្តចំពោះអ្នកដទៃ ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់ បានបញ្ជាឲ្យយើងស្វាគមន៍មនុស្សទាំងអស់ចូលរួមក្នុងការប្រជុំជាសាធារណៈរបស់យើង** ) ។

- តើយើងអាចជួយអ្នកដទៃឲ្យដឹងថា ពួកគេបានទទួលស្វាគមន៍ក្នុងការចូលមកកាន់ការប្រជុំសាសនាចក្ររបស់យើងយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់កាន់តែជ្រៅជ្រះអំពីសេចក្ដីពិតនេះ សូមចែកចាយនូវឧទាហរណ៍ដូចខាងក្រោម ៖

សមាជិកវ័យក្មេងម្នាក់ក្នុងសាសនាចក្រ បានទៅទស្សនាវួដថ្មីមួយជាមួយនឹងគ្រួសាររបស់នាងជាលើកដំបូង ។ បន្ទាប់ពីចប់ម៉ោងសាក្រាម៉ង់ មានសមាជិកក្នុងវួដម្នាក់បានមកស្វាគមន៍គ្រួសារនោះ ហើយបង្ហាញពួកគេពីកន្លែងដែលត្រូវទៅសាលាថ្ងៃអាទិត្យ ។ គាត់បាននាំយុវនារីទៅកាន់ថ្នាក់រៀន ហើយណែនាំនាងដល់គ្រូបង្រៀន ។ យុវជន និង យុវនារី ក្នុងថ្នាក់បានជួបនឹងពួកគេបន្តិច បន្ទាប់មកម្នាក់ៗ សួរសុខទុក្ខគ្នាគេ ដោយពុំខ្វល់ពីនាង ។

- តើស្ថានភាពនេះខុសគ្នាយ៉ាងដូចម្ដេច បើសមាជិកក្នុងថ្នាក់សាលាថ្ងៃអាទិត្យ ធ្វើតាមគោលការណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៣–៦ ?

សូមលើកទឹកចិត្តសិស្សឲ្យស្វាគមន៍ដល់អ្នកទាំងឡាយដែលមកចូលរួមក្នុងការប្រជុំសាសនាចក្រ ក្នុងថ្នាក់រៀន ឬក្នុងសកម្មភាពនានា ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៧–៣៣

*ព្រះអម្ចាស់បានពន្យល់អំពីគោលបំណងចំពោះអំណោយទាននៃព្រះវិញ្ញាណ*

សូមរំឭកដល់សិស្សថា នៅ ខែ កុម្ភៈ ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ បានចូលរួមនឹងពួកបរិសុទ្ធ នៅទីក្រុងខឺតឡង់ ( សូមមើល មេរៀនទី ៥០ នៅក្នុងសៀវភៅសិក្សានេះ ) ។ នៅពេលលោកមកដល់ លោកបានឃើញថាសមាជិកសាសនាចក្រទាំងនេះ បានទទួលយកនូវការអនុវត្តខុសឆ្គងមួយចំនួន ។ ការអនុវត្តខុសឆ្គងមួយ គឺពុំរាប់បញ្ចូលមនុស្សផ្សេងមកក្នុងការប្រជុំសាសនាចក្រដូចបានពន្យល់ពីដំបូងនៅក្នុងមេរៀននេះ ។ ការអនុវត្តខុសឆ្គងមួយទៀត គឺថា សមាជិកមួយចំនួន បានមានឥរិយាបទចម្លែកៗ ពេលពួកគេចូលរួមក្នុងការប្រជុំសាសនាចក្រ ។ ពួកគេបានប្រកាសថា ទង្វើរបស់ពួកគេគឺត្រូវបានបំផុសគំនិតដោយព្រះវិញ្ញាណបរិសុទ្ធ ។ សមាជិកមួយចំនួនជឿលើពួកគេ ហើយអ្នកផ្សេងទៀតមានអារម្មណ៍ថា ឥរិយាបទបែបនោះគឺពុំមែនមកពីព្រះទេ ។ នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ ព្រះអម្ចាស់បានបង្រៀនគោលការណ៍ទាំងឡាយ ដែលនឹងជួយពួកបរិសុទ្ធឲ្យចៀសវាងពីការបោកបញ្ឆោត ហើយដែលនឹងជួយពួកគេឲ្យយល់អំពីអំណោយទាននៃព្រះវិញ្ញាណដ៏ពិត ។

- តើការត្រូវបានបញ្ឆោតមានន័យដូចម្ដេច ? ( នាំឲ្យយល់ខុស ឬប្រើឧបាយកលឲ្យជឿលើអ្វីមួយដែលពុំពិត ) ។ តើអ្នកអាចប្រាប់អំពីគ្រាមួយ ដែលអ្នកត្រូវបានគេបោកបញ្ឆោតបានឬទេ ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៧–៨ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះអម្ចាស់បានទូន្មានដល់រាស្ត្ររបស់ទ្រង់ឲ្យធ្វើដូច្នោះ ដើម្បីពួកគេអាចចៀសវាងពីការត្រូវបានគេបោកបញ្ឆោត ។ អ្នកអាចផ្ដល់យោបល់ថា សិស្សគួរគូសចំណាំនូវអ្វីដែលពួកគេរកឃើញ ។

- តើខទាំងនេះបង្រៀនអ្វីខ្លះ អំពីរបៀបដើម្បីចៀសវាងពីការត្រូវគេបោកបញ្ឆោត ? ( សូមជួយដល់សិស្សឲ្យប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **វិធីមួយដើម្បីចៀសវាងពីការត្រូវគេបោកបញ្ឆោត គឺត្រូវធ្វើតាមការដឹកនាំមកពីព្រះវិញ្ញាណនៅក្នុងគ្រប់ភាពបរិសុទ្ធ** ) ។

- ស្របតាម ខ ៨ តើយើងគួរព្យាយាមស្វែងរកអ្វីខ្លះ ? ( អំណោយទានដ៏ល្អបំផុត ) ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងព្យាយាមស្វែងរកអំណោយទាននានាដែលវិសេសបំផុត. . .*

នៅពេលសិស្សចូលរួមក្នុងសកម្មភាពដូចខាងក្រោម សូមអញ្ជើញពួកគេឲ្យរកមើលពរជ័យដែលនឹងកើតមាន នៅពេលពួកគេស្វែងរកអំណោយទាននៃព្រះវិញ្ញាណ ។ អ្នកអាចនឹងចង់ពន្យល់ថា អំណោយទាននៃព្រះវិញ្ញាណ គឺជា « ពរជ័យ ឬលទ្ធភាពដែលត្រូវបានប្រទានឲ្យដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះប្រទានឲ្យនូវអំណោយទានយ៉ាងហោចណាស់មួយទៅដល់សមាជិកស្មោះត្រង់នៃសាសនាចក្រ » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ១៦៥) ។

*ការរៀបចំពីមុនថ្នាក់រៀន*

នៅពេលអ្នកប្រើកម្មវិធីសិក្សាដើម្បីរៀបចំមេរៀន សូមមើលត្រួសៗនូវយោបល់សម្រាប់ការបង្រៀន ហើយប្រាប់ពីសម្ភារ និងសកម្មភាពណាដែលអ្នកត្រូវការដើម្បីរៀបចំ ឬត្រៀម ពីមុនថ្នាក់រៀនចាប់ផ្ដើម ។ នៅពេលអ្នកបានត្រៀមពីមុនថ្នាក់រៀន នោះអ្នកនឹងអាចគ្រប់គ្រងពេលវេលានៅក្នុងថ្នាក់រៀនបានកាន់តែល្អ ហើយជួយសិស្សឲ្យផ្ដោតទៅលើអ្វីដែលពួកគេកំពុងរៀនក្នុងព្រះគម្ពីរ ។

ពីមុនថ្នាក់រៀន សូមសរសេរលេខ ១៣ ទៅដល់ ២៥ និង ២៧ ហើយពង្រាយ នៅលើសន្លឹកក្រដាស ។ បន្ទាប់មកកាត់ក្រដាសជាចំណែកៗធ្វើជាក្រដាសផ្គុំចំនួនដប់បួន ដែលមានលេខសម្គាល់មួយនៅលើក្រដាសផ្គុំនីមួយៗ ។

ចែកក្រដាសផ្គុំនីមួយៗឲ្យទៅដល់សិស្ស ។ អាស្រ័យទៅលើចំនួនសិស្ស អ្នកអាចនឹងចាំបាច់ត្រូវឲ្យក្រដាសផ្គុំមួយ ទៅដល់ក្រុមតូចមួយ ឬឲ្យច្រើនទៅដល់សិស្សម្នាក់ៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យធ្វើការជាមួយគ្នាដើម្បីផ្គុំក្រដាសនោះ ។

- នៅក្នុងរូបផ្គុំមួយ ហេតុអ្វីក៏ចំរៀករូបផ្គុំនិមួយៗសំខាន់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៨–១២, ២៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលបំណងនៃអំណោយទានដែលព្រះប្រទានឲ្យយើង ។

- តើអំណោយទានខាងវិញ្ញាណ ត្រូវបានប្រើសម្រាប់អ្វី ? ( « សម្រាប់ជាប្រយោជន៍ដល់កូនចៅរបស់ព្រះ » ) ។
- ស្របតាម ខ ៩ តើអំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានឲ្យដល់នរណា ? ( ដល់អ្នកទាំងឡាយដែលស្រឡាញ់ព្រះ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ និងដល់អ្នកទាំងឡាយដែល « ព្យាយាមធ្វើដូច្នោះ » ) ។
- ស្របតាម ខ ១១ តើមានគ្នាយើងប៉ុន្មាននាក់ ដែលត្រូវបានប្រទានឲ្យនូវអំណោយទាននៃព្រះវិញ្ញាណ ?
- ចេញមកពីអ្វីដែលអ្នកបានរៀននៅក្នុងខទាំងនេះ តើអ្នកនឹងបំពេញបញ្ចប់ឃ្លានៅលើក្ដារខៀនយ៉ាងដូចម្ដេច ? ( ទោះជាយ៉ាងណា សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា តែចម្លើយរបស់ពួកគេគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងព្យាយាមស្វែងរកអំណោយទាននានាដែលវិសេសបំផុត នោះព្រះនឹងប្រទានវាមកយើងសម្រាប់ជាប្រយោជន៍ដល់អ្នកដទៃ** ។ អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំឃ្លានៅក្នុងគម្ពីររបស់ពួកគេ ដែលបង្រៀនពីសេចក្ដីពិតនេះ ) ។

សូមនាំចំណាប់អារម្មណ៍របស់សិស្សផ្ដោតទៅលើក្រដាសផ្គុំ ដែលពួកគេបានផ្គុំនោះ ។ សូមរំឭកពួកគេអំពីសារៈសំខាន់នៃចំណែកក្នុងរូបផ្គុំនោះ ។

- ហេតុអ្វីក៏សមាជិកគ្រប់រូបសំខាន់នៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ? ( មនុស្សគ្រប់រូប មានអំណោយទានមួយដែលអាចជាប្រយោជន៍ដល់អ្នកដទៃ ) ។

សូមបំបែករូបផ្គុំចេញពីគ្នា ហើយផ្ដល់ចំណែកនោះត្រឡប់ទៅឲ្យសិស្សវិញ ។ សូមពន្យល់ថា លេខសម្គាល់នៅលើចំណែកក្រដាសនោះ សំដៅទៅលើខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ ហើយថាខទាំងនេះនិមួយៗ មាននូវអំណោយទាននៃព្រះវិញ្ញាណមួយ ។ សូមអញ្ជើញសិស្សឲ្យអានឮៗនូវខ ដែលឆ្លើយឆ្លងទៅនឹងលេខដែលពួកគេត្រូវបានផ្ដល់ឲ្យនោះ ។

បន្ទាប់ពីអានខនិមួយៗហើយ សូមឲ្យសិស្សផ្ដល់យោបល់អំពីស្ថានភាពមួយ ដែលអំណោយទាននោះអាចផ្ដល់ជាប្រយោជន៍ដល់កូនចៅរបស់ព្រះ ។ សិស្សអាចនឹងមានការលំបាកយល់អំពីអំណោយទានមួយចំនួន ។ ការពន្យល់អំពីអំណោយទានមួយចំនួនដូចខាងក្រោម អាចជួយអ្នកដល់ការដឹកនាំក្នុងការពិភាក្សារបស់ពួកគេ ៖

អំណោយទានដើម្បីដឹងពីភាពខុសគ្នានៃការគ្រប់គ្រង គឺជាញឹកញាប់បង្ហាញឲ្យឃើញមាននៅក្នុងខ្លួនអ្នកដឹកនាំ ដែលបានដឹងអំពីរបៀបដែលអំណោយទានរបស់អ្នកដទៃ អាចនឹងជាប្រយោជន៍នៅក្នុងតំណែងនៃការធ្វើការបម្រើផ្សេងៗ ។

អំណោយទានដើម្បីដឹងពីភាពផ្សេងគ្នានៃប្រតិបត្តិការ គឺមានបង្ហាញនៅក្នុងសមត្ថភាពរបស់មនុស្សម្នាក់ ដើម្បីមើលឃើញពីភាពខុសគ្នារវាងអំណោយទានពិតប្រាកដ ឬជាការធ្វើការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងដឹងរវាងវិញ្ញាណខុសឆ្គង គោលលទ្ធិ ឬបទបញ្ញត្តិទាំងឡាយ ។

អំណោយទាននៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ពុំសំដៅទៅលើបទបញ្ញត្តិដែលត្រូវបានស្គាល់ថាជាពាក្យសម្ដីនៃប្រាជ្ញាវាងវៃទេ ។ តែវាសំដៅទៅលើពរជ័យនៃប្រាជ្ញា ដែលកើតមានចំពោះអ្នកទាំងឡាយដែល « សូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា » ( យ៉ាកុប ១:៥ ) ។

អំណោយទាននៃការញែកដឹងខាងវិញ្ញាណ អនុញ្ញាតឲ្យមនុស្សម្នាក់ស្គាល់ ឬយល់អំពីបំណងពិត និងការលើកទឹកចិត្តដែលកប់លាក់ទុករបស់អ្នកដទៃ ។ អំណោយទាននេះ ជួយមនុស្សម្នាក់ឲ្យឃើញពីសេចក្ដីអាក្រក់ដែលកប់លាក់ទុក ហើយឲ្យមើលឃើញពីសេចក្ដីល្អនៅក្នុងខ្លួនអ្នកដទៃ ។

អំណោយទានខាងភាសា និងអំណោយទាននៃការបកប្រែភាសា គឺជាទូទៅបង្ហាញឲ្យឃើញមាននៅក្នុងខ្លួនអ្នកផ្សព្វផ្សាយសាសនា ដែលអាចរៀន ហើយយល់ភាសាបានយ៉ាងឆាប់ ។ អំណោយទានទាំងនេះ ក៏អាចត្រូវបានរីករាយដោយមនុស្សដែលត្រូវការយកឈ្នះលើឧបសគ្គខាងភាសា ដើម្បីរៀន និងបង្រៀនដំណឹងល្អផងដែរ ។

- ហេតុអ្វីក៏យើងត្រូវស្វែងរកអំណោយទានខាងវិញ្ញាណ ? តើអ្នកគិតថា យើងអាចធ្វើអ្វីខ្លះដើម្បីស្វែងរកវាបាន ? ( វាអាចនឹងជាប្រយោជន៍ដើម្បីចង្អុលបង្ហាញថា ព្រះអម្ចាស់ អាចបើកសម្ដែងអំណោយទានខាងវិញ្ញាណតាមរយៈពរជ័យអយ្យកោ ឬការប្រសិទ្ធពរបព្វជិតភាពផ្សេង ៗទៀត ។
- តើអ្នកធ្លាប់បានឃើញនរណាម្នាក់ទទួលអំណោយទានខាងវិញ្ញាណមួយ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ នៅពេលណា ?

សូមឲ្យសិស្សស្វែងរកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៣០–៣៣ ដោយខ្លួនឯងហើយប្រាប់នូវចំនុចបួនយ៉ាង ដែលយើងត្រូវធ្វើ នៅពេលយើងប្រើអំណោយទានខាងវិញ្ញាណ របស់យើង ។ ( ចម្លើយអាចនឹងមានដូចជា យើងគួរតែសូមដើម្បីស្គាល់ពីព្រះហឫទ័យរបស់ព្រះ ធ្វើកិច្ចការនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ថ្លែងអំណរគុណចំពោះពរជ័យទាំងឡាយដែលយើងទទួល ហើយអនុវត្តគុណធម៌ និងភាពបរិសុទ្ធ ) ។

សូមបង្ហាញនូវការដឹងគុណចំពោះអំណោយទាននានាខាងវិញ្ញាណ និងដឹងគុណចំពោះឥទ្ធិពលនៃអំណោយទានទាំងនោះនៅក្នុងជីវិតរបស់អ្នក ។ សូមផ្ដល់ឱកាសដល់សិស្សឲ្យធ្វើដូចគ្នា ។ សូមថ្លែងទីបន្ទាល់អំពីបំណងប្រាថ្នារបស់ព្រះអម្ចាស់ចង់ឲ្យមនុស្សទាំងអស់ដឹងថា ពួកគេត្រូវបានស្វាគមន៍ និងសំខាន់ នៅក្នុងសាសនាចក្ររបស់ទ្រង់ ។

មេរៀនទី ៥៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨

## បុព្វកថា

នៅក្នុងខែ មីនា ឆ្នាំ ១៨៣១ ជិតរយៈពេលមួយឆ្នាំ បន្ទាប់ពីការរៀបចំសាសនាចក្រឡើង នោះព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលឥឡូវត្រូវបានកត់ត្រានៅជា កណ្ឌ ៤៧ និង ៤៨ នៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ ពីមុនគ្រានេះ អូលីវើរ ខៅឌើរី ត្រូវបានដើរតួជាអ្នកប្រវត្តិសាស្ត្រ និងជាអ្នកកត់កំណត់ត្រាសម្រាប់សាសនាចក្រ ។ នៅក្នុងតួនាទីនេះ លោកបានរក្សាកំណត់ត្រាមួយអំពី វិវរណៈនានា ដែលព្យាការីបានទទួល ។ ទោះជាយ៉ាងណាក៏ដោយ អូលីវើរ ខៅឌើរី បានចេញបេសកកម្ម ចាប់តាំងពីខែតុលា ឆ្នាំ ១៨៣០ ហេតុដូច្នោះ លោកពុំអាចបន្តកិច្ចការជាអ្នកប្រវត្តិសាស្ត្រ និងអ្នកកត់កំណត់ត្រាបានទៀតទេ ។ នៅក្នុងវិវរណៈបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧ ព្រះអម្ចាស់ បានហៅយ៉ូហាន វិតមើរ ឲ្យជំនួសអូលីវើរ ក្នុងតំណែងនេះ ។ អំឡុងគ្រានេះ ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ក៏បានស្វែងរកការដឹកនាំ ស្ដីអំពីរបៀបដើម្បីជួយដល់សមាជិកសាសនាចក្រ ផ្លាស់ចេញពីរដ្ឋនូវយ៉ោក ។ នៅក្នុងវិវរណៈ ឥឡូវត្រូវបានដាក់បញ្ចូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨ ព្រះអម្ចាស់បានណែនាំដល់ពួកបរិសុទ្ធឲ្យចែកដីរបស់ពួកគេជាមួយនឹងអ្នកដែលខ្វះខាត ហើយរៀបចំដើម្បីដាក់គ្រឹះនៃក្រុងស៊ីយ៉ូន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដី សញ្ញា ៤៧

*ព្រះអម្ចាស់ បានតែងតាំង យ៉ូហាន វិតមើរ ឲ្យកត់ត្រាប្រវត្តិនៃសាសនាចក្រ*

សូមឲ្យសិស្សគិតអំពីបទពិសោធន៍សំខាន់ៗខាងវិញ្ញាណ ដែលពួកគេបានមាន ដែលពួកគេមានអារម្មណ៍ថាមានតម្លៃក្នុងការចងចាំ ។ ( ឧទាហរណ៍ ពួកគេអាចគិតអំពីព្រឹត្តិការនានា ដូចជា ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ឬការប្រជុំសាសនាចក្រមួយ ឬពួកគេអាចនឹងនឹកគិតអំពីគ្រាមួយ ដែលពួកគេបានទទួលចម្លើយចំពោះការអធិស្ឋានមួយ ឬទទួលអារម្មណ៍ពីវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ ) ។ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយបទពិសោធន៍ទាំងនេះ ។ សូមសួរដល់សិស្សម្នាក់ៗនូវសំណួរដូចខាងក្រោម ៖

- ហេតុអ្វីក៏បទពិសោធន៍នេះ មានអត្ថន័យចំពោះអ្នក ?
- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីចងចាំពីបទពិសោធន៍នេះ ?
- តើកំណត់ត្រាអំពីបទពិសោធន៍នេះ ប្រទានពរដល់កូនចៅជំនាន់ក្រោយរបស់អ្នកយ៉ាងដូចម្ដេច ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាននូវការណែនាំ នៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់បានបង្គាប់ឲ្យរាស្ត្ររបស់ទ្រង់ធ្វើអ្វីខ្លះ ។ បន្ទាប់មកសូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧:១–៣ ដោយស្ងៀមស្ងាត់ ហើយរកមើលព័ត៌មានលម្អិតអំពីការបម្រើរបស់ យ៉ូហាន វិតមើរ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។ ( អ្នកអាចនឹងចង់រំឮកសិស្សថា នៅក្នុងវិវរណៈមុន ព្រះអម្ចាស់បានមានបន្ទូលថា « នឹងមានបញ្ជីមួយកត់ទុក នៅក្នុងចំណោមអ្នករាល់គ្នា » [គ. និង ស. ២១:១] ។ សូមពន្យល់ថា នៅក្នុងសាសនាចក្រសព្វថ្ងៃ គណៈប្រធានទីមួយ បានហៅអ្នកប្រវត្តិសាស្ត្រសាសនាចក្រ និងអ្នកកត់កំណត់ត្រាម្នាក់ [ តាមធម្មតា សំដៅទៅលើអ្នកប្រវត្តិសាស្ត្រសាសនាចក្រ ] ហើយណែនាំគាត់ជាសាធារណៈ ដើម្បីលើកដៃគាំទ្រ ) ។

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដែលប្រវត្តិនៃសាសនាចក្រត្រូវបានកត់ត្រាទុក ?
- តើរឿងមួយចំនួនអ្វីខ្លះ ចេញមកពីប្រវត្តិសាសនាចក្រ ដែលបានបំផុសគំនិតអ្នកជាពិសេស ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ម៉ាលីន ឃេ ជេនសិន នៃពួកចិតសិបនាក់ ដែលបម្រើជាអ្នកប្រវត្តិសាស្ត្រសាសនាចក្រ ចាប់ពីឆ្នាំ ២០០៥ ដល់ ឆ្នាំ ២០១២ ៖



« មានរឿងអស្ចារ្យផ្សេងៗជាច្រើននៅក្នុងប្រវត្តិរបស់យើង ដែលមានតម្លៃដើម្បីដឹង ហើយបង្រៀននៅព្រះវិហារ និងនៅក្នុងគេហដ្ឋាន ។ មេរៀនអំពីទីក្រុងខឺតឡង់ ការសាកល្បងនៅរដ្ឋមីសសួរី ជ័យជំនះ និងទីបំផុតជាការបណ្ដេញពួកបរិសុទ្ធពីរដ្ឋ ណៅវូ ហើយនឹងការធ្វើដំណើររបស់ពួកអ្នកត្រួសត្រាយផ្លូវទៅកាន់ទិសខាងលិច គឺជារឿងដ៏បំផុសគំនិតដល់ពួកបរិសុទ្ធនៅក្នុងគ្រប់ផែនដី និងភាសា ។ ប៉ុន្តែមាននូវរឿងនៃការឆ្ពោះទៅមុខដូចគ្នាផងដែរ អំពីការរីកចម្រើន និងការអភិវឌ្ឍន៍នៃសាសនាចក្រ និងឥទ្ធិពលនៃដំណឹងល្អនៅក្នុងជីវិតរបស់សមាជិកសាមញ្ញៗនៅគ្រប់ជាតិសាសន៍ ដែលត្រូវបានប៉ះដួងចិត្តដោយដំណឹងល្អដែលបានស្ដារឡើងវិញ ។ រឿងទាំងនេះ ត្រូវការនូវការកត់ត្រា និងរក្សាទុកឲ្យល្អផងដែរ ។

« . . . រឿងដ៏អស្ចារ្យៗជាច្រើនរបស់សាសនាចក្រ គឺមាននៅក្នុងប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិគ្រួសារ ហើយទាំងនេះគឺជាចំណែកមួយនៃកេរដំណែលគ្រួសារ និងបុគ្គលម្នាក់ៗ » (There Shall Be a Record Kept among You » *Ensign* ខែ ធ្នូ ឆ្នាំ ២០០៧, ទំព័រ ៣១ ) ។

- ហេតុអ្វីក៏អ្នកគិតថាប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិគ្រួសារសំខាន់ ?

យោងទៅលើបទពិសោធន៍ទាំងឡាយដែលសិស្សបានចងចាំ នៅពេលចាប់ផ្ដើមថ្នាក់រៀន ។ សូមពួកគេឲ្យនឹកស្រម៉ៃថា កូនចៅរបស់ពួកគេ និងចៅៗរបស់ពួកគេកំពុងអានដំណើររឿងផ្ទាល់ខ្លួនទាំងឡាយរបស់ពួកគេអំពីបទពិសោធន៍ទាំងនោះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីសំណួរខាងក្រោមនេះ ៖

- តើចំណែកបទពិសោធន៍ណាមួយ ដែលអ្នកនឹងគូសបញ្ជាក់ ? តើអ្នកចង់ឲ្យគ្រួសាររបស់អ្នកមានអារម្មណ៍ និងដឹងពីលទ្ធផលនៃការអានដំណើររឿងរបស់អ្នកឬទេ ?

សូមពន្យល់ថា គោលការណ៍ទាំងឡាយដែលយ៉ូហាន វិតមើរបានធ្វើតាម ក្នុងនាមជាអ្នកប្រវត្តិសាស្ត្រសាសនាចក្រ និងអ្នកកត់កំណត់ត្រា អាចអនុវត្តចំពោះប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិគ្រួសាររបស់យើងផងដែរ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧:៤ ដោយស្ងាត់ស្ងៀម ដើម្បីរៀននូវអ្វីដែលព្រះអម្ចាស់បានសន្យា បើ យ៉ូហាន វិតមើរ នឹងស្មោះត្រង់នៅក្នុងកិច្ចខិតខំរបស់គាត់នោះ ។

- តើព្រះអម្ចាស់សន្យាអ្វីខ្លះដល់យ៉ូហាន វិតមើរ? ( ព្រះអម្ចាស់ បានសន្យាថា អង្គលួងលោមចិត្ត–ព្រះវិញ្ញាណបរិសុទ្ធ– នឹងជួយគាត់នៅក្នុងកិច្ចខិតខំដើម្បីសរសេរប្រវត្តិនៃសាសនាចក្រ ) ។

- តើយើងអាចភ្ជាប់រឿងនេះទៅនឹងកិច្ចខិតខំរបស់យើងដើម្បីរក្សាប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិគ្រួសារយ៉ាងដូចម្ដេច ? ( សូមជួយសិស្សឲ្យស្គាល់គោលការណ៍ដូចខាងក្រោម ៖ **បើយើងស្មោះត្រង់នៅក្នុងកិច្ចខិតខំរបស់យើង ដើម្បីរក្សាប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិគ្រួសារ នោះព្រះវិញ្ញាណបរិសុទ្ធនឹងជួយយើង ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។

- តើព្រះវិញ្ញាណបរិសុទ្ធអាចជួយមនុស្សម្នាក់ នៅពេលគាត់  រក្សាប្រវត្តិផ្ទាល់ខ្លួន ឬគ្រួសារយ៉ាងដូចម្ដេច ?

នៅពេលសិស្សពិភាក្សាគ្នាអំពីសំណួរនេះ សូមជួយពួកគេឲ្យមើលឃើញថា ព្រះវិញ្ញាណបរិសុទ្ធ អាចនាំរឿងទាំងឡាយមកក្នុងការចងចាំរបស់យើង ( សូមមើល យ៉ូហាន ១៤:២៦) ហើយជួយយើងឲ្យសរសេរអំពីព្រឹត្តការណ៍ និងស្ថានភាពនានា ក្នុងរបៀបមួយ ដែលនឹងប្រទានពរដល់សមាជិកគ្រួសារ និងអ្នកដទៃទៀត ។

សូមលើកទឹកចិត្តដល់សិស្សឲ្យសុំជំនួយពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលពួកគេរក្សាប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិគ្រួសាររបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨

### *ព្រះអម្ចាស់ណែនាំដល់ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូឲ្យជួយដល់អ្នកទាំងឡាយដែលមកពីរដ្ឋនូវយ៉ោក*

សូមឲ្យសិស្សនឹកស្រម៉ៃថា ពួកបរិសុទ្ធនៅក្នុងតំបន់ឆ្ងាយៗ គឺត្រូវតែជម្លៀសចេញពីគេហដ្ឋានរបស់ពួកគេ ។ អ្នកដឹកនាំសាសនាចក្រ បានសុំឲ្យគ្រួសាររបស់សិស្សផ្ដល់ជាម្ហូបអាហារ និងជម្រកដល់ក្រុមគ្រួសារដែលគ្មានកន្លែងស្នាក់នៅមួយចំនួនសម្រាប់រយៈពេលច្រើនខែ ។

- តើសំណួរ និងកង្វល់អ្វីខ្លះ ដែលអ្នក និងគ្រួសាររបស់អ្នក អាចមានចំពោះសំណើរបែបនេះ ?

- តើកង្វល់ និងអារម្មណ៍អ្វីខ្លះ ពេលដែលអ្នកគិតអំពីអ្នកទាំងឡាយ ដែលផ្លាស់មកនៅក្នុងផ្ទះអ្នក ?

សូមអញ្ជើញសិស្សឲ្យបើកទៅទំព័រ ផែនទី ទី៣ ( « រដ្ឋនូវយ៉ោក ផែនសិលវេញ៉ា និង អូហៃអូ នៃសហរដ្ឋអាមេរិក » ) នៅក្នុងវគ្គផែនទីប្រវត្តិសាសនាចក្រក្នុងគម្ពីររបស់ពួកគេ ។ សូមឲ្យពួកគេរកមើល ហ្វាយ៉ែត រដ្ឋ នូវ យ៉ោក និង ទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ ហើយកំណត់ចម្ងាយប្រហាក់ប្រហែលរវាងទីក្រុងទាំងនេះ ( ប្រហែល ២៥០ ម៉ៃល ឬ ៤០០ គ.ម ) ។ សូមរំឭកសិស្សថា

នៅខែធ្នូ ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធនៅរដ្ឋ នូវ យ៉ោក ឲ្យប្រមូលគ្នីគ្នាមកឯរដ្ឋ អូហៃអូ ( សូមមើល គ. និង ស. ៣៧:៣) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់ បានប្រាប់ដល់ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ឲ្យធ្វើសម្រាប់សមាជិកនៃសាសនាចក្រ ដែលបានផ្លាស់ចូលមកតំបន់នោះ ។ រួចហើយឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

- តើព្រះអម្ចាស់បញ្ជាឲ្យពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ធ្វើអ្វីខ្លះ ? ( ទ្រង់បញ្ជាឲ្យអ្នកទាំងឡាយដែលមានដី ឲ្យចែកជាមួយនឹងពួកបរិសុទ្ធដែលផ្លាស់ចូលមកក្នុងតំបន់ ) ។ តើគោលការណ៍មួយដែលយើងអាចរៀនមកពីបទបញ្ញត្តិនេះគឺជាអ្វី ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់ បញ្ជាឲ្យពួកបរិសុទ្ធថ្ងៃចុងក្រោយចែកចាយនូវអ្វីដែលពួកគេមានជាមួយនឹងអ្នកខ្វះខាត ។** វាអាចនឹងជាប្រយោជន៍ដើម្បីចង្អុលបង្ហាញថា ពុំមែនគ្រប់ពួកបរិសុទ្ធនៅក្នុងរដ្ឋអូហៃអូ មានដីចែកទេ ហើយថាសមាជិកមួយចំនួនមកពីរដ្ឋ នូវ យ៉ោក គឺតម្រូវឲ្យទិញដីផ្ទាល់ខ្លួនរបស់ពួកគេ ) ។

- តើវិធីមួយចំនួនដែលយើងអាចចែកចាយនូវអ្វីដែលយើងមានជាមួយអ្នកដទៃមានអ្វីខ្លះ ?

សូមឲ្យសិស្សចែកចាយនូវបទពិសោធន៍ដែលពួកគេមាន នៅពេលពួកគេធ្វើជាសាក្សីពីមនុស្សដែលចែករំលែកជាមួយអ្នកទាំងឡាយដែលខ្វះខាត ។ អ្នកក៏អាចនឹងចង់អញ្ជើញពួកគេឲ្យពិពណ៌នាអំពីគ្រានានា ដែលពួកគេទទួលបានប្រយោជន៍មកពីសេចក្ដីសប្បុរស និងការបម្រើរបស់អ្នកដទៃ ។

### ការប្រើរឿង

ការនិទានរឿងមួយអាចជួយទាក់ទាញសិស្ស ដោយការបង្កើតចំណាប់អារម្មណ៍ និង ការជួយពួកគេឲ្យចូលរួមនៅក្នុងដំណើរការរៀនសូត្រតាមរយៈការស្ដាប់តាមបទពិសោធន៍របស់អ្នកដទៃ ។ រឿងក៏អាចជួយសិស្សឲ្យឃើញពីរបៀបដែលគោលការណ៍នៃដំណឹងល្អ អនុវត្តនៅក្នុងជីវិតរបស់មនុស្សផងដែរ ។

ដើម្បីផ្ដល់ជាឧទាហរណ៍មួយចំពោះការជួយដល់អ្នកទាំងឡាយដែលខ្វះខាត សូមឲ្យសិស្សម្នាក់អាននូវដំណើររឿងខាងក្រោម ដោយប្រធាន ថូម៉ាស អេស ម៉នសុន អំពីបទពិសោធន៍មួយ ដែលលោកបានមានជាមួយនឹងថ្នាក់អង្គការបឋមសិក្សារបស់លោកកាលនៅកុមារភាព ។



« យើងបានធ្វើគម្រោងមួយដើម្បីសន្សំប្រាក់ចំនួនមួយកាក់មួយសេនសម្រាប់ធ្វើពិធីជប់លៀងបុណ្យគ្រីស្ទម៉ាសដ៏ធំមួយ ។ បងស្រី ហ្គើស្ទ បានកត់ត្រាយ៉ាងប្រុងប្រយ័ត្ននូវការរីកចម្រើនរបស់យើង ។ កាលនៅជាក្មេងតូចៗអ្វីដែលចង់បរិភោគក្នុងគំនិតរបស់យើងគឺគិតដល់ នំឃុកគី នំផៃ និងការ៉េមបានច្រើនប៉ុណ្ណា ដែលប្រាក់ទាំងអស់របស់យើងអាចទិញបាន ។ នេះគឺជាព្រឹត្តការណ៍ដ៏រុងរឿងមួយ ។ យើងពុំធ្លាប់មានគ្រូបង្រៀនណាម្នាក់របស់យើងកាលពីមុន ផ្ដល់យោបល់អំពីព្រឹត្តការណ៍ដូចនេះទេ ។

« រដូវក្ដៅបានកន្លងផុតឈានចូលដល់រដូវស្លឹកឈើជ្រុះ ។ រដូវស្លឹកឈើជ្រុះឈានចូលដល់រដូវរងារ ។ គោលដៅពិធីជប់លៀងរបស់យើង ត្រូវបានសម្រេច ។ សិស្សក្នុងថ្នាក់បានធំៗ ។ អារម្មណ៍ល្អបានគ្របដណ្ដប់ ។

« គ្មានគ្នាយើងណាម្នាក់នឹងបំភ្លេចបាននូវព្រឹកព្រលឹមដ៏សែនសោកសៅ ពេលដែលគ្រូបង្រៀនបានប្រកាសប្រាប់យើងថា ម្ដាយមិត្តរួមថ្នាក់របស់យើងម្នាក់បានទទួលមរណៈភាពនោះទេ ។ យើងបានគិតអំពីម្ដាយរបស់យើងផ្ទាល់ ហើយថាតើពួកគាត់មានអត្ថន័យខ្លាំងប៉ុណ្ណាចំពោះយើង ។ យើងបានមានអារម្មណ៍សោកសៅអស់ពីដួងចិត្តចំពោះ ប៊ីលី ឌីនែផត នៅក្នុងការបាត់បង់ដ៏ធំរបស់គាត់នោះ ។

« មេរៀនថ្ងៃអាទិត្យមួយនេះ គឺចេញមកពីសៀវភៅ កិច្ចការ ជំពូកទី ២០ ខ ៣៥ ៖ ‹ នឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ ដែលទ្រង់មានព្រះបន្ទូលថា ដែលឲ្យ នោះបានពរជាជាងទទួល › ។ នៅចុងបញ្ចប់នៃការធ្វើបទបង្ហាញនៃមេរៀនដែលបានរៀបចំដ៏ល្អនោះ លូស៊ី ហ្គើស្ទ បានថ្លែងអំពីស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ ប៊ីលី ។ ទាំងនេះគឺជាគ្រាដ៏មានវិបត្តិធំ ហើយប្រាក់កាសក៏មានតិចតួចស្ដួចស្ដើង ។ ដោយការព្រិចភ្នែក គាត់បានសួរថា ៖ ‹ តើអ្នកនឹងធ្វើតាមការបង្រៀននេះរបស់ព្រះអម្ចាស់របស់យើងយ៉ាងដូចម្ដេច ? តើអ្នកនឹងមានអារម្មណ៍យ៉ាងណាក្នុងការដកប្រាក់សម្រាប់ពិធីជប់លៀងរបស់យើង ហើយយើងទាំងអស់គ្នាតំណាងថ្នាក់ទាំងមូលផ្ដល់ប្រាក់នោះទៅឲ្យគ្រួសារ ឌីនែផត ជាការសម្ដែងសេចក្ដីស្រឡាញ់របស់យើងវិញនោះ ? › ការសម្រេចចិត្តគឺត្រូវបានធ្វើឡើងជាឯកច្ឆន្ទ ។ យើងបានរាប់វាយ៉ាងយកចិត្តទុកដាក់ នូវកាក់និមួយៗ ហើយបានដាក់ចំនួនសរុបនៅក្នុងស្រោមសំបុត្រធំមួយ ។ កាតដ៏ស្អាតមួយ ត្រូវបានទិញ ហើយសរសេរឈ្មោះរបស់ពួកយើង ។

« ទង្វើនៃសន្ដានចិត្តល្អដ៏សាមញ្ញនេះ បានចងភ្ជាប់ពួកយើងជាមួយគ្នា » (« Your Personal Influence, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ២១–២២ ) ។

- តើយើងអាចរៀនអ្វីខ្លះចេញមកពីដំណើររឿងទាំងនេះ ? តើសន្ដានចិត្តល្អ និងការបម្រើ ប្រទានពរដល់ជីវិតនៃអ្នកផ្ដល់ឲ្យក៏ដូចជាអ្នកទទួលយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យចែកចាយនូវបទពិសោធន៍មួយ ដែលពួកគេបានមាន នៅពេលពួកគេបានជួយ ( ឬបានឃើញអ្នកដទៃជួយ ) ដល់អ្នកទាំងឡាយដែលមានការខ្វះខាត ។ សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីរបៀបមួយ ដែលពួកគេអាចជួយនរណាម្នាក់នៅក្នុងសប្ដាហ៍ក្រោយ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨:៤–៦ ដោយការពន្យល់ថា ព្រះអម្ចាស់ចង់ឲ្យពួកបរិសុទ្ធត្រៀមខ្លួនដើម្បីទិញដី ពេលទ្រង់នឹងបើកសម្ដែងពីទីតាំងនៃទីក្រុងស៊ីយ៉ូន ឬទីក្រុងយេរូសាឡិមថ្មី ។ ព្រះអម្ចាស់ បានបញ្ជាពួកបរិសុទ្ធឲ្យសន្សំប្រាក់ទាំងអស់ ដែលពួកគេអាចធ្វើបាន ដើម្បីត្រៀមចាក់គ្រឹះនៃទីក្រុងនោះ ( សូមមើល គ. និង ស. ៤៨:៤–៦ ) ។ សូមប្រាប់សិស្សថា ពួកគេនឹងរៀនកាន់តែច្រើនថែមទៀតអំពីកិច្ចខិតខំរបស់ពួកបរិសុទ្ធ ដើម្បីស្ថាបនាទីក្រុងស៊ីយ៉ូននៅក្នុងមេរៀនក្រោយៗ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥–៤៨ មេរៀនទី ១១

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥–៤៨ ( មេរៀនទី ១១ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៥)

នៅក្នុងការចាប់ផ្ដើមនៃខគម្ពីរក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥, សិស្សបានអានថាព្រះយេស៊ូវគ្រីស្ទបានបង្កើតឋានសួគ៌ និង ផែនដី ហើយថាទ្រង់គឺជាព្រះគាំទ្ររបស់យើងជាមួយព្រះវរបិតា ។ នៅពេលយើងរៀនពីព្រះអង្គសង្គ្រោះ និង អ្វីដែលទ្រង់បានធ្វើសម្រាប់យើង នោះយើងអាចបង្កើនបំណងប្រាថ្នាយើងឲ្យស្ដាប់តាមសំឡេងរបស់ទ្រង់ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៧៥)

ចេញពី ការសិក្សានូវទីសម្គាល់នានានៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នោះសិស្សបានរៀនថា ប្រសិនបើយើងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយទន្ទឹងចាំមើលទីសម្គាល់នានា នោះយើងនឹងត្រៀមខ្លួនជាស្រេចសម្រាប់ព្រឹត្តិការណ៍ដ៏ធំអស្ចារ្យនោះ ។ ចេញពីរឿងប្រៀបប្រដូចនៃស្ត្រីព្រហ្មចារីយដប់នាក់ នោះពួកគេបានរៀនថា ប្រសិនបើយើងទទួលសេចក្ដីពិត ហើយទទួលយកព្រះវិញ្ញាណបរិសុទ្ធធ្វើជាអង្គដឹកនាំផ្លូវយើង នោះយើងនឹងនៅខ្ជាប់ខ្ជួនក្នុងការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ មេរៀននេះក៏បានណែនាំសិស្សផងដែរអំពីព័ត៌មាននៃទីក្រុងយេរូសាឡិមថ្មី ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា៤៦)

សិស្សបានចំណាយពេលនៅក្នុងមេរៀននេះ គិតអំពីរបៀបនៃការដឹកនាំការប្រជុំក្នុងសាសនាចក្រ ។ ពួកគេបានរៀនថា អ្នកដឹកនាំសាសនាចក្រត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ នៅពេលពួកគេដឹកនាំការប្រជុំនានា ហើយថាព្រះអម្ចាស់បានបញ្ជាយើងឲ្យស្វាគមន៍ដល់មនុស្សទាំងអស់ដែលមកក្នុងការប្រជុំជាសាធារណៈរបស់យើង ។ សិស្សក៏បានឃើញពីវិធីនានាដើម្បីចៀសវាងពីការត្រូវបានបោកបញ្ឆោត ៖ (១) ធ្វើតាមព្រះវិញ្ញាណដោយអស់ពីបរិសុទ្ធភាព និង (២) អំពាវនាវទៅកាន់ព្រះ ហើយរស់នៅដោយមានអំណរគុណចំពោះទ្រង់ ។ ក្រោយមកសិស្សបានរៀនអំពី គោលបំណងនៃអំណោយទានខាងវិញ្ញាណ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨)

នៅពេលសិស្សបានរៀនអំពីសារៈសំខាន់នៃការរក្សាកំណត់ត្រារបស់សាសនាចក្រ នោះពួកគេបានឃើញសេចក្ដីពិតថា បើយើងស្មោះត្រង់នៅក្នុងកិច្ចខិតខំរបស់យើង ដើម្បីរក្សាប្រវត្តិផ្ទាល់ខ្លួន នោះព្រះវិញ្ញាណបរិសុទ្ធនឹងជួយយើង ។ នៅពេលសិស្សបានសិក្សាបរិបទប្រវត្តិសាស្ត្រនៃការធ្វើអន្តោប្រវេសន៍របស់ពួកបរិសុទ្ធ មកដល់រដ្ឋអូហៃអូ ដែលចេញមកពីទីក្រុងនូវ យ៉ោក នោះពួកគេបានគិតអំពីការបញ្ជារបស់ព្រះអម្ចាស់ឲ្យចែកចាយនូវអ្វីដែលពួកយើងមានជាមួយអស់អ្នកដែលខ្វះខាត ។

## សេចក្ដីផ្ដើម

មេរៀននេះគឺនិយាយអំពីរបៀបនៃការគិតគូររបស់ព្រះយេស៊ូវគ្រីស្ទចំពោះពួកយើងគ្រប់គ្នា ។ សិស្សនឹងមានឱកាសភ្ជាប់គោលលទ្ធិ និង គោលការណ៍នានាដែលពួកគេបានរៀន ពេញមួយសប្ដាហ៍នេះជាមួយនឹងរបៀប ដែលព្រះអម្ចាស់បើកសម្ដែងសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះពួកយើង ។

*កំណត់ចំណាំ* ៖ នៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ សិស្សធ្វើការទន្ទេញ និង អនុវត្តវគ្គចំណេះចំណានខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៣៣ ។ អ្នកអាចសុំឲ្យពួកគេសូត្រវា ហើយចែកចាយពីរបៀបដែលពួកគេគិតពីយុវវ័យដែលអាច « ប្រព្រឹត្តិដោយគុណធម៌ និង ដោយបរិសុទ្ធភាព នៅចំពោះ [ ព្រះអម្ចាស់ ] ជានិច្ច » ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥–៤៦

*ព្រះអម្ចាស់បង្រៀនអំពីសារៈសំខាន់នៃព្រឹត្តិការណ៍ និង អំណោយទាននានានៅក្នុងថ្ងៃចុងក្រោយ*

សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *តើឥឡូវនេះមាននរណាកំពុងគិតអំពីអ្នកឬទេ ?*

អ្នកអាចលើកទឹកចិត្តសិស្សឲ្យឆ្លៀតពេលមួយសន្ទុះដើម្បីរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥–៤៦, រកមើលខគម្ពីរនានាដែលពួកគេបានគូសចំណាំ និង សេចក្ដីពិតមួយចំនួនដែលពួកគេបានរកឃើញដែលគាំទ្រគំនិតដែលថា ព្រះអង្គសង្គ្រោះកំពុងគិតអំពីពួកគេ ហើយមានចំណាប់អារម្មណ៍ដោយអង្គទ្រង់ផ្ទាល់ចំពោះពួកគេ ។ សូមឲ្យសិស្សពិចារណាពីសំណួរនៅលើក្ដារខៀន ហើយសូមអញ្ជើញពួកគេឲ្យឆ្លើយ ។

- តើអ្នកបានរៀនអ្វីខ្លះនៅក្នុងការសិក្សារបស់អ្នកក្នុងសប្ដាហ៍នេះ ដែលជួយអ្នកឲ្យយល់ថាព្រះអម្ចាស់កំពុងតែគិតគូរពីអ្នក ? ( ចម្លើយរបស់សិស្សអាចឆ្លុះបញ្ចាំងឲ្យឃើញពីគំនិតខាងក្រោមនេះ ៖ ព្រះអង្គសង្គ្រោះគឺជាព្រះគាំទ្ររបស់យើងជាមួយព្រះវរបិតា ព្រះអង្គសង្គ្រោះបង្ហាញសេចក្ដីស្រឡាញ់របស់ទ្រង់សម្រាប់ពួកយើងដោយការបើកបង្ហាញពីព្រឹត្តិការណ៍ដែលកើតមុនការយាងមកជាលើកទីពីរ ហើយព្រះបានប្រទានអំណោយទាននៃព្រះវិញ្ញាណ នៅពេលយើងព្យាយាម និង រស់នៅដោយសក្ដិសមតាមអំណោយទានទាំងនោះ ) ។

សូមរំឭកសិស្សថា នៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រនាជំនាន់នោះ មារសត្រូវបានសាបព្រោះការកុហក និង របាយការណ៍ក្លែងក្លាយអំពីសាសនាចក្រ និង ព្យាការីយ៉ូសែប ស៊្មីធ ។ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ បានរំឭកពួកបរិសុទ្ធជាពិសេសថា អំឡុងពេលនៃគ្រាដ៏លំបាកនេះព្រះអម្ចាស់កំពុងតែគិតគូរអំពីពួកគេ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានការដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយពិចារណាពីរបៀបដែលវិវរណៈនេះអាចលួងលោមពួកបរិសុទ្ធអំឡុងពេលនៃការបៀតបៀននោះ ។ សូមគិតឲ្យសិស្សឈប់មួយសន្ទុះនៅក្នុងការអានរបស់ពួកគេ ដូច្នេះអ្នកអាចសួរសំណួរមួយចំនួនខាងក្រោម បន្ទាប់ពីបានអានខគម្ពីរដែលទាក់ទងនោះ ៖

- តើគោលលទ្ធិដែលថា **ព្រះយេស៊ូវគ្រីស្ទ បានបង្កើតឋានសួគ៌ និង ផែនដី** (គ. និង ស. ៤៥:១) បង្ហាញពីចំណាប់អារម្មណ៍របស់ព្រះអង្គសង្គ្រោះផ្ទាល់ចំពោះអ្នកយ៉ាងដូចម្ដេច ?
- តើព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:២ បង្ហាញពីកង្វល់របស់ទ្រង់ចំពោះយើងយ៉ាងដូចម្ដេច ?
- ចេញពី ខ ៣, តើអ្នកយល់អ្វីខ្លះពីឃ្លាថា « អង្វរជំនួសអ្នករាល់គ្នា ? »
- យោងតាម ខ ៤, តើព្រះអម្ចាស់បានមានបទពិសោធន៍អ្វីខ្លះដែលអាចធ្វើឲ្យទ្រង់ប្រែក្លាយជាព្រះគាំទ្ររបស់យើងជាមួយព្រះវរបិតាសួគ៌ ? ( ទ្រង់បានជួបការរងទុក្ខ និង ការសុគត ព្រមទាំងរស់នៅក្នុងជីវិតដែលគ្មានអំពើបាប ។ អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យពន្យល់ពីតួនាទីនៃអ្នកគាំទ្រចេញពីអ្វីដែលពួកគេបានរៀននៅក្នុងការសិក្សាផ្ទាល់ខ្លួន ) ។
- តើការដឹងថា **ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គគាំទ្រជាមួយព្រះវរបិតាសួគ៌** ជះលទ្ធិពលលើការសម្រេចចិត្ត និង សកម្មភាពរបស់អ្នកក្នុងពេលនេះយ៉ាងដូចម្ដេច ?

ដើម្បីគូសបញ្ជាក់អំពី ការគិតគូររបស់ព្រះអង្គសង្គ្រោះចំពោះយើង សូមអញ្ជើញសិស្សម្នាក់អាន សេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌិង ស៊្មីធឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកគំនិតបន្ថែមអំពីតួនាទីរបស់ព្រះអង្គសង្គ្រោះក្នុងនាមជាព្រះអង្គគាំទ្ររបស់យើង ។



« [ ព្រះយេស៊ូវគ្រីស្ទ ] គង់នៅចន្លោះព្រះវរបិតា និង មនុស្សលោក ។ ទ្រង់ទូលអង្វរជំនួសយើង ។ អ្នកដឹងថា នៅពេលទ្រង់គង់នៅលើផែនដី នោះទ្រង់បានអធិស្ឋានជាញឹកញាប់ ហើយទ្រង់បានអធិស្ឋានសម្រាប់ពួកសិស្សរបស់ទ្រង់ ទូលអង្វរជាមួយព្រះវរបិតាជំនួស ហើយទ្រង់បានទូលអង្វរតាំងពីនោះមក ហើយថាទ្រង់គង់នៅចន្លោះពួកយើង និង ព្រះដែលជាព្រះបិតាយើង » ( នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៥៣ ទំព័រ ៥៨ ) ។

- តើអ្នកគិតថាបុគ្គលម្នាក់អាចថ្លែងអំណរគុណដល់ព្រះអង្គសង្គ្រោះចំពោះការធ្វើជាព្រះអង្គតំណាងរបស់ខ្លួនដោយរបៀបណា ? ( ដើម្បីជួយសិស្សឲ្យចែកចាយចម្លើយដោយមានការគិតគូរចំពោះសំណួរនេះ នោះអ្នកអាចឲ្យពួកគេមើលអ្វីដែលពួកគេបានសរសេរ សម្រាប់ការចាត់ឲ្យសរសេរលើកទីពីររបស់ពួកគេនៅក្នុងមេរៀនរបស់ខ្លួនសម្រាប់ថ្ងៃទី ១ នៃមេរៀននេះ [គ. និង ស. ៤៥:១–១៥] ) ។

សូមឲ្យសិស្សគិតអំពីពេលមួយ ដែលពួកគេបានទទួលអារម្មណ៍ថា គ្មាននរណាម្នាក់គិតអំពីពួកគេ ឬ ពួកគេបានទទួលអារម្មណ៍ថា ពួកគេពុំសូវសំខាន់ជាងអ្នកផ្សេងទៀត ។

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្ដាប់រកមើលនូវរបៀបដែលព្រះអង្គសង្គ្រោះមានអារម្មណ៍អំពីពួកគេម្នាក់ៗ ។



« បងប្អូនប្រុសស្រីរបស់ខ្ញុំអើយ ខ្ញុំសូមថ្លែងទីបន្ទាល់ថា គ្មានពួកយើងណាម្នាក់ត្រូវបានផ្ដល់តម្លៃ ឬ ត្រូវបានស្រឡាញ់ពីព្រះតិចជាងនរណាម្នាក់ទៀតឡើយ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ទ្រង់ស្រឡាញ់ពួកយើងម្នាក់ៗទោះបីយើងនៅក្នុងស្ថានភាព—អសុវត្ថិភាព អន្ទះសារ អត្តរូប និង គ្រប់ស្ថានភាពទាំងអស់ ។ ទ្រង់ពុំវាស់វែងទេពកោសល្យរបស់យើង ឬ ភិនភាគនៃរូបរាងយើងឡើយ ទ្រង់ពុំវាស់វែងពីវិជ្ជាជីវៈ ឬ ទ្រព្យសម្បត្តិយើងឡើយ ។ ទ្រង់សព្វព្រះទ័យលើអ្នករត់ប្រណាំង *គ្រប់រូប* ដែលអំពាវនាវថាការប្រណាំងនោះគឺជំទាស់នឹងអំពើបាប, *មិនមែន* ប្រឆាំងជំទាស់គ្នានឹងគ្នាឡើយ ។ ខ្ញុំដឹងថាប្រសិនបើយើងនឹងស្មោះត្រង់ នោះមានសម្លៀកបំពាក់នៃសេចក្ដីសុចរិតដែលបានកាត់កែតម្រូវដ៏ស្អាតឥតខ្ចោះរួចជាស្រេចទៅហើយដែលកំពុងតែរង់ចាំសម្រាប់ *មនុស្សគ្រប់គ្នា*» (« The Other Prodigal » *Ensign,* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ៦៤ ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ នៅពេលពួកគេមានអារម្មណ៍ថាព្រះគិតគូរពីពួកគេ ឬ នៅពេលពួកគេទទួលអារម្មណ៍ថាព្រះបានលើកទឹកចិត្តរបស់ពួកគេ ។

សូមពន្យល់ថា របៀបមួយដែលព្រះអង្គសង្គ្រោះបានលួងលោមពួកបរិសុទ្ធជំនាន់ដើម អំឡុងពេលនៃការបៀតបៀននោះគឺទ្រង់បានប្រាប់ពួកគេថា ទ្រង់នឹងយាងមកលើផែនដីម្ដងទៀតដើម្បីប្រទានពរដល់ពួកគេ ។ សូមសរសេរសេចក្ដីយោងបទគម្ពីរខាងក្រោមនៅលើក្ដារខៀន ៖ *គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៥៥–៥៩* ។

សូមឲ្យសិស្សអានខគម្ពីរទាំងនេះដោយស្ងាត់ស្ងៀម រកមើលរបៀបដែលពួកបរិសុទ្ធត្រូវបានប្រទានពរឲ្យនៅពេលព្រះអម្ចាស់យាងមក ។

- យោងតាម ខ ៥៧, តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមករបស់ព្រះអង្គសង្គ្រោះ ? ( សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងទទួលសេចក្ដីពិត ហើយទទួលយកព្រះវិញ្ញាណបរិសុទ្ធធ្វើជាអ្នកដឹកនាំយើង នោះយើងនឹងនៅខ្ជាប់ខ្ជួនក្នុងការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ**) ។

- តើអ្នកគិតថាការទទួលសេចក្ដីពិត និង ការទទួលយកព្រះវិញ្ញាណធ្វើជាអ្នកដឹកនាំយើង ជួយរៀបចំយើង សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

- តើអ្នកធ្លាប់បានធ្វើអ្វីខ្លះហើយដើម្បីទទួលបាន និង ទទួលយកសេចក្ដីពិតនៅក្នុងជីវិតរបស់អ្នក ? តើអ្នកធ្លាប់ត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធកាលពីពេលណា ? ( បន្ទាប់ពីសិស្សបានឆ្លើយរួច សូមគិតពីការចែកចាយបទពិសោធន៍មកពីជីវិតអ្នកផ្ទាល់ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨

*ពួកបរិសុទ្ធត្រូវតែរក្សាទុកនូវប្រវត្តិសាស្ត្រឲ្យបានទៀងទាត់ ហើយចែកចាយធនធាននានារបស់ពួកគេដល់គ្នាទៅវិញទៅមក*

សូមរំឭកសិស្សថា ផ្នែកមួយនៃការសិក្សារបស់ពួកគេនៅសប្ដាហ៍នេះ បានផ្ដោតសំខាន់ទៅលើសារៈសំខាន់នៃការរក្សាទុកនូវប្រវត្តិផ្ទាល់ខ្លួន ឬ សៀវភៅកំណត់ហេតុផ្ទាល់ខ្លួន ។ ដើម្បីលើកទឹកចិត្តដល់សមាជិកនៅក្នុងថ្នាក់ឲ្យបន្តកិច្ចខិតខំរបស់ខ្លួន ក្នុងការរក្សាប្រវត្តិផ្ទាល់ខ្លួន ឬ ចាប់ផ្ដើមរក្សាទុកនូវប្រវត្តិផ្ទាល់ខ្លួន នោះអ្នកអាចសួរពួកគេពីមូលហេតុដ៏សំខាន់នៃការរក្សាប្រវត្តិផ្ទាល់ខ្លួន ។

សូមអញ្ជើញសិស្សឲ្យចែកចាយពរជ័យនានាដែលពួកគេបានមាន មកពីការរក្សាទុកនូវប្រវត្តិផ្ទាល់ខ្លួន ឬ ពរជ័យដែលបានមកពីការអានប្រវត្តិសាស្ត្ររបស់ឪពុកម្ដាយ ជីដូនជីតា ឬ បុព្វការីជនផ្សេងៗទៀត ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩–៥៦)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ពួកគេនៅ អំឡុងពេលនៃសប្ដាហ៍, អ្នកក៏អាចអញ្ជើញពួកគេឲ្យពិចារណាពីសំណួរខាងក្រោម ៖ តើយើងផ្សព្វផ្សាយដំណឹងល្អដល់មនុស្សដទៃដោយរបៀបណា ? តើអ្នកអាចប្រាប់ថា អ្នកកំពុងតែបង្រៀន ឬ កំពុងរៀនដោយព្រះវិញ្ញាណតាមរបៀបណា ? តើវាធ្លាប់មានការពិបាកដល់អ្នកដែរឬទេ ដើម្បីញែកឲ្យដឹងថាអ្វីមួយមកពីព្រះ ឬ មកពីប្រភពណាផ្សេងទៀតនោះ ? សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងរៀនពីអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីរបៀប ដើម្បីស្គាល់សេចក្ដីពិត ហើយចៀសវាងពីការបង្រៀនក្លែងក្លាយ ។

មេរៀនទី ៥៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩

## បុព្វកថា

លីម៉ាន ខូប្លី ជាអ្នកផ្លាស់ប្រែចិត្តជឿម្នាក់ចូលក្នុងសាសនាចក្រ បានចង់ឲ្យអ្នកផ្សព្វផ្សាយសាសនា ផ្សាយដំណឹងល្អទៅដល់សមាជិកនៃក្រុមសាសនារបស់គាត់ពីមុន ដែលជាក្រុម សេកើរ ។ ទោះជាយ៉ាងណាក៏ដោយ គាត់បានបន្តកាន់តាមជំនឿខុសឆ្គងមួយចំនួនមកពីសាសនានោះ ។ ដោយមានកង្វល់អំពីជំនឿរបស់ លីម៉ាន នោះ យ៉ូសែប ស្ម៊ីធ បានទូលសួរដល់ព្រះអម្ចាស់នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ ១៨៣១ ហើយបានទទួលវិវរណៈដែលឥឡូវនេះ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩ ។

## យោបល់សម្រាប់ការបង្រៀន

### សូមសម្រេចចិត្តពីអ្វីដែលត្រូវបង្រៀន

មេរៀននេះ មានខ្លឹមសារច្រើនជាងពេលវេលាដែលអ្នកមានដើម្បីបង្រៀន ។ សូមពិចារណាប្រកបដោយការអធិស្ឋានថា គោលលទ្ធិ គោលការណ៍ ឬគំនិតបង្រៀនណាមួយ ដែលនឹងជាប្រយោជន៍ល្អបំផុតសម្រាប់សិស្សនៅក្នុងថ្នាក់របស់អ្នក ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:១–៤

*ព្រះអម្ចាស់ បានហៅស៊ីឌនី រិកដុន, ប៉ាលី ភី ប្រាត្ត, និងលីម៉ាន ខូប្លី ឲ្យផ្សាយទៅកាន់ពួកសេកើរ ។*

មុនពេលថ្នាក់ចាប់ផ្ដើម សូមធ្វើជាអន្ទាក់ចាប់សត្វស្វាមួយ ឬគូររូបដូចមានអមមកជាមួយនៅលើក្ដារខៀន ។ ដើម្បីធ្វើអន្ទាក់ចាប់សត្វស្វា សូមរកប្រអប់ដែលមានគម្រប ។ បិទគម្របប្រអប់ឲ្យជិត ហើយកាត់ប្រឡោះមួយនៅម្ខាងនៃប្រអប់ ឲ្យមានទំហំធំល្មមដែលសិស្សអាចលាដៃចូលបាន ហើយក្ដាប់ដៃចេញមកវិញមិនរួច។ សូមដាក់ផ្លែឈើ ឬបាល់មួយនៅខាងក្នុងប្រអប់ ។



សូមសួរដល់សិស្សថាតើពួកគេដឹងពីរបៀបដើម្បីចាប់សត្វស្វា ។ ( បើពួកគេដឹងវិធីសាស្ត្រដូចខាងក្រោម សូមអញ្ជើញពួកគេឲ្យពន្យល់អំពីរបៀបនោះដល់សិស្សក្នុងថ្នាក់ ។ បើអ្នកបានធ្វើអន្ទាក់មួយ អ្នកក៏អាចអញ្ជើញសិស្សម្នាក់ឲ្យបង្ហាញអំពីរបៀបដែលជាប់ដង្កប់ផងដែរ ) ។ សូមឲ្យយោបល់ថា វិធីមួយដើម្បីដាក់អន្ទាក់សត្វស្វា គឺដាក់វត្ថុអ្វីមួយដែលវាចូលចិត្ត នៅក្នុងប្រអប់មួយ ដែលមានប្រហោងមួយធំល្មមនឹងស្វាអាចលូកដៃវាចូលរួច ។ នៅពេលស្វាចាប់បានវត្ថុនោះហើយ វាមិនអាចដកដៃវាចេញមកវិញបានឡើយ ដោយសារវាចាប់កាន់វត្ថុមួយដែលធំជាងប្រហោងនោះ ។ ដោយការតាំងចិត្តរបស់វាកាន់របស់នោះយ៉ាងជាប់ នោះស្វាមួយចំនួននឹងទុកឲ្យខ្លួនវាត្រូវគេចាប់បាន ។

សូមអញ្ជើញសិស្សឲ្យអានសេចក្ដីណែនាំកណ្ដនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩ ដោយស្ងាត់ស្ងៀម ហើយរកមើលវិធីដែលស្ថានភាព បានពិពណ៌នានោះ គឺដូចជាអន្ទាក់ស្វា ។ នៅពេលសិស្សបានចង្អុលបង្ហាញថា លីម៉ាន ខូប្លី ពុះពារដើម្បីបោះបង់ចោលជំនឿពួកសេកើរ សូមឲ្យពួកគេសរសេរនូវជំនឿរបស់សេកើរមួយចំនួន ។

នៅពេលសិស្សឆ្លើយតប សូមសរសេរចម្លើយពួកគេនៅលើក្ដារខៀនដូចបានបង្ហាញនៅខាងក្រោម ។ សូមកុំបន្ថែមកូឡោនដែលមានចំណងជើងជាមួយក្បាលកណ្ដ « គោលលទ្ធិរបស់ព្រះអម្ចាស់ » ។ អ្នកនឹងបន្ថែមកូឡោននោះនៅពេលក្រោយក្នុងមេរៀន ។

| ជំនឿរបស់ពួកសេកើរ | គោលលទ្ធិរបស់ព្រះអម្ចាស់ |
|---|---|
| ១. ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទបានកើតឡើងរួចហើយ ។ | គ. និង ស. ៤៩:៥–៨ |
| ២. ព្រះគ្រីស្ទ បានលេចមកក្នុងរូបរាងជាស្ត្រីម្នាក់ឈ្មោះ អាន លី ។ | គ. និង ស. ៤៩:២២–២៥ |
| ៣. ពិធីបុណ្យជ្រមុជទឹកដោយទឹក ពុំគិតថាសំខាន់ទេ ។ | គ. និង ស. ៤៩:១១–១៤ |

| ជំនឿរបស់ពួកសេកើរ | គោលលទ្ធិរបស់ព្រះអម្ចាស់ |
|---|---|
| ៤. ពួកគេបានបដិសេធអាពាហ៍ពិពាហ៍ ហើយបានជឿលើការរស់នៅក្នុងជីវិតដែលនៅលីវ ( ចៀសវាងពីអាពាហ៍ពិពាហ៍ និងទំនាក់ទំនងខាងផ្លូវភេទ ) ។ | គ. និង ស. ៤៩:១៥–១៧ |
| ៥. ពួកសេកើរមួយចំនួនបានហាមបរិភោគសាច់សត្វ ។ | គ. និង ស. ៤៩:១៨–២១ |

បើសិស្សចង់ដឹងខ្លាំងអំពីឈ្មោះ *សេកើរ* សូមពន្យល់ថា សមាជិកនៃអ្នកជឿលើការបង្ហាញខ្លួនជាលើកទីពីររបស់ព្រះគ្រីស្ទក្នុងសង្គមសហរដ្ឋ គឺត្រូវបានហៅថា ពួកសេកើរ ដោយសារតែលក្ខណៈនៃការថ្វាយបង្គំរបស់ពួកគេ មានទាក់ទងនឹងការញាក់ញ័រខ្លួន ពេលពួកគេច្រៀង រាំ និងទះដៃរបស់ពួកគេជាភ្លេង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបើកសម្ដែងទាក់ទងនឹងពួកសេកើរ ។

- តើព្រះអម្ចាស់ពិពណ៌នាអំពីពួកសេកើរយ៉ាងដូចម្ដេច ? ( សូមមើល ខ ២ ) ។
- តើអ្នកគិតថាមានន័យយ៉ាងណា ដែល « មានបំណងប្រាថ្នាចង់ដឹងសេចក្ដីពិតខ្លះៗ តែមិនពេញលេញនោះ » ? ( ពួកគេបានទទួលយកការបង្រៀនមួយចំនួនរបស់ព្រះ ប៉ុន្តែបានមិនអើរពើ ឬបានបដិសេធការបង្រៀនផ្សេងទៀត ) ។
- តើសមាជិកសាសនាចក្រមានឥរិយាស្រដៀងគ្នានេះតាមរបៀបណាខ្លះ នៅសព្វថ្ងៃនេះ ?

សូមសរសេរនូវប្រយោគពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *ការត្រឹមត្រូវនៅចំពោះព្រះ រួមមាន. . .*

សូមសួរដល់សិស្សថាតើពួកគេនឹងបំពេញគោលការណ៍នេះ យ៉ាងណា ដោយផ្អែកទៅលើព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងខ ២ ។ នៅពេលសិស្សបានឆ្លើយតប សូមបំពេញគោលការណ៍នៅលើក្ដារខៀន ៖**ការត្រឹមត្រូវនៅចំពោះព្រះអម្ចាស់ រួមមាននូវការមានបំណងប្រាថ្នាដើម្បី ទទួលនូវរាល់សេចក្ដីពិត ដែលទ្រង់បានបើកសម្ដែង ។** អ្នកអាចនឹងចង់ផ្ដល់យោបល់ថា សិស្សគួរសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ខ ២ ។ សូមចង្អុលបង្ហាញថា បើយើងមានបំណងប្រាថ្នាចង់ដឹងសេចក្ដីពិតដោយស្មោះ នោះយើងក៏មានបំណងប្រាថ្នាដើម្បីរស់នៅតាមសេចក្ដីពិតផងដែរ ។

- ហេតុអ្វីក៏ លីម៉ាន ខូព្លី ត្រូវការនូវការប្រឹក្សានៅក្នុង ខ ២ ? តើគោលការណ៍នេះអាចនឹងមានគុណប្រយោជន៍យ៉ាងដូចម្ដេចចំពោះអ្នក ?
- តើមានពរជ័យអ្វីខ្លះ ដែលមនុស្សម្នាក់ខកខានពុំបានទទួល ពេលជ្រើសរើសទទួលយកតែសេចក្ដីពិតខ្លះៗនោះ ?

យោងទៅអន្ទាក់សត្វស្វា ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអន្ទាក់មួយចំនួន ដែលអាចនឹងនាំមនុស្សឲ្យបដិសេធការបង្រៀនមួយចំនួនរបស់ព្រះ– សកម្មភាព និងទង្វើដែលមនុស្សកាន់តាម ដែលរារាំងពួកគេពីការធ្វើត្រឹមត្រូវនៅចំពោះព្រះអម្ចាស់ ។ ( ឧទាហរណ៍មួយចំនួនអាចរួមមានទាំង ទម្លាប់រកលេសដ៏អាក្រក់មួយ ការស្ដាប់តន្ត្រីដែលបណ្ដេញព្រះវិញ្ញាណ ការចូលរួមក្នុងសកម្មភាពនៅថ្ងៃអាទិត្យ ដែលពុំសមរម្យសម្រាប់ថ្ងៃឈប់សម្រាក ការពេញចិត្តនឹងការបង្រៀន និងទស្សនវិជ្ជានៃលោកិយជាងការបង្រៀនរបស់ព្រះ ហើយមិនទទួលយកបទបញ្ញត្តិដើម្បីអភ័យទោសដល់អ្នកដទៃ ) ។

- តើផលវិបាកអ្វីខ្លះនឹងកើតឡើង ចំពោះការប្រកាន់ខ្ជាប់យក សកម្មភាព និងឥរិយាបទដូច្នេះ ? តើរឿងនេះវាជាអន្ទាក់យ៉ាងដូចម្ដេចដែរ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេអាចចាំបាច់ត្រូវបោះបង់ចោលដើម្បីទទួលបាននូវរាល់ពរជ័យដែលព្រះវរបិតាសួគ៌មានព្រះបំណងចង់ឲ្យពួកគេ ។ សូមពិចារណាអញ្ជើញពួកគេឲ្យដាក់គោលដៅមួយដើម្បីបោះបង់ចោលនូវអ្វីដែលរារាំងពួកគេមិនឲ្យមានភាពត្រឹមត្រូវនៅចំពោះព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:៥–២៨

*ព្រះអម្ចាស់កែប្រែគោលលទ្ធិខុសឆ្គងរបស់ពួកសេកើរ ហើយបញ្ជាឲ្យពួកអ្នកបម្រើរបស់ទ្រង់អញ្ជើញពួកគេឲ្យប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក*

សូមរំឭកសិស្សថា ព្រះអម្ចាស់បានបញ្ជាដល់ លីម៉ាន ខូព្លី, ស៊ីឌនី រិកដុន និង ប៉ាលី ភី ប្រាត្ត ឲ្យផ្សាយដំណឹងល្អទៅដល់ពួកសេកើរ ( សូមមើល គ. និង ស. ៤៩:១–៤ ) ។ សូមពន្យល់ថា មុនពេលទទួលបានបញ្ជានេះ លីម៉ាន ខូព្លី បាន « រំភើបចិត្តដែលពួកអែលឌើរមួយចំនួនគួរទៅជួបនឹងពួកបងប្អូនចាស់ៗរបស់គាត់ [ ពួកសេកើរ ] ហើយផ្សាយដំណឹងល្អនោះ » (*Histories, Volume* ២*: Assigned Histories,* ឆ្នាំ ១៨៣១–១៨៤៧, វ៉ុលទី ២ of the Histories series of

*The Joseph Smith Papers* [ ឆ្នាំ ២០១២ ], ទំព័រ ៣៧ ) ។ នៅពេលពួកអែលឌើរទាំងនេះបានទៅជួបពួកសេកើរ នោះពួកគេបានអានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៩ ឲ្យឮៗដល់ពួកគេ ។

នៅលើក្ដារខៀន សូមចម្លងក្ខទ្បានទីពីរក្នុងតារាងមុនមកពីមេរៀននេះ ។

សូមបែងចែកសិស្សក្នុងថ្នាក់ជាប្រាំក្រុម ។ សូមចាត់ឲ្យក្រុមនិមួយៗនូវបទគម្ពីរមួយ ដែលអ្នកបានសរសេរនៅលើក្ដារខៀននោះ ។ ( បើអ្នកមានសិស្សតិច សូមបែងចែកបទគម្ពីរទៅដល់សិស្សទាំងឡាយ ហើយពិភាក្សារួមគ្នា ) ។ សូមអញ្ជើញសិស្សឲ្យអានវគ្គបទគម្ពីរដែលបានចាត់ទៅឲ្យពួកគេនោះ រកមើលគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលកែតម្រូវនូវជំនឿខុសឆ្គងរបស់ពួកសេកើរ ។

នៅពេលសិស្សមានពេលគ្រប់គ្រាន់ដើម្បីសិក្សាបទគម្ពីរទាំងនេះហើយ សូមអញ្ជើញពួកគេឲ្យពិភាក្សានូវសំណួរដូចខាងក្រោមនៅក្នុងក្រុមរបស់ពួកគេ ហើយរៀបចំចែកចាយចម្លើយរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។

- តើគោលលទ្ធិ និងគោលការណ៍អ្វីខ្លះ ដែលពួកសេកើរ និងលីម៉ានកុប្លី ចាំបាច់ត្រូវយល់ ?

- តើខគម្ពីរដែលបានចាត់ទៅឲ្យនោះពន្យល់អំពីសេចក្តីពិតទាំងនេះយ៉ាងដូចម្ដេចខ្លះ ?

នៅពេលក្រុមទាំងឡាយមានពេលគ្រប់គ្រាន់ដើម្បីអាន និងពិភាក្សាអំពីវគ្គបទគម្ពីរដែលចាត់ឲ្យពួកគេរួចហើយនោះ សូមអញ្ជើញសិស្សម្នាក់មកពីក្រុមនិមួយៗឲ្យឆ្លើយសំណួរទាំងនេះសម្រាប់សិស្សក្នុងថ្នាក់ ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំបទគម្ពីរដែលបង្រៀនអំពីសេចក្តីពិតទាំងឡាយ ដែលពួកគេបានរៀបរាប់ប្រាប់នោះ។

សិស្សគួរតែប្រាប់នូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយដូចខាងក្រោម ។ ( កំណត់ចំណាំថា សេចក្តីពិតទាំងនេះគឺត្រូវបានដាក់លេខដើម្បីឆ្លើយឆ្លងជាមួយនឹងជំនឿខុសឆ្គងនៅលើក្ដារខៀន ) ។ នៅពេលសិស្សប្រាប់អំពីសេចក្តីពិតទាំងនេះ សូមពិចារណាធ្វើការសួរសំណួរតាមដានដើម្បីបំផុសឲ្យមានការពិភាក្សាបន្ថែម ។

១. នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៩:៧ សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**គ្មាននរណាដឹងពីពេលវេលានៃការយាងមកជាលើកទីពីរថា នឹងកើតឡើងនៅពេលណាទេ លើកលែងតែព្រះប៉ុណ្ណោះ ។**

២. នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៩:២២–២៥ គោលលទ្ធិមួយដែលពួកសិស្សអាចនឹងប្រាប់ គឺមានដូចខាងក្រោម ៖ **បើយើងដឹងអំពីទីសម្គាល់នៃ ការយាងមកជាលើកទីពីរ នោះយើងនឹងពុំត្រូវបានបញ្ឆោតដោយការអះអាងខុសឆ្គងនោះទេ ។**

   - តើទីសម្គាល់មួយចំនួនដែលបានប្រាប់នៅក្នុង ខ ២៣–២៥ មានអ្វីខ្លះ ? ( អ្នកអាចនឹងចង់ពន្យល់ថា ឈ្មោះយ៉ាកុបនៅក្នុង ខ ២៤ សំដៅទៅលើពូជពង្សសាសន៍អ៊ីស្រាអែល ) ។ តើអ្នកបានឃើញទីសម្គាល់ទាំងនេះនៅក្នុងជំនាន់របស់យើងតាមវិធីណា ?

៣. នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៩:១១–១៤ សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**ព្រះយេស៊ូវគ្រីស្ទ បានបញ្ជាពួកអ្នកបម្រើរបស់ទ្រង់ឲ្យហៅមនុស្សឲ្យជឿទៅលើទ្រង់ ឲ្យប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។**

   - ហេតុអ្វីក៏អ្នកមានអំណរគុណ ដែលអ្នកបានទទួលបុណ្យជ្រមុជទឹក ហើយដែលអ្នកបានទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដូច្នេះ ? ហេតុអ្វីបានជាអ្នកទន្ទឹងជួយមនុស្សដទៃឲ្យទទួលពិធីបរិសុទ្ធទាំងនេះ ?

៤. នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៩:១៥–១៧ សិស្សគួរតែប្រាប់នូវគោលលទ្ធិមួយ ឬច្រើនដូចខាងក្រោម ៖**អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺត្រូវបានតែងតាំងឡើងដោយព្រះហើយស្វាមី និងភរិយា ត្រូវបានបញ្ជាឲ្យរួមគ្នាតែមួយ ហើយមានកូនចៅ ។** អ្នកអាចនឹងចាំបាច់ត្រូវពន្យល់នូវឃ្លា « ដើម្បីឲ្យផែនដីអាចបំពេញគោលបំណងនៃការបង្កបង្កើត ហើយដើម្បីឲ្យផែនដីអាចបានពេញទៅដោយមនុស្ស » ។ វគ្គបទគម្ពីរនេះ បង្រៀនថា គោលបំណងតែមួយនៃការបង្កបង្កើតរបស់ផែនដី គឺត្រូវផ្ដល់ជាកន្លែងមួយដែលកូនចៅរបស់ព្រះ អាចរស់នៅជាក្រុមគ្រួសារ ។

   - តើមានគោលបំណងអ្វីខ្លះ ដែលអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីត្រូវបំពេញនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ?

   - តើ« [ការ]ហាមមិនឲ្យរៀបការ » ត្រូវបានរាប់ចូលក្នុងផែនការរបស់ព្រះវរបិតាសួគ៌យ៉ាងដូចម្ដេច ?

   - ស្របតាម ខ ១៦ ព្រះបានអនុមតិលើអាពាហ៍ពិពាហ៍តាមប្រពៃណីរវាងបុរស និងស្ត្រី ។ តើវិធីមួយចំនួន ដែលមនុស្ស ព្យាយាមដើម្បីរិះគន់ ឬបំផ្លាញទំនៀមទំលាប់ប្រពៃណី មានអ្វីខ្លះ ?

   - តើយុវជន និងយុវនារី អាចធ្វើអ្វីខ្លះក្នុងពេលឥឡូវនេះ ដើម្បីត្រៀមខ្លួនសម្រាប់អាពាហ៍ពិពាហ៍សេឡេស្ទាល ?

៥ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:១៨–២១ សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអម្ចាស់បានផ្ដល់សត្វពាហនៈនៃផែនដីសម្រាប់ជាការប្រើប្រាស់របស់យើង ។** ( អ្នកអាចនឹងចង់ពន្យល់ថាពាក្យ *សំលៀកបំពាក់* មានន័យថា ខោអាវ )។

- តើការព្រមានអ្វីខ្លះ ដែលមាននៅក្នុង ខ ២១ ? ហេតុអ្វីក៏អ្នកគិតថា ព្រះអម្ចាស់ពុំសព្វព្រះទ័យនឹងអ្នកទាំងឡាយដែលសម្លាប់សត្វដោយពុំចាំបាច់ ?

សូមពន្យល់ថា ពួកសេកើរ និងលីម៉ាន ខូប្លី ពុំបានធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់ទេ ។ ពួកសេកើរ បានបដិសេធសារលិខិតរបស់អ្នកផ្សព្វផ្សាយសាសនា ហើយលីម៉ាន ខូប្លី បានត្រឡប់ទៅរកជំនឿពីមុនរបស់គាត់វិញ ហើយបានចាកចេញពីសាសនាចក្រ ។

សូមបញ្ចប់ដោយការសុំឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:២៦–២៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការទូន្មាន និងការសន្យារបស់ព្រះអម្ចាស់ ។ ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យ *ការពារជួរក្រោយ* សំដៅទៅលើនរណាម្នាក់ដែលការពារដល់នរណាម្នាក់ទៀតនៅពីក្រោយខ្នង ) ។

សូមអញ្ជើញសិស្សឲ្យអានសារឡើងវិញនូវខគម្ពីរទាំងនេះដោយស្ងាត់ស្ងៀម ហើយគិតអំពីរបៀបដែលការទូន្មាន និងការសន្យាទាំងឡាយរបស់ព្រះអម្ចាស់ អនុវត្តចំពោះពួកគេម្នាក់ៗ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យទាំងឡាយដែលកើតមាននៅពេលយើងស្វែងរកការបង្រៀនរបស់ព្រះអម្ចាស់ ហើយធ្វើតាម ។

មេរៀនទី ៥៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០

## បុព្វកថា

នៅពេលយ៉ូសែប ស្ម៊ីធ បានមកដល់ទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ លោកបានសង្កេតឃើញថា « មានសញ្ញាណចម្លែកខ្លះៗ និងវិញ្ញាណក្លែងបន្លំ មាននៅក្នុងចំណោម » ពួកបរិសុទ្ធមួយចំនួន ។ លោកបានចាប់ផ្ដើមបង្រៀនដោយ « ការដាស់តឿង និង . . . ដោយប្រាជ្ញា » ដើម្បីយកឈ្នះលើរឿងទាំងនេះ ( សូមមើល *History of the Church,* ១:១៤៦ ) ។ អែលឌើរ ប៉ាលី ភី ប្រាត្ត បានត្រឡប់មកពីបេសកកម្មមួយ ហើយបានសង្កេតឃើញមានឥរិយាបទស្រដៀងគ្នានេះ នៅក្នុងសាខាជាច្រើននៃសាសនាចក្រ នៅក្រៅទីក្រុងខឺតឡង់ ។ លោក និងពួកអែលឌើរដទៃទៀត បានទៅរក យ៉ូសែប ស្ម៊ីធ ដើម្បី ទទួលការណែនាំ ( សូមមើល *History of the Church* ១:១៧០ ) ។ នៅក្នុងខែឧសភា ឆ្នាំ ១៨៣១ ព្យាការីបានទូលសួរដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធឲ្យបង្រៀន និងទទួលយកដំណឹងល្អដោយព្រះវិញ្ញាណ នៃសេចក្ដីពិត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១–៩

*ព្រះអម្ចាស់ព្រមានដល់ពួកអែលឌើរនៃសាសនាចក្រអំពីវិញ្ញាណក្លែងបន្លំ*

សូមឲ្យសិស្សនឹកស្រម៉ៃថា កំពុងចូលរួមក្នុងការប្រជុំសាក្រាម៉ង់មួយដែលមានសមាជិកមជ្ឈិមវ័យក្នុងសាសនាចក្រមួយចំនួនកំពុងឈរនៅលើកៅអី ហើយនិយាយព្រៗ ខណៈដែលអ្នកដទៃទៀតកំពុងរមៀលខ្លួននៅលើកម្រាលឥដ្ឋនោះ ។

- តើអ្នកនឹងមានអារម្មណ៍បែបណា ? តើអ្នកគិតថាមានអ្វីខ្លះនឹងកើតឡើងចំពោះព្រះវិញ្ញាណ ដែលស្ថិតនៅក្រោមស្ថានភាពដូច្នេះ ? ( សូមប្រាកដថា ការពិភាក្សានេះពុំក្លាយទៅជាការរិះគន់អំពីសាសនាមួយ ដែលមនុស្សចូលរួមនៅក្នុងសកម្មភាពដូច្នោះ ) ។

សូមពន្យល់ថា នៅពេល យ៉ូសែប ស្ម៊ីធ បានមកដល់ទីក្រុងខឺតឡង់ ជាលើកដំបូង លោកបានឃើញថា ពួកបរិសុទ្ធមួយចំនួនបានត្រូវបញ្ឆោត ក្នុងគ្រាមួយ ពេលដែលពួកគេពុំមានថ្នាក់ដឹកនាំច្រើន ។ ជាលទ្ធផល « មានសញ្ញាណចម្លែកខ្លះៗ និងវិញ្ញាណក្លែងបន្លំ មាននៅក្នុងចំណោម » ពួកគេ (*History of the Church,* ១:១៤៦ ) ។ សមាជិកថ្មីនៅក្នុងតំបន់ទីក្រុងខឺតឡង់បានណែនាំអំពីសកម្មភាពចម្លែកៗ ព្រៗ ហើយភាន់ច្រឡំនៅក្នុងកម្មវិធីថ្វាយបង្គំរបស់ពួកគេ ។ សកម្មភាពទាំងនេះ បានបង្ក់អារម្មណ៍របស់មនុស្ស ប៉ុន្តែពួកគេពុំត្រូវបានស្អាងឡើងទេ ។ ពួកអែលឌើរនៃសាសនាចក្រមួយចំនួន ពុំយល់នូវអ្វីដែលបានកើតឡើងទេ ដូច្នេះពួកគេបានសុំនូវការទូន្មានពីព្យាការី ។ លោកបានទូលសួរដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈមួយ ដែលនឹងជួយឲ្យពួកបរិសុទ្ធបានស្អាងដល់គ្នាទៅវិញទៅមក នៅពេលពួកគេបានបង្រៀន និងរៀនសេចក្ដីពិតនៃដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលប្រភពនៃឥទ្ធិពលនេះនៅក្នុងចំណោមពួកអ្នកបរិសុទ្ធ ។

- តើប្រភពនៃឥទ្ធិពលនេះគឺជាអ្វី ?
- ស្របតាម ខ ៣ ហេតុអ្វីក៏សាតាំងចង់បោកបញ្ឆោតពួកបរិសុទ្ធ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤–៩ ដោយស្ងាត់ស្ងៀម រកមើលការព្រមានរបស់ព្រះអម្ចាស់អំពីមនុស្សមួយចំនួននៅក្នុងចំណោមសមាជិកសាសនាចក្រនៅរដ្ឋ អូហៃអូ ។

- តើបន្ទូលអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រើដើម្បីពិពណ៌នាអំពីសមាជិកសាសនាចក្រមួយចំនួននៅជំនាន់នេះ ?
- តើមនុស្សលាក់ពុតជាអ្វី ? តើការលាក់ពុតផ្ដល់អំណាចដល់មារសត្រូវយ៉ាងដូចម្ដេច ?
- តើព្រះអម្ចាស់មានបន្ទូលថា អ្វីនឹងកើតឡើងដល់មនុស្សលាក់ពុត ? ( សូមមើល  គ. និង ស. ៥០:៦, ៨ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១០–៣៦

*អ្នកកាន់បព្វជិតភាព ត្រូវបានណែនាំអំពីរបៀបដើម្បីបង្រៀន និងរៀនតាមរយៈព្រះវិញ្ញាណ*

សូមសរសេរ សំណួរខាងក្រោម នៅលើក្ដារខៀន ៖

> *តើតម្រូវឲ្យមានអ្វីខ្លះ ដើម្បីក្លាយជាគ្រូបង្រៀនដំណឹងល្អដ៏មានប្រសិទ្ធភាពម្នាក់ ?*
>
> *តើតម្រូវឲ្យមានអ្វីខ្លះ ដើម្បីក្លាយជាអ្នករៀនដំណឹងល្អដ៏មានប្រសិទ្ធភាពម្នាក់ ?*

សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរទាំងនេះ ។ សូមកត់ត្រាចំណុចសំខាន់ៗរបស់ពួកគេនៅលើក្ដារខៀនក្រោមសំណួរនិមួយៗ ។ សូមបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ សូមអញ្ជើញក្រុមទីមួយអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៣–២០ ដោយស្ងាត់ស្ងៀម រកមើលចម្លើយចំពោះសំណួរទីមួយ ។ សូមអញ្ជើញក្រុមផ្សេងទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៣–២០ ដោយស្ងាត់ស្ងៀម រកមើលចម្លើយចំពោះសំណួរទីពីរ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយអ្វីដែលពួកគេបានរកឃើញ ។

- តើធាតុនៃការបង្រៀន និងការរៀនដំណឹងល្អអ្វីខ្លះ ត្រូវបានលើកឡើងដដែលៗនៅក្នុងខគម្ពីរទាំងនេះ ? ( តម្រូវការសម្រាប់មានព្រះវិញ្ញាណ ) ។

- តើតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធត្រូវបានថ្លែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៤ មានអ្វីខ្លះ ? ( សិស្សគួរតែបង្ហាញថា **ព្រះវិញ្ញាណបរិសុទ្ធ គឺជាអង្គលួងលោមចិត្ត** ហើយថា **ព្រះវិញ្ញាណបរិសុទ្ធបង្រៀនសេចក្ដីពិត** ) ។

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បីបង្រៀនដំណឹងល្អ « ដោយព្រះវិញ្ញាណ » ? (គ. និង ស. ៥០:១៤) ។ តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីបង្រៀន « តាមរបៀបផ្សេង » ? (គ. និង ស. ៥០:១៧) ។

សូមឲ្យសិស្សគិតអំពីឱកាសទាំងឡាយដែលពួកគេត្រូវបង្រៀនដំណឹងល្អ ។ ពួកគេអាចគិតអំពីការបង្រៀននៅផ្ទះជាមួយមិត្តភក្ដិ នៅក្នុងថ្នាក់សិក្ខាសាលា នៅព្រះវិហារ ឬជាគ្រូបង្រៀនតាមផ្ទះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍ទាំងឡាយដែលពួកគេមាន នៅពេលពួកគេមានព្រះវិញ្ញាណបរិសុទ្ធដឹកនាំពួកគេនៅក្នុងការបង្រៀនដំណឹងល្អ ឬការចែកចាយទីបន្ទាល់របស់ពួកគេ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ទទួល [ពាក្យនៃសេចក្ដីពិត] ដោយព្រះវិញ្ញាណនៃសេចក្ដីពិតនោះ » ? (គ. និង ស. ៥០:១៩) ។ តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីទទួលវាតាម « វិធីផ្សេង » នោះ ? (គ. និង ស. ៥០:១៩) ។

- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីទទួលដំណឹងល្អឲ្យបានកាន់តែល្អប្រសើរ នៅពេលវាត្រូវបានបង្រៀនដោយព្រះវិញ្ញាណ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវរឿងដូចខាងក្រោម ដែលបានប្រាប់ដោយអែលឌើរ ចាក អេក. ហ្គូស្លីន នៃពួកចិតសិបនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវគំនិតអំពីរបៀបដែលយើងអាចទទួលបានពាក្យសម្ដីនៃសេចក្ដីពិតតាមព្រះវិញ្ញាណកាន់តែល្អប្រសើរ ។



« តើអ្នករាល់គ្នាប៉ុន្មាននាក់ ដែលមាន ‹ អាការៈធុញទ្រាន់ › អំឡុងពេលម៉ោងប្រជុំសាក្រាម៉ង់ ? អ្នកដឹងអំពីអាការៈនោះថា ៖ ការឱនជ្រុប ការអង្គុយច្រត់ចង្ការ អង្គុយច្រត់ដៃលើជង្គង់ ឈ្ងោកមើលទៅឥដ្ឋជាដើម ។ តើអ្នកធ្លាប់មានឥរិយាបថបែបនេះ ដែលជា *ជម្រើស*របស់អ្នក ទោះជាការប្រជុំនោះមានការចាប់អារម្មណ៍ ឬ អត់ដែរឬទេ ?. . .

« ប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល បានមានប្រសាសន៍អំពីការថ្វាយបង្គំបែបនោះថា ‹ ជាការទទួលខុសត្រូវផ្ទាល់ខ្លួនមួយ ហើយទោះជាអ្វីដែលត្រូវបានថ្លែងចេញពីវេទិកាក៏ដោយ ប្រសិនបើបុគ្គលម្នាក់មានបំណងថ្វាយបង្គំព្រះអម្ចាស់តាមវិញ្ញាណ និង តាមសេចក្ដីពិត នោះគាត់អាចធ្វើដូចនោះបាន ។. . . ប្រសិនបើការប្រជុំនោះជាការធ្វេសប្រហែសចំពោះអ្នក អ្នកបានបរាជ័យហើយ ។ គ្មាននរណាម្នាក់អាចថ្វាយបង្គំជំនួសអ្នកបានឡើយ អ្នកត្រូវតែចាំទទួលព្រះអម្ចាស់ដោយខ្លួនអ្នកផ្ទាល់ › ។ ( *Ensign* ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៥ ) ។

« យុវវ័យម្នាក់បានប្រាប់អំពីបទពិសោធន៍ដំបូង ដែលគាត់មានអំពីវិញ្ញាណនៃការថ្វាយបង្គំ ។ គាត់ពុំសូវមានភាពសកម្មក្នុងការកាន់បព្វជិតភាពអើរ៉ុនរបស់គាត់ឡើយ អស់រយៈពេលជាច្រើនឆ្នាំ ។ នៅពេលគាត់ចូលរួមការប្រជុំសាក្រាម៉ង់ ជាធម្មតាគាត់អង្គុយនៅខាងក្រោយជាមួយក្រុមមិត្តភក្ដិរបស់គាត់ ហើយគាត់ពុំបានធ្វើជាគំរូល្អក្នុងការមានគារវភាពឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ថ្ងៃមួយគាត់បានមកយឺតពេល ហើយពុំមានកន្លែងអង្គុយក្បែរមិត្តភក្ដិរបស់គាត់នោះទេ ។ គាត់បានអង្គុយតែឯង ហើយនោះជាលើកទីមួយហើយនៅក្នុងជីវិតរបស់គាត់ដែលអង្គុយតែឯង គាត់បានបិទភ្នែកពេលអធិស្ឋាន

គាត់បានច្រៀងទំនុកតម្កើង គាត់បានស្ដាប់ការអធិស្ឋានសាក្រាម៉ង់ ហើយគាត់បានយកចិត្តទុកដាក់លើអ្នកឡើងនិយាយ ។ នៅពេលអ្នកឡើងនិយាយទីមួយ និយាយបានប្រហែលពាក់កណ្ដាល គាត់ឃើញថា ទឹកភ្នែកគាត់បានស្រក់ពីភ្នែករបស់គាត់ ។ ដោយការអៀនប្រៀនបន្តិច គាត់បានសម្លឹងមើលទៅជុំវិញខ្លួនដោយប្រុងប្រយ័ត្ន ប៉ុន្តែ គ្មាននរណាម្នាក់មានអារម្មណ៍រំជួលដូចជាគាត់ឡើយ ។ គាត់ពុំបានដឹងថា មានអ្វីបានកើតឡើងចំពោះគាត់នោះទេ ប៉ុន្តែ បទពិសោធន៍នោះបានកែប្រែជីវិតរបស់គាត់ ។ អំឡុងពេលការប្រជុំនោះហើយ ដែលគាត់បានចាប់ផ្ដើមត្រៀមខ្លួនយ៉ាងប្រាកដប្រជាខាងវិញ្ញាណ ដើម្បីបម្រើបេសកកម្ម ។ គាត់ *បានដឹងពី* អ្វីមួយ ហើយជាកុសលល្អ គាត់បានធ្វើតាម ហើយគាំទ្រអារម្មណ៍ទាំងនោះ » (Yagottawanna » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩១, ទំព័រ ៤៦ ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយតើផ្នែកណាមួយនៃរឿងនេះ ដែលធ្វើឲ្យពួកគេចាប់អារម្មណ៍ ។ បន្ទាប់ពីពួកគេពីរបីនាក់បានចែកចាយរួចហើយ នោះអ្នកអាចនឹងចង់ផ្ដល់យោបល់ថា ពួកគេសរសេររបៀបជាក់លាក់មួយ ដែលពួកគេអាចកែលម្អនៅក្នុងការខិតខំរបស់ពួកគេដើម្បីរៀនដោយព្រះវិញ្ញាណ ។

សូមឲ្យសិស្សពិចារណាអំពីរបៀបដែលពួកគេអាចកំណត់ថាតើពួកគេកំពុងតែបង្រៀន ឬកំពុងតែរៀនដោយព្រះវិញ្ញាណឬទេ ។ បន្ទាប់មកអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២១–២២ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលការណែនាំរបស់ព្រះអម្ចាស់អំពីរបៀបដើម្បីធ្វើដូចនេះ ។

- តើមានអ្វីកើតឡើងខ្លះ នៅពេលយើងបង្រៀន និងរៀនដោយព្រះវិញ្ញាណ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ស្អាងឡើង ហើយត្រេកអរជាមួយគ្នា » ? តើអ្នកទទួលបទពិសោធន៍នេះនៅពេលណា ?
- តើអ្នកនឹងសង្ខេបការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៣–២២ ដោយរបៀបណា ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងបង្រៀន និងរៀនដោយព្រះវិញ្ញាណ នោះយើងយល់ពីគ្នាទៅវិញទៅមក ហើយយើងត្រូវបានស្អាងឡើង ហើយត្រេកអរជាមួយគ្នា** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២៣–២៥ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលភាពផ្ទុយគ្នារវាងអ្វីដែលកើតឡើង នៅពេលមនុស្សបង្រៀនដោយព្រះវិញ្ញាណ និងអ្វីដែលកើតឡើងនៅពេលមនុស្សបង្រៀន ហើយរៀនតាម « តាមមាគ៌ាណាមួយទៀត » (គ. និង ស. ៥០:១៧) ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះអម្ចាស់ពិពណ៌នាអំពីការបង្រៀនដែលពុំស្អាងគ្នាឡើងយ៉ាងដូចម្ដេចខ្លះ ?
- តើព្រះអម្ចាស់ពិពណ៌នាអំពីការបង្រៀនដែល « មកពីព្រះ »យ៉ាងដូចម្ដេចខ្លះ ? (គ. និង ស. ៥០:២៤) ។ តើទ្រង់មានបន្ទូលថាយើងនឹងត្រូវបានប្រទានពរយ៉ាងដូចម្ដេច នៅពេលយើងទទួលការបង្រៀនដូច្នេះ ?
- តើគោលលទ្ធិអ្វីខ្លះ ត្រូវបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **អ្វីដែលមកពីព្រះជាពន្លឺ ហើយស្អាងគ្នាឡើង តែអ្វីដែលមិនមកពីព្រះ នាំឲ្យមានការច្របូកច្របល់ និងភាពងងឹត** ។ សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។
- តើអ្នកធ្លាប់ដឹងថា អ្វីមួយដែលអ្នកបានស្ដាប់ឮ មើលឃើញ ឬបានជួបពុំមែនមកពីព្រះនៅពេលណា ? តើព្រះវិញ្ញាណជួយអ្នកឲ្យស្គាល់រឿងនោះយ៉ាងដូចម្ដេច ?

ចូរពន្យល់ទៅសិស្សថា ពួកគេនឹងស្ដាប់ឮ ហើយមើលឃើញសារទាំងឡាយ ដែលមានបំណងចង់បំផ្លាញសេចក្ដីជំនឿរបស់យើង ។ គោលការណ៍ទាំងឡាយ ដែលពួកគេកំពុងរៀននៅថ្ងៃនេះ អាចជាកំផែងការពារពួកគេទប់ទល់នឹងសារទាំងនោះ ។ អ្នកអាចនឹងចង់ចែកចាយបទពិសោធន៍មួយ ដែលអ្នកមាន នៅពេលព្រះវិញ្ញាណបានជួយអ្នកឲ្យញែកដឹងថា សារមួយពុំមែនមកពីព្រះ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២៦–៣៦ ដោយការពន្យល់ថា ព្រះអម្ចាស់បានប្រឹក្សានឹងអ្នកកាន់បព្វជិតភាពទាក់ទងនឹងអំណាច និងទំនួលខុសត្រូវទាំងឡាយ ដែលមានមកជាមួយនឹងការតែងតាំងរបស់ពួកគេ ។ ទ្រង់មានបន្ទូលថា អ្នកកាន់បព្វជិតភាពទាំងឡាយ គឺត្រូវបម្រើអ្នកដទៃ និងរក្សាខ្លួនពួកគេឲ្យបរិសុទ្ធ ។ នៅពេលពួកគេធ្វើដូច្នេះ ព្រះអម្ចាស់ នឹងប្រទានអំណាចដល់ពួកគេដើម្បីយកឈ្នះលើវិញ្ញាណក្លែងបន្លំ ដូចជាវិញ្ញាណទាំងឡាយដែលរកឃើញមាននៅក្នុងចំណោមពួកបរិសុទ្ធមួយចំនួន នៅគ្រាដែលវិវរណៈនេះ ត្រូវបានប្រទានឲ្យនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៣៧–៤៦

*ព្រះអម្ចាស់លើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យបន្តរីកចម្រើននៅក្នុងព្រះគុណ និងសេចក្ដីពិត ហើយទ្រង់អះអាងដល់ពួកគេថា ទ្រង់គង់នៅជាមួយពួកគេ ។*

សូមដាក់បង្ហាញរូបភាព ការអធិស្ឋានជាគ្រួសារ (*សៀវភៅសិល្បៈដំណឹងល្អ* [ឆ្នាំ ២០០៩] ទំព័រ ១១២, សូមមើលផងដែរ LDS.org)។ សូមចង្អុលទៅក្មេងប្រុសតូចជាងគេ ហើយសួរសំណួរដូចខាងក្រោម ៖



- តើអ្នកអាចនឹកស្រម៉ៃពីកុមារតូចនេះបម្រើបេសកកម្មពេញម៉ោង នៅពេលគាត់ធំឡើងដែរឬទេ ? តើរូបភាពនេះផ្ដល់មានយោបល់អ្វីខ្លះ ដែលគាត់អាចនឹងត្រៀមខ្លួនដើម្បីបម្រើ ?
- សូមពិចារណាអំពីកិច្ចការ ដែលព្រះអម្ចាស់មាននៅក្នុងឃ្លាំងសម្រាប់យើងម្នាក់ៗ តើយើងដូចកុមារតូចនេះតាមរបៀបណាខ្លះ ?

សូមចង្អុលបង្ហាញថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៣៧–៤០ មាននូវការប្រឹក្សារបស់ព្រះអម្ចាស់ចំពោះពួកអែលឌើរមួយចំនួន ដែលមានវត្តមាន នៅពេលវិវរណៈនេះត្រូវបានទទួល ។ សូមអញ្ជើញសិស្សម្នាក់អាន ខ ៤០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការប្រឹក្សា ដែលព្រះអម្ចាស់បានផ្ដល់ទៅឲ្យពួកអែលឌើរទាំងនេះ ។

- ស្របតាម ខ ៤០ ហេតុអ្វីក៏ព្រះអម្ចាស់ហៅអ្នកកាន់បព្វជិតភាពទាំងនេះ ថា « ជាកុមារតូចៗ » ដូច្នេះ ? តើយើងដូចជាកុមារតូចៗទាំងនេះយ៉ាងដូចម្ដេច ?
- តើអ្នកគិតថា « ចម្រើនឡើងក្នុងព្រះគុណ » មានន័យយ៉ាងណា ? តើអ្នកគិតថា ចម្រើនឡើង « ក្នុងការចេះដឹងពីសេចក្ដីពិត » មានន័យយ៉ាងណា ?
- តើយើងអាចរៀនអ្វីខ្លះមកពីខនេះ អំពីពរជ័យទាំងឡាយដែលព្រះអង្គសង្គ្រោះចង់ឲ្យយើងទទួល ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះអង្គសង្គ្រោះ ចង់ឲ្យយើងរីកចម្រើននៅក្នុងព្រះគុណ និងក្នុងការចេះដឹងពីសេចក្ដីពិត** ) ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤១–៤៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យនៃការលួងលោមចិត្ត និងការធានាអះអាង ដែលព្រះអម្ចាស់បានប្រទានដល់ពួកអែលឌើរទាំងនេះ និងចំពោះយើង ។

- តើវាមានន័យយ៉ាងណា នៅពេលព្រះអម្ចាស់មានបន្ទូលថា « អ្នកជារបស់ផងយើង » ? តើការអះអាងនេះអាចជួយយើងកុំឲ្យ « ភ័យខ្លាច » យ៉ាងដូចម្ដេច ? (គ. និង ស. ៥០:៤១) ។
- តើការសន្យាផ្សេងទៀតនៅក្នុងខគម្ពីរទាំងនេះ មានអត្ថន័យយ៉ាងណាខ្លះចំពោះអ្នក ?

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងមេរៀនថ្ងៃនេះ ។ សូមលើកទឹកចិត្តសិស្សឲ្យបង្រៀន និងរៀនដោយព្រះវិញ្ញាណកាន់តែពេញលេញបន្ថែមទៀត ។

មេរៀនទី ៥៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១–៥២

## បុព្វកថា

នៅពេលពួកបរិសុទ្ធមួយចំនួនធ្វើអន្តោប្រវេសន៍មកពីរដ្ឋនៅប៉ែកខាងកើតបានចាប់ផ្ដើមមកដល់រដ្ឋ អូហៃអូ នៅក្នុងខែ ឧសភា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានបើកសម្ដែង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១ ដល់ យ៉ូសែប ស៊្មីធ សម្រាប់ប៊ីស្សព អេតវឺត ប៉ាទ្រិច ។ ក្រុមដែលមកដល់ ខូល្វិល រដ្ឋ នូវ យ៉ោក ត្រូវបានដឹកនាំឲ្យទៅ ថមសុន រដ្ឋ អូហៃអូ ជាកន្លែងដែលពួកគេនឹងរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ នៅចុងបញ្ចប់នៃសន្និសីទសាសនាចក្រលើកទី បួន ដែលបានធ្វើឡើងនៅថ្ងៃទី ៣–៦ ខែ មិថុនា ឆ្នាំ ១៨៣១ នៅទីក្រុងខឺតឡង់ នោះព្រះអម្ចាស់បានបញ្ជាឲ្យយ៉ូសែប ស៊្មីធ និងពួកអែលឌើរដទៃទៀត ធ្វើដំណើរជាគូៗទៅរដ្ឋ មិសសួរី ផ្សាយដំណឹងល្អនៅតាមផ្លូវ ។ វិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២ ព្រះអម្ចាស់បានហៅដៃគូនិមួយៗ ហើយប្រទានឲ្យនូវគំរូមួយដើម្បីជួយពួកគេឲ្យចៀសវាងពីការបោកបញ្ឆោត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១:១–២០

*ព្រះអម្ចាស់ដឹកនាំប៊ីស្សព អេតវឺត ប៉ាទ្រិច ឲ្យថ្លែងអំពីតម្រូវការខាងសាច់ឈាមរបស់ពួកបរិសុទ្ធ ។*

ដើម្បីជួយសិស្សចាប់ផ្ដើមគិតអំពីលទ្ធផលមួយនៃការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរដូចខាងក្រោមជាគូៗ ឬក្រុមតូចៗ ឬជាថ្នាក់រៀនទាំងមូល ។

- តើក្រុមដែលមានសាមគ្គីភាពបំផុតដែលអ្នកចូលរួមគឺជាក្រុមអ្វី ? តើអ្នកដឹងថា ក្រុមមួយមានសាមគ្គីភាពដោយរបៀបណា ? តើការអនុវត្ត ឬព្រឹត្តការណ៍ប្រភេទណា ដែលជួយក្រុមមួយឲ្យមានសាមគ្គីភាពនោះ ?

សូមពន្យល់ថា ពួកបរិសុទ្ធដែលផ្លាស់ពីរដ្ឋ នូវ យ៉ោក បានចាប់ផ្ដើមមកដល់រដ្ឋ អូហៃអូ នៅដើមនិទាឃរដូវឆ្នាំ ១៨៣១ ។ ក្រុមមួយបានចេញមកពី ខូលស្វិល រដ្ឋ នូវ យ៉ោក ដោយមានការលះបង់យ៉ាងខ្លាំង ។ ក្រុមនេះត្រូវបានណែនាំឲ្យបោះទីតាំងនៅ ថមសុន រដ្ឋ អូហៃអូ ហើយរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ សូមអញ្ជើញសិស្សឲ្យនឹកស្រមៃអំពីសាមគ្គីភាពដែលជាលទ្ធផលបានមកពីក្រុមមួយ ដែលបានលះបង់ជាមួយគ្នា ដើម្បីធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលទំនួលខុសត្រូវរបស់ប៊ីស្សព អេតវឺត ប៉ាទ្រិច ។

- តើទំនួលខុសត្រូវមួយចំនួនរបស់ ប៊ីស្សព ប៉ាទ្រិច មានអ្វីខ្លះ ? ( អ្នកអាចនឹងចង់ចង្អុលបង្ហាញថា នៅក្នុង ខ ៣ ឃ្លា « ត្រូវបានដូចគ្នាតាមគ្រួសាររបស់ខ្លួន » ពុំមានន័យថា ពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវទទួលជំនួយដូចគ្នានោះទេ ។ ប៊ីស្សពត្រូវគិតអំពីស្ថានភាពរបស់គ្រួសារនីមួយៗផ្សេងៗគ្នា ហើយ « ផ្ដល់ឲ្យ » ពួកគេនូវអ្វីដែលពួកគេត្រូវការ ។ ពួកគេត្រូវបានស្មើគ្នា ដោយសារប៊ីស្សព បានគិត ហើយមើលថែគ្រួសារនីមួយៗដូចៗគ្នា ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១:៩ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះអម្ចាស់បានពន្យល់ដែលជាលទ្ធផលពីរយ៉ាងនៃការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។

- តើព្រះអម្ចាស់រំពឹងអ្វីខ្លះពីរាស្ត្ររបស់ទ្រង់ ? ( សិស្សគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់រំពឹងឲ្យរាស្ត្ររបស់ទ្រង់ ប្រាស្រ័យទាក់ទងគ្នាដោយស្មោះត្រង់ ហើយត្រូវមានសាមគ្គីភាព** ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១:១០–២០ ដោយពន្យល់ថា ព្រះអម្ចាស់បានណែនាំប៊ីស្សព ប៉ាទ្រិច ឲ្យបង្កើតឃ្លាំងមួយ សម្រាប់ផ្ទុកផលិតផលដែលនៅសល់ ។ ទ្រង់បានពន្យល់ថា ទ្រង់បានតាំងដែនដីនេះដល់ពួកបរិសុទ្ធ « សម្រាប់មួយរដូវតូច » (គ. និង ស. ៥១:១៦ ) ។ ទោះបីជាពួកគេពុំដឹងថាពួកគេស្នាក់នៅបានរយៈពេលយូរប៉ុណ្ណាក្ដី ក៏ពួកគេត្រូវ « ប្រព្រឹត្តនៅលើដែនដីនេះហាក់ដូចជានៅច្រើនឆ្នាំ » (គ. និង ស. ៥១:១៧) ដោយធ្វើជាបាវស្មោះត្រង់ ឈ្លាសវៃ និងយុត្តិធម៌នូវអ្វីដែលពួកគេត្រូវបានប្រទានឲ្យ ។ អ្នកក៏អាចនឹងចង់ចង្អុលបង្ហាញថា នៅក្នុង ខ ១០ ពាក្យ *ព្រះវិហារ* សំដៅទៅលើសាខាមួយរបស់សាសនាចក្រ ( សូមមើល គ. និង ស. ៥១:១០ លេខយោង *ក* សូមមើលផងដែរ គ. និង ស. ២០:៨១, ៤៥:៦៤) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–១៣, ២២–៣៦ ។

*ព្រះអម្ចាស់បានបញ្ជាព្យាការី និងពួកអែលឌើរដទៃទៀត ឲ្យធ្វើដំណើរទៅរដ្ឋ មិសសួរី ហើយផ្សាយដំណឹងល្អ អំឡុងពេលនៃការធ្វើដំណើររបស់ពួកគេ*

ពីមុនថ្នាក់ចាប់ផ្ដើមសូមរៀបចំតម្រុយចំនួនបី ដែលតម្រុយនិមួយៗនាំទៅរកតម្រុយមួយទៀត ។ ឧទាហរណ៍ តម្រុយទីមួយអាចនឹងនាំសិស្សឲ្យរកមើលតម្រុយទីពីរ នៅក្រោម ឬនៅក្នុងវត្ថុមួយ នៅកន្លែងណាមួយក្នុងថ្នាក់រៀន ។ តម្រុយទីពីរអាចនឹងនាំពួកគេឲ្យស្វែងរកតម្រុយទីបីនៅកន្លែងផ្សេងក្នុងថ្នាក់រៀន ។ តម្រុយទីបីគួរតែនិយាយថា « អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–៦ ។ សូមរកគោលការណ៍មួយដែលស្រដៀងគ្នាទៅនឹងសកម្មភាពនេះ » ។

សូមបិទតម្រុយទីមួយនៅលើក្ដារខៀន ហើយសរសេរការណែនាំដូចខាងក្រោមនៅជិតវា ៖ *ធ្វើតាមតម្រុយនេះ ដើម្បីរៀនអំពីរបៀបទទួលបានការណែនាំជាបន្តបន្ទាប់មកពីព្រះអម្ចាស់ ។*

បន្ទាប់ពីសិស្សអានតម្រុយទីមួយ សូមអញ្ជើញពួកគេឲ្យធ្វើតាមការណែនាំដើម្បីរកតម្រុយទីពីរ ។ បន្ទាប់មកអញ្ជើញពួកគេឲ្យអានការណែនាំនៅតម្រុយទីពីរ ហើយស្វែងរកតម្រុយទីបី ។

ពីមុនសិស្សធ្វើតាមការដឹកនាំទៅតម្រុយទីបី សូមពន្យល់ថា វគ្គបទគម្ពីរ ដែលពួកគេនឹងស្វែងរក គឺមានការណែនាំដែលបានប្រទានឲ្យយ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំបព្វជិតភាពដទៃទៀត នៅក្នុងសន្និសីទមួយរបស់សាសនាចក្រ ដែលបានធ្វើឡើងនៅក្នុងទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ ក្នុងខែមិថុនា ឆ្នាំ ១៨៣១ ។ សូមរំឭកសិស្សថា ព្រះអម្ចាស់ បានបើកសម្ដែងពីមុនមកថា ពួកបរិសុទ្ធនឹងបង្កើតទីក្រុងមួយ ហៅថា *ស៊ីយ៉ូន* ( សូមមើល គ. និង ស. ២៨:៩) ប៉ុន្តែទ្រង់ពុំទាន់បានបើកសម្ដែងពីទីតាំងនោះទេ ។

សូមអញ្ជើញសិស្សឲ្យធ្វើតាមការណែនាំនៅក្នុងតម្រុយទីបី ។ សូមអញ្ជើញសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអានចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–៦ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម រកមើលគោលការណ៍មួយដែលស្រដៀងគ្នាទៅនឹងសកម្មភាព ដែលពួកគេទើបតែបានបំពេញ ។

- យោងតាម ខ ៤–៥, តើអ្វីខ្លះអាចកើតឡើង នៅពេលយើងស្មោះត្រង់ចំពោះការណែនាំរបស់ព្រះ ? (**នៅពេលយើងធ្វើតាមការណែនាំរបស់ព្រះដោយស្មោះត្រង់ នោះទ្រង់នឹងបើកសម្ដែងព្រះទ័យទ្រង់កាន់តែច្រើនដល់យើង ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើសកម្មភាពនេះស្រដៀងគ្នានឹងគោលការណ៍នេះយ៉ាងដូចម្ដេច ? ( នៅពេលសិស្សធ្វើតាមការណែនាំនីមួយៗ នោះពួកគេបានទទួលការដឹកនាំបន្ថែម ដែលទីបំផុតនាំពួកគេទៅរកចម្លើយ ដែលពួកគេកំពុងស្វែងរក ) ។

- តើអ្នកមានអារម្មណ៍យ៉ាងណា ដែលមនុស្សមួយចំនួនទទួលបានការណែនាំ និងសេចក្ដីពិតរបស់ព្រះអម្ចាស់បន្តិចម្ដងៗ ជាជាងបានទទួលម្ដងទាំងអស់នោះ ?

សូមអញ្ជើញសិស្សដែលមានបទពិសោធន៍មួយជាមួយនឹងគោលការណ៍នេះ ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ឬថ្លែងទីបន្ទាល់អំពីសេចក្ដីពិតពេញលេញ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយ ឬទីបន្ទាល់របស់អ្នកផងដែរ ។ សូមលើកទឹកចិត្តសិស្សឲ្យសរសេរសំណួរ កង្វល់ ឬការសម្រេចចិត្តមួយ ដែលពួកគេកំពុងជួប ដែលពួកគេចង់ទទួលបានជំនួយ និងការដឹកនាំរបស់ព្រះអម្ចាស់ ។ បន្ទាប់មក អញ្ជើញពួកគេឲ្យពិចារណា និងសរសេរនូវការណែនាំនានា ដែលព្រះអម្ចាស់បានប្រទានដល់ពួកគេ ដែលពួកគេអាចនឹងប្រុងស្ដាប់កាន់តែច្រើន ដើម្បីអញ្ជើញឲ្យមានការដឹកនាំបន្ថែមមកពីទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៧–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការណែនាំដែលព្រះអម្ចាស់បានប្រទានដល់អ្នកកាន់បព្វជិតភាពមួយចំនួន ពីមុនពួកគេបានធ្វើដំណើរទៅរដ្ឋ មិសសួរី ។

- តើអ្នកកាន់បព្វជិតភាពទាំងនេះ បានណែនាំឲ្យធ្វើអ្វីខ្លះ នៅពេលពួកគេបានធ្វើដំណើរ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤–២១, ៣៦

*ព្រះអម្ចាស់បើកសម្ដែងគំរូមួយដើម្បីជួយយើងចៀសវាងពីការត្រូវបញ្ឆោតដោយសាតាំង*

សូមរំឭកសិស្សថា នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ ព្រះអម្ចាស់បានព្រមានដល់ពួកអែលឌើរនៃសាសនាចក្រអំពីវិញ្ញាណក្លែងក្លាយ ហើយប្រទានការណែនាំដែលនឹងជួយពួកបរិសុទ្ធស្អាងគ្នាទៅវិញទៅមក នៅពេលពួកគេបានបង្រៀន និងរៀនសេចក្ដីពិតនៃដំណឹងល្អ ។

សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤–២១ ព្រះអម្ចាស់បានបើកសម្ដែងការណែនាំបន្ថែម ដើម្បីជួយពង្រឹងដល់សមាជិកសាសនាចក្រ ជាពិសេសអ្នកទាំងឡាយដែលទ្រង់បានហៅឲ្យផ្សាយដំណឹងល្អ នៅពេលពួកគេបានធ្វើដំណើរទៅរដ្ឋ មិសសួរី ។

### *សូមជួយសិស្សឲ្យរៀបចំដើម្បីរៀន*

សូមជួយសិស្សឲ្យផ្ដោតទៅលើបទពិសោធន៍នៃការរៀនសូត្រ តាមរយៈការប្រើសកម្មភាព វត្ថុជំនួយ ឬសំណួរដែលបំភ្លឺចំណាប់អារម្មណ៍របស់សិស្ស ហើយជួយពួកគេឲ្យមើលឃើញទំនាក់ទំនងទាំងឡាយនៃបទគម្ពីរនៅក្នុងជីវិតរបស់ពួកគេ ។ ទាំងនេះគួរតែត្រូវបានធ្វើឡើងតាមរបៀបមួយ ដែលផ្ដោតទៅលើចំណាប់អារម្មណ៍របស់សិស្ស ហើយនាំពួកគេឲ្យស្រាវជ្រាវបទគម្ពីរក្នុងគោលបំណងកាន់តែអស្ចារ្យ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ឃ្លាដែលព្រះអម្ចាស់បានប្រើដើម្បីពិពណ៌នាអំពីអ្វីដែលទ្រង់ហៀបនឹងបង្រៀន ។ ( « គំរូនៃរឿងគ្រប់យ៉ាង » ) ។

- តើគំរូជាអ្វី ? ( គំរូមួយដែលយើងអាចធ្វើតាម ដើម្បីសម្រេចលទ្ធផលជាក់លាក់មួយ ) ។
- តើព្រះអម្ចាស់បានផ្ដល់មូលហេតុអ្វីខ្លះ ចំពោះការផ្ដល់គំរូនេះ ?

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញសិស្សបួនប្រាំនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៥–១៩ ។ សូមឲ្យពួកគេរកមើលសកម្មភាព និងអាកប្បកិរិយាដែលព្រះអម្ចាស់បានមានបន្ទូលថានឹងជួយរាស្ត្រទ្រង់ចៀសវាងពីការត្រូវបញ្ឆោតដោយសាតាំង ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាស្មៀន ហើយសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។

នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់ពន្យល់ ឬសុំឲ្យពួកគេពន្យល់អំពីអត្ថន័យនៃឃ្លាដូចខាងក្រោម ៖ « ដែលមានវិញ្ញាណទន់ទាប » (គ. និង ស. ៥២:១៥) សំដៅទៅលើមនុស្សម្នាក់ ដែលមានឥរិយាបទប្រែចិត្ត « គោរពតាមពិធីបរិសុទ្ធទាំងឡាយរបស់យើង » (គ. និង ស. ៥២:១៥) សំដៅទៅលើមនុស្សដែលទទួលពិធីបរិសុទ្ធរបស់ព្រះអម្ចាស់ ហើយរក្សានូវសេចក្ដីសញ្ញាទាំងឡាយដែលជាប់ទាក់ទង « ដែលប្រើពាក្យសម្ដីសុភាពហើយស្អាងឡើង » (គ. និង ស. ៥២:១៦) សំដៅទៅលើមនុស្សដែលនិយាយរាបសារ ហើយលើកតម្កើង និងស្ថាបនាអ្នកដទៃ « ដែលញ័ររន្ធត់នៅក្រោមព្រះចេស្ដារបស់យើង » (គ. និង ស. ៥២:១៧) ពិពណ៌នាអំពីមនុស្សដែលមានអារម្មណ៍គារវភាពចំពោះព្រះចេស្ដានៃព្រះ « នឹងនាំផល » (គ. និង ស. ៥២:១៧) សំដៅទៅលើមនុស្សដែលបង្កើតសេចក្ដីល្អ ( ដូចជា « ការសរសើរ និងប្រាជ្ញា » ) ដោយធ្វើតាមវិវរណៈដែលព្រះបានប្រទានឲ្យ ។

សូមទុកពេលឲ្យសិស្សដែលជាដៃគូ ពិភាក្សាអំពីរបៀបដែលពួកគេនឹងសង្ខេបអំពីសេចក្ដីពិត ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤–១៩ ។ បន្ទាប់ពីផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមអញ្ជើញពួកគេឲ្យចែកចាយសេចក្ដីពិតដែលពួកគេបានពិពណ៌នា ។ សិស្សអាចនឹងផ្ដល់ចម្លើយផ្សេងៗគ្នា ប៉ុន្តែអ្នកអាចនឹងចង់គូសបញ្ជាក់គោលការណ៍ដូចខាងក្រោម ៖ **ដើម្បីចៀសវាងពីការត្រូវបញ្ឆោតដោយសាតាំង មនុស្សម្នាក់នោះត្រូវតែគោរពតាមពិធីបរិសុទ្ធរបស់ព្រះអម្ចាស់ ហើយរស់នៅស្របតាមវិវរណៈទាំងឡាយដែលទ្រង់បានប្រទានឲ្យ ។**

សូមរំឭកសិស្សថា នៅពេលព្រះអម្ចាស់បើកសម្ដែងគំរូនេះដើម្បីចៀសវាងពីការបោកបញ្ឆោត នោះទ្រង់កំពុងមានបន្ទូលទៅក្រុមអ្នកកាន់បព្វជិតភាពមួយក្រុម ដែលនឹងផ្សាយដំណឹងល្អដល់អ្នកដទៃ ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់ចំពោះអ្នកទាំងឡាយដែលបង្រៀនដំណឹងល្អដល់អ្នកដទៃ ដើម្បីធ្វើតាមគំរូដែលព្រះអម្ចាស់បានបើកសម្ដែងនៅក្នុងខគម្ពីរទាំងនេះ ? ( ដូច្នេះពួកគេអាចបង្រៀនដោយព្រះវិញ្ញាណ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៣៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការណែនាំបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុងវិវរណៈនេះ ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះអម្ចាស់ណែនាំពួកអែលឌើរនៃសាសនាចក្រឲ្យប្រកាសអ្វីខ្លះ ?
- ហេតុអ្វីក៏យើងអាចមានទំនុកចិត្តទៅលើអ្នកដឹកនាំ ឬគ្រូបង្រៀនម្នាក់ដែលរស់នៅស្របតាមគំរូដែលព្រះអម្ចាស់បានចែងនៅក្នុង ខ ១៤–១៩ ហើយបង្រៀនតែអ្វីដែលពួកព្យាការី និងពួកសាវកបានបង្រៀនដូច្នេះ ?

អ្នកអាចនឹងផ្ដល់យោបល់ថា សិស្សពិចារណាអំពីរបៀបដែលសមាជិកនៃគណៈប្រធានទីមួយ ឬកូរ៉ុមនៃពួកសាវកដប់ពីរនាក់បង្ហាញពីគំរូនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៣៧–៤៤

*ព្រះអម្ចាស់ប្រទានដំបូន្មានដល់ពួកអ្នកដឹកនាំដែលនឹងបន្តនៅក្នុងរដ្ឋ អូហៃអូ*

សូមពន្យល់ថា ខណៈដែលព្រះអម្ចាស់បានហៅពួកអ្នកកាន់បព្វជិតភាពពីជំនាន់មុនជាច្រើនឲ្យផ្សាយនៅតាមផ្លូវរបស់ពួកគេទៅរដ្ឋ មិសសួរី នោះមានពួកអែលឌើរខ្លះទៀតគឺត្រូវនៅក្នុងរដ្ឋ អូហៃអូ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៣៩–៤០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវការណែនាំ ដែលព្រះអម្ចាស់បានប្រទានដល់ពួកអែលឌើរដែលបន្តរស់នៅក្នុងរដ្ឋ អូហៃអូ ។

- តើទំនួលខុសត្រូវអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ពួកអែលឌើរ ដែលបន្តនៅក្នុងរដ្ឋ អូហៃអូ ?
- តើអ្នកគិតថា « . . .នឹកដល់មនុស្សទាល់ក្រ និងទុគត៌ » មានន័យយ៉ាងណា ? ហេតុអ្វីក៏ការគ្រាន់តែគិតអំពីនរណាម្នាក់ដែលមានការខ្វះខាត វាពុំល្មមគ្រប់គ្រាន់ក្នុងការបំពេញតាមដំបូន្មានមកពីព្រះអម្ចាស់ដូច្នេះ ?

- តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ អំពីអ្នកទាំងឡាយដែលនឹងមិនបំពេញតាមទំនួលខុសត្រូវរបស់ពួកគេ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ អំពីការធ្វើជាសិស្សពិតរបស់ព្រះអម្ចាស់ ? ( ទោះជាសិស្សប្រើពាក្យផ្សេងៗ ក៏ពួកគេគួរប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ មើលថែ និងថែទាំដល់អ្នកទាំងឡាយដែលក្រីក្រ ខ្វះខាត ឈឺ និងរងទុក្ខ** ) ។

សូមឲ្យសិស្សគិតអំពីមនុស្សដែលពួកគេស្គាល់ ដែលពួកគេចាត់ទុកថាជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីរបៀបដែលមនុស្សម្នាក់ ដែលពួកគេបានគិត ចំពោះការមើលថែ និងថែទាំដល់អ្នកទាំងឡាយដែលខ្វះខាត ។ អ្នកអាចនឹងចង់សម្ដែងនូវការដឹងគុណ ដែលអ្នកមានចំពោះអ្នកទាំងឡាយដែលបានមើលថែ និងបានជួយអ្នកនៅក្នុងគ្រាខ្វះខាត ។

មេរៀនទី ៥៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៥

## បុព្វកថា

នៅក្នុងខែមិថុនា ឆ្នាំ ១៨៣១ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៥។ វិវរណៈមាននូវការណែនាំរបស់ព្រះអម្ចាស់ចំពោះសមាជិកមួយចំនួននៃសាសនាចក្រដែលបានរស់នៅក្នុងរដ្ឋ អូហៃអូ ប៉ុន្តែមិនយូរប៉ុន្មានបានផ្លាស់ទៅរដ្ឋ មីសសួរី ។

នៅក្នុងវិវរណៈទាំងនេះ ព្រះអម្ចាស់បានមានបន្ទូលទៅកាន់ ស៊ីឌនី ហ្គីលបើត, នូវែល ណៃត និង វិលលាម ដ័បបុលយូ ហ្វែប្ស ដោយប្រទានដល់ពួកគាត់នូវការណែនាំ ដែលជាក់លាក់ចំពោះកិច្ចការសាសនាចក្រ និងទេពកោសល្យរបស់ពួកគាត់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣

*ព្រះអម្ចាស់ ហៅ ស៊ីឌនី ហ្គីលបើត ឲ្យធ្វើជាអែលឌើរម្នាក់ ហើយបានធ្វើដំណើរជាមួយនឹង យ៉ូសែប ស្ម៊ីធ ទៅកាន់រដ្ឋមិសសួរី ។*

សូមអញ្ជើញឲ្យសិស្សពីរនាក់ឡើងមកខាងមុខថ្នាក់ ។ សូមសុំឲ្យសិស្សម្នាក់ណែនាំដល់សិស្សផ្សេងទៀតអំពីរបៀបដើម្បីធ្វើកិច្ចការជាក់លាក់មួយ ។ ឧទាហរណ៍ សិស្សម្នាក់អាចបង្រៀនសិស្សផ្សេងទៀត ឲ្យចងចំណងជាក់លាក់មួយ បត់ជាយន្តហោះក្រដាស ឬសម្ដែងការរាំជាក់លាក់មួយ ។ ( បើអាចធ្វើទៅបាន សូមបាប្រប់ដល់សិស្សម្នាក់ឲ្យរៀបចំខ្លួនដើម្បីបង្រៀនជំនាញមួយពីមុនម៉ោង ) ។

- នៅក្នុងការសម្ដែងនេះ ហេតុអ្វីក៏វាសំខាន់ ដែលអ្នករៀនត្រូវធ្វើតាមការណែនាំទាំងអស់នេះ ? តើនឹងមានអ្វីកើតឡើងបើពួកគេសម្រេចចិត្តថាមិនធ្វើតាមផ្នែកណាមួយនៃការណែនាំនោះ ?

សូមរំឭកសិស្សថា ព្រះអម្ចាស់ បានហៅពួកអ្នកផ្សព្វផ្សាយសាសនាឲ្យធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥២ ) ។ សូមពន្យល់ថា អ្នកផ្លាស់ប្រែចិត្តជឿថ្មីម្នាក់ ឈ្មោះ ស៊ីឌនី ហ្គីលបើត បានរកឃើញថា គាត់ពុំរាប់បញ្ចូលជាអ្នកផ្សព្វផ្សាយម្នាក់ក្នុងចំណោមអ្នកផ្សព្វផ្សាយទាំងឡាយទេ ។ គាត់បានទៅជួបព្យាការីយ៉ូសែប ស្ម៊ីធ ហើយបានសួរថា តើព្រះអម្ចាស់មានព្រះទ័យឲ្យគាត់ធ្វើអ្វី ។ យ៉ូសែប បានទូលសួរ ហើយបានទទួលវិវរណៈនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣, ដែលផ្ដល់នូវជំហានចាប់ផ្ដើមមួយចំនួននៃសេចក្ដីណែនាំដល់ ស៊ីឌនី ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមអញ្ជើញគូនិមួយៗឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣:១–៥ រកមើលការណែនាំដែលព្រះអម្ចាស់បានប្រទានដល់ ស៊ីឌនី ហ្គីលបើត ។ សូមលើកទឹកចិត្តពួកគេឲ្យគូសចំណាំការណែនាំនិមួយៗ ដែលពួកគេរកឃើញ ។

- តើការណែនាំអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ ស៊ីឌនី ហ្គីលបើត ? ( នៅពេលសិស្សរៀបរាប់នូវអ្វីដែលពួកគេរកឃើញ វាអាចនឹងជាប្រយោជន៍ដើម្បីចង្អុលបង្ហាញថា កិច្ចការរបស់បងប្រុស ហ្គីលបើត ឲ្យធ្វើជា « ភ្នាក់ងារមួយចំពោះសាសនាចក្រ » ត្រូវបានពន្យល់កាន់តែពេញលេញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៦–១០, ទំព័រ ១៥ ) ។

សូមពន្យល់ថា ព្រះអម្ចាស់ បានសំដៅទៅលើបញ្ជីនៃ ការណែនាំនេះថាជា « ពិធីបរិសុទ្ធដំបូងទាំងឡាយដែល [ ស៊ីឌនី ] នឹងទទួល » (គ. និង ស. ៥៣:៦ ) ។ ពាក្យ *ពិធីបរិសុទ្ធ* ពេលខ្លះ សំដៅទៅលើច្បាប់មួយ ឬបញ្ញត្តិ មួយ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣:៦ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលគ្រា ដែលព្រះអម្ចាស់ នឹងប្រទានការណែនាំដែលនៅសល់ (« ដែលនៅសល់ » ) ទាំងប៉ុន្មានរបស់ទ្រង់ ដល់ស៊ីឌនី ។

- តើយើងអាចរៀនអ្វីខ្លះមកពី ខ ៦ នេះ ? ( សូមពិចារណាផ្ដល់យោបល់ថា សិស្សអាចយោងបទគម្ពីរនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៤–៥ ។ សិស្សអាចចងចាំប្រាប់អំពីគោលការណ៍ដូចខាងក្រោមនៅក្នុងមេរៀនមុនៗ ៖ **នៅពេលយើងធ្វើតាមការណែនាំរបស់ព្រះដោយស្មោះស្ម័គ្រ នោះទ្រង់នឹងបើកសម្ដែងព្រះឆន្ទៈរបស់ទ្រង់ដល់យើងកាន់តែច្រើន** ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤

*ព្រះអម្ចាស់ ណែនាំពួកបរិសុទ្ធនៅ ខូលស្វិល ឲ្យចាកចេញពី ថមសុន រដ្ឋ អូហៃអូ ហើយផ្លាស់ទៅរដ្ឋ មិសសួរី*

សូមពន្យល់ថា នៅខែមេសា ឆ្នាំ ១៨៣១ នូវែល ណៃត បានដឹកនាំក្រុមនៃពួកបរិសុទ្ធម្នាក់ចេញពី ខូលស្វិល រដ្ឋ នូវ យ៉ោក ទៅចូលរួមនឹងពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ។ នៅខែ ឧសភា ព្យាការីយ៉ូសែប ស្ម៊ីធ បានណែនាំប៊ីស្សព អែតវឺត ប៉ាទ្រិច ឲ្យជួយពួកបរិសុទ្ធទាំងនោះស្នាក់នៅលើទឹកដីក្នុង ភូមិ ថមសុន រដ្ឋ អូហៃអូ ដែលលីម៉ាន ខូព្លី ត្រូវបានធ្វើសេចក្ដីសញ្ញាកាលពីលើកមុន ( ឬ បានសន្យា ) ថាផ្ដល់ឲ្យសម្រាប់គោលបំណងនោះ ។ ពួកគេបានដាំដំណាំនៅទីនោះ ហើយបានចាប់ផ្ដើមបង្កបង្កើនផលនៅលើដីធ្លីនោះ ។ ប៉ុន្តែ ទោះជាពួកគេបានធ្វើការជាមួយគ្នាដើម្បីកែលម្អដល់ដែនដីក្ដី ក៏ពួកគេបានចាប់ផ្ដើមមានចិត្តកំណាញ់ ហើយអត្មានិយម ។ ស្ថានភាពរបស់ពួកគេកាន់តែអាក្រក់ឡើង នៅពេល លីម៉ាន ខូព្លី បានត្រឡប់មកពីបេសកកម្មរបស់គាត់ទៅកាន់ពួកសេកើរវិញ ហើយបានចាប់ផ្ដើមសង្ស័យលើជំនឿរបស់គាត់ ( សូមមើល គ. និង ស. ៤៩ និងមេរៀនទី ៥៦ ) ។ គាត់បានបដិសេធក្នុងការអភិវឌ្ឍទីបន្ទាល់របស់គាត់ អំពីដំណឹងល្អដែលបានស្ដារឡើងវិញ ហើយគាត់បានបញ្ជាឲ្យពួកបរិសុទ្ធចាកចេញពីដី ។ គាត់ក៏បានគិតថ្លៃពីពួកគេ ៦០ ដុល្លារផងដែរ ។ ដោយសារ លីម៉ាន មិនគោរពសេចក្ដីសញ្ញារបស់គាត់ នោះពួកបរិសុទ្ធទាំងនេះឥឡូវគ្មានកន្លែងរស់នៅទេ ។ នូវែល ណៃត និងអ្នកផ្សេងទៀតបានសួរព្យាការី ពីអ្វីដែលពួកគេគួរធ្វើអ្វី ។ ( សូមមើល *Documents, Volume ១: ខែ មិថុនា ឆ្នាំ ១៨២៨–ខែ មិថុនា ឆ្នាំ ១៨៣១* vol. ១ of the Documents series of *The Joseph Smith Papers* [ឆ្នាំ ២០១៣], ទំព័រ ៣៣៤–៣៣៥។ )

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:១–៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលពួកបរិសុទ្ធចាំបាច់ត្រូវធ្វើដើម្បីជួយកែលម្អស្ថានភាពរបស់ពួកគេ ។

- ហេតុអ្វីក៏អ្នកគិតថា ការប្រែចិត្ត និងភាពរាបសារ នឹងជួយដល់ពួកបរិសុទ្ធទាំងនេះ ?

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់ ពុំសព្វព្រះទ័យនឹងពួកបរិសុទ្ធនៅក្នុងភូមិ ថមសុន ដែលបានក្បត់សេចក្ដីសញ្ញារបស់ពួកគេនោះទេ ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:៤–៥ ដោយស្ងាត់ស្ងៀម ហើយរកមើលពាក្យ ឬឃ្លាដែលព្រះអម្ចាស់បានប្រើដើម្បីពិពណ៌នាអំពីអ្វីដែលបានកើតមានឡើងនៅពេលដែលមិនរក្សាសេចក្ដីសញ្ញា ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាចំពោះសេចក្ដីសញ្ញាមួយ « ត្រូវបានលុបចោល ហើយគ្មានប្រសិទ្ធភាពនោះ » ? តើពរជ័យអ្វីខ្លះដែលយើងបានបាត់បង់ នៅពេលយើងពុំរក្សាសេចក្ដីសញ្ញារបស់យើង ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:៦ ដោយស្ងាត់ស្ងៀម រកមើលពរជ័យមួយ ដែលយើងទទួលនៅពេលយើងរក្សាសេចក្ដីសញ្ញារបស់យើង ហើយគោរពតាមបទបញ្ញត្តិទាំងឡាយ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ពួកគេអាចប្រើពាក្យផ្សេងៗ ប៉ុន្តែចម្លើយរបស់ពួកគេគួរតែនាំទៅរកគោលការណ៍ដូចខាងក្រោម ៖ **បើយើងរក្សាសេចក្ដីសញ្ញារបស់យើង ហើយគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងនឹងទទួលបានសេចក្ដីមេត្តាករុណា ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។

- តើអ្នកបានឃើញថា ព្រះអម្ចាស់បានផ្ដល់ក្ដីមេត្តាករុណាដល់អ្នកទាំងឡាយដែលរក្សាសេចក្ដីសញ្ញារបស់ពួកគេជាមួយទ្រង់នៅពេលណា ?

សូមលើកទឹកចិត្តសិស្សឲ្យរក្សាសេចក្ដីសញ្ញាទាំងឡាយដែលពួកគេបានធ្វើនៅពិធីបុណ្យជ្រមុជទឹក ហើយគោរពបទបញ្ញត្តិទាំងឡាយ ដើម្បីពួកគេអាចទទួលបានសេចក្ដីមេត្តាករុណាមកពីព្រះអម្ចាស់ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:៧–៩ ដោយពន្យល់ថា បន្ទាប់ពីពួកបរិសុទ្ធទាំងនេះបានបាត់បង់គេហដ្ឋានរបស់ពួកគេនៅលើដីរបស់ លីម៉ាន ខូព្លី នោះព្រះអម្ចាស់បានបញ្ជាឲ្យពួកគេធ្វើដំណើរទៅរដ្ឋ មិសសួរី ។ ពួកគេត្រូវតែងតាំងនរណាម្នាក់ឲ្យបង់ថ្លៃការចំណាយនៅតាមផ្លូវ ។ ព្រះអម្ចាស់ មានបន្ទូលថា នៅពេលពួកគេទៅដល់រដ្ឋ មិសសួរី នោះពួកគេនឹងធ្វើការសម្រាប់ការរស់នៅរបស់ពួកគេនៅទីនោះ រហូតទាល់តែព្រះអម្ចាស់នឹងរៀបចំកន្លែងមួយសម្រាប់ពួកគេតាំងទីលំនៅ ។

ដើម្បីជួយសិស្សរកឃើញរបៀបដែលព្រះអម្ចាស់ចង់ឲ្យពួកបរិសុទ្ធទាំងនេះឆ្លើយតបចំពោះការសាកល្បងរបស់ពួកគេ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយ រកមើលការទូន្មានរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធទាំងនេះ ។

- តាមបទពិសោធន៍របស់អ្នក តើពរជ័យមួយចំនួនណាខ្លះ ដែលយើងទទួលបាន នៅពេលយើង « មានចិត្តអត់ធន់នៅក្នុងសេចក្ដីលំបាក » ?

- តើនរណាដែលព្រះអម្ចាស់មានបន្ទូលថានឹង « រកឃើញសេចក្ដីសម្រាកដល់ព្រលឹងរបស់ពួកគេ » ? ( សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរនេះជាមួយនឹងប្រយោគ « បើសិនជា– នោះ » ។ នៅពេលពួកគេឆ្លើយសំណួរ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ៖ **បើយើងស្វែងរកព្រះអម្ចាស់ពីមុនៗ នោះយើងនឹងរកឃើញសេចក្ដីសម្រាកដល់ព្រលឹងរបស់យើង** ) ។

ដើម្បីជួយសិស្សយល់នូវអត្ថន័យដើម្បីរកឃើញសេចក្ដីសម្រាកដល់ព្រលឹងរបស់យើង សូមអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ភើរ ជី ម៉ាម នៃពួកចិតសិបនាក់ ៖



« ដើម្បីរកឃើញសេចក្ដីសម្រាកដល់ព្រលឹងរបស់យើង រួមមានសេចក្ដីសុខសាន្តក្នុងគំនិត និងដួងចិត្ត ដែលជាលទ្ធផលមកពីការរៀនសូត្រ និងការធ្វើតាមគោលលទ្ធិនៃព្រះគ្រីស្ទ » (« Rest unto Your Souls,» *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១០១ ) ។

ដើម្បីជួយសិស្សយល់អំពីអត្ថន័យមួយចំនួនចំពោះពាក្យថាស្វែងរកព្រះអម្ចាស់ជាមុន សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីស្វែងរកព្រះអម្ចាស់ជាមុននោះ ? ( ចម្លើយអាចរួមមានថា វាមានន័យថា ឲ្យស្វែងរកទ្រង់តាំងពីក្មេង ដែលវាមានន័យថា ស្វែងរកទ្រង់ជាមុនរាល់ថ្ងៃ ហើយវាមានន័យថា ស្វែងរកជំនួយរបស់ទ្រង់ពីមុនមានការសាកល្បងមកក្នុងជីវិតរបស់យើង ) ។
- ហេតុអ្វីក៏យើងគិតថាយើងរកឃើញសេចក្ដីសម្រាកដល់ព្រលឹងរបស់យើង នៅពេលយើងស្វែងរកព្រះអម្ចាស់ជាមុននោះ ?
- តើការស្វែងរកព្រះអម្ចាស់ជាមុនពីមុនគ្រានៃសេចក្ដីទុក្ខលំបាក ខុសគ្នាពីការស្វែងរកទ្រង់អំឡុងពេលមានគ្រានៃសេចក្ដីទុក្ខលំបាកយ៉ាងដូចម្ដេច ?

សូមអញ្ជើញពួកគេឲ្យសរសេរចម្លើយចំពោះសំណួរនេះចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ អ្នកអាចនឹងចង់សរសេរសំណួរទាំងនេះនៅលើក្ដារខៀន ឬ ចែកជាក្រដាសមួយសន្លឹកដល់ពួកគេ ៖

- តើអ្នកអាចស្វែងរកព្រះអម្ចាស់ជាមុន មុនពេលការសាកល្បងទាំងឡាយនឹងកើតមាននៅក្នុងពេលអនាគតរបស់អ្នកយ៉ាងដូចម្ដេច ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីស្វែងរកព្រះអម្ចាស់ជាមុនរាល់ថ្ងៃ ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីស្វែងរកព្រះអម្ចាស់ពីពេលឥឡូវនេះ ខណៈដែលអ្នកជានៅយុវវ័យនៅឡើយ ?

បន្ទាប់ពីសិស្សបានសរសេររួចហើយ សូមអញ្ជើញឲ្យពួកគេពីរបីនាក់ចែកចាយគំនិតរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥

*ព្រះអម្ចាស់ ហៅ វិលលាម ដ័បបុលយូ ហ្វែល្ប្ស ឲ្យជួយនៅក្នុងការសរសេរ និងការបោះពុម្ពឯកសារនានារបស់សាសនាចក្រ*

សូមសិស្សជាមុនឲ្យមកថ្នាក់រៀន ដោយត្រៀមខ្លួនដើម្បីសម្ដែងនូវទេពកោសល្យ ឬជំនាញមួយ ។ សូមប្រាកដថា បទបង្ហាញរបស់សិស្សនឹងនាំឲ្យមានព្រះវិញ្ញាណ ។ ឬសុំសិស្សឲ្យសរសេរនៅលើក្ដារខៀននូវទេពកោសល្យ និងជំនាញទាំងឡាយដែលពួកគេបានឃើញមានក្នុងខ្លួនរបស់គ្នាទៅវិញទៅមក ។ បន្ទាប់មក ហៅសិស្សម្នាក់តាមឈ្មោះ ហើយសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីក៏អ្នកគិតថា ទេពកោសល្យ និងជំនាញរបស់អ្នក ខុសគ្នាពីទេពកោសល្យ និងជំនាញរបស់អ្នកដទៃក្នុងថ្នាក់ដូច្នេះ ?
- ហេតុអ្វីក៏អ្នកគិតថា អ្នកត្រូវបានប្រទានពរជាមួយនឹងទេពកោសល្យ និងជំនាញទាំងនេះដូច្នេះ ?

> ***សូមទទួលស្គាល់ទេពកោសល្យ និងចំណាប់អារម្មណ៍របស់សិស្សម្នាក់ៗ***
>
> នៅពេលអ្នកលើកយកឧទាហរណ៍ ឬចំណាប់អារម្មណ៍មកពីជីវិតរបស់សិស្ស វានឹងជួយសិស្សម្នាក់ៗដឹងថា ពួកគេត្រូវបានទទួលស្គាល់ ហើយមានអំណរគុណ ។ សូមប្រាកដថា អ្នកប្រើគំរូវិជ្ជមាន ពេលអ្នកទទួលស្គាល់ទេពកោសល្យរបស់សិស្សទាំងឡាយ ។

សូមអញ្ជើញសិស្សឲ្យអានសេចក្ដីណែនាំកណ្ដាលទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥ ដោយស្ងាត់ស្ងៀម រកមើលជំនាញមួយរបស់ វិលលាម ដ័បបុលយូ ហ្វែល្ប្ស ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ។

សូមពន្យល់ថា វិលលាម ដ័បបុលយូ ហ្វែល្ប្ស បាន ទិញព្រះគម្ពីរមរមនមួយច្បាប់ក្នុងរយៈពេលពីរសប្ដាហ៍ បន្ទាប់ពីវាត្រូវបានដាក់លក់ ។ ការណ៍នេះនាំឲ្យគាត់ផ្លាស់ប្រែចិត្តជឿ ។ ក្រោយមកគាត់បានមានប្រសាសន៍ថា « ក្រៅពីរូបកាយខ្ញុំពុំត្រូវបានទទួលបុណ្យជ្រមុជទឹកចូលក្នុងព្រះវិហារនេះរហូតដល់. . . ខែមិថុនា ឆ្នាំ ១៨៣១ ក្ដី ក៏ដួងចិត្តរបស់ខ្ញុំបាននៅទីនោះ ចាប់តាំងពីពេលដែលខ្ញុំបានស្គាល់ព្រះគម្ពីរមរមនមកម្ល៉េះ » ( នៅក្នុង *Documents, Volume ១: ខែ មិថុនា ឆ្នាំ ១៨២៨–ខែ មិថុនា ឆ្នាំ ១៨៣១* ទំព័រ ៣៣៧ ) ។ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៨៣១ មិនយូរប៉ុន្មានបន្ទាប់ពីបងប្រុស ហ្វែល្ប្ស បានមកដល់ទីក្រុងខឺតឡង់ នោះព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥:៤ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ឲ្យរកមើលទេពកោសល្យផ្សេងទៀត ដែលវិលលាម ដំបបុលឈ្ស ហ្វែប្ស មាន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមអញ្ជើញសិស្សផ្សេងទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥:៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលទីតាំងដែលបងប្រុស ហ្វែប្ស ត្រូវបានហៅឲ្យធ្វើកិច្ចការនៃការសរសេរ និងការបោះពុម្ព ។ ( ព្រះអម្ចាស់ បានណែនាំគាត់ឲ្យធ្វើដំណើរជាមួយ យ៉ូសែប ស៊្មីធ ហើយនឹង ស៊ីឌនី រិកដុន ទៅកាន់រដ្ឋ មិសសួរី ) ។

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអាចប្រើទេពកោសល្យ ជំនាញ និងសមត្ថភាពទាំងឡាយរបស់យើង ដើម្បីប្រទានពរដល់កូនចៅរបស់ទ្រង់ ។**

- តើអ្នកបានឃើញព្រះប្រើទេពកោសល្យ និងសមត្ថភាពរបស់មនុស្សឲ្យប្រទានពរដល់កូនចៅរបស់ទ្រង់យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សគិតអំពីទេពកោសល្យ ឬសមត្ថភាពមួយ ដែលពួកគេមាន និងរបៀបដែលពួកគេអាចប្រើសមត្ថភាពនោះដើម្បីជួយដល់អ្នកដទៃ ហើយរំកិលកិច្ចការរបស់ព្រះអម្ចាស់ឆ្ពោះទៅមុខ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិតរបស់ពួកគេ ។

សូមបញ្ចប់មេរៀនដោយការយោងទៅគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានសរសេរនៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យជ្រើសរើសសេចក្ដីពិតមួយ ហើយចែកចាយពីមូលហេតុដែលវាសំខាន់ចំពោះពួកគេ និងអ្វីដែលពួកគេចង់ធ្វើដើម្បីអនុវត្តវាឲ្យកាន់តែពេញលេញក្នុងជីវិតរបស់ពួកគេ ។

មេរៀនទី ៦០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦

## បុព្វកថា

អែសរ៉ា ធេយ័រ ត្រូវបានចាត់ឲ្យរស់នៅ និងធ្វើការ ជាមួយនឹង យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ នៅចម្ការរបស់ ហ្វ្រេដឌើរីក ជី វិល្លាម នៅក្រុងខឺតឡង់ រដ្ឋ អូហៃអូ ។ បងប្រុស ធេយ័រ ក៏បានជួយបង់សងបំណុលមួយចំនួនដែលជំពាក់ថ្លៃដីផងដែរ ។ នៅដើមខែមិថុនា ឆ្នាំ ១៨៣១ គាត់ និង ថូម៉ាស ប៊ី ម៉ាស ត្រូវបានហៅឲ្យបម្រើបេសកកម្មទៅកាន់រដ្ឋ មិសសួរី ( សូមមើល គ និង ស ៥២:២២) ។ ដោយសារតែភាពឆ្មើងឆ្មៃ និងភាពអត្មានិយម បងប្រុស ធេយ័រ ពុំបានត្រៀមខ្លួនដើម្បីចេញដំណើរជាមួយបងប្រុស ម៉ាស ទេ ។ នៅក្នុងវិវរណៈបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦ បានទទួលនៅថ្ងៃទី ១៥ ខែ មិថុនា ព្រះអម្ចាស់បានលុបចោលនូវការហៅបម្រើរបស់បងប្រុស ធេយ័រ ហើយបានចាត់តាំងដៃគូថ្មីដល់បងប្រុស ម៉ាស ។ ព្រះអម្ចាស់បានព្រមានទាស់នឹងភាពឆ្មើងឆ្មៃ ហើយបានបង្រៀនដល់ពួកបរិសុទ្ធថា ទ្រង់មានអ្វីៗយ៉ាងច្រើនសម្រាប់ពួកគេ ប្រសើរជាងដីធ្លី និងប្រាក់កាសទៅទៀត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១–១៣

*ព្រះអម្ចាស់បានលុបចោលនូវការហៅបម្រើបេសកកម្មរបស់បងប្រុស ធេយ័រ ហើយព្រមានដល់គាត់ឲ្យប្រែចិត្ត*

សូមសួរសិស្សប្រសិនបើពួកគេមានស្គាល់នរណាម្នាក់ដែលលះបង់អ្វីដែលសំខាន់ ដើម្បីគោរពតាមបទបញ្ញត្តិមួយរបស់ព្រះអម្ចាស់ ។ ( ឧទាហរណ៍ អាចរួមមានទាំងនរណាម្នាក់ដែលពលិកម្ម ដើម្បីចូលរួមក្នុងសាសនាចក្រ ទៅបេសកកម្ម ឬគោរពតាមបទដ្ឋានជាក់លាក់របស់សាសនាចក្រ ) ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវគំរូរបស់ពួកគេ ។

សូមពន្យល់ថា នៅក្នុងខែមិថុនា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានហៅ អែសរ៉ា ធេយ័រ ឲ្យបម្រើបេសកកម្មនៅរដ្ឋ មិសសួរី ជាមួយនឹង ថូម៉ាស ប៊ី ម៉ាស ។ កង្វល់របស់បងប្រុស ធេយ័រ អំពីទ្រព្យសម្បត្តិ និងលុយកាក់បានបណ្ដាលឲ្យគាត់ពុំបានរៀបចំខ្លួនចាកចេញឡើយ ពេលបងប្រុស ម៉ាស បានត្រៀមខ្លួនរួចរាល់នោះ ដូច្នេះបងប្រុស ម៉ាស បានទៅជួបយ៉ូសែប ស្ម៊ីធ សួរអំពីអ្វីដែលត្រូវធ្វើ ។ នៅពេលព្យាការីបានទូលសូមដល់ព្រះអម្ចាស់ នោះព្រះអម្ចាស់បានឆ្លើយតបមកកាន់លោកជាមួយនឹងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៦ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីអ្នកទាំង ឡាយ ដែលបានបដិសេធក្នុងការគោរពតាមបទបញ្ញត្តិរបស់ទ្រង់ ។

- តើព្រះអម្ចាស់បានមានបន្ទូលអ្វីខ្លះ អំពីអ្នកទាំងឡាយណាដែលបដិសេធក្នុងការគោរពតាមបញ្ញត្តិរបស់ទ្រង់ ?

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន៖ *ដើម្បីបានសង្គ្រោះ នោះយើងត្រូវតែ . . .*

សូមអញ្ជើញសិស្សឲ្យបំពេញសេចក្ដីថ្លែងការណ៍ ស្របតាម ខ ២ ។ សិស្សអាចប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ដើម្បីបានសង្គ្រោះ នោះយើងត្រូវតែផ្ទុកឈើឆ្កាងរបស់យើង ធ្វើតាមព្រះអង្គសង្គ្រោះ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ ។** ( សូមបំពេញគោលការណ៍នៅលើក្ដារខៀន ) ។

- តើអ្នកគិតថា « ផ្ទុកឈើឆ្កាងរបស់យើង » មានន័យយ៉ាងដូចម្ដេច ? ( ដើម្បីជួយសិស្សយល់អំពីឃ្លានេះ អ្នកអាចនឹងចង់អញ្ជើញពួកគេឲ្យអានការបកប្រែដោយយ៉ូសែប ស្ម៊ីធ នៃគម្ពីរម៉ាថាយ ១៦:២៤ មាននៅក្នុង ម៉ាថាយ ១៦:២៤ លេខយោង ង)

- តើបទបញ្ញត្តិអ្វីខ្លះដែលព្រះអម្ចាស់បានប្រទានឲ្យ ដែលតម្រូវឲ្យអ្នកផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយធ្វើការលះបង់ដើម្បីគោរពប្រតិបត្តិ ? ( គំរូមួយចំនួន អាចរកបាននៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ) ។

- តើពរជ័យអ្វីខ្លះ ដែលអ្នកបានទទួល ឬនឹងទទួលបាន ដោយសារអ្នកជ្រើសរើសគោរពប្រតិបត្តិតាម ?

សូមសួរថា តើមនុស្សនៅក្នុងឧទាហរណ៍ដូចខាងក្រោម អាចផ្ទុកឈើឆ្កាងរបស់គេ ហើយគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់តាមវិធីណា ៖

១. យុវជនម្នាក់កំពុងឈានចូលដល់អាយុ ដែលគាត់អាចនឹងបម្រើបេសកកម្មបាន ។ គាត់បារម្ភអំពីអ្វីៗដែលគាត់នឹងទុកចោលនៅពេលគាត់ចេញទៅបម្រើ ។

២. យុវនារីម្នាក់ដឹងថា យុវវ័យនៅក្នុងវួដនាងនឹងទៅទស្សនាព្រះវិហារបរិសុទ្ធក្នុងរយៈពេលពីរបីខែទៀត ប៉ុន្តែនាងពុំមានប័ណ្ណចូលព្រះវិហារបរិសុទ្ធទេ ។ មានអ្វីមួយកើតឡើងក្នុងជីវិតរបស់នាងក្នុងពេលនេះ ដែលរារាំងនាងមិនឲ្យទទួលបានប័ណ្ណនោះ ។

សូមពន្យល់ថា បើយើងជ្រើសរើសមិនផ្ទុកឈើឆ្កាងរបស់យើងទេ នោះយើងអាចនឹងបាត់បង់ឱកាសដើម្បីប្រទានពរដល់អ្នកដទៃ ហើយទទួលពរជ័យសម្រាប់ខ្លួនយើង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:៣–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលបានកើតឡើង ដោយសារ អែសរ៉ា ធេយ័រ ពុំបានត្រៀមខ្លួនទៅរដ្ឋ មិសសួរី ។ មុនពេលសិស្សអាន អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ *លុបចោល* មានន័យថាដកចេញ ឬបដិសេធ ។

- តើ អែសរ៉ា ធេយ័រ បានបាត់បង់អ្វីខ្លះ ដោយសារតែគាត់ពុំត្រៀមខ្លួនជាស្រេចដើម្បីទៅ ? ( គាត់បានបាត់បង់ឱកាសរបស់គាត់ដើម្បីបម្រើបេសកកម្ម ក៏ដូចជាការទទួលពរជ័យដែលនឹងកើតមានផងដែរ ) ។

- ស្របតាម ខ ៤ តើព្រះអម្ចាស់អាចធ្វើអ្វីខ្លះជាមួយនឹងបទបញ្ញត្តិដែលទ្រង់ប្រទានឲ្យ ? ( សិស្សគួរតែប្រាប់ពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់ អាចប្រទានបទបញ្ញត្តិមួយ ឬដកបទបញ្ញត្តិនោះចេញ ពេលទ្រង់ទតឃើញថាសមស្រប )** ។

សូមសួរដល់សិស្ស បើសិនជាពួកគេអាចគិតអំពីឧទាហរណ៍ចេញមកពីបទគម្ពីរ ឬប្រវត្តិសាសនាចក្រ អំពីការប្រទានបទបញ្ញត្តិ និងការដកបញ្ញត្តិចេញរបស់ព្រះអម្ចាស់ ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួន ៖

១. បន្ទាប់ពីព្រះអម្ចាស់បានប្រទានក្រឹត្យវិន័យខ្ពស់ជាងដល់ម៉ូសេ និងរាស្ត្ររបស់ទ្រង់ នោះកូនចៅអ៊ីស្រាអែល បានបះបោរ ហើយចាប់ផ្ដើមថ្វាយបង្គំរូបគោមាស ។ ក្រោយមក ព្រះអម្ចាស់បានប្រទានដល់ពួកគេនូវក្រឹត្យវិន័យទាបជាង ។ ( សូមមើល និក្ខមនំ ៣២–៣៤, ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ និក្ខមនំ ៣៤:១–២, គ និង ស ៨៤:២៣–២៧) ។

២. អំឡុងពេលការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ទ្រង់បានបញ្ជូនពួកសាវកទៅកាន់តែសមាជិកនៃវង្សអ៊ីស្រាអែលប៉ុណ្ណោះ ( សូមមើល ម៉ាថាយ ១០:៥) ។ មិនយូរប៉ុន្មានបន្ទាប់ពីការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ នោះទ្រង់បានប្រាប់ដល់ពួកសាវកឲ្យផ្សាយដំណឹងល្អទៅគ្រប់ជាតិសាសន៍ទាំងអស់ ( សូមមើល ម៉ាថាយ ២៨:១៩) ។

៣. នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធជំនាន់មុនមួយចំនួនឲ្យអនុវត្តពហុពន្ធភាព ។ ព្យាការី យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀតជាច្រើនបានរកឃើញថា បទបញ្ញត្តិនេះពិបាក ប៉ុន្តែពួកគេបានគោរពតាម ។ បន្ទាប់ពីការទទួលបានវិវរណៈ នោះប្រធាន វិលហ្វឌ វូឌរ៉ុព្វ បានចេញសេចក្ដីប្រកាសដែលត្រូវបានទទួលយកដោយសាសនាចក្រ ជាការអនុញ្ញាតជាផ្លូវការ ហើយគោរពតាម នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៨៩០ ។ ការណ៍នេះ នាំទៅរកការបញ្ចប់នូវការអនុវត្តនៃពហុពន្ធភាពក្នុងសាសនាចក្រ ( សូមមើល សេចក្ដីប្រកាសជាផ្លូវការ ទី ១ ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:៦–៧ ដោយការពន្យល់ថា ព្រះអម្ចាស់ក៏បានផ្លាស់ប្ដូរការហៅបម្រើបេសកកម្មរបស់ សេឡា ជេ គ្រិពហ្វិន និង នូវែល ណៃត ផងដែរ ។ សូមរំឭកសិស្សថា ដោយសារការលំបាកជាច្រើនដែលបណ្ដាលឡើងដោយ លីម៉ាន ខូប្លី នៅក្នុង ថមសុន រដ្ឋ អូហៃអូ នោះពួកបរិសុទ្ធនៅខូលស្វិល ត្រូវបានដឹកនាំឲ្យផ្លាស់ទីទៅរដ្ឋ មិសសួរី ។ ពួកគេបានសួរព្យាការី យ៉ូសែប ស្ម៊ីធ បើសិនជាពួកគេអាចធ្វើការផ្លាស់ប្ដូរដោយមាន នូវែល ណៃត ដឹកនាំពួកគេ ដូចដែលគាត់ធ្លាប់ធ្វើ ចាប់តាំងពីចាកចេញពីខូលស្វិល ។ នូវែល ណៃត ត្រូវបានហៅបម្រើជាមួយ សេឡា ជេ គ្រិពហ្វិន ពីមុនការលំបាកទាំងនេះ ( សូមមើល គ. និង ស. ៥២:៣២) ដើម្បីព្រះអម្ចាស់ដឹកនាំសេឡា ជេ គ្រិពហ្វិន ឲ្យជំនួសកន្លែងរបស់ អែសរ៉ា ធេយ័រ ធ្វើជាដៃគូរបស់ ថូម៉ាស ប៊ី ម៉ាស រួចហើយ នូវែល ណៃត បន្តនៅជាមួយពួកបរិសុទ្ធនៅ ខូលស្វិល ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:៨–១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានបញ្ជា អែសរ៉ា ធេយ័រ ឲ្យធ្វើ បន្ទាប់ពីការហៅបម្រើបេសកកម្មរបស់គាត់ ត្រូវបានលុបចោល ។

- តើព្រះអម្ចាស់មានបន្ទូលថា អ្វីនឹងកើតឡើងដល់ អែសរ៉ា ធេយ័រ បើគាត់បានប្រែចិត្ត ? តើនឹងមានអ្វីកើតឡើង ប្រសិនបើគាត់មិនព្រមប្រែចិត្តវិញ ?

សូមពន្យល់ថា អែសរ៉ា បានជ្រើសរើសប្រែចិត្ត ហើយប្រាំពីរខែក្រោយមក គាត់ត្រូវបានហៅឲ្យបម្រើម្ដងទៀត ជាអ្នកផ្សព្វផ្សាយសាសនាជាមួយនឹង ថូម៉ាស ប៊ី ម៉ាស ( សូមមើល គ. និង ស. ៧៥:៣១) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៤–២០

*ព្រះអម្ចាស់ព្រមានដល់ពួកបរិសុទ្ធឲ្យទាស់នឹងដួងចិត្តលោភលន់ និងឆ្មើងឆ្មៃ*

សូមឲ្យសិស្សនឹកស្រមៃថា ពួកគេមានមិត្តម្នាក់ដែលធ្វើអំពើបាប ហើយកំពុងមានអារម្មណ៍សោកស្ដាយ ។ មិត្តនោះបានមករកពួកគេ ហើយសួរថា« តើខ្ញុំចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីប្រែចិត្ត ? » សូមទុកពេលឲ្យសិស្សពិចារណា ហើយឆ្លើយតប ។ បន្ទាប់ពីពួកគេបានឆ្លើយតបហើយ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៤–១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអាកប្បកិរិយា និងសកម្មភាព ដែលរារាំងអំពើបាបរបស់យើងពីការអភ័យទោស ឬអត់ទោស ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៤–១៥ តើអាកប្បកិរិយា ឬសកម្មភាពបែបណា ដែលរារាំងអំពើបាបរបស់យើងពីការអភ័យទោស ឬអត់ទោស ?

- តើអ្នកគិតថាឃ្លា « ស្វែងរកដំបូន្មានតាមអំពើចិត្តរបស់ខ្លួន » មានន័យយ៉ាងណា ? តើឃ្លា « ចិត្តរបស់អ្នកទាំងឡាយពុំបានស្កប់ស្កល់ឡើយ » ផ្ដល់ជាយោបល់អ្វីខ្លះ ? ( វាមានន័យថា ពុំពេញចិត្តនឹងអ្វីដែលអ្នកមាន ) ។

- តើយើងអាចរៀនអ្វីខ្លះមកពី ខ ១៤ និង ១៥ អំពីអ្វីដែលចាំបាច់ដើម្បីប្រែចិត្ត ហើយទទួលបានការអភ័យទោសនោះ ? ( សិស្សអាចនឹងប្រាប់នូវគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា គូសបញ្ជាក់នូវសេចក្ដីពិតដូចខាងក្រោម ៖ **ការប្រែចិត្តរួមមានទាំងការគោរពតាមដំបូន្មានរបស់ព្រះអម្ចាស់ ហើយងាកចេញពីបំណងប្រាថ្នាពុំសុចរិត ។** អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសរសេរសេចក្ដីពិតនេះនៅក្នុងគម្ពីររបស់ពួកគេជិត គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៤–១៥) ។

- ហេតុអ្វីក៏ការគោរពប្រតិបត្តិ និងការងាកចេញពីភាពមិនសុចរិត វាចាំបាច់នៅក្នុងការប្រែចិត្តពិត ?

សូមពន្យល់ថា ការប្រែចិត្តពុំគ្រាន់តែជាការធ្វើតាមជំហានៗដែលតម្រូវឲ្យមានការផ្លាស់ប្ដូរដួងចិត្តទាំងស្រុងនោះទេ– វាជាការតាំងចិត្តមួយដើម្បីគោរពព្រះអម្ចាស់ ហើយងាកចេញពីគ្រប់រឿងមិនសុចរិតទាំងឡាយ ។ នៅពេលវិវរណៈនេះត្រូវបានទទួល វាបង្ហាញថា ភាពអត្មានិយម និងភាពឆ្មើងឆ្មៃ របស់ អ៊ែសរ៉ា ធេយ័រ បានរារាំងគាត់មិនឲ្យគោរពតាមការទូន្មានរបស់ព្រះអម្ចាស់ ។

- តើភាពឆ្មើងឆ្មៃរបស់មនុស្សម្នាក់ ជះឥទ្ធិពលដល់សមត្ថភាពរបស់ពួកគេដើម្បីមានដួងចិត្តផ្លាស់ប្រែយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៦–១៧ ជាមួយដៃគូ ។ សូមឲ្យដៃគូម្នាក់រកមើលរបៀបដែលដួងចិត្តពុំផ្លាស់ប្រែ អាចមាននៅក្នុងខ្លួនមនុស្សម្នាក់ដែលមានទ្រព្យ ។ សូមឲ្យដៃគូម្នាក់រកមើលរបៀបដែលដួងចិត្តពុំផ្លាស់ប្រែ អាចមាននៅក្នុងខ្លួនមនុស្សម្នាក់ដែលក្រីក្រ ។ អ្នកអាចផ្ដល់យោបល់ឲ្យពួកគេគូសចំណាំអ្វីដែលពួកគេរកឃើញ ។ សូមឲ្យសិស្សពន្យល់ពីអ្វីដែលពួកគេរកឃើញចំពោះដៃគូរបស់ពួកគេ បន្ទាប់មកពិភាក្សានូវសំណួរដូចខាងក្រោមជាមួយគ្នា ( អ្នកអាចនឹងចង់សរសេរវានៅលើក្ដារខៀន ) ៖

- តើអ្នកអាចឃើញនូវភាពស្រដៀងគ្នាអ្វីខ្លះ រវាងដួងចិត្តមិនផ្លាស់ប្រែ ទាំងអ្នកមាន និងអ្នកក្រ ?

- ហេតុអ្វីក៏ភាពលោភលន់អាចមានទូទៅ ទាំងក្នុងពួកអ្នកមាន និងអ្នកក្រយ៉ាងដូច្នេះ ?

សូមដល់សិស្សឲ្យពិចារណាថា ពីពេលដែលពួកគេបានឃើញទង្វើទាំងនេះបង្ហាញនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ឬនៅក្នុងជីវិតមនុស្សទាំងឡាយដែលពួកគេស្គាល់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យដែលពិពណ៌នាអំពីដួងចិត្តនៃអ្នកទាំងឡាយដែលនឹងត្រូវបានប្រទានពរ ។

- ស្របតាម ខ ១៨ តើយើងគួរតែមានដួងចិត្តដូចម្ដេច? តើការមានដួងចិត្តសង្រេងមានន័យដូចម្ដេច ? ចុះចំណែកឯវិញ្ញាណទន់ទាបវិញយ៉ាងម៉េចដែរ ? ( ពាក្យទាំងនេះ បង្ហាញពីភាពរាបសា និងការចុះចូលនឹងព្រះអម្ចាស់ ) ។

- បើដួងចិត្តរបស់យើងកំណាញ់ ឬមានអំនួត តើយើងអាចផ្លាស់ប្ដូរយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៩–២០ ជាមួយដៃគូរបស់ពួកគេ ។ សូមឲ្យពួកគេរកមើលពរជ័យទាំងឡាយដែលព្រះអម្ចាស់បានសន្យាដល់អ្នកទាំងឡាយដែលមានដួងចិត្តរាបសា ។ អ្នកអាចផ្ដល់យោបល់ឲ្យសិស្សថាពួកគេគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *អ្នកទាំងឡាយណាដែលមានដួងចិត្តរាបសានឹង. . .*

- ស្របតាម ខ ១៨–២០ តើពរជ័យអ្វីខ្លះ ជួយបំពេញប្រយោគនៅលើក្ដារខៀន ? ( នៅពេលសិស្សប្រាប់អំពីពរជ័យដែលបានប្រាប់នៅក្នុងខគម្ពីរទាំងនេះ សូមសរសេរវានៅលើក្ដារខៀន ។ អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ *ឲ្យរង្វាន់* សំដៅទៅលើរង្វាន់សម្រាប់ទង្វើល្អ និងទណ្ឌកម្មសម្រាប់ទង្វើមិនសុចរិត ) ។

សូមពន្យល់ថា នៅក្រោមក្រឹត្យវិន័យនៃការថ្វាយ ចំណែកដែលត្រូវបានផ្ដល់ទៅឲ្យបុគ្គលម្នាក់ៗ ឬគ្រួសារ ស្របតាមស្ថានភាពរបស់ពួកគេ ដែលត្រូវបានហៅថា « កេរ្ដិ៍អាករ » (គ. និង ស. ៥៧:៧) ។ វាទំនងដូចជាអំឡុងពេលការអនុវត្តក្រឹត្យវិន័យនេះដំបូង មានពួកបរិសុទ្ធមួយចំនួន ដូចជា អ៊ែសរ៉ា ធេយ័រ បានបែរទៅជាមានភាពរំភើបហួសប្រមាណអំពីការទទួលបាន « កេរ្ដិ៍អាករ » របស់ពួកគេ ។

សូមសរសេរពាក្យ *កេរ្ដិ៍អាកររបស់ខ្ញុំ* នៅជិតនឹងពរជ័យទាំងឡាយដែលបានសរសេរនៅលើក្ដារខៀន ។

- ចេញមកពីអ្វីដែលយើងបានសរសេរ តើអ្នកនឹងសង្ខេបពរជ័យទាំងឡាយដែលព្រះអម្ចាស់បានមានក្នុងឃ្លាំងសម្រាប់អ្នកទាំងឡាយដែលមានដួងចិត្តរាបសាយ៉ាងដូចម្ដេច ? ( សិស្សអាចប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **អ្នកទាំងឡាយដែលមានដួងចិត្តរាបសានឹងទទួលគ្រងផែនដី )** ។
- តើពរជ័យទាំងឡាយដែលបានពិពណ៌នានៅក្នុង ខ ១៨–២០ ប្រៀបធៀបទៅនឹងទ្រព្យសម្បត្តិ និងប្រាក់ដែល អ៊ែសរ៉ា ធេយ័រ និងពួកបរិសុទ្ធជំនាន់មុនដទៃទៀត អាចនឹងមានចិត្តរំភើបនឹងរបស់នោះ យ៉ាងដូចម្ដេច ?

សូមថ្លែងទីបន្ទាល់អំពី ពរជ័យ ឬ « កេរ្ដិ៍អាករ » ដែលព្រះអម្ចាស់មានក្នុងឃ្លាំងសម្រាប់យើង នៅពេលយើងបដិសេធរាល់សេចក្ដីមិនសុចរិតចេញពីខ្លួនយើង ហើយតាំងចិត្តធ្វើតាមបទបញ្ញត្តិរបស់ទ្រង់ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩–៥៦ ( មេរៀនទី ១២ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩–៥៦ ( មេរៀនទី ១២) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើ គោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩)

សិស្សបានសិក្សាគោលលទ្ធិ និង គោលការណ៍នានាដែលថា ព្រះអម្ចាស់បានបញ្ជាឲ្យ លីម៉ាន ខូព្លី និង អ្នកផ្សេងទៀតឲ្យបង្រៀនពួកសេកើរ ៖ ថាប្រសិនបើយើងដឹងពីទីសម្គាល់នៃការយាងមកជាលើកទីពីរ នោះយើងនឹងមិនចាញ់បោក ការប្រកាសបោកប្រាស់ឡើយ ថាព្រះយេស៊ូវគ្រីស្ទ បានបញ្ជាឲ្យអ្នកបម្រើរបស់ទ្រង់ហៅមនុស្សឲ្យជឿលើទ្រង់ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ថាអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និង ស្ត្រីម្នាក់គឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយថាស្វាមី និង ភរិយាទាំងឡាយត្រូវបានបានបញ្ជាឲ្យរួមគ្នាតែមួយ ហើយបង្កើតកូនចៅ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០)

សិស្សបានរៀនថា វិញ្ញាណក្លែងក្លាយបានបោកបញ្ឆោតពួកបរិសុទ្ធជំនាន់ដើមមួយចំនួន ។ ព្រះអម្ចាស់បានបង្រៀនដល់ពួកបរិសុទ្ធទាំងនេះថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាអង្គលួងលោមចិត្ត ហើយថាព្រះវិញ្ញាណបរិសុទ្ធបង្រៀនសេចក្ដីពិត ។ ព្រះអម្ចាស់ក៏បានបង្រៀនផងដែរថា អ្វីដែលមកពីព្រះជាពន្លឺ ហើយស្អាងឡើង តែអ្វីដែលមិនមកពីព្រះ នាំឲ្យមានការច្របូកច្របល់ និងភាពងងឹត ។ សិស្សបានឃើញថា នៅពេលយើងបង្រៀន និងរៀនដោយព្រះវិញ្ញាណ នោះយើងយល់ពីគ្នាទៅវិញទៅមក ហើយយើងត្រូវបានស្អាងឡើង ហើយត្រេកអរជាមួយគ្នា ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១–៥២)

សិស្សបានរៀនថា ដើម្បីចៀសវាងពីការត្រូវបានបញ្ឆោតដោយសាតាំង បុគ្គលម្នាក់ត្រូវតែធ្វើតាមការណែនាំទាំងឡាយរបស់ព្រះអម្ចាស់ ហើយរស់នៅតាមវិវរណៈដែលទ្រង់បានប្រទានឲ្យ ។ ពួកគេក៏បានរៀនផងដែរថា ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទឃ្លាំមើល និងថែទាំ ដល់អ្នកទាំងឡាយដែលក្រីក្រ ខ្វះខាត ឈឺ និងរងទុក្ខ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៦)

ខណៈកំពុងសិក្សាអំពីពួកបរិសុទ្ធដែលត្រូវបានបង្ខំឲ្យចាកចេញពីទឹកដីលីម៉ាន ខូព្លី នោះសិស្សបានរៀនថា ប្រសិនបើយើងរក្សាសេចក្ដីសញ្ញារបស់យើង ហើយគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងនឹងទទួលបានសេចក្ដីមេត្តាករុណា ។ នៅពេលសិស្សបានសិក្សាពីបរិបទនៃការហៅបម្រើរបស់វិលាម ដឺបុលយូ ហ្វែប្ស ឲ្យសរសេរ និង បោះពុម្ពសម្រាប់សាសនាចក្រ នោះពួកគេបានរៀនថា ព្រះអម្ចាស់អាចប្រើទេពកោសល្យ ជំនាញ និង សមត្ថភាពរបស់យើងដើម្បីប្រទានពរដល់នគររបស់ទ្រង់ ។ នៅពេលពួកគេបានរៀនអំពីអែសរ៉ា ធេយ័រ នោះពួកគេបានឃើញថា ព្រះអម្ចាស់អាចប្រទានបទបញ្ញត្តិមួយ ឬដកបទបញ្ញត្តិនោះចេញពេលទ្រង់ទតឃើញថាសមស្រប ។

## សេចក្ដីផ្ដើម

នៅក្នុងខែ មិថុនា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានប្រទានវិវរណៈជាច្រើន ដោយអំពាវនាវឲ្យពួកបរិសុទ្ធនៅរដ្ឋអូហៃអូ ធ្វើដំណើរទៅរដ្ឋមិសសួរី ។ មេរៀននេះផ្ដោតលើទំនាក់ទំនងរវាងការគោរពប្រតិបត្តិតាម និង ការទទួលវិវរណៈបន្ថែមមកពីព្រះអម្ចាស់ ។ មេរៀននេះក៏នឹងនិយាយផងដែរពីអត្ថន័យនៃឃ្លា « ផ្ទុកឈើឆ្កាង [ របស់យើង ] » ( សូមមើល គ. និង ស. ៥៦:២) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–១៣, ២២–៣៦

*ព្រះអម្ចាស់បានបញ្ជាព្យាការី និងពួកអែលឌើរដទៃទៀត ឲ្យធ្វើដំណើរទៅរដ្ឋមិសសួរី ហើយផ្សាយដំណឹងល្អអំឡុងពេលនៃការធ្វើដំណើររបស់ពួកគេ*

ពីមុនថ្នាក់ចាប់ផ្ដើម សូមរៀបចំតម្រុយចំនួនបី ដែលតម្រុយនិមួយៗនាំទៅរកតម្រុយមួយទៀត ។ ឧទាហរណ៍ តម្រុយទីមួយអាចនឹងនាំសិស្សឲ្យស្វែងរកតម្រុយទីពីរនៅក្រោម ឬនៅក្នុងវត្ថុមួយ នៅកន្លែងណាមួយក្នុងថ្នាក់រៀន ។ តម្រុយទីពីរអាចនឹងនាំពួកគេឲ្យស្វែងរកតម្រុយទីបីនៅកន្លែងផ្សេងក្នុងថ្នាក់រៀន ។ តម្រុយទីបីគួរតែនិយាយថា « អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–៦ ។ សូមរកគោលការណ៍មួយដែលស្រដៀងគ្នាទៅនឹងសកម្មភាពនេះ » ។

សូមបិទតម្រុយទីមួយនៅលើក្ដារខៀន ហើយសរសេរការណែនាំដូចខាងក្រោមនៅជិតវា ៖ *ធ្វើតាមតម្រុយនេះ ដើម្បីរៀនអំពីរបៀបទទួលបានការណែនាំជាបន្តបន្ទាប់មកពីព្រះអម្ចាស់* ។

បន្ទាប់ពីសិស្សអានតម្រុយទីមួយ សូមអញ្ជើញពួកគេឲ្យធ្វើតាមការណែនាំដើម្បីរកតម្រុយទីពីរ ។ បន្ទាប់មកអញ្ជើញពួកគេឲ្យអានការណែនាំនៅតម្រុយទីពីរ ហើយស្វែងរកតម្រុយទីបី ។

ពីមុនសិស្សធ្វើតាមការដឹកនាំទៅតម្រុយទីបី សូមពន្យល់ថាវគ្គបទគម្ពីរ ដែលពួកគេនឹងស្វែងរក គឺមានការណែនាំដែលបានប្រទានឲ្យព្យាការី យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំបព្វជិតភាពដទៃទៀត នៅក្នុងសន្និសីទមួយរបស់សាសនាចក្រ ដែលបានធ្វើឡើងនៅក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូ ក្នុងខែមិថុនា ឆ្នាំ ១៨៣១ ។ សូមរំឭកសិស្សថា ព្រះអម្ចាស់បានបើកសម្ដែងពីមុនមកថា ពួកបរិសុទ្ធនឹងបង្កើតទីក្រុងមួយ ហៅថា *ស៊ីយ៉ូន* ( សូមមើល គ. និង ស. ២៨:៩) ប៉ុន្តែទ្រង់ពុំទាន់បានបើកសម្ដែងពីទីតាំងនោះទេ ។

សូមអញ្ជើញសិស្សឲ្យធ្វើតាមការណែនាំនៅក្នុងតម្រុយទីបី ។ សូមអញ្ជើញសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអានចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–៦ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម រកមើលគោលការណ៍មួយដែលស្រដៀងគ្នាទៅនឹងសកម្មភាព ដែលពួកគេទើបតែបានបំពេញ ។

- យោងតាម ខ ៤–៥, តើអ្វីខ្លះអាចកើតឡើង នៅពេលយើងស្មោះត្រង់ចំពោះការណែនាំរបស់ព្រះ ? (**នៅពេលយើងធ្វើតាមការណែនាំរបស់ព្រះដោយស្មោះត្រង់ នោះទ្រង់នឹងបើកសម្ដែងព្រះទ័យទ្រង់កាន់តែច្រើនដល់យើង** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។ អ្នកក៏អាចឲ្យយោបល់ដល់សិស្សឲ្យសរសេរវានៅគែមនៃព្រះគម្ពីររបស់ពួកគេផងដែរ ) ។

- តើសកម្មភាពនេះស្រដៀងគ្នានឹងគោលការណ៍នេះយ៉ាងដូចម្ដេច ? ( នៅពេលសិស្សធ្វើតាមការណែនាំនីមួយៗ នោះពួកគេបានទទួលការដឹកនាំបន្ថែម ដែលទីបំផុតនាំពួកគេទៅរកចម្លើយ ដែលពួកគេកំពុងស្វែងរក ) ។

- តើអ្នកមានអារម្មណ៍យ៉ាងណា ដែលមនុស្សមួយចំនួនទទួលបានការណែនាំ និងសេចក្ដីពិតរបស់ព្រះអម្ចាស់បន្តិចម្ដងៗ ជាជាងបានទទួលម្ដងទាំងអស់នោះ ?

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣

*ព្រះអម្ចាស់ហៅ ស៊ីឌនី គិលប៊ឺត ឲ្យធ្វើជាអែលឌើរ ហើយធ្វើដំណើរជាមួយ យ៉ូសែប ស្ម៊ីធ ទៅរដ្ឋមិសសួរី*

ដូចជាឧទាហរណ៍បន្ថែមមួយអំពីសេចក្ដីពិតដែលបានរកឃើញខាងលើ សូមពន្យល់ថា អ្នកផ្លាស់ប្រែចិត្តជឿថ្មីម្នាក់ឈ្មោះ ស៊ីឌនី ហ្គីលប៊ើត បានដឹងថា គាត់ពុំរាប់បញ្ចូលជាអ្នកផ្សព្វផ្សាយម្នាក់នៃអ្នកផ្សព្វផ្សាយទាំងអស់ ដែលបានហៅឲ្យធ្វើដំណើរទៅរដ្ឋមិសសួរី ។ គាត់បានទៅជួបព្យាការីយ៉ូសែប ស្ម៊ីធ ហើយបានសួរថា តើព្រះអម្ចាស់មានព្រះទ័យឲ្យគាត់ធ្វើអ្វី ។ ព្យាការី បានទូលសួរ ហើយបានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣ ។ វិវរណៈបានណែនាំបងប្រុស គិលប៊ឺតឲ្យបោះបង់ពិភពលោកចោល ត្រូវបានតែងតាំងជាអែលឌើរ ហើយធ្វើដំណើរទៅរដ្ឋមិសសួរី ដើម្បីជួយធ្វើជាភ្នាក់ងារចំពោះសាសនាចក្រ ( សូមមើល គ. និង ស. ៥៣:១–៥) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពេលវេលា ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់នឹងប្រទានការណែនាំដែលនៅសល់ទាំងប៉ុន្មាន ( « នៅសល់ » ) ។ ( អ្នកអាចពន្យល់ថា ព្រះអម្ចាស់មានបន្ទូលសំដៅលើបញ្ញើនៃការណែនាំនេះថាជា « ពិធីបរិសុទ្ធ » ។ ពាក្យ *ពិធីបរិសុទ្ធ* ពេលខ្លះសំដៅទៅលើច្បាប់មួយ ឬ ព្រះរាជក្រឹត្យមួយ ) ។

- តើអ្នកគិតថា ហេតុអ្វីយើងត្រូវតែគោរពតាមការណែនាំដែលព្រះអម្ចាស់បានប្រទានដល់យើង ពីមុនយើងអាចរំពឹងទទួលបានបន្ថែមទៀត ?

សូមអញ្ជើញសិស្សដែលមានបទពិសោធន៍មួយជាមួយនឹងគោលការណ៍នេះ ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ឬ ថ្លែងទីបន្ទាល់អំពីសេចក្ដីពិតពេញលេញ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយ ឬទីបន្ទាល់របស់អ្នកផងដែរ ។

សូមលើកទឹកចិត្តសិស្សឲ្យសរសេរសំណួរ កង្វល់ ឬការសម្រេចចិត្តមួយ ដែលពួកគេកំពុងជួប ដែលពួកគេចង់ទទួលបានជំនួយ និងការដឹកនាំរបស់ព្រះអម្ចាស់ ។ បន្ទាប់មក អញ្ជើញពួកគេឲ្យពិចារណា និងសរសេរនូវការណែនាំនានា ដែលព្រះអម្ចាស់បាន ប្រទានដល់ពួកគេ ដែលពួកគេអាចនឹងប្រុងស្ដាប់កាន់តែច្រើន ដើម្បីអញ្ជើញឲ្យមានការដឹកនាំបន្ថែមមកពីទ្រង់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១–៨

*ព្រះអម្ចាស់បានលុបចោលនូវការហៅបម្រើបេសកកម្មរបស់អែសរ៉ា ធេយ័រហើយព្រមានដល់គាត់ឲ្យប្រែចិត្ត*

សូមសួរសិស្សប្រសិនបើពួកគេមានស្គាល់នរណាម្នាក់ដែលលះបង់អ្វីដែលសំខាន់ ដើម្បីគោរពតាមបទបញ្ញត្តិមួយ របស់ព្រះអម្ចាស់ ។ ( ឧទាហរណ៍ អាចរួមមានទាំងនរណាម្នាក់ដែលពលិកម្ម ដើម្បីចូលរួមក្នុងសាសនាចក្រ ទៅបេសកកម្ម ឬ គោរពតាមបទដ្ឋានជាក់លាក់របស់សាសនាចក្រ ) ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំរូរបស់ពួកគេ ។ បន្ទាប់មកសូម ឲ្យសិស្សសង្ខេបពីអ្វីដែលពួកគេបានរៀនអំពី អែសរ៉ា ធេយ័រ នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦ ។ ( ប្រសិនបើពួកគេត្រូវការជំនួយ សូមរំឭកពួកគេថា អែសរ៉ា ធេយ័រ ត្រូវបានបញ្ជាឲ្យបម្រើបេសកកម្មជាមួយថូម៉ាស ប៊ី ម៉ាស្ស ប៉ុន្តែដោយសារតែបញ្ហានៃភាពឆ្មើងឆ្មៃ និង អាត្មានិយម គាត់ពុំបានត្រៀមខ្លួនរួចរាល់ឡើយ នៅពេលការចេញដំណើរមក ដល់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវ អ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីអ្នកទាំង ឡាយ ដែលបានបដិសេធក្នុងការគោរពតាមបទបញ្ញត្តិរបស់ទ្រង់ ។

- តើព្រះអម្ចាស់បានមានបន្ទូលអ្វីខ្លះ អំពីអ្នកទាំងឡាយណាដែលបដិសេធមិនគោរពតាមបញ្ញត្តិរបស់ទ្រង់ ?
- យោងតាម ខ២, តើយើងត្រូវធ្វើអ្វីខ្លះដើម្បីត្រូវបានសង្គ្រោះ ? (**ដើម្បីបានសង្គ្រោះ នោះយើងត្រូវតែផ្ទុកឈើឆ្កាងរបស់យើង ធ្វើតាមព្រះអង្គ សង្គ្រោះ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់** ។ សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។
- តើអ្នកគិតថា « ផ្ទុកឈើឆ្កាង [ របស់យើង ] » មានន័យយ៉ាងដូចម្ដេច ? ( យ៉ូសែប ស្ម៊ីធ បកប្រែម៉ាថាយ ១៦:២៤ បាន ផ្ដល់និយមន័យនៃឃ្លានេះតាមរបៀបនេះ ៖ « ហើយឥឡូវសម្រាប់មនុស្សម្នាក់ដែលផ្ទុកឈើឆ្កាងលើខ្លួន នោះគឺបាន បដិសេធនូវរាល់សេចក្ដីអាក្រក់ និងតណ្ហានៃលោកិយទាំងអស់ ហើយរក្សាបទបញ្ញត្តិរបស់យើង » [ម៉ាថាយ ១៦:២៤, លេខយោង *យ*] ។ ការនិយាយពីឈើឆ្កាងគឺជាការរំឭកមួយនៃប្ដេជ្ញាចិត្តរបស់ព្រះអង្គសង្គ្រោះ ដើម្បីធ្វើតាមព្រះឆន្ទៈរបស់ ព្រះវរបិតាសួគ៌ ។ យើងផ្ទុកឈើឆ្កាងរបស់យើង ដោយបង្ក្រាបឆន្ទៈរបស់យើងដើម្បីគោរពព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយ « បដិសេធខ្លួនយើង » ឬ លះបង់នូវអ្វីៗដែលចាំបាច់ដើម្បីគោរពតាមព្រះ ) ។
- តើបទបញ្ញត្តិអ្វីខ្លះដែលព្រះអម្ចាស់បានប្រទានឲ្យ ដែលតម្រូវឲ្យអ្នកផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយធ្វើការលះបង់ ដើម្បីគោរពប្រតិបត្តិ ? ( គំរូមួយចំនួនអាចរកបាននៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ) ។

សូមអានគំរូខាងក្រោម ( ឬ បង្កើតគំរូមួយចំនួនដែលត្រូវច្រើនទៅនឹងស្ថានភាពរបស់សិស្សនៅក្នុងថ្នាក់របស់អ្នក ) ហើយសួរ ពីរបៀបដែលបុគ្គលម្នាក់ៗអាចផ្ទុកឈើឆ្កាងខ្លួន ហើយគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ៖

១. យុវជនម្នាក់កំពុងឈានចូលដល់អាយុ ដែលគាត់អាចនឹងបម្រើបេសកកម្មបាន ។ គាត់បារម្ភអំពីអ្វីៗដែលគាត់នឹងទុកចោល នៅពេលគាត់ចេញទៅបម្រើ ។

២. យុវនារីម្នាក់ដឹងថា យុវវ័យនៅក្នុងវួដនាងនឹងទៅទស្សនាព្រះវិហារបរិសុទ្ធក្នុងរយៈពេលពីរបីខែទៀត ប៉ុន្តែនាងពុំមាន ប័ណ្ណចូលព្រះវិហារបរិសុទ្ធទេ ។ មានអ្វីមួយកើតឡើងក្នុងជីវិតរបស់នាងក្នុងពេលនេះ ដែលរារាំងនាងមិនឲ្យទទួលបាន ប័ណ្ណនោះ ។

សូមពន្យល់ថា ប្រសិនបើយើងជ្រើសរើសមិនផ្ទុកឈើឆ្កាងរបស់យើងទេ នោះយើងអាចនឹងបាត់បង់ឱកាសដើម្បីប្រទានពរ ដល់អ្នកដទៃ ហើយទទួលពរជ័យសម្រាប់ខ្លួនយើង ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:៣–៨ ដោយរំឭកសិស្សថា ដោយសារ អែសរ៉ា ធេយ័រ ពុំបានគោរពធ្វើតាម នោះបេសកកម្មរបស់គាត់ត្រូវបានលុបចោល ហើយគាត់បាត់បង់ឱកាសដើម្បីបម្រើនៅពេលនោះ ។ សូមអញ្ជើញសិស្សឲ្យ ពិចារណាពីអ្វីដែលពួកគេត្រូវធ្វើ ដើម្បីផ្ទុកឈើឆ្កាងរបស់គេ ហើយគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។ សូមលើកទឹកចិត្តឲ្យ ពួកគេធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេទទួល ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧–៥៩)

សូមសួរសិស្សថា តើវានឹងក្លាយទៅជាយ៉ាងដូចម្ដេចដែរ ដើម្បីរស់នៅក្នុងសហគមន៍មួយដែលមនុស្សគ្រប់គ្នាសុចរិត មានសន្ដានចិត្តល្អ និង មានចិត្តសប្បុរស ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ យើងរៀនពីរបៀបដែលយើងគួរតែរស់នៅ ដើម្បីសមនឹងពរជ័យនៃព្រះវិហារបរិសុទ្ធ ហើយរៀបចំខ្លួនដើម្បីរស់នៅក្នុងវត្តមានរបស់ព្រះ ។

មេរៀនទី ៦១

# កន្លែងកណ្ដាលនៃស៊ីយ៉ូន

## បុព្វកថា

នៅក្នុងរដូវក្ដៅឆ្នាំ ១៨៣១ មានពួកបរិសុទ្ធមួយចំនួនដែលបានប្រមូលគ្នីគ្នានៅរដ្ឋ អូហៃអូ បានចាប់ផ្ដើមការធ្វើដំណើរទៅតាំងទីលំនៅក្នុងតំបន់ ឃុំចាកសុន រដ្ឋ មីសសួរី ។ នៅក្នុងវិវរណៈមួយទៅកាន់ព្យាការី យ៉ូសែប ស្ម៊ីធ នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានកំណត់ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ជា « កន្លែងកណ្ដាល » នៃស៊ីយ៉ូន (គ. និង ស. ៥៧:៣) ។ ពួកបរិសុទ្ធទាំងឡាយបាន ចាប់ផ្ដើមទិញដីនៅតំបន់នោះ ហើយពួកគេក៏រក្សាបទបញ្ញត្តិរបស់ព្រះអម្ចាស់នៅក្នុង ការត្រៀមខ្លួនដើម្បីស្ថាបនាស៊ីយ៉ូនឡើងផងដែរ ។ ទោះជាយ៉ាណាក៏ដោយ ពេលវេលាបានកន្លងផុតទៅ ជម្លោះទាស់ទែងបានកើតឡើង រវាងពួកបរិសុទ្ធ និង ពលរដ្ឋជាច្រើននៅឃុំចាកសុន រដ្ឋ មិសសួរី ដែលនាំឲ្យមានអំពើហឹង្សាដ៏អាក្រក់ ទាស់នឹងពួកបរិសុទ្ធ ។ ពួកបរិសុទ្ធត្រូវបង្ខំឲ្យចាកចេញពីឃុំចាកសុន នៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ ១៨៣៣ ។

## យោបល់សម្រាប់ការបង្រៀន

### ព្រះអម្ចាស់បានកំណត់ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ជាកន្លែងកណ្ដាលនៃស៊ីយ៉ូន

មុនពេលចាប់ផ្ដើមថ្នាក់រៀន សូមសរសេរ *ខឺតឡង់ រដ្ឋ អូហៃអូ* នៅលើស្លាកសញ្ញាមួយ ហើយដាក់វានៅផ្នែកម្ខាងនៃថ្នាក់រៀន ។ ហើយនៅផ្នែកម្ខាងទៀតនៃថ្នាក់រៀន សូមដាក់តាំងស្លាកសញ្ញាមួយដែលអានថា *ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី* ។ ឬ បើអ្នកចង់បាន អ្នកអាចគូសនៅលើក្ដារខៀននូវ ផែនទីសាមញ្ញមួយ អំពីបច្ចិមប្រទេសអាមេរិក ជាមួយនឹងខឺតឡង់ រដ្ឋ អូហៃអូ និង ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ដោយគូសចំណាំឲ្យច្បាស់ ( សូមមើលផែនទីប្រវត្តិសាស្ត្រសាសនាចក្រ ផែនទី ទី ៦ « ដំណើរនៃសាសនាចក្រទៅទិសខាងលិច ») ។ សូមយោងទៅផែនទីនោះពេលអ្នកបង្រៀនមេរៀន ។




សូមចាប់ផ្ដើមដោយសុំឲ្យសិស្សនឹកស្រម៉ៃថា ពួកគេកំពុងបោះជំរុំ ហើយពួកគេដឹងថា មានព្យុះកំពុងតែខិតជិតមក ។

- តើអ្នកអាចរកកន្លែងជ្រកគេចពីព្យុះតាមវិធីមួយចំនួនរបៀបណាខ្លះ ? តើតង់អាចជួយនៅក្នុងស្ថានភាពយ៉ាងដូចម្ដេចដែរ ?

សូមពន្យល់ថា ព្យាការី អេសាយ បានពណ៌នាថា ស៊ីយ៉ូន គឺដូចជាត្រសាលដ៏ធំមួយ ។ លោកបានមានប្រសាសន៍ថា « សូមពង្រីកទីដំឡើងត្រសាលឯងឲ្យធំឡើង ហើយឲ្យវារាល់គ្នាសន្ធឹងសំយាយសំពត់ត្រសាលរបស់ឯងទៅ កុំឲ្យសំចៃឡើយ ត្រូវឲ្យបន្តខ្សែឲ្យវែង ហើយបោះចំរឹងឲ្យមាំឡើងចុះ » (អេសាយ ៥៤:២) ។ នៅក្នុងការបំពេញតាមការព្យាករណ៍នេះ ព្រះអម្ចាស់បានបន្តដឹកនាំគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅក្នុងការស្ថាបនាស្តេកនៃស៊ីយ៉ូន នៅទូទាំងពិភពលោក ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៤១–៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យទាំងឡាយដែលព្រះអម្ចាស់បានសន្យាចំពោះពួកបរិសុទ្ធដែលបានប្រមូលផ្ដុំគ្នីគ្នាទៅកាន់ស៊ីយ៉ូន ។

- តើពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់សន្យាដល់ពួកសុចរិតដែលប្រមូលគ្នីគ្នាទៅកាន់ស៊ីយ៉ូន ?

សូមពន្យល់ថា នៅក្នុងខែកក្កដា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានអះអាងថា ដែនដីមីសសួរីគឺជាដែនដីសន្យានៃក្រុងស៊ីយ៉ូន ហើយអ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី គឺជា « កន្លែងកណ្ដាល » នៃស៊ីយ៉ូន ( សូមមើល គ. និង ស. ៥៧:១–៣) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យឈរ ឬអង្គុយនៅជិតនឹងសញ្ញា *អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យគូរប តង់មួយនៅលើក្ដារខៀន ។ ( បើថ្នាក់រៀនមានទំហំធំល្មម នោះអ្នកអាចនឹងពិចារណាគ្រោងយកតង់មួយមកថ្នាក់រៀន ហើយ អញ្ជើញឲ្យសិស្សម្នាក់ ឬពីរនាក់លាតតង់បោះឡើង តំណាងឲ្យពួកបរិសុទ្ធចាប់ផ្ដើមស្ថាបនាទីក្រុងមួយធ្វើជាទីជម្រក ) ។

- តើអ្នកធ្លាប់តំឡើងតង់មួយមិនត្រឹមត្រូវ ឬក៏ព្យាយាមតំឡើងវាដោយគ្មានបំណែកគ្រប់គ្រាន់ដែរឬទេ ? តើមាន រឿងអ្វីបានកើតឡើង?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៥ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែល « ត្រសាល » នៃស៊ីយ៉ូន ត្រូវតែសង់ឡើងសម្រាប់ព្រះអម្ចាស់ដើម្បីទទួលយកវាបាន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖**ទីក្រុងស៊ីយ៉ូនត្រូវតែស្ថាបនាឡើងនៅលើគោលការណ៍ទាំងឡាយនៃ ក្រឹត្យវិន័យនៃនគរសេឡេស្ទាល** ។ សូមពន្យល់ថា បន្ទាប់ពីព្រះអម្ចាស់បើកសម្ដែងអំពីទីកន្លែងនៃដែនដីស៊ីយ៉ូន ក្នុងឆ្នាំ ១៨៣១ មក ទ្រង់បានប្រទានវិវរណៈជាច្រើនជាងពីរឆ្នាំក្រោយ ដែលពិពណ៌នាអំពីគោលការណ៍ទាំងឡាយដែលពួកបរិសុទ្ធគួរស្ថាបនា ក្រុងស៊ីយ៉ូន ។

សូមសរសេរសេចក្ដីយោងព្រះគម្ពីរដូចខាងក្រោមនៅលើក្ដារខៀន ៖

> *គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ :១៤–១៩*
>
> *គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១០–១៦*
>
> *គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២១–២២, ២៥–២៧ ។*
>
> *គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤–៩*

សូមបែងចែកសិស្សទៅជាបួនក្រុម ហើយចាត់តាំងសេចក្ដីយោងមួយដែលមានសរសេរនៅលើក្ដារខៀនដល់ក្រុមនីមួយៗ ។ សូមអញ្ជើញក្រុមឲ្យអានវគ្គគម្ពីរដែលបានចាត់ឲ្យពួកគេអាន រកមើលគោលការណ៍នៃសេចក្ដីសុចរិត ឬបទបញ្ញត្តិទាំងឡាយ ដែលពួកបរិសុទ្ធនឹងចាំបាច់ត្រូវធ្វើតាមដើម្បីស្ថាបនាស៊ីយ៉ូនដោយជោគជ័យ ។

បន្ទាប់ពីសិស្សបានសិក្សាវគ្គគម្ពីរដែលបានចាត់ឲ្យរបស់ពួកគេរួចហើយ សូមអញ្ជើញពួកគេឲ្យរាយការណ៍នូវអ្វីដែលពួកគេ រកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ ( ចម្លើយរបស់សិស្សគួរតែរួមមានដូច ខាងក្រោម ៖ រស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ហើយស្វែងរកសុខមាលភាពរបស់អ្នកដទៃ [គ. និង ស. ៨២:១៧–១៩] សាងសង់ព្រះវិហារបរិសុទ្ធ ហើយទទួលការណែនាំនៅទីនោះ [គ. និង ស. ៩៧:១០–១៤] បរិសុទ្ធនៅក្នុងដួងចិត្ត [គ. និង ស. ៩៧:១៦, ២១] ពិនិត្យសង្កេតបទបញ្ញត្តិទាំងឡាយ [គ. និង ស. ៩៧:២៥–២៦] និងត្រូវបានញែកចេញ ហើយ « . . . ចេញពី បាប៊ីឡូន » ដែលមានន័យថា ងាកចេញពីលោកិយ [គ. និង ស. ១៣៣:៤–៥] ។

- តើការរស់នៅតាមគោលការណ៍នៃសេចក្ដីសុចរិតទាំងនេះ អាចបានជួយដល់ពួកបរិសុទ្ធស្ថាបនាក្រុងស៊ីយ៉ូន ហើយត្រូវ បានការពារពីព្យុះខាងវិញ្ញាណយ៉ាងដូចម្ដេចខ្លះ ? តើការរស់នៅតាមគោលការណ៍ទាំងនេះ ជួយការពារយើងសព្វថ្ងៃយ៉ាង ដូចម្ដេច ?

អ្នកអាចនឹងពិចារណាធ្វើការអញ្ជើញដល់សិស្សមួយចំនួនឲ្យយកព្រះគម្ពីររបស់ពួកគេមកជាមួយ ហើយឈរ ឬអង្គុយនៅជិតនឹង ផ្លាកសញ្ញា *ក្រុងខឺតឡង់ រដ្ឋ អូហៃអូ* ហើយសុំឲ្យសិស្សម្នាក់ ឬពីរនាក់នៃសិស្សទាំងនេះទៅកាន់ផ្លាកសញ្ញា *អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មីសសួរី* ហើយឈរ ឬអង្គុយនៅទីនោះ ។ សូមពន្យល់ថា បន្ទាប់ពីព្រះអម្ចាស់បានបើកសម្ដែងទីតាំងនៃក្រុងស៊ីយ៉ូននៅខែកក្កដា ឆ្នាំ ១៨៣១ មក នោះមានពួកបរិសុទ្ធជាច្រើន បានធ្វើដំណើរជិត ៩០០ ម៉ែល ទៅកាន់ អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ដើម្បី រស់នៅទីនោះ ហើយស្ថាបនាស៊ីយ៉ូន ។ អ្នកដទៃទៀត បន្តនៅក្នុងក្រុងខឺតឡង់ និងក្នុងតំបន់ផ្សេងៗនៅទិសខាងកើត ។ ស្តេក មួយ នឹងត្រូវបង្កើតឡើងនៅក្រុង ខឺតឡង់ នៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ១៨៣៤ ។

សូមចង្អុលទៅរូបភាពតង់ ( ឬចង្អុលទៅតង់ ដែលអ្នកបានយកមកក្នុងថ្នាក់ ) ។ សូមពន្យល់ថា ក្នុងនាមជាពួកបរិសុទ្ធដែល បានធ្វើការជាមួយគ្នាដើម្បីស្ថាបនាស៊ីយ៉ូន ពរជ័យនៃការការពារនៃស៊ីយ៉ូន ត្រូវបានផ្ដល់ដល់ពួកគេទាំងអស់គ្នា សូម្បីតែ អ្នកទាំងឡាយដែលពុំរស់នៅក្នុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ក៏ដោយ ។ ពួកបរិសុទ្ធបានធ្វើការរួមគ្នាដើម្បីបរិច្ចាគមូលនិធិ និង ធនធាននានាដើម្បីចាក់គ្រឹះទីក្រុងស៊ីយ៉ូន ។ សូមឲ្យសិស្សស្រមៃអំពីការពន្លាតត្រសាលនៃស៊ីយ៉ូន គ្រងបាំងលើពួកបរិសុទ្ធនៅ ក្រុងខឺតឡង់ ។

## ការឈ្លោះទាស់ទែងបានកើតមាន រវាងពួកបរិសុទ្ធ និងពលរដ្ឋមីសសួរីដទៃទៀត

ដើម្បីជួយសិស្សយល់អំពីព្រឹត្តការទាំងឡាយដែលកើតឡើងនៅរដ្ឋ អូហៃអូ និង មីសសួរី រវាងឆ្នាំ ១៨៣១ និង ឆ្នាំ ១៨៣៣ សូមឲ្យសិស្សម្នាក់ដែលនៅជិតនឹងផ្លាកសញ្ញា ក្រុងខឺតឡង់ អានឲ្យឮៗនូវការពន្យល់អំពីរបៀបដែលពួកបរិសុទ្ធក្នុងស្តេកស៊ីយ៉ូន ខឺតឡង់ បានគាំទ្រដល់ការបង្កើតកន្លែងកណ្ដាលនៃស៊ីយ៉ូននៅរដ្ឋមីសសួរីដូចខាងក្រោម ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្ដាប់នូវអ្វីដែលពួកបរិសុទ្ធមួយចំនួននៅក្រុងខឺតឡង់បានធ្វើដើម្បីជួយស្ថាបនាក្រុងស៊ីយ៉ូន ។

**ក្រុងខឺតឡង់ រដ្ឋអូហៃអូ** ៖អំឡុងពេលសន្និសីទមួយបានធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ ១៨៣១ នោះ យ៉ូសែប ស្ម៊ីធ និង អ្នកដឹកនាំសាសនាចក្រដទៃទៀត បានប្រមូលផ្ដុំវិវរណៈទាំងឡាយដែលបានទទួលមករហូតដល់ពេលនោះ ហើយបានរៀបផែនការដើម្បីបោះពុម្ពច្បាប់ចម្លងនៅក្នុងទម្រង់ជាសៀវភៅ ។ អូលីវើរ ខៅឌើរី និង យ៉ូហាន វិតមើរ បានទទួលទំនួលខុសត្រូវដើម្បីនាំវិវរណៈទាំងឡាយទៅរដ្ឋ មិសសួរី ឲ្យ វិលលាម ដ័បបុលយូ ហ្វែប្ប អាចបោះពុម្ពវាជាព្រះគម្ពីរនៃបទបញ្ញត្តិ ។ អំឡុងឆ្នាំ ១៨៣១ ដល់ឆ្នាំ ១៨៣២ យ៉ូសែប បានបន្តទទួលវិវរណៈ និងការបកប្រែព្រះគម្ពីរប៊ីប ។ នៅក្នុងនិទារឃរដូវ ឆ្នាំ ១៨៣២ យ៉ូសែប បានធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ដើម្បីជួបនឹងពួកបរិសុទ្ធនៅស៊ីយ៉ូន ដើម្បីព្រមានពួកគេថា សាតាំងកំពុងព្យាយាមដើម្បី « បំបែរដួងចិត្តរបស់ពួកគេចេញពីសេចក្ដីពិត » (គ. និង ស. ៧៨:១០) ហើយសម្របសម្រួលកិច្ចការនៃឃ្លាំងរបស់ប៊ីស្សពនៅក្នុងក្រុងខឺតឡង់ និងអ៊ិនឌីប៉ែនដែនស៍ ។ សមាជិកសាសនាចក្រមួយចំនួននៅក្នុងរដ្ឋ អូហៃអូ បានបរិច្ចាគប្រាក់ដើម្បីជួយទិញដី និងសម្ភារផ្គត់ផ្គង់នៅរដ្ឋ មិសសួរី ។ ពួកបរិសុទ្ធជាច្រើនរូបបានបន្តផ្លាស់លំនៅទៅស៊ីយ៉ូន ហើយដល់ចុងឆ្នាំ ១៨៣២ មានសមាជិកសាសនាចក្រប្រហែលជាមួយភាគបី បានរស់នៅក្នុងឃុំចាកសុន ។

- តើ យ៉ូសែប ស្ម៊ីធ និង ពួកបរិសុទ្ធដទៃទៀតនៅខឺតឡង់ ជួយពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ចាប់ផ្ដើមស្ថាបនាក្រុងស៊ីយ៉ូនយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អានឮៗអំពីព័ត៌មានអំពីកិច្ចខិតខំរបស់ពួកបរិសុទ្ធដើម្បីស្ថាបនាក្រុងស៊ីយ៉ូន ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលអ្វីដែលពួកបរិសុទ្ធបានធ្វើត្រឹមត្រូវ និងមិនត្រឹមត្រូវ នៅពេលពួកគេចាប់ផ្ដើមស្ថាបនាក្រុងស៊ីយ៉ូន ។

**អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី** ៖ ប៉ាលី ភី ប្រាត្ត បានពិពណ៌នាអំពីការតាំងលំនៅរបស់ពួកបរិសុទ្ធក្នុងស៊ីយ៉ូន ដោយការប្រកាសថា « សេចក្ដីសុខសាន្ត និងភាពបរិបូរណ៍ បានគ្រងមកលើកិច្ចការរបស់ពួកគេ ហើយទីរហោស្ថានបានក្លាយជាចម្ការសម្បូរណ៍ភោគផល » (*Autobiography of Parley P. Pratt,* បានបោះពុម្ពដោយ Parley P. Pratt Jr. [ឆ្នាំ ១៩៣៨ ], ទំព័រ ៩៣) ។ អ្នកដឹកនាំសាសនាចក្រនៅរដ្ឋ មិសសួរី បានធ្វើការដើម្បីបំពេញតាមតម្រូវការនៃពួកបរិសុទ្ធដែលមកដល់ ។ ការណ៍នេះរួមមានទាំងការទិញដី និងបង្កើតឃ្លាំងមួយ និងរោងពុម្ពមួយ ។ ត្រឹមខែកក្កដា ឆ្នាំ ១៨៣៣ ចំនួនពួកបរិសុទ្ធថ្ងៃចុងក្រោយ បានកើនឡើងជិតដល់ ១២០០ នាក់ ។ ប៉ុន្តែអ្នកដឹកនាំ និងពួកបរិសុទ្ធពុំមែនថាគ្មានបញ្ហារបស់ពួកគេនោះទេ ។ សមាជិកមួយចំនួនបានអនុញ្ញាតឲ្យភាពអត្មានិយម និងភាពលោភលន់របស់ពួកគេ រារាំងពួកគេមិនឲ្យរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។

បន្ថែមទៅលើបញ្ហានានា ដែលពួកបរិសុទ្ធបានធ្វើ ដោយសារតែការមិនគោរពប្រតិបត្តិផ្ទាល់ខ្លួនរបស់ពួកគេ នោះពួកគេបានប្រឈមមុខនឹងជម្លោះជាមួយនឹងប្រជាជនដើមក្នុងតំបន់នោះ ។ ប្រជាជនរដ្ឋមីសសួរី បានខ្វល់ជាខ្លាំងអំពីការរីកចម្រើនដ៏លឿនរបស់ « ពួកមរមន » និងឥទ្ធិពលរបស់ពួកគេទៅលើសេដ្ឋកិច្ច និងនយោបាយក្នុងតំបន់ ។ អ្នកដឹកនាំសាសនាក្នុងតំបន់ពុំយល់ស្របចំពោះជំនឿរបស់ពួកបរិសុទ្ធទេ ។ អ្នកដឹកនាំសាសនាម្នាក់ បានផ្សព្វផ្សាយការកុហកអំពីសមាជិកសាសនាចក្រ ហើយលើកទឹកចិត្តប្រជាពលរដ្ឋ ឲ្យប្រព្រឹត្តអំពើហឹង្សាទាស់នឹងពួកគេ ។ ហើយនៅក្នុងខែកក្កដា ឆ្នាំ ១៨៣៣ ដ័បុលយូ ដបុលយូ ហ្វែប បានបោះពុម្ពអត្ថបទមួយចំណងជើងថា « Free People of Color (ការមិនរើសអើងពូជសាសន៍ ) » ដែលដាស់តឿនដល់ពួកអ្នកផ្សព្វផ្សាយសាសនាអំពីការផ្សាយសាសនានៅក្នុងចំណោមពួកទាសករ ។ ពលរដ្ឋមីសសួរី ដែលជាអ្នកគាំទ្រឲ្យមានទាសភាព បានសន្និដ្ឋានដោយពុំត្រឹមត្រូវថា ពួកបរិសុទ្ធកំពុងអញ្ជើញពួកទាសករដែលរួចខ្លួនមកកាន់រដ្ឋមីសសួរី ។ ការណ៍នេះបានបន្ថែមនូវស្ថានភាពតានតឹងរួចទៅហើយនៅក្នុងរដ្ឋ ។ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៨៣៣ ពួកមនុស្សកំណាចបានបោះម៉ាស៊ីនបោះពុម្ពទៅលើផ្លូវ កំទេចការិយាល័យបោះពុម្ព បំផ្លាញសន្លឹកនៃព្រះគម្ពីរបទបញ្ញត្តិដែលពុំទាន់កិបជាសៀវភៅស្ទើរតែទាំងអស់ ហើយបានចាក់ជ័រ និងរោមសត្វលើប៊ីស្សព ប៉ាទ្រិច និងអ្នកប្រែចិត្តជឿឈ្មោះ ឆាលេស អាលែន ហើយបានគំរាមគំហែងពួកលោកឲ្យចេញពីក្រុង ។ ការប្រទុស្តរ៉ាយ បានបន្ត ហើយពួកបរិសុទ្ធបានបង្ខំឲ្យចាកចេញពីឃុំចាកសុន នៅក្នុងខែវិច្ឆិកា និងខែធ្នូ នៃឆ្នាំនោះ ។

- តើអ្នកគិតថា អ្នកនឹងមានអារម្មណ៍យ៉ាងដូចម្ដេច បើអ្នកជាមនុស្សម្នាក់ក្នុងចំណោមពួកបរិសុទ្ធសុចរិតទាំងនោះ ដែលសង្ឃឹមថា ទទួលបានការការពារពីព្រះអម្ចាស់ ប៉ុន្តែបែរជាត្រូវបង្ខំឲ្យចាកចេញពីឃុំចាកសុនទៅវិញនោះ ?

- បើនរណាម្នាក់សួរអ្នកថា ហេតុអ្វីក៏ពួកបរិសុទ្ធជំនាន់មុន ពុំអាចស្ថាបនាក្រុងនៃស៊ីយ៉ូនបាន តើអ្នកនឹងតបយ៉ាងណា ? ( ដើម្បីជួយសិស្សឆ្លើយតបនឹងសំណួរនេះ អ្នកអាចនឹងចង់អញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦–៧, ១០៣:២–៤, ១០៥:៣–៤, ៩) ។

បើអ្នកពុំទាន់បានសុំឲ្យសិស្សត្រឡប់ទៅកន្លែងអង្គុយវិញទេ សូមអញ្ជើញឲ្យពួកគេទៅកន្លែងអង្គុយវិញចុះ ។

## តើអនាគតនៃស៊ីយ៉ូនទៅជាយ៉ាងណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើព្រះអម្ចាស់ពិពណ៌នាអំពីស៊ីយ៉ូនយ៉ាងណាខ្លះ ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំពាក្យដែលបង្រៀននូវសេចក្ដីពិតដូចខាងក្រោមថា ៖**ស៊ីយ៉ូនគឺបរិសុទ្ធនៅក្នុងដួងចិត្ត ។** សូមយោងទៅបញ្ជីនៃគោលការណ៍ និងឥរិយាបទទាំងឡាយនៅលើក្ដារខៀន ហើយសួរសំណួរដូចខាងក្រោម ៖

- តើគោលការណ៍សុចរិតទាំងនេះជួយមនុស្សម្នាក់ឲ្យប្រែជាមានចិត្តល្អសុទ្ធសាធដោយរបៀបណា ?
- តើតួនាទីរបស់យើងនៅក្នុងការស្ថាបនាស៊ីយ៉ូនសព្វថ្ងៃគឺជាអ្វី ? ( យើងអាចរស់នៅដោយសុចរិត ហើយលើកទឹកចិត្តអ្នកដទៃឲ្យរស់នៅសុចរិត ។ នៅពេលយើងរស់នៅ ហើយចែកចាយដំណឹងល្អ នោះព្រំដែនស៊ីយ៉ូនត្រូវបានពង្រីក ស្តេករបស់វាត្រូវបានពង្រឹង ហើយព្រះប្រទានពរដល់ពួកបរិសុទ្ធជាមួយនឹងការការពារ ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីគោលការណ៍ទាំងឡាយនៃសេចក្ដីសុចរិត ដែលបានរៀបរាប់នៅលើក្ដារខៀន ។ សូមលើកទឹកចិត្តដល់ពួកគេសរសេរគោលដៅមួយនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេដើម្បីរស់នៅតាមគោលការណ៍មួយឲ្យកាន់តែស្មោះត្រង់ ។

មេរៀនទី ៦២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧

## បុព្វកថា

នៅខែ មិថុនា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានបញ្ជាឲ្យ យ៉ូសែប ស្ម៊ីធ និង ពួកអែលឌើរផ្សេងទៀត កោះហៅប្រជុំសន្និសីទសាសនាចក្រមួយនៅរដ្ឋ មីសសួរី ( សូមមើល គ. និង ស. ៥២:២) ។ ដោយគោរពប្រតិបត្តិតាមបញ្ញត្តិ នោះយ៉ូសែប ស្ម៊ីធ និងអ្នកផ្សេងទៀត បានធ្វើដំណើរចម្ងាយ ៩០០ ម៉ែល ពី អូហៃអូ ទៅរដ្ឋមីសសួរី ។ បន្ទាប់ពីព្យាការីបានធ្វើដំណើរដល់រដ្ឋ មីសសួរី នោះលោកបានទទួលវិវរណៈ ដែលឥឡូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៧ ។ នៅក្នុងកណ្ឌនេះ ព្រះអម្ចាស់បានបើកសម្ដែងទីតាំងសម្រាប់ទីក្រុង ស៊ីយ៉ូន ដែលបំពេញតាមការសន្យាមួយ ដែលទ្រង់បានធ្វើពីដើមចំពោះពួកបរិសុទ្ធ ( សូមមើល គ. និង ស. ៥២ ) ។ ព្រះអម្ចាស់ ក៏បានណែនាំផងដែរដល់បុគ្គលជាច្រើន ទាក់ទងនឹងតួនាទីរបស់ពួកគេនៅក្នុងការស្ថាបនា ស៊ីយ៉ូន ។

## យោបល់សម្រាប់ការបង្រៀន

*សូមគូសបញ្ជាក់អំពីសេចក្ដីពិតទាំងឡាយ ដែលគាំទ្រដល់គោលបំណងនៃថ្នាក់សិក្ខាសាលា*

នៅពេលអ្នកបង្រៀន សូមគូសបញ្ជាក់ពីសេចក្ដីពិតដែលនឹងជួយសិស្សសម្រេចគោលបំណងថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា ៖ ដើម្បីជួយយុវវ័យ និងមជ្ឈិមវ័យឲ្យយល់ និងពឹងផ្អែកលើការបង្រៀន ព្រមទាំងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ មានភាពសក្ដិសមដើម្បីទទួលពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ និងរៀបចំខ្លួន ក្រុមគ្រួសាររបស់ពួកគេ និងអ្នកដទៃទៀតសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ចជាមួយនឹងព្រះវរបិតារបស់ពួកគេដែលគង់នៅស្ថានសួគ៌ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:១–៦

*ព្រះអម្ចាស់បើកសម្ដែងទីតាំងនៃទីក្រុងស៊ីយ៉ូន*

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយដែលពួកគេមានចំណង់ពិតជាចង់ធ្វើអ្វីមួយយ៉ាងខ្លាំង ដូចជាការប្រារព្ធពិធីសម្រាប់ថ្ងៃឈប់សម្រាកមួយ ឬថ្ងៃខួបកំណើត ការបម្រើបេសកកម្ម ការទៅព្រះវិហារបរិសុទ្ធ ការទទួលអំណោយ ឬការទៅសួរសុខទុក្ខមនុស្សជាទីស្រឡាញ់ ។ សូមសួរសិស្សថា តើពួកគេមានអារម្មណ៍យ៉ាងណា នៅពេលព្រឹត្តការណ៍ដែលពួកគេកំពុងទន្ទឹងរង់ចាំនោះនឹងមកដល់ឆាប់ៗ ។

- ហេតុអ្វីព្រឹត្តការណ៍នេះសំខាន់ខ្លាំងម្ល៉េះចំពោះអ្នក ?
- តើសកម្មភាពរបស់អ្នក ជះឥទ្ធិពលលើការរំភើបចិត្តរបស់អ្នកចំពោះព្រឹត្តការណ៍នេះយ៉ាងដូចម្ដេច ?

សូមរំឭកសិស្សថា តាមរយៈវិវរណៈដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ នោះពួកបរិសុទ្ធបានដឹងថា ស៊ីយ៉ូន នឹងស្ថិតនៅក្នុងទីតាំងណាមួយនៅ រដ្ឋ មីសសួរី ( សូមមើល គ. និង ស. ៥២:២, ៥, ៤២ ) ។ សូមពន្យល់ថា បន្ទាប់ពីព្រះអម្ចាស់ហៅពួកបរិសុទ្ធជំនាន់មុនមួយចំនួនឲ្យធ្វើដំណើរមកពីរដ្ឋ អូហៃអូ ទៅកាន់រដ្ឋ មីសសួរីមក នោះសមាជិកជាច្រើននៃសាសនាចក្របានសិក្សាស្វែងដឹងជាមុន អំពីទីតាំងជាក់លាក់នៃទីក្រុងស៊ីយ៉ូន ។

ដើម្បីជួយសិស្សញាណដឹងអំពីអារម្មណ៍ភ្លៀវភ្លារបស់ពួកបរិសុទ្ធអំពីការស្ថាបនាឡើងនៃស៊ីយ៉ូន សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវដំណើររឿងដូចខាងក្រោមអំពីបងស្រី ប៉ូលី ណៃត៍ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់អំពីរបៀបដែលសកម្មភាពរបស់បងស្រី ណៃត៍ ឆ្លុះបញ្ចាំងអំពី ការគិតទុកជាមុនសម្រាប់ការស្ថាបនានៃក្រុងស៊ីយ៉ូន ។

> « បងស្រី ណៃត៍ ជាម្ដាយរបស់ នូវែល និងជាសមាជិកនៃសាខា ខូលស្វិល បានប្រថុយជីវិតរបស់គាត់ធ្វើដំណើរទៅស៊ីយ៉ូន ។ សុខភាពរបស់ ភូលី បានធ្លាក់ចុះ ប៉ុន្តែចិត្តរំភើបរបស់គាត់ដើម្បីមើលទឹកដីសន្យា គឺខ្លាំងក្លាបំផុត ដែលគាត់បានបដិសេធពុំចង់នៅក្នុងរដ្ឋ អូហៃអូ ។. . . កូនប្រុសរបស់គាត់បានសរសេរថា ‹ បំណងដ៏ធំបំផុតរបស់គាត់តែមួយគត់ គឺដើម្បីទៅជាន់លើទឹកដីស៊ីយ៉ូន និងរូបកាយរបស់គាត់ត្រូវបញ្ចុះនៅក្នុងទឹកដីនោះ › ។. . . ក្រោយមក គាត់បានប្រាប់ថា ‹ ព្រះអម្ចាស់បានប្រទានតាមបំណងនៃដួងចិត្តគាត់ ហើយគាត់បានរស់នៅដើម្បីឈរលើទឹកដីនោះ › [*Scraps of Biography: Tenth Book of the Faith–Promoting Series, 1883* ) ទំព័រ ៧០ សូមមើលផងដែរ *History of the Church*, ១:១៩៩] ។ ភូលី បានទទួលមរណភាព ក្រោយពីទៅដល់ទឹកដីស៊ីយ៉ូន បានពីរសប្ដាហ៍ ហើយគាត់គឺជាពួកបរិសុទ្ធថ្ងៃចុងក្រោយដំបូងគេដែលបានបញ្ចុះសពនៅរដ្ឋ មីសសួរី » (*Church History in the Fulness of Times*, បោះពុម្ពលើកទីពីរ [Church Educational System manual, ២០០៣] ទំព័រ ១០៥ ) ។

សូមរំឭកសិស្សថា មានមនុស្សបីក្រុម ដែលត្រូវបានហៅឲ្យធ្វើដំណើរជិត ៩០០ ម៉ែលទៅរដ្ឋ មីសសួរី ៖ ព្យាការី និងក្រុមតូចមួយនៃពួកអែលឌើរ ( សូមមើល គ. និង ស. ៥២, ៥៣) ក្រុមពួកអ្នកផ្សព្វផ្សាយសាសនាមួយក្រុម ត្រូវបានហៅឲ្យផ្សាយនៅតាមផ្លូវ ( សូមមើល គ. និង ស. ៥២) និងពួកបរិសុទ្ធខូលស្វិល ដែលបានដឹកនាំដោយ នូវែល ណៃត៍ ( សូមមើល គ. និង ស. ៥៤) ។

សូមពន្យល់ថា បន្ទាប់ពីទៅដល់រដ្ឋ មីសសួរី ព្យាការី បានទូលសួរព្រះអម្ចាស់ដើម្បីដឹងច្រើនទៀតអំពីទីកន្លែងនៃក្រុងស៊ីយ៉ូន នឹងត្រូវបោះទីតាំង ហើយពេលណាដែលគួរតែសាងសង់ឡើង ។ ចម្លើយរបស់ព្រះអម្ចាស់ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលកន្លែងដែលព្រះអម្ចាស់មានបន្ទូលអំពីទីក្រុងស៊ីយ៉ូនត្រូវសាងសង់ឡើង ។

- តើទីក្រុងស៊ីយ៉ូនត្រូវសាងសង់ឡើងនៅកន្លែងណា ? ( អ៊ិនឌីប៉ែនដែនស៍ ឃុំចាកសុន រដ្ឋ មីសសួរី ) ។
- តើព្រះវិហារបរិសុទ្ធត្រូវសាងសង់ឡើងនៅកន្លែងណា ដែលទាក់ទងទៅនឹងទីកដីស៊ីយ៉ូន ? ( នៅក្នុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មីសសួរី ជាកន្លែងកណ្ដាលនៃស៊ីយ៉ូន ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៣ សារឡើងវិញដោយស្ងាត់ស្ងៀម រកមើលថាតើព្រះអម្ចាស់មានបន្ទូលថាគួរតាំងនៅកន្លែងណាក្នុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មីសសួរី ជាកន្លែងកណ្ដាលនៃស៊ីយ៉ូន ។

- តើព្រះអម្ចាស់ចង្អុលបង្ហាញពីអ្វីខ្លះ ដែលគួរតែតាំងនៅក្នុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មីសសួរី ឬនៅក្នុងកន្លែងកណ្ដាលនៃស៊ីយ៉ូន ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖**ព្រះវិហារបរិសុទ្ធគឺស្ថិតនៅកន្លែងកណ្ដាលនៃស៊ីយ៉ូន ) ។**

សូមសង្ខេប គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៧:៤–៦ ដោយពន្យល់ថា ព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធទិញដីនៅជុំវិញឃុំចាកសុន រដ្ឋ មីសសួរី ដែលនឹងអាចឲ្យពួកគេចាប់ផ្ដើមស្ថាបនាស៊ីយ៉ូន និងសាងសង់ព្រះវិហារបរិសុទ្ធ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៧–១៦

*ព្រះអម្ចាស់ ណែនាំដល់បុគ្គលម្នាក់ៗ ដែលទាក់ទងនឹងតួនាទីរបស់ពួកគេនៅក្នុងការស្ថាបនា ស៊ីយ៉ូន ។*

សូមអញ្ជើញសិស្សពីរនាក់ឲ្យដើរតួសម្ដែងដូចខាងក្រោម នៅខាងមុខថ្នាក់រៀន ( អ្នកអាចនិយាយជាមួយសិស្សពីរនាក់នោះមុនពេលចាប់ផ្ដើមថ្នាក់រៀន ហើយទុកពេលឲ្យពួកគេរៀបចំខ្លួន ) ៖

សិស្សម្នាក់សួរដល់សិស្សផ្សេងទៀតថា ហេតុអ្វីក៏ពួកគេមិនមកកាន់ការប្រជុំសាសនាចក្រ ឬសកម្មភាពនានាមួយរយៈក្រោយនេះ ។ សិស្សទីពីរតបថា ពួកគាត់មានអារម្មណ៍ថាមិនចាំបាច់ ។ សិស្សពុំមែនជាអ្នកដឹកនាំក្នុងថ្នាក់យុវវ័យ ឬកូរ៉ុម ហើយពុំមានអារម្មណ៍ថាគាត់ធ្វើឲ្យមានភាពខុសប្លែកអ្វីចំពោះអ្នកដទៃនៅក្នុងក្រុម ។

បន្ទាប់ពីសិស្សទីពីរ បានចែកចាយអំពីកង្វល់ទាំងនេះ សូមសួរដល់សិស្សក្នុងថ្នាក់ ថាតើពួកគេនឹងឆ្លើយតបដើម្បីជួយសិស្សនេះយ៉ាងដូចម្ដេច ។ បន្ទាប់ពីពួកគេបានចែកចាយគំនិតរបស់ពួកគេហើយ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយយុវជន ឬយុវនារីនេះ នៅពេលពួកគេសិក្សាផ្នែកដែលនៅសល់ទាំងប៉ុន្មានក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ៥៧ ។

សូមសរសេរសេចក្ដីយោងខគម្ពីរដូចខាងក្រោមនៅលើក្ដារខៀន ៖ *គ. និង ស. ៥៧:៧, គ. និង ស. ៥៧:៨–១០, គ. និង ស. ៥៧:១១–១២, គ. និង ស. ៥៧:១៣។*

សូមបែងចែកសិស្សជាគូៗ ហើយចាត់ឲ្យគូនីមួយៗនូវវគ្គបទគម្ពីរយោងមួយ ដែលបានសរសេរនៅលើក្ដារខៀននោះ ។ សូមឲ្យសិស្សអានវគ្គបទគម្ពីរ ដែលពួកគេបានចាត់ ហើយរកចម្លើយចំពោះសំណួរដូចខាងក្រោម ។ អ្នកអាចនឹងចង់សរសេរសំណួរទាំងនេះលើក្ដារខៀន ។

- តើព្រះអម្ចាស់ចាត់ឲ្យនរណាជួយស្ថាបនាស៊ីយ៉ូន ?
- តើបុគ្គលម្នាក់នេះបានចាត់ឲ្យធ្វើអ្វីខ្លះ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលជាការរកឃើញរបស់ពួកគេ ។ សូមពន្យល់ថា មនុស្សម្នាក់ៗដែលត្រូវបានប្រឹក្សាឲ្យតាំងលំនៅនៅក្នុងរដ្ឋ មីសសួរី មានអំណោយទាន និងទេពកោសល្យ ដែលត្រូវការចាំបាច់ដើម្បីស្ថាបនាស៊ីយ៉ូន ។

- តើពាក្យទូន្មានរបស់ព្រះអម្ចាស់បង្រៀនយើងអ្វីខ្លះ អំពីរបៀបដែលទ្រង់ស្ថាបនានគររបស់ទ្រង់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **យើងគួរតែប្រើកម្លាំងផ្ទាល់ខ្លួនយើងម្នាក់ៗ ដើម្បីជួយស្ថាបនានគររបស់ព្រះអម្ចាស់ នៅពេលទ្រង់ហៅយើងឲ្យធ្វើដូច្នោះ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សសរសេរវានៅគែមព្រះគម្ពីររបស់ពួកគេជិត ខ ៨–១៣ ) ។
- តើការយល់ដឹងអំពីសេចក្ដីពិតនេះ អាចជួយយុវជន ឬយុវនារី ក្នុងការសម្ដែងយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យយល់ពីសេចក្ដីពិតនេះ និងរបៀបដែលវាទាក់ទងនឹងពួកគេកាន់តែល្អ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ហើយសុំឲ្យសិស្សឆ្លើយវានៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

> *តើភាពខ្លាំងរបស់អ្នកគឺជាអ្វី?*
>
> *តើកម្លាំងរបស់អ្នកអាចជាពរជ័យចំពោះគ្រួសារ និងសាសនាចក្ររបស់អ្នកយ៉ាងដូចម្ដេច ?*

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យចែកចាយគំរូអំពីមនុស្សដែលពួកគេស្គាល់ថា បានស្ថាបនាសាសនាចក្រ ដោយការប្រើកម្លាំងផ្ទាល់ខ្លួនអំណោយទានខាងវិញ្ញាណ និងជំនាញដែលពួកគេមាន ។ សូមបញ្ចប់ដោយធ្វើការបញ្ជាក់ថា សិស្សម្នាក់ៗរបស់អ្នកមានតួនាទីសំខាន់មួយ នៅក្នុងការស្ថាបនានគររបស់ព្រះអម្ចាស់ ។ សូមលើកទឹកចិត្តពួកគេឲ្យប្រើដោយអស់កម្លាំងរបស់ពួកគេម្នាក់ៗ ដើម្បីប្រទានពរដល់ក្រុមគ្រួសារ និងសាសនាចក្ររបស់ពួកគេ ។

មេរៀនទី ៦៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–៣៣

## បុព្វកថា

នៅថ្ងៃទី ១ ខែសីហា ឆ្នាំ ១៨៣១ តិចជាងពីសប្ដាហ៍បន្ទាប់ពីព្រះអម្ចាស់បានកំណត់ អិនឌីប៉ែនដែនស៍ រដ្ឋ មីសសួរី ជាចំណុចកណ្ដាលនៃស៊ីយ៉ូន នោះយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨ ។ វិវរណៈនេះត្រូវបានប្រទានឲ្យជាចម្លើយតបចំពោះអ្នកទាំងឡាយណាដែលរំភើបចិត្ត ចង់ដឹងអំពីព្រះហឫទ័យរបស់ព្រះ ស្ដីអំពីពួកគេស្ថិតនៅក្នុងទឹកដីថ្មីនេះ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានទូន្មានដល់ពួកបរិសុទ្ធឲ្យស្មោះត្រង់ ទោះស្ថិតនៅក្នុងទុក្ខវេទនារបស់ពួកគេក្ដី ហើយបានពន្យល់ថា ហេតុអ្វីបានជាទ្រង់បញ្ជូនពួកបរិសុទ្ធឲ្យទៅស៊ីយ៉ូន ។ ព្រះអម្ចាស់ក៏បានលើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យប្រើសេរីភាពរបស់ពួកគេដើម្បីនាំមកនូវសេចក្ដីសុចរិតផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–៥

*ព្រះអម្ចាស់ទូន្មានដល់ពួកបរិសុទ្ធឲ្យស្មោះត្រង់ទោះស្ថិតនៅក្នុងទុក្ខវេទនារបស់ពួកគេក្ដី*

មុនពេលថ្នាក់ចាប់ផ្ដើម សូមសរសេរពាក្យ *បច្ចុប្បន្ន* និង *អនាគត* នៅលើក្ដារខៀន ។

សូមចាប់ផ្ដើមថ្នាក់រៀនដោយការសុំឲ្យសិស្សគិតអំពីឧបសគ្គដ៏បំផុត ដែលពួកគេកំពុងប្រឈមមុខក្នុងពេលថ្មីៗនេះក្នុងជីវិតពួកគេ ។

- តើការគិតអំពីអនាគតរបស់អ្នក នៅក្នុងជីវិតនេះ និងជីវិតបន្ទាប់ អាចជួយអ្នកឲ្យដោះស្រាយចំពោះឧបសគ្គទាំងឡាយដែលអ្នកកំពុងប្រឈមមុខនាពេលនេះយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់អំពីឧបសគ្គទាំងឡាយដែលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានជួបប្រទះក្នុងឆ្នាំ ១៨៣១ ដែលអាចនឹងបណ្ដាលឲ្យពួកគេមួយចំនួនមានការបាក់ទឹកចិត្ត ។

នៅក្នុងខែមករា ឆ្នាំ ១៨៣១ ពួកអ្នកផ្សព្វផ្សាយសាសនាបានរកឃើញ អាមេរិកកាំងដើម ដេឡាវែ កំពុងរស់នៅក្នុងទឹកដីជនជាតិអាមេរិកកាំងដើមហួសទៅភាគខាងលិចនៃព្រំប្រទល់រដ្ឋ មិសសួរី ។ អាមេរិកកាំងដើម ដេឡាវែ មានចំណាប់អារម្មណ៍រៀនដំណឹងល្អដែលមាននៅក្នុងព្រះគម្ពីរមរមន ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែពួកអ្នកផ្សព្វផ្សាយសាសនាពុំទទួលបានការអនុញ្ញាត ដើម្បីចូលទៅក្នុងទឹកដីអាមេរិកកាំងដើម ហើយផ្សាយដំណឹងល្អ និងដោយសារតែមានការជំទាស់មកពីភ្នាក់ងារអាមេរិកកាំងដើម ក្នុងមូលដ្ឋាន និងពួកគ្រូគង្វាល នោះពួកអ្នកផ្សព្វផ្សាយសាសនាមកពីសាសនាចក្រ ត្រូវបានបង្ខំឲ្យចាកចេញពីទឹកដីនោះ ។ ពេលនោះពួកអ្នកផ្សព្វផ្សាយសាសនាបានប៉ុនប៉ងបង្រៀនដល់អ្នកតាំងលំនៅជនជាតិស្បែកសនៅក្នុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី និងតំបន់នៅជុំវិញ ប៉ុន្តែមានអ្នកផ្លាស់ប្រែចិត្តជឿតិចជាងដប់នាក់ បានចូលរួមក្នុងសាសនាចក្រនៅត្រឹមខែ កក្កដា ឆ្នាំ ១៨៣១ ។ នៅពេលពួកអែលឌើរ នៃសាសនាចក្រមកពីអូហៃអូ បានចាប់ផ្ដើមទៅដល់រដ្ឋ មិសសួរី នៅខែ កក្កដា ឆ្នាំ ១៨៣១ នោះពួកគេមួយចំនួនបានខកចិត្តចំពោះអ្វីដែលពួកគេរកឃើញ ។ ពួកគេមួយចំនួនបានរំពឹងថានឹងមើលឃើញសហគមន៍នៃអ្នកជឿ រីកចម្រើនយ៉ាងឆាប់រហ័ស និងមានទីលំនៅមួយដែលត្រូវបានរៀបចំដើម្បីទទួលសមាជិកសាសនាចក្រដែលបានធ្វើអន្តោប្រវេសន៍ចូលមក ។ ពួកគេមួយចំនួនតូចសម្ដែងអំពីកង្វល់ដោយសារតែដែនដីនៅក្នុងអ៊ិនឌីប៉ែនដែនស៍ ពុំបានអភិវឌ្ឍ ។ បន្ថែមពីលើនោះ មានបងប្អូនប្រុសមួយចំនួន បានលើកទឹកចិត្តឲ្យស្នាក់នៅក្នុងរដ្ឋ មិសសួរី ហើយទិញដីដើម្បីរៀបចំស៊ីយ៉ូនសម្រាប់ពួកបរិសុទ្ធដែលនឹងមកដល់ពេលក្រោយទៀត ។

- ហេតុអ្វីអ្នកគិតថាស្ថានភាពនេះ អាចធ្វើឲ្យបាក់ទឹកចិត្តដល់សមាជិកសាសនាចក្រមួយចំនួនយ៉ាងដូច្នេះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ពួកអែលឌើរ ដែលអាចនឹងបានជួយពួកគេឲ្យដោះស្រាយបញ្ហាដែលពួកគេប្រឈមមុខ ។

- តើព្រះអម្ចាស់បានប្រាប់អ្វីខ្លះដល់ពួកអែលឌើរ ?
- តើអ្នកនឹងសង្ខេបសេចក្ដីពិតនៅក្នុង ខ ២ យ៉ាងដូចម្ដេច ? ( សិស្សគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **យើងនឹងត្រូវបានប្រទានពរ បើយើងរក្សាបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។ រង្វាន់ដ៏អស់កល្បជានិច្ចរបស់យើង នឹងមានកាន់តែច្រើន បើយើងបន្តស្មោះត្រង់នៅក្នុងទុក្ខវេទនា ។** អ្នកក៏អាចឲ្យយោបល់ដល់សិស្សគូសចំណាំឃ្លាដែលបង្រៀនគោលលទ្ធិទាំងនេះ នៅ ខ ២ ) ។

សូមយោងទៅលើពាក្យ*បច្ចុប្បន្ន*និង*អនាគត*នៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ពួកអែលឌើរអំពីបច្ចុប្បន្នភាព និងអនាគតភាពរបស់រាស្ដ្រទ្រង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- ស្របតាម ខ ៣ តើជាញឹកញាប់យើងមើលពុំឃើញ ឬពុំយល់អ្វីខ្លះ នៅពេលយើងឆ្លងកាត់សេចក្ដីទុក្ខវេទនា ?

សូមចង្អុលបង្ហាញថា ខគម្ពីរទាំងនេះហាក់ដូចជាបញ្ជាក់ថា ព្រះអម្ចាស់ចង់ឲ្យពួកអែលឌើរមើលរំលងនូវការសាកល្បងទាំងឡាយដែលពួកគេកំពុងស៊ូទ្រាំ ហើយឲ្យផ្ដោតទៅលើអនាគតដ៏រុងរឿង ដែលពួកគេនឹងទទួលពិសោធន៍ជំនួសវិញ បើពួកគេនៅស្មោះត្រង់ ។ សារលិខិតរបស់ព្រះអម្ចាស់ចំពោះពួកបរិសុទ្ធនៅរដ្ឋ មិសសួរី អាចជួយយើងឲ្យស៊ូទ្រាំនឹងឧបសគ្គនានា តាមរយៈការរក្សាផ្ដោតការយកចិត្តទុកដាក់របស់យើងទៅលើពរជ័យទាំងឡាយដែលបានសន្យាដល់អ្នកទាំងឡាយណាដែលស៊ូទ្រាំនឹងសេចក្ដីទុក្ខវេទនាដោយស្មោះត្រង់ ។

- តើការទុកចិត្តថាព្រះអម្ចាស់នឹងប្រទានពរដល់អ្នក ជួយអ្នកឲ្យស៊ូទ្រាំនឹងសេចក្ដីទុក្ខវេទនាដោយស្មោះត្រង់បានយ៉ាងដូចម្ដេច ?
- តើនៅពេលណា ដែលអ្នកមានអារម្មណ៍ថា អ្នកត្រូវបានប្រទានពរចំពោះការនៅស្មោះត្រង់អំឡុងពេលមានសេចក្ដីទុក្ខវេទនានោះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីឧបសគ្គដ៏ធំបំផុត ដែល ពួកគេកំពុងតែជួបក្នុងពេលថ្មីៗនេះម្ដងទៀត ។ សូមលើកទឹកចិត្តពួកគេឲ្យបន្តនៅស្មោះត្រង់ចំពោះដំណឹងល្អ ទោះជាមានឧបសគ្គនានាក្ដី ដើម្បីពួកគេអាចទទួលបានរង្វាន់ដែលព្រះអម្ចាស់មាននៅក្នុងឃ្លាំងសម្រាប់ពួកគេ ទាំងក្នុងពេលនេះ និងនៅក្នុងភាពអស់កល្បជានិច្ច ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៦–១៣

*ព្រះអង្គសង្គ្រោះពន្យល់អំពីមូលហេតុដែលទ្រង់បានបញ្ជូនពួកបរិសុទ្ធទៅស៊ីយ៉ូន*

សូមសួរសិស្សនូវសំណួរដូចខាងក្រោម ៖

- តើអ្នកធ្លាប់ត្រូវបានគេសុំឲ្យធ្វើអ្វីមួយ ប៉ុន្តែអ្នកពុំយល់ពីមូលហេតុដែលអ្នកត្រូវបានសុំឲ្យធ្វើរឿងនោះដែរឬទេ ? តើរឿងនោះធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងណា ?
- ផ្ទុយទៅវិញ តើអ្នកធ្លាប់មាននរណាម្នាក់មកសុំឲ្យអ្នកធ្វើអ្វីមួយ ហើយក៏បានជួយអ្នកឲ្យយល់ពីមូលហេតុដែលត្រូវធ្វើដូច្នោះដែរឬទេ ? តើការដឹងពីមូលហេតុធ្វើឲ្យមានភាពខុសគ្នាយ៉ាងណា ?

សូមពន្យល់ថា ព្រះអម្ចាស់បានបើកសម្ដែងនូវមូលហេតុមួយចំនួនរបស់ទ្រង់ ដែលបញ្ជូលមនុស្សឲ្យទៅចាក់គ្រឹះនៃស៊ីយ៉ូន ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៦–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលព្រះអម្ចាស់បានប្រទានឲ្យ ក្នុងការបញ្ជូនមនុស្សឲ្យទៅចាក់គ្រឹះនៃស៊ីយ៉ូន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៩–១៣ ដោយពន្យល់ថា មូលហេតុមួយដែលព្រះអម្ចាស់បញ្ជូនមនុស្សឲ្យទៅចាក់គ្រឹះនៃស៊ីយ៉ូន គឺដើម្បីរៀបចំផែនដីសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងខទាំងនេះ ព្រះអម្ចាស់ បានសំដៅទៅលើរឿងប្រៀបធៀបព្រះគម្ពីរសញ្ញាថ្មី ដែលបង្រៀនថា មនុស្សនៅគ្រប់ជាតិសាសន៍នឹងត្រូវបានអញ្ជើញឲ្យមកទទួលទានពរជ័យទាំងឡាយនៃដំណឹងល្អ ។

- តើការដឹងថាពួកគេកំពុងរៀបចំផែនដីសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ បានជួយពួកអែលឌើរឲ្យនៅស្មោះត្រង់នៅក្នុងសេចក្ដីទុក្ខវេទនារបស់ពួកគេយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១៤–២៣

*ព្រះអម្ចាស់ពិពណ៌នាអំពីទំនួលខុសត្រូវរបស់ប៊ីស្សព ហើយបញ្ជាឲ្យពួកបរិសុទ្ធរក្សាច្បាប់ដែនដី*



សូមរំឮកសិស្សថាព្រះអម្ចាស់បានហៅប៊ីស្សព អែតវឺត ប៉ាទ្រិច ឲ្យដឹកនាំកិច្ចខិតខំដើម្បីស្ថាបនាទីក្រុងស៊ីយ៉ូន ។ ព្រះអម្ចាស់បានណែនាំដល់ប៊ីស្សព ប៉ាទ្រិច និង ស៊ីឌនី ហ្គីលប៊ើត ឲ្យបន្តនៅក្នុងរដ្ឋ មិសសួរី ដើម្បីគ្រប់គ្រងលើទ្រព្យសម្បត្តិសាសនាចក្រ ហើយទិញដីនៅក្នុង និងនៅជុំវិញ អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥៧:៧–៨ ) ។ សូមពន្យល់ថា នៅពេលពួកបរិសុទ្ធបានរៀបចំដើម្បីទិញដី នោះប៊ីស្សព ប៉ាទ្រិច បានទាស់សម្ដីនឹង យ៉ូសែប ស្ម៊ីធ អំពីគុណភាពដីដែលត្រូវបានជ្រើសរើស ។ គាត់មានអារម្មណ៍ថាដីនៅកន្លែងផ្សេង គួរតែត្រូវបានទិញជំនួសវិញ ។ ការពុំចុះសម្រុងគ្នានេះនាំឲ្យព្រះអម្ចាស់ ស្ដីបន្ទោស។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១៤–១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអម្ចាស់បានប្រាប់ដល់ប៊ីស្សព ប៉ាទ្រិច ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- សូមនាំសិស្សឲ្យត្រឡប់ទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣។ តើសេចក្ដីពិតដែលបានបើកសម្ដែងនៅក្នុងខគម្ពីរនោះបានជួយប៊ីស្សព ប៉ាទ្រិច ជ្រើសរើសប្រែចិត្ត ឈប់ទាស់សម្ដីនឹងព្យាការី អំពីដីចំណែកណាដែលគួរតែទិញយ៉ាងដូចម្ដេច ?

ចូរពន្យល់ដល់សិស្សក្នុងថ្នាក់ថា ប៊ីស្សព ប៉ាទ្រិច បានទទួលយកការស្ដីបន្ទោសរបស់ព្រះអម្ចាស់ដោយរាបសា ហើយបាបរបស់គាត់ត្រូវបានអភ័យទោស។

- តើសេចក្ដីពិតដែលបានបើកសម្ដែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣ អាចជួយយើងឆ្លើយតបចំពោះបទបញ្ញត្តិរបស់ព្រះអម្ចាស់ដោយសេចក្ដីជំនឿ ជាជាងដោយការមិនជឿ និងសេចក្ដីងងឹតនៅក្នុងដួងចិត្តបានយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១៦–២០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ប៊ីស្សព ប៉ាទ្រិច អំពីតួនាទីរបស់គាត់ ក្នុងនាមជាប៊ីស្សព និងទំនួលខុសត្រូវរបស់គាត់ដើម្បីជួយស្ថាបនាស៊ីយ៉ូន ។

- យោងតាមខគម្ពីរទាំងនេះ តើទំនួលខុសត្រូវរបស់ប៊ីស្សពគឺជាអ្វី ?
- តើវិធីមួយចំនួនអ្វីខ្លះ ដែលពួកប៊ីស្សពត្រូវវិនិច្ឆ័យដល់រាស្ត្ររបស់ព្រះអម្ចាស់នាពេលសព្វថ្ងៃនេះ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២១–២៣ ដោយពន្យល់ថា ព្រះអម្ចាស់រំពឹងឲ្យយើងរក្សាច្បាប់នៃដែនដី រហូតដល់ទ្រង់យាងមក ហើយគ្រងរាជ្យអំឡុងសហសវត្សរ៍ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៤–៣៣

*ព្រះអម្ចាស់ទូន្មានពួកបរិសុទ្ធឲ្យប្រើសិទ្ធិជ្រើសរើសរបស់ពួកគេដើម្បីធ្វើល្អ*

សូមបង្ហាញស្ថានភាពដូចខាងក្រោមទៅដល់សិស្សក្នុងថ្នាក់ ៖

សូមស្រម៉ៃថា នៅពេលអ្នកកំពុងដើរតាមផ្លូវ អ្នកបានឃើញមនុស្សចំណាស់ម្នាក់ដួល ។ តើចំនុចខាងក្រោមណាមួយដែលអ្នកគួរធ្វើ ?

ក. រង់ចាំឲ្យព្រះវិញ្ញាណបំផុសគំនិតអ្នកឲ្យជួយ ។

ខ. រង់ចាំឲ្យនរណាម្នាក់ទៀតប្រាប់អ្នកថាត្រូវធ្វើអ្វីខ្លះ ។

គ. រង់ចាំមើលបើសិនជាមាននរណាម្នាក់ផ្សេងទៀតនឹងមកជួយ ។

ឃ. ជួយដល់មនុស្សដែលដួលនោះភ្លាមៗ ។

បន្ទាប់ពីសិស្សបានឆ្លើយតបរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីក៏វាសំខាន់ដើម្បីជួយមនុស្សម្នាក់ដោយពុំចាំបាច់រង់ចាំការដឹកនាំពីមនុស្សម្នាក់ផ្សេងទៀត ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៦–២៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលការណ៍ទាំងឡាយដែលព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធ នៅពេលពួកគេជួបនឹងការលំបាកក្នុងការស្ថាបនាទីក្រុងស៊ីយ៉ូន ។ ( អ្នកអាចនឹងចង់ពន្យល់ថា ឃ្លា « អ្នកណាដែលត្រូវគេបង្ខំនូវគ្រប់អ្វីៗទាំងអស់ » [គ. និង ស. ៥៨:២៦] សំដៅទៅលើនរណាម្នាក់ដែលពុំធ្វើសកម្មភាព ចាំរហូតទាល់តែពួកគេត្រូវបានតម្រូវឲ្យធ្វើដូច្នោះ ) ។

- តើសេចក្ដីពិតអ្វីខ្លះដែលអ្នករកឃើញនៅក្នុង ខ ២៦–២៨ ? ( សិស្សអាចនឹងឆ្លើយតប ជាមួយសេចក្ដីពិតដូចខាងក្រោមថា ៖ **យើងមានអំណាចដើម្បីជ្រើសរើសធ្វើសកម្មភាពសម្រាប់ខ្លួនយើង ។ បើយើងរង់ចាំព្រះអម្ចាស់ប្រាប់អ្វីៗគ្រប់យ៉ាងដល់យើងថាគួរធ្វើអ្វីនោះ នោះយើងនឹងបាត់បង់រង្វាន់យើងហើយ ។ បើយើងប្រើសិទ្ធិជ្រើសរើសរបស់យើងដើម្បីធ្វើរឿងទាំងឡាយដែលនាំមកនូវសេចក្ដីសុចរិត នោះយើងនឹងទទួលបានរង្វាន់ ។** សូមប្រើពាក្យរបស់សិស្ស សរសេរសេចក្ដីពិតទាំងនេះនៅលើក្ដារខៀន ) ។

- តើខគម្ពីរទាំងនេះសំដៅទៅលើ « រង្វាន់» អ្វីខ្លះ ? តើការធ្វើអ្វីៗដែលល្អៗដោយសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់យើងជះឥទ្ធិពលលើរបៀបដែលយើងទទួលជីវិតអស់កល្បជានិច្ចយ៉ាងដូចម្ដេច ?

- តើវិធីមួយចំនួនដែលអ្នកអាចប្រើដោយអន្ទះសារក្នុងការធ្វើល្អនៅគេហដ្ឋានមានអ្វីខ្លះ ? នៅសាលាមានអ្វីខ្លះ ? នៅក្នុងវួដ ឬសាខារបស់អ្នកមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ដែលពួកគេមាន នៅពេលពួកគេត្រូវបានប្រទានពរឲ្យប្រើសិទ្ធិជ្រើសរើសរបស់ពួកគេដើម្បីធ្វើល្អ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៩–៣៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលកើតឡើងចំពោះអ្នកទាំងឡាយដែលពុំប្រើសិទ្ធិជ្រើសរើសរបស់ពួកគេដើម្បីធ្វើល្អ ឬនរណាដែលសង្ស័យចំពោះបទបញ្ញត្តិរបស់ព្រះ ។

- តើមានអ្វីខ្លះកើតឡើងចំពោះអ្នកទាំងឡាយដែលពុំប្រើសិទ្ធិជ្រើសរើសរបស់ពួកគេដើម្បីធ្វើល្អ ឬនរណាដែលសង្ស័យចំពោះបទបញ្ញត្តិរបស់ព្រះ ?

- តើមនុស្សមួយចំនួនឆ្លើយតបយ៉ាងដូចម្ដេច នៅពេលពួកគេពុំទទួលបានពរជ័យ ដោយសារតែភាពខ្ជិលច្រអូស ឬការមិនគោរពប្រតិបត្តិរបស់ពួកគេនោះ ? តើមានការព្រមានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានឲ្យដល់បុគ្គលជាក់លាក់ក្នុង ខ ៣៣?

សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការប្រើសិទ្ធិសេរីភាពរបស់យើងដើម្បីធ្វើល្អ ។ សូមអញ្ជើញសិស្សឲ្យប្រើសិទ្ធិជ្រើសរើសរបស់ពួកគេដើម្បីធ្វើអ្វីមួយល្អ ពីមុនជួបគ្នាម្ដងទៀត ។ សូមប្រាប់សិស្សថា ពួកគេនឹងមានឱកាសមួយដើម្បីចែកចាយនូវអ្វីដែលពួកគេបានធ្វើជាចំណែកនៃមេរៀនក្រោយ ។

មេរៀនទី ៦៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៤–៦៥

## បុព្វកថា

ជាការឆ្លើយតបចំពោះសំណួររបស់ពួកអែលឌើរ អំពីរបៀបដើម្បីដំណើរការស្ថាបនាទីក្រុងនៃស៊ីយ៉ូន ព្រះអម្ចាស់បានប្រទានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨ ថ្ងៃទី ១ ខែសីហា ឆ្នាំ ១៨៣១ ។ ខ ៣៤–៦៥ មាននូវការណែនាំស្ដីអំពីការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយចំពោះអ្នកទាំងឡាយដែលបានផ្លាស់ទៅកាន់ស៊ីយ៉ូន ។ នៅក្នុងខគម្ពីរទាំងនេះ ព្រះអម្ចាស់ក៏បានបង្រៀនផងដែរអំពីគោលការណ៍នៃការប្រែចិត្ត ដែលបានបញ្ជាឲ្យពួកអែលឌើរ ផ្សាយដំណឹងល្អ ហើយទូន្មានពួកគេទាក់ទងនឹងរបៀបដើម្បីស្ថាបនាក្រុងស៊ីយ៉ូន ។

## យោបល់សម្រាប់ការបង្រៀន

នៅក្នុងមេរៀនមុនៗ សិស្សត្រូវបានអញ្ជើញឲ្យប្រើសិទ្ធិសេរីភាពរបស់ពួកគេឲ្យធ្វើអ្វីមួយដែលល្អមុនពេលចាប់ផ្ដើមថ្នាក់នៅថ្ងៃនេះ ។ សូមតាមដានការអញ្ជើញនេះ ដោយសុំឲ្យសិស្សចែកចាយបទពិសោធន៍របស់ពួកគេអំពីការជ្រើសរើស « ឧស្សាហ៍ចូលរួម » (គ. និង ស. ៥៨:២៧) ក្នុងប្រយោជន៍ល្អ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៤–៤៣

*ព្រះអម្ចាស់បានប្រទានការណែនាំស្ដីអំពីស៊ីយ៉ូន ហើយបង្រៀនគោលការណ៍នៃការប្រែចិត្ត*

មុនពេលចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖*តើការប្រែចិត្តមានន័យយ៉ាងណា ?*

សូមឲ្យសិស្សពីរបីនាក់ឆ្លើយតបសំណួរនេះ ។ បន្ទាប់មកសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើខ្ញុំអាចដឹងថាខ្ញុំបានប្រែចិត្តពេញលេញដោយរបៀបណា ? តើខ្ញុំអាចដឹងថា ព្រះអម្ចាស់អភ័យទោសចំពោះអំពើបាបខ្ញុំយ៉ាងដូចម្ដេច ?*

សូមអញ្ជើញសិស្សឲ្យសរសេរសំណួរទាំងនេះក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមឲ្យពួកគេចំណាយពេលពីរបីនាទី ដើម្បីសរសេរចម្លើយចំពោះសំណួរនិមួយៗ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមប្រាប់ពួកគេថា ពួកគេនឹងមានឱកាសមួយដើម្បីមើលចម្លើយពួកគេនៅពេលក្រោយក្នុងមេរៀន ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៤–៣៧ ដោយការពន្យល់ថា ពួកអែលឌើរជាច្រើន ដែលបានធ្វើដំណើរទៅរដ្ឋ មិសសួរី ហើយនឹងរស់នៅទីនោះ ចង់ដឹងពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើដើម្បីរៀបចំ ដាក់ផែនការ និងស្ថាបនាក្រុងស៊ីយ៉ូន ។ ព្រះអម្ចាស់បានណែនាំដល់អ្នកទាំងឡាយដែលផ្លាស់ទៅរដ្ឋ មិសសួរី ឲ្យផ្ដល់ប្រាក់ និងទ្រព្យសម្បត្តិរបស់ពួកគេសម្រាប់ជាបុព្វហេតុនៃការស្ថាបនាស៊ីយ៉ូនឡើង ។ ម៉ាទីន ហារិស ត្រូវបានណែនាំឲ្យធ្វើជាគំរូនៅក្នុងការប្រគល់ប្រាក់ទៅឲ្យប៊ីស្សព ។ គាត់បានបរិច្ចាគប្រាក់យ៉ាងច្រើនដើម្បីជួយប៊ីស្សព អែតវឺត ប៉ាទ្រិច ទិញដីសម្រាប់សាសនាចក្រ ។

សូមសរសេរឈ្មោះដូចខាងក្រោមនៅលើក្ដារខៀន ៖*ម៉ាទីន ហារិស, វិលាម ដ័បុលយូ ហ្វែប្ស* និង *សេបា ភីតើសុន* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៨–៤១, ៦០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការទូន្មានដែលព្រះអម្ចាស់បានប្រទានដល់ ម៉ាទីន ហារិស, វិលាម ដ័បុលយូ ហ្វែប្ស និង សេបា ភីតើសុន នៅពេលពួកគេបានរៀបចំដើម្បីស្ថាបនាក្រុងស៊ីយ៉ូន ។

នៅពេលសិស្សឆ្លើយតបចំពោះសំណួរដូចខាងក្រោម សូមសរសេរចម្លើយរបស់ពួកគេនៅក្រោមឈ្មោះត្រឹមត្រូវនៅលើក្ដារខៀន ។

- តើអំពើបាបអ្វីខ្លះដែលព្រះអម្ចាស់មានបន្ទូលថាជាកំហុសរបស់ ម៉ាទីន ហារីស ? តើព្រះអម្ចាស់ប្រាប់គាត់ឲ្យធ្វើអ្វីខ្លះ ?
- តើអំពើបាបអ្វីខ្លះ ដែលព្រះអម្ចាស់មានបន្ទូលថាជាកំហុសរបស់ វិលាម ដ័បុលយូ ហ្វែប្ស ? តើព្រះអម្ចាស់ប្រាប់គាត់ឲ្យធ្វើអ្វីខ្លះ ? ( អ្នកអាចចាំបាច់ត្រូវពន្យល់ថា ឃ្លា « ស្វែងរកដើម្បីតម្កើងខ្លួន » [ខ ៤១] ពុំមានន័យថាធ្វើ ឬព្យាយាមដើម្បី

តែលម្អដោយអស់ពីលទ្ធភាពរបស់យើងទេ ។ តែឃ្លានេះចង់សំដៅទៅលើបំណងប្រាថ្នាឥតសុចរិត និងប្រកបដោយអំនួត ដើម្បីបង្ហាញថាល្អប្រសើរ ឬសំខាន់ជាងមនុស្សដទៃទៀត ) ។

- តើសេបា ភីតើសុន ព្យាយាមធ្វើអ្វីខ្លះជាមួយនឹងអំពើបាបរបស់គាត់ ?

សូមចង្អុលបង្ហាញថា អំពើបាបទាំងឡាយរបស់មនុស្សទាំងនេះបានគំរាមគំហែងដើម្បីរារាំងពួកគេពីការជួយស្ថាបនាស៊ីយ៉ូន ។

- តើអំពើបាបរបស់យើងអាចនឹងដាក់កំហិតលើសមត្ថភាពរបស់យើងដើម្បីបម្រើព្រះអម្ចាស់តាមវិធីមួយចំនួនណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីការប្រែចិត្ត ។

- យោងតាមខគម្ពីរនេះ តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់យើង បើយើងប្រែចិត្តពីអំពើបាបរបស់យើង ? ( សិស្សគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងប្រែចិត្តពីអំពើបាបរបស់យើង នោះព្រះអម្ចាស់នឹងអភ័យទោសដល់យើង ហើយពុំចងចាំអំពើបាបរបស់យើងទៀតឡើយ** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន។ អ្នកក៏អាចឲ្យយោបល់សិស្សឲ្យគូសចំណាំឃ្លាដែលបង្រៀនគោលលទ្ធិទាំងនេះនៅក្នុង ខ ៤២ ) ។

- តើអំពើបាបរបស់យើងមួយណា ដែលការសន្យានេះត្រូវបានអនុវត្ត ? ( អំពើបាបទាំងអស់ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យ អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊យដ៏ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកពាក្យ ឬឃ្លាដែលទាក់ទងទៅនឹងគោលការណ៍ដែលបានសរសេរនៅលើក្ដារខៀន ។



« មិនថាការរំលងរបស់យើងជាអ្វីនោះទេ មិនថាសកម្មភាពរបស់យើងធ្វើឲ្យអ្នកដទៃឈឺចាប់យ៉ាងណាទេ កំហុសទាំងនោះ អាច ត្រូវបានលុបចោល ។ ចំពោះខ្ញុំ ឃ្លាដែលល្អបំផុតនៅក្នុងបទគម្ពីរទាំងអស់គឺនៅពេលព្រះអម្ចាស់មានបន្ទូលថា ‹ មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ › [គ. និង ស. ៥៨:៤២] ។

« នោះគឺជាការសន្យានៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួន » (The Atonement, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៧៧ ) ។

សូមនាំសិស្សមើលទៅសំណួរនៅលើក្ដារខៀន ។

- តើការសន្យារបស់ព្រះអម្ចាស់នៅក្នុង ខ ៤២ ជួយឆ្លើយសំណួរទីបីយ៉ាងដូចម្ដេច *តើខ្ញុំអាចដឹងថា ព្រះអម្ចាស់បានអភ័យទោសចំពោះអំពើបាបរបស់ខ្ញុំយ៉ាងដូចម្ដេច ?* ( ការសន្យារបស់ព្រះអម្ចាស់ ជួយយើងដឹងថា ទ្រង់តែងតែប្រទាននូវការអភ័យទោសជានិច្ច នៅពេលយើងបានប្រែចិត្តដោយពេញលេញ ) ។

- បន្ថែមពីលើការដឹងថា ព្រះអម្ចាស់ បានសន្យាថាអភ័យទោសដល់យើង នៅពេលយើងប្រែចិត្តដោយពេញលេញ តើយើងអាចដឹងថា យើងត្រូវបានអភ័យទោសយ៉ាងដូចម្ដេច?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរអេស្វ.អុជដូហ្វ នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សស្ដាប់អំពីរបៀបដែលពួកគេអាចដឹងថា តើនៅពេលណាព្រះអម្ចាស់បានអភ័យទោសដល់អំពើបាបរបស់ពួកគេ ។



« នៅពេលយើងពិតជាបានប្រែចិត្តនោះ ព្រះគ្រីស្ទនឹងដកចេញនូវបន្ទុកនៃទោសដែលជាបាបទាំងឡាយរបស់យើង ។ យើងអាចដឹងដោយខ្លួនឯងថា យើងត្រូវបានអត់ឱនឲ្យ ហើយបានធ្វើឲ្យស្អាត ។ ព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ពីការណ៍នេះដល់យើង ។ទ្រង់គឺជាអ្នកញែកឲ្យបរិសុទ្ធ ។ គ្មានទីបន្ទាល់ណាផ្សេងទៀតនៃការអភ័យទោស អាចអស្ចារ្យជាងនេះនោះទេ » « Point of Safe Return, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១០១ ) ។

- តើការដឹងថាអ្នកអាចត្រូវបានអភ័យទោសចំពោះអំពើបាបរបស់អ្នកទាំងអស់ ប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?

សូមពន្យល់ដល់សិស្សថា មនុស្សមួយចំនួនបានគិតដោយខុសឆ្គងថា បើពួកគេអាចនៅតែចងចាំអំពើបាបរបស់ពួកគេ នោះពួកគេពុំទាន់បានប្រែចិត្តពេញលេញទេ ។ សូមអញ្ជើញសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះឲ្យឮៗដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់ពីមូលហេតុដែលយើងអាចនៅចងចាំអំពើបាបរបស់យើង ទោះជាយើងបានប្រែចិត្តរួចហើយក្ដី ។



«សាតាំងនឹងព្យាយាមធ្វើឲ្យយើងជឿថា អំពើបាបរបស់យើងមិនត្រូវបានអត់ទោសទេ ដោយសារ *យើង* អាចចាំវា ។ សាតាំងជាមេកុហក វាព្យាយាមធ្វើឲ្យទស្សនៈរបស់យើងស្រអាប់ ហើយដឹកនាំយើងចេញពីផ្លូវនៃការប្រែចិត្ត និង ការអត់ទោស ។ ព្រះពុំបានសន្យាថា *យើង* នឹងមិនចងចាំអំពើបាបរបស់យើងទៀតនោះទេ ។ ការចងចាំនឹងជួយយើងឲ្យចៀសវាងពីការធ្វើកំហុសដដែលៗម្ដងទៀត ។ ប៉ុន្តែ បើយើងនៅតែពិត និង ស្មោះត្រង់ នោះការចងចាំពីអំពើបាបរបស់យើងនឹងត្រូវបានបន្ទន់ ចំពោះពេលវេលាទៅមុខទៀត ។ នេះនឹងជាចំណែកនៃដំណើរការនៃការព្យាបាល និងការញែកចេញឲ្យបរិសុទ្ធ » ( « Point of Safe Return,» ទំព័រ ១០១ ) ។

សូមចង្អុលបង្ហាញថា ការសន្យាដែលបានសរសេរនៅលើក្ដារខៀន គឺមានលក្ខខណ្ឌ ។ យើងអាចទទួលបានការអភ័យទោសពីព្រះអម្ចាស់ បើសិនជាយើងធ្វើនូវអ្វីៗគ្រប់យ៉ាងដែលយើងអាចធ្វើបាន ដើម្បីប្រែចិត្តពីអំពើបាបរបស់យើងដោយពេញលេញតែប៉ុណ្ណោះ ។

- តើការប្រែចិត្តមានអត្ថន័យយ៉ាងណា ? ( អ្នកអាចអញ្ជើញសិស្សឲ្យយោងទៅលើចម្លើយដែលពួកគេសរសេរ ឆ្លើយនឹងសំណួរនៅលើក្ដារខៀន ) ។

បន្ទាប់ពីសិស្សឆ្លើយតប សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមមកពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រឿងបន្ថែមទៀត ដើម្បីពួកគេអាចរៀនអំពីអត្ថន័យនៃការប្រែចិត្ត ។

« ការប្រែចិត្តគឺសំខាន់ជាងការទទួលស្គាល់កំហុសដ៏សាមញ្ញ ។ វាជាការផ្លាស់ប្ដូរនៃគំនិត និង ដួងចិត្ត ។ វារួមមានការបែរចេញពីអំពើបាប ហើយបែរទៅរកព្រះសម្រាប់ការអភ័យទោស ។ វាត្រូវបានជម្រុញដោយសេចក្ដីស្រឡាញ់ដល់ព្រះ និង បំណងដ៏ស្មោះត្រង់ក្នុងការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ » (*ដើម្បីកម្លាំងនៃយុវជន* កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ២៨ ) ។

សូមពន្យល់ថា ការប្រែចិត្តពិត រួមមាននូវតម្រូវការមួយចំនួន ។ តម្រូវការចំនួនពីរនៃតម្រូវការទាំងនេះ មានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤៣ ។ សូមឲ្យសិស្សម្នាក់អានខគម្ពីរនោះឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរឿងពីរយ៉ាងដែលយើងត្រូវធ្វើដើម្បីប្រែចិត្តពេញលេញពីអំពើបាបរបស់យើង ។

- ស្របតាម ខ ៤៣ តើរឿងពីរយ៉ាងដែលយើងត្រូវធ្វើដើម្បីប្រែចិត្តពីអំពើបាបរបស់យើងពេញលេញមានអ្វីខ្លះ ? ( សិស្សគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **ដើម្បីប្រែចិត្ត យើងត្រូវតែសារភាព ហើយលះបង់ចោលនូវអំពើបាបទាំងឡាយរបស់យើង ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើសេចក្ដីពិតនេះ ជួយយើងឲ្យឆ្លើយចំពោះសំណួរថា*តើយើងអាចដឹងថា បើយើងបានប្រែចិត្តបានពេញលេញដោយរបៀបណា ?* ( សូមជួយសិស្សឲ្យយល់ថា ការសារភាព និងការលះបង់ចោលអំពើបាបទាំងឡាយ គឺសំខាន់ចំពោះការប្រែចិត្តពេញលេញ ) ។

- តើការសារភាពអំពើបាបរបស់យើងមានន័យដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរអំពីអត្ថន័យនៃការសារភាពអំពើបាបរបស់យើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ការសារភាព និងការលះបង់ចោល គឺជាគោលគំនិតដ៏មានអានុភាព ។ វាមានន័យច្រើនជាងពាក្យថា ‹ ខ្ញុំព្រមទទួលកំហុស ខ្ញុំសូមទោស › ។ ការសារភាព គឺជាការទទួលស្គាល់ដោយអស់ពីចិត្ត ពេលខ្លះដោយការឈឺចាប់ចំពោះកំហុស និងការធ្វើទាស់នឹងព្រះ និងមនុស្ស » (« The Divine Gift of Repentance » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៤០ ) ។

- តើការសារភាពអំពើបាបរបស់យើងជួយយើងងាកចេញពីអំពើបាប ហើយបែរទៅរកព្រះសុំការអភ័យទោសយ៉ាងដូចម្ដេច ?

ជាចំណែកនៃការពិភាក្សានេះ សិស្សអាចនឹងងឿងឆ្ងល់ថា អំពើបាបអ្វីខ្លះដែលចាំបាច់ត្រូវសារភាព ហើយត្រូវសារភាពដល់នរណា ។ សូមពន្យល់ថា យើងចាំបាច់ត្រូវសារភាពចំពោះអំពើបាបទាំងអស់របស់យើងចំពោះព្រះវរបិតាសួគ៌ ។ ការរំលងធ្ងន់ធ្ងរ ដូចជាអំពើរំលងខាងផ្លូវភេទ ឬការប្រើរូបអាសគ្រាម គួរតែត្រូវសារភាពដល់ប៊ីស្សព ឬប្រធានសាខាផងដែរ ។

សូមនាំសិស្សទៅកាន់សេចក្ដីពិតចុងក្រោយដែលអ្នកបានសរសេរនៅលើក្ដារខៀន ។

- តើការលះបង់ចោលអំពើបាបរបស់យើងមានន័យដូចម្ដេច ? ( ដើម្បីងាកចេញពីអំពើបាបទាំងស្រុង ហើយឈប់ធ្វើវាតទៅទៀត ) ។

សូមថ្លែងទីបន្ទាល់អំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និងគោលការណ៍នានានៃការប្រែចិត្ត និងការអភ័យទោសដែលអ្នកបានពិភាក្សា ។ សូមអញ្ជើញសិស្សឲ្យពិចារណាថាតើពួកគេមានអំពើបាបណាដែលពួកគេចាំបាច់ត្រូវប្រែចិត្តឬទេ ហើយលើកទឹកចិត្តពួកគេឲ្យប្រែចិត្តដោយការធ្វើតាសេចក្ដីពិតដែលពួកគេបានរៀន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤៤–៦៥

*ព្រះអម្ចាស់បញ្ជាឲ្យពួកអែលឌើរផ្សាយដំណឹងល្អ ហើយប្រឹក្សាពួកគេស្ដីអំពីរបៀបដើម្បីស្ថាបនាស៊ីយ៉ូនឡើង*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤៩–៦២ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រាប់ពួកអែលឌើរ ដែលស្នាក់នៅរដ្ឋមិសសួរី ថាពួកគេគួរតែទិញដី ហើយរៀបចំសម្រាប់ការប្រមូលផ្ដុំនៃពួកបរិសុទ្ធនៅរដ្ឋ មីសសួរី ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤៦–៤៧ ,៦៣–៦៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវដំបូន្មាន ដែលព្រះអម្ចាស់បានប្រទានដល់ពួកអែលឌើរ ដែលត្រឡប់ទៅកាន់រដ្ឋ អូហៃអូ ។

- ស្របតាម ខ ៤៦–៤៧ តើពួកអែលឌើរត្រូវធ្វើអ្វីខ្លះ នៅពេលពួកគេបានត្រឡប់ទៅរដ្ឋ អូហៃអូ វិញ ?

- ស្របតាម ខ ៦៤ តើដំណឹងល្អត្រូវផ្សាយទៅដល់នរណា ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងអំពីសេចក្ដីពិតដូចខាងក្រោម ៖**ដំណឹងល្អ ត្រូវតែផ្សាយដល់មនុស្សគ្រប់រូប ។** អ្នកក៏អាចឲ្យយោបល់សិស្សឲ្យគូសចំណាំឃ្លាដែលបង្រៀនសេចក្ដីពិតនេះ នៅ ខ ៦៤) ។

សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណដើម្បីចែកចាយសេចក្ដីពិតនៃដំណឹងល្អជាមួយនឹងអ្នកទាំងឡាយដែលនៅជុំវិញពួកគេ ។

មេរៀនទី ៦៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩

### បុព្វកថា

នៅថ្ងៃ អាទិត្យទី ៧ ខែសីហា ឆ្នាំ ១៨៣១ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ ខណៈដែលស្ថិតនៅក្នុងឃុំ ចាកសុនរដ្ឋ មិសសួរី ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានដាក់ការពឹងទុករបស់ទ្រង់ចំពោះពួកបរិសុទ្ធដែលបានមកដល់ស៊ីយ៉ូនថ្មីៗ រួមទាំងការរក្សាថ្ងៃឈប់សម្រាកឲ្យត្រឹមត្រូវ ។ ព្រះអម្ចាស់ក៏បានបញ្ជាក់ផងដែរថា អ្នកទាំងឡាយណាដែលរក្សាបទបញ្ញត្តិរបស់ទ្រង់ នឹងទទួលពរជ័យខាងវិញ្ញាណ និងខាងសាច់ឈាម ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១–៤

*ព្រះអម្ចាស់បានពិពណ៌នាអំពីពរជ័យទាំងឡាយ ដែលទ្រង់នឹងប្រទានមកលើពួកបរិសុទ្ធស្មោះត្រង់នៅស៊ីយ៉ូន*

មុនចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖

> *តើអ្នកគិតថា ការស្រឡាញ់ព្រះអម្ចាស់ដោយអស់ពីដួងចិត្តរបស់អ្នក មានន័យយ៉ាងដូចម្ដេច ________________?*
>
> *តើសកម្មភាព ឬអាកប្បកិរិយាណាខ្លះ ដែលអ្នកអាចមើលឃើញនៅក្នុងខ្លួនមនុស្សដែលស្រឡាញ់ព្រះអម្ចាស់ដោយអស់ពីដួងចិត្តរបស់ពួកគេ ________________________________ ផ្ទុយពីអ្នកទាំងឡាយដែលពុំមាន ?*

នៅពេលចាប់ផ្ដើមថ្នាក់ សូមសរសេរឈ្មោះ *ប៉ូលី ណែត់* នៅលើក្ដារខៀន ។ សូមសួរដល់សិស្សនូវអ្វីដែលពួកគេចងចាំអំពីនាងដកស្រង់ចេញពីមេរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ ។ បើសិស្សត្រូវការជំនួយដើម្បីចងចាំ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងអំពី ប៉ូលី ណែត់ ដែលបានផ្ដល់ឲ្យនៅក្នុងមេរៀន ៦២ ។

- តើអ្នកសរសើរ ប៉ូលី ណែត់ ដោយសាមូលហេតុអ្វីខ្លះ ?

សូមប្រាប់សិស្សថា យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ នៅថ្ងៃដែល ប៉ូលី ស្លាប់ ។ សូមអញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១–២ ដោយស្ងាត់ស្ងៀម ហើយស្វែងរកឃ្លាដែលអាចនឹងមានអត្ថន័យចំពោះមិត្ត និងមនុស្សជាទីស្រឡាញ់របស់គាត់ ។ សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេបានរកឃើញ ។

- ស្របតាម ខ ១ តើនរណាដែលវិវរណៈនេះ អនុវត្តចំពោះគេ ក្រៅពី ប៉ូលី ណែត់ ? ( ពួកបរិសុទ្ធដែលគោរពតាមបទបញ្ញត្តិរបស់ព្រះដោយកែវភ្នែកទាំងស្រុងចំពោះសិរីល្អរបស់ទ្រង់ ) ។ តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីមានកែវភ្នែកទាំងស្រុងចំពោះសិរីល្អនៃព្រះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៣–៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលពរជ័យខាងសាច់ឈាម និងខាងវិញ្ញាណ ដែលបានសន្យាចំពោះអ្នកទាំងឡាយដែលគោរពព្រះអម្ចាស់ដោយកែវភ្នែកទាំងស្រុងចំពោះសិរីល្អរបស់ទ្រង់ ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- នៅក្នុង ខ ៤ តើពរជ័យអ្វីខ្លះដែលព្រះអម្ចាស់បានសន្យា ដែលមនុស្សមួយចំនួនអាចនឹងមិនគិតថាជាពរជ័យ ? ( « បទបញ្ញត្តិទាំងឡាយ ពុំមែនតែពីរបីនោះទេ » ) ។ តើបទបញ្ញត្តិជាពរជ័យសម្រាប់យើងតាមវិធីណាខ្លះ ? ( នៅពេលសិស្សឆ្លើយតបចំពោះសំណួរនេះ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យពួកគេអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២០–២១) ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖*បើយើងរក្សាបទបញ្ញត្តិទាំងឡាយដោយកែវភ្នែកទាំងស្រុងចំពោះសិរីល្អនៃព្រះ នោះ*

សូមអញ្ជើញសិស្សឲ្យបំពេញសេចក្ដីថ្លែងការណ៍ដោយប្រើអ្វីដែលពួកគេបានរៀនចេញមកពី ខ ១–៤ វិធីមួយដែលសិស្សអាចបង្ហាញពីគោលការណ៍នេះគឺ **បើសិនជាយើងរក្សាបទបញ្ញត្តិទាំងឡាយដោយភែកតែមួយចំពោះសិរីល្អនៃព្រះ នោះយើងនឹងត្រូវបានប្រទានពរទាំងខាងសាច់ឈាម និងខាងវិញ្ញាណ** ។ សូមអញ្ជើញសិស្សឲ្យស្វែងរកមើលគំរូបន្ថែមទៀតអំពីគោលការណ៍នេះ នៅពេលពួកគេបន្តសិក្សាវិវរណៈនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៥–៨

*ព្រះអម្ចាស់បានប្រទានបទបញ្ញត្តិទាំងឡាយដល់ពួកបរិសុទ្ធ*

សូមពន្យល់ថា ព្រះអម្ចាស់បានបន្តវិវរណៈនេះ តាមរយៈការប្រទានដល់ពួកបរិសុទ្ធនៅស៊ីយ៉ូននូវបទបញ្ញត្តិមួយចំនួន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ ប្រាប់ពីបទបញ្ញត្តិមួយដែលព្រះអម្ចាស់បានប្រទានឲ្យពួកបរិសុទ្ធ ។

ស្របតាមខគម្ពីរនេះ តើព្រះអម្ចាស់រំពឹងអ្វីខ្លះ ពីពួកបរិសុទ្ធរបស់ទ្រង់ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**យើងត្រូវតែស្រឡាញ់ព្រះដោយអស់ពីចិត្ត ពលំ គំនិត និងកម្លាំងរបស់យើង** ) ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមចាត់ឲ្យដៃគូនិមួយៗនូវពាក្យមួយដែលពិពណ៌នាអំពីរបៀបដែលយើងគួរតែស្រឡាញ់ព្រះអម្ចាស់ឲ្យ ( អស់ពីចិត្ត ពលំ គំនិត និងកម្លាំង ) ។ សូមណែនាំសិស្សឲ្យប្រើពាក្យដែលបានចាត់ទៅឲ្យពួកគេបំពេញសំណួរទាំងឡាយដែលអ្នកបានសរសេរនៅលើក្ដារខៀនពីមុខសិស្សក្នុងថ្នាក់ ។ សូមអញ្ជើញសិស្សម្នាក់ក្នុងចំណោមដៃគូនិមួយៗ ឆ្លើយចំពោះសំណួរទីមួយ ហើយសិស្សម្នាក់ទៀតឆ្លើយចំពោះសំណួរទីពីរ ។ ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីពិភាក្សាពីសំណួរទាំងនេះជាគូរួចហើយ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

ដើម្បីជួយសិស្សដឹងអំពីសេចក្ដីពិត និងសារៈសំខាន់នៃបទបញ្ញត្តិឲ្យស្រឡាញ់ព្រះឲ្យអស់ពីអស់ពីចិត្ត ពលំ គំនិត និងកម្លាំងរបស់យើង សូមអញ្ជើញពួកគេឲ្យឆ្លើយតបចំពោះសេចក្ដីថ្លែងការណ៍មួយនៃសេចក្ដីថ្លែងការដូចខាងក្រោមនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ៖

- សូមពិពណ៌នាអំពីគ្រាមួយ ដែលអ្នកមានអារម្មណ៍ថាស្រឡាញ់ព្រះអម្ចាស់យ៉ាងអស្ចារ្យ ។
- សូមពិពណ៌នាអំពីគ្រាមួយដែលក្ដីស្រឡាញ់របស់អ្នកចំពោះព្រះអម្ចាស់មានឥទ្ធិពលទៅលើការសម្រេចចិត្តដែលអ្នកបានធ្វើ ។

> ### *សូមជួយសិស្សឲ្យយល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយ*
>
> គ្រូទាំងឡាយអាចជួយសិស្សយល់ពីគោលលទ្ធិ និង គោលការណ៍នានានៃដំណឹងល្អបានកាន់តែល្អប្រសើរតាមរយៈការសួរសំណួរ ដែលលើកទឹកចិត្តសិស្សឲ្យវិភាគពីអត្ថន័យរបស់វា ។ សំណួរដូច្នេះ គួរតែជួយដល់សិស្សឲ្យយល់អំពីរបៀបដែលសេចក្ដីពិតទាំងនេះអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។ សូមពិភាក្សាអំពីរបៀបដើម្បីអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អនៅក្នុងស្ថានភាពជីវិតពិត អាចជួយសិស្សទទួលបាននូវការយល់ដឹងកាន់តែច្រើនអំពីសេចក្ដីពិត ដែលពួកគេបានរៀននៅក្នុងបទគម្ពីរ ។

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ដល់សិស្សហើយ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេ ។ ( សូមរំឭកសិស្សថាពួកគេមិនគួរចែកចាយពីបទពិសោធន៍ពិសិដ្ឋឬ រឿងផ្ទាល់ខ្លួនខ្លាំងពេកនោះទេ ។ )

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៦–៨ ដោយស្ងាត់ស្ងៀម ហើយប្រាប់អំពីបទបញ្ញត្តិបន្ថែមដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធអំឡុងគ្រានេះ ។

- តើបទបញ្ញត្តិទាំងនេះទាក់ទងទៅនឹងបទបញ្ញត្តិដើម្បីស្រឡាញ់ព្រះអម្ចាស់ឲ្យអស់ពីចិត្ត ពលំ គំនិត និងកម្លាំងរបស់យើងយ៉ាងដូចម្ដេច ?
- តើការស្រឡាញ់អ្នកជិតខាងរបស់យើង បង្ហាញពីក្ដីស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់យ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩–១៩

*ព្រះអម្ចាស់បង្រៀនដល់ពួកបរិសុទ្ធអំពីថ្ងៃឈប់សម្រាក*

សូមផ្ដល់ច្បាប់ចម្លងសេចក្ដីថ្លែងការណ៍ដោយអែលឌើរ ម៉ាក អ៊ី ភីធើរសិននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដូចខាងក្រោមដល់សិស្ស ឬសរសេរវានៅលើក្ដារខៀនពីមុនថ្នាក់ចាប់ផ្ដើម ។ ( សេចក្ដីថ្លែងការណ៍នេះ ត្រូវបានរកឃើញនៅក្នុង « The Sabbath Day » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៤៩ ) ។

> *« ការប្រតិបត្តិតាម ឬ មិនប្រតិបត្តិតាមរបស់យើងចំពោះ ________ គឺជារង្វាស់ដ៏ពិតប្រាកដមួយអំពីអាកប្បកិរិយារបស់យើងផ្ទាល់ចំពោះព្រះអម្ចាស់ និង ចំពោះការរងទុក្ខរបស់ទ្រង់នៅក្នុងសួនច្បារ គែតសេម៉ានី ការសុគតរបស់ទ្រង់នៅលើឈើឆ្កាង និង ការមានព្រះជន្មរស់ពីសុគតឡើងវិញរបស់ទ្រង់» ( អែលឌើរ ម៉ាក អ៊ី ភីធើរសិន )។*

សូមអញ្ជើញសិស្សឲ្យស្មានពាក្យដែលបាត់ពីសេចក្ដីថ្លែងការនេះ ( « ថ្ងៃឈប់សម្រាក » ) ។ បន្ទាប់ពីពួកគេបានចែកចាយគំនិតរបស់ពួកគេហើយ សូមពន្យល់ថា នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ ព្រះអម្ចាស់បានថ្លែងឡើងវិញនូវបទបញ្ញត្តិមួយដែលអាចជួយពួកបរិសុទ្ធឲ្យដាក់ព្រះជាមុននៅក្នុងជីវិតរបស់ពួកគេ ហើយពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយនឹងទ្រង់កាន់តែខ្លាំង ។ នេះគឺជាបទបញ្ញត្តិដែលអែលឌើរ ភីធើរសិន បានសំដៅទៅលើនោះ ។ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩–១០ ឲ្យឮៗ ហើយសុំឲ្យសិស្សម្នាក់ប្រាប់អំពីបទបញ្ញត្តិដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។

- តើបទបញ្ញត្តិអ្វីដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុងខទាំងនេះ ? ( រក្សាថ្ងៃឈប់សម្រាកឲ្យបានបរិសុទ្ធ ) ។

សូមអញ្ជើញសិស្សឲ្យបំពេញសេចក្ដីថ្លែងការណ៍របស់អែលឌើរ ភីធើរសិន ជាមួយនឹងពាក្យ *ថ្ងៃឈប់សម្រាក ។*

- យោងតាមអែលឌើរ ភីធើរសិន តើការប្រតិបត្តិតាមរបស់យើងចំពោះថ្ងៃឈប់សម្រាក ទាក់ទងនឹងការស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់ និងដង្វាយធួនរបស់យើងយ៉ាងដូចម្ដេច ?

សូមចង្អុលបង្ហាញថានៅក្នុង ខ ៩ ព្រះអម្ចាស់បានសន្យានូវពរជ័យដ៏មហិមាមួយចំពោះអ្នកទាំងឡាយដែលគោរពដល់ថ្ងៃឈប់សម្រាកដ៏បរិសុទ្ធរបស់ទ្រង់ ។ សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ នោះវានឹងជួយយើង. . .*

សូមឲ្យសិស្សមើល ខ ៩ ហើយប្រាប់ពីការសន្យាដែលព្រះអម្ចាស់បានប្រទានជាមួយនឹងបទបញ្ញត្តិនេះ ។

- ស្របតាម ខ ៩ តើយើងនឹងត្រូវបានប្រទានពរ ដោយការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធយ៉ាងដូចម្ដេច ? តើអ្នកគិតថាវាមានន័យយ៉ាងណាដែរ ក្នុងការរក្សាខ្លួនយើង « កុំឲ្យប្រឡាក់ពីលោកិយ » ?

សូមអញ្ជើញសិស្សឲ្យបំពេញសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ដោយប្រើពាក្យរបស់ពួកគេផ្ទាល់ ។ នៅខាងក្រោមនេះ គឺជាវិធីមួយដែលសិស្សអាចបង្ហាញពីគោលការណ៍នេះ ៖ **បើយើងរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ នោះវានឹងជួយយើងទប់ទល់នឹងការល្បួង ហើយយកឈ្នះអំពើបាប ។** អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យសរសេរចំណាំគោលកាណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សូមពន្យល់ថា ខ ៩–១៤ ជួយយើងឲ្យយល់នូវអត្ថន័យដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ សូមចាត់ឲ្យសិស្សម្នាក់ៗនូវខគម្ពីរមួយដូចខាងក្រោម ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩, ១០, ១២ និង ១៣ ។ សូមអញ្ជើញសិស្សឲ្យសិក្សានូវខគម្ពីរដែលបានចាត់ទៅឲ្យគេដោយស្ងៀមស្ងាត់ រកមើលនូវគំនិតអំពីរបៀបដែលយើងអាចរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ សូមប្រាប់សិស្សថា ពួកគេនឹងមានឱកាសមួយដើម្បីចែកចាយនូវអ្វីដែលពួកគេបានរកឃើញជាមួយនឹងសិស្សក្នុងថ្នាក់ ។ ពីមុនពេលសិស្សចាប់ផ្ដើមអានខគម្ពីរដែលចាត់ទៅឲ្យពួកគេ វាអាចនឹងជាជំនួយដើម្បីពន្យល់ឃ្លា « ថ្វាយភក្ដីភាពរបស់អ្នក » នៅក្នុង ខ ១០ មានន័យថា ការថ្វាយបង្គំ ឬដើម្បីបង្ហាញសេចក្ដីស្រឡាញ់ និងភក្ដីភាពរបស់យើង ។ បន្ថែមពីលើនោះ អ្នកអាចនឹងចង់ចង្អុលបង្ហាញពីលេខយោងចំពោះពាក្យ *ភាគពួកិច្ច* នៅក្នុង ខ ១២ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សម្នាក់ដែលបានសិក្សា ខ ៩ អាននូវខនោះឲ្យឮៗ ។ សូមអញ្ជើញសិស្សដែលសិក្សាខគម្ពីរនេះ ចែកចាយគំនិតដែលពួកគេរកឃើញអំពីរបៀបដែលយើងអាចរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ សូមចាត់សិស្សម្នាក់ឲ្យធ្វើជាស្មៀន ហើយសរសេរគំនិតទាំងនេះនៅពីក្រោមគោលការណ៍នៅលើក្ដារខៀន ។ ( ឧទាហរណ៍ នៅក្នុង ខ ៩ សិស្សអាចនឹងប្រាប់អំពីការទៅព្រះវិហារ ការអធិស្ឋាន និងការទទួលទានសាក្រាម៉ង់ជាផ្នែកសំខាន់នៃការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ) ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមដំណើរការនេះឡើងវិញជាមួយនឹងខដែលនៅសល់និមួយៗ ។

- តើកិច្ចខិតខំរបស់អ្នកដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធបានជួយអ្នកទប់ទល់នឹងការល្បួង ហើយពង្រឹងដល់អ្នកខាងវិញ្ញាណយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១៥ ដោយស្ងាត់ស្ងៀម រកមើលឃ្លាដែលពិពណ៌នាអំពីអាកប្បកិរិយាដែលយើងគួរមានចំពោះថ្ងៃឈប់សម្រាក ។ សូមឲ្យសិស្សចែកចាយនូវឃ្លាដែលពួកគេបានប្រាប់ ហើយពន្យល់ថាហេតុអ្វីក៏ការមានអាកប្បកិរិយាបែបនេះនៅថ្ងៃឈប់សម្រាក អាចជួយយើងរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធបានដូច្នេះ ។

សូមសង្ខេបដោយខ្លីៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១៦–១៩ ដោយការពន្យល់ថា ព្រះអម្ចាស់បានពន្យល់អំពីពរជ័យខាងសាច់ឈាម និងខាងវិញ្ញាណចំពោះអ្នកទាំងឡាយដែលគោរពថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ សូមចែកចាយអំពីរបៀបដែលការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ មានឥទ្ធិពលលើទំនាក់ទំនងរបស់អ្នកជាមួយព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីមួយដែលពួកគេនឹងធ្វើ ដើម្បីជួយពួកគេរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២០–២៤

*ព្រះអម្ចាស់សន្យាពរជ័យខាងលោកិយ និងភាពអស់កល្បជានិច្ចចំពោះពួកស្មោះត្រង់*

សូមឲ្យសិស្សនឹកគិតថា ពួកគេគឺជាឪពុកម្ដាយដែលប្រទានអំណោយដល់កូនៗរបស់ពួកគេ ។ កូនៗខ្លះតែងតែបង្ហាញនូវការដឹងគុណដោយស្មោះគ្រប់នៅគ្រាដែលបានទទួលអំណោយ ។

- តើរឿងនោះធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ក្នុងនាមជាឪពុកម្ដាយនោះ ? តើរឿងនោះមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកដើម្បីផ្ដល់អំណោយឲ្យកាន់តែច្រើនថែមទៀតដែរឬទេ ? ហេតុអ្វី ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២០–២១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះមានព្រះទ័យយ៉ាងណាអំពីការប្រទានពរដល់យើង និងរបៀបដែលយើងគួរតែឆ្លើយតបចំពោះទ្រង់ នៅពេលយើងទទួលបានពរជ័យនានានោះ ។

- តើព្រះមានព្រះទ័យយ៉ាងណាអំពីការប្រទានពរដល់យើង ? ( រីករាយ ក្នុងការ ... ) ។ ស្របតាម ខ ២១ តើយើងអាចនឹងជំទាស់ព្រះយ៉ាងដូចម្ដេច ? ( សិស្សគួរតែពិពណ៌នានូវគោលការណ៍ដូចខាងក្រោម ៖**យើងជំទាស់នឹងព្រះ នៅពេលយើងពុំបង្ហាញនូវការដឹងគុណចំពោះទ្រង់ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់នោះ** ) ។

សូមជួយសិស្សឲ្យយល់ថា ការជំទាស់ និងសេចក្ដីក្រោធរបស់ព្រះ ដែលបានពិពណ៌នានៅក្នុង ខ ២១ គឺជាភស្តុតាងនៃសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើង ។ ទ្រង់ពុំសព្វព្រះទ័យទេ នៅពេលយើងគ្មានអំណរគុណ និងមិនគោរពប្រតិបត្តិតាមនោះ ដោយសារអាកប្បកិរិយាទាំងនេះ នាំយើងឃ្លាតឆ្ងាយពីទ្រង់ ។

- ហេតុអ្វីក៏អ្នកគិតថា វាធ្វើឲ្យខូចទំនាក់ទំនងរបស់យើងនឹងព្រះ នៅពេលយើងពុំអរគុណទ្រង់ចំពោះពរជ័យទាំងឡាយដែលយើងទទួលបានមកពីទ្រង់នោះ ?

- តើសេចក្ដីពិតនេះ ទាក់ទងនឹងគោលការណ៍ដែលបានប្រាប់ពីខាងដើម អំពីការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធយ៉ាងដូចម្ដេច?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២៣–២៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យទាំងឡាយដែលព្រះអម្ចាស់សន្យាចំពោះ អ្នកទាំងឡាយដែលរក្សាបទបញ្ញត្តិរបស់ទ្រង់ ។

- តើការរស់នៅស្របតាមសេចក្ដីពិត ដែលយើង ត្រូវបានប្រាប់នៅក្នុងវិវរណៈនេះ នាំមកនូវសេចក្ដីសុខសាន្តដល់ជីវិតរបស់អ្នកតាមយ៉ាងដូចម្ដេចខ្លះ ?

សូមបញ្ចប់ដោយការអញ្ជើញសិស្សឲ្យពិចារណាអំពីវិធីជាច្រើន ដែលព្រះបានប្រទានពរដល់ពួកគេចំពោះការរក្សាបទបញ្ញត្តិរបស់ទ្រង់ និងរបៀបដែលពួកគេអាចបង្ហាញនូវការដឹងគុណចំពោះទ្រង់ ។

# កន្លែងកណ្ដាលនៃស៊ីយ៉ូន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧–៥៩ ( មេរៀនទី ១៣ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា « កន្លែងកណ្ដាលនៃស៊ីយ៉ូន » គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧–៥៩ ( មេរៀនទី ១៣) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ( កន្លែងកណ្ដាលនៃស៊ីយ៉ូន )

នៅក្នុងមេរៀននេះសិស្សបានទទួលទស្សនៈនៃការយល់ដឹងមួយអំពីទីក្រុងស៊ីយ៉ូន ។ ពួកគេបានឃើញថាទីក្រុងស៊ីយ៉ូន សំដៅលើទឹកដី និងទីក្រុងមួយព្រមទាំងមនុស្សមួយក្រុមដែលមានដួងចិត្តបរិសុទ្ធ ។ សិស្សបានរៀនផងដែរអំពីទីតាំងនៃទីក្រុងស៊ីយ៉ូន ហើយថាទីក្រុងស៊ីយ៉ូនត្រូវតែសាងសង់លើគោលការណ៍នៃសេចក្ដីសុចរិត ។ សិស្សក៏បានសិក្សាផងដែរ អំពីឧបសគ្គនានាដែលពួកបរិសុទ្ធបានជួបប្រទះ នៅពេលពួកគេបានព្យាយាមស្ថាបនាទីក្រុងស៊ីយ៉ូននៅឃុំចាកសុន រដ្ឋមីសសួរី ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧)

ជាផ្នែកមួយនៃមេរៀននេះ សិស្សបានរៀនថាទីក្រុងស៊ីយ៉ូននឹងត្រូវបានបោះទីតាំងនៅក្នុង ក្រុងអ៊ិនឌីប៉ែនដែនស៍ ឃុំចាកសុន រដ្ឋមិសសួរី ហើយព្រះវិហារបរិសុទ្ធមួយនឹងត្រូវបានសាងសង់ឡើងនៅទីនោះ ។ ព្រះអម្ចាស់បានផ្ដល់ការណែនាំដល់បុគ្គលម្នាក់ៗ ដែលត្រូវបានហៅដើម្បីស្ថាបនាក្រុងស៊ីយ៉ូនឡើង ។ នៅពេលសិស្សបានរៀនអំពីបុគ្គលទាំងនេះ នោះពួកគេបានឃើញថា យើងគួរតែប្រើកម្លាំងផ្ទាល់ខ្លួនយើងម្នាក់ៗ ដើម្បីជួយស្ថាបនានគររបស់ព្រះអម្ចាស់ នៅពេលទ្រង់ហៅយើងឲ្យធ្វើដូច្នោះ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨)

តាមរយៈការសិក្សាព្រះឱវាទដែលព្រះអម្ចាស់បានប្រទានដល់ពួកអែលឌើរ ដែលជួបនឹងកិច្ចការដ៏អស្ចារ្យនៃការស្ថាបនាទីក្រុងស៊ីយ៉ូន នោះសិស្សបានឃើញពីគោលការណ៍ខាងក្រោម ៖ យើងនឹងត្រូវបានប្រទានពរប្រសិនបើយើងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ រង្វាន់អស់កល្បជានិច្ចរបស់យើងនឹងកាន់តែមហិមា ប្រសិនបើយើងនៅតែបន្តស្មោះត្រង់នៅក្នុងទុក្ខលំបាករបស់យើង ហើយប្រសិនបើយើងប្រើសិទ្ធជ្រើសរើសរបស់យើងធ្វើនូវអ្វីៗដែលនាំមកនូវសេចក្ដីសុចរិត នោះយើងនឹងទទួលរង្វាន់ ។ សិស្សក៏បានគិតអំពីការសន្យារបស់ព្រះអម្ចាស់ថា បើយើងប្រែចិត្តពីអំពើបាបរបស់យើង នោះទ្រង់នឹងអភ័យទោសដល់យើង ហើយពុំចងចាំអំពើបាបរបស់យើងទៀតឡើយ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩)

តាមរយៈការសិក្សាការណែនាំរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធដែលបានធ្វើដំណើរទៅរដ្ឋ មិសសួរី នោះសិស្សបានរៀនថា យើងត្រូវតែស្រឡាញ់ព្រះឲ្យអស់ពីចិត្ត ពលំ គំនិត និង កម្លាំងរបស់យើង ហើយថាប្រសិនបើយើងគោរពថ្ងៃឈប់សម្រាកទុកជាបរិសុទ្ធ នោះវានឹងជួយយើងឲ្យទប់ទល់នឹងការល្បួង ហើយយកឈ្នះលើអំពើបាប ។ ពួកគេក៏បានរៀនផងដែរថា យើងជំទាស់នឹងព្រះ នៅពេលយើងពុំបង្ហាញអំណរគុណចំពោះទ្រង់ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់នោះ ។ សិស្សក៏បានរកឃើញពរជ័យនានាដែលពួកគេទទួលបាន ប្រសិនបើពួកគេគោរពបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។

## សេចក្ដីផ្ដើម

មេរៀននេះអាចជួយសិស្សឲ្យ យល់គោលការណ៍នៃការប្រែចិត្តនេះឲ្យបានកាន់តែប្រសើរឡើង ។ នៅពេលសិស្សរៀនពីគោលការណ៍ទាំងនេះ នោះពួកគេអាចពិចារណាពីអ្វីដែលពួកគេត្រូវតែធ្វើដើម្បីប្រែចិត្ត និង របៀបដែលការសន្យានៃអភ័យទោសរបស់ព្រះអម្ចាស់អាចប្រទានពរជ័យដល់ជីវិតរបស់ពួកគេ ។ ដូចដែលចំណុចមួយចំនួននេះត្រូវបានរៀបរាប់នៅក្នុងមេរៀនប្រចាំថ្ងៃ នោះមេរៀននេះផ្ដល់ឱកាសដល់អ្នកឲ្យជួយសិស្សរបស់ខ្លួនយល់កាន់តែប្រសើរឡើង នូវគោលការណ៍នានានៃការប្រែចិត្ត និង របៀបដើម្បីអនុវត្តគោលការណ៍នោះនៅក្នុងជីវិតខ្លួន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៤–៤៣

*ព្រះអម្ចាស់បានប្រទានការណែនាំស្ដីអំពីស៊ីយ៉ូន ហើយបង្រៀនគោលការណ៍នៃការប្រែចិត្ត*

មុនពេលចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើការប្រែចិត្តមានន័យដូចម្ដេច ? តើខ្ញុំអាចដឹងថា ខ្ញុំបានប្រែចិត្តទាំងស្រុងដោយរបៀបណា ?* នៅពេលចាប់ផ្ដើមថ្នាក់ សូមសួរសិស្សពីរបៀបដែលពួកគេនឹងឆ្លើយសំណួរទាំងនោះ ។

សូមសរសេរឈ្មោះខាងក្រោមនៅលើក្ដារខៀន ៖ *ម៉ាទីន ហារិស, វិលាម ដំបុលយូ ហ្វែប្ស* និង *សេបា ភីតើសុន* ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៨–៤១, ៦០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រះឱវាទដែលព្រះអម្ចាស់បានប្រទានដល់បុរសទាំងនោះ នៅពេលពួកគេបានរៀបចំដើម្បីស្ថាបនាក្រុងស៊ីយ៉ូន ។ នៅពេលសិស្សឆ្លើយតបចំពោះសំណួរដូចខាងក្រោម សូមសរសេរចម្លើយរបស់ពួកគេនៅក្រោមឈ្មោះត្រឹមត្រូវនៅលើក្ដារខៀន ។

- តើអំពើបាបអ្វីខ្លះដែលព្រះអម្ចាស់មានបន្ទូលថាជាកំហុសរបស់ ម៉ាទីន ហារីស ? តើព្រះអម្ចាស់ប្រាប់គាត់ឲ្យធ្វើអ្វីខ្លះ ?
- តើអំពើបាបអ្វីខ្លះ ដែលព្រះអម្ចាស់មានបន្ទូលថាជាកំហុសរបស់ វិលាម ដំបុលយូ ហ្វែប្ស ? តើព្រះអម្ចាស់ប្រាប់គាត់ឲ្យធ្វើអ្វីខ្លះ ? ( អ្នកអាចចាំបាច់ត្រូវពន្យល់ថា ឃ្លា « ស្វែងរកដើម្បីតម្កើងខ្លួន » [ខ ៤១] ពុំមានន័យថាធ្វើ ឬព្យាយាមដើម្បីកែលម្អដោយអស់ពីលទ្ធភាពរបស់យើងទេ ។ តែឃ្លានេះចង់សំដៅទៅលើបំណងប្រាថ្នាឥតសុចរិត និងប្រកបដោយអំនួតដើម្បីបង្ហាញថាល្អប្រសើរ ឬសំខាន់ជាងមនុស្សដទៃទៀត ) ។
- តើសេបា ភីតើសុន ព្យាយាមធ្វើអ្វីខ្លះជាមួយនឹងអំពើបាបរបស់គាត់ ?

សូមចង្អុលបង្ហាញថា អំពើបាបទាំងឡាយរបស់មនុស្សទាំងនេះបានគំរាមគំហែងដើម្បីរារាំងពួកគេពីការជួយស្ថាបនាស៊ីយ៉ូន ។

- តើអំពើបាបរបស់យើងអាចនឹងដាក់កំហិតលើសមត្ថភាពរបស់យើងដើម្បីបម្រើព្រះអម្ចាស់តាមវិធីមួយចំនួនណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីការប្រែចិត្ត ។

- យោងតាមខគម្ពីរនេះ តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់យើង បើយើងប្រែចិត្តពីអំពើបាបរបស់យើង ? ( សិស្សគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងប្រែចិត្តពីអំពើបាបរបស់យើង នោះព្រះអម្ចាស់នឹងអភ័យទោសដល់យើង ហើយពុំចងចាំអំពើបាបរបស់យើងទៀតឡើយ** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។ អ្នកក៏អាចឲ្យយោបល់សិស្សឲ្យគូសចំណាំឃ្លាដែលបង្រៀនគោលលទ្ធិទាំងនេះនៅក្នុង ខ ៤២ ) ។
- តើអំពើបាបរបស់យើងមួយណា ដែលការសន្យានេះត្រូវបានអនុវត្ត ? ( អំពើបាបទាំងអស់ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យ អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊យដ៍ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកពាក្យ ឬឃ្លាដែលទាក់ទងទៅនឹងគោលការណ៍ដែលបានសរសេរនៅលើក្ដារខៀន ។



« មិនថាការរំលងរបស់យើងជាអ្វីនោះទេ មិនថាសកម្មភាពរបស់យើងធ្វើឲ្យអ្នកដទៃឈឺចាប់យ៉ាងណាទេ កំហុសទាំងនោះអាចត្រូវបានលុបចោល ។ ចំពោះខ្ញុំ ឃ្លាដែលល្អបំផុតនៅក្នុងបទគម្ពីរស្ទើរទាំងអស់ គឺនៅពេលព្រះអម្ចាស់មានបន្ទូលថា ‹ មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ › ។ [គ. និង ស. ៥៨:៤២] ។

« នោះគឺជាការសន្យានៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួន » (« The Atonement, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៧៧ ) ។

- តើការដឹងថាអ្នកអាចត្រូវបានអភ័យទោសចំពោះអំពើបាបរបស់អ្នកទាំងអស់ ប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?

សូមពន្យល់ថា មនុស្សមួយចំនួនបានគិតដោយខុសឆ្គងថា បើពួកគេអាចនៅតែចងចាំអំពើបាបរបស់ខ្លួន នោះពួកគេពុំទាន់បានប្រែចិត្តពេញលេញនៅឡើយ ។ សូមប្រាកដថាការចងចាំពីអំពើបាបរបស់ខ្លួន អាចជួយពួកគេចៀសវាងពីការធ្វើនូវកំហុសដដែលនោះម្ដងទៀត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយប្រធាន ហារ៉ូល ប៊ី លី ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវអ្វីដែលលោកបានបង្រៀន អំពីភាពសុខសាន្តនៃសតិសម្បជញ្ញៈ ដែលបានទទួលតាមរយៈការប្រែចិត្ត ។



« ប្រសិនបើពេលនោះមកដល់ នៅពេលអ្នកបានធ្វើនូវអ្វីៗទាំងអស់ដែលអ្នកអាចធ្វើដើម្បីប្រែចិត្តចេញពីអំពើបាបរបស់អ្នក មិនថាអ្នកជានរណា អ្នកនៅកន្លែងណា ហើយបានធ្វើការសងថ្លៃ និងការជួសជុលសងវិញអស់ពីសមត្ថភាពរបស់អ្នក ប្រសិនបើវាជាអ្វីមួយដែលប៉ះពាល់ដល់សមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រហើយអ្នកបានទៅរកអ្នកមានសិទ្ធិអំណាចត្រឹមត្រូវ បន្ទាប់មក អ្នកនឹងចង់បានចម្លើយនៃការបញ្ជាក់នោះ ថាតើព្រះអម្ចាស់បានទទួលយកអ្នកឬក៏អត់ ។ នៅក្នុងព្រលឹងដែលខ្វាយខ្វល់របស់អ្នក ប្រសិនបើអ្នកស្វែងរក ហើយអ្នករកឃើញសេចក្ដីសុខសាន្តក្នុងសតិសម្បជញ្ញៈ ដោយការបញ្ជាក់នោះ អ្នកអាចដឹងថា ព្រះអម្ចាស់បានទទួលយកការប្រែចិត្តរបស់អ្នក » (*Stand Ye in Holy Places* [ ឆ្នាំ ១៩៧៤ ] ទំព័រ ១៨៥ ) ។

សូមចង្អុលបង្ហាញថា ការសន្យាដែលបានសរសេរនៅលើក្ដារខៀន គឺមានលក្ខខណ្ឌ ។ យើងអាចទទួលបានការអភ័យទោសពីព្រះអម្ចាស់ ប្រសិនបើជាយើងធ្វើនូវអ្វី ៗគ្រប់យ៉ាងដែលយើងអាចធ្វើបាន ដើម្បីប្រែចិត្តពីអំពើបាបរបស់យើងដោយពេញលេញតែប៉ុណ្ណោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមមកពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលចំណុចនានា ដែលពួកគេអាចរៀនអំពីអត្ថន័យនៃការប្រែចិត្ត ។

« ការប្រែចិត្តគឺសំខាន់ជាងការទទួលស្គាល់កំហុសដ៏សាមញ្ញ ។ វាជាការផ្លាស់ប្ដូរនៃគំនិត និង ដួងចិត្ត ។ វារួមមានការបែរចេញពីអំពើបាប ហើយបែរទៅរកព្រះសម្រាប់ការអភ័យទោស ។ វាត្រូវបានជម្រុញដោយសេចក្ដីស្រឡាញ់ដល់ព្រះ និង បំណងដ៏ស្មោះត្រង់ក្នុងការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ » (*ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ២៨ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរឿងពីរយ៉ាងដែលយើងត្រូវធ្វើដើម្បីប្រែចិត្តយ៉ាងពេញលេញពីអំពើបាបរបស់យើង ។

- យោងតាមខគម្ពីរនេះ តើចំណុចពីរយ៉ាងដែលយើងត្រូវធ្វើដើម្បីប្រែចិត្តពីអំពើបាបរបស់យើងទាំងស្រុងមានអ្វីខ្លះ ? ( សូមសរសេរគោលលទ្ធិខាងក្រោមនេះលើក្ដារខៀន ៖ **ដើម្បីប្រែចិត្ត យើងត្រូវតែសារភាព ហើយលះបង់ចោលនូវអំពើបាបទាំងឡាយរបស់យើង**) ។

- តើគោលលទ្ធិនេះជួយយើងឲ្យឆ្លើយចំពោះសំណួរថា « តើយើងអាចដឹងថាយើងបានប្រែចិត្តបានទាំងស្រុងដោយរបៀបណា ? » ( សូមជួយសិស្សឲ្យយល់ថា ការសារភាព និងការលះបង់ចោលអំពើបាបទាំងឡាយ គឺសំខាន់ចំពោះការប្រែចិត្តទាំងស្រុង ) ។

- តើការសារភាពអំពើបាបរបស់យើងមានន័យដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរអំពីអត្ថន័យនៃការសារភាពអំពើបាបរបស់យើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ការសារភាព និងការលះបង់ចោល គឺជាគោលគំនិតដ៏មានអានុភាព ។ វាមានន័យច្រើនជាងពាក្យថា ‹ ខ្ញុំព្រមទទួលកំហុស ខ្ញុំសូមទោស › ។ ការសារភាព គឺជាការទទួលស្គាល់ដោយអស់ពីចិត្ត ពេលខ្លះដោយការឈឺចាប់ចំពោះកំហុស និងការធ្វើទាស់នឹងព្រះ និងមនុស្ស » (« The Divine Gift of Repentance » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៤០ ) ។

- តើការសារភាពអំពើបាបរបស់យើងជួយយើងងាកចេញពីអំពើបាប ហើយបែរទៅរកព្រះសុំការអភ័យទោសយ៉ាងដូចម្ដេច ?

ជាចំណែកនៃការពិភាក្សានេះ សិស្សអាចនឹងងឿងឆ្ងល់ថា អំពើបាបអ្វីខ្លះដែលចាំបាច់ត្រូវសារភាព ហើយត្រូវសារភាពដល់នរណា ។ សូមពន្យល់ថា យើងចាំបាច់ត្រូវសារភាពអំពើបាបទាំងអស់របស់យើងចំពោះព្រះវរបិតាសួគ៌ ។ អំពើបាបធ្ងន់ធ្ងរ ដូចជាអំពើរំលងខាងផ្លូវភេទ ( រួមមានការប្រើប្រាស់ការណ៍អាសគ្រាម ) គួរតែត្រូវសារភាពដល់ប៊ីស្សព ឬប្រធានសាខាផងដែរ ។

សូមនាំសិស្សទៅកាន់គោលលទ្ធិចុងក្រោយដែលអ្នកបានសរសេរនៅលើក្ដារខៀន ។

- តើការលះបង់ចោលអំពើបាបរបស់យើងមានន័យដូចម្ដេច ? ( ដើម្បីងាកចេញពីអំពើបាបទាំងស្រុង ហើយឈប់ធ្វើវាតទៅទៀត ) ។

សូមថ្លែងទីបន្ទាល់អំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និងគោលការណ៍នានានៃការប្រែចិត្ត និងការអភ័យទោសដែលអ្នកបានពិភាក្សា ។ សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពួកគេមានអំពើបាបណាដែលពួកគេចាំបាច់ត្រូវប្រែចិត្តឬទេ ហើយលើកទឹកចិត្តពួកគេឲ្យប្រែចិត្តដោយការធ្វើតាមសេចក្ដីពិតដែលពួកគេបានរៀន ។

សូមរំឭកសិស្សថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២–៤៣ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីរបៀបដែលពួកគេកំពុងធ្វើក្នុងកិច្ចខិតខំរបស់ខ្លួនដើម្បីទន្ទេញចាំវា ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦៤)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦៤, អ្នកក៏អាចអញ្ជើញពួកគេឲ្យពិចារណាសំណួរខាងក្រោម ៖ ប្រសិនបើមនុស្សម្នាក់ពុំបានអភ័យទោសឲ្យបុគ្គលម្នាក់ទៀតចំពោះកំហុសដែលគាត់បានធ្វើនោះ តើនរណាគេគឺជាអ្នកមានទោសនៃអំពើបាបខ្លាំងជាងគេ ? សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេឆ្លើយតប នៅពេលពួកគេមានការឈើចាប់ដោយសារសកម្មភាព ឬ ពាក្យសម្ដីរបស់បុគ្គលណាម្នាក់ ។ ទោះបីជាមានករណីខុសឆ្គងដ៏ធ្ងន់ធ្ងរក្ដី តើយើងតម្រូវឲ្យសុំការអភ័យទោសពីនរណា ? សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ សិស្សនឹងបានរៀនពីអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីបញ្ហានេះ និង របៀបដើម្បីឆ្លើយតបចំពោះការរវាតចិត្តដោយសារតែមនុស្សដទៃ ។

មេរៀនទី ៦៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២

## បុព្វកថា

នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ និងពួកអែលឌើរជាច្រើននាក់ទៀត បានរៀបចំដើម្បីចេញដំណើរទៅ អ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី ហើយត្រឡប់ទៅរដ្ឋអូហៃអូវិញ ។ ព្រះអម្ចាស់បានណែនាំពួកអែលឌើរឲ្យផ្សាយដំណឹងល្អនៅតាមផ្លូវដែលពួកគេធ្វើដំណើរ–ការណែនាំនោះ ឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០។ នៅថ្ងៃទីបីនៃការធ្វើដំណើររបស់ពួកគេ ក្រុមនោះបានជួបនឹងគ្រោះថ្នាក់នៅទន្លេមីសសួរី ។ នៅពីរថ្ងៃក្រោយមក នៅថ្ងៃទី ១២ និង ១៣ ខែសីហា ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈពីមកពីព្រះអម្ចាស់ ។ វិវរណៈទាំងនេះ ឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១ និង ៦២។ វិវរណៈទាំងនេះ មានទាំងពាក្យណែនាំ ការព្រមាន ការលួងលោមចិត្ត និងការលើកទឹកចិត្ត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០

*ព្រះអម្ចាស់បញ្ជាឲ្យពួកអែលឌើរផ្សាយដំណឹងល្អនៅពេលពួកគេធ្វើដំណើរពីរដ្ឋមិសសួរីទៅរដ្ឋអូហៃអូ*

ពីមុនថ្នាក់ចាប់ផ្ដើម សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើអ្នកអាចគិតអំពីគ្រាមួយដែលអ្នកបានស្ទាក់ស្ទើរក្នុងការប្រាប់អ្នកដទៃអំពីជំនឿរបស់អ្នក ឬស្ទាក់ស្ទើរក្នុងការចែកចាយទីបន្ទាល់របស់អ្នកអំពីដំណឹងល្អដែរឬទេ ?*

សូមចាប់ផ្ដើមដោយការសុំសិស្សឲ្យពិចារណាសំណួរនៅលើក្ដារខៀន ។ នៅពេលសិស្សកំពុងពិចារណា អ្នកអាចនឹងចង់ចែកចាយចម្លើយផ្ទាល់ខ្លួនរបស់អ្នកចំពោះសំណួរនេះ ដោយផ្សាភ្ជាប់បទពិសោធន៍ចេញមកពីជីវិតរបស់អ្នកផ្ទាល់មួយ ។

សូមពន្យល់ថា ក្រុមអែលឌើរ ដែលបានធ្វើដំណើរពីរដ្ឋ អូហៃអូ ទៅចូលរួមក្នុងការឧទ្ទិសឆ្លងទឹកដី និងទីតាំងព្រះវិហារបរិសុទ្ធនៅអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។ ព្រះអម្ចាស់បានបញ្ជាដល់ពួកគេឲ្យផ្សាយដំណឹងល្អដល់អ្នកដទៃ នៅពេលពួកគេធ្វើដំណើរទៅរដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥២:៩–១០) ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០ មាននូវព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះពួកអែលឌើរមួយចំនួននេះ នៅពេលពួកគេបានរៀបចំដើម្បីត្រឡប់ទៅរដ្ឋ អូហៃអូ វិញ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០:១–២ ដោយស្ងាត់ស្ងៀម រកមើលមូលហេតុដែលព្រះអម្ចាស់ពុំសព្វព្រះទ័យជាមួយនឹងពួកអែលឌើរមួយចំនួននេះ ។

- ហេតុអ្វីក៏ព្រះអម្ចាស់ពុំសព្វព្រះទ័យនឹងពួកអែលឌើរមួយចំនួននេះ ? ( ទ្រង់បានមានបន្ទូលថា « ពួកគេមិនព្រមបើកមាត់គេឡើយ ប៉ុន្តែពួកគេលាក់ការប៉ិនប្រសប់របស់ខ្លួន ដែលយើងបានប្រទានដល់ពួកគេទៅវិញ » ។ ភាសាម៉្យាងទៀតគឺថា ពួកគេពុំចែកចាយទីបន្ទាល់របស់ពួកគេអំពីដំណឹងល្អឡើយ ) ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០:២ ហេតុអ្វីក៏ពួកអែលឌើរមួយចំនួនពុំចែកចាយទីបន្ទាល់របស់ពួកគេយ៉ាងដូច្នេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីអ្វីដែលអាចកើតឡើង បើយើងពុំចែកចាយទីបន្ទាល់របស់យើងទេ ។

- តើអ្វីខ្លះអាចកើតមានឡើង បើយើងពុំចែកចាយទីបន្ទាល់របស់យើង ? ( សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **យើងអាចនឹងបាត់បង់ទីបន្ទាល់របស់យើង បើយើងពុំចែកចាយវាទេនោះ** )។

- ហេតុអ្វីក៏អ្នកគិតថាយើងត្រូវចែកចាយទីបន្ទាល់ដើម្បីឲ្យវាស្ថិតនៅជាមួយនឹងយើងដូច្នេះ ? តើអ្នកមានអារម្មណ៍ថាទីបន្ទាល់របស់អ្នកបានរីកចម្រើនកាន់តែរឹងមាំដោយសារអ្នកបានចែកចាយវានៅពេលណា ?

សូមលើកទឹកចិត្តដល់សិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេ នៅពេលពួកគេមានឱកាសដើម្បីធ្វើដូច្នោះ ។ សូមសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ៦០ ដែលនៅសល់ទាំងប៉ុន្មានដោយការពន្យល់ថា ព្រះអម្ចាស់បានបញ្ជាដល់ពួកអែលឌើរទាំងនេះ ដើម្បីប្រកាសដំណឹងល្អ នៅពេលពួកគេធ្វើដំណើរត្រឡប់មកពីរដ្ឋអូហៃអូវិញ ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៦១

*ព្រះអម្ចាស់បានប្រទានការដឹកនាំដល់ យ៉ូសែប ស្ម៊ីធ និងពួកអែលឌើរដទៃទៀតនៅក្នុងការធ្វើដំណើររបស់ពួកគាត់ទៅរដ្ឋ អូហៃអូ*

សូមឲ្យសិស្សគិតអំពីគ្រាមួយ ដែលពួកគេបារម្ភអំពីសុវត្ថិភាព ហើយមានអារម្មណ៍ថាព្រះអម្ចាស់បានការពារដល់ពួកគេ ។ សូមពន្យល់ថា នៅថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៣១ ព្យាការីយ៉ូសែប ស្ម៊ីធ និង ពួកអែលឌើរដប់នាក់ បានឃើញថាពួកគាត់ស្ថិតនៅក្នុងភាពគ្រោះថ្នាក់ នៅពេលពួកគាត់ធ្វើដំណើរតាមទូកដែលមានចរន្តទឹកដ៏ខ្លាំងនៃទន្លេមីសសួរី ។ យ៉ូសែប ស្ម៊ីធ បាននឹកចាំថា នៅថ្ងៃទីបីនៃការធ្វើដំណើរនោះ « ជាទូទៅ គឺមានគ្រោះថ្នាក់ជាច្រើនបានកើតឡើង នៅលើទឹកនៃតំបន់ប៉ែកខាងលិច ហើយបន្ទាប់ពីយើងបានទៅដល់ច្រាំងទន្លេ. . . បងប្រុស [ វិលាម ដបុលយូ] ហ្វែលប្ស នៅក្នុងការនិមិត្តពេលថ្ងៃ បានឃើញមេបំផ្លាញកំពុងតែជិះក្នុងអំណាចនៅលើផ្ទៃទឹកទាំងឡាយ ហើយអ្នកដទៃទៀតបានស្តាប់ឮសំឡេង ប៉ុន្តែពុំបានមើលឃើញការនិមិត្តទេ » ( នៅក្នុង *History of the Church* ១:២០៣ ) ។ ពីមុនការនិមិត្តនេះ « មានការមិនយល់ស្របខ្លះៗ និងអារម្មណ៍មិនល្អខ្លះៗកើតមានឡើងនៅក្នុងចំណោមបងប្អូនប្រុសទាំងនោះ » ( B. H. Roberts *A Comprehensive History of the Church* ១:២៦២–៦៣ ) ។ នាល្ងាចនោះ បងប្អូនប្រុសទាំងឡាយបានពិភាក្សាអំពីការលំបាករបស់ពួកគេ ហើយពួកគេភាគច្រើនបានអភ័យទោសដល់គ្នាទៅវិញទៅមក ។ នៅព្រឹកស្អែកឡើង យ៉ូសែប ស្ម៊ីធ បានអធិស្ឋាន ហើយបានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៦១។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦១:២, ២០, ៣៦–៣៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ និងឃ្លាទាំងឡាយដែលអាចនឹងនាំមកនូវភាពសុខសាន្តដល់ពួកអែលឌើរទាំងនេះ ។

- តើពាក្យ ឬឃ្លាទាំងឡាយណា ដែលអ្នកបានរកឃើញថា អាចនឹងលួងលោមដល់ពួកអែលឌើរទាំងនេះ ? ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់សួរពួកគេឲ្យពន្យល់អំពីរបៀបដែលពាក្យ ឬឃ្លានានា ដែលពួកគេបានប្រាប់អាចនឹងលួងលោមចិត្ត ) ។

សូមពន្យល់ថា នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបង្រៀនថា « មានការបំផ្លិចបំផ្លាញជាច្រើន » នឹងកើតមានឡើងនៅលើផ្ទៃទឹកនៅថ្ងៃចុងក្រោយ ( សូមមើល គ. និង ស. ៦១:៥, ១៤–១៩) ។ ព្រះអម្ចាស់ក៏មានបន្ទូលអំពីព្រះចេស្តារបស់ទ្រង់ផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦១:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វី ដែលព្រះអម្ចាស់បានបង្រៀនអំពីព្រះចេស្តាទ្រង់ ។

- តើព្រះអម្ចាស់ពិពណ៌នាអំពីព្រះចេស្តាទ្រង់នៅក្នុងខគម្ពីរនេះយ៉ាងដូចម្តេចខ្លះ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្តារខៀន ៖**ព្រះអម្ចាស់មានគ្រប់ព្រះចេស្តា** )

អ្នកអាចនឹងចង់ចង្អុលបង្ហាញថា ដោយសារតែ ការនិមិត្តរបស់វិលាម ដបុលយូ ហ្វែលប្ស អំពីមេបំផ្លាញនៅលើផ្ទៃទឹក នោះមានមនុស្សមួយចំនួនបានស្មានថា សាតាំងមានអំណាចលើទឹកទាំងឡាយ ។ ទោះជាយ៉ាងណាក៏ដោយ គោលលទ្ធិ និង សេចក្តីសញ្ញា ៦១:១ បញ្ជាក់ថា ព្រះអម្ចាស់មានគ្រប់ព្រះចេស្តា–រួមទាំងព្រះចេស្តាលើទឹកទាំងឡាយ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦១:៦, ១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលឃ្លាទាំងឡាយដែលអាចនឹងជួយដល់ពួកអែលឌើរមានអំណរគុណបន្ថែមទៀតចំពោះព្រះចេស្តារបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ រួចហើយបន្ថែមទៅលើសេចក្តីថ្លែងការណ៍នោះនៅលើក្តារខៀន ដែលអានដូចខាងក្រោមនេះថា ៖**ព្រះអម្ចាស់មានគ្រប់ព្រះចេស្តា ហើយទ្រង់អាចថែរក្សាយើង ។**

- តើបទពិសោធន៍ណាខ្លះដែលអ្នកធ្លាប់មាន ដែលបានពង្រឹងដល់ទីបន្ទាល់របស់អ្នកអំពីព្រះចេស្តារបស់ព្រះអម្ចាស់ និងសមត្ថភាពរបស់ព្រះអម្ចាស់ដើម្បីការពារយើងពីគ្រោះថ្នាក់ ?

អ្នកអាចសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ៦១ ដែលនៅសល់ទាំងប៉ុន្មាន ដោយពន្យល់ថា ព្រះអម្ចាស់បានប្រទានការណែនាំបន្ថែមដើម្បីដឹកនាំការត្រឡប់ទៅរដ្ឋ អូហៃអូ របស់ពួកអែលឌើរទាំងនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២

*ព្រះអម្ចាស់បានសរសើរដល់ភាពស្មោះត្រង់របស់ក្រុមអែលឌើរមួយក្រុមដែលធ្វើដំណើរទៅអិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី ។*

សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖

> *តើខ្ញុំគួរពាក់អាវពណ៌អ្វីនៅថ្ងៃនេះ ?*
>
> *តើខ្ញុំគួរទៅព្រះវិហារនៅថ្ងៃអាទិត្យឬទេ ?*
>
> *តើខ្ញុំគួរបម្រើបេសកកម្មឬទេ ? បើដូច្នោះ តើនៅពេលណា ?*
>
> *បើម្ដាយរបស់ខ្ញុំប្រាប់ថាគាត់នឹងធ្វើអាហារដែលខ្ញុំចូលចិត្ត តើខ្ញុំគួរជ្រើសរើសមុខម្ហូបមួយណា ?*
>
> *តើខ្ញុំគួរដើរលេងជាគូជាមួយនរណា ? តើខ្ញុំគួរទៅបរិភោគអាហារនៅកន្លែងណាជាមួយនឹងដៃគូដើរលេងរបស់ខ្ញុំ ?*

សូមឲ្យសិស្សពិចារណាអំពីសំណួរទាំងនេះថាមួយណាអាចនឹងសំខាន់បំផុតចំពោះព្រះអម្ចាស់ ។

សូមពន្យល់ថា នៅពេលព្រះអម្ចាស់បានណែនាំដល់ពួកអែលឌើរ ដែលធ្វើដំណើរពីរដ្ឋ មិសសួរី ទៅរដ្ឋ អូហៃអូ នោះទ្រង់បានជួយពួកគេឲ្យយល់ថា ការសម្រេចចិត្តមួយចំនួនដែលពួកគេចាំបាច់ត្រូវធ្វើ គឺសំខាន់ចំពោះទ្រង់ជាងអ្វីៗផ្សេងទៀត ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលគំនិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២ ដែលអាចដឹកនាំពួកគេនៅក្នុងការធ្វើការសម្រេចចិត្ត ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លានានាដែលបង្ហាញថា កិច្ចខិតខំរបស់ពួកអែលឌើរ ដើម្បីផ្សាយដំណឹងល្អគឺសំខាន់ខ្លាំងណាស់ចំពោះព្រះអម្ចាស់ ។

- តើអ្នករកឃើញឃ្លាអ្វីខ្លះ ? តើឃ្លាទាំងនេះបង្ហាញពីរបៀបដែលព្រះអម្ចាស់មានព្រះទ័យអំពីកិច្ចការរបស់ពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះយ៉ាងដូចម្ដេចខ្លះ ?

**សូមគិតពីសេចក្ដីត្រូវការរបស់សិស្ស នៅពេលអ្នកបង្រៀន**

ការកែសម្រួលវិធីសាស្ត្របង្រៀនអាចជួយសិស្សឲ្យបំពេញតួនាទីរបស់ពួកគេដោយជោគជ័យក្នុងនាមជាអ្នករៀនសូត្រ ។ ជាឧទាហរណ៍ ប្រសិនបើសិស្សនឿយហត់ សូមគិតឲ្យពួកគេធ្វើការជាដៃគូរ ដើម្បីជួយពួកគេបន្តក្នុងការរៀនសូត្រ ។ ប្រសិនបើសិស្សមានថាមពលខ្លាំងពេក អ្នកអាចឲ្យពួកគេសិក្សារៀងៗខ្លួន ដើម្បីជួយពួកគេឲ្យបន្តខំធ្វើការ ។

ដើម្បីជួយសិស្សឲ្យពិចារណាអំពីឧទាហរណ៍នៃរឿងដែលសំខាន់ចំពោះព្រះអម្ចាស់ និងរឿងដែលពុំសំខាន់ សូមថតចម្លងតារាងដូចខាងក្រោមនៅលើក្ដារខៀន ឬរៀបចំវាសម្រាប់ចែកចាយ ។ សូមកុំសរសេរព័ត៌មាននៅក្នុងវង់ក្រចក ដោយផ្អែកលើសេចក្ដីត្រូវការរបស់សិស្សសូមពួកគេធ្វើសកម្មភាពនេះរៀងៗខ្លួន ឬ ជាមួយនឹងដៃគូ ។ ឬអ្នកអាចនឹងបញ្ចប់សកម្មភាពក្នុងថ្នាក់ទាំងមូល ។

| | តើអ្វីដែលសំខាន់ចំពោះព្រះអម្ចាស់ | តើអ្វីដែលមិនសំខាន់ចំពោះព្រះអម្ចាស់ |
|---|---|---|
| គ. និងស. ៦០:៥ | ( ថាពួកអែលឌើរត្រូវចេញដំណើរជាបន្ទាន់ទៅកាន់ សន្តលូវិស ) ។ | ( ទោះជាពួកអែលឌើរធ្វើ ឬទិញទូកមួយដើម្បីធ្វើដំណើរទៅក្ដី ) |
| គ. និង ស. ៦១:២១–២២ | ( ថាពួកអែលឌើរត្រូវចេញដំណើរជាបន្ទាន់ ហើយថាពួកគេបំពេញបេសកកម្មរបស់ពួកគេ ) | ( ទោះជាពួកគេត្រូវធ្វើដំណើរតាមផ្លូវទឹក ឬផ្លូវគោកក្ដី ) |
| គ. និង ស. ៦២:៥–៧ | ( ថាពួកអែលឌើរត្រូវស្មោះត្រង់ ថ្លែងទីបន្ទាល់អំពីដំណឹងល្អ ហើយជួយពួកបរិសុទ្ធឲ្យជួបជុំគ្នា ) | ( ទោះជាពួកអែលឌើត្រូវចេញដំណើររួមគ្នា ឬជាគូៗក្ដី ទោះជាពួកអែលឌើរជិះសេះ ឬជិះលា ឬជិះរទេះសេះក្ដី ) |

បន្ទាប់ពីសិស្សបានបំពេញតារាងរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើមានភាពខុសគ្នាអ្វីខ្លះ ដែលអ្នកកត់សម្គាល់ឃើញរវាងរឿងដែលសំខាន់ចំពោះព្រះអម្ចាស់ និងរឿងដែលមិនសំខាន់ចំពោះទ្រង់នោះ ?

- តើគំរូនេះអាចដឹកនាំអ្នក នៅពេលអ្នកធ្វើការសម្រេចចិត្តយ៉ាងដូចម្ដេច ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២:៨ បង្រៀនគោលការណ៍មួយ ដែលអាចដឹកនាំយើងនៅពេលយើងធ្វើការសម្រេចចិត្ត ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរនេះដោយស្ងាត់ស្ងៀម រកមើលគោលការណ៍នោះ ។ បន្ទាប់មកសុំឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ ពួកគេអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖**នៅពេលយើងធ្វើការសម្រេចចិត្ត នោះយើងត្រូវពឹងផ្អែកលើការវិនិច្ឆ័យរបស់យើង និងការដឹកនាំពីព្រះវិញ្ញាណ ។** អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសរសេរគោលការណ៍នេះជាពាក្យ សម្ដីរបស់ពួកគេផ្ទាល់នៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- ហេតុអ្វីក៏អ្នកគិតថាវាសំខាន់ដើម្បីពឹងផ្អែកលើការវិនិច្ឆ័យរបស់យើង ក៏ដូចជាការដឹកនាំមកពីព្រះវិញ្ញាណ នៅពេលយើងធ្វើការសម្រេចចិត្តដូច្នេះ ?
- តើនៅពេលណា ដែលអ្នកបានធ្វើការសម្រេចចិត្ត ផ្អែកទៅលើការវិនិច្ឆ័យរបស់អ្នកក៏ដូចជាផ្អែកលើការដឹកនាំមកពីព្រះវិញ្ញាណ ? តើអ្នកបានទទួលពរដោយព្រោះការធ្វើដូច្នោះយ៉ាងដូចម្ដេចដែរ ?

សូមថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដែលអ្នកបានពិភាក្សានៅក្នុងមេរៀន ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេអាចធ្វើតាមសេចក្ដីពិត ដែលពួកគេបានរៀនមកពីការសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២ របស់ពួកគេ ។ អ្នកអាចអញ្ជើញសិស្សម្នាក់ ឬពីរនាក់ ឲ្យចែកចាយពីរបៀបដែលពួកគេដាក់ផែនការដើម្បីធ្វើតាមសេចក្ដីពិតមួយក្នុងចំណោមសេចក្ដីពិតទាំងនេះ ។

មេរៀនទី ៦៧

# គោលលទ្ធិ និង សេចក្តីសញ្ញា ៦៣:១–២១

## បុព្វកថា

នៅក្នុងរដូវក្តៅឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ គឺជាអ្នកមើលការខុសត្រូវលើការឧទ្ទិសឆ្លងទឹកដីដែលពួកបរិសុទ្ធត្រូវសាងសង់ទីក្រុងស៊ីយ៉ូននៅក្នុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ។ អំឡុងពេលអវត្តមានរបស់ព្យាការី សមាជិកសាសនាចក្រមួយចំនួននៅរដ្ឋ អូហៃអូ បានងាកចេញពីបទបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានត្រឡប់ទៅទីក្រុងខឺតឡង់ នៅថ្ងៃទី ២៧ ខែសីហា ហើយនៅថ្ងៃទី ៣០ ខែសីហា លោកបានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៦៣ ។ មេរៀននេះ គ្របដណ្តប់ចំណែកមួយនៃវិវរណៈនោះ ដែលព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធអំពីផលវិបាកនៃសេចក្តីទុច្ចរិត និងការបះបោរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ៦៣:១–៦

*ព្រះអម្ចាស់ព្រមានពួកបរិសុទ្ធអំពីផលវិបាកនៃសេចក្តីទុច្ចរិត និងការបះបោរ*

សូមអញ្ជើញសិស្សឲ្យនឹកស្រម៉ៃថា មានមិត្តម្នាក់បានសួរសំណួរដូចខាងក្រោម ។ សូមឲ្យសិស្សចែកចាយពីរបៀបដែលពួកគេនឹងឆ្លើយតប ។

- ហេតុអ្វីក៏អ្នកធ្វើតាមការបង្រៀនរបស់សាសនាចក្រជាជាងការលេងសប្បាយទៅវិញ ?

បន្ទាប់ពីសិស្សបានឆ្លើយតបរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីយើងរស់នៅតាមជំនឿរបស់យើងយ៉ាងដូច្នេះ ?

សូមពន្យល់ថានៅក្នុងរដូវក្តៅឆ្នាំ ១៨៣១ ខណៈដែលយ៉ូសែប ស្ម៊ីធ និង អ្នកដឹកនាំសាសនាចក្រដទៃទៀតស្ថិតនៅក្នុងរដ្ឋមិសសួរី ដើម្បីឧទ្ទិសឆ្លងទឹកដី និងទីតាំងព្រះវិហារបរិសុទ្ធនៅស៊ីយ៉ូន នោះមានសមាជិកសាសនាចក្រមួយចំនួននៅរដ្ឋ អូហៃអូបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរដោយសម្ងាត់ ។ បន្ទាប់ពីព្យាការីបានត្រឡប់ទៅដល់រដ្ឋ អូហៃអូវិញ នោះលោកបានទទួលវិវរណៈដែលបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និងសេចក្តីសញ្ញា ៦៣ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦៣:១ ឲ្យឮៗ ហើយសួរដល់សិស្សក្នុងថ្នាក់ឲ្យប្រាប់ថាតើព្រះអម្ចាស់មានព្រះទ័យយ៉ាងណាចំពោះសមាជិកនៃសាសនាចក្រនៅក្នុងខគម្ពីរនេះ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើ *ការហៅ* ខ្លួនយើងថាជារាស្ត្រនៃព្រះអម្ចាស់ ខុសគ្នាពី *ការធ្វើជា* រាស្ត្រនៃព្រះអម្ចាស់យ៉ាងដូចម្តេច ?

សូមឲ្យសិស្សមើលត្រួសៗនូវ ខ ១ ម្តងទៀត ហើយរកមើលការបញ្ជារបស់ព្រះអម្ចាស់ដល់អ្នកទាំងឡាយដែលហៅខ្លួនគេថាជារាស្ត្ររបស់ទ្រង់ ។

- តើព្រះអម្ចាស់មានព្រះទ័យឲ្យយើងធ្វើអ្វីខ្លះក្នុងនាមជារាស្ត្ររបស់ទ្រង់ ? ( សូមសង្ខេបចម្លើយរបស់សិស្សដោយការសរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ក្នុងនាមជារាស្ត្ររបស់ព្រះអម្ចាស់ នោះយើងបើកដួងចិត្តរបស់យើង ហើយស្តាប់តាមព្រះបន្ទូល និងព្រះឆន្ទៈរបស់ទ្រង់ស្តីអំពីយើង**

- តើអ្នកគិតថាការបើកដួងចិត្តរបស់យើងមានន័យយ៉ាងដូចម្តេច ?

- តើការបើកដួងចិត្តរបស់យើង រៀបចំយើងឲ្យស្តាប់តាមសំឡេងរបស់ព្រះអម្ចាស់យ៉ាងដូចម្តេច ?

- តើអ្នកធ្វើអ្វីខ្លះ ដើម្បីជួយអ្នកឲ្យបើកដួងចិត្តរបស់អ្នក ?

សូមអញ្ជើញសិស្សឲ្យបើកដួងចិត្តរបស់ពួកគេចំពោះឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធអំឡុងមេរៀននេះ ។ អ្នកអាចនឹងផ្ដល់យោបល់ឲ្យពួកគេសរសេរនូវចំណាប់អារម្មណ៍ និងការបំផុសគំនិតទាំងឡាយ ដែលពួកគេទទួលបានមកពីព្រះវិញ្ញាណ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២ ,៦ ឲ្យឮៗ ។ ពីមុនសិស្សអាន អ្នកអាចនឹងចង់ពន្យល់ថា នៅក្នុង ខ ៦ ឃ្លា « ថ្ងៃនៃសេចក្ដីក្រោធ » សំដៅទៅលើការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ជាគ្រាមួយដែលអ្នកទាំងឡាយណាដែលពុំប្រែចិត្តចំពោះអំពើបាបរបស់ពួកគេ នឹងរងទុក្ខចំពោះផលវិបាកទាំងឡាយនៃការជ្រើសរើសរបស់ពួកគេ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអម្ចាស់ បានប្រាប់ដល់ពួកទុច្ចរិត និងពួកបះបោរ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

> ### *តួនាទីរបស់សិស្សនៅក្នុងដំណើរការរៀនសូត្រ*
>
> ការរៀនសូត្រខាងវិញ្ញាណដោយបើកដួងចិត្ត តម្រូវឲ្យមាន ទាំងកិច្ចខិតខំ និងសិទ្ធិជ្រើសរើសរបស់អ្នករៀន ។ អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា « អ្នករៀន ត្រូវអនុវត្តសិទ្ធិជ្រើសរើសដោយការធ្វើសកម្មភាពស្របទៅតាមគោលការណ៍ត្រឹមត្រូវដោយបើកដួងចិត្តរបស់គាត់ ចំពោះព្រះវិញ្ញាណបរិសុទ្ធ– ហើយទទួលយកនូវការបង្រៀនរបស់ទ្រង់ អំណាចនៃការថ្លែងទីបន្ទាល់ និងសាក្សីបញ្ជាក់របស់ទ្រង់ » (Seek Learning by Faith »address to CES religious educators, Feb. ៣, ២០០៥], ៣, LDS.org

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៧–២១

### *ព្រះអម្ចាស់ព្រមានទាស់នឹងការស្វែងរកទីសម្គាល់ និងសេចក្ដីទុច្ចរិត*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៦ សូមចង្អុលបង្ហាញនូវបញ្ហាដែលថា « ពួកដែលឥតជំនឿទប់មាត់របស់ពួកគេទុក » ។ សូមពន្យល់ថា នៅគ្រានេះ សមាជិកសាសនាចក្រមួយចំនួន បានឈប់ជឿទៅលើសេចក្ដីពិតពេញលេញនៃសាសនាចក្រ ហើយបាននិយាយជាសាធារណៈទាស់នឹង យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀត ( សូមមើល *History of the Church* ១:២១៦–១៧ ) ។ មនុស្សម្នាក់ដែលរិះគន់សាសនាចក្រខ្លាំងបំផុតជាងគេ គឺជាបុរសម្នាក់ដែលឈ្មោះថា អែសរ៉ា ប៊ូត ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវកថាកណ្ឌពីរដូចខាងក្រោម អំពីបទពិសោធន៍នានាដែលនាំអែសរ៉ា ប៊ូត ឲ្យចូលក្នុងសាសនាចក្រ ។

អែសរ៉ា ប៊ូត គឺជាអ្នកផ្សាយខាងមេតូឌីស នៅរដ្ឋ អូហៃអូ ។ គាត់បានចាប់អារម្មណ៍ទៅលើការស្ដារឡើងវិញនៅដើមឆ្នាំ ១៨៣១ បន្ទាប់ពីការអានព្រះគម្ពីរមរមន ។ គាត់បានធ្វើដំណើរទៅខឺតឡង់ ជាមួយយ៉ូហាន និង អាលីស ចនសុន ដើម្បីជួបនឹងព្យាការី ។ អ្នកស្រី ចនសុន បានរងទុក្ខនឹងរោគសន្លាក់ឆ្អឹង ដែលបណ្ដាលឲ្យមានការឈឺចាប់ ហើម និងរឹងដៃ ។ នៅពេលគាត់បានជួបនឹងយ៉ូសែប ស្ម៊ីធដំបូង គាត់ពុំអាចលើកដៃរបស់គាត់ដាក់លើក្បាលជិតពីរឆ្នាំ ។

> « អំឡុងពេលការសម្ភាសន៍ ការសន្ទនាបានបង្វែរទៅលើប្រធានបទអំពីអំណោយទានដ៏ហួសវិស័យ ដូចជាដែលត្រូវបានប្រគល់ឲ្យនៅក្នុងជំនាន់នៃពួកសាវក ។ មានម្នាក់បាននិយាយថា ‹ នេះជាអ្នកស្រី ចនសុន ដែលពិការដៃ តើព្រះបានប្រទានអំណាចអ្វីដល់មនុស្សលើផែនដីក្នុងពេលនេះដើម្បីព្យាបាលគាត់ ? › បន្តិចក្រោយមក នៅពេលការសន្ទនាបានបង្វែរទៅរកទិសដៅមួយទៀត [ យ៉ូសែប ] ស្ម៊ីធ បានក្រោកឡើង ហើយដើរកាត់បន្ទប់ ដឹកដៃអ្នកស្រី ចនសុន ហើយបានថ្លែងដោយឧឡារិក និងអស្ចារ្យថា ៖ ‹ ស្ត្រីអើយ នៅក្នុងព្រះនាមនៃព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ខ្ញុំបញ្ជាឲ្យអ្នកបានជាសះស្បើយ › រួចក៏បានចេញពីបន្ទប់ភ្លាមទៅ ។. . . អ្នកស្រី ចនសុន ក៏អាចលើកដៃរបស់គាត់បានដោយងាយស្រួល ហើយពេលគាត់ត្រឡប់ទៅផ្ទះវិញនៅថ្ងៃស្អែកឡើង គាត់អាចធ្វើការបោកគក់ជុះលាងដោយគ្មានការលំបាក ឬឈឺចាប់អ្វីឡើយ » ( នៅក្នុង *History of the Church*, ១:២១៥–១៦ ) ។

- តើអ្នកគិតថាអ្នកអាចមានអារម្មណ៍យ៉ាងណា បើអ្នកបានឃើញអព្ភូតហេតុបែបនោះផ្ទាល់ភ្នែក ?

សូមពន្យល់ថា មិនយូរប៉ុន្មានបន្ទាប់ពី អែសរ៉ា ប៊ូត បានធ្វើជាសាក្សីនៃអភ្ភូតហេតុនេះ គាត់បានទទួលបុណ្យជ្រមុជទឹក ។

សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្ដារខៀន ៖*ទីសម្គាល់ និងសេចក្ដីជំនឿ ។*

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៧–៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់នូវអ្វី ដែលព្រះអម្ចាស់បានបង្រៀនអំពីទីសម្គាល់ និងសេចក្ដីជំនឿ ។

- តើយើងរៀនអ្វីខ្លះ ដកស្រង់ចេញអំពីខគម្ពីរទាំងនេះ អំពីទីសម្គាល់ និងសេចក្ដីជំនឿ ? ( សិស្សអាចនឹងប្រាប់អំពីគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា គូសបញ្ជាក់អំពីសេចក្ដីពិតដូចខាងក្រោម ៖ **សេចក្ដីជំនឿពុំកើតមានបន្ទាប់ពីទីសម្គាល់នោះទេ ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន នៅពីខាងក្រោម*ទីសម្គាល់ និង សេចក្ដីជំនឿ )* ។

- តើគំរូមួយចំនួននៅក្នុងបទគម្ពីរអំពីមនុស្ស ដែលធ្វើជាសាក្សីពីទីសម្គាល់ ឬអព្ភូហេតុអស្ចារ្យ ប៉ុន្តែពុំបង្ហាញពីសេចក្ដីជំនឿ និងសេចក្ដីសុចរិតយូរអង្វែង មានអ្វីខ្លះ ? ( ឧទាហរណ៍អាចរួមមានទាំងកូនចៅនៃអ៊ីស្រាអែល [ សូមមើល ជនគណនា ១៤:២២–២៣] និងលេមិន និងលេមយួល [ សូមមើល នីហ្វៃទី ១ ១៧:៤៣–៤៥] ) ។

សូមពន្យល់ថា អែសរ៉ា ប៊ូត គឺជាគំរូនៃមនុស្សម្នាក់ដែលពឹងផ្អែកទៅលើទីសម្គាល់ជាជាងសេចក្ដីជំនឿ ។ បន្ទាប់ពីគាត់បានទទួលបុណ្យជ្រមុជទឹក គាត់បានទទួលបព្វជិតភាព ហើយត្រូវបានបញ្ជូនឲ្យទៅបេសកកម្មមួយនៅរដ្ឋ មិសសួរី ។ ប៊ូត បានចាប់ផ្ដើមបេសកកម្មរបស់គាត់ដោយការរំពឹងទុកដ៏អស្ចារ្យ ដោយស្មានថា គាត់នឹងអាចផ្លាស់ប្រែមនុស្សឲ្យបានច្រើន តាមរយៈដោយបង្ហាញពីទីសម្គាល់ និងអព្ភូតហេតុ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីការផ្សាយដំណឹងល្អបានមួយរយៈពេលខ្លីមក ហើយពុំ

បានឃើញលទ្ធផលដូចដែលគាត់បានស្មានទុក នោះ ប៊ូត « បានងាកចេញ » ហើយបានក្បត់សាសនា ( សូមមើល *History of the Church* ១:២១៦ ) ។ ព្យាការី យ៉ូសែប ស៊្មីធ បានធ្វើការសង្កេតដូចខាងក្រោមអំពី អែសរ៉ា ប៊ូត ៖



« នៅពេលគាត់បានរៀនដឹងដោយពិតថា សេចក្ដីជំនឿ ការបន្ទាបខ្លួន ការអត់ធ្មត់ និងការលំបាក ត្រូវកើតមានពីមុនទទួលបានពរជ័យ ហើយថាព្រះនឹងនាំឲ្យមនុស្សរាបសា មុននឹងទ្រង់តម្កើងគេឡើង និងថា ‹ ព្រះអង្គសង្គ្រោះប្រទានអំណាចដល់គាត់ដើម្បីវាយមនុស្ស ហើយធ្វើឲ្យពួកគេជឿ › ជំនួសវិញ . . . នោះគាត់បានខកចិត្ត » ( នៅក្នុង *History of the Church* ១:២១៦ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១០–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីពិតបន្ថែមអំពីទីសម្គាល់ និងសេចក្ដីជំនឿ ។

- ស្របតាម ខ ១០ តើទីសម្គាល់កើតមានយ៉ាងដូចម្ដេច ? ( សូមជួយសិស្សប្រាប់អំពីសេចក្ដីពិតដូចខាងក្រោម ៖ **ទីសម្គាល់កើតមានដោយសារសេចក្ដីជំនឿ ស្របតាមព្រះទ័យរបស់ព្រះ ។** សូមបន្ថែមសេចក្ដីពិតនេះទៅលើក្ដារខៀន នៅខាងក្រោម *ទីសម្គាល់ និងសេចក្ដីជំនឿ* ) ។

- ហេតុអ្វីក៏អ្នកគិតថា យើងទទួលទីសម្គាល់បន្ទាប់ពីយើងបានអនុវត្តសេចក្ដីជំនឿ ?

- ស្របតាម ខ ១២ តើហេតុផលត្រឹមត្រូវដើម្បីស្វែងរកទីសម្គាល់មានអ្វីខ្លះ ? ( « សម្រាប់មនុស្សសេចក្ដីល្អដល់មនុស្សចំពោះសិរីល្អរបស់ [ ព្រះ ]– មានន័យថា ដើម្បីជួយអ្នកដទៃ និងពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ) ។

សូមចង្អុលបង្ហាញថា ទីសម្គាល់ និងការអស្ចារ្យទាំងឡាយ ពុំបង្ហាញឲ្យឃើញថាអស្ចារ្យជានិច្ចនោះឡើយ ។ ជាញឹកញាប់ យើងអាចនឹងទទួលទីសម្គាល់មួយ ឬសាក្សីមួយអំពីសេចក្ដីពិតពេញលេញនៃដំណឹងល្អតាមរបៀបដ៏ស្ងប់ស្ងាត់ និងផ្ទាល់ខ្លួនមួយ នៅពេលយើងអនុវត្តសេចក្ដីជំនឿរបស់យើង ។

- តើយើងអាចអនុវត្តសេចក្ដីជំនឿដើម្បីទទួលបានសាក្សីមួយនៃដំណឹងល្អបានយ៉ាងដូចម្ដេច ? (អ្នកអាចនឹងចង់កត់ត្រាចម្លើយរបស់សិស្សនៅលើក្ដារខៀន ។ ចម្លើយអាចរួមមានទាំងសកម្មភាពដូចជា ការអធិស្ឋាន ការសិក្សាព្រះគម្ពីរ ការតមអាហារ ការផ្ដល់ការបម្រើ និងការរស់នៅតាមគោលការណ៍ នៃដំណឹងល្អ ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយនឹងការទទួលសាក្សីមួយអំពីសេចក្ដីពិតពេញលេញនៃដំណឹងល្អ ដោយការអនុវត្តសេចក្ដីជំនឿតាមរបៀបមួយនៃរបៀបទាំងនេះ ។

សូមរំឭកសិស្សថា បន្ថែមពីលើការស្វែងរកទីសម្គាល់ នោះសមាជិកសាសនាចក្រមួយចំនួននៅរដ្ឋ អូហៃអូ ក៏បាន « បែរចេញពី [បទ] បញ្ញត្តិទាំងឡាយ » ( គ. និង ស. ៦៣:១៣) ហើយបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១៤–១៩ ដោយស្ងៀមស្ងាត់ ហើយប្រាប់អំពីអំពើបាបមួយចំនួនដែលសមាជិកសាសនាចក្របានប្រព្រឹត្ត ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ( អ្នកអាចពន្យល់ថា ពួកកំផិត គឺជាមនុស្សដែលចូលរួមក្នុងអំពើបាបខាងផ្លូវភេទ ។ ពួកមន្តអាគម គឺជាមនុស្សម្នាក់ដែលចូលរួមនៅក្នុងសកម្មភាព ដែលអញ្ជើញឥទ្ធិពលនៃវិញ្ញាណអាក្រក់ឲ្យមក ) ។

- សូមកត់សម្គាល់អំពីការព្រមានរបស់ព្រះអម្ចាស់អំពីដំរេកសម្រើបនៅក្នុង ខ ១៦ ។ តើវាមានន័យយ៉ាងណា ដែលក្រឡេកឃើញស្ត្រី ហើយមានដំរេកសម្រើប ? ( ដំរេកសម្រើប មានន័យថា « ការមានបំណងប្រាថ្នាដោយពុំត្រឹមត្រូវដ៏ខ្លាំងចំពោះអ្វីមួយ » ឬ នរណាម្នាក់ [ Guide to the Scriptures ] « ដំរេកសម្រើប » scriptures.lds.org] ។ ការមើលទៅនរណាម្នាក់ដោយមានដំរេកសម្រើប មានន័យថាមើលទៅរូបកាយរបស់នរណាម្នាក់ដោយពុំត្រឹមត្រូវ ឬតាមវិធីមួយដែលដាស់អារម្មណ៍ខាងផ្លូវភេទ ។ ការណ៍នេះជាប់ទាក់ទងនឹងការមើលការណ៍ភាពអាសគ្រាម ) ។

- តើមានគោលការណ៍អ្វីខ្លះដែលអ្នកមើលឃើញនៅក្នុងការព្រមានរបស់ព្រះអម្ចាស់ នៅក្នុង ខ ១៦ ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងមើលទៅនរណាម្នាក់ដោយដំរេកសម្រើប នោះយើងនឹងគ្មានព្រះវិញ្ញាណ ហើយយើងបដិសេធសេចក្ដីជំនឿ** ។ អ្នកអាចឲ្យយោបល់សិស្សឲ្យគូសចំណាំពាក្យ ដែលបង្រៀនអំពីគោលការណ៍នេះនៅក្នុងព្រះគម្ពីរ ) ។

- ហេតុអ្វីក៏អ្នកគិតថា ការមានដំរេកសម្រើបចំពោះនរណាម្នាក់ បណ្ដាលឲ្យមនុស្សម្នាក់នោះបាត់បង់ព្រះវិញ្ញាណយ៉ាងដូច្នេះ ?

- តើយើងអាចយកឈ្នះលើការល្បួងដំរេកសម្រើបចំពោះអ្នកដទៃយ៉ាងដូចម្ដេច ?

ជាចំណែកនៃការពិភាក្សាអំពីការចៀសវាងពីដំរេកសម្រើប អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យអាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« សំខាន់បំផុតនោះ ចាប់ផ្ដើមដោយការញែកខ្លួនអ្នកចេញពីមនុស្ស សម្ភារ និងស្ថានភាពនានាដែលនឹងគ្រោះថ្នាក់ដល់អ្នក ។. . .

« . . . ប្រសិនបើឃើញកម្មវិធីទូរទស្សន៍មិនត្រឹមត្រូវនោះសូមបិទវា ។ ប្រសិនបើខ្សែភាពយន្តពុំស្អាតស្អំទេ នោះសូមដើរចេញ ។ ប្រសិនបើទំនាក់ទំនងមិនត្រឹមត្រូវកើតមានឡើង សូមបញ្ចប់ទំនាក់ទំនងនោះ ។ យ៉ាងហោចណាស់នៅគ្រាដំបូងឡើយ ឥទ្ធិពលទាំងនេះអាចនឹងមិនអាក្រក់ខ្លាំងទេ ប៉ុន្តែវាអាចនឹងធ្វើឲ្យរក់រឹងដល់ការវិនិច្ឆ័យរបស់យើង ធ្វើឲ្យជីវភាពខាងវិញ្ញាណរបស់យើងស្រអាប់ ហើយដឹកនាំទៅរកអ្វីមួយដែលអាចនឹងអាក្រក់ ។. . .

« . . .សូមជំនួសគំនិតតម្រេកសម្រើបដោយរូបភាពនៃក្ដីសង្ឃឹម និងអានុស្សាវរីយ៍ប្រកបដោយក្ដីអំណរ រូបភាពនៃទឹកមុខរបស់អ្នកទាំងឡាយដែលអ្នកស្រឡាញ់ ថាអ្វីៗទាំងនោះនឹងត្រូវបំផ្លាញបង់ ប្រសិនបើអ្នកបណ្ដែតបណ្ដោយខ្លួនតាមតណ្ហាបែបនេះ ។. . . មិនថាអ្នកមានគំនិតអ្វីនោះទេ សូមប្រាកដថា វាស្វាគមន៍មកក្នុងចិត្តរបស់អ្នកដោយការអញ្ជើញតែប៉ុណ្ណោះ ។. . .

« សូមបណ្ដុះវាឡើង និងនៅកន្លែងដែលមានព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ សូមប្រាកដថាគេហដ្ឋាន ឬផ្ទះជួលរបស់អ្នកផ្ទាល់មាននូវប្រភេទនៃតន្ត្រី សិល្បៈ និងអក្សរសាស្ត្រដែលរក្សាការពារអ្នកនៅទីនោះ » Place No More for the Enemy of My Soul » *Ensign* ឬ *Liahona*, ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៤៥, ៤៦ ) ។

សូមចង្អុលបង្ហាញទៅគោលការណ៍ទីមួយដែលអ្នកសរសេរនៅលើក្ដារខៀន នៅពេលចាប់ផ្ដើមថ្នាក់រៀន ៖ **ក្នុងនាមជារាស្ត្ររបស់ព្រះអម្ចាស់ យើងត្រូវបើកដួងចិត្តរបស់យើង និងស្ដាប់ព្រះបន្ទូលរបស់ទ្រង់ និងព្រះទ័យរបស់ទ្រង់ចំពោះយើង ។** សូមអញ្ជើញសិស្សឲ្យគិតថា តើដួងចិត្តរបស់ពួកគេបើកចំហរចំពោះការបំផុសគំនិត ឬចំណាប់អារម្មណ៍អំឡុងការសិក្សាអំពីព្រះគម្ពីរនាថ្ងៃនេះរបស់ពួកគេដែរឬទេ ។ សូមលើកទឹកចិត្តពួកគេធ្វើសកម្មភាពតាមការបំផុសគំនិត និងចំណាប់អារម្មណ៍ដែលពួកគេបានទទួលមកពីព្រះអម្ចាស់ ហើយថ្លែងទីបន្ទាល់ថា នៅពេលពួកគេធ្វើដូច្នោះ នោះពួកគេនឹងក្លាយជារាស្ត្ររបស់ព្រះអម្ចាស់ ។

មេរៀនទី ៦៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២២–៦៦

## បុព្វកថា

នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣ ។ មេរៀននេះបានគ្រប់ដណ្ដប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២២–៦៦ ដែលព្រះអម្ចាស់សន្យាថាប្រទានពរជ័យដល់ពួកបរិសុទ្ធ ដែលស្មោះត្រង់នៅក្នុងថ្ងៃចុងក្រោយ ព្រមានពីគ្រោះថ្នាក់នៃភាពឆ្មើងឆ្មៃ និងជាស់តឿនដល់ពួកបរិសុទ្ធរបស់ទ្រង់ឲ្យចងចាំភាពពិសិដ្ឋនៃព្រះនាមរបស់ទ្រង់ ហើយនិយាយដោយការគោរពអំពីរឿងពិសិដ្ឋទាំងឡាយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២២–៥៤

*ព្រះអម្ចាស់សន្យាប្រទានពរជ័យដល់ពួកបរិសុទ្ធនៅក្នុងថ្ងៃចុងក្រោយ*

ពីមុនថ្នាក់រៀន សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *ហេតុអ្វីក៏មនុស្សមួយចំនួនមានក្ដីបារម្ភអំពីការរស់នៅក្នុងថ្ងៃចុងក្រោយ ?*

នៅពេលចាប់ផ្ដើមមេរៀន សូមអញ្ជើញសិស្សឲ្យពិភាក្សាអំពីសំណួរនេះ រួមគ្នាឬជាគូៗ ។

សូមពន្យល់ថានៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣ ព្រះអម្ចាស់បានមានបន្ទូលអំពីការបំផ្លិចបំផ្លាញ ដែលនឹងកើតមានមកលើពួកទុច្ចរិតនៅថ្ងៃចុងក្រោយ ប៉ុន្ដែទ្រង់ក៏បានធ្វើការសន្យាដ៏មានអានុភាពផងដែរចំពោះពួកបរិសុទ្ធ ។ បន្ថែមពីលើនោះ ទ្រង់បានដឹកនាំពួកបរិសុទ្ធនៅជំនាន់នោះឲ្យទិញដី នៅរដ្ឋ មិសសួរី ដើម្បីស្ថាបនាក្រុងស៊ីយ៉ូន ដែលទ្រង់បានសន្យាថាវានឹងក្លាយជាកន្លែងនៃការជ្រកកោន ( សូមមើល គ. និង ស. ៤៥:៦៦–៦៩ ) ។

ដើម្បីជួយសិស្សឲ្យរៀនអំពីការព្យាករណ៍ទាំងឡាយនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣ សូមបង្កើតជាតារាងមួយដែលមាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម។ សូមចាត់សិស្សឲ្យធ្វើការជាគូៗ ។ សូមឲ្យពួកគេកំណត់ថាតើសេចក្ដីថ្លែងការណ៍និមួយៗ ពិត ឬខុស តាមរយៈការស្រាវជ្រាវរកសេចក្ដីយោងបទគម្ពីរដែលទាក់ទង ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំនៅក្នុងបទគម្ពីរនូវសេចក្ដីពិតដែលពួកគេបានរៀន នៅពេលពួកគេបំពេញក្នុងតារាងនេះ ។

____១. អំឡុងសង្គ្រាមនៅថ្ងៃចុងក្រោយ មនុស្សទុច្ចរិតនឹងបំផ្លាញគ្នាទៅវិញទៅមក ។ ( សូមមើល គ. និង ស. ៦៣:៣២–៣៣) ។

____២. ពួកបរិសុទ្ធសុចរិត នឹងចៀសផុតពីការបំផ្លិចបំផ្លាញទាំងអស់នៃថ្ងៃចុងក្រោយដោយងាយ ។ ( សូមមើល គ. និង ស. ៦៣:៣៤) ។

____៣. នៅពេលព្រះយេស៊ូវគ្រីស្ទយាងមកម្ដងទៀត ទ្រង់នឹងបំផ្លាញមនុស្សទុច្ចរិតទាំងអស់ ដែលមាននៅលើផែនដី ។ ( សូមមើល គ. និង ស. ៦៣:៣៤) ។

____៤. អ្នកទាំងឡាយដែលស្មោះត្រង់ នឹងយកឈ្នះលើឧបសគ្គទាំងអស់នៃជីវិតនេះនៅទីបំផុត ។ ( សូមមើល គ. និង ស. ៦៣:៤៧–៤៨) ។

____៥. មនុស្សសុចរិត ដែលស្លាប់មុនការយាងមកជាលើកទីពីរ នឹងត្រូវបានរស់ឡើងវិញ នៅពេលព្រះអង្គសង្គ្រោះយាងមកលើផែនដី ។ ( សូមមើល គ. និង ស. ៦៣:៤៩) ។

____៦. មនុស្សសុចរិត ដែលកំពុងរស់នៅលើផែនដីនៅគ្រានៃការយាងមកជាលើកទីពីរនឹងពុំស្លាប់ឡើយ ។ ( សូមមើល គ. និង ស. ៦៣:៥០–៥១) ។

**ប្រើប្រាស់កម្មវិធីសិក្សា**

នៅពេលអ្នករៀបចំមេរៀនមួយ សូមមើលកម្មវិធីសិក្សាប្រកបដោយការអធិស្ឋាន ព្រមជាមួយនឹងការសិក្សារបស់អ្នកអំពីបណ្ដុំខគម្ពីរ ។ សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយអ្នកសម្របមេរៀននេះទៅតាមតម្រូវការសិស្សរបស់អ្នក ។ អាស្រ័យទៅលើតម្រូវការ និងស្ថានភាពនៃសិស្សរបស់អ្នក អ្នកអាចជ្រើសរើសដើម្បីធ្វើតាមយោបល់កម្មវិធីសិក្សាទាំងអស់ ឬផ្នែកៗ សម្រាប់បន្ទុំខគម្ពីរ ឬសម្របគំនិតការបង្រៀនដែលបានផ្ដល់យោបល់ ។

បន្ទាប់ពីសិស្សបានបំពេញតារាងរួចហើយ សូមឲ្យពួកគេរៀបរាប់អំពីចម្លើយរបស់ពួកគេចំពោះសេចក្ដីថ្លែងការណ៍ពីរដំបូង ។ ( សេចក្ដីថ្លែងការណ៍ទីមួយ គឺពិត ហើយសេចក្ដីថ្លែងការណ៍ទីពីរ គឺខុស ) ។ សូមពិភាក្សាចម្លើយរបស់ពួកគេ ដោយសុំឲ្យពួកគេរំពឹករវគ្គបទគម្ពីរ ដែលបានរៀបរាប់បន្ទាប់ពីសេចក្ដីថ្លែងការណ៍និមួយៗ ។ នៅពេលសិស្សពិភាក្សាអំពីចម្លើយរបស់ពួកគេចំពោះសេចក្ដីថ្លែងការណ៍ទីពីរ សូមអញ្ជើញសិស្សម្នាក់ឲ្យអានអំពីការពន្យល់ដូចខាងក្រោម ដោយព្យាការី យ៉ូសែប ស្ម៊ីធ ៖



« វាគឺជាគំនិតខុសឆ្គងមួយ ដែលពួកបរិសុទ្ធនឹងចៀសផុតពីការជំនុំជម្រះ ខណៈដែលពួកទុច្ចរិតរងទុក្ខ ដ្បិតគ្រប់សាច់ឈាមគឺស្ថិតនៅក្រោមការរងទុក្ខ ហើយ ‹ ពួកបរិសុទ្ធនឹងពិបាកចៀសផុតណាស់ › . . . ពួកសុចរិតជាច្រើន នឹងក្លាយជាជនរងគ្រោះនឹងជំងឺ គ្រោះចង្រៃ ជាដើម ដោយសារតែមូលហេតុនៃភាពទន់ខ្សោយខាងសាច់ឈាម តែនឹងត្រូវបានសង្គ្រោះនៅក្នុងនគរនៃព្រះ » ( នៅក្នុង *History of the Church* ៤:១១; សូមមើលផងដែរ *Journals, Volume ១: ១៨៣២–១៨៣៩* វ៉ុលទី ១ នៃ Journals series of *The Joseph Smith Papers* ឆ្នាំ ២០០៨ ], ទំព័រ ៣៥២–៥៣ ) ។

- តើហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីដឹងថា មនុស្សសុចរិត នឹងមិនត្រូវបានចៀសផុតពីការសាកល្បងទាំងអស់នៃថ្ងៃចុងក្រោយដូច្នេះ ?

សូមសួររកចម្លើយពីសិស្សចំពោះសេចក្ដីថ្លែងការណ៍ ៣–៦ នៅលើតារាង ។ ( សេចក្ដីថ្លែងការណ៍ទី ៣–៥ គឺជាការពិត ហើយសេចក្ដីថ្លែងការទី ៦ គឺខុស ) ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៤៧–៤៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការសន្យាមកពីព្រះអម្ចាស់ ។ សូមលើកទឹកចិត្តពួកគេឲ្យពិចារណាអំពីរបៀបបង្ហាញពីការសន្យារបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរនេះជាសេចក្ដីថ្លែងការណ៍ « បើសិន–នោះ » ។

- តើអ្នកនឹងថ្លែងអំពីការសន្យារបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរនេះ ជាសេចក្ដីថ្លែងការណ៍ « បើសិន–នោះ » យ៉ាងដូចម្ដេច ? ( សិស្សគួរតែបង្ហាញថា**បើយើងស្មោះត្រង់ ហើយស៊ូទ្រាំ នោះពួកយើងនឹងយកឈ្នះលើលោកិយ** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- តើព្រះអម្ចាស់អាចជួយយើង « យកឈ្នះលោកិយ » នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងតាមវិធីណា ?
- តើព្រះអម្ចាស់អាចជួយយើង « យកឈ្នះលោកិយ » បន្ទាប់ពីយើងស្លាប់ទៅតាមវិធីណា ?

ដើម្បីគូសបញ្ជាក់អំពីពរជ័យដ៏អស់កល្បជានិច្ច ដែលយើងអាចទទួល ដែលនឹងជួយយើងយកឈ្នះលើលោកិយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៤៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យទាំងឡាយ ដែលព្រះអម្ចាស់បានសន្យាដល់ពួកសុចរិត ។

អ្នកអាចនឹងចង់ចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យទាំងឡាយ ដែលយើងនឹងទទួលបាន នៅក្នុងជីវិតនេះ និងជីវិតបន្ទាប់ បើយើងស្មោះត្រង់ និងកាន់ខ្ជាប់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៥៥–៥៦

*ព្រះអម្ចាស់សម្ដែងនូវការពុំសព្វព្រះទ័យរបស់ទ្រង់ចំពោះអំនួតរបស់ ស៊ីឌនី រិកដុន*

សូមឲ្យសិស្សម្នាក់អានឧទាហរណ៍ដូចខាងក្រោមឲ្យឮៗ ។ បន្ទាប់ពីសិស្សអានឧទាហរណ៍និមួយៗដូចខាងក្រោមហើយ សូមផ្អាកមួយភ្លែត ហើយសួរដល់សិស្សក្នុងថ្នាក់ឲ្យពន្យល់ពីរបៀបដែលមនុស្សម្នាក់ អាចនឹងត្រូវល្បួងឲ្យឆ្លើយតបដោយអំនួត ឬឆ្មើងឆ្មៃនៅក្នុងស្ថានភាពនោះ ។

១. អ្នកត្រូវបានអញ្ជើញឲ្យថ្លែងទីបន្ទាល់របស់អ្នកនៅមុខយុវវ័យដទៃទៀតជាច្រើនក្នុងសន្និសីទយុវវ័យដ៏ធំមួយ ។

២. បុគ្គលមួយចំនួនក្នុងក្រុមរបស់អ្នក ឬថ្នាក់យុវនារីមួយ បានអរគុណទាំងអំពីសកម្មភាពទាំងឡាយដែលអ្នកបានជួយរៀបផែនការ ។

៣. អ្នកជាអ្នកច្រៀងដ៏មានទេពកោសល្យ ហើយអ្នកត្រូវបានសុំឲ្យច្រៀងចម្រៀងមួយក្នុងម៉ោងសាក្រាម៉ង់ ។

សូមពន្យល់ថា ស៊ីឌនី រិកដុន បានទទួលកិច្ចការសំខាន់មួយ មកពីព្រះអម្ចាស់ ប៉ុន្តែបានឆ្លើយតបដោយអំនួត ។ ព្រះអម្ចាស់បានបញ្ជាគាត់ឲ្យសរសេរ « ការពិពណ៌នាអំពីទឹកដីនៃស៊ីយ៉ូន ហើយនឹងសេចក្ដីថ្លែងការណ៍មួយអំពីព្រះទ័យនៃព្រះ ដូចដែលត្រូវបានធ្វើឲ្យគាត់ដឹងដោយព្រះវិញ្ញាណ » (គ. និង ស. ៥៨:៥០) ។ ការពិពណ៌នាជាលាយលក្ខណ៍អក្សរនេះ នឹងជួយពួកបរិសុទ្ធដែលរស់នៅឆ្ងាយពី អ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី ដឹងថាទឹកដីនោះវាមានលក្ខណៈដូចម្ដេច ( ជំនាន់នោះពុំមានរូបថតទេ) ។ វាក៏នឹងជួយបំផុសគំនិតដល់ពួកបរិសុទ្ធឲ្យបរិច្ចាគប្រាក់សម្រាប់ការទិញដីផងដែរ ( សូមមើល គ. និង ស. ៥៨:៥១) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៥៥–៥៦ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលភស្តុតាងដែលស៊ីឌនី រិកដុន ត្រូវបានរងឥទ្ធិពលដោយអំនួត ពេលគាត់បានបំពេញកិច្ចការរបស់គាត់ដើម្បីសរសេរពិពណ៌នាអំពីក្រុងស៊ីយ៉ូននោះ ។

- តើភស្តុតាងនៃអំនួតដែលអ្នកបានកត់សម្គាល់មានអ្វីខ្លះ ? ( សិស្សគួរតែចង្អុលបង្ហាញថា ស៊ីឌនី « ក្នុងចិត្តបានលើកខ្លួនគាត់ឡើង ហើយពុំទទួលយកការប្រឹក្សា » ) ។

- តើលទ្ធផលនៃអំនួតរបស់ស៊ីឌនីមានអ្វីខ្លះ ? ( គាត់បានសោកសៅក្នុងវិញ្ញាណ ហើយព្រះអម្ចាស់ពុំទទួលយកការសរសេររបស់គាត់ទេ ) ។ អ្នកអាចនឹងចង់ពន្យល់ថា ការសោកសៅក្នុងវិញ្ញាណមានន័យថា រស់នៅក្នុងរបៀបមួយដែលព្រះវិញ្ញាណបរិសុទ្ធដកចេញពីយើង ) ។

- តើយើងអាចរៀនអ្វីខ្លះមកពី ខ ៥៥ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរប្រាប់នូវសេចក្ដីពិតដូចខាងក្រោម ៖ **វិញ្ញាណ ត្រូវបានសោកសៅ បើយើងមានអំនួតក្នុងការធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សពីរបីនាក់អានឲ្យឮៗ នូវឧទាហរណ៍ខាងលើនិមួយៗម្ដងទៀត ។ បន្ទាប់ពីឧទាហរណ៍និមួយៗបានអានរួចហើយ សូមផ្អាកបន្តិច ហើយសួរដល់សិស្សក្នុងថ្នាក់ឲ្យពន្យល់អំពីរបៀបដែលមនុស្សម្នាក់អាចនឹងចូលទៅក្នុងស្ថានភាពនោះដោយភាពរាបសា ជាជាងដោយអំនួត ។ បន្ទាប់ពីការពិភាក្សា សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានប្រទានឱកាសដល់ស៊ីឌនី រិកដុន ឲ្យសរសេរពិពណ៌នាអំពីក្រុងស៊ីយ៉ូនមួយផ្សេងទៀត ( សូមមើល គ. និង ស. ៦៣:៥៦) ។ ស៊ីឌនី បានប្រែចិត្ត ហើយសរសេរការពិពណ៌នាមួយទៀតអំពីទឹកដីស៊ីយ៉ូន ដែលត្រូវបានទទួលយកចំពោះព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៥៧–៦៦

*ព្រះយេស៊ូវគ្រីស្ទ ណែនាំដល់ពួកអ្នកបម្រើរបស់ទ្រង់ឲ្យចាំនូវភាពពិសិដ្ឋនៃព្រះនាមទ្រង់ ហើយថ្លែងដោយគារវភាពអំពីរឿងពិសិដ្ឋទាំងអស់*

សូមអាន ឬសង្ខេបនូវដំណើររឿងដូចខាងក្រោមដកស្រង់ ចេញមកពីជីវិតរបស់ប្រធាន ស្ពែនសឺរ ដបុលយូ឴ ឃឹមបឹល ។ សូមឲ្យសិស្សស្ដាប់រកអ្វីដែលធ្វើឲ្យពួកគេចាប់អារម្មណ៍ ។



« នៅមន្ទីរពេទ្យ សន្ត ម៉ាក នៅទីក្រុង សលត៍ លេក [ ប្រធាន ស្ពែនសឺរ ដបុលយូ ឃឹមបឹល ] ត្រូវបានដាក់ថ្នាំឲ្យសន្លប់ឈឹង ហើយធ្វើការវះកាត់ រួចហើយដាក់គ្រែរុញត្រឡប់មកបន្ទប់របស់លោកវិញ ។ ដោយសារនៅត្រូវជាតិថ្នាំសន្លប់នៅឡើយ លោក ស្ពែនសឺរ បានដឹងថាគ្រែរុញរបស់គាត់បានឈប់នៅជិតនឹងជណ្ដើរយោង ហើយបានស្ដាប់ឮពេទ្យ ខឹងនឹងអ្វីមួយ ដែលបានថ្លែងព្រះនាម របស់ព្រះអម្ចាស់ដោយមិនគោរព ។ ដោយដឹងខ្លួនខ្លះៗ នោះលោកបានសូមអង្វរដោយសំឡេងខំប្រឹងថា ៖ ‹ ខ្ញុំសូមអង្វរកុំនិយាយដូច្នោះឡើយ ។ ខ្ញុំស្រឡាញ់ទ្រង់លើសអ្វីៗទាំងអស់ក្នុងលោកនេះ ។ សូមអង្វរ › ។ រួចក៏មានភាពស្ងាត់ស្ងៀមជ្រងំទៅវិញ ។ បន្ទាប់មកពេទ្យបានតបដោយទន់ភ្លន់វិញថា ៖ ‹ ខ្ញុំពុំគួរនិយាយដូចនោះទេ ។ ខ្ញុំសុំទោស › » ( Edward L. Kimball and Andrew E. Kimball Jr. *Spencer W. Kimball: Twelfth President of The Church of Jesus Christ of Latter–day Saints* [ ឆ្នាំ ១៩៧៧ ], ទំព័រ ២៦៤ ) ។

- តើដំណើររឿងនេះធ្វើឲ្យអ្នកចាប់អារម្មណ៍យ៉ាងដូចម្ដេចដែរ ?

- តើការគោរពចំពោះព្រះនាមរបស់ព្រះអម្ចាស់របស់ប្រធាន ឃឹមបឹល ខុសពីរបៀបដែលមនុស្សជាច្រើននៅក្នុងពិភពលោកសព្វថ្ងៃប្រើព្រះនាមរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឮៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៥៨–៦៤ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ និងឃ្លាដែលជួយពួកគេយល់អំពីរបៀបដែលព្រះអម្ចាស់ សព្វព្រះទ័យឲ្យយើងប្រើព្រះនាមទ្រង់ និងរបៀបដែលទ្រង់ចង់ឲ្យយើងនិយាយអំពីរឿងពិសិដ្ឋទាំងអស់ ។

- តើអ្នករកឃើញអ្វីខ្លះ អំពីរបៀបដែលយើងត្រូវប្រើព្រះនាមរបស់ព្រះនោះ ? ( នៅពេលសិស្សប្រាប់ពាក្យ និងឃ្លាមកពី ខ ៦៤ សូមអញ្ជើញពួកគេឲ្យសង្ខេបនូវផ្នែកដំបូងនៃខគម្ពីរ ។ ពួកគេគួរតែបង្ហាញអំពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទគឺពិសិដ្ឋ ហើយត្រូវតែថ្លែងដោយយកចិត្តទុកដាក់ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាស្មៀននៅលើក្ដារខៀន ។ សូមឲ្យសិស្សក្នុងថ្នាក់ប្រាប់អំពីស្ថានភាពមួយចំនួន ដែលយើងអាចនឹងប្រើព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទដោយត្រឹមត្រូវ ហើយឲ្យស្មៀនសរសេរស្ថានភាពទាំងនេះនៅលើក្ដារខៀន ។ សិស្សអាចនឹងប្រាប់ថា យើងប្រើព្រះនាមរបស់ព្រះអង្គសង្គ្រោះនៅក្នុងការអធិស្ឋាន ការឡើងនិយាយ ការថ្លែងទីបន្ទាល់ មេរៀននៃដំណឹងល្អ និងពិធីបរិសុទ្ធនៃបព្វជិតភាព ។ យើងក៏អាចនឹងថ្លែងអំពីព្រះអង្គសង្គ្រោះនៅក្នុងការសន្ទនាជារៀងរាល់ថ្ងៃរបស់យើងផងដែរ ប៉ុន្តែយើងគួរតែថ្លែងដោយគារវភាពបំផុត ។

- ហេតុអ្វីក៏អ្នកគិតថា យើងត្រូវប្រើព្រះនាមរបស់ព្រះអង្គសង្គ្រោះដោយគារវភាព ?
- តើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៦២ បង្កើនការយល់ដឹងរបស់អ្នកអំពីអត្ថន័យដើម្បីយកព្រះនាមរបស់ព្រះអម្ចាស់ជាអសារឥតការយ៉ាងដូចម្ដេច ? តើខនេះអនុវត្តចំពោះពិធីបរិសុទ្ធបព្វជិតភាពយ៉ាងដូចម្ដេចដែរ ?
- នៅពេលយើងប្រើព្រះនាមរបស់ព្រះអង្គសង្គ្រោះ តើយើងអាចធ្វើអ្វីខ្លះដើម្បីចាំថា វាពិសិដ្ឋ ហើយត្រូវតែថ្លែងដោយយកចិត្តទុកដាក់យ៉ាងដូចម្ដេច ?

សូមជួយសិស្សឲ្យយល់ថា សេចក្ដីពិតទាំងឡាយដែលអ្នកបានពិភាក្សា ពុំអនុវត្តត្រឹមតែចំពោះព្រះនាមរបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះទេ ។

- តើពាក្យ ឬប្រធានបទមួយចំនួនដទៃទៀត ដែល « មកពីស្ថានលើ » ហើយពិសិដ្ឋ មានអ្វីខ្លះ? តើយើងអាចប្រាកដថា យើងថ្លែងដោយ « យកចិត្តទុកដាក់ » យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« គ្មានពាក្យណាដែលពិសិដ្ឋ ឬសំខាន់ នៅក្នុងភាសារបស់យើង ជាងព្រះនាមរបស់ព្រះ ជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទនោះទេ » (Reverent and Clean » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៦, ទំព័រ ៥០ ) ។

- ហេតុអ្វីក៏ព្រះនាមរបស់ព្រះ ជាព្រះបិតា និងព្រះយេស៊ូវគ្រីស្ទ ពិសិដ្ឋចំពោះអ្នកដូច្នេះ ?

សូមថ្លែងទីបន្ទាល់របស់អ្នកអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយពន្យល់ពីមូលហេតុដែលព្រះនាមរបស់ទ្រង់ ពិសិដ្ឋចំពោះអ្នក ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីវិធីនានាដែលពួកគេអាចប្រើព្រះនាមរបស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទកាន់តែមានគារវភាព ហើយលើកទឹកចិត្តពួកគេឲ្យធ្វើដូច្នោះ ។

មេរៀនទី ៦៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩

## បុព្វកថា

នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៨៣១ ព្យាការីយ៉ូសែប ស្ម៊ីធ និងពួកអែលឌើរមួយចំនួនបានត្រឡប់ទៅរដ្ឋ អូហៃអូ ថ្មីៗ ពីការធ្វើដំណើររបស់ពួកគាត់ដើម្បីឧទ្ទិសឆ្លងទឹកដី និងទីតាំងព្រះវិហារបរិសុទ្ធនៅស៊ីយ៉ូន ឬ អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ។ អំឡុងពេលការធ្វើដំណើរទៅមករដ្ឋ មីសសួរី នោះមានពួកអែលឌើរមួយចំនួនបានទាស់គ្នា ហើយបានមានអារម្មណ៍នៃការទាស់ទែងគ្នា ប៉ុន្តែភាគច្រើនអាចផ្សះផ្សាគ្នាវិញបាន ។ នៅថ្ងៃទី ១១ ខែកញ្ញា ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ ។ មេរៀននេះ គ្របដណ្ដប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩ ដែលព្រះអម្ចាស់មានបន្ទូលអំពី ព្រះទ័យរបស់ទ្រង់ដើម្បីអភ័យទោសដល់ពួកអ្នកបម្រើរបស់ទ្រង់ ។ ទ្រង់ក៏បានបញ្ជាដល់សមាជិកសាសនាចក្រឲ្យអភ័យទោសដល់គ្នាទៅវិញទៅមកផងដែរ ។

*កំណត់ចំណាំ* មេរៀនទី ៧០ ផ្ដល់នូវឱកាសមួយសម្រាប់សិស្សពីរនាក់ឡើងមកបង្រៀន ។ បើអ្នកពុំទាន់បានធ្វើដូច្នោះទេ អ្នកអាចនឹងជ្រើសរើសសិស្សពីរនាក់ក្នុងពេលឥឡូវនេះ ហើយផ្ដល់ច្បាប់ចម្លងផ្នែកនៃមេរៀនទី ៧០ ចាត់តាំងដល់ពួកគេ ដើម្បីពួកគេអាចត្រៀមខ្លួន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–៧

*ព្រះអម្ចាស់អះអាងនឹងពួកអែលឌើរអំពីព្រះទ័យរបស់ទ្រង់ដើម្បីអភ័យទោស*

មុនចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖

> *តើពេលណា ដែលអ្នកទទួលអារម្មណ៍ឈឺចាប់ដោយសារតែពាក្យសម្ដី ឬ ទង្វើនៃមនុស្សម្នាក់ទៀត ?*
>
> *តើអ្នកឆ្លើយតបនឹងស្ថានភាពនោះយ៉ាងដូចម្ដេច ?*

សូមចាប់ផ្ដើមដោយការអញ្ជើញសិស្សឲ្យពិចារណាចំពោះសំណួរទាំងឡាយនៅលើក្ដារខៀន ។

សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ ព្រះអម្ចាស់បង្រៀនយើងអំពីរបៀបដើម្បីឆ្លើយតបនៅពេលអ្នកដទៃធ្វើឲ្យយើងឈឺចាប់ ។ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ នៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ១៨៣១ ប្រហែលជាពីរសប្ដាហ៍បន្ទាប់ពីគាត់ និងក្រុមនៃពួកអែលឌើរ បានត្រឡប់ទៅរដ្ឋអូហៃអូ ពីអ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី វិញ។ ពួកអែលឌើរទាំងនេះ និងសមាជិកសាសនាចក្រដទៃទៀត បានជួបនឹងការលំបាកដោយសារតែការមិនយល់ស្រប និងអារម្មណ៍ទាស់ទែងនៅក្នុងចំណោមសមាជិកក្រុមមួយចំនួន ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ បានមានបន្ទូលថា « មានពួកអ្នកនៅក្នុងចំណោមអ្នករាល់គ្នាដែលបានធ្វើបាន » (គ និង ស ៦៤:៣) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលឃ្លាដែលពិពណ៌នាអំពីរបៀបដែលព្រះអម្ចាស់ នឹងឆ្លើយតបចំពោះអ្នកទាំងឡាយដែលបានធ្វើបាប ។ អ្នកអាចឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំឃ្លាដែលពួកគេបានប្រាប់ ។

- តើព្រះអម្ចាស់មានបន្ទូលថាទ្រង់នឹងឆ្លើយតបចំពោះសមាជិកនៃសាសនាចក្រដែលបានធ្វើបាបយ៉ាងដូចម្ដេច ?
- តើការឆ្លើយតបទាំងនេះបង្រៀនអ្វីខ្លះអំពីព្រះអម្ចាស់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់មានក្ដីមេត្តាករុណា ការអភ័យទោស ហើយប្រកបដោយព្រះគុណ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- ហេតុអ្វីក៏សេចក្ដីពិតនេះ សំខាន់ចំពោះសមាជិកនៃសាសនាចក្រដែលបានជួបនឹងការលំបាក ដោយសារតែការមិនយល់ស្រប និងអារម្មណ៍តានតឹងនោះ ? ហេតុអ្វីសេចក្ដីពិតអំពីព្រះអង្គសង្គ្រោះសំខាន់ចំពោះអ្នកដូច្នេះ ?

សូមពន្យល់ថា នៅគ្រានេះ សមាជិកសាសនាចក្រមួយចំនួន រួមទាំងពួកអែលឌើរមួយចំនួនដែលបានធ្វើដំណើរជាមួយនឹង យ៉ូសែប ស្ម៊ីធ បានរិះគន់ដល់ យ៉ូសែប ស្ម៊ីធ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៥–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអម្ចាស់បានមានបន្ទូលអំពី យ៉ូសែបស្ម៊ីធ ។ ពីមុនសិស្សអាន សូមពន្យល់ថា ការស្វែងរកឱកាសដើម្បីទាស់នឹងនរណាម្នាក់ បានបង្ហាញនៅក្នុង ខ ៦ គឺជាការរកកំហុសចំពោះនរណាម្នាក់ ។

- តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះអំពីយ៉ូសែប ស្ម៊ីធ? ( យ៉ូសែប ស្ម៊ីធ បានកាន់កូនសោទាំងឡាយនៃនគររបស់ព្រះអម្ចាស់ ហើយជាអ្នកបម្រើរបស់ព្រះអម្ចាស់ ។ មនុស្សខ្លះចាំចាប់កំហុសយ៉ូសែប ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៧ ដោយស្ងាត់ស្ងៀម រកមើលអ្វីផ្សេងទៀតដែលព្រះអម្ចាស់បាន មានព្រះបន្ទូល អំពីយ៉ូសែប ស្ម៊ីធ ។

- តើយើងអាចរៀនអ្វីខ្លះចេញមកពីខនេះអំពីយ៉ូសែប ស្ម៊ីធ ? ( យ៉ូសែប ស្ម៊ីធ បានធ្វើបាប ប៉ុន្តែព្រះអម្ចាស់មានឆន្ទៈ ដើម្បីអភ័យទោសដល់លោក ។ ដើម្បីជួយសិស្សយល់វគ្គគម្ពីរនេះ អ្នកអាចនឹងចង់ចង្អុលបង្ហាញថា ក៏ដូចជាមនុស្ស ទាំងអស់ដែរ យ៉ូសែប ស្ម៊ីធ មានភាពទន់ខ្សោយ ហើយចាំបាច់ត្រូវស្វែងរកការអភ័យទោសចំពោះអំពើបាបរបស់លោក ពីព្រះអម្ចាស់ ។ ទោះជាយ៉ាងណាក៏ដោយ លោកពុំបានប្រព្រឹត្តកំហុស ធ្វើអំពើបាបធ្ងន់ធ្ងរនោះទេ ) ។
- តើយើងអាចរៀនអ្វីខ្លះចេញមកពីខគម្ពីរនេះ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានការអភ័យទោសពីព្រះអម្ចាស់ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៨–១៩

*ព្រះអម្ចាស់ បញ្ជាពួកអ្នកបម្រើទ្រង់ឲ្យអភ័យទោសដល់គ្នាទៅវិញទៅមក*

បើអាចធ្វើទៅបាន សូមបង្ហាញរូបពស់ពិសមួយ ដែលរស់នៅក្នុងតំបន់របស់អ្នក ឬរូបភាពនៃដំបៅមួយដែលបណ្ដាលមកពី ពស់ចឹក ។

- បន្ថែមពីលើអារម្មណ៍ឈឺចាប់ខាងរាងកាយ តើអារម្មណ៍អ្វីខ្លះដែលអ្នកគិតថា នឹងកើតមានចំពោះអ្នក បើអ្នកត្រូវបាន ពស់ពិសចឹកនោះ ?

សូមពន្យល់ថា មានអ្នកខ្លះនៅក្នុងស្ថានភាពនេះ អាច (១) ដេញតាមពស់ ហើយសម្លាប់វាដោយកំហឹង ឬភ័យខ្លាច ឬ (២) រកវិធីបន្សាបពិសចេញពីរូបកាយរបស់គាត់ភ្លាមៗ ។

- ទង្វើរទាំងពីរនេះ តើទង្វើមួយណាដែលអ្នកគិតថាមានភាពឆ្លាតវៃជាង ? ហេតុអ្វី ?

សូមពន្យល់ថា ជម្រើសរបស់មនុស្សម្នាក់ បន្ទាប់ពីពស់ពិសចឹក អាចប្រៀបធៀបនឹងជម្រើសរបស់យើង នៅពេលយើង មានអារម្មណ៍ឈឺចាប់ដោយសារពាក្យសម្ដី ឬទង្វើរបស់អ្នកដទៃ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដី សញ្ញា ៦៤:៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលផលវិបាកនានាដែលសិស្សរបស់ព្រះអម្ចាស់មួយចំនួនបានជួប ដោយសារតែពួកគេបដិសេធពុំអភ័យទោសដល់គ្នាទៅវិញទៅមក ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើគោលការណ៍អ្វីដែលយើងរៀនមកពី ខ ៨ នេះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរប្រាប់អំពីគោលការណ៍ ដូចខាងក្រោម ៖**នៅពេលយើងបដិសេធពុំអភ័យទោសដល់អ្នកដទៃ នោះគឺយើងនាំទុក្ខដាក់ខ្លួនឯង** ។ សូមពិចារណា អំពីការអញ្ជើញសិស្សឲ្យសរសេរគោលការណ៍នេះជាពាក្យរបស់គេផ្ទាល់នៅក្នុងព្រះគម្ពីររបស់ពួកគេ ។
- តើមនុស្សម្នាក់អាចត្រូវរងទុក្ខ (ឬឈឺចាប់) ដោយការមិនអភ័យទោសដល់អ្នកដទៃយ៉ាងដូចម្ដេច ? តើការណ៍នេះ ដូចគ្នា នឹងលទ្ធផលនៃមនុស្សម្នាក់ដែលរត់ដេញតាមពស់ដែលទើបចឹកគាត់យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៩ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យប្រាប់អំពីលទ្ធផល មួយទៀតនៃការមិនអភ័យទោសដល់ អ្នកដទៃ ។

- ស្របតាម ខ ៩ តើលទ្ធផលនៃការបដិសេធពុំអភ័យទោសដល់អ្នកដទៃមានអ្វីខ្លះ ? (**បើយើងពុំអភ័យទោសដល់អ្នកដទៃ នោះយើងឈរទទួលទោសនៅចំពោះព្រះអម្ចាស់** ។ សូមសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។

ជាចំណែកនៃការពិភាក្សានេះ អ្នកអាចនឹងចង់សុំឲ្យសិស្សអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដេវីឌ អ៊ី ស្វ៊ិនសិន នៃពួកចិតសិបនាក់ ៖



« វាអាចនឹងមានការលំបាកណាស់ដើម្បីអភ័យទោសដល់នរណាម្នាក់ចំពោះការអាក្រក់ដែលពួកគេបានធ្វើមកលើយើង ប៉ុន្តែនៅពេលយើងអភ័យទោស នោះយើងនឹងបើកផ្លូវឲ្យខ្លួនយើងឈានទៅកអនាគតកាន់តែល្អប្រសើរមួយ ។ នោះទង្វើនៃការធ្វើខុសឆ្គងរបស់អ្នកដទៃនឹងឈប់មានឥទ្ធិពលគ្រប់គ្រងលើផ្លូវនៃជីវិតរបស់យើងហើយ ។ នៅពេលយើងអភ័យទោសដល់អ្នកដទៃ វារំដោះយើងឲ្យមានសេរីភាព ដើម្បីជ្រើសរើសថាតើយើងនឹងរស់នៅក្នុងជីវិតរបស់យើងតាមរបៀបណា ។ ការអភ័យទោសមានន័យថា បញ្ហាកាលពីអតីតកាល ឈប់សម្រេចជោគវាសនារបស់យើងទៀតហើយ ហើយយើងអាចផ្ដោតទៅលើអនាគតកាលដោយក្ដីស្រឡាញ់របស់ព្រះនៅក្នុងដួងចិត្តរបស់យើង » (« Forgiveness Will Change Bitterness to Love » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៣ ទំព័រ ១២ ) ។

ដើម្បីជួយសិស្សប្រាប់ ឬអនុវត្តបទបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីអភ័យទោសដល់មនុស្សទាំងអស់ សូមអាននូវឧទាហរណ៍ដូចខាងក្រោម ហើយសួរសំណួរដូចតទៅ ៖

១. យុវនារីម្នាក់ត្រូវបានឈឺចាប់ ហើយមានការខ្មាស់អៀនពេលដែលបានដឹងថាមិត្តរបស់នាងបាននិយាយដើមនាងត ៗគ្នា ។ ក្រោយមក មិត្តមួយចំនួនបានមកសុំទោស ប៉ុន្តែអ្នកដទៃទៀតពុំបានមកទេ ។ យុវនារីនោះបានអភ័យទោសដល់អ្នកដែលមកសុំទោស ប៉ុន្តែបានគុំគួននឹងអ្នកផ្សេងទៀត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១០–១១ ឲ្យឮៗ ។ សូមឲ្យពួកគេគិតអំពីរបៀបដែលខគម្ពីរទាំងនេះទាក់ទងនឹងឧទាហរណ៍ដែលអ្នកបានអាន ។

- តើបទបញ្ញត្តិអ្វីដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុង ខ ១០ ? ( សូមជួយសិស្សស្គាល់បទបញ្ញត្តិដូចខាងក្រោម ៖**ព្រះអម្ចាស់បញ្ជាយើងឲ្យអភ័យទោសដល់មនុស្សទាំងអស់** ) ។
- តើបទបញ្ញត្តិនេះទាក់ទងនឹងយុវនារីនៅក្នុងឧទាហរណ៍យ៉ាងដូចម្ដេច ? ហេតុអ្វីក៏អ្នកគិតថាវាសំខាន់ដើម្បីអភ័យទោសមនុស្សទាំងអស់ មិនថាពួកគេមកសុំទោសចំពោះកំហុសរបស់ពួកគេឬអត់នោះ ?

២. យុវជនម្នាក់ ពុំគោរពបទបញ្ញត្តិមួយ ។ គាត់បានអធិស្ឋានសូមការអភ័យទោស ហើយពិភាក្សាបញ្ហាជាមួយនឹងប៊ីស្សពរបស់គាត់ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីប៊ីស្សពបានអះអាងនឹងយុវជននោះថា គាត់បានប្រែចិត្តពេញលេញក៏យុវជននោះនៅបន្តមានអារម្មណ៍មិនសក្ដិសមដោយសារតែអំពើបាបពីអតីតកាលរបស់គាត់ ។

- តើបទបញ្ញត្តិនៃការអភ័យទោសដល់មនុស្សទាំងអស់ទាក់ទងនឹងយុវជនក្នុងឧទាហរណ៍នេះយ៉ាងដូចម្ដេច? ហេតុអ្វីក៏យើងត្រូវអភ័យទោសឲ្យខ្លួនឯង ?

៣. យុវនារីម្នាក់ មានអារម្មណ៍សោកសៅ ហើយមានការច្របូកច្របល់ ដោយសារតែទង្វើរបស់ឪពុកនាង ។ គាត់បានបោះបង់គ្រួសារចោល ។ ពីមុនគាត់ចាកចេញ គាត់កម្របង្ហាញសេចក្ដីស្រឡាញ់ដល់ក្រុមគ្រួសារ ឬមានចរិកឃោរឃៅជាញឹកញាប់ ។ នាងពុំយល់ថា ហេតុអ្វីក៏ឪពុកនាងមានទង្វើបែបនេះ ហើយនាងមានអារម្មណ៍ខឹងដល់គាត់ ។ នាងបានដឹងថា នាងគួរស្វែងរកការអភ័យទោសឲ្យឪពុក នាង ប៉ុន្តែនាងគិតថា នាងមិនអាចធ្វើបានទេ ។

- តើការទូន្មានរបស់ព្រះអម្ចាស់នៅក្នុង ខ ១១ អាចជួយយុវនារីនេះឲ្យអភ័យទោសដល់ឪពុករបស់នាងយ៉ាងដូចម្ដេច ? តើវាជួយយើងឲ្យទុកការជំនុំជម្រះដល់អ្នកទាំងឡាយដែលធ្វើឲ្យយើងឈឺចាប់ទៅលើព្រះយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សពិចារណាថាតើមាននរណាម្នាក់ដែលពួកគេចាំបាច់ត្រូវអភ័យទោសឲ្យ ។ ដោយទទួលស្គាល់ថា ជួនកាលវាមានការលំបាកណាស់ដើម្បីអភ័យទោសដល់នរណាម្នាក់ ។ សូមអញ្ជើញសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវអ្វីដែលពួកគេអាចធ្វើ បើពួកគេកំពុងមានការលំបាកក្នុងអភ័យទោសដល់នរណាម្នាក់ ។



« ខ្ញុំសូមអង្វរអ្នកឲ្យទូលសុំកម្លាំងមកពីព្រះអម្ចាស់ដើម្បីអភ័យទោស ។. . . វាប្រហែលជាពុំងាយស្រួលទេ ហើយវាអាចនឹងប្រហែលជាពុំកើតមានយ៉ាងឆាប់រហ័សផងដែរ ។ ប៉ុន្តែ បើអ្នកនឹងស្វែងរកវាដោយចិត្តស្មោះសរ ហើយបណ្ដុះវាឡើង នោះវា *នឹង* កើតមានឡើង » (« Of You It Is Required to Forgive » *Ensign* ខែ មិថុនា ឆ្នាំ ១៩៩១ ទំព័រ ៥ ) ។

- តើប្រធាន ហ៊ិងគ្លី បានប្រឹក្សាដល់យើងឲ្យធ្វើអ្វីខ្លះ បើយើងកំពុងពុះពារក្នុងការអភ័យទោសដល់នរណាម្នាក់នោះ ? តើអ្នកគិតថាការអធិស្ឋានសុំកម្លាំងអាចជួយយើងឲ្យអភ័យទោសបានយ៉ាងដូចម្ដេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១២–១៤ ដោយការពន្យល់ថា ព្រះអម្ចាស់បានបង្រៀនថា ជម្រើសរបស់យើងដើម្បីអភ័យទោសដល់អ្នកដទៃ ពុំរំដោះពួកគេពីការទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេនោះទេ ។ ពួកគេនៅតែទទួលខុសត្រូវចំពោះព្រះអម្ចាស់ចំពោះកំហុសដែលពួកគេបានធ្វើ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១៥–១៧ យើងមើលឃើញថា ព្រះអម្ចាស់បានអភ័យទោសដល់ពួកអ្នកបម្រើរបស់ទ្រង់ពីរនាក់យ៉ាងជាក់ គឺ អ៊ីសាក មូលី និង អែតវឺត ប៉ាទ្រិច ដោយសារពួកគេបានប្រែចិត្តពីបាបរបស់ពួកគេ ។

សូមដាក់តាំងរូបភាពនៃព្រះយេស៊ូវគ្រីស្ទ ។ សូមចង្អុលបង្ហាញទៅសេចក្ដីពិតទីមួយដែលអ្នកបានសរសេរនៅលើក្ដារខៀននៅពីមុនមេរៀនថា ៖ **ព្រះអម្ចាស់មានក្ដីមេត្តាករុណា ការអភ័យទោស និងប្រកបដោយព្រះគុណ ។** សូមថ្លែងទីបន្ទាល់ថា នៅពេលយើងអភ័យទោស នោះយើងកាន់តែប្រែក្លាយដូចជាព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេអាចអនុវត្តតាមគោលការណ៍នៃការអភ័យទោសដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមផ្ដល់ពេលដល់ពួកគេឲ្យសរសេរអ្វីដែលពួកគេនឹងធ្វើដើម្បីអនុវត្តសេចក្ដីពិតទាំងនេះ ហើយកត់ត្រាចំណាប់អារម្មណ៍នានា ដែលពួកគេបានទទួល ។

មេរៀនទី ៧០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣

## បុព្វកថា

យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៨៣១ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣ មាននូវការបង្រៀនរបស់ព្រះអម្ចាស់អំពីពលិកម្ម ដែលទ្រង់តម្រូវឲ្យពួកបរិសុទ្ធមាន និងអំពីការស្ថាបនាស៊ីយ៉ូននៅថ្ងៃចុងក្រោយ ។

*កំណត់ចំណាំ ៖* មេរៀននេះ ផ្ដល់នូវឱកាសមួយសម្រាប់សិស្សពីរនាក់ឡើងមកបង្រៀន ។ សូមផ្ដល់ច្បាប់ចម្លងនៃឯកសារដល់សិស្សទាំងនេះជាមុន ដើម្បីពួកគេមានពេលគ្រប់គ្រាន់ដើម្បីត្រៀមខ្លួន ។ ជាជម្រើសមួយ អ្នកអាចនឹងសម្រេចចិត្តដើម្បីបង្រៀនមេរៀនទាំងមូលដោយខ្លួនអ្នក ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–២៥

*ព្រះអម្ចាស់បង្រៀនថា ទ្រង់តម្រូវចំពោះដួងចិត្តរបស់យើង*

សូមឲ្យសិស្សគិតអំពីគ្រាដែលពួកគេបានធ្វើការលះបង់ដើម្បីធ្វើតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។ ( ដើម្បីឲ្យពួកគេគិត អ្នកអាចនឹងចែកចាយឧទាហរណ៍មួយ ដូចជាការឈប់ចូលរួមនៅក្នុងព្រឹត្តការណ៍កីឡា ឬសកម្មភាពស្រដៀងគ្នានេះនៅថ្ងៃឈប់សម្រាក ) ។ សូមអញ្ជើញសិស្សពីរបីនាក់ពិពណ៌នាអំពីបទពិសោធន៍របស់ពួកគេ ហើយចែកចាយពីរបៀបដែលពួកគេទទួល អារម្មណ៍ថា ពួកគេត្រូវបានប្រទានពរដែលបានធ្វើការលះបង់ទាំងនេះ ។

សូមពន្យល់ថា នៅក្នុងការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣ សិស្សនឹងរៀនបន្ថែមអំពីពលិកម្មដែលព្រះអម្ចាស់តម្រូវពីយើង ។ សូមបង្ហាញតារាងខាងក្រោមនេះ ។ ( អ្នកអាចចម្លងតារាងនោះ នៅលើក្ដារខៀន មុនចាប់ផ្ដើមថ្នាក់រៀន ) ។

| | អ៊ីសាក មូលី (គ. និង ស. ៦៤:២០) | ហ្វ្រេឌើរិក ជី វិលលាម្ស (គ. និង ស. ៦៤:២១) |
|---|---|---|
| ព្រះបញ្ញត្តិ | | |
| ការឆ្លើយតប | | |
| លទ្ធផល | | |

សូមពន្យល់ថា អ៊ីសាក មូលី ជាម្ចាស់ចម្ការដ៏ធំមួយនៅទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ ។ គាត់បានអញ្ជើញសមាជិកសាសនាចក្រជាច្រើនដោយរីករាយ រួមទាំង យ៉ូសែប ស្ម៊ីធ និង គ្រួសារគាត់ ឲ្យរស់នៅលើដីកម្មសិទ្ធិរបស់គាត់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់ណែនាំដល់ អ៊ីសាក មូលី ឲ្យធ្វើជាមួយនឹងចម្ការរបស់គាត់ ។

- តើព្រះអម្ចាស់បញ្ជាអ៊ីសាក មូលីឲ្យធ្វើអ្វីខ្លះ ជាមួយនឹងចម្ការរបស់គាត់ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរ *លក់ចម្ការរបស់គាត់* នៅក្នុងតារាងដើម្បីបង្ហាញពីបទបញ្ញត្តិដែលព្រះអម្ចាស់ប្រទានដល់ អ៊ីសាក មូលី ) ។

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានបញ្ជាឲ្យអ៊ីសាក មូលី ធ្វើការលះបង់ដ៏ធំមួយ ។ ប្រាក់ភាគច្រើនដែលបានមកពីការលក់ចម្ការរបស់គាត់ នឹងប្រើសម្រាប់ទិញដីសម្រាប់សមាជិកសាសនាចក្រផ្សេងទៀតនៅក្នុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ។

- តើពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់សន្យាថានឹងផ្ដល់ឲ្យអ៊ីសាក មូលី បើគាត់លក់ចម្ការរបស់គាត់នោះ ? ( ព្រះអម្ចាស់សន្យាថា បើអ៊ីសាក លក់ចម្ការរបស់គាត់ នោះគាត់នឹង « មិនត្រូវបានល្បួងលើសពីសមត្ថភាពដែលគាត់ [អាច] ទ្រាំទ្របាននោះទេ » ) ។

- តើគោលការណ៍អ្វីខ្លះដែលការសន្យានេះបង្រៀនយើងអំពី ការចៀសវាងពីការល្បួង ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖**បើយើងធ្វើតាមឆន្ទៈរបស់ព្រះអម្ចាស់ សម្រាប់យើង នោះយើងនឹងមិនត្រូវបានល្បួងឲ្យលើសពីអ្វីដែលយើងអាចទ្រាំទ្របាននោះទេ )** ។

សូមពន្យល់ថា អ៊ីសាក មូលី បានធ្វើតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីលក់ចម្ការរបស់គាត់ ។ គាត់គឺជាពួកបរិសុទ្ធម្នាក់ដំបូងគេដែលបានតាំងលំនៅនៅក្នុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ដែលគាត់បានព្យាយាមស្ថាបនាក្រុងស៊ីយ៉ូន ។ គាត់បានបម្រើព្រះអម្ចាស់ដោយស្មោះត្រង់ពេញមួយជីវិតរបស់គាត់ ។ នៅក្នុងតារាងនៅលើក្ដារខៀន សូមសរសេរ *ទ្រង់បានគោរពតាម* ដូចការឆ្លើយតបរបស់អ៊ីសាក ។ សូមសរសេរ *គាត់បានទទួលពរជ័យ* ជាលទ្ធផលនៃទង្វើរបស់គាត់ ។

- តើគំរូមួយចំនួនអំពីរបៀបដែលយើងអាចចៀសវាងពីការល្បួងតាមរយៈការធ្វើតាមបទបញ្ញត្តិ និងបទដ្ឋានទាំងឡាយរបស់ព្រះអម្ចាស់មានអ្វីខ្លះ ? ( សូមពិចារណាធ្វើការចែកចាយគំរូមួយចំនួនចេញមកពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ) ។

សូមចង្អុលបង្ហាញថា បុរសម្នាក់ទៀត ឈ្មោះ ហ្វ្រេឌើរិក ជី វិលលាម្ស ក៏ជាម្ចាស់ចម្ការដ៏ធំមួយនៅទីក្រុងខឺតឡង់ផងដែរ ។ សូមសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២១ ដោយស្ងាត់ស្ងៀម រកមើលបទបញ្ញត្តិដែលព្រះអម្ចាស់បានប្រទានឲ្យហ្វ្រេឌើរិក ជី វិលលាម្ស ។

- តើព្រះអម្ចាស់បានបញ្ជាហ្វ្រេឌើរិក ជី វិលលាម្សឲ្យធ្វើអ្វីខ្លះ ជាមួយនឹងចម្ការរបស់គាត់ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរ *កុំលក់ចម្ការរបស់គាត់* នៅកន្លែងត្រឹមត្រូវក្នុងតារាង ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌដូចខាងក្រោម ដោយពន្យល់ថាតើ ហ្វ្រេឌើរិក ជី វិលលាម្ស បានធ្វើអ្វីជាមួយនឹងចម្ការរបស់គាត់ ៖

ទោះជាហ្វ្រេឌើរិក ជី វិលលាម្ស ពុំត្រូវបានសុំឲ្យលក់ចម្ការរបស់គាត់ក្ដី ក៏គាត់នៅតែបង្ហាញពីឆន្ទៈដើម្បីធ្វើការលះបង់ផងដែរ ។ គាត់បានប្រាប់ យ៉ូសែប ស្ម៊ីធ ថា ចម្ការរបស់គាត់អាចត្រូវបានប្រើប្រាស់ជាផ្ទះ ឬជាកន្លែងបីបាច់ដល់សមាជិកសាសនាចក្រដែលខ្វះខាត ។ ក្រោយមក ហ្វ្រេឌើរិក បានប្រគល់ចម្ការរបស់គាត់ទាំងមូលដល់សាសនាចក្រដោយគ្មានទទួលយកការបង់ថ្លៃត្រឡប់វិញឡើយ ។ តាមរយៈការលះបង់របស់ហ្វ្រេឌើរិក ជី វិលលាម្ស និងពួកបរិសុទ្ធស្មោះត្រង់ដទៃទៀតនៅរដ្ឋ អូហៃអូ នោះព្រះអម្ចាស់បានរក្សា « កន្លែងមាំមួនមួយនៅក្នុងដែនដីខឺតឡង់ សម្រាប់រយៈពេលប្រាំឆ្នាំ » គ. និង ស. ៦៤:២១) ។ អំឡុងឆ្នាំទាំងនេះ ពួកបរិសុទ្ធបានស្ថាបនាព្រះវិហារបរិសុទ្ធខឺតឡង់ ដែលជាប្រភពមួយនៃពរជ័យដ៏មហិមាដែលមានដល់ពួកបរិសុទ្ធរួមទាំងបងប្រុស វិលលាម្ស ផងដែរ។

នៅក្នុងតារាងនៅលើក្ដារខៀន ចូរបំពេញកូឡោនសម្រាប់ ហ្វ្រេឌើរិក ជី វិលលាម្ស ដោយការសរសេរ *គាត់បានគោរព* និង *គាត់ត្រូវបានប្រទានពរ* នៅក្នុងកន្លែងត្រឹមត្រូវ ។

- តើយើងអាចរៀនអ្វីខ្លះ អំពីការគោរពប្រតិបត្តិ និងការលះបង់មកពីគំរូរបស់ អ៊ីសាក មូលី និង ហ្វ្រេឌើរិក ជី វិលលាម្ស ? ( សូមសង្ខេបចម្លើយរបស់សិស្ស ដោយការសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖**យើងត្រូវបានប្រទានពរនៅពេលយើងគោរពព្រះអម្ចាស់ ហើយថ្វាយការលះបង់តាមដែលទ្រង់បានសុំពីយើង )** ។

សូមពន្យល់ថា ការលះបង់ដែល អ៊ីសាក មូលី និង ហ្វ្រេឌើរិក ជី វិលលាម្ស បានធ្វើ ស្ដីអំពីចម្ការរបស់ពួកគេ បានបង្ហាញពីការលះបង់មួយទៀតដែលព្រះអម្ចាស់ តម្រូវពីពួកគេ ហើយដែលទ្រង់តម្រូវពីយើងសព្វថ្ងៃនេះដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការលះបង់ដែលព្រះអម្ចាស់តម្រូវពីយើង ។

- ស្របតាម ខ ២២ តើព្រះអម្ចាស់តម្រូវអ្វីខ្លះពីយើង ? ( ពួកសិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**ព្រះអម្ចាស់តម្រូវពីដួងចិត្តរបស់យើង ។** អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដែលថា ព្រះអម្ចាស់តម្រូវពីចិត្តរបស់យើង ?

- តើអ៊ីសាក មូលី និងហ្វ្រេឌើរិក ជី វិលលាម្ស បានបង្ហាញថា ពួកគាត់មានឆន្ទៈដើម្បីថ្វាយដួងចិត្តរបស់ពួកគាត់ដល់ព្រះអម្ចាស់យ៉ាងដូចម្ដេច ? តើគំរូរបស់មនុស្សមួយចំនួនផ្សេងទៀតដែលបានថ្វាយដួងចិត្តដល់ព្រះអម្ចាស់

មាននរណាខ្លះ ? ( អ្នកអាចនឹងចង់ចង្អុលបង្ហាញថា សិស្សអាចចែកចាយពីគំរូមកពីបទគម្ពីរ ឬមកពីជីវិតរបស់មនុស្សដែលពួកគេស្គាល់ ) ។

- តើយើងអាចបង្ហាញព្រះអម្ចាស់ថា យើងមានឆន្ទៈថ្វាយដួងចិត្តរបស់យើងដល់ទ្រង់យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៣–២៥ ឲ្យឮៗ ហើយសួរដល់សិស្សក្នុងថ្នាក់ឲ្យប្រាប់ពីបទបញ្ញត្តិមួយ ដែលយើងអាចរក្សាដើម្បីបង្ហាញថា យើងបានថ្វាយដួងចិត្តរបស់យើងដល់ព្រះអម្ចាស់ ។

- តើព្រះអម្ចាស់បញ្ជារាស្ត្ររបស់ទ្រង់ឲ្យធ្វើអ្វី ? ( ថ្វាយដង្វាយមួយភាគក្នុងដប់ ។ អ្នកអាចនឹងចង់ពន្យល់ថា នៅពេលព្រះអម្ចាស់ប្រទានវិវរណៈនេះ ពួកបរិសុទ្ធបានប្រើពាក្យ *ដង្វាយមួយភាគក្នុងដប់* សំដៅទៅលើការបរិច្ចាគរបស់ពួកគេដល់សាសនាចក្រ ។ ប្រហែលជាប្រាំពីរឆ្នាំក្រោយមក ព្រះអម្ចាស់បានបើកសម្ដែងថា ដង្វាយមួយភាគក្នុងដប់ គឺជា « មួយភាគដប់នូវផលផានក្នុងមួយឆ្នាំ [របស់យើង] » [គ. និង ស. ១១៩:៤] ) ។ តើការថ្វាយដង្វាយមួយភាគក្នុងដប់អាចបង្ហាញថា យើងត្រូវបានថ្វាយចិត្តរបស់យើងដល់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- ស្របតាម ខ ២៣ តើព្រះអម្ចាស់បានផ្ដល់ការសន្យាអ្វីខ្លះ ដល់អ្នកទាំងឡាយដែលថ្វាយដង្វាយមួយភាគក្នុងដប់ ?

សូមពន្យល់ថា ខណៈដែលពរជ័យជាក់លាក់នៅក្នុង ខ ២៣ អនុវត្តនៅពេលអនាគត នោះព្រះអម្ចាស់ក៏បានប្រទានពរដល់យើងក្នុងពេលនេះសម្រាប់ការថ្វាយដង្វាយមួយភាគក្នុងដប់ផងដែរ ។ អ្នកអាចសុំឲ្យសិស្សចែកចាយបទពិសោធន៍ដែលពួកគេបានមាន នៅពេលពួកគេ ឬគ្រួសាររបស់ពួកគេត្រូវបានប្រទានពរ ជាលទ្ធផលមកពីការថ្វាយដង្វាយមួយភាគក្នុងដប់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៦–៤៣

*ព្រះអម្ចាស់បានប្រទានការណែនាំសម្រាប់ការស្ថាបនាស៊ីយ៉ូន*

ដើម្បីផ្ដល់នូវទស្សនៈរួមអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៦–៤៣ សូមពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះ យើងអានអំពីការណែនាំរបស់ព្រះអម្ចាស់សម្រាប់ការស្ថាបនាស៊ីយ៉ូន ។ មេរៀននេះទាំងស្រុងត្រូវបានបង្កើតដើម្បីបានបង្រៀនដោយសិស្ស ។ សូមអញ្ជើញសិស្សទីមួយដែលធ្វើជាគ្រូ ឡើងមកខាងមុខថ្នាក់ ដើម្បីបង្រៀន។

### សិស្សទីមួយដែលធ្វើជាគ្រូគោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៦-៣៣

សូមចាប់ផ្ដើមដោយសួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកត្រូវបានប្រាប់ឲ្យបំពេញកិច្ចការមួយ ដែលពិបាក ឬវាមានភាពលើសលប់នៅពេលណា ? ( បន្ទាប់ពីសិស្សឆ្លើយតបអ្នកអាចចែកចាយឧទាហរណ៍មួយ ) ។

សូមពន្យល់ថា នៅក្នុងខែសីហា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនូវកិច្ចការជាច្រើននៃការទទួលបានប្រាក់ដើម្បីទិញដីទាំងអស់ដែលតម្រូវឲ្យសាងសង់ទីក្រុងស៊ីយ៉ូន នៅឃុំចាកសុន រដ្ឋ មិសសួរី ។ ពួកបរិសុទ្ធបានដឹងថា នៅពេលពួកគេទិញបានដី នោះពួកគេត្រូវធ្វើការខ្លាំងដើម្បីស្ថាបនាទីក្រុង និងព្រះវិហារបរិសុទ្ធនៅទីនោះ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៦–៣០ មាននូវបញ្ជារបស់ព្រះអម្ចាស់ដល់អ្នកបម្រើរបស់ទ្រង់ពីររូប ឈ្មោះ នូវែល ឃេ វីតនី និងស៊ីឌនី ហ្គីលបើត ។ ទ្រង់បានបញ្ជាពួកគេឲ្យប្រើហាងរបស់ពួកគេនៅខឺតឡង់ រដ្ឋ អូហៃអូ ដើម្បីជួយផ្គត់ផ្គង់ដល់តម្រូវការរបស់ពួកបរិសុទ្ធ ។ នេះគឺជាឧទាហរណ៍មួយ អំពីវិធីមួយដែលពួកបរិសុទ្ធមួយចំនួន ត្រូវបានសុំឲ្យធ្វើការលះបង់ និងបរិច្ចាគដើម្បីស្ថាបនាស៊ីយ៉ូន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣១–៣៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលឃ្លាដែលអាចនឹងលើកទឹកចិត្តដល់ពួកបរិសុទ្ធ ដែលព្យាយាមដើម្បីសម្រេចការងារជាច្រើននៃការស្ថាបនាស៊ីយ៉ូន ។

- តើឃ្លាអ្វីខ្លះដែលបានលើកទឹកចិត្តដល់ពួកបរិសុទ្ធទាំងនេះ ? ( នៅពេលសិស្សចែកចាយឃ្លានានា សូមសួរពួកគេអំពីរបៀបដែលពួកគេផ្សាភ្ជាប់ឃ្លាទាំងនោះ ទៅនឹងខ្លួនពួកគេតាមរបៀបណា ) ។

បន្ទាប់ពីសិស្សបានបញ្ចប់ការពិភាក្សាខគម្ពីរទាំងនេះ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖**បើយើងឧស្សាហ៍នៅក្នុងការធ្វើសេចក្ដីល្អ នោះយើងអាចសម្រេចនូវរឿងអស្ចារ្យៗជាច្រើន ។** សូមចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍នេះ ។ អ្នកក៏អាចនឹងចង់ចែកចាយនូវបទពិសោធន៍មួយ ដែលបានជួយអ្នករៀនសេចក្ដីពិតនៃគោលការណ៍នេះផងដែរ ។

*សូមផ្ដល់ឱកាសឲ្យសិស្សបង្រៀន*

ពីមួយគ្រាទៅមួយគ្រា សូមអនុញ្ញាតឲ្យសិស្សបង្រៀនផ្នែកខ្លះនៃមេរៀនមួយ ។ បទពិសោធន៍នេះ អាចជួយពួកគេបំពេញតួនាទីរបស់ពួកគេនៅក្នុងដំណើរការរៀនសូត្រ ហើយរៀបចំពួកគេសម្រាប់ឱកាសនាពេលអនាគតដើម្បីបង្រៀនដំណឹងល្អ ។ នៅពេលអ្នកអញ្ជើញសិស្សឲ្យបង្រៀន សូមប្រាកដថា អ្នកផ្ដល់ការណែនាំច្បាស់លាស់ដល់ពួកគេ ហើយទុកពេលឲ្យគ្រប់គ្រាន់សម្រាប់រៀបចំ ។

## សិស្សទីពីរដែលធ្វើជាគ្រូ–គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣៤–៤៣

សូមឲ្យសិស្សគិតអំពីគ្រាមួយ ដែលពួកគេគោរពឪពុកម្ដាយ អ្នកដឹកនាំ គ្រូបង្រៀន ឬគ្រូបង្វឹក ប៉ុន្ដែធ្វើការគោរពនោះដោយអាកប្បកិរិយាមិនសូវយកចិត្តទុកដាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យដែលពិពណ៌នាអំពីអាកប្បកិរិយាដែលយើងគួរមាន នៅពេលយើងគោរពព្រះអម្ចាស់ ។

- តើពាក្យសម្ដីអ្វីខ្លះ បង្រៀនអំពីអាកប្បកិរិយាល្អចំពោះការគោរពប្រតិបត្តិ ?

បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **យើងត្រូវគោរពព្រះអម្ចាស់ដោយអស់ពីចិត្តរបស់យើង និងដោយចិត្តស្មោះស្ម័គ្រ ។**

- តើអ្នកគិតថា ការគោរពព្រះអម្ចាស់ដោយ « អស់ពីចិត្ត និងដោយចិត្តស្មោះស្ម័គ្រ » មានន័យយ៉ាងណា ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាដែលពួកគេបានគោរពព្រះអម្ចាស់ដោយអស់ពីចិត្ត និងដោយចិត្តស្មោះស្ម័គ្ររបស់ពួកគេ ។

- តើរឿងនេះវាខុសគ្នាពីគ្រាដែលអ្នកពុំគោរពដោយចិត្តស្ម័គ្រស្មោះយ៉ាងដូចម្ដេច ? (អ្នកក៏អាចចែកចាយបទពិសោធន៍មួយផងដែរ) ។

សូមចង្អុលបង្ហាញថា ស្របតាម ខ ៣៤ អ្នកទាំងឡាយដែលគោរពព្រះអម្ចាស់ ដោយអស់ពីចិត្ត និងដោយចិត្តស្មោះស្ម័គ្ររបស់ពួកគេ នឹងរីកលាយនឹងពរជ័យនៃស៊ីយ៉ូននៅថ្ងៃចុងក្រោយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៤១–៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព័ត៌មានអំពីការស្ថាបនាក្រុងស៊ីយ៉ូននៅក្នុងជំនាន់របស់យើង ។ ដើម្បីជួយសិស្សយល់អំពីខគម្ពីរទាំងនេះ សូមពន្យល់ថានៅក្នុងថ្ងៃចុងក្រោយ ស៊ីយ៉ូននឹងត្រូវបានស្ថាបនាឡើងនៅគ្រប់ជាតិសាសន៍ដែលមនុស្សគោរពព្រះអម្ចាស់ដោយអស់ពីចិត្ត និងដោយចិត្តស្មោះស្ម័គ្ររបស់ពួកគេ ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការគោរពតាមព្រះអម្ចាស់អស់ពីចិត្ត និងដោយចិត្តស្មោះស្ម័គ្ររបស់អ្នក ។ សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលពួកគេអាចគោរពព្រះអម្ចាស់កាន់តែអស់ពីចិត្ត និងកាន់តែគោរពប្រតិបត្តិដោយចិត្តស្មោះស្ម័គ្រ។ សូមលើកទឹកចិត្តពួកគេឲ្យកត់សម្គាល់អំពីភាពខុសគ្នានៃការគោរពប្រតិបត្តិប្រភេទនេះនៅក្នុងជីវិតរបស់ពួកគេ ។

*កំណត់ចំណាំ ៖* បន្ទាប់ពីសិស្សទាំងឡាយបានបង្រៀនចំណែករបស់ពួកគេអំពីមេរៀននេះហើយ សូមអរគុណដល់ពួកគេសម្រាប់កិច្ចការរបស់ពួកគេ ។ សូមថ្លែងទីបន្ទាល់ថា ពរជ័យដែលបានសន្យា គឺមានតម្លៃចំពោះការគោរពប្រតិបត្តិ និងការលះបង់ដែលព្រះអម្ចាស់បានសុំឲ្យយើងធ្វើ ។ សូមឲ្យសិស្សសង្ខេបពីអ្វីដែលសិស្សក្នុងថ្នាក់បានរៀននៅថ្ងៃនេះ និងពន្យល់អំពីរបៀបដែលពួកគេនឹងធ្វើសកម្មភាពតាមគោលការណ៍ទាំងនេះ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦៤ ( មេរៀនទី ១៤ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦៤ ( មេរៀនទី ១៤) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើ គោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២)

តាមរយៈការសិក្សាព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះពួកអែលឌើរដែលកំពុងធ្វើដំណើរពីរដ្ឋ មិសសួរី ទៅរដ្ឋអូហៃអូ នោះសិស្សបានរៀន ថា ប្រសិនបើយើងមិនចែកចាយទីបន្ទាល់របស់យើងទេ នោះយើងនឹងបាត់បង់វា ។ សិស្សក៏បានឃើញផងដែរថា ព្រះអម្ចាស់មានគ្រប់ទាំង ព្រះចេស្ដាទាំងអស់ ហើយអាចរក្សាយើងឲ្យគង់វង្ស ហើយថាយើងត្រូវពឹងផ្អែកលើការវិនិច្ឆ័យរបស់ខ្លួន និងការដឹកនាំពីព្រះវិញ្ញាណ នៅពេល យើងធ្វើការសម្រេចចិត្ត ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣)

នៅក្នុងការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣, សិស្សអាចរៀនថា ព្រះអម្ចាស់ស្ដីបន្ទោសដល់អស់អ្នកទាំងឡាយណា ដែលមិនកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ហើយលួងលោមដល់អស់អ្នកណាដែលស្មោះត្រង់ ។ សិស្សបានរៀនថា សេចក្ដីជំនឿពុំបានកើតមកពី ទីសម្គាល់ឡើយ ប៉ុន្តែគឺជាទីសម្គាល់ទេដែលកើតមកពីសេចក្ដីជំនឿនោះដោយស្របតាមព្រះទ័យរបស់ព្រះ ។ ពួកគេក៏រកឃើញផងដែរនូវ សេចក្ដីពិតខាងក្រោមនេះ ៖ ប្រសិនបើយើងក្រឡេកមើលមនុស្សដទៃហើយមានតម្រេកសម្រើបចង់បាន នោះយើងនឹងគ្មានព្រះវិញ្ញាណឡើយ ហើយយើងបានបោះបង់ចោលសេចក្ដីជំនឿហើយ ប្រសិនបើយើងស្មោះត្រង់ ហើយស៊ូទ្រាំនោះយើងនឹងឈ្នះលើលោកិយនេះ និង ព្រះនាមនៃ ព្រះយេស៊ូវគ្រីស្ទគឺពិសិដ្ឋ ហើយត្រូវតែនិយាយពីព្រះនាមនោះដោយប្រុងប្រយ័ត្ន ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩)

នៅពេលសិស្សបានសិក្សាពីព្រះបន្ទូលរបស់ព្រះអម្ចាស់ ចំពោះសមាជិកនៃសាសនាចក្រ ដែលមានអំពើបាប នោះពួកគេបានរៀនថា ព្រះអម្ចាស់ពេញដោយក្ដីសណ្ដោសប្រណី អត់ទោស និង ពេញដោយសេចក្ដីមេត្តាករុណា ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើង ពុំអភ័យទោសឲ្យមនុស្សដទៃទេ នោះយើងនឹងឈរដោយត្រូវបានកាត់ទោសនៅពោះព្រះអម្ចាស់ ហើយថាព្រះអម្ចាស់បានបញ្ជាយើងឲ្យ អភ័យទោសដល់មនុស្សទាំងអស់ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣)

នៅក្នុងមេរៀននេះ សិស្សបានរៀនអំពីការលះបង់ដែលព្រះអម្ចាស់តម្រូវពីពួកបរិសុទ្ធ នៅពេលពួកគេចាប់ផ្ដើមស្ថាបនាក្រុងស៊ីយ៉ូន ។ មេរៀននេះ បានគូសបញ្ជាក់ពី សេចក្ដីពិតខាងក្រោមនេះ ៖ ប្រសិនបើយើងធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់សម្រាប់ពួកយើង នោះយើង នឹងពុំត្រូវបានល្បួងហួសពីកម្លាំងដែលយើងអាចទប់ទល់ឡើយ យើងត្រូវបានប្រទានពរ នៅពេលយើងគោរពធ្វើតាមព្រះអម្ចាស់ ហើយធ្វើ ការលះបង់នានាដែលទ្រង់សុំពីយើង ប្រសិនបើយើងឧស្សាហ៍នៅក្នុងកិច្ចការល្អ នោះយើងអាចសម្រេចបាននូវការណ៍អស្ចារ្យជាច្រើន ហើយ យើងត្រូវតែគោរពតាមព្រះអម្ចាស់ដោយអស់ពីដួងចិត្ត និង បំណងនៃចិត្តយើង ។

## សេចក្ដីផ្ដើម

នៅក្នុងរដូវក្ដៅឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ គឺជាអ្នកមើលការខុសត្រូវលើការឧទ្ទិសឆ្លងទឹកដីដែលពួកបរិសុទ្ធត្រូវសាងសង់ ទីក្រុងស៊ីយ៉ូននៅក្នុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ។ អវត្តមានរបស់ព្យាការី បានធ្វើឲ្យសមាជិកសាសនាចក្រមួយចំនួននៅ រដ្ឋ អូហៃអូ បានងាកចេញពីបទបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរ ។ មេរៀននេះផ្ដោតលើព្រះបញ្ញត្តិមួយ ចំនួន ដែលព្រះអម្ចាស់បានគូសបញ្ជាក់ថា បន្ទាប់ពីយ៉ូសែប ស្ម៊ីធ បានត្រឡប់ទៅរដ្ឋអូហៃអូវិញ—រួមមានទាំងព្រះបញ្ញត្តិដើម្បី ចៀសវាងពីតម្រេកសម្រើបចង់បាន និង ការអភ័យទោសដល់មនុស្សដទៃ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១–២១

*ព្រះអម្ចាស់ព្រមានពួកបរិសុទ្ធអំពីផលវិបាកនៃសេចក្ដីទុច្ចរិត និង ការបះបោរ*

សូមសរសេរសំណួរខាងក្រោមនេះលើក្ដារខៀន ៖ *ហេតុអ្វីអ្នកគិតថាវាសំខាន់ ដែលយើងត្រូវរស់នៅឲ្យស្របតាមជំនឿរបស់យើងក្នុងនាមជា សមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ?* សូមអញ្ជើញសិស្សឲ្យចែកចាយចម្លើយរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមពន្យល់ថានៅក្នុងរដូវក្ដៅឆ្នាំ ១៨៣១ ខណៈដែលយ៉ូសែប ស៊្មីធ និង អ្នកដឹកនាំសាសនាចក្រដទៃទៀតស្ថិតនៅក្នុងរដ្ឋមិសសួរី ដើម្បីឧទ្ទិសឆ្លងទឹកដី និងទីតាំងព្រះវិហារបរិសុទ្ធនៅស៊ីយ៉ូន នោះមានសមាជិកសាសនាចក្រមួយចំនួនបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរដោយសម្ងាត់ ។ បន្ទាប់ពីព្យាការីបានត្រឡប់ទៅដល់រដ្ឋអូហៃអូវិញ នោះលោកបានទទួលវិវរណៈ ដែលបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៦៣ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលព្រះអម្ចាស់មានព្រះបន្ទូលអំពីសមាជិកសាសនាចក្រនៅក្នុងខគម្ពីរទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើ *ការហៅ* ខ្លួនយើងថាជារាស្ត្រនៃព្រះអម្ចាស់ ខុសគ្នាពី *ការធ្វើជា* រាស្ត្រនៃព្រះអម្ចាស់យ៉ាងដូចម្ដេច ? ( នៅពេលសិស្សពិភាក្សាពីសំណួរនេះ អ្នកអាចបង្ហាញថា ពួកបរិសុទ្ធជាច្រើនបានធ្វើអ្វីៗជាច្រើនទៀត ជាជាងគ្រាន់តែហៅខ្លួនគេថាជាព្រះរាស្ត្ររបស់ព្រះអម្ចាស់ ។ ពួកគេបន្តនៅស្មោះត្រង់ ) ។

សូមឲ្យសិស្សអាន ខ ១ ចុះឡើងម្ដងទៀត ហើយរកមើលការបញ្ជារបស់ព្រះអម្ចាស់ដល់អ្នកទាំងឡាយដែលហៅខ្លួនគេថាជារាស្ត្ររបស់ទ្រង់ ។

- តើព្រះអម្ចាស់មានព្រះទ័យឲ្យយើងធ្វើអ្វីខ្លះក្នុងនាមជារាស្ត្ររបស់ទ្រង់ ? ( សូមសង្ខេបចម្លើយរបស់សិស្សដោយការសរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ក្នុងនាមជារាស្ត្ររបស់ព្រះអម្ចាស់ នោះយើងបើកដួងចិត្តរបស់យើង ហើយស្ដាប់តាមព្រះបន្ទូល និងព្រះឆន្ទៈរបស់ទ្រង់ស្ដីអំពីយើង**) ។
- តើអ្នកគិតថាការបើកដួងចិត្តរបស់យើងមានន័យយ៉ាងដូចម្ដេច ?
- តើការបើកដួងចិត្តរបស់យើង រៀបចំយើងឲ្យស្ដាប់តាមសំឡេងរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- តើអ្នកធ្វើអ្វីខ្លះដើម្បីជួយអ្នកឲ្យបើកដួងចិត្តរបស់អ្នក ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២–២១ ដោយពន្យល់ថា ព្រះអម្ចាស់បានស្ដីបន្ទោសដល់អស់អ្នកដែលមិនជឿ ហើយបានព្យាយាមស្វែងរកទីសម្គាល់ ហើយបានប្រព្រឹត្តអំពើកំផិត និង អំពើបានធ្ងន់ធ្ងរដទៃទៀត ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការព្រមានមួយ ដែលព្រះអម្ចាស់បានប្រទានឲ្យ ។

- តើការព្រមានអ្វីដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុង ខ ១៦?
- តើវាមានន័យយ៉ាងណា ដែលក្រឡេកមើលនរណាម្នាក់ ហើយមានតម្រេកសម្រើបចង់បាន ? ( ពាក្យថា *តម្រេកសម្រើបចង់បាន* មានន័យថា « ការមានបំណងប្រាថ្នាដោយពុំត្រឹមត្រូវយ៉ាងលើសលប់ចំពោះអ្វីមួយ » ឬ នរណាម្នាក់ [ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ, « តម្រេកសម្រើបចង់បាន » scriptures.lds.org ] ។ ការមើលទៅនរណាម្នាក់ដោយមានតម្រេកសម្រើបចង់បាន មានន័យថាមើលទៅរូបរាងកាយរបស់នរណាម្នាក់ដោយពុំត្រឹមត្រូវ ឬតាមវិធីមួយដែលដាស់អារម្មណ៍ខាងផ្លូវភេទ ។ ការណ៍នេះជាប់ទាក់ទងនឹងការមើលការណ៍ភាពអាសគ្រាម ) ។
- តើមានគោលការណ៍អ្វីខ្លះដែលអ្នកមើលឃើញនៅក្នុងការព្រមានរបស់ព្រះអម្ចាស់ នៅក្នុង ខ ១៦? ( សិស្សអាចប្រើពាក្យផ្សេងទៀត ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងមើលទៅនរណាម្នាក់ដោយតម្រេកសម្រើបចង់បាន នោះយើងនឹងគ្មានព្រះវិញ្ញាណ ហើយយើងនឹងបដិសេធសេចក្ដីជំនឿ** ។ អ្នកអាចអញ្ជើញសិស្សឲ្យគូសចំណាំគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។
- ហេតុអ្វីក៏អ្នកគិតថា ការមានតម្រេកសម្រើបចង់បានចំពោះនរណាម្នាក់ បណ្ដាលឲ្យមនុស្សម្នាក់នោះបាត់បង់ព្រះវិញ្ញាណយ៉ាងដូច្នេះ ?
- តើយើងអាចយកឈ្នះលើការល្បួងនៃតម្រេកសម្រើបចង់បានចំពោះអ្នកដទៃយ៉ាងដូចម្ដេច ?

ជាចំណែកនៃការពិភាក្សាអំពីការចៀសវាងពីតម្រេកសម្រើបចង់បាន អ្នកអាចឲ្យច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍ខាងក្រោមដល់សិស្សម្នាក់ៗដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានកថាខណ្ឌទាំងនោះឲ្យឮៗ ។ បន្ទាប់ពីអានកថាខណ្ឌនិមួយៗចប់ហើយ សូមសួរសិស្សឲ្យពន្យល់ពីរបៀបដែលការទូន្មានខាងក្រោមនេះ អាចជួយយើងឲ្យយកឈ្នះលើការល្បួងនៃតម្រេកសម្រើបចង់បាននេះ ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន បានបង្រៀនថា ៖



« សំខាន់បំផុតនោះ ចាប់ផ្តើមដោយការញែកខ្លួនអ្នកចេញពីមនុស្ស សម្ភារ និងស្ថានភាពនានាដែលនឹងគ្រោះថ្នាក់ដល់អ្នក ។. . .

« . . . ប្រសិនបើឃើញកម្មវិធីទូរទស្សន៍មិនត្រឹមត្រូវនោះសូមបិទវា ។ ប្រសិនបើខ្សែភាពយន្តពុំស្អាតស្អំទេ នោះសូមដើរចេញ ។ ប្រសិនបើទំនាក់ទំនងមិនត្រឹមត្រូវកើតមានឡើង សូមបញ្ចប់ទំនាក់ទំនងនោះ ។ យ៉ាងហោចណាស់នៅគ្រាដំបូងឡើយ ឥទ្ធិពលទាំងនេះអាចនឹងមិនអាក្រក់ខ្លាំងទេ ប៉ុន្តែវាអាចនឹងធ្វើឲ្យរក់រឺដល់ការវិនិច្ឆ័យរបស់យើង ធ្វើឲ្យជីវភាពខាងវិញ្ញាណរបស់យើងស្រអាប់ ហើយដឹកនាំទៅរកអ្វីមួយដែលអាចនឹងអាក្រក់ ។

« សូមជំនួសគំនិតតម្រេកសម្រើបដោយរូបភាពនៃក្តីសង្ឃឹម និងអានុស្សាវរីយ៍ប្រកបដោយក្តីអំណរ រូបភាពនៃទឹកមុខរបស់អ្នកទាំងឡាយដែលអ្នកស្រឡាញ់ ថាអ្វីៗទាំងនោះនឹងត្រូវបំផ្លាញបង់ ប្រសិនបើអ្នកបណ្តែតបណ្តោយខ្លួនតាមតណ្ហាបែបនេះ ។. . . មិនថាអ្នកមានគំនិតអ្វីនោះទេ សូមប្រាកដថា វាស្វាគមន៍មកក្នុងចិត្តរបស់អ្នកដោយការអញ្ជើញតែប៉ុណ្ណោះ ។

« សូមបណ្តុះវាឡើង និងនៅកន្លែងដែលមានព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ សូមប្រាកដថាគេហដ្ឋាន ឬផ្ទះជួលរបស់អ្នកផ្ទាល់មាននូវប្រភេទនៃតន្ត្រី សិល្បៈ និងអក្សរសាស្ត្រដែលរក្សាការពារអ្នកនៅទីនោះ » (Place No More for the Enemy of My Soul » *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៤៥, ៤៦ ) ។

សូមសួរប្រសិនបើមានសិស្សណាមានបំណងចង់ ចែកចាយទីបន្ទាល់របស់ពួកគេអំពីរបៀបដែលពួកគេបានទទួលពរជ័យចំពោះកិច្ចខិតខំរបស់ខ្លួន ដើម្បីរស់នៅតាមច្បាប់ព្រហ្មចារីភាព ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៦៤:៨–១៩

### *ព្រះអម្ចាស់បញ្ជាពួកអ្នកបម្រើទ្រង់ឲ្យអភ័យទោសដល់គ្នាទៅវិញទៅមក*

សូមរំឭកសិស្សអំពីការចាត់តាំងរបស់ពួកគេពីថ្ងៃទី ៣នៃមេរៀននេះ ដើម្បីព្យាយាមទន្ទេញ គោលលទ្ធិ និង សេចក្តីសញ្ញា ៦៤:៩–១១, ដែលជាវគ្គចំណេះចំណាខគម្ពីរមួយ ។ សូមអញ្ជើញសិស្សឲ្យទន្ទេញខគម្ពីរទាំងនេះឲ្យឮៗជាមួយគ្នា ។ ( សិស្សអាចមើលគម្ពីររបស់ខ្លួនសម្រាប់ជាជំនួយ ) ។ សូមសួរ ប្រសិនបើមានសិស្សដែលចង់សូត្រខគម្ពីរទាំងនេះឲ្យឮៗដោយខ្លួនឯងដល់សិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។ សូមសរសេរព្រះបញ្ញត្តិខាងក្រោមនៅលើក្តារខៀន ៖ **ព្រះអម្ចាស់ចេញបញ្ជាដល់យើងឲ្យអភ័យទោសដល់មនុស្សគ្រប់គ្នា ។**

- ហេតុអ្វីអ្នកគិតថាវាសំខាន់ដើម្បីអភ័យទោសមនុស្សទាំងអស់ មិនថាពួកគេមកសុំអភ័យទោសចំពោះកំហុសរបស់ពួកគេឬអត់នោះ ?
- តើវាជួយយើងដើម្បីទុកឲ្យព្រះ ជាអង្គជំនុំជម្រះដល់អស់អ្នកដែលធ្វើឲ្យយើងឈឺចាប់យ៉ាងដូចម្តេច ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថាបានទទួលពរ ដោយសារតែការអភ័យទោសឲ្យនរណាម្នាក់នោះ ?

សូមចង្អុលបង្ហាញថា ពេលខ្លះយើងមានឆន្ទៈអភ័យទោសឲ្យមនុស្សដទៃ ប៉ុន្តែយើងលំបាកដើម្បីអភ័យទោសឲ្យខ្លួនឯង ។

- ហេតុអ្វីក៏យើងត្រូវអភ័យទោសឲ្យខ្លួនឯង ?

សូមចង្អុលបង្ហាញទៅគោលការណ៍ទីមួយដែលអ្នកសរសេរនៅលើក្តារខៀន នៅពេលចាប់ផ្តើមថ្នាក់រៀន ៖ **ក្នុងនាមជារាស្ត្ររបស់ព្រះអម្ចាស់ យើងត្រូវបើកដួងចិត្តរបស់យើង និងស្តាប់ព្រះបន្ទូលរបស់ទ្រង់ និងព្រះទ័យរបស់ទ្រង់ចំពោះយើង ។** សូមអញ្ជើញសិស្សឲ្យគិតថា តើដួងចិត្តរបស់ពួកគេបើកចំហរចំពោះការបំផុសគំនិត ឬចំណាប់អារម្មណ៍អំឡុងការសិក្សាអំពីព្រះគម្ពីរនាថ្ងៃនេះរបស់ពួកគេដែរឬទេ ។ សូមលើកទឹកចិត្តពួកគេធ្វើសកម្មភាពតាមការបំផុសគំនិត និងចំណាប់អារម្មណ៍ដែលពួកគេបានទទួលមកពីព្រះអម្ចាស់ ហើយថ្លែងទីបន្ទាល់ថានៅពេលពួកគេធ្វើដូច្នោះ នោះពួកគេនឹងក្លាយជារាស្ត្ររបស់ព្រះអម្ចាស់ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៧១)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួន អំឡុងពេលនៃសប្ដាហ៍នេះ អ្នកក៏អាចអញ្ជើញពួកគេឲ្យពិចារណាពីសំណួរខាងក្រោម ៖ តើថ្មមួយអាចរមៀលចេញទៅរហូតដល់បានពេញផែនដីទាំងមូលបានយ៉ាងដូចម្ដេច ? តើព្រះអម្ចាស់ស្គាល់យើងម្នាក់ៗយ៉ាងច្បាស់ដោយរបៀបណា ? ហេតុអ្វីឪពុកម្ដាយមានកាតព្វកិច្ចជាទម្ងន់ ដើម្បីបង្រៀនដំណឹងល្អដល់កូនចៅរបស់ខ្លួន ? តើមានលទ្ធផលអ្វីខ្លះកើតឡើងដល់ឪពុកម្ដាយដែលពុំបានធ្វើការណ៍នោះ ? សូមប្រាប់ដល់សិស្សជាមុនថា អំឡុងពេលនៃការសិក្សាព្រះគម្ពីររបស់ពួកគេនៅសប្ដាហ៍នេះ នោះពួកគេនឹងរកឃើញចម្លើយចំពោះសំណួរទាំងនេះ ។

មេរៀនទី ៧១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥

## បុព្វកថា

នៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ និងគ្រួសាររបស់លោក បានផ្លាស់ពីខឺតឡង់មក រដ្ឋ អូហៃអូ ទៅ ហៃរុម រដ្ឋ អូហៃអូ មានចម្ងាយប្រហែលជា ៣០ ម៉ែលភាគអាគ្នេយ៍នៃទីក្រុងខឺតឡង់ ។ ពួកគេបានធ្វើការផ្លាស់លំនៅនេះ ក្នុងការឆ្លើយតបចំពោះការទូន្មានមកពីព្រះអម្ចាស់ ( សូមមើល គ. និង ស. ៦៣:៦៥) ។ ព្យាការី និងគ្រួសាររបស់លោក បានផ្លាស់ទៅរស់នៅជាមួយគ្រួសារ យ៉ូហាន និង អាលីស ចនសុន ដែលជាអ្នកផ្លាស់ប្រែចិត្តជឿសាសនាចក្រថ្មី ។ មូលហេតុចម្បងមួយនៃការផ្លាស់លំនៅពីទីក្រុងខឺតឡង់ គឺដើម្បីទៅធ្វើកិច្ចការ ការបកប្រែព្រះគម្ពីរប៊ីបដ៏បំផុសគំនិតបន្ត ។ ពេលនៅភូមិ ហៃរ៉ាំ យ៉ូសែប បាន ចាប់ផ្ដើមកិច្ចការនោះ ។ នៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ បាន ទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបង្រៀនថា ដំណឹងល្អនឹងចេញទៅគ្រប់ ជាតិសាសន៍ក្នុងការរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ហើយថាពួកបរិសុទ្ធគឺត្រូវអធិស្ឋានសុំឲ្យមានការរីកចម្រើនដល់នគររបស់ព្រះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥

*ព្រះអម្ចាស់ប្រកាសថា ដំណឹងល្អនឹងបំពេញនៅលើផែនដីទាំងមូល*

សូមអញ្ជើញសិស្សឲ្យសរសេរក្នុងសៀវភៅកំណត់ត្រាក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ នូវរឿង ដែលពួកគេបានអធិស្ឋានសុំជាទៀងទាត់ ។ អ្នកអាចសុំដល់សិស្សពីរបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេបានសរសេរទុក បើពួកគេមានអារម្មណ៍ថាចង់ចែកចាយវា។

សូមអញ្ជើញឲ្យសិស្សម្នាក់អាននូវការណែនាំ នៃក្បាលកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ ឲ្យឮៗ ។ សូមពន្យល់ថា នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រាប់យើងពីអ្វីមួយដែលយើងគួរអធិស្ឋានសុំ–ជាពិសេស នៅពេលយើងធ្វើជាសាក្សីនៃការ បំពេញព្រឹត្តការណ៍ដែលបានព្យាករថានឹងកើតឡើងនៅថ្ងៃចុងក្រោយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើល របៀបដែលព្រះអម្ចាស់បានពិពណ៌នាអំពីការផ្សាយដំណឹងល្អ ។

- តើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនឹងទៅដល់កន្លែងណាខ្លះ ? ( សិស្សគួរតែរកឃើញនូវគោលលទ្ធិខាងក្រោម **៖ដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ នឹងចេញទៅដល់ចុងផែនដីនេះ** ។ សូមសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។

- ស្របតាម ខ ២ តើព្រះអម្ចាស់ « ផ្ទុកផ្ដាក់ដល់មនុស្ស » មានអ្វីខ្លះ ដើម្បីអាចឲ្យដំណឹងល្អបានមានពេញលើផែនដី ទាំងមូល ? ( កូនសោនៃនគរនៃព្រះ ។ អ្នកអាចនឹងចាំបាច់ត្រូវរំឭកដល់សិស្សថា ឃ្លា « កូនសោនៃនគរ » សំដៅទៅលើ សិទ្ធិអំណាចបព្វជិតភាព ដើម្បីធ្វើជាអធិបតីនៅក្នុងសាសនាចក្រ ។ ដោយកូនសោទាំងនេះ ប្រធាន នៃសាសនាចក្រ ដឹកនាំកិច្ចខិតខំរបស់យើងដើម្បីផ្សាយដំណឹងល្អ ។ ទ្រង់បានផ្ទេរកូនសោមួយចំនួនដល់អ្នកដឹកនាំទូទៅ និងអ្នកដឹកនាំ បព្វជិតភាពក្នុងមូលដ្ឋាន ) ។

សូមដាក់បង្ហាញរូបភាពដានីយ៉ែល បកស្រាយសុបិនរបស់ នេប៊ូក្នេសា (*សៀវភៅសិល្បៈដំណឹងល្អ* [ឆ្នាំ ២០០៩ ], ទំព័រ ២៤, សូមមើលផងដែរ LDS.org) ។ សូមអញ្ជើញ សិស្សឲ្យពន្យល់ពីអ្វីដែលពួកគេដឹងអំពីការបកស្រាយរបស់ ដានីយ៉ែល អំពីសុបិនរបស់ស្ដេច នេប៊ូក្នេសា ។ ( អ្នកអាច ពិចារណាធ្វើការអាន ឬសង្ខេប ដានីយ៉ែល ២:៣១–៤៥។ សូមជួយសិស្សឲ្យយល់ថា ស្ដេចនេប៊ូក្នេសា ត្រូវបានស្អុតស្មាញ ដោយសុបិនមួយ ហើយថាព្រះអម្ចាស់បានបើកបង្ហាញសុបិន និងអត្ថន័យរបស់វាដល់ដានីយ៉ែល ។ នៅក្នុងសុបិន មានរូប ដ៏ធំមួយ ដែលតំណាងឲ្យនគរខាងនយោបាយផ្សេងៗគ្នា



***សូមធ្វើបទបង្ហាញ មេរៀនដ៏គួរឲ្យចាប់អារម្មណ៍ មានការទាក់ទងគ្នា និង មានការស្អាងឡើង ។***

នៅពេលអ្នករៀបចំ និងធ្វើបទបង្ហាញ មេរៀនដែលមានការ ស្អាងឡើងឲ្យបានជាប់លាប់ នោះ សិស្សនឹងបង្កើនការរំពឹងទុកមួយថា ពួកគេនឹងរៀនអ្វីមួយ ដែលមានតម្លៃ គ្រប់ពេល ដែលពួកគេចូលរួមក្នុង ថ្នាក់ ។ ប្រធាន ប៊ីយដ៏ យេ ផាកកឺ បាន បង្រៀនថា សិស្ស « នឹងមិនត្រឡប់មក [ថ្នាក់រៀន] វិញដោយមានចិត្ត ភ្លៀវភ្លានោះទេ លើកលែងតែពួកគេ ត្រូវបានបង្រៀនអ្វីមួយពីថ្នាក់នេះ ។ ពួកគេត្រូវតែបានរៀនអ្វីមួយ ដែលធ្វើ ឲ្យចង់ត្រឡប់មកវិញ ។ ពួកគេនឹង មកកាន់ថ្នាក់មួយដោយស្ម័គ្រចិត្ត ដោយ សេចក្ដីស្រេកឃ្លាន . . . ចំពោះអ្វីដែល ពួកគេត្រូវបានផ្ដល់ឲ្យ » (*Teach Ye Diligently* [ ឆ្នាំ ១៩៧៥ ], ទំព័រ ១៥៣–៥៤ ) ។

ត្រូវបានបំផ្លាញដោយថ្មមួយ ដែលបានកាត់ផ្ដាច់ពីភ្នំ ឥតដៃណាធ្វើ ។ ថ្មបានផ្ដើមរីកពីតូចទៅធំ រហូតដល់វាមានពេញផែនដីទាំងមូល ) ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:២ តើថ្មដែលកាត់ចេញពីភ្នំដោយឥតដៃណាធ្វើ នោះគឺជាអ្វី ? ( នគរនៃព្រះ ។ សូមពន្យល់ថា នៅក្នុងខគម្ពីរនេះ ឃ្លា « នគរនៃព្រះ » សំដៅទៅលើនគរនៃព្រះនៅលើផែនដី– សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ អ្នកអាចផ្ដល់យោបល់ថា សិស្សសរសេរការពន្យល់នេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ខ ២ ) ។

បើអាចធ្វើទៅបាន សូមផ្ដល់ឲ្យសិស្សនូវសេចក្ដីថ្លែងការណ៍មួយច្បាប់ដូចខាងក្រោម ដើម្បីពួកគេអាចដាក់វានៅក្នុងគម្ពីររបស់ពួកគេ ។ បើនេះមិនអាចធ្វើបានទេ អ្នកអាចនឹងសរសេរសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ពីមុនថ្នាក់រៀន ហើយអញ្ជើញសិស្សឲ្យសរសេរវានៅក្នុងសៀវភៅកំណត់ត្រាក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍នេះឲ្យឮៗ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានថ្លែងថា ៖



« យើងគឺជាពលរដ្ឋនៅក្នុងនគរដ៏ធំបំផុតនៅលើផែនដី–ជានគរមួយដែលពុំត្រូវបានដឹកនាំដោយប្រាជ្ញាមនុស្សឡើយ ប៉ុន្តែបានដឹកនាំដោយព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។ វត្តមានរបស់នគរគឺមានពិតមែន ។ ជោគវាសនារបស់នគរ គឺមានជាក់ ។ នេះគឺជានគរដែលព្យាការី ដានីយ៉ែល បានថ្លែង– ថ្មមួយដុំ ដែលគួរតែត្រូវបានកាត់ផ្ដាច់ពីភ្នំដោយឥតដៃណាធ្វើ ហើយរមៀលចេញទៅ រហូតដល់បានពេញផែនដីទាំងមូល ។ ( សូមមើល ដានី. ២:៣៤–៣៥) ។

« គ្មានមនុស្សរមែងស្លាប់ណាម្នាក់ បានបង្កើតនគរនេះឡើយ » (Pillars of Truth »*Ensign* ខែ មករា ឆ្នាំ ១៩៩៤ ទំព័រ ៤ ) ។

- តើមានភស្ដុតាងអ្វីខ្លះដែលអ្នកបានឃើញថា ការព្យាករណ៍របស់ដានីយ៉ែល ត្រូវបានបំពេញនៅសព្វថ្ងៃនេះ ?
- តើភស្ដុតាងនេះ ជួយពង្រឹងដល់ទីបន្ទាល់របស់អ្នកអំពី សាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយយ៉ាងដូចម្ដេច ?
- តើវាមានន័យយ៉ាងណា ដែលអ្នកត្រូវមានចំណែកនៃនគររបស់ព្រះនៅលើផែនដី ?

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយអែលឌើរ នែល អិល អាន់ឌើរសិន កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ពីមុនអ្នកអាន សូមប្រាប់ដល់សិស្សថា អ្នកនឹងបញ្ឈប់ការអាននៅពាក់កណ្ដាលនៃប្រយោគចុងក្រោយនៃសេចក្ដីថ្លែងការណ៍ ។ សូមពួកគេឲ្យស្ដាប់ដោយយកចិត្តទុកដាក់ ហើយគិតអំពីរបៀបដែលពួកគេអាចបញ្ចប់ប្រយោគចុងក្រោយ ។



« តើអ្នកធ្លាប់គិតអំពីមូលហេតុ ដែលអ្នកត្រូវបានបញ្ជូនឲ្យមកកើតនៅលើផែនដីនៅជំនាន់ដ៏ពិសេសនេះដែរឬទេ ? អ្នកពុំកើតមកអំឡុងជំនាន់របស់អ័ដាម និង អេវ៉ា ឬនៅពេលដែល ផារ៉ោន បានគ្រប់គ្រងលើប្រទេសអេស៊ីព្ទ ឬអំឡុងពេល រាជវង្ស មីងនោះទេ ។ អ្នកបានមកកាន់ផែនដីនៅគ្រានេះ ២០ សតវត្សរ៍ បន្ទាប់ពីការយាងមករបស់ព្រះគ្រីស្ទពីដំបូង ។ បព្វជិតភាពរបស់ព្រះ ត្រូវបានស្ដារឡើងវិញនៅលើផែនដី ហើយព្រះអម្ចាស់បានដាក់ព្រះហស្តទ្រង់រៀបចំពិភពលោកសម្រាប់ការត្រឡប់មកវិញដ៏រុងរឿងរបស់ទ្រង់ ។ ទាំងនេះ គឺជាបណ្ដាពេលវេលានៃឱកាស និងការទទួលខុសត្រូវទាំងឡាយដ៏សំខាន់ ។ ទាំងនេះ គឺជាពេលវេលារបស់អ្នក ។. . . ទំនួលខុសត្រូវសំខាន់មួយរបស់អ្នក គឺត្រូវ . . . » (Preparing the World for the Second Coming,» *Ensign* ឬ *លីអាហូណា,* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ៤៩ ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យនិយាយអំពីរបៀបដែលពួកគេនឹងបំពេញប្រយោគចុងក្រោយនៃសេចក្ដីថ្លែងការណ៍របស់អែលឌើរ អាន់ឌើរសិន ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលបញ្ញារបស់ព្រះអម្ចាស់ចំពោះយើង ក្នុងនាមជាសមាជិកនៃនគររបស់ទ្រង់ ។

- តើវាមានន័យយ៉ាងណា ដែលយើងត្រូវរៀបចំផ្លូវទទួលព្រះអម្ចាស់ និងរៀបចំភោជនាអាហារទទួលកូនចៀម ហើយរៀបចំជាស្រេចចាំប្ដីថ្មោងថ្មីនោះ ? ( ឃ្លាទាំងនេះសំដៅទៅលើទំនួលខុសត្រូវដើម្បីរៀបចំពិភពលោកសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ) ។

សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **យើងមានទំនួលខុសត្រូវមួយដើម្បីត្រៀមខ្លួនយើង និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។** អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសរសេរសេចក្ដីពិតនេះនៅក្នុងគម្ពីររបស់ពួកគេជិត គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៣) ។ សូមពន្យល់ថា អែលឌើរ នែល អិល អាន់ឌើរសិន ថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនេះ ។ សូមអានការបំពេញប្រយោគចុងក្រោយចេញមកពីសេចក្ដីថ្លែងការណ៍របស់លោក ៖ « ការទទួលខុសត្រូវដ៏សំខាន់មួយរបស់អ្នក គឺត្រូវជួយរៀបចំពិភពលោកសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ » (Preparing the World, » ទំព័រ ៤៩ ។

- នៅពេលអ្នកគិតអំពីទំនួលខុសត្រូវរបស់អ្នកដើម្បីរៀបចំខ្លួន និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីរ តើអ្នកមានគំនិត និងអារម្មណ៍យ៉ាងណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលយើងអាចធ្វើដើម្បីរៀបចំខ្លួនយើង និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីរ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើយើងអាច «ប្រកាសប្រាប់ពីកិច្ចការដ៏អស្ចារ្យ [របស់ទ្រង់] នៅក្នុងចំណោមប្រជាជន » តាមវិធីណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៥–៦ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ឲ្យរកមើលនូវអ្វីដែលយើងគួរអធិស្ឋានសុំ ។

- ស្របតាមខគម្ពីរទាំងនេះ តើយើងគួរអធិស្ឋានសម្រាប់អ្វីខ្លះ នៅពេលយើងរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ? ( នៅពេលសិស្សឆ្លើយតបចំពោះសំណួរនេះ អ្នកអាចអញ្ជើញពួកគេឲ្យប្រៀបធៀប ខ ៦ ជាមួយនឹងពាក្យនៃការអធិស្ឋានរបស់ព្រះអម្ចាស់នៅក្នុង ម៉ាថាយ ៦:១០) ។
- តើការអធិស្ឋានសម្រាប់រឿងទាំងនេះ ជួយយើងរៀបចំខ្លួនយើង និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយ ប្រធាន ថូម៉ាស អេស ម៉នសុន ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកអ្វីមួយដែលយើងគួរតែដាក់បញ្ចូលទៅក្នុងការអធិស្ឋានរបស់យើង ។



« ខ្ញុំស្នើសុំឱ្យសេចក្ដីជំនឿ និងការអធិស្ឋានរបស់អ្នកបន្ដធ្វើឡើង ដល់គ្រប់តំបន់ទាំងឡាយ ដែលឥទ្ធិពលរបស់ យើងនៅមានកំណត់ ហើយនៅកន្លែងដែលយើងពុំត្រូវអនុញ្ញាត ឱ្យចែកចាយដំណឹងល្អដោយសេរីក្នុងពេលនេះ។ អព្ភូតហេតុទាំងឡាយនឹងកើតឡើងប្រសិនបើយើងធ្វើដូច្នេះ » (Welcome to Conference » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៩, ទំព័រ ៦ ) ។

- ស្របតាមប្រធាន ម៉នសុន តើយើងគួរអធិស្ឋានសុំអ្វីខ្លះ ? តើការអធិស្ឋានទាំងនេះ ជួយរៀបចំផ្លូវសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សក្នុងថ្នាក់ត្រឡប់ទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:១–២ ហើយសុំឲ្យសិស្សម្នាក់អានខគម្ពីរទាំងនេះឮៗ ។

- តើយើងចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ដើម្បីបំពេញផែនដីដោយដំណឹងល្អរបស់ទ្រង់តាមវិធីណា ? ( នៅពេលសិស្សឆ្លើយតបចំពោះសំណួរនេះ សូមជួយពួកគេឲ្យមើលឃើញថា ពួកគេអាចចូលរួមនៅក្នុងកិច្ចការនេះជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ ក៏សូមជួយពួកគេឲ្យមើលឃើញថា ពួកគេចូលរួមក្នុងកិច្ចការនេះឥឡូវ តាមរយៈឥទ្ធិពលរបស់ពួកគេនៅក្នុងគេហដ្ឋាន វួដ និងសាខា សាលារៀន និងសហគមន៍របស់ពួកគេ ) ។

សូមលើកទឹកចិត្តសិស្សឲ្យត្រៀមខ្លួន និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីរ ។

មេរៀនទី ៧២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦

## បុព្វកថា

បន្ទាប់ពី វិលាម អ៊ី ម៉ុកខ្លេលិន បានទទួលបុណ្យជ្រមុជទឹកនៅរដូវក្ដៅឆ្នាំ ១៨៣១ គាត់បានទទួលការហៅឲ្យផ្សាយដំណឹងល្អ ។ នៅក្នុងខែតុលា គាត់បានធ្វើដំណើរទៅរដ្ឋ អូហៃអូ ដើម្បីចូលរួមក្នុងសន្និសីទនៃសាសនាចក្រ ។ នៅទីនោះ គាត់បានជួបនឹងព្យាការី យ៉ូសែប ស្ម៊ីធ ហើយនៅថ្ងៃទី ២៩ ខែតុលា ឆ្នាំ ១៨៣១ គាត់បានសុំឲ្យ យ៉ូសែប ស្ម៊ីធ ទូលសុំដល់ព្រះអម្ចាស់ជំនួសគាត់ ។ ចម្លើយចំពោះសំណើរនេះ ព្រះអម្ចាស់បានប្រទានដល់ យ៉ូសែប ស្ម៊ីធ នូវវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦ ។ វិវរណៈនេះ មាននូវការប្រឹក្សាជាក់លាក់អំពីជំហរខាងវិញ្ញាណរបស់បងប្រុស ម៉ុកខ្លេលិន ក្នុងការហៅឲ្យផ្សាយដំណឹងល្អ និងសក្ដានុពលរបស់គាត់ដើម្បីទទួលពរជ័យមហិមាជាច្រើន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១–៣

*ព្រះអម្ចាស់បានប្រកាសថា វិលាម អ៊ី ម៉ុកខ្លេលិន ត្រូវបានប្រទានពរ ដោយសារតែគាត់បានទទួលដំណឹងល្អ*

មុនចាប់ផ្ដើមថ្នាក់ សូមគូរឌីយ៉ាក្រាមខាងក្រោមនៅលើក្ដារខៀន ។

←——————————————————→

ឃ្លាតឆ្ងាយពីព្រះ　　　　　　　　　　　　　　　　ខិតជិតព្រះ

> ***ការប្រើក្ដារខៀនដី–ស ឬក្ដារខៀន***
>
> សូមប្រើក្ដារខៀនដីស ឬក្ដារខៀន ឲ្យមានប្រសិទ្ធភាព អំឡុងពេលបង្រៀន អាចរៀបចំសិស្សឲ្យរៀន និងអញ្ជើញឲ្យមានការចូលរួម ប្រកបដោយ អត្ថន័យជាពិសេស សម្រាប់អ្នកទាំងឡាយណាដែលចង់រៀនដោយការមើលរូបភាព ។

នៅពេលថ្នាក់ចាប់ផ្ដើម សូមអញ្ជើញសិស្សឲ្យពិនិត្យមើលឌីយ៉ាក្រាមនៅលើក្ដារខៀន ។ សូមឲ្យពួកគេពិចារណាដោយស្ងាត់ស្ងៀមពីកន្លែង ដែលពួកគេនឹងដាក់ខ្លួនពួកគេនៅលើរូបនោះ ។ សូមផ្ដល់យោបល់ផងដែរថា ពួកគេពិចារណាអំពីទិសដៅដែលពួកគេត្រូវផ្លាស់ទី—ទៅកាន់តែជិតនឹងព្រះ ឬទៅកាន់តែឆ្ងាយពីទ្រង់ ។ បន្ទាប់មកអញ្ជើញសិស្សម្នាក់អានឲ្យឮនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកវិធីដែលយើងអាចខិតទៅកាន់តែជិតនឹងព្រះ ។



« ប្រសិនបើអ្នកចង់នៅជិតនឹងនរណាម្នាក់ដែលអ្នកស្រឡាញ់ ប៉ុន្តែជាអ្នកដែលនៅបែកពីអ្នក នោះអ្នកដឹងថាត្រូវធ្វើយ៉ាងណាហើយ ។ អ្នកនឹងរកវិធីមួយដើម្បីនិយាយនឹងពួកគេ អ្នកនឹងស្ដាប់ពួកគេ ហើយអ្នកនឹងរកឃើញដំណោះស្រាយធ្វើរឿងទាំងឡាយសម្រាប់គ្នាទៅវិញទៅមក ។ កាលណាវាកើតឡើងកាន់តែញឹកញាប់ ហើយបន្តទៅកាន់តែយូរ នោះចំណងនៃសេចក្ដីស្រឡាញ់នឹងមានកាន់តែជ្រាលជ្រៅ ។ ប្រសិនបើពេលវេលាជាច្រើនបានកន្លងផុតទៅដោយគ្មានការនិយាយ ការស្ដាប់ និងធ្វើអ្វីបន្តិចសោះនោះ នោះចំណងទំនាក់ទំនងនឹងត្រូវទន់ខ្សោយ ។

« ព្រះគឺល្អឥតខ្ចោះ ព្រមទាំងមានគ្រប់ព្រះចេស្ដា ហើយអ្នក និងខ្ញុំ គឺជាមនុស្សរមែងស្លាប់ ។ ប៉ុន្តែទ្រង់គឺជាព្រះបិតារបស់យើង ទ្រង់ស្រឡាញ់យើង ហើយទ្រង់ប្រទានឱកាសដូចគ្នានេះ ដើម្បីឲ្យយើងខិតទៅកាន់តែជិតនឹងទ្រង់ ក៏ដូចជាមិត្តម្នាក់ដែរ ។ ហើយអ្នកនឹងធ្វើវាតាមរបៀបដែលស្រដៀងគ្នានេះ ៖ ការនិយាយ ការស្ដាប់ និងការធ្វើ » (« To Draw Closer to God » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩១ ទំព័រ ៦៦ ) ។

- ស្របតាមប្រធាន អាវរិង តើយើងអាចខិតទៅកាន់តែជិតព្រះយ៉ាងដូចម្ដេច ? តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីនិយាយ ស្ដាប់ និងធ្វើនោះ ?

សូមពន្យល់ថា នៅជំនាន់មុនក្នុងសាសនាចក្រ មានបុរសម្នាក់ឈ្មោះ វិលលាម អ៊ី ម៉ុកខ្លេលិន បានខិតទៅកាន់តែជិតព្រះនៅពេលគាត់បានរៀនអំពីការស្ដារឡើងវិញនៃដំណឹងល្អ ។ លោកបានជ្រមុជទឹកនៅថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៨៣១ ។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ លោកត្រូវបានតែងតាំងជាអែលឌើរ ហើយគាត់បានរួមដំណើរជាមួយ ហៃរ៉ុម ស្ម៊ីធ ពីរបីសប្ដាហ៍ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។ នៅខែតុលា ឆ្នាំ ១៨៣១ គាត់ធ្វើដំណើរទៅរដ្ឋ អូហៃអូ សម្រាប់សន្និសីទរបស់សាសនា

ចក្រ ។ ខណៈពេលនៅទីនោះ គាត់បានជួបនឹង ព្យាការីយ៉ូសែប ស្ម៊ីធ ។ នៅខែតុលា ថ្ងៃទី ២៩ បងប្រុស ម៉ុកខ្លេលិន បាន អធិស្ឋានជាសម្ងាត់ ទូលសុំដល់ព្រះអម្ចាស់ឲ្យបើកសម្ដែងចម្លើយចំពោះសំណួរជាក់លាក់ចំនួនប្រាំរបស់គាត់ តាមរយៈ យ៉ូសែប ស្ម៊ីធ ។ ដោយពុំបានប្រាប់អំពីសំណួរដល់ យ៉ូសែប ស្ម៊ីធ នោះបងប្រុស ម៉ុកខ្លេលិន បានស្នើសុំវិវរណៈមួយ ។ នៅពេលព្យាការី បានសរសេរវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦ បងប្រុស ម៉ុកខ្លេលិន បានរកឃើញថា សំណួរនិមួយៗ របស់គាត់ត្រូវបានឆ្លើយតប ។ ព្រះអម្ចាស់បានប្រទានដល់លោកនូវការណែនាំ និងការព្រមានដើម្បីជួយលោកឲ្យនៅស្មោះត្រង់ និងទទួលបានជីវិតដ៏អស់កល្បជានិច្ចនៅទីបំផុត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើល មូលហេតុ ដែលព្រះអម្ចាស់បានប្រទានពរដល់បងប្រុស ម៉ុកខ្លេលិន នៅអំឡុងវិវរណៈនេះ ។

- ហេតុអ្វីក៏បងប្រុសម៉ុកខ្លេលិន អាចទទួលបានពរជ័យមកពីព្រះអម្ចាស់ ? ( ដោយសារលោកបានងាកចេញពីអំពើបាប របស់ខ្លួន បានទទួលសេចក្ដីពិតរបស់ព្រះអម្ចាស់ ហើយបានទទួលភាពពេញលេញនៃដំណឹងល្អ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:៣ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះអម្ចាស់បានមាន បន្ទូលថា បងប្រុស ម៉ុកខ្លេលិន នៅតែចាំបាច់ត្រូវធ្វើ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ស្អាតហើយ ប៉ុន្តែពុំមែនទាំងអស់ទេ » នោះ ? ( អ្នកអាចនឹងចាំបាច់ត្រូវជួយ សិស្សឲ្យយល់ថា ទោះបីជាបងប្រុស ម៉ុកខ្លេលិន បានធ្វើការរីកចម្រើនយ៉ាងខ្លាំងក្ដី ហើយត្រូវបានប្រទានពរចំពោះកិច្ចខិតខំ របស់លោកក្ដី ក៏លោកនៅតែចាំបាច់ត្រូវប្រែចិត្ត ពីអំពើបាបមួយចំនួនទៀតផងដែរ ) ។

- តើយើងអាចរៀនអ្វីខ្លះមកពីព្រះឱវាទរបស់ព្រះអម្ចាស់នៅក្នុង ខ ៣? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាង ក្រោម ៖**យើងត្រូវបានបញ្ជាឲ្យប្រែចិត្តពីអំពើបាបរបស់យើងទាំងអស់** ។ សូមសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។

- ហេតុអ្វីក៏វាសំខាន់ដើម្បីប្រែចិត្តពីអំពើបាបរបស់យើងទាំងអស់ ហើយពុំគ្រាន់តែមួយចំនួននោះ?

សូមអញ្ជើញសិស្សឲ្យអាន ខ ៣ ម្ដងទៀតដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់នឹងធ្វើដើម្បីជួយ វិលលាម អ៊ី ម៉ុក ខ្លេលិនប្រែចិត្តពីអំពើបាបរបស់គាត់ទាំងអស់ ។

- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរនេះ អំពីរបៀបដែលព្រះអម្ចាស់នឹងជួយយើងនៅក្នុងការប្រែចិត្តរបស់យើង ? ( សិស្សគួរ តែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់នឹងបង្ហាញយើងនូវរឿងទាំងឡាយដែលយើងចាំបាច់ត្រូវប្រែចិត្ត** ។ សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

- តើវិធីមួយចំនួនដែលព្រះអម្ចាស់អាចបង្ហាញយើងអំពីរឿងដែលយើងចាំបាច់ត្រូវប្រែចិត្តមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហិនរី ប៊ី អាវរិង ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់ រកវិធីមួយ ដែលយើងអាចទូលសូមព្រះអម្ចាស់ដើម្បីជួយយើងឲ្យប្រែចិត្ត ។



« សំណួរមួយដែលយើងត្រូវទូលសូមពីព្រះវរបិតាសួគ៌របស់យើង គឺនៅក្នុងការអធិស្ឋានតែម្នាក់ឯងដូច នេះថា ៖ ‹ តើទូលបង្គំបានធ្វើអ្វីខ្លះនៅថ្ងៃនេះ ឬពុំបានធ្វើអ្វីសោះ ដែលនាំឲ្យទ្រង់ពុំសព្វព្រះទ័យ ? ប្រសិនបើទូលបង្គំអាចគ្រាន់តែដឹង ទូលបង្គំនឹងប្រែចិត្តអស់ពីដួងចិត្តដោយគ្មានបង្អង់ឡើយ › ។ ការអធិស្ឋានដោយរាបសានោះនឹងត្រូវបានឆ្លើយតប » (« Do Not Delay » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៣៤ ) ។

សូមលើកទឹកចិត្តដល់សិស្សឲ្យគិតអំពីពរជ័យនានាដែលពួកគេបានទទួល នៅពេលពួកគេបានងាកចេញពីអំពើបាប ហើយបាន ទទួលដំណឹងល្អ ។ សូមអញ្ជើញពួកគេឲ្យស្វែងយល់អំពីរឿងដែលពួកគេចាំបាច់ត្រូវប្រែចិត្ត ដើម្បី ពួកគេអាចទទួលបានពរជ័យ កាន់តែច្រើន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:៤–១៣

*ព្រះអម្ចាស់បញ្ជាឲ្យវិលលាម អ៊ី អ៊ី ម៉ុកខ្លេលិន ប្រកាសដំណឹងល្អ លះបង់ចោលនូវសេចក្ដីអសុចរិតទាំងអស់ ហើយ បន្តស្មោះត្រង់ដល់ទីបំផុត ។*

យោងទៅលើការសន្យារបស់ព្រះអម្ចាស់ ដើម្បីបង្ហាញដល់ វិលលាម អ៊ី អ៊ី ម៉ុកខ្លេលិន នូវអំពើបាបទាំងឡាយដែលគាត់ចាំបាច់ ត្រូវប្រែចិត្ត ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីផ្សេងទៀតដែលព្រះអម្ចាស់បានសន្យាដើម្បីបង្ហាញដល់បងប្រុសអ៊ី ម៉ុកខ្លេលិន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែល ពួកគេរកឃើញ ។

- ហេតុអ្វីក៏ជាពរជ័យដើម្បីដឹងពីព្រះទ័យរបស់ព្រះមានចំពោះយើង ?

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមឲ្យដៃគូនោះអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:៥–៩ ជាមួយគ្នា រកមើលនូវអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យបងប្រុស ម៉ុកខ្លេលិនធ្វើ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម ខ ៨–៩ តើពរជ័យអ្វីខ្លះដែលបងប្រុស ម៉ុកខ្លេលិន នឹងទទួល បើគាត់នឹងស្មោះត្រង់ធ្វើតាមព្រះទ័យរបស់ព្រះអម្ចាស់ ? ( ព្រះអម្ចាស់នឹងគង់នៅជាមួយគាត់ ហើយនឹងប្រទានពរដល់គាត់ដើម្បីអាចពង្រឹងដល់ពួកស្មោះត្រង់ និងព្យាបាលដល់ពួកអ្នកឈឺ ) ។

- តើយើងអាចរៀនអ្វីខ្លះមកពីខទាំងនេះអំពីពរជ័យនានាដែលយើងអាចទទួលបាន នៅពេលយើងធ្វើតាមព្រះទ័យរបស់ព្រះអម្ចាស់សម្រាប់យើង ? ( សិស្សគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងស្មោះត្រង់នៅក្នុងការធ្វើតាមព្រះទ័យរបស់ព្រះអម្ចាស់ នោះទ្រង់នឹងគង់នៅជាមួយយើង ហើយនឹងប្រទានពរដល់យើង ដើម្បីយើងអាចសម្រេចនូវអ្វីដែលទ្រង់តម្រូវពីយើង ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

សូមពន្យល់ថា បន្ថែមពីលើការផ្ដល់ការណែនាំដល់បងប្រុស ម៉ុកខ្លេលិន អំពីអ្វីដែលត្រូវធ្វើនោះ ព្រះអម្ចាស់បានប្រទានការព្រមានដល់គាត់ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាននូវការណែនាំ នៃក្បាលកណ្ដាលក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១០ ឲ្យឮៗ ។ ពីមុនពួកគេអានសូមចង្អុលបង្ហាញថា ប្រយោគទីមួយមាននូវពាក្យ *អំពល់* ។ សូមពន្យល់ថាអ្វីមួយៗដែលអំពល់ដល់យើង ប្រសិនបើវាបង្វាំងផ្លូវរបស់យើង ឬ ធ្វើកិច្ចការដ៏លំបាកបំផុតដើម្បីបានសម្រេច ។

- ព្រះអម្ចាស់បានបញ្ជាដល់បងប្រុស ម៉ុកខ្លេលិន « បោះបង់ចោលអស់ទាំងសេចក្ដីដ៏ឥតសុចរិត » ។ តើភាពមិនសុចរិតឬអំពើបាប អំពល់ដល់កិច្ចការផ្សព្វផ្សាយសាសនារបស់បងប្រុស ម៉ុកខ្លេលិន មានយ៉ាងដូចម្ដេចខ្លះ ? តើសេចក្ដីអសុចរិតអំពល់ដល់យើងខាងវិញ្ញាណយ៉ាងដូចម្ដេចខ្លះ ?

បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ចង់ឲ្យយើងលះបង់ចោលនូវអ្វីៗទាំងអស់ដែលអំពល់ដល់ការរីកចម្រើនខាងវិញ្ញាណរបស់យើង ។**

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាដោយស្ងាត់ស្ងៀមអំពីរឿងនៅក្នុងជីវិតរបស់ពួកគេ ដែលអាចនឹងធ្វើឲ្យពួកគេអំពល់ ។

សូមអានប្រយោគទីបីនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១០ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់រកមើលនូវការព្រមានជាក់លាក់មួយ ដែលព្រះអម្ចាស់បានប្រទានដល់បងប្រុសម៉ុកខ្លេលិន ។

- យោងតាម ខ ១០, តើបងប្រុស ម៉ុកខ្លេលិន មានការពុះពារលើការល្បួងអ្វីខ្លះ ?

- ចេញមកពី ខ ១០ តើយើងអាចរៀនអ្វីខ្លះ អំពីចំណេះដឹងរបស់ព្រះអម្ចាស់ចំពោះយើងម្នាក់ៗ ? ( សូមជួយសិស្សឲ្យមើលឃើញថា **ព្រះអម្ចាស់ស្គាល់ពីបញ្ហា និងសេចក្ដីល្បួងជាក់លាក់របស់យើង**ក៏ដូចជាទ្រង់បានជ្រាបពីបងប្រុស ម៉ុកខ្លេលិនផងដែរ ) ។ សូមគិតពីការអញ្ជើញសិស្សឲ្យសរសេរសេចក្ដីពិតនេះជាប់នឹង ខទី ១០) ។

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីយល់ថា ព្រះអម្ចាស់ដឹងអំពីបញ្ហា និងការល្បួងជាក់លាក់របស់យើង ?

សូមចង្អុលបង្ហាញថា បន្ថែមពីលើការដឹងអំពីបញ្ហា និងការល្បួងទាំងឡាយរបស់យើង ព្រះអម្ចាស់ដឹងអំពីកម្លាំង និងសមត្ថភាពនានារបស់យើងផងដែរ ។ ទ្រង់ដឹងអ្វីៗទាំងអស់អំពីយើងម្នាក់ៗ ។ ជាមួយនឹងការយល់ដឹងមួយថា ទ្រង់ស្រឡាញ់យើង ហើយស្គាល់យើងយ៉ាងល្អឥតខ្ចោះ នោះយើងអាចស្វែងរក និងធ្វើតាមព្រះទ័យរបស់ទ្រង់ដោយមានទំនុកចិត្ត និងទុកចិត្តទៅលើទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១១–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការប្រឹក្សាបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យ វិលលាម ម៉ុកខ្លេលិន ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពរជ័យដែលព្រះអម្ចាស់បានសន្យាបើបងប្រុស ម៉ុកខ្លេលិន នឹងធ្វើតាមការប្រឹក្សានោះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម ខ ១២ តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះដើម្បីទទួលជីវិតដ៏នៅអស់កល្បជានិច្ច ? ( សូមជួយសិស្សឲ្យទទួលស្គាល់ថា **ប្រសិនបើយើងបន្តស្មោះត្រង់ដល់ទីបញ្ចប់ នោះយើងនឹងទទួលបានជីវិតដ៏អស់កល្បជានិច្ច ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើដើម្បីឲ្យអ្នកបន្តស្មោះត្រង់រហូតដល់ទីបញ្ចប់ វាមានន័យយ៉ាងណាសម្រាប់អ្នក ?

សូមពន្យល់ថា នៅពេលដែលវិវរណៈនេះត្រូវបានប្រទានឲ្យ នោះបងប្រុស ម៉ុកខ្លេលិន បានទទួលទីបន្ទាល់មួយអំពីការស្ដារឡើងវិញនៃដំណឹងល្អ ។ បន្ទាប់ពីវិវរណៈត្រូវបានប្រទានឲ្យ នោះគាត់បានថ្លែងទីបន្ទាល់អំពីការហៅជាព្យាការីរបស់យ៉ូសែប ស្ម៊ីធ ។ គាត់បានមានប្រសាសន៍ថា « យ៉ូសែបស្ម៊ីធ គឺជាព្យាការីពិត របស់ព្រះអម្ចាស់. . . ហើយ. . . មានអំណាច និងបានទទួលវិវរណៈមកពីព្រះ » (សំបុត្រមកពី វិលលាម អ៊ី ម៉ុកខ្លេលិន ថ្ងៃទី ៤ ខែសីហា ឆ្នាំ ១៨៣២ RLDS Archives, 4; quoted in M. Russell Ballard, « What Came from Kirtland » [Church Educational System fireside for young adults, ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ], ទំព័រ ៨, speeches.byu.edu។ បងប្រុស ម៉ុកខ្លេលិន បានបម្រើដោយស្មោះត្រង់អស់ជាច្រើនឆ្នាំ ហើយត្រូវបានហៅឲ្យបម្រើជាសមាជិកទីមួយម្នាក់ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ។ ទោះជាយ៉ាងណាក៏ដោយ គាត់ពុំបានបន្តដោយស្មោះត្រង់ដល់ពីបញ្ចប់នោះទេ ។ តាមពិតទៅ គាត់បានងាកមកប្រឆាំងនឹងព្យាការី យ៉ូសែប ស្ម៊ីធ ហើយគាត់ត្រូវបានកាត់កាលចេញពីសាសនាចក្រក្នុងឆ្នាំ ១៨៣៨ ។ អ្នកអាចអានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ៖

> « ខណៈដែលយ៉ូសែប ស្ថិតនៅក្នុងគុក នៅ រីចម៉ុន្ដ រដ្ឋមីសសួរី នោះ ម៉ុកខ្លេលិនដែលជាបុរសមានមាឌធំ ហើយរហ័សរហួនបានទៅជួបនឹងទាហានឈ្លប ហើយបានសុំឯកសិទ្ធិដើម្បីវាយគ្នាជាមួយព្យាការី ។ ការអនុញ្ញាតត្រូវបានទទួលយកក្នុងលក្ខខណ្ឌដែលថា យ៉ូសែប នឹងវាយគ្នា ។ ទាហានឈ្លបបានទទួលយក . . . សំណើរដើម្បីទទួលរបស់ ម៉ុកខ្លេលិន ដែលយ៉ូសែបយល់ព្រម បើសិនជាគេដោះខ្នោះចេញពីដៃរបស់លោក ។ ម៉ុកខ្លេលិន បន្ទាប់មកបានបដិសេធក្នុងការវាយគ្នា លុះត្រាតែគាត់មានអាវុធមួយ ដែលយ៉ូសែបយល់ព្រមតាមសំណើរនោះ ប៉ុន្តែទាហានឈ្លប ពុំអនុញ្ញាតឲ្យពួកគេវាយគ្នាដោយលក្ខខណ្ឌពុំស្មើភាពគ្នាដូច្នោះនោះទេ » (« History of Brigham Young, » *Millennial Star,* ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៨៦៤, ទំព័រ ៨០៨) ។

សូមបង្វែរចំណាប់អារម្មណ៍របស់សិស្សទៅលើឌីយ៉ាក្រាម នៅលើក្ដារខៀន ហើយឲ្យយោបល់ថា ពួកគេនឹងត្រូវពិចារណាម្ដងទៀតពីកន្លែងដែលពួកគេនឹងដាក់ខ្លួនគេនៅក្នុងឌីយ៉ាក្រាមនោះ ។ សូមឲ្យពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖

- តើអ្នកនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីខិតទៅកាន់តែជិតព្រះ ហើយបន្តនៅស្មោះត្រង់រហូតដល់ទីបំផុត ?

សូមថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលអ្នកបានពិភាក្សា ហើយលើកទឹកចិត្តសិស្សឲ្យធ្វើសកម្មភាពដោយខ្លួនគេ ។

មេរៀនទី ៧៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧

## បុព្វកថា

នៅខែវិច្ឆិកា ឆ្នាំ ១៨៣១ ក្រុមនៃពួកអែលឌើរមួយក្រុមបានមកជួបជុំគ្នាសម្រាប់សន្និសីទពិសេសមួយនៅ ហៃរ៉ាំ រដ្ឋ អូហៃអូ ។ ចំណុចមួយដែលត្រូវលើកមកពិភាក្សានៅក្នុងសន្និសីទនោះគឺអំពីការបោះពុម្ពផ្សាយវិវរណៈដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួល ។ អំឡុងការប្រជុំនេះ ព្រះអម្ចាស់បានប្រទានវិវរណៈមួយដល់ យ៉ូសែប ស្ម៊ីធ ហើយបានកំណត់វាជាអារម្ភកថា ចំពោះគម្ពីរនៃវិវរណៈដែលនឹងត្រូវបានបោះពុម្ព ។ ឥឡូវ វិវរណៈនោះ គឺ នៅក្នុងកណ្ឌទីមួយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ។ ក្រោយមកទៀត នៅក្នុងសន្និសីទ ព្រះអម្ចាស់បានប្រទានវិវរណៈមួយ ដែលឥឡូវនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានថ្លែងទៅពួកបងប្អូនប្រុសដែលមានសំណួរអំពីភាសានៃវិវរណៈ ដែលទ្រង់បានប្រទានដល់ព្យាការី ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១–៣

*ព្រះអម្ចាស់បានស្ដាប់ឮការអធិស្ឋានរបស់យើង ហើយដឹងពីដួងចិត្តរបស់យើង*

ពីមុនថ្នាក់ចាប់ផ្ដើម សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើអ្នកមានអារម្មណ៍ថា ការអធិស្ឋានរបស់អ្នកត្រូវបានស្ដាប់ឮ និងឆ្លើយតបនៅពេលណា ?* នៅពេលចាប់ផ្ដើមថ្នាក់រៀន សូមអញ្ជើញសិស្សឲ្យឆ្លើយតបចំពោះសំណួរនេះ ។

សូមពន្យល់ថា នៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៨៣១ ក្រុមនៃពួកអែលឌើរមួយក្រុម រួមទាំង យ៉ូសែប ស្ម៊ីធ បានជួបជុំគ្នាពិភាក្សាអំពីការបោះពុម្ពវិវរណៈដែលព្យាការីបានទទួល ។ យ៉ូសែប ស្ម៊ីធ បានសុំឲ្យពួកអែលឌើរ ថ្លែងទីបន្ទាល់ថា វិវរណៈទាំងឡាយគឺមកពីព្រះអម្ចាស់ ប៉ុន្តែពួកគេមួយចំនួនបានស្ទាក់ស្ទើរក្នុងការថ្លែងទីបន្ទាល់ ។ ការស្ទាក់ស្ទើរនេះនាំឲ្យមានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១–២ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូល អំពីការអធិស្ឋាន ។

- នៅក្នុងខគម្ពីរទាំងនេះ តើព្រះអម្ចាស់មានបន្ទូលអំពីបំណងព្រះទ័យរបស់ទ្រង់ចំពោះការអធិស្ឋានរបស់យើងអ្វីខ្លះ ? ( ទោះជាសិស្សរបស់អ្នកអាចនឹងផ្ដល់ចម្លើយផ្សេងៗជាច្រើនក្ដី សូមប្រាកដថា ពួកគេប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់ស្ដាប់ឮការអធិស្ឋានរបស់យើង ហើយដឹងដួងចិត្តរបស់យើង ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើការដឹងពីគោលការណ៍នេះ អាចជួយអ្នកឲ្យកែលម្អការអធិស្ឋានរបស់អ្នកដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យដឹងពីសារៈសំខាន់នៃគោលការណ៍នៅលើក្ដារខៀន សូមអញ្ជើញពួកគេពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេដឹងថា ព្រះវរបិតាសួគ៌បានស្ដាប់ឮការអធិស្ឋានរបស់ពួកគេ ហើយដឹងពីបំណងប្រាថ្នានៃដួងចិត្តរបស់ពួកគេ ។ បន្ទាប់ពីសិស្សពីរបីនាក់បានមានឱកាសចែកចាយរួចហើយ សូមលើកទឹកចិត្តសិស្សឲ្យអធិស្ឋានសុំចំណេះដឹងថា ព្រះបានស្ដាប់ឮការអធិស្ឋានរបស់ពួកគេ ហើយដឹងពីដួងចិត្តរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:៣ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីមូលហេតុដែលពួកអែលឌើរមួយចំនួនពុំបានទទួលពរជ័យដែលព្រះអម្ចាស់បានផ្ដល់ឲ្យពួកគេ ។

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖*តើការភ័យខ្លាចអាចបណ្ដាលឲ្យនរណាម្នាក់បាត់បង់ពរជ័យយ៉ាងដូចម្ដេច ?* សូមឲ្យសិស្សឆ្លើយ ។ នៅពេលពួកគេពិភាក្សាអំពីសំណួរនេះ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងទុកឲ្យភាពភ័យខ្លាចមាននៅក្នុងដួងចិត្តរបស់យើង នោះយើងអាចនឹងបាត់បង់ពរជ័យ ។**

- តើការភ័យខ្លាចអ្វីខ្លះ ដែលមនុស្សមាន ដែលអាចនឹងបញ្ឈប់ពួកគេពីការទទួលបានពរជ័យ ? ( ឧទាហរណ៍ អាចមានដូចជា ភាពភ័យខ្លាចនៃការមិនចុះនឹងគេ ភាពភ័យខ្លាចនៃការធ្វើកំហុស ភាពភ័យខ្លាចនៃការផ្លាស់ប្ដូរជីវិតរបស់ពួកគេ ភាពភ័យខ្លាចនៃការបរាជ័យ ភាពភ័យខ្លាចនៃការប្រែចិត្ត ជាដើម ) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីភាពភ័យខ្លាចដែលអាចនឹងរារាំងពួកគេពុំឲ្យធ្វើសកម្មភាពក្នុងសេចក្ដីជំនឿ ។ សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកជំនួយរបស់ព្រះអម្ចាស់ជំនួសឲ្យភាពភ័យខ្លាចរបស់ពួកគេដោយសេចក្ដីជំនឿ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:៤–៩

*ព្រះអម្ចាស់ប្រទានផ្លូវមួយសម្រាប់ពួកអែលឌើរឲ្យទទួលបាននូវទីបន្ទាល់នៃវិវរណៈតាមរយៈ យ៉ូសែប ស្ម៊ីធ*

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *ហេតុអ្វីក៏យើងគួរតែនៅគាំទ្រដល់ពួកអ្នកដឹកនាំសាសនាចក្ររបស់យើង ទោះជាយើងដឹងថាពួកគេពុំល្អឥតខ្ចោះក៏ដោយ ?*

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការណែនាំក្បាលកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧។ សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអារម្មណ៍ដែលពួកអែលឌើរមានអំពីវិវរណៈទៅជាយ៉ាងណា ដែលនឹងត្រូវបោះពុម្ពនៅក្នុងព្រះគម្ពីរនៃព្រះបញ្ញត្តិ ។ ( អ្នកអាចប្រាប់សិស្សថា ការចងក្រងដំបូងនៃវិវរណៈរបស់ យ៉ូសែប ស្ម៊ីធ គឺដាក់ចំណងជើងថា ព្រះគម្ពីរនៃព្រះបញ្ញត្តិ ។ នៅក្នុងឆ្នាំ ១៨៣៥ ព្រះគម្ពីរត្រូវបានបោះពុម្ពនៅក្រោមចំណងជើងថា គោលលទ្ធិ និង សេចក្ដីសញ្ញា ) ។

- តើពួកអែលឌើរមានអារម្មណ៍យ៉ាងណាអំពីវិវរណៈ ? ( ពួកអែលឌើរជាច្រើន « បានថ្លែងទីបន្ទាល់ជាឧឡារិក » អំពីសេចក្ដីពិតពេញលេញនៃវិវរណៈ ។ ទោះជាយ៉ាងណាក៏ដោយ « ការសន្ទនាមួយចំនួនគឺមានការបារម្ភអំពីភាសាដែលបានប្រើនៅក្នុងវិវរណៈទាំងឡាយ » ។ ស្របតាម ខ ៥ ពួកអែលឌើរមួយចំនួនបានគិតថា ពួកគេអាច « ថ្លែងបានប្រសើរជាងភាសារបស់ [យ៉ូសែប ស្ម៊ីធ] ») ។

សូមពន្យល់ថា ពួកអែលឌើរមួយចំនួនបានបារម្ភអំពីភាសាដែលវិវរណៈត្រូវបានថ្លែង ។ ពួកគេអាចមានអារម្មណ៍ថា វិវរណៈចាំបាច់ត្រូវធ្វើការកែសម្រួលយ៉ាងច្រើនដើម្បីត្រៀមធ្វើការបោះពុម្ព ហើយពួកគេអាចនឹងភ័យខ្លាចអំពីអ្វីដែលមារសត្រូវរបស់សាសនាចក្រនឹងប្រព្រឹត្តជាមួយនឹងវិវរណៈទាំងឡាយ នៅពេលដែលវាត្រូវបានបោះពុម្ពចេញមក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:៤–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលចម្លើយរបស់ព្រះអម្ចាស់អំពីភាសានៃវិវរណៈ ។

- តើព្រះអម្ចាស់ បានដឹងអ្វីខ្លះអំពីយ៉ូសែប ស្ម៊ីធ?

សូមចង្អុលបង្ហាញថា ជំនាញភាសារបស់ យ៉ូសែប ស្ម៊ីធ ពុំល្អឥតខ្ចោះនោះទេ ។ លោកពុំមានភាពប្រសប់ក្នុងការនិយាយនោះទេ។ តែទោះជាយ៉ាងណាក្ដី ព្រះអម្ចាស់បានបើកសម្ដែងសេចក្ដីពិតដល់លោក ហើយបានអនុញ្ញាតឲ្យលោកថ្លែងបានល្អបំផុតតាមដែលលោកអាចធ្វើទៅបាន ។

- ហេតុអ្វីក៏វាជាជំនួយដើម្បីដឹងថា ព្រះអម្ចាស់បើកសម្ដែងព្រះទ័យរបស់ទ្រង់ចំពោះ យ៉ូសែប ស្ម៊ីធ ទោះជាទ្រង់បានដឹងថា យ៉ូសែប ពុំល្អឥតខ្ចោះក្ដី ?

សូមអញ្ជើញសិស្សបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:៦–៩ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវសំណូមពរដែលព្រះអម្ចាស់បានប្រទានដល់អ្នកទាំងឡាយដែលរិះគន់ដល់ភាសានៃវិវរណៈ ។

- តើសំណូមពរអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់អ្នកទាំងឡាយដែលបានគិតថា ពួកគេអាចថ្លែងបានល្អជាងភាសានៃវិវរណៈនោះ ?

សូមសួរសិស្សអំពីអ្វីដែលពួកគេចងចាំមកពី មេរៀនមុនៗអំពី វិលលាម អ៊ី ម៉ុកឡេលិន ។ សូមពន្យល់ថា វិលលាម បានសម្រេចចិត្តទទួលយកសំណូមពររបស់ព្រះអម្ចាស់ដើម្បីសរសេរវិវរណៈមួយមកប្រៀបធៀបនឹងវិវរណៈទាំងឡាយដែលយ៉ូសែប ស្ម៊ីធ បានទទួល ។ បន្ទាប់មកអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមមកពីប្រវត្តិរបស់ យ៉ូសែប ស្ម៊ីធ ៖



« វិលលាម អ៊ី ម៉ុកឡេលិន ជាបុរសដ៏ឈ្លាសវៃម្នាក់ គាត់ពូកែប៉ាន់ស្មាន គាត់រៀនបានច្រើនហើយអាចញាណដឹង គាត់បានខិតខំដើម្បីសរសេរបញ្ញត្តិមួយ ដូចជាបញ្ញត្តិមួយរបស់ព្រះអម្ចាស់ ប៉ុន្តែបានបរាជ័យ វាគឺជាការទទួលខុសត្រូវដ៏អាក្រក់មួយ ដើម្បីសរសេរនៅក្នុងព្រះនាមរបស់ព្រះអម្ចាស់ ។ ពួកអែលឌើរ និងមនុស្សទាំងអស់ដែលមានវត្តមាន បានធ្វើជាសាក្សីអំពីការប៉ុនប៉ងដ៏ឥតប្រយោជន៍នេះរបស់មនុស្សដើម្បីធ្វើតាមភាសារបស់ព្រះយេស៊ូវគ្រីស្ទ បានរំឭកសេចក្ដីជំនឿរបស់ពួកគេនៅក្នុងភាពពេញលេញនៃដំណឹងល្អ និងនៅក្នុងសេចក្ដីពិតនៃបទបញ្ញត្តិ និងវិវរណៈទាំងឡាយដែលព្រះអម្ចាស់បានប្រទានដល់សាសនាចក្រ តាមរយៈភាពជាឧបករណ៍របស់ខ្ញុំ ហើយពួកអែលឌើរបានបង្ហាញពីការស្ម័គ្រចិត្តដើម្បីថ្លែងទីបន្ទាល់អំពីសេចក្ដីពិតរបស់ពួកគេចំពោះពិភពលោកទាំងមូល » ( នៅក្នុង *History of the Church* ១:២២៦ ) ។

សូមពន្យល់ថា បន្ទាប់ពីព្រឹត្តការណ៍នេះ ពួកអែលឌើរជាច្រើនបានបង្ហាញឯកសារចុះហត្ថលេខាមួយ ដែលបានផ្ដល់នូវទីបន្ទាល់ជាផ្លូវការរបស់ពួកគេអំពីភាពពិតពេញលេញនៃវិវរណៈនៅក្នុងព្រះគម្ពីរនៃបទបញ្ញត្តិ ។

- ហេតុអ្វីក៏អ្នកគិតថា យ៉ូសែប ស៊្មីធ ជាមនុស្សដែលមានការសិក្សាតិចតួច អាចនាំវិវរណៈទាំងនេះចេញមកបាន ប៉ុន្តែ វិលលាម អ៊ី ម៉ុកឡេលិន ដែលជាមនុស្សមានការអប់រំខ្ពស់ បែរជាពុំអាចធ្វើបានទៅវិញយ៉ាងដូច្នេះ ?
- តើយើងអាចរៀនអ្វីខ្លះមកពីដំណើររឿងនេះអំពីការវិនិច្ឆ័យដល់ពួកអ្នកដឹកនាំរបស់យើង ដោយសារតែភាពពុំល្អឥតខ្ចោះរបស់ពួកគេនោះ ?

សូមចង្អុលបង្ហាញពីសំណួរនៅលើក្ដារខៀន អំពីការធ្វើតាមអ្នកដឹកនាំពុំល្អឥតខ្ចោះ ។ សូមអញ្ជើញសិស្សឲ្យសរសេរចម្លើយរបស់ពួកគេខាងក្រោមសំណួរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១០–១៤

*ព្រះអម្ចាស់ប្រឹក្សាដល់ពួកអ្នកដើរតាមទ្រង់អំពីរបៀបដើម្បីត្រៀមខ្លួននៅក្នុងវត្តមានរបស់ព្រះ*

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖*តើពរជ័យមួយចំនួនដែលអាចកើតមាន នៅពេលយើងមានការអត់ធ្មត់ចំពោះខ្លួនឯង និងអ្នកដទៃមានអ្វីខ្លះ ?* សូមអញ្ជើញឲ្យសិស្សឆ្លើយ ។

សូមសិស្សម្នាក់ឲ្យអានឮៗនូវដំណើររឿងដូចខាងក្រោម ដែលបានចែកចាយដោយប្រធាន ឌៀថើរ អេហ្វ.អុជដូហ្វ នៃគណៈប្រធានទីមួយ ៖



« អំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ មានសាស្ត្រាចារ្យមួយរូបនៅសាកលវិទ្យាល័យ ស្ទែនហ្វដ បានធ្វើការសាកល្បងធ្វើបទពិសោធន៍តូចមួយអំពីកម្លាំងឆន្ទៈរបស់កុមារតូចៗ ដែលមានអាយុបួនឆ្នាំ ។ គាត់ដាក់នំម៉ាស្សម៉ាឡូដ៏ធំមួយនៅចំពោះមុខកុមារតូចៗនោះ ហើយបានប្រាប់កុមារទាំងនោះថា ពួកគេអាចញ៉ាំនំនោះភ្លាមតែម្ដង ឬ បើអាចចាំតែ ១៥ នាទីទៀត នឹងទទួលបាននំម៉ាស្សម៉ាឡូនោះដល់ទៅពីរ ។

« បន្ទាប់មក គាត់បានទុកឲ្យកុមារនោះនៅតែឯង ហើយឃ្លាំមើលពីក្រោយកញ្ចក់ដែលអាចឃើញតែម្ខាង ។ កុមារខ្លះបានញ៉ាំនំ ម៉ាស្សម៉េឡូ ភ្លាមតែម្ដង ហើយខ្លះទៀតអាច រង់ចាំបានតែប៉ុន្មាននាទីមុនពេលពួកវាចុះចាញ់ការល្បួង ។ មានតែ ៣០ ភាគរយប៉ុណ្ណោះដែលអាចរង់ចាំបាន » (បន្តដោយភាពអត់ធន់ » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៥៦ ) ។

- តើអ្នកគិតថាការពិសោធន៍ និងការរកឃើញរបស់សាស្ត្រាចារ្យរូបនេះ អាចទាក់ទងនឹងយើងយ៉ាងដូចម្ដេច ?
- តើពរជ័យអ្វីខ្លះ ដែលអ្នកបានទទួល ដោយសារតែអ្នកអត់ធ្មត់ ?

សូមអញ្ជើញសិស្សឲ្យបង្កើតតារាងដែលមានពីរកូឡោនក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមឲ្យពួកគេដាក់ស្លាកនៅក្នុងកូឡោនទីមួយថា *រង្វាន់* ហើយកូឡោនទីពីរថា *របៀបដើម្បីទទួលបានរង្វាន់* ។ សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១០–១៤ ជាមួយនឹងដៃគូរបស់ពួកគេ ហើយរកមើលរង្វាន់ដែលបានសន្យាដោយព្រះអង្គសង្គ្រោះ និងសកម្មភាពដែលចាំបាច់ត្រូវមានដើម្បីទទួលបានរង្វាន់ ។ សូមអញ្ជើញពួកគេឲ្យកត់ត្រាចម្លើយរបស់ពួកគេនៅក្នុងកូឡោនត្រឹមត្រូវក្នុងតារាងរបស់ពួកគេ ។

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីសិក្សា និងពិភាក្សាវគ្គបទគម្ពីរ សូមប្រើសំណួរដូចខាងក្រោមដើម្បីជួយពួកគេរាយការណ៍អំពីការស្វែងរកឃើញរបស់ពួកគេទៅដល់សិស្សក្នុងថ្នាក់ ។

- តើរង្វាន់អ្វីខ្លះដែលព្រះអម្ចាស់ផ្ដល់ដល់ពួកអែលឌើរទាំងនេះ ?
- តើពួកអែលឌើរចាំបាច់ត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានរង្វាន់ទាំងនេះ ? ( នៅពេលសិស្សប្រាប់ឃ្លា « នៅក្នុងវត្តមាននៃព្រះ » អ្នកអាចនឹងចង់ពន្យល់ថាពាក្យ *នៅ* មានន័យថា ស្ថិតនៅ ឬបន្តនៅក្នុងកន្លែងជាក់លាក់មួយ ) ។

សូមពន្យល់ថា វគ្គគម្ពីរនេះអនុវត្តចំពោះយើងទាំងអស់គ្នា ។ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងកំចាត់ខ្លួនចេញពីសេចក្ដីច្រណែន និងសេចក្ដីខ្លាច ហើយបន្ទាបខ្លួន និងបន្តនៅក្នុងភាពអត់ធន់ នោះយើងនឹងនៅក្នុងវត្តមានរបស់ព្រះ ។**

- ហេតុអ្វីអ្នកគិតថា យើងចាំបាច់ត្រូវអត់ធន់នៅក្នុងកិច្ចខិតខំរបស់យើង ដើម្បីមានភាពសក្ដិសមដើម្បីនៅក្នុងវត្តមានរបស់ព្រះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវការរកឃើញដូចខាងក្រោមឲ្យឮៗចេញមកពីការធ្វើពិសោធន៍ នំ ម៉ាស្សម៉េល្លូ ដូចបានដំណាលប្រាប់ដោយប្រធាន អុជដូហ្វ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវអ្វីដែលយើងអាចរៀនអំពីការប្រែក្លាយទៅជាបរិសុទ្ធនៅចំពោះព្រះ ។



« ប៉ុន្តែនៅពេលដែលពេលវេលាកន្លងទៅ [ សាស្ត្រាចារ្យ ] បាន តាមដានកុមារទាំងនោះ ហើយចាប់ផ្ដើមសម្គាល់ ឃើញនូវភាពស្របគ្នាដ៏គួរឱ្យចាប់អារម្មណ៍ថា ៖ កុមារទាំងនោះដែលមិនអាចរង់ចាំបាន ក្រោយមកតែងនឹងមានបញ្ហានៅក្នុងជីវិត និងមានបញ្ហាផ្នែកអាកប្បកិរិយាជាងកុមារដែលអាចរង់ចាំបាន នៅពេលដែលកុមារដែលអាចរង់ចាំបាន ទំនងជាមានភាពវិជ្ជមានជាង និងមានការលើកទឹកចិត្តជាង មានពិន្ទុ និងចំណូលខ្ពស់ជាង ហើយមានទំនាក់ទំនងល្អជាងកុមារដែលមិនអាចរង់ចាំបាន ។

« . . .លទ្ធភាពដើម្បីរង់ចាំ–អត់ធន់–គឺជាលក្ខណៈសម្បត្តិនៃអត្តចរិតដែលជាគន្លឹះ អាចព្យាករនូវភាពជោគជ័យក្រោយមកក្នុងជីវិត ។. . .

« . . . ដោយគ្មានការអត់ធន់ យើងមិនអាចធ្វើឱ្យព្រះសព្វព្រះហឫទ័យឡើយ យើងមិនអាចទទួលបានភាពគ្រប់លក្ខណ៍ឡើយ ។ យ៉ាងពិតប្រាកដ ការអត់ធន់ គឺជាដំណើរការឲ្យមានបរិសុទ្ធភាព ដែលដុសខាត់ការយល់ដឹង បង្កើនសុភមង្គល ផ្ដោតទង្វើ ហើយនិងផ្ដល់ក្ដីសង្ឃឹមសម្រាប់ភាពសុខសាន្ត » (« បន្តដោយភាពធត់ធន់ » ទំព័រ ៥៦ ) ។

- តើយើងអាចរៀនអ្វីខ្លះចេញមកពីការធ្វើពិសោធន៍នេះ អំពីពរជ័យដែលកើតមាន នៅពេលយើងអត់ធន់ ?

សូមអញ្ជើញសិស្សឲ្យពិចារណា ឬអធិស្ឋានអំពីផ្នែកជាច្រើននៃជីវិតរបស់ពួកគេ ដែលពួកគេចាំបាច់ត្រូវមានការអត់ធន់កាន់តែច្រើនចំពោះខ្លួនគេ និងអ្នកដទៃ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅមួយ ដែលនឹងជួយពួកគេឲ្យកាន់តែមានភាពសក្តិសម ដើម្បីនៅក្នុងវត្តមានរបស់ព្រះ ។

### *ការពិចារណា និងការអធិស្ឋាន*

ដើម្បីពិចារណាគឺការសញ្ជឹង ឬគិតដោយជ្រាលជ្រៅអំពីអ្វីមួយ ។ កិច្ចខិតខំរបស់យើងដើម្បីពិចារណាត្រូវបានពង្រឹងនៅពេលយើងបញ្ចូលវាទៅក្នុងការអធិស្ឋាន ។ នៅពេលសិស្សរៀនពិចារណា និងអធិស្ឋាន នោះពួកគេនឹងត្រៀមខ្លួនដើម្បីទទួលការដឹកនាំមកពីព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងជួយពួកគេឲ្យដឹងពីរបៀបដែលពួកគេអាចប្រែក្លាយកាន់តែដូចជាព្រះយេស៊ូវគ្រីស្ទ ។

មេរៀនទី ៧៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨

## បុព្វកថា

នៅថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៨៣១ ព្យាការីយ៉ូសែប ស្ម៊ីធ បានជួបនឹងក្រុមនៃពួកអែលឌើរនៅភូមិ ហៃរ៉ាំ រដ្ឋ អូហៃអូ សម្រាប់សន្និសីទពិសេសមួយ ។ ពួកគាត់បានពិភាក្សាអំពីការបោះពុម្ពព្រះគម្ពីរនៃបទបញ្ញត្តិ ជាការប្រមូលផ្ដុំនៃវិវរណៈដែលព្យាការីបានទទួល ។ ពួកអែលឌើរបួននាក់នៅក្នុងសន្និសីទនោះ បានសុំឲ្យ យ៉ូសែប ស្ម៊ីធ ទូលសួរដល់ព្រះអម្ចាស់អំពីព្រះទ័យរបស់ទ្រង់ចំពោះពួកគេ ។ ជាការឆ្លើយតបចំពោះសំណើរនេះ ព្យាការីបានទទួលវិវរណៈមួយដែលឥឡូវនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨ ។ វិវរណៈរួមមាននូវការប្រឹក្សាទៅដល់អ្នកទាំងឡាយដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ការណែនាំទាំងឡាយអំពីការហៅរបស់ប៊ីស្សព និងបញ្ញត្តិមួយថា ឪពុកម្ដាយបង្រៀនកូនចៅអំពីគោលការណ៍ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:១–១២

*ព្រះអង្គសង្គ្រោះប្រឹក្សាដល់អ្នកទាំងឡាយដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ*

បើអ្នក ឬនរណាម្នាក់នៅជិតអ្នកបានបម្រើបេសកកម្មសម្រាប់សាសនាចក្រ សូមចាប់ផ្ដើមថ្នាក់ដោយការចែកចាយអំពីអារម្មណ៍មួយចំនួន ដែលមនុស្សនោះទទួលបទពិសោធន៍ នៅពេលពួកគេត្រៀមខ្លួនដើម្បីចាកចេញពីផ្ទះ ហើយធ្វើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- តើការបារម្ភ ឬកង្វល់អ្វីខ្លះ អាចកើតមានចំពោះមនុស្សដែលហៀបនឹងបម្រើបេសកកម្មពេញម៉ោង ?
- តើមូលហេតុមួយចំនួនអ្វីខ្លះដែលមនុស្ស ពេលខ្លះមានអារម្មណ៍ភិតភ័យចំពោះការចែកចាយដំណឹងល្អជាមួយសមាជិកគ្រួសារ ឬមិត្តភក្ដិរបស់ពួកគេ ?

សូមពន្យល់ថា នៅក្នុងសន្និសីទមួយដែលបានធ្វើឡើងអំឡុងថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៨៣១ មានពួកអែលឌើរបួននាក់ ដែលនឹងបម្រើជាអ្នកផ្សព្វផ្សាយសាសនា បានទៅជួបនឹង យ៉ូសែប ស្ម៊ីធ ហើយបានសុំដើម្បីដឹងពីព្រះទ័យរបស់ព្រះអម្ចាស់អំពីពួកគេ ។ នៅក្នុងការឆ្លើយតប ព្រះអម្ចាស់បានបើកសម្ដែងគំរូមួយនៃការផ្សាយដំណឹងល្អ ។ សូមអញ្ជើញសិស្សប្រាំនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗដែលដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:១–៥ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលធាតុទាំងឡាយនៃគំរូនោះ ។ មុនពេលពួកគេអាន សូមចង្អុលបង្ហាញថា ខ ២ និង ៣ មាននូវពាក្យ *ជាគំរូ* ។ គំរូមួយគឺជាលំនាំ ឬម៉ូត ។

- តើអ្នកបានឃើញអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះអំពីរបៀបដែលយើងគួរតែផ្សាយដំណឹងល្អ ?
- នៅក្នុង ខ ៣–៥ តើព្រះអម្ចាស់បានប្រទានដល់ពួកអ្នកបម្រើទ្រង់នូវការសន្យាអ្វីខ្លះ ?
- តើពាក្យបំផុសគំនិតរបស់ពួកអ្នកផ្សព្វផ្សាយសាសនានឹងចំពោះអ្នកទាំងឡាយដែលទទួលពួកគេមានអ្វីខ្លះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **នៅពេលអ្នកបម្រើរបស់ព្រះអម្ចាស់បានមានពេញដោយព្រះវិញ្ញាណបរិសុទ្ធ នោះពាក្យសម្ដីរបស់ពួកគេនឹងដឹកនាំមនុស្សទៅរកសេចក្ដីសង្គ្រោះ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- តើយើងអាចធ្វើខ្លះដើម្បីអញ្ជើញឲ្យមានឥទ្ធិពលមកពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលយើងចែកចាយដំណឹងល្អ ?

សូមពន្យល់ថា ខណៈដែលអ្នកទាំងឡាយដែលត្រូវបានតែងតាំងដើម្បីផ្សាយដំណឹងល្អ អាចជួយមនុស្សទទួលបានទីបន្ទាល់មួយអំពីសេចក្ដីពិត នោះមានតែប្រធានសាសនាចក្រម្នាក់ប៉ុណ្ណោះ ដែលមានសិទ្ធិទទួល និងប្រកាសពីព្រះទ័យនៃព្រះអម្ចាស់សម្រាប់សាសនាចក្រទាំងមូលបាន ។ នៅក្រោមការដឹកនាំរបស់លោក សមាជិកនៃគណៈប្រធានទីមួយដទៃទៀត និងសមាជិកនៃ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ក៏មានសិទ្ធិអំណាចដើម្បីប្រកាសពីព្រះទ័យរបស់ព្រះចំពោះយើងផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការលើកទឹកចិត្តបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យអ្នកបម្រើរបស់ទ្រង់ ។

- តើអ្នកមើលឃើញសេចក្ដីពិតអ្វីខ្លះនៅក្នុងខគម្ពីរនេះ ដែលអាចនាំមកនូវការលួងលោមចិត្តដល់អ្នកផ្សព្វផ្សាយសាសនាម្នាក់ ?
- ហេតុអ្វីក៏វាសំខាន់សម្រាប់អ្នក ដើម្បីដឹងថា ព្រះអម្ចាស់គង់នៅជិតនឹងអ្នកបម្រើស្មោះត្រង់របស់ទ្រង់ ?

សូមចង្អុលបង្ហាញថា ខ ៦ ចែងអំពីទំនួលខុសត្រូវនៃពួកអ្នកបម្រើរបស់ព្រះអម្ចាស់ជាចម្បងថា ៖ ត្រូវថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងបេសកកម្មរបស់ទ្រង់នៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។ បន្ទាប់មក សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៧–១២ ដោយការពន្យល់ថា ព្រះអម្ចាស់ហៅពួកអែលឌើរស្មោះត្រង់នៃសាសនាចក្រឲ្យផ្សាយដំណឹងល្អ និងជ្រមុជទឹកដល់អ្នកទាំងឡាយដែលជឿ ។

សូមពិចារណាធ្វើការចែកចាយបទពិសោធន៍មួយ ដែលអ្នកត្រូវបានដឹកនាំដោយព្រះវិញ្ញាណដើម្បីដឹងអំពីរបៀបចែកចាយដំណឹងល្អជាមួយនរណាម្នាក់។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:១៣–២៤

*ព្រះអម្ចាស់បើកសម្ដែងថា គណៈប្រធានទីមួយ គឺត្រូវមើលខុសត្រូវលើការហៅពួកប៊ីស្សព*

សូមឲ្យសិស្សគិតស្រមៃថា មានមិត្តម្នាក់ដែលជឿសាសនាផ្សេង បានសួរថា « តើគេជ្រើសរើសប៊ីស្សពរបស់អ្នកយ៉ាងដូចម្ដេច ?»

- តើអ្នកនឹងតបដោយរបៀបណា ?

សូមពន្យល់ថា អែតវើត ប៉ាទ្រិច គឺជាប៊ីស្សពដំបូងគេ ដែលបានហៅនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ( នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ១៨៣១ សូមមើល គ. និង ស. ៤១:៩) ។ ពីមុន យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨ ( នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៨៣១ ) ប៊ីស្សព ប៉ាទ្រិច គឺជាប៊ីស្សពតែម្នាក់គត់នៅក្នុងសាសនាចក្រ ។ ប៊ីស្សពផ្សេងទៀតត្រូវបានហៅមិនយូរប៉ុន្មានបន្ទាប់ពី ព្យាការី បានទទួលវិវរណៈនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:១៤–១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលត្រូវជ្រើសរើសប៊ីស្សព ។

*កំណត់ចំណាំ ៖* ខ ១៥–២០ មាននូវការណែនាំអំពីពូជពង្សនៃលោកអើរ៉ុនពិត ដែលអាចនឹងត្រូវបានហៅជាប៊ីស្សពជាអធិបតី ។ ឃ្លា « ពូជពង្សនៃលោកអើរ៉ុនពិត » សំដៅទៅលើកូនចៅរបស់បងប្រុសរបស់ ម៉ូសេ ឈ្មោះ អើរ៉ុន នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ពូជពង្សដូច្នេះ នឹងមានសិទ្ធិនៅក្នុងតំណែងនៃប៊ីស្សពជាអធិបតី បើគាត់ត្រូវបានហៅ និងបានអនុមតិដោយគណៈប្រធានទីមួយ ។ ខ ១៦–២០ ទាក់ទងតែប៊ីស្សពជាអធិបតីប៉ុណ្ណោះ ពុំមែនជាប៊ីស្សពក្នុងវួដនោះទេ ( សូមមើល យ៉ូសែប ហ្វីលឌិង ស៊្មីធ *គោលលទ្ធិនៃសេចក្ដីសង្គ្រោះ* ចងក្រងដោយ ប្រ៊ូស អរ ម៉ាក់ខនគី វ៉ុល ៣ [ ឆ្នាំ ១៩៥៤–៥៦ ], ៣:៩២–៩៣ ) ។ នៅក្នុងអក្សរសាស្ត្រសាសនាចក្រជំនាន់មុន ជាញឹកញាប់សំដៅទៅលើប៊ីស្សព ប៉ាទ្រិច ថាជាប៊ីស្សពជាអធិបតី ។ ទំនួលខុសត្រូវរបស់ប៊ីស្សពជាអធិបតី បានបង្កើតឡើង ហើយជាច្រើនឆ្នាំក្រោយមកបានផ្លាស់ប្ដូរ ។ នៅក្រោមការដឹកនាំរបស់ប្រធាន ព្រិកហាំ យ៉ង់ នោះទំនួលខុសត្រូវទាំងឡាយរបស់ប៊ីស្សពជាអធិបតី ត្រូវបានបញ្ជាក់កាន់តែពេញលេញ នៅឆ្នាំ ១៨៤៧ នៅ វិនទើរ ខ្វរទើរ្ស ជាមួយនឹងប៊ីស្សព នូវែល ឃេ វីតនី ដែលបានទទួលការហៅនោះ ។

អ្នកអាចនឹងចង់ពន្យល់ថា នៅក្នុងសាសនាចក្រជំនាន់មុន សមាជិកនៃគណៈប្រធានទីមួយ បានតែងតាំង និងញែកចេញជាប៊ីស្សពទាំងអស់ ។ នៅក្នុងសាសនាចក្រសព្វថ្ងៃ ការណ៍នេះនៅតែពិតចំពោះគណៈប៊ីស្សពជាអធិបតី ។ ទោះជាយ៉ាងណាក៏ដោយ ការហៅ ការតែងតាំង និងការញែកចេញនៃពួកប៊ីស្សព គឺត្រូវបានដឹកនាំដោយប្រធានស្ដេក នៅក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ ។ ប្រធានស្ដេកម្នាក់ ដោយមានការគាំទ្រមកពីទីប្រឹក្សារបស់លោក នៅក្នុងគណៈប្រធានស្ដេក ស្វែងរកវិវរណៈដើម្បីស្គាល់នៅពេលណាត្រូវហៅប៊ីស្សពថ្មី ឬត្រូវហៅនរណា ។ លោកផ្ញើអនុសាសន៍របស់លោកទៅកាន់គណៈប្រធានទីមួយសុំការអនុមតិ ។ នៅពេលគណៈប្រធានទីមួយ អនុមតិការហៅរួចហើយ នោះពួកលោក អនុញ្ញាតឲ្យប្រធានស្ដេកតែងតាំង និងញែកចេញដល់ប៊ីស្សពថ្មី ។ ( សម្រាប់ព័ត៌មានបន្ថែម សូមមើល *ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* [ ឆ្នាំ ២០១០ ] ១៩.៦) ។

- ហេតុអ្វីក៏វាសំខាន់ចំពោះអ្នកដើម្បីដឹងថា គណៈប្រធានទីមួយ បានអនុមតិការហៅរបស់ប៊ីស្សពរបស់អ្នក ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៥–៣៥

*ព្រះអម្ចាស់បញ្ជាឪពុកម្ដាយឲ្យបង្រៀនដំណឹងល្អដល់កូនចៅរបស់ពួកគេ*

សូមឲ្យសិស្សគិតអំពីព្រឹត្តិការណ៍ ដែលពួកគេអាចធ្វើជាឪពុកម្ដាយនៅក្នុងពីរបីឆ្នាំទៀត ។ សូមចង្អុលបង្ហាញថា ព្រះអម្ចាស់ផ្ដល់ដល់ម្ដាយ និងឪពុកទាំងឡាយ នូវទំនួលខុសត្រូវដ៏មហិមាជាច្រើន– ពួកគេត្រូវបង្រៀនដំណឹងល្អដល់កូនចៅរបស់ពួកគេ

ដោយពាក្យសម្ដី និងគំរូ ( សូមមើល គ. និង ស. ២៩:៤៦, ៥០ និង « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ដែលមាននៅក្នុងសេចក្ដីបន្ថែមនៅចុងសៀវភៅសិក្សានេះ ) ។ សូមអញ្ជើញពួកគេឲ្យសរសេរនៅក្នុង សៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរ របស់ពួកគេនូវគោលការណ៍បីយ៉ាង ដែលពួកគេនឹងចង់បង្រៀនដល់កូនចៅរបស់ពួកគេ ។

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមពួកគេឲ្យអានបញ្ជីរបស់ពួកគេដល់គ្នាទៅវិញទៅមក។ បន្ទាប់មក អញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៥–២៧ ជាមួយគ្នា រកមើលនូវអ្វីៗដែលពួកគេអាចបន្ថែមទៅលើបញ្ជីរបស់ពួកគេ ។

*សកម្មភាពជាក្រុមតូច*

សកម្មភាពជាក្រុមតូច អនុញ្ញាតឲ្យសិស្សជាច្រើនចូលរួមបាន ។ វាអាចផ្ដល់បរិយាកាសមួយ ដែលសិស្សអាចមានអារម្មណ៍សុវត្ថិភាពដើម្បីចែកចាយពីអារម្មណ៍ គំនិត និងទីបន្ទាល់ ។ វាអាចផ្ដល់ជាឱកាសដល់សិស្សដើម្បីបង្រៀនដំណឹងល្អដល់គ្នាទៅវិញទៅមកផងដែរ ដែលអាចជួយពួកគេត្រៀមខ្លួនសម្រាប់ឱកាសដែលពួកគេនឹងត្រូវបង្រៀនដំណឹងល្អនៅពេលអនាគត ។ ជាទូទៅ សិស្សនឹងចូលរួមនៅក្នុងសកម្មភាពទាំងនេះដោយចំណាប់អារម្មណ៍កាន់តែខ្លាំង បើអ្នកអញ្ជើញពួកគេឲ្យត្រៀមខ្លួនចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់អំពីអ្វីមួយដែលពួកគេនឹងរៀន ។

- តើព្រះអម្ចាស់បានបញ្ជាដល់ឪពុកម្ដាយឲ្យបង្រៀនកូនចៅរបស់ពួកគេអ្វីខ្លះ ? ( សិស្សគួរប្រាប់នូវគោលលទ្ធិ ដូចខាងក្រោម ៖ **ព្រះអម្ចាស់បានបញ្ជាឲ្យ ឪពុកម្ដាយបង្រៀនកូនៗរបស់ពួកគេឲ្យយល់ គោលលទ្ធិអំពី ការប្រែចិត្ត, សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ, បុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។** អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំឃ្លានៅក្នុង ខទី ២៥ ដែលបង្រៀនពីគោលលទ្ធិនេះ ) ។
- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់សម្រាប់កូនតូចៗយល់អំពីការប្រែចិត្ត ? សេចក្ដីជំនឿលើព្រះគ្រីស្ទ ? ពិធីបុណ្យជ្រមុជទឹក ? អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ?

សូមអញ្ជើញសិស្សឲ្យសរសេរអំពីគ្រាមួយ ដែលពួកគេបានឃើញឪពុកម្ដាយបង្រៀនគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៥ ។ ក្រោយពីពួកគេមានពេលសរសេរហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។

សូមឲ្យសិស្សបន្តធ្វើការជាដៃគូនៅក្នុងសកម្មភាពបន្ទាប់ ។ សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៨–៣១ ព្រះអម្ចាស់បានប្រទានការប្រឹក្សាបន្ថែមដល់ឪពុកម្ដាយ ។ សូមឲ្យច្បាប់ចម្លងនៃព័ត៌មានដូចខាងក្រោមមួយច្បាប់ទៅដល់ដៃគូនិមួយៗ ។ សូមលើកទឹកចិត្តដៃគូទាំងឡាយឲ្យអានវគ្គគម្ពីរនិមួយៗ ហើយពិភាក្សាអំពីសំណួរជាមួយគ្នា ។ សូមពន្យល់ថា នៅពេលពួកគេបានបញ្ចប់ នោះពួកគេនឹងរៀបរាប់អំពីការរកឃើញរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

១. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៨ ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បញ្ជាដល់ឪពុកម្ដាយឲ្យបង្រៀនកូនចៅរបស់ពួកគេ ។
   - ហេតុអ្វីអ្នកគិតថា វានឹងសំខាន់ចំពោះអ្នកដើម្បីបង្រៀនកូនចៅឲ្យអធិស្ឋាន ?
   - តើអ្នកត្រូវបានបង្រៀនឲ្យអធិស្ឋានយ៉ាងដូចម្ដេច ? តើការអធិស្ឋានបានប្រទានពរដល់អ្នក និងគ្រួសារអ្នកយ៉ាងដូចម្ដេច ?
   - តើអ្នកគិតថា « ឲ្យដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់ » មានន័យយ៉ាងដូចម្ដេច ?

២. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៩ ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បញ្ជាឲ្យយើងធ្វើ ។
   - តើអ្នករៀនអ្វីខ្លះអំពីការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ?
   - តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបានបរិសុទ្ធ ?

៣. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៣០ ហើយរកមើលការព្រមានរបស់ព្រះអម្ចាស់ ។ សូមកត់ចំណាំថា ពាក្យ *ខ្ជិលច្រអូស* សំដៅទៅលើនរណាម្នាក់ដែលខ្ជិល ។
   - តើអ្នកបានមើលឃើញពរជ័យដែលកើតចេញមកពីការខិតខំធ្វើការយ៉ាងលំបាកនៅពេលណា ?

   សូមអាននូវការដកស្រង់ដូចខាងក្រោមមកពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន ៖*

   « ព្រះអម្ចាស់បានបញ្ជាដល់យើងកុំឲ្យខ្ជិលច្រអូស ។ ភាពខ្ជិលច្រអូស អាចដឹកនាំទៅរកអាកប្បកិរិយាមិនសមរម្យ ធ្វើឲ្យខូចទំនាក់ទំនង និងមានបាប ។ ទម្រង់មួយនៃភាពខ្ជិលច្រអូសគឺការចំណាយពេលហួសហេតុទៅលើសកម្មភាពទាំងឡាយ ដែលរាំងអ្នកពីកិច្ចការដែលមានប្រយោជន៍ ដូចជាការប្រើអ៊ីនធឺណែត លេងវីដេអូហ្គេម និង មើលទូរទស្សន៍ជាដើម » (*ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ៤០ ) ។
   - តើភាពខ្ជិលច្រអូលនាំទៅរកសេចក្ដីទុច្ចរិតយ៉ាងដូចម្ដេច?
   - តើរឿងមួយចំនួនណាខ្លះ ដែលអាចនឹងជួយមនុស្សម្នាក់យកឈ្នះលើទំនោរទៅរកភាពខ្ជិលច្រអូស ?

៤. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៣១–៣២ រួចហើយកមើលនូវការប្រឹក្សារបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធក្នុងស៊ីយ៉ូន ។
- តើអ្នកគិតថាការលោភលន់អាចនឹងជះឥទ្ធិពលដល់គ្រួសារមួយយ៉ាងដូចម្ដេច ?
- តើយើងអាចធ្វើអ្វីខ្លះនៅក្នុងជីវិតរបស់យើងដើម្បីយកឈ្នះលើភាពអត្មានិយម និងភាពលោភលន់ ?

បន្ទាប់ពីសិស្សបញ្ចប់សកម្មភាពនេះ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។ ( សូមគិតសុំឲ្យសិស្សម្នាក់សរសេរចម្លើយរបស់សិស្សផ្សេងៗនៅលើក្ដារខៀន ) ។ គោលការណ៍មួយ ដែលអ្នកអាចចង់គូសបញ្ជាក់ដកស្រង់មកពី ខ ៣១ និង ៣២ គឺថា **យើងត្រូវលុបបំបាត់ចោលនូវភាពខ្ជិលច្រអូស និងភាពលោភលន់ចេញពីក្នុងជីវិតរបស់យើង ។** ( នៅពេលសិស្សពិភាក្សាអំពីគោលការណ៍នេះ អ្នកអាចចង្អុលបង្ហាញថា យើងពុំចាំបាច់តម្រូវឲ្យមានអ្វីៗទាំងអស់ដែលមិត្តរបស់យើងមាន ដើម្បីមានភាពរីករាយនោះទេ ) ។

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ចំពោះឪពុកម្ដាយ បង្រៀន និងរស់នៅតាមបទដ្ឋានដំណឹងល្អ ?
- តើយុវជន និងយុវនារី អាចធ្វើអ្វីខ្លះ ដើម្បីជួយក្រុមគ្រួសាររបស់ពួកគេ « ឲ្យដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់ » ?

បើអ្នកជាឪពុកម្ដាយ សូមពិចារណាអំពីការបង្ហាញនូវការថ្លែងអំណរគុណចំពោះរបៀបនានាដែលកូនៗរបស់អ្នក បានធ្វើតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨ ។ បន្ទាប់មក សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយដែលនឹងជួយពួកគេត្រៀមខ្លួនធ្វើជាឪពុកម្ដាយល្អ ។ ឬអញ្ជើញពួកគេឲ្យសរសេរគោលដៅមួយដើម្បីជួយឪពុកម្ដាយរបស់ពួកគេក្នុងទំនួលខុសត្រូវរបស់ពួកគាត់ ។ បើមានពេល អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយគោលដៅរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។

មេរៀនទី ៧៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១

## បុព្វកថា

នៅចុងខែតុលា ឬដើមខែវិច្ឆិកា ឆ្នាំ ១៨៣១ អូលីវើរ ខៅឌើរី បានទទួលការចាត់តាំងមួយដើម្បីនាំយកឯកសារសរសេរដោយដៃសម្រាប់ព្រះគម្ពីរនៃព្រះបញ្ញត្តិមកពីរដ្ឋ អូហៃអូ ទៅកាន់ រដ្ឋមិសសួរី ។ នៅរដ្ឋ មិសសួរី វិលលាម ដ័បុលយូ ហ្វែលប្ស នឹងបោះពុម្ពព្រះគម្ពីរនៅក្នុងរោងពុម្ពរបស់គាត់ ។ នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានចាត់តាំង យ៉ូហាន វិតមើរ ឲ្យធ្វើជាដៃគូធ្វើដំណើររបស់ អូលីវើរ ហើយបានបញ្ជាគាត់ឲ្យបន្តនៅក្នុងកាតព្វកិច្ចរបស់គាត់ ក្នុងនាមជាអ្នកប្រវត្តិសាស្ត្រសាសនាចក្រ ( សូមមើល គ. និង ស. ៦៩) ។ នៅថ្ងៃបន្ទាប់ព្រះអម្ចាស់បានតែងតាំងបុរសប្រាំមួយនាក់ ឲ្យបម្រើជាអ្នកកាន់កាប់ត្រួតត្រាលើវិវរណៈ ( សូមមើល គ. និង ស. ៧០) ។ នៅក្នុងខែ ធ្នូ ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានបញ្ជា យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ឲ្យបម្រើបេសកកម្មមួយដើម្បីលុបបំបាត់ចោលនូវអារម្មណ៍អមិត្តទាស់នឹងសាសនាចក្រ ហើយត្រៀមផ្លូវសម្រាប់វិវរណៈ និងបទបញ្ញត្តិជាច្រើន ដែលត្រូវបោះពុម្ព ( សូមមើល គ និង ស ៧១) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩

*ព្រះអម្ចាស់បើកសម្ដែងពីសារៈសំខាន់នៃការរក្សាប្រវត្តិសាស្ត្រ*

ពីមុនថ្នាក់ចាប់ផ្ដើម សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖*តើធ្លាប់មាននរណាម្នាក់ ទុកចិត្តអ្នកដោយផ្ញើរបស់មានតម្លៃឲ្យអ្នកមើលថែដែរឬទេ ?*

នៅពេលចាប់ផ្ដើមមេរៀន សូមផ្ដល់ពេលដល់សិស្សឲ្យគិតអំពីសំណួរនៅលើក្ដារខៀន ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកត្រូវបានគេទុកចិត្តឲ្យធ្វើអ្វីខ្លះ ? តើការទុកចិត្តនោះ មានឥទ្ធិពលលើការយកចិត្តទុកដាក់របស់អ្នកទៅលើរបស់មានតម្លៃនោះយ៉ាងដូចម្ដេច ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានឲ្យឮៗនូវការណែនាំ នៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែល អូលីវើរ ខៅឌើរី ត្រូវបានទទួលនូវការទុកចិត្ត ។

- តើអូលីវើរ ខៅឌើរី ត្រូវបានទទួលនូវការទុកចិត្តលើអ្វីខ្លះ ?
- បើអ្នកត្រូវបានទទួលនូវការទុកចិត្តឲ្យថែទាំវត្ថុមានតម្លៃទាំងនេះ តើអ្នកនឹងមើលថែវាយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការប្រឹក្សា ដែលព្រះអម្ចាស់បានផ្ដល់ឲ្យ ទាក់ទងនឹងវត្ថុមានតម្លៃទាំងនេះ ។

- ហេតុអ្វីក៏អ្នកគិតថា វានឹងជាការឈ្លាសវៃ ដើម្បីមានមនុស្សច្រើនជាងម្នាក់ដើម្បីកាន់វត្ថុមានតម្លៃទាំងនេះ ?

សូមពន្យល់ថា ព្រះអម្ចាស់ ទុកព្រះទ័យលើ យ៉ូហាន វិតមើរ នូវទំនួលខុសត្រូវសំខាន់ផ្សេងទៀត បន្ថែមពីលើការជួយ អូលីវើរ នាំយកវិវរណៈ និងប្រាក់កាសទៅរដ្ឋ មិសសួរី ។ សូមអញ្ជើញសិស្សមួយចំនួនឲ្យផ្លាស់វេនគ្នាអានឮៗ ដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩:៣–៨ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីផ្សេងទៀតដែលព្រះអម្ចាស់បានទុកចិត្តដល់ យ៉ូហាន វិតមើរ ឲ្យធ្វើ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចនឹងចង់រំឭកសិស្សថា យ៉ូហាន វិតមើរ ត្រូវបានហៅបម្រើជាអ្នកកត់ត្រា និងអ្នកប្រវត្តិសាស្ត្រសាសនាចក្រ នៅដើមឆ្នាំ ១៨៣១ ( សូមមើល គ. និង ស. ៤៧) ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩:៣ តើព្រះអម្ចាស់បានបញ្ជា យ៉ូហាន វិតមើរឲ្យកត់ត្រាអ្វីខ្លះ ?
- ស្របតាម ខ ៨ ហេតុអ្វីបានវាសំខាន់ដើម្បីឲ្យ យ៉ូហាន វិតមើរ កត់ត្រាប្រវត្តិសាសនាចក្រ ?

សូមពន្យល់ថា ចាប់តាំងពីជំនាន់ យ៉ូសែប ស្ម៊ីធ អ្នកដឹកនាំសាសនាចក្រ បានព្យាយាមធ្វើតាមការដឹកនាំរបស់ព្រះអម្ចាស់ឲ្យកត់ត្រា « ការណ៍ដ៏សំខាន់ៗទាំងឡាយ. . . ពីសាសនាចក្រ » ដោយឧស្សាព្យាយាម (គ. និង ស. ៦៩:៣) ។ ពួកគេបានរក្សា « គ្រប់ការទាំងអស់ដែលនឹងទៅជាការល្អដល់សាសនាចក្រ » (គ. និង ស. ៦៩:៨) ទោះជាពេលដែលការណ៍ទាំងនោះមួយចំនួនអាចនឹងបណ្ដាលឲ្យមានការខ្មាស់អៀនខ្លះៗក្ដី ។ ឧទាហរណ៍ គោលលទ្ធិ និង សេចក្ដីសញ្ញា អាចមាននូវវិវរណៈមួយចំនួន ដែលព្រះអម្ចាស់បានវាយផ្ចាលពួកអ្នកដឹកនាំសាសនាចក្រជំនាន់មុន ( សូមមើល គ. និង ស. ៣:៥–៩, ៩៣:៤១–៥០) ។ សព្វថ្ងៃនេះ អ្នកប្រវត្តិសាស្ត្រសាសនាចក្រ នៅក្រោមការដឹកនាំនៃគណៈប្រធានទីមួយ ដឹកនាំកិច្ចខិតខំនៃការិយាល័យផ្នែកប្រវត្តិសាស្ត្រសាសនាចក្រ ឲ្យរក្សាប្រវត្តិត្រឹមត្រូវមួយ « នៃរឿងសំខាន់ៗទាំងអស់ » ។

ដើម្បីជួយសិស្សស្គាល់ពីគោលការណ៍មួយនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩:៣, ៨ សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *ព្រះអម្ចាស់រំពឹងឲ្យរក្សាប្រវត្តិសាស្ត្រសម្រាប់ជាការល្អនៃ . . .*

សូមសួរសិស្សថាតើពួកគេនឹងបំពេញសេចក្ដីថ្លែងការណ៍នេះ អាស្រ័យទៅលើ ខ ៣ និង ខ ៨ តាមរបៀបណា ។ នៅពេលពួកគេឆ្លើយតប សូមបំពេញសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ៖ **ព្រះអម្ចាស់រំពឹងឲ្យរក្សាប្រវត្តិសាស្ត្រសម្រាប់ជាការល្អនៃសាសនាចក្រ និងជំនាន់ដែលកំពុងពេញវ័យ ។** អ្នកអាចនឹងចង់ឲ្យប្រាកដថា សិស្សបានយល់ថា ឃ្លា « ជំនាន់ដែលកំពុងពេញវ័យ » សំដៅទៅលើពួកគេ ដែលជាយុវវ័យនៃសាសនាចក្រ ។

- តាមគំនិតរបស់អ្នក តើប្រវត្តិសាសនាចក្រ និងប្រវត្តិផ្ទាល់ខ្លួន មានប្រយោជន៍ដល់សាសនាចក្រយ៉ាងដូចម្ដេច ? តើវាផ្ដល់ប្រយោជន៍ដល់ជំនាន់ដែលកំពុងពេញវ័យយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សគិតអំពីដំណើររឿងមកពីប្រវត្តិសាស្ត្រសាសនាចក្រ ឬប្រវត្តិគ្រួសាររបស់ពួកគេ ដែលបានជួយដល់ពួកគេ ។ សូមបំបែកសិស្សជាគូរៗ ហើយសុំឲ្យពួកគេចែកចាយដំណើររឿងរបស់ពួកគេជាមួយគ្នាទៅវិញទៅមក ។ ក៏សុំឲ្យពួកគេនិយាយអំពីរបៀបដែលដំណើររឿងទាំងឡាយ មានឥទ្ធិពលលើពួកគេ ។ ឬអ្នកអាចនឹងចង់អញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយដំណើររឿងទាំងឡាយរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០

*ព្រះអង្គសង្គ្រោះបានតែងតាំងអ្នកកាន់កាប់ត្រួតត្រាឲ្យមើលថែវិវរណៈទាំងឡាយរបស់ទ្រង់*

សូមអញ្ជើញសិស្សឲ្យអានស្ងាត់ៗនូវការណែនាំ នៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០ ហើយរកមើលនូវអ្វីដែលប្រវត្តិរបស់ យ៉ូសែប ស្ម៊ីធ បានថ្លែងអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា (ពីដើមត្រូវបានហៅថា ព្រះគម្ពីរនៃព្រះបញ្ញត្តិ ) ។

- តើព្យាការីពិពណ៌នាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា យ៉ាងដូចម្ដេច ?

***សូមជួយសិស្សឲ្យទទួលអារម្មណ៍ពីសេចក្ដីពិត និង សារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍ទាំងឡាយ***

របៀបមួយដើម្បីជួយសិស្សទទួលអារម្មណ៍ពីសេចក្ដីពិតនិងសារៈសំខាន់នៃគោលលទ្ធិនិងគោលការណ៍ទាំងឡាយ គឺត្រូវលើកទឹកចិត្តពួកគេឲ្យនឹកគិតអំពីបទពិសោធន៍ផ្ទាល់ខ្លួន ។ នៅពេលពួកគេពិចារណាអំពីបទពិសោធន៍របស់ពួកគេ ហើយចែកចាយដោយត្រឹមត្រូវ នោះព្រះវិញ្ញាណបរិសុទ្ធនឹងជួយពួកគេមើលឃើញពរជ័យកាន់តែច្បាស់ ដែលពួកគេ និងអ្នកផ្សេងទៀតបានទទួល តាមរយៈការរស់នៅតាមគោលលទ្ធិ និងគោលការណ៍ដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:១ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ឲ្យរកមើលឈ្មោះនៃអ្នកដឹកនាំសាសនាចក្រប្រាំមួយនាក់ ។ បន្ទាប់មកអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:២–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការទទួលខុសត្រូវដែលព្រះអម្ចាស់បានប្រទានដល់បុរសទាំងប្រាំមួយនាក់នេះ ។

- តើទំនួលខុសត្រូវអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រគល់ទៅឲ្យបុរសទាំងប្រាំមួយនាក់ ? ( ពួកគេគឺត្រូវកាន់កាប់ត្រួតត្រាលើវិវរណៈ និងបទបញ្ញត្តិទាំងឡាយ ) ។

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:៤ តើព្រះអម្ចាស់បានមានបន្ទូលអ្វីខ្លះ ថាទ្រង់នឹងតម្រូវឲ្យបុរសទាំងនេះធ្វើអ្វីខ្លះនៅក្នុងថ្ងៃនៃការជំនុំជំរះ ? ( ទ្រង់នឹងតម្រូវនូវដំណើររឿងមួយអំពីការកាន់កាប់ត្រួតត្រារបស់ពួកគេ ។ ជាពាក្យម្យ៉ាងទៀត ទ្រង់នឹងសុំឲ្យពួកគាត់រាយការណ៍អំពីការបម្រើរបស់ពួកគាត់ ) ។

- តើការណ៍នេះផ្ដល់ជាយោបល់អំពីអ្វីដែលព្រះអម្ចាស់នឹងតម្រូវពីយើងនៅថ្ងៃនៃការជំនុំជំរះអ្វីខ្លះ ? ( នៅពេលសិស្សឆ្លើយតប សូមជួយពួកគេឲ្យស្គាល់សេចក្ដីពិតដូចខាងក្រោម ៖ **ព្រះអម្ចាស់នឹងឲ្យយើងទទួលខុសត្រូវ ចំពោះកាតព្វកិច្ចទាំងឡាយដែលទ្រង់បាន ទុកព្រះទ័យមកលើយើង ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

- តើសេចក្ដីពិតនេះ មានឥទ្ធិពលទៅលើរបៀបដែលយើងឆ្លើយតបចំពោះការហៅ និងការចាត់តាំងទាំងឡាយក្នុងសាសនាចក្ររបស់យើង យ៉ាងដូចម្ដេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:៥–១៨ ដោយការពន្យល់ថា ព្រះអម្ចាស់បានប្រាប់ដល់បុរសទាំងប្រាំមួយនាក់ឲ្យកាន់កាប់ត្រួតត្រាលើវិវរណៈទាំងឡាយ « ជាមុខងាររបស់ពួកគេនៅក្នុងសាសនាចក្រនៃព្រះ គឺដើម្បីចាត់ចែងការណ៍ទាំងនោះ និងរឿងរ៉ាវទាំងនោះ មែនហើយ គឺផលប្រយោជន៍ដែលបានមកពីការណ៍ទាំងនោះ » (គ. និង ស. ៧០:៥) ។ ស្របទៅតាមក្រឹត្យវិន័យនៃការថ្វាយ រាល់ចំណូលដែលពួកគេបានទទួល ដែលលើសពីតម្រូវការរបស់ពួកគេ គឺត្រូវប្រគល់ទៅក្នុងឃ្លាំងរបស់ព្រះអម្ចាស់ ដើម្បីមើលថែទាំដល់ជនក្រីក្រ ( សូមមើល គ. និង ស. ៧០:៧) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១

*ព្រះអម្ចាស់បង្រៀន យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន អំពីរបៀបឆ្លើយតបចំពោះការរិះគន់ដល់សាសនាចក្រ*

សូមសួរដល់សិស្សបើមានពួកគេណាម្នាក់ធ្លាប់ស្ដាប់ឮការរិះគន់អំពីសាសនាចក្រ ។ អ្នកអាចនឹងគិតអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់អំពីបទពិសោធន៍របស់ពួកគេ ។

- តើរបៀបត្រឹមត្រូវដើម្បីឆ្លើយតបចំពោះការរិះគន់អំពីសាសនាចក្រមានអ្វីខ្លះ ?

ដើម្បីជួយសិស្សយល់អំពីបរិបទនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១ សូមអញ្ជើញសិស្សម្នាក់ឲ្យអានព័ត៌មានដូចខាងក្រោមឲ្យឮៗ ( ឬអានឃ្លាដោយខ្លួនឯង ) ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់អំពីរបៀបដែលសាសនាចក្រ និងអ្នកដឹកនាំ ត្រូវបានគេរិះគន់នៅគ្រានៃវិវរណៈនេះត្រូវបានផ្ដល់ឲ្យ ។

អែសរ៉ា ប៊ូត គឺជាអតីតអាចារ្យពួកមេតូឌីស ដែលបានក្លាយជាសមាជិកសាសនាចក្រ បន្ទាប់ពីបានអានព្រះគម្ពីរមរមន បាននិយាយជាមួយយ៉ូសែប ស៊្មីធ ហើយបានធ្វើជាសាក្សីនៃការព្យាបាលមួយ ។ គាត់បានធ្វើដំណើរជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ទៅកាន់រដ្ឋ មិសសូរី ប៉ុន្តែបានខកចិត្ត នៅពេលគាត់ពុំអាចធ្វើអព្ភូតហេតុដើម្បីបញ្ចុះបញ្ចូលអ្នកដទៃជឿសេចក្ដីពិតបាន ។ បន្ថែមពីលើនោះ ប៊ូត ពុំជឿថា ទង្វើរបស់ យ៉ូសែប ស៊្មីធ សមរម្យដើម្បីធ្វើជាព្យាការី ឬអ្នកដឹកនាំខាងវិញ្ញាណនោះទេ ។ គាត់បានរិះគន់ដល់ យ៉ូសែប ស៊្មីធ យ៉ាងខ្លាំង បានចាកចេញពីសាសនាចក្រ ហើយបានសរសេរសំបុត្ររិះគន់ប្រាំបួនច្បាប់ដល់សាសនាចក្រ និងពួកអ្នកដឹកនាំ ។ សំបុត្រទាំងនេះ បានបោះពុម្ពនៅក្នុងកាសែតមួយ ដែលហៅថា *Ohio Star, (តារាអូហៃអូ)* បាននាំមនុស្សមួយចំនួនឲ្យមានអារម្មណ៍ពុំចូលចិត្តសាសនាចក្រ និងអ្នកដឹកនាំទាំងឡាយ ។ ប្រវត្តិរបស់ ព្យាការី យ៉ូសែប ស៊្មីធ បានហៅការសរសេររបស់ អែសរ៉ា ប៊ូត ថាជា « លំដាប់សំបុត្រ ដែលលាបពណ៌ ការក្លែងបន្លំ និងបំណងឥតប្រយោជន៍ដើម្បីបំផ្លាញកិច្ចការនៃព្រះអម្ចាស់ បានបើកឲ្យឃើញនូវភាពទន់ខ្សោយ ភាពទុច្ចរិត និង ភាពល្ងង់របស់គាត់ [ប៊ូត] ហើយបានបង្កើននូវការរំពុកខ្លួនគ្រាន់តែរឿងដ៏ខ្មាស់អៀននេះ ដើម្បីឲ្យពិភពលោកមានការជឿងឆ្ងល់ » (*History of the Church* ១:២១៦–១៧ ) ។ ស៊ីម៉ូនស៍ រ៉ៃឌើរ ជាសមាជិកដែលមានការអាក់អន់ចិត្តម្នាក់ទៀត បានផ្ដល់ច្បាប់ចម្លងនៃវិវរណៈមួយចំនួនទៅឲ្យអ្នកកាសែតផ្សេងទៀត ដោយប៉ុនប៉ងធ្វើឲ្យមនុស្សបាក់ទឹកចិត្តពុំចូលរួមក្នុងសាសនាចក្រ ។

សូមពន្យល់ថា ការរំខានដែលបណ្ដាលមកពី អែសរ៉ា ប៊ូត និង ស៊ីម៉ូនស៍ រ៉ៃឌើរ បានក្លាយទៅជាបញ្ហាកាន់តែធ្ងន់ធ្ងរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១:១–៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ឲ្យធ្វើ ដើម្បីរម្ងាប់នូវអារម្មណ៍អមិត្ត ដែលជាលទ្ធផលមកពីអត្ថបទកាសែត ។

- ស្របតាម ខ ១ តើព្រះអម្ចាស់ណែនាំ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ឲ្យធ្វើអ្វីខ្លះ ដើម្បីរម្ងាប់អារម្មណ៍អវិជ្ជមានរបស់ប្រជាជនអំពីសាសនាចក្រ ? ( ពួកគេត្រូវប្រើបទគម្ពីរ និងព្រះចេស្ដានៃព្រះវិញ្ញាណ ដែលព្រះអម្ចាស់នឹងប្រទានដល់ពួកគេ ) ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីការណែនាំនេះ អំពីរបៀបដើម្បីឆ្លើយតបទៅនឹងការរិះគន់របស់សាសនាចក្រ ? ( ទោះជាសិស្សអាចនឹងផ្ដល់ចម្លើយត្រឹមត្រូវជាច្រើនក្ដី សូមប្រាកដថាពួកគេបានប្រាប់គោលការណ៍ដូចខាងក្រោម ៖ **នៅពេលមនុស្សរិះគន់សាសនាចក្រ យើងអាចឆ្លើយតបដោយការចែកចាយសេចក្ដីពិតចេញមកពីបទគម្ពីរ ហើយធ្វើតាមការដឹកនាំពីព្រះវិញ្ញាណ** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើយើងអាចធ្វើអ្វីខ្លះនាពេលឥឡូវនេះ ដើម្បីឆ្លើយតបចំពោះការរិះគន់ទាស់នឹងសាសនាចក្រ ឬអ្នកដឹកនាំ ?

ដើម្បីជួយសិស្សយល់អំពីសារៈសំខាន់នៃការមានការណែនាំពីព្រះវិញ្ញាណ នៅពេលពួកគេឆ្លើយតបចំពោះការរិះគន់ទាស់នឹងសាសនាចក្រ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ រ៉ូប៊ឺត ឌី ហែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវរបៀបដែលព្រះវិញ្ញាណអាចជួយយើងឆ្លើយតបចំពោះការរិះគន់ទាស់នឹងសាសនាចក្រ ។



« ពេលយើងឆ្លើយតបនឹងអ្នកដទៃ កាលៈទេសៈនីមួយៗនឹងខុសគ្នា ។ សំណាងល្អ ព្រះអម្ចាស់ជ្រាបពីដួងចិត្តនៃអ្នកចោទប្រកាន់យើង និង របៀបដែលយើងអាចឆ្លើយតបទៅកាន់ពួកគេវិញដោយមានប្រសិទ្ធភាពបំផុត ។ *ក្នុងនាមជាសិស្សដ៏ពិតស្វែងរកការណែនាំមកពីព្រះវិញ្ញាណ នោះពួកគេទទួលបានការបំផុសគំនិតដែលទាក់ទងនឹងរឿងប្រឈមនីមួយៗ* ។ ហើយនៅគ្រប់ការប្រឈមនីមួយៗ *សិស្សដ៏ពិតឆ្លើយតបតាមរបៀបដែលអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់* The Price of Discipleship » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧៣ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១:៥–១១ ឲ្យឮៗ។ សូមឲ្យសិស្សរកមើលការប្រឹក្សា និងការលួងលោមចិត្ត ដែលព្រះអម្ចាស់បានប្រទានដល់អ្នកទាំងឡាយដែលឆ្លើយតបចំពោះការរិះគន់ទាស់នឹងសាសនាចក្រ ។

- តើមានការប្រឹក្សាអ្វីខ្លះ ដែលអ្នកឃើញនៅក្នុង ខ ៧?

សូមពន្យល់ថា ស៊ីឌនី រិកដុន បានគោរពតាមការប្រឹក្សារបស់ព្រះអម្ចាស់ ហើយបានអញ្ជើញ អែសរ៉ា ប៊ូថ ឲ្យចូលរួមនឹងគាត់នៅក្នុងទីក្រុង រ៉ាវែនណា ជាកន្លែងដែលពួកគេនឹងពិភាក្សាជាសាធារណៈអំពីសំបុត្រដែល អែសរ៉ា បានបញ្ជូនទៅឲ្យអ្នកកាសែត ។ ស៊ីឌនី ក៏បានសំណូមពរឲ្យ ស៊ីម៉ូនស៍ រ៉ៃឌើរ ពិភាក្សាជាសាធារណៈអំពីព្រះគម្ពីរមរមន ។ បុរសទាំងពីរនាក់ពុំទទួលយកការអញ្ជើញនោះទេ ។ ស៊ីឌនី នៅតែថ្លែងទីបន្ទាល់អំពីសេចក្ដីពិត នៅ រ៉ាវែនណា និងទីតាំងផ្សេងទៀត ។

- តើការប្រឹក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១:៨–១០ ជាការលួងលោមចិត្តដល់អ្នកទាំងឡាយដែលឆ្លើយតបទៅនឹងរិះគន់ទាស់នឹងសាសនាចក្រយ៉ាងដូចម្ដេចខ្លះ ?

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីត្រៀមខ្លួនកាន់តែល្អប្រសើរ ដើម្បីឆ្លើយតបទៅនឹងការរិះគន់ទាស់នឹងសាសនាចក្រ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសាសនាចក្រ និងអ្នកដឹកនាំ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៧១ ( មេរៀនទី ១៥ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៧១ ( មេរៀនទី ១៥ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៦៦)

អំឡុងពេលសិក្សាមេរៀននេះ សិស្សបានរៀនថា ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ នឹងចេញរហូតដល់ចុងផែនដី ។ ពួកគេបានឃើញថា យើងមានទំនួលខុសត្រូវមួយដើម្បីត្រៀមខ្លួនយើង និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧)

នៅក្នុងមេរៀននេះ សិស្សបានរកឃើញគោលលទ្ធិខាងក្រោម ៖ ព្រះអម្ចាស់ឮការអធិស្ឋានរបស់យើង ហើយជ្រាបដឹងពីដួងចិត្តរបស់យើង ប្រសិនបើយើងទុកឲ្យភាពភ័យខ្លាចមាននៅក្នុងដួងចិត្តរបស់យើង នោះយើងអាចនឹងបាត់បង់ពរជ័យនោះ ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងកម្ចាត់ខ្លួនចេញពីសេចក្ដីច្រណែន និងសេចក្ដីខ្លាច ហើយបន្ទាបខ្លួន និងបន្តនៅក្នុងភាពអត់ធន់ នោះយើងនឹងអាចនៅជាប់នៅក្នុងទីវត្តមានរបស់ព្រះអម្ចាស់ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨)

ជាផ្នែកនៃមេរៀននេះ សិស្សបានរៀនថា នៅពេលពួកអ្នកបម្រើរបស់ព្រះអម្ចាស់ត្រូវបានបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះពាក្យសម្ដីរបស់ពួកលោកនឹងដឹកនាំមនុស្សទៅរកសេចក្ដីសង្គ្រោះ ។ សិស្សក៏បានរៀនផងដែរថា ប៊ីស្សពត្រូវតែបានអនុមតិដោយគណៈប្រធានទីមួយ និង ត្រូវបានតែងតាំងដោយអ្នកមានសិទ្ធអំណាចត្រឹមត្រូវ ។ លើសពីនេះទៀត សិស្សបានឃើញថាព្រះអម្ចាស់បានបញ្ជាដល់ឪពុកម្ដាយឲ្យបង្រៀនកូនៗរបស់ខ្លួនឲ្យយល់គោលលទ្ធិនៃការប្រែចិត្ត, សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ, បុណ្យជ្រមុជទឹក និង អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១)

ចេញពីព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះ យ៉ូហាន វិតមើរ នោះសិស្សបានរៀនថា ព្រះអម្ចាស់រំពឹងឲ្យរក្សាប្រវត្តិសាស្ត្រសម្រាប់ជាការណ៍ល្អនៃសាសនាចក្រ និងជំនាន់ដែលកំពុងពេញវ័យ ។ សិស្សក៏បានឃើញផងដែរថា ព្រះអម្ចាស់នឹងឲ្យយើងទទួលខុសត្រូវ ចំពោះកាតព្វកិច្ចទាំងឡាយ ដែលទ្រង់បានទុកព្រះទ័យមកលើយើងផងដែរ ។ ជាចុងក្រោយសិស្សបានរៀនថា នៅពេលមនុស្សរិះគន់សាសនាចក្រ នោះយើងអាចឆ្លើយតបដោយការចែកចាយសេចក្ដីពិតចេញមកពីបទគម្ពីរ ហើយធ្វើតាមការដឹកនាំពីព្រះវិញ្ញាណ ។

## សេចក្ដីផ្ដើម

មេរៀននេះផ្ដោតលើព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះ វិលលាម អ៊ី ម៉ុកឡេលិន នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦ ។ តាមរយៈការសិក្សារបស់ពួកគេនៃកណ្ឌនេះ នោះសិស្សអាចរៀនពីសារៈសំខាន់នៃការប្រែចិត្តពីអំពើបាបទាំងអស់របស់ខ្លួនដកយកចេញពីជីវិតពួកគេនូវអ្វីៗដែលរារាំងការរីកចម្រើនខាងវិញ្ញាណរបស់ពួកគេ និង បន្តនៅស្មោះត្រង់រហូតដល់ទីបំផុត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦

*ព្រះអម្ចាស់បញ្ជាឲ្យវីលលាម អ៊ី ម៉ុកខ្លេលិន ប្រកាសដំណឹងល្អ លះបង់ចោលនូវសេចក្ដីទុច្ចរិតទាំងអស់ ហើយបន្ត ស្មោះត្រង់ដល់ទីបំផុត ។*

មុនចាប់ផ្ដើមថ្នាក់ សូមគូរ រូប ខាងក្រោមនៅលើក្ដារខៀន ។

ឃ្លាតឆ្ងាយពីព្រះ ⟷ ខិតជិតព្រះ

នៅពេលថ្នាក់ចាប់ផ្ដើម សូមអញ្ជើញសិស្សឲ្យពិនិត្យមើលរូបនៅលើក្ដារខៀន ។ សូមឲ្យពួកគេពិចារណាដោយស្ងាត់ស្ងៀមពីកន្លែង ដែលពួកគេនឹងដាក់ខ្លួនពួកគេនៅលើរូបនោះ ។ សូមផ្ដល់យោបល់ផងដែរថា ពួកគេពិចារណាអំពីទិសដៅដែលពួកគេត្រូវផ្លាស់ទី—ទៅកាន់តែជិតនឹងព្រះ ឬទៅកាន់តែឆ្ងាយពីទ្រង់ ។ បន្ទាប់មកអញ្ជើញសិស្សម្នាក់អានឲ្យឮនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកវិធីដែលយើងអាចខិតទៅកាន់តែជិតនឹងព្រះ ។



« ប្រសិនបើអ្នកចង់នៅជិតនឹងនរណាម្នាក់ដែលអ្នកស្រឡាញ់ ប៉ុន្តែជាអ្នកដែលនៅបែកពីអ្នក នោះអ្នកដឹងថាត្រូវធ្វើយ៉ាងណាហើយ ។ អ្នកនឹងរកវិធីមួយដើម្បីនិយាយនឹងពួកគេ អ្នកនឹងស្ដាប់ពួកគេ ហើយអ្នកនឹងរកឃើញដំណោះស្រាយធ្វើរឿងទាំងឡាយសម្រាប់គ្នាទៅវិញទៅមក ។ កាលណាវាកើតឡើងកាន់តែញឹកញាប់ ហើយបន្តទៅកាន់តែយូរ នោះចំណងនៃសេចក្ដីស្រឡាញ់នឹងមានកាន់តែជ្រាលជ្រៅ ។ ប្រសិនបើពេលវេលាជាច្រើនបានកន្លងផុតទៅដោយគ្មានការនិយាយ ការស្ដាប់ និងធ្វើអ្វីបន្តិចសោះនោះ នោះចំណងទំនាក់ទំនងនឹងត្រូវទន់ខ្សោយ ។

« ព្រះគឺល្អឥតខ្ចោះ ព្រមទាំងមានគ្រប់ព្រះចេស្ដា ហើយអ្នក និងខ្ញុំ គឺជាមនុស្សរមែងស្លាប់ ។ ប៉ុន្តែទ្រង់គឺជាព្រះបិតារបស់យើង ទ្រង់ស្រឡាញ់យើង ហើយទ្រង់ប្រទានឱកាសដូចគ្នានេះ ដើម្បីឲ្យយើងខិតទៅកាន់តែជិតនឹងទ្រង់ ក៏ដូចជាមិត្តម្នាក់ដែរ ។ ហើយអ្នកនឹងធ្វើវាតាមរបៀបដែលស្រដៀងគ្នានេះ ៖ ការនិយាយ ការស្ដាប់ និងការធ្វើ » (« To Draw Closer to God » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩១ ទំព័រ ៦៦ ) ។

- យោងតាមប្រធាន អាវរិង តើយើងអាចខិតទៅកាន់តែជិតព្រះយ៉ាងដូចម្ដេច ?

- តើអ្នកគិតថាវាមានន័យយ៉ាងណាដើម្បីនិយាយ ស្ដាប់ និងធ្វើ នៅពេលយើងព្យាយាមខិតទៅកាន់តែជិតព្រះនោះ ?

សូមពន្យល់ថានៅជំនាន់មុនក្នុងសាសនាចក្រ មានបុរសម្នាក់ឈ្មោះ វីលលាម អ៊ី ម៉ុកខ្លេលិន បានខិតទៅកាន់តែជិតព្រះនៅពេលលោកបានរៀនអំពីការស្ដារឡើងវិញនៃដំណឹងល្អ ។ លោកបានជ្រមុជទឹកនៅថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៨៣១ ។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ លោកត្រូវបានតែងតាំងជាអែលឌើរ ហើយគាត់បានរួមដំណើរជាមួយ ហៃរ៉ុម ស៊្មីធ ពីរបីសប្ដាហ៍ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។ នៅខែតុលា ឆ្នាំ ១៨៣១ គាត់ធ្វើដំណើរទៅរដ្ឋ អូហៃអូ សម្រាប់សន្និសីទរបស់សាសនាចក្រ ។ ពេលនៅទីនោះលោកបានជួបនឹងព្យាការីយ៉ូសែប ស្ម៊ីធ ។ នៅខែ តុលា ថ្ងៃទី ២៩ បងប្រុសម៉ុកខ្លេលិនបានអធិស្ឋានជាសម្ងាត់ ទូលសុំដល់ព្រះអម្ចាស់ឲ្យបើកសម្ដែងចម្លើយចំពោះសំណួរជាក់លាក់ចំនួនប្រាំរបស់លោកតាមរយៈព្យាការី ។ ដោយពុំបានប្រាប់អំពីសំណួរដល់យ៉ូសែប ស្ម៊ីធ នោះបងប្រុសម៉ុកខ្លេលិន បានស្នើសុំវិវរណៈមួយ ។ នៅពេលព្យាការីបានសរសេរវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦, បងប្រុស ម៉ុកខ្លេលិនបានរកឃើញថាសំណួរនិមួយៗរបស់លោកត្រូវបានឆ្លើយតប ។ ព្រះអម្ចាស់បានប្រទានដល់លោកនូវការណែនាំ និង ការព្រមានដើម្បីជួយលោកឲ្យនៅស្មោះត្រង់ និងទទួលបានជីវិតដ៏អស់កល្បជានិច្ចនៅទីបំផុត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុ ដែលព្រះអម្ចាស់បានប្រទានពរដល់បងប្រុស វីលលាម ម៉ុកខ្លេលិន នៅអំឡុងវិវរណៈនេះ ។

- ហេតុអ្វីក៏បងប្រុសម៉ុកខ្លេលិន អាចទទួលបានពរជ័យមកពីព្រះអម្ចាស់ ? ( ដោយសារលោកបានងាកចេញពីអំពើបាបរបស់ខ្លួន បានទទួលសេចក្ដីពិតរបស់ព្រះអម្ចាស់ ហើយបានទទួលភាពពេញលេញនៃដំណឹងល្អ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:៣ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា បងប្រុសម៉ុកខ្លេលិន នៅតែចាំបាច់ត្រូវធ្វើ ដើម្បីគាប់ព្រះទ័យទ្រង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ស្អាតហើយ ប៉ុន្តែពុំមែនទាំងអស់ទេ » នោះ ? ( អ្នកអាចនឹងចាំបាច់ត្រូវជួយសិស្សឲ្យយល់ថា ទោះបីជាបងប្រុស ម៉ុកខ្លេលិន បានធ្វើការរីកចម្រើនយ៉ាងខ្លាំងក្ដី ហើយត្រូវបានប្រទានពរចំពោះកិច្ចខិតខំរបស់លោកក្ដី ក៏លោកនៅតែចាំបាច់ត្រូវប្រែចិត្ត ពីអំពើបាបមួយចំនួនទៀតផងដែរ ) ។
- តើយើងអាចរៀនអ្វីខ្លះមកពីព្រះឱវាទរបស់ព្រះអម្ចាស់នៅក្នុង ខ ៣? ( សិស្សគួរតែរកឃើញព្រះបញ្ញត្តិខាងក្រោមនេះ ៖ **យើងត្រូវបានបញ្ជាឲ្យប្រែចិត្តពីអំពើបាបរបស់យើងទាំងអស់**) ។
- ហេតុអ្វីវាសំខាន់ ដើម្បីប្រែចិត្តពីអំពើបាបរបស់យើងទាំងអស់ ហើយពុំគ្រាន់តែមួយចំនួននោះ ?
- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរនេះ អំពីរបៀបដែលព្រះអម្ចាស់នឹងជួយយើងនៅក្នុងការប្រែចិត្តរបស់យើង ? ( ចម្លើយរបស់សិស្សអាចមានផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់នឹងបង្ហាញយើងនូវការណ៍ទាំងឡាយដែលយើងចាំបាច់ត្រូវប្រែចិត្ត**) ។

សូមអញ្ជើញសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហិនរី ប៊ី អាវរិង ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកវិធីមួយ ដែលយើងអាចទូលសូមព្រះអម្ចាស់ដើម្បីជួយយើងឲ្យប្រែចិត្ត ។



« សំណួរមួយដែលយើងត្រូវទូលសូមពីព្រះវរបិតាសួគ៌របស់យើង គឺនៅក្នុងការអធិស្ឋានតែម្នាក់ឯងដូចនេះថា ៖ ‹ តើទូលបង្គំបានធ្វើអ្វីខ្លះនៅថ្ងៃនេះ ឬពុំបានធ្វើអ្វីសោះ ដែលនាំឲ្យទ្រង់ពុំសព្វព្រះទ័យ ? ប្រសិនបើទូលបង្គំអាចគ្រាន់តែដឹង ទូលបង្គំនឹងប្រែចិត្តអស់ពីដួងចិត្តដោយគ្មានបង្អង់ឡើយ › ។ ការអធិស្ឋានដោយរាបសារនោះនឹងត្រូវបានឆ្លើយតប » (« Do Not Delay » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៣៤ ) ។

សូមលើកទឹកចិត្តដល់សិស្សឲ្យគិតអំពីពរជ័យនានាដែលពួកគេបានទទួល នៅពេលពួកគេបានងាកចេញពីអំពើបាប ហើយបានទទួលដំណឹងល្អ ។ សូមអញ្ជើញពួកគេឲ្យស្វែងយល់អំពីរឿងដែលពួកគេចាំបាច់ត្រូវប្រែចិត្ត ដើម្បីឲ្យពួកគេអាចទទួលបានពរជ័យកាន់តែច្រើន ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យដៃគូនោះអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:៥–៩ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យបងប្រុស ម៉ុកខ្លេលិនធ្វើ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម ខ ៨–៩ តើពរជ័យអ្វីខ្លះដែលបងប្រុស ម៉ុកខ្លេលិន នឹងទទួល ប្រសិនបើគាត់នឹងស្មោះត្រង់ធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ?
- តើយើងអាចរៀនអ្វីខ្លះមកពីខទាំងនេះអំពីពរជ័យនានាដែលយើងអាចទទួលបាន នៅពេលយើងធ្វើតាមព្រះទ័យរបស់ព្រះអម្ចាស់សម្រាប់យើង ? ( សិស្សគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងស្មោះត្រង់នៅក្នុងការធ្វើតាមព្រះទ័យរបស់ព្រះអម្ចាស់ នោះទ្រង់នឹងគង់នៅជាមួយយើង ហើយនឹងប្រទានពរដល់យើង ដើម្បីយើងអាចសម្រេចនូវអ្វីដែលទ្រង់តម្រូវពីយើង**) ។

សូមពន្យល់ថា បន្ថែមពីលើការផ្ដល់ការណែនាំដល់ វិលលាម ម៉ុកខ្លេលិន អំពីអ្វីដែលលោកត្រូវធ្វើនោះ ព្រះអម្ចាស់បានប្រទានការព្រមានដល់គាត់ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាននូវការណែនាំ នៃប្រយោគទាំងពីរដំបូងក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១០ ឲ្យឮៗ ។ ពីមុនពួកគេអានសូមចង្អុលបង្ហាញថា ប្រយោគទីមួយមាននូវពាក្យ *អំពល់* ។ សូមពន្យល់ថា អ្វីមួយៗដែលអំពល់ដល់យើង ប្រសិនបើវាបង្ខាំងផ្លូវរបស់យើង ឬ ធ្វើកិច្ចការដ៏លំបាកបំផុតដើម្បីបានសម្រេច ។

- ព្រះអម្ចាស់បានបញ្ជាដល់បងប្រុស ម៉ុកខ្លេលិន « បោះបង់ចោលអស់ទាំងសេចក្ដីដ៏ឥតសុចរិត » ។ តើភាពទុច្ចរិត ឬ អំពើបាប អំពល់ដល់កិច្ចការផ្សព្វផ្សាយសាសនារបស់គាត់យ៉ាងដូចម្ដេចខ្លះ ?
- តើសេចក្ដីទុច្ចរិតអំពល់ដល់វិញ្ញាណរបស់យើងយ៉ាងដូចម្ដេចខ្លះ ?

សូមអានប្រយោគទីបីនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១០ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់រកមើលនូវការព្រមានជាក់លាក់មួយ ដែលព្រះអម្ចាស់បានប្រទានដល់ វិលលាម ម៉ាកខ្លេលិន ។

- យោងតាម ខ ១០, តើបងប្រុស ម៉ាកខ្លេលិន មានការពុះពារលើការល្បួងអ្វីខ្លះ ?
- តើយើងអាចរៀនអ្វីខ្លះពី ខ ១០ អំពីចំណេះដឹងរបស់ព្រះអម្ចាស់ចំពោះយើងម្នាក់ ? ( សូមជួយសិស្សឲ្យមើលឃើញថា **ព្រះអម្ចាស់ស្គាល់ពីបញ្ហា និងសេចក្ដីល្បួងជាក់លាក់របស់យើង** ក៏ដូចជាទ្រង់បានជ្រាបពីបងប្រុស ម៉ាកខ្លេលិនផងដែរ ) ។
- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីយល់ថា ព្រះអម្ចាស់ជ្រាបពីបញ្ហា និងការល្បួងជាក់លាក់របស់យើង ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១១–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រះឱវាទបន្ថែមទៀត ដែលព្រះអម្ចាស់បានប្រទានឲ្យ វិលលាម ម៉ាកខ្លេលិន ។

- យោងតាម ខ ១២ តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះដើម្បីទទួលជីវិតដ៏នៅអស់កល្បជានិច្ច ? ( សូមជួយសិស្សឲ្យទទួលស្គាល់ថា **ប្រសិនបើយើងបន្តស្មោះត្រង់ដល់ទីបញ្ចប់ នោះយើងនឹងទទួលបានជីវិតដ៏អស់កល្បជានិច្ច ។**)
- តើដើម្បីឲ្យអ្នកបន្តស្មោះត្រង់រហូតដល់ទីបញ្ចប់ មានន័យយ៉ាងណាសម្រាប់អ្នក ?

សូមពន្យល់ថា នៅពេលដែលវិវរណៈនេះត្រូវបានប្រទានឲ្យ នោះវិលលាម ម៉ាកខ្លេលិន បានទទួលទីបន្ទាល់មួយអំពីការស្ដារឡើងវិញនៃដំណឹងល្អ ។ បន្ទាប់ពីវិវរណៈត្រូវបានប្រទានឲ្យ នោះគាត់បានថ្លែងទីបន្ទាល់អំពីការហៅជាព្យាការីរបស់ យ៉ូសែប ស្ម៊ីធ ។ បងប្រុស ម៉ាកខ្លេលិន បានបម្រើដោយស្មោះត្រង់អស់ជាច្រើនឆ្នាំ ហើយត្រូវបានហៅឲ្យបម្រើជាសមាជិកទីមួយម្នាក់ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ។ ទោះជាយ៉ាងណាក៏ដោយ គាត់ពុំបានបន្តដោយស្មោះត្រង់ដល់ពីបញ្ចប់នោះទេ ។ តាមពិតទៅ គាត់បានងាកមកប្រឆាំងនឹងព្យាការី យ៉ូសែប ស្ម៊ីធ ហើយគាត់ត្រូវបានកាត់កាលចេញពីសាសនាចក្រក្នុងឆ្នាំ ១៨៣៨ ។

សូមបង្វែរចំណាប់អារម្មណ៍របស់សិស្សទៅលើរូប នៅលើក្ដារខៀន ហើយឲ្យយោបល់ថា ពួកគេនឹងត្រូវពិចារណាម្ដងទៀតពីកន្លែងដែលពួកគេនឹងដាក់ខ្លួនគេនៅលើរូបនោះ ។ សូមឲ្យពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖

- តើអ្នកនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីខិតទៅកាន់តែជិតព្រះ ហើយបន្តនៅស្មោះត្រង់រហូតដល់ទីបំផុត ?

សូមថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលអ្នកបានពិភាក្សា ហើយលើកទឹកចិត្តសិស្សឲ្យអនុវត្តតាមសេចក្ដីពិតទាំងនេះ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៦)

សូមឲ្យសិស្សស្រមៃបន្តិចថាស្ថាននរក ( ពិភពងងឹងខាងក្រៅ ) មានសភាពបែបណា ហើយថាការឈឺចាប់ផ្សេងទៀតនៃភាពមិនមែនជាព្រះ ហើយក្រោយមកទទួលការនិមិត្តមួយអំពីនគរនៃសិរីល្អ សេឡេស្ទាល ទេរេសទ្រាល និង នគរទេឡេស្ទាល ។ សូមពន្យល់ថា ដោយសារកិច្ចការរបស់ពួកគេស្ដីពី ការបកប្រែប្រកបដោយការបំផុសគំនិតនៃព្រះគម្ពីរប៊ីប នោះព្យាការីយ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ត្រូវបានអនុញ្ញាតឲ្យមើលឃើញការនិមិត្តមួយនៃកម្រិតទាំងបីនៃនគរសិរីល្អ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។

មេរៀនទី ៧៦

# គោលលទ្ធិ និង សេចក្តីសញ្ញា ៧២–៧៤

## បុព្វកថា

ការពង្រីកសាសនាចក្រទៅក្នុងរដ្ឋ មិសសួរី និងការប្តូរទីតាំងរបស់ប៊ីស្សព អែតវឺត ប៉ាទ្រិច នៅទីនោះ បានបង្កើតឲ្យមានតម្រូវការប៊ីស្សពម្នាក់ទៀត ត្រូវបានហៅនៅក្នុងរដ្ឋ អូហៃអូ ។ នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ១៨៣១ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈចំនួនបី ដែលត្រូវបានបញ្ចូលនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧២។ វិវរណៈទាំងនេះ បានទទួលស្គាល់ការហៅរបស់នូវល ខេ វិតនី ជាប៊ីស្សពថ្មី នៅរដ្ឋ អូហៃអូ បានបើកសម្តែងអំពីកាតព្វកិច្ចរបស់ប៊ីស្សព វិតនី ខ្លះៗ ហើយបានប្រទានការណែនាំទាំងឡាយទាក់ទងនឹងការប្រមូលគ្នីគ្នាទៅកាន់ស៊ីយ៉ូន ។ វិវរណៈបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៣ ដែលបានប្រទានឲ្យនៅខែ មករា ឆ្នាំ ១៨៣២ ដែលមាននូវការដឹកនាំរបស់ព្រះអម្ចាស់ដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ដើម្បីចាប់ផ្តើមការងាររបស់ពួកគាត់នៅក្នុងការបកប្រែព្រះគម្ពីរប៊ីប ។ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៤ ត្រូវបានទទួលនៅឆ្នាំ ១៨៣០ ពីមុនសាសនាចក្រត្រូវបានស្ថាបនាឡើងវិញ ។ វាមាននូវការពន្យល់របស់ព្រះអម្ចាស់អំពី កូរិនថូសទី ១ ៧:១៤ ខគម្ពីរមួយ ដែលត្រូវបានប្រើដោយមនុស្សមួយចំនួនដើម្បីដោះសារអំពីរឿងពិធីបុណ្យជ្រមុជទឹកដល់ទារក ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ៧២:១–៨

*ព្រះអម្ចាស់ហៅ នូវល ខេ វិតនី ជាប៊ីស្សពនៅរដ្ឋ អូហៃអូ*

សូមសួរដល់សិស្សថាតើការហៅបម្រើមួយណា ដែលពួកគេគិតថាលំបាកខ្លាំង ។

- តើអ្នកធ្លាប់ទទួលការហៅបម្រើមួយ ឬត្រូវបានសុំឲ្យធ្វើអ្វីមួយដែលពិបាកនៅក្នុងសាសនាចក្រ ឬមានអារម្មណ៍ថាវាលើសលប់ ឬអសមត្ថភាពក្នុងការធ្វើវាដែរឬទេ ? បើធ្លាប់ ហេតុអ្វី ?

សូមឲ្យសិស្សស្រាវជ្រាវក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧២:១–២ ដោយស្ងាត់ស្ងៀម ហើយប្រាប់អំពីការហៅដែលចាំបាច់ត្រូវធ្វើនៅក្នុងសាសនាចក្រ ។ ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ឃ្លា « នៅក្នុងផ្នែកនេះនៃចម្ការទំពាំងបាយជូររបស់ព្រះអម្ចាស់ » បានសំដៅទៅលើរដ្ឋ អូហៃអូ ) ។

- តើការហៅអ្វីខ្លះ ដែលចាំបាច់ត្រូវហៅនៅរដ្ឋ អូហៃអូ ?

ដើម្បីជួយសិស្សយល់ពីមូលហេតុដែលប៊ីស្សពថ្មី ត្រូវការនៅក្នុងរដ្ឋ អូហៃអូ សូមឲ្យពួកគេរកនឹកថានរណាត្រូវបានហៅជាប៊ីស្សពដំបូងគេនៅក្នុងសាសនាចក្រ ( អែតវឺត ប៉ាទ្រិច សូមមើល គ. និង ស. ៤១:៩) ។ សូមពន្យល់ថា ជាមួយនឹងការពង្រីកសាសនាចក្រនៅរដ្ឋ មិសសួរី និងការប្តូរទីតាំងរបស់ប៊ីស្សព ប៉ាទ្រិច ទៅ អ៊ិនឌីប៉ែនដែនស៍ រដ្ឋមីសសួរី ( មានចម្ងាយជិតស្មើនឹង ១០០០ ម៉ែលពីទីក្រុងខឺតឡង់ ) ព្រះអម្ចាស់បានប្រកាសថា ប៊ីស្សពថ្មី គឺចាំបាច់ត្រូវមាននៅរដ្ឋ អូហៃអូ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេនគ្នាអានឲ្យឮៗដកស្រង់ចេញពី គោលលទ្ធិ និង សេចក្តីសញ្ញា ៧២:៣–៦ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលឃ្លា ដែលពន្យល់ពីមូលហេតុដែលពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ត្រូវការប៊ីស្សព ។

- ស្របតាម ខ ៣ និង ខ ៥ ហេតុអ្វីក៏ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ត្រូវការប៊ីស្សព ? ( ដូច្នេះពួកគេអាចមានទំនួលខុសត្រូវចំពោះប៊ីស្សព សម្រាប់ការកាន់កាប់ត្រួតត្រារបស់ពួកគេ ) ។

- តើការណ៍នេះស្រដៀងគ្នាទៅនឹងទំនួលខុសត្រូវរបស់យើងចំពោះប៊ីស្សព ឬប្រធានសាខាសព្វថ្ងៃនេះយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧២:៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ថានរណាត្រូវបានហៅជាប៊ីស្សពថ្មីនៅរដ្ឋ អូហៃអូ ហើយនរណាបានជ្រើសរើសគាត់ឲ្យបំពេញការហៅបម្រើនេះ ។

- តើនរណាត្រូវបានហៅជាប៊ីស្សពថ្មីនៅរដ្ឋ អូហៃអូ ?

- តើនរណាបានជ្រើសរើស នូវល ខេ វីតនីជាប៊ីស្សពថ្មី ?
- តើគោលលទ្ធិអ្វីខ្លះ ដែលយើងអាចរៀនមកពី ខ ៨ ស្ដីអំពីការហៅបម្រើនៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ? ( ចម្លើយរបស់សិស្សអាចនឹងឆ្លុះបញ្ចាំងអំពីគោលលទ្ធិដូចខាងក្រោម ៖**ការហៅបម្រើនៅក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទកើតមកពីព្រះអង្គសង្គ្រោះ** )។

សូមឲ្យសិស្សពិចារណាអំពីរបៀបដែលពួកគេអាចនឹងទទួលអារម្មណ៍ដឹង បើពួកគេត្រូវបានហៅទៅក្នុងការបម្រើក្នុងសាសនាចក្រដ៏លំបាកមួយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានរឿងដូចខាងក្រោមឲ្យឮៗ ដែលបានប្រាប់ដោយចៅប្រុសរបស់នូវល ខេ វីតនី ឈ្មោះ អែលឌើរ អូរសុន អែហ្វ វិតនី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់អំពីរបៀបដែលបងប្រុស វិតនី ទទួលអារម្មណ៍យ៉ាងណា នៅពេលគាត់ត្រូវបានហៅជាប៊ីស្សពម្នាក់ និងអ្វីដែលគាត់បានរៀនថាការហៅរបស់គាត់បានចេញមកពីណា ។



« គំនិតនៃការស្មានអំពីទំនួលខុសត្រូវសំខាន់នេះ ( តំណែងនៃប៊ីស្សព ) គឺស្ទើរតែមានច្រើនជាងដែល [ នូវល ខេ វីតនី ] អាចទ្រាំទ្របាន ។. . . គាត់ . . . មិនទុកចិត្តលើសមត្ថភាពរបស់គាត់ ហើយបាន [ មានអារម្មណ៍ ] ថាអសមត្ថភាពក្នុងការធ្វើកិច្ចការដែលផ្ដល់នូវការទុកចិត្តដ៏ខ្ពស់ និងបរិសុទ្ធនោះ ។ នៅក្នុងភាពវិលវល់របស់គាត់ គាត់បានទៅប្ដឹងព្យាការី ៖

« ‹ ខ្ញុំមើលពុំឃើញថារូបខ្ញុំសមជាប៊ីស្សពសោះ បងប្រុស យ៉ូសែប ប៉ុន្តែបើលោកនិយាយថា វាគឺជាព្រះឆន្ទៈរបស់ព្រះអម្ចាស់ ខ្ញុំនឹងព្យាយាម › ។

ព្យាការីបានតបដោយសណ្ដានចិត្តថា «‹ អ្នកពុំចាំបាច់យកតាមពាក្យខ្ញុំនោះទេ សូមទៅទូលដល់ព្រះបិតាដោយខ្លួនអ្នកផ្ទាល់ចុះ › ។

« នូវល . . . បានតាំងចិត្តធ្វើដូចដែល [ ព្យាការី ] បានទូន្មាន ។. . . ការអធិស្ឋានដ៏រាបសា និង ស្មោះអស់ពីចិត្តរបស់គាត់ត្រូវបានឆ្លើយតប ។ នៅក្នុងបន្ទប់តែម្នាក់ឯងក្នុងយប់ស្ងាត់ គាត់បានស្ដាប់ឮសំឡេងពីស្ថានសួគ៌ថា ៖‹ *កម្លាំងរបស់អ្នកគឺនៅនឹងយើង* › ។ ពាក្យតែពីរបីម៉ាត់ និងសាមញ្ញនេះ មានអត្ថន័យដ៏សំខាន់បំផុត ។ ការសង្ស័យរបស់គាត់ ត្រូវបានរលត់បាត់ ដូចជាទឹកសន្សើមមុនពេលអរុណរះ ។ គាត់បានស្វែងរកព្យាការីដោយផ្ទាល់ បានប្រាប់លោកថា គាត់ស្កប់ស្កល់ចិត្ត ហើយមានឆន្ទៈនឹងទទួលយកតំណែងដែលគាត់ត្រូវបានហៅ » ( « The Aaronic Priesthood »*Contributor* ខែមករា ឆ្នាំ១៨៨៥ ទំព័រ ១២៦ ) ។

- តើអ្វីខ្លះ ដែលបានជួយ នូវល  ខេ វិតនី ទទួលយកការហៅរបស់គាត់ដើម្បីបម្រើជាប៊ីស្សពដោយស្ម័គ្រចិត្ត ?
- តើយើងអាចរៀនអ្វីខ្លះមកពីបទពិសោធន៍របស់គាត់ ដើម្បីអាចជួយយើង បើយើងមានអារម្មណ៍ថាវាលើសលប់ដោយការហៅបម្រើ ឬការចាត់តាំងមួយនៅក្នុងសាសនាចក្រនោះ ?
- តើការយល់ថា ការហៅបម្រើនៅក្នុងសាសនាចក្រមកពីព្រះអង្គសង្គ្រោះ ជួយអ្នកឲ្យទទួលយក ហើយព្យាយាមដោយឧស្សាហ៍ដើម្បីបំពេញការហៅរបស់អ្នកយ៉ាងដូចម្ដេច ?

សូមពិចារណាធ្វើការចែកចាយបទពិសោធន៍មួយ ដែលបានពង្រឹងដល់ទីបន្ទាល់របស់អ្នកថា ការហៅបម្រើទាំងឡាយនៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ គឺមកពីទ្រង់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:៩–២៦

### *ព្រះអម្ចាស់ពន្យល់អំពីកាតព្វកិច្ចទាំងឡាយរបស់ប៊ីស្សពម្នាក់*

សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ប៊ីស្សព និងប្រធានសាខា គ្រប់គ្រងកិច្ចការខាងវិញ្ញាណ និងខាងសាច់ឈាមរបស់សាសនាចក្រនៅក្នុងវួដ ឬសាខារបស់ពួកគាត់ ។** ( អ្នកអាចនឹងចង់ពន្យល់ថា*ខាងសាច់ឈាម*សំដៅទៅលើអ្វីៗដែលទាក់ទងនឹងជីវិតខាងសាច់ឈាម ។ ឧទាហរណ៍ ប៊ីស្សព និងប្រធានសាខា គ្រប់គ្រងលើទ្រព្យសម្បត្តិសាសនាចក្រ មូលនិធិសាសនាចក្រ និងការប្រើប្រាស់សម្ភារនៅក្នុងឃ្លាំងរបស់ប៊ីស្សព ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:៩–២៦ ដោយពន្យល់ថា ខគម្ពីរទាំងនេះ ពិពណ៌នាអំពីកាតព្វកិច្ចមួយចំនួនរបស់ប៊ីស្សព វិតនី ។ សូមពន្យល់ថា កាតព្វកិច្ចរបស់ប៊ីស្សពម្នាក់ បានពិពណ៌នាដោយព្រះអម្ចាស់នៅក្នុងវិវរណៈនេះជាចម្បងទាក់ទងនឹងតួនាទីរបស់ប៊ីស្សពនៅក្រោមក្រឹត្យវិន័យនៃការថ្វាយ ។ អំឡុងគ្រានេះ សាសនាចក្រពុំបានបំបែកជាវួដដោយមានប៊ីស្សពធ្វើជាអធិបតីនៅក្នុងវួដនីមួយៗ ដូចឥឡូវនេះទេ ។ នៅគ្រានោះ មានប៊ីស្សពតែពីរនាក់ប៉ុណ្ណោះ ៖ ប៊ីស្សព វិតនី គឺជាប៊ីស្សពសម្រាប់ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ហើយប៊ីស្សព ប៉ាទ្រិច គឺជាប៊ីស្សពសម្រាប់អ្នកទាំងឡាយនៅរដ្ឋ មិសសួរី ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣

*ព្រះអម្ចាស់ដឹកនាំ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ឲ្យបន្តបកប្រែព្រះគម្ពីរប៊ីប*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣:១–២ ដោយពន្យល់ថា ព្រះអម្ចាស់បានណែនាំថា ពួកអែលឌើរ ដែលកំពុងផ្សាយ ត្រូវបន្តធ្វើដូច្នោះទៀត រហូតដល់សន្និសីទលើកក្រោយ ដែលនឹងធ្វើឡើងនៅពីរសប្ដាហ៍ ។ ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានផ្សាយដើម្បីជួយលុបបំបាត់ចោលនូវព័ត៌មានខុសឆ្គងអំពីសាសនាចក្រ ដែលជាលទ្ធផលមកពីការបោះពុម្ពសំបុត្ររបស់ អែរ៉ាស ប៊ូត ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣:៣–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានផ្ដោតទៅលើ បន្ទាប់ពីសន្និសីទរួច ។

- តើព្រះអម្ចាស់បានសុំឲ្យ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុនឲ្យផ្ដោតកិច្ចខិតខំរបស់ពួកគាត់ទៅលើអ្វីខ្លះ ? តើ « កិច្ចការនៃការបកប្រែ » គឺជាអ្វីដែលព្រះអម្ចាស់សំដៅទៅលើឬ ? ( កំណែថ្មីនៃព្រះគម្ពីរប៊ីប ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤

*ព្រះអម្ចាស់ពន្យល់អំពីអត្ថន័យនៃ កូរិនថូសទី ១ ៧:១៤*

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពួកគេកំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងសម្រាប់សាសនាចក្រ ។ ខណៈពេលកំពុងនិយាយនឹងគូស្វាមីភរិយាដែលបានរៀបការមួយគូ ដែលកំពុងសិក្សាពីសាសនាចក្រ នោះពួកគេបានដឹងថា ពួកគាត់មានកូនប្រុសម្នាក់ដែលបានស្លាប់ ពេលគាត់កើតមកទើបបានតែពីរបីខែប៉ុណ្ណោះ ។ គូស្វាមីភរិយានេះ ត្រូវបានអ្នកដឹកនាំខាងសាសនារបស់ពួកគេថា កូនប្រុសពួកគេពុំអាចឡើងទៅស្ថានសួគ៌បានទេ ដោយសារតែកូនតូចនោះពុំទាន់បានជ្រមុជទឹក ពីមុនគាត់ស្លាប់ ។ ឪពុកម្ដាយមានអារម្មណ៍សោកសៅយ៉ាងខ្លាំង ដោយសារតែការបាត់បង់កូនរបស់ពួកគេ ហើយជំនឿរបស់ពួកគេប្រាប់ថា កូនរបស់ពួកគេបានបាត់បង់សេចក្ដីសង្គ្រោះរបស់ខ្លួន ។

សូមឲ្យសិស្សគិតអំពីរបៀបដែលពួកគេនឹងឆ្លើយតបទៅនឹងស្ថានភាពនេះ ហើយប្រាប់ពួកគេថា ពួកគេនឹងមានឱកាសឆ្លើយតបនៅក្នុងមេរៀននៅពេលក្រោយ ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤ មាននូវការពន្យល់របស់ព្រះអម្ចាស់អំពី កូរិនថូសទី ១ ៧:១៤។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:១ ដែលជាពាក្យរបស់សាវកប៉ុលមកពី កូរិនថូសទី ១ ៧:១៤។ សូមប្រាប់សិស្សថា ខគម្ពីរនេះនៅក្នុង កូរិនថូសទី ១ ត្រូវបានប្រើដើម្បីគាំទ្រដល់ការអនុវត្តពិធីបុណ្យជ្រមុជទឹកដល់ទារកតូច ។ ( អ្នកក៏អាចនឹងចង់ពន្យល់ថា ពាក្យ *ពុំជឿ* នៅក្នុង ខ ១ សំដៅទៅលើពួកយូដា ដែលពុំបានទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទទេ ។ ប៉ុល ពុំថ្លែងថា មនុស្សម្នាក់អាចត្រូវបានសង្គ្រោះដោយសារសេចក្ដីសុចរិតរបស់ប្ដីឬប្រពន្ធរបស់គេនោះទេ ប៉ុន្តែដោយការផ្លាស់ប្រែចិត្តជឿរបស់ប្ដី ឬប្រពន្ធ ដើម្បីអាចនាំមកនូវឥទ្ធិពលនៃការញែកចេញជាបរិសុទ្ធនៅក្នុងគ្រួសារ ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេនគ្នាអានឲ្យឮៗដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:២–៦ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលបញ្ហានានា ដែលត្រូវបានបង្កើតឡើងនៅក្នុងជំនាន់របស់សាវក ប៉ុល នៅពេលប្ដី ឬប្រពន្ធម្នាក់ ដែលរៀបការនឹងគ្នា បានផ្លាស់ប្រែចិត្តជឿទៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយម្នាក់ទៀតនៅតែអនុវត្តតាមច្បាប់របស់ម៉ូសេ ។

- តើមានភាពខុសគ្នាអ្វីខ្លះ ត្រូវបានជួបប្រទះនៅក្នុងអាពាហ៍ពិពាហ៍ប្រភេទនេះ ? ( ស្វាមីភរិយានឹងឈ្លោះគ្នា ថាតើកូនៗរបស់ពួកគេនឹងត្រូវបង្រៀនឲ្យជឿ ហើយគោរពតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ឬក្រឹត្យវិន័យរបស់ម៉ូសេ [សូមមើល ខ ៣] កូនៗដែលចិញ្ចឹមបីបាច់ ក្រោមការគោរពតាមក្រឹត្យវិន័យនៃម៉ូសេ បានធំឡើងដោយពុំជឿដល់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទទេ [សូមមើល ខ ៤])។

- តើការជឿជំនឿសាសនាខុសគ្នានៅក្នុងអាពាហ៍ពិពាហ៍អាចមានឥទ្ធិពលលើគ្រួសាររបស់គូស្វាមីភរិយានោះយ៉ាងដូចម្ដេច ?

សូមពន្យល់ថា ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទបានបំពេញនូវក្រឹត្យវិន័យរបស់ ម៉ូសេ ហើយការកាត់ស្បែកឈប់តម្រូវឲ្យមានទៀតហើយ ។ ទោះជាយ៉ាងណាក៏ដោយ ពួកសាសន៍យូដាដែលធ្វើតាមក្រឹត្យវិន័យរបស់ ម៉ូសេ បានជឿថាកូនប្រុស គឺពុំស្អាតស្អំទេ លុះត្រាតែកូននោះត្រូវកាត់ស្បែកសិន ។ ជំនឿនេះ បានបណ្ដាលឲ្យមានបញ្ហាជាច្រើននៅក្នុងគ្រួសារដែលមានឪពុក ឬម្ដាយម្នាក់ដែលបានជឿទៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយម្នាក់ទៀត ជឿលើក្រឹត្យវិន័យរបស់ម៉ូសេ ។ ជម្លោះស្រដៀងគ្នានេះនៅក្នុងជំនឿសាសនា និងការអនុវត្ត អាចកើតមាននៅសព្វថ្ងៃនេះ ក្នុងក្រុមគ្រួសារដែលមានស្វាមី ឬភរិយាម្នាក់ ជាសមាជិកនៃសាសនាចក្រ ហើយម្នាក់ទៀតពុំជឿ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីកុមារតូចៗ ។

- តើព្រះអម្ចាស់បានបង្រៀនអ្វីខ្លះស្ដីអំពីកុមារតូចៗ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងដូចខាងក្រោម ៖**កុមារតូចៗ បរិសុទ្ធ ត្រូវបានញែកឲ្យបរិសុទ្ធ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។** ( អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំគោលលទ្ធិនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។

សូមរំឭកសិស្សអំពីស្ថានភាពរបស់អ្នកផ្សព្វផ្សាយសាសនា ដែលបានបង្ហាញពីខាងដើមក្នុងមេរៀន ។ សូមអញ្ជើញសិស្សឲ្យសរសេរ មរ៉ូណៃ ៨:៨–១២ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៦–៥០ ជាសេចក្ដីយោងបទគម្ពីរនៅជិតនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:៧។ សូមចាត់សិស្សឲ្យអាន មរ៉ូណៃ ៨:៨–១២ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៦–៥០ ជាមួយនឹងដៃគូ បន្ទាប់មកពិភាក្សាអំពីសំណួរដូចខាងក្រោមជាមួយគ្នា ៖

- សូមប្រើនូវអ្វីដែលអ្នកបានរៀន អំពីសេចក្ដីសង្គ្រោះរបស់កុមារតូចៗ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:៧ និង មរ៉ូណៃ ៨:៨–១២ តើអ្នកនឹងបង្រៀនអ្វីខ្លះ ដល់គូស្វាមីភរិយាដែលបានរៀបការ ដែលមានអារម្មណ៍ថា កូនដែលបានស្លាប់ទៅរបស់ពួកគេពុំអាចចូលក្នុងស្ថានសួគ៌នោះ ?

សូមអញ្ជើញដៃគូមួយ ឬពីរ ឲ្យពន្យល់ពីអ្វីដែលពួកគេនឹងបង្រៀន ។ សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីព្រះចេស្ដានៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ដើម្បីប្រោសលោះដល់កុមារតូចៗ ។

មេរៀនទី ៧៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥

## បុព្វកថា

នៅក្នុងសន្និសីទសាសនាចក្រដែលបានធ្វើឡើងនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៨៣២ ព្យាការីយ៉ូសែប ស៊្មីធ បានទទួលវិវរណៈពីរ ដែលទាំងពីរនោះមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥។ វិវរណៈទីមួយ បានកត់ត្រានៅក្នុង ខ ១–២២ ត្រូវបានប្រទានឲ្យក្រុមអែលឌើរមួយក្រុម ដែលបានដាក់បញ្ជូនឈ្មោះរបស់ពួកគេ ធ្វើការបម្រើបេសកកម្ម ។ ព្រះអម្ចាស់បានណែនាំដល់ពួកអែលឌើរទាំងនេះ អំពី កាតព្វកិច្ចផ្សព្វផ្សាយសាសនារបស់ពួកគេ ហើយបានចាត់តាំងដៃគូបេសកកម្ម របស់ពួកគេ ។ វិវរណៈទីពីរ បានកត់ត្រានៅក្នុង ខ ២៣–៣៦ ត្រូវបានប្រទាន ឲ្យទៅក្រុមអែលឌើរទីពីរ ដែលចង់ដឹងពីព្រះទ័យរបស់ព្រះអម្ចាស់អំពីពួកគេ ។ ព្រះអម្ចាស់បានណែនាំពួកអែលឌើរទាំងនេះដើម្បីប្រាកដថាក្រុមគ្រួសាររបស់ពួកគេ នឹងផ្គត់ផ្គង់ ហើយទទួលយកការហៅដើម្បីផ្សាយដំណឹងល្អរបស់ពួកគេ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១–៥

*ព្រះអម្ចាស់បានថ្លែងអំពីអ្នកទាំងឡាយដែលមានបំណងប្រាថ្នាដើម្បីផ្សាយដំណឹងល្អ*

នៅរយៈពេលពីរបីថ្ងៃពីមុនអ្នកបង្រៀនមេរៀននេះ សូមអញ្ជើញសិស្សម្នាក់ដែលបានទទួលការហៅបម្រើបេសកកម្មមួយ ជាសិស្សម្នាក់ដែលអាចនឹងដាក់បេសកកម្មក្នុងពេលឆាប់ៗ ឬអ្នកត្រឡប់មកពីផ្សព្វផ្សាយសាសនាថ្មីៗម្នាក់ ឲ្យជួយបង្រៀនអំពីការចែកចាយដំណឹងល្អ ។ សូមឲ្យគម្រោងការបង្រៀនដូចខាងក្រោមមួយច្បាប់ដល់គេ ហើយសុំឲ្យគាត់សិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១–៤ ហើយត្រៀមខ្លួនបង្រៀននៅផ្នែកនោះក្នុងមេរៀន ។

បន្ទាប់ពីការប្រជុំបើកថ្នាក់រៀន សូមបង្វែទៅសិស្ស ឬអ្នកត្រឡប់មកពីផ្សព្វផ្សាយសាសនាឲ្យបង្រៀនពីអ្វីដែលពួកគេបានរៀបចំ ។

#### យោបល់សម្រាប់ការបង្រៀន គម្រោងសម្រាប់ –គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១–៤

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនរណាដែលព្រះអម្ចាស់បានថ្លែងនៅក្នុងខគម្ពីរទាំងនេះ ។

សូមសួរថា ៖ តើព្រះអម្ចាស់កំពុងមានបន្ទូលទៅកាន់នរណា ក្នុងខគម្ពីរទាំងនេះ ? ( ពួកអែលឌើរ ដែលបានដាក់បញ្ជូនឈ្មោះរបស់ពួកគេដើម្បីធ្វើកិច្ចការផ្សព្វផ្សាយសាសនា ) ។

សូមប្រាប់សិស្សក្នុងថ្នាក់ថា តាមពិតមានវិវរណៈពីរដែលបានដាក់បញ្ចូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ ហើយថាវាត្រូវបានប្រទានឲ្យនៅក្នុងសន្និសីទមួយរបស់សាសនាចក្រ ។ វិវរណៈទីមួយត្រូវបានប្រទានឲ្យដល់ក្រុមអ្នកផ្សព្វផ្សាយសាសនាមួយក្រុម ហើយបានពន្យល់អំពីរបៀបដែលពួកគេជួយអ្នកដទៃឲ្យយល់ពីសារលិខិតរបស់ពួកគេកាត់តែមានប្រសិទ្ធភាព ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៣–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការប្រឹក្សារបស់ព្រះអម្ចាស់ដល់ពួកអែលឌើរស្ដីអំពីការហៅបម្រើរបស់ពួកគេឲ្យផ្សាយដំណឹងល្អ ។ អ្នកអាចផ្ដល់យោបល់ថាសិស្សគួរគូសចំណាំនូវអ្វីដែលពួកគេរកឃើញនៅក្នុងគម្ពីររបស់ពួកគេ ។

សូមសួរថា ៖ ស្របតាម ខ ៣–៤ តើព្រះអម្ចាស់ចង់ឲ្យពួកអែលឌើរធ្វើអ្វីខ្លះ ខណៈពេលផ្សាយដំណឹងល្អ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់អំពីអ្វីដែលពួកគេគិតថា ឃ្លា « ចេញទៅ ហើយមិនបង្អង់នៅ » « ឬក៏ខ្ជិលច្រអូសឡើយ » ហើយ « ធ្វើការដោយកម្លាំងរបស់អ្នកចុះ » មានន័យយ៉ាងណា ។

> បន្ទាប់ពីសមាជិកក្នុងថ្នាក់បានឆ្លើយតបរួចហើយ សូមពន្យល់ពីមូលហេតុដែលអ្នកគិតថា អ្នកទាំងឡាយដែលត្រូវបានហៅឲ្យប្រកាសដំណឹងល្អត្រូវតែដឹង ហើយបង្រៀនអំពីវិរណៈ និងបទបញ្ញត្តិទាំងឡាយដែលព្រះអម្ចាស់បានប្រទានដល់យើង ( សូមមើល ខ ៤) ។
>
> សូមសួរថា ៖ ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដែលពួកអ្នកផ្សព្វផ្សាយសាសនារបស់ព្រះអម្ចាស់ បម្រើទ្រង់តាមរបៀបទាំងនេះ ?
>
> សូមចែកចាយជាមួយសិស្សក្នុងថ្នាក់អំពីអ្វីដែលអ្នកកំពុងធ្វើ (ឬអ្វីដែលអ្នកបានធ្វើ បើសិនជាអ្នកបានបម្រើបេសកកម្ម ) ដើម្បីរៀបចំប្រកាសដំណឹងល្អតាមរបៀបដែលព្រះអម្ចាស់ បានពិពណ៌នានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៣–៤។ សូមបញ្ចប់ដោយការចែកចាយអំពីគំនិតរបស់អ្នកចំពោះអ្វីដែលសិស្សអាចធ្វើដើម្បីចែកចាយដំណឹងល្អតាមរបៀបនេះនៅគ្រានេះក្នុងជីវិតរបស់ពួកគេ ។

បន្ទាប់ពីសិស្ស ឬអ្នកផ្សព្វផ្សាយសាសនាដែលត្រឡប់មកវិញ បានបញ្ចប់ការបង្រៀន សូមសរសេរសេចក្ដីថ្លែងមិនពេញលេញនៅលើក្ដារខៀនថា ៖*បើសិនជាយើងស្មោះត្រង់នៅក្នុងការប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹង* . . .

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៥ ដោយស្ងាត់ស្ងៀម ហើយប្រាប់ពីការសន្យាដែលព្រះអម្ចាស់ បានផ្ដល់ឲ្យពួកអ្នកផ្សព្វផ្សាយសាសនាទាំងនោះ ។

- តើព្រះអម្ចាស់បានសន្យា អ្វីជាមួយនឹងអស់អ្នកណា ដែលប្រកាសដំណឹងល្អរបស់ទ្រង់ដោយស្មោះត្រង់ ?

អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យ *កណ្ដាប់* សំដៅទៅលើការកាត់គួស្រូវ ហើយបន្ទាប់មកចងវាជាដុំៗ ឬជាកណ្ដាប់ ។ ការមាន « កណ្ដាប់ជាច្រើន » មានន័យថា ជាការច្រូតកាត់ដ៏ច្រើនសន្ធឹក ។

- តើអាចមាន « កណ្ដាប់ » មួយចំនួនណាខ្លះ ដែលអ្នកផ្សព្វផ្សាយស្មោះត្រង់នៅក្នុងការចែកចាយដំណឹងល្អ បានទទួល ? ( កណ្ដាប់ ក៏អាចសំដៅទៅលើមនុស្សដែលទទួលយកសារលិខិតរបស់ពួកគេ [អ្នកផ្លាស់ប្រែចិត្តជឿ] ក៏ដូចជាពរជ័យដ៏អស់កល្បដែលបានសរសេរនៅក្នុង ខ ៥។

សូមឲ្យសិស្សសង្ខេបនូវការសន្យាទាំងឡាយដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៥ ដោយការបំពេញសព្វគ្រប់នូវសេចក្ដីថ្លែងការណ៍អំពីគោលការណ៍នៅលើក្ដារខៀន ។ ខាងក្រោម គឺជាវិធីមួយដែលសិស្សសូត្រគោលការណ៍នេះ ៖ **បើសិនជាយើងស្មោះត្រង់នៅក្នុងការប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងនូវកិត្តិយស សិរីល្អ និងជីវិតដ៏អស់កល្បជានិច្ច ។**

- ហេតុអ្វីក៏អ្នកគិតថា អ្នកទាំងឡាយដែលប្រកាសដំណឹងល្អដោយស្មោះត្រង់ នឹងទទួលបានពរជ័យអស់កល្បជានិច្ចដ៏មហិមាដូច្នេះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៦–២២

*ព្រះអម្ចាស់ហៅ និងណែនាំអំពីដៃគូអ្នកផ្សព្វផ្សាយសាសនា*

សូមពន្យល់ថា បន្ទាប់ពីព្រះអម្ចាស់បានប្រទានការណែនាំ និងការសន្យាដល់ពួកអែលឌើរ ដែលនឹងចេញទៅបម្រើបេសកកម្ម នោះទ្រង់បានដាក់ពួកគេជាដៃគូ ហើយប្រទានការណែនាំជាក់លាក់អំពីដៃគូនិមួយៗ ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យសិស្សម្នាក់នៅក្នុងក្រុមនិមួយៗអានដោយស្ងាត់ស្ងៀមនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៦–១២ ហើយសិស្សម្នាក់ទៀតអាន ខ ១៣–១៤។ សូមពួកគេឲ្យរកមើលចម្លើយចំពោះសំណួរដូចខាងក្រោម នៅពេលពួកគេអាន ៖

១. តើព្រះអម្ចាស់កំពុងមានបន្ទូលទៅកាន់នរណា ?

២. តើពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់សន្យានឹងពួកគេ បើពួកគេស្មោះត្រង់នៅក្នុងការប្រកាសដំណឹងល្អនោះ ?

បន្ទាប់ពីសិស្សបានអាននូវខគម្ពីរជាក់លាក់របស់ពួកគេ សូមអញ្ជើញពួកគេឲ្យចែកចាយជាមួយដៃគូរបស់ពួកគេនូវចម្លើយចំពោះសំណួរដូចខាងលើ ។

- តើការប្រឹក្សាបន្ថែមអ្វីខ្លះទៀត ដែលព្រះអម្ចាស់បានប្រទានដល់ វិលលាម អ៊ី ម៉ុកខ្លេលិន និង លូកា ចនសុន នៅក្នុង ខ ៨–១១ ដែលអាចជួយយើងប្រកាសដំណឹងល្អប្រកបដោយប្រសិទ្ធភាព ? ( អធិស្ឋានដើម្បីទទួលបានអង្គលួងលោមចិត្ត– ព្រះវិញ្ញាណបរិសុទ្ធ – ដើម្បីបង្រៀនយើង និងសុំកម្លាំងដើម្បីបន្តនៅស្មោះត្រង់ ) ។

- តើការសន្យាអ្វីខ្លះ ដែលព្រះអម្ចាស់បានថ្លែងដដែល ៗអំពីដៃគូទាំងឡាយនៅក្នុង ខ ១១ ១៣ និង ១៤ ? ( ទ្រង់នឹងគង់នៅជាមួយពួកគេ ។ អ្នកអាចឲ្យយោបល់ថា សិស្សគួរតែគូសចំណាំការសន្យានេះទុក ) ។

សូមសិស្សឲ្យបង្ហាញគោលការណ៍មួយ ដែលពួកគេបានរៀនមកពីខគម្ពីរទាំងនេះ ។ ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងក្ដី ក៏ពួកគេគួរតែអាចប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖**បើយើងស្មោះត្រង់នៅក្នុងការប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង ។**

- តើបទពិសោធន៍អ្វីខ្លះដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានអះអាងដល់អ្នកថា ព្រះអម្ចាស់នឹងគង់នៅជាមួយអ្នកទាំងឡាយដែលចែកចាយដំណឹងល្អដោយស្មោះត្រង់ជាមួយអ្នកដទៃ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេនឹងនិយាយទៅកាន់មិត្ត ឬសមាជិកគ្រួសារម្នាក់ ដែលកំពុងមានបញ្ហាខណៈពេលកំពុងបម្រើបេសកកម្មពេញម៉ោង ។ សូមឲ្យពួកគេប្រើគោលការណ៍ទាំងឡាយដែលពួកគេបានរៀននៅក្នុងមេរៀនថ្ងៃនេះ ហើយសរសេរសំបុត្រលើកទឹកចិត្តខ្លីមួយ ដល់អ្នកផ្សព្វផ្សាយសាសនានោះ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យចែកចាយក្នុងសំបុត្រនូវអ្វីដែលអ្នកផ្សព្វផ្សាយសាសនាអាចធ្វើដើម្បីប្រកាសដំណឹងល្អកាន់តែស្មោះត្រង់ និងពរជ័យមួយចំនួនខ្លះទៀត ដែលកើតមានមកដល់អ្នកទាំងឡាយដែលធ្វើដូច្នោះ ។

ក្រោយពីសិស្សមានពេលសរសេរសំបុត្រគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១៥–២២ ដោយពន្យល់ថា ព្រះអម្ចាស់បានណែនាំដល់អ្នកផ្សព្វផ្សាយសាសនាដើម្បី ប្រទានពរដល់គ្រួសារនៃអ្នកទាំងឡាយដែលបានទទួលពួកគេ ។ ទ្រង់ក៏បានបង្រៀនពួកគេផងដែរនូវអ្វីដែលត្រូវធ្វើ ពេលពួកគេត្រូវបានមនុស្សដែលពួកគេចែកចាយដំណឹងល្អជាមួយបដិសេធ ។ ( អ្នកអាចនឹងចង់ពន្យល់ថា ការរលាស់ធូលីពីជើងដូចជាទីបន្ទាល់មួយទាស់នឹងអ្នកទាំងឡាយដែលបដិសេធអ្នកផ្សព្វផ្សាយសាសនា និងសារលិខិតរបស់ពួកគេ ត្រូវបានធ្វើឡើងតែ ក្នុងស្ថានភាពដ៏កម្របុ៉ណ្ណោះ នៅពេលព្រះអម្ចាស់បញ្ជា ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:២៣–២៩

*ព្រះអម្ចាស់ពន្យល់អំពីរបៀបដែលក្រុមគ្រួសារនៃអ្នកទាំងឡាយ ដែលទ្រង់បានហៅឲ្យបម្រើបេសកកម្មគួរត្រូវបានទទួលនូវការគាំទ្រ*

សូមពន្យល់ថា វិវរណៈទីពីរ មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ គឺត្រូវបានប្រទានឲ្យដល់ក្រុមអែលឌើរផ្សេងមួយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:២៣ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ រកមើលបំណងប្រាថ្នាដែលអែលឌើរទាំងនោះ ចង់ដឹង។

សូមពន្យល់ថា នៅក្នុងសាសនាចក្រជំនាន់មុន បុរសជាច្រើនដែលត្រូវបានហៅឲ្យបម្រើបេសកកម្ម មានប្រពន្ធ និងកូនដែលពឹងផ្អែកទៅលើពួកគេដើម្បីផ្គត់ផ្គង់ ។ ការទទួលយកការហៅបម្រើ គឺជាការលះបង់ដ៏ធំមួយរបស់គ្រួសារទាំងមូល ។ ជាទូទៅកង្វល់របស់ពួកអែលឌើរទាំងនោះភាគច្រើនគឺថា តើនឹងមានអ្វីកើតឡើងចំពោះគ្រួសារពួកគេ បើពួកគេទទួលយកការហៅឲ្យផ្សាយដំណឹងល្អនៅឆ្ងាយពីផ្ទះនោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:២៤–២៨ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលការណែនាំរបស់ព្រះអម្ចាស់ចំពោះពួកអែលឌើរ ដែលចាំបាច់ត្រូវផ្សាយដំណឹងល្អ ប៉ុន្តែមានក្រុមគ្រួសារត្រូវមើលថែផងដែរ ។

- ស្របតាម ខ ២៤ នៅពេលស្វាមី និងឪពុក បម្រើបេសកកម្មពេញម៉ោង តើនរណាគួរជួយផ្គត់ផ្គង់ដល់គ្រួសាររបស់គាត់ ?

- នៅក្នុង ខ ២៦ តើព្រះអម្ចាស់ដឹកនាំពួកអែលឌើរឲ្យធ្វើអ្វីខ្លះ បើពួកគេអាចរកបានកន្លែងមួយ ដែលក្រុមគ្រួសាររបស់ពួកគេនឹងទទួលបាននូវការផ្គត់ផ្គង់ ?

- នៅក្នុង ខ ២៨ តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ ដល់អ្នកទាំងឡាយដែលស្ថានភាពនឹងពុំអនុញ្ញាតឲ្យពួកគេចាកចេញពីក្រុមគ្រួសាររបស់ពួកគេដើម្បីប្រកាសដំណឹងល្អ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:២៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកការទូន្មានដែលព្រះអម្ចាស់បានប្រទានដល់បុរសទាំងអស់នេះ ។ វាជាជំនួយដើម្បីពន្យល់ថា មនុស្សខ្ជិលច្រអូស គឺជាបុគ្គលម្នាក់ដែលពុំស្ម័គ្រចិត្តធ្វើការ ។

- តើឃ្លាណានៅក្នុង ខ ២៩ ដែលអ្នកអាចប្រើដើម្បីសង្ខេបការទូន្មានរបស់ព្រះអម្ចាស់ចំពោះពួកអែលឌើរ ដែលអាចបម្រើបេសកកម្ម និងអ្នកទាំងឡាយដែលចាំបាច់ត្រូវនៅផ្ទះដើម្បីមើលថែក្រុមគ្រួសាររបស់ពួកគេ ? ( « សូមឲ្យមនុស្សគ្រប់រូបមានចិត្តឧស្សាហ៍ក្នុងគ្រប់ជំពូកទាំងអស់ » ។ សូមប្រាកដថាសិស្សយល់ថា ឃ្លានេះអនុវត្តចំពោះយើងទាំងអស់គ្នា ហើយថា**ព្រះអម្ចាស់បញ្ជាយើងឲ្យឧស្សាហ៍ក្នុងគ្រប់ជំពូកទាំងអស់** ) ។
- តើវាមានន័យដូចម្ដេចចំពោះ « ការឧស្សាហ៍ក្នុងគ្រប់ជំពូកទាំងអស់ » ? ( ត្រូវមានភាពខ្ជាប់ខ្ជួន ស្វិ ប្រុងស្មារតី និងខិតខំធ្វើការ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៣០–៣៦

*ព្រះអម្ចាស់ចាត់តាំងពួកអែលឌើរឲ្យបម្រើជាដៃគូផ្សព្វផ្សាយសាសនា*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៣០–៣៦ ដោយការពន្យល់ថា នៅចុងបញ្ចប់នៃវិវរណៈនេះ ព្រះអម្ចាស់បានចាត់ដៃគូអ្នកផ្សព្វផ្សាយសាសនាកាន់តែច្រើនឡើង ។

សូមបញ្ចប់មេរៀនដោយការអញ្ជើញដល់សិស្សឲ្យសរសេរនូវអ្វីដែលពួកគេអាចធ្វើនៅថ្ងៃនេះ ដើម្បីកាន់តែឧស្សាហ៍នៅក្នុងការបម្រើរបស់ពួកគេចំពោះព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សម្នាក់ ឬពីរនាក់ឲ្យចែកចាយគំនិត និងទីបន្ទាល់របស់ពួកគេអំពីគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។

មេរៀនទី ៧៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–១៩

## បុព្វកថា

នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៨៣២ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន កំពុងធ្វើការជាមួយនឹងកំណែថ្មីដ៏បំផុសគំនិតចំពោះព្រះគម្ពីរប៊ីប ( ពេលខ្លះត្រូវបានហៅថា ការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ) ។ ខណៈដែលពួកគេកំពុងបកប្រែ និងពិចារណាអំពីអត្ថន័យនៃ យ៉ូហាន ៥:២៩ នោះពួកគេត្រូវបានបង្ហាញនូវការនិមិត្តមួយ ដែលត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។ អំឡុងការនិមិត្តនេះ ព្រះអង្គសង្គ្រោះបានបង្ហាញដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន នូវដំណើរតៗគ្នានៃការនិមិត្តជាក់លាក់ ដែលបញ្ជាក់ពីភាពពិត និងភាពជាព្រះរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានបង្រៀនអំពីការធ្លាក់របស់សាតាំង និងពួកកូនអន្តរធាន ហើយបានបើកសម្ដែងពីលក្ខណៈនៃនគរនៃសិរីល្អទាំងឡាយ និងអ្នកទាំងឡាយដែលនឹងទទួលគ្រងមរតក ។ ប្រធាន វិលហ្វូឌ វូឌ្រុព្វ បានមានប្រសាសន៍ថា « ខ្ញុំនឹងសំដៅទៅលើតែ ‹ ការនិមិត្ត › [នៅក្នុងកណ្ឌ ៧៦] តែប៉ុណ្ណោះ ថាជាវិវរណៈមួយ ដែលផ្ដល់នូវពន្លឺកាន់តែខ្លាំង កាន់តែពិត និងមានគោលការណ៍ច្រើនជាងវិវរណៈណាៗទាំងអស់ ដែលមាននៅក្នុងគម្ពីរផ្សេងទៀតដែលយើងធ្លាប់អាន ។ វានឹងពន្យល់កាន់តែច្បាស់ដើម្បីឲ្យយើងយល់ដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់យើង ថាយើងមកពីណា ហេតុអ្វីយើងនៅទីនេះ និងតើយើងនឹងទៅកន្លែងណា ។ មនុស្សម្នាក់អាចដឹងតាមរយៈវិវរណៈនេះ អំពីផ្នែក និង ស្ថានភាពដែលគាត់នឹងមាន » (*Teachings of Presidents of the Church: Wilford Woodruff* [ ឆ្នាំ ២០០៤ ], ទំព័រ ១២០–២១) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ នឹងត្រូវបានបង្រៀនជាបួនមេរៀន ។ មេរៀននេះគ្របដណ្ដប់នូវទស្សនៈរួមសង្ខេបមួយអំពីការនិមិត្ត ពរជ័យដែលបានសន្យារបស់ព្រះអម្ចាស់ដល់ពួកស្មោះត្រង់ និងទង្វើទាំងឡាយដែលនាំឲ្យ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានទទួលការនិមិត្ត ។

## យោបល់សម្រាប់ការបង្រៀន

### ទស្សនៈរួមនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦

សូមឲ្យសិស្សប្រាប់ពីទីកន្លែងមួយចំនួនដែលពួកគេចង់ទៅនៅវិស្សមកាល ឬនៅថ្ងៃបុណ្យ ។ ( សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ) ។ សូមគូសរង្វង់លើទិសដៅមួយដែលបានសរសេរនៅលើក្ដារខៀន ។ សូមឲ្យសិស្សសរសេរនូវការពិពណ៌នាមួយអំពីផ្លូវដែលពួកគេនឹងចាំបាច់ត្រូវធ្វើដំណើរដើម្បីទៅដល់ទិសដៅដែលពួកគេបានជ្រើសរើស ។ បន្ទាប់ពីមួយឬ ពីរនាទី សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពិពណ៌នាអំពី អ្វីដែលពួកគេបានសរសេរ ។ បន្ទាប់មកជ្រើសរើសទិសដៅមួយ ដែលមានរៀបរាប់នៅលើក្ដារខៀន ដែលមានចំណុចពិសេសខុសគ្នាពីទិសដៅទីមួយ រួចហើយសួរសំណួរដូចខាងក្រោម ៖

- បើអ្នកធ្វើតាមផ្លូវដែលអ្នកបានពិពណ៌នាសម្រាប់ទិសដៅទីមួយ តើវានឹងនាំអ្នកទៅកាន់ទិសដៅផ្សេងនេះឬទេ ?
- តើទិសដៅដែលអ្នកជ្រើសរើសមានឥទ្ធិពលលើផ្លូវដែលអ្នកត្រូវតែធ្វើដំណើរដើម្បីទៅដល់ទីនោះយ៉ាងដូចម្ដេច ?

សូមពន្យល់ថា នៅខែកុម្ភៈ ឆ្នាំ ១៨៣២ ព្យាការីយ៉ូសែប ស្ម៊ីធ និង ស៊ីឌីនី រិកដុន បានទទួលការនិមិត្តមួយ ដែលបានបើកសម្ដែងពីទិសដៅដ៏អស់កល្បជានិច្ចរបស់មនុស្សលោកដែលអាចមាន ។ ការនិមិត្តនេះ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ពិពណ៌នាអំពីកម្រិតទាំងបី ( ឬនគរ ) នៃសិរីល្អ និងកម្រិតនៃការអភិវឌ្ឍខាងវិញ្ញាណរបស់មនុស្សទាំងឡាយដែលនឹងទទួលគ្រងវា ។ សូមអញ្ជើញសិស្សឲ្យប្រាប់ពីជម្រើសដែលនាំទៅរកជីវិតអស់កល្បនៅក្នុងនគរសេឡេស្ទាល នៅពេលពួកគេសិក្សាអំពីការនិមិត្តនេះនៅមេរៀនបួនខាងក្រោយទៀត ។ បន្ថែមពីលើនោះ សូមអញ្ជើញពួកគេឲ្យពិចារណាថា បើសិនជាជម្រើសដែលពួកគេបានធ្វើថ្មីៗនេះ កំពុងនាំពួកគេទៅកាន់ទិសដៅអស់កល្បជានិច្ច ដែលនឹងនាំពួកគេទៅកាន់សុភមង្គលដ៏មហិមាបំផុត ។

ដើម្បីផ្ដល់នូវទស្សនៈរួមសង្ខេបមួយអំពីមាតិកានៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ សូមផ្ដល់ច្បាប់ចម្លងនៃឌីយ៉ាក្រាមអមដល់សិស្សម្នាក់មួយច្បាប់ ។ ( អ្នកអាចនឹងចង់ធ្វើការថតចម្លងតូចៗល្មម ដើម្បីសិស្សអាចនឹងដាក់ស៊កវានៅក្នុងគម្ពីររបស់ពួកគេ ហើយអាចយកវាមកមើល នៅពេលពួកគេសិក្សាកណ្ឌ ៧៦ ) ។ សូមពន្យល់ថា ឌីយ៉ាក្រាម ចែងពីអ្វីដែល យ៉ូសែប និង ស៊ីឌនី បានឃើញ និងបានរៀន នៅក្នុងការនិមិត្តដែលពួកលោកបានទទួល ។




## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–១០

*ព្រះអម្ចាស់សន្យាថាប្រទានពរជ័យជាច្រើនដល់អ្នកទាំងឡាយដែលស្មោះត្រង់ចំពោះទ្រង់*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលពាក្យ ឬឃ្លាទាំងឡាយ ដែលពិពណ៌នាអំពីលក្ខណៈរបស់ ព្រះយេស៊ូវគ្រីស្ទ ។

- តើលក្ខណៈរបស់ ព្រះយេស៊ូវគ្រីស្ទ ដែលបានប្រាប់នៅក្នុងខទាំងនេះមួយណា ដែលសំខាន់ចំពោះអ្នក ? ហេតុអ្វី ?

សូមទាញចំណាប់អារម្មណ៍របស់សិស្សផ្ដោតទៅលើលក្ខណៈរបស់ព្រះអង្គសង្គ្រោះ ដែលបានពិពណ៌នានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥។

- ស្របតាម ខ ៥ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមានបទពិសោធន៍នៃក្ដីមេត្តា និងព្រះគុណរបស់ព្រះអម្ចាស់ ? ( យើងត្រូវតែកោតខ្លាចដល់ទ្រង់ ។ សូមពន្យល់ថា នៅក្នុងបរិបទនេះ ដើម្បី *កោតខ្លាច* ព្រះអម្ចាស់ មានន័យថា មានគារវភាព គោរព និងស្រឡាញ់ទ្រង់ ) ។

- តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានកិត្តិយសពីព្រះអម្ចាស់ ? តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីបម្រើព្រះអម្ចាស់ « ដោយនូវសេចក្ដីសុចរិត និងដោយនូវសេចក្ដីពិតរហូតដល់ចុងបំផុត » ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៦–៩ ដោយស្ងាត់ស្ងៀម ហើយរកមើលពរជ័យដែលព្រះអម្ចាស់បានសន្យាដល់អ្នកទាំងឡាយណា ដែលមានគារវភាព និងបម្រើទ្រង់ ។

- យោងតាមខគម្ពីរទាំងនេះ តើពរជ័យអ្វីខ្លះ នឹងកើតមានដល់អ្នកទាំងឡាយដែលមានគារវភាព និងបម្រើដល់ព្រះអម្ចាស់ ? ( អ្នកអាចនឹងចង់រំឭកសិស្សថា ពាក្យ *សេចក្ដីអាថ៌កំបាំង* នៅក្នុង ខ ៧ សំដៅទៅលើសេចក្ដីពិតខាងវិញ្ញាណ ដែលអាចនឹងត្រូវបានស្គាល់តែតាមរយៈវិវរណៈប៉ុណ្ណោះ ) ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងគោរពដល់ព្រះអម្ចាស់ ហើយបម្រើទ្រង់ដល់ទីបំផុត នោះទ្រង់នឹងប្រទានកិត្តិយសដល់យើងដោយ . . .*

សូមអញ្ជើញសិស្សឲ្យបំពេញគោលការណ៍នៅលើក្ដារខៀន ។ ពួកគេគួរតែប្រាប់ដូចខាងក្រោម ៖ **បើយើងគោរពដល់ព្រះអម្ចាស់ ហើយបម្រើទ្រង់ដល់ទីបំផុត នោះទ្រង់នឹងប្រទានកិត្តិយសដល់យើងដោយការបើកសម្ដែងសេចក្ដីពិតមកកាន់យើង ។**

ដើម្បីជួយសិស្សយល់អំពីរបៀបដែលព្រះអម្ចាស់អាចបើកសម្ដែងសេចក្ដីពិតដល់យើង សូមលើកអំពូលភ្លើង ( ឬពិល ) ឡើង ហើយសួរថាតើវាទាក់ទងនឹងឥទ្ធិពលនៃព្រះវិញ្ញាណយ៉ាងដូចម្ដេច ។ បន្ទាប់ពីពួកគេបានឆ្លើយតបហើយ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវគំនិតបន្ថែមអំពីរបៀបដែលអំពូលភ្លើងមួយ (ឬពិល) មួយ អាចទាក់ទងទៅនឹងឥទ្ធិពលនៃព្រះវិញ្ញាណ ។

- តើឥទ្ធិពលនៃព្រះវិញ្ញាណដូចជាប្រភពនៃពន្លឺមួយ ដូចជាអំពូលភ្លើងយ៉ាងដូចម្ដេច ? ( ចម្លើយរបស់សិស្សអាចនឹងឆ្លុះបញ្ចាំងអំពីសេចក្ដីពិតដូចខាងក្រោម ៖**ព្រះអម្ចាស់បំភ្លឺគំនិតយើងតាមរយៈព្រះវិញ្ញាណ** )។

- តើ *ការបំភ្លឺ* មានន័យយ៉ាងណា ? ( ដើម្បីផ្ដល់ចំណេះដឹង ឬគំនិតខាងវិញ្ញាណដែលបង្កើនការយល់ដឹងរបស់យើង ឬជួយយើងឲ្យមើលឃើញសេចក្ដីពិត ) ។

- តើអ្នកទទួលបទពិសោធន៍ពី ការទទួលបានការបំភ្លឺដោយព្រះវិញ្ញាណនៅពេលណា ? ( បន្ទាប់ពីសិស្សបានឆ្លើយតបរួចហើយ អ្នកក៏អាចចង់ចែកចាយបទពិសោធន៍មួយរបស់អ្នកផងដែរ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១–១៩

*យ៉ូសែប ស្ម៊ីធ និងស៊ីឌនី រិកដុន បានពិពណ៌នាអំពីស្ថានភាពទាំងឡាយដែលនាំទៅរកការនិមិត្តរបស់ពួកលោក*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១–១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវការបំពេញនៃការសន្យាដែលបានប្រាប់នៅក្នុង ខ ៥–១០។

- តើបទពិសោធន៍របស់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បំពេញនូវការសន្យាទាំងឡាយដែលបានប្រាប់នៅក្នុង ខ ៥–១០ តាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាដែលពួកគេបានអានព្រះគម្ពីរ ហើយពុំយល់នូវអ្វីដែលពួកគេកំពុងអាន ។

- តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីយល់ពីបទគម្ពីរឲ្យបានល្អប្រសើរ ?

សូមពន្យល់ថា សកម្មភាពរបស់ យ៉ូសែប ស្ម៊ីធ និងស៊ីឌនី រិកដុនពីមុនការទទួលបាននូវការនិមិត្តនេះ អាចបង្រៀនយើងអំពីរបៀបដែលយើងអាចយល់ពីបទគម្ពីរកាន់តែល្អប្រសើរ ហើយអញ្ជើញព្រះវិញ្ញាណដើម្បីបើកសម្ដែងសេចក្ដីពិតមកកាន់យើង ។

សូមចាត់សិស្សឲ្យធ្វើការជាគូៗ ។ សូមអញ្ជើញឲ្យសិស្សម្នាក់ក្នុងចំណោមដៃគូនិមួយៗ អាននូវការណែនាំ នៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ឲ្យឮៗ ។ សូមអញ្ជើញសិស្សម្នាក់ទៀតក្នុងចំណោមដៃគូនិមួយៗ ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១៥–១៩ ដោយស្ងាត់ស្ងៀម ។ សូមឲ្យសិស្សរកមើលនូវអ្វីដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានធ្វើ ឬកំពុងធ្វើ ដែលបានរៀបចំពួកគេឲ្យទទួលបានការយល់ដឹងអំពីបទគម្ពីរតាមរយៈវិវរណៈ ។ ( ដើម្បីជួយសិស្សយល់កាន់តែល្អប្រសើរនូវសេចក្ដីណែនាំកណ្ឌ នោះអ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យ *sundry (ផ្សេងៗ)* មានន័យច្រើន ។ អ្នកក៏អាចនឹងចង់ពន្យល់ថា នៅក្នុងជំនាន់របស់ យ៉ូសែប ស្ម៊ីធ មនុស្សភាគច្រើនបំផុតដែលជឿទៅលើព្រះគម្ពីរប៊ីប បានគិតថា បន្ទាប់ពីការជំនុំជម្រះចុងក្រោយ នោះមនុស្សទាំងអស់នឹងត្រូវបានបញ្ជូនទៅស្ថានសួគ៌ ឬទៅស្ថាននរក ) ។ បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីអានហើយ សូមពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញទៅដល់ដៃគូរបស់ពួកគេ ។ បន្ទាប់មក សូមសួរសិស្សនូវសំណួរដូចខាងក្រោមនេះ ៖

- តើ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានធ្វើអ្វីខ្លះ ដែលបានរៀបចំពួកលោកឲ្យទទួលការនិមិត្តនេះ ? ( ពួកលោក កំពុងសិក្សា និងសញ្ជឹងគិតអំពី យ៉ូហាន ៥:២៩) ។

- តើវាមានន័យយ៉ាងណាដើម្បីសញ្ជឹងគិតព្រះគម្ពីរ ? ( ចម្លើយអាចរួមមានទាំង ការពិចារណា ឬការគិតអំពីអ្វីដែលអ្នកកំពុងអាន ការសួរសំណួរអំពីអ្វីដែលអ្នកកំពុងអាន និងការភ្ជាប់នូវអ្វីដែលអ្នកកំពុងតែរៀនជាមួយនឹងអ្វីដែលអ្នកបានដឹងរួចហើយ ) ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីគំរូរបស់យ៉ូសែប ស្ម៊ីធ និងស៊ីឌនី រិកដុន ? ( សិស្សអាចនឹងផ្ដល់យោបល់អំពីគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា គូសបញ្ជាក់អំពីគោលការណ៍ដូចខាងក្រោម ៖**នៅពេលយើងសិក្សា និងពិចារណាបទគម្ពីរប្រកបដោយការអធិស្ឋាន នោះយើងបានត្រៀមខ្លួនដើម្បីទទួលនូវការយល់ដឹងមកពីព្រះអម្ចាស់ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ** )។

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរអំពីរបៀបដើម្បីសិក្សា និងពិចារណាបទគម្ពីរប្រកបដោយការអធិស្ឋាន សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលសកម្មភាពដែលជាប់ទាក់ទងជាមួយនឹងការសិក្សា និងការពិចារណាបទគម្ពីរប្រកបដោយការអធិស្ឋាន ។ ( អ្នកអាចនឹងចង់ផ្ដល់ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍ដល់សិស្សម្នាក់មួយច្បាប់ ដើម្បីពួកគេអាចធ្វើតាម ) ។



« នៅពេលដែលខ្ញុំនិយាយថា ‹ សិក្សា › ខ្ញុំមានន័យថាជាអ្វីមួយ ដែលពិសេសជាងការគ្រាន់តែអានទៅទៀត ។. . . ខ្ញុំឃើញថា ពេលខ្លះអ្នកអានពីរបីខគម្ពីរ ឈប់ ដើម្បីសញ្ជឹងគិតអំពីខគម្ពីរនោះ សូមអានខគម្ពីរនេះម្ដងទៀតដោយយកចិត្តទុកដាក់ ហើយនៅពេលអ្នកគិតអំពីអត្ថន័យរបស់វា សូមអធិស្ឋានដើម្បីទទួលបានការយល់ដឹង សួរសំណួរនៅក្នុងគំនិតរបស់អ្នក រង់ចាំការបំផុសគំនិតខាងវិញ្ញាណ រួចសរសេរទុកនូវការបំផុសគំនិត និង ទស្សនវិស័យជ្រៅជ្រះដែលនឹងកើតមាន ដើម្បីឲ្យអ្នកអាចចងចាំ ហើយរៀនសូត្របានកាន់តែប្រសើរឡើង ។ ការសិក្សារបៀបនេះ អ្នកប្រហែលមិនបានអានច្រើនជំពូក ឬ ច្រើនខគម្ពីរនៅក្នុងរយៈពេលកន្លះម៉ោងនោះទេ ប៉ុន្តែអ្នកនឹងទុកកន្លែងមួយសម្រាប់ព្រះបន្ទូលនៃព្រះនៅក្នុងដួងចិត្តរបស់អ្នក ហើយទ្រង់នឹងមានព្រះបន្ទូលមកកាន់អ្នក » ។ (When Thou Art Converted,» *Ensign* ឬ *លីអាហូណា* ខែឧសភា ឆ្នាំ ២០០៤, ទំព័រ ១១ ) ។

- តើសកម្មភាពអ្វីខ្លះ ដែលអែលឌើរ គ្រីស្ទូហ្វឺសិន បានភ្ជាប់ជាមួយនឹងការសិក្សា និងការពិចារណាបទគម្ពីរប្រកបដោយការអធិស្ឋាននោះ ?
- បន្ថែមពីលើយោបល់របស់អែលឌើរ គ្រីស្ទូហ្វឺសិន តើអ្នកបានធ្វើអ្វីផ្សេងទៀតដើម្បីសិក្សា និងពិចារណាបទគម្ពីរប្រកបដោយការអធិស្ឋាន ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- តើអ្នកមានបទពិសោធន៍អ្វីខ្លះ ជាលទ្ធផលមកពីការសិក្សា និងការពិចារណាបទគម្ពីរប្រកបដោយការអធិស្ឋាន ?

សូមលើកទឹកចិត្តដល់សិស្សឲ្យអនុវត្តសកម្មភាពទាំងឡាយ ដែលបានពិភាក្សានៅថ្ងៃនេះ នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមពិចារណាធ្វើការចែកចាយទីបន្ទាល់របស់អ្នកអំពីការសិក្សា និងការពិចារណាប្រកបដោយការអធិស្ឋាន ។

*សូមជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយ*

នៅពេលសិស្សអនុវត្តគោលការណ៍ទាំងឡាយដែលពួកគេបានរៀនមកពីបទគម្ពីរ នោះការយល់ដឹង និងទីបន្ទាល់របស់ពួកគេអំពីសេចក្ដីពិតទាំងឡាយនឹងរីកចម្រើនឡើង ។ សូមផ្ដល់ពេលដល់សិស្សក្នុងថ្នាក់ឲ្យពិចារណាអំពីអ្វីដែលពួកគេបានរៀន និងពិចារណាអំពីរបៀបដែលពួកគេអាចធ្វើនូវអ្វីដែលពួកគេបានរៀន ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិតដែលពួកគេទទួលមកពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលពួកគេពិចារណា ។

មេរៀនទី ៧៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–៤៩

## បុព្វកថា

នៅផ្នែកដំបូងនៃកំណែថ្មី បានបង្ហាញដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន នៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ១៨៣២ ពួកលោកបានមើលឃើញសិរីល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយបានថ្លែងជាសាក្សីអំពីទ្រង់ ។ ពួកលោកបានមើលឃើញសាតាំងត្រូវបានបណ្ដេញចេញពីវត្តមានរបស់ព្រះ នៅក្នុងជីវិតមុនជីវិតរមែងស្លាប់ ដោយសារការបះបោរ ។ ពួកលោកក៏ត្រូវបានបង្ហាញផងដែរអំពីកូនអន្តរធាន ហើយបានរៀនអំពីលទ្ធផលដ៏អស់កល្បនៃអ្នកទាំងឡាយដែលជ្រើសរើសដើរតាមសាតាំង ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–២៤

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានមើលឃើញការនិមិត្តមួយអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ*

សម្រាប់ទំនុកដម្កើងធម្មានិដ្ឋាន សូមអញ្ជើញសិស្សក្នុងថ្នាក់ច្រៀងបទ « ខ្ញុំដឹងថា ព្រះប្រោសលោះខ្ញុំនៅរស់ » (*ទំនុកតម្កើង* ទំព័រ ១៣៦ ) ។ ពាក្យពេចន៍នៃទំនុកតម្កើងនេះ អាចជួយសិស្សឲ្យមានអារម្មណ៍ពីព្រះចេស្ដានៃសេចក្ដីពិតដែលពួកគេនឹងរៀននៅថ្ងៃនេះ ។

សូមចាប់ផ្ដើមថ្នាក់រៀនដោយការអញ្ជើញសិស្សពិចារណាអំពីស្ថានភាពដូចខាងក្រោម ៖ ខណៈពេលកំពុងអង្គុយនៅក្នុងថ្នាក់រៀនមួយនៅសាលារៀន គ្រូបង្រៀនរបស់អ្នកចាប់ផ្ដើមការពិភាក្សាអំពីសាសនាក្នុងពិភពលោក ។ គ្រូបង្រៀនបានសួរថា បើមាននរណាជាគ្រីស្ទសាសនិកក្នុងថ្នាក់នេះ សូមស្ម័គ្រចិត្តចែកចាយអំពីជំនឿរបស់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទ ។

- បើអ្នកស្ថិតនៅក្នុងស្ថានភាពនេះ តើអ្នកនឹងនិយាយថា អ្នកជឿ ហើយស្គាល់អំពីព្រះយេស៊ូវគ្រីស្ទយ៉ាងណាខ្លះ ?

> *សូមជួយសិស្សឲ្យទទួលអារម្មណ៍ពីសេចក្ដីពិត និងសារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍ទាំងឡាយ*
>
> ឥទ្ធិពលនៃព្រះវិញ្ញាណអាចជួយសិស្សដឹងពីសេចក្ដីពិត និងសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ ការស្ដាប់ ឬការច្រៀងទំនុកតម្កើងពិសិដ្ឋ ការពិចារណាអំពីសេចក្ដីពិតនៃដំណឹងល្អ ហើយចែកចាយទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលសិស្សបានស្គាល់ គឺជាមធ្យោបាយសម្រាប់ពួកគេអញ្ជើញឥទ្ធិពលនៃព្រះវិញ្ញាណចូលក្នុងដួងចិត្តរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យមើលទៅឌីយ៉ាក្រាម ដែលពួកគេបានទទួលពីមុនរៀនមេរៀន ដែលចែងអំពីការនិមិត្តដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។ សូមពន្យល់ថា នៅក្នុងមេរៀនថ្ងៃនេះ ពួកគេនឹងរៀនអំពីផ្នែកបីដំបូងនៃការនិមិត្ត ដែលបានបើកបង្ហាញដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ។ នៅផ្នែកទីមួយនៃការនិមិត្ត ពួកលោកបានមើលឃើញព្រះវរបិតា និង ព្រះរាជបុត្រា នៅកណ្ដាលសិរីល្អរបស់ទ្រង់ ។ សូមសរសេរក្បាលរឿងបីដូចខាងក្រោមនៅលើក្ដារខៀន ៖

| *អ្វីដែលពួកលោកបានមើលឃើញ* | *អ្វីដែលពួកលោកបានស្ដាប់ឮ* | *អ្វីដែលពួកលោកបានរៀន* |
|---|---|---|

សូមសិស្សឲ្យសរសេរក្បាលរឿងក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ រួចហើយអញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–២៤ ដោយស្ងាត់ស្ងៀមហើយសរសេរពាក្យ ឬឃ្លានានាដកស្រង់ចេញពីខគម្ពីរ នៅពីក្រោមក្បាលរឿងដែលត្រូវ ។ បន្ទាប់ពីផ្ដល់ពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យមកកាន់ក្ដារខៀន ហើយធ្វើជាស្មៀន។ សូមឲ្យសិស្សក្នុងថ្នាក់ចែកចាយពាក្យ ឬឃ្លាទាំងឡាយ ដែលពួកគេបានប្រាប់នៅក្រោមក្បាលរឿងពីរដំបូង ខណៈដែលសិស្សសរសេរវានៅក្រោមក្បាលរឿងត្រឹមត្រូវនៅលើក្ដារខៀន ។

- តើគោលលទ្ធិក្នុងខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ? ( សូមអញ្ជើញសិស្សឲ្យសរសេរបញ្ជីចម្លើយរបស់សិស្សក្នុងថ្នាក់ដាក់នៅលើក្ដារខៀន នៅពីក្រោមក្បាលរឿង *អ្វីដែលពួកលោកបានស្ដាប់ឮ* )។

សិស្សអាចនឹងប្រាប់អំពីគោលលទ្ធិផ្សេងៗ រួមមានដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទជាតួអង្គមានព្រះជន្មរស់ ជាតួអង្គរុងរឿង ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ គឺជាតួអង្គផ្សេងពីគ្នា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រាសំណប់តែមួយគត់របស់ព្រះបិតា ព្រះយេស៊ូវគ្រីស្ទ គឺជាអង្គបង្កបង្កើតនៃពិភពលោកនេះ និងពិភពដទៃទៀត ហើយ យើងគឺជាបុត្រាបុត្រីសំណប់របស់ព្រះ ។**

សូមជួយសិស្សឲ្យត្រៀមខ្លួនចែកចាយពីអារម្មណ៍ និងទីបន្ទាល់របស់ពួកគេ អំពីសេចក្ដីពិតដែលពួកគេបានពិពណ៌នានៅក្នុង ខ ២០–២៤ ដោយសុំឲ្យពួកគេឆ្លើយតបនឹង *សំណួរមួយ* នៃ សំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬ សៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ( សូមសរសេរសំណួរទាំងនេះនៅលើក្ដារខៀន ) ៖

> *តើសេចក្ដីពិតទាំងនេះណាមួយ ដែលអ្នកមានអំណរគុណជាពិសេស ហើយហេតុអ្វី ?*
>
> *តើគោលលទ្ធិទាំងនេះណាមួយ ដែលអ្នកអាចថ្លែងទីបន្ទាល់ ? តើអ្នកដឹងថាវាជាការពិតដោយរបៀបណា ?*
>
> *សូមបញ្ចប់ប្រយោគនេះថា ៖ ស្ដីអំពីព្រះយេស៊ូវគ្រីស្ទ ខ្ញុំដឹង. . .*

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីសរសេរ សូមឲ្យសិស្សម្នាក់អានឲ្យឮៗអំពីទីបន្ទាល់របស់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន នៅក្នុង គ. និង ស. ៧៦:២២។ បន្ទាប់មកអញ្ជើញសិស្សណាម្នាក់ដែលស្ម័គ្រចិត្តដើម្បីចែកចាយអារម្មណ៍ និងទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេអំពីព្រះអង្គសង្គ្រោះដែលបានរស់ឡើងវិញ ដើម្បីធ្វើដូច្នោះ ។ សូមពិចារណាធ្វើការចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះអង្គសង្គ្រោះផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២៥–២៩

### *យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានមើលឃើញការនិមិត្តមួយអំពីការធ្លាក់របស់លូស៊ីហ្វើរ*

បើអាចធ្វើទៅបាន សូមផ្ដល់ដល់សិស្សម្នាក់ៗនូវច្បាប់ចម្លងនៃលំហាត់ ត្រូវ/ខុស ដូចខាងក្រោម ឬសរសេរសេចក្ដីថ្លែងការណ៍នៃលំហាត់នោះនៅលើក្ដារខៀន ។ សូមណែនាំសិស្សឲ្យសរសេរនៅលើច្បាប់ចម្លង ឬក្រដាសរបស់ពួកគេថាតើសេចក្ដីថ្លែងការណ៍និមួយៗ ត្រូវ ឬខុស ។

> ____១. *សាតាំងត្រូវបានស្គាល់ថាជា លូស៊ីហ្វើរ ។*
>
> ____២. *សាតាំង គឺជាវិញ្ញាណមួយមានសិទ្ធិអំណាចនៅក្នុងវត្តមានរបស់ព្រះ ។*
>
> ____៣. *សាតាំង ពុំមានបំណងមិនចង់គោរពតាមព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទនោះទេ ។*
>
> ____៤. *មានការសប្បាយរីករាយនៅស្ថានសួគ៌ នៅពេលសាតាំងត្រូវបានបណ្ដេញចេញ ។*
>
> ____៥. *សាតាំងធ្វើសង្គ្រាមជាមួយនឹងពួកបរិសុទ្ធនៃព្រះ ។*

បន្ទាប់ពីសិស្សបានបញ្ចប់លំហាត់ហើយ សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២៥–២៩ ពិពណ៌នាអំពីការនិមិត្តដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានមើលឃើញការធ្លាក់របស់ លូស៊ីហ្វើរ ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរទាំងនេះដោយស្ងាត់ស្ងៀម ហើយធ្វើការផ្លាស់ប្ដូរទៅលើចម្លើយរបស់ពួកគេដោយផ្ដោតទៅលើអ្វីដែលពួកគេបានអាន ។ បន្ទាប់ពីសិស្សបានបញ្ជាក់អំពីចម្លើយរបស់ពួកគេហើយ សូមមើលសេចក្ដីថ្លែងការណ៍និមួយៗរបស់សិស្សក្នុងថ្នាក់ ហើយអញ្ជើញសិស្សឲ្យពន្យល់អំពីចម្លើយរបស់ពួកគេ ដោយប្រើនូវអ្វីដែលពួកគេបានរៀន ។ សេចក្ដីថ្លែងការណ៍ទី ១ គឺ ត្រូវ ( សូមមើល គ. និង ស. ៧៦:២៦) ។ សេចក្ដីថ្លែងការណ៍ទី ២ គឺ ត្រូវ ផងដែរ ( សូមមើល គ. និង ស. ៧៦:២៥–២៧) ។ អ្នកអាចនឹងចង់ពន្យល់ដល់សិស្សថា ឈ្មោះ*លូស៊ីហ្វើរ* មានន័យថា អ្នកនាំពន្លឺ ឬការបញ្ចេញពន្លឺមួយ ។ វាក៏ត្រូវបានស្គាល់ថាជា « បុត្រានៃពេលព្រឹក » ។ ( សូមមើល Bible Dictionary « Lucifer » សេចក្ដីណែនាំដល់ព្រះគម្ពីរ « Lucifer » scriptures.lds.org ) ។

ដូចសិស្សពន្យល់ចម្លើយរបស់ពួកគេចំពោះសេចក្ដីថ្លែងការណ៍ទី ៣ ដែលខុស ( សូមមើល គ. និង ស. ៧៦:២៥ ២៨) ជួយពួកគេឲ្យយល់ថា សាតាំងបានបះបោរ ។ វាបានព្យាយាមដើម្បីដណ្ដើមបល្ល័ង្ករបស់ព្រះបិតាសួគ៌ ហើយចង់យកអំណាចនគរ និងសិរីល្អទ្រង់ ។

- ស្របតាម ខ ២៥ តើលទ្ធផលនៃការបះបោររបស់លូស៊ីហ្វើរទាស់នឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទមានអ្វីខ្លះ ? ( អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសរសេរគោលលទ្ធិដូចខាងក្រោមនៅរឹមទំព័រនៃគម្ពីររបស់ពួកគេនៅជិតនឹង ខ ២៥៖ **នៅក្នុងជីវិតមុនជីវិតលើផែនដី លូស៊ីហ្វើរបានបះបោរទាស់នឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានបណ្ដេញចេញ** )។

បន្ទាប់ពីសិស្សពន្យល់អំពីចម្លើយរបស់ពួកគេចំពោះសេចក្ដីថ្លែងការណ៍ទី ៤ ដែលខុស ( សូមមើល គ. និង ស. ៧៦:២៦ ) សូមពន្យល់ថា *កូនអន្ដរធាន* គឺជាឈ្មោះដែលដាក់ឲ្យលូស៊ីហ្វើរ មានន័យថា ការបំផ្លិចបំផ្លាញ ឬការវិនាសហិនហោច ។

នៅពេលសិស្សពន្យល់ចម្លើយរបស់ពួកគេចំពោះសេចក្ដីថ្លែងការណ៍ទី ៥ ដែលពិត ( សូមមើល គ. និង ស. ៧៦:២៩) សូមពិចារណាធ្វើការអញ្ជើញពួកគេឲ្យគូសចំណាំឃ្លានៅក្នុង ខ ២៩ ដែលបង្រៀនថា **សាតាំងបានបង្កើតសង្គ្រាមជាមួយនឹងពួកបរិសុទ្ធនៃព្រះ ។**

- តើសង្គ្រាមជាមួយនឹងសាតាំងនេះ ចាប់ផ្ដើមនៅពេលណា ? ( នៅក្នុងជីវិតមុនជីវិតនេះ ) ។ តើពាក្យដកស្រង់ចេញពី ខ ២៩ ណាខ្លះ ដែលពន្យល់ថាសង្គ្រាមដែលចាប់ផ្ដើមនៅស្ថានសួគ៌បានបន្តនៅសព្វថ្ងៃនេះ ? ( ពាក្យ *ធ្វើ* និង *ព័ទ្ធជុំវិញ* គឺទាំងពីរនេះ ត្រូវបានប្រើនៅក្នុងកាលបច្ចុប្បន្នកាល ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ព័ទ្ធជុំវិញ មានន័យថា ត្រូវបានហ៊ុំព័ទ្ធទាំងស្រុង ) ។

- តើសាតាំងបង្កើតសង្គ្រាមទាស់នឹងពួកបរិសុទ្ធនៃព្រះនៅសព្វថ្ងៃនេះយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣០–៤៩

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានមើលឃើញការនិមិត្តមួយអំពីការរងទុក្ខរបស់ពួកកូនអន្តរធាន*

- នៅក្នុងសង្គ្រាមមួយ តើជនក្បត់ជាអ្វី ?

សូមអញ្ជើញសិស្សឲ្យមើលត្រួសៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣០–៣២ រកមើលពួកជនក្បត់ព្រះអង្គសង្គ្រោះដែលព្រះអម្ចាស់បានបង្ហាញដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន នៅក្នុងការនិមិត្ត ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣០–៣៥ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលជម្រើសដែលនាំឲ្យបុគ្គលម្នាក់ៗក្លាយទៅជាពួកកូនអន្តរធាន ។

- តើជម្រើសអ្វីខ្លះ ដែលដឹកនាំឲ្យក្លាយទៅជាកូនអន្តរធាន ? ( ការជ្រើសរើសធ្វើតាមសាតាំង ការបដិសេធសេចក្ដីពិត និងបន្ថោកបន្ទាបព្រះចេស្ដាព្រះ បន្ទាប់ពីបានស្គាល់ [ សូមមើល គ. និង ស. ៧៦:៣១] ការបដិសេធព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីបានទទួល ហើយបដិសេធព្រះអង្គសង្គ្រោះ [ សូមមើល គ. និង ស. ៧៦:៣៥] ) ។

ពេលខ្លះ សិស្សមានកង្វល់ថា មនុស្សជាទីស្រឡាញ់ដែលប្រែជាមិនសូវសកម្មនៅក្នុងដំណឹងល្អ គឺជាពួកកូនអន្តរធាន ។ សូមពន្យល់ថា ពួកកូនអន្តរធាន គឺខុសពីសមាជិកសាសនាចក្រ ដែលមានទីបន្ទាល់អំពីសេចក្ដីពិតនៅពេលមួយ ប៉ុន្តែបានអសកម្មនៅក្នុងដំណឹងល្អ ។ ពួកកូនអន្តរធាន បានប្រព្រឹត្តអំពើបាបដែលមិនអាចលើកលែងឲ្យបាន គឺការបដិសេធព្រះវិញ្ញាណបរិសុទ្ធ ។

ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឹល បានបង្រៀនថា ៖



« អំពើបាបទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ តម្រូវឲ្យមានចំណេះដឹងខ្ពង់ខ្ពស់ ដែលសម្ដែងចេញយ៉ាងច្បាស់នូវរឿងដែលមិនអាចធ្វើទៅរួច ក្នុងការប្រព្រឹត្តអំពើបាបនោះ *The Miracle of Forgiveness* ឆ្នាំ ១៩៦៩ ] ទំព័រ ១២៣ ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣៦–៣៨, ៤៤–៤៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីស្ថានភាពនៃពួកកូនអន្តរធាន ។

- តើអ្នកនឹងពិពណ៌នាអំពីការរងទុក្ខដែលពួកកូនអន្តរធាននឹងទទួលបទពិសោធន៍សម្រាប់ភាពអស់កល្បជានិច្ចយ៉ាងដូចម្ដេច ?

- ស្របតាម ខ ៣៧ តើសេចក្ដីស្លាប់ប្រភេទណា ដែលពួកកូនអន្តរធាននឹងមាន ជាអ្នកដែលទទួលបទពិសោធន៍តែម្នាក់គត់នោះ ?

សូមពន្យល់ថា ពួកកូនអន្តរធាន នឹងមិនត្រូវបានប្រោសលោះពីការស្លាប់ខាងវិញ្ញាណជាលើកទីពីរឡើយ និងមិនស្នងនគរនៃសិរីល្អទុកជាមរតកដែរ បន្ទាប់ពីពួកគេត្រូវបានប្រោសឲ្យរស់ឡើងវិញនោះ ។ ផ្ទុយទៅវិញ ពួកគេនឹងរងទុក្ខដ៏អស់កល្បជានិច្ច ។

សូមចង្អុលបង្ហាញថា នៅក្នុងកណ្ដាលការនិមិត្តអំពីពួកកូនអន្តរធាន យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានរៀនពីសេចក្ដីពិតដ៏មានសង្ឃឹមមួយ ។ ដើម្បីជួយសិស្សស្គាល់សេចក្ដីពិតនេះ សូមឲ្យសិស្សរៀបរាប់អំពីព័ត៌មានដ៏ល្អបំផុត ដែលពួកគេបានទទួលអំឡុងសប្ដាហ៍មុន ។ ( អ្នកអាចនឹងចង់នាំមកនូវឧទាហរណ៍អំពីដំណឹងល្អមួយចំនួន ចេញមកពីកាសែត ឬប្រភពផ្សេងៗ ) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣៩–៤៣ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវព័ត៌មានល្អៗមួយចំនួនដែលពិភពលោកបានទទួល ។

- តើព័ត៌មានល្អអ្វីខ្លះ ដែលពិភពលោកនឹងទទួល ? ( អ្នកអាចពន្យល់ថាពាក្យ *ដំណឹងល្អ* មានន័យដើមថា ព័ត៌មានល្អ ) ។

ដើម្បីជួយសិស្សប្រាប់អំពីគោលលទ្ធិទាំងឡាយដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣៩–៤៣ សុំឲ្យពួកគេសរសេរដើមរឿងខ្លីមួយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ សរុបអំពី « ព័ត៌មានល្អ » ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។ ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយដើមរឿងរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ បន្ទាប់ពីសិស្សឆ្លើយតប អ្នកអាចនឹងចង់ផ្ដល់យោបល់ថាពួកគេគួសចំណាំឃ្លានៅក្នុង ខ ៣៩–៤៣ ដែលបង្រៀនអំពីគោលលទ្ធិដូចខាងក្រោម ៖ **តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ កូនចៅទាំងអស់របស់ព្រះនឹងគ្រងកន្លែងមួយនៅក្នុងនគរនៃសិរីល្អ លើកលែងតែពួកកូនអន្តរធានប៉ុណ្ណោះ ។**

- ហេតុអ្វីបានជាដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទគឺជា «ព័ត៌មានល្អ »សម្រាប់អ្នក ?

អ្នកអាចនឹងចង់បញ្ចប់មេរៀននេះ ដោយការចែកចាយនូវចម្លើយរបស់អ្នកចំពោះសំណួរនេះ ។

មេរៀនទី ៨០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០

## បុព្វកថា

ខណៈពេលកំពុងតែធ្វើការបកប្រែព្រះគម្ពីរប៊ីប នៅថ្ងៃទី ១៦ ខែកុម្ភៈឆ្នាំ ១៨៣២ យ៉ូសែប ស្ម៊ីធ បានធ្វើការផ្លាស់ប្ដូរដ៏បំផុសគំនិតចំពោះ យ៉ូហាន ៥:២៩ ស្ដីអំពីការរស់ឡើងវិញនៃមនុស្សសុចរិត និងមនុស្សទុច្ចរិត ។ បន្ទាប់ពីមើលឃើញការនិមិត្តអំពីសិរីល្អនៃព្រះបិតា និងព្រះរាជបុត្រា ការធ្លាក់របស់លូស៊ីហ្វើរ និងពួកកូនអន្ដរធាន នោះ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ត្រូវបានបង្ហាញការនិមិត្តអំពីអ្នកទាំងឡាយដែលនឹងមានចំណែកក្នុងការរស់ឡើងវិញនៃមនុស្សសុចរិត ៖ ជាប្រជាជននៃនគរសេឡេស្ទាល និងទេរេស្រ្ទាល ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៧០

*ព្រះអម្ចាស់បើកសម្ដែងអំពីតម្រូវការនានា និងពរជ័យទាំងឡាយនៃការទទួលបានការលើកតម្កើងនៅក្នុងនគរសេឡេស្ទាល*

សូមយកនំប៉ុងមួយចំណិតមកថ្នាក់រៀន និងគ្រឿងផ្សំសម្រាប់ធ្វើនំប៉ុង ។ ( ឬអ្នកអាចប្រើប្រភេទនៃផលិតផលដុតនំផ្សេងទៀតដែលតម្រូវឲ្យមានគ្រឿងផ្សំច្រើន ) ។ សូមសរសេរ*រូបមន្តសម្រាប់ធ្វើនំប៉ុង*នៅលើក្ដារខៀន ។ សូមឲ្យសិស្សប្រាប់អំពីគ្រឿងផ្សំសម្រាប់ធ្វើនំប៉ុង ហើយបង្ហាញវត្ថុទាំងនោះ នៅពេលសិស្សនិយាយពីវា ។ ( បើអ្នកពុំមានគ្រឿងផ្សំច្រើនទេ អ្នកអាចសរសេរវានៅលើក្ដារខៀន នៅពេលពួកគេប្រាប់ ) ។ សូមប្រាប់សិស្សថា ដំណើរការនៃ ការធ្វើនំប៉ុង អាចជួយពួកគេយល់អំពីសេចក្ដីពិតដែលនឹងប្រាប់ពួកគេនៅក្នុងការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០។

សូមជួយសិស្សមើលបរិបទ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ដោយការសួរសំណួរដូចខាងក្រោម ៖

- តើ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានធ្វើអ្វីខ្លះ ពីមុនការទទួលបានការនិមិត្ត ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦? ( ការបកប្រែ និងការពិចារណា យ៉ូហាន ៥:២៩។ បើសិស្សត្រូវការជំនួយដើម្បីចងចាំបរិបទនេះ សូមអញ្ជើញពួកគេឲ្យមើលត្រួសៗនូវប្រយោគចុងក្រោយចង្អស់នៃសេចក្ដីណែនាំដល់កណ្ឌ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូហាន ៥:២៩ ឲ្យឮៗ ។ សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន កំពុងពិចារណាអំពីការពិពណ៌នារបស់យ៉ូហាន អំពីការរស់ឡើងវិញនៃអ្នកទាំងឡាយដែលបានធ្វើល្អ និងការរស់ឡើងវិញនៃអ្នកទាំងឡាយដែលធ្វើអាក្រក់ នៅពេលពួកលោកបានទទួលការនិមិត្ត ដែលបានកត់ត្រានៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលយ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ត្រូវបានបើកបង្ហាញ បន្ទាប់ពីការនិមិត្តអំពីពួកកូនអន្ដរធាន ។ ( អ្នកអាចនឹងចង់ពន្យល់ថានៅក្នុងខនេះ ពាក្យ*ល្អ*មានន័យថា សុចរិត ) ។

- ស្របតាម ខ ៥០ តើនរណាដែលព្យាការី និង ស៊ីឌនី រិកដុន មើលឃើញនៅក្នុងការនិមិត្តបន្ទាប់អំពីពួកកូនអន្ដរធាន ? ( អ្នកទាំងឡាយដែលនឹងចេញមក ក្នុងដំណើររស់ឡើងវិញនៃមនុស្សសុចរិត ) ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០ ពិពណ៌នាអំពីអ្នកទាំងឡាយដែលនឹងត្រូវបានរស់ឡើងវិញនៅក្នុងការរស់ឡើងវិញនៃមនុស្សសុចរិត ។ សូមឲ្យសិស្សមើលត្រួសៗអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧០ ហើយពិពណ៌នាប្រាប់អំពីក្រុមមនុស្សដំបូងដែលនឹងត្រូវបានរស់ឡើងវិញ អំឡុងការរស់ឡើងវិញនៃមនុស្សសុចរិត ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមសរសេរ*រូបមន្តសម្រាប់ការក្លាយជាមនុស្សសេឡេស្ទាល* នៅលើក្ដារខៀន ។ សូមពន្យល់ថា ជាចំណែកនៃការនិមិត្តនេះ ព្រះអម្ចាស់បានបើកសម្ដែងដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុននូវការពិពណ៌នាមួយអំពីអ្នកទាំងឡាយដែលនឹងទទួលគ្រងការលើកតម្កើងនៅក្នុងនគរសេឡេស្ទាល ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥១–៥៣ ដោយស្ងាត់ស្ងៀម ហើយរកមើលតម្រូវការនានា (គ្រឿងផ្សំ ) ដើម្បីប្រែក្លាយទៅជាមនុស្សសេឡេស្ទាល ។ សូមណែនាំសិស្សថា នៅពេលពួកគេរកឃើញតម្រូវការមួយ នោះពួកគេត្រូវបានអញ្ជើញឲ្យមកកាន់ក្ដារខៀន ហើយសរសេរនូវអ្វីដែលពួកគេរកឃើញ ។

បន្ទាប់ពីសិស្សបានសរសេរអំពីតម្រូវការនានានៅលើក្ដារខៀនហើយ អ្នកអាចនឹងចង់ជួយពួកគេឲ្យយល់កាន់តែល្អប្រសើរអំពីពាក្យមួយចំនួននៅក្នុងខគម្ពីរទាំងនេះ ។

- តើអ្នកគិតថា វាមានន័យដូចម្ដេច ដើម្បី « [ទទួល] ទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ » ? (គ. និង ស. ៧៦:៥១) ។ ( ចម្លើយនានាអាចនឹងរួមមាន ការមានសេចក្ដីជំនឿទៅលើបេសកកម្មដ៏ទេវភាពរបស់ព្រះអង្គសង្គ្រោះ និងការដើរតាមដំណឹងល្អរបស់ទ្រង់ ) ។
- តើមនុស្សម្នាក់ « បានឈ្នះដោយសារសេចក្ដីជំនឿ » ដោយរបៀបណា ? (គ. និង ស. ៧៦:៥៣) ។ ( ដើម្បី « បានឈ្នះដោយសារសេចក្ដីជំនឿ » មានន័យថា ដើម្បីយកឈ្នះលើការល្បួង និងអំពើបាបទាំងឡាយ ដោយការអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងដើម្បីស៊ូទ្រាំគ្រប់ការសាកល្បងទាំងអស់ ) ។
- តើវាមានន័យយ៉ាងណា ដើម្បី « បានភ្ជាប់ដោយសារព្រះវិញ្ញាណនៃសេចក្ដីសន្យា » ? (គ. និង ស. ៧៦:៥៣) ។ ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ព្រះវិញ្ញាណបរិសុទ្ធ នៃសេចក្ដីសន្យា គឺជាព្រះវិញ្ញាណបរិសុទ្ធ ។ យើងត្រូវបានផ្សាភ្ជាប់ដោយសារព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា នៅពេលព្រះវិញ្ញាណបរិសុទ្ធថ្លែងជាសាក្សីទៅកាន់ព្រះវរបិតាសួគ៌ថា ពិធីបរិសុទ្ធទាំងឡាយ ដែលយើងបានទទួល ត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ហើយថា យើងបានស្មោះត្រង់ចំពោះសេចក្ដីសញ្ញាទាំងឡាយដែលយើងបានធ្វើ ។ ព្រះវិញ្ញាណបរិសុទ្ធ ក៏អាចបញ្ជាក់ដល់យើងថា សេចក្ដីស្មោះត្រង់របស់យើងចំពោះពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាទាំងឡាយត្រូវបានទទួលយកចំពោះព្រះដងដែរ ) ។

សូមសង្ខេបដោយខ្លី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥៤–៦៨ ដោយពន្យល់ថា វគ្គគម្ពីរនេះ មានរៀបរាប់នូវពរជ័យជាច្រើនដែលប្រទានដល់អ្នកគ្រងនគរសេឡេស្ទាលដ៏តម្កើងឡើង នឹងទទួល ។ បើមានពេល អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥៤–៦៨ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យទាំងនេះ ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំរាល់ពរជ័យដែលមានអត្ថន័យពិសេសចំពោះពួកគេ ។

- តើពរជ័យមួយណាដែលមានអត្ថន័យជាពិសេសចំពោះអ្នក ? ហេតុអ្វី ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៦៩–៧០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលតម្រូវឲ្យបុគ្គលម្នាក់ៗមានភាពសក្ដិសមចំពោះនគរសេឡេស្ទាល ។

- ទោះជាយើងព្យាយាមដើម្បីមានគ្រប់គ្រឿងផ្សំដែលចាំបាច់ទាំងអស់នៅក្នុងជីវិតរស់នៅរបស់យើងក្ដី តើខគម្ពីរទាំងនេះបាននិយាយថា យើងនៅតែចាំបាច់ត្រូវធ្វើអ្វីខ្លះទៀត ដើម្បីមានភាពសក្ដិសមទទួលគ្រងនគរសេឡេស្ទាល ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ក្រោមពាក្យថា *រូបមន្តដើម្បីក្លាយទៅជាមនុស្សសេឡេស្ទាល* **យើងអាចត្រូវបានធ្វើឲ្យល្អឥតខ្ចោះតែតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ )**

សូមពន្យល់ថា ខណៈដែលកិច្ចខិតខំដ៏ល្អបំផុតរបស់យើងដើម្បីរក្សារាល់បទបញ្ញត្តិពុំធ្វើឲ្យយើងបានល្អឥតខ្ចោះក្ដី ក៏កិច្ចខិតខំរបស់យើងនោះ បានជួយធ្វើឲ្យយើងសក្ដិសមដើម្បីទទួលព្រះគុណរបស់ព្រះអង្គសង្គ្រោះ និងត្រូវបានសម្អាតដោយ « ដង្វាយធួនដ៏ល្អឥតខ្ចោះតាមរយៈការបង្ហូរលោហិតរបស់ទ្រង់. . . » (គ. និង ស. ៧៦:៦៩) ។ សេចក្ដីពិតនេះអាចលើកទឹកចិត្តយើងឲ្យរក្សាបទបញ្ញត្តិទាំងឡាយ ហើយទទួលពិធីបរិសុទ្ធនានានៃសេចក្ដីសង្គ្រោះ ដូច្នេះយើងអាចទទួលពរជ័យដ៏អស់កល្បទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីសំណួរដូចខាងក្រោម រួចហើយសរសេរចម្លើយរបស់ពួកគេនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើគោលលទ្ធិនៅក្នុង ខ ៦៩ អាចជួយយើងឲ្យយកឈ្នះលើការបាក់ទឹកចិត្ត នៅពេលយើងព្យាយាមដើម្បីមានការលើកតម្កើងឡើងនៅក្នុងនគរសេឡេស្ទាលយ៉ាងដូចម្ដេច ?

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ដល់សិស្សហើយ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេ ។ សូមពិចារណាអំពីការចែកចាយទីបន្ទាល់របស់អ្នកអំពីតួនាទីរបស់ព្រះអង្គសង្គ្រោះនៅក្នុងការជួយយើងឲ្យប្រែក្លាយជាល្អឥតខ្ចោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧១–៨០

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ក៏ត្រូវបានបង្ហាញនូវការនិមិត្តមួយអំពីនគរទេរេសទ្រាល ។*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ត្រូវបានបង្ហាញបន្ទាប់ទៀត ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- ស្របតាមខគម្ពីរនេះ តើសិរីល្អនៃនគរទេរេសទ្រាលប្រៀបទៅនឹងសិរីល្អនៃនគរសេឡេស្ទាលយ៉ាងដូចម្ដេច ?

សូមពន្យល់ថា បទគម្ពីរប្រើក្នុងអំណាចនៃពន្លឺផ្សេងគ្នា ដែលបញ្ចេញរស្មីមកពីព្រះចន្ទ និងព្រះអាទិត្យ ដើម្បីជានិមិត្តរូបនៃភាពខុសគ្នារវាងសិរីល្អនៃនគរទេរេសទ្រាល និង នគរសេឡេស្ទាល ។ ខណៈដែលអ្នកទទួលគ្រងនគរសេឡេស្ទាល និង នគរទេរេស

ទ្រាល គឺទាំងពីរត្រូវបានរាប់បញ្ចូលនៅក្នុងការរស់ឡើងវិញនៃមនុស្សសុចរិត អ្នកទាំងឡាយដែលទទួលរូបកាយសេឡេស្ទាល នឹងត្រូវបានរស់ឡើងវិញដោយសិរីល្អកាន់តែមហិមា ហើយមានពរជ័យច្រើនជាងអ្នកទាំងឡាយដែលទទួលបានរូបកាយទេរេសទ្រាល ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧២–៨០ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលខុសគ្នារវាងអ្នកគ្រងមរតកនៃនគរទេរេសទ្រាល នឹងអ្នកគ្រងមរតកនៃនគរសេឡេស្ទាល ។ បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីអានហើយ សូមឲ្យពួកគេពិពណ៌នាអំពីភាពខុសគ្នាដែលពួកគេបានរកឃើញ ។

- ស្របតាមខគម្ពីរទាំងនេះ តើការពិពណ៌នាជាទូទៅមួយចំនួនអំពីអ្នកទាំងឡាយដែលនឹងគ្រងនគរទេរេសទ្រាលមានអ្វីខ្លះ ? ( ចម្លើយអាចរួមមានដូចខាងក្រោម ៖ អ្នកទាំងឡាយ « ដែលបានស្លាប់ទៅដោយគ្មានក្រឹត្យវិន័យ » [ខ ៧២] អ្នកទាំងឡាយ « ដែលពុំបានទទួលទីបន្ទាល់ពីព្រះយេស៊ូវកាលនៅក្នុងសាច់ឈាម ប៉ុន្តែក្រោយមកបានទទួលទីបន្ទាល់នោះ » [ខ ៧៣–៧៤] « ដែលជាមនុស្សមានកិត្តិយសនៅលើផែនដី ដែលខ្វាក់ដោយសារឧបាយកលនៃមនុស្ស » [ខ ៧៥] និង « ពួកគេដែលពុំក្លាហាននៅក្នុងទីបន្ទាល់ពីព្រះយេស៊ូវ » [ខ ៧៩] ) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែល្អប្រសើរនូវសេចក្ដីយោងចំពោះអស់អ្នកដែលបានស្លាប់ដោយគ្មានក្រឹត្យវិន័យ ឬអ្នកដែលបានទទួលដំណឹងល្អ បន្ទាប់ពីការស្លាប់ ( សូមមើល ខ ៧២–៧៤) សូមពន្យល់ថា ព្រះអម្ចាស់បានប្រទានការយល់ដឹងបន្ថែមដល់បុគ្គលម្នាក់ៗទាំងនោះ ពេលទ្រង់បានបើកសម្ដែងដល់ យ៉ូសែប ស្ម៊ីធ នូវជោគវាសនាចុងក្រោយរបស់បងប្រុសលោក អាល់វិន ដែលបានស្លាប់ទៅពីមុនគាត់បានទទួលបុណ្យជ្រមុជទឹក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៧–៩ ឲ្យឮៗ ។ បន្ទាប់មក សួរសំណួរដូចខាងក្រោមនេះ ៖

- តើការបញ្ជាក់បន្ថែមអ្វីខ្លះទៀត ដែលព្រះអម្ចាស់បានប្រទានឲ្យ ទាក់ទងនឹងអ្នកទាំងឡាយដែលនឹងទទួលយកដំណឹងល្អ បើសិនពួកគេត្រូវបានអនុញ្ញាតឲ្យនៅរស់វិញនោះ ?

- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៩ តើនរណានឹងវិនិច្ឆ័យយើងស្របតាមកិច្ចការរបស់យើង និងបំណងប្រាថ្នានៃដួងចិត្តរបស់យើងនោះ ?

សូមអានឲ្យឮៗនូវសេចក្ដីថ្លែងដូចខាងក្រោមថា ៖ « សូមចងចាំថា មានតែព្រះតែប៉ុណ្ណោះ ដែលស្គាល់ដួងចិត្តរបស់បុគ្គលម្នាក់ៗ ដែលទ្រង់អាចធ្វើការវិនិច្ឆ័យចុងក្រោយដល់បុគ្គលម្នាក់ៗនោះបាន » (*សេចក្ដីពិតចំពោះសេចក្ដីជំនឿ ៖ សេចក្ដីយោងដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ៩០ ) ។ សូមគូសបញ្ជាក់ថា ដោយសារតែព្រះអម្ចាស់អាចស្គាល់ដួងចិត្តរបស់យើង នោះយើងពុំគួរធ្វើការវិនិច្ឆ័យអំពីនគរណាមួយ ដែលយើងជឿថាអ្នកដទៃនឹងទទួលគ្រងមរតកនោះទេ ។

- តើអ្នកគិតថា « ដែលខ្វាក់ដោយសារឧបាយកលនៃមនុស្ស » មានន័យដូចម្ដេច ? (គ. និង ស. ៧៦:៧៥) ។ ( មនុស្សមួយចំនួន ត្រូវបានខ្វាក់ចំពោះសារៈសំខាន់នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដោយសារតែឥទ្ធិពលខាងលោកិយ ) ។ តើមនុស្សមួយចំនួននៅសព្វថ្ងៃនេះខ្វាក់ដោយសារឧបាយកលនៃមនុស្សយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យយល់ឃ្លា « ពុំក្លាហាននៅក្នុងទីបន្ទាល់ពីព្រះយេស៊ូវ » ( គ. និង ស. ៧៦:៧៩ ) សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ប្រូស អរ ម៉ាក់ខនគី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« តើភាពក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូវមានន័យដូចម្ដេច ?. . .

មូលដ្ឋានគ្រឹះដ៏ធំនៃភាពក្លាហាននៅក្នុងបុព្វហេតុនៃសុចរិតភាព គឺជាការគោរពប្រតិបត្តិចំពោះក្រឹត្យវិន័យទាំងអស់នៃដំណឹងល្អទាំងស្រុង ។. . .

« ក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូគឺ ត្រូវជឿលើព្រះគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ជាមួយនឹងជំនឿឥតងាករេ ។. . .

« ប៉ុន្តែវាមិនទាន់អស់នៅឡើយទេ ។ វាលើសពីការជឿ និង ការដឹងទៅទៀត ។ យើងត្រូវតែធ្វើជាអ្នករស់នៅតាមព្រះបន្ទូល ពុំមែនគ្រាន់តែជាអ្នកស្ដាប់នោះឡើយ ។ វាលើសពីការថាបម្រើតែមាត់ វាពុំមែនគ្រាន់តែជាការសារភាពតែនឹងមាត់ពីភាពជាព្រះរាជបុត្រារបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះទេ ។ វាគឺជាការគោរពប្រតិបត្តិ និង ការធ្វើតាមវិន័យ និងសេចក្ដីសុចរិតផ្ទាល់ខ្លួន ។. . .

« ដើម្បីក្លាហាននៅក្នុងទីបន្ទាល់ពីព្រះយេស៊ូវគឺត្រូវ . . . ‹ កាន់ខ្ជាប់ដរាបដល់ចុងបំផុត › ។ (នីហ្វៃទី ២ ៣១:២០) ។ គឺត្រូវរស់នៅតាមសាសនារបស់យើង ដើម្បីអនុវត្តនូវអ្វីដែលយើងផ្សាយ ដើម្បីរក្សាបទបញ្ញត្តិទាំងឡាយ » (Be Valiant in the Fight of Faith, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៤ ទំព័រ ៣៥ ) ។

- សូមគិតអំពីនរណាម្នាក់ដែលអ្នកស្គាល់ ដែលអ្នកគិតថា មានភាពក្លាហាននៅក្នុងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ។ តើអត្តចរិត និង សកម្មភាពអ្វីខ្លះ ដែលបង្ហាញពីភាពក្លាហានរបស់ពួកគេ ?
- តើមានអ្វីខ្លះ ដែលបានជួយអ្នកឲ្យក្លាហាននៅក្នុងទីបន្ទាល់របស់អ្នកពីព្រះយេស៊ូវគ្រីស្ទ ?
- បើយើងក្លាហាននៅក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ តើយើងនឹងទទួលបានអ្វីខ្លះ ? ( នៅពេលសិស្សឆ្លើយតប នោះពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងក្លាហាននៅក្នុងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលបាននគរសេឡេស្ទាលនៃព្រះ ។** សូមបន្ថែមសេចក្ដីពិតនេះទៅក្នុង *រូបមន្តសម្រាប់ការក្លាយទៅជាមនុស្សសេឡេស្ទាល* នៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីអ្វីមួយ ដែលពួកគេអាចធ្វើដើម្បីកាន់តែក្លាហាន ទៅលើទីបន្ទាល់របស់ពួកគេពីព្រះយេស៊ូវគ្រីស្ទ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា ពួកគេម្នាក់ៗមានសក្ដានុពលដើម្បីទទួលបាននគរសេឡេស្ទាល ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៦:៨០ ( មេរៀនទី ១៦ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៦:៨០ ( មេរៀនទី ១៦ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៤)

នៅពេលសិស្សបានសិក្សាការហៅបម្រើរបស់នូវល ខេ វីតនី ឲ្យធ្វើជាប៊ីស្សព នោះពួកគេបានរៀនថាការហៅបម្រើនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទគឺមកពីព្រះអង្គសង្គ្រោះ ។ ពួកគេក៏បានរៀនផងដែរថា ប៊ីស្សព និងប្រធានសាខាគ្រប់គ្រងកិច្ចការខាងសាច់ឈាម និង ខាងវិញ្ញាណរបស់សាសនាចក្រនៅក្នុងវួដ ឬសាខារបស់ពួកគាត់ ។ អំឡុងពេលរៀនអំពីកិច្ចការបកប្រែដ៏បំផុសគំនិតនៃព្រះគម្ពីរប៊ីបរបស់ព្យាការីយ៉ូសែប ស៊្មីធ នោះសិស្សបានរកឃើញគោលការណ៍ថា កូនក្មេងតូចៗគឺមានភាពបរិសុទ្ធ ត្រូវបានញែកដោយដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥)

តាមរយៈការសិក្សាការណែនាំរបស់ព្រះអម្ចាស់ ចំពោះពួកអែលឌើរមួយក្រុមនៃសាសនាចក្រ នោះសិស្សបានរៀនអំពីពរជ័យនានា ដែលព្រះអម្ចាស់ប្រទានដល់អស់អ្នកដែលស្មោះត្រង់នៅក្នុងការប្រកាសដំណឹងល្អ ។ តាមរយៈព្រះឌិវាទរបស់ព្រះអម្ចាស់ចំពោះពួកអែលឌើរមួយក្រុមផ្សេងទៀត នោះសិស្សបានឃើញថាព្រះអម្ចាស់បញ្ជាយើងឲ្យឧស្សាហ៍ក្នុងគ្រប់ជំពូកទាំងអស់ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–៤៩)

ខណៈដែលព្យាការីយ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុនបានពិចារណាពីអត្ថន័យនៃ យ៉ូហាន ៥:២៩ ពួកគេត្រូវបានប្រទានការនិមិត្តមួយពីព្រះអម្ចាស់ ។ មុននឹងសិក្សាអំពីការនិមិត្តនេះ សិស្សបានឃើញគោលការណ៍នានាទាក់ទងនឹងព្រះឆន្ទៈរបស់ព្រះអម្ចាស់ដើម្បីបើកសម្ដែងសេចក្ដីពិតដល់ពួកយើង ។ នៅពេលសិស្សបានសិក្សាផ្នែកដំបូងនៃការនិមិត្ត នោះពួកគេបានរកឃើញគោលលទ្ធិជាច្រើនអំពីព្រះយេស៊ូវគ្រីស្ទ និង សាតាំង ។ សិស្សក៏បានរៀនផងដែរថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ កូនចៅទាំងអស់របស់ព្រះ លើកលែងតែពួកកូនអន្តរធានប៉ុណ្ណោះ អាចត្រូវបានសង្គ្រោះចេញពីអំពើបាបផង និង សេចក្ដីស្លាប់ផង ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០)

អំឡុងពេលសិក្សាពីអ្វីដែលព្យាការីយ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន បានឃើញនៅក្នុងការនិមិត្តទាក់ទងនឹងនគរសេឡេស្ទាល នោះសិស្សបានរកឃើញពីពរជ័យដ៏នៅអស់កល្បជានិច្ច ដែលនឹងត្រូវប្រទានមកដល់អស់អ្នកដែលទទួលទីបន្ទាល់អំពីព្រះយេស៊ូវ ហើយគោរពព្រះបញ្ញត្តិរបស់ទ្រង់ ។ សិស្សក៏បានឃើញផងដែរថា យើងអាចត្រូវបានធ្វើឲ្យល្អឥតខ្ចោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ តាមរយៈការប្រៀបធៀបនូវភាពខុសគ្នារវាងនគរសេឡេស្ទាល និង នគរទេរេសេទ្រាល នោះសិស្សបានរៀនថា ប្រសិនបើយើងក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ នោះយើងអាចគ្រងនគរសេឡេស្ទាលនៃព្រះបាន ។

## សេចក្ដីផ្ដើម

មេរៀននេះផ្ដោតលើអ្វីដែលយ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុនបានរៀនអំពីព្រះអង្គសង្គ្រោះ និង នគរសេឡេស្ទាល និង នគរទេរេសេទ្រាលតាមរយៈការនិមិត្តដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។

## យោបល់សម្រាប់ការបង្រៀន

*កំណត់ចំណាំ ៖* ដើម្បីជួយសិស្សក្នុងកិច្ចខិតខំរបស់ពួកគេដើម្បីទន្ទេញវគ្គចំណេះចំណានខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៤០–៤១, អ្នកអាចសូត្រវាជាមួយពួកគេនៅពេលចាប់ផ្ដើម ឬ ពេលចប់ថ្នាក់នេះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–២៤

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានមើលឃើញការនិមិត្តមួយអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ*

សម្រាប់ទំនុកដម្កើងធម្មានិដ្ឋាន សូមអញ្ជើញសិស្សក្នុងថ្នាក់ច្រៀងបទ « ខ្ញុំដឹងថា ព្រះប្រោសលោះខ្ញុំនៅរស់ » (*ទំនុកតម្កើង* ទំព័រ ៧៦ ) ។ ពាក្យពេចន៍នៃទំនុកតម្កើងនេះ អាចជួយសិស្សឲ្យមានអារម្មណ៍ពីព្រះចេស្ដានៃគោលការណ៍ទាំងឡាយដែលពួកគេនឹងរៀននៅថ្ងៃនេះ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីស្ថានភាពដូចខាងក្រោម ៖ អំឡុងពេលកំពុងអង្គុយនៅក្នុងថ្នាក់រៀនមួយនៅសាលារៀន គ្រូបង្រៀនរបស់អ្នកចាប់ផ្ដើមពិភាក្សាអំពីសាសនាក្នុងពិភពលោក ។ នៅពេលនិយាយពីគ្រិស្តសាសនា គ្រូបង្រៀនសួរបើមាននរណាជាគ្រិស្តសាសនិកក្នុងថ្នាក់នេះ ដែលស្ម័គ្រចិត្តចែកចាយអំពីជំនឿរបស់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទ ។

- ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពនេះ តើអ្នកនឹងនិយាយថាអ្នកជឿ ហើយស្គាល់អ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ?

សូមចង្អុលបង្ហាញថាយើងអាចរៀនសេចក្ដីពិតជាច្រើនអំពីព្រះយេស៊ូវគ្រីស្ទនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។ សូមជួយសិស្សឲ្យរំឭកបរិបទនៃវិវរណៈនេះឡើងវិញដោយសួរសំណួរខាងក្រោម ៖

- តើព្យាការីយ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុនបានធ្វើអ្វីខ្លះពីមុនពួកលោកបានទទួលការនិមិត្ត ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦? ( ប្រសិនបើចាំបាច់ សូមលើកទឹកចិត្តសិស្សឲ្យមើលការណែនាំកណ្ឌនេះឡើងវិញ ) ។
- តើយ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុនបានឃើញនរណាមុនគេនៅក្នុងការនិមិត្តនោះ ? ( ប្រសិនបើសិស្សពុំអាចចាំទេ សូមអញ្ជើញពួកគេឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–២៤ ដើម្បីស្វែងរកចម្លើយ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–២៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីពិតដែលយ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុនបានរៀនអំពីព្រះយេស៊ូវគ្រីស្ទ ។

- តើមានសេចក្ដីពិតអ្វីខ្លះដែលយ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុនបានរៀនអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈការនិមិត្តនេះ ? ( សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ) ។

សិស្សអាចនឹងរកឃើញគោលលទ្ធិផ្សេងៗ រួមមានដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទជាតួអង្គមានព្រះជន្មរស់ មានព្រះកាយសិរីរុងរឿង ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ គឺជាតួអង្គផ្សេងពីគ្នា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រាសំណព្វតែមួយគត់របស់ព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទ គឺជាអង្គបង្កបង្កើតនៃពិភពលោកនេះ និងពិភពដទៃទៀតហើយ យើងគឺជាបុត្រាបុត្រីសំណព្វរបស់ព្រះ** ។ ( ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរឡើងនូវគោលការណ៍ចុងក្រោយនេះ នោះអ្នកអាចអញ្ជើញពួកគេឲ្យអាន ម៉ូសាយ ៥:៧) ។

- តើសេចក្ដីពិតណាមួយដែលបានសរសេរនៅលើក្ដារខៀន ដែលអ្នកអាចថ្លែងទីបន្ទាល់អំពីវាបាន ? តើអ្នកដឹងថាវាជាការពិតដោយរបៀបណា ?

សូមគិតពីការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកអំពីព្រះអង្គសង្គ្រោះ ។

សូមរំឭកសិស្សថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២២–២៤ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមឲ្យពួកគេប្រាប់ឈ្មោះពីមនុស្សដទៃទៀតដែលព្រះយេស៊ូវគ្រីស្ទ បានបង្ហាញព្រះកាយទ្រង់ដល់ពួកគេក្រៅពីព្យាការីយ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ។ ( នៅក្នុងមេរៀនសិក្សានៅផ្ទះរបស់ពួកគេសម្រាប់ថ្ងៃទី ៣ សិស្សត្រូវបានចាត់ឲ្យស្វែងរកបទគម្ពីរយោង ទៅនឹងដំណើររឿងផ្សេងទៀតនៅក្នុងព្រះគម្ពីរ ដែលព្យាការីបានថ្លែងទីបន្ទាល់អំពីការឃើញព្រះអង្គសង្គ្រោះ ។ ឧទាហរណ៍សូមមើល និក្ខមនំ ៣៣:១១; ពង្សាវតារក្សត្រទី ១ ១១:៩; និង អេសាយ ៦:៥; សូមមើលផងដែរ ម៉ាថាយ ៥:៨) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុនឃើញនគរសេឡេស្ទាល និង នគរទេរេសទ្រាលនៅក្នុងការនិមិត្ត*

សូមឲ្យសិស្សប្រាប់ពីឈ្មោះទីកន្លែងមួយចំនួនដែលពួកគេចង់ទៅពេលវិស្សមកាល ឬ នៅថ្ងៃបុណ្យជាតិ ។ ( សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ) ។ សូមគូសរង្វង់លើទិសដៅមួយដែលបានសរសេរនៅលើក្ដារខៀន ។ សូមឲ្យសិស្សពិពណ៌នាពីផ្លូវដែលពួកគេនឹងត្រូវតែធ្វើដំណើរ ដើម្បីទៅដល់ទិសដៅដែលពួកគេបានជ្រើសរើស ។ សូមជ្រើសរើសយកទិសដៅមួយទៀតចេញពីបញ្ជីទាំងនោះដែលសរសេរនៅលើក្ដារខៀន ដែលមានចំណុចពិសេសខុសៗគ្នាពីទិសដៅទីមួយដែលអ្នកបានគូសរង្វង់ ។

- ប្រសិនបើអ្នកធ្វើដំណើរតាមផ្លូវនៃទិសដៅទីមួយដែលអ្នកបានពិពណ៌នា តើវានឹងនាំអ្នកទៅកាន់ទិសដៅផ្សេងទៀតឬទេ ?
- តើទិសដៅដែលអ្នកជ្រើសរើសមានឥទ្ធិពលលើផ្លូវ ដែលអ្នកត្រូវតែធ្វើដំណើរដើម្បីទៅដល់ទីនោះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យបើកសៀវភៅមគ្គុទេសន៍ការសិក្សារបស់ពួកគេទៅ « គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ៖ ចំណុចសំខាន់ៗនៃការនិមិត្ត » រូបនៅក្នុងមេរៀនសម្រាប់ថ្ងៃទី ៣ ។




- តើការពិភាក្សារបស់យើងអំពីផ្លូវ និង ទិសដៅនានាទាក់ទងនឹងការនិមិត្តដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ យ៉ាងដូចម្ដេច ? ( ចេញពីការនិមិត្តនេះយើងរៀនអំពីផ្លូវ ឬ ជម្រើសនានាដែលនាំទៅរកទិសដៅដ៏អស់កល្បជានិច្ចដែលអាចមានដល់យើងម្នាក់ៗ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥១–៥៣ ឲ្យឮៗ ដែលពិពណ៌នាអំពីផ្លូវឆ្ពោះទៅកាន់ភាពតម្កើងឡើង នៅក្នុងនគរសេឡេស្ទាល ។ សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧២–៧៩ ឲ្យឮៗដែល ពិពណ៌នាអំពីផ្លូវដែលនាំទៅរកនគរទេរេសទ្រាល ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលផ្លូវដែលនាំឆ្ពោះទៅកាន់នគរសេឡេស្ទាល ខុសពីផ្លូវដែលនាំទៅកាន់នគរទេរេសទ្រាលយ៉ាងដូចម្ដេច ។

- តើអ្នកបានសម្គាល់ឃើញភាពខុសគ្នាអ្វីខ្លះ រវាងអ្នកដែលគ្រងមរតកនៃភាពតម្កើងឡើងនៅក្នុងនគរសេឡេស្ទាល និង អស់អ្នកដែលគ្រងមរតកនៃនគរទេរេសទ្រាល ? ( ភាពខុសគ្នាមួយសំខាន់ ដែលសិស្សអាចសម្គាល់ឃើញនោះគឺថា អស់អ្នកដែលគ្រងនគរទេរេសទ្រាល « ពុំក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ » ឡើយ (គ. និង ស. ៧៦:៧៩ ) ។

សូមឲ្យសិស្សរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥១–៥៣ ដោយរកមើលគោលការណ៍មួយដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនោះ ។

សូមសរសេរគោលការណ៍ពុំពេញលេញខាងក្រោមនៅលើក្ដារខៀន ៖ *ប្រសិនបើយើងក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ នោះ. . .*

- ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង ខ ៥១–៥៣ តើអ្នកនឹងបំពេញគោលការណ៍នេះយ៉ាងដូចម្ដេច ? ( ពួកគេអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែសិស្សគួរតែរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងក្លាហាននៅក្នុងទីបន្ទាល់ពីព្រះយេស៊ូវ នោះយើងអាចទទួលបានភាពតម្កើងឡើងនៅក្នុងនគរសេឡេស្ទាលនៃព្រះ**) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរឡើងអំពីគោលការណ៍នេះ សូមពិភាក្សាសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថាអ្វីខ្លះជាភាពខុសគ្នារវាងការមានទីបន្ទាល់ពីព្រះអង្គសង្គ្រោះ និង ការមានភាពក្លាហាននៅក្នុងទីបន្ទាល់នោះ ?
- តើទង្វើ និង ឥរិយាបទមួយចំនួនណាខ្លះ ដែលអ្នកបានឃើញនៅក្នុងខ្លួននៃអស់អ្នកដែលក្លាហានក្នុងទីបន្ទាល់របស់ខ្លួនពីព្រះអង្គសង្គ្រោះ ?
- តើមានអ្វីខ្លះដែលបានជួយអ្នកឲ្យក្លាហាននៅក្នុងទីបន្ទាល់របស់ខ្លួនពីព្រះយេស៊ូវគ្រីស្ទ ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា ពួកគេម្នាក់ៗមានសក្ដានុពល ដើម្បីទទួលភាពតម្កើងឡើងនៅក្នុងនគរសេឡេស្ទាល ។ សូមអញ្ជើញពួកគេឲ្យពិចារណាថា តើជម្រើសដែលពួកគេកំពុងធ្វើ នាំពួកគេទៅកាន់ទិសដៅអស់កល្បជានិច្ច ដែលនឹងនាំពួកគេទៅកាន់សុភមង្គលដ៏មហិមាបំផុតឬទេ ។ សូមលើកទឹកចិត្តពួកគេឲ្យក្លាហាននៅក្នុងទីបន្ទាល់របស់ខ្លួនពីព្រះយេស៊ូវគ្រីស្ទ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧–៨៣)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួន អំឡុងពេលនៃសប្ដាហ៍ក្រោយនេះ អ្នកក៏អាចអញ្ជើញពួកគេឲ្យពិចារណាពីសំណួរខាងក្រោម ៖ ហេតុអ្វីបានជាព្រះអម្ចាស់រំពឹងកាន់តែខ្លាំងពីអស់អ្នកដែលបានទទួលពន្លឺ និង ចំណេះដឹងកាន់តែច្រើនយ៉ាងដូច្នេះ ? ក្រៅពីបញ្ចប់ការសិក្សារបស់ពួកគេអំពីការនិមិត្តដែលបានប្រទានឲ្យព្យាការីយ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុនដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦, នោះនៅក្នុងមេរៀនបន្ទាប់សិស្សនឹងរៀនពីអ្វី ដែលព្រះអម្ចាស់រំពឹងចង់បានពីអស់អ្នកដែលទ្រង់បានប្រទានឲ្យនូវអ្វីៗជាច្រើន ។ សិស្សក៏នឹងអានផងដែរអំពីការពន្យល់នៃពាក្យ « តួមានជីវិតបួន » ដែលមាននៅក្នុង វិវរណៈ ៤:៦–៩ ។

មេរៀនទី ៨១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩

## បុព្វកថា

មេរៀននេះពិភាក្សាចំពោះការនិមិត្តអំពីសិរីល្អទេវឡេស្ទាល ដែលបានបង្ហាញដល់ យ៉ូសែប និង ស៊ីឌនី រិកដុន ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦ ។ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានពិពណ៌នាអំពីអ្វីដែលពួកលោកបានរៀនអំពីអ្នកទាំងឡាយដែលនឹងទទួលគ្រងនគរទេវឡេស្ទាល និងអំពីលទ្ធផលនៃការបដិសេធទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ ។ ពួកលោកក៏បានពិពណ៌នាអំពីរបៀបដែលនគរទេវឡេស្ទាលខុសពីនគរសិរីល្អផ្សេងៗទៀតផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១២

*ព្រះអម្ចាស់បង្ហាញដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន នូវការនិមិត្តមួយអំពីនគរទេវឡេស្ទាល*

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា មានមិត្តម្នាក់ដែលជាសមាជិកនៃជំនឿគ្រីស្ទសាសនាផ្សេងទៀត និយាយទៅកាន់ពួកគេថា « គ្រូគង្វាលរបស់ខ្ញុំបានប្រាប់យើងថា បន្ទាប់ពីយើងស្លាប់ទៅ នោះយើងអាចនឹងទៅស្ថានសួគ៌ ឬទៅស្ថាននរក ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំពុំល្អគ្រប់គ្រាន់ដើម្បីទៅស្ថានសួគ៌ឥឡូវនេះទេ ប៉ុន្តែខ្ញុំក៏ពុំមានអារម្មណ៍ថា ខ្ញុំអាក្រក់ខ្លាំង ដែលគួរទៅស្ថាននរកនោះដែរ ។ តើសាសនារបស់អ្នកបង្រៀនអ្វីខ្លះ អំពី ស្ថានសួគ៌ និងស្ថាននរក ? »

- តើអ្នកនឹងឆ្លើយតបចំពោះមិត្តរបស់អ្នកយ៉ាងណាដែរ ?

សូមបង្ហាញឱ្យាក្រាម ដកស្រង់មកពីមេរៀន ៧៨ ដែលហៅថាគោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦ ៖ ការថែងអំពីការនិមិត្ត » ឬអញ្ជើញសិស្សឲ្យដកនូវច្បាប់ចម្លងនៃឱ្យាក្រាមផ្ទាល់ខ្លួនរបស់ពួកគេចេញមក ) ។ នៅពេលសិស្សពិភាក្សាផ្នែកដែលនៅសល់នៃ គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦ សូមលើកទឹកចិត្តដល់ពួកគេឲ្យស្វែងរកសេចក្ដីពិត ដែលអាចនឹងជួយមិត្តម្នាក់នេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–៨៣, ១០១, ១០៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ និងឃ្លាទាំងឡាយដែលពិពណ៌នាអំពីមនុស្សដែលនឹងទទួលគ្រងនគរទេវឡេស្ទាល ។

- តើពាក្យ និងឃ្លាអ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះ ដែលពិពណ៌នាអំពីមនុស្សដែលនឹងគ្រងនគរទេវឡេស្ទាល ? (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ ថា *គ្រូមន្តអាគម* គឺជាមនុស្សម្នាក់ដែលចូលរួមក្នុងសកម្មភាពទាំងឡាយដែលអញ្ជើញឲ្យមានឥទ្ធិពលនៃវិញ្ញាណអាក្រក់មក ។ *ពួកកំផិត* គឺជាមនុស្សម្នាក់ដែលចូលរួមក្នុងអំពើបាបខាងផ្លូវភេទ ) ។

- ស្របតាម ខ ៨២ និង ១០១ មនុស្សមួយចំនួននឹងគ្រងនគរទេវឡេស្ទាលដោយសារពួកគេបានបដិសេធទទួលយកពរជ័យដ៏មហិមាដែលបានប្រទានដល់ពួកគេ ។ តើពរជ័យអ្វីខ្លះដែលពួកគេបានបដិសេធ ? ( ពួកគេបានបដិសេធទីបន្ទាល់ពីព្រះយេស៊ូវ និងដំណឹងល្អដោយស្ម័គ្រចិត្ត ។ ដោយសារពួកគេបដិសេធព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់ នោះពួកគេបដិសេធឱកាសដើម្បីប្រែចិត្តពីអំពើបាបរបស់ពួកគេ ហើយត្រូវបានលាងសម្អាតតាមរយៈដង្វាយធួននោះ ។ នៅពេលសិស្សពិភាក្សាអំពីសំណួរនេះ អ្នកអាចនឹងចង់រំឭកពួកគេអំពីអ្វីដែលពួកគេបានរៀននៅមេរៀនមុនៗអំពីការមានភាពក្លាហានចំពោះទីបន្ទាល់អំពីព្រះយេស៊ូវ ។ សូមចង្អុលបង្ហាញថា សិរីល្អ ដែលយើងគ្រងនឹងអាស្រ័យទៅលើរបៀបដែលយើងទទួលទីបន្ទាល់នេះ [ សូមមើល គ. និង ស. ៧៦:៥០–៥១, ៦៩, ៧៨–៧៩, ៨១–៨២, ១០១] ) ។

- ស្របតាម ខ ៨៣ តើអ្នកទាំងឡាយដែលនឹងទទួលគ្រងនគរទេវឡេស្ទាលខុសពីពួកកូនអន្តរធានយ៉ាងដូចម្ដេច ? ( ពួកគេពុំបានធ្វើបាបដែលពុំអាចអភ័យទោសនៃការបដិសេធព្រះវិញ្ញាណបរិសុទ្ធនោះទេ [ សូមមើល គ និងស ៧៦:៣៥] ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦:៨៤–៨៥, ១០៤–១០៦ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលនឹងកើតឡើងចំពោះមនុស្សទុច្ចរិត មុនពេលពួកគេអាចទទួលបានសិរីល្អទេឡេស្ទាល ។

### ការឲ្យនិយមន័យពាក្យ ឬ ឃ្លាពិបាកៗ

ចំណែកនៃការយល់ដឹងអំពីមាតិកានៃបទគម្ពីរ គឺជាការរៀនសូត្រអំពីអត្ថន័យនៃពាក្យ ឬឃ្លាពិបាកៗ ។ នៅពេលអ្នករៀបចំដើម្បីបង្រៀន សូមប្រាប់ពាក្យ ឬឃ្លាចេញមកពីបទគម្ពីរ ដែលសិស្សអាចនឹងពុំធ្លាប់ស្គាល់ ។ បន្ទាប់មករកមើលសេចក្ដីពន្យល់នៅក្នុងវចនានុក្រមសៀវភៅសិក្សា លេខយោង និងជំនួយការសិក្សាបទគម្ពីរ ដើម្បីជួយអ្នកឲ្យមានការយល់ដឹងត្រឹមត្រូវអំពីអត្ថន័យរបស់វា ។ សូមបង្រៀនសិស្សអំពីរបៀបដើម្បីរកមើលធនធានទាំងនេះ ដោយខ្លួនគេ ដើម្បីពង្រីកការសិក្សាបទគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

- តើអ្វីខ្លះនឹងកើតឡើងចំពោះពួកទុច្ចរិត ពីមុនពួកគេនឹងត្រូវបានប្រោសលោះ ហើយអនុញ្ញាតឲ្យទទួលគ្រងនគរទេឡេស្ទាល ? ( សូមជួយសិស្សឲ្យប្រាប់នូវសេចក្តីពិតដូចខាងក្រោម ៖**អ្នកទាំងឡាយដែលទទួលគ្រងនគរទេឡេស្ទាលត្រូវតែរងទុក្ខក្នុងនរកពីមុនពួកគេត្រូវបានប្រោសលោះដោយព្រះអង្គសង្គ្រោះ ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ) ។

ដើម្បីជួយសិស្សយល់អំពីអត្ថន័យនៃពាក្យ *នរក* សូមពន្យល់ថា បទគម្ពីរប្រើពាក្យនេះតាមរបៀប យ៉ាងហោចណាស់ ពីរយ៉ាង ។ ទីមួយ នរក គឺជាផ្នែកនៃពិភពវិញ្ញាណដែលបានគ្រងដោយពួកទុច្ចរិត ហើយវាមានពិតមែន ប៉ុន្តែជាស្ថានភាពបណ្តោះអាសន្ននៃទណ្ឌកម្ម និងការរងទុក្ខខាងវិញ្ញាណ ។ ទីពីរ ពេលខ្លះបទគម្ពីរប្រើពាក្យ *នរក* សំដៅទៅលើស្ថានភាពជាអចិន្ត្រៃយ៍នៃទណ្ឌកម្ម និងការរងទុក្ខសម្រាប់ពួកកូនអន្តរាធាន ។ ( សូមមើល BibleDictionary « Hell » សេចក្តីណែនាំដល់ព្រះគម្ពីរ « Hell »scriptures.lds.org ) ។

- តើពាក្យនៅក្នុង ខ ៨៤–៨៥ និង ១០៤–១០៦ ពិពណ៌នាអ្វីខ្លះ អំពីការរងទុក្ខដែលពួកទុច្ចរិតនឹងទទួលបទពិសោធន៍បន្ទាប់ពីពួកគេស្លាប់ទៅ ? ( អ្នកអាចចាំបាច់ត្រូវពន្យល់ថា នៅក្នុង ខ ១០៥ ឃ្លា « ភ្លើងដ៏ឆេះអស់កល្បជានិច្ច » គឺបង្ហាញពីការប្រៀបធៀប ដែលសំដៅទៅលើការរងទុក្ខរបស់ពួកទុច្ចរិត ដែលនឹងគ្រងនគរទេឡេស្ទាល ។ វាពុំមានន័យថាការរងទុក្ខរបស់ពួកគេនឹងគ្មានទីបញ្ចប់នោះឡើយ ។ សូមមើល គ. និង ស. ១៩:៤–១២) ។

សូមគូសបញ្ជាក់ថា ស្ថានភាពទាំងឡាយនៅក្នុងស្ថាននរក ចំពោះអស់អ្នកដែលនឹងគ្រងនគរទេឡេស្ទាលបានទទួលបទពិសោធន៍ ដោយគ្រាន់តែទទួលបណ្តោះអាសន្នប៉ុណ្ណោះ ។ ដោយសារតែបុគ្គលម្នាក់ៗទាំងនេះនឹងមិនប្រែចិត្ត ហើយអនុវត្តពរជ័យនៃដង្វាយធួននៅក្នុងជីវិតរបស់ពួកគេ នោះពួកគេនឹងបន្តស្ថិតនៅក្នុងស្ថាននរក ពេញមួយសហស្សវត្សរ៍ បង់ថ្លៃទោសកំហុសសម្រាប់អំពើបាបរបស់ពួកគេតាមរយៈអ្វីៗដែលពួកគេរងទុក្ខ ។

- តើឃ្លាអ្វីខ្លះ ចេញមកពី ខ ៨៥ និង ១០៦ ដែលបង្រៀនថា នរកនឹងជាស្ថានភាពបណ្តោះអាសន្នមួយសម្រាប់អ្នកទាំងឡាយដែលនឹងគ្រងនគរទេឡេស្ទាល ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន យ៉ូសែប ហ្វីលឌិង ស្ម៊ីធ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្តាប់រកលទ្ធផលនៃការរងទុក្ខ ដែលពួកទុច្ចរិតនឹងទទួលពិសោធន៍នៅក្នុងស្ថាននរក ៖



« ការរងទុក្ខនេះនឹងជាមធ្យោបាយមួយនៃការលាងសម្អាត ឬការបរិសុទ្ធ ហើយតាមរយៈវានោះពួកទុច្ចរិត នឹងនាំមកនូវស្ថានភាពមួយដែលពួកគេអាចនឹងនៅ ដែលតាមរយៈការប្រោសលោះនៃព្រះយេស៊ូវគ្រីស្ទ នោះគេទទួលបាននូវជីវិតអមតៈ ។ វិញ្ញាណ និងរូបកាយរបស់ពួកគេនឹងត្រូវបានផ្គុំគ្នាសារជាថ្មី ហើយពួកគេនឹងរស់នៅក្នុងនគរទេឡេស្ទាល ។ ប៉ុន្តែការរស់ឡើងវិញនេះ នឹងពុំកើតមានទេ ហូតទាល់តែចុងបំផុតនៃលោកិយ » ( *Doctrines of Salvation* ចងក្រងដោយ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី វ៉ុល ៣ [ ឆ្នាំ ១៩៥៤–៥៦ ] ២:២៩៨ ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:១០៦–១០៨ ដោយពន្យល់ថា ពួកទុច្ចរិតនឹងរងទុក្ខចំពោះអំពើបាបរបស់ពួកគេ ហូតដល់ព្រះយេស៊ូវគ្រីស្ទ បញ្ចប់កិច្ចការរបស់ទ្រង់ ហើយលើកនគរនៃព្រះនៅលើផែនដីទៅថ្វាយព្រះបិតាទ្រង់ ។ ពេលនោះព្រះគ្រីស្ទ នឹងត្រូវបំពាក់មកុដដោយសិរីល្អ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:១០៩–១១១ ឲ្យឮៗ ។ បន្ទាប់មកអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៧:៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលនឹងកើតឡើងនៅពេលអ្នកទាំងឡាយដែលត្រូវគ្រងនគរទេឡេស្ទាល មកខាងមុខបល្ល័ង្កនៃព្រះដើម្បីជំនុំជំរះនោះ ។

- ស្របតាម គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:១១០ តើមានអ្វីនឹងកើតឡើង នៅពេលមនុស្សទាំងនេះ ត្រូវបាននាំទៅខាងមុខបល្ល័ង្កនៃព្រះដើម្បីជំនុំជំរះនោះ ? ( ពួកគេនឹងលុតជង្គង់ចុះ ហើយទទួលស្គាល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះរបស់ពួកគេ ) ។

- ស្របតាម គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:១១១ និង ១៣៧:៩ តើព្រះអម្ចាស់នឹងជំនុំជំរះផ្អែកទៅលើរឿងអ្វីខ្លះ ?

សូមពន្យល់ថាទោះជា ខ ១១១ សំដៅជាក់លាក់ទៅលើអ្នកទាំងឡាយដែលនឹងគ្រងនគរទេឡេស្ទាលក្តី ក៏សេចក្តីពិតបានបង្រៀននៅក្នុងខនេះ អនុវត្តចំពោះមនុស្សគ្រប់រូបផងដែរ ។

- ស្របតាម ខ ១១១ តើកត្តាអ្វីខ្លះ នឹងកំណត់អំពីនគរនៃសិរីល្អដែលយើងនឹងគ្រងនោះ ? ( សូមជួយសិស្សស្គាល់នូវគោលលទ្ធិដូចខាងក្រោម ៖**នគរនៃសិរីល្អ ដែលយើងគ្រង នឹងត្រូវបានកំណត់ដោយទង្វើរបស់យើងនៅក្នុងជីវិតនេះ និងបំណងប្រាថ្នានៃដួងចិត្តរបស់យើង** ។ អ្នកអាចសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។
- តើគោលលទ្ធិនេះមានឥទ្ធិពលទៅលើការជ្រើសរើសរបស់អ្នកយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨៦–៨៩, ៩៨, ១១២ ដោយស្ងាត់ស្ងៀម ហើយរកមើលពាក្យ និងឃ្លាដែលពិពណ៌នាអំពីជីវិតអមតមានទម្រង់យ៉ាងណា ចំពោះអ្នកទាំងឡាយដែលគ្រងនគរទេឡេស្ទាល ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើពាក្យ និងឃ្លាទាំងនោះបង្ហាញសេចក្ដីស្រឡាញ់ និងក្ដីមេត្តារបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអាន ការដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៩១–៩៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលនគរនៃសិរីល្អប្រៀបធៀបនឹងគ្នា ។

- តើសិរីល្អនៃនគរសេឡេស្ទាល ខុសពីសិរីល្អនៃនគរទេរេទ្រាល និងទេឡេស្ទាលយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងអំពីសេចក្ដីពិតដូចខាងក្រោម ៖**សិរីល្អនៃនគរសេឡេស្ទាលល្អលើសលប់ជាងសិរីល្អនៃនគរទេរេទ្រាល និងនគរទេឡេស្ទាល** )។
- ស្របតាម ខ ៩២–៩៥ តើពរជ័យអ្វីខ្លះនឹងកើតមានចំពោះអ្នកទាំងឡាយដែលទទួលការលើកតម្កើងនៅក្នុងនគរសេឡេស្ទាល ? តើពរជ័យទាំងឡាយនេះ ប្រៀបធៀបនឹងពរជ័យទាំងឡាយដែលនឹងត្រូវបានផ្ដល់ទៅដល់អ្នកទាំងឡាយដែលគ្រងនគរទេឡេស្ទាលយ៉ាងដូចម្ដេចដែរ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១៣–១១៩

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ពន្យល់អំពីរបៀបដែលអ្នកដទៃអាចទទួលបានចំណេះដឹងដែលពួកលោកបានទទួល*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១៣–១១៩ ដោយពន្យល់ថា បន្ទាប់ពីការពិពណ៌នាអំពីការនិមិត្តនេះ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានថ្លែងថា ព្រះអម្ចាស់បានបញ្ជាពួកលោកកុំឲ្យសរសេរនូវអ្វីៗទាំងអស់ដែលពួកលោកត្រូវបានបើកបង្ហាញឲ្យឃើញនោះឡើយ ។ ពួកលោកក៏បានពន្យល់ផងដែរនូវអ្វីដែលយើងត្រូវធ្វើដើម្បីអាចមើលឃើញ និងយល់នូវអាថ៌កំបាំងនៃនគរនៃព្រះ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១៦–១១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលយើងអាចមើលឃើញ និងយល់នូវអាថ៌កំបាំងនៃនគរនៃព្រះ ។

- ស្របតាមខទាំងនេះ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីអាចមើលឃើញ និងយល់នូវអាថ៌កំបាំងនៃនគរនៃព្រះ ? ( សូមមើលផងដែរ គ. និង ស. ៧៦:៥–១០ ) ។

ដើម្បីជួយសិស្សពន្យល់ និងថ្លែងទីបន្ទាល់អំពីគោលលទ្ធិនានា ដែលពួកគេបានរៀនមកពីការសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ សូមរំឭកពួកគេអំពីសំណួរដែលពួកគេបានពិភាក្សានៅពេលចាប់ផ្ដើមថ្នាក់រៀនថា ៖ « តើសាសនារបស់អ្នកបង្រៀនអ្វីខ្លះ អំពី ស្ថានសួគ៌ និងស្ថាននរក ? » សូមបំបែកសិស្សជាគូៗ ហើយសុំឲ្យពួកគេធ្វើការជាមួយគ្នាដើម្បីបង្កើតជាគម្រោងមួយអំពីរបៀបដែលពួកគេអាចឆ្លើយតបចំពោះសំណួរនេះ ។ សូមប្រាប់ពួកគេថា បន្ទាប់ពីរយៈពេលពីរបីនាទីមក នោះដៃគូនិមួយៗនឹងមានឱកាសដើម្បីចែកចាយនូវចម្លើយរបស់ពួកគេដល់គូផ្សេងៗទៀត ។

ដើម្បីជួយសិស្សនៅក្នុងការរៀបចំរបស់ពួកគេ សូមចែកសំណួរដូចខាងក្រោម ឬសរសេរសំណួរនៅលើក្ដារខៀនមុនពេលចាប់ផ្ដើមថ្នាក់រៀន ៖

> តើព្រះអម្ចាស់បើកសម្ដែងអ្វីខ្លះ អំពីស្ថានសួគ៌ និងស្ថាននរក នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦?
>
> តើភាពខុសគ្នារវាងនគរសិរីល្អនិមួយៗមានអ្វីខ្លះ ?
>
> តើភាពខុសគ្នាអ្វីខ្លះ នឹងកើតមានដោយសារជម្រើសដែលបានធ្វើឡើងពីសំណាក់អ្នកទាំងឡាយដែលគ្រងនគរទាំងនេះ និងអ្នកទាំងឡាយដែលពុំគ្រងនគរនៃសិរីល្អណាមួយនោះ ?
>
> តើការពិតអ្វីខ្លះដែលអ្នកបានដឹងអំពីព្រះអង្គសង្គ្រោះ និងតួនាទីរបស់ទ្រង់នៅក្នុងសេចក្ដីសង្គ្រោះរបស់យើង ?

សូមផ្ដល់យោបល់ដល់សិស្សឲ្យពិចារណាសំណួរទាំងនេះ នៅពេលពួកគេរៀបចំដើម្បីពន្យល់នូវអ្វីដែលសាសនាចក្របង្រៀនអំពីស្ថានសួគ៌ និងស្ថាននរក ។ បន្ថែមពីលើនោះ សូមឲ្យសិស្សប្រើសេចក្ដីយោងបទគម្ពីរយ៉ាងហោចណាស់ឲ្យបានពីរដកស្រង់ចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ជាផ្នែកនៃការពន្យល់របស់ពួកគេ ។

បន្ទាប់ពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញដៃគូនិមួយៗធ្វើការជាមួយដៃគូផ្សេងទៀត ។ សូមអញ្ជើញដៃគូមួយបង្រៀនដល់សិស្សពីរនាក់ផ្សេងទៀតដោយប្រើគម្រោងរបស់ពួកគេ ។ នៅពេលដៃគូនៃសិស្សទីមួយ មានឱកាសដើម្បីពន្យល់គោលលទ្ធិរួចហើយ សូមអញ្ជើញដៃគូទីពីរឲ្យបង្រៀនម្ដង ។ បន្ទាប់ពីសិស្សបានបញ្ចប់ការបង្រៀនហើយ អ្នកអាចនឹងអញ្ជើញពួកគេឲ្យចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់នូវអ្វីដែលពួកគេបានរៀន ។

ដើម្បីជួយសិស្សអនុវត្តនូវអ្វីដែលពួកគេបានរៀនមកពីការសិក្សាអំពីនគរនៃសិរីល្អ សូមសរសេរប្រយោគពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ហើយអញ្ជើញសិស្សឲ្យបំពេញបញ្ចប់ប្រយោគនោះនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេថា ៖

> *ជាលទ្ធផលនៃអ្វីដែលខ្ញុំបានរៀនមកពីការសិក្សាអំពីនគរនៃសិរីល្អ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ៖*
>
> *ខ្ញុំដឹង. . .*
>
> *ខ្ញុំចង់. . .*
>
> *ខ្ញុំនឹង. . .*

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីបំពេញសកម្មភាពនេះ សូមលើកទឹកចិត្តពួកគេឲ្យពិចារណាថាតើការជ្រើសរើស ដែលពួកគេកំពុងធ្វើ នឹងនាំឲ្យពួកគេសក្ដិសមដើម្បីគ្រងនគរសេឡេស្ទាលដែរឬទេ ។ ក៏សូមលើកទឹកចិត្តដល់ពួកគេឲ្យស្វែងរកជំនួយរបស់ព្រះអម្ចាស់ដើម្បីធ្វើការផ្លាស់ប្ដូរនានាដែលពួកគេមានអារម្មណ៍ថា ពួកគេចាំបាច់ត្រូវធ្វើការផ្លាស់ប្ដូរនោះ ។ សូមពិចារណាធ្វើការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិតដែលអ្នកបានរៀនមកពីការសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។

មេរៀនទី ៨២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧

## បុព្វកថា

នៅខែកុម្ភៈ និង ខែមិនា ឆ្នាំ ១៨៣២ យ៉ូសែប ស្ម៊ីធ បានបន្តធ្វើកំណែថ្មីនៃព្រះគម្ពីរសញ្ញាថ្មីដ៏បំផុសគំនិតរបស់លោក ។ នៅពេលលោកបានចាប់ផ្ដើមធ្វើការទៅលើគម្ពីរនៃ វិវរណៈ នោះលោកបានងឿងឆ្ងល់អំពីអត្ថន័យនៃបទគម្ពីរមួយចំនួន ។ លោកបានទូលសួរដល់ព្រះអម្ចាស់ដើម្បីបកប្រែនិមិត្តរូប និងព្រឹត្តការមួយចំនួនដែល យ៉ូហាន ជាអ្នកទទួលវិវរណៈ បានពិពណ៌នា ។ ជាការឆ្លើយតបចំពោះសំណួររបស់ យ៉ូសែប ស្ម៊ីធ អំពីជំពូក ១–១១ នៃព្រះគម្ពីរវិវរណៈ នោះព្រះអម្ចាស់បានប្រទានវិវរណៈដែលត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ។

*កំណត់ចំណាំ ៖* ខណៈដែលមេរៀននេះថ្លែងអំពីមាតិកានៅក្នុងគម្ពីរនៃវិវរណៈ នោះវាពុំមែនជាមេរៀនមួយអំពីព្រះគម្ពីរវិវរណៈទេ ។ សូមចំណាយពេលក្នុងមេរៀនភាគច្រើន ពិភាក្សាអំពី គោលលទ្ធិ និង គោលការណ៍ដែលបានបង្ហាញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ពុំមែនជាព្រះគម្ពីរវិវរណៈ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:១–១៥

*ព្រះអម្ចាស់ឆ្លើយតបចំពោះសំណួររបស់ យ៉ូសែប ស្ម៊ីធ អំពីព្រះគម្ពីរនៃវិវរណៈ*

សូមឲ្យសិស្សពិចារណាដោយស្ងាត់ស្ងៀមអំពីអ្វីដែលពួកគេបានរៀននៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ អំឡុងពេលពីរបីថ្ងៃកន្លងទៅនេះ ។ សូមឲ្យពួកគេពីរបីនាក់ចែកចាយគំនិតដែលពួកគេបានទទួល ។ បន្ទាប់មក សូមឲ្យសិស្សមួយចំនួនចែកចាយចម្ងល់ដែលពួកគេមាន អំឡុងពេល ឬបន្ទាប់ពីការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេនោះ ។ ទាំងនេះអាចរួមមាន ចម្ងល់អំពីអត្ថន័យនៃពាក្យ ឬឃ្លាណាមួយ ជីវប្រវត្តិខាងប្រវត្តិសាស្ត្រ អំពីអ្វីដែលពួកគេអាន ឬសារៈសំខាន់នៃខគម្ពីរជាក់លាក់មួយ ។ ( គោលបំណងនៃការអនុវត្តនេះ គឺពុំមែនឆ្លើយដល់សំណួររបស់សិស្សអំពីបទគម្ពីរនោះទេ ប៉ុន្តែគឺដើម្បីគូសបញ្ជាក់អំពីសារៈសំខាន់នៃការសួរសំណួរ នៅពេលយើងសិក្សា ) ។ បន្ទាប់ពីសិស្សពីរបីនាក់បានចែកចាយរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្វីខ្លះដែលបានជួយអ្នកឲ្យរកឃើញចម្លើយចំពោះ សំណួររបស់អ្នក និងជួយឲ្យការយល់ដឹងរបស់អ្នកអំពីបទគម្ពីរកាន់តែល្អប្រសើរឡើង ?

ដើម្បីជួយសិស្សយល់បរិបទនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ សូមអញ្ជើញពួកគេឲ្យអានសេចក្ដីណែនាំកណ្ឌ ហើយរកមើលអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ បានកំពុងធ្វើ នៅពេលលោកបានទទួលវិវរណៈនេះ ។ បន្ទាប់ពីសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ នោះអ្នកអាចចង្អុលបង្ហាញថាឃ្លា « ទាក់ទងទៅនឹងការបកប្រែព្រះគម្ពីរ » គឺសំដៅទៅលើបញ្ជារបស់ព្រះអម្ចាស់ថា យ៉ូសែប ស្ម៊ីធត្រូវធ្វើកំណែថ្មីដែលបានបំផុសគំនិតចំពោះព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ ។ កំណែថ្មីទាំងនេះឥឡូវត្រូវបានស្គាល់ថាជាការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ។ សូមពន្យល់ថាអំឡុងពេលដែលយ៉ូសែប ស្ម៊ីធកំពុងធ្វើការបកប្រែគម្ពីរវិវរណៈ នោះលោកបានទូលសួរព្រះអម្ចាស់អំពីអត្ថន័យនៃខគម្ពីរមួយចំនួន ។ សំណួរដែលលោកបានសួរ និងចម្លើយដែលព្រះអម្ចាស់បានបើកសម្ដែង គឺត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលគំនិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ដែលអាចជួយពួកគេឲ្យយល់ដឹងអំពីព្រះគម្ពីរកាន់តែជ្រៅជ្រះ ។

សូមអញ្ជើញសិស្សឲ្យបើកទៅ គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៧ ហើយសុំឲ្យពួកគេពន្យល់អំពី របៀបដែលទម្រង់នៃកណ្ឌនេះមានភាពខុសគ្នាពីកណ្ឌផ្សេងទៀតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ។ ពួកគេគួរតែកត់សម្គាល់អក្សរ*ស*និង*ច* នៅជិតនឹងខគម្ពីរ ឬឃ្លា និមួយៗ នៅក្នុងកណ្ឌនោះផងដែរ ។ សូមពន្យល់ថាអក្សរ *ស*និមួយៗ នាំមុខនូវសំណួរមួយមកពី យ៉ូសែប ស្ម៊ីធ ហើយអក្សរ *ច* និមួយៗ នាំមុខដោយចម្លើយរបស់ព្រះអម្ចាស់ ។

សូមសួរដល់សិស្ស បើមានពួកគេណាម្នាក់បានអានគម្ពីរនៃវិវរណៈខ្លះៗ ឬទាំងអស់រួចហើយ ។

- តើការអានគម្ពីរវិវរណៈអាចមានឧបសគ្គអ្វីខ្លះ ? ( បើសិស្សពុំបានប្រាប់ទេ អ្នកអាចពន្យល់ថា គម្ពីរវិវរណៈអាចនឹងពិបាកយល់ ដោយសារតែមាននូវនិមិត្តរូប ) ។

### *សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ*

គ្មានរឿងតូចតាចណា ដែលនឹងមានឥទ្ធិពលសម្រាប់កិច្ចការល្អ យូរអង្វែងជាងការជួយសិស្សឲ្យអភិវឌ្ឍនូវទម្លាប់នៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃនោះឡើយ ។ សូមលើកទឹកចិត្តសិស្សឲ្យឆ្លៀតពេលវេលារាល់ថ្ងៃ សម្រាប់ការសិក្សាព្រះគម្ពីរ ។ វិធីមួយដើម្បីលើកទឹកចិត្តឲ្យសិក្សាព្រះគម្ពីរប្រចាំថ្ងៃ គឺតាមរយៈការផ្ដល់ឱកាសដល់សិស្សជាទៀងទាត់នៅក្នុងថ្នាក់ ដើម្បីចែកចាយដល់គ្នាទៅវិញទៅមកអំពីអ្វីដែលពួកគេកំពុងរៀន និងមានអារម្មណ៍អំឡុងពេលការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេនោះ ។

ដើម្បីផ្ដល់នូវឧទាហរណ៍អំពីរូបភាពនៃនិមិត្តរូបនៅក្នុងគម្ពីរវិវរណៈ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេនគ្នាអានឲ្យឮៗចេញមកពី វិវរណៈ ៤:២–៨ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនិមិត្តរូបនៅក្នុងខគម្ពីរទាំងនេះ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យប្រាប់ពីនិមិត្តរូបទាំងនេះ ហើយសុំឲ្យសិស្សម្នាក់សរសេរវានៅលើក្ដារខៀន ។ ( ចម្លើយអាចរួមមាន ឥន្ទធនូព័ទ្ធជុំវិញបល្ល័ង្ក បល្ល័ង្កម្ភៃបួន មកុដមាស ចង្កៀងប្រាំពីរឆេះ សមុទ្រកែវ និង តួមានជីវិតបួន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសំណួររបស់ យ៉ូសែប ស្ម៊ីធ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:១។ សូមឲ្យសិស្សម្នាក់គូសរង្វង់និមិត្តសញ្ញានៅលើក្ដារខៀន ដែល យ៉ូសែប ស្ម៊ីធ បានទូលសួរដល់ព្រះអម្ចាស់ដើម្បីជួយគាត់យល់ ( សមុទ្រកែវ ) ។ បន្ទាប់មកឲ្យសិស្សម្នាក់ទៀតអានការពន្យល់របស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:១។

- តើចម្លើយនេះជួយយើងយល់កាន់តែប្រសើរឡើងពី វិវរណៈ ៤:៦ យ៉ាងដូចម្ដេច ?

សូមបែងចែកសិស្សជាគូៗ ។ សូមឲ្យគូនិមួយៗអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:២–៥ ជាមួយគ្នា រកមើលនូវសំណួរបន្ថែមដែល យ៉ូសែប ស្ម៊ីធ បានសួរអំពីនិមិត្តរូបនៅក្នុង វិវរណៈ ៤ និងចម្លើយដែលព្រះអម្ចាស់បានប្រទានឲ្យចំពោះសំណួរទាំងនោះ ។ បន្ទាប់មានពេលគ្រប់គ្រាន់ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីរបៀបដែលចម្លើយរបស់ព្រះអម្ចាស់ឆ្លើយចំពោះសំណួររបស់ យ៉ូសែប ស្ម៊ីធ ជួយពួកគេឲ្យយល់អំពីរូបភាពនិមិត្តរូបមួយចំនួននៅក្នុង វិវរណៈ ៤:២–៨។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេនឹងប្រើអ្វីដែលពួកគេបានរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ដើម្បីសង្ខេបអ្វីដែលយ៉ូហានបានពិពណ៌នានៅក្នុង វិវរណៈ ៤:២–៨។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយការសង្ខេបរបស់ពួកគេ ។ បន្ទាប់មកសូមសួរសំណួរខាងក្រោមនេះ ៖

- តើយើងអាចរៀនអ្វីខ្លះដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ អំពីតួនាទីរបស់ព្យាការីម្នាក់នៅក្នុងការជួយយើងឲ្យយល់អំពីអត្ថន័យនៃបទគម្ពីរ ? ( ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងក្ដី ក៏ពួកគេគួរបង្ហាញនូវគោលលទ្ធិដូចខាងក្រោម ៖**ព្រះអម្ចាស់បើកសម្ដែងការបកប្រែអំពីបទគម្ពីរត្រឹមត្រូវ តាមរយៈពួកព្យាការីរបស់ទ្រង់ ។** ( អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យសរសេរគោលលទ្ធិនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។

ដើម្បីជួយសិស្សយល់ពីគោលលទ្ធិនេះ សូមសួរសំណួរដូចខាងក្រោម៖

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីរៀននូវអ្វីដែលពួកព្យាការីបានបង្រៀនទាក់ទងនឹងអ្វីដែលយើងសិក្សានៅក្នុងបទគម្ពីរដូច្នេះ ?

ដើម្បីជួយសិស្សឲ្យទទួលបានគំនិតយោបល់បន្ថែមចំពោះសំណួរនេះ សូមសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមឲ្យឮៗ ដោយអែលឌើរ ប្រ៊ូស អរ ម៉ាក់ខនគី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ពួកព្យាការីបានផ្ដល់ព្រះគម្ពីរឲ្យ ហើយពួកព្យាការី ត្រូវតែបកប្រែវា ។ បុរសបរិសុទ្ធជំនាន់ដើម បានទទួលវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធ ដែលពួកលោកបានកត់ត្រាជាគម្ពីរ ឥឡូវមនុស្សត្រូវតែមានព្រះវិញ្ញាណបរិសុទ្ធដូចគ្នា ដើម្បីបើកសម្ដែងនូវអត្ថន័យរបស់វាតាមរយៈព្រះគម្ពីរ– បើមិនដូច្នោះទេនឹងមាននូវការដឹកនាំទៅរកការបកប្រែផ្ទាល់ខ្លួន ហើយលទ្ធផល នឹងនាំឲ្យមានព្រះវិហារខុសគ្នាជាច្រើន ហើយមិនចុះសម្រុងជាច្រើន ដែលជាស្ថានភាពជាក់ស្ដែងនៅក្នុងពិភពលោកខាងសាសនានាសព្វថ្ងៃនេះ » ( នៅក្នុង Conference Report, ខែ តុលា ឆ្នាំ ១៩៦៤, ទំព័រ ៣៨) ។

- ស្របតាមអែលឌើរ ម៉ាក់ខនឃី ហេតុអ្វីក៏យើងត្រូវការព្យាការីម្នាក់ដើម្បីបកប្រែអត្ថន័យត្រឹមត្រូវក្នុងព្រះគម្ពីរ ?
- តើយើងអាចរកបានការបង្រៀនរបស់ពួកព្យាការីអំពីអត្ថន័យនៃអ្វីដែលយើងអាននៅក្នុងព្រះគម្ពីរនៅកន្លែងណា ? ( ចម្លើយអាចរួមមាន យើងរកបានការបង្រៀនដូច្នេះ នៅក្នុងសុន្ទរកថាសន្និសីទទូទៅ និងនៅក្នុងទស្សនាវដ្ដីសាសនាចក្រ និងការបោះពុម្ពរបស់សាសនាចក្រផ្សេងៗទៀត ) ។

នៅពេលសិស្សឆ្លើយតបចំពោះសំណួរនេះ សូមចង្អុលបង្ហាញថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ បង្ហាញថា ពាក្យសម្ដីរបស់ពួកព្យាការី ដែលបានកត់ត្រានៅក្នុងព្រះគម្ពីរអាចជួយពន្យល់បទគម្ពីរផ្សេងទៀត ។ ជាច្រើនលើកច្រើនគ្រា ពាក្យសម្ដីរបស់ព្យាការីម្នាក់ ដែលបានកត់ត្រានៅក្នុងវគ្គបទគម្ពីរមួយ នឹងពន្យល់ ឬបកប្រែនូវអ្វីដែលបានបើកសម្ដែងនៅក្នុងវគ្គបទគម្ពីរមួយទៀត ។ សូមពន្យល់ថា លេខយោងមាននូវក្នុងបទគម្ពីរ ជាញឹកញាប់ផ្ដល់ជាសេចក្ដីយោងចំពោះវគ្គបទគម្ពីរដ៏ជាជំនួយទាំងនេះ ។

### *បានបរិយាយអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ*

គោលលទ្ធិ និងគោលការណ៍ជាច្រើនពុំថ្លែងចំៗដោយអ្នកទាំងឡាយដែលបានសរសេរបទគម្ពីរទេ ប៉ុន្តែត្រូវបានបរិយាយជំនួសវិញ ។ គោលការណ៍ដែលបានបរិយាយទាំងឡាយ អាចត្រូវបានបង្ហាញនៅក្នុងខ្សែរឿង ឬបរិបទខាងប្រវត្តិសាស្ត្រអំពីខគម្ពីរមួយ ។ គោលការណ៍ដោយប្រយោលជាញឹកញាប់អាចត្រូវបានរកឃើញដោយការស្វែងរកពីមូលហេតុ និងប្រសិទ្ធភាព ទំនាក់ទំនងនៅក្នុង បណ្ដុំបទគម្ពីរដែលបានសិក្សា ។

ដើម្បីបង្ហាញអំពីចំណុចនេះ សូមអញ្ជើញសិស្សឲ្យអាន វិវរណៈ ៥:១ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលយ៉ូហានបានឃើញនៅក្នុងដៃរបស់មនុស្សម្នាក់ដែលអង្គុយនៅលើបល្ល័ង្ក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ បើសិស្សកំពុងប្រើការបោះពុម្ពរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ សូមអញ្ជើញពួកគេឲ្យបើកទៅបទគម្ពីរដែលបានយោងនៅក្នុង លេខយោងខនៅក្នុង វិវរណៈ ៥:១ (គ. និង ស. ៧៧:៦) ។ បើសិស្សពុំមានកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍របស់ ពួកបរិសុទ្ធថ្ងៃចុងក្រោយទេ សូមអញ្ជើញពួកគេឲ្យបើកទៅកា ន់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:៦ ដោយផ្ទាល់ បន្ទាប់ពីពួកគេបានពិពណ៌នានូវអ្វីដែលពួកគេបានរកឃើញនៅក្នុង វិវរណៈ ៥:១។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួររបស់ យ៉ូសែបស្ម៊ីធ អំពី វិវរណៈ ៥:១ ក៏ដូចជាចម្លើយរបស់ព្រះអម្ចាស់ផងដែរ ។ ( វាអាចនឹងជាប្រយោជន៍ដើម្បីពន្យល់ថា ៧០០០ ឆ្នាំ សំដៅទៅលើគ្រា ចាប់តាំងពីការធ្លាក់នៃលោកអ័ដាម និង អេវ៉ាមកម្ល៉េះ ។ វាពុំសំដៅទៅលើអាយុកាលពិតប្រាកដនៃផែនដី រួមទាំងអាយុកាលនៃការបង្កបង្កើតនោះទេ ) ។

សូមឲ្យសិស្សប្រើពាក្យសម្ដីផ្ទាល់របស់ពួកគេដើម្បីសង្ខេបសំណួរ និងចម្លើយទាំងឡាយ ។ បន្ទាប់ពីបញ្ចប់សកម្មភាពនេះ សូមចង្អុលបង្ហាញពីរបៀបដែលការប្រើប្រាស់លេខយោង នៅពេលយើងសិក្សាបទគម្ពីរ អាចជួយយើងឲ្យរកឃើញអ្វីដែលព្រះអម្ចាស់បានមានបន្ទូល អំពីបទគម្ពីរដែលយើងកំពុងអាន ។

សូមចង្អុលបង្ហាញថា ទោះបីជាមានតែព្យាការីម្នាក់គត់ដែលមានសិទ្ធិអំណាចដើម្បីបកប្រែព្រះគម្ពីរសម្រាប់ពិភពលោកក្ដី ក៏យើងម្នាក់ៗគួរតែស្រាវជ្រាវដើម្បីមានការយល់ដឹង និង អនុវត្តផ្ទាល់ខ្លួននៅពេលសិក្សាព្រះគម្ពីរដោយខ្លួនឯង ។

- តើយើងអាចប្រៀបប្រដូចអ្វីដែលយ៉ូសែប ស្ម៊ីធបានធ្វើនៅពេលលោកបានសិក្សា និង ពិចារណាអំពីគម្ពីរវិវរណៈទៅនឹងការសិក្សាគម្ពីរផ្ទាល់ខ្លួនរបស់យើងយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងរកឃើញគោលការណ៍មួយដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងទូលសុំដល់ព្រះអម្ចាស់ នោះទ្រង់អាចជួយយើងឲ្យយល់បទគម្ពីរទាំងឡាយ** )។

- ហេតុអ្វីវាសំខាន់ដើម្បីស្រាវជ្រាវរកអត្ថន័យត្រឹមត្រូវនៃបទគម្ពីរ រួចហើយព្យាយាមអនុវត្តដោយផ្ទាល់ខ្លួនដូច្នេះ ?

សូមឲ្យសិស្សពិចារណាអំពីគ្រាមួយ នៅពេលដែលពួកគេបានសុំព្រះអម្ចាស់ឲ្យជួយពួកគេយល់នូវបទគម្ពីរ និង របៀបដើម្បីអនុវត្តការបង្រៀននៅក្នុងបទគម្ពីរចំពោះស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមពន្យល់ថា អ្វីដែលនៅសល់ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ មាននូវសំណួរជាច្រើនទៀតដែល យ៉ូសែប ស្ម៊ីធ បានសួរអំពីគម្ពីរវិវរណៈ និងចម្លើយរបស់ព្រះអម្ចាស់ ចំពោះសំណួរទាំងឡាយនេះ ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:៨–១៥ ដោយការប្រាប់សិស្សថា វិវរណៈនេះ បានអនុញ្ញាតឲ្យ យ៉ូសែប ស្ម៊ីធ រៀនអំពីព្រឹត្តការណ៍មួយចំនួនដែលនឹងកើតឡើង មុនពេលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។

សូមប្រាប់សិស្សថា នៅពេលពួកគេសិក្សាគម្ពីរវិវរណៈនាពេលអនាគត នោះចម្លើយរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ អាចជួយពួកគេយល់អំពីអត្ថន័យនៃរូបភាពជានិមិត្តរូបនៅក្នុងគម្ពីរ ។

សូមបញ្ចប់មេរៀននេះដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀននេះ ឬដោយការចែកចាយបទពិសោធន៍មួយ ដែលអ្នកមាន ជាលទ្ធផលមកពី ការងាកទៅរកព្រះអម្ចាស់សុំជំនួយដើម្បីយល់បទគម្ពីរ ។

មេរៀនទី ៨៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨–៨០

## បុព្វកថា

នៅថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានបើកសម្ដែងដល់ យ៉ូសែប ស្ម៊ីធ នូវវិវរណៈ ដែលឥឡូវនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានដឹកនាំព្យាការីឲ្យបង្កើតក្រុមហ៊ុនមួយ ( ដែលក្រោយមកត្រូវបានគេស្គាល់ថា ជាក្រុមហ៊ុនសហរដ្ឋ ) ដើម្បីគ្រប់គ្រងឃ្លាំងទាំងឡាយ និងគ្រប់គ្រងកិច្ចខិតខំបោះពុម្ពផ្សាយរបស់សាសនាចក្រ ។ ព្រះអម្ចាស់ក៏បានពិពណ៌នាអំពីពរជ័យទាំងឡាយដែលពួកបរិសុទ្ធនឹងទទួលផងដែរ បើពួកគេបានគោរពដល់បទបញ្ញត្តិដើម្បីរៀបចំបង្កើតក្រុមហ៊ុននេះ ។ នៅក្នុងកិច្ចខិតខំដើម្បីការពារដល់ដំណើរការក្រុមហ៊ុនរបស់សាសនាចក្រនេះពីមារសត្រូវនោះភាសាមួយចំនួននៃវិវរណៈនេះ ត្រូវបានផ្លាស់ប្ដូរ នៅពេលដែលវាត្រូវបានបោះពុម្ពលើកដំបូងក្នុងឆ្នាំ ១៨៣៥ ការបោះពុម្ពនៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ ឧទាហរណ៍ ក្រុមហ៊ុនសហភាព គឺសំដៅថាជា « របៀប » ឬ « របៀបរួម » ។ ក្នុងពេលដំណាលគ្នា ដែលព្រះអម្ចាស់បានបញ្ជា យ៉ូសែប ស្ម៊ីធ ឲ្យបង្កើតក្រុមហ៊ុនសហភាព នោះព្រះអម្ចាស់បានប្រទានវិវរណៈដែលត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៩–៨០។ នៅក្នុងវិវរណៈទាំងនេះ ព្រះអម្ចាស់បានហៅយ៉ារេឌ ខារតើរ, ស្ទេផាន បើរណែត និង អេដែន ស្ម៊ីធ ដើម្បីបម្រើជាពួកអ្នកផ្សព្វផ្សាយសាសនា ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១–១៦

*ព្រះអម្ចាស់បញ្ជាព្យាការី យ៉ូសែប ស្ម៊ីធ ដើម្បីរៀបចំក្រុមហ៊ុនសហភាព ។*

សូមលើកក្រដាសប្រាក់ប៉ុន្មានសន្លឹកឡើង ហើយសួរសំណួរដូចខាងក្រោម ៖

- តើប្រាក់អាចត្រូវបានប្រើសម្រាប់គោលបំណងអាក្រក់យ៉ាងដូចម្ដេច ?
- តើប្រាក់អាចត្រូវបានប្រើដើម្បីពន្លឿនបុព្វហេតុល្អយ៉ាងដូចម្ដេច ?

បន្ទាប់ពីសិស្សឆ្លើយតប ចូរពន្យល់ថា នៅក្នុងខែ ឧសភា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានបញ្ជាថា ឃ្លាំងមួយ ត្រូវស្ថាបនាឡើង ដើម្បីប្រមូលផលិតផល និងប្រាក់កាស សម្រាប់ជាប្រយោជន៍ដល់អ្នកក្រីក្រ ( សូមមើល គ. និង ស. ៥១) ។ ក្រោយមកឃ្លាំងពីរ ត្រូវបានបង្កើតឡើង ៖ ឃ្លាំងមួយដំណើរការដោយ ស៊ីឌនី ហ្គីលបើត នៅ អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ហើយមួយទៀតបានដំណើរការដោយ នូវែល ឃេ វីតនី នៅក្រុងខឺតឡង់ រដ្ឋ អូហៃអូ ។ នៅក្នុងទំនួលខុសត្រូវនេះ បងប្រុស ហ្គីលបើត និង បងប្រុស វីតនី បានធ្វើជាភ្នាក់ងារសម្រាប់សាសនាចក្រ ។ ឃ្លាំងទាំងនេះ ផ្គត់ផ្គង់របស់របបដែលចាំបាច់ដល់ពួកបរិសុទ្ធ ខណៈពេលបង្កើតមូលនិធិដើម្បីទិញដី និងដើម្បីផ្គង់ផ្គង់ហិរញ្ញវត្ថុដល់ការបោះពុម្ពវិវរណៈ ដែលយ៉ូសែប ស្ម៊ីធ បានទទួលផងដែរ ។ ឃ្លាំងទាំងនេះ ក៏ត្រូវជួយដល់អ្នកទាំងឡាយដែលខ្វះខាតផងដែរ ( សូមមើល គ. និង ស. ៧២:១០–១២) ។

ដើម្បីជួយសិស្សយល់អំពីបរិបទនៃ វិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីណែនាំចំពោះកណ្ឌនោះ នៅក្នុងការបោះពុម្ពព្រះគម្ពីរ ឆ្នាំ ២០១៣ ថា ៖

> « ពីដើមឡើយ វិវរណៈនេះបានណែនាំដល់ព្យាការី ស៊ីឌនី រិកដុន និង នូវែល ខេ វីតនី ឲ្យធ្វើដំណើរទៅរដ្ឋ មិសសួរី ហើយរៀបចំការបោះពុម្ព និងអាជីវកម្មរបស់សាសនាចក្រ ដោយការបង្កើតជា « ក្រុមហ៊ុន » មួយ ដែលនឹងមើលខុសត្រូវលើកិច្ចខិតខំទាំងនេះ ដោយការបង្កើតមូលនិធិសម្រាប់ការស្ថាបនាស៊ីយ៉ូន និងសម្រាប់ជាប្រយោជន៍ដល់ជនក្រីក្រ ។ ក្រុមហ៊ុននេះ ត្រូវបានស្គាល់ថា ក្រុមហ៊ុនសហភាព ត្រូវបានរៀបចំឡើងនៅខែមេសា ឆ្នាំ ១៨៣២ ហើយបានបញ្ឈប់ទៅវិញនៅឆ្នាំ ១៨៣៤ ( សូមមើល កណ្ឌ ៨២) ។ ពេលមួយបន្ទាប់ពីវាបានបញ្ឈប់ទៅ ក្រោមការដឹកនាំរបស់ យ៉ូសែប ស្ម៊ីធ ឃ្លា ‹ កិច្ចការនៃឃ្លាំងសម្រាប់ជនក្រីក្រ › បានជំនួសពាក្យ « ការស្ថាបនាការបោះពុម្ព និងអាជីវកម្ម » នៅក្នុងវិវរណៈ ហើយពាក្យ « របៀប » បានជំនួសពាក្យ ‹ ក្រុមហ៊ុន › » ។

សូមប្រាកដថា សិស្សយល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨ ពាក្យ *របៀប* ( សូមមើល ខ ៤ សំដៅទៅលើសហសមាគម ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៣–៤ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលថាក្រុមហ៊ុន ឬរបៀប ដែលអនុញ្ញាតឲ្យពួកបរិសុទ្ធធ្វើ ។

- ស្របតាម ខ ៤ តើបុព្វហេតុអ្វីដែលព្រះអម្ចាស់ចង់ឲ្យរីកចម្រើនតាមរយៈការស្ថាបនាក្រុមហ៊ុននេះ ? ( សេចក្ដីសង្គ្រោះនៃមនុស្សលោក ) ។

- តើវិធីមួយចំនួនដែលប្រាក់អាចត្រូវបានយកមកប្រើប្រាស់ដើម្បីចម្រើនបុព្វហេតុនៃសេចក្ដីសង្គ្រោះមានអ្វីខ្លះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៥–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុថាហេតុអ្វីព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធរបស់ទ្រង់ជួយ « មនុស្សទ័លក្រក្នុងវាស្ដ្រ [របស់ទ្រង់] » (គ. និង ស. ៧៨:៣) ។ សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេ។

- តើការជួយដល់មនុស្សទ័លក្រ នឹងជួយឲ្យពួកបរិសុទ្ធក្លាយជា « បានស្មើគ្នានៅក្នុងអ្វីៗខាងផែនដី » យ៉ាងដូចម្ដេច ?

អ្នកអាចនឹងចាំបាច់រំឭកដល់សិស្សថា នៅក្នុងវិវរណៈមុនមួយ ដែលព្រះអម្ចាស់បានកំណត់ពីភាពដូចគ្នា តាមស្ថានភាព តម្រូវការ និងចំណង់របស់គ្រួសារ ( សូមមើល គ. និង ស. ៥១:៣) ។ ហេតុដូច្នោះហើយ បទបញ្ញាឲ្យបានស្មើគ្នាចំពោះអ្វីៗខាងផែនដី ពុំថ្លែងបញ្ជាក់ថា មនុស្សគ្រប់រូបនឹងមានចំនួនធនធានស្មើគ្នាទាំងស្រុងនោះទេ ប៉ុន្តែថា គ្រប់គ្រួសារនឹងមានគ្រប់គ្រាន់សម្រាប់តម្រូវការ និងចំណង់របស់ពួកគេ ស្របតាមស្ថានភាពនិមួយៗរបស់ពួកគេ ។

សូមចង្អុលបង្ហាញថា ឃ្លា « អ្វីៗខាងស្ថានសួគ៌ » នៅក្នុង ខ ៥–៦។

- តើ « អ្វីៗខាងស្ថានសួគ៌ » អ្វីខ្លះ ដែលអ្នកគិតថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងមានភាពស្មើគ្នា ?

- តើការមានភាពស្មើគ្នាចំពោះអ្វីៗខាងផែនដី អាចអនុញ្ញាតឲ្យយើងស្មើគ្នានៅក្នុងការទទួលបានអ្វីៗខាងស្ថានសួគ៌យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលមូលហេតុបន្ថែមមួយថា ហេតុអ្វីព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធមើលថែដល់មនុស្សទ័លក្រ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើអ្នកគិតថា ការមើលថែដល់ជនទ័លក្រ នឹងរៀបចំពួកបរិសុទ្ធឲ្យគ្រងនគរសេឡេស្ទាលតាមវិធីណាខ្លះ ?

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរនេះ ដែលអនុវត្តចំពោះយើងសព្វថ្ងៃនេះ ? ( សិស្សអាចប្រើពាក្យផ្សេងៗ ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម ៖**ការគោរពប្រតិបត្តិចំពោះបទបញ្ញត្តិរបស់ព្រះអម្ចាស់ រៀបចំយើងសម្រាប់កន្លែងមួយនៅក្នុងនគរសេឡេស្ទាល** )។

សូមឲ្យសិស្សសរសេរបទបញ្ញត្តិរបស់ព្រះអម្ចាស់ឲ្យបានច្រើនតាមដែលគេអាចធ្វើទៅបាននៅក្នុងមួយនាទី ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន។ សូមអញ្ជើញសិស្សឲ្យជ្រើសរើសបទបញ្ញត្តិមួយដែលបានសរសេរនៅលើក្ដារខៀន ហើយសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ នូវប្រយោគពីរបី ដែលពន្យល់អំពីរបៀបដែលការគោរពតាមបទបញ្ញត្តិនោះ នឹងជួយរៀបចំពួកគេសម្រាប់នគរសេឡេស្ទាល ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

ដើម្បីជួយសិស្សឲ្យកាន់តែយល់បន្ថែមអំពីគោលបំណងរបស់ព្រះអម្ចាស់ចំពោះការប្រទានដល់យើងនូវបទបញ្ញត្តិទាំងឡាយ សូមសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« វាមិនគ្រប់គ្រាន់ទេសម្រាប់នរណាម្នាក់ដែលគ្រាន់តែធ្វើអ្វីមួយទៅតាមតែអារម្មណ៍នោះ ។ ព្រះបញ្ញត្តិ ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងឡាយ នៃ ដំណឹងល្អ គឺមិនមែនជាបញ្ជីនៃការដាក់ប្រាក់ ដែលតម្រូវឲ្យធ្វើនៅក្នុងគណនីសួគ៌មួយចំនួននោះទេ ។ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាផែនការមួយដែលបង្ហាញយើងពីរបៀបដើម្បីប្រែក្លាយជាអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងប្រែក្លាយ » (The Challenge to Become,» *Ensign*, ខែ វិច្ឆិកា ឆ្នាំ ២០០០, ទំព័រ ៣២ ) ។

- តើការយល់ពីគោលបំណងរបស់ព្រះអម្ចាស់ក្នុងការប្រទានបទបញ្ញត្តិទាំងឡាយដល់យើង អាចជួយយើងឲ្យគោរពដល់ទ្រង់កាន់តែស្មោះត្រង់ខ្លាំងឡើងយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សពីរនាក់ឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៨–៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលឈ្មោះនៃអ្នកទាំងឡាយដែលព្រះអម្ចាស់បានតែងតាំងឲ្យរៀបចំសហសមាគមនោះឡើង។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- ស្របតាម ខ ៩ តើបុរសទាំងបីរូបនេះ បានបញ្ជាឲ្យអង្គុយជាមួយនរណានៅក្នុងការប្រឹក្សា ? ( សូមជួយសិស្សឲ្យយល់ថា ឃ្លា « ពួកបរិសុទ្ធ . . . នៅក្នុងស៊ីយ៉ូន » សំដៅទៅលើសមាជិកសាសនាចក្រនៅអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ) ។

ចូរពន្យល់ថា យ៉ូសែប ស៊្មីធ, នូវែល ខេ វិតនី, ស៊ីឌនី រិកដុន, ពេត្រុស វិតមើរ ជុញ្ញ័រ និង ចែស៊ី កស បានគោរពតាមបទបញ្ញត្តិនេះ ហើយបានធ្វើដំណើរទៅរដ្ឋ មិសសួរី ក្នុងខែ មេសា ឆ្នាំ ១៨៣២ ។ មិនយូរប៉ុន្មានបន្ទាប់ពីការមកដល់របស់ពួកគាត់ បុរសទាំងបីរូបបានមានក្រុមប្រឹក្សាមួយ ដែលពួកគេបានរៀបចំក្រុមហ៊ុនសហភាព ស្របតាមការដឹកនាំនៅក្នុងវិវរណៈនេះ ។ ក្រុមហ៊ុននោះ មានសមាសភាព យ៉ូសែប ស៊្មីធ, ស៊ីឌនី រិកដុន, នូវែល ខេ វិតនី, អែតវើត ប៉ាទ្រិច, ស៊ីឌនី ហ្គីលបើត, អូលីវើរ ខៅឌើរី, យ៉ូហាន វិតមើរ, វិលាម ដបុលយូ ហ្វែប្ស និង ម៉ាទីន ហារិស ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១០–១៦ ដោយការពន្យល់ថា នៅក្នុងគម្ពីរទាំងនេះ ព្រះអម្ចាស់បានគូសបញ្ជាក់ថា សមាជិកនៃក្រុមហ៊ុន គួរតែចងភ្ជាប់ខ្លួនរួមគ្នាតាមរយៈសេចក្ដីសញ្ញាមួយដើម្បីគ្រប់គ្រងសហគ្រាសរបស់សាសនាចក្រ ។ ដោយការស្មោះត្រង់ចំពោះសេចក្ដីសញ្ញានេះ ពួកគេនឹងមានជំនួយរបស់ព្រះអម្ចាស់នៅក្នុងការសម្រេចនូវបទបញ្ញត្តិរបស់ទ្រង់ ។ ព្រះអម្ចាស់ក៏បានពន្យល់ផងដែរថា បើពួកបរិសុទ្ធបានធ្វើតាមការណែនាំរបស់ទ្រង់ នោះសាសនាចក្រនឹងអាចឈរដោយឯករាជ្យពីអង្គភាពនានាផ្សេងទៀតនៅលើផែនដីទាំងអស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៧–២២

*ព្រះអម្ចាស់បានពិពណ៌នាអំពីពរជ័យនានាដែលមានសម្រាប់អ្នកទាំងឡាយដែលរក្សាបទបញ្ញត្តិទាំងឡាយរបស់ទ្រង់*

សូមសួរដល់សិស្សឲ្យរៀបរាប់នូវអំណោយ ឬពរជ័យមួយចំនួនដែលពួកគេបានទទួល នៅពេលពួកគេនៅក្មេង ដែលពួកគេមានអំណរគុណកាន់តែខ្លាំងនៅពេលនេះ កាលដែលពួកគេកាន់តែធំដឹងក្ដី ។

- ហេតុអ្វីក៏អ្នកមានអំណរគុណចំពោះ អំណោយ ឬពរជ័យទាំងឡាយនេះកាន់តែច្រើននាពេលឥឡូវនេះ ?
- តើអ្នកគិតថា ការណ៍នេះអាចទាក់ទងនឹងពរជ័យដែលព្រះវរបិតាសួគ៌របស់យើងបានរៀបចំសម្រាប់យើងយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៧–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីរបៀបដែលពួកបរិសុទ្ធប្រៀបដូចជាកុមារតូចៗ ។

- ហេតុអ្វីក៏ពេលខ្លះវាពិបាកសម្រាប់យើងដើម្បីយល់អំពីពរជ័យទាំងឡាយដែលព្រះអម្ចាស់បានមាននៅក្នុងឃ្លាំងសម្រាប់យើង ?
- ទោះជាយើងមិនអាចយល់ ឬទ្រាំទ្រនូវរឿងគ្រប់យ៉ាងក្ដី តើព្រះអម្ចាស់បានផ្ដល់ការអញ្ជើញអ្វីខ្លះដល់យើង ? ( សូមមានចិត្តរីករាយចុះ ) ។
- តើការដឹងថា ព្រះអម្ចាស់ « នឹងដឹកនាំ [យើង] រាល់គ្នា » (គ. និង ស. ៧៨:១៨) ឆ្លងកាត់នូវរឿងទាំងឡាយដែលយើងមិនអាចយល់ ឬទ្រាំទ្រ អាចជួយយើងឲ្យមានចិត្តអរសប្បាយយ៉ាងដូចម្ដេច ?

សូមសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៩ ដោយស្ងាត់ស្ងៀមរកមើលការដឹកនាំរបស់ព្រះអម្ចាស់ប្រទានទៅដល់ពួកបរិសុទ្ធ ។ បន្ទាប់មក សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

- តើព្រះអម្ចាស់បានមានបន្ទូលអ្វីខ្លះនឹងកើតឡើងសម្រាប់អ្នកទាំងឡាយដែលជ្រើសរើសដើម្បីទទួលនូវគ្រប់ការណ៍ទាំងអស់ដោយក្ដីអំណរគុណនោះ ? ( សិស្សគួរតែប្រាប់នូវគោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ដូចខាងក្រោម ៖ **បើសិនជាយើងទទួលគ្រប់ការណ៍ទាំងអស់ដោយមានអំណរគុណ នោះព្រះអម្ចាស់នឹងប្រទានពរជ័យដល់យើងទ្វេដង** )។
- ហេតុអ្វីក៏អ្នកគិតថា ព្រះអម្ចាស់នឹងប្រទានពរជ័យទ្វេដងដល់អ្នកទាំងឡាយដែលទទួលគ្រប់ការណ៍ទាំងអស់ដោយអំណរគុណយ៉ាងដូច្នេះ ?
- តើការជ្រើសរើសដើម្បីទទួលគ្រប់ការណ៍ទាំងអស់ដោយអំណរគុណ ក៏អាចជួយយើងឲ្យមានចិត្តរីករាយយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេអាចទទួលនូវគ្រប់ការណ៍ទាំងអស់ដោយមានអំណរគុណកាន់តែពេញលេញយ៉ាងណា។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:២០–២២ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា យើងគួរតែធ្វើ ដើម្បីមានលទ្ធផលមួយនៃការយល់ដឹងអំពីការសន្យាទាំងឡាយដែលបានពិពណ៌នានៅក្នុង ខ ១៩។ សូមឲ្យសិស្សចែកចាយពីអ្វីដែលពួកគេបានរកឃើញ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៩–៨០

*យ៉ារេដ ខារតើរ, ស្ទេផាន បើរណែត និង អេដែន ស្មីធ ត្រូវបានហៅឲ្យបម្រើបេសកកម្ម*

សូមប្រាប់សិស្សឲ្យដឹងថា នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៩ និង ៨០ ព្រះអម្ចាស់បានហៅបុរសបីនាក់ឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ សូមចាត់ឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូម្នាក់សិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៩ ហើយសុំឲ្យដៃគូម្នាក់ទៀតសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨០។ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍ទាំងឡាយដែលអនុវត្តចំពោះកិច្ចការផ្សព្វផ្សាយសាសនា នៅពេលពួកគេសិក្សាកណ្ឌដែលបានចាត់ឲ្យពួកគេនោះ ។

បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមសិស្សឲ្យចែកចាយជាមួយនឹងដៃគូរបស់ពួកគេអំពីគោលការណ៍ទាំងឡាយដែលពួកគេបានរកឃើញ។ បន្ទាប់មក សូមសុំឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេនូវគោលការណ៍មួយដែលពួកគេបានរៀន ។ សូមអញ្ជើញពួកគេឲ្យសរសេរប្រយោគពីរបីអំពីរបៀបដែលពួកគេអាចប្រើគោលការណ៍នោះ ដើម្បីចែកចាយដំណឹងល្អជាមួយនរណាម្នាក់ដែលពួកគេស្គាល់ ។

សូមបញ្ចប់មេរៀននេះដោយការថ្លែងទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលអ្នកបានពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។

មេរៀនទី ៨៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១

## បុព្វកថា

នៅថ្ងៃទី ៨ ខែ មិនា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានហៅ ចែសី កស និង ស៊ីឌនី រិកដុន ឲ្យបម្រើជាទីប្រឹក្សារបស់ យ៉ូសែប ស្ម៊ីធ ។ នៅមួយសប្ដាហ៍ក្រោយមក នៅថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានប្រទានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១។ នៅក្នុងវិវរណៈនេះ ទ្រង់បានពិពណ៌នាអំពីតួនាទីរបស់ទីប្រឹក្សាទៅកាន់ប្រធានសាសនាចក្រ និងបានចែងពីពរជ័យទាំងឡាយសម្រាប់អ្នកទាំងឡាយដែលស្មោះត្រង់នៅក្នុងការបម្រើរបស់ពួកគេ ។ ចែសី កស ពុំបន្តនៅស្មោះត្រង់ទេ រួចព្រះអម្ចាស់បានហៅ ហ្វ្រេឌើរិក ជី វិលលាម្ស ដែលឥឡូវមានឈ្មោះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ ឲ្យជំនួសតំណែងរបស់ កស នៅក្នុងគណៈប្រធាន ។ នៅគ្រានៃវិវរណៈនេះ ប្រធាននៃសាសនាចក្រ និងទីប្រឹក្សារបស់លោក ត្រូវបានហៅជាគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ។ ចាប់ផ្ដើមនៅក្នុងឆ្នាំ ១៨៣៤ វិវរណៈសំដៅទៅលើប្រធាន និងទីប្រឹក្សារបស់លោក ក្នុងនាមជាគណៈប្រធានទីមួយ ( សូមមើល គ. និង ស. ១០២:២៦–២៨) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:១–៧

*ព្រះអម្ចាស់ពិពណ៌នាអំពីតួនាទីនៃទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ*

ពីមុនថ្នាក់ចាប់ផ្ដើម សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖

> *ហេតុអ្វីព្រះអម្ចាស់ប្រទានដល់យើងនូវការហៅបម្រើនៅក្នុងសាសនាចក្ររបស់ទ្រង់ ?*
>
> *តើពរជ័យនៃការបំពេញការហៅបម្រើដោយស្មោះត្រង់ មានអ្វីខ្លះ ?*
>
> *ចុះបើនរណាម្នាក់ជ្រើសរើសមិនបំពេញការហៅបម្រើរបស់ពួកគេដោយស្មោះត្រង់វិញនោះ ?*

សូមចាប់ផ្ដើមដោយការអញ្ជើញសិស្សឲ្យឆ្លើយតបនឹងសំណួរនៅលើក្ដារខៀន ។ ជាចំណែកនៃការពិភាក្សា អ្នកអាចពន្យល់ថា ទោះជាអ្នកដឹកនាំសាសនាចក្រម្នាក់ អាចនឹងទទួលការបំផុសគំនិតដើម្បីហៅសមាជិកនៃសាសនាចក្រម្នាក់ផ្ដល់នូវតំណែងជាក់លាក់មួយក្ដី ក៏វាគឺអាស្រ័យទៅលើបុគ្គលដែលទទួលការហៅឲ្យឆ្លើយតបចំពោះការហៅដោយស្មោះត្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការណែនាំក្បាលកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលគំរូមួយរបស់មនុស្សម្នាក់ដែលបានហៅដោយព្រះអម្ចាស់ ប៉ុន្តែពុំបានធ្វើការហៅរបស់គាត់ដោយស្មោះត្រង់ ។

- តើនរណាដែលព្រះអម្ចាស់បានហៅដំបូងគេឲ្យបម្រើជាទីប្រឹក្សាដល់ យ៉ូសែប ស្ម៊ីធ នៅក្នុងគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ?
- ហេតុអ្វី ចែសី កស បាត់បង់ការហៅរបស់គាត់ ?

សូមពន្យល់ថា ចែសី កស ត្រូវបានហៅឲ្យធ្វើជាទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ នៅខែមិនា ឆ្នាំ ១៨៣២ ។ នៅក្នុងថ្ងៃទី ១ ខែសីហា ឆ្នាំ ១៨៣២ គាត់បានចេញដំណើរទៅបេសកកម្មមួយជាមួយ ស៊ីប៊ីឌី ខូលទ្រីន ។ ខណៈដែលនៅក្នុងបេសកកម្មនេះ បងប្រុស កស បានជួបនឹងភរិយារបស់គាត់ ហើយបានព្យាយាមដើម្បីបញ្ចុះបញ្ចូលនាងអំពីសេចក្ដីពិត ប៉ុន្តែនាងបដិសេធមិនចូលរួមក្នុងសាសនាចក្រ ។ មិនយូរប៉ុន្មានក្រោយមក បងប្រុស ខូលទ្រីន បានឈឺជាទម្ងន់ រួចបានត្រឡប់ទៅខឺតឡង់វិញ ។ ជាអកុសល បងប្រុស កស ពុំបានបញ្ចប់បេសកកម្មរបស់គាត់ ហើយពុំបាននៅស្មោះត្រង់នៅក្នុងសាសនាចក្រទេ ។

- ស្របតាមសេចក្ដីណែនាំកណ្ឌ តើព្រះអម្ចាស់បានហៅនរណាឲ្យជំនួស ចែសី កស ?

អ្នកអាចនឹងចង់ឲ្យផ្ដល់យោបល់ថា សិស្សគួរសចំណាំនូវឃ្លាដូចខាងក្រោម នៅក្នុងសេចក្ដីណែនាំកណ្ឌ ៖ « វិវរណៈ. . . គួរតែទុកជាជំហានមួយដើម្បីរៀបចំជាផ្លូវការនូវគណៈប្រធានទីមួយ » ។ សូមពន្យល់ថា ប្រធាននៃសាសនាចក្រ និងទីប្រឹក្សារបស់លោក ( គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ) នឹងពុំសំដៅជា « គណៈប្រធានទីមួយ » ទេ រហូតដល់ឆ្នាំ ១៨៣៤

( សូមមើល គ. និង ស. ១០២:២៦–២៨) ។ ព្រះអម្ចាស់ពុំបើកសម្ដែងនូវការរៀបចំពេញលេញនៃសាសនាចក្ររបស់ទ្រង់ដល់យ៉ូសែប ស្ម៊ីធ ពីព្យាការីទាំងអស់ក្នុងពេលតែម្ដងនោះទេ ។ ទ្រង់បានបើកសម្ដែងផ្នែកផ្សេងគ្នានៃការរៀបចំនៅពេលដែលតម្រូវការកើតមានឡើង និងពេលពួកបរិសុទ្ធត្រៀមខ្លួនជាស្រេចដើម្បីទទួលយក ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានបង្រៀន ហ្វ្រេឌើរិក ជី វិលលាម្ស អំពីគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ។

- ស្របតាម ខ ២ តើគណៈប្រធានកាន់អ្វីខ្លះ ? ( សិស្សគួរតែស្គាល់នូវសេចក្ដីពិតដូចខាងក្រោម ៖**គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ កាន់កូនសោនៃនគររបស់ព្រះនៅលើផែនដី ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំពាក្យ និងឃ្លានានាដែលបង្រៀនពីសេចក្ដីពិតនេះ ) ។

ដើម្បីជួយសិស្សយល់នូវគោលលទ្ធិនេះ សូមរំឭកពួកគេថា « កូនសោបព្វជិតភាពគឺជាសិទ្ធិអំណាចព្រះ ដែលបានប្រទានដល់អ្នកដឹកនាំបព្វជិតភាពទាំងឡាយដើម្បី ដឹកនាំ គ្រប់គ្រង និង ត្រួតត្រាការប្រើប្រាស់បព្វជិតភាពរបស់ទ្រង់នៅលើផែនដី ។ ការអនុវត្តសិទ្ធិអំណាចនៃបព្វជិតភាព គឺត្រូវបានគ្រប់គ្រងដោយអ្នកទាំងឡាយដែលកាន់កូនសោ ( សូមមើល គ. និង ស. ៦៥:២, ៨១:២, ១២៤:១២៣) ។ អ្នកទាំងឡាយដែលកាន់កូនសោមានសិទ្ធិដើម្បីធ្វើជាអធិបតី និងដឹកនាំសាសនាចក្រនៅក្នុងដែនកំណត់មួយ ។

> « ព្រះយេស៊ូវគ្រីស្ទបានកាន់កូនសោបព្វជិតភាពទាំងអស់សម្រាប់សាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានប្រគល់ឲ្យពួកសាវកេរបស់ទ្រង់ម្នាក់ៗនូវរាល់កូនសោ ដែលមានសម្រាប់នគរព្រះនៅលើផែនដី ។ សាវកច្បងដែលនៅរស់ ជាប្រធានសាសនាចក្រ គឺជាបុគ្គលតែម្នាក់គត់នៅលើផែនដីដែលត្រូវបានផ្ដល់សិទ្ធិអំណាចឲ្យដើម្បីអនុវត្តរាល់កូនសោបព្វជិតភាព (*ក្បួនខ្នាតកាត ២ ៖ ការគ្រប់គ្រងសាសនាចក្រ* [ ឆ្នាំ ២០១០ ], ២.១.១ ) ។

- តើកូនសោនៃបព្វជិតភាពអាចជួយឲ្យគណៈប្រធានទីមួយធ្វើអ្វីខ្លះ ? ( ដឹកនាំកិច្ចការព្រះអម្ចាស់នៅលើផែនដី ) ។

សូមបង្ហាញរូបភាពមួយរបស់គណៈប្រធានទីមួយបច្ចុប្បន្ន ឬរូបភាពផ្សេងៗគ្នានៃសមាជិកនៃគណៈប្រធាន ) ។ សូមសួរដល់សិស្ស បើពួកគេអាចរៀបរាប់ឈ្មោះរបស់គណៈប្រធានទីមួយ ។

សូមសរសេរក្បាលរឿងដូចខាងក្រោមនៅលើក្ដារខៀន ៖*ទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធានទីមួយ* ។



- តាមការយល់ដឹងរបស់អ្នក តើកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយមានអ្វីខ្លះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការណែនាំដែលព្រះអម្ចាស់បានប្រទានដល់ហ្វ្រេឌើរិក ជី វិលលាម្ស អំពីការហៅរបស់លោកក្នុងនាមជាទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធានទីមួយ ។

- ស្របតាម ខ ៣ តើហ្វ្រេឌើរិក ជី វិលលាម្ស ត្រូវធ្វើអ្វីខ្លះក្នុងនាមជាទីប្រឹក្សាម្នាក់នៅក្នុង គណៈប្រធានទីមួយ ? ( សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ក្រោមក្បាលរឿង។ អ្នកអាចនឹងចង់ពន្យល់ថា ទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ គាំទ្រ និងពង្រឹងដល់ប្រធាន ) ។

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បីឲ្យទីប្រឹក្សាម្នាក់ « ស្មោះត្រង់នៅក្នុងការប្រឹក្សា » ទៅដល់ប្រធាន ?

ដើម្បីជួយសិស្សឲ្យយល់បានកាន់តែល្អប្រសើរពីអត្ថន័យនៅស្មោះត្រង់នៅក្នុងការប្រឹក្សា សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្ដីថ្លែងការដូចខាងក្រោម ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវរបៀបដែលទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធាន គួរតែប្រឹក្សាជាមួយប្រធាន ។



« [ ទីប្រឹក្សាម្នាក់ ] គឺជា *ជំនួយការនៃប្រធានរបស់គាត់* ។. . .

« ក្នុងនាមជាជំនួយការម្នាក់ នោះទីប្រឹក្សាមិនមែនជាប្រធានឡើយ ។ គាត់មិនអាចសន្មត់អំពីការទទួលខុសត្រូវ ហើយនាំមុខប្រធានរបស់ខ្លួននោះទេ ។

« នៅក្នុងការប្រជុំគណៈប្រធាន ទីប្រឹក្សាម្នាក់ៗមានសេរីភាពបញ្ចេញមតិរបស់ខ្លួន ទៅលើបញ្ហាដែលមានចំពោះមុខគណៈប្រធាន ។ ទោះជាយ៉ាងណាក៏ដោយ វាគឺជាបុព្វសិទ្ធិរបស់ប្រធានដើម្បីធ្វើការសម្រេចចិត្ត ហើយវាគឺជាករណីយកិច្ចរបស់ទីប្រឹក្សា ដែលត្រូវគាំទ្រលោកលើការសម្រេចចិត្តនោះ ។ ការសម្រេចចិត្តរបស់លោក បន្ទាប់មកក្លាយជាការសម្រេចចិត្តរបស់ពួកគេ មិនថាគំនិតពីមុនរបស់ពួកគេយ៉ាងណាទេ » (In . . . Counsellors There Is Safety » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ទំព័រ ៥៩ ) ។

- ស្របតាមប្រធាន ហ៊ិងគ្លី តើទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធានមួយ គួរប្រឹក្សាជាមួយប្រធានយ៉ាងដូចម្ដេច ?

- តើការយល់ដឹងអំពីរបៀបដើម្បីស្មោះត្រង់នៅក្នុងការប្រឹក្សាជួយនរណាម្នាក់ ដែលកំពុងបម្រើជាទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធានក្នុងសាសនាចក្រយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាដែលពួកគេបានបម្រើ ( ឬបានឃើញអ្នកដទៃបម្រើ ) នៅក្នុងគណៈប្រធាននៅក្នុងសាសនាចក្រ ។ ( អ្នកអាចនឹងចង់ចង្អុលបង្ហាញថា គណៈប៊ីស្សពធ្វើជាគណៈប្រធានមួយក្នុងវួដ ) ។ សូមឲ្យពួកគេពិចារណាអំពីអ្វីដែលពួកគេ ឬអ្នកដទៃបានធ្វើដើម្បីផ្ដល់ការគាំទ្រដោយមានប្រសិទ្ធភាពនៅក្នុងគណៈប្រធានក្នុងក្រុមបព្វជិតភាពរបស់ពួកគេ ឬថ្នាក់យុវនារី ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយគំនិតរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៤ ដោយស្ងាត់ស្ងៀម ដើម្បីរកមើលនូវអ្វីដែលព្រះអម្ចាស់បានសន្យានឹង ហ្វ្រេឌើរិក ជី វិលលាម្ស បើលោកនឹងស្មោះត្រង់នៅក្នុងការហៅរបស់លោកនោះ ។ អ្នកអាចនឹងចង់ពន្យល់ថា ឃ្លា « តម្កើងសិរីល្អដល់ព្រះអម្ចាស់របស់អ្នក . . . » នៅក្នុងបរិបទនេះ អនុវត្តថា ដោយការស្មោះត្រង់នៅក្នុងការហៅរបស់យើង នោះយើងអាចជួយដឹកនាំមនុស្សឲ្យគោរព និងថ្វាយបង្គំដល់ព្រះអម្ចាស់ ។

- ស្របតាម ខ ៤ តើយើងអាចធ្វើអ្វីខ្លះ បើយើងស្មោះត្រង់នៅក្នុងការហៅរបស់យើង ? (ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងក្ដី ក៏ចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម ៖**បើយើងស្មោះត្រង់នៅក្នុងការហៅរបស់យើង នោះយើងអាចធ្វើការល្អអស្ចារ្យចំពោះអ្នកដទៃ ហើយតម្កើងសិរីល្អថ្វាយព្រះ ។** សូមប្រើពាក្យរបស់សិស្ស សរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើការបម្រើដោយស្មោះត្រង់នៅក្នុងការហៅបម្រើក្នុងសាសនាចក្ររបស់យើង ជួយយើងឲ្យធ្វើការល្អអស្ចារ្យចំពោះមនុស្សដទៃយ៉ាងដូចម្ដេច ?

- តើការបម្រើដោយស្មោះត្រង់នៅក្នុងការហៅបម្រើក្នុងសាសនាចក្ររបស់យើង ជួយតម្កើងសិរីល្អថ្វាយព្រះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ដែលពួកគេបានឃើញបុគ្គលម្នាក់ធ្វើរឿងល្អអស្ចារ្យចំពោះអ្នកដទៃ ដោយការបម្រើដោយស្មោះត្រង់នៅក្នុងការហៅបម្រើរបស់ពួកគេនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយការសង្កេតឃើញរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការប្រឹក្សាបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស ។

- ផ្ដោតទៅលើអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ហ្វ្រេឌើរិក ជី វិលលាម្ស នៅក្នុង ខ ៥ តើយើងអាចរៀនអ្វីខ្លះ អំពីការស្មោះត្រង់នៅក្នុងការហៅបម្រើក្នុងសាសនាចក្ររបស់យើង ឬការធ្វើជាសមាជិកនៃសាសនាចក្រដ៏ស្មោះត្រង់ ?

- តើអ្នកគិតថាការ «ជួយអ្នកទន់ខ្សោយ លើកដៃដែលធោយ ហើយចម្រើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង» មានន័យដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ម៉ារិន ជេ អាស្តុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកគំនិតដែលជួយបំភ្លឺពីអត្ថន័យនៃឃ្លាទាំងនេះ ។

### *សូមជួយសិស្សរៀនស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ*

ពេលខ្លះអ្នកនឹងចង្អុលបង្ហាញពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅពេលសិស្សក្នុងថ្នាក់សិក្សាព្រះគម្ពីរជាមួយគ្នា ។ នៅពេលផ្សេងទៀត អ្នកគួរតែដឹកនាំ លើកទឹកចិត្ត និងអនុញ្ញាតឲ្យសិស្សស្វែងរកសេចក្ដីពិតទាំងនេះដោយខ្លួនឯង ។ សូមជួយសិស្សអភិវឌ្ឍលទ្ធភាពដើម្បីប្រាប់ពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដោយខ្លួនគេ ហើយបង្ហាញវាដោយពាក្យសម្ដីពួកគេផ្ទាល់ ។



« នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៥ខនេះអាចត្រូវបានបកប្រែជាការជម្រុញរបស់ព្រះអម្ចាស់ដល់ហ្វ្រេឌើរិក ជី វិលលាម្ស ផ្ដល់កម្លាំងដល់មនុស្សទន់ខ្សោយ (ជួយអ្នកទន់ខ្សោយ) ផ្ដល់ការលើកទឹកចិត្តដល់អ្នកទាំងឡាយដែលនឿយហត់ ឬបាក់ទឹកចិត្ត ( លើកដៃដែលរោយ) ហើយផ្ដល់ភាពក្លាហាន និងកម្លាំងដល់អ្នកទាំងឡាយដែលមានក្បាលជង្គង់ញ័រ និងដួងចិត្តភ័យខ្លាច » (Strengthen the Feeble Knees,» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៧០ ) ។

- តើវិធីមួយចំនួនដែលយើងអាច «ជួយអ្នកទន់ខ្សោយ លើកដៃដែលរោយ ហើយចំរើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង» មានអ្វីខ្លះ ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- តើអ្នកបានលើកទឹកចិត្ត ឬពង្រឹងដល់នរណាម្នាក់ នៅពេលណា ?

សូមសំណូមពរដល់សិស្សឲ្យរើសយកវត្ថុមួយចេញពីបញ្ជីចម្លើយនៅលើក្ដារខៀន ហើយស្វែងរកឱកាសដើម្បីជួយអ្នកទាំងឡាយដែលនៅជុំវិញពួកគេ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យទាំងឡាយដែលព្រះអម្ចាស់បានសន្យាដល់ហ្វ្រេឌើរិក ជី វិលលាម្ស បើលោកនឹងស្មោះត្រង់រហូតដល់ទីបញ្ចប់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការបន្តនៅស្មោះត្រង់នៅក្នុងការហៅរបស់យើង និងការជួយដល់អ្នកទាំងឡាយដែលនៅជុំវិញយើង ដើម្បីពួកគេអាចសក្ដិសមសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ ។

មេរៀនទី ៨៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២–៨៣

## បុព្វកថា

នៅក្នុង ខែ មេសា ឆ្នាំ ១៨៣២ ព្យាការីយ៉ូសែប ស្ម៊ីធ និងអ្នកដទៃទៀតបានធ្វើដំណើរទៅកាន់រដ្ឋអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មីសសួរីដោយគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីស្ថាបនាអង្គការមួយសម្រាប់ស្ថាបនាស៊ីយ៉ូនឡើង ហើយមើលថែដល់អ្នកក្រីក្រ ( សូមមើល គ. និង ស. ៧៨ រួមមាន សេចក្ដីណែនាំកណ្ឌ ) ។ នៅថ្ងៃទី ២៦ ខែ មេសា ព្យាការីបានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ អំឡុងក្រុមប្រឹក្សានៃពួកសង្ឃជាន់ខ្ពស់ និងពួកអែលឌើរនៃសាសនាចក្រនៅ អ៊ិនឌីប៉ែនដែនស៍ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានអភ័យទោសដល់បងប្អូនប្រុសចំពោះអំពើរំលងទាំងឡាយរបស់ពួកគេ ហើយបានព្រមានពួកគេឲ្យបែរចេញពីអំពើបាប ។ ព្រះអម្ចាស់ក៏បានណែនាំដល់បងប្អូនប្រុសទាំងនេះអំពីរបៀបដើម្បីគ្រប់គ្រងកិច្ចការខាងសាច់ឈាមនៃស៊ីយ៉ូនផងដែរ ។ បួនថ្ងៃក្រោយមក យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣ ដែលព្រះអម្ចាស់បានណែនាំដល់ពួកអែលឌើរនៃសាសនាចក្រអំពីរបៀបមើលថែដល់ពួកស្ត្រីមេម៉ាយ និងកុមារកំព្រា ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១–៧

*ព្រះអម្ចាស់ព្រមានដល់អ្នកទាំងឡាយដែលបានទទួលច្រើនមកពីទ្រង់*

មុនពេលថ្នាក់ចាប់ផ្ដើម សូមប្រមូលក្រដាសធំៗជាច្រើនសន្លឹកមក ព្រមទាំងហ្វឺតផងដែរ ។ ( នាពេលក្រោយ ក្នុងមេរៀននេះ សិស្សនឹងប្រើរបស់ទាំងនេះដើម្បីធ្វើបញ្ជី ដែលអាចបង្ហាញដល់សិស្សផ្សេងទៀតមើលឃើញ ) ។

សូមចាប់ផ្ដើមមេរៀនដោយសុំឲ្យសិស្សគិតអំពី គ្រាមួយដែលពួកគេបានជំទាស់នឹងមិត្ត ឬសមាជិកសាសនាចក្រ តែក្រោយមកអាចដោះស្រាយវិញបាន។

- តើអ្នកបានមានអារម្មណ៍យ៉ាងណាដែរ នៅពេលអ្នកបានដោះស្រាយជំទាស់របស់អ្នកនោះ ?

សូមប្រាប់ដល់សិស្សថា ស៊ីឌនី រិកដុន នៅរដ្ឋ អូហៃអូ និង ប៊ីស្សព អែតវើត ប៉ាទ្រិច នៅរដ្ឋ មិសសួរី បានមានអារម្មណ៍ពុំល្អនឹងគ្នាអស់រយៈពេលជាច្រើនខែ ។ នៅក្នុងខែ មេសា ឆ្នាំ ១៨៣២ ព្យាការីយ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀតបានធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ដោយគោរពប្រតិបត្តិចំពោះបទបញ្ញត្តិរបស់ព្រះអម្ចាស់ ដែលពួកគាត់បាន « អង្គុយប្រឹក្សាជាមួយពួកបរិសុទ្ធ ដែលនៅក្រុងស៊ីយ៉ូន » (គ. និង ស. ៧៨:៩) ។ ពេលពួកលោកមកដល់ នោះការប្រឹក្សាក្នុងក្រុមសង្ឃជាន់ខ្ពស់នៃសាសនាចក្រ បានធ្វើឡើង ។ នៅចន្លោះសម័យប្រជុំសន្និសីទពេលព្រឹក និងពេលរសៀល នោះស៊ីឌនី រិកដុន និង អែតវើត ប៉ាទ្រិច បានដោះស្រាយនូវទំនាស់របស់ពួកលោក ។ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ ត្រូវបានទទួលអំឡុងសម័យប្រជុំពេលរសៀល ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ ស៊ីឌនី រិកដុន និង អែតវើត ប៉ាទ្រិច អំពីការដោះស្រាយទំនាស់របស់ពួកលោក ។

- ស្របតាម ខ ១ តើទំនាក់ទំនងរវាងការអភ័យទោសដល់អ្នកដទៃ និងការទទួលបាននូវការអភ័យទោសរបស់ព្រះអម្ចាស់គឺជាអ្វី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:២ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ រកមើលការព្រមានដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។

- តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះដែលនឹងកើតមានដល់អ្នកទាំងឡាយដែលពុំ « បែរចេញពីអំពើបាប » ?

ដើម្បីជួយសិស្សយល់នូវអំពើបាបមួយចំនួន ដែលព្រះអម្ចាស់បានសំដៅទៅលើ សូមពន្យល់ថា នៅពេលសមាជិកនៃសាសនាចក្របានផ្លាស់ទៅកាន់រដ្ឋ មិសសួរី នោះមានពួកគេជាច្រើនរូបពុំបានគោរពតាមការទូន្មានរបស់អ្នកដឹកនាំនៃសាសនាចក្រទេ ហើយមួយចំនួនបានបដិសេធឈប់រស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ ជាលទ្ធផល សមាជិកសាសនាចក្រមួយចំនួនទាំងនេះ បានដឹងខ្លួនខុសចំពោះការច្រណែន ការលោភលន់ និងការពុំយកចិត្តទុកដាក់ចំពោះកាតព្វកិច្ច ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៣–៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម ហើយរកមើលនូវមូលហេតុមួយ ថាហេតុអ្វីក៏ការជំនុំជម្រះដែលបានប្រាប់នៅក្នុង ខ ២ នឹងកើតមានមកលើអ្នកទាំងឡាយដែលបន្តស្ថិតនៅក្នុងអំពើបាប ។

- តើពួកបរិសុទ្ធទាំងនេះ មានគុណសម្បត្តិសក្ដិសមជារាស្ត្រដែលបានទទួល « ពន្លឺកាន់តែធំ » តាមវិធីណា ?
- តើព្រះអម្ចាស់បានបង្រៀនអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះអំពីទំនួលខុសត្រូវរបស់យើងចំពោះអ្វីដែលទ្រង់បានប្រទានដល់យើង ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់តម្រូវការយ៉ាងច្រើនពីអ្នកទាំងឡាយ ដែលទ្រង់បានប្រទានឲ្យច្រើន** ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។
- ហេតុអ្វីក៏អ្នកគិតថា អ្នកទាំងឡាយដែលបានទទួលច្រើនមកពីព្រះអម្ចាស់ នោះតម្រូវច្រើនពីពួកគេផងដែរយ៉ាងដូច្នេះ ?

សូមបែងចែកសិស្សឲ្យធ្វើការជាក្រុមតូចៗ ។ សូមឲ្យទៅក្រុមនិមួយៗនូវក្រដាសមួយផ្ទាំងធំ និងហ្វឺតមួយដើម ។ សូមអញ្ជើញពួកគេឲ្យសរសេរពរជ័យឲ្យបានច្រើនបំផុតដែលពួកគេបានទទួលមកពីព្រះអម្ចាស់ តាមដែលអាចធ្វើទៅបានក្នុងរយៈពេលពីរនាទី ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់បញ្ចូលទាំងពរជ័យទាំងឡាយដែលបានកើតមានចំពោះពួកគេក្នុងនាមជាសមាជិកនៃសាសនាចក្រផងដែរ ។ នៅពេលពួកគេបានសរសេរចប់ សូមដាក់តាំងបញ្ជីនោះនៅខាងមុខថ្នាក់រៀន ហើយសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីអ្នកគិតថា យើងសក្ដិសមជារាស្ត្រ « ដែលត្រូវបានប្រទានឲ្យច្រើន » ដូច្នេះ ?
- ដោយសារតែព្រះអម្ចាស់បានប្រទានដល់យើងយ៉ាងច្រើន តើតម្រូវការមួយចំនួនអ្វីខ្លះដែលទ្រង់តម្រូវពីយើង ?

ដើម្បីជួយសិស្សអនុវត្តគោលការណ៍ចេញមកពី ខ ៣ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវពរជ័យមួយនៃពរជ័យទាំងឡាយដែលពួកគេបានទទួលមកពីព្រះអម្ចាស់ ។ បន្ទាប់មក សូមឲ្យពួកគេសរសេរនូវអ្វីដែលពួកគេបានដឹងថាព្រះអម្ចាស់រំពឹងឲ្យពួកគេធ្វើ ដោយសារតែពួកគេបានទទួលពរជ័យនោះ ។ ទីបំផុត សូមអញ្ជើញពួកគេឲ្យសរសេរគោលដៅមួយនៃអ្វីដែលពួកគេអាចចាប់ផ្ដើមធ្វើដើម្បីបំពេញតាមការរំពឹងទុកនោះ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៥–៦ ដោយពន្យល់ថា ព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធថា ការគ្រប់គ្រងនិងអំណាចនៃសាតាំងលើផែនដីកំពុងតែកើនឡើង ។ សូមអានប្រយោគទីបីនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៧ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់រកមើលនូវការព្រមានបន្ថែមដែលព្រះអម្ចាស់បានប្រទានឲ្យអំពីអំពើបាប ។

- ស្របតាម ខ ៧ ហេតុអ្វីបានជាវាសំខាន់ចំពោះអ្នកទាំងឡាយណាដែលប្រែចិត្តឲ្យលះបង់អំពើបាប ? ( នៅពេលយើងបានងាកចេញពីសេចក្ដីសុចរិតទៅរកអំពើបាបដោយការដឹងច្បាស់ នោះ « អំពើបាបពីមុនរបស់យើងនឹងត្រឡប់មកវិញ » ) ។
- ហេតុអ្វីក៏អ្នកគិតថា អំពើបាបពីមុនរបស់យើងត្រឡប់មកវិញ បើយើងធ្វើបាបដោយចេតនា បន្ទាប់ពីបានស្វែងរកការអភ័យទោសពីព្រះអម្ចាស់ហើយនោះ ? ( សូមជួយសិស្សឲ្យយល់ថា ដើម្បីប្រែចិត្តពេញលេញ ហើយត្រូវបានអភ័យទោស នោះយើងត្រូវតែលះបង់ចោលអំពើបាបរបស់យើង ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៨–២៤

*ព្រះអម្ចាស់បញ្ជាបុរសប្រាំបួននាក់ឲ្យបង្កើតសមាគមមួយដើម្បីគ្រប់គ្រងកិច្ចការខាងសាច់ឈាមរបស់សាសនាចក្រ*

សូមរៀបចំសិស្សជាគូ ។ សូមឲ្យគូនិមួយៗគិត អំពីស្ថានភាពពីដែលយុវជន ឬយុវនារីម្នាក់ អាចនឹងត្រូវការនូវការអះអាងថាព្រះរក្សានូវការសន្យារបស់ទ្រង់ ។ ( ឧទាហរណ៍ យុវនារីម្នាក់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងជីដូននាង ដែលកំពុងតែរងទុក្ខដោយសារជំងឺដែលនឹងត្រូវបញ្ចប់ជីវិតគាត់ ) ។ យុវនារីរូបនេះ អាចនឹងចាំបាច់ត្រូវបានទទួលការអះអាងប្រាប់សារជាថ្មីអំពីការសន្យាទាំងឡាយនៃក្រុមគ្រួសារដ៏អស់កល្បជានិច្ច និងការរស់ឡើងវិញ ) ។ សូមឲ្យសិស្សចែកចាយនូវស្ថានភាពមួយចំនួនរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមពន្យល់ថា អំឡុងពេលនៃក្រុមប្រឹក្សាសង្ឃជាន់ខ្ពស់នៅ រដ្ឋ មិសសួរី នោះព្រះអម្ចាស់បានសន្យាអះអាងជាថ្មីដល់អ្នកទាំងឡាយដែលគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ សូមលើកទឹកចិត្តដល់សិស្សឲ្យរកមើលសេចក្ដីពិតដែលអាចនឹងផ្ដល់នូវការអះអាងដល់អ្នកទាំងឡាយដែលស្ថិតនៅក្នុងស្ថានភាពនានា ដែលពួកគេបានពិភាក្សា នៅពេលពួកគេបន្តសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៨–៩ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា ទ្រង់នឹងប្រទានដល់ពួកបរិសុទ្ធអំឡុងក្រុមប្រឹក្សានេះ ។

- ស្របតាម ខ ៨ តើព្រះអម្ចាស់មានបន្ទូលថាទ្រង់នឹងប្រទានអ្វីខ្លះ ដល់អ្នកទាំងឡាយដែលមកជួបជុំនៅក្នុងក្រុមប្រឹក្សា ?
- ចេញពីពីអ្វីដែលអ្នកបានអាននៅក្នុង ខ ៨–៩ តើទ្រង់មានមូលហេតុអ្វីខ្លះ ចំពោះការចេញនូវបទបញ្ញត្តិថ្មីនេះ ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- តើមូលហេតុទាំងនេះ អនុវត្តចំពោះបទបញ្ញត្តិដែលព្រះអម្ចាស់ប្រទានដល់យើងយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវគោលការណ៍មួយដែលអាចផ្ដល់ទំនុកចិត្តដល់យើង នៅពេលយើងព្យាយាមដើម្បីគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ។

- តើគោលការណ៍អ្វីខ្លះ ដែលអ្នករកឃើញថា អាចផ្ដល់ទំនុកចិត្តដល់អ្នក នៅពេលអ្នកព្យាយាមគោរពតាមព្រះអម្ចាស់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចម្លើយរបស់ពួកគេ គួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖**បើសិនជាយើងនឹងគោរពព្រះអម្ចាស់ នោះទ្រង់នឹងរក្សាការសន្យារបស់ទ្រង់ដើម្បីប្រទានពរដល់យើងជានិច្ច** )។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីបទពិសោធន៍ទាំងឡាយ ដែលពួកគេមាន ដែលបានបង្ហាញដល់ពួកគេថា គោលការណ៍នេះពិត ។ សូមទុកពេលឲ្យពួកគេសរសេរអំពីបទពិសោធន៍មួយនៃបទពិសោធន៍ទាំងឡាយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។ អ្នកក៏អាចនឹងចង់ចែកចាយបទពិសោធន៍មួយចេញពីជីវិតផ្ទាល់របស់អ្នកដែលបានបញ្ជាក់អំពីគោលការណ៍នេះ ។

សូមរំឭកសិស្សថា នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨ នោះពួកគេបានរៀនអំពីរបៀបដែលព្រះអម្ចាស់បានបញ្ជាដល់ពួកអ្នកដឹកនាំសាសនាចក្ររបស់ទ្រង់នៅទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ ឲ្យខិតខំបង្កើតសមាគមមួយដើម្បីគ្រប់គ្រងឃ្លាំងរបស់សាសនាចក្រ និងកិច្ចការបោះពុម្ព ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១១, ១៥–១៧ ដោយការប្រាប់ដល់សិស្សថា នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានដឹកនាំការរៀបចំសមាគមនេះពិតៗ–ដែលបានស្គាល់ថាសហសមាគម– ហើយបានតែងតាំងសមាជិកនៃសមាគមនោះ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១២ ដោយស្ងាត់ស្ងៀម ហើយរកមើលគោលបំណងនៃសហសមាគម ។ នៅពេលពួកគេអាន វាអាចនឹងជាប្រយោជន៍ដើម្បីរំឭកពួកគេថា កាតព្វកិច្ចមួយនៃកាតព្វកិច្ចទាំងឡាយរបស់ប៊ីស្សព គឺដើម្បីជួយដល់សេចក្ដីត្រូវការខាងសាច់ឈាមរបស់សមាជិកសាសនាចក្រ ។

- ស្របតាម ខ ១២ តើគោលបំណងនៃសហសមាគមគឺជាអ្វី ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១៤, ១៨–១៩ ដោយស្ងាត់ស្ងៀម រកមើលពាក្យ ឬឃ្លានានាដែលពន្យល់បន្ថែមអំពីមូលហេតុដែលព្រះអម្ចាស់បានបញ្ជាឲ្យបង្កើតសហសមាគមនេះ ។

- ហេតុអ្វីបានជាវាសំខាន់ចំពោះពួកបរិសុទ្ធដើម្បីអភិវឌ្ឍនូវទស្សនៈវិស័យ ដែលបានសំដៅទៅលើ នៅក្នុង ខ ១៩ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:២០–២៤ ដោយការពន្យល់ថា ព្រះអម្ចាស់បានបញ្ចប់នូវវិវរណៈនេះដោយការព្រមានដល់អ្នកដឹកនាំសាសនាចក្រឲ្យស្មោះត្រង់ចំពោះសេចក្ដីសញ្ញាដែលពួកគេនឹងធ្វើ ក្នុងនាមជាសមាជិកនៃសហសមាគម ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣

*ព្រះអម្ចាស់បើកសម្ដែងអំពីរបៀបដើម្បីមើលថែស្ដ្រីមេម៉ាយ និងកុមារកំព្រា*

សូមប្រាប់សិស្សថា រយៈពេលបួនថ្ងៃបន្ទាប់ពីការទទួលបានវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ ព្យាការីយ៉ូសែប ស៊្មីធ បានទទួលវិវរណៈមួយអំពីរបៀបដើម្បីថ្លែងអំពីបញ្ហាលំបាកក្នុងការយកចិត្តទុកដាក់ចំពោះសេចក្ដីត្រូវការខាងសាច់ឈាមនៃពួកបរិសុទ្ធ ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣:១ ដោយស្ងាត់ស្ងៀម ហើយរកមើលថាតើតម្រូវការរបស់នរណា ដែលបានថ្លែងដោយវិវរណៈនេះ ។

- តើតម្រូវការរបស់នរណា ដែលត្រូវបានថ្លែងនៅក្នុងវិវរណៈនេះ ?

សូមរំឭកសិស្សថា មានពួកបរិសុទ្ធជាច្រើន កំពុងរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ហើយបានទទួល « កេរមរតក » ឬដីធ្លីពីសាសនាចក្រ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបើកសម្ដែងនូវអ្វីដែលគប្បីកើតមានឡើងចំពោះកេរមរតករបស់គ្រួសារមួយ បើសិនជាស្វាមី ឬឪពុកបានចែកឋានហើយនោះ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣:២–៣ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវការណែនាំរបស់ព្រះអម្ចាស់អំពីការមើលថែដល់ស្ដ្រីដែលបាត់បង់ស្វាមីរបស់ពួកគេ ។

- បើបុរសម្នាក់ស្លាប់ ហើយភរិយារបស់គាត់បន្តនៅស្មោះត្រង់ តើពរជ័យអ្វីខ្លះ ដែលភរិយាទទួលបាន ?

សូមពន្យល់ថា នៅគ្រាដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ស្ត្រីភាគច្រើនបានពឹងផ្អែកលើស្វាមីរបស់ពួកគេដើម្បីផ្គត់ផ្គង់ខាងសាច់ឈាមរបស់ពួកគេ ។ ដើម្បី « ទទួលការរាប់អាននៅក្នុងសាសនាចក្រ » មានន័យថា ដោយសារតែអ្នកផ្គត់ផ្គង់គ្រួសារទទួលមរណភាព នោះសាសនាចក្រនឹងជួយដល់គាត់នៅពេលគាត់ក្លាយជាអ្នកផ្គត់ផ្គង់តែម្នាក់គត់នៅក្នុងគ្រួសារ ។ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣:៤–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលសាសនាចក្រអាចជួយដល់កុមារកំព្រា និងស្ត្រីមេម៉ាយ ។

- តើខគម្ពីរទាំងនេះ បង្រៀនអ្នកអំពីរបៀបដែលព្រះអម្ចាស់មានព្រះទ័យចំពោះស្ត្រីមេម៉ាយ កុមារកំព្រា និងអ្នកទាំងអស់ណាដែលខ្វះខាតយ៉ាងណាខ្លះ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យដឹងកាន់តែច្រើនអំពីសេចក្ដីត្រូវការរបស់អ្នកទាំងឡាយណាដែលនៅជុំវិញខ្លួនពួកគេ ហើយរកមើលនូវរបៀបដើម្បីអនុវត្តនូវការទូន្មានរបស់ព្រះអម្ចាស់ចំពោះការស្វែងរកចំណូលចិត្តអ្នកជិតខាងរបស់ពួកគេ (សូមមើល គ. និង ស. ៨២:១៩) ។ ដូចបានណែនាំដោយព្រះវិញ្ញាណ សូមបញ្ចប់មេរៀនដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិត ដែលបានបង្រៀននៅក្នុងវិវរណៈនេះ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧–៨៣ ( មេរៀនទី ១៧ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧–៨៣ ( មេរៀនទី ១៧ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ៖ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧)

នៅពេលសិស្សបញ្ចប់ការសិក្សារបស់ពួកគេអំពីការនិមិត្តនៃនគរនៃសិរីរុងរឿង នោះពួកគេបានរៀនថា អ្នកទាំងឡាយដែលទទួលគ្រងមរតកនៃនគរទេឡេស្ទាល ត្រូវតែរងទុក្ខក្នុងស្ថាននរកពីមុនពួកគេត្រូវបានប្រោសលោះដោយព្រះអង្គសង្គ្រោះ ។ ពួកគេក៏បានរៀនផងដែរថា នគរនៃសិរីល្អដែលយើងគ្រងជាមរតកនឹងត្រូវបានកំណត់ តាមរយៈទង្វើរបស់យើងនៅក្នុងជីវិតនេះ និង បំណងប្រាថ្នានៃដួងចិត្តរបស់យើង ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨–៨០)

អំឡុងពេលសិក្សាព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីបង្កើតក្រុមហ៊ុនរួមមួយ នោះសិស្សបានរៀនថាការធ្វើកិច្ចការនានាដែលព្រះអម្ចាស់បានបញ្ជា រៀបចំយើងមានកន្លែងមួយនៅក្នុងនគរសេឡេស្ទាល ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងទទួលបានអ្វីទាំងអស់ដោយអំណរគុណ នោះព្រះអម្ចាស់នឹងគុណទ្វេពជ័យរបស់យើង ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១)

នៅពេលសិស្សបានរៀនអំពីការណែនាំរបស់ព្រះអម្ចាស់ចំពោះទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ នោះពួកគេបានឃើញថាគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ កាន់កូនសោនៃនគររបស់ព្រះនៅលើផែនដី ។ ក្រៅពីនោះទៀត ពួកគេបានរៀនថាទីប្រឹក្សានៅក្នុងគណៈប្រធានគឺដើម្បីគាំទ្រ និង ពង្រឹងដល់ប្រធាន ។ សិស្សក៏បានរៀនផងដែរថា ប្រសិនបើយើងស្មោះត្រង់នៅក្នុងការហៅបម្រើរបស់យើង នោះយើងអាចធ្វើកិច្ចការបានយ៉ាងអស្ចារ្យដល់មនុស្សដទៃទៀត ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២–៨៣)

ចេញពីការណែនាំរបស់ព្រះអម្ចាស់ទៅកាន់ថ្នាក់ដឹកនាំសាសនាចក្រពីជំនាន់មុនៗ នោះសិស្សអាចរៀនផងដែរថា « ដល់អ្នកណាដែលត្រូវបានប្រទានឲ្យច្រើន នោះក៏មានតម្រូវការជាច្រើនវិញ » (គ. និង ស. ៨២:៣) ។ សិស្សបានសិក្សាពីការព្រមានរបស់ព្រះអម្ចាស់ថា ប្រសិនបើយើងប្រព្រឹត្តអំពើបាបម្ដងទៀតបន្ទាប់ពីយើងប្រែចិត្តហើយ នោះអំពើបាបពីមុនៗរបស់យើងនឹងត្រឡប់មកវិញផងដែរ ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងនឹងគោរពតាមព្រះអម្ចាស់ នោះទ្រង់នឹងរក្សាការសន្យារបស់ទ្រង់ជានិច្ច ដើម្បីប្រទានពរដល់យើង ។

## សេចក្ដីផ្ដើម

មេរៀននេះអាចជួយសិស្សឲ្យរកឃើញគោលការណ៍នានា ចេញពីគំរូដែលបានធ្វើឡើងដោយព្យាការីយ៉ូសែប ស្ម៊ីធ នៅពេលលោកបានសួរសំណួរដល់ព្រះអម្ចាស់អំពីគម្ពីរវិវរណៈ ។

## យោបល់សម្រាប់ការបង្រៀន

*កំណត់ចំណាំ ៖* សិស្សបានរៀនអំពីវគ្គចំណេះចំណានខគម្ពីរពីរនៅសប្តាហ៍នេះ ។ ពួកគេបានប្រើ គោលលទ្ធិ និង សេចក្តីសញ្ញា ៧៨:១៩ ដើម្បីសរសេរការនិយាយរយៈពេលពីរនាទី ។ អ្នកអាចអញ្ជើញឲ្យសិស្សពីរបីនាក់ធ្វើបទបង្ហាញការនិយាយរបស់ពួកគេក្នុងថ្នាក់ ។ ពួកគេក៏ទន្ទេញ គោលលទ្ធិ និង សេចក្តីសញ្ញា ៨២:១០ ផងដែរ ។ សូមគិតពីការអញ្ជើញសិស្សក្នុងថ្នាក់ឲ្យសូត្រខគម្ពីរនេះជាមួយគ្នា ។

### គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧

*ព្រះអម្ចាស់ឆ្លើយតបចំពោះសំណួររបស់យ៉ូសែប ស្ម៊ីធ អំពីគម្ពីរវិវរណៈ*

សូមឲ្យសិស្សពិចារណាដោយស្ងៀមស្ងាត់អំពីអ្វី ដែលពួកគេបានរៀននៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមឲ្យពួកគេពីរបីនាក់ចែកចាយគំនិតដែលពួកគេបានទទួល ។ បន្ទាប់មក សូមឲ្យសិស្សមួយចំនួនចែកចាយចម្ងល់ដែលពួកគេមានអំឡុងពេលសិក្សាផ្ទាល់ខ្លួនរបស់ពួកគេនោះ ។ ទាំងនេះអាចរួមមានចម្ងល់អំពីអត្ថន័យនៃពាក្យ ឬឃ្លាណាមួយ ជីវប្រវត្តិខាងប្រវត្តិសាស្ត្រ អំពីអ្វីដែលពួកគេអាន ឬសារៈសំខាន់នៃខគម្ពីរជាក់លាក់មួយ ។ ( គោលបំណងនៃការអនុវត្តនេះ គឺពុំមែនឆ្លើយដល់សំណួររបស់សិស្សអំពីបទគម្ពីរនោះទេ ប៉ុន្តែដើម្បីគូសបញ្ជាក់អំពីសារៈសំខាន់នៃការសួរសំណួរនៅពេលយើងសិក្សា ) ។ បន្ទាប់ពីសិស្សពីរបីនាក់បានចែកចាយរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើមានអ្វីខ្លះដែលជួយអ្នកឲ្យយល់ព្រះគម្ពីរបានកាន់តែប្រសើរឡើង ហើយរកឃើញចម្លើយចំពោះសំណួរទាំងឡាយដែលអ្នកមាន ?

ដើម្បីជួយសិស្សយល់បរិបទនៃ គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧, សូមអញ្ជើញពួកគេឲ្យអានសេចក្តីណែនាំកណ្ឌ ហើយរកមើលអ្វីដែលព្យាការីយ៉ូសែប ស្ម៊ីធបានកំពុងធ្វើនៅពេលលោកបានទទួលវិវរណៈនេះ ។ បន្ទាប់ពីសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ នោះអ្នកអាចចង្អុលបង្ហាញថាឃ្លា « ទាក់ទងទៅនឹងការបកប្រែព្រះគម្ពីរ » គឺសំដៅទៅលើបញ្ជារបស់ព្រះអម្ចាស់ថា យ៉ូសែប ស្ម៊ីធត្រូវធ្វើកំណែថ្មីដែលបានបំផុសគំនិតចំពោះព្រះគម្ពីរប៊ីបរបស់ស្តេចជេមស៍ ។ កំណែថ្មីទាំងនេះឥឡូវត្រូវបានស្គាល់ថាជាការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ។ សូមពន្យល់ថាអំឡុងពេលដែលយ៉ូសែប ស្ម៊ីធកំពុងធ្វើការបកប្រែគម្ពីរវិវរណៈ នោះលោកបានទទួលសួរព្រះអម្ចាស់អំពីអត្ថន័យនៃខគម្ពីរមួយចំនួន ។ សំណួរដែលលោកបានសួរ និង ចម្លើយដែលព្រះអម្ចាស់បានបើកសម្តែងគឺត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលការយល់ដឹងនៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧ ដែលអាចជួយពួកគេឲ្យយល់ដឹងអំពីព្រះគម្ពីរកាន់តែជ្រៅជ្រះ ។

សូមអញ្ជើញសិស្សឲ្យសម្គាល់ពីរបៀបដែលទម្រង់នៃ គោលលទ្ធិ និងសេចក្តីសញ្ញា ៧៧ មានភាពខុសគ្នាពីកណ្ឌផ្សេងទៀតនៅក្នុងគោលលទ្ធិ និង សេចក្តីសញ្ញា ។ ពួកគេគួរតែកត់ចំណាំអក្សរ *ស* និង *ច* នៅជិតនឹងខគម្ពីរ ឬ ឃ្លា និមួយៗពេញទាំងកណ្ឌនោះ ។ សូមពន្យល់ថាអក្សរ *ស* និមួយៗ តំណាងឲ្យសំណួរមួយមកពីយ៉ូសែប ស្ម៊ីធ ហើយអក្សរ *ច* និមួយៗតំណាងឲ្យចម្លើយរបស់ព្រះអម្ចាស់ ។

សូមសួរសិស្សប្រសិនបើមាននរណាបានអានគម្ពីរវិវរណៈខ្លះៗ ឬ អានទាំងអស់រួចហើយ ។

- តើការអានគម្ពីរវិវរណៈអាចមានឧបសគ្គអ្វីខ្លះ ? ( ប្រសិនបើសិស្សពុំប្រាប់ទេ អ្នកអាចពន្យល់ថាគម្ពីរវិវរណៈអាចនឹងពិបាកយល់ ដោយសារតែនិមិត្តរូបដែលមាននៅក្នុងគម្ពីរនោះ ) ។

ដើម្បីផ្តល់នូវឧទាហរណ៍អំពីរូបភាពនៃនិមិត្តរូបនៅក្នុងគម្ពីរវិវរណៈ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេនគ្នាអានឲ្យឮៗចេញមកពី វិវរណៈ ៤:២–៨។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនិមិត្តរូបនៅក្នុងខគម្ពីរទាំងនេះ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យប្រាប់ពីនិមិត្តរូបទាំងនេះ ហើយសុំឲ្យសិស្សម្នាក់សរសេរវានៅលើក្តារខៀន ។ ( ចម្លើយអាចរួមមាន ឥន្ទធនូព័ទ្ធជុំវិញបល្ល័ង្ក បល្ល័ង្កម្ភៃបួន មកុដមាស ចង្កៀងប្រាំពីរឆេះ សមុទ្រកែវ និង តួមានជីវិតបួន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសំណួររបស់យ៉ូសែប ស្ម៊ីធនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:១ ឲ្យឮៗ ។ សូមឲ្យសិស្សម្នាក់គូសរង្វង់លើនិមិត្តសញ្ញានៅលើក្តារខៀនដែលយ៉ូសែប ស្ម៊ីធបានទូលសួរព្រះអម្ចាស់ដើម្បីជួយលោកឲ្យយល់ ( សមុទ្រកែវ ) ។ បន្ទាប់មកឲ្យសិស្សម្នាក់ទៀតអានការពន្យល់របស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:១។

- តើចម្លើយនេះជួយយើងយល់កាន់តែប្រសើរឡើងពី វិវរណៈ ៤:៦យ៉ាងដូចម្តេច ?

សូមចែកសិស្សជាគូៗ ។ សូមឲ្យដៃគូនិមួយៗអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:២–៥ ជាមួយគ្នា រកមើលសំណួរបន្ថែមដែល យ៉ូសែប ស្ម៊ីធ បានសួរអំពីនិមិត្តរូបនៅក្នុង វិវរណៈ ៤ និងចម្លើយដែលព្រះអម្ចាស់បានប្រទានឲ្យចំពោះសំណួរទាំងនោះ ។ បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីរបៀបដែលចម្លើយរបស់ព្រះអម្ចាស់ឆ្លើយចំពោះសំណួររបស់យ៉ូសែប ស្ម៊ីធ ជួយពួកគេឲ្យយល់អំពីរូបភាពនិមិត្តរូបមួយចំនួននៅក្នុង វិវរណៈ ៤:២–៨។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេនឹងប្រើអ្វីដែលពួកគេបានរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ដើម្បីសង្ខេបអ្វីដែលយ៉ូហានបានពិពណ៌នានៅក្នុង វិវរណៈ ៤:២–៨។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយការសង្ខេបរបស់ពួកគេ ។ បន្ទាប់មកសូមសួរសំណួរខាងក្រោមនេះ ៖

- តើយើងអាចរៀនអ្វីខ្លះពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ អំពីតួនាទីរបស់ព្យាការីក្នុងការជួយយើងឲ្យយល់អំពីអត្ថន័យនៃបទគម្ពីរ ? ( ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នាក្ដី ក៏ពួកគេគួរបង្ហាញគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអម្ចាស់បើកសម្ដែងការបកស្រាយត្រឹមត្រូវអំពីបទគម្ពីរតាមរយៈពួកព្យាការីរបស់ទ្រង់ ។** អ្នកអាចផ្ដល់យោបល់ឲ្យសិស្សសរសេរគោលលទ្ធិនេះនៅក្នុងគម្ពីររបស់ពួកគេជិតការចាប់ផ្ដើមនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧) ។

- ហេតុអ្វីអ្នកគិតថាវាសំខាន់ដើម្បីរៀនពីអ្វីដែលពួកព្យាការីបានបង្រៀនទាក់ទងនឹងអ្វីដែលយើងសិក្សានៅក្នុងបទគម្ពីរដូច្នេះ ?

- តើយើងអាចរកការបង្រៀនរបស់ពួកព្យាការីអំពីអត្ថន័យនៃអ្វីដែលយើងអាននៅក្នុងព្រះគម្ពីរនៅកន្លែងណា ?

នៅពេលសិស្សឆ្លើយសំណួរនេះ សូមចង្អុលបង្ហាញថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ បង្ហាញថាពាក្យសម្ដីរបស់ពួកព្យាការីដែលបានកត់ត្រានៅក្នុងព្រះគម្ពីរអាចជួយពន្យល់បទគម្ពីរនានាផ្សេងទៀត ។ ជាច្រើនលើកច្រើនគ្រា វគ្គបទគម្ពីរមួយនឹងពន្យល់ ឬ បកស្រាយនូវអ្វីដែលបានបើកសម្ដែងនៅក្នុងវគ្គបទគម្ពីរមួយទៀត ។ សូមពន្យល់ថាជាញឹកញាប់លេខយោងមាននូវក្នុងបទគម្ពីរផ្ដល់ជាសេចក្ដីយោងចំពោះវគ្គបទគម្ពីរដ៏មានប្រយោជន៍ទាំងនេះ ។

ដើម្បីបង្ហាញអំពីចំណុចនេះ សូមអញ្ជើញសិស្សឲ្យអាន វិវរណៈ ៥:១ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលយ៉ូហានបានឃើញនៅក្នុងដៃរបស់មនុស្សម្នាក់ដែលអង្គុយនៅលើបល្ល័ង្ក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ ប្រសិនបើសិស្សកំពុងប្រើការបោះពុម្ពរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ សូមអញ្ជើញពួកគេឲ្យបើកទៅសេចក្ដីយោងខគម្ពីរដែលនៅក្នុង លេខយោង ខ នៅក្នុង វិវរណៈ ៥:១ (គ. និង ស. ៧៧:៦) ។ ( ប្រសិនបើសិស្សពុំមានព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍របស់ពួកបរិសុទ្ធថ្ងៃចុងក្រោយទេ សូមអញ្ជើញពួកគេឲ្យបើកទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:៦ ដោយផ្ទាល់បន្ទាប់ពីពួកគេបានពិពណ៌នាពីអ្វីដែលពួកគេបានរកឃើញនៅក្នុង វិវរណៈ ៥:១) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួររបស់យ៉ូសែបស្ម៊ីធអំពី វិវរណៈ ៥:១ ក៏ដូចជាចម្លើយរបស់ព្រះអម្ចាស់ផងដែរ ។ វាអាចនឹងមានប្រយោជន៍ ដើម្បីពន្យល់ថា ៧០០០ឆ្នាំសំដៅទៅលើពេលវេលា ចាប់តាំងពីការធ្លាក់នៃអ័ដាម និង អេវ៉ាមកម្ល៉េះ ។ វាពុំសំដៅទៅលើអាយុកាលពិតប្រាកដនៃផែនដី រួមទាំងអាយុកាលនៃការបង្កបង្កើតនោះទេ ។

សូមឲ្យសិស្សប្រើពាក្យសម្ដីផ្ទាល់របស់ពួកគេដើម្បីសង្ខេបសំណួរ និងចម្លើយទាំងឡាយ ។ បន្ទាប់ពីបញ្ចប់សកម្មភាពនេះ សូមចង្អុលបង្ហាញពីរបៀបដែលការប្រើប្រាស់លេខយោង នៅពេលយើងសិក្សាបទគម្ពីរ អាចជួយយើងឲ្យរកឃើញអ្វីដែលព្រះអម្ចាស់បានមានបន្ទូល អំពីបទគម្ពីរដែលយើងកំពុងអាន ។

សូមចង្អុលបង្ហាញថា ទោះបីជាមានតែព្យាការីម្នាក់គត់ដែលមានសិទ្ធិអំណាចដើម្បីបកប្រែព្រះគម្ពីរសម្រាប់ពិភពលោកក្ដី ក៏យើងម្នាក់ៗគួរតែស្រាវជ្រាវដើម្បីមានការយល់ដឹង និង អនុវត្តផ្ទាល់ខ្លួននៅពេលសិក្សាព្រះគម្ពីរដោយខ្លួនឯង ។

- តើយើងអាចប្រៀបប្រដូចអ្វីដែលយ៉ូសែប ស្ម៊ីធបានធ្វើនៅពេលលោកបានសិក្សា និង ពិចារណាអំពីគម្ពីរវិវរណៈទៅនឹងការសិក្សាគម្ពីរផ្ទាល់ខ្លួនរបស់យើងយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងរកឃើញគោលការណ៍មួយដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងទូលសុំដល់ព្រះអម្ចាស់ នោះទ្រង់អាចជួយយើងឲ្យយល់បទគម្ពីរទាំងឡាយ** )។

- ហេតុអ្វីវាសំខាន់ដើម្បីស្រាវជ្រាវរកអត្ថន័យត្រឹមត្រូវនៃបទគម្ពីរ រួចហើយព្យាយាមអនុវត្តដោយផ្ទាល់ខ្លួនដូច្នេះ ?

សូមឲ្យសិស្សពិចារណាអំពីគ្រាមួយ នៅពេលដែលពួកគេបានសុំព្រះអម្ចាស់ឲ្យជួយពួកគេយល់នូវបទគម្ពីរ និង របៀបដើម្បីអនុវត្តការបង្រៀននៅក្នុងបទគម្ពីរចំពោះស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ខ្លួន ។

សូមពន្យល់ថាខគម្ពីរដែលនៅសល់ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ មានសំណួរជាច្រើនទៀតដែលយ៉ូសែប ស្ម៊ីធបានសួរអំពីគម្ពីរវិវរណៈ និងចម្លើយរបស់ព្រះអម្ចាស់ចំពោះសំណួរទាំងនេះ ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:៨–១៥ ដោយប្រាប់សិស្សថាវិវរណៈនេះបានអនុញ្ញាតឲ្យយ៉ូសែប ស្ម៊ីធរៀនអំពីព្រឹត្តការណ៍មួយចំនួនដែលនឹងកើតឡើង មុនពេលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។

សូមប្រាប់សិស្សថានៅពេលពួកគេសិក្សាគម្ពីរវិវរណៈនាពេលខាងមុខ នោះចម្លើយរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ អាចជួយពួកគេយល់អំពីអត្ថន័យនៃរូបភាពជានិមិត្តរូបនៅក្នុងគម្ពីរ ។

សូមបញ្ចប់មេរៀននេះដោយចែកចាយទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ និង គោលការណ៍នានាដែលបានពិភាក្សានៅក្នុងមេរៀននេះ ឬ ដោយចែកចាយបទពិសោធន៍មួយ ដែលអ្នកមាន ជាលទ្ធផលមកពី ការងាកទៅរកព្រះអម្ចាស់សុំជំនួយដើម្បីយល់បទគម្ពីរ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤–៨៧)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួននៅអំឡុងពេលនៃសប្ដាហ៍នេះ អ្នកអាចអញ្ជើញពួកគេឲ្យពិចារណាពីសំណួរខាងក្រោម ៖ តើអ្នកធ្លាប់គិតពីអ្វីៗទាំងអស់ដែលព្រះវរបិតាសួគ៌មានដែរឬទេ ? តើអ្នកបានដឹងទេថាទ្រង់បានសន្យាចែករំលែកនូវអ្វីៗទាំងអស់ដែលទ្រង់មានជាមួយពួកយើងដែរឬទេ ? ការសិក្សារបស់អ្នកនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤–៨៧ នឹងជួយអ្នកឲ្យយល់កាន់តែប្រសើរឡើងនូវអ្វីដែលអ្នកត្រូវតែធ្វើ ដើម្បីស្គាល់ព្រះ និង ទទួលនូវគ្រប់ពរជ័យទាំងអស់ដែលទ្រង់មាននៅក្នុងឃ្លាំងសម្រាប់អ្នក ។

មេរៀនទី ៨៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤៤

## បុព្វកថា

នៅខែកញ្ញា ឆ្នាំ ១៨៣២ ពួកអ្នកផ្សព្វផ្សាយសាសនា បានត្រឡប់ទៅកាន់ទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ បន្ទាប់ពីការផ្សាយដំណឹងល្អ នៅក្នុងសហរដ្ឋអាមេរិកប៉ែកខាងកើត ។ នៅក្នុងការជួបជុំដ៏រីករាយរបស់ពួកលោក ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលឥឡូវនេះ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ ។ លោកបានទទួលវិវរណៈអស់រយៈពេលពីរថ្ងៃ ៖ ថ្ងៃទី ២២ និងទី ២៣ ខែ កញ្ញា ឆ្នាំ ១៨៣២ ។ នៅក្នុងសៀវភៅសិក្សានេះ កណ្ឌ ៨៤ ត្រូវបានបែងចែកជាបីមេរៀន។ មេរៀនទីមួយនេះ ផ្ដោតទៅលើការណែនាំរបស់ព្រះអម្ចាស់អំពីបព្វជិតភាព និងអំពីរបៀបដែលបព្វជិតភាពអាចរៀបចំយើងដើម្បីទទួលនូវអ្វីៗទាំងអស់ដែលព្រះវរបិតាសួគ៌មាន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៣០

*ព្រះអម្ចាស់ប្រកាសថា ព្រះវិហារបរិសុទ្ធមួយ នឹងត្រូវបានសាងសង់ឡើង ហើយពន្យល់អំពីគោលបំណងនៃបព្វជិតភាព*

បើអាចធ្វើទៅបាន សូមយកច្បាប់ចម្លងខ្សែស្រឡាយនៃសិទ្ធិអំណាចបព្វជិតភាពរបស់នរណាម្នាក់មកក្នុងថ្នាក់ ( ជារបស់អ្នក ឬរបស់សមាជិកគ្រួសារម្នាក់ ) ។ ( អ្នកអាចថតចម្លងខ្សែស្រឡាយនៃសិទ្ធិអំណាចនៅលើក្ដារខៀន ) ។ សូមជួយសិស្សឲ្យយល់ថា ខ្សែស្រឡាយនៃសិទ្ធិអំណាចបព្វជិតភាព បង្ហាញពីសិទ្ធិអំណាចបព្វជិតភាពដែលត្រូវបានប្រគល់ ពីសំណាក់អ្នកកាន់បព្វជិតភាពម្នាក់ទៅដល់ម្នាក់ទៀត ចាប់តាំងពីព្រះយេស៊ូវគ្រីស្ទ ទៅឲ្យអ្នកកាន់បព្វជិតភាពនាសព្វថ្ងៃនេះ ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ មាននូវវិវរណៈមួយ អំពីបព្វជិតភាព និងរបៀបដែលវាប្រទានពរដល់កូនចៅរបស់ព្រះវរបិតាសួគ៌ ។ ផ្នែកទីមួយនៃវិវរណៈ បើកសម្ដែងអំពីខ្សែស្រឡាយបព្វជិតភាពរបស់ ម៉ូសេ ។ សូមអញ្ជើញសិស្សឲ្យមើលត្រួសៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦–១៩ ដោយស្ងាត់ស្ងៀម ហើយរកមើលរបៀបដែលម៉ូសេ អាចគូសដានសិទ្ធិអំណាចបព្វជិតភាពរបស់លោកទៅដល់ព្រះ ។

- ហេតុអ្វីក៏អ្នកគិតថាវាសំខាន់ ដែលសិទ្ធិអំណាចបព្វជិតភាពត្រូវប្រទានឲ្យតាមខ្សែត្រង់ត្រឡប់ទៅរកព្រះវិញដូច្នេះ ? ( សូមមើល ហេព្រើរ ៥:៤ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវឃ្លាដែលពិពណ៌នាអំពីលក្ខណៈដ៏អស់កល្បនៃបព្វជិតភាព ( « ដោយគ្មានថ្ងៃចាប់ផ្ដើម ឬឆ្នាំបញ្ចប់ឡើយ » ) ។ អ្នកអាចនឹងចង់ថ្លែងទីបន្ទាល់ថា បព្វជិតភាព គឺជាអំណាច និងសិទ្ធិអំណាចដ៏អស់កល្បជានិច្ចនៃព្រះ ហើយចែកចាយនូវការដឹងគុណរបស់អ្នកចំពោះព្រះ ដែលបានប្រទានអំណាចនេះ មកលើមនុស្សលោកសម្រាប់ជាប្រយោជន៍នៃកូនចៅរបស់ទ្រង់ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១៩–២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវពរជ័យទាំងឡាយដែលយើងអាចទទួលបាន តាមរយៈបព្វជិតភាពមិលគីស្សាដែក ។

- ស្របតាម ខ ១៩–២២ តើពរជ័យអ្វីខ្លះ ដែលយើងអាចទទួលបានតាមរយៈបព្វជិតភាពមិលគីស្សាដែក ? ( សិស្សអាចចែកចាយនូវចម្លើយមួយចំនួន ។ សូមប្រាកដថា ពួកគេប្រាប់ពីគោលលទ្ធិដូចខាងក្រោម ៖ **នៅក្នុងពិធីបរិសុទ្ធនៃបព្វជិតភាពមិលគីស្សាដែក អំណាចនៃភាពជាព្រះត្រូវបានសម្ដែងឡើង ។** សូមសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។
- តើពិធីបរិសុទ្ធនៃការសង្គ្រោះមួយណា ដែលត្រូវធ្វើឡើង ដោយសិទ្ធិអំណាចនៃបព្វជិតភាពមិលគីស្សាដែក ? ( ពិធីបញ្ជាក់ការប្រគល់នៃបព្វជិតភាពមិលគីស្សាដែក អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ និងការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុ

> ***សូមជួយសិស្សឲ្យយល់អំពីគោលលទ្ធិមូលដ្ឋាន***
>
> សិស្សនឹងរៀននូវគោលលទ្ធិមូលដ្ឋាន នៅពេលពួកគេសិក្សា និងពិភាក្សាអំពីបទគម្ពីរជារៀងរាល់ថ្ងៃ និងនៅពេលពួកគេចាំបទគម្ពីរគន្លឹះ ។ អ្នកពុំគួរបង្វែរចេញពីការសិក្សាបទគម្ពីរតាមលំដាប់លំដោយ ទៅផ្ដោតលើគោលលទ្ធិមូលដ្ឋាននោះទេ ។ ផ្ទុយទៅវិញ អ្នកគួរយកចិត្តទុកដាក់ទៅលើគោលលទ្ធិទាំងឡាយ នៅពេលវាមាននៅក្នុងវគ្គសិក្សា ។ ឧទាហរណ៍ នៅក្នុងមេរៀននេះ អ្នកអាចគូសបញ្ជាក់អំពីគោលលទ្ធិនៃបព្វជិតភាព ដែលត្រូវបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤។

ទ្ធ ។ សូមសរសេរពិធីបរិសុទ្ធទាំងនេះនៅលើក្ដារខៀន ) ។ តើអ្នកបានឃើញអំណាចនៃភាពជាព្រះសម្ដែងឲ្យឃើញនៅក្នុងពិធីបរិសុទ្ធទាំងនេះយ៉ាងដូចម្ដេច ?

- ស្របតាម ខ ២២ ហេតុអ្វីក៏វាសំខាន់ ដែលយើងទទួលពិធីបរិសុទ្ធនៃបព្វជិតភាពមិលគីស្សាដែក ? ( « អំណាចនៃភាពជាព្រះ » ដែលសម្ដែងឡើងនៅក្នុងពិធីបរិសុទ្ធទាំងនេះ នឹងអនុញ្ញាតឲ្យយើងមើលឃើញព្រះភ័ក្ត្ររបស់ព្រះ ហើយរស់ ) ។

សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ដើម្បីក្លាយដូចជាព្រះ ហើយរស់នៅក្នុងវត្តមានរបស់ទ្រង់ នោះយើងត្រូវទទួលពិធីបរិសុទ្ធនៃបព្វជិតភាពមិលគីស្សាដែក ។**

សំដៅទៅលើបញ្ជីនៃពិធីបរិសុទ្ធនៃបព្វជិតភាពមិលគីស្សាដែកនៅលើក្ដារខៀន ។

- តើពិធីបរិសុទ្ធទាំងនេះណាមួយ ដែលអាចត្រូវបានទទួលតែនៅក្នុងព្រះវិហារបរិសុទ្ធ ?

បន្ទាប់ពីសិស្សឆ្លើយតប សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ថា ៖



« ព្រះវិហារបរិសុទ្ធជាគោលបំណងនៃរាល់សកម្មភាព រាល់មេរៀន រាល់ជំហានដែលរីកចម្រើននៅក្នុងសាសនាចក្រ ។. . . ពិធីបរិសុទ្ធទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ គឺសំខាន់ខ្លាំងណាស់ ។ យើងពុំអាចត្រឡប់ទៅកេសិរីល្អនៃព្រះដោយគ្មានវាបានឡើយ » (Prepare for the Blessings of the Temple, » *Ensign* ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៤១ ) ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:២៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់នូវអ្វីដែលម៉ូសេបានធ្វើដើម្បីរៀបចំរាស្ត្ររបស់លោកឲ្យមើលឃើញព្រះភ័ក្ត្ររបស់ព្រះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ *ញែកចេញ* មានន័យថា ស្អាតស្អំ ហើយធ្វើឲ្យបរិសុទ្ធ ។ យើងអាចត្រូវបានញែកចេញតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:២៤–៣០ ដោយការពន្យល់ថា ដោយសារកូនចៅនៃអ៊ីស្រាអែលមានចិត្តរឹងរូសពេក នោះពួកគេបានបាត់បង់ឱកាសដើម្បីទទួលបព្វជិតភាពមិលគីស្សាដែក និងពិធីបរិសុទ្ធទាំងឡាយដែលជាប់ទាក់ទងនឹងវានៅក្នុងជីវិតនេះ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់បានបន្តជួយពួកគេឲ្យរីកចម្រើន ។ ទ្រង់បានអនុញ្ញាតឲ្យមានបព្វជិតភាពទាបជាង ឬបព្វជិតភាពអើរ៉ុន ដើម្បីបន្តមានជាមួយពួកគេ ( សូមមើល គ. និង ស. ៨៤:២៦–២៧) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣១–៤៤

*ព្រះអម្ចាស់បង្រៀនអំពីសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព*

សូមសួរដល់សិស្សម្នាក់ដែលកាន់បព្វជិតភាពឲ្យឆ្លើយតបចំពោះសំណួរដូចខាងក្រោម ៖

- តើអ្នកត្រូវបានប្រទានពរ ដោយសារអ្នកកាន់បព្វជិតភាពយ៉ាងដូចម្ដេច ? តើអ្នកត្រូវបានប្រទានពរ ដោយសារអ្នកដទៃកាន់បព្វជិតភាពយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣១–៣២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលដែលព្រះអម្ចាស់បានប្រើដើម្បីសំដៅទៅលើអ្នកទាំងឡាយដែលកាន់បព្វជិតភាព ។

- តើព្រះអម្ចាស់សំដៅទៅលើអ្នកទាំងឡាយដែលកាន់បព្វជិតភាពយ៉ាងដូចម្ដេច ? ( សូមជួយសិស្សយល់ថា ឃ្លា « កូនប្រុសរបស់លោកម៉ូសេ » សំដៅទៅលើអ្នកទាំងឡាយដែលកាន់បព្វជិតភាពមិលគីស្សាដែក ហើយថា ឃ្លា « កូនប្រុសរបស់អើរ៉ុន » សំដៅទៅលើអ្នកទាំងឡាយដែលកាន់បព្វជិតភាពអើរ៉ុន ) ។

សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្ដារខៀន ៖*សម្បថ និងសេចក្ដីសញ្ញា នៃបព្វជិតភាព* ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣៣–៤៤ ត្រូវបានស្គាល់ថាជា សេចក្ដីសម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព ។ ខគម្ពីរទាំងនេះ ចែងថា (១) ជាសេចក្ដីសញ្ញាដែលមនុស្សម្នាក់ធ្វើ នៅពេលគាត់ទទួលបានបព្វជិតភាព ហើយ (២) ការសន្យាដែលព្រះអម្ចាស់បានធ្វើជាមួយពួកអ្នកកាន់បព្វជិតភាពស្មោះត្រង់ ។

សូមសរសេរសេចក្តីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោម នៅលើក្តារខៀន៖ *បើអ្នកទាំងឡាយដែលទទួលបព្វជិតភាព*
*នឹង* ______________________________________________________________ *នោះព្រះ*
*នឹង* ______________________________________________________________.

សូមអញ្ជើញសិស្សឲ្យសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:៣៣–៤៤ ដោយស្ងៀមស្ងាត់ ឬជាគូៗ ។ សូមពួកគេឲ្យបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀនដោយផ្អែកទៅលើខគម្ពីរទាំងនោះ ។

- តើអ្នកបំពេញសេចក្តីថ្លែងការណ៍យ៉ាងដូចម្តេច ? ( សិស្សគួរតែស្គាល់គោលការណ៍ដូចខាងក្រោម ៖**បើអ្នកទាំងឡាយណាដែលទទួលបព្វជិតភាព នឹងតម្កើងការហៅរបស់ពួកគេ ធ្វើតាមព្រះអម្ចាស់ និងពួកអ្នកបម្រើទ្រង់ ហើយស្តាប់ព្រះបន្ទូលនៃជីវិតដ៏អស់កល្បជានិច្ច នោះព្រះនឹងញែកពួកគេចេញ ហើយប្រទានដល់ពួកគេនូវអ្វីៗទាំងអស់ដែលទ្រង់មាន** )។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ៖



« យើងតម្កើងបព្វជិតភាពយើង ហើយពង្រីកការហៅរបស់យើង នៅពេលយើងបម្រើដោយមានចិត្តឧស្សាហ៍ព្យាយាម និង សេចក្តីសោមនស្សក្នុងការទទួលខុសត្រូវដែលយើងត្រូវបានហៅដោយសិទ្ធអំណាចត្រឹមត្រូវ ។. . . យើងតម្កើងការហៅយើង យើងពង្រីកសក្តានុពលនៃបព្វជិតភាពយើងនៅពេលយើងឈោងទៅជួយអ្នកដែលមានទុក្ខព្រួយ ហើយចម្រើនកម្លាំងដល់អ្នកដែលជំពប់ជើងដួល ។. . . យើងតម្កើងការហៅរបស់យើង នៅពេលយើងដើរដោយទៀងត្រង់ និងសេចក្តីសុចរិត » (Magnify Your Calling, » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៩ ទំព័រ ៤៨–៤៩ ) ។

សូមពន្យល់ថា នៅពេលយើងទទួលការហៅនៅក្នុងសាសនាចក្រ នោះយើងមានឱកាសដើម្បីរៀបចំខ្លួនយើង និងអ្នកដទៃឲ្យទទួលពិធីបរិសុទ្ធនៃការសង្គ្រោះនៃបព្វជិតភាព ។ សូមសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖



« ហើយតើមនុស្សម្នាក់តម្កើងការហៅមួយដោយរបៀបណា ? វាសាមញ្ញណាស់ គឺតាមរយៈការបំពេញការបម្រើដែលទាក់ទងទៅនឹងការហៅនោះ ។. . . ខ្ញុំសង្ឃឹមដោយអស់ពីដួងចិត្ត និងព្រលឹងរបស់ខ្ញុំថាយុវជនគ្រប់រូបដែលទទួលបព្វជិតភាព នឹងផ្តល់តម្លៃឲ្យបព្វជិតភាពនោះ ហើយស្មោះត្រង់ចំពោះទំនុកចិត្តដែលត្រូវបានទទួលនៅពេលវាត្រូវបានប្រគល់ឲ្យ » (Priesthood Power » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៤៩, ៥១ ) ។

- តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកកាន់បព្វជិតភាពអើរ៉ុនតម្កើងការហៅរបស់ពួកគេក្នុងបព្វជិតភាព ?

- តើនៅពេលណាដែលអ្នកត្រូវបានប្រទានពរ ដោយសារតែនរណាម្នាក់បានតម្កើងការហៅបម្រើរបស់ពួកគេនោះ ?

សូមជួយសិស្សឲ្យមើលឃើញថា ពរជ័យនៃសេចក្តីសម្បថ និងសេចក្តីសញ្ញាបព្វជិតភាព គឺពុំគ្រាន់តែសម្រាប់អ្នកកាន់បព្វជិតភាពនោះទេ ។ ពរជ័យដ៏ធំបំផុតរបស់ព្រះ កើតមានដល់បុរស និងស្ត្រី ដែលត្រូវបានផ្សាភ្ជាប់នឹងគ្នាទៅវិញទៅមកក្នុងព្រះវិហារបរិសុទ្ធ ។ សូមអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយ អែលឌើរ រ័សុល អិម ណិលសុន ៖



« នៅថ្ងៃណាមួយ ស៊ីស្ទើរ ណិលសុន និងខ្ញុំ នឹងរស់នៅជុំគ្នាក្នុងវត្តមាននៃគ្រួសាររបស់យើង និងព្រះអម្ចាស់ជារៀងរហូត ។ យើងនឹងស្មោះត្រង់ចំពោះសេចក្តីសញ្ញាទាំងឡាយដែលយើងបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ ហើយស្មោះត្រង់ចំពោះសម្បថ និងសេចក្តីសញ្ញានៃបព្វជិតភាព ដែលបានអះអាងដល់យើង នៅក្នុងព្រះបន្ទូលនៃព្រះអម្ចាស់ថា ‹ គ្រប់អ្វីៗទាំងអស់ដែលព្រះវរបិតាយើងមាននោះនឹងត្រូវបានប្រទានដល់ [អ្នក] នោះដែរ › (គ. និង ស. ៨៤:៣៨) ។

« ស្ត្រីស្មោះត្រង់ចែករំលែកពរជ័យនៃបព្វជិតភាព ។ សូមគិតអំពីពាក្យទាំងនេះថា ‹ គ្រប់អ្វីៗទាំងអស់ដែលព្រះវរបិតាយើងមាន › ។. . . វាមានន័យថា គ្មានរង្វាន់ខាងលោកិយ៍ណា – គ្មានជោគជ័យណា– អាចសងថ្លៃចំពោះពរជ័យទាំងឡាយ ដែលព្រះនឹងចាក់ស្រោចមកលើអ្នកទាំងឡាយដែលស្រឡាញ់ទ្រង់ រក្សាបទបញ្ញត្តិរបស់ទ្រង់ឡើយ ( សូមមើល ម៉ូរ៉ូណៃ ៤:៣ ហើយកាន់ខ្ជាប់ដល់ចុងបំផុតនោះទេ » ( សូមមើលគ. និង ស. ១៤:៧ Identity, Priority, and Blessings,» *Ensign* ខែ សីហា ឆ្នាំ ២០០១ ទំព័រ ១០ ) ។

ដើម្បីជួយសិស្សយល់នូវការសន្យាជាក់លាក់ដែលព្រះអម្ចាស់បានធ្វើ ជាចំណែកនៃសេចក្ដីសម្បថ និងសេចក្ដីសញ្ញា នៃបព្វជិតភាព សូមសរសេរនូវសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖*ដែលព្រះអម្ចាស់សន្យាចំពោះ. . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឡើងវិញនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣៣–៣៤ ,៣៨,៤២ ដោយស្ងាត់ស្ងៀម ។ សូមពួកគេឲ្យប្រាប់ពីពរជ័យទាំងឡាយដែលព្រះអម្ចាស់សន្យា ដែលជាចំណែកនៃសេចក្ដីសម្បថ និងសេចក្ដីសញ្ញា នៃបព្វជិតភាព ។ អ្នកគួរតែសរសេរចម្លើយរបស់ពួកគេ នៅលើក្ដារខៀន ។ ពួកគេអាចប្រាប់ថា ព្រះអម្ចាស់នឹង ៖ ( ១) ញែកយើងជាបរិសុទ្ធដោយព្រះវិញ្ញាណ ( សូមមើល ខ ៣៣) (២) កសាងរូបកាយរបស់យើងជាថ្មី ( សូមមើល ខ ៣៣) (៣) រាប់យើងនៅក្នុងចំណោមពូជរបស់អ័ប្រាហាំ –ជាពាក្យម្យ៉ាងទៀតថា ប្រទានដល់យើងនូវពរជ័យដែលបានសន្យាដល់អ័ប្រាហាំ និងពូជរបស់លោក ( សូមមើល ខ ៣៤) (៤) ធ្វើឲ្យយើងក្លាយជាពួកជម្រើស ឬពួកដែលត្រូវបានជ្រើសរើសរបស់ទ្រង់ ( សូមមើល ខ ៣៤) (៥) ប្រទានដល់យើងនូវអ្វីៗទាំងអស់ដែលព្រះបិតាមាន ( សូមមើល ខ ៣៨) ហើយ (៦) ប្រទានពួកទេវតារបស់ទ្រង់ឲ្យមើលថែយើង ( សូមមើល ខ ៤២) ។ ( នៅពេលសិស្សប្រាប់ពីការសន្យានៅក្នុង ខ ៣៨ អ្នកអាចនឹងចង់លើកទឹកចិត្តពួកគេឲ្យគិតអំពីលក្ខណៈ និងសិរីល្អរបស់ព្រះ ពុំមែនការមានបានទ្រព្យសម្បត្តិ និងសម្ភារនោះទេ ។ ឧទាហរណ៍ យើងអាចទទួលសេចក្ដីពិតរបស់ទ្រង់ សេចក្ដីស្រឡាញ់របស់ទ្រង់ ក្ដីអំណររបស់ទ្រង់ និងភាពសុខសាន្តរបស់ទ្រង់ ។ យើងអាចត្រូវបានប្រទានពរដោយភាពពេញលេញនៃព្រះចេស្ដាទ្រង់ ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយថា ហេតុអ្វីបានជាបព្វជិតភាពមានន័យចំពោះពួកគេ ។ សូមពិចារណាចែកចាយពីទីបន្ទាល់របស់អ្នកអំពីពរជ័យនៃបព្វជិតភាព ។

មេរៀនទី ៨៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–៦១

## បុព្វកថា

នៅថ្ងៃទី ២២ និង ២៣ ខែ កញ្ញា ឆ្នាំ ១៨៣២ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបើកសម្ដែងសេចក្ដីពិតអំពីបព្វជិតភាព ដូចបានពិភាក្សានៅក្នុងមេរៀនមុនៗ ។ ព្រះអម្ចាស់ក៏បានបង្រៀនផងដែរដល់ពួកបរិសុទ្ធអំពីសារៈសំខាន់នៃការស្ដាប់ឮព្រះបន្ទូលរបស់ព្រះ ។ ទ្រង់បានវាយផ្ចាលពួកគេដែលរាប់ថា ព្រះគម្ពីរមរមន និងបទបញ្ញត្តិដទៃទៀត និងវិវរណៈទាំងឡាយគ្មានប្រយោជន៍ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–៥៣

*ព្រះអម្ចាស់បង្រៀនអំពីសារៈសំខាន់នៃការស្ដាប់ឮព្រះបន្ទូលរបស់ព្រះ*

សូមរំឭកដល់សិស្សអំពីគោលដៅដែលពួកគេបានដាក់ នៅដើមឆ្នាំដើម្បីសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ។ សូមអញ្ជើញពួកគេឲ្យពិចារណាអំពីរបៀបដែលពួកគេកំពុងធ្វើបានយ៉ាងល្អប៉ុណ្ណាជាមួយនឹងគោលដៅនេះ ។ បន្ទាប់ពីសិស្សបានពិចារណារឿងនេះរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើឧបសគ្គមួយចំនួនដែលអ្នកប្រឈមមុខក្នុងការព្យាយាមដើម្បីសិក្សាព្រះគម្ពីររាល់ថ្ងៃមានអ្វីខ្លះ ? ( នៅពេលសិស្សឆ្លើយតប សូមទទួលស្គាល់ថា វាអាចនឹងពិបាកដើម្បីរក្សាទម្លាប់នៃការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ) ។
- ហេតុអ្វីក៏អ្នកជ្រើសរើសដើម្បីសិក្សាគម្ពីរ ទោះជាជួនកាលវាអាចនឹងពិបាកដើម្បីធ្វើក៏ដោយនោះ ?

សូមពន្យល់ថា នៅក្នុងមេរៀនថ្ងៃនេះ សិស្សនឹងរៀនអំពីសេចក្ដីពិតមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ ដែលអាចបំផុសគំនិតពួកគេឲ្យបន្តការខិតខំក្នុងការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–៤៤ ដោយស្ងាត់ស្ងៀម ហើយប្រាប់នូវពាក្យ និងឃ្លាដែលបង្រៀនអំពីសារៈសំខាន់នៃការសិក្សា និងការអនុវត្តព្រះបន្ទូលនៃព្រះអម្ចាស់ ។

- តើពាក្យ និងឃ្លាអ្វីខ្លះ ដែលអ្នករកឃើញ ដែលបង្រៀនអំពីសារៈសំខាន់នៃការសិក្សា និងការអនុវត្តនូវព្រះបន្ទូលនៃព្រះអម្ចាស់ ? ( សិស្សអាចនឹងប្រាប់នូវពាក្យ និងឃ្លាដូចជា « បទបញ្ញត្តិ » « ប្រុងស្ដាប់តាម » និង « រស់ដោយសារគ្រប់ទាំងព្រះបន្ទូល» ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៥–៤៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម និងរកមើលនូវពាក្យ និងឃ្លាទាំងឡាយនៅក្នុងវគ្គគម្ពីរនេះ ដែលមានន័យដូចគ្នានឹង « ព្រះបន្ទូលនៃព្រះអម្ចាស់ » ។

- តើពាក្យ និង ឃ្លាអ្វីខ្លះ ដែលអ្នកបានរកឃើញ ? ( ចម្លើយគួរមានដូចជា « សេចក្ដីពិត » « ពន្លឺ » « ព្រះវិញ្ញាណ » « ព្រះវិញ្ញាណនៃព្រះយេស៊ូវ គ្រីស្ទ » និង « សំឡេងនៃព្រះវិញ្ញាណ » ) ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងប្រុងស្ដាប់តាមព្រះបន្ទូលនៃព្រះ នោះ. . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៥–៤៦ ដោយស្ងាត់ស្ងៀម ។

> ***សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ***
>
> គ្មានរឿងតូចតាចណា ដែលមានឥទ្ធិពលយូរអង្វែងឲ្យធ្វើការល្អ ជាងការជួយសិស្សឲ្យអភិវឌ្ឍនូវទម្លាប់នៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃនោះទេ ។ សូមលើកទឹកចិត្តសិស្សឲ្យញែកពេលវេលារាល់ថ្ងៃ សម្រាប់ការសិក្សាព្រះគម្ពីរ ។ សូមផ្ដល់ដល់សិស្សនូវឱកាសជាទៀងទាត់នៅក្នុងថ្នាក់ ដើម្បីចែកចាយនូវអ្វីដែលពួកគេកំពុងរៀន និង មានអារម្មណ៍ ពេលពួកគេសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនផងដែរ ។ នៅពេលលើកទឹកចិត្តដល់ការសិក្សាព្រះគម្ពីរជាប្រចាំ គួរតែប្រយ័ត្នក្នុងការធ្វើឲ្យមានខ្មាសអៀន ឬ មិនលើកទឹកចិត្តដល់សិស្ស មួយចំនួន ដែលអាចស្មុគស្មាញក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់គេ ។

- ផ្អែកលើអ្វីដែលអ្នកបានរកឃើញនៅក្នុង ខ ៤៥–៤៦ តើអ្នកនឹងបញ្ចប់សេចក្ដីថ្លែងការណ៍នៅលើក្ដារខៀនយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងផ្ដល់ចម្លើយផ្សេង ។ សូមបំពេញគោលការណ៍នៅលើក្ដារខៀន ដូច្នេះវានាំទៅរកគោលការណ៍ដូចខាងក្រោម ៖ **បើយើងប្រុងស្ដាប់តាមព្រះបន្ទូលនៃព្រះ នោះយើងនឹងត្រូវបានបំភ្លឺគំនិតតាមរយៈព្រះវិញ្ញាណនៃព្រះគ្រីស្ទ )**

សូមបង្វែចំណាប់អារម្មណ៍របស់សិស្សទៅយកចិត្តទុកដាក់លើឃ្លា « ព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ » នៅក្នុង ខ ៤៥។ សូមពន្យល់ថា ឃ្លាផ្សេងទៀតដែលមានន័យដូចគ្នាគឺ « ពន្លឺនៃព្រះគ្រីស្ទ » ។ ពន្លឺនៃព្រះគ្រីស្ទ គឺជា « អានុភាពមួយនៃសេចក្ដីល្អដែលមាននៅក្នុងមនុស្សទូទៅ ។. . . | ទោះជាយ៉ាងណាក៏ដោយ | ពន្លឺនៃព្រះគ្រីស្ទ ពុំគួរត្រូវបានច្រឡំនឹងព្រះវិញ្ញាណបរិសុទ្ធនោះទេ ។ វាពុំមែនជាតួអង្គមួយ ដូចជាព្រះវិញ្ញាណបរិសុទ្ធនោះទេ » (*ពិតចំពោះសេចក្ដីជំនឿ* | ឆ្នាំ ២០០៤ | ទំព័រ ៩៦ ) ។ ពន្លឺនៃព្រះគ្រីស្ទ គឺមាននៅក្នុងបុគ្គលម្នាក់ៗ ហើយផ្ដល់នូវ « ចំណេះដឹងនៃភាពត្រឹមត្រូវ និងភាពខុសឆ្គង | ឬ | ជាញាណខាងសីលធម៌ ឬមនសិការ » ។ វា « អាចនាំយើងឲ្យគ្រប់គ្រងសកម្មភាពរបស់យើង– លុះត្រាតែយើងជំនះវា ឬសម្លាប់វា » ( ប៊ិយដ៍ យេ ផាកកឺ The Light of Christ,» *Ensign* ខែ មេសា ឆ្នាំ ២០០៥ ទំព័រ ៩ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៧–៤៨ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយប្រាប់ថាយើងនឹងមានពរជ័យយ៉ាងណា បើយើងប្រុងស្ដាប់តាមព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ ។

- ស្របតាម ខ ៤៧ តើយើងនឹងត្រូវបានប្រទានពរយ៉ាងដូចម្ដេច បើយើងប្រុងស្ដាប់តាមព្រះវិញ្ញាណនៃព្រះយេស៊ូវ គ្រីស្ទ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្ដែពួកគេគួរតែស្គាល់គោលការណ៍ដូចខាងក្រោម ៖ **បើយើងប្រុងស្ដាប់តាមព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងមករកព្រះបិតា ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- ស្របតាម ខ ៤៨ តើអ្វីខ្លះដែលព្រះវរបិតានឹងធ្វើ នៅពេលយើងមករកទ្រង់ ? ( ទ្រង់នឹងបង្រៀនយើង ) ។
- នៅក្នុង ខ ៤៨ យើងអានថា ព្រះបិតា នឹងបង្រៀនយើងពុំគ្រាន់តែសម្រាប់ជាប្រយោជន៍របស់យើងប៉ុណ្ណោះទេ ប៉ុន្ដែក៏សម្រាប់ប្រយោជន៍នៃពិភពលោកទាំងមូលផងដែរ ។ តើការណ៍នេះមានអត្ថន័យយ៉ាងណាចំពោះអ្នក ?

សូមចង្អុលបង្ហាញថា ដើម្បីមានពន្លឺនៃព្រះគ្រីស្ទ នោះបុគ្គលម្នាក់ៗអាចទទួលភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីពួកគេចូលក្នុងសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។ តាមរយៈអំណោយទាននេះ ពួកគេអាចទទួលពន្លឺបន្ថែម ហើយត្រូវបានដឹកនាំត្រឡប់ទៅវត្តមាននៃព្រះបិតា ដើម្បីទទួលជីវិតដ៏អស់កល្បជានិច្ច ។

សូមអញ្ជើញសិស្សឲ្យបិទភ្លើងនៅក្នុងបន្ទប់ រួចហើយត្រឡប់ទៅកន្លែងរបស់ពួកគេវិញ ។ ( សូមប្រាកដថា មានពន្លឺគ្រប់គ្រាន់ល្មមនៅក្នុងបន្ទប់ដើម្បីសិស្សអាចដើរដោយសុវត្ថិភាព ) ។ សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាដែលពួកគេត្រូវតែដើរនៅក្នុងស្ថានភាពងងឹតសូន្យសុង ។ សូមឲ្យសិស្សពីរបីនាក់ពិពណ៌នាថាបទពិសោធន៍នេះ វាយ៉ាងណាខ្លះចំពោះពួកគេ ។ បន្ទាប់មកសូមបើកភ្លើងមកវិញ ។

សូមពន្យល់ថា ជាញឹកញាប់ក្នុងខគម្ពីរ ពាក្យភាពងងឹត សំដៅទៅលើការពិពណ៌នានៃនិមិត្តរូបអំពីស្ថានភាពខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៩–៥៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយពិពណ៌នាប្រាប់ថានរណាដែលព្រះអម្ចាស់បានមានបន្ទូលថានៅក្នុងភាពងងឹតខាងវិញ្ញាណ ហើយហេតុអ្វីបានជាពួកគេស្ថិតនៅក្នុងស្ថានភាពនោះ ។

- តើនរណាស្ថិតនៅក្នុងភាពងងឹត ? ហេតុអ្វីក៏ពួកគេស្ថិតនៅក្នុងភាពងងឹត ?

សូមចង្អុលបង្ហាញថា នៅក្នុងខគម្ពីរទាំងនេះ អ្នកទាំងឡាយដែលត្រូវបានពិពណ៌នាថាស្ថិតនៅក្នុងពិភពងងឹត ក៏ត្រូវបានពិពណ៌នាផងដែរថាជាអ្នកដែលស្ថិតនៅក្រោមសេវកភាពនៃអំពើបាប ។ នេះមានន័យថា ពួកគេត្រូវជាប់អន្ទាក់នៅក្នុងផលនៃអំពើបាបរបស់ពួកគេ ដោយសារពួកគេពុំបានប្រែចិត្ត ។

- តើការរស់នៅក្នុងសេវកភាពនៃអំពើបាប ដូចគ្នាទៅនឹងការនៅក្នុងភាពងងឹតយ៉ាងដូចម្ដេចដែរ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៤–៦១

*ព្រះអម្ចាស់បានវាយផ្ចាលដល់ពួកបរិសុទ្ធដែលរាប់ថាព្រះគម្ពីរមរមនឥតប្រយោជន៍*

សូមពន្យល់ថា ដើម្បីថ្លែងថា ពិភពលោកស្ថិតនៅក្នុងភាពងងឹត នោះព្រះអម្ចាស់មានបន្ទូលថា គំនិតរបស់សមាជិកនៃសាសនាចក្រត្រូវបានងងឹត ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៤–៥៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវមូលហេតុពីរយ៉ាង ថាហេតុអ្វីគំនិតរបស់សមាជិកនៃសាសនាចក្រត្រូវបានប្រែជាងងឹតដូច្នេះ ។

- ស្របតាម ខ ៥៤ ហេតុអ្វីក៏គំនិតរបស់សមាជិកនៃសាសនាចក្រត្រូវបានងងឹត ?
- តើការចាត់ទុកអ្វីមួយជារបស់ឥតប្រយោជន៍មានន័យយ៉ាងណា ? ( មិនអើពើនឹងអ្វីមួយ ឬចាត់ទុកថាវាមិនគួរឲ្យគោរព ឬដោយមិនយកចិត្តទុកដាក់ ) ។ តើការមិនជឿ ឬការចាត់ទុករឿងពិសិដ្ឋមួយជាការឥតប្រយោជន៍ អាចបណ្ដាលឲ្យគំនិតរបស់មនុស្សម្នាក់ត្រូវប្រែជាងងឹតយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វី ដែលពួកបរិសុទ្ធ ចាត់ទុកថាឥតប្រយោជន៍ ។

- តើពួកបរិសុទ្ធចាត់ទុកអ្វីខ្លះដែលគ្មានប្រយោជន៍ ? ( ព្រះគម្ពីរមរមន និង « បទបញ្ញត្តិពីមុនៗ » របស់ព្រះអម្ចាស់ ឬវិវរណៈមុនៗ រួមទាំងវិវរណៈទាំងឡាយដែលមាននៅក្នុងព្រះគម្ពីរបរិសុទ្ធ ) ។
- ស្របតាមអ្វីដែលអ្នកបានរៀនមកពី ខ ៥៤–៥៨ តើយើងនឹងជួបផលវិបាកអ្វីខ្លះ បើយើងចាត់ទុកព្រះបន្ទូលនៃព្រះគ្មានប្រយោជន៍នោះ ? ( សិស្សគួរបង្ហាញថា**បើយើងចាត់ទុកព្រះបន្ទូលនៃព្រះគ្មានប្រយោជន៍ នោះគំនិតយើងនឹងត្រូវងងឹត ហើយយើងនឹងនាំទៅរកការដាក់ទោស ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្វ បែនសិន ស្ដីអំពីព្រះគម្ពីរមរមន ៖



«តើលទ្ធផលដ៏អស់កល្បជានិច្ច ស្ថិតនៅលើការអនុវត្តរបស់អ្នកចំពោះព្រះគម្ពីរនេះដែរឬទេ ? ពិតមែនហើយ មិនថាចំពោះពរជ័យរបស់យើង ឬ ការដាក់ទោសរបស់យើងនោះទេ ។

« ពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូប គួរតែសិក្សាព្រះគម្ពីរនេះពេញមួយជីវិតខ្លួន ។ បើមិនដូច្នោះទេ គេកំពុងតែដាក់ព្រលឹងខ្លួនក្នុងគ្រោះថ្នាក់ និង ការធ្វេសប្រហែសដែលអាចផ្ដល់ភាពរួមគ្នាខាងវិញ្ញាណ និងបញ្ញាពេញមួយជីវិតរបស់ខ្លួនទាំងមូល ។ មានភាពខុសគ្នារវាងអ្នកប្រែចិត្តជឿដែលសាងសង់លើថ្មនៃព្រះគ្រីស្ទ តាមរយៈព្រះគម្ពីរមរមន ហើយកាន់ខ្ជាប់ដំបងដែកនោះ និង អ្នកដែលមិនបានធ្វើដូចនោះ » (« The Book of Mormon Is the Word of God » *Ensign,* ខែ មករា ឆ្នាំ ១៩៨៨ ទំព័រ ៥ ) ។

« សូមយើងកុំនៅក្រោមការដាក់ទោស ដោយនូវការវាយ និង សេចក្ដីជំនុំជម្រះរបស់វា ព្រោះតែការរាប់អំណោយទានដ៏មហិមា និង ដ៏អស្ចារ្យ ដែលព្រះអម្ចាស់បានប្រទានដល់យើងនេះ ទុកជាគ្មានផលប្រយោជន៍នោះឡើយ ។ តែសូមយើងទទួលបានជោគជ័យលើសេចក្ដីសន្យាទាំងឡាយ ដែលជាប់ទាក់ទងនឹងការរក្សាទុកវានៅក្នុងដួងចិត្តរបស់យើងវិញ » (The Book of Mormon—Keystone of Our Religion, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៧ ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេប្រព្រឹត្តចំពោះព្រះគម្ពីរមរមន ហើយតើពួកគេអាចធ្វើឲ្យការសិក្សារបស់ពួកគេអំពីព្រះគម្ពីរមរមនជាការ ស្វែងយល់ពេញមួយជីវិតតាមរបៀបណា ។

សូមឲ្យសិស្សមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៧ ដោយស្ងាត់ស្ងៀម ។

- តើព្រះអម្ចាស់បានមានបន្ទូលទៅពួកបរិសុទ្ធថាចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីប្រែចិត្តពីការចាត់ទុកព្រះបន្ទូលរបស់ទ្រង់គ្មានប្រយោជន៍នោះ ? ( សូមជួយសិស្សឲ្យមើលឃើញថា បន្ថែមពីលើការចងចាំព្រះគម្ពីរមរមន និង «បទបញ្ញត្តិមុនៗ» ដែលព្រះអម្ចាស់បានប្រទានឲ្យ នោះពួកបរិសុទ្ធចាំបាច់ត្រូវធ្វើនូវអ្វីដែលបានសរសេរក្នុងគម្ពីរ ) ។
- តើអ្នកនឹងសង្ខេបនូវអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងធ្វើចំពោះព្រះគម្ពីរមរមនយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងប្រាប់នូវគោលការណ៍ផ្សេងៗ ប៉ុន្តែសូមប្រាកដថាត្រូវគូសបញ្ជាក់ដូចខាងក្រោម ៖ **យើងត្រូវសិក្សាព្រះគម្ពីរមរមនដោយស្មោះត្រង់ ហើយរស់នៅស្របតាមការបង្រៀននោះ ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យគូៗនោះចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរដូចខាងក្រោម ៖

- តើនរណាជាគំរូល្អចំពោះអ្នកអំពីការសិក្សាព្រះគម្ពីរមរមន និងការរស់នៅស្របតាមការបង្រៀននោះ ?

ដើម្បីបញ្ចប់ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦០–៦១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការណែនាំបន្ថែម ដែលព្រះអម្ចាស់បានប្រទានដល់អ្នកទាំងឡាយណាដែលទទួលព្រះបន្ទូលរបស់ទ្រង់តាមរយៈព្រះគម្ពីរមរមន ។ បន្ទាប់ពីបានអានខទាំងឡាយហើយ សូមចង្អុលបង្ហាញថា ស្របតាម ខ ៦១ អ្នកទាំងឡាយដែលទទួលព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងព្រះគម្ពីរមរមន គឺត្រូវថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យថ្លែងទីបន្ទាល់អំពីរបៀបដែលពួកគេត្រូវបានប្រទានពរ ពេលពួកគេបានសិក្សាព្រះគម្ពីរមរមន ហើយព្យាយាមរស់នៅស្របតាមសេចក្ដីពិតដែលគម្ពីរបង្រៀន ។ ( អ្នកអាចនឹងផ្ដល់ដល់សិស្សនូវគ្រាមួយ ដើម្បីគិតអំពីបទពិសោធន៍របស់ពួកគេ មុននឹងសុំពួកគេឲ្យឆ្លើយតប ) ។

សូមរំឭកដល់សិស្សអំពីគោលដៅរបស់ពួកគេដើម្បីសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ។ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ហើយអញ្ជើញសិស្សឲ្យសរសេរចម្លើយរបស់ពួកគេនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

> *តើអ្នកបានរៀនអ្វីខ្លះនៅថ្ងៃនេះ ដែលបានបំផុសគំនិតអ្នកឲ្យបន្តសិក្សាព្រះគម្ពីរមរមន ?*
>
> *តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីសិក្សាព្រះគម្ពីរមរមនឲ្យកាន់តែឧស្សាព្យាយាម ហើយរស់នៅតាមសេចក្ដីពិតដែលអ្នកបានរៀនមកពីព្រះគម្ពីរនោះ ?*
>
> *តើអ្នកនឹងប្រើព្រះគម្ពីរមរមនដើម្បីចែកចាយដំណឹងល្អជាមួយអ្នកដទៃយ៉ាងដូចម្ដេច ?*

សូមថ្លែងទីបន្ទាល់ថា សិស្សនឹងខិតទៅកាន់តែជិតព្រះវរបិតាសួគ៌ នៅពេលពួកគេរស់នៅតាមសេចក្ដីពិតដែលបានពិភាក្សានៅថ្ងៃនេះក្នុងថ្នាក់រៀន ។

មេរៀនទី ៨៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦២–១២០

## បុព្វកថា

នៅខែ កញ្ញា ឆ្នាំ ១៨៣២ បន្ទាប់ពីការបើកសម្ដែងសេចក្ដីពិតអំពីបព្វជិតភាព និងសារៈសំខាន់នៃការប្រុងស្ដាប់តាមព្រះបន្ទូលទ្រង់ ព្រះអម្ចាស់បានគូសបញ្ជាក់អំពីការបញ្ជាឲ្យពួកសាវក និងពួកអ្នកកាន់បព្វជិតភាពដទៃទៀតឲ្យផ្សាយដំណឹងល្អនៅទូទាំងពិភពលោក ។ វិវរណៈនេះបានសង្កត់ធ្ងន់ទៅលើ ការផ្សាយដំណឹងល្អ និងផ្ដល់ការណែនាំស្រដៀងគ្នាទៅដល់អ្នកទាំងឡាយដែលព្រះយេស៊ូវគ្រីស្ទបានប្រគល់ទៅឲ្យពួកសាវកបន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ។ ព្រះអម្ចាស់ក៏បានពន្យល់ផងដែរអំពីរបៀបដែលកិច្ចការនេះត្រូវសម្រេច រួមទាំងរបៀបដែលអ្នកទាំងឡាយចូលរួមក្នុងកិច្ចការនេះ នឹងត្រូវបានគាំទ្រ និងបន្តនៅក្នុងកិច្ចខិតខំរបស់ពួកគេ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦២–៧៦

*ព្រះអម្ចាស់បានចេញការហៅមួយឲ្យពួកបរិសុទ្ធថ្លែងទីបន្ទាល់អំពីគោលការណ៍ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ*

សូមអញ្ជើញសិស្សឲ្យគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលថ្មីៗនេះ បានទទួលការហៅបម្រើបេសកកម្ម ឬបានចាកចេញទៅបេសកកម្ម ។ សូមឲ្យសិស្សប្រាប់ដល់សិស្សក្នុងថ្នាក់ពីទីកន្លែងដែលអ្នកផ្សព្វផ្សាយសាសនាទាំងឡាយត្រូវបានហៅឲ្យបម្រើ ។ សូមពិចារណាប្រើភូគោលផែនដី ឬផែនទី ដើម្បីជួយសិស្សមើលឃើញពីទីកន្លែងដែលព្រះអម្ចាស់បានហៅពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះ ។

សូមពន្យល់ថា មនុស្សម្នាក់ៗចាំបាច់ត្រូវមានឱកាសដើម្បីរៀនដំណឹងល្អ ។ សូមប្រាប់ពីចំនួនប្រជាជននៅលើផែនដីបច្ចុប្បន្ននេះ ( ប្រហែលជា ៧ កោដ ) ហើយពន្យល់ថា វានឹងមិនអាចទៅរួចទេ ដែលគណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងពួកចិតសិបនាក់ និងអស់អ្នកដែលកាន់តំណែងនានា ក្នុងការប្រកាសដំណឹងល្អដល់គ្រប់ជាតិសាសន៍ គ្រប់ទីកន្លែង និងបង្រៀនដល់មនុស្សគ្រប់គ្នាបាននោះទេ ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលទិសដៅដែលព្រះអម្ចាស់បានប្រទានដល់អ្នកទាំងឡាយដែលមានទំនួលខុសត្រូវក្នុងការផ្សាយដំណឹងល្អ ។

- ស្របតាម ខ ៦២ តើពួកអ្នកបម្រើរបស់ព្រះអម្ចាស់ត្រូវផ្សាយដំណឹងល្អនៅកន្លែងណាខ្លះ ?
- បន្ថែមពីលើពួកអ្នកដឹកនាំបព្វជិតភាព តើនរណាផ្សេងទៀតដែលមានទំនួលខុសត្រូវដើម្បីចែកចាយដំណឹងល្អនៅទូទាំងពិភពលោក ? ( សូមជួយសិស្សឲ្យយល់ថា ទោះជាការបម្រើផ្សព្វផ្សាយសាសនាពេញម៉ោងភាគច្រើនត្រូវបានធ្វើឡើងដោយយុវជន យុវនារី និងពួករៀបការក្ដី ក៏ **ពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងអស់ មានទំនួលខុសត្រូវដើម្បីពាំនាំដំណឹងល្អទៅកាន់ពិភពលោកទាំងមូលផងដែរ** )។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ស្ពែនសើរ ដបុលយូ឴ឃីមបឹល ៖



« បទគម្ពីរជាច្រើនបានថ្លែងយ៉ាងច្បាស់ថា សមាជិកនៃសាសនាចក្រគ្រប់រូប មានទំនួលខុសត្រូវដើម្បីធ្វើកិច្ចការផ្សព្វផ្សាយសាសនា ។. . .

« ពួកព្យាការីក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ក៏បានបង្រៀនយ៉ាងច្បាស់អំពីបរិបទដែលថា ការងារផ្សព្វផ្សាយសាសនាគឺជាការទទួលខុសត្រូវរបស់សមាជិកទាំងអស់ដែរ ។ ប្រធាន ដេវីឌ អូ មិកឃេ បានបង្រៀនអំពីគោលការណ៍នេះ ដោយមានប្រសាសន៍អញ្ជើញថា ‹ សមាជិកគ្រប់រូបគឺជាអ្នកផ្សព្វផ្សាយសាសនា ! › ( សូមមើល *របាយការណ៍សន្និសីទ* ខែ មេសា ឆ្នាំ ១៩៥៩ ទំព័រ ១២២ ) » « It Becometh Every Man, » *Ensign,* ខែ តុលា ឆ្នាំ ១៩៧៧,ទំព័រ ៣ ) ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីអ្វីដែលអ្នកទាំងឡាយជឿ ហើយត្រូវបានទទួលបុណ្យជ្រមុជទឹក អាចទទួលបាន ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ អំពីចម្លើយរបស់ពួកគេ ។

- ហេតុអ្វីក៏វាសំខាន់សម្រាប់មនុស្សទទួលយកដំណឹងល្អ ទទួលបុណ្យជ្រមុជទឹក និងទទួលព្រះវិញ្ញាណបរិសុទ្ធ ? ( យើងត្រូវតែទទួលបុណ្យជ្រមុជទឹក ហើយទទួលព្រះវិញ្ញាណបរិសុទ្ធដើម្បីចូលទៅក្នុងនគរនៃព្រះ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦៥–៧៣ ដោយស្ងាត់ស្ងៀម ហើយប្រាប់ពីអ្វីដែលព្រះអម្ចាស់បានសន្យាដល់អ្នកទាំងឡាយដែលជឿដល់ពួកអ្នកបម្រើទ្រង់ ហើយត្រូវបានជ្រមុជទឹក ។ សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

- ហេតុអ្វីអ្នកគិតថាអំណោយទានទាំងនេះ នឹងសំខាន់សម្រាប់អ្នកទាំងឡាយដែលផ្សាយ និងអ្នកទាំងឡាយដែលជឿដំណឹងល្អយ៉ាងដូច្នេះ ?
- តើបទបញ្ញត្តិអ្វីដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុង ខ ៧៣ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៧៤–៧៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីអ្វីដែលបានកើតឡើងដល់បុគ្គលម្នាក់ៗដែលជ្រើសរើសមិនជឿដំណឹងល្អ ហើយមិនទទួលបុណ្យជ្រមុជទឹក ។

- តើមានអ្វីកើតឡើងដល់អ្នកទាំងឡាយដែលជ្រើសរើសមិនជឿ និងមិនព្រមទទួលបុណ្យជ្រមុជទឹក ?
- ផ្អែកទៅលើអ្វីដែលអ្នកបានអានមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ តើអ្នកនឹងសង្ខេបអំពីសារៈសំខាន់នៃការបង្រៀនអ្នកដទៃអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៧៧–១២០

*ព្រះអម្ចាស់ប្រទានការណែនាំដល់អ្នកទាំងឡាយដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អរបស់ទ្រង់*

- តើមានអ្វីខ្លះដែលបណ្ដាលឲ្យមនុស្សម្នាក់ស្ទាក់ស្ទើរពុំបម្រើព្រះអម្ចាស់ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ? ( ចម្លើយអាចរួមមាន ការភ័យខ្លាចក្នុងការចាកចេញពីផ្ទះ និងគ្រួសារ ការលះបង់ពេលវេលា និងឱកាស ឧបសគ្គខាងហិរញ្ញវត្ថុ ឧបសគ្គក្នុងការនិយាយទៅកាន់មនុស្សចម្លែកអំពីដំណឹងល្អ និង បារម្ភអំពីការរៀនភាសាថ្មី ) ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៧៧–៨៨ កត់ត្រាអំពីការអះអាងរបស់ព្រះអម្ចាស់ចំពោះអ្នកផ្សព្វផ្សាយសាសនាថា ទ្រង់នឹងមើលថែតម្រូវការរបស់ពួកគេ ។ ទ្រង់ក៏បានសន្យានឹងពួកគេផងដែរនូវពរជ័យផ្សេងទៀត បើពួកគេនឹងបំពេញទំនួលខុសត្រូវរបស់ពួកគេដើម្បីផ្សាយដំណឹងល្អ ។

សូមថតចម្លង តារាងដូចខាងក្រោម នៅលើក្ដារខៀន ហើយសុំឲ្យសិស្សចម្លងវាចូលទៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

| ការបម្រើបេសកកម្ម | |
|---|---|
| ទំនួលខុសត្រូវ | ពរជ័យទាំងឡាយ |
| | |

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៨០, ៨៥, ៨៧–៨៨ ហើយរកមើលទំនួលខុសត្រូវ និងពរជ័យទាំងឡាយនៃការបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ ( អ្នកអាចនឹងចង់សរសេរសេចក្ដីយោងបទគម្ពីរនេះនៅលើក្ដារខៀន ) ។ អ្នកអាចនឹងផ្ដល់យោបល់ឲ្យសិស្សអាន ជាគូៗ ដោយសិស្សម្នាក់រកមើលទំនួលខុសត្រូវ ហើយសិស្សម្នាក់ទៀតប្រាប់អំពីពរជ័យទាំងឡាយ ។ សូមសិស្សឲ្យសរសេរអំពីការរកឃើញរបស់ពួកគេនៅក្នុងកូឡោនត្រឹមត្រូវក្នុងតារាងរបស់ពួកគេ ។

ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នករៀនបានអ្វីខ្លះ អំពីទំនួលខុសត្រូវនៃការបម្រើជាអ្នកផ្សព្វផ្សាយសាសនា ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពួកអ្នកផ្សព្វផ្សាយសាសនា « ចេញទៅស្ដីបន្ទោសមនុស្សលោក » (គ. និង ស. ៨៤:៨៧) ដោយការបង្រៀនអ្នកដទៃអំពីគោលលទ្ធិនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងដោយការអញ្ជើញពួកគេឲ្យប្រែចិត្ត ហើយរស់នៅតាមគោលលទ្ធិទាំងនោះដោយសុទ្ធចិត្ត ) ។
- តើព្រះអម្ចាស់នឹងប្រទានពរដល់យើងយ៉ាងដូចម្ដេច នៅពេលយើងចែកចាយដំណឹងល្អជាមួយអ្នកដទៃ ? ( សិស្សអាចប្រើពាក្យផ្សេង ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម ៖**ព្រះអម្ចាស់នឹងពង្រឹងយើង ហើយ**

> ***សូមធ្វើការជាដៃគូៗ***
>
> ការធ្វើការជាគូ អាចផ្ដល់ឱកាសឲ្យសិស្សដើម្បី « បង្រៀនគ្នាទៅវិញទៅមកអំពីគោលលទ្ធិនៃនគរ » (គ. និង ស. ៨៨:៧៧)។ បន្ថែមពីលើនោះ ការធ្វើការជាមួយសិស្សផ្សេងទៀត អាចបណ្ដុះទំនុកចិត្តនៅក្នុងខ្លួនរបស់សិស្សដែលមានការខ្មាស់អៀននោះ ដោយលើកទឹកចិត្តពួកគេឲ្យមានការចូលរួមកាន់តែមានអត្ថន័យ។ សូមគិតឲ្យច្បាស់លាស់អំពី សិស្សដែលអ្នកចាត់ឲ្យធ្វើការជាមួយគ្នា ព្រោះសិស្សមួយចំនួនអាចនឹងត្រូវការជំនួយការ ឬជាការខិតខំដោយអ្នកទាំងឡាយដែលពួកគេចាប់ដៃគូជាមួយនោះ ។

**គង់នៅជាមួយយើង នៅពេលយើងចែកចាយដំណឹងល្អជាមួយអ្នកដទៃ ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើការសន្យាដែលបានថ្លែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៨០, ៨៥, និង ៨៨ អាចមានឥទ្ធិពលដល់បំណងប្រាថ្នា និងលទ្ធភាពរបស់បុគ្គលម្នាក់ៗ ដើម្បីចែកចាយដំណឹងល្អយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ៖



« យើងពុំចាំបាច់ព្រួយចិត្តថា យើងនៅឯកកោ និងគ្មានក្ដីស្រឡាញ់នៅក្នុងការបម្រើរបស់ព្រះអម្ចាស់នោះទេ ពីព្រោះ យើងពុំមែនបែបនោះទេ ។ យើងអាចទទួលអារម្មណ៍ពីក្ដីស្រឡាញ់របស់ព្រះ ។ ព្រះអង្គសង្គ្រោះបានសន្យាថាពួកទេវតានឹងនៅខាងឆ្វេងយើង និងខាងស្ដាំយើងដើម្បីលើកទ្រយើងឡើង ។ ( សូមមើល គ. និង ស. ៨៤:៨៨) ។ ហើយទ្រង់តែងតែរក្សានូវព្រះបន្ទូលទ្រង់ » (Mountains to Climb » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ២៦ ) ។

ថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងពង្រឹងយើង ហើយគង់នៅជាមួយយើង នៅពេលយើងចែកចាយដំណឹងល្អជាមួយអ្នកដទៃ ។ អ្នកក៏អាចនឹងចង់ចែកចាយបទពិសោធន៍មួយចេញពីជីវិតផ្ទាល់របស់អ្នកដែលបង្ហាញពីគោលការណ៍នេះ ។

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *ខ្ញុំនឹងបំពេញទំនួលខុសត្រូវរបស់ខ្ញុំដើម្បីចែកចាយដំណឹងល្អដោយ . . .*

សូមអញ្ជើញពួកគេឲ្យបំពេញសេចក្ដីថ្លែងការណ៍នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៨៩–៩៧ ដោយការពន្យល់ថា ព្រះអម្ចាស់បញ្ជាក់ថា អ្នកទាំងឡាយដែលទទួលអ្នកផ្សព្វផ្សាយសាសនារបស់ទ្រង់ ក៏ទទួលយកទ្រង់ដែរ ហើយនឹងត្រូវបានប្រទានពរ ។ ផ្ទុយទៅវិញ អ្នកទាំងឡាយដែលបដិសេធពួកអ្នកបម្រើរបស់ព្រះ និងព្រះបន្ទូលរបស់ទ្រង់ នឹងបាត់បង់ពរជ័យ ហើយនឹងត្រូវបណ្ដាសា ។

ចូរពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៩៨–១០២ មាននូវទំនុកចម្រៀងនៃក្ដីអំណរ និងការសរសើរ ទាក់ទងនឹងការប្រោសលោះនៃស៊ីយ៉ូន ។ ឃ្លា « ការប្រោសលោះនៃស៊ីយ៉ូន » សំដៅទៅលើស្ថានភាពដែលរាស្ត្រនៃសេចក្ដីសញ្ញារបស់ព្រះនៅថ្ងៃមួយនឹងរីករាយ ដោយសារពួកគេបានជ្រើសរើសមករកទ្រង់ ហើយទទួលរាល់ពិធីបរិសុទ្ធ និងពរជ័យនៃដំណឹងល្អ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៩៨ ឲ្យឮៗ ។ សូមចង្អុលបង្ហាញថា ចម្រៀងនៃការប្រោសលោះនៃស៊ីយ៉ូន នឹងត្រូវបានច្រៀងបន្ទាប់ពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលមនុស្សទាំងអស់ដែលនៅលើផែនដីនឹងមកស្គាល់ទ្រង់ ។

សូមបង្ហាញរូបភាពនៃដៃគូអ្នកផ្សព្វផ្សាយសាសនាមួយគូ ។ ( បើអ្នកបានបម្រើជាអ្នកផ្សព្វផ្សាយសាសនា អ្នកអាចនឹងចង់បង្ហាញដល់សិស្សនូវរូបភាពមួយអំពីខ្លួនអ្នកជាមួយនឹងដៃគូ ដែលជាប្រភពនៃកម្លាំងចំពោះអ្នក ) ។

- ហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់ហៅអ្នកផ្សព្វផ្សាយសាសនាឲ្យបម្រើជាដៃគូដូច្នេះ ?
- តើការហៅមួយចំនួនទៀតនៅក្នុងសាសនាចក្រដែលយើងបម្រើជាមួយនឹងមនុស្សផ្សេងទៀតមានអ្វីខ្លះ ? ( ចម្លើយអាចរួមមាន គណៈប្រធាន ដៃគូបង្រៀនតាមផ្ទះ និងដៃគូសួរសុខទុក្ខតាមផ្ទះ និងគណៈកម្មការនានា ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១០៦ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយប្រាប់នូវអ្វីដែលព្រះអម្ចាស់បានណែនាំដល់សមាជិកសាសនាចក្រឲ្យធ្វើដើម្បីពង្រឹងដល់គ្នាទៅវិញទៅមក ។

- តើព្រះអម្ចាស់ប្រាប់ឲ្យសមាជិកសាសនាចក្រធ្វើអ្វីខ្លះ ដើម្បីពង្រឹងដល់គ្នាទៅវិញទៅមក? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **អ្នកទាំងឡាយដែលរឹងមាំនៅក្នុងព្រះវិញ្ញាណ គឺត្រូវស្ពាន់ដល់អ្នកទាំងឡាយដែលទន់ខ្សោយ** )។
- តើអ្នកគិតថា « រឹងមាំនៅក្នុងព្រះវិញ្ញាណ » វាមានន័យយ៉ាងណា ? តើនៅពេលណាដែលអ្នកត្រូវបានលើកតម្កើងតាមរយៈការធ្វើការជាមួយនរណាម្នាក់ដែលរឹងមាំនៅក្នុងព្រះវិញ្ញាណ ? ( បន្ទាប់ពីសិស្សឆ្លើយតប អ្នកអាចនឹងចង់ចែកចាយបទពិសោធន៍មួយ ។ បើអ្នកមានរូបថតខ្លួនឯង និងដៃគូផ្សព្វផ្សាយសាសនា មកដាក់តាំង នោះអ្នកអាចពន្យល់អំពីរបៀបដែលដៃគូនេះបានជួយពង្រឹងដល់អ្នក) ។

សូមឲ្យសិស្សពិចារណាអំពីស្ថានភាពខាងវិញ្ញាណបច្ចុប្បន្នរបស់ពួកគេ ។ សូមអញ្ជើញអ្នកទាំងឡាយដែលគិតថាខ្លួនឯងទន់ខ្សោយខាងវិញ្ញាណឲ្យគិតអំពីនរណាម្នាក់ ដែលពួកគេស្គាល់ ដែលរឹងមាំខាងវិញ្ញាណ ហើយស្វែងរកឱកាសដើម្បីរៀនមកពីបុគ្គលនេះ ។ សូមអញ្ជើញអ្នកទាំងឡាយដែលគិតថា ខ្លួនគេរឹងមាំខាងវិញ្ញាណឲ្យស្វែងរកវិធីដើម្បីលើកទឹកចិត្ត និងពង្រឹងដល់អ្នកដទៃ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១០៩–១១០ ដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីមួយទៀតដែលសមាជិកនៃសាសនាចក្រអាចធ្វើដើម្បីពង្រឹងដល់គ្នាទៅវិញទៅមក ។

- នៅក្នុងខគម្ពីរទាំងនេះ តើចំណែកផ្សេងៗនៃរូបកាយតំណាងឲ្យអ្វី ? ( សមាជិកទាំងឡាយនៃសាសនាចក្រ ) ។ តើនិមិត្តរូបនេះអាចបង្រៀនយើងអំពីការពង្រឹងដល់គ្នាទៅវិញទៅមកយ៉ាងណាខ្លះ ? ( យើងចាំបាច់ត្រូវចងចាំអំពីតម្លៃ និងសារៈសំខាន់នៃសមាជិកម្នាក់ៗក្នុងសាសនាចក្រ ) ។

សូមបញ្ជាក់ថា ព្រះអម្ចាស់ស្រឡាញ់យើងម្នាក់ៗ ហើយបានប្រទានដល់យើងម្នាក់ៗនូវទេពកោសល្យផ្សេងៗគ្នា ដែលយើងអាចប្រើដើម្បីបម្រើដល់អ្នកដទៃ ។

សូមពន្យល់ថា បន្ទាប់ពីការផ្ដល់ការណែនាំខ្លះៗដល់ ប៊ីស្សព នូវ៉ល ខេ វីតនី និង អ្នកកាន់បព្វជិតភាពដទៃទៀត ( សូមមើល គ. និង ស. ៨៤:១១១–១១៧) ព្រះអម្ចាស់បានធ្វើសេចក្ដីសន្យាមួយដល់ពួកអ្នកបម្រើរបស់ទ្រង់ដែលបានចេញទៅដោយសេចក្ដីជំនឿ ។ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១១៨–១១៩ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វី ដែលព្រះអម្ចាស់បានសន្យា ។

- ស្របតាមខគម្ពីរទាំងនេះ តើព្រះអម្ចាស់បានសន្យាដល់ ពួកអ្នកបម្រើស្មោះត្រង់របស់ទ្រង់ថា មើលឃើញអ្វីខ្លះ ? តើអ្នកបានមើលឃើញព្រះអម្ចាស់ប្រើព្រះចេស្ដានៃស្ថានសួគ៌នៅក្នុងជំនាន់របស់យើងយ៉ាងដូចម្ដេច ?

សូមថ្លែងទីបន្ទាល់ថា ទោះជាមនុស្សមួយចំនួនក្នុងពិភពលោក ពុំអាចមើលឃើញព្រះចេស្ដារបស់ព្រះអម្ចាស់ក្ដី ក៏ថ្ងៃមួយនឹងមកដល់ ពេលដែលមនុស្សទាំងអស់នឹងមើលឃើញទ្រង់ ហើយស្គាល់ថាទ្រង់ជានរណា ។

មេរៀនទី ៨៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦

## បុព្វកថា

នៅចុងខែ វិច្ឆិកា ឆ្នាំ ១៨៣២ ពួកបរិសុទ្ធមួយចំនួនបានផ្លាស់ទៅកាន់ទីក្រុង ស៊ីយ៉ូន ប៉ុន្តែពុំបានថ្វាយទ្រព្យសម្បត្តិរបស់ពួកគេ ដូចដែលព្រះអម្ចាស់បានបញ្ជាទេ ។ ដោយសារតែពួកគេពុំបានថ្វាយទ្រព្យសម្បត្តិរបស់ពួកគេ នោះពួកគេពុំទទួលបានមរតករបស់ពួកគេស្របតាមលំដាប់ដែលបានបង្កើតឡើងរបស់សាសនាចក្រឡើយ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងអំពីបញ្ហានេះនៅក្នុងសំបុត្រដ៏បំផុសគំនិតមួយទៅកាន់ វិលាម ដឺបុលយូ ហ្វែល្ប ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៨៣២ ។ ចំណែកនៃសំបុត្រនេះ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥ ។ ក្រោយមក នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ១៨៣២ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦ នៅពេលលោកកំពុងធ្វើចំពោះកំណែថ្មីនៃព្រះគម្ពីរប៊ីបដ៏បំផុសគំនិត ។ វិវរណៈនេះ បានផ្ដល់ឲ្យដោយពន្យល់បន្ថែមអំពីរឿងប្រៀបធៀបនៃស្រូវ និងស្រងែ និងតួនាទីរបស់បព្វជិតភាពនៅក្នុងការជួយព្រះអម្ចាស់ប្រមូលពួកសុចរិតនៅក្នុងថ្ងៃចុងក្រោយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥

*ស្មៀនរបស់ព្រះអម្ចាស់គឺត្រូវរក្សាកំណត់ត្រាមួយអំពីរាស្ដ្ររបស់ព្រះ*

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពួកគេទើបតែត្រូវបានផ្ដល់រង្វាន់តំណែងជាកីឡាករជើងចាស់នៅក្នុងក្រុមកីឡាមួយ ។ ( អ្នកអាចរៀបរាប់អំពីក្រុមកីឡាដ៏ធំបំផុតនៅក្នុងវប្បធម៌របស់អ្នក និងក្រុមដ៏មានប្រជាប្រិយមួយដែលលេងកីឡានោះ ) ។ បន្ទាប់ពីលេងបានពីរបីថ្ងៃជាមួយនឹងក្រុមនេះ ពួកគេបានសង្កេតឃើញថា សមាជិកក្រុមម្នាក់ គឺជាអ្នកលេងដ៏អត្មានិយមម្នាក់ សមាជិកក្រុមខ្លះទៀតមិនលេងតាមផ្នែករបស់គេត្រឹមត្រូវទេ ហើយអ្នកផ្សេងទៀតពុំស្ដាប់គ្រូបង្វឹកឡើយ ។

- ហេតុអ្វីក៏វាពិបាកសម្រាប់ក្រុមនេះដើម្បីយកឈ្នះ ? តើអ្វីខ្លះដែលចាំបាច់ត្រូវផ្លាស់ប្ដូរដើម្បីក្រុមនេះអាចលេងបានល្អប្រសើរជាងនេះ ?

ចូរពន្យល់ថា ស្ថានភាពស្រដៀងគ្នាមួយបានចាប់ផ្ដើមកើតមានឡើងនៅឆ្នាំ ១៨៣២ ជាការកើនចំនួនពួកបរិសុទ្ធដែលបានមកដល់រដ្ឋ មិសសួរី ។ វិវរណៈពីជំនាន់មុន បានរៀបរាប់ថា ទីក្រុងស៊ីយ៉ូន នឹងត្រូវបានសាងសង់ឡើងនៅក្នុងភូមិចាកសុន រដ្ឋ មិសសួរី ស្របតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ និងក្រោមការដឹកនាំនៃបព្វជិតភាព ។ ស្របតាមក្រឹត្យវិន័យទាំងនេះ នោះសមាជិកសាសនាចក្រពុំធ្វើដំណើរទៅស៊ីយ៉ូនឡើយ លុះត្រាតែពួកគេបានទទួលវិញ្ញាបនបត្រមួយមកពីថ្នាក់ដឹកនាំសាសនាចក្រ ។ នៅពេលពួកគេបានទៅដល់ ពួកគេត្រូវថ្វាយប្រាក់ និងទ្រព្យសម្បត្តិរបស់ពួកគេទាំងអស់ទៅសាសនាចក្រ ហើយទទួលមរតកមួយមកពីប៊ីស្សព ។ បន្ថែមពីលើនោះ ពួកគេត្រូវរក្សារាល់បទបញ្ញត្តិរបស់ព្រះ ។ ( សូមមើល គ. និង ស. ៦៤:៣៤–៣៥; ៧២:១៥–១៩, ២៤–២៦) ។

ដើម្បីជួយសិស្សយល់បរិបទនៃវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥ សូមពន្យល់ថា ពួកបរិសុទ្ធជាច្រើននៅរដ្ឋ មិសសួរី បានរស់នៅសុខដុមនឹងក្រឹត្យវិន័យដែលព្រះអម្ចាស់បានដាក់ឲ្យដើម្បីស្ថាបនាស៊ីយ៉ូនឡើង ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកសាសនាចក្រមួយចំនួនពុំគោរពតាមបញ្ជារបស់ព្រះអម្ចាស់ដើម្បីថ្វាយទ្រព្យសម្បត្តិរបស់ពួកគេទេ ហើយបានធ្វើដំណើរទៅស៊ីយ៉ូន ទាំងគ្មានវិញ្ញាបនបត្រមកពីថ្នាក់ដឹកនាំរបស់ពួកគេផង ។ ដោយសារតែការណ៍នេះ ពួកគេពុំទទួលបានមរតករបស់ពួកគេឡើយ ។

- ហេតុអ្វីក៏វាមានការលំបាកដើម្បីស្ថាបនាទីក្រុងស៊ីយ៉ូននៅក្រោមស្ថានភាពទាំងនេះ ?

សូមពន្យល់ថា នៅក្នុងចម្លើយចំពោះការលំបាកទាំងនេះនៅក្នុងរដ្ឋ មិសសួរី នោះយ៉ូសែប ស្ម៊ីធ បានផ្ញើសំបុត្រមួយច្បាប់ទៅ វិលាម ដឺបុលយូ ហ្វែល្ប ជាអ្នកដឹកនាំសាសនាចក្រម្នាក់ ដែលកំពុងរស់នៅ អ៊ិនឌីប៉ែនដែនស៍ នាគ្រានោះ ( សូមមើល សេចក្ដីណែនាំកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥) ។

សូមពន្យល់ថា សំបុត្ររបស់ព្យាការីបានផ្ដល់ការណែនាំសម្រាប់ស្មៀនរបស់ព្រះអម្ចាស់ យ៉ូហាន វីតមើរ ដែលបានរស់នៅក្នុងរដ្ឋ មិសសួរី ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់ បានណែនាំដល់ស្មៀនអំពីសាសនាចក្រ នៅរដ្ឋ មិសសួរី ឲ្យធ្វើ ។

*សូមជួយសិស្សឲ្យយល់អំពីបរិបទនៃបណ្ដុំបទគម្ពីរ*

នៅពេលសិស្សយល់អំពីបរិបទនៃអត្ថបទគម្ពីរដែលពួកគេកំពុងសិក្សា នោះពួកគេនឹងអាចយល់មាតិការបានកាន់តែល្អផងដែរ ។ បរិបទផ្ដល់នូវព័ត៌មានផ្ទៃរឿងដែលបញ្ជាក់ និងជួយឲ្យយល់កាន់តែខ្លាំងអំពីព្រឹត្តិការណ៍ គោលការណ៍ និងគោលលទ្ធិនៅក្នុងអត្ថបទគម្ពីរ ។ បរិបទអាចរួមមានសំណួរ ឬស្ថានភាព ដែលបានបំផុសនូវការបង្រៀនដាក់លាក់មួយ ព័ត៌មានអំពីអ្នកដែលកំពុងនិយាយទៅកែ និងមូលហេតុ ព្រមទាំងទីតាំងជាប្រវត្តិសាស្ត្រ ខាងវប្បធម៌ ឬខាងភូមិសាស្ត្រនៃអត្ថបទ ។

- តើស្មៀនត្រូវបានណែនាំឲ្យកត់ត្រាអ្វីខ្លះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥:៣–៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលនរណាដែលព្រះអម្ចាស់បានមានបន្ទូលថា ពុំគួរមានឈ្មោះសរសេរនៅក្នុងកំណត់ត្រានៃសាសនាចក្រឡើយ ។

- តើមនុស្សណាខ្លះដែលពុំមានឈ្មោះរបស់ពួកគេត្រូវបានសរសេរនៅក្នុងកំណត់ត្រានៃសាសនាចក្រ ?

សូមពន្យល់ថា កំណត់ត្រារបស់សាសនាចក្រត្រូវបានរក្សានៅក្នុងជំនាន់របស់យើង ក៏ដូចជានៅជំនាន់របស់ យ៉ូសែប ស៊្មីធ ផងដែរ ។ គោលបំណងមួយសម្រាប់ការណ៍នេះ គឺដើម្បីរក្សាកំណត់ត្រានៃឈ្មោះជនស្មោះត្រង់ និងដំណើររឿងនៃកិច្ចការរបស់ពួកគេផងដែរ ។

- តើរឿងមួយចំនួនដែលយើងត្រូវធ្វើដើម្បីមានឈ្មោះរបស់យើងបានកត់ត្រាជាសមាជិកស្មោះត្រង់សាសនាចក្រមានអ្វីខ្លះ ?

បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរនូវសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងរស់នៅតាមក្រឹត្យវិន័យនៃព្រះ នោះឈ្មោះរបស់យើងនឹងត្រូវបានសរសេរនៅក្នុងកំណត់ត្រានៃសាសនាចក្រ ក្នុងនាមជាសមាជិកស្មោះត្រង់** ។ សូមពន្យល់ថា សកម្មភាពទាំងឡាយរបស់ជនស្មោះត្រង់ ដែលបានកត់ត្រានៅលើផែនដី ក៏ត្រូវបានកត់ត្រានៅក្នុងស្ថានសួគ៌ ជាអ្វីដែលត្រូវបានហៅថា សៀវភៅជីវិត ( សូមមើល គ. និង ស. ១២៨:៦–៧) ។ សូមអញ្ជើញសិស្សឲ្យមើលគ្រួសៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥:៥, ៩, ១១ ហើយប្រាប់អំពីចំណងជើងផ្សេងទៀត ដែលបានប្រើដើម្បីពិពណ៌នាអំពីកំណត់ត្រាដែលត្រូវបានរក្សានៅលើផែនដីអំពីអ្នកទាំងឡាយដែលស្មោះត្រង់ ។ សូមប្រាប់ឲ្យពួកគេរៀបរាប់នូវអ្វីដែលពួកគេរកឃើញ ។

ដើម្បីជួយសិស្សមានអារម្មណ៍ដឹងអំពីសារៈសំខាន់នៃសេចក្ដីពិត ដែលអ្នកបានសរសេរនៅលើក្ដារខៀន សូមអញ្ជើញពួកគេឲ្យស្រមៃថា ពួកគេមានផែនការដើម្បីចូលរួមក្នុងព្រឹត្តការដ៏មានកិត្យានុភាពមួយ ។ សូមសួរពួកគេថា តើពួកគេនឹងមានអារម្មណ៍យ៉ាងណា បើពួកគេទៅដល់ព្រឹត្តការនោះ ប៉ុន្តែពុំត្រូវបានអនុញ្ញាតឲ្យចូលរួម ដោយសារតែឈ្មោះរបស់ពួកគេពុំមាននៅក្នុងបញ្ជីអញ្ជើញ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥:៩–១១ ដោយស្ងាត់ស្ងៀម ហើយស្រមៃអំពីតើអារម្មណ៍បែបនោះនឹងទៅជាយ៉ាងណា ដែលឃើញថាឈ្មោះរបស់ពួកគេត្រូវបានបាត់ពីសៀវភៅនៃការចងចាំរបស់ព្រះអម្ចាស់នោះ ។

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដែលអ្នកទាំងឡាយមានឈ្មោះពុំត្រូវបានកត់ត្រា « នឹងពុំទទួលមរតក » ជាមួយពួកបរិសុទ្ធនោះ ? ( ពួកគេនឹងពុំទទួលពរជ័យដែលនឹងត្រូវបានប្រទានឲ្យពួកស្មោះត្រង់នោះទេ ) ។
- ស្របតាម ខ ១១ តើអ្វីខ្លះដែលអាចបណ្ដាលឲ្យសមាជិកសាសនាចក្រត្រូវដកឈ្មោះចេញពីសៀវភៅនៃក្រឹត្យវិន័យរបស់ព្រះ ?
- តើអ្នកនឹងសង្ខេបនូវអ្វីដែលអ្នកបានរៀនអំពីសារៈសំខាន់នៃការមានឈ្មោះរបស់អ្នកបានកត់ត្រាជាសមាជិកស្មោះត្រង់នៃសាសនាចក្រយ៉ាងដូចម្ដេច ?

សូមថ្លែងទីបន្ទាល់ថា កំណត់ត្រានានាត្រូវបានរក្សាទុកទាំងនៅទីនេះលើផែនដី និងនៅស្ថានសួគ៌ ។ យើងទាំងអស់គ្នានឹងត្រូវទទួលខុសត្រូវចំពោះសកម្មភាព និងភាពស្មោះត្រង់របស់យើងក្នុងការរស់នៅតាមក្រឹត្យវិន័យនៃព្រះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអាកប្បកិរិយារបស់ពួកគេ និងការគោរពប្រតិបត្តិរបស់ពួកគេចំពោះក្រឹត្យវិន័យនៃព្រះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦

*ព្រះអម្ចាស់ពន្យល់រឿងប្រៀបធៀបអំពីស្រូវ និងស្រងែ*

មុនចាប់ផ្ដើមថ្នាក់ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ១៣:២៤–៣០ ហើយត្រៀមខ្លួនដើម្បីសង្ខេបរឿងប្រៀបធៀបអំពីស្រូវ និងស្រងែសម្រាប់សិស្សក្នុងថ្នាក់ ។ សូមសរសេរនូវពាក្យដូចខាងក្រោមនៅលើក្ដារខៀន ៖*ស្រូវ ស្រងែ វាលស្រែ អ្នកព្រោះពូជ មារសត្រូវ* ។

បន្ទាប់ពីសិស្សដែលបានជ្រើសរើសនោះ បានសង្ខេបរឿងប្រៀបធៀបរួចហើយ សូមសួរដល់សិស្សក្នុងថ្នាក់នូវសំណួរដូចខាងក្រោម ៖

- តើស្រូវ និងស្រងែជានិមិត្តរូបឲ្យអ្វីខ្លះ ? ( ស្រូវ ជានិមិត្តរូបនៃសុចរិតភាព ហើយស្រងែជានិមិត្តរូបនៃទុច្ចរិតភាព [សូមមើល ម៉ាថាយ ១៣:៣៨] ) ។
- ហេតុអ្វីក៏បុរសក្នុងរឿងប្រៀបធៀបរង់ចាំចង់ឲ្យដកស្រងែចេញ ?

សូមដាក់តាំងរូបភាពដែលមានអមជាមួយអំពីស្រូវ និងស្រងែ ឬគូររូបនៅលើក្ដារខៀន ។ សូមពន្យល់ថា ស្រងែជាប្រភេទស្មៅពុល ។ ស្រូវ និងស្រងែ គឺមើលទៅស្ទើរតែដូចគ្នានៅពេលវាដុះពន្លកចេញមក ប៉ុន្តែវាអាចមើលទៅខុសគ្នាពេលវាធំឡើង ។ បើអ្នកច្រូតកាត់ ព្យាយាមដកស្រងែចេញមុនពេលស្រូវ និងស្រងែធំ នោះហាក់ដូចជាគាត់បំផ្លាញស្រូវអស់ច្រើនផងដែរ ។




សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអានដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:១–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអត្ថន័យនៃចម្ការអ្នកព្រោះពូជ និងមារសត្រូវ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

- ដោយផ្អែកទៅលើការពន្យល់របស់ព្រះអម្ចាស់អំពីនិមិត្តរូប តើអ្នកនឹងសង្ខេបអត្ថន័យនៃរឿងប្រៀបធៀបយ៉ាងដូចម្ដេច ?

សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ បានពិនិត្យមើល ហើយបានកែសម្រួលកំណែថ្មីនៃព្រះគម្ពីរប៊ីបដ៏បំផុសគំនិត ( ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ) នៅពេលលោកបានទទួលវិវរណៈនេះ ។ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦ ពន្យល់បន្ថែមអំពីរឿងប្រៀបធៀប ដូចដែលបានកត់ត្រានៅក្នុង ម៉ាថាយ ១៣:២៤–៣០។ ឧទាហរណ៍ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦ យើងរៀនថា អ្នកព្រោះពូជនៅក្នុងរឿងប្រៀបធៀង តំណាងឲ្យពួកសាវករបស់ព្រះអម្ចាស់ ( សូមមើល ខ ២) ហើយថា ស្រងែ « ដុះគ្របពីលើស្រូវ ហើយនាំព្រះវិហារចូលក្នុងទីរហោស្ថាន » (ខ ៣) ។ យើងក៏រៀនផងដែរថា « នៅថ្ងៃចុងក្រោយ » សំណាបស្រូវថ្មី នឹងចាប់ផ្ដើម « ដុះឡើងពន្លក » (ខ ៤)។ ការព្រោះស្រងែ អាចតំណាងឲ្យការក្បត់សាសនា ហើយការដុះពន្លកស្រូវថ្មី អាចតំណាងឲ្យការស្ដារឡើងវិញ ។

សូមចង្អុលបង្ហាញថា នៅក្នុងរឿងប្រៀបធៀប លោកចៅហ្វាយណែនាំដល់ពួកអ្នកបម្រើទ្រង់ឲ្យប្រមូលស្រងែមុនគេដើម្បីដុតចោល រួចហើយទើបប្រមូលស្រូវដាក់ក្នុងជម្រុក ( សូមមើល ម៉ាថាយ ១៣:២៧–៣០) ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:៧ ដោយស្ងាត់ស្ងៀម ដើម្បីរកមើលទស្សនៈនៃវិវរណៈនេះ ផ្ដល់ឲ្យដែលបញ្ជាក់អំពីលំដាប់នៃការប្រមូលទុក ។

- តើយើងរៀនអ្វីខ្លះមកពី ខ ៧ អំពីលំដាប់នៃការប្រមូលផ្ដុំ ?

- តើរឿងនេះបង្រៀនអំពីអ្វីដែលនឹងកើតឡើងដល់ពួកសុចរិត និងពួកទុច្ចរិតនៅថ្ងៃចុងក្រោយអ្វីខ្លះ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអម្ចាស់នឹងប្រមូលពួកសុចរិតអំឡុងថ្ងៃចុងក្រោយ រួចហើយបំផ្លាញពួកទុច្ចរិតនៅក្នុងការយាងមកជាលើកទីពីររបស់ទ្រង់** )។

សូមដាក់តាំងរូបពួកអ្នកផ្សព្វផ្សាយសាសនា ៖ ពួកអែលឌើរនិងអ្នកផ្សព្វផ្សាយសាសនា ៖ ពួកស៊ីស្ទើរ *សៀវភៅរូបភាពដំណឹងល្អ* ឆ្នាំ ២០០៩| លេខ





- តើរូបភាពទាំងនេះទាក់ទងទៅនឹងរឿងប្រៀបធៀបអំពីស្រូវ និងស្រងែយ៉ាងដូចម្ដេច ? ( សូមជួយសិស្សឲ្យមើលឃើញថា យើងអាចជួយនៅក្នុងការប្រមូលពួកសុចរិត ដោយការចែកចាយដំណឹងល្អជាមួយអ្នកដទៃ ) ។

សូមពន្យល់ថា ការចងចាំវិធីជាច្រើន ដែលយើងត្រូវបានប្រទានពរក្នុងនាមជាសមាជិកនៃសាសនាចក្ររបស់ព្រះអម្ចាស់ អាចបង្កើនបំណងប្រាថ្នារបស់យើងដើម្បីចែកចាយពរជ័យទាំងនោះជាមួយអ្នកដទៃ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:៨–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវវិធីដែលយើងត្រូវបានប្រទានពរក្នុងនាមជាសមាជិកនៃសាសនាចក្ររបស់ព្រះអម្ចាស់ ។

- ស្របតាម ខ ៨–១០ តើវិធីមួយចំនួនដែលយើងត្រូវបានប្រទានពរ ក្នុងនាមជាសមាជិកនៃសាសនាចក្ររបស់ព្រះអម្ចាស់មានអ្វីខ្លះ ?

សូមចង្អុលបង្ហាញនូវឃ្លា « អ្នកគឺជាអ្នកគ្រងមរតកស្របច្បាប់ » នៅក្នុង ខ ៩។ សូមពន្យល់ថា នេះ មានន័យថា សមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺមានចំណែកនៃសេចក្ដីសញ្ញារបស់ព្រះ បានធ្វើជាមួយនឹងអ័ប្រាហាំ ដែលអ័ប្រាហាំ ត្រូវបានសន្យាថា កូនចៅរបស់លោក នឹងរីករាយនឹងពរជ័យនៃបព្វជិតភាព ហើយនឹងចែករំលែកពរជ័យទាំងនោះជាមួយអ្នកដទៃ ( សូមមើល អ័ប្រាហាំ ២:៩–១១) ។

- តើអ្នកបានទទួលពរជ័យ តាមរយៈបព្វជិតភាពយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:១១ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ ប្រាប់អំពីវិធីដែលយើងត្រូវជួយដល់អ្នកដទៃ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **យើងអាចនាំសេចក្ដីសង្គ្រោះដល់អ្នកដទៃដោយការជួយពួកគេឲ្យទទួលពរជ័យនៃបព្វជិតភាព ។**

សូមអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ដែលពួកគេមាន នៅពេលពួកគេអាចធ្វើគំរូសុចរិតសម្រាប់មនុស្សម្នាក់ទៀត ឬនៅពេលពួកគេជួយមនុស្សដទៃឲ្យទទួលបាននូវពរជ័យនៃបព្វជិតភាព ។

មេរៀនទី ៩០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧

## បុព្វកថា

នៅពេញ ឆ្នាំ ១៨៣២ ព្យាការីយ៉ូសែប ស៊្មីធ និងសមាជិកសាសនាចក្រដទៃទៀត ទំនងជាបានរៀនតាមរយៈរបាយការណ៍កាសែតអំពីការរងទុក្ខដែលកំពុងតែបោសសម្អាតផែនដី ។ ឧទាហរណ៍ ពួកលោកបានដឹងអំពីជម្លោះ នៃភាពជាទេសករនៅក្នុងសហរដ្ឋ ហើយពួកលោកក៏បានដឹងអំពីបញ្ហាទាស់នឹងពន្ធសហព័ន្ធនៅក្នុង រដ្ឋសៅខារូឡាញណា ។ ព្យាការីបានថ្លែងថា « រូបរាងនៃបញ្ហាទាំងឡាយនៅក្នុងចំណោមជាតិសាសន៍នានា កាន់តែបង្ហាញរូបរាងច្បាស់នៅជំនាន់នេះ ជាងនៅជំនាន់មុន ដែលពីដំបូងសាសនាចក្រចេញពីទីរហោស្ថាន » (*Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ២៤៩) ។ នៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៨៣២ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈ ដែលឥឡូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ដែលរួមមានទាំងការព្យាករណ៍អំពីសង្គ្រាម និងការជំនុំជម្រះ ដែលនឹងចាក់ស្រោចមកលើគ្រប់ជាតិសាសន៍នៅថ្ងៃចុងក្រោយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១–៨

*តាមរយៈយ៉ូសែប ស៊្មីធ ព្រះអម្ចាស់បានព្យាករថា សង្គ្រាមនឹងចាក់ស្រោចមកលើគ្រប់ជាតិសាសន៍ទាំងអស់*

សូមចាប់ផ្ដើមបង្រៀនដោយការសួរសំណួរខាងក្រោមនេះ ៖

- តើទំនាយ ខុសគ្នាជាមួយនិងការព្យាករ ដូចម្ដេច ? ( ទំនាយគឺជាគំនិតមួយអំពីអ្វីដែលអាចនឹងកើតមានឡើងនាពេលអនាគត ។ ផ្ទុយទៅវិញ ការព្យាករណ៍ គឺជាការប្រកាសអំពីទីសម្គាល់ ឬព្រឹត្តការណ៍មួយក្នុងពេលអនាគតដូចដែលបានបើកសម្ដែងដោយព្រះវិញ្ញាណបរិសុទ្ធ ) ។

សូមសរសេរឈ្មោះដូចខាងក្រោមនៅលើក្ដារខៀន ៖*ណូអេ, យ៉ូសែប នៃស្រុកអេស៊ីព្ទ, លីហៃ និងសាំយ៉ូអែលសាសន៍លេមិន ។* ( អ្នកក៏អាចចង់ដាក់តាំងរូបភាពនៃពួកព្យាការីទាំងនេះផងដែរ ) ។ សូមអញ្ជើញសិស្សឲ្យថ្លែងនូវពាក្យព្យាករដោយពួកព្យាការីបុរាណម្នាក់ៗទាំងនេះ ។ ( ចម្លើយអាចរួមមានដូចខាងក្រោម ៖ ណូអេ បានព្យាករអំពីទឹកជំនន់, យ៉ូសែបនៃស្រុកអេស៊ីព្ទ បានព្យាករថា នឹងមានរយៈពេលប្រាំពីរឆ្នាំសម្បូរសប្បាយ ហើយបន្ទាប់មកនឹងមានគ្រោះទុរភិក្សរយៈពេលប្រាំពីរឆ្នាំ, លីហៃបានព្យាករថា យេរូសាឡិមនឹងត្រូវបំផ្លាញ ហើយ សាំយូអែលជាសាសន៍លេមិន បានព្យាករអំពីទីសម្គាល់ និងព្រឹត្តការណ៍ទាំងឡាយដែលនឹងកើតមានជាមួយនឹងការប្រសូត្រ និងការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ) ។

បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរពាក្យ *យ៉ូសែប ស៊្មីធ* នៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១–៤ ដោយស្ងាត់ស្ងៀម ហើយរកមើលការព្យាករណ៍មួយ ដែលបានបើកសម្ដែងដល់ យ៉ូសែប ស៊្មីធ ។

- តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ ថានឹង « កើតឡើងនៅពេលឆាប់ៗ » ? ( សង្គ្រាម នឹងកើតឡើងនៅពេលឆាប់ៗ ដោយចាប់ផ្ដើមជាមួយនឹងការបះបោរនៅរដ្ឋ សៅខារូឡាញណា ដែលនឹងនាំឲ្យមានការស្លាប់ និងទុក្ខវេទនាដល់ព្រលឹងជាច្រើន ) ។
- តើយើងរៀនអ្វីខ្លះអំពីព្រះអម្ចាស់ចេញមកពី ខ ១–៤ ? ( បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖**ព្រះអម្ចាស់អាចបើកសម្ដែងអំពីអនាគតកាលដល់យើង តាមរយៈពួកព្យាការីរបស់ទ្រង់** ) ។
- តើការដឹងថា ព្រះអម្ចាស់បើកសម្ដែងអនាគតកាលតាមរយៈពួកព្យាការីជាពរជ័យមួយចំពោះសាសនាចក្រយ៉ាងដូចម្ដេច ? តើការណ៍នេះអាចជាពរជ័យមួយដល់អ្នក និងគ្រួសារអ្នកយ៉ាងដូចម្ដេច ?

**សហរដ្ឋអាមេរិកនៅក្នុង ១៨៤៧**




សូមសុំសិស្សឲ្យស្រាវជ្រាវនៅក្នុងសេចក្ដីណែនាំកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ រកមើលកាលបរិច្ឆេទដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ។ បន្ទាប់មកសូមសង្ខេបកថាកណ្ឌដូចខាងក្រោម ឬអញ្ជើញសិស្សម្នាក់ឲ្យអានវាឲ្យឮៗ ៖

យ៉ូសែប ស្ម៊ីធ បានដឹងអំពីជម្លោះខាងនយោបាយរវាងរដ្ឋ ខារ៉ូឡាញណា និងរដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិកអំពីពន្ធនាំចូល ។ ( តម្លៃគយ គឺជាពន្ធនៃការនាំចូល ) ។ ដោយសារតែប្រជាជននៃរដ្ឋ សៅខារ៉ូឡាញណា ពឹងផ្អែកទៅលើផលិតផលនាំចូល ច្រើនជាងប្រជាជននៅរដ្ឋភាគខាងជើង នោះពួកគេគិតថា តម្លៃគយរបស់រដ្ឋពុំត្រឹមត្រូវ ហើយថាពួកគេត្រូវបានប្រមូលដោយចេតនា លើវាល់ការចំណាយនៃភាគខាងត្បូង ។ ថ្នាក់ដឹកនាំរដ្ឋាភិបាលនៅរដ្ឋ សៅខារ៉ូឡាញណា បានបង្កើតច្បាប់មួយដែលមិនអាចទទួលយកបាន ឬ ទុកជាមោឃៈ ដែលជាច្បាប់រដ្ឋ ហើយប្រជាជនរដ្ឋ សៅខារ៉ូឡាញណា ជាច្រើន បានចាប់ផ្ដើមត្រៀមខ្លួនធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាល ។ ប្រធានាធិបតីនៃសហរដ្ឋ បានពោលអះអាងថា គាត់នឹងរក្សាច្បាប់នៃសហរដ្ឋ ដោយកងកម្លាំង ។ ក្នុងខែ ធ្នូ ឆ្នាំ ១៨៣២ សារព័ត៌មានពាសពេញសហរដ្ឋ បានចុះផ្សាយអំពីទំនាស់នេះ ។ គឺនៅពេលនេះហើយ ដែល យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ដែលបានព្យាករថា « សង្គ្រាមទាំងឡាយ. . . នឹងកើតឡើងនៅពេលឆាប់ៗដូច្នេះថា គឺចាប់ផ្ដើមនឹងការបះបោរពីរដ្ឋ សៅខារ៉ូឡាញណា » ( គ. និង ស. ៨៧:១ ) ។ នៅដើមឆ្នាំ ១៨៣៣ មិនយូរប៉ុន្មានបន្ទាប់ពីការព្យាការណ៍នេះ ត្រូវបានផ្ដល់ឲ្យ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានដោះស្រាយបញ្ហាជាមួយនឹងរដ្ឋសៅខារ៉ូឡាញណា ដោយសន្តិភាព ។ មនុស្សមួយចំនួនបានជឿថា វិបត្តិបានកន្លងផុតទៅហើយ ប៉ុន្តែវាគ្រាន់តែឈប់បណ្ដោះអាសន្នប៉ុណ្ណោះ ហើយរដ្ឋសៅខារ៉ូឡាញណា នឹងនៅតែបះបោរ ។

- តើអ្នកនឹងឆ្លើយតបយ៉ាងដូចម្ដេច បើពាក្យសម្ដីរបស់ព្យាករី ពុំត្រូវបានបំពេញតាមរបៀបដែលអ្នករំពឹងទុក ?

### *ការប្រើបទគម្ពីរយោង*

បទគម្ពីរយោង គឺជាសេចក្ដីយោងបទគម្ពីរមួយ ដែលអាចផ្ដល់ព័ត៌មានបន្ថែម និងផ្ដល់ការយល់ដឹងទៅលើវគ្គព្រះគម្ពីរដែលបានសិក្សានោះ ។ បទគម្ពីរយោង មានន័យថា ជាការទំនាក់ទំនងសេចក្ដីយោងបទគម្ពីរដែលជួយពន្យល់អំពីគោលលទ្ធិ និងគោលការណ៍មួយ ឬជាតុផ្សេងៗមួយចំនួនអំពីវគ្គបទគម្ពីរ ។ អ្នកអាចរកបទគម្ពីរយោងនៅលេខយោង និងជំនួយការសិក្សាផ្សេងទៀត នៅក្នុងសៀវភៅគ្រូបង្រៀន និង សៀវភៅសិស្ស ព្រមទាំងនៅក្នុងប្រសាសន៍នៃសន្និសីទទូទៅ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលបទគម្ពីរយោងដែលទាក់ទងនៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ ។

សូមចង្អុលបង្ហាញថាបទគម្ពីរយោងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១ លេខយោង *គ* ។ អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យគូសចំណាំលេខយោងនេះ ។ សូមឲ្យសិស្សបើកទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–១៣ ហើយសុំឲ្យសិស្សម្នាក់អានខគម្ពីរទាំងនេះឲ្យឮៗ ។

- តើ យ៉ូសែប ស្ម៊ីធ បានបញ្ជាក់ឡើងវិញនៅក្នុងការព្យាករណ៍នេះអំពីអ្វីខ្លះ? ( ថាសង្គ្រាមនឹងកើតឡើងនៅក្នុងរដ្ឋ សៅខារ៉ូឡាញណា ) ។

សូមអញ្ជើញសិស្សឲ្យយោងទៅលើសេចក្ដីណែនាំកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ ហើយប្រាប់អំពីឆ្នាំ ដែល យ៉ូសែប ស្ម៊ីធ បានផ្ដល់នូវការប្រកាសជាថ្មីអំពីការព្យាករណ៍នេះនៅក្នុង កណ្ឌ ៨៧។

- តើឆ្នាំណា ដែល យ៉ូសែប ស្ម៊ីធ បានប្រកាសឡើងវិញអំពីការព្យាករណ៍នៅក្នុងកណ្ឌទី ៨៧ ? ( ឆ្នាំ ១៨៤៣ ) ។

សូមរំឭកសិស្សថា វិបត្តិរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និង រដ្ឋ សៅខារ៉ូឡាញណា ត្រូវបានដោះស្រាយតាំងពី ១០ ឆ្នាំ មុនមកម្ល៉េះ នៅក្នុងឆ្នាំ ១៨៣៣ ។

- តើការប្រកាសឡើងវិញអំពីការព្យាករណ៍របស់ យ៉ូសែប ស្ម៊ីធ ដែលលោកបានទទួល ១០ ឆ្នាំមុន អាចបង្រៀនអ្នកអំពីសេចក្ដីជំនឿរបស់លោកអ្វីខ្លះ ? ( ទោះជាប្រជាជនមួយចំនួនបានអះអាងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីក្លែងក្លាយក្ដី តែលោកបានបន្តរក្សាសេចក្ដីជំនឿទៅលើការព្យាករណ៍ ដែលព្រះអម្ចាស់បានបើកសម្ដែងតាមរយៈលោក ) ។

បន្ទាប់មកសូមអានកថាខណ្ឌដូចខាងក្រោម ឬសុំសិស្សម្នាក់ឲ្យអានវាឲ្យឮៗ ។ ( អ្នកអាចនឹងចង់ថតចម្លងវាសម្រាប់សិស្សដើម្បីដាក់ក្នុងគម្ពីររបស់ពួកគេ ) ។

នៅឆ្នាំ ១៨៦១ សង្គ្រាមប៉ែកខាងត្បូងបានចាប់ផ្ដើមផ្ទុះឡើងទៅលើកងទ័ពសហព័ន្ធសហរដ្ឋអាមេរិក ដែលបោះទីតាំងនៅហ្វត សាំតើរ នៅ សាឡេស្តុន ហាប៊ើរ រដ្ឋ សៅខារូឡាញណា ។ នៅរដ្ឋប៉ែកខាងត្បូងផ្សេងទៀត បានចូលរួមនឹងរដ្ឋ សៅខារូឡាញណា ក្នុងសង្គ្រាមស៊ីវិលទាស់នឹងរដ្ឋប៉ែកខាងជើង ។ ពេលនោះ រដ្ឋប៉ែកខាងត្បូងបានសុំជំនួយពីអាណាចក្រអង់គ្លេស ។ បន្ថែមពីលើនោះ មានមនុស្សជាច្រើនដែលត្រូវបានចាប់ជាឈ្លើយនៅប៉ែកខាងត្បូង បានចូលកងទ័ពនៅខាងជើង ហើយបានវាយទាស់នឹងចៅហ្វាយដើមរបស់ពួកគេ ។ សង្គ្រាមស៊ីវិលរបស់អាមេរិក បានមានរយៈពេលយូរអង្វែង រហូតដល់ឆ្នាំ ១៨៦៥ ហើយជាលទ្ធផល គឺមានទាហានស្លាប់ប្រហែលជា ៦២០ ០០០ លាននាក់ ( អ្នកប្រវត្តិសាស្ត្រមួយចំនួនបានប៉ាន់ស្មានថា មានច្រើនដល់ទៅ ៧៥០ ០០០ លាននាក់ ) ។

- តើការបំពេញនូវការព្យាករណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ អាចបង្រៀនយើងអំពី យ៉ូសែប ស្ម៊ីធ អ្វីខ្លះ ? ( ចម្លើយអាចរួមមានថា ការព្យាកររបស់ យ៉ូសែប ស្ម៊ីធ គឺពិត ហើយថា លោកគឺជាព្យាការីម្នាក់របស់ព្រះ ) ។ បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន **៖យ៉ូសែប ស្ម៊ីធ គឺជាព្យាការីពិតរបស់ព្រះ ) ។**

អ្នកអាចនឹងចង់ថ្លែងទីបន្ទាល់ថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីពិត ។ បន្ទាប់មកសូមពន្យល់ថា បន្ថែមពីលើព្រឹត្តការណ៍ទាំងឡាយដែលបានបើកសម្ដែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១–៤ ព្រះអម្ចាស់បានព្យាករណ៍តាមរយៈ យ៉ូសែប ស្ម៊ីធ អំពីរឿងផ្សេងៗដែលនឹងកើតឡើង ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:៦–៧ ដោយខ្លួនគេ ហើយប្រាប់អំពីព្រឹត្តការណ៍ផ្សេងទៀតដែលព្រះអម្ចាស់បានមានបន្ទូលថា នឹងកើតឡើងនៅក្នុងថ្ងៃចុងក្រោយ ។

- តើព្រឹត្តការណ៍អ្វីខ្លះ ដែលព្រះអម្ចាស់បានមានបន្ទូលថា នឹងកើតមានឡើងនៅក្នុងថ្ងៃចុងក្រោយ ?

- ស្របតាម ខ ៦ និង ៧ តើមូលហេតុមួយចំនួនដែលរឿងទាំងនេះនឹងកើតឡើងគឺជាអ្វី ?

សូមជួយសិស្សឲ្យយល់ថា « ការវាយផ្ចាល ដោយព្រះហស្ត» របស់ព្រះ សំដៅទៅលើភាពពិតដែលថា ព្រះអម្ចាស់បានប្រើការជំនុំជម្រះរបស់ទ្រង់ ដើម្បីបំផុសឲ្យកូនចៅរបស់ទ្រង់បានប្រែចិត្តពីអំពើបាបរបស់ពួកគេ ( សូមមើល ហេលេមិន ១២:៣) ។ បន្ថែមពីលើនោះ ការជំនុំជម្រះមួយចំនួនដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ នឹងកើតមានឡើង នៅពេលព្រះអម្ចាស់ដាក់ទោសដល់ពួកទុច្ចរិត ចំពោះការប្រព្រឹត្តអយុត្តិធម៌របស់ពួកគេដល់ពួកសុចរិត ។

សូមបញ្ជាក់ថា គ្រប់ការណ៍ព្យាករ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ត្រូវបាន ឬនឹងត្រូវបានបំពេញ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:៨ ដើម្បីរៀនអំពីអ្វីដែលព្រះបានដឹកនាំយើងឲ្យធ្វើដូច្នោះ ដែលយើងនឹងបានត្រៀមខ្លួនសម្រាប់សង្គ្រាម និងគ្រោះមហន្តរាយ ដែលនឹងកើតមានចំពោះផែនដីនៅថ្ងៃចុងក្រោយ ។

- តើព្រះអម្ចាស់បានបញ្ជាយើងឲ្យធ្វើអ្វីខ្លះ ? ( សិស្សគប្បីប្រាប់នូវគោលការណ៍ដូចខាងក្រោម **៖យើងត្រូវឈរនៅទីបរិសុទ្ធ ហើយកុំមិនឡើយ រហូតដល់ព្រះអម្ចាស់យាងមក ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើទីបរិសុទ្ធមួយចំនួនណាខ្លះ ដែលអាចផ្ដល់សេចក្ដីសុខសាន្ត និងសុវត្ថិភាពដល់យើងនោះ ? ( អ្នកអាចនឹងចង់ឲ្យសិស្សសរសេរចម្លើយរបស់ពួកគេនៅលើក្ដាខៀន ។ ចម្លើយអាចរួមមាន គេហដ្ឋាន, ព្រះវិហារ, ព្រះវិហារបរិសុទ្ធ និងថ្នាក់សិក្ខាសាលា ) ។

សូមចង្អុលបង្ហាញថា ទីបរិសុទ្ធទាំងឡាយ គឺជាទីតាំងទាំងឡាយដែលយើងអាចដឹងពីវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលជួយយើងខិតទៅកាន់តែជិតនឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយរៀនអំពីទ្រង់ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីឈរនៅទីបរិសុទ្ធ និង « កុំរើឡើយ » នោះ (គ. និង ស. ៨៧:៨) ?

- តើមនុស្សម្នាក់អាចនឹងរើចេញពីទីបរិសុទ្ធទាំងនេះបានយ៉ាងដូចម្ដេច ?

- តើអ្នកមានអារម្មណ៍ថា ត្រូវបានប្រទានពរនូវសេចក្ដីសុខសាន្ត និងសុវត្ថិភាពដោយការឈរនៅទីបរិសុទ្ធមួយនៃទីបរិសុទ្ធទាំងនេះ យ៉ាងដូចម្ដេច ?

សូមពន្យល់ថា បន្ថែមពីលើទីតាំងខាងរូបកាយ ដែលបរិសុទ្ធ « ទីបរិសុទ្ធទាំងឡាយ » អាចមានទាក់ទងទៅនឹង *របៀប* ដែលយើងរស់នៅ ច្រើនជាង *ទីកន្លែង* ដែលយើងរស់នៅ ។ បើយើងរស់នៅសក្ដិសមមានព្រះវិញ្ញាណបរិសុទ្ធជាដៃគូជាប្រចាំ នោះមានន័យថា យើងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយហើយ ។ សូមលើកទឹកចិត្តដល់សិស្សឲ្យធ្វើឲ្យដួងចិត្តរបស់ពួកគេក្លាយជាទីបរិសុទ្ធ ដែលពេញដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ នៅពេលពួកគេអញ្ជើញព្រះវិញ្ញាណចូលមកក្នុងជីវិតរស់នៅរបស់ពួកគេ នោះពួកគេអាចអនុញ្ញាតឲ្យទ្រង់មានឥទ្ធិពលលើគេហដ្ឋានរបស់ពួកគេ ហើយធ្វើឲ្យពួកគេក្លាយជាទីបរិសុទ្ធ ។

- តើអ្នកអាចព្យាយាមដើម្បីធ្វើឲ្យដួងចិត្តរបស់អ្នកក្លាយជាទីបរិសុទ្ធយ៉ាងដូចម្ដេច ?
- តើវិធីមួយចំនួនដែលអ្នកអាចជួយធ្វើឲ្យគេហដ្ឋានរបស់អ្នកក្លាយជាទីបរិសុទ្ធមានអ្វីខ្លះ ? ( ចម្លើយអាចរួមមាន ការគាំទ្រដល់ការអធិស្ឋានជាគ្រួសារ និងការសិក្សាព្រះគម្ពីរ និងការមានសណ្ដានចិត្តល្អនឹងសមាជិកគ្រួសារទាំងឡាយ ) ។
- បើព្យាការីទៅមើលបន្ទប់របស់អ្នក តើលោកនឹងមើលឃើញវាជាទីបរិសុទ្ធមួយដែរឬទេ ? ចុះអ្នកវិញ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវអ្វីមួយដែលពួកគេនឹងធ្វើដើម្បីឈរនៅក្នុងទីបរិសុទ្ធកាន់តែស្មោះត្រង់ ហើយកុំរើចេញពីទីនោះ ។ បន្ទាប់ពីសិស្សបានបញ្ចប់ការសរសេរហើយ អ្នកអាចនឹងចង់សុំពួកគេមួយចំនួនឲ្យចែកចាយគោលដៅរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ សូមលើកទឹកចិត្តដល់សិស្សទាំងអស់ឲ្យធ្វើតាមគោលដៅដែលពួកគេបានដាក់នោះ ។ បន្ទាប់មកអ្នកអាចនឹងចង់បញ្ចប់មេរៀនដោយការថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤–៨៧ ( មេរៀនទី ១៨ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤–៨៧ ( មេរៀនទី ១៨ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤២)

សិស្សបានសិក្សាពីវិវរណៈមួយអំពីព្រះវិហារបរិសុទ្ធ ដែលត្រូវបានសាងសង់ឡើងនៅក្នុងទីក្រុងយេរ៉ូសាឡិមថ្មី ហើយពួកគេក៏បានអានផងដែរអំពីកិច្ចខិតខំរបស់ម៉ូសេ ដើម្បីរៀបចំប្រជាជនរបស់លោកឲ្យចូលទៅក្នុងវត្តមានរបស់ព្រះ ។ សិស្សបានរៀនគោលការណ៍ខាងក្រោម ៖ ដើម្បីប្រែក្លាយដូចជាព្រះ ហើយរស់នៅក្នុងវត្តមានរបស់ទ្រង់បាន នោះយើងត្រូវតែទទួលពិធីបរិសុទ្ធនានានៃបព្វជិតភាពមិលគីស្សាដែក ហើយប្រសិនបើអស់អ្នកដែលបានទទួលបព្វជិតភាពតម្កើងការហៅបម្រើរបស់ខ្លួន នោះព្រះនឹងញែកពួកគេចេញឲ្យបានបរិសុទ្ធ ហើយប្រទានដល់ពួកគេនូវអ្វីៗទាំងអស់ដែលទ្រង់មាន ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–១២០)

នៅក្នុងមេរៀននេះសិស្សបានរៀនអំពីគោលការណ៍ពីរ ដែលអាចជួយពួកគេឲ្យត្រឡប់ទៅក្នុងវត្តមានរបស់ព្រះវិញ៖ ប្រសិនបើយើងព្យាយាមស្ដាប់តាមព្រះបន្ទូលរបស់ព្រះ នោះយើងនឹងត្រូវបានបំភ្លឺដោយព្រះវិញ្ញាណនៃព្រះគ្រីស្ទ ហើយប្រសិនបើយើងស្ដាប់តាមព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងអាចទៅកាន់ព្រះវរបិតា ។ សិស្សក៏បានរៀនផងដែរថាដួងចិត្តរបស់យើងនឹងត្រូវក្លាយជាងងឹត ហើយយើងនឹងត្រូវបានដាក់នៅក្នុងក្រោមការកាត់ទោស ប្រសិនបើយើងចាត់ទុកព្រះបន្ទូលនៃព្រះគ្មានប្រយោជន៍នោះ ។ ព្រះឱវាទឲ្យសិក្សាព្រះគម្ពីរដោយស្មោះត្រង់ ហើយរស់នៅតាមអ្វីដែលពួកគេរៀនក៏ត្រូវបានបញ្ជាក់ម្ដងទៀតនៅក្នុងមេរៀននេះ ។ លើសពីនោះទៀត សិស្សបានរៀនថាពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូបមានទំនួលខុសត្រូវ ដើម្បីធ្វើនូវចំណែករបស់ខ្លួន ក្នុងការជួយឲ្យដំណឹងល្អឆ្ពោះទៅកាន់ពិភពលោកទាំងមូល ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦)

នៅក្នុងមេរៀននេះសិស្សបានពិចារណាអំពីសារៈសំខាន់នៃកំណត់ត្រារបស់សាសនាចក្រ ។ ពួកគេបានរៀនថា ប្រសិនបើយើងរស់នៅតាមក្រឹត្យវិន័យនៃព្រះ នោះឈ្មោះរបស់យើងនឹងត្រូវបានសរសេរនៅក្នុងកំណត់ត្រានៃសាសនាចក្រក្នុងនាមជាសមាជិកស្មោះត្រង់ ។ សិស្សក៏ទទួលបាននូវការយល់ដឹងបន្ថែមទៀតផងដែរនៅក្នុងការប្រៀបធៀបរវាងស្រូវសាលី និង ដើមស្រងែ ព្រមទាំងបានឃើញថាព្រះអម្ចាស់នឹងប្រមូលពួកសុចរិតអំឡុងពេលថ្ងៃចុងក្រោយ ហើយបំផ្លាញពួកទុច្ចរិតនៅក្នុងការយាងមកជាលើកទីពីររបស់ទ្រង់ ។ ក្រៅពីនោះសិស្សបានរៀនថា យើងអាចនាំសេចក្ដីសង្គ្រោះដល់អ្នកដទៃដោយការជួយពួកគេឲ្យទទួលពរជ័យនៃដំណឹងល្អ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧)

សិស្សបានសិក្សាការព្យាកររបស់ព្យាការីយ៉ូសែប ស្ម៊ីធទាក់ទងនឹងសង្គ្រាមនៅក្នុងថ្ងៃចុងក្រោយ ហើយបានរៀនថា ព្រះអម្ចាស់អាចបើកសម្ដែងអំពីអនាគតកាលដល់យើង តាមរយៈពួកព្យាការីរបស់ទ្រង់ ។ សិស្សក៏បានរៀនផងដែរថា ព្រះបន្ទូលរបស់ព្រះអម្ចាស់តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ត្រូវបានបំពេញ និង អំពីរបៀបដែលព្រះបន្ទូលទាំងនោះត្រូវបានបំពេញ ។ ពួកគេក៏គិតផងដែរពីសារៈសំខាន់នៃការឈរនៅទីបរិសុទ្ធនានា ហើយកុំរើឡើយរហូតដល់ព្រះអម្ចាស់យាងមក ។

## សេចក្ដីផ្ដើម

មេរៀននេះនឹងជួយសិស្សឲ្យយល់ និង ពន្យល់កាន់តែច្រើនអំពីគោលលទ្ធិនៃបព្វជិតភាព ។ មេរៀននេះក៏ផ្ដល់ឱកាសឲ្យសិស្សចែកចាយនូវអ្វីដែលពួកគេបានរៀននៅសប្ដាហ៍នេះ ពីការសិក្សារបស់ពួកគេស្ដីពីរបៀបដែលពួកយើងអាចធ្វើកាន់តែប្រសើរឡើង ក្នុងនាមឧបករណ៍នៃព្រះ ហើយតម្កើងបព្វជិតភាពរបស់យើង ។

## យោបល់សម្រាប់ការបង្រៀន

*កំណត់ចំណាំ* ៖ នៅក្នុងការរៀបចំសម្រាប់មេរៀននេះ សូមអញ្ជើញសិស្សម្នាក់ឲ្យយកក្រដាសតំណនៃសិទ្ធិអំណាចបព្វជិតភាពមកកាន់ថ្នាក់រៀន ( ជារបស់សមាជិកគ្រួសារ ឬ ប្រហែលជារបស់ផ្ទាល់ខ្លួនពួកគេ ) ។ ក្រដាសក្រដាសតំណនៃសិទ្ធិអំណាចបព្វជិតភាពផ្ទាល់ខ្លួនរបស់សមាជិកម្នាក់ អាចទទួលបានពីកំណត់ត្រាសមាជិក និង ស្ថិតិនៃសាសនាចក្រដោយអ៊ីម៉ែលស្នើសុំទៅ lineofauthority@ldschurch.org ជាមួយ PLA នៅក្នុងបន្ទាត់នៃប្រធានបទ ។ សារឆ្លើយតបដោយស្វ័យប្រវត្តិមួយនឹងផ្ញើទម្រង់បែបបទមួយដើម្បីបំពេញ ហើយបញ្ជូនត្រឡប់ទៅវិញ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤

*ព្រះអម្ចាស់ស្គាល់តំណបព្វជិតភាពរបស់ម៉ូសេ*

សូមជួយសិស្សឲ្យរំឭកពីសារពន្ធសព្ទមួយចំនួនដែលពួកគេបានរៀននៅសប្ដាហ៍នេះ ដោយចែកសិស្សជាគូៗ ។ ក្នុងដៃគូនិមួយៗ សូមឲ្យសិស្សម្នាក់បែរចេញពីក្ដារខៀន ដើម្បីគាត់ពុំអាចឃើញវាឡើយ ។ សូមពន្យល់ថាអ្នកនឹងសរសេរពាក្យគន្លឹះ ឬ ឃ្លាមួយនៅលើក្ដារខៀនទាក់ទងនឹងគោលលទ្ធិគ្រឹះនៃដំណឹងល្អ ។ សិស្សដែលកំពុងមើលទៅក្ដារខៀននឹងផ្ដល់និយមន័យ ឬ ពិពណ៌នាពាក្យគន្លឹះ ឬ ឃ្លានោះស្ទាត់ៗដល់ដៃគូរបស់ខ្លួន ហើយដៃគូរបស់គាត់នឹងទាយពីពាក្យ ឬ ឃ្លានោះ ។ ក្រោយមកសិស្សនឹងផ្លាស់ប្ដូរតួនាទីគ្នា ហើយអ្នកអាចបន្តសកម្មភាពនេះដោយសរសេរពាក្យ ឬ ឃ្លាថ្មីមួយនៅលើក្ដារខៀន ។

សូមចាប់ផ្ដើមសកម្មភាព ហើយសរសេរពាក្យ *បព្វជិតភាព* នៅលើក្ដារខៀន ។ នៅពេលសិស្សបានរកឃើញពាក្យនេះ សូមបន្តសកម្មភាពនេះដោយប្រើពាក្យ និង ឃ្លាខាងក្រោមនេះ ៖ *ពិធីបរិសុទ្ធ បព្វជិតភាពអើរ៉ុន សេចក្ដីសញ្ញាបព្វជិតភាពមិលគីស្សាដែក ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ* ។ ( ប្រសិនបើអ្នកមានអារម្មណ៍ថាមានប្រយោជន៍ អ្នកអាចចង់ឈប់បន្ទាប់ពីសិស្សបានរកឃើញពាក្យ ឬ ឃ្លាគន្លឹះនោះ ហើយរំឭកខ្លីៗពីនិយមន័យរបស់វាជាមួយសិស្សក្នុងថ្នាក់ ។ និយមន័យខ្លីៗសម្រាប់ពាក្យមួយចំនួននេះមាននៅក្នុងសកម្មភាពផ្ទផ្ទង់នៅក្នុងមេរៀនទៅ ១៨ ៖ ថ្ងៃទី ១ នៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ ។ សម្រាប់ការពន្យល់កាន់តែស៊ីជម្រៅសូមមើល « បព្វជិតភាព និង កូនសោបព្វជិតភាព » ឬ « ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញា » នៅក្នុងវគ្គគោលលទ្ធិគ្រឹះនៃឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅសិក្សានេះ ) ។ បន្ទាប់ពីសកម្មភាពបានចប់ហើយ សូមសួរសំណួរខាងក្រោម ៖

- តើពិធីបរិសុទ្ធណាមួយនៃដំណឹងល្អគឺជាពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ? ( នៅពេលសិស្សឆ្លើយ សូមសរសេរពិធីបរិសុទ្ធខាងក្រោមនេះនៅលើក្ដារខៀន ៖ *បុណ្យជ្រមុជទឹក ពិធីបញ្ជាក់ ការប្រគល់បព្វជិតភាពមិលគីស្សាដែក [ សម្រាប់បុរស ] អំណោយទានពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ*, និង *ការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ*) ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ បង្រៀនថាបំណងប្រាថ្នារបស់ព្យាការីម៉ូសេ គឺជួយមនុស្សដទៃទៀតឲ្យខិតកាន់តែជិតព្រះតាមរយៈពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះនៃបព្វជិតភាព ។ សូមអញ្ជើញសិស្សឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦–១៧ ចុះឡើង ដើម្បីរកឲ្យឃើញពីរបៀបដែលម៉ូសេអាចប្រដេញរកសិទ្ធិអំណាចបព្វជិតភាពរបស់លោករហូតដល់អ័ដាមដែលជាអ្នកដែលបានទទួលវាមកពីព្រះ ។

- តើអ្នករៀនអ្វីខ្លះអំពីបព្វជិតភាពមកពីខគម្ពីរទាំងនេះ ? ( សិស្សអាចរកឃើញគោលការណ៍ផ្សេងៗគ្នា ប៉ុន្តែត្រូវគូសបញ្ជាក់ឲ្យបាក្រដនូវចំណុចខាងក្រោមនេះ ៖ **បព្វជិតភាពមកពីព្រះ ហើយត្រូវបានប្រគល់ឲ្យតាមរយៈការដាក់ដៃលើដោយអស់អ្នកដែលនៅក្នុងសិទ្ធិអំណាចនោះ**) ។

ត្រង់ចំណុចនេះនៃមេរៀន សូមអញ្ជើញសិស្សឲ្យបង្ហាញគំរូនៃខ្សែស្រឡាយនៃសិទ្ធិអំណាចដោយអានវាក៏បាន ឬ សរសេរវានៅក្ដារខៀនក៏បាន ។ សូមជួយសិស្សឲ្យយល់ថា តំណនៃសិទ្ធិអំណាចបព្វជិតភាពបង្ហាញពីសិទ្ធិអំណាចបព្វជិតភាពដែលត្រូវបានប្រគល់ឲ្យ ពីសំណាក់អ្នកកាន់បព្វជិតភាពម្នាក់ទៅដល់ម្នាក់ទៀត ចាប់តាំងពីព្រះយេស៊ូវគ្រីស្ទទៅឲ្យអ្នកកាន់បព្វជិតភាពនាសព្វថ្ងៃនេះ ។

- ហេតុអ្វីអ្នកគិតថាវាសំខាន់ដែលអ្នកកាន់បព្វជិតភាពអាចប្រដេញរកសិទ្ធិអំណាចបព្វជិតភាពរបស់ខ្លួនរហូតដល់ព្រះវិញដូច្នេះ ? ( សូមមើល ហេព្រើរ ៥:៤ ) ។

- តើអ្នកធ្លាប់មានបទពិសោធន៍អ្វីខ្លះដែលបានពង្រឹងដល់ទីបន្ទាល់របស់អ្នកអំពីបព្វជិតភាព ។

សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអានសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាពនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣៣–៤៤ ឲ្យឮៗ ។

- តើព្រះអម្ចាស់សន្យាអ្វីខ្លះចំពោះអ្នកទាំងឡាយដែលទទួលបព្វជិតភាព ហើយតម្កើងការហៅរបស់ខ្លួន ? ( សិស្សគួរតែរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើអ្នកទាំងឡាយណាដែលទទួលបព្វជិតភាព តម្កើងការហៅរបស់ខ្លួន នោះព្រះនឹងញែកពួកគេចេញ ហើយប្រទានដល់ពួកគេនូវអ្វីៗទាំងអស់ដែលទ្រង់មាន**) ។

- តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកកាន់បព្វជិតភាពអើរ៉ុនតម្កើងការហៅរបស់ពួកគេក្នុងបព្វជិតភាព ?

- តើនៅពេលណាដែលអ្នកត្រូវបានប្រទានពរដោយសារអ្នកកាន់បព្វជិតភាពម្នាក់បានតម្កើងការហៅរបស់ខ្លួន ?

ដើម្បីជួយសិស្សឲ្យចែកចាយការយល់ដឹងមួយចំនួនដែលពួកគេបានទទួលអំឡុងពេលការសិក្សារបស់ពួកគេនៅសប្ដាហ៍នេះ អ្នកអាចសួរសំណួរមួយចំនួន ឬ ទាំងអស់ខាងក្រោមនេះ ៖ (*កំណត់ចំណាំ ៖* នៅពេលអ្នករៀបចំផ្នែកនេះនៃមេរៀន អ្នកអាចរំឭកឡើងវិញនូវថ្ងៃទី ២ នៃមេរៀននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ ) ។

- តើអ្នកបានរៀនអ្វីខ្លះអំពីសារៈសំខាន់នៃការព្យាយាមស្ដាប់ព្រះបន្ទូលរបស់ព្រះ ? ( សូមមើល គ. និង ស. ៨៤:៤៣–៤៥, ៥៤–៥៨ ) ។

- តើការសិក្សាព្រះគម្ពីរដោយស្មោះត្រង់ និង ការអនុវត្តតាមព្រះបន្ទូលនៃព្រះបានធ្វើឲ្យជីវិតរបស់អ្នកផ្លាស់ប្ដូរយ៉ាងណាខ្លះ ?

- តើយើងមានទទួលខុសត្រូវអ្វីខ្លះចំពោះមនុស្សនៅលើពិភពលោកនេះ ។ ( សូមមើល គ. និង ស. ៨៤:៦១–៦២, ៨៥–៨៨) ។

- តើអ្នកអាចជួយបំពេញករណីកិច្ចដើម្បីនាំយកដំណឹងល្អទៅកាន់ពិភពលោកទាំងមូលដោយរបៀបណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧

*យ៉ូសែប ស្ម៊ីធព្យាករថាសង្គ្រាមនឹងចាក់ស្រោចមកលើគ្រប់ជាតិសាសន៍ទាំងអស់*

សូមឲ្យសិស្សសង្ខេបពីអ្វីដែលពួកគេបានរៀនអំពីការព្យាករដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ។

- តើការសិក្សារបស់អ្នកអំពីវិវរណៈនេះបានពង្រឹងសេចក្ដីជំនឿដែលថាព្រះអម្ចាស់អាចបើកសម្ដែងព្រឹត្តិការណ៍នាអនាគតតាមរយៈពួកព្យាការីរបស់ទ្រង់ដោយរបៀបណា ?

- តើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ពង្រឹងទីបន្ទាល់របស់អ្នកថាយ៉ូសែប ស្ម៊ីធគឺជាព្យាការីពិតយ៉ាងដូចម្ដេច ?

សូមបញ្ជាក់ថាគ្រប់ការព្យាករណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ត្រូវបាន ឬ នឹងត្រូវបានបំពេញ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:៨ ដើម្បីរៀនអំពីអ្វីដែលព្រះបានដឹកនាំយើងឲ្យធ្វើដូច្នោះ ដែលយើងនឹងបានត្រៀមខ្លួនសម្រាប់សង្គ្រាម និង គ្រោះមហន្តរាយដែលនឹងកើតមានចំពោះផែនដីនៅថ្ងៃចុងក្រោយ ។

- តើព្រះអម្ចាស់បានបញ្ជាយើងឲ្យធ្វើអ្វីខ្លះ ? ( សូមជួយពួកគេរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **យើងត្រូវឈរនៅទីបរិសុទ្ធ ហើយកុំមិចេញឡើយរហូតដល់ព្រះអម្ចាស់យាងមក**) ។

- តើទីបរិសុទ្ធមួយចំនួនណាខ្លះដែលអាចផ្ដល់សេចក្ដីសុខសាន្ត និង សុវត្ថិភាពដល់យើងនោះ ?

- តើអ្នកមានអារម្មណ៍ថាត្រូវបានប្រទានពរឲ្យសេចក្ដីសុខសាន្ត និង សុវត្ថិភាពដោយការឈរនៅទីបរិសុទ្ធយ៉ាងដូចម្ដេច ?

សូមបញ្ចប់មេរៀននេះ ដោយថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដែលអ្នកបានពិភាក្សា ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨–៨៩)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨–៨៩, អ្នកអាចអញ្ជើញពួកគេឲ្យពិចារណាពីសំណួរខាងក្រោម ៖ តើអ្នកធ្លាប់មានអារម្មណ៍ថាឯកោ ឬ ព្រួយបារម្ភថាព្រះវរបិតាសួគ៌ពុំជ្រាបដឹងពីកាលៈទេសៈ ឬ សេចក្ដីត្រូវការផ្ទាល់ខ្លួនរបស់អ្នកដែរឬទេ ? នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨, សូមស្វែងរកចម្លើយរបស់ព្រះអម្ចាស់ចំពោះអារម្មណ៍បែបនោះ ។ តើពាក្យ « អំពើអាក្រក់ទាំងឡាយ និង ផែនការទាំងឡាយ. . .ដែលមាននៅក្នុងដួងចិត្តមនុស្សដែលរួមគំនិតប្រព្រឹត្តិអំពើទុច្ចរិត (គ. និង ស. ៨៩:៤) នៅថ្ងៃចុងក្រោយបង្អស់មានន័យដូចម្ដេច ? នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩, សូមស្វែងរកព្រះឱវាទរបស់ព្រះអម្ចាស់ដែលបានប្រទានមក ដែលអាចការពារអ្នកពីអំពើអាក្រក់ និង ផែនការទាំងនោះ ។

មេរៀនទី ៩១

# គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១–៤០

## បុព្វកថា

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានថ្លែងថា គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨ គឺជា « វិវរណៈដ៏មហិមាបំផុតមួយដែលបានប្រទានដល់មនុស្ស » (*Doctrines of Salvation* comp. Bruce R. McConkie, វ៉ុលទី ៣ [ឆ្នាំ ១៩៥៤–៥៦] ៣:១៨១ ) ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះអស់រយៈពេលជាងបីថ្ងៃ–ថ្ងៃទី ២៧–២៨ ខែ ធ្នូ ឆ្នាំ ១៨៣២ និង ថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៨៣៣ – បន្ទាប់ពីពួកសង្ឃជាន់ខ្ពស់នៅក្នុងសន្និសីទមួយ បានអធិស្ឋានដើម្បីដឹងពីព្រះទ័យរបស់ព្រះអម្ចាស់ ស្តីអំពីការស្ថាបនានៃស៊ីយ៉ូន ។ នេះគឺជាមេរៀនទីមួយនៃមេរៀនទាំងបួនអំពី គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨។ ផ្នែកនៃវិវរណៈដែលបានពិភាក្សានៅក្នុងមេរៀននេះ រួមមាន (១) ការប្រកាសរបស់ព្រះអម្ចាស់ថាទ្រង់គឺជាពន្លឺ ដែលគ្រប់គ្រង និងនៅក្នុងគ្រប់អ្វីៗទាំងអស់ ហើយ (២) ការពន្យល់របស់ទ្រង់អំពីក្រឹត្យវិន័យដែលគ្រប់គ្រងនគរ និងរាស្ត្ររបស់ទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១–១៣

*ព្រះអម្ចាស់ប្រកាសថា ទ្រង់គឺជាពន្លឺនៅក្នុងគ្រប់អ្វីទាំងអស់*

សូមសួរដល់សិស្សបើសិនជាពួកគេធ្លាប់ស្ថិតនៅក្នុងស្ថានភាពងងឹតសូន្យសុងឬទេ ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។ សូមដាក់តាំងពិល ឬទៀន ឬរូបនៅលើក្តារខៀន ។

- តើការស្ថិតនៅក្នុងស្ថានភាពងងឹតសូន្យសុងនឹងជួយអ្នកថ្លែងអំណរគុណចំពោះពរជ័យនៃការមានពន្លឺយ៉ាងដូចម្តេច ?
- តើពន្លឺតំណាងឲ្យអ្វីនៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨ រួមមានទាំងការបង្រៀនរបស់ព្រះអម្ចាស់អំពីសារៈសំខាន់នៃពន្លឺ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះអស់រយៈពេលជាងបីថ្ងៃ បន្ទាប់ពីពួកសង្ឃជាន់ខ្ពស់នៅក្នុងសន្និសីទមួយ បានអធិស្ឋានដើម្បីដឹងពីព្រះទ័យរបស់ព្រះអម្ចាស់ ស្តីអំពីការស្ថាបនានៃស៊ីយ៉ូន ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១–២ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីរបៀបដែលទ្រង់ និងពួកទេវតា មានអារម្មណ៍ថាយ៉ាងណា នៅពេលពួកអ្នកបម្រើរបស់ទ្រង់អធិស្ឋានសុំដឹងពីព្រះទ័យរបស់ទ្រង់នោះ ។

- ហេតុអ្វីក៏អ្នកគិតថា ព្រះអម្ចាស់សព្វព្រះទ័យ ហើយពួកទេវតាអរសប្បាយ នៅពេលយើងអធិស្ឋានទូលសុំចង់ដឹងនូវព្រះទ័យរបស់ព្រះអម្ចាស់ ?
- តើការដឹងនូវព្រះទ័យរបស់ព្រះប្រៀបដូចជាពន្លឺចំពោះអ្នកទាំងឡាយណាដែលកំពុងស្វែងរកវាយ៉ាងដូចម្តេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:៣–៥ ដោយពន្យល់ថា ព្រះអម្ចាស់បានបង្រៀនដល់បងប្អូនប្រុសទាំងនេះថាពួកគេអាចទទួលការអះអាងនូវជីវិតដ៏អស់កល្បជានិច្ច តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវបានហៅថា ជាអង្គលួងលោមចិត្ត និងព្រះវិញ្ញាណបរិសុទ្ធនៃការសន្យាផងដែរ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីប្រភពនៃពន្លឺទាំងអស់ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- នៅក្នុង ខ ៧ តើពាក្យអ្វី ដែលត្រូវបានប្រើសំដៅទៅលើពន្លឺនៃសេចក្តីពិត ?

- ស្របតាម ខ ១២–១៣ តើពន្លឺទាំងអស់កើតចេញមកពីកន្លែងណា ?

- តើការបង្កបង្កើតរបស់ទ្រង់ តាមរយៈពន្លឺនៃព្រះគ្រីស្ទ ព្រះមានឥទ្ធិពលយ៉ាងដូចម្ដេច? ( សូមជួយសិស្សប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**តាមរយៈពន្លឺនៃព្រះគ្រីស្ទ ព្រះប្រទានពន្លឺ និងជីវិតដល់គ្រប់ការបង្កបង្កើតរបស់ទ្រង់ទាំងអស់ ។** អ្នកអាចនឹងចង់សរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ។ សិស្សក៏អាចប្រាប់ផងដែរថា ពន្លឺនៃព្រះគ្រីស្ទ គឺជាក្រឹត្យវិន័យ ដែលគ្រប់គ្រងសាកលលោក និងប្រជារាស្ត្រ ហើយវា « ប្រោស » ការយល់ដឹងរបស់យើង ។ *ប្រោស* មានន័យថា ធ្វើឲ្យរស់រវើក ។ ដោយសារពាក្យនេះត្រូវបានប្រើក្រោយទៀតនៅក្នុងវិវរណៈ សូមពិចារណាធ្វើការអញ្ជើញដល់សិស្សឲ្យសរសេរនិយមន័យនេះ នៅក្នុងរឹមទំព័រគម្ពីររបស់ពួកគេជិតនឹង ខ ១១) ។

បើចាំបាច់ សូមបន្ថែមការពន្យល់របស់សិស្សអំពីពន្លឺនៃព្រះគ្រីស្ទ ដោយការពន្យល់ថា វាគឺជា « ថាមពលទេវភាព ព្រះចេស្ដា ឬឥទ្ធិពលដែលចេញមកពីព្រះ តាមរយៈព្រះគ្រីស្ទ ហើយផ្ដល់ជីវិត និងពន្លឺចំពោះគ្រប់របស់ទាំងអស់ » ( Guide to the Scriptures, «Light of Christ,» scriptures.lds.org ) ។

ដើម្បីជួយសិស្សពិចារណាអំពីរបៀបដែលពួកគេត្រូវបានប្រទានពរ តាមរយៈពន្លឺនៃព្រះគ្រីស្ទ សូមសរសេរផ្នែកដូចខាងក្រោមនៅលើក្ដារខៀន ៖

> *ពន្លឺខាងរូបកាយ ការយល់ដឹង ជីវិត ក្រឹត្យវិន័យ*

សូមអញ្ជើញសិស្សឲ្យសរសេរឧទាហរណ៍នៅលើក្ដារខៀនអំពីរបៀបដែលការបើកសម្ដែងអំពីពន្លឺនៃព្រះគ្រីស្ទទាំងនេះមានឥទ្ធិពលលើពួកគេប្រចាំថ្ងៃ ។ ( ឧទាហរណ៍មួយចំនួន អាចរួមមាន លទ្ធភាពដើម្បីមើលឃើញ លទ្ធភាពដើម្បីរៀន និងស្គាល់សេចក្ដីពិត ការដុះលូតលាស់នៃដើមរុក្ខជាតិ និងសត្វ ដែលផ្ដល់ជាអាហារ និងសំលៀកបំពាក់ដល់យើង និងលទ្ធភាពដើម្បីស្គាល់ភាពខុសគ្នារវាងល្អ និងអាក្រក់ ) ។

- តើសេចក្ដីពិតដែលយើងបានពិភាក្សាអំពីពន្លឺ នៃព្រះគ្រីស្ទ អាចជួយយើងថ្លែងអំណរគុណចំពោះឥទ្ធិពលរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៤–៤០

*ព្រះអម្ចាស់ពន្យល់ថា មានក្រឹត្យវិន័យជាច្រើនទាក់ទងនឹងនគរនៃសិរីល្អ*

សូមបង្ហាញស្រោមដៃ ហើយពន្យល់ថា វាតំណាងឲ្យរូបកាយសាច់ឈាម ។ សូមអញ្ជើញសិស្សម្នាក់ឲ្យពាក់ស្រោមដៃ ហើយកម្រើកម្រាមដៃរបស់គេ ។ សូមចង្អុលបង្ហាញថា ដៃកម្រើក ឬផ្ដល់ភាពរស់រវើកដល់ស្រោមដៃ ។

- បើស្រោមដៃតំណាងឲ្យរូបកាយសាច់ឈាម តើដៃអាចតំណាងឲ្យអ្វី ? ( រូបកាយខាងវិញ្ញាណមួយ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់ បានហៅ ចំពោះការផ្គុំគ្នានៃវិញ្ញាណ និងរូបកាយ។

- តើព្រះអម្ចាស់ហៅការផ្គុំគ្នានៃវិញ្ញាណ និងរូបកាយថាជាអ្វី ? (**វិញ្ញាណ និងរូបកាយ គឺជាព្រលឹងមនុស្ស។** ( អ្នកអាចស្នើថាសិស្សគួរគូសចំណាំគោលលទ្ធិនេះ ) ។

- តើរឿងទាំងឡាយដែលជះឥទ្ធិពលដល់រូបកាយរបស់យើង អាចជះឥទ្ធិពលដល់វិញ្ញាណរបស់យើងយ៉ាងដូចម្ដេច ? ( នៅពេលសិស្សឆ្លើយតប សូមលើកទឹកចិត្តពួកគេឲ្យផ្ដល់ឧទាហរណ៍មួយចំនួន ) ។

ដើម្បីជួយសិស្សយល់បន្ថែមទៀតអំពីទំនាក់ទំនងរវាងរូបកាយ និងវិញ្ញាណរបស់យើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយ ប្រធាន ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់អំពីរបៀបដែលវិញ្ញាណ និងរូបកាយអាចជះឥទ្ធិពលដល់គ្នាទៅវិញទៅមក ។



« ពុំត្រូវចោទសួរថាតើសុខភាពរូបកាយ ប៉ះពាល់ដល់វិញ្ញាណដែរឬទេនោះឡើយ បើពុំសោតទេនោះ ព្រះអម្ចាស់នឹងមិនចាំបាច់បើកសម្ដែងពាក្យសម្ដីនៃប្រាជ្ញាវាងវៃនោះទេ ។ ព្រះពុំប្រទានបទបញ្ញត្តិខាងសាច់ឈាមណាមួយទេ–ដែលជះឥទ្ធិពលដល់រូបកាយរបស់យើង និង [វិញ្ញាណ] របស់យើងផង ។. . .

« . . . អំពើបាបធ្វើឲ្យបាត់បង់ភាពរឹងមាំ ។ វាជះឥទ្ធិពល មិនគ្រាន់តែដល់ [វិញ្ញាណ] ប៉ុណ្ណោះទេ ប៉ុន្តែដល់រូបកាយផងដែរ ។ បទគម្ពីរមានពេញទៅដោយឧទាហរណ៍អំពីអំណាចខាងរូបកាយ ដែលអាចរួមគ្នានឹងសេចក្ដីសុចរិត ។ ផ្ទុយទៅវិញ អំពើបាបដែលពុំប្រែចិត្ត អាចធ្វើឲ្យថាមពលសាយភាយ ហើយនាំឲ្យកើតមានជំងឺទាំងខាងសតិអារម្មណ៍ និងខាងរូបកាយ » (In His Steps » *Ensign* ខែ កញ្ញា ឆ្នាំ ១៩៨៨ ទំព័រ ៥ ) ។

### *សូមជួយសិស្សឲ្យយល់ គោលលទ្ធិ និង គោលការណ៍ទាំងឡាយ*

នៅពេលសិស្សយល់ពីគោលលទ្ធិ ឬ គោលការណ៍មួយ នោះពួកគេមិនត្រឹមតែដឹងពីអត្ថន័យនៃពាក្យទាំងឡាយប៉ុណ្ណោះទេ ប៉ុន្តែក៏ដឹងពីរបៀបដែលគោលលទ្ធិ ឬ គោលការណ៍ អាចមានឥទ្ធិពលចំពោះជីវិតរបស់ពួកគេផងដែរ ។ អ្នកអាចជួយសិស្សឲ្យកាន់តែយល់គោលលទ្ធិ ឬគោលការណ៍មួយតាមរយៈការពិភាក្សាអំពីរបៀបដែលសេចក្ដីពិតអាចអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ដោយការអញ្ជើញសិស្សឲ្យពន្យល់គោលលទ្ធិ ឬគោលការណ៍តាមសម្ដីរបស់ពួកគេ និងតាមរយៈការងាកទៅរកការបង្រៀនរបស់ពួកព្យាការី និងពួកសាវកថ្ងៃចុងក្រោយ ។

- តើការយល់ដឹងអំពីទំនាក់ទំនងរវាងរូបកាយអ្នក និងវិញ្ញាណរបស់អ្នក អាចជួយអ្នកធ្វើការសម្រេចចិត្តសុចរិតយ៉ាងដូចម្ដេច ?

ដើម្បីរៀបចំសិស្សធ្វើការពិភាក្សាអំពីសេចក្ដីពិត អំពីការរស់ឡើងវិញ សូមអញ្ជើញសិស្សឲ្យឡើងមកក្ដាខៀន ហើយដកស្រោមដៃចេញពីដៃគាត់ ហើយដាក់ស្រោមដៃនោះនៅលើតុ ឬកៅអី ។

- តើសកម្មភាពនេះ អាចតំណាងឲ្យអ្វី ? ( សេចក្ដីស្លាប់ខាងរូបកាយ ) ។

- តើមានអ្វីកើតឡើងចំពោះព្រលឹងនៅពេលស្លាប់ ? ( វិញ្ញាណ និងរូបកាយ ត្រូវបានបំបែកចេញពីគ្នា ) ។

សូមអញ្ជើញសិស្សឲ្យយកស្រោមដៃមក ហើយពាក់វាម្ដងទៀត ។

- តើសកម្មភាពនេះ អាចតំណាងឲ្យអ្វី ? ( ការរស់ឡើងវិញ ) ។

- តើមានអ្វីកើតឡើងចំពោះព្រលឹងនៅពេលការរស់ឡើងវិញ ? ( វិញ្ញាណ និងរូបកាយ ត្រូវបានផ្គុំគ្នាវិញ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៤, ១៦–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះអម្ចាស់ពិពណ៌នាអំពីការរស់ឡើងវិញ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើនរណាដែលបានធ្វើឲ្យព្រលឹងរបស់យើងត្រូវបានប្រោសលោះ ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះយេស៊ូវគ្រីស្ទ បានធ្វើឲ្យព្រលឹងរបស់យើងត្រូវបានប្រោសលោះឡើងវិញ )**

- បន្ទាប់ពីព្រលឹងរបស់យើងត្រូវបានប្រោសលោះ តើព្រលឹងនៃ « ជនក្រីក្រ និង រាបសារ » នឹងទទួលគ្រងអ្វីខ្លះ ? ( ផែនដី ) ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៨–២០ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយរកមើលនូវអ្វីដែលនឹងកើតឡើងចំពោះផែនដី ពីមុនព្រលឹងដែលបានប្រោសលោះទាំងឡាយ អាចគ្រងមរតក។

- តើមានអ្វីខ្លះនឹងកើតឡើងចំពោះផែនដី ពីមុនព្រលឹងប្រោសលោះអាចបានគ្រងមរតកនោះ?

- ស្របតាម ស ១៩ តើនរណានឹងមានវត្តមាន នៅលើផែនដីដែលបានញែកចេញបរិសុទ្ធ ?

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖« *តើនរណានឹងសក្ដិសមដើម្បីរស់នៅក្នុងនគរសេឡេស្ទាល ហើយរីករាយជាមួយវត្តមានរបស់ព្រះវរបិតាសួគ៌* ? សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេនឹងឆ្លើយសំណួរនេះ ។

សូមពន្យល់ថា ក៏ដូចជាផែនដីដែលនឹងទទួលសិរីល្អ បន្ទាប់ពីវាត្រូវបានញែកចេញជាបរិសុទ្ធ នោះរូបកាយរបស់យើងក៏នឹងត្រូវបានផ្លាស់ប្ដូរ ហើយបានទទួលសិរីល្អនៅក្នុងការរស់ឡើងវិញផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ពុំមែនមនុស្សទាំងអស់នឹងទទួលបានកម្រិតនៃសិរីល្អដូចគ្នាទាំងអស់នោះទេ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:២១–២៤ ដោយស្ងាត់ស្ងៀម ហើយប្រាប់នូវអ្វីដែលកំណត់កម្រិតនៃសិរីល្អ ដែលមនុស្សម្នាក់ទទួលបាននៅក្នុងការរស់ឡើងវិញ ។

- តើអ្វីខ្លះដែលកំណត់អំពីកម្រិតនៃសិរីល្អរបស់មនុស្សម្នាក់ ដែលនឹងទទួលនៅក្នុងការរស់ឡើងវិញ ? ( សូមសរសេរគោលលទ្ធិខាងក្រោមនៅលើក្ដារខៀន ៖ អ្នកក៏អាចឲ្យយោបល់ដល់សិស្សឲ្យសរសេរវានៅរឹមនៃព្រះគម្ពីររបស់ពួកគេផងដែរ ។ **នៅក្នុងការរស់ឡើងវិញ យើងនឹងទទួលបានសិរីល្អស្របតាមក្រឹត្យវិន័យដែលយើងគោរពតាម )** ។

ដើម្បីជួយសិស្សយល់បន្ថែមអំពីសេចក្ដីពិតនេះសូមអញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:២៥–៣៣ ជាមួយដៃគូ ។ សូមឲ្យពួកគេរកមើលរបៀបដែលការគោរពប្រតិបត្តិចំពោះក្រឹត្យវិន័យរបស់ព្រះគ្រីស្ទនឹងជះឥទ្ធិពលលើផែនដី និងយើងម្នាក់ៗយ៉ាងដូចម្ដេចខ្លះ ។ អ្នកអាចផ្ដល់យោបល់ឲ្យសិស្សថា ពួកគេគួរតែគូសចំណាំចំពោះអ្វីដែលពួកគេរកឃើញ ។

- តើអ្នករកឃើញអ្វីខ្លះ ដែលគាំទ្រសេចក្ដីពិតថា នៅក្នុងការរស់ឡើងវិញ យើងនឹងទទួលបានសិរីល្អ ស្របតាមក្រឹត្យវិន័យដែលយើងគោរពតាម ?

- សូមកត់សម្គាល់នៅក្នុង ខ ២៨ តើព្រះអម្ចាស់សំដៅទៅលើនរណាដែល « ជាវិញ្ញាណនៃសេឡេស្ទាល » ? តើអ្នកគិតថា « ជាវិញ្ញាណនៃសេឡេស្ទាល » មានន័យយ៉ាងណា ?

សូមជួយសិស្សឲ្យយល់ថា អ្នកទាំងឡាយណាដែលជាវិញ្ញាណនៃសេឡេស្ទាល គឺជាបុគ្គលទាំងឡាយណាដែលរស់នៅស្របតាមក្រឹត្យវិន័យនៃនគរសេឡេស្ទាល ។ សូមរំឭកសិស្សក្នុងថ្នាក់ថា យើងដឹងមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ថា ក្រឹត្យវិន័យនៃនគរសេឡេស្ទាល រួមមានទាំងការមានទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ការរក្សាបទបញ្ញត្តិ ការចុះ និងរក្សា

សេចក្ដីសញ្ញាទាំងឡាយ ការយកឈ្នះដោយសេចក្ដីជំនឿ និងការទទួលព្រះវិញ្ញាណបរិសុទ្ធនៃការសន្យា ( សូមមើល គ. និង ស. ៧៦:៥០–៥៣, ៦៩–៧០) ។

- នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:២៨–២៩ តើព្រះអម្ចាស់ពិពណ៌នាអំពីរូបកាយដែលបានរស់ឡើងវិញរបស់អ្នកទាំងឡាយដែលទទួលសិរីល្អសេឡេស្ទាលយ៉ាងដូចម្ដេច ?
- ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៣០–៣១ បើមនុស្សម្នាក់គោរពតាមក្រឹត្យវិន័យទេរេស្ទ្រាល និងទេឡេស្ទាល តែប៉ុណ្ណោះនៅលើផែនដី តើរូបកាយប្រភេទណា ដែលពួកគេនឹងទទួលបាននៅក្នុងការរស់ឡើងវិញ ? ( សូមជួយសិស្ស ឲ្យយល់ថា រូបកាយដែលរស់ឡើងវិញរបស់យើង នឹងត្រូវគ្នានៅក្នុងសិរីល្អជាមួយនឹងប្រភេទនៃវិញ្ញាណដែលយើងបាន ប្រែក្លាយឡើយ ) ។

ដើម្បីជួយសិស្សយល់បន្ថែមទៀតអំពីគោលលទ្ធិ ដែលយើងទទួលសិរីល្អ ស្របតាមក្រឹត្យវិន័យដែលយើងគោរពតាម សូមអញ្ជើញពួកគេឲ្យធ្វើការជាបីក្រុម ឬបួននាក់ ដើម្បីបំពេញកិច្ចការចាត់តាំងដូចខាងក្រោម។ អ្នកអាចចែកច្បាប់ចម្លងនៃសេចក្ដីណែនាំ ឬសរសេរវានៅលើក្ដារខៀន ។

១. សូមពិភាក្សាសំណួរដូចខាងក្រោមរួមគ្នា ៖ តើអត្ថប្រយោជន៍មួយចំនួនចំពោះការគោរពដល់ច្បាប់ចរាចរ មាន អ្វីខ្លះ ? តើលទ្ធផលមួយចំនួនចំពោះការមិនគោរពច្បាប់ចរណ៍មានអ្វីខ្លះ ?

២. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៣៤–៣៥ ហើយរកមើលលទ្ធផលនៃការរស់នៅ និងការបដិសេធ ក្នុងការរស់នៅតាមក្រឹត្យវិន័យរបស់ព្រះ ។ សូមពិភាក្សាអំពីអ្វីដែលអ្នករកឃើញ ។

៣. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤០ ពិភាក្សាអំពីគុណសម្បត្តិនៃមនុស្សដែលនឹងខិតទៅជិតនគរ សេឡេស្ទាល ។ សូមសិក្សាខនេះជាមួយគ្នា ហើយប្រាប់អំពីគុណសម្បត្តិទាំងឡាយ ។ រួចពិភាក្សានូវអ្វីដែល យើងអាចធ្វើ ដើម្បីអភិវឌ្ឍ ឬពង្រឹងដល់គុណសម្បត្តិទាំងនេះនៅក្នុងជីវិតរបស់យើង ។

បន្ទាប់ពីសិស្សពិភាក្សាអំពីគុណសម្បត្តិទាំងនេះក្នុងក្រុមរបស់ពួកគេ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពន្លឺ ដែលបំពេញ ក្នុងជីវិតរបស់យើង នៅពេលយើងព្យាយាមរស់នៅតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សឲ្យចែកចាយ ពីរបៀបដែលពួកគេបានមើលឃើញសេចក្ដីពិតនេះ បើកសម្ដែងនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមជួយសិស្សអនុវត្ត នូវអ្វីដែលពួកគេបានរៀន ដោយការសុំឲ្យពួកគេសរសេរពីគោលដៅមួយ ដែលនឹងជួយពួកគេឲ្យរស់នៅតាមក្រឹត្យវិន័យនៃនគរ សេឡេស្ទាល ហើយត្រូវបានប្រទានពរដោយគុណសម្បត្តិទាំងនេះ ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយគោលដៅរបស់ ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ប្រសិនបើពួកគេអាចធ្វើដូច្នោះបាន ។

មេរៀនទី ៩២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៦៩

## បុព្វកថា

នេះគឺជាមេរៀនទីពីរនៃមេរៀនទាំងបួននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ ។ ផ្នែកនៃវិវរណៈដែលបានពិភាក្សានៅក្នុងមេរៀននេះ ត្រូវបានផ្ដល់ឲ្យនៅក្នុងសន្និសីទមួយអំពីពួកសង្ឃជាន់ខ្ពស់នៅទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ នៅថ្ងៃទី ២៧ និង ២៨ ខែ ធ្នូ ឆ្នាំ ១៨៣២ ។ វាមានរួមបញ្ចូលទាំងការពន្យល់របស់ព្រះយេស៊ូវគ្រីស្ទ អំពីរបៀបដែលព្រះគ្រប់គ្រងការបង្កបង្កើតរបស់ទ្រង់ និងការអញ្ជើញឲ្យយើងខិតទៅជិតទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៥០

*ព្រះអង្គសង្គ្រោះបើកសម្ដែងថា អ្វីៗទាំងអស់ត្រូវបានគ្រប់គ្រងដោយក្រឹត្យវិន័យដ៏ទេវភាព*

សូមបង្ហាញរូបផ្កាយ ដូចជាព្រះអម្ចាស់បានបង្កើតវត្ថុទាំងអស់ (*សៀវភៅរូបភាពសិល្បៈនៃដំណឹងល្អ* [ឆ្នាំ ២០០៩ ] លេខ ២ សូមមើលផងដែរ LDS.org) ឬគូសរូបផ្កាយមួយចំនួននៅលើក្ដារខៀន ។

- តើអ្នកធ្លាប់បានមើលទៅហ្វូងតារា ហើយគិតអំពីព្រះ និងការបង្កបង្កើតរបស់ទ្រង់ដែរឬទេ ? តើសំណួរ ឬគំនិតអ្វីខ្លះ ដែលអ្នកបានពិចារណានៅពេលអ្នកសម្លឹងមើលទៅលើមេឃ ?



សូមចង្អុលបង្ហាញថា នៅពេលមនុស្សសញ្ជឹងគិតអំពីភាពធំធេងនៃការបង្កបង្កើតរបស់ព្រះ ពេលខ្លះពួកគេមានអារម្មណ៍ថាខ្លួនឯងតូចតាច ហើយពុំសំខាន់ ។ ពួកគេអាចនឹងពិចារណាថាតើព្រះបានដឹងអំពីពួកគេឬទេ ។ សូមប្រាប់សិស្សថា នៅពេលពួកគេពិភាក្សាអំពីខគម្ពីរនៅក្នុងមេរៀនថ្ងៃនេះ ពួកគេនឹងយល់ឃើញថា ទោះជាព្រះគ្រប់គ្រងការបង្កបង្កើតដ៏ច្រើននៅទូទាំងស្ថានសួគ៌ក្ដី ក៏ទ្រង់ជ្រាបដឹងអំពីយើងម្នាក់ៗ ហើយចង់ខិតមកជិតនឹងយើង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលរបៀបដែលខគម្ពីរនេះបង្ហាញថា ព្រះមានព្រះចេស្ដាគ្រប់គ្រងរាល់ការបង្កបង្កើតរបស់ទ្រង់ទាំងអស់ ហើយបានដឹងអំពីយើងម្នាក់ៗ ។

- តើខគម្ពីរនេះបង្ហាញថាព្រះមានព្រះចេស្ដាជ្រាបដឹងពីយើងម្នាក់ៗ និងដឹងពីតម្រូវការរបស់យើងយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤២–៤៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ប្រាប់អំពីរបៀបដែលព្រះគ្រប់គ្រងការបង្កបង្កើតរបស់ទ្រង់ ។

- តើព្រះគ្រប់គ្រងការបង្កបង្កើតរបស់ទ្រង់យ៉ាងដូចម្ដេច ? ( ដោយក្រឹត្យវិន័យរបស់ទ្រង់ ) ។

*សូមបង្កើតបរិយាកាសនៃក្ដីស្រឡាញ់ និងការគោរព*

នៅពេលអ្នកកែចម្រើននៅក្នុងក្ដីស្រឡាញ់ និងការគោរពដល់សិស្សរបស់អ្នក នោះអ្នកនឹងសាយភាយនូវក្ដីស្រឡាញ់ដ៏សុទ្ធសាធរបស់ព្រះគ្រីស្ទ និងបង្រៀនដោយភាពអត់ធ្មត់ និងក្ដីមេត្តា ។ សកម្មភាពដូចខាងក្រោមនឹងជួយអ្នកអភិវឌ្ឍក្ដីស្រឡាញ់ និងការគោរពកាន់តែខ្លាំងដល់សិស្សរបស់អ្នក ៖ (១) រៀនស្គាល់ឈ្មោះពួកគេ ហើយព្យាយាមដើម្បីដឹងពីចំណាប់អារម្មណ៍ ទេពកោសល្យ បញ្ហា និងលទ្ធភាពនានា (២) អធិស្ឋានសម្រាប់ពួកគេ ជារួម និងជាបុគ្គល (៣) ស្វាគមន៍សិស្សម្នាក់ៗមកក្នុងថ្នាក់រៀនដោយផ្ទាល់ ហើយឲ្យសិស្សម្នាក់ៗមានឱកាសរួមចំណែក ។

សូមអញ្ជើញសិស្សឲ្យគិតអំពីការបង្កបង្កើតមួយរបស់ព្រះ ដែលធ្វើឲ្យពួកគេអស្ចារ្យក្នុងចិត្តជាខ្លាំង ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិតរបស់ពួកគេ ។ ជាឧទាហរណ៍មួយ អ្នកអាចបង្ហាញពីកម្មវត្ថុ ឬរូបភាពមួយដែលតំណាងឲ្យការបង្កបង្កើតរបស់ព្រះមួយ ហើយពន្យល់ថាហេតុអ្វីក៏ការបង្កបង្កើតនោះធ្វើឲ្យអ្នកអស្ចារ្យក្នុងចិត្តខ្លាំងម្ល៉េះ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤៦–៤៧ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលយើងកំពុងមើលឃើញ នៅពេលយើងមើលទៅការបង្កបង្កើតរបស់ព្រះ ។

- តើយើងមើលឃើញអ្វីខ្លះ នៅពេលយើងមើលទៅលើសូម្បីតែរបស់ដ៏តូចមួយនៃការបង្កបង្កើតរបស់ព្រះក្ដី ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចម្លើយរបស់ពួកគេគួរបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងមើលទៅការបង្កបង្កើតរបស់ព្រះ នោះយើងមើលឃើញពីព្រះចេស្ដា និងមហិឫទ្ធិរបស់ទ្រង់ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើការបង្កបង្កើតដែលអ្នកមើលឃើញនៅក្នុងស្ថានសួគ៌ និងនៅលើផែនដី មានឥទ្ធិពលដល់ទីបន្ទាល់របស់អ្នកអំពីព្រះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤៨–៥០ ដោយស្ងាត់ស្ងៀម ។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេម្នាក់ឡើងសង្ខេបអំពីខគម្ពីរទាំងឡាយតាមពាក្យសម្ដីផ្ទាល់របស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥១–៦១

*ព្រះអម្ចាស់ប្រាប់នូវរឿងប្រៀបធៀបមួយអំពីបុរសដែលធ្វើការនៅក្នុងស្រែ និងការដែលត្រូវបានចៅហ្វាយទៅជួបនឹងពួកគេ ។*

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥១–៦០ មាននូវរឿងប្រៀបធៀបមួយ ដែលជួយយើងយល់អំពីការប្រាស្រ័យទាក់ទងរបស់ព្រះជាមួយនឹងនគរទាំងឡាយ ឬពិភពទាំងឡាយ ដែលទ្រង់បានបង្កើត ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥១–៥៥ ឲ្យឮៗ ។ សូមសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលបុរសនៅក្នុងរឿងប្រៀបធៀបបានបញ្ជាដល់អ្នកបម្រើរបស់គាត់ម្នាក់ៗឲ្យធ្វើ និងអ្វីដែលគាត់បានសន្យានឹងពួកអ្នកបម្រើម្នាក់ៗរបស់គាត់ ។

- តើបុរសបញ្ជាពួកអ្នកបម្រើរបស់គាត់ឲ្យធ្វើអ្វីខ្លះ ? តើគាត់បានសន្យាអ្វីខ្លះដល់ពួកអ្នកបម្រើរបស់គាត់ ? ( គាត់បានបញ្ជាពួកគេឲ្យធ្វើការនៅក្នុងស្រែរបស់គាត់ ។ គាត់បានសន្យាថា គាត់នឹងទៅជួបពួកគេម្នាក់ៗម្ដងៗ ) ។

សូមសង្ខេបគោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥៦–៦០ដោយការពន្យល់ថា នៅក្នុងរឿងប្រៀបធៀប ម្ចាស់ស្រែបានទៅជួបនឹងពួកអ្នកបម្រើរបស់គាត់ម្ដងម្នាក់ៗតាមវេនរបស់ពួកគេ ។ អ្នកបម្រើម្នាក់ៗ « បានទទួលរស្មីនៅលើមុខចៅហ្វាយរបស់ខ្លួន គឺមនុស្សម្នាក់ៗតាមម៉ោងរបស់ខ្លួន » (គ. និង ស. ៨៨:៥៨) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលរឿងប្រៀបធៀបនេះ បង្រៀនយើងអំពីរបៀបដែលព្រះប្រាស្រ័យទាក់ទងនឹងនគរទាំងឡាយដែលទ្រង់បានបង្កើតឡើង ។

- តើរឿងប្រៀបធៀបនេះ បង្រៀនអ្វីខ្លះ អំពីរបៀបដែលព្រះប្រាស្រ័យទាក់ទងជាមួយនឹងនគរដែលទ្រង់បានបង្កើត ? ( សូមជួយសិស្សឲ្យប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **ព្រះនឹងទៅជួបនឹងនគរទាំងឡាយរបស់ទ្រង់ និងមនុស្សក្នុងនគរនោះម្ដងម្នាក់ៗ តាមពេលរបស់ទ្រង់ ។** សូមសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦២–៦៩

*ព្រះសន្យាថានឹងចូលមកជិតយើងនៅពេលយើងចូលមកជិតទ្រង់*

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានមកនគររបស់ទ្រង់នៅលើផែនដីនេះ ហើយថាទ្រង់នឹងយាងមកម្ដងទៀត ហើយគ្រងរាជ្យនៅទីនេះ អំឡុងពេលនៃសហសវត្សរ៍ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦២–៦៩ ព្រះអម្ចាស់បង្រៀននូវអ្វីដែលយើងអាចធ្វើ ដើម្បីទ្រង់នឹងចូលមកជិតយើងឥឡូវនេះ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណួរខាងក្រោមនេះ ៖

- តើអ្នកមានអារម្មណ៍ថានៅជិតនឹងព្រះអម្ចាស់ដល់កម្រិតណា ? តើអ្នកចង់មានអារម្មណ៍កាន់តែជិតស្និតនឹងទ្រង់ដែរឬទេ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦២–៦៣ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីៗដែលយើងអាចធ្វើដើម្បីយាងអញ្ជើញព្រះអម្ចាស់មកជិតយើង ។

- តើខគម្ពីរទាំងនេះបង្រៀនគោលការណ៍អ្វីខ្លះ អំពីការចូលទៅជិតនឹងព្រះអម្ចាស់ ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងចូលទៅជិតព្រះអម្ចាស់ នោះទ្រង់នឹងចូលមកជិតយើង )** ។

- តើពាក្យនៅក្នុង ខ ៦៣ បង្រៀនអ្វីខ្លះ អំពីរបៀបដែលយើងអាចចូលទៅជិតព្រះអម្ចាស់ ? (*ស្វែងរក សូម* និង *គោះ* )។

សូមចង្អុលបង្ហាញថា ពាក្យ *ស្វែងរក សូម* និង *គោះ* គឺជាពាក្យដែលមានសកម្មភាព ។

- តើសកម្មភាពមួយចំនួនណាខ្លះ ដែលបានជួយអ្នក ស្វែងរក សូម និងគោះ ដើម្បីចូលទៅកាន់តែជិតនឹងព្រះអម្ចាស់ ?

ដើម្បីជួយសិស្សយល់អំពីរបៀបមួយដែលពួកគេអាចចូលទៅជិតព្រះអម្ចាស់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល ៖



«ខ្ញុំរកឃើញថា ពេលខ្ញុំធ្វើឲ្យទំនាក់ទំនងខ្ញុំនឹងព្រះអាទិទេពមានភាពសាមញ្ញ ហើយកាលព្រះហាក់ដូចជាមិនបានស្ដាប់ ហើយមានបន្ទូលមកកាន់ខ្ញុំ នោះខ្ញុំឃ្លាតពីទ្រង់កាន់តែឆ្ងាយហើយ។ បើសិនខ្ញុំផ្ដោតយកចិត្តទុកដាក់ទាំងស្រុងលើព្រះគម្ពីរ នោះផ្លូវឆ្ងាយនឹងត្រូវបានបង្រួញ ហើយ ផ្លូវវិញ្ញាណនឹងត្រឡប់មកវិញ » (*Teachings of Presidents of the Church: Spencer W. Kimball* [ឆ្នាំ ២០០៦ ]ទំព័រ ៦៧) ។

ដើម្បីជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីរបៀបដែលព្រះវរបិតាសួគ៌ ឆ្លើយការអធិស្ឋានរបស់ពួកគេ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៤–៦៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម ហើយរកមើលនូវការសន្យារបស់ព្រះអង្គសង្គ្រោះដល់យើង បើយើងអធិស្ឋានដល់ព្រះបិតានៅក្នុងព្រះនាមរបស់ទ្រង់ ។

- នៅក្នុងខគម្ពីរនេះ តើព្រះអង្គសង្គ្រោះបង្រៀនអ្វីខ្លះ អំពីរបៀបដែលព្រះវរបិតាសួគ៌ ឆ្លើយតបការអធិស្ឋានរបស់យើង ? ( សូមជួយសិស្សឲ្យប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ព្រះវរបិតាសួគ៌ឆ្លើយតបការអធិស្ឋានរបស់យើង តាមរបៀបជាច្រើនដែលទ្រង់ស្គាល់វាល្អបំផុតសម្រាប់យើង** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

ដើម្បីជួយសិស្សយល់នូវគោលការណ៍នេះ អ្នកអាចនឹងចង់ផ្ដល់ឲ្យពួកគេនូវច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កុត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់នូវអ្វីដែលយើងគួរធ្វើ នៅពេលព្រះវរបិតាសួគ៌ ឆ្លើយតបការអធិស្ឋានមួយ តាមរបៀបមួយដែលខុសពីអ្វីដែលយើងសង្ឃឹម ឬ រំពឹងទុកនោះ ។



« វាលំបាកណាស់ នៅពេលការអធិស្ឋានដ៏ស្មោះសម្រាប់អ្វីមួយដែលចង់បានជាងខ្លាំង នោះមិនបានទទួលចម្លើយដូចដែលអ្នកចង់បាន ។ វាពិបាកដើម្បីយល់អំពីមូលហេតុ ដែលការអនុវត្តសេចក្ដីជំនឿដ៏ជ្រាលជ្រៅ និង ស្មោះរបស់អ្នកដោយរស់នៅក្នុងជីវិតមួយ ដែលមានការគោរពប្រតិបត្តិ បែរជាមិនបានទទួលលទ្ធផលដែលចង់បានទៅវិញ ។. . . ពេលខ្លះវាពិបាក ដើម្បីស្គាល់អំពីអ្វីដែលជា *ការប្រសើរបំផុត* ឬ *ការចាំបាច់* សម្រាប់អ្នកណាស់ ។ ជីវិតរបស់អ្នកនឹងកាន់តែងាយស្រួល នៅពេលអ្នកទទួលស្គាល់ថាអ្វីដែលព្រះបានធ្វើឲ្យមាននៅក្នុងជីវិតរបស់អ្នក គឺសម្រាប់សេចក្ដីល្អ *ដ៏អស់កល្បជានិច្ច*របស់អ្នក » (Using the Supernal Gift of Prayer » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៩ ) ។

សូមគិតពីការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍មួយ ដែលពួកគេមាន នៅពេលព្រះវរបិតាសួគ៌ បានឆ្លើយតបរាល់ការអធិស្ឋានរបស់ពួកគេ ដោយនូវអ្វីដែលល្អបំផុតសម្រាប់ពួកគេ ។ អ្នកអាចចែកចាយបទពិសោធន៍របស់អ្នកផងដែរ ។

សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៦ យើងដឹងថា វិធីមួយដែលព្រះទំនាក់ទំនងនឹងយើងគឺ « ដូចជាសំឡេងនៃមនុស្សម្នាក់កំពុងតែស្រែកនៅក្នុងទីរហោស្ថាន » ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៦ ដោយស្ងាត់ស្ងៀម រកមើលពីរបៀបដែលសំឡេងរបស់ព្រះឮមកកាន់យើង ។

- ស្របតាមខគម្ពីរនេះ តើសំឡេងរបស់ព្រះដូចជា « សំឡេងនៃមនុស្សម្នាក់កំពុងតែស្រែកនៅក្នុងទីរហោស្ថាន » យ៉ាងដូចម្ដេច ?

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះបានគង់នៅជិតអ្នក ទោះបីជាអ្នកពុំបានឃើញទ្រង់ក៏ដោយនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៧–៦៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវរបៀបបន្ថែមដែលយើងអាចចូលទៅជិតនឹងព្រះអម្ចាស់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមសរសេរនូវសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖*បើសិនជាភ្នែករបស់ខ្ញុំស្មោះត្រង់ទាំងស្រុងទៅចំពោះសិរីល្អរបស់ព្រះ នោះ. . .*

សូមអញ្ជើញសិស្សឲ្យបំពេញសេចក្ដីថ្លែងការណ៍ដោយប្រើនូវអ្វីដែលពួកគេបានរៀនក្នុង ខ ៦៧ ។ សេចក្ដីថ្លែងការណ៍អាចអានដូចតទៅនេះ ៖ **បើសិនជាភ្នែករបស់ខ្ញុំស្មោះត្រង់ទាំងស្រុងទៅចំពោះសិរីល្អរបស់ព្រះ នោះខ្ញុំនឹងបានពោរពេញទៅដោយពន្លឺ ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំគោលការណ៍នេះ ដូចមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៧ ។

- តើអ្នកគិតថា ភ្នែករបស់អ្នក « ស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ [ព្រះអម្ចាស់] មានន័យយ៉ាងណា ?» ( នៅពេលសិស្សឆ្លើយតបចំពោះសំណួរនេះ ពួកគេអាចនឹងប្រាប់អំពីឧទាហរណ៍ជាក់លាក់ផ្សេងពីនេះ ។ តែសូមប្រាកដថា ពួកគេយល់ថា ជាទូទៅ ឃ្លានោះមានន័យថា លះបង់ទាំងស្រុងចំពោះកិច្ចការ និងគោលបំណងទាំងឡាយរបស់ព្រះ ) ។

- សូមគិតអំពីមនុស្សដែលអ្នកស្គាល់ ដែលហាក់ដូចជាបានពោរពេញទៅដោយពន្លឺរបស់ព្រះអម្ចាស់ ។ តើអ្នកមើលឃើញពន្លឺនេះនៅក្នុងខ្លួនពួកគេដោយវិធីណា ?

- ស្របតាម ខ ៦៨ តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះ សម្រាប់គំនិតរបស់យើងដើម្បីស្មោះត្រង់ទាំងស្រុងចំពោះព្រះ ? ( អ្នកអាចនឹងចង់ពន្យល់ថា ឃ្លា « ញែកខ្លួនអ្នករាល់គ្នាជាបរិសុទ្ធ » សំដៅទៅលើតម្រូវការរបស់យើង ដើម្បីបានបរិសុទ្ធ និងស្អាតពីអំពើបាប ។ យើងបានក្លាយជាញែកចេញបរិសុទ្ធតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលយើងប្រែចិត្តពីអំពើបាបរបស់យើង ទទួលពិធីបរិសុទ្ធនៃបព្វជិតភាព ហើយរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់យើង ) ។

សូមអញ្ជើញសិស្សឲ្យអានឡើងវិញនូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលអ្នកបានសរសេរនៅលើក្ដារខៀន ។ បន្ទាប់មក សុំពួកគេឲ្យនឹកស្រមៃថា ពួកគេកំពុងសម្លឹងមើលទៅហ្វូងតារាជាមួយមិត្តម្នាក់ ដែលមានអារម្មណ៍ថា ព្រះពុំបានដឹងអំពីគាត់ ឬនាងទេ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវអ្វីដែលពួកគេនឹងនិយាយទៅកាន់មិត្តរបស់គេនោះ ដោយប្រើគោលការណ៍នៅលើក្ដារខៀន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ អ្នកអាចនឹងចង់បញ្ចប់ដោយការអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ នៃគណៈប្រធានទីមួយ ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកអំពីឥទ្ធិពលរបស់ព្រះនៅក្នុងជីវិតរបស់អ្នក នៅពេលអ្នកបានខិតខំដើម្បីចូលទៅជិតទ្រង់ផងដែរ ។



« បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ. . . ជួនកាល យើងអាច. . . មានអារម្មណ៍ថាខ្លួនពុំសំខាន់ គ្មានអ្នកណាមើលឃើញ ឯកោ ហើយត្រូវបានគេបំភ្លេចចោល ។ ប៉ុន្តែ សូមចងចាំជានិច្ចថា— អ្នកសំខាន់ចំពោះទ្រង់ !. . .

« ព្រះទតមើលអ្នក ពុំមែនគ្រាន់តែជាមនុស្សរមែងស្លាប់នៅក្នុងភពតូចមួយ ដែលយើងរស់នៅមួយរយៈនេះនោះទេ— ទ្រង់ទតមើលលើអ្នក ក្នុងនាមជាបុត្ររបស់ទ្រង់ ។ ទ្រង់ទតមើលអ្នកជាតួអង្គ ដែលមានសមត្ថភាព និង បានរៀបចំរចនាអ្នកឡើងឲ្យប្រែក្លាយទៅជាដូចនោះ ។ ទ្រង់ចង់ឲ្យអ្នកដឹងថា អ្នកសំខាន់ចំពោះទ្រង់» («You Matter to Him» *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១,ទំព័រ ២២)។

មេរៀនទី ៩៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១១៧

## បុព្វកថា

នេះគឺជាមេរៀនទីបីនៃមេរៀនទាំងបួនអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ ។ ចំណែកនៃវិវរណៈដែលមេរៀននឹងផ្ដោតទៅលើ ត្រូវបានប្រទានឲ្យនៅក្នុងសន្និសីទមួយអំពីពួកសង្ឃជាន់ខ្ពស់ នៅថ្ងៃទី ២៧ – ២៨ ខែ ធ្នូ ឆ្នាំ ១៨៣២ ។ នៅក្នុងនោះ ព្រះអម្ចាស់បានណែនាំដល់ពួកអែលឌើរនៃសាសនាចក្រឲ្យបង្រៀនដល់គ្នាទៅវិញទៅមក និងរៀបចំខ្លួនដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ ព្រះអម្ចាស់ក៏បានបង្រៀនផងដែរ អំពីទីសម្គាល់នៃការយាងមកជាលើកទីពីរ ជាបង្គាប់ចុងទៅដែលមនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ ហើយព្រឹត្តការណ៍មួយចំនួននៅជុំវិញចម្បាំងចុងក្រោយជាមួយសាតាំង ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១១៧

*ព្រះអម្ចាស់ត្រាស់បញ្ជាឲ្យពួកអែលឌើរនៃសាសនាចក្រត្រៀមខ្លួនសម្រាប់ការបម្រើរបស់ពួកគេ ហើយបានបើកសម្ដែងអំពីព្រឹត្តការណ៍ជុំវិញការយាងមកជាលើកទីពីររបស់ទ្រង់*

សូមអញ្ជើញសិស្សម្នាក់ឲ្យមកខាងមុខក្ដារខៀន ហើយបង្រៀនសិស្សម្នាក់ទៀតអំពីរបៀបធ្វើការសាមញ្ញមួយ ដូចជាចងក្រវ៉ាត់ក ( ឬការងារផ្សេងមួយដែលសិស្សទីពីរពុំចេះធ្វើ ) ។ សូមឲ្យសិស្សក្នុងថ្នាក់លើកដៃ បើពួកគេបានជួយបង្រៀនមេរៀនមួយ ឬជំនាញមួយដល់នរណាម្នាក់ទៀតក្នុងពេលថ្មីៗនេះ ។ សូមឲ្យសិស្សពីរបីនាក់ពិពណ៌នាពីអ្វីដែលពួកគេបានបង្រៀន ។ បន្ទាប់មក សូមពិភាក្សាសំណួរខាងក្រោមនេះ ៖

- តើអ្នកបានរៀនអ្វីខ្លះតាមរយៈការត្រៀមបង្រៀន និង តាមរយៈការបង្រៀននរណាម្នាក់ ?
- ហេតុអ្វីអ្នកគិតថា ជាញឹកញាប់យើងរៀនមកពីការត្រៀមខ្លួនដើម្បីបង្រៀន ច្រើនជាងត្រូវបានបង្រៀនដោយនរណាម្នាក់ទៀត ?

សូមរំឭកសិស្សថា ព្រះអម្ចាស់បានប្រទានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ ដល់ក្រុមអ្នកកាន់បព្វជិតភាពមួយក្រុមដែលបានអធិស្ឋានដើម្បីដឹងអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ អំពីការស្ថាបនាស៊ីយ៉ូន ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានសំដៅទៅលើក្រុមនេះអំពីពួកអ្នកកាន់បព្វជិតភាព ជា « អ្នកធ្វើការមុនដំបូង នៅក្នុងនគរចុងក្រោយនេះ » ( សូមមើល គ. និង ស. ៨៨:៧០, ៧៤) ហើយបានបង្គាប់ពួកគេឲ្យរៀបចំ និងចូលរៀនក្នុងសាលារៀនមួយ ដើម្បីត្រៀមខ្លួនពួកគេចេញផ្សាយដំណឹងល្អនៅក្នុងចំណោមជាតិសាសន៍នៅលើផែនដី ( សូមមើល គ. និង ស. ៨៨:៧៤, ៨៤, ១២៧) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៣–៧៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានបញ្ជាដល់ពួកអ្នកកាន់បព្វជិតភាពទាំងនេះឲ្យធ្វើដើម្បីត្រៀមខ្លួនបង្រៀនដល់អ្នកដទៃ ។

- តើ « ពួកអ្នកធ្វើការដំបូងគេ » ទាំងនេះត្រូវបានបញ្ជាឲ្យធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនបង្រៀនដល់អ្នកដទៃក្នុងនាមជាពួកអ្នកផ្សព្វផ្សាយសាសនា ? ( អ្នកអាចនឹងសូមសិស្សម្នាក់ឲ្យធ្វើជាអ្នកសរសេរ ហើយសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បី « រៀបចំ » « ត្រៀមខ្លួន » និង « ញែកចេញ » ខ្លួនយើងជាបរិសុទ្ធ ដើម្បីកាន់តែមានប្រសិទ្ធភាពក្នុងការចែកចាយដំណឹងល្អ ?
- តើការត្រូវបានសម្អាតពីអំពើបាប មានឥទ្ធិពលលើលទ្ធភាពរបស់យើង ដើម្បីចែកចាយដំណឹងល្អយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៧–៨០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់ បានបញ្ជាដល់អ្នកកាន់បព្វជិតភាពទាំងនេះឲ្យធ្វើ នៅពេលពួកគេជួបជាមួយគ្នា ។ សូមឲ្យសិស្ស រាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះអម្ចាស់សន្យាអ្វីខ្លះ ចំពោះអស់អ្នកដែលបង្រៀនដោយឧស្សាហ៍ព្យាយាម ? ( ថាព្រះគុណទ្រង់នឹងនៅជាមួយពួកគេ ហើយថាពួកគេនឹងត្រូវបានបង្រៀនកាន់តែល្អឥតខ្ចោះបន្ថែមទៀតនៅក្នុងគ្រប់អ្វីដែលពួកគេចាំបាច់ត្រូវយល់ដឹង ទាក់ទង ទៅនឹងនគរនៃព្រះ ) ។

- តើពាក្យថា « ព្រះគុណរបស់ព្រះអម្ចាស់នឹងនៅជាមួយអ្នក » មានន័យយ៉ាងណា (គ. និង ស. ៨៨:៧៨) ? ( ព្រះអម្ចាស់ នឹងជួយយើង នៅពេលយើងស្វែងរកដោយព្យាយាមដើម្បីបង្រៀន និងរៀនដំណឹងល្អ ) ។

- ចេញមកពីអ្វីដែលអ្នកបានរៀននៅក្នុង ខ ៧៧–៧៨ តើអ្នកនឹងថ្លែងនូវគោលការណ៍មួយស្ដីអំពីការបង្រៀនយ៉ាង ដូចម្ដេច ? ( សិស្សអាចនឹងប្រាប់នូវគោលការណ៍មួយចំនួន រួមមានដូចខាងក្រោម ៖ **នៅពេលយើងបង្រៀនគ្នា ទៅវិញទៅមកដោយឧស្សាហ៍ព្យាយាម នោះព្រះអម្ចាស់នឹងជួយយើងយល់សេចក្ដីពិតរបស់ទ្រង់កាន់តែបានល្អឥតខ្ចោះ ។ តាមរយៈការបង្រៀនដល់នរណាម្នាក់ នោះយើងអាចត្រៀមខ្លួនដើម្បីចែកចាយដំណឹងល្អជាមួយអ្នកដទៃ ។** អ្នកអាច សរសេរគោលការណ៍ទាំងនេះនៅលើក្ដារខៀន ដោយប្រើពាក្យសម្ដីរបស់សិស្ស ) ។

- តើការបង្រៀនដំណឹងល្អដល់អ្នកដទៃបានជួយអ្នកឲ្យយល់កាន់តែល្អប្រសើរអំពីដំណឹងល្អតាមវិធីណា ?

- យោងតាម ខ ៧៩ តើប្រធានបទណាផ្សេងទៀតដែលសំខាន់ដើម្បីយើងយល់ដឹង ? តើការទទួលបាននូវចំណេះដឹង ទូលំទូលាយដូច្នេះ អាចជួយយើងបង្រៀនដំណឹងល្អដល់អ្នកដទៃយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សមានអារម្មណ៍ពីសារៈសំខាន់ ហើយអនុវត្តគោលការណ៍ដែលពួកគេបានប្រាប់ពីខាងលើ សូមចាត់ ក្រុមសិស្សបួននាក់ឲ្យត្រៀមខ្លួន ហើយបង្រៀនមេរៀនតូចៗដូចខាងក្រោមទៅដល់សមាជិកក្រុមរបស់ពួកគេ ។ សូមសិស្សពីរនាក់នៅក្នុងក្រុមនិមួយៗឲ្យធ្វើការជាមួយគ្នាដើម្បីត្រៀមខ្លួនបង្រៀន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨១–៨៦ ហើយសិស្សពីរនាក់ទៀតឲ្យធ្វើការជាមួយគ្នាដើម្បីត្រៀមខ្លួនបង្រៀន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨៧–៩៨។ សូម ថតចម្លងសេចក្ដីណែនាំដូចខាងក្រោមសម្រាប់ក្រុមនិមួយៗ ។ សូមពួកគេឲ្យអានសេចក្ដីណែនាំ និងខព្រះគម្ពីរទាំងឡាយ រួចហើយសម្រេចពីរបៀបដែលពួកគេនឹងបង្រៀនមេរៀនតូចៗនិមួយៗនោះ ។ ( សូមលើកទឹកចិត្តសិស្សទាំងពីរនាក់នៅក្នុងចំណោមដៃគូនិមួយៗឲ្យចូលរួមនៅក្នុងការបង្រៀន ) ។ សូមពន្យល់ថា ដៃគូនឹងមានរយៈពេលប្រហែលជាប្រាំនាទី ដើម្បី ត្រៀមខ្លួន ហើយប្រហែលជាប្រាំពីរនាទី ដើម្បីបង្រៀន ។ បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីត្រៀមខ្លួនហើយ សូម អញ្ជើញដៃគូដែលបានចាត់តាំងឲ្យសិក្សាក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨១–៨៦ ដើម្បីបង្រៀនសិស្សដទៃទៀតនៅក្នុង ក្រុមរបស់ពួកគេ ។ បន្ទាប់មកសួរដល់សិស្សឲ្យផ្លាស់តួនាទី ហើយអញ្ជើញដៃគូដែលបានចាត់តាំងឲ្យសិក្សាក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨៧–៩៨ ដើម្បីបង្រៀន ។ (*កំណត់ចំណាំ ៖* បើអ្នកចង់បាន អ្នកអាចជ្រើសរើសបង្រៀនមេរៀនតូចៗ ដោយខ្លួនអ្នក ជំនួសឲ្យការសុំដល់សិស្សបង្រៀនដល់គ្នាទៅវិញទៅមក ) ។

### មេរៀនតូចៗ ទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨១–៨៦

សូមចាប់ផ្ដើមមេរៀនរបស់អ្នកដោយការសួរសំណួរខាងក្រោមនេះ ៖

- តើនៅពេលណា ដែលអ្នកមានអំណរគុណ ដោយសារតែនរណាម្នាក់បានព្រមានដល់អ្នកអំពីអ្វីមួយ ? (អ្នកក៏អាចចែកចាយ បទពិសោធន៍មួយផងដែរ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨១–៨៣ ឲ្យឮៗ ។ សូមឲ្យអ្នកដទៃទៀត រកមើលអ្វី ដែលព្រះអម្ចាស់បានបង្រៀនអំពីការព្រមាន ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ បន្ទាប់មក សួរ សំណួរដូចខាងក្រោមនេះ ៖

- តើវាមានន័យយ៉ាងណា ដែលយើងត្រូវបានព្រមាននោះ ? ( យើងត្រូវបានបង្រៀនអំពីសេចក្ដីពិតនៃដំណឹងល្អដែលបានស្ដារឡើង វិញរបស់ព្រះយេស៊ូវគ្រីស្ទ ) ។
- តើសេចក្ដីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? ( អ្នកទាំងឡាយដែលអ្នកបង្រៀន អាចប្រើពាក្យផ្សេង ប៉ុន្តែពួកគេ គួរប្រាប់អំពីគោលការណ៍ស្រដៀងគ្នាដូចខាងក្រោម ៖**ដោយសារតែយើងត្រូវបានព្រមានតាមរយៈសារលិខិតនៃដំណឹងល្អ នោះព្រះអម្ចាស់រំពឹងឲ្យយើងព្រមានដល់អ្នកជិតខាងយើងផងដែរ** ។ អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំសេចក្ដីពិតនេះ នៅក្នុង ខ ៨១) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨៤–៨៥ ដោយការពន្យល់ថា ព្រះអម្ចាស់បានណែនាំដល់ ពួកអ្នកកាន់បព្វជិតភាពដែលមានវត្តមាន នៅពេលយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះ ដើម្បីធ្វើការដោយឧស្សាហ៍ ព្យាយាមដើម្បីត្រៀមខ្លួនពួកគេ និងពួកបរិសុទ្ធឲ្យចៀសផុតពីការជំនុំជំរះនាពេលអនាគតដែលរង់ចាំពួកទុច្ចរិត ។

**សូមផ្ដល់ឱកាសដល់សិស្ស ឲ្យពន្យល់ ចែកចាយ និងថ្លែងទីបន្ទាល់**

ការអនុញ្ញាតឲ្យសិស្សបង្រៀនគ្នាទៅវិញទៅមក ផ្ដល់ឱកាសដល់ពួកគេពន្យល់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ចែកចាយគំនិត និងបទពិសោធន៍ ហើយថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដ៏ទេវភាព ។ ការធ្វើដូច្នេះ អាចជួយសិស្សកែលម្អការដល់ការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ និងលទ្ធភាពរបស់ពួកគេដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ នៅពេលអ្នកពន្យល់ ចែកចាយ ហើយ ថ្លែងទីបន្ទាល់ នោះព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំអ្នកឲ្យមានទីបន្ទាល់កាន់តែរឹងមាំអំពីសេចក្ដីពិតដែលអ្នកកំពុងតែបង្រៀននោះ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨៦ ឲ្យឮៗ ។ សូមឲ្យក្រុមរបស់អ្នកកមើលរបៀបដែលយើងគួរតែរស់នៅតាម នៅពេលដែលយើងត្រៀមខ្លួនចែកចាយដំណឹងល្អ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើ « ការកុំជាប់ជំពាក់ខ្លួនក្នុងអំពើបាប » មានន័យយ៉ាងណា ? តើការណែនាំនេះអាចអនុវត្តនៅក្នុងជីវិតរបស់អ្នក នៅពេលអ្នកត្រៀមខ្លួនដើម្បីទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ បម្រើបេសកកម្មពេញម៉ោង ឬរៀបការ ហើយមានគ្រួសារមួយយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សគិតអំពីរបៀបដែលការជាប់ជំពាក់ទៅនឹងអំពើបាប អាចជះឥទ្ធិពលលើលទ្ធភាពរបស់ពួកគេដើម្បីថ្លែងទីបន្ទាល់អំពីសេចក្ដីពិត សូមអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« គ្មានអ្នកផ្សព្វផ្សាយសាសនាណាអាចមិនប្រែចិត្តពីអំពើរំលងខាងផ្លូវភេទ ឬភាសាអាសគ្រាម ឬបណ្ដោយខ្លួនតាមរូបភាពអាសគ្រាម រួចហើយមករំពឹងទុកឲ្យអ្នកដទៃប្រែចិត្តចំពោះរឿងទាំងអស់នេះនោះទេ ! អ្នកមិនអាចធ្វើដូច្នោះបានឡើយ ។ ព្រះវិញ្ញាណនឹងពុំគង់នៅជាមួយអ្នកឡើយ ហើយពាក្យទាំងឡាយនឹងត្រូវស្លាក់នៅក្នុងបំពង់កអ្នក ពេលអ្នកថ្លែងវាចេញមក ។ អ្នកពុំអាចធ្វើដំណើរតាមផ្លូវដែល លីហៃ បានហៅថា ‹ផ្លូវហាមឃាត់ › នោះឡើយ នីហ្វៃទី ១ ៨:២៨ ហើយរំពឹងថាដឹកនាំអ្នកដទៃឲ្យដើរលើ ‹ ផ្លូវត្រង់ និងចង្អៀត › នោះឡើយ នីហ្វៃទី ២ ៣១:១៨ វាពុំអាចធ្វើទៅរួចទេ » ( We Are All Enlisted » *Ensign* ឬ *លីអាហូណា* ខែវិច្ឆិកា ឆ្នាំ ២០១១,ទំព័រ ៤៥ ) ។

អ្នកអាចនឹងចង់ចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការបន្តមានភាពស្អាតស្អំ ដើម្បីមានឥទ្ធិពលនៅក្នុងការចែកចាយដំណឹងល្អ ។ សូមលើកទឹកចិត្តដល់អ្នកទាំងឡាយដែលអ្នកកំពុងបង្រៀន ដើម្បីស្វែងរកភាពស្អាតស្អំចេញពីការជាប់ជំពាក់នឹងអំពើបាប ។

### មេរៀនតូចៗ ទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨៧–៩៨

សូមសួរដល់អ្នកទាំងឡាយដែលអ្នកបង្រៀន បើសិនជាពួកគេធ្លាប់ឮនរណាម្នាក់បានចែកចាយទីបន្ទាល់ប្រកបដោយអានុភាព ។ សូមអញ្ជើញពួកគេឲ្យពិពណ៌នាអំពីទីបន្ទាល់ និងពីអារម្មណ៍របស់ពួកគេ នៅពេលពួកគេបានស្ដាប់ឮអំពីវា ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨៧–៩១ ឲ្យឮៗ ។ សូមដល់សិស្សដែលអ្នកកំពុងបង្រៀនឲ្យរកមើលគំរូនៃទីបន្ទាល់ដ៏មានអានុភាព ។ បន្ទាប់ពីសិស្សបានអានរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- ពីមុនការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ តើទីបន្ទាល់ប្រភេទណាខ្លះ នឹងមានមកតាមទីបន្ទាល់របស់ពួកអ្នកផ្សព្វផ្សាយសាសនា ?

សូមអញ្ជើញសិស្សដែលអ្នកបង្រៀនឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៩២ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលពួកទេវតាស្ថានសួគ៌ នឹងមានបន្ទូល អំឡុងគ្រានេះពីមុនការយាងមកជាលើកទីពីរ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ សូមប្រាប់ពួកគេថា ពាក្យ *កូនកម្លោះ* សំដៅទៅលើព្រះយេស៊ូវគ្រីស្ទ ។

- ហេតុអ្វីក៏វាសំខាន់ដើម្បីយើងអាចបានត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៩៥–៩៨ ឲ្យឮៗ ។ សូមឲ្យសិស្សដែលអ្នកបង្រៀនរកមើលក្រុមមនុស្សពីរផ្សេងគ្នា ដែលនឹងលើកឡើងទៅជួបនឹងព្រះអង្គសង្គ្រោះនៅពេលទ្រង់យាងមក ។ បន្ទាប់មកសូមសួរសំណួរខាងក្រោមនេះ ៖

- តើនរណានឹងត្រូវលើកឡើង ឲ្យទៅជួបនឹងព្រះយេស៊ូវគ្រីស្ទ នៅពេលទ្រង់យាងមក ? ( ពួកបរិសុទ្ធរបស់ទ្រង់ ដែលនៅរស់ និងពួកបរិសុទ្ធរបស់ទ្រង់ ដែលបានស្លាប់ទៅហើយនោះ ) ។ អ្នកអាចនឹងផ្ដល់យោបល់ដល់សិស្សដែលអ្នកកំពុងបង្រៀនឲ្យគូសចំណាំពាក្យ ឬឃ្លាទាំងឡាយនៅក្នុងខគម្ពីរទាំងនេះ ដែលបង្រៀនអំពីសេចក្ដីពិតដូចខាងក្រោម ៖**ពួកសុចរិតនឹងត្រូវបានលើកឡើងឲ្យទៅជួបព្រះគ្រីស្ទ នៅពេលទ្រង់យាងមក )**។

សូមឲ្យអ្នកទាំងឡាយដែលអ្នកកំពុងបង្រៀន រំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៩៨ ហើយស្វែងរកពាក្យ ឬឃ្លាដែលពិពណ៌នាអំពីក្រុមនៃពួកសុចរិត ដែលនឹងចូលរួមនៅក្នុងការយាងមករបស់ព្រះអម្ចាស់ ។ បន្ទាប់មកសូមសួរសំណួរខាងក្រោមនេះ ៖

- តើពាក្យ ឬ ឃ្លាអ្វីខ្លះ ដែលអ្នកបានរកឃើញ ? ( អ្នកអាចនឹងចង់ពន្យល់ថា ឃ្លា « ផលដំបូង » សំដៅទៅលើពួកបរិសុទ្ធសុចរិត ដែលនឹងចេញមកនៅក្នុងការរស់ឡើងវិញជាលើកទីមួយ ) ។

សូមចែកចាយអំពីការស្រមៃរបស់អ្នកថា តើអ្នកនឹងមានអារម្មណ៍ថាទៅជាយ៉ាងណា ដើម្បីនៅក្នុងវត្តមាននៃការយាងមក ជាលើកទីពីរ ដូចបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

បន្ទាប់ពីក្រុមសិស្សបានបង្រៀនដល់គ្នាទៅវិញទៅមកហើយ សូមសួរសំណួរដូចខាងក្រោមទៅដល់សិស្សទាំងអស់ ៖

- តើការបង្រៀនអ្វីខ្លះ ដែលលេចធ្លោនៅក្នុងការពិភាក្សារបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨១–៩៨?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៩៧–១០៧ ដោយពន្យល់ថា ព្រះអម្ចាស់បានបើកសម្ដែងថា មនុស្សស្លាប់នឹង ត្រូវបានរស់ឡើងវិញតាមលំដាប់នៃសេចក្ដីសុចរិតរបស់ពួកគេ ។ អ្នកទាំងឡាយដែលត្រូវបានរស់ឡើងវិញដំបូងគេ នឹងគ្រង នគរសេឡេស្ទាល (សូមមើល គ. និង ស. ៨៨:៩៧–៩៨) ។ អ្នកទាំងឡាយដែលត្រូវបានរស់ឡើងវិញទីពីរ នឹងគ្រងនគរទេរេ ទ្រាល ( សូមមើល គ. និង ស. ៨៨:៩៩) ។ អ្នកទាំងឡាយដែលនឹងគ្រងនគរទេឡេស្ទាល នឹងត្រូវបានរស់ឡើងវិញ បន្ទាប់ពី សហសវត្សរ៍ ( សូមមើល គ. និង ស. ៨៨:១០០–១០១) ។ ទីបញ្ចប់ អ្នកទាំងឡាយដែល « ស្ថិតនៅក្នុងភាពសោកគ្រោក » –ជាអ្នកទាំងឡាយដែលបានរស់នៅលើផែនដី ហើយបានក្លាយជាកូនអន្តរធាន– នឹងត្រូវបានរស់ឡើងវិញហើយបណ្ដេញ ចេញទៅក្នុងភាពងងឹតសូន្យសុង (សូមមើល គ. និង ស. ៨៨:១០២) ។ បន្ទាប់ពីចុងបញ្ចប់នៃមួយពាន់ឆ្នាំក្នុងភាពសុខសាន្ត ដែលត្រូវបានស្គាល់ថា សហសវត្សរ៍ នោះសាតាំង និងអ្នកដើរតាមរបស់វា នឹងមកធ្វើចម្បាំងទាស់នឹងរាស្ត្រនៃព្រះ ដែលបាន ដឹកនាំដោយ មីកែល ( ឬអ័ដាម ) ។ សាតាំង និង អ្នកដើរតាមវា នឹងត្រូវចាញ់ ហើយត្រូវបណ្ដេញចេញទៅក្នុងភាពងងឹត សូន្យសុង ។

សូមចង្អុលបង្ហាញពីគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ « នៅពេលយើងបង្រៀនគ្នាទៅវិញទៅមកដោយឧស្សា ហ៍ព្យាយាម នោះព្រះអម្ចាស់នឹងជួយយើងយល់សេចក្ដីពិតរបស់ទ្រង់កាន់តែបានល្អឥតខ្ចោះ » ។ បន្ទាប់មកសូមសួរសំណួរ ខាងក្រោមនេះ ៖

- តើការយល់ដឹងរបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨១–៨៦ ឬ ៨៨:៨៧–៩៨ កាន់តែជ្រៅជ្រះប៉ុណ្ណា នៅពេលអ្នកបង្រៀនវាទៅអ្នកដទៃនៅថ្ងៃនេះ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យស្វែងរកឱកាសដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យទាំងឡាយ ដែលពួកគេនឹងទទួលសម្រាប់ការធ្វើដូច្នោះ ។

មេរៀនទី ៩៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១៤១

## បុព្វកថា

នេះគឺជាមេរៀនទីបួនចុងក្រោយគេ ក្នុងការពិភាក្សាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ ។ វិវរណៈត្រូវបានប្រគល់ឲ្យនៅក្នុងសន្និសីទមួយនៃពួកសង្ឃជាន់ខ្ពស់ នៅថ្ងៃទី ២៧–២៨ ខែធ្នូ ឆ្នាំ ១៨៣២ (ខ ១–១២៦) និងថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៨៣៣ (ខ ១២៧–១៤១) ។ មេរៀននេះគ្របដណ្ដប់ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១៤១ នៅក្នុងផ្នែកនៃវិវរណៈនេះ ព្រះអម្ចាស់បានត្រាស់បង្គាប់ដល់ក្រុមអ្នកកាន់បព្វជិតភាពឲ្យរៀបចំសាលារបស់ពួកព្យាការី នៅក្រោមការដឹកនាំរបស់ យ៉ូសែប ស្ម៊ីធ ។ អ្នកទាំងឡាយដែលចូលរួមនៅក្នុងសាលារៀន គឺត្រូវរៀនជាមួយគ្នាដោយការសិក្សា និងដោយសេចក្ដីជំនឿ ហើយបង្ហាញសេចក្ដីស្រឡាញ់ និងមិត្តភាពចំពោះគ្នាទៅវិញទៅមក ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១២៦

*ព្រះអម្ចាស់ពិពណ៌នាអំពីគំរូនៃការរៀនសូត្រ*

សូមចាប់ផ្ដើមដោយការពិភាក្សានូវសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកកំពុងរៀនបានអ្វីខ្លះនៅសាលារៀននៅពេលនេះ ? នៅផ្ទះ ? នៅកន្លែងធ្វើការ ? នៅព្រះវិហារ ?
- តើការរៀនអំពីប្រធានបទនៅសាលារៀន ដូចជាមុខវិជ្ជាគណិតវិទ្យា ឬវិទ្យាសាស្ត្រខុសពីការរៀនសូត្រអំពីដំណឹងល្អយ៉ាងដូចម្ដេចដែរ ? តើវាអាចដូចគ្នាយ៉ាងដូចម្ដេច ?

សូមពន្យល់ថា នៅក្នុងទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ នៅខែ មករា ឆ្នាំ ១៨៣៣ ក្រុមនៃអ្នកកាន់បព្វជិតភាពមួយក្រុមបានធ្វើតាមការបង្គាប់របស់ព្រះអម្ចាស់ឲ្យជួបជុំគ្នានៅកន្លែងមួយ ដែលហៅថា សាលានៃពួកព្យាការី ដើម្បីត្រៀមខ្លួនផ្សាយដំណឹងល្អនៅពេញផែនដី ។ នៅពេលពួកគាត់ជួបជុំគ្នា ព្រះអម្ចាស់បានបង្រៀនដល់បងប្អូនប្រុសទាំងនេះអំពីរបៀបដើម្បីត្រូវបានស្អាង ឬលើកតម្កើង តាមរយៈព្រះវិញ្ញាណ នៅពេលពួកគេរៀនជាមួយគ្នា ។ សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍ទាំងឡាយអំពីការរៀនសូត្រ នៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១៤១ នៅថ្ងៃនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលសមាជិកនៃសាលានៃពួកព្យាការីត្រូវស្វែងរកការរៀនសូត្រ ។

- តើបងប្អូនប្រុសទាំងនេះត្រូវស្វែងរកការរៀនសូត្រយ៉ាងដូចម្ដេច ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាក្នុងការរៀនសូត្រ « ដោយសារការសិក្សា និង ដោយសារសេចក្ដីជំនឿផង » នោះ ?

ដើម្បីជួយសិស្សយល់អំពីអត្ថន័យនៃការរៀនសូត្រដោយសេចក្ដីជំនឿ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ថា ៖



ការរៀនសូត្រដោយសេចក្ដីជំនឿ តម្រូវឲ្យមានកិច្ចខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និង ខាងរូបកាយ ហើយពុំមែនគ្រាន់តែជាការទទួលភាពអកម្មនោះទេ ។. . .

« . . .ការរៀនសូត្រដោយសេចក្ដីជំនឿ ពុំអាចត្រូវបានផ្ទេរពីគ្រូបង្រៀនទៅសិស្សម្នាក់តាមរយៈការបង្រៀន ការបង្ហាញ ឬតាមសកម្មភាពក្នុងថ្នាក់រៀនទេ តែសិស្សម្នាក់ត្រូវតែអនុវត្តសេចក្ដីជំនឿ និងធ្វើសកម្មភាព ដើម្បីទទួលបានចំណេះដឹងសម្រាប់ខ្លួនគាត់ » (Seek Learning by Faith» *Ensign* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៦៤ ) ។

ចូរពន្យល់ថា យើងអាចរៀនសូត្រដោយសេចក្ដីជំនឿ នៅពេលយើងចូលរួមដោយសកម្ម និងប្រកបដោយការអធិស្ឋាននៅក្នុងឱកាសរៀនសូត្រទាំងឡាយ បន្ទាប់មកអនុវត្តនូវអ្វីដែលយើងបានរៀននោះ ។ យើងរៀននៅពេលយើងអនុវត្តសេចក្ដីជំនឿរបស់យើង តាមរយៈការគោរពប្រតិបត្តិ ។

- សូមកត់សម្គាល់នៅដើម ខ ១១៨ ថាព្រះអម្ចាស់បានចង្អុលបង្ហាញថាមនុស្សមួយចំនួនពុំមានសេចក្ដីជំនឿទេ ។ តើយើងអាចរៀនអ្វីខ្លះ មកពីខនេះ អំពីរបៀបដើម្បីបង្កើនសេចក្ដីជំនឿរបស់យើង ? ( សូមជួយសិស្សឲ្យប្រាប់គោលការណ៍ស្រដៀងគ្នាដូចខាងក្រោម ៖**បើយើងស្វែងរកការរៀនសូត្រដោយសកម្ម តាមរយៈការសិក្សា និងសេចក្ដីជំនឿ នោះសេចក្ដីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទនឹងរីកចម្រើន ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។

ដើម្បីជួយសិស្សយល់អំពីស្ថានភាពមួយចំនួនដែលពួកគេអាចអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ សូមអានឮៗនូវស្ថានភាពដូចខាងក្រោម ។ បន្ទាប់ពីការអាននិមួយៗ សូមសិស្សឲ្យពន្យល់អំពីរបៀបដែលមនុស្សអាចស្វែងរកការរៀនសូត្រដោយសកម្ម តាមរយៈការសិក្សា និងសេចក្ដីជំនឿ ។ សូមពួកគេឲ្យពន្យល់អំពីរបៀបដែលការធ្វើដូច្នោះនឹងជួយបុគ្គលនោះឲ្យបង្កើនសេចក្ដីជំនឿផងដែរ ។

១. យុវនារីម្នាក់អានព្រះគម្ពីរជាទៀងទាត់ ប៉ុន្តែនាងកម្រឈប់មួយសន្ទុះដើម្បីគិតអំពីអ្វីដែលនាងអានណាស់ ។ នាងពុំដែលមានអារម្មណ៍ថា ការអានព្រះគម្ពីរមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់នាងនោះទេ ។

២. យុវជនម្នាក់ចូលរួមក្នុងការប្រជុំនៅព្រះវិហាររបស់គាត់ ហើយរីករាយនឹងការចូលរួមក្នុងការពិភាក្សាក្នុងថ្នាក់រៀន ។ ពេលខ្លះគាត់មានអារម្មណ៍បំផុសគំនិតឲ្យធ្វើការផ្លាស់ប្ដូរនៅក្នុងជីវិតរបស់គាត់ដោយផ្អែកទៅលើអ្វីដែលគាត់បានរៀន ប៉ុន្តែតាមធម្មតា គាត់ពុំអនុវត្តតាមការបំផុសគំនិតទាំងនោះទេ ។

បន្ទាប់ពីសិស្សក្នុងថ្នាក់បានពិភាក្សាអំពីស្ថានភាពទាំងនេះរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា សេចក្ដីជំនឿរបស់អ្នកកើនឡើង ដែលជាលទ្ធផលបានមកពីការស្វែងរកការរៀនសូត្រដោយសកម្ម តាមរយៈការសិក្សា និងសេចក្ដីជំនឿ ? តើសកម្មភាពរបស់អ្នកជួយឲ្យសេចក្ដីជំនឿរបស់អ្នករីកចម្រើនយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៩–១២០ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ឲ្យពួកបរិសុទ្ធធ្វើ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា ក្នុងការឆ្លើយតបចំពោះបទបញ្ញត្តិដើម្បីសាងសង់ដំណាក់ឡើង ដែលបានពិពណ៌នានៅក្នុង ខ ១១៩ នៅទីបំផុតពួកបរិសុទ្ធបានសាងសង់ព្រះវិហារបរិសុទ្ធខឺតឡង់ ។ ខណៈដែលព្រះវិហារបរិសុទ្ធស្ថិតនៅក្នុងការសាងសង់នៅឡើយ នោះសាលារៀនពួកព្យាការីបានជួបជុំគ្នានៅបន្ទប់ខាងលើនៃហាងរបស់ នូវល ខេ វិតនី នៅទីក្រុងខឺតឡង់ ។

- តើការទូន្មាននៅក្នុង ខ ១១៩ ក៏អាចជាប់ទាក់ទងទៅនឹងទីកន្លែង ដែលបងប្អូនប្រុសបានជួបគ្នាសម្រាប់សាលារៀននៃពួកព្យាការីយ៉ាងដូចម្ដេច ? ទាក់ទងទៅនឹងគេហដ្ឋានរបស់យើងយ៉ាងដូចម្ដេច ? ទាក់ទងទៅនឹងកិច្ចខិតខំផ្ទាល់ខ្លួនរបស់អ្នកដើម្បីសិក្សានៅសាលារៀនយ៉ាងដូចម្ដេច ? ( សាលានៃពួកព្យាការី ត្រូវបានធ្វើជាគំរូ បន្ទាប់ពីគោលការណ៍ទាំងឡាយត្រូវបានបង្រៀននៅក្នុងខគម្ពីរនេះ ។ គេហដ្ឋានរបស់យើង អាចត្រូវបានប្រទានពរឲ្យជាកន្លែងនៃការអធិស្ឋាន ការតមអាហារ សេចក្ដីជំនឿ ការរៀនសូត្រ និងរបៀបរៀបរយ ) ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២១–១២៦ ជាមួយដៃគូរបស់ពួកគេ ហើយប្រាប់អំពីរបៀបដែលព្រះអម្ចាស់បានរំពឹងទុកឲ្យបងប្អូនប្រុសនៅសាលានៃពួកព្យាការី ឲ្យរៀបរយខ្លួនគេ ។ អ្នកអាចស្នើឲ្យ ពួកគេគូសចំណាំចំពោះអ្វីដែល ពួកគេរកឃើញ ។ នៅពេលសិស្សកំពុងសិក្សាអំពីខគម្ពីរទាំងនេះ សូមសរសេរការណែនាំដូចខាងក្រោមនៅលើក្ដារខៀន សម្រាប់ដៃគូនិមួយៗឲ្យបំពេញជាមួយគ្នាបន្ទាប់ពីពួកគេបានស្រាវជ្រាវបទគម្ពីរហើយ ៖

> *សូមសម្រេចថាតើចំណុចនៃការទូន្មានមួយណា ដែលជាជំនួយពិសេសសម្រាប់យុវវ័យ ដែលកំពុងស្វែងរកការរៀនសូត្រដំណឹងល្អ ។ ចូរពិភាក្សាថាហេតុអ្វីក៏អ្នកគិតថា សកម្មភាពទាំងនេះសំខាន់នៅក្នុងការជួយដល់នរណាម្នាក់រៀនដំណឹងល្អ ។*

បន្ទាប់ពីសិស្សមានពេលអាន និងពិភាក្សាអំពីដំបូន្មានរបស់ព្រះអម្ចាស់គ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់នូវអ្វីដែលពួកគេបានរៀននៅក្នុងការពិភាក្សារបស់ពួកគេ ។ នៅពេលពួកគេឆ្លើយតប សូមពិចារណាអំពីការប្រើសំណួរ និងការពន្យល់ដូចខាងក្រោមមួយចំនួន ដើម្បីជួយពួកគេយល់នូវដំបូន្មានខ្លះៗរបស់ព្រះអម្ចាស់ ៖

- តើអ្នកគិតថា « ការឈប់ពីសម្ដីអសារឥតការទាំងអស់របស់អ្នក ពីសំណើចទាំងអស់. . . និងគំនិតផ្ដេសផ្ដាសទាំងអស់របស់អ្នក » (ខ ១២១) មានន័យយ៉ាងណា ? ហេតុអ្វីក៏ការឈប់ធ្វើនូវរឿងទាំងនោះនៅក្នុងកន្លែងខាងវិញ្ញាណ អាចជាជំនួយនៅក្នុងកិច្ចខិតខំរបស់យើងដើម្បីរៀននូវរឿងទាំងឡាយដែលពិសិដ្ឋដូច្នេះ ?

សូមពន្យល់ថា ការជួបជុំសម្រាប់សាលានៃពួកព្យាការី គឺពិសិដ្ឋ ។ ការណែនាំទាំងនេះស្ដីអំពីការសើច និងការនិយាយសម្ដីអសារឥតការ មានន័យថា អ្នកទាំងឡាយដែលចូលរួមនៅក្នុងសាលានៃពួកព្យាការី ចាំបាច់ត្រូវមានគារវភាពនៅក្នុងកន្លែងពិសិដ្ឋ ។ ការជួបជុំទាំងនេះ នឹងធ្វើឡើងនៅក្នុងព្រះវិហារបរិសុទ្ធ ។

- សូមកត់សម្គាល់នូវពាក្យដដែលៗថា *ទាំងអស់គ្នា* នៅក្នុង ខ ១២២។ តើសិស្សម្នាក់ អាចទទួលរងឥទ្ធិពលដែរឬទេ បើសិស្សក្នុងថ្នាក់ *ទាំងអស់គ្នា* រៀនមេរៀន ហើយព្យាយាមដើម្បីរៀនមកពីគ្នាទៅវិញទៅមកនោះ ?

- តើអ្នកគិតថាការដេក « យូរជាងដែលត្រូវការ » ជះឥទ្ធិពលដល់លទ្ធភាពនៃការរៀនសូត្ររបស់យើង ឬការទទួលអារម្មណ៍ខាងវិញ្ញាណយ៉ាងដូចម្ដេច ? តើអ្នកគិតថាការដេកក្នុងចំនួនម៉ោងត្រឹមត្រូវ និងការក្រោកពីព្រលឹម អាចជួយយើងរៀនសូត្របានកាន់តែល្អប្រសើរតាមវិធីណា ?

- តើអ្នកនឹងសង្ខេបដំបូន្មានអំពីការរៀនសូត្រដែលត្រូវបានផ្ដល់ឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១២៦ ដោយរបៀបណា ? ( សិស្សអាចនឹងប្រាប់អំពីគោលការណ៍ផ្សេងៗ។ បន្ទាប់ពីពួកគេឆ្លើយតបរួច សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ការធ្វើសកម្មភាពសុចរិត និងការឈប់ពីសកម្មភាពពុំសុចរិត នឹងជួយយើងរៀនសូត្រ ហើយត្រូវបានស្អាងឡើង** )

- តើឥរិយាបទណា ដែលបានប្រាប់នៅក្នុងខគម្ពីរទាំងឡាយ អាចឲ្យសិស្សក្នុងថ្នាក់សិក្ខាសាលារបស់យើង អាចទទួលយក ឬបោះបង់ ដើម្បីយើងអាចរៀនសូត្រអំពីដំណឹងល្អបានកាន់តែល្អប្រសើរ ហើយត្រូវបានស្អាងជាមួយគ្នា ?

សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២១–១២៦ ហើយពិចារណាថាតើដំបូន្មានអ្វីដែលពួកគេចាំបាច់ត្រូវទទួលយកឲ្យបានកាន់តែពេញលេញនៅក្នុងជីវិតនោះ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរនូវគោលដៅមួយដើម្បីធ្វើសកម្មភាពទៅលើអ្វីដែលពួកគេបានរៀន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៧–១៤១

### *ព្រះអម្ចាស់បានរៀបចំរបៀបរៀបរយនៃសាលាពួកព្យាការី*

សូមអញ្ជើញសិស្សមកកាន់ក្ដារខៀន ហើយសរសេរពីទីកន្លែងមួយចំនួនដែលពួកគេសិក្សាដំណឹងល្អ ។ ( ចម្លើយអាចរួមមានដូចខាងក្រោម ៖*ថ្នាក់សាលាថ្ងៃអាទិត្យ ថ្នាក់យុវនារី ឬកូរ៉ុមបព្វជិតភាព ថ្នាក់សិក្ខាសាលា* និង *គេហដ្ឋាន*) ។ សូមឲ្យសិស្សពិចារណាថា បើមានមនុស្សនៅក្នុងកន្លែងទាំងនេះ ដែលពួកគេពុំធ្លាប់ស្គាល់ច្បាស់ ឬដែលពួកគេកំពុងតែពុះពារដើម្បីចុះសម្រុងជាមួយនោះ ។ សូមអញ្ជើញពួកគេឲ្យគិតអំពីមនុស្សម្នាក់នៃមនុស្សទាំងនេះ នៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៧–១៤១។ សូមឲ្យពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖

- តើទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងអ្នកទាំងនេះ ដែលខ្ញុំរៀនដំណឹងល្អជាមួយនោះ ជះឥទ្ធិពលលើសមត្ថភាពរបស់ខ្ញុំដើម្បីរៀនសូត្រ និងត្រូវបានស្អាងឡើងដោយព្រះវិញ្ញាណយ៉ាងដូចម្ដេច ?

សូមពន្យល់ថា ព្រះអម្ចាស់រំពឹងឲ្យសមាជិកនៃសាលាពួកព្យាការី បង្កើតទំនាក់ទំនងល្អនឹងគ្នាទៅវិញទៅមក នៅពេលពួកគេរៀនជាមួយគ្នា ។ សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៨–១៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវតួនាទីរបស់គ្រូបង្រៀននៅក្នុងការបង្កើតបរិយាកាសរៀនសូត្រខាងវិញ្ញាណនៅក្នុងសាលាពួកព្យាការី ។

- តើគ្រូបង្រៀននៃសាលាពួកព្យាការីបង្កើតបរិយាកាសរៀនសូត្រខាងវិញ្ញាណយ៉ាងដូចម្ដេច ? ( អ្នកអាចនឹងពន្យល់ថា គ្រូបង្រៀនស្វាគមន៍សមាជិកនៃថ្នាក់រៀន មានន័យថាគាត់ជំរាបសួរពួកគេ នៅពេលពួកគេចូលថ្នាក់រៀន ។ នេះគឺជាការស្វាគមន៍ជាក់លាក់មួយនៅក្នុងសាលាពួកព្យាការី ) ។

- តើអ្នកកត់សម្គាល់អំពីការស្វាគមន៍ ឬការជំរាបសួរនៅក្នុង ខ ១៣៣ អ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៣៥–១៣៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវតួនាទីរបស់សិស្សនៅក្នុងការបង្កើតបរិយាកាសរៀនសូត្រល្អ ។

- តើទំនាក់ទំនងប្រភេទណា ដែលសមាជិកនៃសាលានៃពួកព្យាការីមានចំពោះគ្នាទៅវិញទៅមក ?

- ស្របតាម ខ ១៣៧ តើព្រះអម្ចាស់សន្យាអ្វីខ្លះ បើសមាជិកនៃសាលានៃពួកព្យាការី នឹងធ្វើតាមការណែនាំរបស់ទ្រង់ ? ( សាលានឹងក្លាយទៅជាកន្លែងបរិសុទ្ធមួយ ដែលព្រះវិញ្ញាណ នឹងស្អាងពួកលោកឡើង ) ។

- តើអ្វីខ្លះអាចនឹងកើតឡើងនៅក្នុងសាលារៀននៃសាសនាចក្ររបស់យើង ឬ គេហដ្ឋានរបស់យើង បើយើងធ្វើតាមការណែនាំរបស់ព្រះអម្ចាស់នៅក្នុង ខ ១២៨–១៣៧? ( សិស្សអាចនឹងប្រាប់នូវគោលការណ៍ផ្សេងៗ ប៉ុន្តែអ្នកអាចនឹងចង់គូសបញ្ជាក់ដូចខាងក្រោម ៖**បើយើងបង្ហាញមិត្តភាព និងក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក នោះយើងអាចអញ្ជើញព្រះវិញ្ញាណ នៅពេលយើងសិក្សាដំណឹងល្អជាមួយគ្នា** )។

សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅមើលគារវកិច្ចនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៣៣ ។

- តើអ្នកគិតថាយើងអាចបង្ហាញ « នូវការសម្រេចចិត្តដែលជាប់ ឥតកម្រើក ហើយឥតប្រែប្រួលដើម្បីជាមិត្ត [ម្នាក់] » ចំពោះសិស្សក្នុងថ្នាក់ ឬសមាជិកគ្រួសារដែលយើងអាចនឹងពុំស្គាល់ច្បាស់ ឬអាចនឹងពិបាកដើម្បីស្រឡាញ់នោះយ៉ាងដូចម្ដេច ?

- តើនៅពេលណា ដែលអ្នកមានបទពិសោធន៍ទទួលបានបរិយាកាសរៀនសូត្រដំណឹងល្អ ចាត់ទុកជាកន្លែងសម្រាប់មនុស្សគ្រប់រូបត្រូវបានសម្រេចចិត្តដើម្បីធ្វើជាមិត្តនោះ ? ( សូមពិចារណាធ្វើការចែកចាយបទពិសោធន៍របស់អ្នកផ្ទាល់ ) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលពួកគេអាចអភិវឌ្ឍការតាំងចិត្តក្នុងការស្រឡាញ់អ្នកទាំងឡាយដែលពួកគេរៀនដំណឹងល្អជាមួយ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួល ដើម្បីបង្ហាញនូវសណ្ដានចិត្តល្អ និងសេចក្ដីស្រឡាញ់កាន់តែខ្លាំងចំពោះមិត្តរួមថ្នាក់ និងសមាជិកគ្រួសារ ។ សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងជួយពួកគេ នៅពេលពួកគេព្យាយាមដើម្បីស្រឡាញ់អ្នកដទៃ ។

មេរៀនទី ៩៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩

## បុព្វកថា

នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ១៨៣៣ យ៉ូសែប ស្ម៊ីធ បានទូលសួរដល់ព្រះអម្ចាស់ អំពីការប្រើថ្នាំជក់របស់ពួកអ្នកកាន់បព្វជិតភាពនៅក្នុងការប្រជុំរបស់ពួកគេ ។ នៅក្នុងការឆ្លើយតប ព្រះអម្ចាស់បានប្រទានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ដែលត្រូវបានស្គាល់ថាជា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ នៅក្នុងនោះ ព្រះអម្ចាស់បានព្រមានទាស់នឹងការប្រើសារធាតុគ្រោះថ្នាក់ ហើយបានលើកទឹកចិត្តឲ្យបរិភោគអាហារដែលមានសុខភាពល្អ ។ ព្រះអម្ចាស់ក៏បានសន្យាផងដែរថា អ្នកទាំងឡាយដែលធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ នឹងត្រូវបានប្រទានពរទាំងខាងរូបកាយ និងខាងវិញ្ញាណ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១–៣

*ព្រះអម្ចាស់ណែនាំវិវរណៈដែលត្រូវបានស្គាល់ថាជា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ*

សូមសរសេរ *ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ* លើក្ដារខៀន ហើយសួរសំណួរដូចខាងក្រោម ៖

- តើអ្នកធ្លាប់ត្រូវពន្យល់ដល់នរណាម្នាក់ថា ហេតុអ្វីអ្នកពុំផឹកស្រា ផឹកតែ ឬផឹកកាហ្វេ ឬប្រើថ្នាំជក់ដែរឬទេ ? តើអ្នកនិយាយយ៉ាងដូចម្ដេចខ្លះ ? តើមនុស្សឆ្លើយតបយ៉ាងដូចម្ដេច ? ( បើអ្នកចង់ អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្ដារខៀនមុនពេលថ្នាក់រៀន ។ នៅពេលចាប់ផ្ដើមថ្នាក់រៀន អ្នកអាចបំបែកសិស្សជាគូៗ ហើយអញ្ជើញពួកគេឲ្យឆ្លើយសំណួរទាំងបីនេះជាមួយគ្នា ។ បន្ទាប់មក សុំឲ្យពួកគេរៀបរាប់អំពីបទពិសោធន៍មួយចំនួនរបស់ពួកគេដល់ថ្នាក់ទាំងមូល ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្ដីផ្ដើមកថាខណ្ឌសម្រាប់ គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៩ ។ សូមឲ្យសិស្សក្នុងថ្នាក់ប្រាប់អំពីស្ថានភាពទាំងឡាយដែលនាំឲ្យយ៉ូសែប ទទួលបានវិវរណៈនេះ ។ សូមអញ្ជើញពួកគេឲ្យរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ ឬឃ្លាដែលពិពណ៌នាអំពីគោលបំណងរបស់ព្រះអម្ចាស់ក្នុងការប្រទានឲ្យនូវវិវរណៈនេះ ។

- ស្របតាម ខ ២–៣ ហេតុអ្វីក៏វិវរណៈនេះត្រូវបានប្រទានឲ្យ ? ( អ្នកអាចចាំបាច់ត្រូវពន្យល់ថាឃ្លា « សេចក្ដីសង្គ្រោះខាងសាច់ឈាម » ទាក់ទងទៅនឹងសុខុមាលភាពខាងរូបកាយរបស់យើង និងឥទ្ធិពលរបស់វាទៅលើសុខុមាលភាពខាងវិញ្ញាណរបស់យើង ) ។

សូមចង្អុលបង្ហាញថា ពីដំបូងព្រះអម្ចាស់ពុំប្រទានពាក្យសម្ដី នៃប្រាជ្ញាវាងវៃដល់ពួកបរិសុទ្ធជាបទបញ្ញត្តិមួយឡើយ ( សូមមើល គ. និង ស. ៨៩:២) ។ ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានពន្យល់ថា ៖



« បើសិនជា [ ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ] ត្រូវបានប្រទានឲ្យជាបទបញ្ញត្តិមួយ នោះវានឹងនាំមនុស្សគ្រប់គ្នា ដែលបានញៀននឹងការប្រើគ្រឿងគ្រោះថ្នាក់ទាំងនេះ ស្ថិតនៅក្រោមការដាក់ទោសជាមិនខាន ដូច្នេះព្រះអម្ចាស់ដ៏ប្រកបដោយក្ដីមេត្តា បានប្រទានដល់ពួកគេនូវឱកាសដើម្បីយកឈ្នះ មុនពេលដែលទ្រង់នាំពួកគេទៅដាក់នៅក្រោមក្រឹត្យវិន័យ ( នៅក្នុង Conference Report, ខែ តុលា ឆ្នាំ ១៩១៣, ទំព័រ ១៤ ) ។

សូមពន្យល់ថា ដោយសារតែការណ៍នេះ យើងគួរតែប្រុងប្រយ័ត្នកុំវិនិច្ឆ័យដល់ពួកអ្នកដឹកនាំ និងសមាជិកសាសនាចក្រជំនាន់មុនមួយចំនួនឡើយ ទោះជាបន្ទាប់ពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃត្រូវបានបើកសម្ដែងហើយក្ដី ក៏ការប្រើសារធាតុទាំងនោះត្រូវបានហាមឃាត់នៅសព្វថ្ងៃនេះដែរ។ ក្នុងប្រវត្តិសាស្ត្រសាសនាចក្រជំនាន់មុនទាំងមូល ពួកអ្នកដឹកនាំបានអញ្ជើញពួកបរិសុទ្ធឲ្យរស់នៅតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃឲ្យកាន់តែពេញលេញ ។ នៅក្នុងសន្និសីទទូទៅនាសរទរដូវ ឆ្នាំ ១៨៥១ ព្រិកហាំ យ៉ង់ បានដាក់ស្នើសុំឲ្យពួកបរិសុទ្ធទាំងអស់ ចុះសេចក្ដីសញ្ញាជាផ្លូវការដើម្បីចៀសវាងពី តែ កាហ្វេ ថ្នាំជក់ និងស្រាវីស្គី ។ នៅថ្ងៃទី ១៣

ខែតុលា ឆ្នាំ ១៨៨២ ព្រះអម្ចាស់បានបើកសម្ដែងដល់ប្រធាន យ៉ូហាន ថេលើរ ថាពាក្យសម្ដីនៃប្រាជ្ញាវាងវៃត្រូវបានចាត់ទុកថាជាបទបញ្ញត្តិមួយ ។ នៅក្នុងឆ្នាំ ១៩១៩ គណៈប្រធានទីមួយ នៅក្រោមការដឹកនាំរបស់ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត បានធ្វើឲ្យការគោរពពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ជាតម្រូវការមួយដើម្បីទទួលបានប័ណ្ណចូលព្រះវិហារបរិសុទ្ធ ។ ពាក្យសម្ដីនៃប្រាជ្ញាវាងវៃបន្តជាបញ្ញត្តិសំខាន់មួយនៅបច្ចុប្បន្ននេះ ហើយការគោរពតាមវា គឺជាលក្ខខណ្ឌមួយសម្រាប់ពិធីបុណ្យជ្រមុជទឹក ការចូលរួមក្នុងព្រះវិហារបរិសុទ្ធ ការបម្រើផ្សព្វផ្សាយសាសនា និងការបម្រើសក្ដិសមដទៃទៀតនៅក្នុងសាសនាចក្រ ។

នៅលើក្ដារខៀន ពីខាងក្រោមពាក្យ *ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ* បន្ថែម សូមសរសេរឃ្លា *គោលការណ៍ដោយសេចក្ដីសន្យា* ចេញមកពី ខ ៣ ត្រូវបានគេស្គាល់ដូចខាងក្រោម ។ អ្នកក៏អាចស្នើឲ្យសិស្សគូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់ពួកគេផងដែរ ។ ឃ្លានេះនឹងធ្វើជាគម្រោងមួយសម្រាប់មេរៀនដែលនៅសល់ ។

> *គោលការណ៍ ដោយ សេចក្ដីសន្យា*

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:៤–៩

*ព្រះអម្ចាស់ព្រមានដល់ពួកបរិសុទ្ធកុំឲ្យប្រើស្រា ថ្នាំជក់ តែ ឬកាហ្វេ*

សូមបង្ហាញសិស្សនូវដងសន្ទូចមួយ និងនុយខ្លះៗឬគូររូបភាពនៅលើក្ដារខៀន ។



- តើអ្នកស្ទូចត្រីបញ្ឆោតត្រីសឹនុយសន្ទូចតាមវិធីណាខ្លះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថានរណាដែលព្រះអម្ចាស់បានព្រមានថានឹងជាអ្នកដាក់នុយបញ្ឆោតពួកបរិសុទ្ធនៅថ្ងៃចុងក្រោយ ។

- តើព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធអ្វីខ្លះ នៅក្នុងខនេះ ?

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀនពីក្រោមពាក្យ *គោលការណ៍* ៖ **ដោយសារអំពើអាក្រក់ និងផែនការទាំងឡាយដែលមាននៅថ្ងៃចុងក្រោយ នោះព្រះអម្ចាស់បានព្រមានដល់យើងកុំឲ្យប្រើសារធាតុដែលនាំឲ្យគ្រោះថ្នាក់ទាំងឡាយ ។** សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:៥–៩ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលជាសារធាតុ ដែលព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធកុំឲ្យទទួលទានចូលក្នុងរូបកាយរបស់ពួកគេ ។ អ្នកអាចផ្ដល់យោបល់ថា សិស្សគួរគូសចំណាំចំពោះអ្វីដែលពួកគេរកឃើញ ។

- តើសារធាតុអ្វីខ្លះ ដែលព្រះអម្ចាស់ព្រមានដល់ពួកបរិសុទ្ធកុំឲ្យទទួលទានចូលក្នុងរូបកាយរបស់ពួកគេ ? ( អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពួកអ្នកដឹកនាំសាសនាចក្របានថ្លែងថា ពាក្យ « ភេសជ្ជៈក្ដៅ » សំដៅទៅលើ តែ និង កាហ្វេ ) ។ តើសារធាតុទាំងនេះមានគ្រោះថ្នាក់អ្វីខ្លះ ?

សូមចង្អុលបង្ហាញថា ស្រា និងថ្នាំជក់ មាននូវការប្រើប្រាស់ត្រឹមត្រូវ និងការប្រើប្រាស់មិនត្រឹមត្រូវផងដែរ ( សូមមើល គ. និង ស. ៨៩:៧–៨) ។ នៅសព្វថ្ងៃនេះ មានសារធាតុដទៃទៀត ដែលអាចត្រូវបានប្រើប្រាស់ខុសឆ្គង ហើយជាលទ្ធផលវាក្លាយជាគ្រោះថ្នាក់ និងញៀន ។ ពួកអ្នកដឹកនាំសាសនាចក្របានព្រមានទាស់នឹងការប្រើប្រាស់នូវរាល់ភេសជ្ជៈ ថ្នាំញៀន សារធាតុជាតិគីមី ឬការប្រើប្រាស់ដែលគ្រោះថ្នាក់ ដែលនាំឲ្យដេះតទិ្ធពល « ខ្ពស់ » ឬឥទ្ធិពលក្លែងក្លាយដទៃទៀត ដែលអាចគ្រោះថ្នាក់ដល់រូបកាយ ឬគំនិតរបស់យើង ។ សារធាតុទាំងនេះ រួមមាន កញ្ឆា ថ្នាំស្រវឹង ការមិនគោរពតាមវេជ្ជបញ្ជា ឬ ឱសថដែលអាចជាវដោយឥតមានវេជ្ជបញ្ជា ដែលត្រូវបានគេ បំពាន និង សារធាតុគីមីដែលប្រើនៅតាមផ្ទះ ។ ( សូមមើល *ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ, ឆ្នាំ ២០១១], ទំព័រ ២៦) ។

- ហេតុអ្វីក៏មនុស្សមួយចំនួនព្យាយាមបញ្ចុះបញ្ចូលអ្នកឲ្យទទួលទានសារធាតុទាំងឡាយដែលព្រះអម្ចាស់បានហាមឃាត់ដូច្នេះ ? ( មនុស្សមួយចំនួន មានអារម្មណ៍ថាវាមានប្រជាប្រិយភាពដើម្បីទទួលទាននូវសារធាតុទាំងនេះ ។ អ្នកផ្សេងទៀតព្យាយាមរកប្រាក់ចំណេញដោយការលក់សារធាតុញៀនទាំងឡាយទៅដល់អ្នកដទៃ ) ។
- តើការញៀនប្រៀបដូចជាផ្លែសន្ទូចដែលអ្នកស្ទូចត្រីប្រើដើម្បីចាប់ត្រីយ៉ាងដូចម្ដេចខ្លះ ? តើការញៀនធ្វើឲ្យខូចបង់ដល់ការរីកចម្រើនដ៏អស់កល្បជានិច្ចរបស់យើងតាមយ៉ាងដូចម្ដេចខ្លះ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីរបៀបដែលការព្រមានឲ្យចៀសវាងពីសារធាតុដែលនាំឲ្យញៀន និងប្រកបដោយគ្រោះថ្នាក់ បានប្រទានពរដល់ជីវិតរបស់ពួកគេ ឬជីវិតមិត្តភក្តិរបស់ពួកគេ ឬសមាជិកគ្រួសាររបស់ពួកគេ ។ អ្នកអាច

ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកផងដែរ ។ សូមអញ្ជើញសិស្សឲ្យធ្វើការសម្រេចចិត្តដើម្បីកុំទទួលទានសារធាតុទាំងឡាយដែលផ្ទុយទៅនឹងពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១០–១៧

*ព្រះលើកទឹកចិត្តឲ្យប្រើប្រាស់តិណទេស ផ្លែឈើ សាច់ និង គ្រាប់ធុញ្ញជាតិ*

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១០–១៧ ដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីដែលព្រះអម្ចាស់លើកទឹកចិត្តយើងឲ្យបរិភោគ ។ អ្នកអាចផ្ដល់យោបល់ដល់សិស្សថា ពួកគេគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើអាហារអ្វីខ្លះដែលព្រះអម្ចាស់ឲ្យយើងបរិភោគដែលជាចំណែកនៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ?
- ស្របតាម ខ ១១ តើអាកប្បកិរិយាប្រភេទណា ដែលយើងគួរមាន នៅពេលយើងទទួលទានអាហារដែលប្រកបដោយសុខភាពល្អទាំងនេះ ? ( យើងគួរតែទទួលទានអាហារទាំងនេះដោយការប្រុងប្រយ័ត្ន និងដោយការថ្លែងអំណរគុណ ។ អ្នកអាចចាំបាច់ត្រូវបញ្ជាក់ថា « ដោយការប្រុងប្រយ័ត្ន » មានន័យថា ដោយឈ្លាសវៃ និងប្រយ័ត្នប្រយែង ។ ការទទួលទានលើសកំណត់ ឬពុំមានតុល្យភាព ទោះជាទទួលទានអាហារល្អក្ដី ក៏អាចនាំឲ្យមានខុសភាពមិនល្អដែរ ) ។
- ផ្ដោតទៅលើអ្វីដែលយើងរៀននៅក្នុងខគម្ពីរទាំងនេះ តើគោលការណ៍អំពីអាហារដែលមានសុខភាពអ្វីខ្លះ ដែលយើងអាចបន្ថែមនៅលើក្ដារខៀន ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀននៅក្រោមគោលការណ៍អំពីសារធាតុដែលមានគ្រោះថ្នាក់ ៖ **យើងត្រូវប្រើប្រាស់តិណទេស ផ្លែឈើ សាច់ និង គ្រាប់ធុញ្ញជាតិដោយឈ្លាសវៃ និងប្រកបដោយអំណរគុណ** )

សូមពន្យល់ថា ឧទាហរណ៍មួយនៃការចេះប្រើប្រាស់អាហារ អាចត្រូវបានរកឃើញនៅក្នុងការណែនាំដែលព្រះអម្ចាស់បានប្រទានឲ្យអំពីសាច់ នៅក្នុង ខ ១២–១៣។ ពាក្យ *ដោយសំចៃ* ផ្ដល់យោបល់ថា ជាសាច់ដែលត្រូវប្រើតាមមធ្យម ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–២១

*ព្រះអម្ចាស់សន្យាអំពីសុខភាព ប្រាជ្ញា និងការការពារដល់អ្នកទាំងឡាយដែលគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ*

សូមសរសេរដូចខាងក្រោមនៅលើក្ដារខៀន នៅក្រោមពាក្យ *ការសន្យា ៖ បើយើងធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ និងបទបញ្ញត្តិដទៃទៀតរបស់ព្រះអម្ចាស់ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងជាមួយនឹង. . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីពរជ័យដែលអាចបំពេញបញ្ចប់ប្រយោគនៅលើក្ដារខៀន ។

- តើពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់សន្យាចំពោះអ្នកទាំងឡាយ ដែលរក្សាថ្ងៃបរិសុទ្ធជាបរិសុទ្ធ ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀនដើម្បីបំពេញបញ្ចប់ប្រយោគ ) ។

អ្នកអាចនឹងចង់ពន្យល់ថា ការសន្យាសុខភាពល្អរបស់ព្រះអម្ចាស់នៅក្នុង ខ ១៨ ពុំមានន័យថា ពាក្យសម្ដី នៃប្រាជ្ញាវាងវៃគឺជាការព្យាបាលដល់ជំងឺរ៉ាំរ៉ៃ ឬជំងឺបានជាសះស្បើយនោះទេ ។ ផ្ទុយទៅវិញ វាជួយមនុស្សឲ្យមានសុខភាពល្អបំផុត ហើយមានកម្លាំងដែលរូបកាយរបស់ពួកគេមានសមត្ថភាព ។

- តើការរក្សាពាក្យសម្ដីនៃប្រាជ្ញាវាងវៃ អាចជួយយើងទទួលបានប្រាជ្ញានិងចំណេះដឹងយ៉ាងដូចម្ដេច ?

សូមជួយសិស្សឲ្យយល់ថា ការគោរពពាក្យសម្ដីនៃប្រាជ្ញាវាងវៃ អនុញ្ញាតឲ្យយើងរីករាយនឹងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ដែលបង្ហាញពីប្រាជ្ញា និងចំណេះដឹងទៅអ្នកដែលស្មោះត្រង់ ។ ជាចំណែកនៃការពិភាក្សានេះ អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ប្រធាន ប៊យដ៏ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ខ្ញុំបានដឹង . . . ថា គោលបំណងចម្បងនៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ត្រូវកើតឡើងជាមួយនឹងវិវរណៈ ។. . .

« បើមនុស្សម្នាក់ ‹ នៅក្រោមឥទ្ធិពលនេះ › ស្ទើរតែមិនអាចស្ដាប់ការនិយាយធម្មតាផង តើពួកគេអាចឆ្លើយតបទៅនឹងការបំផុសគំនិតខាងវិញ្ញាណ ដែលធ្វើឲ្យអារម្មណ៍ដ៏ទន់ភ្លន់បំផុតរបស់គេរំជួលដោយរបៀបណា ?

« ‹ ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ មានតម្លៃដូចជាក្រឹត្យវិន័យនៃសុខភាពដែរ វាអាចមានតម្លៃសម្រាប់វិញ្ញាណអ្នក ជាងសម្រាប់រាងកាយអ្នកទៅទៀត › (« Prayers and Answers,» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ទំព័រ ២០ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:២០–២១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវពរជ័យបន្ថែមដែលអាចកើតមានតាមរយៈការធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។

- តើពរជ័យបន្ថែមអ្វីខ្លះ ដែលព្រះអម្ចាស់សន្យាចំពោះអ្នកទាំងឡាយ ដែលធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ?

ដើម្បីជួយសិស្សយល់អំពីឃ្លា « ទេវតាដែលបំផ្លាញនឹងបង្ហួសពួកគេ » សំដៅទៅលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:២១ លេខយោង *ក*។ សូមពន្យល់ថា ការសន្យានៃការការពារដ៏ទេវភាពនេះ អាចសំដៅទៅលើសុវត្ថិភាពខាងរូបកាយ ក៏ដូចជាខាងវិញ្ញាណផងដែរ ។ សូមបញ្ចប់ប្រយោគនៅលើក្ដារខៀនដើម្បីវាឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងធ្វើតាមពាក្យសម្ដី នៃប្រាជ្ញាវាងវៃ និងបទបញ្ញត្តិដទៃទៀតរបស់ព្រះអម្ចាស់ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងឲ្យមានសុខភាពល្អ មានប្រាជ្ញា មានកម្លាំង និងការការពារ ។**

- តើនៅពេលណាដែលអ្នកមើលឃើញការសន្យានៅក្នុង ខ ១៨–២១ បានបំពេញនៅក្នុងជីវិតរបស់អ្នក ឬជីវិតរបស់មនុស្សម្នាក់ដែលអ្នកស្គាល់ ?

សូមឲ្យសិស្សចែកចាយ ( ជាមួយនឹងសិស្សដទៃទៀតក្នុងថ្នាក់ ឬជាមួយដៃគូ ) នូវអ្វីដែលពួកគេបានរៀន ឬបានដឹងអំពីពាក្យសម្ដី នៃប្រាជ្ញាវាងវៃ នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ សព្វថ្ងៃនេះ ។ សូមអញ្ជើញពួកគេឲ្យពិចារណាអំពី គោលការណ៍ និងការសន្យាទាំងឡាយដែលបានសរសេរនៅលើក្ដារខៀន ហើយបានដាក់គោលដៅមួយដើម្បីរស់នៅតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃកាន់តែមានភាពស្មោះត្រង់ ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យទាំងឡាយដែលនឹងកើតមានចំពោះពួកគេនៅពេលពួកគេរស់នៅតាមក្រឹត្យវិន័យនេះ ។

# គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨–៨៩ ( មេរៀនទី ១៩ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្តីសង្ខេបនៃគោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨–៨៩ ( មេរៀនទី ១៩ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើ គោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១–៤០)

នៅពេលសិស្សបានសិក្សាវិវរណៈមួយដែលបានប្រទានដល់ព្យាការីយ៉ូសែប ស្ម៊ីធ និង ពួកសង្ឃជាន់ខ្ពស់មួយក្រុម នោះពួកគេបានរៀនថា ព្រះប្រទានពន្លឺ និង ជីវិតដល់គ្រប់អ្វីៗទាំងអស់តាមរយៈពន្លឺនៃព្រះគ្រីស្ទ ។ ពួកគេក៏បានរៀនផងដែរថាវិញ្ញាណ និង រូបកាយគឺជាព្រលឹងនៃមនុស្ស ដែលត្រូវបានប្រោសលោះនៅក្នុងការរស់ឡើងវិញតាមរយៈព្រះយេស៊ូវគ្រីស្ទ ហើយថានៅក្នុងការរស់ឡើងវិញ យើងនឹងទទួលបានសិរីរុងរឿងស្របទៅតាមក្រឹត្យវិន័យដែលយើងបានគោរពតាម ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:៤១–៦៩)

នៅក្នុងមេរៀននេះ សិស្សបានរៀនថាពួកគេអាចឃើញឫទ្ធានុភាព និង ព្រះចេស្ដារបស់ព្រះនៅពេលពួកគេមើលពីការបង្កបង្កើតរបស់ទ្រង់ ។ សិស្សបានសិក្សាខគម្ពីរអំពីរបៀបដែលព្រះអម្ចាស់នឹងយាងទៅជួបនគរនិមួយៗរបស់ទ្រង់ ព្រមទាំងប្រជាជនក្នុងនគរនោះតាមកំណត់ពេលរបស់ទ្រង់ ។ សិស្សក៏បានរៀនផងដែរថា នៅពេលពួកគេខិតកាន់តែជិតព្រះ នោះទ្រង់នឹងខិតជិតពួកគេផងដែរ ។ ពួកគេបានឃើញថា ព្រះវរបិតាសួគ៌ឆ្លើយតបការអធិស្ឋានរបស់ពួកគេ តាមរបៀបដែលទ្រង់ជ្រាបថាជាចម្លើយដ៏ល្អបំផុតសម្រាប់ពួកគេ ហើយថាប្រសិនបើពួកគេមានភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អនៃព្រះ នោះពួកគេនឹងពេញដោយពន្លឺ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:៧០–១៤១)

នៅពេលសិស្សបានសិក្សាការណែនាំរបស់ព្រះអម្ចាស់សម្រាប់ការសាងសង់សាលានៃពួកព្យាការី នោះពួកគេបានរៀនថា ប្រសិនបើពួកគេបង្រៀនគ្នាទៅវិញទៅមក ហើយស្វែងរកការរៀនសូត្រដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿផង នោះសេចក្តីជំនឿរបស់ពួកគេលើព្រះយេស៊ូវគ្រីស្ទនឹងកើនឡើង ។ ពួកគេបានរកឃើញអាកប្បកិរិយាសុចរិតដែលនឹងជួយពួកគេរៀន និង ត្រូវបានស្អាងឡើង ព្រមទាំងទង្វើទុច្ចរិតនានាដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកយើងឈប់ធ្វើវាទៀត ។ ពួកគេក៏បានរៀនផងដែរថាការបង្ហាញមិត្តភាព និង សេចក្តីស្រឡាញ់ដល់អស់អ្នកដែលរៀនដំណឹងល្អ អញ្ជើញព្រះវិញ្ញាណនៅពេលពួកគេសិក្សាជាមួយគ្នា ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្តីសញ្ញា ៨៩)

ចេញពីព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះបងប្អូនប្រុសដែលចូលរៀននៅសាលានៃពួកព្យាការី នោះសិស្សបានរៀនថាដោយសារផែនការអាក្រក់ទាំងឡាយដែលមនុស្សរួមគំនិតប្រព្រឹត្តិអំពើទុច្ចរិតនៅថ្ងៃចុងក្រោយ នោះព្រះអម្ចាស់បានព្រមានដល់យើងកុំឲ្យប្រើសារធាតុដែលនាំឲ្យគ្រោះថ្នាក់ទាំងឡាយ ។ ពួកគេបានរកឃើញការព្រមានរបស់ព្រះអម្ចាស់អំពីការការប្រើខុសនូវសារធាតុជាក់លាក់មួយចំនួន ហើយបានរៀនថាពួកគេគួរតែបរិភោគអាហារដែលនាំឲ្យមានសុខភាពល្អដោយឆ្លាតវៃ និង ដោយមានអំណរគុណ ។ សិស្សបានរៀនថា ប្រសិនបើយើងធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងឲ្យមានសុខភាពល្អ មានប្រាជ្ញា មានកម្លាំង និង ការការពារ ។

## សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យទទួលស្គាល់ពីតម្លៃនៅក្នុងការបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ នៅពេលពួកគេបង្រៀនគ្នាទៅវិញទៅមកនូវគោលការណ៍មួយចំនួន ដែលពួកគេបានសិក្សាអំឡុងពេលសប្ដាហ៍នេះ នោះពួកគេនឹងមានឱកាសទទួលបានបទពិសោធន៍នៃគោលការណ៍មួយចំនួន ដែលព្រះអម្ចាស់បានបង្រៀនដល់អស់អ្នកដែលបានចូលរៀននៅក្នុងសាលានៃពួកព្យាការី ។

## យោបល់សម្រាប់ការបង្រៀន

*កំណត់ចំណាំ* ៖ នៅពេលសិស្សបានសិក្សាវគ្គចំណេះចំណានខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៤ នៅសប្ដាហ៍នេះ ពួកគេត្រូវបានអញ្ជើញឲ្យទន្ទេញវាឲ្យចាំ ហើយសូត្រវានៅពេលពួកគេចូលរៀនថ្នាក់សិក្ខាសាលា និង ថ្នាក់ផ្សេងៗនៃសាសនាចក្រ ។ ការអញ្ជើញនេះមានបំណងចង់ជួយពួកគេឲ្យចងចាំថា ការធ្វើទង្វើសុចរិតនានា និង ការឈប់ពីទង្វើទុច្ចរិតនឹងជួយយើងឲ្យរៀនសូត្រ ហើយត្រូវបានស្អាងឡើង ។ អ្នកអាចរំឭកសិស្សអំពីចំណុចនេះ ហើយអញ្ជើញពួកគេឲ្យសូត្រវគ្គបទគម្ពីរនោះជាមួយគ្នា ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យរស់នៅតាមព្រះឱវាទដែលបានប្រទានឲ្យក្នុងវគ្គបទគម្ពីរនេះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១១៧

*ព្រះអម្ចាស់ត្រាស់បញ្ជាឲ្យពួកអែលឌើរនៃសាសនាចក្រត្រៀមខ្លួនសម្រាប់ការបម្រើរបស់ពួកគេ ហើយបានបើកសម្ដែងអំពីព្រឹត្តការណ៍ជុំវិញការយាងមកជាលើកទីពីររបស់ទ្រង់*

សូមអញ្ជើញសិស្សម្នាក់ឲ្យមកខាងមុខក្ដារខៀន ហើយបង្រៀនសិស្សម្នាក់ទៀតអំពីរបៀបធ្វើការសាមញ្ញមួយ ដូចជាចងក្រវ៉ាត់ក ( ឬការងារផ្សេងមួយដែលសិស្សទីពីរពុំចេះធ្វើ ) ។ សូមឲ្យសិស្សក្នុងថ្នាក់លើកដៃ ប្រសិនបើពួកគេបានធ្លាប់ជួយបង្រៀនមេរៀនមួយ ឬ ជំនាញមួយដល់នរណាម្នាក់ទៀតក្នុងពេលថ្មីៗនេះ ។ សូមឲ្យមនុស្សមួយចំនួនដែលលើកដៃរបស់ពួកគេរៀបរាប់ពីអ្វីដែលពួកគេបានបង្រៀន និង មនុស្សដែលពួកគេបានបង្រៀន ។ សូមតាមដានដោយសួរសំណួរខាងក្រោម ៖

- តើអ្នកបានរៀនអ្វីខ្លះតាមរយៈការត្រៀមបង្រៀន និង តាមរយៈការបង្រៀននរណាម្នាក់ ?
- ហេតុអ្វីអ្នកគិតថា ជាញឹកញាប់យើងរៀនមកពីការត្រៀមខ្លួនដើម្បីបង្រៀនច្រើនជាងត្រូវបានបង្រៀនពីនរណាម្នាក់ទៀត ?

សូមរំឭកសិស្សថា ព្រះអម្ចាស់បានប្រទានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ អស់ជាច្រើនថ្ងៃនៅចុងខែ ធ្នូ ឆ្នាំ ១៨៣២ និង នៅដើមខែ មករា ឆ្នាំ ១៨៣៣ ដល់អ្នកកាន់បព្វជិតភាពមួយក្រុមដែលបានអធិស្ឋានដើម្បីដឹងអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់អំពីការស្ថាបនាស៊ីយ៉ូន ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានសំដៅទៅលើក្រុមនៃពួកអ្នកកាន់បព្វជិតភាពនេះថាជា « អ្នកធ្វើការមុនដំបូង នៅក្នុងនគរចុងក្រោយបង្អស់នេះ » (គ. និង ស. ៨៨:៧០, ៧៤) ហើយបានបញ្ជាពួកគេឲ្យរៀបចំ និង ចូលរៀនក្នុងសាលារៀនមួយ ដើម្បីត្រៀមខ្លួនពួកគេចេញផ្សាយដំណឹងល្អនៅក្នុងចំណោមជាតិសាសន៍នៅលើផែនដី ( សូមមើល គ. និង ស. ៨៨:៧៤, ៨៤, ១២៧) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៣–៧៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលព្រះអម្ចាស់បានបញ្ជាដល់ពួកអ្នកកាន់បព្វជិតភាពទាំងនេះឲ្យធ្វើដើម្បីត្រៀមខ្លួនបង្រៀនដល់អ្នកដទៃ ។

- តើ « ពួកអ្នកធ្វើការដំបូងគេ » ទាំងនេះត្រូវបានបញ្ជាឲ្យធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនបង្រៀនដល់អ្នកដទៃក្នុងនាមជាពួកអ្នកផ្សព្វផ្សាយសាសនា ? ( អ្នកអាចនឹងសូមសិស្សម្នាក់ឲ្យធ្វើជាអ្នកសរសេរ ហើយសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បី « រៀបចំ » « ត្រៀមខ្លួន » និង « ញែកចេញ » ខ្លួនយើងជាបរិសុទ្ធ ដើម្បីកាន់តែមានប្រសិទ្ធភាពក្នុងការចែកចាយដំណឹងល្អ ?
- តើការត្រូវបានសម្អាតពីអំពើបាប មានឥទ្ធិពលលើលទ្ធភាពរបស់យើង ដើម្បីចែកចាយដំណឹងល្អយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៧–៨០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់ បានបញ្ជាដល់អ្នកកាន់បព្វជិតភាពទាំងនេះឲ្យធ្វើ នៅពេលពួកគេជួបជាមួយគ្នា ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះចំពោះអស់អ្នកដែលឧស្សាហ៍ព្យាយាមបង្រៀន ? ( ទ្រង់បានសន្យាថាព្រះគុណរបស់ទ្រង់នឹងនៅជាមួយពួកគេ ហើយថាពួកគេនឹងត្រូវបានបង្រៀនកាន់តែល្អឥតខ្ចោះបន្ថែមទៀតនៅក្នុងគ្រប់អ្វីៗដែលពួកគេចាំបាច់ត្រូវយល់ដឹង ទាក់ទងទៅនឹងនគរនៃព្រះ ) ។
- តើពាក្យថា « ព្រះគុណរបស់ព្រះអម្ចាស់នឹងនៅជាមួយអ្នក » មានន័យយ៉ាងណា (គ. និង ស. ៨៨:៧៨) ? ( ព្រះអម្ចាស់នឹងជួយយើង នៅពេលយើងស្វែងរកដោយព្យាយាមដើម្បីបង្រៀន និងរៀនដំណឹងល្អ ) ។
- ចេញមកពីអ្វីដែលអ្នកបានរៀននៅក្នុង ខ ៧៧–៧៨ តើអ្នកនឹងថ្លែងនូវគោលការណ៍មួយស្ដីអំពីការបង្រៀនយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងរកឃើញគោលការណ៍មួយចំនួន ។ បន្ទាប់ពីពួកគេឆ្លើយហើយ អ្នកអាចសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **នៅពេលយើងបង្រៀនគ្នាទៅវិញទៅមកដោយឧស្សាហ៍ព្យាយាម នោះព្រះអម្ចាស់នឹងជួយយើង**

**យល់សេចក្ដីពិតរបស់ទ្រង់កាន់តែបានល្អឥតខ្ចោះ ។ តាមរយៈការបង្រៀនដល់នរណាម្នាក់ នោះយើងអាចត្រៀមខ្លួនដើម្បីចែកចាយដំណឹងល្អជាមួយអ្នកដទៃ)** ។

- តើការបង្រៀនដំណឹងល្អដល់អ្នកដទៃបានជួយអ្នកឲ្យយល់កាន់តែល្អប្រសើរអំពីដំណឹងល្អតាមវិធីណា ?
- យោងតាម ខ ៧៩ តើប្រធានបទណាផ្សេងទៀតដែលសំខាន់ដើម្បីយើងយល់ដឹង ? តើការទទួលបានចំណេះដឹងទូលំទូលាយដូច្នេះ អាចជួយយើងបង្រៀនដំណឹងល្អដល់អ្នកដទៃយ៉ាងដូចម្ដេច ?

*កំណត់ចំណាំ ៖* សកម្មភាពខាងក្រោមនេះគឺត្រូវបានសរសេរឡើងសម្រាប់សិស្សជាក្រុម ៗដែលមួយក្រុមមានសិស្សបួននាក់ដើម្បីរៀបចំ និង បង្រៀនគ្នាទៅវិញទៅមកនៅក្នុងភាពជាដៃគូ ។ ប្រសិនបើអ្នកមានសិស្សតិច អ្នកអាចឲ្យសិស្សរៀបចំ ហើយបង្រៀនបុគ្គលម្នាក់ៗ ឬ អ្នកអាចឲ្យសិស្សបង្រៀនអ្នកនូវមេរៀនមួយ ហើយបន្ទាប់មកអ្នកអាចបង្រៀនពួកគេនូវមេរៀនផ្សេងទៀត ។

សូមពន្យល់សិស្សថា អ្នកចង់ជួយពួកគេឲ្យទទួលអារម្មណ៍នៃភាពសំខាន់ និង អនុវត្តគោលការណ៍ពីរនៃការបង្រៀនដែលពួកគេរកឃើញ ។ សូមចែកសិស្សជាក្រុម ៗដែលមានគ្នាបួននាក់ ។ សូមឲ្យសិស្សពីរនាក់នៅក្នុងក្រុមនិមួយ ៗធ្វើការជាមួយគ្នា ដោយប្រើព្រះគម្ពីរ និង សៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេដើម្បីរៀបចំបង្រៀន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៣–៦៨ ដល់សិស្សពីរនាក់ផ្សេងទៀត ។ សូមឲ្យសិស្សពីរនាក់ផ្សេងទៀតធ្វើការជាមួយគ្នា ដើម្បីរៀបចំបង្រៀនវគ្គចំណេះចំណានខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–២១ ដល់សិស្សពីរនាក់ដំបូង ។

សូមចែកច្បាប់ចម្លងនៃ សេចក្ដីណែនាំខាងក្រោមនេះ សម្រាប់ក្រុមនិមួយ ៗ ។ សូមឲ្យពួកគេអានសេចក្ដីណែនាំ និង ខព្រះគម្ពីរនានា រួចហើយសម្រេចពីរបៀបដែលពួកគេនឹងបង្រៀនមេរៀននិមួយ ៗ ។ ( សូមលើកទឹកចិត្តសិស្សទាំងពីរនាក់នៅក្នុងដៃគូនិមួយ ៗឲ្យចូលរួមនៅក្នុងការបង្រៀន ) ។ សូមពន្យល់ថាដៃគូនិមួយ ៗនឹងមានរយៈពេលប្រហែលជា ៨–១០នាទី ដើម្បីរៀបចំមេរៀន ហើយប្រហែលជា៥នាទីដើម្បីបង្រៀនរបស់ខ្លួន ។

*សេចក្ដីណែនាំសម្រាប់សិស្សដែលនឹងបង្រៀន ៖*

១. សូមអានវគ្គបទគម្ពីរទាំងអស់ដែលបានចាត់ដល់អ្នក ។ អ្នកអាចអធិស្ឋាននៅក្នុងចិត្តរបស់ខ្លួនថា ព្រះវិញ្ញាណបរិសុទ្ធនឹងជួយអ្នកនៅពេលអ្នករៀបចំ និង នៅពេលអ្នកបង្រៀន ។

២. សូមមើលកំណត់ចំណាំ ឬ ការគូសចំណាំនានាដែលអ្នកបានធ្វើនៅក្នុងព្រះគម្ពីរ និង នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ដើម្បីជួយអ្នកឲ្យចាំនូវអ្វីដែលអ្នកបានរៀនមកពីការសិក្សាវគ្គបទគម្ពីររបស់អ្នកអំឡុងពេលសប្ដាហ៍នេះ ។

៣. សូមកត់ ឬ គូសចំណាំគោលលទ្ធិ ឬ គោលការណ៍មួយដែលអ្នកចង់បង្រៀន ។

៤. សូមសម្រេចចិត្តពីរបៀបដើម្បីបង្រៀនមេរៀនគោលលទ្ធិ ឬ គោលការណ៍ ។ សូមគិតពីការប្រើយោបល់ខាងក្រោមនេះនៅពេលអ្នកបង្កើតគម្រោងមេរៀន ៖

ក. សូមគិតពីសំណួរសាមញ្ញមួយដើម្បីសួរ ឬ គិតពីឧបករណ៍មេរៀនមួយដែលអ្នកអាចប្រើវា ដើម្បីទាក់ទាញការចាប់អារម្មណ៍ពីអស់អ្នកដែលអ្នកបង្រៀន ហើយណែនាំឲ្យស្គាល់ប្រធានបទ ។

ខ.. សូមពន្យល់អ្វីដែលអ្នកស្គាល់ពីប្រវត្តិ និង មាតិកានៃវិវរណៈនេះ ហើយអញ្ជើញអស់អ្នកដែលអ្នកបង្រៀនអានផ្នែកមួយ ឬ ទាំងអស់នៃវគ្គបទគម្ពីរដែលអ្នកត្រូវបានចាត់ឲ្យអាន ។

គ.. សូមសួរសំណួរនានាដែលជួយដល់អស់អ្នកដែលអ្នកបង្រៀនរកឃើញគោលលទ្ធិ ឬ គោលការណ៍ ហើយបន្ទាប់មកសួរសំណួរបន្ថែមទៀតដើម្បីមើលថាបើពួកគេយល់វាដែលឬអត់ ។

ឃ.. សូមចែកចាយបទពិសោធន៍មួយដែលអ្នកមានជាមួយគោលលទ្ធិ ឬ គោលការណ៍នោះ ហើយថ្លែងទីបន្ទាល់អំពីសារៈសំខាន់ និង សេចក្ដីពិតរបស់វា ។ អ្នកក៏អាចអញ្ជើញអស់អ្នកដែលអ្នកបង្រៀនចែកចាយបទពិសោធមួយ ដែលពួកគេមានជាមួយនឹងគោលលទ្ធិ និង គោលការណ៍នេះ ។

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីរៀបចំមេរៀនហើយ សូមអញ្ជើញដៃគូដែលបានចាត់តាំងឲ្យសិក្សាក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៣–៦៨ ដើម្បីបង្រៀនសិស្សដទៃទៀតនៅក្នុងក្រុមរបស់ពួកគេ ។ បន្ទាប់មកសូមឲ្យសិស្សផ្លាស់តួនាទីគ្នា ហើយអញ្ជើញដៃគូដែលបានចាត់តាំងឲ្យសិក្សាក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–២១ ឲ្យបង្រៀន ។

បន្ទាប់ពីសិស្សបានបង្រៀនគ្នាទៅវិញទៅមករួចហើយនោះ សូមចង្អុលបង្ហាញពីគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ « នៅពេលយើងបង្រៀនគ្នាទៅវិញទៅមកដោយឧស្សាហ៍ព្យាយាម នោះព្រះអម្ចាស់នឹងជួយយើងយល់សេចក្ដីពិតរបស់ទ្រង់កាន់តែបានល្អឥតខ្ចោះ » ។ បន្ទាប់មកសូមសួរសិស្សនូវសំណួរខាងក្រោម ៖

- តើអ្នកមានការយល់ដឹងកាន់តែខ្លាំងប៉ុណ្ណាអំពីខគម្ពីរទាំងនេះ នៅពេលអ្នកបង្រៀនវាដល់អ្នកដទៃនាថ្ងៃនេះ ?
- តើអ្នកទទួលអារម្មណ៍ថាព្រះអម្ចាស់បានជួយអ្នកយ៉ាងដូចម្ដេចខ្លះ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យស្វែងរកឱកាសដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យទាំងឡាយដែលពួកគេនឹងទទួលចំពោះការធ្វើដូច្នោះ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩៧)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួន អំឡុងពេលនៃសប្ដាហ៍នេះ អ្នកអាចអញ្ជើញពួកគេឲ្យពិចារណាសំណួរខាងក្រោម ៖ តើព្រះអម្ចាស់បានដាក់លក្ខខណ្ឌអ្វីខ្លះដែលរាប់ទុកជាគុណសម្បត្តិដើម្បីឃើញព្រះភក្ត្រទ្រង់ ? តើពរជ័យនៃការ « មានចិត្តបរិសុទ្ធ » មានអ្វីខ្លះ (គ. និង ស. ៩៧:១៦) នៅពេលអ្នកចូលព្រះវិហារបរិសុទ្ធ ? តើអ្នកធ្លាប់ឆ្ងល់ទេថាតើ *ការថ្វាយបង្គំ* ដល់ព្រះមានន័យដូចម្ដេច ? នៅក្នុងការសិក្សារបស់អ្នកនៅសប្ដាហ៍ក្រោយនេះ សូមរកមើល *នរណា* ដែលយើងថ្វាយបង្គំ និង *របៀប* ដែលយើងថ្វាយបង្គំ ។

មេរៀនទី ៩៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២

## បុព្វកថា

នៅថ្ងៃទី ៨ ខែ មិនា ឆ្នាំ ១៨៣៣ ព្រះអម្ចាស់បានប្រទានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០ ។ វិវរណៈនេះមាននូវការណែនាំដល់គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ និងជា « ជំហានបន្ត » នៅក្នុងការបង្កើតនៃគណៈប្រធានទីមួយ ( សូមមើល សេចក្ដីណែនាំកណ្ឌ ) ។ នៅថ្ងៃទី ៩ ខែ មិនា ឆ្នាំ ១៨៣៣ យ៉ូសែប ស្ម៊ីធ បានទូលសួរបើសិនជាលោកគួរតែបញ្ចូលអាប៉ូគ្រីផានៅក្នុងការបកប្រែព្រះគម្ពីរប៊ីបរបស់លោកឬអត់ ។ ព្រះអម្ចាស់បានឆ្លើយតបចំពោះសំណួររបស់ យ៉ូសែប ស្ម៊ីធ តាមរយៈវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១ ហើយប្រាប់លោកថា វាពុំចាំបាច់ត្រូវបកប្រែទេ ។ គ្រាន់តែប៉ុន្មានថ្ងៃក្រោយមក នៅថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៨៣៣ ព្យាការីបានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២ ដែលណែនាំដល់ ហ្វ្រេឌើរិក ជី វិលលាម្ស ជាទីប្រឹក្សាម្នាក់របស់ យ៉ូសែប ស្ម៊ីធ ឲ្យធ្វើជាសមាជិកសកម្មម្នាក់នៃក្រុមហ៊ុនសហភាព ដែលបានស្ថាបនាឡើងដើម្បីមើលខុសត្រូវលើសុខុមាលភាព និងកិច្ចការអាជីវកម្មរបស់សាសនាចក្រ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១–១៨

*ព្រះអម្ចាស់បានណែនាំដល់គណៈប្រធានអំពីបព្វជិតភាពជាន់ខ្ពស់ស្ដី អំពីទំនួលខុសត្រូវរបស់ពួកគេ*

សូមចាប់ផ្ដើមមេរៀនដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអំណោយដ៏មានតម្លៃបំផុត ដែលអ្នកធ្លាប់បានទទួលគឺជាអ្វី ? តើហេតុអ្វីវាមានតម្លៃ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១–៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីមួយដែលមានតម្លៃ ដែលព្រះអម្ចាស់បានប្រទានដល់ យ៉ូសែប ស្ម៊ីធ ។

- តើយ៉ូសែប ស្ម៊ីធ បានកាន់កាប់អ្វី ? ( កូនសោនៃនគរ ដែលមានន័យថា ជាសិទ្ធិទាំងឡាយនៃគណៈប្រធាន ឬព្រះចេស្ដាដែលព្រះប្រទានដល់មនុស្សដើម្បីគ្រប់គ្រង និងដឹកនាំនគររបស់ទ្រង់នៅលើផែនដី ) ។ ហេតុអ្វីក៏របស់នោះមានតម្លៃ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:៤–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីការព្រមានដែលព្រះអម្ចាស់បានប្រទានដល់ពួកអ្នកបរិសុទ្ធ ។ ( អ្នកអាចត្រូវពន្យល់ថា ដូចបានប្រើនៅក្នុង ខ ៤–៥ ពាក្យ *ព្រះបន្ទូលទាំងឡាយ* សំដៅទៅលើវិវរណៈទាំងឡាយមកពីព្រះតាមរយៈពួកព្យាការីរបស់ទ្រង់ ) ។

- តើការព្រមានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ? តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីការព្រមាននេះ ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម ៖**បើយើងរាប់វិវរណៈទាំងឡាយដែលព្រះប្រទានឲ្យតាមរយៈពួកព្យាការីរបស់ទ្រង់ជាឥតការ នោះ យើងនឹងជំពប់ ហើយដួល** ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើអ្នកគិតថា ការរាប់វិវរណៈទាំងឡាយ ដែលព្រះប្រទានឲ្យតាមរយៈពួកព្យាការីរបស់ទ្រង់ជា«ឥតការ» វាមានន័យយ៉ាងណា ? តើគំរូនៃវិវរណៈមួយចំនួនដែលមនុស្សអាចនឹងត្រូវបានល្បួងឲ្យរាប់ជាឥតការមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:៦ ដោយស្ងាត់ស្ងៀម រកមើលអ្នកណាផ្សេងទៀតដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា នឹងកាន់កូនសោទាំងឡាយនៃនគរនោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា នៅថ្ងៃទី ១៨ ខែមិនា ឆ្នាំ ១៨៣៣ ជារយៈពេលដប់ថ្ងៃបន្ទាប់ពី កណ្ឌទី ៩០ ត្រូវបានប្រទានឲ្យ នោះ យ៉ូសែប ស្ម៊ីធ បានញែក ស៊ីឌនី រិកដុន និង ហ្វ្រេឌើរិក ជី វិលលាម្ស ជាទីប្រឹក្សានៅក្នុងគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ដែលក្រោយមកត្រូវបានហៅថាជាគណៈប្រធានទីមួយនៃសាសនាចក្រ ។

- តើគោលលទ្ធិអ្វីដែលយើងរៀនមកពី ខ ៦ នេះ ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីគោលលទ្ធិដូចខាងក្រោម ៖**គណៈប្រធានទីមួយ កាន់កូនសោទាំងឡាយនៃនគរ ។** សូមប្រាកដថា សិស្សយល់ថា ទោះបីជាសមាជិកម្នាក់ៗនៃគណៈប្រធានទីមួយ កាន់កូនសោទាំងឡាយនៃនគរក្ដី ក៏ប្រធានសាសនាចក្រ គឺជាមនុស្សតែម្នាក់គត់ដែលអាចទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:៧–១០ ដោយការពន្យល់ថា គណៈប្រធានទីមួយ ត្រូវបានណែនាំឲ្យរៀបចំសមាជិកនៃសាលានៃពួកព្យាការី ដើម្បីផ្សាយដំណឹងល្អទៅទូទាំងពិភពលោក ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១១ ដោយស្ងាត់ស្ងៀម ហើយពិចារណាអំពីរបៀបដែលខគម្ពីរនេះ ត្រូវបានបំពេញនៅសព្វថ្ងៃនេះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

អ្នកក៏អាចនឹងចង់សង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១២–១៨ ផងដែរ ។ ខគម្ពីរទាំងនេះ បង្រៀនថា ព្យាការី យ៉ូសែប ស៊្មីធ និងទីប្រឹក្សារបស់លោក គឺត្រូវរៀបចំឲ្យកិច្ចការនៃសាសនាចក្រមានរបៀបរៀបរយ ។

> ***សង្ខេប***
> អ្នកនឹងមិនមានពេលដើម្បីបង្រៀនអ្វីៗគ្រប់យ៉ាង នៅក្នុងវគ្គព្រះគម្ពីរមួយ ដោយបញ្ជាក់គ្រប់ចំណុចទាំងអស់នោះទេ ។ ក្នុងឱកាសនេះ អ្នកអាចសង្ខេបខ្សែរឿង ឬ ការបង្រៀននៅក្នុងផ្នែកមួយនៃវគ្គព្រះគម្ពីរមួយ ដើម្បីឲ្យមានពេលគ្រប់គ្រាន់ទុករៀនពីអត្ថបទ គោលលទ្ធិ ឬ គោលការណ៍ដែលមានសារៈសំខាន់ជាងនេះ នៅក្នុងផ្នែកផ្សេងទៀតនៃវគ្គនេះ ។ ការសង្ខេបប្រសើរជាងការលុបចោលនូវផ្នែកនៃវគ្គព្រះគម្ពីរមួយ អាចជួយសិស្សឲ្យយល់កាន់តែច្បាស់ពីសារលិខិតនៃវគ្គនេះទាំងមូល ។

អ្នកអាចថ្លែងទីបន្ទាល់ថា គណៈប្រធានទីមួយ កាន់កូនសោទាំងឡាយនៃនគរ ហើយចែកចាយអារម្មណ៍របស់អ្នក អំពីសារៈសំខាន់នៃការស្ដាប់តាមពាក្យសម្ដីរបស់ពួកលោក។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១៩–៣៧

*ព្រះអម្ចាស់ណែនាំដល់ពួកបរិសុទ្ធនៅក្រុងស៊ីយ៉ូន*

សូមពន្យល់ថា នៅពេលយ៉ូសែប ស៊្មីធ បានទទួលវិវរណៈ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០ លោក និងអ្នកដឹកនាំសាសនាចក្រដទៃទៀត ស្ថិតនៅក្នុងស្ថានភាពលំបាកមួយ ដោយសារតែសាសនាចក្រខ្វះធនធានហិរញ្ញវត្ថុ ។

- តើអ្នកត្រូវធ្វើយ៉ាងណា នៅពេលស្ថានភាពនានានៅក្នុងជីវិតរបស់អ្នកកាន់តែយ៉ាប់យ៉ឺនទៅៗនោះ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១៩–៣៧ មាននូវការណែនាំរបស់ព្រះអម្ចាស់ចំពោះអ្នកដឹកនាំជំនាន់មុនអំពីរបៀបដើម្បីគ្រប់គ្រងស្ថានភាពពិបាកៗដែលពួកគេជួបប្រទះ ។ សូមឲ្យអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:២៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីការប្រឹក្សាដែលអាចលួងលោមចិត្តដល់បុគ្គលម្នាក់ៗដែលកំពុងឆ្លងកាត់គ្រាលំបាកៗ ។

- តើការប្រឹក្សានៅក្នុង ខ ២៤ អាចលួងលោមចិត្តបុគ្គលទាំងឡាយដែលកំពុងឆ្លងកាត់គ្រាលំបាកៗយ៉ាងដូចម្ដេចខ្លះ ? តើអ្នកនឹងថ្លែងអំពីសារលិខិតរបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរនេះ ជាគោលការណ៍យ៉ាងដូចម្ដេច ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖**បើយើងស្រាវជ្រាវដោយឧស្សាហ៍ព្យាយាម អធិស្ឋានជានិច្ច ជឿ និងរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់យើង នោះគ្រប់អ្វីៗទាំងអស់ នឹងធ្វើការរួមគ្នាសម្រាប់សេចក្ដីល្អរបស់យើង** )។

- តើអ្នកគិតថា រឿងគ្រប់យ៉ាងនឹងធ្វើការជាមួយគ្នាសម្រាប់សេចក្ដីល្អរបស់យើង មានន័យយ៉ាងដូចម្ដេច?

- តើនៅពេលណាដែលអ្នកព្យាយាមមានភាពស្មោះត្រង់ អំឡុងគ្រាលំបាក ហើយមានអារម្មណ៍ថាបានទទួលពរជ័យ ដែលជាលទ្ធផលតបវិញនោះ ?

សូមពន្យល់ថា សមាជិកនៃសាសនាចក្រម្នាក់ ដែលបង្ហាញនូវសេចក្ដីជំនឿដ៏អស្ចារ្យអំឡុងគ្រាពិបាក គឺ វីអែរណា ចាកស៍ ។ សូមចាត់ឲ្យសិស្សធ្វើការជាដៃគូ ។ សូមផ្ដល់ច្បាប់ចម្លងនៃព័ត៌មានដូចខាងក្រោមដល់សិស្សម្នាក់មួយច្បាប់ៗអំពី វីអែរណា ចាកស៍ ។ សូមអញ្ជើញដៃគូទាំងឡាយឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:២៨–៣១ ជាមួយគ្នា ហើយប្រាប់អំពីការណែនាំជាក់លាក់ ដែលព្រះអម្ចាស់បានប្រទានដល់ វីអែរណា ។ បន្ទាប់មក សូមឲ្យពួកគេសិក្សាឯកសារដែលចែកឲ្យនោះ ហើយរកមើលរបៀបដែលវីអែរណាមានភាពស្មោះត្រង់ ។

> វីអែនណា ចាកស៍ គឺជាគំរូនៃមនុស្សមានចិត្តស្មោះត្រង់មួយរូប ក្នុងចំណោមពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននៅជំនាន់ដំបូង ។ គាត់បានកើតនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៧៨៧ ។ បន្ទាប់ពីគាត់បានជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនានៅទីក្រុង បូស្តុន រដ្ឋ ម៉ាស្សាឈូសេត ស.រ.អា គាត់បានធ្វើដំណើរទៅកាន់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ក្នុងឆ្នាំ ១៨៣១ ។ គាត់ស្នាក់នៅទីនោះប្រាំមួយសប្ដាហ៍ ហើយបានទទួលពិធីបុណ្យជ្រមុជទឹក ។ ពេលត្រឡប់ទៅ បូស្តុន វិញ វីអែរណា បានជួយនាំសមាជិកជាច្រើនរូបនៃគ្រួសាររបស់គាត់មកក្នុងសាសនាចក្រ ។ បន្ទាប់មក គាត់ « លក់អាជីវកម្មរបស់គាត់ ហើយបានត្រឡប់ទៅខឺតឡង់វិញដើម្បីរួបរួមកិច្ចខិតខំ និងចូលរួមសកម្មភាពនានាជាមួយនឹងសាសនាចក្រជារៀងរហូត» ( « Home Affairs» *Woman's Exponent,* ថ្ងៃទី ១ ខែកក្កដា ឆ្នាំ ១៨៧៨ ទំព័រ ២១ ) ។ នៅឆ្នាំ ១៨៣៣ វីអែរណា បានឧទ្ទិសទ្រព្យសម្បត្តិទាំងអស់របស់គាត់ រួមមាន ១៤០០ ដុល្លារអាមេរិកដល់សាសនាចក្រ អំឡុងគ្រាមួយដែលប្រាក់ជាតម្រូវការចាំបាច់ ។ បន្ទាប់មក គាត់បានធ្វើដំណើរទៅរដ្ឋ មិសសួរី ដើម្បីទទួលកេរមរតករបស់គាត់នៅស៊ីយ៉ូន ។ ទោះជាយ៉ាងណាក៏ដោយ មិនយូប៉ុន្មានបន្ទាប់ពីគាត់ទៅដល់ទីនោះ គាត់បានរងទុក្ខសេចក្ដីបៀតបៀន

> ជាមួយពួកបរិសុទ្ធ ។ បន្ទាប់ពីត្រូវបានគេបណ្ដេញចេញពីគេហដ្ឋានរបស់គាត់នៅរដ្ឋ មិសសួរី គាត់បានចូលរួមមើលថែអ្នកជំងឺក្នុងជំរុំសីយ៉ូន ។ ហ៊ីប៊ើ ស៊ី ឃីមប៊ល បានសរសេរថា « ខ្ញុំបានទទួលសណ្ដានចិត្តដ៏អស្ចារ្យ . . . ពីបងស្រី វីអែណា ចាកស៍ ដែលបានបម្រើខ្ញុំ និងបងប្អូនប្រុសរបស់ខ្ញុំ តាមតម្រូវការ – សូមព្រះអម្ចាស់ប្រទានពរដល់ [គាត់] ចំពោះសណ្ដានចិត្តល្អ [របស់គាត់] » («Extracts from H. C. Kimball's Journal,» *Times and Seasons,* ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៨៤៥ ទំព័រ ៨៣៩–៤០ ) ។
>
> ខណៈពេលនៅក្នុងរដ្ឋ មិសសួរី វីអែណាបានរៀបការនឹង ដានីយ៉ែល សៀរីរ ។ គាត់បានធ្វើដំណើរពីទិសខាងលិចទៅរដ្ឋ យូថាហ៍ នៅឆ្នាំ ១៨៤៧ ហើយនៅអាយុ ៦០ ឆ្នាំ បានបររទេះគោដោយខ្លួនឯងឆ្លងកាត់វាលទំនាប ។ គាត់បានតាំងលំនៅនៅទីក្រុងសលត៍ លេក ហើយបានធ្វើការធ្ងន់ពេញមួយជីវិត ដើម្បីផ្គត់ផ្គង់ខ្លួនគាត់ និងសិក្សាព្រះគម្ពីរយ៉ាងឧស្សាហ៍ព្យាយាម ។ វីអែណា បានទទួលមរណភាពនៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៨៨៤ នៅអាយុ ៩៦ ឆ្នាំ ។ ក្នុងពិធីបុណ្យសពរបស់គាត់ បានថ្លែងថា « គាត់ស្មោះត្រង់ចំពោះសេចក្ដីសញ្ញារបស់គាត់ ហើយបានគោរពដល់ការស្ដារឡើងវិញនៃដំណឹងល្អ ចាត់ទុកជាទ្រព្យសម្បត្តិដ៏ពុំអាចកាត់ថ្លៃបាន » («In Memoriam» *Woman's Exponent* ថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៨៤ ទំព័រ ១៥២ ) ។ ( សូមមើលផងដែរ ស៊ូសាន អេស្ទុន ប្លាក «Happiness in Womanhood,» *Ensign* ខែ មិនា ឆ្នាំ ២០០២ ទំព័រ ១២–១៤ ) ។

នៅពេលដែលគូទាំងឡាយបានបញ្ចប់ការអាន សូមពិភាក្សាអំពីសំណួរដូចខាងក្រោមជាមួយសិស្សក្នុងថ្នាក់ ៖

- តើវីអែណា ចាកស៍ បំពេញតាមការណែនាំដែលព្រះអម្ចាស់បានប្រទានដល់គាត់យ៉ាងដូចម្ដេច ? តើមានអ្វីខ្លះ ដែលបានធ្វើឲ្យអ្នកចាប់អារម្មណ៍អំពី វីអែណា ចាកស៍ ?
- តើអ្នកបានរៀនអ្វីខ្លះមកពីអ្វីដែលអ្នកអានអំពី វីអែណា ចាកស៍ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១

*ព្រះអង្គសង្គ្រោះណែនាំដល់ យ៉ូសែប ស្ម៊ីធ កុំឲ្យបកប្រែអាប៉ូគ្រីផា*

បើអាចធ្វើទៅបាន សូមបង្ហាញប្រភពនៃព័ត៌មានដែលបានកត់ត្រាទុកផ្សេងៗមួយចំនួន ដូចជាសៀវភៅ កាសែត ឬទស្សនាវដ្ដី ឬទូរសព្ទ ។

- តើអ្នកអាចដឹងយ៉ាងដូចម្ដេច ថាអ្វីមួយដែលអ្នកបានអានពីធនធានទាំងនេះគឺជាការពិត ?

សូមពន្យល់ថា វិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១ បានណែនាំយ៉ូសែប ស្ម៊ីធ ពីរបៀបដើម្បីញែកឲ្យដឹង ថាអ្វីដែលគាត់កំពុងអានគឺត្រឹមត្រូវ ។ សូមឲ្យសិស្សម្នាក់អានសេចក្ដីណែនាំកណ្ឌឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែល យ៉ូសែប បានកំពុងធ្វើ ក្នុងពេលដែលលោកបានទទួលវិវរណៈនេះ ។ សូមអញ្ជើញពួកគេឲ្យរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមពន្យល់ថា អាប៉ូគ្រីផា គឺជាការប្រមូលផ្ដុំនៃសៀវភៅពិសិដ្ឋៗរបស់ប្រជាជនយូដា ដែលពុំត្រូវបានដាក់បញ្ចូលនៅក្នុងគម្ពីរហេព្រើរ ( សញ្ញាចាស់ ) ប៉ុន្តែត្រូវបានដាក់បញ្ចូលទៅក្នុងការបកប្រែភាសាក្រិចនៃគម្ពីរប៊ីប មិនយូរប៉ុន្មានបន្ទាប់ពីជំនាន់របស់ព្រះគ្រីស្ទ ។ គម្ពីរមួយចំនួនជាស្ពានភ្ជាប់ពេលវេលា ចម្លោះគ្រាព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ។ នៅពេលពួកសាសនិកជនជំនាន់មុនបានប្រមូលផ្ដុំគម្ពីរទាំងឡាយនៃព្រះគម្ពីរប៊ីប ប៉ុន្មានសតវត្សរ៍ក្រោយ នោះពួកគេបានដាក់បញ្ចូលគម្ពីរនៃអាប៉ូគ្រីផាចូលគ្នា ប៉ុន្តែមានសំណួរទាំងឡាយថាតើគម្ពីរទាំងនេះស្ថិតនៅខាងណានៃព្រះគម្ពីរ ។ ព្រះគម្ពីរបរិសុទ្ធដែលយ៉ូសែប ស្ម៊ីធ បានប្រើដើម្បីបង្កើតការបកប្រែដ៏បំផុសគំនិតរបស់លោកនោះមាននូវគម្ពីរអាប៉ូគ្រីផាផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែសុពលភាពនៃអាប៉ូគ្រីផា ស្ថិតនៅក្នុងចម្ងល់ នោះ យ៉ូសែប បានទូលសួរដល់ព្រះអម្ចាស់ បើសិនជាការបកប្រែព្រះគម្ពីរប៊ីបរបស់គាត់ គួរតែដាក់បញ្ចូលនូវគម្ពីរទាំងនេះឬទេ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែល យ៉ូសែប ស្ម៊ីធ បានរៀនអំពីអាប៉ូគ្រីផា ។ ( អ្នកចាំបាច់ត្រូវពន្យល់ថា *ពាក្យបញ្ចូលបញ្ចូល* គឺជាអ្វីមួយដែលបានដាក់ចូលទៅក្នុងការសរសេរដោយដៃ ពេលខ្លះវាបណ្ដាលឲ្យបង្ខូចអត្ថន័យនៃអត្ថបទដើម ) ។

បន្ទាប់ពីសិស្សរាយការណ៍នូវអ្វីដែលពួកគេរកឃើញហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១:៤–៦ ឲ្យឮៗ ។ សូមឲ្យសិស្សប្រាប់អំពីរបៀបដែល យ៉ូសែប ស្ម៊ីធ អាចដឹងនូវអ្វីដែលពិតនៅក្នុងអាប៉ូគ្រីផា ។

- តើយ៉ូសែប អាចដឹងថាអ្វីជាការពិតនៅក្នុងអាប៉ូគ្រីផាយ៉ាងដូចម្ដេច ?
- តើការប្រឹក្សានៅក្នុង ខ ៤–៦ អាចជួយយើងយល់អ្វីដែលយើងអានយ៉ាងដូចម្ដេច ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖**ព្រះវិញ្ញាណបរិសុទ្ធ អាចជួយយើងដឹង បើសិនជាអ្វីដែលយើងបានអានជាការពិត** )។

អ្នកអាចអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍មួយ ដែលពួកគេបានមាន នៅពេលពួកគេទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ បញ្ជាក់ថា អ្វីដែលពួកគេបានអានជាការពិត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២

*ហ្វ្រេឌើរិក ជី វិលលាម្ស គឺត្រូវទទួលឲ្យចូលទៅក្នុងសហសមាគម*

សូមពន្យល់ថា វិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២ បានណែនាំដល់ពួកអ្នកដឹកនាំសាសនាចក្រ ដែលមានចំណែកនៅក្នុងសហសមាគម ( ក៏បានហៅថាជាសណ្ដាប់រួម ) ដើម្បីទទួល ហ្វ្រេឌើរិក ជី វិលលាម្ស ចូលក្នុង សហសមាគម ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីរបៀបដែលព្រះអម្ចាស់ចង់ឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស ធ្វើជាសមាជិកក្នុងសមាគម ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថា ហ្វ្រេឌើរិក ជី វិលលាម្ស ជា « សមាជិកសកម្ម » មានន័យយ៉ាងណា ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីអាចធ្វើជាសមាជិកសកម្មរបស់សាសនាចក្រសព្វថ្ងៃនេះ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនមកពី ខ ២ អំពីពរជ័យទាំងឡាយដែលបានសន្យាដល់ពួកស្មោះត្រង់ ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម ៖**បើសិនជាយើងស្មោះត្រង់នៅក្នុងការរក្សាបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងនឹងត្រូវបានប្រទានពរជារៀងរហូត** )។

សូមបញ្ចប់ជាមួយនឹងទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានប្រាប់នៅក្នុងមេរៀននេះ ។

មេរៀនទី ៩៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–២០

## បុព្វកថា

នៅថ្ងៃទី ៦ ខែឧសភា ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣ ។ វិវរណៈនេះ នឹងត្រូវបានបង្រៀនជាពីរផ្នែក ។ មេរៀននេះ ផ្ដោតទៅលើ ខ ១–២០ ដែលព្រះយេស៊ូវគ្រីស្ទ បានពន្យល់អំពីគោលបំណងនៃវិវរណៈ ៖ « យើងប្រទានដល់អ្នកនូវពាក្យទាំងនេះ ដើម្បីឲ្យអ្នកអាចយល់ ហើយចេះថ្វាយបង្គំ ហើយស្គាល់នូវអ្វីដែលខ្លួនថ្វាយបង្គំ ប្រយោជន៍ឲ្យអ្នកអាចចូលមកឯព្រះវរបិតាដោយនូវព្រះនាមរបស់យើង ហើយនៅវេលាកំណត់ ឲ្យបានទទួលនូវភាពពោរពេញរបស់ទ្រង់ » (គ. និង ស. ៩៣:១៩) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–៥

*ព្រះយេស៊ូវគ្រីស្ទបង្រៀនអំពីរបៀបដែលបុគ្គលម្នាក់ៗអាចមើលឃើញព្រះភក្ត្ររបស់ទ្រង់ ហើយដឹងថាពិតជាមានទ្រង់មែន*

សូមបង្ហាញរូបភាពមនុស្សល្បីម្នាក់ ដែលសិស្សរបស់អ្នកនឹងស្គាល់ ហើយសួរដល់ពួកគេបើពួកគេស្គាល់ឈ្មោះរបស់បុគ្គលម្នាក់នោះ ។ ( ប្រសិនបើអ្នកពុំមានរូបភាពដាក់បង្ហាញទេ សូមសរសេរឈ្មោះរបស់បុគ្គលនោះនៅលើក្ដារខៀន ហើយសូមឲ្យសិស្សពន្យល់ថាអ្នកនោះជានរណា ហើយអ្វីដែលធ្វើឲ្យគាត់ល្បី ) ។

- ហេតុអ្វីមនុស្សជាច្រើនស្គាល់មនុស្សម្នាក់នេះ ?
- តើអ្នកគិតថាវាសំខាន់ឬទេដើម្បីស្គាល់មនុស្សម្នាក់នេះ ? ហេតុអ្វី ?

សូមដាក់តាំងរូបភាពរបស់ ព្រះយេស៊ូវគ្រីស្ទ ( អ្នកអាចប្រើរូបព្រះយេស៊ូវគ្រីស្ទ[*សៀវភៅរូបភាពសិល្បៈដំណឹងល្អ* (ឆ្នាំ ២០០៩ ) លេខ ១ ] សូមមើលផងដែរ LDS.org) ហើយពន្យល់ថា មនុស្សជាច្រើនសព្វថ្ងៃនេះ ពុំស្គាល់ថាទ្រង់ជានរណាទេ ។



- ហេតុអ្វីអ្នកគិតថាវាសំខាន់ដើម្បីស្គាល់ថាព្រះយេស៊ូវគ្រីស្ទថាជានរណា ?

ថ្លែងទីបន្ទាល់ថាយើងពុំអាចសម្រេចសក្ដានុពលពេញលេញរបស់យើង ក្នុងនាមជាកូនចៅរបស់ព្រះបានទេ លុះត្រាតែយើងស្គាល់ព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣ ព្រះអម្ចាស់បានបង្រៀនអំពីរបៀបដែលយើងអាចបង្កើនចំណេះដឹងរបស់យើងអំពីទ្រង់ និងអំពីព្រះចេស្ដារបស់ទ្រង់ដើម្បីប្រទានពរយើងនៅពេលឥឡូវនេះ និងរហូតដល់ភាពអស់កល្បជានិច្ច ។ សូមសរសេរសំណួរពីដូចខាងក្រោមនៅលើក្ដារខៀន ទុកកន្លែងសម្រាប់ឲ្យសិស្សសរសេរចម្លើយរបស់ពួកគេនៅក្រោមសំណួរទាំងឡាយ ។

*តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ?*
*តើយើងអាចដឹងអ្វីខ្លះពីទ្រង់ប្រសិនបើយើងធ្វើតាមចំណុចទាំងនេះ ?*

***ចែកចាយទីបន្ទាល់របស់អ្នក***
សូមឆ្លៀតឱកាសដើម្បីធ្វើទីបន្ទាល់ឲ្យញឹកញាប់ពីសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះវរបិតាសួគ៌ និង បុត្រាទ្រង់ ព្រះយេស៊ូវ គ្រីស្ទ និងពីសេចក្ដីពិត និងតម្លៃនៃគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ ខណៈពេលដែលវាសមរម្យដើម្បីបញ្ចប់មេរៀនដោយទីបន្ទាល់របស់អ្នក សូមចែកចាយទីបន្ទាល់របស់អ្នក អំឡុងមេរៀនមួយដែលអាចអញ្ជើញព្រះវិញ្ញាណបរិសុទ្ធដើម្បីថ្លែងជាសាក្សីនៃសេចក្ដីពិតដែលត្រូវបានពិភាក្សា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–៥ ឲ្យឮៗ ។ មុនពេលសិស្សចាប់ផ្ដើមអាន សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់រកមើលចម្លើយចំពោះសំណួរទីមួយ ហើយសិស្សពាក់កណ្ដាលថ្នាក់ទៀតរកមើលចម្លើយចំពោះសំណួរទីពីរ ។ បន្ទាប់ពីខគម្ពីរត្រូវបានអាន សូមអញ្ជើញសិស្សពីរបីនាក់ឡើងមកមុខក្ដារខៀន ហើយសរសេរចម្លើយរបស់ពួកគេតបនឹងសំណួរទាំងនោះ ។ បន្ទាប់មកសូមសួរសិស្សនូវសំណួរខាងក្រោម ៖

- តើអ្នកនឹងថ្លែងអំពីសេចក្ដីសន្យានៅក្នុង ខ ១ ជាគោលការណ៍ « ប្រសិនបើ–នោះ » យ៉ាងដូចម្ដេច ? ( ការឆ្លើយតបរបស់សិស្សគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងបោះបង់ចោលអំពើបាបរបស់យើង មករកព្រះគ្រីស្ទ អំពាវនាវរកព្រះនាមរបស់ទ្រង់ គោរពតាមសំឡេងទ្រង់ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ បន្ទាប់មកយើងនឹងមើលឃើញព្រះភក្ត្រទ្រង់ ហើយស្គាល់ទ្រង់ថាជានរណា** )។

អ្នកអាចគូសបញ្ជាក់ថាពរជ័យនេះនឹងកើតមានតាមពេលវេលារបស់ព្រះអម្ចាស់ផ្ទាល់ តាមមាគ៌ារបស់ទ្រង់ ហើយស្របតាមព្រះទ័យទ្រង់ ( សូមមើល គ. និង ស. ៨៨:៦៨; សូមមើលផងដែរ អេណុស ១:២៧) ។

- តើសកម្មភាពនិមួយៗនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១ ជួយយើងឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?
- ចេញមកពីអ្វីដែលអ្នកបានរៀននៅក្នុង ខ ៣ តើគោលលទ្ធិអ្វីដែលសំខាន់ដើម្បីយល់ដឹងអំពីព្រះវរបិតា និងព្រះរាជបុត្រា ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**ព្រះបិតា និងព្រះរាជបុត្រា គឺរួមគ្នាតែមួយ**)។
- តើឃ្លាថា ព្រះវរបិតា និងព្រះរាជបុត្រាគឺរួមគ្នាតែមួយមានន័យយ៉ាងណា ?

សូមជួយសិស្សយល់ដឹងថា ព្រះវរបិតា និងព្រះរាជបុត្រា គឺមានតួអង្គផ្សេងគ្នា ហើយជាក់ស្ដែង ដែលតួអង្គនិមួយៗ មានរូបកាយ សាច់ និងឆ្អឹងដ៏រុងរឿងមួយ ( សូមមើល គ. និង ស. ១៣០:២២) ។ ទោះជាយ៉ាងណាក៏ដោយ ព្រះវរបិតា និងព្រះរាជបុត្រា គឺមានគោលបំណង និងគោលលទ្ធិរួមគ្នាតែមួយ ។ ពួកទ្រង់រួមសាមគ្គីគ្នាដ៏ឥតខ្ចោះក្នុងការនាំមកនូវផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតា ។

សូមចង្អុលបង្ហាញនូវឃ្លាដូចខាងក្រោមនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤៖ « ជាព្រះវរបិតាពីព្រោះព្រះអង្គបានប្រទានដល់យើងនូវភាពពោរពេញរបស់ទ្រង់ » ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១៧–២៦ ឲ្យឮៗ ។ សូមសួរសំណួរខាងក្រោម ៖

- តើការដែលព្រះយេស៊ូវគ្រីស្ទបានទទួលនូវភាពពោរពេញរបស់ព្រះវរបិតាមានន័យដូចម្ដេច ? ( សូមមើល គ. និង ស. ៩៣:១៦–១៧, ២៦ ) ។
- តើសេចក្ដីពិតនៅក្នុង ខ ៤–៥ ជួយយើងយល់អំពីអត្ថន័យដែលថា ព្រះបិតា និងព្រះរាជបុត្រា គឺរួមគ្នាតែមួយ យ៉ាងដូចម្ដេច ?

សូមពន្យល់ថា ដោយសារតែព្រះបិតា និងព្រះរាជបុត្រា គឺរួមគ្នាតែមួយ នោះយើងនឹងបានស្គាល់ទាំងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នៅពេលយើងធ្វើនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៦–២០

*កំណត់ត្រារបស់យ៉ូហាន ត្រូវបានប្រើដើម្បីជួយយើងយល់ដឹងអំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទ បានទទួលនូវភាពពេញលេញនៃសិរីល្អរបស់ព្រះវរបិតាសួគ៌*

សូមពន្យល់ថា យើងអាចរៀនច្រើនអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈការសិក្សាព័ត៌មាន ដែលព្រះអម្ចាស់បានប្រទានឲ្យដកស្រង់ចេញមកពីកំណត់ត្រារបស់យ៉ូហាន នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣។ វាអាចជាជំនួយដើម្បីពន្យល់ផងដែរថា សាវក យ៉ូហាន គឺជាសិស្សរបស់យ៉ូហាន បាទីស្ទ នៅពេលព្រះយេស៊ូវគ្រីស្ទ បានចាប់ផ្ដើមការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ។ នៅក្នុងការសរសេររបស់លោក សាវកយ៉ូហាន បានផ្ដល់ដំណើររឿងខ្លះៗអំពីភាពជាសាក្សីរបស់យ៉ូហានបាទីស្ទ បានថ្លែងអំពីព្រះអង្គសង្គ្រោះ ។

សូមបែងចែកសិស្សជាក្រុមៗ ដែលមានសមាជិកបួននាក់ ។ សូមឲ្យក្រុមនិមួយៗអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៦–១១ ជាមួយគ្នា ហើយប្រាប់អំពីចំណងជើងដែលបានប្រើដើម្បីពិពណ៌នាអំពីព្រះអង្គសង្គ្រោះ ។ ចំណងជើងដែលសិស្សរកឃើញគួរតែរួមមានដូចតទៅ « ជាព្រះបន្ទូលគឺជាសារទូតអំពីសេចក្ដីសង្គ្រោះ » (ខ ៨) « ជាពន្លឺ និង ជាព្រះដ៏ប្រោសលោះនៃពិភពលោក » (ខ ៩) « ជាព្រះវិញ្ញាណនៃសេចក្ដីពិត » (ខ ៩) « ព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា » (ខ ១១) ។

នៅពេលពួកគេបានបញ្ចប់ការអានខគម្ពីរទាំងនេះ សូមផ្តល់ដល់សិស្សម្នាក់ៗនូវច្បាប់ចម្លងនៃព័ត៌មានដូចខាងក្រោមអំពីចំណងជើងដែលបានប្រាប់នៅខាងលើ ។ សូមឲ្យសមាជិកក្រុមនិមួយៗ ជ្រើសរើសចំណងជើងមួយ ហើយសិក្សាអំពីព័ត៌មានដែលទាក់ទងដោយស្ងាត់ស្ងៀម ។ សូមណែនាំដល់សិស្សឲ្យត្រៀមខ្លួនដើម្បីពន្យល់ដល់ក្រុមរបស់ពួកគេនូវអ្វីជាអត្ថន័យនៃចំណងជើង ហើយចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរដូចខាងក្រោម ។ អ្នកអាចបង្ហាញសំណួរនៅលើក្តារខៀន ឬដាក់បញ្ចូលវានៅក្នុងក្រដាសចែកចាយ ដូច្នេះសិស្សអាចយោងទៅលើវាតាមត្រូវការ ។

- តើព័ត៌មាននេះ ជួយអ្នកស្គាល់ មានអំណរគុណ និងដើរតាមព្រះយេស៊ូវគ្រីស្ទកាន់តែល្អប្រសើរយ៉ាងដូចម្តេច ?

### « ជាព្រះបន្ទូលគឺជាសារទូតអំពីសេចក្តីសង្គ្រោះ »

ព្រះយេស៊ូវគ្រីស្ទ គឺត្រូវបានសំដៅទៅលើថាជា « ព្រះបន្ទូល » នៅក្នុង យ៉ូហាន ១:១ ។ អែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖



« នៅក្នុងភាសាក្រិច នៃព្រះគម្ពីរសញ្ញាថ្មី ពាក្យថា*ព្រះបន្ទូល*គឺជា*និមិត្តរូប*ឬ ‹ ការបង្ហាញ › ។. . . វាក្យសព្ទនោះ អាចមើលទៅដូចជាចម្លែក ប៉ុន្តែវាសមរម្យ ។ យើងប្រើពាក្យទាំងឡាយដើម្បីប្រាប់អំពីការបង្ហាញរបស់យើងដល់អ្នកដទៃ ។ ដូច្នេះ ព្រះយេស៊ូវគឺជាព្រះបន្ទូល ឬការបង្ហាញ អំពីព្រះវរបិតារបស់ទ្រង់ទៅដល់ពិភពលោក » («Jesus the Christ: Our Master and More,» *Ensign,* ខែ មេសា ឆ្នាំ ២០០០,ទំព័រ ៤ ) ។ ព្រះយេស៊ូវគ្រីស្ទ ត្រូវបានហៅជាសារទូតអំពីសេចក្តីសង្គ្រោះ ដោយសារតែទ្រង់បានប្រកាសព្រះបន្ទូលរបស់ព្រះបិតាចំពោះយើង ហើយអ្នកទាំងឡាយណាដែលស្តាប់ ហើយគោរពតាមសារលិខិតរបស់ទ្រង់នឹងទទួលសេចក្តីសង្គ្រោះ ( សូមមើល យ៉ូហាន ១២:៤៩–៥០) ។

### « ទ្រង់គឺជាពន្លឺ និង ព្រះប្រោសលោះនៃពិភពលោក »

តាមរយៈពន្លឺនៃព្រះគ្រីស្ទ ព្រះយេស៊ូវគ្រីស្ទបានប្រទានជីវិត និងពន្លឺដល់រឿងគ្រប់យ៉ាង ។ ទ្រង់ក៏ត្រូវបានហៅឲ្យធ្វើជាពន្លឺនៃលោកិយដោយសារតែទ្រង់បានប្រទានគំរូដ៏ឥតខ្ចោះអំពីរបៀបដែលមនុស្សទាំងអស់គួររស់នៅ ។ ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះប្រោសលោះនៃពិភពលោក ដោយសារតែដង្វាយធួនរបស់ទ្រង់ ទ្រង់បានបង់ថ្លៃចំពោះអំពើបាបនៃមនុស្សលោកទាំងអស់ ហើយបានធ្វើឲ្យមានការរស់ឡើងវិញដល់មនុស្សគ្រប់រូប ។

### « ព្រះវិញ្ញាណនៃសេចក្តីពិត »

ចំណងជើងថា « ព្រះវិញ្ញាណនៃសេចក្តីពិត » ជួយយើងយល់ដឹងថាព្រះយេស៊ូវ គ្រីស្ទ ពុំកុហកឡើយ ហើយថាទ្រង់មាននូវគ្រប់ភាពពេញលេញនៃសេចក្តីពិត ( សូមមើលអេណុស ១:៦, គ. និង ស. ៩៣:២៦) ។ ទ្រង់បានបើកសម្តែងសេចក្តីពិតដល់មនុស្សលោក ( សូមមើល គ. និង ស. ៧៦:៧–៨) ។ ចំណងជើងនេះ ត្រូវបានប្រើសំដៅទៅលើព្រះវិញ្ញាណបរិសុទ្ធ ដែលថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ( សូមមើល យ៉ូហាន ១៥:២៦) ។

### « ទ្រង់ គឺជាបុត្រសំណព្វតែមួយគត់របស់ព្រះវរបិតា » ។

ព្រះយេស៊ូវគ្រីស្ទ គឺជាតួអង្គដ៏មហិមាបំផុតដែលបានចាប់កំណើតនៅលើផែនដីនេះ ។ ព្រះ គឺជាព្រះបិតានៃវិញ្ញាណរបស់មនុស្សលោកទាំងអស់ ប៉ុន្តែព្រះយេស៊ូវគ្រីស្ទ គឺជាមនុស្សតែម្នាក់គត់ដែលបានកើតមកក្នុងពិភពលោក ជាបុត្រានៃព្រះក្នុងសាច់ និងឆ្អឹង ។ ដោយសារតែព្រះយេស៊ូវគ្រីស្ទ បានកើតមកពីព្រះបិតាអមត នោះទ្រង់មានអំណាចដើម្បីយកឈ្នះលើសេចក្តីស្លាប់ ( សូមមើល យ៉ូហាន ៥:២៦) ។ អំណាចនេះ បានអនុញ្ញាតឲ្យទ្រង់សម្រេចនូវដង្វាយធួន និងការរស់ឡើងវិញដល់មនុស្សលោកទាំងអស់ ។

បន្ទាប់ពីក្រុមទាំងឡាយមានពេលគ្រប់គ្រាន់ដើម្បីបញ្ចប់ការពិភាក្សារបស់ពួកគេរួចហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៣:១២–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានប្រែក្លាយដូចជាព្រះបិតាទ្រង់ ។

- តើព្រះយេស៊ូវគ្រីស្ទប្រែក្លាយដូចជាព្រះបិតាទ្រង់យ៉ាងដូចម្តេច ? ( ចម្លើយរបស់សិស្ស គួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖**ព្រះយេស៊ូវគ្រីស្ទបានធំឡើងពីព្រះគុណថែមលើព្រះគុណ រហូតដល់ទ្រង់ទទួលបាននូវភាពពេញលេញនៃសិរីល្អរបស់ព្រះបិតា** )។

- តើអ្នកគិតថាព្រះយេស៊ូវគ្រីស្ទបានបន្តពីព្រះគុណថែមលើព្រះគុណរហូតដល់ទ្រង់បានទទួលបាននូវភាពពេញលេញយ៉ាងដូចម្តេច ?

សូមជួយសិស្សយល់ថា ព្រះគុណគឺជាកម្លាំង និង ជាព្រះចេស្ដាមកពីព្រះដែលអនុញ្ញាតឲ្យយើងទទួលបានជីវិតដ៏អស់កល្បជានិច្ច និង ភាពតម្កើងឡើង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១៩–២០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីមូលហេតុដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យ សម្រាប់ការបើកសម្ដែង អំពីរបៀបដែលទ្រង់ទទួលបានភាពពេញលេញនៃព្រះវរបិតា ។

- យោងតាម ខ ១៩, ហេតុអ្វីព្រះអង្គសង្គ្រោះបើកសម្ដែងពីរបៀបដែលទ្រង់ទទួលបានភាពពេញលេញនៃព្រះវរបិតាដូច្នេះ ?

សូមជួយសិស្សឲ្យមើលឃើញថា ព្រះអង្គសង្គ្រោះបានបើកសម្ដែងអំពីរបៀបដែលទ្រង់បានទទួលភាពពេញលេញមួយ គឺដើម្បីឲ្យយើងអាច « យល់ និងស្គាល់ » ទ្រង់ និងព្រះវរបិតាសួគ៌ ហើយស្គាល់របៀបដើម្បីថ្វាយបង្គំព្រះបិតា និងទទួលនូវភាពពេញលេញរបស់ទ្រង់ ។ សូមសរសេរសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅលើក្ដាខៀន ៖ (សេចក្ដីថ្លែងនេះត្រូវបានរកឃើញនៅក្នុង *The Promised Messiah : The First Coming of Christ* (ឆ្នាំ ១៩៧៨) ទំព័រ ៥៦៨ ]។

> *« ការថ្វាយបង្គំដ៏ឥតខ្ចោះគឺជាការត្រាប់តាម ។ យើងគោរពដល់អ្នកទាំងឡាយដែលយើងត្រាប់តាម » ( អែលឌើរ ប្រ៊ូស អរ ម៉ាក់ខនឃី ) ។*

- តើអ្នកគិតថាការថ្វាយបង្គំមានន័យដូចម្ដេច ?
- តើយើងថ្វាយបង្គំដល់ព្រះវរបិតាសួគ៌របស់យើងយ៉ាងដូចម្ដេច ? ( សិស្សគួរបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **យើងត្រូវថ្វាយបង្គំដល់ព្រះវរបិតាសួគ៌ ដោយការធ្វើតាមគំរូនៃព្រះយេស៊ូវគ្រីស្ទ** )។
- តើការរីកចម្រើនរបស់ព្រះអង្គសង្គ្រោះពីព្រះគុណថែមលើព្រះគុណ ស្រដៀងគ្នាទៅនឹងដំណើរការនៃការរៀនសូត្រ និងការរីកចម្រើនដែលយើងអាចទទួលបទពិសោធន៍របៀបណា ?
- តើសេចក្ដីសន្យាអ្វីខ្លះ ត្រូវបានប្រទានឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២០ ដល់អ្នកទាំងឡាយណាដែលធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ ? ( សិស្សគួរបង្ហាញគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងរក្សាបទបញ្ញត្តិទាំងឡាយ នោះយើងអាចទទួលបានភាពពេញលេញនៃព្រះវរបិតា ដូចដែលព្រះយេស៊ូវគ្រីស្ទទទួលបានផងដែរ** )។

សូមលើករូបភាពរបស់ព្រះអង្គសង្គ្រោះឡើង ដែលអ្នកបានដាក់តាំងនៅពេលចាប់ផ្ដើមថ្នាក់ ។

- ហេតុអ្វីវាសំខាន់ដើម្បីមានទីបន្ទាល់មួយអំពីគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ការបង្រៀន និងជង្វាយធួនរបស់ទ្រង់ ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីបន្ត « ព្រះគុណថែមលើព្រះគុណ » (គ. និង ស. ៩៣:១៣) ហើយកាន់តែក្លាយដូចជាទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ឡូរ៉េនសូ ស្នូ ហើយសុំឲ្យសិស្សក្នុងថ្នាក់គិតអំពីអ្វីដែលពួកគេចង់ធ្វើដើម្បីប្រែក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះ ៖



« សូមកុំរំពឹងឲ្យបានល្អឥតខ្ចោះក្នុងពេលតែមួយឡើយ ។ បើអ្នករំពឹងដូច្នោះ នោះអ្នកនឹងខកចិត្តហើយ ។ សូមឲ្យថ្ងៃនេះបានល្អប្រសើរជាងកាលពីម្សិលមិញ ហើយមានថ្ងៃស្អែកបានល្អប្រសើរជាងថ្ងៃនេះ ។ ការល្បួងដែលវាប្រហែលជាបានយកឈ្នះលើយើងខ្លះៗនៅថ្ងៃនេះ ចូរកុំឲ្យវាយកឈ្នះលើយើងនៅថ្ងៃស្អែកឡើយ ។ ដូច្នេះសូមបន្តធ្វើឲ្យបានល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយកុំទុកឲ្យជីវិតរបស់អ្នកត្រូវបញ្ចប់ដោយគ្មានសម្រេចសេចក្ដីល្អដល់អ្នកដទៃក៏ដូចជាខ្លួនឯងឡើយ » (*Teachings of Presidents of the Church: Lorenzo Snow* [ ឆ្នាំ ២០១២ ], ទំព័រ ១០៣) ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវរបៀបជាក់លាក់មួយ ដែលពួកគេនឹងស្វែងរកការរីកចម្រើន និងការកែលម្អដោយការធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ។

មេរៀនទី ៩៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–៥៣

## បុព្វកថា

នេះគឺជាផ្នែកទីពីរនៃមេរៀនពីរអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះ នៅថ្ងៃទី ៦ ខែឧសភា ឆ្នាំ ១៨៣៣ ។ នៅក្នុងផ្នែកខាងក្រោយនៃវិវរណៈ ព្រះអម្ចាស់បានបើកសម្ដែងសេចក្ដីពិតសំខាន់អំពីជីវិតមុនជីវិតនេះរបស់យើង ។ នៅគ្រានៃវិវរណៈនេះ បានទទួលមានមនុស្សជាច្រើនបានជឿថា ជីវិតរបស់យើង បានចាប់ផ្ដើមពេលចាប់ទំផ្ទៃម្ដាយ ឬនៅពេលចាប់កំណើតមក ។ ការគិតដូច្នេះ គឺមានជាទូទៅនៅសព្វថ្ងៃនេះផងដែរ ។ ព្រះអម្ចាស់បានបង្រៀន យ៉ូសែប ស្ម៊ីធ ថា « កាលដើមដំបូងមនុស្សក៏បាននៅជាមួយនឹងព្រះដែរ » (គ. និង ស. ៩៣:២៩) ហើយថាវិញ្ញាណរបស់យើង គឺអស់កល្បជានិច្ច ។ ទ្រង់ក៏បានបង្រៀនអំពីរបៀបដែលយើងអាចទទួលបានសេចក្ដីពិត និង ពន្លឺ ហើយបានណែនាំព្យាការី និងអ្នកដឹកនាំសាសនាចក្រដទៃទៀតឲ្យរៀបចំគេហដ្ឋានរបស់ពួកគេឲ្យមានរបៀបរៀបរយ ដើម្បីគ្រួសាររបស់ពួកគេអាចត្រូវបានពង្រឹង និងការពារ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–៣៩

*ព្រះអម្ចាស់បានណែនាំពួកអ្នកបម្រើរបស់ទ្រង់អំពីរបៀបដើម្បីទទួលសេចក្ដីពិត និងពន្លឺ*

សូមស្នើរដល់សិស្ស ដែលជាកូនច្បងនៅក្នុងគ្រួសាររបស់ពួកគេឲ្យក្រោកឈរឡើង ។

- តើអ្នកគិតថាទំនួលខុសត្រូវមួយចំនួននៃការធ្វើជាកូនច្បងមានអ្វីខ្លះ ?

សូមឲ្យសិស្សអង្គុយចុះវិញ ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–២៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះយេស៊ូវ គ្រីស្ទ បានបើកសម្ដែងអំពីព្រះអង្គទ្រង់ ។

- ស្របតាម ខ ២១ តើភាពខុសប្លែកអ្វីខ្លះ ដែលព្រះយេស៊ូវគ្រីស្ទ មាននៅក្នុងចំណោមកូនវិញ្ញាណនៃព្រះវរបិតាសួគ៌ទាំងអស់ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**ព្រះយេស៊ូវគ្រីស្ទ គឺជាកូនច្បងនៃកូនចៅខាងវិញ្ញាណនៃព្រះវរបិតាសួគ៌ទាំងអស់** )។

សូមពន្យល់ថា ដោយសារតែព្រះយេស៊ូវគ្រីស្ទ គឺជាកូនច្បងនៃព្រះបិតា នោះទ្រង់គឺជា « អ្នកទទួលមរតកដែលបានតែងតាំង » លើអ្វីៗទាំងអស់ដែលព្រះបិតាមាន (ហេព្រើរ ១:២) ។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់ចង់ឲ្យកូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ចែកចាយគ្នានៃកេរតំណែលនេះ ។ យើងមានឱកាសដើម្បីធ្វើជា « អ្នកគ្រងមរតកនៃព្រះជាមួយព្រះគ្រីស្ទ » (រ៉ូម ៨:១៧) ហើយត្រូវបានរាប់នៅក្នុងចំណោម « សាសនាចក្រនៃកូនច្បង » (គ. និង ស. ៩៣:២២, សូមមើលផងដែរ គ. និង ស. ៧៦:៥១–៥៤) ។ នៅតាមរបៀបនេះ យើងក៏អាចទទួលនូវអ្វីៗទាំងអស់ដែលព្រះបិតាមានផងដែរ ( សូមមើល គ. និង ស. ៧៦:៥៥, ៨៤:៣៧–៣៨) ។

- ស្របតាមគោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២២តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីធ្វើជាអ្នកទទួលសិរីល្អនៃបុត្រច្បង ?
- តើការធ្វើជាកូនសំណប់តាមរយៈព្រះយេស៊ូវគ្រីស្ទមានន័យដូចម្ដេច ? ( ដើម្បីកើតម្ដងទៀតខាងវិញ្ញាណ ហើយបានស្អាតពីគ្រប់អំពើបាបតាមរយៈព្រះចេស្ដានៃដង្វាយធួន ) ។
- សូមកំណត់សម្គាល់នៅក្នុង ខ ២១ ថា ព្រះយេស៊ូវគ្រីស្ទ បានមានបន្ទូលថា ទ្រង់គឺជា « កាលដើមដំបូងគង់នៅជាមួយព្រះវរបិតា » ។ ស្របតាម ខ ២៣ តើនរណាផ្សេងទៀតដែលកាលដំបូងបាននៅជាមួយព្រះវរបិតា ? ( ពាក្យ *អ្នករាល់គ្នា* នៅក្នុងខនេះសំដៅទៅលើកូនចៅវិញ្ញាណទាំងអស់របស់ព្រះវរបិតាសួគ៌ ។ អ្នកអាចផ្ដល់យោបល់ដល់សិស្សឲ្យជំនួសពាក្យ *អ្នករាល់គ្នា* នៅក្នុង ខ ២៣ ដោយឈ្មោះរបស់ពួកគេ ហើយសរសេរវានៅរឹមទំព័រនៃព្រះគម្ពីររបស់ពួកគេ ) ។

សូមពន្យល់ថា ខណៈដែលយើងបានរស់នៅជាមួយព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នៅក្នុងជីវិតមុនជីវិតនេះ នោះយើងត្រូវបានបង្រៀនដោយព្រះបិតា និងព្រះរាជបុត្រា ហើយមានឱកាសដើម្បីទទួលយក ឬបដិសេធសេចក្ដីពិត ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៤–២៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអម្ចាស់បានបង្រៀនអំពីសេចក្ដីពិតនៅក្នុងខគម្ពីរទាំងនេះ ។

- តើអ្នករៀនមកពីនិយមន័យនៃសេចក្ដីពិតរបស់ព្រះអម្ចាស់នៅក្នុង ខ ២៤ អ្វីខ្លះ ?
- តើនរណាត្រូវបានពិពណ៌នានៅក្នុង ខ ២៥? ( សាតាំង ) ។
- តើសាតាំងព្យាយាមមានឥទ្ធិពលលើចំណេះដឹងអំពីសេចក្ដីពិតរបស់យើងយ៉ាងដូចម្ដេចខ្លះ ? ( ឃ្លា « ការណ៍ណាដែលលើស ឬតិចជាងនេះ » បង្ហាញថា សាតាំងព្យាយាមបង្ខូច ហើយកាត់បន្ថយចំណេះដឹងរបស់យើងអំពីសេចក្ដីពិត ) ។
- តើយើងរៀនអ្វីខ្លះមកពី ខ ២៦ អំពីព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៣៦–៣៧ ដោយស្ងាត់ស្ងៀម ហើយប្រាប់ពីសេចក្ដីពិតបន្ថែមដែលព្រះអម្ចាស់បានបើកសម្ដែងអំពីពន្លឺ និងសេចក្ដីពិត ។

- តើព្រះអម្ចាស់បានបើកសម្ដែងអំពីពន្លឺ និងសេចក្ដីពិតនៅក្នុងខគម្ពីរទាំងនេះអ្វីខ្លះ ? ( សូមជួយសិស្សឲ្យយល់ថា ពន្លឺ និងសេចក្ដីពិត ក៏ហៅថាជាបញ្ញាផងដែរ គឺជាចរិកលក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ និង ព្រះវរបិតាសួគ៌ ) ។
- តើយើងទទួលប្រយោជន៍ដោយការទទួលពន្លឺ និងសេចក្ដីពិតយ៉ាងដូចម្ដេច ? ( សិស្សអាចផ្ដល់ចម្លើយផ្សេងៗគ្នា ។ នៅពេលពួកគេឆ្លើយតប សូមជួយពួកគេស្គាល់នូវគោលការណ៍ដូចខាងក្រោម ៖**ដោយការទទួលពន្លឺ និងសេចក្ដីពិត នោះយើងអាចប្រែក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាសួគ៌** )។




សូមថតចម្លងឌីយ៉ាក្រាមដែលអមជាមួយនៅលើក្ដារខៀន ប៉ុន្តែកុំដាក់សេចក្ដីថ្លែងការណ៍នៅក្នុងប្រអប់ទាំងពីរឡើយ ។ សិស្សនឹងរកឃើញថាគោលការណ៍ទាំងនេះជាការរីកចម្រើនក្នុងមេរៀន ។ ( អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យចម្លងឌីយ៉ាក្រាមទុកនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ) ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៦–២៨ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយរកមើលនូវអ្វីដែលយើងត្រូវតែធ្វើដើម្បីទទួលសេចក្ដីពិត និងពន្លឺ ។

- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលសេចក្ដីពិត និងពន្លឺ ? ( សិស្សគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **យើងទទួលសេចក្ដីពិត និងពន្លឺ នៅពេលយើងរក្សាបទបញ្ញត្តិ ។** សូមសរសេរគោលការណ៍នេះនៅក្នុងប្រអប់នៅខាងស្ដាំដៃនៃឌីយ៉ាក្រាមនៅលើក្ដារខៀន ) ។

- តើការគោរពបទបញ្ញត្តិជួយយើងទទួលបានសេចក្ដីពិត និងពន្លឺយ៉ាងដូចម្ដេច ?
- តើពេលណាដែលអ្នកមានអារម្មណ៍ថា អ្នកបានទទួលសេចក្ដីពិត និងពន្លឺដោយការរក្សាបទបញ្ញត្តិ ?

សូមពន្យល់ថា នៅពេលយើងរស់នៅជាមួយព្រះមុនពេលយើងកើតមក នោះយើងមានសិទ្ធិសេរីភាព–ជាលទ្ធភាពដើម្បីជ្រើសរើស និងធ្វើសកម្មភាពសម្រាប់ខ្លួនយើង ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៩–៣២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលការប្រើសិទ្ធិសេរីភាពរបស់យើង មានឥទ្ធិពលលើលទ្ធភាពរបស់យើង ដើម្បីទទួលពន្លឺ និងសេចក្ដីពិតដោយរបៀបណា ។ បន្ទាប់មក សូមអញ្ជើញសិស្សឲ្យរាយការណ៍នូវអ្វីដែលពួកគេរកឃើញ ។

- ស្របតាម ខ ៣១–៣២ តើមានផលវិបាកអ្វីខ្លះ បើយើងជ្រើសរើសពុំទទួលយកពន្លឺ ? ( យើងដាក់ខ្លួនយើងនៅក្រោមការដាក់ទោស ។ នេះមានន័យថា យើងបង្អាក់ការរីកចម្រើនខាងវិញ្ញាណរបស់យើង ដោយការបដិសេធពុំទទួលយកពន្លឺដែលមានដល់យើងនោះ ) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណួរខាងក្រោមនេះ ៖

- តើយើងអាចបាត់បង់ពន្លឺ និងសេចក្ដីពិត ដែលយើងបានទទួលរួចហើយដែរឬទេ ? ( ដើម្បីជួយសិស្សឆ្លើយសំណួរនេះ សូមអញ្ជើញឲ្យពួកគេស្វែងរកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៣៩) ។ អ្នកក៏អាចអញ្ជើញពួកគេឲ្យស្វែងរកនៅក្នុង អាលម៉ា ១២:១០–១១) ។
- តើមានអ្វីខ្លះ ដែលបណ្ដាលឲ្យយើងបាត់បង់ពន្លឺ និងសេចក្ដីពិត ? ( សិស្សគួរប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ការមិនគោរពប្រតិបត្តិ និងទំនៀមទម្លាប់ខុសឆ្គង បណ្ដាលឲ្យយើងបាត់បង់ពន្លឺ និងសេចក្ដីពិត ។** សូមសរសេរគោលការណ៍នេះនៅក្នុងប្រអប់នៅខាងឆ្វេងដៃនៃឌីយ៉ាក្រាមនៅលើក្ដារខៀន ) ។
- តើគំរូនៃទំនៀមទំលាប់ ឬសកម្មភាពទូទៅដែលមនុស្សជាច្រើនបានធ្វើមួយចំនួនណាខ្លះ ដែលអាចបណ្ដាលឲ្យយើងបាត់បង់ពន្លឺ និងសេចក្ដីពិតពីព្រះវរបិតាសួគ៌របស់យើង ?

សកម្មភាពដូចខាងក្រោម អាចជួយបង្ហាញពីរបៀបដែលជម្រើសផ្ទាល់ខ្លួនរបស់យើង ដើម្បីគោរព ឬមិនគោរពតាមបទបញ្ញត្តិរបស់ព្រះ ជះឥទ្ធិពលលើលទ្ធភាពរបស់យើង ដើម្បីទទួលបានពន្លឺ និងសេចក្ដីពិត ឬបាត់បង់វា ។ សូមបង្ហាញ ព័ត៌មានដូចខាងក្រោម នៅលើក្ដារខៀន ឬ ចម្លងវានៅលើក្រដាសចែកសម្រាប់សិស្សម្នាក់ៗ ។ សូមអញ្ជើញសិស្សម្នាក់អានកថាខណ្ឌទីមួយឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ពន្យល់ពីរបៀប និងមូលហេតុដែលការជ្រើសរើសរបស់ ម៉ារៀ នឹងជះឥទ្ធិពលលើលទ្ធភាពរបស់នាងដើម្បីទទួលពន្លឺ និងសេចក្ដីពិតយ៉ាងណាខ្លះ ។ បន្ទាប់ពីសិស្សរៀបរាប់នូវអ្វីដែលពួកគេបានរកឃើញហើយ សូមធ្វើដំណើរការនេះជាមួយនឹងកថាកណ្ឌ ២–៤ ម្ដងទៀត ។

១. ម៉ារៀ អធិស្ឋានរៀងរាល់ព្រឹក និងល្ងាច ។ នាងមានអារម្មណ៍សេចក្ដីអំណរដែលបានធ្វើការបម្រើ រក្សាសេចក្ដីសញ្ញារបស់នាង និង ស្រាវជ្រាវបទគម្ពីរជារៀងរាល់ថ្ងៃ ។ នាងបានជួយប្រមូលគ្រួសាររបស់នាងមកសិក្សាព្រះគម្ពីរ និង អធិស្ឋានជាគ្រួសារយ៉ាងទៀងទាត់ ។ នាងទន្ទឹងរង់ចាំទទួលទានសាក្រាម៉ង់រាល់សប្ដាហ៍នៅព្រះវិហារ ។

២. ម៉ារៀ អធិស្ឋាន ហើយសិក្សាគម្ពីរជាញឹកញាប់ ប៉ុន្តែពុំមែនជារៀងរាល់ថ្ងៃនោះទេ ។ ភាគច្រើននាងចូលរួមក្នុងព្រះវិហារ ហើយតាមធម្មតា នាងស្ដាប់អ្នកទាំងឡាយដែលឡើងនិយាយ និងបង្រៀន ។ នាងទៅសកម្មភាពយុវនារី បើនាងដឹងថា មិត្តរបស់នាងនឹងទៅទីនោះ ។

៣. ម៉ារៀ អធិស្ឋានថាបើសិនជានាងពុំនឿយហត់ ឬស្រេកឃ្លាន។ នាងជួយកិច្ចការងារផ្ទះមិនពេញដៃពេញជើង ហើយអានគម្ពីរជាមួយគ្រួសារតែពេលដែលងាយស្រួលប៉ុណ្ណោះ ។ តាមធម្មតានាងបានគេចព្រះវិហារ ហើយគេចពីសកម្មភាពយុវនារី ។ ជួនកាលនាងពុំគោរពច្បាប់នៃប្រាជ្ញាវាងវៃ ។

៤. ម៉ារៀ ពុំដែលអធិស្ឋាន អានព្រះគម្ពីរ ឬចូលរួមក្នុងការប្រជុំសាសនាចក្រទេ ។ ប៊ីស្សព បានសុំជួបនាង ប៉ុន្តែនាងនឹងពុំនិយាយជាមួយប៊ីស្សពទេ ។ នាងល្មើសនឹងពាក្យសម្ដីនៃប្រាជ្ញាវាងវៃជាញឹកញាប់ ។ នាងតែងឈ្លោះប្រកែកជាមួយសមាជិកគ្រួសារ ។ នាងមានអារម្មណ៍នៅឆ្ងាយពីព្រះវរបិតាសួគ៌ ។

- ផ្អែកទៅលើឧទាហរណ៍ទាំងនេះ តើអ្នកនឹងសង្ខេបអំពីសារៈសំខាន់នៃការសម្រេចចិត្តប្រចាំថ្ងៃរបស់យើង និងឥទ្ធិពលរបស់ពួកគេទៅលើពន្លឺ និងសេចក្ដីពិតដែលយើងទទួលយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤០–៥៣

*ព្រះអម្ចាស់ទូន្មានដល់ពួកអ្នកបម្រើទ្រង់ឲ្យរៀបចំគេហដ្ឋានឲ្យមានរបៀបរៀបរយ*

សូមអញ្ជើញឲ្យសិស្សពិភាក្សាសំណួរខាងក្រោមជាមួយនឹងដៃគូពួកគេ ៖

- តើការប្រាស្រ័យទាក់ទងរបស់អ្នកជាមួយនឹងឪពុកម្ដាយអ្នក ឬសមាជិកគ្រួសារដទៃទៀត ជួយអ្នកឲ្យរីកចម្រើននៅក្នុងពន្លឺ និងសេចក្ដីពិតយ៉ាងដូចម្ដេច ?

បន្ទាប់ពីសិស្សបានពិភាក្សាអំពីសំណួរទាំងនេះ សូមអញ្ជើញពួកគេពីរបីនាក់ឲ្យចែកចាយនូវចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ទាំងមូល ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការទទួលខុសត្រូវដែលព្រះបានប្រទានដល់ឪពុកម្ដាយ ។

- តើការទទួលខុសត្រូវអ្វីខ្លះ ដែលព្រះបានប្រទានដល់ឪពុកម្ដាយ ?

- តើឪពុកម្ដាយចិញ្ចឹមបីបាច់កូនរបស់ពួកគេ « នៅក្នុងពន្លឺ និងសេចក្ដីពិត » យ៉ាងដូចម្ដេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤១–៤៨ ដោយការពន្យល់ថា ព្រះអម្ចាស់បានណែនាំ ហ្វ្រេឌើរិក ជី វិលលាស៍, ស៊ីឌនី រិកដុន និង យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ឲ្យធ្វើឲ្យល្អប្រសើរនៅក្នុងការបង្រៀនដល់កូនចៅរបស់ពួកគេអំពីពន្លឺ និងសេចក្ដីពិត ហើយរៀបចំក្រុមគ្រួសារពួកគេឲ្យមានរបៀបរៀបរយ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤៩–៥០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមានមួយ ដែលអនុវត្តចំពោះក្រុមគ្រួសាររបស់យើង។

- តើការព្រមានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុងខទាំងនេះ ? ( សូមជួយសិស្សឲ្យប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖**យើងត្រូវតែអធិស្ឋានជានិច្ច ហើយឧស្សាហ៍ព្យាយាម និងខ្វល់ខ្វាយអំពីគេហដ្ឋានជានិច្ច ក្រែងសាតាំងនឹងមានអំណាចលើយើង** )។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ឧស្សាហ៍ព្យាយាម និងខ្វល់ខ្វាយអំពីគេហដ្ឋាន » ?

សូមចង្អុលបង្ហាញថា ទោះបីជាការព្រមាននេះ ត្រូវបានផ្ដល់ដល់ឪពុកក្ដី ក៏វាអនុវត្តចំពោះក្រុមគ្រួសាររបស់ពួកគាត់ផងដែរ ។ សូមអញ្ជើញសិស្សឲ្យផ្ដល់យោបល់នូវវិធីទាំងឡាយ ដែលយុវវ័យអាចឧស្សាហ៍ព្យាយាម និងខ្វល់ខ្វាយអំពីគេហដ្ឋាន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយ មកពីសិស្សក្នុងថ្នាក់នៅលើក្ដារខៀន ។

សូមបញ្ចប់មេរៀននេះដោយការថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅក្នុងមេរៀននេះ ។ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរមួយក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

> ១. *ប្រាប់នូវបទបញ្ញត្តិមួយ ដែលអ្នកអាចគោរពតាមកាន់តែស្មោះត្រង់ ដើម្បីអ្នកអាចបង្កើនពន្លឺ និងសេចក្ដីពិត ។ តើអ្នកនឹងធ្វើអ្វីខ្លះ ដើម្បីកាន់តែស្មោះត្រង់នៅក្នុងការរក្សាបទបញ្ញត្តិនោះ ?*
>
> ២. *តើអ្នកអាចកាន់តែឧស្សាហ៍ព្យាយាម និងខ្វល់ខ្វាយអំពីគេហដ្ឋានយ៉ាងដូចម្ដេច ? សូមសរសេរគោលដៅមួយ ដែលប្រាប់ពីវិធីមួយ ដែលអ្នកនឹងព្យាយាមដើម្បីកែលម្អអំឡុងសប្ដាហ៍ក្រោយ ។*

មេរៀនទី ៩៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦

## បុព្វកថា

ព្រះអម្ចាស់បានបើកសម្ដែងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤ នៅថ្ងៃទី ២ ខែសីហា ឆ្នាំ ១៨៣៣ ហើយបានដឹកនាំពួកបរិសុទ្ធឲ្យស្ថាបនាទីក្រុងខឺតឡង់ស្រដៀងគ្នានឹងរបៀបដែលទ្រង់បានណែនាំពួកគេឲ្យស្ថាបនាទីក្រុងស៊ីយ៉ូននៅរដ្ឋ មិសសួរី ផងដែរ។ ព្រះអម្ចាស់ក៏បានបញ្ជាពួកបរិសុទ្ធឲ្យសាងសង់កន្លែងមួយសម្រាប់គណៈប្រធាន ( អគារវដ្ឋបាលសាសនាចក្រ ) និងកន្លែងសម្រាប់បោះពុម្ពបន្ថែមពីលើព្រះវិហារបរិសុទ្ធ ដែលទ្រង់ធ្លាប់បានបង្គាប់កាលពីមុនដល់ពួកបរិសុទ្ធឲ្យសាងសង់ ។ ពីរខែមុន នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៨៣៣ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលរកបាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥ ដែលព្រះអម្ចាស់បានវាយផ្ចាលពួកបរិសុទ្ធសម្រាប់ការពន្យាពេលការសាងសង់ព្រះវិហារបរិសុទ្ធ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦ មាននូវការណែនាំរបស់ព្រះអម្ចាស់សម្រាប់តែងតាំង នូវល ខេ វិតនី « កាន់កាប់ » (គ. និង ស. ៩៦:២) ជាអចលនទ្រព្យដែលព្រះវិហារបរិសុទ្ធខឺតឡង់នឹងត្រូវបានសាងសង់លើនោះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤

*ព្រះអម្ចាស់បង្គាប់ឲ្យពួកបរិសុទ្ធសាងសង់គេហដ្ឋានពីរ ហើយបញ្ជាក់បន្ថែមអំពីសេចក្ដីត្រូវការដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ។*

សូមឲ្យសិស្សស្រមៃពីឱកាសដែលពួកគេមានដើម្បីធ្វើដំណើរពេញប្រទេសទៅកាន់ទីក្រុងជាច្រើន ។ នៅពេលពួកគេធ្វើដំណើរ ពួកគេបានកត់សម្គាល់ថា មានកីឡាដ្ឋាននៅកណ្ដាលទីក្រុងក្នុងទីក្រុងទាំងឡាយ ។

- តើការណ៍នេះអាចនឹងផ្ដល់យោបល់អំពីមនុស្សនៃប្រទេសនេះយ៉ាងណាខ្លះ ?
- បើអ្នកនឹងទៅរៀបចំទីក្រុងធំមួយ តើអ្នកនឹងដាក់អ្វីខ្លះនៅកណ្ដាលទីក្រុង ? ហេតុអ្វី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤:១, ៣, ១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីអគារចំនួនបី ដែលព្រះអម្ចាស់បានបង្គាប់ដល់ពួកបរិសុទ្ធនៅក្នុងទីក្រុងខឺតឡង់ រដ្ឋ អូហៃអូត្រូវសាងសង់ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- អគារទាំងបីនេះ បង្ហាញអ្វីខ្លះ ដែលសំខាន់ចំពោះព្រះអម្ចាស់ ? ( ពិធីបរិសុទ្ធទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ កិច្ចការនៃគណៈប្រធានទីមួយ នៅក្នុងការទទួលបានវិវរណៈ និងការបម្រើក្នុងសាសនាចក្រ និងការបោះពុម្ពព្រះគម្ពីរ និងកិច្ចការដទៃទៀតដែលព្រះអម្ចាស់បង្គាប់មក ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤:១៣–១៧ ដោយការពន្យល់ថា ព្រះអម្ចាស់បានណែនាំដល់ ហៃរ៉ុម ស្ម៊ីធ, រេយណុល្ស ខាហ៊ូន និង យ៉ារេឌ ខារតើរ ដើម្បីបង្កើតជាគណៈកម្មការមួយសម្រាប់អគារទាំងឡាយដែលបានប្រាប់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤:១៦ ដោយស្ងាត់ស្ងៀម ដើម្បីរកនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ពួកបរិសុទ្ធអំពីការសាងសង់អគារទាំងឡាយសម្រាប់គណៈប្រធាន និងសម្រាប់ការបោះពុម្ព ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីសង់ព្រះវិហារបរិសុទ្ធឡើង មុនអគារពីរផ្សេងទៀត ? តើការណ៍នេះអាចបង្រៀនយើងអំពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេចខ្លះ ? ( អ្នកអាចប្រាប់ដល់សិស្សថា អគារពីរផ្សេងទៀត ពុំដែលបានសាងសង់ឡើងទេ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥

*ព្រះអម្ចាស់បានវាយផ្ចាលដល់ពួកបរិសុទ្ធសម្រាប់ការពន្យាពេលសាងសង់ព្រះវិហារបរិសុទ្ធ*

សូមរំឭកសិស្សថា ដំបូងឡើយព្រះអម្ចាស់ចេញបទបញ្ញត្តិឲ្យសង់ព្រះវិហារបរិសុទ្ធខឺតឡង់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៩ ដែលបានកត់ត្រានៅថ្ងៃទី ២៧ និង ២៨ ខែធ្នូ ឆ្នាំ ១៨៣២ ។ ( សូមសរសេរកាលបរិច្ឆេទនេះនៅលើក្ដារខៀន ) ។ សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវនៅក្នុងសេចក្ដីណែនាំកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥ អំពីកាលបរិច្ឆេទដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ។ សូមឲ្យពួកគេគណនាអំពីពេលវេលាប្រហាក់ប្រហែលដែលបានកន្លងទៅនៅចន្លោះកាលបរិច្ឆេទទាំងពីរនេះ ។ សូមពន្យល់ថា អំឡុងគ្រានេះ អ្នកដឹកនាំសាសនាចក្របានដឹងអំពីដីកម្មសិទ្ធិនៅទីក្រុងខឺតឡង់ ដែលត្រូវសាងសង់ព្រះវិហារបរិសុទ្ធ ។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ១៨៣៣ ពួកបរិសុទ្ធពុំបានចាប់ផ្ដើមសាងសង់ព្រះវិហារបរិសុទ្ធ ឬរៀបចំចាត់គ្រឹះឡើយ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ប្រាប់នូវអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ពួកបរិសុទ្ធអំពីការពន្យាពេលរបស់ពួកគេនៅក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើព្រះអម្ចាស់ធ្វើអ្វីខ្លះ សម្រាប់អ្នកទាំងឡាយដែលទ្រង់ស្រឡាញ់ ? ( សិស្សគួរតែប្រាប់អំពីសេចក្ដីពិតដូចខាងក្រោម ៖**ព្រះបានវាយផ្ចាលដល់អ្នកទាំងឡាយដែលទ្រង់ស្រឡាញ់** ។ អ្នកអាចឲ្យយោបល់សិស្សឲ្យគូសចំណាំពាក្យ ដែលបង្រៀនអំពីសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។

- តើការវាយផ្ចាលមានអត្ថន័យយ៉ាងណា ? ( ដើម្បីលត់ដំ ឬកែតម្រូវ ) ។ ស្របតាមខគម្ពីរទាំងនេះ ហេតុអ្វីព្រះវាយផ្ចាលដល់អ្នកទាំងឡាយដែលទ្រង់ស្រឡាញ់យ៉ាងដូច្នេះ ?

សូមឲ្យសិស្សពិចារណាអំពីរបៀបដែលពួកគេឆ្លើយតបជាញឹកញាប់ នៅពេលពួកគេត្រូវបានវាយផ្ចាល ឬកែតម្រូវដោយនរណាម្នាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សស្ដាប់អំពីរបៀបដែលពួកបរិសុទ្ធមួយចំនួនបានឆ្លើយតបចំពោះការវាយផ្ចាលរបស់ព្រះអម្ចាស់ ៖

បន្ទាប់ពី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥ ពួកអ្នកដឹកនាំសាសនាចក្រ បានធ្វើសន្និសីទមួយដើម្បីពិភាក្សាអំពីការសាងសង់ព្រះវិហារបរិសុទ្ធ ។ « មនុស្សមួយចំនួនចូលចិត្តក្នុងការសាងសង់គ្រោងនៃផ្ទះ ហើយអ្នកដទៃទៀតចង់សង់ផ្ទះពីឈើហ៊ុប ។ យ៉ូសែប បានរំឭកពួកគាត់ថា ពួកគាត់ពុំមែនសាងសង់ដំណាក់មួយឡើងសម្រាប់មនុស្សនោះទេ ប៉ុន្តែគឺសម្រាប់ព្រះ លោកបានមានប្រសាសន៍ថា ‹ បងប្អូនប្រុសទាំងឡាយអើយ តើយើងនឹងសាងសង់ដំណាក់សម្រាប់ព្រះរបស់យើងពីឈើហ៊ុបឬ ? ទេ ខ្ញុំមានផែនការល្អប្រសើរជាងនោះ ។ ខ្ញុំមានប្លង់នៃដំណាក់របស់ព្រះអម្ចាស់ ដែលព្រះអង្គផ្ទាល់បានប្រទានឲ្យ › ។ បន្ទាប់មក យ៉ូសែប បានពន្យល់អំពី គំរូពេញលេញនៃព្រះវិហារបរិសុទ្ធនោះបងប្អូនប្រុសទាំងអស់មានចិត្តរំភើបរីករាយ ។ ពួកគេបានធ្វើដំណើរទៅទីតាំងនៃការសាងសង់ ដករបង ហើយបានដាក់ដីបំពេញក្នុងស្រែដែលបានដាំដុះដោយគ្រួសារស៊្មីធកាលពីមុន ។ បន្ទាប់មកស្រូវបានជម្រះយ៉ាងស្អាត រួចហើយ ហៃរ៉ុម ស៊្មីធ « បានចាប់ផ្ដើមជីកធ្វើជាគ្រឹះជញ្ជាំង » ។ (សូមមើល លូស៊ី ម៉ាក ស៊្មីធ *History of Joseph Smith by His Mother,* បានបោះពុម្ពដោយ Preston Nibley [ឆ្នាំ ១៩៥៨], ទំព័រ ២៣០, ២៣១ )។

- តើយើងអាចរៀនមកពីពួកបរិសុទ្ធទាំងនេះអ្វីខ្លះ អំពីរបៀបដើម្បីឆ្លើយតបចំពោះការវាយផ្ចាល ?

សូមចង្អុលបង្ហាញថា នៅក្នុង ខ ៣ ព្រះអម្ចាស់បានពិពណ៌នាអំពីការពន្យាពេលការសាងសង់ព្រះវិហារបរិសុទ្ធរបស់ពួកបរិសុទ្ធគឺជា « អំពើបាបដ៏ធ្ងន់ណាស់ » ។ សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:៥–៦ ដើម្បីមើលឃើញនូវអ្វីដែលព្រះអម្ចាស់បានប្រៀបធៀបជាអំពើបាបដ៏ធ្ងន់ធ្ងរ ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

- តើការមិនអើពើនឹងបទបញ្ញត្តិរបស់ព្រះអម្ចាស់ក្នុងការស្ថាបនាព្រះវិហារបរិសុទ្ធ ដូចជា « ដើរនៅក្នុងសេចក្ដីងងឹតទាំងកណ្ដាលថ្ងៃត្រង់ » យ៉ាងដូចម្ដេច ? តើយើងអាច « ដើរនៅក្នុងសេចក្ដីងងឹតទាំងកណ្ដាលថ្ងៃត្រង់ » យ៉ាងដូចម្ដេច បើយើងជ្រើសរើសបដិសេធបទបញ្ញត្តិផ្សេងទៀតនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:៤, ៨–៩ ជាមួយដៃគូ ។ សូមឲ្យពួកគេប្រាប់អំពីមូលហេតុដែលព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធឲ្យសាងសង់ព្រះវិហារបរិសុទ្ធខឺតឡង់ ។ ( អ្នកអាចពន្យល់ថា ឃ្លា « ប្រយោជន៍ឲ្យយើងអាចសម្រេចកិច្ចការប្លែកៗរបស់យើងបាន » [ខ ៤] អាចសំដៅទៅលើរបៀបដែលមនុស្សពុំជឿទៅលើវិវរណៈ ការយាងមកជួបពីស្ថានសួគ៌ និងរឿងខាងវិញ្ញាណដទៃទៀត អាចមើលឃើញថាការស្ដារឡើងវិញនៃដំណឹងល្អ គឺជារឿងចម្លែក ) ។

- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរទាំងនេះ អំពីមូលហេតុដែលព្រះអម្ចាស់បញ្ជាឲ្យយើងសាងសង់ព្រះវិហារបរិសុទ្ធ ? ( បន្ទាប់ពីសិស្សឆ្លើយតប អ្នកអាចនឹងចង់សរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖**នៅក្នុងព្រះវិហារបរិសុទ្ធ ព្រះអម្ចាស់បានរៀបចំពួកអ្នកបម្រើទ្រង់ ឲ្យធ្វើកិច្ចការរបស់ទ្រង់ ហើយប្រទានអំណាចដល់ពួកគេ** )។

សូមពន្យល់ថា *ប្រទាន* មានន័យថា ផ្ដល់ដល់នរណាម្នាក់នូវអំណោយមួយ ។ ការទទួលអំណោយទានពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធ មានន័យថាទទួលបានអំណាច និងចំណេះដឹងខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖



«ទាល់តែអ្នកបានចូលក្នុងដំណាក់នៃព្រះអម្ចាស់ ហើយបានទទួលគ្រប់ពរជ័យដែលរង់ចាំអ្នកនៅទីនោះ បើមិនដូច្នោះទេ អ្នកមិនបានទទួលអ្វីៗទាំងអស់ដែលសាសនាចក្របានផ្ដល់ឲ្យទេ ។ ពរជ័យសំខាន់ និងអស្ចារ្យបំផុតទាំងអស់ នៃសមាជិកភាពនៅក្នុងសាសនាចក្រ គឺជាពរជ័យទាំងឡាយណាដែលយើងបានទទួលនៅក្នុងដំណាក់នៃព្រះ » ( The Holy Temple—a Beacon to the World» *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៩៣ ) ។

- តើពិធីបរិសុទ្ធនៃការសង្គ្រោះពីរ ដែលយើងអាចទទួលតែនៅក្នុងព្រះវិហារបរិសុទ្ធនៃព្រះ មានអ្វីខ្លះ ? ( អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ និងការផ្សាភ្ជាប់អាពាហ៍ពិពាហ៍ ) ។

- តើរឿងមួយចំនួនដែលអ្នកអាចធ្វើនាពេលឥឡូវនេះ ដើម្បីត្រៀមខ្លួនទទួលពិធីបរិសុទ្ធ និងពរជ័យនៅក្នុងព្រះវិហារបរិសុទ្ធទាំងនេះមានអ្វីខ្លះ? ( ចម្លើយអាចរួមមានការស្មោះត្រង់ចំពោះសេចក្ដីសញ្ញា និងពិធីបរិសុទ្ធនានា ដែលពួកគេបានទទួលរួចហើយ និងរស់នៅដោយសក្ដិសមជានិច្ច ដើម្បីទទួលប័ណ្ណចូលព្រះវិហារបរិសុទ្ធ) ។

សូមពន្យល់ថា ការសាងសង់ព្រះវិហារបរិសុទ្ធ ខឺតឡង់ គឺជាកិច្ចការដ៏ធំដែលត្រូវសម្រេចរបស់ពួកបរិសុទ្ធ ។ នៅដើមឆ្នាំ ១៨៣៣ មានសមាជិកសាសនាចក្រប្រហែលជា តិចជាង ២០០ នាក់នៅក្នុងរដ្ឋ អូហៃអូ ហើយភាគច្រើនគឺជាអ្នកក្រ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១១–១២ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពីអ្វីដែលព្រះអម្ចាស់បានសន្យាថា បើពួកបរិសុទ្ធនឹងរក្សាបទបញ្ញត្តិរបស់ទ្រង់ ។

- តើព្រះអម្ចាស់សន្យាអ្វីខ្លះ បើពួកបរិសុទ្ធនឹងគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ?

សូមជូនដំណឹងដល់សិស្សក្នុងថ្នាក់ថា ពួកបរិសុទ្ធនៅ អូហៃអូ បានបន្តមានសេចក្ដីជំនឿទៅលើការសន្យារបស់ព្រះអម្ចាស់ ហើយបានសាងសង់ព្រះវិហារបរិសុទ្ធ ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនមកពី ខ ១១ នេះ ? (សិស្សគួរប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖**បើយើងរក្សាបទបញ្ញត្តិទាំងឡាយ នោះយើងនឹងមានអំណាចដើម្បីធ្វើអ្វី ដែលព្រះអម្ចាស់បានសុំឲ្យយើងធ្វើ** )។

- តើស្ថានភាពមួយចំនួន ដែលអ្នកអាចនឹងប្រឈមមុខក្នុងគោលលទ្ធិនេះអាចអនុវត្តមានអ្វីខ្លះ ? តើអ្នកមានអារម្មណ៍ថា អ្នកបានទទួលជំនួយរបស់ព្រះអម្ចាស់ឲ្យធ្វើអ្វីមួយ ដោយសារតែអ្នករក្សាបទបញ្ញត្តិទ្រង់ នៅពេលណា ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១៣–១៧ ដោយការពន្យល់ថា ព្រះអម្ចាស់បានប្រទានការណែនាំអំពីទំហំ និងមុខងារនៃបន្ទប់ជាក់លាក់នៃព្រះវិហារបរិសុទ្ធខឺតឡង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ខ ១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវរបៀបមួយ ដែលព្រះអម្ចាស់បានបង្ហាញថា ទ្រង់នឹងបំពេញនូវការសន្យានេះ ដើម្បីប្រទានដល់ពួកគេនូវព្រះចេស្ដាដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ។ សូមអញ្ជើញឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ ( អ្នកអាចបង្ហាញថា ព្រះអម្ចាស់បានសន្យាថានឹងបង្ហាញដល់មនុស្សបីនាក់អំពីរបៀបដែលព្រះវិហារបរិសុទ្ធគួរត្រូវបានសាងសង់ ។ បុរសទាំងបីរូបនេះ គឺជាគណៈប្រធានទីមួយ ) ។

ដើម្បីជួយសិស្សមើលឃើញពីរបៀបដែលការសន្យានេះ ត្រូវបានបំពេញ សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌដូចខាងក្រោមឲ្យឮៗ ៖

យ៉ូសែប ស៊្មីធ, ស៊ីឌនី រិកដុន និង ហ្វ្រេឌើរិក ជី វិលលាម្ស បានអធិស្ឋានរួមគ្នា ហើយបានឃើញព្រះវិហារបរិសុទ្ធនៅក្នុងការនិមិត្ត ។ បន្ទាប់ពីការមើលឃើញនូវផ្នែកខាងក្រៅយ៉ាងលម្អិត « អគារហាក់ដូចជាលេចមកលើ [ពួកលោក] » ហើយពួកលោកបានមើលឃើញផ្នែកខាងក្នុងនៃអគារ ដូចជាពួកលោកបានស្ថិតនៅខាងក្នុងអគារនោះ ( សូមមើល *Teachings of Presidents of the Church: Joseph Smith* ២០០៧], ទំព័រ២៧១ ) ។ ក្រោយមក នៅពេលព្រះវិហារបរិសុទ្ធសាងសង់ជិតហើយ នោះហ្វ្រេឌើរិក ជី វិលលាម្ស បាននិយាយថា វាមានរូបរាងដូចគំរូដែលគាត់បានមើលឃើញនៅក្នុងការនិមិត្តចាប់តាំងពីរឿងលម្អិតៗតូចតាចបំផុត ហើយគាត់ពុំអាចប្រាប់ពីភាពខុសគ្នារវាងគំរូព្រះវិហារបរិសុទ្ធនៅក្នុងការនិមិត្ត និងព្រះវិហារបរិសុទ្ធដែលបានសាងសង់នោះទេ ។

- នៅក្នុងឧទាហរណ៍នេះ តើព្រះអម្ចាស់បានប្រទានពរដល់ពួកបរិសុទ្ធនូវអំណាចដើម្បីធ្វើនូវអ្វីដែលទ្រង់បានសុំឲ្យពួកគេធ្វើយ៉ាងដូចម្ដេចខ្លះ ?

***ផ្ដោតទៅលើព្រះវិហារបរិសុទ្ធ***

ផ្នែកមួយនៃគោលបំណងរបស់ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា គឺដើម្បីជួយយុវជន និងយុវមជ្ឈិមវ័យសម្រាប់ពរជ័យនៃព្រះវិហារបរិសុទ្ធ ។ នៅពេលអ្នកបង្រៀន សូមពិចារណាអំពីរបៀបដែលអ្នកអាចជួយសិស្សឲ្យយល់ដឹង មានអារម្មណ៍ថាសំខាន់ និងអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយទាក់ទងនឹងព្រះវិហារបរិសុទ្ធ ។ នៅពេលអ្នកធ្វើដូច្នោះ អ្នកអាចបំផុសគំនិតសិស្សឲ្យរស់នៅដោយមានភាពសក្ដិសមនឹងពរជ័យនៃព្រះវិហារបរិសុទ្ធ គឺជាអាទិភាពមួយនៅក្នុងជីវិតរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦

*នូវែល ខេ វីតនី ត្រូវបានចាត់តាំងឲ្យកាន់កាប់នូវរាល់ទ្រព្យសម្បត្តិរបស់សាសនាចក្រទាំងអស់*

សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦ ព្រះអម្ចាស់បានណែនាំថា ប៊ីស្សព នូវែល ខេ វីតនី គួរតែកាន់កាប់នូវរាល់ទ្រព្យសម្បត្តិរបស់សាសនាចក្រ ។ ព្រះវិហារបរិសុទ្ធនឹងសាងសង់នៅកន្លែងដែលបានកំណត់ដោយព្រះអម្ចាស់ ហើយប៊ីស្សព វិតនី នឹងបែកចែកដីធ្លីដែលនៅសល់ជាឡូដ៍ៗសម្រាប់អ្នកទាំងឡាយដែលនឹងស្វែងរកកេរមរតក ។ ដីឡូដ៍ៗមួយចំនួនទាំងនេះ ត្រូវបានកំណត់ដើម្បីអ្នកដឹកនាំសាសនាចក្រ មើលខុសត្រូវសម្រាប់ការបោះពុម្ពវិវរណៈទាំងឡាយ ។ ការទទួលបានកេរតមរតកនេះ នឹងជួយពួកគេលះបង់ពេលវេលារបស់ពួកគេដើម្បីធ្វើកិច្ចការរបស់ព្រះអម្ចាស់ ដែលរួមមានទាំងការបោះពុម្ពព្រះបន្ទូលនៃព្រះផងដែរ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦:៤–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម និងប្រាប់អំពីរបៀបដែលការបោះពុម្ពព្រះបន្ទូលនៃព្រះ នឹងជួយដល់ពួកបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

សូមពន្យល់ថា នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានដឹកនាំផងដែរថា យ៉ូហាន ចនសុន គួរតែអនុញ្ញាតឲ្យចូលជាសមាជិកនៃសហសមាគម ដែលមើលខុសត្រូវលើហិរញ្ញវត្ថុរបស់សាសនាចក្រ ការបោះពុម្ព និងប្រតិបត្តិការអាជីវកម្មទាំងឡាយ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យសង្ខេបសេចក្ដីពិត ដែលពួកគេបានរៀនមកពីមេរៀននេះ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យធ្វើតាមសេចក្ដីពិត ដែលពួកគេបានរៀន ។

មេរៀនទី ១០០

# គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧

## បុព្វកថា

យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧ នៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ១៨៣៣ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រទានការណែនាំ និងការលើកទឹកចិត្តដល់ ប៉ាលី ភី ប្រាត្ត ដែលធ្វើជាអធិបតីលើសាលារៀនសម្រាប់អ្នកកាន់តំណែងបព្វជិតភាពនៅរដ្ឋ មិសសួរី និងសម្រាប់មនុស្សដែលចូលរួមនៅក្នុងសាលានោះ ។ ព្រះអម្ចាស់ក៏បានបញ្ជាក់អំពីព្រះទ័យរបស់ទ្រង់ថា ពួកបរិសុទ្ធនៅក្នុងរដ្ឋ មិសសួរី សាងសង់ព្រះវិហារបរិសុទ្ធ ។ ទ្រង់បានសន្យាថា បើពួកគេបានធ្វើដូច្នោះ ហើយបើដួងចិត្តរបស់ពួកគេបរិសុទ្ធ នោះសិរីល្អ និងវត្តមានរបស់ទ្រង់នឹងនៅទីនោះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:១–៩

*ព្រះអម្ចាស់បង្រៀនសមាជិកអំពី សាលានៃពួកអែលឌើរ នៅរដ្ឋ មិសសួរី អំពីអ្វីដែលពួកគេត្រូវតែធ្វើដើម្បីទទួលយកទ្រង់ ។*

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ។ សូមសិស្សឲ្យបំពេញសេចក្តីថ្លែងការណ៍ទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

> *ខ្ញុំទៅសាលាដោយសារតែ . . .*
>
> *ខ្ញុំទៅព្រះវិហារដោយសារតែ . . .*

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ ចែកចាយរបៀបដែលពួកគេបានបំពេញសេចក្តីថ្លែងការណ៍ ។

សូមរំឭកសិស្សថា នៅក្នុងរដូវរងានៃឆ្នាំ ១៨៣២–៣៣ ព្រះអម្ចាស់បានដឹកនាំពួកអ្នកដឹកនាំសាសនាចក្រដើម្បីបង្កើតសាលានៃពួកព្យាការីនៅក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូ ។ ប៉ាលី ភី ប្រាត្ត ធ្វើជាអធិបតីលើសាលារៀនមួយដែលស្រដៀងគ្នា នៅអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មីសសួរី– ជាសាលាសម្រាប់ពួកអែលឌើរ ។ សមាជិកនៃសាលានេះ បានសរសេរទៅកាន់ យ៉ូសែប ស្ម៊ីធ ដែលនៅក្នុងរដ្ឋ អូហៃអូ ។ ជាការឆ្លើយតប លោកបានទទួលវិវរណៈដែលឥឡូវនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:១ ដោយស្ងាត់ស្ងៀម ហើយប្រាប់អំពីរបៀបដែលព្រះអម្ចាស់បានពិពណ៌នាអំពីបងប្អូនប្រុសជាច្រើននៅក្នុងដែនដីនៃស៊ីយ៉ូន ( រដ្ឋ មិសសួរី) ។

- តើព្រះអម្ចាស់បានពិពណ៌នាអំពីបងប្អូនប្រុសជាច្រើននៅក្នុងរដ្ឋ មិសសួរី យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់អំពីអ្វីដែលព្រះអម្ចាស់ បានសន្យាដល់បុរសទាំងនេះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- នៅក្នុង ខ ១–២ តើគោលការណ៍អ្វីខ្លះដែលអ្នកមើលឃើញស្ដីអំពីរបៀបដែលយើងអាចទទួលបានប្រាជ្ញា និងសេចក្តីពិត ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែប្រាប់អំពីគោលការណ៍មួយស្រដៀងគ្នាដូចខាងក្រោម ៖**បើយើងបន្ទាបខ្លួនយើង ហើយស្វែងរកការរៀនសូត្រដោយឧស្សាហ៍ព្យាយាម នោះយើងនឹងទទួលបានប្រាជ្ញា និងសេចក្តីពិត** )។

- តើអ្នកគិតថា ភាពរាបសារ និងភាពឧស្សាហ៍ អាចជួយយើងទទួលបានប្រាជ្ញា និងសេចក្តីពិតយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:៣–៥ ដោយស្ងៀមស្ងាត់ រកមើលរបៀបដែលព្រះអម្ចាស់មានព្រះទ័យពីការបម្រើរបស់ ប៉ាលី ភី ប្រាត្ត ហើយអ្វីដែលព្រះអម្ចាស់បានសន្យានឹងបងប្រុស ប្រាត្ត ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។ សូមអះអាងនឹងពួកគេថា ដូចជា ប៉ាលី ភី ប្រាត្ត ពួកគេអាចដឹងថា ព្រះអម្ចាស់សព្វព្រះទ័យជាមួយនឹងពួកគេ នៅពេលពួកគេបន្តធ្វើតាមទ្រង់ ។

### *ការបំពាក់បំប៉នអំពីការបម្រើ*

ការបំពាក់បំប៉នអំពីការបម្រើផ្តល់ដល់អ្នកនូវឱកាសមួយដើម្បីសិក្សា និងពិភាក្សាអំពីបទគម្ពីរដើម្បីធ្វើឲ្យការយល់ដឹងរបស់អ្នកកាន់តែជ្រៅជ្រះ ។ អ្នកអាចរៀននូវវិធីបំផុសគំនិតអំពីការបង្រៀន និងចែកចាយគំនិតទាំងឡាយដើម្បីជួយគ្រូបង្រៀនអ្នកដទៃទៀត ដូចជាគំនិតសម្រាប់បង្កើនការចុះឈ្មោះរបស់សិស្ស ការចូលរួម និងការបញ្ចប់ ។ អ្នកក៏អាចរៀនផងដែរអំពីរបៀបដើម្បីបំពេញនូវការទទួលខុសត្រូវខាងការគ្រប់គ្រង ។

ដើម្បីរៀបចំសិស្សឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៦–៩ សូមអញ្ជើញសិស្សពីរនាក់ឲ្យគូសរូបនៅលើក្ដារខៀន ។ សូមឲ្យសិស្សម្នាក់គូររូបដើមឈើ ដែលមានផ្លែឈើល្អៗ ហើយដែលបានដុះនៅដីដែលមានជីជាតិល្អនៅជិតនឹងអូរមួយ (សូមមើល ខ ៩) ។ សូមឲ្យសិស្សដទៃទៀតគូររូបដើមឈើដែលពុំឲ្យផលផ្លែល្អ ដោយមានពូថៅដាក់នៅនឹងគល់វា ( សូមមើល ខ ៧) ។



សូមពន្យល់រូបភាពទាំងពីរ ដើមឈើតំណាងឲ្យសមាជិកនៃសាសនាចក្រ ។ សូមរំឭកសិស្សថា សមាជិកជាច្រើននៅសាលានៃពួកអែលឌើរ មានចិត្តរាបសារ ហើយស្មោះត្រង់ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកដទៃទៀតបានក្លាយជាមានភាពឆ្មើងឆ្មៃ និងមិនគោរពប្រតិបត្តិ ។

- បើសិនជាដើមឈើតំណាងឲ្យសមាជិកនៃសាសនាចក្រ តើអ្នកគិតថាផ្លែរបស់វាតំណាងឲ្យអ្វី ? ( កិច្ចការ ឬសកម្មភាពរបស់សមាជិកនៃសាសនាចក្រ ។ បើសិស្សមានការលំបាកក្នុងការប្រាប់អំពីចម្លើយនេះ អ្នកអាចនឹងចង់អញ្ជើញពួកគេឲ្យអានគោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧: ៦ ដោយស្ងាត់ស្ងៀមរកមើលចម្លើយនៅទីនោះ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៦–៧ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ឲ្យរកមើលគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។



- តើគោលការណ៍មួយចំនួនណាខ្លះ ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៨–៩ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ឲ្យរកមើលគោលការណ៍ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។

- តើគោលការណ៍មួយចំនួនណាខ្លះ ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ?
- តើការពិពណ៌នាអំពីអ្វីដែលបានកើតឡើងចំពោះដើមឈើទាំងឡាយ អាចជម្រុញទឹកចិត្តយើងឲ្យកាន់តែស្មោះត្រង់យ៉ាងដូចម្ដេច ?

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន៖ *ដើម្បីបានទទួលយកដោយព្រះអម្ចាស់ នោះយើងត្រូវតែ . . .*

សូមអញ្ជើញសិស្សឲ្យរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៨ ហើយប្រាប់អំពីចរិតលក្ខណៈរបស់មនុស្សម្នាក់ដែលត្រូវបានព្រះអម្ចាស់ទទួលយក ។ នៅពេលពួកគេប្រាប់អំពីចរិតលក្ខណៈទាំងនេះ សូមបំពេញសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀនដូចខាងក្រោម ៖ **ដើម្បីត្រូវបានព្រះអម្ចាស់ទទួលយក នោះយើងត្រូវតែមានដួងចិត្តស្មោះត្រង់ និងទន់ទាប ហើយវិញ្ញាណសោកសង្រេង និងមានឆន្ទៈប្រតិបត្តិតាមរាល់សេចក្ដីសញ្ញារបស់យើង ដោយការពលិកម្ម ។**

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីមានចិត្តសង្រេង និង វិញ្ញាណទន់ទាប?
- តើអ្នកគិតថា វាមានន័យយ៉ាងដូចម្ដេច ដើម្បីប្រតិបត្តិតាមរាល់សេចក្ដីសញ្ញារបស់យើង ដោយការពលិកម្មនោះ ? ( ចម្លើយមួយដែលអាចឆ្លើយគឺ វាមានន័យថា ត្រូវធ្វើនូវអ្វីៗដែលយើងត្រូវធ្វើដើម្បីរក្សាសេចក្ដីសញ្ញាទាំងឡាយដែលយើងបានធ្វើជាមួយនឹងព្រះអម្ចាស់ ) ។
- តើការពលិកម្មមួយចំនួនដែលអ្នកបានធ្វើ ដើម្បីរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់អ្នកមានអ្វីខ្លះ ?

សូមផ្ដល់ពេលឲ្យសិស្សពិចារណាអំពីជំហររបស់ពួកគេនៅចំពោះព្រះអម្ចាស់ ហើយគិតអំពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍ចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៨ នៅក្នុងជីវិតរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១០–២១

*ព្រះអម្ចាស់ក៏បានបញ្ជាក់អំពីព្រះទ័យរបស់ទ្រង់ថា ពួកបរិសុទ្ធនៅក្នុងរដ្ឋ មិសសួរី គួរសាងសង់ព្រះវិហារបរិសុទ្ធមួយ*

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១០–១២ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលនូវការពលិកម្មដែលព្រះអម្ចាស់តម្រូវពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។

- តើពលិកម្មអ្វីខ្លះ ដែលព្រះអម្ចាស់តម្រូវពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ? ( ពួកគេត្រូវសាងសង់ព្រះវិហារបរិសុទ្ធមួយ–ជាដំណាក់មួយថ្វាយព្រះអម្ចាស់ ) ។

សូមរំឭកសិស្សថា ព្រះអម្ចាស់បានកំណត់ទីតាំងសម្រាប់សាងសង់ព្រះវិហារបរិសុទ្ធរយៈពេលពីរឆ្នាំមុន ( សូមមើល គ. និង ស. ៥៧:១–៣) ។ នៅក្នុង ខែ មិថុនា ឆ្នាំ ១៨៣៣ យ៉ូសែប ស្ម៊ីធ បានសរសេរទៅកាន់ពួកអ្នកដឹកនាំសាសនាចក្រនៅក្នុងរដ្ឋ មិសសួរី ហើយបានណែនាំពួកគេឲ្យចាប់ផ្ដើមការសាងសង់ព្រះវិហារបរិសុទ្ធជាបន្ទាន់ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ ត្រូវបានផ្ដល់ឲ្យនៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ១៨៣៣ នោះពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ពុំទាន់បានចាប់ផ្ដើមការសាងសង់នៅឡើយទេ ។ បន្ថែមពីលើនោះ ពួកមនុស្សអាក្រក់ដំបូងគេបានទាស់នឹងពួកបរិសុទ្ធនៅឃុំចាកសុន ដែលបានកើតឡើងពីមុនលិខិតនៃវិវរណៈនេះបានផ្ញើទៅដល់ ដែលធ្វើឲ្យមានការពិបាកកាន់តែខ្លាំងក្នុងការគោរពបទបញ្ញត្តិនេះ ។

សូមឲ្យសិស្សស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១២–១៤ ដោយស្ងាត់ស្ងៀម ប្រាប់អំពីមូលហេតុនានាដែលព្រះអម្ចាស់ចង់ឲ្យពួកបរិសុទ្ធនៅក្នុងរដ្ឋ មិសសួរី សាងសង់ព្រះវិហារបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ អំពីការស្វែងរករបស់ពួកគេ ។ បន្ទាប់មកសូមសួរសំណួរខាងក្រោមនេះ ៖

- តើព្រះវិហារបរិសុទ្ធជា « កន្លែងនៃសេចក្ដីអំណរគុណ » សម្រាប់អ្នកយ៉ាងដូចម្ដេច ?  តើវាជា « កន្លែងនៃការបង្គាប់ » យ៉ាងដូចម្ដេច ?

សូមចាត់ឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១៥–២០ ជាមួយនឹងដៃគូរបស់ពួកគេ រកមើលនូវការសន្យាទាំងឡាយដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ បើពួកគេនឹងស្ថាបនាព្រះវិហារបរិសុទ្ធមួយឡើង ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ អំពីការស្វែងរករបស់ពួកគេ ។

ដើម្បីជួយសិស្សយល់ថា ការសន្យាអំពីការមើលឃើញព្រះនៅក្នុងព្រះវិហារបរិសុទ្ធ អាចមានច្រើនជាងការគ្រាន់តែឃើញទ្រង់ដោយភ្នែកខាងសាច់ឈាមរបស់យើង សូមអាននូវសេចក្ដីថ្លែងដូចខាងក្រោម ដោយអែលឌើរ ដាវីឌ ប៊ី ហេត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ជាការពិតថា មានមនុស្សមួយចំនួនពិតជាបានឃើញព្រះអង្គសង្គ្រោះ ប៉ុន្តែនៅពេលមានការពិគ្រោះនៅក្នុងវចនានុក្រម គាត់បានដឹងថាមានអត្ថន័យច្រើនផ្សេងទៀតចំពោះពាក្យ *មើលឃើញ* នេះ ដូចជាការមកស្គាល់ទ្រង់ ការញែកដឹងពីទ្រង់ ការទទួលស្គាល់ទ្រង់ និងកិច្ចការរបស់ទ្រង់ ការយល់ដឹងអំពីសារៈសំខាន់របស់ទ្រង់ ឬការបានយល់ដឹងអំពីទ្រង់ » (Temples and Work Therein,» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩០, ទំព័រ ៦១) ។

- ស្របតាម ខ ១៥–១៧ តើយើងសក្ដិសមដើម្បីទទួលបទពិសោធន៍នៃសិរីល្អ និងវត្តមានរបស់ព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធបានយ៉ាងដូចម្ដេច ?

បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **នៅក្នុងព្រះវិហារបរិសុទ្ធ ព្រះនឹងបើកសម្ដែងព្រះអង្គទ្រង់ដល់អ្នកទាំងឡាយដែលមានដួងចិត្តបរិសុទ្ធ ។**

- តើអ្នកគិតថា ដួងចិត្តបរិសុទ្ធមានន័យយ៉ាងដូចម្ដេច ?

- តើយើងអាចធ្វើអ្វីខ្លះដើម្បីធ្វើឲ្យដួងចិត្តរបស់យើងបានបរិសុទ្ធ ដូច្នេះយើងអាចទទួលបានពរជ័យនៃព្រះវិហារបរិសុទ្ធ ?

- តើអ្នកមានអារម្មណ៍ថាត្រូវបានប្រទានពរដោយរបៀបណា នៅពេលអ្នកបានចូលរួមក្នុងព្រះវិហារបរិសុទ្ធដោយសក្ដិសម ? ( បើអ្នកមានសិស្សនៅក្នុងថ្នាក់រៀនរបស់អ្នក ដែលពុំទាន់មានឱកាសចូលរួមក្នុងព្រះវិហារបរិសុទ្ធ នោះអ្នកអាចនឹងចង់សួរសំណួរដូចខាងក្រោមជំនួសវិញ ៖ តើអ្នកមានអារម្មណ៍ថាមានពរជ័យយ៉ាងណា នៅពេលអ្នកព្យាយាមដើម្បីធ្វើឲ្យដួងចិត្តរបស់អ្នកបានបរិសុទ្ធ ? )

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២១, ដោយស្ងាត់ស្ងៀម ហើយប្រាប់ពីរបៀបដែលព្រះអម្ចាស់បានកំណត់ន័យនៃពាក្យ *ស៊ីយ៉ូន ។* សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**ស៊ីយ៉ូនគឺជាភាពបរិសុទ្ធនៅក្នុងចិត្ត ។**

## គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:២២–២៨

*ព្រះអម្ចាស់ពន្យល់អំពីអ្វីដែលយើងត្រូវតែធ្វើដើម្បីចៀសផុតពីការពិរោធរបស់ទ្រង់ ហើយទទួលបានពរជ័យរបស់ទ្រង់*



ដើម្បីរៀបចំសិស្សឲ្យយល់អំពីសារលិខិតរបស់ព្រះអម្ចាស់ នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:២២–២៤ សូមបង្ហាញ ឬគូររូបភាពនៃខ្យល់គួច។ សូមពន្យល់ថា ខ្យល់គួច កើតមាននៅទូទាំងពិភពលោក ។ ខ្យល់គួច ខ្លាំង អាចបង្វែរទៅជាខ្យល់ព្យុះដ៏សាហាវ ដែលបណ្តាលឲ្យ មានការខូចខាតយ៉ាងធ្ងន់ធ្ងរ ។ សូមសួរសិស្ស បើពួកគេ ធ្លាប់បានឃើញខ្យល់គួច ឬខ្យល់ព្យុះដ៏ធំដោយផ្ទាល់ ឬមើល ឃើញនៅក្នុងវីដេអូមួយ ។ សូមឲ្យសិស្សពិពណ៌នាអំពី បទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:២២–២៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ ប្រាប់ ពីអ្វីដែលព្រះអម្ចាស់ បានប្រៀបធៀបទៅនឹងខ្យល់កួច។ សូមប្រាប់ឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូម ព្យល់ថា នៅក្នុង ខ ២២ ពាក្យ*សេចក្តីសងសឹក*សំដៅទៅលើ ផលវិបាកនៃការមិនគោរពដល់ព្រះអម្ចាស់ ។

- តើសេចក្តីសងសឹករបស់ព្រះអម្ចាស់ដូចជាខ្យល់គួចយ៉ាង ដូចម្តេច ?

សូមឲ្យសិស្សស្រាវជ្រាវនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧:២៥–២៨ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលយើង ចាំបាច់ត្រូវធ្វើដើម្បីគេចចេញពីសេចក្តីសងសឹករបស់ព្រះអម្ចាស់ ហើយទទួលបានពរជ័យរបស់ទ្រង់វិញ ។ អ្នកអាចនឹងចង់ផ្តល់ យោបល់ឲ្យសិស្សគូសចំណាំពាក្យ *បើសិន* ត្រង់កន្លែងណាដែលឃើញមានពាក្យនោះនៅក្នុងខគម្ពីរទាំងនេះ ។

- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីគេចចេញពីសេចក្តីសងសឹករបស់ព្រះអម្ចាស់ ហើយទទួលបានពរជ័យទាំងឡាយរបស់ទ្រង់វិញ ?
- តើសារលិខិតរបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះទាក់ទងនឹងរូបភាពនៃដើមឈើពីរដើមដែលយើងបានពិភាក្សា កាលពីមុនយ៉ាងដូចម្តេចដែរ ? តើ ខ ២៧–២៨ បង្រៀនអំពីការប្រែចិត្ត និងការអភ័យទោសអ្វីខ្លះ ?

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ដូចខាងក្រោម ៖**បើយើងគោរពប្រតិបត្តិ នោះយើងនឹងគេចចេញពី សេចក្តីសងសឹករបស់ព្រះអម្ចាស់ ហើយទទួលបានពរជ័យរបស់ទ្រង់យ៉ាងច្រើនអនេក ។**

អ្នកអាចនឹងចង់ពន្យល់ថា ស្របតាម ប៉ាលី ភី ប្រាត្ត វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧ « ពុំមែនគ្រប់ថ្នាក់ដឹកនាំ និងសមាជិកទូទៅទាំងអស់នៃសាសនាចក្រនៅក្នុងរដ្ឋ មិសសួរី គោរពតាមនោះទេ ទោះជាអ្នកដឹកនាំ និងសមាជិកភាគច្រើន មានភាពរាបសារ និងស្មោះត្រង់ក្តី ។ ហេតុដូច្នោះហើយ ការជំនុំជំរះដោយគំរាមគំហែង ត្រូវបានចាក់ស្រោចមកលើពួកគេ ដែល នឹងបង្ហាញក្នុងប្រវត្តិសាស្ត្រក្នុងរយៈពេលប្រាំឆ្នាំបន្ទាប់នោះ » (*Autobiography of Parley P. Pratt,* បានបោះពុម្ពដោយ ប៉ាលី ភី ប្រាត្ត ជុញ្ញ័រ [ឆ្នាំ ១៩៣៨] ទំព័រ ៩៦ ) ។ ត្រឹមខែវិច្ឆិកា ឆ្នាំ ១៨៣៣ ពួកបរិសុទ្ធត្រូវបានបណ្តេញចេញពី ឃុំ ចាកសុន រដ្ឋ មិសសួរី ហើយពួកគេបានបន្តប្រឈមមុខនឹងការបៀតបៀននៅក្នុងរដ្ឋ មីសសួរី រហូតដល់ពួកគេត្រូវបានបណ្តេញចេញពីរដ្ឋ នៅឆ្នាំ ១៨៣៨ និង ឆ្នាំ ១៨៣៩ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេមានអារម្មណ៍បំផុសគំនិតដើម្បីធ្វើ នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ៩៧។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិតទាំងនោះ ដើម្បីពួកគេអាចទទួលបានពរជ័យទាំងឡាយ របស់ព្រះអម្ចាស់ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩៧ ( មេរៀនទី ២០ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោម នេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩៧ ( មេរៀនទី ២០ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើ គោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២)

នៅក្នុងមេរៀននេះសិស្សបានរៀនថា ប្រសិនបើយើងរាប់វិវរណៈទាំងឡាយដែលព្រះប្រទានឲ្យតាមរយៈពួកព្យាការីរបស់ទ្រង់ជាឥតការ នោះយើងនឹងជំពប់ជើង ហើយដួល ។ ពួកគេក៏បានរកឃើញថា ប្រសិនបើយើងស្រាវជ្រាវដោយឧស្សាហ៍ព្យាយាម អធិស្ឋានជានិច្ច ជឿ និងរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់យើង នោះគ្រប់អ្វីៗទាំងអស់នឹងធ្វើការរួមគ្នាសម្រាប់សេចក្ដីល្អរបស់យើង ។ ចេញពីការសិក្សាវិវរណៈមួយអំពីអាប៉ូគ្រីផា សិស្សបានរៀនថាព្រះវិញ្ញាណបរិសុទ្ធ អាចជួយយើងដឹងប្រសិនបើអ្វីដែលយើងបានអានជាការពិត ។ ក្រៅពីនោះទៀត សិស្សបានរកឃើញគោលការណ៍ដែលថា ប្រសិនបើយើងស្មោះត្រង់នៅក្នុងការរក្សាបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងនឹងត្រូវបានប្រទានពរជារៀងរហូត ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣)

នៅក្នុងការសិក្សានៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣, សិស្សបានរៀនថាព្រះយេស៊ូវគ្រីស្ទគឺកូនច្បងនៃកូនវិញ្ញាណទាំងអស់របស់ព្រះវរបិតាសួគ៌ ហើយថាតាមរយៈការទទួលពន្លឺ និង សេចក្ដពិត នោះយើងអាចប្រែក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ និង ព្រះវរបិតាសួគ៌ ។ ពួកគេក៏បានរៀនផងដែរថាយើងទទួលសេចក្ដីពិត និង ពន្លឺនៅពេលយើងគោរពព្រះបញ្ញត្តិ ហើយថាការមិនគោរពប្រតិបត្តិ និង ទំនៀមទម្លាប់ខុសឆ្គងដែលបណ្ដាលឲ្យយើងបាត់បង់ពន្លឺ និងសេចក្ដីពិត ។ ចេញពីព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះពួកដឹកនាំមួយចំនួនរបស់សាសនាចក្រ នោះសិស្សក៏បានរៀនផងដែរថាយើងត្រូវតែអធិស្ឋានជានិច្ច ហើយឧស្សាហ៍ព្យាយាម និង ខ្វល់ខ្វាយអំពីគេហដ្ឋានជានិច្ច ក្រែងលោសាតាំងនឹងមានអំណាចលើយើង ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦)

ចេញពីការស្ដីបន្ទោសរបស់ព្រះអម្ចាស់ចំពោះពួកបរិសុទ្ធសម្រាប់ភាពធ្វេសប្រហែសរបស់ពួកគេក្នុង ការសាងសង់ព្រះវិហារបរិសុទ្ធខឺតឡង់ នោះសិស្សបានរៀនថាព្រះវាយផ្ចាលដល់អស់អ្នកដែលទ្រង់ស្រឡាញ់ ។ ពួកគេក៏បានរៀនផងដែរថា នៅក្នុងព្រះវិហារបរិសុទ្ធព្រះអម្ចាស់បានរៀបចំពួកអ្នកបម្រើរបស់ទ្រង់ឲ្យធ្វើកិច្ចការរបស់ទ្រង់ ហើយប្រទានអំណាចដល់ពួកគេ ។ ក្រៅពីនេះទៀត សិស្សបានរកឃើញថា ប្រសិនបើយើងរក្សាបទបញ្ញត្តិទាំងឡាយ នោះយើងនឹងមានអំណាចដើម្បីធ្វើអ្វីៗដែលព្រះអម្ចាស់បានសុំឲ្យយើងធ្វើ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧)

ចេញពីការណែនាំរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធនៅក្នុងរដ្ឋមិសសួរី នោះសិស្សបានរៀនថាប្រសិនបើយើងបន្ទាបខ្លួនយើង ហើយស្វែងរកការរៀនសូត្រដោយឧស្សាហ៍ព្យាយាម នោះយើងនឹងទទួលបានប្រាជ្ញា និង សេចក្ដីពិត ។ សិស្សក៏រកឃើញផងដែរនូវអ្វីដែលយើងត្រូវតែធ្វើដើម្បីត្រូវបានទទួលយកដោយព្រះអម្ចាស់ ហើយបានរៀនថានៅក្នុងព្រះវិហារបរិសុទ្ធ ព្រះនឹងបង្ហាញព្រះកាយទ្រង់ដល់អ្នកទាំងឡាយដែលមានដួងចិត្តបរិសុទ្ធ ។ ក្រៅពីនេះទៀត សិស្សបានរៀនថាទីក្រុងស៊ីយ៉ូនគឺជាអ្នកដែលមានដួងចិត្តបរិសុទ្ធ ហើយប្រសិនបើយើងគោរពប្រតិបត្តិ នោះយើងនឹងគេចចេញពីសេចក្ដីក្រោធរបស់ព្រះអម្ចាស់ ហើយទទួលបានពរជ័យរបស់ទ្រង់យ៉ាងច្រើនអនេក ។

## សេចក្ដីផ្ដើម

ព្រះអម្ចាស់បានប្រទានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣ នៅថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៨៣៣ ។ មេរៀននេះផ្ដោតទៅលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–២០, ដែលរៀបរាប់ខ្លីៗតែប៉ុណ្ណោះនៅក្នុងមេរៀនសិស្សសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣។ នៅក្នុងខគម្ពីរទាំងនេះព្រះយេស៊ូវគ្រីស្ទបានបង្រៀនពីរបៀបដែលយើងអាចស្គាល់ទ្រង់ និង របៀបដែលយើងអាចប្រែក្លាយដូចជាទ្រង់ និង ព្រះវរបិតាសួគ៌របស់យើង ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–៥

*ព្រះយេស៊ូវគ្រីស្ទបង្រៀនអំពីរបៀបដែលបុគ្គលម្នាក់ៗអាចមើលឃើញព្រះភក្ត្ររបស់ទ្រង់ ហើយដឹងថាពិតជាមានទ្រង់មែន*

សូមបង្ហាញរូបភាពមនុស្សល្បីម្នាក់ ដែលសិស្សរបស់អ្នកនឹងស្គាល់ ហើយសួរដល់ពួកគេបើពួកគេស្គាល់ឈ្មោះរបស់បុគ្គលម្នាក់នោះ ។ ( ប្រសិនបើអ្នកពុំមានរូបភាពដាក់បង្ហាញទេ សូមសរសេរឈ្មោះរបស់បុគ្គលនោះនៅលើក្ដារខៀន ហើយសូមឲ្យសិស្សពន្យល់ថាអ្នកនោះជានរណា ហើយអ្វីដែលធ្វើឲ្យគាត់ល្បី ) ។

- ហេតុអ្វីមនុស្សជាច្រើនស្គាល់មនុស្សម្នាក់នេះ ?
- តើអ្នកគិតថាវាសំខាន់ឬទេដើម្បីស្គាល់មនុស្សម្នាក់នេះ ? ហេតុអ្វី ?

សូមដាក់តាំងរូបភាពរបស់ព្រះយេស៊ូវគ្រីស្ទ ( អ្នកអាចប្រើរូបព្រះយេស៊ូវគ្រីស្ទ [*សៀវភៅរូបភាពសិល្បៈដំណឹងល្អ* ( ឆ្នាំ ២០០៩ ) លេខ ១ ] សូមមើលផងដែរ LDS.org) ហើយពន្យល់ថា មនុស្សជាច្រើនសព្វថ្ងៃនេះ ពុំស្គាល់ថាទ្រង់ជានរណាទេ ។

- ហេតុអ្វីអ្នកគិតថាវាសំខាន់ដើម្បីស្គាល់ថាព្រះយេស៊ូវគ្រីស្ទថាជានរណា ?

សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣ ព្រះអម្ចាស់បានបង្រៀនអំពីរបៀបដែលយើងអាចបង្កើនចំណេះដឹងរបស់យើងអំពីទ្រង់ និង អំពីព្រះចេស្ដារបស់ទ្រង់ដើម្បីប្រទានពរដល់យើងនៅពេលឥឡូវនេះ និង រហូតដល់ភាពអស់កល្បជានិច្ច ។ សូមសរសេរសំណួរពីខាងក្រោមនៅលើក្ដារខៀន ដោយទុកចន្លោះឲ្យសិស្សសរសេរចម្លើយរបស់ពួកគេនៅក្រោមសំណួរទាំងនោះ ៖

> *តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ?*
> *តើយើងអាចដឹងអ្វីខ្លះពីទ្រង់ប្រសិនបើយើងធ្វើតាមចំណុចទាំងនេះ ?*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–៥ ឲ្យឮៗ ។ មុនពេលសិស្សចាប់ផ្ដើមអាន សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់រកមើលចម្លើយចំពោះសំណួរទីមួយ ហើយសិស្សពាក់កណ្ដាលថ្នាក់ទៀតរកមើលចម្លើយចំពោះសំណួរទីពីរ ។ បន្ទាប់ពីខគម្ពីរត្រូវបានអាន សូមអញ្ជើញសិស្សពីរបីនាក់ឡើងមកមុខក្ដារខៀន ហើយសរសេរចម្លើយរបស់ពួកគេតបនឹងសំណួរទាំងនោះ ។ បន្ទាប់មកសូមសួរសិស្សនូវសំណួរខាងក្រោម ៖

- តើអ្នកនឹងថ្លែងអំពីសេចក្ដីសន្យានៅក្នុង ខ ១ ជាគោលការណ៍ « ប្រសិនបើ–នោះ » យ៉ាងដូចម្ដេច ? ( ការឆ្លើយតបរបស់សិស្សគួរតែឆ្លុះបញ្ចាំងនូវគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងបោះបង់ចោលអំពើបាបរបស់យើង មករកព្រះគ្រីស្ទ អំពាវនាវរកព្រះនាមរបស់ទ្រង់ គោរពតាមសំឡេងទ្រង់ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ បន្ទាប់មកយើងនឹងមើលឃើញព្រះភក្ត្រទ្រង់ ហើយស្គាល់ទ្រង់ថាជានរណា** ) ។

អ្នកអាចគូសបញ្ជាក់ថាពរជ័យនេះនឹងកើតមានតាមពេលវេលារបស់ព្រះអម្ចាស់ផ្ទាល់ តាមមាគ៌ារបស់ទ្រង់ ហើយស្របតាមព្រះទ័យទ្រង់ ( សូមមើល គ. និង ស. ៨៨:៦៨; សូមមើលផងដែរ អេណុស ១:២៧) ។

- តើសកម្មភាពនិមួយៗនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១ ជួយយើងឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?
- ចេញមកពីអ្វីដែលអ្នកបានរៀននៅក្នុង ខ ៣ តើគោលលទ្ធិអ្វីដែលសំខាន់ដើម្បីយល់ដឹងអំពីព្រះវរបិតា និង ព្រះរាជបុត្រា ? ( សិស្សគួរតែរកឃើញគោលលទ្ធិខាងក្រោម ៖ **ព្រះវរបិតា និង ព្រះរាជបុត្រាគឺតែមួយ** ) ។
- តើឃ្លាថាព្រះវរបិតា និង ព្រះរាជបុត្រាគឺតែមួយមានន័យដូចម្ដេច ?

សូមជួយសិស្សយល់ថាព្រះវរបិតា និង ព្រះរាជបុត្រាគឺមានតួអង្គពីផ្សេងគ្នា ហើយដាច់ដោយឡែកពីគ្នា មួយអង្គៗមានព្រះកាយជាសាច់ និង ឆ្អឹងដែលមានសិរីរុងរឿង ( សូមមើល គ. និង ស. ១៣០:២២) ។ ទោះជាយ៉ាងណាក៏ដោយព្រះវរបិតា និង ព្រះរាជបុត្រាគឺព្រះរាជបំណង និង គោលលទ្ធិរួមគ្នាតែមួយ ។ ពួកទ្រង់រួមសាមគ្គីគ្នាដ៏ឥតខ្ចោះក្នុងការនាំមកនូវផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតា ។

សូមចង្អុលបង្ហាញនូវឃ្លាដូចខាងក្រោមនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤៖ « ជាព្រះវរបិតាពីព្រោះព្រះអង្គបានប្រទានដល់យើងនូវភាពពោរពេញរបស់ទ្រង់ » ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១៧–២៦ ឲ្យឮៗ ។ សូមសួរសំណួរខាងក្រោម ៖

- តើការដែលព្រះយេស៊ូវគ្រីស្ទបានទទួលនូវភាពពោរពេញរបស់ព្រះវរបិតាមានន័យដូចម្ដេច ? ( សូមមើល គ. និង ស. ៩៣:១៦–១៧, ២៦ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៦–២០

*កំណត់ត្រារបស់យ៉ូហាន ត្រូវបានប្រើដើម្បីជួយយើងយល់ដឹងអំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទ បានទទួលនូវភាពពេញលេញនៃសិរីល្អរបស់ព្រះវរបិតាសួគ៌*

សូមគិតពីការរៀបចំជាមុននូវការបង្ហាញខាងក្រោម ដើម្បីរៀបចំសិស្សឲ្យយល់ពីរបៀបដែលព្រះអង្គសង្គ្រោះបានទទួលនូវភាពពេញលេញរបស់ព្រះវរបិតាសួគ៌ ។ សូមអញ្ជើញសិស្សដែលបានបង្កើននូវជំនាញពិសេសមួយ ដូចជាលេងកីឡាពិសេសណាមួយ ឬ លេងឧបករណ៍តន្ត្រីមួយ ឬ បង្កើតសិល្បៈផ្សេងៗ ដើម្បីធ្វើបទបង្ហាញខ្លីៗ ឬ ពិពណ៌នាពីជំនាញនោះ ។ បន្ទាប់មកសូមឲ្យសិស្សទាំងនោះប្រាប់សិស្សក្នុងថ្នាក់ អំពីឱកាសមួយដែលគាត់បានអភិវឌ្ឍជំនាញនោះ ។ ( ចម្លើយរបស់សិស្សគួរតែជួយសិស្សក្នុងថ្នាក់យល់ថា ដើម្បីប្រែក្លាយជាកីឡាករ តន្ត្រីករ ឬ ជាងគំនូរដ៏ជំនាញម្នាក់ វាគឺជាដំណើរការដែលតម្រូវឲ្យមានការខ្នះខ្នែងជាប់ជានិច្ច ហើយវាពុំអាចកើតមានឡើងភ្លាមៗក្នុងមួយពព្រិចភ្នែកឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១២–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានប្រែក្លាយដូចជាព្រះវរបិតាទ្រង់ ។

- តើព្រះយេស៊ូវគ្រីស្ទប្រែក្លាយដូចជាព្រះវរបិតាទ្រង់យ៉ាងដូចម្ដេច ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទបានធំឡើងពីព្រះគុណថែមលើព្រះគុណ រហូតដល់ទ្រង់ទទួលបាននូវភាពពេញលេញនៃសិរីល្អរបស់ព្រះវរបិតា** ។ អ្នកអាចឲ្យយោបល់សិស្សគូសចំណាំគោលការណ៍នេះនៅក្នុង ខ ១៣) ។

- តើអ្នកគិតថាព្រះយេស៊ូវគ្រីស្ទបានបន្តពីព្រះគុណថែមលើព្រះគុណរហូតដល់ទ្រង់បានទទួលបាននូវភាពពេញលេញយ៉ាងដូចម្ដេច ?

សូមជួយសិស្សយល់ថា ព្រះគុណគឺជាកម្លាំង និង ជាព្រះចេស្ដាមកពីព្រះដែលអនុញ្ញាតឲ្យយើងទទួលបានជីវិតដ៏អស់កល្បជានិច្ច និង ភាពតម្កើងឡើង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១៩–២០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីមូលហេតុដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យ សម្រាប់ការបើកសម្ដែង អំពីរបៀបដែលទ្រង់ទទួលបានភាពពេញលេញនៃព្រះវរបិតា ។

- យោងតាម ខ ១៩, ហេតុអ្វីព្រះអង្គសង្គ្រោះបើកសម្ដែងពីរបៀបដែលទ្រង់ទទួលបានភាពពេញលេញនៃព្រះវរបិតាដូច្នេះ ?

សូមជួយសិស្សឲ្យយល់ថា ព្រះអង្គសង្គ្រោះបានបើកសម្ដែងអំពីរបៀបដែលទ្រង់បានទទួលភាពពេញលេញមួយ គឺដើម្បីឲ្យយើងអាច « យល់ និង ស្គាល់ » ទ្រង់ និង ព្រះវរបិតាសួគ៌ ហើយស្គាល់របៀបដើម្បីថ្វាយបង្គំព្រះវរបិតា និង ទទួលនូវភាពពេញលេញរបស់ទ្រង់ ។ សូមសរសេរសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅលើក្ដារខៀន ៖ ( សេចក្ដីថ្លែងនេះត្រូវបានរកឃើញនៅក្នុង *The Promised Messiah :The First Coming of Christ* ( ឆ្នាំ ១៩៧៨ ) ទំព័រ ៥៦៨ ) ។

> *« ការថ្វាយបង្គំដ៏ឥតខ្ចោះគឺជាការត្រាប់តាម ។ យើងគោរពដល់អ្នកទាំងឡាយដែលយើងត្រាប់តាម » ( អែលឌើរ ប្រ៊ូស អរ ម៉ាក់ខនឃី ) ។*

- តើអ្នកគិតថាការថ្វាយបង្គំមានន័យដូចម្ដេច ?

- តើយើងថ្វាយបង្គំដល់ព្រះវរបិតាសួគ៌របស់យើងយ៉ាងដូចម្ដេច ? ( សិស្សអាចបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **យើងត្រូវថ្វាយបង្គំដល់ព្រះវរបិតាសួគ៌ ដោយការធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ** ។ អ្នកអាចស្នើឲ្យសិស្សសរសេរគោលការណ៍នេះ នៅក្បែរគែមទំព័រនៃព្រះគម្ពីររបស់ពួកគេ ) ។

- តើការរីកចម្រើនរបស់ព្រះអង្គសង្គ្រោះពីព្រះគុណថែមលើព្រះគុណ ស្រដៀងគ្នាទៅនឹងដំណើរការនៃការរៀនសូត្រ និង ការរីកចម្រើនដែលយើងអាចទទួលបទពិសោធន៍របៀបណា ?

- តើសេចក្ដីសន្យាអ្វីខ្លះ ត្រូវបានប្រទានឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២០ ដល់អ្នកទាំងឡាយណាដែលធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ ? ( សិស្សគួរបង្ហាញគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងរក្សាបទបញ្ញត្តិទាំងឡាយ នោះយើងអាចទទួលបានភាពពេញលេញនៃព្រះវរបិតា ដូចដែលព្រះយេស៊ូវគ្រីស្ទទទួលបានផងដែរ** )។

សូមលើករូបភាពរបស់ព្រះអង្គសង្គ្រោះឡើង ដែលអ្នកបានដាក់តាំងនៅពេលចាប់ផ្ដើមថ្នាក់ ។

- ហេតុអ្វីវាសំខាន់ដើម្បីមានទីបន្ទាល់មួយអំពីគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ការបង្រៀន និងដង្វាយធួនរបស់ទ្រង់ ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីបន្ត « ព្រះគុណថែមលើព្រះគុណ » (គ. និង ស. ៩៣:១៣) ហើយកាន់តែក្លាយដូចជាទ្រង់ ?

សូមឲ្យសិស្សគិតអំពីរបៀបជាក់លាក់មួយដែលពួកគេនឹងស្វែងរក ដើម្បីរីកចម្រើន និង កែលម្អតាមរយៈការធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញពួកគេឲ្យដាក់ចំណុចនោះជាគោលដៅហើយព្យាយាមសម្រេចវាឲ្យបាន ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨–១០១)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួននៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨–១០១ អ្នកអាចអញ្ជើញពួកគេឲ្យពិចារណាពីសំណួរខាងក្រោម ៖ តើអ្នកធ្លាប់ត្រូវបានគេធ្វើបាប ហើយតើអ្នកធ្លាប់ឆ្ងល់ពីរបៀបដែលអ្នកគួរតែមានប្រតិកម្មតបតនឹងការធ្វើបាបនោះដោយរបៀបណា ? នៅក្នុងមេរៀនបន្ទាប់ អ្នកនឹងរៀនអំពីការបៀតបៀន និង រងទុក្ខរបស់ពួកបរិសុទ្ធដែលបានជួបប្រទះនៅក្នុងរដ្ឋមិសសួរី ។ អ្នកនឹងរៀនផងដែរអំពីអ្វីដែលព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធអំពីការឆ្លើយតបចំពោះការបៀតបៀន រួមទាំងព្រះទ័យរបស់ទ្រង់អំពីការចេញទៅធ្វើសង្គ្រាម ។

មេរៀនទី ១០១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–២២

## សេចក្ដីផ្ដើម

នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៨៣៣ មានក្រុមប្រជាជនរដ្ឋមិសសួរីចំនួន ៤០០ ទៅ ៥០០នាក់ បានទាមទារថា មិនឲ្យពួកបរិសុទ្ធផ្លាស់ទៅរស់នៅឃុំ ចាកសុនទៀតទេ ហើយពួកអ្នកដែលរស់នៅក្នុងឃុំនោះរួចហើយ ត្រូវតែចាកចេញ ។ មុនពេលដែលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី អាចឆ្លើយតបបាន ក្រុមពួកមនុស្សកំណាចបានចាប់ផ្ដើមបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ ហើយគំរាមកំហែងដល់អាយុជីវិតរបស់ពួកគេ ។ នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ ក្នុងនោះគឺជាអ្វីដែលព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធ អំពីរបៀបឆ្លើយតបទៅនឹងការបៀតបៀន ។ ទោះបីជាព័ត៌មាននៃបញ្ហាមួយចំនួនក្នុងរដ្ឋ មិសសួរី ប្រហែលជាបានឮដល់ព្យាការីនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ដែលមានចម្ងាយប្រហែល ១៤៥០ គីឡូម៉ែត្រ ក្ដីក៏លោកអាចយល់ពីស្ថានភាពធ្ងន់ធ្ងរតាមរយៈវិវរណៈដែរ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានជ្រាបពីការរងទុក្ខរបស់ពួកបរិសុទ្ធក្នុងរដ្ឋ មិសសួរី និងរដ្ឋ អូហៃអូ ។ ទ្រង់បានទូន្មានពួកគេឲ្យធ្វើតាមច្បាប់រដ្ឋធម្មនុញនៃដែនដី ហើយរក្សាសេចក្ដីសញ្ញាទាំងឡាយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–៣

*ព្រះអម្ចាស់ បានអះអាងនឹងពួកបរិសុទ្ធក្នុងពេលពួកគេកំពុងរងទុក្ខ*

មុនពេលចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរដូចខាងក្រោមនេះ នៅលើក្ដារខៀន ៖ *តើអ្នកនឹងមានអារម្មណ៍យ៉ាងណា ?*

សូមឲ្យសិស្សម្នាក់អានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្ស គិតពីអារម្មណ៍ដែលពួកគេអាចមាន បើពួកគេស្ថិតនៅក្នុងស្ថានភាពបែបនេះ ។

នៅថ្ងៃ សៅរ៍ទី ២០ ខែ កក្កដា ឆ្នាំ ១៨៣៣ មានប្រជាជនខឹងសម្បាក្នុងរដ្ឋ មិសសួរី ប្រមាណជា ៤០០ ទៅ ៥០០នាក់ បានជួបជុំគ្នានៅសាលាក្ដីក្នុងក្រុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី ។ ពួកគេបានជ្រើសរើសគណៈកម្មការមួយ ដើម្បីព្រៀងឯកសារមួយដែលសង្ខេបពីការទាមទារចង់បានរបស់ខ្លួនពីពួកមរមន ។ ពួកគេបានទាមទារថា ពុំអនុញ្ញាតឲ្យមានពួកបរិសុទ្ធថ្ងៃចុងក្រោយផ្លាស់ប្ដូរទីលំនៅទៅឃុំចាកសុនទៀតឡើយ ហើយបាននិយាយថាអស់អ្នកដែលកំពុងរស់នៅទីនោះត្រូវតែសច្ចាថាចាកចេញពីទីនោះឲ្យបានឆាប់តាមដែលអាចធ្វើបាន ។ លើសពីនោះទៀត ពួកគេបានទាមទារសាសនាចក្រឲ្យបញ្ឈប់ការបោះពុម្ពផ្សាយកាសែត ។ នៅពេលការទាមទារនេះត្រូវបានដាក់បង្ហាញដល់ថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងរដ្ឋមិសសួរី ថ្នាក់ដឹកនាំសាសនាចក្រមានការភ្ញាក់ផ្អើល ហើយបានស្នើសុំរយៈពេលបីខែដើម្បីពិចារណាពីសំណើនោះ និង ដើម្បីពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំនៅក្នុងរដ្ឋអូហៃអូ ។ ក្រុមប្រជាពលរដ្ឋនៃរដ្ឋមិសសួរីបានបង្ហាញពីការទាមទារដែលបដិសេធនឹងការស្នើសុំរបស់ថ្នាក់ដឹកនាំសាសនាចក្រ ។ ក្រោយមកពួកបរិសុទ្ធបានស្នើសុំរយៈពេល ១០ថ្ងៃ ប៉ុន្តែពួកគេបានអនុញ្ញាតឲ្យរយៈពេលតែ ១៥នាទីប៉ុណ្ណោះដើម្បីឆ្លើយតប ។ ( សូមមើល *Church History in the Fulness of Times Student Manual,* បោះពុម្ពទី ២ [Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ១៣២–៣៣ ) ។

សូមឲ្យសិស្សមើលសំណួរនៅលើក្ដារខៀន ហើយសួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកមានអារម្មណ៍យ៉ាងណា បើអ្នកជាពួកបរិសុទ្ធម្នាក់រស់នៅក្នុងទីក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី នៅពេលនោះ ?

បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមឲ្យសិស្សម្នាក់ទៀតអាននូវឃ្លាដូចខាងក្រោមឲ្យឮៗ ៖

ប្រជាជនរដ្ឋ មិសសួរី ដែលជួបជុំគ្នានៅសាលាក្ដីក្នុងទីក្រុង អ៊ិនឌីប៉ែនដែនស៍ បានក្លាយជាពួកមនុស្សកំណាចយ៉ាងរហ័ស ហើយបានសម្រេចថាត្រូវកំទេចការិយាល័យបោះពុម្ព និងម៉ាស៊ីនបោះពុម្ពចោល ។ ពួកគេបានទំលុះចូលការិយាល័យបោះពុម្ព បោះគ្រឿងសង្ហារឹមចេញទៅលើផ្លូវ និងលើសួនច្បារ កំទេចម៉ាស៊ីនបោះពុម្ពកម្ចាយរបស់របរ ហើយបំផ្លាញកិច្ចការបោះពុម្ពស្ទើតែទាំងអស់ រួមទាំងសន្លឹកគម្ពីរនៃព្រះបញ្ញត្តិដែលមិនទាន់បានផ្គុំបញ្ចូលគ្នាទៀងផង ។ បន្ទាប់មក ក្រុមពួកមនុស្សកំណាចបានទៅកំទេចហាងរបស់ហ្គីលបើត និង វីតនី ទៀត ។ ប៉ុន្តែ ស៊ីឌនី ហ្គីលបើត បានជួបពួកមនុស្សកំណាចមុនពេលពួកគេអាចចាប់ផ្ដើមសកម្មភាព ហើយបានសន្យាថាគាត់នឹងរើឥវ៉ាន់ចេញក្នុងរយៈពេលបីថ្ងៃ ។ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៣៣ ) ។

### *សូមជួយសិស្សឲ្យយល់កាន់តែច្បាស់ពីបរិបទនៃព្រះគម្ពីរ*

សិស្សអាចសម្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយកាន់តែប្រសើរបាន នៅពេលពួកគេយល់ពីបរិបទខាងប្រវត្តិសាស្ត្រនៅក្នុងបណ្ដុំខគម្ពីរ ។ វិធីមួយដើម្បីជួយសិស្សឲ្យធ្វើកិច្ចការនេះ គឺត្រូវអញ្ជើញពួកគេឲ្យដាក់ខ្លួនគេនៅក្នុងស្ថានភាពរបស់អ្នកដែលនៅក្នុងខគម្ពីរ ហើយឲ្យពួកគេពិចារណាពីអ្វីដែលពួកគេអាចមានអារម្មណ៍ នៅក្នុងស្ថានភាពបែបនោះ ។

សូមឲ្យសិស្សចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរនៅលើក្ដារខៀន ដែលទាក់ទងទៅនឹងរឿងនេះ ។ ក្រោយពីសិស្សបានចែកចាយគំនិតរបស់ពួកគេហើយ សូមឲ្យសិស្សទីបីអានឃ្លាខាងក្រោមនេះ ៖

បីថ្ងៃក្រោយមក នៅថ្ងៃទី ២៣ ខែ កក្កដា ក្រុមពួកមនុស្សកំណាចបានមកឃុំ ចាកសុន រដ្ឋ មិសសួរី ម្ដងទៀត ម្ដងនេះពួកគេមានកាន់កាំភ្លើងវែង កាំភ្លើងខ្លី ខ្សែតី និងដំបង ។ ពួកគេបានដុតភ្នក់ចំបើង និងស្រែ ហើយបានកំទេចផ្ទះ ជង្រុកស្រូវ និងកន្លែងរកស៊ីមួយចំនួន ។ ចុងក្រោយពួកគេបានជួបជាមួយនឹងថ្នាក់ដឹកនាំក្នុងសាសនាចក្រប្រាំមួយនាក់ ដែលឃើញថាទ្រព្យសម្បត្តិ និងជីវិតរបស់ពួកបរិសុទ្ធកំពុងស្ថិតក្នុងភាពអន្តរាយ ហើយបានស្នើដាក់ជីវិតរបស់ពួកគេជាការលោះវិញ ។ ពួកគេបានបដិសេធការស្នើសុំនោះ ហើយពួកអ្នកដឹកនាំក្រុមមនុស្សកំណាចបានគំរាមគំហែងថាត្រូវវាយ បុរស ស្ត្រី និងកុមាររហូតដល់ពួកគេព្រមចេញពីភូមិនោះ ។ ដោយស្ថិតនៅក្រោមសំពាធ បងប្អូនប្រុសបានចុះហត្ថលេខាលើការព្រមព្រៀងចាកចេញពីឃុំ ចាកសុន ។ សមាជិកសាសនាចក្រពាក់កណ្ដាល និងថ្នាក់អ្នកដឹកនាំស្ទើរតែទាំងអស់ នឹងចាកចេញនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៨៣៤ ហើយអ្នកដែលនៅសល់នឹងចាកចេញនៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៨៣៤ ។ ក្រុមពួកមនុស្សកំណាចអនុញ្ញាតឲ្យ យ៉ូហាន ខូរីល និង ស៊ីឌនី ហ្គីលបើត នៅលក់ទ្រព្យសម្បត្តិរបស់ពួកបរិសុទ្ធដែលត្រូវបានបណ្ដេញចេញ ។ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៣៤ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលបានបំផុសដល់វិវរណៈនេះ ។ សូមឲ្យសិស្សរាយការណ៍អំពីចម្លើយរបស់ពួកគេ ។

- ស្របទៅតាមសេចក្ដីណែនាំអំពីកណ្ឌ តើអ្វីទៅដែលគួរឲ្យកត់សម្គាល់ពី ពេលវេលានៃវិវរណៈនេះ ?

សូមពន្យល់ថា ពួកបរិសុទ្ធនៅក្នុងរដ្ឋ អូហៃអូ ក៏បានជួបប្រទះការបៀតបៀនក្នុងពេលនេះផងដែរ ។ គោលការណ៍នៅក្នុងវិវរណៈនេះ បានអនុវត្តចំពោះពួកគេ ហើយវាក៏អាចអនុវត្តចំពោះយើងដែរ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សរកមើលការប្រឹក្សា ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។ ( វាអាចមានប្រយោជន៍ ដើម្បីពន្យល់ថា *សាបោត*, នៅក្នុង ខ ២, គឺជាពាក្យក្នុងភាសាហេព្រើរ ដែលមានន័យថា « អ្នកមើលថៃ » ឬ « កងទ័ព » ។ វាត្រូវបានប្រើនៅទីនេះ ដើម្បីបញ្ជាក់ថាព្រះអម្ចាស់ត្រួតត្រាការពារពួកពលទេវតា ឬ អ្នកមើលថៃ និងកងទ័ពអ៊ីស្រាអែល ឬពួកបរិសុទ្ធ ។ [ សូមមើល Bible Dictionary, « Sabaoth » ] ) ។

- តើព្រះអម្ចាស់បានប្រទានព្រះឱវាទអ្វីខ្លះដល់ពួកបរិសុទ្ធ ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- ហេតុអ្វីវាសំខាន់ដើម្បីឲ្យពួកបរិសុទ្ធថ្លែងអំណរគុណអំឡុងគ្រាដ៏លំបាកនេះ ?
- តើអ្នកគិតថាដោយអត់ឱនរង់ចាំព្រះអម្ចាស់ មានន័យដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូបឺត ឌី ហែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកអត្ថន័យនៃឃ្លា ដោយអត់ឱនរង់ចាំព្រះអម្ចាស់ ។



« អញ្ចឹងតើវាមានន័យយ៉ាងណាដើម្បីរង់ចាំព្រះអម្ចាស់នោះ ? នៅក្នុងព្រះគម្ពីរពាក្យ *រង់ចាំ* មានន័យថា សង្ឃឹម ចូលរួម និង ទុកចិត្ត ។ សង្ឃឹម និង ទុកចិត្តលើព្រះអម្ចាស់តម្រូវឲ្យមានសេចក្ដីជំនឿ ការអត់ធ្មត់ ការបន្ទាបខ្លួន ភាពស្លូតបូត ការអត់ទ្រាំ រក្សាព្រះបញ្ញត្តិ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត » (« Waiting upon the Lord: Thy Will Be Done » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧២ ) ។

- ហេតុអ្វីបានជាព្រះឱវាទដើម្បីអត់ឱនរង់ចាំព្រះអម្ចាស់មានសារៈសំខាន់ចំពោះពួកបរិសុទ្ធនៅក្នុងរដ្ឋមិសសួរី ?
- តើពាក្យលួងលោមចិត្ត ដែលអ្នកឃើញនៅក្នុង ខ ២មានអ្វីខ្លះ ?

សូមសរសេរឃ្លាដែលមិនពេញលេញខាងក្រោមនេះ នៅលើក្ដារខៀន ៖ *បើយើងថ្លែងអំណរគុណក្នុងគ្រប់ការណ៍ទាំងអស់ ហើយរង់ចាំដោយអត់ធ្មត់លើព្រះអម្ចាស់ នោះ . . .*

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពីអ្វីដែលព្រះអម្ចាស់បានសន្យាចំពោះពួកបរិសុទ្ធ ប្រសិនបើពួកគេគោរពតាមព្រះឱវាទរបស់ទ្រង់ ។

- តើអ្នកនឹងបំពេញគោលការណ៍នៅលើក្ដារខៀន ដោយផ្អែកទៅលើ ខ ៣ យ៉ាងដូចម្ដេច ? ( នៅខាងក្រោមនេះ គឺជាវិធីមួយដែលសិស្សអាចបំពេញនូវគោលការណ៍នោះ ៖ **បើយើងថ្លែងអំណរគុណក្នុងគ្រប់ការណ៍ទាំងអស់ នោះព្រះអម្ចាស់អាចធ្វើឲ្យការរងទុក្ខរបស់យើង ធ្វើការរួមគ្នាសម្រាប់ការណ៍ល្អ)** ។

សូមឲ្យសិស្សគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ជាអ្នកដែលរង់ចាំព្រះអម្ចាស់ដោយការអត់ធ្មត់ លើព្រះអម្ចាស់ក្នុងគ្រាលំបាក ហើយបានរកឃើញហេតុផលមួយ ដើម្បីមានអំណរគុណ ។

- តើការរងទុក្ខ នាំមកនូវសេចក្ដីល្អក្នុងជីវិតរបស់បុគ្គលនោះតាមវិធីណាខ្លះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៤–១០

*ព្រះអម្ចាស់ទូន្មានពួកបរិសុទ្ធ ឲ្យគាំទ្រក្រឹត្យវិន័យរបស់ដែនដី*

សូមពន្យល់ថា បន្ថែមពីលើការទូន្មានពួកបរិសុទ្ធឲ្យរង់ចាំដោយអត់ធ្មត់ នោះព្រះអម្ចាស់បានមានបន្ទូលប្រាប់ពួកគេឲ្យគោរពតាមព្រះបញ្ញត្តិទាំងអស់របស់ទ្រង់ ( សូមមើល គ. និង ស. ៩៨:៤ ) ហើយមានបន្ទូលថាពួកគេត្រូវបានរាប់ថាសុចរិត « ក្នុងការគាំទ្រក្រឹត្យវិន័យនោះ ដែលជាក្រឹត្យវិន័យត្រឹមត្រូវនៃដែនដី » ( គ. និង ស. ៩៨:៦ ) ទ្រង់បានពន្យល់ថា ច្បាប់រដ្ឋធម្មនុញ្ញនៃដែនដីគាំទ្រ « គោលការណ៍នៃសេរីភាពនោះ ក្នុងការទ្រទ្រង់សិទ្ធិ និងឯកសិទ្ធិទាំងឡាយ » នោះគឺសម្រាប់« មនុស្សទាំងអស់ » ( គ. និង ស. ៩៨:៥ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៩–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពី ពួកអ្នកដឹកនាំរដ្ឋាភិបាល ។ សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេ ។

- តើការទូន្មានរបស់ព្រះអម្ចាស់ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៤–១០ អាចជួយយើងនៅក្នុងពេលនេះ មិនថាយើងរស់នៅប្រទេសណាយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១១–១៨

*ព្រះអម្ចាស់ណែនាំពួកបរិសុទ្ធ ឲ្យរក្សាសេចក្ដីសញ្ញា ទោះជានៅក្នុងគ្រាលំបាកក្ដី*

សូមឲ្យសិស្សពិចារណាពីសំណួរខាងក្រោម ៖

- តើរង្វាន់អ្វីដែលកើតមានចំពោះអ្នកដែលដាក់ជីវិតខ្លួន សម្រាប់បុព្វហេតុរបស់ព្រះយេស៊ូវគ្រីស្ទ និងព្រះនាមរបស់ទ្រង់ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១១–១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលចម្លើយចំពោះសំណួរនោះ និងអ្វីដែលព្រះអម្ចាស់បានមានបន្ទូលប្រាប់ដល់ពួកបរិសុទ្ធអំពីការសាកល្បង និងការពិសោធន៍ ។

- តើ ព្រះអម្ចាស់បានប្រទានបទបញ្ញត្តិ អ្វីខ្លះដល់ពួកបរិសុទ្ធ ? ( សូមមើល គ. និង ស. ៩៨:១១–១២ ) ។

- យោងទៅតាម ខ ១៣–១៥, តើហេតុផលអ្វីដែលព្រះអម្ចាស់ត្រូវសាកល្បងយើង ? ( បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនេះ នៅលើក្ដារខៀន ៖ **ព្រះអម្ចាស់សាកល្បងយើង ដើម្បីឃើញថាតើយើងរក្សាសេចក្ដី សញ្ញារបស់យើងបានឬទេ ទោះបីវាពិបាកធ្វើក៏ដោយ)** ។

- តើហេតុអ្វីបានជាវាអាចមានសារៈសំខាន់ សម្រាប់ពួកបរិសុទ្ធដែលរស់នៅរដ្ឋ មិសសួរី ក្នុងឆ្នាំ ១៨៣៣ ក្នុងការដឹងការពិតនេះ ? តើហេតុអ្វីបានជាការពិតនេះ មានសារៈសំខាន់សម្រាប់ឲ្យយើងចងចាំនៅសព្វថ្ងៃនេះ ?

សូមឲ្យសិស្សគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលជាគំរូល្អនៃការរក្សាសេចក្ដីសញ្ញាក្នុងគ្រាលំបាកនានា ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេនៅក្នុងថ្នាក់ ។

សូមសូមឲ្យសិស្សពិចារណាអំពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីនៅតែរឹងមាំ និងរក្សាសេចក្ដីសញ្ញាពួកគេ ទោះជាមានការលំបាកក្នុងការធ្វើវាក្ដី ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១៦–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលអ្វីដែលព្រះអម្ចាស់បានត្រាប់បង្គាប់ឲ្យពួកបរិសុទ្ធធ្វើ ។ សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១៩–២២

*ព្រះអម្ចាស់មានបន្ទូលប្រាប់ពួកបរិសុទ្ធនៅទីក្រុង ខឺតឡង់ ឲ្យប្រែចិត្ត*

សូមពន្យល់ថា ក្នុងពេលដែលព្រះអម្ចាស់បានប្រទាននិវរណៈនេះ ពួកបរិសុទ្ធក្នុងទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ ក៏បានជួបប្រទះនឹងការលំបាកនានាផងដែរ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១៩–២២, យើងបានអានសារលិខិតរបស់ព្រះអម្ចាស់សម្រាប់ពួកគេ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១៩–២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីពួកបរិសុទ្ធក្នុងទីក្រុងខឺតឡង់ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីពួកបរិសុទ្ធក្នុងទីក្រុងខឺតឡង់ ទាក់ទងទៅនឹងអ្វីដែលទ្រង់បានប្រាប់ដល់ពួកបរិសុទ្ធនៅក្នុងរដ្ឋ មិសសួរី យ៉ាងដូម្ដេច ? ( សូមមើល គ. និង ស. ៩៨:១១ ) ។
- តើសារលិខិតរបស់ព្រះអម្ចាស់ នៅក្នុង ខ ១១ អាចអនុវត្តចំពោះយើងរបៀបណា ? ( សូមជួយសិស្សឲ្យយល់ថាការ « កាន់ខ្ជាប់ » ខាងសេចក្ដីល្អ គឺជាការប្ដេជ្ញាដោយមិនងាករេ ) ។

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នក អំពីគោលការណ៍ទាំងឡាយដែលយើងបានពិភាក្សានៅថ្ងៃនេះ ។ សូមលើកទឹកចិត្តសិស្សឲ្យលះបង់ចោលនូវអំពើបាបរបស់ពួកគេ ហើយកាន់ខ្ជាប់ខាងសេចក្ដីល្អវិញ ។

មេរៀនទី ១០២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៣–៤៨

## សេចក្ដីផ្ដើម

ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៨ នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៣ ប្រហែលពីសប្ដាហ៍បន្ទាប់ពីការបៀតបៀននៃពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានក្លាយជាអំពើហឹង្សា ។ វិវរណៈនេះផ្ដល់នូវការដឹកនាំសម្រាប់ពួកបរិសុទ្ធ ដែលត្រូវបានគេធ្វើបាប ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធពីរបៀបដែលពួកគេគួរឆ្លើយតបចំពោះសត្រូវរបស់ពួកគេ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៣–៣២

*ព្រះអម្ចាស់បើកសម្ដែងពីរបៀបដែលពួកបរិសុទ្ធ ត្រូវឆ្លើយតបនឹងការបៀតបៀន*

មុនពេលចាប់ផ្ដើមរៀន សូមគូសជួរឈរបីជួរ នៅលើក្ដារខៀន ហើយសរសេរចំណងជើងដូចខាងក្រោមលើជួរនិមួយៗ ៖ *ក្រឹត្យវិន័យនៃការសងសឹករបស់ព្រះអម្ចាស់ ( គ. និង ស. ៩៨:២៣–៣២ ); ក្រឹត្យវិន័យនៃសង្គ្រាមរបស់ព្រះអម្ចាស់ ( គ. និង ស. ៩៨:៣៣–៣៨ );* និង *ក្រឹត្យវិន័យនៃការលើកលែងទោសរបស់ព្រះអម្ចាស់ (គ. និង ស. ៩៨:៣៩–៤៨ )* ។

សូមឲ្យសិស្សពិពណ៌នាពីរបៀបពីរបីយ៉ាងដែលមនុស្សអាចមានប្រតិកម្ម ពេលពួកគេត្រូវធ្វើឲ្យអន់ចិត្ត ឬយាយីដោយនរណាម្នាក់ ។ សូមពន្យល់ថា ក្នុងវិវរណៈដែលបានកត់ត្រាក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨, ព្រះអម្ចាស់បានបង្រៀនពីគោលការណ៍ទាំងឡាយដែលអាចជួយយើងឲ្យដឹងពីរបៀបឆ្លើយតប ពេលយើងត្រូវបានយាយីដោយពាក្យសម្ដី ឬទង្វើរបស់មនុស្សដទៃ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលគោលការណ៍នេះពេញមួយមេរៀននៅថ្ងៃនេះ ។

> **ការប្រើប្រាស់ក្ដារខៀន**
>
> ប្រើក្ដារខៀន ដើម្បីព្រាងចំណុច ឬ គោលការណ៍សំខាន់ទាំងឡាយ ។ សូមប្រើក្ដារខៀនឲ្យមានប្រសិទ្ធភាពអំឡុងពេលបង្រៀន អាចរៀបចំសិស្សឲ្យរៀន និងអញ្ជើញឲ្យមានការចូលរួមប្រកបដោយអត្ថន័យ ជាពិសេសសម្រាប់អ្នកទាំងឡាយណាដែលរៀនដោយការមើលរូបភាព ។

សូមរំឭកសិស្សថា វិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ ត្រូវបានប្រទានឲ្យក្នុងឆ្នាំ ១៨៣៣ បន្ទាប់ពីការបៀតបៀននៃពួកបរិសុទ្ធក្នុងរដ្ឋ មិសសួរី បានក្លាយជាអំពើហឹង្សា ។ សូមសិស្សរំឭលពីភាពលម្អិតពីមេរៀនមុនអំពីការធ្វើបាបដែលពួកបរិសុទ្ធបានជួបប្រទះ ។

សូមឲ្យសិស្សចម្លងតារាងនៅលើក្ដារខៀន ចូលក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៣–២៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធអំពីការសងសឹក ។ សូមឲ្យពួកគេសរសេរការទូន្មានម្ដងហើយម្ដងទៀតរបស់ព្រះអម្ចាស់ដែលនៅក្នុង ខ ទាំងនេះ ។

- តើឃ្លាសូនគ្នាមួយណាដែលបង្រៀនអំពីការសងសឹក ? ( អ្នកអាចឲ្យយោបល់ថា សិស្សឲ្យគូសចំណាំឃ្លា « មិនដេរប្រមាថ » ហើយ « អត់ទ្រាំ » នៅក្នុង ខ ២៣–២៧ ) ។
- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ពួកបរិសុទ្ធ បើពួកគេអត់ទ្រាំនឹងការបៀតបៀន ហើយមិនសងសឹកវិញនោះ ?
- តើគោលការណ៍អ្វី ដែលយើងអាចរៀនមកពីព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង ខ ២៣–២៧ ? ( សូមជួយសិស្សឲ្យរកមើលគោលការណ៍ដូចខាងក្រោម ៖ **បើយើងអត់ទ្រាំនឹងការធ្វើបាប ដោយគ្មានការសងសឹក ព្រះអម្ចាស់នឹងប្រទានរង្វាន់ដល់យើង** ។ សូមឲ្យសិស្សសរសេរសេចក្ដីពិតនេះនៅក្នុងចំណងជើង *ក្រឹត្យវិន័យរបស់នៃការសងសឹករបស់ព្រះអម្ចាស់* ) ។

សូមពន្យល់ថា ពេលក្រុមមនុស្សកំណាចប្រមូលផ្ដុំនៅឃុំ ចាកសុន រដ្ឋ មិសសួរី នៅថ្ងៃសៅរ៍ ទី ២០ ខែ កក្កដា ឆ្នាំ ១៨៣៣ ពួកគេចង់ធ្វើលើសពីការបំផ្លាញទ្រព្យសម្បត្តិទៅទៀត ។ ពួកគេក៏ព្យាយាមធ្វើបាបសមាជិកសាសនាចក្រផងដែរ ។ សូមឲ្យសិស្សអានកំណត់ត្រាប្រវត្តិសាស្ត្រខាងក្រោមនេះឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រករបៀបដែលប៊ីស្សព អែតវើត ប៉ាទ្រិច និង ឆាលស៍ អាលែន ជាអ្នកប្រែចិត្តជឿអាយុ២៧ឆ្នាំមកពីរដ្ឋ ផែនសិលវេញ៉ា ឆ្លើយតបទៅនឹងការបៀតបៀននេះ ។



« មនុស្សកំណាចបានចាប់ប៊ីស្សព អែតវឺត ប៉ាទ្រិច និង ឆាលស៍ អេលែន ហើយបានអូសពួកគាត់កាត់ហ្វូងមនុស្សដែលកំពុងមានកំហឹងពុះកញ្ជ្រោល ហើយបានប្រមាថ ថែមទាំងបានធ្វើទុក្ខទោសដល់ពួកលោកនៅតាមផ្លូវទៅកាន់ទីលានសាធារណៈ ។ ជាជម្រើសទាំងពីរ ដែលបានផ្ដល់ដល់ពួកគាត់គឺពួកគាត់ត្រូវតែជ្រើសរើសបោះបង់ចោលសេចក្ដីជំនឿទៅលើ *ព្រះគម្ពីរមរមន* ឬ ជ្រើសរើសចាកចេញពីឃុំនោះ ។ ពួកគាត់ពុំបានជ្រើសរើសបដិសេធ *ព្រះគម្ពីរមរមន* ហើយក៏មិនបានជ្រើសរើសចាកចេញពីឃុំនោះដែរ ។ ដោយបានទទួលការអនុញ្ញាតឲ្យនិយាយ ប៊ីស្សព ប៉ាទ្រិច បានបន្លឺថា ពួកបរិសុទ្ធបានរងទុក្ខនឹងសេចក្ដីបៀតបៀននៅគ្រប់ជំនាន់ទាំងអស់ក្នុងប្រវត្តិសាស្ត្រពិភពលោក ហើយពួកគេមានឆន្ទៈដើម្បីរងទុក្ខដោយសារតែព្រះគ្រីស្ទ ដូចជាពួកបរិសុទ្ធនៅជំនាន់បុរាណបានធ្វើដែរ ដែលពួកគេពុំបានប្រព្រឹត្តអ្វីខុសទាល់តែសោះ ហើយបើសិនជាមនុស្សធ្វើទុក្ខទោសដល់ពួកគេ នោះនឹងបានធ្វើបាបដល់ជនឥតទោស ។ សំឡេងរបស់គាត់ត្រូវបានគ្របដណ្ដប់ដោយសំឡេងជ្រួលច្របល់នៃហ្វូងមនុស្ស មនុស្សជាច្រើនបានស្រែក ៖ ‹ ហៅព្រះឯងឲ្យរំដោះឯងទៅ . . . ! › បងប្អូនប្រុសទាំងពីរនាក់ គឺ ប៉ាទ្រិច និងអាលែន ត្រូវបានសម្រាតខោអាវចេញ ហើយត្រូវបានលាបដោយជ័រកៅស៊ូលាយជាមួយកំបោរស ឬអាស៊ីដដែលស៊ីសាច់ដទៃទៀត ហើយត្រូវបានចាក់រោមសត្វពីលើ ។ ពួកគេបានអត់ទ្រាំនឹងទង្វើឃោរឃៅនិងការធ្វើបាបនេះដោយការអត់ធ្មត់ និងភាពស្លូតបូត ដែលធ្វើឲ្យហ្វូងមនុស្សនៅស្ងៀម ហើយហាក់ដូចជាភ្ញាក់ផ្អើលនឹងអ្វីដែលពួកគេបានឃើញ ។ បងប្អូនប្រុសទាំងពីរត្រូវបានដោះលែងដោយស្ងៀមស្ងាត់ » ( B. H. Roberts, *A Comprehensive History of the Church*, ១:៣៣៣; សូមមើលផងដែរ *Church History in the Fulness of Times Student Manual*, 2nd ed. [Church Educational System manual], ឆ្នាំ ២០០៣,ទំព័រ ១៣៣ )

- តើអ្វីដែលធ្វើឲ្យអ្នកចាប់អារម្មណ៍អំពី ឆាលស៍ អាលែន និងប៊ីស្សព ប៉ាទ្រិច ឆ្លើយតបនឹងការបៀតបៀន ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៨–៣២ ដោយពន្យល់ថា ព្រះអម្ចាស់បានទូន្មានពួកបរិសុទ្ធថា បើសត្រូវបានធ្វើទុក្ខទោសដល់ពួកគេបីដងដោយគ្មានការសងសឹកពីព្រះ ពួកគេគួរព្រមានសត្រូវនៅក្នុងព្រះនាមរបស់ព្រះអម្ចាស់កុំឲ្យធ្វើទុក្ខទោសពួកគេម្ដងទៀត ។ បើសត្រូវបន្តធ្វើបាបពួកគេបន្ទាប់ពីការព្រមាននេះ ពួកបរិសុទ្ធនឹងរាប់ជាសុចរិតហើយ « [ សង ] អ្នកនោះតាមការទាំងឡាយ ដែលគាត់ប្រព្រឹត្ត » ។ ប៉ុន្តែ ពួកបរិសុទ្ធក៏ត្រូវបានប្រាប់ផងដែរថា បើពួកគេលើកលែងឲ្យសត្រូវរបស់ពួកគេ ទោះជាចង់សងសឹកក៏ដោយ នោះពួកគេនឹងបានរង្វាន់វិញសម្រាប់សេចក្ដីសុចរិតរបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣២–៣៨

*ព្រះអម្ចាស់ពន្យល់អំពីពេលដែលសង្គ្រាមត្រូវបានរាប់ថាសុចរិត*

សូមសូមឲ្យសិស្សពិចារណាថាពួកគេដឹងពីអ្វី ដែលព្រះអម្ចាស់បានមានបន្ទូលពីសង្គ្រាមឬអត់ ។ អ្នកក៏អាចសួរសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា ក្រឹត្យវិន័យនៃសង្គ្រាមរបស់ព្រះអម្ចាស់ជាអ្វី ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣២–៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលព្រះអម្ចាស់បានប្រាប់ព្យាការីសម័យបុរាណអំពីសង្គ្រាម ។

- ស្របតាម ខ ៣៣ តើក្រឹត្យវិន័យអ្វីដែលត្រូវបានប្រទានឲ្យព្យាការីសម័យបុរាណ ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀនក្រោមចំណងជើង *ក្រឹត្យវិន័យនៃសង្គ្រាមរបស់ព្រះអម្ចាស់* ។ សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានប្រទានក្រឹត្យវិន័យជាពិសេសដល់ប្រជាជន ដែលរស់នៅក្នុងសម័យកាលខុសគ្នា និងក្នុងវប្បធម៌ខុសគ្នា ។ ទោះជាគោលការណ៍នៃក្រឹត្យវិន័យនេះពិតក្ដី សព្វថ្ងៃនេះយើងក៏ស្ថិតនៅក្រោមច្បាប់ប្រទេសជាតិដែលយើងរស់នៅដែរ ) ។

- តើព្យាការីសម័យបុរាណនឹងធ្វើអ្វីខ្លះ បើមាននរណាម្នាក់ប្រកាសសង្គ្រាមប្រឆាំងនឹងពួកគេនោះ ? ( សូមបន្ថែមចម្លើយនៅលើក្ដារខៀន ក្រោមចំណងជើង *ក្រឹត្យវិន័យនៃសង្គ្រាមរបស់ព្រះអម្ចាស់* ) ។

សូមសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៥–៣៨ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់មានបន្ទូលប្រាប់ព្យាការីសម័យបុរាណឲ្យធ្វើ បើការផ្ដល់ជូននៃសេចក្ដីសុខសាន្តរបស់ពួកគេមិនត្រូវបានទទួលស្គាល់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរទាំងនេះ អំពីក្រឹត្យវិន័យនៃសង្គ្រាមរបស់ព្រះអម្ចាស់ ? ( សិស្សអាចស្នើនូវគោលការណ៍ខុស ៗគ្នា ប៉ុន្តែសូមប្រាកដថាត្រូវតែគូសបញ្ជាក់នូវចំណុចដូចខាងក្រោម ៖ **សង្គ្រាមអាចត្រូវបានរាប់ថាសុចរិតនៅក្នុងកាលៈទេសៈដែលពិពណ៌នាដោយព្រះអម្ចាស់** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ក្រោមចំណងជើង *ក្រឹត្យវិន័យនៃសង្គ្រាមរបស់ព្រះអម្ចាស់* ) ។

សូមពន្យល់ថា យើងភាគច្រើននឹងមិនចាំបាច់ត្រូវសម្រេចថាត្រូវទៅច្បាំងនឹងជាតិសាសន៍ដទៃឬអត់ទេ ។ ប៉ុន្តែ ការបង្រៀនទាំងនេះអាចជួយយើងឲ្យដឹងពីអ្វីដែលត្រូវធ្វើ នៅក្នុងទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើង—ឧទាហរណ៍ នៅពេលយើងមិនចុះសម្រុងជាមួយអ្នកដទៃ ។

- ផ្អែកទៅលើអ្វីដែលអ្នកបានរៀនអំពីដំបូន្មានរបស់ព្រះអម្ចាស់អំពីសង្គ្រាម តើយើងគួរធ្វើអ្វីនៅពេលយើងមិនចុះសម្រុងជាមួយអ្នកដទៃនោះ ? ( សូមជួយសិស្សរកមើលសេចក្ដីពិតដូចខាងក្រោម ៖ **យើងគួរស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះការមិនចុះសម្រុងរបស់យើង** ) ។

- តើពរជ័យអ្វីខ្លះ ដែលអាចកើតឡើងពីការស្វែងរកដំណោះស្រាយដោយសន្តិវិធីនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៩–៤៨

*ព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធពីរបៀបដែលពួកគេគួរឆ្លើយតបនឹងសត្រូវរបស់ពួកគេ ។*

សូមឲ្យសិស្សអាន ដំណើររឿងខាងក្រោមឲ្យឮៗ ៖



« នៅក្នុងប្រទេសហូឡង់ ក្នុងអំឡុងសង្គ្រាមលោកលើកទី II ក្រុមគ្រួសាររបស់ ខាសភើ ធេន ប៊ូម បានប្រើផ្ទះរបស់ពួកគេជាកន្លែងលាក់ខ្លួនសម្រាប់អ្នកទាំងឡាយដែលគេចខ្លួនពីពួកណាស៊ី ។ នេះជារបៀបដែលពួកគេរស់តាមជំនឿជាគ្រីស្ទបរិស័ទ ។ សមាជិកបួននាក់នៃក្រុមគ្រួសារនោះ បានបាត់បង់ជីវិតដោយសារតែការផ្ដល់ជម្រកនេះ ។ ខូរី ធែន ប៊ូម និង បងស្រីរបស់នាង បែស៊ី បានជាប់ក្នុងគុករ៉ាវែនស្ប្រុខ យ៉ាងវេទនា អស់រយៈពេលជាច្រើនខែ ។ បែស៊ី បានបាត់បង់ជីវិតនៅក្នុងគុកនោះ—ហើយ ខូរី នៅរស់រានមានជីវិត ។

« នៅក្នុងគុក រ៉ាវែនស្ប្រុខ នោះ ខូរី និង បែស៊ី បានស្វែងយល់ថា ព្រះជួយពួកយើងឲ្យចេះអត់ទោស ។ ក្រោយពីសង្គ្រាមបានបញ្ចប់ទៅ ខូរី បានសម្រេចចិត្តចែកចាយសារលិខិតមួយនេះ ។ នៅក្នុងឱកាសមួយ នាងបានថ្លែងទៅកាន់មនុស្សមួយក្រុមនៅប្រទេស អាល្លឺម៉ង់ ដែលរងទុក្ខដោយសារការបំផ្លិចបំផ្លាញនៃសង្គ្រាម ។ សារលិខិតរបស់នាងមានចំណងជើងថា ‹ ព្រះទ្រង់អត់ទោស › ។ នៅពេលនោះហើយ ដែលភាពស្មោះត្រង់របស់ ខូរី ធែន ប៊ូម បាននាំឲ្យមានពរជ័យ ។

« មានបុរសម្នាក់បានដើរសំដៅមករកនាង ។ នាងបានស្គាល់បុរសនោះថាជា ឆ្មាំយាមគុកដ៏ឃោរឃៅបំផុត ។ គាត់បាននិយាយថា ‹ បងស្រីបានថ្លែងអំពីគុក រ៉ាវែនស្ប្រុខ នៅក្នុងសុន្ទរកថារបស់បងស្រី › ។ ‹ ខ្ញុំគឺជាឆ្មាំយាមនៅទីនោះ ។. . . ប៉ុន្តែបន្ទាប់ពីនោះមក . . . ខ្ញុំបានក្លាយទៅជាគ្រីស្ទបរិស័ទ ។ គាត់រៀបរាប់ថា គាត់បានស្វែងរកការអត់ទោសពីព្រះចំពោះទង្វើដ៏ឃោរឃៅ ដែលគាត់បានប្រព្រឹត្ត ។ គាត់បានហុចដៃរបស់គាត់ ហើយស្នើដូច្នេះថា ‹ តើបងស្រីនឹងអត់ទោសឲ្យខ្ញុំដែរឬទេ › ?

« ខូរី ធែន ប៊ូម បានបន្លឺ ៖

« ‹ វាគ្រាន់តែជាវេលាតែមួយភ្លែតប៉ុណ្ណោះ ដែលគាត់បានឈរនៅទីនោះ—ហើយហុចដៃរបស់គាត់មក—ប៉ុន្តែសម្រាប់ខ្ញុំវិញ វាហាក់ដូចជា ខ្ញុំបានពុះពារនៅក្នុងកិច្ចការដ៏លំបាកបំផុត ដែលខ្ញុំធ្លាប់បានធ្វើ ។

« ‹. . . សារលិខិតដែលថា ព្រះទ្រង់អត់ទោសមាន. . . លក្ខខណ្ឌមួយ ៖ គឺយើងត្រូវអត់ទោសដល់ មនុស្សដែលបានព្យាបាទយើង ។. . .

“. . .‹ ជួយកូនផង! › ខ្ញុំបានអធិស្ឋានដោយស្ងាត់ៗ ។ ‹ ខ្ញុំអាចលើកដៃឡើង ។ ខ្ញុំអាចធ្វើបានតែប៉ុណ្ណឹង ។ សូមផ្ដល់អារម្មណ៍ឲ្យខ្ញុំ › ។

« ‹ . . . ខ្ញុំបានដាក់ដៃរបស់ខ្ញុំលើដៃគាត់ដែលលូកមករកខ្ញុំដោយសោះអង្គើយ ។ នៅពេលខ្ញុំបានធ្វើដូចនោះ រឿងមួយដ៏អស្ចារ្យបានកើតឡើង ។ អារម្មណ៍មួយបានចាប់ផ្ដើមចេញពីស្មារបស់ខ្ញុំ រត់ទៅតាមដៃ ហើយចូលទៅក្នុងប្រអប់ដៃទាំងពីររបស់យើងដែលកំពុងចាប់នោះ ។ ហើយការព្យាបាលដ៏កក់ក្ដៅនេះ ហាក់ដូចជានៅពេញខ្លួនខ្ញុំ ដែលធ្វើឲ្យខ្ញុំយំ ។

« ‹ ខ្ញុំអភ័យទោសឲ្យបងប្រុស ! › ខ្ញុំបានយំ ។ ‹ ដោយអស់ពីដួងចិត្តខ្ញុំ ›

« យើងបានចាប់ដៃគ្នាយ៉ាងយូរ អតីតឆ្មាំគុក និងអតីតអ្នកទោស ។ ខ្ញុំមិនធ្លាប់ដឹងពីក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះដូចដែលខ្ញុំបានដឹងនៅពេលនោះទេ › ។ [ ខូរី ធែន ប៊ូម *Tramp for the Lord* ( ឆ្នាំ ១៩៧៤ ) ទំព័រ ៥៤–៥៥ ] » ។ ( ឃើត ប៊ី ម៉ាក់ម៉ូលីន, Our Path of Duty » *Ensign* ឬ *លីអាហូណា,* ខែ ឧសភា ឆ្នាំ ២០១០,ទំព័រ ១៣ ) ។

បន្ទាប់ពីសិស្សបានអានរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើរឿងនេះ ធ្វើឲ្យអ្នកចាប់អារម្មណ៍ អ្វីខ្លះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៩–៤០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ឲ្យរកមើលក្រឹត្យវិន័យនៃការអភ័យទោសរបស់ព្រះអម្ចាស់ ។

- ស្របតាមខគម្ពីរទាំងនេះ តើយើងគួរធ្វើអ្វីនៅពេលនរណាម្នាក់សូមការអភ័យទោសពីយើង ?
- ស្របតាម ខ ៤០ តើយើងត្រូវអភ័យទោសឲ្យនរណាម្នាក់ដែលប្រែចិត្ត ហើយស្វែងរកការអភ័យទោសប៉ុន្មានដង ? ( « *រហូតដល់ចិតសិបគុណឲ្យប្រាំពីរ* » មានន័យថា យើងគួរអភ័យទោសឲ្យអ្នកដទៃច្រើនដងជាងចំនួនដែលគេប្រែចិត្ត ហើយស្វែងរកការអភ័យទោសពីយើង បន្ទាប់ពីធ្វើឲ្យយើងអាក់អន់ចិត្ត ឬឈឺចាប់រួចមក ។ ទោះជាយើងត្រូវបានបញ្ជាឲ្យអភ័យទោសក្ដី វាក៏មិនមែនមានន័យថាយើងគួរអនុញ្ញាតឲ្យអ្នកដទៃបន្តធ្វើបាបយើងទៀតដែរ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៤១–៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីពិតដែលព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធទាក់ទងនឹងសត្រូវរបស់ពួកគេដែលមិនព្រមប្រែចិត្ត ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើហេតុអ្វីបានជាសេចក្ដីពិតទាំងនេះមានសារៈសំខាន់ សម្រាប់ពួកបរិសុទ្ធដែលរស់នៅរដ្ឋ មិសសួរី ត្រូវយល់ ?
- តើអ្នកនឹងសង្ខេបក្រឹត្យវិន័យនៃការអភ័យទោសរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ? ( សូមជួយសិស្សឲ្យប្រាប់បទបញ្ញត្តិដូចខាងក្រោម ៖ **ព្រះអម្ចាស់បញ្ជាយើងឲ្យអភ័យទោសឲ្យសត្រូវរបស់យើង ។** សូមសរសេរព្រះបញ្ញត្តិនេះនៅលើក្ដារខៀនក្រោមចំណងជើង *ក្រឹត្យវិន័យនៃការអភ័យទោសរបស់ព្រះអម្ចាស់* ) ។
- តើហេតុអ្វីអ្នកគិតថា យើងត្រូវបានបញ្ជាឲ្យអភ័យទោសឲ្យអ្នកដទៃ ទោះបីជាពួកគេមិនសូមការអភ័យទោសក៏ដោយនោះ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៤៤–៤៨ ដោយពន្យល់ថា ព្រះអម្ចាស់បានសន្យាថា បើសត្រូវរបស់ពួកគេបរិសុទ្ធប្រែចិត្ត ពួកគេនឹងគេចរួចពីការសងសឹករបស់ទ្រង់ ។ ( *កំណត់ចំណាំ ៖* នៅក្នុង ខ ៤៤ ឃ្លា « អ្នកមិនត្រូវអត់ទោស » មានន័យថាជនល្មើសគួរតែទទួលខុសត្រូវសម្រាប់ទង្វើរបស់ខ្លួន ហើយពួកបរិសុទ្ធពុំគួរបន្តមានអារម្មណ៍ស្អប់ខ្ពើមទៀតឡើយ ) ។

សូមបញ្ចប់ដោយលើកទឹកចិត្តសិស្សឲ្យធ្វើតាមក្រឹត្យវិន័យនៃការអភ័យទោសរបស់ព្រះអម្ចាស់ ដោយព្យាយាមអភ័យទោសដល់មនុស្សរាល់គ្នាដែលបានឃាយីពួកគេ ឬអ្នកទាំងឡាយដែលពួកគេខ្វល់ខ្វាយ ។

មេរៀនទី ១០៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០

## បុព្វកថា

យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៨៣២ ។ នៅក្នុងវិវរណៈនេះព្រះអម្ចាស់បានហៅ យ៉ូហាន មើដក់ ឲ្យបន្តបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០ នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៨៣៣ ពេលលោក និង ស៊ីឌនី រិកដុន នៅទីក្រុង នូវ យ៉ោក បម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ នៅក្នុងវិវរណៈនេះព្រះអម្ចាស់បានធានាដល់ពួកគេថា ក្រុមគ្រួសាររបស់ពួកគេនៅរដ្ឋ អូហៃអូ នឹងសុខសប្បាយ ។ ព្រះអម្ចាស់ក៏បានលួងលោមពួកគេអំពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលកំពុងរងទុក្ខពីការបៀតបៀនផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

> *សូមសម្រេចចិត្តពីអ្វីដែលត្រូវបង្រៀន*
>
> មេរៀនជាច្រើននៅក្នុងសៀវភៅសិក្សានេះ មាននូវឯកសារច្រើនជាងអ្នកអាចបង្រៀនចប់តែមួយពេលក្នុងថ្នាក់ ។ បន្ទាប់ពីបានសិក្សាព្រះគម្ពីរ និងកម្មវិធីសិក្សា សូមពិចារណាប្រកបដោយការអធិស្ឋានថា គោលលទ្ធិ គោលការណ៍ និង គំនិតដើម្បីបង្រៀនណាមួយដែលនឹងជាប្រយោជន៍ល្អបំផុតសម្រាប់សិស្សរបស់អ្នក ។ នៅពេលអ្នកសម្រេចថាត្រូវបង្រៀនអ្វី សូមបន្តស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩

*ព្រះអម្ចាស់ បានហៅ យ៉ូហាន មើដក់ ឲ្យប្រកាសដំណឹងល្អ*

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា មានមិត្តម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ សួរពួកគេថា ហេតុអ្វីបានជាមាននរណាម្នាក់សុខចិត្តលះបង់រយៈពេល ២ ឆ្នាំក្នុងជីវិតរបស់ពួកគេ ដើម្បីបម្រើបេសកកម្មយ៉ាងដូច្នេះ ។

- តើអ្នកនឹងឆ្លើយសំណួរនេះយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សអានព័ត៌មានខាងក្រោម អំពីបុរសដែលមាន ឈ្មោះ យ៉ូហាន មើដក់ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យស្ដាប់មើលការលះបង់ដែលបងប្រុស មើដក់ បានធ្វើដើម្បីបម្រើព្រះអម្ចាស់ ។

យ៉ូហាន មើដក់ ពិនិត្យសង្កេតមើលព្រះវិហារជាច្រើន ហើយបានសន្និដ្ឋានថា សាសនាទាំងអស់បានវង្វេងផ្លូវ ។ ប៉ុន្ដែនៅចុងឆ្នាំ ១៨៣០ លោកបានអានព្រះគម្ពីរមរមន ហើយបានមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់ពីសេចក្ដីពិតរបស់វា ។ លោកបានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៨៣០ ។ មិនយូរប៉ុន្មានក្រោយមក លោកបានបម្រើបេសកកម្ម ហើយបានជ្រមុជទឹកឲ្យមនុស្សប្រហែល ៧០ នាក់ក្នុងរយៈពេលបួនខែ ក្នុងទីក្រុង អូរ៉េង រដ្ឋ អូហៃអូ និងទីក្រុង វ៉ារិនស៊ីល រដ្ឋ អូហៃអូ ។

នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៨៣១ មិនយូរប៉ុន្មានបន្ទាប់បងប្រុស មើដក់ បានត្រឡប់មកពីបេសកកម្មរបស់លោកវិញ ភរិយារបស់លោក គឺ ជូលា បានស្លាប់ បន្ទាប់ពីផ្ដល់កំណើតឲ្យកូនភ្លោះ ។ នៅខែ មិថុនា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានហៅលោកឲ្យទៅរដ្ឋ មិសសួរី ហើយប្រកាសដំណឹងល្អនៅតាមផ្លូវ ( សូមមើល គ. និង ស. ៥២:៨–៩ ) ។ មុនពេលលោកអាចទៅបានលោកត្រូវធានាថាកូនទាំងប្រាំនាក់របស់លោក ដែលមានអាយុក្រោមប្រាំពីរឆ្នាំ ត្រូវបានមើលថែទាំ ។ លោកបានរៀបចំមនុស្សពីរបីនាក់ឲ្យថែទាំកូន ៗច្បងរបស់លោក ហើយយ៉ូសែប នឹងអិមម៉ា ស្ម៊ីធ ទទួលចិញ្ចឹមកូនភ្លោះរបស់លោក ។ ពេញឆ្នាំ ១៨៣១ រហូតដល់ពាក់កណ្ដាលឆ្នាំ ១៨៣២ យ៉ូហាន មើដក់ បានបង្រៀននៅរដ្ឋ ព្រំប្រទល់រដ្ឋ មីឈីហ្កែន រដ្ឋ អ៊ិនឌីអាណា រដ្ឋ មិសសួរី និងរដ្ឋ អូហៃអូ ។ នៅពេលលោកត្រឡប់ទៅទីក្រុងហៃរ៉ុម រដ្ឋ អូហៃអូ វិញនៅខែមិថុនា ឆ្នាំ ១៨៣២ លោកបានធ្លាក់ខ្លួនឈឺជាទម្ងន់ដោយសារជម្ងឺរាំរៃ ប្រចាំកាយ ។ លោកបានដឹងថា កូនភ្លោះរបស់លោកបានឈឺ ហើយបានស្លាប់ដោយសារត្រូវខ្យល់ត្រជាក់នៅពេលមានការវាយប្រហារមកលើ យ៉ូសែប ស្ម៊ីធ ។

- តើចំណុចណានៃរឿងរបស់យ៉ូហាន មើដក់ ដែលលេចធ្លោចំពោះអ្នក ?

សូមពន្យល់ថា ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៩ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៨៣២ ប្រហែលពីរខែបន្ទាប់ពីបងប្រុសមើដក់ បានត្រឡប់មកផ្ទះពីបេសកកម្មទីពីររបស់លោកវិញ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩:១ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បានហៅបងប្រុស មើដក់ ឲ្យធ្វើ ។

- តើព្រះអម្ចាស់បានហៅឲ្យ យ៉ូហាន មើដក់ ឲ្យធ្វើអ្វីខ្លះ ?
- តើការហៅបម្រើបេសកកម្មនេះ អាចសាកល្បងសេចក្ដីជំនឿ និងការគោរពរបស់បងប្រុស មើដក់ យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩:២–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់បានសន្យានឹង យ៉ូហាន មើដក់ ។

- តើគោលលទ្ធិ និងគោលការណ៍អ្វីដែលយើងអាចរៀនពី ខ ២–៣ ? ( ចម្លើយរបស់សិស្សអាចរួមបញ្ចូលចំណុចដូចខាងក្រោម ៖ **យើងតំណាងឲ្យព្រះអម្ចាស់ ពេលយើងបម្រើបេសកកម្ម ។ ពេលយើងទទួល និងធ្វើតាមអ្នកបម្រើរបស់ព្រះអម្ចាស់ នោះយើងកំពុងទទួល និងធ្វើតាមទ្រង់** ) ។
- តើអ្នកបានទទួលពរជ័យយ៉ាងណាដែរ ពេលដែលអ្នកធ្វើតាមអ្នកបម្រើរបស់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩:៤ –៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា នឹងកើតឡើងចំពោះអ្នកដែលបដិសេធសារលិខិតដែល យ៉ូហាន មើដក់ នឹងបង្រៀនពួកគេ ។

- យោងតាម ខ៤ តើអ្វីជាលទ្ធផលនៃការបដិសេធសារលិខិតដំណឹងល្អ ដែលបានបង្រៀនដោយអ្នកបម្រើរបស់ព្រះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩:៦–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលភស្តុតាងដែលព្រះអម្ចាស់ បានដឹងជាមុនអំពី តម្រូវការរបស់ យ៉ូហាន មើដក់ និងការលះបង់ដែលគាត់បានធ្វើ ។

- តើព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់ យ៉ូហាន មើដក់ បានបង្ហាញយើងអ្វីខ្លះ ?

សូមពន្យល់ថា បងប្រុស មើដក់ បានធ្វើតាមដំបូន្មានរបស់ព្រះអម្ចាស់ ។ លោកបានធ្វើការរៀបចំសម្រាប់កូនច្បងបីនាក់របស់លោក ឲ្យរស់នៅជាមួយក្រុមគ្រួសារខុសៗគ្នាក្នុងរដ្ឋ មិសសួរី ហើយលោកបានចាកចេញនៅ ខែ កញ្ញា ឆ្នាំ ១៨៣២ ដើម្បីប្រកាសដំណឹងល្អ ។ លោកបានបម្រើពីរបីបេសកកម្មទៀត ហើយបន្ទាប់មកលោកបានមកជួបកូនកូនៗច្បងរបស់លោកនៅរដ្ឋមិសសួរី ។ លោកបានបម្រើព្រះអម្ចាស់ដោយស្មោះត្រង់ពេញមួយជីវិតរបស់លោក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១–១២

*ព្រះអម្ចាស់បានប្រទានដល់ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន នូវការលួងលោមចិត្ត និងការបង្រៀន*

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើការព្រួយបារម្ភអ្វីខ្លះ ដែលអ្នកផ្សព្វផ្សាយអាចមាន នៅពេលពួកគេចាប់ផ្ដើមបេសកកម្មរបស់ពួកគេ ?* សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាស្មៀន ហើយសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ។ ( ចម្លើយរបស់សិស្ស អាចរួមបញ្ចូលសំណួរដូចខាងក្រោម ៖ តើខ្ញុំអាចរកមនុស្សដើម្បីបង្រៀនបានដូចម្ដេច ? តើខ្ញុំនឹងដឹងពីអ្វីដែលត្រូវនិយាយយ៉ាងដូចម្ដេច ? តើខ្ញុំនឹងចុះសម្រុងជាមួយដៃគូខ្ញុំឬក៏អត់ ? តើគ្រួសាររបស់ខ្ញុំនឹងសុខសប្បាយទេ ពេលដែលខ្ញុំទៅបាត់ ?

សូមពន្យល់ថា នៅខែមេសា ឆ្នាំ ១៨៣៣ បុរសម្នាក់ឈ្មោះ ហ្វ្រីមែន នីកឃើសុន បានចូលរួមក្នុងសាសនាចក្រនៅ នូវ យ៉ោក ហើយបានមកទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ ពេលដែលហ្វ្រីមែន បានជួប យ៉ូសែប ស៊្មីធ គាត់បានសូមឲ្យព្យាការីទៅលេងគ្រួសារ នីកឃើសុន នៅ នូវ យ៉ោក និងនៅកាណាដា ។ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន បានយល់ព្រមទៅនឹងសំណើរបស់គាត់ ហើយពួកគេបានចាកចេញពី ខឺតឡង់ ជាមួយគាត់នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៨៣៣ ។ ពួកគេបានប្រកាសប្រាប់ដំណឹងល្អនៅតាមផ្លូវ ។ បន្ទាប់ពីពួកគេមកដល់ផ្ទះរបស់ នីកឃើសុន នៅ ផើរីស្បើគ នូវ យ៉ោក យ៉ូសែប បានទទួលវិវរណៈ ដែលបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០ ។

សូមអញ្ជើញសិស្សឲ្យអានសេចក្ដីណែនាំអំពីកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០ ដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីដែលធ្វើឲ្យ យ៉ូសែប ស៊្មីធ និងស៊ីឌនី រិកដុន មានការព្រួយបារម្ភពីការមកដល់ នូវ យ៉ោក ។ បន្ទាប់ពីសិស្សបានរាយការណ៍ពីអ្វីដែលពួកគេរកឃើញហើយ សូមពន្យល់ថា យ៉ូសែប ស៊្មីធ បានសរសេរពីការព្រួយបារម្ភរបស់លោកនៅក្នុងសៀវភៅកំណត់ហេតុលោក ថា ៖ « ខ្ញុំដឹងយ៉ាងច្បាស់ក្នុងគំនិតថា ព្រះអម្ចាស់គង់នៅជាមួយយើង ប៉ុន្តែមានការសោកសៅរស់ជាខ្លាំងអំពីក្រុមគ្រួសាររបស់ខ្ញុំ » ( *Journals, Volume 1: 1832–1839,* vol. 1 of the Journals series of *The Joseph Smith Papers* [ ឆ្នាំ ២០០៨ ],ទំព័រ ១៤ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះទៅនឹងការព្រួយបារម្ភរបស់ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ។

- តើឃ្លានៅក្នុងខគម្ពីរទាំងនេះ អាចលុបចេញនូវការព្រួយបារម្ភរបស់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ដែរឬទេ ? តើខគម្ពីរទាំងនេះ អាចជួយអ្នកផ្សព្វផ្សាយសាសនាសព្វថ្ងៃនេះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០: ៣–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអម្ចាស់បានសន្យាដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ។

- តើអ្នកគិតថា វាមានន័យដូចម្ដេចក្នុងការមាន « ទ្វារដ៏សក្ដិសិទ្ធ » បានបើកសម្រាប់ការចែកចាយដំណឹងល្អនោះ ?

- តើមានវិធីមួយចំនួនណាខ្លះ ដែលព្រះអម្ចាស់ « បើកទ្វារ »សម្រាប់ឲ្យយើងធ្វើកិច្ចការផ្សព្វផ្សាយសាសនា ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៥–៨ ដោយស្ងាត់ស្ងៀម សម្រាប់ការសន្យាបន្ថែមពីព្រះអម្ចាស់ ។ បន្ទាប់ពីសិស្សបានរាយការណ៍ពីអ្វី ដែលពួកគេបានរកឃើញហើយ សូមសរសេរនៅលើក្ដារខៀននូវ *បើ* ________________________________________ *នោះ* ________________________________________.

- តើយើងអាចរៀនអ្វីខ្លះមកពី ខ ៥– ៦ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់ពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងនឹងបន្លឺសំឡេងយើង ដើម្បីចែកចាយដំណឹងល្អ នោះព្រះអម្ចាស់នឹងជួយយើងឲ្យដឹងពីអ្វីដែលត្រូវនិយាយ** ) ។

- យោងតាម ខ ៧ តើព្រះអម្ចាស់មានព្រះទ័យចង់ឲ្យអ្នកផ្សព្វផ្សាយសាសនាផ្សាយដំណឹងល្អយ៉ាងដូចម្ដេច ?

- យោងតាម ខ ៨, តើព្រះអម្ចាស់បានសន្យាអ្វី បើយើងផ្សាយដំណឹងល្អដោយ « នូវចិត្តម៉ឹងម៉ាត់ » និង « ដោយនូវវិញ្ញាណស្លូតបូត » ? ( សិស្សគួរបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងចែកចាយដំណឹងល្អជាមួយអ្នកដទៃដោយនូវចិត្តម៉ឹងម៉ាត់ និងដោយនូវវិញ្ញាណស្លូតបូត នោះព្រះវិញ្ញាណបរិសុទ្ធនឹងថ្លែងជាសាក្សីនៃសារលិខិតរបស់យើង** ) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីពេលមួយ ដែលព្រះអម្ចាស់បានជួយពួកគេឲ្យដឹងពីអ្វីដែលត្រូវនិយាយ ពេលពួកគេចែកចាយដំណឹងល្អ ។ សូមអញ្ជើញពួកគេគិតអំពីពេលដែលពួកគេបានមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធថ្លែងជាសាក្សីនៃអ្វីដែលពួកគេបាននិយាយផងដែរ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៩–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការណែនាំដែលព្រះអម្ចាស់បានប្រទានដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ។

- យោងតាម ខ ១២ តើហេតុអ្វីបានជា យ៉ូសែប ស្ម៊ីធ និងស៊ីឌនី រិកដុន អាច « ឲ្យចិត្ត[ពួកគេ]បានសប្បាយរីករាយ » ?

- តើការសន្យានៅក្នុង ខ ១២ អាចមានន័យយ៉ាងណាចំពោះអ្នក បើអ្នកកំពុងបម្រើបេសកកម្មនោះ ?

សូមពន្យល់ថា ការខិតខំប្រឹងប្រែងផ្សព្វផ្សាយសាសនារបស់ យ៉ូសែប ស្ម៊ីធ និងស៊ីឌនី រិកដុន មានឥទ្ធិពលដ៏យូរអង្វែងនៅក្នុងសាសនាចក្រ ។ ឧទាហរណ៍ យ៉ូសែប ស្ម៊ីធ និងស៊ីឌនី រិកដុន បានផ្សាយដល់ក្រុមដ៏ធំមួយនៅផ្ទះរបស់ នីកឃើសុន និងក្រុមផ្សេងទៀតនៅកាណាដា ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានជ្រមុជទឹកឲ្យមនុស្សជិត ២០នាក់ រួមទាំង ម៉ូសេ នីកឃើសុន ហើយបានរៀបចំសាខានៃសាសនាចក្រមួយ ។ នៅឆ្នាំ ១៨៣៦ ប៉ាលី ភី ប្រាត្ត បានទៅសាខានោះ នៅពេលលោកបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅកាណាដា ។ ម៉ូសេ នីកឃើសុន បានណែនាំអែលឌើ ប្រាត្ត ឲ្យស្គាល់ យ៉ូហាន ថេល័រ ។ អែលឌើរ ប្រាត្ត បានជ្រមុជទឹកឲ្យ យ៉ូហាន ថេល័រ ដែលក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏ជោគជ័យ ហើយក្រោយមកក្លាយជាប្រធាននៃសាសនាចក្រ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១៣–១៧

*ព្រះអម្ចាស់បានលួងលោមចិត្ត យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ទាក់ទងនឹងការសោកល្បងរបស់ពួកបរិសុទ្ធនៅរដ្ឋមិសសួរី ។*

សូមពន្យល់ថា ប្រហែលពីរខែមុនពេល យ៉ូសែប ស្ម៊ីធ បានចេញទៅបម្រើបេសកកម្ម អូលីវើរ ខៅឌើរី បាននាំពាក្យមកពីរដ្ឋ មិសសួរី ថាសត្រូវរបស់សាសនាចក្របានប្រើអំពើហិង្សាប្រឆាំងនឹងពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ យ៉ូសែប ស្ម៊ីធ បានបញ្ជូនអូរសុន ហៃឌ និងយ៉ូហាន ហ្គូដ ឲ្យនាំការប្រឹក្សាពីលោកទៅកាន់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ ដំណើរនេះនឹងអាចមហន្តរាយព្រោះពួកគេធ្វើដំណើរកាត់តាមតំបន់ពួកមនុស្សកំណាចដែលប្រឆាំងពួកមរមន ។ ព្យាការីបានបារម្ភពីបងប្រុស ហៃឌ និងបងប្រុស ហ្គូដ និងពួកបរិសុទ្ធទាំងអស់ដែលត្រូវបានបៀតបៀននៅរដ្ឋ មិសសួរី ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១៣–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលប្រាប់ យ៉ូសែប ស្ម៊ីធ ។ សូមឲ្យសិស្សសង្ខេបពីអ្វីដែលពួកគេរកឃើញ ។

- តើការសន្យាអ្វី ដែលអ្នកឃើញនៅក្នុង ខ ១៥–១៧ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **គ្រប់ការណ៍ទាំងអស់នឹងបានផ្សំគ្នាសម្រាប់សេចក្ដីល្អ បើយើងដើរដោយទៀតត្រង់នៅចំពោះព្រះអម្ចាស់** ) ។
- តើអ្នកគិតថា « ដើរដោយទៀងត្រង់ » នៅចំពោះព្រះអម្ចាស់ មានន័យយ៉ាងដូចម្ដេច ?
- តើការសន្យានៅក្នុង ខ ១៥–១៧ អាចជួយអ្នកក្នុងពេលលំបាក យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយឧទាហរណ៍អំពីរបៀបដែលពួកគេបានឃើញការសន្យានេះបានសម្រេច ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកពីសេចក្ដីពិតនេះផងដែរ ។ សូមអញ្ជើញសិស្សឲ្យគិតពីរឿងជាក់លាក់មួយ ដែលពួកគេអាចធ្វើដើម្បី « ដើរដោយទៀងត្រង់ » នៅចំពោះព្រះអម្ចាស់ ។

មេរៀនទី ១០៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦

## បុព្វកថា

នៅថ្ងៃទី ១៦ និង ១៧ ខែ ធ្នូ ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយអំពីការរងទុក្ខរបស់ពួកបរិសុទ្ធបានជួបប្រទះនៅរដ្ឋ មិសសួរី ។ វិវរណៈនេះ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ នឹងត្រូវបានបំបែកជាបីមេរៀន ។ មេរៀនដំបូងនេះ រួមមានការពន្យល់របស់ព្រះអម្ចាស់ពីមូលហេតុដែលទ្រង់ទុកឲ្យពួកបរិសុទ្ធរងទុក្ខ ។ វាក៏បញ្ចូលព្រះបន្ទូលនៃការទូន្មាន និងការលួងលោមចិត្តរបស់ទ្រង់ដល់ពួកបរិសុទ្ធដែលកំពុងរងទុក្ខផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–៨

*ព្រះអម្ចាស់បានពន្យល់ពីមូលហេតុដែលទ្រង់ទុកឲ្យពួកបរិសុទ្ធជួបប្រទះការសោកល្បង*

សូមគូរ រូបផែនទីដែលមានអមមកជាមួយ នៅលើក្ដារខៀនមុនពេលចូលរៀន ។ អ្នកអាច មើលតាមផែនទីពេញមួយមេរៀន ដើម្បីជួយសិស្សឲ្យយល់ពីរឿងប្រវិត្តិសាស្ត្រនៅក្នុងមេរៀន ។




ដើម្បីចាប់ផ្ដើមមេរៀន សូមសួរសំណួរដូចខាងក្រោម ៖

- តើគំរូនៃការបៀតបៀនអ្វីខ្លះ ដែលពួកបរិសុទ្ធបានរងទុក្ខនៅក្នុងឃុំ ចាកសុន រដ្ឋ មិសសួរី ? (អ្នកប្រហែលត្រូវរំឭកសិស្សពីការបំផ្លិចបំផ្លាញការិយាល័យបោះពុម្ព ផ្ទះ និងដំណាំរបស់ពួកបរិសុទ្ធ ហើយបានស្រោចជ័រកៅស៊ូ និងចាក់រោមសត្វលើ អែតវើត ប៉ាទ្រិច និង ឆាលស៍ អាឡែន )។

សូមសង្ខេប ឬអានឃ្លាខាងក្រោម ឬសូមឲ្យសិស្សម្នាក់អានវា ។

ព្រោះតែការប្រើអំពើហិង្សារបស់ក្រុមពួកមនុស្សកំណាចក្នុងឃុំ ចាកសុន រដ្ឋ មិសសួរីនៅខែ កក្កដា ឆ្នាំ ១៨៣៣ នោះអ្នកដឹកនាំសាសនាចក្រក្នុងរដ្ឋ មិសសួរី បានយល់ព្រមចាកចេញពីឃុំនោះ ។ ប៉ុន្តែ នៅ ខែ សីហា ឆ្នាំ ១៨៣៣ ក្រុមប្រឹក្សានៃអ្នកដឹកនាំសាសនាចក្រទៅក្នុងទីក្រុង ខឺតឡង់ បានជួបពិភាក្សាពីការលំបាកនៅរដ្ឋ មិសសួរី ។ ពួកគេបានផ្ញើសេចក្ដីណែនាំថា ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី មិនគួរលក់ដីរបស់ខ្លួន ឬផ្លាស់ចេញពីភូមិនោះឡើង លុះត្រាតែពួកគេបានចុះកិច្ចព្រមព្រៀងឲ្យធ្វើដូច្នោះសិន ។ ពួកអ្នកដឹកនាំសាសនាចក្របានស្នើដល់រដ្ឋាភិបាល ហើយបានប្រើវិធីស្របច្បាប់ដើម្បីរក្សាដីធ្លីរបស់ពួកគេនៅរដ្ឋ មិសសួរី និងស្វែងរកយុត្តិធម៌ពីសំណាក់អ្នកដែលទទួលខុសត្រូវលើអំពើហិង្សា ។ បន្ទាប់ពីបានឮពីទង្វើទាំងនេះ ហើយដោយជឿថាពួកបរិសុទ្ធគ្មានគម្រោងចាកចេញដូចដែលបានរំពឹងទុកនោះទេ អ្នកដែលមិនមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយ បាន

***ការកំណត់ ភូមិសាស្ត្រ***

ព័ត៌មានសាមញ្ញអំពីការកំណត់ភូមិសាស្ត្រនៃរឿងនៅក្នុងព្រះគម្ពីរ អាចជួយសិស្សឲ្យយល់កាន់តែច្បាស់ពីមាតិកានៃព្រះគម្ពីរ ។ ផែនទីអាចជួយសិស្សឲ្យយល់ពីទំនាក់ទំនងរវាងកន្លែងផ្សេងៗគ្នា ។ រូបគំនូរ និងរូបភាពអាចជួយពួកគេឲ្យមើលឃើញទីកន្លែង ។

វាយប្រហារពួកបរិសុទ្ធម្ដងទៀត ។ នៅយប់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៨៣៣ ពួកមនុស្សកំណាចជិះសេះប្រហែល ៥០នាក់ បានវាយឆ្មក់លំនៅដ្ឋានរបស់ វិតមើរ នៅភាគខាងលិចនៃ ទីក្រុងអ៊ីនឌីប៉ែនដែនស៍ ។ ពួកគេបានរុះរើផ្ទះ១៣ខ្នង និងបានវាយបុរសមួយចំនួនស្ទើរស្លាប់ ។ ការវាយប្រហារនេះបានបន្តដល់ពីរយប់បន្ទាប់ នៅទីក្រុង អ៊ីនឌីប៉ែនដែនស៍ និង ទីតាំងផ្សេងទៀតដែលពួកបរិសុទ្ធបានរស់នៅ ។ មនុស្សប្រុសត្រូវបានវាយដំ ហើយស្ត្រី និងកុមារត្រូវបានបំភ័យ ។

- តើសំណួរអ្វីខ្លះដែលអ្នកគិតថា ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី អាចមាននៅពេលនោះ ? ( បើសិស្សត្រូវការជំនួយក្នុងការឆ្លើយនឹងសំណួរនេះ សូមពិចារណាពីសំណើដែលពួកបរិសុទ្ធអាចឆ្ងល់ពីមូលហេតុ ដែលព្រះអម្ចាស់ទុកឲ្យពួកគេត្រូវបៀតបៀន ) ។

សូមសួរសិស្សថា តើពួកគេធ្លាប់ឆ្ងល់ពីមូលហេតុដែលព្រះអម្ចាស់ទុកឲ្យពួកគេ ឬមនុស្សដែលពួកគេស្គាល់ជួបប្រទះនឹងការរងទុក្ខដែរឬទេ ។

សូមពន្យល់ថា ពេលពួកបរិសុទ្ធក្នុងរដ្ឋ មិសសួរី កំពុងរងទុក្ខតាមរយៈការសាកល្បងទាំងនេះ ព្រះអម្ចាស់បានសម្ដែងការពិតអំពីមូលហេតុដែលទ្រង់ទុកឲ្យប្រជាជនទ្រង់ជួបប្រទះនឹងការរងទុក្ខ ។ សូមឲ្យសិស្សមើលសេចក្ដីណែនាំអំពីកណ្ឌក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ ហើយប្រាប់ពីកាលបរិច្ឆេទដែល យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះ ។ ហើយសូមឲ្យពួកគេរកមើលក្នុងកណ្ឌទាំងមូល ដើម្បីរកមើលទុក្ខវេទនាផ្សេងទៀតដែលពួកបរិសុទ្ធបានជួបប្រទះរវាងការវាយប្រហារពីពួកមនុស្សកំណាចនៅថ្ងៃទី ៣១ ខែ តុលា និងកាលបរិច្ឆេទពេលដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( បន្ទាប់ពីពួកគេរាយការណ៍ហើយ អ្នកអាចពន្យល់ថា មានពួកបរិសុទ្ធច្រើនជាង ១០០០នាក់ ដែលត្រូវបានបណ្ដេញពីផ្ទះរបស់ពួកគេក្នុងឃុំ ចាកសុន ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលមូលហេតុដែលព្រះអម្ចាស់បានទុកឲ្យពួកបរិសុទ្ធនៅក្នុងឃុំ ចាកសុន រងទុក្ខពីការបៀតបៀន និងការឈឺចាប់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើយើងអាចរៀនអ្វីពី ខ ២ អំពីលទ្ធផលនៃការប្រឆាំងនឹងព្រះបញ្ញត្តិរបស់ព្រះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរបង្ហាញអំពីគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងប្រឆាំងនឹងព្រះបញ្ញត្តិ នោះព្រះទុកឲ្យយើងរងទុក្ខ** ) ។

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ក្នុងការយល់ពីគោលការណ៍នេះ ?

សូមចង្អុលបង្ហាញថា ទោះជាពួកបរិសុទ្ធជាច្រើននៅរដ្ឋ មិសសួរី មានការស្មោះត្រង់ និងគោរពតាមព្រះបញ្ញត្តិក្ដី ពួកគេនៅតែរងទុក្ខដោយសារការបៀតបៀនដែរ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលមូលហេតុដែលព្រះអម្ចាស់ទុកឲ្យពួកបរិសុទ្ធដែលសុចរិតរងទុក្ខ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចពន្យល់ថា ពាក្យ *ការវាយផ្ចាល* មានន័យថាត្រូវណែនាំ ឬ កែតម្រូវ ពាក្យ*ការល្បង* មានន័យថាត្រូវសាកល្បង ហើយពាក្យ *ការញែកចេញជាបរិសុទ្ធ* មានន័យថាត្រូវធ្វើឲ្យនរណាម្នាក់ ឬអ្វីមួយបានបរិសុទ្ធ និងពិសិដ្ឋ។

- ស្របតាមខគម្ពីរទាំងនេះ តើហេតុអ្វីបានជាព្រះអម្ចាស់វាយផ្ចាល និងល្បងប្រជាជនរបស់ទ្រង់ ? ( សិស្សគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងមិនស៊ូទ្រាំនឹងការវាយផ្ចាលទេ នោះយើងមិនអាចត្រូវបានញែកចេញជាបរិសុទ្ធទេ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

- តើការវាយផ្ចាល អាចជួយយើងឲ្យត្រូវបានញែកចេញជាបរិសុទ្ធយ៉ាងដូចម្ដេច ?

- តើសារលិខិតនៅក្នុងខគម្ពីរទាំងនេះ មានឥទ្ធិពលយ៉ាងណាចំពោះពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលត្រូវវាយផ្ចាល និងសាកល្បង ជួយយើងឲ្យបានញែកចេញជាបរិសុទ្ធ សូមឲ្យសិស្សអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« បន្ថែមពីលើការជម្រុញការប្រែចិត្តរបស់យើង បទពិសោធន៍នៃការការស៊ូទ្រាំនឹងការវាយផ្ចាល អាចសម្រាំង និងរៀបចំយើងសម្រាប់ឯកសិទ្ធខាងវិញ្ញាណអស្ចារ្យជាងនេះ » ( As Many as I Love, I Rebuke and Chasten » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៩៨ ) ។

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់សំដៅទៅ អ័ប្រាហាំ ជាគំរូមួយនៃមនុស្សម្នាក់ដែលត្រូវបានវាយផ្ចាល និងត្រូវបានសាកល្បង ។ អ្នកអាចសូមឲ្យសិស្សសង្ខេបយ៉ាងខ្លីនូវរឿងដែលព្រះអម្ចាស់បញ្ជារឲ្យ អ័ប្រាហាំ បូជាកូនប្រុសរបស់លោក គឺអ៊ីសាក ធ្វើជាយញ្ញបូជា ( សូមមើល លោកុប្បត្តិ ២២:១–១៤ ) ។ សូមពន្យល់ថា ការស្មោះត្រង់របស់ អ័ប្រាហាំ ក្នុងពេលសាកល្បងនោះ និងក្នុងពេលសាកល្បងដទៃទៀត បានរៀបចំលោកឲ្យទទួលបានពរជ័យខាងវិញ្ញាណយ៉ាងអស្ចារ្យ ( សូមមើល លោកុប្បត្តិ ២២:១៥–១៨ ) ។ សូមឲ្យសិស្សមើលគោលការណ៍ ដែលអ្នកបានសរសេរនៅលើក្ដារខៀន ។

- តើសេចក្ដីពិតនេះ អាចជួយយើងក្នុងពេលលំបាកយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦–៨ ដោយស្ងៀមស្ងាត់ រកមើលអំពើបាបដែលបានធ្វើដោយពួកបរិសុទ្ធមួយចំនួននៅរដ្ឋ មិសសួរី ដែលបានដឹកនាំទៅរកការរងទុក្ខសម្រាប់ពួកគេគ្រប់គ្នា ។ សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេ ដល់សិស្សក្នុងថ្នាក់ ។

- តើយើងរៀនអ្វីខ្លះពី ខ ៧–៨ ?
- យោងតាម ខ ៨ តើមនុស្សមួយចំនួនចង់ធ្វើអ្វី ពេលជីវិតពួកគេមានភាពសុខសាន្ដ ?
- ស្របតាម ខ ៨ តើមនុស្សមួយចំនួនចាប់ផ្ដើមធ្វើអ្វី នៅក្នុងការរងទុក្ខរបស់ពួកគេ ? តើអ្នកគិតថាការ « រាវរក » ព្រះអម្ចាស់មានន័យយ៉ាងណា ?

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីបទពិសោធន៍ ពេលការសាកល្បងរបស់ពួកគេបាននាំគេឲ្យបែរដួងចិត្តពួកគេមករកព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩–១៦

*ព្រះអម្ចាស់បានប្រឹក្សា និងលួងលោមចិត្តដល់ពួកបរិសុទ្ធ*

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ រកមើលសារលិខិតនៃសេចក្ដីសង្ឃឹមដែលព្រះអម្ចាស់បានប្រទានឲ្យពួកបរិសុទ្ធ ដែលរងទុក្ខនៅរដ្ឋ មិសសួរី ។

- តើសារលិខិតអ្វីដែលព្រះអម្ចាស់បានប្រទាននៅ ខ ៩ ដែលអាចជួយយើងពេលយើងទទួលរងលទ្ធផលនៃអំពើបាបរបស់យើង ? ( ចម្លើយរបស់សិស្សអាចនឹងមានខុសៗគ្នា ប៉ុន្ដែពួកគេបានកំណត់ពីសេចក្ដីពិតដូចខាងក្រោមនេះ ៖ **ទោះជានៅពេលដែលយើងបានធ្វើអំពើបាប ក៏ព្រះអម្ចាស់នៅតែមានសេចក្ដីមេត្ដាចំពោះយើងដែរ ។** សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ។ អ្នកក៏អាចផ្ដល់យោបល់ដែរថា សិស្សគួរតែកត់ត្រាវានៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។
- តើសេចក្ដីពិតនេះ អាចនាំមកនូវសេចក្ដីសង្ឃឹមដល់យើងដោយរបៀបណា ?

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីមួយដែលពួកគេអាចធ្វើដើម្បីបង្វែរដួងចិត្តរបស់ពួកគេទៅព្រះអម្ចាស់ និងទទួលបទពិសោធន៍ពីសេចក្ដីមេត្តារបស់ទ្រង់ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១០–១១ ដោយពន្យល់ថា ទោះជាព្រះអម្ចាស់បានទុកឲ្យពួកបរិសុទ្ធត្រូវបានបៀតបៀនក្ដី តែទ្រង់បានមានព្រះបន្ទូលថា ទ្រង់នឹងផ្ដន្ទាទោសអ្នកដែលបៀតបៀនពួកគេ ។ សូមឲ្យសិស្សម្នាក់អានឃ្លាខាងក្រោមឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលការសាកល្បងបន្ថែម ដែលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានជួបប្រទះ ។ អ្នកអាចអញ្ជើញសិស្សឲ្យនឹកស្រមៃថាតើពួកគេមានអារម្មណ៍យ៉ាងណា បើបានធ្វើជាសាក្សី ឬជួបប្រទះការសាកល្បងទាំងនោះ ។

ក្រុមពួកមនុស្សកំណាចនៅឃុំ ចាកសុន បានបន្ដបៀតបៀនពួកបរិសុទ្ធរហូតដល់សមាជិកទាំងអស់ក្នុងសាសនាចក្រ ត្រូវបានបណ្ដេញចេញពីភូមិនោះ ។ ឡៃម៉ាន វ៉ៃត បានរាយការណ៍ថា « ខ្ញុំបានឃើញស្ដ្រី និងកុមារមួយរយកៅសិបនាក់បានដើរឆ្លងកាត់វាលស្មៅចម្ងាយ៤៨ គីឡូម៉ែត្រ ជាមួយនឹងបុរសចំណាស់បីនាក់គ្រាន់តែបានជាគ្នា នៅក្នុងខែវិច្ឆិកា ភ្លៀងលាយព្រិលបានកកជាប់នៅលើផ្លូវយ៉ាងស្ដើង ហើយខ្ញុំអាចរកផ្លូវដែលពួកគេដើរបានយ៉ាងងាយ ដោយ*ឈាមដែលហូរចេញពីជើងដែលរបួសរបស់ពួកគេ*នៅលើជញ្ជ្រាំងដែលបានឆេះ ។ ( នៅក្នុង *History of the Church* ៣:៤៣៩ ) ។

ពួកបរិសុទ្ធស្ទើតែទាំងអស់បានភៀសខ្លួនទៅភាគខាងជើង ហើយពួកគេត្រូវឆ្លងទន្លេមិសសួរី ។ ឆ្នេរទន្លេនៅជិតសាឡាងត្រូវបានតម្រង់ជួរដោយអ្នកភៀសខ្លួន ។ មនុស្សមួយចំនួនមានសំណាងដែលបានភៀសខ្លួនជាមួយនឹងរបស់របរនៅក្នុងផ្ទះ ប៉ុន្ដែមនុស្សជាច្រើនទៀតបានបាត់បង់អ្វីគ្រប់យ៉ាង ។ ប៉ាលី ភី ប្រាត្ត បានសរសេរថា ៖ « មនុស្សជាច្រើនរយនាក់ ត្រូវបានឃើញបែកខ្ញែកទៅគ្រប់ទិសទី មនុស្សខ្លះនៅក្នុងតង់ ហើយមនុស្សខ្លះទៀតនៅខាងក្រៅនៅជុំវិញភ្នក់ភ្លើង ពេលដែលភ្លៀងធ្លាក់យ៉ាង

ដោកដាំ ។ ស្វាមីជាច្រើនកំពុងមើលថែដល់ភរិយាខ្លួន ភរិយាជាច្រើនកំពុងមើលថែស្វាមីខ្លួន ឪពុកម្ដាយជាច្រើនកំពុងមើលថែកូនៗខ្លួន និង កូនៗជាច្រើនកំពុងមើលថែឪពុកម្ដាយខ្លួន ។. . . ទិដ្ឋភាពនេះគឺគួរឲ្យខ្លោចផ្សាបំផុត ខ្ញុំប្រាកដណាស់ថា ការណ៍នេះបានធ្វើឲ្យមនុស្សនៅលើផែនដីមានចិត្តអាណិតអាសូរ លើកលែងតែជនគៀបសង្កត់ដ៏ឯងឹតងងល់ និង ក្រុមមនុស្សដែលល្ងង់ខ្លៅ និង អវិជ្ជាប៉ុណ្ណោះ » (*Autobiography of Parley P. Pratt,* ការបោះពុម្ពនៃ ប៉ាលី ភី ប្រាត្ត ជុញ្ញ័រ [ ឆ្នាំ ១៩៣៨ ] ទំព័រ ១០២ ) ។

- តើផ្នែកមួយណានៃការសាកល្បងទាំងនេះ នឹងមានការពិបាកបំផុតសម្រាប់អ្នកធ្វើជាសាក្សី ឬជួបប្រទះ ?
- តើអ្នកគិតថាអ្នកអាចឆ្លើយតបយ៉ាងណា បើអ្នកបានជួបប្រទះការរងទុក្ខបែបនោះ ? ( អ្នកអាចទុកពេលឲ្យសិស្សសញ្ជឹងគិតពីសំណួរនេះ ដោយមិនចាំបាច់ឆ្លើយឮៗទេ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១២–១៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការសន្យារបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធដ៏ស្មោះត្រង់ទាំងនេះ ។ សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេ។ សូមពន្យល់ថានៅក្នុង ខ ១២ ឃ្លា« អស់ទាំងពួកសាសន៍អ៊ីស្រាអែល » សំដៅទៅលើពួកអ្នកដែលស្មោះត្រង់ទៅនឹងសេចក្ដីសញ្ញានៃដំណឹងល្អ ។

- តើគោលការណ៍អ្វីដែលអ្នករៀនពី ខ ១២–១៦ ? ( សូមសង្ខេបចម្លើយរបស់សិស្សជាប្រយោគមួយ ហើយសរសេរនៅលើក្ដារខៀន ។ ចម្លើយរបស់ពួកគេ គួរតែបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងរស់នៅដោយសុចរិត យើងអាចស្វែងរកការលួងលោមនៅក្នុងការដឹងថា មនុស្សទាំងអស់គឺនៅក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់**) ។
- នៅក្នុង ខ ១៦, តើអ្នកគិតថាអ្វីទៅដែលជានិយមន័យរបស់ព្រះបញ្ញត្តិឲ្យ « សូមបង្អង់សិន ឲ្យបានដឹងថាយើងជាព្រះ » ?
- តើ « តើការបង្អង់ » អាចជួយយើងឲ្យទទួលបានការលួងលោមដោយរបៀបណា ?

សូមឲ្យសិស្សគិតអំពីពេលវេលា ដែលពួកគេមានអារម្មណ៍សុខសាន្ត ហើយដឹងថាពួកគេនៅក្រោមការគ្រប់គ្រងរបស់ព្រះ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយនូវបទពិសោធន៍របស់ពួកគេ ។ អ្នកអាចចែកចាយបទពិសោធន៍មួយ ដែលអ្នកមាន នៅពេលអ្នកត្រូវបានប្រសិទ្ធិពរដោយភាពសុខសាន្ត នៅក្នុងពេលនៃការរងទុក្ខ ។

សូមលើកទឹកចិត្តសិស្សឲ្យបន្តបែរទៅរកព្រះអម្ចាស់ និងទុកចិត្តថាទ្រង់នឹងធ្វើអ្វីដែលប្រសើរបំផុតសម្រាប់ពួកគេ ។

មេរៀនទី ១០៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២

## សេចក្ដីផ្ដើម

នៅថ្ងៃទី ១៦ និង១៧ ខែ ធ្នូ ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយអំពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលបានចាកចេញពីផ្ទះរបស់ពួកគេ ដើម្បីគេចចេញពីការបៀតបៀនដ៏ឃោរឃៅ ។ ពួកបរិសុទ្ធជាច្រើន ត្រូវបានបង្ខំឲ្យបោះបង់ចោលទ្រព្យសម្បត្តិរបស់ពួកគេ ។ វិវរណៈដែលព្យាការីបានទទួល បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ ត្រូវលើកមកពិភាក្សាជាបីមេរៀននៅក្នុងសៀវភៅសិក្សានេះ ។ មេរៀនទីពីរនេះ រួមមានការពិពណ៌នារបស់ព្រះអម្ចាស់ពីលក្ខខណ្ឌមួយចំនួននៃសហសវត្សន៍ ។ វាក៏បញ្ចូលព្រះបន្ទូលនៃការលួងលោមចិត្ត និងការទូន្មានដល់ពួកបរិសុទ្ធផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៣៤

*ព្រះអម្ចាស់ពិពណ៌នាពីលក្ខខណ្ឌមួយចំនួននៃសហសវត្សន៍*

សូមឲ្យសិស្សរៀបរាប់ឈ្មោះព្រឹត្តិការណ៍នាពេលអនាគត ដែលពួកគេបានរៀបចំខ្លួនសម្រាប់ ។ សូមសរសេរព្រឹត្តិការណ៍ទាំងនេះនៅលើក្ដារខៀន ។ សូមសួរសិស្សថា តើពួកគេកំពុងធ្វើអ្វីដើម្បីរៀបចំខ្លួនសម្រាប់ព្រឹត្តិការណ៍ទាំងនោះ ។

- តើហេតុអ្វីបានជាអ្នកខិតខំប្រឹងប្រែង ដើម្បីរៀបចំខ្លួន ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ មានន្ទូវការបង្រៀនពីការរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ និងសហសវត្សន៍ ។ សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–២១ ដោយពន្យល់ថា ការសន្យារបស់ព្រះអម្ចាស់ដើម្បីប្រមូលផ្ដុំពួកបរិសុទ្ធនៅក្នុងទីក្រុងស៊ីយ៉ូននៅឃុំ ចាកសុន រដ្ឋ មិសសួរី « សូមបន្តរង់ចាំ នៅពេលដែលប្រជាជនត្រូវបានញែកចេញជាបរិសុទ្ធ សម្រាប់អំណោយទានដ៏អស្ចារ្យ និងសម្រាប់ទំនួលខុសត្រូវដែលមានមកជាមួយគ្នានោះ ។ នៅចន្លោះពេលនោះ ពួកអ្នកមានចិត្តទៀងត្រង់បានប្រមូលគ្នានៅប្រកភ្នំរ៉ក់គី [ និងនៅស្តេកទូទាំងពិភពលោក ] ។. . . ព្រះវិហារបរិសុទ្ធត្រូវបានកសាងឡើង ។. . . ប៉ុន្តែ ទីក្រុងស៊ីយ៉ូនពុំទាន់ត្រូវបានស្ថាបនានៅលើទីតាំងដែលបានជ្រើសនៅឡើយទេ ( ជេម អ៊ី ថាលម៉េហ្គ *The Articles of Faith,* ការបោះពុម្ពលើកទី ១២ [ឆ្នាំ ១៩២៤],ទំព័រ ៣៥៣; សូមមើលផងដែរ *Doctrine and Covenants Student Manual,* ការបោះពុម្ពលើកទី ២. [Church Educational System manual, ឆ្នាំ ២០០១],ទំព័រ ២៤០ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២២–២៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់មានបន្ទូលប្រាប់ពួកបរិសុទ្ធឲ្យធ្វើ ដើម្បីរៀបចំខ្លួនការយាងមកជាលើកទីពីររបស់ទ្រង់ ។

- យោងតាម ខ ២២ និង ២៣, តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរៀបចំខ្លួន សម្រាប់ការយាងមកជាលើកទីពីរ ? ( សិស្សគួរបង្ហាញថា **យើងអាចរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ដោយស្រែកហៅព្រះនាមទ្រង់ រស់នៅស្របតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ ប្រមូលផ្ដុំគ្នា នឹងឈរនៅក្នុងទីបរិសុទ្ធ** ។ សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។
- តើការ« ឈរនៅក្នុងទីបរិសុទ្ធ » មានន័យដូចម្ដេចចំពោះអ្នក ? តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា អ្នកកំពុងនៅក្នុងទីបរិសុទ្ធ ?
- តើការប្រមូលផ្ដុំនៅក្នុងទីបរិសុទ្ធជាមួយពួកបរិសុទ្ធថ្ងៃចុងក្រោយដទៃទៀត ជួយអ្នកឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

ដើម្បីរៀបចំសិស្សឲ្យយល់ពីព្រះបន្ទូលរបស់ព្រះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២៤–៣៤, សូមពន្យល់ថា ខគម្ពីរទាំងនេះ សំដៅទៅការបំផ្លិចបំផ្លាញនៃជនទុច្ចរិតនៅពេលនៅការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ហើយវាជាលក្ខខណ្ឌដែលកើតមាននៅលើផែនដីក្នុងពេលសហសវត្សន៍ ។ សូមបែងចែកសិស្សជាគូៗ ។ សូមអញ្ជើញដៃគូឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២៤–៣៤ រកមើលលក្ខខណ្ឌដែលនឹងកើតមាននៅក្នុងសហសវត្សន៍ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសុំឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។

- តើលក្ខខណ្ឌនៅលើក្ដារខៀនមួយណា ដែលអ្នកចង់ជួបប្រទះជាងគេ ? ហេតុអ្វី ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៥–៣៨

*ព្រះអម្ចាស់បានអះអាងជាមួយពួកបរិសុទ្ធនៅក្នុងរដ្ឋ មិសសួរី ថាបើពួកគេស៊ូទ្រាំដោយសេចក្ដីជំនឿ នោះនៅទីបញ្ចប់ពួកគេនឹងអាចទទួលបានសិរីល្អរបស់ទ្រង់ ។*

សូមរំឭកសិស្សថា នៅពេលព្រះអម្ចាស់ប្រទានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានជួបប្រទះនូវទុក្ខលំបាកយ៉ាងខ្លាំង ។ អ្នកអាចឲ្យសិស្សសង្ខេប ពីទុក្ខលំបាកមួយចំនួនដែលពួកគេបានរៀនក្នុងមេរៀនមុន ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៥–៣៨ ឲ្យឮៗ ។ សូមឲ្យសមាជិកក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីពិតដែលព្រះអម្ចាស់បានបង្រៀន និងការទូន្មានដែលទ្រង់បានប្រទានឲ្យ ដើម្បីលួងលោមចិត្ត និងពង្រឹងពួកបរិសុទ្ធនៅក្នុងការសាកល្បងរបស់ពួកគេ ។

- តើសេចក្ដីពិត និងការទូន្មានអ្វីនៅក្នុង ខ ៣៥–៣៨ ដែលអាចនាំការលួងលោមចិត្តដល់ពួកបរិសុទ្ធដែលកំពុងរងទុក្ខនៅរដ្ឋ មិសសួរី ? ( នៅពេលសិស្សឆ្លើយ សូមសួរពួកគេពីរបៀបដែលការពិត ឬការទូន្មានដែលពួកគេបានលើកឡើង អាចនាំមកនូវការលួងលោមចិត្តដល់ពួកបរិសុទ្ធ ) ។

- តើអ្នកអាចបង្ហាញការសន្យារបស់ព្រះអម្ចាស់នៅក្នុង ខ ៣៥ ដោយពាក្យសម្ដីផ្ទាល់របស់អ្នកយ៉ាងដូចម្ដេច ? (សិស្សគួរតែឆ្លើយតបដោយលើកឡើងពីគោលការណ៍ដូចខាងក្រោមនេះ ៖ **អ្នកដែលរងទុក្ខការបៀតបៀនព្រោះព្រះនាមរបស់ព្រះអង្គសង្គ្រោះ ហើយស៊ូទ្រាំដោយសេចក្ដីជំនឿ នោះនឹងទទួលបានសិរីល្អរបស់ព្រះ ។** អ្នកអាចសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

សូមពន្យល់ថា សិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទតែងតែដើរតាមទ្រង់ទោះជានៅពេលពួកគេត្រូវបានបៀតបៀនដោយសារសេចក្ដីជំនឿរបស់ពួកគេក៏ដោយ ។ សូមឲ្យសិស្សម្នាក់អាន រឿងខាងក្រោម,ដែលបានប្រាប់ដោយប្រធាន ជេមស៍ អ៊ី ហ្វោស្ដនៃគណៈប្រធានទីមួយឲ្យឮៗ ។ មុនពេលគេអាន សូមពន្យល់ថា រឿងនោះគឺអំពី រ៉ាហ្វាអែល ម៉ុនរ៉យ និង វិនសិន ម៉ូរ៉ាល ជាពួកបរិសុទ្ធពីរនាក់ដែលរស់នៅក្នុងប្រទេសម៉ិកស៊ិក នៅដើមឆ្នាំ ១៩០០ ។ ក្នុងឆ្នាំ ១៩១៥ ពួកគេត្រូវបានចាប់ខ្លួន ដោយក្រុមទាហានហឹង្សាមួយក្រុម ។ សូមឲ្យសិស្សស្ដាប់រកមើលរបៀបដែលបងប្រុស ម៉ុនរ៉យ និងបងប្រុស ម៉ូរ៉ាល មានភាពស្មោះត្រង់នៅពេលពួកគេស៊ូទ្រាំនឹងការបៀតបៀន ។



« រ៉ាហ្វាអែល ម៉ុនរ៉យ គឺជាប្រធានសាខានៃសាខាតូចមួយនៅទីក្រុង សាន់ ម៉ាកុស ប្រទេស ម៉ិកស៊ិក និង វីសិនទែ ម៉ូរ៉ាឡែស គឺជាទីប្រឹក្សាទីមួយរបស់គាត់ ។. . . គេបានប្រាប់ពួកគាត់ថា ពួកគាត់នឹងរួចជីវិតបើពួកគាត់ទម្លាក់អាវុធចុះ ហើយលះបង់សាសនាដ៏ចម្លែករបស់ពួកគេចោល ។ បងប្រុស ម៉ុនរ៉យ បានប្រាប់អ្នកចាប់ខ្លួនគាត់ថា គាត់ពុំមានអាវុធណាមួយឡើយ ហើយបានដកយកព្រះគម្ពីរមរមនចេញពីហោប៉ៅរបស់គាត់ដោយធម្មតា ។ គាត់បានស្រដីថា ‹ លោក អាវុធតែមួយគត់ ដែលខ្ញុំមាន វាគឺជាអាវុធនៃសេចក្ដីពិតដែលប្រឆាំងនឹងភាពខុសឆ្គងទាំងឡាយ › ។

« នៅពេលគេពុំឃើញមានអាវុធទេ នោះបងប្អូនប្រុសទាំងពីរនាក់នេះ ត្រូវបានគេវាយធ្វើបាបយ៉ាងឃោរឃៅ ដើម្បីឲ្យពួកគាត់ប្រាប់ពីកន្លែងដែលអាវុធត្រូវបានលាក់ទុក ។ ប៉ុន្តែ ពុំមានអាវុធដែលត្រូវបានលាក់ទុកឡើយ ។ ក្រោយមកពួកគាត់ត្រូវបានគេនាំយកទៅឃុំឃាំងនៅជាយក្រុង ជាកន្លែងដែលអ្នកចាប់ខ្លួនពួកគាត់ ចាប់ចងផ្អោបពួកគាត់ទៅនឹងដើមឈើធំមួយ ដើម្បីធ្វើការប្រហារជីវិតនៅមុខពួកទាហាន ។ នាយទាហាននោះទទួលបន្ទុកដោះលែងពួកគាត់ បើពួកគាត់លះបង់ចោលសាសនារបស់ខ្លួន ហើយចូលរួមជាមួយ [ កងទាហាន ] ប៉ុន្តែ បងប្រុស ម៉ុនរ៉យ បានវាចាតបថា ‹ ខ្ញុំស្រឡាញ់សាសនារបស់ខ្ញុំជាងជីវិតរបស់ខ្ញុំទៅទៀត ហើយខ្ញុំមិនអាចលះបង់វាចោលបានឡើយ › ។

« លំដាប់នោះ គេបានប្រាប់ពួកគាត់ថា ពួកគាត់នឹងត្រូវគេបាញ់ប្រហារជីវិត ហើយបានសួរថាតើពួកគាត់មានសំណើអ្វីដែរឬទេ ។ បងប្រុស រ៉ាហ្វាអែល បានស្នើសុំឲ្យគាត់អាចអធិស្ឋាន ពីមុនគាត់ត្រូវបានប្រហារជីវិត ។ គាត់បានលុតជង្គង់ចុះនៅទីនោះ ក្នុងចំណោមពួកអ្នកប្រហារជីវិត អធិស្ឋានដោយបញ្ចេញសំឡេងឮៗ សូមឲ្យព្រះប្រទានពរ ហើយថែរក្សាមនុស្សដ៏ជាទីស្រឡាញ់ទាំងឡាយរបស់គាត់ ថែមទាំងថែរក្សាសាខាដ៏តូចដែលកំពុងពុះពារ ដែលនឹងត្រូវបាត់បង់អ្នកដឹកនាំនោះ ។ នៅពេលគាត់បានបញ្ចប់ការអធិស្ឋាន គាត់បានថ្លែងចេញព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ កាលទ្រង់ត្រូវបានដំដែកគោលភ្ជាប់លើឈើឆ្កាង ហើយបានអធិស្ឋានសម្រាប់ពួកអ្នកប្រហារជីវិតទ្រង់ ៖ ‹ ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ › ។ [លូកា ២៣:៣៤] ។ ក្រុមពេជ្ឈឃាដបានបាញ់សម្លាប់បងប្រុស ម៉ុនរ៉យ និងបងប្រុស ម៉ូរ៉ាល (« Discipleship » *Ensign* ឬ *លីអាហូណា,* ខែ វិច្ឆិកា ឆ្នាំ ២០០៦,ទំព័រ ២១–២២; យោងតាម Rey L. Pratt, « A Latter–day Martyr » *Improvement Era,* ខែ មិថុនា ឆ្នាំ ១៩១៨,ទំព័រ ៧២០–២៦ ) ។

- តើបងប្រុស ម៉ុនរ៉យ និងបងប្រុស ម៉្វារ៉ាល បញ្ជាក់ពីគោលការណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៥ យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សគិតអំពីគ្រាដែលពួកគេត្រូវបានបៀតបៀន ( ចំអក ឬ ប្រមាថ ) ដោយសារសេចក្ដីជំនឿរបស់ពួកគេចំពោះព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់ ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ ចែកចាយបទពិសោធន៍របស់របស់ពួកគេ ។

- ពេលអ្នកត្រូវបានបៀតបៀនដោយសារសេចក្ដីជំនឿចំពោះព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់ តើអ្នកអាចធ្វើអ្វីខ្លះដើម្បីឆ្លើយតបដោយសេចក្ដីជំនឿ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៩–៤២

*ព្រះអម្ចាស់ប្រកាសថា ប្រជាជននៃសេចក្ដីសញ្ញារបស់ទ្រង់ ជាអំបិលនៃផែនដី*

ដើម្បីរៀបចំសិស្សឲ្យយល់ការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៩–៤២, សូមបង្ហាញគំរូអំបិលពីរប្រភេទ ៖ គំរូអំបិលសុទ្ធមួយ ហើយមួយទៀតជាគំរូអំបិលដែលបានលាយជាមួយសារធាតុផ្សេងទៀត ដូចជាដី ។

សូមនាំចំណាប់អារម្មណ៍របស់សិស្សផ្ដោតទៅលើគំរូអំបិលទីមួយ ។

- តើអំបិលត្រូវបានប្រើធ្វើអ្វីខ្លះ ? ( ចម្លើយអាចរួមមាន ថាអំបិលអាចត្រូវបានប្រើដើម្បីផ្ដល់រស់ជាតិ និងរក្សាអាហារ និងព្យាបាលរបួសដូចជាថ្នាំលាងរបួស ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៩ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ រកមើលមនុស្សដែលព្រះអម្ចាស់បានប្រៀបធៀបទៅនឹងអំបិល ។

- តើនរណាដែលព្រះអម្ចាស់មានបន្ទូលថាជា « អំបិលនៃផែនដី ? »

សូមពន្យល់ថាពាក្យ *ជាតិប្រៃ* សំដៅទៅលើរស់ជាតិ ឬគុណសម្បត្តិដែលប្លែកពីគេ ។

- តើអ្នកគិតថា ជាតិប្រៃនៃមនុស្ស មានន័យដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីអត្ថន័យនៃការធ្វើជាជាតិប្រៃនៃមនុស្ស សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្ដីថ្លែងការណ៍ដោយអែលឌើរ ខាឡូស អ៊ី អាសេ នៃក្រុមចិតសិបនាក់ ៖



« នៅពេលព្រះអម្ចាស់ប្រើពាក្យ ‹ ជាតិប្រៃនៃមនុស្ស › ទ្រង់មានបន្ទូលពីអ្នកទាំងឡាយដែលតំណាងឲ្យទ្រង់ ។ ទ្រង់សំដៅទៅមនុស្សដែលបានប្រែចិត្ត ជាអ្នកដែលបានលាងសម្អាតនៅក្នុងទឹកនៃការជ្រមុជទឹក ហើយជាអ្នកដែលបានធ្វើសេចក្ដីសញ្ញាថានឹងលើកដាក់លើខ្លួនពួកគេនូវព្រះនាម និងបុព្វហេតុរបស់ទ្រង់ ។ មួយវិញទៀត ទ្រង់មានព្រះបន្ទូលអំពីអ្នកទាំងឡាយ ដែលរួមចំណែកក្នុងអំណាចបព្វជិតភាពរបស់ខ្លួន តាមរយៈសេចក្ដីសញ្ញា ។ ទ្រង់មានបន្ទូលពីអ្នក និងខ្ញុំ » ( Salt of the Earth: Savor of Men and Saviors of Men » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨០ ទំព័រ ៤២ ) ។

- តើឃ្លា « អំបិលនៃផែនដី » និង « ជាតិប្រៃនៃមនុស្ស » អាចបង្រៀនយើងអំពីទំនួលខុសត្រូវរបស់យើងចំពោះអ្នកដទៃអ្វីខ្លះ ?

សូមជួយសិស្សឲ្យយល់ថា យើងមានទំនួលខុសត្រូវជួយដល់មនុស្សទាំងអស់នៃ ផែនដីឲ្យទទួលបានពរជ័យរបស់ទ្រង់ ដូចជាប្រជាជននៃសេចក្ដីសញ្ញាដែរ ( សូមមើល អ័ប្រាហាំ ២:៨–១១ ) ។ សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *ដើម្បីជួយមនុស្សនៃផែនដីឲ្យទទួលបានពរជ័យនៃព្រះ យើងត្រូវ* . . .

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤០–៤២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមាន និងការសន្យារបស់ព្រះអម្ចាស់ ។

សូមចង្អុលបង្ហាញថា ខ ៤០ រួមមានឃ្លា « បើសិនជាអំបិលនៃផែនដីបាត់ជាតិប្រៃ » ។ ដើម្បីជួយសិស្សយល់អត្ថន័យនៃឃ្លានេះ សូមនាំចំណាប់អារម្មណ៍របស់ពួកគេទៅគំរូអំបិលទីពីរ ។ សូមពន្យល់ថា អំបិលមិនបាត់បង់រស់ជាតិរបស់វាទេនៅពេលទុកយូរ ។ វាបាត់បង់រស់ជាតិ នៅពេលវាលាយជាមួយសារធាតុផ្សេងទៀត ហើយបានធ្វើឲ្យកខ្វក់ ។

### *ឧបករណ៍សម្រាប់មេរៀន*

សូមគេមើលវិធីប្រើឧបករណ៍ ដែលនឹងជួយសិស្សឲ្យយល់គោលការណ៍ទាំងឡាយខាងវិញ្ញាណ ។ តាមរយៈឧបករណ៍សម្រាប់មេរៀនដ៏មានប្រសិទ្ធភាព អ្នកអាចជួយសិស្សឲ្យមើលឃើញ វិភាគ និងយល់បទគម្ពីរទាំងឡាយ ។ អ្នកក៏អាចប្រើឧបករណ៍សម្រាប់មេរៀនដើម្បីជម្រុញការពិភាក្សាផងដែរ ។

- យោងតាម ខ ៤១ តើអ្វីដែលធ្វើឲ្យយើងបាត់បង់ជាតិប្រៃរបស់យើងជាអំបិលនៃផែនដី ? ( អំពើបាប ) ។ តើហេតុអ្វីបានជាអ្នកគិតថា អំពើបាបរបស់យើងធ្វើឲ្យពិបាកសម្រាប់យើងដើម្បីជួយអ្នកឲ្យទទួលពរជ័យរបស់ព្រះអម្ចាស់ ?
- តើអ្នកអាចនិយាយ ខ ៤២ ឡើងវិញជាពាក្យសម្ដីផ្ទាល់របស់អ្នកយ៉ាងដូចម្ដេច ? ( ប្រសិនបើសិស្សត្រូវការជំនួយក្នុងការឆ្លើយសំណួរនេះ សូមពន្យល់ថានរណាម្នាក់ដែលបានតម្កើងខ្លួនជាអ្នកអំនួត ហើយនរណាដែលដាក់ខ្លួននោះជាអ្នកមានភាពរាបទាបចំពោះព្រះអម្ចាស់វិញ )។
- យើងតាមការព្រមាន និងការសន្យារបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤០–៤២ តើអ្នកនឹងបំពេញគោលការណ៍នៅលើក្ដារខៀនដូចម្ដេច ? ( សូមបំពេញគោលការណ៍នៅលើក្ដារខៀន ដោយប្រើចម្លើយរបស់សិស្ស ។ ទោះជាសិស្សអាចប្រើពាក្យផ្សេងពីនេះ ពួកគេប្រើគោលការណ៍ដូចខាងក្រោម ៖ **ដើម្បីជួយមនុស្សនៃផែនដីឲ្យទទួលបានពរជ័យរបស់ព្រះ យើងត្រូវប្រែចិត្តពីអំពើបាបយើង ហើយមានការបន្ទាបខ្លួន**) ។
- តើយើងអាចធ្វើអ្វីខ្លះជារៀងរាល់ថ្ងៃ ដែលនឹងជួយយើងឲ្យចៀសវាងពីការបំពុលនៃអំពើបាប ?

សូមឲ្យសិស្សពិចារណាដោយស្ងៀមស្ងាត់ថា តើអំពើបាបធ្វើឲ្យជីវិតរបស់ពួកគេកខ្វក់ឬអត់ ។ សូមលើកទឹកចិត្តពួកគេឲ្យប្រែចិត្តពីអំពើបាបទាំងនោះ ដូច្នេះពួកគេអាចក្លាយជាបរិសុទ្ធចំពោះព្រះភក្ត្រព្រះអម្ចាស់ ហើយពួកគេអាចជួយអ្នកដ៏ទៃឲ្យទទួលបានពរជ័យទ្រង់ដោយមានប្រសិទ្ធភាព ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨–១០១:៤២ ( មេរៀនទី ២១ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨–១០១:៤២ ( មេរៀនទី ២១ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨)

នៅពេលសិស្សបានសិក្សាអំពីពួកជនកំណាចមួយចំនួនបានធ្វើអំពើឃោឃៅព្រៃផ្សៃចំពោះពួកបរិសុទ្ធដែលបានជួបនៅក្នុងឃុំ ចាកសុន រដ្ឋមិសសួរី នោះពួកគេបានរៀនថា យើងបង្ហាញខ្លួនយើងចំពោះព្រះអម្ចាស់តាមរយៈការរក្សានូវសេចក្ដីសញ្ញារបស់យើង សូម្បីតែវាលំបាកដើម្បីធ្វើវាក្ដី ។ សិស្សក៏បានរៀនផងដែរថា ប្រសិនបើយើងស៊ូទ្រាំនឹងចំពោះការបំពានខុសឆ្គងដោយអត់ធ្មត់ និង ដោយគ្មានការសងសឹងតបវិញ នោះព្រះអម្ចាស់នឹងប្រទានរង្វាន់ដល់យើង ។ ជាចុងក្រោយ ពួកគេបានរៀនថាការចូលរួមក្នុងសង្គ្រាមអាចជាការត្រឹមត្រូវនៅក្រោមកាលៈទេសៈដែលបានដាក់បញ្ញត្តិដោយព្រះអម្ចាស់ប៉ុណ្ណោះ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០)

នៅក្នុងមេរៀននេះសិស្សបានរៀនថា យើងតំណាងឲ្យព្រះអម្ចាស់ នៅពេលយើងបម្រើបេសកកម្ម ហើយថាអស់អ្នកដែលទទួលយកដំណឹងល្អ « ដូចជាកូនក្មេងមួយ » (គ. និង ស. ៩៩:៣) ទទួលបានសេចក្ដីមេត្តាករុណា ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងនឹងបន្លឺសំឡេងរបស់យើងដើម្បីចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ដោយចិត្តម៉ឺងម៉ាត់ និង ដោយនូវវិញ្ញាណស្លូតបូត នោះព្រះអម្ចាស់នឹងជួយយើងឲ្យដឹងពីអ្វីដើម្បីនិយាយ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងថ្លែងទីបន្ទាល់នៃសារលិខិតរបស់យើង ។ សិស្សក៏បានឃើញផងដែរថាគ្រប់ការណ៍ទាំងអស់ផ្សំគ្នាសម្រាប់សេចក្ដីល្អដល់យើង ប្រសិនបើយើងដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់នោះ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦)

នៅពេលសិស្សបានសិក្សាអំពីការបណ្ដេញចេញរបស់ពួកបរិសុទ្ធពីឃុំចាកសុន រដ្ឋមិសសួរី នោះពួកគេបានរៀនថា នៅពេលយើងរំលងព្រះបញ្ញត្តិ នោះព្រះបណ្ដោយយើងរងទុក្ខ ការណ៍នេះគឺខុសពីការសាកល្បង និង បទពិសោធន៍លំបាកៗនានានៃអស់អ្នកដែលសុចរិត ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងមិនស៊ូទ្រាំនឹងការវាយផ្ចាលទេនោះ យើងនឹងពុំអាចញែកចេញបានឡើយ ។ សិស្សបានឃើញថាសូម្បីតែនៅពេលយើងបានធ្វើអំពើបាប នោះព្រះអម្ចាស់នឹងមានសេចក្ដីអាណិតអាសូរចំពោះយើង ។ នៅពេលយើងរស់នៅដោយសុចរិត នោះយើងអាចស្វែងរកការលួងលោមនៅក្នុងការចេះដឹងថាមនុស្សទាំងអស់គឺនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២)

ជាផ្នែកនៃមេរៀននេះ សិស្សបានរៀនពីរបៀបនានាដែលយើងអាចត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ ពួកគេក៏បានរកឃើញគោលការណ៍ដែលថា អស់អ្នកដែលស៊ូទ្រាំនឹងការបៀតបៀន ដោយព្រោះព្រះនាមរបស់ព្រះអង្គសង្គ្រោះ ហើយកាន់ខ្ជាប់ក្នុងសេចក្ដីជំនឿនឹងបានទទួលនូវសិរីល្អរបស់ព្រះ ។ ក្រៅពីនេះទៀត ពួកគេរកឃើញថាដើម្បីជួយមនុស្សនៅលើផែនដីនេះឲ្យទទួលពរជ័យរបស់ព្រះ នោះយើងត្រូវតែប្រែចិត្តពីអំពើបាបរបស់យើង និង មានការបន្ទាបខ្លួន ។

## សេចក្តីផ្តើម

មេរៀននេះផ្តោតលើការណែនាំមួយចំនួននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធដែលកំពុងត្រូវបានបៀតបៀនដោយពួកជនកំណាច ។ មេរៀននេះអាចជួយសិស្សឲ្យយល់ពីរបៀបដែលយើងគួរតែមានប្រតិកម្មតបតចំពោះស្ថានភាពលំបាកៗ ហើយវាអាចជួយពង្រឹងទីបន្ទាល់របស់ពួកគេអំពីព្រះចេស្ដា និង សេចក្ដីសប្បុរសរបស់ព្រះអម្ចាស់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨

*ព្រះអម្ចាស់លើកទឹកចិត្តដល់ពួកបរិសុទ្ធអំឡុងពេលនៃការវេទនារបស់ពួកគេ*

មុនពេលចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *តើអ្នកនឹងមានអារម្មណ៍បែបណា ? តើអ្នកនឹងធ្វើអ្វីខ្លះ ?*

សូមពន្យល់ថានៅក្នុងមេរៀនថ្ងៃនេះ ពួកគេនឹងរៀនអំពីការសាកល្បង និង ការបៀតបៀនមួយចំនួនមកលើពួកបរិសុទ្ធដែលរស់នៅក្នុងឃុំ ចាកសុន រដ្ឋមិសសួរី ដែលបានជួបនៅក្នុងខែ កក្កដា ឆ្នាំ ១៨៣៣ ។ សូមពន្យល់ថាពួកមិសសួរីមួយចំនួនបានប្រែជាខឹងនឹងពួកបរិសុទ្ធ ដោយសារតែភាពខុសគ្នានៃរឿងនយោបាយ សង្គម សេដ្ឋកិច្ច និង សាសនា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌខាងក្រោមឲ្យឮៗ ៖

នៅថ្ងៃសៅរ៍ ទី ២០ ខែ កក្កដា ឆ្នាំ ១៨៣៣ ប្រជាពលរដ្ឋមិសសួរីដែលមានកំហឹងប្រមាណជា ៤០០ទៅ ៥០០នាក់បានជួបប្រជុំគ្នានៅសាលាក្ដីនៅក្នុងទីក្រុងអ៊ីនឌីប៉ែនឌិន រដ្ឋមិសសួរី ។ ពួកគេបានជ្រើសរើសគណៈកម្មការមួយ ដើម្បីព្រៀងឯកសារមួយដែលសង្ខេបពីការទាមទារចង់បានរបស់ខ្លួនពីពួកមរមន ។ ពួកគេបានទាមទារថា ពុំអនុញ្ញាតឲ្យមានពួកបរិសុទ្ធថ្ងៃចុងក្រោយផ្លាស់ប្ដូរទីលំនៅទៅឃុំចាកសុនទៀតឡើយ ហើយបាននិយាយថាអស់អ្នកដែលកំពុងរស់នៅទីនោះត្រូវតែសច្ចាថាចាកចេញពីទីនោះឲ្យបានឆាប់តាមដែលអាចធ្វើបាន ។ លើសពីនោះទៀត ពួកគេបានទាមទារសាសនាចក្រឲ្យបញ្ឈប់ការបោះពុម្ពផ្សាយកាសែត ។ នៅពេលការទាមទារនេះត្រូវបានដាក់បង្ហាញដល់ថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងរដ្ឋមិសសួរី ថ្នាក់ដឹកនាំសាសនាចក្រមានការភ្ញាក់ផ្អើល ហើយបានស្នើសុំរយៈពេលបីខែដើម្បីពិចារណាពីសំណើនោះ និង ដើម្បីពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំនៅក្នុងរដ្ឋអូហៃអូ ។ ក្រុមប្រជាពលរដ្ឋនៃរដ្ឋមិសសួរីបានបង្ហាញពីការទាមទារដែលបដិសេធនឹងការស្នើសុំរបស់ថ្នាក់ដឹកនាំសាសនាចក្រ ។ ក្រោយមកពួកបរិសុទ្ធបានស្នើសុំរយៈពេល ១០ថ្ងៃ ប៉ុន្តែពួកគេបានអនុញ្ញាតឲ្យរយៈពេលតែ ១៥នាទីប៉ុណ្ណោះដើម្បីឆ្លើយតប ។ ( សូមមើល *Church History in the Fulness of Times Student Manual*, បោះពុម្ពទី ២ [ Church Educational System manual ឆ្នាំ ២០០៣ ], ទំព័រ ១៣២–៣៣ ) ។

បន្ទាប់មកសូមឲ្យសិស្សឆ្លើយសំណួរនៅលើក្ដារខៀន ។

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអានកថាខណ្ឌខាងក្រោមឲ្យឮៗ ៖

ពួកមិសសួរីដែលនៅឯការប្រជុំនៅក្នុងសាលាក្ដីទីក្រុងអ៊ីនឌីប៉ែនដែនស៍ បានប្រែជាពួកជនកំណាចមួយពព្រិចភ្នែក ហើយបានសម្រេចចិត្តបំផ្លាញការិយាល័យបោះពុម្ព និង កាសែតចោល ។ ពួកជនកំណាចបានទំលាយទ្វារចូលទៅក្នុងការិយាល័យបោះពុម្ព គ្រវែងគ្រឿងសង្ហារិមទៅលើផ្លូវ និង សួនច្បារ ហែកកំទេចកាសែត ពង្រាយឯកសារនានា ហើយបានបំផ្លាញសមិទ្ធផលនៃការបោះពុម្ពស្ទើរតែទាំងស្រុង រួមទាំងក្រដាសនៃព្រះគម្ពីរនៃបទបញ្ញត្តិដែលមិនទាន់បានផ្គុំបញ្ចូលគ្នាស្ទើរតែទាំងអស់ ។ បន្ទាប់មកពួកជនកំណាចបានចង់បំផ្លាញហាងរបស់គិលប៊ឺត និង វិតនី ។ ប៉ុន្តែ ស៊ិឌនី គិលប៊ឺតបានជួបពួកជនកំណាចពីមុនពួកគេអាចធ្វើតាមគម្រោងការ និង ការសន្យារបស់ខ្លួនដែលថា លោកនឹងវេចខ្ចប់ឥវ៉ាន់ទាំងនោះ ហើយចាកចេញក្នុងរយៈពេលបីថ្ងៃ ។ ( សូមមើល *Church History in the Fulness of Times*, ទំព័រ ១៣៣ ) ។

បន្ទាប់មកសូមឲ្យសិស្សឆ្លើយសំណួរនៅលើក្ដារខៀនម្ដងទៀត ។

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអានកថាខណ្ឌខាងក្រោមឲ្យឮៗ ៖

បីថ្ងៃក្រោយមក នៅថ្ងៃទី ២៣ ខែ កក្កដា ពួកជនកំណាចបានលេចមុខម្ដងទៀតនៅឃុំចាកសុន រដ្ឋមិសសួរី ម្ដងនេះពួកវាប្រដាប់ដោយកាំភ្លើងវែង កាំភ្លើងខ្លី ខ្សែតី និង ដំបង ។ ពួកជនកំណាចបានដុះគំនរចំបើង និង វាលស្រែ ហើយបានបំផ្លាញផ្ទះជាច្រើនខ្នង ជង្រុកស្រូវ និង អ្វីៗជាច្រើនទៀត ។ ទីបំផុតពួកជនកំណាចបានប្រឈមមុខគ្នាជាមួយថ្នាក់ដឹកនាំសាសនាចក្រប្រាំមួយនាក់ ដោយឃើញថាទ្រព្យសម្បត្តិ និង ជីវិតនៃពួកបរិសុទ្ធបានធ្លាក់ក្នុងភាពគ្រោះថ្នាក់ ដោយបានប្រគល់ជីវិតរបស់ខ្លួនជាថ្លៃលោះនៃអ្វីៗទាំងនោះ ។ ពួកជនកំណាចបានបដិសេធការផ្ដល់ឲ្យនោះ ពួកអ្នកដឹកនាំពួកជនកំណាចនោះបានគំរាមថា

បុរស ស្ត្រី និង កូនក្មេងគ្រប់រូបនឹងវាយនឹងខ្សែតី ប្រសិនបើពួកគេមិនយល់ព្រមចាកចេញពីឃុំនោះទេ ។ ដោយការគាបសង្កត់ បងប្អូនប្រុសបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងចាកចេញពីឃុំចាកសុន—សមាជិកសាសនាចក្រពាក់កណ្ដាល និង ថ្នាក់ដឹកនាំស្ទើរតែទាំងអស់គ្នាបានចាកចេញនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៨៣៤ ហើយអ្នកនៅសល់បានចាកចេញនៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៨៣៤ ។ ពួកជនកំណាចបានអនុញ្ញាតឲ្យ យ៉ូហាន ខូរិល និង ស៊ិឌនី គិលប៊ឺត ឲ្យបន្តនៅលក់ទ្រព្យសម្បត្តិរបស់ពួកបរិសុទ្ធដែលត្រូវបានបណ្ដេញចេញនោះ ។ ( សូមមើល *Church History in the Fulness of Times* ទំព័រ ១៣៤ ) ។

បន្ទាប់មកសូមឲ្យសិស្សឆ្លើយសំណួរនៅលើក្ដារខៀនម្ដងទៀត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវការណែនាំនៃក្បាលកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលបានបំផុសគំនិតឲ្យមានវិវរណៈនេះ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- យោងតាមការណែនាំនៃក្បាលកណ្ឌ តើអ្វីទៅដែលជាអព្ភូតហេតុដ៏អស្ចារ្យអំពីការកំណត់ពេលវេលានៃវិវរណៈនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រះឱវាទដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។ ( វាអាចមានប្រយោជន៍ដើម្បីពន្យល់ថា *សាបោត*, នៅក្នុង ខ ២, គឺជាពាក្យរបស់ភាសាហេព្រើរដែលតែងតែមានន័យថា បរិវារ ឬ ពលទ័ព ។ ការប្រើពាក្យនេះនៅក្នុងខគម្ពីរនេះ បញ្ជាក់ឲ្យឃើញថាព្រះអម្ចាស់មានពលទ័ពនៃពួកទេវតា ឬ បរិវារ និង ពលទ័ពនៃសាសន៍អ៊ីស្រាអែល ឬ ពួកបរិសុទ្ធតាមការបញ្ជារបស់ទ្រង់ ។ [ សូមមើល Bible Dictionary, « Sabaoth »] ) ។

- តើព្រះអម្ចាស់បានប្រទានព្រះឱវាទអ្វីខ្លះដល់ពួកបរិសុទ្ធ ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។
- ហេតុអ្វីវាសំខាន់ដើម្បីឲ្យពួកបរិសុទ្ធថ្លែងអំណរគុណអំឡុងគ្រាដ៏លំបាកនេះ ?
- តើអ្នកគិតថាដោយអត់ឱនរង់ចាំព្រះអម្ចាស់ មានន័យដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូប៊ើត ឌី ហេល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកអត្ថន័យនៃឃ្លា ដោយអត់ឱនរង់ចាំព្រះអម្ចាស់ ។



« តើ. . .ដោយអត់ឱនរង់ចាំព្រះអម្ចាស់មានន័យដូចម្ដេច ? នៅក្នុងព្រះគម្ពីរពាក្យ *រង់ចាំ* មានន័យថា សង្ឃឹម ចូលរួម និង ទុកចិត្ត ។ សង្ឃឹម និង ទុកចិត្តលើព្រះអម្ចាស់តម្រូវឲ្យមានសេចក្ដីជំនឿ ការអត់ធ្មត់ ការបន្ទាបខ្លួន ភាពស្លូតបូត ការអត់ទ្រាំ រក្សាព្រះបញ្ញត្តិ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត » (« Waiting upon the Lord: Thy Will Be Done » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧២ ) ។

- តើសេចក្ដីថ្លែងការណ៍របស់អែលឌើរ ហេលជួយអ្នកឲ្យយល់ពីអត្ថន័យនៃឃ្លា ដោយអត់ឱនរង់ចាំព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- ហេតុអ្វីបានជាព្រះឱវាទដើម្បីអត់ឱនរង់ចាំព្រះអម្ចាស់មានសារៈសំខាន់ចំពោះពួកបរិសុទ្ធនៅក្នុងរដ្ឋមិសសួរី ?
- តើព្រះបន្ទូលលួងលោមអ្វីខ្លះដែលព្រះអម្ចាស់បានប្រទានឲ្យដល់ពួកបរិសុទ្ធនៅក្នុង ខ ២?

សូមសរសេរសេចក្ដីថ្លែងការណ៍ពុំពេញលេញខាងក្រោមនៅលើក្ដារខៀន ៖ *ប្រសិនបើយើងថ្លែងអំណរគុណនៅក្នុងគ្រប់ការណ៍ទាំងអស់ ហើយអត់ឱនរង់ចាំព្រះអម្ចាស់ នោះ. . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពីអ្វីដែលព្រះអម្ចាស់បានសន្យាចំពោះពួកបរិសុទ្ធ ប្រសិនបើពួកគេគោរពតាមព្រះឱវាទរបស់ទ្រង់ ។

- តើអ្នកនឹងបំពេញគោលការណ៍នៅលើក្ដារខៀននេះយ៉ាងដូចម្ដេច ដោយផ្អែកលើ ខ ៣? ( ខាងក្រោមនេះគឺជារបៀបមួយដើម្បីបំពេញគោលការណ៍នេះ ៖ **ប្រសិនបើយើងថ្លែងអំណរគុណនៅក្នុងគ្រប់ការណ៍ទាំងអស់ ហើយអត់ឱនរង់ចាំព្រះអម្ចាស់ នោះព្រះអម្ចាស់អាចធ្វើឲ្យការរងទុក្ខរបស់យើងផ្សំគ្នាសម្រាប់ជាសេចក្ដីល្អរបស់យើង**) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលបានអត់ឱនរង់ចាំព្រះអម្ចាស់ អំឡុងពេលលំបាកនានា ហើយបានរកឃើញហេតុផលដើម្បីថ្លែងអំណរគុណ ។

- តើការរងទុក្ខបាននាំមកនូវសេចក្ដីល្អនៅក្នុងជីវិតរបស់មនុស្សម្នាក់នោះតាមរបៀបណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យដែលពួកស្មោះត្រង់នឹងទទួលបាន ។

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់អំពីគោលការណ៍ទាំងឡាយដែលអ្នកបានពិភាក្សាគ្នានៅក្នុងថ្នាក់រៀនថ្ងៃនេះ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២–១០៥)

សូមអញ្ជើញសិស្សឲ្យស្រមៃពីរបៀបដែលពួកគេអាចឆ្លើយតប ប្រសិនបើពួកគេត្រូវបានហៅដោយព្រះអម្ចាស់ ឲ្យធ្វើដំណើររាប់រយគីឡូម៉ែត្រ អស់រយៈពេលជាច្រើនខែដើម្បីជួយសមាជិកសាសនាចក្រដែលទីទ័លក្រ ។ សូមពន្យល់ថានៅពេលពួកគេសិក្សាខគម្ពីរដែលនៅសល់នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ និង កណ្ឌទី ១០២ រហូតដល់ ១០៥ អំឡុងសប្ដាហ៍ខាងមុខនេះ នោះពួកគេនឹងរៀនអំពីក្រុមមនុស្សដែលស្ម័គ្រចិត្តធ្វើដំណើរពីរដ្ឋអូហៃអូ ទៅរដ្ឋមិសសួរីដើម្បីជួយសមាជិកសាសនាចក្រ ។ ក្រុមនេះត្រូវបានគេស្គាល់ថាជាជំរំស៊ីយ៉ូន ។

មេរៀនទី ១០៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១

## បុព្វកថា

នៅថ្ងៃទី ១៦ និង ១៧ ខែ ធ្នូ ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈអំពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលបានចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ដើម្បីគៀសខ្លួនចេញពីសេចក្ដីបៀតបៀន ។ ពួកបរិសុទ្ធជាច្រើន ត្រូវបានបង្ខំឲ្យទុកទ្រព្យសម្បត្តិរបស់ពួកគេចោល ។ វិវរណៈដែលព្យាការីបានទទួល បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ ត្រូវបានបែងចែកទៅជាបីមេរៀន នៅក្នុងសៀវភៅសិក្សានេះ ។ មេរៀនទីបីនេះ រួមមានរឿងប្រដូចរបស់ព្រះអម្ចាស់នៃបុរសត្រកូលខ្ពស់ និងដើមអូលីវ ការបង្រៀនពីព្រះទ័យរបស់ទ្រង់អំពីសេចក្ដីប្រោសលោះនៃស៊ីយ៉ូន ។ វាក៏រួមមានទាំងការទូន្មានរបស់ព្រះអម្ចាស់ថា ពួកបរិសុទ្ធត្រូវបន្តប្រមូលផ្ដុំគ្នា ( ជាមួយនឹងសេចក្ដីយោងនៃរឿងប្រៀបធៀបរបស់ទ្រង់ពីស្រូវសាលី និងស្រងែ ) ហើយព្យាយាមសងការធ្វើខុសដែលបានធ្វើប្រឆាំងនឹងពួកគេ ( ជាមួយនឹងសេចក្ដីយោងនៃរឿងប្រៀបធៀបរបស់ទ្រង់នៃស្ត្រី និងចៅក្រមដ៏ឥតយុត្តិធម៌ម្នាក់ ) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–៦២

*ព្រះអម្ចាស់ប្រទានរឿងប្រៀបប្រដូចនៃបុរសត្រកូលខ្ពស់ និងដើមអូលីវ*

សូមសរសេរ នៅលើក្ដារខៀននូវ *រឿងប្រៀបប្រដូចនៃ . . .*

សូមពន្យល់ថា រឿងប្រៀបប្រដូចគឺជា « រឿងសាមញ្ញមួយដែលត្រូវបានប្រើ ដើម្បីបង្ហាញ និងបង្រៀន សេចក្ដីពិតខាងវិញ្ញាណ ឬពីគោលការណ៍ ។ រឿងប្រៀបប្រដូច គឺផ្អែកលើការប្រៀបធៀបកម្មវត្ថុមួយ ឬព្រឹត្តិការណ៍ធម្មតាមួយទៅនឹងរឿងពិត ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « រឿងប្រៀបប្រដូច » scriptures.lds.org ) ។

សូមឲ្យសិស្សសរសេររឿងប្រៀបប្រដូចមួយចំនួនដែលព្រះអង្គសង្គ្រោះបានបង្រៀន ក្នុងពេលនៃការបម្រើខាងសាច់ឈាមរបស់ទ្រង់ ។ ឧទាហរណ៍ សិស្សអាចរំឭកពីរឿងប្រៀបប្រដូចនៃសាសន៍សាម៉ារីដ៏ល្អ ឬរឿងប្រៀបប្រដូចនៃស្ត្រីព្រហ្មចារីទាំងដប់នាក់ ។

សូមពន្យល់ថា នៅក្នុងមេរៀនថ្ងៃនេះ សិស្សនឹងពិភាក្សាពីរឿងប្រៀបប្រដូចដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យតាមរយៈ យ៉ូសែប ស្ម៊ីធ ។ សូមបំពេញឃ្លាខាងក្រោមនៅលើក្ដារខៀន ដែលនិយាយថា ៖ *រឿងប្រៀបប្រដូចនៃបុរសត្រកូលខ្ពស់ និងដើមអូលីវ* ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសារលិខិតដែលព្រះអម្ចាស់បានមានបន្ទូលថា ទ្រង់មានព្រះទ័យចង់ប្រាប់យើងតាមរយៈរឿងប្រៀបប្រដូចនេះ ។ ( ទ្រង់ចង់ឲ្យមនុស្សយល់ពី « ព្រះទ័យទ្រង់អំពីសេចក្ដីប្រោះលោះនៃនៃស៊ីយ៉ូន » ) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ :៤៤ –៤៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយយកចិត្តទុកដាក់លើសាច់រឿងលម្អិតនៃរឿងប្រៀបធៀបនេះ ។ ដើម្បីធានាថាសិស្សយល់ពីសាច់រឿង សូមសួរសំណួរដូចខាងក្រោម ៖

- តើបុរសត្រកូលខ្ពស់ បានបញ្ជាអ្នកបម្រើរបស់គាត់ឲ្យធ្វើអ្វី ?
- តើហេតុអ្វីបានជាបុរសត្រកូលខ្ពស់ចង់បានអ្នកយាមនៅក្នុងចម្ការរបស់គាត់ ? ហេតុអ្វីបានជាគាត់ចង់ឲ្យអ្នកយាមនៅលើប៉មចាំយាម ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាតើអ្នកបម្រើធ្វើតាមការណែនាំរបស់បុរសត្រកូលខ្ពស់បានល្អដល់កម្រិតណា ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៧–៥០ ដោយស្ងាត់ស្ងៀម រកមើលថាតើអ្នកបម្រើធ្វើតាមការណែនាំរបស់បុរសត្រកូលខ្ពស់បានល្អដល់កម្រិតណា ។

*គោលការណ៍ដែលបង្កប់អត្ថន័យ*

គោលការណ៍ជាច្រើន ពុំបានថ្លែងដោយផ្ទាល់នៅក្នុងព្រះគម្ពីរទេ ប៉ុន្តែវាបន្កប់អត្ថន័យវិញ ។ ជារឿយៗ គោលការណ៍ដែលបង្កប់អត្ថន័យ អាចរកឃើញដោយការមើលទៅលើទំនាក់ទំនងមូលហេតុ និងផលប៉ះពាល់ ។ ដើម្បីជួយសិស្សឲ្យរកឃើញគោលការណ៍ដែលបង្កប់អត្ថន័យ សូមគិតពីការសុំឲ្យពួកគេពន្យល់ចំណុចសំខាន់ៗ ឬដំបូន្មានរបស់រឿងនិទាននោះ ។

- តើអ្នកបម្រើបានធ្វើតាមការណែនាំល្អដល់កម្រិតណា ? ( អ្នកអាចពន្យល់ថា នៅក្នុង ខ ៥០ ឃ្លា « ដដែកគ្នាទៅវិញទៅមក » មានន័យថា អ្នកបម្រើប្រកែកគ្នាទៅវិញទៅមក ) ។
- តើហេតុអ្វីបានជាអ្នកបម្រើបរាជ័យក្នុងការសាងសង់ប៉មចាំយាម ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ រកមើលអ្វីដែលបានកើតឡើងដោយសារតែអ្នកបម្រើមិនបានសាងសង់ប៉មចាំយាម ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥២–៥៤ ឲ្យសិស្សស្ដាប់ ។ សូមឲ្យពួកគេផ្ទៀងតាម រកមើលពាក្យរបស់បុរសត្រកូលខ្ពស់ទៅកាន់អ្នកបម្រើរបស់គាត់ ។

- យោងតាម ខ ៥៤ តើហេតុអ្វីបានបុរសត្រកូលខ្ពស់មិនសប្បាយចិត្តពេលដែលអ្នកបម្រើរបស់គាត់មិនបានសង់ប៉មចាំយាម ?
- តើព្រឹត្តិការណ៍នានាដែលបានពិពណ៌នានៅក្នុងរឿងប្រៀបប្រដូចនេះ ទាក់ទងទៅនឹងអ្វីដែលបានកើតឡើងដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី យ៉ាងដូចម្ដេច?

ជាផ្នែកនៃការពិភាក្សានេះ អ្នកអាចរំឭកសិស្សថា នៅក្នុងវិវរណៈដែលបានប្រទានឲ្យនៅខែ កក្កដា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានកំណត់ទីតាំងសម្រាប់ព្រះវិហារបរិសុទ្ធ នៅទីក្រុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥៧ ) ។ នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ បានឧទ្ទិសទីតាំងព្រះវិហារបរិសុទ្ធនៅទីក្រុង អ៊ិនឌីប៉ែនដែនស៍ ។ ទោះជាយ៉ាងណាពួកបរិសុទ្ធមិនបានធ្វើអ្វីដើម្បីកសាងព្រះបរិសុទ្ធឡើយ ។ នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៨៣៣ ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ម្ដងទៀតឲ្យកសាងព្រះវិហារបរិសុទ្ធ ( សូមមើល គ. និង ស. ៩៧ ) ។

- តើប៉មចាំយាមនៅក្នុងរឿងប្រៀបប្រដូច អាចទាក់ទងនឹងព្រះវិហារបរិសុទ្ធដែលពួកបរិសុទ្ធបរាជ័យក្នុងការកសាងយ៉ាងដូចម្ដេច ?
- តើគោលការណ៍ អ្វីខ្លះនៅក្នុងរឿងប្រៀបប្រដូចនេះ ដែលយើងអាចអនុវត្តនៅក្នុងជីវិតយើង ? ( ព្រោះថារឿងប្រៀបប្រដូចអាចមានន័យច្រើន សិស្សអាចស្នើនូវគោលការណ៍មួយចំនួនដែលមានដូចខាងក្រោមនេះ ៖ **នៅពេលយើងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងត្រូវបានពង្រឹងឲ្យស៊ូទ្រាំនឹងសត្រូវទាំងខាងវិញ្ញាណនិងខាងសាច់ឈាម ។ ពួកព្យាការីបម្រើជាអ្នកយាមនៅលើប៉មចាំយាម ព្រមានយើងពីគ្រោះថ្នាក់ដែលនឹងកើតឡើង ។ តាមរយៈកិច្ចការព្រះវិហារបរិសុទ្ធ យើងរៀបចំខ្លួនដើម្បីស៊ូទ្រាំនឹងមារសត្រូវ** ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥៥–៦២ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលបុរសត្រកូលខ្ពស់បានបញ្ជាដល់អ្នកបម្រើគាត់ឲ្យធ្វើ ។

- តើបុរសត្រកូលខ្ពស់បានប្រាប់អ្នកបម្រើគាត់ឲ្យធ្វើអ្វី ? ( ឲ្យប្រមូលផ្ដុំពលទ័ព ហើយរំដោះចម្ការទំពាំងបាយជូរឡើងវិញ ) ។

សូមពន្យល់ថា អ្នកបម្រើដែលបានលើកឡើងនៅក្នុង ខ ៥៥ តំណាងឲ្យ យ៉ូសែប ស្ម៊ីធ ( សូមមើល គ. និង ស. ១០៣:២១ ) ។ យ៉ូសែប ស្ម៊ីធ បានធ្វើតាមបញ្ជារបស់ព្រះអម្ចាស់ ហើយបានរៀបចំក្រុមមួយដែលហៅថា ជុំរំស៊ីយ៉ូន ដើម្បីរំដោះដែនដីស៊ីយ៉ូនឡើងវិញ ។ ជុំរំស៊ីយ៉ូន នឹងត្រូវបានពិភាក្សានៅក្នុងមេរៀនទី ១០៨ និងមេរៀនទី ១១០ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៣–៧៥

*ព្រះអម្ចាស់ដាស់តឿនពួកបរិសុទ្ធឲ្យបន្តធ្វើការរួមគ្នា*

សូមពន្យល់ថា ទោះជាពួកបរិសុទ្ធនៅឃុំ ចាកសុន រដ្ឋ មិសសួរី ត្រូវបានបណ្ដេញចេញពីផ្ទះសម្បែងរបស់ពួកគេក្ដី ព្រះអម្ចាស់បានបញ្ជាពួកគេឲ្យបន្តកសាងនគររបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៣–៦៤ ឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បានបន្ទូលថា ទ្រង់នឹងបន្តធ្វើ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៥–៦៦ ដោយស្ងាត់ស្ងៀម រកមើលរឿងប្រៀបប្រដូចដែលព្រះអម្ចាស់បានមានបន្ទូល ។

- តើស្រូវសាលី និងស្រងែនៅក្នុងរឿងប្រៀបប្រដូចនេះ តំណាងឲ្យអ្វី ? ( ស្រូវសាលីតំណាងឲ្យសមាជិកស្មោះត្រង់នៃសាសនាចក្រ ហើយស្រងែតំណាងឲ្យមនុស្សទុច្ចរិតនៃពិភពលោក ។ អ្នកអាចពន្យល់ថា ស្រងែជាស្មៅដែលដូចជាស្រូវសាលីពេលវានៅខ្ចី ) ។

ដើម្បីជួយសិស្សឲ្យយល់រឿងប្រៀបប្រដូចនេះ សូមពន្យល់ថាសម័យបុរាណ ជង្រុកគឺជាកន្លែងដែលស្រូវសាលីត្រូវបានប្រមូល ហើយរក្សាទុកឲ្យត្រឹមត្រូវ ។ ដោយផ្អែកលើរឿងប្រដូចនេះ និងការបង្រៀនផ្សេងទៀតនៅក្នុងព្រះគម្ពីរ អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា « ជង្រុក គឺជាព្រះវិហារបរិសុទ្ធ » (« Honorably Hold a Name and Standing » *Ensign* ឬ *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០០៩,ទំព័រ ៩៧ ) ។ សូមសរសេរពាក្យដូចខាងក្រោមនៅលើក្ដារខៀន៖ *ជង្រុក = ព្រះវិហារបរិសុទ្ធ*

- យោងតាមរឿងប្រៀបប្រដូចនេះ តើពរជ័យអ្វីដែលយើងនឹងទទួល ដោយការប្រមូលផ្ដុំ ហើយបម្រើនៅព្រះវិហារបរិសុទ្ធ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរប្រាប់អំពីគោលការណ៍ដូចខាងក្រោម ៖**នៅពេលយើងប្រមូលផ្ដុំគ្នានៅព្រះវិហារបរិសុទ្ធ យើងទទួលបានការការពារ ហើយរៀបចំខ្លួនយើងសម្រាប់ជីវិតដ៏អស់កល្បជានិច្ច** ) ។

- តើអ្នកគិតថាសេចក្ដីសញ្ញានៅក្នុងព្រះវិហារបរិសុទ្ធ អាចការពារ ហើយរៀបចំយើងសម្រាប់ជីវិតដ៏នៅអស់កល្ប ជានិច្ច យ៉ាងដូចម្ដេច ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ឲ្យចែកចាយអំពីរបៀបដែលព្រះវិហារបរិសុទ្ធជាប្រភពនៃការការពារ និងការរៀបចំសម្រាប់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ ។ អ្នកអាចបន្ថែមទីបន្ទាល់របស់អ្នកលើគោលការណ៍នេះផងដែរ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៧–៧៥ ដោយពន្យល់ថា ទោះជាពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីឃុំ ចាកសុន រដ្ឋ មិសសួរី ក្ដីក៏ព្រះអម្ចាស់បានទូន្មានពួកគេឲ្យបន្តទិញដីនៅទីនោះ និងនៅឃុំជិតខាងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១: ៧៦ –១០១

*ព្រះអម្ចាស់ទូន្មានពួកបរិសុទ្ធឲ្យបន្តស្វែងរកវិធីត្រឡប់ទៅផ្ទះពួកគេនៅរដ្ឋ មិសសួរី វិញ*

សូមពន្យល់ថា លើសពីការណែនាំពួកបរិសុទ្ធឲ្យទិញអចលទ្រព្យ ព្រះអម្ចាស់បានមានបន្ទូលប្រាប់ពួកគេឲ្យ « តវ៉ាសូមឲ្យកែសាទុក្ខ » ដោយសារទង្វើរបស់ពួកអ្នកដែលបានបៀតបៀនពួកគេ ( សូមមើល គ. និង ស. ១០១:៧៦ ) ។ ពាក្យម្យ៉ាងវិញទៀត ទ្រង់មានបន្ទូលឲ្យពួកគេស្វែងរកយុត្តិធម៌តាមប្រព័ន្ធស្របច្បាប់របស់រដ្ឋាភិបាល ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៧៦–៨០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលប្រព័ន្ធច្បាប់ដែលនឹងអនុញ្ញាតឲ្យពួកបរិសុទ្ធស្វែងរកជំនួយពីថ្នាក់ដឹកនាំក្នុងរដ្ឋាភិបាល ។

- ស្របតាមខគម្ពីរទាំងនេះ ព្រះអម្ចាស់បានដឹកនាំការស្ថាបនារដ្ឋធម្មនុញ្ញសម្រាប់សហរដ្ឋប៉ុន្មានឆ្នាំមុននោះ។ តើហេតុអ្វីបានជាទ្រង់ចង់ឲ្យរក្សារដ្ឋធម្មនុញ្ញ ?

- ព្រះអម្ចាស់បានមានបន្ទូលថាគោលបំណងមួយនៃ « សិទ្ធិជ្រើសរើសខាងសិលធម៌ » គឺដើម្បីធានាថាយើង « ទទួលខុសត្រូវចំពោះអំពើបាបទាំងឡាយរបស់[យើង] » ( គ. និង ស. ១០១:៧៨ ) ។ តើហេតុអ្វីបានជាការទទួលខុសត្រូវ—ទំនួលខុសត្រូវសម្រាប់ទង្វើរបស់យើង—ជាផ្នែកសំខាន់នៃសិទ្ធិជ្រើសរើស ? តើអ្នកនឹងឆ្លើយទៅនឹងនរណាម្នាក់ដែលនិយាយថា « ខ្ញុំមានសេរីភាពនឹងធ្វើអ្វីៗដែលខ្ញុំចង់ធ្វើ » យ៉ាងដូចម្ដេច?

- ព្រះអម្ចាស់បានមានបន្ទូលថា គ្មាននរណាម្នាក់គួរជាប់ក្នុងទាសភាពរបស់នរណាម្នាក់ឡើយ ។ តើហេតុអ្វីបានជាអ្នកគិតថាវាសំខាន់ដែលមនុស្សមិនជាប់ចំណងនោះ ?

ជាផ្នែកនៃការពិភាក្សានេះ សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្ដារខៀន ៖ *ព្រះបានប្រទានឲ្យយើងនូវសិទ្ធិជ្រើសរើសខាងសិលធម៌ ជាអំណាចដើម្បីជ្រើសរើស ប៉ុន្តែយើង . . .*

សូមអញ្ជើញសិស្សឲ្យបំពេញឃ្លាខាងក្រោមយោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៧៨ ។ ( នៅពេលសិស្សប្រាប់គោលការណ៍ដូចខាងក្រោម សូមបំពេញឃ្លានៅលើក្ដារខៀន ៖ **ព្រះប្រទានសិទ្ធិជ្រើសរើសខាងសិលធម៌ ជាអំណាចដើម្បីជ្រើសរើស ប៉ុន្តែយើងទទួលខុសត្រូវសម្រាប់ជម្រើសរបស់យើង**) ។

សូមពន្យល់ថា ព្រះអម្ចាស់ប្រើរឿងប្រៀបប្រដូចដើម្បីលើកទឹកចិត្តពួកបរិសុទ្ធឲ្យស្វែងរកជំនួយពីថ្នាក់ដឹកនាំក្នុងរដ្ឋាភិបាល ។ សូមអញ្ជើញសិស្សឲ្យអានរឿងប្រៀបប្រដូចនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៨១–៨៤ ( សូមមើលផងដែរ លូកា ១៨:១–៨ ) ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយពិចារណាពីរបៀបដែលរឿងប្រៀបប្រដូចនោះអនុវត្តចំពោះពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ បន្ទាប់មកឲ្យសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៨៥–៨៨ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលព្រះអង្គសង្គ្រោះ អនុវត្តរឿងប្រៀបប្រដូចនោះចំពោះពួកបរិសុទ្ធ ។

- ក្នុងពេលនៃប្រវត្តិសាសនាចក្រនេះ តើស្ត្រីមេម៉ាយអាចតំណាងឲ្យនរណា ? ( សមាជិកទាំងឡាយនៃសាសនាចក្រ ) ។ តើចៅក្រមតំណាងឲ្យនរណា ? ( ចៅក្រមអាចតំណាងឲ្យពួកចៅក្រមទាំងឡាយ និងថ្នាក់ដឹកនាំក្នុងរដ្ឋាភិបាល ជាអ្នកដែលពួកបរិសុទ្ធនឹងសុំជំនួយ ។ គាត់ក៏អាចតំណាងឲ្យព្រះវរបិតាសួគ៌ ជាអ្នកដែលពួកបរិសុទ្ធនឹងបន្តអធិស្ឋានទៅរកផងដែរ ) ។
- ដោយប្រើរឿងប្រៀបប្រដូចនេះ តើរឿងជាក់លាក់អ្វីមួយដែលព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធធ្វើ ?

សូមពន្យល់ថា ពួកបរិសុទ្ធបានប្ដឹងសាទុក្ខទៅចៅក្រមក្នុងសាលាក្ដីប្រចាំតំបន់ ប៉ុន្តែមិនបានទទួលការគាំទ្រដែលពួកគេសង្ឃឹមចង់បាននោះទេ ។ ពួកគេបានសូមឲ្យ ដានីយ៉ែល ដាក់គ្លីន ជាអភិបាលរដ្ឋ មិសសួរី និង អែនដ្រូ ចាកសុន ជាប្រធានាធិបតីសហរដ្ឋ ឲ្យជួយពួកគេត្រឡប់ទៅផ្ទះ និងឲ្យដីធ្លីរបស់ពួកគេវិញ និងផ្ដល់នូវការការពារសម្រាប់ពួកគេ ។ ពួកអ្នកដឹកនាំទាំងពីរបានបដិសេធមិនជួយពួកគេ ។ ពួកបរិសុទ្ធក៏បានដាក់ពាក្យស្នើទៅ និតិបញ្ញត្តិរដ្ឋមិសសួរី ផងដែរ ប៉ុន្តែពួកគេបដិសេធមិនជួយ ។

សូមយោងទៅលើគោលការណ៍ ដែលអ្នកបានសរសេរនៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៨៩ –៩១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលថ្នាក់ដឹកនាំរដ្ឋាភិបាល នឹងត្រូវឲ្យទទួលខុសត្រូវបើពួកគេបដិសេធន៍មិនជួយពួកបរិសុទ្ធ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩២–៩៥ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលប្រាប់ពួកបរិសុទ្ធឲ្យធ្វើសម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាលរបស់ពួកគេ ។

- តើ ខ ៩២ បង្រៀនយើងអ្វីខ្លះអំពីព្រះអម្ចាស់ ? ( ទ្រង់មិនចង់ដាក់ទោសមនុស្សទេ ។ ទ្រង់មានព្រះទ័យចង់ឲ្យមនុស្សទាំងអស់ប្រែចិត្ត ដូច្នេះទ្រង់អាចមេត្តាដល់ពួកគេ ) ។

សូមសង្ខេប គោលលទ្ធិ និងសេចក្ដីសញ្ញា ១០១:៩៦–១០១ ដោយពន្យល់ថា ព្រះអម្ចាស់បានទូន្មានពួកបរិសុទ្ធឲ្យរក្សាទ្រព្យសម្បត្តិរបស់ពួកគេក្នុងឃុំ ចាកសុន ទោះជាពួកគេមិនបានអនុញ្ញាតឲ្យរស់នៅទីនោះក៏ដោយ ។ ទ្រង់បានសន្យាថា បើពួកគេរស់នៅដោយមានភាពសក្ដិសម នៅថ្ងៃណាមួយពួកគេនឹងអាចរស់នៅទីនោះវិញ ។

ដើម្បីបញ្ចប់ សូមថ្លែងទីបន្ទាល់របស់អ្នកពីគោលការណ៍ដែលសិស្សបានពិភាក្សា ។

មេរៀនទី ១០៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២

## សេចក្ដីផ្ដើម

ត្រឹមខែ មករា ឆ្នាំ ១៨៣៤ សាសនាចក្របានរីកចម្រើន ហើយមានសមាជិកច្រើនជាង៣០០០នាក់ ។ ការរីកចម្រើននេះ បានបង្កើតឲ្យមានតម្រូវការសម្រាប់ថ្នាក់ដឹកនាំបន្ថែមទៀត ដើម្បីគ្រប់គ្រងកិច្ចការសាសនាចក្រ ។ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៨៣៤ សង្ឃជាន់ខ្ពស់ម្ភៃបួននាក់ បានប្រមូលផ្ដុំគ្នានៅក្នុងផ្ទះរបស់ យ៉ូសែប ស្ម៊ីធ សម្រាប់សន្និសីទ ដែលក្រុមប្រឹក្សាជាន់ខ្ពស់ទីមួយត្រូវបានរៀបចំឡើង ។ អូរសុន ហៃឌ ជាស្មៀននៃការប្រជុំ បានសម្គាល់ឃើញថា ក្រុមប្រឹក្សាជាន់ខ្ពស់អាចមានកំហុសឆ្គងមួយចំនួននៅក្នុងការកត់ត្រានៃការប្រជុំនោះ ។ ដូច្នេះ ក្រុមប្រឹក្សាបានបោះឆ្នោតថាព្យាការី គួរតែធ្វើការកែតម្រូវដែលចាំបាច់ ។ យ៉ូសែប ស្ម៊ីធ បានចំណាយពេលនៅថ្ងៃបន្ទាប់ នៅថ្ងៃទី ១៨ ខែ កុម្ភៈ បានធ្វើការកែតម្រូវដ៏បំផុសគំនិតសម្រាប់កំណត់ត្រាពីមុនទាំងប៉ុន្មាន ។ កំណត់ត្រាត្រូវបានកែតម្រូវ និងទទួលយកនៅថ្ងៃបន្ទាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ។ ឥឡូវវាត្រូវបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២ កំណត់ត្រាទាំងនេះពន្យល់ពីការស្ថាបនាក្រុមប្រឹក្សាជាន់ខ្ពស់ និងផ្ដល់នូវការដឹកនាំសម្រាប់គណៈប្រធានស្តេក និងក្រុមប្រឹក្សាជាន់ខ្ពស់ពេលពួកគេចាត់ចែងការណែនាំសម្រាប់បុគ្គលដែលបានធ្វើការរំលងដ៏ធ្ងន់ធ្ងរ ។ ( សូមចំណាំថា គណៈប្រធានមណ្ឌល និងទីប្រឹក្សាមណ្ឌលក៏អាចអនុញ្ញាតឲ្យធ្វើតាមដំណើរការទាំងនេះដែរ )។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:១–៥

*ក្រុមប្រឹក្សាជាន់ខ្ពស់ដំបូងបំផុតនៃសាសនាចក្រត្រូវបានរៀបចំឡើង*

**សូមអាន ដំណើររឿងខាងក្រោម ដែលប្រាប់ដោយប្រធាន ហារ៉ូល ប៊ី លី ឲ្យឮៗ ៖**



« ប៉ុន្មានឆ្នាំមុន . . . ខ្ញុំបានបម្រើជាប្រធានស្តេក ។ យើងមានករណីដ៏សោកសៅមួយដែលត្រូវបាននាំមកចំពោះទីប្រឹក្សាជាន់ខ្ពស់ និងគណៈប្រធានស្តេក ដែលជាលទ្ធផលនៃការកាត់កាលចោលបុរសម្នាក់ដែលបានបង្កគ្រោះថ្នាក់ដល់យុវនារីដ៏គួរឲ្យស្រឡាញ់ម្នាក់ ។ បន្ទាប់ពីការប្រជុំស្ទើរតែពេញមួយយប់ទាក់ទងនឹងករណីនោះមក ខ្ញុំបានទៅការិយាល័យរបស់ខ្ញុំដោយអស់កម្លាំងនៅព្រឹកបន្ទាប់ ហើយត្រូវបានប្រឈមមុខជាមួយបងប្រុសរបស់បុរសនោះ ដែលយើង [ បានជួបនៅក្នុងក្រុមប្រឹក្សា ] នៅយប់មុននោះ ។ បុរសនេះបាននិយាយថា ‹ ខ្ញុំចង់ប្រាប់អ្នកថា ប្អូនប្រុសរបស់ខ្ញុំ គ្មានកំហុសដូចដែលអ្នកបានចោទប្រកាន់នោះទេ › ។

« ‹ តើអ្នកដឹងថា គេគ្មានកំហុសដោយរបៀបណា ? ខ្ញុំបានសួរ ។

« ‹ បុរសនោះបានឆ្លើយថា ‹ ដោយសារខ្ញុំបានអធិស្ឋាន ហើយព្រះអម្ចាស់បានប្រាប់ខ្ញុំថា គេគ្មានកំហុសទេ ›»
( *Teachings of Harold B. Lee,* ed. Clyde J. Williams [ឆ្នាំ ១៩៩៦],ទំព័រ ៤២០–២១ ) ។

*ការប្រើរឿងនិទាន*

រឿងនិទានអាចជួយទាក់ទាញសិស្ស ដោយបង្កើតចំណាប់អារម្មណ៍ និង ដោយអនុញ្ញាតឲ្យពួកគេរៀនតាមរយៈការស្ដាប់បទពិសោធន៍របស់អ្នកដទៃទៀត ។ រឿងនិទានក៏អាចជួយសិស្សឲ្យឃើញពីរបៀបដែលគោលការណ៍ទាំងឡាយនៃដំណឹងល្អ អនុវត្តនៅក្នុងជីវិតរបស់មនុស្សផងដែរ ។

- នៅក្នុងគំនិតរបស់អ្នក តើបុរសនោះអាចបានទទួលចម្លើយខុសពីការសម្រេចចិត្តដែលបានធ្វើឡើងដោយគណៈប្រធានស្តេក និងក្រុមប្រឹក្សាជាន់ខ្ពស់បានយ៉ាងដូចម្ដេច ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២ មាននូវគោលការណ៍ដែលជួយយើងឲ្យយល់ពីរបៀបដែលគណៈប្រធានស្តេក និងក្រុមប្រឹក្សាជាន់ខ្ពស់ព្យាយាមស្វែងយល់ព្រះទ័យព្រះអម្ចាស់ អំពីរបៀបដើម្បីជួយសមាជិកសាសនាចក្រ ដែលបានប្រព្រឹត្តការរំលងដ៏ធ្ងន់ធ្ងរ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ថា ក្រុមប្រឹក្សាជាន់ខ្ពស់ជាអ្វី ។

- តើក្រុមប្រឹក្សាជាន់ខ្ពស់ជាអ្វី ? ( ជាក្រុមដែលមានសង្ឃជាន់ខ្ពស់ ១២នាក់ ដោយមាន« ម្នាក់ឬបីនាក់ ក្នុងចំណោមគណៈប្រធានទី១ » ជាអធិបតី ។ នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ ប្រធានស្តេក និងទីប្រឹក្សារបស់លោក ជាអធិបតីលើក្រុមប្រឹក្សាជាន់ខ្ពស់ ) ។

សូមពន្យល់ថា ក្រុមប្រឹក្សាជាន់ខ្ពស់ត្រូវបានពិពណ៌នានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២ មានភាពខុសគ្នាមួយចំនួនពីក្រុមប្រឹក្សាជាន់ខ្ពស់នៅក្នុងស្ដេកសព្វថ្ងៃនេះ ។ វាជាតុលាការទូទៅនៅក្នុងទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ និងតំបន់ដែលនៅជុំវិញនោះ ហើយជាអធិបតីគ្រប់គ្រងដោយ គណៈប្រធានទីមួយ ។ ប៉ុន្ដែ នៅពេលសមាជិកភាពនៅក្នុងសាសនាចក្របានកើនឡើង ស្ដេកត្រូវបានរៀបចំឡើង ហើយគណៈប្រធានស្ដេក និងក្រុមប្រឹក្សាជាន់ខ្ពស់ត្រូវបានហៅឲ្យបម្រើសាសនាចក្រនៅក្នុងដែនកំណត់ស្ដេកនីមួយៗ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលគោលបំណងនៃក្រុមប្រឹក្សាជាន់ខ្ពស់ និងរបៀបដែលវាត្រូវបានចាត់តាំងឡើង ។

- តើក្រុមប្រឹក្សាជាន់ខ្ពស់ត្រូវបានចាត់តាំងឡើងយ៉ាងដូចម្ដេច ? តើគោលបំណងរបស់វាជាអ្វី ?

បន្ទាប់ពីសិស្សឆ្លើយតបទៅនឹងសំណួរខាងលើ សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ក្រុមប្រឹក្សាជាន់ខ្ពស់ត្រូវបានចាត់តាំងដោយវិវរណៈ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗដែលកើតឡើងនៅក្នុងសាសនាចក្រ ។** សូមពន្យល់ថា ជាធម្មតា « បញ្ហាសំខាន់ »សំដៅទៅលើស្ថានភាពដែលសមាជិកបានប្រព្រឹត្តអំពើរំលងធ្ងន់ធ្ងរ ។

សូមពន្យល់ថា ដំណើររឿងរបស់ប្រធាន លី នៅខាងដើមមេរៀនផ្ដល់នូវឧទាហរណ៍នៃការទទួលខុសត្រូវមួយរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ ៖ ដើម្បីតំណាងជាក្រុមប្រឹក្សាវិន័យ នៅក្រោមការដឹកនាំរបស់គណៈប្រធានស្ដេក ។ ដើម្បីជួយសមាជិកក្នុងថ្នាក់ឲ្យយល់ពីគោលបំណងនៃក្រុមប្រឹក្សាវិន័យ សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់ពីគោលបំណងបីយ៉ាង នៃក្រុមប្រឹក្សាវិន័យសាសនាចក្រ ។

> « អំពើរំលងដ៏ធ្ងន់ធ្ងរបំផុត ដូចជាប្រព្រឹត្តអំពើហឹង្សាប្រឆាំងនឹងច្បាប់រដ្ឋប្បវេណី រំលោភបំពានប្ដី ឬប្រពន្ធ រំលោភបំពានលើកុមារ ផិតក្បត់ ប្រាសចាកសិលធម៌ រំលោភសេពសន្ថវៈ និងស្មន់ភាព ដែលជារឿងតម្រូវឲ្យមានការដាក់វិន័យជាផ្លូវការរបស់សាសនាចក្រ ។ ការដាក់វិន័យជាផ្លូវការរបស់សាសនាចក្រ អាចរួមមានការដាក់កម្រិតលើសិទ្ធិជាសមាជិកភាពសាសនាចក្រ ឬបាត់បង់សមាជិកភាពក្នុងសាសនាចក្រ ។. . .
>
> « . . . គោលបំណងរបស់ក្រុមប្រឹក្សាវិន័យ គឺត្រូវ [១] សង្គ្រោះព្រលឹងជនដែលប្រព្រឹត្តអំពើរំលង, [២] ការពារជនស្មោះត្រង់ និង [៣] ការពារភាពបរិសុទ្ធ ភាពត្រឹមត្រូវ និងកិត្តិយសរបស់សាសនាចក្រ ។
>
> « វិន័យរបស់សាសនាចក្រ គឺជាដំណើរការដ៏បំផុសគំនិត ដែលត្រូវការពេលវេលាយូរ ។ តាមរយៈដំណើរការនេះ និងតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ សមាជិកម្នាក់អាចទទួលបានការអភ័យទោសនៃអំពើបាប ទទួលបានភាពសុខសាន្តនៅក្នុងចិត្តម្ដងទៀត និងចម្រើនឡើងនូវកម្លាំង ដើម្បីចៀសវាងពីការរំលងនាពេលអនាគត » (*ពិតចំពោះសេចក្ដីជំនឿ ៖ សេចក្ដីយោងនៃដំណឹងល្អ* [ ឆ្នាំ២០០៤ ] ទំព័រ ៣៧–៣៨ ) ។

- តើគោលបំណងទាំងបីនៃក្រុមប្រឹក្សាវិន័យរបស់សាសនាចក្រ គឺជាអ្វី ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលពិពណ៌នាអំពីរបៀបដែលសមាជិកនៃក្រុមប្រឹក្សាជាន់ខ្ពស់បំពេញកាតព្វកិច្ចរបស់ពួកគេ ។ រួចហើយឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:៦–៣៤

### *ដំណើរការសម្រាប់ក្រុមប្រឹក្សាវិន័យត្រូវបានបង្កើតឡើង*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:៦–១១ ដោយប្រាប់សិស្សថា ខគម្ពីរទាំងនេះពន្យល់ពីរបៀបដែលក្រុមប្រឹក្សាជាន់ខ្ពស់ដំណើរការ នៅពេលដែលសមាជិកក្នុងក្រុមទាំងអស់អវត្តមាន ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:១២–១៤ ដោយស្ងាត់ស្ងៀម ដើម្បីរៀនពីរបៀបដែលសមាជិកក្រុមប្រឹក្សាម្នាក់ត្រូវបានជ្រើសរើសឲ្យនិយាយនៅក្នុងក្រុមប្រឹក្សាវិន័យ ។ រួចហើយឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើការចាប់ឆ្នោតមានន័យដូចម្ដេច ? ( ក្នុងករណីនេះ វាមានន័យថា សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ចាប់ពីលេខ ១ ដល់លេខ ១២ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:១៥–១៨ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុដែលក្រុមប្រឹក្សាជាន់ខ្ពស់ចាប់លេខ ។

- តើយើងអាចរៀនអ្វីពី ខ ១៥–១៦ អំពីរបៀបដែលក្រុមប្រឹក្សាវិន័យត្រូវបានដឹកនាំ ? ( បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ **នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ក្រុមប្រឹក្សាវិន័យត្រូវបានដឹកនាំស្របតាមសមធម៌ និងយុត្តិធម៌**) ។

- បើក្រុមប្រឹក្សាជាន់ខ្ពស់ម្នាក់ចាប់បានលេខគូអំឡុង ពេល ការប្រជុំក្រុមប្រឹក្សាវិន័យ តើទំនួលខុសត្រូវរបស់លោកជាអ្វី ? តើការណ៍នេះបង្ហាញពីព្រះទ័យព្រួយបារម្ភរបស់ព្រះអម្ចាស់ សម្រាប់សមាជិកសាសនាចក្រ ដែលបានប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលប្រធាននៃក្រុមប្រឹក្សាត្រូវធ្វើ បន្ទាប់ពីឮរឿងពីភាគីទាំងសងខាងហើយ ។ រួចហើយឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើវាជួយដល់ប្រធានស្ដេកឲ្យធ្វើការសម្រេចចិត្តស្ដាប់សមាជិកនៃក្រុមប្រឹក្សានិយាយពីចំណាប់អារម្មណ៍របស់ជនជាប់ចោទក៏ដូចជាចំណាប់អារម្មណ៍របស់សាសនាចក្រយ៉ាងដូចម្ដេច ?

សូមសូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ហើយសូមឲ្យសិស្សក្នុងថ្នាក់សង្កេតមើលពីអ្វីដែលប្រធានក្រុមប្រឹក្សាធ្វើ បន្ថែមពីលើការស្ដាប់រឿងពីភាគីទាំងសងខាង ៖



« ខ្ញុំសូមអះអាងនឹងអ្នកថា . . . ខ្ញុំគិតថាមិនដែលមានការវិនិច្ឆ័យណាត្រូវបានសម្រេចមុនការអធិស្ឋាននោះទេ ។ លទ្ធផលដែលចេញពីការវិនិច្ឆ័យរបស់មនុស្ស គឺជាទង្វើទាស់នឹងសមាជិកម្នាក់ដ៏ធ្ងន់ធ្ងរ ជាពិសេសដោយសារមនុស្សតែម្នាក់ ។ វាត្រូវតែមានការដឹកនាំពីព្រះវិញ្ញាណ ដើម្បីឲ្យមានភាពយុត្តិធម៌ដោយការព្យាយាមស្វែងរកដោយស្មោះហើយធ្វើតាម » ( In . . . Counsellors There Is Safety » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩០, ទំព័រ ៥០ ) ។

- តើប្រធានស្ដេកធ្វើអ្វី បន្ថែមពីលើការស្ដាប់រឿងពីភាគីទាំងសងខាងហើយ ?

- យោងតាម ខ ១៩ តើប្រធានស្នើសុំឲ្យក្រុមប្រឹក្សាធ្វើអ្វីបន្ទាប់ពីលោកបានធ្វើការសម្រេចចិត្តហើយនោះ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:២០–២២ ដោយការពន្យល់ថា ខគម្ពីរទាំងនេះ ផ្ដល់ការណែនាំអំពីអ្វីដែលត្រូវធ្វើ បើគ្មានការច្បាស់លាស់អំពីការសម្រេចចិត្តនោះ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:២៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីអ្វីដែលគួរតែធ្វើក្នុងករណីដែលបញ្ហាគោលលទ្ធិមិនច្បាស់លាស់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

- តើសេចក្ដីពិតអ្វីដែលបានបង្រៀននៅក្នុង ខ ២៣ ? ( បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បានសម្ដែងព្រះទ័យទ្រង់ដល់អ្វីដែលជាអធិបតីលើក្រុមប្រឹក្សាវិន័យ**

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២:២៧–៣៤ ដោយពន្យល់ថា ការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាវិន័យស្ដេកអាចត្រូវបានដាក់ស្នើដល់គណៈប្រធានទីមួយ ។

សូមពិនិត្យមើលដំណើររឿងដែលប្រាប់ដោយប្រធាន ហារ៉ូល ប៊ី លី នៅខាងដើមនៃមេរៀននេះជាមួយសិស្ស ។

- តើអ្នកមានទំនុកចិត្តលើនរណាជាង—រវាងគណៈប្រធានស្ដេក និងក្រុមប្រឹក្សាជាន់ខ្ពស់ ឬបុរសដែលប្រឆាំងទាស់នឹងការសម្រេចចិត្តរបស់ពួកគេ ?

- ផ្អែកលើសេចក្ដីពិតដែលអ្នកបានរៀន នៅក្នុងការសិក្សារបស់អ្នកក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២ ហេតុអ្វីបានជាយើងអាចមានទំនុកចិត្តក្នុងការសម្រេចចិត្តដែលធ្វើឡើងដោយក្រុមប្រឹក្សាវិន័យនៃសាសនាចក្រ ?

បន្ទាប់ពីសិស្សបានឆ្លើយតបហើយ អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងរបស់ប្រធាន លី ដែលនៅសល់ឲ្យឮៗ ៖



« ខ្ញុំបានសូមឲ្យគាត់ចូលមកក្នុងការិយាល័យ ហើយយើងបានអង្គុយចុះ ហើយខ្ញុំបានសួរថា ‹ តើខ្ញុំអាចសួរអ្នកនូវសំណួរផ្ទាល់ខ្លួនមួយចំនួនបានទេ ? ›

« គាត់បាននិយាយថា ‹ ពិតជាមិនបានទេ › ។. . .

« ‹ តើអ្នកមានអាយុប៉ុន្មានហើយ ? ›

« ‹ សែសិបប្រាំពីរឆ្នាំ › ។

« ‹ តើអ្នកកាន់បព្វជិតភាពថ្នាក់អ្វី ? ›

« គាត់បាននិយាយថា គាត់គិតថាគាត់កាន់បព្វជិតភាពថ្នាក់គ្រូបង្រៀន ។

« ‹ តើអ្នករក្សាច្បាប់សុខភាពទេ ? ›

« ‹ អត់ទេ › . . .

« ‹ តើអ្នកបង់ដង្វាយមួយភាគក្នុងដប់ទេ ? ›

« គាត់បាននិយាយថា ‹ ទេ ›—ហើយគាត់មិនដែលគិតចង់ធ្វើវាទេ ដរាបណា . . . បុរសនោះនៅជាប៊ីស្សពនៃវួដទីសាមសិបពីរនោះ ។

« ខ្ញុំបាននិយាយថា ‹ តើអ្នកចូលរួមការប្រជុំបព្វជិតភាពរបស់អ្នកទេ ? ›

« គាត់បានតបថា ‹ អត់ទេលោក ! ›. . .

« ‹ តើអ្នកមិនបានចូលរួមការប្រជុំសាក្រាម៉ង់ដែរមែនទេ ? ›

« ‹ អត់ទេលោក › ។

« ‹ តើអ្នកមានការអធិស្ឋានជាក្រុមគ្រួសារទេ ? › ហើយគាត់បាននិយាយថា ទេ ។

« ‹ តើអ្នកបានសិក្សាព្រះគម្ពីរទេ ? › គាត់បាននិយាយថា ភ្នែករបស់គាត់មើលមិនច្បាស់ ហើយគាត់មិនអាចអានបានច្រើនទេ ។. . .

«ខ្ញុំបាននិយាយថា ‹ ឥឡូវមើលចុះ › ‹ បុរសដប់ប្រាំនាក់ដែលល្អបំផុតនៅក្នុងស្តេក ផាយអូនៀ បានអធិស្ឋានកាលពីយប់មិញ. . .ហើយបុរសម្នាក់បានរួបរួមគ្នា ។. . . ហើយពេលនេះ អ្នកគឺជាអ្នកដែលមិនបានធ្វើការណ៍ទាំងនេះសោះ អ្នកបែរជានិយាយថា អ្នកបានអធិស្ឋាន ហើយបានទទួលចម្លើយដែលផ្ទុយពីនោះ ។ តើអ្នកនឹងពន្យល់វាបានយ៉ាងដូចម្តេច ? ›

« ហើយបុរសនោះបានផ្តល់ចម្លើយមួយ ដែលខ្ញុំគិតថាជាចម្លើយដ៏សមរម្យ ។ គាត់បាននិយាយថា ‹ ប្រធាន លី ខ្ញុំគិតថា ខ្ញុំទទួលបានចម្លើយពីប្រភពខុសហើយ › ( *Teachings of Harold B. Lee,* ទំព័រ ៤២១–២២ ) ។

សូមគិតពីការចែកចាយទីបន្ទាល់អ្នកទាក់ទងនឹងមូលហេតុ ដែលយើងអាចទុកចិត្តលើការសម្រេចចិត្តរបស់គណៈប្រធានស្តេក និងក្រុមប្រឹក្សាជាន់ខ្ពស់ក្នុងសាសនាចក្រ ។

មេរៀនទី ១០៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣

## បុព្វកថា

ក្នុងការប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់ក្នុងទីក្រុងខឺតឡង់ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៨៣៤ ប៉ាលី ភី ប្រាត្ត និង ឡៃម៉ាន វ៉ៃត បានស្វែងរកការដឹកនាំពីរបៀបដែលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី អាចទទួលបានជំនួយខាងសាច់ឈាម និងទទួលបានកម្មសិទ្ធិដីធ្លីរបស់ពួកគេនៅឃុំ ចាកសុន ។ នៅថ្ងៃដដែលនោះ យ៉ូសែប ស្ម៊ីធ ទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ ដែល ព្រះអម្ចាស់បានសន្យាថាដែនដីស៊ីយ៉ូននឹងត្រូវបានប្រោសលោះ ។ ព្រះអម្ចាស់បានណែនាំពួកអ្នកដឹកនាំសាសនាចក្រឲ្យប្រមូលធនធាន និងកេណ្ឌអ្នកស្ម័គ្រចិត្តទៅជួយពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ ក្រុមនេះ ត្រូវបានស្គាល់ថា ជាជំរុំស៊ីយ៉ូន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:១–២០

*ព្រះអម្ចាស់សន្យាថា ទីក្រុងស៊ីយ៉ូននឹងត្រូវបានប្រោសលោះ*

សូមចាប់ផ្ដើមថ្នាក់ដោយការសួរសំណួរខាងក្រោមនេះ ៖

- តើសត្រូវអ្វីដែលពួកសុចរិតមាននៅថ្ងៃនេះ ?

សូមឲ្យសិស្សគិតអំពីរបៀបដែលសត្រូវរបស់ព្រះអម្ចាស់ ព្យាយាមបង្អាក់ការរីកចម្រើនខាងវិញ្ញាណរបស់ពួកគេ ។

- តើហេតុអ្វីបានជាអ្នកគិតថា សត្រូវរបស់ព្រះអម្ចាស់អាចបង្អាក់ការរីកចម្រើនខាងវិញ្ញាណរបស់កូនចៅព្រះអម្ចាស់មួយចំនួនបាន ?

នៅពេលសិស្សចាប់ផ្ដើមការសិក្សា និងការពិភាក្សានៅថ្ងៃនេះក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៣ សូមលើកទឹកចិត្តដល់ពួកគេឲ្យរកមើលគោលការណ៍ដែលនឹងជួយពួកគេឲ្យយកឈ្នះសត្រូវបែបនោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែល ប៉ាលី ភី ប្រាត្ត និង ឡៃម៉ាន វ៉ៃត បានមកទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ពីរដ្ឋ មិសសួរី ។

- តើហេតុអ្វីបានជាបងប្រុស ប្រាត្ត និង បងប្រុស វ៉ៃត មកទីក្រុងខឺតឡង់ ?

សូមពន្យល់ថា យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ នៅថ្ងៃជាមួយគ្នាដែលអ្នកដឹកនាំទាំងពីរបានជួបជាមួយលោក និងក្រុមប្រឹក្សាជាន់ខ្ពស់នៅទីក្រុង ខឺតឡង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា១០៣:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុដែលព្រះអម្ចាស់ អនុញ្ញាតឲ្យមានការបៀតបៀនដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។

- យោងទៅតាម ខ ៣–៤, តើហេតុផលពីរយ៉ាងដែលព្រះអម្ចាស់អនុញ្ញាតឲ្យសត្រូវរបស់ទ្រង់ បៀតបៀនពួកបរិសុទ្ធជាអ្វី ? ( ហេតុផលទីមួយ គឺអនុញ្ញាតឲ្យអ្នកបៀតបៀន « អាចបំពេញកម្រិតនៃសេចក្ដីទុច្ចរិតទាំងឡាយរបស់ពួកគេ ប្រយោជន៍ឲ្យពែងរបស់ពួកគេអាចបានពេញ »—តាមពាក្យម្យ៉ាងទៀតគឺ ដើម្បីធ្វើការជំនុំជំរះរបស់ទ្រង់ចំពោះពួកទុច្ចរិតដោយត្រឹមត្រូវ ។ ហេតុផលមួយទៀត គឺដើម្បីវាយផ្ចាលពួកបរិសុទ្ធដែលមិនស្ដាប់បង្គាប់ ) ។
- ស្របតាម ខ ៤ តើហេតុអ្វីបានជាពួកបរិសុទ្ធត្រូវការការវាយផ្ចាលយ៉ាងដូច្នេះ ? តើអ្នកគិតថាឃ្លា « ពុំបានស្ដាប់តាម » មានន័យយ៉ាងណា ? ( ពួកគេមិនបានស្ដាប់បង្គាប់ព្រះអម្ចាស់ទាំងស្រុងទេ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:៥–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធ ពីអ្វីដែលពួកគេត្រូវធ្វើដើម្បីយកឈ្នះលើសត្រូវរបស់ទ្រង់ ។ ( អ្នកអាចពន្យល់ថា ពាក្យ *ឈ្នះ* មានន័យថា ខ្លាំងជាងគូបដិបក្ខ ឬមានជ័យជំនះ ) ។

- បើពួកបរិសុទ្ធធ្វើតាមដំបូន្មានរបស់ព្រះអម្ចាស់ « ចាប់ពីម៉ោង[នោះ]តទៅ » តើពួកគេនឹងទទួលពរជ័យអ្វី ? ( ពួកគេនឹងបានឈ្នះសត្រូវរបស់ព្រះអម្ចាស់ « ចាប់ពីម៉ោង[នោះ]តទៅ » ) ។
- តើខគម្ពីរទាំងនេះ បង្រៀនអំពីរបៀបដែលយើងអាចឈ្នះឥទ្ធិពលលោកិយដោយរបៀបណា ? ( សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងចាប់ផ្ដើមស្ដាប់តាមការទូន្មានរបស់ព្រះអម្ចាស់ នោះយើងទទួលបានកម្លាំងដើម្បីយកឈ្នះលោកិយ** ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:៨–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើល អ្វីដែលព្រះអម្ចាស់បានព្រមានថានឹងកើតឡើង បើយើងជ្រើសរើសមិនគោរពតាមព្រះបន្ទូលរបស់ទ្រង់ ។

- តើការជ្រើសរើសមិនស្ដាប់តាមព្រះបន្ទូលព្រះអម្ចាស់ នាំមកនូវលទ្ធផលអ្វីខ្លះ ? ( សិស្សអាចប្រាប់គោលការណ៍ផ្សេងគ្នា រួមទាំងគោលការណ៍ដូចខាងក្រោម ៖ **បើយើងមិនស្ដាប់តាមព្រះបញ្ញត្តរបស់ព្រះអម្ចាស់ នោះលោកិយនិងយកឈ្នះយើង ។ បើយើងមិនរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ទាំងអស់ទេ នោះយើងបាត់បង់សមត្ថភាពដើម្បីធ្វើជាពន្លឺដល់អ្នកដទៃ** ) ។
- តើហេតុអ្វីបានជាអ្នកគិតថា នរណាម្នាក់ដែលមិនស្ដាប់បង្គាប់ ឬស្ដាប់បង្គាប់ព្រះអម្ចាស់តែបន្តិចបន្តួច មិនអាចយកឈ្នះលើសត្រូវនៃព្រះអម្ចាស់បាន ?
- តើឧទាហរណ៍ពីរបៀបដែលប្រជាជនអាចទទួលបានជ័យជំនះ លើសត្រូវរបស់ព្រះដោយការព្យាយាមគោរពតាមព្រះបន្ទូលរបស់ព្រះអម្ចាស់មានអ្វីខ្លះ ? ( ឧទាហរណ៍អាចរួមមានមនុស្សដែលបានទទួលកម្លាំងពីព្រះអម្ចាស់ឲ្យយកឈ្នះលើការញៀនតាមរយៈការស្ដាប់បង្គាប់ ឬ រស់នៅតាមដំណឹងល្អបន្ទាប់ពីបានរស់នៅតាមរបៀបលោកិយ ) ។

*សូមជួយសិស្សដឹងពីរបៀបដើម្បីស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយ*

នៅពេលអ្នកជួយសិស្សឲ្យដឹងពីរបៀបស្គាល់គោលលទ្ធិ និង គោលការណ៍នៅក្នុងព្រះគម្ពីរ ពួកគេនឹងអាចសិក្សាព្រះគម្ពីរមានប្រសិទ្ធភាពជាងនេះដោយខ្លួនឯង ។ សូមបង្រៀនពួកគេឲ្យរកមើលឃ្លាដូចជា « ហើយយ៉ាងនោះយើងបានឃើញ » « ហេតុដូច្នេះហើយ » « ហេតុដូច្នេះហើយ » « ត្បិតមើលចុះ » ឬ « ប្រសិនបើ . . . នោះ . . . » ដែលជាញឹកញាប់ វាបង្ហាញពីគោលការណ៍ ឬ សេចក្ដីថ្លែងការនៃគោលលទ្ធិ ។

អ្នកអាចនឹងចង់ពន្យល់ថា នៅពេលយើងមិនអាចគោរពតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ឲ្យបានឥតខ្ចោះ តែបើយើងព្យាយាមស្ដាប់តាមទ្រង់ ហើយប្រែចិត្តដោយស្មោះនៅពេលដែលយើងទន់ខ្សោយ នោះព្រះអម្ចាស់នឹងជួយយើងឲ្យយកឈ្នះលើសត្រូវរបស់ទ្រង់ ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរអំពីគោលការណ៍មួយដែលពួកគេអាចចាប់ផ្ដើមធ្វើតាម « ចាប់ពីម៉ោងនេះទៅ » ដើម្បីឲ្យបានស្ដាប់ឮការទូន្មានរបស់ព្រះអម្ចាស់កាន់តែប្រសើរ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:១១–២០ ដោយពន្យល់ថា ព្រះអម្ចាស់បានសន្យានឹងពួកបរិសុទ្ធថា បន្ទាប់ពីការរងទុក្ខរបស់ពួកគេ ទីក្រុងស៊ីយ៉ូននឹងត្រូវបានប្រោសលោះ ដោយព្រះចេស្ដារបស់ទ្រង់ ។ ប៉ុន្តែ បើពួកបរិសុទ្ធបំពុលមរតករបស់ខ្លួន នោះមរតកទាំងឡាយនឹងត្រូវដកចេញពីពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:២១–៤០

*ព្រះអម្ចាស់បានបើកសម្ដែងពីរបៀបដែលទីក្រុងស៊ីយ៉ូនត្រូវបានប្រោសលោះ*

មុនពេលចាប់ផ្ដើមថ្នាក់ សូមធ្វើស្លាកមួយដែលសរសេរថា *ត្រូវការអ្នកស្ម័គ្រចិត្ត !* សូមបង្ហាញវានៅកន្លែងដែលសិស្សអាចមើលឃើញ ។ បន្ថែមពីលើនោះ សូមរៀបចំ ការប្រកាស ដូចខាងក្រោមនៅលើក្រដាសមួយផ្ទាំង ៖

> ត្រូវការអ្នកស្ម័គ្រចិត្ត ! ពួកបរិសុទ្ធនៅឃុំ ចាកសុន រដ្ឋ មិសសួរី ត្រូវបានបង្ខំឲ្យចាកចេញពីដីធ្លីរបស់ខ្លួន ដោយពួកមនុស្សកំណាចដែលគ្មានមេត្តា ។ សូមចូលរួមក្នុងការសង្គ្រោះដល់ពួកបរិសុទ្ធទាំងនេះ ហើយជួយការពារពួកគេខណៈដែលពួកគេទទួលបាន និងរក្សាដីរបស់ពួកគេនៅក្នុងទីក្រុងស៊ីយ៉ូនវិញ ។ ចាកចេញពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៨៣៤ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:២១–២៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានណែនាំពួកអ្នកដឹកនាំសាសនាចក្រឲ្យធ្វើដើម្បីប្រោសលោះដីនៃទីក្រុងស៊ីយ៉ូន ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សឈរនៅជិតស្លាកដែលសរសេរថា *ត្រូវការអ្នកស្ម័គ្រចិត្ត !* សូមផ្តល់ឲ្យសិស្សនូវសេចក្តីប្រកាសដែលអ្នកបានរៀបចំ មុនចាប់ផ្តើមថ្នាក់ ហើយសូមឲ្យគេអានវាឮៗ ។ បន្ទាប់មក សូមសួរសិស្សក្នុងថ្នាក់នូវសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា អ្នកនឹងស្ម័គ្រចិត្តទៅឃុំ ចាកសុន ដើម្បីជួយពួកបរិសុទ្ធឬទេ ? តើហេតុអ្វីបានជាអ្នកស្ម័គ្រចិត្តទៅ ឬ មិនទៅ ?

សូមពន្យល់ថា បុរសមួយក្រុមដែល យ៉ូសែប ស្ម៊ីធបានដឹកនាំទៅរដ្ឋ មិសសួរី ត្រូវបានស្គាល់ថាជាជំរុំស៊ីយ៉ូន ។ ( អ្នកអាចពន្យល់ថា *ជំរុំ* ជាពាក្យម្យ៉ាងទៀតសម្រាប់កងទ័ព [ សូមមើល Noah Webster, *វចនានុក្រមអាមេរិក នៃភាសាអង់គ្លេស*, ច្បាប់ចម្លងនៃការបោះពុម្ពលើកទីមួយ (ឆ្នាំ ១៨២៨; repr., ឆ្នាំ ១៩៦៧ ), ពាក្យ « ជំរុំ » ] ) ។ សមាជិកភាពជំរុំស៊ីយ៉ូន មានគោលបំណងសំខាន់ពីរ ។ ទីមួយ ពួកគេត្រូវនាំយកធនធានទៅឲ្យពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដើម្បីផ្តល់ការជួយសង្គ្រោះ និងជួយឲ្យពួកគេត្រឡប់ទៅផ្ទះសម្បែងគេវិញ ហើយទិញដីបន្ថែមទៀត ។ ទីពីរ ដូចដែលបានអនុញ្ញាតដោយ ដានីយ៉ែល ដាក់គ្លីន ជាអភិបាលរដ្ឋ មិសសួរី ថាឲ្យសមាជិកជំរុំស៊ីយ៉ូននៅជួយរក្សាសណ្តាប់ធ្នាប់ និងភាពសុខសាន្តនៅទីនោះ បន្ទាប់ពីកងជីវពលរដ្ឋ មិសសួរី បានអមដំណើរពួកបរិសុទ្ធទៅឃុំ ចាកសុន វិញ ។

- បើអ្នកជាសមាជិកនៃសាសនាចក្រនៅពេលនោះ តើអ្នកមានការព្រួយបារម្ភអ្វីខ្លះ អំពីការស្ម័គ្រចិត្តចូលរួមជំរុំស៊ីយ៉ូន ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និងសេចក្តីសញ្ញា ១០៣:២០ ដោយស្ងាត់ស្ងៀម ។

- តើការសន្យានៅក្នុងខគម្ពីរនេះ មានឥទ្ធិពលលើការសម្រេចចិត្ត ក្នុងការស្ម័គ្រចិត្តរបស់អ្នក យ៉ាងដូចម្តេច ?

សូមពន្យល់ថា ការចូលរួមក្នុងជំរុំស៊ីយ៉ូន តម្រូវឲ្យចាកចោលក្រុមគ្រួសារ និងទំនួលខុសត្រូវការងារ ត្រូវដើរជាក្បួនចម្ងាយប្រហែល ១៤៥០ គីឡូម៉ែត្រ ក្នុងស្ថានភាពនឿយហត់ជាខ្លាំងទៅក្នុងបរិស្ថានដែលពេញដោយសត្រូវ និងគ្រោះថ្នាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៣:២៧–២៨ ឲ្យឮៗ ។ សូមសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់ពួកអ្នកដែលនឹងចូលរួមក្នុងជំរុំស៊ីយ៉ូន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថាឃ្លា « ប្តូរជីវិតរបស់ខ្លួនដោយយល់ដល់ព្រះនាមរបស់យើង » មានន័យយ៉ាងណា ?
- យោងតាមខគម្ពីរទាំងនេះ តើព្រះអម្ចាស់ហៅនរណាដែលព្រមប្តូរជីវិតរបស់ខ្លួនដោយយល់ដល់ព្រះនាមព្រះអម្ចាស់ដូចម្តេច ? ( បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ **សិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ព្រមប្តូរជីវិតរបស់ខ្លួនដោយយល់ដល់ព្រះនាមរបស់ទ្រង់**) ។

សូមចង្អុលបង្ហាញថា សម្រាប់ពួកបរិសុទ្ធទៅក្នុងជំរុំស៊ីយ៉ូន ឱកាសនៃការស្លាប់គឺពិតប្រាកដ ។ ខណៈដែលយើងមិនជួបប្រទះនឹងគ្រោះថ្នាក់ដូចគ្នានោះ សេចក្តីពិតនេះនៅតែអនុវត្តចំពោះយើង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន សេចក្តីថ្លែងការណ៍ខាងក្រោម,ដែលបានថ្លែងដោយប្រធាន ជេមស៍ អ៊ី ហ្វោស្ត នៃគណៈប្រធានទីមួយឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកវិធីមួយដែលយើងអាច ប្តូរជីវិតរបស់យើងដោយយល់ដល់ព្រះនាមរបស់ទ្រង់ ។



« សម្រាប់យើងភាគច្រើន . . . អ្វីដែលតម្រូវឲ្យយើងធ្វើមិនមែនជា *ការស្លាប់* ដើម្បីសាសនាចក្រនោះទេ ប៉ុន្តែត្រូវ *រស់នៅ* ដើម្បីសាសនាចក្រវិញ ។ សម្រាប់មនុស្សជាច្រើន ការរស់នៅដូចជាព្រះយេស៊ូវជារៀងរាល់ថ្ងៃ អាចមានការលំបាក ជាងការប្តូរជីវិតខ្លួនទៅទៀត » ( Discipleship » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២២ ) ។

- តើហេតុអ្វីបានជាអ្នកគិតថា វាមានការលំបាកក្នុងការរស់នៅដើម្បីព្រះអម្ចាស់ ជាងការស្លាប់ដើម្បីទ្រង់ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៣:៣០–៣៤ ដោយស្ងាត់ស្ងៀម រកមើលថាព្រះអម្ចាស់មានព្រះទ័យចង់បានអ្នកស្ម័គ្រចិត្តចូលក្នុងជំរុំស៊ីយ៉ូនប៉ុន្មាននាក់ ។

- តើព្រះអម្ចាស់មានព្រះទ័យចង់បានអ្នកស្ម័គ្រចិត្តប៉ុន្មាននាក់ ? (៥០០ នាក់) ។ តើចំនួនអប្បបរមាដែលព្រះអម្ចាស់ចង់បានមានប៉ុន្មាន ? (១០០ នាក់ ) ។

សូមពន្យល់ថា នៅទីបញ្ចប់នៃការប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់ ដែលពួកអ្នកដឹកនាំសាសនាចក្របានពិភាក្សាពីស្ថានភាពរបស់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា លោកនឹងធ្វើដំណើរទៅទីក្រុងស៊ីយ៉ូន ហើយជួយប្រោសលោះវា ។ មានបុរសប្រហែល ៣០ ឬ៤០នាក់ដែលមានវត្តមានក្នុងការប្រជុំនោះ ក៏បានស្ម័គ្រចិត្តដែរ ។ បន្ទាប់មកព្រះអម្ចាស់បានចាត់បុរស ៨ នាក់ឲ្យទៅតាមក្រុមជំនុំរបស់សាសនាចក្រទាំងមូល ដើម្បីប្រមូលផ្ដុំអ្នកស្ម័គ្រចិត្តសម្រាប់ជំរុំស៊ីយ៉ូន ហើយដើម្បីស្វែងរកការបរិច្ចាកជាគ្រឿងបរិភោគ និងថវិការសម្រាប់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ( សូមមើល គ. និង ស. ១០៣:៣៧–៤០ ) ។ មនុស្សប្រហែល ២០០ នាក់ បានទៅជាមួយជំរុំស៊ីយ៉ូន រួមទាំងស្ត្រី និងកុមារមួយចំនួនផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៣:៣៥–៣៦ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យប្រាប់ពីអ្វីដែលពួកបរិសុទ្ធត្រូវធ្វើ ដើម្បីទទួលបានជោគជ័យក្នុងការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការប្រោសលោះទីក្រុងស៊ីយ៉ូន ។

- ស្របតាមការសន្យារបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះ តើគោលការណ៍អ្វីដែលយើងអាចរៀនអំពីរបៀបដែលយើងអាចទទួលបានអស់ទាំងជ័យជំនះ និងសិរីល្អ ? ( សិស្សគួរតែប្រាប់គោលការណ៍ដូចខាងក្រោម ៖ **អស់ទាំងជ័យជំនះ និងសិរីល្អត្រូវបានធ្វើឲ្យសម្រេចដល់យើង តាមរយៈការឧស្សាហ៍ ការស្មោះត្រង់ និងការអធិស្ឋានដោយសេចក្តីជំនឿរបស់យើង** ) ។

សូមថ្លែងទីបន្ទាល់ថា យើងនឹងទទួលបានជ័យជំនះលើសត្រូវរបស់ព្រះអម្ចាស់ បើយើងព្យាយាមដោយឧស្សាហ៍ ហើយគោរពតាមព្រះបន្ទូលរបស់ព្រះដោយស្មោះត្រង់ ។ សូមលើកទឹកចិត្តឲ្យសិស្សអនុវត្តអ្វីដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ របស់ពួកគេ ឬក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ « ពីម៉ោងនេះទៅ » ។

មេរៀនទី ១០៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤

## បព្វកថា

នៅនិទាឃរដូវឆ្នាំ ១៨៣៤ សាសនាចក្រមានបញ្ហាខាងហិរញ្ញវត្ថុ ហើយកិច្ចប្រឹងប្រែងដើម្បីប្រមូលមូលនិធិសម្រាប់ជំនួយត្រូវបានបរាជ័យ ។ នៅខែ មិនា ឆ្នាំ ១៨៣២ ថ្នាក់ដឹកនាំសាសនាចក្រក្នុងរដ្ឋ អូហៃអូ បានបង្កើតអង្គការមួយដែលហៅថាសហសមាគម ដើម្បីគ្រប់គ្រងពាណិជ្ជកម្មរបស់សាសនាចក្រ ប្រតិបត្តិការអាជីវកម្ម និងផ្នែកជំនួញដែលនឹងជួយស្ថាបនាទីក្រុងស៊ីយ៉ូន និងផ្គត់ផ្គង់ជនក្រីក្រ ( សូមមើល គ. និង ស. ៧៨ ) ។ នៅខែ មេសា ឆ្នាំ ១៨៣២ យ៉ូសែប ស្ម៊ីធ និងសមាជិកដទៃទៀតបានជួបជាមួយពួកអ្នកដឹកនាំនៅរដ្ឋ មិសសួរី ហើយបានរៀបចំសាខាសហសមាគមមួយនៅឃុំ ចាកសុន ( សូមមើល គ. និង ស. ៨២ ) ។ សាខាទាំងពីរនេះ—មួយនៅរដ្ឋ អូហៃអូ ហើយមួយទៀតនៅរដ្ឋ មិសសួរី—បានបន្តរយៈពេលពីរឆ្នាំ ។ នៅក្នុងការប្រជុំមួយដែលធ្វើឡើងនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៨៣៤ សមាជិកសមាគមបានសម្រេចចិត្តរំលាយអង្គការនោះចោល ។ ប៉ុន្តែ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយប្រហែលពីសប្ដាហ៍ក្រោយមក « សហសមាគម ត្រូវបានរៀបចំឡើងវិញ » ហើយ « ទ្រព្យសម្បត្តិទាំងឡាយ ត្រូវចែកជាការកាន់កាប់ត្រួតត្រា នៅក្នុងចំណោមសមាជិកនៃសមាគម ( សេចក្ដីណែនាំកណ្ឌ គ. និង ស. ១០៤ ) ។ នៅក្រោមការដឹកនាំរបស់ យ៉ូសែប ស្ម៊ីធ ពាក្យ « សមាគម » ត្រូវបានជំនួសដោយពាក្យ « សហសមាគម » នៅក្នុងវិវរណៈនេះ ។ ព្រះអម្ចាស់ក៏បានទូន្មានអ្នកដឹកនាំសាសនាចក្រ ពីបំណុលរបស់ពួកគេ ហើយបានបង្រៀនដល់សមាជិកសាសនាចក្រទាំងអស់ពីរបៀបដែលពួកគេអាចថែទាំដល់ជនក្រីក្រ ។

## យោបល់សម្រាប់ការបង្រៀន

### ការសិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ

រឿងតូចតាចមួយចំនួនគ្មានឥទ្ធិពលយូរអង្វែង ដូចការជួយសិស្សឲ្យរៀនស្រឡាញ់ព្រះគម្ពីរ និងសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃនោះទេ។ សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរជាទៀងទាត់ដោយផ្ដល់ឲ្យសិស្សនូវឱកាសក្នុងថ្នាក់ដើម្បីចែកចាយអ្វីដែលពួកគេកំពុងរៀន និងទទួលអារម្មណ៍អំឡុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១–១៨

*ព្រះអម្ចាស់បានប្រទានការណែនាំអំពីសហសមាគម*

សូមដាក់វត្ថុធ្ងន់មួយ ( ដូចជាសៀវភៅក្រាស់មួយក្បាល ឬដុំថ្មមួយដុំ ) នៅមុខថ្នាក់រៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យលើកវត្ថុនោះឡើង ដោយប្រើតែម្រាមដៃមួយ ។ វានឹងមានការពិបាក ឬមិនអាចលើកបានឡើយ ប៉ុន្តែសូមឲ្យសិស្សសាកល្បង ។ ហើយសូមអនុញ្ញាតឲ្យសិស្ស ហៅសិស្សដទៃឲ្យជួយលើកវត្ថុនោះ ។ សិស្សដែលជួយ ត្រូវសន្យាថាត្រូវជួយរហូតដល់លើកវត្ថុនោះរួច ហើយពួកគេក៏ត្រូវប្រើតែម្រាមដៃមួយដែរ ។ សូមអនុញ្ញាតឲ្យសិស្សទីមួយបន្តហៅសិស្សថែមទៀត រហូតដល់ពួកគេអាចលើកវត្ថុនោះរួច ។

- តើអ្វីដែលចាំបាច់ ដើម្បីលើកវត្ថុធ្ងន់នោះ ? ( ចម្លើយអាចរួមមាន ការធ្វើការជាក្រុម សាមគ្គីភាព និងចំណុចផ្សេងៗទៀត ) ។

សូមពន្យល់ថា ពេលចាប់ផ្ដើមសាសនាចក្រដំបូង បញ្ហាហិរញ្ញវត្ថុគឺជាបន្ទុកដ៏ធ្ងន់សម្រាប់សាសនាចក្រ ។ នៅខែ មិនា និង មេសា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានណែនាំអ្នកដឹកនាំសាសនាចក្រឲ្យរៀបចំសហសមាគមឡើង ដែលមានសមាជិកធ្វើសន្តិសញ្ញាថានឹងធ្វើការរួមគ្នា ហើយមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យវិស័យពាណិជ្ជកម្ម និងការបោះពុម្ព ដើម្បីកាត់បន្ថយបំណុលរបស់សាសនាចក្រ មើលថែទាំជនក្រីក្រ និងពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។ ដើមឡើយស្ថាប័ននេះ ត្រូវបានហៅថាសហសមាគម ( សូមមើល សេចក្ដីណែនាំកណ្ឌ ៧៨, ៨២, និង ១០៤ នៅក្នុងការបោះពុម្ពឆ្នាំ ២០១៣ នៃគោលលទ្ធិ និង សេចក្ដីសញ្ញា ) ។ នៅនិទាឃរដូវ ឆ្នាំ ១៨៣៤ បំណុលបានធ្វើឲ្យអ្នកដឹកនាំសាសនាចក្រ គិតពីការរំលាយសមាគមចោល ។ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៨៣៤ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤ ក្នុងនោះ ព្រះអម្ចាស់បានបើកសម្ដែងអ្វីដែលត្រូវធ្វើជាមួយនឹងសហសមាគម និងទ្រព្យសម្បត្តិរបស់វា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវការណែនាំ នៃក្បាលកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យអ្នកដឹកនាំសាសនាចក្រធ្វើ ជាមួយនឹងសហសមាគម ។ ( មុនពេលសិស្សអាន សូមពន្យល់ថា ក្រោយមក យ៉ូសែប ស្ម៊ីធ បានកែប្រែពាក្យ « សមាគម »ទៅជាពាក្យ « សហសមាគម » នៅក្នុងវិវរណៈដែលបានបោះពុម្ព ) ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១–៤ ឲ្យឮៗ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមូលហេតុមួយដែលសហសមាគមមានបញ្ហា ។ អ្នកអាចត្រូវពន្យល់ថា នៅក្នុង ខ ៤, ពាក្យ *លោភលន់* សំដៅលើបំណងដ៏អត្មានិយមដើម្បីបានអ្វីមួយ ជាធម្មតាគឺអ្វីមួយដែលជាកម្មសិទ្ធិរបស់មនុស្សផ្សេងទៀត ។

- តើបងប្អូនប្រុសមួយចំនួនបានធ្វើខុសអ្វីខ្លះ ដោយសារតែភាពលោភលន់ ?

សូមរំឭកសិស្សពីវត្ថុសម្រាប់មេរៀន នៅដើមមេរៀន ។ សូមឲ្យពួកគេពិចារណាពីអ្វីនឹងកើតឡើង បើសិស្សមួយចំនួនបានសន្យាថាជួយ ប៉ុន្តែក្រោយមកបែរជាផ្លាស់ប្ដូរគំនិតហើយបានសម្រេចចិត្តចាកចេញ នៅពេលវត្ថុនោះកំពុងត្រូវលើកឡើង ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៥–១០ ដោយពន្យល់ថា ព្រះអម្ចាស់បានចេញបញ្ញត្តិថាលទ្ធផលនៃការរំលងសេចក្ដីសញ្ញា ដែលទាក់ទងនឹងសហសមាគម នឹងត្រូវបណ្ដាសា ហើយនឹងត្រូវកាត់ចេញពីសាសនាចក្រ ( សូមមើលផងដែរ គ. និង ស. ៧៨:១១–១២; ៨២:១១–២១ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១១–១៣ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូល អំពីអ្វីដែលសហសមាគមនឹងទទួលបាន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចពន្យល់ថា អ្នកកាន់កាប់ត្រួតត្រាគឺជាបុគ្គលម្នាក់ដែលត្រូវបានប្រគល់ទំនួលខុសត្រូវឲ្យមើលការខុសត្រូវទ្រព្យសម្បត្តិរបស់មនុស្សផ្សេងទៀត ។

- ស្របតាម ខ ១២–១៣ តើហេតុអ្វីបានជាព្រះអម្ចាស់តាំងឲ្យមានអ្នកកាន់កាប់ត្រួតត្រាលើសមាជិកម្នាក់នៃសហសមាគម ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថានរណាជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិដែលនៅក្នុងសហសមាគម ។

- តើនរណាជាម្ចាស់លើទ្រព្យសម្បត្តិ ដែលត្រូវផ្ដល់ឲ្យសមាជិកសហសមាគម ? ( បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បានបង្កើតផែនដី ហើយអ្វីគ្រប់យ៉ាងដែលនៅលើផែនដី ជារបស់ផងទ្រង់**) ។
- តើសេចក្ដីពិតនេះ មានឥទ្ធិពលលើរបៀបដែលអ្នកគិត និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់អ្នកយ៉ាងដូចម្ដេចខ្លះ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៥–១៨ ដោយស្ងាត់ស្ងៀម ។ សូមសូមពួកគេប្រាប់ពីរបៀបដែលព្រះអម្ចាស់បានបង្រៀន អ្នកកាន់កាប់ត្រួតត្រារបស់ទ្រង់ឲ្យប្រើរបស់នៃលោកិយ ។

- តើព្រះអម្ចាស់មានព្រះទ័យចង់ឲ្យពួកបរិសុទ្ធរបស់ទ្រង់ត្រូវបានផ្គត់ផ្គង់របៀបណា ?
- តើអ្នកគិតថា ឃ្លា « មនុស្សទ័លក្រត្រូវបានតម្កើងឡើង ក្នុងការមនុស្សមានត្រូវបានបន្ទាបចុះ » ?

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃឃ្លានេះ សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ យ៉ូសែប ប៊ី វឺតលីន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ឲ្យឮៗ ៖



« របៀបរបស់ព្រះអម្ចាស់រួមមានការជួយមនុស្សឲ្យជួយខ្លួនឯង ។ មនុស្សទ័លក្រត្រូវបានតម្កើងឡើង ដោយសារពួកគេធ្វើការសម្រាប់ជំនួយបណ្ដោះអាសន្នដែលពួកគេទទួល ពួកគេត្រូវបានបង្រៀនគោលការណ៍ពិត ហើយពួកគេអាចរួចចេញពីភាពក្រីក្រ ទៅកាន់ភាពខ្លួនទីពឹងខ្លួន ។ អ្នកមានត្រូវបានបន្ទាបចុះ ដោយសារពួកគេមានភាពរាបទាប ក្នុងការចែករំលែកទ្រព្យសម្បត្តិពួកគេដល់មនុស្សទ័លក្រដោយសទ្ធា » ( Inspired Church Welfare » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៩ ទំព័រ ៧៧ )

- តើគោលការណ៍នៅក្នុង ខ ១៧–១៨ បង្រៀនអំពីទំនួលខុសត្រូវរបស់យើង ដើម្បីជួយអ្នកដទៃអ្វីខ្លះ ? ( សិស្សអាចប្រាប់ពីគោលការណ៍ផ្សេងគ្នា រួមទាំងគោលការណ៍ដូចខាងក្រោម ៖ **យើងមានទំនួលខុសត្រូវក្នុងការប្រើអ្វី ដែលព្រះអម្ចាស់បានប្រទានដល់យើង ដើម្បីជួយអ្នកដទៃ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សឲ្យគិតពី « មនុស្សទ័លក្រ និងមនុស្សទុគ៌ត » ថាពួកគេមិនត្រឹមតែត្រូវការជំនួយខាងហិរញ្ញវត្ថុប៉ុណ្ណោះទេ ពួកគេក៏ត្រូវការជំនួយខាងវិញ្ញាណ ខាងអារម្មណ៍ ខាងផ្លូវចិត្ត និងខាងសង្គមផងដែរ ។ ដូចគ្នាផងដែរ យើងអាចគិតពីភាពសម្បូរសប្បាយរបស់យើង លើសពីប្រាក់កាស ឬទ្រព្យសម្បត្តិដែលយើងមានទៅទៀត ។ ភាពសម្បូរសប្បាយរបស់យើង រួមទាំងពេលវេលា ទេពកោសល្យ ចំណេះដឹង ទីបន្ទាល់ និងជំនាញរបស់យើង ។

- តើហេតុអ្វីបានជាអ្នកគិតថា វាសំខាន់ដែលយើងត្រូវចែកចាយភាពសម្បូរសប្បាយរបស់យើង ដល់ជនទុគ៌តនោះ ?
- តើយើងអាចជួយអ្នកដទៃ តាមវិធីរបស់ព្រះអម្ចាស់ដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យគិតពីការប្រឹងប្រែងរបស់ពួកគេក្នុងការជួយមនុស្សទ័លក្រ និងមនុស្សទុគ៌ត ។ សូមឲ្យពួកគេសរសេរគោលដៅមួយ ពីរបៀបដែលពួកគេនឹងប្រើអ្វីដែលព្រះអម្ចាស់បានប្រទានឲ្យពួកគេ ដើម្បីជួយនរណាម្នាក់ដែលត្រូវការ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤: ១៩–៧៧

*ព្រះអម្ចាស់ប្រទានការណែនាំទាក់ទងនឹងសហសមាគម អ្នកកាន់កាប់ត្រួតត្រា និងឃ្លាំង*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៩–៥៣ ដោយពន្យល់ថា ព្រះអម្ចាស់ប្រទានការណែនាំជាក់លាក់អំពីអ្នកកាន់កាប់ត្រួតត្រា ដែលទ្រង់បានចាត់ដល់សមាជិកនៃសហសមាគម ។ សូមសរសេរសេចក្ដីយោងដូចខាងក្រោមនៅលើក្ដារខៀន ៖ *គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:២៣,២៥, ៣១, ៣៣, ៣៥, ៣៨, ៤២, ៤៦* ។ សូមឲ្យសិស្សអានខគម្ពីរទាំងនេះដោយស្ងៀមស្ងាត់ រកមើលលំនាំដែលព្រះអម្ចាស់សន្យាដល់សមាជិកម្នាក់ៗនៅក្នុងសមាគម ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ ពីអ្វីដែលពួកគេរកឃើញ ។

សូមសួរសិស្សថា តើពាក្យ ឬឃ្លាមួយណាដែលលើកឡើងម្ដងហើយម្ដងទៀតក្នុងខគម្ពីរទាំងនេះ ។ សូមចង្អុលបង្ហាញថា ឃ្លា « ដរាបណា » មានន័យថា « បើតាមដែល » ឬ « ដែលថា » ។

- តើឃ្លាទាំងនេះអាចបង្រៀនយើងអំពីរបៀបដែលការគោរពរបស់យើងមានឥទ្ធិពលលើពរជ័យដែលយើងបង្រៀនអ្វីខ្លះ ?

សូមសរសេរនៅលើក្ដារខៀននូវឃ្លា *ដរាបណាយើងបន្ទាបខ្លួន និងស្មោះត្រង់ នោះព្រះអម្ចាស់ នឹង . . .*

សូមសួរសិស្សពីរបៀបដែលពួកគេនឹងបំពេញគោលការណ៍នេះ ។ ( សូមប្រើពាក្យរបស់គេផ្ទាល់ ដើម្បីបញ្ចប់គោលការណ៍មិនពេញលេញនៅលើក្ដារខៀន ។ ឧទាហរណ៍ ៖ **ដរាបណាយើងបន្ទាបខ្លួន និងស្មោះត្រង់ នោះព្រះអម្ចាស់នឹងប្រទានពរជ័យដល់យើងទ្វេឡើង**) ។

- តើពេលណា ដែលអ្នកបានឃើញនរណាម្នាក់ ត្រូវបានប្រទានពរឲ្យសម្រាប់ការស្មោះត្រង់ នៅក្នុងទំនួលខុសត្រូវរបស់ខ្លួនចំពោះព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀប ដែលពួកគេអាចស្មោះត្រង់ចំពោះទំនួលខុសត្រូវ ដែលព្រះអម្ចាស់បានប្រទានដល់ពួកគេ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៥៤–៧៧ ដោយការពន្យល់ថា ព្រះអម្ចាស់បានប្រទានសេចក្ដីណែនាំសម្រាប់ការស្ថាបនាឃ្លាំង ដើម្បីការពារមូលនិធិដែលនឹងត្រូវប្រើសម្រាប់ជាប្រយោជន៍របស់សាសនាចក្រ ដូចជាការបោះពុម្ពព្រះគម្ពីរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៧៨–៨៦

*ព្រះអម្ចាស់ណែនាំដល់ពួកអ្នកដឹកនាំសាសនាចក្រទាក់ទងនឹងបំណុលរបស់សហសមាគម*

សូមឲ្យសិស្សពិចារណាថាតើពួកគេធ្លាប់ត្រូវបានសូមឲ្យធ្វើអ្វីមួយ ដែលពួកគេគិតថាមិនអាចទៅរួចដែរឬទេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមពន្យល់ថា នៅក្នុងដំណើរការនៃការគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ សហមាគមមានបំណុលយ៉ាងច្រើន ។ ព្រឹត្តិការណ៍មួយចំនួនបានរាំងស្ទះមិនឲ្យសមាគមសងបំណុលបាន ។ ឧទាហរណ៍ ការបំផ្លិចបំផ្លាញរបស់ពួកមនុស្សកំណាចទៅលើម៉ាស៊ីនបោះពុម្ពនៅរដ្ឋ ចាកសុន រដ្ឋ មិសសួរី បានរួមចំណែកដល់បញ្ហាសេដ្ឋកិច្ច ហើយពួកមនុស្សកំណាចបានរាំងស្ទះមិនឲ្យពួកបរិសុទ្ធប្រើឃ្លាំងនៅទីក្រុង អ៊ិនឌីប៉ែនដែនស៍ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៧៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីណែនាំរបស់ព្រះអម្ចាស់អំពីបំណុលរបស់សាសនាចក្រ ។

- តើព្រះអម្ចាស់បានណែនាំឲ្យសមាជិកនៃសហសមាគមធ្វើអ្វីខ្លះ ?

សូមចង្អុលបង្ហាញថា ការសងបំណុលហាក់ដូចជាមិនអាចទៅរួចចំពោះពួកបរិសុទ្ធ ប៉ុន្តែព្រះអម្ចាស់បានផ្ដល់ការណែនាំដើម្បីជួយពួកគេ ។ សូមសរសេរពាក្យ *បើ* និង *នោះ* នៅក្នុងកូឡោនពីរនៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៨០–៨២ ឲ្យឮៗ ។ សូមសូមឲ្យសិស្សពាក់កណ្ដាលក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានសូមដល់សមាជិកសមាគមឲ្យធ្វើ ដើម្បីទទួលបានជំនួយពីទ្រង់ក្នុងការសងបំណុលរបស់ពួកគេ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ពាក់កណ្ដាលទៀតផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានសន្យាថាទ្រង់នឹងធ្វើ ដើម្បីជួយពួកបរិសុទ្ធឲ្យសងបំណុលរបស់ខ្លួន ។ សូមឲ្យក្រុមទីមួយសរសេរចម្លើយរបស់ខ្លួននៅក្រោមពាក្យ « បើ » ហើយឲ្យក្រុមទីពីរសរសេរចម្លើយរបស់ខ្លួននៅក្រោម « នោះ » ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៨០–៨២ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់ពីគោលការណ៍ មួយចំនួនដូចខាងក្រោម ៖ **បើយើងបន្ទាបខ្លួន ហើយស្មោះត្រង់ ហើយអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះទ្រង់នឹងជួយយើងឲ្យសម្រេចបាននូវអ្វីដែលទ្រង់បានសូមឲ្យយើងធ្វើ** ) ។

- តើព្រះអម្ចាស់សូមឲ្យសមាជិកសាសនាចក្រធ្វើអ្វីខ្លះនៅពេលនេះ ដែលចាត់ទុកថាពិបាកនោះ ? តើអ្នកគិតថា ការបន្ទាបខ្លួន ការស្មោះត្រង់ និងការអធិស្ឋាន មានតួនាទីក្នុងការសម្រេចបាននូវអ្វីដែលព្រះអម្ចាស់សូមឲ្យយើងធ្វើអ្វីខ្លះ ?
- តើនៅក្នុងព្រះគម្ពីរ នរណាខ្លះទៅដែលជាគំរូនៃគោលការណ៍ដែលបានប្រាប់នៅក្នុង ខ ៨០–៨២ ? តើសព្វថ្ងៃនេះ អ្នកស្គាល់នរណាខ្លះដែលជាគំរូនៃគោលការណ៍នេះ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ខ្លួន ឬនៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរ ពីវិធីមួយ ដែលពួកគេអាចមានការបន្ទាបខ្លួន ស្មោះត្រង់ ឬព្យាយាមកាន់តែខ្លាំង ដើម្បីឲ្យព្រះអម្ចាស់អាចជួយពួកគេឲ្យសម្រេចបាន នូវរឿងដែលទ្រង់បានសូមឲ្យពួកគេធ្វើ ។

មេរៀនទី ១១០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥

## សេចក្ដីផ្ដើម

ក្នុងការគោរពតាមការណែនាំរបស់ព្រះអម្ចាស់ ព្យាការីយ៉ូសែប ស្ម៊ីធ និងអ្នកស្ម័គ្រចិត្ត និងសមាជិកប្រមាណ២០០នាក់ផ្សេងទៀត បានរៀបចំជាជំរុំស៊ីយ៉ូនដើម្បីជួយដល់ពួកបរិសុទ្ធ ដែលបាននិរទេសចេញពីឃុំ ចាកសុន រដ្ឋ មិសសួរី ។ នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៨៣៤ ពេលកំពុងបោះជំរុំនៅជិតទន្លេ ហ្វីស៊ីង ក្នុងរដ្ឋ មិសសួរី យ៉ូសែប ស្ម៊ីធបានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បញ្ជាក់ប្រាប់ពួកបរិសុទ្ធថា ដែនដីស៊ីយ៉ូននឹងមិនត្រូវបានប្រោសលោះ នៅពេលនោះទេ ។ ព្រះអម្ចាស់ក៏បានផ្ដល់ការណែនាំ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីឲ្យទីក្រុងស៊ីយ៉ូនត្រូវបានប្រោសលោះឡើងវិញនាពេលអនាគត ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:១–១៩

*ព្រះអម្ចាស់ណែនាំឲ្យពួកបរិសុទ្ធរង់ចាំការប្រោសលោះនៃទីក្រុងស៊ីយ៉ូន*

មុនពេលចាប់ផ្ដើមរៀន សូមយក ពែងក្រដាសមួយ កៅស៊ូកងមួយ និងខ្សែបីសរសៃ ។ បរិមាត្ររបស់កៅស៊ូកង ត្រូវតែតូចជាងបរិមាត្ររបស់ពែង ។ សូមចងខ្សែទាំងនោះជាប់នឹងកៅស៊ូកងដោយប្រវែងស្មើគ្នា ។



សូមចាប់ផ្ដើមមេរៀនដោយសូមអ្នកស្ម័គ្រចិត្តបីនាក់ ។ សូមដាក់ពែងនៅលើផ្ទៃរាបស្មើ ហើយបង្គាប់ឲ្យអ្នកស្ម័គ្រចិត្តទាំងនោះចាប់លើកពែងឡើងដោយប្រើតែកៅស៊ូកង និង ខ្សែនោះប៉ុណ្ណោះ ។ សូមប្រាប់ពួកគេថាពួកគេពុំអាចបះកៅស៊ូកងឡើយ ពួកគេត្រូវតែកាន់តែខ្សែ ។ ( ដើម្បីសម្រេចបានកិច្ចការនេះ សិស្សនឹងត្រូវធ្វើការរួមគ្នា ហើយទាញខ្សែស្រុះគ្នាដោយប្រើកម្លាំងស្មើដើម្បីទាញឲ្យកៅស៊ូកងនោះយឺតល្មមដើម្បីដាក់ពែងចូលកណ្ដាល ហើយបន្ទាប់មកលើកវាឡើង ) ។

បន្ទាប់ពីសិស្សបានបំពេញសកម្មភាពនេះរួចហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើភាពសាមគ្គីមានតួនាទីអ្វីនៅក្នុងការសម្រេចកិច្ចការនេះ ?

សូមរំឭកសិស្សថា នៅខែ កុម្ភៈ ឆ្នាំ ១៨៣៤ ព្រះអម្ចាស់បានណែនាំព្យាការី យ៉ូសែប ស្ម៊ីធ និងអ្នកផ្សេងទៀតឲ្យប្រមូលធនធានបណ្ដោះអាសន្ន និងក្រុមអ្នកស្ម័គ្រចិត្តឲ្យជួយពួកបរិសុទ្ធ ដែលត្រូវបានបណ្ដេញចេញពីឃុំ ចាកសុន រដ្ឋ មិសសួរី ដើម្បីទាមទារដីពួកគេមកវិញ ។ នៅពេលសិស្សចាប់ផ្ដើមការពិភាក្សាថ្ងៃនេះនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៥ សូមលើកទឹកចិត្តដល់ពួកគេឲ្យរកមើលតួនាទីរបស់ភាពសាមគ្គី ដែលដើរតួក្នុងការទាមទារដែនដីនៃទីក្រុងរបស់ពួកបរិសុទ្ធមកវិញ ។

សូមសូមឲ្យសិស្សរំឭកពីការសិក្សារបស់ពួកគេនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ ពីចំនួនអ្នកស្ម័គ្រចិត្តដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យចូលរួមក្នុងជំរុំស៊ីយ៉ូន ( ៥០០នាក់ ) និងចំនួនអប្បរិមាដែលទ្រង់ចង់បាន ( ១០០ នាក់ ) ។ សូមឲ្យសិស្សម្នាក់អានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលចំនួនមនុស្ស ដែលបានស្ម័គ្រចិត្តក្នុងជំរុំស៊ីយ៉ូននៅពេលដែលក្រុមនោះបានចេញដំណើរជាលើកដំបូង ។

ចម្លើយទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់ព្យាការី យ៉ូសែប ស្ម៊ីធ និងក្រុមអ្នកស្ម័គ្រចិត្ត និងធនធានសម្រាប់ជុំរុំស៊ីយ៉ូន គឺមិនជោគជ័យដូចដែលបានសង្ឃឹមទុកនោះទេ ។ ទំរាំដល់ពេលដែលជុំរុំ ឬពលទាហានបានចាប់ផ្ដើមក្បួនដើរដង្ហែនៅដើមខែឧសភា ឆ្នាំ ១៨៣៤ មានតែមនុស្សចំនួន ១២២នាក់ប៉ុណ្ណោះដែលបានស្ម័គ្រចិត្តទៅ ។ ការប្រមូលអ្នកស្ម័គ្រចិត្តបន្ថែមសម្រាប់ជុំរុំស៊ីយ៉ូន នៅតាមផ្លូវទៅរដ្ឋ មិសសួរី ។ នៅពេលក្រុមដែល ហៃរ៉ុម ស្ម៊ីធ និង ឡៃម៉ាន វ៉ៃត បានប្រមូលពីទឹកដីរដ្ឋ មីឈីហ្គែន បានមកជួបជាមួយក្រុមរបស់ យ៉ូសែប ស្ម៊ីធ នៅដើមខែ មិថុនា ឆ្នាំ ១៨៣៤ ជុំរុំស៊ីយ៉ូនមានបុរស ២០០នាក់ ស្ត្រី ១២នាក់ និងកុមារ ៩នាក់ប៉ុណ្ណោះ ( សូមមើល Alexander L. Baugh, Joseph Smith and Zion's Camp » *Ensign,* ខែមិថុនា ឆ្នាំ ២០០៥,ទំព័រ ៤៥ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលហេតុផលមួយដែលសមាជិកសាសនាចក្រមួយចំនួន មិនបានជ្រើសរើសជួយពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ រួចហើយឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:១–៦ ឲ្យឮៗ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលការមិនស្ដាប់បង្គាប់ និងការខ្វះសាមគ្គី បណ្ដាលឲ្យមានឥទ្ធិពលលើសមាជិកនៃសាសនាចក្រ ។ ( ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីអត្ថន័យនៅក្នុង ខ ៥ វាអាចមានប្រយោជន៍ក្នុងការពន្យល់ថា « ក្រឹត្យវិន័យនៃនគរសេឡេស្ទាល » រួមមានក្រឹត្យវិន័យ និងគោលការណ៍ទាំងអស់ដែលយើងត្រូវគោរពតាម ពិធីបរិសុទ្ធនានាដែលយើងត្រូវទទួល និងសេចក្ដីសញ្ញាដែលយើងត្រូវរក្សា ដើម្បីស្នងនគរសេឡេស្ទាលទុកជាមរតក ) ។

- តើសមាជិកសាសនាចក្របរាជ័យក្នុងការសាមគ្គី និងស្ដាប់បង្គាប់តាមរបៀបណា ?
- ស្របតាមខគម្ពីរទាំងនេះ តើយើងត្រូវធ្វើអ្វី ដើម្បីជួយស្ថាបនាទីក្រុងស៊ីយ៉ូន ? ( នៅពេលសិស្សឆ្លើយតប សូមជួយពួកគេឲ្យរកគោលការណ៍ដូចខាងក្រោម ៖ **ដើម្បីជួយស្ថាបនាទីក្រុងស៊ីយ៉ូន យើងត្រូវតែសាមគ្គី ហើយគោរពតាមអ្វីដែលព្រះអម្ចាស់បានសូមឲ្យយើងធ្វើទាំងអស់** ) ។
- តើអ្នកគិតថាហេតុអ្វីបានជាការរួបរួមគ្នា និង ការគោរពប្រតិបត្តិ ត្រូវបានតម្រូវឲ្យមានដើម្បីឲ្យស៊ីយ៉ូនត្រូវបានស្ថាបនាឡើង ?
- តើបទពិសោធន៍អ្វីខ្លះ ដែលបាន ជួយអ្នកឲ្យយល់ ពីសារៈសំខាន់នៃភាពសាមគ្គីរបស់សមាជិកសាសនាចក្រ ?

> ***សំណួរទាំងឡាយដែលពង្រឹងការយល់ដឹង***
> សំណួរដែលលើកទឹកចិត្តសិស្សឲ្យគិតអំពីគោលលទ្ធិ ឬគោលការណ៍នៅក្នុងបរិបទទំនើប អាចជួយពួកគេឲ្យយល់សេចក្ដីពិតដែលគេរកឃើញកាន់តែច្បាស់ ។

សូមពន្យល់ថា អ្នកដែលបានស្ម័គ្រចិត្តចូលជុំរុំស៊ីយ៉ូន បានជួបឧបសគ្គ និងអព្ភូតហេតុជាច្រើនពេញបេសកកម្មរបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់អានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមសូមឲ្យសិស្សនៅក្នុងថ្នាក់គិតពីរបៀបដែលពួកគេអាចឆ្លើយតបទៅនឹងបញ្ហាមួយចំនួន ។

ជុំរុំស៊ីយ៉ូន បានដើរប្រហែលជា ១៤៥០គីឡូម៉ែត្រកាត់តាមរដ្ឋ៤ ធ្វើដំណើរប្រហែល ៣០–៦០គីឡូម៉ែត្រក្នុងមួយថ្ងៃ អស់រយៈពេល៤៥ថ្ងៃ ។ សមាជិកក្នុងជុំរុំបានមានពងបែកជើង អាកាសធាតុក្ដៅហើយសើម ខ្វះស្បៀងអាហារ និងអាហារគ្មានគុណភាព ។ នៅពេលខ្លះ ការស្រេកទឹកខ្លាំង បាននាំឲ្យសមាជិកជុំរុំផឹកទឹកភក់ដែលបានត្រងពងមុសចេញ ( ពេលខ្លះប្រើធ្មេញរបស់ពួកគេធ្វើជាតម្រង ) ឬផឹកទឹកថ្លុកដក់តាមដានក្រចកសេះបន្ទាប់ពីភ្លៀងរួច ។ ពេញមួយបេសកកម្មនោះ ជុំរុំស៊ីយ៉ូនត្រូវបានគំរាមកំហែងដោយអំពើហិង្សាពីអ្នកជទៃជាញឹកញយ ។ ( សូមមើល *Church History in the Fulness of Times Student Manual,* បោះពុម្ពលើកទី ២ [Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ១៤៣–៤៥ ) ។

- តើអ្នកគិតថា អ្នកនឹងឆ្លើយតបទៅនឹងបញ្ហាទាំងនោះដោយរបៀបណាដែរ ?

សូមពន្យល់ថា បន្ទាប់ពីសមាជិកជុំរុំស៊ីយ៉ូនបានមកដល់រដ្ឋ មិសសួរី ពួកគេបានដឹងថា ដានីយ៉ែល ដាក់គ្លីន ជាអភិបាលរដ្ឋមិសសួរី មិនបានរក្សាការសន្យារបស់លោកថាជួយពួកបរិសុទ្ធឲ្យត្រឡប់ទៅដីធ្លីនៅក្នុងឃុំ ចាកសុនវិញទេ ។ ទោះបីជាមានដំណឹងមិនល្អនេះក្ដី ជុំរុំស៊ីយ៉ូនបានបន្តធ្វើដំណើរទៅឃុំ ចាកសុន រង់ចាំការដឹកនាំបន្ថែមទៀតពីព្រះអម្ចាស់ ។

សូមប្រាប់សិស្សថា ការដឹកនាំដែលត្រូវការនោះមានក្នុងវិវរណៈដែលមកពីព្រះអម្ចាស់នៅ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៨៣៤ បន្ទាប់ពីជុំរុំស៊ីយ៉ូនបានធ្វើដំណើរជិតប្រាំពីរសប្ដាហ៍ ហើយនៅសល់តែចម្ងាយប្រហែលតែ ១៥–៣០គីឡូម៉ែត្រពីឃុំ ចាកសុន ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៩–១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបន្ទូលថាពួកគេត្រូវធ្វើអ្វី ដើម្បីប្រោសលោះទីក្រុងស៊ីយ៉ូន ។

- តើព្រះអម្ចាស់បានណែនាំឲ្យជុំរុំឲ្យធ្វើអ្វី ដើម្បីប្រោសលោះទីក្រុងស៊ីយ៉ូន ?
- បើអ្នកជាសមាជិកនៅក្នុងជុំរុំស៊ីយ៉ូន តើអ្នកមានអារម្មណ៍យ៉ាងណានៅពេលបានឮវិវរណៈមុនទៅដល់គោលដៅតែបន្តិចបែបនេះ ?
- តើហេតុផលអ្វីខ្លះ ដែលព្រះអម្ចាស់ទុកឲ្យទីក្រុងស៊ីយ៉ូនមិនត្រូវបានប្រោសលោះនៅពេលនោះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:១៨–១៩ ឲ្យឮៗ ។ សូមឲ្យសមាជិកក្នុងថ្នាក់រកមើលពីមូលហេតុដែលព្រះអម្ចាស់បានដឹកនាំជុំរុំស៊ីយ៉ូនឲ្យធ្វើដំណើរដ៏សែនឆ្ងាយទៅកាន់រដ្ឋ មិសសួរី ហើយបន្ទាប់មកបានបើកសម្ដែងថាពួកគេមិនត្រូវជួយពួកបរិសុទ្ធឲ្យទៅកាន់ដីធ្លីរបស់ខ្លួននៅទីក្រុងស៊ីយ៉ូនវិញនៅពេលនោះទេ ។

- យោងតាមខគម្ពីរទាំងនេះ តើហេតុអ្វីបានជាព្រះអម្ចាស់បញ្ជាឲ្យជុំរុំស៊ីយ៉ូនធ្វើដំណើររហូតដល់រដ្ឋ មិសសួរី ហើយបន្ទាប់មកបើកសម្ដែងថាទីក្រុងស៊ីយ៉ូនពុំទាន់អាចប្រោសលោះបានទៅវិញ ? ( វាគឺជាការសាកល្បងនៃសេចក្ដីជំនឿ ។ វាអាចមានប្រយោជន៍ក្នុងការពន្យល់ថា ការសាកល្បងនៃសេចក្ដីជំនឿអាចសំដៅលើការល្បងថាតើយើងនឹងជ្រើសរើសទុកចិត្ត និងគោរពតាមព្រះអម្ចាស់មិនថានៅក្នុងស្ថានភាពបែបណា ) ។
- តើតាមវិធីណាខ្លះដែលសេចក្ដីជំនឿរបស់សមាជិកនៃជុំរុំស៊ីយ៉ូន ត្រូវបានសាកល្បងតាមរយៈបទពិសោធន៍របស់ពួកគេ ?
- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរទាំងនេះ ? ( គោលការណ៍មួយដែលសិស្សអាចរកឃើញគឺ **ព្រះបានរៀបចំពរជ័យដ៏អស្ចារ្យសម្រាប់អ្នកដែលស្មោះត្រង់តាមរយៈការសាកល្បងរបស់ពួកគេ** ) ។
- តើពេលណាដែលអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ បានជួបប្រទះការសាកល្បងនៃសេចក្ដីជំនឿ ? តើការសាកល្បងនៃសេចក្ដីជំនឿរបស់អ្នក បានរៀបចំអ្នកសម្រាប់ពរជ័យដ៏អស្ចារ្យដូចម្ដេច ?

សូមប្រាប់សិស្សថា បុរសជាច្រើនដែលបានបម្រើក្នុងជុំរុំស៊ីយ៉ូន ត្រូវបានប្រទានពរនូវឱកាសដើម្បីបម្រើនៅក្នុងនគររបស់ព្រះអម្ចាស់ ។ នៅខែ កុម្ភៈ ឆ្នាំ ១៨៣៥ កូរ៉ុមនៃពួកដប់ពីរនាក់ និងកូរ៉ុមទីមួយនៃពួកចិតសិបនាក់ ត្រូវបានរៀបចំឡើង ។ សាវក៩នាក់ និងសមាជិកទាំងអស់ក្នុងកូរ៉ុមនៃពួកចិតសិបនាក់បានបម្រើនៅក្នុងជុំរុំស៊ីយ៉ូន ។ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៥១ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយព្យាការី យ៉ូសែប ស្ម៊ីធ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលតួនាទីរបស់ជុំរុំស៊ីយ៉ូននៅក្នុងការរៀបចំបុរសទាំងឡាយសម្រាប់តំណែងដឹកនាំនានា ៖



« ព្រះមិនចង់ឲ្យអ្នកឈ្លោះគ្នានោះទេ ។ ទ្រង់មិនអាចរៀបចំនគររបស់ទ្រង់ដោយមនុស្សតែដប់ពីរនាក់ដើម្បីបើកផ្លូវដំណឹងល្អដល់ប្រជាជាតិនានានៃពិភពលោក និងបុរសចិតសិបនាក់នៅក្រោមឱវាទរបស់ពួកគេ ដើម្បីធ្វើតាមគំរូរបស់ពួកគេឡើយ លើកលែងតែទ្រង់បានរើសពួកគេក្នុងចំណោមអ្នកដែលបានប្ដូរជីវិតរបស់ខ្លួន និងអ្នកដែលមានការលះបង់យ៉ាងធំដូចជាអ័ប្រាហាំបានធ្វើដែរ » ( នៅក្នុង *History of the Church,* ២ : ១៨២សូមមើលផងដែរ *Church History in the Fulness of Times,* ទំព័រ ១៥១ ) ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការទុកចិត្ត និងគោរពតាមព្រះអម្ចាស់ នៅពេលសេចក្ដីជំនឿយើងត្រូវបានសាកល្បង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:២០–៤១

*ព្រះអម្ចាស់បង្រៀនពួកបរិសុទ្ធនូវអ្វីដែលពួកគេត្រូវធ្វើ មុនពេលដែលទីក្រុងស៊ីយ៉ូនត្រូវបានប្រោសលោះ*

សូមសង្ខេប គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៥:២០–៣៧ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រាប់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ពីរបៀបដែលពួកគេត្រូវឆ្លើយតបទៅនឹងការបៀតបៀន ដែលពួកគេនឹងជួបប្រទះពេលកំពុងរង់ចាំការប្រោសលោះទីក្រុងស៊ីយ៉ូននាថ្ងៃខាងមុខ ។ ទ្រង់បានទូន្មានពួកគេឲ្យបន្ទាបខ្លួន ហើយចៀសវាងការបង្កជម្លោះ ។ ទ្រង់បានពន្យល់ថាពួកគេត្រូវលះបង់ក្នុងការរៀបចំខ្លួនសម្រាប់ការប្រោសលោះទីក្រុងស៊ីយ៉ូននៅទីបញ្ចប់ ។ ទ្រង់បានមានបន្ទូលនៅក្នុងវិវរណៈដូចគ្នាពីមុនមកថា ពួកគេត្រូវ « បានបង្រៀនឲ្យបានល្អឥតខ្ចោះទៅទៀត ហើយមានការពិសោធន៍ ហើយចេះឲ្យបានល្អឥតខ្ចោះអំពីកាតព្វកិច្ចរបស់ពួកគេ និងអ្វីៗដែលយើងតម្រូវពីស្នាដៃរបស់ពួកគេ » ( គ. និង ស. ១០៥:១០ ) ។

- តើយើងគួរឆ្លើយតបនឹងការបៀតបៀនតាមរបៀបណាខ្លះ ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៣៨–៤១ ដោយស្ងាត់ស្ងៀម ហើយជ្រើសរើសឃ្លាពីខគម្ពីរដែលសង្ខេបនូវអ្វី ដែលព្រះអម្ចាស់បានដឹកនាំពួកបរិសុទ្ធឲ្យធ្វើ ក្នុងការឆ្លើយតបទៅនឹងសង្កត់សង្កិនលើពួកគេ ។

- ស្របតាម ខ ៤០ តើពរជ័យអ្វីខ្លះនឹងកើតមានដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បើពួកគេព្យាយាមបង្កើតសន្តិភាពជាមួយអ្នកដទៃនោះ ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងព្យាយាមបង្កើតសន្តិភាពជាមួយអ្នកដទៃ នោះអ្វីគ្រប់យ៉ាងនឹងសម្រេចទៅបានសម្រាប់ការល្អរបស់យើង** ) ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជួយបង្កើតសន្តិភាពជាមួយអ្នកដទៃ ?

- តើអ្នកធ្លាប់បានទទួលពរជ័យយ៉ាងដូចម្ដេច ពេលអ្នកព្យាយាមបង្កើតសន្តិភាព រួមទាំងជាមួយអ្នកដែលបៀតបៀនអ្នកនោះ ?

សូមឲ្យសិស្សពិចារណាពីរឿងមួយ ដែលពួកគេអាចធ្វើបានក្នុងការព្យាយាមបង្កើតសន្តិភាពជាមួយអ្នកនៅក្នុងជីវិតពួកគេឲ្យកាន់តែប្រសើរឡើង ជាពិសេសនៅពេលដែលពួកគេអាចត្រូវបានគេជិះជាន់ ហើយសរសេរគោលដៅមួយនៅក្នុងសៀវភៅសរសេរ ឬក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ដើម្បីធ្វើតាមគោលការន៍នេះ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២–១០៥ ( មេរៀនទី ២២ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២–១០៥ ( មេរៀនទី ២២ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ៖ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២)

សិស្សបានសិក្សារឿងប្រៀបធៀបបីដែលព្រះអម្ចាស់បានប្រើ ដើម្បីបង្រៀនពួកបរិសុទ្ធពីព្រះឆន្ទៈរបស់ទ្រង់ទាក់ទងនឹងសេចក្ដីប្រោសលោះនៃស៊ីយ៉ូន ។ នៅពេលពួកគេបានសិក្សា នោះសិស្សបានរៀនគោលការណ៍ខាងក្រោមនេះ ៖ តាមរយៈកិច្ចការនៃព្រះវិហារបរិសុទ្ធ ការរស់នៅដោយសុចរិត ហើយធ្វើតាមព្យាការី នោះយើងត្រៀមខ្លួនដើម្បីទប់ទល់នឹងសេចក្ដីវេទនា នៅពេលយើងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងត្រូវបានពង្រឹងឲ្យទប់ទល់នឹងមារសត្រូវខាងវិញ្ញាណ និង ខាងរូបកាយ នៅពេលយើងមកជួបជុំគ្នាដើម្បីទៅព្រះវិហារបរិសុទ្ធ នោះយើងទទួលបានការការពារ ហើយត្រៀមខ្លួនយើងសម្រាប់ជីវិតអស់កល្បជានិច្ច ហើយព្រះបានប្រទានសិទ្ធិជ្រើសរើសដល់យើង អំណាចដើម្បីជ្រើសរើស ប៉ុន្តែយើងត្រូវតែទទួលខុសត្រូវចំពោះជម្រើសនានារបស់យើង ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣)

នៅពេលសិស្សបានសិក្សាការណែនាំរបស់ព្រះអម្ចាស់ទាក់ទងនឹងសេចក្ដីប្រោសលោះនៃស៊ីយ៉ូន នោះពួកគេបានរកឃើញពរជ័យដែលយើងទទួលនៅពេលយើងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ និង លទ្ធផលដែលកើតឡើងនៅពេលយើងពុំបានគោរពតាម ។ សិស្សក៏បានរៀនផងដែរថា កូនសិស្សរបស់ព្រះព្រះយេស៊ូវគ្រីស្ទមានឆន្ទៈថ្វាយជីវិតរបស់ខ្លួនដោយព្រោះព្រះនាមរបស់ទ្រង់ ហើយថាអស់ទាំងជ័យជំនះ និងសិរីល្អត្រូវបានធ្វើឲ្យសម្រេចដល់យើងតាមរយៈសេចក្ដីឧស្សាហ៍ សេចក្ដីស្មោះត្រង់ និង ពាក្យអធិស្ឋានទាំងឡាយនៃសេចក្ដីជំនឿរបស់យើង ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤)

ចេញពីការណែនាំរបស់ព្រះអម្ចាស់ចំពោះការរៀបចំឡើងវិញនូវសហសមាគម ( ជាញឹកញាប់ត្រូវបានហៅថាជាសណ្ដាប់ធ្នាប់សមាគម ) នោះសិស្សបានរៀនថាព្រះអម្ចាស់បានបង្កើតផែនដីនេះ ហើយថាអ្វីៗទាំងអស់ដែលនៅលើផែនដីនេះគឺជារបស់ទ្រង់ ។ ពួកគេបានរកឃើញគោលការណ៍ថា យើងត្រូវទទួលខុសត្រូវដើម្បីប្រើប្រាស់នូវអ្វីដែលព្រះអម្ចាស់បានប្រទានដល់យើងដើម្បីជួយមនុស្សដទៃ ។ សិស្សក៏បានរៀនផងដែរអំពីពរជ័យនានា ដែលយើងទទួលបានពីការបន្ទាបខ្លួន និង ភាពស្មោះត្រង់ ព្រមទាំងការអំពាវនាវរកព្រះនាមរបស់ព្រះអម្ចាស់ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥)

បន្ទាប់ពីក្រុមជំរំស៊ីយ៉ូនបានទៅដល់រដ្ឋមិសសួរី នោះព្រះអម្ចាស់បានបើកសម្ដែងថា ក្រុងស៊ីយ៉ូននឹងពុំត្រូវបានប្រោសលោះនៅពេលនោះឡើយ ។ ចេញពីការណែនាំរបស់ព្រះអម្ចាស់ចំពោះពួកបរិសុទ្ធ នោះសិស្សបានរៀននូវគោលការណ៍ខាងក្រោម ៖ យើងត្រូវតែរួបរួមគ្នា ហើយគោរពធ្វើតាមអ្វីៗទាំងអស់ដែលព្រះស្នើសុំ ដើម្បីឲ្យទីក្រុងស៊ីយ៉ូនត្រូវបានបង្កើតឡើង ព្រះបានរៀបចំពរជ័យដ៏មហិមាសម្រាប់អ្នកដែលស្មោះត្រង់ដោយឆ្លងកាត់ការសាកល្បងរបស់ពួកគេ ហើយប្រសិនបើយើងស្វែងរកបង្កើតសន្តិភាពជាមួយមនុស្សដទៃ នោះគ្រប់ការណ៍ទាំងអស់នឹងផ្សំគ្នាសម្រាប់សេចក្ដីល្អដល់យើង ។ ជាញឹកញាប់ កាលវិភាគរបស់ព្រះអម្ចាស់គឺខុសពីកាលវិភាគផ្ទាល់របស់យើង ។

## សេចក្ដីផ្ដើម

មេរៀននេះនឹងជួយសិស្សឲ្យអនុវត្តមេរៀននានានៃជំរំស៊ីយ៉ូននៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥

*ព្រះអម្ចាស់បើកសម្ដែងនូវអ្វីៗដែលពួកបរិសុទ្ធត្រូវតែធ្វើ ទាក់ទងនឹងឧបសគ្គនានានៅក្នុងដែនដីស៊ីយ៉ូន*

ពីមុនចាប់ផ្ដើមថ្នាក់, សូមស្វែងរកពែងក្រដាសមួយ កៅស៊ូកងមួយ និង ខ្សែបីចង្វាយ។ រង្វង់របស់កៅស៊ូកងត្រូវតែតូចជាងរង្វង់របស់ពែងក្រដាស ។ សូមចងខ្សែទាំងនោះជាប់នឹងកៅស៊ូកងដោយប្រវែងស្មើគ្នា ។



សូមចាប់ផ្ដើមមេរៀនដោយសូមអ្នកស្ម័គ្រចិត្តបីនាក់ ។ សូមដាក់ពែងនៅលើផ្ទៃរាបស្មើ ហើយបង្គាប់ឲ្យអ្នកស្ម័គ្រចិត្តទាំងនោះចាប់លើកពែងឡើងដោយប្រើតែកៅស៊ូកង និង ខ្សែនោះប៉ុណ្ណោះ ។ សូមប្រាប់ពួកគេថាពួកគេពុំអាចប៉ះកៅស៊ូកងឡើយ ពួកគេត្រូវតែកាន់តែខ្សែ ។ ( ដើម្បីសម្រេចកិច្ចការនេះ សិស្សនឹងត្រូវធ្វើការជាមួយគ្នា ហើយទាញខ្សែរៀងៗខ្លួនព្រមគ្នា ដោយប្រើកម្លាំងឲ្យស្មើគ្នា ដើម្បីពង្រីកកៅស៊ូកងឲ្យធំល្មមដើម្បីដាក់វាជុំវិញពែងនោះ ហើយលើកវាឡើង ) ។

បន្ទាប់ពីសិស្សបានបំពេញសកម្មភាពនេះហើយសូមសួរសំណួរខាងក្រោម ៖

- តើការរួបរួមគ្នាដើរតួយ៉ាងណាខ្លះនៅក្នុងការសម្រេចនូវកិច្ចការនេះ ?

សូមរំឭកសិស្សថា អំឡុងពេលការសិក្សារបស់ពួកគេកាលពីសប្ដាហ៍មុន នោះពួកគេបានមានឱកាសសិក្សាវិវរណៈពីព្រះអម្ចាស់ទាក់ទងនឹងជំរំស៊ីយ៉ូន និង បេសកកម្មរបស់វាដើម្បីជួយពួកបរិសុទ្ធដែលនិរទេសនៅក្នុងទីក្រុងស៊ីយ៉ូន ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលការរួបរួមគ្នាដើរតួនៅក្នុងការព្យាយាមរបស់ពួកបរិសុទ្ធ ដើម្បីទទួលកម្មសិទ្ធិវិញនៃដែនដីស៊ីយ៉ូនតាមរយៈមេរៀនថ្ងៃនេះ ។

សូមអញ្ជើញសិស្សឲ្យប្រាប់ពីរឿងនៃជំរំស៊ីយ៉ូន ដោយផ្អែកលើអ្វីដែលពួកគេបានអាននៅក្នុងការសិក្សារបស់ពួកគេនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ និង ១០៥។ សំណួរខាងក្រោមនេះអាចត្រូវបានសួរ ដើម្បីជួយសិស្សនៅពេលពួកគេរំឭកពីអ្វីដែលពួកគេបានរៀន ៖

- ហេតុអ្វីពួកបរិសុទ្ធនៅក្នុងទីក្រុងស៊ីយ៉ូន ( ឃុំចាកសុន រដ្ឋមិសសួរី ) ត្រូវការជំនួយ? ( ពួកគេត្រូវបានបង្ខំឲ្យចាកចេញពីដែនដីរបស់ខ្លួនដោយពួកជនកំណាច ) ។

- តើជំរំស៊ីយ៉ូនគឺជាអ្វី ? ( ក្រុមមួយដែលមានបុរសជាង ២០០នាក់ ស្ត្រី ១២នាក់ និង កូនក្មេង ៩នាក់—បានស្ម័គ្រចិត្ត ហើយជ្រើសរើស—ដឹកនាំដោយព្យាការីយ៉ូសែប ស្ម៊ីធ ហើយបានរៀបចំឡើងតាមការគោរពចំពោះការណែនាំរបស់ព្រះអម្ចាស់ ) ។

- តើគោលបំណងចម្បងរបស់ជំរំស៊ីយ៉ូនគឺជាអ្វី ? ( នាំយកធនធានដ៏ចាំបាច់នានាទៅកាន់ពួកបរិសុទ្ធដែលនិរទេសនៅរដ្ឋមិសសួរី ហើយជួយពួកគេក្នុងការទាមទារមកវិញនូវដែនដីរបស់ពួកគេនៅក្នុងឃុំចាកសុន ) ។

សូមរំឭកសិស្សថាវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥ ត្រូវបានប្រទានឲ្យនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៨៣៤ បន្ទាប់ពីក្រុមជំរំស៊ីយ៉ូនកំពុងធ្វើដំណើរអស់ជិតប្រាំពីរសប្ដាហ៍ និង បានចម្ងាយប្រមាណតែ ១០ ទៅ ២០ ម៉ាយ ( ប្រហែល ១៥–៣០គីឡូម៉ែត្រ ) ពីឃុំចាកសុន ។ សូមសួរសិស្សប្រសិនបើមាននរណាម្នាក់អាចប្រាប់ពីការណែនាំរបស់ព្រះអម្ចាស់ ដែលបានប្រទានឲ្យនៅពេលនោះដល់ក្រុមជំរំស៊ីយ៉ូនទាក់ទងនឹងសេចក្ដីប្រោសលោះនៃស៊ីយ៉ូន ។ ( ពួកគេត្រូវរង់ចាំជួយពួកបរិសុទ្ធដែលនិរទេសឲ្យទាមទារយកវិញនូវដែនដីស៊ីយ៉ូនវិញ ។ ប្រសិនបើសិស្សត្រូវការជំនួយពីការចងចាំពីព័ត៌មានលម្អិតនេះ សូមអញ្ជើញពួកគេឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៩) សារចុះសារឡើង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៥:៣–៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រំពឹងពីហេតុផលមួយចំនួនដែលព្រះអម្ចាស់បានប្រទាននូវការពន្យាពេលនៃសេចក្តីប្រោសលោះនៃស៊ីយ៉ូន ។

- តើមានហេតុផលអ្វីខ្លះដែលព្រះអម្ចាស់បានប្រទានចំពោះការពុំស្តារឡើងវិញដល់ពួកបរិសុទ្ធនូវដែនដី និង ផ្ទះសម្បែងរបស់ខ្លួននៅក្នុងក្រុងស៊ីយ៉ូននៅពេលនោះ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរទាំងនេះ អំពីអ្វីដែលយើងត្រូវតែធ្វើដើម្បីកសាងក្រុងស៊ីយ៉ូននោះ ? ( សិស្សអាចផ្តល់គោលការណ៍ផ្សេង ៗគ្នា ប៉ុន្តែសូមជួយពួកគេឲ្យរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **យើងត្រូវតែរួបរួមគ្នា ហើយគោរពធ្វើតាមអ្វីៗទាំងអស់ដែលព្រះស្នើសុំ ដើម្បីឲ្យទីក្រុងស៊ីយ៉ូនត្រូវបានស្ថាបនាឡើង ។** អ្នកអាចចង់សរសេរគោលការណ៍នេះនៅលើក្តារខៀន ) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរឡើងពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ការពន្យល់របស់អែលឌើរគ្រីស្តូហ្វឺសិនអំពីអត្ថន័យនៃក្រុងស៊ីយ៉ូន និង អ្វីដែលត្រូវតែកើតឡើងចំពោះវា ដើម្បីវាត្រូវបានស្ថាបនាឡើង ។



« ស៊ីយ៉ូនគឺជាទីតាំងផង និង ជាមនុស្សផង ។. . .

« ស៊ីយ៉ូន គឺជាក្រុងស៊ីយ៉ូនដោយសារតែចរិត លក្ខណៈ និង ភាពស្មោះត្រង់របស់ពលរដ្ឋនៃក្រុងនោះ ។ សូមចងចាំថា ‹ ព្រះអម្ចាស់ទ្រង់បានហៅរាស្ត្រទ្រង់ថាស៊ីយ៉ូន ពីព្រោះពួកគេមានចិត្តតែមួយ និង គំនិតតែមួយ រស់នៅក្នុងសេចក្តីសុចរិត ហើយគ្មានមនុស្សក្រីក្រនៅក្នុងចំណោមពួកគេឡើយ › (ម៉ូសេ ៧:១៨) ។ ប្រសិនបើយើងនឹងស្ថាបនាស៊ីយ៉ូននៅក្នុងគេហដ្ឋានសាខា វួដ និង ស្តេករបស់យើង នោះយើងត្រូវតែចាប់យកបទដ្ឋាននេះ ។ វានឹងចាំបាច់ (១) ដើម្បីមានសាមគ្គីភាពក្នុងដួងចិត្ត ហើយគំនិតតែមួយ (២) ដើម្បីប្រែក្លាយជារាស្ត្រដ៏បរិសុទ្ធទាំងជាបុគ្គល និង ជារួមព្រមទាំង (៣) ដើម្បីមើលថែដល់អ្នកទ័លក្រ និង ទុគ៌ត ដោយមានប្រសិទ្ធភាពដូច្នេះ ដើម្បីយើងលុបបំបាត់ភាពក្រីក្រនៅក្នុងចំណោមពួកយើង ។ យើងពុំអាចរង់ចាំរហូតដល់ក្រុងស៊ីយ៉ូនមកដល់ ដើម្បីមានអ្វីៗទាំងនេះកើតឡើងនោះទេ—ក្រុងស៊ីយ៉ូន នឹងមកដល់តែពេលដែលអ្វីៗទាំងនេះកើតឡើងហើយប៉ុណ្ណោះ » (Come to Zion » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៨, ទំព័រ ៣៧, ៣៨ ) ។

សូមគិតពីការសួរសំណួរខាងក្រោមមួយចំនួន ដើម្បីជួយសិស្សឲ្យយល់ដឹងកាន់តែជ្រៅជ្រះអំពីក្រុងស៊ីយ៉ូន ៖

- តើស៊ីយ៉ូនគឺជាអ្វី ?
- តើអ្វីខ្លះត្រូវតែកើតឡើងដើម្បីស្ថាបនាក្រុងស៊ីយ៉ូន ?
- តើអ្នកគិតថាហេតុអ្វីបានជាការរួបរួមគ្នា និង ការគោរពប្រតិបត្តិ ត្រូវបានតម្រូវឲ្យមានដើម្បីឲ្យស៊ីយ៉ូនត្រូវបានស្ថាបនាឡើង ?
- យោងតាម គោលលទ្ធិ និង សេចក្តីសញ្ញា ១០៥:៣–៥, មនុស្សដែលរួបរួមគ្នាកំពុងគោរពតាមក្រឹត្យវិន័យនៃនគរនៃសិរីល្អណាមួយ ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីពង្រឹងសាមគ្គីភាពនៅក្នុងគ្រួសារ ថ្នាក់រៀនក្នុងសាសនាចក្រ ឬ កូរ៉ុមរបស់អ្នក ? តើអ្នកអាចលើកទឹកចិត្តមនុស្សដទៃនៅក្នុងក្រុមទាំងនេះឲ្យរួបរួមគ្នា ហើយគោរពប្រតិបត្តិចំពោះព្រះអម្ចាស់យ៉ាងដូចម្តេច ?
- តើការធ្វើនូវកិច្ចការទាំងនេះជួយអ្នក និង មនុស្សដទៃឲ្យស្ថាបនាស៊ីយ៉ូនយ៉ាងដូចម្តេច ?
- តើមានបទពិសោធន៍អ្វីខ្លះដែលបានជួយអ្នកឲ្យយល់ពីសារៈសំខាន់នៃសាមគ្គីភាពនៅក្នុងក្រុម ?

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីមួយដែលពួកគេអាចធ្វើដើម្បីពង្រឹងសាមគ្គីភាពនៅក្នុងក្រុមគ្រួសារ ឬ ថ្នាក់រៀនក្នុងសាសនាចក្រ ឬ កូរ៉ុមរបស់ពួកគេ ? សូមឲ្យសិស្សពិភាក្សាជាមួយដៃគូអំពីអ្វីដែលពួកគេនឹងធ្វើ ។ សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការមានភាពសាមគ្គី និងការគោរពប្រតិបត្តិ ពេលយើងព្យាយាមសម្រេចព្រះរាជបំណងរបស់ព្រះអម្ចាស់ ។

សូមពន្យល់ថា ព្រះអម្ចាស់បានរួមបញ្ចូលវិវរណៈនេះនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១០៥ ដោយណែនាំពួកបរិសុទ្ធពីរបៀបដែលពួកគេគប្បីឆ្លើយតបចំពោះមារសត្រូវរបស់ខ្លួន ។ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៥:៣៨–៤១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយជ្រើសរើសឃ្លា មួយចេញពីខគម្ពីរទាំងនោះ ដែលសង្ខេបពីអ្វីដែលព្រះអម្ចាស់បានដឹកនាំពួកបរិសុទ្ធឲ្យធ្វើ ក្នុងការឆ្លើយតបនឹងពួកអ្នកសង្កត់សង្កិនខ្លួន ។ បន្ទាប់មកសូមឲ្យសិស្សពន្យល់ពីមូលហេតុដែលពួកគេបានជ្រើសរើសឃ្លាទាំងនោះ ។

- ដោយផ្អែកទៅលើការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះ តើពរជ័យអ្វីខ្លះអាចត្រូវបានប្រទានឲ្យប្រសិនបើយើងព្យាយាមបង្កើតសន្តិភាពជាមួយមនុស្សដទៃនោះ ? ( សូមគិតពីការអញ្ជើញសិស្សឲ្យគូសពាក្យ ឬ ឃ្លានានាដែលបង្រៀននូវគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងព្យាយាមបង្កើតសន្តិភាពជាមួយមនុស្សដទៃ នោះការណ៍គ្រប់យ៉ាងនឹងផ្សំគ្នាសម្រាប់ជាសេចក្ដីល្អដល់យើង**) ។
- តើអ្នកធ្លាប់បានឃើញពរជ័យអ្វីខ្លះដែលបានទទួល នៅពេលអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ព្យាយាមធ្វើជាអ្នកផ្សះផ្សារគេ ?

សូមលើកទឹកចិត្តសិស្សឲ្យព្យាយាមបង្កើតសន្តិភាព នៅក្នុងទំនាក់ទំនងជាមួយមនុស្សដទៃ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦–១០៨; ១៣៧)

សូមសួរសិស្សប្រសិនបើពួកគេធ្លាប់ឆ្ងល់ពីអ្វីនឹងកើតឡើងដល់មនុស្សដែលស្លាប់ទៅ ដោយពុំបានជ្រមុជទឹក ឬ ដោយពុំបានឮដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងរកឃើញចម្លើយចំពោះសំណួរនោះ ។ ពួកគេក៏នឹងរៀនផងដែរអំពីឈ្មោះដើមនៃបព្វជិតភាពមិលគីស្សាដែក និង មុខងារនៃតំណែងបព្វជិតភាព ។

មេរៀនទី ១១១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:១–១០៧:២០

## បុព្វកថា

នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៨៣៤ ព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានហៅ វ៉ារិន អេ ខៅឌើរី និងបងប្រុសរបស់ អូលីវើ ខៅឌើរី ឲ្យធ្វើជាអធិបតីលើសាសនាចក្រនៅទីក្រុង ហ្វ្រីដុម រដ្ឋ នូវ យ៉ោក និងសហគមនៅជុំវិញនោះ ។ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ប្រហែលក្នុងខែ មេសា ឆ្នាំ ១៨៣៥ ថាសមាជិកទាំងអស់ក្នុងកូរ៉ុមនៃសាវកដប់ពីរនាក់ ត្រូវរៀបចំខ្លួនដើម្បីបម្រើបេសកកម្មនៅភាគខាងកើតនៃសហរដ្ឋ ។ នៅក្នុងសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរមួយ ក្រុមសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ៖ « ពេលដែលយើងត្រូវបែកគ្នាជិតមកដល់ហើយ មានតែព្រះដែលជ្រាបថា យើងនឹងជួបគ្នាម្ដងទៀត ដូច្នេះយើងសូមអ្នកដែលយើងទទួលស្គាល់ថាជាព្យាការី និងអ្នកមើលឆុតឲ្យអធិស្ឋាន និងទទួលវិវរណៈសម្រាប់ពួកយើង . . . ដែរយើងនឹងពឹងផ្អែកលើវានៅពេលដែលយើងបែកគ្នាហើយដួងចិត្តរបស់យើងអាចត្រូវបានលួងលោម »( នៅក្នុង *History of the Church,* ២:២០៩–១០ ) ។ វិវរណៈនេះត្រូវបានកត់ត្រានៅក្នុងឆ្នាំ ១៨៣៥, ប៉ុន្តែ « កំណត់ត្រាប្រវត្តិសាស្ត្របញ្ជាក់ថាវិវរណៈភាគច្រើននៃ ខ ៦០ ដល់ខ ១០០ បញ្ចូលវិវរណៈដែលបានប្រទានឲ្យតាមរយៈ យ៉ូសែប ស៊្មីធ នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ » ( បុព្វកថាក្នុង គ. និង ស. ១០៧ ) ។ នេះគឺជាមេរៀនទីមួយនៃមេរៀនទាំងបីនៅក្នុងសៀវភៅសិក្សានេះលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦

*ព្រះអម្ចាស់បានហៅ វ៉ារិន ខៅឌើរី ជាសង្ឃជាន់ខ្ពស់ជាអធិបតី នៅទីក្រុង ហ្វ្រីដុម រដ្ឋ នូវ យ៉ោក*

សូមឲ្យសិស្សគិតពីពេលដែលពួកគេបានគាំទ្រប៊ីស្សព ឬប្រធានសាខាថ្មីម្នាក់ ។

- តើអ្នកគិតថា បុគ្គលម្នាក់មានអារម្មណ៍យ៉ាងដូចម្ដេច នៅពេលដែលលោកត្រូវបានគាំទ្រ ?

សូមពន្យល់ថា ក្នុងឆ្នាំ ១៨៣៤ សាសនាចក្របានជួបប្រទះការរីកចម្រើនដ៏គួរឲ្យកត់សម្គាល់ នៅទីក្រុង ហ្វ្រីដុម រដ្ឋ ញូវយ៉ក ចម្ងាយប្រមាណជា ៣២០គីឡូម៉ែត្រពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ ព្រះអម្ចាស់បានហៅអ្នកដឹកនាំបព្វជិតភាពម្នាក់ ឲ្យធ្វើជាអធិបតីលើសមាជិកនៅទីនោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:១–៣ ដោយស្ងាត់ស្ងៀម ។

- តើព្រះអម្ចាស់ណែនាំ វ៉ារិន ខៅឌើរី ឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា អារម្មណ៍របស់បងប្រុស ខៅឌើរី ប្រហែលជាដូចអ្នកដែលជាប៊ីស្សព ឬប្រធានសាខាសព្វថ្ងៃនេះដែរ ។ ព្រះអម្ចាស់បានចែកចាយពាក្យលួងលោម នៅពេលដែលបងប្រុស ខៅឌើរី បានទទួលយកការហៅបម្រើថ្មីរបស់លោក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលមូលហេតុដែលព្រះអម្ចាស់មានសេចក្ដីអំណរជាមួយបងប្រុស ខៅឌើរី ។

- តើអ្នកគិតថាឃ្លា « ក្រាបចំពោះដំបងពេជ្ររបស់យើង » មានន័យយ៉ាងណា ? ( ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ អ្នកអាចពន្យល់ថា ដំបងពេជ្រគឺជារបស់ដែលកាន់ដោយស្ដេច និងម្ចាស់ក្សត្រី ។ វាគឺជានិមិត្តសញ្ញានៃអំណាច ) ។
- តើអ្នកគិតថាឃ្លា « បំបែកខ្លួនចេញពីកលល្បិចនៃមនុស្ស » មានអត្ថន័យដូចម្ដេច ?

សូមសេរសេរពាក្យ *បើនៅលើក្ដារខៀន*________________________________________*នោះ*
________________________.សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការទូន្មាន និងការសន្យារបស់ព្រះអម្ចាស់ចំពោះបងប្រុស ខៅឌើរី ។ សូមអញ្ជើញសិស្សឲ្យ

សរសេរអ្វីដែលពួកគេរកឃើញ ដោយសរសេរគោលការណ៍ « បើ–នោះ » នៅក្នុងព្រះគម្ពីររបស់ពួកគេ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគោលការណ៍ដែលពួកគេបានរកឃើញនោះ ។ (សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងមានក្ដីមេត្តាករុណាមកលើយើង តម្កើងយើង ហើយប្រទានឲ្យយើងនូវព្រះគុណ និងការលួងលោម** ) ។

- តើព្រះអម្ចាស់តម្កើងអ្នកដែលបន្ទាបខ្លួនចំពោះទ្រង់តាមវិធីណា ?

សូមថ្លែងទីបន្ទាល់ថាយើងអាចទទួលបានពរជ័យ ដែលបានសន្យាដល់ វ៉ារិន ខោវឌើរី ដែលថា បើយើងបន្ទាបខ្លួនចំពោះព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១–២០

*ព្រះអម្ចាស់បង្រៀនអំពី បព្វជិតភាព អើរ៉ុន និង បព្វជិតភាព មិលគីស្សាដែក*

សូមពន្យល់ថា វិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ បានជួយបញ្ជាក់ពីការរៀបចំ និងទំនួលខុសត្រូវរបស់គណៈប្រធានទីមួយ កូរ៉ុមនៃពួកដប់ពីរនាក់ និងកូរ៉ុមនៃពួកចិតសិបនាក់ ។

សូមអានការពិពណ៌នាពីព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ ដូចខាងក្រោម ។ សូមអញ្ជើញសិស្សឲ្យទាយថាអ្នកកំពុងពិពណ៌នាពីនរណា ។

ព្យាការីនេះ « គឺជាបុរសនៃសេចក្ដីជំនឿ ដែលសម្ដែងនូវភាពសុចរិត ហើយកាលលោកនៅជាកុមារ លោកខ្លាចព្រះ ហើយបានបិតមាត់របស់ហ្វូងតោ ហើយបានពន្លត់ភ្លើងដ៏សន្ធោសន្ធៅ » ( ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ, លោកុប្បត្តិ ១៤:២៦ [ នៅក្នុង the Bible appendix ] ) ។ ក្នុងនាមជាស្ដេចក្រុងសាឡិម ទ្រង់ « បានបង្កើតសេចក្ដីសុខសាន្តនៅក្នុងស្រុកនៅសម័យទ្រង់ ហេតុដូច្នេះហើយ ទ្រង់ត្រូវបានហៅថាជាម្ចាស់នៃសេចក្ដីសុខសាន្ត » ( អាលម៉ា ១៣:១៨ ) ។ ព្យាការី អ័ប្រាហាំបានថ្វាយដង្វាយមួយភាគដប់ដល់ទ្រង់ ( សូមមើល អាលម៉ា ១៣:១៥ ) ។

បន្ទាប់ពីសិស្សបីបួននាក់បានសាកល្បងទាយឈ្មោះរបស់ព្យាការីនេះហើយ សូមសរសេរ *មិលគីស្សាដែក* នៅលើក្ដារខៀន ។ សូមឲ្យសិស្សស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១–៤ ដោយស្ងាត់ស្ងៀម រកមើលខទាំងនេះដែលបង្រៀនអំពីមិលគីស្សាដែក ។

- តើបព្វជិតភាព មិលគីស្សាដែក ត្រូវបានហៅថាជាអ្វីមុនជំនាន់របស់មិលគីស្សាដែក ? តើហេតុអ្វីបានជាវាត្រូវបានហៅថាបព្វជិតភាពមិលគីស្សាដែក ?

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **បព្វជិតភាពមិលគីស្សាដែក គឺត្រូវបានហៅតាមបញ្ញារបស់ព្រះរាជបុត្រានៃព្រះ** ។ អ្នកអាចស្នើសិស្សឲ្យគូសចំណាំឃ្លានេះនៅក្នុង ខ ៣ ។

- តើគោលការណ៍នេះបង្ហាញអំពីរបៀបដែលពួកអ្នកកាន់បព្វជិតភាពគួរតែបំពេញទំនួលខុសត្រូវរបស់ពួកគេអ្វីខ្លះ?

ជាចំណែកនៃការពិភាក្សានេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ប៊ យដ៍ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« អំណាចបព្វជិតភាពត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ គឺនៅពេលអ្នកកាន់បព្វជិតភាពធ្វើអ្វីដែលទ្រង់ព្រះយេស៊ូវគ្រីស្ទនឹងធ្វើ បើទ្រង់គង់នៅ » ( The Power of the Priesthood » *Ensign* ខែ ឧសភា ឆ្នាំ ២០១០, ទំព័រ ៧ ) ។

សូមសរសេរអង្គការរបស់សាសនាចក្រនៅលើក្ដារខៀន ៖ *សមាគមសង្គ្រោះ ថ្នាក់សាលាថ្ងៃអាទិត្យ យុវជន យុវនារី* និង *ថ្នាក់អង្គការបឋមសិក្សា* ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៥, ៨–៩ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវឃ្លាមួយដែលបង្រៀនពីរបៀបដែលអង្គការទាំងនេះទាក់ទងនឹងបព្វជិតភាពមិលគីស្សាដែក ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

**សូមជួយសិស្សឲ្យយល់អំពីគោលលទ្ធិគ្រឹះ**

សិស្សនឹងរៀនគោលលទ្ធិគ្រឹះនៅពេលពួកគេសិក្សា និង ពិភាក្សាខគម្ពីររាល់ថ្ងៃ និង នៅពេលពួកគេសូត្រចាំវគ្គព្រះគម្ពីរគន្លឹះ ។ អ្នកពុំគួរបង្វែរចេញពីការបង្រៀនតាមលំដាប់លំដោយនៃប្រវត្តិព្រះគម្ពីរ ដើម្បីផ្ដោតលើគោលលទ្ធិគ្រឹះទាំងនេះឡើយ ។ ផ្ទុយទៅវិញ អ្នកគួរយកចិត្តទុកដាក់ទៅលើគោលលទ្ធិទាំងឡាយនៅពេលវាមាននៅក្នុងវគ្គសិក្សា ។ ឧទាហរណ៍ នៅក្នុងមេរៀននេះ អ្នកអាចគូសបញ្ជាក់អំពីគោលលទ្ធិនៃបព្វជិតភាព និង កូនសោបព្វជិតភាព ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ។

- តើផ្នែកបន្ថែមជាអ្វី ? ( ជាផ្នែកនៃរាងកាយ ដូចជាដៃ ឬជើង ) ។

- យោងតាម ខ ៨, តើសិទ្ធិ និងអំណាចអ្វីដែលបព្វជិតភាពមិលគីស្សាដែកកាន់ ? ( នៅពេលដែលសិស្សឆ្លើយ អ្នកអាចនឹងចង់សរសេរសេចក្ដីពិតខាងក្រោមនៅលើក្ដារខៀន ៖ **បព្វជិតភាពមិលគីស្សាដែកមានសិទ្ធិខាងគណៈប្រធាន និងសិទ្ធិអំណាចលើអស់ទាំងតំណែងនៅក្នុងសាសនាចក្រ និងមានអំណាចដើម្បីចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ ។** សូមពន្យល់ថា « [ការ]ចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ » រួមបញ្ចូលការចាត់ចែងការប្រសិទ្ធិពរ ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញា ) ។

សូមពន្យល់ថា គណៈប្រធានដែលបានលើកឡើងនៅក្នុង ខ ៩ គឺជាគណៈប្រធានទីមួយ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថា តើនរណាផ្សេងទៀតដែលមានសិទ្ធិធ្វើការក្នុងដំណែងរបស់ខ្លួនក្រោមការដឹកនាំនៃគណៈប្រធានទីមួយ ។ នៅពេលសិស្សរាយការណ៍លើអ្វីដែលពួកគេបានរៀន សូមជួយពួកគេឲ្យយល់ថា គណៈប្រធានស្តេក និងគណៈប៊ីស្សព គឺជាឧទាហរណ៍នៃសង្ឃជាន់ខ្ពស់ធ្វើការក្នុងដំណែងរបស់ខ្លួននៅក្រោមការដឹកនាំនៃគណៈប្រធានទីមួយ ។

សូមមើលឈ្មោះអង្គការដែលអ្នកបានសរសេរនៅលើក្ដារខៀន ។ ដើម្បីជួយសិស្សឲ្យយល់ពីទំនាក់ទំនងរវាងអង្គការ និងស្តេក និងអ្នកដឹកនាំបព្វជិតភាពក្នុងវួដទាំងនេះ សូមអញ្ជើញសិស្សឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ឲ្យឮៗ ៖



« គ្មានរដ្ឋាភិបាលនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ដាច់ដោយឡែក ឬជាផ្នែកនៅខាងលើ ឬនៅក្រៅពីបព្វជិតភាពដ៏បរិសុទ្ធ ឬអំណាចរបស់វាឡើយ ។. . . [ អង្គការជំនួយ ] មិននៅក្រៅ ឬនៅលើ ហើយក៏មិនហួសពីវាឡើយ ។ ពួកគេទទួលស្គាល់គោលការណ៍នៃបព្វជិតភាព ។ គ្រប់ទីកន្លែងដែលពួកគេទៅ ពួកគេតែងតែនាំទិដ្ឋភាពនៃការសម្រេចបាននូវកិច្ចការល្អមួយចំនួន ការសង្គ្រោះព្រលឹងខាងសាច់ឈាម និងខាងវិញ្ញាណ » ( *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប អេហ្វ ស្ម៊ីធ* [ ឆ្នាំ ១៩៩៨ ], ទំព័រ ៣៤១–៤២ ) ។

សូមអញ្ជើញសិស្សឲ្យស្វែងរក គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១៨–១៩ ដោយស្ងាត់ស្ងៀម ដើម្បីរកមើលអំណាចបន្ថែមដែលបព្វជិតភាពមិលគីស្សាដែកកាន់ ។

- ស្របតាម ខ ១៨ តើអំណាចអ្វីទៅ ដែលបព្វជិតភាពមិលគីស្សាដែកកាន់ ? ( សូមសរសេរសេចក្ដីពិតខាងក្រោមនៅលើក្ដារខៀន នៅពេលសិស្សបាប្រប់ថា ៖ **បព្វជិតភាពមិលគីស្សាដែកកាន់កូនសោនៃពរជ័យខាងវិញ្ញាណនៅក្នុងសាសនាចក្រទាំងអស់**) ។

ដើម្បីជួយសិស្សឲ្យយល់សេចក្ដីពិតនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ ដោយព្យាការី យ៉ូសែប ស្ម៊ីធ ឲ្យឮៗ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលពរជ័យខាងវិញ្ញាណ ដែលមកតាមរយៈបព្វជិតភាពមិលគីស្សាដែក ។



«[ បព្វជិតភាពមិលគីស្សាដែក ] គឺជាផ្លូវដែលចំណេះដឹង គោលលទ្ធិ ផែនការនៃសេចក្ដីសង្គ្រោះ និងរឿងសំខាន់ៗទាំងអស់ ត្រូវបានបើកសម្ដែងពីស្ថានសួគ៌មក » ( នៅក្នុង *History of the Church*, ៤:២០៧ ) ។

- តើពរជ័យខាងវិញ្ញាណមួយណាដែលបានពិពណ៌នានៅក្នុង ខ ១៩ ដែលលេចធ្លោចំពោះអ្នក ? ហេតុអ្វី ?

សូមជួយសិស្សឲ្យយល់ថាអ្នកដែលកាន់បព្វជិតភាពមិលគីស្សាដែក ប្រើវាដើម្បីជួយមនុស្សដទៃឲ្យទទួលបានពរជ័យ ដូចជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងពរជ័យនៃព្រះវិហារបរិសុទ្ធ ។

- តើពរជ័យណាខ្លះ ដែលអ្នកបានទទួលតាមរយៈបព្វជិតភាពមិលគីស្សាដែក ?

សូមពន្យល់ថា ព្រះអម្ចាស់ក៏បានពិពណ៌នាពីសេចក្ដីពិតដែលបានបើកសម្ដែង អំពីសិទ្ធិអំណាចបព្វជិតភាពអើរ៉ុនផងដែរ ។ សូមអញ្ជើញសិស្សបីនាក់ឲ្យឆ្លាស់វេណគ្នាអានឲ្យឮៗមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១៣–១៤, ២០ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីសិទ្ធិអំណាចដែលបព្វជិតភាពអើរ៉ុនកាន់ ។

- តើសិទ្ធិអំណាចអ្វី ដែលបព្វជិតភាពអើរ៉ុនកាន់ ? ( សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **បព្វជិតភាពអើរ៉ុនកាន់កូនសោនៃការចាត់ចែងពួកទេវតា និងការចាត់ចែងពិធីបរិសុទ្ធខាងក្រៅ** ) ។
- តើពិធីបរិសុទ្ធអ្វីទៅដែលលើកឡើងនៅក្នុង ខ ២០ ? តើពិធីបរិសុទ្ធអ្វីខ្លះទៀតដែលបានចាត់ចែងដោយសិទ្ធិអំណាចនៃបព្វជិតភាពអើរ៉ុន ? ( ពិធីសាក្រាម៉ង់ ) ។
- តើពរជ័យអ្វីខ្លះ ដែលអ្នកបានទទួលតាមរយៈបព្វជិតភាពអើរ៉ុន ?

សូមសរសេរ ចំណងជើង ដូចខាងក្រោមនៅលើក្ដារខៀន ៖

> *ដំណែងបព្វជិតភាពមិលគីស្សាដែក ដំណែងបព្វជិតភាអើរ៉ុន*

មុនពេលចូលរៀន សូមសរសេរដំណែងបព្វជិតភាពខាងក្រោម នៅលើក្រដាសមួយផ្ទាំង ៖ *ឌីកុន គ្រូ សង្ឃ ប៊ីស្សព អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ សាវក* ។ សូមដាក់ក្រដាសចូលក្នុងប្រអប់មួយ មិនតាមលំដាប់លំដោយ ។

នៅចំណុចណាមួយក្នុងមេរៀន សូមចែកក្រដាសឲ្យសិស្សបីបួននាក់ ។ សូមអញ្ជើញសិស្សឡើងមកលើក្ដារខៀន ហើយដាក់តំណែងនិមួយៗនៅក្រោមចំណងជើងដែលត្រឹមត្រូវ ។

សិស្សមួយចំនួនអាចនិយាយថាតំណែងប៊ីស្សព គឺជាតំណែងបព្វជិតភាពមិលគីស្សាដែក ។ បើពួកគេយល់ដូច្នោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១៣ ១៥ ឲ្យឮៗ ។ សូមសូមឲ្យសិស្សប្រើខគម្ពីរទាំងនេះដើម្បីសម្រេចទីកន្លែងដែលពួកគេគួរដាក់ដំណែងប៊ីស្សពនៅលើក្ដារខៀន ។ សូមពន្យល់ថា តំណែងប៊ីស្សព គឺជាតំណែងនៅក្នុងបព្វជិតភាពអើរ៉ុន ៖ ប៊ីស្សពម្នាក់ គឺជាប្រធាននៃបព្វជិតភាពអើរ៉ុន និងជាសង្ឃជាន់ខ្ពស់ជាអធិបតីនៅក្នុងវួដរបស់គាត់ ។ ( សូមចំណាំថា ការហៅនៃពូជពង្សនៃលោកអើរ៉ុនពិត ដូចដែលបានលើកឡើងនៅក្នុង ខ ១៦–១៧ ត្រូវបានលើកឡើងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:១៥–២១ និងមេរៀនទី ៧៤ ) ។

សូមប្រាកដថា តំណែងទាំងឡាយត្រូវបានដាក់យ៉ាងត្រឹមត្រូវនៅលើក្ដារខៀន ។ ( តំណែងបព្វជិតភាពមិលគីស្សាដែកមាន អែលឌើ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ និងសាវក ។ តំណែងនៃបព្វជិតភាពអើរ៉ុនមាន ឌីកុន គ្រូ សង្ឃ និង ប៊ីស្សព ។ សូមពន្យល់ថា បញ្ជីទាំងនេះ នឹងរៀបចំសិស្សសម្រាប់មេរៀនពីរបន្ទាប់ទៀត ហើយពួកគេនឹងរៀនបន្ថែមទៀតអំពីតំណែងបព្វជិតភាព ។

សូមបញ្ចប់ ដោយអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេ អំពីអ្វីដែលពួកគេបានរៀន និងពីអារម្មណ៍ដែលមាននៅក្នុងថ្នាក់ថ្ងៃនេះ ។

មេរៀនទី ១១២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨

## សេចក្ដីផ្ដើម

នៅខែ មេសា ឆ្នាំ ១៨៣៥ សមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដែលទើបតែបានតែងតាំងនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ បានរៀបចំខ្លួនចេញទៅបម្រើបេសកកម្មជាកូរ៉ុមដំបូង ។ មុនពេលពួកគេចាកចេញ ពួកគេបានសំណូមពរឲ្យព្យាការី យ៉ូសែប ស្ម៊ីធ ស្វែងរកវិវរណៈដើម្បីជួយពួកគេ កាលដែលពួកគេបែកចេញទៅ ( សូមមើល សេចក្ដីណែនាំដល់មេរៀនទី ១១១ ) ។ វិវរណៈដែលលោកបានទទួល គឺត្រូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៧ ។ នេះគឺជាមេរៀនទីពីរនៃមេរៀនទាំងបី ដែលពិភាក្សានៅក្នុងមេរៀននេះ ។ នៅក្នុងផ្នែកនៃវិវរណៈនេះ ព្រះអម្ចាស់បានពន្យល់ពីតួនាទីនៃកូរ៉ុមជាអធិបតីក្នុងសាសនាចក្រ ៖ គណៈប្រធានទីមួយ កូរ៉ុមនៃពួកដប់ពីរនាក់ និងកូរ៉ុមនៃពួកចិតសិបនាក់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–២៦

*ព្រះអម្ចាស់ពន្យល់ពីតួនាទី និងសិទ្ធិអំណាចរបស់កូរ៉ុមជាអធិបតីនៃសាសនាចក្រ*

មុនចាប់ផ្ដើមមេរៀន សូមសរសេរពាក្យខាងក្រោមនេះនៅលើក្ដារខៀន ៖ *ជួយ* និង *គាំទ្រ* ។ នៅពេលចាប់ផ្ដើមមេរៀន សូមឲ្យសិស្សគិតអំពីគ្រាដែលមាននរណាម្នាក់ជួយ ឬគាំទ្រពួកគេ ។ ហើយសូមឲ្យសិស្សបែរទៅរកដៃគូម្នាក់ ហើយពិពណ៌នាអំពីបទពិសោធន៍របស់ពួកគេ ។

- តើមានភាពខុសប្លែកគ្នាយ៉ាងណា កាលអ្នកដឹងថានរណាម្នាក់បានជួយ និងគាំទ្រអ្នកនោះ ?

សូមសរសេរពាក្យ *គាំទ្រ* នៅលើក្ដារខៀន ហើយពន្យល់ថាការគាំទ្រនរណាម្នាក់ មានន័យថា យើងជួយ និងគាំទ្របុគ្គលនោះ ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–២២ ដោយស្ងាត់ស្ងៀម រកមើលថានរណាដែលព្រះអម្ចាស់បានមានព្រះបន្ទូលឲ្យសមាជិកគួរតែគាំទ្រ ។

- តើនរណាដែលព្រះអម្ចាស់មានបន្ទូលថាយើងគួរគាំទ្រ ? ( នៅពេលដែលសិស្សឆ្លើយតប សូមសរសេរ *គណៈប្រធានទីមួយ* ជាចំណងជើងនៅលើក្ដារខៀន ) ។

សូមឲ្យសិស្សមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៨–៩ ដោយស្ងាត់ស្ងៀម ។ មុនពេលដែលពួកគេអានខគម្ពីរទាំងនេះ សូមពន្យល់ថានៅក្នុង ខ ៩ ឃ្លា « គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ តាមរបៀបលោកមិលគីស្សាដែក » សំដៅទៅលើគណៈប្រធានទីមួយ ។ សូមសូមឲ្យសិស្សរកមើលអ្វីដែលខគម្ពីរទាំងនេះបង្រៀន អំពីគណៈប្រធានទីមួយ ។

- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីគណៈប្រធានទីមួយ ? ( នៅក្រោមចំណងជើង សូមសរសេរសេចក្ដីពិតដូចខាងក្រោម ៖ **គណៈប្រធានទីមួយមានទំនួលខុសត្រូវ និងសិទ្ធិអំណាចដើម្បីធ្វើជាអធិបតីលើគ្រប់ការិយាល័យនៃសាសនាចក្រ**) ។

- ស្របតាម ខ ២២តើយើងអាចគាំទ្រគណៈប្រធានទីមួយយ៉ាងដូចម្ដេច ? ( ចម្លើយរបស់សិស្សគួរតែឆ្លុះបញ្ចាំងអំពីសេចក្ដីពិតដូចខាងក្រោម ៖ **គណៈប្រធានទីមួយ ត្រូវបានគាំទ្រដោយសេចក្ដីទុកចិត្ត សេចក្ដីជំនឿ និងការអធិស្ឋាននៃសាសនាចក្រ** ។ អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សគូសចំណាំពាក្យ ឬឃ្លានៅក្នុង ខ ២២ ដែលបង្រៀនពីគោលការណ៍នេះ ) ។

- តើហេតុអ្វីបានជាអ្នកគិតថា យើងត្រូវគាំទ្រគណៈប្រធានទីមួយ ?

សូមឲ្យសិស្សម្នាក់អានឮនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ៖ សូមសូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលពីអ្វី ដែលលោកបានមានប្រសាសន៍ថាយើងគួរធ្វើដើម្បីទ្រទ្រង់ ឬគាំទ្រអ្នកដឹកនាំសាសនាចក្ររបស់យើង ។

*សូមបង្ហាញរូបភាពនៃពួកអ្នកដឹកនាំសាសនាចក្រ*

ការបង្ហាញរូបភាពនៃពួកអ្នកដឹកនាំសាសនាចក្រ នឹងជួយសិស្សឲ្យស្គាល់អ្នកទាំងឡាយណាដែលព្រះអម្ចាស់បានហៅឲ្យធ្វើជាព្យាការី ជាអ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ នៅក្នុងមេរៀននេះ សិស្សនឹងរៀនអំពីតួនាទីដែលព្រះអម្ចាស់បានប្រទានដល់អ្នកដឹកនាំទាំងនេះ ។ មុនពេលចាប់ផ្ដើមបង្រៀន អ្នកអាចរករូបភាពបច្ចុប្បន្ននៃសមាជិកនៃគណៈប្រធានទីមួយ កូរ៉ុមនៃពួកដប់ពីរនាក់ គណៈប្រធាននៃក្រុមចិតសិបនាក់ និងកូរ៉ុមទីមួយនៃក្រុមចិតសិបនាក់ ។ រូបភាពទាំងនេះត្រូវបានរួមបញ្ចូលនៅក្នុងទស្សនាវដ្ដីសាសនាចក្រស្ដីពីសន្និសីទ និងអាចរកបាននៅលើគេហទំព័រ LDS.org ។



« ចំពោះយើង ដើម្បីគាំទ្រដល់អ្នកទាំងឡាយ ដែលត្រូវបានហៅ . . . យើងត្រូវតែពិនិត្យពិច័យលើជីវិតរបស់យើង ប្រែចិត្តបើចាំបាច់ សន្យាថានឹងគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ហើយធ្វើតាមពួកអ្នកបម្រើរបស់ទ្រង់ ។. . .

« . . . វានឹងជារឿងឈ្លាសវៃក្នុងការប្ដេជ្ញាចិត្តថានឹងគាំទ្រដោយសេចក្ដីជំនឿ និង សេចក្ដីអធិស្ឋានរបស់យើង ដល់អ្នកទាំងឡាយដែលបម្រើយើងនៅក្នុងនគរ ។ ខ្ញុំយល់ច្បាស់ដោយខ្លួនខ្ញុំផ្ទាល់ អំពីអំណាចនៃសេចក្ដីជំនឿរបស់សមាជិកសាសនាចក្រ ក្នុងការគាំទ្រដល់អ្នកទាំងឡាយដែលត្រូវបានហៅ ។. . . ខ្ញុំបានមានអារម្មណ៍ពីការអធិស្ឋាន និងសេចក្ដីជំនឿរបស់មនុស្សដែលខ្ញុំមិនស្គាល់ ហើយពួកគេបានស្គាល់ខ្ញុំថាជាមនុស្សម្នាក់ដែលត្រូវបានហៅឲ្យបម្រើ តាមរយៈកូនសោបព្វជិតភាព » ( The True and Living Church » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៨, ទំព័រ ២១ ) ។

- តើប្រធាន អាវរិង បានមានប្រសាសន៍ថា យើងត្រូវធ្វើអ្វីដើម្បីគាំទ្រដល់ពួកអ្នកដឹកនាំសាសនាចក្ររបស់យើង ?
- តើយើងអាចគាំទ្រពួកអ្នកដឹកនាំសាសនាចក្ររបស់យើង ដូចជាគណៈប្រធានទីមួយ ដែលយើងស្គាល់ដោយផ្ទាល់ដោយរបៀបណា ?

សូមឲ្យសិស្សគិតអំពីអ្វីដែលពួកគេកំពុងធ្វើ ដើម្បីគាំទ្រគណៈប្រធានទីមួយ និងអ្នកដឹកនាំសាសនាចក្រដទៃទៀត ។ សូមសូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅសរសេររបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីដែលពួកគេនឹងធ្វើនាពេលអនាគត ដើម្បីជួយ និងគាំទ្រថ្នាក់ដឹកនាំសាសនាចក្រកាន់តែប្រសើរឡើង ។

សូមសរសេរ *កូរ៉ុមនៃពួកដប់ពីរនាក់* ជាចំណងជើងនៅលើក្ដារខៀន ។ សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៣ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូល អំពីតួនាទីរបស់ពួកសាវកដប់ពីរនាក់ ។

- ស្របតាម ខ ២៣ តើពួកសាវកដប់ពីរនាក់ត្រូវបានហៅឲ្យធ្វើអ្វី ? ( បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមសរសេរគោលលទ្ធិនៅលើក្ដាខៀនក្រោមចំណងជើង « កូរ៉ុមនៃពួកដប់ពីរនាក់ » ៖ **ពួកសាវកជាសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទនៅពាសពេញពិភពលោក ។** ( អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំគោលលទ្ធិនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។
- តើអ្នកគិតថា ពួកសាវកជាសាក្សីពិសេសនៃព្រះនាមនៃព្រះគ្រីស្ទ មានន័យដូចម្ដេច ?

សូមឲ្យសិស្សអានអ្វីដែល Bible Dictionary និយាយអំពីពាក្យ និងតួនាទី *របស់សាវក ។* សូមឲ្យសិស្សរាយការណ៍អំពីការរកឃើញរបស់ពួកគេ។

សូមពន្យល់ថា ប្រធានសាសនាចក្រគឺជាសាវកច្បងនៅលើផែនដី ហើយថាទីប្រឹក្សានៅ ក្នុងគណៈប្រធានទីមួយក៏ជាសាវកដែរ ។ ដូច្នេះ សមាជិកនៃគណៈប្រធានទីមួយ ក៏ជាសាក្សីពិសេសនៃព្រះនាមនៃព្រះគ្រីស្ទដែរ ។ សូមឲ្យសិស្សគិតអំពីអារម្មណ៍ដែលពួកគេមាន នៅពេលពួកគេបានស្ដាប់ ឬអានភស្ដុតាង ឬទីបន្ទាល់របស់ពួកសាវក ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយពីអារម្មណ៍របស់ពួកគេជាមួយមិត្តរួមថ្នាក់ ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៤ ដោយស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីសិទ្ធិអំណាច និងអំណាចនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

- នៅក្នុង ខ ២៤ តើយើងអាចរៀនអ្វីខ្លះ អំពីសិទ្ធិ និងអំណាចនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ? ( ក្រុមកូរ៉ុមមានសិទ្ធិ និងអំណាចស្មើនឹងគណៈប្រធានទីមួយ ។ អ្នកអាចសរសេរព័ត៌មាននេះ នៅលើក្ដារខៀនក្រោមចំណងជើង « នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ » ) ។

សូមពន្យល់ថា ពេលបុរសណាម្នាក់ត្រូវបានតែងតាំងជាពួកសាវក នោះពួកគេត្រូវបានផ្ដល់កូនសោបព្វជិតភាពដូចគ្នានឹងប្រធាននៃសាសនាចក្រដែរ ។ ប៉ុន្តែ ប្រធាននៃសាសនាចក្រ ដែលជាសង្ឃជាន់ខ្ពស់ជាអធិបតីលើបព្វជិតភាពមិលគីស្សាដែកគឺជាបុរសតែម្នាក់នៅលើផែនដីដែលត្រូវបានអនុញ្ញាតឲ្យអនុវត្តកូនសោនៃបព្វជិតភាពទាំងអស់ ។ ពួកសាវកផ្សេងទៀត ប្រើកូនសោបព្វជិតភាពទាំងនេះដូចដែលបានអនុញ្ញាតដោយប្រធាននៃសាសនាចក្រ ។ នៅពេលប្រធានសាសនាចក្រស្លាប់ គណៈប្រធានទីមួយត្រូវបានរំសាយ ហើយកូរ៉ុមនៃពួកដប់ពីរនាក់ ដែលមានសិទ្ធិ និងអំណាចស្មើគ្នាទៅនឹងគណៈប្រធានទីមួយ ក្លាយជាក្រុមអធិបតីនៃសាសនាចក្រ ។ ក្នុងនាមជាប្រធាននៃកូរ៉ុមនៃពួកដប់ពីរនាក់ សាវកច្បងដែលនៅរស់ ត្រូវបានអនុញ្ញាតឲ្យអនុវត្តកូនសោបព្វជិតភាពទាំងអស់ ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៥ ដោយស្ងាត់ស្ងៀម រកមើលកូរ៉ុមបព្វជិតភាពមួយទៀត ដែលបានរំឭកឡើងនៅក្នុងវិវរណៈនេះ និងតួនាទីរបស់សមាជិកក្នុងកូរ៉ុមនោះ ។

- តើក្វ៉ូរ៉ុមទីបីដែលព្រះអម្ចាស់បានលើកឡើងនៅក្នុងវិវរណៈនេះជាអ្វី ? ( នៅពេលដែលសិស្សឆ្លើយ សូមសរសេរ *ក្រុមចិតសិបនាក់* ជាចំណងជើងនៅលើក្ដារខៀន ) ។

- តើក្រុមចិតសិបនាក់មានតួនាទីអ្វី ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរសេចក្ដីពិតដូចតទៅនៅលើក្ដារខៀន ក្រោមចំណងជើង « ក្រុមចិតសិបនាក់ » ៖ **ក្រុមចិតសិបនាក់ ត្រូវបានហៅឲ្យបង្រៀនដំណឹងល្អ និងធ្វើជាសាក្សីពិសេសនៃព្រះនាមនៃព្រះគ្រីស្ទនៅទូទាំងពិភពលោក**) ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៦ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីសិទ្ធិអំណាចនៃក្រុមចិតសិបនាក់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

ដើម្បីជួយសមាជិកក្នុងថ្នាក់ឲ្យយល់ពីអ្វីដែលព្រះអម្ចាស់មានបន្ទូលអំពីសិទ្ធិអំណាចនៃក្រុមចិតសិបនាក់ សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោម ៖

> « ព្រះយេស៊ូវគ្រីស្ទបានកាន់កូនសោបព្វជិតភាពទាំងអស់សម្រាប់សាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានប្រទានឲ្យពួកសាវករបស់ទ្រង់ម្នាក់ៗវាល់កូនសោ ដែលមានសម្រាប់នគរព្រះនៅលើផែនដី ។ សាវកចាស់ជាងគេដែលកំពុងរស់នៅ ដែលជាប្រធានសាសនាចក្រ គឺជាបុគ្គលតែម្នាក់គត់នៅលើផែនដីនេះ ដែលត្រូវបានប្រទានសិទ្ធិអំណាចឲ្យប្រើវាល់កូនសោបព្វជិតភាព ។. . .
>
> « ពួកចិតសិបនាក់ បម្រើតាមការចាត់តាំង និងតាមការផ្ទេរសិទ្ធិអំណាច ពីគណៈប្រធានទីមួយ និងក្វ៉ូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។. . . គណៈប្រធាននៃពួកចិតសិបនាក់ត្រូវបានញែកចេញ ហើយត្រូវបានផ្ដល់ឲ្យនូវកូនសោ ដើម្បីធ្វើជាអធិបតីលើក្វ៉ូរ៉ុមនៃពួកចិតសិបនាក់ » ( *ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* [ ឆ្នាំ ២០១០ ], ២.១.១

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍ទាំងឡាយដែលពួកគេមាន នៅពេលពួកគេបានអាន ឬបានស្ដាប់សុន្ទរកថាដោយសមាជិកនៃគណៈប្រធានទីមួយ ក្វ៉ូរ៉ុមនៃពួកដប់ពីរនាក់ និងក្រុមចិតសិបនាក់ ។ បើសិស្សបានជួបអ្នកដឹកនាំទាំងនេះ សូមឲ្យពួកគេចែកចាយបទពិសោធន៍នោះផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៧–៣២

*ព្រះអង្គសង្គ្រោះពន្យល់ពីរបៀបដែលក្វ៉ូរ៉ុមជាអធិបតីក្នុងសាសនាចក្រ ធ្វើការសម្រេចចិត្ត ។*

សូមប្រាប់សិស្សថាអ្នកចង់ឲ្យពួកគេធ្វើការសម្រេចចិត្តសាមញ្ញមួយជាក្រុម ( ឧទាហរណ៍ ពួកគេអាចសម្រេចយកបទចម្រៀងបិទសម្រាប់ការប្រជុំធម្មនិដ្ឋាននៅម៉ោងរៀនលើកក្រោយ ) ។ សូមលើកទឹកចិត្តសិស្សឲ្យពិភាក្សាពីជម្រើសរបស់ពួកគេ ហើយសម្រេចយកជម្រើសនោះរួមគ្នា ។ បន្ទាប់ពីសិស្សបានសម្រេចចិត្តហើយ សូមពិភាក្សាដូចខាងក្រោម ៖

- តើជាធម្មតា មនុស្សមួយក្រុមធ្វើការសម្រេចចិត្តយ៉ាងដូចម្ដេច ។

- តើអ្នកគិតថា វិធីសាស្ត្រទាំងនេះ អាចប្រៀបធៀបនឹងការសម្រេចចិត្តគណៈប្រធានទីមួយ ក្វ៉ូរ៉ុមនៃពួកដប់ពីរនាក់ និងក្រុមចិតសិបនាក់ យ៉ាងណាទៅ ?

សូមបែងចែកសិស្សជាគូៗ ។ សូមឲ្យពួកគេ អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៧–៣២ រួមគ្នា ហើយរកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពី របៀបដែលក្វ៉ូរ៉ុមជាអធិបតីនៃសាសនាចក្រធ្វើការសម្រេចចិត្ត ។ ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីសិក្សាខគម្ពីរទាំងនេះហើយ សូមពិភាក្សានូវសំណួរដូចខាងក្រោម ៖

- យោងតាមខគម្ពីរទាំងនេះ តើក្វ៉ូរ៉ុមជាអធិបតីធ្វើការសម្រេចចិត្តយ៉ាងដូចម្ដេច ? ( បន្ទាប់ពីសិស្សឆ្លើយតបហើយ អ្នកអាចសង្ខេបចម្លើយរបស់ពួកគេ ដោយសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ការសម្រេចចិត្តរបស់ក្វ៉ូរ៉ុមជាអធិបតីនៃសាសនាចក្រ ត្រូវបានធ្វើឡើងនៅក្នុងសាមគ្គី និងសេចក្ដីសុចរិត**) ។

- តើគុណសម្បត្តិអ្វីខ្លះដែលរំឭកឡើងនៅក្នុង ខ ៣០ ដែលមានសារៈសំខាន់សម្រាប់បងប្អូនប្រុសទាំងនេះ ដើម្បីឲ្យមានការសម្រេចចិត្តរួមគ្នា ?

- ស្របតាម ខ ៣១ តើព្រះអម្ចាស់សន្យាអ្វីខ្លះដល់ក្វ៉ូរ៉ុមជាអធិបតីនៃសាសនាចក្រ នៅពេលពួកគេធ្វើការសម្រេចចិត្តដោយប្រើគុណសម្បត្តិទាំងនេះ ?

- តើការដឹងថាព្រះអម្ចាស់នឹងប្រទានពរដល់គណៈប្រធានទីមួយ ក្វ៉ូរ៉ុមនៃសាវកពួកដប់ពីរនាក់ និងក្រុមចិត្តសិបនាក់ជាមួយនឹងព្រះប្រាជ្ញាទ្រង់ ជួយអ្នកឲ្យគាំទ្រអ្នកដឹកនាំទាំងនេះ ដោយសេចក្ដីទុកចិត្តសេចក្ដីជំនឿ និងការអធិស្ឋាន ហើយធ្វើតាមការទូន្មានរបស់ពួកគេយ៉ាងដូចម្ដេច ?

> ***អានខគម្ពីររួមគ្នា***
>
> ការអានខគម្ពីររួមគ្នា អាចជួយសិស្សឲ្យស្គាល់ និងយល់ដឹងពីខគម្ពីរដែលពួកគេកំពុងសិក្សាបានកាន់តែប្រសើរឡើង ។ វាក៏អាចជួយពួកគេមានជំនឿចិត្តកាន់តែខ្លាំងលើសមត្ថភាពរបស់ពួកគេ ក្នុងការសិក្សាព្រះគម្ពីរដោយខ្លួនគេផ្ទាល់ ។ មានវិធីជាច្រើនក្នុងការអានខគម្ពីររួមគ្នានៅក្នុងថ្នាក់ រួមទាំងការអញ្ជើញសិស្សឲ្យអានឮៗដោយខ្លួនឯង ឬរួមគ្នា ឬការសូមឲ្យសិស្សអានឲ្យគ្នាស្ដាប់ទៅវិញទៅមកផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៣–៣៨

*ព្រះអម្ចាស់បានផ្ដល់ការដឹកនាំបន្ថែមទៀត ដល់កូរ៉ុមជាអធិបតីនៃសាសនាចក្រ*

សូមចាត់ឲ្យសិស្សម្នាក់ៗនូវខគម្ពីរមួយដូចខាងក្រោម ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៣, ៣៤, ឬ ៣៥ ។ សូមឲ្យសិស្សសិក្សាខគម្ពីរ ហើយរកមើលសេចក្ដីពិតអំពីសាវកដប់ពីរនាក់ ឬក្រុមចិតសិបនាក់ ។ បន្ទាប់ពីផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យទៅមុខក្ដារខៀន ហើយសរសេរសេចក្ដីពិតដែលពួកគេរកឃើញ នៅខាងក្រោមចំណងជើង « កូរ៉ុមនៃពួកដប់ពីរនាក់ » ឬ « ក្រុមចិតសិបនាក់ » ។

ក្នុងចំណោមសេចក្ដីពិតទាំងឡាយ សិស្សអាចរកឃើញសេចក្ដីពិតដូចខាងក្រោម ៖ **ពួកសាវកដប់ពីរនាក់ ធ្វើកិច្ចការនៅក្នុងព្រះនាមនៃព្រះអម្ចាស់ និងនៅក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ ក្នុងការស្ថាបនាសាសនាចក្រ ។ ក្រុមចិតសិបនាក់ធ្វើកិច្ចការនៅក្នុងព្រះនាមនៃព្រះអម្ចាស់ ក្រោមការដឹកនាំរបស់ពួកសាវកដប់ពីរនាក់ ។ ពួកសាវកដប់ពីរនាក់កាន់កូនសោនៃការប្រកាសដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។**

សូមបញ្ចប់មេរៀននេះដោយការថ្លែងទីបន្ទាល់របស់អ្នក អំពីទំនួលខុសត្រូវដ៏ពិសិដ្ឋរបស់អ្នកដែលត្រូវបានហៅដោយព្រះអម្ចាស់ឲ្យដឹកនាំសាសនាចក្ររបស់ទ្រង់ ។ សូមលើកទឹកចិត្តសិស្សឲ្យគាំទ្រ និងទ្រទ្រង់ពួកអ្នកដឹកនាំ ដោយស្ដាប់តាមការដឹកនាំដ៏បំផុសគំនិតរបស់ពួកគេ ។

មេរៀនទី ១១៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០

## សេចក្ដីផ្ដើម

នេះគឺផ្នែកចុងក្រោយនៃមេរៀនទាំងបី ដែលពិភាក្សាពីវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ។ វិវរណៈនេះត្រូវបានកត់ត្រានៅក្នុងឆ្នាំ ១៨៣៥, ប៉ុន្តែ « កំណត់ត្រាប្រវត្តិសាស្ត្របញ្ជាក់ថាវិវរណៈភាគច្រើននៃ ខ ៦០ ដល់ខ ១០០ បញ្ចូលវិវរណៈដែលបានប្រទានឲ្យតាមរយៈ យ៉ូសែប ស្ម៊ីធ នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ » ( បុព្វកថាក្នុង គ. និង ស. ១០៧ ) ។ ខគម្ពីរដែលបានពិភាក្សានៅក្នុងមេរៀននេះ រួមមានព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីការប្រតិបត្តិពីបុរាណនៃការផ្ទេរបព្វជិតភាពមិលគីស្សាដែកពីឪពុកមកកូនប្រុស ។ វាក៏បានផ្ដល់នូវការណែនាំទាក់ទងនឹង តួនាទីរបស់ថ្នាក់ដឹកនាំបព្វជិតភាពផ្សេងៗផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–៥៧

*ព្រះអម្ចាស់បានបើកសម្ដែងថា បព្វជិតភាពមិលគីស្សាដែកត្រូវបានផ្ទេរមកពីសម័យបុរាណពីឪពុកទៅកូនប្រុស*

មុនពេលចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើស្ថានភាពអ្វីខ្លះដែលអ្នកកំពុងជួបប្រទះ ឬនឹងជួបប្រទះក្នុងពេលឆាប់ៗ ហើយអ្នកអាចទទួលប្រយោជន៍ពីការដឹកនាំ ឬការលួងលោមពីព្រះវរបិតាសួគ៌របស់អ្នកនោះ ?*

នៅពេលចាប់ផ្ដើមមេរៀន សូមឲ្យសិស្សគិតពីសំណួរនេះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេ ។ នៅពេលដែលសិស្សចាប់ផ្ដើមការពិភាក្សាសម្រាប់ថ្ងៃនេះនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០ សូមលើកទឹកចិត្តពួកគេឲ្យរកមើលគោលការណ៍ដែលអាចជួយពួកគេទទួលបានការដឹកនាំ និងការលួងលោមចិត្តពីព្រះវរបិតាសួគ៌របស់ពួកគេ ។

សូមរំឭកសិស្សថានៅក្នុងមេរៀនមុន ពួកគេបានរៀនអំពីគណៈប្រធានទីមួយ កូរ៉ុមនៃពួកដប់ពីរនាក់ និងក្រុមចិតសិបនាក់ ។ សូមសូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ រកមើលតួនាទីមួយរបស់ពួកសាវកដប់ពីរនាក់ ។ សូមពន្យល់ថាពាក្យ *អ្នកធ្វើការងារបម្រើខាងការផ្សាយដំណឹងល្អ* សំដៅទៅលើអ្នកដែលកាន់តំណែងលោកអយ្យកោនៅក្នុងបព្វជិតភាពមិលគីស្សាដែក ( សូមមើល Guide to the Scriptures, « Evangelist » scriptures.lds.org; Bible Dictionary, « Evangelist » ) ។

- យោងតាម ខ ៣៩ តើលោកអយ្យកោត្រូវបានតែងតាំងឲ្យកាន់តំណែងយ៉ាងដូចម្ដេច ? ( ពេលសិស្សឆ្លើយ សូមជួយពួកគេឲ្យយល់ពីសេចក្ដីពិតដូចខាងក្រោម ៖ **លោកអយ្យកោត្រូវបានហៅដោយវិវរណៈ ហើយត្រូវបានតែងតាំងនៅក្នុងការដឹកនាំរបស់ពួកសាវកដប់ពីរនាក់** ) ។

សូមឲ្យសិស្សពន្យល់ពីតួនាទីរបស់អ្នកដែលកាន់តំណែងលោកអយ្យកោ ។ ( លោកអយ្យកោផ្ដល់ការប្រទានពរបព្វជិតភាពពិសេស ដែលហៅថា ពររបស់លោកអយ្យកោ ដល់សមាជិកសក្ដិសមក្នុងសាសនាចក្រទាំងអស់ ) ។ បន្ថែមពីលើនោះ សូមសួរថាតើមាននរណាម្នាក់អាចរំឭកដល់សិស្សក្នុងថ្នាក់ ថាពររបស់លោកអយ្យកោជាអ្វី ។ ( ពររបស់លោកអយ្យកោរួមមានការប្រឹក្សារបស់ព្រះអម្ចាស់ សម្រាប់បុគ្គលម្នាក់ៗ និងប្រកាសពីពូជពង្សរបស់បុគ្គលនោះនៅក្នុងខ្សែស្រឡាយនៃសាសន៍អ៊ីស្រាអែល ។ សូមមើល *ពិតចំពោះសេចក្ដីជំនឿ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] « Patriarchal Blessings» ទំព័រ ១១១–១៣ ) ។

អ្នកអាចអញ្ជើញសិស្សដែលបានទទួលពររបស់លោកអយ្យកោ ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីការបម្រើរបស់លោកអយ្យកោក្នុងស្តេក ។ ( សូមដាស់តឿនសិស្សថា ពររបស់លោកអយ្យកោជាពរដ៏ពិសិដ្ឋ ហើយផ្ទាល់ខ្លួន ហើយពួកគេមិនគួរចែកចាយជាមួយមនុស្សទូទៅ ក្រៅពីសមាជិកគ្រួសារនោះទេ ) ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យនៃការទទួលពររបស់លោកអយ្យកោ និងការសិក្សាការប្រឹក្សាដែលមាននៅក្នុងនោះ ។

សូមពន្យល់ថាពាក្យ *លោកអយ្យកោ* ក៏សំដៅលើឪពុកនៅក្នុងគ្រួសារដែរ ។ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន បានបង្រៀនថា ៖



« ពេលខ្លះ លំដាប់នៃបព្វជិតភាពដែលបាននិយាយនៅក្នុងព្រះគម្ពីរ គឺសំដៅទៅលំដាប់លោកអយ្យកោ ព្រោះថាវាផ្ទេរពីឪពុកទៅកូនប្រុស » ( What I Hope You Will Teach Your Children about the Temple » *Ensign,* ខែ សីហា ឆ្នាំ ១៩៨៥ ទំព័រ ៩ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៤០ ឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលបព្វជិតភាពមិលគីស្សាដែកត្រូវបានផ្ទេរនៅសម័យបុរាណ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមចង្អុលបង្ហាញថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៤១–៥៧ យើងអានអំពីរឿងមួយចំនួនដែល អ័ដាម បានធ្វើក្នុងនាមជាលោកអយ្យកោដ៏សុចរិត ។ សូមឲ្យសិស្សអានខ្សែៗក្នុង ខ ៤១–៥០ ដោយស្ងៀមស្ងាត់ ហើយ រកមើលលំនាំ—ពីររបៀបដែលអ័ដាមបានធ្វើដដែលៗនៅពេលលោកធ្វើជាអធិបតីលើគ្រួសាររបស់លោក ។

> ### *សូមជួយសិស្សឲ្យរកឃើញលំនាំនោះ*
> លំនាំ គឺជាគំរូដែលអាចដឹកនាំសកម្មភាពរបស់យើង ។ អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « ព្រះគម្ពីរពេញទៅដោយលំនាំខាងវិញ្ញាណ » ( « A Reservoir of Living Water ») [ Church Educational System fireside for young adults, ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ],ទំព័រ ៤; LDS.org ) ។ ការរកមើលលំនាំ គឺជាជំនាញការសិក្សាព្រះគម្ពីរដ៏មានតម្លៃមួយ ។ សូមឈប់ម្ដងម្កាលក្នុងពេលបង្រៀនមេរៀន ដើម្បីពិភាក្សាពីជំនាញនេះ និងជំនាញផ្សេងៗទៀត លើកទឹកចិត្តសិស្សឲ្យប្រើវាក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ ។

- តើសកម្មភាពពីរអ្វីខ្លះ ដែលអ័ដាមធ្វើដដែលៗពេលលោកធ្វើជាអធិបតីលើគ្រួសាររបស់ពួកលោក ? ( លោកបានតែងតាំងកូនចៅប្រុសដែលសក្ដិសមកាន់តំណែងបព្វជិតភាព ហើយលោកបានប្រទានពរដល់ពួកគេ ) ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៥៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ រកមើលអ្នកដែល អ័ដាម បានប្រទានពរឲ្យ បន្ថែមពីលើកូនចៅប្រុសដែលសក្ដិសមរបស់លោក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( សូមធ្វើឲ្យប្រាកដថា ពួកគេយល់ថា អ័ដាម បានប្រទានពរដល់ពូជពង្សដែលសក្ដិសមរបស់លោកទាំងអស់ រួមទាំងកូនចៅស្រីផងដែរ ) ។

- តើគំរូរបស់ អ័ដាម អាចធ្វើជាលំនាំសម្រាប់ឪពុកទាំងឡាយយ៉ាងដូចម្ដេច ? ( បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ឪពុកដែលកាន់បព្វជិតភាពមិលគីស្សាដែក មានសិទ្ធិអំណាចដើម្បីប្រទានពរដល់កូនចៅរបស់ពួកគេ**) ។
- បន្ថែមពីលើការតែងតាំងកូនប្រុសឲ្យកាន់បព្វជិតភាព តើឪពុកអាចផ្ដល់ការប្រសិទ្ធពរបព្វជិតភាពដល់កូនប្រុស ឬកូនស្រីនៅពេលណា ? ( ចម្លើយអាចរួមមានថា ឪពុកអាចចាត់ចែងការប្រសិទ្ធពរបព្វជិតភាពក្នុងពេលដែលមានជម្ងឺ និងផ្ដល់ការដឹកនាំ ឬការលួងលោម ) ។

សូមពន្យល់ថា បន្ថែមពីលើការប្រទានពរដល់កូនចៅរបស់ពួកគេ អ្នកកាន់បព្វជិតភាពមិលគីស្សាដែកអាចប្រសិទ្ធពរដល់សមាជិកគ្រួសារផ្សេងទៀត និងដល់អ្នកផ្សេងទៀតដែលសូមការប្រសិទ្ធពរ ។ សូមឲ្យសិស្សម្នាក់អានឮៗពីសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ប៊ យ ដ៍ យេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« គេហដ្ឋានដែលគ្មានបព្វជិតភាព ត្រូវតែទទួលបានការមើលការខុសត្រូវ និងបម្រើដោយកូរ៉ុមនៃបព្វជិតភាព ។ ។ ការធ្វើបែបនេះ នឹងនាំឲ្យគ្មានការស្រេកឃ្លានពរជ័យក្នុងចំណោមសមាជិកនៃសាសនាចក្រឡើយ » ( The Power of the Priesthood » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១០,ទំព័រ ៩ ) ។

សូមឲ្យសិស្សប្រាប់អំពីពេលវេលា ដែលពួកគេបានទទួលប្រយោជន៍ពីការទទួលការប្រសិទ្ធពរបព្វជិតភាព ពីឪពុករបស់គេ ឬពីអ្នកកាន់បព្វជិតភាពផ្សេងទៀត ។ បើពួកគេពុំទាន់មានឱកាសដើម្បីទទួលពរបព្វជិតភាពទេនោះ សូមឲ្យពួកគេគិតពីរបៀបដែលគេអាចទទួលប្រយោជន៍ ពីការស្វែងរកពរជ័យនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍ និងគំនិតរបស់ពួកគេ ។

សូមឲ្យពួកគេមើលសំណួរដែលអ្នកបានសរសេរនៅលើក្ដារខៀន មុនពេលចាប់ផ្ដើមមេរៀន ។ សូមចែកចាយសក្ខីភាពរបស់អ្នកថា សិស្សអាចស្វែងរកការដឹកនាំ និងការលួងលោមពីព្រះវរបិតាសួគ៌ តាមរយៈពររបស់លោកអយ្យកោ និងតាមរយៈពរជ័យបព្វជិតភាពដែលបានចាត់តាំងដោយឪពុករបស់ពួកគេ ឬអ្នកកាន់បព្វជិតភាពផ្សេងទៀត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៥៨–១០០

*ព្រះអម្ចាស់បើកសម្ដែងតួនាទីរបស់ប្រធាននៃកូរ៉ុមបព្វជិតភាព*

ជាការរំឭកខ្លីមួយ សូមសរសេរពាក្យ *បព្វជិតភាពមិលគីស្សាដែក* និង *បព្វជិតភាពអើរ៉ុន* នៅលើក្ដារខៀន ។ សូមសូមឲ្យសិស្សសរសេរតំណែងនៃបព្វជិតភាពនៅក្រោមចំណងជើងដែលត្រឹមត្រូវ ។ សូមសូមឲ្យសិស្សម្នាក់សរសេរតំណែងមួយនៃបព្វជិតភាព ហើយហុចដីស ឬហ្វឺតបន្តឲ្យសិស្សម្នាក់ទៀត សូមបន្តធ្វើសកម្មភាពនេះរហូតដល់សិស្សបានសរសេរតំណែងទាំងអស់នៃបព្វជិតភាព ។ សូមលើកទឹកចិត្តសិស្សឲ្យជួយគ្នាទៅវិញទៅមកនៅពេលចាំបាច់ ។ ( តំណែងនៃបព្វជិតភាពមិលគីស្សាដែករួមមាន អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ និង សាវក ។ តំណែងនៃបព្វជិតភាពអើរ៉ុនមាន ឌីកុន គ្រូ សង្ឃ និង ប៊ីស្សព ) ។

- តើកូរ៉ុមនៃបព្វជិតភាពគឺជាអ្វី ? ( ជាក្រុមដែលបានរៀបចំឡើងដែលមានបងប្អូនប្រុសដែលកាន់តំណែងបព្វជិតភាពដូចគ្នា ) ។

សូមអញ្ជើញសិស្សម្នាក់ឡើងមកក្ដារខៀន ហើយគូសរង្វង់លើតំណែងបព្វជិតភាពណាដែលត្រូវបានរៀបចំជាកូរ៉ុម ។ សូមលើកទឹកចិត្តសិស្សឲ្យជួយគ្នាតាមការគួរ ។ ( តំណែងខាងក្រោមនេះមានកូរ៉ុម ៖ សាវក ពួកចិតសិបនាក់ សង្ឃជាន់ខ្ពស់ អែលឌើរ សង្ឃ គ្រូ និង ឌីកុន ។ អ្នកអាចពន្យល់ថា ស្តេកនិមួយៗមានកូរ៉ុមសង្ឃជាន់ខ្ពស់មួយ ដែលមានប្រធានស្តេកគឺជាប្រធានកូរ៉ុមនោះ ។ នៅក្នុងវួដនិមួយៗ ពួកសង្ឃជាន់ខ្ពស់ត្រូវបានរៀបចំជាក្រុមសង្ឃជាន់ខ្ពស់មួយ ) ។

សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦០–៦៣, ៨៥–៨៩, ៩៣–៩៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលចំណុចរួមមួយអំពីកូរ៉ុមទាំងនេះដែលបាននិយាយនៅក្នុងខគម្ពីរទាំងនេះ ។

- យោងតាមខគម្ពីរទាំងនេះ តើកូរ៉ុមបព្វជិតភាពទាំងនេះមានអ្វីដែលដូចគ្នា ? ( សូមជួយសិស្សប្រាប់អំពីសេចក្ដីពិតដូចខាងក្រោម ៖ **ប្រធានត្រូវបានចាត់តាំងឲ្យធ្វើជាអធិបតី ហើយចាត់តាំងកិច្ចការដល់កូរ៉ុមបព្វជិតភាពម្នាក់ៗ** ) ។
- យោងតាម ខ ៨៧–៨៨ តើកូរ៉ុមសង្ឃខុសពីកូរ៉ុមឌីកុន និង កូរ៉ុមគ្រូយ៉ាងដូចម្ដេចខ្លះ ? ( ប៊ីស្សពនៅវួដធ្វើជាអធិបតីលើកូរ៉ុមសង្ឃ ។ គាត់ក៏ធ្វើជាអធិបតីលើអ្នកកាន់បព្វជិតភាពអើរ៉ុនទាំងអស់នៅក្នុងវួដផងដែរ ។ នៅក្នុងសាខា ប្រធានសាខាដើរតួជាប្រធាននៃកូរ៉ុមសង្ឃ ) ។
- ហេតុអ្វីអ្នកគិតថាវាសំខាន់ដែលកូរ៉ុមនៃបព្វជិតភាពនិមួយៗមានប្រធានម្នាក់ ? តើប្រធានកូរ៉ុមបព្វជិតភាព អាចជួយសមាជិកកូរ៉ុមរបស់គាត់យ៉ាងដូចម្ដេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦៨–៨៤ ដោយពន្យល់ថា ខគម្ពីរទាំងនេះ ផ្ដល់ការបង្រៀនទាក់ទងនឹងការិយាល័យប៊ីស្សព និងតួនាទីក្រុមប្រឹក្សាសាសនាចក្រ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦៥–៦៦ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់កត់សម្គាល់អ្នកដឹកនាំសាសនាចក្រ ដែលធ្វើជាអធិបតីលើអ្នកកាន់បព្វជិតភាពទាំងអស់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមប្រាកដថា ពួកគេយល់ថាខគម្ពីរទាំងនេះសំដៅលើប្រធានសាសនាចក្រ ។

សូមសូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦៧ ៩១–៩២ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យ និងឃ្លាដែលពិពណ៌នាពីសិទ្ធិអំណាច និងទំនួលខុសត្រូវនៃប្រធានសាសនាចក្រ ។

- ស្របតាមខគម្ពីរទាំងនេះ តើអ្នកនឹងសង្ខេបសិទ្ធិអំណាច និងទំនួលខុសត្រូវជាប្រធានសាសនាចក្រយ៉ាងដូចម្ដេច ? ( ទោះជាសិស្សអាចប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្ដីពិតដូចខាងក្រោម ៖ **ប្រធានសាសនាចក្រមានសិទ្ធិអំណាចគ្រប់គ្រងពិធីបរិសុទ្ធ និងពរជ័យទាំងអស់ ហើយធ្វើជាអធិបតីលើសាសនាចក្រទាំងមូល ។** អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

សូមបង្ហាញរូបភាពរបស់ព្យាការីសាសនាចក្របច្ចុប្បន្ន ។

- តើវិធីអ្វីខ្លះ ដែលអ្នកត្រូវបានប្រទានពរឲ្យដោយសារតែសិទ្ធិអំណាចបព្វជិតភាព ដែលកាន់ដោយប្រធានសាសនាចក្រ ?

សូមចង្អុលបង្ហាញថា សមាជិកសាសនាចក្រមួយចំនួនអាចមានអារម្មណ៍ថា ការហៅបម្រើ ឬទំនួលខុសត្រូវរបស់ពួកគេនៅក្នុងសាសនាចក្រ មិនសំខាន់ ។ សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមពន្យល់ថា ប្រធាន ហ៊ិងគ្លី បានមានប្រសាសន៍ពីការណ៍នេះដល់សមាជិកសាសនាចក្រទាំងអស់ ។



« ទំនួលខុសត្រូវក្នុងការហៅបម្រើរបស់អ្នក សំខាន់ដូចជាទំនួលខុសត្រូវរបស់ខ្ញុំក្នុងហៅបម្រើរបស់ខ្ញុំដែរ ។ គ្មានការហៅបម្រើមួយណានៅក្នុងសាសនាចក្រ ដែលមិនសំខាន់នោះទេ ។ យើងទាំងអស់គ្នាខិតខំបំពេញតួនាទីរបស់យើង ដើម្បីប្រទានពរដល់ជីវិតរបស់អ្នកដទៃ » ( « This Is the Work of the Master » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៥ ទំព័រ ៧១ ) ។

- តើអ្នកគិតថា « គ្មានការហៅបម្រើមួយណានៅក្នុងសាសនាចក្រ ដែលមិនសំខាន់ » មានន័យយ៉ាងណា ?

- តើសេចក្ដីថ្លែងការណ៍របស់ប្រធាន ហ៊ិងគ្លី បង្រៀនអ្នកអំពីទំនួលខុសត្រូវអ្វីខ្លះនៅក្នុងសាសនាចក្រ ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៩៩–១០០ ដោយស្ងាត់ស្ងៀម ហើយគិតពីរបៀបដែលសេចក្ដីថ្លែងការណ៍របស់ប្រធាន ហ៊ិងគ្លី ទាក់ទងនឹងខគម្ពីរទាំងនេះ ។

- យោងតាម ខ ៩៩–១០០ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមានភាពសក្តិសមនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ? ( សិស្សគួររកឃើញគោលការណ៍ដូចខាងក្រោម ៖ **ដើម្បីមានភាពសក្តិសមនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ យើងត្រូវរៀនពីតួនាទីរបស់យើង ហើយបំពេញតួនាទីនោះដោយឧស្សាហ៍** ) ។ អ្នកអាចផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

ទោះជាខគម្ពីរទាំងនេះ សំដៅត្រង់ចំពោះអ្នកកាន់បព្វជិតភាពក្ដី តែគោលការណ៍ដែលខគម្ពីរទាំងនោះបង្រៀន អនុវត្តចំពោះសមាជិកសាសនាចក្រទាំងអស់ ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យពិភាក្សាអំពីសំណួរខាងក្រោម ៖ សូមអានសំណួរម្ដងមួយ ឬសរសេរវានៅលើក្ដារខៀន ។

- តើអ្នកធ្លាប់បានទទួលពរមកពីការបម្រើ នៃសមាជិកសាសនាចក្រម្នាក់ដែលបំពេញកាតព្វកិច្ចរបស់គាត់ដោយឧស្សាហ៍ព្យាយាមដែលឬទេ ?

- តើអ្នកកំពុងធ្វើអ្វីខ្លះដើម្បីរៀនពីកាតព្វកិច្ចរបស់អ្នក ហើយប្រតិបត្តិដោយសេចក្ដីឧស្សាហ៍គ្រប់ជំពូកដើម្បីបំពេញកាតព្វកិច្ចនោះ ?

សូមផ្ដល់ឱកាសឲ្យសិស្សថ្លែងទីបន្ទាល់ ពីសារៈសំខាន់នៃ ការបំពេញតួនាទីរបស់យើងនៅក្នុងសាសនាចក្រ និងនៅក្នុងក្រុមគ្រួសាររបស់យើង ។ សូមឲ្យពួកគេកំណត់គោលដៅ ដើម្បីបំពេញតួនាទីរបស់ពួកគេដោយឧស្សាហ៍ ។

មេរៀនទី ១១៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨

## បុព្វកថា

នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៨៣៥ ឡៃម៉ាន ស៊ើម៉ាន ជាសមាជិកស្មោះត្រង់ក្នុងជំរុំស៊ីយ៉ូន និងប្រធានម្នាក់ក្នុងចំណោមប្រធានប្រាំពីរនាក់ នៃកូរ៉ុមនៃក្រុមចិតសិបនាក់ បានធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ឲ្យសួរព្យាការី យ៉ូសែប ស៊្មីធ រកការដឹកនាំទាក់ទងនឹងតួនាទីរបស់លោក ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ មានវិវរណៈដែលបានប្រទានដល់ ឡៃម៉ាន តាមរយៈព្យាការី ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:១–៣

*ព្រះអម្ចាស់អភ័យទោសឲ្យ ឡៃម៉ាន ស៊ើម៉ាន ចំពោះអំពើបាបរបស់គាត់*

សូមចាប់ផ្ដើមបង្រៀនដោយសួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកធ្លាប់ត្រូវបានបំផុសគំនិត ដោយព្រះវិញ្ញាណឲ្យធ្វើអ្វីមួយដែរឬទេ ? តើពរជ័យអ្វីខ្លះដែលអ្នកបានទទួល ពេលអ្នកធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណនោះ ?

សូមអញ្ជើញសិស្សឲ្យអានសេចក្ដីណែនាំកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ ដោយស្ងាត់ស្ងៀម រកមើលអ្នកដែលបានមករកព្យាការី ដើម្បីស្នើសុំវិវរណៈ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានពត៌មានខាងក្រោម ដោយ ឡៃម៉ាន ស៊ើម៉ាន ឲ្យឮៗ ៖

ឡៃម៉ាន ស៊ើម៉ាន ជាសមាជិកស្មោះត្រង់ម្នាក់របស់សាសនាចក្រ ដែលបានបម្រើនៅក្នុងជំរុំស៊ីយ៉ូន ហើយត្រូវបានហៅជាប្រធានម្នាក់ក្នុងចំណោមប្រធានប្រាំពីរនាក់ នៃកូរ៉ុមនៃក្រុមចិតសិបនាក់ ។ ព្យាការី យ៉ូសែប ស៊្មីធ បានកត់ត្រានៅក្នុងកំណត់ហេតុរបស់លោកនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៨៣៥ ថា « បងប្រុស ឡៃម៉ាន ស៊ើម៉ាន បានមករកខ្ញុំ ហើយបានស្នើសុំព្រះបន្ទូលរបស់ព្រះអម្ចាស់តាមរយៈខ្ញុំ គាត់បាននិយាយថា ‹ ព្រោះខ្ញុំត្រូវបានបំភ្លឺឲ្យដឹងថា ខ្ញុំត្រូវបង្ហាញអារម្មណ៍ និងបំណងប្រាថ្នារបស់ខ្ញុំដល់ព្យាការី ហើយខ្ញុំត្រូវបានសន្យាថា នឹងទទួលបាននូវវិវរណៈដែលបង្ហាញប្រាប់ពីតួនាទីរបស់ខ្ញុំ › » ( នៅក្នុង *History of the Church,* ២:៣៤៥ សូមមើលផងដែរ *Journals, វ៉ុល ១: ១៨៣២–១៨៣៩*, វ៉ុល ១ of the Journals series of *The Joseph Smith Papers* [ឆ្នាំ ២០០៨]ទំព័រ ១៣៧ ) ។

- តើអ្នកគិតថា ឡៃម៉ាន មានន័យយ៉ាងណានៅពេលដែលគាត់និយាយថា « បំភ្លឺ » ឲ្យនិយាយទៅកាន់ យ៉ូសែប ស៊្មីធ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:១ ឲ្យឮៗ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពរជ័យដែលព្រះអម្ចាស់បានប្រទានឲ្យ ឡៃម៉ាន ស៊ើម៉ាន ព្រោះលោកធ្វើតាមការបំផុសគំនិតឲ្យនិយាយទៅកាន់ព្យាការី ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាមអ្វីដែលព្រះអម្ចាស់បានបើកសម្ដែងដល់ ឡៃម៉ាន ស៊ើម៉ាន តើពរជ័យអ្វីដែលយើងចង់អោយមានក្នុងជីវិតរបស់យើង នៅពេលយើងធ្វើតាមព្រះសូរសៀងរបស់ព្រះអម្ចាស់ដោយពេញចិត្តនោះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរបង្ហាញអំពីគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងធ្វើតាមព្រះបន្ទូលព្រះអម្ចាស់ នោះយើងត្រូវបានអញ្ជើញឲ្យសុំការអភ័យទោសពីទ្រង់** ។ អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។

- តើអ្នកគិតថា ហេតុអ្វីបានជាការធ្វើតាមការបំផុសគំនិតពីព្រះអម្ចាស់ គឺជាអញ្ជើញឲ្យមានការអភ័យទោស ?

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមពន្យល់ថា ព្រះបន្ទូលរបស់ព្រះអម្ចាស់ អាចត្រូវបានស្ដាប់ឮតាមរយៈព្រះគម្ពីរ ពាក្យសម្ដីព្យាការីថ្ងៃចុងក្រោយរបស់ទ្រង់ និងការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ ការធ្វើតាមព្រះ រួមមានការបំពេញជីវិតរបស់យើងដោយសកម្មភាពសុចរិត ដែលនាំមកនូវអំណាចខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សឲ្យអានការពន្យល់ដូចខាងក្រោមដកស្រង់ពី *ពិតចំពោះសេចក្ដីជំនឿឲ្យឮៗ* ៖ « ការគោរពយ៉ាងឥតល្អៀង នាំមកនូវអំណាចពេញលេញនៃដំណឹងល្អមកក្នុងជីវិតរបស់អ្នក រួមទាំងការបង្កើនកម្លាំងឲ្យយកឈ្នះលើភាពទន់ខ្សោយ ។ ការគោរពនេះ រួមមានសកម្មភាពដែល

អ្នកមិនអាចគិតដល់ពីដំបូងនៃផ្នែកនៃការប្រែចិត្តដូចជា ការចូលរួមការប្រជុំ ការបង់ដង្វាយមួយភាគដប់ ការផ្ដល់ការបម្រើ និងការអភ័យទោសដល់អ្នកដទៃ ។ ព្រះអម្ចាស់បានសន្យាថា ‹ អ្នកណាដែលប្រែចិត្ត ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះនឹងបានអត់ទោស › ( គ. និង ស. ១:៣២ *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ]ទំព័រ ១៣៥ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:២ ដោយស្ងាត់ស្ងៀម ហើយរកមើលដំបូន្មានរបស់ព្រះអម្ចាស់ទៅកាន់ ឡៃម៉ាន ស៊ើម៉ាន បន្ទាប់ពីគាត់ ត្រូវបានប្រាប់ថាអំពើបាបរបស់គាត់ត្រូវបានអត់ទោស ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថា « សូមឲ្យព្រលឹងអ្នកបានស្ងប់ស្ងៀមអំពីជំហរខាងវិញ្ញាណរបស់អ្នកចុះ » មានន័យយ៉ាងណា ?
- តើអ្នកគិតថា ការប្រឹក្សា « កុំប្រឆាំងនឹងសំឡេងរបស់[ ព្រះអម្ចាស់ ] » អាចជួយនរណាម្នាក់ឲ្យព្រលឹងបានស្ងប់ស្ងៀមដោយរបៀបណា ?

សូមឲ្យសិស្សប្រាប់ពីគោលការណ៍ដែលដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:១–២ អំពីការអត់ទោសរបស់ព្រះអម្ចាស់នាំមកនូវអ្វី ។ ( សិស្សអាចនឹងប្រាប់អំពីគោលការណ៍ផ្សេងៗ ប៉ុន្តែសូមប្រាកដថា ត្រូវគូសបញ្ជាក់អំពីសេចក្ដីពិតដូចខាងក្រោម ៖ **ការអត់ទោសរបស់ព្រះអម្ចាស់នាំមកនូវការស្ងប់ស្ងៀមដល់ព្រលឹងរបស់យើង** ) ។

សូមចង្អុលបង្ហាញថា ពេលខ្លះមនុស្សដែលបានប្រែចិត្ត ឆ្ងល់ថាតើពួកគេត្រូវបានអត់ទោសបាបហើយឬនៅ ព្រោះពួកគេនៅតែមានអារម្មណ៍ពីបន្ទុករបស់អំពើបាប ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលដំបូន្មាន សម្រាប់អ្នកដែលអាចកំពុងពុះពារ ឲ្យព្រលឹងពួកគេបានស្ងាត់ស្ងៀម ។

ប្រធាន ប៊ីយឌ៍ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ ៖



« [ព្រឹក] ព្រលឹមនៃការអត់ទោស អាចនឹងមិនកើតឡើងទាំងអស់ក្នុងពេលតែមួយនោះទេ ។ សូមកុំចុះចាញ់ បើអ្នកបរាជ័យលើកដំបូងនោះ ។ ជាញឹកញាប់ ចំណុចដ៏ពិបាកបំផុតនៃការប្រែចិត្ត គឺត្រូវអត់ទោសឲ្យខ្លួនឯង ។ ការបាក់ទឹកចិត្ត គឺជាចំណែកមួយនៃការសាកល្បងនោះ ។ សូមកុំចុះចាញ់ ។ ទិវាដ៏ចែងចាំងនឹងកើតឡើង ។

« យ៉ាងនោះ ‹ សេចក្ដីសុខសាន្តរបស់ព្រះ ដែលហួសលើសពី . . . គំនិត › នឹងកើតមាននៅក្នុងជីវិតរបស់អ្នកសាជាថ្មី ។ [ ភីលីព ៤:៧ ] ។ ហើយនោះអ្នកនឹងបានដូចទ្រង់ គឺមិននឹកចាំអំពើបាបរបស់អ្នកទៀតឡើយ ។ តើអ្នកនឹងដឹងដោយរបៀបណា ? អ្នកនឹងដឹង ! [ សូមមើល ម៉ូសាយ ៤:១–៣ ] » ។ « The Brilliant Morning of Forgiveness » *Ensign*, ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ២០ ) ។

- តើអ្នកនឹងពិពណ៌នាថាតើការធ្វើឲ្យព្រលឹងអ្នកបានស្ងប់ស្ងៀម ធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងណាដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៣ ដោយស្ងាត់ស្ងៀម ហើយរកមើលការទូន្មានដែលព្រះអម្ចាស់បានប្រទានដល់ ឡៃម៉ាន ស៊ើម៉ាន។

- តើការទូន្មានអ្វីដែលព្រះអម្ចាស់បានប្រទានដល់បងប្រុស ស៊ើម៉ាន ? ( ដើម្បី « ក្រោកឡើង ហើយសូមប្រយ័ត្នពីពេលនេះតទៅ ក្នុងការគោរពតាមសម្បថទាំងឡាយរបស់[គាត់] » ។ ពាក្យ *គោរពតាម* មានន័យថា ព្រមធ្វើតាម ឬប្រតិបត្តិតាម ។ ពាក្យសម្បថ គឺជាការសន្យា ឬជាសេចក្ដីសញ្ញា ) ។
- តើយើងបានធ្វើសម្បថអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀប ដែលពួកគេអាច « ប្រយ័ត្នពីពេលនេះតទៅ » ក្នុងការគោរពតាមសម្បថរបស់ពួកគេ ។ បើមានពេល អញ្ជើញពួកគេឲ្យសរសេរពីរបៀបដែលពួកគេអាចមានការប្រយ័ត្នកាន់តែខ្លាំងក្នុងការគោរពតាមសម្បថរបស់ពួកគេ ។

សូមអញ្ជើញសិស្សពីរបីនាក់ ពន្យល់ ពីរបៀបនៃសេចក្ដីពិតដែលពួកគេរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:១–៣ អាចលើកទឹកចិត្តពួកគេ ឬមិត្តភក្តិ ឬសមាជិកក្រុមគ្រួសារឲ្យគោរពតាមសំឡេងរបស់ព្រះអម្ចាស់ និងទទួលបានការអត់ទោស ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍ទាំងនេះ ហើយមានអារម្មណ៍ស្ងប់ស្ងៀមអំពីជំហរខាងវិញ្ញាណរបស់អ្នក នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ។

***ពន្យល់***

សូមផ្ដល់ឱកាសឲ្យសិស្សពន្យល់ពីគោលលទ្ធិ ឬគោលការណ៍ដែលលើកទឹកចិត្តពួកគេឲ្យគិតកាន់តែច្រើន និងស្វែងរកការយល់ដឹងកាន់តែប្រសើរមុនពេលបង្រៀនអ្នកដទៃ ។ អ្នកអាចអញ្ជើញសិស្សឲ្យពន្យល់គោលលទ្ធិ និងគោលការណ៍ជាដៃគូ ឬជាក្រុមតូច ជាការសម្ដែងជាមួយសិស្សក្នុងថ្នាក់ ឬជាការសរសេរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៤–៨

*ព្រះអម្ចាស់ប្រទានការទូន្មាន និងការសន្យាបន្ថែមដល់ ឡៃម៉ាន សើម៉ាន*

សូមសួរដល់សិស្សថាតើពួកគេបានឮពីសេចក្ដីប្រកាសឲ្យមានជំនុំមុតមាំមួយឬទេ ។ បើមាននរណាម្នាក់បានឮ សូមសួរឲ្យពួកគេពន្យល់ពីអ្វីដែលពួកគេបានយល់អំពីសេចក្ដីប្រកាសនោះ ។ បើពួកគេត្រូវការជំនួយ សូមពន្យល់ថាសេចក្ដីប្រកាសឲ្យមានជំនុំមុតមាំមួយ គឺការប្រមូលផ្ដុំពិសេសសម្រាប់ « ការបង្រៀនពិសេសដល់អ្នកដឹកនាំបព្វជិតភាព និងការគាំទ្រសម្រាប់ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ និងការគាំទ្រប្រធានសាសនាចក្រថ្មី » ( David B. Haight, « Solemn Assemblies » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ទំព័រ ១៤ ) ។ នៅខែ ធ្នូ ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានសន្យាចំពោះពួកបរិសុទ្ធថា បើពួកគេសាងសង់ព្រះវិហារបរិសុទ្ធ និងមានក្រុមជំនុំដ៏មុតមាំមួយ នោះព្រះអម្ចាស់នឹងប្រទានពរជ័យដ៏អស្ចារ្យមកលើពួកបរិសុទ្ធ ( សូមមើល គ. និង ស. ៨៨:៧០–៧៥, ១១៧–១១៩ ) ។ នៅខែ ធ្នូ ឆ្នាំ ១៨៣៥ នៅពេលដែលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ ត្រូវបានប្រទានដល់ ឡៃម៉ាន សើម៉ាន នោះព្រះវិហារបរិសុទ្ធ ខឺតឡង់ នៅសល់តែបីខែទៀតប៉ុណ្ណោះដើម្បីធ្វើការឧទ្ទិស ។ នៅចន្លោះខែ មករា និងខែ ឧសភា ឆ្នាំ ១៨៣៦ មានការប្រជុំមួយចំនួនត្រូវបានធ្វើឡើងនៅទីក្រុង ខឺតឡង់ ការប្រជុំមួយចំនួនត្រូវបានចាត់ថាជាជំនុំមុតមាំ ។ អំឡុងសប្ដាហ៍នៅថ្ងៃទី ២៧ ខែមិនា ឆ្នាំ ១៨៣៦ ជំនុំមុតមាំ ត្រូវបានធ្វើឡើងជាផ្នែកនៃការឧទ្ទិសឆ្លងនៃព្រះវិហារបរិសុទ្ធ ខឺតឡង់ រួមទាំងជំនុំមុតមាំមួយដើម្បីបង្រៀនដល់អ្នកដឹកនាំបព្វជិតភាព ដែលបានធ្វើឡើងនៅថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ១៨៣៦ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៤–៦ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានសន្យានឹង ឡៃម៉ាន ថាលោកនឹងបានទទួលនៅក្នុងជំនុំមុតមាំ ។

- តើព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ ឡៃម៉ាន សើម៉ាន ថាគាត់នឹងទទួលបានអ្វី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨: ៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការបង្រៀន ដែលព្រះអម្ចាស់បានប្រទានដល់បងប្រុស សើម៉ាន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចត្រូវពន្យល់ថា សេចក្ដីដាស់តឿន គឺជាពាក្យនៃការទូន្មាន ឬការលើកទឹកចិត្ត ។

- តើព្រះអម្ចាស់មានព្រះទ័យចង់ឲ្យ ឡៃម៉ាន សើម៉ាន ពង្រឹងដល់បងប្អូនប្រុសរបស់គាត់ដោយរបៀបណា ?

សូមសួរឲ្យសិស្សរកមើលសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៧–៨ ។ ពួកគេអាចរកឃើញសេចក្ដីពិតខុសៗគ្នា រួមទាំងសេចក្ដីពិតដូចខាងក្រោម ៖ **យើងពង្រឹងអ្នកដទៃតាមរយៈការសន្ទនា និងទង្វើរបស់យើង។** អ្នកអាចផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- តើអ្នកអាចពង្រឹងមនុស្សទាំងឡាយដែលនៅជុំវិញខ្លួនអ្នកតាមរយៈការសន្ទនាដោយរបៀបណា ? តើអ្នកអាចពង្រឹងមនុស្សទាំងឡាយដែលនៅជុំវិញខ្លួនអ្នកតាមរយៈទង្វើរបស់អ្នកដោយរបៀបណា ?

សូមឲ្យសិស្សរៀបរាប់បទពិសោធន៍ ពេលដែលនរណាម្នាក់បានពង្រឹងពួកគេតាមរបៀបដែលព្រះអម្ចាស់បានទូន្មានដល់ ឡៃម៉ាន សើម៉ាន នៅក្នុង ខ ៧ ។

សូមអញ្ជើញសិស្សឲ្យគិតពីនរណាម្នាក់ដែលពួកគេអាចពង្រឹងនៅថ្ងៃនេះ និងសកម្មភាពជាក់លាក់ណាមួយដែលពួកគេនឹងធ្វើដើម្បីពង្រឹងអ្នកនោះ ។

សូមប្រាប់សិស្សថា ឡៃម៉ាន សើម៉ាន បន្តមានសេចក្ដីជំនឿរហូតដល់គាត់ស្លាប់ ។ ព្យាការី យ៉ូសែប ស្ម៊ីធ ដែលនៅក្នុងគុកលីប៊ើធី បានហៅ ហើយតែងតាំង ឡៃម៉ាន ធ្វើជាសមាជិកម្នាក់ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៨៣៩ ប៉ុន្តែ ឡៃម៉ាន បានស្លាប់មុនពេលទទួលសំបុត្រពីការហៅថ្មីរបស់គាត់ពីព្យាការី ។

សូមបញ្ចប់ដោយការចែកចាយបទពិសោធន៍ ពេលនរណាម្នាក់បានពង្រឹងអ្នក ឬពេលអ្នកបានពង្រឹងនរណាម្នាក់ ។

មេរៀនទី ១១៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧

## បុព្វកថា

នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៨៣៦ ព្យាការី យ៉ូសែប ស្ម៊ីធ បានជួបជាមួយទីប្រឹក្សានៃគណៈប្រធានទីមួយរបស់លោក គណៈប៊ីស្សពមកពីទីក្រុង ខឺតឡង់ រដ្ឋ មិសសួរី ឪពុករបស់លោក និងស្មៀនរបស់លោក នៅបន្ទប់ជាន់ខាងលើនៃព្រះវិហារបរិសុទ្ធខឺតឡង់ដែលជិតនឹងសាងសង់រួច ។ បុរសទាំងប៉ុន្មាននាក់នេះ បានជួបជុំគ្នាសម្រាប់ការគ្រប់គ្រងនៃពិធីបរិសុទ្ធក្នុងការរៀបចំខ្លួនសម្រាប់ការឧទ្ទិសព្រះវិហារបរិសុទ្ធ ។ ក្នុងពេលនោះ ព្យាការីបានឃើញការនិមិត្តមួយពីនគរសេឡេស្ទាល ហើយបានឮព្រះអម្ចាស់ប្រកាសពីរបៀបដែលទ្រង់នឹងកាត់សេចក្ដីអ្នកដែលបានស្លាប់ ដោយគ្មានចំណេះដឹងនៃដំណឹងល្អ ។ វ៉ារិន ផារីស ដែលជាស្មៀនរបស់យ៉ូសែប ស្ម៊ីធ នៅពេលនោះបានកត់ត្រាការនិមិត្តនៅក្នុងសៀវភៅកំណត់ហេតុរបស់ព្យាការី ។ ផ្នែកមួយនៃកំណត់ត្រាក្នុងការនិមិត្តនោះ ក្រោយមកត្រូវបានបញ្ចូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា កណ្ឌ ១៣៧ ។

*សូមផ្ដល់ពេលវេលាដល់សិស្សគិត*

នៅពេលអ្នកសួរសំណួរ សូមផ្ដល់ពេលដល់សិស្សគិតអំពីចម្លើយរបស់ពួកគេ ។ ជាញឹកញាប់ សំណួរដែលមានប្រសិទ្ធិភាពនាំទៅរកការគិត និង ការពិចារណា ហើយសិស្សអាចត្រូវការពេលវេលា ដើម្បីរកចម្លើយនៅក្នុងព្រះគម្ពីររបស់ពួកគេ ឬ ដើម្បីគិតពីចម្លើយដ៏មានន័យ ។ ទោះបីជាចម្លើយរបស់សិស្សមិនល្អឥតខ្ចោះក្ដី ក៏សិស្សនឹងរៀនពីមេរៀនដ៏សំខាន់នៅពេលពួកគេគិតអំពីសេចក្ដីពិតនៃដំណឹងល្អ និង ចែកចាយពីគំនិតរបស់ពួកគេ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១–៦

*យ៉ូសែប ស្ម៊ីធ បានឃើញការនិមិត្តនៃនគរសេឡេស្ទាល*

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណួរខាងក្រោមនេះ ។ ( អ្នកអាចអញ្ជើញពួកគេឲ្យសរសេរចម្លើយរបស់ពួកគេនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬក្នុងសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ) ។

- តើនរណាគេខ្លះដែលជាមនុស្សសំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក ? តើហេតុអ្វីបានជាពួកគេសំខាន់ចំពោះអ្នក ?

ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីគិតហើយ អញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។

- តើហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នកក្នុងការដឹងថា មនុស្សដែលអ្នកស្រឡាញ់ នឹងមានឱកាសដើម្បីរស់នៅក្នុងនគរសេឡេស្ទាលនោះ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ មាននូវការពិពណ៌នាពីការនិមិត្តរបស់ យ៉ូសែប ស្ម៊ីធ ថាលោកបានឃើញនគរសេឡេស្ទាល ។ នៅក្នុងការពិពណ៌នានេះ លោកបានប្រាប់ឈ្មោះបុគ្គលមួយចំនួនដែលលោកបានឃើញនៅទីនោះ ។ សូមអញ្ជើញសិស្សឲ្យអានសេចក្ដីណែនាំកណ្ឌក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ ដើម្បីរៀនពីប្រវត្តិនៃវិវរណៈនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលពាក្យ និងឃ្លាដែលពិពណ៌នាពីនគរសេឡេស្ទាល ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៥–៦ ឲ្យឮៗ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់មនុស្សដែល យ៉ូសែប ស្ម៊ីធ បានឃើញនៅក្នុងនគរសេឡេស្ទាល ។

- តើ យ៉ូសែប ស្ម៊ីធ បានឃើញនរណានៅក្នុងនគរសេឡេស្ទាល ? ( ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ អ័ដាម អ័ប្រាហាំ ម្ដាយ និងឪពុករបស់យ៉ូសែប និង អាលវិន ជាបងប្រុសរបស់ យ៉ូសែប ។ វាអាចមានប្រយោជន៍ក្នុងការចង្អុលបង្ហាញថា ឪពុក និងម្ដាយរបស់ យ៉ូសែប នៅរស់នៅឡើយទេក្នុងពេលនោះ តាមពិតទៅឪពុករបស់លោកកំពុងនៅក្នុបន្ទប់នោះជាមួយលោក កាលលោកបានឃើញការនិមិត្តនោះ ។ វាមានន័យថា ការនិមិត្តនោះ លោកមិនបានឃើញអ្នកដែលនៅនគរសេឡេស្ទាលរួចហើយនោះទេ ប៉ុន្តែជាការនិមិត្តពីអ្នកដែលនឹងទៅទីនោះ )។
- ស្របតាម ខ ៦ តើហេតុអ្វីបានជា យ៉ូសែប មានការញាប់ញ័រពេលលោកបានឃើញថា អាលវិនជាបងប្រុសរបស់លោកនឹងនៅក្នុងនគរសេឡេស្ទាលនោះ ?

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតពីមូលហេតុ ដែលបទពិសោធន៍នេះមានអត្ថន័យជាពិសេសសម្រាប់ យ៉ូសែប ស៊្មីធ សូមអញ្ជើញសិស្សឲ្យអាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ៖

យ៉ូសែប ស៊្មីធ ស្រឡាញ់ និងកោតសរសើរ អាលវិន ជាបងប្រុសរបស់លោកខ្លាំងណាស់ ។ អាលវិន ក៏ស្រឡាញ់ យ៉ូសែប ដែរ ហើយគាត់បានគាំទ្រ យ៉ូសែប ក្នុងការរៀបចំខ្លួនដើម្បីទទួលផ្ទាំងចំណារមាសពីទេវតា ម៉្រូណៃ ។ នៅខែ វិច្ឆិកា ឆ្នាំ ១៨២៣ កាល អាលវិន អាយុ ២៥ ឆ្នាំ ហើយយ៉ូសែបអាយុ ១៧ ឆ្នាំ អាលវិនស្រាប់ធ្លាក់ខ្លួនឈឺជាទម្ងន់ ។ នៅពេលស្ថានភាពជំងឺរបស់គាត់កាន់តែធ្ងន់ធ្ងរ ហើយវាបង្ហាញថាគាត់នឹងស្លាប់ឆាប់ៗ នោះលោកបានទូន្មានយ៉ូសែបថា ៖ « បងចង់ឲ្យប្អូនក្លាយជាក្មេងល្អ ហើយធ្វើអ្វីគ្រប់យ៉ាងក្នុងអំណាចរបស់ប្អូនដើម្បីទទួលកំណត់ត្រា ។ សូមមានសេចក្ដីស្មោះត្រង់ក្នុងការទទួលការណែនាំ ហើយរក្សាគ្រប់បទបញ្ញត្តិដែលបានប្រទានមកដល់ប្អូន » ( ដកស្រង់ចេញពី *Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ៤០១ សូមមើលផងដែរ *Church History in the Fulness of Times Student Manual* បោះពុម្ពលើកទី ២ [Church Educational System manual ឆ្នាំ ២០០៣]ទំព័រ ៤១–៤២ ) ។

ការស្លាប់របស់ អាលវិន បាននាំមកនូវការសោកសៅយ៉ាងខ្លាំងដល់គ្រួសារ ស៊្មីធ ។ អាចារ្យក្នុង ភូមិ ប៉ាលម៉ៃរ៉ា រដ្ឋ នូវយ៉ោក បានចាត់ចែងពិធីបុណ្យសពរបស់ អាលវិន ។ « ដោយសារ អាលវិន មិនធ្លាប់ជាសមាជិកនៅក្នុងក្រុមជំនុំរបស់លោកអាចារ្យនោះ គាត់បានឆ្លៀតបង្រៀនថា អាលវិន និងមិនត្រូវបានសង្គ្រោះឡើយ ។ វិល្លាម ស៊្មីធ ដែលជាប្អូនប្រុសរបស់ យ៉ូសែប បានរំឭកឡើងថា ៖ ‹ [អាចារ្យ] . . . បានប្រកាសយ៉ាងច្បាស់ថា [អាលវិន] បានចុះឋាននរក ដោយសារអាលវិនមិនមែនជាសមាជិកព្រះវិហារ ប៉ុន្តែគាត់ជាក្មេងល្អ ហើយឪពុកខ្ញុំមិនពេញចិត្តចំពោះរឿងនេះទេ›» ( ដកស្រង់ចេញពី  ទំព័រ ៤០១, ៤០៣ ) ។




ផ្លាកព្រលឹងសម្គាល់កន្លែងបញ្ចុះ អាលវិន ស៊្មីធ ដែលជាបងប្រុសច្បងរបស់ព្យាការី យ៉ូសែប ស៊្មីធ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីអារម្មណ៍របស់ យ៉ូសែប ស៊្មីធ កាលលោកឃើញ អាលវិន នៅក្នុងនគរសេឡេស្ទាល ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧: ៧–១០

*ព្រះអម្ចាស់បើកសម្ដែងពីរបៀបដែលទ្រង់នឹងកាត់សេចក្ដីមនុស្សដែលស្លាប់ ដោយគ្មានចំណេះដឹងនៃដំណឹងល្អ*

សូមសរសេរសំណួរដូចខាងក្រោម នៅលើក្ដារខៀន ៖ *តើហេតុអ្វីបានជា អាលវិន អាចចូលក្នុងនគរសេឡេស្ទាលបាន ទោះបីជាលោកមិនបានទទួលបុណ្យជ្រមុជទឹក ពេលដែលលោកនៅរស់ក៏ដោយ ?*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧: ៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលសេចក្ដីពិតដែលជួយឆ្លើយនឹងសំណួរនៅលើក្ដារខៀន ។

- តើសេចក្ដីពិតអ្វី ដែលព្រះអម្ចាស់បើកសម្ដែងដល់ យ៉ូសែប ស៊្មីធ ដែលអាចឆ្លើយនឹងសំណួរនៅលើក្ដារខៀន ? ( សិស្សគួរប្រាប់នូវសេចក្ដីពិតដូចខាងក្រោម ៖ **មនុស្សទាំងអស់ដែលស្លាប់ដោយគ្មានចំណេះដឹងនៃដំណឹងល្អ អ្នកដែលនឹងទទួលយកដំណឹងល្អ នឹងស្នងនគរសេឡេស្ទាលទុកជាមរតក ។**)
- តើសេចក្ដីពិតនេះអាចលួងលោកដល់អ្នក ដែលមានមនុស្សជាទីស្រឡាញ់បានស្លាប់ដោយគ្មានចំណេះដឹងនៃដំណឹងល្អយ៉ាងដូចម្ដេច ?

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានបើកសម្ដែងសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៧–៨ មុនទ្រង់បានបើកសម្ដែងគោលការណ៍នៃការធ្វើបុណ្យជ្រមុជទឹកសម្រាប់មរណៈជន ។ សិស្សនឹងសិក្សាវិវរណៈនៃពិធីបុណ្យជ្រមុជទឹកសម្រាប់មរណៈជន នៅក្នុងមេរៀនបន្ទាប់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៩ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀន អំពីវិធីដែលទ្រង់នឹងកាត់សេចក្ដីមនុស្សទាំងអស់ ។

- ស្របតាម ខ ៩ តើព្រះអម្ចាស់នឹងកាត់សេចក្ដីយើងដោយរបៀបណា ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងអំពីគោលការណ៍ដូចខាងក្រោម ៖ **ព្រះអម្ចាស់នឹងកាត់សេចក្ដីយើង តាមកិច្ចការរបស់យើង និងបំណងនៃដួងចិត្តរបស់យើង ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។
- តើហេតុអ្វីបានជាអ្នកគិតថា បំណងប្រាថ្នារបស់យើង និងកិច្ចការរបស់យើងមានសារៈសំខាន់ទាំងពីរ ?

សូមអានឧទាហរណ៍និមួយៗ ដូចខាងក្រោមឲ្យឮៗ ។ បន្ទាប់ពីឧទាហរណ៍និមួយៗ សូមឲ្យសិស្សឆ្លើយតបទៅនឹងសំណួរនេះ ៖

- តើឧទាហរណ៍នេះ បង្ហាញពីសារៈសំខាន់នៃបំណងប្រាថ្នារបស់យើង ក៏ដូចជាកិច្ចការរបស់យើងយ៉ាងដូចម្ដេច ?

១. សមាជិកនៃសាសនាចក្រម្នាក់ មានបំណងប្រាថ្នាសុចរិត ដើម្បីរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់ពីការបម្រើយ៉ាងស្មោះត្រង់នៅក្នុងសាសនាចក្រពេញមួយជីវិត សមាជិកម្នាក់នេះស្លាប់ដោយគ្មានឱកាស ដើម្បីផ្សារភ្ជាប់ជាស្វាមីភរិយានៅក្នុងព្រះវិហារបរិសុទ្ធទេ ។

២. យុវជនម្នាក់រក្សាសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់គាត់យ៉ាងខ្ជាប់ខ្ជួន ហើយបំពេញតួនាទីបព្វជិតភាពអើរ៉ុនរបស់ខ្លួន ។ គាត់មានបំណងប្រាថ្នាដ៏មុតមាំ ដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ប៉ុន្តែមិនអាចធ្វើដូច្នោះបាន ដោយសារតែពិការភាព ។

៣. យុវនារីម្នាក់ មានការគុំគួននឹងយុវនារីម្នាក់ទៀត ។ នាងធ្វើពុតជារាក់ទាក់ ប៉ុន្តែចង់ឲ្យមានរឿងអាក្រក់កើតឡើងចំពោះយុវនារីម្នាក់ទៀតនោះ ។

៤. យុវជនម្នាក់ មានគំនិតលោភលន់ ហើយគេមិនបានស្វែងរកជំនួយពីព្រះអម្ចាស់ ដើម្បីផ្លាស់ប្ដូរគំនិត និងអារម្មណ៍ដែលមិនត្រឹមត្រូវរបស់ខ្លួនឡើយ ។

ជាចំណែកនៃការពិភាក្សានេះ អ្នកអាចអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« តើអ្នកប្រាកដដែរឬទេ ថានឹងពុំមានទោសនៅក្រោមក្រឹត្យវិន័យនៃព្រះ បើយើងគ្រាន់តែចៀសវាងចេញពីអំពើអាក្រក់នោះ ? ចុះបើសិនជាអ្នកពីការយនឹងគំនិត និង បំណងប្រាថ្នាដែលអាក្រក់ទៅវិញនោះ ?

« តើអារម្មណ៍សម្អប់ នឹងមិនត្រូវបានលើកឡើងនៅថ្ងៃនៃការជំនុំជម្រះទេឬអី ? ចុះការច្រណែនវិញ ? ចុះការលោភចង់បាននោះ ?. . .

« ចម្លើយរបស់យើងទៅនឹងសំណួរបែបនោះ បង្ហាញពីអ្វីដែលយើងអាចហៅថា ដំណឹងអាក្រក់ ថាយើងអាចមានអំពើបាប ទោះបីមិនបានប្រព្រឹត្តក្ដី ដោយគ្រាន់តែគិតតាមអារម្មណ៍ និងបំណងនៃដួងចិត្តរបស់យើងប៉ុណ្ណោះ ។

« វាក៏មានដំណឹងល្អផងដែរ ។ ក្រោមក្រឹត្យវិន័យរបស់ព្រះ យើងអាចត្រូវបានផ្ដល់រង្វាន់ឲ្យសម្រាប់សេចក្ដីសុចរិត ទោះជាយើងមិនបានធ្វើអ្វីដែលទាក់ទងនឹងពរជ័យទាំងនោះក៏ដោយ ។

« ពេលនរណាម្នាក់ចង់ធ្វើអ្វីមួយសម្រាប់ឪពុកក្មេករបស់ខ្ញុំ ប៉ុន្តែត្រូវបានបង្អាក់ដោយសារស្ថានភាពណាមួយ គាត់និងនិយាយថា ‹ អរគុណ ។ សម្រាប់បំណងល្អរបស់អ្នក › ។ ស្រដៀងគ្នានោះដែរ ខ្ញុំជឿថា ព្រះវរបិតាសួគ៌របស់យើងនឹងទទួលយកបំណងប្រាថ្នាពិត ចេញពីបេះដូងរបស់យើង ជំនួសឲ្យសកម្មភាពដែលពុំអាចធ្វើទៅបានដោយពិតនោះទេ » (The Desires of Our Hearts," *Ensign,* ខែ មិថុនា ឆ្នាំ ១៩៨៦,ទំព័រ ៦៦ ) ។

- តើវាមានឥទ្ធិពលដល់អ្នកយ៉ាងណាដែរ ដោយដឹងថាអ្នកនឹងត្រូវបានកាត់សេចក្ដីស្របតាមកិច្ចការ និងបំណងប្រាថ្នានៃដួងចិត្តរបស់អ្នក ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១០ ឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់ រកមើលសេចក្ដីពិតមួយទៀតដែលព្រះអម្ចាស់បានបង្រៀនអំពីអ្នកដែលនឹងស្នងនគរសេឡេស្ទាលទុកជាមរតក ។

- ស្របតាម ខ ១០ តើនរណានឹងត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល ? ( សិស្សគួរបង្ហាញគោលលទ្ធិដូចខាងក្រោម ៖ **ក្មេងៗទាំងអស់ដែលស្លាប់មុនអាយុទទួលខុសត្រូវ នឹងត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល** ) ។

សូមប្រាប់សិស្សថា ពេល យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះ លោក និង អិមម៉ាបានរងទុក្ខ ពីការស្លាប់នៃកូនទាំងបួនរបស់ពួកលោករួមទាំងកូនចិញ្ចឹមម្នាក់ផង ។ ក្រោយមក កូនពីរនាក់ទៀតរបស់ពួកលោក ក៏បានស្លាប់កាលនៅជាទារកដែរ ។




ផ្លាកព្រលឹងសម្គាល់កន្លែងបញ្ចុះ អាលវិនៃ ស្ម៊ីធ ជាកូនប្រុសរបស់ យ៉ូសែប និង អិមម៉ា ស្ម៊ីធ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលសេចក្ដីពិតបានបើកសម្ដែងនៅក្នុង ខ ១០ អាចនាំមកនូវការលួងលោមចិត្តដល់ក្រុមគ្រួសារ ដែលកើតទុក្ខដោយសាការស្លាប់របស់កូន។ សូមផ្ដល់ពេលឲ្យពួកគេគិតពីបទពិសោធន៍ ដែលពួកគេមាន ឬដែលសមាជិកគ្រួសារមាន ពេលដែលសេចក្ដីពិតនេះបាននាំមកនូវការលួងលោមចិត្ត ។

- តើយើងបានរៀនអ្វីខ្លះចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ អំពីកិច្ចខិតខំរបស់ព្រះអម្ចាស់ ដើម្បីប្រទានដល់មនុស្សទាំងអស់នូវឱកាសដើម្បីរស់នៅក្នុងនគរសេឡេស្ទាល ?

សូមថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដែលអ្នកបានពិភាក្សានៅថ្ងៃនេះ ។ អ្នកអាចផ្ដល់ឱកាសឲ្យសិស្សចែកចាយទីបន្ទាល់របស់ពួកគេដែរ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦–១០៨; ១៣៧ ( មេរៀនទី ២៣ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦–១០៨; ១៣៧ ( មេរៀនទី ២៣ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ៖(គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦; ១០៧:១–២០)

តាមរយៈការសិក្សាព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះ វ៉ារិន ខៅឌើរីនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦ សិស្សបានរៀនថា ប្រសិនបើយើងបន្ទាបខ្លួនចំពោះព្រះអម្ចាស់ នោះទ្រង់នឹងមានសេចក្ដីមេត្តាករុណាមកលើយើង លើកយើងឡើង ហើយផ្ដល់ព្រះគុណ និង ការធានាអះអាងដល់យើង ។ សិស្សក៏បានចាប់ផ្ដើមការសិក្សារបស់ខ្លួនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ដែលជាវិវរណៈមួយលើបព្វជិតភាព ។ ចេញពីកណ្ឌនេះពួកគេបានរៀនថា បព្វជិតភាពមិលគីស្សាដែកគឺតាមរបៀបនៃព្រះរាជបុត្រានៃព្រះ ។ ពួកគេក៏បានសិក្សាផងដែរពីតំណែង និង ទំនួលខុសត្រូវនានានៃបព្វជិតភាពអើរ៉ុន និង មិលគីស្សាដែក ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨)

នៅពេលសិស្សបានបន្តការសិក្សារបស់ខ្លួនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧, នោះពួកគេបានរៀនអំពីទំនួលខុសត្រូវនៃគណៈប្រធានកូរ៉ុមនៃសាសនាចក្រ ៖ គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង កូរ៉ុមនៃពួកចិតសិបនាក់ ។ ពួកគេក៏បានរៀនផងដែរថា ការសម្រេចចិត្តនៃគណៈប្រធានកូរ៉ុមទាំងនេះគឺធ្វើឡើងដោយសាមគ្គីភាព និង ដោយសេចក្ដីសុចរិត ។

### ថ្ងៃទី ៣ ៖ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០; ១០៨)

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧, សិស្សបានរៀនថា លោកអយ្យកោត្រូវបានហៅតាមរយៈវិវរណៈ ហើយត្រូវបានតែងតាំងឡើងក្រោមការដឹកនាំនៃពួកសាវកដប់ពីរនាក់ ហើយថាឪពុកដែលកាន់បព្វជិតភាពមិលគីស្សាដែកមានសិទ្ធិអំណាចប្រសិទ្ធិពរដល់កូនៗរបស់ខ្លួន ។ សិស្សក៏បានរៀនផងដែរអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះ ឡៃម៉ាន ស៊ើម៉ាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨។ ពួកគេបានឃើញថានៅពេលយើងគោរពតាមសំឡេងរបស់ព្រះអម្ចាស់ នោះយើងអញ្ជើញការអត់ទោសរបស់ទ្រង់ ដែលនាំសេចក្ដីសម្រាកដល់ព្រលឹងរបស់យើង ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧)

នៅក្នុងមេរៀននេះ សិស្សបានរៀនអំពីការនិមិត្តរបស់ព្យាការីយ៉ូសែប ស្ម៊ីធអំពីនគរសេឡេស្ទាល និង មនុស្សដែលលោកបានឃើញនៅក្នុងនគរនោះ ។ មេរៀននេះគូសបញ្ជាក់ពីគោលការណ៍ខាងក្រោមនេះ ៖ មនុស្សទាំងអស់ដែលស្លាប់ដោយគ្មានការចេះដឹងពីដំណឹងល្អ ដែលនឹងទទួលយកដំណឹងល្អដោយអស់ពីដួងចិត្តរបស់ខ្លួន នឹងគ្រងមរតកនៃនគរសេឡេស្ទាល ព្រះអម្ចាស់នឹងជំនុំជម្រះពួកយើង តាមរយៈកិច្ចការ និង បំណងប្រាថ្នានៃដួងចិត្តរបស់យើង ហើយក្មេងៗទាំងអស់ដែលស្លាប់ទៅពីមុនពួកគេចាប់ផ្ដើមអាចទទួលខុសត្រូវ នឹងត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល ។

## សេចក្ដីផ្ដើម

នៅក្នុងកិច្ចការប្រចាំសប្ដាហ៍របស់ពួកគេ សិស្សពុំត្រូវបានសុំឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦០–១០០ ឲ្យស៊ីជម្រៅនោះទេ ។ មេរៀននេះនឹងផ្ដល់ឱកាសនោះដល់ពួកគេ ។ វាអាចជួយពួកគេឲ្យស្គាល់តំណែងបព្វជិតភាព ហើយយល់កាន់តែប្រសើរឡើងអំពីតួនាទីរបស់ខ្លួនក្នុងនាមជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ? សិស្សនឹងរៀនផងដែរពីព្រះឱវាទដែលបានប្រទានដល់ឡៃម៉ាន ស៊ើម៉ានដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨។

នៅក្នុងការសិក្សាពីតំណែងនៃបព្វជិតភាពនៅក្នុងមេរៀននេះ វាសំខាន់ដើម្បីជួយសិស្សឲ្យយល់ថា អំឡុងពេលដែលបុរសជាច្រើនរូបបំពេញតំណែងផ្សេងៗទាំងនេះ ក្នុងនាមជាអ្នកកាន់បព្វជិតភាព នោះពរជ័យនៃបព្វជិតភាពនឹងអាចមានដល់មនុស្សគ្រប់គ្នា ។ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖ « បព្វជិតភាពគឺជាព្រះចេស្ដានៃព្រះដែលបានប្រើដើម្បីប្រទានពរដល់កូនចៅរបស់ទ្រង់ទាំងអស់ ទាំងប្រុសទាំងស្រី ។ ការបង្ហាញខ្លីៗរបស់យើងមួយចំនួនដូចជា ‹ ស្ត្រី និង បព្វជិតភាព › បង្ហាញឲ្យឃើញគំនិតខុសឆ្គងមួយ ។ ពួកបុរសពុំមែនជា ‹ បព្វជិតភាព › ទេ ។ ការប្រជុំបព្វជិតភាពគឺជាការប្រជុំមួយនៃអស់អ្នកដែលកាន់ និង អនុវត្តអំណាចបព្វជិតភាព ។ ពរជ័យទាំងឡាយនៃបព្វជិតភាពដូចជាពិធីបុណ្យជ្រមុជទឹក ទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ អំណោយទានពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ និង អាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច គឺមានសម្រាប់បុរស និង ស្ត្រីដូចគ្នា ។ សិទ្ធិអំណាចនៃមុខងារបព្វជិតភាពនៅក្នុងគ្រួសារ និង សាសនាចក្រ ស្របតាមគោលការណ៍នានាដែលព្រះអម្ចាស់បានបង្កើតឡើង » (« Priesthood Authority in the Family and the Church » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ២៥–២៦ ) ។ បុរស និង ស្ត្រីមានតួនាទីសំខាន់ស្មើគ្នានៅក្នុងក្រុមគ្រួសារ និង សាសនាចក្រ ( សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ) ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦០–១០០

*ព្រះអម្ចាស់បើកសម្ដែងពីកាតព្វកិច្ចនៃប្រធាននៃកូរ៉ុមបព្វជិតភាព*

ជាការរំឭកខ្លីមួយ សូមសរសេរពាក្យ *បព្វជិតភាពមិលគីស្សាដែក* និង *បព្វជិតភាពអើរ៉ុន* នៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរតំណែងនានានៃបព្វជិតភាពឲ្យបានត្រឹមត្រូវខាងក្រោមពាក្យនោះ ។ សូមឲ្យសិស្សម្នាក់សរសេរតំណែងមួយនៃបព្វជិតភាព ហើយបន្ទាប់មកហុចដីស ឬ ហ៊្វឺតឲ្យសិស្សម្នាក់ទៀត បន្តដំណើរការនេះរហូតដល់សិស្សបានសរសេរគ្រប់អស់ទាំងតំណែងនៃបព្វជិតភាព ។ សូមលើកទឹកចិត្តសិស្សឲ្យជួយគ្នាទៅវិញទៅមកតាមការគួរ ។ ( តំណែងនៃបព្វជិតភាពមិលគីស្សាដែករួមមាន អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ និង សាវក ។ តំណែងនៃបព្វជិតភាពអើរ៉ុនមាន ឌីកុន គ្រូ សង្ឃ និង ប៊ីស្សព ) ។

- តើកូរ៉ុមនៃបព្វជិតភាពគឺជាអ្វី ? ( ជាក្រុមដែលបានរៀបចំឡើងដែលមានបងប្អូនប្រុសដែលកាន់តំណែងបព្វជិតភាពដូចគ្នា ) ។

សូមអញ្ជើញសិស្សម្នាក់ឡើងមកក្ដារខៀន ហើយគូសរង្វង់លើតំណែងបព្វជិតភាពណាដែលត្រូវបានរៀបចំជាកូរ៉ុម ។ សូមលើកទឹកចិត្តសិស្សឲ្យជួយគ្នាតាមការគួរ ។ ( តំណែងខាងក្រោមនេះមានកូរ៉ុម ៖ សាវក ពួកចិតសិបនាក់ សង្ឃជាន់ខ្ពស់ អែលឌើរ សង្ឃ គ្រូ និង ឌីកុន ។ អ្នកអាចពន្យល់ថា ស្ដេកនិមួយៗមានកូរ៉ុមសង្ឃជាន់ខ្ពស់មួយ ដែលមានប្រធានស្ដេកគឺជាប្រធានកូរ៉ុមនោះ ។ នៅក្នុងវួដនិមួយៗ ពួកសង្ឃជាន់ខ្ពស់ត្រូវបានរៀបចំជាក្រុមសង្ឃជាន់ខ្ពស់មួយ ) ។

សូមឲ្យសិស្សពីរបីនាក់ផ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០ ៧:៦០–៦៣, ៨៥–៨៩, ៩៣–៩៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលចំណុចរួមមួយអំពីកូរ៉ុមទាំងនេះដែលបាននិយាយនៅក្នុងខគម្ពីរទាំងនេះ ។

- យោងតាមខគម្ពីរទាំងនេះ តើកូរ៉ុមបព្វជិតភាពទាំងនេះ មានអ្វីដែលរួមគ្នា ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេរកឃើញសេចក្ដីពិតខាងក្រោម ៖ **ប្រធានគឺត្រូវបានតាំងឡើងដើម្បីត្រួតត្រា និង ដឹកនាំកិច្ចការនៃកូរ៉ុមបព្វជិតភាពនិមួយៗ**) ។

- យោងតាម ខ ៨៧–៨៨ តើកូរ៉ុមសង្ឃខុសពីកូរ៉ុមឌីកុន និង កូរ៉ុមគ្រូយ៉ាងដូចម្ដេចខ្លះ ? ( ប៊ីស្សពនៅវួដធ្វើជាអធិបតីលើកូរ៉ុមសង្ឃ ។ គាត់ក៏ធ្វើជាអធិបតីលើអ្នកកាន់បព្វជិតភាពអើរ៉ុនទាំងអស់នៅក្នុងវួដផងដែរ ។ នៅក្នុងសាខា ប្រធានសាខាដើរតួជាប្រធាននៃកូរ៉ុមសង្ឃ ) ។

- ហេតុអ្វីអ្នកគិតថាវាសំខាន់ដែលកូរ៉ុមនៃបព្វជិតភាពនិមួយៗមានប្រធានម្នាក់ ? តើប្រធាននៃកូរ៉ុមនៃបព្វជិតភាពអាចជួយសមាជិកនៃកូរ៉ុមរបស់គាត់យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦៥–៦៦ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលថ្នាក់ដឹកនាំសាសនាចក្រដែលត្រួតត្រាលើអ្នកកាន់បព្វជិតភាពទាំងអស់ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមប្រាកដថាសិស្សយល់ថាខគម្ពីរទាំងនេះសំដៅលើប្រធាននៃសាសនាចក្រ ។

សូមឲ្យសិស្សម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦៧, ៩១–៩២ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ និង ឃ្លានានាដែលពិពណ៌នាអំពីសិទ្ធិអំណាច និង ទំនួលខុសត្រូវរបស់ប្រធានសាសនាចក្រ ។

- ផ្ដែកទៅលើអ្វីដែលអ្នកបានរៀនពីខគម្ពីរទាំងនេះ តើអ្នកនឹងសង្ខេបពីសិទ្ធិអំណាច និង ទំនួលខុសត្រូវរបស់ប្រធានសាសនាចក្រយ៉ាងដូចម្ដេច ? ( ទោះជាសិស្សអាចប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្ដីពិតដូចខាងក្រោម ៖ **ប្រធានសាសនាចក្រមានសិទ្ធិអំណាចគ្រប់គ្រងពិធីបរិសុទ្ធ និងពរជ័យទាំងអស់ ហើយធ្វើជាអធិបតីលើសាសនាចក្រទាំងមូល ។** សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

អ្នកអាចពន្យល់ពាក្យមួយចំនួននៅក្នុង ខ ៩២ ឲ្យបានច្បាស់ជាមួយនឹងនិយមន័យខាងក្រោមមកពីអែលឌើរ ចន អេ វីតសូវនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ព្យាការីគឺជាគ្រូបង្រៀនអំពីសេចក្ដីពិតម្នាក់ ជាអ្នកមើលឆុតគឺជាអ្នកយល់ដឹងដោយញាណនូវសេចក្ដីពិតដែលអាថ៌កំបាំង ជាអ្នកទទួលវិវរណៈគឺជាអ្នកទទួលនូវសេចក្ដីពិតថ្មី ។ តាមន័យដ៏ទូលំទូលាយ ជាពាក្យដែលគេប្រើយ៉ាងច្រើនបំផុត គឺងារព្យាការីរួមបញ្ចូលទាំងងារផ្សេងទៀត » ( *Evidences and Reconciliations,* arr. G. Homer Durham, វ៉ុល ៣ នៅក្នុង ១ [ ឆ្នាំ ១៩៦០ ] ទំព័រ ២៥៨ ) ។

សូមបង្ហាញរូបភាពមួយរបស់ព្យាការីបច្ចុប្បន្ននៃសាសនាចក្រ ។

- តើអ្នកត្រូវបានប្រទានពរជ័យតាមរបៀបណាខ្លះតាមរយៈសិទ្ធិអំណាចបព្វជិតភាព ដែលត្រូវបានកាន់ដោយប្រធាននៃសាសនាចក្រ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៩៩–១០០ ដោយស្ងៀមស្ងាត់ ។

- ស្របតាមខគម្ពីរទាំងនេះ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីនឹងឈរដោយសក្តិសមនៅចំពោះព្រះអម្ចាស់ ? ( សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **ដើម្បីឈរដោយសក្តិសមនៅចំពោះព្រះអម្ចាស់ យើងត្រូវតែរៀនពីកាតព្វកិច្ចរបស់យើង ហើយប្រតិបត្តិដោយសេចក្ដីឧស្សាហ៍គ្រប់ជំពូកដើម្បីបំពេញកាតព្វកិច្ចនោះ**) ។

ទោះបីជាខគម្ពីរទាំងនេះនិយាយដោយផ្ទាល់ចំពោះអ្នកកាន់បព្វជិតភាពក្ដី ក៏គោលការណ៍ដែលខគម្ពីរនេះបង្រៀនអនុវត្តចំពោះសមាជិកសាសនាចក្រគ្រប់រូបផងដែរ ។

សូមចែកសិស្សជាគូៗ ។ សូមអញ្ជើញពួកគេឲ្យពិភាក្សាពីសំណួរខាងក្រោម ។ សូមអានសំណួរមួយម្ដងៗ ឬ សរសេរវានៅលើក្ដារខៀន ។

- តើអ្នកធ្លាប់បានទទួលពរមកពីការបម្រើ នៃសមាជិកសាសនាចក្រម្នាក់ដែលបំពេញកាតព្វកិច្ចរបស់គាត់ដោយឧស្សាហ៍ព្យាយាមដែលឬទេ ?

- តើអ្នកកំពុងធ្វើអ្វីខ្លះដើម្បីរៀនពីកាតព្វកិច្ចរបស់អ្នក ហើយប្រតិបត្តិដោយសេចក្ដីឧស្សាហ៍គ្រប់ជំពូកដើម្បីបំពេញកាតព្វកិច្ចនោះ ?

សូមផ្ដល់ឱកាសដល់សិស្ស ដើម្បីថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការធ្វើកាតព្វកិច្ចរបស់ខ្លួននៅក្នុងសាសនាចក្រ និងក្រុមគ្រួសារ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៤–៨

### *ព្រះអម្ចាស់ប្រទានព្រះឱវាទ និង ការសន្យាដល់ឡៃម៉ាន សើម៉ាន*

សូមរំឮកសិស្សថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ មាននូវវិវរណៈមួយអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ចំពោះឡៃម៉ាន សើម៉ាន ដែលបានមកជួបព្យាការីយ៉ូសែប ស្ម៊ីធ ហើយស្នើសុំចង់ដឹងបន្ថែមទៀតទាក់ទងនឹងកាតព្វកិច្ចរបស់ខ្លួន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការណែនាំរបស់ព្រះអម្ចាស់ដែលបានប្រទានដល់ឡៃម៉ាន ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ អ្នកត្រូវពន្យល់ថា *សេចក្ដីដាស់តឿន* គឺជាពាក្យទូន្មាន ឬ ការលើកទឹកចិត្ត ។

- តើព្រះអម្ចាស់បានចង់ឲ្យឡៃម៉ាន សើម៉ានពង្រឹងបងប្អូនប្រុសរបស់ខ្លួនតាមរបៀបណាខ្លះ ?

សូមឲ្យសិស្សស្វែងរកគោលការណ៍មួយពីការណែនាំរបស់ព្រះអម្ចាស់ចំពោះ ទ្បេម៉ានៅក្នុង ខ ៧–៨? ពួកគេអាចរកឃើញគោលការណ៍ផ្សេងៗ រួមមានដូចខាងក្រោមនេះ ៖ **យើងត្រូវពង្រឹងមនុស្សដទៃតាមគ្រប់វាចា និង ការប្រព្រឹត្តិរបស់អ្នក ។** ( អ្នកអាចផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំគោលកាណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។

- តើអ្នកអាចពង្រឹងដល់អ្នកដែលនៅជុំវិញខ្លួនរបស់អ្នក តាមវាចារបស់អ្នកយ៉ាងដូចម្ដេច ?
- តើអ្នកអាចពង្រឹងដល់អ្នកដែលនៅជុំវិញខ្លួនរបស់អ្នក តាមការប្រព្រឹត្តរបស់អ្នកយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សពិពណ៌នាពីបទពិសោធនមួយដែលពួកគេមាន នៅពេលនរណាម្នាក់បានពង្រឹងពួកគេតាមរយៈការធ្វើទង្វើមួយដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ ។ សូមគិតពីការចែកចាយនូវបទពិសោធន៍ផ្ទាល់ខ្លួនអ្នក ។ សូមអញ្ជើញសិស្សគិតពីមនុស្សម្នាក់ដែលពួកគេពង្រឹងនៅថ្ងៃនេះ និង ទង្វើជាក់លាក់មួយដែលពួកគេនឹងយកទៅធ្វើ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩–១១២)

ដើម្បីជួយសិស្សរៀបចំសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩–១១២, សូមអញ្ជើញពួកគេឲ្យពិចារណាពីសំណួរខាងក្រោម ៖ ហេតុអ្វីបានព្រះវិហារបរិសុទ្ធសំខាន់ ? តើអ្នកធ្លាប់ចូលរួមការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធដែលឬទេ ? សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងរៀនអំពីការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធខឺតឡង់ ។ ពួកគេនឹងរៀនបន្ថែមទៀតអំពីអ្វីដែលបានកើតឡើង និង នរណាដែលបានបង្ហាញខ្លួននៅទីនោះ និង របៀបដែលអ្វីដែលបានបើកសម្ដែងនៅទីនោះអាចប្រទានពរដល់ពួកគេ និង ក្រុមគ្រួសាររបស់ពួកគេជារៀងរហូត ។

មេរៀនទី ១១៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១–៤៦

## បុព្វកថា

ពួកបរិសុទ្ធធ្វើការអស់រយៈពេលជិតបីឆ្នាំ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ ពេលពួកគេបានបញ្ចប់ ព្រះអម្ចាស់បានបើកសម្ដែងដល់ព្យាការី យ៉ូសែប ស្ម៊ីធ ពីការអធិស្ឋានដើម្បីឧទ្ទិសព្រះវិហារបរិសុទ្ធ ។ ព្យាការីបានអានការអធិស្ឋាន ជាផ្នែកមួយនៃការឧទ្ទិសនៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៨៣៦ ។ ការអធិស្ឋាននោះ គឺត្រូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៩ ។ មេរៀននេះ បង្ហាញពីផ្នែកទីមួយនៃការអធិស្ឋាន ដែលមានការទូលអង្វរដល់ព្រះអម្ចាស់ឲ្យទទួល យកព្រះវិហារបរិសុទ្ធ និងបំពេញការសន្យាដែលទ្រង់បានធ្វើទាក់ទងនឹងព្រះវិហារ បរិសុទ្ធ រួមទាំងការការពារ និងពរជ័យសម្រាប់អ្នកដែលគោរពបូជានៅទីនោះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១–២៣

*យ៉ូសែប ស្ម៊ីធ បានទូលសូមឲ្យព្រះអម្ចាស់ទទួលយកព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ហើយសូមឲ្យទ្រង់ប្រទានពរ ដល់អ្នកដែលគោរពបូជានៅទីនោះ ។*

សូមបង្ហាញរូបព្រះវិហារបរិសុទ្ធពីរបីសន្លឹក ។ អ្នកអាចសួរសិស្សថាតើពួកគេស្គាល់ថាព្រះវិហារនិមួយៗមានទីតាំងនៅទីណា ឬទេ ។

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើហេតុអ្វីបានជាយើងសាងសង់ព្រះវិហារបរិសុទ្ធ ?* សូមអញ្ជើញសិស្សឲ្យចាប់គូ ហើយពិភាក្សារកចម្លើយ ចំពោះសំណួរនេះ ។ ក្រោយពីបានផ្ដល់ពេលវេលាគ្រប់គ្រាន់ហើយ សូមពន្យល់ថា យើងអាចស្វែងរកចម្លើយ ចំពោះសំណួរនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ ។



បង្ហាញរូបភាព នៃ ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ( សូមមើល *Gospel Art Book* [ឆ្នាំ ២០០៩] ទំព័រ ១១៧ សូមមើលផងដែរ LDS.org និង josephsmith.net ) ។ សូមពន្យល់ថា ពួកបរិសុទ្ធបានធ្វើការ ហើយបានលះបង់អស់រយៈពេលជិតបីឆ្នាំ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ ពួកគេបានឃើញការបំពេញការសន្យារបស់ព្រះអម្ចាស់ថា បើពួកគេកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះពួកគេនឹង « មានអំណាច ដើម្បីកសាងគេហដ្ឋាននោះ » ( គ. និង ស. ៩៥:១១ ) ។ នៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៨៣៦ ពួកបរិសុទ្ធបានចូលរួមការឧទ្ទិសព្រះវិហារបរិសុទ្ធ ហើយព្យាការី យ៉ូសែប ស្ម៊ីធ បានផ្ដល់ការអធិស្ឋានបើកឧទ្ទិសឆ្លង ។ លោកបានទទួលពាក្យអធិស្ឋាន ដោយវិវរណៈមុនពេលពិធីឧទ្ទិសឆ្លង ។ វិវរណៈនោះ គឺត្រូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ ។

សូមពន្យល់ថា ពួកបរិសុទ្ធថ្ងៃចុងក្រោយជិត ១,០០០នាក់បានចូលរួមការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ មានសមាជិកជាច្រើនទៀតដែលចង់ចូលរួម ប៉ុន្តែអគារនោះ បានពេញហើយ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានរៀបចំឲ្យពួកគេចូលរួមការប្រជុំនៅក្នុងអគារមួយផ្សេងទៀត ហើយ ការឧទ្ទិសឆ្លងបានធ្វើឡើងវិញម្ដងហើយម្ដងទៀតចំនួនពីរបីថ្ងៃសម្រាប់ពួកគេ ។

***ប្រើជំនួយសិក្សាព្រះគម្ពីរ***

ការបកប្រែភាគច្រើននៃគោលលទ្ធិ និង សេចក្ដីសញ្ញា រួមបញ្ចូលជំនួយសិក្សាព្រះគម្ពីរ ដូចជាលេខយោង លិបិក្រម រូបភាព និងផែនទី ។ ឧទាហរណ៍ ច្បាប់បោះពុម្ពជាច្រើន រួមបញ្ចូលផ្នែកមួយដែលហៅថា ប្រវត្តិសាសនាចក្រតាមលំដាប់ពេលកើតឡើង ផែនទី និងរូបថតទាំងឡាយ ដែលមានរូបថតនៃព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើជំនួយការសិក្សា នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យស្រមៃពីការចូលរួមក្នុងពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ៖ ពួកគេមានអារម្មណ៍ត្រេកអរយ៉ាងខ្លាំង ខណៈពេលក្រុមចម្រៀងច្រៀងចម្រៀងបើក ។ ហើយ ស៊ីឌនី រិកដុន បានផ្ដល់ទេសនកថា ។ បន្ទាប់ពីការសម្រាកបន្តិចមក ពួកគេមានឱកាសផ្ដល់ការគាំទ្រដល់ពួកអ្នកដឹកនាំសាសនាចក្រ ។ បន្ទាប់មក ព្យាការី យ៉ូសែប ស្ម៊ីធ បានឈរ ហើយអានការអធិស្ឋានឧទ្ទិសឆ្លង ។




ប្លង់ជាន់ខាងក្រោមនៃព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យក្រោកឈរ ហើយអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលហេតុផលទីមួយដែលពួកបរិសុទ្ធកសាងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។

- តើអ្វីជាមូលហេតុទីមួយ ដែលធ្វើឲ្យពួកបរិសុទ្ធកសាងព្រះវិហារបរិសុទ្ធ ខឺតឡង់? ( សិស្សគួរឃើញថា ពួកបរិសុទ្ធកសាងព្រះវិហារបរិសុទ្ធ ដោយសារព្រះអម្ចាស់បានបញ្ជា ។ សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បញ្ជាយើងឲ្យកសាងព្រះវិហារបរិសុទ្ធ**) ។

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យក្រោកឈរ ហើយអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលរៀបរាប់ពីការលះបង់របស់ពួកបរិសុទ្ធ ដើម្បីកសាងព្រះវិហារបរិសុទ្ធ ។

- តើអ្នកបានសម្គាល់ឃើញឃ្លាអ្វី ? ( ចម្លើយអាចមាន « ការវេទនាដ៏ខ្លាំង » « ចេញពីភាពក្រខ្សត់ » និង « ថ្វាយរបស់របរនៃទូលបង្គំទាំងអស់គ្នា » ) ។

ដើម្បីជួយសិស្សឲ្យយល់ពីការលះបង់ដែលពួកបរិសុទ្ធបានធ្វើ ដើម្បីកសាងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ សូមឲ្យសិស្សម្នាក់អានសេចក្ដីសង្ខេបដូចខាងក្រោម ៖

នៅចន្លោះខែ មិថុនា ឆ្នាំ ១៨៣៣ និងខែ មិនា ឆ្នាំ ១៨៣៦ សមាជិកសាសនាចក្របានលះបង់ពេលវេលា ប្រាក់កាស និងទ្រព្យសម្បត្តិដើម្បីជួយកសាងព្រះរាជដំណាក់សម្រាប់ព្រះអម្ចាស់ ។ បុរសទាំងឡាយបានស្ម័គ្រចិត្តផ្ដល់កម្លាំងជួយសាងសង់ ។ ស្ត្រីទាំងឡាយបានដេរសម្លៀកបំពាក់ និងផ្ដល់កន្លែងស្នាក់នៅ ។ នៅពេលបុរសជាច្រើនបានចេញទៅឆ្វាយជាមួយជំរុំស៊ីយ៉ូន ស្ត្រីមួយចំនួនបានបន្តសាងសង់ព្រះវិហារបរិសុទ្ធ ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួន ដូចជា ចន ថានណឺ និង វីអែណា ចាកស៍ បានផ្ដល់ទ្រព្យសម្បត្តិមួយចំនួនធំ ដើម្បីកសាងព្រះវិហារបរិសុទ្ធ ។ អ្នកដទៃទៀតបានផ្ដល់ជំនាញពលកម្ម ។ ឧទាហរណ៍ ព្រិកហាំ យ៉ង់ បានធ្វើបុណ្យជ្រមុជទឹកឲ្យបុរសម្នាក់ដែលមានឈ្មោះថា អាថេមុស មីលលែត នៅប្រទេសកាណាដា ។ បងប្រុស មីលលែត បានបោះបង់ការងាររបស់គាត់ជាជាងថ្មកំបោរឲ្យរដ្ឋាភិបាល កាណាដា ដូច្នេះគាត់ និងក្រុមគ្រួសារគាត់អាចផ្លាស់ទៅរស់នៅទីក្រុង ខឺតឡង់ ហើយគាត់បានបម្រើជាមេជាងនៃការកសាងព្រះវិហារបរិសុទ្ធ ។ សរុបមក ព្រះវិហារបរិសុទ្ធមានតម្លៃប្រហែល ៦០,០០០ ដុល្លារអាមេរិក ជាចំនួនដ៏ច្រើននៅសម័យនោះ ជាពិសេសបើគិតពីភាពក្រីក្ររបស់ពួកបរិសុទ្ធ ។ បើប្រៀបធៀបនឹងចំនួនទឹកប្រាក់សព្វថ្ងៃនេះ ចំនួននោះអាចលើសពី ១,០០០,០០០ ដុល្លារអាមេរិក ។

- តើអ្វីដែលធ្វើឲ្យអ្នកចាប់អារម្មណ៍អំពីការលះបង់របស់ពួកបរិសុទ្ធ បានធ្វើដើម្បីកសាងព្រះវិហារបរិសុទ្ធ ?

សូមអញ្ជើញសិស្សឲ្យអាន ខ ៥ ដោយស្ងៀមស្ងាត់ ហើយរកមើលសេចក្ដីពិតដែលពន្យល់ពីមូលហេតុដែលពួកបរិសុទ្ធបានលះបង់ជាច្រើន ដើម្បីកសាងព្រះវិហារបរិសុទ្ធ ។

- តើសេចក្ដីពិតអ្វីដែលអ្នករកឃើញ អំពីមូលហេតុដែលពួកបរិសុទ្ធចង់កសាងព្រះវិហារបរិសុទ្ធ ? ( សិស្សគួរតែបង្ហាញថា **នៅក្នុងព្រះវិហារបរិសុទ្ធ ព្រះអម្ចាស់អាចបើកសម្ដែងអង្គទ្រង់ដល់យើង** ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១០–១១ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែល យ៉ូសែប ស្ម៊ីធ បានទូលសូមឲ្យព្រះអម្ចាស់ធ្វើ ដើម្បីឲ្យមនុស្សអាចទទួលបានពរជ័យនៃព្រះវិហារបរិសុទ្ធ ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១២–១៣ ដោយស្ងាត់ស្ងៀម រកមើលឃ្លាដែលជួយ

ពួកគេឲ្យយល់ពីរបៀបដែលព្រះអម្ចាស់សម្ដែងអង្គទ្រង់ដល់យើងនៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់ពីមានពេលគ្រប់គ្រាន់ហើយ សូមសួរក្រុមទីមួយនូវសំណួរដូចខាងក្រោម ៖

- តើ យ៉ូសែប ស្ម៊ីធ បានទូលសូមឲ្យព្រះអម្ចាស់ធ្វើអ្វី ដើម្បីឲ្យមនុស្សគ្រប់រូបអាចទទួលបានពរជ័យនៃព្រះវិហារបរិសុទ្ធ ? ( ដើម្បីជួយពួកគេដោយព្រះគុណទ្រង់ ដូច្នេះពួកគេអាចមានភាពសក្ដិសមនៅក្នុងព្រះនេត្រទ្រង់ ) ។
- នៅពេលយើងព្យាយាមឲ្យមានភាពសក្ដិសម ដើម្បីចូលក្នុងព្រះវិហារបរិសុទ្ធ តើហេតុអ្វីបានជាយើងត្រូវការព្រះគុណព្រះអម្ចាស់ ?

សូមសួរក្រុមទីពីរនូវសំណួរខាងក្រោម ៖

- តើឃ្លាអ្វីដែលអ្នករកឃើញថាជួយអ្នកឲ្យយល់ ពីរបៀបដែលព្រះអម្ចាស់សម្ដែងអង្គទ្រង់ដល់យើងនៅក្នុងព្រះវិហារបរិសុទ្ធ ? ( អ្នកអាចសូមឲ្យសិស្សគូសចំណាំឃ្លាដែលមិត្តរួមថ្នាក់របស់ពួកគេបានចែកចាយ ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយជាគូ ឬជាមួយនឹងសិស្សក្នុងថ្នាក់ទាំងអស់ នូវបទពិសោធន៍ដែលពួកគេមាន ពេលដែលពួកគេមានអារម្មណ៍ថានៅជិតព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធ ។ សូមរំឭកថា បទពិសោធន៍មួយចំនួនពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ ដែលពុំគួរចែកចាយទេ ។ សូមគិតពីការចែកចាយនូវបទពិសោធន៍ផ្ទាល់ខ្លួនអ្នក ។

- តើការមានអារម្មណ៍ថានៅជិតព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធ មានឥទ្ធិពលយ៉ាងណានៅក្នុងជីវិតរបស់អ្នក ពេលអ្នកនៅក្រៅព្រះវិហារបរិសុទ្ធ ?

សូមអញ្ជើញសិស្សបន្តអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១៤–២៣ ដោយខ្លួនឯង ហើយរកមើលពរជ័យបន្ថែមដែលព្រះអម្ចាស់បានសន្យាចំពោះអ្នកដែលគោរពបូជានៅក្នុងព្រះវិហារបរិសុទ្ធ ។

- តើពរជ័យបន្ថែមអ្វីខ្លះដែលព្រះអម្ចាស់បានសន្យាចំពោះអ្នកដែលគោរពបូជានៅក្នុងព្រះវិហារបរិសុទ្ធ ? ( សិស្សគួររកឃើញពរជ័យជាច្រើននៅក្នុងខគម្ពីរទាំងនេះ ។ ( អ្នកអាចសរសេរពរជ័យទាំងនេះនៅលើក្ដារខៀន ) ។

ពី ខ ២២–២៣តើការគោរពបូជានៅក្នុងព្រះវិហារបរិសុទ្ធ នាំមកនូវលទ្ធផលអ្វីខ្លះ ? ( ក្នុងការភ្ជាប់ទៅនឹងចម្លើយដែលសិស្សផ្ដល់ឲ្យ សូមជួយពួកគេឲ្យប្រាប់ពីសេចក្ដីពិតដូចខាងក្រោម ៖ **ការទទួលបានពរជ័យនៃព្រះវិហារបរិសុទ្ធ ផ្ដល់ឲ្យយើងនូវព្រះស្ដា និងជំនួយរបស់ព្រះអម្ចាស់ ពេលដែលយើងបម្រើទ្រង់** ។ សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ។ អ្នកក៏អាចផ្ដល់យោបល់ដែរថា សិស្សគួរតែកត់ត្រាវានៅក្នុងព្រះគម្ពីររបស់ពួកគេផងដែរ ) ។

- តើអ្នកគិតថាការ « ប្រដាប់ទៅដោយព្រះចេស្ដារបស់ [ព្រះអម្ចាស់] » មានអត្ថន័យយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរអំពីអត្ថន័យនៃការប្រដាប់ទៅដោយព្រះចេស្ដារបស់ព្រះអម្ចាស់ សិស្សអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ យ៉ូសែប ប៊ី វឺតលីន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ឲ្យឮៗ ៖



នៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ សមាជិកស្មោះត្រង់នៅក្នុងសាសនាចក្រ អាចត្រូវបានប្រទានអំណោយទានដល់ ‹ ដោយព្រះចេស្ដាពីស្ថានលើ › [ គ. និង ស. ៩៥:៨ជាព្រះចេស្ដាដែលនឹងជួយយើងឲ្យទប់ទល់នឹងការល្បួង គោរពតាមសេចក្ដីសញ្ញា ធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ និងថ្លែងទីបន្ទាល់ដល់គ្រួសារ មិត្តភក្ដិ និងអ្នកជិតខាងដោយភាពក្លៀវក្លា »( Cultivating Divine Attributes » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨,ទំព័រ ២៧ ) ។

- តើព្រះចេស្ដាបែបនេះ អាចជាពរជ័យដល់អ្នក និងក្រុមគ្រួសាររបស់អ្នកដោយរបៀបណា ? តើព្រះចេស្ដាបែបនេះ អាចជាពរជ័យដល់អ្នកផ្សព្វផ្សាយសាសនាពេញម៉ោងយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:០៤–៤៦

*យ៉ូសែប ស្ម៊ីធ បានទូលសូមដល់ព្រះអម្ចាស់ឲ្យការពារ និងប្រទានពរដល់អ្នកដែលគោរពបូជានៅក្នុងព្រះវិហារបរិសុទ្ធ និងអ្នកដែលផ្សាយដំណឹងល្អ ។*

សូមគូររូប ស្លាបព្រាបាយអ និងដាវ នៅលើក្ដារខៀន ។ អ្នកអាចពន្យល់ថា ស្លាបព្រាបាយអ គឺត្រូវបានប្រើដើម្បីបៀកបាយអនៅចន្លោះឥដ្ឋ ឬថ្ម ។ សូមសួរសិស្សពីរបៀបដែលឧបករណ៍ទាំងនេះ ត្រូវបានប្រើក្នុងការកសាងព្រះវិហារបរិសុទ្ធ ។



សូមពន្យល់ថា នៅពេលសាងសង់ព្រះវិហារបរិសុទ្ធ ខឺតឡង់ ពួកមនុស្សកំណាចបានគំទេចព្រះវិហារបរិសុទ្ធ ។ ប្រធាន ព្រិកហាំ យ៉ង់ បានប្រាប់ « អ្នករៀបជញ្ជាំង ឲ្យកាន់ដាវនៅដៃម្ខាងដើម្បីការពារខ្លួនគេពីពួកមនុស្សកំណាច ហើយដៃម្ខាងទៀតរៀបឥដ្ឋ និងបៀកបាយអ » ( *Discourses of Brigham Young,* sel. John A. Widtsoe [ឆ្នាំ ១៩៥៤],ទំព័រ ៤១៥ ) ។ មានពេលខ្លះ បុរសដែលសាងសង់ព្រះវិហារបរិសុទ្ធនៅពេលថ្ងៃ ត្រូវយាមនៅពេលយប់ ។

សូមពន្យល់ថា បន្ថែមពីលើការធ្វើការដោយឧស្សាហ៍ដើម្បីការពារព្រះវិហារបរិសុទ្ធ និងខ្លួនគេហើយ ពួកបរិសុទ្ធបានទូលសូមការការពារពីព្រះអម្ចាស់ផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:២៤–២៨ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ រកមើលការការពារដែលព្យាការី យ៉ូសែប ស៊្មីធ ស្នើសុំព្រះអម្ចាស់ បន្ទាប់ពីព្រះវិហារបរិសុទ្ធបានសាងសង់ហើយ។

- តើការការពាប្រភេទណាដែល យ៉ូសែប ស៊្មីធ បានអធិស្ឋានសូម ?
- យោងតាម ខ ២៤ តើយើងអាចធ្វើអ្វីដើម្បីទទួលបានការការពារដូចនេះ ?
- តើយើងអាចរៀនអ្វីខ្លះពីខគម្ពីរទាំងនេះ អំពីការទទួលការការពារពីអំពើអាក្រក់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **បើប្រជាជនរបស់ព្រះអម្ចាស់មានភាពសក្ដិសម ហើយគោរពបូជាទ្រង់នៅក្នុងព្រះវិហារបរិសុទ្ធ នោះអំពើអាក្រក់នឹងមិនអាចយកឈ្នះលើពួកគេឡើយ ។**)

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:២៩–៤៦ ដោយពន្យល់ថា ព្យាការីបានអធិស្ឋានថាអ្នកដែលផ្សាយការកុហកពីពួកបរិសុទ្ធនឹងត្រូវបានធ្វើឲ្យខ្មាស ហើយថាសមាជិកសាសនាចក្រ នឹងអាចក្រោកឡើង ហើយធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។ លោកក៏បានទូលសូមដល់ព្រះអម្ចាស់ឲ្យបំពេញព្រះវិហារបរិសុទ្ធដោយសិរីល្អរបស់ទ្រង់ ហើយផ្ដល់ឲ្យអ្នកបម្រើរបស់ទ្រង់នូវទីបន្ទាល់ និងព្រះចេស្ដាដែលពួកគេត្រូវការដើម្បីប្រកាសដំណឹងល្អ ។

ដើម្បីបញ្ចប់ សូមលើកទឹកចិត្តសិស្សឲ្យកាន់បណ្ណចូលព្រះវិហារបរិសុទ្ធដែលមានសុពលភាពជានិច្ច ទោះបីជាពួកគេមិនរស់នៅជិតព្រះវិហារបរិសុទ្ធក៏ដោយ ។ សូមចែកចាយសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហាវើដ ដបុលយូ ហ៊ុនធើរ ៖



« ជាការពិតណាស់ ព្រះអម្ចាស់សព្វព្រះទ័យឲ្យរាស្ត្រទ្រង់ ធ្វើជាមនុស្សដែលមានការជម្រុញចិត្តចង់ធ្វើកិច្ចការព្រះវិហារបរិសុទ្ធ ។ វាជាបំណងប្រាថ្នាដ៏ជ្រាលជ្រៅបំផុតចេញពីដួងចិត្តរបស់ខ្ញុំ សូមឲ្យសមាជិកគ្រប់រូប នៃសាសនាចក្រមានភាពសក្តិសមសម្រាប់ព្រះវិហារបរិសុទ្ធ ។. . . សូមឲ្យយើងធ្វើជាមនុស្សដែលចូលរួម និងស្រឡាញ់ព្រះវិហារបរិសុទ្ធ។ សូមយើងប្រញាប់ទៅកាន់ព្រះវិហារបរិសុទ្ធឲ្យកាន់តែញឹកញាប់តាមពេលវេលា តាមមធ្យោបាយ និងតាមស្ថានភាពដែលអំណោយផលឲ្យ » ( The Great Symbol of Our Membership » *Ensign,* ខែ តុលា ឆ្នាំ ១៩៩៤,ទំព័រ ៥ ) ។

មេរៀនទី ១១៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៨០

## បុព្វកថា

នៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៨៣៦ ព្យាការី យ៉ូសែប ស៊្មីធ បានប្រកាសការអធិស្ឋានពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ ជាការអធិស្ឋានដែលព្រះអម្ចាស់បានបើកសម្ដែងដល់លោកពីលើកមុន ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ ។ នេះគឺជាផ្នែកទីពីរនៃមេរៀនទីពីរអំពីការអធិស្ឋាន ។ វាមានការទូលអង្វររបស់ព្យាការីសូមឲ្យព្រះអម្ចាស់ប្រទានពរដល់ពួកបរិសុទ្ធ ដែលត្រូវបានគេសង្កត់សង្កិននៅក្នុងភូមិ ចាកសុន រដ្ឋ មិសសួរី និងសូមឲ្យព្រះអម្ចាស់ប្រទានពរដល់អ្នកដែលសង្កត់សង្កិនលើពួកគេដែរផងដែរ ។ វាក៏មាននូវសំណើរបស់ព្យាការីថា មនុស្សទូទាំងពិភពលោក ជាពិសេសសាសន៍អ៊ីស្រាអែលដែលបែកខ្ញែក អាចត្រូវបានប្រែចិត្តជឿចំពោះដំណឹងល្អដ៏ពេញលេញ ហើយថា ព្រះវរបិតាសួគ៌នឹងទទួលយកការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ និងប្រទានពរដល់ក្រុមគ្រួសារនៃសាសនាចក្រទាំងនោះ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៥៣

*យ៉ូសែប ស៊្មីធ បានសូមឲ្យព្រះវរបិតាសួគ៌ជួយពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។*

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា មិត្តភក្តិម្នាក់ ឬសមាជិកគ្រួសារម្នាក់កំពុងតស៊ូ ឬរងទុក្ខដោយរបៀបណាមួយ ។ ហើយ សូមឲ្យពួកគេស្រមៃថា ពួកគេមិនអាចធ្វើអ្វីបានដោយខ្លួនឯង ដើម្បីជួយមិត្តភក្តិ ឬសមាជិកគ្រួសារម្នាក់នេះឡើយ។ ក្រោយពីសិស្សមានពេលគិតហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកអាចជួយសម្រាលការរងទុក្ខរបស់នរណាម្នាក់ ទោះជាអ្នកមិនអាចធ្វើអ្វីបានដោយខ្លួនអ្នក តាមវិធីណា ?

បន្ទាប់ពីសិស្សបានចែកចាយគំនិតមួយចំនួនហើយ សូមរំឭកពួកគេថា ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានរងទុក្ខយ៉ាងខ្លាំងដោយសារអំពើហឹង្សាពីសំណាក់ពួកមនុស្សកំណាចនៅ ឃុំ ចាកសុន ។ នៅខែ មេសា ឆ្នាំ ១៨៣៦ ព្យាការី យ៉ូសែប ស៊្មីធ នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ ទោះជាពេលនោះលោកមិនអាចធ្វើអ្វីបានដោយខ្លួនលោក ដើម្បីជួយសម្រាលការរងទុក្ខនៃពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ក្ដី ក៏ លោកបានធ្វើអ្វីមួយនៅពេលឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ដើម្បីជួយពង្រឹងពួកគេដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៤៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរឿងមួយដែលយើងអាចធ្វើបាន ដើម្បីជួយអ្នកដទៃក្នុងគ្រាលំបាក ។

- នៅការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ តើព្យាការីធ្វើអ្វីសម្រាប់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ? ( លោកបានអធិស្ឋានសម្រាប់ពួកគេ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាអ្នកសរសេរនៅលើក្ដារខៀន ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ដល់យោបល់ពីសេចក្ដីពិត ដែលយើងអាចរៀនពីពាក្យអធិស្ឋានរបស់ព្យាការីនៅក្នុងខគម្ពីរទាំងនេះ ។ នៅពេលដែលសិស្សឆ្លើយតប ស្មៀនអាចសរសេរសេចក្ដីពិតដូចខាងក្រោម ៖ **ការអធិស្ឋានរបស់យើង អាចនាំមកនូវជំនួយ និងកម្លាំងដល់អ្នកដែលកំពុងត្រូវការជំនួយ ។**

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ ឬបានឃើញអំណាចនៃការអធិស្ឋានជួយនរណាម្នាក់ដែលត្រូវការជំនួយ ? ( អ្នកអាចចង្អុលបង្ហាញថា ពេលខ្លះការអធិស្ឋានដូចនោះត្រូវបានឆ្លើយតបតាមរយៈការបំផុសគំនិតដែលយើងទទួលដើម្បីជួយអ្នកដទៃ )។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមនុស្សដទៃទៀតដែលព្យាការីបានអធិស្ឋានសម្រាប់ពួកគេ ។

- តើមាននរណាខ្លះទៀតដែលព្យាការីបានអធិស្ឋានសម្រាប់ពួកគេនោះ ?

- តើហេតុអ្វីបានជាអ្នកគិតថាយើងគួតែអធិស្ឋាន សម្រាប់សត្រូវរបស់យើង ? ( ដើម្បីជួយសិស្សឆ្លើយសំណួរនេះ អ្នកអាចឲ្យពួកគេអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៣ និង នីហ្វៃទី៣ ១២:៤៣–៤៥ ) ។

- តើយើងអាចរៀនអ្វីខ្លះមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥០ អំពីរបៀបដែលការអធិស្ឋានរបស់យើងអាចជះឥទ្ធិពលលើមនុស្សដទៃ ? ( បន្ទាប់ពីសិស្សឆ្លើយហើយ សូមឲ្យអ្នកសរសេរសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **ការអធិស្ឋានរបស់យើងអាចជះឥទ្ធិពលដល់មនុស្សឲ្យប្រែចិត្ត ។** បន្ទាប់មកសូមអញ្ជើញអ្នកសរសេរឲ្យអង្គុយចុះវិញ ) ។

សូមឲ្យសិស្សពិចារណាពីសំណួរខាងក្រោម ៖

- តើវាប្រែជាយ៉ាងដូចម្ដេចដែរ ប្រសិនបើមនុស្សដែលយើងអធិស្ឋានឲ្យពុំព្រមជ្រើសប្រែចិត្តនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥១–៥៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលទទួលស្គាល់ព្រះឆន្ទៈរបស់ព្រះអម្ចាស់ និង សិទ្ធិជ្រើសរើសរបស់មនុស្សដទៃ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( មុនពេលដែលសិស្សអានខគម្ពីរទាំងនេះ អ្នកអាចពន្យល់ថា ពេលខគម្ពីរដែលរួមបញ្ចូលសេចក្ដីថ្លែងការណ៍អំពីព្រះអម្ចាស់លាតព្រះពាហុរបស់ទ្រង់ ខគម្ពីរនោះមានន័យថា ទ្រង់សម្ដែងព្រះចេស្ដារបស់ទ្រង់ ។)

សូមអញ្ជើញសិស្សឲ្យអានម្ដងទៀតនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥៣ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះវរបិតាសួគ៌នឹងធ្វើសម្រាប់ពួកអ្នកដែលប្រែចិត្ត ។ ( អ្នកអាចត្រូវពន្យល់ថា សេចក្ដីក្រោធរបស់ព្រះអម្ចាស់ បញ្ចេញតាមការដាក់ទោស ឬការរងទុក្ខដែលយើងជួបប្រទះស្របតាមសេចក្ដីយុត្តិធម៌របស់ទ្រង់ ដោយសារតែអំពើបាបរបស់យើង ។ ឃ្លា « នៅពេលព្រះអង្គទតទៅលើព្រះភក្ត្រនៃអ្នកដែលទ្រង់បានចាក់ប្រេងតាំង » សំដៅលើព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ ប្រទានសេចក្ដីមេត្តាករុណាដោយសារតែពលិកម្មដ៏ធួននៃព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ) ។

- ហេតុអ្វីបានជាព្រះវរបិតាសួគ៌បង្វែរសេចក្ដីក្រោធរបស់ទ្រង់ចេញពីអស់អ្នកដែលប្រែចិត្តដូច្នេះ ? ( សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែសូមជួយពួកគេរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **ដោយសារតែពលិកម្មដ៏ធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះសេចក្ដីក្រោធរបស់ព្រះវរបិតាសួគ៌នឹងត្រូវបែរចេញពីអស់អ្នកដែលប្រែចិត្ត** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ) ។

> ***នឹកគិតនៅក្នុងចិត្ត***
> ម្ដងម្កាល សូមអញ្ជើញសិស្សឲ្យស្រមៃក្នុងចិត្តពីអ្វីដែលកើតឡើងនៅក្នុងដំណើររឿងព្រះគម្ពីរ ។ ការធ្វើដូច្នេះអាចជួយធ្វើឲ្យបទគម្ពីរ កាន់តែរស់រវើក និងពិតសម្រាប់ពួកគេ ។

ដើម្បីជួយសិស្ស ឲ្យនឹកគិតក្នុងចិត្ត ពីការរៀបរាប់នៅក្នុង ខ ៥៣ សូមអញ្ជើញពួកគេឲ្យធ្វើដូចខាងក្រោម ៖

សូមស្រមៃថា អតីតសមាជិកក្រុមមនុស្សកំណាចប្រឆាំងនឹងពួកមរមន កំពុងឈរនៅចំពោះព្រះភក្ត្រព្រះដើម្បីជំនុំជំរះ ។ ឥឡូវសូមស្រមៃពីប៉ុន្មានឆ្នាំមុន ពីមុនបុគ្គលនេះស្លាប់ គាត់ពិតជាបានប្រែចិត្ត ហើយបានសុំការអភ័យទោស ហើយបានប្រោសលោះតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដោយសារតែព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ សម្រាប់អំពើបាបរបស់បុគ្គលនេះព្រះវរបិតាសួគ៌នឹងបង្វែរការដាក់ទោស ហើយប្រទានសេចក្ដីមេត្តាដល់មនុស្សមានបាបដែលបានប្រែចិត្ត ។

សូមលើកទឹកចិត្តសិស្សឲ្យអភិវឌ្ឍអត្តចរិតនេះ ចំពោះអ្នកដែលបានធ្វើឲ្យពួកគេអាក់អន់ចិត្ត ឬបានធ្វើឲ្យពួកគេរងទុក្ខ ។ សូមឲ្យសិស្សស្រមៃពីមនុស្សដែលប្រែចិត្តបែបនេះ កំពុងឈរនៅពីមុខព្រះភក្ត្រព្រះវរបិតាសួគ៌ ។ សូមអញ្ជើញសិស្សឲ្យអធិស្ឋាន ដូចជា យ៉ូសែប ស៊្មីធ បានធ្វើសម្រាប់មនុស្សដែលបានធ្វើឲ្យពួកគេអាក់អន់ចិត្ត ឬធ្វើបាបទាស់នឹងពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩: ៥៤ –៦៧

*ព្យាការីអធិស្ឋានឲ្យមនុស្សទូទាំងពិភពលោក ឲ្យប្រែចិត្តជឿចំពោះភាពពេញលេញនៃដំណឹងល្អ*

សូមឲ្យសិស្សលើកដៃ បើពួកគេបានធ្វើអ្វីមួយដូចខាងក្រោម ៖

បានអធិស្ឋានសម្រាប់អ្នកផ្សព្វផ្សាយសាសនាពេញម៉ោងទាំងឡាយ

បានអធិស្ឋានសម្រាប់សាសនាចារ្យដែលរៀនអំពីសាសនាចក្រ

បានអធិស្ឋានសម្រាប់មនុស្សដែលមិនទាន់បានឮដំណឹងល្អ

- តើអ្នកគិតថាការអធិស្ឋានរបស់អ្នកជួយដល់មនុស្សទាំងនេះ ដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥៤–៥៨ ឲ្យឮៗ ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់រកមើលមនុស្សដែល យ៉ូសែប ស៊្មីធ បានអធិស្ឋានឲ្យ ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់ទៀត រកមើលអ្វីដែលព្យាការីបានទូលសូមដល់ព្រះអម្ចាស់ធ្វើ សម្រាប់មនុស្សទាំងនោះ ។ រួចហើយសូមឲ្យក្រុមនិមួយៗរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើព្យាការីបានអធិស្ឋានថា នឹងមានអ្វីកើតឡើងចំពោះអ្នកដែលឮទីបន្ទាល់អ្នកបម្រើរបស់ព្រះអម្ចាស់ ?
- តើគោលការណ៍អ្វី ដែលអ្នកបានឃើញនៅក្នុងខគម្ពីរទាំងនេះ ? ( សិស្សអាចរកឃើញសេចក្ដីពិតមួយចំនួន រួមទាំងសេចក្ដីពិតដូចខាងក្រោម ៖ **ការថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ រៀបចំយើងឲ្យថ្លែងទីបន្ទាល់ដល់អ្នកដទៃ ។ បើយើងអធិស្ឋានសម្រាប់អ្នកដទៃ នោះដួងចិត្តពួកគេអាចត្រូវបានបន្ទន់ ដើម្បីទទួលអ្នកបម្រើរបស់ព្រះអម្ចាស់ ។** នៅពេលសិស្សប្រាប់ពីគោលការណ៍ទាំងនោះ អ្នកអាចសរសេរនៅលើក្ដារខៀន ) ។

សូមផ្ដល់ឱកាសឲ្យសិស្សថ្លែងទីបន្ទាល់ នៃគោលការណ៍ទាំងឡាយដែលពួកគេបានស្គាល់ ។ អ្នកអាចចែកចាយទីបន្ទាល់របស់អ្នក និងបទពិសោធន៍ដែលទាក់ទងនឹងមេរៀននេះ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥៩–៦៧ ដោយការពន្យល់ថា យ៉ូសែប ស្ម៊ីធ បានអធិស្ឋានថា ព្រះអម្ចាស់នឹងបង្កើតស្តេកនៃស៊ីយ៉ូនថែមទៀត ម្ល៉ោះហើយមនុស្សនៅទូទាំងពិភពលោកអាចប្រមូលគ្នាទៅស្តេកទាំងនោះ ។ លោកបានអធិស្ឋានជាពិសេសសម្រាប់ពូជពង្សរបស់ព្យាការី យ៉ាកុប ( អ៊ីស្រាអែល ) ឲ្យដឹងពីសេចក្ដីពិត និងការប្រែចិត្ត ទៅរកភាពពេញលេញនៃដំណឹងល្អ ។ នេះគឺជាវិធីមួយដ៏សំខាន់ ដែលសាសន៍អ៊ីស្រាអែល ត្រូវបានប្រមូលផ្ដុំគ្នានៅថ្ងៃចុងក្រោយ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩: ៦៨ –៨០

*ព្យាការីអធិស្ឋានសម្រាប់សាសនាចក្រ និងទូលសូមឲ្យព្រះអម្ចាស់ទទួលយកការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ*

សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវឡើងវិញនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៦៨–៦៩, ៧១–៧៣ ,៧៨–៨០ ដោយស្ងាត់ស្ងៀម ។ អ្នកអាចសរសេរលេខនៅខគម្ពីរទាំងនេះ នៅលើក្ដារខៀន ដូច្នេះសិស្សអាចយោងទៅក្នុងនោះ។ សូមសូមឲ្យសិស្សរកមើលសំណើបន្ថែម ដែលព្យាការីបានសុំនៅក្នុងការអធិស្ឋានឧទ្ទិសឆ្លង ។ សូមផ្ដល់យោបល់ ឲ្យពួកគេគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើ យ៉ូសែប ស្ម៊ីធ បានអធិស្ឋានសម្រាប់នរណា ហើយបានអធិស្ឋានធ្វើអ្វី?
- តើផលប្រយោជន៍អ្វីដែលបានមកពីការរួមបញ្ចូលសំណូមពរដូច្នោះនៅក្នុងការអធិស្ឋានរបស់យើង ?

សូមអញ្ជើញសិស្សឲ្យច្រៀងបទ « ព្រះវិញ្ញាណនៃព្រះ » ( *ទំនុកតម្កើង* ទំព័រ ២ ) ។ សូមបង្វែរចំណាប់អារម្មណ៍របស់សិស្សទៅរកការពន្យល់ក្នុងអត្ថបទទំនុកតម្កើងខាងក្រោម ដែលនិយាយថាទំនុកតម្កើតនេះត្រូវបានច្រៀងនៅការឧទ្ទិសឆ្លង ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ ( ក្រុមចម្រៀងច្រៀងបទនោះភ្លាមបន្ទាប់ពីការអធិស្ឋានឧទ្ទិសឆ្លង ) ។ វាត្រូវបានបន្តច្រៀងនៅការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនៅសព្វថ្ងៃនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីសង្ខេបដូចខាងក្រោម ពីអ្វីដែលបានកើតឡើងនៅក្នុងព្រះវិហារបរិសុទ្ធនៅល្ងាចថ្ងៃទី ២៧ ខែមិនា ឆ្នាំ ១៨៣៦ បន្ទាប់ពីការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ៖

នៅល្ងាចនោះ កូរ៉ុមបព្វជិតភាពបានជួបប្រជុំនៅក្នុងព្រះវិហារបរិសុទ្ធ ។ យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា លោក « បានប្រទានដល់ពួកគាត់នូវសេចក្ដីណែនាំអំពីវិញ្ញាណនៃការព្យាករណ៍ ហើយលោកបានចាត់ឲ្យអ្នកចូលរួមឡើងថ្លែង ។. . . ចច អេ ស្ម៊ីធ បានក្រោកឈរឡើង ហើយបានចាប់ផ្ដើមព្យាករ នោះមានសំឡេងមួយបានឮឡើងដូចជាសំឡេងខ្យល់ដ៏ខ្លាំង ដែលឮខ្ទរពេញព្រះវិហារបរិសុទ្ធ ហើយក្រុមជំនុំបានក្រោកឈរឡើងព្រមគ្នា ត្រូវបានសណ្ឋិតដោយព្រះចេស្ដាអរូបី មនុស្សជាច្រើនចាប់ផ្ដើមនិយាយភាសាផ្សេងៗ ហើយចាប់ផ្ដើមព្យាករ អ្នកផ្សេងទៀតបានឃើញការនិមិត្តដ៏រុងរឿង ហើយមើលចុះ ខ្ញុំបានប្រកាសដល់ក្រុមជំនុំថា ព្រះវិហារបរិសុទ្ធបានពោរពេញទៅដោយទេវតា ។ មនុស្សម្នាក់ដែលនៅជិតខាង បានរត់មកមើល ( ពួកគេឮសំឡេងដែលមិនប្រក្រតីពីក្នុងនោះ ហើយបានឃើញពន្លឺដ៏ភ្លឺដូចជាសសរភ្លើង សណ្ឋិតនៅលើព្រះវិហារបរិសុទ្ធ ) ហើយមានការភ្ញាក់ផ្អើលអំពីអ្វីដែលកំពុងកើតឡើង » ( នៅក្នុង *History of the Church* ២:៤២៨ ) ។ មនុស្សមួយចំនួន បានឃើញទេវតានៅលើព្រះវិហារបរិសុទ្ធ ហើយបានឮពួកទេវតាច្រៀង ( សូមមើល *Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទី ២ [ Church Educational System manual ឆ្នាំ ២០០៣ ], ទំព័រ ១៦៧ ) ។

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់ពីពរជ័យ ដែលយើងអាចទទួលបាននៅពេលដែលយើងចូលក្នុងព្រះវិហារបរិសុទ្ធដោយភាពសក្ដិសម ។

មេរៀនទី ១១៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០

## បុព្វកថា

នៅថ្ងៃ អាទិត្យ ទី ៣ ខែ មេសា ឆ្នាំ ១៨៣៦ ការប្រជុំសាក្រាម៉ង់មួយត្រូវបានធ្វើឡើងនៅក្នុងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ ក្នុងពេលប្រជុំនោះ យ៉ូសែប ស៊្មីធ និងអូលីវើរ ខៅឌើរី ទៅកន្លែងមួយនៃព្រះវិហារ ជាកន្លែងដែលវាំងនននបានបំបែកពួកគេចេញពីក្រុមជំនុំ ។ ពួកលោកបានថ្វាយការអធិស្ឋាននៅទីនោះ ។ បន្ទាប់ពីពួកលោកបញ្ចប់ការអធិស្ឋាន ព្រះគ្រីស្ទ បានបង្ហាញអង្គទ្រង់ចំពោះពួកលោក ហើយបានទទួលយកព្រះវិហារបរិសុទ្ធដែលទើបតែបានឧទ្ទិសឆ្លងនោះ ។ បន្ទាប់មក ម៉ូសេ អេលីយ៉ាស់ និង អេលីយ៉ា បានបង្ហាញខ្លួនដល់ពួកលោក ហើយកូនសោបព្វជិតភាពត្រូវបានស្ដារឡើងវិញ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ គឺជារឿងនៃការនិមិត្តនេះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១–១០

*ព្រះអម្ចាស់បង្ហាញអង្គទ្រង់ ហើយទទួលយកព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់*

សូមសួរសិស្សថា អ្វីដែលបានសរសេរនៅខាងក្រៅព្រះវិហារបរិសុទ្ធគ្រប់កន្លែង ។ ( « ព្រះអម្ចាស់ដ៏បរិសុទ្ធ—ព្រះដំណាក់នៃព្រះអម្ចាស់ » ) ។

- តើ ឃ្លា « ព្រះដំណាក់នៃព្រះអម្ចាស់ » មានអត្ថន័យយ៉ាងណាចំពោះអ្នក ?

បន្ទាប់ពីសិស្សបានពិភាក្សាសំណួរនេះហើយ សូមពន្យល់ថាព្រះអម្ចាស់បានយាងមកព្រះរាជដំណាក់របស់ទ្រង់នៅក្នុងទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ បន្ទាប់ពីបានឧទ្ទិសហើយ ។ ដើម្បីជួយសិស្សឲ្យយល់ពីស្ថានភាពនៅជុំវិញព្រឹត្តិការណ៍ដ៏ពិសិដ្ឋនេះ អញ្ជើញសិស្សឲ្យអានបុព្វកថាកណ្ដាលក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាមានវត្តមាននរណាខ្លះ ហើយថាពួកគេបានធ្វើអ្វីមុនពេលដែលការនិមិត្តនេះប្រាកដឡើង ។

- តើនរណាខ្លះមានវត្តមានអំឡុងពេលនៃការនិមិត្តនេះ ? តើពួកគេបានធ្វើអ្វីខ្លះ មុនពេលដែលការនិមិត្តនេះប្រាកដឡើង ?

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១–៣ ឲ្យឮៗ ។ មុនពេលដែលសិស្សអាន សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយព្យាយាមគិតក្នុងចិត្តពីអ្វីដែលបានរៀបរាប់នៅក្នុងខគម្ពីរទាំងនេះ ។

សូមអញ្ជើញសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៤–៥ ដោយស្ងាត់ស្ងៀម ដើម្បីរៀនពីអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលទៅកាន់ យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ។

- តើខគម្ពីរទាំងនេះ មានអត្ថន័យយ៉ាងណាខ្លះចំពោះអ្នក ? ហេតុអ្វី ?

សូមអញ្ជើញសិស្សបួនប្រាំនាក់ឲ្យឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៦–១០ ឲ្យឮៗ ។ សូមសូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលព្រះអម្ចាស់មានបន្ទូលថាពួកបរិសុទ្ធត្រូវអរសប្បាយ ។

- ស្របតាម ខ ៧ តើហេតុអ្វីបានជាពួកបរិសុទ្ធមានហេតុផលដើម្បីអរសប្បាយ ? ( ព្រះអម្ចាស់បានទទួលយកព្រះវិហារបរិសុទ្ធ ហើយបានសន្យាថានឹងបើកសម្ដែងអង្គទ្រង់ដល់អ្នកដែលនៅក្នុងព្រះវិហារបរិសុទ្ធនោះ ) ។
- តើព្រះអម្ចាស់បើកសម្ដែងអង្គទ្រង់ដល់មនុស្សនៅក្នុងព្រះវិហារបរិសុទ្ធដោយរបៀបណា ? ( ពាក្យ *បើកសម្ដែង* មានន័យថា បើកសម្ដែង ឬ បង្ហាញ ។ សូមរំឭកសិស្សថា ពួកគេបានពិភាក្សាពីរឿងនេះពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ ។ ជារឿយៗ ព្រះអម្ចាស់បង្ហាញអង្គទ្រង់ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ) ។

សូមអញ្ជើញសិស្សប្រាប់ពីគោលការណ៍មួយដកស្រង់ចេញពីការសន្យានៅក្នុង ខ ៧–៨ ។ សិស្សអាចនឹងប្រាប់នូវគោលការណ៍ផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា គួសបញ្ជាក់នូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយ**

**រក្សាព្រះដំណាក់របស់អង្គទ្រង់ឲ្យបរិសុទ្ធ នោះទ្រង់នឹងបើកសម្ដែងអង្គទ្រង់ដល់យើងនៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់ ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅលើក្ដារខៀន ។

ដើម្បីជួយសិស្សយល់ពីគោលការណ៍នេះកាន់តែប្រសើរ សូមពិភាក្សាពីសំណួរដូចខាងក្រោម ៖

- តើយើងអាចរក្សាព្រះដំណាក់របស់ព្រះអម្ចាស់ឲ្យបរិសុទ្ធ និងស្អាតតាមរបៀបណា ?
- តើហេតុអ្វីបានជាអ្នកគិតថា ព្រះអម្ចាស់តម្រូវឲ្យយើងស្ដាប់បង្គាប់ និងស្អាតស្អំមុនពេលដែលទ្រង់នឹងសម្ដែងអង្គទ្រង់ដល់យើង នៅក្នុងព្រះដំណាក់របស់ទ្រង់ ?

បើសិស្សបានចូលរួមក្នុងព្រះវិហារបរិសុទ្ធ សូមឲ្យពួកគេគិតពីបទពិសោធន៍ដែលពួកគេបានមាន ពេលពួកគេបានមានអារម្មណ៍ខិតជិតព្រះអម្ចាស់នៅទីនោះ ។ សូមគិតពីការចែកចាយពីរបៀបដែលអ្នកមានអារម្មណ៍ កាលអ្នកថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៩–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្នកដែលនឹងអរសប្បាយ និងពីមូលហេតុនោះ ។

- ស្របតាមខគម្ពីរទាំងនេះ តើនរណានឹងត្រូវបានប្រទានពរឲ្យដោយសារការស្ដារឡើងវិញនៃពរជ័យព្រះវិហារបរិសុទ្ធ ?
- តើពិភពលោកនឹងត្រូវបានប្រទានពរ ដោយសារព្រះវិហារបរិសុទ្ធ និងកិច្ចការនៃសេចក្ដីសង្គ្រោះសម្រាប់អ្នកដែលនៅរស់ និងអ្នកដែលបានស្លាប់ដោយរបៀបណា ?
- តើព្រះវិហារបរិសុទ្ធជាពរជ័យនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០: ១១–១៦

*ម៉ូសេ អេលីយ៉ាស និង អេលីយ៉ា បានបង្ហាញខ្លួន ហើយកូនសោទាំងឡាយនៃបព្វជិតភាពត្រូវបានស្ដារឡើងវិញដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើ ខៅឌើរី*

សូមអញ្ជើញសិស្សឲ្យប្រាប់អំពីពេល ដែលសមាជិកក្រុមគ្រួសាររបស់ពួកគេ បានបែកចេញពីគ្នាជាបណ្ដោះអាសន្ន ។ សូមឲ្យសិស្សចែកចាយពីរបៀបដែលពួកគេមានអារម្មណ៍ពីការបែកគ្នានេះ ។ នៅពេលសិស្សសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១–១៦, សូមអញ្ជើញពួកគេឲ្យរកមើលរបៀបដែលការនិមិត្តនេះ ធានាថាក្រុមគ្រួសាររបស់យើងអាចយកឈ្នះលើការបែកគ្នានេះ ។

សូមចម្លង តារាងខាងក្រោម ដាក់លើក្ដារខៀន ។ សូមកុំសរសេរព័ត៌មាននៅក្នុងវង់ក្រចក ។

| | ម៉ូសេ<br>គ. និង ស. ១១០:១១ | អេលីយ៉ាស<br>គ. និង ស. ១១០:១២ | អេលីយ៉ា<br>គ. និង ស. ១១០:១៣–១៦ |
|---|---|---|---|
| កូនសោបព្វជិតភាពត្រូវបានស្ដារឡើងវិញ | ( កូនសោនៃការប្រមូលផ្ដុំកូនចៅអ៊ីស្រាអែល ) | ( ការកាន់កាប់ត្រួតត្រានៃដំណឹងល្អនៃអ័ប្រាហាំ ) | ( កូនសោនៃការកាន់កាប់ត្រួតត្រានេះ ) |
| តើកូនសោទាំងនេះដឹកនាំទៅរកអ្វី | ( កិច្ចការផ្សព្វផ្សាយសាសនា ) | ( អាពាហ៍ពិពាហ៍សេឡេស្ទាល និងពូជពង្សដ៏អស់កល្ប ) | ( អំណាចនៃការផ្សារភ្ជាប់ រួមទាំងកិច្ចការនៅក្នុងព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ ) |

សូមពន្យល់ថា បន្ទាប់ពីការនិមិត្តនៃព្រះអង្គសង្គ្រោះត្រូវបានបញ្ចប់ នោះមានបុគ្គលបីនាក់ទៀតបានបង្ហាញខ្លួនម្ដងម្នាក់ៗដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើ ខៅឌើរី ។ សូមបង្ហាញរូបភាពរបស់ ម៉ូសេ និង អេលីយ៉ាស ( សូមមើល *សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] លេខ ១៤, ២០ សូមមើលផងដែរ LDS.org) ។ សូមឲ្យសិស្សពន្យល់ថាតើ ម៉ូសេ និងអេលីយ៉ា ជានរណា ហើយឲ្យប្រាប់ពីរឿងសំខាន់ដែលពួកលោកបានធ្វើ ( បើសិស្សត្រូវការជំនួយ សូមផ្ដល់យោបល់ឲ្យពួកគេរកមើលព្យាការីទាំងនេះនៅក្នុង Bible Dictionary ) ។ សូមពន្យល់ថា អេលីយ៉ាស អាចជាព្យាការីដែលរស់នៅក្នុងជំនាន់ អ័ប្រាហាំ ។ បន្ថែមពីលើឈ្មោះ *អេលីយ៉ាស* ក៏ជាងារដែលមានន័យថា អ្នកនាំមុខ ឬអ្នកស្ដារឡើងវិញ ( សូមមើល Bible Dictionary ឬ Guide to the Scriptures, « Elias » scriptures.lds.org ) ។





សូមបែងចែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ សូមចាត់ឲ្យក្រុមនិមួយៗនូវឈ្មោះមួយក្នុងចំណោមឈ្មោះទាំងបី នៅក្នុងតារាងលើក្ដារខៀន ។ សូមពន្យល់ថា អ្នកនាំសារនិមួយៗ បានប្រគល់កូនសោបព្វជិតភាពដល់ យ៉ូសែប ស៊្មីធ និង អូលីវើ ខៅឌើរី ។ សូមឲ្យសិស្សសិក្សាវគ្គបទគម្ពីរ ដែលបានសរសេរនៅក្រោមឈ្មោះដែលពួកគេបានចាត់ឲ្យ និងរកឃើញអ្វីដែលទេវតានាំសារបានស្ដារឡើងវិញ ។ បន្ទាប់ពីផ្ដល់ពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់មកពីក្រុមនិមួយៗ អានវគ្គបទគម្ពីរដែលគេបានចាត់ឲ្យដល់សិស្សក្នុងថ្នាក់ ។ សូមអញ្ជើញសិស្សទីពីរមកពីក្រុមនិមួយៗ សរសេរអ្វីដែលអ្នកនាំសារបានស្ដារឡើងវិញ នៅជួរដែលមានចំណងជើងថា « កូនសោបព្វជិតភាពដែលបានស្ដារឡើងវិញ » ក្នុងតារាងនៅលើក្ដារខៀន ។

ដើម្បី ជួយសិស្សឲ្យយល់ពីអ្វីដែលជាកូនសោនៃការប្រមូលផ្ដុំកូនចៅអ៊ីស្រាអែល សូមពិភាក្សាសំណួរខាងក្រោម ៖

- នៅក្នុងជំនាន់របស់យើង តើព្រះអម្ចាស់បានប្រមូលផ្ដុំកូនចៅទ្រង់ មកក្នុងនគររបស់ទ្រង់យ៉ាងដូចម្ដេច ?

បន្ថែមពីលើ ឬបញ្ជាក់ចម្លើយរបស់សិស្ស ដោយការអញ្ជើញនរណាម្នាក់ឲ្យអានការពន្យល់ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« កិច្ចការផ្សព្វផ្សាយសាសនា មានសារៈសំខាន់ដល់ការប្រមូលផ្ដុំនៃកូនចៅអ៊ីស្រាអែល ។. . . នៅក្នុងប្រទេសជាតិជាច្រើន អ្នកផ្សព្វផ្សាយសាសនារបស់យើងបានស្វែងរកកូនចៅនៃសាសន៍អ៊ីស្រាអែលដែលបានបែកខ្ញែក » ( The Gathering of Scattered Israel » *Ensign* ឬ *លីអាហូណា*ខែវិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ៨១ ) ។

សូមសរសេរ *កិច្ចការផ្សព្វផ្សាយសាសនា* នៅលើក្ដារខៀនក្រោម « ម៉ូសេ » នៅជួរដែលមានចំណងជើងថា « អ្វីដែលកូនសោទាំងនេះចាក់ចេញ» ។

- តើជីវិតរបស់អ្នកបានរងឥទ្ធិពលពីការស្ដារឡើងវិញនូវកូនសោរគ្រប់គ្រងកិច្ចការផ្សព្វផ្សាយសាសនារបស់ម៉ូសេ ដោយរបៀបណា ?

ការកាន់កាប់ត្រួតត្រានៃដំណឹងល្អនៃអ័ប្រាហាំ បានប្រគល់ឲ្យ យ៉ូសែប ស៊្មីធ និង អូលីវើ ខៅឌើរី ដោយ អេលីយ៉ាស បានស្ដារឡើងវិញនូវការសន្យាដែលព្រះអម្ចាស់បានធ្វើជាមួយ អ័ប្រាហាំ ។ ដើម្បីជួយសិស្សឲ្យយល់ពីការកាន់កាប់ត្រួតត្រានៃដំណឹងល្អនៃអ័ប្រាហាំដែលបានស្ដារឡើងវិញដោយ អេលីយ៉ាស សូមអញ្ជើញសិស្សឲ្យអានការពន្យល់ដូចខាងក្រោម ដោយអែលឌើរ ប្រ៊ូស អរ ម៉ាក់ខនឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



«អេលីយ៉ាសបាននាំមកវិញនូវ ‹ ដំណឹងល្អនៃអ័ប្រាហាំ › ជាសេចក្ដីសញ្ញារបស់អ័ប្រាហាំ ដែលថាមនុស្សស្មោះត្រង់ទទួលបាននូវការរីកចម្រើនដ៏អស់កល្ប សន្យាថាតាមរយៈអាពាហ៍ពិពាហ៍សេឡេស្ទាល ពូជពង្សដ៏អស់កល្បរបស់ពួកគេនឹងរាប់មិនអស់ដូចជាគ្រាប់ខ្សាច់នៅលើឆ្នេរសមុទ្រ ឬដូចជាផ្កាយដ៏ឥតគណនានៅលើមេឃ ។ អេលីយ៉ាស ផ្ដល់នូវការសន្យា—ដែលបានទទួលពីបុរាណដោយ អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប—ហើយមនុស្សនៅសម័យទំនើប និងពូជពង្សគ្រប់ជំនាន់នឹងត្រូវបានប្រទានពរ ។ ហើយយើងកំពុងផ្ដល់ពរជ័យរបស់ អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប ដល់អ្នកដែលនឹងទទួលយកវា » ( The Keys of the Kingdom » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨៣ ទំព័រ ២២ ) ។

- ស្របតាមអែលឌើរ ម៉ាក់ខនឃី តើសេចក្ដីសន្យាអ្វីដែលបានប្រទានដល់ អ័ប្រាហាំ ? ( នៅពេលដែលសិស្សឆ្លើយ សូមសរសេរ *អាពាហ៍ពិពាហ៍សេឡេស្ទាល ពូជពង្សដ៏អស់កល្ប* នៅលើកក្ដារខៀនក្នុងជួរឈរក្រោម « អេលីយ៉ាស » ) ។
- តើពរជ័យនៃអាពាហ៍ពិពាហ៍សេឡេស្ទាល និងពូជពង្សដ៏អស់កល្បមានអត្ថន័យយ៉ាងណាចំពោះអ្នក ? តើហេតុអ្វីបានជាវាសំខាន់ចំពោះអ្នក ?

ដើម្បីជួយសិស្សឲ្យយល់ពីកូនសោដែលបានស្ដារឡើងវិញដោយ អេលីយ៉ា សូមឲ្យសិស្សពីរនាក់អាននូវគោលការណ៍ដូចខាងក្រោម ៖



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានបង្រៀន ៖ « អំណាចនៃការផ្សារភ្ជាប់នេះបានប្រទានដល់ អេលីយ៉ា គឺជាអំណាចដែលចងភ្ជាប់ស្វាមី និង ភរិយា ព្រមទាំងកូនចៅទៅនឹងឪពុកម្ដាយសម្រាប់ពេលនេះ និង ពេលដ៏នៅអស់កល្បជានិច្ច ។ វាគឺជាអំណាចនៃចងភ្ជាប់ ដែលមាននៅក្នុងគ្រប់ពិធីបរិសុទ្ធទាំងអស់នៃដំណឹងល្អ ។. . . ដោយសារតែអំណាចនេះហើយ ទើបគ្រប់ពិធីបរិសុទ្ធទាំងអស់ដែលទាក់ទងនឹងសេចក្ដីសង្គ្រោះត្រូវបានចងភ្ជាប់ ឬ ផ្សារភ្ជាប់ ហើយនោះគឺជាបេសកកម្មរបស់អេលីយ៉ា ដែលត្រូវបង្ហាញខ្លួនមក ហើយស្ដារវាឡើងវិញ » (*Elijah the Prophet and His Mission* ឆ្នាំ ១៩៥៧ ] ទំព័រ ៥ ) ។



អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា ៖ « ក្នុងនាមជាសមាជិកនៃសាសនាចក្រដែលបានស្ដារឡើងវិញរបស់ព្រះគ្រីស្ទ យើងមានទំនួលខុសត្រូវដែលភ្ជាប់ជាមួយសេចក្ដីសញ្ញា ដើម្បីនឹងស្រាវជ្រាវស្វែងរកដូនតារបស់យើង ហើយធ្វើពិធីបរិសុទ្ធនៃការសង្គ្រោះក្នុងដំណឹងល្អដល់ពួកលោក ។. . . « ដោយសារតែមូលហេតុនេះហើយ ទើបយើងធ្វើការស្រាវជ្រាវពង្សប្រវត្តិ កសាងព្រះវិហារបរិសុទ្ធ និង ធ្វើពិធីបរិសុទ្ធជំនួសមនុស្សដែលបានចែកឋានទៅ ។ ដោយសារហេតុផលនេះ អេលីយ៉ា ត្រូវបានបញ្ជូនឲ្យទៅស្ដារអំណាចផ្សារភ្ជាប់ ចំណងនៅលើផែនដី និងនៅស្ថានសួគ៌ » ( The Hearts of the Children Shall Turn » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៥–២៦ ) ។

- ស្របតាមការពន្យល់ទាំងនេះ តើព្រះចេស្ដា ឬសិទ្ធិអំណាចអ្វីដែល អេលីយ៉ាបានស្ដារឡើងវិញ ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរ *អំណាចផ្សារភ្ជាប់ រួមទាំងកិច្ចការព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ* នៅលើក្ដារខៀនក្នុងជួរឈរក្រោម « អេលីយ៉ា » ។ អ្នកអាចនឹងចង់រំឭកសិស្សថា បើគ្មានកូនសោបព្វជិតភាពទាំងនេះទេ « នោះផែនដីទាំងមូល នឹងត្រូវកំទេចចោលសូន្យឈឹង ក្នុងកាល [ព្រះអម្ចាស់] យាងមក » [ គ. និង ស. ២:៣ ] ។
- តើអ្នកត្រូវបានប្រទានពរដោយការស្ដារឡើងវិញ នៃអំណាចផ្សារភ្ជាប់យ៉ាងណាខ្លះ ?

សូមពន្យល់ថា ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានកត់ចំណាំថា ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ « ត្រូវបានកសាងឡើងដើម្បីស្ដារឡើងវិញនូវកូនសោនៃសិទ្ធិអំណាច ។ ក្នុងការទទួលបានកូនសោទាំងនេះ ភាពពេញលេញនៃពិធីបរិសុទ្ធនៃដំណឹងល្អ [ត្រូវបាន] បើកសម្ដែង » ( *Doctrines of Salvation* comp. Bruce R. McConkie, វ៉ុល ៣ [ ឆ្នាំ១៩៥៤–៥៦ ] ២:២៤២ ) ។ ប្រធាននៃសាសនាចក្រ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បន្តអនុវត្តកូនសោនៃបព្វជិតភាពទាំងនេះ រហូតដល់សព្វថ្ងៃនេះ ។

សូមសរសេរសេចក្ដីថ្លែងការណ៍ដែលពុំពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖ *កូនសោនៃកិច្ចការផ្សព្វផ្សាយសាសនា ក្រុមគ្រួសារដ៏អស់កល្ប និងកិច្ចការព្រះវិហារបរិសុទ្ធ ជួយយើងឲ្យ. . .*

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១–១៦ ដោយស្ងាត់ស្ងៀម រកមើលរបៀបដែលពួកគេអាចបំពេញគោលការណ៍នេះ ។

- ស្របតាមខគម្ពីរទាំងនេះ តើហេតុអ្វីបានជាកិច្ចការផ្សព្វផ្សាយសាសនា ក្រុមគ្រួសារអស់កល្ប និងកិច្ចការព្រះវិហារបរិសុទ្ធមានសារៈសំខាន់ ? ( នៅពេលដែលសិស្សឆ្លើយ សូមបំពេញសេចក្ដីថ្លែងនោះនៅលើក្ដារខៀន ។ ចម្លើយរបស់ពួកគេ គួរតែឆ្លុះបញ្ចាំងពីគោលការណ៍ ដូចខាងក្រោម ៖ **កូនសោនៃកិច្ចការផ្សព្វផ្សាយសាសនា ក្រុមគ្រួសារដ៏អស់កល្ប និងកិច្ចការព្រះវិហារបរិសុទ្ធ ជួយយើងឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់**) ។

ដើម្បីជួយសិស្សឲ្យយល់គោលលទ្ធិនេះ សូមចាត់ឲ្យក្រុមនិមួយៗគិតពីសំណួរមួយដូចខាងក្រោម ៖ (១) តើកិច្ចការផ្សព្វផ្សាយសាសនារៀបចំមនុស្សសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់របៀបណា? (២) តើការសន្យានៃអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារដ៏អស់កល្ប រៀបចំមនុស្សសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ? (៣) តើកិច្ចការព្រះវិហារបរិសុទ្ធរៀបចំមនុស្ស សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ? បន្ទាប់ពីផ្ដល់ពេលឲ្យគ្រប់គ្រាន់ហើយ សូមសួរសិស្សម្នាក់ពីក្រុមនិមួយៗ ពីរបៀបដែលគេនឹងឆ្លើយសំណួរ ។

សូមសរសេរ សំណួរដូចខាងក្រោម នៅលើក្ដារខៀន ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

> *តើអ្នកត្រូវបានប្រទានពរ ដោយសារកូនសោបព្វជិតភាពដែលត្រូវបានស្ដារឡើងវិញដោយរបៀបណា ?*
>
> *តើអ្នកអាចធ្វើអ្វីដើម្បីជួយនរណាម្នាក់ ឲ្យទទួលបានពរជ័យតាមរយៈកូនសោដែលបានស្ដារឡើងវិញទាំងនេះ ?*

បន្ទាប់ពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពិភាក្សាពីគំនិតរបស់ពួកគេជាមួយដៃគូ ។ សូមគិតពីការចែកចាយ ពីរបៀបដែលជីវិតអ្នកត្រូវបានប្រទានពរ ដោយសារកូនសោបព្វជិតភាពដែលបានស្ដារឡើងវិញទាំងនេះ ។

មេរៀនទី ១១៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១

## បុព្វកថា

ក្នុងឆ្នាំ ១៨៣៦ សាសនាចក្របានជំពាក់បំណុលយ៉ាងច្រើន ។ ព្យាការី យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀត បានធ្វើដំណើរទៅទីក្រុង សាឡិម រដ្ឋម៉ាស្សាជូសសែត្ស ជាកន្លែងដែលពួកលោកមានសង្ឃឹមថានឹងអាចរកបានថវិកា ដើម្បីសងបំណុលដែលសាសនាចក្រជំពាក់ ។ នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៦ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១១១ ក្នុងនោះ ព្រះអម្ចាស់បានលួងលោមលោក អំពីការព្រួយបារម្ភរបស់លោក ចំពោះបំណុល និងសុខុមាលភាពរបស់ទីក្រុងស៊ីយ៉ូន ។ ព្រះអម្ចាស់ក៏បានប្រទានការណែនាំទាក់ទងនឹងការស្នាក់នៅរបស់សាសនាចក្រក្នុងទីក្រុង សាឡិម ដល់ព្យាការីផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១

*ព្រះអម្ចាស់ប្រទានការលួងលោម និងការដឹកនាំសម្រាប់ យ៉ូសែប ស្ម៊ីធ និងពួកអ្នកដឹកនាំសាសនាចក្រផ្សេងៗទៀត ។*

សូមចាប់ផ្ដើមមេរៀនដោយសូមឲ្យសិស្សសរសេរនូវចម្លើយ ទៅនឹងសំណួរដូចខាងក្រោមនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើអ្វីខ្លះ ដែលនាំឲ្យមានភាពតានតឹង ឬការថប់អារម្មណ៍នៅក្នុងជីវិតរបស់អ្នក ?

អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យ ចែកចាយគំនិតរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ ( សូមរំឭកសិស្សថា គំនិត និងបទពិសោធន៍មួយចំនួន មានភាពផ្ទាល់ខ្លួនពេកដែលពុំគួរចែកចាយឡើយ ) ។

សូមពន្យល់ថា នៅរដូវក្ដៅក្នុងឆ្នាំ ១៨៣៦ យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រផ្សេងទៀត បានជួបប្រទះការព្រួយបារម្ភពីហិរញ្ញវត្ថុរបស់សាសនាចក្រ ។ នៅឆ្នាំមុនៗ សាសនាចក្របានជាប់ជំពាក់បំណុលយ៉ាងច្រើន ដោយសារអ្នកដឹកនាំសាសនាចក្របានធ្វើតាមការបញ្ជារបស់ព្រះអម្ចាស់ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ទិញដីនៅរដ្ឋ អូហៃអូ និងរដ្ឋ មិសសួរី និងជួយឧបត្ថម្ភជំរុំស៊ីយ៉ូន ។ សាសនាចក្រក៏ត្រូវការថវិការ ដើម្បីទិញដីសម្រាប់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលត្រូវបានបង្ខំឲ្យចេញពីផ្ទះសម្បែងរបស់ខ្លួន ។ ក្នុងឆ្នាំ ១៨៣៤ ព្រះអម្ចាស់បានណែនាំ យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀតឲ្យ « បង់បំណុល [របស់ពួកគេ]ឲ្យអស់ » ( គ. និង ស. ១០៤:៧៨ ) ។ ប៉ុន្តែ ការខិតខំរបស់ពួកគេដើម្បីសងបំណុលនោះ ត្រូវបានរាំងស្ទះដោយសារការបាត់បង់ចំណូលផ្នែកពាណិជ្ជកម្មនៅរដ្ឋ មិសសួរី ។ ដូច្នោះហើយ អ្នកដឹកនាំសាសនាចក្រពុំមានថវិការគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការរបស់ម្ចាស់បំណុលឡើយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៨០ ឲ្យឮៗ ។ សូមឲ្យសមាជិកក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានសន្យាថាធ្វើ ដើម្បីជួយអ្នកដឹកនាំសាសនាចក្រដោះស្រាយបញ្ហាបំណុលរបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

សូមពន្យល់ថា ក្នុងឆ្នាំ ១៨៣៦ សមាជិកសាសនាចក្រម្នាក់ ដែលមានឈ្មោះថា វិល្លាម ប៊ឺហ្គេស បានមកដល់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ហើយបានប្រាប់ដល់អ្នកដឹកនាំសាសនាចក្រពីចំនួនទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ដែលមាននៅក្នុងក្រុងសាឡិម រដ្ឋ ម៉ាស្សាជូសសែត្ស ។ លោកបាននិយាយថា លុយត្រូវបានលាក់នៅលើដំបូលផ្ទះមួយ ហើយលោកគឺជាបុគ្គលតែម្នាក់ ដែលនៅរស់ ដែលដឹងពីទីតាំងរបស់លុយនោះ ។

សូមប្រាប់សិស្សថា យ៉ូសែប ស្ម៊ីធ ស៊ីឌនី រិកដុន អូលីវើ ខៅឌើរី និង ហៃរ៉ុម ស្ម៊ីធ បានចាកចេញពីទីក្រុងខឺតឡង់នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៨៣៦ ដើម្បីជួបនឹងម្ចាស់បំណុលនៅរដ្ឋ ញូវយ៉ោក ។ បន្ទាប់ពីស្នាក់នៅរដ្ឋ នូវ យ៉ោក បានពីរបីថ្ងៃ ពួកលោកបាន ធ្វើដំណើរទៅសាឡិម ។ បងប្រុស ប៊ឺហ្គេស បានជួបពួកលោកនៅទីនោះ ប៉ុន្តែលោកបាននិយាយថា ទីក្រុងនោះមានការផ្លាស់ប្ដូរយ៉ាងខ្លាំង ចាប់តាំងពីលោកបានចេញទៅ ហើយលោកមិនអាចចាំទីតាំងផ្ទះដែលមានលុយនោះទេ ។ បងប្រុស ប៊ឺហ្គេសបានចាកចេញយ៉ាងឆាប់រហ័សបន្ទាប់ពីនោះ ។




- តើអ្នកគិតថាអ្នកមានអារម្មណ៍យ៉ាងណា បន្ទាប់ពីធ្វើដំណើរទៅទីក្រុង សាឡិម ដោយសង្ឃឹមថានឹងរកឃើញមធ្យោបាយដើម្បីជួយសងបំណុលរបស់សាសនាចក្រ ហើយបែរជារកមិនឃើញអ្វីដែលអ្នកបានរំពឹងទុកទៅវិញនោះ ? តើអ្នកនឹងធ្វើអ្វីខ្លះ ?

សូមពន្យល់ថា ពួកអ្នកដឹកនាំសាសនាចក្របានចំណាយពេលរកមើលផ្ទះដែលបានរាយការណ៍ថាមានលុយនោះ ។ នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៦ ពេលកំពុងនៅក្នុងទីក្រុង សាឡិមនៅឡើយនោះ យ៉ូសែប ស៊្មីធ បានទទួលវិវរណៈមួយដែលបានបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអារម្មណ៍របស់ព្រះអម្ចាស់អំពីដំណើររបស់បុរសទាំងនេះទៅទីក្រុង សាឡិម ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( នៅពេលដែលសិស្សឆ្លើយ អ្នកអាចពន្យល់ថាពាក្យ *ចំកួត* អាចមានន័យថា « ទន់ខ្សោយ ឬទង្វើមិនទំនងដែលមិនមែនបទឧក្រិដ្ឋធ្ងន់ធ្ងរ ជាទង្វើមិនជាប់លាប់ ដែលមិនសមហេតុផល ឬខ្វះការពិចារណាដិតដល់ » [ Noah Webster, *An American Dictionary of the English Language*, facsimile of the first edition (១៨២៨; repr., ១៩៦៧), "Folly"] ) ។

- តើការធ្វើដំណើរទៅទីក្រុង សាឡិម អាចចាត់ទុកថាជាទង្វើចំកួតដែរឬទេ ?

សូមប្រាប់សិស្សថា ទោះជាការស្វែងរកលុយក្នុងទីក្រុង សាឡិម គ្មានជោគជ័យក៏ដោយ ព្រះអម្ចាស់បានបញ្ជាក់ថា ដំណើរនេះនៅតែអាចមានប្រយោជន៍ដល់នគររបស់ព្រះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ រកមើលអ្វីដែលព្រះអម្ចាស់បានបន្ទូលនៅក្នុងទីក្រុង សាឡិម ។

- តើព្រះអម្ចាស់មានបន្ទូលថា ទ្រង់មានអ្វីនៅទីក្រុងសាឡិម ? ( សម្បត្តិ និងមនុស្សជាច្រើន ) ។

- តើព្រះអម្ចាស់មានបន្ទូលថាទ្រង់នឹងប្រមូលផ្ដុំប្រជាជនទ្រង់មកក្នុងទីក្រុង សាឡិម នៅពេលណា ? ( នៅពេលកំណត់ ) ។

សូមប្រាប់សិស្សថា យ៉ូសែប ស៊្មីធ និងអ្នកដែលធ្វើដំណើរជាមួយលោក បានចំណាយពេលបីបួនសប្ដាហ៍នៅទីក្រុង សាឡិម ហើយពួកគេបានបង្រៀនដំណឹងល្អពេលពួកគេនៅទីនោះ ។ ប្រាំឆ្នាំក្រោយមក អ៊ីរ៉ាស្ទុស ស្នូ ត្រូវបានហៅឲ្យបម្រើបេសកកម្មនៅទីក្រុង សាឡិម ជាកន្លែងដែលគាត់បានរៀបចំសាខាមួយដែលមានសមាជិក ១២០នាក់ឡើង ( សូមមើល *Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទីពីរ [Church Educational System manual, ឆ្នាំ ២០០៣],ទំព័រ ១៧០–៧១ ) ។

- តើយើងអាចរៀនអ្វីពីបទពិសោធន៍របស់ យ៉ូសែប ស៊្មីធ នៅទីក្រុង សាឡិម និងការបង្រៀនរបស់ព្រះអម្ចាស់ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:១–២ ? ( សិស្សអាចផ្ដល់ចម្លើយល្អផ្សេងៗគ្នា ។ ជាផ្នែកមួយក្នុងការពិភាក្សានេះ សូមសរសេរគោលការណ៍ខាងក្រោម នៅលើក្ដារខៀន ៖ **ព្រះអម្ចាស់អាចនាំមកនូវសេចក្ដីល្អពីការខិតខំដ៏ស្មោះត្រង់របស់យើង**) ។

- តើព្រះអម្ចាស់អាចនាំមកនូវសេចក្ដីល្អពីការខិតខំរបស់យើង ទោះដើមឡើយជាកំហុស ដោយរបៀបណា ? ( ចម្លើយមួយអាចនិយាយបានថា ទ្រង់អាចជួយយើងឲ្យរៀនពីបទពិសោធន៍របស់យើង ) ។

- តើវាមានឥទ្ធិពលធ្វើឲ្យអ្នកដឹងថា ព្រះអម្ចាស់អាចនាំមកនូវសេចក្ដីល្អពីការខិតខំដ៏ស្មោះត្រង់របស់អ្នក ដោយរបៀបណា ?

សូមពន្យល់ថា ព្រះអម្ចាស់បានផ្ដល់សេចក្ដីណែនាំដល់ យ៉ូសែប ស្ម៊ីធ និងក្រុមរបស់លោក ដើម្បីជួយពួកលោកឲ្យសម្រេចបាននូវសេចក្ដីល្អពេលពួកគេនៅក្នុងទីក្រុង សាឡិម ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:៥–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យ យ៉ូសែប ស្ម៊ីធ និងដៃគូរបស់លោកធ្វើ ។

- តើព្រះអម្ចាស់បានលួងលោម យ៉ូសែប ស្ម៊ីធ និងក្រុមរបស់លោកទាក់ទងនឹងបំណុលរបស់សាសនាចក្រ និងស្ថានភាពរបស់ទីក្រុងស៊ីយ៉ូន យ៉ាងដូចម្ដេច ?

- ស្របតាម ខ ៨តើ យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀតដឹងពីកន្លែងដែលត្រូវនៅ កាលពួកគេនៅក្នុងទីក្រុងសាឡិម យ៉ាងដូចម្ដេច ?

- តើសេចក្ដីពិតអ្វីខ្លះដែលយើងអាចរៀន ពីការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង ខ ៨ ? ( នៅពេលសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **យើងអាចទទួលបានការដឹកនាំរបស់ព្រះអម្ចាស់តាមរយៈសេចក្ដីសុខសាន្ត និងព្រះចេស្ដានៃព្រះវិញ្ញាណរបស់ទ្រង់**) ។

- តើគោលការណ៍នេះ ជួយអ្នកឲ្យប្រឈមមុខនឹងការព្រួយបារម្ភ និងបញ្ហាដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:៩–១០ ដោយស្ងាត់ស្ងៀម ហើយរកមើលកិច្ចការបន្ថែមដែលព្រះអម្ចាស់បានបញ្ជាឲ្យ យ៉ូសែប ស្ម៊ីធ និងក្រុមរបស់លោកបំពេញពេលពួកគេនៅក្នុងទីក្រុង សាឡិម ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។

សូមប្រាប់សិស្សថា យ៉ូសែប ស្ម៊ីធ និងបុរសដទៃទៀត បានធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់ ឲ្យ « ខំសាកសួរពីបណ្ដាជនពីបុរាណកាល និងពួកអ្នកដែលរកឃើញទីក្រុងនេះ » ( គ. និង ស. ១១១:៩ ) ។ ពួកគេបានទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រពេលពួកគេនៅក្នុងទីក្រុង សាឡិម ។ ពីការទស្សនកិច្ចនេះ ពួកគេបានរៀនថា ប្រជាជនមួយចំនួននៅទីក្រុងសាឡិម រដ្ឋម៉ាស្សាជូសសែត្ស និងនៅជុំវិញតំបន់ នូវ អ៊ីងលែន ត្រូវបានប្រហារ និងសម្លាប់ចោលដោយសារតែការមិនអត់ឱនខាងសាសនា និងការចង្អៀតចង្អល់ ។ ( សូមមើល *History of the Church* ២:៤៦៤–៦៥ ) ។ ព្រឹត្តិការណ៍ទាំងនេះ បាននាំឲ្យ យ៉ូសែប ស្ម៊ីធ សរសេរនៅក្នុងប្រវត្តិថា « តើពេលណាទៅ ដែលមនុស្សឈប់ធ្វើសង្គ្រាមនឹងគ្នា ហើយអនុវត្តសិទ្ធិសេរីភាពដ៏ពិសិដ្ឋ ដើម្បីថ្វាយបង្គំព្រះរបស់ខ្លួន ស្របតាមសតិសម្បជញ្ញៈវិញ ? » ( នៅក្នុង *History of the Church* ២:៤៦៥ ) ។ ក្រោយមក ព្យាការីបានរំឭកឡើងវិញនូវសារៈសំខាន់នៃការអនុញ្ញាតឲ្យមនុស្សទាំងអស់អនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនខាងសាសនា ( សូមមើល មាត្រានៃសេចក្ដីជំនឿ ១:១១ ) ។ ទោះជា យ៉ូសែប ស្ម៊ីធ និងក្រុមរបស់លោកមិនទទួលបានលុយដែលពួកលោកបានគិតថា ពួកគេអាចរកឃើញនៅក្នុងទីក្រុង សាឡិមក៏ ពួកលោកទទួលបានសម្បត្តិផ្សេងទៀតពីដំណើរនេះ រួមទាំងសម្បត្តិនៃចំណេះដឹងផងដែរ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការការទូន្មានចុងក្រោយរបស់ព្រះអម្ចាស់នៅក្នុងវិវរណៈនេះ ។ សូមពន្យល់ថា ពាក្យ *រៀបចំ* ដែលប្រើនៅក្នុង ខ ១១ មានន័យថាការចាត់ចែង ។

- តើអ្នកអាចនិយាយឡើងវិញនូវការទូន្មានរបស់ព្រះអម្ចាស់នៅក្នុង ខ ១១ យ៉ាងដូចម្ដេច ? ( ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេយល់ពីគោលការណ៍ដូចខាងក្រោម ៖ **បើយើងឆ្លាតវៃ ហើយចៀសវាងអំពើបាប នោះព្រះអម្ចាស់នឹងរៀបចំអ្វីគ្រប់យ៉ាង សម្រាប់សេចក្ដីល្អរបស់យើង ។** អ្នកអាចពន្យល់ថា ទោះជាពេលដែលមនុស្សសុចរិតជួបប្រទះការសាកល្បង ព្រះអម្ចាស់ « រៀបចំអ្វីៗ [ទាំងនេះ] សម្រាប់សេចក្ដីល្អ [របស់ពួកគេ] » ) ។

- តើជម្រើសឆ្លាតវៃអ្វីខ្លះ ដែលយើងអាចធ្វើបាន ? ( សិស្សអាចឆ្លើយនូវចម្លើយផ្សេងៗ រួមទាំងការព្យាយាមធ្វើតាមព្រះបញ្ញត្តិទាំងឡាយ ) ។

- តើអ្នកគិតថា ព្រះអម្ចាស់ « នឹងរៀបចំអ្វីៗទាំងអស់ សម្រាប់សេចក្ដីល្អ [របស់យើង] » មានន័យយ៉ាងណា ?

- តើអ្នកបានឃើញគំរូនៃគោលការណ៍នេះនៅពេលណា ?

*អនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ*

ទោះជាការអនុវត្តដ៏ណឹងល្អផ្ទាល់ខ្លួន ត្រូវបានធ្វើឡើងនៅក្រៅថ្នាក់រៀនភាគច្រើនក្ដី ក៏អ្នកអាចផ្ដល់ឲ្យសិស្សនូវឱកាសដើម្បីគិតពីស្ថានភាព ហើយពិចារណាពីវិធីជាក់លាក់ណាមួយ ដែលពួកគេអាចអនុវត្តគោលការណ៍ និងគោលលទ្ធិទាំងឡាយ ។ នៅពេលពួកគេគិតពីគោលការណ៍មួយ ហើយពិចារណាពីរបៀបធ្វើតាមគោលការណ៍ខាងក្រោមនៅក្នុងជីវិតរបស់ពួកគេ នោះព្រះវិញ្ញាណបរិសុទ្ធអាចបំផុសគំនិតពួកគេម្នាក់ៗ ។

សូមអញ្ជើញសិស្សឲ្យពិនិត្យមើលចម្លើយដែលពួកគេបានសរសេរ ឆ្លើយតបទៅនឹងចម្លើយដែលអ្នកបានសួរនៅពេលចាប់ផ្ដើមរៀន ។ សូមឲ្យពួកគេ គិតពីអ្វីដែលពួកគេបានរៀនពីការសិក្សាខគម្ពីររបស់ពួកគេនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១ ដែលអាចជួយពួកគេជាមួយនឹងបញ្ហាដែលពួកគេបានជួបប្រទះ ។ សូមអញ្ជើញពួកគេឲ្យកត់ត្រាគំនិតរបស់ពួកគេចូលក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកពីគោលការណ៍ ដែលអ្នកបានពិភាក្សា ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគោលការណ៍ទាំងនេះ ។

មេរៀនទី ១២០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២

## បុព្វកថា

នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៨៣៧ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ សម្រាប់ ថូម៉ាស ប៊ី ម៉ាស្ស ដែលក្រោយមកគឺជាប្រធាន កូរ៉ុមនៃពួកសាវកទាំងដប់ពីរនាក់ ។ ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ព្រះអម្ចាស់បានប្រទានការទូន្មានទាក់ទងនឹងទំនួលខុសត្រូវនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១–១៣

*ព្រះអម្ចាស់ប្រទានការទូន្មាន និងសន្យាថាប្រទានពរជ័យដល់ ថូម៉ាស ប៊ី ម៉ាស*

សូមសរសេរពាក្យដូចខាងក្រោមនៅលើក្ដារខៀន ៖ *ខឹង ខកចិត្ត អាក់អន់ចិត្ត ច្រណែន* ។ សូមអញ្ជើញសិស្សឲ្យគិតអំពីពេលដែលពួកគេអាចមានបទពិសោធន៍ទទួលអារម្មណ៍ទាំងនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកស្ថានភាពដែល ថូម៉ាស ប៊ី ម៉ាស បានជួបប្រទះដែលបាននាំលោកឲ្យទទួលបទពិសោធន៍នៃអារម្មណ៍ទាំងនោះ ដែលបានសរសេរនៅលើក្ដារខៀន ។

មិនយូរប៉ុន្មានបន្ទាប់ពី ថូម៉ាស ប៊ី ម៉ាស ត្រូវបានហៅជាសាវកក្នុងឆ្នាំ ១៨៣៥ លោកត្រូវបានតែងតាំងជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ នៅនិទាឃរដូវឆ្នាំ ១៨៣៧ ប្រធាន ម៉ាស បានដឹងថាមានសាវកម្នាក់ក្នុងចំណោមសាវកដប់ពីរនាក់ គឺអែលឌើរ បាលី ភី ប្រាត្ត បានរៀបចំចេញបេសកកម្មទៅប្រទេសអង់គ្លេសដោយគ្មានការដឹកនាំពីប្រធាន ម៉ាស ។ ប្រធាន ម៉ាស ដែលពេលនោះនៅរដ្ឋ មិសសួរី បានសរសេរទៅអែលឌើរ ប្រាត្ត និងសមាជិកដទៃនៃពួកដប់ពីរនាក់ ហើយបានអញ្ជើញពួកគេមកជួបលោកនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៨៣៧ ដូច្នេះពួកគេអាចរួបរួមតែមួយក្នុងការរៀបចំសម្រាប់បេសកកម្ម ។ ប៉ុន្តែ មួយខែមុនការប្រជុំនោះកើតឡើង សមាជិកនៃពួកសាវកពីរនាក់ទៀតគឺ អែលឌើរ ហ៊ីប៊ើ សី ឃីមបឹល និងអូរសុន ហៃឌ បានចាកចេញទៅប្រទេស អង់គ្លេសបន្ទាប់ពីបានទទួលការហៅបម្រើពីព្យាការី យ៉ូសែប ស្ម៊ីធ ។ ប្រធាន ម៉ាស្ស មានការអន់ចិត្តដែលសមាជិកនៃពួកសាវកដប់ពីរនាក់បានចេញទៅផ្សាយដំណឹងល្អនៅប្រទេស អង់គ្លេស ដោយគ្មានការចូលរួមពីលោក ។

- នៅក្នុងស្ថានភាពនេះ តើប្រធាន ម៉ាស្ស អាចធ្វើអ្វីបានដើម្បីចៀសវាងពីអារម្មណ៍ដែលបានសរសេរនៅលើក្ដារខៀន ? តើគ្រោះថ្នាក់អ្វីខ្លះអាចកើតឡើងនៅពេលយើងអនុញ្ញាតឲ្យអារម្មណ៍បែបនោះគ្រប់គ្រងគំនិត និងទង្វើរបស់យើង ?

សូមពន្យល់ថាប្រធាន ម៉ាស្ស បានចែកចាយការព្រួយបារម្ភរបស់លោកជាមួយព្យាការី យ៉ូសែប ស្ម៊ីធ ហើយសូមការប្រឹក្សា ។ ក្នុងការឆ្លើយតប ព្រះអម្ចាស់បានប្រទានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១–៣ ឲ្យឮៗ ។ សូមសូមឲ្យសិស្សពាក់កណ្ដាលថ្នាក់រកមើលការព្រមាន ដែលព្រះអម្ចាស់បានប្រទានដល់ប្រធាន ថូម៉ាស ប៊ី ម៉ាស្ស ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់ទៀតរកមើលអ្វីដែលព្រះអម្ចាស់បានថាប្រធាន ម៉ាស្ស បានធ្វើ ។ ( មុនពេលសិស្សអាន អ្នកអាចនឹងចង់ពន្យល់ថាពាក្យ *បន្ទាបខ្លួន* នៅក្នុង ខ ៣ មានន័យថា ប្រធាន ម៉ាស បានបន្ទាបខ្លួនលោក ) ។

- តើព្រះអម្ចាស់បានប្រទានការព្រមានអ្វីដល់ ថូម៉ាស ប៊ី ម៉ាស្ស ?

- តើរឿងល្អអ្វីដែលព្រះអម្ចាស់មានបន្ទូលថាប្រធាន ម៉ាស្ស បានធ្វើ ?

សូមពន្យល់ថា ព្រះអម្ចាស់បានប្រទានការទូន្មានបន្ថែមដល់ប្រធាន ម៉ាស្ស ហើយបានបើកសម្ដែងពីពរជ័យមួយចំនួនដែលប្រធាន ម៉ាស្ស អាចទទួលបានសម្រាប់ការស្មោះត្រង់របស់លោក ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮៗពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:៤–១០ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការសន្យាដែលព្រះអម្ចាស់បានប្រទានដល់ ថូម៉ាស ប៊ី ម៉ាស្ស ។ សូមពិចារណាអញ្ជើញសិស្សឲ្យសរសេរការសន្យាទាំងនេះ នៅលើក្ដារខៀនពេលដែលពួកគេរកឃើញ ។

- តើអ្នកអាចនិយាយឡើងវិញនូវការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង ខ ១០ ដោយពាក្យសម្ដីផ្ទាល់របស់អ្នកយ៉ាងដូចម្ដេច ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួររកឃើញនូវគោលការណ៍ដូចខាងក្រោម ៖ **បើយើងបន្ទាបខ្លួន នោះព្រះអម្ចាស់នឹងដឹកនាំយើង ហើយប្រទានចម្លើយចំពោះការអធិស្ឋានរបស់យើង** ) ។

- តើហេតុអ្វីបានជាអ្នកគិតថា ការបន្ទាបខ្លួនអាចជួយយើងឲ្យទទួលបានការដឹកនាំពីព្រះអម្ចាស់ ?

- តើនៅពេលណាដែលអ្នកបានមានអារម្មណ៍ថាត្រូវបានដឹកនាំ ដោយព្រះអម្ចាស់បន្ទាប់ពីអ្នកបន្ទាបខ្លួននោះ ?

សូមពន្យល់ថា ក្នុងខែ កក្កដា ឆ្នាំ ១៨៣៧ នៅពេលព្រះអម្ចាស់បានប្រទានវិវរណៈនេះ សាសនាចក្រកំពុងជួបប្រទះការបែកបាក់សាមគ្គី ការឈ្លោះប្រកែកគ្នា និងការក្បត់សាសនា ។ ភាពអំនួត និងភាពលោភលន់ បាននាំសមាជិកសាសនាចក្រមួយចំនួន រិះគន់ព្យាការី យ៉ូសែប ស្ម៊ីធ ដោយចំហរ ហើយមានមន្ទិលពីសិទ្ធិអំណាចរបស់លោក ។ សមាជិកសាសនាចក្រមួយចំនួនរួមទាំងពួកសាវកដប់ពីរនាក់មួយចំនួន បានព្យាយាមដក យ៉ូសែប ស្ម៊ីធ ចេញពីប្រធានសាសនាចក្រ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១១–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យប្រធាន ម៉ាស្ស ធ្វើដើម្បីជួយសមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ដែលកំពុងជួបបញ្ហា ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១៤–៣៤

*ព្រះអម្ចាស់បង្រៀន ថូម៉ាស ប៊ី ម៉ាស្ស ពីកាតព្វកិច្ចរបស់ពួកសាវកដប់ពីរនាក់*

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានប្រទានឲ្យប្រធាន ថូម៉ាស ប៊ី ម៉ាស្ស នូវទំនួលខុសត្រូវសំខាន់ៗជាច្រើន ។ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើអ្វីទៅដែលអាចជួយអ្នកឲ្យមានការបន្ទាបខ្លួន នៅពេលអ្នកទទួលបានទំនួលខុសត្រូវ ឬការទទួលស្គាល់ដ៏សំខាន់នោះ ?* សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីសំណួរនេះ។

សូមពន្យល់ថា ព្រះអម្ចាស់បានជួយ ថូម៉ាស ប៊ី ម៉ាស្ស ឲ្យទទួលស្គាល់សារៈសំខាន់នៃទំនួលខុសត្រូវរបស់លោកជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ខណៈបន្តរំឭកលោកឲ្យបន្ទាបខ្លួន ។ សូមចម្លង តារាង នៅលើក្ដារខៀន ឬរៀបចំវាជាក្រដាសចែក ។ សូមឲ្យសិស្សអានខគម្ពីរដែលបានចាត់ឲ្យ ហើយបំពេញតារាងជាដៃគូ ( ឬបំពេញវាជាមួយសិស្សក្នុងថ្នាក់ ) ។

| | គ. និង ស. ១១២:១៤–២២ ២៨–៣៣ |
|---|---|
| ឃ្លាទាំងនេះ សង្កត់ធ្ងន់លើសារៈសំខាន់នៃទំនួលខុសត្រូវរបស់ប្រធាន ម៉ាស្ស និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ | |
| ឃ្លាដែលរំឭកប្រធាន ម៉ាស្ស និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ពីតម្រូវការឲ្យមានការបន្ទាបខ្លួន ។ | |

ក្រោយពីសិស្សបានមានពេលគ្រប់គ្រាន់ដើម្បីបំពេញតារាងនេះហើយ សូមសួរសំណួរខាងក្រោម ៖

- តើឃ្លាអ្វីដែលអ្នករកឃើញថា គួសបញ្ជាក់ពីសារៈសំខាន់នៃទំនួលខុសត្រូវរបស់ប្រធាន ម៉ាស្ស ។

- ស្របតាម ខ ១៦–១៧ តើកូនសោរអ្វីដែលត្រូវបានកាន់ដោយប្រធាននៃកូរ៉ុមសាវកដប់ពីរនាក់ ? ( សិស្សអាចប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួររកឃើញសេចក្ដីពិតដូចខាងក្រោម ៖ **ប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ កាន់កូនសោរដើម្បីដឹកនាំកិច្ចការរបស់ពួកដប់ពីរនាក់ ក្នុងការប្រកាសដំណឹងល្អដល់គ្រប់ប្រជាជាតិ** ។)

- ស្របតាម ខ ៣០–៣២ តើព្រះអម្ចាស់បង្រៀនអ្វីដល់ ថូម៉ាស ប៊ី ម៉ាស្ស អំពីកូនសោបព្វជិតភាពដែលលោកកាន់នោះ ? ( សិស្សអាចបាប្រប់ពីគោលការណ៍ផ្សេងៗ ប៉ុន្តែសូមប្រាកដថាពួកគេប្រាប់ពីសេចក្ដីពិតដូចខាងក្រោម ៖ **កូនសោបព្វជិតភាពដែលត្រូវបានស្ដារឡើងវិញជាលើកចុងក្រោយក្នុង** ការកាន់កាប់ត្រួតត្រា **នៅពេលពេញកំណត់** ។ អ្នកអាចរំឭកឡើងវិញយ៉ាងសង្ខេបពី អត្ថន័យនៃពាក្យ *ការកាន់កាប់ត្រួតត្រា* [ សូមមើល Bible Dictionary, « Dispensations » ] ) ។

- តើឃ្លាអ្វីដែលអ្នករកឃើញ ហើយរំឭកអ្នកថាប្រធាន ថូម៉ាស ប៊ី ម៉ាស្ស ត្រូវបន្ទាបខ្លួននោះ ?

- តើព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង ខ ១៥ និង ខ ៣០ បង្រៀនអ្វីខ្លះពីទំនាក់ទំនងរវាងទំនួលខុសត្រូវរបស់ប្រធាន ថូម៉ាស ប៊ី ម៉ាស្ស ជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងទំនួលខុសត្រូវរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ជាប្រធាននៃសាសនាចក្រ ?

ដើម្បីជួយសិស្សឲ្យឃើញថា ថូម៉ាស ប៊ី ម៉ាស្ស មានបញ្ហាក្នុងការធ្វើតាមការទូន្មានដែលលោកបានទទួលនៅក្នុងវិវរណៈនេះ សូមអញ្ជើញសិស្សឲ្យអានឃ្លាដូចខាងក្រោម ៖

### *សូមជួយសិស្សឲ្យយល់អំពីគោលលទ្ធិគ្រឹះ*

សិស្សនឹងរៀននូវគោលលទ្ធិគ្រឹះ នៅពេលពួកគេសិក្សា និងពិភាក្សាអំពីបទគម្ពីរជារៀងរាល់ថ្ងៃ និងនៅពេលពួកគេទន្ទេញចាំបទគម្ពីរគន្លឹះ ។ អ្នកពុំគួរបង្វែរការចាប់អារម្មណ៍ចេញពីការសិក្សាបទគម្ពីរតាមលំដាប់លំដោយ ទៅផ្ដោតលើគោលលទ្ធិគ្រឹះនោះទេ ។ ផ្ទុយទៅវិញ អ្នកគួរយកចិត្តទុកដាក់ទៅលើគោលលទ្ធិទាំងឡាយនៅពេលវាប្រាកដឡើងនៅក្នុងវគ្គសិក្សា ។ ឧទាហរណ៍ នៅក្នុងមេរៀននេះ អ្នកអាចគូសបញ្ជាក់អំពីគោលលទ្ធិនៃការកាន់កាប់ត្រួតត្រាទាក់ទងទៅនឹងអ្វីដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ។

មិនយូរប៉ុន្មានបន្ទាប់ពីវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ត្រូវបានប្រទាន ថូម៉ាស ប៊ី ម៉ាស្ស បានប្រាប់ វីឡេត គិមប៊ឹល ថា អែលឌើរ ហ៊ីប៊ើ ស៊ី គិមប៊ឹល ជាស្វាមីរបស់គាត់ នឹងគ្មានប្រសិទ្ធិភាពក្នុងបេសកកម្មរបស់គាត់នៅប្រទេសអង់គ្លេសឡើយ ។ ពិតណាស់ ប្រធាន ម៉ាស្ស មានអារម្មណ៍ថា ដោយសារការប្រកាសដំណឹងល្អនៅបរទេស គឺជាទំនួលខុសត្រូវរបស់លោក នោះឱកាសផ្សព្វផ្សាយសាសនានៅប្រទេសអង់គ្លេស នឹងមិនអាចបើកទាល់តែលោកបញ្ជូននរណាម្នាក់ដោយផ្ទាល់ ឬលោកទៅដោយខ្លួនឯង ។

- តើព្រឹត្តិការណ៍នេះ បង្ហាញថាប្រធាន ម៉ាស្ស អាចមានបញ្ហាក្នុងការបន្ទាបខ្លួន យ៉ាងដូចម្ដេច ?

សូមយោងទៅលើសំណួរ ដែលអ្នកបានសរសេរនៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរ ។ ក្នុងផ្នែកនៃការពិភាក្សានេះ សូមគិតពីការប្រើសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ នៃគណៈប្រធានទីមួយ ៖



« យើងមិនរកឃើញការបន្ទាបខ្លួនដោយ *ការ* បន្ទាបបន្ថោកខ្លួនយើងនោះឡើយ តែយើងរកឃើញការបន្ទាបខ្លួន ដោយការ *មិនផ្ដោតលើ* ខ្លួនយើង ។ វាកើតឡើងពេលយើងធ្វើការដោយមាន អាកប្បកិរិយានៃការបម្រើព្រះ និងបងប្អូនយើង ។

«. . . នៅពេលដែលយើងឈប់ឈ្លក់វង្វេងនឹងខ្លួនយើង ហើយភ្លេចខ្លួនយើងក្នុងការបម្រើ នោះភាពអំណួតរបស់យើងនឹងថយចុះ ហើយចាប់ផ្ដើមបាត់បង់ទៅ ( Pride and the Priesthood » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៥៨ ) ។

សូមរំឭកសិស្សពីពរជ័យ ដែលព្រះអម្ចាស់បានសន្យាដល់ប្រធាន ម៉ាស្ស ( សូមមើល គ. និង ស. ១១២:៤–១០ ) ។ អ្នកអាចឲ្យសិស្សសរសេរពរជ័យទាំងនេះនៅលើក្ដារខៀនជាមុន។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីអ្វីដែលប្រធាន ម៉ាស្ស ត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងនេះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ បន្ទាប់មក សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **យើងត្រូវតែស្មោះត្រង់ ដើម្បីទទួលបានពរជ័យសន្យារបស់ព្រះអម្ចាស់ ។**

ដើម្បីជួយសិស្សឲ្យយល់គោលការណ៍នេះ សូមអាន ឬសង្ខេបរឿងនៃការធ្លាក់ចេញពីសាសនាចក្រ និងការត្រឡប់មកវិញរបស់ថូម៉ាស ប៊ី ម៉ាស្ស ៖

មានពេលមួយ ប្រធាន ម៉ាស្ស បានធ្វើតាមការទូន្មានដែលលោកបានទទួល ។ គាត់បានខិតខំពង្រឹងសាសនាចក្រ ហើយគាំទ្រ យ៉ូសែប ស្ម៊ីធ ។ ទោះជាយ៉ាងណាក៏ដោយ នៅមិនយូរប៉ុន្មានគាត់បានត្រឡប់ជាមានអារម្មណ៍ជំទាស់នឹងរបៀបដែលសាសនាចក្រត្រូវបានដឹកនាំទៅវិញ ។ អារម្មណ៍ទាំងនេះបូកផ្សំជាមួយនឹងកង្វល់អំពីទំនាស់រវាងសមាជិកសាសនាចក្រដែលពុំគោរពប្រតិបត្តិ និង ឈ្លានពាន ព្រមទាំងអ្នកជិតខាងរបស់ខ្លួននៅរដ្ឋ មិសសួរី ។ ក្នុងខែ កញ្ញា ឆ្នាំ ១៨៣៨ កាលគាត់ត្រូវបានជុំជិតដោយគំនិតក្បត់សាសនា នោះភរិយារបស់គាត់ អេលីស្សាបែត បានពាក់ព័ន្ធនឹងជម្លោះមួយ ។ គាត់ និង ស្ត្រីម្នាក់ទៀត ទាំងពីរនាក់គឺជាសមាជិកសាសនាចក្រ បានព្រមព្រៀងគ្នាដោះដូរទឹកដោះគោជាប្រចាំ ដើម្បីមានទឹកដោះគោគ្រប់គ្រាន់ក្នុងការធ្វើឈីស ប៉ុន្តែបងស្រី ម៉ាស្ស បានប្ដឹងគាត់ថាល្មើសនឹងកិច្ចព្រមព្រៀង ដោយបានទុកចំណែកទឹកដោះគោដែលមានសារធាតុខ្លាញ់ទឹកដោះច្រើន ។ បញ្ហានេះត្រូវបាននាំទៅដល់ថ្នាក់ដឹកនាំសាសនាចក្រ ជាច្រើនដង ។ វាក៏ត្រូវបាននាំទៅដល់គណៈប្រធានទីមួយផងដែរ ។ រាល់ពេល វាត្រូវបានសម្រេចថា បងស្រី ម៉ាស្ស ពិតជាខុសមែន ។ ប្រធាន ម៉ាស្ស មានការខឹងសម្បារ និងមិនពេញចិត្តនឹងការសម្រេចចិត្តទាំងនេះ ( សូមមើល George A. Smith, « Discourse » *Deseret News,* ខែ មេសា ឆ្នាំ ១៨៥៦ ទំព័រ ៤៤ ) ។ បញ្ហានេះ មិនបាននាំលោកឲ្យចាកចេញពីសាសនាចក្រទេ ប៉ុន្តែវាគរបន្ថែមលើការខកចិត្តដទៃទៀត ។ លោកទិតៀនដល់អ្នកដឹកនាំសាសនាចក្រកាន់តែខ្លាំង ហើយនៅទីបំផុតលោកបានប្រឆាំងនឹងពួកបរិសុទ្ធ ។ ក្រោយមកលោកបានរំឭកឡើងវិញថា « ខ្ញុំមានការច្រណែននឹងព្យាការី . . . ហើយមើលរំលងអ្វីគ្រប់យ៉ាងដែលត្រឹមត្រូវ ហើយចំណាយពេលទាំងអស់របស់ខ្ញុំផ្ដោតលើរឿងអាក្រក់ៗទៅវិញ » ( « Remarks » *Deseret News,* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៨៥៧ ទំព័រ ២២០ ) ។

ក្នុងខែ តុលា ឆ្នាំ ១៨៣៨ ប្រធាន ថូម៉ាស ប៊ី ម៉ាស្ស បានស្បថចំពោះមុខអង្គចៅក្រមថា យ៉ូសែប ស្ម៊ីធ និងពួកបរិសុទ្ធថ្ងៃចុងក្រោយជាសត្រូវរបស់រដ្ឋ មិសសួរី ។ លិខិតថ្លែងសច្ចានេះ បានរួមចំណែកដល់ការចេញបញ្ជាពីរដ្ឋាភិបាលឲ្យមានការប្រល័យដែលធ្វើឲ្យមានពួកបរិសុទ្ធច្រើនជាង ១៥,០០០នាក់ត្រូវបណ្ដេញចេញពីផ្ទះរបស់ខ្លួននៅរដ្ឋ មិសសួរី ។

ដប់ប្រាំបីឆ្នាំបន្ទាប់ពី ថូម៉ាស ប៊ី ម៉ាស្ស បានចាកចេញពីសាសនាចក្រ លោកបានសរសេរសំបុត្រមួយច្បាប់ដោយបន្ទាបខ្លួន ទៅកាន់ប្រធាន ហ៊ីប៊ើ ស៊ី គិមប៊ឹល នៃគណៈប្រធានទីមួយ សូមការអភ័យទោស និងសុំអនុញ្ញាតដើម្បីចូលក្នុងសាសនាចក្រវិញ ។ លោកបានពន្យល់ថា លោកបានរៀនពីកំហុសខ្លួនឯងថា ៖ « ព្រះអម្ចាស់អាចធ្វើកិច្ចការទោះបីជាគ្មានខ្ញុំ ហើយទ្រង់មិនបាត់បង់អ្វីដោយការធ្លាក់ចេញរបស់ខ្ញុំដែរ ប៉ុន្តែ តើខ្ញុំបានបាត់បង់អ្វីខ្លះទៅ ? » ! ( Thomas B. Marsh letter to Heber C. Kimball, ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៨៥៧, Brigham Young Collection, Church History Library,

as quoted in Kay Darowski, « The Faith and Fall of Thomas Marsh » Revelations in Context, history.lds.org ) ។

សូមយោងទៅលើគោលការណ៍នៅលើក្ដារខៀន ។ សូមពន្យល់ថា ថូម៉ាស ប៊ី ម៉ាស្ស បានស្វាគមន៍ឲ្យត្រឡប់មកជាសមាជិកសាសនាចក្រវិញ ។ ប៉ុន្តែ ដោយសារលោកមិនបានធ្វើតាមការទូន្មានឲ្យបន្ទាបខ្លួន និងស្មោះត្រង់ក្នុងការធ្វើជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នោះលោកមិនបានទទួលពរជ័យដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:៤–១០ ទេ ។

សូមឲ្យសិស្សពីរបីនាក់សង្ខេបពីអ្វីដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមអញ្ជើញសិស្សឲ្យជ្រើសរើសវិធីមួយដែលពួកគេអាចមានការបន្ទាបខ្លួន និងមានភាពស្មោះត្រង់កាន់តែខ្លាំង ហើយសរសេរគោលដៅមួយដើម្បីធ្វើតាម ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩–១១២ ( មេរៀនទី ២៤ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀននៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩–១១២ ( មេរៀនទី ២៤ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩)

នៅពេលសិស្សបានសិក្សាការអធិស្ឋានឧទ្ទិសឆ្លងនៃព្រះវិហារបរិសុទ្ធខឺតឡង់ នោះពួកគេបានឃើញហេតុផលមួយចំនួនដែលយើងសាងសង់ព្រះវិហារបរិសុទ្ធ ។ ពួកគេបានរៀនថា ប្រសិនបើយើងថ្វាយបង្គំដោយភាពសក្ដិសមនៅក្នុងព្រះវិហារបរិសុទ្ធ នោះព្រះអម្ចាស់នឹងបង្ហាញអង្គទ្រង់ដល់ពួកយើង បំពាក់យើងដោយព្រះចេស្ដា និង ជំនួយរបស់ទ្រង់ ព្រមទាំងប្រទានពរដល់យើងដូច្នេះអំពើទុច្ចរិតនឹងពុំអាចឈ្នះលើយើងបានឡើយ ។ បទពិសោធន៍របស់ពួកបរិសុទ្ធនៅឯការឧទ្ទិសនៃព្រះវិហារបរិសុទ្ធខឺតឡង់ គឺវាស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងអ្វី ដែលបានកើតឡើងចំពោះសាវកពីបុរាណនៅបុណ្យថ្ងៃទីហាសិប ( សូមមើល កិច្ចការ ២) ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០)

ផ្នែកនៃពរជ័យដែលបានទទួលដោយពួកបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ នោះព្រះយេស៊ូវគ្រីស្ទបានបង្ហាញព្រះកាយទ្រង់ដល់យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ។ សិស្សបានរៀនថាប្រសិនបើយើងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយរក្សាព្រះដំណាក់របស់ទ្រង់ឲ្យបានបរិសុទ្ធ នោះទ្រង់នឹងបង្ហាញអង្គទ្រង់ដល់ពួកយើងនៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់ ។ សិស្សក៏បានរៀនផងដែរថាម៉ូសេ អេលីយ៉ាស និង អេលីយ៉ា បានបង្ហាញខ្លួននៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ហើយបានប្រគល់កូនសោនៃបព្វជិតភាពឲ្យព្យាការី យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ។ សិស្សបានរៀនថា កូនសោនៃកិច្ចការផ្សព្វផ្សាយសាសនា ក្រុមគ្រួសារដ៏អស់កល្ប និង កិច្ចការព្រះវិហារបរិសុទ្ធ រៀបចំខ្លួនយើងសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១)

ចេញពីវិវរណៈដែលបានប្រទានឲ្យព្យាការីយ៉ូសែប ស៊្មីធនៅក្នុងក្រុងសាលិម រដ្ឋម៉ាស្សាឈូសេត នោះសិស្សបានរៀនថាព្រះអម្ចាស់អាចនាំមកនូវសេចក្ដីល្អសម្រាប់កិច្ចខិតខំដ៏ស្មោះត្រង់របស់យើង ។ ពួកគេក៏បានរៀនផងដែរថា យើងអាចទទួលបានការណែនាំរបស់ព្រះអម្ចាស់តាមរយៈសេចក្ដីសុខសាន្ត និង ព្រះចេស្ដានៃព្រះវិញ្ញាណរបស់ទ្រង់ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២)

តាមរយៈព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះថូម៉ាស ប៊ី ម៉ាស្ស នោះសិស្សបានរៀនថា ប្រសិនបើយើងបន្ទាបខ្លួន នោះព្រះអម្ចាស់នឹងដឹកនាំយើង និងប្រទានចម្លើយចំពោះការអធិស្ឋានរបស់យើង ។ ព្រះអម្ចាស់បានប្រាប់ប្រធានម៉ាស្សថា ក្នុងនាមជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីនាក់ នោះលោកបានកាន់កូនសោដើម្បីដឹកនាំកិច្ចការនៃពួកដប់ពីនាក់ នៅក្នុងការប្រកាសប្រាប់ដំណឹងល្អនៅក្នុងគ្រប់អស់ទាំងសាសន៍ ។ កូនសោទាំងនេះត្រូវបានស្ដារឡើងវិញជាលើកចុងក្រោយបង្អស់ នៅក្នុងគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ។ សិស្សក៏បានរៀនផងដែរថា ពួកគេត្រូវតែស្មោះត្រង់ ដើម្បីទទួលបានការសន្យានៃពរជ័យរបស់ព្រះអម្ចាស់ ។

## សេចក្ដីផ្ដើម

នៅក្នុងផ្នែកនៃពាក្យអធិស្ឋានឧទ្ទិសឆ្លងសម្រាប់ព្រះវិហារបរិសុទ្ធខឺតឡង់ នោះព្យាការីយ៉ូសែប ស៊្មីធ បានអធិស្ឋានសម្រាប់សុខុមាលភាពរបស់មនុស្សដទៃ ។ បន្ទាប់ពីព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លង នោះព្យាការីពីគ្រាកាន់កាប់ត្រួតត្រាជំនាន់ដើមបានប្រគល់កូនសោបព្វជិតភាពទៅលើព្យាការីយ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី រួមទាំងកូនសោនៃការផ្សារភ្ជាប់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៥៣

*យ៉ូសែប ស្ម៊ីធបានសូមព្រះវរបិតាសួគ៌ឲ្យជួយពួកបរិសុទ្ធនៅក្នុងរដ្ឋមិសសួរី*

សូមអញ្ជើញសិស្សឲ្យគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលកំពុងប្រឈមមុខនឹងឧបសគ្គ ឬ រងទុក្ខតាមរបៀបមួយចំនួន ។ ក្រោយពីពួកគេមានពេលវេលាគ្រប់គ្រាន់ដើម្បីគិតហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- តើមានវិធីណាខ្លះដែលអ្នកអាចជួយសម្រាលការរងទុក្ខរបស់នរណាម្នាក់ ?

បន្ទាប់ពីសិស្សបានចែកចាយយោបល់មួយចំនួន សូមរំឭកពួកគេថាពួកបរិសុទ្ធនៅក្នុងរដ្ឋមិសសួរី បានរងទុក្ខយ៉ាងខ្លាំងដោយសារអំពើដ៏សាហាវព្រៃផ្សៃនៃពួកជនកំណាចនៅក្នុងឃុំចាកសុន ។ ពួកបរិសុទ្ធដ៏ល្អទាំងនោះត្រូវបានចងចាំនៅក្នុងការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធខឺតឡង់ ។ សូមអញ្ជើញសិស្សឲ្យអានផ្នែកនៃការអធិស្ឋានឧទ្ទិសឆ្លងដែលបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៤៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីមួយដែលយើងអាចធ្វើដើម្បីជួយមនុស្សដទៃអំឡុងពេលលំបាក ។

- នៅឯការឧទ្ទិសឆ្លងនៃព្រះវិហារបរិសុទ្ធខឺតឡង់ តើព្យាការីយ៉ូសែប ស្ម៊ីធបានធ្វើអ្វីខ្លះសម្រាប់ពួកបរិសុទ្ធនៅក្នុងរដ្ឋមិសសួរី ?

សូមអញ្ជើញសិស្សម្នាក់ធ្វើជាអ្នកសរសេរ ។ សូមឲ្យសិស្សផ្ដល់គោលការណ៍មួយ ដែលយើងអាចរៀនពីការអធិស្ឋានរបស់ព្យាការីនៅក្នុងខគម្ពីរទាំងនោះ ។ នៅពេលសិស្សឆ្លើយ អ្នកសរសេរអាចសរសេរគោលការណ៍ខាងក្រោមនេះ ៖ **ការអធិស្ឋានរបស់យើងអាចនាំជំនួយ និង ផ្ដល់កម្លាំងដល់អស់អ្នកដែលខ្វះខាត ។**

- តើនៅពេលណាដែរ ដែលអ្នកបានទទួលអារម្មណ៍ ឬ បានឃើញអំណាចនៃការអធិស្ឋានជួយមនុស្សម្នាក់ដែលត្រូវការជំនួយ ? ( អ្នកអាចបង្ហាញថាការអធិស្ឋានបែបនោះភាគច្រើនបានទទួលចម្លើយតាមរយៈការបំផុសគំនិត ដែលយើង ឬ មនុស្សដទៃទៀតបានទទួលអំពីអ្វីដែលយើងអាចធ្វើដើម្បីជួយមនុស្សដទៃ ។ អ្នកក៏អាចចែកចាយបទពិសោធន៍ពីរបៀបដែលអ្នកបានឃើញគោលការណ៍នេះបានបំពេញនៅក្នុងជីវិតរបស់អ្នក ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមនុស្សដទៃទៀតដែលព្យាការីបានអធិស្ឋានសម្រាប់ពួកគេ ។

- តើមាននរណាខ្លះទៀតដែលព្យាការីបានអធិស្ឋានសម្រាប់ពួកគេនោះ ?
- តើអ្នកគិតថាហេតុអ្វីបានជាយើងគួរតែអធិស្ឋានសម្រាប់មារសត្រូវរបស់យើង ?
- តើយើងអាចរៀនអ្វីខ្លះមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥០ អំពីរបៀបដែលការអធិស្ឋានរបស់យើងអាចជះឥទ្ធិពលលើមនុស្សដទៃ ? ( បន្ទាប់ពីសិស្សឆ្លើយហើយ សូមឲ្យអ្នកសរសេរសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **ការអធិស្ឋានរបស់យើងអាចជះឥទ្ធិពលដល់មនុស្សឲ្យប្រែចិត្ត ។** បន្ទាប់មកសូមអញ្ជើញអ្នកសរសេរឲ្យអង្គុយចុះវិញ ) ។

សូមឲ្យសិស្សពិចារណាពីសំណួរខាងក្រោម ៖

- តើវាប្រែជាយ៉ាងដូចម្ដេចដែរ ប្រសិនបើមនុស្សដែលយើងអធិស្ឋានឲ្យពុំព្រមជ្រើសប្រែចិត្តនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥១–៥៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលទទួលស្គាល់ព្រះឆន្ទៈរបស់ព្រះអម្ចាស់ និង សិទ្ធិជ្រើសរើសរបស់មនុស្សដទៃ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( ពីមុនសិស្សអានខគម្ពីរទាំងនេះ អ្នកអាចពន្យល់ថា នៅពេលព្រះគម្ពីរលើកឡើងនូវឃ្លាដែលថាព្រះអម្ចាស់ត្រដាងព្រះហស្តរបស់ទ្រង់ នោះវាសំដៅលើការបង្ហាញព្រះចេស្ដារបស់ទ្រង់ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥៣ ឲ្យឮៗម្ដងទៀត ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះវរបិតាសួគ៌នឹងធ្វើចំពោះអស់អ្នកដែលប្រែចិត្ត ។ ( អ្នកត្រូវតែពន្យល់ថា សេចក្ដីក្រោធរបស់ព្រះជាញឹកញាប់ត្រូវបានបង្ហាញនៅក្នុងការដាក់ទោស ឬ រកទុក្ខនូវបទពិសោធន៍ដែលយើងជួបប្រទះ ដោយសារតែអំពើបាបរបស់យើង ស្របតាមសេចក្ដីយុត្តិធម៌របស់ទ្រង់ ។ ឃ្លា « នៅពេលព្រះអង្គទតទៅលើព្រះភក្ត្រនៃអ្នកដែលទ្រង់បានចាក់ប្រេងតាំង » សំដៅលើព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ ប្រទានសេចក្ដីមេត្តាករុណាដោយសារតែពលិកម្មដ៏ធួននៃព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ) ។

- ហេតុអ្វីបានជាព្រះវរបិតាសួគ៌បង្វែរសេចក្ដីក្រោធរបស់ទ្រង់ចេញពីអស់អ្នកដែលប្រែចិត្តដូច្នេះ ? ( សិស្សអាចប្រើពាក្យផ្សេង ៗគ្នា ប៉ុន្តែសូមជួយពួកគេរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **ដោយសារតែពលិកម្មដ៏ធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះសេចក្ដីក្រោធរបស់ព្រះវរបិតាសួគ៌នឹងត្រូវបែរចេញពីអស់អ្នកដែលប្រែចិត្ត**) ។

ដើម្បីជួយសិស្សឲ្យឃើញពីការពិពណ៌នានៅក្នុង ខ ៥៣ សូមអញ្ជើញពួកគេឲ្យធ្វើចំណុចខាងក្រោមនេះ ៖

សូមស្រមៃពីសមាជិកពីមុនម្នាក់របស់ពួកជនកំណាច ដែលប្រឆាំងនឹងពួកបរិសុទ្ធ ហើយបានចូលរួមក្នុងការដកហូតទ្រព្យរបស់ពួកគេ ... 

សូមស្រមៃពីសមាជិកពីមុនម្នាក់របស់ពួកជនកំណាច ដែលប្រឆាំងនឹងពួកមរមនឈរនៅចំពោះព្រះភក្ត្រព្រះដើម្បីត្រូវបានជំនំជម្រះ ។ ឥឡូវសូមស្រមៃពីប៉ុន្មានឆ្នាំមុន ពីមុនបុគ្គលនេះស្លាប់ គាត់ពិតជាបានប្រែចិត្ត ហើយបានសុំការអភ័យទោស ហើយបានប្រោសលោះតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដោយសារព្រះយេស៊ូវគ្រីស្ទបានរងទុក្ខសម្រាប់អំពើបាបរបស់បុគ្គលនេះ នោះព្រះវរបិតាសួគ៌នឹងបង្វែរការដាក់ទោសចេញ ហើយប្រទាននូវសេចក្ដីមេត្តាករុណាដល់អ្នកមានបាបដែលប្រែចិត្ត ។

- តើឥរិយាបថអ្វីខ្លះដែលចាំបាច់សម្រាប់មនុស្សឲ្យអធិស្ឋានដោយស្មោះសរ ដើម្បីឲ្យមារសត្រូវរបស់ពួកគេអាចត្រូវបានបែរចេញពីសេចក្ដីក្រោធរបស់ព្រះវរបិតាសួគ៌ពីពួកគេ ?

សូមលើកទឹកចិត្តសិស្សឲ្យអភិវឌ្ឍន៍ឥរិយាបថនេះ ចំពោះអស់អ្នកដែលបានធ្វើឲ្យពួកគេអន់ចិត្ត ឬ បានបណ្ដាលឲ្យពួកគេឈឺចាប់ ។ សូមឲ្យសិស្សស្រមៃពីមនុស្សដែលប្រែចិត្តបែបនេះ កំពុងឈរនៅពីមុខព្រះភក្ត្រព្រះវរបិតាសួគ៌ ។ សូមអញ្ជើញសិស្សឲ្យអធិស្ឋានដូចជាយ៉ូសែប ស្ម៊ីធបានអធិស្ឋាន សម្រាប់មនុស្សដែលធ្វើឲ្យពួកគេអន់ចិត្ត ឬ ធ្វើអំពើបាបទាស់នឹងពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១៣–១៦

*អេលីយ៉ាប្រគល់កូនសោនៃការផ្សារភ្ជាប់ឲ្យយ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី*

សូមរំឭកសិស្សថានៅចុងសប្ដាហ៍នៃការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធខឺតឡង់ នោះព្រះយេស៊ូវគ្រីស្ទបានបង្ហាញអង្គទ្រង់ដល់យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី នៅក្នុងព្រះវិហារបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យមើលនៅក្នុងសេចក្ដីណែនាំកណ្ឌនៃគោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ ហើយរកមើលកាលបរិច្ឆេទនៃការនិមិត្តនោះ ។ បន្ទាប់ពីពួកគេរកឃើញហើយ សូមពន្យល់ថានៅចុងសប្ដាហ៍នៃថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៨៣៦ គឺជាបុណ្យរំលងសម្រាប់ជនជាតិយូដានៅទូទាំងពិភពលោក ។ អស់ពេលជាច្រើនសតវត្សមកហើយ ពួកគ្រួសារនៃសាសន៍យូដាបានទុកកៅអីទំនេរ នៅឯពិធីជប់លៀងនៃបុណ្យរំលងរបស់ពួកគេ ដោយផ្អែកលើការព្យាករមួយដោយម៉ាឡាគី នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដោយមានការចូលរួមរបស់អេលីយ៉ាដើម្បី « បង្វែរចិត្តពួកឪពុកមកឯកូន និង ចិត្តកូនមកឯឪពុកវិញ » (ម៉ាឡាគី ៤:៦) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១៣–១៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលការព្យាកររបស់ម៉ាឡាគីត្រូវបានបំពេញនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

ប្រធានយ៉ូសែប ហ្វីលឌិង ស្ម៊ីធ បានបង្រៀនថាអេលីយ៉ាបានប្រគល់ដល់យ៉ូសែប ស្ម៊ីធនូវ « អំណាចនៃការផ្សារភ្ជាប់នៃបព្វជិតភាព ដែលគ្រប់អ្វីៗទាំងអស់នឹងត្រូវបានចងភ្ជាប់នៅលើឋានសួគ៌ ព្រមទាំងនៅលើផែនដីផងដែរ ។ វាបានផ្ដល់សិទ្ធិអំណាចដល់យ៉ូសែប ស្ម៊ីធ ដើម្បីធ្វើពិធីបរិសុទ្ធទាំងអស់នៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះ ដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះទាំងអ្នកនៅរស់ និង មរណជន » (*Doctrines of Salvation,* បានបោះពុម្ព ប្រ៊ូស អរ ម៉ាក់ខនឃី ភាគទី ៣ [ ឆ្នាំ ១៩៥៤–៥៦ ], ២:១១៨ ) ។

- តើយើងកំពុងផ្ដល់អ្វីខ្លះដល់បុព្វការីជនដែលបានចែកឋានរបស់យើង នៅពេលយើងជួយធ្វើពិធីបរិសុទ្ធទាំងនេះនៅក្នុងព្រះវិហារបរិសុទ្ធជំនួសពួកគាត់នោះ ? ( សូមគិតពីការសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **យើងផ្ដល់សេចក្ដីសង្គ្រោះដល់បុព្វការីជនរបស់យើង នៅពេលយើងធ្វើកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធសម្រាប់ពួកគេ**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កុត កូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ អ្នកអាចនឹងផ្ដល់ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍នេះដល់សិស្ស ។ សូមឲ្យពួកគេស្ដាប់រកមើលពរជ័យ ដែលអាចប្រទានមកដល់អស់អ្នកដែលជួយនៅក្នុងកិច្ចការពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធ ។



« កិច្ចការអ្វីដែលអ្នកធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ គឺជាពេលដែលចំណាយបានល្អ ប៉ុន្តែការទទួលពិធីបរិសុទ្ធជំនួសជីដូនជីតាផ្ទាល់ខ្លួនរបស់អ្នក នឹងធ្វើឲ្យពេលវេលាក្នុងព្រះវិហារបរិសុទ្ធកាន់តែពិសិដ្ឋ ហើយថែមទាំងទទួលបានពរជ័យកាន់តែអស្ចារ្យទៀតផង ។. . .

« តើមនុស្សវ័យក្មេងដូចជាអ្នកចង់បានវិធីដ៏ប្រាកដមួយ ដើម្បីលុបបំបាត់ឥទ្ធិពលរបស់មារសត្រូវមានក្នុងជីវិតរបស់អ្នកឬទេ ? សូមជ្រមុជខ្លួនអ្នកទៅក្នុងការស្រាវជ្រាវរកជីដូនជីតាអ្នក រៀបចំឈ្មោះរបស់ពួកគាត់សម្រាប់ពិធីបរិសុទ្ធជំនួសដ៏ពិសិដ្ឋដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ រួចហើយទៅព្រះវិហារបរិសុទ្ធ ដើម្បីឈរជាអ្នកទទួលពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធជំនួសពួកគាត់ ។ នៅពេលអ្នកធំឡើង អ្នកនឹងអាចចូលរួមក្នុងការទទួលពិធីបរិសុទ្ធផ្សេងទៀតផងដែរ ។ ខ្ញុំគិតមិនឃើញនូវកិច្ចការពារដ៏មហិមាពីឥទ្ធិពលរបស់មារសត្រូវក្នុងជីវិតរបស់អ្នកនោះឡើយ » ( « The Joy of Redeeming the Dead » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៩៣–៩៤ ) ។

- តើពរជ័យអ្វីខ្លះដែលនឹងប្រទានឲ្យដល់អស់អ្នកដែលធ្វើកិច្ចការព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ ?
- តើពេលណាដែលអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់បានជួបបទពិសោធន៍នៃពរជ័យទាំងនេះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីអ្វីដែលពួកគេអាចធ្វើដើម្បីបង្កើនកិច្ចខិតខំរបស់ពួកគេនៅក្នុងកិច្ចការពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធ ។

## មេរៀនបន្ទាប់ ( សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១២០)

ដើម្បីរៀបចំសិស្សសម្រាប់ការសិក្សារបស់ខ្លួនអំឡុងពេលនៃសប្ដាហ៍នេះ អ្នកអាចអញ្ជើញពួកគេឲ្យពិចារណាសំណួរខាងក្រោមនេះ ៖ តើសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយបានទទួលឈ្មោះរបស់ខ្លួនដោយរបៀបណា ? តើច្បាប់ដង្វាយមួយភាគក្នុងដប់ត្រូវបានណែនាំប្រាប់នៅពេលណា ? សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងបានរៀនពីចម្លើយចំពោះសំណួរទាំងនេះ និង អំពីរបៀបដែលយើងអាចអំពាវនាវដល់ព្រះសុំជំនួយឲ្យបន្តនៅពិតស្មោះត្រង់ចំពោះសេចក្ដីជំនឿ និងសេចក្ដីសញ្ញារបស់យើង ។

មេរៀនទី ១២១

# សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង

## បុព្វកថា

ក្នុង ១៨៣៧ និង ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ និង ពួកអ្នកដឹកនាំដទៃទៀតនៃសាសនាចក្របានដឹកនាំសាសនាចក្រឆ្លងកាត់គ្រាដ៏លំបាកមួយ ។ ជាលទ្ធផលនៃវិបត្តិសេដ្ឋកិច្ច សេចក្ដីលោភលន់ ការស្វែងរកកំហុស និង ការបៀតបៀននោះពួកបរិសុទ្ធ ១០ ទៅ ១៥ ភាគរយនៅក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូ និង រដ្ឋមិសសួរីភាគខាងជើងបានក្បត់សាសនា រួមមានទាំងថ្នាក់ដឹកនាំសាសនាចក្រដែលលេចធ្លោមួយចំនួនផងដែរ ។ ពួកបរិសុទ្ធស្មោះត្រង់នៅក្នុងរដ្ឋអូហៃអូ បានចាប់ផ្ដើមប្ដូរទីលំនៅទៅចូលរួមជាមួយពួកអ្នកដែលនៅក្នុងរដ្ឋមិសសួរីភាគខាងជើង ។ មេរៀននេះអាចជួយសិស្សឲ្យយល់ និង រៀនពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានា ហើយផ្ដល់ការយល់ដឹងដល់ពួកគេអំពីវិវរណៈដែលបានទទួលអំឡុងពេលនោះ ។

## យោបល់សម្រាប់ការបង្រៀន

### ការក្បត់សាសនា និង ទីក្រុងនៃភូមិ ហ្វា វែស្ទ

*អំឡុងពេលនៃការក្បត់សាសនា និង ការបៀតបៀន ពួកបរិសុទ្ធស្មោះត្រង់បានប្ដូរទីលំនៅទៅរដ្ឋ មិសសួរីភាគខាងជើង*

ពីមុនចាប់ផ្ដើមបង្រៀន សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *តើការលំបាក និង ការសាកល្បងជួយពង្រឹងសេចក្ដីជំនឿរបស់យើង ឬក៏បណ្ដាលឲ្យយើងបាត់បង់សេចក្ដីជំនឿ ?* អ្នកក៏អាច គូរផែនទីមួយ នៅលើក្ដារខៀនបង្ហាញពីទីតាំងនៃទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ និង ការតាំងទីលំនៅផ្សេងទៀតនៅរដ្ឋមិសសួរីភាគខាងជើងផងដែរ ។




សូមចាប់ផ្ដើមថ្នាក់ដោយអញ្ជើញសិស្សឲ្យឆ្លើយសំណួរនៅលើក្ដារខៀន ។ បន្ទាប់ពី សិស្សបានចែកចាយការយល់ដឹងរបស់ខ្លួនរួចហើយ សូមពន្យល់ថានៅក្នុងឆ្នាំ ១៨៣៧ និង ១៨៣៨ ជារយៈពេលមួយនៃការសាកល្បងដែលបាននាំឲ្យពួកបរិសុទ្ធជាច្រើនប្រឈមមុខនឹងសំណួរដូចគ្នានេះផងដែរ ។ សូមពន្យល់ថា នៅក្នុងមេរៀននេះសិស្សនឹងរៀនអំពីព្រឹត្តិការណ៍លំបាក ៗទាំងនេះ និង របៀបដែលពួកបរិសុទ្ធឆ្លើយតបទៅនឹងការលំបាកទាំងនោះ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពី របៀបដែលយើងមានប្រតិកម្មចំពោះការសាកល្បងអាចពង្រឹងជំនឿ ឬ ក៏ធ្វើឲ្យជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទទន់ខ្សោយ ។

អ្នកអាចពន្យល់ដល់សិស្សផងដែរថា មេរៀននេះអាចជួយពួកគេឲ្យយល់ពីទិដ្ឋភាពប្រវត្តិនៃវិវរណៈនានាដែលពួកគេនឹងសិក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១២៣ ។

សូមចង្អុលទៅរដ្ឋមិសសួរីនៅលើផែនទី ។ សូមពន្យល់ថា នៅពេលពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីឃុំ ចាកសុន រដ្ឋ មិសសួរី នៅក្នុងឆ្នាំ ១៨៣៣ ប្រជាពលរដ្ឋនៃឃុំ ក្លេ ដែលជាអ្នកភូមិជិតខាងផងរបងកៀ្ស បានស្វាគមន៍ពួកគេជាច្រើននាក់ ហើយបានធ្វើឲ្យពួកគេធូរស្បើយ ដោយគិតថាពួកបរិសុទ្ធនឹងស្នាក់នៅបណ្ដោះអាសន្នតែប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ពួកបរិសុទ្ធបានរស់នៅទីនោះអស់រយៈពេលជិតបីឆ្នាំប៉ុណ្ណោះ ប្រជាពលរដ្ឋទាំងនេះបានចាប់ផ្ដើមគាបសង្កត់ពួកគេឲ្យចាកចេញពីឃុំនោះ ។

សូមចង្អុលទៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូនៅលើផែនទី ។ សូមពន្យល់ថានៅក្នុង ១៨៣៧ ជាឆ្នាំបន្ទាប់ពីព្រះវិហារបរិសុទ្ធខឺតឡង់ ត្រូវបានឧទ្ទិសឆ្លង នោះពួកបរិសុទ្ធបានជួបការសាកល្បងដែលពិសោធន៍ពីសេចក្ដីជំនឿរបស់ពួកគេ ។ ពួកបរិសុទ្ធមួយចំនួនបានក្បត់សាសនា ហើយបានចាកចេញពីសាសនាចក្រ រួមមានថ្នាក់ដឹកនាំសាសនាចក្រដែលលេចធ្លោមួយចំនួនផងដែរ ។

សូមចែកសិស្សជាពីរក្រុម ។ សូមផ្ដល់ឲ្យនូវច្បាប់ចម្លងនៃ សេចក្ដីសង្ខេបប្រវត្តិសាស្ត្រខាងក្រោម មួយច្បាប់ដល់ក្រុមនិមួយៗ ។ ( បើសិនអ្នកមានសិស្សច្រើន អ្នកអាចចង់ចែកសិស្សជាបួន ឬ ប្រាំមួយក្រុម ហើយឲ្យសេចក្ដីសង្ខេបមួយច្បាប់ដល់ក្រុមនិមួយៗ ។ ការណ៍នេះនឹងធ្វើឲ្យសិស្សច្រើនទៀតចូលរួមនៅក្នុងការពិភាក្សានេះ ) ។ សូមឲ្យក្រុមនិមួយៗអានសេចក្ដីសង្ខេបនោះជាមួយគ្នា ហើយពិភាក្សាសំណួរនៅពេលអានសេចក្ដីសង្ខេបនោះចប់ ។ សូមចាត់សិស្សម្នាក់នៅក្នុងក្រុមនិមួយៗឲ្យដឹកនាំការពិភាក្សា ហើយជួយក្រុមឲ្យសរសេរគោលការណ៍មួយចែកចាយជាមួយសិស្សក្នុងថ្នាក់នៅពេលក្រោយ ។

### សេចក្ដីសង្ខេបប្រវត្តិសាស្ត្រទី ១—ការក្បត់សាសនានៅទីក្រុង ខឺតឡង់

ក្នុងឆ្នាំ ១៨៣៧ ពួកបរិសុទ្ធនៅក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូបានជួបនឹងបញ្ហាហិរញ្ញវត្ថុខ្លះៗ ។ ដើម្បីជួយដល់ពួកបរិសុទ្ធឲ្យកាន់តែមានភាពពឹងផ្អែកខ្លួនឯងលើផ្នែកហិរញ្ញវត្ថុ នោះយ៉ូសែប ស៊្មីធ និងពួកអ្នកដឹកនាំដទៃទៀតនៃសាសនាចក្របានស្ថាបនាក្រុមហ៊ុនមួយ ដែលស្រដៀងទៅនឹងធនាគារ ហើយត្រូវបានហៅថា ក្រុមហ៊ុនសុវត្ថិភាពទីក្រុងខឺតឡង់ ។ ដោយសារតែការរីករាលដាលនៃការធ្លាក់ចុះខាងសេដ្ឋកិច្ចអំឡុងពេលនោះ ធនាគារជាច្រើនបានដួលរលំទូទាំងប្រទេស ។ សមាគមសង្គមសុវត្ថិភាពទីក្រុងខឺតឡង់ ក៏បានដួលរលំនៅរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ ១៨៣៧ ដែរ ។ អ្នកវិនិយោគពីរយនាក់នៅក្នុងធនាគារបានបាត់បង់អ្វីៗស្ទើរតែទាំងអស់ ដោយមាន យ៉ូសែប ស៊្មីធ ទទួលរងការការខូចខាតខ្លាំងជាងគេ ។ ទោះបីជាក្រុមហ៊ុនសុវត្ថិភាពទីក្រុងខឺតឡង់មិនត្រូវបានឧបត្ថម្ភដោយសាសនាចក្រក្ដី ក៏ពួកបរិសុទ្ធខ្លះបានគិតថាវាជាធនាគាររបស់សាសនាចក្រមួយ ឬធនាគាររបស់ព្យាការីមួយ ហើយបានបន្ទោស ដល់យ៉ូសែប ស៊្មីធ ចំពោះបញ្ហាហិរញ្ញវត្ថុរបស់ពួកគេ ។ អ្នកខ្លះថែមទាំងចាប់ផ្ដើមហៅលោកថាជាព្យាការីបរាជ័យម្នាក់ ។ ប៉ុន្តែ ថ្វីបើធនាគារបានបរាជ័យក៏អ្នកដទៃផ្សេងទៀតជាច្រើន ដែលបានខាតបង់ប្រាក់កាក់នោះ បានបន្តនៅក្នុងសេចក្ដីជំនឿ និងបានបន្តស្មោះត្រង់លើព្យាការីដដែល ។ ( សូមមើល *Church History in the Fulness of Times Student Manual,* [Church Educational System manual, ឆ្នាំ ២០០៣ ] ទំព័រ ១៧១–៧៣ ) ។

វិញ្ញាណនៃការក្បត់សាសនា និងការស្វែងរកកំហុសបានចាប់ផ្ដើមរីករាលដាលនៅក្នុងចំណោមពួកបរិសុទ្ធជាច្រើន ។ ព្រិកហាំ យ៉ង់ បានពិពណ៌នាពីគ្រាមួយនៅពេលដែលអ្នកដឹកនាំសាសនាចក្រ និង សមាជិកមួយចំនួន បានជួបដើម្បីបដិសេធព្យាការីយ៉ូសែប ស៊្មីធ ហើយបានតែងតាំងព្យាការីថ្មីម្នាក់ទៀត ៖



« ពួកដប់ពីរនាក់មួយចំនួនដែលជាសាក្សីនៃព្រះគម្ពីរមរមន និង អ្នកផ្សេងទៀតដែលមានសិទ្ធិអំណាចនៃសាសនាចក្រ បានប្រជុំក្រុមប្រឹក្សានៅបន្ទប់ខាងលើនៃព្រះវិហារបរិសុទ្ធ ។ សំណួរដែលចោទសួរនោះ គឺថាតើព្យាការី យ៉ូសែប អាចត្រូវទម្លាក់ ហើយតែងតាំង ដាវីឌ វិតមើរ ជាប្រធានសាសនាចក្រជំនួសវិញដោយរបៀបណា ។. . . ខ្ញុំបានក្រោកឈរឡើង ដោយប្រឡេតហើយបានប្រាប់ទៅពួកគេថា ខ្ញុំដឹងថា យ៉ូសែប គឺជាព្យាការីម្នាក់ ហើយពួកគេអាចតិះដៀល និងនិយាយបង្ខូចលោកបានតាមពួកគេត្រូវការ ប៉ុន្តែពួកគេមិនអាចបំផ្លាញការជ្រើសតាំងរបស់ព្យាការីនៃព្រះបានទេ ពួកគេអាចត្រឹមតែបំផ្លាញសិទ្ធិអំណាចរបស់ខ្លួនឯង និងកាត់ចំណងដែលចងពួកគេទៅនឹងព្យាការី និងព្រះ ហើយពន្លិចខ្លួនទៅក្នុងនរកប៉ុណ្ណោះ » ( *Manuscript History of Brigham Young, ១៨០១–១៨៤៤*, ed. Elden Jay Watson [១៩៦៨], ទំព័រ ១៥–១៦ ) ។

នៅត្រឹមខែ មិថុនា ឆ្នាំ ១៨៣៨ មានអ្នកក្បត់សាសនាប្រហែលជា ២០០ ឬ ៣០០ នាក់បានចាកចេញពីសាសនាចក្រ រួមមានទាំងពួកសាវកបួនរូប ដែលជាសាក្សីបីនាក់នៃព្រះគម្ពីរមរមន និងសមាជិកម្នាក់នៃគណៈប្រធានទីមួយផងដែរ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៧៧ ) ។ ទោះជាយ៉ាងណាក្ដី ពួកបរិសុទ្ធភាគច្រើនបានឆ្លើយតបទៅនឹងរយៈពេលនៃការសាកល្បងនេះដោយសេចក្ដីជំនឿ គឺដូចជាព្រិកហាំ យ៉ង់ បានធ្វើដែរ ។ ពួកគេត្រូវបានពង្រឹងដោយព្រះអម្ចាស់ ហើយពួកគេនៅតែស្មោះចំពោះទីបន្ទាល់របស់ពួកគេ ។ មានមនុស្សបួនប្រាំនាក់នៃអស់អ្នកដែលបានចាកចេញពីសាសនាចក្រអំឡុងពេលនៃការក្បត់សាសនានេះ ក្រោយមកបានត្រឡប់មកវិញ និងបានស្នើសុំរួបរួមគ្នាជាថ្មីម្ដងទៀតជាមួយនឹងសាសនាចក្ររបស់ព្រះអម្ចាស់ ។ នៅក្នុងចំណោមពួកគេនោះគឺមាន អូលីវើរ ខៅឌើរី ម៉ាទីន ហារីស លូកា ចនសុន និងហ្វ្រេឌើរិក ជី វិលលាម្ស ។

នៅអំឡុងពេលនៃការលំបាកទាំងនេះនៅក្នុងទីក្រុងខឺតឡង់ នោះពួកអ្នកក្បត់សាសនាពីរបីនាក់បានចង់សម្លាប់ យ៉ូសែប ស៊្មីធ ។ ដោយត្រូវបានព្រមានពីព្រះវិញ្ញាណ នោះលោក និង ស៊ីឌនី រិកដុន បានចាកចេញនាយប់ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៨៣៨ ។ សត្រូវបានដេញតាមពួកលោកជាច្រើនថ្ងៃ ប៉ុន្តែព្រះអម្ចាស់បានការពារពួកលោក ។ ពួកលោកបានមកជួបជុំគ្រួសាររបស់ខ្លួននៅក្នុង ហ្វា វែស្ទ រដ្ឋមិសសួរី នៅថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៨៣៨ ។

សូមពិភាក្សាសំណួរខាងក្រោមនេះជាក្រុម ៖

- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងនេះ ?
- តើអ្នកនឹងធ្វើអ្វីដើម្បីបន្តនៅស្មោះត្រង់ចំពោះព្យាការីអំឡុងពេលនៃការស្វែងរកកំហុស ?
- តើពេលណាដែលការស៊ូទ្រាំចំពោះការសាកល្បងដោយសេចក្ដីជំនឿបានពង្រឹងសេចក្ដីជំនឿរបស់អ្នកលើព្រះអង្គសង្គ្រោះ ?
- តើការធ្វើតាមព្យាការីបានក្លាយជាការការពារខាងវិញ្ញាណមួយសម្រាប់អ្នកដោយរបៀបណា ?

## សេចក្ដីសង្ខេបប្រវត្តិសាស្ត្រទី ២—ថ្នាក់ដឹកនាំរដ្ឋ មិសសួរីភាគខាងជើង

នៅក្នុងរដូវក្ដៅ ឆ្នាំ ១៨៣៦ នៅពេលប្រជាពលរដ្ឋនៃឃុំ ក្លេ រដ្ឋ មិសសួរី កំពុងគាបសង្កត់ពួកបរិសុទ្ធឲ្យស្វែងរកផ្ទះសម្បែងដែលកាន់តែអចិន្ត្រៃយ៍ នោះយ៉ូហាន វិតមើរ និង វិលលាម ដ័បបុលយូ ហ្វែប្សដែលជាទីប្រឹក្សាទាំងពីរនៅក្នុងគណៈប្រធានស្តេក មិសសួរី បានចំណាយលុយរបស់សាសនាចក្រដើម្បីទិញដីនៅទីតាំងមួយដែលបានស្គាល់ថា ហ្វាវេស រដ្ឋ មិសសួរី ភាគខាងជើង ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលពួកគេបានផ្ដល់ឲ្យនូវដីមួយផ្នែកដល់ពួកបរិសុទ្ធដែលនឹងចូលមក នោះពួកគេបានលក់ដីនោះសម្រាប់តែប្រយោជន៍តួចមួយ ដែលពួកគេបានទុកសម្រាប់ខ្លួនគេតែប៉ុណ្ណោះ ។ ការអាក់អន់ចិត្តដោយការណ៍នេះ និង ការទាស់ចិត្តផ្សេងៗទៀត នោះក្រុមប្រឹក្សាជាន់ខ្ពស់នៅ ក្នុងរដ្ឋមិសសួរីបានទម្លាក់គណៈប្រធានស្តេកចេញពីតំណែង ។

យ៉ូសែប ស្ម៊ីធ បានគាំទ្រវិធានការរបស់ក្រុមប្រឹក្សានោះ ហើយ វិលលាម ដ័បបុលយូ ហ្វែប្សបានអាក់អន់ចិត្ត ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៨៣៨ បងប្រុស ហ្វែប្ស បានចុះហត្ថលេខាលើលិខិតថ្លែងសច្ចាមួយប្រឆាំងនឹងព្យាការី ។ លិខិតថ្លែងសច្ចានេះ បានបណ្ដាលឲ្យព្យាការី យ៉ូសែប ស្ម៊ីធ និង មនុស្សផ្សេងទៀតត្រូវចាប់ខ្លួន ហើយបញ្ជូលចូលទៅក្នុងគុកលីប៊ើធីអស់រយៈពេលមួយរដូវរងា ។ បងប្រុស ហ្វែប្ស ត្រូវបានកាត់កាលចេញពីសាសនាចក្រមិនយូរប៉ុន្មានក្រោយពីការណ៍នោះ ។

នៅក្នុងគុក យ៉ូសែប ស្ម៊ីធ និង អស់អ្នកដែលនៅជាមួយលោកបានរងទុក្ខវេទនាយ៉ាងអនេក មិនគ្រាន់តែបណ្ដាលមកពីស្ថានភាពដ៏ឃោរឃៅនៃការឃុំឃាំងរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមកពីរបាយការណ៍មកថា ពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីផ្ទះសម្បែង និង ត្រូវបានធ្វើបាបតាមរូបភាពគ្រប់យ៉ាង ។ ពួកមនុស្សកំណាចនៅក្នុងរដ្ឋ មិសសួរី ដែលមិនអាចគ្រប់គ្រងបានដោយអភិបាលខេត្ត បានបំផ្លាញទ្រព្យសម្បត្តិ និង អាយុជីវិត រួមទាំងសម្លាប់រង្គាលមនុស្សចំនួន ១៧ នាក់ នៅរោងម៉ាស៊ីនកិនស្រូវមួយដែលម្ចាស់វា មានឈ្មោះយ៉ាកុប ហន ។

មួយឆ្នាំ ក្រោយមកវិលលាម ដ័បបុលយូ ហ្វែប្ស បានរងការឈឺចាប់ខាងវិញ្ញាណចំពោះទង្វើរបស់ខ្លួន ហើយលោកបានសរសេរសំបុត្រមួយច្បាប់ឲ្យ យ៉ូសែប ស្ម៊ីធសុំការអភ័យទោស ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានសរសេរតបវិញ ៖



« ពិតណាស់ យើងបានរងការឈឺចាប់យ៉ាងខ្លាំងដោយសារតែលទ្ធផលនៃទង្វើរបស់អ្នក ។. . .

« ប៉ុន្តែ ពែងនោះត្រូវបានផឹកហើយ ព្រះទ័យរបស់ព្រះវរបិតាត្រូវបានសម្រេច ហើយពួកយើងនៅមានជីវិតនៅឡើយ នោះហើយជាហេតុផលដែលយើងអរព្រះគុណដល់ព្រះអម្ចាស់ ។. . .

« ដោយជឿថាការសារភាពរបស់អ្នកពិត ហើយអ្នកប្រាកដជាប្រែចិត្តមែន ខ្ញុំមានភាពរីករាយក្នុងការផ្ដល់សិទ្ធិឲ្យអ្នកធ្វើជាសមាជិកម្ដងទៀត ហើយរីករាយចំពោះការត្រឡប់មកវិញរបស់កូនប្រុសខ្ជះខ្ជាយ ។. . .

« ‹ សូមមកចុះបងប្រុសជាទីស្រឡាញ់ ដោយសារសង្គ្រាមបានចប់ហើយ

« ដ្បិតដំបូងយើងគឺជាមិត្តភក្តិនឹងគ្នា ហើយចុងក្រោយយើងក៏នៅតែជាមិត្តភក្តិនឹងគ្នាម្ដងទៀត › »
( នៅក្នុង *History of the Church* ៤:១៦៣ ១៦៤ ) ។

សូមពិភាក្សាសំណួរខាងក្រោមនេះជាក្រុម ៖

- ហេតុអ្វីបានជាវាពិបាកដើម្បីអភ័យទោសដល់មិត្តភក្តដែលបានក្បត់អ្នក ហើយធ្វើឲ្យអ្នកមានការឈឺចាប់នោះ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីគំរូរបស់យ៉ូសែប ស្ម៊ីធ ?
- តើមេរៀនអ្វីផ្សេងទៀតដែលយើងអាចរៀនពីបទពិសោធន៍នេះ ?

ក្រោយពីក្រុមទាំងនោះមានពេលអាន និង ពិភាក្សាពីប្រវត្តិសាស្ត្រដែលបានសង្ខេបហើយ សូមឲ្យពួកគេនិយាយប្រវត្តិដែលពួកគេបានរៀន និងគោលការណ៍ដែលពួកគេបានរកឃើញ ប្រាប់ដល់សិស្សក្នុងថ្នាក់ ។ នៅពេលពួកគេបង្រៀន សូមឲ្យពួកគេសរសេរគោលការណ៍នោះនៅលើក្ដារខៀន ។ គោលការណ៍ទាំងនោះអាចរួមមានដូចខាងក្រោម ៖ **នៅពេលយើងជ្រើសដើម្បីឆ្លើយតបចំពោះការសាកល្បងនានាដោយមានជំនឿជាជាងចម្ងល់ នោះទីបន្ទាល់របស់យើងអាចត្រូវបានពង្រឹង នៅពេលយើងគាំទ្រព្យាការី ហើយធ្វើតាមការទូន្មានរបស់លោក នោះយើងទទួលបានសុវត្ថិភាពខាងវិញ្ញាណ ដែលចងយើងជាប់នឹងព្រះ** ( សូមមើលសេចក្ដីសង្ខេបប្រវត្តិសាស្ត្រទី ១ ) ។ **នៅពេលយើងអភ័យទោសឲ្យមនុស្សដទៃ នោះព្រះអម្ចាស់អាចព្យាបាលទំនាក់ទំនងរបស់យើង** ( សូមមើលសេចក្ដីសង្ខេបប្រវត្តិសាស្ត្រទី ២ ) ។

នៅពេលសិស្សស្វែងរកគោលការណ៍នោះ សូមសួរសំណួរតាមដាននានា ដើម្បីជួយពួកគេឲ្យយល់ ហើយទទួលអារម្មណ៍អំពីសារៈសំខាន់នៃសេចក្ដីពិតទាំងនេះ ។ សំណួរទាំងនោះអាចរួមមានដូចខាងក្រោម ៖

- ហេតុអ្វីវាសំខាន់ដើម្បីឲ្យយើងចងចាំពីគោលការណ៍នេះ ?
- តើអ្នកនឹងពន្យល់សេចក្ដី ពិតនេះដល់មិត្តភក្ដិរបស់អ្នកយ៉ាងដូចម្ដេច ?
- តើអ្នកបានមានបទពិសោធន៍ ឬ បានឃើញគំរូមួយអំពីគោលការណ៍នេះនៅពេលណា ?

ដើម្បីជួយសិស្សឲ្យអនុវត្តសេចក្ដីពិតដែលពួកគេបានរៀន សូមឲ្យពួកគេជ្រើសរើសគោលការណ៍មួយ ឬពីរដែលក្រុមនោះបានរកឃើញ ។ រួចសូមឲ្យពួកគេសរសេរចម្លើយចំពោះសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- ដោយព្រោះគោលការណ៍នេះ ឬ គោលការណ៍នានាដែលខ្ញុំបានរៀននាថ្ងៃនេះ តើខ្ញុំនឹងធ្វើអ្វីផ្សេងពីនេះខ្លះ ?

## ព្រឹត្តិការណ៍នានាដែលនាំឲ្យមានការបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋ មិសសួរីភាគខាងជើង

សូមឲ្យសិស្សលើកដៃឡើង បើពួកគេបានឃើញសមាជិកសាសនាចក្រណាម្នាក់បានសម្រេចចិត្ត ដែលបណ្ដាលឲ្យមនុស្សម្នាក់ផ្សេងទៀតបង្ហាញអារម្មណ៍អវិជ្ជមានចំពោះសាសនាចក្រ ។ ( សូមកុំឲ្យពួកគេចែកចាយពីបទពិសោធន៍របស់ពួកគេឡើយ ) ។ អ្នកក៏អាចសូមឲ្យសិស្សពិចារណាពីរបៀបដែលទង្វើផ្ទាល់ខ្លួនរបស់ពួកគេបានជះឥទ្ធិពលដល់ការបង្ហាញអារម្មណ៍របស់មនុស្សដទៃចំពោះសាសនាចក្រ ។

- ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីគិតអំពីរបៀបដែលទង្វើ ឬ ពាក្យសម្ដីរបស់យើង ជះឥទ្ធិពលលើសាសនាចក្រ ?

សូមពន្យល់ថានៅក្នុងឆ្នាំ ១៨៣៨ ទង្វើ និង ពាក្យសម្ដីរបស់សមាជិកមួយចំនួនបានបន្ថែមអារម្មណ៍អវិជ្ជមានលើប្រជាពលរដ្ឋមួយចំនួននៃរដ្ឋ មិសសួរី ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ សូមឲ្យច្បាប់ចម្លង សេចក្ដីសង្ខេបប្រវត្តិសាស្ត្រខាងក្រោម, ហើយអញ្ជើញសិស្សម្នាក់អានវាឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលពួកបរិសុទ្ធមួយចំនួនបាននិយាយ និង បានធ្វើដែលធ្វើឲ្យសាសនាចក្រ និង សមាជិកមានការឈឺចាប់ ។ សូមគិតពីការអញ្ជើញសិស្សឈប់មួយសន្ទុះបន្ទាប់ពីអានចប់កថាខណ្ឌនិមួយៗ ។ នៅពេលឈប់ម្ដងៗ សូមសួរសំណួរខាងក្រោមដល់សិស្ស ៖

- តើពួកបរិសុទ្ធមួយចំនួនបាននិយាយ ឬ ធ្វើអ្វីខ្លះ ដែលបណ្ដាលឲ្យមានប្រតិកម្មអវិជ្ជមានចំពោះសាសនាចក្រ ?

> នៅក្នុងឆ្នាំ ១៨៣៧ និង ១៨៣៨ សមាជិកនៃសាសនាចក្រដែលខូចមិត្តភាព និងត្រូវកាត់កាលចេញពីសាសនាចក្រខ្លះដែលបានរស់នៅក្នុងចំណោមពួកបរិសុទ្ធនៅក្នុងហ្វា វេស បានចាប់ផ្ដើមប្ដឹងផ្ដល់សាសនាចក្រ និងអ្នកដឹកនាំ ហើយដើម្បីរំខានដល់សាសនាចក្រ ។ ពួកបរិសុទ្ធមួយចំនួនបានចាប់ផ្ដើមបង្កើនភាពគ្មានអំណត់ជាមួយការបះបោរទាំងនេះ ។ នៅក្នុងខែ មិថុនា ឆ្នាំ ១៨៣៨ ស៊ីឌនី រិកដុន បានថ្លែងដោយខឹងសម្បារ ដែលវាត្រូវបានគេស្គាល់ថាជា « ទេសនកថាអំបិល » ។ លោកបាននិយាយពី ម៉ាថាយ ៥:១៣ ហើយបានថ្លែងថា ប្រសិនបើអំបិលបាត់បង់រសជាតិរបស់វា នោះវាគ្មានប្រយោជន៍សោះ ហើយគួរតែកាត់ចេញទៅ ដោយបង្កប់ន័យថា អស់អ្នកដែលបានចាកចេញពីសាសនាចក្រគួរតែត្រូវបានកាត់ចេញពីក្នុងចំណោមពួកបរិសុទ្ធទៅ ។ បន្ថែមពីលើនោះ សមាជិកសាសនាចក្រ ៨៤ នាក់បានចុះហត្ថលេខាលើឯកសារមួយដែលបញ្ជាឲ្យពួកក្បត់សាសនាចាកចេញពីឃុំនោះ ។ ពីរសប្ដាហ៍ក្រោយមកនៅថ្ងៃទី ៤ ខែ កក្កដា ស៊ីឌនី រិកដុន បានថ្លែងសុន្ទរកថាមួយ ដែលលោកបានសន្យាថា ពួកបរិសុទ្ធនឹងការពារខ្លួនគេថ្វីបើមាន « សង្គ្រាមនៃការបំផ្លាញចោល » កើតឡើងក្ដី ។ ទោះបីជាសុន្ទរកថាទាំងពីរនេះហាក់ដូចជាប្រឆាំងនឹងការណែនាំរបស់ព្រះអម្ចាស់ដើម្បី « តវ៉ាសូមសេចក្ដីសុខសាន្ត » ( គ. និង ស. ១០៥:៣៨ ) ក្ដី ក៏សុន្ទរកថាទាំងពីរនេះត្រូវបានបោះពុម្ព និងបានបណ្ដាលឲ្យមានការបង្កើលដល់ពួកអ្នកមិនមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយដែរ ។ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៩១–៩២ ) ។

> នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៨ នៅពេលពួកបរិសុទ្ធមួយក្រុមបានព្យាយាមបោះឆ្នោតនៅ ក្នុង ទីក្រុង ហ្គាឡាទីន រដ្ឋ មិសសួរី នោះពួកគេត្រូវបានរុញទៅម្ខាង ដោយមនុស្សមួយក្រុម នៅរដ្ឋ មិសសួរី ហើយបុរសម្នាក់ក្នុងមូលដ្ឋាននោះបានវាយពួកបរិសុទ្ធម្នាក់ ។ ពួកបរិសុទ្ធបានវាយត្រឡប់ទៅវិញ ហើយមនុស្សមួយចំនួនបានរងរបួសទាំងសងខាង ។ ព្រឹត្តិការណ៍នេះបាននាំឲ្យមានជម្លោះ និង ការគំរាមកំហែងបន្ថែមទៀត ព្រមទាំងបង្កើនការយល់ច្រឡំរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និង អ្នកជិតខាងរបស់ខ្លួននៅក្នុងរដ្ឋ មិសសួរី ។
>
> អំឡុងពេលនេះ អ្នកប្រែចិត្តជឿម្នាក់ឈ្មោះ សេមសិន អាវើត បានធ្វើសម្បថសម្ងាត់ចំពោះអស់អ្នកដែលនឹងចូលរួមជាមួយនឹងគាត់ក្នុងការបង្កើតក្រុមមួយនៃពួកចោរប្លន់ ដែលហៅថា ពួកឌែណៃ ។ អាវើត បានណែនាំពួកគេឲ្យលួច និងប្លន់ពួកអ្នកនៅរដ្ឋមិសសួរី ដោយនិយាយថា ការណ៍នេះនឹងជួយកសាងដល់នគររបស់ព្រះ ។ អាវើត បានបញ្ឆោតបញ្ចូលដល់អ្នកដើរតាមខ្លួនថា ការដឹកនាំរបស់គាត់បានមកពីគណៈប្រធានទីមួយ ។ ក្រោយមក ការពិតត្រូវបានលាតត្រដាង ហើយអាវើតត្រូវបានកាត់កាល់ចេញ ។ សកម្មភាពរបស់អាវើត បានបណ្ដាលឲ្យមានការខូចខាតដ៏ខ្លាំងដល់កិត្តិនាមរបស់សាសនាចក្រ និងបានធ្វើឲ្យព្យាការីត្រូវគេចាប់ដាក់គុកលីប៊ើធី ។
>
> នៅក្នុងខែ តុលា ឆ្នាំ ១៨៣៨ សង្គ្រាមមួយរវាងសមាជិកសាសនាចក្រមួយចំនួន និងពួកទាហានមិសសួរីបានធ្វើឲ្យមនុស្សពីរបីនាក់ស្លាប់ពីភាគីម្ខាងៗ ។ របាយការណ៍បំផ្លើសពន្លើសនៃសង្គ្រាមនេះបានឮទៅដល់លោកអភិបាលលីលប៊ើន ដបុលយូ ប៉ុហ្គស៍ ជាអភិបាលរដ្ឋមិសសួរី ដែលពេលនោះបានចេញដីកាដែលហៅថាជា ដីកាបំផ្លាញចោល ៖ « ត្រូវតែចាត់ទុកពួកមរមនថាជាសត្រូវ និង *ត្រូវតែបំផ្លាញចោល* ឬបណ្ដេញចេញពីរដ្ឋនេះ ប្រសិនបើចាំបាច់ដើម្បីប្រយោជន៍សាធារណៈ » ( បានដកស្រង់នៅក្នុង *History of the Church* ៣:១៧៥ ) ។ ភ្លាមៗនោះ ទីក្រុងហ្វា វេស ត្រូវបានឡោមព័ទ្ធដោយទាហានមួយក្រុម ដែលមានចំនួនច្រើនលើសលុបលើកម្លាំងរបស់ពួកបរិសុទ្ធប្រាំដង ។ យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំដទៃទៀតនៃសាសនាចក្រត្រូវបានចាប់ដាក់គុកលីប៊ើធី ជាកន្លែងដែលពួកលោកជាប់នៅទីនោះពេញមួយរដូវរងានោះ ។ ពួកបរិសុទ្ធទាំងឡាយផ្សេងទៀតត្រូវបានបង្ខំឲ្យចាកចេញពីរដ្ឋនេះ ។

- ហេតុអ្វីបានជាវាអាចជាការសំខាន់សម្រាប់យើងដើម្បីទទួលស្គាល់ថា ការបៀតបៀនមួយចំនួនដែលពួកបរិសុទ្ធបានរងទុក្ខគឺជាលទ្ធផលមកពីទង្វើរបស់សមាជិកសាសនាចក្រ ?
- តើយើងអាចរៀនពីព្រឹត្តិការណ៍ទាំងនេះ អំពីរបៀបដែលទង្វើផ្ទាល់ខ្លួន និង ពាក្យសម្ដីរបស់យើងអាចជះឥទ្ធិពលដល់មនុស្សដទៃ ? ( នៅពេលសិស្សឆ្លើយ សូមគូសបញ្ជាក់គោលការណ៍ខាងក្រោម ៖ **ទង្វើ និង ពាក្យសម្ដីរបស់យើងអាចជះឥទ្ធិពលលើរបៀបដែលមនុស្សដទៃគិតពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។** អ្នកអាចសូមសិស្សឲ្យអាន អាលម៉ា ៣៩:១១) ។

សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍ដែលពួកគេមាន នៅពេលដែលអ្នកបានឃើញពាក្យសម្ដី ឬសកម្មភាពរបស់មនុស្សផ្សេងទៀតជះឥទ្ធិពលលើនរណាម្នាក់ទៀតឲ្យមានទស្សនៈវិជ្ជមានមួយអំពីសាសនាចក្រ ។

សូមបញ្ចប់ដោយយោងទៅសំណួរដែលអ្នកបានសរសេរនៅលើក្ដារខៀនម្ដងទៀតពីមុនចាប់ផ្ដើមថ្នាក់រៀន ។ សូមអញ្ជើញសិស្សឲ្យចែកចាយពីអ្វីដែលពួកគេបានរៀនថ្ងៃនេះ អំពីរបៀបដែលចម្លើយរបស់យើងចំពោះឧបសគ្គ និង ការសាកល្បងអាចពង្រឹងជំនឿ ឬ ក៏ធ្វើឲ្យជំនឿរបស់យើងទន់ខ្សោយ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពី អំណាចនៃការបន្តនៅស្មោះត្រង់ចំពោះដំណឹងល្អអំឡុងគ្រាលំបាកនានា ។

មេរៀនទី ១២២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១១៤

## បុព្វកថា

បន្ទាប់ពីមកដល់ក្រុងហ្វារវែស្ទ រដ្ឋ មិសសួរី នៅខែ មិនា ឆ្នាំ ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានឆ្លើយសំណួរនានាអំពីវគ្គព្រះគម្ពីរចេញមកពីគម្ពីរអេសាយ ។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ១៨៣៨ យ៉ូសែប ស្ម៊ីធបានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១១៤, ដែលព្រះអម្ចាស់បានដឹកនាំ ដាវីឌ ដ័បុលយូ ប៉ាទិន ជាសមាជិកម្នាក់នៃកូរ៉ុមនៃពួកដប់ពីរនាក់ឲ្យរៀបចំខ្លួនបម្រើបេសកកម្មមួយ ។

## យោបល់សម្រាប់ការបង្រៀន

*ការបង្រៀនតាមលំដាប់លំដោយនៃព្រះគម្ពីរ*

នៅក្នុងវគ្គសិក្សាថ្នាក់សិក្ខាសាលាជំពូក និង កណ្ឌនានានៃព្រះគម្ពីរ ជាទូទៅត្រូវបង្រៀនតាមលំដាប់លំដោយដែលវាបានបង្ហាញនៅ ក្នុងបទដ្ឋានព្រះគម្ពីរ ។ មេរៀននិមួយៗតែងធ្វើតាមលំដាប់លំដោយនៃខគម្ពីរជានិច្ច ។ ខណៈដែលមេរៀននេះរៀបរាប់ពីការព្យាករណ៍មួយនៅក្នុងគម្ពីរអេសាយ នោះវាពុំមែនជាមេរៀនស្ដីអំពីគម្ពីរអេសាយឡើយ ។ អ្នកគួរតែបង្រៀន គោលលទ្ធិ និង គោលការណ៍នានានៃដំណឹងល្អដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ ហើយចៀសវាងពីការចំណាយពេលច្រើនទៅពន្យល់ពីគម្ពីរអេសាយឡើយ ។

### គោលលទ្ធិ និងសេចក្ដីសញ្ញា ១១៣

*នោះព្រះអម្ចាស់បានឆ្លើយសំណួរនានាអំពីវគ្គបទគម្ពីរចេញមកពីគម្ពីរអេសាយ*

សូមចាប់ផ្ដើមបង្រៀនដោយសួរសំណួរខាងក្រោមនេះដល់សិស្ស ៖

- តើអ្នកធ្លាប់មានការលំបាកយល់ពីអ្វីដែលអ្នកបានអានពីព្រះគម្ពីរដែរឬទេ ?

សូមបង្ហាញថាការព្យាករណ៍មួយចំនួននៅ ក្នុងព្រះគម្ពីររួមមាននិមិត្តរូបដែលពិបាកយល់ ។ សូមពន្យល់ថានៅក្នុង ហ្វា វែស្ទ រដ្ឋ មិសសួរី បងប្អូនប្រុសមួយចំនួនបានសួរយ៉ូសែប ស្ម៊ីធឲ្យបញ្ជាក់ន័យនៃវគ្គបទគម្ពីរនៅក្នុងជំពូក ១១ និង ៥២ នៅក្នុងគម្ពីរអេសាយ ។ ចម្លើយរបស់ព្រះអម្ចាស់ចំពោះសំណួរទាំងនោះ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ ។ អ្នកអាចពន្យល់ថា នៅពេលមរ៉ូណៃបានជួប យ៉ូសែប ស្ម៊ីធលើកដំបូង នោះលោកបានដកស្រង់ការព្យាករណ៍នៅក្នុង អេសាយ ១១ ។ មរ៉ូណៃ បាន ប្រាប់ យ៉ូសែប ស្ម៊ីធ ថា ការព្យាករណ៍នេះជិតនឹងបាន សម្រេចហើយ ( សូមមើល យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៤០) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន អេសាយ ១១:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលវត្ថុបួនដែលបានរៀបរាប់ក្នុងខនេះ ។

- តើអ្នកបានរកឃើញវត្ថុអ្វីខ្លះ ? ( សិស្សគួរតែរៀបរាប់ថាជា លំពង់ ១ គល់ ១ មែក ១ និង ឫស ។ សូមចង្អុលបង្ហាញថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ មានការពន្យល់ពីលំពង់ គល់ មែក និង ឫស ) ។

សូមពន្យល់ថាពាក្យ *គល់* នៅក្នុង អេសាយ ១១:១ ត្រូវបានបកប្រែពីភាសាហេព្រើរដែលសំដៅលើដើម ឬ គល់របស់ឈើ—ទោះជាឈើដែលបានកាត់ ឬ ដើមឈើដែលបានដាំក្ដី ។ សូមឲ្យសិស្សម្នាក់ គូរគល់ឈើមួយលើក្ដារខៀន ហើយសរសេរពាក្យ *គល់* នៅក្បែររូបនោះ ។ បន្ទាប់មកសូមសិស្សឲ្យបន្ថែមឫស ហើយសរសេរជាពាក្យថា *ឫស* ។




- យោងតាម អេសាយ ១១:១ តើអ្វីដែលចេញមកពីគល់ឈើ ? ( លំពង់—ពាក្យម្យ៉ាងទៀតថា ដើមដុះថ្មី ) ។

សូមឲ្យសិស្សគូរដើមដុះថ្មីចេញពី គល់ហើយសរសេរថា *លំពង់* ។

សូមពន្យល់ថាវត្ថុទាំងនេះគឺជានិមិត្តរូប ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:១–៦ ដោយស្ងាត់ស្ងៀម រកមើលនិយមន័យនៃនិមិត្តរូបនោះ ។

- យោងតាម ខ ១–២ តើគល់របស់អ៊ីសាយតំណាងឲ្យនរណា ?

សូមឲ្យសិស្សម្នាក់សរសេរពាក្យ *ព្រះយេស៊ូវគ្រីស្ទ* នៅលើក្ដារខៀនជាប់នឹងពាក្យ *គល់* ។

សូមពន្យល់ថា អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានចែកចាយពីការបកស្រាយមួយអំពីឬស និង លំពង់—ដែលវត្ថុទាំងពីរនេះតំណាងឲ្យយ៉ូសែប ស្ម៊ីធ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ៖



« តើយើងនិយាយខុសឬដែល ថាព្យាការីដែលបានលើកឡើងនៅទីនេះគឺជាយ៉ូសែប ស្ម៊ីធ ដែលមានបព្វជិតភាព ដែលបានទទួលកូនសោទាំងឡាយនៃនគរ និង ដែលបានលើកទង់ដើម្បីប្រមូលរាស្ត្ររបស់ព្រះអម្ចាស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រារបស់យើងឬ ? ហើយតើលោកក៏មិនមែនជា ‹ អ្នកបម្រើនៅក្នុងព្រះហស្តនៃព្រះគ្រីស្ទដែលជាពូជពង្សរបស់អ៊ីសាយខ្លះ និង ពូជពង្សរបស់អេប្រាអិមខ្លះ ឬ ជាវង្សនៃយ៉ូសែបដែលមានអំណាចដ៏ខ្លាំង › ទេឬអី ? ( គ. និង ស. ១១៣:៤–៦ ) ។ អ្នកដែលយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការណ៍ដ៏ទេវភាពនោះនឹងដឹងអំពីអត្ថន័យនៃការណ៍ទាំងនេះ » ( *The Millennial Messiah: The Second Coming of the Son of Man* [ ឆ្នាំ ១៩៨២ ] ទំព័រ ៣៣៩–៤០ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរ *យ៉ូសែប ស្ម៊ីធ* នៅលើក្ដារខៀនជាប់នឹងពាក្យ *ឬស* និង *លំពង់* ។

- តើយ៉ូសែប ស្ម៊ីធបានធ្វើអ្វីខ្លះក្នុងនាមជា « អ្នកបម្រើនៅក្នុងព្រះហស្តនៃព្រះគ្រីស្ទ ? » (គ. និង ស. ១១៣:៤) ។
- នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៦, តើការប្រទានកូនសោទាំងឡាយនៃនគរឲ្យដល់ព្យាការីយ៉ូសែប ស្ម៊ីធមានបំណងអ្វី ? ( នៅពេលសិស្សពិភាក្សាសំណួរនេះ សូមសរសេរសេចក្ដីពិតខាងក្រោមនៅលើក្ដារខៀន ៖ **យ៉ូសែប ស្ម៊ីធ បានទទួលកូនសោទាំងឡាយនៃនគរសម្រាប់ប្រមូលសាសន៍អ៊ីស្រាអែលនៅថ្ងៃចុងក្រោយ** ។ អ្នកអាចសូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១) ។

សូមពន្យល់ថា បន្ទាប់ពីព្រះអម្ចាស់បានបើកសម្ដែងចម្លើយចំពោះសំណួរអំពី អេសាយ ១១, អេលីយ៉ាស ហ៊ីកប៊ី បានសួរសំណួរដែលទាក់ទងនឹង អេសាយ ៥២ ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៧–៨ ដោយស្ងាត់ស្ងៀម ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ទៀតឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៩–១០ ដោយស្ងាត់ស្ងៀម ។ សូមឲ្យសិស្សទាំងពីរក្រុមស្វែងរកព្រះទ័យរបស់ព្រះអម្ចាស់សម្រាប់ប្រជារាស្ត្រនៃក្រុងស៊ីយ៉ូន ។

- យោងតាម ខ ៧–៨, តើយើងគួរ « ពាក់ » អ្វី ? យោងតាម ខ ៨ តើកម្លាំងរបស់ក្រុងស៊ីយ៉ូននោះជាអ្វី ? ( សិស្សគួរតែបង្ហាញសេចក្ដីពិតខាងក្រោមនេះ ៖ **សិទ្ធិអំណាចបព្វជិតភាពគឺជាកម្លាំងនៃក្រុងស៊ីយ៉ូន**) ។

សូមពន្យល់ថា ខ ៩ រួមមានសំណួរមួយអំពីទីក្រុងស៊ីយ៉ូន « ដោះចំណងពីកនាងចេញ » ។ នៅក្នុងខនេះពាក្យ *ចំណង* សំដៅទៅលើឧបករណ៍ប្រើដើម្បីឃាត់នរណាម្នាក់ឲ្យនៅក្នុងសេវកភាព ។

- យោងតាម ខ ១០, តើឃ្លា « ចំណងទាំងឡាយនៅកនាង » មានន័យដូចម្ដេច ? »
- តើវិធីមួយចំនួនដែលសិទ្ធិអំណាចនៃបព្វជិតភាពជួយយើងទាំងអស់គ្នាឲ្យ « ពាក់កម្លាំង [ របស់យើង ] មានអ្វីខ្លះ ? »
- តើមានអ្វីខ្លះដែលយើងអាចធ្វើដើម្បីដោះខ្លួនយើងចេញពី « ចំណងទាំងឡាយ » នោះ ? តើយើងអាចជួយមនុស្សដទៃទៀតឲ្យធ្វើការណ៍ទាំងនេះយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និងសេចក្ដីសញ្ញា ១១៤

### *ព្រះអម្ចាស់ចេញបញ្ជាដល់ ដាវីឌ ដបុលយូ ប៉ាទិន ឲ្យរៀបចំខ្លួនបម្រើបេសកកម្ម*

សូមពន្យល់ថាមនុស្សម្នាក់ដែលព្រះអម្ចាស់បានជ្រើសរើសដើម្បីជួយទីក្រុងស៊ីយ៉ូន « ពាក់កម្លាំងរបស់នាង » នោះគឺជាមនុស្សម្នាក់ដែលមានឈ្មោះថា ដាវីឌ ដបុលយូ ប៉ាទិន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពិពណ៌នាខាងក្រោមឲ្យឮៗ ៖

ដាវីឌ ដបុលយូ ប៉ាទិន បានចូលរួមសាសនាចក្រនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៨៣២ ។ លោកត្រូវបានតែងតាំងជាសាវកនៅឆ្នាំ ១៨៣៥ ។ លោកគ្មានការភ័យខ្លាចក្នុងការការពារសេចក្ដីជំនឿ និងព្យាការី យ៉ូសែប ស្ម៊ីធឡើយ ។ ក្នុងការការពារដល់ពួកបរិសុទ្ធប្រឆាំងនឹងពួកមនុស្សកំណាចនៅរដ្ឋ មិសសួរី ដាវីឌ ដបុលយូ ប៉ាទិន ត្រូវបានស្គាល់ថាជា « មេបញ្ជាការដែលមិនចេះខ្លាច » ។ ( សូមមើល លីខុហ្គាស អេ វិលសុន *Life of David W. Patten: The First Apostolic Martyr* [ ឆ្នាំ ១៩០០ ] ទំព័រ ៥, ៣២, ៥២, ៦២ ) ។

សូមពន្យល់ថា អែលឌើរ ប៉ាទិន បានសុំឲ្យព្យាការីយ៉ូសែប ស្ម៊ីធស្វែងរកវិវរណៈជំនួសលោក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៤:១ ឲ្យឮៗ ។ សូមឲ្យសិស្សរកមើលអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យចង់ឲ្យ អែលឌើរ ប៉ាទិន ធ្វើ ។

- តើព្រះអម្ចាស់សព្វព្រះទ័យចង់ឲ្យអែលឌើរ ប៉ាទិន ធ្វើអ្វីខ្លះ ?
- យោងតាម ខ ១ តើមានមនុស្សប៉ុន្មាននាក់ដែលត្រូវបានហៅដោយព្រះអម្ចាស់ដើម្បីបម្រើបេសកកម្មនេះ ? ( ដប់ពីរនាក់ ។ ខនេះសំដៅលើក្រុមនៃពួកសាវកដប់ពីរនាក់ និង បេសកកម្មបន្ទាប់ទៀតរបស់ពួកគេទៅប្រទេស អង់គ្លេស ) ។
- តើអែលឌើរ ដាវីឌ ប៉ាទិន ចេញបេសកកម្មនៅពេលណា ? សូមមើលនៅក្នុងសេចក្ដីផ្ដើមនៃកណ្ឌ ហើយសម្គាល់ពីកាលបរិច្ឆេទនៃវិវរណៈនេះដែលបានប្រទានឲ្យ ។ តើ ដាវីឌមានពេលប៉ុន្មានពីមុនលោកចាកចេញនោះ ? ( ប្រហែលមួយឆ្នាំ ) ។

សូមប្រាប់សិស្សថា មានសោកនាកម្មមួយបានកើតឡើងក្រោយពីវិវរណៈនេះត្រូវបានប្រទានដល់ ដាវីឌ ប៉ាទិន ប្រាំមួយខែក្រោយមក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោមឲ្យឮៗ អំពីសង្គ្រាមនៅទន្លេគ្រូក ៖

នៅរដូវស្លឹកឈើជ្រុះនៃ ឆ្នាំ ១៨៣៨ ជម្លោះ និង ការបៀតបៀននានាបានកើនឡើងម្ដងទៀតប្រឆាំងនឹងពួកបរិសុទ្ធនៅក្នុងរដ្ឋមិសសួរី ។ នៅថ្ងៃទី ២៤ ខែ តុលា មនុស្សកំណាចមួយក្រុមបានចាប់ជំរិតពួកបរិសុទ្ធបីនាក់ ហាក់ដូចជាមានគម្រោងសម្លាប់ពួកគេនៅយប់នោះ ។ ដោយបានឮពីរឿងនេះ ចៅក្រមក្នុងមូលដ្ឋានម្នាក់ឈ្មោះ អេលីយ៉ាស ហ៊ីកប៊ី ជាសមាជិកសាសនាចក្របានបញ្ជាឲ្យអនុសេនីយ៍ទោ ខូលូណែល ចច អិម ហ៊ីងខ្លេនៃពលទាហានរដ្ឋ ដែលជាសមាជិកផងដែរនោះ ឲ្យរៀបចំបុរសមួយក្រុមដើម្បីបំបែកក្រុមមនុស្សកំណាច ហើយសង្គ្រោះឈ្លើយសឹក ។ បុរសចិតសិបប្រាំនាក់បានប្រមូលគ្នានៅពាក់កណ្ដាលយប់ដែលមាន ដាវីឌ ដ័បុលយូ ប៉ាទិន ជាមេបញ្ជាការរបស់ពួកគេ ។ អែលឌើរ ប៉ាទិន សង្ឃឹមថានឹងធ្វើឲ្យពួកជនកំណាចភ្ញាក់ផ្អើល ហើយសង្គ្រោះពួកឈ្លើយសឹកដោយពុំកំចាយឈាមឡើយ ប៉ុន្តែនៅពេលក្រុមបុរសនោះបានទៅដល់ទន្លេ គ្រូក សមាជិកនៃពួកមនុស្សកំណាចដែលលាក់ខ្លួនបានបាញ់កាំភ្លើងមួយគ្រាប់ ។ ជាទ្រីក អូ បាននៀន សមាជិកម្នាក់នៃទាហានពួកបរិសុទ្ធបានដួលចុះ ។ មេបញ្ជាការ ប៉ាទិនបានដឹកនាំបុរស១៥ នាក់ទៀតនៅឆ្ងាយពីក្រុមទាំងអស់ បានឮសំឡេងកាំភ្លើង ហើយបាននាំកងកម្លាំងទាំងនោះទៅតំបន់នោះ ។ ការវាយប្រហារបន្ទាប់ភ្លាមៗមួយបានធ្វើឡើង ហើយមនុស្សបីបួននាក់បានរងរបួស ។ គេឌាន ខាតើរ បានស្លាប់ភ្លាមៗ ហើយជាទ្រីក អូ បាននៀនក៏បានស្លាប់នៅយប់នោះដែរ ។ អែលឌើរ ប៉ាទិនក៏ជាម្នាក់ក្នុងចំណោមអ្នករងរបួសទាំងនោះដែរ ។

អែលឌើរ ប៉ាទិនបានស្លាប់បីបួនម៉ោងបន្ទាប់ពីការប្រយុទ្ធគ្នានោះ ។ សេចក្ដីជំនឿរបស់គាត់នៅក្នុងដំណឹងល្អដែលបានស្ដារឡើងវិញ នោះគឺថាគាត់បានបង្ហាញដល់ព្យាការី យ៉ូសែប ស្ម៊ីធ នូវវត្ថុនៈដើម្បីស្លាប់ក្នុងនាមជាទុក្ករបុគ្គល ។ « ព្យាការី វន្ទត់ចិត្តជាខ្លាំងបានបង្ហាញការសោកស្ដាយជាពន់ពេក ដែលលោកបានមានប្រសាសន៍ទៅកាន់ដាវីឌថា ‹ ដ្បិតនៅពេលមនុស្សម្នាក់ដែលមានសេចក្ដីជំនឿដូចជាអ្នកសុំព្រះអម្ចាស់នូវអ្វីមួយ នោះភាគច្រើនគាត់នឹងទទួលវា (*Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទី ២ [ Church Educational System manual, ២០០៣ ], ទំព័រ ២០០; ការដកស្រង់ យ៉ូសែប ស្ម៊ីធ នៅក្នុង *Life of David W. Patten,* ទំព័រ ៥៣ ) ។ ពីមុនពិធីបុណ្យសពរបស់អែលឌើរ ប៉ាទិន នៅ ហ្វា វេស នោះយ៉ូសែប ស្ម៊ីធ បានចង្អុលទៅសពរបស់អែលឌើរ ប៉ាទិន ហើយមានប្រសាសន៍ថា « នេះគឺជាបុរសម្នាក់ដែលបានធ្វើដូចអ្វីដែលគាត់បាននិយាយ—គាត់បានលះបង់ជីវិតខ្លួនដើម្បីមិត្តភក្តិរបស់គាត់ » ( នៅក្នុង *History of the Church* ៣:១៧៥ ) ។

សូមចង្អុលបង្ហាញថា នៅពេលអែលឌើរ ប៉ាទិន បានស្លាប់ នោះគាត់កំពុងតែរៀបចំខ្លួនតាមរយៈភាពស្មោះត្រង់របស់គាត់ដើម្បីបម្រើបេសកកម្ម ។ សូមឲ្យសិស្សចាប់ដៃគូហើយពិភាក្សាសំណួរខាងក្រោម ៖

- តើអ្នកគិតថា ការបញ្ជារបស់ព្រះអម្ចាស់ដើម្បីរៀបចំខ្លួនសម្រាប់បេសកកម្មបានជះឥទ្ធិពលដល់អែលឌើរ ប៉ាទិន យ៉ាងដូចម្ដេច ? តើការបញ្ជានេះអាចក្លាយជាពរជ័យមួយដល់អែលឌើរ ប៉ាទិន យ៉ាងដូចម្ដេច ទោះបីជាគាត់ពុំធ្លាប់បានបំពេញបេសកកម្ម ដូចដែលគាត់រំពឹងនឹងធ្វើនោះក្ដី ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីការណ៍នេះ ? ( សិស្សអាចចែកចាយការយល់ដឹង និង សេចក្ដីពិតមួយចំនួនផ្សេងៗពីគ្នា រួមមានគោលការណ៍ខាងក្រោម ៖ **បើសិនយើងស្ដាប់តាមការណែនាំរបស់ព្រះអម្ចាស់ នោះយើងនឹងត្រូវបានរៀបចំខ្លួនសម្រាប់អ្វីដែលទ្រង់បានរៀបផែនការសម្រាប់យើង**) ។
- តើអ្នកធ្លាប់បានធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់ ហើយបានឃើញថាវាបានធ្វើឲ្យអ្នករៀបចំខ្លួនសម្រាប់អ្វីមួយដែលអ្នកមិនបានរំពឹងទុកនៅពេលណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៤:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា នឹងកើតឡើងនៅពេលមនុស្សមិនបានបំពេញការហៅបម្រើរបស់ខ្លួន ។ ( អ្នកអាចពន្យល់ថានៅក្នុងខគម្ពីរនេះពាក្យថា *គណៈប៊ីស្សព* សំដៅទៅលើទំនួលខុសត្រូវរបស់មនុស្សម្នាក់ ពុំមែនសំដៅលើប៊ីស្សព និង ទីប្រឹក្សារបស់គាត់ទេ ។ សូមមើល ទំនុកតម្កើង ១០៩:៨; កិច្ចការ ១:២០) ។

- តើយើងអាចរៀនអ្វីមកពី ខ ២ អំពីអ្វីដែលនឹងកើតឡើងបើសិនជាយើងមិនបានស្មោះត្រង់នៅក្នុងការហៅបម្រើយើងនោះ ? ( មនុស្សម្នាក់ទៀតនឹងត្រូវបានហៅដើម្បីបំពេញទំនួលខុសត្រូវរបស់យើង ) ។

សូមពន្យល់ថា នៅពេលអែលឌើរ ដាវីឌ ដបុលយូ ប៉ាទិន ដេកស្លាប់លើគ្រែរបស់ខ្លួន នោះលោកបាននិយាយពីបងប្អូនពួកបរិសុទ្ធរបស់លោកមួយចំនួន រួមមានទាំងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលពុំមានចិត្តស្មោះត្រង់ ។ លោកបានបន្លឺឡើងថា « ឱ បើសិនពួកគេនៅក្នុងសភាពដូចជាខ្ញុំនេះ ! ដ្បិតខ្ញុំមានអារម្មណ៍ថាខ្ញុំបានរក្សាសេចក្ដីជំនឿ ខ្ញុំបានបញ្ចប់កិច្ចការរបស់ខ្ញុំ ហេតុដូច្នេះហើយនឹងមានមកុដមួយសម្រាប់ខ្ញុំ ដែលព្រះអម្ចាស់ជាចៅក្រមដ៏សុចរិតនឹងប្រទានដល់ខ្ញុំ » ។ គាត់បាននិយាយទៅកាន់ភរិយាគាត់ថា « ទោះជាអូនធ្វើអ្វីក៏ដោយ តែសូមកុំបោះបង់ចោលសេចក្ដីជំនឿឡើយ » ( សេចក្ដីសម្រង់ Heber C. Kimball, នៅក្នុង *Life of David W. Patten,* ទំព័រ ៦៩ ) ។

ដើម្បីជួយសិស្សឲ្យទទួលអារម្មណ៍ពីភាពសំខាន់នៃការជ្រើសរើសក្នុងពេលឥឡូវនេះដើម្បីស្មោះត្រង់ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬ សៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ខ្លួនអំពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីធ្វើតាមព្រះឱវាទរបស់ព្រះអម្ចាស់ ហើយបំពេញការរំពឹងទុកនានាដែលទ្រង់មានចំពោះពួកគេ ។

មេរៀនទី ១២៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥–១១៦

## បុព្វកថា

នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥ ។ នៅក្នុងនោះព្រះអម្ចាស់បានបើកសម្ដែងឈ្មោះរបស់សាសនាចក្រ និងបានបញ្ជាពួកបរិសុទ្ធឲ្យ « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ » ( គ. និង ស. ១១៥:៥ ) ហើយបានបើកសម្ដែងព្រះទ័យទ្រង់ទាក់ទងនឹងព្រះវិហារបរិសុទ្ធនៅក្នុងភូមិហ្វារវេសត៍ ។ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៨៣៨ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦ ដែលបានរកឃើញថា ស្ព្រីង ហិល រដ្ឋ មិសសួរី ថាជា អ័ដាម អុនដៃ អាម៉ាន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១–៦

*ព្រះអម្ចាស់បញ្ជាឲ្យសមាជិកនៃសាសនាចក្ររបស់ទ្រង់ឲ្យ « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ »*

មុនចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរខាងក្រោម នៅលើក្ដារខៀន ៖

*១. តើឈ្មោះរបស់អង្គការនេះបង្ហាញពីអ្វី ?*

*២. តើនរណាជាអ្នកដឹកនាំអង្គការនេះ ?*

*៣. តើអង្គការនេះធ្វើអ្វីខ្លះ ?*

សូមតាំងបង្ហាញឈ្មោះ ឬ ស្លាកសញ្ញារបស់ក្រុមហ៊ុន ឬ អង្គការសមរម្យមួយចំនួន ដែលសិស្សរបស់អ្នកទំនងជាស្គាល់ ។ សូមឈប់មួយសន្ទុះបន្ទាប់ពីការបង្ហាញស្លាកសញ្ញាមួយនោះៗ ហើយសូមឲ្យសិស្សឆ្លើយសំណួរដែលបានសរសេរលើក្ដារខៀននោះ ។

សូមបង្ហាញឈ្មោះ និង ស្លាកសញ្ញារបស់សាសនាចក្រ ។ សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយចំពោះសំណួរទាំងឡាយនៅលើក្ដារខៀន ដែលទាក់ទងនឹងឈ្មោះរបស់សាសនាចក្រនៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១–៣ ដោយពន្យល់ថា វិវរណៈនេះត្រូវបានប្រទានឲ្យតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ដល់បុរសទាំងអស់ដែលមានឈ្មោះនៅក្នុង ខ ១–២ និង ចំពោះសមាជិកទាំងអស់នៃសាសនាចក្រ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៤ ដោយស្ងាត់ស្ងៀម រកមើលឈ្មោះដែលព្រះអម្ចាស់បានរៀបចំឡើងសម្រាប់សាសនាចក្ររបស់ទ្រង់ ។ នៅពេលសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ សូមសរសេរឈ្មោះនៃសាសនាចក្រនៅលើក្ដារខៀន ដូចខាងក្រោម ៖

*សាសនាចក្រ*

*នៃព្រះយេស៊ូវគ្រីស្ទ*

*នៃពួកបរិសុទ្ធ*

*ថ្ងៃចុងក្រោយ*

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃឈ្មោះរបស់សាសនាចក្រ សូមអញ្ជើញសិស្សឲ្យពិភាក្សាជាមួយដៃគូគិតពីអត្ថន័យនៃពាក្យ ឬ ឃ្លានិមួយៗដែលបានសរសេរនៅលើក្ដារខៀន ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយការយល់ដឹងរបស់ខ្លួនទាក់ទងនឹងអត្ថន័យនៃពាក្យ ឬ ឃ្លានិមួយៗនោះ ។ បើសិនសិស្សត្រូវការជំនួយអ្នកអាចចង់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ពាក្យថា *សាសនាចក្រ*បង្ហាញពីគោលជំហរពិសេសនៃសាសនាចក្រដែលបានស្តារឡើងវិញក្នុងចំណោមសាសនានានានៃពិភពលោក ។

« ពាក្យ *សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ*ប្រកាសថា វាជាសាសនាចក្ររបស់ទ្រង់ ។. . .

«*នៃថ្ងៃចុងក្រោយ*ពន្យល់ថា វាជាសាសនាចក្រតែមួយនឹងសាសនាចក្រដែលព្រះយេស៊ូវគ្រីស្ទបានបង្កើតឡើងក្នុងពេល នៃការគ្រប់គ្រងខាងសាច់ឈាមរបស់ទ្រង់ ហើយត្រូវបានស្តារឡើងវិញនៅថ្ងៃចុងក្រោយនេះ ។. . .

«*ពួកបរិសុទ្ធ* . . .សំដៅយ៉ាងសាមញ្ញលើអស់អ្នកណាដែលព្យាយាមធ្វើឲ្យជីវិតរបស់ខ្លួនបរិសុទ្ធដោយចុះសេចក្តីសញ្ញាធ្វើតាមព្រះគ្រីស្ទ » (The Importance of a Name » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៨០ ) ។

- តើសេចក្តីពិតសំខាន់ណាខ្លះ ដែលបង្ហាញដោយឈ្មោះរបស់សាសនាចក្រនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១១៥:៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់រំពឹងចង់បានពីអស់អ្នកដែលជាសមាជិកនៃសាសនាចក្ររបស់ទ្រង់ ។

- តើព្រះអម្ចាស់រំពឹងអ្វីខ្លះពីយើងដែលជាសមាជិកនៃសាសនាចក្ររបស់ទ្រង់ ?
- តើអ្នកគិតថា « សូមក្រោក ឡើង ហើយបញ្ចាំងពន្លឺចេញទៅ » មានន័យដូចម្តេច ក្នុងនាមអ្នកជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ?
- យោងតាម ខ ៥,តើពរជ័យអ្វីខ្លះនឹងបានប្រទានដល់យើងក្នុងនាមជាសមាជិកនៃសាសនាចក្រដែលបានធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់ឲ្យក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅនោះ ? ( សិស្សគួរតែរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **បើសិនយើងក្រោកឡើង ហើយ បញ្ចាំងពន្លឺចេញទៅនោះពន្លឺរបស់យើងនឹងក្លាយជាបមាណីយដល់សាសន៍នានា ។** អ្នកអាចឲ្យយោបល់សិស្សគូសចំណាំគោលការណ៍នេះនៅក្នុង ខ ៥) ។

ដើម្បីជួយសិស្សយល់ពីគោលការណ៍នេះកាន់តែប្រសើរ សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថាវាមានន័យយ៉ាងណាដែលថា ពន្លឺ ឬ គំរូរបស់យើងអាចក្លាយជា « បមាណីយដល់សាសន៍នានា ? » ( បមាណីយគឺជាទង់ជ័យ ឬ បដាមួយដែលត្រូវបានប្រើជាទីតាំងប្រមូលផ្តុំមួយ ឬ និមិត្តរូបនៃការបំផុសខាងវិញ្ញាណ ។ គំរូរបស់យើងក្នុងនាមជាសមាជិកនៃសាសនាចក្រ អាចបំផុសគំនិតមនុស្សដទៃ ហើយនាំពួកគេឲ្យខិតជិតព្រះអម្ចាស់ ) ។
- តើព្រះបញ្ញត្តិរបស់ព្រះអង្គសង្គ្រោះខាងក្រោមនេះដែលឲ្យក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ អាចទាក់ទាញមនុស្សដទៃទៀតឲ្យមកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលពន្លឺរបស់យើងអាចជួយមនុស្សដទៃ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ដំណើររឿងខាងក្រោមដែលបានចែកចាយដោយប្រធាន ជែមស៍ អ៊ី ហ្វាស្ត នៃគណៈប្រធានទីមួយ ៖



« ជាច្រើនឆ្នាំមុន ខនស្វែន ជានិសិត្សគិលានុបដ្ឋាម្នាក់ត្រូវបានចាត់ឲ្យព្យាយាមជួយស្ត្រីម្នាក់ដែលមានរបួសជើងនៅក្នុងគ្រោះថ្នាក់មួយ ។ ស្ត្រីម្នាក់នោះបានបដិសេធជំនួយផ្នែកពេទ្យ ដោយសារតែគាត់មានបទពិសោធន៍មិនល្អជាមួយនរណាម្នាក់នៅមន្ទីរពេទ្យ ។ គាត់មានការភ័យខ្លាច ហើយបានដកខ្លួនចេញពីសង្គម ។ លើកទីមួយដែល ខនស្វែន បានទៅផ្ទះគាត់ ស្ត្រីរងរបួសនោះបានបញ្ជាឲ្យនាងចេញ ។ នៅក្នុងការព្យាយាមលើកទីពីរ គាត់ពុំអនុញ្ញាតឲ្យ ខនស្វែន ចូលមកឡើយ ។ ប៉ុន្តែឥឡូវនេះជើងរបស់ស្ត្រីនោះបានមានដំបៅកាន់តែធំឡើងៗ ហើយមានសាច់មួយចំនួនបានរលួយ ។ ប៉ុន្តែ គាត់នៅតែមិនចង់ទទួលការព្យាបាល ។

« ខនស្វែន បានអធិស្ឋានពីរឿងនោះ ហើយមួយថ្ងៃ ឬពីរថ្ងៃក្រោយមក នាងបានទទួលចម្លើយ ។ នាងបានយកទឹកលាងរបួស ទៅជាមួយនៅពេលនាងទៅលើកក្រោយ ។ ដោយសារតែវាមិនធ្វើឲ្យឈឺ ស្ត្រីចំណាស់នោះបានព្រមឲ្យនាងប្រើវានៅលើជើងគាត់ ។ ហើយពួកគេបាននិយាយអំពីការព្យាបាលដែលប្រាកដប្រជាជាងនេះ ។ ខនស្វែន បានអះអាងនឹងគាត់ថា មន្ទីរពេទ្យនឹងព្យាយាមធ្វើឲ្យគាត់ស្នាក់នៅយ៉ាងសុខស្រួល ។ មួយថ្ងៃ ឬពីរថ្ងៃក្រោយមក ស្ត្រីនោះមានចិត្តក្លាហានទៅមន្ទីរពេទ្យ ។ នៅពេល ខនស្វែន ទៅសួរសុខទុក្ខគាត់ ស្ត្រីនោះបានញញឹម ហើយបាននិយាយថា ‹ ក្មួយបានធ្វើឲ្យខ្ញុំផ្លាស់ប្តូរគំនិត › ។ ហើយគាត់បានសួរ ខនស្វែន ដោយមិនបានរំពឹងទុកថា ‹ តើក្មួយជាសមាជិករបស់សាសនាចក្រមួយណាដែរ ? › ខនស្វែន បានប្រាប់គាត់ថា នាងគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ស្ត្រីនោះបាននិយាយថា ៖ ‹ ខ្ញុំដឹងហើយ ។ ខ្ញុំដឹងថា ក្មួយត្រូវបានបញ្ជូនមកខ្ញុំ តាំងពីថ្ងៃទីមួយដែលខ្ញុំបានឃើញក្មួយ ។ មានពន្លឺមួយនៅលើមុខរបស់ក្មួយ ដែលខ្ញុំបានសម្គាល់ឃើញមាននៅលើមុខរបស់អ្នកដទៃទៀត ដែលមានជំនឿដូចក្មួយ ។ ខ្ញុំត្រូវទុកចិត្តលើក្មួយ › ។

« ជើងដំបៅរបស់គាត់បានជាសះស្បើយទាំងស្រុងក្នុងរយៈពេលបីខែ ។ សមាជិកនៅវួដដែលស្ត្រីចំណាស់នោះរស់នៅបានធ្វើផ្ទះ និង ជួសជុលរានហាលរបស់គាត់ ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានជួបជាមួយគាត់ ហើយមិនយូរប៉ុន្មានក្រោយមកគាត់បានជ្រមុជទឹក [ សូមមើល Constance Polve ] « A Battle Won » *New Era,* ខែ មេសា ឆ្នាំ ១៩៨០ ទំព័រ ៤៤–៤៥ ] ។ ការណ៍ទាំងនេះ ដោយសារតែគាត់បានកត់សម្គាល់ពីពន្លឺដែលមានលើមុខរបស់និស្សិតគិលានុបដ្ឋាយិកាក្មេងនោះ » (The Light in Their Eyes » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ២២ ) ។

- តើខុនស្តេនបានធ្វើអ្វីខ្លះដើម្បី « ក្រោកឡើងហើយបញ្ចាំងពន្លឺចេញទៅ ? »
- តើពន្លឺនៅលើមុខរបស់ខុនស្តេនគឺជាបមាណីយដល់ស្ត្រីរបួសនោះយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សឲ្យបានទទួលអារម្មណ៍ពីសេចក្តីពិត និង ពីសារៈសំខាន់នៃគោលការណ៍នេះ សូមអញ្ជើញពួកគេឲ្យគិតអំពីមនុស្សដែលពួកគេស្គាល់ ដែលជាគំរូល្អអំពីការក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្នកដែលពួកគេបានគិត និង របៀបដែលគំរូរបស់បុគ្គលម្នាក់នោះក្លាយជាពរជ័យមួយសម្រាប់ពួកគេ ។ នៅពេលអ្នកស្ដាប់ ចម្លើយរបស់ពួកគេ សូមសួរសំណួរតាមដាននានាដែលនឹងបំផុសគំនិតសិស្សឲ្យចែកចាយបន្ថែមពីអ្វីដែលពួកគេកំពុងគិត និង ទទួលអារម្មណ៍ ។

### *ស្ដាប់ដោយយកចិត្តទុកដាក់*

នៅពេលអ្នកសង្កេត និង ការស្ដាប់សិស្សដោយយកចិត្តទុកដាក់ដល់ចម្លើយរបស់ពួកគេ នោះអ្នកអាចដឹងពីតម្រូវការរបស់ពួកគេ ហើយដឹកនាំការពិភាក្សានៅក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមប្រាកដថាអ្នកយល់ចម្លើយរបស់សិស្សដោយការសួរ សំណួរដូចជា « តើអ្នកអាចជួយខ្ញុំឲ្យយល់ពីអ្វីដែលអ្នកចង់ មានន័យបានដែរឬទេ ? » ឬ « តើអ្នកអាចផ្ដល់ឧទាហរណ៍មួយអំពីអ្វីដែលចង់និយាយបានទេ ? » ការសួរសំណួរតាមដានដូចនេះញឹកញាប់ នាំឲ្យមានវិញ្ញាណនៃទីបន្ទាល់នៅក្នុងចម្លើយរបស់សិស្ស ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីប្រែក្លាយកាន់តែជាបមាណីយដល់មនុស្សដែលនៅជុំវិញខ្លួនពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៦ ឲ្យឮៗ ។ សូមឲ្យសិស្សស្វែងរកពរជ័យដែលបានសន្យាដល់អស់អ្នកដែលបានប្រមូលផ្ដុំគ្នាជាមួយសាសនាចក្រនៅក្នុងស្ដេកនៃស៊ីយ៉ូន ?

- តើពរជ័យអ្វីខ្លះដែលបានសន្យាដល់អស់អ្នកដែលបានប្រមូលផ្ដុំគ្នានៅក្នុងស្ដេកនៃស៊ីយ៉ូន ? ( បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរសេចក្ដីពិតខាងក្រោមនេះនៅលើក្ដារខៀន ៖ **យើងប្រមូលផ្ដុំគ្នាទៅស្ដេកនៃស៊ីយ៉ូនសម្រាប់ការការពារ និង ជាទីជម្រក**
- តើយើងចាំបាច់ត្រូវការពារខ្លួនយើងពីអ្វីខ្លះ ? តើយើងចាំបាច់ត្រូវការទីជម្រកគេចពីអ្វីខ្លះ ? តើអ្នកបានឃើញការប្រមូលផ្ដុំគ្នាក្នុងនាមជាពួកបរិសុទ្ធ ជួយយើងការពារខ្លួនយើង និង ស្វែងរកទីជម្រកយ៉ាងដូចម្ដេចខ្លះ ?

សូមអញ្ជើញសិស្សឲ្យគិតពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលបានទទួលផលប្រយោជន៍មកពីការប្រមូលគ្នាជាមួយពួកបរិសុទ្ធ ។ សូមលើកទឹកចិត្តសិស្សឲ្យពន្លឺរបស់ពួកគេបញ្ចាំងចេញទៅ ដូច្នេះមនុស្សដទៃអាចត្រូវបាននាំទៅរកភាពសុខសាន្ត សុវត្ថិភាព និង ទីជម្រកដែលផ្ដល់ឲ្យដោយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៧–១៩

*ព្រះអម្ចាស់បញ្ជាពួកបរិសុទ្ធឲ្យស្ថាបនាទីក្រុង ហ្វារវេស ហើយឲ្យកសាងព្រះវិហារបរិសុទ្ធ*

សូមពន្យល់ថារបៀបមួយដែលយើងអាចទទួលបានការការពារពីព្រះអម្ចាស់ និង សុវត្ថិភាពគឺតាមរយៈការថ្វាយបង្គំទ្រង់នៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់ពីពួកបរិសុទ្ធបានចាប់ផ្ដើមប្ដូរទីលំនៅទៅហ្វារវេស រដ្ឋ មិសសួរី នៅក្នុង ឆ្នាំ ១៨៣៦ ថ្នាក់ដឹកនាំសាសានាចក្រ បានរៀបចំផែនការកសាងព្រះវិហារបរិសុទ្ធមួយស្រដៀងទៅនឹងព្រះវិហារនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ ទោះបីជាដីមួយចំនួនត្រូវបានជីកហើយក្ដី ក៏ការសាងសង់បន្ថែមត្រូវពន្យាពេល រហូតដល់ព្យាការី យ៉ូសែប ស្ម៊ីធអាចទទួលសេចក្ដីណែនាំបន្ថែមទៀតពីព្រះអម្ចាស់ ។ ព្រះអម្ចាស់បានបើកសម្ដែងព្រះឆន្ទៈរបស់ទ្រង់អំពីព្រះវិហារបរិសុទ្ធដែលជាផ្នែកមួយនៃវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៧–១៦ ដោយពន្យល់ថា ព្រះអម្ចាស់បានបើកសម្ដែងថាព្រះវិហារបរិសុទ្ធមួយគួរតែត្រូវបានសាងសង់ឡើងនៅហ្វា វេស ស្របតាមគំរូដែលទ្រង់នឹងប្រទានដល់គណៈប្រធានទីមួយ ។ ព្រះអម្ចាស់ក៏បានផ្ដល់ព្រះឱវាទដល់ថ្នាក់ដឹកនាំសាសនាចក្រ មិនឲ្យជំពាក់បំណុលគេដើម្បីកសាងព្រះវិហារបរិសុទ្ធឡើយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១៧–១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអម្ចាស់ចង់ឲ្យពួកបរិសុទ្ធធ្វើ ក្រោមការណែនាំរបស់យ៉ូសែប ស្ម៊ីធ នៅហ្វា វេស និង នៅតំបន់ក្បែរៗនោះ ។

- តើព្រះអម្ចាស់សព្វព្រះទ័យចង់ឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះនៅហ្វា វេស ? តើកិច្ចការអ្វីខ្លះដែលពួកគេធ្វើក្រោមការណែនាំរបស់យ៉ូសែប ស្ម៊ីធនៅក្នុងតំបន់ជុំវិញ ហ្វា វេស ?
- យោងតាម ខ ១៩, តើគុណសម្បត្តិអ្វីខ្លះដែលប្រធានសាសនាចក្របច្ចុប្បន្ននេះមានដើម្បីដឹកនាំកិច្ចការរបស់ព្រះអម្ចាស់លើផែនដីនេះ ? ( សិស្សគួររកឃើញគោលលទ្ធិខាងក្រោមនេះ ៖ **ប្រធាននៃសាសនាចក្រកាន់កូនសោដើម្បីដឹកនាំកិច្ចការរបស់ព្រះអម្ចាស់នៅលើផែនដីនេះ**) ។ អ្នកអាចឲ្យយោបល់សិស្សគូសចំណាំឃ្លាដែលបង្រៀនគោលលទ្ធិទាំងនេះនៅ ខ ១៩ ) ។

សូមឲ្យសិស្សមើលទៅសំណួរនៅលើក្ដារខៀន ហើយសុំឲ្យពួកគេពន្យល់ពីរបៀបដែលពួកគេឆ្លើយនឹងសំណួរទាំងនោះដោយផ្អែកលើអ្វីដែលពួកគេបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦:១

*ព្រះអម្ចាស់បានបញ្ជាក់ថា អ័ដាម អុនដៃ អាម៉ាន គឺជាទីតាំងនៃកន្លែងប្រជុំនាពេលអនាគតរវាងព្រះអម្ចាស់ និងប្រជារាស្ត្ររបស់ទ្រង់*

សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ បានធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១៨ ហើយបានពិនិត្យមើលតំបន់នានានៅជុំវិញ ហ្វា វេស ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីណែនាំកណ្ឌសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦ ឲ្យឮៗ ហើយសូមឲ្យសិស្សរកមើលឈ្មោះនៃទីតាំងដែលយ៉ូសែបបានពិនិត្យមើល ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦:១ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បានបើកសម្ដែងអំពី ស្ព្រីង ហិល រដ្ឋ មិសសួរី ។ អ្នកអាចណែនាំឲ្យសិស្សបើកទៅ ផែនទី និង រូបភាពនៃ អ័ដាម អុនដៃ អាម៉ាននៅខាងក្រោយព្រះគម្ពីររបស់ពួកគេ ( សូមមើល ផែនទីប្រវត្តិសាស្ត្រសាសនាចក្រ ផែនទីទី ៥ « មិសសួរី អិលលីណោយ និង អៃអូវ៉ា តំបន់នៃ ស.រ.អា. » និង រូបថតប្រវត្តិសាសនាចក្រ រូបថតទី ១០ « អ័ដាម អុនដៃ អាម៉ាន ») ។




សូមពន្យល់ថា វិវរណៈនេះប្រាប់ពីទីតាំងនៃការបំពេញការព្យាករណ៍នាអនាគតដែលបានព្យាករណ៍តាំងពីបុរាណដោយព្យាការីដានីយ៉ែល ( សូមមើល ដានីយ៉ែល ៧:៩–១០, ១៣–១៤) ។ ការព្យាករណ៍នោះពិពណ៌នាអំពីព្រឹត្តិការណ៍នៃថ្ងៃចុងក្រោយដែលព្រះអង្គសង្គ្រោះ និង អ័ដាម នឹងមកផែនដី ហើយធ្វើជាអធិបតីលើការប្រជុំមួយពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទដល់ពិភពលោកទាំងមូល ( សូមមើល គ. និង ស. ២៧:៥–១៤) ។ សូមគិតអំពីការបញ្ចូលមេរៀនដោយឲ្យសិស្សច្រៀងទំនុកតម្កើងបទ « Adam–ondi–Ahman » (*ទំនុកតម្កើង* លេខ ៤៩ ) ។

មេរៀនទី ១២៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–១១៨

## បុព្វកថា

នៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៨៣៨នៅ ហ្វា វេស រដ្ឋ មិសសួរី ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈបួនដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–១២០ ។ ក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧, ព្រះអម្ចាស់បានចេញបញ្ជាដល់នូវែល ខេ វិតនី និង វិលលាម ម៉ាក្ស ដើម្បីចាត់ចែងធុរកិច្ចរបស់ខ្លួនយ៉ាងឆាប់នៅក្នុងទីក្រុង ខឺតឡង់ ហើយចូលរួមជាមួយពួកបរិសុទ្ធស្មោះត្រង់ ដែលបានប្រមូលផ្ដុំគ្នានៅហ្វា វេស ។ ព្រះអម្ចាស់បានមានព្រះបន្ទូលផងដែរថា អូលីវើរ គ្រេងគើរ ត្រូវបម្រើជាអ្នកតំណាងនៃគណៈប្រធានទីមួយដើម្បីលក់ទ្រព្យសម្បត្តិសាសនាចក្រ និង ចាត់ចែងធុរកិច្ចរបស់យ៉ូសែប ស្ម៊ីធ ។ នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨, ព្រះអម្ចាស់បានហៅសាវកថ្មីឲ្យបំពេញកន្លែងរបស់អស់អ្នកដែលបានវង្វេងចេញ ហើយបានហៅសមាជិកទាំងអស់នៃកូរ៉ុមនៃពួកដប់ពីរនាក់ឲ្យបម្រើបេសកកម្មនៅចក្រភព អង់គ្លេស ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១–១១

*ព្រះអម្ចាស់បញ្ជា វិលលាម ម៉ាក្ស និង នូវែល ខេ វិតនី ឲ្យចាត់ចែងធុរកិច្ចរបស់ពួកគេឲ្យបានលឿន ហើយចាកចេញពីទីក្រុង ខឺតឡង់*

សូមឲ្យសិស្សធ្វើបញ្ជីមូលហេតុដែលបុគ្គលម្នាក់អាចស្ទាក់ស្ទើរធ្វើតាមព្រះបញ្ញត្តិមួយពីព្រះអម្ចាស់ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។

សូមអញ្ជើញសិស្សឲ្យពិនិត្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១ ហើយរកមើលថាតើវិវរណៈនេះត្រូវបានប្រទានឲ្យដល់នរណា ? សូមពន្យល់ថា នូវែល ខេ វិតនី គឺជាប៊ីស្សពនៅក្នុងទីក្រុង ខឺតឡង់ ។ លោកគឺជាម្ចាស់អាជីវកម្មដ៏មានជោគជ័យម្នាក់ ហើយលោកបានលះបង់ទ្រព្យសម្បត្តិខ្លួនយ៉ាងច្រើនដល់សាសនាចក្រ ។ វិលលាម ម៉ាក្ស ត្រូវបានហៅឲ្យបម្រើជាភ្នាក់ងារដល់ប៊ីស្សព វិតនីនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៨៣៧ ។ លោកមាន មុខរបរបើកហាងលក់សៀវភៅ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់បានបង្គាប់ឲ្យរាស្ត្ររបស់ទ្រង់ធ្វើអ្វីខ្លះ ។ ( អ្នកអាចនឹងពន្យល់ថាពាក្យ*ចាប់ផ្ដើមធ្វើការ*មានន័យថា ផ្ដើមធ្វើ) ។

- តើព្រះអម្ចាស់បានបញ្ជាឲ្យ នូវែល ខេ វិតនី និង វិលលាម ម៉ាក្សធ្វើអ្វីខ្លះ ? ( ទ្រង់បានបញ្ជាពួកគេឲ្យចាត់ចែងធុរកិច្ចរបស់ពួកគេឲ្យបានលឿន ហើយចាកចេញពីទីក្រុង ខឺតឡង់ ។ ពួកគេត្រូវធ្វើដំណើរពីមុនព្រះអម្ចាស់នឹងចាត់ឲ្យព្រិលធ្លាក់នៅតំបន់នោះ ។ ម្យ៉ាងទៀត ពួកគេត្រូវតែចាកចេញក្នុងរយៈពេលបួនខែ ) ។

សូមរំឭកសិស្សថា នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣៨ ព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធឲ្យប្រមូលផ្ដុំគ្នានៅ ហ្វា វេស រដ្ឋមិសសួរី និង កន្លែងផ្សេង ៗទៀត ( សូមមើល គ. និង ស. ១១៥:១៧–១៨) ។ នៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ១៨៣៨ ក្រុមមួយដែលបានស្គាល់ថាក្រុមបោះជំរុំខឺតឡង់ ដែលមានពួកបរិសុទ្ធជាង ៥០០ នាក់មកពីតំបន់ ខឺតឡង់ បានចេញដំណើរទៅរដ្ឋមិសសួរី ( សូមមើល *Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទី ២ [ Church Educational System manual, ឆ្នាំ ២០០៣ ] ទំព័រ ១៧៨–៧៩ ) ។

សូមចង្អុលបង្ហាញថា នៅពេលយើងអានព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:៤–៥, នោះយើងឃើញថាប៊ីស្សព វិតនី និង វិលលាម ម៉ាក្ស បានបារម្ភជាខ្លាំងអំពីទ្រព្យសម្បត្តិសាសនាចក្រនៅក្នុងទីក្រុង ខឺតឡង់ ។ ដោយសារតែការហៅបម្រើរបស់ពួកគេជាប៊ីស្សព និង ជាភ្នាក់ងាររបស់ប៊ីស្សព នោះពួកគេមានទំនួលខុសត្រូវលើទ្រព្យសម្បត្តិទាំងនេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ខ ៤ ឲ្យឮៗ ហើយសូមសិស្សឲ្យស្ដាប់សំណួររបស់ព្រះអម្ចាស់នៅក្នុងខនេះ ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្ដារខៀន ៖ *តើអ្វីទៅជារបស់របរដល់យើង ?*

- តើអ្នកគិតថាវាមានន័យយ៉ាងណា ?

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃសំណួររបស់ព្រះអម្ចាស់នៅក្នុង ខ ៤, សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេនគ្នាអានឲ្យឮៗដកស្រង់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:៥–៨ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកមូលហេតុដែលព្រះអម្ចាស់នឹងមានព្រះបន្ទូលថា « តើអ្វីទៅជារបស់របរដល់យើង ? » ( អ្នកអាចពន្យល់ថាឃ្លា « ភ្នំទាំងឡាយនៅអូឡាហា ស៊ីនេហា » សំដៅលើតំបន់ដែលនៅជុំវិញ អ័ដាម អុនដៃ អាម៉ាននៅក្នុងរដ្ឋ មិសសួរី ) ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « លោភចង់បាន. . .តំណក់ ហើយចោលសេចក្ដីដែលមានទម្ងន់ជាងឬ ? » (គ. និង ស. ១១៧:៨) ។ តើទ្រព្យសម្បត្តិនៅក្នុងទីក្រុង ខឺតឡង់ « តំណក់ » ប្រៀបធៀបទៅនឹងពរជ័យដែលព្រះអម្ចាស់អាចប្រទានដល់ប៊ីស្សព វិតនី និងប្រធានម៉ាក្សយ៉ាងដូចម្ដេច ? ( បន្ទាប់ពីសិស្សពិភាក្សាសំណួរទាំងនេះ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **ការលោភចង់បានទ្រព្យសម្បត្តិខាងសាច់ឈាមអាចបណ្ដាលឲ្យយើងចោលសេចក្ដីដែលមានទម្ងន់ជាង**) ។

សូមឲ្យសិស្សពិចារណាអំពីរបៀបដែលពួកគេអាចផ្ដោតយកចិត្តទុកដាក់កាន់តែខ្លាំង ទៅលើអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់ពួកគេ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១០ ដោយពន្យល់ថា ព្រះអម្ចាស់បានឲ្យវិលលាម ម៉ាក្ស បន្តបម្រើជាអ្នកដឹកនាំសាសនាចក្រ នៅពេលលោកទៅដល់ ហ្វា វេស ។ ព្រះអម្ចាស់មានបន្ទូលផងដែរថា បើសិនប្រធាន ម៉ាក្សនឹងនៅបន្ត « ស្មោះត្រង់ត្រួតលើរបស់បន្តិចនេះ » នោះនៅទីបំផុតលោកនឹង « ត្រួតលើរបស់ជាច្រើន » ទៀត ( សូមមើល ម៉ាថាយ ២៥:២៣) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១១ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់ឲ្យរកមើលការស្ដីបន្ទោសរបស់ព្រះអម្ចាស់ចំពោះ នូវល ខេ វិតនី ។ បន្ទាប់ពីសិស្សអានខគម្ពីរនេះហើយ សូមពន្យល់ថាពួកនីកូឡាគឺពួកនិកាយសាសនាពីបុរាណ ។ ពួកគេបាននិយាយថាពួកគេជាពួកគ្រិស្តសាសនិក ប៉ុន្តែពួកគេវង្វេងចេញពីគោលការណ៍ដំណឹងល្អ ហើយធ្វើតាមការប្រតិបត្តិខាងលោកិយ ( សូមមើល *Doctrine and Covenants Student Manual* [ Church Educational System manual, ឆ្នាំ ២០០១ ] ទំព័រ ២៩០ ) ។

- បើសិន នូវល ខេ វិតនី បានសម្រេចចិត្តផ្ដោតលើទ្រព្យសម្បត្តិនៅទីក្រុង ខឺតឡង់ច្រើនជាងការប្រមូលផ្ដុំជាមួយពួកបរិសុទ្ធ តើទង្វើរបស់គាត់អាចស្រដៀងទៅនឹងទង្វើរបស់ពួកនីកូឡាយ៉ាងដូចម្ដេច ?

សូមពន្យល់ថាដោយសារការពន្យាពេលចេញដំណើររបស់ពួកគេពីទីក្រុងខឺតឡង់ និង ការបៀតបៀននៅរដ្ឋ មិសសួរី វិលលាម ម៉ាក្ស និង នូវល ខេ វិតនីពុំអាចមកជួបជុំពួកបរិសុទ្ធនៅ ហ្វា វេសឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានធ្វើតាមព្រះឱវាទរបស់ព្រះអម្ចាស់ ហើយបន្តស្មោះត្រង់ ហើយក្រោយមកពួកគេប្រមូលផ្ដុំជាមួយពួកបរិសុទ្ធនៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ជាកន្លែងដែល វិលលាម ម៉ាក្ស បានបម្រើជាប្រធានស្ដេក ហើយ នូវល ខេ វិតនី បានបម្រើជាប៊ីស្សព ។

> ### *សំណួរទាំងឡាយដែលនាំសិស្សឲ្យវិភាគសម្រាប់ការយល់ដឹង*
> សូមប្រើសំណួរវិភាគទាំងឡាយ ដើម្បីលើកទឹកចិត្តសិស្សឲ្យគិតអំពីអត្ថន័យនៃខគម្ពីរដែលពួកគេកំពុងសិក្សា ។ ជាញឹកញាប់ សំណួរបែបនេះចាប់ផ្ដើមដោយឃ្លាដូចជា « ហេតុអ្វីបានជាអ្នកគិតថា » ឬ « តើអ្នកគិតថាយ៉ាងម៉េចដែរ » ។ ឧទាហរណ៍ អ្នកអាចសួរថា « តើអ្នកគិតថា ( ឃ្លា ឬ ពាក្យ ) នេះមានន័យយ៉ាងម៉េចដែរ ? » ជាធម្មតាអ្នកគួរតែសួរសំណួរទាំងនេះ ក្រោយពីសិស្សស្គាល់ខគម្ពីរដែលអ្នកកំពុងសួរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១២–១៦

*ព្រះអម្ចាស់ ផ្ដល់សិទ្ធិអំណាចដល់អូលីវើរ គ្រេងគើរ តំណាងគណៈប្រធានទីមួយនៅក្នុងការដោះស្រាយធុរកិច្ចនៅទីក្រុង ខឺតឡង់*

សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្ដារខៀន នូវការហៅបម្រើផ្សេងៗ ឬ ការចាត់តាំងរបស់សាសនាចក្រដែលពួកគេអាចទទួល ។

សូមពន្យល់ថាព្រះអម្ចាស់បានបញ្ជាបុរសម្នាក់ឈ្មោះ អូលីវើរ គ្រេងគើរ ឲ្យចាកចេញពី ហ្វា វេស ហើយត្រឡប់ទៅទីក្រុងខឺតឡង់ដើម្បី « ឧស្សាហ៍ធ្វើការ ដើម្បីសេចក្ដីប្រោសលោះនៃគណៈប្រធានទីមួយក្នុងសាសនាចក្ររបស់យើងចុះ » (គ. និង ស. ១១៧:១៣) ។ ការចាត់តាំងនេះរួមមានការលក់ទ្រព្យសម្បត្តិសាសនាចក្រ និង ចាត់ចែងធុរកិច្ចរបស់យ៉ូសែបស្ម៊ីធ ។ ការណ៍នេះនឹងតម្រូវឲ្យអូលីវើរ គ្រេងគើរ ដែលជិតនឹងងងឹតភ្នែកនោះធ្វើការលះបង់ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១២–១៥ ដោយស្ងាត់ស្ងៀម រកមើលពរជ័យដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា អូលីវើរ គ្រេងគើរនឹងទទួលនៅពេលលោកបំពេញការចាត់តាំងនេះ ។

- តើពរជ័យអ្វីខ្លះដែលអូលីវើរ គ្រេងគើរនឹងទទួល ?

- តើព្រះអម្ចាស់មានព្រះទ័យយ៉ាងណា ចំពោះការបូជារបស់អូលីវើរ គ្រេងគើរ ? ( អ្នកអាចត្រូវពន្យល់ថាសេចក្ដីថ្លែងការណ៍ថា « ការបូជារបស់គាត់នឹងត្រូវបានរាប់ថាពិសិដ្ឋដល់យើងជាងការតម្លើងរបស់គាត់ទៅទៀត » បង្ហាញថាព្រះអម្ចាស់យកព្រះទ័យទុកដាក់យ៉ាងខ្លាំងអំពីការបូជារបស់អូលីវើរ ជាជាងលុយដែលអូលីវើរអាចទទួល នៅពេលគាត់បំពេញការចាត់តាំងរបស់គាត់ ។ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **ការបូជាដែលយើងធ្វើនៅក្នុងការបម្រើរបស់ព្រះអម្ចាស់គឺពិសិដ្ឋចំពោះទ្រង់**) ។

សូមមើលទៅការហៅបម្រើ និង ការចាត់តាំងដែលអ្នកបានសរសេរនៅលើក្ដារខៀន ។ សូមសួរសិស្សថា តើការហៅបម្រើ និង ការចាត់តាំងនេះតម្រូវឲ្យធ្វើការបូជាអ្វីខ្លះ ។

- ហេតុអ្វីបានជាសំខាន់ដើម្បីធ្វើអ្វីៗទាំងអស់ ដែលយើងអាចបំពេញការចាត់តាំង ឬ ការហៅបម្រើ ?

សូមពន្យល់ថា អូលីវើរ គ្រែងគើរ បានស្លាប់នៅក្នុងទីក្រុង ខឺតឡង់ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៨៤១ ។ នៅពេលនោះ លោកបានបន្តធ្វើជាគណៈប្រធានទីមួយ ដែលតំណាងឲ្យធុរកិច្ចរបស់ពួកគេ ។ ទោះបីជាលោក ពុំបានជោគជ័យពេញលេញនៅក្នុងការចាត់ចែងធុរកិច្ចរបស់សាសនាចក្រ នោះលោកបានធ្វើការដោយរក្សាសេចក្ដីថ្លៃថ្នូររបស់សាសនាចក្រ និង កិត្តិនាមល្អ ។ លោកពិតចំពោះព្រះអម្ចាស់ និង ព្យាការី យ៉ូសែប ស្ម៊ីធ ។

សូមឲ្យសិស្សម្នាក់អានឮៗពីសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ប៊យដ៍ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« តើ អូលីវើរ គ្រែងគើ បានធ្វើអ្វី បានជាឈ្មោះគាត់គួរត្រូវបានរំឭកយ៉ាងពិសិដ្ឋ ? គាត់មិនបានធ្វើអ្វីច្រើនទេ ។ វាមិនមែនជាអ្វីដែលគាត់បានធ្វើនោះទេ ប៉ុន្តែគឺខ្លួនគាត់ផ្ទាល់ទេតើ ។. . .

« ព្រះអម្ចាស់មិនបានរំពឹងឲ្យ អូលីវើ មានភាពឥតខ្ចោះនោះទេ ប្រហែលជាមិនរំពឹងឲ្យគាត់ជោគជ័យផងដែរ ។. . .

« យើងមិនអាចរំពឹងដើម្បីមានជោគជ័យជានិច្ចនោះទេ ប៉ុន្តែយើងគួរតែព្យាយាមឲ្យអស់ពីសមត្ថភាពដែលយើងអាចធ្វើបាន » (The Least of These » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០០៤ ទំព័រ ៨៦ ) ។

- ហេតុអ្វីបានជាអ្នកគិតថាការបូជារបស់យើងគឺពិសិដ្ឋចំពោះព្រះអម្ចាស់ ទោះបីជាយើងពុំមានអារម្មណ៍ថាមានជោគជ័យពេញលេញក្នុងកិច្ចខិតខំរបស់យើងនោះក្ដី ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨

*ព្រះអម្ចាស់បានតែងតាំងសាវកថ្មី ហើយហៅសាវកទាំងអស់ឲ្យបម្រើបេសកកម្ម ។*

សូមពន្យល់ថានៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៨៣៨ ព្រះអម្ចាស់បានហៅសាវកថ្មីបួននាក់ដើម្បីជំនួស លូកា ចនសុន, ឡៃម៉ាន អ៊ី ចនសុន, វិលលាម អ៊ី ម៉ុកខ្លេលិន និង យ៉ូហាន អេហ្វ បោញតុន ដែលបានក្បត់សាសនា ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨:៣ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់មានព្រះហឫទ័យចង់ឲ្យសាវកធ្វើ ។

- តើព្រះអម្ចាស់បានបញ្ជាឲ្យសាវករបស់ទ្រង់ឲ្យធ្វើអ្វី ?

- តើពាក្យ និង ឃ្លាអ្វីដែលនៅក្នុង ខ ៣ ដែលពិពណ៌នាពីរបៀបដែលព្រះអម្ចាស់ចង់ឲ្យសាវកបង្រៀនដំណឹងល្អ ?

សូមសរសេរឃ្លាខាងក្រោមនៅលើក្ដារខៀន ៖ *បើយើងបង្រៀនដំណឹងល្អតាមរបៀបរបស់ព្រះអម្ចាស់. . .*

- ដោយផ្អែកលើ ខ ៣, តើរបៀបពីរយ៉ាងអ្វីខ្លះដែលយើងអាចបំពេញប្រយោគនេះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **បើយើងបង្រៀនដំណឹងល្អតាមរបៀបរបស់ព្រះអម្ចាស់ នោះទ្រង់នឹងផ្គត់ផ្គង់ដល់គ្រួសាររបស់យើង ។ បើសិនយើងបង្រៀនដំណឹងល្អតាមរបៀបរបស់ព្រះអម្ចាស់ នោះទ្រង់នឹងរៀបចំមនុស្សដទៃឲ្យទទួលសារលិខិតរបស់ទ្រង់**) ។

អ្នកអាចសូមឲ្យសិស្សចែកចាយពីរបៀបដែលពួកគេត្រូវបានប្រទានពរ តាមរយៈកិច្ចការអ្នកផ្សព្វផ្សាយសាសនា ជាមួយបងប្អូនបង្កើត ឬ សមាជិកគ្រួសារដទៃទៀត ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨:៤–៥ ដោយពន្យល់ថា ព្រះអម្ចាស់បានហៅសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យ « ចេញទៅលើទឹកដ៏ធំធេង » ( មហាសមុទ្រ អាត្លង់ទិច ) ដើម្បីប្រកាសដំណឹងល្អរបស់ទ្រង់ ដោយចាប់ផ្ដើមបេសកកម្មរបស់ពួកគេនៅបរិវេណព្រះវិហារបរិសុទ្ធនៅ ហ្វា វេស ។ ពួកគេនឹងបម្រើនៅក្នុងចក្រភពអង់គ្លេស ។

- យោងតាម ខ ៥ តើសាវកទាំងនេះនឹងចេញទៅបម្រើបេសកកម្មនៅពេលណា ? តើពួកគេចាកចេញពីកន្លែងណា ?

សូមពន្យល់ថា ប៉ុន្មានខែក្រោយពីវិវរណៈនេះផ្ដល់ឲ្យ នោះការបៀតបៀនបានកើនឡើងនៅក្នុងរដ្ឋ មិសសួរី ។ នៅទីបំផុតពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីរដ្ឋនោះ ។ ស្ថានការណ៍នេះបានបង្កគ្រោះថ្នាក់ដល់ពួកបរិសុទ្ធ ក្នុងការបំពេញព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីទៅជួបជុំគ្នានៅក្រុងហ្វាវែស្ទ ។ ប្រជាជនរដ្ឋ មិសសួរី បានអួតអាងយ៉ាងបើកចំហរថា ពួកគេ

នឹងទប់ស្កាត់មិនឲ្យវិវរណៈរបស់ព្រះអម្ចាស់បានសម្រេច ។ ប៉ុន្តែពួកដប់ពីរនាក់បានសម្រេចចិត្តធ្វើតាមការបញ្ជារបស់ព្រះអម្ចាស់ ។ នៅព្រឹកថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៨៣៩ អែលឌើរ ព្រិកហាំ យ៉ង់, ហីប៊ើរ ស៊ី គិលបុល និង អូរសុន ប្រាត្ត ជាមួយនឹងអែលឌើរ យ៉ូហាន អ៊ី ភេច និង យ៉ូហាន ថេល័រ ដែលបច្ចុប្បន្ននេះត្រូវបានតែងតាំងជាសាវក ( សូមមើល គ. និង ស. ១១៨:៦), បានទៅបរិវេណព្រះវិហារបរិសុទ្ធ ហ្វា វេស ។ ( ពុំមានសមាជិកស្មោះត្រង់ទាំងអស់នៃកូរ៉ុមអាចនៅទីនោះរហូតឡើយ ។ ឧទាហរណ៍ អែលឌើរ ប៉ាលី ភី ប្រាត្តត្រូវបានចាប់ខ្លួន ហើយដាក់គុកដោយសារការចោទប្រកាន់ខុសឆ្គង ) ។ ពួកគេបានផ្ដល់អនុសាសន៍ឲ្យចាក់គ្រឹះនៃព្រះវិហារបរិសុទ្ធ ( សូមមើល គ. និង ស. ១១៥:១១) ដោយដាក់ថ្មធំមួយនៅក្បែរកាច់ជ្រុងទិសខាងត្បូងនៃទីតាំងនោះ ។ ពួកគេក៏បានតែងតាំង សាវកថ្មី អែលឌើរ វិលហ្វូឌ វូឌ្រុព្វ ( សូមមើល គ. និង ស. ១១៨:៦) និង ចច អេ ស្ម៊ីធ ឲ្យបំពេញមុខងារនៅក្នុងកូរ៉ុមនៃពួកដប់ពីរនាក់ ។ ដោយការបំពេញតាមការណែនាំរបស់ព្រះអម្ចាស់ នោះពួកគេបានចាកចេញ ដែលអស់អ្នកដែលរៀបផែនការបញ្ឈប់ពួកគេពុំចាប់ពួកលោកបានឡើយ ។ វិលឡ៊ឺឌ រិចិឌ្ស ដែលបាននិយាយនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨:៦ ត្រូវបានតែងតាំងជាសាវកប្រហែលជាមួយឆ្នាំក្រោយមកនៅថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៨៤០ ។ ( សម្រាប់ដំណើររឿងពេញលេញបន្ថែមទៀតអំពីបទពិសោធន៍នេះ សូមមើល *Teachings of Presidents of the Church: Wilford Woodruff* [ ឆ្នាំ ២០០៤ ], ទំព័រ ១៣៩–៤១) ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀនថ្ងៃនេះ ។

មេរៀនទី ១២៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩–១២០

## បុព្វកថា

នៅក្នុងរដូវក្ដៅឆ្នាំ ១៨៣៨ ពួកបរិសុទ្ធកំពុងជួបវិបត្តិខាងផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង នៅពេលពួកគេព្យាយាមស្ថាបនាសាសនាចក្រនៅក្នុងរដ្ឋ មិសសួរីភាគខាងជើង ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានព្យាយាមសុំការណែនាំពីព្រះអម្ចាស់ ហើយនៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៨៣៨ លោកបានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩ និង ១២០ ។ នៅក្នុងវិវរណៈទាំងនេះ ព្រះអម្ចាស់បានបង្រៀនច្បាប់ដង្វាយមួយភាគក្នុងដប់ និង បានផ្ដល់សិទ្ធិជាក់លាក់ដល់ថ្នាក់ដឹកនាំសាសនាចក្រ ដើម្បីសម្រេចពីរបៀបដែលមូលនិធិនៃដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:១–៤

*ព្រះអម្ចាស់បើកសម្ដែងពីច្បាប់ដង្វាយមួយភាគក្នុងដប់*

សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោមឲ្យឮៗ ដែលបានប្រាប់ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ៖



« ស្ត្រីម្នាក់នៅក្នុងទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល. . .បានធ្វើការផង និង រៀនផងដើម្បីផ្គត់ផ្គង់គ្រួសារនាង ។ ខ្ញុំសូមប្រើពាក្យពេចន៍ផ្ទាល់របស់នាងក្នុងការប្រាប់រឿងនេះ ។ នាងថ្លែងថា ៖

« សាកលវិទ្យាល័យដែលខ្ញុំបានសិក្សានោះ មានច្បាប់មួយដែលហាមឃាត់សិស្សដែលមិនទាន់បង់លុយឲ្យធ្វើការប្រឡងនោះឡើយ ។. . .

« ‹ ខ្ញុំបានចាំពីពេលមួយ នៅពេលដែលខ្ញុំ . . . មានបញ្ហាលំបាកខ្លាំងខាងផ្នែកហិរញ្ញវត្ថុ ។. . . នៅពេលដែលខ្ញុំចាត់ចែងថវិកាប្រចាំខែរបស់ខ្ញុំ នោះខ្ញុំចាប់អារម្មណ៍ថា គ្មានប្រាក់គ្រប់គ្រាន់ដើម្បីបង់ [ ទាំង ] ដង្វាយមួយភាគក្នុងដប់ និង ថ្លៃសាកលវិទ្យាល័យរបស់ខ្ញុំ ។ ខ្ញុំត្រូវតែជ្រើសរើសរវាងតម្រូវការទាំងពីរនោះ ។ ការប្រឡងរៀងរាល់ពីរខែម្ដង នឹងចាប់ផ្ដើមនៅសប្ដាហ៍បន្ទាប់ ហើយបើសិនខ្ញុំមិនបានប្រឡងទេ នោះខ្ញុំនឹងធ្លាក់ក្នុងឆ្នាំនោះ ។ ខ្ញុំមានអារម្មណ៍ច្របូកច្របល់យ៉ាងខ្លាំង ។. . . ខ្ញុំមានការសម្រេចចិត្តដ៏ពិបាកក្រៃលែងនៅចំពោះមុខ ហើយខ្ញុំមិនដឹងថាត្រូវសម្រេចចិត្តយ៉ាងណានោះទេ › » (We Walk by Faith » *Ensign,* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ៧៣ ) ។

- តើអ្នកនឹងនិយាយយ៉ាងដូចម្ដេចទៅកាន់មនុស្សម្នាក់ដែលស្ថិតនៅក្នុងស្ថានភាពដ៏លំបាកបែបនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងបន្តទៀត ៖



« ‹ អារម្មណ៍នេះបាននៅតែដក់ក្នុងគំនិតខ្ញុំ ហើយនៅជាប់នឹងខ្ញុំ [ អស់ជាច្រើនថ្ងៃ ] ។ បន្ទាប់មក ខ្ញុំបានចងចាំថា នៅពេលខ្ញុំបានជ្រមុជទឹក ខ្ញុំបានយល់ព្រមដើម្បីរស់នៅតាមច្បាប់ដង្វាយមួយភាគក្នុងដប់ ។ ខ្ញុំបានលើកដាក់មកលើខ្លួនខ្ញុំនូវកាតព្វកិច្ចនេះ មិនមែនជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនានោះទេ ប៉ុន្តែជាមួយនឹងព្រះវរបិតាសួគ៌របស់ខ្ញុំ ។ នៅពេលនោះ ការឈឺចាប់បានចាប់ផ្ដើមវិនាសបាត់ទៅ ដោយបន្សល់ទុកនូវអារម្មណ៍ដ៏រីករាយនៃភាពស្ងប់ស្ងាត់ និងការប្ដេជ្ញាចិត្ត ។. . .

« ‹ នាយប់នោះ នៅពេលខ្ញុំបានអធិស្ឋាន ខ្ញុំបានទូលសុំព្រះអម្ចាស់ឲ្យអភ័យទោសឲ្យខ្ញុំចំពោះការសម្រេចចិត្តរបស់ខ្ញុំ ។ នៅថ្ងៃអាទិត្យ. . .ខ្ញុំបានបង់ដង្វាយមួយភាគក្នុងដប់ និង ដង្វាយតមអាហារដោយក្ដីរីករាយបំផុត ។ នោះគឺជាថ្ងៃមួយដ៏ពិសេស ។ ខ្ញុំមានអារម្មណ៍រីករាយ និង មានភាពសុខសាន្តនៅក្នុងដួងចិត្តខ្ញុំជាមួយនិង ព្រះវរបិតាសួគ៌ › » (We Walk by Faith » ទំព័រ ៧៣ ) ។

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចឆ្លើយតបចំពោះស្ថានភាពនេះ ។ សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍នានាអំឡុងពេលពួកគេសិក្សាខគម្ពីរថ្ងៃនេះ ដែលអាចជួយពួកគេនៅពេលពួកគេជួបស្ថានភាពស្រដៀងគ្នានេះ ។

សូមពន្យល់ថានៅដើមឆ្នាំ ១៨៣៧ សាសនាចក្រកំពុងជួបវិបត្តិខាងផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង ព្រមទាំងសមាជិកនៃសាសនាចក្រជាច្រើននាក់ទៀតផងដែរ ។ បញ្ហាហិរញ្ញវត្ថុនេះបណ្ដាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់ប្រទេស មនុស្សកំណាចប្រើអំពើហិង្សានៅក្នុងរដ្ឋ មិសសួរី និង រដ្ឋ អូហៃអូ ដែលបណ្ដេញពួកបរិសុទ្ធចេញពីផ្ទះសម្បែងរបស់ខ្លួន និងពួកបរិសុទ្ធមួយចំនួនគ្មានឆន្ទៈដើម្បីរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ នៅឆ្នាំ ១៨៣៨ ជាមួយនឹងការប្រមូលផ្ដុំនៃពួកបរិសុទ្ធទៅកាន់ឃុំ ខលវ៉េល រដ្ឋ មិសសួរី សាសនាចក្រត្រូវការប្រាក់ដើម្បីសម្រេចចំពោះអ្វីដែលព្រះអម្ចាស់បានចេញបញ្ជាដល់ពួកគេឲ្យធ្វើ ដូចជាការសាងសង់ព្រះវិហារបរិសុទ្ធនៅហ្វា វេស ។ ប៊ីស្សពនៅក្នុងរដ្ឋ អូហៃអូ និង មិសសួរី ត្រូវបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យនាំដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗរបស់ខ្លួនទៅទុកក្នុងឃ្លាំង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីណែនាំ នៃក្បាលកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលយ៉ូសែប ស្ម៊ីធបានទូលសួរនៅពេលនោះ ។

- តើយ៉ូសែប ស្ម៊ីធ បានសួរអ្វីខ្លះដល់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលចម្លើយរបស់ព្រះអម្ចាស់ ចំពោះការស្នើសុំរបស់យ៉ូសែប ស្ម៊ីធ ។

- យោងតាម ខ ៤, តើដង្វាយមួយភាគក្នុងដប់គឺជាអ្វី ? ( សិស្សគួរតែរកឃើញព្រះបញ្ញត្តិខាងក្រោមនេះ ៖ **ព្រះអម្ចាស់បញ្ជាឲ្យពួកយើងបង់មួយភាគក្នុងដប់នៃទ្រព្យធនធានរបស់យើងថ្វាយទ្រង់ ទុកជាដង្វាយមួយភាគក្នុងដប់ ។** អ្នកអាចសរសេរព្រះបញ្ញត្តិនេះនៅលើក្ដារខៀន ) ។

ដើម្បីជួយសិស្សឲ្យយល់អត្ថន័យនៃពាក្យ *ធនធាន* នៅក្នុង ខ ៤ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហារើដ ដបុលយូ ហ៊ីនធើរ ឲ្យឮៗ ៖



« ក្រឹត្យវិន័យនេះគឺថ្លែងយ៉ាងសាមញ្ញថា ‹ មួយភាគដប់នៃធនធានទាំងអស់របស់ពួកគេ › ។ ធនធានមានន័យថា ប្រាក់ចំណេញ ប្រាក់សំណង ប្រាក់កំណើន ។ វាគឺជាប្រាក់ខែរបស់និយោជិតមួយរូប ជាប្រាក់ចំណេញពីការធ្វើអាជីវកម្ម ជាប្រាក់កំណើនរបស់បុគ្គលម្នាក់ដែលរីកចម្រើន ឬ រកបាន ឬ ជាប្រាក់ចំណូលរបស់មនុស្សម្នាក់ទោះមកពីប្រភពណាក៏ដោយ ។ ព្រះអម្ចាស់បានមានបន្ទូលថា វាជាក្រឹត្យវិន័យដែលនៅ ‹ អចិន្ត្រៃយ › ដូចដែលវាមានពីបុរាណកាលផងដែរ » ( នៅក្នុង Conference Report, ខែ មេសា ឆ្នាំ ១៩៦៤, ទំព័រ ៣៥ ) ។

- តើអ្នករៀនអ្វីខ្លះពីការបញ្ជារបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធឲ្យថ្វាយដង្វាយមួយភាគក្នុង នៅចំពេលដែលវាមានការលំបាកចំពោះពួកគេដើម្បីធ្វើការណ៍នោះដូច្នេះ ?

- តើការបង់ដង្វាយមួយភាគក្នុងដប់ជាទង្វើធ្វើឡើងដោយសេចក្ដីជំនឿតាមរបៀបណាខ្លះ ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបបង់ដង្វាយមួយភាគក្នុងដប់ សូមបង្ហាញក្រដាសបង់ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ ។ សូមឲ្យសិស្សស្រមៃថា ពួកគេទើបតែរកបានប្រាក់មួយចំនួន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យប៉ាន់ស្មានពីចំនួនប្រាក់នោះ ។

- តើប្រាក់ចំនួនប៉ុណ្ណឹងត្រូវបង់ដង្វាយមួយភាគដប់ប៉ុន្មាន ?

សូមកត់ចំនួនប្រាក់នៃដង្វាយមួយក្នុងដប់នោះនៅកន្លែងត្រឹមត្រូវនៅលើក្រដាសនោះ ហើយសួរសំណួរខាងក្រោម ៖

- ប្រសិនបើយើងចែក ១០ភាគរយនៃប្រាក់ចំណូលរបស់យើងក្នុងចំណោមខ្ទង់បរិច្ចាគផ្សេងៗទៀតនៅលើក្រដាសនេះ តើយើងបានបង់ដង្វាយមួយភាគក្នុងដប់ពេញលេញដែរឬទេ ? ( សូមប្រាកដថាសិស្សយល់ថា ១០ភាគរយនៃប្រាក់ចំណូលរបស់យើងគួរតែត្រូវដាក់ក្នុងខ្ទង់ដង្វាយមួយភាគក្នុងដប់ ។ ការបរិច្ចាគផ្សេងៗទៀតដែលពួកគេបរិច្ចាគ គឺជាមូលនិធិផ្សេងទៀតក្រៅពី ១០ភាគរយនោះ ) ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យពួកគេពន្យល់គ្នាទៅវិញទៅមកអំពីការយល់ដឹងរបស់ពួកគេ អំពីរបៀបដែលមូលនិធិនៃដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់ ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអានការពន្យល់របស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:២។

- យោងតាម ខ ២, តើមូលនិធិដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើសម្រាប់អ្វីខ្លះ ? ( ដង្វាយមួយភាគក្នុងដប់ ត្រូវបានប្រើ « សម្រាប់ការកសាងដំណាក់របស់ [ ព្រះអម្ចាស់ ] [ កសាងព្រះវិហារបរិសុទ្ធ ] និង « សម្រាប់ការសង់គ្រឹះនៃស៊ីយ៉ូន និង សម្រាប់បព្វជិតភាព » [ ផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ផ្នែកផ្សេងទៀតនៃកិច្ចការរបស់ព្រះអម្ចាស់ ដូចជាការសាងសង់ និងការថែរក្សាសាលាប្រជុំ ការបកប្រែ និងបោះពុម្ពព្រះគម្ពីរ និងការឧបត្ថមដល់អ្នកផ្សព្វផ្សាយសាសនា និងកិច្ចការពង្សប្រវត្តិនៅទូទាំងពិភពលោក ] ។ អ្នកអាចចង្អុលបង្ហាញថា សព្វថ្ងៃនេះសាសនាចក្រពុំជំពាក់បំណុលរបស់គេទេ ។ សូមសរសេរសេចក្ដីពិតខាងក្រោមនៅលើក្ដារខៀន ៖ **មូលនិធិនៃដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ និង ដើម្បីសម្រេចកិច្ចការរបស់ព្រះអម្ចាស់ ។**

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:៥–៧

### *ព្រះអម្ចាស់ពន្យល់ពីច្បាប់ដង្វាយមួយភាគក្នុងដប់*

> ***ការសម្ដែង***
>
> ការសម្ដែងជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អទៅក្នុងស្ថានភាពជីវិតជាក់ស្ដែង ។ ការសម្ដែងនឹងកាន់តែមានជោគជ័យបន្ថែមទៀត បើអ្នកផ្ដល់ឲ្យអ្នកចូលរួមសម្ដែងនូវព័ត៌មានគ្រប់គ្រាន់ ហើយផ្ដល់ពេលឲ្យរៀបចំខ្លួន ។ នៅពេលសិស្សសម្ដែង ពួកគេនឹងមានកំហុសឆ្គង ។ សូមយល់ពីអារម្មណ៍ និងអាកប្បកិរិយារបស់ពួកគេ ហើយមិនត្រូវរិះគន់ចំពោះកំហុសឆ្គងរបស់ពួកគេឡើយ ។ នៅចុងបញ្ចប់នៃការសម្ដែង វាអាចមានប្រយោជន៍ដើម្បីសួរអ្នកមើល បើមានគំនិតផ្សេងដែលពួកគេអាចនឹងលើកឡើង បើសិនពួកគេជាតួអង្គក្នុងការសម្ដែងវិញនោះ ។

សូមអញ្ជើញសិស្សពីរនាក់ឲ្យចូលរួមក្នុង ការសម្ដែងមួយ ។ សូមចាត់តាំងឲ្យសិស្សម្នាក់ធ្វើសមាជិកស្មោះត្រង់នៃសាសនាចក្រ ហើយសិស្សទីពីរដើរតួជាម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ។ សូមឲ្យសិស្សទីពីរនូវក្រដាសមួយសន្លឹកដោយសរសេរសំណួរខាងក្រោមនៅលើក្រដាសនោះ ៖ *ខ្ញុំបានឮថាអ្នកបានបង់ ១០ភាគរយនៃប្រាក់ចំណូលរបស់អ្នកទៅក្នុងសាសនាចក្ររបស់អ្នក ។ ហេតុអ្វីអ្នកចង់ធ្វើបែបនោះ ?*

សូមឲ្យសិស្សទីពីរអានសំណួរឲ្យឮៗ ហើយអញ្ជើញសិស្សទីមួយឲ្យឆ្លើយ ។ បន្ទាប់ពីសម្ដែងចប់ សូមសួរសិស្សក្នុងថ្នាក់ពីរបៀបដែលពួកគេអាចឆ្លើយចំពោះសំណួរនោះ ។ សូមចង្អុលបង្ហាញថាមានចម្លើយល្អៗជាច្រើនចំពោះសំណួរនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកអ្វីដែលបានសម្រេចដោយការធ្វើតាមច្បាប់ដង្វាយមួយភាគក្នុងដប់នេះ ។

- យោងតាម ខ ៦ តើមានអ្វីខ្លះដែលសម្រេចបានតាមរយៈការគោរពប្រតិបត្តិចំពោះច្បាប់ដង្វាយមួយភាគក្នុងដប់ ? ( ញែកដែនដីស៊ីយ៉ូនចេញជាបរិសុទ្ធដល់ព្រះអម្ចាស់ ) ។

ដើម្បីជួយសិស្សឲ្យយល់ខគម្ពីរនេះ សូមពន្យល់ថាការញែកចេញជាបរិសុទ្ធ សំដៅលើការគ្មានអំពើបាប—បរិសុទ្ធ ស្អាតស្អំ និងបរិសុទ្ធតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះ សូមរំឭកសិស្សថាស៊ីយ៉ូនគឺជាមានន័យលើសពីទីតាំងទៅទៀត វាគឺជាមនុស្សដែលជា« អ្នកដែលមានចិត្តល្អសុទ្ធសាធ » (គ. និង ស. ៩៧:២១) ។

សូមអញ្ជើញសិស្សឲ្យសង្ខេបឥទ្ធិពលនៃការគោរពតាមច្បាប់ដង្វាយមួយភាគក្នុងដប់ជាពាក្យសម្ដីផ្ទាល់របស់ខ្លួន ។ ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នាក្ដី ពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **ការបង់ដង្វាយមួយភាគក្នុងដប់ញែកយើងម្នាក់ៗ និង សាសនាចក្រចេញជាបរិសុទ្ធ ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។ អ្នកអាចស្នើថា សិស្សគួរតែសរសេរវានៅក្បែរគែមទំព័រនៃព្រះគម្ពីររបស់ពួកគេ ។

ដើម្បីជួយសិស្សឲ្យយល់ និងទទួលអារម្មណ៍ពីភាពសំខាន់នៃគោលការណ៍នេះ សូមឲ្យពួកគេឆ្លើយសំណួរមួយខាងក្រោមនេះនៅក្នុងសៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ឬ សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ខ្លួន ៖

- តើការបង់ដង្វាយមួយភាគក្នុងដប់បានជួយញែកអ្នកចេញជាបរិសុទ្ធយ៉ាងដូចម្ដេច ?
- តើអ្នកគិតថាការបង់ដង្វាយមួយភាគក្នុងដប់នឹងជួយមនុស្សម្នាក់ឲ្យត្រូវបានញែកចេញជាបរិសុទ្ធតាមវិធីណា ?

ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់ពីអ្វីដែលពួកគេបានសរសេរ ។ អ្នកក៏អាចចែកចាយនូវបទពិសោធន៍មួយ និង ថ្លែងទីបន្ទាល់របស់ខ្លួនអំពីច្បាប់ដង្វាយមួយភាគក្នុងដប់នេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២០

### *ព្រះអម្ចាស់បង្កើតក្រុមប្រឹក្សា លើការរៀបចំដង្វាយមួយ ភាគក្នុងដប់*

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីណែនាំក្បាលកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលបំណងនៃវិវរណៈនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២០:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលថានរណាដែលព្រះអម្ចាស់បានជ្រើសរើសដើម្បីធ្វើជាផ្នែកមួយនៃក្រុមប្រឹក្សាដែលសម្រេចពីរបៀបដែលមូលនិធិនៃដង្វាយមួយភាគក្នុងដប់ត្រូវចំណាយ ។

- តើនរណាជាអ្នកសម្រេចពីរបៀបដើម្បីប្រើប្រាស់មូលនិធិនៃដង្វាយមួយភាគក្នុងដប់ ?

អ្នកអាចពន្យល់ថាក្រុមប្រឹក្សាដែលបាននិយាយនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២០ គឺមានទំនួលខុសត្រូវសម្រាប់គ្រប់គ្រងលើការបង់ និង ការចំណាយទាំងអស់សម្រាប់សាសនាចក្រទាំងមូល ។ បច្ចុប្បន្នក្រុមប្រឹក្សានេះត្រូវបានស្គាល់ថាជាក្រុមប្រឹក្សាលើការរៀបចំដង្វាយមួយភាគក្នុងដប់ ហើយរួមមាន គណៈប្រធានទីមួយ កូរ៉ុមសាវកដប់ពីរនាក់ និង គណៈប៊ីស្សពជាអធិបតី ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២០:១, តើសមាជិកនៃក្រុមប្រឹក្សានេះសម្រេចពីរបៀបប្រើមូលនិធិដង្វាយមួយភាគក្នុងដប់នេះដោយរបៀបណា ? ( តាមរយៈ« សំឡេងព្រះអង្គសង្គ្រោះផ្ទាល់ចំពោះពួកលោក » ។ ឬនិយាយម្យ៉ាងទៀតថា តាមរយៈវិវរណៈ ) ។

សូមឲ្យសិស្សសង្ខេបជាពាក្យសម្ដីរបស់ពួកគេផ្ទាល់ ពីអ្វីដែលវិវរណៈនេះបង្រៀនអំពីនរណាដែលដឹកនាំការប្រើប្រាស់មូលនិធិដង្វាយមួយភាគក្នុងដប់នេះ ។ ( ទោះបីជាសិស្សអាចប្រើពាក្យផ្សេងគ្នាក្ដី ក៏ពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **ព្រះអម្ចាស់ដឹកនាំការប្រើប្រាស់មូលនិធិដង្វាយមួយភាគក្នុងដប់តាមរយៈអ្នកបម្រើជម្រើសរបស់ទ្រង់**) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលគោលការណ៍នេះដំណើរការនៅក្នុងសាសនាចក្រសព្វថ្ងៃនេះ សូមពន្យល់ថាវួដ ឬសាខានិមួយៗបានផ្ញើមូលនិធិដែលប្រមូលបានទៅកាន់ទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ។ ពួកអ្នកដឹកនាំប្រចាំមូលដ្ឋានពុំសម្រេចពីរបៀបដែលមូលនិធិពិសិដ្ឋទាំងនេះត្រូវបានប្រើប្រាស់ឡើយ ។ ក្រុមប្រឹក្សា លើការរៀបចំដង្វាយមួយភាគក្នុងដប់នេះធ្វើការសម្រេចចិត្តទាំងនោះក្រោមការដឹកនាំពីព្រះអម្ចាស់ ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លីបានមានប្រសាសន៍អំពីការគោរពដ៏ជ្រាលជ្រៅចំពោះ ក្រុមប្រឹក្សាលើការរៀបចំដង្វាយមួយភាគក្នុងដប់សម្រាប់មូលនិធិ ដង្វាយមួយភាគក្នុងដប់ ៖



« ខ្ញុំបានរក្សាប្រាក់ស្លឹងមួយរបស់ស្ត្រីមេម៉ាយ នៅលើទូក្រោយតុរបស់ខ្ញុំដែលគេបានឲ្យខ្ញុំនៅក្នុងទីក្រុងយេរូសាឡិមកាលពីច្រើនឆ្នាំមុនទុកជាវត្ថុរំឭក រំឭកជានិច្ចនៃការញែកមូលនិធិដែលយើងត្រូវចែកចាយ ។ ប្រាក់ដង្វាយនោះមកពីស្ត្រីមេម៉ាយ វាគឺជាការបូជារបស់នាងព្រមទាំង ដង្វាយមួយភាគដប់របស់អ្នកមានទ្រព្យនោះ ហើយវាត្រូវបានប្រើប្រាស់ដោយការយកចិត្តទុកដាក់ និង ដោយការសម្រេចចិត្តសម្រាប់គោលបំណងនានារបស់ព្រះអម្ចាស់ ។ យើងប្រើវាដោយប្រុងប្រយ័ត្ន និង ការពារវា ហើយព្យាយាមគ្រប់បែបយ៉ាងដែលយើងអាចធ្វើបាន ដើម្បីឃើញថាយើងបានប្រើប្រាស់វាដូចដែលយើងមានអារម្មណ៍ថាព្រះអម្ចាស់សព្វព្រះទ័យឲ្យប្រើវាសម្រាប់ការលើកស្ទួយកិច្ចការរបស់ទ្រង់ និង ផ្ដល់ប្រយោជន៍ដល់មនុស្ស » (This Thing Was Not Done in a Corner » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ទំព័រ ៥០ ) ។

សូមអញ្ជើញសិស្សឲ្យចែកចាយការយល់ដឹង ឬ ទីបន្ទាល់បន្ថែមទៀតរបស់ខ្លួនអំពីច្បាប់ដង្វាយមួយភាគក្នុងដប់នេះ ។

# សាសនាចក្រប្តូរទៅរដ្ឋមិសសួរីភាគខាងជើង គោលលទ្ធិ និង សេចក្តីសញ្ញា ១១៣–១២០ ( មេរៀនទី ២៥ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា « សាសនាចក្រប្តូរទៅរដ្ឋមិសសួរីភាគខាងជើង » និង គោលលទ្ធិ និង សេចក្តីសញ្ញា ១១៣–១២០ ( មេរៀនទី ២៥ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ( សាសនាចក្រប្តូរទៅរដ្ឋមិសសួរីភាគខាងជើង )

នៅពេលសិស្សបានសិក្សាអំពីព្រឹត្តិការណ៍ដែលនាំឲ្យទីស្នាក់ការកណ្តាលរបស់សាសនាចក្រផ្លាស់ប្តូរទៅរដ្ឋមិសសួរីភាគខាងជើង នោះពួកគេបានរៀនថា នៅពេលយើងជ្រើសរើសទប់ទល់នឹងការសាកល្បងដោយសេចក្តីជំនឿជាជាងការរឿងធ្ងល់ នោះទីបន្ទាល់របស់យើងអាចត្រូវបានពង្រឹង ។ ពួកគេក៏បានរៀនផងដែរថានៅពេលពួកគេគាំទ្រព្យាការី ហើយធ្វើតាមការទូន្មានរបស់លោក នោះយើងទទួលបានសុវត្ថិភាពខាងវិញ្ញាណដែលចងភ្ជាប់យើងទៅនឹងព្រះ ។ សិស្សបានឃើញថា នៅពេលយើងអភ័យទោសឲ្យមនុស្សដទៃ នោះព្រះអម្ចាស់អាចផ្សះផ្សារទំនាក់ទំនងរបស់យើង ។ ក្រៅពីនេះទៀត មេរៀននេះផ្តល់ឱកាសដល់សិស្សឲ្យពិចារណាពីរបៀបដែលទង្វើ និង ពាក្យសម្តីរបស់យើងអាចជះឥទ្ធិពលដល់មនុស្សដទៃដែលគិតអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្តីសញ្ញា ១១៣–១១៤)

មិនយូរប៉ុន្មានបន្ទាប់ពីបានទៅដល់ ហ្វា វេស រដ្ឋមិសសួរីហើយនោះ ព្យាការីយ៉ូសែប ស្ម៊ីធ បានត្រូវបានសួរឲ្យបញ្ជាក់ឲ្យច្បាស់ពីវគ្គបទគម្ពីរលំបាកៗមួយចំនួននៅក្នុងគម្ពីរអេសាយ ។ ចេញពីវិវរណៈរបស់ព្រះអម្ចាស់ដែលជាចម្លើយចំពោះសំណួរទាំងនោះ នោះសិស្សបានរៀនថាព្យាការីយ៉ូសែប ស្ម៊ីធបានទទួលកូនសោនៃនគរសម្រាប់ការប្រមូលសាសន៍អ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ។ នៅពេលសិស្សបានសិក្សាអំពីដាវីឌ ដ័បុលយូ ប៉ាទិន ដែលជាសាវកម្នាក់នៃសាវកសម័យមុន នោះពួកគេបានឃើញថា ប្រសិនបើយើងស្តាប់តាមការណែនាំរបស់ព្រះអម្ចាស់ នោះយើងនឹងត្រូវបានរៀបចំសម្រាប់អ្វីៗដែលទ្រង់មានផែនការសម្រាប់ពួកយើង ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្តីសញ្ញា ១១៥–១១៦)

នៅក្នុងមេរៀននេះ សិស្សបានរៀនថាប្រសិនបើពួកគេក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ នោះពន្លឺរបស់យើងទៅជាបមាណីយដល់សាសន៍នានា ។ ពួកគេក៏បានឃើញផងដែរថា អស់អ្នកដែលប្រមូលគ្នាទៅស្តេកនៃស៊ីយ៉ូន អាចទទួលបានការការពារ និង មានសុវត្ថិភាព ហើយថាប្រធានសាសនាចក្រកាន់កូនសោដើម្បីដឹកនាំកិច្ចការរបស់ព្រះអម្ចាស់នៅលើផែនដីនេះ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្តីសញ្ញា ១១៧–១២០)

ចេញពីព្រះឱវាទរបស់ព្រះអម្ចាស់ចំពោះ នូវល ខេ វីតនី និង វិលលាម ម៉ាក ទាក់ទងនឹងទ្រព្យសម្បត្តិនៅក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូ សិស្សបានរៀនថាការលោភចង់បានអ្វីៗខាងសាច់ឈាមអាចបណ្តាលឲ្យយើងចោលសេចក្តីដែលមានទម្ងន់ជាង ។ ចេញពីគំរូរបស់ អូលីវើរ គ្រែងគើរ នោះពួកគេបានរៀនថាការលះបង់ដែលយើងធ្វើនៅក្នុងការបម្រើនៃព្រះអម្ចាស់គឺពិសិដ្ឋចំពោះទ្រង់ ។

## សេចក្តីផ្តើម

មេរៀននេះនឹងជួយសិស្សឲ្យយល់ពីច្បាប់ដង្វាយមួយភាគក្នុងដប់ និង ពរជ័យនានាដែលទទួលបាននៅពេលយើងរស់នៅតាមច្បាប់នេះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:១–៤

*ព្រះអម្ចាស់បើកសម្ដែងច្បាប់ដង្វាយមួយភាគក្នុងដប់*

សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *តើយើងត្រូវបានប្រទានពរតាមរបៀបណាខ្លះ នៅពេលយើងរស់នៅតាមច្បាប់ដង្វាយមួយភាគក្នុងដប់នោះ ?*

សូមពន្យល់ថានៅដើមឆ្នាំ ១៨៣៧ សាសនាចក្របានជួបប្រទះនឹងវិបត្តិខាងហិរញ្ញវត្ថុយ៉ាងខ្លាំង ព្រមទាំងសមាជិកគ្រប់រូបនៃសាសនាចក្រផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីណែនាំក្បាលកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្យាការីយ៉ូសែប ស៊្មីធ បានសួរដែលនាំឲ្យមាននូវវិវរណៈនេះ ។

- តើយ៉ូសែប ស៊្មីធ បានសួរអ្វីខ្លះដល់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលចម្លើយរបស់ព្រះអម្ចាស់ចំពោះការស្នើសុំរបស់យ៉ូសែប ស៊្មីធ ។

- យោងតាម ខ ៤, តើដង្វាយមួយភាគក្នុងដប់គឺជាអ្វី ? ( សិស្សគួរតែរកឃើញព្រះបញ្ញត្តិខាងក្រោមនេះ ៖ **ព្រះអម្ចាស់បញ្ជាឲ្យពួកយើងបង់មួយភាគក្នុងដប់នៃទ្រព្យធនធានរបស់យើងថ្វាយទ្រង់ ទុកជាដង្វាយមួយភាគក្នុងដប់ ។** អ្នកអាចសរសេរព្រះបញ្ញត្តិនេះនៅលើក្ដារខៀន ) ។

ដើម្បីជួយសិស្សឲ្យយល់អត្ថន័យនៃពាក្យ *ធនធាន* នៅក្នុង ខ ៤សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហាវើដ ដបុលយូ ហ៊ីនធើរ ឲ្យឮៗ ៖



« ក្រឹត្យវិន័យនេះគឺថ្លែងយ៉ាងសាមញ្ញថា ‹ មួយភាគដប់នៃធនធានទាំងអស់របស់ពួកគេ › ។ ធនធានមានន័យថា ប្រាក់ចំណេញ ប្រាក់សំណង ប្រាក់កំណើន ។ វាគឺជាប្រាក់ខែរបស់និយោជិតម្នាក់ ជាប្រាក់ចំណេញពីការធ្វើអាជីវកម្ម ជាប្រាក់កំណើនរបស់បុគ្គលម្នាក់ដែលរីកចម្រើន ឬ រកបាន ឬ ជាប្រាក់ចំណូលរបស់មនុស្សម្នាក់ទោះមកពីប្រភពណាក៏ដោយ ។ ព្រះអម្ចាស់បានមានបន្ទូលថា វាជាក្រឹត្យវិន័យដែលនៅ ‹ អចិន្ត្រៃយ៍ › ដូចដែលវាមានពីបុរាណកាលផងដែរ » ( នៅក្នុង Conference Report, ខែ មេសា ឆ្នាំ ១៩៦៤, ទំព័រ ៣៥ ) ។

- តើអ្នករៀនអ្វីខ្លះពីការបញ្ជារបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធឲ្យថ្វាយដង្វាយមួយភាគក្នុង នៅចំពេលដែលវាមានការលំបាកចំពោះពួកគេដើម្បីធ្វើការណ៍នោះដូច្នេះ ?

- តើការថ្វាយដង្វាយមួយភាគក្នុងដប់គឺជាទង្វើនៃសេចក្ដីជំនឿដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ជេមស៍ អ៊ី ហ្វោស្ដ នៃគណៈប្រធានទីមួយ ៖



« ហេតុអ្វីសមាជិកទូទាំងពិភពលោកគួរតែ ត្រូវបានលើកទឹកចិត្តឲ្យរក្សាច្បាប់ដង្វាយមួយភាគក្នុងដប់របស់ព្រះអម្ចាស់ ទោះបីជាពួកគេភាគច្រើនគ្មានប្រាក់គ្រប់គ្រាន់សម្រាប់បំពេញសេចក្ដីត្រូវការប្រចាំថ្ងៃរបស់ខ្លួនក៏ដោយ ? ដូចដែរប្រធាន ហ៊ិងគ្លី បានមានប្រសាសន៍នៅក្នុងទីក្រុង សេប៊ូ ទឹកដីនៃប្រទេសភីលីពថា ‹ ទោះបីសមាជិករស់នៅក្នុងភាពក្ដីក្រ និង វេទនាក្ដី. . .ប្រសិនបើពួកគេទទួលយកដំណឹងល្អហើយរស់នៅតាមវា បង់ដង្វាយមួយភាគក្នុងដប់ និង ដង្វាយនានារបស់ពួកគេ សូម្បីតែអ្នកទាំងឡាយណាដែលមានស្ដួចស្ដើង . . .នោះពួកគេនឹងមានបាយនៅក្នុងចាន និង សម្លៀកបំពាក់សម្រាប់បិទបាំងខ្លួនប្រាណ និង មានទីជម្រកសម្រាប់ពួកគេ ។ ខ្ញុំពុំឃើញដំណោះស្រាយណាផ្សេងទៀតឡើយ › [« Inspirational Thoughts » *Ensign,* ខែ សីហា ឆ្នាំ ១៩៩៧ ទំព័រ ៧ ] ។

« មានមនុស្សមួយចំនួនប្រហែលមានអារម្មណ៍ថា ពួកគេពុំអាចមានប្រាក់គ្រប់គ្រាន់ដើម្បីថ្វាយដង្វាយមួយភាគក្នុងដប់ឡើយ ប៉ុន្តែព្រះអម្ចាស់បានសន្យាថា ទ្រង់នឹងរៀបចំផ្លូវសម្រាប់ពួកយើងដើម្បីរក្សាគ្រប់ទាំងព្រះបញ្ញត្តិរបស់ទ្រង់ [ សូមមើល នីហ្វៃទី ១ ៣:៧] ។ ដើម្បីថ្វាយដង្វាយមួយភាគក្នុងដប់តម្រូវឲ្យមានសេចក្ដីជំនឿយ៉ាងខ្លាំងនៅពេលដំបូង ។. . . ខ្ញុំជឿថា វាអាចផ្ដាច់ចំណងនៃភាពក្រីក្រ ដោយការមានជំនឿថ្វាយត្រឡប់ទៅព្រះអម្ចាស់វិញនូវផ្នែកដែលមានបន្តិចបន្តួចរបស់យើង » (Opening the Windows of Heaven » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៥៩ ) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបថ្វាយដង្វាយមួយភាគក្នុងដប់ សូមបង្ហាញក្រដាសដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ ។ សូមឲ្យសិស្សស្រមៃថា ពួកគេទើបតែរកបានប្រាក់មួយចំនួន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យប៉ាន់ស្មានពីចំនួនប្រាក់នោះ ។

- តើប្រាក់ចំនួនប៉ុណ្ណឹងត្រូវបង់ដង្វាយមួយភាគដប់ប៉ុន្មាន ?

សូមកត់ចំនួនប្រាក់នៃដង្វាយមួយក្នុងដប់នោះនៅកន្លែងត្រឹមត្រូវនៅលើក្រដាសនោះ ហើយសួរសំណួរខាងក្រោម ៖

- ប្រសិនបើយើងចែក ១០ភាគរយនៃប្រាក់ចំណូលរបស់យើងក្នុងចំណោមខ្ទង់បរិច្ចាគផ្សេងៗទៀតនៅលើក្រដាសនេះ តើយើងបានបង់ដង្វាយមួយភាគក្នុងដប់ពេញលេញដែរឬទេ ? ( សូមប្រាកដថាសិស្សយល់ថា ១០ភាគរយនៃប្រាក់ចំណូលរបស់យើងគួរតែត្រូវដាក់ក្នុងខ្ទង់ដង្វាយមួយភាគក្នុងដប់ ។ ការបរិច្ចាគផ្សេងៗទៀតដែលពួកគេបរិច្ចាគ គឺជាមូលនិធិផ្សេងទៀតក្រៅពី ១០ភាគរយនោះ ) ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យពួកគេពន្យល់គ្នាទៅវិញទៅមកអំពីការយល់ដឹងរបស់ពួកគេ អំពីរបៀបដែលមូលនិធិនៃដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់ ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអានការពន្យល់របស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១១៩:២។

- យោងតាម ខ ២, តើមូលនិធិដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើសម្រាប់អ្វីខ្លះ ? ( ដង្វាយមួយភាគក្នុងដប់ ត្រូវបានប្រើ ‹ សម្រាប់ការកសាងដំណាក់របស់ [ ព្រះអម្ចាស់ ] [ កសាងព្រះវិហារបរិសុទ្ធ ] និង « សម្រាប់ការសង់គ្រឹះនៃស៊ីយ៉ូន និងសម្រាប់បព្វជិតភាព » [ ផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ផ្នែកផ្សេងទៀតនៃកិច្ចការរបស់ព្រះអម្ចាស់ ដូចជាការសាងសង់ និងការថែរក្សាសាលាប្រជុំ ការបកប្រែ និងបោះពុម្ពព្រះគម្ពីរ និងការឧបត្ថមដល់អ្នកផ្សព្វផ្សាយសាសនា និងកិច្ចការពង្សប្រវត្តិនៅទូទាំងពិភពលោក ] ។ អ្នកអាចចង្អុលបង្ហាញថា សព្វថ្ងៃនេះសាសនាចក្រពុំជំពាក់បំណុលរបស់គេទេ ។ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **មូលនិធិនៃដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ និង ដើម្បីសម្រេចកិច្ចការរបស់ព្រះអម្ចាស់** ) ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ១១៩:៥–៧

*ព្រះអម្ចាស់ពន្យល់ពីច្បាប់ដង្វាយមួយភាគក្នុងដប់*

សូមអញ្ជើញសិស្សពីនាក់ឲ្យចូលរួមដើរតួសម្តែងមួយ ។ សូមចាត់ឲ្យសិស្សម្នាក់សម្តែងធ្វើជាសមាជិកស្មោះត្រង់ម្នាក់នៃសាសនាចក្រ ហើយសិស្សទីពីរសម្តែងធ្វើជាអ្នកមិនមែនជាសមាជិកសាសនាចក្រ ។ សូមឲ្យសិស្សទីពីរទុកក្រដាសមួយសន្លឹកដោយសរសេរសំណួរខាងក្រោមនៅលើក្រដាសនោះ ៖ *ខ្ញុំបានឮថាអ្នកបានបង់ ១០ភាគរយនៃប្រាក់ចំណូលរបស់អ្នកទៅក្នុងសាសនាចក្ររបស់អ្នក ។ ហេតុអ្វីអ្នកចង់ធ្វើបែបនោះ ?*

សូមឲ្យសិស្សទីពីរអានសំណួរឲ្យឮៗ ហើយអញ្ជើញសិស្សទីមួយឲ្យឆ្លើយ ។ បន្ទាប់ពីសម្តែងចប់ សូមសួរសិស្សក្នុងថ្នាក់ពីរបៀបដែលពួកគេអាចឆ្លើយចំពោះសំណួរនោះ ។ សូមចង្អុលបង្ហាញថាមានចម្លើយល្អៗជាច្រើនចំពោះសំណួរនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ១១៩:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីខ្លះបានដែលសម្រេចបានតាមរយៈការគោរពប្រតិបត្តិចំពោះច្បាប់ដង្វាយមួយភាគក្នុងដប់ ។

- យោងតាម ខ ៦ តើមានអ្វីខ្លះដែលសម្រេចបានតាមរយៈការគោរពប្រតិបត្តិចំពោះច្បាប់ដង្វាយមួយភាគក្នុងដប់ ? ( ញែកដែនដីស៊ីយ៉ូនចេញជាបរិសុទ្ធដល់ព្រះអម្ចាស់ ) ។

ដើម្បីជួយសិស្សឲ្យយល់ខគម្ពីរនេះ សូមពន្យល់ថាការញែកចេញជាបរិសុទ្ធ សំដៅលើការគ្មានអំពើបាប—បរិសុទ្ធ ស្អាតស្អំ និងបរិសុទ្ធតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះ សូមរំឭកសិស្សថាស៊ីយ៉ូនគឺជាមានន័យលើសពីទីតាំងទៅទៀត វាគឺជាមនុស្សដែលជា« អ្នកដែលមានចិត្តល្អសុទ្ធសាធ » (គ. និង ស. ៩៧:២១) ។

សូមអញ្ជើញសិស្សឲ្យសង្ខេបឥទ្ធិពលនៃការគោរពតាមច្បាប់ដង្វាយមួយភាគក្នុងដប់ជាពាក្យសម្តីផ្ទាល់របស់ខ្លួន ។ ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នាក្តី ពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **ការបង់ដង្វាយមួយភាគក្នុងដប់ញែកយើងម្នាក់ៗ និង សាសនាចក្រចេញជាបរិសុទ្ធ ។**

ដើម្បីជួយសិស្សឲ្យយល់ និង ដឹងពីសារៈសំខាន់នៃគោលការណ៍នេះ សូមសួរសំណួរខាងក្រោម ៖

- តើមានវិធីណាខ្លះ ដែលអ្នកគិតថាការបង់ដង្វាយមួយភាគក្នុងដប់ជួយញែកបុគ្គលម្នាក់ឲ្យបរិសុទ្ធ ?

សូមមើលសំណួរនៅលើក្តារខៀន ៖ *តើយើងត្រូវបានប្រទានពរតាមវិធីណាខ្លះនៅពេលយើងរស់នៅតាមច្បាប់ដង្វាយមួយភាគក្នុងដប់នោះ ?* អ្នកអាចអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ និង ថ្លែងទីបន្ទាល់របស់ពួកគេអំពីច្បាប់ដង្វាយមួយភាគក្នុងដប់ ។ អ្នកក៏អាចថ្លែងទីបន្ទាល់បានផងដែរ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តសេចក្តីជំនឿដោយការថ្វាយ ១០ភាគរយនៃធនធានរបស់ពួកគេជាដង្វាយមួយភាគក្នុងដប់ចំពោះព្រះអម្ចាស់ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣ ការស្ថាបនាទីក្រុងណៅវូ )

សូមអញ្ជើញសិស្សឲ្យគិតអំពីការសាកល្បងនានាដែលពួកគេបានជួបប្រទះ និង អ្វីដែលពួកគេបានរៀនពីបទពិសោធន៍ទាំងនោះ ។ តើអ្នកមានអារម្មណ៍បែបណា ប្រសិនបើអ្នកត្រូវបានចោទប្រកាន់ដោយខុសឆ្គង ហើយចាប់ដាក់គុកនោះ ? សូមពន្យល់ថានៅអំឡុងសប្ដាហ៍ក្រោយ ពួកគេនឹងសិក្សាពីគោលការណ៍មួយចំនួនដែលព្យាការីយ៉ូសែប ស៊្មីធ បានរៀនអំឡុងពេលការដាក់គុកដោយអយុត្តិធម៌របស់លោកនៅក្នុងគុកលីប៊ើរធី រួមទាំងព្រះរាជបំណងរបស់ព្រះអម្ចាស់ ដែលបណ្ដោយឲ្យយើងទទួលនូវបទពិសោធននៃការសាកល្បងនោះ ។

មេរៀនទី ១២៦

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣ មានសំបុត្រដែលបានជ្រើសរើសឬសំបុត្រមកពីព្យាការីយ៉ូសែប ស្ម៊ីធទៅកាន់សាសនាចក្រ កាលបរិច្ឆេទចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៨៣៩ ។ យ៉ូសែប ស្ម៊ីធ បានសរសេរសំបុត្រមួយខណៈដែលលោក និង ដៃគូពីរបីនាក់ទៀតកំពុងជាប់នៅក្នុងគុកលីប៊ើធី ។ នៅក្នុងសំបុត្រនេះ ព្យាការីបញ្ចូលការអធិស្ឋានខ្លះរបស់លោក ដោយបានសុំព្រះអម្ចាស់ឲ្យប្រទានពរដល់លោក និង ដៃគូផ្សេងៗរបស់លោក និង ពួកបរិសុទ្ធទាំងអស់ដែលរងទុក្ខ ដោយសារទង្វើរបស់មារសត្រូវរបស់ខ្លួន ។ លោកក៏បានបញ្ចូលចម្លើយដែលលោកបានទទួល ទៅ ក្នុងការអធិស្ឋានទាំងនោះផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–៦

*យ៉ូសែប ស្ម៊ីធ អធិស្ឋានសម្រាប់ពួកបរិសុទ្ធដែលរងទុក្ខ*

សូមអញ្ជើញសិស្សឲ្យស្រមៃថា មានមិត្តម្នាក់ ឬមនុស្សជាទីស្រឡាញ់កំពុងឆ្លងកាត់បទពិសោធន៍លំបាកមួយ ។ នាងបង្ហាញអ្នកថា នាងពុំយល់ពីមូលហេតុដែលនាងកំពុងរងទុក្ខបែបនោះឡើយ ហើយថានាងមានអារម្មណ៍ថាព្រះហាក់បីដូចជាបោះបង់នាងចោល ។

- តើអ្នកនឹងប្រាប់អ្វីខ្លះដល់មិត្តរបស់អ្នក ? តើអ្នកនឹងធ្វើអ្វីខ្លះបើសិនអ្នកជាម្នាក់ដែលជួបបទពិសោធន៍នៃការរងទុក្ខទាំងនេះ ?

សូមពន្យល់ថា ព្រះអម្ចាស់បានទូន្មាន និង លួងលោមព្យាការីយ៉ូសែប ស្ម៊ីធ អំឡុងពេលនៃបទពិសោធន៍ដ៏លំបាកបំផុតមួយ ។ សូមលើកទឹកចិត្តសិស្ស ឲ្យស្វែងរករបៀបនានាដែលព្រះបន្ទូលនៃព្រះឱវាទ និង ការលួងលោមរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:–១២៣ អាចជួយពួកគេឆ្លងកាត់ការសាកល្បងរបស់ខ្លួនផ្ទាល់ ។

សូមពន្យល់ថានៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៨៣៨ ចច ហ៊ីងខ្លេ ជាសមាជិកម្នាក់នៃសាសនាចក្រ និង ជាវរសេនីយឯកម្នាក់នៅក្នុងជួរជីវពល រដ្ឋ មិសសួរី បានក្បត់នឹងព្យាការីយ៉ូសែប ស្ម៊ីធ ។ ហ៊ីងខ្លេ បានប្រាប់យ៉ូសែប ស្ម៊ីធថាសមាជិកនៃជួរជីវពល រដ្ឋ មិសសួរី ដែលបានវាយប្រហារពួកបរិសុទ្ធនៅ ហ្វា វេស រដ្ឋ មិសសួរី ចង់ជួបលោកសាកសួរដើម្បីរកដំណោះស្រាយចំពោះភាពមិនចុះសម្រុងគ្នាដោយសន្តិភាព ។ នៅពេលយ៉ូសែប និង អ្នកដឹកនាំសាសនាចក្រដទៃទៀត បានមកដល់សម្រាប់ការសាកសួរ នោះពួកជីវពលបានចាប់ដោយចោទពួកគេថាជាទណ្ឌិតសង្គ្រាម ។ ដោយសារនៅខែបន្ទាប់មក យ៉ូសែប ស្ម៊ីធ និង អ្នកពាក់ព័ន្ធនឹងលោកត្រូវបានធ្វើបាប និង ជេរស្ដី នៅពេលសត្រូវរបស់ពួកលោកបានដាក់ពួកលោកក្នុងគុកនៅ អ៊ីនឌីប៉ែនដែនស៍ រដ្ឋមិសសួរី និង រិចម៉ុន រដ្ឋ មិសសួរី ។ ខណៈកំពុងរង់ចាំការសាកល្បងនេះ ដែលផ្ដោតលើការចោទប្រកាន់ខុសឆ្គង និង ធ្វើឡើងដោយគ្មានដំណើរការត្រឹមត្រូវ នោះយ៉ូសែប ស្ម៊ីធ និង អ្នកដឹកនាំសាសនាចក្រដទៃទៀតត្រូវបានប្ដូរឲ្យទៅនៅក្នុងគុកមួយនៅលីប៊ើធី រដ្ឋ មិសសួរី នៅថ្ងៃទី ១ ខែ ធ្នូ ។

អំឡុងពេលបួនខែក្រោយមកបងប្រុសរបស់ព្យាការី ហៃរុម អាឡិចសាន់ឌើរ ម៉ាករ៉េ ឡៃម៉ាន វ៉ៃត និង កាលីប បាលវីន ត្រូវបានជាប់នៅក្នុងគុកងងឹតជាន់ក្រោមនៃគុក លីប៊ើធី អំឡុងពេលរដូវរងាដែលត្រជាក់ដ៏ល្វីងជូរចត់ ។ ស៊ីឌនី រិកដុន ក៏បាននៅជាមួយពួកគេមួយរយៈដែល ប៉ុន្តែចៅក្រមបានអនុញ្ញាតឲ្យគាត់រួចទោសនៅចុងខែ មករា ឆ្នាំ ១៨៣៩ ។ ដោយខ្លាចការគំរាមកំហែងពីពួកខ្លាំងសត្រូវបងប្រុស រិកដុន ពុំបានចេញពីគុកឡើយរហូតដល់ដើមខែ កុម្ភៈ ។

ដើម្បីជួយសិស្សឲ្យដឹងពីពីស្ថានភាពយោរយៅដែលព្យាការី និង មិត្តភក្តិរបស់លោកបានជួប ខណៈនៅក្នុងគុកលីប៊ើធី នោះអ្នកអាចប្រើស្កុត ឬ អ្វីផ្សេងទៀតដើម្បីគូសផ្ទៃកម្រាលឥដ្ឋឲ្យមានរាងបួនជ្រុងដែលមានទំហំ ៤.៣ គុណ ៤.៣ ម៉ែត្រ ។ សូមពន្យល់ថានេះគឺជាទំហំប្រហាក់ប្រហែលនឹងកម្រាលនៃគុកនោះ ។ ដំបូលគុកមានកំពស់ប្រហែល ១.៨ ម៉ែត្រ និង ២ ម៉ែត្រ ។

អ្នកក៏អាចឲ្យយោបល់ដល់សិស្សមើលរូបភាពនៃគុក លីប៊ើធីនៅក្នុងព្រះគម្ពីររបស់ពួកគេផងដែរ ( សូមមើលរូបថតប្រវត្តិសាស្ត្រសាសនាចក្រ រូបថតទី ១២ « គុក លីប៊ើធី ») ។ សូមអញ្ជើញសិស្សឲ្យស្រមៃថាតើវាមានសភាពបែបណា ដែលនៅជាប់ក្នុងគុកដ៏តូចបែបនោះជាមួយមនុស្ស៤ ឬ ៥ នាក់ទៀតអស់រយៈពេល៤ខែនារដូវរងានោះ ។ របាំងបង្អួចពីរតូចផ្ដល់ពន្លឺតិចៗ ហើយនៅខាងក្រៅបង្អួចទាំងនេះ មនុស្សនានាបានសើចចំអក និង ជេរស្ដីទណ្ឌិត ។ ទណ្ឌិតដេកលើចំបើងដ៏កខ្វក់លើកម្រាលនោះ ។ ការផ្ដល់ឲ្យដ៏ស្ដួចស្ដើងរបស់ពួកលោករួមមានធុងមួយសម្រាប់ដាក់លាមក ។ មានពេលខ្លះ យ៉ូសែបគ្មានសូម្បីតែភួយមួយ ដែលវាគ្រាន់តែទុកឲ្យទណ្ឌិតដណ្ដប់ការពារពីអាកាសធាតុដ៏សែនត្រជាក់ប៉ុណ្ណោះ ។ ម្ដងម្កាលអាហារមានជាតិពុល ហើយនៅពេលខ្លះវាគួរឲ្យខ្ពើមណាស់ ដែលពួកលោកគ្រាន់តែបរិភោគដើម្បីកុំឲ្យឃ្លានប៉ុណ្ណោះ ។ ពួកលោកកម្រមានអ្នកមកសួរសុខទុក្ខណាស់ ហើយមានការឈឺចាប់ជាខ្លាំងដោយបានឮការរងទុក្ខរបស់ពួកបរិសុទ្ធដែលត្រូវបណ្ដេញចេញពីរដ្ឋមិសសួរីនៅពាក់កណ្ដាលនៃរដូវរងារនោះ ។

- តើអារម្មណ៍ ឬ គំនិតអ្វីខ្លះដែលអ្នកអាចមាន បើសិនជាអ្នកបាននៅក្នុងស្ថានភាពដូចយ៉ូសែបនោះ ?

សូមពន្យល់ថា គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១–១២៣ រួមមាននូវសំបុត្រមួយដែលបានជ្រើសរើសមកពីព្យាការីទៅកាន់ពួកបរិសុទ្ធដែលលោកបានសរសេរនៅជិតចុងបញ្ចប់នៃការជាប់ឃុំឃាំងរបស់លោកនៅគុកលីប៊ើធី ។ សំបុត្រនោះរួមមានការអធិស្ឋានមួយចំនួនរបស់យ៉ូសែបទូលអង្វរដល់ព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សពីរបីឲ្យនាក់ផ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–៦ ឲ្យឮៗ ។ សូមឲ្យសិស្សរកមើលសំណួរ និង ការទូលអង្វរដែលព្យាការីបានបង្ហាញដល់ព្រះអម្ចាស់ ។ ( ដើម្បីជួយសិស្សឲ្យយល់ ខ ១ និង ៤, អ្នកអាចពន្យល់ថា ពន្លាគឺជាអគារមួយ ឬ សំណង់មួយផ្សេងទៀតដែលផ្ដល់ជាទីជម្រក ) ។

- តើសំណួរ និង ការទូលអង្វរអ្វីខ្លះដែលអ្នកបានរកឃើញ ? តើមានអ្វីខ្លះទៀតដែលធ្វើឲ្យអ្នកមានភាពអស្ចារ្យពីខគម្ពីរទាំងនេះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–១០; ១២២

### *ព្រះអម្ចាស់លួងលោមព្យាការី យ៉ូសែប ស្ម៊ីធ*

សូមពន្យល់ថាចម្លើយមួយចំនួនរបស់ព្រះអម្ចាស់ទៅនឹងការអធិស្ឋានរបស់យ៉ូសែប ស្ម៊ីធមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–២៥ និង ១២២:១–៩ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលគោលការណ៍នានាដែលបានជួយ យ៉ូសែប ស្ម៊ីធ និង ដៃគូរបស់លោកអំឡុងពេលពួកគេនៅក្នុងគុកលីប៊ើធី ។ សូមអញ្ជើញសិស្សឲ្យសរសេរគោលលទ្ធិ និង គោលការណ៍នានាដែលពួកគេរៀនពីខគម្ពីរទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមឲ្យសិស្សចែកចាយគោលលទ្ធិ និង គោលការណ៍ដែលពួកគេបានរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេ នៅលើក្ដារខៀន ។ គោលការណ៍ខាងក្រោមនេះគឺជាគោលការណ៍បីដែលពួកគេអាចរកឃើញ ៖

**នៅពេលយើងអំពាវនាវទៅកាន់ទ្រង់នៅក្នុងគ្រានៃសេចក្ដីវេទនា និង ការឈឺចាប់ នោះយើងអាចទទួលក្ដីសុខសាន្តរបស់ទ្រង់ ។**

**បើសិនយើងតស៊ូនឹងការសាកល្បងបានប្រសើរនៅក្នុងជីវិតរមែងស្លាប់នេះ នោះព្រះនឹងប្រទានពរដល់យើងនាពេលនេះ និងនៅក្នុងពេលដ៏អស់កល្ប ។**

**នៅពេលនៃការសាកល្បង នោះយើងអាចរកឃើញការលួងលោម និងការគាំទ្រពីសំណាក់មិត្តភក្ដិដ៏ពិតទាំងឡាយ ។**

សូមចែកសិស្សជាគូៗ ហើយសូមអញ្ជើញពួកគេឲ្យពិភាក្សាពីសំណួរខាងក្រោម ។ សូមសួរមួយសំណួរម្ដងៗ ដោយទុកពេលគ្រប់គ្រាន់ដើម្បីពិភាក្សា ។

- តើការស៊ូទ្រាំនឹងការសាកល្បងខុសគ្នានឹងការស៊ូទ្រាំការសាកល្បងដោយអំណត់ដូចម្ដេចខ្លះ ?

- តើអ្នកស្គាល់នរណាម្នាក់ដែលជាគំរូនៃការស៊ូទ្រាំនឹងការសាកល្បងដោយអំណត់ដែរឬទេ ?

បន្ទាប់មក សូមលើកទឹកចិត្តសិស្សពីរបីនាក់ឲ្យចែកចាយដល់សិស្សក្នុងថ្នាក់ទាំងអស់ពីអ្វីដែលពួកគេបានពិភាក្សាជាមួយដៃគូរបស់ខ្លួន ។

- ព្រះអម្ចាស់បានមានព្រះបន្ទូលថា សេចក្ដីទំនាស់ និង សេចក្ដីវេទនារបស់យ៉ូសែបស្ម៊ីធ គឺ « គ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ » (គ. និង ស. ១២១:៧) ។ តើអ្នកគិតថាវាមានន័យយ៉ាងដូចម្ដេចខ្លះ ? តើទស្សនវិស័យនេះអាចជួយយើងឲ្យស៊ូទ្រាំការសាកល្បងរបស់យើងដោយអំណត់យ៉ាងដូចម្ដេចទៅ ?

សូមទុកឱកាសឲ្យសិស្សចែកចាយបទពិសោធន៍ដែលពួកគេមាន នៅពេលពួកគេបានទទួលភាពសុខសាន្តរបស់ព្រះអង្គសង្គ្រោះអំឡុងពេលនៃការលំបាក ។

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើនរណានឹងស្វែងរកការទូន្មាន និង ពរជ័យតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ?*

សូមអញ្ជើញសិស្សឲ្យអានរកមើលចម្លើយចំពោះសំណួរនេះនៅពេលពួកគេអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:១–៤ ដោយស្ងៀមស្ងាត់ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញពួកគេឲ្យពិចារណាថាតើ ខ ២–៣ ពិពណ៌នាពីចម្លើយនោះឬអត់ ។

- តើយើងបន្តទទួលការទូន្មានពី យ៉ូសែប ស្ម៊ីធតាមរបៀបណាខ្លះ ? តើយើងទទួលសិទ្ធិអំណាច និង ពរជ័យតាមរយៈលោកដោយរបៀបណាខ្លះ ?

- តើការសន្យាអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស្ម៊ីធ ?

សូមអញ្ជើញសិស្សបីនាក់ឲ្យឆ្លាស់វេនគ្នាអានពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៥–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលការណ៍ដែលព្រះអម្ចាស់បានបង្រៀនយ៉ូសែប ស្ម៊ីធ អំពីការលំបាកដែលលោក និង មនុស្សដទៃទៀតកំពុងជួបប្រទះ ។

- យោងតាម ខ ៧, តើលទ្ធផលវិជ្ជមានអ្វីខ្លះដែលបានទទួលមកពីសេចក្ដីវេទនា និង ការឈឺចាប់ ? ( នៅពេលសិស្សឆ្លើយសំណួរនេះ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **ការឈឺចាប់អាចផ្ដល់ជាបទពិសោធន៍ និងជាសេចក្ដីល្អសម្រាប់យើង**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដី ថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ យ៉ូសែប ប៊ី វើតលីន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្ដាប់ពីរបៀបដែលការឈឺចាប់អាចកើតមានសម្រាប់ជាសេចក្ដីល្អសម្រាប់យើង ។



« អ្នកប្រហែលជាមានអារម្មណ៍ឯកោ នៅពេលសេចក្ដីទំនាស់ចូលមកក្នុងជីវិតអ្នក ។ អ្នកគ្រវីក្បាល ហើយនឹកឆ្ងល់ថា ‹ ហេតុអ្វីជារូបខ្ញុំ › ?

« ប៉ុន្តែនៅទីបំផុតទុក្ខព្រួយនេះនឹងកើតមានចំពោះយើងម្នាក់ៗ ។ នៅពេលខុសៗគ្នា មនុស្សគ្រប់រូបត្រូវតែជួបនឹងទុក្ខព្រួយ ។ គ្មាននរណាម្នាក់ចៀសផុតឡើយ » ។. . .

« ការរៀនស៊ូទ្រាំក្នុងគ្រានៃការខកចិត្ត ការរងទុក្ខ និងសោកសៅ គឺជាផ្នែកនៃការបំពាក់បំប៉នការងាររបស់យើង ។ ជាញឹកញាប់ បទពិសោធន៍ទាំងនេះហាក់បីដូចជាពិបាកទ្រាំទ្រ តែវាក៏ជាប្រភេទនៃបទពិសោធន៍ជាក់លាក់ដែលពង្រីកការយល់ដឹងរបស់យើង ស្ថាបនាចរិកលក្ខណៈរបស់យើង ហើយបង្កើនសេចក្ដីមេត្តារបស់យើងចំពោះអ្នកដទៃ » (Come What May, and Love It » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២៧ ) ។

- តើអែលឌើរ វើតលីន បានមានប្រសាសន៍អំពីបទពិសោធន៍លំបាករបស់យើងអាចជួយយើងអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬ សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីរបៀបដែលការសាកល្បងបានផ្ដល់បទពិសោធន៍ និងសម្រាប់ជាសេចក្ដីល្អដល់ពួកគេ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ អ្នកអាចសូមឲ្យសិស្សពីរបីនាក់ចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យមកមុខក្ដារខៀន ហើយធ្វើជាអ្នកសរសេរ ។ សូមឲ្យគាត់គូសបន្ទាត់ផ្ដេកមួយ ប្រហែលមួយភាគបីពីផ្នែកខាងក្រោមនៃក្ដារខៀន ។ បន្ទាប់មកសូមឲ្យសិស្សសរសេរអំពីស្ថានភាពឧបសគ្គនានាដែលមនុស្សជួបប្រទះ ។ សូមឲ្យអ្នកសរសេរកត់ត្រាចម្លើយរបស់ពួកគេខាងលើបន្ទាត់នោះ ។

បន្ទាប់ពីសិស្សមានពេលធ្វើបញ្ជីនោះគ្រប់គ្រាន់ហើយ សូមសួរពួកគេបើសិនពួកគេធ្លាប់ឮនរណាម្នាក់និយាយថា « គ្មាននរណាម្នាក់យល់ពីអ្វីដែលខ្ញុំកំពុងឆ្លងកាត់នោះទេ » ។ សូមអញ្ជើញពួកគេឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៨ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់ អាចមានបន្ទូលឆ្លើយតបចំពោះសេចក្ដីអធិប្បាយនេះ ។ នៅពេលពួកគេរាយការណ៍ពីចម្លើយរបស់ខ្លួន សូមឲ្យអ្នកសរសេរសរសេរពាក្យ *ព្រះយេស៊ូវគ្រីស្ទ* នៅក្រោមបន្ទាត់នៅលើក្ដារខៀន ។

- តើអ្នកគិតថា ព្រះអង្គសង្គ្រោះ « បានចុះទាបជាងការណ៍ទាំងនោះទៅទៀត » វាមានន័យយ៉ាងណា ? ( ពីមុនសិស្សឆ្លើយសំណួរនេះ អ្នកអាចឲ្យពួកគេអាន នីហ្វៃទី ២ ៩:២០–២១, អាលម៉ា ៧:១១, និង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥–៦ ។ សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញអំពីគោលលទ្ធិខាងក្រោមនេះ ៖ **ព្រះអង្គសង្គ្រោះបានរងទុក្ខនូវការឈឺចាប់ និង សេចក្ដីវេទនានៃមនុស្សទាំងអស់**) ។
- តើអ្នកគិតថាសេចក្ដីពិតនេះអាចមានប្រយោជន៍ចំពោះយ៉ូសែប ស្ម៊ីធ និង ដៃគូរបស់លោកនៅក្នុងគុកលីបើធីយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់អំពីគោលលទ្ធិនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ វ៉ុតលីនឲ្យឮៗ ៖



« ដោយសារព្រះយេស៊ូវគ្រីស្ទបានរងទុក្ខយ៉ាងមហិមា ទ្រង់យល់ពីការរងទុក្ខរបស់យើង ។ ទ្រង់យល់ពីភាពសោកសៅរបស់យើង ។ យើងជួបរឿងលំបាកៗដើម្បីយើងអាចមានសេចក្ដីមេត្តាករុណា និង ការយល់ដឹងកាន់តែច្រើនចំពោះមនុស្សផ្សេងទៀត ។

« សូមចងចាំបន្ទូលដ៏ឧត្តមរបស់ព្រះអង្គសង្គ្រោះទៅកាន់ព្យាការីយ៉ូសែប ស្ម៊ីធ នៅពេលលោកបានរងទុក្ខជាមួយនឹងពួកដៃគូរបស់លោកនៅក្នុងភាពងងឹតអាប់អួរនៃគុកលិបើធី ។. . .

« . . .យ៉ូសែប បានទទួលការល្បួងលោមដោយសារព្រះបន្ទូលនេះ ហើយយើងក៏អាចធ្វើដូច្នោះផងដែរ » (« Come What May, and Love It, »ទំព័រ ២៧ ) ។

- តើការជួប « បញ្ហាលំបាកៗ » អាចបង្កើនការអាណិតអាសូរ និង ការយល់ចិត្តមនុស្សដទៃទៀតដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៩ ដោយស្ងៀមស្ងាត់ ហើយពិចារណាអំពីរបៀបដែលខគម្ពីរនេះទាក់ទងនឹងជីវិត និង ការបម្រើរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ។

- តើអ្នកមានអារម្មណ៍ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៩ ទាក់ទងនឹងអ្នកដូចម្ដេច ? តើខគម្ពីរនេះអាច ពង្រឹងអ្នកអំឡុងពេលជួបការលំបាកដូចម្ដេច ?

សូមពន្យល់ថា មិនយូរប៉ុន្មានបន្ទាប់ពីសំបុត្រនេះត្រូវបានសរសេររួច ព្រះអម្ចាស់បានបើកផ្លូវឲ្យយ៉ូសែប និង ដៃគូរបស់លោកបានជួបជុំជាមួយពួកបរិសុទ្ធម្ដងទៀតនៅរដ្ឋ អិលលីណោយ ។ សូមថ្លែងទីបន្ទាល់ថាព្រះគង់នៅជាមួយអ្នកបម្រើទ្រង់ គឺយ៉ូសែប ស្ម៊ីធពេញមួយជីវិតរបស់យ៉ូសែប ។ សូមជួយសិស្សឲ្យយល់ថា បើសិនយើងបន្តនៅស្មោះត្រង់អំឡុងពេលនៃការសាកល្បងរបស់យើង នោះព្រះនឹងគង់នៅជាមួយយើងផងដែរ ។ ដើម្បីបញ្ចប់ សូមចែកចាយទីបន្ទាល់ខាងក្រោមដែលយ៉ូសែប ស្ម៊ីធ បានថ្លែងនៅជិតចុងបញ្ចប់នៃជីវិតរបស់លោក ៖ « ព្រះដ៏មានមហិទ្ធិឫទ្ធិគឺជាខែលរបស់ខ្ញុំ ហើយតើនរណាហ៊ានធ្វើអ្វីខ្ញុំ ព្រោះព្រះគឺជាមិត្តសំឡាញ់របស់ខ្ញុំនោះ ? » ( នៅក្នុង *History of the Church,* ៥:២៥៩ ) ។

### *សូមជួយសិស្សឲ្យយល់ពីមាតិកានៃខគម្ពីរ*

សូមសួរសំណួរដែលនឹងជួយសិស្សឲ្យវិភាគពីនៃខគម្ពីរ ។ ឧទាហរណ៍ អ្នកអាចសួរសំណួរដែលជួយសិស្សឲ្យ (១) ពិនិត្យមើលពីវគ្គបទព្រះគម្ពីរមួយដោយទទួលពន្លឺពីបទគម្ពីរផ្សេងទៀត (២) ពន្យល់ឲ្យច្បាស់ពីអត្ថន័យនៃពាក្យ ឬ ឃ្លា ឬ (៣) វិភាគព័ត៌មានលម្អិតនៃខ្សែរឿងឲ្យកាន់តែយល់បានស៊ីជម្រៅ ។ ការឆ្លើយសំណួរបែបនោះនឹងជួយសិស្សឲ្យរៀបចំខ្លួនរកឃើញគោលលទ្ធិ និង គោលការណ៍នានា ។

មេរៀនទី ១២៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១ គឺជាការដកស្រង់ពីលិខិតដ៏បំផុសគំនិតដែលយ៉ូសែប ស្ម៊ីធបានសរសេរទៅកាន់ពួកបរិសុទ្ធចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៨៣៩ ពីគុក លីបឺធី ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣ ពិពណ៌នាអំពីការជំនុំជម្រះដែលនឹងធ្លាក់លើពួកទុច្ចរិត និង វិវរណៈដែលបានសន្យាដល់មនុស្សដែលក្លាហាន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–២៥

*ព្រះអម្ចាស់ ពិពណ៌នាអំពីការជំនុំជម្រះដែលនឹងធ្លាក់លើអស់អ្នកដែលបៀតបៀនពួកបរិសុទ្ធ*

មុនចាប់ផ្ដើមថ្នាក់ សូមសរសេរប្រយោគខាងក្រោមនៅលើក្ដារខៀន ៖ « *ត្រូវចាត់ទុកពួកមរមនជាសត្រូវ ហើយត្រូវសម្លាប់ផ្ដាច់ពូជ* » ។

នៅពេលចាប់ផ្ដើមថ្នាក់រៀន សូមអញ្ជើញសិស្សឲ្យស្រមៃគិតថានាព្រឹកមួយ នៅពេលពួកគេកំពុងចេញពីផ្ទះ នោះពួកគេបានឃើញការប្រកាសនេះបិទនៅមាត់ទ្វារផ្ទះរបស់ខ្លួន ។

- តើអ្នកភ័យខ្លាចដែលត្រូវចេញពីផ្ទះដែរឬទេ ? តើអ្នកនឹងទៅរកជំនួយនៅកន្លែងណា ? តើអ្នកនឹងមានអារម្មណ៍ដូចម្ដេចបើសិនអ្នកដឹងថាសេចក្ដីប្រកាសនោះចេញមកពីមិត្តភក្ដិចាស់ៗមួយចំនួនរបស់អ្នកនោះ ?

> *សូមជួយសិស្សឲ្យយល់បរិបទនៃព្រះគម្ពីរ*
>
> សិស្សអាចស្គាល់គោលលទ្ធិ និងគោលការណ៍ក្នុងព្រះគម្ពីរបានកាន់តែប្រសើរ នៅពេលពួកគេយល់ពីបរិបទប្រវត្តិសាស្ត្រនៅក្នុងបណ្ដុំខគម្ពីរដែលពួកគេកំពុងសិក្សា ។ វិធីមួយដើម្បីធ្វើកិច្ចការនេះ គឺត្រូវឲ្យសិស្សដាក់ខ្លួនគេនៅក្នុងស្ថានភាពរបស់អ្នកដែលនៅក្នុងខគម្ពីរ ហើយពិចារណាពីរបៀបដែលពួកគេមានអារម្មណ៍ និង ធ្វើសកម្មភាពនៅក្នុងស្ថានភាពស្រដៀងគ្នានេះ ។

ដើម្បីជួយសិស្សយល់ បរិបទប្រវត្តិសាស្ត្រ នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១, សូមពន្យល់ថាមានមិត្តភក្ដិរបស់យ៉ូសែប ស្ម៊ីធមួយចំនួនដែលធ្លាប់ស្មោះត្រង់នឹងលោកបែរជាប្រឆាំងទាស់នឹងលោកទៅវិញ ។ មានមិត្តភក្ដិពីរនាក់ គឺ ថូម៉ាស ប៊ី ម៉ាស និង អូរសុន ហៃឌ ជាសមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ ។ បុរសទាំងពីរនាក់នេះបានចុះហត្ថលេខាលើសេចក្ដីថ្លែងសច្ចា ( សេចក្ដីសម្បថ ) ក្លែងក្លាយមួយដោយចោទប្រកាន់យ៉ូសែប ស៊្មីធ និង សមាជិកសាសនាចក្រដទៃទៀតអំពីផែនការនៃការបណ្តេញសត្រូវរបស់ខ្លួនចេញដោយការដុត និង បំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ ។ លិខិតថ្លែងសច្ចានោះបានជម្រុញឲ្យរដ្ឋាភិបាលនៃរដ្ឋ មិសសួរីចេញសេចក្ដីថ្លែងការណ៍មួយ ដែលស្គាល់ថាជាការបញ្ជាឲ្យសម្លាប់ផ្ដាច់ពូជ ដោយប្រកាសថាត្រូវតែកំទេចពួកមរមនចោលឲ្យសាបសូន្យ ឬ បណ្ដេញចេញពីរដ្ឋនេះ ។ សេចក្ដីថ្លែងការណ៍នៅលើក្ដារខៀននេះគឺជាការដកស្រង់ផ្ទាល់មកពីការបញ្ជាឲ្យសម្លាប់ផ្ដាច់ពូជ ។ ( ថូម៉ាស ប៊ី ម៉ាសត្រូវបានកាត់កាលចេញនៅថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ១៨៣៩ ហើយបានជ្រមុជទឹកម្ដងទៀតនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៨៥៧ ។ អូរសុន ហៃឌ ត្រូវបានដកចេញពីកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ១៨៣៩ ហើយបានដាក់ចូលក្នុងកូរ៉ុមវិញនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៣៩ ) ។

សូមរំឭកសិស្សថា គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១–១២៣ គឺជាផ្នែកនៃលិខិតដ៏បំផុសគំនិតមួយរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ដែលបានសរសេរឲ្យពួកបរិសុទ្ធ នៅខែ មិនា ឆ្នាំ ១៨៣៩ ខណៈដែលលោកនៅជាប់គុកលីបឺធី ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–១៧ ដោយស្ងៀមស្ងាត់ ដើម្បីរកមើលអ្វីដែលព្យាការីបានរៀនពី ព្រះអម្ចាស់ទាក់ទងនឹងអ្វីដែលនឹងកើតឡើងចំពោះអស់អ្នកដែលបានចោទប្រកាន់អ្នកបម្រើរបស់ព្រះអម្ចាស់អំពីអំពើរំលង ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថាឃ្លា « សេចក្ដីសង្ឃឹមរបស់ពួកគេនឹងត្រូវបែកខ្ទេចខ្ទី ហើយសេចក្ដីប្រាថ្នារបស់ពួកគេនឹងត្រូវបានរលាយបាត់ទៅ » មានន័យដូចម្ដេច ? ( អស់អ្នកដែលប្រឆាំងទាស់នឹងអ្នកបម្រើរបស់ព្រះអម្ចាស់នៅទីបំផុតនឹងគ្មានជោគជ័យតាមបំណងខ្លួនឡើយ ) ។

- នៅក្នុង ខ ១៣ និង ១៧, តើហេតុផលអ្វីខ្លះដែលព្រះអម្ចាស់បានប្រទានសម្រាប់មូលហេតុដែលមនុស្សខ្លះបានចោទប្រកាន់ដល់អ្នកបម្រើរបស់ព្រះអម្ចាស់អំពីអំពើបាប ? ( អ្នកចោទប្រកាន់ « ដួងចិត្ត [ ត្រូវបាន ] ពុករលួយ » ហើយពួកគេគឺជា « ពួកអ្នកបម្រើនៃអំពើបាប » និង « កូនចៅនៃការមិនគោរពប្រតិបត្តិ » ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១៨–២២ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាមនៅក្នុងគម្ពីរពួកគេ រកមើលលទ្ធផលបន្ថែមទៀតដែលនឹងកើតមានមកលើអស់អ្នកដែលចោទប្រកាន់ខុសឆ្គង ហើយប្រឆាំងនឹងពួកបរិសុទ្ធ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចពន្យល់ថាដើម្បីត្រូវបាន « កាត់ចេញពីពិធីបរិសុទ្ធទាំងឡាយនៃដំណាក់របស់ [ ព្រះអម្ចាស់ ] » (ខ ១៩) មានន័យថាត្រូវបាត់បង់ ឬ បំបែកចេញពីពរជ័យដែលទាក់ទងជាមួយនឹងពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ។

សូមប្រាប់សិស្សថាសេចក្ដីថ្លែងការណ៍ក្លែងក្លាយមកពីសមាជិកសាសនាចក្រដែលក្បត់សាសនាចក្រ និង មនុស្សដទៃទៀត រួមជាមួយនឹងការបញ្ជាឲ្យសម្លាប់ផ្ដាច់ពូជរបស់រដ្ឋាភិបាល បានជម្រុញឲ្យពួកមនុស្សកំណាចបង្កើនការបៀតបៀនលើពួកបរិសុទ្ធ ។ សូមអានដំណើររឿងខាងក្រោមឲ្យឮៗ ហើយសូមឲ្យសិស្សស្ដាប់ឧទាហរណ៍មួយពីរបៀបដែលពួកបរិសុទ្ធត្រូវបានប្រព្រឹត្តយ៉ាងអយុត្តិធម៌នៅពេលនោះ ៖

នៅថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៨៣៨ គឺបីថ្ងៃបន្ទាប់ពីការបញ្ជាឲ្យសម្លាប់ផ្ដាច់ពូជត្រូវបានចេញ មានមនុស្សប្រហែល ២៤០ នាក់បានមកដល់ភូមិឋានពួកមរមនជាកន្លែងមួយហៅថា រោងម៉ាស៊ីនកិនស្រូវហន ។ ស្ត្រី និង ក្មេងៗបានរត់ភាសខ្លួនចូលទៅក្នុងព្រៃ ខណៈដែលបុរសៗបានព្យាយាមការពារខ្លួននៅក្នុងរោងជាងដែក ។ ថ្នាក់ដឹកនាំម្នាក់របស់ពួកបរិសុទ្ធ គឺដេវីឌ អេវ៉ានស៍ បានគ្រវីមួករបស់គាត់ ហើយស្រែកសុំសន្តិភាព ។ សំឡេងកាំភ្លើងរាប់រយបានឆ្លើយតបនឹងការសុំរបស់គាត់ ភាគច្រើនបាញ់តម្រង់ទៅហាងជាងដែកនោះ ។ ពួកមនុស្សកំណាចនោះបានលើកកាំភ្លើងបាញ់ដោយគ្មានក្ដីមេត្តាទៅលើមនុស្សគ្រប់គ្នាដែលពួកគេឃើញ រួមទាំងស្ត្រី បុរសចំណាស់ និងកុមារផងដែរ ។ អាមេនដា ស្មីធ បានឆក់កូនស្រីតូចពីរនាក់របស់ខ្លួន ហើយបានរត់ទៅជាមួយម៉ារី ស្ដេដវេល កាត់ទឹកតាមផ្លូវដើរ ។ អាម៉ានដាបាននិយាយថា « ទោះបីជាយើងជាស្ត្រី ដែលមានកូនតូចៗ បានរត់ដើម្បីរស់រានមានជីវិត ក៏ពួកជនកំណាចនៅបន្តបាញ់សម្លាប់ពួកយើង » ( នៅក្នុង អេនឌ្រូ ជេនសិន *The Historical Record,* ខែ កក្កដា ឆ្នាំ ១៨៨៦ ទំព័រ ៨៤ ) ។

ពួកមនុស្សកំណាចបានចូលទៅក្នុងរោងជាងដែក ហើយបានឃើញ រួចសម្លាប់ សាឌៀស ស្មីធ កូនប្រុសរបស់អាម៉ានដា ស្មីធ ដែលបានលាក់ខ្លួននៅក្នុងខាងក្រោមស្នប់រោងជាងដែកនោះ ។ ក្រោយមកពួកនោះនិយាយគ្នាថា « អាពងចៃ [ កូនចៃ ] នេះនឹងក្លាយជាចៃ ហើយបើសិនជាទុកឲ្យវានៅរស់នោះវានឹងក្លាយជាពួកមរមន »( នៅក្នុង ជេនសិន *The Historical Record,* ខែ ធ្នូ ឆ្នាំ ១៨៨៨ ទំព័រ ៦៧៣; សូមមើលផងដែរ ជេម ប៊ី អាឡែន និង ហ្គិន អិម ឡេអូណាត *The Story of the Latter–day Saints* [ ឆ្នាំ ១៩៧៦ ] ទំព័រ ១២៧–២៨ ) ។ អាលម៉ា ស្មីធ ជាប្អូនប្រុសសាឌៀស អាយុប្រាំពីរឆ្នាំ បានឃើញពីការធ្វើឃាតលើឪពុក និង បងប្រុសរបស់ខ្លួន ព្រមទាំងខ្លួនផ្ទាល់ត្រូវបានបាញ់ចំភ្លៅ ។ ក្រុមមនុស្សកំណាចរកវាមិនឃើញឡើយ ហើយក្រោយមកត្រូវបានជាសះស្បើយយ៉ាងអព្ភូតហេតុតាមរយៈការអធិស្ឋាន និង សេចក្ដីជំនឿ ។ ទោះបីជាមានបុរសពីរបីនាក់ រួមនឹងស្ត្រី ព្រមទាំងកូនក្មេងបានរត់គេចឆ្លងទន្លេចូលទៅក្នុងកូនភ្នំរួចក្ដី យ៉ាងហោចណាស់មានមនុស្ស ១៧ នាក់ត្រូវបានសម្លាប់ ហើយមាន១៣នាក់ត្រូវរងរបួស ។ ( សូមមើល *Church History in the Fulness of Times Student Manual* [ Church Educational System manual, ឆ្នាំ ២០០៣ ]ទំព័រ ២០១ ២០៣–៤; សូមមើលផងដែរ *History of the Church* ៣:១៨៣–៨៧ ) ។ មនុស្សកំណាចឃោរឃៅទាំងនោះ មិនត្រូវបាននាំទៅកាត់ទោសចំពោះអំពើឃាតកម្មរបស់ពួកគេនៅក្នុងតុលាការរដ្ឋ មិសសួរី ឬ ដោយសហព័ន្ធដែលមានសិទ្ធិអំណាចឡើយ ។

- តើអ្នកអាចមានអារម្មណ៍ដូចម្ដេចខ្លះ បើសិនអ្នកជួបនូវរឿងដ៏ព្រៃផ្សៃបែបនេះ ? តើអ្នកនឹងមានអារម្មណ៍ដូចម្ដេចនៅពេលអ្នកបានដឹងថាអ្នកវាយប្រហារយើងនឹងមិនត្រូវបានទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួននោះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៣–២៥ ដោយស្ងៀមស្ងាត់ រកមើលឃ្លាដែលបង្ហាញថាព្រះនឹងឲ្យពួកសត្រូវរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។

- តើគោលការណ៍អ្វីខ្លះដែលយើងបានរៀនពី ខ ២៣–២៥ ? ( នៅពេលសិស្សឆ្លើយ សូមគូសបញ្ជាក់គោលការណ៍ខាងក្រោមនេះ ដោយសរសេរវានៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ទតឃើញ ហើយជ្រាបដឹងគ្រប់កិច្ចការរបស់យើង ។ អស់អ្នកដែលប្រឆាំងទាស់នឹងព្រះអម្ចាស់ និង ប្រជារាស្ត្ររបស់ទ្រង់នឹងទទួលការជំនុំជម្រះរបស់ព្រះ នៅពេលកំណត់របស់ទ្រង់**) ។

សូមអញ្ជើញសិស្សគិតឲ្យអំពីពេល ដែលពួកគេបានឃើញមនុស្សដែលធ្វើខុស ហើយពុំឃើញលទ្ធផលភ្លាមៗ ។

- តើគោលការណ៍ដែលយើងឃើញនៅក្នុង ខ ២៣–២៥ អាចទាក់ទងនឹងស្ថានភាពសព្វថ្ងៃនេះ នៅពេលមនុស្សចង់គេចចេញពីលទ្ធផលនៃទង្វើខុសឆ្គងរបស់ខ្លួនយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៦–៣៣

*ព្រះសន្យាបើកសម្ដែងសេចក្ដីពិតដ៏អស់កល្បតាមរយៈ ព្រះវិញ្ញាណបរិសុទ្ធ*

បើអាចធ្វើបាន សូមដាក់បង្ហាញរូបភាព យ៉ូសែប ស្ម៊ីធ នៅ ក្នុងគុកលីប៊ើធី (*សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] ទំព័រ ៩៧ សូមមើលផងដែរ LDS.org) ។



- តើការលំបាកអ្វីខ្លះដែលយ៉ូសែប ស៊្មីធ និង ដៃគូរបស់លោកបានស៊ូទ្រាំនៅក្នុងគុក លីប៊ើធី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីពិតមួយដែល យ៉ូសែប ស្ម៊ីធបានកត់ត្រា នៅពេលលោកជាប់ឃុំនៅក្នុងគុកលីប៊ើធី ។

- តើសេចក្ដីពិតអ្វីដែលយ៉ូសែបស្ម៊ីធបានកត់ត្រានៅក្នុង ខ ២៦ ? ( សិស្សគួរតែរកឃើញចំណុចដូចខាងក្រោមនេះ ៖ **ព្រះនឹងផ្ដល់ចំណេះដឹងដល់យើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ**) ។

ដើម្បីជួយសិស្សយល់ពីរបៀបដែលសេចក្ដីពិតនេះអាចទាក់ទងនឹងពួកគេនៅពេលពួកគេជួបបទពិសោធន៍លំបាក សូមអញ្ជើញសិស្សម្នាក់ឲ្យអានទីបន្ទាល់ខាងក្រោមដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« អ្នកអាចមានបទពិសោធន៍ដឹកនាំដ៏ពិសិដ្ឋ ដ៏មានវិវរណៈយ៉ាងជ្រាលជ្រៅជាមួយនឹងព្រះអម្ចាស់ *នៅក្នុងបទពិសោធន៍ដ៏ឈឺចាប់ក្នុងជីវិតអ្នក*នៅក្នុងដំណើរដ៏អាក្រក់បំផុត ខណៈស៊ូទ្រាំនឹងភាពអយុត្តិធម៌ដ៏ខ្លោចផ្សា នៅពេលប្រឈមមុខនឹងរឿងរ៉ាវដែលពុំអាចឈ្នះបាន និង ការសង្កត់សង្កិនដែលអ្នកធ្លាប់បានជួបប្រទះពីមុន » (Lessons from Liberty Jail » *Ensign,* ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ២៨ ) ។

- តើការទទួលចំណេះដឹងតាមរយៈព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងដូចម្ដេចខ្លះ នៅពេលយើងជួបការលំបាក ?
- តើពេលណាដែលអ្នកបានទទួលចំណេះដឹង ឬ ការណែនាំពីព្រះវិញ្ញាណបរិសុទ្ធដែលជួយអ្នកឲ្យឆ្លងកាត់ពេលដ៏លំបាកនោះ ? ( សូមរំឭកសិស្សថា បទពិសោធន៍មួយចំនួន គឺពិសិដ្ឋ ឬផ្ទាល់ខ្លួនណាស់ពុំគួរចែកចាយទេ ) ។

ដើម្បីបង្ហាញសេចក្ដីពិតបន្ថែមទៀតដែលសិស្សរកឃើញនៅក្នុង ខ ២៦, អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោមដោយ លូស៊ី ម៉ាក ស្ម៊ីធ ដែលបានទទួលចំណេះដឹង និង ការលួងលោមតាមរយៈព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីយ៉ូសែប និង ហៃរ៉ុម ត្រូវបានចាប់យកទៅជាទណ្ឌិត ហើយគំរាមគំហែងដោយសេចក្ដីស្លាប់ ៖



« នៅក្នុងអំឡុងពេលនៃសេចក្ដីសោកសៅរបស់ខ្ញុំ នោះខ្ញុំបានឃើញការលួងលោម ដែលមានហួសពីការលួងលោមនៃអស់ទាំងខាងលោកិយ ។ ខ្ញុំបានពោរពេញដោយព្រះវិញ្ញាណនៃព្រះ ហើយបានទទួលចំណេះដឹងដូចតទៅនេះតាមរយៈអំណោយទាននៃការព្យាករ ៖ ‹ សូមឲ្យដួងចិត្តអ្នកទទួលបានការលួងលោមទាក់ទងនឹងរឿងកូនៗរបស់អ្នក មារសត្រូវរបស់ពួកគេនឹងមិនបៀតបៀនពួកគេឡើយ ។. . .ការណ៍នេះបានធ្វើឲ្យចិត្តខ្ញុំធូរស្បើយ ហើយខ្ញុំត្រូវបានរៀបចំដើម្បីលួងលោមកូនៗរបស់ខ្ញុំ ។ ខ្ញុំបានប្រាប់ពួកគេពីអ្វីដែលបានបើកសម្ដែងដល់ខ្ញុំ ដែលលួងលោមចិត្តរបស់ពួកគេយ៉ាងខ្លាំង » (*History of Joseph Smith by His Mother,* បានបោះពុម្ព ប្រេសតុន នីប្លី [ ឆ្នាំ ១៩៥៨ ] ទំព័រ ២៩១ ) ។

- តើការសន្យានៃវិវរណៈរបស់ព្រះអម្ចាស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធអាចលួងលោមយ៉ូសែប ស្ម៊ីធ និង ពួកបរិសុទ្ធអំឡុងពេលនៃការបៀតបៀនដោយរបៀបណា ?

សូមសង្ខេប ខ ២៦–៣៣ ដោយពន្យល់ថាព្រះអម្ចាស់បានសន្យាថាបើកសម្ដែងចំណេះដឹងដែល « ពុំទាន់បានបើកសម្ដែងប្រាប់ចាប់តាំងពីកំណើតលោកិយ » (គ. និង ស. ១២១:២៦) ហើយប្រទានពរជ័យដ៏រុងរឿងដល់អស់អ្នកដែលស៊ូទ្រាំដោយ « ក្លាហានដើម្បីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » (គ. និង ស. ១២១:២៩) ។

សូមប្រាប់សិស្សថានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១២១:៣៣, ព្យាការីយ៉ូសែប ស៊្មីធ បានប្រើការប្រដូចមួយដើម្បីជួយពួកបរិសុទ្ធឲ្យយល់ថាព្រះអម្ចាស់មានព្រះចេស្ដាច្រើនជាងអស់អ្នកដែលកំពុងបៀតបៀនពួកបរិសុទ្ធ ហើយព្យាយាមរារាំងកិច្ចការរបស់ព្រះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរូបភាពមួយដែលយ៉ូសែប ស្ម៊ីធ បានប្រើដើម្បីបង្ហាញពីព្រះចេស្ដានៃព្រះ ។ ( « ទឹកហូរ » និង « ទន្លេមិសសួរី » ។ អ្នកអាចពន្យល់ថាទន្លេមិសសួរីគឺជាទន្លេធំមួយ ហើយជាទន្លេដ៏មានឥទ្ធិពលដែលពួកបរិសុទ្ធកាលពីដើមបានរស់នៅក្បែរនោះ ហើយបានស្គាល់ទីនោះ ) ។

សូមអញ្ជើញសិស្សឲ្យគិតពីពេល ដែលពួកគេបានឃើញទឹកហូរគំហុកដូចជាទន្លេ ឬ ស្ទឹងមួយដែលហូរពីលើភ្នំ ។ សូមឲ្យសិស្សគិតពីពេល ដែលពួកគេបានឃើញទឹកនឹងថ្កល់ដូចជាស្រះមួយ ។ បើអាចធ្វើបាន អ្នកអាចបង្ហាញរូបភាពនៃទឹកដែលផ្ទុយពីនោះ ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះចេញពីខគម្ពីរនេះ ? ( សូមជួយសិស្សស្វែងរកគោលការណ៍ខាងក្រោមនេះ ៖ **គ្មានអ្វីមួយអាចបញ្ឈប់កិច្ចការរបស់ព្រះអម្ចាស់ឲ្យបន្តរីកចម្រើនបានឡើយ**) ។

- តើវាធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងណាដើម្បីដឹងថា កិច្ចការរបស់ព្រះអម្ចាស់នឹងបន្តទោះបីជាមានការប្រឆាំងក៏ដោយ ?

ដើម្បីបញ្ចប់ អ្នកអាចរំឭកដោយសង្ខេបអំពី គោលការណ៍នានាដែលសិស្សបានរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១ ។ សូមអញ្ជើញសិស្សឲ្យចែកចាយពីរបៀបដែលពួកគេអាចធ្វើតាមគោលការណ៍ទាំងនេះនៅក្នុងជីវិតពួកគេ ។ អ្នកក៏អាចថ្លែងទីបន្ទាល់អំពី របៀបដែលសេចក្ដីពិតទាំងនេះបានប្រទានពរដល់អ្នក ។

មេរៀនទី ១២៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦ គឺជាផ្នែកមួយនៃសំបុត្រដ៏បំផុសគំនិតរបស់យ៉ូសែប ស្ម៊ីធពីគុកលីប៊ើធី ។ នៅក្នុងផ្នែកនៃសំបុត្រនេះ ព្យាការីបង្រៀនគោលការណ៍នានាអំពីព្រះចេស្ដា និង សិទ្ធិអំណាចនៃបព្វជិតភាព ។ លោកពន្យល់ពីមូលហេតុដែលថាមានមនុស្សជាច្រើនដែលត្រូវបានហៅ ប៉ុន្តែមានតែបន្តិចប៉ុណ្ណោះដែលត្រូវបានរើស និង របៀបដែលអ្នកកាន់បព្វជិតភាពអាចទទួលអំណាចនានានៃឋានសួគ៌ដើម្បីបម្រើមនុស្សដទៃ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤០

*យ៉ូសែប ស្ម៊ីធ បង្រៀនថា សិទ្ធិនៃបព្វជិតភាពត្រូវបានភ្ជាប់ទៅនឹងអំណាចសួគ៌*

សូមបង្ហាញអំពូលភ្លើងមួយដែលពុំដោតនឹងព្រីភ្លើង ។ សូមប្រាកដថា កុងតាក់អំពូលភ្លើងនោះត្រូវបាន « បិទ » ដើម្បីនៅពេលដោតនឹងព្រីភ្លើង អំពូលនោះពុំភ្លឺឡើយ ។ ប្រសិនបើអ្នកពុំអាចយកអំពូលភ្លើងមកបាន សូមគូសរូប អំពូលភ្លើងដែលមានដូចរៀបរាប់មកនេះ ( ដោយពុំដាក់ពាក្យឡើយ ) នៅលើក្ដារខៀន ។




សូមពន្យល់ថាមេរៀនថ្ងៃនេះ អំពូលភ្លើងតំណាងឲ្យអ្នកកាន់បព្វជិតភាព ។ ពន្លឺពីអំពូលភ្លើងតំណាងឲ្យពរជ័យដែលមនុស្សអាចទទួលបានពីព្រះតាមរយៈការបម្រើនៃអ្នកកាន់បព្វជិតភាព ។ បើសិនអ្នកមានអំពូលភ្លើងមកជាមួយអ្នក សូមបិទលើអំពូលភ្លើងនោះថា *អ្នកកាន់បព្វជិតភាព* ។ បើសិនពុំមានអំពូលភ្លើងទេ សូមសរសេរឃ្លានេះនៅលើកន្លែងណាមួយដែលសមរម្យលើរូប ។

នៅពេលសិស្សចាប់ផ្ដើមការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦ ថ្ងៃនេះ សូមឲ្យពួកគេពិចារណាពីរបៀបនៃសេចក្ដីសុចរិតផ្ទាល់ខ្លួនរបស់អ្នកកាន់បព្វជិតភាព ជះឥទ្ធិពលលើសមត្ថភាពខ្លួន ដើម្បីជួយមនុស្សដទៃឲ្យទទួល

ពរជ័យនានាពីបព្វជិតភាព ។ សូមចង្អុលបង្ហាញថា ទោះបីជាខគម្ពីរទាំងនេះនិយាយផ្ទាល់ចំពោះអ្នកកាន់បព្វជិតភាពក្ដី ក៏ខគម្ពីរទាំងនេះមាននូវគោលការណ៍ដែលអនុវត្តចំពោះសមាជិកសាសនាចក្រគ្រប់រូប ។

សូមរំឮកសិស្សថា គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១ មានផ្នែកនានានៃសំបុត្រដ៏បំផុសគំនិតដែលយ៉ូសែប ស៊្មីធ បានសរសេរនៅពេលលោកជាប់នៅក្នុងគុកលីប៊ើធី ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សរកត់ចំណាំសំណួរនៅក្នុងខគម្ពីរនេះ ។

ដើម្បីជួយសិស្សឲ្យពិចារណា និង ពិភាក្សាពីអត្ថន័យដែលថា អ្នកកាន់បព្វជិតភាពត្រូវបាន « ហៅ » និង « ជ្រើសរើស » សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ជេមស៍ អ៊ី ហ្វោស្ត នៃ គណៈប្រធានទីមួយដែលបានថ្លែងទៅកាន់អ្នកកាន់បព្វជិតភាពឲ្យឮៗ ៖



« យើងត្រូវបានហៅនៅពេលគេដាក់ដៃលើក្បាលរបស់យើង ហើយយើងត្រូវបានប្រទាននូវបព្វជិតភាព ប៉ុន្តែយើងមិនត្រូវបានជ្រើសរើសនៅឡើយទេ រហូតដល់យើងបានបង្ហាញដល់ព្រះពីសេចក្ដីសុចរិតភាពស្មោះត្រង់ និង ការតាំងចិត្តរបស់យើងជាមុនសិន » (Called and Chosen » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៥៥ ) ។

- ស្របតាមប្រធាន ហ្វោស្ត តើវាមានន័យដូចម្ដេចនៅពេលក្មេងប្រុសម្នាក់ត្រូវបាន « ហៅ » នោះ ?

សូមចង្អុលបង្ហាញថាការត្រូវបាន « ហៅ » គឺមិនដូចគ្នានឹងការត្រូវបាន « ជ្រើសរើស » ឡើយ ។ ដើម្បីក្លាយជា « មនុស្សជម្រើស » របស់ព្រះ អ្នកកាន់បព្វជិតភាពត្រូវតែរស់នៅតាមរបៀបមួយដែលអាចឲ្យគាត់ទទួលយកអំណាចនៃឋានសួគ៌ ដើម្បីជួយមនុស្សដទៃឲ្យទទួលពរជ័យនៃបព្វជិតភាព ។

សូមពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៥–៣៩, យើងរៀនពីមូលហេតុដែលអ្នកកាន់បព្វជិតភាពមួយចំនួនមិនត្រូវបានជ្រើសរើសឡើយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៥–៣៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមេរៀនមួយដែលអ្នកកាន់បព្វជិតភាពគ្រប់រូបគួរតែរៀន ។

- យោងតាម ខ ៣៦, តើមេរៀនអ្វីដែលអ្នកកាន់បព្វជិតភាពគ្រប់រូបគួរតែរៀន ?

ដើម្បីជួយសិស្សឲ្យយល់អំពីមេរៀននៅក្នុង ខ ៣៦,សូមមើលទៅប្រភពនៃចរន្តអគ្គិសនីនៅក្នុងថ្នាក់រៀន ឬ នៅក្នុងរូបលើក្ដារខៀន ។

- តាមឃ្លានៅក្នុង ខ ៣៦ តើចរន្តអគ្គិសនីអាចតំណាងឲ្យអ្វី ? ( « អំណាចទាំងឡាយនៃស្ថានសួគ៌ » ។ សូមសរសេរ *អំណាចទាំងឡាយនៃស្ថានសួគ៌* នៅលើក្ដារខៀនជាប់នឹងរូបព្រីភ្លើង ឬ បិទស្លាកនេះនៅជាប់នឹងប្រភពថាមពលភ្លើងពិត ) ។
- នៅក្នុង ខ ៣៦, តើអ្នកគិតថាឃ្លា « សិទ្ធិទាំងឡាយនៃបព្វជិតភាព » សំដៅទៅលើអ្វី ? ( ចម្លើយរបស់សិស្សគួរតែបញ្ជាក់ថា បុរសម្នាក់ទទួលសិទ្ធិដើម្បីអនុវត្តបព្វជិតភាព នៅពេលសិទ្ធិអំណាចនៃបព្វជិតភាពត្រូវបាន ប្រគល់ឲ្យគាត់ដោយការដាក់ដៃលើ ) ។

សូមបិទស្លាកលើខ្សែភ្លើងថា *សិទ្ធិអំណាចបព្វជិតភាព* ។ បើសិនអ្នកបង្ហាញពីអំពូលភ្លើងមួយ សូមអញ្ជើញសិស្សម្នាក់ឲ្យដោតខ្សែឌុយទៅក្នុងព្រីភ្លើង ។

- ហេតុអ្វីក៏អំពូលភ្លើងអត់ភ្លឺ ? ( ដោយសារកុងតាក់បិទ ) ។
- តាមឃ្លានៅក្នុង ខ ៣៦ តើកុងតាក់អាចប្រដូចទៅនឹងអ្វី ? ( « គោលការណ៍នៃសេចក្ដីសុចរិត » ។ សូមពន្យល់ថាឃ្លានេះសំដៅលើទំនួលខុសត្រូវរបស់អ្នកកាន់បព្វជិតភាពឲ្យរស់នៅដោយសុចរិត ) ។

សូមបិទស្លាកលើកុងតាក់ថា *គោលការណ៍នៃសេចក្ដីសុចរិត* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យបើកកុងតាក់ភ្លើង ។

- ក្នុងការប្រៀបធៀបនេះ តើការរស់នៅដោយសុចរិតប្រដូចទៅនឹងការបើកកុងតាក់ភ្លើងនេះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យថ្លែងជាសម្ដីខ្លួនផ្ទាល់ពីគោលការណ៍ដែលដកស្រង់ពី ខ ៣៦ ។ សូមសង្ខេបចម្លើយរបស់ពួកគេ ដោយសរសេរគោលការណ៍ខាងក្រោមនេះ—ឬ សរសេរអ្វីដូចនេះ—លើក្ដារខៀន ៖ **អ្នកកាន់បព្វជិតភាពអាចទទួលអំណាចទាំងឡាយនៃឋានសួគ៌បាន បើសិនពួកគេរស់នៅដោយសេចក្ដីសុចរិតតែប៉ុណ្ណោះ** ។ អ្នកអាចប្រាប់សិស្សឲ្យសរសេរគោលកាណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៧–៣៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលកើតឡើងចំពោះសមត្ថភាពរបស់អ្នកកាន់បព្វជិតភាពម្នាក់ ដើម្បីទទួលបានអំណាចនានានៃឋានសួគ៌ បើសិន គាត់មិនបានរស់នៅដោយសុចរិតទេនោះ ។

- តើមានអ្វី កើតឡើងនៅពេលដែលអ្នកកាន់បព្វជិតភាពមិនរស់នៅដោយសុចរិតនោះ ? ( អំណាចទាំងឡាយនៃឋានសួគ៌ ដកខ្លួនចេញ ហើយសិទ្ធិអំណាចរបស់គាត់ត្រូវបានបញ្ចប់ ។ អ្នកអាចពន្យល់ថា ឃ្លា « ធាក់ជល់នឹងជន្លួញ » សំដៅលើសត្វពាហនៈមួយដែលតតាំងនឹងឈើស្រួចមួយដែលប្រើដើម្បី នាំផ្លូវវាទៅកាន់គោលដៅដែលចង់ទៅ ។ សម្រាប់ពួកយើង ឃ្លានេះសំដៅលើការតតាំងនឹងការណែនាំពីព្រះអម្ចាស់ ឬ អ្នកបម្រើទ្រង់ ) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នៅលើក្ដារខៀន សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊យដ៏ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



*សិទ្ធិអំណាច*នៅក្នុងបព្វជិតភាពបានមកដោយការតែងតាំង *អំណាច*នៅក្នុងបព្វជិតភាពបានមក តាមរយៈសេចក្ដីស្មោះត្រង់ និង ការប្រតិបត្តិតាម ការរស់នៅក្នុងការគោរពសេចក្ដីសញ្ញាទាំងឡាយ ។ វានឹងកើនឡើងតាមរយៈការអនុវត្ត និង ប្រើបព្វជិតភាពនៅក្នុងសេចក្ដីសុចរិត » ( The Power of the Priesthood » *Ensign* ឬ *Liahona*, ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៩ ) ។

សូមសរសេរប្រយោគ ខាងក្រោម នៅលើក្ដាខៀន ៖

*ធ្វើឲ្យទំនាក់ទំនងចុះខ្សោយ ពង្រឹងទំនាក់ទំនង*

សូមអញ្ជើញសិស្សឲ្យអាន ខ ៣៥ និង ៣៧ ដោយស្ងៀមស្ងាត់ រកមើលចរិតលក្ខណៈ និង សកម្មភាពដែលមិនសុចរិត ដែលបណ្ដាលឲ្យទំនាក់ទំនងនៃអ្នកកាន់បព្វជិតភាពជាមួយអំណាចទាំងឡាយនៃឋានសួគ៌ចុះខ្សោយ ។ អ្នកអាចចង់ឲ្យ ពួកគេគូរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាអ្នកសរសេរ ដោយសរសេរចម្លើយនៅក្រោមឃ្លា « ធ្វើឲ្យទំនាក់ទំនងចុះខ្សោយ » ។ បន្ទាប់ពីសរសេរចម្លើយសិស្សហើយ សូមអានឧទាហរណ៍ខាងក្រោមនេះ ។ សម្រាប់ឧទាហរណ៍និមួយៗ សូមឲ្យសិស្សស្វែងរកឥរិយាបទ ឬ សកម្មភាពដែលពួកគេបានសរសេរលើក្ដារខៀន ។

១. ដើម្បីត្រូវគ្នានឹងមនុស្សដ៏មានប្រជាប្រិយរបស់ខ្លួន អ្នកកាន់បព្វជិតភាពចូលរួមជាមួយពួកគេ ហើយសើចចំអកដល់មិត្តរួមថ្នាក់នៅឯសាលា ។

២. ប្រធានកូរ៉ុមគ្រូម្នាក់ចូលចិត្តកីឡា ហើយគាត់បានបដិសេធមិនចូលរួមការដាក់ផែនការនៃសកម្មភាពកូរ៉ុម ដែលមិនទាក់ទងនឹងការលេងបាល់ទាត់ ឬ បាល់បោះឡើយ ។ នៅពេលកូរ៉ុមចូលរួមក្នុងសកម្មភាពមួយ ឬ បម្រើ គាត់បញ្ជាឲ្យយុវជនផ្សេងទៀតធ្វើតាមអ្វីដែលខ្លួននិយាយ ដោយសារគាត់ជាប្រធានកូរ៉ុម ។

- តើមានគំរូអ្វីខ្លះនៃមនុស្សដែលព្យាយាមលាក់បាំងអំពើបាបរបស់ពួកគេ ?
- តើមានគំរូអ្វីខ្លះនៃមនុស្សដែលដាក់ដួងចិត្តរបស់ពួកគេភ្ជាប់ទៅលើអ្វីៗទាំងឡាយនៃលោកនេះ ហើយប្រាថ្នាចង់បានកិត្តិយសនៃមនុស្សលោក ?
- តើអ្នកគិតថា ហេតុអ្វីបានជាឥរិយាបទ និង សកម្មភាពនានារារាំងអ្នកកាន់បព្វជិតភាពពីការទទួលអំណាចទាំងឡាយនៃឋានសួគ៌ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៩–៤០ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលហេតុផលដែលមនុស្សមួយចំនួនអនុវត្តការគ្រប់គ្រងដែលមិនសុចរិត ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- ដោយផ្អែកទៅលើអ្វីដែលអ្នកបានរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤០, តើអ្នកនឹងសង្ខេបពីមូលហេតុដែលមនុស្សជាច្រើនត្រូវបានហៅ ប៉ុន្តែមានតែមួយចំនួនតូចដែលត្រូវបានរើសយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៦

*យ៉ូសែប ស្ម៊ីធបង្រៀនពីរបៀបដែលពួកអ្នកកាន់បព្វជិតភាពគួរប្រព្រឹត្ត*

សូមពន្យល់ថា បន្ទាប់ពីការបង្រៀនអំពីឥរិយាបថ និង សកម្មភាពដែលធ្វើឲ្យទំនាក់ទំនងរវាងអ្នកកាន់បព្វជិតភាព និង អំណាចទាំងឡាយនៃឋានសួគ៌ចុះខ្សោយ យ៉ូសែប ស្ម៊ីធ បានបង្រៀនអំពីឥរិយាបថ និង សកម្មភាពដែលពង្រឹងទំនាក់ទំនងនោះ ។ សូមចែកសិស្សជាគូៗ ហើយសូមឲ្យពួកគេ អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៥ ជាមួយគ្នា ។ សូមឲ្យពួកគេរកមើលឥរិយាបទ និង សកម្មភាពនានាដែលជួយអ្នកកាន់បព្វជិតភាពឲ្យទទួលអំណាចទាំងឡាយនៃឋានសួគ៌ដើម្បីជួយមនុស្សដទៃទៀត ។ ( ពីមុនពួកគេអាន អ្នកអាចចង្អុលបង្ហាញថានៅក្នុង ខ ៤១, ពាក្យថា *លើកលែង* មានន័យថា « លើកលែងតែ » ) ។

ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាអ្នកសរសេរ ដោយសរសេរចម្លើយនៅក្រោមពាក្យ « ពង្រឹងទំនាក់ទំនង » ។ សូមឲ្យសិស្សសរសេរគោលការណ៍នានានៃសេចក្ដីសុចរិត អ្នកអាចឲ្យពួកគេពន្យល់ ឬ ផ្ដល់ឧទាហរណ៍ពីគោលការណ៍និមួយៗ ។ បើចាំបាច់ សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថាធ្វើដោយការស្រឡាញ់ស្មោះត្រង់ និង ដោយឥតលាក់ពុត ឬ ដោយឥតមានឧបាយកលឡើយមានន័យដូចម្ដេច ? ( ចម្លើយអាចរួមមានដូចជា វាមានន័យថា ស្រឡាញ់មនុស្សដោយស្ម័គ្រស្មោះ និង ពិតប្រាកដ ហើយមានការជម្រុញចិត្តដ៏សុចរិត ) ។ ហេតុអ្វីបានជាអាកប្បកិរិយាទាំងនេះសំខាន់ចំពោះអ្នកកាន់បព្វជិតភាព ?

- នៅក្នុង ខ ៤៣, ពាក្យ *ស្ដីបន្ទោស* សំដៅទៅលើទង្វើនៃការប្រាប់នរណាម្នាក់ថាគាត់កំពុងធ្វើខុសហើយជាទូទៅប្រាប់បែបសុភាព ឬ សន្ដានចិត្តល្អ ។ ពាក្យ *សមពេលសមហេតុ* មានន័យថា « មុនពេល » ឬ « ក្នុងលក្ខណៈទាន់ពេលវេលា » ។ ពាក្យ *ការតឹងរ៉ឹង* អាចសំដៅទៅលើសេចក្ដីត្រូវការដើម្បីបង្ហាញខ្លួនយើងឲ្យច្បាស់លាស់ ។ តើអ្នកគិតថា ហេតុអ្វីវាជាការសំខាន់សម្រាប់ថ្នាក់ដឹកនាំបព្វជិតភាពម្នាក់ដើម្បីស្ដីបន្ទោសឲ្យច្បាស់លាស់ ចំពេល ហើយស្របតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីបង្ហាញការបង្កើនសេចក្ដីស្រឡាញ់ បន្ទាប់ពីស្ដីបន្ទោសនរណាម្នាក់ហើយនោះ ? តើអ្នកធ្លាប់ទទួលអត្ថប្រយោជន៍ពីការកែប្រែបែបនោះដែរឬទេ ?

- តើអ្នកគិតថា សូមឲ្យចិត្តអ្នកពេញទៅដោយសេចក្ដីសប្បុរសដល់មនុស្សទាំងអស់ មានន័យដូចម្ដេច ? ( សូមមើល ខ ៤៥ ) ។ ហេតុអ្វីអ្នកគិតថា វាសំខាន់សម្រាប់អ្នកកាន់បព្វជិតភាព ដើម្បីមានភាពស្លូតបូត និង មានសន្ដានចិត្តល្អក្នុងទំនាក់ទំនងជាមួយមនុស្សដទៃ ?

- តើអ្នកគិតថា សូមឲ្យគុណធម៌តុបតែងគំនិតអ្នកដោយឥតឈប់ឈរឡើយ មានន័យដូចម្ដេច ? ( សូមមើល ខ ៤៥ ) ។ តើមានអ្វីខ្លះដែលយើងអាចធ្វើបានដើម្បីរក្សាគំនិតរបស់យើងឲ្យមានគុណធម៌ ?

- តើអ្នកគិតថាហេតុអ្វីបានជា អ្នកកាន់បព្វជិតភាពត្រូវតែធ្វើតាមគោលការណ៍នៃសេចក្ដីសុចរិត ដើម្បីទទួលបានអំណាចទាំងឡាយនៃឋានសួគ៌ ?

សូមចង្អុលបង្ហាញពាក្យ *ខណៈនោះ* នៅក្នុង ខ ៤៥ ។ សូមពន្យល់ថា ពាក្យនេះចង្អុលបង្ហាញទៅលទ្ធផលនៃការរស់នៅស្របតាមគោលការណ៍នៃសេចក្ដីសុចរិតដែលមាននៅក្នុង ខ ៤១–៤៥ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤៥–៤៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យដែលបានប្រទានមកដល់អ្នកកាន់បព្វជិតភាព ដែលបានទទួលអំណាចនានានៃឋានសួគ៌តាមរយៈការរស់នៅដោយសុចរិត ។ ( មុនពេលសិស្សអាន អ្នកអាចពន្យល់ថា ដំបងពេជ្រគឺជាដំបងដែលកាន់ដោយព្រះមហាក្សត្រ ឬ ម្ចាស់ក្សត្រី ។ វាគឺជានិមិត្តរូបនៃសិទ្ធិអំណាច និង ព្រះចេស្ដា ) ។

- តើមានពរជ័យអ្វីខ្លះនៃការរស់នៅតាមគោលការណ៍នៃសេចក្ដីសុចរិត ?

- សូមគិតពីអ្នកកាន់បព្វជិតភាពម្នាក់ដែលអ្នកស្គាល់ ដែលរស់នៅក្នុងរបៀបមួយដែលជួយគាត់ទទួលបានអំណាចទាំងឡាយនៃឋានសួគ៌ ។ តើអ្នកបានទទួលពរជ័យតាមរយៈការបម្រើរបស់គាត់យ៉ាងដូចម្ដេច ?

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យដែលអ្នកបានទទួលតាមរយៈសិទ្ធិអំណាចបព្វជិតភាព និង អំណាចបព្វជិតភាព ។ សូមអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេផងដែរ ។ សូមអញ្ជើញពួកគេឲ្យជ្រើសរើសគោលការណ៍មួយនៃសេចក្ដីសុចរិតដែលបានរៀបរាប់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៥ ហើយដាក់គោលដៅដើម្បីរស់នៅតាមគោលការណ៍នោះឲ្យបានកាន់តែប្រសើរ ។

មេរៀនទី ១២៩

# គោលលទ្ធិ និង សេចក្តីសញ្ញា ១២៣

## បុព្វកថា

អំឡុងពេលដែលព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងគុកលីប៊ើធី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៨៣៨ ដល់ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣៩ លោកបានសរសេរសំបុត្រនៃការលួងលោម និង ទូន្មានដល់ពួកបរិសុទ្ធ ។ គោលលទ្ធិ និង សេចក្តីសញ្ញា ១២៣ គឺជាការដកស្រង់មួយចេញពីសំបុត្រនោះដែលចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៨៣៩ ដែលលោកបានសរសេរទៅកាន់ពួកបរិសុទ្ធ ។ នៅក្នុងការដកស្រង់នេះ ព្យាការីបានសូមឲ្យពួកបរិសុទ្ធប្រមូល និង បោះពុម្ពដំណើររឿងនៃការបៀតបៀន និង ការរងទុក្ខរបស់ពួកគេ ហើយជួយដល់អស់អ្នកដែលបំពាន់ដោយគោលលទ្ធិក្លែងក្លាយ ។

*កំណត់ចំណាំ ៖* មេរៀនបន្ទាប់ ( « ការកសាងទីក្រុងណៅវូ » មេរៀនទី ១៣០ ) នឹងផ្តល់ឱកាសមួយឲ្យសិស្សពីរនាក់បង្រៀនផ្នែកនៃមេរៀននោះ ។ អ្នកអាចនឹងជ្រើសរើសសិស្សពីរនាក់ក្នុងពេលឥឡូវនេះ ហើយផ្តល់ច្បាប់ចម្លងមួយផ្នែក នៃមេរៀនទី ១៣០ ដែលបានចាត់តាំងដល់ពួកគេ ដើម្បីពួកគេអាចរៀបចំមេរៀននោះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ១២៣:១–៦

*យ៉ូសែប ស្ម៊ីធ ទូន្មានឲ្យពួកបរិសុទ្ធប្រមូល និង បោះពុម្ពដំណើររឿងនៃការបៀតបៀន និង ការរងទុក្ខរបស់ពួកគេ*

សូមចាប់ផ្តើមដោយអានសេចក្តីថ្លែងខាងក្រោមនេះ ៖

> « នេះសូមបញ្ជាក់ថា ខ្ញុំឈ្មោះឌែលា រីដ បានប្តូរមកនៅរដ្ឋ មិសសួរីនៅក្នុងឆ្នាំ ១៨៣៦ ។ ស្វាមីរបស់ខ្ញុំបានស្លាប់មិនយូរប៉ុន្មាន បន្ទាប់ពីយើងបានមកដល់ទីនេះ ហើយទុកកូនតូចៗប្រាំពីរនាក់ជាមួយខ្ញុំ ។. . . នៅពេលភាពច្របូកច្របល់បានកើតមានឡើងរវាងពួកប្រជាជន និង ពួកមរមន នោះខ្ញុំជាមួយនឹងសមាគមទាំងអស់របស់យើង ត្រូវបានបង្ខំឲ្យចាកចេញពីរដ្ឋនោះ ។. . . ខ្ញុំត្រូវបានបង្ខំឲ្យលះបង់ទ្រព្យសម្បត្តិភាគច្រើន [ និង ] គ្រួសាររបស់ខ្ញុំ [ បាន ] ព្រាត់ប្រាស់គ្នា ហើយខ្ញុំត្រូវទទួលអាហារបន្តិចបន្តួចពី ជនដែលខ្ញុំមិនស្គាល់ » ( ឌែលា រីដ នៅក្នុង *Mormon Redress Petitions: Documents of the ១៨៣៣–១៨៣៨ Missouri Conflict,* បានបោះពុម្ពដោយ ខ្លាក វី ចនសុន [ ឆ្នាំ ១៩៩២ ] ទំព័រ ៥២៣ វណ្ណយុត្ត អក្សរធំ និង ការប្រកបពាក្យដែលមានបទដ្ឋាន ) ។

សូមពន្យល់ថានេះគឺជាសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់បងស្រី រីដ ដែលបានផ្តល់ឲ្យមន្ត្រីចៅក្រម ។ បន្ទាប់មក សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និងសេចក្តីសញ្ញា ១២៣:១ ដោយស្ងៀមស្ងាត់ ។

- ចេញពីអ្វីដែលអ្នកបានរៀនពីខគម្ពីរនេះ តើបងស្រី រីដផ្តល់សេចក្តីថ្លែងការណ៍នេះក្នុងគោលបំណងអ្វី ?

សូមរំឮកសិស្សថាចាប់ពី ខែ ធ្នូ ឆ្នាំ ១៨៣៨ ដល់ ខែ មេសា ឆ្នាំ ១៨៣៩ ព្យាការី យ៉ូសែប ស្ម៊ីធ និង អ្នកដឹកនាំសាសនាចក្រមួយចំនួនផ្សេងទៀតត្រូវបានជាប់ឃុំនៅក្នុងគុកនៅលីប៊ើធី រដ្ឋ មិសសួរី ។ នៅតំណាលគ្នានោះ ពួកបរិសុទ្ធត្រូវបានបណ្តេញចេញពីរដ្ឋ មិសសួរី អំឡុងពេលរដូវរងាដ៏ត្រជាក់ជាច្រើនខែ ដោយសារតែការចេញបញ្ជាឲ្យសម្លាប់ផ្តាច់ពូជរបស់រដ្ឋាភិបាល លិបបឺន បកស៍ ។ សូមពន្យល់ថា គោលលទ្ធិ និង សេចក្តីសញ្ញា ១២៣ គឺជាការដកស្រង់មួយនៃសំបុត្ររបស់ព្យាការីយ៉ូសែប ស្ម៊ីធ ដែលបានសរសេរនៅខែ មិនា ឆ្នាំ ១៨៣៩ ពីគុកលីប៊ើធីដែលផ្តល់ការទូន្មានដល់ពួកបរិសុទ្ធអំឡុងពេលដ៏លំបាកនេះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២៣:១–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលអ្វីដែលយ៉ូសែបបានណែនាំឲ្យពួកបរិសុទ្ធដែលរងការបៀតបៀនធ្វើតាម ។ ដើម្បីជួយសិស្សឲ្យយល់ខគម្ពីរទាំងនោះ អ្នកអាចត្រូវការពន្យល់ថានៅក្នុង ខ ៥ ឃ្លា « ប្រជុំអំពើទុច្ចរិត » សំដៅលើការប្រមូលនៃការកុហក់ទុច្ចរិត និង ឃ្លា « ការបង្ខំដ៏អាក្រក់អាស្រូវ និង ឃាតកម្មទាំងឡាយ » សំដៅលើអំពើអាក្រក់ និង ទង្វើហិង្សា ។

- តើព្យាការីបានទូន្មានឲ្យ ពួកបរិសុទ្ធធ្វើអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ?

ពួកបរិសុទ្ធជាច្រើនបានគោរពប្រតិបត្តិតាមការទូន្មានរបស់ព្យាការី ហើយបានប្រមូលដំណើររឿងនៃការបៀតបៀនរបស់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២៣:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម

រកមើលមូលហេតុដែលពួកបរិសុទ្ធត្រូវបានប្រាប់ឲ្យប្រមូលដំណើររឿងនៃការបៀតបៀន និង ការរងទុក្ខរបស់ពួកគេ ។ អ្នកអាចពន្យល់ថាឃ្លា « ដែលតម្រូវពីយើង » មានន័យថា « តម្រូវឲ្យពួកយើង » ។ អ្នកអាចរំឭកពួកគេថាព្រះអម្ចាស់បានសន្យាកាលពីមុនថា ប្រាសលោះពួកបរិសុទ្ធដែលត្រូវបានគេបៀតបៀនហើយ « យាងចេញពីទីកំបាំងរបស់ទ្រង់ ហើយនៅក្នុងសេចក្ដីខ្ញាល់របស់ទ្រង់នឹងធ្វើទុក្ខដល់ប្រទេស » (គ. និង ស. ១០១:៨៩) ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:៦, ហេតុអ្វីបានជាព្រះវរបិតាសួគ៌បញ្ជាឲ្យពួកបរិសុទ្ធប្រមូលដំណើររឿងនានានៃការបៀតបៀនរបស់ពួកគេ ?

- តើខគម្ពីរនេះបង្រៀនអ្វីខ្លះ ដែលយើងត្រូវធ្វើពីមុនពេលដែលព្រះអម្ចាស់បំពេញការសន្យារបស់ទ្រង់ ?

សូមអញ្ជើញសិស្សឲ្យសរសេរសេចក្ដីថ្លែងការណ៍ដែលជាគោលការណ៍ ដែលបញ្ជាក់ពីទំនាក់ទំនងរវាងកិច្ចខិតខំរបស់យើង និងការសន្យារបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយគោលការណ៍ដែលពួកគេបានរកឃើញ ។ ខាងក្រោម គឺជារបៀបមួយដែលសិស្សអាចសរសេរគោលការណ៍នេះ ៖ **ព្រះអម្ចាស់នឹងបំពេញការសន្យារបស់ទ្រង់ បន្ទាប់ពីយើងបានធ្វើផ្នែករបស់យើងជាមុនសិន ។** សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។

- តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់រំពឹងឲ្យយើងធ្វើផ្នែករបស់យើង ពីមុនទ្រង់នឹងបំពេញការសន្យារបស់ទ្រង់ ?

- តើអ្នកធ្លាប់បានឃើញគោលការណ៍នេះបញ្ជាក់នៅក្នុងជីវិតរបស់អ្នក ឬ នៅក្នុងជីវិតរបស់នរណាម្នាក់ដែលអ្នកស្គាល់នៅពេលណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:៧–១៧

*យ៉ូសែប ស្ម៊ីធ ទូន្មានឲ្យពួកបរិសុទ្ធជួយដល់អស់អ្នកដែលបំភាន់ដោយពាក្យកុហក*

សូមអញ្ជើញសិស្សឲ្យស្រមៃថាពួកគេត្រូវបានចាត់តាំងឲ្យសរសេររបាយការណ៍អំពីសាសនាចក្រសម្រាប់នរណាម្នាក់នៅក្នុងសាលារៀនរបស់ពួកគេ ។ ផ្នែកមួយនៃតម្រូវការនោះ ពួកគេត្រូវតែរួមបញ្ចូលយ៉ាងហោចណាស់ប្រភពបីយ៉ាង ។

- តើធនធានអ្វីដែលអ្នកអាចប្រើសម្រាប់របាយការណ៍របស់អ្នក ?

- ហេតុអ្វីបានជាវាសំខាន់ពីធនធានដែលអ្នកប្រើដើម្បីសរសេរអំពីសាសនាចក្រនោះ ?

- តើអ្នកដឹងថាធនធានមួយពិតដែលពិពណ៌នាពីសាសនាចក្រដោយរបៀបណា ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:៧–១០ ដោយពន្យល់ថា នៅពេលយ៉ូសែប ស្ម៊ីធ បានកត់ត្រាខគម្ពីរទាំងនេះ មានការកុហកជាច្រើនបានផ្សព្វផ្សាយអំពីសាសនាចក្រ ។ ពួកបរិសុទ្ធត្រូវបានគេប្រាប់ថាវាគឺជា « កាតព្វកិច្ចដ៏ចាំបាច់ » (គ. និង ស. ១២៣:៧) ដើម្បីឆ្លើយតបនឹងការកុហកទាំងនេះ ហើយប្រមូល និង បោះពុម្ពដំណើររឿងនៃការបៀតបៀន និងការរងទុក្ខរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១១–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលមូលហេតុបន្ថែមដែលពួកបរិសុទ្ធត្រូវបានដឹកនាំឲ្យប្រមូល និង បោះពុម្ពដំណើររឿងនៃការបៀតបៀន និង ការរងទុក្ខរបស់ពួកគេ ។ សូមឲ្យសិស្សរាយការណ៍ពីការរកឃើញរបស់ពួកគេ ។

- យោងតាម ខ ១២, តើមានមានមនុស្សប៉ុន្មាននាក់ដែលមានចិត្តបរិសុទ្ធដែលបានលាក់បាំងពីសេចក្ដីពិត ?

- តើអ្នកគិតថាការកុហកអំពីសាសនាចក្រប៉ះពាល់ដល់អស់អ្នកដែលមិនមែននៅក្នុងជំនឿរបស់យើងយ៉ាងដូចម្ដេចខ្លះ ?

- យោងតាម ខ ១២ ហេតុអ្វីបានជាមានមនុស្សជាច្រើននាក់នៅលើផែនដីនេះត្រូវបានលាក់បាំងពីសេចក្ដីពិត ? ( សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែរកឃើញសេចក្ដីពិតខាងក្រោម ៖ **មានមនុស្សជាច្រើនត្រូវបានលាក់បាំងពីសេចក្ដីពិតដោយសារពួកគេមិនដឹងជាទៅរកសេចក្ដីពិតនៅឯណាឡើយ** ) ។

- តើការបោះពុម្ពសេចក្ដីពិតអំពីការបៀតបៀន និង ការរងទុក្ខរបស់ពួកបរិសុទ្ធនៅពេលនោះអាចជួយមនុស្សឲ្យរកសេចក្ដីពិតយ៉ាងដូចម្ដេច ?

សូមរំឭកសិស្សថា នៅតែមានមនុស្សជាច្រើននាពេលបច្ចុប្បន្ននេះ « ដែលបានខ្វាក់ដោយសារឧបាយកលដ៏ប្រសប់នៃមនុស្ស » ហើយដែលត្រូវបានលាក់ពីសេចក្ដីពិត ពីព្រោះពួកគេមិនដឹងជាទៅរកសេចក្ដីពិតឯណាទេ (គ. និង ស. ១២៣:១២) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សស្ដាប់ដោយស្វែងរកអ្វីដែលលាក់មនុស្សពីការដឹងសេចក្ដីពិតអំពី សាសនាចក្រនៅជំនាន់របស់យើងនេះ ។



« មានមនុស្សជាច្រើន ដែលមានការយល់ដឹងតិចតួចអំពីសាសនាចក្រ ដោយសារតែព័ត៌មានភាគច្រើន ដែលពួកគេបានឮពីយើង គឺមកពីព័ត៌មានប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជាញឹកញាប់ជំរុញដោយការជំទាស់ ។ ការផ្ដោតចិត្តច្រើនពេកលើការជំទាស់បាននាំឲ្យជះឥទ្ធិពលអវិជ្ជមានលើការយល់ដឹងរបស់មនុស្សអំពីភាពពិត ដែលសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយមាន » (Sharing the Gospel Using the Internet » *Ensign*, ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៦២ ) ។

- យោងតាម អែលឌើរ បាឡឺដ តើអ្វីខ្លះដែលលាក់បាំងមនុស្សពីការដឹងសេចក្ដីពិតអំពី សាសនាចក្រនៅជំនាន់របស់យើងនេះ ?

សូមពន្យល់ថា ស្រដៀងនឹងពួកបរិសុទ្ធក្នុងឆ្នាំ ១៨៣៩ យើងត្រូវបានដឹកនាំឲ្យជួយមនុស្សដទៃឲ្យមានការយល់ដឹងត្រឹមត្រូវអំពីសាសនាចក្រនេះគឺយល់ដឹងពី—សមាជិក អ្នកដឹកនាំ ជំនឿ ប្រវត្តិ ការបង្រៀន និង ការអនុវត្ត ។

- តើអ្វីអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយមនុស្សដទៃឲ្យទទួលបានការយល់ដឹងត្រឹមត្រូវអំពីសាសនាចក្រ ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ អិម រ័សុល បាឡឺដ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកវិធីមួយដែលយើងអាចជួយមនុស្សដទៃឲ្យទទួលបានការយល់ដឹងត្រឹមត្រូវអំពីសាសនាចក្រ ។



« មានការសន្ទនាជាច្រើនអំពីសាសនាចក្រឥតឈប់ឈរ ។ ការសន្ទនានោះនឹងបន្ត ទោះបីជាយើងជ្រើសរើសចូលរួម ឬ មិនចូលរួមក៏ដោយ ។ ប៉ុន្តែយើងមិនអាចឈរនៅស្ងៀម ខណៈដែលមនុស្សដទៃរួមទាំងអ្នករិះគន់របស់យើងព្យាយាមកំណត់ពីអ្វីដែលសាសនាចក្របង្រៀនឡើយ ។ ខណៈដែលការសន្ទនាមួយចំនួនមានអ្នកស្ដាប់រាប់ពាន់ ឬ រាប់លានអ្នកក៏ដោយ ការសន្ទនានោះគឺជារឿងតូចតាចទេ ។ ប៉ុន្តែការសន្ទនាទាំងនោះមានឥទ្ធិពលលើអស់អ្នកដែលចូលរួមក្នុងការសន្ទនានោះ ។ ការយល់ដឹងអំពីសាសនាចក្រត្រូវបានកកើតឡើងនៅក្នុងការសន្ទនាម្ដងៗ ។. . .

« ឥឡូវនេះខ្ញុំសូមឲ្យអ្នកចូលរួមសន្ទនាតាមរយៈ ការចូលរួមតាមអ៊ិនធើណែត ដើម្បីចែកចាយដំណឹងល្អ ហើយសូមពន្យល់នូវសារលិខិតដ៏សាមញ្ញ និងច្បាស់លាស់នៃការស្ដារឡើងវិញ ។. . . *ពិតមែនហើយ ការណ៍នេះតម្រូវឲ្យអ្នកយល់គោលការណ៍គ្រឹះនៃដំណឹងល្អសិន* ។ វាគឺជាការណ៍សំខាន់ដែលអ្នកអាចផ្ដល់ជាសាក្សីដ៏ *ច្បាស់* និង *ត្រឹមត្រូវ* អំពីសេចក្ដីពិតនៃដំណឹងល្អ » (Sharing the Gospel Using the Internet »ទំព័រ ៦១,៦២ ) ។

សូមបន្ថែមយោបល់របស់អែលឌើរ បាឡឺដ លើយោបល់ដែលមាននៅលើក្ដារខៀននោះ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដើម្បីជួយមនុស្សដទៃ រៀនអំពីសេចក្ដីពិតដែលបានសរសេរលើក្ដារខៀន ។ សូមឲ្យពួកគេជ្រើសរើសសេចក្ដីពិតមួយដែលពួកគេមានអារម្មណ៍ថាអាចយកទៅប្រើ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យរាយការណ៍អំពីយោបល់ណាមួយដែលពួកគេបានជ្រើសរើស និង របៀបដែលពួកគេរៀបផែនការប្រើវា ដើម្បីជួយមនុស្សដទៃឲ្យមានការយល់ដឹងត្រឹមត្រូវអំពីសាសនាចក្រ ។ សូមលើកទឹកចិត្តសិស្សទាំងអស់ឲ្យធ្វើតាមយោបល់ដែលពួកគេបានជ្រើសរើស ដើម្បីជួយមនុស្សដទៃឲ្យស្វែងរកសេចក្ដីពិត ។

សូមឲ្យសិស្សគិតអំពីគ្រាមួយ ដែលពួកគេបានជួយមនុស្សដទៃឲ្យមានការយល់ដឹងត្រឹមត្រូវអំពី សាសនាចក្រ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យ ចែកចាយបទពិសោធន៍របស់ខ្លួន ជាមួយសិស្សក្នុងថ្នាក់ ។

*សូមអញ្ជើញសិស្សឲ្យចែកចាយពីបទពិសោធន៍នានា*

ក្រោយពីចែកចាយទីបន្ទាល់ និង បទពិសោធន៍របស់អ្នកហើយសូមផ្ដល់ឱកាសឲ្យសិស្សចែកចាយពីគំនិត និង ការយល់ដឹង របស់ពួកគេ ព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនដែលពួកគេមានជាមួយនឹងគោលលទ្ធិ ឬ គោលការណ៍មួយ ។ ពួកគេក៏អាចរៀបរាប់ពីបទពិសោធន៍ដែលពួកគេបានឃើញនៅក្នុងជីវិតរបស់អ្នកដទៃផងដែរ ។ នៅពេលសិស្សចែកចាយ ព្រះវិញ្ញាណបរិសុទ្ធនឹងថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនៃគោលលទ្ធិ ឬ គោលការណ៍ដែលកំពុងពិភាក្សា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១៣–១៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលពួកបរិសុទ្ធត្រូវបានប្រាប់អំពីកិច្ចខិតខំរបស់ពួកគេដើម្បីបង្ហាញដំណើររឿងពិតអំពីសេចក្ដីពិតដល់មនុស្សដទៃ ។

- យោងតាម ខ ១៥, ហេតុអ្វីបានជាពួកបរិសុទ្ធត្រូវបានប្រាប់ថាកុំចាត់ទុកកិច្ចខិតខំរបស់ពួកគេថាជា « ការណ៍តូចឡើយ ? »

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីការទូន្មានរបស់ព្រះអម្ចាស់នៅក្នុង ខ ១៥ អំពីការសម្រេចចិត្តតូចតាចដែលយើងធ្វើក្នុងពេលឥឡូវនេះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **ការសម្រេចចិត្តរបស់យើងដើម្បី ធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដែលហាក់បីដូចជាតូចតាច អាចមានឥទ្ធិពលធំធេងលើជីវិតរបស់យើងនាពេលអនាគត**) ។

- តើការសម្រេចចិត្តតូចតាចដើម្បី មានការសន្ទនាអំពីដំណឹងល្អជាមួយនរណាម្នាក់អាចមានឥទ្ធិពលធំធេងយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលខគម្ពីរនេះទាក់ទងនឹងសេចក្ដីពិតដែលបានសរសេរលើក្ដារខៀនពីមុន ៖ *ព្រះអម្ចាស់នឹងបំពេញការសន្យារបស់ទ្រង់ បន្ទាប់ពីយើងបានធ្វើផ្នែករបស់យើងជាមុន* ។ សូមអញ្ជើញសិស្សចែកចាយការយល់ដឹងរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បី « ប្រព្រឹត្តការណ៍ទាំងនេះដែលនៅក្នុងអំណាចយើង » *ដោយរីករាយចុះ* ?
- ផ្អែកលើ ខ ១៧ តើយើងអាចត្រូវបានធានាអ្វីខ្លះ បើសិនយើងធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបានដើម្បី គោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់នោះ ? ( សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **បើយើងប្រព្រឹត្តការណ៍ទាំងនេះដែលនៅក្នុងអំណាចយើង ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងអាចទទួលការធានាអះអាងថាព្រះនឹងប្រើព្រះចេស្ដារបស់ទ្រង់ដើម្បីជួយយើងស្របតាមព្រះឆន្ទៈ និង ពេលវេលារបស់ទ្រង់** ) ។
- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បីមានការធានាថាព្រះនឹងប្រើព្រះចេស្ដារបស់ទ្រង់ ដើម្បីជួយយើងបើសិនយើង « ប្រព្រឹត្តការណ៍ទាំងនេះដែលនៅក្នុងអំណាចយើងដោយរីករាយ ? » តើមានអ្វីខ្លះដែលអ្នកអាចធ្វើដើម្បីមានការធានាអះអាងនោះនៅក្នុងជីវិតរបស់អ្នក ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងអាចមានទំនុកចិត្តថា នៅពេលយើងបានធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបាន ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ នោះទ្រង់នឹងបំពេញការសន្យារបស់ទ្រង់ ។

មេរៀនទី ១៣០

# ការកសាងទីក្រុងណៅវូ

## បុព្វកថា

បន្ទាប់ពីការបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋ មិសសួរីមក ពួកគេបានដើរឆ្លងវាលកក់ល្បប់តាមដងទន្លេ មីស៊ីស៊ីពី ចូលក្នុងទីក្រុងណៅវូទឹកដីដ៏ស្រស់ត្រកាល ។ ទីក្រុងណៅវូ រដ្ឋ អិលលីណោយបានក្លាយជាទីស្នាក់ការកណ្ដាលរបស់សាសនាចក្រពីឆ្នាំ ១៨៣៩ ដល់ ១៨៤៦ ។ សមាគមសង្គ្រោះត្រូវបានបង្កើតឡើងនៅទីនោះ ហើយចេញពីទីក្រុងណៅវូ ទីស្នាក់ការកណ្ដាលនៃអ្នកផ្សព្វផ្សាយសាសនាបានផ្សព្វផ្សាយកាន់តែច្រើនលើផែនដី ។

*កំណត់ចំណាំ ៖* មេរៀននេះ ផ្ដល់នូវឱកាសមួយសម្រាប់សិស្សពីនាក់ឡើងមកបង្រៀន ។ សូមជ្រើសរើសសិស្សពីរនាក់ឲ្យបានពីរបីថ្ងៃមុនមេរៀននេះ ហើយផ្ដល់ច្បាប់ចម្លងនៃផ្នែកដែលបានចាត់តាំងដើម្បីពួកគេអាចរៀបចំមេរៀននោះ ។

## យោបល់សម្រាប់ការបង្រៀន

### ពួកបរិសុទ្ធបានកសាងទីក្រុងណៅវូ




រំឭកសិស្សថា ពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីរដ្ឋ មិសសួរី អំឡុងពេលនៃរដូវរងាឆ្នាំ ១៨៣៨–៣៩ ខណៈយ៉ូសែប ស្ម៊ីធ ជាប់ឃុំឃាំងនៅក្នុងគុកលីបើធី ។

- តើអ្នកគិតថាពួកបរិសុទ្ធអាចមានអារម្មណ៍បែបណានៅពេលពួកគេត្រូវបានបណ្ដេញចេញពីរដ្ឋ មិសសួរី ? ( ចម្លើយអាចរួមមានថា ពួកបរិសុទ្ធឆ្ងល់ថាតើពួកគេនឹងត្រូវទៅទីណា ) ។

សូមពន្យល់ថាបន្ទាប់ពីការបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋមិសសួរី ពួកគេបានរកឃើញទីជម្រកនៅ ឃ្វីនស៊ី រដ្ឋ អិលលីណោយ និង តាមសហគមតូច ៗផ្សេងទៀត ។ សូមអញ្ជើញសិស្សឲ្យប្រាប់ពី ទីតាំងនៃ ឃ្វីនស៊ី នៅក្នុងផែនទី ៦ (« ការប្ដូរទីលំនៅទៅភាគខាងលិចនៃសាសនាចក្រ ») នៅក្នុងផ្នែកផែនទីប្រវត្តិសាសនាចក្រនៃព្រះគម្ពីររបស់ពួកគេ ។ នៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៨៣៩ យ៉ូសែប ស្ម៊ីធ និង មិត្តភក្ដិដែលជាប់ទោសជាមួយលោកត្រូវបានប្រាប់ថា ពួកគេនឹងប្ដូរទៅទីតាំងមួយផ្សេងទៀត ។

នៅតាមផ្លូវទៅទីតាំងថ្មីនេះ ពួកអ្នកយាមរបស់ពួកលោកបានឲ្យពួកលោករត់គេច ដោយដឹងពីភាពអយុត្តិធម៌នៃការបង្ខាំងទុកពួកលោកជាយូរមកនោះ ។ ប្រហែលជាមួយសប្តាហ៍ក្រោយមក យ៉ូសែប ស្ម៊ីធ បានជួបជុំជាមួយគ្រួសាររបស់លោកវិញនៅឃ្វីនស៊ី ។ ក្រោមការដឹកនាំរបស់យ៉ូសែប ស្ម៊ីធ សាសនាចក្របានទិញដីនៅសងខាងទន្លេ មីស៊ីស៊ីពី ភាគខាងជើងនៃឃ្វីនស៊ី ។ ភាគខាងលិចនៃទន្លេនោះគឺជាផ្នែកមួយទឹកដីរដ្ឋ អៃអូវ៉ា ហើយភាគខាងកើតគឺផ្នែកមួយនៃរដ្ឋ អិលលីណោយ ។ ពួកបរិសុទ្ធបានកសាងទីស្នាក់ការកណ្តាលថ្មីមួយរបស់សាសនាចក្រនៅផ្នែកម្ខាងនៃរដ្ឋ អិលលីណោយ នៅកន្លែងមួយដែលហៅថា ខមមើស ដែលក្រោយមកពួកគេបានដាក់ឈ្មោះថ្មីហៅថាណៅវូ ។

សូមអញ្ជើញសិស្សទីមួយឲ្យដែលត្រូវបង្រៀនចេញមក ហើយបង្រៀនខ្លីៗដល់សិស្សអំពីការកសាងទីក្រុងណៅវូ ។

### សិស្សដែលត្រូវបង្រៀនទី ១ ៖ ពួកបរិសុទ្ធបានប្តូរឈ្មោះ ខមមើស រដ្ឋ អិលលីណោយ ទៅជា ណៅវូ—ទឹកដីដ៏ស្រស់ត្រកាល ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ *តើមានកាលៈទេសៈណាខ្លះនៅក្នុងជីវិតអ្នកក្នុងពេលនេះដែលពិបាក ឬ មិនរីករាយ ?* សូមទុកពេលឲ្យសិស្សពិចារណាអំពីសំណួរនេះ ។

សូមអញ្ជើញសិស្សឲ្យស្វែងរកការយល់ដឹងអំពីរបៀបដែលពួកគេអាចដោះស្រាយជាមួយកាលៈទេសៈដែលលំបាក ឬ មិនរីករាយ នៅពេលពួកគេរៀនអំពីពួកបរិសុទ្ធដែលបានកសាងទីក្រុងណៅវូ ។

សូមពន្យល់ថាសមាជិកសាសនាចក្របានប្តូរឈ្មោះទឹកដីតូចមួយដែលហៅថា ខមមើស ទៅជាណៅវូវិញ ដែលភាសាហេព្រើរមានន័យថាស្រស់ស្អាត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពិពណ៌នាខាងក្រោមនេះអំពីស្ថានភាពនៃតំនប់នេះកាលពេលបរិសុទ្ធបានទៅដល់ទីនោះលើកដំបូងនៅក្នុងឆ្នាំ ១៨៣៩ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ ហើយពិចារណាពីប្រតិកម្មរបស់ពួកគេអំពីស្ថានភាពនៃតំបន់នោះ ។

នៅពេលពួកបរិសុទ្ធបានទៅដល់កន្លែងមួយដែលពួកគេនឹងហៅថា ណៅវូ ភាគច្រើននៃដីនោះគឺជាវាលភក់ល្បប់ដែលមានសុទ្ធតែមូស ។ មូសទាំងនោះចម្លងជំងឺមួយហៅថាគ្រុនចាញ់ ដែលបណ្តាលឲ្យមានការក្តៅខ្លួនខ្លាំង និង រងាញាក់ ហើយអាចបណ្តាលឲ្យស្លាប់បាន ។ ពួកបរិសុទ្ធជាច្រើនបានឆ្លងជំងឺនោះហើយធ្លាក់ខ្លួនឈឺ ។ អ្នកជំងឺមួយចំនួនឈឺកាន់តែធ្ងន់ ពួកគេបានត្រឹមតែលូនក្នុងការជួយគ្នាទៅវិញទៅមក ហើយពួកគេមួយចំនួនបានស្លាប់ ។ ( សូមមើល *Church History in the Fulness of Times Student Manual,* បោះពុម្ពលើកទី ២ [Church Educational System manual ឆ្នាំ ២០០៣] ទំព័រ ២១៧–១៨ ) ។

- តើអ្នកនឹងហៅទីនោះថាជាទឹកដីដ៏ស្រស់ត្រកាលដែរឬទេ ? ហេតុអ្វីអ្នកគិតថា ព្យាការីយ៉ូសែប ស្ម៊ីធបានជ្រើសរើសហៅវាលភក់ល្បប់នេះថាជាទឹកដីដ៏ស្រស់ត្រកាលទៅវិញ ?

សូមអញ្ជើញសិស្សម្នាក់អានកថាខណ្ឌខាងក្រោម ដែលពន្យល់ពីរបៀបដែលពួកបរិសុទ្ធឆ្លើយតបនឹងឧបសគ្គដែលពួកគេបានជួបប្រទះក្នុងកន្លែងដែលជាគេហដ្ឋានថ្មីរបស់ពួកគេ ។

យ៉ូសែប ស្ម៊ីធក៏បានកើតជំងឺគ្រុនចាញ់ផងដែរ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយពីឈឺមក លោកបានជាឡើងវិញនៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៨៣៩ ហើយបានពោរពេញដោយព្រះវិញ្ញាណនៃព្រះ ។ លោកបានប្រសិទ្ធពរអ្នកជំងឺជាច្រើននៅក្បែរផ្ទះរបស់លោក ។ មានពេលមួយនោះ យ៉ូសែប បានទៅដល់តង់មួយដែលជាកម្មសិទ្ធរបស់សមាជិកសាសនាចក្រ ឈ្មោះ ហិនរី ជី ស៊ើរ្វឌ ដែលហៀបនឹងស្លាប់ទៅហើយ ។ នៅពេលព្យាការីបានបញ្ជាឲ្យគាត់ក្រោកឡើង ហើយចេញពីតង់ បងប្រុស ស៊ើរ្វឌបានធ្វើតាម ហើយបានជាសះស្បើយ ។

យ៉ូសែបបានឆ្លងទន្លេទៅផ្នែកម្ខាងទៀតនៃរដ្ឋ អៃអូវ៉ា ហើយបន្តប្រសិទ្ធពរដល់អ្នកឈឺ ។ នៅពេលយ៉ូសែបកំពុងរៀបចំត្រឡប់មកខាងរដ្ឋ អិលលីណោយវិញនោះ មានបុរសម្នាក់ដែលមិនមែនជាសមាជិកសាសនាចក្រ បានសុំព្យាការីឲ្យទៅប្រសិទ្ធពរដល់កូនភ្លោះរបស់គាត់ដែលមានចម្ងាយប្រហែលពីរម៉ាយពីទីនោះ ។ « យ៉ូសែប បាននិយាយថា គាត់មិនអាចទៅបានឡើយ ប៉ុន្តែគាត់បានឲ្យកន្សែងដៃ សូត្រពណ៌ក្រហម ឲ្យទៅ វិលហ្វូឌ វូឌដ្រុព្វ ហើយបានប្រាប់លោកឲ្យទៅប្រសិទ្ធពរដល់ពួកគេ ដោយសន្យាថានៅពេលលោកជូតកន្សែងនេះលើមុខរបស់ពួកគេ នោះពួកគេនឹងបានជាសះស្បើយ » (*Church History in the Fulness of Times,* ទំព័រ ២១៩ ) ។ វិលហ្វូឌ បានធ្វើតាមការណែនាំនោះ ហើយក្មេងទាំងពីរនោះបានជាសះស្បើយមែន ។ វិលហ្វូឌ បានហៅថ្ងៃនោះថា « ជាថ្ងៃនៃព្រះចេស្តានៃព្រះ » ( វិលហ្វូឌ វូឌដ្រុព្វ សៀវភៅទិន្នានុប្បវត្តិថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៨៣៩ ដែលបានដកស្រង់នៅក្នុង *Church History in the Fulness of Times,* ទំព័រ ២១៨ ) ។

ទោះបីជាមានសេចក្ដីជំនឿ និង ព្រះចេស្ដានៃថ្ងៃនោះ ជំងឺនៅតែបន្តកើតមានចំពោះពួកបរិសុទ្ធអស់រយៈពេលជាច្រើនខែ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានបន្តថែទាំគ្នាទៅវិញទៅមក ហើយបានធ្វើការសាងសង់ផ្ទះថ្មីរបស់ពួកគេ ។ ពួកគេបានជីក អណ្ដូងដើម្បីបង្ហូរទឹក ចេញពីវាលភក់ល្បប់ចូលទៅក្នុងទន្លេ ដែលធ្វើឲ្យដីកាន់តែមានប្រយោជន៍ ហើយកាត់បន្ថយបញ្ហាមូស ។ ទីបំផុតពួកគេបានសង់ ផ្ទះ និង សំណង់ដទៃផ្សេងទៀត ជាច្រើនរួមទាំង ព្រះវិហារបរិសុទ្ធណៅវូ ដែលមានមនុស្សមួយចំនួនចាត់ទុកថាវាជាអគារដែលស្រស់ស្អាតជាងគេបំផុតនៅក្នុងប្រទេស ។

- តើ« ថ្ងៃនៃព្រះចេស្ដានៃព្រះ » នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ១៨៣៩ ជួយអ្នកឲ្យមានសេចក្ដីជំនឿកាន់តែខ្លាំងលើព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- តើពួកបរិសុទ្ធបានធ្វើឲ្យទីក្រុងណៅវូជាទីកន្លែងដ៏ស្រស់ត្រកាលរបៀបណា ?
- តើយើងអាចរៀនអ្វីខ្លះពីគំរូរបស់ពួកគេ ?

បន្ទាប់ពីសិស្សបានពិភាក្សាអំពីគំរូរបស់ពួកបរិសុទ្ធដែលព្យាយាមធ្វើការសាងសង់ទីក្រុងណៅវូ សូមសួរសំណួរខាងក្រោម ៖

- តើមានអ្វីខ្លះអាចកើតមានឡើងនៅពេលយើងព្យាយាមកែលម្អបរិស្ថានជុំវិញខ្លួនយើង ?

នៅពេលសិស្សឆ្លើយតបសូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **នៅពេលយើងព្យាយាមកែលម្អបរិស្ថាននៅជុំវិញខ្លួនយើង នោះខ្លួនយើងនឹងរីកចម្រើនកាន់តែប្រសើរ ។** សូមអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ដែលបង្ហាញនៅក្នុងគោលការណ៍នេះ ។ អ្នកអាចចែកចាយបទពិសោធន៍ ឬថ្លែងទីបន្ទាល់អំពីគោលការណ៍នេះផងដែរ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលឱកាសនានាក្នុងពេលបច្ចុប្បន្ននេះ ដើម្បីកែលម្អបរិស្ថាននៅជុំវិញពួកគេ ។

## សិស្សដែលត្រូវបង្រៀនទី ២ ៖ សមាគមសង្គ្រោះត្រូវបានបង្កើត

*កំណត់ចំណាំ ៖* ពីមុនចាប់ផ្ដើមថ្នាក់ សូមឲ្យសមាជិកម្នាក់នៃសមាគមសង្គ្រោះ ( ដូចជាសមាជិកគ្រួសារ ឬ មិត្តភក្តិ ) ឲ្យប្រាប់អ្នកអំពីរបៀបមួយចំនួនដែលសមាគមសង្គ្រោះបានផ្ដល់ឱកាសដល់គាត់ចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ ហើយបានប្រទានពរដល់ជីវិតគាត់ ។ សូមគិតពីការសរសេរនូវអ្វីដែលអ្នកបានរៀនពីគាត់ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីស្ត្រីនៅក្នុងព្រះគម្ពីរដែលពួកគេពេញចិត្ត ។ សូមឲ្យពួកគេប្រាប់ដៃគូម្នាក់អំពីស្ត្រីនោះ និងមូលហេតុដែលពួកគេកោតសសើរគាត់ ។ បន្ទាប់ពីដៃគូនិមួយៗមានពេលពិភាក្សា សូមពន្យល់ថាស្ត្រីនៅក្នុងទីក្រុងណៅវូគឺជាកម្លាំងដ៏អស្ចារ្យមួយនៅក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។

សូមពន្យល់ថានៅក្នុងឆ្នាំ ១៨៤២ ស្ត្រីមួយចំនួននៅក្នុងទីក្រុងណៅវូ បានជួបជុំគ្នាពិភាក្សាពី របៀបដែលពួកគេអាចជួយក្នុងការកសាងព្រះវិហារបរិសុទ្ធណៅវូ ។ ពួកគេបានបង្កើតសមាគមមួយ ហើយបានសរសេរច្បាប់ និង ក្រឹត្យក្រមដើម្បីគ្រប់គ្រងកិច្ចការរបស់ពួកគេ ។ ពួកគេបានបង្ហាញច្បាប់ និង ក្រឹត្យក្រមនោះដល់ព្យាការី យ៉ូសែប ស្ម៊ីធ ដែលបានមានប្រសាសន៍ថាច្បាប់នេះជា « ច្បាប់ល្អបំផុតដែលលោកធ្លាប់បានឃើញ » ។ ប៉ុន្តែក្រោយមកលោកបានមានប្រសាសន៍ថាព្រះអម្ចាស់មាន « អ្វីមួយដែលប្រសើរជាងមុនសម្រាប់ពួកគេជាងច្បាប់ដែលបានសរសេរនោះ » ។ លោកបានអញ្ជើញពួកគេឲ្យជួបជាមួយលោកនៅសប្ដាហ៍បន្ទាប់ នៅពេលលោកនឹង « រៀបចំស្ត្រីនៅក្រោមបព្វជិតភាពតាមគំរូនៃបព្វជិតភាព » ( សារ៉ា អិម ឃីមបឹល « Auto–biography » *Woman's Exponent,* ថ្ងៃទី ១ ខែកញ្ញា ១៨៨៣ ទំព័រ ៥១ បានដកស្រង់ក្នុង *Daughters in My Kingdom: The History and Work of Relief Society* [ ឆ្នាំ ២០១១ ] ទំព័រ ១២) ។ អង្គការនេះគឺជាសមាគមសង្គ្រោះ ។

អិមម៉ា ស្ម៊ីធ ត្រូវបានហៅឲ្យធ្វើជាប្រធានសមាគមសង្គ្រោះទូទៅដំបូងគេ ។ អ៊ីឡៃស្សា អរ ស្នូ ជាលេខានៃសមាគមសង្គ្រោះនៅទីក្រុងណៅវូ ហើយក្រោយមកក្លាយជាប្រធានសមាគមសង្គ្រោះទូទៅទីពីរបានបង្រៀនថា « ថ្វីដ្បិតតែឈ្មោះ [ សមាគមសង្គ្រោះ ] មានភាពទំនើបក្ដី ប៉ុន្តែស្ថាបននេះមានប្រភពដើមពីបុរាណ ។ យើងត្រូវបានប្រាប់ដោយ [ ព្យាការី យ៉ូសែប ស្ម៊ីធ ] ថាអង្គការដូចគ្នានេះបានមានក្នុងសាសនាចក្រកាលពីបុរាណ » ( « Female Relief Society » *Deseret News,* ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៨៦៨ ទំព័រ ១ សូមមើលផងដែរ *Daughters in My Kingdom,* ទំព័រ ៧) ។

- តើយើងអាចរៀនអ្វីខ្លះអំពីសមាគមសង្គ្រោះពីសេចក្តីថ្លែងការណ៍របស់ អ៊ីឡៃហ្សា អរ ស្នូ ? ( នៅពេលសិស្សឆ្លើយ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ៖ **សមាគមសង្គ្រោះគឺជាផ្នែកដ៏បំផុសគំនិតមួយនៃការស្តារឡើងវិញនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ**) ។
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងឲ្យយល់ពីសេចក្តីពិតនេះ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដែលទាក់ទងនឹងគោលបំណងនៃសមាគមសង្គ្រោះ ៖

« សមាគមសង្គ្រោះត្រូវបានបង្កើតឡើង ដើម្បីជួយរៀបចំបុត្រីរបស់ព្រះដើម្បីទទួលពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ គោលបំណងនៃសមាគមសង្គ្រោះ គឺដើម្បីបង្កើនសេចក្តីជំនឿ និងសេចក្តីសុចរិតផ្ទាល់ខ្លួន ពង្រឹងក្រុមគ្រួសារ និងគេហដ្ឋាន និងផ្តល់ការសង្គ្រោះដោយស្វែងរក និងជួយអ្នកទាំងឡាយណាដែលត្រូវការជំនួយ » (*Daughters in My Kingdom,*xi ) ។

សូមប្រាប់សិស្សក្នុងថ្នាក់អំពីការសន្ទនាដែលអ្នកមានជាមួយសមាជិកម្នាក់នៃសមាគមសង្គ្រោះ រួមទាំងគំនិតរបស់អ្នកអំពីអ្វីដែលអ្នកបានរៀន ។ សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីគោលការណ៍ទាំងឡាយដែលអ្នកបានសរសេរលើក្តារខៀន ។

## កិច្ចការអ្នកផ្សព្វផ្សាយសាសនាផ្សព្វផ្សាយទូទាំងផែនដី

សូមអរគុណដល់សិស្សដែលបានបង្រៀន ។ ដើម្បីរៀបចំសិស្សឲ្យរៀនអំពីការរីកចម្រើននៃសាសនាចក្រអំឡុងពេលនៅណៅវូ សូមសួរសំណួរខាងក្រោម ៖

- តើវត្ថុអ្វីខ្លះដែលធ្វើឲ្យយើងអាចពន្លត់ភ្លើងបាន ?
- តើអ្វីខ្លះដែលអាចធ្វើឲ្យភ្លើងកាន់តែឆេះខ្លាំងឡើយ ?
- យ៉ូសែប ស្ម៊ីធ បានប្រៀបធៀបកិច្ចការរបស់ព្រះអម្ចាស់ទៅនឹងភ្លើង ។ តើអ្នកគិតថាការបៀតបៀនដែលពួកបរិសុទ្ធបានជួបនៅរដ្ឋ មិសសួរី ដូចជាទឹកដែលបានចាប់ផ្តើមពន្លត់កិច្ចការរបស់ព្រះ ឬ ដូចជាប្រេងសាំងដែលធ្វើឲ្យកិច្ចការនោះកាន់តែរីកចម្រើន ? ហេតុអ្វី ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានសរសេរនៅក្នុងលិខិតមួយទៅកាន់អ្នកបោះពុម្ពកាសែតឈ្មោះ ចន វិនវ៉ស នៅថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៤២ ៖



« ការបៀតបៀនពុំបានបញ្ឈប់ការរីកចម្រើននៃសេចក្តីពិតឡើយ ប៉ុន្តែវាកាន់តែបន្ថែមប្រេងសាំងទៅលើភ្លើងទៅវិញ ។. . .

«. . .បទដ្ឋាននៃសេចក្តីពិតត្រូវបានបង្កើតឡើង គ្មានដៃដែលមិនស្អាតស្អំណា អាចបញ្ឈប់កិច្ចការនេះពីការរីកចម្រើនឡើយ ការបៀតបៀនអាចកញ្ជ្រោលឡើង ពួកមនុស្សកំណាចអាចប្រមូលផ្តុំគ្នា ពួកទាហានអាចប្រជុំគ្នា ពួកអ្នកមួលបង្កាច់អាចបង្ខូចកេរ្តិ៍ឈ្មោះ តែសេចក្តីពិតនៃព្រះនឹងឆ្ពោះទៅមុខដោយក្លៀវក្លា ថ្លៃថ្នូរ និង ឯករាជរហូតទាល់តែវាបានដល់គ្រប់ទាំងទ្វីប គ្រប់តំបន់ គ្រប់ប្រទេស និង បានឮដល់គ្រប់ត្រចៀក រហូតដល់គោលបំណងនៃព្រះនឹងបានសម្រេច ហើយព្រះយេហូវ៉ាដ៏អស្ចារ្យនឹងមានបន្ទូលថា កិច្ចការបានចប់ហើយ » ( នៅក្នុង *History of the Church,* ៤:៥៤០ ) ។

- តើយើងអាចរៀនអ្វីខ្លះពីសេចក្តីថ្លែងការណ៍នេះ ? ( សិស្សអាចរកឃើញគោលការណ៍សេចក្តីពិតផ្សេង ៗគ្នា ប៉ុន្តែសូមគូសបញ្ជាក់ដូចខាងក្រោមនេះ ៖ **គ្មានអ្វីអាចបញ្ឈប់កិច្ចការរបស់ព្រះទូទាំងផែនដីនេះមិនឲ្យរីកចម្រើនបានឡើយ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ) ។

សូមពន្យល់ថា នៅពេលយ៉ូសែប ស្ម៊ីធ បានកត់ត្រានៅក្នុងការព្យាករណ៍នេះ នោះព្រះអម្ចាស់បានចាប់ផ្តើមហៅអ្នកផ្សព្វផ្សាយសាសនាឲ្យបង្រៀនដំណឹងល្អនៅក្នុងប្រទេសជាច្រើន ។ ជាលទ្ធផល មនុស្សរាប់ពាន់នាក់—ជាពិសេសចក្រភពអង់គ្លេស—បានជ្រមុជទឹក ។ សមាជិកថ្មីនោះបានធ្វើឲ្យសាសនាចក្រកាន់តែរឹងមាំ ហើយមានមនុស្សជាច្រើនបានធ្វើដំណើរមកចូលរួមជាមួយពួកបរិសុទ្ធនៅក្នុងទីក្រុងណៅវូ ។

ដើម្បីបង្ហាញពីសេចក្ដីពិតនៅលើក្ដារខៀន សូមរកអ្នកស្ម័គ្រចិត្តបួននាក់ដើម្បីចូលរួមដើរតួអំពីបទពិសោធន៍មួយ ដែល វិលហ្វូឌ វូឌដ្រុព្វ បានមានខណៈផ្សព្វផ្សាយដំណឹងល្អនៅក្នុងហៀហ្វតស្ស៊ើ ប្រទេសអង់គ្លេសនៅក្នុងឆ្នាំ ១៨៤០ ។ សូមចាត់តាំងអ្នកស្ម័គ្រចិត្តនូវផ្នែកខាងក្រោម ៖ វិលហ្វូឌ វូឌដ្រុព្វ អាចារ្យ ប៉ូលីស អ្នកពោល ។ សូមផ្ដល់ច្បាប់ចម្លងនៃ នាដកថាដូចខាងក្រោម ដល់អ្នកស្ម័គ្រចិត្តគ្រប់រូបដើម្បីប្រើក្នុងការដើរតួ ៖

**វិលហ្វូឌ វូឌដ្រុព្វ** *( និយាយម្នាក់ឯងថា )* ៖ ហ៊ឺ ។ នេះជាការបង្រៀនទីពីរដែលខ្ញុំបានបង្រៀនថ្ងៃនេះ ។ បន្ទាប់ពីការប្រជុំនាល្ងាចនេះ ខ្ញុំគិតថានឹងមានមនុស្សជិតមួយពាន់នាក់នឹងបានស្ដាប់ឮសារលិខិតរបស់ព្រះអម្ចាស់ថ្ងៃនេះ ។

**អាចារ្យ** *( ឈរនៅជ្រុងម្ខាងនៃថ្នាក់រៀន ដោយនិយាយទៅកាន់ប៉ូលីស )* ៖ លោកប៉ូលីស អ្នកផ្សព្វផ្សាយពួកមរមននេះត្រូវតែឈប់ ។ ខ្ញុំមានមនុស្សតែដប់ប្រាំនាក់ប៉ុណ្ណោះដែលចូលរួមក្នុងព្រះវិហារកាតូលិករបស់ខ្ញុំនៅថ្ងៃនេះ ។ តែដប់ប្រាំនាក់ ! ខ្ញុំគិតថាមនុស្សផ្សេងទៀតនឹងត្រូវបានដឹកនាំទៅស្ដាប់ការបង្រៀនរបស់វា ។ ខ្ញុំមិនអាចធ្វើឲ្យព្រះវិហារកាតូលិករបស់ខ្ញុំបន្តខ្សត់មនុស្សឡើយ ខណៈដែលអ្នកស្ដាប់ពួកមរមននេះបានកើនឡើងនោះ ។ ខ្ញុំចង់ឲ្យលោកចាប់វា ហើយបញ្ឈប់កិច្ចការរបស់វាទៅ ។

**ប៉ូលីស ៖** ខ្ញុំនឹងព្យាយាមធ្វើឲ្យអស់ពីលទ្ធភាព ។

**អ្នកអត្ថាធិប្បាយ ៖** ពេលអែលឌើរ វូឌដ្រុព្វ ក្រោកឡើងនិយាយនៅក្នុងការប្រជុំនាល្ងាចនោះ ប៉ូលីសបានមកដល់មាត់ទ្វារ ។

**ប៉ូលីស** *( ឥឡូវនិយាយទៅកាន់ វិលហ្វូឌ វូឌដ្រុព្វ )* ៖ សុំទោសលោក ។ ខ្ញុំគឺជាប៉ូលីស ហើយអាចារ្យម្នាក់នៃព្រះវិហារកាតូលិកក្នុងមូលដ្ឋាននេះបានឲ្យខ្ញុំមកជាមួយនឹងដីកាចាប់ខ្លួនលោក ។

**វិលហ្វូឌ វូឌដ្រុព្វ ៖** តើចាប់ពីបទឧក្រិដ្ឋអ្វីដែរ ?

**ប៉ូលីស ៖** ពីបទផ្សព្វផ្សាយដល់ប្រជានជន ។

**វិលហ្វូឌ វូឌដ្រុព្វ ៖** ខ្ញុំអាចធានានឹងលោកថាខ្ញុំមានអាជ្ញាប័ណ្ណដើម្បីផ្សាយដំណឹងល្អដល់ប្រជាជន ដូចជាអាចារ្យម្នាក់នោះបានផ្សាយដែរ ។ បើសិនលោកអង្គុយចាំ នោះខ្ញុំនឹងនិយាយជាមួយលោកបន្ថែមទៀតអំពីបញ្ហានេះបន្ទាប់ពីការប្រជុំ ប៉ុន្តែខ្ញុំត្រូវតែចាប់ផ្ដើមបង្រៀនឥឡូវនេះហើយ ។. . . . *( សូមធ្វើត្រាប់ការនិយាយនោះដល់សិស្ស )*

**អ្នកអត្ថាធិប្បាយ ៖** ប៉ូលីសនោះបានយកកៅអីដែលអែលឌើរ វូឌដ្រុព្វ អង្គុយមកដាក់អង្គុយក្បែរអែលឌើរ វូឌដ្រុព្វ ខណៈដែលលោកបានបង្រៀនដំណឹងល្អអស់រយៈពេលជាងមួយម៉ោង ។ វិលហ្វូឌ វូឌដ្រុព្វ បាននិយាយអំពីបទពិសោធន៍នេះ ៖

**វិលហ្វូឌ វូឌដ្រុព្វ ៖** ព្រះចេស្ដានៃព្រះបានស្ថិតមកលើរូបខ្ញុំ ព្រះវិញ្ញាណបានស្ថិតនៅពេញផ្ទះនោះ ហើយមនុស្សទាំងអស់បានប្រែចិត្តជឿ ។

**អ្នកអត្ថាធិប្បាយ ៖** នៅពេលប្រជុំចប់ អែលឌើរ វូឌដ្រុព្វ បានអញ្ជើញឲ្យពួកគេជ្រមុជទឹក ។

**វិលហ្វូឌ វូឌដ្រុព្វ ៖** ខ្ញុំសូមអញ្ជើញអស់អ្នកដែលមានបំណងចង់ឲ្យអំពើបាបរបស់អ្នកបានអត់ទោសឲ្យ ហើយចូលរួមជាមួយនឹងសាសនាចក្ររបស់ព្រះអម្ចាស់ដែលបានស្ដារឡើងវិញ ឲ្យចុះទៅក្នុងទឹកនៃបុណ្យជ្រមុជទឹកនាថ្ងៃនេះ ។

**ប៉ូលីស** *( បានក្រោកចេញពីកៅអី ហើយនិយាយទៅកាន់ វិលហ្វូឌ វូឌដ្រុព្វ )* ៖ លោក វូឌដ្រុព្វ ខ្ញុំចង់ទទួលបុណ្យជ្រមុជទឹក ។

**អ្នកអត្ថាធិប្បាយ ៖** ប៉ូលីសនោះបានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃនោះ ជាមួយនឹងគ្រូផ្សព្វផ្សាយបួននាក់ និង មនុស្សពីរនាក់ផ្សេងទៀត ។ ប៉ូលីសបានត្រឡប់ទៅជួបអាចារ្យនោះវិញ ហើយបានពន្យល់ប្រាប់ពីស្ថានភាពនោះ ។

**ប៉ូលីស** *( និយាយទៅកាន់ អាចារ្យ )* ៖ បើសិនអ្នកចង់ចាប់ខ្លួនលោក វូឌដ្រុព្វ អ្នកត្រូវតែចាប់គាត់ដោយខ្លួនឯងទៅ ដ្បិតខ្ញុំបានឮគាត់បង្រៀនតែសេចក្ដីពិតនៃដំណឹងល្អប៉ុណ្ណោះ ដែលខ្ញុំបានស្ដាប់ពេញមួយជីវិតខ្ញុំមកហើយ ។

> **អ្នកអត្ថាធិប្បាយ ៖** ក្រោយមក អាចារ្យនោះបានបញ្ជូនស្មៀនពីនាក់ទៀតឲ្យចូលរួមក្នុងការប្រជុំហើយស្វែងយល់អំពីអ្វីដែលអែលឌើរ វូឌ្រុព្វ កំពុងបង្រៀន ។ ពួកគេក៏បានប្រែចិត្តជឿលើសេចក្ដីពិតនៃសារលិខិតរបស់អែលឌើរ វូឌ្រុព្វ ហើយបានជ្រមុជទឹក ។ អាចារ្យនោះពុំបានបញ្ជូននរណាទៀតឲ្យទៅ ស្ដាប់ការបង្រៀនរបស់អែលឌើរ វូឌ្រុព្វទៀតឡើយ ។
>
> ( កែសម្រួលពី វិលហ្វូឌ វូឌ្រុព្វ, *Leaves from My Journal* [ ឆ្នាំ ១៨៨១ ] ទំព័រ ៨០–៨១ ) ។

បន្ទាប់ពីអ្នកស្ម័គ្រចិត្តបានបញ្ចប់ហើយ សូមសួរសិស្សក្នុងថ្នាក់នូវសំណួរដូចខាងក្រោម ៖

- តើបទពិសោធន៍របស់អែលឌើរ វូឌ្រុព្វបង្ហាញពី គោលការណ៍ដែលថា គ្មានអ្វីអាចបញ្ឈប់កិច្ចការរបស់ព្រះឲ្យរីកចម្រើនដោយរបៀបណា ?
- តើការព្យាករណ៍របស់យ៉ូសែប ស្ម៊ីធ ទាក់ទងនឹងការរីកចម្រើននៃកិច្ចការរបស់ព្រះចាប់ផ្ដើមបំពេញនៅថ្ងៃនេះដោយរបៀបណា ? តើអ្នកមានអារម្មណ៍យ៉ាងណាដែរ អំពីការចូលរួមក្នុងកិច្ចការនេះ ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយឲ្យកិច្ចការរបស់ព្រះបានផ្សព្វផ្សាយក្នុងចំណោមប្រជាជនទាំងអស់ ? ( អ្នកអាចឲ្យសិស្សឆ្លើយសំណួរនេះនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ) ។

សូមពន្យល់ថានៅមេរៀនបន្ទាប់ សិស្សនឹងរៀនបន្ថែមទៀតអំពីព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើង និង គោលការណ៍នានាដែលត្រូវបានបង្រៀនខណៈដែល សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានបន្តរក្សាទីស្នាក់ការកណ្ដាលនៅក្នុងទីក្រុងណៅវូ ពី ឆ្នាំ ១៨៣៩ ដល់ ១៨៤៦ ។ សូមថ្លែងទីបន្ទាល់អំពីគោលការណ៍ទាំងឡាយដែលបានពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ហើយសូមអញ្ជើញសិស្សអនុវត្តអ្វីដែលពួកគេបានរៀន ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣ ការស្ថាបនាទីក្រុងណៅវូ ( មេរៀនទី ២៦ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣ និង មេរៀនស្ដីអំពី « ការស្ថាបនាទីក្រុងណៅវូ » ( មេរៀនទី ២៦ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២)

នៅពេលសិស្សបានសិក្សាអំពីការចាប់ដាក់គុករបស់ព្យាការីយ៉ូសែប ស្ម៊ីធ និង មនុស្សដទៃទៀតនៅក្នុងគុកលីប៊ើរធី នោះពួកគេបានឃើញគោលការណ៍ខាងក្រោម ៖ នៅពេលយើងអំពាវនាវហៅព្រះអម្ចាស់អំឡុងពេលលំបាក និង រងទុក្ខ នោះយើងអាចទទួលបាននូវសន្តិភាពរបស់ទ្រង់ ។ ប្រសិនបើយើងស៊ូទ្រាំនឹងឧបសគ្គបានល្អនៅក្នុងជីវិតរមែងស្លាប់នេះ នោះព្រះនឹងប្រទានពរដល់យើងនាពេលនេះ និងនៅក្នុងភាពដ៏អស់កល្ប ។ ទុក្ខលំបាកអាចផ្ដល់ការពិសោធដល់យើង និងទៅជាការណ៍ល្អដល់យើងទៅវិញ ។ សិស្សក៏បានរៀនផងដែរថា ព្រះអង្គសង្គ្រោះបានរងនូវការឈឺចាប់ និង ទុក្ខលំបាកនៃមនុស្សទាំងអស់ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣)

បន្ទាប់ពីការសិក្សាអំពីទុក្ខលំបាក និង ការបៀតបៀនដែលពួកបរិសុទ្ធបានជួបប្រទះដោយសារតែមារសត្រូវរបស់ពួកគេនៅក្នុងរដ្ឋមិសសួរី នោះសិស្សបានរៀនថាព្រះអម្ចាស់ទតឃើញ និង ស្គាល់ពីគ្រប់កិច្ចការទាំងអស់របស់យើង ហើយថាអស់អ្នកដែលប្រព្រឹត្តិខុសនឹងទទួលនូវការជំនុំជម្រះរបស់ព្រះនៅពេលកំណត់របស់ទ្រង់ ។ ពួកគេក៏បានឃើញថាព្រះនឹងបើកសម្ដែងការចេះដឹងដល់យើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយថាការសាកល្បងរបស់យើងអាចជួយញែកយើងចេញជាបរិសុទ្ធ ព្រមទាំងរៀបចំខ្លួនយើងដើម្បីទទួលនូវវិវរណៈ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦)

នៅក្នុងផ្នែកនៃលិខិតដ៏បំផុសគំនិតរបស់ព្យាការីយ៉ូសែប ស្ម៊ីធមកពីគុកលីប៊ើរធី នោះសិស្សបានរៀនថា អ្នកកាន់បព្វជិតភាពអាចទទួលអំណាចទាំងឡាយនៃឋានសួគ៌បាន ប្រសិនបើពួកគេរស់នៅដោយសុចរិតតែប៉ុណ្ណោះ ។ សិស្សក៏បានពិចារណាផងដែរអំពីទង្វើជាក់លាក់នានា ដែលអាចធ្វើឲ្យអំណាចនៃអ្នកកាន់បព្វជិតភាពម្នាក់ប្រែទៅជាខ្សោយ ឬ ប្រែជាខ្លាំង ។

### ថ្ងៃទី ៤ ៖គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣; ការស្ថាបនាទីក្រុងណៅវូ

នៅពេលសិស្សបានសិក្សាពីកាតព្វកិច្ចរបស់ពួកបរិសុទ្ធនៅក្នុងការទាក់ទងជាមួយនឹងអ្នកដែលធ្វើការបៀតបៀនខ្លួន នោះពួកគេបានរៀនគោលការណ៍ទាំងនេះ ៖ ព្រះអម្ចាស់នឹងបំពេញតាមការសន្យារបស់ទ្រង់ បន្ទាប់ពីយើងបានធ្វើផ្នែករបស់យើងសិន ។ មានមនុស្សជាច្រើនដែលលាក់ពីសេចក្ដីពិត ពីព្រោះពួកគេមិនដឹងជាទៅរកសេចក្ដីពិតឯណាទេ ។ ការសម្រេចចិត្តរបស់យើងដើម្បី ធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដែលហាក់បីដូចជាតូចតាចក្ដី អាចមានឥទ្ធិពលមហិមានាពេលអនាគត ។ សិស្សក៏បានរៀនផងដែរ អំពីទីស្នាក់ការកណ្ដាលរបស់សាសនាចក្រត្រូវបានស្ថាបនានៅក្នុងទីក្រុងណៅវូ រដ្ឋអិលលីណោយ ហើយបានឃើញសមាគមសង្គ្រោះ គឺជាផ្នែកដ៏បំផុសគំនិតនៃការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

## សេចក្ដីផ្ដើម

នៅក្នុងមេរៀននេះ សិស្សនឹងរំឭកឡើងវិញនូវការបង្រៀនមួយចំនួនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២២ ដែលអាចជួយពួកយើង នៅពេលយើងជួបប្រទះនឹងបញ្ហាលំបាកនៅក្នុងជីវិត ។ ពួកគេនឹងឃើញផងដែរថាការបៀតបៀនអាចជះឥទ្ធពលដល់កិច្ចការរបស់ព្រះឲ្យឆ្ពោះទៅមុខជាជាងបញ្ឈប់ការរីកចម្រើនរបស់វា ។ ជាចុងក្រោយ សិស្សនឹងរៀនអំពីការស្ថាបនាសមាគមសង្គ្រោះនៅក្នុងទីក្រុងណៅវូ រដ្ឋអិលលីណោយ និងចែកចាយពីរបៀបដែលសមាគមសង្គ្រោះ ប្រទានពរដល់មនុស្សនាពេលបច្ចុប្បន្ននេះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២២

*ពួកបរិសុទ្ធបានរៀនពីមេរៀនសំខាន់ចេញពី បទពិសោធន៍របស់ខ្លួនជាមួយនឹងការបៀតបៀន*

នៅលើក្ដារខៀនសូមសរសេរពាក្យ *ការបញ្ជាឲ្យសម្លាប់ផ្ដាច់ពូជ រោងម៉ាស៊ីនកិនស្រូវហន* និង *គុកលីប៊ើធី* ។ សូមអញ្ជើញសិស្សឲ្យប្រើពាក្យទាំងនេះ សង្ខេបពីអ្វីដែលពួកគេបានរៀនអំពីការបៀតបៀននានា ដែលពួកបរិសុទ្ធបានជួបប្រទះនៅក្នុងរដ្ឋមិសសួរីនៅក្នុងឆ្នាំ ១៨៣៨–៣៩ ។

សូមសរសេរ *គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–១០; ១២២:៧–៩* នៅលើក្ដារខៀន ។ សូមរំឭកសិស្សថានៅក្នុងខគម្ពីរទាំងនេះព្រះអម្ចាស់បានបើកសម្ដែងគោលការណ៍នានាដល់ព្យាការីយ៉ូសែប ស្ម៊ីធ ដើម្បីលួងលោមលោក និង ពួកបរិសុទ្ធអំឡុងពេលនៃការសាកល្បងរបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរទាំងនេះដោយស្ងាត់ស្ងៀម រកមើលរបៀបនៃការបង្រៀនក្នុងខគម្ពីរទាំងនេះអាចជួយពួកគេអំឡុងពេលនៃការសាកល្បងរបស់ខ្លួន ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វីដែលពួកគេបានរកឃើញ ។

អំឡុងសប្ដាហ៍នេះ សិស្សបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៦, ៤១–៤២, ដែលជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចសូមឲ្យពួកគេរំឭកពីខគម្ពីរនេះដោយការសូត្រ ខ ៣៦ ជាមួយគ្នា ។ អ្នកក៏អាចគិតពីការសូមឲ្យពួកគេសរសេរទង្វើសុចរិតនានាដែលព្រះអម្ចាស់បានមានបន្ទូលនៅក្នុង ខ ៤១–៤២ ផងដែរ ។

- តើអ្នកស្គាល់នរណាដែលជាគំរូនៃគោលការណ៍សុចរិតទាំងនេះ ?

សូមចែកចាយអំណរគុណដែលអ្នកមានចំពោះអ្នកកាន់បព្វជិតភាពសុចរិត និង អស់ទាំងពរជ័យដែលមនុស្សបានទទួលតាមរយៈអំណាចនៃបព្វជិតភាព ។

### ការស្លាបនាទីក្រុងណៅវូ

សូមឲ្យសិស្សរកឈ្មោះវត្ថុនានាដែលអាចពន្លត់ភ្លើងបាន ។ ក្រោយមកសួរពួកគេពីវត្ថុនានាដែលអាចធ្វើឲ្យភ្លើងកាន់តែឆេះខ្លាំងឡើង ។ សូមពន្យល់ថាយ៉ូសែប ស្ម៊ីធ បានប្រៀបធៀបកិច្ចការរបស់ព្រះអម្ចាស់ទៅនឹងភ្លើង ។

- តើអ្នកគិតថាការបៀតបៀនដែលពួកបរិសុទ្ធបានជួបនៅរដ្ឋមិសសួរី ដូចជាទឹកដែលបានចាប់ផ្ដើមពន្លត់កិច្ចការរបស់ព្រះ ឬ ដូចជាប្រេងសាំងដែលជួយឲ្យកិច្ចការនោះកាន់តែរីកចម្រើន ? ហេតុអ្វី ?

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយព្យាការីយ៉ូសែប ស្ម៊ីធឲ្យឮៗ ។ សូមពន្យល់ថាព្យាការីយ៉ូសែប ស្ម៊ីធ បានសរសេរសេចក្ដីថ្លែងការនេះនៅក្នុងលិខិតមួយទៅកាន់អ្នកបោះពុម្ពកាសែតឈ្មោះ ចន វីនវ័ស នៅថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៤២ ។



« ការបៀតបៀនពុំបានបញ្ឈប់ការរីកចម្រើននៃសេចក្ដីពិតឡើយ ប៉ុន្តែវាកាន់តែបន្ថែមប្រេងសាំងទៅលើភ្លើងទៅវិញ ។. . .

«. . .បទដ្ឋាននៃសេចក្ដីពិតត្រូវបានបង្កើតឡើង គ្មានដៃដែលមិនស្អាតស្អំណា អាចបញ្ឈប់កិច្ចការនេះពីការរីកចម្រើនឡើយ ការបៀតបៀនអាចកញ្ជ្រោលឡើង ពួកមនុស្សកំណាចអាចប្រមូលផ្ដុំគ្នា ពួកទាហានអាចប្រជុំគ្នា ពួកអ្នកមួលបង្កាច់អាចបង្ខូចកេរ្ដិ៍ឈ្មោះ តែសេចក្ដីពិតនៃព្រះនឹងឆ្ពោះទៅមុខដោយក្លៀវក្លា ថ្លៃថ្នូរ និង ឯករាជរហូតទាល់តែវាបានដល់គ្រប់ទាំងទ្វីប គ្រប់តំបន់ គ្រប់ប្រទេស និង បានឮដល់គ្រប់ត្រចៀក រហូតដល់គោលបំណងនៃព្រះនឹងបានសម្រេច ហើយព្រះយេហូវ៉ាដ៏អស្ចារ្យនឹងមានបន្ទូលថា កិច្ចការបានចប់ហើយ » ( នៅក្នុង *History of the Church,* ៤:៥៤០ ) ។

- តើយើងរៀនគោលការណ៍អ្វីខ្លះពីសេចក្ដីថ្លែងការណ៍នេះ ? ( សិស្សអាចរកឃើញគោលការណ៍សេចក្ដីពិតផ្សេងៗគ្នា ប៉ុន្តែសូមគូសបញ្ជាក់ដូចខាងក្រោមនេះ ៖ **គ្មានអ្វីអាចបញ្ឈប់កិច្ចការរបស់ព្រះទូទាំងផែនដីនេះមិនឲ្យរីកចម្រើនបានឡើយ**) ។
- តើមានភស្ដុតាងអ្វីខ្លះដែលអ្នកឃើញអំពីគោលការណ៍នេះនៅពេលបច្ចុប្បន្ន ?
- តើមានវិធីណាខ្លះដែលអ្នកអាចចូលរួមក្នុងការធ្វើឲ្យកិច្ចការរបស់ព្រះរីកចម្រើន ?

សូមពន្យល់ថា នៅពេលយ៉ូសែប ស្ម៊ីធ បានសរសេរនៅក្នុងការព្យាករណ៍នេះនៅក្នុងលិខិតរបស់លោកទៅកាន់ចន វីនវ័ស នោះព្រះអម្ចាស់បានចាប់ផ្ដើមហៅអ្នកផ្សព្វផ្សាយសាសនាឲ្យបង្រៀនដំណឹងល្អនៅក្នុងប្រទេសជាច្រើន ។ ការព្យាករនោះត្រូវបាន

បំពេញនៅពេលមនុស្សរាប់ពាន់នាក់—ជាពិសេសចក្រភពអង់គ្លេស—បានជ្រមុជទឹក ។ សមាជិកថ្មីនោះបានធ្វើឲ្យសាសនាចក្រកាន់តែរឹងមាំ ហើយមានមនុស្សជាច្រើនបានធ្វើដំណើរមកចូលរួមជាមួយពួកបរិសុទ្ធនៅក្នុងទីក្រុងណៅវូ ។

សូមប្រាប់សិស្សថានៅទីក្រុងណៅវូ រដ្ឋអិលលីណោយស្ត្រីនៃសាសនាចក្រគឺជាកម្លាំងដ៏អស្ចារ្យមួយនៅក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឃ្លាពីរខាងក្រោម ៖

នៅក្នុងឆ្នាំ ១៨៤២ស្ត្រីមួយចំនួននៅក្នុងទីក្រុងណៅវូ រដ្ឋអិលលីណោយបានជួបជុំគ្នាពិភាក្សាពី របៀបដែលពួកគេអាចជួយក្នុងការសាងសង់ព្រះវិហារបរិសុទ្ធណៅវូ ។ ពួកគេបានបង្កើតសមាគមមួយ ហើយក្រោយមកបានសូមគំនិតពីព្យាការី យ៉ូសែប ស្ម៊ីធ អំពីសមាគមនោះ ។ លោកបានអនុមតិវា ប៉ុន្តែលោកត្រូវបានបំផុសគំនិតឲ្យរៀបចំសមាគមសង្គ្រោះឡើង « រៀបចំស្ត្រីនៅក្រោមបព្វជិតភាព តាមគំរូនៃបព្វជិតភាព » (*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ], ទំព័រ ៤៥១ សូមមើល *Daughters in My Kingdom: The History and Work of Relief Society* [ ឆ្នាំ ២០១១ ], ទំព័រ ១២) ។

អិមម៉ា ស្ម៊ីធ ត្រូវបានហៅឲ្យធ្វើជាប្រធានសមាគមសង្គ្រោះទូទៅដំបូងគេ ។ បងស្រីអ៊ីឡៃស្សា អរ ស្នូ ដែលបានបម្រើជាលេខានៃសមាគមសង្គ្រោះនៅទីក្រុង ណៅវូ ហើយក្រោយមកត្រូវបានហៅឲ្យបម្រើជាប្រធានសមាគមសង្គ្រោះទូទៅទីពីរបានបង្រៀនថា « ថ្វីដ្បិតតែឈ្មោះ [ សមាគមសង្គ្រោះ ] មានភាពទំនើបក្ដី ប៉ុន្តែស្ថាប័ននេះមានប្រភពដើមពីបុរាណ ។ យើងត្រូវបានប្រាប់ដោយ [ ព្យាការី យ៉ូសែប ស្ម៊ីធ ] ថាអង្គការដូចគ្នានេះបានមានក្នុងសាសនាចក្រកាលពីបុរាណ » ( « Female Relief Society » *Deseret News,* ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៨៦៨ ទំព័រ ១ សូមមើលផងដែរ *Daughters in My Kingdom,* ទំព័រ ៧) ។

- តើយើងអាចរៀនអ្វីខ្លះអំពីសមាគមសង្គ្រោះពីសេចក្ដីថ្លែងការណ៍របស់ អ៊ីឡៃស្សា អរ ស្នូ ? ( នៅពេលសិស្សឆ្លើយ សូមសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ៖ **សមាគមសង្គ្រោះគឺជាផ្នែកដ៏បំផុសគំនិតមួយនៃការស្ដារឡើងវិញនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ**) ។
- តើអ្នកគិតថា ហេតុអ្វីវាសំខាន់សម្រាប់យើងឲ្យយល់ពីសេចក្ដីពិតនេះ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោម ដែលទាក់ទងនឹងគោលបំណងនៃសមាគមសង្គ្រោះឲ្យឮៗ ៖

> « សមាគមសង្គ្រោះត្រូវបានបង្កើតឡើង ដើម្បីជួយរៀបចំបុត្រីរបស់ព្រះដើម្បីទទួលពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ គោលបំណងនៃសមាគមសង្គ្រោះ គឺដើម្បីបង្កើនសេចក្ដីជំនឿ និងសេចក្ដីសុចរិតផ្ទាល់ខ្លួន ពង្រឹងក្រុមគ្រួសារ និងគេហដ្ឋាន និងផ្ដល់ការសង្គ្រោះដោយស្វែងរក និងជួយអ្នកទាំងឡាយណាដែលត្រូវការជំនួយ » (*Daughters in My Kingdom,* xi ) ។

សូមឲ្យសិស្សរំឭកឡើងវិញពីអ្វីដែលពួកគេបានសរសេរ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេសម្រាប់ថ្ងៃទី ៤ កិច្ចការទី ៧ ។ ( ពួកគេត្រូវបានសុំឲ្យនិយាយជាមួយសមាជិកម្នាក់នៃសមាគមសង្គ្រោះ ហើយសរសេររបៀបមួយចំនួនដែលសមាគមសង្គ្រោះបានប្រទានពរដល់ជីវិតនាង និង បានផ្ដល់ឱកាសឲ្យនាងចូលរួមនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ) ។ សូមអញ្ជើញសិស្សឲ្យចែកចាយនូវអ្វីដែលពួកគេបានរៀនពីសកម្មភាពនេះ ។

សូមបញ្ចប់មេរៀននេះដោយចែកចាយទីបន្ទាល់របសអ្នកពីរបៀបដែលកិច្ចខិតខំនៃបុរស និង ស្ត្រីទាំងនេះសព្វថ្ងៃនេះ កំពុងជួយកិច្ចការរបស់ព្រះអម្ចាស់ឲ្យបន្តសាយភាយទូទាំងផែនដី ។ សូមអញ្ជើញសិស្សឲ្យរស់នៅដោយស្មោះត្រង់ ដូច្នេះពួកគេអាចបន្តចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤–១២៨)

សូមឲ្យសិស្សគិតអំពីគ្រានានា នៅពេលពួកគេបានចូលរួមពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់សម្រាប់មរណជន ។ សូមពន្យល់ថាការសិក្សារបស់ពួកគេភាគច្រើននៅសប្ដាហ៍ក្រោយគឺសិក្សាអំពីព្រះវិហារបរិសុទ្ធទីក្រុងណៅវូ និង ការស្ដារឡើងវិញនៃពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹកសម្រាប់មរណជន ។

មេរៀនទី ១៣១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–២១

## បុព្វកថា

នៅពេលព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៨៤១ នោះ ពួកបរិសុទ្ធបាននៅក្នុងទីក្រុងណៅវូ អិលលីណោយ ប្រហែលជិតពីរឆ្នាំហើយ ។ បន្ទាប់ការបៀតបៀន និង ទុក្ខវេទនាដែលពួកគេបានជួបមក ឥឡូវនេះពួកបរិសុទ្ធបានមានកន្លែងមួយដែលពួកគេអាចប្រមូលផ្ដុំ ហើយស្ថាបនាទីក្រុងមួយដោយភាពសុខសាន្ត គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ គឺជាវិវរណៈដំបូងដែលយ៉ូសែប ស៊្មីធ បានទទួលនៅក្នុងទីក្រុងណៅវូ ដែលនឹងត្រូវបានញែកចេញ ។ កណ្ឌនេះនឹងត្រូវបានបំបែកជាបីមេរៀន ។ មេរៀននេះពិភាក្សា ខ ១–២១ ។ នៅក្នុងខគម្ពីរទាំងនេះ ព្រះអម្ចាស់បានបញ្ជាថាការប្រកាសមួយនឹងត្រូវបានផ្ញើទៅអ្នកគ្រប់គ្រងនៃផែនដីទាក់ទងនឹងការស្ដារដំណឹងល្អឡើងវិញ និង ស្ដេកនៃស៊ីយ៉ូននៅក្នុងទីក្រុងណៅវូ ។ លោកក៏បានសរសើរ និង ផ្ដល់ការទូន្មានដល់អ្នកដឹកនាំសាសនាចក្រកាលពីដើម ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–១៤

*ព្រះអម្ចាស់បញ្ជាថាការប្រកាសមួយនឹងត្រូវបានផ្ញើទៅអ្នកគ្រប់គ្រងនៃផែនដី*

សូមសរសេរពាក្យ *ខ្លាំងក្លា* នៅលើក្ដារខៀន ។ សូមសួរសិស្សថា តើមនុស្សបែបណា ដែលស្របតាមបទដ្ឋានរបស់លោកិយត្រូវបានគេចាត់ទុកថាខ្លាំងក្លា ។ នៅពេលសិស្សឆ្លើយ សូមសរសេរចម្លើយពួកគេនៅលើក្ដារខៀនក្រោមពាក្យ *ខ្លាំងក្លា* ។ សូមសរសេរពាក្យ *ទន់ខ្សោយ* នៅលើក្ដារខៀន ។ សូមសួរសិស្សថា តើអត្តចរិតអ្វីខ្លះ ដែលស្របតាមបទដ្ឋានរបស់លោកិយដែលទាក់ទងជាមួយភាពទន់ខ្សោយ ។

- តើពិភពលោកព្យាយាមធ្វើឲ្យយុវជន ឬ យុវនារីមានអារម្មណ៍ថាទន់ខ្សោយតាមរយៈបទដ្ឋានរបស់លោកិយដោយវិធីណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១ ដោយស្ងៀមស្ងាត់ រកមើលថានរណាដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាជាអ្នកទន់ខ្សោយ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេបានឃើញ ។

- តើយ៉ូសែប ស៊្មីធ អាចមានភាពទន់ខ្សោយតាមរបៀបណាខ្លះ នៅពេលលោកត្រូវបានហៅដើម្បីស្ដារដំណឹងល្អឡើងវិញនោះ ? យោងតាម ខ ១, ហេតុអ្វីព្រះអម្ចាស់ហៅមនុស្សទន់ខ្សោយឲ្យធ្វើកិច្ចការរបស់ទ្រង់ ។ ( នៅពេលសិស្សឆ្លើយ សូមសង្ខេបចម្លើយរបស់ពួកគេដោយសរសេរគោលការណ៍ស្រដៀងគ្នាខាងក្រោមនេះនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បើកបង្ហាញព្រះប្រាជ្ញារបស់ទ្រង់តាមរយៈអ្វីៗដែលទន់ខ្សោយនៃផែនដីនេះ**

- តើព្រះអម្ចាស់បានបើកបង្ហាញព្រះប្រាជ្ញារបស់ទ្រង់តាមរយៈព្យាការីយ៉ូសែប ស៊្មីធ យ៉ាងដូចម្ដេចខ្លះ ?

- តើព្រះអម្ចាស់បានតម្កើងសមត្ថភាពរបស់យ៉ូសែប ស៊្មីធដូចម្ដេច ?

សូមឲ្យសិស្សប្រាប់ពីការហៅបម្រើ ឬ ការចាត់តាំងនានាដែលពួកគេអាចទទួល ខណៈពួកគេនៅក្នុងភាពជាយុវវ័យ ។ ( ចម្លើយអាចរួមមាន គ្រូបង្រៀនតាមផ្ទះ សមាជិកនៃថ្នាក់ ឬ គណៈប្រធានកូរ៉ុម អ្នកផ្សព្វផ្សាយសាសនា និយាយនៅក្នុងការប្រជុំសាក្រាម៉ង់ ឬ ស្វាគមន៍នរណាម្នាក់នៅក្នុងវួដ ឬ សាខារបស់ពួកគេ ) ។

សូមមើលគោលការណ៍ដែលបានសរសេរលើក្ដារខៀន ហើយសួរសំណួរខាងក្រោម ៖

- តើការចងចាំពីសេចក្ដីពិតនេះអាចជួយយើងដូចម្ដេច នៅពេលយើងទទួលការហៅ និង ការចាត់តាំងផ្សេងៗដើម្បីបម្រើនៅក្នុងសាសនាចក្រ ?

- តើអ្នកបានទទួលពរជ័យ តាមរយៈអស់អ្នកដែលបានបម្រើព្រះអម្ចាស់ដោយស្មោះត្រង់ ដោយរបៀបណា ទោះបីជាពួកគេមើលទៅដូចជាទន់ខ្សោយនៅក្នុងក្រសែភ្នែកនៃលោកិយក្ដី ?

សូមរំឭកសិស្សថា អំឡុងរដូវរងាឆ្នាំ ១៨៣៨–៣៩ ពួកបរិសុទ្ធបានរត់ភៀសខ្លួនចេញពីរដ្ឋ មិសសួរី ហើយបានតាំងទីលំនៅនៅក្នុងរដ្ឋ អិលលីណោយលើដងទន្លេ មីស៊ីស៊ីពី ។ នៅទីនោះពួកបរិសុទ្ធបានចាប់ផ្ដើមកសាងទីក្រុងណៅវូ ។ បន្ទាប់ពីមានការស៊ូទ្រាំនឹងការបៀតបៀន ព្រមទាំងការលំបាកជាច្រើននោះពួកបរិសុទ្ធបានមានកន្លែងមួយដែលពួកគេអាចប្រមូលផ្ដុំគ្នា ហើយកសាងទីក្រុងមួយដោយសុខសាន្ត ។ នៅខែ ធ្នូ ឆ្នាំ ១៨៤០ នីតិបញ្ញត្តិនៃរដ្ឋ អិលលីណោយ បានផ្ដល់លិខិតអនុញ្ញាតឲ្យកសាងទីក្រុងណៅវូ ដែលអនុញ្ញាតឲ្យពួកបរិសុទ្ធរៀបចំរដ្ឋាភិបាលក្នុងមូលដ្ឋានមួយ កសាងសាកលវិទ្យាល័យ និង បង្កើតកងជីវពលក្នុងមូលដ្ឋាន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យយ៉ូសែប ស្ម៊ីធ ធ្វើឥឡូវនេះ ដែលពួកបរិសុទ្ធបានតាំងទីលំនៅនៅក្នុងទីក្រុងណៅវូ ។ ( អ្នកអាចត្រូវតែពន្យល់ពួកគេថាពាក្យ *ស្តេកនេះ* នៅក្នុង ខ ២ សំដៅលើទីក្រុងណៅវូ ) ។

- តើព្រះអម្ចាស់ហៅព្យាការី យ៉ូសែប ស្ម៊ីធឲ្យធ្វើអ្វីខ្លះ ? ( ធ្វើសេចក្ដីប្រកាសមួយអំពីដំណឹងល្អទៅកាន់អ្នកគ្រប់គ្រងនៃផែនដី ) ។

សូមអញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទី សរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីដែលពួកគេនឹងដាក់បញ្ចូលទៅក្នុងសេចក្ដីប្រកាសអំពីដំណឹងល្អទៅកាន់អ្នកគ្រប់គ្រងនៃផែនដី ។ ដើម្បីជួយសិស្ស អ្នកអាចឲ្យពួកគេពិចារណាពីអ្វីដែលពួកគេដឹងថាពិតនៅក្នុងដំណឹងល្អ ហើយស្នើឲ្យពួកគេបញ្ចូលទីបន្ទាល់មួយនៃសេចក្ដីពិតទាំងនោះក្នុងការប្រកាសរបស់ពួកគេ ។ ពីរបីនាទីក្រោយមក សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយជាមួយសិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានសរសេរ ។

សូមឲ្យសរសេររបៀបផ្សេង ៗដែលយើងអាចចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ។ ( ឧទាហរណ៍អាចរួមមានការចែកចាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ការសរសេរទីបន្ទាល់មួយនៅក្នុងព្រះគម្ពីរមរមន ហើយឲ្យវាទៅមិត្តណាម្នាក់ និង ការអញ្ជើញនរណាម្នាក់ឲ្យមកព្រះវិហារ ឬ ថ្នាក់សិក្ខាសាលា ) ។ សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ។

- តើមានរបៀបដែលមានប្រសិទ្ធភាពខ្លាំងបំផុតណាខ្លះ ដែលអ្នកអាចចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ?

សូមសរសេរពាក្យទាំងពីរខាងក្រោមនៅលើក្ដារខៀន ៖ *របៀបណា ?* និង *ហេតុអ្វី ?*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៤–៨ ដោយស្ងៀមស្ងាត់ ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់ស្វែងរករបៀបដែលព្រះអម្ចាស់ចង់ឲ្យសរសេរសេចក្ដីប្រកាសនេះ ហើយសូមឲ្យសិស្សពាក់កណ្ដាលថ្នាក់ទៀតរកមើលមូលហេតុដែលព្រះអម្ចាស់ចង់ឲ្យសរសេរសេចក្ដីប្រកាសនេះ ។ ក្រោយពីសិស្សមានពេលគ្រប់គ្រាន់សិក្សាខគម្ពីរនេះហើយ សូមអញ្ជើញពួកគេពីរបីនាក់ឲ្យឡើងមកមុខក្ដារខៀន ហើយសរសេរអ្វីដែលពួកគេបានរកឃើញនៅខាងក្រោមពាក្យដែលត្រឹមត្រូវ ។

> ### *ការយល់ដឹងពីគោលលទ្ធិ និង គោលការណ៍*
>
> ដើម្បីយល់ពីគោលលទ្ធិ និង គោលការណ៍នានា សិស្សត្រូវតែយល់ពាក្យដែលបង្ហាញពីវា ហើយរៀនពីរបៀបដែលគោលលទ្ធិ និង គោលការណ៍ទាំងនោះអាចជះឥទ្ធិពលក្នុងជីវិតរបស់ពួកគេ ។ សូមសួរសំណួរដែលនឹងជួយពួកគេឲ្យវិភាគពីអត្ថន័យនៃពាក្យ និង ឃ្លានៅក្នុងគោលលទ្ធិ និង គោលការណ៍ដែលពួកគេរកឃើញ ។ អ្នកអាចចែកចាយការបង្រៀនរបស់ព្យាការី និង សាវកថ្ងៃចុងក្រោយ ដែលបានពន្យល់ជាក់លាក់អំពីគោលលទ្ធិ និង គោលការណ៍ ហើយបានប្រាប់ពីរបៀបដែលវាអនុវត្តនៅក្នុងជីវិតរបស់យើង ។

សូមអញ្ជើញសិស្សឲ្យស្វែងរកគោលការណ៍មួយពី ខ ៤ ដែលបង្រៀនពី *របៀប* ដែលព្រះអម្ចាស់ចង់ឲ្យពួកយើងចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ។ ( សិស្សអាចនឹងប្រើពាក្យផ្សេង ៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ដូចខាងក្រោម ៖ **យើងត្រូវប្រកាសដំណឹងល្អដោយរាបទាប និង ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ**) ។

- តើអ្នកគិតថា ប្រកាសដំណឹងល្អដោយរាបទាបមានន័យដូចម្ដេច ? តើអ្នកគិតថាប្រកាសដំណឹងល្អដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធមានន័យដូចម្ដេច ?

- សូមមើលបញ្ជីនៃរបៀបនានាដើម្បីចែកចាយដំណឹងល្អនៅលើក្ដារខៀន ។ តើយើងអាចចែកចាយដំណឹងល្អដោយរាបទាប និង ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធដោយប្រើប្រាស់វិធីសាស្ត្រទាំងនេះយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៩ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាទ្រង់នឹងចង់ធ្វើនៅពេលពួកបរិសុទ្ធប្រកាសដំណឹងល្អ ។

សូមអញ្ជើញសិស្សឲ្យស្វែងរកគោលលទ្ធិមួយដែលបានបង្រៀននៅក្នុង ខ ៩ ដែលទាក់ទងនឹងអ្វីដែលព្រះអម្ចាស់អាចធ្វើសម្រាប់អស់អ្នកដែលស្ដាប់តាមដំណឹងល្អ ។ សិស្សអាចនឹងប្រើពាក្យផ្សេង ៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញសេចក្ដីពិត ដែលស្រដៀងនឹងសេចក្ដីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់អាចបន្ទន់ចិត្តនៃអស់អ្នកដែលស្ដាប់ដំណឹងល្អ ។**

- តើគោលការណ៍នេះអាចទាក់ទងនឹងសេចក្ដីពិតអំពីរបៀបដែលយើងគួរតែប្រកាសដំណឹងល្អដោយរាបទាប និង ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធដូចម្ដេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១០–១៤ ដោយពន្យល់ថា ព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់នឹងហៅអ្នកគ្រប់គ្រងនៃផែនដីឲ្យផ្ដល់ជំនួយដល់ពួកបរិសុទ្ធនៅពេលពួកបរិសុទ្ធបានប្រកាសដំណឹងល្អដល់ពួកគេ ។ ក្រៅពីនោះ ព្រះអម្ចាស់បានបញ្ជា រ៉ូប៊ើត ប៊ី ថមសុន ឲ្យជួយយ៉ូសែប ស្ម៊ីធ សរសេរសេចក្ដីប្រកាសដំណឹងល្អនេះ ។

សូមពន្យល់ថាទោះបីជាកិច្ចការនៃការសរសេរសេចក្ដីប្រកាសនេះបានចាប់ផ្ដើមភ្លាម បន្ទាប់ពីវិវរណៈនេះបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ ដែលបានទទួលនេះក៏ដោយ ក៏មានកត្តាមួយចំនួនដែលរារាំងវាមិនឲ្យបញ្ចប់ ហើយបោះពុម្ពឡើយ រហូតដល់ប៉ុន្មានឆ្នាំក្រោយមក ។ រ៉ូប៊ើត ប៊ី ថមសុន បានស្លាប់ប្រាំពីរខែបន្ទាប់ពីការសរសេរបានចាប់ផ្ដើម ។ មរណភាពរបស់លោក គឺក្នុងអំឡុងពេលដែលបានធ្វើការលះបង់ ដើម្បីកសាងព្រះវិហារបរិសុទ្ធ ណៅវូ និង ចំពេលបំពេញកាតព្វកិច្ចផ្សេងៗទៀតដែលបានរាំងស្ទះការបញ្ចប់សេចក្ដីប្រកាសនេះពីមុនមរណភាពរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។ ទីបំផុតសេចក្ដីប្រកាសនេះត្រូវសរសេរចប់ ដោយ ប៉ាលី ភី ប្រាត្ត ហើយបានបោះពុម្ពជាកូនសៀវភៅនៅក្នុងទីក្រុង នូវ យ៉ោក នៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៤៥ ហើយដោយ *Millennial Star* នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៨៤៥ ។ ( សូមមើល អ៊ែរសា ថាហ្វ ប៊ែនសឹន « A Message to the World » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៣២–៣៤ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៥–២១

*ព្រះអម្ចាស់ប្រទានការណែនាំដល់អ្នកដឹកនាំសាសនាចក្រនៅក្នុងទីក្រុងណៅវូ*

សូមឲ្យសិស្សគិតអំពីគ្រាមួយដែលមាននរណាម្នាក់បានសរសើរពួកគេដោយស្មោះសរ ។ សូមអញ្ជើញសិស្សឲ្យពីរបីនាក់ចែកចាយបទពិសោធន៍ និង មូលហេតុនៃការសរសើរទាំងនេះមានអត្ថន័យចំពោះពួកគេ ។

សូមពន្យល់ថា ព្រះអម្ចាស់បានមានបន្ទូលពីបុគ្គលមួយចំនួននៅក្នុងវិវរណៈនេះ ហើយបានបញ្ជាពួកគេដោយចង្អុលបង្ហាញពីកម្លាំង និង ការរួមចំណែករបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យស្ទង់មើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៥–២០ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីបុគ្គលទាំងនេះ ។ អ្នកអាចស្នើឲ្យពួកគេគូសចំណាំឃ្លាណាដែលលេចធ្លោចំពោះពួកគេ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបែរទៅរកដៃគូរបស់ខ្លួន ហើយចែកចាយចាយអ្វីដែលពួកគេបានរកឃើញ ដោយបញ្ចូលឃ្លាដែលលេចធ្លោចំពោះពួកគេ និង ហេតុផលរបស់វា ។

អ្នកអាចចង្អុលបង្ហាញថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៩ ព្រះអម្ចាស់បានប្រកាសថាបុរសស្មោះត្រង់បីរូបដែលទើបនឹងស្លាប់ ( ដាវីឌ ដឹបុលយូ ប៉ាទិន ,អែតវិត ប៉ាទ្រិច និង យ៉ូសែប ស៊្មីធ ស៊ីញ័រ ឪពុករបស់ព្យាការី ) ត្រូវបានទទួលឲ្យចូលទៅក្នុងវត្តមានរបស់ព្រះអម្ចាស់ហើយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យរំឭកឡើងវិញនូវអ្វីដែលព្រះអម្ចាស់មានបន្ទូលអំពី ហៃរ៉ុម ស្ម៊ីធ និង ជួច មិលលើ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៥, ២០ ។

- តើព្រះអម្ចាស់មានព្រះទ័យដូចម្ដេច ចំពោះអស់អ្នកដែលមានសេចក្ដីទៀងត្រង់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **ព្រះអម្ចាស់សព្វព្រះទ័យ ហើយទុកព្រះទ័យលើអស់អ្នកដែលមានសេចក្ដីទៀងត្រង់នៃចិត្ត** ។ អ្នកអាចប្រាប់សិស្សឲ្យគូសចំណាំពាក្យដែលបង្រៀនគោលការណ៍នេះនៅក្នុង ខ ១៥ និង ២០) ។

- តើអ្នកឲ្យនិយមន័យនៃពាក្យសេចក្ដីទៀងត្រង់នៃចិត្តដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ដោយអែលឌើរ យ៉ូសែប ប៊ី វឺតលីន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ចំពោះខ្ញុំសេចក្ដីទៀងត្រង់មានន័យថា ត្រូវធ្វើអ្វីដែលត្រឹមត្រូវ និង ល្អជានិច្ចមិនថាកើតមានលទ្ធផលភ្លាមៗយ៉ាងណានោះទេ ។ វាមានន័យថាត្រូវមានសេចក្ដីសុចរិតចេញពីជម្រៅនៃដួងព្រលឹងរបស់យើង មិនមែនគ្រាន់តែការប្រព្រឹត្តនោះទេ ប៉ុន្តែអ្វីដែលសំខាន់នោះគឺ ក្នុងគំនិត និង ក្នុងដួងចិត្តរបស់យើង ។ សេចក្ដីទៀងត្រង់ផ្ទាល់ខ្លួនបញ្ជាក់ពីការទុកចិត្ត និង បរិសុទ្ធភាពនោះ ដែលយើងមិនអាចត្រូវបានបោកបញ្ឆោតឲ្យទុកចិត្ត ឬ ធ្វើសេចក្ដីសញ្ញាឡើយ » (« Personal Integrity » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩០ ទំព័រ ៣០ ) ។

- ដោយផ្អែកលើនិយមន័យរបស់អែលឌើរ វ៉ឺតលីន ហេតុអ្វីអ្នកគិតថាព្រះអម្ចាស់សព្វព្រះទ័យដល់អស់អ្នកដែលមានសេចក្ដីទៀងត្រង់នៃចិត្ត ?

សូមអញ្ជើញសិស្សឲ្យពិចារណា អំពីផ្នែកមួយនៃជីវិតរបស់ខ្លួនដែលពួកគេអាចមានសេចក្ដីទៀងត្រង់នៃចិត្ត ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅផ្ទាល់ខ្លួនមួយ ដើម្បីបង្កើនសេចក្ដីទៀងត្រង់នៅក្នុងចំណុចនោះ ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិតដែលសិស្សបានរៀនថ្ងៃនេះ ។

មេរៀនទី ១៣២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២២–៨៣

## បុព្វកថា

នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៨៤១ ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធឲ្យសាងសង់ព្រះវិហារបរិសុទ្ធក្នុងទីក្រុងណៅវូ រដ្ឋ អិលលីណោយ ។ នៅក្នុងវិវរណៈនេះដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤, ព្រះអម្ចាស់បានពន្យល់ពីពរជ័យដែលអាចកើតមានចំពោះពួកបរិសុទ្ធ បើសិនពួកគេព្យាយាមក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ ។ ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធឲ្យសាងសង់ផ្ទះមួយ ដែលអ្នកធ្វើដំណើរអាចស្នាក់នៅក្នុងទីក្រុងណៅវូ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២២–៤១, ៥៦–៨៣

*ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធឲ្យសាងសង់ព្រះវិហារបរិសុទ្ធ និង ផ្ទះមួយសម្រាប់ភ្ញៀវមកទស្សនាទីក្រុងណៅវូ*

មុនពេលចាប់ផ្ដើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *តើលទ្ធផលអ្វីខ្លះ ដែលអ្នកសម្រេចបានដែលតម្រូវឲ្យអ្នកប្រើពេលវេលា កិច្ចខិតខំ ឬ ការលះបង់ដ៏ពិសេសពីខ្លួនអ្នក ?* នៅពេលសិស្សមកដល់ សូមឲ្យពួកគេរៀបចំខ្លួនឆ្លើយសំណួរនេះ ។ ក្រោយពីការប្រជុំធម្មនិដ្ឋានហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

- ហេតុអ្វីបានជាស្នាដៃរបស់អ្នកវាសក្ដិសមទៅនឹងពេលវេលា កិច្ចខិតខំ ឬ ការបូជាដែលតម្រូវឲ្យធ្វើ ?

សូមពន្យល់ថានៅឆ្នាំ ១៨៤១ពួកបរិសុទ្ធមួយចំនួនធំបានបោះទីតាំងជាថ្មីទៅទីក្រុងណៅវូ រដ្ឋ អិលលីណោយ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២៥–២៧ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធនៅក្នុងទីក្រុងណៅវូ ឲ្យធ្វើ ។

- តើព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ?

- តើព្រះអម្ចាស់សព្វព្រះទ័យចង់ឲ្យពួកបរិសុទ្ធប្រើអ្វីដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលហេតុផលដែលព្រះអម្ចាស់ បានប្រទានដល់ពួកបរិសុទ្ធចាំបាច់ត្រូវសាងសង់ព្រះវិហារបរិសុទ្ធ ។

- ហេតុអ្វីពួកបរិសុទ្ធត្រូវតែសាងសង់ព្រះវិហារបរិសុទ្ធ ? ( ដើម្បីផ្ដល់ទីតាំងមួយជាកន្លែងដែលព្រះអម្ចាស់យាងមក និង ស្ដារភាពពោរពេញនៃបព្វជិតភាពឡើងវិញ ) ។

ដើម្បីជួយសិស្សយល់ឃ្លា « ភាពពោរពេញនៃបព្វជិតភាព » នៅក្នុង ខ ២៨, សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖



« មនុស្សគ្រប់រូបដែលស្មោះត្រង់ ហើយមានឆន្ទៈទទួលពិធីបរិសុទ្ធ និង ពរជ័យទាំងនេះទទួលភាពពោរពេញនៃបព្វជិតភាព ហើយព្រះអម្ចាស់មានព្រះបន្ទូលថា ‹ ហើយព្រះអង្គ ធ្វើឲ្យពួកគេបានស្មើគ្នានៅក្នុងអំណាច និង នៅក្នុងពលំ និង នៅក្នុងអាណាចក្រ › [គ. និង ស. ៧៦:៩៥ សូមមើលផងដែរ គ. និង ស. ៨៨:១០៧] ។. . . ព្រះអម្ចាស់បានធ្វើឲ្យពរជ័យនេះអាចកើតមានចំពោះមនុស្សគ្រប់គ្នានៅក្នុងសាសនាចក្រនេះ តាមរយៈការគោរពប្រតិបត្តិរបស់គាត់ ដើម្បីទទួលបានភាពពេញលេញនៃបព្វជិតភាពតាមរយៈពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធរបស់ព្រះអម្ចាស់ ។ ការណ៍នេះពុំអាចត្រូវបានទទួលនៅទីណាផ្សេងទៀតឡើយ » ( នៅក្នុង *Doctrines of Salvation,* និពន្ធ ដោយ ប្រូស អ័រ ម៉ាក់ខន់ឃី ភាគទី ៣. [ ឆ្នាំ ១៩៥៤–៥៦ ], ៣:១៣២–៣៣ ) ។

សូមពន្យល់ថាសមាជិកសាសនាចក្រទាំងអស់—ទាំងបុរស និង ស្ត្រី—អាចទទួលភាពពោរពេញនៃ ពរជ័យទាំងឡាយនៃបព្វជិតភាព តាមរយៈការទទួលពិធីបរិសុទ្ធទាំងអស់នៃព្រះវិហារបរិសុទ្ធ ។ តាមរយៈពិធីបរិសុទ្ធទាំងនេះ យើងអាចទទួលបាននូវពរជ័យទាំងអស់ដែលព្រះវរបិតាសួគ៌មានព្រះទ័យចង់ប្រទានពរដល់កូនចៅរបស់ទ្រង់ ។ សូមចង្អុលបង្ហាញថាការស្ដារឡើងវិញនៃពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ និង សេចក្ដីសញ្ញា បានចាប់ផ្ដើមនៅក្នុងព្រះវិហារបរិសុទ្ធ ខឺតឡង់ ប៉ុន្តែពុំបានចប់សព្វគ្រប់ឡើយ ។ ការសាងសង់ព្រះវិហារបរិសុទ្ធនៅទីក្រុងណៅវូ នឹងធ្វើឲ្យការស្ដារពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ និងសេចក្ដីសញ្ញានឹងបន្តឡើងវិញ ( សូមមើល គ. និង ស. ១២៤:២៨, ៤០–៤១) ។

- តើពិធីបរិសុទ្ធជាអ្វី ? ( ជាពិធីដ៏ពិសិដ្ឋ និង ជាផ្លូវការមួយដែលបានធ្វើឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាព ) ។

សូមពន្យល់ថាពិធីបរិសុទ្ធមួយចំនួនគឺចាំបាច់សម្រាប់ភាពតម្កើងឡើង ហើយពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះទាំងនេះអាចធ្វើបានតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២៩ ដោយស្ងាត់ស្ងៀម រកមើលពិធីបរិសុទ្ធមួយដ៏ចាំបាច់ដែលព្រះអម្ចាស់បានបង្ហាញថាចាំបាច់ត្រូវតែស្ដារឡើងវិញ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

> ## *សូមជួយសិស្សឲ្យយល់ពីគោលលទ្ធិគ្រឹះ*
>
> សិស្សនឹងរៀនគោលលទ្ធិគ្រឹះនៅពេលពួកគេសិក្សា និង ពិភាក្សាខគម្ពីររាល់ថ្ងៃ និង នៅពេលពួកគេសូត្រចាំវគ្គព្រះគម្ពីរគន្លឹះ ។ អ្នកពុំគួរបង្វែរចេញពីការបង្រៀនតាមលំដាប់លំដោយនៃប្រវត្តិព្រះគម្ពីរ ដើម្បីផ្ដោតលើគោលលទ្ធិគ្រឹះទាំងនេះឡើយ ។ ផ្ទុយទៅវិញ អ្នកគួរតែផ្ដល់ការយកចិត្តទុកដាក់ចំពោះ គោលលទ្ធិ ទាំងនេះ នៅពេលវាប្រាកដឡើងនៅក្នុងវគ្គសិក្សា ។ ឧទាហរណ៍នៅក្នុងមេរៀននេះ អ្នកអាចគូសបញ្ជាក់ពីគោលលទ្ធិនៃពិធីបរិសុទ្ធដែលទាក់ទងនឹងអ្វីដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ ។

សូមពន្យល់ថានៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៨៤០ ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនដំបូងថាពួកបរិសុទ្ធអាចធ្វើពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះបាន ដូចជាពិធីបុណ្យជ្រមុជទឹកជំនួសឲ្យមរណជននៃគ្រួសារ ឬ មិត្តភក្តិរបស់ខ្លួនដែលពុំមានឱកាសទទួលដំណឹងល្អ ( សូមមើល *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ], ៤០៣) ។ បន្ទាប់ពីការប្រកាសនេះ មានបុណ្យជ្រមុជទឹកជាច្រើនសម្រាប់មរណជនត្រូវបានធ្វើឡើងនៅក្នុងទន្លេមីស៊ីស៊ីពី ឬ នៅជិតស្ទឹងក្បែរនោះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៤:៣០–៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការណែនាំរបស់ព្រះអម្ចាស់ ពីទីកន្លែងដែលពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ត្រូវធ្វើឡើង ។

- តើព្រះអម្ចាស់មានព្រះបន្ទូលថាពិធីបរិសុទ្ធ នៃបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ចាំបាច់ត្រូវតែធ្វើនៅទីណាដើម្បីទ្រង់អាចទទួលយកនោះ ? ហេតុអ្វីបានជាព្រះអម្ចាស់អនុញ្ញាតឲ្យ ពួកបរិសុទ្ធធ្វើពិធីបុណ្យជ្រមុជទឹកខាងក្រៅព្រះវិហារបរិសុទ្ធបណ្ដោះសន្ទសិន ?



អ្នកអាចបង្ហាញរូបភាពនៃ ព្រះវិហារបរិសុទ្ធណៅវូ (*សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] លេខ ១១៨ សូមមើលផងដែរ LDS.org) ។ សូមពន្យល់ថាបន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤, ធ្វើការកសាងព្រះវិហារបរិសុទ្ធកាន់តែរីកចម្រើនឡើងឆាប់ៗ ។ នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ១៨៤១ បន្ទាប់ពីជាន់ថ្នាល់ដីនៃព្រះវិហារបរិសុទ្ធបានសង់ហើយបានមួយចំនួន យ៉ូសែប ស្ម៊ីធ បានប្រាប់ពួកបរិសុទ្ធថា « គ្មានពិធីបុណ្យជ្រមុជទឹកបន្ថែមទៀតសម្រាប់មរណជនឡើយ រហូតដល់ពិធីបរិសុទ្ធនោះអាចត្រូវបានចូលមកធ្វើនៅក្នុងដំណាក់នៃព្រះអម្ចាស់ ។ . . . *ដ្បិតព្រះអម្ចាស់ទ្រង់មានបន្ទូលថាដូច្នេះ !* » (*ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ៤៦៩) ។ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៨៤១ បន្ទាប់ពី អាងជ្រមុជទឹក និងការឧទ្ទិសនៅជាន់ថ្នាល់ដីនៃព្រះវិហារបរិសុទ្ធណៅវូបានធ្វើសង់រួច នោះពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជនបានបន្តមានទៀត ។ ( សូមមើល *Church History in the Fulness of Times Student Manual,* បានបោះពុម្ពលើកទី ២ [ Church Educational System manual, ឆ្នាំ ២០០៣ ], ទំព័រ ២៥១–៥២; *ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ៤៦៩–៧០) ។




នៅពេលព្រះវិហារបរិសុទ្ធណៅវូបានសាងសង់ ព្យាការីយ៉ូសែប ស្ម៊ីធបានណែនាំថា អាងជ្រមុជទឹកត្រូវតែសង់នៅជាន់ផ្ទាល់ដីនៅលើខ្នងនៃគោឈ្មោលដប់ពីរក្បាល ដែលតំណាងឲ្យកុលសម្ព័ន្ធអ៊ីស្រាអែលទាំងដប់ពីរ ។

- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤, តើកន្លែងណាមួយដែលភាពពោរពេញនៃពិធីបរិសុទ្ធបព្វជិតភាពអាចត្រូវបានទទួលសម្រាប់សេចក្ដីប្រោសលោះទាំងអ្នកនៅរស់ និង មរណជន ? ( សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលលទ្ធិខាងក្រោម ៖ **ព្រះវិហារបរិសុទ្ធគឺជាកន្លែងតែមួយគត់ដែលយើងអាចទទួលបានភាពពោរពេញនៃពិធីបរិសុទ្ធនៃបព្វជិតភាពនៃសេចក្ដីប្រោសលោះនៃអ្នកនៅរស់ និង មរណជន**) ។

- តើគោលលទ្ធិនេះអាចជម្រុញពួកបរិសុទ្ធឲ្យធ្វើការលះបង់ដ៏ចាំបាច់ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធនៅទីក្រុងណៅវូយ៉ាងដូចម្ដេច ?

ដើម្បីជួយសិស្សយល់អំពីសេចក្ដីពិត និងសារៈសំខាន់នៃគោលលទ្ធិនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយប្រធាន ថូម៉ាស អេស ម៉នសុន ឲ្យឮៗ ។ ( អ្នកអាចនឹងចង់ផ្ដល់ ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍ដល់សិស្សមួយច្បាប់ម្នាក់ៗ ) ។



« អ្នកដែលយល់ពីពរជ័យដ៏អស់កល្បជានិច្ច មកពីព្រះវិហារបរិសុទ្ធដឹងថា គ្មានការពលិកម្មណាមួយមហិមាខ្លាំងពេក គ្មានតម្លៃណាធ្ងន់ធ្ងរពេក និង គ្មានការពុះពារណាលំបាកពេក ក្នុងការទទួលពរជ័យទាំងនេះនោះទេ ។ ពួកគេនឹងធ្វើដំណើរទៅ មិនថាឆ្ងាយប៉ុណ្ណានោះទេ មិនថាមានឧបសគ្គយ៉ាងណាដើម្បីយកឈ្នះនោះដែរឬស៊ូទ្រាំគ្រប់ទាំងភាពមិនងាយស្រួលទាំងអស់ ។ ពួកគេយល់ថាពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះទាំងឡាយ ដែលបានទទួលក្នុងព្រះវិហារបរិសុទ្ធ ដែលអនុញ្ញាតឲ្យយើងត្រឡប់ទៅព្រះវរបិតាសួគ៌នៅថ្ងៃមួយក្នុងទំនាក់ទំនងគ្រួសារអស់កល្បជានិច្ច និង ត្រូវបានប្រទានឲ្យនូវពរជ័យ និងអំណាចមកពីទីខ្ពស់ គឺមានតម្លៃគ្រប់ការពលិកម្ម និងការខិតខំទាំងអស់ ។ (The Holy Temple—a Beacon to the World » *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៩២ ) ។

- តើការបូជាអ្វីខ្លះដែលអ្នកអាចធ្វើដើម្បីសក្ដិសម និង រៀបចំខ្លួនដើម្បីទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៣៨–៤១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលមូលហេតុដែលព្រះអម្ចាស់បានបញ្ជាឲ្យម៉ូសេសាងសង់រោងឧបោសថនៅក្នុងទីរហោស្ថាន និង មូលហេតុដែលទ្រង់បានបង្គាប់ដល់ប្រជារាស្ត្រទ្រង់សាងសង់ព្រះវិហារបរិសុទ្ធនៅក្នុងដែនដីសន្យា ។ ( អ្នកត្រូវតែពន្យល់ថាម៉ូសេ និង ប្រជាជនរបស់លោកពុំបានធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជនឡើយ ។ គ្មានកិច្ចការសម្រាប់មរណជនត្រូវបានធ្វើឡើងឡើយរហូតដល់ព្រះអង្គសង្គ្រោះបានដឹកនាំកិច្ចការនោះនៅក្នុងពិភពវិញ្ញាណបន្ទាប់ពីការសុគតរបស់ទ្រង់ ) ។

- យោងតាម ខ ៣៨, ហេតុអ្វីបានជាព្រះអម្ចាស់បានបញ្ជាឲ្យសាសន៍អ៊ីស្រាអែលបុរាណឲ្យសាងសង់រោងឧបោសថ និង ព្រះវិហារបរិសុទ្ធ ?

សូមសរសេរ សំណួរពីរខាងក្រោម នៅលើក្តារខៀន ៖

> *ហេតុអ្វីព្រះវិហារបរិសុទ្ធសំខាន់ចំពោះអ្នក ? ហេតុអ្វីបានជាសាសនាចក្រសាងសង់ព្រះវិហារបរិសុទ្ធ ?*

សូមចាត់តាំងឲ្យសិស្សធ្វើការជាគូៗ ។ សូមឲ្យសិស្សម្នាក់ៗជ្រើសរើសសំណួរមួយនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យបែរទៅដៃគូខ្លួន ហើយឆ្លាស់វេនគ្នាឆ្លើយសំណួររបស់ពួកគេដោយផ្អែកលើអ្វីដែលពួកគេបានរៀននៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១២៤:២៥–៤១ ។ ក្រោយពីនោះ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយការយល់ដឹងរបស់ពួកគេ ( ឬ ដៃគូរបស់ពួកគេ ) ជាមួយសិស្សក្នុងថ្នាក់ ។

អ្នកអាចសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ១២៤:២២–២៤, ៥៦–៨៣ ដោយពន្យល់ថា ក្រៅពីព្រះវិហារបរិសុទ្ធព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធឲ្យសាងសង់សំណង់មួយផ្សេងទៀតហៅថាណៅវូហោស ជាកន្លែងដែលភ្ញៀវមកទស្សនាទីក្រុងណៅវូអាចស្នាក់នៅបាន ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ១២៤:៤២–៥៥

*ព្រះអម្ចាស់ពន្យល់ពីអ្វីដែលនឹងកើតឡើង បើសិនពួកបរិសុទ្ធគោរពតាមព្រះបញ្ញត្តិឲ្យកសាងព្រះវិហារបរិសុទ្ធ*

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២៤:៤២–៤៥ ដោយស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថានឹងកើតឡើង បើសិនពួកបរិសុទ្ធនឹងសាងសង់ព្រះវិហារបរិសុទ្ធ និង ស្តាប់តាមសំឡេងរបស់ទ្រង់ និង សំឡេងរបស់អ្នកបម្រើទ្រង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ១២៤:៤៦–៥៤ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រាប់ពួកបរិសុទ្ធពីអ្វីដែលនឹងកើតឡើង បើសិនពួកគេបានសាងសង់ព្រះវិហារបរិសុទ្ធ ប៉ុន្តែមិនស្តាប់តាមសំឡេងរបស់ទ្រង់ ឬ សំឡេងរបស់អ្នកបម្រើទ្រង់ ។ ព្រះអម្ចាស់ក៏បានពន្យល់ផងដែរថា ទ្រង់នឹងទទួលយកកិច្ចខិតខំរបស់ពួកបរិសុទ្ធ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ ( រួមមានការសាងសង់ព្រះវិហារបរិសុទ្ធ ) ទោះបីជាពួកគេត្រូវបានរារាំងមិនឲ្យធ្វើដូច្នេះក្តី ដោយសារការបៀតបៀនដែលពួកគេជួបប្រទះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២៤:៥៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានប្រកាសឲ្យពួកបរិសុទ្ធ នឹងបង្ហាញដល់ទ្រង់តាមរយៈការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ដើម្បីកសាងព្រះវិហារបរិសុទ្ធណៅវូ ។

- យោងតាម ខ ៥៥, តើយើងធ្វើអ្វីដើម្បីបង្ហាញដល់ព្រះអម្ចាស់នៅពេលយើងគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់នោះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **តាមរយៈការគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងបង្ហាញពីភាពស្មោះត្រង់របស់យើង ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យពិចារណាពីកិច្ចខិតខំ ពេលវេលា និង ការបូជាមួយចំនួនដែលទាក់ទងជាមួយនឹងការគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។

- តើឱកាសដើម្បីបង្ហាញភាពស្មោះត្រង់របស់យើងចំពោះព្រះអាចជំរុញចិត្តរបស់យើងឲ្យគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់យ៉ាងដូចម្តេច ?

- យោងតាម ខ ៥៥ តើពរជ័យបន្ថែមអ្វីខ្លះទៀតដែលព្រះអម្ចាស់សន្យាដល់ពួកបរិសុទ្ធ បើសិនពួកគេនឹងសាងសង់ព្រះវិហារបរិសុទ្ធនៅណៅវូ ?

សូមចង្អុលបង្ហាញថាពរជ័យនៃការបំពាក់កិត្តិយស អមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដែលបានសន្យានៅក្នុង ខ ៥៥ គឺអស់កល្បជានិច្ច ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ថា ពរជ័យដែលយើងទទួលសម្រាប់ភាពស្មោះត្រង់របស់យើងចំពោះព្រះអម្ចាស់មិនអាចបានមកភ្លាមៗ ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីពេលវេលានៅក្នុងជីវិតរបស់ពួកគេ នៅពេលពួកគេបានគោរពធ្វើតាមព្រះបញ្ញត្តិរបស់ព្រះចេញពី បំណងប្រាថ្នាដ៏មានភក្តីភាពចំពោះព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះរបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍ និង អារម្មណ៍របស់ពួកគេអំពីការបង្ហាញភក្តីភាព និង ភាពស្មោះត្រង់របស់ពួកគេ ។ សូមអញ្ជើញសិស្សរកមើលឱកាសនានាដើម្បីបង្ហាញភាពស្មោះត្រង់របស់ខ្លួនចំពោះព្រះអម្ចាស់ ។

មេរៀនទី ១៣៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–១២៦

## បុព្វកថា

នេះគឺជាមេរៀនទីបីចុងក្រោយ ក្នុងការពិភាក្សាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ ។ វាក៏ពិភាក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥ និង ១២៦ ផងដែរ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥, ព្រះអម្ចាស់បានប្រទានព្រះឱវាទដល់សមាជិកសាសនាចក្រម្នាក់ៗ និង បានដាក់ឈ្មោះដល់អស់អ្នកដែលនឹងបម្រើនៅក្នុងតំណែងផ្សេងៗនៃថ្នាក់ដឹកនាំបព្វជិតភាព ។ នៅក្នុងខែ មិនា ឆ្នាំ ១៨៤១ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៥, ដែលព្រះអម្ចាស់បានបើកសម្ដែងព្រះឆន្ទៈរបស់ទ្រង់ទាក់ទងនឹងការប្រមូលផ្ដុំពួកបរិសុទ្ធនៅក្នុងទឹកដីអៃអូវ៉ា ។ នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ១៨៤១ លោកបានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៦, ដែលព្រះអម្ចាស់បានប្រាប់ ព្រិកហាំ យ៉ង់ ថាលោកនឹងពុំតម្រូវឲ្យចាកចេញពីគ្រួសាររបស់លោកដើម្បីបម្រើបេសកកម្មទៀតឡើយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១២២

*ព្រះអម្ចាស់បានប្រទានដំបូន្មានដល់បុគ្គលជាក់លាក់ទាំងឡាយ*

ពីមុនចាប់ផ្ដើមថ្នាក់ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្រដាសមួយសន្លឹក ៖ **បើសិនយើងប្រុងស្ដាប់តាមការទូន្មានរបស់ព្យាការី នោះយើងនឹងបានសេចក្ដីសុខ** ។ សូមដាក់ក្រដាសនោះនៅក្នុងស្រោមសំបុត្រ ហើយនៅក្រៅស្រោមសំបុត្រនោះ សូមសរសេរថា *របៀបដែលយើងអាចប្រទានពរទាំងពេលនេះ និង ជានិរន្តរ៍* ។

សូមចាប់ផ្ដើមមេរៀនដោយបង្ហាញស្រោមសំបុត្រនោះដល់សិស្ស ។ សូមប្រាប់ពួកគេថា ស្រោមសំបុត្រនេះមានសេចក្ដីណែនាំពីរបៀបដែលយើងអាចរីករាយក្នុងពេលនេះ គេចផុតពីឧបសគ្គដែលពុំសំខាន់នៅក្នុងជីវិតយើង ហើយទទួលពរជ័យដទៃទៀត ។ សូមពន្យល់ថាសេចក្ដីណែនាំនេះអនុវត្តចំពោះពួកគេម្នាក់ៗ ទោះជាក្នុងកាលៈទេសៈពិសេសរបស់ពួកគេក្ដី ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណួរខាងក្រោមនេះ ៖

- តើវាអាចសំខាន់សម្រាប់អ្នកយ៉ាងដូចម្ដេច ដើម្បីទទួលបានការណែនាំនៅក្នុងស្រោមសំបុត្រនោះ ?
- បើសិនអ្នកអាចមានការណែនាំនោះ តើអ្នកនឹងធ្វើតាមការណែនាំនោះខ្លាំងប៉ុណ្ណា ?

សូមថតចម្លង តារាងដែលអមមកជាមួយ នៅលើក្ដារខៀន ពីមុនចាប់ផ្ដើមថ្នាក់ ។ សូមមើលទៅក្នុងតារាង០ហើយពន្យល់ថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១១៨ ព្រះអម្ចាស់បានប្រាស់បង្គាប់ដល់សមាជិកសាសនាចក្រជាក់លាក់ម្នាក់ៗ បើសិនពួកគេធ្វើតាម នោះពួកគេនឹងទទួលបានពរជ័យដ៏មហិមា ។ សូមអញ្ជើញសិស្សម្នាក់ៗឲ្យអានសេចក្ដីយោងពីរ ឬច្រើនជាងនេះនៅលើក្ដារខៀនដោយស្ងៀមស្ងាត់ ។ សូមឲ្យពួកគេ រកមើល ភាពស្រដៀងគ្នារវាងសេចក្ដីណែនាំដែលបានប្រទានឲ្យដល់បុគ្គលម្នាក់ៗនៅពេលពួកគេអាន ។

| | | | |
|---|---|---|---|
| វិលាម ឡ៉ូវ<br>(គ. និង ស. ៨៩–៩០) | ហៃរ៉ុម ស្ម៊ីធ<br>(គ. និង ស. ៩៤–៩៦) | អេម៉ុស ដាវីស<br>(គ. និង ស១១១–១១៤) | រ៉ូបឺត ហ្វូស្ទើរ<br>(គ. និង ស ១១៥–១១៨) |

ក្រោយពីសិស្សមានពេលអានគ្រប់គ្រាន់ហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកបានកត់សម្គាល់ឃើញមានភាពស្រដៀងគ្នាអ្វីខ្លះក្នុងការណែនាំដែលបានប្រទានដល់បុរសទាំងនេះ ? ( វគ្គនិមួយៗមានការណែនាំឲ្យធ្វើតាមការទូន្មានរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ) ។

> ***សកម្មភាពដែលអញ្ជើញសិស្សឲ្យស្រាវជ្រាវរកព័ត៌មាន***
>
> សកម្មភាពស្រាវជ្រាវជួយសិស្សឲ្យបង្កើតការយល់ដឹងគ្រឹះរបស់ពួកគេអំពីព្រះគម្ពីរ ។ សូមសួរសំណួរដែលនាំឲ្យពួកគេ រកមើលព័ត៌មានលំអិតសំខាន់ដែលទាក់ទងទៅនឹងបរិបទនៃបណ្ដុំព្រះគម្ពីរ ។ វាមានប្រយោជន៍ដើម្បីសរសេរសំណួរបែបនោះលើក្ដារខៀន ដូច្នេះសិស្សអាចចាំពី អ្វីដែលពួកគេត្រូវស្វែងរកនៅពេលពួកគេអាន ។

សូមអញ្ជើញសិស្សឲ្យមើលខគម្ពីរទាំងនោះឡើងវិញឲ្យពួកគេអាន ហើយរកមើលពរជ័យដែលព្រះអម្ចាស់បានសន្យានឹងប្រទានឲ្យ បើសិនពួកបុរសទាំងនេះធ្វើតាមការទូន្មានដែលទ្រង់បានប្រទានដល់ពួកគេ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។

- តើអ្នកនឹងសង្ខេបការសន្យាដែលព្រះអម្ចាស់ធ្វើដល់បុរសទាំងនេះយ៉ាងដូចម្ដេច បើសិនពួកគេស្ដាប់តាមព្យាការី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យបើកស្រោមសំបុត្រ ហើយអានគោលការណ៍នៅលើក្រដាសនោះឲ្យឮៗ ។

- តើពរជ័យដែលបានសន្យានិមួយៗសរសេរនៅលើក្ដារខៀនទាក់ទងនឹងឃ្លាថា « យើងនឹងបានសេចក្ដីសុខ » យ៉ាងដូចម្ដេច ?

សូមឲ្យសិស្សសរសេរការទូន្មានជាក់លាក់ ដែលប្រធានសាសនាចក្របានផ្ដល់ឲ្យកាលពីប៉ុន្មានឆ្នាំនេះ ហើយអញ្ជើញសិស្សឲ្យសរសេរចម្លើយលើក្ដារខៀន ។

- តើនៅពេលណាដែលអ្នកត្រូវបានប្រទានពរដោយការស្ដាប់តាមការទូន្មានរបស់ពួកព្យាការី ? ( អ្នកក៏អាចពិចារណាដោយចែកចាយបទពិសោធន៍មួយផងដែរ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់មានបន្ទូលថា សមាជិកសាសនាចក្រម្នាក់ឈ្មោះ អាលម៉ុន បាបបិត បានកំពុងធ្វើកិច្ចការដោយមិនធ្វើតាមការទូន្មានរបស់គណៈប្រធានទីមួយ ។

- យោងតាម ខ ៨៤, តើអាលម៉ុន បាបបិត បានធ្វើអ្វីដែលមិនធ្វើតាមការទូន្មានរបស់គណៈប្រធានទីមួយ ? ( គាត់មានមហិច្ឆិតាបង្កើតការទូន្មានផ្ទាល់ខ្លួន ។ អ្នកអាចពន្យល់ថា លោកបានព្យាយាមបញ្ចុះបញ្ចូលមនុស្សមួយចំនួន « ឈប់មួយរយៈ » ក្នុងការធ្វើអន្តោប្រវេសន៍ទៅទីក្រុងណៅវូ ហើយទៅតាំងទីលំនៅលើក្នុងទីក្រុងខឺតឡង់វិញ [ សូមមើល *History of the Church,* ៤:៤៧៦ ] ) ។
- តើមានគំរូអ្វីខ្លះអំពីរបៀបដែលមនុស្សអាចបង្កើតការទូន្មានផ្ទាល់ខ្លួននៅក្នុងសម័យរបស់យើងនេះ ?

សូមអញ្ជើញសិស្សពិចារណាអំពីចម្លើយរបស់ពួកគេ ទៅនឹងសំណួរដែលពួកគេបានគិតកាលពីដើមមេរៀនអំពីបំណងប្រាថ្នារបស់ពួកគេដើម្បីទទួល និង ធ្វើតាមការណែនាំនៅក្នុងស្រោមសំបុត្រ ។ សូមឲ្យពួកគេសរសេរគោលដៅជាក់លាក់សម្រាប់កែលម្អកិច្ចខិតខំរបស់ខ្លួន ដើម្បីស្ដាប់តាមការទូន្មានរបស់ព្យាការីរស់នៅ ដូច្នេះពួកគេអាចទទួលពរជ័យដែលបានសន្យា ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១១៩–១២២ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រទានការណែនាំបន្ថែមដល់សាសនាចក្រទាក់ទងនឹងការសាងសង់ណៅវូហោស ដែលក្លាយជាសណ្ឋាគារផ្ទាល់របស់សាសនាចក្រ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១២៣–១៤៥

*ព្រះអម្ចាស់ប្រាប់ឈ្មោះនៃអស់អ្នកដែលត្រូវបម្រើនៅក្នុងមុខងារផ្សេងៗនៃថ្នាក់ដឹកនាំបព្វជិតភាព*

សូមឲ្យសិស្សសរសេរពីមុខងាររបស់ថ្នាក់ដឹកនាំបព្វជិតភាពក្នុងសាសនាចក្រមួយចំនួនលើក្ដារខៀន ។

សូមពន្យល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១២៣–១៤៥, ព្រះអម្ចាស់បានប្រាប់ឈ្មោះជាក់លាក់របស់មនុស្សមួយចំនួនដើម្បីបម្រើក្នុងមុខងារផ្សេងៗនៃថ្នាក់ដឹកនាំបព្វជិតភាព ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់អានពី ខ ១២៣–១៣២ ហើយសុំឲ្យសិស្សពាក់កណ្ដាលថ្នាក់ទៀតអានពី ខ ១៣៣–១៤២, ដោយរកមើលមុខងារថ្នាក់ដឹកនាំបព្វជិតភាពដែលព្រះអម្ចាស់បានលើកឡើង ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ សូមសរសេរមុខងារថ្នាក់ដឹកនាំបព្វជិតភាពណាដែលមិនទាន់បានសរសេរពីមុនលើក្ដារខៀន ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលព្រះអម្ចាស់បានហៅពួកអ្នកដឹកនាំបព្វជិតភាព ហើយប្រទានកូនសោបព្វជិតភាពដល់ពួកលោក ។

- ហេតុអ្វីព្រះអម្ចាស់ហៅពួកអ្នកដឹកនាំបព្វជិតភាព ហើយប្រទានកូនសោបព្វជិតភាពដល់ពួកលោកយ៉ាងដូច្នេះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោម ៖ **ព្រះអម្ចាស់ហៅពួកអ្នកដឹកនាំបព្វជិតភាពដើម្បីគ្រប់គ្រងកិច្ចការនៃការបម្រើ ហើយជួយពួកបរិសុទ្ធឲ្យបានគ្រប់លក្ខណ៍**) ។

សូមអញ្ជើញសិស្សឲ្យពិចារណាពីរបៀបដែលអ្នកដឹកនាំបព្វជិតភាពបានជួយពួកគេក្នុងកិច្ចខិតខំដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទឲ្យបានកាន់តែប្រសើរ និងប្រែក្លាយឲ្យកាន់តែដូចទ្រង់ ។ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥

*ព្រះអម្ចាស់ដឹកនាំពួកបរិសុទ្ធឲ្យប្រមូលផ្ដុំគ្នាទៅកន្លែងនានាដែលទ្រង់បានកំណត់*

សូមពន្យល់ថាបន្ទាប់ពីពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីរដ្ឋ មិសសួរី នៅរដូវរងាឆ្នាំ ១៨៣៨–៣៩ ពួកគេបានធ្វើដំណើរចូលទៅរដ្ឋ អិលលីណោយ និង អៃអូវ៉ា ជាកន្លែងដែលពួកគេបានតាំងទីលំនៅទាំងសងខាងលើច្រាំងទន្លេ មីស៊ីស៊ីពី ។ សូមសង្ខេបវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥ ដោយពន្យល់ថាវាបានទទួលនៅខែ មិនា ឆ្នាំ ១៨៤១ ហើយបានបើកសម្ដែងពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ទាក់ទងនឹងពួកបរិសុទ្ធដែលរស់នៅក្នុងទឹកដី អៃអូវ៉ា និង អស់អ្នកដែលមានគម្រោងនឹងទៅទីនោះ ។ នៅក្នុងវិវរណៈនេះព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធឲ្យប្រមូលផ្ដុំគ្នា ហើយសាងសង់ទីតាំងនានាដែលព្រះអម្ចាស់បានកំណត់ទុកតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ រួមមានទីក្រុង អៃអូវ៉ា ដែលត្រូវបានដាក់ឈ្មោះថា សារ៉ាហិមឡា ។ សាសនាចក្របានទិញដីនៅក្នុងរដ្ឋ អៃអូវ៉ា ច្រើនជាងទិញដីនៅរដ្ឋ អិលលីណោយ ដោយផ្ដល់យោបល់ថាថ្នាក់ដឹកនាំសាសនាចក្រគ្មានបំណងថា ពួកបរិសុទ្ធនឹងតាំងទីលំនៅនៅក្នុងទីក្រុង ណៅវូទាំងអស់គ្នានោះទេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៦

*ព្រិកហាំ យ៉ង់ ពុំតម្រូវឲ្យចាកចេញពីគ្រួសាររបស់លោកដើម្បីបម្រើបេសកកម្មបន្ថែមទៀតឡើយ*

សូមអញ្ជើញសិស្សឲ្យស្រមៃពីស្ថានភាពដែលពួកគេចាកចេញពីគ្រួសាររបស់ខ្លួនដើម្បីបម្រើបេសកកម្មសម្រាប់ព្រះអម្ចាស់ក្នុងរយៈពេលរដូវក្ដៅប្រាំឆ្នាំបន្ទាប់ទៀត ហើយបន្ទាប់មកនឹងត្រូវបានហៅបម្រើបេសកកម្មមួយទៀតនៅបរទេសរយៈពេលជិតពីរឆ្នាំ ។

- តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច អំពីការចាកចេញពីគ្រួសារអ្នកច្រើនដងបែបនេះ ?

- តើអ្នកមានអារម្មណ៍យ៉ាងណា បើសិនអ្នកមានទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់សេចក្ដីត្រូវការរបស់គ្រួសារអ្នក ?

សូមប្រាប់សិស្សថាបន្ទាប់ពី ព្រិកហាំ យ៉ង់ បានចូលរួមសាសនាចក្រនៅខែ មេសា ឆ្នាំ ១៨៣២ លោកបានបម្រើបេសកកម្មមួយចំនួនច្រើនជាងប្រាំបួនឆ្នាំ ។ បេសកកម្មដំបូងរបស់លោកគឺអំឡុងពេលនៃរដូវរងា បន្ទាប់ពីលោកបានទទួលបុណ្យជ្រមុជទឹករួច ។ ការបម្រើបេសកកម្មប្រាំផ្សេងទៀត រួមមានការចូលរួមរបស់លោកនៅក្នុងជំរុំស៊ីយ៉ូន បានកើតឡើងរាល់រដូវក្ដៅពីឆ្នាំ ១៨៣៣ ដល់ ១៨៣៧ ។ បេសកកម្មទាំងនេះមានរយៈពេលចាប់ពីបីទៅប្រាំខែ ។ នៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៨៣៨ ព្រិកហាំ យ៉ង់ ជាមួយនឹងសាវកផ្សេងទៀតត្រូវបានហៅឲ្យបម្រើបេសកកម្មនៅចក្រភពអង់គ្លេស ។ ពួកគេបានធ្វើតាមការណែនាំរបស់ព្រះអម្ចាស់ ដើម្បីចាកចេញទៅបេសកកម្មនេះពី ហ្វា វែស្ទ រដ្ឋ មិសសួរី នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣៩ ( សូមមើល គ. និង ស. ១១៨) ។ ព្រិកហាំ យ៉ង់ និង សាវកផ្សេងទៀតបានចំណាយពេលពីរបីខែបន្ទាប់នៅក្នុងរដ្ឋ អៃអូវ៉ា និង អិលលីណោយ ធ្វើការរៀបចំបន្ថែមទៀតដើម្បីធ្វើដំណើរទៅចក្រភពអង់គ្លេស ។ ការឆ្លងរោគគ្រុនចាញ់ បានកើតមាននៅក្នុងតំបន់នោះនារដូវក្ដៅឆ្នាំ ១៨៣៩ ហើយពួកគេក៏បានឆ្លងជំងឺនោះផងដែរ ។

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន ព្រិកហាំ យ៉ង់ឲ្យឮៗ ៖ សូមឲ្យសិស្សស្ដាប់តាមរកមើលឥរិយាបថរបស់លោកចំពោះការបម្រើព្រះអម្ចាស់ ទោះបីជាលោកឈឺដែលស្ទើរតែមិនអាចដើរចូលក្នុងរទេះបើសិនគ្មានអ្នកជួយគ្រានៅពេលលោកបានចេញដំណើរ ។



« ខ្ញុំត្រូវបានកំណត់ឲ្យទៅប្រទេសអង់គ្លេស ឬ ក៏ធ្វើការណ៍នោះរហូតដល់ស្លាប់ ។ ខ្ញុំមានការតាំងចិត្តយ៉ាងមុតមាំថា ខ្ញុំនឹងធ្វើអ្វីដែលខ្ញុំបានតម្រូវឲ្យធ្វើនៅក្នុងដំណឹងល្អនៃជីវិត និង សេចក្ដីសង្គ្រោះ ឬ ខ្ញុំនឹងស្លាប់ដោយការព្យាយាមធ្វើការណ៍នេះ » (*Teachings of Presidents of the Church: Brigham Young* [ ឆ្នាំ ១៩៩៧ ], ទំព័រ ៥) ។

សូមពន្យល់ថាការបម្រើជាអ្នកផ្សព្វផ្សាយសាសនារបស់ព្រិកហាំ យ៉ង់ ក៏បានតម្រូវឲ្យគ្រួសាររបស់លោកធ្វើការលះបង់ផងដែរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីសង្ខេបខាងក្រោមនេះអំពីស្ថានភាពរបស់គ្រួសារព្រិកហាំ យ៉ង់ នៅពេលលោកបានចេញទៅបម្រើបេសកកម្មរបស់ខ្លួនទៅចក្រភពអង់គ្លេស ៖

ព្រិកហាំ យ៉ង់ បានចេញពី ម៉ុនទ្រូស រដ្ឋ អៃអូវ៉ា ទៅចក្រភពអង់គ្លេសនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៨៣៩ គឺ១០ថ្ងៃបន្ទាប់ពីភរិយារបស់លោក ម៉ារី អាន បានឆ្លងទន្លេកូនទីបួនរបស់ខ្លួន ។ ម៉ារី អាន បានរងទុក្ខដោយសារជំងឺគ្រុនចាញ់ ។ នេះគឺជាលើកទីប្រាំហើយតាំងពីពួកគេបានរៀបការដែលគាត់បានឲ្យព្រិកហាំចេញទៅបេសកកម្ម ។ ដោយត្រូវបានបណ្ដេញចេញពីផ្ទះ និង បានបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេនៅក្នុងរដ្ឋ មិសសួរីកាលពីឆ្នាំមុនពួកគេមានភាពក្រតោកយ៉ាក ។ ព្រិកហាំ បានបន្សល់

ប្រាក់តែ ២.៧២ ដុល្លារ ឲ្យម៉ារី អាន សម្រាប់គ្រួសាររបស់ពួកលោក ។ ព្រិកហាំ និង ម៉ារី អានបានទុកចិត្តថា ព្រះអម្ចាស់នឹងប្រទានពរដល់ពួកគេ និង ពឹកផ្អែកលើការសន្យាពីព្យាការីយ៉ូសែប ស្ម៊ីធ ថា ក្រុមគ្រួសាររបស់ពួកសាវកនឹងទទួលបានការថែទាំសម្រាប់សេចក្ដី ត្រូវការនានាខណៈដែលពួកសាវកទាំងនោះចេញទៅបម្រើបេសកកម្ម ។ ( សូមមើល Leonard J. Arrington, *Brigham Young: American Moses* [ ឆ្នាំ ១៩៨៥ ] ទំព័រ ៧៤–៧៥, ៤១៣, ៤២០ ) ។

សូមពន្យល់ថា បន្ទាប់ពីការដឹកនាំកិច្ចការអ្នកផ្សព្វផ្សាយសាសនារបស់សាសនាចក្រនៅក្នុងចក្រភពអង់គ្លេស ព្រិកហាំ យ៉ង់ បានទៅដល់ទីក្រុងណៅវូ រដ្ឋ អិលលីណោយនៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៨៤១ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៦ ប្រាំបីថ្ងៃក្រោយមក ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៦:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានប្រាប់ព្រិកហាំអំពីការបម្រើរបស់លោក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( អ្នកអាចចាំបាច់ត្រូវពន្យល់ថា ពាក្យ *កិច្ចការធ្ងន់* សំដៅទៅលើការព្យាយាមធ្វើការក្នុងរយៈពេលដ៏វែង ) ។

សូមពន្យល់ថា ទោះបីជាព្រះអម្ចាស់ពុំតម្រូវឲ្យលោកចាកចេញពីគ្រួសាររបស់ខ្លួនក៏ដោយ ក៏ក្រោយមកព្រិកហាំ យ៉ង់ បានបម្រើបេសកកម្មរយៈពេលខ្លីៗ ។ សូមអញ្ជើញសិស្សឲ្យប្រាប់គោលការណ៍មួយពី ខ ១–២ ដែលបង្រៀនពី អ្វីដែលនឹងកើតឡើង បើសិនយើងធ្វើការដោយឧស្សាហ៍សម្រាប់ព្រះអម្ចាស់ ។ ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ដូចខាងក្រោម ៖ **បើយើងធ្វើការដោយព្យាយាមសម្រាប់ព្រះអម្ចាស់ នោះទ្រង់នឹងទទួលយកការថ្វាយដ៏សុចរិតរបស់យើង** ។ អ្នកអាចស្នើថា សិស្សគួរតែសរសេរគោលការណ៍នេះនៅក្បែរគែមទំព័រនៃព្រះគម្ពីររបស់ពួកគេ ) ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានសព្វព្រះទ័យនឹងការបម្រើរបស់អ្នក ?

សូមអញ្ជើញសិស្សឲ្យគិតអំពីឱកាសនានាដែលពួកគេមានដើម្បីបម្រើព្រះអម្ចាស់ ។ សូមលើកទឹកចិត្តពួកគេ ឲ្យធ្វើតាមគំរូរបស់អ្នកដឹកនាំដូចជា ព្រិកហាំ យ៉ង់ ដើម្បីធ្វើការដោយព្យាយាមនៅក្នុងឱកាសទាំងនេះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះអម្ចាស់នឹងទទួលយកការថ្វាយដ៏សុចរិតនៃកិច្ចខិតខំព្យាយាមរបស់ពួកគេក្នុងកិច្ចការរបស់ទ្រង់ ។

មេរៀនទី ១៣៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧ មានលិខិតមួយមកពីព្យាការីយ៉ូសែប ស្ម៊ីធ ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ១៨៤២ ដែលបានណែនាំពួកបរិសុទ្ធឲ្យរក្សាកំណត់ត្រានៃបុណ្យជ្រមុជទឹកដែលពួកគេបានធ្វើសម្រាប់មរណជន ។ ប្រហែលជាមួយសប្ដាហ៍ក្រោយមក យ៉ូសែបបានសរសេរសំបុត្រមួយទៀតអំពីប្រធានបទនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨ អត្ថន័យក្នុងលិខិតនេះបង្រៀនពីមូលហេតុដែលយើងរក្សាកំណត់ត្រានៃពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:១–៤

*យ៉ូសែប ស្ម៊ីធ នៅតែអររីករាយទោះមានការបៀតបៀន និង សេចក្ដីទុក្ខលំបាក*

សូមចាប់ផ្ដើមថ្នាក់ ដោយបង្ហាញ នូវក្រឡាធំថ្លាមួយដែលមានបិទពាក្យថា *ជីវិតមែងស្លាប់* និង ទឹកមួយថូរបិទពាក្យ *សេចក្ដីទុក្ខលំបាក* ។ សូមសួរសិស្សពីអ្វីដែលជាសេចក្ដីទុក្ខលំបាករបស់ពួកគេដែលបានធ្លាប់ជួប ឬ បានឃើញមនុស្សដទៃបានជួប ។ សម្រាប់សេចក្ដីទុក្ខលំបាកនិមួយៗដែលពួកគេលើកឡើង សូមចាក់ទឹកខ្លះចេញពីថូរទៅក្នុងក្រឡថ្លានោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីទុក្ខលំបាកអ្វីខ្លះដែលយ៉ូសែប ស្ម៊ីធបានជួបប្រទះនៅក្នុងទីក្រុងណៅវូ ឆ្នាំ ១៨៤២ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថានៅក្នុងខែ ឧសភា ឆ្នាំ ១៨៤២ លីលបឺន ដបុលយូ បកស៏ ដែលជាអតីតអភិបាលនៃរដ្ឋ មិសសួរីដែលបានចេញបញ្ជាឲ្យសម្លាប់ផ្ដាច់ពូជប្រឆាំងនឹងពួកបរិសុទ្ធ ត្រូវបានរងរបួសដោយឃាតករមិនស្គាល់មុខម្នាក់ ។ អាជ្ញាធររដ្ឋ មិសសួរី បានចោទប្រកាន់យ៉ូសែប ស្ម៊ីធពីការរៀបចំមនុស្សម្នាក់នោះឲ្យមកធ្វើឃាត លោក បកស៏ ហើយបានព្យាយាមនាំយកព្យាការីត្រឡប់ទៅរដ្ឋ មិសសួរីវិញដើម្បីកាត់ទោស ។ យ៉ូសែប ស្ម៊ីធ បានចាកចេញពីរដ្ឋ មិសសួរីប៉ុន្មានឆ្នាំមុន ហើយបានរស់នៅក្នុតតំបន់នៃទីក្រុង ណៅវូ រដ្ឋ អិលលីណោយនៅពេលនោះ ។ ដោយដឹងថា បើសិនលោកត្រឡប់ទៅរដ្ឋ មិសសួរីវិញលោកនឹងត្រូវគេសម្លាប់ នោះព្យាការីបានលាក់ខ្លួនពីអជ្ញាធររដ្ឋ មិសសួរីមួយរយៈដើម្បីចៀសវាងពីការចាប់ខ្លួនដោយខុសច្បាប់នោះ ។ នៅក្នុងខែ មករា ឆ្នាំ ១៨៤៣ ដីកាចាប់ខ្លួនយ៉ូសែប ស្ម៊ីធ និង បត្យាប័ននាំខ្លួនលោកមករដ្ឋ មិសសួរីគឺខុសច្បាប់ ។

សូមពន្យល់ថា គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៧ គឺជាលិខិតមួយដែលយ៉ូសែប ស្ម៊ីធបានសរសេរទៅសមាជិកនៃសាសនាចក្រខណៈដែលលោកកំពុងប្ដូរទីលំនៅដើម្បីគេចពីការចាប់ខ្លួនខុសច្បាប់ពីសំណាក់អជ្ញាធរ រដ្ឋ មិសសួរី ។ លិខិតនេះត្រូវបានអានឲ្យពួកបរិសុទ្ធនៅទីក្រុងណៅវូប៉ុន្មានថ្ងៃក្រោយមក ។

សូមបង្ហាញបាល់ពីរដល់សិស្ស ដែលបាល់នោះមានទំហំប្រហាក់ប្រហែលគ្នា បាល់មួយអណ្ដែតទឹក ហើយមួយទៀតលិច ។ ( ឧទាហរណ៍ អ្នកអាចប្រើបាល់វាយកូនហ្គោលផ្លាស្ទីក និង បាល់វាយកូនហ្គោលធម្មតា ) ។ សូមដាក់បាល់ទាំងពីរនោះនៅក្នុងក្រឡទឹកនោះ ហើយសួរសំណួរដូចខាងក្រោម ៖

- តើបាល់ទាំងពីរនេះ អាចតំណាងឲ្យវិធីផ្សេងគ្នាដែលមនុស្សឆ្លើយតបនឹងសេចក្ដីទុក្ខលំបាកយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីរបៀបដែលយ៉ូសែប ស្ម៊ីធបានឆ្លើយតបចំពោះ សេចក្ដីទុក្ខលំបាកនោះ ។

- តើបាល់មួយណាដែលតំណាងឲ្យការឆ្លើយតបចំពោះសេចក្ដីទុក្ខលំបាករបស់យ៉ូសែប ស្ម៊ីធ ? ហេតុអ្វី ?

- តើយ៉ូសែប ស្ម៊ីធ បានដឹងថាលោកនឹងឈ្នះលើសេចក្ដីទុក្ខលំបាក និង គ្រោះថ្នាក់របស់លោកដោយរបៀបណា ?
- យោងតាមអ្វីដែលយ៉ូសែប ស្ម៊ីធ បានសរសេរទៅកាន់ពួកបរិសុទ្ធ តើអ្វីដែលអាចជួយយើងឲ្យស៊ូទ្រាំនឹងសេចក្ដីទុក្ខលំបាកបាន ? ( នៅពេលសិស្សឆ្លើយតប សូមសង្ខេបប្រយោគរបស់ពួកគេ ដោយសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **ការទុកចិត្តលើព្រះវរបិតាសួគ៌អាចជួយយើងឲ្យស៊ូទ្រាំនឹងសេចក្ដីទុក្ខលំបាក**) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីមនុស្សម្នាក់ដែលពួកគេស្គាល់ ( ឬ ធ្លាប់រៀនពីម្នាក់នោះ ) ដែលអាចស៊ូទ្រាំសេចក្ដីទុក្ខលំបាកដោយសារគាត់បានទុកចិត្តលើព្រះវរបិតាសួគ៌ ។ សូមឲ្យសិស្សពីរបីនាក់ពន្យល់ពីមនុស្សដែលពួកគេបានគិតដល់នោះ និងរបៀបដែលការទុកចិត្តលើព្រះវរបិតាសួគ៌ បានជួយបុគ្គលនេះឲ្យស៊ូទ្រាំទុក្ខវេទនា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:៣–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្យាការីបានប្រាប់ពួកបរិសុទ្ធ ។ សូមអញ្ជើញសិស្សស្វែងរក ហើយចែកចាយឃ្លាដែលមានអត្ថន័យចំពោះពួកគេ ។

- យោងតាម ខ ៣ តើហេតុអ្វីពួកបរិសុទ្ធគួរតែរីករាយអំឡុងពេលនៃសេចក្ដីទុក្ខលំបាក ?
- នៅក្នុង ខ ៤, តើព្រះអម្ចាស់បានសន្យាអ្វី ខ្លះដល់អស់អ្នកដែលស៊ូទ្រាំនឹងការបៀតបៀន ?
- តើការទុកចិត្តលើព្រះវរបិតាសួគ៌បានជួយអ្នកឲ្យស៊ូទ្រាំនឹងពេលវេលាលំបាកៗនៅក្នុងជីវិតអ្នកដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:៥–១២

*ព្យាការីយ៉ូសែប ស្ម៊ីធ ទូន្មានពួកបរិសុទ្ធឲ្យកត់ត្រាកំណត់ត្រានៃបុណ្យជ្រមុជទឹកដែលពួកគេបានធ្វើសម្រាប់មរណជន*

សូមរំឭកសិស្សថា ប្រហែលជាមួយឆ្នាំកន្លះពីមុនយ៉ូសែប ស្ម៊ីធ បានសរសេរលិខិតនេះ ព្រះអម្ចាស់បានប្រាប់ពួកបរិសុទ្ធថា ពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់គួរតែត្រូវបានធ្វើឡើងនៅក្នុងព្រះវិហារបរិសុទ្ធ ( សូមមើល គ. និង ស. ១២៤:៣០) ។ ទោះជាយ៉ាងណា ព្រះអម្ចាស់បានអនុញ្ញាតឲ្យពួកបរិសុទ្ធធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជននៅក្នុងទន្លេ និង ស្ទឹងដែលនៅក្បែរនោះសម្រាប់មួយរយៈពេលខ្លី ។ ព្រះអម្ចាស់បានប្រាប់ពួកគេថានៅពេលព្រះវិហារបរិសុទ្ធសង់រួចស្រេចបាច់ ពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់អាចទទួលយកបានបើសិនបានធ្វើឡើងនៅតែក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ។ ពួកបរិសុទ្ធបានចាប់ផ្ដើមធ្វើបុណ្យជ្រមុជទឹកសម្រាប់មរណជននៅក្នុងព្រះវិហារបរិសុទ្ធទីក្រុង ណៅវូ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៨៤១ ។

សូមឲ្យសិស្សគិតអំពីពេលចុងក្រោយគេដែលពួកគេបានចូលរួមនៅក្នុងពិធីបុណ្យជម្រុជទឹកសម្រាប់មរណជន ។ សូមអញ្ជើញពួកគេឲ្យពិពណ៌នាពីបទពិសោធន៍ រួមទាំងអស់អ្នកដែលអង្គុយនៅក្បែរអាងជ្រមុជទឹកអំឡុងពេលបុណ្យជ្រមុជទឹក ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:៥–៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថានរណាដែលគួរតែមានវត្តមាននៅពេលគេធ្វើបុណ្យជ្រមុជទឹកសម្រាប់មរណជន ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម ខ ៧, ហេតុអ្វីបានវាសំខាន់ថាកំណត់ត្រាគឺជាសាក្សីនៃពិធីបុណ្យជ្រមុជទឹក ?

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្ដារខៀន ៖ *ពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ដែលយើងធ្វើនៅលើផែនដីនេះគឺ. . .*

សូមអញ្ជើញសិស្សឲ្យបំពេញសេចក្ដីថ្លែងការណ៍យោងតាម ខ ៥–៩ ។ ( សិស្សគួរតែបំពេញសេចក្ដីថ្លែងការណ៍នេះ ដែលឲ្យស្រដៀងទៅនឹងសេចក្ដីពិតដូចខាងក្រោម ៖ **ពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធដែលយើងធ្វើនៅលើផែនដីនេះកំពុងតែចងវានៅក្នុងឋានសួគ៌ដែរ**) ។

- តើអ្នកគិតថាវាមានន័យយ៉ាងណាដែលថាពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធនឹងត្រូវចងភ្ជាប់នៅក្នុងឋានសួគ៌ ?
- តើការដឹងពីសេចក្ដីពិតនេះអាច ជួយអ្នកបំពេញទំនួលខុសត្រូវដើម្បីធ្វើពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធសម្រាប់ « មរណជនរបស់អ្នក » យ៉ាងដូចម្ដេច ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:១០–១២ ដោយពន្យល់ថា យ៉ូសែប ស្ម៊ីធ ចង់បង្រៀនពួកបរិសុទ្ធបន្ថែមទៀតអំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ប៉ុន្តែដោយសារលោកកំពុងលាក់ខ្លួននោះលោកពុំអាចបង្រៀនពួកគេបានឡើយ ។ លោកបានសន្យាថាសរសេរលិខិតបន្ថែមឲ្យពួកបរិសុទ្ធអំពីបុណ្យជ្រមុជទឹកសម្រាប់មរណជន និង ប្រធានបទសំខាន់ដទៃទៀត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១–១១

*យ៉ូសែប ស្ម៊ីធ ពន្យល់ពីមូលហេតុដែលយើងរក្សាកំណត់ត្រាសម្រាប់ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ*

ប្រហែលជាមួយសប្ដាហ៍បន្ទាប់ពីលោកបានសរសេរលិខិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧, យ៉ូសែប បានសរសេរលិខិតមួយទៀតឲ្យពួកបរិសុទ្ធទាក់ទងនឹងពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន ។ លិខិតនេះមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១–៥ ដោយពន្យល់ថា យ៉ូសែប បានបង្រៀនថាកំណត់ត្រាក្នុងមូលដ្ឋានគួរតែត្រូវបានធ្វើឡើងដើម្បីជាសាក្សី និង កត់ត្រាអំពីពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ។ លោកក៏បានបង្រៀនថាអ្នកកត់ត្រាទូទៅ គួរតែត្រូវបានតែងតាំងដើម្បីចងក្រងកំណត់ត្រាក្នុងមូលដ្ឋានឲ្យទៅជាកំណត់ត្រាសាសនាចក្រទូទៅ ។

សូមបង្ហាញលិខិតឆ្លងដែនមួយ ( ឬ រូបភាពនៃលិខិតឆ្លងដែន ) ។ សូមសួរថាតើឯកសិទ្ធបែបណាដែលអ្នកកាន់លិខិតឆ្លងដែនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ ។

- ហេតុអ្វីបានជាអ្នកពុំអាចប្រើលិខិតឆ្លងដែនអ្នកដទៃចូលទៅក្នុងប្រទេសមួយទៀតបាន ?
- តើនឹងមានអ្វីកើតឡើងបើសិនអ្នកព្យាយាមចូលទៅក្នុងប្រទេសមួយទៀត ប៉ុន្តែព័ត៌មាននៅក្នុងលិខិតឆ្លងដែនរបស់អ្នកពុំបានបំពេញចប់សព្វគ្រប់នោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលថាតើកំណត់ត្រាអ្វីដែលនឹងត្រូវបានប្រើប្រាស់ដើម្បីសម្រេច ថាបើសិនយើងអាចត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងវត្តមានរបស់ព្រះ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមចង្អុលបង្ហាញថា យ៉ូហាន និងយ៉ូសែប ស្ម៊ីធ បាននិយាយពីកំណត់ត្រាជាច្រើន ៖ « បញ្ជីបានបើកឡើង » ហើយ « បញ្ជីមួយទៀត. . .គឺជាបញ្ជីជីវិត » ។

- យោងតាម ខ ៧, តើបញ្ជីដំបូងដែលបាននិយាយដោយយ៉ូហាននោះគឺជាបញ្ជីអ្វី ? ( បញ្ជីទាំងឡាយដែលបានរក្សាទុកនៅលើផែនដី ) ។
- តើបញ្ជីជីវិតគឺជាអ្វី ? ( បញ្ជាដែលបានរក្សាទុកនៅលើឋានសួគ៌ ) ។
- តើមានអ្វីខ្លះដែលបានកត់ត្រានៅក្នុងបញ្ជីទាំងនេះ ? ( កិច្ចការរបស់យើង ) ។
- តើកិច្ចការអ្វី ខ្លះដែលត្រូវតែកត់ត្រានៅក្នុងបញ្ជីនេះ ដើម្បីត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងវត្តមានរបស់ព្រះបាន ?

បន្ទាប់ពីសិស្សចែកចាយគំនិតរបស់ពួកគេទាក់ទងនឹងសំណួរនោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៏ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញា ក្លាយជាប័ណ្ណសម្គាល់ខ្លួនយើងសម្រាប់ការចូលទៅក្នុងវត្តមាន [ វត្តមានរបស់ព្រះ ] (« Covenants » *Ensign,* ឧសភា ឆ្នាំ ១៩៨៧ ទំព័រ ២៤ ) ។

- យោងតាមសេចក្ដីថ្លែងការណ៍របស់ប្រធាន ផាកកឺ តើអ្វីនឹងកើតឡើងនៅថ្ងៃនៃសេចក្ដីជំនុំជម្រះ បើសិនបញ្ជីរបស់មនុស្សម្នាក់បង្ហាញថាគាត់ពុំធ្លាប់ទទួលពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹកនោះ ?

សូមសរសេរឃ្លាខាងក្រោមលើក្ដារខៀន ៖ *មិនថាអ្វីដែលអ្នកចងភ្ជាប់នៅលើផែនដីនេះ នោះនឹងត្រូវបានចងភ្ជាប់លើនៅឋានសួគ៌ដែរ ។* សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្យាការីយ៉ូសែប ស្ម៊ីធ បានពន្យល់ពីសេចក្ដីថ្លែងការណ៍នេះទៅកាន់ពួកបរិសុទ្ធ ។ នៅពេលសិស្សរាយការណ៍ពីអារម្មណ៍របស់ពួកគេ សូមជំនួសពាក្យ *ចង* ជាមួយពាក្យ *បញ្ជី* ដោយពាក្យ *បានចង* ដោយពាក្យ *បានកត់ត្រា* នៅលើក្ដារខៀន ។

- តើយើងរៀនអ្វីខ្លះពី ខ ៨ អំពីការកត់ត្រាពិធីបរិសុទ្ធដែលយើងទទួលនោះ ? ( អ្នកអាចពន្យល់ថាឃ្លា « *ដោយខ្លួនពួកគេផ្ទាល់* » សំដៅលើមនុស្សដែលបានជ្រមុជទឹកសម្រាប់ខ្លួនពួកគេ ហើយឃ្លា « ភ្នាក់ងាររបស់គេផ្ទាល់ » សំដៅលើអស់អ្នកដែលបានជ្រមុជទឹកក្នុងនាមជាអ្នកជំនួស ) ។

សូមសរសេរដូចខាងក្រោមនៅលើក្ដារខៀន ៖ *នៅពេលពិធីបរិសុទ្ធមួយត្រូវបានធ្វើឡើងដោយ ________ ហើយបានរក្សាយ៉ាងត្រឹមត្រូវ ________________________________ពិធីបរិសុទ្ធនេះត្រូវបានចងនៅលើផែនដី និង នៅលើឋានសួគ៌ ។*

- យោងតាម ខ ៨, តើអ្វីដែលចាំបាច់ត្រូវតែកើតមានដើម្បីឲ្យពិធីបរិសុទ្ធត្រូវបានចងនៅលើផែនដី និង នៅឋានសួគ៌ ? ( នៅពេលសិស្សឆ្លើយ សូមអញ្ជើញសិស្សឲ្យបំពេញសេចក្ដីពិតនៅលើក្ដារខៀនដូចខាងក្រោមនេះ ៖ **នៅពេលពិធីបរិសុទ្ធមួយត្រូវបានធ្វើឡើងដោយអ្នកមានសិទ្ធិអំណាចបព្វជិតភាព ហើយកំណត់ត្រាត្រូវបានរក្សាត្រឹមត្រូវ នោះពិធីបរិសុទ្ធនោះកំពុងបានចងនៅលើផែនដី និងនៅក្នុងឋានសួគ៌**) ។

- តើសេចក្ដីសង្ឃឹមអ្វីខ្លះដែលគោលការណ៍នេះផ្ដល់ដល់អស់អ្នកដែលបានស្លាប់ទៅ ដោយពុំមានចំណេះដឹងអំពីដំណឹងល្អនោះ ?

- តើការទទួលខុសត្រូវអ្វីខ្លះដែលយើងត្រូវមានដើម្បីបំពេញគោលការណ៍នេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែល យ៉ូសែប ស្ម៊ីធបានប្រសាសន៍អំពីគោលការណ៍នេះ ។

- តើព្រះអម្ចាស់បានធ្វើអ្វីខ្លះនៅក្នុងគ្រប់សម័យកាន់កាប់ត្រួតត្រាទាំងអស់នៃបព្វជិតភាព ? ( ព្រះអម្ចាស់បានប្រទានសិទ្ធិអំណាចយ៉ាងហោចណាស់ដល់អ្នកបម្រើរបស់ទ្រង់ម្នាក់ដើម្បីកាន់ និង ប្រើប្រាស់កូនសោនៃការផ្សារភ្ជាប់នៃបព្វជិតភាព ) ។

- យោងតាម ខ ៩, តើអ្វីកើតឡើងនៅពេលពិធីបរិសុទ្ធមួយត្រូវបានធ្វើឡើងដោយសិទ្ធិអំណាចបព្វជិតភាព និង បានរក្សាកំណត់ត្រាត្រឹមត្រូវនោះ ? ( វាក្លាយជាក្រឹត្យវិន័យមួយលើផែនដី និង នៅក្នុងឋានសួគ៌ ហើយមិនអាចក្លាយជាអសារឥតការឡើយ លុះត្រាតែបុគ្គលនោះដែលទទួលវានោះរស់នៅពុំសក្ដិសម ) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១០–១១ ដោយពន្យល់ថា គឺដូចជាព្រះអង្គសង្គ្រោះបានប្រទានកូនសោផ្សារភ្ជាប់នៃបព្វជិតភាពដល់ពេត្រុស នោះទ្រង់បានប្រទានកូនសោនោះដល់ជំនាន់យើងនេះម្ដងទៀត ។

> *លំហាត់សរសេរ*
>
> ការអញ្ជើញសិស្សឲ្យឆ្លើយតបនឹងសំណួរបំផុសគំនិត ដោយការសរសេរអាចជួយធ្វើឲ្យពួកគេគិតបានជ្រៅជ្រះ និងច្បាស់លាស់អំពីគំនិត និង អារម្មណ៍របស់ខ្លួន ។ ការអញ្ជើញសិស្សឲ្យឆ្លើយសំណួរមួយដោយការសរសេរមុនពេលចែកចាយពីគំនិតរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់រៀន គឺផ្ដល់ពេលវេលាឲ្យពួកគេដើម្បីរៀបចំគំនិត និង ទទួលការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ។

សូមបញ្ចប់មេរៀនដោយសរសេរ សំណួរខាងក្រោម នៅលើក្ដារខៀន ហើយ សូមឲ្យសិស្សឆ្លើយសំណួរទាំងនោះ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

> *តើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន និង កូនសោនៃការផ្សារភ្ជាប់ទាក់ទងគ្នាយ៉ាងដូចម្ដេច ?*
>
> *តើអ្នកត្រូវបានបំផុសគំនិតឲ្យធ្វើអ្វីខ្លះ ដោយសារតែអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ ?*

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វីដែលពួកគេបានសរសេរជាមួយសិស្សនៅក្នុងថ្នាក់ ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកអំពីការធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន ។

មេរៀនទី ១៣៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥

## បុព្វកថា

មេរៀននេះមាននូវផ្នែកទាំងអស់នៃលិខិតដែលព្យាការីយ៉ូសែប ស្ម៊ីធ បានសរសេរឲ្យពួកបរិសុទ្ធនៅដើមខែ កញ្ញា ឆ្នាំ ១៨៤២ ។ នៅក្នុងផ្នែកនៃលិខិតនេះ ព្យាការីបង្រៀនអំពីសេចក្ដីសង្គ្រោះរបស់អ្នកនៅរស់ និង មរណជន ។ លោកបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យស្មោះត្រង់ចំពោះកិច្ចការរបស់ខ្លួនសម្រាប់មរណជន ហើយបង្ហាញសេចក្ដីអំណររបស់លោកនៅក្នុងការស្ដារឡើងវិញនៃដំណឹងល្អ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–១៨

*យ៉ូសែប ស្ម៊ីធ បង្រៀនអំពីសេចក្ដីសង្គ្រោះរបស់អ្នកនៅរស់ និង មរណជន ។*



សូមបង្ហាញរូបភាពមួយនៃអាងជ្រមុជទឹកនៅក្នុងព្រះវិហារបរិសុទ្ធ ( ឧទាហរណ៍, « អាងជ្រមុជទឹកព្រះវិហារបរិសុទ្ធ » *សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] លេខ ១២១; សូមមើលផងដែរគេហទំព័រ LDS.org) ។ សូមឲ្យសិស្សស្រមៃថាពួកគេកំពុងចូលរួមការសម្ពោធបើកឲ្យប្រើប្រាស់ព្រះវិហារបរិសុទ្ធជាមួយមិត្តម្នាក់ដែលមិនមែនជាសមាជិកសាសនាចក្រ ។ បន្ទាប់ពីបានដើរកាត់កន្លែងជ្រមុជទឹកមិត្តរបស់ពួកគេសួរថា « ហេតុអ្វីបានជាអ្នកត្រូវតែលិចខ្លួនទាំងស្រុងចូលទៅក្នុងទឹកនៅពេលអ្នកទទួលបុណ្យជ្រមុជទឹកដូច្នេះ ? » មិត្តរបស់ពួកគេក៏សួរផងដែរថា « ហេតុអ្វីបានជាអ្នកជ្រមុជទឹកជំនួសអ្នកដែលស្លាប់ទៅយ៉ាងដូច្នេះ ? »

សូមរំឭកសិស្សថាខណៈពេលយ៉ូសែប ស្ម៊ីធ បានលាក់ខ្លួនពីមនុស្សដែលស្វែងរកចាប់ខ្លួនលោកខុសច្បាប់នោះ លោកបានសរសេរលិខិតមួយឲ្យពួកបរិសុទ្ធ ។ នៅក្នុងសំបុត្រនោះ លោកបានបង្រៀនពួកគេបន្ថែមអំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការបង្រៀនរបស់យ៉ូសែប ស្ម៊ីធ អំពីនិមិត្តរូបនៃបុណ្យជ្រមុជទឹក ។

- តើអ្នកអាចប្រើការបង្រៀននៅក្នុង ខ ១២–១៣ ដើម្បីជួយនរណាម្នាក់ឲ្យយល់ពីមូលហេតុដែលបុណ្យជ្រមុជទឹកត្រូវធ្វើឡើងដោយការពន្លិចខ្លួនយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលមូលហេតុដែលយើងធ្វើបុណ្យជ្រមុជទឹកសម្រាប់មរណជន ។

- យោងតាម ខគម្ពីរនេះ ហេតុអ្វីបានជាដូនតារបស់យើងត្រូវការយើងឲ្យធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជនដូច្នេះ ? ( បើចាំបាច់ សូមទាញចំណាប់អារម្មណ៍សិស្សមកពាក្យ « ពួកគេពុំអាចបានល្អឥតខ្ចោះ ក្រៅពីយើងឡើយ » ។ សូមជួយសិស្សឲ្យស្វែងរកគោលលទ្ធិខាងក្រោម ៖ **ជីដូនជីតារបស់យើង ដែលបានស្លាប់ដោយគ្មានដំណឹងល្អ មិនអាចរីកចម្រើនទៅកាន់ភាពល្អឥតខ្ចោះឡើយ ទាល់តែមានពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះនៃដំណឹងល្អ ត្រូវបានធ្វើឡើងសម្រាប់ពួកគាត់** ) ។

បើសិនសិស្សត្រូវការជំនួយដើម្បីឆ្លើយសំណួរនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ៖

« ជីដូនជីតាដែលបានទទួលមរណភាពទៅហើយរបស់អ្នករស់នៅកន្លែងមួយដែលហៅថា ពិភពវិញ្ញាណ ។ នៅទីនោះ ពួកគេមានឱកាសដើម្បីស្ដាប់ និង ទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេមិនអាចទទួលពិធីបរិសុទ្ធនៃដំណឹងសម្រាប់ខ្លួនពួកគេឡើយ ហើយពួកគេពុំអាចរីកចម្រើនឡើងលើកលែងតែមានមនុស្សដទៃទៀតផ្ដល់ពិធីបរិសុទ្ធទាំងនេះសម្រាប់ពួកគេ ។

« ឯកសិទ្ធិ និង ទំនួលខុសត្រូវរបស់អ្នកគឺត្រូវផ្ដល់អំណោយនេះដល់ពួកគេដោយការស្វែងរកពួកគេ ហើយធានាថាពិធីបរិសុទ្ធទាំងនេះត្រូវបានធ្វើឡើងជំនួសពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់មក ពួកគេអាចជ្រើសរើសថាព្រមទទួលយកកិច្ចការដែលបានធ្វើនេះឬក៏ អត់ » ( *Member's Guide to Temple and Family History Work* [ ឆ្នាំ ២០០៩ ] ទំព័រ ២ ) ។

- តើអ្នកគិតថាជីដូនជីតារបស់អ្នកអាចមានអារម្មណ៍បែបណាចំពោះអ្នក នៅពេលអ្នកធ្វើកិច្ចការនេះសម្រាប់ពួកគេនោះ ?
- យោងតាម ខ ១៥, តើហេតុផលអ្វីមួយផ្សេងទៀតដែលយើងធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជននោះ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិខាងក្រោមនេះលើក្ដារខៀន ៖ **សេចក្ដីសង្គ្រោះសម្រាប់ជីដូនជីតាដែលបានស្លាប់របស់យើងគឺចាំបាច់ ហើយសំខាន់ចំពោះ សេចក្ដីសង្គ្រោះរបស់យើង**) ។
- ហេតុអ្វីអ្នកគិតថា « សេចក្ដីសង្គ្រោះរបស់ពួកគេគឺចាំបាច់ ហើយសំខាន់ចំពោះសេចក្ដីសង្គ្រោះរបស់យើង ? » ( បន្ទាប់ពីសិស្សមានពេលដើម្បីពិភាក្សាសំណួរនេះហើយ សូមប្រាប់ពួកគេថាពួកគេនឹងរៀនបន្ថែមទៀតអំពីគោលលទ្ធិនៅពេលពួកគេបន្តសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៦–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលព្យាការីនៅក្នុងព្រះគម្ពីរប៊ីបដែលបានសរសេរអំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើវគ្គព្រះគម្ពីរប៊ីបទាំងនេះអាចមានសារៈប្រយោជន៍ចំពោះមិត្តម្នាក់ដែលមិនមែនជាសមាជិកសាសនាចក្រដូចម្ដេច ?

សូមបង្ហាញ ច្រវ៉ាក់ ដែលដែលមានច្រើនកាំ ឬ សូមគូសវានៅលើក្ដារខៀន ។



សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលតំណនៃច្រវ៉ាក់នេះទាក់ទងនឹងការបង្រៀនរបស់យ៉ូសែប ស៊្មីធ អំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ។ ( អ្នកអាចរំឭកសិស្សថាសម័យកាន់កាប់ត្រួតត្រាគឺជាអំឡុងពេលដែលព្រះអម្ចាស់បើកសម្ដែងគោលលទ្ធិ ពិធីបរិសុទ្ធ និង បព្វជិតភាពរបស់ទ្រង់ ។ អ្នកអាចពន្យល់ថានៅក្នុងខគម្ពីរនេះ ពាក្យថា *កូនៗ* សំដៅលើពួកយើង ហើយពាក្យថា *ឪពុក* សំដៅលើជីដូនជីតារបស់យើង ) ។

- តើតំណនៃច្រវ៉ាក់នេះទាក់ទងនឹងការបង្រៀនរបស់យ៉ូសែប ស៊្មីធ អំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់យ៉ាងដូចម្ដេច ? ( សិស្សគួរតែរកឃើញសេចក្ដីពិតខាងក្រោមនេះ ៖ **បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ជួយភ្ជាប់យើងជានិរន្តរ៍ជាមួយនឹងជីដូនជីតារបស់យើង** ។ សូមពន្យល់ថា ក្រៅពីបុណ្យជ្រមុជទឹក ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះផ្សេងទៀត—ពិធីបញ្ជាក់ ការតែងតាំងបព្វជិតភាពមិលគីស្សាដែក [ សម្រាប់បុរស ] ពិធីអំណោយទានពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ និង ពិធីបរិសុទ្ធនៃការផ្សារភ្ជាប់—ក៏សំខាន់ដើម្បីសង្គ្រោះតំណនៃការផ្សារភ្ជាប់គ្នារវាងជីដូនជីតារបស់យើង និង ខ្លួនយើង ) ។

ដើម្បីជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិ និង គោលការណ៍ដែលពួកគេបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–១៨, សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន យ៉ូសែប ហ្វីលឌីង ស៊្មីធឲ្យឮៗ ៖



« ត្រូវតែមានអង្គការគ្រួសារមួយជាអង្គភាពក្រុមគ្រួសារមួយ ហើយជំនាន់និមួយៗត្រូវតែផ្សារភ្ជាប់ជាមួយនឹងច្រវ៉ាក់ដែលបានទៅមុនដើម្បី នាំមកនូវភាពល្អឥតខ្ចោះនៅក្នុងអង្គភាពគ្រួសារ ។ ដូច្នេះនៅទីបំផុត យើងនឹងក្លាយជាគ្រួសារដ៏ធំមួយតាំងពីដំបូងជាមួយនឹងអ័ដាម មីកែល មេទ័ពពួកទេវតាធ្វើជាអធិបតីលើពូជពង្សរបស់លោក » (*Doctrines of Salvation,* បាននិពន្ធដោយ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ភាគទី ៣ [ ឆ្នាំ ១៩៥៤–៥៦ ] ២:១៧៥ ) ។

សូមចង្អុលបង្ហាញថាយោងតាម ខ ១៨, ផែនដីនឹងត្រូវបានវាយដោយសេចក្ដីបណ្ដាសា លើងលែងតែមានចំណងភ្ជាប់ណាមួយ រវាងពួកឪពុក និង កូនៗ ។ ដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិនេះ សូមអានសុន្ទរកថាខាងក្រោមនេះដែលពន្យល់ដោយ ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖



« បើសិនគ្មានតំណភ្ជាប់គ្នារវាងពួកឪពុក និងកូនៗ—ដែលជាកិច្ចការសម្រាប់មនុស្សស្លាប់ទេ— នោះយើងទាំងអស់គ្នានឹងត្រូវកំទេចចោល ហើយកិច្ចការរបស់ព្រះទាំងមូលនឹងបរាជ័យ និង ត្រូវកំទេចចោលសូន្យឈឹង » (*Doctrines of Salvation*,២:១២២ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៩–២៥

*យ៉ូសែប ស៊្មីធ បង្ហាញពីសេចក្ដីអំណរនៅក្នុងស្ដារឡើងវិញនៃដំណឹងល្អ ហើយលើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យ ស្មោះត្រង់ នៅពេលពួកគេធ្វើកិច្ចការសម្រាប់សេចក្ដីសង្គ្រោះដល់មរណជន*

សូមអញ្ជើញសិស្សឲ្យគិតអំពី ពេលមួយដែលពួកគេមានភាពរីករាយដោយបានឮដំណឹងដ៏ល្អ ។ សូមឲ្យសិស្សពីរបីនាក់ ចែកចាយបទពិសោធន៍របស់ពួកគេ ។ បន្ទាប់ពីពួកគេចែកចាយហើយ សូមសួរពួកគេបើសិនពួកគេចង់ចែកចាយព័ត៌មាននេះ ជាមួយមនុស្សដទៃ និង មូលហេតុអ្វី ។

សូមពន្យល់ថាពាក្យមួយទៀតសម្រាប់ពាក្យ *ព័ត៌មាន* គឺ *ដំណឹង* ។ បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលដំណឹងដែល យ៉ូសែប ស៊្មីធបាននិយាយដែល យើងបានទទួល ។

- តើ « ដំណឹងល្អ » អ្វីដែលយើងបានទទួល ? ( ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ) ។
- តើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺជាសំឡេងរីករាយសម្រាប់អ្នករស់ និង មរណជនយ៉ាងដូចម្ដេច ?

សូមពន្យល់ថាយ៉ូសែប ស៊្មីធ បានរៀបរាប់ពីបទពិសោធន៍មួយចំនួន ដែលលោកបានមានជាមួយសារទូតឋានសួគ៌នៅពេល ដំណឹងល្អត្រូវបានស្ដារឡើងវិញតាមរយៈលោក ។ សូមអញ្ជើញសិស្សឲ្យអានស្ងួសៗ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:២០–២១ ហើយរកមើលបទពិសោធន៍ និង សារទូតទាំងនោះ ។ អ្នកអាចចង់ឲ្យពួកគេគួរគូសចំណាំអ្វីដែលពួកគេ រកឃើញ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។ បន្ទាប់ពីសិស្សបានចែកចាយអ្វីដែលពួកគេបានឃើញ ហើយ សង្ខេបយោបល់របស់ពួកគេដោយការសរសេរគោលលទ្ធិនៅលើក្ដារខៀន ៖ **កូនសោ អំណាច និង សិទ្ធិអំណាចនៃសម័យ កាន់កាប់ត្រួតត្រាពី ដើមត្រូវបានស្ដារឡើងវិញនៅក្នុងសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នេះ ។**

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូហាន ថេលើរ ឲ្យឮៗ ៖



« គោលការណ៍ដែល [ យ៉ូសែប ស៊្មីធ ] ត្រូវបានដឹកនាំឲ្យធ្លាក់ចូលទៅក្នុងការសន្ទនា ជាមួយ ព្រះអម្ចាស់ ហើយមិនមែនត្រឹមតែជាមួយព្រះអម្ចាស់ឡើយ ប៉ុន្តែជាមួយសាវក និង ព្យាការីបុរាណ បុរសទាំងនោះរួមមាន ដូចជា អ័ប្រាហាំ អ៊ីសាក យ៉ាកុប ណូអេ អ័ដាម សេត អេណុក និង ព្រះយេស៊ូវ និងព្រះវរបិតា និង សាវកដែលបានរស់នៅលើទ្វីបនេះ ព្រមទាំងអស់អ្នកដែលបានរស់នៅក្នុងទ្វីបអាស៊ី ផងដែរ ។ លោកហាក់បីដូចជាស្គាល់មនុស្សទាំងនោះនៅពេលយើងបាននៅជាមួយគ្នា ។ ហេតុអ្វី ? ដោយសារលោកត្រូវតែណែនាំនូវគ្រាកាន់កាប់ត្រួតត្រាមួយដែលត្រូវបានហៅថាសម័យកាន់កាប់ ត្រួតត្រានៃពេលពេញកំណត់ ហើយវាត្រូវបានទទួលស្គាល់ដោយអ្នកបម្រើពីបុរាណនៃព្រះ (*The Gospel Kingdom* [ ឆ្នាំ ១៩៨៧ ] ទំព័រ ៣៥៣ ) ។

- តើមានអ្វីខ្លះបានផ្លាស់ប្ដូរនៅក្នុងជីវិតរបស់អ្នកដោយការដឹងថា ដំណឹងល្អបានស្ដារឡើងវិញលើផែនដីតាមរយៈសារទូតឋាន សួគ៌ ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:២២–២៣ មានការបង្ហាញពីសេចក្ដីអំណររបស់យ៉ូសែប ស៊្មីធដោយសារ កូនសោនៃបព្វជិតភាពត្រូវបានស្ដារឡើងវិញ ហើយដោយសារពួកបរិសុទ្ធអាចជួយសង្គ្រោះដល់មរណជន ។ សូមអញ្ជើញ សិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម រកមើលឃ្លានានា ដែលមានអត្ថន័យពិសេសចំពោះ ពួកគេ ។ ( អ្នកអាចចង់ស្នើថា ពួកគេគូសចំណាំឃ្លាទាំងនោះ ) ។ បន្ទាប់មកសូមឲ្យសិស្សផ្ទៀងតាម ហើយពន្យល់មូលហេតុ ដែលឃ្លាទាំងនោះមានន័យចំពោះពួកគេ ។

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:២៤ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលអ្វីដែលព្យាការី បានណែនាំពួកបរិសុទ្ធឲ្យធ្វើ ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាមខគម្ពីរនេះ តើអ្វីទៅជាការថ្វាយដង្វាយដោយសេចក្ដីសុចរិតដែលយើងថ្វាយដល់ព្រះអម្ចាស់ ? ( បញ្ជីមួយដែល មានបញ្ជីនៃពួកអ្នកស្លាប់របស់យើង ) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីរួមចំណែកនៅក្នុង « បញ្ជី » នេះ ? តើ ខ ២៤ បង្រៀនអ្វីខ្លះអំពីការចូលរួមរបស់យើងនៅក្នុង កិច្ចការនៃពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញ គោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងធ្វើកិច្ចការពង្សប្រវត្តិ ហើយទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធសម្រាប់ ជីដូនជីតារបស់យើង នោះយើងធ្វើការថ្វាយដង្វាយដោយសុចរិតដល់ព្រះអម្ចាស់ហើយ** ។ សូមសរសេរគោលការណ៍នេះ នៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវក ដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់ការពិពណ៌នារបស់អែលឌើរ បែដណាអំពីតួនាទីរបស់ពួកគេនៅក្នុងកិច្ចការនៃ សេចក្ដីសង្គ្រោះដល់មរណជន ៖



« មានអ្នករាល់គ្នាជាច្រើនប្រហែលជាគិតថា កិច្ចការពង្សប្រវត្តិគឺត្រូវតែធ្វើឡើងដោយពួកមនុស្សវ័យ ចំណាស់ ។ ប៉ុន្តែខ្ញុំដឹងថាគ្មានការកំណត់អាយុណាមួយបានរៀបរាប់នៅក្នុងព្រះគម្ពីរ ឬសេចក្ដីណែនាំ ណាមួយដែលបានប្រកាសដោយពួកអ្នកដឹកនាំសាសនាចក្របានដាក់កំហិតលើការបម្រើដ៏សំខាន់ នេះទេ ។. . .

« វាមិនមែនជាការចៃដន្យទេ ដែលកម្មវិធីស្រាវជ្រាវពង្សប្រវត្តិ. . .ឧបករណ៍ទាំងឡាយដទៃទៀត ត្រូវបង្កើតឡើងនៅចំពេលដែលមនុស្សវ័យក្មេងមានការចេះដឹងយ៉ាងទូលំទូលាយអំពីបច្ចេកវិទ្យាព័ត៌មាន និង ទំនាក់ទំនង នោះ ។. . . ជំនាញ និង ភាពឆ្លាតវៃក្នុងចំណោមពួកយុវវ័យជាច្រើនរបស់យើងសព្វថ្ងៃនេះ រៀបចំដើម្បីចូលរួមចំណែកជួយ ដល់កិច្ចការនៃសេចក្ដីសង្គ្រោះ ។

« . . .ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យសិក្សា ស្វែងរកជីដូនជីតារបស់អ្នក ហើយត្រៀមខ្លួនរបស់អ្នកដើម្បី ធ្វើបុណ្យជ្រមុជទឹក ជំនួសនៅក្នុងដំណាក់របស់ព្រះអម្ចាស់សម្រាប់ *មរណជន* របស់អ្នក ។. . . យើងខ្ញុំសូម ជម្រុញអ្នកឲ្យជួយមនុស្សដទៃ ស្វែងរកពង្សប្រវត្តិរបស់ពួកគេ » (The Hearts of the Children Shall Turn » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៦ ) ។

- តើតាមរបៀបណាខ្លះដែលអ្នកអាចចូលរួមក្នុងកិច្ចការពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធ ?
- តើនៅពេលណា ដែលអ្នកបានថ្វាយដង្វាយតាមរយៈកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ? តើអ្នកត្រូវបានប្រទានពរ តាមរបៀបណាខ្លះនៅពេលអ្នកបានធ្វើការថ្វាយដង្វាយទាំងនេះ ?

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យទាំងឡាយដែលសិស្សនឹងទទួលបាននៅពេលពួកគេចូលរួមនៅក្នុងកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យដាក់គោលដៅដែលនឹងជួយពួកគេធ្វើកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។

### *សំណួរដែលអញ្ជើញឲ្យ ដឹង និង មានទីបន្ទាល់*

សំណួរមួយចំនួនអាចនាំសិស្សឲ្យ គិតអំពីបទពិសោធន៍ខាងវិញ្ញាណ ពីអតីតកាល ហើយជួយពួកគេឲ្យ មានអារម្មណ៍កាន់តែជ្រាលជ្រៅលើ សេចក្ដីពិត និង សារៈសំខាន់នៃ គោលលទ្ធិ ឬ គោលការណ៍នៃដំណឹង ល្អ ។ ជាញឹកញាប់សំណួរទាំងនេះ ធ្វើឲ្យសិស្សចែកចាយពីអារម្មណ៍ បទពិសោធន៍ និង ទីបន្ទាល់ ។ សំណួរ ទាំងនេះជួយនាំដំណឹងល្អចេញពីគំនិត សិស្សចូលទៅក្នុងដួងចិត្តរបស់ពួកគេ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤–១២៨ ( មេរៀនទី ២៧ )

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤–១២៨ ( មេរៀនទី ២៧ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–៨៣)

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ គឺជាវិវរណៈដំបូងនៅក្នុងទីក្រុងណៅវូ រដ្ឋអិលលីណោយ ដែលត្រូវបានបោះពុម្ពនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។ នៅពេលសិស្សបានសិក្សាការបញ្ជារបស់ព្រះអម្ចាស់ ឲ្យសាងសង់ព្រះវិហារបរិសុទ្ធនៅក្នុងទីក្រុងណៅវូ នោះពួកគេបានរៀនថាព្រះវិហារបរិសុទ្ធ គឺជាកន្លែងតែមួយគត់ដែលយើងអាចទទួលបានភាពពោរពេញ នៃពិធីបរិសុទ្ធនៃបព្វជិតភាពសម្រាប់សេចក្ដីប្រោសលោះដល់អ្នកនៅរស់ និង អ្នកស្លាប់ ។ ពួកគេបានឃើញថា តាមរយៈការគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងបង្ហាញពីភាពស្មោះត្រង់របស់យើង ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–១២៦)

នៅពេលសិស្សបញ្ចប់ការសិក្សារបស់ខ្លួនអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤, នោះពួកគេបានរៀនថា ប្រសិនបើពួកគេស្ដាប់តាមការទូន្មានរបស់ព្យាការី នោះវាជាការណ៍ល្អជាមួយនឹងយើង ហើយថាព្រះអម្ចាស់ហៅពួកអ្នកដឹកនាំបព្វជិតភាពដើម្បីគ្រប់គ្រងកិច្ចការនៃការបម្រើ ហើយជួយពួកបរិសុទ្ធឲ្យបានគ្រប់លក្ខណ៍ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥ និង ១២៦, សិស្សបានរៀនថាប្រសិនបើយើងធ្វើការដោយព្យាយាមសម្រាប់ព្រះអម្ចាស់ នោះទ្រង់នឹងទទួលយកការថ្វាយដ៏សុចរិតរបស់យើង ។

### ថ្ងៃទី ៣ ៖(គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១)

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧ និង ១២៨ ត្រូវបានដកស្រង់ចេញពីលិខិតរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ដែលបានសរសេរទៅកាន់ពួកបរិសុទ្ធ ខណៈដែលលោកកំពុងប្ដូរទីលំនៅដើម្បីចៀសវាងពីការចាប់ខ្លួនខុសច្បាប់ដោយមន្ត្រីរដ្ឋមិសសួរី ។ នៅក្នុងកណ្ឌនេះសិស្សបានឃើញថាការទុកចិត្តលើព្រះវរបិតាសួគ៌ អាចជួយយើងឲ្យទប់ទល់នឹងសេចក្ដីទុក្ខលំបាក ហើយថានៅពេលត្រូវបានកត់ត្រាត្រឹមត្រូវនូវពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធដែលយើងធ្វើនៅលើផែនដីនេះ នោះវាកំពុងតែចងភ្ជាប់នៅក្នុងឋានសួគ៌ផងដែរ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥)

អំឡុងពេលសិក្សារបស់ពួកគេនៃខគម្ពីរដែលនៅសល់នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨, នោះសិស្សបានរកឃើញគោលការណ៍ខាងក្រោមទាក់ទងនឹងកិច្ចការព្រះវិហារ ៖ សេចក្ដីសង្គ្រោះដល់មរណជនរបស់យើងគឺចាំបាច់ ហើយសំខាន់ចំពោះសេចក្ដីសង្គ្រោះរបស់យើង ។ បុណ្យជ្រមុជទឹកសម្រាប់មរណជន ជួយតភ្ជាប់យើងជានិរន្តរ៍ជាមួយនឹងជីដូនជីតារបស់យើង ។ កូនសោ អំណាច និង សិទ្ធិអំណាចនៃគ្រាកាន់កាប់ត្រួតត្រាពីមុនៗ ត្រូវបានស្ដារឡើងវិញនៅក្នុងគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នេះ ។ នៅពេលយើងធ្វើកិច្ចការពង្សប្រវត្តិ ហើយទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធសម្រាប់ជីដូនជីតារបស់យើង នោះយើងធ្វើការថ្វាយដង្វាយដោយសុច្ចរិតដល់ព្រះអម្ចាស់ហើយ ។

## សេចក្ដីផ្ដើម

មេរៀននេះផ្ដោតលើ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–២១។ នៅពេលសិស្សសិក្សាខគម្ពីរទាំងនេះ នោះពួកគេនឹងរៀនអំពីយ៉ូសែប និង ហៃរ៉ុម ស្ម៊ីធ ព្រមទាំងតួនាទីរបស់ពួកគេនៅក្នុងការស្ដារឡើងវិញនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–១៤

*ព្រះអម្ចាស់ពន្យល់ពីមូលហេតុដែលទ្រង់បានហៅយ៉ូសែប ស្ម៊ីធ ឲ្យស្ដារដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទឡើងវិញ*

សូមសរសេរពាក្យ *ខ្លាំងក្លា* នៅលើក្ដារខៀន ។ សូមសួរសិស្សថា តើលក្ខណៈអ្វីខ្លះដែលស្របតាមបទដ្ឋានរបស់លោកិយ ដែលត្រូវបានចាត់ទុកថាជាការពិពណ៌នាអំពីមនុស្សដែលខ្លាំងក្លាម្នាក់ ។ នៅពេលសិស្សឆ្លើយ សូមសរសេរចម្លើយពួកគេនៅលើក្ដារខៀនក្រោមពាក្យ *ខ្លាំងក្លា* ។ បន្ទាប់មកសូមសរសេរពាក្យ *ខ្សោយ* នៅលើក្ដារខៀន ។ សូមសួរសិស្សថា តើលក្ខណៈអ្វីខ្លះដែលស្របតាមបទដ្ឋានរបស់លោកិយ ដែលត្រូវបានចាត់ទុកថាជាការពិពណ៌នាអំពីមនុស្សដែលខ្សោយម្នាក់ ។

- តើពិភពលោកព្យាយាមធ្វើឲ្យយុវជន ឬ យុវនារីមានអារម្មណ៍ថាទន់ខ្សោយតាមរយៈបទដ្ឋានរបស់លោកិយតាមរបៀបណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៣ ឲ្យឮៗ ។ បន្ទាប់មកសូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១ ដោយស្ងាត់ស្ងៀម រកមើលថានរណាដែលព្រះអម្ចាស់បានពិពណ៌នាថាជាអ្នកទន់ខ្សោយ ។

- តើយ៉ូសែប ស្ម៊ីធ អាចមានភាពទន់ខ្សោយតាមរបៀបណាខ្លះ នៅពេលលោកត្រូវបានហៅដើម្បីស្ដារដំណឹងល្អឡើងវិញនោះ ?
- យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១, ហេតុអ្វីព្រះអម្ចាស់ហៅមនុស្សទន់ខ្សោយឲ្យធ្វើកិច្ចការរបស់ទ្រង់ ។ ( នៅពេលសិស្សឆ្លើយ សូមសង្ខេបចម្លើយរបស់ពួកគេដោយសរសេរសេចក្ដីពិតស្រដៀងគ្នាទៅនឹងគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បើកបង្ហាញព្រះប្រាជ្ញារបស់ទ្រង់តាមរយៈអ្វីៗដែលទន់ខ្សោយនៃផែនដីនេះ**) ។
- តើព្រះអម្ចាស់បានបើកបង្ហាញព្រះប្រាជ្ញារបស់ទ្រង់តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ តាមរបៀបណាខ្លះ ?

សូមឲ្យសិស្សប្រាប់ពីការហៅបម្រើ និង ការចាត់តាំងមួយចំនួនដែលពួកគេអាចទទួល អំឡុងពេលពួកគេនៅក្នុងភាពជាយុវវ័យ ។ ( ចម្លើយអាចរួមមាន គ្រូបង្រៀនតាមផ្ទះ សមាជិកនៃថ្នាក់ ឬ គណៈប្រធានកូរ៉ុម អ្នកផ្សព្វផ្សាយសាសនា និយាយនៅក្នុងការប្រជុំសាក្រាម៉ង់ ឬ ស្វាគមន៍នរណាម្នាក់នៅក្នុងវួដ ឬ សាខារបស់ពួកគេ ) ។

- តើការចងចាំពីគោលការណ៍ដែលបានសរសេរលើក្ដារខៀននេះ អាចជួយយើងដូចម្ដេចខ្លះ នៅពេលយើងទទួលការហៅ និង ការចាត់តាំងផ្សេងៗដើម្បីបម្រើនៅក្នុងសាសនាចក្រ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២–១៤ ដោយពន្យល់ថា ព្រះអម្ចាស់បានបញ្ជាឲ្យយ៉ូសែប ស្ម៊ីធសរសេរសេចក្ដីប្រកាសនៃដំណឹងល្អដល់អ្នកដឹកនាំនានានៃផែនដី ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៥–២១

*ព្រះអម្ចាស់ប្រទានការណែនាំដល់អ្នកដឹកនាំសាសនាចក្រនៅក្នុងទីក្រុងណៅវូ*

សូមឲ្យសិស្សគិតអំពីគ្រាមួយដែលមាននរណាម្នាក់បានសរសើរពួកគេដោយស្មោះសរ ។ សូមអញ្ជើញសិស្សឲ្យពីរបីនាក់ចែកចាយបទពិសោធន៍ និង មូលហេតុនៃការសរសើរទាំងនេះមានអត្ថន័យចំពោះពួកគេ ។

សូមពន្យល់ថាព្រះអម្ចាស់បានមានបន្ទូលពីបុគ្គលមួយចំនួននៅក្នុងវិវរណៈនេះ ហើយបានបញ្ជាពួកគេដោយចង្អុលបង្ហាញពីកម្លាំង និង ការរួមចំណែករបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៥–២០ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីបុគ្គលទាំងនេះ ។ អ្នកអាចស្នើឲ្យពួកគេគូសចំណាំឃ្លាណាដែលលេចធ្លោចំពោះពួកគេ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបែរទៅរកដៃគូរបស់ខ្លួន ហើយចែកចាយចាយអ្វីដែលពួកគេបានរកឃើញ ដោយបញ្ចូលឃ្លាដែលលេចធ្លោចំពោះពួកគេ និង ហេតុផលរបស់វា ។

អ្នកអាចចង្អុលបង្ហាញថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៩ ព្រះអម្ចាស់បានប្រកាសថាបុរសស្មោះត្រង់បីរូប ដែលទើបនឹងស្លាប់ ( ដាវីឌ ដឹបុលយូ ប៉ាទិន អែតវិត ប៉ាទ្រិច និង យ៉ូសែប ស៊្មីធ ស៊ីញ៉រ ឪពុករបស់ព្យាការី ) ត្រូវបានទទួលឲ្យចូលទៅក្នុងវត្តមានរបស់ព្រះអម្ចាស់ហើយ ។

សូមអញ្ជើញសិស្សឲ្យរំពឹក គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៥, ២០, រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីហៃរ៉ុម ស៊្មីធ និង ចច មីលលើ ។

- តើព្រះអម្ចាស់បានមានបន្ទូលអ្វីខ្លះអំពីហៃរ៉ុម ស៊្មីធ និង ចច មីលលើ ?
- តើព្រះអម្ចាស់មានព្រះទ័យដូចម្ដេច ចំពោះអស់អ្នកដែលមានសេចក្ដីទៀងត្រង់នោះ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញសេចក្ដីពិតខាងក្រោម ៖ **ព្រះអម្ចាស់សព្វព្រះទ័យ ហើយទុកព្រះទ័យលើអស់អ្នកដែលមានសេចក្ដីទៀងត្រង់នៃចិត្ត**) ។
- តើអ្នកឲ្យនិយមន័យនៃពាក្យសេចក្ដីទៀងត្រង់នៃចិត្តដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ដោយអែលឌើរ យ៉ូសែប ប៊ី វីតលីន នៃកូរ៉ុមនៃពួកសាវក ដប់ពីរនាក់ឲ្យឮៗ ៖



« ចំពោះខ្ញុំសេចក្ដីទៀងត្រង់មានន័យថា ត្រូវធ្វើអ្វីដែលត្រឹមត្រូវ និង ល្អជានិច្ចមិនថាកើតមានលទ្ធផលភ្លាមៗយ៉ាងណានោះទេ ។ វាមានន័យថាត្រូវមានសេចក្ដីសុចរិតចេញពីជម្រៅនៃដួងព្រលឹងរបស់យើង មិនមែនគ្រាន់តែការប្រព្រឹត្តនោះទេ ប៉ុន្តែអ្វីដែលសំខាន់នោះគឺ ក្នុងគំនិត និង ក្នុងដួងចិត្តរបស់យើង ។ សេចក្ដីទៀងត្រង់ផ្ទាល់ខ្លួនបញ្ជាក់ពីការទុកចិត្ត និង បរិសុទ្ធភាពនោះ ដែលយើងមិនអាចត្រូវបានបោកបញ្ឆោតឲ្យទុកចិត្ត ឬ ធ្វើសេចក្ដីសញ្ញាឡើយ » (« Personal Integrity » *Ensign*, ខែ ឧសភា ឆ្នាំ ១៩៩០ ទំព័រ ៣០ ) ។

- ដោយផ្ដែកលើនិយមន័យរបស់អែលឌើរ វីតលីន ហេតុអ្វីអ្នកគិតថាព្រះអម្ចាស់សព្វព្រះទ័យដល់អស់អ្នកដែលមានសេចក្ដីទៀងត្រង់នៃចិត្ត ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលហៃរ៉ុម ស៊្មីធ បានធ្វើជាគំរូនៃសេចក្ដីទៀងត្រង់នៃចិត្ត សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ អិម រ័សុល បាឡឺដនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ហៃរ៉ុម ស៊្មីធ ជាបងប្រុស ជាមិត្ត និង ជាអ្នកផ្ដល់យោបល់ដល់ព្យាការី បានបង្ហាញភាពពិតទាំងស្រុងសេចក្ដីស្រឡាញ់ ភាពស្មោះត្រង់ និង ភក្ដីភាពចំពោះព្រះអម្ចាស់ដែលពុំអាចថ្លែងបាន និង ចំពោះប្អូនប្រុសរបស់ខ្លួនគឺ យ៉ូសែប ។ ភាពជាបងប្អូនរបស់ពួកគេពុំមាននរណាល្អជាងនរណាឡើយ ។. . .

« យ៉ូសែប បានមានប្រសាសន៍ពី ហៃរ៉ុម ថា ‹ ខ្ញុំចង់អធិស្ឋាននៅក្នុងដួងចិត្តរបស់ខ្ញុំថាបងប្អូនប្រុសរបស់ខ្ញុំទាំងអស់ ដូចជាបងប្រុសជាទីស្រឡាញ់របស់ខ្ញុំហៃរ៉ុម ដែលមាននូវភាពទន់ភ្លន់នៃកូនចៀម និង សេចក្ដីទៀងត្រង់នៃយ៉ូប និង និយាយជារួម មានភាពស្លូតបូត និង ភាពរាបទាបនៃព្រះគ្រីស្ទ ហើយខ្ញុំស្រឡាញ់គាត់ជាមួយនឹងសេចក្ដីស្រឡាញ់នោះគឺខ្លាំងជាងសេចក្ដីស្លាប់ទៅទៀត ដ្បិតខ្ញុំពុំដែលធ្លាប់មានពេលស្ដីបន្ទោសគាត់ ហើយគាត់ក៏ពុំដែលស្ដីបន្ទោសខ្ញុំផងដែរ › ។ *History of the Church*, ២:៣៣៨ ) ។. . .

« ហៃរ៉ុមពុំដែលរារែកឡើយ សូម្បីតែប្រឈមមុខនឹងសេចក្ដីស្លាប់ ។ បន្ទាប់ពីការបង្អត់អាហារ និង ការបៀតបៀនមួយរយៈពេលដ៏យូរមក គាត់បានសរសេរ ៖

« ‹ ខ្ញុំសូមថ្លែងអំណរគុណព្រះថា ខ្ញុំមានអារម្មណ៍ថាការសម្រេចចិត្តដើម្បីស្លាប់ ជាជាងបដិសេធនូវអ្វីៗដែលភ្នែករបស់ខ្ញុំបានឃើញ ដែលដៃរបស់ខ្ញុំបានកាន់ [ ផ្ទាំងដែលត្រូវបានបកប្រែទៅជាព្រះគម្ពីរមរមន ] និង អ្វីដែលខ្ញុំបានថ្លែងទីបន្ទាល់ ទោះបីជាខ្ញុំត្រូវចាត់ទៅទីណាក៏ដោយ ហើយខ្ញុំអាចអះអាងជាមួយបងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំថា ខ្ញុំអាចថ្លែងទីបន្ទាល់ដែលវាជាទីបន្ទាល់ដ៏រឹងមាំដែលខ្ញុំធ្លាប់ថ្លែងនៅក្នុងជីវិតខ្ញុំ › ។ (*Times and Seasons,* ខែ ធ្នូ ឆ្នាំ ១៨៣៩ ទំព័រ ២៣ ) » ។ (« The Family of the Prophet Joseph Smith » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៧ ) ។

- តើហៃរ៉ុម ស្ម៊ីធបានបង្ហាញសេចក្ដីទៀតត្រង់របស់ខ្លួនតាមរបៀបណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីផ្នែកមួយនៃជីវិតរបស់ខ្លួន ដែលពួកគេអាចមានសេចក្ដីទៀងត្រង់កាន់តែច្រើនឡើង ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅផ្ទាល់ខ្លួនមួយ ដើម្បីបង្កើនសេចក្ដីទៀងត្រង់នៅក្នុងចំណុចនោះ ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នក អំពីគោលការណ៍នានាដែលបានបង្រៀននៅថ្ងៃនេះ ។

### មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩–១៣២)

សូមសួរសិស្ស ប្រសិនបើពួកគេស្គាល់ពីកម្រិតនានាដែលមាននៅក្នុងនគរសេឡេស្ទាល ។ សូមពន្យល់ថានៅក្នុងការសិក្សានៅសប្ដាហ៍បន្ទាប់ ពួកគេនឹងឃើញពីគោលការណ៍មួយចំនួនដែលទាក់ទងនឹងនគរសេឡេស្ទាល និង ផែនការនៃសេចក្ដីសង្គ្រោះ ។

មេរៀនទី ១៣៦

# គោលលទ្ធិ និង សេចក្តីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣

## បុព្វកថា

នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានផ្តល់ការណែនាំដើម្បីជួយពួកបរិសុទ្ធឲ្យដឹងពីរបៀបខុសប្លែកគ្នានៃលក្ខណៈនៃការបម្រើរបស់ពួកទេវតា និង វិញ្ញាណទាំងឡាយ ។ សេចក្តីណែនាំទាំងនេះត្រូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និងសេចក្តីសញ្ញា ១២៩ ។ គោលលទ្ធិ និង សេចក្តីសញ្ញា ១៣០ មាន ការបង្រៀនរបស់ព្យាការីយ៉ូសែប ស្ម៊ីធ អំពីគោលលទ្ធិផ្សេងៗខណៈដែលលោកកំពុងជួបពួកបរិសុទ្ធនៅ រ៉ាម៉ូស រដ្ឋ អិលលីណោយ នៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៨៤៣ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ១២៩

*ព្យាការី យ៉ូសែប ស្ម៊ីធ បានផ្តល់ការណែនាំអំពីលក្ខណៈនៃការបម្រើរបស់ពួកទេវតា និង វិញ្ញាណទាំងឡាយ ។*

សូមសួរសិស្សថា តើពួកគេនឹងប្រាប់អ្វីខ្លះដល់នរណាម្នាក់ដែលចង់ដឹងថា តើពួកបរិសុទ្ធថ្ងៃចុងក្រោយជឿលើពួកទេវតាឬទេ ។ បន្ទាប់ពីសិស្សឆ្លើយហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជេហ្វ្រី អ័រ.ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ចាប់តាំងពីការចាប់ផ្តើម រហូតមកដល់គ្រប់ការកាន់កាប់ត្រួតត្រាទាំងអស់ ព្រះបានប្រើពួកទេវតាជាអ្នកផ្សព្វផ្សាយរបស់ទ្រង់នៅក្នុងការបង្ហាញសេចក្តីស្រឡាញ់ និង ការខ្វល់ខ្វាយចំពោះកូនចៅរបស់ទ្រង់ ។. . .

« ជាទូទៅទេវតាទាំងនោះគឺមនុស្សមើល *មិន* ឃើញឡើយ ។ ពេលខ្លះមើលឃើញ ។ ប៉ុន្តែទោះបីឃើញ ឬ មិនឃើញក្តីពួកគេគឺ *តែង* នៅក្បែរជានិច្ច ។ ពេលខ្លះការចាត់តាំងរបស់ពួកគេគឺធំអស្ចារ្យ ហើយមានសារៈសំខាន់ចំពោះពិភពលោកទាំងមូល ។ ពេលខ្លះ សារលិខិតនោះគឺសម្ងាត់ណាស់ ។ យូរៗម្តងគោលបំណងនៃពួកទេវតាគឺដើម្បីព្រមាន » (The Ministry of Angels » *Ensign* ឬ *Liahona*,  ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២៩ ) ។

សូមពន្យល់ថានៅដើមឆ្នាំ ១៨៣៩ និង បន្តរហូតដល់ ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានផ្តល់ការណែនាំដល់មនុស្សជាច្រើនដើម្បីជួយឲ្យពួកគេដឹងពីភាពខុសប្លែកគ្នាអំពីលក្ខណៈនៃការបម្រើរបស់ពួកទេវតា និង វិញ្ញាណទាំងឡាយ ។ ការណែនាំមួយចំនួនត្រូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១២៩ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២៩:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលចំណុចសំខាន់ផ្សេងគ្នាមួយរវាងពួកទេវតា និង វិញ្ញាណទាំងឡាយ ។ ( អ្នកអាចពន្យល់ថាពាក្យ *សុចរិត* មានន័យថាពួកអ្នកសុចរិត ) ។

- តើពួកទេវតាខុសពីវិញ្ញាណទាំងឡាយដូចម្តេច ? ( ពួកទេវតាមានរូបកាយរស់ឡើងវិញជាសាច់ និង ឆ្អឹង វិញ្ញាណទាំងឡាយពុំមានរូបកាយជាសាច់ និង ឆ្អឹងឡើយ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២៩:៤–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបមួយដើម្បីដឹងពីភាពខុសគ្នារវាងពួកទេវតា និង វិញ្ញាណសុចរិតទាំងឡាយ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើយើងរៀនអ្វីខ្លះពី ខ ៧ អំពីលក្ខណៈពិតនៃសារទូតដែលបានបញ្ជូនមកពីព្រះវរបិតាសួគ៌ ? ( បន្ទាប់ពីសិស្សឆ្លើយហើយ អ្នកអាចស្នើឲ្យពួកគេសរសេរគោលលទ្ធិខាងក្រោមនេះនៅគែមព្រះគម្ពីររបស់ពួកគេ ៖ **សារទូតពិតដែលបានបញ្ជូនមកពីព្រះវរបិតាសួគ៌នឹងមិនបោកប្រាស់យើងឡើយ**) ។

សូមពន្យល់ថា ពេលខ្លះអារក្សព្យាយាមក្លែងខ្លួនជា « ទេវតានៃពន្លឺ » ដើម្បីបោកប្រាស់មនុស្ស ( សូមមើល គ. និង ស ១២៩:៨) ។ លើសពីនោះ« ព្រះគម្ពីរបាននិយាយផងដែរអំពីទេវតានៃអារក្ស ។ ទាំងនោះគឺជាពួកវិញ្ញាណដែលបានធ្វើតាមលូស៊ីហ្វើ ហើយត្រូវបានបណ្ដេញចេញពីវត្តមានរបស់ព្រះនៅក្នុងជីវិតមុនឆាកជីវិតនេះ ហើយដេញចុះមកលើផែនដីនេះ (វិវរណៈ ១២:១–៩; នីហ្វៃ ទី ២ ៩:៩, ១៦; គ. និង ស. ២៩:៣៦–៣៧) » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ពួកទេវតា » scriptures.lds.org ) ។ សូមកុំនិយាយពី បទពិសោធន៍ទាក់ទងនឹងសាតាំង ឬ វិញ្ញាណអាក្រក់ ឬ ធ្វើឲ្យការពិភាក្សាដែលបង្កើតឲ្យមានការទាក់ទងនឹង រឿងដែលបំផ្លើស និង អ្វីដែលកុហកឡើយ ។

> *ចៀសវាងពីការដកស្រង់ ឬ រឿងដែលបំផ្លើស ឬ កុហក*
>
> យូរៗម្ដងការដកស្រង់ ឬ រឿងដែលបំផ្លើស ( មិនពិត ) ឬ កុហក មាននៅក្នុងចំណោមសមាជិកសាសនាចក្រ ។ វាសំខាន់ដើម្បីទទួលស្គាល់ថាព្រះវិញ្ញាណពុំថ្លែងទីបន្ទាល់ពីអ្វីដែលពុំពិត ឬ ពុំត្រឹមត្រូវឡើយ ។ នៅពេលអ្នកបង្រៀន សូមឲ្យព្រះវិញ្ញាណបរិសុទ្ធនាំសិស្សទៅកាន់ព្រះគ្រីស្ទ មិនមែនដំណើរឿងបំផ្លើសឡើយ ។ សូមចៀសវាងពីការពិភាក្សាពីរឿងដែលមិនស្គាល់ ឬ លើកតម្កើងគ្នាឡើង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩:៨–៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដើម្បីទទួលស្គាល់វិញ្ញាណអាក្រក់ដែលស្វែងរកបោកប្រាស់ដោយការក្លែងខ្លួនជាទេវតានៃពន្លឺ ។ ( សូមពន្យល់ថាពាក្យ *ចាត់ចែង* នៅក្នុង ខ ៩ សំដៅលើការបង្ហាញ ឬ ការមកជួបពីទេវតា ឬ វិញ្ញាណ ) ។ សូមអញ្ជើញសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។

- បន្ថែមពីលើសេចក្ដីណែនាំនៅក្នុងខគម្ពីរទាំងនេះ តើព្រះវរបិតាសួគ៌បានប្រទានអ្វីទៀតដល់អ្នកដើម្បីជួយអ្នកឲ្យដឹងពីការបោកប្រាស់របស់សាតាំង ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១–១១, ២២–២៣

*ព្យាការី យ៉ូសែប ស៊្មីធ បានបញ្ជាក់ពីគោលលទ្ធិផ្សេងៗ*

សូមពន្យល់ថានៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៨៤៣ យ៉ូសែប ស៊្មីធ បានប្រារព្ធធ្វើសន្និសីទស្តេកជាមួយពួកបរិសុទ្ធនៅ រ៉ាមូស រដ្ឋអិលលីណោយ ដែលមានចម្ងាយ២០ ម៉ែលភាគអាគ្នេយ៍នៃទីក្រុងណៅវូ ។ អំឡុងការប្រជុំពេលព្រឹក អែលឌើរ អូរសុន ហៃឌ បានផ្សព្វផ្សាយទេសកថាមួយ ហើយបានបង្រៀនការបកស្រាយព្រះគម្ពីរដែលលោកបានរៀនកាលពីមុនជាមួយព្រះវិហារផ្សេង ។

- តើ ទំនួលខុសត្រូវអ្វីខ្លះដែលព្យាការីបានមាននៅក្នុងស្ថានភាពនេះ ? ( កែប្រែគោលលទ្ធិក្លែងក្លាយដែលបានបង្រៀននៅក្នុងការប្រជុំ ) ។

សូមពន្យល់ថាថ្នាក់ដឹកនាំជាអធិបតីនៅក្នុងសាសនាចក្រដូចជាព្យាការី ប្រធានស្តេក និង ប៊ីស្សពមានទំនួលខុសត្រូវដើម្បីប្រាកដថាគោលលទ្ធិត្រឹមត្រូវត្រូវបានបង្រៀននៅក្នុងការប្រជុំសាសនាចក្រ ។ បន្ទាប់ការប្រជុំនៅពេលព្រឹក យ៉ូសែប ស៊្មីធ អូរសុន ហៃឌ នឹងមនុស្សពីរបីនាក់ផ្សេងទៀត បានទទួលទានអាហារថ្ងៃត្រង់នៅផ្ទះរបស់ប្អូនស្រីយ៉ូសែប ស៊្មីធ សុហ្វ្រូនៀ ។ អំឡុងពេលអាហារថ្ងៃត្រង់នោះព្យាការីបាននិយាយថាលោក « នឹងផ្ដល់ការកែតម្រូវមួយចំនួនចំពោះការបង្រៀនរបស់ [ បងប្រុស ហៃឌ ] » ។ បងប្រុស ហៃឌ បានឆ្លើយថា « ពួកគេនឹងទទួលដោយអំណរគុណ » ( នៅក្នុង History of the Church, ៥:៣២៣ ) ។

- តើយើងអាចរៀនអ្វីខ្លះពីរបៀបដែលយ៉ូសែប ស៊្មីធ បានដោះស្រាយក្នុងស្ថានភាពនោះ ?

- តើយើងអាចរៀនអ្វីខ្លះមកពីការឆ្លើយតបរបស់អូរសុន ហៃឌចំពោះព្យាការី ?

សូមពន្យល់ថានៅក្នុងការនិយាយនាព្រឹកនោះ អូរសុន ហៃឌ បានបកស្រាយខុសនូវខគម្ពីរ យ៉ូហាន ១៤:២៣ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរនោះឲ្យឮៗ ។

សូមប្រាប់សិស្សក្នុងថ្នាក់ថា បន្ទាប់ពីអូរសុន ហៃឌបាននិយាយពីខគម្ពីរនេះហើយ លោកបានប្រាប់មនុស្សថា វាគឺជា « ឯកសិទ្ធិរបស់យើងដើម្បីមានព្រះវរបិតា និង ព្រះរាជបុត្រាគង់នៅក្នុងដួងចិត្តរបស់យើង » ( នៅក្នុង History of the Church, ៥:៣២៣ ) ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ មានការកែប្រែរបស់យ៉ូសែប ស៊្មីធអំពីគំនិតនេះ ។ វាក៏មានការបង្រៀនបន្ថែមមួយចំនួនទៀតផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ហើយរកមើលអ្វីដែលជាសេចក្ដីថ្លែងការណ៍របស់អូរសុន ហៃឌទាក់ទងនឹងអត្ថន័យនៃគម្ពីរ យ៉ូហាន ១៤:២៣ គឺខុសឆ្គង ។ សូមឲ្យពួកគេរាយការណ៍អ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថាមនុស្សជាច្រើនសព្វថ្ងៃនេះទោះបីជាពុំគិតអំពីព្រះ ឬ ប្រហែលជាដូចជា អូរសុន ហៃឌ ដែលធ្លាប់ជាគ្រូបង្រៀនពួកខេមប៊ែលីតមានការយល់ដឹងខុសពីលក្ខណៈនៃអទិទេព ដោយសារតែទំនៀមទម្លាប់ក្លែងក្លាយនានា ។ យើងអាចជួយមនុស្សដទៃឲ្យយល់ពីលក្ខណៈពិតរបស់ព្រះវរបិតាសួគ៌ និង ទំនាក់ទំនងរបស់ពួកគេទៅកាន់ទ្រង់ ។

- តើយើងអាចឆ្លើយតបដោយសេចក្ដីសប្បុរស និង ការយល់ដឹង នៅពេលពិភាក្សាពីដំណឹងល្អជាមួយអស់អ្នកដែលមានគំនិតខុសឆ្គងដោយសារទំនៀមទម្លាប់ខុសឆ្គងដូម្ដេចខ្លះ?

សូមអញ្ជើញសិស្សម្នាក់ឲ្យ អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២–២៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលគោលលទ្ធិដែលពួកគេអាចពន្យល់នៅពេលបង្រៀនមនុស្សដទៃអំពីក្រុមព្រះ ។

- តើគោលលទ្ធិអ្វីខ្លះដែលត្រូវបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ? ( សិស្សគួរតែរកឃើញពីគោលលទ្ធិខាងក្រោម ៖ **ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ជាអង្គពីរផ្សេងគ្នាដោយមានរូបរាងកាយជាសាច់ និងឆ្អឹង ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាតួអង្គវិញ្ញាណ**) ។

- ហេតុអ្វីអ្នកគិតថាវាសំខាន់ដើម្បីយល់ថាព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ជាតួអង្គពីរខុសគ្នាដោយមានរូបរាងកាយជាសាច់ និងឆ្អឹង ?

ដើម្បីជួយសិស្សឲ្យយល់បន្ថែមពីគោលលទ្ធិនៃក្រុមព្រះ សូមចាត់តាំងពួកគេឲ្យធ្វើការជាគូ ។ សូមឲ្យដៃគូនិមួយៗ នូវ សេចក្ដីថ្លែងការណ៍ខាងក្រោម ។ សូមអញ្ជើញពួកគេឲ្យសិក្សាសេចក្ដីថ្លែងនោះជាមួយដៃគូខ្លួន ហើយគូសបន្ទាត់ពីក្រោមសេចក្ដីពិតនានាអំពីព្រះបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធដែលលេចធ្លោចំពោះពួកគេ ។

> *ព្រះជាព្រះវរបិតា* ៖ជាទូទៅគឺជាព្រះវរបិតា ឬ អ៊ីឡូហិម ដែលត្រូវបានហៅថាដោយព្រះនាមព្រះ ។ ទ្រង់ត្រូវបានហៅថាជាព្រះវរបិតាដោយសារទ្រង់គឺជាព្រះវរបិតាខាងវិញ្ញាណរបស់យើង ។. . . ព្រះវរបិតាគឺជាអង្គគ្រប់គ្រងដ៏ខ្ពស់បំផុតនៃសាកលលោកនេះ ។ ទ្រង់មានព្រះចេស្ដាទាំងអស់. . .ជ្រាបដឹងអ្វីៗទាំងអស់. . .ហើយទ្រង់មានវត្តមានគ្រប់ទីន្លែងតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ ។. . . មនុស្សមានទំនាក់ទំនងពិសេសជាមួយព្រះដែលបានញែកមនុស្សចេញពីការបង្កើតអ្វីៗផ្សេងទៀតទាំងអស់ ៖ បុរស និង ស្ត្រីគឺជាបុត្រាបុត្រីខាងវិញ្ញាណរបស់ព្រះ ។. . .
>
> «*ព្រះដែលជាព្រះរាជបុត្រា* ៖ព្រះដែលបានស្គាល់ថាជាព្រះយេហូវ៉ា គឺជាព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ ។. . . ព្រះយេស៊ូវធ្វើការក្រោមការដឹកនាំរបស់ព្រះវរបិតា ហើយចុះសម្រុងទាំងស្រុងជាមួយទ្រង់ ។ មនុស្សលោកទាំងអស់គឺជាបងប្អូនប្រុសស្រីរបស់ទ្រង់ ដ្បិតទ្រង់គឺជាកូនច្បងខាងវិញ្ញាណរបស់ អេឡូហិម ។ [ ទ្រង់គឺជាអង្គប្រោសលោះ ដែលរងទុក្ខនៃអំពើបាប និង ការឈឺចាប់របស់មនុស្សលោកទាំងអស់ ហើយបានយកឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយសម្រាប់មនុស្សទាំងអស់ ] ។. . .
>
> «*ព្រះដែលជាព្រះវិញ្ញាណបរិសុទ្ធ* ៖ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះមួយអង្គផងដែរ ហើយត្រូវបានហៅថា ព្រះវិញ្ញាណបរិសុទ្ធ ព្រះវិញ្ញាណ ព្រះវិញ្ញាណនៃព្រះ ក្នុងចំណោមឈ្មោះ និង ព្រះនាមស្រដៀងនេះ [ មានដូចជា អង្គលួងលោម ] ។ ដោយមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធ មនុស្សអាចដឹងពីព្រះឆន្ទៈរបស់ព្រះជាព្រះវរបិតា ហើយដឹងថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះ ក្រុមព្រះ » scriptures.lds.org) ។ តួនាទីចម្បងរបស់ព្រះវិញ្ញាណបរិសុទ្ធគឺដើម្បីថ្លែងទីបន្ទាល់អំពីព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ ។ ព្រះវិញ្ញាណបរិសុទ្ធបង្រៀន និងបញ្ជាក់ពីសេចក្ដីពិត ។

បន្ទាប់ពីសិស្សបានបំពេញការចាត់តាំងនេះរួចមក សូមឲ្យពួកគេមួយចំនួនរាយការណ៍ពីអ្វីដែលពួកគេបានគូស ហើយពន្យល់ពីមូលហេតុដែលសេចក្ដីពិតទាំងនោះលេចធ្លោចំពោះពួកគេ ។ អ្នកអាចបញ្ចប់សកម្មភាពនេះដោយអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីក្រុមព្រះជាមួយសិស្សក្នុងថ្នាក់ ។

ដើម្បីជួយសិស្សឲ្យរកឃើញគោលលទ្ធិមួយទៀតដែលយ៉ូសែប ស្ម៊ីធ បានបង្រៀនដល់ពួកបរិសុទ្ធនៅក្នុង រ៉ាមូស សូមអញ្ជើញពួកគេឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២, រកមើលអ្វីដែលលោកបានមានប្រសាសន៍អំពីទំនាក់ទំនងរបស់យើង ។

- តើពាក្យថា *ទំនាក់ទំនង* មានន័យយ៉ាងណា ? ( ទំនាក់ទំនងសំដៅលើលក្ខណៈនៃការប្រាស្រ័យគ្នា និង ការទាក់ទងផ្ទាល់ខ្លួន ) ។

- តើព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនអ្វីទាក់ទងនឹងលក្ខណៈនៃទំនាក់ទំនងរបស់យើងនៅក្នុងឋានសួគ៌ ? ( សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញសេចក្ដីពិតខាងក្រោម ៖ **ទំនាក់ទំនងដែលយើងអាចមាននៅក្នុងឋានសួគ៌គឺដូចគ្នាទៅនឹងទំនាក់ទំនងទាំងអស់ដែលយើងរីករាយនៅលើផែនដីនេះ ប៉ុន្តែវានឹងរួមបញ្ចូលជាមួយសិរីរុងរឿងនៃភាពអស់កល្បជានិច្ច**) ។

- តើសេចក្ដីពិតនេះអាចជម្រុញឲ្យអ្នកមានការប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃទៀតយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមអំពីទំនាក់ទំនងអស់កល្បជានិច្ចដោយប្រធាន ហិនរី ប៊ី អាវរិង នៃ គណៈប្រធានទីមួយឲ្យឮៗ ៖



« ដោយសារការស្ដារឡើងវិញនៃចំណេះដឹងអំពីក្រុមគ្រួសារអស់កល្បជានិច្ច នោះយើងមានសង្ឃឹម និង មានចិត្តសប្បុរសកាន់តែច្រើននៅក្នុងទំនាក់ទំនងគ្រួសាររបស់យើងទាំងអស់ ។ សេចក្ដីអំណរដ៏អស្ចារ្យបំផុតនៅក្នុងជីវិតនេះគឺនៅក្នុងក្រុមគ្រួសារ នៅពេលពួកគេនឹងនៅក្នុងពិភពខាងមុខទៀត ។ ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះការអះអាងដែលខ្ញុំមាន បើសិនយើងស្មោះត្រង់ នោះទំនាក់ទំនងដដែរនោះដែលរីករាយនៅទីនេះនៅក្នុងជីវិតនេះ នឹងបន្តនៅអស់កល្បជាមួយយើងនៅក្នុងពិភពខាងមុខនៅក្នុងសិរីរុងរឿងដ៏អស់កល្ប » [ សូមមើល គ. និង ស ១៣០:២] (The True and Living Church » *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ២២ ) ។

សូមអញ្ជើញសិស្សឲ្យគិតពីទំនាក់ទំនងរបស់ពួកគេជាមួយមនុស្សដទៃ ជាពិសេសជាមួយសមាជិកគ្រួសារពួកគេ ។ សូមអញ្ជើញពួកគេឲ្យសរសេរគោលដៅមួយដើម្បីពង្រឹងទំនាក់ទំនងទាំងនោះ ។

ដើម្បីជួយសិស្សរកឃើញគោលលទ្ធិផ្សេងទៀតដែលព្យាការីបានបង្រៀននៅពេលប្រជុំនៅ រ៉ាមូស សូមអញ្ជើញសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:៤–១១ ឲ្យឮៗ ។

- តើយើងរៀនអ្វីខ្លះអំពីពួកទេវតាពី ខ ៤–៧ ?
- តើយើងរៀនអ្វីខ្លះពី ខ ៩ អំពីអនាគតរបស់ផែនដី ?

អ្នកអាចពន្យល់ថាយោងតាម ខ ១០–១១, អស់អ្នកដែលគ្រងមរតកនៃនគរសេឡេស្ទាលនឹងទទួល យូរីម និង ធូមីម មួយដើម្បីជួយពួកគេឲ្យរៀន និង យល់អំពីអ្វីៗនៃឋានសួគ៌ ។ ព្យាការីពុំបានបរិយាយល្អិតល្អន់អំពីការបង្រៀននេះឡើយ ។

មេរៀនទី ១៣៧

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១

## បុព្វកថា

មេរៀននេះមានគោលលទ្ធិដែល យ៉ូសែប ស្ម៊ីធបានបង្រៀននៅក្នុងការប្រជុំសាសនាចក្រមួយនៅរ៉ាមូស រដ្ឋ អិលលីណោយ នៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៨៤៣ ។ ការបង្រៀនទាំងនេះបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ ។ ព្យាការីបានបង្រៀនអំពីព្រឹត្តិការណ៍នាពេលអនាគត រួមទាំងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកក៏បានបង្រៀនពួកគេអំពីសមត្ថភាពរបស់យើង ដើម្បីរក្សាចំណេះដឹង និង បញ្ញាបន្ទាប់ពីយើងស្លាប់ទៅ ហើយបានពន្យល់ពីរបៀបដែលយើងអាចទទួលពរជ័យរបស់ព្រះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–១៧

*យ៉ូសែប ស្ម៊ីធ បង្រៀនអំពីការយាងមកជាលើកទីពីរ*

ពីមុនរៀន សូមសរសេរសេចក្ដីថ្លែងការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ *មនុស្សជាច្រើនបានឆ្ងល់អំពីកាលបរិច្ឆេទជាក់លាក់នៃការយាងមកជាលើកទីពីរ ។*

- តើអ្នកធ្លាប់ ចង់ដឹងជាក់លាក់ពីពេលនៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទដែរឬទេ ?

សូមពន្យល់ថានៅសម័យយ៉ូសែប ស្ម៊ីធ អ្នកផ្សព្វផ្សាយគ្រិស្តសាសនាល្បីល្បាញម្នាក់ឈ្មោះ វីល្លាម មីលល័រ បានប្រកាសអំពីការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះនឹងកើតឡើងនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៨៤៣ ។ មួយថ្ងៃមុនកាលបរិច្ឆេទនៃការព្យាករណ៍របស់មីលល័រអំពីការយាងមកជាលើកទីពីរ ព្យាការីយ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ទៅកាន់ពួកបរិសុទ្ធនៅរ៉ាមូស រដ្ឋ អិលលីណោយ ហើយបានបញ្ជាក់ថា លោកបានអធិស្ឋានដើម្បីដឹងពីពេលនៃការយាងមកជាលើកទីពីរ ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៤–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលយ៉ូសែប ស្ម៊ីបានរៀននៅពេលលោកបានអធិស្ឋានអំពីពេលវេលានៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

- តើព្រះអម្ចាស់បានបើកសម្ដែងដល់យ៉ូសែប ស្ម៊ីធ អំពីកាលបរិច្ឆេទច្បាស់លាស់អំពីការយាងមកជាលើកទីពីរដែរឬទេ ?
- តើព្រះអម្ចាស់បានប្រាប់ឲ្យ យ៉ូសែប ស្ម៊ីធធ្វើអ្វីខ្លះ ? ( បន្ទាប់ពីសិស្សឆ្លើយហើយ អ្នកអាចផ្ដល់យោបល់ឲ្យពួកគេគូសចំណាំឃ្លា « សូមកុំរំខានយើងពីការណ៍នេះទៀតឡើយ » នៅក្នុងបទគម្ពីររបស់ពួកគេ ។ សូមពិចារណានាំសិស្សមើលលេខយោងនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៥ *ក* ដើម្បីគូសបញ្ជាក់បន្ថែមទៀតថាគ្មាននរណាម្នាក់ដឹងដោយជាក់លាក់ពីពេលវេលាដែលព្រះអង្គសង្គ្រោះនឹងត្រឡប់មកវិញឡើយ ) ។

*បង្កើតឲ្យមានភាពទាក់ទង និង គោលបំណង*

របៀបដ៏មានប្រសិទ្ធភាពមួយដើម្បីជួយសិស្សរៀបចំរៀន គឺចាប់ផ្ដើមថ្នាក់រៀនដោយសូមឲ្យពួកគេសញ្ជឹងគិតអំពីសំណួរ ឬ ស្ថានភាពមួយដែលទាក់ទងនឹងពួកគេ ហើយថានឹងត្រូវបានឆ្លើយតបនៅក្នុងព្រះគម្ពីរមកពីអ្វីដែលអ្នកកំពុងបង្រៀន ។ ចំណុចនេះនឹងជួយសិស្សឲ្យសិក្សាព្រះគម្ពីរដោយមានគោលបំណង ។

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឹដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ខ្ញុំត្រូវបានហៅជាសាវកម្នាក់ដើម្បីធ្វើជាសាក្សីពិសេសរបស់ព្រះគ្រីស្ទ. . .ហើយខ្ញុំមិនដឹងពីពេលវេលាដែលទ្រង់នឹងយាងមកម្ដងទៀតឡើយ ។ អ្វីដែលខ្ញុំដឹង គឺថាគ្មានបងប្អូនណាម្នាក់នៅក្នុងកូរ៉ុមនៃពួកដប់ពីរនាក់ ឬ សូម្បីតែនៅក្នុងគណៈប្រធានទីមួយបានដឹងឡើយ ។ ហើយខ្ញុំចង់ប្រាប់ដោយរាបទាបថា បើសិនយើងមិនដឹងពីរឿងនោះទេនោះគ្មាននរណាដឹងឡើយ ។. . . ព្រះអង្គសង្គ្រោះបានមានបន្ទូលថា ‹ អំពីថ្ងៃ និង កាលវេលានោះ គឺគ្មាននរណាម្នាក់ដឹងឡើយ សូម្បីតែពួកទេវតានៃព្រះនៅឯស្ថានសួគ៌ ប៉ុន្តែមានតែព្រះវរបិតាយើងមួយអង្គគត់ › [ Joseph Smith—Matthew ១:៤០

« ខ្ញុំជឿថា នៅពេលព្រះអម្ចាស់មានបន្ទូលថា ‹ គ្មានអ្នកណា › ដឹង ទ្រង់ពិតជាមានន័យថា គ្មានម្នាក់ដឹងឡើយ » (When Shall These Things Be ? » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៥៦) ។

- តើយើងរៀនបានអ្វីខ្លះពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៤–១៧ និង សេចក្ដីថ្លែងការណ៍របស់អែលឌើរ បាឡឹដ ? ( សិស្សអាចរកឃើញសេចក្ដីពិតផ្សេងៗគ្នា ប៉ុន្តែពួកគេគួររកឃើញសេចក្ដីពិតខាងក្រោមនេះ ៖ **មានតែព្រះប៉ុណ្ណោះដែលដឹងច្បាស់លាស់ពី ពេលវេលានៃការយាងមកជាលើកទីពីរនឹងកើតឡើង**) ។

សូមចង្អុលបង្ហាញថានៅក្នុងសម័យរបស់យើងនេះ មនុស្សមួយចំនួនព្យាយាមព្យាករណ៍ពីពេលវេលាជាក់លាក់នៃការយាងមកជាលើកទីពីរ ឬ ចុងបំផុតនៃលោកិយ ។

- តើការចងចាំពីគោលការណ៍នេះ អាចជួយអ្នកកុំឲ្យត្រូវបានដឹកនាំដោយខុសឆ្គងដោយការប្រកាសក្លែងក្លាយដោយរបៀបណា ?

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៨–១៩

*យ៉ូសែប ស៊្មីធបង្រៀនអំពីសារៈសំខាន់នៃការទទួលបានចំណេះដឹង និង បញ្ញានៅក្នុងជីវិតនេះ*

បើសិនអាចធ្វើបាន សូមបង្ហាញវ៉ាលី ឬ កាបូបមួយ ។ សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថាពួកគេកំពុងចាកចេញពីផ្ទះ ហើយទៅកន្លែងមួយដែលពួកគេមិនធ្លាប់ទៅពីមុន ។ ពួកគេត្រូវបានអនុញ្ញាតឲ្យយកតែរបស់របរល្មមពេញតែវ៉ាលី ( ឬ កាបូប ) នេះប៉ុណ្ណោះ ។

- តើអ្នកនឹងចង់វិចខ្ចប់ឥវ៉ាន់អ្វីខ្លះដាក់នៅក្នុងវ៉ាលីនេះ ? ( សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ) ។

សូមឲ្យសិស្សស្រមៃថាគោលដៅរបស់ពួកគេគឺពិភពវិញ្ញាណ ជាកន្លែងដែលពួកយើងនឹងទៅនៅពេលយើងស្លាប់ ។

- តើឥវ៉ាន់អ្វីខ្លះនៅពេលធ្វើដំណើរ ដែលអ្នកនឹងអាចយកតាមខ្លួនបាននៅពេលអ្នកស្លាប់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៨–១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលយើងអាចនាំទៅជាមួយយើងពីក្នុងជីវិតនេះនៅពេលយើងស្លាប់ ។

- យោងតាម ខ ១៨–១៩, តើមានអ្វីខ្លះដែលយើងអាចយកទៅជាមួយពេលយើងស្លាប់ ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួររកឃើញសេចក្ដីពិតខាងក្រោមនេះ ៖ **ចំណេះវិជ្ជា និង បញ្ញានានាដែលយើងទទួលនៅក្នុងជីវិតនេះនឹងមាននៅជាប់ជាមួយយើងនៅពេលយើងរស់ឡើងវិញ** ។

ដើម្បីជួយសិស្សឲ្យយល់ពី អត្ថន័យនៃពាក្យ *ចំណេះវិជ្ជា* និង *បញ្ញា*, សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដោយអែលឌើរ នែល អេ ម៉ាក់ស្វែលនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« បើសិនយើងពិចារណាពីអ្វី ដែលនឹងមានជាប់ជាមួយយើងនៅពេលរស់ឡើងវិញនោះ វាហាក់បីដូចជាច្បាស់ថាបញ្ញារបស់យើងនឹងមាននៅជាប់ជាមួយយើង មិនមែនជាបញ្ញាសាមញ្ញរបស់យើងឡើយ ប៉ុន្តែគឺជាសមត្ថភាពរបស់យើងដើម្បីទទួល ហើយអនុវត្តសេចក្ដីពិតរបស់យើង ។ ទេពកោសល្យ លក្ខណៈ និងជំនាញរបស់យើងនឹងក្រោកឡើងជាមួយយើង ពិតណាស់រួមទាំងសមត្ថភាពរបស់យើងដើម្បីរៀន កម្រិតនៃទំនុកចិត្តរបស់យើង និង សមត្ថភាពធ្វើការរបស់យើងផងដែរ » ( *We Will Prove Them Herewith* ឆ្នាំ ១៩៨២ ] ទំព័រ ១២ ) ។

- យោងតាមអែលឌើរ ម៉ាក់ស្វែលតើពាក្យ *បញ្ញា* មានន័យដូចម្ដេចដែរនៅក្នុង ខ១៨–១៩ ?
- យោងតាម ខ ១៩, តើយើងអាចទទួលចំណេះវិជ្ជា និង បញ្ញាកាន់តែប្រសើរឡើងដោយរបៀបណា ? ( អ្នកអាចចង់ចង្អុលបង្ហាញថាចំណេះវិជ្ជា និង បញ្ញាមួយចំនួនអាចត្រូវបានទទួលតែ « ដោយសារ . . . ការព្យាយាម និង ការគោរព » ) ប៉ុណ្ណោះ ។
- តើនៅពេលណាដែលអ្នកបានទទួលចំណេះវិជ្ជា ឬ បញ្ញាដោយសារការព្យាយាម និង ការគោរពប្រតិបត្តិ ? ( អ្នកក៏អាចចែកចាយបទពិសោធន៍មួយផងដែរ ) ។

សូមចង្អុលបង្ហាញថាយោងតាម ខ ១៩, អ្នកទាំងឡាយណាដែលទទួលចំណេះវិជ្ជា និង បញ្ញាកាន់តែច្រើននៅក្នុងក្នុងជីវិតនេះនឹងមានប្រៀបច្រើននៅពិភពខាងមុខ ។

- តើអ្នកគិតថាការទទួលចំណេះវិជ្ជា និង បញ្ញានៅក្នុងក្នុងជីវិតនេះអាចមានប្រៀបកាន់តែច្រើននៅពិភពខាងមុខយ៉ាងដូចម្ដេច ?

សូមពន្យល់ថាអ្វីដែលយើងរៀននៅក្នុងជីវិតនេះទាំងខាងសាច់ឈាម និង ខាងវិញ្ញាណនឹងមានប្រយោជន៍ចំពោះយើងរហូតដល់អស់កល្បជានិច្ច ។ យើងនឹងអាចស្ថាបនាលើចំណេះវិជ្ជាដែលយើងទទួលបានក្នុងជីវិតនេះ ដើម្បីប្រែក្លាយខ្លួនឲ្យកាន់តែដូចព្រះវរបិតាសួគ៌ ។

ដើម្បីជួយសិស្សឲ្យបន្តទទួលបានចំណេះវិជ្ជា និង បញ្ញា សូមលើកទឹកចិត្តពួកគេឲ្យបន្តចូលរួមនៅក្នុងថ្នាក់សិក្ខាសាលាឥឡូវនេះ ហើយដើម្បីគ្រោងចូលរួមថ្នាក់វិទ្យាស្ថាន បន្ទាប់ពីពួកគេបញ្ចប់ពីថ្នាក់សិក្ខាសាលា ។ សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយ ដែលនឹងជួយពួកគេទទួលបានចំណេះវិជ្ជា និង បញ្ញាបន្ថែមទៀត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២០–២១

*យ៉ូសែប ស្ម៊ីធ ពន្យល់ពីរបៀបដែលយើងទទួលបានពរជ័យ*

សូមអញ្ជើញសិស្សឲ្យស្រមៃថាពួកគេចង់អភិវឌ្ឍជំនាញការសរសេររបស់ពួកគេ ដូច្នេះពួកគេសម្រេចចិត្តតែចម្ងាយបីម៉ោយប្រាំថ្ងៃក្នុងមួយសប្ដាហ៍រយៈពេលមួយខែ ។

- តើលទ្ធផលនឹងទៅជាយ៉ាងណា ? ហេតុអ្វី ?
- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីឲ្យជំនាញការសរសេររបស់អ្នកបានកាន់តែប្រសើរឡើង ?

សូមចង្អុលបង្ហាញថា គឺដូចជាយើងត្រូវយល់ពីរបៀបទទួលលទ្ធផលដែលយើងចង់បាន នោះយើងត្រូវយល់ពី របៀបដើម្បីទទួលពរជ័យដែលព្រះវរបិតាសួគ៌មានព្រះទ័យចង់ប្រទានឲ្យយើង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២០–២១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀបដែលយើងអាចទទួលពរជ័យដែលព្រះវរបិតាសួគ៌មានព្រះទ័យចង់ប្រទានឲ្យយើង ។ ( អ្នកអាចចង់ពន្យល់ថាពាក្យ« ផ្អែក » មានន័យថា « ផ្អែកទៅលើ » ហើយថាក្រឹត្យវិន័យមួយដែល « ពុំអាចដកចេញបាន » មានន័យថានៅជាអចិន្ត្រៃ ហើយពុំប្រែលប្រួលឡើយ ) ។

- យោងតាម ខ ២០–២១, តើយើងអាចទទួលពរជ័យពីព្រះតាមរបៀបណា ?

សូមអញ្ជើញឲ្យសិស្សសរសេរគោលការណ៍ « បើសិន–នោះ » ដោយផ្អែកលើ ខ ២០–២១ ។ បន្ទាប់ពីទុកពេលគ្រប់គ្រាន់ ហើយសូមឲ្យសិស្សពីរបីនាក់អានសេចក្ដីថ្លែងការណ៍របស់ពួកគេឲ្យឮ ។ សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលការណ៍ខាងក្រោមនេះ ៖ **បើសិនយើងចង់ទទួលបានពរជ័យពីព្រះ នោះយើងត្រូវតែគោរពតាមក្រឹត្យវិន័យដែលគ្រប់ព្រះពរទាំងអស់ផ្អែកទៅលើ ។**

ដើម្បីជួយសិស្សឲ្យយល់កាន់តែជ្រាលជ្រៅអំពីសេចក្ដីពិតនេះ សូមសរសេរ តារាងខាងក្រោម លើក្ដារខៀន ( អ្នកអាចធ្វើវាពីមុនចាប់ផ្ដើមថ្នាក់រៀន ) ។ សូមអញ្ជើញសិស្សឲ្យចម្លងតារាងចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អានវគ្គព្រះគម្ពីរទីមួយដែលបានសរសេរឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលក្រឹត្យវិន័យមួយ និង ពរជ័យដែលទាក់ទងនោះ ។ នៅពេលពួកគេប្រាប់ពីចម្លើយ សូមបំពេញវានៅក្នុងចន្លោះដែលត្រឹមត្រូវនៅលើតារាង ។ សូមអញ្ជើញសិស្សឲ្យបំពេញតារាងរបស់ខ្លួនដោយខ្លួនឯង ។

បើសិនយើងចង់ទទួលបានពរជ័យពីព្រះ នោះយើងត្រូវតែគោរពតាមក្រឹត្យវិន័យដែលគ្រប់ព្រះពរទាំងអស់ផ្អែកទៅលើ ។

| វគ្គបទគម្ពីរ | ក្រឹត្យវិន័យ | ពរជ័យ |
|---|---|---|
| *គ. និង ស. ១០:៥* | | |
| *គ. និង ស. ៨៨:១២៤* | | |
| *នីហ្វៃទី ២ ៣២:៣* | | |
| *យ៉ូហាន ៧:១៧* | | |

បន្ទាប់ពីសិស្សបញ្ចប់សកម្មភាពនេះ សូមឲ្យពួកគេគិតពីពរជ័យដែលពួកគេបានទទួលពីព្រោះពួកគេបានធ្វើតាមក្រឹត្យវិន័យ ។ សូមអញ្ជើញពួកគេឲ្យចែកចាយពីបទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យសរសេរពរជ័យដែលពួកគេចង់បាន ។ រួចសូមអញ្ជើញពួកគេសរសេរពីក្រឹត្យវិន័យមួយ ឬ ច្រើនដែលពួកគេត្រូវតែគោរពតាមដើម្បីទទួលបានពរជ័យទាំងនោះ ។

សូមចង្អុលបង្ហាញថាក្រឹត្យវិន័យ និង ពរជ័យមួយចំនួនគឺពិសេសណាស់ខណៈដែលក្រឹត្យវិន័យ និង ពរជ័យផ្សេងទៀតមានភាពសាមញ្ញ ។ សូមចង្អុលបង្ហាញផងដែរថាពរជ័យដែលបានសន្យាមួយចំនួនអាចទទួលបាននៅជីវិតបន្ទាប់ ។

ដើម្បីបញ្ចប់មេរៀនថ្ងៃនេះ សូមអញ្ជើញសិស្សរំឭកពីសេចក្ដីពិតមួយចំនួនដែលពួកគេបានរៀនពីការបង្រៀនរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ ។

- តើសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ ជួយអ្នកឲ្យមានអំណរគុណចំពោះយ៉ូសែប ស្ម៊ីធយ៉ាងដូចម្ដេច ?

សូមបញ្ចប់មេរៀនដោយអញ្ជើញសិស្សឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោយដោយប្រធាន ព្រិកហាំ យ៉ង់ អំពីសមត្ថភាពរបស់យ៉ូសែប ស្ម៊ីធ ដើម្បីពន្យល់ពីការណ៍នានារបស់ព្រះ ។



« សិរីល្អដ៏អស្ចារ្យបំផុតនៃអកប្បកិរិយារបស់បងប្រុស យ៉ូសែប ស្ម៊ីធ គឺថាលោកអាចប្រាប់ការណ៍ផ្សេងៗពីឋានសួគ៌ដើម្បីឲ្យមនុស្សធម្មតាយល់បាន ។ នៅពេលលោកបង្រៀនមនុស្ស—ទាក់ទងនឹងរឿងរបស់ព្រះ ព្រះឆន្ទៈរបស់ព្រះ ផែនការនៃសេចក្ដីសង្គ្រោះ គោលបំណងនៃព្រះយេហូវ៉ា ទំនាក់ទំនងដែលយើងមានចំពោះទ្រង់ និងចំពោះតួអង្គសួគ៌ាទាំងអស់ លោកបានសម្របការបង្រៀនរបស់លោកទៅ នឹងសមត្ថភាពរបស់បុរស ស្ត្រី និង កូនក្មេងគ្រប់រូប ដោយធ្វើឲ្យពួកគេយល់ច្បាស់ដូចជាផ្លូវដែលមានផ្លាកសញ្ញាយ៉ាងច្បាស់ ។ ការណ៍នេះគួរតែបានបញ្ចុះបញ្ចូលមនុស្សគ្រប់រូបដែលធ្លាប់បានឮពីលោកអំពីសិទ្ធិអំណាច និង អំណាចដ៏ទេវភាពរបស់លោក ដ្បិតគ្មានមនុស្សណាម្នាក់ផ្សេងទៀតអាចបង្រៀនយើងដូចលោកបានធ្វើឡើយ ហើយគ្មានបុគ្គលណាបើកសម្ដែងពីការណ៍របស់ព្រះឡើយ ប៉ុន្តែដោយវិវរណៈអំពីព្រះយេស៊ូវគ្រីស្ទ » (*Teachings of Presidents of the Church: Brigham Young* [ ឆ្នាំ ១៩៩៧ ] ទំព័រ ៣៤៧) ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីការហៅបម្រើរបស់យ៉ូសែប ស្ម៊ីធ ក្នុងនាមជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមគោលលទ្ធិ និង គោលការណ៍នានាដែលពួកគេបានរៀនពីការបង្រៀនរបស់ព្យាការីនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ ។

មេរៀនទី ១៣៨

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ រួមមាននូវការបកស្រាយមួយអំពីគោលការណ៍ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនកាលនៅរ៉ាមូស រដ្ឋ អិលលីណោយ នៅថ្ងៃទី ១៦–១៧ ខែ ឧសភា ឆ្នាំ ១៨៤៣ ។ លោកបានបង្រៀនអំពីសេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ចនៃអាពាហ៍ពិពាហ៍ និង ការសន្យានៃជីវិតដ៏នៅអស់កល្បជានិច្ចសម្រាប់អ្នកស្មោះត្រង់ ។ លោកក៏បានបង្រៀនថាវិញ្ញាណទាំងអស់គឺជាធាតុ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១–៤

*យ៉ូសែប ស្ម៊ីធបង្រៀនអំពីសារៈសំខាន់នៃសេចក្ដីសញ្ញាអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច*

សូមបង្ហាញដល់សិស្សនូវ សោដែលមានលេខសម្ងាត់សាមញ្ញមួយ ។ អ្នកអាចគិតប្រើវាដើម្បីចាក់សោគម្របប្រអប់មួយឲ្យមានសុវត្ថិភាព ។ បើសិនអ្នកគ្មានសោទេនោះ សូមគូររូបសោនេះលើក្ដារខៀន ។ សូមអញ្ជើញសិស្សប្រុសម្នាក់ និង សិស្សស្រីម្នាក់ឲ្យឈរនៅខាងមុខក្ដារខៀន ។ សូមឲ្យក្រដាសមួយសន្លឹកដែលមានផ្នែកដំបូងនៃលេខសម្ងាត់សរសេរនៅលើនោះទៅសិស្សម្នាក់ ។ សូមឲ្យក្រដាសមួយសន្លឹកទៀត ដែលមានផ្នែកនៅសល់នៃលេខសម្ងាត់មួយទៀតសរសេរនៅលើនោះឲ្យទៅសិស្សម្នាក់ទៀត ។ បើសិនអ្នកបាននាំយកសោមួយមកថ្នាក់រៀន សូមឲ្យសិស្សម្នាក់បើកសោនៅដោយពុំឲ្យសិស្សផ្សេងទៀតជួយឡើយ ។ បន្ទាប់មកសូមឲ្យពួកគេធ្វើការជាមួយគ្នាដើម្បីបើកសោនោះ ។




សូមសរសេរសំណួរខាងក្រោមលើក្ដារខៀន ( ឬ សូមសរសេរវានៅក្រដាសមួយនៅក្នុងប្រអប់ដែលសិស្សពីរនាក់ទើបតែបានចាក់សោ ) ៖ *បើសិនសោតំណាងឲ្យច្រកចូលទៅក្នុងកម្រិតដ៏ខ្ពស់បំផុតនៃនគរសេឡេស្ទាល តើលេខសម្ងាត់នោះតំណាងឲ្យអ្វី ?* សូមឲ្យសិស្សអានរកមើលចម្លើយចំពោះសំណួរនេះនៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ ។

សូមពន្យល់ថានៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៨៤៣ យ៉ូសែប ស្ម៊ីធ បានធ្វើដំណើរទៅកាន់ រ៉ាមូស រដ្ឋ អិលលីណោយ ។ ខណៈនៅផ្ទះរបស់បេនយ៉ាមីន និងមីលីសា ចនសិន លោកបានធ្វើពិធីផ្សារភ្ជាប់ឲ្យពួកគេជាស្វាមី និង ភរិយាសម្រាប់ភាពអស់កល្បជានិច្ច ។ លោកក៏បានបង្រៀនពួកគេពី របៀបដែលអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ចទាក់ទងនឹងនគរសេឡេស្ទាល ។ សេចក្ដីពិតទាំងនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣១:១–៤ ។ ( សូមមើល *History of the Church,* ៥:៣៩១–៩២ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្ដីពិតដែលព្យាការីបានបើកសម្ដែងអំពីនគរសេឡេស្ទាល ។

- តើយ៉ូសែប ស្ម៊ីធបានបើកសម្ដែងអ្វីខ្លះអំពីនគរសេឡេស្ទាល ?

សូមពន្យល់ថាជាញឹកញាប់យើងនិយាយពី ការទទួលកម្រិតនៃសិរីរុងរឿងដ៏ខ្ពស់បំផុតនៅក្នុងនគរសេឡេស្ទាល ថាជា ភាពតម្កើងឡើង ឬ ជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមសរសេរពាក្យ *ភាពតម្កើងឡើង* នៅលើក្ដារខៀន ។ សូមពន្យល់ថាអស់អ្នកដែលទទួលកម្រិតនៃសិរីរុងរឿងនៃនគរសេឡេស្ទាលនេះនឹងរស់នៅដូចជាព្រះវរបិតាសួគ៌ទ្រង់រស់នៅដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យ អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:២–៤ ឲ្យឮៗ, ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលយើងត្រូវតែធ្វើដើម្បីទទួលបានកម្រិតដ៏ខ្ពស់បំផុតនៃនគរសេឡេស្ទាល ។

- តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានកម្រិតដ៏ខ្ពស់បំផុតនៃនគរសេឡេស្ទាល ? ( សិស្សគួររកឃើញគោលលទ្ធិខាងក្រោម ៖ **ដើម្បីទទួលបានកម្រិតខ្ពស់បំផុតនៃនគរសេឡេស្ទាល នោះយើងត្រូវតែចូលទៅក្នុងសេចក្ដីសញ្ញាថ្មី ហើយដ៏អស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍**) ។

- តើអ្នកគិតថាវាមានន័យដូចម្ដេចនៅក្នុង ខ ៤ ដែលថាបើសិនយើងមិនបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធដោយសិទ្ធិអំណាចត្រឹមត្រូវនោះយើង « ពុំអាចបានភាពចម្រើនឡើយ ? » ( ដើម្បីជួយសិស្សឲ្យយល់ខនេះអ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា *ចម្រើន* សំដៅលើឱកាសដើម្បីបន្តមានកូនចៅនៅក្នុងនគរសេឡេស្ទាល ) ។

ដើម្បីជួយសិស្សឲ្យយល់ឃ្លា « សេចក្ដីសញ្ញាថ្មី ហើយដ៏អស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ » សូមពន្យល់ពាក្យ *ថ្មី* នៅក្នុងបរិបទនេះមានន័យថា សេចក្ដីសញ្ញានេះត្រូវបានស្ដារឡើងវិញថ្មីនៅក្នុងសម័យកាន់កាប់ត្រួតត្រារបស់យើង ។ ពាក្យ *ដ៏អស់កល្បអស់កាលជានិច្ច* មានន័យថាសេចក្ដីសញ្ញាដ៏ចាំបាច់នេះនឹងបន្តឆ្ពោះទៅរកភាពអស់កល្ប ។ សូមរំឭកសិស្សថាពួកគេចូលទៅក្នុងសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍សេឡេស្ទាលនេះនៅក្នុងព្រះវិហារបរិសុទ្ធ ) ។

- តើអ្នកគិតថាអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និង ស្ត្រីម្នាក់រៀបចំពួកគេសម្រាប់ភាពតម្កើងឡើងតាមរបៀបណាខ្លះ ?

សូមឲ្យសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ សូមឲ្យសិស្សស្ដាប់ដោយរកមើលពីរបៀបដែលអាពាហ៍ពិពាហ៍ជួយយើងរៀបចំខ្លួនសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។



« ហេតុផលខាងគោលលទ្ធិពីរជួយយើងឲ្យយល់ដឹងពីហេតុផលដែលអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចគឺជារឿងដ៏សំខាន់នៅក្នុងផែនការរបស់ព្រះវរបិតា ។

« មូលហេតុទី ១ ៖ ធម្មជាតិនៃវិញ្ញាណភេទប្រុស និងភេទស្រី បំពេញកង្វះគ្នាទៅវិញទៅមក និងជួយគ្នាទៅវិញទៅមកឲ្យល្អឥតខ្ចោះ ហេតុដូច្នោះហើយ បុរស និងស្ត្រី គឺមានបំណងចង់រីកចម្រើនទៅជាមួយគ្នាឆ្ពោះទៅរកភាពតម្កើងឡើង ។. . .

« តាមរយៈការរចនាដ៏ទេវភាព បុរស និង ស្ត្រី ត្រូវបានតាំងចិត្តដើម្បីរីកចម្រើនជាមួយគ្នាឆ្ពោះទៅកាន់ភាពល្អឥតខ្ចោះ និង ភាពដ៏ពេញលេញនៃសិរីល្អ ។ ដោយសារភាពខុសគ្នានៃនិស្ស័យ និង សមត្ថភាពរបស់ខ្លួន បុរស និង ស្ត្រីគ្រប់រូបនាំមកកាន់ទំនាក់ទំនងអាពាហ៍ពិពាហ៍នូវទស្សនវិស័យ និង បទពិសោធន៍ដ៏ពិសេស ។ បុរស និង ស្ត្រីមានលក្ខណៈផ្សេងគ្នា ប៉ុន្តែមានភាពស្មើគ្នាតែមួយ និង សាមគ្គីភាព ដែលកិច្ចការទាំងនេះមិនអាចទទួលបានជោគជ័យបានតាមវិធីផ្សេងឡើយ ។ បុរសបំពេញ និងធ្វើឲ្យស្ត្រីបានគ្រប់លក្ខណ៍ ហើយស្ត្រីបំពេញ និងធ្វើឲ្យបុរសបានគ្រប់លក្ខណ៍ នៅពេលពួកគេរៀនពីគ្នា ហើយពង្រឹង និងប្រទានពរដល់គ្នាទៅវិញទៅមកនោះ ។

« ហេតុផលទី ២ ៖ តាមរយៈការតាក់តែងដ៏ទេវភាពទាំងបុរស និង ស្ត្រីគឺចាំបាច់ត្រូវនាំកូនចូលមកក្នុងជីវិតរមែងស្លាប់នេះ ហើយផ្ដល់គំរូដ៏ល្អបំផុតដើម្បីចិញ្ចឹម និង ថែទាំកូនចៅ » (« Marriage Is Essential to His Eternal Plan » *Ensign,* ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៨៣–៨៤ អក្សរជិត និង ទ្រេតត្រូវបានដកចេញ ) ។

- យោងតាមអែលឌើរ បែដណា ហេតុអ្វីអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និង ស្ត្រីម្នាក់ចាំបាច់សម្រាប់ភាពតម្កើងឡើងរបស់ពួកគេ ?

- តើការយល់ដឹងពីគោលលទ្ធិដែលថាអាពាហ៍ពិពាហ៍សេឡេស្ទាលចាំបាច់សម្រាប់ភាពតម្កើងឡើងអាចជះលទ្ធិពលលើអ្វីដែលអ្នកស្វែងរកចំពោះអនាគតស្វាមី ឬ ភរិយាយ៉ាងដូចម្ដេច ?

- ហេតុអ្វីបានជាវាសំខាន់ដែលនៅក្នុងវ័យរបស់អ្នក ត្រូវដាក់ផែនការការរៀបអាពាហ៍ពិពាហ៍អស់កល្បជានិច្ចក្នុងព្រះវិហារបរិសុទ្ធ គឺជាអាទិភាពយ៉ាងដូច្នេះ ?

អ្នកអាចពន្យល់ថាពរជ័យនៃភាពតម្កើងឡើងនឹងមានដល់មនុស្សទាំងអស់ដែលពុំមានឱកាសសម្រាប់អាពាហ៍ពិពាហ៍សេឡេស្ទាលនៅក្នុងជីវិតនេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ដកស្រង់ពីសៀវភៅ *ពិតចំពោះសេចក្ដីជំនឿ* ៖

> « សមាជិកសាសនាចក្រខ្លះនៅតែនៅលីវ ដោយមិនមែនជាកំហុសរបស់គេ ទោះបីជាពួកគេចង់រៀបការក្តី ។ ប្រសិនបើអ្នកឃើញខ្លួនអ្នកស្ថិតនៅក្នុងស្ថានភាពនេះ សូមប្រាកដថា ‹ គ្រប់ការណ៍ទាំងអស់ផ្សំគ្នាសម្រាប់សេចក្តីល្អ ដល់ពួកអ្នកដែលស្រឡាញ់ព្រះ › ( រ៉ូម ៨:២៨ ) ។ នៅពេលអ្នកបន្តមានភាពសក្តិសម នោះនៅថ្ងៃណាមួយ នៅក្នុងជីវិតនេះ ឬជីវិតបន្ទាប់ អ្នកនឹងបានពរជ័យទាំងឡាយនៃទំនាក់ទំនងគ្រួសារដ៏អស់កល្ប » ( *ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងដំណឹងល្អ* [ ឆ្នាំ ២០០៤ ], ទំព័រ ៩៩ ) ។

- តើការរក្សាសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នកក្នុងពេលនេះ អាចជួយអ្នករៀបចំខ្លួនដើម្បីទទួលបានពរជ័យនៃព្រះវិហារបរិសុទ្ធបៀបណា ? តើយុវជន និងយុវនារីអាចធ្វើអ្វីខ្លះក្នុងពេលឥឡូវនេះ ដើម្បីធ្វើឲ្យអាពាហ៍ពិពាហ៍សេឡេស្ទាលនៅក្នុងព្រះវិហារបរិសុទ្ធក្លាយជាអាទិភាពមួយ ? ( អ្នកអាចសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ។)

សូមលើកទឹកចិត្តសិស្សឲ្យដាក់អាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ចនៅក្នុងព្រះវិហារបរិសុទ្ធជាអាទិភាពសម្រាប់ពួកគេ ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យទាំងឡាយដែលបានមកពីលទ្ធផលនៃអាពាហ៍ពិពាហ៍សេឡេស្ទាល ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ១៣១:៥–៦

*ព្យាការីពន្យល់ពី « ពាក្យព្យាការណ៍ដ៏ពិតជាង »*

សូមបង្ហាញសំបុត្រធានាខុសត្រូវ ឬ សំបុត្រធានាមួយច្បាប់ ។

- តើការមានអ្នកធានាម្នាក់វាមានប្រយោជន៍អ្វីខ្លះ ?
- ហេតុអ្វីបានជាការធានាមួយមកពីព្រះវរបិតាសួគ៌ មានតម្លៃពិសេសយ៉ាងដូច្នេះ ?

សូមពន្យល់ថានៅរ៉ាមូស រដ្ឋ អិលលីណោយ នៅព្រឹកថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៨៤៣ យ៉ូសែប ស៊្មីធ បានបង្រៀនឃ្លាមួយដែលមាននៅក្នុង ពេត្រុសទី ២ ១:១៩ ដែលតំណាងឲ្យអ្នកធានាមួយមកពីព្រះ ( សូមមើល *History of the Church,* ៥:៣៩២ ) សូមអញ្ជើញសិស្សឲ្យអាន ពេត្រុសទី ២ ១:១៩ ដោយស្ងាត់ស្ងៀម ហើយរកមើលឃ្លានោះ ។ ( ពាក្យទំនាយដ៏ពិតជាង » ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣១:៥ ហើយរកមើលអត្ថន័យនៃឃ្លា « ពាក្យព្យាការណ៍ដ៏ពិតជាង » ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម ខ ៥, តើព្រះវរបិតាសួគ៌ធានាអ្វីខ្លះដល់មនុស្សម្នាក់តាមរយៈពាក្យព្យាការណ៍ដ៏ពិតជាងនោះ ? ( ជីវិតដ៏នៅអស់កល្បជានិច្ច) ។
- តើអ្នកគិតថាអ្នកនឹងមានអារម្មណ៍ដូចម្តេចដើម្បីទទួលការធានាបែបនោះ ? ហេតុអ្វី ?

*កំណត់ចំណាំ ៖* សូមកុំមើលស្រាលបុគ្គលដែលនៅរស់ដែលអាចនឹងទទួលបាន « ពាក្យព្យាការណ៍ដ៏ពិតជាង »ឡើយ ។ ទោះជាយ៉ាងណាក៏ដោយព្រះគម្ពីរប្រាប់យើងពី បុគ្គលមួយចំនួនដែលបានទទួលការធានានៃជីវិតដ៏នៅអស់កល្បជានិច្ចអំឡុងពេលនៅក្នុងជីវិតរមែងស្លាប់នេះនៅឡើយ ។ ឧទាហរណ៍ ព្រះអម្ចាស់បានបង្ហាញនៅក្នុងការធានាអះអាងនេះចំពោះយ៉ូសែប ស៊្មីធ ( សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៤៩) និង ចំពោះអាលម៉ា ( សូមមើល ម៉ូសាយ ២៦:២០) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣១:៦ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលនឹងរារាំងមនុស្សម្នាក់ពីការទទួលជីវិតអស់កល្បជានិច្ច ។

- តើយ៉ូសែប ស៊្មីធបានមានប្រសាសន៍ពីកិច្ចការអ្វីខ្លះ ដែលធ្វើឲ្យយើងមិនបានសង្គ្រោះ ឬ ទទួលជីវិតអស់កល្បជានិច្ច ? ( សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដថាពួកគេយល់ថា **យើងមិនអាចបានសង្គ្រោះនៅក្នុងភាពល្ងង់ខ្លៅឡើយ ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ) ។

សូមអញ្ជើញសិស្សឲ្យអានការពន្យល់ខាងក្រោម អំពីសេចក្តីពិតដែលបានផ្តល់ឲ្យដោយប្រធាន ម៉ារ៉ុន ជី រ៉មនី នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សស្តាប់រកមើលចំណេះវិជ្ជាបែបណាដែលយើងត្រូវការ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។



« ចំណេះវិជ្ជានៃការ ‹ ស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែមួយ និង ព្រះយេស៊ូវគ្រីស្ទ › (យ៉ូហាន ១៧:៣) គឺជាចំណេះវិជ្ជាដ៏សំខាន់បំផុតនៅលើសាកលលោកនេះ វាគឺជាចំណេះវិជ្ជាដែលយ៉ូសែប ស្ម៊ីធបានមានប្រសាសន៍ថាបើគ្មានចំណេះនេះ នោះគ្មាននរណាបានសង្គ្រោះឡើយ ។ ការខ្វះនូវចំណេះវិជ្ជានេះគឺជាភាពល្ងង់ខ្លៅសំដៅទៅក្នុងវិវរណៈដែលបានសរសេរក្នុងនោះថា ៖ ‹ គឺគ្មានផ្លូវទេសម្រាប់ឲ្យមនុស្សបានសង្គ្រោះក្នុងការល្ងង់ខ្លៅឡើយ › ។ ( គ. និង ស. ១៣១:៦ ) » ។ (« Except a Man Be Born Again » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨១ ទំព័រ ១៤ ) ។

- តើចំណេះវិជ្ជាបែបណាដែលយើងត្រូវតែមាន ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ? តើអ្នកគិតថា ហេតុអ្វីចំណេះវិជ្ជាបែបនេះចាំបាច់សម្រាប់សេចក្ដីសង្គ្រោះ ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីបង្កើនចំណេះវិជ្ជារបស់យើងអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៧–៨

*យ៉ូសែប ស្ម៊ីធបង្រៀនថាវិញ្ញាណទាំងអស់គឺជាធាតុ*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៧–៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើវិញ្ញាណផ្សំឡើងពីអ្វីខ្លះ ។

- តើអ្នករៀនអ្វីខ្លះពីខគម្ពីរទាំងនេះ ? ( គ្រប់អស់ទាំងការបង្កបង្កើតផ្សំពីធាតុនានា ប៉ុន្តែធាតុនៃវិញ្ញាណគឺ « ហ្មត់ ឬ សុទ្ធសាធ » ) ។

សូមថ្លែងទីបន្ទាល់អំពីគោលការណ៍ដែលបានពិភាក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១, ហើយសូមលើកទឹកចិត្តសិស្សឲ្យបន្តទទួលចំណេះវិជ្ជាអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ដូច្នេះពួកគេអាចប្រែក្លាយកាន់តែដូចពួកទ្រង់ ។

មេរៀនទី ១៣៩

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣–៣៣

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ មានវិវរណៈមួយអំពីសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍ ។ ទោះបីជាវិវរណៈនេះត្រូវបានកត់ត្រាទុកនៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៨៤៣ ក្ដីសេចក្ដីពិតមួយចំនួននៅក្នុងវិវរណៈនេះត្រូវបានទទួលស្គាល់ ហើយបង្រៀនដោយព្យាការី យ៉ូសែប ស្ម៊ីធនៅដើមឆ្នាំ ១៨៣១ ។ វិវរណៈនេះនឹងត្រូវបានពិភាក្សាជាពីរមេរៀន ។ មេរៀននេះពិភាក្សាអំពីលក្ខខណ្ឌនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍ និង ការសន្យាដែលប្រទានដល់អស់អ្នកដែលគោរពដល់វា ។ មេរៀនបន្ទាប់នឹងពិភាក្សាពីគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣–១៨

*ព្រះអម្ចាស់កំណត់ពីលក្ខខណ្ឌនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ។*

*កំណត់ចំណាំ ៖* គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–២ គឺមាននៅក្នុងមេរៀនទី ១៤០ ជាផ្នែកមួយនៃការពិភាក្សាអំពីអាពាហ៍ពិពាហ៍ពហុពន្ធភាព ។

ពីមុនចាប់ផ្ដើមថ្នាក់សូមសរសេរ សំណួរខាងក្រោមនេះ នៅលើក្ដារខៀន ៖

> *ហេតុអ្វីអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចសំខាន់ចំពោះអ្នក ?*
>
> *ដោយចាប់ផ្ដើមពីថ្ងៃនេះ តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីរៀបចំខ្លួនចូលទៅព្រះវិហារបរិសុទ្ធ ហើយរៀបអាពាហ៍ពិពាហ៍ចំពោះវេលាកាល និង ភាពអស់កល្បជានិច្ច ?*
>
> *តើពរជ័យអ្វីខ្លះដែលអាចត្រូវបានទទួលនៅក្នុងជីវិតនេះចំពោះអស់អ្នកដែលធ្វើតាមក្រឹត្យវិន័យរបស់ព្រះ ដើម្បីត្រូវបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ?*

សូមអញ្ជើញសិស្សឲ្យពិចារណាពីសំណួរទាំងនេះនៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ ថ្ងៃនេះ ។

សូមចាប់ផ្ដើមដោយសួរសំណួរខាងក្រោមនេះ ៖

- តើសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនោះជាអ្វី ?

ដើម្បីជួយសិស្សឲ្យយល់អត្ថន័យនៃឃ្លា « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច » សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌិង ស្ម៊ីធ ៖



« ឥឡូវនេះមាននិយមន័យដ៏ច្បាស់មួយយ៉ាងលម្អិតអំពីសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ។ វាគឺជាអ្វីគ្រប់យ៉ាង—ភាពពោរពេញនៃដំណឹងល្អ ។ ដូច្នេះអាពាហ៍ពិពាហ៍ត្រឹមត្រូវត្រូវបានធ្វើឡើង ពិធីបុណ្យជ្រមុជទឹក ពិធីតែងតាំងបព្វជិតភាព អ្វីគ្រប់យ៉ាងផ្សេងទៀត—គ្រប់កិច្ចសន្យា កាតព្វកិច្ច ការធ្វើពិធី នានាដែលទាក់ទងនឹងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធ នៃសេចក្ដីសន្យាយោងតាមក្រឹត្យវិន័យរបស់ទ្រង់ដែលបានប្រទានមក គឺជាផ្នែកមួយនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច » (*Doctrines of Salvation,* និពន្ធដោយ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ភាគទី ៣. [ ឆ្នាំ ១៩៥៤–៥៦ ], ១:១៥៨ បានដកអក្សរទ្រេតចេញ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣–៥ ដោយស្ងៀមស្ងាត់ រកមើលលទ្ធផលនៃការបដិសេធទៅនឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ដែលរួមមានសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍សេឡេស្ទាល ។

### *សូមប្រយ័ត្ន*

អ្នកអាចមានសិស្សនៅក្នុងថ្នាក់ដែលមានការលំបាកដើម្បីនិយាយពីអាពាហ៍ពិពាហ៍អស់កល្បជានិច្ច ។ ប្រធានបទនេះប្រហែលជាលំបាកសម្រាប់ពួកគេ បើសិនឪពុកម្ដាយពួកគេបានលែងលះគ្នា បើសិនជាឪពុក ម្ដាយ ឬ ទាំងឪពុក និងម្ដាយមិនមែនជាសមាជិកសាសនាចក្រ បើសិនពួកគេជាគ្រួសារដែលឪពុក ឬ ម្ដាយចុង ឬ ដោយសារតែស្ថានភាពគ្រួសារផ្សេងៗទៀត ។ នៅពេលអ្នកបង្រៀនពីគោលលទ្ធិនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច សូមប្រយ័ត្នចំពោះតម្រូវការ និង កង្វល់របស់សិស្សទាំងនេះ ។

- តើមានលទ្ធផលអ្វីខ្លះចំពោះការបដិសេធទៅនឹងសេចក្ដីសញ្ញាថ្មី និងអស់កល្បអស់កាលជានិច្ច ? ( នៅពេលសិស្សឆ្លើយសំណួរនេះ អ្នកអាចពន្យល់ថាពាក្យ *ជាប់ទោស* មានន័យថាបុគ្គលម្នាក់ត្រូវបានបញ្ឈប់នៅក្នុងដំណើរការដ៏អស់កល្បរបស់ខ្លួន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យដែលព្រះអម្ចាស់សន្យាដល់អស់អ្នកដែលស្មោះត្រង់ចំពោះសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ។

- យោងតាម ខ ៦,តើយើងទទួលអ្វីខ្លះបើសិនយើងស្មោះត្រង់ចំពោះ សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ? ( នៅពេលសិស្សឆ្លើយសំណួរនេះ អ្នកអាចចង់ចង្អុលបង្ហាញពីភាពផ្ទុយគ្នារវាងការជាប់ទោស ឬ រាំងមិនឲ្យរីកចម្រើន និង ការទទួល « ភាពពោរពេញនៃសិរីល្អ [ របស់ព្រះអម្ចាស់ ] » ) ។

សូមចង្អុលបង្ហាញថាជាញឹកញាប់មនុស្សធ្វើកិច្ចសន្យា ឬ កិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៧ ឲ្យឮៗ ។ សូមចាត់តាំងសិស្សពាក់កណ្ដាលថ្នាក់ ឲ្យរកមើលអ្វីដែលកើតឡើងលើមនុស្សដែលចុះកិច្ចសន្យានៅពេលពួកគេស្លាប់ ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ទៀត ស្វែងរកលក្ខខណ្ឌពីរសម្រាប់សេចក្ដីសញ្ញាដែលត្រូវបានភ្ជាប់បន្ទាប់ពីយើងស្លាប់ ។

- តើមានអ្វីកើតឡើង ចំពោះមនុស្សដែលធ្វើកិច្ចសន្យានោះ ? ( ពួកគេបានបញ្ចប់នៅពេលស្លាប់ ) ។
- យោងតាម ខ ៧, តើចំណុចពីរយ៉ាងដែលត្រូវតែកើតឡើងសម្រាប់សេចក្ដីសញ្ញាដើម្បីត្រូវបានភ្ជាប់បន្ទាប់ពីយើងស្លាប់នោះជាអ្វី ? ( វាត្រូវតែបានធ្វើឡើងតាមរយៈសិទ្ធិអំណាចបព្វជិតភាព ហើយវាត្រូវតែ « ចូល ហើយភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា » ) ។

សូមពន្យល់ថា « ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា ។. . . ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យាធ្វើជាសាក្សីដល់ព្រះវរបិតាថា ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ ហើយថាសេចក្ដីសញ្ញាដែលបានទាក់ទងជាមួយនឹងពួកគេត្រូវបានរក្សាទុក » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ព្រះវិញ្ញាណនៃសេចក្ដីសន្យា » scriptures.lds.org ) ។ បន្ទាប់មកសូមអញ្ជើញសិស្សឲ្យអាន ខ ៧ ម្ដងទៀត ហើយសង្ខេបវាជាសេចក្ដីថ្លែងការណ៍មួយនៃគោលលទ្ធិ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ ឧទាហរណ៍ អ្នកអាចសរសេរសេចក្ដីថ្លែងការណ៍ដែលស្រដៀងគ្នានេះ ទៅនឹងសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ៖ **មានតែសេចក្ដីសញ្ញាដែលត្រូវបានធ្វើឡើងតាមរយៈសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវប៉ុណ្ណោះ និង ត្រូវបានផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា បើមិនដូច្នេះទេ វានឹងត្រូវបញ្ចប់នៅពេលស្លាប់ ។**

ដើម្បីជួយសិស្សឲ្យពង្រីកការយល់ដឹងអំពីគោលលទ្ធិនេះ សូមឲ្យពួកគេនិយាយម្ដងទៀតជាឃ្លាស្របវិញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ ឧទាហរណ៍ អ្នកអាចសរសេរសេចក្ដីថ្លែងការណ៍ដែលស្រដៀងគ្នានេះ ទៅនឹងសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ៖ **នៅពេលសេចក្ដីសញ្ញាត្រូវបានធ្វើឡើងតាមរយៈសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ និង ត្រូវបានផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសញ្ញា វានឹងនៅជាប់ជានិរន្ដរ៍ ។**

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៨–១៤ ដោយពន្យល់ថា ព្រះអម្ចាស់បានបន្ដកំណត់លក្ខខណ្ឌនានានៃក្រឹត្យវិន័យ និង ពិធីបរិសុទ្ធរបស់ទ្រង់ ។ ទ្រង់បានប្រកាសថា អ្វីគ្រប់យ៉ាងដែលទ្រង់បានបង្កើតឡើងនឹងបន្ដនៅជានិរន្ដរ៍ ប៉ុន្ដែអ្វីផ្សេងទៀតនឹងត្រូវបំផ្លាញចោលនៅទីបញ្ចប់ ។

សូមអញ្ជើញសិស្សបួននាក់ឲ្យឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៥–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបពីយ៉ាងដែលបុរស និង ស្ត្រីអាចចូលទៅក្នុងអាពាហ៍ពិពាហ៍ជាមួយគ្នា ។ បន្ទាប់មកសូមអានឧទាហរណ៍ខាងក្រោមនេះឲ្យឮៗ ។ បន្ទាប់ពីឧទាហរណ៍និមួយៗ សូមសួរសិស្សថាតើមានសេចក្ដីពិតអ្វីខ្លះដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៥–១៨ អនុវត្តនៅក្នុងស្ថានភាពនោះ ។

ឧទាហរណ៍ ទី១ ៖ បុរស និង ស្ត្រីមួយគូស្រឡាញ់គ្នាគោរពច្បាប់ព្រហ្មចារីភាព ហើយរៀបការយ៉ាងរីករាយដោយអ្នកដឹកនាំរដ្ឋាភិបាលក្នុងមូលដ្ឋាន ។ ពួកគេពុំបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធឡើយ ។ ពិធីរៀបអាពាហ៍ពិពាហ៍របស់ពួកគេមានពាក្យ « រហូតទាល់តែសេចក្ដីស្លាប់បំបែកអ្នកចេញ » ។ ពីរបីឆ្នាំក្រោយមក ស្វាមីម្នាក់នោះបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ។ តើសេចក្ដីពិតណាខ្លះដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៥–១៧ អនុវត្តចំពោះរឿងនេះ ? ( ស្វាមី និង ភរិយានេះពុំបាននៅតែរៀបការជាមួយគ្នាទៀតឡើយ ) ។

ឧទាហរណ៍ទី ២ ៖ បុរស និង ស្ត្រីមួយគូបានរៀបការហើយ ។ ពួកគេសន្យានឹងគ្នាថា ពួកគេនឹងស្រឡាញ់គ្នាជានិច្ច ហើយថាពួកគេនឹងនៅជាមួយគ្នារហូត ប៉ុន្ដែពួកគេពុំបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធឡើយ ។ ពួកគេជឿថា ដោយសារសេចក្ដីស្រឡាញ់របស់ពួកគេ នោះព្រះនឹងអនុញ្ញាតឲ្យពួកគេនៅជាមួយគ្នាជានិរន្ដរ៍ ។ តើសេចក្ដីពិតណាខ្លះដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៨ អនុវត្តចំពោះរឿងនេះ ? ( អាពាហ៍ពិពាហ៍របស់ពួកគេនឹងមិនបន្ដទៀតឡើយបន្ទាប់ពីពួកគេស្លាប់ទៅ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–៣៣

*ព្រះអម្ចាស់សន្យាប្រទានពរជ័យដល់អស់អ្នកដែលគោរពតាមក្រឹត្យវិន័យនៃអាពាហ៍ពិពាហ៍សេឡេស្ទាល*

សូមអញ្ជើញសិស្សម្នាក់ឲ្យអានបទពិសោធន៍ខាងក្រោម ដែលបានចែកចាយដោយអែលឌើរ អែនរីក អរ ហ្វាឡាប៊ែឡានៃពួកចិតសិបនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលអ្វីដែលធ្វើឲ្យអែលឌើរ និង ស៊ិស្ទើរ ហ្វាឡាប៊ែឡា កើតទុក្ខ ហើយអ្វីដែលធ្វើឲ្យពួកគាត់រីករាយ ។



« នៅពេលខ្ញុំត្រឡប់មកពីបេសកកម្មវិញ ខ្ញុំបានជួបនឹងយុវនារីដ៏ស្រស់ស្អាតម្នាក់ ។. . . នាងបានធ្វើឲ្យខ្ញុំជាប់ចិត្ត តាំងពីគ្រាដំបូងដែលខ្ញុំបានជួបនាង ។

« ភរិយារបស់ខ្ញុំ បានដាក់គោលដៅរៀបការនៅព្រះវិហារបរិសុទ្ធ ទោះជាកាលនោះព្រះវិហារបរិសុទ្ធដែលជិតបំផុតតម្រូវឲ្យយើងធ្វើដំណើរច្រើនជាង ៦៤០០ គីឡូម៉ែត្រក៏ដោយ ។

« ពិធីរៀបការស៊ីវិលរបស់យើងមានទាំងរឿងរីករាយ និង កើតទុក្ខ ដ្បិតយើងបានរៀបការដែលមានកាលបរិច្ឆេទពេលយើងបញ្ចប់ជីវិតនេះ ។ មន្ត្រីនោះបានប្រកាសពាក្យថា ‹ ហើយឥឡូវនេះខ្ញុំសូមប្រកាសថាអ្នកគឺជាស្វាមី និង ភរិយា › ប៉ុន្តែបន្តិចក្រោយមកគាត់បាននិយាយថា ‹ ដល់ពេលស្លាប់អ្នកនឹងបែកគ្នា › ។

« ដូច្នេះដោយមានការលះបង់នោះយើងបានទិញសំបុត្រយន្តហោះទៅព្រះវិហារបរិសុទ្ធ មេសា អារីហ្សូណា ។

« នៅពេលយើងលុតជង្គង់ចុះលើអាសនានៃព្រះវិហារបរិសុទ្ធ អ្នកបម្រើដែលមានសិទ្ធិអំណាចម្នាក់បានប្រកាសពាក្យដែលខ្ញុំចង់ស្ដាប់យូរមកហើយ ដែលបានប្រកាសថាពួកយើងគឺជាស្វាមី និង ភរិយាសម្រាប់វេលាកាលនេះ និង រហូតដល់ភាពអស់កល្បជានិច្ច » (« The Home: The School of Life, » *Ensign* ឬ *Liahona*, ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១០២ ) ។

- ហេតុអ្វីគ្រួសារហ្វាឡាប៊ែឡា ពុំពេញចិត្តជាមួយនឹងអាពាហ៍ពិពាហ៍ស៊ីវិលរបស់ពួកគេ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–២១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យដែលព្រះអម្ចាស់សន្យាដល់អស់អ្នកដែលពិតចំពោះសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ។ ដោយសារវគ្គព្រះគម្ពីរនេះវែងហើយពិបាកយល់ នោះអ្នកអាចចាំបាច់ឈប់ពីរបីដងដើម្បីពន្យល់ ហើយឆ្លើយសំណួរ ។ ព័ត៌មានខាងក្រោមនេះអាចជួយដល់អ្នកបានដែរ ៖

ពាក្យ *នៅជាប់* មានន័យថាទទួល ឬ បន្ត ដូច្នេះឃ្លា « នៅជាប់ក្នុងសេចក្ដីសញ្ញារបស់យើង » (ខ ១៩) និង « នៅជាប់នឹងក្រឹត្យវិន័យរបស់យើង » (ខ ២១) មានន័យថាបន្តនៅពិតចំពោះសេចក្ដីសញ្ញា និង ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ។

ខ ១៩ មានការសន្យាដែលថា បើសិនបុរស និង ស្ត្រីរៀបការនៅក្នុង « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច » ហើយ « សេចក្ដីសញ្ញានោះបានភ្ជាប់ដល់ពួកគេដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា » នោះ ពួកគេ « នឹងត្រូវបានក្រោកឡើងនៅក្នុងដំណើររស់ឡើងវិញលើកទីមួយ ហើយ. . .គ្រងបល្ល័ង្កទាំងឡាយ នគរទាំងឡាយ ក្សត្របុរីទាំងឡាយ និង អំណាចទាំងឡាយ » ដរាបណាពួកគេ « នៅជាប់ក្នុងសេចក្ដីសញ្ញារបស់យើង ហើយមិនប្រព្រឹត្តិឃាតកម្ម ដោយការកំចាយឈាមអ្នកដែលគ្មានទោសឡើយ » ។ ( សូមមើលផងដរ គ. និង ស. ១៣២:២៧) ។

ឃ្លា « ពូជដ៏បរិបូរ និង បន្តបន្ទាប់ជារៀងដរាបតទៅ » (ខ ១៩) និង « ពួកគេមានបន្តទៅ » (ខ ២០) សំដៅលើការសន្យាដែលគ្រួសារ និង ពូជពង្សរបស់យើងអាចបន្តរហូតអស់កល្បជានិច្ច ។

សូមសរសេរ *បើសិន*________________________________________ *នោះ*________________________ នៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សឲ្យបំពេញចន្លោះដើម្បី សង្ខេបការសន្យាដែលបានផ្ដល់ឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–២១ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ ពួកគេអាចរកឃើញគោលការណ៍ដូចខាងក្រោមនេះ ៖

**បើសិនបុរសម្នាក់ និងស្ត្រីម្នាក់រស់នៅតាមសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះពួកគេនឹងទទួលបានភាពតម្កើងឡើង និងសិរីល្អ ។**

**បើសិនបុរសម្នាក់ និងស្ត្រីម្នាក់នៅជាប់នឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះពួកគេនឹងមានការកើនឡើងនៃពូជពង្សដ៏អស់កល្បជានិច្ច ។**

**បើសិនបុរសម្នាក់ និងស្ត្រីម្នាក់នៅជាប់នឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះអាពាហ៍ពិពាហ៍របស់ពួកគេនឹងមានប្រសិទ្ធិភាពរហូតដល់អស់កល្បអស់កាលជានិច្ច ។**

**បើសិនបុរសម្នាក់ និងស្ត្រីម្នាក់នៅជាប់នឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះពួកគេនឹងប្រែក្លាយដូចជាព្រះ ។**

សូមអានឧទាហរណ៍ខាងក្រោមនេះ ៖

ឧទាហរណ៍ទី៣ ៖ យុវជន និង យុវនារីម្នាក់បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធដោយសិទ្ធិអំណាចបព្វជិតភាព ។ ពួកគេទាំងពីររស់នៅដោយស្មោះត្រង់ ហើយគោរពសេចក្ដីសញ្ញារបស់ខ្លួន ។ តើសេចក្ដីពិតណាខ្លះដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–២១ អនុវត្តចំពោះរឿងនេះបន្ទាប់ពីពួកគេស្លាប់ទៅនោះ ? ( អាពាហ៍ពិពាហ៍របស់ពួកគេបន្តជានិរន្តរ៍ ។ ពួកគេនឹងក្លាយដូចជាព្រះវរបិតាដែលគង់នៅឋានសួគ៌ ហើយនឹងត្រូវបានប្រទានពរជាមួយនឹងសិរីល្អភាពតម្កើងឡើង និង គ្រួសាររស់កល្បជានិច្ច ) ។

- តើអ្នកគិតថាស្វាមី និង ភរិយាត្រូវតែធ្វើអ្វីខ្លះដើម្បីនៅជាប់នឹងសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ ? ( ចម្លើយអាចរួមមាន រស់នៅតាមព្រះបន្ទូលរបស់ព្រះ គោរពប្រតិបត្តិតាមគ្រប់អស់ទាំងពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ មានគុណធម៌ និង សក្តិសម ស្រឡាញ់គ្នា ធ្វើការរួមគ្នាដើម្បីធ្វើជាឪពុកម្ដាយល្អ ចិញ្ចឹមកូនចៅដោយសេចក្ដីស្រឡាញ់ និង សុចរិត ហើយត្រឡប់ទៅព្រះវិហារបរិសុទ្ធជាមួយគ្នាជាទៀងទាត់ ) ។

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:២២–២៥ ដោយស្ងៀមស្ងាត់ដោយផ្ដោតយកចិត្តទុកដាក់ជាពិសេសចំពោះ ការពិពណ៌នារបស់ព្រះអម្ចាស់អំពីពាក្យ « ទ្វារ » និង ពាក្យ « ផ្លូវ » ដែលនាំទៅកាន់ភាពតម្កើងឡើង ។ ពីមុនពួកគេអាន សូមពន្យល់ថាពាក្យ *ចង្អៀត* នៅក្នុង ខ ២២ មានន័យថាតូច ឬ យ៉ាងប្រិតប្រៀនដែលមិនឲ្យអ្វីមួយឆ្លងកាត់បាន ។

- តើរូបភាពនៃទ្វារដ៏ធំ និង ផ្លូវដ៏ទូលាយអាចតំណាងឲ្យទស្សនៈនៅក្នុងសង្គមបច្ចុប្បន្នអំពីទំនាក់ទំនងគូស្វាមីភរិយា និង អាពាហ៍ពិពាហ៍តាមរបៀបណាខ្លះ ? តើទស្សនៈទាំងនេះផ្ទុយទៅនឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍យ៉ាងដូចម្ដេច ?

- យោងតាម ខ ២២ និង ខ ២៥, ហេតុអ្វីមានមនុស្សជាច្រើនបានបរាជ័យក្នុងការចូលតាមផ្លូវចង្អៀតដែលនាំទៅរកភាពតម្កើងឡើងយ៉ាងដូច្នេះ ? ( ពួកគេពុំទទួលព្រះយេស៊ូវគ្រីស្ទ ពុំចង់ស្គាល់ទ្រង់ ឬ ពុំនៅជាប់នៅក្នុងក្រឹត្យវិន័យទ្រង់ ) ។

- យោងតាម ខ ២១–២៤, តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះដើម្បីទទួលជីវិតដ៏នៅអស់កល្បជានិច្ច ? ( សូមសង្ខេបចម្លើយរបស់សិស្ស ដោយសរសេរនូវគោលការណ៍ខាងក្រោមនេះលើក្ដារខៀន ៖ **ដើម្បីទទួលបានភាពតម្កើងឡើង និង ជីវិតអស់កល្បជានិច្ចយើងត្រូវតែស្គាល់ព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ ប្រែក្លាយដូចជាពួកទ្រង់ ហើយនៅជាប់ជាមួយក្រឹត្យវិន័យរបស់ទ្រង់**) ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:២៩–៣៣ ដោយពន្យល់ថា អ័ប្រាហាំស្មោះត្រង់ និង គោរពតាមក្រឹត្យវិន័យនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចរបស់ព្រះអម្ចាស់ ហើយថាលោកបានទទួលការសន្យានៃការកើនឡើងនៃពូជពង្សដ៏នៅអស់កល្បជានិច្ច ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងធ្វើតាមក្រឹត្យវិន័យរបស់ព្រះ នោះយើងអាចរស់នៅជាមួយទ្រង់ ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមមើលសំណួរដែលអ្នកបានសរសេរនៅលើក្ដារខៀនពីមុនចាប់ផ្ដើមថ្នាក់រៀន ។ សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរទាំងនេះក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយ អ្នកអាចចង់អញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ចែកចាយអារម្មណ៍របស់ពួកគេជាមួយសិស្សក្នុងថ្នាក់ទាំងមូល ។

សូមបញ្ចប់ដោយបង្ហាញរូបភាពក្រុមគ្រួសាររបស់អ្នក ។ សូមចែកចាយអារម្មណ៍ និង ទីបន្ទាល់របស់អ្នកអំពីពរជ័យនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច ។ សូមលើកទឹកចិត្តសិស្សឲ្យរៀបចំខ្លួនក្នុងពេលឥឡូវនេះ ដើម្បីទៅព្រះវិហារបរិសុទ្ធ ហើយរៀបអាពាហ៍ពិពាហ៍សម្រាប់ភាពអស់កល្បជានិច្ច ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យដែលបានសន្យានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ និង សេចក្ដីអំណរដែលបានមកពីការរៀបចំខ្លួនសម្រាប់អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ។

មេរៀនទី ១៤០

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–២, ៣៤–៦៦

## បុព្វកថា

ខណៈដែលព្យាការី យ៉ូសែប ស្ម៊ីធ កំពុងធ្វើកំណែថ្មីដ៏បំផុសគំនិតនៃព្រះគម្ពីរ ប៊ីបនៅឆ្នាំ ១៨៣១ នោះលោកបានសុំព្រះអម្ចាស់ប្រទានការយល់ដឹងអំពី លោកអយ្យកោជំនាន់បុរាណដែលមានភរិយាច្រើនជាងម្នាក់ ។ នៅពេលនោះ ព្យាការីបានចាប់ផ្ដើមទទួលវិវរណៈនេះជាចម្លើយចំពោះសំណួររបស់លោក ។ ប៉ុន្មាន ឆ្នាំក្រោយមក ព្រះអម្ចាស់បានបញ្ជាឲ្យព្យាការី និង ពួកបរិសុទ្ធថ្ងៃចុងក្រោយផ្សេង ទៀតឲ្យរស់នៅតាមគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ នៅក្នុង ខែ កក្កដា ឆ្នាំ ១៨៤៣ ខណៈដែលសាសនាចក្រមានទីស្នាក់ការកណ្ដាលនៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ នោះព្យាការីបានកត់ត្រាវិវរណៈដែលលោកបានទទួល ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ មានកត់ត្រាអំពីការបង្រៀនរបស់ព្រះអម្ចាស់ ទាក់ទងនឹងអាពាហ៍ពិពាហ៍ពហុពន្ធភាព រួមទាំងពាក្យទូន្មានដល់យ៉ូសែប និង អិមម៉ា ស្ម៊ីធ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–២, ៣៤–៤៨

*ព្រះអម្ចាស់បើកសម្ដែងគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព*

សូមចាប់ផ្ដើមដោយពន្យល់ថា ខណៈដែលយ៉ូសែប ស្ម៊ីធ កំពុងធ្វើការបកប្រែដ៏បំផុសគំនិតនៃព្រះគម្ពីរសញ្ញាចាស់ នៅក្នុងឆ្នាំ ១៨៣១ នោះលោកបានអានអំពីទំនៀមទម្លាប់នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពរបស់ព្យាការីសម័យបុរាណ ( ក៏ត្រូវបានហៅពហុពន្ធភាពផងដែរ ) ។ ក្នុងទំនៀមទម្លាប់នេះ បុរសម្នាក់ត្រូវបានរៀបការជាមួយភរិយាដែលកំពុង នៅមានជីវិតជាច្រើននាក់ ។ ព្យាការីបានសិក្សាព្រះគម្ពីរ ពិចារណាពីអ្វីដែលបានរៀន ហើយទីបំផុតបានយកសំណួរអំពីអាពាហ៍ ពិពាហ៍ពហុពន្ធភាពសួរដល់ព្រះវរបិតាដោយការអធិស្ឋាន ។

សូមសរសេរ *លោកុប្បត្តិ ១៦:១–៣* នៅលើក្ដារខៀន ។ សូមពន្យល់ថាខគម្ពីរទាំងនេះ ពិពណ៌នាអំពីសកម្មភាពរបស់សារ៉ាយ និង អាប់រ៉ាមដែលក្រោយមកហៅថា សារ៉ា និង អ័ប្រាហាំ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយគិតអំពីសំណួរនានាដែលពួកគេអាចមានអំពីព្រឹត្តិការណ៍នៅក្នុងជីវិតរបស់អាប់រ៉ាម និង សារ៉ាយ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្យាការីយ៉ូសែប ស្ម៊ីធ បានសួរនៅពេលលោកបានសិក្សាវគ្គបទគម្ពីរនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ទាក់ទងនឹងការអនុវត្តនៃអាពាហ៍ពិពាហ៍ ពហុពន្ធភាព ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( អ្នកអាចពន្យល់ថាពាក្យ *ប្រពន្ធចុង* គឺជាពាក្យមួយ ដែលត្រូវបានប្រើដើម្បីប្រាប់ពីស្ត្រីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលនៅសម័យ និង វប្បធម៌ដែលពួកគេបានរស់នៅ ដែលជា ស្ត្រីដែលបានរៀបការពេញច្បាប់នឹងបុរសម្នាក់ ប៉ុន្តែមានឋានៈក្នុងសង្គមទាបជាងប្រពន្ធដើម ។ ប្រពន្ធចុងមិនមែនជាផ្នែកនៃ ទំនៀមទម្លាប់នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងសម័យកាន់កាប់ត្រួតត្រារបស់យើងឡើយ ) ។

សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *ហេតុអ្វីបានជាព្រះអម្ចាស់បញ្ជាបុរស និង ស្ត្រីសុចរិតទាំងនោះ ឲ្យធ្វើតាម គោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅជំនាន់នោះ ?*

សូមពន្យល់ថានៅក្នុងការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២, សិស្សអាចរកឃើញចម្លើយចំពោះ សំណួរទាំងនោះនៅលើក្ដារខៀន និង សំណួរផ្សេងទៀតដែលពួកគេអាចមានទាក់ទងនឹងអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សូម អញ្ជើញពួកគេឲ្យសរសេរគោលលទ្ធិ និង គោលការណ៍ដែល ពួកគេរកឃើញអំឡុងពេលការសិក្សារបស់ពួកគេថ្ងៃនេះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៤–៣៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុង ថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលអ័ប្រាហាំ និងសារ៉ាបានចាប់ផ្ដើមអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។

> *ប្រើសម្ភារៈដែលបានអនុមតិ*
>
> សម្ភារៈកម្មវិធីសិក្សារបស់ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានត្រូវបានផ្ដល់ឲ្យជាធនធានសំខាន់ដើម្បីជួយអ្នករៀបចំ និង បង្រៀនមេរៀនឲ្យមានប្រសិទ្ធិភាព ។ អ្នកអាចប្រើធនធានបន្ថែមទាំងឡាយមានដូចជាទស្សនាវដ្ដីសាសនាចក្រ នៅពេលអ្នកគាំទ្រការយល់ដឹងរបស់សិស្សអំពីបណ្ដុំបទគម្ពីរ ។ ធនធានដទៃទៀតមិនគួរត្រូវបានប្រើដើម្បីស្មាន ឬ បំផ្លើស ប្រធានបទមេរៀន ឬ បង្រៀនគំនិតនានាដែលពុំបានបង្កើតឡើងដោយសាសនាចក្រឡើយ ។ សូម្បីតែមានធនធានដែលបានបោះពុម្ពពីមុនក៏ដោយក៏វានៅតែអាចមិនសមរម្យសម្រាប់ប្រើនៅក្នុងថ្នាក់រៀនដែរ ។ សូមជ្រើសរើសសម្ភារៈមេរៀនដោយឆ្លាតវៃ ដូច្នេះមេរៀនអាចបង្កើតឲ្យសិស្សមានសេចក្ដីជំនឿ និង ទីបន្ទាល់ ។

- យោងតាម ខ ៣៤, ហេតុអ្វីក៏សារ៉ាអនុញ្ញាតឲ្យអ័ប្រាហាំយកភរិយាមួយទៀត ? តើការណ៍នេះបង្រៀនយើងអ្វីខ្លះ អំពីគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ? ( នៅពេលសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **អាពាហ៍ពិពាហ៍ពហុពន្ធភាពត្រូវបានអនុមតិពីព្រះអម្ចាស់ តែនៅពេលដែលទ្រង់បញ្ជាឲ្យធ្វើតែប៉ុណ្ណោះ**) ។
- តើការគោរពប្រតិបត្តិតាមរបស់សារ៉ា និង អ័ប្រាហាំបានជួយបំពេញអ្វីខ្លះ ? ( ការសន្យារបស់ព្រះអម្ចាស់ចំពោះអ័ប្រាហាំរួមមានការសន្យាថាអ័ប្រាហាំនឹងមានពូជពង្សច្រើនរាប់មិនអស់ដូចជាផ្កាយ [ សូមមើល លោកុប្បត្តិ ១៥:៥] ) ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតអំពីគោលការណ៍ដែលអ្នកបានសរសេរនៅលើក្ដារខៀន សូមស្នើឲ្យពួកគេសរសេរ *យ៉ាកុប ២:២៧, ៣០* នៅក្នុងព្រះគម្ពីររបស់ពួកគេនៅក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៤ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឲ្យឮៗ ។ សូមចង្អុលបង្ហាញថាអាពាហ៍ពិពាហប្ដីមួយប្រពន្ធមួយ ( អាពាហ៍ពិព៌ាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់ ) គឺជាបទដ្ឋានរបស់ព្រះចំពោះអាពាហ៍ពិពាហ៍ លុះត្រាតែទ្រង់បញ្ជាឲ្យធ្វើប៉ុណ្ណោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៧–៣៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលពិពណ៌នាអំពីឧទាហរណ៍នានាពេលដែលព្រះអម្ចាស់បានបញ្ជាឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៩, ៤១–៤៣ ដោយពន្យល់ថា ព្រះអម្ចាស់បានបញ្ជាក់ថានៅពេលមនុស្សអនុវត្តគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពអាស្រ័យលើបទបញ្ញារបស់ទ្រង់ នោះពួកគេពុំមានកំហុសនឹងអំពើបាបនៃអំពើកំផិតឡើយ ។ ទោះជាយ៉ាងណាក្ដី ប្រសិនបើនរណាម្នាក់ដែលអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពក្នុងលក្ខខណ្ឌណាមួយដែលព្រះអម្ចាស់ពុំបានបញ្ជា នោះពួកគេធ្វើខុសនឹងអំពើកំផិតហើយ ។ ( សូមកត់ចំណាំថាពាក្យ *ត្រូវបំផ្លាញចោល* នៅក្នុង ខ ៤១ បង្ហាញថា អស់អ្នកដែលរំលងសេចក្ដីសញ្ញាដ៏ពិសិដ្ឋរបស់ខ្លួន នោះនឹងត្រូវបំបែកចេញពីព្រះ និងពីវាស្ត្រនៃសេចក្ដីសញ្ញារបស់ទ្រង់ [ សូមប្រៀបធៀប កិច្ចការ ៣:២២–២៣; នីហ្វៃទី ១ ២២:២០] ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤០ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាទ្រង់នឹងធ្វើវា ។

- យោងតាម ខ ៤០ តើព្រះអម្ចាស់នឹងធ្វើអ្វី ? (សាងឡើងវិញនូវការណ៍គ្រប់យ៉ាង ។ សូមពន្យល់ថាពាក្យ « ការណ៍គ្រប់យ៉ាង » សំដៅលើច្បាប់ និងពិធីបរិសុទ្ធនៃដំណឹងល្អនានាដែលត្រូវបានបើកសម្ដែងនៅក្នុងសម័យកាន់កាប់ត្រួតត្រាមុនៗ ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ៖ **បទបញ្ញត្តិដើម្បីរស់នៅតាមច្បាប់អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងថ្ងៃចុងក្រោយ គឺជាផ្នែកនៃការស្ដារឡើងវិញនៃការណ៍ទាំងឡាយ** ។ [ សូមមើលផងដែរ កិច្ចការ ៣:២០–២១] ) ។

> ***ចៀសវាងការប៉ាន់ស្មាន***
>
> សូមកុំប៉ាន់ស្មានអំពីអាពាហ៍ពិពាហ៍ពហុពន្ធភាពថាជាតម្រូវការមួយសម្រាប់នគរសេឡេស្ទាលឡើយ ។ យើងពុំមានចំណេះដឹងថា អាពាហ៍ពិពាហ៍ពហុពន្ធភាពនឹងក្លាយជាតម្រូវការមួយសម្រាប់ភាពតម្កើងឡើងទេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤៥, ៤៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានប្រគល់ដល់យ៉ូសែប ស៊្មីធ ឲ្យនាំមកនូវការសាងឡើងវិញនូវការណ៍គ្រប់យ៉ាង ។

- តើព្រះអម្ចាស់បានប្រគល់អ្វីដល់យ៉ូសែប ស៊្មីធ ដើម្បីនាំមកនូវការសាងឡើងវិញនូវការណ៍គ្រប់យ៉ាង ? ( កូនសោ និង អំណាចនៃបព្វជិតភាព ) ។
- តើយើងរៀនអ្វីខ្លះពី ខ ៤៥ និង ៤៨ អំពីអាពាហ៍ពិពាហ៍ពហុពន្ធភាព ? ( នៅពេលសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះលើក្ដារខៀន ៖ **អាពាហ៍ពិពាហ៍ពហុពន្ធភាពអាចត្រូវបានអនុញ្ញាតឲ្យមាន តែតាមរយៈកូនសោនៃបព្វជិតភាពដែលត្រូវបានប្រទានដល់ប្រធាននៃសាសនាចក្រតែប៉ុណ្ណោះ**) ។

សូមពន្យល់ថានៅដើមដំបូងនៃសម័យកាន់កាប់ត្រួតត្រានេះ ក្នុងផ្នែកមួយនៃការស្ដារឡើងវិញនៃការណ៍ទាំងឡាយ ព្រះអម្ចាស់បានបញ្ជាដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយជំនាន់ដើម មួយចំនួនឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព តាមរយៈកូនសោបព្វជិតភាពដែលបានកាន់ដោយព្យាការីយ៉ូសែប ស៊្មីធ និង ប្រធានសាសនាចក្របន្តបន្ទាប់ទៀត—ព្រិកហាំ យ៉ង់ យ៉ូហាន ថេលើរ និង វិលហ្វូឌ វូឌ្រូហ្វ ។ នៅឆ្នាំ ១៨៩០ ប្រធាន វូឌ្រូហ្វ ដោយប្រើកូនសោបព្វជិតភាពដដែលនោះ បានទទួលវិវរណៈថាការអនុវត្តនៃអាពាហ៍ពិពាហ៍ពហុពន្ធភាពគួរតែបញ្ចប់ ( សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ១) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤៩–៦៦

*ព្រះអម្ចាស់ប្រទានព្រះឱវាទដល់យ៉ូសែប និង អិមម៉ា ស៊្មីធ ទាក់ទងនឹងអាពាហ៍ពិពាហ៍ពហុពន្ធភាព*

សូមពន្យល់ថា ព្យាការីយ៉ូសែប ស៊្មីធ មានការស្ទាក់ស្ទើរដើម្បីចាប់ផ្ដើមអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ លោកបានថ្លែងថា លោកមិនបានចាប់ផ្ដើមអនុវត្តវាឡើយ រហូតដល់លោកត្រូវបានព្រមានថាលោកនឹងត្រូវបំផ្លាញចោលបើសិនលោកមិនគោរពធ្វើតាមទេនោះ ( សូមមើល « Plural Marriage » *Historical Record,* ខែ ឧសភា ឆ្នាំ ១៨៨៧ ទំព័រ ២២២ ) ។ ដោយសារការខ្វះឯកសារប្រវត្តិសាស្ត្រ នោះយើងពុំដឹងអំពីការព្យាយាមដំបូងរបស់យ៉ូសែប ស៊្មីធ ដើម្បីធ្វើតាមបទបញ្ញត្តិនេះឡើយ ។ ទោះជាយ៉ាងណាក៏ដោយនៅឆ្នាំ ១៨៤១ ព្យាការីបានចាប់ផ្ដើមគោរពតាមព្រះបញ្ញត្តិនេះ ហើយបង្រៀនវាដល់សមាជិកមួយចំនួននៃសាសនាចក្រ ហើយបីឆ្នាំជាងក្រោយមក លោកបានរៀបការប្រពន្ធបន្ថែមទៀត ស្របទៅតាម

ការបញ្ជារបស់ព្រះអម្ចាស់ ។ ការគោរពប្រតិបត្តិតាមរបស់ព្យាការីយ៉ូសែប ស៊្មីធចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីអនុវត្ត អាពាហ៍ពិពាហ៍ពហុពន្ធភាពគឺជាការសាកល្បងមួយនៃសេចក្ដីជំនឿសម្រាប់លោក និង អិមម៉ាដែលជាភរិយាលោក ដែលលោក ស្រឡាញ់យ៉ាងខ្លាំង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤៩–៥០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ រកមើល ពរជ័យដែលព្រះអម្ចាស់បានសន្យាចំពោះយ៉ូសែប ស៊្មីធ ។

- តើពរជ័យអ្វីខ្លះដែលព្រះអម្ចាស់បានសន្យាចំពោះយ៉ូសែប ស៊្មីធ ?
- យោងតាម ខ ៥០, ហេតុអ្វីបានជាព្រះអម្ចាស់សន្យាពរជ័យទាំងនោះចំពោះយ៉ូសែប ស៊្មីធ ?

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៥២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើល ព្រះឱវាទដែលព្រះអម្ចាស់បានប្រទានដល់អិមម៉ា ស៊្មីធ ។

- យោងតាម ខ ៥២, តើអិមម៉ាបានទទួលព្រះឱវាទអ្វីខ្លះ ? ( « អស់អ្នកណាដែលត្រូវបានប្រទានដល់យ៉ូសែប ស៊្មីធជាអ្នក បម្រើយើង » សំដៅលើអស់អ្នកដែលបានផ្សារភ្ជាប់ជាមួយនឹងយ៉ូសែប ស៊្មីធ ) ។

សូមពន្យល់ថាក្រៅពីការបញ្ជាដល់អិមម៉ា ឲ្យទទួលអស់អ្នកដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងស្វាមីខ្លួនហើយ ព្រះអម្ចាស់បាន បញ្ជាឲ្យគាត់នៅជាប់នឹងក្រឹត្យវិន័យរបស់ទ្រង់ ហើយអភ័យទោសដល់យ៉ូសែបចំពោះការប្រព្រឹត្តិរបស់លោក ។ សូមអញ្ជើញ សិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៥៦ ដោយស្ងៀមស្ងាត់ ដើម្បីរៀនពីអ្វីដែលព្រះអម្ចាស់បានសន្យាដល់ អិមម៉ា ស៊្មីធ ។

- តើព្រះអម្ចាស់បានសន្យាអ្វីជាមួយអិមម៉ា បើសិនគាត់នឹងគោរពតាមបទបញ្ញារបស់ទ្រង់នោះ ?

សូមពន្យល់ថានៅក្នុងឆ្នាំ ១៨៤១ យ៉ូសែប ស៊្មីធ បានចាប់ផ្ដើមបង្រៀនដល់បុរស និង ស្ត្រីស្មោះត្រង់ផ្សេងទៀតអំពីគោលការណ៍ នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនេះ ។ នៅពេលដំបូងពួកគេក៏មានការលំបាកដើម្បីយល់ និង ទទួលយកគោលការណ៍នេះ ដែរ ។ ឧទាហរណ៍ នៅពេលដំបូងដែលព្រិកហាំ យ៉ង់បានរៀនពីបទបញ្ញត្តិនេះដើម្បីអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព នោះ លោកបានមានប្រសាសន៍ថា លោកមានអារម្មណ៍ថាលោកចង់ស្លាប់ជាជាងយកប្រពន្ធច្រើន ( សូមមើល ស៊ូសា យ៉ង់ ហ្គេត និង លៀ ឌី វីតស្វ, [ ឆ្នាំ ១៩៣០ ] ទំព័រ ៣២១ ) ។ ទោះបីជាសមាជិកសាសនាចក្រដ៏ស្មោះត្រង់ទាំងនេះមានការស្ទាក់ស្ទើរ និង លំបាកចំពោះបទបញ្ញត្តិនេះនៅពេលដំបូងក៏ដោយ ក៏ពួកគេបានទទួលការបញ្ជាក់រៀងៗខ្លួនតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយ ទទួលយកគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនេះ ។ វីលេត គិមបុល ភរិយាទីមួយរបស់អែលឌើរ ហេ៊ើប៊ើរ ស៊ី គិមបុល បានទទួល ហើយធ្វើតាមគោលលទ្ធិនៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ហើយ « ពុំឆ្ងល់ឡើយថាការបញ្ជានៃអាពាហ៍ពិពាហ៍ ពហុពន្ធភាពនោះគឺមកពីព្រះ ដ្បិតព្រះអម្ចាស់បានបើកសម្ដែងវាដល់គាត់នៅក្នុងចម្លើយចំពោះការអធិស្ឋាន » ( Helen Mar Kimball, នៅក្នុង Orson F. Whitney, *Life of Heber C. Kimball* [ ឆ្នាំ ១៩៦៧ ] ទំព័រ ៣២៥ សូមមើល ផងដែរ ទំព័រ ៣២៦–២៨ ) ។

ការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពបាននាំឲ្យមានឧបសគ្គបន្ថែមទៀត ។ ដ្បិតដំបូងការអនុវត្តនេះធ្វើឡើងដោយលាក់លាម នោះពាក្យចចាមអារ៉ាមបានចាប់ផ្ដើមរាលដាលអំពីអ្នកដឹកនាំសាសនាចក្របានរៀបការប្រពន្ធថែមទៀត ។ ពាក្យចចាមអារ៉ាម ទាំងនេះបង្ខូចបង្កាច់សេចក្ដីពិត បានបង្ខូចឈ្មោះរបស់ព្យាការី និង អ្នកដឹកនាំសាសនាចក្រដទៃទៀត ហើយបានបង្កឲ្យមាន ការបៀតបៀនកើនឡើងប្រឆាំងនឹងពួកបរិសុទ្ធ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៦៣ ឲ្យឮៗ ដោយចាប់ផ្ដើមជាមួយឃ្លា « ដ្បិតពួកគេត្រូវបានប្រគល់ដល់ គាត់ » ។ ពីមុនអ្នកអាន សូមពន្យល់ថាខគម្ពីរនេះជួយយើងឲ្យយល់ពី ហេតុផលមួយដែលព្រះអម្ចាស់បានបញ្ជាយ៉ូសែប ស៊្មីធ និង មនុស្សដទៃផ្សេងទៀតដើម្បីអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលគោលបំណង ពិសេសនោះ ។

- តើបទបញ្ញត្តិអ្វីដែលព្រះអម្ចាស់បានមានបន្ទូលនៅក្នុង ខ ៦៣ ? ( ព្រះបញ្ញត្តិឲ្យបង្កើតកូនឲ្យចម្រើនជាច្រើន ឡើង ហើយមានពេសពេញលើផែនដី) ។ តើការបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ហើយមានពេសពេញលើផែនដី មានន័យយ៉ាងណា ? ( បង្កើតកូនចៅ ) ។

សូមចង្អុលបង្ហាញឃ្លាខាងក្រោមនៅក្នុង ខ ៦៣: « ដ្បិតការណ៍នេះហើយទើបកិច្ចការនៃព្រះវរបិតារបស់យើងបានបន្តទៅ » ។

- តើការមានកូនចៅធ្វើឲ្យឪពុកម្ដាយក្លាយជាផ្នែកមួយនៃការបន្តកិច្ចការរបស់ព្រះវរបិតាសួគ៌យ៉ាងដូចម្ដេច ?

ជាចំណែកនៃការពិភាក្សានេះ អ្នកអាចអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃ ពួកសាវកដប់ពីរនាក់ ៖



« នៅពេលកូនម្នាក់បានកើតមកដោយឪពុក និងម្ដាយ នោះពួកគេកំពុងបំពេញផ្នែកនៃផែនការរបស់ព្រះវរបិតាសួគ៌ដើម្បី នាំកូនចៅមកលើផែនដីនេះ ។ ព្រះអម្ចាស់មានបន្ទូលថា ‹ នេះហើយជាកិច្ចការរបស់យើងនិង សិរីល្អរបស់យើង—គឺដើម្បីនាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស › [ម៉ូសេ ១:៣៩] ។ ពីមុនពួកគេមានអមតភាព នោះពួកគេត្រូវតែមានជីវិតរមែងស្លាប់សិន » (Children » *Ensign* ឬ *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៨ ) ។

- ផ្អែកលើអ្វីដែលអ្នកបានរៀនពី ខ ៦៣, តើអ្វីទៅជាមូលហេតុមួយដែលព្រះអម្ចាស់បានបញ្ជាឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ? ( បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បានបញ្ជាឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពដើម្បីផ្ដល់ឱកាសបន្ថែមទៀតដល់ប្រជារាស្ដ្ររបស់ទ្រង់ចិញ្ចឹមកូនចៅសុចរិតថ្វាយទ្រង់ ។** អ្នកអាចអាន យ៉ាកុប ២:៣០) ។

សូមមើលសំណួរដែលអ្នកបានសរសេរលើក្ដារខៀននៅពេលជិតចាប់ផ្ដើមថ្នាក់រៀន ៖ *ហេតុអ្វីបានជាព្រះអម្ចាស់បញ្ជាឲ្យបុរស និង ស្ដ្រីសុចរិតទាំងនោះ ឲ្យធ្វើតាមគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅជំនាន់នោះ ?* អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យសង្ខេបដល់សិស្សនៅក្នុងថ្នាក់ អំពីអ្វីដែលពួកគេបានរៀនពីការសិក្សារបស់ខ្លួនដកស្រង់ពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ និង យ៉ាកុប ២:២៧, ៣០ ដែលជួយពួកគេឲ្យឆ្លើយសំណួរនេះ ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីព្យាការីយ៉ូសែប ស្ម៊ីធ ហើយថាលោកបានទទួល ព្រមទាំងគោរពតាមវិវរណៈពីព្រះ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩–១៣១; ១៣២:១–៣៣ ( មេរៀនទី ២៨)

## ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩–១៣១; ១៣២:១–៣៣ ( មេរៀនទី ២៨ ) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣)

នៅពេលសិស្សបានសិក្សាការបង្រៀនមួយចំនួនរបស់ព្យាការីយ៉ូសែប ស្ម៊ីធ នោះពួកគេបានរៀនថា សារទូតពិតដែលបានបញ្ជូនមកពីព្រះវរបិតាសួគ៌នឹងមិនបោកបញ្ឆោតយើងឡើយ ។ ពួកគេក៏បានឃើញថាគោលលទ្ធិទាក់ទងនឹងសមាជិកនៃក្រុមព្រះ ។ សិស្សបានរៀនថា ទំនាក់ទំនងដែលយើងអាចមាននៅក្នុងឋានសួគ៌គឺដូចគ្នាទៅនឹងទំនាក់ទំនងទាំងអស់ ដែលយើងរីករាយនៅលើផែនដីនេះ ប៉ុន្តែវានឹងរួមបញ្ចូលជាមួយសិរីរុងរឿងនៃភាពអស់កល្បជានិច្ច ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១)

នៅក្នុងមេរៀននេះ សិស្សបានរៀនអំពីគោលការណ៍ខាងក្រោម ៖ មានព្រះតែមួយអង្គគត់ដែលជ្រាបដឹងពីពេលវេលាពិតប្រាកដនៃការយាងមកជាលើកទីពីរ ។ ចំណេះដឹង និង បញ្ញាដែលយើងបានទទួលនៅក្នុងជីវិតនេះ នោះនឹងនៅជាប់នឹងយើងក្នុងដំណើររស់ឡើងវិញ ។ ប្រសិនបើយើងចង់ទទួលបានពរជ័យពីព្រះ នោះយើងត្រូវតែគោរពតាមក្រឹត្យវិន័យដែលគ្រប់ព្រះពរទាំងអស់ផ្អែកទៅលើ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១)

នៅពេលសិស្សបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១, នោះ ពួកគេបានឃើញថា ដើម្បីទទួលបានកម្រិតខ្ពស់បំផុតនៃនគរសេឡេស្ទាល នោះយើងត្រូវតែចូលទៅក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ ។ សិស្សក៏បានរៀនផងដែរអំពីអត្ថន័យនៃឃ្លា « ពាក្យព្យាករណ៍ដ៏ពិតជាង » និង បានរៀនអំពីលក្ខណៈនៃវិញ្ញាណរបស់យើង ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–៣៣)

នៅក្នុងមេរៀននេះសិស្សបានរៀនថា នៅពេលសេចក្ដីសញ្ញាត្រូវបានធ្វើឡើងតាមរយៈសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ និង ត្រូវបានផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសញ្ញា វានឹងជាប់ជានិរន្តរ៍ ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើបុរសម្នាក់ និងស្ត្រីម្នាក់នៅជាប់នឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះពួកគេនឹងមានការកើនឡើងនៃពូជពង្សដ៏អស់កល្បជានិច្ច ។

## សេចក្ដីផ្ដើម

សិស្សបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–៣៣ នៅក្នុងមេរៀនរបស់ខ្លួននៅថ្ងៃទី ៤ ។ មេរៀនថ្ងៃនេះអាចជួយពួកគេឲ្យយល់បានកាន់តែប្រសើរឡើងពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ ទាំងអស់ និង គោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សិស្សនឹងបង្កើនការយល់ដឹងរបស់ខ្លួនអំពីមូលហេតុ ដែលអាពាហ៍ពិពាហ៍ពហុពន្ធភាពត្រូវបានអនុវត្តកាលពីសម័យមុន ។

*កំណត់ចំណាំ ៖* សិស្សបានរៀនវគ្គចំណេះចំណានខគម្ពីរពីរនៅក្នុងមេរៀននេះ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២–២៣ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១–៤ ។ នៅពេលចាប់ផ្ដើមមេរៀននេះ សូមគិតពីការអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ឲ្យពន្យល់អ្វីដែលពួកគេបានរៀនមកពីវគ្គបទគម្ពីរទីមួយ ហើយសិស្សពាក់កណ្ដាលថ្នាក់ទៀតពន្យល់ពីអ្វីដែលពួកគេបានរៀនពីវគ្គបទគម្ពីរទីពីរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣–៦, ៣៤–៤៨

*ព្រះអម្ចាស់កំណត់ពីលក្ខខណ្ឌនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ហើយបើកសម្ដែងគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព*

ពីមុនថ្នាក់ចាប់ផ្ដើម សូមសរសេរ សំណួរខាងក្រោម នៅលើក្ដារខៀន ៖

> *ហេតុអ្វីអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចសំខាន់ចំពោះអ្នក ?*
>
> *ដោយចាប់ផ្ដើមពីថ្ងៃនេះ តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីរៀបចំខ្លួនចូលទៅព្រះវិហារបរិសុទ្ធ ហើយរៀបអាពាហ៍ពិពាហ៍ចំពោះវេលាកាល និង ភាពអស់កល្បជានិច្ច ?*
>
> *តើពរជ័យអ្វីខ្លះដែលអាចត្រូវបានទទួលនៅក្នុងជីវិតនេះចំពោះអស់អ្នកដែលធ្វើតាមក្រឹត្យវិន័យរបស់ព្រះ ដើម្បីត្រូវបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ?*

សូមអញ្ជើញសិស្សឲ្យពិចារណាពីសំណួរទាំងនេះនៅពេលពួកគេសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ ថ្ងៃនេះ ។

សូមពន្យល់ថាខណៈដែលយ៉ូសែប ស្ម៊ីធ កំពុងធ្វើការបកប្រែដ៏បំផុសគំនិតនៃព្រះគម្ពីរសញ្ញាចាស់នៅក្នុងឆ្នាំ ១៨៣១ នោះលោកបានអានអំពីការអនុវត្តនៃអាពាហ៍ពិពាហ៍ពហុពន្ធភាពរបស់ព្យាការីសម័យបុរាណ ( ក៏ត្រូវបានហៅពហុពន្ធភាពផងដែរ ) ។ ក្នុងការអនុវត្តនេះ បុរសម្នាក់ត្រូវបានរៀបការជាមួយភរិយាដែលកំពុងនៅរស់ច្រើនជាងម្នាក់ ។ ព្យាការីបានសិក្សាព្រះគម្ពីរពិចារណាពីអ្វីដែលបានរៀន ហើយទីបំផុតបានយកសំណួរអំពីអាពាហ៍ពិពាហ៍ពហុពន្ធភាពសួរដល់ព្រះវរបិតាដោយការអធិស្ឋាន ។

សូមសរសេរ *លោកុប្បត្តិ ១៦:១–៣* នៅលើក្ដារខៀន ។ សូមពន្យល់ថាខគម្ពីរទាំងនេះ ពិពណ៌នាអំពីសកម្មភាពរបស់សារ៉ាយ និង អាប់រ៉ាមដែលក្រោយមកហៅថា សារ៉ា និង អ័ប្រាហាំ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយគិតអំពីសំណួរនានាដែលពួកគេអាចមានអំពីព្រឹត្តិការណ៍នៅក្នុងជីវិតរបស់អាប់រ៉ាម និង សារ៉ាយ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលព្យាការីយ៉ូសែប ស្ម៊ីធ បានសួរនៅពេលលោកបានសិក្សាវគ្គបទគម្ពីរនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ទាក់ទងនឹងការអនុវត្តនៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ( អ្នកអាចចង់ពន្យល់ថាពាក្យ *ប្រពន្ធចុង* គឺជាពាក្យមួយដែលត្រូវបានប្រើដើម្បីប្រាប់ពីស្ត្រីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលនៅសម័យ និង វប្បធម៌ដែលពួកគេបានរស់នៅ ដែលជាស្ត្រីដែលបានរៀបការពេញច្បាប់នឹងបុរសម្នាក់ ប៉ុន្តែមានឋានៈក្នុងសង្គម និង ស្របច្បាប់ទាបជាងប្រពន្ធ ។ ប្រពន្ធចុងមិនមែនជាផ្នែកនៃការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព នៅក្នុងសម័យកាន់កាប់ត្រួតត្រារបស់យើងឡើយ ) ។

សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *ហេតុអ្វីបានជាព្រះអម្ចាស់បញ្ជាបុរស និង ស្ត្រីសុចរិតទាំងនោះ ឲ្យធ្វើតាមគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅជំនាន់នោះ ?*

សូមពន្យល់ថានៅក្នុងការសិក្សារបស់ពួកគេអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២, សិស្សអាចរកឃើញចម្លើយចំពោះសំណួរលើក្ដារខៀន និង សំណួរផ្សេងទៀតដែលពួកគេអាចមានទាក់ទងនឹងអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សូមអញ្ជើញពួកគេឲ្យសរសេរសេចក្ដីពិតដែលពួកគេរកឃើញអំឡុងពេលការសិក្សារបស់ពួកគេថ្ងៃនេះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៤–៣៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលអ័ប្រាហាំ និងសារ៉ាបានចាប់ផ្ដើមអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។

- យោងតាម ខ ៣៤, ហេតុអ្វីក៏សារ៉ាអនុញ្ញាតឲ្យអ័ប្រាហាំយកភរិយាមួយទៀត ? តើការណ៍នេះបង្រៀនយើងអ្វីខ្លះ អំពីគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ? ( នៅពេលសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **អាពាហ៍ពិពាហ៍ពហុពន្ធភាពត្រូវបានអនុមតិពីព្រះអម្ចាស់ តែនៅពេលដែលទ្រង់បញ្ជាឲ្យធ្វើតែប៉ុណ្ណោះ ។** ដើម្បីជួយសិស្សឲ្យយល់គោលការណ៍នេះ នោះអ្នកអាចសូមឲ្យពួកគេអាន យ៉ាកុប ២:២៧, ៣០។ អ្នកអាចផ្ដល់យោបល់ឲ្យសិស្សថា ពួកគេអាចសរសេរសេចក្ដីយោងនេះនៅក្នុងគម្ពីររបស់ពួកគេក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៤) ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៧–៣៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលពិពណ៌នាអំពីឧទាហរណ៍នានាពេលដែលព្រះអម្ចាស់បានបញ្ជាឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៩, ៤១–៤៣ ដោយពន្យល់ថា ព្រះអម្ចាស់បានបញ្ជាក់ថានៅពេលមនុស្ស អនុវត្តគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពអាស្រ័យលើបទបញ្ញារបស់ទ្រង់ នោះពួកគេពុំមានកំហុសនឹងអំពើបាបនៃ អំពើកំផិតឡើយ ។ ទោះជាយ៉ាងណាក្ដី ប្រសិនបើនរណាម្នាក់ដែលអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពក្នុងលក្ខខណ្ឌណាមួយ ដែលព្រះអម្ចាស់ពុំបានបញ្ជា នោះពួកគេធ្វើខុសនឹងអំពើកំផិតហើយ ។ ( សូមកត់ចំណាំថាពាក្យ *ត្រូវបំផ្លាញចោល* នៅក្នុង ខ ៤១ បង្ហាញថា អស់អ្នកដែលរំលងសេចក្ដីសញ្ញាដ៏ពិសិដ្ឋរបស់ខ្លួន នោះនឹងត្រូវបំបែកចេញពី ព្រះ និងពីរាស្ត្រនៃសេចក្ដីសញ្ញា របស់ទ្រង់ [ សូមប្រៀបធៀប កិច្ចការ ៣:២២–២៣; នីហ្វៃទី ១ ២២:២០] ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤០ យស្ងៀមស្ងាត់ រកមើលអ្វីដែលព្រះអម្ចាស់បានមាន ព្រះបន្ទូលថាទ្រង់នឹងធ្វើវា ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថាពាក្យ « ការណ៍ទាំងឡាយ » សំដៅលើច្បាប់ និងពិធីបរិសុទ្ធនៃដំណឹងល្អនានាដែលត្រូវបានបើកសម្ដែង នៅក្នុងសម័យកាន់កាប់ត្រួតត្រាមុនៗ ។ សូមសរសេរគោលការណ៍នេះនៅលើក្ដារខៀន ៖ **បទបញ្ញត្តិដើម្បីរស់នៅតាមច្បាប់ អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងថ្ងៃចុងក្រោយ គឺជាផ្នែកនៃការស្ដារឡើងវិញនៃការណ៍ទាំងឡាយ ។** ( សូមមើលផងដែរ កិច្ចការ ៣:២០–២១) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤៥, ៤៨ ឲ្យឮៗ ។

- តើយើងរៀនអ្វីខ្លះចេញពីខគម្ពីរទាំងនេះអំពីអាពាហ៍ពិពាហ៍ពហុពន្ធភាព ? ( នៅពេលសិស្សឆ្លើយ សូមសរសេរ គោលការណ៍ខាងក្រោមនេះលើក្ដារខៀន ៖ **អាពាហ៍ពិពាហ៍ពហុពន្ធភាពអាចត្រូវបានអនុញ្ញាតឲ្យមាន តែតាមរយៈកូនសោ នៃបព្វជិតភាពដែលត្រូវបានប្រទានដល់ប្រធាននៃសាសនាចក្រតែប៉ុណ្ណោះ** ) ។

សូមពន្យល់ថានៅដើមដំបូងនៃសម័យកាន់កាប់ត្រួតត្រានេះ ក្នុងផ្នែកមួយនៃការស្ដារឡើងវិញនៃការណ៍ទាំងឡាយ ព្រះអម្ចាស់ បានបញ្ជាដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយជំនាន់ដើម មួយចំនួនឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព តាមរយៈកូនសោ បព្វជិតភាពដែលបានកាន់ដោយព្យាការីយ៉ូសែប ស្ម៊ីធ និង ប្រធានសាសនាចក្របន្តបន្ទាប់ទៀត—ព្រិកហាំ យ៉ង់ យ៉ូហាន ថេល័រ និង វិលហ្វដ វូឌ្រុហ្វ ។ នៅឆ្នាំ ១៨៩០ ប្រធាន វូឌ្រុហ្វ ដោយប្រើកូនសោបព្វជិតភាពដដែលនោះ បានទទួលវិវរណៈ ថាការអនុវត្តនៃអាពាហ៍ពិពាហ៍ពហុពន្ធភាពគួរតែបញ្ចប់ ( សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ១) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤៩–៦៦

*ព្រះអម្ចាស់ប្រទានព្រះឱវាទដល់យ៉ូសែប និង អិមម៉ា ស្ម៊ីធ ទាក់ទងនឹងអាពាហ៍ពិពាហ៍ពហុពន្ធភាព*

សូមពន្យល់ថា ព្យាការីយ៉ូសែប ស្ម៊ីធ មានការស្ទាក់ស្ទើរដើម្បីចាប់ផ្ដើមអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ លោកបានថ្លែងថា លោកមិនបានចាប់ផ្ដើមអនុវត្តវាឡើយ រហូតដល់លោកត្រូវបានព្រមានថាលោកនឹងត្រូវបំផ្លាញចោលប្រសិនបើលោកមិនគោរព ធ្វើតាមទេនោះ ( សូមមើល « Plural Marriage » *Historical Record,* ខែ ឧសភា ឆ្នាំ ១៨៨៧ ទំព័រ ២២២ ) ។ ដោយសារការខ្វះឯកសារប្រវត្តិសាស្ត្រ នោះយើងដឹងបានតិចតួចបំផុតអំពីការខិតខំការពីដំបូងរបស់លោកដើម្បីធ្វើតាម ព្រះបញ្ញត្តិនេះ ។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ ១៨៤១ ព្យាការីបានគោរពធ្វើតាមព្រះបញ្ញត្តិនេះ ហើយបីឆ្នាំជាងក្រោយមក លោកបានរៀបការប្រពន្ធបន្ថែមទៀត ស្របទៅតាមការបញ្ជារបស់ព្រះអម្ចាស់ ។ ការគោរពប្រតិបត្តិតាមរបស់ព្យាការីយ៉ូសែប ស្ម៊ីធចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព គឺជាការសាកល្បងមួយនៃសេចក្ដីជំនឿសម្រាប់ លោក និង អិមម៉ាដែលជាភរិយាលោកដែលលោកស្រឡាញ់យ៉ាងខ្លាំង ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤៩–៥៦ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រទានព្រះឱវាទដល់យ៉ូសែប និង អិមម៉ា ស្ម៊ីធ ហើយបានសន្យាដល់ពួកគេនូវពរជ័យ ប្រសិនបើពួកគេនឹងគោរពតាមគោលការណ៍នៃអាពាហ៍ពិពាហ៍ ពហុពន្ធភាព ។ សូមពន្យល់ថានៅក្នុងឆ្នាំ ១៨៤១ ព្យាការីយ៉ូសែប ស្ម៊ីធ បានចាប់ផ្ដើមបង្រៀនដល់បុរស និង ស្ត្រីស្មោះត្រង់ ផ្សេងទៀតអំពីគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនេះ ។ ទោះបីជា សមាជិកសាសនាចក្រដ៏ស្មោះត្រង់ទាំងនេះ មាន ការស្ទាក់ស្ទើរ និង លំបាកចំពោះបទបញ្ញត្តិនេះនៅពេលដំបូងក៏ដោយ ក៏ពួកគេបានទទួលការបញ្ជាក់រៀងៗខ្លួនតាមរយៈ ព្រះវិញ្ញាណបរិសុទ្ធ ហើយទទួលយកគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៦៣ ឲ្យឮដោយចាប់ផ្ដើមជាមួយឃ្លា « ដ្បិតពួកគេត្រូវបានប្រគល់ដល់អ្នក នោះ » ។ ពីមុនអ្នកអាន សូមពន្យល់ថាខគម្ពីរនេះជួយយើងឲ្យយល់ពី ហេតុផលមួយដែលព្រះអម្ចាស់បានបញ្ជាយ៉ូសែប ស្ម៊ីធ និង មនុស្សដទៃផ្សេងទៀតដើម្បីអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលគោលបំណង ពិសេសនោះ ។ ( បន្ទាប់ពីអ្នកអានហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បានបញ្ជាឲ្យ អនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពដើម្បីផ្ដល់ឱកាសបន្ថែមទៀតដល់ប្រជារាស្ត្ររបស់ទ្រង់ចិញ្ចឹមកូនចៅថ្វាយទ្រង់ ។** ( អ្នកអាច មើល យ៉ាកុប ២:៣០ ម្ដងទៀត ) ។

- តើ « ឲ្យបង្កើតកូនជាច្រើនឡើង ហើយមានពេសពេញលើផែនដី » នោះមានន័យដូចម្ដេច ? ( បង្កើតកូនចៅ ) ។
- តើការមានកូនចៅធ្វើឲ្យឪពុកម្ដាយក្លាយជាផ្នែកមួយនៃការបន្តកិច្ចការរបស់ព្រះវរបិតាសួគ៌យ៉ាងដូចម្ដេច ?

សូមមើលសំណួរដែលអ្នកបានសរសេរលើក្ដារខៀននៅពេលជិតចាប់ផ្ដើមថ្នាក់រៀន ៖ *ហេតុអ្វីបានជាព្រះអម្ចាស់បញ្ជាឲ្យបុរស និង ស្ត្រីសុចរិតទាំងនោះឲ្យធ្វើតាមគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅជំនាន់នោះ ?* អ្នកអាចអញ្ជើញសិស្សឲ្យសង្ខេបដល់សិស្សនៅក្នុងថ្នាក់អំពីអ្វី ដែលពួកគេបានរៀនពីការសិក្សារបស់ខ្លួនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ និង យ៉ាកុប ២:២៧, ៣០ ដែលជួយពួកគេឲ្យឆ្លើយសំណួរនេះ ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីព្យាការីយ៉ូសែប ស្ម៊ីធ ហើយថាលោកបានទទួល ព្រមទាំងគោរពតាមវិវរណៈពីព្រះ ( សូមមើល គ. និង ស. ១៣២:៣៧) ។

## មេរៀនបន្ទាប់ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣–១៣៥)

សូមសួរសិស្សពីអ្វីដែលពួកគេនឹងធ្វើ ប្រសិនបើពួកគេត្រូវបានឲ្យជ្រើសរើសរវាងការស្លាប់ ឬ រត់គេចខ្លួនចេញពីអស់អ្នកដែលបានព្យាយាមសម្លាប់ពួកគេ ។ ចុះប្រសិនបើការជ្រើសរើសដើម្បីប្រឈមមុខនឹងសេចក្ដីស្លាប់អាចសង្គ្រោះជីវិតរបស់ក្រុមគ្រួសារ មិត្តភក្តិរបស់អ្នក និង មនុស្សដទៃរាប់រយអ្នកទៀតនោះ ? តើអ្នកនឹងធ្វើដូចម្ដេច ? ព្យាការីយ៉ូសែប ស្ម៊ីធ មានឆន្ទៈជ្រើសរើសប្រឈមមុខនឹងសេចក្ដីស្លាប់ដោយនិយាយថា « ខ្ញុំទៅដូចជាចៀមដឹកទៅសំឡាប់ ប៉ុន្តែខ្ញុំស្ងប់ចិត្តដូចជាព្រឹកព្រលឹមនារដូវក្ដៅ » (គ. និង ស. ១៣៥:៤) ។ សិស្សនឹងអានអំពីទុក្ករកម្មរបស់ព្យាការី យ៉ូសែប ស្ម៊ីធនៅក្នុងមេរៀនបន្ទាប់ ។

មេរៀនទី ១៤១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥

## បុព្វកថា

នៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ១៨៣១ រយៈពេលពីរថ្ងៃបន្ទាប់ពីព្រះអម្ចាស់បានដឹកនាំ យ៉ូសែប ស្ម៊ីធ ឲ្យបោះពុម្ពព្រះគម្ពីរនៃព្រះបញ្ញត្តិ ព្យាការីបានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣។ វិវរណៈនេះត្រូវបានដាក់បញ្ចូលនៅក្នុងការបោះពុម្ពឆ្នាំ ១៨៣៥ នៃគោលលទ្ធិ និង សេចក្ដីសញ្ញា ជាកណ្ឌទី ១០០ ហើយត្រូវបានកំណត់ទុកថាជាសេចក្ដីបន្ថែមរបស់ព្រះគម្ពីរ ។ អ្នកទាំងឡាយណាដែលកំពុងធ្វើការជាមួយនឹងឯកសារសរសេរដោយដៃកាលពីដើម មានបំណងចង់ដាក់វិវរណៈនេះនៅខាងក្រោយគេនៃការបោះពុម្ពឆ្នាំ ១៨៣៥ ។ វិវរណៈនឹងត្រូវបានបែងចែកជាមេរៀនពីរ ។ មេរៀននេះពិភាក្សាអំពីបញ្ជារបស់ព្រះអម្ចាស់ថា រាស្ត្ររបស់ទ្រង់ត្រូវរៀបចំខ្លួនគេ និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីរ ។ វាក៏ពិភាក្សាអំពីការព្យាករណ៍អំពីព្រឹត្តការណ៍ទាំងឡាយដែលទាក់ទងនឹងយាងមកជាលើកទីពីររបស់ទ្រង់ និងរាជ្យនៃសហស្សវត្សរ៍ផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣

*ព្រះអម្ចាស់ពិពណ៌នាអំពីការយាងមកជាលើកទីពីរ*

មុនចាប់ផ្ដើមថ្នាក់ សូមសរសេរសេចក្ដីថ្លែងការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ។ ( សេចក្ដីថ្លែងមាននៅក្នុង « Preparation for theSecond Coming » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៧ ) ។

> *« ថ្ងៃនេះ ខ្ញុំមានអារម្មណ៍បំផុសឲ្យនិយាយអំពីសារៈសំខាន់នៃការត្រៀមខ្លួនសម្រាប់ព្រឹត្តការណ៍នាពេលអនាគតមួយដែលសំខាន់យ៉ាងខ្លាំងចំពោះយើងម្នាក់ៗ–______________________» ( អែលឌើរ ដាល្លិន អេក អូក ) ។*

សូមចាប់ផ្ដើមថ្នាក់ដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកធ្លាប់ទៅសាលារៀន ហើយបានដឹងថា អ្នកបានភ្លេចត្រៀមខ្លួនសម្រាប់ការប្រឡងដែរឬទេ ? បើធ្លាប់ តើអ្នកមានអារម្មណ៍ដូចម្ដេច ?
- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលដែលអ្នកបានត្រៀមខ្លួនយ៉ាងល្អសម្រាប់ការប្រឡងមួយនោះ ?

សូមបង្វែរអារម្មណ៍របស់សិស្សឲ្យផ្ដោតលើសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍នេះឲ្យឮៗ។ បន្ទាប់មកសួរសិស្សក្នុងថ្នាក់នូវសំណួរខាងក្រោម ៖

- តើព្រឹត្តការណ៍អ្វីខ្លះដែលអ្នកគិតថា អែលឌើរ អូក កំពុងតែសំដៅទៅលើ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រឹត្តការណ៍ដែលយើងត្រូវធ្វើ ដើម្បីត្រៀមខ្លួន និងមូលហេតុមួយថា ហេតុអ្វីយើងត្រូវត្រៀមខ្លួននោះ ។ ( មុនពេលសិស្សអាន អ្នកអាចនឹងចង់ពន្យល់ថា ឃ្លា « លាតព្រះពាហុបរិសុទ្ធរបស់ទ្រង់ » សំដៅទៅលើព្រះអម្ចាស់បើកសម្ដែងនូវកម្លាំង និងព្រះចេស្ដារបស់ទ្រង់ដល់ពិភពលោក ) ។

- តើព្រឹត្តការណ៍អ្វីខ្លះ ដែលព្រះអម្ចាស់សំដៅទៅលើក្នុងខគម្ពីរទាំងនេះ ? ( បើសិស្សត្រូវការជំនួយ សូមអញ្ជើញពួកគេឲ្យមើលទៅ ខ ២ លេខយោង *ក* ។ បន្ទាប់មក បំពេញសេចក្ដីថ្លែងការណ៍របស់អែលឌើរ អូក នៅលើក្ដារខៀនដោយការសរសេរ*ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់* )។
- ស្របតាម ខ ២ តើអ្វីខ្លះនឹងកើតឡើងចំពោះពួកអាក្រក់ ឬពួកទុច្ចរិត នៅក្នុងការយាងមកជាលើកទីពីរ ? ( សិស្សគប្បីប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖ **នៅក្នុងការយាងមកជាលើកទីពីរ ព្រះយេស៊ូវគ្រីស្ទនឹងយាងមកជំនុំជំរះ ជំទាស់នឹងពួកមនុស្សអាក្រក់ ។** អ្នកអាចផ្ដល់យោបល់ឲ្យសិស្សសរសេរគោលលទ្ធិនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ខ ២) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤–១៦

*ព្រះអម្ចាស់បញ្ជាដល់រាស្ត្ររបស់ទ្រង់ឲ្យរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់*

ដើម្បីជួយសិស្សយល់អំពីបរិបទនៃវិវរណៈនេះ សូមអញ្ជើញសិស្សឲ្យអានឮៗនូវសេចក្ដីណែនាំដល់កណ្ឌចំពោះ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣។ សូមឲ្យសិស្សផ្ទៀងតាម រកមើលរបៀបដែលវិវរណៈនេះត្រូវបានដាក់បញ្ចូលពីដើមនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ។ បន្ទាប់ពីពួកគេរាយការណ៍នូវអ្វីដែលពួកគេរកឃើញ សូមអញ្ជើញសិស្សឲ្យកត់សម្គាល់អំពីកាលបរិច្ឆេទដែលវិវរណៈនេះដែលត្រូវបានផ្ដល់ឲ្យ ។ សូមពន្យល់ថា វិវរណៈនេះគឺនៅក្រៅលំដាប់នៃមាតិកា ព្រោះតែវាត្រូវបានដាក់បន្ថែមពីដើមដំបូងទៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ។ វិវរណៈនេះ និងកណ្ឌ ១ ត្រូវបានចងក្រងសម្រាប់វិវរណៈទាំងឡាយដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ។

សូមអញ្ជើញសិស្សឲ្យមើលត្រួសៗនូវ ខ ៤ ដោយស្ងាត់ស្ងៀម ហើយស្វែងរកនូវអ្វីដែលព្រះអម្ចាស់បានបញ្ជាដល់រាស្ត្ររបស់ទ្រង់ឲ្យធ្វើ ទាក់ទងនឹងការយាងមកជាលើកទីពីររបស់ទ្រង់ ។

- តើព្រះអម្ចាស់បញ្ជារាស្ត្ររបស់ទ្រង់ឲ្យធ្វើអ្វីខ្លះ ? ( ត្រៀមខ្លួន ហើយប្រមូលផ្ដុំគ្នានៅក្នុងស៊ីយ៉ូន ) ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្ដារខៀន ៖ ______________________ *ជួយរៀបចំយើងសម្រាប់ការយាងមកលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។*

សូមបំបែកសិស្សជាគូ ៗ ។ សូមអញ្ជើញដៃគូឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤–១៦ ជាមួយគ្នា រកមើលនូវពាក្យ និងឃ្លាដែលបង្រៀនអំពីរបៀបដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

សូមអញ្ជើញដៃគូនិមួយៗឲ្យរាយការណ៍នូវអ្វីដែលពួកគេបានរកឃើញ ហើយសុំសិស្សម្នាក់ឲ្យបំពេញសេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន ដោយការសរសេរចម្លើយរបស់សិស្សនៅក្រោមកន្លែងទំនេរ ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែល្អប្រសើរ អំពីរបៀបមួយចំនួនដែលយើងអាចត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់សូមថតចម្លងសកម្មភាពដូចខាងក្រោមសម្រាប់សិស្សម្នាក់ៗ ។ សូមអញ្ជើញសិស្សឲ្យបំពេញសកម្មភាពជាមួយដៃគូរបស់ពួកគេ ហើយត្រៀមខ្លួនដើម្បីចែកចាយការយល់ដឹងរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។ ( អ្នកអាចនឹងលើកទឹកចិត្តដល់សិស្សឲ្យសរសេរចម្លើយរបស់ពួកគេ មុនពេលពួកគេចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់ ) ។

### ការរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ

១. សូមពិភាក្សាជាមួយនឹងដៃគូរបស់អ្នកថា ហេតុអ្វីចម្លើយដែលបានសរសេរនៅលើក្ដារខៀនហាក់ដូចជាសំខាន់ដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទដូច្នេះ ។

២. សូមកត់សម្គាល់នូវឃ្លាទាំងឡាយអំពីក្រុងបាប៊ីឡូន នៅក្នុង ខ ៥, ៧ និង ១៤ ។ នៅក្នុងគ្រានៃព្រះគម្ពីរសញ្ញាចាស់ ទីក្រុងបាប៊ីឡូន គឺជាកន្លែងមួយនៃសេចក្ដីទុច្ចរិតដ៏ធំ ។ នៅក្នុងខគម្ពីរទាំងនេះ ក្រុងបាប៊ីឡូន ត្រូវបានប្រើជានិមិត្តរូបនៃភាពខាងលោកិយ ។

   ក. តើវាអាចនឹងមានន័យយ៉ាងណា នៅពេលព្រះអម្ចាស់ដឹកនាំយើងឲ្យ « ចេញពីក្រុងបាប៊ីឡូន » ?

   ខ. តើយើងអាចរត់គៀសពីទីក្រុង បាប៊ីឡូន បានដោយរបៀបណា ? តើរឿងទាំងនេះអាចរៀបចំយើងសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្ដេច ?

   គ. តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីដកខ្លួនចេញពីឥទ្ធិពលខាងលោកិយ ?

៣. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៥ សារឡើងវិញ ហើយរកមើលនូវអ្វីដែលព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធជំនាន់មុន កុំឲ្យធ្វើ នៅពេលពួកគេចេញពីក្រុងបាប៊ីឡូន ។ អ្នកអាចនឹងគូសចំណាំនូវអ្វីដែលអ្នករកឃើញ ហើយពិចារណាអំពីរបៀបដែលការព្រមាននេះ អនុវត្តនៅក្នុងជីវិតរបស់អ្នក ។

   ក. តើអ្នកគិតថាពាក្យ « កុំងាកមើលក្រោយ » បន្ទាប់ពីយើងបានដកខ្លួនយើងចេញពីឥទ្ធិពលខាងលោកិយមានន័យយ៉ាងម៉េច ? ( យើង « ងាកមើលក្រោយ » នៅពេលយើងព្យាយាមលះបង់ខាងលោកិយ ប៉ុន្តែបន្ទាប់មកត្រឡប់ទៅផ្លូវចាស់របស់យើងវិញ ។ ជាជាងអនុញ្ញាតឲ្យដួងចិត្តយើងផ្លាស់ប្ដូរ នោះយើងមានទំនោរចង់ត្រឡប់ទៅរកជីវិតពីមុនរបស់យើង ។

ខ. តើយើងអាចរៀនគោលការណ៍អ្វីចេញមកពី ខ ១៥ នេះ ? ___________________________________

គ. សូមពិភាក្សាជាមួយដៃគូរបស់អ្នកអំពី របៀបដែលយុវវ័យពួកបរិសុទ្ធថ្ងៃចុងក្រោយ « ពុំអាចងាកមើលក្រោយ » នៅពេលពួកគេខំប្រឹងប្រែងរីកចម្រើនខាងវិញ្ញាណ ហើយចូលមកកាន់តែជិតនឹងព្រះអង្គសង្គ្រោះ ។

ឃ. សូមគិតអំពីមនុស្សដែលអ្នកស្គាល់ ដែលតែងតែទន្ទឹងរង់ចាំ ត្រៀមខ្លួនជានិច្ចសម្រាប់ការយាងមកជាលើកទីពីរ ។ តើអ្នកមើលឃើញថាពួកគេធ្វើអ្វីខ្លះ ? _________________________________________

បន្ទាប់ពីមានពេលគ្រប់គ្រាន់ហើយនោះ សូមអញ្ជើញសិស្សឲ្យចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ ( ដើម្បីជួយឲ្យសិស្សគ្រប់រូបចូលរួម សូមអនុញ្ញាតឲ្យដៃគូផ្សេង ៗឆ្លើយតបចំពោះសំណួរផ្សេង ៗ ) ។ នៅពេលសិស្សពិភាក្សា ខ ១៥ ពួកគេគប្បីប្រាប់គោលការណ៍មួយស្រដៀងគ្នាដូចខាងក្រោម ៖**បើយើងត្រឡប់ទៅរកសេចក្ដីទុច្ចរិត និងអំពើបាបពីអតីតកាលរបស់យើងវិញ នោះយើងនឹងពុំបានត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទឡើយ ។**

យោងត្រឡប់ទៅការសរសេរនៅលើក្ដារខៀនអំពីអ្វីៗទាំងឡាយដែលយើងអាចធ្វើដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមចង្អុលបង្ហាញថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យរាស្ត្រគ្រប់រូបរបស់ទ្រង់ ត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីរ ។ សូមអញ្ជើញសិស្សឲ្យមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤–១៥ យ៉ាងរហ័ស ហើយប្រាប់អំពីខទាំងឡាយដែលបង្រៀនយើងអំពីរបៀបដើម្បីផ្សាយដំណឹងល្អ និងអញ្ជើញអ្នកដទៃឲ្យមករកព្រះគ្រីស្ទ ។

- តើខគម្ពីរណាខ្លះ បង្រៀនយើងថា យើងចាំបាច់ត្រូវផ្សាយដំណឹងល្អ ហើយអញ្ជើញអ្នកដទៃឲ្យមករកព្រះគ្រីស្ទ ? ( សិស្សគប្បីប្រាប់ថា ខ ៨–១០) ។

- តើយើងអាចរៀនអ្វីខ្លះចេញមកពីខទាំងនេះអំពីកិច្ចការផ្សព្វផ្សាយសាសនា ? ( សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោមនេះ ៖ **នៅពេលយើងចែកចាយដំណឹងល្អ នោះយើងជួយអ្នកដទៃឲ្យត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។** អ្នកអាចនឹងផ្ដល់យោបល់ដល់សិស្សឲ្យសរសេរចំណាំគោលកាណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ឲ្យឮៗដូចខាងក្រោម ដោយ អែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្ដាប់នូវអ្វីដែលអែលឌើរ អាន់ឌើរសិន បានប្រាប់ថាជាការទទួលខុសត្រូវរបស់យើង និងជាវិធីមួយដែលយើងអាចបំពេញនូវទំនួលខុសត្រូវនោះ ។



« ការទទួលខុសត្រូវដ៏ចាំបាច់មួយរបស់អ្នក គឺត្រូវជួយរៀបចំមនុស្សទទួលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។. . .

« បេសកកម្មរបស់អ្នកនឹងក្លាយជាឱកាសមួយដ៏ពិសិដ្ឋក្នុងការនាំមនុស្សទូទៅមករកព្រះគ្រីស្ទ ហើយជួយរៀបចំពួកគេទទួលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។. . .

« . . . ពិភពលោកកំពុងត្រូវបានរៀបចំសម្រាប់ការយាង មកជា លើក ទីពីររបស់ព្រះអង្គសង្គ្រោះ នៅក្នុងទំហំដ៏ធំមួយ ដោយសារ តែកិច្ចការរបស់ព្រះអម្ចាស់ តាមរយៈអ្នក ផ្សព្វផ្សាយសាសនារបស់ទ្រង់ » ( Preparing the World for the Second Coming, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ៤៩, ៥០, ៥១ ) ។

- ហេតុអ្វីអ្នកគិតថា ការរៀបចំតែខ្លួនឯង មិនគ្រប់គ្រាន់សម្រាប់ការយាងមកជាលើកទីពីរ ?

- តើអ្នកគិតថា ការជួយអ្នកដទៃឲ្យរៀបចំសម្រាប់ការយាងមកជាលើកទីពីរ នឹងជួយអ្នកឲ្យរៀបចំខ្លួនផងដែរដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីអ្នកទាំងឡាយដែលបានជួយពួកគេឲ្យចូលមកកាន់តែជិតព្រះគ្រីស្ទ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយរបៀបដែលអ្នកដទៃបានជះឥទ្ធិពល និងបានជួយដល់ពួកគេ ។

សូមឲ្យសិស្សមើលឡើងវិញក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៦ ដោយស្ងៀមស្ងាត់ រកមើលនូវអ្វីដែលព្រះអម្ចាស់បានបញ្ជារាស្ត្រទាំងអស់ឲ្យធ្វើ ដើម្បីត្រៀមខ្លួនដើម្បីជួបទ្រង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នករកឃើញអ្វីខ្លះនៅក្នុង ខ ១៦ ដែលទាក់ទងទៅនឹងនឹងកិច្ចការផ្សព្វផ្សាយសាសនា ?

### *ការគូសចំណាំ និងការសរសេរសេចក្ដីពន្យល់បទគម្ពីរបន្ថែម*

របៀបដែលជាជំនួយមួយសម្រាប់សិស្សដើម្បីចងចាំនូវអ្វីដែលពួកគេបានរៀន គឺគូសចំណាំ និងចារសេចក្ដីពន្យល់បទគម្ពីររបស់ពួកគេ ។ ពួកគេអាចធ្វើដូចនេះដោយការគូសបន្ទាត់ពីខាងក្រោម ផាត់ពណ៌ ឬសង្វៃពាក្យ ឬឃ្លាសំខាន់ៗ ។ សិស្សក៏អាចសរសេរគោលការណ៍ ប្រសាសន៍ព្យាករ និងការយល់ដឹងជ្រៅជ្រះផ្ទាល់ខ្លួន និងចំណាប់អារម្មណ៍ទាំងឡាយនៅក្នុងខគម្ពីររបស់ពួកគេ ។ ទោះយ៉ាងណាក្ដី អ្នកគួរតែគោរពសិទ្ធិជ្រើសរើសរបស់សិស្ស និង មិនត្រូវតម្រូវឲ្យពួកគេសរសេរនៅក្នុងព្រះគម្ពីររបស់ពួកគេនោះទេ ។ ផ្ទុយទៅវិញ សូមធ្វើការស្នើសុំ និង អនុញ្ញាតឲ្យសិស្សសម្រេចចំពោះអ្វីដែលសមរម្យសម្រាប់គេ ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចប្រាប់នៅក្នុង ខ ១៦ ដែលនឹងជួយយើងត្រៀមខ្លួនដើម្បីជួបនឹងព្រះអម្ចាស់នៅពេលទ្រង់យាងមក ? ( វិធីមួយដែលសិស្សអាចសម្ដែងគោលការណ៍នេះ គឺថា **នៅពេលយើងប្រែចិត្ត នោះយើងត្រៀមខ្លួនដើម្បីជួបនឹងព្រះអម្ចាស់** ) ។
- តើការប្រែចិត្តជួយរៀបចំយើងសម្រាប់ការយាងមកលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

សូមសរសេរប្រយោគមិនពេញលេញដូចខាងក្រោមនៅលើក្ដារខៀន ៖

> *ខ្ញុំនឹងត្រៀមខ្លួនខ្ញុំសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះដោយ . . .*
> *ខ្ញុំនឹងជួយអ្នកដទៃត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរដោយ . . .*

ដើម្បីជួយសិស្សអនុវត្តសេចក្ដីពិតដែលពួកគេបានរៀនសព្វថ្ងៃនេះ សូមឲ្យពួកគេបំពេញបញ្ចប់សេចក្ដីថ្លែងការណ៍នៅលើក្ដារខៀន នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៧–៣៥

*ព្រះអម្ចាស់បានបើកសម្ដែងព្រឹត្តការណ៍មួយចំនួនដែលជាប់ទាក់ទងនឹងការយាងមកជាលើកទីពីរ និងរាជ្យនៃសហស្សវត្សរ៍របស់ទ្រង់*

សូមពន្យល់ថា បន្ទាប់ពីការបង្រៀនអំពីរបៀបដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ នោះព្រះអម្ចាស់បានបង្គាប់ឲ្យយើងត្រៀមខ្លួន ។

សូមបែងចែកសិស្សជាគូៗម្ដងទៀត ដូច្នេះពួកគេមានដៃគូថ្មី ។ សូមអញ្ជើញដៃគូពាក់កណ្ដាលឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៧–២៥ ជាមួយគ្នា រកមើលព្រឹត្តការណ៍ដែលទាក់ទងនឹងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យដៃគូពាក់កណ្ដាលទៀតធ្វើដូចគ្នាជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:២៦–២៥។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញដៃគូនិមួយៗឲ្យរៀបរាប់ទៅដល់សិស្សក្នុងថ្នាក់នូវរឿងមួយដែលពួកគេបានរកឃើញ ។

- ស្របតាម ខ ១៧ តើយើងគួរធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ? ហេតុអ្វីបានជាការណ៍នេះសារៈសំខាន់ខ្លាំងម្ល៉េះ ? ( ដើម្បីជួយសិស្សឆ្លើយតបសំណួរនេះ អ្នកអាចនឹងផ្ដល់យោបល់ឲ្យពួកគេអាន អាលម៉ា ៧:៩, ១៤–១៩។ សូមចង្អុលបង្ហាញថា ឃ្លា « តម្រង់ផ្លូវតូចថ្វាយទ្រង់ » ទាក់ទងនឹងទំនួលខុសត្រូវរបស់យើងដើម្បីប្រែចិត្ត ហើយផ្សាយដំណឹងល្អដល់អ្នកដទៃ ដូច្នេះពួកគេអាចប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ) ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការប្រែចិត្តនៅក្នុងការត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ សូមលើកទឹកចិត្តសិស្សឲ្យរស់នៅដោយសុចរិត ដើម្បីពួកគេអាចទទួលបានបទពិសោធន៍នៃភាពពេញលេញតាមការសន្យារបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ។

មេរៀនទី ១៤២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៧៤

## បុព្វកថា

មេរៀននេះពិភាក្សានូវផ្នែកទីពីរនៃវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣។ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះ នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ ។ វាឆ្លើយតបទៅនឹងសំណួរដែលពួកអ្នកផ្សព្វផ្សាយសាសនាបានមានអំពីការផ្សាយដំណឹងល្អ និងការប្រមូលផ្ដុំវង្សអ៊ីស្រាអែល ។ វាក៏ពិពណ៌នាអំពីការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ហើយពន្យល់នូវអ្វីដែលយើងចាំបាច់ត្រូវធ្វើដើម្បីបានរៀបចំសម្រាប់ការយាងមកជាលើកទីពីរផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៤០

*ព្រះអម្ចាស់ប្រកាសថា ដំណឹងល្អដែលបានស្ដារឡើងវិញ នឹងត្រូវផ្សាយចេញទៅគ្រប់កន្លែងក្នុងពិភពលោក*

សូមចាប់ផ្ដើមមេរៀនដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើពេលណា ដែលអ្នកធ្លាប់បានមានចិត្តរំភើបយ៉ាងខ្លាំង ដើម្បីជួបនឹងនរណាម្នាក់ ? (សូមអញ្ជើញសិស្សពីរបីនាក់ឲ្យរៀបរាប់អំពីបទពិសោធន៍របស់ពួកគេ ។ អ្នកក៏អាចចែកចាយបទពិសោធន៍មួយផងដែរ) ។

សូមដាក់បង្ហាញរូបភាពការយាងមកជាលើកទីពីរ *សៀវភៅសិល្បៈដំណឹងល្អ* ២០០៩ ។ ទំព័រ ៦៦, សូមមើលផងដែរ LDS.org



- តើអ្នកមានចិត្តរំភើប ដើម្បីជួបនឹងព្រះអង្គសង្គ្រោះនៅការយាងមកជាលើកទីពីររបស់ទ្រង់ដែរឬទេ ? ហេតុអ្វី ?

សូមពន្យល់ថា ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទនឹងជាបទពិសោធន៍ដ៏ផ្អែមល្ហែម ហើយអស្ចារ្យមួយសម្រាប់មនុស្សមួយចំនួន ហើយវាក៏ជាបទពិសោធន៍ដ៏ភ័យខ្លាចសម្រាប់មនុស្សផ្សេងទៀតផងដែរ ។ សូមថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះមានព្រះទ័យចង់ឲ្យមនុស្សគ្រប់រូបត្រៀមខ្លួនសម្រាប់ការយាងមករបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៣៩ ឲ្យឮ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលភស្តុតាងដែលថាព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យមនុស្សទាំងអស់ត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។

- តើមានភស្តុតាងអ្វីខ្លះ ដែលអ្នកបានឃើញនៅក្នុងខគម្ពីរទាំងនេះ ដែលថាព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យមនុស្សទាំងអស់ត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ? ( ទ្រង់បានបញ្ជូនទេវតាមួយអង្គ [ឬពួកទេវតា] ឲ្យស្ដារដំណឹងល្អនៅលើផែនដី ។ ទ្រង់កំពុងបញ្ជូនពួកអ្នកបម្រើរបស់ទ្រង់ឲ្យផ្សាយដំណឹងល្អដល់មនុស្សគ្រប់រូបផងដែរ ។

### *បង្រៀនដោយព្រះវិញ្ញាណ*

ក្នុងនាមជាគ្រូបង្រៀនដំណឹងល្អម្នាក់ អ្នកត្រូវស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ សម្រាប់ការរៀបចំមេរៀន និងការបង្រៀនរបស់អ្នក ។ « ព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នកដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ ហើយបើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀនឡើយ » (គ. និង ស. ៤២:១៤) ។

- តើនរណាជាពួកអ្នកបម្រើរបស់ព្រះ ដែលនឹងផ្សាយសារនៃដំណឹងល្អដែលបានស្តារឡើងវិញ ? ( សមាជិកគ្រប់រូបនៃសាសនាចក្រ គឺជាពួកអ្នកបម្រើនៃព្រះ ដែលមានទំនួលខុសត្រូវដើម្បីចែកចាយដំណឹងល្អជាមួយអ្នកដទៃ ។ អ្នកអាចនឹងប្រាប់ឲ្យសិស្សសរសេរគោលការណ៍ដូចខាងក្រោមនៅក្នុងគម្ពីររបស់ពួកគេ ៖ **ក្នុងនាមជាពួកអ្នកបម្រើរបស់ព្រះ យើងអាចជួយអ្នកដទៃឲ្យត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ដោយការចែកចាយដំណឹងល្អជាមួយពួកគេ** ) ។

- ស្របតាម ខ ៣៨ តើយើងប្រកាសដំណឹងល្អយ៉ាងដូចម្ដេច ? តើអ្នកគិតថាវាអាចមានន័យដូចម្ដេច ដើម្បីចែកចាយដំណឹងល្អ « ដោយបន្លឺសំឡេងយ៉ាងខ្លាំង » ? ( ចម្លើយអាចរួមមានដូចជា យើងគប្បីចែកចាយដំណឹងល្អដោយចិត្តក្លាហាន និងដោយជំនឿស៊ប់ ) ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤០ ដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីមួយផ្សេងទៀត ដែលពួកអ្នកបម្រើនៃព្រះនឹងធ្វើ ពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

- ស្របតាម ខ ៤០ តើអ្នកបម្រើរបស់ព្រះនឹងធ្វើអ្វីខ្លះ ពីមុនការយាងមកជាលើកទីពីរ ? ( ពួកគេនឹងអធិស្ឋានសុំសម្រាប់ការយាងត្រឡប់មកវិញរបស់ព្រះអង្គសង្គ្រោះ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤១–៥៦

*ព្រះយេស៊ូវគ្រីស្ទពិពណ៌នាអំពីការយាងមកជាលើកទីពីររបស់ទ្រង់*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤១–៤៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវពរជ័យទាំងឡាយដែលនឹងកើតមានចំពោះអ្នកទាំងឡាយណាដែលអធិស្ឋាន ហើយរង់ចាំការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

- ស្របតាម ខ ៤៥ តើព្រះអម្ចាស់សន្យាអ្វីខ្លះ ដល់អ្នកទាំងឡាយដែលនឹងរង់ចាំទ្រង់នោះ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរនូវសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់បានត្រៀមពរជ័យដ៏មហិមាទាំងឡាយសម្រាប់អ្នកទាំងឡាយដែលរង់ចាំទ្រង់** ) ។

- តើអ្នកគិតថា ការរង់ចាំព្រះអម្ចាស់មានន័យយ៉ាងណា ? ( សូមជួយសិស្សយល់ថា ឃ្លា « រង់ចាំព្រះអម្ចាស់ » មានន័យច្រើនជាងហួសពីការគ្រាន់តែរង់ចាំឲ្យពេលវេលាកន្លងផុតទៅរហូតដល់ទ្រង់យាងមកនោះទេ ។ វាមានន័យថា ឃ្លាំចាំមើល ហើយត្រៀមខ្លួន និងចូលរួមនៅក្នុងកិច្ចការរបស់ទ្រង់ ) ។

ដើម្បីជួយសិស្សយល់កាន់តែល្អប្រសើរអំពីរបៀបដែលពួកគេអាចរង់ចាំព្រះអម្ចាស់ និងការយាងមកជាលើកទីពីររបស់ទ្រង់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយ អែលឌើរ ជែហ្វ្រី អរ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្ដាប់រកមើលសកម្មភាពនានា ដែលយើងគួរធ្វើ នៅពេលយើងរង់ចាំការយាងមកជាលើកទីពីរ ។



« ចំពោះអ្នករាល់គ្នាណា ដែលបានខ្វល់ខ្វាយអំពីអនាគត. . .

« ព្រះមានព្រះទ័យរំពឹងឲ្យអ្នកមានសេចក្ដីជំនឿគ្រប់គ្រាន់ និង ការប្ដេជ្ញាចិត្ត ហើយទុកចិត្តលើទ្រង់ ដើម្បីបន្តទៅមុខ បន្តរស់នៅ និងបន្តមានចិត្តរីករាយ ។ ប្រាកដណាស់ ទ្រង់មិនមានព្រះទ័យរំពឹងឲ្យអ្នក *ប្រឈមមុខ* នឹងអនាគតកាលដោយជម្មតា ( ដែលហាក់ដូចជាក្រៀមក្រំ និង បណ្ដោយតាមវាសនា ) នោះទេ ដ្បិតទ្រង់មានព្រះទ័យរំពឹងឲ្យអ្នកឱបក្រសោបយក ហើយ *រៀបចំ* អនាគតកាល—ដើម្បីចេះស្រឡាញ់ ហើយអរសប្បាយនឹងអនាគតកាល ហើយធ្វើឲ្យរីកាយឡើងនៅក្នុងជីវិតរបស់អ្នក ។

« ព្រះទ្រង់ទន្ទឹងរង់ចាំដោយអន្ទះសា ចំពោះឱកាសដើម្បីឆ្លើយតបការអធិស្ឋានរបស់អ្នក ហើយបំពេញតាមសេចក្ដីប្រាថ្នាដែលអ្នកមាន ដូចដែលទ្រង់ធ្លាប់បានធ្វើរួចមកហើយ ។ ប៉ុន្តែទ្រង់ពុំអាចធ្វើបានទេ បើអ្នកមិនអធិស្ឋាន ហើយទ្រង់ពុំអាចធ្វើបានទេ បើអ្នកពុំសុបិនចង់បាននោះ ។ សរុបឲ្យខ្លី ទ្រង់ពុំអាចធ្វើបានទេ បើអ្នកពុំជឿនោះ » ( « Terror, Triumph, and a Wedding Feast » [Church Educational System devotional, ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០៤], ទំព័រ ៣, speeches.byu.edu) ។

- តើអែលឌើរ ហូឡិន បានមានប្រសាសន៍ថា យើងគប្បីធ្វើអ្វីខ្លះ នៅពេលយើងរង់ចាំការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤៦–៤៧ ដោយស្ងាត់ស្ងៀម ហើយរៀបរាប់នូវអ្វីដែលពួកគេបានរៀនអំពីមនុស្សមួយចំនួនដែលនឹងនៅលើផែនដីក្នុងគ្រានៃការយាងមកជាលើកទីពីរ ។ សិស្សគប្បីទទួលស្គាល់ថា ពុំមែនមនុស្សទាំងអស់នឹងស្គាល់ថាព្រះយេស៊ូវគ្រីស្ទគឺជានរណាទេ នៅពេលនៃការយាងមកជាលើកទីពីររបស់ទ្រង់នោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤៨–៤៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវការពិពណ៌នាមួយអំពីព្រះយេស៊ូវគ្រីស្ទមានរូបរាងយ៉ាងម៉េច នៅពេលនៃការយាងមកជាលើកទីពីររបស់ទ្រង់ ។

- តើនឹងមានសភាពជាក់លាក់បែបណាខ្លះ អំពីរូបរាងរបស់ព្រះអង្គសង្គ្រោះនៅគ្រានៃការយាងមកជាលើកទីពីររបស់ទ្រង់ ? ( ទ្រង់នឹងយាងមកក្នុងព្រះពស្ត្រពណ៌ក្រហម ហើយទ្រង់នឹងលេចមកនៅក្នុងសិរីល្អដ៏មហិមា ) ។



ដើម្បីជួយសិស្សយល់អំពីនិមិត្តរូបនៃព្រះពស្ត្រពណ៌ក្រហមរបស់ព្រះអង្គសង្គ្រោះ សូមចង្អុលបង្ហាញពាក្យ*ធុងទំពាំងបាយជូរ* នៅក្នុង ខ ៤៨។ សូមដាក់តាំងរូបភាពដែលមានអមមកជាមួយនៃធុងទំពាំងបាយជូរ (ក៏ត្រូវបានហៅថា ធុងស្រាផងដែរនោះ) ឬគូររូបមួយនៅលើក្ដារខៀន ។ សូមពន្យល់ថា នៅក្នុងជំនាន់បុរាណ ធុងស្រាគឺជាបាសាំងធំមួយ ដែលប្រើដើម្បីជាន់យកទឹកទំពាំងបាយជូរចេញពីផ្លែ ។ បាសាំងនឹងត្រូវដាក់បំពេញដោយផ្លែទំពាំងបាយជូរ ហើយមនុស្សមួយចំនួននឹងចូលទៅក្នុងបាសាំងនោះ ហើយជាន់ទន្ទ្រាំពីលើផ្លែទំពាំងបាយជូរ ដើម្បីឲ្យទឹកវាចេញមក ។ នៅពេលមនុស្សជាន់លើទំពាំងបាយជូរពណ៌ក្រហម ឬពណ៌ស្វាយ នោះទឹកទំពាំងបាយជូរនឹងប្រឡាក់ជាប់ជើង និងសម្លៀកបំពាក់របស់ពួកគេដោយពណ៌ក្រហមជាំ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥០–៥១ ឲ្យឮៗ ។

- តើខគម្ពីរទាំងនេះជួយយើងឲ្យយល់អំពីសេចក្ដីយុត្តិធម៌របស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ? (អ្នកអាចនឹងរំឭកសិស្សថា ពួកទុច្ចរិតដែលពុំព្រមប្រែចិត្តត្រូវតែរងទុក្ខទៅតាមតម្រូវការនៃសេចក្ដីយុត្តិធម៌ ហើយនឹងមិនអាចធន់នៅក្នុងថ្ងៃនៃការយាងមកជាលើកទីពីរនោះទេ [សូមមើល គ. និង ស. ៣៨:៨] ។ ព្រះពស្ត្រពណ៌ក្រហមរបស់ព្រះអម្ចាស់ជាតំណាងឲ្យលោហិតនៃពួកទុច្ចរិតដែលនឹងត្រូវបានបំផ្លាញចោល នៅពេលសេចក្ដីយុត្តិធម៌ចាក់មកលើពួកគេនៅការយាងមកជាលើកទីពីរ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥២–៥៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលពួកសុចរិត នឹងចងចាំ ហើយថ្លែងនៅគ្រានៃការយាងមកជាលើកទីពីរ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥៤–៥៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ថានរណានឹងលេចចេញមកជាមួយនឹងព្រះអង្គសង្គ្រោះនៅការយាងមកជាលើកទីពីរ ។

- តើនរណានឹងលេចចេញមកជាមួយព្រះអង្គសង្គ្រោះនៅការយាងមកជាលើកទីពីរ ? ( ពួកសុចរិតដែលបានរស់នៅពីមុនព្រះយេស៊ូវគ្រីស្ទ និងដែលបានរស់ឡើងវិញហើយនោះ នឹងមកជាមួយទ្រង់នៅក្នុងសិរីល្អរបស់ទ្រង់ ។ បន្ថែមពីលើនោះ ពួកសុចរិតដែលរស់នៅ និងបានស្លាប់ទៅ បន្ទាប់ពីព្រះយេស៊ូវគ្រីស្ទ នឹងត្រូវបានរស់ឡើងវិញ ហើយចេញមកចូលរួមនឹងព្រះអង្គសង្គ្រោះ និងអ្នកទាំងឡាយណាដែលនៅជាមួយទ្រង់ ។ អ្នកអាចនឹងថ្លែងថា ការណ៍នេះរួមមានទាំងសមាជិកគ្រួសារសុចរិតរបស់យើង ដែលបានស្លាប់ទៅផងដែរ ។ ពួកសុចរិត ដែលនៅរស់នៅលើផែនដី នឹង « ត្រូវបានលើកឡើង » ទៅជួបនឹងព្រះអង្គសង្គ្រោះ [សូមមើល ថែស្សាឡូនិចទី ១ ៤:១៧, គ. និង ស. ១០៩:៧៥]) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥៧–៧៤

*ដំណឹងល្អត្រូវបានបញ្ជូនចេញទៅ ដើម្បីរៀបចំផែនដីសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ*

សូមបែងចែកសិស្សជាដៃគូៗ ។ សូមអញ្ជើញពួកគេឲ្យពិភាក្សាសំណួរខាងក្រោមជាមួយនឹងដៃគូពួកគេ ៖

- តើអ្នកបានរៀនអ្វីខ្លះចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣ អំពីការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ? តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកគិតអំពីព្រឹត្តការណ៍ទាំងនេះ ?

បន្ទាប់ពីសិស្សបានពិភាក្សាសំណួរទាំងនេះ សូមអញ្ជើញពួកគេឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥៧–៦២ ជាមួយនឹងដៃគូរបស់ពួកគេ ហើយរកមើលសេចក្ដីពិតទាំងឡាយអំពីមូលហេតុដែលដំណឹងល្អនឹងចេញទៅពីមុនការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងរៀនដំណឹងល្អ ហើយរស់នៅតាម នោះយើងនឹងត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

- ស្របតាម ខ ៦២ តើពរជ័យដ៏ធំបំផុតដែលយើងនឹងទទួលមានអ្វីខ្លះ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖**អ្នកទាំងឡាយណាដែលប្រែចិត្ត ហើយញែកខ្លួនពួកគេចេញជាបរិសុទ្ធ នឹងទទួលជីវិតដ៏អស់កល្បជានិច្ច** ) ។

ដើម្បីជួយសិស្សភ្ជាប់គោលការណ៍នេះជាមួយនឹងគោលការណ៍មួយដែលពួកគេបានប្រាប់ពីមុននេះ សូមសួរសំណួរដូចខាងក្រោម ៖

- តើគោលការណ៍នៅក្នុង ខ ៦២ ទាក់ទងទៅនឹងគោលការណ៍ដែលយើងប្រាប់នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤៥ ដែលបានថ្លែងថា « ព្រះអម្ចាស់បានរៀបចំពរជ័យដ៏មហិមាទាំងឡាយសម្រាប់អ្នកទាំងឡាយដែលរង់ចាំទ្រង់ យ៉ាងដូចម្ដេច » ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៦៣–៧៤ ដោយពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះ ព្រះអម្ចាស់បានប្រាប់អំពីផលវិបាកមួយចំនួនដល់អ្នកទាំងឡាយដែលនឹងពុំប្រែចិត្ត ហើយពុំត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ ផលវិបាកមួយចំនួនទាំងនេះ រួមមានទាំងការកាត់ចេញពីព្រះអម្ចាស់ និងរាស្ត្រសុចរិតរបស់ទ្រង់ ( សូមមើល គ. និង ស. ១៣៣:៦៣) ហើយ « ត្រូវបានប្រគល់ទៅឯសេចក្ដីងងឹត » ( គ. និង ស. ១៣៣:៧២) មានន័យថា ជាមនុស្សទុច្ចរិតដែលបានស្លាប់នៅក្នុងការយាងមកជាលើកទីពីរ នឹងត្រូវចូលទៅកន្លែងមួយដែលហៅថា ស្ថានឃុំវិញ្ញាណ ឬស្ថាននរក ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរ « ស្ថាននរក » scriptures.lds.org) ។

ដើម្បីបញ្ចប់មេរៀននេះ សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវអ្វីដែលពួកគេបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣ ដែលបានពង្រឹងដល់ការយល់ដឹង និងទីបន្ទាល់របស់ពួកគេ អំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមគិតអំពីការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិតទាំងនេះជាមួយនឹងសិស្សក្នុងថ្នាក់ ។ សូមថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដែលអ្នកបានពិភាក្សា ។

### *សូមជួយសិស្សឲ្យប្រាប់អំពីទំនាក់ទំនងនៅក្នុងបទគម្ពីរនានា*

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « ការភ្ជាប់គ្នាគឺជាទំនាក់ទំនង ឬ តំណរវាងគំនិត មនុស្ស វត្ថុ ឬ ព្រឹត្តិការណ៍នានា ហើយបទគម្ពីរមានពេញទៅដោយការភ្ជាប់គ្នានេះ ។. . . ការសម្គាល់មើលប្រកបដោយការអធិស្ឋាន ការរៀនអំពី និងការពិចារណាចំពោះការទាក់ទងគ្នាដូច្នេះ. . . នាំទៅរកការយល់ដឹងដ៏បំផុសគំនិត » (« A Reservoir of Living Water » [ Church Educational System devotional, ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ],ទំព័រ ៤, speeches.byu.edu) ។ ពីមួយគ្រាទៅមួយគ្រា សូមឈប់មួយសន្ទុះក្នុងអំឡុងមេរៀន ដើម្បីពិភាក្សាអំពីជំនាញនេះ និងជំនាញសិក្សាបទគម្ពីរដទៃទៀត ដោយលើកទឹកចិត្តដល់សិស្សឲ្យប្រើវានៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ ។

មេរៀនទី ១៤៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤

## បុព្វកថា

នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៨៣៥ ការប្រជុំទូទៅមួយនៃសាសនាចក្របានធ្វើឡើងនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ដើម្បីពិចារណាលើមាតិកាដែលបានស្នើសម្រាប់ការបោះពុម្ពលើកដំបូងនៃគោលលទ្ធិ និង សេចក្ដីសញ្ញា ។ ដោយសារតែព្យាការី យ៉ូសែប ស្ម៊ីធ កំពុងតែទៅសួរសុខទុក្ខដល់ពួកបរិសុទ្ធនៅ ទីក្រុងមីឈីហ្គេន នោះ អូលីវើរ ខៅឌើរី បានធ្វើជាអធិបតីក្នុងការប្រជុំនេះ ។ នៅក្នុងការប្រជុំពួកបរិសុទ្ធបានបោះឆ្នោតដោយអនាមិកដើម្បីដាក់បញ្ចូលនូវសេចក្ដីប្រកាសមួយដែល អូលីវើរ ខៅឌើរី បានបង្ហាញទាក់ទងនឹងជំនឿនៃសាសនាចក្រ ពាក់ព័ន្ធនឹងរដ្ឋាភិបាល និងច្បាប់ទាំងឡាយ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១–៤

*ទំនួលខុសត្រូវទាំងឡាយរបស់រដ្ឋាភិបាលត្រូវបានស្ថាបនាឡើង*

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពួកគេកំពុងតែបង្កើតប្រទេសថ្មីមួយ ។ សូមតែងតាំងសិស្សម្នាក់ឲ្យធ្វើជាអ្នកដឹកនាំនៅក្នុងរដ្ឋាភិបាលថ្មីនេះ ។ សូមអញ្ជើញសិស្សឲ្យយកគម្ពីររបស់ពួកគេមកខាងមុខសិស្សក្នុងថ្នាក់ ។ សូមសួរដល់សិស្សដែលជាអ្នកដឹកនាំនោះ នូវសំណួរដូចខាងក្រោម ៖

- តើច្បាប់ណាខ្លះ ដែលអ្នកចង់អនុមតិឲ្យប្រជាជននៅក្នុងប្រទេសថ្មីនេះអនុវត្តតាម ? ( អ្នកអាចនឹងសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ។ )

សូមសួរសិស្ស ៖

- តើអ្នកគិតថា ច្បាប់ណាខ្លះដែលអ្នកដឹកនាំរបស់អ្នកបានបង្កើតឡើង ? តើអ្នកមានផែនការធ្វើតាមច្បាប់ទាំងនោះឲ្យបានល្អកម្រិតណា ?
- តើអ្នកគិតថា គោលបំណងរបស់រដ្ឋាភិបាលមួយគឺជាអ្វី ?

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ មាននូវឯកសារមួយដែលប្រកាសអំពីជំនឿរបស់សាសនាចក្រ ទាក់ទងនឹងរដ្ឋាភិបាល និងច្បាប់ទាំងឡាយ ។ នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ១៨៣៥ ខណៈពេលការរៀបចំចុងក្រោយត្រូវបានធ្វើឡើងដើម្បីបោះពុម្ពច្បាប់ដំបូងនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា នោះអូលីវើរ ខៅឌើរី បានធ្វើជាអធិបតីនៅក្នុងការប្រជុំទូទៅមួយនៃសមាជិកសាសនាចក្រ ។ លោកបានបង្ហាញឯកសារ ហើយសមាជិកបានចូលរួមបោះឆ្នោតដោយអនាមិកដើម្បីដាក់បញ្ចូលវាទៅក្នុងព្រះគម្ពីរ ។ យ៉ូសែប ស្ម៊ីធ និង ហ្វ្រេឌើរិក ជី វិលលាម្ស ដែលជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ ពុំមានវត្តមាននៅក្នុងការប្រជុំនេះទេ ។ ពួកលោកកំពុងផ្សាយដំណឹងល្អនៅរដ្ឋ មីឈីហ្គេន ។ នៅពេលពួកលោកបានត្រឡប់មកវិញ យ៉ូសែប ស្ម៊ីធ បានអនុញ្ញាតឲ្យឯកសារនោះត្រូវបានដាក់បញ្ចូលទៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ។

សូមអញ្ជើញឲ្យសិស្សដែលជាអ្នកដឹកនាំអាននូវសេចក្ដីណែនាំក្នុងកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវមូលហេតុដែលពួកបរិសុទ្ធមានអារម្មណ៍ថា ការប្រកាស គឺចាំបាច់ត្រូវបានបោះពុម្ព ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ។ សូមឲ្យសិស្សពាក់កណ្ដាលថ្នាក់រកមើលថា តើនរណាជាអ្នកបង្កើតគំនិតអំពីរដ្ឋាភិបាល ហើយនឹងគោលបំណងចម្បងនៃ រដ្ឋាភិបាលទាំងឡាយ ។ សូមអញ្ជើញសិស្សពាក់កណ្ដាលថ្នាក់ទៀតឲ្យរកមើលអ្វីដែលព្រះកាន់ទំនួលខុសត្រូវជាផ្លូវការរបស់រដ្ឋាភិបាល ។ សូមអញ្ជើញក្រុមនីមួយៗឲ្យរាយការណ៍អំពីអ្វីដែលពួកគេរកឃើញ ។ នៅពេលសិស្សប្រាប់អំពីសេចក្ដីពិតដូចខាងក្រោម សូមសរសេរវានៅលើក្ដារខៀន ៖

**រដ្ឋាភិបាលទាំងឡាយ ត្រូវបានបង្កើតឡើងដោយព្រះសម្រាប់ជាប្រយោជន៍ដល់មនុស្ស ។**

**មន្ត្រីរដ្ឋាភិបាល គឺទទួលខុសត្រូវចំពោះព្រះសម្រាប់ការណ៍ល្អ និងសន្តិសុខក្នុងសង្គម ។**

- តើមានវិធីណាខ្លះ ដែលអ្នកដឹកនាំក្នុងរដ្ឋាភិបាលអាចធ្វើសម្រាប់ការល្អ និងសន្តិសុខក្នុងសង្គម ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើល សិទ្ធិរបស់រដ្ឋាភិបាលបីយ៉ាង គប្បីការពារដល់បុគ្គលម្នាក់ៗ ។ ពីមុនសិស្សអាន អ្នកអាចនឹង ពន្យល់ថា ពាក្យធានា*មានន័យថា សុវត្ថិភាព ឬមិនល្មើស* ។

- ស្របតាម ខ ២ តើសិទ្ធិអ្វីខ្លះ ដែលរដ្ឋាភិបាលគប្បីមានដើម្បីធានាសុវត្ថិភាពដល់ប្រជាពលរដ្ឋរបស់ពួកគេ ? ( « សេរីភាពខាងសតិសម្បជញ្ញៈខាងសិទ្ធិ, សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និង សិទ្ធិការពារជីវិត » ។ អ្នកអាចនឹងប្រាប់សិស្សថា ប្រធាន អែសរ៉ា ថាហ្វ បែនសឹន បានមានប្រសាសន៍ថា « ជីវិត, សេរីភាព [ និង ] ទ្រព្យសម្បត្តិ [គឺជា] សិទ្ធិដ៏ធំបីយ៉ាងរបស់ មនុស្សលោក » [«Our Divine Constitution» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ ទំព័រ ៤ ] ) ។

- តើអ្នកគិតថា ការអនុវត្តខាងសតិសម្បជញ្ញៈរបស់អ្នក មានន័យយ៉ាងដូចម្ដេច ? ហេតុអ្វីវាសំខាន់ ដើម្បីមានសិទ្ធិអនុវត្តខាង សតិសម្បជញ្ញៈរបស់អ្នកដោយសេរីនោះ ?

> ### និយមន័យពាក្យ និង ឃ្លាពិបាកៗ
> នៅពេលសិស្សសិក្សាបទគម្ពីរ ពួកគេអាចនឹងជួបនូវពាក្យ ឬឃ្លាពិបាកៗ ដែលពុំធ្លាប់ស្គាល់ ឬដែលពិបាកយល់ ។ អ្នកអាចជួយពួកគេរកមើលនិយមន័យនៃពាក្យ និងឃ្លាដូច្នេះ ដោយការលើកទឹកចិត្តពួកគេឲ្យរកមើលក្នុងវចនានុក្រម សៀវភៅសិក្សារបស់សិស្ស លេខយោង និងជំនួយការសិក្សាបទគម្ពីរដទៃទៀត ។ បើចាំបាច់ អ្នកអាចនឹងផ្ដល់នូវនិយមន័យទាំងនេះខ្លះដោយខ្លួនអ្នក ។ ឧទាហរណ៍ អ្នកអាចនឹងសរសេរពាក្យពិបាកៗ និងនិយមន័យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ នៅលើក្ដារខៀន នៅពេលត្រូវបានលើកឡើងអំឡុងមេរៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសិទ្ធិផ្សេងទៀត ដែលរដ្ឋាភិបាលគប្បីការពារ ។ ( ពីមុនសិស្សអាន អ្នកអាចនឹងពន្យល់ថា ពាក្យ *ទទួលខុស ត្រូវ* មានន័យថា ចេះទទួលខុសត្រូវ ហើយថាអ្នកកាន់អំណាចរដ្ឋបាលស៊ីវិល គឺជាមន្ត្រីសាធារណៈមួយ ដែលគ្រប់គ្រងច្បាប់ ) ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- ហេតុអ្វីអ្នកគិតថាវាសំខាន់ ចំពោះមនុស្សត្រូវទទួលខុសត្រូវចំពោះព្រះ ពុំមែនរដ្ឋាភិបាល ចំពោះរបៀបដែលពួកគេអនុវត្ត សាសនារបស់ពួកគេ ?

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បីបង្ក្រាបលើឧក្រិដ្ឋកម្ម ហើយដាក់ទោសកំហុស ដោយពុំព្យាយាមគ្រប់គ្រងលើ មនសិកា ឬបំផ្លាញសេរីភាពរបស់មនុស្សនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ដើម្បីស្វែងរកមើល អ្វីមួយដែលពលរដ្ឋនៃប្រទេសមួយចំនួនអាចធ្វើ ដើម្បីជួយមើលឲ្យប្រាកដថា អ្នកដឹកនាំក្នុងរដ្ឋាភិបាលរបស់ពួកគេនឹងជួយលើក កម្ពស់ដល់ច្បាប់ ។ ( ដើម្បីជួយសិស្សឲ្យយល់នូវខគម្ពីរអ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា សាធារណរដ្ឋ គឺជារដ្ឋាភិបាលមួយ ដែលប្រជាជនជ្រើសរើសអ្នកដឹកនាំឲ្យធ្វើជាតំណាងរបស់ពួកគេ ហើយថាមហាក្សត្រគឺជាអ្នកគ្រប់គ្រងដ៏ខ្ពស់ខ្ពង់ ដូចជាស្ដេច ឬ ម្ចាស់ក្សត្រី ) ។

- តើ « សំឡេងរបស់ប្រជាជន » ស្វែងរក និងលើកកម្ពស់ដល់អ្នកដឹកនាំល្អយ៉ាងដូចម្ដេច ? ( បើចាំបាច់ សូមចង្អុល បង្ហាញថា ឃ្លា « សំឡេងរបស់ប្រជាជន » សំដៅទៅលើការអនុវត្តនៃការបោះឆ្នោតរើសអ្នកដឹកនាំ ) ។

សូមយោងទៅលើសិស្សដែលអ្នកបានចាត់តាំងឲ្យធ្វើជាអ្នកដឹកនាំលើប្រទេសថ្មីកាលពីពេលចាប់ផ្ដើមមេរៀនដំបូង ។ សូម អញ្ជើញសិស្សក្នុងថ្នាក់ឲ្យដាក់បញ្ចូលឈ្មោះសិស្សច្រើនទៀតដើម្បីជួយដល់អ្នកដឹកនាំនេះ ។ បន្ទាប់មកធ្វើការបោះឆ្នោតមួយ ដើម្បីសិស្សក្នុងថ្នាក់អាចជ្រើសរើសសិស្សពីរនាក់ដែលត្រូវបានដាក់បញ្ចូលឈ្មោះនោះ ។ សូមអញ្ជើញអ្នកដឹកនាំថ្មីទាំងនេះ ឲ្យយកព្រះគម្ពីររបស់ពួកគេមក ហើយចូលរួមនឹងអ្នកដឹកនាំទីមួយ ( ជាមនុស្សម្នាក់ដែលអ្នកបានតែងតាំងមុនគេ ) មកខាង មុខថ្នាក់ ។ សូមឲ្យអ្នកដឹកនាំទាំងបីនាក់នេះ ពន្យល់អំពីអ្វីដែលពួកគេបានរៀនរហូតមកដល់ពេលនេះ អំពីទំនួលខុសត្រូវ របស់ពួកគេក្នុងនាមជាមន្ត្រីរដ្ឋាភិបាល ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៥–៦, ៨

### *ទំនួលខុសត្រូវទាំងឡាយរបស់ពលរដ្ឋត្រូវបានរៀបចំឡើង*

សូមឲ្យអ្នកដឹកនាំទាំងបីរូបនោះ សរសេរនូវទំនួលខុសត្រូវមួយចំនួនដែលពលរដ្ឋគួរតែមាននៅក្នុងប្រទេសថ្មីរបស់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ បន្ទាប់មក សូមសួរសិស្ស ៖

- តើអ្នកគិតថាបញ្ជីនៃទំនួលខុសត្រូវនេះយ៉ាងម៉េចដែរ ? តើអ្នកនឹងផ្លាស់ប្ដូរបញ្ជីនេះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៥–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវ ទំនួលខុសត្រូវរបស់ប្រជាពលរដ្ឋ ។ ( នៅពេលសិស្សអាន អ្នកអាចនឹងសុំពួកគេឲ្យផ្អាកមួយភ្លែតសិន ដើម្បីអ្នកអាចឲ្យន័យ នៃពាក្យដូចខាងក្រោម ៖ *ឥតដកចេញបាន* សំដៅទៅលើអ្វីមួយដែលពុំអាចយកចេញបាន ពាក្យ *ការចាក់រុក* សំដៅទៅលើ ការបះបោរទាស់នឹងអ្នកដឹកនាំរដ្ឋាភិបាល ពាក្យ *ព្រមធ្វើតាម* មានន័យថា យល់ព្រម ឬចុះចូល ពាក្យ *បានជំនួស* មានន័យថា បានជួស *អនាធិបតេយ្យ* មានន័យថាភាពគ្មានច្បាប់ទម្លាប់–ភាពអវត្តមាននៃច្បាប់ និងរដ្ឋាភិបាល ឬការបះបោរទាស់នឹងច្បាប់ និងរដ្ឋាភិបាល ) ។

- ស្របតាម ខ ៥–៦ តើយើងមានទំនួលខុសត្រូវអ្វីខ្លះចំពោះរដ្ឋាភិបាលរបស់យើង ? ( សិស្សគួរតែបង្ហាញពីអ្វីមួយស្រដៀងគ្នាទៅនឹងសេចក្ដីពិតដូចខាងក្រោម ៖ **យើងត្រូវគាំទ្រ និងលើកកម្ពស់ដល់រដ្ឋាភិបាលដែលយើងរស់នៅ ។** សូមពិចារណាសរសេរគោលការណ៍នេះនៅលើក្ដារខៀន ។ សូមចង្អុលបង្ហាញថា គោលការណ៍នេះរួមមានទាំង ការសន្មត់ថា រដ្ឋាភិបាលរបស់យើង រក្សាច្បាប់ទាំងឡាយដែលការពារយើងនៅក្នុង « សិទ្ធិកំណើត និងឥតអាចដកចេញបាន » ) ។

- តើមាត្រានៃសេចក្ដីជំនឿមួយណា ដែលគោលការណ៍នេះរំឭកអ្នកអំពីវា ? ( អ្នកអាចអញ្ជើញសិស្សឲ្យអាន ឬសូត្រមាត្រានៃសេចក្ដីជំនឿទីដប់ពីរ )។

- តើក្នុងនាមជាប្រជាពលរដ្ឋយើងអាចធ្វើដូចម្ដេច ដើម្បីគាំទ្រ និងលើកកម្ពស់ដល់រដ្ឋាភិបាល ? ( ចម្លើយអាចរួមមានថា យើងអាចគោរពច្បាប់ លើកទឹកចិត្តអ្នកដទៃឲ្យគោរពតាម បម្រើនៅក្នុងសហគមន៍ បង្ហាញការគោរពដល់មន្ត្រីរដ្ឋាភិបាល និងការបោះឆ្នោត ) ។

ដើម្បីជួយសិស្សប្រាប់អំពីសេចក្ដីពិតផ្សេងទៀត អំពីការលើកកម្ពស់ដល់រដ្ឋាភិបាល និងច្បាប់ទាំងឡាយ សូមសួរសំណួរដូចខាងក្រោម ៖

- ស្របតាម ខ ៦ តើព្រះមានព្រះទ័យយ៉ាងណាអំពីការគោរពប្រតិបត្តិរបស់យើងចំពោះក្រឹត្យវិន័យរបស់ព្រះ និងច្បាប់របស់មនុស្ស ? ( បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះចង់ឲ្យយើងធ្វើតាម និងគោរពដល់ក្រឹត្យវិន័យរបស់ព្រះ និងច្បាប់របស់មនុស្ស** ) ។

ដើម្បីជួយសិស្សឆ្លើយសំណួរពីមុន សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ជេម អ៊ី ថាលម៉េហ្គ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់នូវរបៀបដែលយើងគប្បីប្រព្រឹត្តចំពោះច្បាប់នៃដែនដី នៅពេលវាទាស់នឹងជំនឿរបស់យើង ៖



« នៅក្នុងករណីមានទំនាស់រវាងការទាមទារដែលធ្វើឡើងពីព្រះបន្ទូលនៃព្រះដែលបានបើកសម្ដែង និងពីស្ថានភាពដែលត្រូវបានបង្ខំដោយច្បាប់លោកិយ តើភាគីណាមួយដែលសមាជិកសាសនាចក្រត្រូវគោរពតាម ?. . .

« ទន្ទឹមនឹងការរង់ចាំ [ ព្រះ ] ទ្រង់គ្រប់គ្រងលើអ្វីទាំងអស់ ដើម្បីមានសេរីភាពខាងសាសនានោះ វាគឺជាករណីយកិច្ចរបស់ពួកបរិសុទ្ធ ដែលត្រូវចុះចូលទៅនឹងច្បាប់នៃប្រទេសរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេគួរតែប្រើប្រាស់គ្រប់វិធី ក្នុងនាមជាប្រជាពលរដ្ឋ ឬ ដាក់សំណើទៅកាន់រដ្ឋាភិបាលរបស់ខ្លួន ដើម្បីជានាដល់ពួកគេ និង ដល់មនុស្សទាំងពួង ឲ្យទទួលបានគុណប្រយោជន៍នៃសេរីភាពខាងកិច្ចការសាសនា ។ វាពុំតម្រូវពួកគេឲ្យទទួលការរងទុក្ខដោយគ្មានការប្រឆាំងតវ៉ាចំពោះការធ្វើទុក្ខពីអ្នកបៀតបៀនដែលគ្មានច្បាប់ ឬតាមរយៈការប្រតិបត្តិច្បាប់ដោយអយុត្តិធម៌ឡើយ ប៉ុន្តែការប្រឆាំងតវ៉ារបស់ពួកគេ គប្បីផ្ដល់ឲ្យតាមច្បាប់ និងលំដាប់ត្រឹមត្រូវ ។ ពួកបរិសុទ្ធពិតជាបានបង្ហាញនូវការទទួលយកគោលលទ្ធិរបស់ពួកគេតាមការប្រតិបត្តិ ដែលវាល្អប្រសើរជាងដើម្បីរងទុក្ខទង្វើអាក្រក់ ជាជាងការធ្វើខុស ដោយការប្រឆាំងចំពោះអ្នកមានសិទ្ធិអំណាចដែលអយុត្តិធម៌ដោយពុំត្រឹមត្រូវនោះ » (*មាត្រានៃសេចក្ដីជំនឿទី* ១២ បានបោះពុម្ព [ឆ្នាំ ១៩២៤] ទំព័រ ៤២២, ៤២៣ ] ) ។

សូមអញ្ជើញសិស្សឲ្យគិតអំពី មនុស្សដែលពួកគេស្គាល់ ដែលគោរពតាមគោលការណ៍ទាំងឡាយនៃការគាំទ្រ និងការលើកកម្ពស់ដល់រដ្ឋាភិបាល និងច្បាប់របស់ពួកគេ ។ អ្នកអាចនឹងសុំឲ្យសិស្សពីរបីនាក់ចែកចាយរបៀបដែលពលរដ្ឋទាំងនេះលើកកម្ពស់ដល់រដ្ឋាភិបាល ។ បន្ទាប់មកសូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីមួយដែលពួកគេនឹងធ្វើដោយខ្លួនឯងដើម្បីគាំទ្រ និងលើកកម្ពស់ដល់រដ្ឋាភិបាល និងច្បាប់ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៨ ដោយការពន្យល់ថា រដ្ឋាភិបាលមានទំនួលខុសត្រូវមួយដើម្បីដាក់ទោសដល់អស់អ្នកទាំងឡាយណាដែលប្រព្រឹត្តបទឧក្រិដ្ឋ ហើយថាប្រជាពលរដ្ឋ មានទំនួលខុសត្រូវមួយដើម្បីជួយ « នាំអ្នកមានទោសដែលទាស់នឹងច្បាប់ល្អត្រឹមត្រូវមកដាក់ទោស » ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៧, ៩–១០, ១២

*ទំនាក់ទំនងរវាងសាសនា និងរដ្ឋាភិបាលត្រូវបានពិពណ៌នា*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៧, ៩–១០, ១២ ដោយការពន្យល់ថា អូលីវើរ ខៅឌើរី បានសរសេរថា រដ្ឋាភិបាលគប្បីតែបង្កើតច្បាប់ដែលការពារដល់គោរពខាងសាសនា ប៉ុន្តែពួកគេពុំគប្បីលំអៀងទៅលើសាសនាមួយជាងសាសនាមួយទៀតឡើយ ។ បន្ថែមពីលើនោះ លោកបានសរសេរថា សង្គមសាសនាទាំងឡាយ មានសិទ្ធិដើម្បីដាក់ទោស

ចំពោះសមាជិកដែលពុំគោរពតាមរបស់ពួកគេ ដោយការកាត់កាលពួកគេចេញ ឬដកសមាជិកភាពរបស់ពួកគេចេញ ប៉ុន្តែសង្គមដូច្នេះ ពុំមានសិទ្ធិធ្វើការវិនិច្ឆ័យ ឬដាក់ទណ្ឌកម្មនានា ដែលនឹងដកហូរយកទ្រព្យសម្បត្តិរបស់សមាជិកពួកគេ ឬធ្វើឲ្យគ្រោះថ្នាក់ដល់រាងកាយពួកគេឡើយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១១

*សិទ្ធិដើម្បីអំពាវនាវសុំជំនួយមកពីរដ្ឋាភិបាល គឺត្រូវបានពន្យល់*

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១១ ដោយការពន្យល់ថា ស្របតាមខគម្ពីរនេះ ពលរដ្ឋគប្បីអនុញ្ញាតឲ្យសុំដល់រដ្ឋាភិបាលរបស់ពួកគេដើម្បី « កែកំហុស » បើពួកគេបានធ្វើខុស ។ ពាក្យ *កែកំហុស* មានន័យថា បានធ្វើអ្វីមួយត្រូវ ។ ខគម្ពីរក៏មានបញ្ចូលទាំងការប្រកាសមួយ ដែលពលរដ្ឋមានមូលហេតុត្រឹមត្រូវនៅក្នុងការការពារខ្លួន និងអ្នកដទៃ នៅពេលដែលមានតម្រូវការបន្ទាន់មួយ ហើយរដ្ឋាភិបាលពុំអាចជួយបាន ។

សូមឲ្យសិស្សចែកចាយនូវអ្វីដែលពួកគេថ្លែងអំណរគុណចំពោះប្រទេស និងសហគមន៍របស់ពួកគេ ។ សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការគាំទ្រ និងការលើកកម្ពស់រដ្ឋាភិបាល និងច្បាប់ទាំងឡាយ ។

មេរៀនទី ១៤៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ ភាគ ១

## បុព្វកថា

នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤ ព្យាការីយ៉ូសែប ស៊្មីធ និង បងប្រុសរបស់លោក ហៃរ៉ុម ដែលជាជំនួយការប្រធាន និងជាលោកអយ្យកោរបស់សាសនាចក្រ ត្រូវបានធ្វើទុក្ករកម្មនៅក្នុងគុកកាតេជេច រដ្ឋ អិលលីណោយ ។ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានអនុមតិការប្រកាសអំពីទុក្ករកម្មមួយ ឲ្យដាក់បញ្ចូលនៅក្នុងការបោះពុម្ពនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា នៅចុងឆ្នាំ ១៨៤៤ ដែលហៀបនឹងត្រូវបានបោះពុម្ព ។ សេចក្ដីប្រកាសនោះសរសេរតាមដំណើររឿងដែលអែលឌើរ យ៉ូហាន ថេលើរ និង វិលឡើឌ រិចឺស្ស ជាសមាជិកក្នុងកូរ៉ុមនៃពួកដប់ពីរនាក់ បានឃើញដោយផ្ទាល់ភ្នែក ។ វីរៈណៈនេះ ឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៥ ។

*កំណត់ចំណាំ ៖*មេរៀននេះ រួមមាននូវដំណើររឿងជាប្រវត្តិសាស្ត្រមួយចំនួនដែលអាចត្រូវបានអានដោយសិស្ស ។ អ្នកអាចនឹងគិតធ្វើការថតចម្លងដំណើររឿងទាំងនេះ ហើយចែកវាទៅឲ្យសិស្សនៅពេលចាប់ផ្ដើមថ្នាក់រៀន ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:១–៧

*ទុក្ករកម្មរបស់ យ៉ូសែប និង ហៃរ៉ុម ស៊្មីធ ត្រូវបានប្រកាស*

សូមចាប់ផ្ដើមថ្នាក់ដោយការសួរដល់សិស្ស បើមានពួកគេណាម្នាក់ចាំថា ពួកគេនៅកន្លែងណា នៅពេលពួកគេបានដឹងអំពីការស្លាប់របស់ប្រធាននៃសាសនាចក្រ ឬមនុស្សជាទីស្រឡាញ់ ។

សូមអញ្ជើញសិស្សឲ្យស្រមៃថា ពួកគេជាសមាជិកនៃសាសនាចក្រដែលរស់នៅក្នុងទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ក្នុងឆ្នាំ ១៨៤៤ ហើយពួកគេបានទទួលដំណឹង ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:១ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរនេះឲ្យឮៗ ។

- តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច បន្ទាប់ពីបានស្ដាប់ឮអំពីសោកនាដកម្មនេះ ?

សូមពន្យល់ថា ពួកបរិសុទ្ធជាច្រើន បានរញ្ជួយចិត្តជាខ្លាំងជាមួយនិងភាពសោកសៅ នៅពេលពួកគេបានដឹងអំពីការស្លាប់របស់ យ៉ូសែប និង ហៃរ៉ុម ស៊្មីធ ។ សូមលើកទឹកចិត្តដល់សិស្សឲ្យនឹកគិតអំពីអារម្មណ៍ផ្ទាល់ខ្លួន និងទីបន្ទាល់របស់ពួកគេអំពីព្យាការី យ៉ូសែប ស៊្មីធ នៅពេលពួកគេដឹងអំពីថ្ងៃចុងក្រោយនៃជីវិតរបស់លោក ។

សូមប្រាប់សិស្សថា យ៉ូសែប ស៊្មីធ និង ពួកបរិសុទ្ធ បានរស់នៅដោយភាពសុខសាន្តក្នុងរដ្ឋ អិលលីណោយ ប្រហែលរយៈពេលបីឆ្នាំ ។ ទោះជាយ៉ាងណាក៏ដោយ ត្រឹមឆ្នាំ ១៨៤២ ពួកគេបានចាប់ផ្ដើមជួបនឹងការជំទាស់ប្រឆាំងម្ដងទៀត ។ អ្នកប្រឆាំងនៅក្នុងសាសនាចក្រ និងបក្សប្រឆាំងនៅខាងក្រៅសាសនាចក្រ បានរួមកម្លាំងគ្នាដើម្បីប្រឆាំងនឹងព្យាការី ព្រមទាំងសាសនាចក្រ ។ ពលរដ្ឋមួយចំនួននៅរដ្ឋ អិលលីណោយ បានចាប់ផ្ដើមមានភាពភ័យខ្លាច ហើយស្អប់ឥទ្ធិពលខាងនយោបាយរបស់ពួកបរិសុទ្ធ ។ អ្នកដទៃទៀតកាន់តែច្រណែននឹងការរីកចម្រើនខាងសេដ្ឋកិច្ចរបស់សាសនាចក្រនៅទីក្រុងណៅវូ ហើយបានរិះគន់នឹងអំណាចរបស់អភិបាលក្រុងណៅវូ និងក្រុមជីវពលរបស់ក្រុង ។ មនុស្សមួយចំនួនទៀតបានចាប់ផ្ដើមមិនចូលចិត្តពួកបរិសុទ្ធ ដោយសារតែការយល់ច្រឡំអំពីគោលលទ្ធិ និងការអនុវត្តរបស់ពួកមរមនដ៏ចម្លែក ដូចជាអាពាហ៍ពិពាហ៍ពហុពន្ធភាព ហើយមួយចំនួនទៀតបានយល់ខុស ដោយសារតែសមាជិកនៃសាសនាចក្រដែលក្បត់សាសនា ។ ( សូមមើល *Church History in the Fulness of Times Student Manual,* បោះពុម្ពទី ២ [Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ២៦៣–៦៦, ២៧០–៧១ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កថាកណ្ឌដូចខាងក្រោម ៖

## សិស្សទី ១

ត្រឹមខែ មិថុនា ឆ្នាំ ១៨៤៤ ភាពអនាមិកប្រឆាំងនឹងសាសនាចក្រកាន់តែតានតឹងខ្លាំងឡើងៗ ។ ប្រជាជនខ្លះនៅក្នុងរដ្ឋ អិលលីណោយ បានពិភាក្សាពីការបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋ ខណៈអ្នកផ្សេងទៀតបានគ្រោងសម្លាប់ព្យាការី ។ អ្នកខ្លះដែលបានរួមគំនិតក្បត់នឹងព្យាការី និង សាសនាចក្រ ជាអតីតសមាជិកនៃសាសនាចក្រ ដែលបានក្បត់សាសនា ។ នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៨៤៤ វិល្លៀម ឡរ ដែលបានបម្រើជាទីប្រឹក្សាទីពីរនៃគណៈប្រធានទីមួយ និងអ្នកក្បត់សាសនាផ្សេងទៀត បានបោះពុម្ពកាសែតលេខទីមួយដែលហៅថា *Nauvoo Expositor* ។ ដោយមានបំណងចង់ញុះញង់ដល់សាធារណជន ឲ្យប្រឆាំងនឹងព្យាការី និងសាសនាចក្រ បុរសទាំងនេះបានប្រើកាសែតដើម្បីនិយាយបង្ខូចដល់ យ៉ូសែប ស្ម៊ីធ និងពួកអ្នកដឹកនាំសាសនាចក្រផ្សេងទៀត ។ យ៉ូសែប ស្ម៊ីធ និងក្រុមប្រឹក្សាក្រុងណៅវូភាគច្រើនបានដឹងថា កាសែតអុជអាលនេះ នឹងនាំទៅកេអំពើហិង្សាឥតសណ្ដាប់ធ្នាប់ប្រឆាំងក្នុងក្រុងនេះ ។ ពួកគេបានប្រកាសដល់សាធារណៈជនថាជាសារព័ត៌មានខ្ទេចខ្ទាំ និងបានបញ្ជាឲ្យបំផ្លាញកាសែត *Nauvoo Expositor* ។

សូមពន្យល់ថា មាតិកាអំពី *Nauvoo Expositor* ព្រមជាមួយនឹងការបំផ្លាញការបោះពុម្ព បានបណ្ដាលឲ្យមានកំហឹងទំនាស់ប្រឆាំងនឹងពួកមរមន កើនឡើងរឹតតែខ្លាំង ។ ម្ចាស់រោងពុម្ពបានដាក់បណ្ដឹងស្របច្បាប់ទាស់នឹង យ៉ូសែប ស្ម៊ីធ និង អ្នកដឹកនាំក្នុងក្រុងដទៃទៀត ដោយចោទប្រកាន់ពួកគេអំពីការបង្កឲ្យមានកុប្បកម្មឡើង ។ យ៉ូសែប ស្ម៊ីធ ត្រូវបានរួចពីការចោទប្រកាន់ ប៉ុន្តែការដោះលែងលោក កាន់តែធ្វើឲ្យមារសត្រូវ របស់លោកខឹងខ្លាំងឡើងៗប៉ុណ្ណោះ ។ នៅពេលការវាយការណ៍បានចាប់ផ្ដើមសាយភាយ ដែលពួកមនុស្សកំណាចបានប្រមូលផ្ដុំគ្នាវាយប្រហារលើទីក្រុង ណៅវូ នោះ យ៉ូសែប ស្ម៊ីធ ក្នុងនាមជាអភិបាលខេត្ត បានប្រកាសថាទីក្រុង ណៅវូ ត្រូវស្ថិតនៅក្រោមច្បាប់ទ័ព ( ច្បាប់ទ័ពបណ្ដោះអាសន្ន ) ។ ដោយមានការដឹកនាំពីអភិបាល ថូម៉ាស ហ្វត នៃរដ្ឋ អិលលីណោយ យ៉ូសែប បានបញ្ជាទ័ពផ្លូវការនៅណៅវូ ការពារដល់ទីក្រុង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌពីរដូចខាងក្រោម ៖

## សិស្សទី ២

ការរំជើបរំជួលនៅក្នុងតំបន់បានរីកធំឡើងៗ ដែលធ្វើឲ្យអភិបាល ហ្វត ចេញទៅ កាតធេច ជាទីស្នាក់ការកណ្ដាលនៃរដ្ឋាភិបាល ស៊ុកងទ័ព ដើម្បីបង្រ្កាបស្ថានភាពហឹង្សាដ៏ខ្លាំងនោះ ។ គាត់បានសរសេរសំបុត្រទៅកាន់ យ៉ូសែប ស្ម៊ីធ ថា មានតែតាមរយៈការសម្រេចក្ដីរបស់ព្យាការី និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រត្រូវបានធ្វើឡើងដោយក្រុមចៅក្រមមិនមែនជាពួកមរមន នៅក្រុងកាតធេច ទេ ទើបអាចធ្វើឲ្យប្រជាពលរដ្ឋស្ងប់ចិត្តបាន ។ អភិបាល ហ្វត ក៏បានសន្យានឹងពួកគេថា នឹងការពារ ហើយកាត់ទោសដោយយុត្តិធម៌ទាំងស្រុង បើពួកគេចូលមកដោយស្ម័គ្រចិត្ត ។ យ៉ូសែប បានតបថា ជីវិតរបស់លោកនឹងស្ថិតនៅក្នុងភាពគ្រោះថ្នាក់នៅតាមផ្លូវ ហើយថាលោកនឹងពុំចូលខ្លួនទេ ។

នៅពេល យ៉ូសែប ស្ម៊ីធ បានប្រឹក្សាជាមួយនឹងបងប្អូនប្រុសរបស់លោកអំពីអ្វីត្រូវធ្វើបន្ទាប់ទៀត នោះលោកមានអារម្មណ៍ថា បើលោក និងហៃរ៉ុម ចាកចេញពី ណៅវូ ហើយធ្វើដំណើរទៅទិសខាងលិច នោះពួកគេបរិសុទ្ធនៅរដ្ឋ ណៅវូ នឹងពុំមានគ្រោះថ្នាក់ទេ ។ យ៉ូសែប និង ហៃរ៉ុមបានធ្វើដំណើរឆ្លងកាត់ទន្លេមីស៊ីស៊ីពី ទៅ អៃអូវ៉ា តាមការប្រឹក្សានេះ ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកសាសនាចក្រមួយចំនួននៅណាវូ បានសង្ស័យចំពោះផែនការរបស់ព្យាការី ។ មានមនុស្សមួយចំនួនបានមកជួបលោក បានចោទលោកថា កំសាក ដោយនិយាយថា លោកបានបោះបង់ចោលពួកបរិសុទ្ធ ហើយទុកឲ្យពួកគេនៅប្រឈមមុខនឹងការបៀតបៀនតែឯង ។ ព្យាការីបានតបថា « បើសិនជាជីវិតមិត្តរបស់ខ្ញុំពុំមានតម្លៃចំពោះជីវិតខ្ញុំ នោះខ្ញុំគ្មានតម្លៃអ្វីទេ » ( នៅក្នុង*History of the Church* ៦:៥៤៩) ។ បន្ទាប់ពីបានប្រឹក្សាជាមួយគ្នាហើយ យ៉ូសែប និង ហៃរ៉ុម បានត្រឡប់មកទីក្រុង ណៅវូ វិញ ។ នៅព្រឹកព្រលឹមថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៨៤៤ ពួកលោកបានចាកចេញទៅកាតធេច ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្យាករដែលយ៉ូសែប ស្ម៊ីធ បានធ្វើ នៅពេលលោកជិតទៅដល់ទីក្រុងកាតធេច ។

- តើយ៉ូសែបបានប្រាប់ថា មានអ្វីនឹងកើតឡើងដល់លោក ?

- តើអ្នកគិតថា ព្យាការីនឹងមានអារម្មណ៍យ៉ាងណា នៅពេលដែលលោកចាកចេញពីគ្រួសារលោក ដោយដឹងថា លោកនឹងពុំត្រឡប់មកជួបពួកគេវិញនោះ ?

- ហេតុអ្វីក៏អ្នកគិតថា យ៉ូសែប « មានចិត្តស្ងប់ស្ងាត់ដូចជាព្រឹកព្រលឹមនៅរដូវក្ដៅ » នៅពេលលោកបានដឹងថា លោកនឹង « ដូចជាកូនចៀមដែលនឹងត្រូវសម្លាប់ » យ៉ាងដូច្នោះ ?

សូមពន្យល់ថា ព្យាការីបានដឹងថាការស្លាប់របស់លោក នឹងការពារដល់ជីវិតរបស់ពួកបរិសុទ្ធ ។

នៅពេលហៃរ៉ុម ស្ម៊ីធ បានរៀបចំធ្វើដំណើរទៅគុកកាតធេច នោះលោកបានអាន អេធើរ ១២:៣៦–៣៨ ហើយបន្ទាប់មក បានបត់ទំព័រនោះទុក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៥ ឲ្យឮៗ ។ សូមឲ្យសិស្សត្រៀមខ្លួន ហើយកត់សម្គាល់នូវអ្វីដែលហៃរ៉ុមបានអាន និងបានគូសចំណាំពីមុនចាកចេញទៅគុកកាតធេច ។

- ហេតុអ្វីអ្នកគិតថា ខគម្ពីរមកពីគម្ពីរអេធើរទាំងនេះ អាចមានអត្ថន័យយ៉ាងខ្លាំងចំពោះហៃរ៉ុមដើម្បីអាននៅគ្រានោះ ?

- តើអ្នកគិតថាឃ្លា « មនុស្សទាំងអស់នឹងដឹងថា អាវរបស់ខ្ញុំគ្មានប្រឡាក់ដោយឈាមរបស់អ្នកឡើយ » (គ. និង ស. ១៣៥:៥) មានន័យដូចម្ដេច ?

សូមឲ្យសិស្សពិចារណាពីរបៀបដែល យ៉ូសែប និងហៃរ៉ុម អាចមានអារម្មណ៍បែបណា នៅពេលដឹងថាពួកលោកបានបំពេញតាមការហៅបម្រើ និងកាតព្វកិច្ចរបស់ពួកលោកមកពី ព្រះដោយអស់ពីលទ្ធភាពខ្លួនហើយនោះ ។

- តើយើងអាចរៀនអ្វីខ្លះ ពីគំរូរបស់យ៉ូសែប និងហៃរ៉ុម ស្ម៊ីធ ដែលអាចជួយយើងឲ្យបំពេញការហៅនានាដែលយើងទទួលបានមកពីព្រះ ?

**សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីសង្ខេបដូចខាងក្រោមអំពីព្រឹត្តការណ៍ទាំងឡាយដែលកើតឡើងនៅថ្ងៃទី ២៥–២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ ៖**

### សិស្សទី ៣

នៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៨៤៤ យ៉ូសែប និង ហៃរ៉ុម ស្ម៊ីធ និងអ្នកដឹកនាំដទៃទៀត បានបង់ប្រាក់ធានាអនុញ្ញាតឲ្យនៅក្រៅឃុំ នៅកាតធេច ហើយបាននៅក្រៅឃុំរហូតដល់ថ្ងៃការកាត់ក្ដីជាផ្លូវការ នឹងធ្វើឡើង ដែលចោទប្រកាន់អំពីការបង្ករឲ្យមានកុប្បកម្មនោះ ( សំដៅទៅលើការបំផ្លាញកាសែត *Nauvoo Expositor*) ។ ទោះជាយ៉ាងណាក៏ដោយ នៅល្ងាចនោះ យ៉ូសែប និង ហៃរ៉ុម ត្រូវបានបង្ខាំងឲ្យនៅក្នុងគុកកាតធេច ទាក់ទងនឹងការចោទមួយថាក្បត់ជាតិ ដែលថា យ៉ូសែប និង មេធាវីរបស់លោក បានតវ៉ាថាពុំស្របច្បាប់ឡើយ ដោយថា ការចោទនោះពុំបានបរិយាយអំពី ប្រាក់ធានាអនុញ្ញាតឲ្យនៅក្រៅឃុំ សម្រាប់សវនាការពីដំបូងរបស់ពួកលោក ។ គ្មានប្រាក់ធានាអនុញ្ញាតឲ្យនៅក្រៅឃុំចំពោះករណីក្បត់ជាតិទេ ដូច្នេះពួកលោកត្រូវតែស្ថិតនៅក្នុងគុកកាតធេច– ហើយស្ថិតនៅក្នុងគ្រោះថ្នាក់ដដែល ។

នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៨៤៤ យ៉ូសែប បានជួបនឹងអភិបាល ហ្វត នៅក្នុងគុក ។ លោកអភិបាល ហ្វដ បានគិតអំពីការធ្វើដំណើរទៅទីក្រុង ណៅវូ ហើយ យ៉ូសែប បានសុំទៅជាមួយ ដោយមានអារម្មណ៍ថាលោកពុំមានសុវត្ថិភាពនៅក្នុងគុក កាតធេច នេះឡើយ ។ អភិបាល ហ្វត បានសន្យាថា បើលោកចាកចេញពី កាតធេច នោះលោកនឹងនាំ យ៉ូសែប និង ហៃរ៉ុមទៅជាមួយ ។ នាល្ងាចនោះ ព្យាការីបានថ្លែងទីបន្ទាល់ទៅដល់ពួកអ្នកយាមអំពីភាពពិតនៃព្រះគម្ពីរមរមន និងការស្ដារឡើងវិញនៃដំណឹងល្អ ។

នៅព្រឹកថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤ យ៉ូសែប បានសរសេរនៅក្នុងសំបុត្រមួយទៅ អិមម៉ា ថា ៖ « បងទទួលយកស្ថានភាពរបស់បង ដោយដឹងថាបងត្រឹមត្រូវ ហើយបានធ្វើល្អបំផុតតាមដែលបងអាចធ្វើបានហើយ ។ សូមផ្ដល់ក្ដីស្រឡាញ់របស់បងដល់កូនៗ និងមិត្តភក្តិទាំងអស់របស់បងផង » ( នៅក្នុង *History of the Church,* ៦:៦០៥ ) ។ ក្រោយមកនៅថ្ងៃដដែលនោះ ដោយដឹងថាប្រជាពលរដ្ឋក្នុងមូលដ្ឋានមានផែនការនឹងសម្រុកចូលទៅក្នុងគុកដើម្បីសម្លាប់អ្នកទោសទាំងឡាយ នោះ អភិបាល ហ្វត បានចាកចេញពីទីក្រុងកាតធេច ដើម្បីនិយាយទៅកាន់ប្រជាពលរដ្ឋនៅណៅវូ ។ លោកបានក្បត់សន្យារបស់លោក ហើយពុំបាននាំ យ៉ូសែប និង ហៃរ៉ុម ទៅជាមួយឡើយ ។ មុនពេលចាកចេញ អភិបាល ហ្វត បានដាក់កាតធេថនៅក្នុងភាពក្រៀមក្រំ–ដែលទាហានឃោរឃៅជាច្រើនបានប្រមូលផ្ដុំគ្នានៅទីក្រុងកាតធេច– ទទួលបញ្ជាយាមគុក ហើយបានបណ្ដេញទាហានផ្សេងទៀតឲ្យត្រឡប់ទៅផ្ទះវិញ ។

សូមប្រាប់សិស្សថា នៅក្នុងពេលល្ងាចដ៏ក្ដៅ និង សើមនៅថ្ងៃទី ២៧ ខែមិថុនា នោះសាវក យ៉ូហាន ថេលើរ និង វិលឡឺឌ រីឆាដ នៅជាមួយនឹង យ៉ូសែប និង ហៃរ៉ុម នៅក្នុងគុកកាតធេច ។ អារម្មណ៍នៃភាពអស់សង្ឃឹមបានមកគ្របដណ្ដប់លើព្យាការី និង អ្នកទាំងឡាយដែលនៅជាមួយលោក នៅពេលពួកគេបានអង្គុយនៅក្នុងបន្ទប់ក្នុងគុកនៅជាន់ទីពីរ ។ ហៃរុម ស៊្មីធ បានសុំឲ្យ យ៉ូហាន ថេលើរ ច្រៀងបទ « អ្នកធ្វើដំណើរដ៏ក្រតោកយ៉ាក » ( សូមមើល *ទំនុកតម្កើង* ទំព័រ ១៧ ) ។ បើទំនុកតម្កើងនេះមានក្នុងសៀវភៅទំនុកតម្កើងរបស់អ្នក សូមអញ្ជើញសិស្សឲ្យច្រៀងពីរបីវគ្គ ។ នៅពេលពួកគេច្រៀង សូមអញ្ជើញពួកគេឲ្យគិតអំពីទំនុកតម្កើងនេះ អាចមានន័យយ៉ាងណាចំពោះ យ៉ូសែប និង ហៃរុម ស៊្មីធ នៅក្នុងគ្រានេះ ។

សូមអញ្ជើញសិស្សបីនាក់ឲ្យឆ្លាស់វេនគ្នាអានសេចក្ដីសង្ខេបដូចខាងក្រោមអំពីទុក្ករកម្ម ។ សូមឲ្យសិស្សក្នុងថ្នាក់ព្យាយាមបង្កើតជាចក្ខុវិស័យអំពីព្រឹត្តការណ៍ទាំងនេះដូចជាពួកគេនៅជាមួយនឹងព្យាការីក្នុងគុកកាតធេច ។

***ការប្រើតន្ត្រីនៅក្នុងមេរៀន***

តន្ត្រី ជាពិសេសទំនុកតម្កើងរបស់សាសនាចក្រ អាចដើរតួយ៉ាងសំខាន់មួយ នៅក្នុងការជួយដល់សិស្សឲ្យទទួលអារម្មណ៍ដឹងអំពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងបទពិសោធន៍នៃការរៀនសូត្រ អំពីដំណឹងល្អរបស់ពួកគេ ។ ការច្រៀងទំនុកតម្កើងដែលទាក់ទងផ្ទាល់ទៅនឹងមេរៀនរបស់អ្នក អាចជួយសិស្សឲ្យរៀនគោលការណ៍ដំណឹងល្អ និងពិចារណាអំពីគំនិតបន្ថែមទៀត ។

### សិស្សទី ៤

មិនយូរប៉ុន្មានបន្ទាប់ពីម៉ោង ៥:០០ ល្ងាច នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤ មានពួកមនុស្សកំណាចមួយក្រុម ដែលមានចំនួនប្រហែលជា ១៥០–២០០ នាក់ ដោយមានលាបមុខដើម្បីលាក់បាំងអត្តសញ្ញាណរបស់ពួកគេ បានមកព័ទ្ធគុក ។ អ្នកយាមពុំបានឃាត់ពួកគេទេ ពេលពួកមនុស្សកំណាចមួយចំនួនបានសម្រុករត់ឡើងមកជាន់លើ ត្រង់កន្លែងដែលព្យាការី និងមិត្តភក្ដិរបស់លោកស្ថិតនៅនោះ ។

យ៉ូសែប និងអ្នកដទៃទៀតបានរុញទប់ទ្វារការពារកុំឲ្យពួកមនុស្សកំណាចសម្រុកបើកបាន ។ មានម្នាក់ក្នុងក្រុមមនុស្សកំណាចបានបាញ់កាំភ្លើងទៅផ្នែកខាងលើនៃទ្វារ ដោយបានទម្លុះច្រមុះរបស់ហៃរុមផ្នែកខាងឆ្វេង ។ គាត់បានដួលផ្ងារក្រោយ ដោយបានស្រែកថា « ខ្ញុំស្លាប់ហើយ ! » ( នៅក្នុង *History of the Church* ៦:៦១៧ ) ។ យ៉ូហាន ថេលើរ បានមានប្រសាសន៍ថា « ខ្ញុំពុំអាចបំភ្លេចបានទេ នូវអារម្មណ៍ដ៏សោរសៅ និងគោរពដ៏ជ្រាលជ្រៅ ដែលបានបង្ហាញនៅលើទឹកមុខ យ៉ូសែប នៅពេលដែលលោកបានទៅជិតហៃរុម ហើយទ្រោបខ្លួនលើលោក ដោយស្រែកថា ‹ ឱ! បងប្រុសកំសត់ជាទីស្រឡាញ់របស់ប្អូនអើយ ! ›» ( នៅក្នុង *History of the Church* ៧:១០២ ) ។

### សិស្សទី ៥

នាព្រឹកថ្ងៃនោះ មានអ្នកមកសួរសុខទុក្ខម្នាក់បានឲ្យកាំភ្លើងមួយដើមទៅ យ៉ូសែប ។ ដោយការពារដល់មនុស្សគ្រប់រូបនៅក្នុងបន្ទប់ យ៉ូសែប បានរត់ទៅមាត់ទ្វា ហើយបានបាញ់ចេញទៅក្រៅមាត់ទ្វា ។ មានតែបីគ្រាប់ចំណោមប្រាំមួយគ្រាប់ប៉ុណ្ណោះដែលបាញ់ចេញ ដែលធ្វើឲ្យសមាជិកមួយចំនួននាក់នៃពួកមនុស្សកំណាចរងរបួសខ្លះ ។ ពេលនោះ ពួកមនុស្សកំណាចបានប្រើកាំភ្លើងរបស់គេរុញចូលតាមប្រហោងទ្វារដែលពាក់កណ្ដាលបើក ហើយយ៉ូហាន ថេលើរ បានព្យាយាមវាយកាណុងកាំភ្លើងរបស់ពួកគេឲ្យដកថយវិញដោយដងឈើច្រត់មួយ ។

នៅពេលភាពចលាចលនៅទ្វារនោះមានកាន់តែខ្លាំងឡើង នោះយ៉ូហាន ថេលើរ បានព្យាយាមរត់គេចដោយផ្លោះតាមបង្អួច ។ នៅពេលលោកចង់លោតចេញពីបង្អួច លោកត្រូវបានគេបាញ់ចំភ្លៅ ដែលបាញ់ពីមាត់ទ្វារ ហើយក៏ត្រូវគេបាញ់ចំពីខាងក្រៅផងដែរ ។ លោកបានដួលទៅលើកម្រាលឥដ្ឋ ហើយខណៈដែលខំវារទៅក្រោមគ្រែក្បែរបង្អួចនោះ លោកត្រូវបានគេបាញ់បីគ្រាប់ទៀត ធ្វើឲ្យរបួសយ៉ាងធ្ងន់ ។ ទន្ទឹមនឹងគ្នានោះ នៅពេលកាំភ្លើងជាច្រើនបានបាញ់ចូលមកតាមមាត់ទ្វារ នោះវិលឡឺឌ រីឆាដ បានចាប់ផ្ដើមតតាំងនឹងពួកគេដោយឈើច្រត់មួយ ។

### សិស្សទី ៦

បន្ទាប់មក យ៉ូសែប ស៊្មីធ បានព្យាយាមគេចតាមបង្អួចដដែលនោះ ដែលទំនងជានឹងរក្សាជីវិតលោក តែមនុស្សខ្លះបានជឿថា គឺដើម្បីជួយជីវិតរបស់ វិលឡឺឌ រីឆាដ និង យ៉ូហាន ថេលើរ ។ នៅពេលវិលឡឺឌ រីឆាដ បានបន្តវាយរុញច្រានឡប់ពួកមនុស្សកំណាចនៅឯមាត់ទ្វារ នោះព្យាការីបានលោតទៅបង្អួចដែលបើករួចនោះ ។ នៅពេលលោកបានធ្វើដូច្នោះ មានគ្រាប់កាំភ្លើងជាច្រើនទាំងក្នុង និងក្រៅគុកបានបាញ់សំដៅទៅលោក ។ លោកបានធ្លាក់ចេញពីបង្អួចដោយស្រែកថា « ឱ ព្រះអម្ចាស់ ជាព្រះខ្ញុំអើយ » ហើយក៏បានធ្លាក់មកដី ។ សមាជិកពួកមនុស្សកំណាចខ្លះដែលនៅក្នុងគុក បានរត់ចេញទៅក្រៅដើម្បីបញ្ជាក់ថា យ៉ូសែប បានស្លាប់មែន ។ ទោះបីជាគ្មានសមាជិកសាសនាចក្រណាម្នាក់នៅតាមផ្លូវទៅទីក្រុងកាតធេច ក៏មានមនុស្សម្នាក់បានស្រែកថា « ពួកមរមនមកហើយ » ហើយហ្វូងមនុស្សកំណាចទាំងមូលក៏រត់គេចចេញអស់ទៅ ។ ( សូមមើល *History of the Church,* ៦:៦១៨, ៦២០–២១; សូមមើលផងដែរ *History in the Fulness of Times Student Manual,* ទំព័រ ២៨៣ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយកត់ចំណាំការពិពណ៌នាអំពីជោគវាសនារបស់ យ៉ូហាន ថេលើរ និង វិលឡើឌ រីឆាដ ។ សូមប្រាប់សិស្សថា វិលឡើឌ រីឆាដ គ្រាន់តែត្រូវគ្រាប់កាំភ្លើងមួយគ្រាប់ហោះប្រធិតៗនឹងត្រចៀកខាងឆ្វេងរបស់គាត់តែប៉ុណ្ណោះ ដែលបានបំពេញតាមការព្យាករណ៍ដែលយ៉ូសែប បានព្យាករអស់ជាងមួយឆ្នាំមុនថា « ពេលវេលានឹងមកដល់ ដែលគ្រាប់កាំភ្លើងនឹងហោះនៅជុំវិញគាត់ដូចជាគ្រាប់ព្រិលធ្លាក់ ហើយគាត់នឹងមើលឃើញមិត្តរបស់គាត់ដួលស្លាប់នៅខាងឆ្វេង និងខាងស្ដាំ ប៉ុន្តែនឹងគ្មានគ្រាប់កាំភ្លើងមួយគ្រាប់ណាមកប៉ះនឹងអាវរបស់គាត់ឡើយ » (នៅក្នុង *History of the Church* ៦:៦១៩ ) ។

សូមនាំសិស្សទៅកាន់ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:១ ហើយសួរសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថាឃ្លា « ដើម្បីបិទទីបន្ទាល់នៃព្រះគម្ពីរនេះ និងព្រះគម្ពីរមរមន » មានន័យដូចម្ដេច ? ( វាអាចនឹងជួយពន្យល់ថានៅក្នុងបរិបទនេះ ដើម្បី *បិទ* គឺបង្កើតអ្វីមួយដ៏និរន្តន៍ ដូចជាទីបន្ទាល់ជាដើម ) ។

សូមចង្អុលបង្ហាញថាពាក្យ *ទុក្ករកម្ម* នៅក្នុង ខ ១ ហើយសួរថា ៖

- តើទុក្ករជនជាអ្វី ? ( មនុស្សម្នាក់ដែលរងទុក្ខដល់ស្លាប់ ក្នុងការធ្វើជាសាក្សីចំពោះសេចក្ដីពិតអំពីជំនឿ ឬបុព្វហេតុរបស់គាត់ ឬនាង ។ សូមពន្យល់ថា ពាក្យ *ទុក្ករជន* ចេញមកពីពាក្យភាសាក្រិចថា *សាក្សី* [សូមមើល Bible Dictionary, « Martyr » ។

សូមឲ្យសិស្សមើលត្រួសៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៧ រកមើលនូវអ្វីថាតើទុក្ករកម្មរបស់ យ៉ូសែប និង ហៃរុម ស្ម៊ីធ ធ្វើជាសាក្សីចំពោះអ្វីខ្លះ ។

- តាមរយៈការស្លាប់របស់ពួកលោកជាទុក្ករជន តើ យ៉ូសែប និង ហៃរុម ស្ម៊ីធ បានបិទទីបន្ទាល់របស់ពួកលោកអំពីអ្វីខ្លះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគប្បីប្រាប់នូវសេចក្ដីពិតដូចខាងក្រោម ៖**យ៉ូសែប និង ហៃរុម ស្ម៊ីធ បានបិទសាក្សីរបស់ពួកលោកអំពីសេចក្ដីពិតដ៏ពេញលេញនៃដំណឹងល្អដែលបានស្ដារឡើងវិញដោយជីវិតរបស់ពួកលោក ។** អ្នកអាចសរសេរសេចក្ដីពិតនេះនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីសំណួរដូចខាងក្រោម រួចហើយសរសេរចម្លើយរបស់ពួកគេនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើចំណេះដឹងរបស់អ្នកអំពីទីបន្ទាល់របស់ យ៉ូសែប និង ហៃរុម ស្ម៊ីធ និងការស្ម័គ្រចិត្តស្លាប់របស់ពួកលោកដើម្បីសេចក្ដីពិតមានឥទ្ធិពលមកលើទីបន្ទាល់របស់អ្នកយ៉ាងដូចម្ដេច ?

បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សដែលមានឆន្ទៈចែកចាយទីបន្ទាល់របស់ពួកគេឲ្យឡើងចែកចាយ ។ សូមបញ្ចប់មេរៀន ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីព្យាការី យ៉ូសែប ស្ម៊ីធ ។

មេរៀនទី ១៤៥

# គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៥ ភាគ ២

## សេចក្ដីផ្ដើម

នេះគឺជាផ្នែកទីពីរនៃមេរៀនទីពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ និងទុក្ករកម្មរបស់ យ៉ូសែប និង ហៃរ៉ាំស្ម៊ីធ នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤ ។

ក្នុងមេរៀននេះ សិស្សនឹងពិភាក្សាអំពីតួនាទីរបស់ព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងសេចក្ដីសង្គ្រោះរបស់កូនចៅព្រះ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥

*ទុក្ករកម្មរបស់ យ៉ូសែប និង ហៃរ៉ុម ស្ម៊ីធ ត្រូវបានប្រកាស*

មុននឹងចាប់ផ្ដើម សូមដាក់តាំងរូបភាពមួយរបស់យ៉ូសែប ស្ម៊ីធនៅខាងមុខថ្នាក់រៀន ( សូមមើល *Gospel Art Book* [ឆ្នាំ ២០០៩] លេខ ៨៧ សូមមើលផងដែរ LDS.org)។ អ្នកអាចនឹងចង់សុំដល់សិស្សឲ្យច្រៀងបទ « សរសើរដល់លោក » (*ទំនុកតម្កើង* លេខ ១៦ ) សម្រាប់ជាទំនុកតម្កើងប្រជុំធម្មនិដ្ឋាន ។ ពីមុនច្រៀងទំនុកតម្កើង សូមពន្យល់ថា ដឺបុលយូ ដបុលយូ ហ្វែប បានសរសេរពាក្យនៃទំនុកតម្កើង នៅក្នុងការចងចាំដល់ព្យាការី យ៉ូសែប ស្ម៊ីធ ក្រោយពីការធ្វើទុក្ករកម្មបន្តិច ។

សូមចាប់ផ្ដើមមេរៀនដោយសួរសំណួរខាងក្រោមនេះ ៖



- តើអ្នកធ្លាប់ជជែកជាមួយនរណាម្នាក់ដែលមិនមែនជាសមាជិកសាសនាចក្រអំពីព្យាការី យ៉ូសែប ស្ម៊ីធដែរឬទេ ? បើធ្លាប់ តើអ្នកនិយាយអំពីអ្វីខ្លះ ? ( បើគ្មាននរណាម្នាក់ធ្លាប់មានបទពិសោធន៍នេះទេ សូមសួរដល់សិស្សថាតើពួកគេចង់ប្រាប់អ្នកដទៃអំពី យ៉ូសែប ស្ម៊ីធ ដែរឬទេ ) ។

សូមរំឭកសិស្សថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ មាននូវការប្រកាសមួយអំពីទុក្ករកម្មរបស់ យ៉ូសែប និង ហៃរុម ស្ម៊ីធ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានប្រយោគទីមួយនៃ គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៥:៣ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ។

- តើសារលិខិតនៃខគម្ពីរនេះគឺជាអ្វី ? ( សិស្សគួរតែបង្ហាញថា **យ៉ូសែប ស្ម៊ីធបានធ្វើកិច្ចការច្រើនជាងគេ លើកលែងតែព្រះយេស៊ូវប៉ុណ្ណោះ សម្រាប់សេចក្ដីសង្គ្រោះដល់មនុស្សលោកនេះ ជាងមនុស្សផ្សេង ៗទៀតដែលធ្លាប់រស់នៅក្នុងលោកនេះ**) ។

- តើព្យាការីយ៉ូសែប ស្ម៊ីធបានធ្វើអ្វីខ្លះសម្រាប់សេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើងរបស់យើង ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឃ្លាទាំងអស់នៃ គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៥:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលពិពណ៌នាអំពីអ្វីដែលយ៉ូសែប ស្ម៊ីធបានធ្វើសម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។ សូមឲ្យសិស្សស្វែងរកចំណុចបន្ថែមទៀតដើម្បីបន្ថែមលើបញ្ជីនៅលើក្ដារខៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយប្រធានយ៉ូសែប ហ្វៀស ស្ម៊ីធ ។ សូមឲ្យសិស្សស្ដាប់រកមើលនរណាដែលត្រូវបានទទួលរងឥទ្ធិពល តាមរយៈកិច្ចការនៃព្យាការីយ៉ូសែប ស្ម៊ីធ ។



« កិច្ចការដែលយ៉ូសែប ស្ម៊ីធ បានចូលប្រឡូកពុំត្រូវបានកំណត់ចំពោះតែជីវិតនេះនោះទេ ប៉ុន្តែវាជាប់ទាក់ទងនឹងជីវិតឯបរលោកនាយ និង ជីវិតដែលធ្លាប់មានផងដែរ ។ និយាយម៉្យាងទៀតថា វាជាប់ទាក់ទងនឹងអ្នកទាំងឡាយណាដែលបានរស់នៅលើផែនដីនេះ អ្នកទាំងឡាយណាដែលកំពុងរស់នៅ និង អ្នកទាំងឡាយណាដែលនឹងមកបន្ទាប់ពីយើង ។ វាពុំមែនជាអ្វីដែលគ្រាន់តែទាក់ទងនឹងមនុស្សអំឡុងពេលពួកគេរស់នៅក្នុងរោងឧបោសថនៅក្នុងសាច់ឈាមនោះទេ ប៉ុន្តែគឺសម្រាប់គ្រួសារមនុស្សទាំងអស់ចេញពីភាពអស់កល្បទៅភាពអស់កល្ប » (*Gospel Doctrine,* ការបោះពុម្ពលើកទី ៥. [ ឆ្នាំ ១៩៣៩ ] ទំព័រ ៤៨១ ) ។

សូមមើលការពិពណ៌នារបស់យ៉ូសែប ស្ម៊ីធអំពីការនាំចេញមកនូវព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញានៅក្នុង ខ ៣។ ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតអំពីសារៈសំខាន់នៃកិច្ចការនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលហេតុផលដែលព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាត្រូវបាននាំចេញមក ។

- យោងតាម ខ ៦, ហេតុអ្វីបានជាព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាត្រូវបាននាំចេញមក ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួររកឃើញសេចក្ដីពិតខាងក្រោមនេះ ៖ **ព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាត្រូវបាននាំចេញមកសម្រាប់សេចក្ដីសង្គ្រោះដល់ពិភពលោក**) ។
- តើគម្ពីរទាំងនេះជួយនាំមកនូវសេចក្ដីសង្គ្រោះដល់ពិភពលោកតាមវិធីណា ?
- យោងតាម ខ ៦, តើអ្វីខ្លះដែលធ្វើឲ្យព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាមានតម្លៃខ្លាំងបំផុតក្នុងចំណោមព្រះគម្ពីរដែលអ្នកមាន ?

សូមឲ្យសិស្សពិចារណាពីអ្វីដែលពួកគេបានធ្វើជាមួយព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញានៅក្នុងជីវិតរបស់ពួកគេ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីបង្ហាញការដឹងគុណរបស់យើងចំពោះការបូជារបស់យ៉ូសែប និង ហៃរ៉ុម ស្ម៊ីធដើម្បីនាំចេញមកនូវព្រះគម្ពីរទាំងនេះ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬ សៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវរបៀបជាក់លាក់មួយ ដែលពួកគេអាចបង្ហាញការដឹងគុណរបស់ខ្លួនចំពោះការបូជាដែលបានធ្វើឡើង ដើម្បីនាំចេញមកនូវព្រះគម្ពីរទាំងនេះ ។

សូមយោងទៅលើបញ្ជីដែលបានសរសេរនៅលើក្ដារខៀនពីដើមដំបូងមេរៀន ។ សូមថ្លែងទីបន្ទាល់ថា តាមរយៈការជួយស្ដារព្រះគម្ពីរឡើងវិញ គោលលទ្ធិពិត សិទ្ធិអំណាច និងកូនសោបព្វជិតភាព ពិធីបរិសុទ្ធសម្រាប់អ្នកនៅរស់ និងអ្នកស្លាប់ និងការរៀបចំសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ យ៉ូសែប ស្ម៊ីធបានជួយកូនចៅរបស់ព្រះទាំងអស់ទទួលបាននូវពរជ័យពេញលេញនៃដង្វាយធួន ។

ចូរពន្យល់ថា មនុស្សមួយចំនួនអាចនឹងយល់ខុសអំពីអារម្មណ៍ និងការជឿរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយចំពោះព្យាការី យ៉ូសែប ស្ម៊ីធ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់មើលអំពីរបៀបដែលសមាជិកនៃសាសនាចក្រយល់ឃើញអំពី យ៉ូសែប ស្ម៊ីធ ចំពោះព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។ ប្រសិនបើអាចធ្វើបាន អ្នកអាចផ្ដល់ ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍នេះដល់សិស្សមួយច្បាប់ម្នាក់ ។



« យើងមិនថ្វាយបង្គំព្យាការីទេ ។ យើងថ្វាយបង្គំព្រះជាព្រះវរបិតាសួគ៌របស់យើង និង ព្រះអម្ចាស់ដែលបានមានព្រះជន្មរស់ឡើងវិញគឺព្រះយេស៊ូវគ្រីស្ទ ។ ប៉ុន្តែយើងទទួលស្គាល់ព្យាការី យើងប្រកាសអំពីលោក យើងគោរពលោក យើងមានគារវភាពចំពោះលោកថាជាឧបករណ៍នៅក្នុងព្រះហស្តនៃព្រះដ៏មានមហិទ្ធិឫទ្ធិ ក្នុងការស្ដារឡើងវិញមកលើផែនដីនូវសេចក្ដីពិតពីបុរាណនៃដំណឹងល្អរបស់ព្រះ រួមជាមួយនឹងបព្វជិតភាពតាមរយៈសិទ្ធិអំណាចរបស់ព្រះ គឺត្រូវបានអនុវត្តនៅក្នុងកិច្ចការនៃសាសនាចក្ររបស់ទ្រង់ និង សម្រាប់ពរជ័យនៃប្រជារាស្ត្ររបស់ទ្រង់ » (Joseph Smith Jr.—Prophet of God, Mighty Servant » *Ensign,* ខែ ធ្នូ ឆ្នាំ ២០០៥ ទំព័រ ៤ ) ។

- ជាពាក្យរបស់អ្នកផ្ទាល់ តើអ្នកនឹងពន្យល់ពីអារម្មណ៍របស់សមាជិកសាសនាចក្រអំពីព្យាការីយ៉ូសែប ស្ម៊ីធយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យគិតអំពីឥទ្ធិពលការបម្រើរបស់ព្យាការីយ៉ូសែប ស្ម៊ីធបានមាននៅក្នុងជីវិតរបស់ពួកគេ ហើយក្នុងជីវិតមនុស្សរាប់លាននៅទូទាំងពិភពលោក ។ សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ហើយសុំសិស្សឲ្យឆ្លើយសំណួរមួយក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

> *តើជីវិតរបស់អ្នកអាចខុសគ្នា យ៉ាងដូចម្ដេចខ្លះ ប្រសិនបើគ្មានការបម្រើរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ទេនោះ ?*
>
> *តើព្យាការី យ៉ូសែប ស្ម៊ីធ បានមានឥទ្ធិពលលើចំណេះដឹង និងទំនាក់ទំនងរបស់អ្នកជាមួយព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?*

សូមសិស្សម្នាក់អានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស. ម៉នសុន ។ សូមឲ្យសិស្សស្ដាប់មើលអំពីរបៀបដែលយើងអាចជួយអ្នកដទៃទទួលបទពិសោធន៍ក្ដីអំណរនៃដំណឹងល្អ ។



«[ព្យាការី យ៉ូសែប ស្ម៊ីធ] បានបន្សល់ទុកនូវកេរតំណែលមួយ ដែលជួយឲ្យមានអ្នកដើរតាម [រាប់លានអ្នក] នៅសព្វថ្ងៃនេះ នៅលើគ្រប់ទ្វីបដើម្បីប្រកាសអំពីលោកថាជាព្យាការីម្នាក់របស់ព្រះ ។ សូមឲ្យយើងម្នាក់ៗ ព្យាយាមដើម្បីបន្តនូវការនិមិត្តរបស់ព្យាការី យ៉ូសែប ចំពោះ កិច្ចការនេះ ហើយតម្កើងកេរដំណែលរបស់លោក តាមរយៈកិច្ចការរបស់យើង និងទីបន្ទាល់ដល់អ្នកដទៃ ដើម្បីពួកគេអាចស្គាល់លោក ដូចជាយើង ហើយដើម្បីឲ្យពួកគេអាចមានបទពិសោធន៍នៃភាពសុខសាន្ត និងក្ដីអំណរនៃដំណឹងល្អ ដែលលោកបានស្ដារឡើងវិញ » ( Brother Joseph» *Church News* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ទំព័រ ៤ ) ។

- តើយើងអាចជួយអ្នកដទៃទទួលបទពិសោធន៍ក្ដីអំណរនៃដំណឹងល្អ ដូចដែលបានស្ដារឡើងវិញតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ យ៉ាងដូចម្ដេច ?

សូមពន្យល់ថា សម្រាប់សិស្សនៅសល់ក្នុងថ្នាក់ អាចចែកចាយទីបន្ទាល់របស់ពួកគេអំពីព្យាការី យ៉ូសែប ស្ម៊ីធ និងការស្ដារឡើងវិញនៃដំណឹងល្អ ។ សូមអញ្ជើញពួកគេឲ្យពិចារណាអំពីការប្រើចម្លើយពួកគេចេញមកពីសកម្មភាពសរសេរពីខាងដើមនៅពេលពួកគេបង្ហាញពីទីបន្ទាល់របស់ពួកគេ ។

សូមបញ្ចប់មេរៀន ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីព្យាការី យ៉ូសែប ស្ម៊ីធ និងការស្ដារឡើងវិញ ។ សូមអញ្ជើញសិស្សឲ្យរកមើលឱកាសនៅពីរបីថ្ងៃខាងមុខនេះដើម្បីចែកចាយទីបន្ទាល់របស់ពួកគេជាមួយនឹងអ្នកដទៃអំពីព្យាការី យ៉ូសែប ស្ម៊ីធ និងតួនាទីរបស់លោកក្នុងការស្ដារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ ។

### *ការថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនៃដំណឹងល្អ*

ការធ្វើទីបន្ទាល់អំពីសេចក្ដីពិតនៃដំណឹងល្អ ផ្ដល់ឱកាសនានាសម្រាប់ព្រះវិញ្ញាណបរិសុទ្ធ ឲ្យធ្វើជាសាក្សីនៃគោលលទ្ធិ និង គោលការណ៍ពិតប្រាកដ នៃដំណឹងល្អ ដែលបានស្ដារឡើងវិញ ។ នៅពេលអ្នកផ្ដល់ឱកាសដល់សិស្សដើម្បីថ្លែងទីបន្ទាល់អំពីគោលការណ៍ដំណឹងល្អដល់មិត្តភក្ដិពួកគេ សូមប្រយ័ត្នចំពោះលក្ខណៈពិសិដ្ឋ និងភាពផ្ទាល់ខ្លួននៃទីបន្ទាល់ ។ សូមអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេ ប៉ុន្តែអ្នកពុំគួរតម្រូវឲ្យគេធ្វើដូច្នោះឡើយ ។

មេរៀនសិក្សានៅផ្ទះ

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣–១៣៥ ( មេរៀនទី ២៩ )

## ការរៀបចំមេរៀនសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបមេរៀនសម្រាប់សិស្សសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣–១៣៥ ( មេរៀនទី ២៩ ) ។ សេចក្ដីសង្ខេបនេះមិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនសម្រាប់មេរៀនទី ២៩ ផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥)

នៅពេលសិស្សបានសិក្សាអំពីការបង្រៀនរបស់ព្រះអម្ចាស់ ទាក់ទងនឹងការយាងមកជាលើកទីពីររបស់ទ្រង់ ពួកគេបានរៀនថាការយាងមកជាលើកទីពីររបស់ទ្រង់ នោះទ្រង់នឹងយាងមកនៅក្នុងការជំនុំជំម្រះប្រឆាំងទាស់នឹងពួកអាក្រក់ ។ សិស្សក៏បានរកឃើញផងដែរនូវរបៀបនានាដែលយើងអាចរៀបចំខ្លួនយើង និងអ្នកដទៃសម្រាប់ការយាងមកជាលើកទីពីរ ។ ការរៀបចំខ្លួននេះរួមមានការប្រែចិត្ត និង ពុំត្រឡប់ទៅរកអំពើបាបពីមុនៗរបស់ខ្លួនវិញឡើយ ។

### ថ្ងៃទី ២ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៥–៧៤)

នៅក្នុងមេរៀននេះ សិស្សបានបន្តការសិក្សារបស់ខ្លួនអំពីការបង្រៀនរបស់ព្រះអម្ចាស់ទាក់ទងនឹងការយាងមកជាលើកទីពីររបស់ទ្រង់ ។ ពួកគេបានរៀនថាក្នុងនាមជាអ្នកបម្រើរបស់ព្រះ ពួកគេអាចជួយមនុស្សដទៃឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ តាមរយៈការចែកចាយដំណឹងល្អជាមួយពួកគេ ។ សិស្សក៏បានឃើញផងដែរថាព្រះអម្ចាស់បានរៀបចំពរជ័យដ៏មហិមាសម្រាប់អស់អ្នកដែលរង់ចាំទ្រង់ ហើយថាអស់អ្នកដែលប្រែចិត្ត ហើយញែកខ្លួនពួកគេចេញជាបរិសុទ្ធនឹងបានទទួលជីវិតដ៏នៅអស់កល្បជានិច្ច ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤)

នៅពេលសិស្សបានសិក្សាសេចក្ដីប្រកាសនេះអំពីជំនឿរបស់សាសនាចក្រទាក់ទងនឹងរដ្ឋាភិបាល និង ក្រឹត្យវិន័យនានានោះពួកគេបានរកឃើញសេចក្ដីពិតដូចតទៅ ៖ រដ្ឋាភិបាលត្រូវបានតែងតាំងឡើងដោយព្រះសម្រាប់ជាប្រយោជន៍នៃមនុស្ស ហើយរដ្ឋាភិបាលមានទំនួលខុសត្រូវចំពោះព្រះ ដើម្បីការពារសិទ្ធិរបស់បុគ្គលម្នាក់ៗ រួមទាំងសេរីភាពសាសនាផងដែរ ។ ពួកគេក៏បានរៀនផងដែរថា យើងមានកាតព្វកិច្ចដើម្បីគាំទ្រ និង ទ្រទ្រង់រដ្ឋាភិបាលនៅក្នុងកន្លែងដែលយើងរស់នៅ ហើយថាព្រះនឹងឲ្យយើងទទួលខុសត្រូវចំពោះការរំលងក្រឹត្យវិន័យរបស់ទ្រង់ និង ច្បាប់របស់មនុស្ស ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥)

ជាផ្នែកនៃមេរៀននេះ សិស្សបានរៀនអំពីព្រឹត្តិការណ៍នានាដែលទាក់ទងនឹងទុក្ករកម្មនៃ យ៉ូសែប និង ហៃរ៉ុម ស្ម៊ីធ ហើយបានសិក្សាពីសេចក្ដីប្រកាសមួយដែលបានសរសេរអំពីមរណភាពរបស់ពួកលោក ។ តាមរយៈការធ្វើដូច្នេះ នោះសិស្សបានឃើញថាយ៉ូសែប និង ហៃរ៉ុម ស្ម៊ីធ បានផ្សារភ្ជាប់ទីបន្ទាល់របស់ពួកលោកអំពីភាពពោរពេញនៃសេចក្ដីពិតនៃដំណឹងល្អ ដែលបានស្ដារឡើងវិញជាមួយជីវិតរបស់ពួកគេ ។

## សេចក្ដីផ្ដើម

មេរៀននេះនឹងជួយសិស្សឲ្យយល់ពីកិច្ចការមួយចំនួនដែលព្យាការី យ៉ូសែប ស្ម៊ីធបានធ្វើសម្រាប់សេចក្ដីសង្គ្រោះរបស់មនុស្សលោក ។ សិស្សនឹងមានឱកាសផងដែរដើម្បីចែកចាយទីបន្ទាល់របស់ពួកគេអំពីព្យាការីយ៉ូសែប ស្ម៊ីធ និង ការស្ដារឡើងវិញនៃដំណឹងល្អ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:១–៧

*ទុក្ករកម្មនៃព្យាការីយ៉ូសែប និង ហៃរ៉ុម ស្ម៊ីធ ត្រូវបានប្រកាស*

ពីមុនថ្នាក់រៀន សូមបង្ហាញរូបភាពរបស់ យ៉ូសែប ស្ម៊ីធ ( សូមមើល *សៀវភៅសិល្បៈដំណឹងល្អ* [ ឆ្នាំ ២០០៩ ] លេខ ៨៧ សូមមើលផងដែរ LDS.org) ។ អ្នកអាចគិតពីការឲ្យសិស្សច្រៀងបទ « សរសេរដល់លោក » (*ទំនុកតម្កើង*, លេខ ១៦ ) សម្រាប់ទំនុកតម្កើងការប្រជុំធម្មនិដ្ឋាន ។ ពីមុនការប្រជុំធម្មនិដ្ឋានសូមពន្យល់ថា ដំបុលយូ ដបុលយូ ហ្វែល្ប បានសរសេរទំនុកបទនៃទំនុកតម្កើងនេះដើម្បីរំឮកចាំពីយ៉ូសែប ស្ម៊ីធ មិនយូរប៉ុន្មានបន្ទាប់ពីទុក្ករកម្មរបស់ព្យាការី ។



សូមចាប់ផ្ដើមមេរៀនដោយសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកធ្លាប់ជជែកជាមួយនរណាម្នាក់ដែលមិនមែនជាសមាជិកសាសនាចក្រអំពីព្យាការី យ៉ូសែប ស្ម៊ីធដែរឬទេ ? ប្រសិនបើបានជជែកគ្នាមែន តើអ្នកបានជជែកគ្នាពីអ្វី ? ( ប្រសិនបើគ្មាននរណាម្នាក់ធ្លាប់ជជែកគ្នាពីរឿងនោះទេ សូមសួរសិស្សនូវអ្វីដែលពួកគេចង់ប្រាប់មនុស្សអំពីព្យាការី យ៉ូសែប ស្ម៊ីធ ) ។

សូមរំឮកសិស្សថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ មាននូវសេចក្ដីប្រកាសនៃទុក្ករកម្មរបស់យ៉ូសែប និងហៃរ៉ុម ស្ម៊ីធ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានប្រយោគទីមួយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៣ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ។

- តើសារលិខិតនៃខគម្ពីរនេះគឺជាអ្វី ? ( សិស្សគួរតែបង្ហាញថា **យ៉ូសែប ស្ម៊ីធបានធ្វើកិច្ចការច្រើនជាងគេ លើកលែងតែព្រះយេស៊ូវប៉ុណ្ណោះ សម្រាប់សេចក្ដីសង្គ្រោះដល់មនុស្សលោកនេះ ជាងមនុស្សផ្សេងៗទៀតដែលធ្លាប់រស់នៅក្នុងលោកនេះ**) ។
- តើព្យាការីយ៉ូសែប ស្ម៊ីធបានធ្វើអ្វីខ្លះសម្រាប់សេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើងរបស់យើង ? ( សូមសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឃ្លាទាំងអស់នៃ គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៥:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលពិពណ៌នាអំពីអ្វីដែលយ៉ូសែប ស្ម៊ីធបានធ្វើសម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។ សូមឲ្យសិស្សស្វែងរកចំណុចបន្ថែមទៀតដើម្បីបន្ថែមលើបញ្ជីនៅលើក្ដារខៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយប្រធានយ៉ូសែប ហ្វែស ស្ម៊ីធ ។ សូមឲ្យសិស្សស្ដាប់រកមើលនរណាដែលត្រូវបានទទួលរងឥទ្ធិពល តាមរយៈកិច្ចការនៃព្យាការីយ៉ូសែប ស្ម៊ីធ ។



« កិច្ចការដែលយ៉ូសែប ស្ម៊ីធ បានចូលប្រឡូកពុំត្រូវបានកំណត់ចំពោះតែជីវិតនេះនោះទេ ប៉ុន្តែវាជាប់ទាក់ទងនឹងជីវិតឯបរលោកនាយ និង ជីវិតដែលធ្លាប់មានផងដែរ ។ និយាយម្យ៉ាងទៀតថា វាជាប់ទាក់ទងនឹងអ្នកទាំងឡាយណាដែលបានរស់នៅលើផែនដីនេះ អ្នកទាំងឡាយណាដែលកំពុងរស់នៅ និង អ្នកទាំងឡាយណាដែលនឹងមកបន្ទាប់ពីយើង ។ វាពុំមែនជាអ្វីដែលគ្រាន់តែទាក់ទងនឹងមនុស្សអំឡុងពេលពួកគេរស់នៅក្នុងរោងឧបោសថនៅក្នុងសាច់ឈាមនោះទេ ប៉ុន្តែគឺសម្រាប់គ្រួសារមនុស្សទាំងអស់ចេញពីកាលអស់កល្បទៅកាលអស់កល្ប » (*Gospel Doctrine*, ការបោះពុម្ពលើកទី ៥. [ ឆ្នាំ ១៩៣៩ ] ទំព័រ ៤៨១ ) ។

សូមមើលការពិពណ៌នារបស់យ៉ូសែប ស្ម៊ីធអំពីការនាំចេញមកនូវព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញានៅក្នុង ខ ៣។ ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតអំពីសារៈសំខាន់នៃកិច្ចការនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលហេតុផលដែលព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាត្រូវបាននាំចេញមក ។

- យោងតាម ខ ៦, ហេតុអ្វីបានជាព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាត្រូវបាននាំចេញមក ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្ដែពួកគេគួររកឃើញសេចក្ដីពិតខាងក្រោមនេះ ៖ **ព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាត្រូវបាននាំចេញមកសម្រាប់សេចក្ដីសង្គ្រោះដល់ពិភពលោក**) ។

- តើមានវិធីណាខ្លះដែលព្រះគម្ពីរទាំងនេះរួមចំណែកផ្ដល់សេចក្ដីសង្គ្រោះដល់ពិភពលោក ?

- យោងតាម ខ ៦, តើអ្វីខ្លះដែលធ្វើឲ្យព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញាមានតម្លៃខ្លាំងបំផុតក្នុងចំណោមព្រះគម្ពីរដែលអ្នកមាន ?

សូមឲ្យសិស្សពិចារណាពីអ្វីដែលពួកគេបានធ្វើជាមួយព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញានៅក្នុងជីវិតរបស់ពួកគេ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីបង្ហាញការដឹងគុណរបស់យើងចំពោះការបូជារបស់យ៉ូសែប និង ហៃរ៉ុម ស្ម៊ីធដើម្បីនាំចេញមកនូវព្រះគម្ពីរទាំងនេះ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬ សៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវរបៀបជាក់លាក់មួយ ដែលពួកគេអាចបង្ហាញការដឹងគុណរបស់ខ្លួនចំពោះការបូជាដែលបានធ្វើឡើង ដើម្បីនាំចេញមកនូវព្រះគម្ពីរទាំងនេះ ។

សូមមើលបញ្ជីដែលបានសរសេរលើក្ដារខៀនពីពេលចាប់ផ្ដើមមេរៀនដំបូង ។ សូមថ្លែងទីបន្ទាល់ថាតាមរយៈការជួយស្ដារព្រះគម្ពីរ គោលលទ្ធិពិត សិទ្ធិអំណាចនៃបព្វជិតភាព និង កូនសោ ពិធីបរិសុទ្ធ និង រចនាសម្ព័ន្ធនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ នោះយ៉ូសែប ស្ម៊ីធ បានជួយកូនចៅរបស់ព្រះទាំងអស់ទទួលបានសិទ្ធិពេញលេញ ដើម្បីទទួលពរជ័យនៃដង្វាយធួន ។

សូមពន្យល់ថាមនុស្សមួយចំនួនអាចយល់ច្រឡំអំពីអារម្មណ៍ ឬ ជំនឿរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយចំពោះព្យាការីយ៉ូសែបស្ម៊ីធ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលរបៀបដែលសមាជិកសាសនាចក្រយល់ឃើញចំពោះយ៉ូសែប ស្ម៊ីធនៅក្នុងទំនាក់ទំនងចំពោះព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ ប្រសិនបើអាចធ្វើបាន អ្នកអាចផ្ដល់ ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍នេះដល់សិស្សមួយច្បាប់ម្នាក់ ។



« យើងមិនថ្វាយបង្គំព្យាការីទេ ។ យើងថ្វាយបង្គំព្រះជាព្រះវរបិតាសួគ៌របស់យើង និង ព្រះអម្ចាស់ដែលបានមានព្រះជន្មរស់ឡើងវិញគឺព្រះយេស៊ូវគ្រីស្ទ ។ ប៉ុន្ដែយើងទទួលស្គាល់ព្យាការី យើងប្រកាសអំពីលោក យើងគោរពលោក យើងមានគារវភាពចំពោះលោកថាជាឧបករណ៍នៅក្នុងព្រះហស្ដនៃព្រះដ៏មានមហិទ្ធិឫទ្ធិ ក្នុងការស្ដារឡើងវិញមកលើផែនដីនូវសេចក្ដីពិតពីបុរាណនៃដំណឹងល្អរបស់ព្រះ រួមជាមួយនឹងបព្វជិតភាពតាមរយៈសិទ្ធិអំណាចរបស់ព្រះ គឺត្រូវបានអនុវត្តនៅក្នុងកិច្ចការនៃសាសនាចក្ររបស់ទ្រង់ និង សម្រាប់ពរជ័យនៃប្រជារាស្ដ្ររបស់ទ្រង់ » (Joseph Smith Jr.—Prophet of God, Mighty Servant » *Ensign,* ខែ ធ្នូ ឆ្នាំ ២០០៥ ទំព័រ ៤ ) ។

- ជាពាក្យរបស់អ្នកផ្ទាល់ តើអ្នកនឹងពន្យល់ពីអារម្មណ៍របស់សមាជិកសាសនាចក្រអំពីព្យាការីយ៉ូសែប ស្ម៊ីធយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យគិតពីឥទ្ធិពលនៃ ការបម្រើរបស់ព្យាការីយ៉ូសែប ស្ម៊ីធ មាននៅក្នុងជីវិតរបស់ពួកគេ និង ក្នុងជីវិតមនុស្សរាប់លាននាក់ទូទាំងពិភពលោក ។ សូមសរសេរ សំណួរដូចខាងក្រោម នៅលើក្ដារខៀន ហើយសូមឲ្យសិស្សឆ្លើយសំណួរទាំងនេះ ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

> *តើជីវិតរបស់អ្នកអាចខុសគ្នាយ៉ាងដូចម្ដេចខ្លះ ប្រសិនបើគ្មានការបម្រើរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ទេនោះ ?*
>
> *តើព្យាការីយ៉ូសែប ស្ម៊ីធបានជួយឲ្យចំណេះដឹងរបស់អ្នកមានអនុភាពយ៉ាងដូចម្ដេចខ្លះ អំពីទំនាក់ទំនងរបស់អ្នកជាមួយព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ?*

សូមអញ្ជើញសិស្សឲ្យចំណាយពេលដែលសល់នៅក្នុងថ្នាក់ទាំងប៉ុន្មាន ដើម្បីចែកចាយអារម្មណ៍ និង ទីបន្ទាល់របស់ពួកគេអំពីព្យាការីយ៉ូសែប ស្ម៊ីធ និង ការស្ដារឡើងវិញនៃដំណឹងល្អ ។ សូមអញ្ជើញពួកគេឲ្យគិតពីការប្រើប្រាស់ចម្លើយរបស់ពួកគេចេញពីសកម្មភាពសរសេរ កាលពីចាប់ផ្ដើមថ្នាក់រៀន នៅពេលពួកគេបង្ហាញអារម្មណ៍ និង ទីបន្ទាល់របស់ខ្លួន ។

សូមបញ្ចប់មេរៀនតាមរយៈការចែកចាយទីបន្ទាល់របស់អ្នកអំពីព្យាការី យ៉ូសែប ស្ម៊ីធ និង ការស្ដារឡើងវិញ ។ សូមអញ្ជើញសិស្សឲ្យរកមើលឱកាសនៅពីរបីថ្ងៃខាងមុខនេះ ដើម្បីចែកចាយជាមួយនឹងអ្នកដទៃអំពីទីបន្ទាល់របស់គេអំពីព្យាការីយ៉ូសែប ស្ម៊ីធ និង តួនាទីរបស់លោកក្នុងការស្ដារដំណឹងល្អឡើងវិញ ។ អ្នកអាចលើកទឹកចិត្តពួកគេផងដែរឲ្យកត់ត្រាពីទីបន្ទាល់របស់ពួកគេអំពីព្យាការីយ៉ូសែប ស្ម៊ីធ និង ការស្ដារឡើងវិញនៃដំណឹងល្អ នៅក្នុងសៀវភៅកំណត់ហេតុផ្ទាល់របស់ពួកគេ ។

*កំណត់ចំណាំ ៖* សូមទុកពេលគ្រប់គ្រាន់ឲ្យសិស្សចែកចាយទីបន្ទាល់របស់ពួកគេនៅចុងមេរៀន វាសំខាន់ជាងការប្រើសកម្មភាពខាងក្រោមនេះ ។ ប្រសិនបើទីបន្ទាល់របស់សិស្សប្រើពេលនៅសល់នៃម៉ោងរៀនរបស់អ្នក នោះអ្នកអាចនឹងប្រើសកម្មភាពនេះនៅថ្ងៃផ្សេង នៅពេលអ្នកមានពេលច្រើន ។

សូមឲ្យបញ្ជីនៃសេចក្ដីយោងនៃចំណេះចំណានខគម្ពីរទាំង ២៥ នៃគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រដល់សិស្ស ។ សូមអញ្ជើញពួកគេឲ្យពិចារណាពីវគ្គចំណេះចំណានខគម្ពីរណាមួយដែលពួកគេអាចប្រើដើម្បីបង្រៀននរណាម្នាក់ អំពីការស្ដារឡើងវិញនៃដំណឹងល្អតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ។ សូមឲ្យសិស្សសរសេរមេរៀន ឬ ការនិយាយខ្លីមួយដោយប្រើប្រាស់វគ្គចំណេះចំណាន ខគម្ពីរមួយចំនួនដែលពួកគេបានរកឃើញ ។ ពួកគេអាចសរសេរមេរៀន ឬ ការនិយាយលើក្រដាស ឬ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមគិតអំពីការអញ្ជើញសិស្សពីរបីនាក់ឲ្យបង្រៀនមេរៀនរបស់ខ្លួន ឬ អានការនិយាយដល់សិស្សដែលជាផ្នែកមួយនៃការប្រជុំធម្មនិដ្ឋាននាពេលខាងមុខ ។

## មេរៀនបន្ទាប់ ( ការធ្វើដំណើរទៅទិសខាងលិច )

សូមឲ្យសិស្សស្រមៃថាព្យាការីបានសុំពួកគេឲ្យរៀបចំឥវ៉ាន់របស់ពួកគេ ហើយធ្វើដំណើរចំណាយរាប់រយគីឡូម៉ែត្រនៅក្នុងទេះសេះ ឬ រុញរទេះទៅមុខដោយគ្មានទិសដៅ ។ សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងរៀនអំពីការធ្វើដំណើរទៅទិសខាងលិចរបស់ពួកបរិសុទ្ធ ។ ពួកគេក៏នឹងរៀនផងដែរអំពីរបៀបដែលព្រះអម្ចាស់បានបន្តដឹកនាំសាសាចក្រ រួមទាំងការបង្កើតអ្នកដឹកនាំបន្តបន្ទាប់ ក្រោយពីការស្លាប់របស់ព្យាការី យ៉ូសែប ស្ម៊ីធ ។

មេរៀនទី ១៤៦

# ការស្នងតំណែងបន្តនៅក្នុងគណៈប្រធានទីមួយ

## បុព្វកថា

បន្ទាប់ពីទុក្ករកម្មរបស់ព្យាការី យ៉ូសែប ស្ម៊ីធ និង បងប្រុសរបស់លោក ហៃរុម នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤មក មនុស្សមួយចំនួនបានច្របូកច្របល់ក្នុងចិត្តថា តើនរណានឹងដឹកនាំសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ប៉ុន្តែមុនពេលលោកស្លាប់ ព្យាការីបានរៀបចំសម្រាប់ការផ្ទេរនូវភាពជាអ្នកដឹកនាំនេះដោយការប្រគល់កូនសោ និងអំណាចនៃបព្វជិតភាពទាំងអស់ទៅឲ្យក្រុមនៃពួកសាវកដប់ពីរនាក់ ។ នៅពេល ព្រិកហាំ យ៉ង់ ដែលជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទៅកាន់ពួកបរិសុទ្ធនៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៨៤៤ ថា មានសមាជិកសាសនាចក្រជាច្រើនបានទទួលសាក្សីខាងវិញ្ញាណមួយថា លោកត្រូវបានហៅ និងរៀបចំដោយព្រះដើម្បីដឹកនាំសាសនាចក្រ ។

## យោបល់សម្រាប់ការបង្រៀន

### បន្ទាប់ពីទុក្ករកម្មរបស់យ៉ូសែប និង ហៃរុម ស្ម៊ីធ មនុស្សមួយចំនួនបានអះអាងសិទ្ធិដឹកនាំសាសនាចក្រ

ពីមុនថ្នាក់ចាប់ផ្ដើម សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖

*នៅពេលដែលប្រធាននៃសាសនាចក្របច្ចុប្បន្នស្លាប់ទៅ តើនរណានឹងក្លាយជាប្រធាននៃសាសនាចក្របន្ទាប់ទៀត ? តើលោកនឹងត្រូវបានជ្រើសរើសយ៉ាងដូចម្ដេច ?*

*តើប្រធាននៃសាសនាចក្រទទួលសិទ្ធិអំណាចបព្វជិតភាពចាំបាច់ ដើម្បីធ្វើជាអធិបតីលើសាសនាចក្រយ៉ាងដូចម្ដេច ?*

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេនឹងឆ្លើយសំណួរនៅលើក្ដារខៀន ។ សូមលើកទឹកចិត្តពួកគេឲ្យស្ដាប់ចម្លើយចំពោះសំណួរទាំងនេះនៅថ្ងៃនេះ ពេលពួកគេរៀនអំពីការផ្លាស់ប្ដូរនៅក្នុងថ្នាក់ដឹកនាំនៃសាសនាចក្រ ដែលកើតមានឡើងបន្ទាប់ពីការស្លាប់របស់ព្យាការី យ៉ូសែប ស្ម៊ីធ និង បងប្រុសលោក ហៃរុម ។

សូមពន្យល់ថា បន្ទាប់ពី យ៉ូសែប និង ហៃរុម ស្ម៊ីធ ត្រូវបានធ្វើទុក្ករកម្ម នោះពួកបរិសុទ្ធបានជួបនឹងការទុក្ខសោកយ៉ាងខ្លាំង ។ ពួកគេមួយចំនួនក៏បានភាន់ច្រឡំផងដែរអំពីនរណានឹងត្រូវដឹកនាំសាសនាចក្រ ។ ពេលអវត្តមានប្រធានសាសនាចក្រ នោះមនុស្សមួយចំនួនបានយល់ថា ភាពជាអ្នកដឹកនាំត្រូវធ្លាក់ទៅលើកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដោយត្រឹមត្រូវ ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សមួយចំនួនបានដាក់នូវការអះអាងខុសឆ្គងថា ពួកគេមានសិទ្ធិដើម្បីដឹកនាំសាសនាចក្រ ។ នៅក្នុងចំណោមពួកគេគឺមាន ស៊ីឌនី រិកដុន និង ជេម ស្ត្រាង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌចំនួនបីដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់ និងស្វែងរកមូលហេតុដែល ស៊ីឌនី រិកដុន ដែលបានធ្វើជាអ្នកដឹកនាំដ៏សំខាន់មួយរូបនៅក្នុងសាសនាចក្រអស់រយៈពេលជាច្រើនឆ្នាំ បានគិតថាគាត់គួរតែដឹកនាំសាសនាចក្រ ។

> « ស៊ីឌនី រិកដុន ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានមកដល់ [ទីក្រុងណៅវូ] ពីភិតស្បឺក រដ្ឋផែនស៊ីលវេញ៉ា នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៨៤៤ ។ នៅក្នុងឆ្នាំមុននេះ គាត់បានចាប់ផ្ដើមដើរផ្លូវទាស់នឹងការប្រឹក្សារបស់ព្យាការី យ៉ូសែប ស្ម៊ីធ ហើយបានបំបែកខ្លួនចេញពីសាសនាចក្រ ។ គាត់បានបដិសេធមិនជួបជាមួយសមាជិកបីរូបនៃពួកដប់ពីរនាក់រួចទៅហើយ កាលនៅទីក្រុង ណៅវូ ហើយជំនួសឲ្យការមកជួបនោះ គាត់បែរជាទៅថ្លែងទៅកាន់ពួកបរិសុទ្ធមួយក្រុមធំ ដែលមកជួបជុំគ្នាថ្វាយបង្គំនៅថ្ងៃអាទិត្យ » (*ករដំណែលរបស់យើង ៖ ប្រវត្តិសង្ខេបរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយឆ្នាំ* ១៩៩៦ ] ទំព័រ ៦៦ ) ។

ស៊ីឌនី រិកដុន បានកោះហៅឲ្យមានការប្រជុំជាពិសេសមួយនៅថ្ងៃអង្គារ ទី ៦ ខែ សីហា ដើម្បីឲ្យសមាជិកសាសនាចក្រអាចជ្រើសរើសអ្នកគាំពារសាសនាចក្រម្នាក់ ។ វាមើលទៅហាក់ដូចជា ស៊ីឌនី រិកដុន បានព្យាយាមដើម្បីធ្វើឲ្យការប្រជុំនេះមាន

### ចែកចាយទីបន្ទាល់របស់អ្នក

សូមពិចារណាប្រើមេរៀននេះជាឱកាសមួយ ដើម្បីថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងការបន្តសិទ្ធិអំណាចបព្វជិតភាពដែលពុំអាចកាត់ផ្ដាច់បានមកពី យ៉ូសែប ស្ម៊ីធ ទៅដល់ព្យាការីនាពេលបច្ចុប្បន្ននេះ ។ អ្នកអាចនឹងលើកទឹកចិត្តសិស្សឲ្យថ្លែងទីបន្ទាល់របស់ពួកគេផងដែរ ។ ការចែកចាយទីបន្ទាល់ ប្រទានពរដល់មនុស្សដែលថ្លែងពីវា និងអាចពង្រឹងសេចក្ដីជំនឿ និង ទីបន្ទាល់របស់អ្នកដទៃផងដែរ ។

សមាជិកសាសនាចក្រអនុម័តឲ្យគាត់មានតំណែងជាអ្នកគាំពារសាសនាចក្រ មុនពេលពួកសាវកដប់ពីរនាក់ទាំងអស់ បានត្រឡប់មកពីបេសកកម្មរបស់ពួកគេពីភាគខាងកើតនៃសហរដ្ឋអាមេរិកវិញ ។ ពួកអ្នកដឹកនាំសាសនាចក្រមួយចំនួន បានដឹងថា បងប្រុស រិកដុន អាចនឹងគ្រោង « ឈ្លៀតយកឱកាសពីស្ថានភាពរបស់ពួកបរិសុទ្ធ » (*History of the Church* ៧:២២៥ ) ។ ជាអកុសល ដោយសារតែការខិតខំរបស់អែលឌើរ វិលឡឺឌ រីឆាដ និងអែលឌើរ ប៉ាលី ភី ប្រាត្ត ការប្រជុំនោះត្រូវលើកទៅថ្ងៃព្រហស្បតិ៍ ទី ៨ ខែ សីហា ឆ្នាំ ១៨៤៤ ដែលជាពេលដែលពួកសាវកភាគច្រើនបានត្រឡប់មកដល់ទីក្រុងណៅវូវិញ ។

ស៊ីឌនី រិកដុន បានទាមទារថា ដោយសារគាត់ត្រូវបានហៅ និងតែងតាំងជាអ្នកនាំពាក្យរបស់យ៉ូសែប ស្ម៊ីធ ពីមុនមក ( សូមមើល គ. និង ស. ១០០:៩ នោះវាជាទំនួលខុសត្រូវរបស់គាត់ដើម្បី « មើលថា សាសនាចក្រនេះត្រូវបានដឹកនាំតាមរបៀបត្រឹមត្រូវ » ( នៅក្នុង *History of the Church* ៧:២២៩ ) ។ គាត់ក៏បានអះអាងថា គាត់គួរតែជា « អ្នកគាំពារដល់ប្រជាជន » ហើយថានៅក្នុងការបំពេញនូវទំនួលខុសត្រូវនេះ នោះគាត់កំពុងធ្វើនូវអ្វីដែលព្រះបានបញ្ជាគាត់ឲ្យធ្វើ ( សូមមើល *History of the Church* ៧:២៣០ ) ។

- បើអ្នកបានទៅទីក្រុង ណៅវូ ក្នុងគ្រានោះ តើអ្នកគិតថាការអះអាងរបស់ ស៊ីឌនី រិកដុនយ៉ាងណាដែរ ? តើអ្នកអាចនឹងមានការបារម្ភអ្វីខ្លះ អំពីបងប្រុស រិកដុន ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកពីមូលហេតុដែល ជេម ស្ត្រាំង បាននិយាយថា គាត់គួរតែដឹកនាំសាសនាចក្រ ។

ជេម ស្ត្រាំង ដែលបានទទួលបុណ្យជ្រមុជទឹកនៅខែកុម្ភៈ ឆ្នាំ ១៨៤៤ បានរកឃើញទីតាំងមួយ សម្រាប់ពួកបរិសុទ្ធនៅ រដ្ឋវីស្កុនស៊ីន ក្នុងនិទារឃរដូវឆ្នាំ ១៨៤៤ ។ បន្ទាប់ពីទុក្ករកម្ម នោះជេម ស្ត្រាំង បានអះអាងថា បានទទួលសំបុត្រមួយមកពី យ៉ូសែប ស្ម៊ីធ ដោយថ្លែងថា គាត់ត្រូវបានតែងតាំងឲ្យធ្វើជាអ្នកស្នងតំណែងយ៉ូសែប ។ សំបុត្ររបស់ ជេម ស្ត្រាំង ដែលគាត់បានបង្ហាញដល់សមាជិកសាសនាចក្រ បានមាននូវហត្ថលេខារបស់ យ៉ូសែប ស្ម៊ីធ ។ ជេម ស្ត្រាំង បានអះអាងឲ្យធ្វើជាព្យាការីបន្ទាប់ ហើយបានប្រកាសតំណែងរបស់គាត់នៅក្នុងសន្និសីទមួយរបស់សាសនាចក្រ នៅទីក្រុងមីឈីហ្គែន នៅថ្ងៃទី ៥ ខែសីហា ឆ្នាំ ១៨៤៤ ។

- បើអ្នកបាននៅជាមួយនឹងពួកបរិសុទ្ធនៅ ទីក្រុងមីឈីហ្គែន តើអ្នកគិតថាអ្នកនឹងជឿទៅលើការអះអាងរបស់ ជេម ស្ត្រាំង ដែរឬទេ ? តើអ្នកអាចនឹងមានការបារម្ភអ្វីខ្លះ អំពីការអះអាងទាំងនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌចំនួនប្រាំដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សស្ដាប់នូវអ្វីដែល ព្រិកហាំ យ៉ង់ បានប្រាប់ដល់អ្នកដឹកនាំបព្វជិតភាពដទៃទៀត ដោយរួមទាំងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលនៅទីក្រុង ណៅវូ អំពីនរណាគួរតែដឹកនាំសាសនាចក្រ ៖

អែលឌើរ យ៉ូហាន ថេលើរ, វិលឡឺដ រីឆាដ, ប៉ាលី ភី ប្រាត្ត គឺបាននៅក្នុងទីក្រុងណៅវូស្រាប់ នៅពេលស៊ីឌនី រិកដុន បានមកដល់ ។ ពួកសាវកឯទៀតភាគច្រើនព្រមទាំង ព្រិកហាំ យ៉ង់ បានត្រឡប់មកដល់ទីក្រុង ណៅវូ វិញនាល្ងាចថ្ងៃទី ៦ ខែសីហា ឆ្នាំ ១៨៤៤ ។ នៅថ្ងៃបន្ទាប់ ថ្ងៃទី ៧ ខែ សីហា ពួកសាវកបានជួបជុំក្រុមប្រឹក្សានៅផ្ទះរបស់យ៉ូហាន ថេលើរ ។ នាពេលរសៀលនៅថ្ងៃនោះ ពួកសាវកដប់ពីរនាក់ ក្រុមប្រឹក្សាជាន់ខ្ពស់ និងពួកសង្ឃជាន់ខ្ពស់បានជួបជុំគ្នា ។ ប្រធាន យ៉ង់ បានសួរដល់ស៊ីឌនី រិកដុន ឲ្យថ្លែងប្រាប់ពីសារលិខិតរបស់គាត់ដល់ពួកបរិសុទ្ធ ។ ស៊ីឌនី រិកដុន បានប្រកាសដោយអង់អាចថា គាត់បានឃើញការនិមិត្តមួយ ហើយថាគ្មានបុរសណាអាចបន្តតំណែង យ៉ូសែប ស្ម៊ីធ ជាប្រធាននៃសាសនាចក្រទេ ។ ភ្លាមនោះលោកបានស្នើថា លោកត្រូវបានតែងតាំងជាអាណាព្យាបាលនៃប្រជាជននេះ ។

ក្រោយពី ស៊ីឌនី រិកដុន បានបញ្ចប់សុន្ទរកថារបស់គាត់ ព្រិកហាំ យ៉ង់ បានមានប្រសាសន៍ ៖



« ខ្ញុំមិនខ្វល់ថានរណាដឹកនាំសាសនាចក្រនោះទេ . . . ប៉ុន្តែមានរឿងមួយដែលខ្ញុំត្រូវតែដឹង ហើយថានោះជាអ្វីដែលព្រះមានបន្ទូលអំពីវា ។ ខ្ញុំមានកូនសោ និង មានវិធីជាច្រើនក្នុងការទទួលបានព្រះឆន្ទៈនៃព្រះលើការងារនេះ ។. . .

« យ៉ូសែប បានប្រគល់មកលើក្បាលយើង [សំដៅទៅលើកូរ៉ុមនៃពួកសាវកដប់ពីរនាក់] នូវកូនសោ និងអំណាចទាំងអស់ ដែលជារបស់ផងសាវក ដែលលោកផ្ទាល់បានកាន់ មុនពេលលោកត្រូវបាននាំយកទៅ ។. . .

« តើយ៉ូសែប បាននិយាយប៉ុន្មានដងដល់ពួកសាវកថា ‹ ខ្ញុំបានដាក់គ្រឹះ ហើយអ្នកត្រូវតែសាងនៅលើវា ដ្បិតនៅលើស្មាអ្នកនោះនគរនឹងសម្រាក › » ( នៅក្នុង *History of the Church* ៧:២៣០ ) ។

- ហេតុអ្វីបានជាទីបន្ទាល់របស់ព្រិកហាំ យ៉ង់ អំពីកូនសោនៃបព្វជិតភាពសំខាន់ម្ល៉េះ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖**ពួកសាវកកាន់កូនសោទាំងអស់នៃអំណាចបព្វជិតភាពដែលចាំបាច់ដើម្បីធ្វើជាអធិបតីដល់សាសនាចក្រ**) ។

សូមពន្យល់ថា នៅពេលសាវកម្នាក់ត្រូវបានតែងតាំង នោះលោកត្រូវបានប្រគល់ឲ្យនូវកូនសោចាំបាច់ទាំងអស់នៃបព្វជិតភាពនៅលើផែនដីនេះ ( សូមមើល គ. និង ស. ១១២:៣០–៣២) ប៉ុន្តែសិទ្ធិអំណាចដើម្បីអនុវត្តកូនសោទាំងនោះ ត្រូវបានកំណត់ចំពោះតែសាវកមុខច្បង ប្រធាននៃសាសនាចក្រតែប៉ុណ្ណោះ ។

សូមអានឲ្យឮៗនូវសេចក្ដីណែនាំដូចខាងក្រោម ដែលបានផ្ដល់ឲ្យ ដោយ យ៉ូសែប ស្ម៊ីធ ទៅកាន់ កូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅខែមករា ឆ្នាំ ១៨៣៦ មានរយៈពេលច្រើនជាងប្រាំបីឆ្នាំ មុនពេលលោកបានស្លាប់ ៖



« ពួកដប់ពីរនាក់ ពុំស្ថិតនៅក្រោមអ្នកផ្សេងក្រៅពី គណៈប្រធានទីមួយ នោះឡើយ. . . ‹ ហើយកន្លែងណាបើគ្មានខ្ញុំ នោះគ្មានគណៈប្រធានទីមួយ ធ្វើជាអធិបតីលើពួកដប់ពីរនាក់ឡើយ ›» ( នៅក្នុង *History of the Church* ២:៣៧៤ ) ។

- ផ្ដេកទៅលើសេចក្ដីថ្លែងការណ៍នេះ តើមានអ្វីកើតឡើងចំពោះគណៈប្រធានទីមួយ នៅពេលប្រធានសាសនាចក្រស្លាប់ ? តើនរណាដឹកនាំសាសនាចក្រ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖**នៅពេលប្រធាននៃសាសនាចក្រស្លាប់ទៅ នោះគណៈប្រធានទីមួយ ត្រូវបានរំលាយ ហើយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានក្លាយជាកូរ៉ុមជាអធិបតី** ) ។

សូមពន្យល់ថា នៅពេលប្រធានសាសនាចក្រស្លាប់ នោះទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ នឹងត្រឡប់ទៅតំណែងពួកលោកម្ដងទៀតក្នុងនាមជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដោយផ្អែកលើភាពជាសិស្សច្បងរបស់ខ្លួននៅក្នុងកូរ៉ុម ។ នៅពេលកូរ៉ុមត្រូវបានបង្កើតឡើងដំបូងនៅក្នុងឆ្នាំ ១៨៣៥ នោះភាពជារៀមច្បង គឺត្រូវបានសម្រេចដោយវ័យ ។ ឥឡូវ ភាពជារៀមច្បង គឺត្រូវបានកំណត់ដោយកាលបរិច្ឆេទដែលបុរសម្នាក់បានក្លាយទៅជាសមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១២៧–១២៨ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់រកមើលថាតើនរណា គឺជាសាវកមុខច្បង និងជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅគ្រាដែលយ៉ូសែប ស្ម៊ីធ ស្លាប់ ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

- ផ្ដេកទៅលើអ្វីដែលអ្នកបានរៀន ហេតុអ្វីបានជាអ្នកស្ម័គ្រចិត្តធ្វើតាម ព្រិកហាំ យ៉ង់ បន្ទាប់ពីការស្លាប់របស់ ព្យាការីយ៉ូសែប ស្ម៊ីធ ?

សូមបំពេញគោលលទ្ធិនៅលើក្ដារខៀនដោយបន្ថែមនូវផ្នែកដែលបានគូសបន្ទាត់ពីក្រោម ៖**នៅពេលប្រធាននៃសាសនាចក្រស្លាប់ នោះគណៈប្រធានទីមួយ ត្រូវបានរំលាយ ហើយកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានក្លាយទៅជាកូរ៉ុមជាអធិបតី នៅក្រោមការដឹកនាំរបស់សាវកមុខច្បង** ។

## ពួកបរិសុទ្ធជាច្រើន បានទទួលសាក្សីមួយថា ព្រិកហាំ យ៉ង់ គួរតែដឹកនាំសាសនាចក្រ

សូមពន្យល់ថា នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៤៤ ពួកបរិសុទ្ធនៅទីក្រុងណៅវូបានប្រជុំគ្នានៅម៉ោង ១០ ព្រឹក ដើម្បីស្ដាប់ ស៊ីឌនី រិកដុន ធ្វើការអះអាងខ្លួនថាជាអ្នកគាំពារសាសនាចក្រ ។ ដោយសារតែខ្យល់បានបោកបក់ទៅចំវេទិកា នោះ ស៊ីឌនី រិកដុន បាននៅត្រង់កន្លែងក្នុងរទេះសេះមួយ ពីខាងក្រោយក្រុមជំនុំដែលបានជួបជុំគ្នា ដូច្នេះប្រជាជនពុំអាចឮសំឡេងគាត់ច្បាស់ឡើយ ។ ដែលក្រុមជំនុំត្រូវបែរក្រោយដើម្បីពួកគេអាចមើលឃើញស៊ីឌនី រិកដុន នៅពេលគាត់និយាយ ។ គាត់បាននិយាយដល់ពួកបរិសុទ្ធដែលមកប្រជុំរាប់ពាន់នាក់ អស់រយៈពេលមួយម៉ោងកន្លះ ដោយពន្យល់ពីមូលហេតុដែលគាត់គួរតែក្លាយជាអ្នកគាំពារសាសនាចក្រ ។ មនុស្សបីបួននាក់បាននិយាយថា សុន្ទរកថារបស់គាត់មិនមែនជាការបំផុសគំនិតនោះទេ ។

ប្រធាន ព្រិកហាំ យ៉ង់ និង អ្នកដឹកនាំសាសនាចក្រដទៃទៀត បានមកចូលរួម ហើយអង្គុយនៅលើវេទិកាប្រទល់មុខនឹង ស៊ីឌនី រិកដុន ដែលកំពុងតែថ្លែងនោះ ។ ខ្យល់បានស្ងប់ទៅវិញ ត្រង់ពេលនេះ ។ បន្ទាប់ពី ស៊ីឌនី រិកដុនបានបញ្ចប់ ប្រធាន ព្រិកហាំ យ៉ង់ បានមានប្រសាសន៍ ។ បណ្ដាជនទាំងឡាយបានងាកត្រឡប់មកស្ដាប់ ព្រិកហាំ យ៉ង់ មានប្រសាសន៍ ហើយបែរខ្នងទៅរទេះសេះដែលស៊ីឌនី រិកដុនស្ថិតនៅនោះវិញ ។ ( សូមមើល George Q. Cannon, « Discourse, » *Deseret News,* ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ១៨៨៣, ៦៧ ) ។ ប្រធាន ព្រិកហាំ យ៉ង់ បាននិយាយដោយខ្លី ហើយបានថ្លែងថា លោកចង់ត្រឡប់មកក្រុងណៅវូ ដើម្បីចូលរួមរំលែកទុក្ខដល់ព្យាការី ជាជាងដើម្បីមកតែងតាំងអ្នកដឹកនាំថ្មីមួយ ។ លោកបានប្រកាសថាការប្រមូលផ្ដុំនៃថ្នាក់ដឹកនាំ និងសមាជិកនឹងធ្វើឡើងពេលក្រោយនៅថ្ងៃនោះវេលាម៉ោង ២ រសៀល ។ ក្រោយមកសមាជិកមួយ

ចំនួនរបស់សាសនាចក្របានថ្លែងទីបន្ទាល់ថា ពេលប្រធាន ព្រិកហាំ យ៉ង់ បានមានប្រសាសន៍ នោះពួកគេបានឃើញថាទឹកមុខរបស់លោកបានផ្លាស់ប្ដូរ ហើយបានឮសំឡេងរបស់លោកបានផ្លាស់ប្ដូរ ហើយលោកបានបានមានទឹកមុខ និងសំឡេងដូចនឹងព្យាការី យ៉ូសែប ស៊្មីធ ។ ព្រឹត្តការណ៍ដ៏អព្ភូតហេតុនេះ បានជួយឲ្យពួកបរិសុទ្ធជាច្រើនបានដឹងថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យ ព្រិកហាំ យ៉ង់ ដឹកនាំសាសនាចក្រ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវឧទាហរណ៍ដូចខាងក្រោមអំពីអ្វីដែលពួកបរិសុទ្ធជាច្រើនបានមើលឃើញ និងបានស្ដាប់ឮៗ ៖



បេនយ៉ាមីន អេហ្វ ចនសុន បានរំឭកថា « រំពេចដែលលោក [ព្រិកហាំ យ៉ង់] មានប្រសាសន៍ភ្លាម នោះខ្ញុំបានក្រោកឈរឡើង ដ្បិតវាគឺជាសំឡេងរបស់ យ៉ូសែប គ្រប់ពាក្យ ហើយរូបរាងលោកផ្ទាល់ ទាំងអាកប្បកិរិយា សម្លៀកបំពាក់ និងរូបរាង គឺដូចជា យ៉ូសែបផ្ទាល់ នៅរស់រើក ហើយខ្ញុំដឹងមួយរំពេចនោះថា ព្រះវិញ្ញាណ និងមានជារូបរបស់យ៉ូសែបមកគ្របលើលោក » (*My Life's Review* ១០៤ ដូចបានដកស្រង់នៅក្នុង *Church History in the Fulness of Times Student Manual,* បោះពុម្ពជាលើកទីពីរ [Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ២៩១) ។

វិលលាម សី ស្ទេន បានពិពណ៌នាថា ព្រិកហាំ យ៉ង់ នៅពេលកំពុងតែនិយាយ « សំឡេងលោកគឺដូចជាសំឡេងរបស់ព្យាការីយ៉ូសែប ។ ខ្ញុំបានគិតវា ជាយ៉ូសែប ហើយមានមនុស្សរាប់ពាន់បានស្ដាប់ឮដូចគ្នានេះដែរ » (នៅក្នុង *History of the Church* ៧:២៣៦ ) ។



វិលហ្វូឌ វូឌរ្រុព្វ បានសរសេរថា « បើខ្ញុំពុំធ្លាប់បានឃើញ ព្រិកហាំ យ៉ង់ ដោយផ្ទាល់ភ្នែករបស់ខ្ញុំទេ នោះគ្មាននរណាម្នាក់ ដែលអាចមកបញ្ចុះបញ្ចូលខ្ញុំឲ្យជឿថាអ្នកដែលឡើងនិយាយនោះពុំមែនជា យ៉ូសែប ស៊្មីធ នោះឡើយ ហើយមនុស្សគ្រប់រូបដែលបានស្គាល់បុរសទាំងពីររូបនេះ អាចថ្លែងទីបន្ទាល់ចំពោះព្រឹត្តិការណ៍នេះបាន ( នៅក្នុង *History of the Church* ៧:២៣៦ ) ។

សូមពន្យល់ថា អំឡុងការប្រជុំបានធ្វើឡើងក្រោយមកនៅថ្ងៃនោះ វេលាម៉ោង ២:០០ រសៀល នោះ ព្រិកហាំ យ៉ង់ និងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ផ្សេងទៀតបានមានប្រសាសន៍ ។ នៅពេលលោកបាននិយាយនារសៀលនោះ មានពួកបរិសុទ្ធជាច្រើនបាននិយាយថា ព្រិកហាំ យ៉ង់ បានមើលទៅ និងស្ដាប់ទៅឮដូចជាយ៉ូសែប ស៊្មីធ ។ ចច យូ្យ ខានុន ដែលមានអាយុ ១៧ ឆ្នាំនាគ្រានោះ បានចងចាំថា « វាគឺជាសំឡេងរបស់ យ៉ូសែប ផ្ទាល់មែន ។. . . វាហាក់ដូចជានៅក្នុងភ្នែករបស់មនុស្សដែលនៅទីនោះ មើលឃើញថាជាយ៉ូសែប ដែលកំពុងឈរនៅចំពោះមុខពួកគេនោះ » ( នៅក្នុង *History of the Church,* ៧:២៣៦; សូមមើលផងដែរ Edward William Tullidge, *Life of Brigham Young* ឆ្នាំ ១៨៧៧], ទំព័រ ១១៥) ។ បន្ថែមលើអព្ភូតហេតុនោះ ពួកបរិសុទ្ធជាច្រើនក៏បានមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធធ្វើជាសាក្សីដល់ពួកគេថា ព្រិកហាំ យ៉ង់ និងកូរ៉ុមនៃពួកដប់ពីរនាក់ត្រូវបានហៅដោយព្រះដើម្បីដឹកនាំសាសនាចក្រ ។ នៅពេលបញ្ចប់នៃការប្រជុំនេះ ពួកបរិសុទ្ធនៅទីក្រុងណៅវូបានបោះឆ្នោតដោយអនាមិកដើម្បីគាំទ្រដល់កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដោយមានព្រិកហាំ យ៉ង់ ជាប្រធានដើម្បីដឹកនាំសាសនាចក្រ ។ ទោះជាយ៉ាងណាក្ដី ពុំមែនសមាជិកគ្រប់រូបនៃសាសនាចក្របានជ្រើសរើសដើម្បីធ្វើតាមពួកសាវកនៅទីបញ្ចប់នោះទេ ។ ប្រជាជនខ្លះបានជ្រើសរើសធ្វើតាមបុគ្គលនានាដូចជា ស៊ីឌនី រិកដុន និងជេម ស្ត្រាង ដែលបានបង្កើតសាសនាចក្រផ្ទាល់ខ្លួនរបស់ពួកគេទៅវិញ ។

- តើព្រះអម្ចាស់បានប្រទានពរដល់ពួកបរិសុទ្ធឲ្យដឹងថា តើនរណាដែលទ្រង់បានចាត់តាំងឲ្យដឹកនាំសាសនាចក្រយ៉ាងដូចម្ដេច ?
- តើយើងអាចដឹងថា អ្នកដឹកនាំសាសនាចក្រសព្វថ្ងៃនេះត្រូវបានហៅដោយព្រះដោយរបៀបណា ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **តាមរយៈព្រះវិញ្ញាណបរិសុទ្ធ យើងអាចទទួលបានសាក្សីមួយថា អស់អ្នកដែលដឹកនាំសាសនាចក្រត្រូវបានហៅបម្រើដោយព្រះ** ) ។
- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីទទួលទីបន្ទាល់មួយថា អ្នកដឹកនាំសាសនាចក្ររបស់យើង ត្រូវបានហៅពីព្រះ ?
- តើនៅពេលណា ដែលអ្នកបានទទួលសាក្សីមួយថា អ្នកដឹកនាំនៃសាសនាចក្រម្នាក់ ត្រូវបានហៅពីព្រះ ? តើអ្នកបានធ្វើអ្វីខ្លះដើម្បីទទួលបានសាក្សីនោះ ?

សូមពន្យល់ថា នៅពេលយ៉ូសែប ស្ម៊ីធ បានស្លាប់ទៅ សាវករៀមច្បង (ព្រិកហាំ យ៉ង់ ) គឺអាចអនុវត្តកូនសោអំណាចបព្វជិតភាពទាំងអស់បានភ្លាមៗ ។ លោកមានសិទ្ធិដើម្បីទទួលវិវរណៈស្ដីអំពីពេលវេលាណា ដើម្បីរៀបចំគណៈប្រធានទីមួយថ្មី ។ នៅក្នុងឆ្នាំ ១៨៤៧ – មានរយៈពេលច្រើនជាងពីរឆ្នាំ បន្ទាប់ពីការធ្វើទុក្ករកម្ម– ព្រិកហាំ យ៉ង់ ត្រូវបានបំផុសគំនិតឲ្យរៀបចំគណៈប្រធានទីមួយម្ដងទៀត ជាជាងបន្តដឹកនាំសាសនាចក្រក្នុងនាមជាប្រធាននៃ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

សូមបង្ហាញរូបភាពនៃគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ពេលបច្ចុប្បន្ន ។ ដើម្បីផ្ដល់ឱកាសដល់សិស្សសង្ខេបនូវអ្វីដែលពួកគេបានរៀន សូមឲ្យពួកគេពន្យល់នូវអ្វីដែលបានកើតឡើងចំពោះគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅពេលប្រធាននៃសាសនាចក្រស្លាប់ ។ សូមឲ្យពួកគេប្រាប់ថា នរណានឹងក្លាយជាប្រធានសាសនាចក្រឬសាវករៀមច្បង បើប្រធានសាសនាចក្របច្ចុប្បន្នស្លាប់នៅថ្ងៃនេះនោះ ។

អ្នកអាចនឹងចង់បញ្ចប់មេរៀននេះដោយការថ្លែងទីបន្ទាល់ថា កូនសោ និងអំណាចបព្វជិតភាពដូចគ្នាដែលយ៉ូសែប ស្ម៊ីធ បានប្រគល់ដល់ព្រិកហាំ យ៉ង់ និងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ត្រូវបានកាន់នៅថ្ងៃនេះដោយប្រធាននៃសាសនាចក្រ ទីប្រឹក្សារបស់លោកនៅក្នុងគណៈប្រធានទីមួយ និងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ អ្នកក៏អាចចែកចាយផងដែរពីរបៀបដែលអ្នកទទួលបានទីបន្ទាល់ថា អ្នកដឹកនាំសាសនាចក្រត្រូវបានហៅដោយព្រះ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកប្រកបដោយការអធិស្ឋានដើម្បីទទួលបាន ឬពង្រឹងដល់ទីបន្ទាល់របស់ពួកគេអំពីសេចក្ដីពិត ដែលពួកគេបានពិភាក្សាថ្ងៃនេះ ។

មេរៀនទី ១៤៧

# ការចាកចេញពីទីក្រុងណៅវូ

## បុព្វកថា

បន្ទាប់ពីព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវគេធ្វើទុក្ករកម្ម នោះកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅក្រោមការដឹកនាំរបស់ប្រធានកូរ៉ុមពួកគេ គឺ ព្រិកហាំ យ៉ង់ បានដឹកនាំសាសនាចក្រ ហើយបន្តធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។ ពួកលោកបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធណៅវូ ។ ដោយសារតែមានការបៀតបៀនឥតឈប់ឈរ នោះពួកលោកបានប្រឹក្សាដល់ពួកបរិសុទ្ធឲ្យត្រៀមខ្លួនដើម្បីចេញដំណើរទៅទិសខាងលិចផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### ពួកបរិសុទ្ធបានធ្វើការដោយឧស្សាហ៍ព្យាយាម ដើម្បីទទួលពរជ័យនៃព្រះវិហារបរិសុទ្ធ

សូមឲ្យសិស្សគិតអំពីគ្រាមួយ ដែលពួកគេបានធ្វើអ្វីមួយដ៏លំបាក ដោយសារតែពួកគេបានដឹងថា លទ្ធផលនឹងមានតម្លៃក្នុងការខិតខំនោះ ។ សូមពិចារណាធ្វើការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនជាមួយសិស្សក្នុងថ្នាក់ ។ បន្ទាប់មកសូមអញ្ជើញសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមពន្យល់ថា បន្ទាប់ពីការស្លាប់របស់ព្យាការីយ៉ូសែប ស្ម៊ីធ នោះពួកបរិសុទ្ធមានការងារដ៏លំបាក ដើម្បីបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធណៅវូ ។

- ហេតុអ្វីអ្នកគិតថា វាមានការលំបាកសម្រាប់ពួកបរិសុទ្ធដើម្បីបំពេញតាមបទបញ្ញត្តិមួយនេះ ដែលបានផ្តល់ឲ្យតាមរយៈយ៉ូសែប ស្ម៊ីធ ?

សូមបង្ហាញរូបភាព ព្រះវិហារបរិសុទ្ធណៅវូ អិលលីណោយ ដល់សិស្ស ( សូមមើល *សៀវភៅរូបភាពដំណឹងល្អ* [ ឆ្នាំ ២០០៩ ] លេខ ១១៨ សូមមើលផងដែរគេហទំព័រ LDS.org ) ។ សូមពន្យល់ថា វាត្រូវការពលិកម្មដ៏ខ្លាំងពីពួកបរិសុទ្ធដើម្បីសាងសង់ព្រះវិហារបរិសុទ្ធណៅវូ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់មើលអំពីការពលិកម្មទាំងឡាយដែលពួកបរិសុទ្ធបានធ្វើការលះបង់ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធដំបូងនៅទីក្រុងណៅវូ ។

នៅសន្និសីទទូទៅខែតុលា ឆ្នាំ ១៨៤៤ ប្រធាន ព្រិកហាំ យ៉ង់ បានសុំឲ្យពួកបរិសុទ្ធថ្វាយដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេង ៗរបស់ពួកគេដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ។ ក្នុងការឆ្លើយតប បងស្រីសមាគមសង្គ្រោះម្នាក់ៗ បានបរិច្ចាគប្រាក់មួយសេនរាល់សប្ដាហ៍ ដើម្បីផ្គត់ផ្គង់ដល់ការសាងសង់ ។ បុរសជាច្រើនបានថ្វាយដង្វាយមួយភាគដប់ជាពេលវេលារបស់ពួកគេ ដោយការធ្វើការសាងសង់ព្រះវិហារបរិសុទ្ធមួយថ្ងៃក្នុងរយៈពេលដប់ថ្ងៃ ។ អ្នកផ្សេងទៀតបានថ្វាយច្រើនជាងមួយភាគក្នុងដប់ទៅតាមមធ្យោបាយរបស់ពួកគេផ្ទាល់ ។ យ៉ូសែប តូរ៉ុនតូ បានប្រគល់ដល់ ព្រិកហាំ យ៉ង់ នូវមាសដែលមានតម្លៃស្មើរនឹងទឹកប្រាក់ចំនួន ២៥០០ ដុល្លា ហើយបាននិយាយថា គាត់ចង់ថ្វាយអ្វីៗទាំងអស់ដែលគាត់មាន ដើម្បីស្ថាបនានគរនៃព្រះ ។ (សូមមើល *Church History in the Fulness of Times Student Manual,* បានបោះពុម្ពជាលើកទី ២ [Church Educational System manual, ២០០៣], ៣០២; *Our Heritage* [១៩៩៦], ៥៩–៦០ ) ។



- ហេតុអ្វីអ្នកគិតថា ពួកបរិសុទ្ធស្ម័គ្រចិត្តលះបង់យ៉ាងច្រើនដើម្បីសាងសង់ព្រះវិហារបរិសុទ្ធដូច្នេះ ?

បន្ទាប់ពីសិស្សពិភាក្សាសំណួរនេះហើយ សូមពន្យល់ថា ការបៀតបៀនបានធ្វើឲ្យមានការលំបាកក្នុងការសាងសង់ព្រះវិហារបរិសុទ្ធណៅវូឲ្យហើយ ។ មានមារសត្រូវរបស់សាសនាចក្រជាច្រើន បានគិតថា កាលណា យ៉ូសែប ស្ម៊ីធ ត្រូវគេសម្លាប់ហើយ នោះសាសនាចក្រនឹងត្រូវរលំចុះ ។ តែទោះជាយ៉ាងណា នៅពេលសាសនាចក្របន្តរីកចម្រើន និងលូតលាស់ នោះពួកមារសត្រូវនៃសាសនាចក្របានបង្កើននូវការខិតខំរបស់ពួកគេដើម្បីបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋ អិលលីណោយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលនូវអ្វីដែលពួកមារសត្រូវនៃសាសនាចក្របានធ្វើ ដើម្បីព្យាយាមបំផ្លាញសាសនាចក្រ ។

នៅក្នុងខែកញ្ញា ឆ្នាំ ១៨៤៤ វរសេនីឯក លេវី វិលលាម ជាមនុស្សម្នាក់នៃអ្នកទាំងនោះ ដែលក្រោយមកបានកាត់ទោសថាជាអ្នកសម្លាប់ យ៉ូសែប និង ហៃរុម ស្ម៊ីធ បានរៀបចំបង្កើតក្រុមកងទ័ពមួយដ៏ធំដើម្បីបង្ខំពួកបរិសុទ្ធថ្ងៃចុងក្រោយចេញពីរដ្ឋ អិលលីណោយ ។ វាត្រូវបានផ្សព្វផ្សាយសាសនាជា « ឆ្កែចចកដ៏ធំប្រមាញ់នៅក្នុងឃុំ ហែនខក » (David E. Miller and Della S. Miller, *Nauvoo: The City of Joseph* [ឆ្នាំ ១៩៧៤] ទំព័រ ១៨៦ ) ។ ពេលបានឮអំពីរឿងនេះ អភិបាល ថូម៉ាស ហ្វត នៃរដ្ឋ អិលលីណោយ បានបញ្ជូនឧត្ដមសេនី ចន ហាឌីន នៃកងចល័តរដ្ឋឲ្យទៅកាន់ឃុំនោះ ដើម្បីរក្សាភាពសុខសាន្ត ។ មួយឆ្នាំក្រោយមក នៅខែកញ្ញា ឆ្នាំ ១៨៤៥ វរសេនីឯក វិលលាម បានដឹកនាំក្រុមមនុស្សអាក្រក់មួយក្រុមដែលមានមនុស្ស ៣០០ នាក់ ទៅវាយប្រហារដល់ជម្រករបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅតំបន់ជាយៗ ដោយការដុតផ្ទះជាច្រើនខ្នង និងដុតអគារកសិដ្ឋាន រោងកិនស្រូវ និងស្រូវអង្ករអស់ជាច្រើន ។ នៅពាក់កណ្ដាលខែកញ្ញា ប្រធាន ព្រិកហាំ យ៉ង់ បានស្វែងរកអ្នកស្ម័គ្រចិត្តដើម្បីទៅជួយសង្គ្រោះពួកបរិសុទ្ធទាំងនោះ ។ ពួកបរិសុទ្ធនៅទីក្រុង ណៅវូ បានត្រៀមរទេះសេះចំនួន ១៣៤ ដើម្បីដឹកក្រុមគ្រួសារដែលរស់នៅតំបន់ឆ្ងាយដាច់ស្រយាលមកទីក្រុង ណៅវូ ដែលជាទីជម្រកមានសុវត្ថិភាព ។ ( សូមមើល *History of the Church* ៧:៤៥–៤៦ *Church History in the Fulness of Times Student Manual,* ទំព័រ ៣០១ David E. Miller and Della S. Miller, *Nauvoo: The City of Joseph* ទំព័រ ១៨៥–៨៦ ) ។

- តើការវាយប្រហារទាំងនេះ បានធ្វើឲ្យវាមានការលំបាកដើម្បីបន្តធ្វើការសាងសង់ព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច?

សូមពន្យល់ថា មានប្រជាជនរដ្ឋ អិលលីណោយ ជាច្រើនរូប បានភ័យខ្លាចថា វត្តមានរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ អាចនាំឲ្យកើតមានសង្គ្រាមស៊ីវិល ។ ពួកគេបានសុំឲ្យពួកបរិសុទ្ធចាកចេញពីរដ្ឋ ។ នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៨៤៥ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបោះពុម្ពលិខិតមួយសន្យាថា សាសនាចក្រនឹងចាកចេញនៅនិទាឃរដូវក្រោយ ។

- ហេតុអ្វីបានជាព្រឹត្តិការណ៍នេះក្លាយជាការសម្រេចចិត្តដ៏លំបាកយ៉ាងដូច្នេះ ?

- តើអ្នកគិតថាការសម្រេចចិត្តចាកចេញពីទីក្រុងណៅវូ អាចប៉ះទង្គិចដល់ការខិតខំប្រឹងប្រែងរបស់ពួកបរិសុទ្ធ ដើម្បីបញ្ចប់ការសង់ព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ?

បន្ទាប់ពីសិស្សពិភាក្សាអំពីសំណួរនេះ ចូរពន្យល់ថា ទោះជាពួកបរិសុទ្ធបានដឹងថា ពួកគេត្រូវតែចាកចេញពីរដ្ឋ អិលលីណោយក្ដី ក៏ពួកគេបានបន្តធ្វើការសាងសង់ព្រះវិហារបរិសុទ្ធ ។

- តើអ្នកគិតថា ហេតុអ្វីពួកបរិសុទ្ធបានបន្តធ្វើការសាងសង់ព្រះវិហារបរិសុទ្ធ ថ្វីបើពួកគេបានដឹងថា ពួកគេនឹងចាកចេញទៅក្ដី ?

សូមរំឭកសិស្សថា នៅគ្រានោះពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ដែលចាំបាច់សម្រាប់ការលើកតម្កើង ពុំទាន់មានចំពោះសមាជិកភាពទូទៅនៃសាសនាចក្រនៅឡើយ ។ នៅក្នុងវិវរណៈមួយក្នុងឆ្នាំ ១៨៤១ ព្រះអម្ចាស់បានសន្យានឹងពួកបរិសុទ្ធថា បើពួកគេសាងសង់ព្រះវិហារបរិសុទ្ធ ណៅវូ នោះពួកគេអាចនឹងទទួលបានពិធីបរិសុទ្ធទាំងនោះ ( សូមមើល គ. និង ស. ១២៤:២៧–៤៤) ។

- តើយើងម្នាក់ៗអាចរៀនដូចម្ដេចខ្លះ អំពីដំណើររឿងនៃការពលិកម្ម និងទុក្ខលំបាកទាំងឡាយរបស់ពួកបរិសុទ្ធ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ? ( សិស្សអាចរកឃើញគោលការណ៍ផ្សេងៗដូចខាងក្រោមនេះ ៖ **ការទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធមានតម្លៃនឹងការខិតខំ និងពលិកម្មដ៏សុចរិតទាំងអស់របស់យើង ។** សូមសរសេរគោលការណ៍នេះ និងសេចក្ដីថ្លែងដទៃទៀតដែលសិស្សបានប្រាប់នៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស. ម៉នសុន ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមើលការពលិកម្មរបស់ពួកបរិសុទ្ធសម័យទំនើបមួយចំនួន ដែលពួកគេបានធ្វើដើម្បីទទួលបានពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ។



« អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានអានអំពីក្រុមសមាជិកជាងមួយរយនាក់ ដែលបានចាកចេញពី មេណូស ដែលស្ថិតនៅកណ្ដាលព្រៃលិចទឹកអាម៉ាហ្សូន ធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធដែលនៅជិតបំផុត ស្ថិតនៅទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល –(ចម្ងាយប្រហែល ៤000 គីឡូម៉ែត្រ)ពី មេណូស។ ពួកបរិសុទ្ធស្មោះត្រង់ទាំងនោះ បានធ្វើដំណើរតាមទូកអស់រយៈពេលបួនថ្ងៃ តាមទន្លេអាម៉ាហ្សូន និង តាមដៃទន្លេ អាម៉ាស្សូន ។ បន្ទាប់ពីបានបញ្ចប់ការធ្វើដំណើរតាមទឹកនេះ ពួកគេបានឡើងជិះឡានក្រុង ធ្វើដំណើររយៈពេលបីថ្ងៃទៀត តាមផ្លូវលោក់ ហើយមានអាហារបរិភោគបន្តិចបន្តួចប៉ុណ្ណោះ ហើយគ្មានកន្លែងសម្រាកស្រួលបួលនោះទេ ។ ប្រាំពីរយប់ប្រាំពីរថ្ងៃក្រោយមក ពួកគេបានមកដល់ព្រះវិហារបរិសុទ្ធនៅ សៅ ផាឡូ ដែលនៅទីនោះពិធីបរិសុទ្ធដ៏អស់កល្បទាំងឡាយត្រូវបានធ្វើឡើង ។ ប្រាកដណាស់ការធ្វើដំណើរត្រឡប់មកវិញរបស់ពួកគេ មានការលំបាកដូចនឹងពេលធ្វើដំណើរទៅដែរ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានទទួលពិធីបរិសុទ្ធ និងពរជ័យនៃព្រះវិហារបរិសុទ្ធ ហើយទោះបីជាក្នុងសំពាយ របស់ពួកគេគ្មាននៅសល់ប្រាក់ក្ដីក៏ពួកគេបានពោរពេញទៅដោយអារម្មណ៍ នៃព្រះវិហារបរិសុទ្ធ ហើយមានអំណរ គុណចំពោះពរជ័យទាំងឡាយដែលពួកគេបានទទួលផងដែរ » (The Holy Temple—a Beacon to the World,» *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ៩១) ។

- **តើ ពួកបរិសុទ្ធមកពីមេណូសបានធ្វើពលិកម្មអ្វីខ្លះ ដើម្បីទទួលបានពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ?**

**សូមអញ្ជើញសិស្សបីនាក់ឲ្យមកខាងមុខសិស្សក្នុងថ្នាក់ ហើយអានដំណើររឿងដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់កិច្ចខិតខំដ៏សុចរិតរបស់ពួកបរិសុទ្ធ ណៅវូ ដើម្បីទទួលបានពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ។**

១. អ្នកដឹកនាំសាសនាចក្របានឧទ្ទិសឆ្លងបន្ទប់ទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ នៅពេលដែលបានសាងសង់ចប់សព្វគ្រប់ ដើម្បីកិច្ចការនៃពិធីបរិសុទ្ធអាចចាប់ផ្ដើមឲ្យឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។ បន្ទប់ខាងលើនៃព្រះវិហារបរិសុទ្ធ ត្រូវបានឧទ្ទិសឆ្លងសម្រាប់កិច្ចការនៃពិធីបរិសុទ្ធនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៨៤៥ ។ ពួកបរិសុទ្ធបានចាប់ផ្ដើមទទួលពិធីអំណោយទានពិសិដ្ឋរបស់ពួកគេ នាពេលល្ងាចថ្ងៃទី ១០ ខែធ្នូ ដែលមានវគ្គពិធីអំណោយទានពិសិដ្ឋបានបន្តរហូតដល់ម៉ោង ៣ ព្រឹកនៅថ្ងៃទី ១១ ខែធ្នូ ។ ( សូមមើល *Church History in the Fulness of Times Student Manual Religion* ទំព័រ ៣០៣ ) ។

២. មកត្រឹមចុងឆ្នាំ ១៨៤៥ មានសមាជិកច្រើនជាង ១000 នាក់បានទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ។ នៅខែមករា ឆ្នាំ ១៨៤៦ ប្រធាន ព្រិកហាំ យ៉ង់ បានកត់ត្រាថា ៖ « ការណ៍បែបនោះបានបង្ហាញឲ្យឃើញថាពួកបរិសុទ្ធមានចិត្តអន្ទះសា ដើម្បីទទួលបានពិធីបរិសុទ្ធ [ នៃព្រះវិហារបរិសុទ្ធ ] ហើយមានចិត្តអន្ទះសាក្នុងចំណែករបស់យើង ដើម្បីបម្រើដល់ពួកគេ រហូតដល់ខ្ញុំបានលះបង់ខ្លួនខ្ញុំទាំងស្រុងចំពោះកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធទាំងយប់ទាំងថ្ងៃ ដោយចូលសម្រាកជាមធ្យមលើសពីបួនម៉ោងក្នុងមួយថ្ងៃទេ ហើយទៅផ្ទះតែម្ដងប៉ុណ្ណោះក្នុងមួយសប្ដាហ៍ » ( នៅក្នុង *History of the Church* ៧:៥៦៧ ) ។ បុរសស្ត្រីជាច្រើនរូប បានចូលរួមចំណែកដោយការបោកគក់សម្លៀកបំពាក់ព្រះវិហារបរិសុទ្ធរាល់យប់ ដើម្បីឲ្យកិច្ចការអាចបន្តមាននៅព្រឹកស្អែកឡើងដោយពុំមានការបង្អង់ឡើយ ។ ( សូមមើល *Church History in the Fulness of Times Student Manual Religion* ទំព័រ ៣០៣ ) ។

៣. នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ១៨៤៦ ប្រធាន យ៉ង់ បានចាកចេញពីព្រះវិហារបរិសុទ្ធ ដើម្បីលោកអាចត្រៀមខ្លួនចាកចេញពីទីក្រុង ណៅវូ នៅថ្ងៃបន្ទាប់ ។ ប៉ុន្តែនៅពេលលោកបានដើរចេញទៅខាងក្រៅ លោកបានឃើញមនុស្សមួយក្រុមធំ ដែលកំពុងតែរង់ចាំដើម្បីទទួលពិធីអំណោយទានពិសិដ្ឋរបស់ពួកគេ ។ ដោយមានអារម្មណ៍អាណិតអាសូរ ចំពោះបងប្អូនពួកបរិសុទ្ធទាំងនេះ លោកបានត្រឡប់ទៅក្នុងព្រះវិហារបរិសុទ្ធវិញ ដើម្បីបម្រើពួកគេ ។ លោកពុំអាចចាកចេញពីទីក្រុង ណៅវូ បានទេ រហូតដល់ពីរសប្ដាហ៍ក្រោយមក ។ កំណត់ត្រាព្រះវិហារបរិសុទ្ធបានបង្ហាញថាមានពួកបរិសុទ្ធចំនួន ៥៦១៥ នាក់ត្រូវបានទទួលអំណោយទានពិសិដ្ឋមុនពេលធ្វើដំណើរទៅទិសខាងលិច។ ( សូមមើល ទំព័រ ៣០៣–៤) ។

*លំហាត់សរសេរ*

លំហាត់សរសេរផ្ដល់ដល់សិស្សនូវឱកាសគិតពិចារណា ទទួលការបំផុសគំនិត រៀបចំដើម្បី បង្រៀន និង ចែកចាយអារម្មណ៍របស់ពួកគេជាមួយអ្នកដទៃ ទទួលស្គាល់ព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់គេ និង ថ្លែងទីបន្ទាល់ ។

- **តើអ្វីដែលពិតជាធ្វើឲ្យអ្នកចាប់អារម្មណ៍ អំពីកិច្ចខិតខំរបស់ពួកបរិសុទ្ធដើម្បីទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ?**

**ដើម្បីជួយសិស្សដឹងពីសេចក្ដីពិត និងសារៈសំខាន់នៃគោលការណ៍ទាំងឡាយ ដែលអ្នកបាន សរសេរនៅលើក្ដារខៀន និងដើម្បីជួយពួកគេអនុវត្តគោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ សូមអញ្ជើញពួកគេឲ្យឆ្លើយតបចំពោះសំណួរ**

ទាំងឡាយនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរ របស់ពួកគេ ។ ( សូមសរសេរសំណួរនៅលើក្ដារខៀន ) ។

> *តើការខំប្រឹងប្រែង និងពលិកម្មអ្វីខ្លះ ដែលយើងត្រូវធ្វើ ដើម្បីទទួលបានពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ?*
>
> *ហេតុអ្វីអ្នកគិតថា ការទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធគឺមានតម្លៃឲ្យខិតខំ និងធ្វើពលិកម្មយ៉ាងខ្លាំងដូច្នោះ ?*
>
> *តើអ្នកចាំបាច់ត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីអ្នកអាចទទួលបានពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ? ( តើអ្នកចាំបាច់ត្រូវឈប់ ឬចាប់ផ្ដើមធ្វើអ្វីខ្លះ ? )*

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ស្ម័គ្រចិត្តចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរទីពីរ ។

## ពួកបរិសុទ្ធចាកចេញពីទីក្រុងណៅវូ

សូមពន្យល់ថា បន្ទាប់ពីបានទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធហើយ ពួកបរិសុទ្ធបានចាប់ផ្ដើមចាកចេញពីទីក្រុង ណៅវូ នៅខែកុម្ភៈ ឆ្នាំ ១៨៤៦ ។ ប៉ុន្មានខែក្រោយមក ពួកគេបានបន្តចាកចេញពីទីក្រុង ណៅវូ ហើយមានក្រុមផ្សេង ៗជាច្រើន បានបោះជម្រកបណ្ដោះអាសន្ននៅពេលឆ្លងកាត់រដ្ឋ អៃអូវ៉ា ។ មកដល់ត្រឹមចុងខែមេសា ពួកបរិសុទ្ធភាគច្រើនបានចាកចេញពីទីក្រុង ណៅវូ ។ ទោះជាយ៉ាងណាក៏ដោយ ពុំមែនសមាជិកសាសនាចក្រទាំងអស់អាចចាកចេញទៅបានទេ ។ មានមនុស្សមួយចំនួនតូច បានបន្តនៅក្នុងទីក្រុង ណៅវូ អំឡុងរដូវក្ដៅឆ្នាំ ១៨៤៦ ដោយសារតែពួកគេឈឺធ្ងន់ពេក ក្រខ្លាំងពេក ឬខ្សោយខ្លាំងពេក ពុំអាចធ្វើដំណើរទៅបាន ។ មានមួយចំនួនតូចផ្សេងទៀត បានជ្រើសរើសនៅទីនោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮ ៗនូវកថាកណ្ឌដូចខាងក្រោម ដែលទាក់ទងនឹងអ្វីបានកើតឡើងចំពោះមនុស្សជាច្រើន ដែលមិនបានចាកចេញពីក្រុងនោះ ។

នៅខែកញ្ញា ឆ្នាំ ១៨៤៦ មានមនុស្សប្រហែលជា ៨០០ នាក់ បំពាក់ដោយកាំភ្លើងកាណុងធំប្រាំមួយ បានរៀបចំមកវាយប្រហារលើទីក្រុង ណៅវូ ។ ពួកបរិសុទ្ធដែលនៅសល់ និងពលរដ្ឋថ្មី ៗមួយចំនួន ដែលមានបុរសចំនួនប្រហែលជា ១៥០ នាក់ បានត្រៀមខ្លួនដើម្បីប្រយុទ្ធការពារទីក្រុង ។ បន្ទាប់ពីមានការប្រយុទ្ធគ្នាអស់រយៈពេលពីរបីថ្ងៃ នោះពួកបរិសុទ្ធជាច្រើនត្រូវបានបង្ខំឲ្យចុះចាញ់ ហើយត្រូវបានប្រាប់ថា ឲ្យចាកចេញពីទីក្រុងជាបន្ទាន់ ។ បន្ទាប់មក ពួកមនុស្សអាក្រក់ បានចូលមកក្នុងទីក្រុង ឆក់ប្លន់តាមផ្ទះ ហើយបានបំផ្លាញព្រះវិហារបរិសុទ្ធចោល ។ ពួកបរិសុទ្ធមួយចំនួនដែលពុំអាចភៀសខ្លួនបានលឿន ត្រូវបានគេវាយធ្វើបាប ឬបោះចូលទៅក្នុងទន្លេមីស៊ីស៊ីពី ។ បន្ទាប់ពីពួកបរិសុទ្ធដែលនៅសល់ទាំងនេះ ត្រូវបានគេបង្ខំឲ្យចេញពីទីក្រុង ណៅវូហើយ នោះពួកគេបានបោះជំរុំជនភៀសខ្លួន នៅតាមដងទន្លេរដ្ឋអៃអូវ៉ា ។ ពួកគេពុំមានអាហារ សម្ភារ ឬកម្លាំងខាងរាងកាយគ្រប់គ្រាន់ដើម្បីទ្រទ្រង់ខ្លួនទេ ។ ( សូមមើល *Church History in the Fulness of Times Student Manual Religion* ទំព័រ ៣១៨ ) ។

សូមពន្យល់ថា ពួកអ្នកដឹកនាំសាសនាចក្របានបញ្ជូនក្រុមជួយសង្គ្រោះឲ្យធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា ត្រឡប់មកជួយដល់ពួកបរិសុទ្ធដែលកំពុងរងទុក្ខ ។

- តើអ្នកគិតថា អ្នកអាចមានអារម្មណ៍យ៉ាងណា បើអ្នកត្រូវបានហៅឲ្យត្រឡប់ទៅកាន់ទីក្រុង ណៅវូ វិញនោះ ?

សូមអញ្ជើញសិស្សម្នាក់អានឮ ៗនូវសាររបស់ ព្រិកហំ យ៉ង់ បានបញ្ជូនទៅឲ្យបុរស ៗដែលគ្រប់គ្រងក្នុងការជ្រើសរើសក្រុមជួយសង្គ្រោះ ៖



« សូមឲ្យភ្លើងនៃសេចក្ដីសញ្ញា ដែលអ្នកបានធ្វើនៅក្នុងដំណាក់នៃព្រះអម្ចាស់ បានដុតរោលរាលក្នុងដួងចិត្តអ្នក ដូចជាអណ្ដាតភ្លើងដែលពុំអាចពន្លត់បាន រហូតដល់អ្នកបាន . . . ជួយដល់មនុស្សគ្រប់រូប. . . ដែល [ អាចចាកចេញមកបាន ] ហើយចែកភ្លើងនោះទៅដល់ព្រលឹងរបស់គាត់ រហូតដល់គាត់អាចក្រោកឡើង. . . ហើយចេញទៅភ្លាម ហើយនាំក្រុមមនុស្សក្រីក្រចេញពីទីក្រុង ណៅវូ ។. . .

« . . . នេះគឺជាជំនាន់នៃការធ្វើសកម្មភាព » ( Journal History of The Church of Jesus Christ of Latter–day Saints, ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ១៨៤៦, ទំព័រ ៥–៦, Church History Library, Salt Lake City ) ។

- តើសេចក្ដីថ្លែងការណ៍របស់ព្រិកហំ យ៉ង់ បង្រៀនយើងអំពីសេចក្ដីសញ្ញាដែលយើងបានធ្វើអ្វីខ្លះ ? ( សូមប្រាកដថា សិស្សយល់ថា វាពុំគ្រប់គ្រាន់ទេ ដោយគ្រាន់តែធ្វើសេចក្ដីសញ្ញានោះ– តែយើងចាំបាច់ត្រូវរក្សាសេចក្ដីសញ្ញាទាំងឡាយ ។ សូមសរសេរសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖**ព្រះអម្ចាស់តម្រូវឲ្យយើងរស់នៅតាមសេចក្ដីសញ្ញាទាំងឡាយដែលយើងធ្វើ** ) ។

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖

> *តើពលិកម្មអ្វីខ្លះដែលអ្នកបានធ្វើ ដើម្បីរក្សាសេចក្ដីសញ្ញាទាំងឡាយ ?*
>
> *តើពរជ័យអ្វីខ្លះដែលអ្នកបានដកបទពិសោធន៍ ដោយសារតែអ្នកបានរស់នៅស្របតាមសេចក្ដីសញ្ញាទាំងឡាយដែលអ្នកបានធ្វើនោះ ?*

សូមបំបែកសិស្សជាក្រុមៗ ហើយអញ្ជើញពួកគេឲ្យជ្រើសរើសសំណួរមួយនៃសំណួរទាំងឡាយ ហើយពិភាក្សាចម្លើយរបស់ពួកគេជាមួយនឹងដៃគូ ។ អ្នកអាចនឹងចង់អញ្ជើញឲ្យសិស្សពីរបីនាក់ ឲ្យចែកចាយការឆ្លើយតបរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ផងដែរ ។

សូមបញ្ចប់ដោយការសុំឲ្យសិស្សពិចារណាអំពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើដើម្បីរស់នៅតាមសេចក្ដីសញ្ញាទាំងឡាយដែលពួកគេបានធ្វើ ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យទាំងឡាយចំពោះការរក្សាសេចក្ដីសញ្ញារបស់យើង ។

# មេរៀនទី ១៤៨ ៖ ការធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨

## បុព្វកថា

នៅខែកុម្ភៈ ឆ្នាំ ១៨៤៦ ពួកបរិសុទ្ធបានចាប់ផ្ដើមចាកចេញពីទីក្រុងណៅវូ ហើយធ្វើដំណើរទៅ កាន់ទិសខាងលិចឆ្លងកាត់រដ្ឋ អៃអូវ៉ា ។ ព្រិកហាំ យ៉ង់ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦ នៅវិនទើរ ខ្វទើរ្ស រដ្ឋ នេប្រាស្កា នៅខែមករា ឆ្នាំ ១៨៤៧ ។ មេរៀននេះ ពិភាក្សាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨ ដែលរួមមាននូវការទូន្មានរបស់ព្រះអម្ចាស់ ដើម្បីជួយពួកបរិសុទ្ធរៀបចំខ្លួន ហើយត្រៀមខ្លួនដើម្បីបន្តការធ្វើដំណើរទៅកាន់ទិសខាងលិច ។

## យោបល់សម្រាប់ការបង្រៀន

### ពួកបរិសុទ្ធថ្ងៃចុងក្រោយ បានឆ្លងកាត់រដ្ឋ អៃអូវ៉ា ហើយបានបង្កើតទីស្នាក់ការកណ្ដាលនៅវិនទើរ ខ្វទើរ្ស

សូមចងកន្សែងបិទភ្នែកសិស្សម្នាក់ ហើយដាក់គាត់នៅម្ខាងនៃបន្ទប់រៀន ។ បន្ទាប់មកសូមរៀបចំរបស់របរមួយចំនួននៅក្នុងថ្នាក់ឡើងវិញ សូមធ្វើវាឲ្យឮសំឡេងដូច្នេះសិស្សអាចប្រាប់ថាតវ៉ាន់នោះត្រូវបានផ្លាស់ប្ដូរទីតាំង ។ សូមឲ្យសិស្សដែលត្រូវបានបិទមុខនោះជ្រើសរើសមិត្តរួមថ្នាក់ម្នាក់ឲ្យនិយាយប្រាប់ ដើម្បីជួយគាត់ដើរទៅដល់ជ្រុងម្ខាងទៀតនៃបន្ទប់ ។ នៅពេលសិស្សជ្រើសរើសនរណាម្នាក់ហើយនោះ សូមសួរ ៖

- ហេតុអ្វីអ្នកជ្រើសរើសបុគ្គលម្នាក់នោះ ?
- តើការទុកចិត្តរបស់យើងទៅលើមនុស្សម្នាក់ទៀត មានឥទ្ធិពលទៅលើរបៀបដែលយើងធ្វើតាមការណែនាំរបស់ពួកគេដោយយកចិត្តទុកដាក់យ៉ាងដូចម្ដេច?

សូមឲ្យអ្នកប្រាប់ផ្លូវនោះផ្ដល់ទិសដៅនានា ដើម្បីឲ្យសិស្សដែលមានកន្សែងចងបិទភ្នែកនោះ នឹងអាចដើរដោយសុវត្ថិភាពទៅកាន់ផ្នែកម្ខាងទៀតនៃថ្នាក់រៀន ។ ក្រោយមកសូមបង្គាប់សិស្សទាំងពីរនោះឲ្យត្រឡប់ទៅអង្គុយវិញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោម អំពីការធ្វើដំណើររបស់ពួកបរិសុទ្ធចេញពីទីក្រុងណៅវូ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់អំពីរបៀបនានានៃបទពិសោធន៍របស់ពួកបរិសុទ្ធអាចមាន ដែលស្រដៀងនឹងបទពិសោធន៍នៃសិស្សដែលត្រូវបានដឹកនាំឲ្យដើរឆ្លងក្នុងបន្ទប់រៀននោះ ។

ក្រោមការគម្រាមកំហែងដ៏សាហាវព្រៃផ្សៃមកពីពួកជនកំណាចក្នុងមូលដ្ឋាន នោះពួកបរិសុទ្ធបានចាប់ផ្ដើមចាកចេញពីទីក្រុងណៅវូ នៅខែ កុម្ភៈ ឆ្នាំ ១៨៤៦ ធ្វើដំណើរទៅទិសខាងលិចដោយឆ្លងកាត់រដ្ឋអៃអូវ៉ា ។ « ការចាកចេញពីទីក្រុងណៅវូគឺជា ទង្វើមួយនៃសេចក្ដីជំនឿរបស់ពួកបរិសុទ្ធ ។ ពួកគេបានចាកចេញទៅដោយពុំដឹងពីទីកន្លែងពិតប្រាកដថានឹងទៅទីណា ឬ នៅពេលណាពួកគេនឹងទៅដល់កន្លែងមួយដែលពួកគេអាចបោះទីតាំងរស់នៅបានឡើយ ។ ពួកគេគ្រាន់តែដឹងថាពួកគេត្រូវបានបណ្ដេញចេញពីរដ្ឋអិលលីណោយ ដោយសារមារសត្រូវរបស់ខ្លួន ហើយថាថ្នាក់ដឹកនាំរបស់ពួកគេបានទទួលវិវរណៈដើម្បីបោះទីតាំងនៃជនភាសខ្លួននៅកន្លែងមួយនៅក្នុងតំបន់ រ៉ុកគី ម៉ោនធីន » (*Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទី ២ [ Church Educational System manual ឆ្នាំ ២០០៣ ] ទំព័រ ៣០៩ ) ។

- តើបទពិសោធន៍របស់ពួកបរិសុទ្ធក្នុងការចាកចេញពីទីក្រុងណៅវូ ស្រដៀងគ្នាទៅនឹងបទពិសោធន៍របស់សិស្ស ដែលត្រូវបាននាំដើរកាត់បន្ទប់រៀនយ៉ាងដូចម្ដេច ? ( បទពិសោធន៍ទាំងពីរ បានពឹងផ្អែកទៅលើចក្ខុវិស័យ និងការដឹកនាំរបស់មនុស្សម្នាក់ ដែលពួកគេទុកចិត្តឲ្យជួយពួកគេទៅដល់ទិសដៅរបស់ពួកគេ ) ។

- តើយើងអាចរៀនអ្វីខ្លះមកពីបទពិសោធន៍របស់ពួកបរិសុទ្ធអំពីការចាកចេញពីទីក្រុងណៅវូ ? ( សិស្សអាចនឹងប្រើពាក្យសម្ដីផ្សេង ប៉ុន្តែពួកគេគប្បីបង្ហាញនូវគោលការណ៍ដូចខាងក្រោម ៖ **យើងអនុវត្តសេចក្ដីជំនឿរបស់យើង នៅពេលយើងធ្វើតាមការទូន្មាន និងការដឹកនាំរបស់ពួកអ្នកដឹកនាំសាសនាចក្ររបស់យើង** )។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោមអំពី វីល្លាម ក្លេតុន ។ សូមឲ្យសិស្សស្ដាប់រកមើលគំរូនៃសេចក្ដីជំនឿរបស់បងប្រុសក្លេតុន ។

> « វីល្លាម ក្លេតុន ត្រូវបានហៅឲ្យនៅក្នុងក្រុមទីមួយដើម្បីចាកចេញពីទីក្រុងណៅវូ ហើយទុកចោលភរិយារបស់គាត់ ឌីអាន់ថា ឲ្យនៅនឹងឪពុកម្ដាយរបស់គាត់ រយៈពេលតែមួយខែមុនពេលគាត់សម្រាលកូនដំបូងរបស់គាត់ប៉ុណ្ណោះ ។ ការធ្វើដំណើរឆ្លងកាត់ដីល្បាប់ និងបោះជំរុំនៅក្នុងត្រសាលត្រជាក់ បានធ្វើឲ្យគាត់ព្រួយបារម្ភ និងមានការមួរម៉ៅ ដោយសារគាត់បារម្ភអំពីសុខុមាលភាពរបស់ឌីអាន់ថា ។ រយៈពេលពីរខែក្រោយមក គាត់នៅតែពុំបានដឹង បើសិនថានាងបានសម្រាល [កូន] ដោយសុវត្ថិភាព ឬអត់ ប៉ុន្តែនៅទីបំផុត គាត់បានទទួលពាក្យប្រកបដោយអំណរថា ‹ កូនប្រុសដ៏ត្រលុកត្រលន់ › បានកើតមកហើយ ។ រំពេចដែលគាត់បានឮដំណឹងនោះភ្លាម វីល្លាមបានអង្គុយចុះ ហើយបាននិពន្ធបទចម្រៀងមួយបទ ដែលពុំគ្រាន់តែមានអត្ថន័យពិសេសចំពោះគាត់តែប៉ុណ្ណោះទេ ប៉ុន្តែវាក្លាយទៅជាភ្លេងជាតិដ៏បំផុសគំនិត ហើយប្រកបដោយការដឹងគុណដល់សមាជិកនៃសាសនាចក្រជាច្រើនតំណរ ។ ចម្រៀងនោះមានចំណងជើងថា ‹ មក មក ពួកបរិសុទ្ធ ›» (*Our Heritage: A Brief History of The Church of Jesus Christ of Latter–day Saints* [ ឆ្នាំ ១៩៩៦ ], ទំព័រ ៧១) ។

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យច្រៀងបទជាមួយគ្នានៅវគ្គបីដំបូងនៃបទ « មក មក ពួកបរិសុទ្ធ » (*ទំនុកតម្កើង* ទំព័រ ១៨ ) ។ ( ឬទាក់ទងនឹងសិស្សម្នាក់ ឬសិស្សមួយក្រុមជាមុន ហើយអញ្ជើញពួកគេឲ្យត្រៀមខ្លួនដើម្បីច្រៀងវគ្គបីដំបូងនៃទំនុកតម្កើងនេះ ) ។ មុនពេលទំនុកតម្កើងត្រូវបានច្រៀង សូមសិស្សឲ្យរកមើល ឬស្ដាប់ឃ្លាទាំងឡាយដែលបង្ហាញពីជំនឿរបស់ពួកបរិសុទ្ធទៅលើព្រះយេស៊ូវគ្រីស្ទ ហើយនឹងទំនុកចិត្តទៅលើពួកអ្នកដឹកនាំរបស់ពួកគេ ។

***តន្ត្រីពិសិដ្ឋ***

តន្ត្រីពិសិដ្ឋ ជាពិសេសទំនុកតម្កើងរបស់សាសនាចក្រ អាចដើរតួយ៉ាងសំខាន់មួយ នៅក្នុងការជួយដល់សិស្សឲ្យទទួលអារម្មណ៍ដឹងអំពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ និងរៀនគោលលទ្ធិដំណឹងល្អ ។

បន្ទាប់ពីវគ្គបីដំបូងត្រូវបានច្រៀង សូមសួរថា ៖

- តើទំនុកតម្កើងនេះបង្ហាញពីសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងទំនុកចិត្តទៅលើពួកអ្នកដឹកនាំរបស់ពួកគេយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗអំពីដំណើររឿងដូចខាងក្រោមរបស់ អូរសុន ប្រាត្ត និង ខាធើរិន ស្ពែនសើរ ។ សូមឲ្យសិស្សស្ដាប់រកមើលគំរូនៃសេចក្ដីជំនឿ និងទំនុកចិត្តរបស់ស្ពែនសើរ ។

> « បន្ទាប់ពីចាកចេញពីទីក្រុងណៅវូ [ខាធើរិន] ទន់ខ្សោយ ហើយបានធ្លាក់ខ្លួនឈឺ ដោយសារតែទុក្ខលំបាកជាច្រើនដែលនាងបានជួបប្រទះ ។ ស្វាមីដ៏ប្រកបដោយទុក្ខព្រួយ បានសរសេរសំបុត្រអង្វរករដល់ឪពុកម្ដាយរបស់ភរិយា សុំឲ្យពួកគាត់ទទួលនាងទៅនៅនឹងពួកគាត់ ទម្រាំតែពួកបរិសុទ្ធរកបានកន្លែងនឹងនរមួយ ។ ចម្លើយបានតបមកថា ‹ សូមឲ្យនាងបោះបង់ចោលជំនឿដ៏គួរខ្មាស់អៀនរបស់នាងនោះចោលទៅ ទើបនាងអាចត្រឡប់មកនៅជាមួយយើងវិញ បើមិនដូច្នោះទេ នាងពុំអាចមកវិញឡើយ › ។
>
> « នៅពេលសំបុត្រត្រូវបានអានឲ្យនាងស្ដាប់ នោះនាងបានសុំឲ្យស្វាមីនាងបើកព្រះគម្ពីរប៊ីបរបស់គាត់ទៅគម្ពីរនាងរស់ ហើយអានជំពូកទីមួយ ខទីដប់ប្រាំមួយ និងដប់ប្រាំពីរ ៖ ‹ សូមកុំទទូចឲ្យខ្ញុំទៅចោលអ្នកម្ដាយនឹងវិលទៅវិញ លែងតាមអ្នកម្ដាយនោះឡើយ ដ្បិតកន្លែងណាដែលអ្នកម្ដាយអញ្ជើញទៅ នោះខ្ញុំនឹងទៅតាម ហើយកន្លែងដែលអ្នកម្ដាយស្នាក់នៅ នោះខ្ញុំក៏នឹងទៅដែរ ។ សាសន៍របស់អ្នកម្ដាយនឹងបានជាសាសន៍របស់ខ្ញុំ ហើយព្រះរបស់អ្នកម្ដាយ នឹងបានជាព្រះរបស់ខ្ញុំដែរ › » ( *Memoirs of John R. Young: Utah Pioneer ១៨៤៧* [ ឆ្នាំ ១៩២០ ] ទំព័រ ១៧–១៨ ) ។ ខាធើរិន ស្ពែនសើរ បានស្លាប់នៅមិនយូរប៉ុន្មានក្រោយមក ។

សូមអញ្ជើញសិស្សឲ្យច្រៀងវគ្គទីបួននៃបទ « មក មក ពួកបរិសុទ្ធ » ។ សូមឲ្យពួកគេគិតអំពីរបៀបដែលពាក្យពេចន៍ទាំងនោះនៅក្នុងវគ្គនេះ ទាក់ទងនឹងខាធើរិន ស្ពែនសើរ ។ បន្ទាប់ពីពួកគេបានច្រៀងវគ្គនេះរួចហើយ សូមសួរថា ៖

- តើពាក្យនៃវគ្គនេះ ទាក់ទងនឹងខាធើរិន ស្ពែនសើរ យ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយដើម្បីអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយធ្វើតាមដំបូន្មាន និងការដឹកនាំរបស់ពួកអ្នកដឹកនាំសាសនាចក្ររបស់ពួកគេកាន់តែល្អប្រសើរ ។

សូមអញ្ជើញសិស្សឲ្យបើកទៅផែនទី ទី ៦ (« ដំណើរនៃសាសនាចក្រទៅទិសខាងលិច ») នៅក្នុងវគ្គផែនទីប្រវត្តិសាស្ត្រសាសនាចក្រនៃព្រះគម្ពីររបស់ពួកគេ ហើយរកមើលទីក្រុង ណៅវូ និង វិនទើរ ខ្វរទើរ្ស ។ សូមពន្យល់ថា ដោយសារតែភ្លៀងធ្លាក់យ៉ាងខ្លាំង និងការផ្គត់ផ្គង់មិនគ្រប់គ្រាន់ នោះពួកបរិសុទ្ធដែលបានចាកចេញពីទីក្រុងណៅវូនៅខែ កុម្ភៈ ឆ្នាំ ១៨៤៦ បានចំណាយពេលបួនខែធ្វើដំណើរឆ្លងកាត់រដ្ឋអៃអូវ៉ាចម្ងាយ ៤៨០គីឡូម៉ែត្រ ។ ល្បឿននៃការធ្វើដំណើររបស់ក្រុមនេះមានការយឺតយ៉ាវ ដោយសារតែលក្ខខណ្ឌទាំងនេះ និង ដោយសារពួកគេបានបាត់បង់ការបម្រើពីបុរស ៗនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជាង ៥០០ នាក់ ។ បុរសទាំងនេះ ដែលបានស្គាល់ថាជាកងវរសេនាតូចមរមន បានស្ដាប់តាមការអំពាវនាវរបស់ប្រធាន យ៉ង់ ឲ្យចូលបម្រើកងទ័ពសហរដ្ឋ ដើម្បីរកប្រាក់ជួយដល់សមាជិកសាសនាចក្រដែលក្រីក្រឲ្យធ្វើដំណើរទៅទិសខាងលិច ។ ការបូជានេះបានជួយយ៉ាងច្រើន ប៉ុន្តែវាក៏បានបន្សល់ទុកនូវក្រុមគ្រួសារជាច្រើនឲ្យគ្មានស្វាមី និង ឪពុកក្នុងការធ្វើដំណើរជាមួយពួកគេផងដែរ ។ ដោយគិតពីការធ្វើដំណើរយ៉ាងយឺតនោះ អ្នកដឹកនាំសាសនាចក្របានសម្រេចចិត្តមិនបន្តដំណើរទៅភាគខាងលិចនៃភ្នំរ៉ុកគី ម៉ោនធីនឡើយរហូតដល់រដូវផ្ការីកឆ្នាំ ១៨៤៧ ។ ពួកលោកបានទូន្មានដល់ពួកបរិសុទ្ធ ឲ្យបោះទីលំនៅសម្រាកសម្រាប់រដូវរងានោះ ។ ការបោះទីលំនៅដ៏ធំបំផុតមួយ ត្រូវបានធ្វើឡើងនៅវិនធើរ ខ្វតធើរនៅភាគខាងលិចនៃដងទន្លេមិសសួរី ដែលបច្ចុប្បន្ននេះគឺជារដ្ឋណេប្រាស្កា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីសង្ខេបខាងក្រោមដែលពិពណ៌នាអំពីវិនធើរ ខ្វតធើរ និង ការបោះទីលំនៅបណ្ដោះអាសន្នផ្សេង ៗទៀត ៖

ពួកបរិសុទ្ធជាច្រើនបានរស់នៅក្នុងផ្ទះដាច់ ៗពីគ្នា និង នៅក្នុងខ្ទមដែលធ្វើពីឈើ និង ដី ។ មានមនុស្សជាច្រើនដែលខ្វះជម្រកជ្រកពីអាកាសធាតុត្រជាក់នេះ ។ ជម្ងឺដូចជា គ្រុនចាញ់ ជម្ងឺលាកសួត ជម្ងឺរបេង អាសន្នរោគ និងជំងឺកង្វះវីតាមីនសេ៊ ដែលជាលទ្ធផលនាំឲ្យមានការឆ្លងរាលដាល និងបណ្ដាលឲ្យស្លាប់ ។ មានមនុស្សច្រើនជាងប្រាំពីររយនាក់បានស្លាប់ នៅក្នុងការបោះជំរុំនៅចុងបញ្ចប់នៃរដូវត្រជាក់ទីមួយ ។ ( សូមមើល *គេហដំណែលរបស់យើង* ៧១–៧២; ៣១៩–២០) ។

- បើអ្នកបាននៅជាមួយនឹងពួកបរិសុទ្ធនៅ វិនទើរ ខ្វរទើរ្ស តើអ្នកមានអារម្មណ៍យ៉ាងណា ពេលដឹងថាអ្នកនឹងត្រូវធ្វើដំណើររាប់រយម៉ែលបន្តទៅទៀតនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨

*ព្រះអម្ចាស់បានប្រឹក្សាឲ្យពួកបរិសុទ្ធរៀបចំខ្លួនគេ ហើយត្រៀមខ្លួនដើម្បីបន្តការធ្វើដំណើរទៅកាន់ទិសខាងលិច*

សូមសុំសិស្សឲ្យស្រាវជ្រាវនៅក្នុងសេចក្ដីណែនាំកណ្ឌ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦ រកមើលកាលបរិច្ឆេទដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១ ឲ្យឮ ៗ ។

- តើអ្នកគិតថាវាអាចនឹងជួយដល់ពួកបរិសុទ្ធយ៉ាងដូចម្ដេច ពេលដឹងថា ព្រះអម្ចាស់បានបន្តបើកសម្ដែងពីព្រះទ័យរបស់ទ្រង់ចំពោះពួកគេនោះ ? ( ចម្លើយអាចរួមមានថា វិវរណៈនេះ បានជួយពួកគេដឹងថា ព្រះអម្ចាស់បានដឹងអំពីពួកគេ ថាទ្រង់នឹងជួយពួកគេបន្តដំណើរទៅទិសខាងលិច ហើយថាទ្រង់មានបន្ទូលតាមរយៈប្រធាន ព្រិកហាំ យ៉ង់ ដូចជាទ្រង់បានមានបន្ទូលតាមរយៈ ព្យាការីយ៉ូសែប ស៊្មីធ ) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានឲ្យឮ ៗនូវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:២–៥ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធធ្វើ ដើម្បីរៀបចំបន្តការធ្វើដំណើរទៅភាគខាងលិចរបស់ពួកគេ ។

- តើក្រុមនិមួយ ៗត្រូវបានរៀបចំយ៉ាងដូចម្ដេច ?

- ហេតុអ្វីអ្នកគិតថា វាមានប្រយោជន៍ដើម្បីរៀបចំពួកបរិសុទ្ធជាក្រុម ៗជាមួយនឹងអ្នកដឹកនាំដែលបានជ្រើសតាំងដូច្នេះ ? តើការណ៍នេះស្រដៀងគ្នាទៅនឹង របៀបដែលសាសនាចក្រត្រូវបានរៀបចំឡើងនៅសព្វថ្ងៃយ៉ាងដូចម្ដេច ? ( នៅពេលសិស្សឆ្លើយតបចំពោះសំណួរទាំងនេះ អ្នកអាចនឹងចង់សរសេរសេចក្ដីពិតដូចតទៅនេះនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់រៀបចំពួកបរិសុទ្ធរបស់ទ្រង់ទៅជាក្រុម ៗ ដើម្បីឲ្យបុគ្គលម្នាក់ ៗអាចត្រូវបានដឹកនាំ និងត្រូវបានយកចិត្តទុកដាក់ថែទាំ** ) ។

- តើ ខ ៤ ផ្ដល់យោបល់អំពីរបៀបដែលពួកបរិសុទ្ធនឹងទទួលបានកម្លាំងយ៉ាងដូចម្ដេចខ្លះ ?

សូមពន្យល់ថា ដោយសារតែជម្ងឺ និងការស្លាប់នៅ វិនទើរ ខ្វរទើរ្ស និងជំរុំដែលនៅជុំវិញ នោះមានក្រុមគ្រួសារជាច្រើន និងបុគ្គលម្នាក់ ៗជាច្រើនរូបត្រូវការជំនួយខាងហិរញ្ញវត្ថុ ដើម្បីពួកគេអាចបន្តដំណើរទៅទិសខាងលិចបាន ។

សូមចែកសិស្សជាគូៗ ។ សូមពួកគេឲ្យសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៦–១១ រកមើលជាមួយគ្នានូវរបៀបដែលពួកបរិសុទ្ធត្រូវបានមើលថែដល់អ្នកទាំងឡាយដែលខ្វះខាត ។ ពីមុនសិស្សអានវគ្គនេះ សូមពន្យល់ថា ពុំមែនពួកបរិសុទ្ធទាំងអស់បានចាកចេញពី វិនទើរ ខ្វរទើរ្ស នៅក្នុងពេលតែមួយទេ ។ ឃ្លា « អស់អ្នកដែលត្រូវនៅ » នៅក្នុង ខ ៦ សំដៅលើពួកបរិសុទ្ធដែលបន្តនៅមួយរយៈពេលទៀតនៅវិនធើរ ខ្វតធើរ និង ជុំវិញនោះ ។

- តើពាក្យ ឬឃ្លាណាខ្លះនៅក្នុង ខ ៦–១១ ដែលបង្ហាញពីរបៀបដែលពួកបរិសុទ្ធត្រូវមើលថែទាំដល់អស់អ្នកដែលខ្វះខាតនោះ ?
- តើមានពាក្យអ្វីនៅក្នុង ខ ៧ ដែលសំដៅទៅលើមនុស្សដែលរៀបចំផ្លូវសម្រាប់មនុស្សដទៃនោះ ? ( ពួកអ្នកត្រួសត្រាយ ) ។

សូមសរសេរ និយមន័យខាងក្រោមនេះ នៅលើក្ដារខៀន ។ ( វាត្រូវបានដកស្រង់ចេញពី *Oxford English Dictionary,* ការបោះពុម្ពលើកទីពីរ [ ឆ្នាំ ១៩៨៩ ] « pioneer » ) ។

> *អ្នកត្រួសត្រាយ ៖ មនុស្សដែលដើរទៅមុន ដើម្បីរៀបចំ ឬ បើកផ្លូវសម្រាប់មនុស្សដទៃទៀតឲ្យដើរតាម ។*

- យោងតាម ខ ១១, តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់អស់អ្នកដែលនឹងជួយមនុស្សដទៃដែលខ្វះខាត និង រៀបចំផ្លូវសម្រាប់ពួកគេ ? តើយើងអាចរៀនអ្វីចេញពីការណ៍នេះ ? ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់នឹងប្រទានពរដល់យើង នៅពេលយើងជួយដល់អ្នកដទៃ និងរៀបចំផ្លូវសម្រាប់ពួកគេ** ) ។

សូមអញ្ជើញសិស្សឲ្យពិភាក្សាសំណួរដូចខាងក្រោមជាមួយនឹងដៃគូពួកគេ ៖

- តើនរណាបានរៀបចំផ្លូវសម្រាប់អ្នក ដើម្បីឲ្យអ្នកបានរីករាយនឹងពរជ័យនៃដំណឹងល្អ ?

សូមឲ្យសិស្សពិចារណាពីសំណួរខាងក្រោម ។ បន្ទាប់មកសូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

- តើអ្នកនឹងធ្វើអ្វីខ្លះ ដើម្បីក្លាយជាអ្នកត្រួសត្រាយ–ដើម្បីជួយអ្នកដទៃដែលខ្វះខាត ហើយរៀបចំផ្លូវសម្រាប់ពួកគេដើម្បីឲ្យពួកគេបានរីករាយនឹងពរជ័យទាំងឡាយនៃដំណឹងល្អ ?

សូមសង្ខេប គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១២–១៨ ដោយពន្យល់ថា ព្រះអម្ចាស់បានបញ្ជាដល់ពួកអ្នកបម្រើរបស់ទ្រង់ឲ្យបង្រៀនវិវរណៈនេះដល់ពួកបរិសុទ្ធ ។

សូមបញ្ចប់ ដោយការថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សា ហើយលើកទឹកចិត្តសិស្សឲ្យធ្វើតាមសេចក្ដីពិតទាំងនោះ។

មេរៀនទី ១៤៩

# គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៦:១៩–៤២

## បុព្វកថា

នៅខែមករា ឆ្នាំ ១៨៤៧ ព្រិកហាំ យ៉ង់ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦ នៅវិនទើរ ខ្វរទើរ្ស រដ្ឋ នេប្រាស្កា ។ មេរៀននេះ ពិភាក្សាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២ ដែលរួមមានទាំង ការដឹកនាំរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធអំពីរបៀបដើម្បីធ្វើការរួមគ្នា ហើយទទួលបានកិច្ចការពាររបស់ទ្រង់នៅក្នុងការធ្វើដំណើររបស់ពួកគេទៅទិសខាងលិច ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–២៩

*ព្រះអម្ចាស់ដឹកនាំពួកបរិសុទ្ធអំពីរបៀបដើម្បីធ្វើកិច្ចការនៅក្នុងការធ្វើដំណើររបស់ពួកគេ*

សូមចាប់ផ្ដើមមេរៀនដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើឱកាសអ្វីខ្លះដែលអ្នកមានដើម្បីប្រាស្រ័យទាក់ទងនឹងមនុស្សដទៃនៅក្នុងក្រុមមួយ ? ( ចម្លើយអាចរួមមាន ក្រុមគ្រួសារ កូរ៉ុមបព្វជិតភាព និង ថ្នាក់យុវនារី ក្រុមកីឡា មិត្តនៅសាលារៀន និងក្រុមការងារ ) ។
- តើទិដ្ឋភាពវិជ្ជមានមួយចំនួននៃការធ្វើការជាមួយអ្នកដទៃនៅក្នុងក្រុមមួយមានអ្វីខ្លះ ?

សូមពន្យល់ថា នៅពេលពួកបរិសុទ្ធត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងណៅវូ នៅដើមឆ្នាំ ១៨៤៦ ហើយបានចាប់ផ្ដើមធ្វើដំណើរទៅទិសខាងលិច នោះមានមនុស្សជាច្រើនពុំបានត្រៀមខ្លួនដើម្បីធ្វើដំណើរទេ ។ ពួកបរិសុទ្ធដំបូងគេ បានចេញទៅដោយបែកខ្ញែកគ្នាជាច្រើនគីឡូម៉ែត្រ ដែលធ្វើឲ្យពួកគេពុំអាចជួយគ្នាទៅវិញទៅមក ។ នៅក្នុងវិវរណៈមួយ ព្រិកហាំ យ៉ង់ បានទទួលនៅវិនទើរ ខ្វរទើរ្ស រ ប្រហែលជាមួយឆ្នាំក្រោយមក ព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធរៀបចំខ្លួនដើម្បីពួកគេអាចជួយគ្នាទៅវិញទៅមក នៅពេលពួកគេបានបន្តការធ្វើដំណើរ ។

សូមអញ្ជើញសិស្សឲ្យរំឭកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:២, ៨–១០ ដោយស្ងាត់ស្ងៀម ហើយរាយការណ៍អំពីរបៀបដែលព្រះអម្ចាស់បានណែនាំដល់ពួកបរិសុទ្ធឲ្យជួយគ្នាទៅវិញទៅមក ។

សូមចង្អុលបង្ហាញថា ថ្វីដ្បិតតែការធ្វើការជាក្រុមអនុញ្ញាតឲ្យយើងជួយគ្នាទៅវិញទៅមកក្ដី ក៏វាអាចបង្កើតជាបញ្ហាច្រើនផងដែរ ។

- នៅក្នុងបទពិសោធន៍របស់អ្នក តើឧបសគ្គមួយចំនួនមកពីការធ្វើការជាក្រុមមានអ្វីខ្លះ ?

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញដៃគូនិមួយៗឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–២៧ ឲ្យឮៗ ។ សូមឲ្យពួកគេរកមើលការដឹកនាំរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធ នៅពេលពួកគេបានធ្វើដំណើរ និងធ្វើការរួមគ្នា ។ បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយនោះ សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកមើលឃើញថា មានការដឹកនាំអ្វីខ្លះដែលនឹងជួយដល់ពួកបរិសុទ្ធធ្វើដំណើរ និងធ្វើការរួមគ្នា ? តើអ្នកគិតថា ហេតុអ្វីបានជាការដឹកនាំនេះ អាចចាំបាច់ ?
- តើអ្នកអាចយកការដឹកនាំនេះមកអនុវត្ត នៅពេលអ្នកប្រាស្រ័យទាក់ទង និងធ្វើការជាមួយមនុស្សដទៃតាមរបៀបណា ?
- តើមានលទ្ធផលអ្វីខ្លះ នៅពេលមនុស្សមិនគោរពតាមដំបូន្មាននេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:២៣–២៤ ឲ្យឮៗ ។ សូមសួរសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពីមូលហេតុដែលព្រះអម្ចាស់បានដឹកនាំពួកបរិសុទ្ធឲ្យ « ឈប់ការផឹកប្រមឹក »

***សូមសម្របសម្រួលមេរៀននេះទៅតាមតម្រូវការរបស់សិស្ស***

នៅពេលសិស្សរីកចម្រើននៅក្នុងវគ្គសិក្សាថ្នាក់សិក្ខាសាលា សូមព្យាយាមរៀនអំពីភាពខ្លាំង ការលំបាក និង សេចក្ដីត្រូវការរបស់ពួកគេ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងជួយអ្នកឲ្យសម្របសម្រួលមេរៀននិមួយៗទៅតាមតម្រូវការរបស់ពួកគេ ។ នៅពេលអ្នកបង្រៀនមេរៀននេះ សូមពិភាក្សាអំពីដំបូន្មានរបស់ព្រះអម្ចាស់មកពីវគ្គបទគម្ពីរ ដែលអ្នកមានអារម្មណ៍ ដើម្បីជួយដល់សិស្សរបស់អ្នកឲ្យបានល្អបំផុត ។

ទោះជាពួកគេបានទទួលពាក្យសម្ដីនៃប្រាជ្ញាវាងវៃហើយក្ដីនោះ ។ សូមរំឭកពួកគេថា ពួកបរិសុទ្ធបានរីកចម្រើនបន្ដិចម្ដងៗ នៅក្នុងការគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃរបស់ពួកគេ ។ នៅពេលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦ ត្រូវបានប្រទានឲ្យ ពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានហាមឃាត់ពីការប្រើគ្រឿងស្រវឹងទាំងអស់ ដូចជាយើងនៅសព្វថ្ងៃនេះដែរ ។

- ស្របតាម ខ ២៤ តើពាក្យសម្ដីរបស់យើងនឹងធ្វើយ៉ាងណាចំពោះអ្នកទាំងឡាយដែលនៅជុំវិញយើង ? ( សិស្សគួរស្គាល់នូវសេចក្ដីពិតដូចខាងក្រោម ៖ **ពាក្យសម្ដីរបស់យើងគួរស្អាងគ្នាទៅវិញទៅមក ។** អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ដើម្បីស្អាងគ្នា មានន័យថា ស្ថាបនានរណាម្នាក់ឡើងខាងវិញ្ញាណ ឬខាងសតិអារម្មណ៍ ) ។
- ហេតុអ្វីអ្នកគិតថា វាសំខាន់សម្រាប់ពួកបរិសុទ្ធដើម្បីប្រើពាក្យស្អាងគ្នា នៅពេលពួកគេធ្វើដំណើរជាមួយគ្នានោះ ?
- តើអ្នកធ្លាប់ឃើញនរណាម្នាក់ប្រើពាក្យដែលស្អាងដល់មនុស្សដទៃនៅពេលណា ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេអាចនិយាយថា នឹងស្អាងដល់អ្នកទាំងឡាយដែលនៅជុំវិញពួកគេ ។

សូមអញ្ជើញសិស្សពីរនាក់អានឆ្លាស់គ្នានូវដំណើររឿងបទពិសោធន៍របស់ពួកបរិសុទ្ធក្នុងការធ្វើដំណើររបស់ពួកគេឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់គិតអំពីអត្តចរិតរបស់ពួកបរិសុទ្ធស្មោះត្រង់ទាំងឡាយ ។

ម៉ារី អាណេ វេស្តុន មូហាន បានសរសេរថា ៖

> « យើងត្រូវបានហៅឲ្យបញ្ចុះសពមនុស្សពីរនាក់នៃក្រុមយើង ដែលបានស្លាប់នៅព្រឹកនេះដោយសារតែជំងឺអាសន្នរោគ ដែលជាបុរសម្នាក់ឈ្មោះ ប្រោណ និងកុមារតូចម្នាក់ ។ មានមនុស្សឈឺច្រើនទៀតនៅក្នុងក្រុម ។ ដោយបានទៅដល់ ទន្លេប្លាត ពេញមួយថ្ងៃ ។ បានធ្វើដំណើរ ២៤ គីឡូម៉ែត្រ បានបោះជំរុំនៅ សលត៍ ក្រិក ។ មិនយូរប៉ុន្មាន ក្មេងម្នាក់ទៀតក្នុងជំរុំយើងបានស្លាប់ ។ ពួកគេបានបញ្ចុះសពនៅពេលថ្ងៃលិច តាមច្រាំងទន្លេក្រិក ។ មានមនុស្សច្រើនទៀតឈឺ ។ វាធ្វើឲ្យយើងមានអារម្មណ៍សោកសៅដែលត្រូវបញ្ចុះសពមិត្តរបស់យើងនៅតាមផ្លូវ ។ អាកាសធាតុក្ដៅខ្លាំង » (Mary Ann Weston Maughan journal, វ៉ុលទី ៣., ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៨៥០, ២:១, Family History Library, Salt Lake City; spelling, capitalization, and punctuation modernized ) ។

ក្លារីសា យ៉ង់ ស្ពែនសើរ ( កូនស្រីរបស់ ព្រិកហាំ យ៉ង់ ) បានសរសេរថា ៖

> « គុណសម្បត្តិល្អបំផុតរបស់លោកឪពុកក្នុងនាមជាអ្នកដឹកនាំម្នាក់គឺជាឥរិយាបទដែលលោកបានមើលថែដល់សុខុមាលភាពរបស់ប្រជាជនលោកទាំងខាងសាច់ឈាម និងខាងសង្គម ព្រមទាំងដឹកនាំពួកគេនៅក្នុងសេចក្ដីត្រូវការខាងវិញ្ញាណរបស់ពួកគេផងដែរ ។ នៅក្នុងការធ្វើដំណើរដ៏ខ្លាំងឆ្លងកាត់ទីវាលទំនាប ពេលដែលមនុស្សគ្រប់គ្នាដើរដោយទន់ល្វើយក្នុងផ្លូវដ៏វែងឆ្ងាយ ពួកបរិសុទ្ធនឹងជួបជុំគ្នាជុំគុក្កភ្លើង ដើម្បីកំសាន្តនៅពេលល្ងាច បើសិនជាអាកាសធាតុមានសភាពល្អនោះ ។ មានចម្រៀងនឹងច្រៀងឡើង តន្ត្រីប្រគុំដោយអ្នកលេងវីយូឡុង ហើយបុរសស្ត្រីទាំងឡាយនឹងបំភ្លេចនូវភាពនឿយហត់ក្នុងការដើរអស់ចម្ងាយ ២៤ គីឡូម៉ែត្រជាដើមនៅលើវាលខ្សាច់ល្អរល្វេវ ខណៈដែលពួកគេចូលរួមនៅក្នុងការរាំជារង្វង់ ។ នេះជារបៀបរបស់លោកក្នុង ‹សីលធម៌› មុនពេលនឹងមានពាក្យមួយត្រូវបានប្រើ » ( ជាមួយ Mabel Harmer *One Who Was Valiant* [ ឆ្នាំ ១៩៤០] ទំព័រ ១៦២ ) ។

- ផ្អែកទៅលើដំណើររឿងទាំងនេះ តើអ្នកនឹងពិពណ៌នាអំពីអ្នកត្រួសត្រាយដ៏ស្មោះត្រង់ទាំងនេះយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:២៨–២៩ ឲ្យឮៗ ។

សូមសួរសិស្សអំពីដំបូន្មានណាខ្លះ ដែលមាននៅក្នុងខគម្ពីរទាំងនេះ ។ បន្ទាប់ពីសិស្សរាយការណ៍នូវអ្វីដែលពួកគេបានរកឃើញ ហើយ សូមសរសេរនូវសេចក្ដីពិតដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងរីករាយ នោះយើងគប្បីសរសើរ និងថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ ។ បើយើងសោកសៅ យើងគប្បីអធិស្ឋានសុំឲ្យព្រលឹងរបស់យើងបានប្រកបដោយក្ដីអំណរ ។**

- តើអ្នកគិតថា គោលការណ៍ទាំងនេះបានជួយដល់ពួកបរិសុទ្ធ ក្នុងការធ្វើដំណើររបស់ពួកគេដោយរបៀបណា ?
- តើគោលការណ៍ទាំងនេះ អាចជួយការពារយើងសព្វថ្ងៃយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សគិតអំពីគ្រាដែលព្រះវរបិតាសួគ៌បានឆ្លើយតបនឹងការអធិស្ឋានរបស់ពួកគេ ដោយការជួយពួកគេឲ្យមានភាពរីករាយ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមលើកទឹកចិត្តពួកគេឲ្យសរសើរ និងថ្លែងអំណរគុណដល់ព្រះអម្ចាស់ នៅពេលពួកគេរីករាយ ហើយអធិស្ឋានសុំជំនួយនៅពេលពួកគេសោកសៅ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៣០–៤២

*ព្រះអម្ចាស់បានអះអាងដល់ពួកបរិសុទ្ធ ហើយដឹកនាំពួកគេឲ្យឧស្សាហ៍ព្យាយាម នៅក្នុងការរក្សាបទបញ្ញត្តិទាំងអស់របស់ទ្រង់*

សូមរំឭកសិស្សថា ពួកបរិសុទ្ធបានស៊ូទ្រាំនឹងការសាកល្បងដ៏ធំ ហើយថាពួកគេបានដឹងថា ការធ្វើដំណើរបន្តទៅមុខទៀតរបស់ពួកគេ នឹងជាការលំបាកដ៏ខ្លាំងផងដែរ ។

- តើអ្នកគិតថា មានអ្វីខ្លះដែលបានជួយដល់ពួកបរិសុទ្ធឲ្យបន្តមានចិត្តស្មោះត្រង់ ទោះជាស្ថិតនៅក្រោមស្ថានភាពដ៏លំបាកដូច្នេះក្ដីនោះ ?

សូមបែងចែកសិស្សធ្វើការជាពីរក្រុម ។ សូមអញ្ជើញក្រុមទីមួយឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៣០–៣៣ ឲ្យឮៗ ។ សូមអញ្ជើញក្រុមទីពីរឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៣៤–៤០ ឲ្យឮៗ ។ សូមឲ្យក្រុមទាំងពីររកមើលគោលការណ៍ទាំងឡាយដែលអាចនឹងលើកទឹកចិត្តដល់ពួកបរិសុទ្ធ ។

បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សក្នុងក្រុមនិមួយៗរាយការណ៍ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។ ចម្លើយរបស់ពួកគេអាចរួមមាននូវគោលការណ៍ និងគោលលទ្ធិទាំងឡាយដូចខាងក្រោម ៖

**យើងពុំគួរខ្លាចមារសត្រូវរបស់យើងឡើយពីព្រោះពួកគេស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់**

**ការសាកល្បងរបស់យើង អាចរៀបចំយើងឲ្យទទួលបានសិរីល្អដែលព្រះមានសម្រាប់យើង ។**

**បើយើងបន្ទាបខ្លួន ហើយអំពាវនាវដល់ព្រះ នោះព្រះវិញ្ញាណនឹងបំភ្លឺចិត្តយើង ។**

**បើយើងស្មោះត្រង់នៅក្នុងការរក្សាព្រះបន្ទូលទាំងអស់ដែលព្រះអម្ចាស់ប្រទានដល់យើង នោះយើងនឹងមើលឃើញសិរីល្អរបស់ទ្រង់នៅថ្ងៃណាមួយ ។**

**ព្រះអម្ចាស់ប្រទានដល់យើងនូវព្រះបន្ទូលទ្រង់ តាមរយៈពួកព្យាការីរបស់ទ្រង់ ។**

**ព្រះអម្ចាស់អាចរំដោះយើងពីមារសត្រូវរបស់យើង ។**

- តើអ្នកគិតថា គោលការណ៍ទាំងនេះបានជួយដល់ពួកបរិសុទ្ធបន្តមានចិត្តស្មោះត្រង់ដោយរបៀបណា ?
- តើគោលការណ៍ទាំងនេះ អាចជួយយើងបន្តស្មោះត្រង់ ក្នុងអំឡុងពេលបទពិសោធន៍លំបាកផ្ទាល់ខ្លួនរបស់យើងយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យរំពឹកដោយឆាប់រហ័សនូវគោលការណ៍នៅលើក្ដារខៀន ។ សូមឲ្យពួកគេពិចារណាអំពីសារលិខិតទាំងមូល ដែលពួកគេគិតថា ពួកគេបរិសុទ្ធប្រហែលជាបានរៀន ។ សូមឲ្យសិស្សរាយការណ៍ អំពីចម្លើយរបស់ពួកគេ ។ សិស្សអាចប្រាប់នូវសារលិខិតផ្សេងៗ ប៉ុន្តែសូមជួយពួកគេយល់ថា ព្រះអម្ចាស់បានប្រទាននូវការអះអាងដល់ពួកបរិសុទ្ធថាមានដំណោះស្រាយចំពោះអ្វីៗទាំងអស់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៤១–៤២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការអះអាង និងការទូន្មានបន្ថែមមកពីព្រះអម្ចាស់ ។

- តើសារលិខិតរបស់ព្រះអម្ចាស់នៅក្នុង ខ ៤១ អាចលួងលោមដល់ពួកបរិសុទ្ធយ៉ាងដូចម្ដេច ?
- តើយើងអាចរៀនមកពីការបង្គាប់របស់ព្រះអម្ចាស់នៅក្នុង ខ ៤២ អ្វីខ្លះ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **បើយើងឧស្សាហ៍ព្យាយាមនៅក្នុងការរក្សាបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះការជំនុំជំរះរបស់ព្រះអម្ចាស់ នឹងពុំធ្លាក់មកលើយើងឡើយ ហើយសេចក្ដីជំនឿរបស់យើងនឹងបានរឹងមាំ ហើយមារសត្រូវរបស់យើងនឹងពុំអាចយកឈ្នះលើយើងឡើយ** ) ។
- តើគោលការណ៍នេះបានជួយដល់ពួកបរិសុទ្ធក្នុងការធ្វើដំណើររបស់ពួកគេដោយរបៀបណា ? តើវាអាចជួយយើងយ៉ាងដូចម្ដេច ?

សូមពន្យល់ថា ពួកបរិសុទ្ធបានគោរពដល់បទបញ្ញត្តិរបស់ព្រះអម្ចាស់ ។ ក្រុមទីមួយនៃអ្នកត្រួសត្រាយផ្លូវបានចាកចេញពីវិនធើរខ្វរធើរ នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៨៤៧ ។ ពួកគេបានធ្វើដំណើរជាង ១៦០០ គីឡូម៉ែត្រ និងបានមកដល់ច្រកភ្នំ សលត៍លេក នៅចុងខែ កក្កដា ឆ្នាំ ១៨៤៧ ។ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៨៤៧ ប្រធាន ព្រិកហាំ យ៉ង់ បានចូលទៅក្នុងច្រកភ្នំ និងបានទទួលការបញ្ជាក់ថា ពួកបរិសុទ្ធបានរកឃើញលំនៅដ្ឋានថ្មីរបស់ពួកគេហើយ ។ លោកបានជិះពីខាងក្រោយរទេះរបស់វិលហ្វូឌ វូឌដ្រុព្វ នៅពេលនោះ ដោយសារតែគាត់មានជម្ងឺគ្រុនក្ដៅ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮៗនូវដំណើររឿង របស់ប្រធាន វិលហ្វូឌ វូឌដ្រុព្វអំពី ការមើលឃើញជ្រលងភ្នំសលត៍ លេករបស់ព្រិកហាំ យ៉ង់ ៖



« នៅពេលយើងមកដល់. . . មើលឃើញទិដ្ឋភាពទាំងមូលនៃជ្រលងភ្នំ ខ្ញុំបានបង្វែររទេះរបស់ខ្ញុំមួយជុំ បង្វែរវាទៅកាន់ទិសខាងលិច ហើយប្រធាន ព្រិកហាំ យ៉ង់ បានក្រោកឡើងពីដំណេកលោក រួចស្ទង់មើលទៅលើស្រុកនេះ ។ នៅពេលកំពុងមើលទៅទិដ្ឋភាពពីខាងមុខយើង លោកបានបើកការនិមិត្ត ចេញមកអស់រយៈពេលជាច្រើននាទី ។ លោកបានឃើញជ្រលងភ្នំនេះពីមុននៅក្នុងការនិមិត្ត ហើយនៅពេលនេះ លោកបានឃើញអនាគតដ៏រុងរឿងនៃស៊ីយ៉ូន និង នៃសាសន៍អ៊ីស្រាអែល ។. . . នៅពេលការនិមិត្តបានបញ្ចប់ទៅ នោះលោកបានមានប្រសាសន៍ថា ‹ វាគ្រប់គ្រាន់ហើយ ។ នេះគឺជាកន្លែងត្រឹមត្រូវហើយ ។ សូមបន្តទៅមុខទៀត › » (*Teachings of Presidents of the Church: Wilford Woodruff* [ ឆ្នាំ ២០០៤], ទំព័រ ១៤៦) ។

- ហេតុអ្វីបានជាវាសំខាន់សម្រាប់ ព្រិកហាំ យ៉ង់ និង ពួកបរិសុទ្ធទទួលការបញ្ជាក់ថា ជ្រលងភ្នំ សលត៍ លេក គឺជាកន្លែងដែលត្រឹមត្រូវដើម្បីតាំងលំនៅ ?

សូមបញ្ចប់ដោយការអញ្ជើញសិស្សឲ្យព្យាយាមដើម្បីក្សោរាល់បទបញ្ញត្តិ ហើយស្ដាប់ការអះអាងរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ។

មេរៀនទី ១៥០

# ក្រុមអ្នកត្រួសត្រាយរទេះអូស ឆ្នាំ ១៨៥៦–១៨៦០

## សេចក្ដីផ្ដើម

ពួកបរិសុទ្ធបានមកដល់ជ្រលងភ្នំ សលត៍ លេក នៅឆ្នាំ ១៨៤៧ បានចេញទៅធ្វើការដាំដំណាំដាំដុះ និងបង្កើតធនធានដទៃទៀត សម្រាប់អន្តោប្រវេសន៍នាពេលអនាគត ។ នៅខែ កញ្ញា ឆ្នាំ ១៨៥១ ព្រិកហាំ យ៉ង់ និងទីប្រឹក្សារបស់លោកនៅក្នុងគណៈប្រធានទីមួយ បានបញ្ជាក់ឡើងវិញដល់ពួកបរិសុទ្ធទាំងអស់កំពុងរស់នៅក្នុងរដ្ឋ អៃអូវ៉ា និងនៅជុំវិញពិភពលោក មកជួបជុំគ្នានៅជ្រលងភ្នំសលត៍ លេក ។ មានពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនបានឆ្លើយតបចំពោះការអំពាវនាវរបស់ប្រធាន យ៉ង់ ដោយមានការលះបង់ដ៏ធំក្រៃលែង ។ សមាជិកនៃពួកដប់ពីរនាក់ ត្រូវបានបញ្ជូនឲ្យទៅមើលអន្តោប្រវេសន៍ ហើយនៅក្នុងឆ្នាំ ១៨៥២ មានពួកបរិសុទ្ធកាន់តែច្រើនបានធ្វើដំណើរតាមផ្លូវរទេះទៅកាន់ជ្រលងភ្នំសលត៍ លេក ដែលច្រើនជាងឆ្នាំនានាឯទៀត ។ បន្ថែមពីលើនោះ មានពួកបរិសុទ្ធជាច្រើនធ្វើដំណើរទៅជ្រលងភ្នំ សលត៍ លេក នៅក្នុងក្រុមរទេះរុញ ចន្លោះឆ្នាំ ១៨៥៦ និង ឆ្នាំ ១៨៦០ ។

## យោបល់សម្រាប់ការបង្រៀន

### ពួកបរិសុទ្ធបានគោរពតាមដំបូន្មានឲ្យប្រមូលផ្ដុំគ្នានៅជ្រលងភ្នំសលត៍ លេក

សូមឲ្យសិស្សនឹកគិតថា ពួកគេត្រូវបានសុំឲ្យធ្វើដំណើរចម្ងាយ ១៣០០ ម៉ែល (ប្រហែលជា ២០៩០ គីឡូម៉ែត្រ ) ថ្មើរជើងខណៈដែលត្រូវអូសរទេះផងដែរ ហើយពួកគេអនុញ្ញាតឲ្យយក តែ១៧ ផោន (ប្រហែលជា ៧.៧ គីឡូក្រាម ) នូវរបស់របរផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ សូមសួរថាតើមានសិស្សណាខ្លះដែលចង់ស្ម័គ្រចិត្តធ្វើដំណើរ ។

សូមបង្ហាញដល់សិស្សនូវរូបភាពរទេះអូស ឬគូររូប ដែលមានអមមកជាមួយ នៅលើក្ដារខៀន ។ សូមពន្យល់ថានៅក្នុងឆ្នាំ ១៨៥៦ ប្រធាន ព្រិកហាំ យ៉ង់ បានស្នើសុំឲ្យអ្នកធ្វើអន្តោប្រវេសន៍ គប្បីធ្វើដំណើរដោយការប្រើរទេះអូសជំនួសឲ្យរទេះសេះ ដោយសារតែមានការខ្វះខាតខាងហិរញ្ញវត្ថុ ។ ក្រុមរទេះអូស ពុំសូវចំណាយច្រើនទេ ហើយអនុញ្ញាតឲ្យមានពួកបរិសុទ្ធកាន់តែច្រើនរូប ធ្វើអន្តោប្រវេសន៍ ។ នៅចន្លោះឆ្នាំ ១៨៥៦ និង ១៨៦០ មានពួកបរិសុទ្ធស្ទើរតែ ៣០០០ នាក់ បានជ្រើសរើសធ្វើដំណើរទៅទិសខាងលិចកាត់វាលទំនាបនៃសហរដ្ឋអាមេរិកទៅកាន់រដ្ឋយូថាហ៍ ដោយអូសរបស់របរពួកគេនៅក្នុងរទេះអូស ។ ក្រុមរទេះរុញច្រើនបំផុតបានដាក់ស្បៀងអាហារ និងសម្ភារផ្ទាល់ខ្លួន និងអាហារខ្លះៗនៅក្នុងរទេះ ហើយដើរពីទីក្រុង អៃអូវ៉ា រដ្ឋអៃអូវ៉ា ធ្វើដំណើរទៅកាន់ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ។ ក្រុមបីចុងក្រោយគេ បានចាប់ផ្ដើមការធ្វើដំណើរនៅទីក្រុងហ្លរិន រដ្ឋ នេប្រាស្កា ។

សូមដាក់តាំងប្រអប់ ឬថង់មួយដែលមានទម្ងន់ចំនួន ១៧ ផោន ( ប្រហែលជា ៧.៧ គ.ក ) ។ សូមឲ្យសិស្សពីរបីនាក់លើកវត្ថុនោះឡើង ។ សូមពន្យល់ថា មនុស្សពេញវ័យដែលធ្វើដំណើរក្នុងក្រុមរទេះអូស ត្រូវបានអនុញ្ញាតឲ្យយកសម្ភារផ្ទាល់ខ្លួនទម្ងន់ចំនួន ១៧ ផោន ។ កុមារតូចៗអាចយកទម្ងន់ចំនួន ១០ ផោន ( ប្រហែលជា ៤.៥ គ.ក ) ។ សម្ភារផ្ទាល់ខ្លួនរួមមានសម្លៀកបំពាក់ និងវត្ថុផ្សេងទៀត ។ សម្ភារត្រូវបានថ្លឹងទៅតាមបុគ្គលម្នាក់ៗ ហើយអ្វីៗដែលលើសពីកម្រិតនៃទម្ងន់នេះ ត្រូវបោះបង់ចោល ។



- បើអ្នកជាអ្នកត្រួសត្រាយផ្លូវក្រុមរទេះអូសទាំងអស់នេះ តើសម្ភារផ្ទាល់ខ្លួនអ្វីខ្លះ ដែលអ្នកនឹងជ្រើសរើសយក ? ហេតុអ្វី ?
- ហេតុអ្វីអ្នកគិតថា ពួកបរិសុទ្ធស្ម័គ្រចិត្តធ្វើពលិកម្មយ៉ាងច្រើនដើម្បីទៅដល់រដ្ឋយូថាហ៍ដូច្នេះ ?

ទោះជាការធ្វើដំណើរមានការលំបាកក្ដី មានក្រុមរទេះអូសចំនួនប្រាំបីក្នុងចំណោមដប់ក្រុម បានធ្វើដំណើរទៅដោយជោគជ័យនៅចន្លោះឆ្នាំ ១៨៥៦ និងឆ្នាំ ១៨៦០ ។ ប៉ុន្តែនៅឆ្នាំ ១៨៥៦ មានក្រុមរទេះអូសទីបួន និងទីប្រាំ បានចេញដំណើរយឺតពេលក្នុងរដូវ ហើយបានជួបនឹងការលំបាកដ៏ធ្ងន់ធ្ងរ ។ ពួកគេគឺជាក្រុមរទេះអូស វីលី ដែល

ដឹកនាំដោយ ជេម ជី វីលី និង ក្រុមរទេះអូស ម៉ាទីន ដែលដឹកនាំដោយ អែតវើត ម៉ាទីន ។ បន្ទាប់ពីបានធ្វើដំណើរប្រហែលជា ១០០០ ម៉ែល ( ប្រហែលជា ១៦០០ គីឡូម៉ែត្រ ) ខាងលិចរដ្ឋ អៃអូវ៉ា ក្រុមរទេះអូសទាំងឡាយបានខ្វះខាតគ្រឿងសម្ភារ និង អាហារយ៉ាងខ្លាំង ។ នៅខែតុលា ក្រុមទាំងពីរនេះ ត្រូវជាប់នៅក្នុងព្យុះទឹកកករដូវរងារដ៏ធ្ងន់ធ្ងរនៅលើទីវាលទំនាបនៃរដ្ឋវ៉ាយអូមីង ដែលបានបង្អាក់ការធ្វើដំណើរទៅមុខរបស់ពួកគេ ។ ពួកបរិសុទ្ធទាំងនេះបានរងទុក្ខយ៉ាងលំបាកនៅក្នុងភាពត្រជាក់ និងទឹកកកដ៏ក្រាស់ ។ ( សូមគិតធ្វើការដាក់បង្ហាញរូបភាពនៃពួកអ្នកត្រួសត្រាយផ្លូវរទេះអូស ដូចជា ក្រុមត្រួសត្រាយផ្លូវដែលអូសរទេះនោះបានមកដល់ជ្រលងភ្នំសលត៍ លេក [*Gospel Art Book* (២០០៩) លេខ ១០២ សូមមើលផងដែរ LDS.org]) ។

## *សូមប្រាប់ដំណើររឿងពិត*

ដំណើររឿងពិតទាំងឡាយ គឺជារឿងត្រឹមត្រូវដែលអាចជួយស្ថាបនាសេចក្ដីជំនឿរបស់សិស្សទៅលើដំណឹងល្អរបស់ព្រះយេស៊ូវ គ្រីស្ទ ។ រឿងនោះអាចធ្វើឲ្យមានចំណាប់អារម្មណ៍ និងជួយសិស្សឲ្យយល់ពីដំណឹងល្អ តាមរយៈបទពិសោធន៍របស់មនុស្សផ្សេងៗគ្នា ។ ដំណើររឿងពិតក៏អាចមានឥទ្ធិពលជាក់លាក់ផងដែរនៅក្នុងការជួយដល់សិស្សឲ្យយល់គោលការណ៍ដំណឹងល្អ ។ ខណៈដែលដំណើររឿងបែបនេះអាចជួយសិស្ស ឲ្យដឹងពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេគប្បីកុំប្រើនូវការនិយាយបំភ្លើសក្នុងអារម្មណ៍ឡើយ ។

បើអាចធ្វើទៅបាន សូមផ្ដល់ដល់សិស្សនូវច្បាប់ចម្លងនៃដំណើររឿងរបស់អើរ៉ុន និង អេលីស្សាប៊ែត ចាកសុន ដូចខាងក្រោម ។ សូមពន្យល់ថា ចាកសុនធ្វើដំណើរជាមួយក្រុមរបស់ ម៉ាទីន ដែលធ្វើដំណើរប្រហែលជា ១០០ ម៉ែល ( ប្រហែលជា ១៦០ គ.ម) ពីក្រោយក្រុមរបស់វីលី ។ សូមអញ្ជើញសិស្សម្នាក់ឲ្យ អានសេចក្ដីថ្លែងការណ៍នេះឲ្យព្ធ ៗ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលភស្តុតាងនៃសេចក្ដីជំនឿរបស់អើរ៉ុន និងអេលីស្សាប៊ែត ។



នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៨៥៦ សមាជិកក្នុងក្រុមរទេះអូសរបស់ ម៉ាទីន ត្រូវឆ្លងកាត់ទន្លេដ៏ធំមួយ អំឡុងពេលព្យុះទឹកកកមួយ ។ សមាជិកក្នុងក្រុមនោះជាច្រើននាក់ រួមមានទាំង អើរ៉ុន ចាកសុន ផងដែរ បានទន់ខ្សោយ ហើយបានធ្លាក់ខ្លួនឈឺ រីឯការធ្វើដំណើរឆ្លងកាត់ទន្លេ គឺមានឥទ្ធិពលកាន់តែអាក្រក់លើពួកគេ ។ អេលីស្សាប៊ែត ចាកសុន បានពិពណ៌នាអំពីអ្វីដែលបានកើតឡើងចំពោះស្វាមីរបស់គាត់នៅពីរបីថ្ងៃក្រោយមក ៖

> « ខ្ញុំបានចូលដេក នៅម៉ោងប្រហែលជាប្រាំបួន ។. . . វាដូចជា ខ្ញុំបានដេករហូតដល់ម៉ោងប្រហែលជាពាក់កណ្ដាលអធ្រាត្រ ។ ខ្ញុំត្រជាក់យ៉ាងខ្លាំង ។ អាកាសធាតុកាន់តែត្រជាក់ខ្លាំង ។ ខ្ញុំបានស្ដាប់ថាតើស្វាមីរបស់ខ្ញុំនៅមានដង្ហើមឬទេ–ព្រោះគាត់ដេកនឹងថ្កល់ ។ ខ្ញុំស្ដាប់ពុំឮដង្ហើមរបស់គាត់ទេ ។ ខ្ញុំបានដឹងភ្លាម ។ ខ្ញុំបានដាក់ដៃខ្ញុំលើខ្លួនគាត់ នៅពេលនោះបានដឹងដោយរន្ធត់ចិត្តជាខ្លាំង ហើយភាពភ័យខ្លាចបំផុតរបស់ខ្ញុំបានចាប់ផ្ដើម ។ ស្វាមីរបស់ខ្ញុំបាន *ស្លាប់ហើយ* ។. . . ខ្ញុំបានស្រែកហៅរកជំនួយពីមនុស្សដែលនៅក្នុងតង់ផ្សេងទៀត ។ ពួកគេពុំអាចជួយខ្ញុំ អ្វីបានទេ ។. . . នៅពេលព្រឹកឡើង នោះបុរសមួយចំនួនមកពីក្នុងក្រុម បានរៀបចំបញ្ចុះសពរបស់គាត់ ។. . . ពួកគេបានរុំសពគាត់នៅក្នុងភួយមួយ ហើយបានដាក់គាត់នៅក្នុងគំនរនៃមនុស្សស្លាប់ដប់បីនាក់ទៀត រួចក៏គ្របដណ្ដប់គាត់ដោយពំនូកទឹកកក ។. . .
>
> « ខ្ញុំពុំចង់ពិពណ៌នាអំពីអារម្មណ៍របស់ខ្ញុំ ពេលឃើញថាខ្លួនត្រូវបានបន្សល់ទុកឲ្យនៅជាស្ត្រីមេម៉ាយជាមួយនឹងកូនបីនាក់ ស្ថិតនៅក្រោមស្ថានភាពដ៏ឈឺចាប់ដូច្នេះទេ ។ ខ្ញុំពុំអាចធ្វើបានទេ ។ ប៉ុន្តែខ្ញុំជឿទៅលើកំណត់ត្រាទេវតាដែលបានពិពណ៌នានៅក្នុងកំណត់ត្រាខាងលើ ហើយថាការរងទុក្ខរបស់ខ្ញុំដើម្បីជាប្រយោជន៍របស់ដំណឹងល្អនឹងញែកចេញជាបរិសុទ្ធចំពោះខ្ញុំ សម្រាប់ជាសេចក្ដីល្អរបស់ខ្ញុំ » (*Leaves from the Life of Elizabeth Horrocks Jackson Kingsford* [ឆ្នាំ ១៩០៨], ទំព័រ ៦–៧; សូមមើលផងដែរ history.lds.org) ។

- តើអេលីស្សាប៊ែត បាននិយាយយ៉ាងណាអំពី ការរងទុក្ខរបស់គាត់សម្រាប់ជាប្រយោជន៍នៃដំណឹងល្អ ? តើអ្នកគិតយ៉ាងណាចំពោះឃ្លា « ញែកខ្ញុំចេញជាបរិសុទ្ធសម្រាប់សេចក្ដីល្អរបស់ខ្ញុំនោះ ? ( ការរងទុក្ខរបស់គាត់ នឹងធ្វើឲ្យទៅជាពិសិដ្ឋ និងបរិសុទ្ធ សម្រាប់ជាប្រយោជន៍របស់គាត់ ) ។

- តើអ្វីខ្លះអាចកើតមានចំពោះយើង បើយើងចាំបាច់ត្រូវរងទុក្ខដោយអត់ធ្មត់ចំពោះប្រយោជន៍នៃដំណឹងល្អនោះ ? ( សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖**បើយើងរងទុក្ខដោយអត់ធ្មត់ដើម្បីប្រយោជន៍នៃដំណឹងល្អ នោះវាអាចញែកខ្លួនយើងចេញជាបរិសុទ្ធសម្រាប់សេចក្ដីល្អ ។** [សូមមើល គ. និង ស. ១២២:៧; នីហ្វៃទី ២ ២: ២]) ។

- ទោះជាអ្នកពុំរងទុក្ខដូចជា អេលីស្សាប៊ែត ចាកសុន ក្ដី តើអ្នកអាចនឹងត្រូវរងទុក្ខដើម្បីប្រយោជន៍នៃដំណឹងល្អតាមរបៀបណាខ្លះ ? តើអ្នកអាចទទួលពរ តាមរយៈបទពិសោធន៍ទាំងនេះយ៉ាងដូចម្ដេច ?

សូមពន្យល់ថា អំឡុងពេលពីរបីថ្ងៃក្រោយ បន្ទាប់ពី អើរ៉ុន ចាកសុន បានស្លាប់ នោះក្រុមរទេះអូស ម៉ាទីន បានធ្វើដំណើរឆ្ពោះទៅមុខទៀត បានប្រហែលជា ១០ ម៉ែល ( ប្រហែលជា ១៦ គីឡូម៉ែត្រ ) ។ មនុស្សជាច្រើនបានស្លាប់អំឡុងពេលនេះ ។ នាយប់មួយ អំឡុងពេលធ្វើដំណើរនេះ គ្មាននរណាម្នាក់មានកម្លាំងគ្រប់គ្រាន់ដើម្បីបោះតង់នោះទេ ។ អេលីស្សាប៊ែត ចាកសុន បានអង្គុយនៅលើថ្មមួយដុំ ដែលកូនម្នាក់អង្គុយនៅលើភ្លៅ ហើយកូនម្នាក់ទៀតអង្គុយនៅសងខាងគាត់ ។ គាត់បាននៅអង្គុយដូច្នោះរហូតដល់ព្រឹក ។ អេលីស្សាប៊ែតបាក់ទឹកចិត្តខ្លាំងណាស់ ។ រួចហើយនាយប់ថ្ងៃទី ២៧ ខែតុលា គាត់បានទទួលបទពិសោធន៍មួយ ដែលផ្តល់ក្តីសង្ឃឹមដល់គាត់ដើម្បីរួចពីគ្រោះថ្នាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោមឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់ពីអ្វីដែលអេលីស្សាប៊ែតបានរៀននៅក្នុងសុបិនមួយនោះ ។

« មនុស្សនឹងអាចយល់ហើយថា នៅក្រោមស្ថានភាពដ៏អាក្រក់ដូច្នេះ ខ្ញុំអស់សង្ឃឹមជាខ្លាំង ។ ខ្ញុំនៅចម្ងាយប្រាំបួនពាន់ប្រាំរយ ឬ មួយម៉ឺនមួយពាន់គីឡូម៉ែតពីដែនដីកំណើតរបស់ខ្ញុំ នៅក្នុងតំបន់ព្រៃភ្នំក្រោមថ្ម នៅក្នុងស្ថានភាពដ៏អស់សង្ឃឹមដែលផ្ទៃដីគ្របដណ្តប់ដោយព្រិល ទឹកត្រូវបានគ្របដណ្តប់ដោយទឹកកក ហើយខ្ញុំនៅជាមួយនឹងកូនបីនាក់ដែលគ្មានឪពុក គ្មានអ្វីជួយការពារពួកគេពីព្យុះដ៏កំណាចឡើយ ។ ពេលខ្ញុំចូលដេកនៅពេលយប់ នៅថ្ងៃទី ២៧ ខែតុលា នោះខ្ញុំមាននិវរណៈយ៉ាងអស្ចារ្យមួយ ។ នៅក្នុងសុបិនរបស់ខ្ញុំ ប្តីរបស់ខ្ញុំបានឈរនៅជិតខ្ញុំ ហើយបាននិយាយថា– ‹ សូមរីករាយឡើង អេលីស្សាប៊ែត ការជួយសង្គ្រោះជិតមកដល់ហើយ ›»(*Leaves from the Life of Elizabeth Horrocks Jackson Kingsford* ៨ សូមមើលផងដែរ history.lds.org ) ។

សូមប្រាប់សិស្សថា សុបិនត្រូវបានបំពេញ នៅពេលដែលពួកជួយសង្គ្រោះមកពីទីក្រុងសលត៍ លេក បានមកដល់ក្រុមម៉ាទីន នៅថ្ងៃស្អែកឡើងនោះ ។

សូមពន្យល់ថា នៅថ្ងៃទី ៤ ខែតុលា ឆ្នាំ ១៨៥៦ អស់ជាច្រើនសប្តាហ៍មុនពេលមានព្យុះទឹកកក បានវាយប្រហារលើក្រុមរទេះអូស នោះពួកអ្នកធ្វើដំណើរបានរាយការណ៍ទៅប្រធាន ព្រិកហាំ យ៉ង់ថា ក្រុមត្រួសត្រាយផ្លូវ កំពុងស្ថិតនៅលើទីវាលទំនាបនៅឡើយ ហើយនៅសល់រាប់រយម៉ែលទៀត ។ នៅថ្ងៃស្អែកឡើង ក្នុងការប្រជុំថ្ងៃអាទិត្យ ព្រិកហាំ យ៉ង់ បានថ្លែងអំពីការជួយសង្គ្រោះដល់ពួកត្រួសត្រាយផ្លូវរទេះអូសទាំងនេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌដូចខាងក្រោមនៅក្នុងប្រសាសន៍របស់លោក ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ ហើយស្វែងរកគោលការណ៍មួយដែលប្រធាន យ៉ង់ កំពុងបង្រៀនដល់ពួកបរិសុទ្ធ ។ ( បើអាចធ្វើទៅបាន សូមផ្តល់ច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍នេះដល់សិស្សម្នាក់មួយច្បាប់ ដើម្បីពួកគេអាចធ្វើតាម ) ។



« ពួកបងប្អូនប្រុសស្រីរបស់យើងជាច្រើននាក់កំពុងស្ថិតនៅតំបន់វាលទំនាបដោយមានរទេះអូសជាច្រើន ហើយប្រហែលជាពួកគេជាច្រើន ឥឡូវនេះស្ថិតនៅចម្ងាយប្រមាណ ១១០០ គីឡូម៉ែត្រពីទីកន្លែងនេះ យើងត្រូវនាំពួកគេមកទីនេះ ដូច្នេះយើងត្រូវតែបញ្ជូនជំនួយដល់ពួកគេ ។. . .

« នោះជាសាសនារបស់ខ្ញុំ នេះជាការបង្ហាញប្រាប់ដល់ខ្ញុំពីព្រះវិញ្ញាណបរិសុទ្ធ ថាត្រូវសង្គ្រោះដល់មនុស្ស ។. . . នេះគឺជាសេចក្តីសង្គ្រោះ ដែលខ្ញុំកំពុងស្វែងរកនាពេលនេះ ដើម្បីសង្គ្រោះបងប្អូនប្រុសរបស់យើង ដែលនឹងត្រូវវិនាស ឬ រងទុក្ខដ៏ធ្ងន់ធ្ងរ បើសិនជាយើងមិនបញ្ជូនជំនួយដល់ពួកគេទេនោះ ។

« ខ្ញុំនឹងពុំរង់ចាំរហូតដល់ថ្ងៃស្អែក ឬ រហូតដល់ថ្ងៃស្អែកឡើយ ខ្ញុំនឹងហៅឲ្យពួកប៊ីស្សពនៅថ្ងៃនេះ រកគោល្អៗចំនួន ៦០ ក្បាល និង រទេះ ១២ ឬ ១៥ រទេះ. . . [ ព្រមទាំង ] ម្សៅ ១២ តោន និង មនុស្សបររទេះរឹងមាំ ៤០ នាក់ ក្រៅពីអ្នកទាំងឡាយដែលដឹកនាំក្រុម ។. . .

« ខ្ញុំនឹងប្រាប់អ្នកទាំងអស់គ្នាថា សេចក្តីជំនឿរបស់អ្នក សាសនា និងវិជ្ជាជីវៈសាសនារបស់អ្នក នឹងពុំសង្គ្រោះដល់ព្រលឹងណាម្នាក់ ក្នុងចំណោមអ្នករាល់គ្នានៅក្នុងនគរសេឡេស្ទាលនៃព្រះរបស់យើងឡើយ លុះត្រាតែអ្នកអនុវត្តនូវគោលការណ៍ទាំងឡាយនេះ ដែលខ្ញុំកំពុងតែបង្រៀនអ្នកនាពេលនេះប៉ុណ្ណោះ ។ សូមចេញទៅ ហើយនាំអស់អ្នកដែលកំពុងតែនៅលើវាលទំនាបនាពេលឥឡូវនេះ » ( « Remarks » *Deseret News* ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៨៥៦, ទំព័រ ២៥២ ) ។

- តើប្រធាន ព្រិកហាំ យ៉ង់ បានបង្រៀនដល់ពួកបរិសុទ្ធអ្វីខ្លះ ? ( សិស្សអាចនឹងប្រាប់អំពីគោលការណ៍ផ្សេងៗ ប៉ុន្តែសូមប្រាកដថា ពួកគេយល់**ក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ យើងត្រូវជួយដល់អ្នកទាំងឡាយដែលខ្វះខាត** )។

សូមពន្យល់ថា មានបុរស និងស្ត្រីជាច្រើនបានឆ្លើយតបតាមការសុំ ហើយអំឡុងពេលពីរថ្ងៃបន្ទាប់ពីទេសនកថារបស់ប្រធាន យ៉ង់ នោះមានបុរសៗបានចេញទៅរកពួកអន្តោប្រវេសន្ត៍ ដោយបររទេះគោដឹកជញ្ជូនសម្ភារជាច្រើន ។

- តើកិច្ចខិតខំជួយសង្គ្រោះនេះ អាចជាពលិកម្មមួយចំពោះពួកបរិសុទ្ធនៅជ្រលងភ្នំសលត៍ លេកយ៉ាងដូចម្តេច ?

- តើពលិកម្មមួយចំនួនណាខ្លះដែលយើងអាចធ្វើដើម្បីជួយដល់អ្នកទាំងឡាយដែលមានតម្រូវការខាងរូបកាយ ?
- តើពលិកម្មមួយចំនួនណាខ្លះដែលយើងអាចធ្វើដើម្បីជួយដល់អ្នកទាំងឡាយដែលមានតម្រូវការខាងវិញ្ញាណ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ ហើយស្វែងរកវិធីបន្ថែមទៀត ដែលយើងអាចជួយដល់អ្នកទាំងឡាយដែលខ្វះខាត ។



« ខ្ញុំមានអំណរគុណដែលថ្ងៃនេះ ពុំមានមនុស្សរបស់យើងណាម្នាក់ ជាប់នៅទីខ្ពស់នៃរដ្ឋ វ៉ាយអូមីង ។ ប៉ុន្តែខ្ញុំដឹងថា ក្រៅពីយើងនោះមានមនុស្សជាច្រើនដែលត្រូវការជំនួយ ហើយដែលគួរត្រូវបានជួយសង្គ្រោះ ។ បេកកម្មនៅក្នុងជីវិតរបស់យើង ក្នុងនាមជាអ្នកដើរតាមព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ គឺត្រូវតែជាបេសកកម្មនៃការជួយសង្គ្រោះ ។ មានមនុស្សឥតជម្រក ស្រេកឃ្លាន និងទាល់ក្រ ។ ស្ថានភាពរបស់ពួកគេមើលឃើញជាក់ស្តែង ។ យើងបានសម្រេចអ្វីៗជាច្រើន ។ យើងអាចធ្វើបានកាន់តែច្រើនទៀត ដើម្បីជួយដល់អ្នកទាំងឡាយដែលរស់នៅស្ទើរតែមិនរស់ ។

« យើងអាចឈោងទៅជួយពង្រឹងដល់អ្នកទាំងឡាយដែលជាប់នៅក្នុងរូបអាសគ្រាម ភាពអសីលធម៌ដ៏អាក្រក់ និងគ្រឿងញៀន ។ មានមនុស្សជាច្រើនបានក្លាយជាមនុស្សញៀនកាន់តែខ្លាំង ដែលពួកគេបានបាត់បង់អំណាចគ្រប់គ្រងលើដោគវាសនាផ្ទាល់ខ្លួនរបស់ពួកគេ ។ ពួកគេស្ថិតក្នុងសភាពអាក្រក់ និងខ្ទេចខ្ទាំ ។ ពួកគេអាចត្រូវបានជួយសង្គ្រោះ និងស្រោចស្រង់បាន ។. . .

« យើងពុំចាំបាច់ខ្វល់ខ្វាយនឹងអ្នកទាំងឡាយដែលស្ថិតនៅទីវាលនៃរដ្ឋ វ៉ាយអូមីង ទៀតទេ ។ យើងខ្វល់ខ្វាយនឹងមនុស្សជាច្រើនដែលនៅជិតៗជុំវិញខ្លួនយើងនេះ នៅក្នុងក្រុមគ្រួសាររបស់យើង នៅក្នុងវួដ និងស្តេករបស់យើង នៅក្នុងអ្នកជិតខាង និងសហគមន៍របស់យើង » (Our Mission of Saving» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៥៩ ) ។

- តើអ្នកធ្លាប់បានឃើញនរណាម្នាក់ ដែលបានជួយដល់អ្នកទាំងឡាយដែលខ្វះខាតខាងរូបកាយ និងខាងវិញ្ញាណ នៅពេលណា ? តើពួកគេជួយបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណា និងអធិស្ឋានដើម្បីដឹងរបៀបដែលពួកគេអាចជួយដល់នរណាម្នាក់ទៀត ។ អ្នកអាចនឹងផ្តល់ពេលឲ្យពួកគេមួយសន្ទុះ សរសេរគំនិតរបស់ពួកគេទុកនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

ដើម្បីជួយសិស្សមើលឃើញថា យើងត្រូវបានប្រទានពរនៅពេលយើងស៊ូទ្រាំនឹងការសាកល្បងដោយសេចក្តីជំនឿ អញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងដូចខាងក្រោម ៖

នៅក្នុងឆ្នាំ ១៨៥៦ ហ្វ្រែនស៊ីស និងបេតស៊ី មានប្រាក់គ្រប់គ្រាន់ដើម្បីធ្វើដំណើរទៅរដ្ឋ យូថាហ៍ តាមរទេះសេះ ប៉ុន្តែពួកគេបានបរិច្ចាគប្រាក់របស់ពួកគេចូលមូលនិធិ ដែលបានបង្កើតឡើង ដើម្បីជួយដល់ពួកបរិសុទ្ធដែលធ្វើអន្តប្រវេសន៍ទៅរដ្ឋយូថាហ៍ ( មូលនិធិអន្តោប្រវេសន៍អចិន្ត្រៃយ៍ ) ។ ការបរិច្ចាគរបស់ពួកគេបានអនុញ្ញាតឲ្យមនុស្សប្រាំបួននាក់បន្ថែមទៀតធ្វើដំណើរតាមរទេះអូស ។ ហ្វ្រែនស៊ីស និង បេតស៊ី ដែលកំពុងពពោះ បានធ្វើដំណើរទៅទីក្រុងសលត៍ លេក ជាមួយក្រុមរទេះអូស ម៉ាទីន ហើយបានរងទុក្ខលំបាកនៅតាមផ្លូវជាមួយនឹងអស់អ្នកផ្សេងទៀតក្នុងក្រុម ។

ប៉ុន្មានឆ្នាំក្រោយមក នៅពេលបងប្រុស វិបស្ទើរ អង្គុយនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ នោះគាត់បានស្តាប់ឮសមាជិកសាសនាចក្រមួយចំនួន រិះគន់ដល់ពួកអ្នកដឹកនាំសាសនាចក្រ ចំពោះទុក្ខលំបាករបស់ក្រុមរទេះអូស ។ ដោយពុំអាចទប់បាន គាត់បានក្រោកឈរឡើង រួចថ្លែងទីបន្ទាល់អំពីពរជ័យនៃការនៅជាមួយក្រុមរទេះអូស ម៉ាទីន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ទីបន្ទាល់របស់ ហ្វ្រែនស៊ីស វិបស្ទើរ ឮៗ ហើយសុំឲ្យសិស្សប្រាប់ពីរបៀបមួយ ដែលអ្នកទាំងឡាយដែលបានរងទុក្ខជាមួយនឹងក្រុមរទេះអូស បានទទួលពរជ័យ ។

« ខ្ញុំសុំឲ្យអ្នកបញ្ឈប់នូវការរិះគន់នេះ ដ្បិតអ្នកកំពុងតែពិភាក្សាអំពីរឿងមួយដែលអ្នកពុំដឹងអ្វីទាល់តែសោះ ។ អង្គហេតុជាប្រវត្តិសាស្ត្រ ពុំមានន័យអ្វីទេនៅទីនេះ ដ្បិតវាពុំបានផ្ដល់នូវការបកស្រាយត្រឹមត្រូវចំពោះសំណួរដែលជាប់ពាក់ព័ន្ធទេ ។ តើវាជាកំហុសឆ្គងដែលបញ្ជូនក្រុមរទេះអូសចេញទៅយឺតពេលនៅក្នុងរដូវនោះ ? មែនហើយ ។ ប៉ុន្តែខ្ញុំបាននៅក្នុងក្រុមនោះ ហើយភរិយារបស់ខ្ញុំក៏នៅទីនោះដែរ ។. . . យើងបានរងទុក្ខហួសពីអ្វីដែល អ្នកគិតឃើញទៅទៀត ហើយមានមនុស្សជាច្រើនបានស្លាប់ដោយ ហេវហត់ និងសេចក្ដីស្រេកឃ្លាន ។ តើអ្នកធ្លាប់ឮមនុស្សដែលនៅមានជីវិតពីក្រុមនោះថ្លែងពាក្យរិះគន់ឬទេ ?. . .

« ខ្ញុំបានងាកមើលក្រោយជាច្រើនដង ដើម្បីមើលថាតើនរណាដែលបានរុញរទេះរបស់ខ្ញុំ តែខ្ញុំមើលពុំឃើញថាមាននរណាម្នាក់ទេ ។ រួចហើយខ្ញុំដឹងថា ពួកទេវតានៃព្រះគង់នៅទីនោះ ។

« តើខ្ញុំសោកស្ដាយដែលខ្ញុំបានជ្រើសរើសធ្វើដំណើរមកដោយការអូសរទេះមែនទេ ? អត់ទេ ។ គ្មានសោះឡើយនៅក្នុងជីវិតរបស់ខ្ញុំ ទាំងនាពេលនោះ ហើយពេលនេះក៏គ្មានដែរ ។ តម្លៃដែលយើងបានបង់ថ្លៃដើម្បីស្គាល់ព្រះ គឺជាឯកសិទ្ធិដើម្បីបង់ថ្លៃ ហើយខ្ញុំមានអំណរគុណដែលខ្ញុំមានឯកសិទ្ធិដើម្បីមកដល់ស៊ីយ៉ូន នៅក្នុងក្រុមរទេះអូសម៉ាទីន » ( នៅក្នុង William R. Palmer «Pioneers of Southern Utah» *The Instructor* វ៉ុលទី ៧៩, លេខ ៥ [ខែ ឧសភា ឆ្នាំ ១៩៤៤], ទំព័រ ២១៧–១៨ ) ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនមកពីទីបន្ទាល់របស់ ហ្វ្រេនស៊ីស វិបស្ទើរ ? ( សិស្សគប្បីតែសម្គាល់ឃើញនូវគោលលទ្ធិដូចខាងក្រោម ៖**បើយើងស៊ូទ្រាំរងទុក្ខដោយស្មោះត្រង់ នោះយើងអាចបានស្គាល់ព្រះ** )។

- តើអាកប្បកិរិយា ឬឥរិយាបទប្រភេទណាខ្លះ ដែលអ្នកបានមើលឃើញ នៅក្នុងខ្លួនអស់អ្នកទាំងឡាយដែលស៊ូទ្រាំការរងទុក្ខដោយស្មោះត្រង់នោះ ? តើតាមវិធីណាខ្លះ ដែលអ្នកបានស្គាល់ព្រះ តាមរយៈការសាកល្បងដែលអ្នកបានជួបប្រទះ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីគោលការណ៍មួយ ដែលយើងបានរៀននៅក្នុងមេរៀនថ្ងៃនេះ ។ អ្នកអាចចង់ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកផងដែរ ។

មេរៀនសិក្សានៅផ្ទះ

# ការស្នងតំណែងបន្តនៅក្នុងគណៈប្រធាន ការចាកចេញពីទីក្រុងណៅវូ និង ការធ្វើដំណើរទៅទិសខាងលិច ( មេរៀនទី ៣០ )

## ការរៀបចំមេរៀនសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបមេរៀនសម្រាប់សិស្សសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សាមេរៀនទី ៣០ ។ សេចក្ដីសង្ខេបនេះមិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនសម្រាប់មេរៀនទី ៣០ ផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ( ការស្នងតំណែងបន្តនៅក្នុងគណៈប្រធាន )

សិស្សបានរៀនពីគោលការណ៍ខាងក្រោមអំពីការស្នងតំណែងបន្តនៅក្នុងគណៈប្រធាន ៖ ពួកសាវកកាន់កូនសោទាំងឡាយនៃអំណាចបព្វជិតភាពដែលចាំបាច់ដល់ការដឹកនាំសាសនាចក្រ ។ នៅពេលប្រធានសាសនាចក្រទទួលមរណភាព គណៈប្រធានទីមួយត្រូវបានរំលាយ ហើយកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក្លាយជាកូរ៉ុមជាអធិបតីក្រោមការណែនាំរបស់សាវកច្បង ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ យើងអាចទទួលបានសាក្សីមួយថា អស់អ្នកដែលដឹកនាំសាសនាចក្រត្រូវបានហៅបម្រើដោយព្រះ ។

### ថ្ងៃទី ២ ( ការចាកចេញពីទីក្រុងណៅវូ ការធ្វើដំណើរឆ្លងកាត់រដ្ឋអៃអូវ៉ា; គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨)

តាមរយៈការសិក្សាអំពីកិច្ចខិតខំរបស់ពួកបរិសុទ្ធដើម្បីបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធណៅវូ ពីមុនពួកគេត្រូវបានបង្ខំឲ្យចាកចេញពីរដ្ឋអិលលីណោយ សិស្សបានរៀនថា ការទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធគឺវាសមនឹងកិច្ចខិតខំ និង ការបូជាដ៏សុចរិតទាំងអស់របស់យើង ។ ពួកគេក៏បានរៀនផងដែរថា ព្រះអម្ចាស់តម្រូវឲ្យពួកយើងរស់នៅតាមសេចក្ដីសញ្ញាដែលយើងធ្វើ ។

### ថ្ងៃទី ៣ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២)

នៅពេលសិស្សបានសិក្សាវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦ ពួកគេបានរៀនថា ប្រសិនបើយើងរីករាយយើងគួរតែសរសើរ និង ថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ ហើយថាប្រសិនបើយើងមានទុក្ខព្រួយ នោះយើងគួរតែអធិស្ឋានសូមឲ្យដួងព្រលឹងរបស់យើងមានក្ដីអំណរផង ។ ពួកគេបានឃើញថាការសាកល្បងរបស់យើង អាចរៀបចំយើងឲ្យទទួលសិរីល្អរបស់ព្រះដែលមានសម្រាប់ពួកយើង ហើយថាប្រសិនបើយើងបន្ទាបខ្លួន ហើយអំពាវនាវរកព្រះ នោះព្រះវិញ្ញាណនឹងបំភ្លឺយើង ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងឧស្សាហ៍ព្យាយាមក្នុងការគោរពព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះការជំនុំជម្រះរបស់ព្រះអម្ចាស់នឹងពុំមានមកលើយើងឡើយ សេចក្ដីជំនឿរបស់យើងនឹងរឹងមាំ ហើយមារសត្រូវរបស់យើងនឹងគ្មានជ័យជំនះលើយើងឡើយ ។

### ថ្ងៃទី ៤ ( ក្រុមអ្នកត្រួសត្រាយរទេះអូសឆ្នាំ ១៨៥៦–៦០ )

សិស្សបានរៀនអំពីការសាកល្បងនៃក្រុមអ្នកត្រួសត្រាយរទេះអូស ហើយបានឃើញថា ប្រសិនបើយើងស៊ូទ្រាំដោយអត់ធ្មត់ចំពោះដំណឹងល្អ នោះយើងអាចត្រូវបានញែកចេញសម្រាប់សេចក្ដីល្អ ។ ពួកគេក៏បានរៀនផងដែរថា ក្នុងនាមជាកូនសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងត្រូវតែជួយដល់អស់អ្នកខ្វះខាត ។ ពួកគេក៏បានរៀនផងដែរថា នៅពេលយើងស៊ូទ្រាំការរងទុក្ខដោយស្មោះត្រង់ នោះយើងអាចកាន់តែស្គាល់ទ្រង់ ។

## សេចក្តីផ្តើម

តាមរយៈមេរៀននេះ សិស្សនឹងយល់ថាពួកគេអនុវត្តសេចក្តីជំនឿ នៅពេលពួកគេធ្វើតាមការទូន្មាន និង ការណែនាំនៃថ្នាក់ដឹកនាំសាសនាចក្ររបស់យើង ។ ពួកគេនឹងរៀនផងដែរថា ព្រះអម្ចាស់នឹងប្រទានពរពួកគេនៅពេលពួកគេជួយមនុស្សដទៃដែលខ្វះខាត ហើយរៀបចំផ្លូវដល់ពួកគេ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦:១–១៨

*ព្រះអម្ចាស់ប្រទានព្រះឱវាទដល់ពួកបរិសុទ្ធឲ្យរៀបចំខ្លួនពួកគេ និង រៀបចំបន្តដំណើររបស់ពួកគេទៅទិសខាងលិច*

សូមបិទមុខសិស្សម្នាក់ ហើយយកគាត់ទៅដាក់នៅជ្រុងម្ខាងនៃបន្ទប់ ។ បន្ទាប់មកសូមរៀបចំរបស់របរមួយចំនួននៅក្នុងថ្នាក់ឡើងវិញ សូមធ្វើវាឲ្យឮសំឡេងដូច្នេះសិស្សអាចប្រាប់ថាឥវ៉ាន់នោះត្រូវបានផ្លាស់ប្តូរទីតាំង ។ សូមឲ្យសិស្សដែលត្រូវបានបិទមុខនោះជ្រើសរើសមិត្តរួមថ្នាក់ម្នាក់ឲ្យនិយាយប្រាប់ ដើម្បីជួយគាត់ដើរទៅដល់ជ្រុងម្ខាងទៀតនៃបន្ទប់ ។ នៅពេលសិស្សជ្រើសរើសនរណាម្នាក់ហើយនោះ សូមសួរ ៖

- ហេតុអ្វីអ្នកជ្រើសរើសបុគ្គលម្នាក់នោះ ?
- តើការទុកចិត្តរបស់យើងលើបុគ្គលផ្សេងទៀតជះឥទ្ធិពលលើរបៀប ដែលយើងធ្វើតាមការណែនាំរបស់ពួកគេយ៉ាងដូចម្តេច ?

សូមឲ្យសិស្សដែលនាំផ្លូវដល់សិស្សដែលត្រូវបានបិទមុខនោះ និយាយប្រាប់ផ្លូវដែលនឹងជួយឲ្យគាត់ដើរទៅដល់ជ្រុងម្ខាងទៀតនៃបន្ទប់ ។ ក្រោយមកសូមបង្គាប់សិស្សទាំងពីរនោះឲ្យត្រឡប់ទៅអង្គុយវិញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោម អំពីការធ្វើដំណើររបស់ពួកបរិសុទ្ធចេញពីទីក្រុងណៅវូ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់អំពីរបៀបនានានៃបទពិសោធន៍របស់ពួកបរិសុទ្ធអាចមាន ដែលស្រដៀងនឹងបទពិសោធន៍នៃសិស្សដែលត្រូវបានដឹកនាំឲ្យដើរឆ្លងក្នុងបន្ទប់រៀននោះ ។

ក្រោមការគម្រាមកំហែងដ៏សាហាវព្រៃផ្សៃមកពីពួកជនកំណាចក្នុងមូលដ្ឋាន នោះពួកបរិសុទ្ធបានចាប់ផ្តើមចាកចេញពីទីក្រុងណៅវូ នៅខែ កុម្ភៈ ឆ្នាំ ១៨៤៦ ធ្វើដំណើរទៅទិសខាងលិចដោយឆ្លងកាត់រដ្ឋអៃអូវ៉ា ។ « ការចាកចេញពីទីក្រុងណៅវូគឺជា ទង្វើមួយនៃសេចក្តីជំនឿរបស់ពួកបរិសុទ្ធ ។ ពួកគេបានចាកចេញទៅដោយពុំដឹងពីទីកន្លែងពិតប្រាកដថានឹងទៅទីណា ឬ នៅពេលណាពួកគេនឹងទៅដល់កន្លែងមួយដែលពួកគេអាចបោះទីតាំងរស់នៅបានឡើយ ។ ពួកគេគ្រាន់តែដឹងថាពួកគេត្រូវបានបណ្តេញចេញពីរដ្ឋអិលលីណោយ ដោយសារមារសត្រូវរបស់ខ្លួន ហើយថាថ្នាក់ដឹកនាំរបស់ពួកគេបានទទួលវិវរណៈដើម្បីបោះទីតាំងនៃជនភាសខ្លួននៅកន្លែងមួយនៅក្នុងតំបន់ រ៉ក់គី ម៉ោនធីន » (*Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទី ២ [ Church Educational System manual ឆ្នាំ ២០០៣ ] ទំព័រ ៣០៩ ) ។

- បទពិសោធន៍របស់ពួកបរិសុទ្ធដែលចាកចេញពីទីក្រុងណៅវូ ស្រដៀងទៅនឹងបទពិសោធន៍នៃសិស្សដែលត្រូវបានដឹកនាំឲ្យដើរឆ្លងក្នុងបន្ទប់រៀននោះយ៉ាងដូចម្តេច ?
- តើយើងអាចរៀនអ្វីខ្លះចេញពីបទពិសោធន៍របស់ពួកបរិសុទ្ធដែលចាកចេញពីទីក្រុងណៅវូ ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ៗគ្នា ប៉ុន្តែពួកគេគួរតែប្រាប់គោលការណ៍ខាងក្រោម ៖ **យើងអនុវត្តសេចក្តីជំនឿនៅពេលយើងធ្វើតាមការទូន្មាន និង ការណែនាំរបស់ថ្នាក់ដឹកនាំសាសនាចក្រ**) ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ) ។

សូមអញ្ជើញសិស្សឲ្យបើកទៅផែនទីទី ៦ (« ដំណើរនៃសាសនាចក្រទៅទិសខាងលិច ») នៅក្នុងផ្នែកផែនទីប្រវត្តិសាសនាចក្រនៃព្រះគម្ពីររបស់ពួកគេ និង ប្រាប់ពីទីតាំងនៃទីក្រុងណៅវូ និង វិនធើរ ខ្វតធើរ ។ សូមពន្យល់ថា ដោយសារតែភ្លៀងធ្លាក់យ៉ាងខ្លាំង និងការផ្គត់ផ្គង់មិនគ្រប់គ្រាន់ នោះពួកបរិសុទ្ធដែលបានចាកចេញពីទីក្រុងណៅវូនៅខែ កុម្ភៈ ឆ្នាំ ១៨៤៦ បានចំណាយពេលបួនខែធ្វើដំណើរឆ្លងកាត់រដ្ឋអៃអូវ៉ាចម្ងាយ ៤៨០គីឡូម៉ែត្រ ។ ល្បឿននៃការធ្វើដំណើររបស់ក្រុមនេះមានការយឺតយ៉ាវ ដោយសារតែលក្ខខណ្ឌទាំងនេះ និង ដោយសារពួកគេបានបាត់បង់ការបម្រើពីបុរស ៗនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជាង ៥០០ នាក់ ។ បុរសទាំងនេះ ដែលបានស្គាល់ថាជាកងវរសេនាតូចមរមន បានស្តាប់តាមការអំពាវនាវរបស់ប្រធាន យ៉ង់ឲ្យចូលបម្រើកងទ័ពសហរដ្ឋ ដើម្បីរកប្រាក់ជួយដល់សមាជិកសាសនាចក្រដែលក្រីក្រឲ្យធ្វើដំណើរទៅទិសខាងលិច ។ ការបូជា

នេះបានជួយយ៉ាងច្រើន ប៉ុន្តែវាក៏បានបន្សល់ទុកនូវក្រុមគ្រួសារជាច្រើនឲ្យគ្មានស្វាមី និង ឪពុកក្នុងការធ្វើដំណើរជាមួយពួកគេផងដែរ ។ ដោយគិតពីការធ្វើដំណើរយ៉ាងយឺតនោះ អ្នកដឹកនាំសាសនាចក្របានសម្រេចចិត្តមិនបន្តដំណើរទៅភាគខាងលិចនៃភ្នំរ៉ុកគី ម៉ោនធីនឡើយរហូតដល់រដូវផ្ការីកឆ្នាំ ១៨៤៧ ។ ពួកលោកបានទូន្មានដល់ពួកបរិសុទ្ធ ឲ្យបោះទីលំនៅសម្រាកសម្រាប់រដូវរងានោះ ។ ការបោះទីលំនៅដ៏ធំបំផុតមួយ ត្រូវបានធ្វើឡើងនៅវិនធើរ ខ្វតធើរនៅភាគខាងលិចនៃដងទន្លេមិសស៊ូរី ដែលបច្ចុប្បន្ននេះគឺជារដ្ឋណេប្រាស្កា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីសង្ខេបខាងក្រោមដែលពិពណ៌នាអំពីវិនធើរ ខ្វតធើរ និង ការបោះទីលំនៅបណ្ដោះអាសន្នផ្សេងៗទៀត ៖

ពួកបរិសុទ្ធជាច្រើនបានរស់នៅក្នុងផ្ទះដាច់ៗពីគ្នា និង នៅក្នុងខ្ទមដែលធ្វើពីឈើ និង ដី ។ មានមនុស្សជាច្រើនដែលខ្វះជម្រកជ្រកពីអាកាសធាតុត្រជាក់នេះ ។ ជំងឺជាច្រើនដូចជា គ្រុនចាញ់ រលាកសួត របេង អាសន្នរោគ និង ជំងឺខ្វះវីតាមីនសេ ដែលធ្វើឲ្យមានការរងទុក្ខ និង ស្លាប់ជាច្រើននាក់ ។ មានមនុស្សជាង ៧០០នាក់បានស្លាប់នៅក្នុងជំរំនៅចុងរដូវរងាដំបូងនោះ ។ ( សូមមើល *Our Heritage: A Brief History of The Church of Jesus Christ of Latter–day Saints* [ ឆ្នាំ ១៩៩៦ ] ទំព័រ ៧១–៧២; *Church History in the Fulness of Times Student Manual,* ទំព័រ ៣១៩–២០ ) ។

- ប្រសិនបើអ្នកបាននៅជាមួយពួកបរិសុទ្ធនៅវិនធើរ ខ្វតធើរ តើអ្នកនឹងមានអារម្មណ៍បែបណា ដោយដឹងថាអ្នកនឹងនៅតែត្រូវធ្វើដំណើរទៅមុខរាប់រយគីឡូម៉ែត្រទៀតដូច្នេះនោះ ?

អ្នកអាចបង្ហាញថា ទោះបីជាអំឡុងពេលនៃការរងទុក្ខ និង សេចក្តីស្លាប់នោះ ពួកបរិសុទ្ធដ៏សុចរិតត្រូវបានប្រទានពរដោយសារសេចក្តីសញ្ញាដែលពួកគេបានធ្វើ ។ អ្នកក៏អាចពន្យល់ផងដែរថា ព្រះអម្ចាស់បានសន្យានូវពរជ័យដ៏មហិមាដល់អស់អ្នកដែលស្លាប់នៅក្នុងការបម្រើរបស់ទ្រង់ ( សូមមើល អាលម៉ា ៤០:១១–១២; ៦០:១៣; គ. និង ស. ៤២:៤៦) ។

សូមឲ្យសិស្សមើលសារចុះសារឡើងនៅក្នុងសេចក្តីណែនាំកណ្ឌនៃ គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦ រកមើលទីកន្លែងដែលវិវរណៈនេះបានប្រទានឲ្យ និង នរណាបានទទួលវា ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦:១ ឲ្យឮៗ ។

- តើអ្នកគិតថាខគម្ពីរអាចជួយពួកបរិសុទ្ធដឹងឲ្យថា ព្រះអម្ចាស់បានបន្តបើកសម្ដែងព្រះឆន្ទៈរបស់ទ្រង់ចំពោះពួកគេតាមរបៀបណា ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លាស់វេនគ្នាអានពី គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦:២–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធធ្វើ ដើម្បីរៀបចំបន្តការធ្វើដំណើរទៅភាគខាងលិចរបស់ពួកគេ ។

- តើក្រុមនិមួយៗត្រូវបានរៀបចំយ៉ាងដូចម្តេច ?
- ហេតុអ្វីអ្នកគិតថា វាមានប្រយោជន៍ដើម្បីរៀបចំពួកបរិសុទ្ធជាក្រុមៗជាមួយនឹងអ្នកដឹកនាំដែលបានជ្រើសតាំងដូច្នេះ ? តើការណ៍នេះស្រដៀងគ្នាទៅនឹង របៀបដែលសាសនាចក្រត្រូវបានរៀបចំឡើងនៅសព្វថ្ងៃយ៉ាងដូចម្តេច ? ( នៅពេលសិស្សឆ្លើយសំណួរទាំងនេះ អ្នកអាចសរសេរសេចក្តីពិតដូចតទៅនេះនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់រៀបចំពួកបរិសុទ្ធរបស់ទ្រង់ទៅជាក្រុមៗ ដើម្បីឲ្យបុគ្គលម្នាក់ៗអាចត្រូវបានដឹកនាំ និង ត្រូវបានយកចិត្តទុកដាក់ដល់ពួកគេ** ) ។

សូមពន្យល់ថាដោយសារតែជំងឺ និង សេចក្តីស្លាប់នៅវិនធើរ ខ្វតធើរ និង នៅជំរំជុំវិញនោះ មានក្រុមគ្រួសារ និង មនុស្សជាច្រើននាក់ត្រូវការជំនួយហិរញ្ញវត្ថុ ដូច្នេះពួកគេអាចបន្តដំណើររបស់ខ្លួនទៅទិសខាងលិចទៀត ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យពួកគេសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦:៦–១១ ជាមួយគ្នា ដោយស្វែងរកមើលរបៀបនានា ដែលពួកបរិសុទ្ធបានថែទាំដល់អស់អ្នកដែលខ្វះខាត ។ ( អ្នកអាចផ្ដល់យោបល់ឲ្យ សិស្សគូសចំណាំអ្វីដែលពួកគេរកឃើញ ) ។ ពីមុនសិស្សអានវគ្គព្រះគម្ពីរនេះ សូមពន្យល់ថាពួកបរិសុទ្ធទាំងអស់គ្នាពុំបានចាកចេញពីវិនធើរ ខ្វតធើរនៅពេលតែមួយជាមួយគ្នានោះឡើយ ។ ឃ្លា « អស់អ្នកដែលត្រូវនៅ » នៅក្នុង ខ ៦ សំដៅលើពួកបរិសុទ្ធដែលបន្តនៅមួយរយៈពេលទៀតនៅវិនធើរ ខ្វតធើរ និង ជំរំជុំវិញនោះ ។

- តើពាក្យ ឬឃ្លាណាខ្លះនៅក្នុង ខ ៦–១១ ដែលបង្ហាញពីរបៀបដែលពួកបរិសុទ្ធត្រូវមើលថែទាំដល់អស់អ្នកដែលខ្វះខាតនោះ ?
- តើមានពាក្យអ្វីនៅក្នុង ខ ៧ ដែលសំដៅទៅលើមនុស្សដែលរៀបចំផ្លូវសម្រាប់មនុស្សដទៃនោះ ? ( ពួកអ្នកត្រួសត្រាយ ) ។

សូមសរសេរ និយមន័យខាងក្រោមនេះ នៅលើក្ដារខៀន ។ ( វាត្រូវបានដកស្រង់ចេញពី *Oxford English Dictionary,* ការបោះពុម្ពលើកទីពីរ [ ឆ្នាំ ១៩៨៩ ] « pioneer » ) ។

> *អ្នកត្រួសត្រាយ ៖ មនុស្សដែលដើរទៅមុន ដើម្បីរៀបចំ ឬ បើកផ្លូវសម្រាប់មនុស្សដទៃទៀតឲ្យដើរតាម ។*

- យោងតាម ខ ១១, តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់អស់អ្នកដែលនឹងជួយមនុស្សដទៃដែលខ្វះខាត និងរៀបចំផ្លូវសម្រាប់ពួកគេ ? តើយើងអាចរៀនអ្វីចេញពីការណ៍នេះ ? ( បន្ទាប់ពីសិស្សឆ្លើយហើយ អ្នកអាចសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់នឹងប្រទានដល់យើង នៅពេលយើងជួយដល់អ្នកដទៃដែលទីទ័លក្រ និងរៀបចំផ្លូវសម្រាប់ពួកគេ**) ។
- តើនរណាបានរៀបចំផ្លូវសម្រាប់អ្នក ដើម្បីឲ្យអ្នកបានរីករាយនឹងពរជ័យនៃដំណឹងល្អ ?

សូមឲ្យសិស្សពិចារណាពីសំណួរខាងក្រោម ។ បន្ទាប់មកសូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីក្លាយជាអ្នកត្រួសត្រាយផ្លូវ—ជួយដល់អ្នកដទៃដែលទីទ័លក្រ និង រៀបចំផ្លូវសម្រាប់ពួកគេឲ្យរីករាយនឹងពរជ័យនៃដំណឹងល្អ ?

សូមបញ្ចប់មេរៀន ដោយថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលអ្នកបានពិភាក្សា ហើយលើកទឹកចិត្តអញ្ជើញដល់សិស្សឲ្យធ្វើតាមសេចក្ដីពិតទាំងនោះ ។

## មេរៀនបន្ទាប់ ( សង្គ្រាមនៅយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ ការលេចចេញមកនៃព្រះគម្ពីរមុក្ដាដ៏មានតម្លៃមហិមា សេចក្ដីប្រកាសជាផ្លូវការទី ១, និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨)

ដើម្បីជួយសិស្សរៀនចំខ្លួនសម្រាប់ ការសិក្សារបស់ពួកគេអំឡុងពេលនៃសប្ដាហ៍នេះ សូមឲ្យ ពួកគេពិចារណាសំណួរខាងក្រោមនេះ ៖ តើលទ្ធផលអ្វីខ្លះនឹងកើតឡើងតាមរយៈការលាក់បាំងអំពើបាប ? នៅក្នុងមេរៀនបន្ទាប់សិស្សនឹងរៀន អំពីព្រឹត្តិការណ៍ដ៏សោកនាដកម្មមួយដែលបានហៅថាការសម្លាប់រង្គាលនៅភ្នំម៉េដូ ដែលបានកើតឡើងនៅពេលសមាជិកសាសនាចក្រមួយចំនួនបានព្យាយាមលាក់បាំងអំពើបាបរបស់ខ្លួន ។ ពួកគេក៏នឹងរៀនផងដែរអំពីវឌ្ឍនៈភាពរបស់សាសនាចក្រ នៅពេលពួកបរិសុទ្ធបានបោះទីលំនៅក្នុងជ្រលងភ្នំសលត៍ លេក ។

មេរៀនទី ១៥១

# សង្គ្រាមនៅយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ

### បុព្វកថា

អំឡុងទសវត្សរ៍ឆ្នាំ ១៨៥០ ភាពតានតឹង និង ទំនាក់ទំនងយល់ច្រឡំរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និង ពួកមន្ត្រីរដ្ឋាភិបាលសហរដ្ឋអាមេរិកបាននាំឲ្យមានសង្គ្រាមនៅរដ្ឋយូថាហ៍នាឆ្នាំ ១៨៥៧–៥៨ ។ ក្នុងខែ កញ្ញា ឆ្នាំ ១៨៥៧ មានជម្លោះមួយកើតឡើងផងដែររវាងពួកបរិសុទ្ធមួយចំនួន និង សមាជិកក្រុមរទេះសេះដែលបានធ្វើអន្តោប្រវេសន៍ឆ្លងកាត់រដ្ឋ យូថាហ៍ ។ ដោយសារតែបានជំរុញដោយកំហឹង និង ភាពភ័យខ្លាច នោះពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួននៅខាងត្បូងរដ្ឋយូថាហ៍ បានរៀបផែនការ ហើយអនុវត្តការសម្លាប់រង្គាលពួកអន្តោប្រវេសន៍ប្រមាណជា ១២០ នាក់ ដែលធ្វើដំណើរទៅរដ្ឋ កាលីហ្វូញ៉ា ។ ភាពសាហាវយ៉ង់ឃ្នងនេះត្រូវបានគេហៅពេលនេះ ថាជាការសម្លាប់រង្គាលនៅភ្នំម៉េដូ ។

## យោបល់សម្រាប់ការបង្រៀន

### ភាពតានតឹងដែលបានកើតឡើងរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និងរដ្ឋាភិបាលសហរដ្ឋអាមេរិក

សូមពន្យល់ថានៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៨៥៧ ប្រធាន ព្រិកហាំ យ៉ង់ បាននៅជាមួយនឹងក្រុមពួកបរិសុទ្ធមួយដែលកំពុងប្រារព្ធខួបរំឭកលើកទី ១០ នៃការមកដល់របស់ពួកគេនៅក្នុងជ្រលងភ្នំសលត៍ លេកនេះ នៅពេលលោកបានទទួលការបញ្ជាក់អំពីដំណឹងពីមុននោះថា កងទព័មួយក្រុមកំពុងមកកាន់ទីក្រុង សលត៍ លេក ។ កាលពីប៉ុន្មានឆ្នាំមុន មានការមិនយល់ព្រម និងការខ្វែងគំនិតគ្នាដែលបន្សល់ទុកនូវការកើនឡើងនូវភាពតានតឹងរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និងពួកមន្ត្រីរាជការនៃរដ្ឋាភិបាលសហរដ្ឋ ។ ពួកបរិសុទ្ធចង់បានអ្នកដឹកនាំដែលពួកគេបានជ្រើសរើស ហើយបានបដិសេធនូវការចាត់តាំងរបស់សហពន្ធ័ ដែលមិនបានឲ្យតម្លៃដល់ពួកគេ ។ នោះនាំឲ្យមន្ត្រីសហព័ន្ធមួយចំនួនបានគិតថា ពួកគេបានបះបោរទាស់នឹងរដ្ឋាភិបាលអាមេរិក ។ ដោយគ្មានការអនុមតិមកពីរដ្ឋសភា នោះប្រធានាធិបតី ជេម ប៊ូឃែន្និន បានបញ្ជូនកងទ័ពប្រហែលជា ១៥០០ ទៅកាន់ទីក្រុងសលត៍លេក បង្ខំឲ្យពួកយូថាហ៍ទទួលយកជាផ្លូវការថ្មី ។

- ប្រសិនបើអ្នកជាពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់នៅឆ្នាំ ១៨៥៧ ហើយបានឮថា កងទ័ពដ៏ធំមួយក្រុមកំពុងតែចូលមកដល់ទីក្រុងរបស់អ្នក តើអ្នកអាចនឹងមានការបារម្ភអ្វីខ្លះ ? ( សិស្សប្រហែលជាលើកឡើងថា ពួកបរិសុទ្ធត្រូវបានបណ្ដេញយ៉ាងព្រៃផ្សៃចេញពីរដ្ឋអូហៃអូ មិសសួរី និងអិលលីណយ ហើយមនុស្សជាច្រើនបានបាត់បង់របស់ និងដីធ្លី ដ៏មានតម្លៃ ហើយអ្នកខ្លះត្រូវបានគេសម្លាប់ ឬបានស្លាប់ក្នុងអំឡុងពេលបៀតបៀនទាំងនេះ ។ ដំណឹងនៃការមកដល់របស់កងទ័ពបានបណ្ដាលឲ្យពួកបរិសុទ្ធខ្លះបារម្ភថា ព្រឹត្តិការណ៍បែបនោះក៏អាចនឹងកើតឡើងនៅក្នុងរដ្ឋយូដាហ៍ដែរ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ៖

នៅក្នុងទេសនកថាដល់ពួកបរិសុទ្ធ ប្រធាន យ៉ង់ និងអ្នកដឹកនាំសាសនាចក្រផ្សេងទៀតបានចាត់ទុកកងទ័ពដែលនឹងមកនោះថាជាសត្រូវ ។ ប្រធាន យ៉ង់ ដែលបានសុំឲ្យពួកបរិសុទ្ធសន្សំទុកគ្រាប់ធញ្ញជាតិអស់រយៈពេលជាច្រើនឆ្នាំមកហើយ បានផ្ដល់ការណែនាំជាថ្មីរបស់លោក ដើម្បីឲ្យពួកគេនឹងមានអាហារបរិភោគ ក្នុងករណីពួកគេត្រូវរត់គេចពីកងទ័ពនេះ ។ ក្នុងនាមជាអភិបាលរដ្ឋយូថាហ៍ លោកក៏បានដឹកនាំឲ្យក្រុមជីវពលដែនដីរៀបចំការពារដល់បូរណភាពទឹកដីដែរ ។

### ជម្លោះបានកើតឡើងរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួន និងសមាជិកនៃពួកអន្តោប្រវេសន៍ក្រុមរទេះសេះ

សូមបង្ហាញផែនទី ១ ដែលស្រដៀងគ្នានឹងការដាក់បញ្ចូលនៅទីនេះមួយ ឬគូរវានៅលើក្ដារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮនូវកថាកណ្ឌពីរខាងក្រោម ៖




ក្រុមរទេះសេះ ដែលធ្វើអន្តោប្រវេសន៍ បានធ្វើដំណើរមកភាគខាងលិចពីរដ្ឋអាកាន់សាស ទៅកាន់រដ្ឋកាលីហ្វ័រញ៉ា បានចូលមក រដ្ឋ យូថាហ៍ ចំពេលដែលពួកបរិសុទ្ធថ្ងៃចុងក្រោយកំពុងរៀបចំការពារដែនដី ប្រឆាំងនឹងការមកដល់នៃកងទ័ពរបស់សហរដ្ឋ ។ សមាជិកនៃក្រុមរទេះខ្លះបានមានចិត្តរសាប់រសល់ ដោយសារតែពួកគេពិបាកនឹងទិញគ្រាប់ធុញ្ញជាតិដែលត្រូវការជាខ្លាំងពីពួកបរិសុទ្ធ ដែលត្រូវបានណែនាំឲ្យរក្សាគ្រាប់ធុញ្ញជាតិនោះទុក ។ ពួកជនអន្តោប្រវេសន៍នោះក៏បានមានជម្លោះជាមួយនឹងពួកបរិសុទ្ធ ដែលមិនចង់ឲ្យសេះ និងសត្វគោរបស់ក្រុមរទេះនេះស៊ីអាហារនិង ផឹកទឹកដែលពួកបរិសុទ្ធត្រូវការសម្រាប់សត្វរបស់ពួកគេផ្ទាល់ដែរ ។

ទំនាស់បានផ្ទុះឡើងនៅទីក្រុងសេដា ជាទីតាំងចុងក្រោយគេនៅក្នុងរដ្ឋ យូថាហ៍តាមដងផ្លូវទៅកាន់រដ្ឋកាលីហ្វ័រញ៉ា ។ ការប្រឈមមុខជាច្រើនបានកើតឡើង រវាងសមាជិកនៃក្រុមរទេះសេះខ្លះ និង ពួកបរិសុទ្ធថ្ងៃចុងក្រោយខ្លះ ។ សមាជិកក្រុមរទេះសេះខ្លះបានគំរាមកំហែងថា នឹងចូលរួមក្នុងកងទ័ពរដ្ឋាភិបាលដែលកំពុងតែចេញដំណើរមកប្រឆាំងនឹងពួកបរិសុទ្ធនោះ ។ ទោះបីជាមេបញ្ជាការនៃក្រុមរទេះសេះនេះបានស្ដីបន្ទោសដល់ដៃគូរបស់លោកដោយសារបានធ្វើការគម្រាមកំហែងទាំងនេះក្ដី ក៏អ្នកដឹកនាំទីក្រុងសេដាខ្លះ និងអ្នករស់នៅទីនោះបានចាត់ទុកថាជនអន្តោប្រវេសន៍នេះជាសត្រូវដែរ ។ ក្រុមរទេះសេះនេះបានចាកចេញពីទីក្រុងក្រោយពីបានមកដល់តែត្រឹមប្រហែលមួយម៉ោងប៉ុណ្ណោះ ប៉ុន្តែប្រជាជន និងអ្នកដឹកនាំខ្លះនៅទីក្រុងសេដាបានចង់ដេញតាម និងដាក់ទោសដល់មនុស្សទាំងឡាយដែលបានមើលងាយដល់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីពេល ដែលពួកគេបានជួបនឹងជម្លោះជាមួយនឹងមនុស្សផ្សេងទៀត ឬមនុស្សមួយក្រុម ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ៣ ១២:២៥ ឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម រកមើលគោលការណ៍មួយដែលព្រះយេស៊ូវបានបង្រៀន ដែលអាចដឹកនាំយើង នៅពេលយើងជួបនឹងភាពតានតឹងជាមួយនឹងអ្នកដទៃ ។

- តើអ្នកគិតថា វាមានន័យដូចម្ដេចក្នុងឃ្លា « ព្រមព្រៀងជាមួយនឹងអ្នកដើមចោទអ្នកជាប្រញាប់ » ?

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃឃ្លានេះ អ្នកអាចសុំឲ្យសិស្សម្នាក់អានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ៖

អែលឌើរ ដេវីឌ អ៊ី សូរិនសិន នៃពួកចិតសិបនាក់ បានបង្រៀនថា ឃ្លា « ព្រមព្រៀងជាមួយនឹងអ្នកដើមចោទអ្នកជាប្រញាប់ » មានន័យថា « ដោះស្រាយនូវភាពខុសគ្នារបស់យើងឲ្យបានរហ័ស បើមិនដូច្នោះទេ កំហឹងមួយគ្រានោះនឹងកើនឡើងទៅជាហិង្សាខាងរាងកាយ ឬសតិអារម្មណ៍ ហើយយើងបានជាប់ក្នុងកំហឹងរបស់យើង » Forgiveness Will Change Bitterness to Love » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៣, ទំព័រ ១១) ។

- តើអ្នកគប្បីសង្ខេបការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១២:២៥ តាមពាក្យរបស់អ្នក ដោយរបៀបណា ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរគោលការណ៍ស្រដៀងគ្នាទៅនឹងអ្វីដូចតទៅនៅលើក្ដារខៀន ៖ **បើយើងដោះស្រាយជម្លោះជាមួយនឹងអ្នកដទៃតាមរបៀបរបស់ព្រះអម្ចាស់ នោះយើងអាចចៀសវាងពីឥទ្ធិពលដែលនាំឲ្យមហន្តរាយដោយការទាស់ទែងគ្នា** ) ។

- តើការគោរពតាមគោលការណ៍នៅក្នុង នីហ្វៃទី ៣ ១២:២៥ បានជួយពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលបានអាក់អន់ចិត្តនឹងសមាជិកនៃក្រុមរទេះសេះយ៉ាងដូចម្ដេច ?

សូមពន្យល់ថា ដោយសារពួកបរិសុទ្ធទាំងនេះមិនបានដោះស្រាយនូវជម្លោះរបស់ពួកគេជាមួយនឹងពួកជនអន្តោប្រវេសន៍តាមរបៀបរបស់ព្រះអម្ចាស់ នោះស្ថានការណ៍នេះបានក្លាយទៅជាកាន់តែធ្ងន់ទៅៗ ។ អ៊ីសាក ហេត ជាអភិបាលក្រុងសេដា ជាវរសេនីយត្រីជីវពល និងជាប្រធានស្តេក បានស្នើសុំការអនុញ្ញាតពីមេបញ្ជាការជីវពល ដែលបានរស់នៅក្បែរទីក្រុងផារ៉ូវ៉ាន់ ឲ្យកោះហៅជីវពលឲ្យជួយបង្ក្រាបពួកអ្នកមើលងាយពីក្រុមរទេះ ។ មេបញ្ជាការជីវពលឈ្មោះ វិល្លាម ដេម បានប្រឹក្សានឹងអ៊ីសាក ហេត កុំឲ្យខ្វល់នឹងការគម្រាមរបស់ពួកអន្តោប្រវេសន៍នោះ ។ ជាជាងស្តាប់តាមការប្រឹក្សានេះ អ៊ីសាក ហេត និងអ្នកដឹកនាំទីក្រុងសេដាផ្សេងទៀតបានសម្រេចចិត្តទៅបញ្ចុះបញ្ចូលពួកសាសន៍អាមេរិកាំងដើមក្នុងស្រុកខ្លះឲ្យវាយប្រហារក្រុមរទេះសេះ និងទៅលួចគោរបស់ពួកគេ ដើម្បីជារបៀបមួយក្នុងការដាក់ទោសដល់ពួកជនអន្តោប្រវេសន៍នោះ ។ អ៊ីសាក ហេត បានសុំឲ្យ ចន ឌី លី ជាសមាជិកព្រះវិហារក្នុងមូលដ្ឋានម្នាក់ និងជាវរសេនីយត្រី ដឹកនាំការវាយប្រហារនេះ ហើយបុរសទាំងពីររូបនេះបានគ្រោងដើម្បីទម្លាក់កំហុសលើពួកសាសន៍អាមេរិកាំងដើមចំពោះទង្វើនេះ ។

- តើអ្នកដឹកនាំទីក្រុងសេដា គួរតែបានធ្វើអ្វីខ្លះ នៅពេលវិល្លាម ដេម បានប្រឹក្សាដល់ពួកគេកុំឲ្យប្រើក្រុមជីវពល ? តើការមិនធ្វើយោបល់នាពេលនោះ បាននាំពួកគេឲ្យធ្វើអ្វីខ្លះ ? ( បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរនូវគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ប្រសិនបើយើងមិនព្រមស្តាប់តាមការប្រឹក្សាឲ្យធ្វើអ្វីដែលត្រូវទេ នោះយើងនឹងកាន់តែមានចិត្តលំអៀងទៅកាន់ការជ្រើសរើសអ្វីដែលមិនល្អ ) ។**

សូមចង្អុលបង្ហាញថា បុរសទាំងនេះ បានធ្វើផ្ទុយទៅនឹងការទទួលខុសត្រូវបព្វជិតភាពរបស់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១២១:៣៦–៣៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមានរបស់ព្រះអម្ចាស់ចំពោះអ្នកកាន់បព្វជិតភាព ដែលធ្វើទង្វើមិនសុចរិត ។

- តើ ព្រះអម្ចាស់បានប្រទានការព្រមានអ្វីខ្លះ ដល់អ្នកកាន់បព្វជិតភាព ដែលព្យាយាមដើម្បីគ្របបាំងអំពើបាបរបស់ពួកគេ ឬធ្វើទង្វើមិនសុចរិតនោះ ?

សូមអាន ឬសង្ខេបកថាខណ្ឌដូចខាងក្រោម ហើយអញ្ជើញសិស្សឲ្យស្តាប់មើលរបៀបអ្នកដឹកនាំនៅទីក្រុង សេដា បានបន្តធ្វើការជ្រើសរើសពុំល្អ បន្ទាប់ពីពុំស្តាប់តាមការទូន្មានដែលពួកគេបានទទួលនោះ ។

អ៊ីសាក ហេត បានបង្ហាញគម្រោងវាយប្រហារក្រុមរទេះនេះដល់ក្រុមប្រឹក្សាអ្នកដឹកនាំសាសនាចក្រ សហគមន៍ និងជីវពលក្នុងមូលដ្ឋាន ។ សមាជិកក្រុមប្រឹក្សាខ្លះមិនយល់ព្រមសោះឡើយ ចំពោះគម្រោងនេះ ហើយបានសួរ ហេត ថាតើលោកបានប្រឹក្សាជាមួយនឹងប្រធាន ព្រិកហាំ យ៉ង់ អំពីបញ្ហានេះហើយឬនៅ ។ ដោយបាននិយាយថា លោកមិនទាន់បានសួរនៅឡើយ លោកហេត បានយល់ព្រមបញ្ជូនសារទូតម្នាក់ គឺលោកជេម ហេសឡេម ទៅកាន់ទីក្រុងសលត៍ លេក អមដោយសំបុត្រមួយច្បាប់ពន្យល់ពីស្ថានការណ៍ និងសួរថាត្រូវតែធ្វើអ្វី ។ ទោះជាយ៉ាងណាក្តី ដោយសារទីក្រុងសលត៍ លេក មានរយៈចម្ងាយប្រហែល ២៥០ ម៉ាយល៍ ( ៤០០ គីឡូម៉ែត្រ ) ពីទីក្រុងសេដា វាត្រូវការប្រហែលជាមួយសប្តាហ៍ក្នុងការជិះសេះយ៉ាងលឿនដើម្បីទៅដល់ទីក្រុងសលត៍ លេក និងត្រឡប់មកទីក្រុងសេដាវិញដោយមានដំបូន្មានពីប្រធាន យ៉ង់ ជាមួយនឹងសារទូតនោះ ។

អំឡុងពេលយ៉ាងខ្លី មុនពេលអ៊ីសាក ហេត បានបញ្ជូនសាររបស់លោកជាមួយនឹងសារទូត ចន ឌី លី និងពួកអាមេរិកកាំងស្បែកក្រហមមួយក្រុមបានវាយប្រហារជំរុំក្រុមជនអន្តោប្រវេសន៍នៅកន្លែងមួយដែលហៅថា ភ្នំម៉េដូ ។ លី បានដឹកនាំការវាយប្រហារនេះ ប៉ុន្តែបានលាក់អត្តសញ្ញាណរបស់លោក ដើម្បីឲ្យវាមើលទៅមានតែពួកអាមេរិកកាំងស្បែកក្រហមប៉ុណ្ណោះដែលបានពាក់ព័ន្ធក្នុងរឿងនេះ ។ ជនអន្តោប្រវេសន៍ខ្លះត្រូវបានគេសម្លាប់ ឬរងរបួស ហើយអ្នកនៅសេសសល់បានបណ្តេញពួកអ្នកវាយប្រហារពួកគេ ដោយបង្ខំ ដោយលោកលី និងពួកអាមេរិកកាំងស្បែកក្រហមឲ្យដកថយ ។ ជនអន្តោប្រវេសន៍បានទាញរទេះសេះរបស់ខ្លួនជារង្វង់ ឬក្រោលមួយយ៉ាងមាំភ្លាមៗដើម្បីការពារខ្លួន ។ ការវាយប្រហារពីរដងទៀតបានកើតឡើងអំឡុងពេលការឡោមព័ទ្ធប្រាំថ្ងៃដល់ក្រុមរទេះ ។

នៅពេលមួយនោះ ពួកជីវពលទីក្រុងសេដាបានដឹងថាមានជនអន្តោប្រវេសន៍ពីរនាក់បានចេញពីក្រោលរទេះនោះ ។ ពួកជីវពលបានបាញ់ពួកគេ ដោយបានសម្លាប់គេម្នាក់ ។ បុរសម្នាក់ទៀតបានរត់គេចផុត ហើយបាននាំដំណឹងនេះទៅដល់ជុំរំរទេះសេះថាមានបុរសស្បែកសពាក់ព័ន្ធនឹងការវាយលុកប្រឆាំងនឹងពួកគេ ។ ឥឡូវនេះ អស់អ្នកដែលបានគ្រោងការវាយប្រហារនេះត្រូវបានគេដឹងពីល្បិចកលខ្លួន ។ ប្រសិនបើជនអន្តោប្រវេសន៍ត្រូវបានអនុញ្ញាតឲ្យបន្តធ្វើដំណើរទៅរដ្ឋកាលីហ្វ័រញ៉ា នោះដំណឹងនេះនឹងលេចឮថា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានទាក់ទងនឹងការវាយប្រហារលើពួកក្រុមរទេះសេះនេះ ។ ពួកអ្នករួមគំនិតក្បត់ បានខ្លាចថាដំណឹងនេះនឹងនាំឲ្យមានលទ្ធផលអវិជ្ជមាន មកដល់ខ្លួនគេ និងប្រជាជនរបស់ពួកគេ ។

- តើមានលទ្ធផលអ្វីខ្លះ កើតមកពីការសម្រេចចិត្តមិនគោរពតាមការប្រឹក្សារបស់មេបញ្ជាការជីវពល ?

- នៅចំណុចនេះ តើជម្រើសណាខ្លះ ដែលជាទំនួលខុសត្រូវរបស់អស់អ្នកដែលបានធ្វើការវាយប្រហារទាំងនោះ ? ( ពួកគេអាចសារភាពពីអ្វីដែលពួកគេបានធ្វើ និងបានទទួលលទ្ធផលនានា ឬពួកគេអាចព្យាយាមលាក់កំបាំងនូវបទឧក្រិដ្ឋ និងអំពើបាបទាំងឡាយ ។ សូមមើល គ. និង ស. ១២១:៣៧) ។

- តើពួកគេបានធ្វើអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណួរខាងក្រោមនេះ ៖

- តើអ្នកធ្វើអ្វីខ្លះ នៅពេលអ្នកធ្វើអ្វីមួយខុស ? តើអ្នកសារភាពពីអ្វីដែលអ្នកបានធ្វើខុស និងបានទទួលលទ្ធផលនានា ឬតើអ្នកព្យាយាមលាក់បាំងនូវអំពើបាបទាំងនោះតាមរយៈការបោកបញ្ឆោត ?

## ពួកបរិសុទ្ធថ្ងៃចុងក្រោយខ្លះបានគ្រោងសម្លាប់រង្គាលនៅភ្នំម៉េដូ

សូមពន្យល់ថា សមាជិកសាសនាចក្រដែលបានពាក់ព័ន្ធនៅក្នុងការវាយប្រហារពួកអន្តោប្រវេសន៍នេះ បានជ្រើសរើសយកការព្យាយាមលាក់បាំងអំពើបាបរបស់ពួកគេ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្តាប់នូវអ្វីដែលបានកើតឡើង ជាលទ្ធផលមកពីការសម្រេចចិត្តនេះ នៅពេលអ្នកអាន ឬសង្ខេបកថាកណ្ឌដូចខាងក្រោម ៖

នៅក្នុងបំណងដើម្បីរារាំងព័ត៌មាននេះកុំឲ្យរាលដាលថា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានចូលរួមនៅក្នុងការវាយប្រហារលើក្រុមរទេះសេះនេះ នោះអ៊ីសាក ហេត, ចន ឌី លី និងអ្នកដឹកនាំសាសនាចក្រក្នុងមូលដ្ឋាន និងក្រុមជីវពលបានបង្កើតគម្រោងមួយដើម្បីសម្លាប់អ្នកនៅរស់ទាំងអស់ លើកលែងតែកូនក្មេងតូចៗប៉ុណ្ណោះ ។ ក្នុងការអនុម័តគម្រោងការនេះ ចន ឌី លី បានទៅដល់ពួកអន្តោប្រវេសន៍ ហើយបាននិយាយថា ពួកជីវពលនឹងការពារពួកគេកុំឲ្យរងការវាយប្រហារផ្សេងទៀត ដោយនឹងជួយនាំពួកគេត្រឡប់ទៅកាន់ទីក្រុងសេដាវិញដោយសុវត្ថិភាព ។ នៅពេលពួកអន្តោប្រវេសន៍បានដើរទៅកាន់ទីក្រុងសេដា ពួកជីវពលបានត្រឡប់ក្រោយ និងបានបាញ់ពួកគេ ។ ពួកអាមេរិកកាំងស្បែកក្រហមខ្លះដែលបានចូលរួមនឹងពួកប្រជាជននោះបានរត់ចេញពីកន្លែងពួនមកដើម្បីជួយបាញ់បន្ថែម ។ មានជនអន្តោប្រវេសន៍ប្រហែល ១៤០ នាក់ដែលបានចូលរួមនៅក្នុងក្រុមរទេះសេះនេះ មានតែកូនក្មេង ១៧ នាក់ប៉ុណ្ណោះដែលនៅរស់ ។

ពីរថ្ងៃបន្ទាប់ពីការសម្លាប់រង្គាលនោះ ជេម ហេលឡេម បានមកដល់ទីក្រុងសេដាដោយមានសារឆ្លើយតបរបស់ប្រធាន យ៉ង់ មកផង ដែលបានណែនាំឲ្យពួកអ្នកដឹកនាំក្នុងតំបន់ឲ្យអនុញ្ញាតឲ្យក្រុមរទេះសេះនោះធ្វើដំណើរបន្តទៀតដោយមានសន្តិភាព ។ « នៅពេលហេត បានអានពាក្យរបស់ប្រធាន យ៉ង់ លោកបានយំដូចជាកូនក្មេងម្នាក់ ហើយអាចនិយាយចេញតែពាក្យ ‹ យឺតពេលហើយ យឺតពេលហើយ › » ( Richard E. Turley Jr., « The Mountain Meadows Massacre » *Ensign,* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ២០ ) ។

សូមពន្យល់ថា ជម្រើសរបស់ពួកអ្នកដឹកនាំ និងអ្នករស់នៅដែលជាបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួននៅក្នុងដែនដីរដ្ឋ យូថាហ៍ ភាគខាងត្បូង បានដឹកនាំឲ្យមានសោកនាដកម្មនោះការសម្លាប់រង្គាលនៅភ្នំម៉េដូ ។ ផ្ទុយទៅវិញ អ្នកដឹកនាំសាសនាចក្រ និងអ្នកដឹកនាំដែនដីនៅក្នុងទីក្រុងសលត៍ លេក បានដោះស្រាយជម្លោះជាមួយនឹងរដ្ឋាភិបាលសហរដ្ឋតាមរយៈការនិយាយ និងការចរចារដោយសន្តិភាពនៅក្នុងឆ្នាំ ១៨៥៨ ។ អំឡុងពេលនៃជម្លោះនេះ —ដែលក្រោយមកត្រូវបានហៅថា សង្គ្រាមរដ្ឋយូថាហ៍ — ពួកទាហានសហរដ្ឋ និងពួកជីវពលរដ្ឋយូថាហ៍បានប្រឡូកនឹងសកម្មភាពនៃការឈ្លានពាន ប៉ុន្តែមិនដែលចូលរួមក្នុងចម្បាំងឡើយ ។

- តើអ្នកនឹងសង្ខេបនូវជម្រើសដែលបាននាំទៅរកការសម្លាប់រង្គាលនៅភ្នំម៉េដូដោយរបៀបណា ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីសោកនាដកម្មនេះ ? ( សិស្សអាចស្គាល់គោលការណ៍ផ្សេងៗ ប៉ុន្តែចម្លើយរបស់ពួកគេអាចរួមមានដូចជា ៖ **ការជ្រើសរើសលាក់បាំងអំពើបាបរបស់យើង អាចនាំយើងឲ្យប្រព្រឹត្តអំពើបាបកាន់តែធ្ងន់ ។ ការជ្រើសរើសដើម្បីលាក់បាំងអំពើបាបរបស់យើងអាចនាំមកនូវការសោកស្តាយ និងការរងទុក្ខ** ) ។

សូមពន្យល់ថា ការសម្លាប់រង្គាលនៅភ្នំម៉េដូ មិនត្រឹមតែធ្វើឲ្យមាននូវការស្លាប់របស់ជនរងគ្រោះប្រហែល ១២០ នាក់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបណ្តាលឲ្យមានការរងទុក្ខជាខ្លាំងផងដែរចំពោះកូនក្មេងដែលនៅរស់ និងសាច់ញាតិផ្សេងទៀតរបស់ជនរងគ្រោះទាំងនោះ ។ ពួកអាមេរិកកាំងស្បែកក្រហមឈ្មោះដៃយូតក៏បានរងនូវការស្តីបន្ទោសដ៏អយុត្តិធម៌ចំពោះបទឧក្រិដ្ឋកម្មនេះ ។ បន្ថែមទៀតនោះ អស់អ្នក « ដែលបានធ្វើការសម្លាប់រង្គាលនេះ បានរស់នៅក្នុងជីវិតមួយស្ថិតនៅក្រោមអារម្មណ៍ជាប់ទោសដ៏អាប់អួរ និងបានមានបទពិសោធន៍យ៉ាងអាក្រក់ចំពោះអ្វីដែលពួកគេធ្វើ និងបានឃើញ » ( Richard E. Turley Jr., « The Mountain Meadows Massacre »ទំព័រ ២០) ។

សូមបញ្ជាក់ប្រាប់ដល់សិស្សថា ប្រសិនបើពួកគេបានចាប់ផ្តើមដើរលើផ្លូវនៃអំពើខុស និងផ្លូវនៃអំពើបាបហើយ នោះពួកគេអាចការពារមិនឲ្យមាននូវការឈឺចិត្ត និងការសោកស្តាយនាពេលអនាគតបាន ដោយការបែរទៅរកព្រះអម្ចាស់ និងការប្រែចិត្តពីអំពើបាបរបស់ពួកគេ ។

សូមពន្យល់ថា ដោយសារពួកបរិសុទ្ធថ្ងៃចុងក្រោយក្នុងមូលដ្ឋានមួយចំនួន បានទទួលខុសត្រូវលើការគ្រោង និងការអនុវត្តក្នុងការសម្លាប់រង្គាលនៅលើភ្នំម៉េដូ នោះប្រជាជនខ្លះបានអនុញ្ញាតឲ្យហេតុការណ៍នេះជះឥទ្ធិពលអវិជ្ជមានលើការគិតអំពីសាសនាចក្រទាំងមូលរបស់ពួកគេ ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីដឹងថា ការធ្វើខុសរបស់សមាជិកសាសនាចក្រខ្លះ មិនបានសម្រេចដល់សេចក្តីពិតពេញលេញទាំងមូលនៃដំណឹងល្អ ?

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ៖



« ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលយើងឱបក្រសោប ស្អប់ខ្ពើមការសម្លាប់ដ៏ឃោរឃៅដល់បុរស ស្ត្រី និងកូនក្មេង ។ ពិតណាស់ វាបានគាំទ្រដល់សេចក្ដីសុខសាន្ត និង ការអភ័យទោស ។ អ្វីដែលបានធ្វើដោយសមាជិកនៃសាសនាចក្ររបស់ [នៅភ្នំម៉េដូ] ជាយូរលង់មកនោះ តំណាងឲ្យការឃ្លាតចេញពីការបង្រៀន និងទង្វើជាពួកគ្រីស្ទានដ៏អាក្រក់ និងពុំអាចដោះសារបានឡើយ » (« 150th Anniversary of Mountain Meadows Massacre,» ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៧, mormonnewsroom.org/article/150th–anniversary–of–mountain–meadows–massacre ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេលេមិន ៥:១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលយើងអាចធ្វើបានដើម្បីអភិវឌ្ឍ និងរក្សាទីបន្ទាល់របស់យើង ដើម្បីពេលណាយើងជួបនឹងគ្រាលំបាកនានា នោះសេចក្ដីជំនឿរបស់យើងនឹងមិនដែលរង្គោះរង្គើឡើយ ព្រោះយើងរៀនពីបទពិសោធន៍ ដែលសមាជិកសាសនាចក្រមិនបានរស់នៅស្របតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទនោះ ។

- ស្របតាម ហេលេមិន ៥:១២ តើយើងអាចធ្វើអ្វីខ្លះដើម្បីអភិវឌ្ឍ និងរក្សានូវទីបន្ទាល់របស់យើងឲ្យបានគង់វង្ស ? ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖ **យើងអាចអភិវឌ្ឍទីបន្ទាល់ដ៏រឹងមាំទាំងឡាយ ដោយការសាងសង់សេចក្ដីជំនឿរបស់យើងនៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទ** ) ។

ដើម្បីបង្ហាញនូវគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌដូចខាងក្រោម ៖

« ជេម សេនឌើរ គឺជាចៅទួតប្រុសរបស់. . . ដែលជាក្មេងម្នាក់ដែលបាននៅរស់ពីការសម្លាប់រង្គាល [ ហើយក៏ជាសមាជិកម្នាក់នៃ សាសនាចក្រផងដែរ ] ។. . . បងប្រុស សេនឌើរ. . . បានមានប្រសាសន៍ថា ការដឹងពីដូនតារបស់លោកថាត្រូវបានគេសម្លាប់នៅក្នុងការសម្លាប់រង្គាល ‹ មិនបានប៉ះពាល់ដល់សេចក្ដីជំនឿរបស់ខ្ញុំនោះទេ ដោយសារវាផ្អែកលើព្រះយេស៊ូវគ្រីស្ទ មិនមែនលើមនុស្សនៅក្នុងសាសនាចក្រនោះទេ › » ( Richard E. Turley Jr., The Mountain Meadows Massacre » ទំព័រ ២១) ។

- តើសេចក្ដីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ អាចពង្រឹងដល់យើងយ៉ាងណា នៅពេលយើងរៀនអំពីបទពិសោធន៍នានា ដែលសមាជិកសាសនាចក្រខ្លះ មិនបានរស់នៅស្របតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះនោះ ?

- តើអ្នកបានធ្វើអ្វីខ្លះដើម្បីជួយដល់ខ្លួនអ្នកឲ្យសាងសេចក្ដីជំនឿរបស់អ្នកនៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទ ?

សូមថ្លែងទីបន្ទាល់អំពីសារសំខាន់នៃការរស់នៅតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះ និងការផ្អែកសេចក្ដីជំនឿរបស់យើងទៅលើទ្រង់ និងដំណឹងល្អរបស់ទ្រង់ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីរបៀបដែលពួកគេអាចសាងសេចក្ដីជំនឿរបស់ពួកគេឲ្យបានកាន់តែប្រសើរឡើង នៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទ និងដើម្បីអាចដាក់គោលដៅមួយដើម្បីធ្វើដូច្នោះ ។

មេរៀនទី ១៥២

# ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា

## បុព្វកថា

នៅឆ្នាំ ១៨៥១ អែលឌើរ ហ្វ្រែងគ្លីន ឌី រីឆាដ ជាសមាជិកនៃកូរ៉ុមនៃពួកសាវក ដប់ពីរនាក់ និងជាប្រធានបេសកកម្មអង់គ្លេស បានបោះពុម្ពវិវរណៈ ការបកប្រែ និងការសរសេររបស់យ៉ូសែប ស្ម៊ីធមួយចំនួន ហើយបានចងក្រងជាមុក្តាដ៏មានតម្លៃមហិមា ។ អំឡុងសន្និសីទទូទៅមួយរបស់សាសនាចក្រនៅខែតុលា ឆ្នាំ ១៨៨០ សាសនាចក្របានទទួលយកមុក្តាដ៏មានតម្លៃមហិមាជាព្រះគម្ពីរ–ជាចំណែកនៃព្រះគម្ពីរបទដ្ឋាន ។ « ព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា គឺជាការជ្រើសរើសដ៏ជម្រើសនៃឯកសារទាំងឡាយ ដែលគ្របលើទិដ្ឋភាពដ៏សំខាន់ជាច្រើន អំពីសេចក្ដីជំនឿ និងគោលលទ្ធិនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » (បុព្វកថាមុក្តាដ៏មានតម្លៃមហិមា )។

## យោបល់សម្រាប់ការបង្រៀន

### ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា

សូមបង្ហាញ ឬគូររូបមុក្តា ឬគុជមួយ ។ សូមសួរដល់សិស្សថាតើពួកគេដឹងថាគុជធ្វើមកពីអ្វីឬទេ ។ បើពួកគេមិនដឹង សូមពន្យល់ថា មុក្តា ឬគុជមួយគ្រាប់ត្រូវបានបង្កបង្កើតឡើងនៅក្នុងខ្យងសមុទ្រ នៅពេលខ្យងសមុទ្រដែលវាគិតថាជាគ្រាប់ខ្សាច់ដ៏រំខានមួយគ្រាប់ ។ ខ្យងសមុទ្របង្កើតជាសារធាតុមួយដែលរុំជុំវិញគ្រាប់ខ្សាច់ ដែលយូរៗទៅបង្កើតបានជាគុជ ។ គុជធម្មជាតិ គឺកម្រមានណាស់ ហើយវាត្រូវបានចាត់ទុកថាមានតម្លៃបំផុត ។



សូមពន្យល់ថា នៅថ្ងៃនេះ សិស្សនឹងរៀនអំពីធាតុដើមនៃគម្ពីរដែលមានចំណងជើងថា មុក្តាដ៏មានតម្លៃមហិមា ។ ពួកគេនឹងរកឃើញនូវមូលហេតុមួយចំនួន ដែលមុក្តាដ៏មានតម្លៃមហិមាមានតម្លៃពិត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានអំពីកថាកណ្ឌទីមួយនៅក្នុងបុព្វកថាដល់មុក្តាដ៏មានតម្លៃមហិមា សូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលមាននៅក្នុងមុក្តាដ៏មានតម្លៃមហិមា ។ ពីមុនពួកគេអាន អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ *ទស្សនាវដ្ដី* សំដៅទៅលើកាសែត ឬទស្សនាវដ្ដី– ជាការបោះពុម្ពទាំងឡាយដែលត្រូវបានចែកចាយជាទៀងទាត់ ដូចជាប្រចាំថ្ងៃ ប្រចាំសប្ដាហ៍ ឬប្រចាំខែ ។

- តើអ្នកគិតថាមុក្តាដ៏មានតម្លៃមហិមា គឺជាវត្ថុកម្រ និងមានតម្លៃ តាមរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌទីពីរនៃសេចក្ដីណែនាំ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីមូលហេតុដែលមុក្តាដ៏មានតម្លៃមហិមា ត្រូវបានចងក្រងឡើង ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមសង្ខេបកថាកណ្ឌទីបីនៃ បុព្វកថា ដោយពន្យល់ថា ចាប់តាំងពីការបោះពុម្ពជាលើដំបូងនៃមុក្តាដ៏មានតម្លៃមហិមា មាតិកាមួយចំនួនត្រូវបានបន្ថែម ឬបានផ្លាស់ប្ដូរ ។ មាតិកាមួយចំនួនត្រូវបានបន្ថែម ហើយក្រោយមកត្រូវបានដកចេញទៅដាក់ក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។

សូមអញ្ជើញសិស្សឲ្យអានឮៗនូវកថាកណ្ឌដែលចាប់ផ្តើមជាមួយនឹងឃ្លាថា « ការជ្រើសរើសចេញមកពីគម្ពីរម៉ូសេ » ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែល យ៉ូសែប ស៊្មីធ បានទទួលវិវរណៈនៅក្នុងគម្ពីរនេះ ។

សូមអញ្ជើញសិស្សឲ្យមើលគម្ពីរម៉ូសេត្រួសៗ ហើយរកមើលយ៉ាងតិចណាស់ ខគម្ពីរមួយ ដែលមាននូវសេចក្តីពិតមួយ ដែលពួកគេគិតថាមានតម្លៃ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សចែកចាយខគម្ពីររបស់ពួកគេនឹងដៃគូ ឬដល់សិស្សក្នុងថ្នាក់ ។

សូមឲ្យសិស្សត្រឡប់ទៅ បុព្វកថាមុក្តាដ៏មានតម្លៃមហិមា។ សូមអញ្ជើញសិស្សឲ្យអានឮៗនូវកថាកណ្ឌដែលចាប់ផ្តើមជាមួយនឹងឃ្លាថា « ការជ្រើសរើសចេញមកពីគម្ពីរអ័ប្រាហាំ » ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវរបៀបដែល យ៉ូសែប ស៊្មីធ បានទទួលការសរសេរនៅក្នុងគម្ពីរអ័ប្រាហាំ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

ដើម្បីជួយពន្យល់អំពីរបៀបដែល យ៉ូសែប ស៊្មីធ បានទទួលនូវការសរសេរពីបុរាណនៅក្នុងគម្ពីរអ័ប្រាហាំ សូមអាន ឬអញ្ជើញសិស្សម្នាក់ឲ្យអានដូចខាងក្រោម ៖

> « នៅថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ១៨៣៥ មានបុរសម្នាក់ឈ្មោះ មីកែល ចានលើរ បាននាំយកសាកសពអេស៊ីព្ទចំនួនបួន និងរមូរក្រដាសផ្ទាំងចារិកជាច្រើន ដែលមានអក្សរអេស៊ីព្ទបុរាណយកទៅទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ ។ សាកសព និងរមូរផ្ទាំងចរិក ត្រូវបានរកឃើញនៅក្នុងប្រទេសអេស៊ីព្ទជាច្រើនឆ្នាំមុនដោយ អានតូនីញ៉ូ លីបូឡូ ។ ទីក្រុង ខឺតឡង់ គឺជាកន្លែងដែលរដ្ឋជាច្រើនចូលសំចត នៃសហរដ្ឋអាមេរិកប៉ែកខាងកើត ដើម្បីមើលការតាំងពិពណ៌សាកសពម៉ូមីរបស់ ចានលើរ ។ ចានលើរ បានដាក់លក់សាកសពម៉ូមី និង ផ្ទាំងរមូរទាំងឡាយ ហើយដោយមានការជម្រុញពីព្យាការី យ៉ូសែប ស៊្មីធ នោះសមាជិកមួយចំនួននៃសាសនាចក្រ បានបរិច្ចាគប្រាក់ដើម្បីទិញវា ។ នៅក្នុងសេចក្តីថ្លែងការមួយចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៨៣៥ យ៉ូសែប ស៊្មីធ បានប្រកាសអំពីសារៈសំខាន់នៃអត្ថបទរបស់ជនជាតិអេហ្ស៊ីបពីបុរាណទាំងនេះ ដែលបានកត់ត្រា ៖ ‹ ខ្ញុំបានចាប់ផ្តើមបកប្រែតួអក្សរ ឬ អក្សរសញ្ញាសម្គាល់មួយចំនួន ហើយសេចក្តីអំណររបស់យើងគឺមានដ៏លើសលប់ដែលរកឃើញថា ផ្ទាំងរមូរមួយមាននូវការសរសេររបស់អ័ប្រាហាំ ។. . . យើងពិតជាអាចនិយាយថា ព្រះអម្ចាស់កំពុងចាប់ផ្តើមបើកសម្តែងនូវសេចក្តីសុខសាន្ត និងសេចក្តីពិតដ៏ច្រើន › (*History of the Church* ២:២៣៦ ) » (*The Pearl of Great Price Student Manual* [ Church Educational System manual, ឆ្នាំ ២០០០ ],ទំព័រ ២៨ ) ។

មនុស្សមួយចំនួនបានងឿងឆ្ងល់ថា តើព្យាការីបានបកប្រែការសរសេរពីបុរាណដោយរបៀបណា ។ សូមពន្យល់ថា « ព្យាការី យ៉ូសែប ស៊្មីធ ពុំដែលទំនាក់ទំនងវិធីសាស្ត្ររបស់លោកនៃការបកប្រែកំណត់ត្រាទាំងនេះទេ ។ ក៏ដូចជាគម្ពីរដទៃផ្សេងទៀតទាំងអស់ ទីបន្ទាល់នៃសេចក្តីពិតពេញលេញអំពីការសរសេរនេះ គឺជារឿងនៃសេចក្តីជំនឿជាចម្បង ។ ភស្តុតាងដ៏មហិមាបំផុតនៃសេចក្តីពិតពេញលេញអំពីគម្ពីរអ័ប្រាហាំ គឺពុំមាននៅក្នុងការវិភាគអំពីភស្តុតាងផ្នែកសាច់ឈាម ឬជីវប្រវត្តិខាងប្រវត្តិសាស្ត្រទេ ប៉ុន្តែនៅក្នុងការពិចារណាប្រកបដោយការអធិស្ឋានអំពីមាតិការ និងអំណាចរបស់វា » (*The Pearl of Great Price Student Manual* ទំព័រ ២៨ ) ។ ទោះជាយើងមិនដឹងពីវិធីសាស្ត្រពិតប្រាកដដែល យ៉ូសែប ស៊្មីធ បានប្រើក្នុងការបកប្រែឯកសារទាំងឡាយក្តី ក៏យើងដឹងថាលោកបានបកប្រែគម្ពីរអ័ប្រាហាំ ដោយអំណោយទាន និងព្រះចេស្តានៃព្រះ ។

- ហេតុអ្វីវាសំខាន់ដើម្បីទទួលបានសាក្សីខាងវិញ្ញាណអំពីសេចក្តីពិតពេញលេញនៃគម្ពីរអ័ប្រាហាំ ?

សម្រាប់ផ្នែកនៃមេរៀនតទៅនេះ សូមពិចារណាធ្វើការអញ្ជើញសិស្សពីរនាក់មកខាងមុខថ្នាក់ ហើយដើរតួរជាអ្នករាយការណ៍សារព័ត៌មាន កំពុងសម្ភាសដល់អ្នកប្រាជ្ញមួយរូបដែលបានលះបង់ពេលវេលាដ៏ច្រើនដើម្បីសិក្សាអំពីមាតិការ និងធាតុពិតនៃគម្ពីរទាំងឡាយនៅក្នុងមុក្តាដ៏មានតម្លៃមហិមា ។ សូមឲ្យពួកគេអានប្រវ៉ូលដូចខាងក្រោម ៖

**អ្នករាយការណ៍ ៖** ហេតុអ្វីយ៉ូសែប ស៊្មីធ និយាយថា លោកបានបកប្រែការសរសេរនៃគម្ពីរអ័ប្រាហាំ ទោះជាឯកសារសរសេរដោយដៃនោះ ពុំមានកាលបរិច្ឆេទចាប់តាំងពីជំនាន់អ័ប្រាហាំផងហ្នឹង ?

**អ្នកប្រាជ្ញ ៖** ព្យាការី យ៉ូសែប ស៊្មីធ ពុំដែលប្រកាសថា រមូរផ្ទាំងចរិក គឺជាការសរសេររបស់អ័ប្រាហាំដ៏ពិតដែរ ។ លោកបានមានប្រសាសន៍ថា គម្ពីរអ័ប្រាហាំ គឺជា « ការបកប្រែនៃកំណត់ត្រាពីបុរាណមួយចំនួន ដែលបានធ្លាក់មកក្នុងដៃរបស់យើង មកពីខេតខូមស៍របស់អេស៊ីព្ទ ដែលគាំទ្រធ្វើជាការសរសេររបស់អ័ប្រាហាំ ខណៈដែលលោកនៅក្នុងប្រទេសអេស៊ីព្ទ » (*Times and Seasons* ថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៤២ ទំព័រ ៧០៤ ) ។

« នៅក្នុងឆ្នាំ ១៩៦៦ រមូរផ្ទាំងចរិកចំនួនដប់មួយបំណែក ដែលធ្លាប់ជាកម្មសិទ្ធិរបស់ ព្យាការីយ៉ូសែប ស៊្មីធ ត្រូវបានរកឃើញមាននៅសារៈមន្ទីរសិល្បៈមេត្រូប៉ូលីតាន នៅក្នុងទីក្រុងញូវ យ៉ក ។ ពួកគេបានប្រគល់ដល់សាសនាចក្រ ហើយអ្នកប្រាជ្ញបានវិភាគឃើញពីកាលបរិច្ឆេទវត្ថុទាំងនោះ គឺនៅចន្លោះ ឆ្នាំ ១០០ ម.គ និង គ.ស ។ ការជំទាស់ភាគច្រើនចំពោះភាពពិតនៃគម្ពីរអ័ប្រាហាំគឺថាការសរសេរដោយដៃ មិនត្រូវបានប្រាប់គ្រប់គ្រាន់ថាត្រូវបានសរសេរដោយអ័ប្រាហាំ ដែលបានរស់នៅជិតពីរយឆ្នាំពីមុនព្រះយេស៊ូគ្រីស្ទឡើយ ។ យ៉ូសែប ស៊្មីធ មិនធ្លាប់ប្រកាសថា ផ្ទាំងចារិក

នោះ មានសរសេរនិពន្ធផ្ទាល់ (បានសរសេរដោយអ័ប្រាហាំផ្ទាល់ ) ឬ វាមានកាលបរិច្ឆេទចេញមកពីជំនាន់របស់អ័ប្រាហាំឡើយ ។ ជាធម្មតា វាសំដៅទៅលើកិច្ចការរបស់អ្នកនិពន្ធម្នាក់ថា ជាការនិពន្ធ ‹របស់លោក› ទោះជាលោកបានសរសេរដោយខ្លួនឯង ឬសរសេរឲ្យអ្នកដទៃ ឬអ្នកផ្សេងចម្លងការសរសេររបស់លោកក្រោយមកជាដើម » (*The Pearl of Great Price Student Manual* ទំព័រ ២៨ ) ។

**អ្នករាយការណ៍ ៖** តើយ៉ូសែប ស៊្មីធ បានធ្វើអ្វីខ្លះជាមួយនឹងការបកប្រែរបស់លោក ?

**អ្នកប្រាជ្ញ ៖** « គម្ពីរអ័ប្រាហាំ ត្រូវបានបោះពុម្ពជាលើកដំបូងដោយមានការដកស្រង់តែចំនួនពីរបីមួយលើកៗនៅក្នុង *Times and Seasons* ការបោះពុម្ពផ្សាយរបស់សាសនាចក្រ ចាប់ផ្ដើមនៅខែ មិនា ឆ្នាំ ១៨៤២ នៅទីក្រុងណៅវូ រដ្ឋ អិលលីណោយ ( សូមមើល [បុព្វកថា] នៅដើមគម្ពីរមុក្ដាដ៏មានតម្លៃមហិមា ) ។ ព្យាការី យ៉ូសែប ស៊្មីធ បានចង្អុលបង្ហាញថា លោកនឹងបោះពុម្ពគម្ពីរអ័ប្រាហាំបន្ថែមទៀតនៅពេលក្រោយ ប៉ុន្តែលោកត្រូវបានគេសម្លាប់ មុនពេលលោកអាចបោះពុម្ពបន្ថែមទៀត ។ ស្ដីអំពីរយៈពេលជាចម្បងនៃការបកប្រែបានបញ្ចប់ អូលីវើរ ខៅឌើរី គ្រាមួយនោះបានមានប្រសាសន៍ថា ‹ វ៉ុល › ចាំបាច់ត្រូវមានដាក់នៅក្នុងនោះ ( សូមមើល *Messenger and Advocate* ខែ ធ្នូ ឆ្នាំ ១៨៣៥ ទំព័រ ២៣៦ ) ។

« បន្ថែមពីលើអក្សរអេស៊ីព្វបុរាណ នោះឯកសារសរសេរដោយដៃ ក៏មាននូវគំនូរអេស៊ីព្វផងដែរ ។ នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៨៤២ ព្យាការីយ៉ូសែប ស៊្មីធ បានសុំ រ៉ូប៊ិន ហែតឡាក់ ជាអ្នកឆ្លាក់ឈើដ៏ជំនាញមួយរូប ហើយជាសមាជិកនៃសាសនាចក្រ ដើម្បីរៀបចំកាត់ឈើឆ្លាក់ជាពុម្ពចំនួនបីដើម្បីពួកគេអាចបោះពុម្ពបាន ។ ហែតឡាក់ បានបញ្ចប់ការឆ្លាក់ក្នុងមួយសប្ដាហ៍ ហើយ យ៉ូសែប ស៊្មីធ បានបោះពុម្ពច្បាប់ចម្លង ( សំណៅ ) ព្រមជាមួយនឹងគម្ពីរអ័ប្រាហាំ ។ ការពន្យល់របស់ យ៉ូសែប ស៊្មីធ អំពីគំនូរព្រមជាមួយនឹងសំណៅ » (*The Pearl of Great Price Student Manual,* ទំព័រ ២៨–២៩ ) ។

**អ្នករាយការណ៍ ៖** តើមានអ្វីកើតឡើងចំពោះសាកសព និង រមូរផ្ទាំងចរិកនោះ ?

**អ្នកប្រាជ្ញ ៖** « បន្ទាប់ពីមរណភាពរបស់ ព្យាការីយ៉ូសែប ស៊្មីធ នោះមានសាកសពចំនួនបួន និងរមូរផ្ទាំងចរិកបានក្លាយទៅជាកម្មសិទ្ធិរបស់ម្ដាយរបស់យ៉ូសែប ឈ្មោះ លូស៊ី ម៉ាក ស៊្មីធ » (*The Pearl of Great Price Student Manual* ទំព័រ ២៩ ) ។ បន្ទាប់ពី លូស៊ី ម៉ាក ស៊្មីធ បានទទួលមរណភាព នោះវត្ថុទាំងនោះត្រូវបានលក់ទៅឲ្យបុរសម្នាក់ឈ្មោះ អេបិល ខូមស៍ ។ វត្ថុទាំងនោះ អាចនឹងត្រូវបានលក់ដោយភរិយារបស់ យ៉ូសែប ស៊្មីធ ឈ្មោះ អិមម៉ា ឬវាត្រូវបានលក់ដោយប្អូនប្រុសរបស់លោក ឈ្មោះ វីល្លាម ។ លោក ខូមស៍ បានលក់វត្ថុមួយចំនួនទៅឲ្យសារៈមន្ទីរមួយនៅ សេន លូវីស រដ្ឋមិសសួរី ។ គាត់បានរក្សានូវចំណែកផ្សេងទៀត ហើយក្រោយមកបានឲ្យខ្លះទៅអ្នកដទៃទៀត ។ ( សូមមើល *The Pearl of Great Price Student Manual,*ទំព័រ ២៩ អេក ឌុន ភីទើសុន *The Story of the Book of Abraham: Mummies, Manuscripts, and Mormonism* [ឆ្នាំ ១៩៩៥], ទំព័រ ២០៤–៩, ២៥៧ ) ។

« ទ្រឹស្ដីមួយចំនួនត្រូវបានផ្ដល់ឲ្យ ស្ដីអំពីអ្វីដែលបានកើតឡើង. . . ចំពោះសាកសព និងរមូរផ្ទាំងចរិក ។ មានសាកសពយ៉ាងហោចណាស់ចំនួនពីរ ដែលហាក់ដូចជា ត្រូវបានឆេះនៅក្នុងពេលមានអគ្គិសភ័យដ៏ធំនៅរដ្ឋ ឈីកាហ្គោក្នុងឆ្នាំ ១៨៧១ ( សូមមើល B. H. Roberts, *New Witnesses for God* វ៉ុលទី ៣ [ ឆ្នាំ ១៩០៩–១១], ២:៣៨០–៣៨២ ) ។

« នៅដើមនិទាឃរដូវឆ្នាំ ១៩៩៦ វេជ្ជ. អាហ្ស៊ីស អេស. អាទីយ៉ា ជាសាស្ត្រាចារ្យសាកលវិទ្យាល័យយូថាហ៍ [បានប្រាប់ឲ្យសាសនាចក្រដឹងទីតាំងនៃបំណែករមូរផ្ទាំងចរិកមួយចំនួនរបស់យ៉ូសែប ស៊្មីធ] នៅសារៈមន្ទីរសិល្បៈមេត្រូប៉ូលីតានក្នុងទីក្រុង ញូវ យ៉ក ។ បំណែកទាំងនេះ ត្រូវបានបង្ហាញដល់សាសនាចក្រ ដោយនាយកសារៈមន្ទីរ នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៦៧ ។ ពុំមានដំណឹងអំពីទីតាំងបច្ចុប្បន្នភាពរបស់សាកសពផ្សេងទៀត និងបំណែកផ្សេងទៀតនៃផ្ទាំងចារិកនោះទេ [សូមមើល H. Donl Peterson, « Some Joseph Smith Papyri Rediscovered (ឆ្នាំ១៩៦៧),» នៅក្នុង *Studies in Scripture, Volume Two: The Pearl of Great Price*បានបោះពុម្ពដោយ Robert L. Millett and Kent P. Jackson (ឆ្នាំ ១៩៨៥), ទំព័រ ១៨៣–៨៥] » ( *The Pearl of Great Price Student Manual,* ទំព័រ ២៩ ) ។

សូមអញ្ជើញសិស្សឲ្យមើលគម្ពីរអ័ប្រាហាំត្រួសៗ ហើយរកមើលខគម្ពីរយ៉ាងតិចណាស់មួយដែលពួកគេគិតថាមានតម្លៃ ។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយនោះ សូមអញ្ជើញសិស្សឲ្យចែកចាយខគម្ពីររបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមឲ្យសិស្សត្រឡប់ទៅបុព្វកថាវិញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវកថាកណ្ឌដែលចាប់ផ្ដើមជាមួយនឹងឃ្លាថា « យ៉ូសែប ស៊្មីធ–ម៉ាថាយ » ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលពីរបៀបដែលយ៉ូសែប ស៊្មីធ បានទទួលវិវរណៈនេះ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ អំពីការស្វែងរករបស់ពួកគេ ។

សូមពន្យល់ថា មូលហេតុមួយដែល យ៉ូសែប ស៊្មីធ–ម៉ាថាយ មានតម្លៃគឺថា វាមាននូវទេសនកថាអំពីការយាងមកជាលើកទីពីរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវកថាកណ្ឌដែលចាប់ផ្ដើមជាមួយនឹងឃ្លាថា « យ៉ូសែប ស៊្មីធ–ប្រវត្តិ » ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាតើយ៉ូសែប ស៊្មីធ បានរៀបចំប្រវត្តិសាស្ត្រនេះនៅពេលណា ។

សូមអញ្ជើញសិស្សឲ្យមើលយ៉ូសែប ស៊្មីធ–ប្រវត្តិត្រួសៗ ហើយរកមើលខគម្ពីរមួយយ៉ាងតិច ដែលពួកគេគិតថាមានតម្លៃ ។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយនោះ សូមឲ្យសិស្សចែកចាយខគម្ពីរទាំងឡាយរបស់ពួកគេជាមួយនឹងដៃគូ ឬសិស្សក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យនឹកគិតថា មិត្តម្នាក់បានសុំឲ្យពួកគេពន្យល់អំពីជំនឿនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយរយៈពេលពីរនាទី ។ សូមឲ្យសិស្សក្នុងថ្នាក់សរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីរបៀបដែលពួកគេនឹងឆ្លើយតប ។ បន្ទាប់ពីរយៈពេលពីរបីនាទីមក សូមអញ្ជើញសិស្សមួយចំនួនឲ្យអាននូវអ្វីដែលពួកគេបានសរសេរ ។

សូមចង្អុលបង្ហាញថា មាត្រានៃសេចក្ដីជំនឿ បានផ្ដល់នូវការសង្ខេបដ៏ល្អមួយអំពីជំនឿរបស់យើង ។ ដើម្បីជួយសិស្សយល់អំពីធាតុដើមនៃមាត្រានៃសេចក្ដីជំនឿ សូមពន្យល់ថា នៅថ្ងៃទី ១ ខែមិនា ឆ្នាំ ១៨៤២ ព្យាការីយ៉ូសែប ស៊្មីធ បានឆ្លើយតបចំពោះសំណើរមួយមកពី យ៉ូហាន វ៉ែនវើត ជាអ្នកកែសម្រួលកាសែត ដើម្បីផ្ដល់ព័ត៌មានអំពីរូបលោក និងប្រវត្តិ និងជំនឿរបស់សាសនាចក្រ ។ រឿងនេះត្រូវបានគេស្គាល់ជាទូទៅថា សំបុត្ររបស់វ៉ែនវើត ។ នៅក្នុងសំបុត្រនោះ យ៉ូសែប បានប្រកាសគោលការណ៍គ្រឹះនៃដំណឹងល្អចំនួន ១៣ ។ ជំនឿទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុង មុក្ដាដ៏មានតម្លៃមហិមា ជា មាត្រានៃសេចក្ដីជំនឿ។ ទោះបីជាអ្វីទាំងនោះពុំមែនជាសេចក្ដីថ្លែងការណ៍មួយអំពីជំនឿរបស់យើងទាំងអស់ក្ដី តែវាជាគោលលទ្ធិ និងគោលការណ៍មួយចំនួនដ៏សំខាន់ ។

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមចាត់ឲ្យដៃគូនិមួយៗនូវមាត្រានៃសេចក្ដីជំនឿយ៉ាងហោចណាស់មួយ ។ ( អ្នកអាចចាត់ដៃគូនិមួយៗនូវ មាត្រានៃសេចក្ដីជំនឿមួយ ឬច្រើន អាស្រ័យលើតម្រូវការរបស់សិស្ស និងទំហំនៃថ្នាក់រៀនរបស់អ្នក ) ។ សូមឲ្យដៃគូនិមួយៗអានមាត្រានៃសេចក្ដីជំនឿដែលបានចាត់ទៅឲ្យពួកគេ ហើយធ្វើតាមការណែនាំដូចខាងក្រោម ។ អ្នកអាចធ្វើការថតចម្លងការដឹកនាំទាំងនេះ ឬសរសេរវានៅលើក្ដារខៀន ។ សិស្សអាចនឹងធ្វើតាមការណែនាំទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

១. បន្ទាប់ពីការអានមាត្រានៃសេចក្ដីជំនឿដែលរបស់អ្នកដែលបានចាត់ឲ្យ សូមសរសេរគោលលទ្ធិ ឬគោលការណ៍ដែលវាបង្រៀន តាមពាក្យរបស់អ្នកផ្ទាល់ ។

២. សូមរកមើលខគម្ពីរមួយ ដែលគាំទ្រ ឬពន្យល់អំពីគោលលទ្ធិ ឬគោលការណ៍នៅក្នុងមាត្រានៃសេចក្ដីជំនឿរបស់អ្នកដែលបានចាត់ឲ្យអ្នក ។ សូមសរសេរអំពីគំនិតដឹងសីជម្រៅ ដែលបទគម្ពីរបានបន្ថែមទៅក្នុងការយល់ដឹងរបស់អ្នកអំពីគោលការណ៍នេះ ។

៣. សូមសរសេរនូវវិធីនានា ដែលការយល់ដឹង និងការជឿលើមាត្រានៃសេចក្ដីជំនឿនេះ អាចនាំពរជ័យចូលមកក្នុងជីវិតរបស់មនុស្សម្នាក់ ។

បន្ទាប់ពីសិស្សមានពេលសរសេរគ្រប់គ្រាន់ ដើម្បីបញ្ចប់នូវកិច្ចការរបស់ពួកគេហើយ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេបានសរសេរ ។ អ្នកអាចនឹងចង់សរសេរនូវសេចក្ដីពិតមួយចំនួន ដែលពួកគេបានប្រាប់នៅលើក្ដារខៀន ។

- ហេតុអ្វីបានជា មាត្រានៃសេចក្ដីជំនឿ មានតម្លៃចំពោះអ្នក ?

*ការចែកចាយគំនិត និងបទពិសោធន៍*

គ្រូ និង សិស្សគួរតែមានឱកាស ដើម្បីចែកចាយពីគំនិត និង ការយល់ដឹងរបស់ពួកគេក៏ដូចជាបទពិសោធន៍ផ្ទាល់ខ្លួន ដែល ពួកគេមានផងដែរ ។ ពួកគេក៏អាចរៀបរាប់អំពីបទពិសោធន៍ដែលពួកគេបានធ្វើជាសាក្សីនៅក្នុងជីវិតរបស់អ្នកដទៃផងដែរ ។ នៅពេលពួកគេចែកចាយ ព្រះវិញ្ញាណបរិសុទ្ធនឹងថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដែលត្រូវបានពិភាក្សានោះ ។

សូមអញ្ជើញសិស្ស ឲ្យចែកចាយបទពិសោធន៍ ដែលពួកគេបានមាន នៅពេល មាត្រានៃសេចក្ដីជំនឿ ឬសេចក្ដីពិតទាំងឡាយដែលមាននៅក្នុងនោះ បានជួយដល់ពួកគេពន្យល់ដំណឹងល្អដល់នរណាម្នាក់ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយរបស់អ្នកដែរ ។

សូមសំណូមពរដល់សិស្សឲ្យសិក្សា និងទន្ទេញចាំនូវ មាត្រានៃសេចក្ដីជំនឿ។ អ្នកអាចប្រើនូវសកម្មភាពទន្ទេញចាំមួយ ដែលមាននៅក្នុងសេចក្ដីបន្ថែមនៃសៀវភៅសិក្សានេះ ដើម្បីជួយសិស្សឲ្យទន្ទេញចាំនូវមាត្រានៃសេចក្ដីជំនឿមួយទាំងអស់គ្នា ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើចំណេះដឹងរបស់ពួកគេអំពី មាត្រានៃសេចក្ដីជំនឿ នៅពេលពួកគេពន្យល់អំពីជំនឿដល់អ្នកដទៃទៀត ។

សូមសរសេរនូវសេចក្ដីថ្លែងការណ៍ពុំពេញលេញនៅលើក្ដារខៀន ៖*មុក្ដាដ៏មានតម្លៃមហិមា គឺជាភស្ដុតាងដែលថា យ៉ូសែប ស៊្មីធ គឺជា . . .*

សូមជួយសិស្សឲ្យបំពេញបញ្ចប់នូវសេចក្ដីថ្លែងការណ៍ ដោយការសួរសំណួរដូចខាងក្រោម ៖

- តើវគ្គមាននៃសេចក្ដីពិតដ៏មានតម្លៃនៅក្នុងមុក្ដាដ៏មានតម្លៃមហិមា បង្រៀនយើងអ្វីខ្លះ អំពីព្យាការី យ៉ូសែប ស្ម៊ីធ ? ( សូមបំពេញសេចក្ដីពិតនៅលើក្ដារខៀន ដូចតទៅនេះ ៖**មុក្ដាដ៏មានតម្លៃមហិមា គឺជាភស្ដុតាងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ )**
- តើអ្នកគិតថា មុក្ដាដ៏មានតម្លៃមហិមា គឺជាភស្ដុតាងអំពីការហៅបម្រើរបស់ យ៉ូសែប ស្ម៊ីធ ក្នុងនាមជាព្យាការី ដោយវិធីណា ?

សូមថ្លែងទីបន្ទាល់ថា មុក្ដាដ៏មានតម្លៃមហិមា គឺជាភស្ដុតាងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។ សៀវភៅនេះ បង្រៀនយើងពីសេចក្ដីពិតដ៏មានតម្លៃ អំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។

មេរៀនទី ១៥៣

# សេចក្ដីប្រកាសជាផ្លូវការទី ១ និងការអភិវឌ្ឍកិច្ចការព្រះវិហារបរិសុទ្ធជាបន្តបន្ទាប់

## បុព្វកថា

បន្ទាប់ពីព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដើម្បីដឹកនាំលោកឲ្យបង្រៀនគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព នោះសមាជិកសាសនាចក្រមួយចំនួនបានចាប់ផ្ដើមអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព នៅក្រោមការដឹកនាំរបស់លោកនៅដើមឆ្នាំ ១៨៤០ ។ នៅអំឡុងជាច្រើនទស្សវត្សរ៍ក្រោយមក សាសនាចក្របានទទួលបទពិសោធន៍នៃការប្រឆាំងជំទាស់ជាសាធារណៈ ដោយសារតែការអនុវត្តនេះ ។ « បន្ទាប់ពីការទទួលបានវិវរណៈ នោះប្រធាន វិលហ្វូឌ វូឌ្រុព្វ បានចេញ. . . [សេចក្ដីប្រកាសជាផ្លូវការទី ១] ដែលត្រូវបានទទួលយកដោយសាសនាចក្រ ជាការអនុញ្ញាតជាផ្លូវការ ហើយគោរពតាម នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៨៩០ ។ សេចក្ដីថ្លែងការណ៍នេះ បាននាំទៅរកការបញ្ចប់នូវការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងសាសនាចក្រ ( សេចក្ដីប្រកាសជាផ្លូវការទី ១ បុព្វកថា ) ។ ទោះជាពួកបរិសុទ្ធបានជួបនឹងការជំទាស់ក្ដី ក៏ពួកគេបានធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ជាកន្លែងដែលពួកគេបានទទួលពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះសម្រាប់ខ្លួនគេ និងសម្រាប់មរណជន ។ ពួកគេបានសាងសង់ ហើយបានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធចំនួនប្រាំ នៅចន្លោះឆ្នាំ ១៨៤៦ និង ១៨៩៣ ។

## យោបល់សម្រាប់ការបង្រៀន

### ព្រះអម្ចាស់បានបើកបង្ហាញថា ពួកបរិសុទ្ធថ្ងៃចុងក្រោយគួរតែបញ្ឈប់នូវការអនុវត្តន៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព

សូមឲ្យសិស្សប្រាប់ឈ្មោះមនុស្សសុចរិតនៅក្នុងគម្ពីរ ដែលត្រូវបានចាប់ខ្លួន ឬដាក់គុគ ដោយសារតែបានធ្វើតាមអ្វីដែលព្រះបានបញ្ជាពួកគេឲ្យធ្វើ ។ ( ចម្លើយទាំងឡាយអាចរួមមាន ដានីយ៉ែល អាប៊ីណាដៃ ពេត្រុស យ៉ូសែប ស្ម៊ីធ និងព្រះអង្គសង្គ្រោះ ) ។

សូមពន្យល់ថា មានបុរស ៗថ្ងៃចុងក្រោយជាច្រើនរូប ត្រូវបានចាប់ខ្លួន ហើយដាក់គុក ដោយសារតែពួកគេបានបន្ដគោរពបទបញ្ញត្តិដើម្បីអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព បន្ទាប់ពីរដ្ឋាភិបាលសហរដ្ឋអាមេរិក បានអនុម័តច្បាប់ ធ្វើឲ្យការអនុវត្តនេះខុសច្បាប់ ។ ស្ត្រីមួយចំនួនត្រូវបានចាប់ខ្លួនផងដែរ ជាធម្មតាដោយសារតែពួកគេពុំព្រមប្រាប់ពីកន្លែងលាក់ខ្លួនរបស់ប្ដីពួកគេដែលបានរត់ទៅលាក់ខ្លួនពីការតាមចាប់នោះ ។

សូមឲ្យសិស្សសង្ខេបអំពីរបៀបដែលការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព បានចាប់ផ្ដើមមាននៅក្នុងចំណោមសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ( ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈអំពីគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព ហើយការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ត្រូវបានស្ថាបនាឡើងនៅក្នុងចំណោមសមាជិកសាសនាចក្រ នៅដើមឆ្នាំ ១៨៤០ ជាការឆ្លើយតបចំពោះបទបញ្ជារបស់ព្រះអម្ចាស់ [សូមមើល គ. និង ស. ១៣២]) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់មើលនូវការលំបាក ៗដែលសមាជិកសាសនាចក្រមួយចំនួន បានជួបប្រទះ នៅពេលពួកគេបានគោរពតាមបទបញ្ជារបស់ព្រះអម្ចាស់ដើម្បីអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។

នៅខែសីហា ឆ្នាំ ១៨៥២ ជាចំណែកនៃសន្និសីទមួយនៅក្នុងទីក្រុង សលត៍ លេក អែលឌើរ អ្សូរសុន ប្រាត្តបានប្រកាសជាសាធារណៈថា នៅក្នុងការគោរពតាមបទបញ្ញត្តិមួយមកពីព្រះ នោះសមាជិកសាសនាចក្រមួយចំនួនកំពុងតែអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ អែលឌើរ ប្រាត្ត បានធ្វើសេចក្ដីប្រកាសនេះ នៅក្រោមការដឹកនាំរបស់ប្រធានព្រិកហាំ យ៉ង់ ។ មានអ្នកដឹកនាំសាសនា និងអ្នកដឹកនាំនយោបាយជាច្រើននៅក្នុងសហរដ្ឋ បានប្រឆាំងទៅនឹងប្រព័ន្ធអាពាហ៍ពិពាហ៍បែបនោះ ដែលពួកគេចាត់ទុកថាប្រព័ន្ធនេះគឺអសីលធម៌ និងគ្មានអរិយធម៌ ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនរូបត្រូវបានគេសើចចំអកក្នុងទីសាធារណៈនៅក្នុងសុន្ទរកថា សៀវភៅ ទស្សនាវដ្ដី និង កាសែតនានា ។ សភាសហរដ្ឋបានចេញច្បាប់ជាច្រើនដែលដាក់កម្រិតដល់សេរីភាពរបស់សមាជិកសាសនាចក្រ ហើយបានសង្កត់សង្កិនដល់សាសនាចក្រខាងសេដ្ឋកិច្ច

ដោយរឹតបន្តឹងចំនួនអចលនទ្រព្យដែលសាសនាចក្រអាចកាន់កាប់បាន ។ ច្បាប់ទាំងនេះ នៅទីបំផុតនាំទៅរកការចាប់ខ្លួន និងការដាក់គុកបុរស ៗដែលមានប្រពន្ធច្រើនជាងមួយ ។ បុរសទាំងនេះត្រូវបានគេបដិសេធ « មិនឲ្យមានសិទ្ធិបោះឆ្នោត គ្មានសិទ្ធិឯកជននៅក្នុងផ្ទះរបស់ពួកគេ ហើយគ្មានសិទ្ធិរីករាយនឹងសេរីភាពស៊ីវិលដទៃទៀតឡើយ » (*កេរដំណែលរបស់យើង ៖ ប្រវត្តិសង្ខេបរបស់សាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* [ឆ្នាំ ១៩៩៦] ទំព័រ ៩៧ ) ។ នៅត្រឹមឆ្នាំ ១៨៩០ មានពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ជាច្រើនរយនាក់បានជាប់គុក ។ អ្នកផ្សេងទៀតបានរត់ពួនដើម្បីចៀសវាងពីការចាប់ខ្លួន និងដាក់គុក ។ នៅក្នុងស្ថានភាពបែបនេះ មានគ្រួសារជាច្រើនបានរងទុក្ខដោយភាពតានតឹង ទុក្ខសោក ភាពក្រីក្រ និង ការអត់ឃ្លាន ។

បន្ទាប់ពីសេចក្តីប្រកាសនៅឆ្នាំ ១៨៥២ អាពាហ៍ពិពាហ៍ពហុពន្ធភាពបានប្រែទៅជាមានភាពរីករាលដាលកាន់តែខ្លាំងឡើង ហើយបុរស និងស្ត្រីរាប់ពាន់នាក់ ត្រូវបានផ្សារភ្ជាប់នៅក្នុងអាពាហ៍ពិពាហ៍ពហុពន្ធភាព នៅក្រោមការដឹកនាំរបស់ពួកអ្នកដឹកនាំបព្វជិតភាព ។ ទោះបីជាពិភពលោកបានចំអកឡកឡឺយដល់ពួកគេដោយសារការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពក្តី ក៏មានពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ជាច្រើនបានទ្រទ្រង់ក្នុងការអនុវត្តន៍នេះ និងបានថ្លែងទីបន្ទាល់ថា ពួកគេបានដឹងថា វាត្រូវបានបើកបង្ហាញមកពីព្រះ តាមរយៈព្យាការី យ៉ូសែប ស៊្មីធ ។

- តើយើងនឹង សង្ខេបអំពីភាពលំបាកវេទនារបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយកាលពីជំនាន់ដើម ដែលបានជួបផលលំបាកដោយសារតែពួកគេបានគោរពតាមការដឹកនាំរបស់ព្រះអម្ចាស់ក្នុងការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពនេះយ៉ាងដូចម្តេច ?



សូមពន្យល់ថា ស្ថានភាពដ៏លំបាកទាំងនេះបាននាំឲ្យប្រធាន វិលហ្វូឌ វូឌរ្រុព្វ ស្វែងរកដោយការអធិស្ឋានទូលសូមការដឹកនាំពីព្រះអម្ចាស់ទាក់ទងទៅនឹងការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពរបស់ពួកបរិសុទ្ធទាំងឡាយ ។ នៅក្នុងឆ្នាំ ១៨៨៩ ប្រធាន វូដរ្រុព្វ បានណែនាំអ្នកដឹកនាំសាសនាចក្រទាំងឡាយឲ្យបញ្ឈប់ការបង្រៀនគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនេះទៀត ។ នៅត្រឹមឆ្នាំ ១៨៩០ មានតែអាពាហ៍ពិពាហ៍ពហុពន្ធភាពពីរបីប៉ុណ្ណោះដែលកើតមានឡើង ហើយការណ៍នេះត្រូវបានធ្វើឡើងដើម្បីប្រឆាំងនឹងការទូន្មានរបស់ប្រធាន វូឌរ្រុព្វ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានមនុស្សខ្លះបានបោះពុម្ពចេញផ្សាយរបាយការណ៍ជាច្រើនថា សាសនាចក្រនៅតែបន្តឲ្យមានការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពដដែល ។ របាយការណ៍ទាំងនេះ បានបង្កើតជាការរុកគួនដល់សាសនាចក្រ ។ នៅខែ កញ្ញា ឆ្នាំ ១៨៩០ ប្រធាន វូឌ រ្រុព្វ បានចេញជាសេចក្តីប្រកាសមួយដែលក្នុងពេលនេះត្រូវបានគេស្គាល់ថាជា សេចក្តីប្រកាសជាផ្លូវការទី ១ ដែលមាននៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា ។

### *ការយល់ដឹងអំពីបរិបទ*

ការយល់អំពីបរិបទមួយ មានដូចជាជីវប្រវត្តិខាងប្រវត្តិសាស្ត្រ ការស្ថាបនាគ្រឹះមួយដើម្បីបើកឲ្យឃើញនូវគោលលទ្ធិ និងគោលការណ៍គ្រឹះ ។ បន្ទាប់ពីការចែកចាយបរិបទអំពីវិវរណៈមួយ ឬវគ្គបទគម្ពីរមួយ របៀបមួយដើម្បីធ្វើឲ្យប្រាកដថាសិស្សយល់ត្រឹមត្រូវអំពីបរិបទ គឺត្រូវអញ្ជើញពួកគេឲ្យសង្ខេបជាពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ។

សូមសង្ខេបកថាខណ្ឌបីដំបូងនៃ សេចក្តីប្រកាសជាផ្លូវការទី ១ ដោយពន្យល់ថា ប្រធាន វូឌរ្រុព្វ បានអះអាងថា របាយការណ៍ចោទប្រកាន់ថា សាសនាចក្រនៅតែលើកទឹកចិត្តឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព គឺជារឿងមិនត្រឹមត្រូវ ។ បន្ទាប់មក អញ្ជើញសិស្សបីនាក់ឲ្យផ្លាស់វេនគ្នាអានឮៗនូវកថាខណ្ឌទីបួន និងទីប្រាំនៃ សេចក្តីប្រកាសជាផ្លូវការទី ១ ( ចាប់ផ្តើមនៅត្រង់ « ដរាបណាដែលមានច្បាប់ » ) និងសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់ដោយប្រធាន ឡូរ៉េនសូ ស្នូ ដែលពេលនោះជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលប្រធាន វូឌរ្រុព្វ បានណែនាំដល់ពួកបរិសុទ្ធឲ្យធ្វើ ។

- តើពួកបរិសុទ្ធត្រូវបានណែនាំឲ្យធ្វើអ្វីខ្លះ ? ( ចៀសវាងពីការចុះកិច្ចព្រមព្រៀង ឬការបង្កើតនូវអាពាហ៍ពិពាហ៍ពហុពន្ធភាពគ្រប់ប្រភេទ ) ។

- យោងតាមសេចក្តីថ្លែងការណ៍ដោយប្រធាន ឡូរ៉េនសូ ស្នូ ហេតុអ្វីក៏វាសំខាន់ដែលការដឹកនាំឲ្យចៀសវាងពីការចុះកិច្ចព្រមព្រៀងលើអាពាហ៍ពិពាហ៍ពហុពន្ធភាពតទៅទៀត ត្រូវចេញមកពីប្រធាននៃសាសនាចក្រ ? ( ដោយសារលោកគឺជាមនុស្សតែម្នាក់គត់នៅលើផែនដី ដែលកាន់កូនសោនៃអំណាចផ្សារភ្ជាប់ ។ អ្នកអាចនឹងចង់រំឭកសិស្សថា អាពាហ៍ពិពាហ៍ពហុពន្ធភាព អាចត្រូវបានអនុញ្ញាតតែតាមរយៈកូនសោបព្វជិតភាព ដែលត្រូវបានប្រទានឲ្យប្រធាននៃសាសនាចក្រតែប៉ុណ្ណោះ [សូមមើល គ. និង ស. ១៣២:៧, ៤៨ ] ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវកថាខណ្ឌទីមួយនៃ « ការដកស្រង់មកពីប្រសាសន៍ចំនួនបី ដោយប្រធាន វិលហ្វូឌ វូឌរ្រុព្វ ទាក់ទងនឹងគោលនយោបាយ » ដែលយកតាមអត្ថបទនៃគោលនយោបាយ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលគោលការណ៍មួយ ដែលប្រធាន វូឌរ្រុព្វបានបង្រៀនដល់ពួកបរិសុទ្ធ ។

- តើប្រធាន វិលហ្វឺ វ៉ូឌ្រុព្វបានបង្រៀនដល់ពួកបរិសុទ្ធអ្វីខ្លះ ? ( នៅពេលសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់នឹងពុំដែលអនុញ្ញាតឲ្យប្រធាននៃសាសនាចក្រដឹកនាំសាសនាចក្រឲ្យវង្វេងឡើយ ។** អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំពាក្យ ឬ ឃ្លានៅក្នុងគម្ពីររបស់ពួកគេដែលបង្រៀនអំពីគោលលទ្ធិនេះ ) ។
- តើគោលការណ៍នេះ អាចជួយយើងនៅសព្វថ្ងៃយ៉ាងដូចម្ដេច ?

សូមពន្យល់ថា សមាជិកសាសនាចក្រមួយចំនួន បានងឿងឆ្ងល់ថាហេតុអ្វីក៏ពួកគេត្រូវបានដឹកនាំឲ្យរស់នៅតាមគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពហើយ បែរជាមកដឹកនាំឲ្យបញ្ឈប់ទៅវិញដូច្នេះ ។ ព្រះអម្ចាស់បានដឹកនាំប្រធាន វ៉ូឌ្រុព្វ ឲ្យសួរសំណួរដល់ពួកបរិសុទ្ធ ។ សូមអញ្ជើញសិស្សបីនាក់ឲ្យផ្លាស់វេនគ្នាអានឮៗនូវកថាខណ្ឌទីបី ទីបួន និងទីប្រាំនៃ « ការដកស្រង់ចេញមកពីសុន្ទរកថាបីរបស់ប្រធាន វិលហ្វឺ វ៉ូឌ្រុព្វ » ( ចាប់ផ្ដើមត្រង់ « ខ្ញុំមានវិវរណៈមួយចំនួន » ) ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួរដែលប្រធាន វ៉ូឌ្រុព្វបានសួរដល់ពួកបរិសុទ្ធ ។

- តើអ្នកនឹងសង្ខេបសំណួររបស់ប្រធាន វ៉ូឌ្រុព្វ ដែលត្រូវបានបំផុសឲ្យសួរដល់ពួកបរិសុទ្ធយ៉ាងដូចម្ដេច ?

សូមពន្យល់ថា ពួកបរិសុទ្ធគឺស្ថិតនៅក្នុងភាពគ្រោះថ្នាក់នៃការបាត់បង់ព្រះវិហារបរិសុទ្ធសេន្ត ចច យូថាហ៍ ព្រះវិហារបរិសុទ្ធឡូហ្គិន យូថាហ៍ ព្រះវិហារបរិសុទ្ធម៉ាន់ថៃយូថាហ៍ និងព្រះវិហារបរិសុទ្ធសលត៍ លេកដែលហៀបនឹងសាងសង់បញ្ចប់នោះ ។ ( បើអាចធ្វើទៅបាន អ្នកអាចនឹងចង់ដាក់តាំងរូបភាពព្រះវិហារបរិសុទ្ធទាំងនេះ ) ។

- តើកិច្ចការសំខាន់អ្វីខ្លះ នឹងត្រូវបញ្ចប់ បើព្រះវិហារបរិសុទ្ធត្រូវបានរឹបអូសយកនោះ ?

សូមឲ្យសិស្សម្នាក់អានឮៗនូវកថាខណ្ឌទីប្រាំពីរនៃ «ការដកស្រង់ចេញមកពីប្រសាសន៍ទាំងបីរបស់ប្រធាន វិលហ្វឺ វ៉ូឌ្រុព្វ » ( ចាប់ផ្ដើមត្រង់ « ខ្ញុំបានឃើញយ៉ាងច្បាស់ » ) ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលនូវអ្វីដែលប្រធាន វ៉ូឌ្រុព្វនឹងបានធ្វើ បើព្រះពុំបានបញ្ជាលោកឲ្យណែនាំដល់ពួកអ្នកដឹកនាំសាសនាចក្រឲ្យបញ្ឈប់ការអនុវត្តនូវការធ្វើពិធីអាពាហ៍ពិពាហ៍ពហុពន្ធភាពនោះ ។

- តើប្រធាន វ៉ូឌ្រុព្វ គួរបានធ្វើអ្វីខ្លះ ?
- តើយើងអាចរៀនអ្វីខ្លះមកពីសេចក្ដីថ្លែងការណ៍របស់ប្រធាន វ៉ូឌ្រុព្វ « ខ្ញុំបានសរសេរនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ឲ្យខ្ញុំសរសេរ ? » ( បន្ទាប់ពីសិស្សឆ្លើយតប អ្នកអាចនឹងចង់សរសេរនូវគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់តាមរយៈវិវរណៈទៅដល់ប្រធានសាសនាចក្រ** )។
- តើគោលលទ្ធិនេះបានជះឥទ្ធិពលលើអ្នកយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីសេចក្ដីពិតដែលអ្នកបានសរសេរនៅលើក្ដារខៀន ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកផងដែរ ។



សូមពន្យល់ថា ពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួនតូច បានបន្តចូលទៅក្នុងអាពាហ៍ពិពាហ៍ពហុពន្ធភាពថ្មី បន្ទាប់ពីត្រូវបានប្រគល់ឲ្យនូវគោលនយោបាយនោះ ។ នៅក្នុងឆ្នាំ ១៩០៤ ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានប្រកាស « ថារាល់អាពាហ៍ពិពាហ៍ [ពហុពន្ធភាព] គឺត្រូវបានហាមឃាត់ ហើយបើមានអ្នកកាន់តំណែងណាមួយ ឬសមាជិកនៃសាសនាចក្រណាម្នាក់ ទទួលយកដោយគោរព ឬចូលទៅក្នុងអាពាហ៍ពិពាហ៍ប្រភេទនេះ នោះគាត់នឹងត្រូវ. . . កាត់កាលចេញពីសាសនាចក្រ » ( នៅក្នុង Conference Report, ខែ មេសា ឆ្នាំ ១៩០៤, ទំព័រ ៧៥) ។ គោលនយោបាយនេះបន្តនៅមានសព្វថ្ងៃនេះ ។

- ផ្អែកទៅលើអ្វីដែលអ្នកបានរៀន តើអ្នកនឹងឆ្លើយតបយ៉ាងដូចម្ដេច បើសិនជានរណាម្នាក់បានសួរថាតើពួកបរិសុទ្ធថ្ងៃចុងក្រោយពិតជាបានអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពមែនដែរឬទេ ? ( សូមជួយសិស្សឲ្យយល់ថា សមាជិកសាសនាចក្របានអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពមួយរយៈ ក្នុងការគោរពតាមបញ្ញារបស់ព្រះអម្ចាស់ ប៉ុន្តែការអនុវត្តនោះបានបញ្ឈប់ជាយូរលង់មកហើយ ស្របតាមបញ្ញារបស់ព្រះអម្ចាស់ផងដែរ ។ អាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់ គឺជាបទដ្ឋានអាពាហ៍ពិពាហ៍របស់ព្រះ លុះត្រាតែគាត់ប្រកាសតាមរបៀបផ្សេងទៀតប៉ុណ្ណោះ ( សូមមើល យ៉ាកុប ២:២៧–៣០ ) ) ។

### ព្រះអម្ចាស់បានបើកសម្ដែងថា ពួកបរិសុទ្ធថ្ងៃចុងក្រោយគប្បីផ្សារភ្ជាប់សមាជិកក្រុមគ្រួសាររបស់ពួកគេ ។

សូមពន្យល់ថា បន្ទាប់ពីគោលនយោបាយត្រូវបានប្រគល់ឲ្យមក ការគម្រាមគំហែងរឹបអូសយកព្រះវិហារបរិសុទ្ធរបស់រដ្ឋាភិបាលសហព័ន្ធ និងសម្បត្តិរបស់សាសនាចក្រត្រូវបានបញ្ចប់ ។ បើគ្មានការរំខានដូច្នោះទេ នោះពួកបរិសុទ្ធអាចនឹងត្រូវបានផ្ដោតអារម្មណ៍កាន់តែខ្លាំងទៅលើកិច្ចការព្រះវិហារបរិសុទ្ធ។ នៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៩៣ រយៈពេលសែសិបឆ្នាំ បន្ទាប់ពីថ្មជ្រុងនៃព្រះវិហារបរិសុទ្ធសលត៍ លេកត្រូវបានបញ្ចុះ ប្រធាន វិលហ្វឺឌ វូឌរ៉ុហ្វ បានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនោះ ដោយនាំឲ្យមានព្រះវិហារបរិសុទ្ធមានដំណើរការបានចំនួនបួន ។

នៅខែមេសា ឆ្នាំ ១៩៨៩៤ រយៈពេលមួយឆ្នាំ បន្ទាប់ពីការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធសលត៍ លេក ប្រធាន វិលហ្វឺឌ វូឌរ៉ុហ្វ បានប្រកាសថា លោកបានទទួលវិវរណៈមួយ ។ មុនពេលវិវរណៈនេះ សមាជិកសាសនាចក្រ បានធ្វើតាមចំណេះដឹងដែលពួកគេមាន ដែលពួកគេបានផ្សារភ្ជាប់ខ្លួនពួកគេ ឬ « បានធ្វើជាសាច់ញាតិចិញ្ចឹម » ទៅនឹងអ្នកដឹកនាំសាសនាចក្រដូចជា យ៉ូសែប ស្ម៊ីធ ឬ ព្រិកហាំ យ៉ង់ ជាជាងផ្សារភ្ជាប់ទៅនឹងឪពុកម្ដាយផ្ទាល់ខ្លួនរបស់ពួកគេ ។ ប៉ុន្ដែប្រធាន វូឌរ៉ុហ្វ បានដឹងតាមវិវរណៈថា លោកគួរតែដឹកនាំពួកបរិសុទ្ធ « ឲ្យសរសេរពង្សប្រវត្តិរបស់ពួកគេឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយត្រូវផ្សារភ្ជាប់ទៅនឹងឪពុក និងម្ដាយរបស់ពួកគេ ។ សូមឲ្យកូនៗផ្សារភ្ជាប់នឹងឪពុកម្ដាយរបស់ពួកគេ ហើយប្រើការតជាខ្សែរតំណរនេះ ទៅកាន់ជំនាន់ដើមតាមដែលអ្នកអាចរកបាន ។. . . នេះគឺជាព្រះទ័យរបស់ព្រះអម្ចាស់ចំពោះរាស្ត្ររបស់ទ្រង់ » (នៅក្នុង James R. Clark, ចងក្រង *Messages of the First Presidency of The Church of Jesus Christ of Latter–day Saints,* វ៉ុលទី ៦ [ឆ្នាំ ១៩៦៥–៧៥], ៣:២៥៦–២៥៧; សូមមើលផងដែរ *Teachings of Presidents of the Church: Wilford Woodruff* ២០០៤ ], xxxiii–xxxv) ។

- តើអ្នកណាខ្លះដែលយើងអាចត្រូវបានផ្សារភ្ជាប់តាមរយៈពិធីបរិសុទ្ធ ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរសេចក្ដីពិតនៅលើក្ដារខៀន ៖**យើងអាចត្រូវបានផ្សារភ្ជាប់ទៅសមាជិកគ្រួសាររបស់យើង រួមមានទាំងអស់អ្នកដែលបានទទួលមរណភាព និងអ្នកដែលមកក្រោយយើង តាមរយៈអំណាចនៃការផ្សារភ្ជាប់** ) ។

- តើអ្នកមានអារម្មណ៍យ៉ាងណាអំពីការដឹងថា អ្នកអាចត្រូវបានផ្សារភ្ជាប់ទៅនឹងសមាជិកគ្រួសាររបស់អ្នក ?

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីអំណាចនៃការផ្សារភ្ជាប់ និងសារៈសំខាន់នៃការតភ្ជាប់ខ្លួនយើងទៅនឹងជំនាន់នៃគ្រួសាររបស់យើងតាមរយៈពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ។

មេរៀនទី ១៥៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–២៤

## បុព្វកថា

នៅថ្ងៃទី ៣ ខែតុលា ឆ្នាំ ១៩៨១ នៅក្នុងបីហៃ ហោស៍ នៅទីក្រុងសលត៍ លេក (ជាផ្ទះដែលប្រធាន ព្រិកហាំ យ៉ង់ បានរស់នៅ ពេលលោកជាប្រធានសាសនាចក្រ ) ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានទទួលការនិមិត្តដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨។ នៅក្នុងការនិមិត្តនេះ ប្រធានស្ម៊ីធ បាន ឃើញព្រះអង្គសង្គ្រោះ ចន្លោះពេលនៃការសុគត និងការរស់ឡើងវិញរបស់ទ្រង់ បម្រើទៅដល់វិញ្ញាណសុចរិតនៅស្ថានបរមសុខ ដែលកំពុងរង់ចាំការរំដោះឲ្យរួចពី ចំណងនៃសេចក្ដីស្លាប់ ។ នេះគឺជាមេរៀនទីមួយនៃមេរៀនចំនួនពីរ ដែលពិភាក្សា អំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–១១

*ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ពិចារណាអំពីបទគម្ពីរទាំងឡាយ និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ*

សូមឲ្យសិស្សនឹកគិត អំពីផែនការនៃសេចក្ដីសង្គ្រោះ និងអ្វីដែលបានកើតឡើងទៅដល់វិញ្ញាណ និងរូបកាយនៅពេលស្លាប់ ។

- តើមានអ្វីនឹងកើតឡើងចំពោះវិញ្ញាណ និងរូបកាយរបស់យើង ពេលយើងស្លាប់ ? តើវិញ្ញាណរបស់យើងនឹងទៅកន្លែងណា ?
- តើអ្នកនឹកគិតថា ពិភពវិញ្ញាណមានលក្ខណៈដូចម្ដេច ?

សូមពន្យល់ថា ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ជាប្រធានសាសនាចក្រទីប្រាំមួយ បានទទួលវិវរណៈមួយអំពីពិភពវិញ្ញាណ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានន្ទការណែនាំ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលប្រធាន ស្ម៊ីធ បានទទួលពិសោធន៍នៅក្នុងពេលជាច្រើនខែពីមុនសន្និសីទទូទៅខែតុលា ឆ្នាំ ១៩១៨ ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមប្រាប់សិស្សថា នៅក្នុងខែទាំងនោះ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធកំពុងកាន់ទុក្ខចំពោះការបាត់បង់កូនប្រុសរបស់លោក ហៃរ៉ុម ម៉ាក់ ស្ម៊ីធ ដែលបានបម្រើជាសមាជិកមួយរូបនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ អែលឌើរ ស្ម៊ីធ បានទទួលមរណភាពនៅដើមឆ្នាំនោះ ដោយសារធ្លាយពោះវៀនដុះខ្នែង នៅក្នុងវ័យ ៤៥ ឆ្នាំ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគោលលទ្ធិដែលប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ពិចារណានៅថ្ងៃទី ៣ ខែតុលា ឆ្នាំ ១៩១៨ នៅពេលលោកនៅស្ងាត់ម្នាក់ឯងក្នុងបន្ទប់លោក ។

- តើគោលលទ្ធិអ្វីដែលប្រធាន ស្ម៊ីធ ពិចារណា ? ( បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖ **តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងតាមរយៈការគោរពប្រតិបត្តិចំពោះគោលការណ៍ទាំងឡាយនៃដំណឹងល្អ មនុស្សទាំងអស់អាចត្រូវបានសង្គ្រោះ** ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលប្រធាន ស្ម៊ីធ បានជួបបទពិសោធន៍ នៅពេលលោកពិចារណាអំពីដង្វាយធួន ។

- តើមានអ្វីខ្លះបានចូលមកក្នុងគំនិតរបស់ប្រធាន ស្ម៊ីធ នៅពេលលោកបានពិចារណាអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ?

សូមសួរដល់សិស្សបើពួកគេធ្លាប់មានវគ្គគម្ពីរណាមួយ ដែលផុសចេញមកក្នុងគំនិតរបស់ពួកគេ នៅពេលពួកគេបានពិចារណាចំណែកមួយនៃដំណឹងល្អ ។ សូមអញ្ជើញពួកគេឲ្យចែកចាយពីបទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៦–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការបង្រៀនដែលបានធ្វើឲ្យប្រធានស្ម៊ីធរំភើបចិត្ត ។ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ បន្ទាប់មកសូមពន្យល់ថា ប្រធាន ស្ម៊ីធ បានទទួលការនិមិត្តមួយដែលជួយយើងយល់អំពីការបង្រៀនរបស់ពេត្រុស អំពីពិភពវិញ្ញាណ ។

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១១ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលប្រធាន ស្ម៊ីធ បានមើលឃើញ នៅពេលលោកពិចារណាអំពីបទគម្ពីរ ។ សូមសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា ពីមុនសិស្សរៀនអំពីការនិមិត្តរបស់ប្រធាន ស្ម៊ីធ អំពីពិភពវិញ្ញាណ ពួកគេគួរតែកត់សម្គាល់អំពីដំណើរការនៃវិវរណៈដែលលោកបានពិពណ៌នា ៖ នៅពេលលោកពិចារណាអំពីបទគម្ពីរ លោកបាននឹកគិតដល់គោលលទ្ធិនៃដង្វាយធួន និងក្ដីស្រឡាញ់ដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទមានចំពោះមនុស្សលោកទាំងអស់ ។ គំនិតទាំងនេះ បាននាំឲ្យលោកនឹកចាំអំពីពាក្យសម្ដីរបស់ពេត្រុស ។ បន្ទាប់មក ពេលលោកពិចារណាអំពីពាក្យសម្ដីរបស់ពេត្រុស « កែវភ្នែកនៃការយល់ដឹងរបស់ [លោក] ត្រូវបានបើកឡើង » ព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតមកលើលោក ហើយលោកបានឃើញពិភពវិញ្ញាណ ។

- តើយើងអាចរៀនអ្វីខ្លះមកពីប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ អំពីការត្រៀមខ្លួនដើម្បីទទួលវិវរណៈ ? ( សិស្សអាចប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគប្បីប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖**នៅពេលយើងអាន និងពិចារណាបទគម្ពីរ នោះយើងត្រៀមខ្លួនយើងដើម្បីទទួលវិវរណៈ ។** អ្នកអាចស្នើឲ្យសិស្សសរសេរគោលការណ៍នេះ នៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ខ ១១ ។)
- តើការអាន និងការពិចារណាបទគម្ពីរជួយអ្នកអញ្ជើញឲ្យមានវិវរណៈយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ( បើអាចធ្វើទៅបាន សូមផ្ដល់ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍ដល់សិស្ស ហើយសុំឲ្យពួកគេផ្ទៀងតាម ) ។ សូមឲ្យសិស្សស្ដាប់ការពិពណ៌នារបស់អែលឌើរ គ្រីស្តូហ្វឺសិន អំពីរបៀបដែលយើងគប្បីសិក្សាបទគម្ពីរ ៖



« នៅពេលដែលខ្ញុំនិយាយថា ‹ សិក្សា › ខ្ញុំមានន័យថាជាអ្វីមួយ ដែលពិសេសជាងការគ្រាន់តែអានទៅទៀត ។. . . ខ្ញុំឃើញថា ពេលខ្លះអ្នកអានខគម្ពីរមួយចំនួន រួចហើយឈប់ ដើម្បីសញ្ជឹងគិតអំពីខគម្ពីរនោះ សូមអានខគម្ពីរនេះម្ដងទៀតដោយយកចិត្តទុកដាក់ ហើយនៅពេលអ្នកគិតពីន័យរបស់វា សូមអធិស្ឋានសម្រាប់ការយល់ដឹង សួរសំណួរនៅក្នុងគំនិតរបស់អ្នក រង់ចាំការបំផុសគំនិតខាងវិញ្ញាណ និងសរសេរទុកនូវការបំផុសគំនិត និង ទស្សនៈវិស័យជ្រៅជ្រះដែលនឹងមក ដូច្នេះអ្នកអាចចងចាំ និងរៀនបានច្រើនជាង » (When Thou Art Converted, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ១១ ) ។

- តើពេលណាដែលអ្នកបានធ្វើតាមគំរូនេះ នៅក្នុងការសិក្សាគម្ពីររបស់អ្នក ? តើវាបានផ្លាស់ប្ដូរបទពិសោធន៍របស់អ្នកយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយ ដើម្បីអាន និងពិចារណាអំពីបទគម្ពីរតាមរបៀបដែលអែលឌើរ គ្រីស្តូហ្វឺសិន បានពិពណ៌នា ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១២–២៤, ៣៨–៥០

*យ៉ូសែប អែហ្វ ស្ម៊ីធ មើលឃើញមរណជនសុចរិត កំពុងរង់ចាំការរស់ឡើងវិញរបស់ពួកគេ*

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ បន្ទាប់មក សូមឲ្យពួកគេពិភាក្សាសំណួរខាងក្រោមជាមួយនឹងដៃគូរបស់ពួកគេ ៖

- តើព្រឹត្តការណ៍នាពេលអនាគតអ្វីខ្លះ ដែលអ្នកកំពុងទន្ទឹងចាំខ្លាំងបំផុតនោះ ? ហេតុអ្វីអ្នករំភើបចិត្តចំពោះវា ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ប្រាប់ចម្លើយរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។ សូមពន្យល់ថា នៅពេលប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានមើលឃើញពិភពវិញ្ញាណនៅក្នុងការនិមិត្ត នោះលោកបានឃើញនូវការប្រមូលផ្ដុំគ្នាដ៏ធំនៃពួកវិញ្ញាណ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១២–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការពិពណ៌នាអំពីពួកវិញ្ញាណដែលបានប្រមូលផ្ដុំគ្នានោះ ។

- តើប្រធាន ស្ម៊ីធ ពិពណ៌នាអំពីពួកវិញ្ញាណដែលលោកបានមើលឃើញយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៣៨–៤៩ ដោយស្ងាត់ស្ងៀម រកមើលឈ្មោះនៃពួកវិញ្ញាណមួយចំនួនដែលនៅទីនោះ ។ ( អ្នកអាចនឹងចង់ផ្ដល់យោបល់ឲ្យសិស្សគូសចំណាំឈ្មោះទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ) ។ សូមឲ្យសិស្សរាយការណ៍ពីឈ្មោះមួយចំនួនដែលពួកគេរកឃើញ ។

- ស្របតាម ខ ៤៩ តើពួកវិញ្ញាណទាំងនេះកំពុងរង់ចាំអ្វី ? ( ការរំដោះឲ្យរួច ) ។

### *រក្សាចំណាប់អារម្មណ៍*

ដោយសារតែសិស្សពេលខ្លះមានរយៈពេលចំណាប់អារម្មណ៍មានកម្រិត សូមដាក់ផែនការសកម្មភាព និងសំណួរដែលនឹងបង្កើតចំណាប់អារម្មណ៍ ហើយជួយអ្នករៀនឲ្យផ្ដោតចំណាប់អារម្មណ៍ និងការយកចិត្តទុកដាក់របស់ពួកគេទៅលើបទគម្ពីរនៅក្នុងមេរៀន ។ សកម្មភាពទាំងនេះគឺមានប្រសិទ្ធភាពបំផុត នៅពេលវាសង្ខេបខ្លី និងពេលដែលវាជួយអ្នករៀនឲ្យផ្ដោតទៅលើគោលការណ៍ចម្បងនៅក្នុងផ្នែកផ្សេងៗនៃមេរៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៤–១៦, ៥០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវមូលហេតុដែលក្រុមវិញ្ញាណសុចរិតទាំងនេះ ពោរពេញដោយសេចក្ដីអំណរ និងភាពសប្បាយរីករាយ ។

- ហេតុអ្វីបានជាពួកវិញ្ញាណសុចរិតទាំងនេះបានពោរពេញដោយសេចក្ដីអំណរ និងសេចក្ដីអររីករាយ ? ( « ដោយសារតែថ្ងៃនៃសេចក្ដីរំដោះរបស់គេនៅជិតដែបង្ហើយ » [ខ ១៥] ។ ជាពាក្យម្យ៉ាងទៀតថា ពួកគេបានដឹងថា ពួកគេនឹងត្រូវបានរស់ឡើងវិញក្នុងពេលឆាប់ៗ ដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ) ។
- ហេតុអ្វីអ្នកគិតថា ការផ្គុំឡើងវិញនៃវិញ្ញាណ និងរូបកាយ នឹងនាំមកនូវសេចក្ដីរំដោះចំពោះពួកវិញ្ញាណសុចរិតទាំងនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៧ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវពរជ័យទាំងឡាយដែលក្រុមព្រលឹងសុចរិត ទទួលបាន បន្ទាប់ពីវិញ្ញាណ និងរូបកាយរបស់ពួកគេផ្គុំឡើងវិញ ។ អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំអ្វី ដែលពួកគេបានរកឃើញ ។

- តើយើងអាចទទួលបានអ្វីខ្លះ នៅពេលយើងត្រូវបានរស់ឡើងវិញ ? ( ភាពពេញលេញនៃសេចក្ដីអំណរ ) ។
- តើយើងអាចរៀនអ្វីខ្លះមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៤–១៧, ៥០ អំពីការរំដោះឲ្យរួចពីការស្លាប់ខាងរូបកាយ ? ( សិស្សអាចនឹងប្រាប់ អំពីគោលលទ្ធិ និងគោលការណ៍ផ្សេងៗ ប៉ុន្តែសូមប្រាកដថា ពួកគេយល់នូវគោលលទ្ធិពីរដូចខាងក្រោម ៖ **តាមរយៈព្រះគុណនៃព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងត្រូវបានរំដោះឲ្យរួចពីចំណងនៃសេចក្ដីស្លាប់** ហើយ **យើងអាចទទួលបានសេចក្ដីអំណរពេញលេញតាមរយៈការរស់ឡើងវិញ** ។ អ្នកអាចនឹងចង់សរសេរគោលលទ្ធិទាំងនេះលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ដែលបានអធិប្បាយអំពីតម្រូវការ និងពរជ័យនៃការមានរូបកាយសាច់ឈាម ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់មើលមូលហេតុនៃការមានរូបកាយសាច់ឈាម មានសារៈសំខាន់ចំពោះផែនការរបស់ព្រះវរបិតាសួគ៌ចំពោះយើង ដើម្បីមានភាពពេញលេញនៃសេចក្ដីអំណរ ។



« រូបកាយសាច់ឈាមរបស់យើង ធ្វើឲ្យមានបទពិសោធន៍ទូលំទូលាយ ជ្រាលជ្រៅ និង កម្លាំង ដែលជាធម្មតាពុំអាចទទួលបាននៅក្នុងរូបកាយមុនជីវិតមែងស្លាប់របស់យើងបានឡើយ ។ ដូច្នេះទំនាក់ទំនងរបស់យើងជាមួយមនុស្សទូទៅ សមត្ថភាពរបស់យើងដើម្បីស្គាល់ និង ប្រព្រឹត្តស្របតាមសេចក្ដីពិត និង លទ្ធភាពរបស់យើងដើម្បីគោរពតាមគោលការណ៍ និង ពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានពង្រីកឲ្យកាន់តែល្អឡើងតាមរយៈរូបកាយសាច់ឈាមរបស់យើង ។. . .

« ផែនការរបស់ព្រះវរបិតា ត្រូវបានគ្រោងឡើង ដើម្បីផ្ដល់ការដឹកនាំចំពោះកូនចៅរបស់ទ្រង់ ដើម្បីជួយពួកគេឲ្យរីករាយ ហើយនាំពួកគេត្រឡប់ទៅផ្ទះវិញ ទៅឯទ្រង់ដោយសុវត្ថិភាព ជាមួយនឹងរូបកាយដែលរស់ឡើងវិញ និងតម្កើងឡើង » (We Believe in Being Chaste,» *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៤១, ៤៣ ) ។

- ហេតុអ្វីយើងត្រូវការរូបកាយសាច់ឈាមដើម្បីទទួលបានសេចក្ដីអំណរពេញលេញ ?

ដើម្បីបន្ថែមពីលើចម្លើយរបស់សិស្ស អ្នកអាចនឹងចង់ពន្យល់ថា ភាពពេញលេញនៃសេចក្ដីអំណរ គឺជាប្រភេទនៃសេចក្ដីអំណរដែលព្រះវរបិតាសួគ៌មានបទពិសោធន៍ ។ ព្រះវរបិតាសួគ៌ មានរូបកាយសាច់ឈាមជា សាច់ និងឆ្អឹង ( សូមមើល គ. និង ស. ១៣០:២២) ។ នៅពេលវិញ្ញាណ និងរូបកាយរបស់យើងត្រូវបានបំបែកចេញពីគ្នា យើងពុំដូចជាទ្រង់ឡើង ហើយពុំអាចទទួលភាពពេញលេញនៃសេចក្ដីអំណរឡើយ ( សូមមើល គ. និង ស. ៩៣:៣៣–៣៤) ។ នៅពេលវិញ្ញាណ និងរូបកាយរបស់យើងភ្ជាប់នឹងគ្នាដោយពុំអាចបំបែកបាន–នៅពេលយើងត្រូវបានរស់ឡើងវិញ– នោះយើងអាចប្រែក្លាយដូចជាព្រះវរបិតាសួគ៌របស់យើង ហើយមានសេចក្ដីអំណរពេញលេញនៅទីបំផុត ។

សូមពន្យល់ថា ពួកសុចរិតនៅក្នុងពិភពវិញ្ញាណ កំពុងរង់ចាំ «ការយាងមក» ឬការយាងមកដល់របស់ព្រះរាជបុត្រានៃព្រះ ដើម្បីរំដោះពួកគេ ហើយស្ដារពួកគេឡើងនៅក្នុង « រូបរាងពេញខ្នាត » (គ. និង ស. ១៣៨:១៦–១៧) ។ សូមអញ្ជើញសិស្សឲ្យនឹកគិតក្នុងចិត្តនូវអ្វីដែលបានកើតឡើងនៅលើផែនដី ខណៈដែលពួកវិញ្ញាណសុចរិតទាំងនេះ ត្រូវបានប្រមូលផ្ដុំ ។ ព្រះយេស៊ូវគ្រីស្ទ បានធ្វើដង្វាយធួនសម្រាប់កូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ តាមរយៈការរងទុក្ខរបស់ទ្រង់នៅក្នុងសួនច្បារគេតសេម៉ានី និងនៅលើឈើឆ្កាង ។ ពួកវិញ្ញាណសុចរិតមួយចំនួន ដែលនៅក្នុងពិភពវិញ្ញាណ បានរង់ចាំអស់រាប់ពាន់ឆ្នាំសម្រាប់សេចក្ដីរំដោះរបស់ពួកគេ ។ ការពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ រួមមានទាំងការប្រោសលោះពីអំពើបាបរបស់ពួកគេ ក៏ដូចជាសេចក្ដីសង្គ្រោះពីសេចក្ដីស្លាប់ខាងរូបកាយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៨–១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម នឹកស្រមៃពីព្រឹត្តិការណ៍ដែលអាចកើតមាន ដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

- តើអ្នកគិតថា ការលេចព្រះកាយរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងពិភពវិញ្ញាណអាចនឹងមានលក្ខណៈយ៉ាងដូចម្ដេចចំពោះអ្នកទាំងឡាយដែលទ្រង់បានយាងទៅជួប ?
- តើព្រះអង្គសង្គ្រោះបង្រៀនដល់ពួកវិញ្ញាណទាំងនេះអ្វីខ្លះ ?
- តើអ្នកអាចឆ្លើយតបចំពោះព្រះអង្គសង្គ្រោះ ដែលបានធ្វើដង្វាយធួនសម្រាប់អ្នកយ៉ាងដូចម្ដេច បើអ្នកបាននៅទីនោះស្ដាប់ឮទ្រង់ផ្សាយនៅក្នុងពិភពវិញ្ញាណ ? ( អ្នកអាចសុំឲ្យសិស្សពិចារណាអំពីសំណួរនេះដោយស្ងាត់ស្ងៀម ជាជាងឆ្លើយដោយឮៗ ។ )

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:២៣–២៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលពួកវិញ្ញាណសុចរិតបានឆ្លើយតបចំពោះការយាងមកជួបរបស់ព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមចង្អុលបង្ហាញទៅគោលលទ្ធិទីមួយ ដែលអ្នកបានសរសេរនៅលើក្ដារខៀន ៖ **តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង តាមរយៈការគោរពប្រតិបត្តិចំពោះគោលការណ៍ទាំងឡាយនៃដំណឹងល្អ មនុស្សទាំងអស់អាចត្រូវបានសង្គ្រោះ ។** សូមពន្យល់ថា នៅពេលសិស្សបន្តសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ នោះពួកគេនឹងរៀនអំពីរបៀបដែលព្រះវរបិតាសួគ៌ បានផ្ដល់នូវមាគ៌ាមួយចំពោះកូនចៅទាំងអស់របស់ទ្រង់ ដើម្បីទទួលប្រយោជន៍មកពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។

មេរៀនទី ១៥៥

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៧–៦០

## បុព្វកថា

មេរៀននេះ គឺជាមេរៀនទីពីរអំពីវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨។ នៅពេលប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានពិចារណាអំពីបទគម្ពីរមួយចំនួននៅក្នុងគម្ពីរសញ្ញាថ្មី លោកបានមើលឃើញការនិមិត្តមួយ អំពីពិភពវិញ្ញាណ និងអំពីវិញ្ញាណជនសុចរិតដែលរង់ចាំសេចក្ដីរំដោះ ឲ្យរួចពីចំណងនៃសេចក្ដីស្លាប់ ។ ប្រធាន ស្ម៊ីធ ក៏បានមើលឃើញផងដែរថា ព្រះយេស៊ូវគ្រីស្ទបានរៀបចំ និងអនុញ្ញាតឲ្យពួកអ្នកបម្រើសុចរិតបង្រៀនដំណឹងល្អដល់ពួកវិញ្ញាណដែលនៅក្នុងស្ថានឃុំព្រលឹង នៅចន្លោះពេលនៃការសុគត និងការរស់ឡើងវិញរបស់ទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៧–៣៧

*ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានរៀនអំពីរបៀបដែលដំណឹងល្អត្រូវបានផ្សាយនៅក្នុងពិភពវិញ្ញាណ*

សូមប្រាប់សិស្សថាមនុស្សនៅទូទាំងពិភពលោកប្រកាន់ជំនឿផ្សេង ៗគ្នា អំពីអ្វីដែលកើតឡើងចំពោះពួកយើងបន្ទាប់ពីយើងស្លាប់ ។ សូមសួរ ប្រសិនបើសិស្សធ្លាប់ជួបនរណាម្នាក់ដែលមានជំនឿផ្សេង ដែលទាក់ទងនឹងអ្វីដែលកើតឡើងចំពោះពួកយើងបន្ទាប់ពីយើងស្លាប់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ខ្លួន ។ ( សូមប្រយ័ត្នកុំនិយាយអវិជ្ជមាន ឬនិយាយមើលងាយដល់ជំនឿរបស់សាសនាដទៃឡើយ ) ។

- តើយើងអាចដឹងយ៉ាងដូចម្ដេចថា ជំនឿណាមួយអំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ថាត្រឹមត្រូវ ? ( អ្នកអាចអាចនឹងចង្អុលបង្ហាញថា ទោះជាពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួន ក៏អាចមានជំនឿពុំត្រឹមត្រូវអំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ដែរ ) ។

ដើម្បីបន្ថែមដល់ចម្លើយរបស់សិស្ស សូមសិស្សម្នាក់អានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« បទគម្ពីរគឺជាថ្មសាកមាស ដើម្បីវាស់នូវភាពត្រឹមត្រូវ និងភាពពិត » (The Blessing of Scripture» *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៣៤ ) ។

សូមបញ្ជាក់ថា យើងអាចដឹងពីភាពត្រឹមត្រូវនៃជំនឿផ្សេងៗ អំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ដោយការប្រៀបធៀបជំនឿទាំងនោះជាមួយនឹងសេចក្ដីពិតទាំងឡាយ ដែលព្រះអម្ចាស់បានបើកសម្ដែងនៅក្នុងបទគម្ពីរ ដូចជានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨។

សូមគូស ឌីយ៉ាក្រាមដែលអមមកជាមួយ នៅលើក្ដារខៀន ។ អ្នកអាចពន្យល់ខ្លីៗថា តាមរបៀបមួយចំនួននៅក្នុងពិភពវិញ្ញាណទាំងមូលអាចចាត់ទុកថាជាស្ថានឃុំវិញ្ញាណ ដោយសារសូម្បីតែពួកសុចរិតបានគិតថាការបែកចេញពីរាងកាយរបស់ខ្លួននោះគឺជាសេវកភាព ( សូមមើល គ. និង ស. ១៣៨:៤៩–៥០) ។




ដើម្បីជួយសិស្សរំឭកដោយសង្ខេបអំពីសេចក្ដីពិត ដែលពួកគេបានរៀននៅក្នុងមេរៀនមុននៅកណ្ឌ ១៣៨ ដោយចាត់ឲ្យសិស្សពាក់កណ្ដាលថ្នាក់ស្រាវជ្រាវនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១២–១៥, ២២ នូវព័ត៌មានលម្អិត អំពីអ្នកដែលនឹងទៅស្ថានបរមសុខពេលស្លាប់ទៅ និងស្ថានភាពនានាដែលពួកគេនឹងជួបប្រទះនៅទីនោះ ។ សូមចាត់សិស្សពាក់កណ្ដាលថ្នាក់ទៀតស្រាវជ្រាវ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:២០–២២ រកព័ត៌មានលម្អិតអំពីអ្នកដែលនឹងទៅស្ថានឃុំព្រលឹង បន្ទាប់ពីស្លាប់ទៅ និងស្ថានភាពនានាដែលពួកគេនឹងជួប ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមចង្អុលបង្ហាញថា ពុំមែនមានតែពួកមនុស្សទុច្ចរិត និងមនុស្សប្រព្រឹត្តិល្មើសលើបញ្ញត្តិប៉ុណ្ណោះទេ ដែលទៅស្ថានឃុំព្រលឹងនៅពេលពួកគេស្លាប់ទៅនោះ ប៉ុន្តែក៏មានអ្នកទាំងឡាយដែលស្លាប់ទៅនៅក្នុងអំពើបាបរបស់ពួកគេ ដោយគ្មានចំណេះដឹងនៃដំណឹងល្អផងដែរ ( សូមមើល គ. និង ស. ១៣៨:៣២) ។ សូមរំឭកសិស្សថា ខណៈដែលប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ ពិចារណាអំពីខគម្ពីរនៅក្នុងពេត្រុសទី ១ នោះព្រះអម្ចាស់បានបើកសម្ដែងដល់លោកអំពីរបៀបដែលអ្នកនៅក្នុងស្ថានឃុំព្រលឹងនឹងមានឱកាសដើម្បីទទួលពរជ័យទាំងឡាយនៃដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៧–១០ ឲ្យឮៗ ។ សូមដល់សិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលនូវអ្វីដែលពេត្រុសបានថ្លែងអំពីអ្វីដែលព្រះយេស៊ូវបានធ្វើ បន្ទាប់ពីទ្រង់ត្រូវបាន «គេធ្វើគតខាងសាច់ឈាម » ។

- តើពេត្រុសបានថ្លែងថាព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ នៅពេលទ្រង់យាងទៅពិភពវិញ្ញាណ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:២៥–២៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយប្រាប់ពីអ្វីដែលប្រធាន ស្ម៊ីធ បានងឿងឆ្ងល់ នៅពេលលោកបាននឹកគិតអំពីកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងពិភពវិញ្ញាណនោះ ។

- តើប្រធានស្ម៊ីធមានចម្ងល់អ្វីខ្លះ ? ( នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់សរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើវាអាចធ្វើទៅបានដោយរបៀបណា ដើម្បីឲ្យព្រះអម្ចាស់ផ្សាយដំណឹងល្អទៅកាន់អស់អ្នកដែលស្ថិតនៅក្នុងស្ថានឃុំព្រលឹងត្រឹមតែបីថ្ងៃនោះ ? )*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:២៩–៣២ ឲ្យឮៗ ហើយសុំដល់សិស្សក្នុងថ្នាក់ឲ្យរកមើលចម្លើយដែលប្រធាន ស្ម៊ីធ បានទទួលនៅពេលលោកបានគិតពិចារណា ។

- តើព្រះអង្គសង្គ្រោះផ្សាយដំណឹងល្អដល់អ្នកទាំងឡាយដែលស្ថិតនៅក្នុងស្ថានឃុំវិញ្ញាណ ក្នុងរយៈពេលដ៏ខ្លីដូច្នេះដោយរបៀបណា ?

សូមឲ្យសិស្សប្រើនូវអ្វីដែលពួកគេបានរៀននៅក្នុង ខ ២៩–៣២ ដើម្បីថ្លែងពីសេចក្ដីពិតអំពីរបៀបដែលដំណឹងល្អត្រូវបានបង្រៀននៅក្នុងពិភពវិញ្ញាណ ។ ពួកគេគប្បីប្រាប់អ្វីខ្លះដែលស្រដៀងគ្នាទៅនឹងសេចក្ដីពិតដូចខាងក្រោម ៖ **នៅក្រោមការដឹកនាំរបស់ព្រះយេស៊ូវគ្រីស្ទ សារទូតសុចរិតបង្រៀនដំណឹងល្អដល់អ្នកទាំងឡាយដែលស្ថិតនៅស្ថានឃុំព្រលឹង ។** អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំឃ្លានៅក្នុងខ ៣០ដែលបង្រៀនពីសេចក្ដីពិតនេះ ។

ក្នុងតារាងនៅលើក្ដារខៀន សូមគូរបព្រួញមួយមកពីស្ថានបរមសុខ ទៅកាន់ស្ថានឃុំព្រលឹងដើម្បីតំណាងឲ្យពួកសារទូតសុចរិតរបស់ព្រះអម្ចាស់ ដែលកំពុងផ្សាយដំណឹងល្អនៅក្នុងស្ថានឃុំព្រលឹង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៣៣–៣៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលពួកសារទូតសុចរិតរបស់ព្រះអម្ចាស់បានបង្រៀនដល់ពួក វិញ្ញាណក្នុងស្ថានឃុំព្រលឹង ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើការបង្រៀនទាំងនេះប្រៀបធៀបនឹងអ្វីដែលមនុស្សត្រូវបានបង្រៀន នៅពេលពួកគេត្រៀមខ្លួនដើម្បីធ្វើបុណ្យជ្រមុជទឹកនៅក្នុងជីវិតរមែងស្លាប់ដោយរបៀបណា ?

### *ការគូសចំណាំ និងការចារសេចក្ដីពន្យល់បទគម្ពីរ*

គ្រូបង្រៀនទាំងឡាយ អាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំបទគម្ពីរដោយប្រាប់អ្វីខ្លះដូចនេះថា « នៅពេលអ្នកស្រាវជ្រាវខទាំងនេះ ខ្ញុំសុំអញ្ជើញអ្នកឲ្យដាក់គូសចំណាំនូវគោលការណ៍គន្លឹះមួយ ដែលអ្នករកឃើញ » ឬថា « នេះជាសេចក្ដីយោងបទគម្ពីរដ៏សំខាន់មួយ ។ អ្នកអាចនឹងចង់សរសេរដូចនេះ នៅក្នុងព្រះគម្ពីររបស់អ្នក » ។ វាល្អប្រសើរដើម្បីបង្រៀន បង្ហាញ និងអនុវត្តនូវជាតុទាំងឡាយក្នុងបទគម្ពីរដែលបានគូសចំណាំ ជាជាងបង្រៀននូវរបៀបគូសចំណាំជាក់លាក់មួយ ។ សូមគោរពសិទ្ធិជ្រើសរើសរបស់សិស្សជានិច្ច និងមិនត្រូវតម្រូវឲ្យពួកគេសរសេរនៅក្នុងព្រះគម្ពីររបស់ពួកគេនោះទេ ។ ផ្ទុយទៅវិញ សូមធ្វើការស្នើសុំ និងអនុញ្ញាតឲ្យសិស្សសម្រេចអ្វីដែលសមរម្យសម្រាប់គេ ។

- តើ « បុណ្យជ្រមុជទឹកជំនួស » គឺជាអ្វី ?
- ស្របតាម ខ ៣៤ ហេតុអ្វីក៏គោលការណ៍នៃដំណឹងល្អទាំងនេះចាំបាច់ ដើម្បីផ្សាយទៅកាន់អ្នកទាំងឡាយដែលស្ថិតនៅក្នុងស្ថានឃុំព្រលឹងដូច្នេះ ? (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ដោយ « ត្រូវបានជំនុំជំរះតាមមនុស្សក្នុងសាច់ឈាម » មានន័យថា កូនចៅរបស់ព្រះទាំងអស់ ទាំងរស់ ឬទាំងស្លាប់ ចាំបាច់ត្រូវមាននូវឱកាសដើម្បីរៀនអំពីការទទួលយកដំណឹងល្អ ដើម្បីពួកគេអាចត្រូវបានជំនុំជំរះតាមបទដ្ឋានដូចគ្នា ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៣៥–៣៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវរបៀបដែលពួកវិញ្ញាណជាច្រើន នឹងមានឱកាសមួយ ដើម្បីទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់អ្វីម្ល៉េះ ដើម្បីដឹងថា កូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ នឹងមានឱកាសដើម្បីស្ដាប់ឮ ហើយទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដូច្នេះ ?

ដើម្បីជួយសិស្សយល់អំពីរបៀបដែលមនុស្សគ្រប់រូបនឹងស្ដាប់ឮដំណឹងល្អ សូមពន្យល់ថា ទោះជាព្រះអង្គសង្គ្រោះបានយាងទៅពិភពវិញ្ញាណសម្រាប់រយៈពេលខ្លីបន្ទាប់ពីការសុគតរបស់ទ្រង់ក្ដី ក៏ទ្រង់បានរៀបចំពួកវិញ្ញាណសុចរិតឲ្យផ្សាយដំណឹងល្អដល់អ្នកដែលនៅក្នុងស្ថានឃុំព្រលឹងផងដែរ ។ កិច្ចការនេះនៅតែបន្តនាពេលបច្ចុប្បន្ននេះ ។ នៅពេលមនុស្សពុំបានស្ដាប់ឮ ឬទទួលយកដំណឹងល្អនៅក្នុងជីវិតរបស់យើង ពេលស្លាប់ទៅ នោះពួកគេក៏នឹងមានឱកាសដើម្បីស្ដាប់ឮ ហើយទទួលយកដំណឹងល្អ នៅក្នុងពិភពវិញ្ញាណផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៣៨–៦០

*ប្រធាន ស្ម៊ីធ បានមើលឃើញក្រុមវិញ្ញាណថ្លៃថ្នូ និងអស្ចារ្យ ដែលនឹងផ្សាយដំណឹងល្អនៅក្នុងស្ថានឃុំព្រលឹង ។*

សូមឲ្យសិស្សគិតអំពីសមាជិកគ្រួសារ ឬជីដូនជីតាសុចរិតរបស់ពួកគេដែលបានស្លាប់ទៅ ។

- តើអ្នកធ្លាប់ងឿងឆ្ងល់អំពីអ្វីដែលពួកគេកំពុងធ្វើនៅក្នុងពិភពវិញ្ញាណដែរឬទេ ?

សូមរំឭកសិស្សថានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៣៨–៤៩ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានរៀបរាប់ឈ្មោះនៃពួកវិញ្ញាណ « ដែលជាពួកអ្នកធំ និងពូកែ » ដែលលោកបានឃើញនៅក្នុងពិភពវិញ្ញាណដែលកំពុងរង់ចាំព្រះអង្គសង្គ្រោះ ដើម្បីលេចមកជួបពួកគេបន្ទាប់ពីការសុគតរបស់ទ្រង់នៅលើឈើឆ្កាង ។ ពួកវិញ្ញាណមួយចំនួន ដែលព្រះអង្គសង្គ្រោះបានយាងទៅជួបគឺពួកព្យាការីគម្ពីរសញ្ញាចាស់ និងគម្ពីរមរមន ។ នៅសេចក្ដីផ្ដើម ខ ៥៣ យើងអានថា ប្រធាន ស្ម៊ីធ ក៏បានមើលឃើញពួកវិញ្ញាណជម្រើសផងដែរ ដែលនឹងមកនៅក្នុងថ្ងៃចុងក្រោយ រួមមានទាំងព្យាការី យ៉ូសែប ស្ម៊ីធ ( ឪពុកមារបស់លោក ) និង ហៃរុម ស្ម៊ីធ ( ឪពុករបស់លោក ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥៣–៥៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលបុគ្គលទាំងនេះបានរួមចំណែក អំឡុងពេលពួកគេបានមានជីវិតនៅលើផែនដីដើម្បីសេចក្ដីសង្គ្រោះនៃអស់អ្នកដែលនៅក្នុងស្ថានឃុំវិញ្ញាណ ។

- តើថ្នាក់ដឹកនាំសាសនាចក្រថ្ងៃចុងក្រោយនេះ បានជួយវិញ្ញាណនៅក្នុងស្ថានឃុំវិញ្ញាណដោយរបៀបណា ?

បន្ទាប់ពីសិស្សបានរកឃើញ ពួកព្យាការីថ្ងៃចុងក្រោយដែលបានជួយនៅក្នុងការប្រោសលោះដល់មរណជន តាមរយៈការសាងសង់ព្រះវិហារបរិសុទ្ធ និងការបម្រើពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ សម្រាប់មរណជន សូមដាក់តាំង ឬគូររូបភាពព្រះវិហារបរិសុទ្ធមួយនៅជិតនឹងតារាងនៅលើក្ដារខៀន ។

- ស្របតាម ខ ៥៥–៥៦ តើពួកអ្នកដឹកនាំទាំងនេះចាប់ផ្ដើមរៀបចំសម្រាប់កិច្ចការ ដែលពួកគេនឹងធ្វើនៅទីនេះលើផែនដីនៅពេលណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលពួកអែលឌើរសុចរិតនឹងបន្តធ្វើបន្ទាប់ពីពួកគេបានស្លាប់ទៅ ។

- តើពួកអែលឌើរស្មោះត្រង់នឹងបន្តធ្វើអ្វីខ្លះ បន្ទាប់ពីពួកគេបានស្លាប់ទៅ ?

ដើម្បីបញ្ជាក់ថា កិច្ចការនៅក្នុងពិភពវិញ្ញាណ គឺពុំមានលក្ខខណ្ឌដាក់កំហិតចំពោះអ្នកទាំងឡាយដែលកាន់បព្វជិតភាពមិលគីស្សាដែក សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់មើលនូវអ្វីដែលស្ត្រីស្មោះត្រង់ធ្វើនៅក្នុងពិភពវិញ្ញាណ ៖



« ស្ត្រីល្អៗទាំងនេះ ត្រូវបានញែកចេញ តែងតាំងចំពោះកិច្ចការ. . . នឹងត្រូវបានផ្ដល់សិទ្ធិ និងអំណាចពេញលេញ ដើម្បីផ្សាយដំណឹងល្អ ហើយបម្រើដល់ស្ត្រីៗ ខណៈដែលពួកអែលឌើរ និង ពួកព្យាការីកំពុងផ្សាយដំណឹងល្អទៅដល់បុរសៗ » (*Gospel Doctrine* បោះពុម្ពលើកទី ៥ [ឆ្នាំ ១៩៣៩] ទំព័រ ៤៦១ ) ។

អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំឃ្លានៅក្នុង ខ ៥៧ ដែលបង្រៀនសេចក្ដីពិតដូចខាងក្រោម ៖ **បន្ទាប់ពីចាកចេញពីជីវិតរមែងស្លាប់ នោះពួកបរិសុទ្ធស្មោះត្រង់ នឹងបន្តកិច្ចការរបស់ពួកគេនៅក្នុងការផ្សាយដំណឹងល្អ ។**

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥៨–៥៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើល អ្វីដែលមរណជនត្រូវតែធ្វើដើម្បីត្រូវបានប្រោសលោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើមានអ្វីខ្លះនឹងកើតឡើងចំពោះអ្នកទាំងឡាយដែលប្រែចិត្តនៅក្នុងពិភពវិញ្ញាណ ? ( សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលលទ្ធិខាងក្រោម ៖ **វិញ្ញាណដែលប្រែចិត្តនឹងត្រូវបានប្រោសលោះ តាមរយៈការគោរពប្រតិបត្តិតាមពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ត្រូវបានជ្រះស្អាតតាមរយៈដង្វាយធួន ហើយបានទទួលរង្វាន់របស់ខ្លួន**) ។

- តើយើងអាចជួយនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះសម្រាប់មរណជន តាមរបៀបណាអំឡុងពេលយើងនៅទីនេះលើផែនដី ? ( ដោយការបញ្ចប់កិច្ចការពង្សប្រវត្តិ ហើយចូលរួមនៅក្នុងពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធសម្រាប់មរណជន ) ។

ជាចំណែកនៃការពិភាក្សានេះ អ្នកអាចនឹងចង់អញ្ជើញសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ប្រធាន រីឆាដ ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« កិច្ចការអ្វីដែលអ្នកធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ គឺចំណាយពេលបានល្អ ប៉ុន្តែការទទួលពិធីបរិសុទ្ធជំនួសជីដូនជីតាផ្ទាល់ខ្លួនរបស់អ្នក នឹងធ្វើឲ្យពេលវេលាក្នុងព្រះវិហារបរិសុទ្ធកាន់តែពិសិដ្ឋ ហើយទទួលបានពរជ័យកាន់តែធំអស្ចារ្យថែមទៀតផង » (The Joy of Redeeming the Dead,» *Ensign* ឬ *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០១២, ទំព័រ ៩៣–៩៤) ។

សូមចង្អុលទៅរូបភាពនៃព្រះវិហារបរិសុទ្ធនៅលើក្ដារខៀន ។ សូមថ្លែងទីបន្ទាល់ថានៅពេលយើងទៅព្រះវិហារបរិសុទ្ធ ដើម្បីធ្វើពិធីបរិសុទ្ធសម្រាប់អស់អ្នកដែលបានចែកឋានទៅ នោះយើងជួយពួកគេ—ប្រសិនបើពួកគេជ្រើសរើសទទួលពិធីបរិសុទ្ធទាំងនោះ—ដើម្បីត្រូវបានប្រោសលោះចេញពីស្ថានឃុំវិញ្ញាណ ហើយចូលរួមជាមួយវិញ្ញាណសុចរិតនៅស្ថានបរមសុខ ។

លើរូបនៅលើក្ដារខៀន សូមគូរសញ្ញាព្រួញមួយចេញពីស្ថានឃុំវិញ្ញាណទៅស្ថានបរមសុខ ដើម្បីតំណាងពីការប្រោសលោះនៃវិញ្ញាណដែលប្រែចិត្តពីស្ថានឃុំវិញ្ញាណ ។

- តើចំណេះដឹងនេះ អាចមានឥទ្ធិពលចំពោះបទពិសោធន៍របស់អ្នក នៅក្នុងការធ្វើកិច្ចការព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិយ៉ាងដូចម្ដេច ?

- តើអ្នកបានទទួលពរជ័យដោយសារការចូលរួមក្នុងកិច្ចការពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ? ( អ្នកក៏អាចចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកផងដែរ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៦០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើល ទីបន្ទាល់របស់ប្រធានយ៉ូសែប អែហ្វ ស្ម៊ីធអំពីសេចក្ដីពិតដែលលោកបានកត់ត្រា ។

សូមលើកទឹកចិត្តសិស្សឲ្យដាក់កាលវិភាគធ្វើកិច្ចការពង្សប្រវត្តិ ឬ កិច្ចការព្រះវិហារបរិសុទ្ធនៅពីរបីសប្ដាហ៍ខាងមុខទៀត ។

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពី ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ និងពរជ័យទាំងឡាយនៃដង្វាយធួនមានចំពោះទាំងអ្នកនៅរស់ និងមរណជន ។

# សង្គ្រាមនៅយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា សេចក្ដីប្រកាសជាផ្លូវការទី ១, និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ ( មេរៀនទី ៣១ )

## ការរៀបចំមេរៀនសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបមេរៀនសម្រាប់សិស្សសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សាមេរៀនទី ៣១ ។ សេចក្ដីសង្ខេបនេះមិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនសម្រាប់មេរៀនទី ៣១ ផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ( សង្គ្រាមនៅយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ )

នៅពេលសិស្សបានរៀនពីព្រឹត្តិការនៃសោកនាដកម្មមួយនៅក្នុងប្រវត្តិសាសនាចក្រ នោះពួកគេបានពិចារណាពីគោលការណ៍ថា ប្រសិនបើយើងដោះស្រាយជម្លោះជាមួយនឹងអ្នកដទៃតាមរបៀបរបស់ព្រះអម្ចាស់ នោះយើងអាចចៀសវាងពីឥទ្ធិពលដែលនាំឲ្យមហន្តរាយដោយការទាស់ទែងគ្នា ។ សិស្សក៏បានរៀនផងដែរថា ប្រសិនបើយើងព្រងើយកន្តើយនឹងការទូន្មានឲ្យធ្វើអ្វីដែលត្រូវ នោះយើងនឹងកាន់តែមានចិត្តស្រាលក្នុងការជ្រើសរើសអ្វីដែលមិនល្អ ។ សិស្សបានឃើញថាការជ្រើសរើសដើម្បីលាក់បាំង អំពើបាបរបស់យើងអាចនាំឲ្យយើងប្រព្រឹត្តិអំពើបាបច្រើនឡើង ហើយអាចនាំមកនូវវិប្បដិសារី និង ការរងទុក្ខ ។ ជាចុងក្រោយ សិស្សបានរៀនថា ប្រសិនបើយើងអាចអភិវឌ្ឍទីបន្ទាល់ដ៏រឹងមាំដោយការស្ថាបនាសេចក្ដីជំនឿរបស់យើងនៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទ ។

### ថ្ងៃទី ២ ( ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា )

សិស្សបានឃើញថាព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមាគឺជាភស្ដុតាងថាយ៉ូសែប ស្ម៊ីធគឺជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ ពួកគេបានរៀនអំពីការលេចចេញមកនៃគម្ពីរម៉ូសេ និង គម្ពីរអ័ប្រាហាំ ។ ពួកគេក៏បានរកឃើញគោលលទ្ធិ និង គោលការណ៍មួយចំនួននៅក្នុងមាត្រានៃសេចក្ដីជំនឿផងដែរ ។

### ថ្ងៃទី ៣ (សេចក្ដីប្រកាសជាផ្លូវការទី ១)

នៅពេលសិស្សបានសិក្សាសេចក្ដីប្រកាស ទាក់ទងនឹងការបញ្ឈប់នៃការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព នោះពួកគេបានរៀនថា ព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់តាមរយៈវិវរណៈដល់ប្រធាននៃសាសនាចក្រ ហើយថាព្រះអម្ចាស់នឹងពុំដែលអនុញ្ញាតឲ្យប្រធាននៃសាសនាចក្រដឹកនាំសាសនាចក្រឲ្យវង្វេងនោះទេ ។ អំឡុងពេលរៀនអំពីការីកចម្រើននៃកិច្ចការពង្សប្រវត្តិនៅក្នុងទសវត្សរ៍ឆ្នាំ១៨៩០ នោះសិស្សបានឃើញផងដែរថា យើងអាចត្រូវបានផ្សារភ្ជាប់ជាមួយសមាជិកគ្រួសាររបស់យើង រួមមានអស់អ្នកដែលកើតមកមុនយើង និង អស់អ្នកដែលកើតក្រោយយើងតាមរយៈពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ ។

### ថ្ងៃទី ៤ (គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨)

តាមរយៈការសិក្សាបទពិសោធន៍របស់ប្រធានយ៉ូសែប អ្វែស ស្ម៊ីធក្នុងការទទួលវិវរណៈ នោះសិស្សបានឃើញថានៅពេលយើងអាន និង ពិចារណាព្រះគម្ពីរនេះ នោះយើងរៀបចំខ្លួនយើងដើម្បីទទួលវិវរណៈ ។ លើសពីនេះទៀត ពួកគេបានរៀនតាមរយៈដង្វាយធួននៃព្រះយេស៊ូវ គ្រីស្ទ និង តាមរយៈការគោរពប្រតិបត្តិតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះ ។ សិស្សក៏បាន រៀនផងដែរថា តាមរយៈព្រះគុណនៃព្រះជាព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទនោះយើងនឹងត្រូវបានរំដោះឲ្យរួចពីចំណងនៃសេចក្តីស្លាប់ ហើយ យើងអាចទទួលបានសេចក្តីអំណរដ៏ពេញលេញ តាមរយៈការរស់ឡើងវិញ ។

## សេចក្តីផ្តើម

មេរៀននេះនឹងជួយសិស្សឲ្យយល់ ពីរបៀបដែលវិញ្ញាណនានានៅក្នុងពិភពវិញ្ញាណត្រូវបានបង្រៀនដំណឹងល្អ ។ វាក៏អាចជួយ សិស្សឲ្យយល់របៀប ដែលពួកគេអាចក្លាយជាផ្នែកមួយនៃកិច្ចការដ៏មហិមានៃសេចក្តីសង្គ្រោះ សម្រាប់មរណជននេះផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

ពីមុនបង្រៀនមេរៀននេះអំពី គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨ អ្នកក៏អាចសួរសិស្សប្រសិនបើ ពួកគេមានសំណួរអំពី អ្វីៗដែលពួកគេបានសិក្សាអំឡុងសប្តាហ៍នេះ ។ ឧទាហរណ៍ ពួកគេអាចមានសំណួរអំពីការសម្លាប់រង្គាលនៅភ្នំម៉េដូ ឬ សេចក្តីប្រកាសជាផ្លូវការទី ១ ។

### គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨

*ប្រធានយ៉ូសែប អែហ្វ ស្ម៊ីធ រៀនពីរបៀបដែលដំណឹងល្អត្រូវបានផ្សព្វផ្សាយនៅក្នុងពិភពវិញ្ញាណ*

សូមប្រាប់សិស្សថាមនុស្សនៅទូទាំងពិភពលោកប្រកាន់ជំនឿផ្សេង ៗគ្នា អំពីអ្វីដែលកើតឡើងចំពោះពួកយើងបន្ទាប់ពីយើង ស្លាប់ ។ សូមសួរ ប្រសិនបើសិស្សធ្លាប់ជួបនរណាម្នាក់ដែលមានជំនឿផ្សេង ដែលទាក់ទងនឹងអ្វីដែលកើតឡើងចំពោះពួកយើង បន្ទាប់ពីយើងស្លាប់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ខ្លួន ។ ( សូមប្រយ័ត្នកុំនិយាយអវិជ្ជមាន ឬ និយាយមើលងាយដល់ជំនឿរបស់សាសនាដទៃឡើយ ) ។

- តើយើងអាចដឹងថាជំនឿណាមួយអំពីជីវិតក្រោយពីស្លាប់នោះត្រឹមត្រូវ ? ( អ្នកអាចនឹងពន្យល់ថា សូម្បីតែពួកបរិសុទ្ធមួយ ចំនួនអាចមានជំនឿពុំប្រាកដប្រជាឡើយអំពីជីវិតក្រោយពីស្លាប់ ) ។

ដើម្បីបន្ថែមលើចម្លើយរបស់សិស្សសូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ព្រះគម្ពីរគឺជាប៉ាន់គំរូ [ បទដ្ឋាន ] សម្រាប់វាស់វែងភាពត្រឹមត្រូវ និង សេចក្តីពិត » (The Blessing of Scripture » *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៣៤ ) ។

សូមបញ្ជាក់ថាយើងអាចដឹងពីភាពត្រឹមត្រូវនៃជំនឿផ្សេង ៗគ្នាទាក់ទងនឹងជីវិតក្រោយពីស្លាប់ តាមរយៈការប្រៀបធៀប ជំនឿទាំងនោះជាមួយសេចក្តីពិតដែលព្រះអម្ចាស់បានបើកសម្តែងនៅក្នុងព្រះគម្ពីរដូចជានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨។

សូមគូស រូបដែលអមមកជាមួយ ខាងក្រោមនេះនៅលើក្តារខៀន ។ អ្នកអាចពន្យល់ខ្លីៗថា តាមរបៀបមួយចំនួននៅក្នុងពិភព វិញ្ញាណទាំងមូលអាចចាត់ទុកថាជាស្ថានឃុំវិញ្ញាណ ដោយសារសូម្បីតែពួកសុចរិតបានគិតថាការបែកចេញពីរាងកាយរបស់ខ្លួន នោះគឺជាសេវកភាព ( សូមមើល គ. និង ស. ១៣៨:៤៩–៥០) ។

ដើម្បីជួយសិស្សរំឮកខ្លីៗអំពីសេចក្តីពិតដែលពួកគេបានសិក្សានៅក្នុង កណ្ឌ ១៣៨ សូមចាត់ឲ្យសិស្សពាក់កណ្តាលថ្នាក់ស្រាវជ្រាវ គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:១២–១៥, ២២ សម្រាប់សេចក្តីលម្អិតទាក់ទងនឹងជនមួយចំនួនដែលទៅស្ថានបរមសុខនៅពេលស្លាប់ និង លក្ខខណ្ឌនានាដែលពួកគេនឹងទទួលបទពិសោធន៍នៅទីនោះ ។ សូមចាត់សិស្សពាក់កណ្តាលថ្នាក់ទៀតឲ្យស្រាវជ្រាវ គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:២០–២២ សម្រាប់សេចក្តីលម្អិតទាក់ទងនឹងជនមួយចំនួនដែលទៅស្ថានឃុំវិញ្ញាណនៅពេលស្លាប់ និង លក្ខខណ្ឌនានាដែលពួកគេនឹងទទួលបទពិសោធន៍ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។




សូមចង្អុលបង្ហាញថាមិនគ្រាន់តែពួកទុច្ចរិត និង ពួកបះបោរប៉ុណ្ណោះទេដែលទៅស្ថានឃុំវិញ្ញាណនៅពេលពួកគេស្លាប់ឡើយ ប៉ុន្តែអស់អ្នកដែលស្លាប់ទៅក្នុងអំពើបាបរបស់ខ្លួនដោយគ្មានការចេះដឹងអំពីដំណឹងល្អផងដែរ ( សូមមើល គ. និង ស. ១៣៨:៣២) ។ សូមរំឮកសិស្សថាខណៈដែលប្រធាន យ៉ូសែប អែ្វស ស្ម៊ីធកំពុងពិចារណាអំពីវគ្គបទគម្ពីរនៅក្នុងពេត្រុសទី ១, ព្រះអម្ចាស់បានបើកសម្តែងដល់លោកនូវរបៀប ដែលមនុស្សនៅក្នុងស្ថានឃុំវិញ្ញាណនឹងមានឱកាសដើម្បីទទួលពរជ័យនានានៃដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:២៩–៣២ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់ឲ្យរកមើល របៀបដែលដំណឹងល្អត្រូវបានបង្រៀននៅក្នុងពិភពវិញ្ញាណ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ពួកគេគួរតែរកឃើញសេចក្តីពិតស្រដៀងខាងក្រោមនេះ ៖ **នៅក្រោមការដឹកនាំរបស់ព្រះយេស៊ូវគ្រីស្ទ សារទូតសុចរិតបង្រៀនដំណឹងល្អដល់អស់អ្នកដែលស្ថិតនៅក្នុងស្ថានឃុំវិញ្ញាណ ។**

លើរូបនៅលើក្តារខៀន សូមគូរសញ្ញាព្រួញមួយចេញពីស្ថានបរមសុខទៅស្ថានឃុំវិញ្ញាណ ដើម្បីតំណាងពីសារទូតសុចរិតរបស់ព្រះអម្ចាស់ប្រកាសដំណឹងល្អនៅក្នុងស្ថានឃុំវិញ្ញាណ ។

សូមសង្ខេប គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:៣៣–៣៧ ដោយពន្យល់ថា កូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់នឹងមានឱកាសដើម្បីទទួលយកគោលការណ៍ និង ពិធីបរិសុទ្ធនៃដំណឹងល្អរបស់ព្រះវិញ្ញាណបរិសុទ្ធ ទោះជានៅលើផែនដី ឬ នៅពិភពវិញ្ញាណក្តី ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលមនុស្សគ្រប់គ្នានឹងស្តាប់ដំណឹងល្អ សូមពន្យល់ថា ទោះបីជាព្រះអង្គសង្គ្រោះបានយាងទៅពិភពវិញ្ញាណ សម្រាប់មួយរយៈពេលខ្លីបន្ទាប់ពីការសុគតរបស់ទ្រង់ ទ្រង់បានរៀបចំវិញ្ញាណសុចរិត ដើម្បីផ្សព្វផ្សាយដំណឹងល្អដល់អស់អ្នកដែលនៅស្ថានឃុំវិញ្ញាណ ។ កិច្ចការនេះនៅតែបន្តនាពេលបច្ចុប្បន្ននេះ ។ នៅពេលមនុស្សដែលពុំធ្លាប់ឮដំណឹងល្អ ឬ ទទួលយកដំណឹងល្អ នៅក្នុងជីវិតរបស់យើង នៅពេលស្លាប់ទៅពួកគេក៏នឹងមានឱកាសដើម្បីស្តាប់ និង ទទួលយកដំណឹងល្អនៅក្នុងពិភពវិញ្ញាណ ។

សូមរំឮកសិស្សថានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:៣៨–៤៩, ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានធ្វើបញ្ជីឈ្មោះជាច្រើននៃវិញ្ញាណ « អ្នកធំ និង អ្នកពូកែទាំងឡាយ » ដែលលោកបានឃើញនៅក្នុងពិភពវិញ្ញាណ ដែលកំពុងរង់ចាំព្រះអង្គសង្គ្រោះបង្ហាញព្រះកាយដល់ពួកគេបន្ទាប់ពីការសុគតរបស់ទ្រង់នៅលើឈើឆ្កាង ។ វិញ្ញាណមួយចំនួនដែលព្រះអង្គសង្គ្រោះបានជួបគឺជាព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ និង ព្រះគម្ពីរមរមន ។ ដោយចាប់ផ្តើមនៅក្នុង ខ ៥៣, យើងបានអានថាប្រធាន ស្ម៊ីធ ក៏បានឃើញវិញ្ញាណជម្រើសនានាដែលនឹងកើតមក នៅក្នុងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយនេះ រួមមាន ព្យាការីយ៉ូសែប ស្ម៊ីធ ( ឪពុកមារបស់លោក ) និង ហៃរ៉ុម ស្ម៊ីធ ( ឪពុករបស់លោក ) ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:៥៣–៥៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីរបៀបដែលបុគ្គលទាំងនេះបានរួមចំណែក អំឡុងពេលពួកគេបានមានជីវិតនៅលើផែនដីដើម្បីសេចក្តីសង្គ្រោះ នៃអស់អ្នកដែលនៅក្នុងស្ថានឃុំវិញ្ញាណ ។

- តើថ្នាក់ដឹកនាំសាសនាចក្រថ្ងៃចុងក្រោយនេះ បានជួយវិញ្ញាណនៅក្នុងស្ថានឃុំវិញ្ញាណដោយរបៀបណា ?

បន្ទាប់ពីសិស្សឃើញថាព្យាការីថ្ងៃចុងក្រោយនេះ ជួយនៅក្នុងសេចក្តីប្រោសលោះដល់មនុស្សស្លាប់ តាមរយៈការសាងសង់ព្រះវិហារបរិសុទ្ធ និង ការធ្វើពិធីបរិសុទ្ធនានានៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់មរណជន សូមដាក់ ឬ គូសរូបព្រះវិហារបរិសុទ្ធនៅជាប់នឹងរូបនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥៨–៥៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើល អ្វីដែលមរណជនត្រូវតែធ្វើដើម្បីត្រូវបានប្រោសលោះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើមានអ្វីខ្លះនឹងកើតឡើងចំពោះអ្នកទាំងឡាយដែលប្រែចិត្តនៅក្នុងពិភពវិញ្ញាណ ? ( សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលលទ្ធិខាងក្រោម ៖ **វិញ្ញាណដែលប្រែចិត្តនឹងត្រូវបានប្រោសលោះ តាមរយៈការគោរពប្រតិបត្តិតាមពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ត្រូវបានជ្រះស្អាតតាមរយៈដង្វាយធួន ហើយបានទទួលរង្វាន់របស់ខ្លួន**) ។

- តើយើងអាចជួយក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះដល់អ្នកស្លាប់ អំឡុងពេលដែលយើងរស់នៅលើផែនដីនេះដោយរបៀបណា ? ( តាមរយៈការបំពេញកិច្ចការពង្សប្រវត្តិ និង ការចូលរួមនៅក្នុងពិធីបរិសុទ្ធនានាក្នុងព្រះវិហារបរិសុទ្ធសម្រាប់អ្នកស្លាប់ ) ។

សូមចង្អុលទៅរូបភាពនៃព្រះវិហារបរិសុទ្ធនៅលើក្ដារខៀន ។ សូមថ្លែងទីបន្ទាល់ថានៅពេលយើងទៅព្រះវិហារបរិសុទ្ធ ដើម្បីធ្វើពិធីបរិសុទ្ធសម្រាប់អស់អ្នកដែលបានចែកឋានទៅ នោះយើងជួយពួកគេ—ប្រសិនបើពួកគេជ្រើសរើសទទួលពិធីបរិសុទ្ធទាំងនោះ—ដើម្បីត្រូវបានប្រោសលោះចេញពីស្ថានឃុំវិញ្ញាណ ហើយចូលរួមជាមួយវិញ្ញាណសុចរិតនៅស្ថានបរមសុខ ។

លើរូបនៅលើក្ដារខៀន សូមគូរសញ្ញាព្រួញមួយចេញពីស្ថានឃុំវិញ្ញាណទៅស្ថានបរមសុខ ដើម្បីតំណាងពីការប្រោសលោះនៃវិញ្ញាណដែលប្រែចិត្តពីស្ថានឃុំវិញ្ញាណ ។

- តើការចេះដឹងនេះអាចជះឥទ្ធិពលយ៉ាងដូចម្ដេចលើបទពិសោធន៍របស់អ្នកជាមួយនឹងកិច្ចការព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិ ?

- តើអ្នកបានទទួលពរជ័យដោយសារការចូលរួមក្នុងកិច្ចការពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ? ( អ្នកក៏អាចចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកផងដែរ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៦០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលទីបន្ទាល់របស់ប្រធានយ៉ូសែប អែហ្វ ស្ម៊ីធអំពីសេចក្ដីពិតដែលលោកបានកត់ត្រា ។

សូមលើកទឹកចិត្តសិស្សឲ្យដាក់កាលវិភាគធ្វើកិច្ចការពង្សប្រវត្តិ ឬ កិច្ចការព្រះវិហារបរិសុទ្ធនៅពីរបីសប្ដាហ៍ខាងមុខទៀត ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នក អំពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និង ពរជ័យនានានៃដង្វាយធួនដែលមានដល់អ្នកនៅរស់ និង អ្នកស្លាប់ ។

## មេរៀនបន្ទាប់ ( កម្មវិធី និង អង្គការសាសនាចក្រ សេចក្ដីប្រកាសជាផ្លូវការទី ២ ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ ការប្រកាសអំពីក្រុមគ្រួសារ និង ព្យាការីនៅរស់ )

សូមសួរសិស្សពីរបៀបដែលពួកគេដឹងថា ព្រះអម្ចាស់កំពុងដឹកនាំសាសនាចក្រទ្រង់សព្វថ្ងៃនេះ ។ ហេតុអ្វីវាសំខាន់ដើម្បីមានព្យាការីដែលកំពុងនៅរស់ ? ហេតុអ្វីក្រុមគ្រួសារមានសារៈសំខាន់ ? សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលចម្លើយចំពោះសំណួរទាំងនេះ នៅពេលពួកគេសិក្សាមេរៀននានានៅក្នុងសប្ដាហ៍ក្រោយ ។

មេរៀនទី ១៥៦

# កម្មវិធី និងអង្គការសាសនាចក្រ

## បុព្វកថា

នៅពេលសាសនាចក្របន្តរីកចម្រើន ព្រះអម្ចាស់បានបំផុសគំនិតដល់អ្នកដឹកនាំសាសនាចក្រ និងសមាជិកឲ្យអនុវត្តនូវអង្គការ និងកម្មវិធីនៅក្នុងសាសនាចក្រ ដើម្បីប្រទានពរដល់ពួកបរិសុទ្ធ ។ នៅពេលអង្គការ និងកម្មវិធីមួយចំនួនទាំងនេះ ត្រូវបានស្ថាបនាជាលើកដំបូង នោះវាពុំមែនជាតម្រូវការចាំបាច់ទេ ប៉ុន្តែខណៈពេលសាសនាចក្រលូតលាស់ នោះវាក្លាយទៅជាផ្នែកដ៏សំខាន់នៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ដើម្បីសេចក្ដីសង្គ្រោះនៃកូនចៅរបស់ទ្រង់ ។

## យោបល់សម្រាប់ការបង្រៀន

### អង្គការ និងកម្មវិធីសាសនាចក្រ ជួយយើងរៀបចំខ្លួន និងលូតលាស់ឆ្ពោះទៅរកជីវិតដ៏អស់កល្បជានិច្ច

សូមចាប់ផ្ដើមថ្នាក់រៀនដោយសុំឲ្យសិស្សស្រមៃគិតអំពីមិត្តម្នាក់ដែលពុំចង់ទៅក្នុងការប្រជុំ ឬសកម្មភាពថ្នាក់យុវនារីរបស់នាង ។ នាងបាននិយាយថា សប្បាយគួរសមដែរ តែពុំសូវមានប្រយោជន៍ចំពោះនាងទេ ។

បន្ទាប់ពីអ្នកបង្ហាញឧទាហរណ៍នេះ សូមអញ្ជើញឲ្យសិស្សគិតពិចារណាដោយស្ងាត់ស្ងៀមអំពីអ្វីដែលពួកគេអាចនិយាយ ដើម្បីជួយដល់មិត្តម្នាក់នេះ ឲ្យយល់ពីគោលបំណងនៃការប្រជុំ និងសកម្មភាពថ្នាក់យុវនារីរបស់នាង ។

- តើអ្នកនឹងនិយាយអ្វីខ្លះ អំពីគោលបំណងនៃក្រុមយុវនារី និងអង្គការយុវនារី ?
- តើការដឹងអំពីគោលបំណងនៃអង្គការមួយ អាចជួយដល់អស់អ្នកដែលចូលរួមចំណែកយ៉ាងដូចម្ដេច ?

សូមអញ្ជើញសិស្សឲ្យអាន ម៉ូសេ ១:៣៩ ដោយស្ងាត់ស្ងៀម រកមើលគោលបំណងរបស់ព្រះវរបិតាសួគ៌ចំពោះអ្វីៗទាំងអស់ដែលទ្រង់ធ្វើ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចនឹងចាំបាច់រំឭកដល់សិស្សថា*អមតភាព*សំដៅទៅលើស្ថានភាពនៃការរស់នៅជារៀងរហូត នៅក្នុងស្ថានភាពរស់ឡើងវិញមួយ ។ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ ដោយមិនគិតអំពីអំពើទុច្ចរិត ឬសុចរិតរបស់ពួកគេនៅក្នុងជីវិតនេះទេ ។ *ជីវិតដ៏នៅអស់កល្បជានិច្ច*សំដៅទៅលើ ការរស់នៅជានិរន្តរ៍ជាមួយក្រុមគ្រួសារក្នុងវត្តមានរបស់ព្រះ និង ការប្រែក្លាយដូចជាទ្រង់ ។ ក៏ដូចជាជីវិតអមតផងដែរ ជីវិតដ៏នៅអស់កល្បជានិច្ច នឹងកើតមានឡើង តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ទោះជាយ៉ាងណាក៏ដោយវា ក៏តម្រូវឲ្យមាននូវ « ការគោរពតាមក្រឹត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ » របស់យើងផងដែរ (មាត្រានៃសេចក្ដីជំនឿ ១:៣) ។

- បើគោលបំណងរបស់ព្រះវរបិតាសួគ៌ គឺដើម្បីនាំមកនូវអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់កូនចៅរបស់ទ្រង់ ចុះតើគោលបំណងនៃសាសនាចក្រនេះគឺជាអ្វី ?

បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរនូវសេចក្ដីពិតដូចខាងក្រោម នៅលើក្ដារខៀន ៖**សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជួយព្រះវរបិតាសួគ៌នាំមកនូវជីវិតដ៏អស់កល្បជានិច្ចដល់កូនចៅរបស់ទ្រង់ ។** បន្ទាប់មកសូមសួរ ៖

- តើវិធីមួយចំនួនណាខ្លះ ដែលសាសនាចក្រជួយនាំមកនូវអមតភាព និងជីវិតដ៏អស់កល្បជានិច្ចមកដល់កូនចៅរបស់ព្រះវរបិតាសួគ៌ ?

សូមពន្យល់ថា សាសនាចក្រមានអង្គការជាច្រើន–ដែលហៅថា អង្គការជំនួយចំពោះបព្វជិតភាព–ហើយនិងកម្មវិធីផ្សេងៗដែលជួយយើងឲ្យរីកចម្រើនឆ្ពោះទៅរកជីវិតអស់កល្បជានិច្ច ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ឈ្មោះអង្គការមួយចំនួននោះ ។ ( ចម្លើយអាចរួមមាន សមាគមសង្គ្រោះ យុវជន យុវនារី អង្គការបឋមសិក្សា និងថ្នាក់សាលាថ្ងៃអាទិត្យ ព្រមទាំងកម្មវិធីទាំងឡាយ ដូចជា រាត្រីជួបជុំក្រុមគ្រួសារ និងថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា ) ។

ដើម្បីជួយសិស្សយល់អំពីរបៀបដែលអង្គការសាសនាចក្រ និងកម្មវិធីទាំងឡាយជួយយើងឲ្យរៀន និងរីកចម្រើននៅក្នុងដំណឹងល្អ ដើម្បីយើងអាចទទួលបានជីវិតអស់កល្បជានិច្ច សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ប៊ីយ៉ដ៍ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមពន្យល់ថា សេចក្ដីថ្លែងការណ៍នេះគឺអំពីកម្មវិធីថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ប៉ុន្តែគោលការណ៍ដែលវាបង្រៀនក៏អាចយកមកអនុវត្តចំពោះអង្គការជំនួយសាសនាចក្រដទៃទៀត និងកម្មវិធីទាំងឡាយផងដែរ។



« កម្មវិធីទាំងនេះ ត្រូវបានចាប់ផ្តើម វាល្អ ប៉ុន្តែវាពុំត្រូវការជាចាំបាច់នោះទេ ។ វាផ្តល់នូវរដូវកាលមួយដើម្បីចម្រើន និងលូតលាស់ទៅជាបន្ទាយការពារសម្រាប់សាសនាចក្រ ។ ឥឡូវនេះ អង្គការទាំងនេះក្លាយទៅជាការបញ្ជូនមកពីព្រះ សម្រាប់សេចក្តីសង្គ្រោះដល់សាសន៍អ៊ីស្រាអែលសម័យទំនើប នៅក្នុងម៉ោងពេលដ៏លំបាកបំផុតមួយ » (« Teach the Scriptures» [address to CES religious educators, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៧៧], ទំព័រ ៣, LDS.org) ។

- តើថ្នាក់សិក្ខាសាលាបានជួយអ្នកត្រៀមខ្លួនសម្រាប់ឧបសគ្គមួយចំនួនក្នុងជីវិតយ៉ាងដូចម្តេច ?

សូមពន្យល់ថា ព្រះអម្ចាស់បានបំផុសគំនិតអំពីកម្មវិធី និងអង្គការជាច្រើននៅក្នុងសាសនាចក្រ ដើម្បីរៀបចំយើងសម្រាប់ឧបសគ្គនៃជីវិត និងដើម្បីជួយយើងរីកចម្រើនឆ្ពោះទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។ ដើម្បីជួយសិស្សឲ្យពិភាក្សាអំពីជំនួយ ដែលពួកគេទទួលបានមកពីអង្គការ និងកម្មវិធីសាសនាចក្រមួយចំនួន សូមបំបែកថ្នាក់ទៅជាប្រាំមួយក្រុម ។ សូមផ្តល់ដល់ក្រុមនិមួយៗនូវច្បាប់ចម្លងនៃសំណួរដូចខាងក្រោម(ឬសរសេរវានៅលើក្តារខៀន ) និងឲ្យសេចក្តីសង្ខេបខាងប្រវត្តិសាស្ត្រដូចខាងក្រោមមួយច្បាប់ផងដែរ ។ សូមឲ្យសិស្សសិក្សាសេចក្តីសង្ខេបនៅក្នុងក្រុមរបស់ពួកគេ ហើយរៀបចំឆ្លើយនឹងសំណួរ ។

តើអង្គការ ឬកម្មវិធីនេះបានចាប់ផ្តើមមានឡើងយ៉ាងដូចម្តេច ?

តើអ្នកគិតថា វារៀបចំយើងដើម្បីប្រឈមមុខនឹងការសាកល្បង និងឧបសគ្គនានាក្នុងជំនាន់របស់យើងយ៉ាងដូចម្តេច ?

តើអ្នកគិតថា វាជួយយើងរីកចម្រើនឆ្ពោះទៅរកជីវិតអស់កល្បជានិច្ចយ៉ាងដូចម្តេច ?

## ថ្នាក់សាលាថ្ងៃអាទិត្យ

នៅឆ្នាំ ១៨៤៩ សមាជិកសាសនាចក្រម្នាក់ ឈ្មោះ រីឆាដ បាឡាទីន មានអារម្មណ៍ថា កុមារតូចៗត្រូវការកន្លែងមួយដើម្បីរៀនអំពីដំណឹងល្អនៅថ្ងៃបរិសុទ្ធ ។ ពួកបរិសុទ្ធនៅចក្រភពអង់គ្លេស មានថ្នាក់សាលាថ្ងៃអាទិត្យរួចទៅហើយ ហើយបងប្រុស បាឡាទីន បានចាប់ផ្តើមថ្នាក់សាលាថ្ងៃអាទិត្យដំបូងគេនៅរដ្ឋ យូថាហ៍ នៅក្នុងវួដទីក្រុងសលត៍ លេករបស់គាត់ នៅខែធ្នូ ឆ្នាំ ១៨៤៩ ។ មិនយូរប៉ុន្មានក្រោយមក វួដផ្សេងទៀត បានចាប់ផ្តើមទទួលយកការអនុវត្តដូចគ្នានេះ ដោយវួដនិមួយៗប្រើកម្មវិធីសិក្សារៀងៗខ្លួន ។ ក្នុងឆ្នាំ ១៨៦៧ ថ្នាក់អ្នកដឹកនាំសាសនាចក្របានបង្កើតសហព័ន្ធសាលាថ្ងៃអាទិត្យដេសេរ៉េត ដែលលើកទឹកចិត្តឲ្យមានភាពរួបរួមគ្នាក្នុងកម្មវិធីសិក្សាតែមួយ ។ ត្រឹមឆ្នាំ ១៨៧០ នោះមានថ្នាក់សាលាថ្ងៃអាទិត្យច្រើនជាង ២០០ ថ្នាក់ ត្រូវបានបង្កើតឡើង ។ សព្វថ្ងៃនេះ វួដ និងសាខាទាំងឡាយ មានថ្នាក់សាលាថ្ងៃអាទិត្យចម្រុះ ។

## យុវនារី

ប្រធាន ព្រិកហាំ យ៉ង់ បានជួបនឹងកូនស្រីទាំងឡាយរបស់លោកនៅក្នុងផ្ទះរបស់លោកនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៨៦៩ ហើយបានសុំពួកគេឲ្យធ្វើជាអ្នកដឹកនាំ ដើម្បីជួយដល់មិត្តភក្តិដែលមានអាយុប្រហាក់ប្រហែលនឹងពួកគេទទួលបានទីបន្ទាល់នៃដំណឹងល្អ ដើម្បីមានភាពរមទម្យនៅក្នុង ការស្លៀកពាក់ និងទង្វើរបស់ពួកគេ ហើយចៀសវាងពីទំនោរ និងអាកប្បកិរិយាខាងលោកិយ ។ នៅឆ្នាំ ១៨៧០ អង្គការយុវនារីជាផ្លូវការមួយ ត្រូវបានរៀបចំឡើងដើម្បីលើកស្ទួយដល់គោលបំណងទាំងនេះ ។ អង្គការនេះ នៅទីបំផុតបានត្រូវគេស្គាល់ថាជា សមាគមកែលម្អគ្នាទៅវិញទៅមករបស់ក្រុមយុវនារី (វ៉ាយ.ដបុលយូ.អិម.អាយ.អេ ) ដែលក្រោយមកបានផ្លាស់ប្តូរទៅជាអង្គការយុវនារី ។ នៅដើមឆ្នាំ ១៩៧០ ពួកអ្នកដឹកនាំបានណែនាំអំពីកម្មវិធីអភិវឌ្ឍខ្លួន ។ នៅឆ្នាំ ១៩៨៥ ពួកគាត់បានណែនាំអំពីគុណសម្បត្តិ និងបាវចនាយុវនារី ។

## យុវជន

សមាគមកែលម្អគ្នាទៅវិញទៅមករបស់ក្រុមយុវជន (វ៉ាយ.អិម.អិម.អាយ.អេ ) ត្រូវបានរៀបចំឡើងនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៨៧៥ នៅក្រោមការដឹកនាំរបស់ប្រធាន ព្រិកហាំ យ៉ង់ ។ អង្គការនេះ គឺមានបំណងដើម្បីជួយដល់ក្រុមយុវជនអភិវឌ្ឍខាងវិញ្ញាណ និងខាងបញ្ញាស្មារតី ក៏ដូចជាផ្តល់ដល់ពួកគេនូវសកម្មភាពផ្នែកប្រឌិតផងដែរ ។ នៅឆ្នាំ ១៩១៣ សាសនាចក្របានចូលសហការជាមួយនឹងក្រុមកាយឫទ្ធិអាមេរិកកាំងនៅក្នុងសហរដ្ឋអាមេរិក ។ ភាពជាដៃគូជាមួយនឹងកម្មវិធីក្រុមកាយឫទ្ធិផ្សេងទៀត ត្រូវបានបង្កើតឡើងជាអន្តរជាតិ នៅកន្លែងណាដែលអាចធ្វើទៅបាន ។ ឈ្មោះរបស់អង្គការត្រូវបានផ្លាស់ប្តូរផងដែរ ដែលដំបូងឡើងបានផ្លាស់ប្តូរទៅជាបព្វជិតភាពអើរ៉ុន–អិម.អាយ.អេ បន្ទាប់មកក្លាយទៅជាបព្វជិតភាពអើរ៉ុន ហើយបន្ទាប់មកទៀតទៅជាក្រុមយុវជន ។ នៅឆ្នាំ ២០០១ ពួកអ្នកដឹកនាំសាសនាចក្រ បានណែនាំកម្មវិធីកាតព្វកិច្ចចំពោះព្រះ ។

## អង្គការបឋមសិក្សា

នៅឆ្នាំ ១៨៧៧ អូរេលៀ ស្ពែនសើរ រ៉ូជើរ « ទទួលអារម្មណ៍យ៉ាងខ្លាំងថា មានអ្វីមួយត្រូវធ្វើឡើង អំពីឥរិយាបទរបស់ក្មេងប្រុសនៅជិតខាងដែលរត់លេងដោយសេរីពេញទីក្រុងទាំងថ្ងៃទាំងយប់ ។ នាងមានអារម្មណ៍ថា កុមារទាំងនេះ ពុំត្រូវបានបង្រៀននូវគោលការណ៍ និងគុណតម្លៃជាមូលដ្ឋាន [ដើម្បីរៀបចំពួកគេ] ទាំងខាងចំណេះដឹង ឬឥរិយាបទ ដើម្បីនាំយកដំណឹងល្អឆ្ពោះទៅមុខ ឬដើម្បីក្លាយជាឪពុកម្ដាយ ឬពលរដ្ឋល្អ » («History of Primary»lds.org/callings/primary/getting–started/history–of–primary) ។ នាងបានជួបនឹង អេលីស្សា អ ស្នូ ដែលពេលនោះបម្រើជាប្រធានសមាគមសង្គ្រោះទូទៅ ហើយពួកគេបានទទួលការអនុញ្ញាតមកពីប្រធាន យ៉ូហាន ថេលើរ ដើម្បីរៀបចំអង្គការបឋមសិក្សានៅក្នុងក្រុង ហ្វាមីងតុន រដ្ឋយូថាហ៍ នៅក្រោមការដឹកនាំរបស់ប៊ីស្សព យ៉ូហាន ហេស្ស ។ ការប្រជុំអង្គការបឋមសិក្សាដំបូង បានធ្វើឡើងនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៨៧៨ ដែលមានកុមារ និងកុមារីចំនួន ២២៤ នាក់ ។ នៅឆ្នាំ ១៨៨០ ប្រធានអង្គការបឋមសិក្សាទូទៅត្រូវបានហៅ ហើយថ្នាក់អង្គការបឋមសិក្សាបានចាប់ផ្ដើមរៀបចំឡើងនៅក្នុងវួដជាច្រើន ។

## ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាននៃសាសនា

នៅឆ្នាំ ១៨៨៨ សាសនាចក្របានបង្កើតគណៈកម្មការអប់រំ និងវិទ្យាស្ថានសាសនាចក្រ ហើយបានបង្កើតថ្នាក់ខាងសាសនា ដើម្បីផ្ដល់គ្រឹះខាងវិញ្ញាណសម្រាប់ការរៀនសូត្រ ដែលមិនទាក់ទងនឹងសាសនាសម្រាប់អ្នកទាំងឡាយ ដែលពុំបានចូលរួមក្នុងវិទ្យាស្ថានសាសនាចក្រ ។ នៅឆ្នាំ ១៩១២ យ៉ូសែប អែហ្វ មើរីល សាស្ត្រាចារ្យម្នាក់ និងសមាជិកសាសនាចក្រ បានដាក់ស្នើសុំផែនការមួយដើម្បីអនុញ្ញាតឲ្យសិស្សនៅក្នុងសាលារដ្ឋមកចូលរួមថ្នាក់សាសនាជាផ្នែកមួយនៃ ការសិក្សារាល់ថ្ងៃរបស់ពួកគេ ។ វាហៅថាថ្នាក់សិក្ខាសាលា ហើយថ្នាក់ដំបូងត្រូវបានបង្រៀននៅជិតវិទ្យាល័យហ្គ្រេនិត នៅទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ហើយមានសិស្សចុះឈ្មោះចំនួន ៧០ នាក់ ។ នៅពេលកម្មវិធីថ្នាក់សិក្ខាសាលាបានរីកសុះសាយ នោះកម្មវិធីស្រដៀងគ្នាមួយត្រូវបានបង្កើតឡើងសម្រាប់យុវវ័យដែលស្ថិតក្នុងវ័យរៀននៅសាកលវិទ្យាល័យ ។ វាត្រូវបានដាក់ឈ្មោះថា វិទ្យាស្ថានសាសនាពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយថ្នាក់វិទ្យាស្ថានបានចាប់ផ្ដើមនៅក្នុងឆ្នាំ ១៩២៦ នៅក្នុងទីក្រុង ម៉ូស្កូ រដ្ឋ អៃដាហូ ។ នៅដើមឆ្នាំ ១៩៥០ កម្មវិធីថ្នាក់សិក្ខាសាលានៅពេលព្រឹកព្រលឹម បានចាប់ផ្ដើមនៅក្នុងរដ្ឋ កាលីហ្វូញ៉ា កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ បានចាប់ផ្ដើមនៅឆ្នាំ ១៩៦០ ហើយថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា បានចាប់ផ្ដើមនៅក្នុងអំឡុងបណ្ដាឆ្នាំ ១៩៦០ ហើយថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា បានបន្តពង្រីកនៅទូទាំងពិភពលោក ។

## រាត្រីជួបជុំក្រុមគ្រួសារ

ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានបង្រៀនថាកម្មវិធីសាសនាចក្រ គប្បី « បន្ថែមទៅក្នុងការបង្រៀន និងការបំពាក់បំប៉នរបស់យើងនៅក្នុងគេហដ្ឋាន ។ បើបរិដ្ឋាន គំរូ និង ការបំពាក់បំប៉ននៅក្នុងគេហដ្ឋាន មានភាពចុះសម្រុងនឹងសេចក្ដីពិតនៅក្នុងដំណឹងល្អនៃព្រះគ្រីស្ទ នោះគឺគ្មានកុមារណាម្នាក់ក្នុងចំនួនមួយរយនាក់នឹងត្រូវវង្វេងឡើយ » («Worship in the Home,» *Improvement Era* ខែ ធ្នូ ឆ្នាំ ១៩០៣ ទំព័រ ១៣៨ ) ។ នៅក្នុងឆ្នាំ ១៩០៩ ស្តេកហ្គ្រេនិតនៅក្នុងទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ បានចាប់ផ្ដើមកម្មវិធីរាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្ដាហ៍ ដែលប្រសាសន៍របស់ប្រធាន ស្ម៊ីធ ត្រូវបានបំផុសគំនិត ។ នៅក្នុងឆ្នាំ ១៩១៥ គណៈប្រធានទីមួយ បានចេញអនុសាសន៍ថា រាត្រីជួបជុំក្រុមគ្រួសារប្រចាំខែ ត្រូវបានអនុវត្តទូទាំងសាសនាចក្រ ។ គណៈប្រធានទីមួយបានសន្យា ៖ « បើពួកបរិសុទ្ធគោរពតាមដំបូន្មាននេះ [ ដើម្បីរក្សារាត្រីជួបជុំក្រុមគ្រួសារ ] នោះយើងសន្យាថា ពរជ័យដ៏មហិមា នឹងកើតមានឡើង ។ សេចក្ដីស្រឡាញ់ក្នុងផ្ទះ និងការគោរពប្រតិបត្តិដល់ឪពុកម្ដាយនឹងកើនឡើង ។ សេចក្ដីជំនឿ នឹងបង្កើតឡើងនៅក្នុងដួងចិត្តរបស់យុវវ័យនៃអ៊ីស្រាអែល ហើយពួកគេនឹងទទួលបានអំណាចដើម្បីទប់ទល់នឹងឥទ្ធិពល និងការល្បួងរបស់អារក្សឡោមព័ទ្ធពួកគេ » ( នៅក្នុង James R. Clark, comp., *Messages of the First Presidency of The Church of Jesus Christ of Latter–day Saints,* វ៉ុលទី ៦ [១៩៦៥–៧៥], ៤:៣៣៩) ។ ហាសិបឆ្នាំក្រោយមក សាសនាចក្របានបោះពុម្ពសៀវភៅសិក្សាសម្រាប់ក្រុមគ្រួសារឲ្យប្រើប្រាស់នៅក្នុងការបង្រៀនដំណឹងល្អប្រចាំសប្ដាហ៍ ។ នៅក្នុងឆ្នាំ ១៩៧០ អ្នកដឹកនាំសាសនាចក្រ បានជ្រើសរើសល្ងាចថ្ងៃចន្ទសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ហើយបានប្រកាសថា សកម្មភាពសាសនាចក្រដទៃទៀត ពុំត្រូវធ្វើឡើងនៅល្ងាចនោះទេ ។

បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយនោះ សូមឲ្យសិស្សនៅក្នុងក្រុមនិមួយៗសង្ខេបប្រវត្តិនៃអង្គការ ឬកម្មវិធីដែលបានចាត់ទៅឲ្យពួកគេ ហើយពន្យល់ចម្លើយរបស់ពួកគេចំពោះសំណួរដែលពួកគេបានពិភាក្សា ។

សូមពន្យល់ថា អង្គការ និងកម្មវិធីសាសនាចក្រនីមួយៗ បានប្រតិបត្តិឡើងជាឯករាជ្យពីដំបូងឡើយ ។ នៅពេលសាសនាចក្រពង្រីកកាន់តែធំនៅក្នុងឆ្នាំ ១៩៥០ នោះពួកអ្នកដឹកនាំសាសនាចក្របានឃើញពីតម្រូវការដើម្បីធ្វើការវាយតម្លៃទៅលើរបៀបដែលអង្គការសាសនាចក្របំពេញតាមគោលបំណងរបស់សាសនាចក្រ ។ ពួកគាត់បានសម្រេចចិត្តដើម្បីរួបរួម ហើយសម្របសម្រួលគ្រប់អង្គការ និងកម្មវិធីសាសនាចក្រទាំងអស់ ទាំងនៅក្នុងការគ្រប់គ្រង និងនៅក្នុងការជ្រើសរើសកម្មវិធីសិក្សា ។ ការផ្លាស់ប្ដូរទាំងនេះ បានជួយអង្គការ និងកម្មវិធីនានា ឲ្យបំពេញតាមតម្រូវការនៃការលូតលាស់របស់សាសនាចក្រ និងដើម្បីពង្រឹងក្រុមគ្រួសារកាន់តែល្អប្រសើរ ។ នៅក្រោមកិច្ចខិតខំសហសម្ព័ន្ធនេះ**អង្គការសាសនាចក្រទាំងអស់ បានប្រតិបត្តិនៅក្រោមការដឹកនាំរបស់អ្នកដឹកនាំបព្វជិតភាព ដែលកាន់កូនសោជាអធិបតី ។**

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« សហសម្ព័ន្ធ គឺជាប្រព័ន្ធនៃការគ្រប់គ្រងរបស់សាសនាចក្រ ដែលនៅក្នុងនោះ យើងយកកម្មវិធីទាំងអស់របស់សាសនាចក្រមក ដាក់វានៅក្នុងចំណុចរួមមួយ រួចដាក់វាបញ្ចូលក្នុងប្រព័ន្ធតែមួយ ប្រតិបត្តិវាជាកម្មវិធីមួយ ដែលសមាជិកសាសនាចក្រទាំងអស់មានជាប់ទាក់ទងនៅក្នុងកិច្ចប្រតិបត្តិការ– ហើយធ្វើវាទាំងអស់នៅក្រោមការដឹកនាំបព្វជិតភាព » (*Let Every Man Learn His Duty* [ កូនសៀវភៅ, ឆ្នាំ ១៩៧៦ ], ទំព័រ ២ ) ។

សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្ដារខៀន ៖**នៅពេលយើងចូលរួមនៅក្នុងអង្គការ និងកម្មវិធីនានារបស់សាសនាចក្រ នោះយើងទទួលបានពរជ័យដែលមាននៅក្នុងកម្មវិធី និងអង្គការទាំងនោះ ។** បន្ទាប់មកសូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

*តើអង្គការ និងកម្មវិធីនានារបស់សាសនាចក្រ បានប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ? តើកម្មវិធីកាតព្វកិច្ចចំពោះព្រះ ឬកម្មវិធីអភិវឌ្ឍខ្លួន បានប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?*

*តើអ្នកនឹងចូលរួមកាន់តែពេញលេញនៅក្នុងកម្មវិធីយុវជន ឬយុវនារីយ៉ាងដូចម្ដេច ? នៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ ? ក្នុងរាត្រីជួបជុំក្រុមគ្រួសារ ? នៅក្នុងថ្នាក់សិក្ខាសាលា ?*

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ អ្នកក៏អាចចែកចាយគំនិតយោបល់របស់អ្នកអំពីរបៀបដែលអង្គការនានារបស់សាសនាចក្រប្រទានពរដល់ជីវិតរបស់អ្នក ហើយជួយអ្នក និងគ្រួសារអ្នករីកចម្រើនឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ច ។

មេរៀនទី ១៥៧

# សេចក្ដីប្រកាសជាផ្លូវការទី ២

## បុព្វកថា

អំឡុងសតវត្សរ៍ទី ២០ កិច្ចការផ្សព្វផ្សាយសាសនា បានសាយភាយទៅទូទាំងផែនដី ។ អ្នកដឹកនាំសាសនាចក្រ បានអធិស្ឋានសុំការដឹកនាំពាក់ព័ន្ធទៅនឹងលក្ខខណ្ឌចំពោះការតែងតាំងបព្វជិតភាព និងពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធសម្រាប់សមាជិកសាសនាចក្រដែលជាកូនចៅរបស់ជនជាតិអាហ្វ្រិក ។ វិវរណៈដ៏ជាក់លាក់មួយបានប្រទានដល់ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល ហើយត្រូវបានអះអាងបញ្ជាក់ដល់ទីប្រឹក្សារបស់លោកនៅក្នុងគណៈប្រធានទីមួយ និង សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅក្នុងព្រះវិហារបរិសុទ្ធសលត៍ លេក នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៨ ។ នៅក្នុងសំបុត្រមួយដែលចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៩៧៨ ពួកលោកបានប្រកាសវិវរណៈនោះ ។

## យោបល់សម្រាប់ការបង្រៀន

### សេចក្ដីប្រកាសជាផ្លូវការទី ២

*ព្រះអម្ចាស់បើកសម្ដែងថា ពរជ័យបព្វជិតភាព និងពរជ័យព្រះវិហារបរិសុទ្ធ អាចផ្ដល់ទៅឲ្យគ្រប់សមាជិកសាសនាចក្រដែលមានភាពសក្ដិសម ។*

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យនឹកស្រមៃថា ពួកគេមានមិត្តម្នាក់ដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយកំពុងតែមានចម្ងល់ចំពោះសំណួរខ្លះៗអំពីសាសនាចក្រ ។

- តើអ្នកនឹងលើកទឹកចិត្តឲ្យមិត្តរបស់អ្នកធ្វើអ្វីខ្លះ ?

បន្ទាប់ពីសិស្សឆ្លើយតប សូមអានឮៗនូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ឌៀថើរ អេហ្វ. អុជដូហ្វ នៃគណៈប្រធានទីមួយ ៖



មិត្តភក្ដិយុវវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំអើយ យើងគឺជាមនុស្សដែលសួរសំណួរ ដោយសារយើងដឹងថាសំណួរនាំទៅរកសេចក្ដីពិត ។. . .

« . . .ចម្ងល់គឺជាទីកំណើតនៃទីបន្ទាល់ ។ អ្នកខ្លះអាចមានអារម្មណ៍អៀនខ្មាស់ ឬ ថាមិនស័ក្ដិសមដោយសារពួកគេបានរកសំណួរដែលទាក់ទងទៅនឹងដំណឹងល្អ ប៉ុន្តែពួកគេមិនចាំបាច់មានអារម្មណ៍បែបនោះទេ ។ ការសួរសំណួរ មិនមែនជាសញ្ញានៃភាពទន់ខ្សោយនោះទេ វាគឺជាប្រផ្នូលមួយនៃការរីកចម្រើន ។

« ព្រះបានបញ្ជាយើងឲ្យស្វែងរកចម្លើយចំពោះសំណួររបស់យើង ( សូមមើល យ៉ាកុប ១:៥–៦ ) ហើយសួរតែអ្វីដែលយើងស្វែងរក ‹ ដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ › ( មរ៉ូណៃ ១០:៤ ) ។ នៅពេលយើងធ្វើដូច្នោះ សេចក្ដីពិតនៃការណ៍ទាំងអស់អាចត្រូវបានបង្ហាញដល់យើង ‹ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ › (មរ៉ូណៃ ១០:៥) ។

« សូមកុំខ្លាចឡើយ សូមសួរសំណួរ ។ សូមចង់ដឹង ប៉ុន្តែកុំសង្ស័យឡើយ ! សូមកាន់ខ្ជាប់ទៅនឹងសេចក្ដីជំនឿ និងពន្លឺ ដែលអ្នកបានទទួលរួចហើយជានិច្ច » ( «The Reflection in the Water» [ ការប្រជុំពិសេសប្រព័ន្ធអប់រំសាសនាចក្រសម្រាប់មជ្ឈិមវ័យវ័យក្មេង ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ] នៅ LDS.org ) ។

- តើប្រធាន អុជដូហ្វ បានបង្រៀនអ្វីខ្លះ ដែលអាចជួយដល់នរណាម្នាក់ដែលមានសំណួរអំពីសាសនាចក្រនោះ ?

សូមឲ្យសិស្សម្នាក់អានដំណើររឿងដូចខាងក្រោមអំពីមនុស្សពីរនាក់ ឈ្មោះ ហេលវេសឺអូ និង រូដា ម៉ាទិន ដែលព្យាយាមចង់ទទួលបាន និងយល់អំពីសេចក្ដីពិត តាមការសួរសំណួរ ៖

« នៅយប់ភ្លឺថ្លាខែមេសា ឆ្នាំ ១៩៧២ . . . ហេលវេសីអូ ម៉ាទិន បានសញ្ជឹងគិតអំពីការស្វែងរកសេចក្ដីពិតរបស់គ្រួសារគាត់ ។ គាត់ និងភរិយា រូដា បានសើបអង្កេតអំពីសាសនាជាច្រើន ប៉ុន្តែហាក់ដូចជាគ្មានបំពេញនូវភាពទទេស្អាតខាងវិញ្ញាណរបស់ពួកគេសោះ ។ គាត់និយាយថា ‹ ខ្ញុំបានសន្ទនាជាមួយព្រះនាយប់នោះ ដោយទូលសុំជំនួយ ›» («Elder Helvécio Martins of the Seventy» *Ensign* ខែ ឧសភា ឆ្នាំ ១៩៩០ ទំព័រ ១៦០ ) ។



អែលឌើរ ហេលវេសីអូ ម៉ាទិន

ប៉ុន្មានថ្ងៃក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាបានមកដល់ផ្ទះរបស់ពួកគេនៅ រីយ៉ូ ដេ ចានេរ្យូ ប្រទេសប្រេស៊ីល ។ អែលឌើរ ម៉ាទីន បាននឹកចាំថា « នៅគ្រាដែលយុវជនទាំងពីរនាក់នោះ បានបោះជំហានចូលមកក្នុងផ្ទះរបស់យើងភ្លាម នោះភាពងងឹត និងភាពរសាប់រសល់ខាងវិញ្ញាណទាំងអស់របស់ខ្ញុំត្រូវបានរលាយបាត់មួយរំពេច ហើយត្រូវបានដាក់ជំនួសវិញដោយភាពស្ងប់ស្ងាត់ ដែលឥឡូវខ្ញុំដឹងថា វាបានមកពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ » ( ដោយ Mark Grover, *The Autobiography of Elder Helvécio Martins* [ឆ្នាំ ១៩៩៤] ទំព័រ ៤៣ ) ។

នៅពេល ហេលវេសីអូ និង រូដា ដែលជាកូនចៅជនជាតិអាហ្វ្រិក បានសន្ទនាជាមួយអ្នកផ្សព្វផ្សាយសាសនានោះ ហេលវេសីអូ បានសួរអំពីតួនាទីរបស់ប្រជាជនស្បែកខ្មៅនៅក្នុងសាសនាចក្រ ។ ម៉ាទិនបានដឹងថា នៅគ្រានោះ គោលនយោបាយសាសនាចក្រ បានដាក់កំហិតចំពោះបុរសស្បែកខ្មៅដែលជាកូនចៅជនជាតិអាហ្វ្រិក ពីការត្រូវបានតែងតាំងបព្វជិតភាព ។ រឿងនេះបាននាំឲ្យពួកគេសួរសំណួរបន្ថែមទៀតដល់ពួកអ្នកផ្សព្វផ្សាយសាសនា ។

- បើអ្នកស្ថិតនៅក្នុងស្ថានភាពគ្រួសារម៉ាទិន តើសំណួរអ្វីខ្លះដែលអ្នកអាចនឹងសួរ នៅពេលអ្នកបានដឹងអំពីការដាក់កំហិតចំពោះបព្វជិតភាព ?

សូមបង្ហាញពីសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដែលជាចំណែកមួយនៃសេចក្ដីណែនាំទៅកាន់ សេចក្ដីប្រកាសជាផ្លូវការទី ២។ ( អ្នកអាចនឹងចង់បោះពុម្ព ច្បាប់នៃសេចក្ដីថ្លែងការណ៍នេះដល់សិស្សដែលពុំទាន់មានកំណែថ្មីនៃព្រះគម្ពីរសម្រាប់ឆ្នាំ ២០១៣ ) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ឲ្យឮ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលចម្លើយចំពោះសំណួរដែលបុគ្គលម្នាក់ៗ អាចនឹងមានអំពីការដាក់កំហិតចំពោះបព្វជិតភាព ។

> « ព្រះគម្ពីរមរមនបង្រៀនថាគ្រប់ ‹ មនុស្សទាំងអស់ក៏ដូចគ្នានៅចំពោះព្រះ › រួម ‹ ទាំងខ្មៅ និងស ទាំងបាវគេ និងសេរី ទាំងប្រុស និងស្រី ›( នីហ្វៃទី ២ ២៦:៣៣ ) ។ ពេញទាំងប្រវត្តិសាស្ត្រនៃសាសនាចក្រ មនុស្សទាំងអស់នៃអស់ទាំងសាសន៍ និងជាតិពន្ធនៅក្នុងប្រទេសជាច្រើន បានជ្រមុជទឹក និងបានរស់នៅជាសមាជិកដ៏ស្មោះត្រង់នៃសាសនាចក្រ ។ អំឡុងពេល យ៉ូសែប ស្ម៊ីធ នៅមានជីវិត មានបុរសស្បែកខ្មៅពីរបីនាក់ដែលជាសមាជិកនៃសាសនាចក្រ ត្រូវបានតែងតាំងឲ្យមានបព្វជិតភាព ។ កាលពីដើមនៅក្នុងប្រវត្តិសាស្ត្រ ថ្នាក់ដឹកនាំសាសនាចក្របានបញ្ឈប់ការអនុញ្ញាតឲ្យមានបព្វជិតភាពដល់បុរសស្បែកខ្មៅដែលមានពូជអំបូរអាហ្វ្រិក ។ កំណត់ត្រាសាសនាចក្រ ពុំបានផ្ដល់នូវការយល់ដឹងច្បាស់លាស់ នៅក្នុងច្បាប់ដើមនៃការអនុវត្តនេះទេ » ។

- តើសំណួរណាខ្លះ អំពីការដាក់កំហិតបព្វជិតភាព ដែលអាចត្រូវបានឆ្លើយតាមរយៈសេចក្ដីថ្លែងការណ៍នេះ ?

សូមចង្អុលបង្ហាញផ្នូរដែលថ្លែងថា « កំណត់ត្រានៃសាសនាចក្រ ពុំបានផ្ដល់នូវការយល់ដឹងច្បាស់លាស់អំពីការអនុវត្តបែបនេះពីដើមដំបូងឡើយ » ។ សូមប្រាកដថា សិស្សយល់ថា ខណៈដែលមនុស្សមួយចំនួន អាចនឹងផ្ដល់នូវមូលហេតុដែលបុរសអំបូរអាហ្វ្រិក មិនត្រូវបានតែងតាំងឲ្យមានបព្វជិតភាពមួយរយៈនោះ មូលហេតុទាំងនោះប្រហែលមិនត្រឹមត្រូវឡើយ ។ សេចក្ដីថ្លែងការណ៍ដែលទើបតែបានអានរួច មានតំណាងឲ្យតំណែងជាផ្លូវការនៅក្នុងសាសនាចក្រ ។

សូមអញ្ជើញសិស្សផ្សេងទៀតឲ្យអាននូវកថាកណ្ឌដូចខាងក្រោម ពិពណ៌នាអំពីអ្វីដែលគ្រួសារម៉ាទីន បានធ្វើ បន្ទាប់ពីពួកគេបានដឹងអំពីដំណឹងល្អដែលបានស្ដារឡើងវិញ ៖

> ***ការឆ្លើយតបចំពោះសំណួរលំបាកៗ***
>
> ប្រធាន បិយដ៍ យេ ផាកកឺ បានបង្រៀនថា ៖ « គ្រូបង្រៀនម្នាក់ ត្រូវតែដឹងថានឹងមានសំណួរពិបាកៗត្រូវបានចោទជាញឹកញាប់ ។ ជាញឹកញាប់ សំណួរទាំងនេះ គឺមិនផ្ដល់នូវចម្លើយដែលគាប់ចិត្ត និងស្ងប់ចិត្តនោះទេ ។ គ្រូបង្រៀនម្នាក់ ពុំអាចដឹងអ្វីៗទាំងអស់ឡើយ ។ ព្រះអម្ចាស់ពុំទាន់បានបើកសម្ដែងអ្វីៗគ្រប់យ៉ាងទេ ។ ប៉ុន្តែចំពោះគ្រូបង្រៀន សំណួរនឹងកើតមាន សួរអំពីអ្វីគ្រប់យ៉ាង ។ [គ្រូបង្រៀន] គប្បីមានចិត្តរបសារនិយាយថា ‹ ខ្ញុំពុំដឹងទេ › ។ ជាញឹកញាប់ នោះនឹងជាចម្លើយពិតតែមួយគត់ » (*Teach Ye Diligently* [ ឆ្នាំ ១៩៧៥ ], ទំព័រ ៦៥ ) ។

គ្រួសារម៉ាទិន បានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃទី ២ ខែកក្កដា ឆ្នាំ ១៩៧២ ហើយបានបម្រើដោយស្មោះត្រង់នៅក្នុងសាសនាចក្រ ។ នៅពេលកូនប្រុសច្បងរបស់ពួកគេ ម៉ាគឹស បានទទួលពររបស់លោកអយ្យកោរបស់គាត់ ក្នុងនោះបានសន្យាថាគាត់នឹងផ្សាយដំណឹងល្អ ។ ទោះជាមានការដាក់កំហិតបព្វជិតភាពនៅគ្រានោះដែលបានរារាំង ម៉ាគឹសមិនឲ្យបម្រើបេសកកម្មពេញម៉ោងក្ដី ក៏ឪពុកម្ដាយគាត់ បានបើកគណនីសន្សំប្រាក់ចេញផ្សាយសាសនាឲ្យគាត់ដែរ ។ នៅឆ្នាំ ១៩៧៥ សាសនាចក្របានប្រកាសថា ព្រះវិហារបរិសុទ្ធនឹងត្រូវសាងសង់នៅក្នុងទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល ។ ដើម្បីជួយដល់ការរៃអង្គាសបងស្រីម៉ាទិន បានលក់គ្រឿងអលង្ការរបស់គាត់ ។ បងប្រុស ម៉ាទិន បានបម្រើដោយស្មោះត្រង់ជាសមាជិកនៃគណៈកម្មការសាធារណៈសម្រាប់ព្រះវិហារបរិសុទ្ធ ។ គ្រួសារម៉ាទិន បានធ្វើការលះបង់ទាំងនេះ ទោះជាពួកគេបានដឹងថា ពួកគេនឹងពុំមានឱកាសទទួលពិធីបរិសុទ្ធបព្វជិតភាពនៅក្នុងព្រះវិហារបរិសុទ្ធក្ដី ។

- ហេតុអ្វីអ្នកគិតថា គ្រួសារម៉ាទិស មានឆន្ទៈទទួលបុណ្យជ្រមុជទឹក ហើយបម្រើដោយស្មោះត្រង់នៅក្នុងសាសនាចក្រ ទោះជាពួកគេរងឥទ្ធិពលដោយការដាក់កំហិតបព្វជិតភាពនៅគ្រានោះដូច្នេះ ?

បន្ទាប់ពីសិស្សពិភាក្សាអំពីសំណួរនេះ សូមអានចម្លើយរបស់បងប្រុស ម៉ាទីន ៖



« ‹យើងបានរកឃើញសេចក្ដីពិត ហើយគ្មានអ្វីនឹងបញ្ឈប់យើងពីការរស់នៅតាមសេចក្ដីពិតនោះទេ › ។. . . នៅពេលព្រះវិញ្ញាណប្រាប់អ្នកថា ដំណឹងល្អពិត តើអ្នកអាចបដិសេធដោយរបៀបណា ?» ( នៅក្នុង « Elder Helvécio Martins of the Seventy,» ទំព័រ ១០៦ ) ។

សូមចង្អុលបង្ហាញថា ដោយសារតែគ្រួសារម៉ាទីន បានទទួលទីបន្ទាល់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេអាចដើរឆ្ពោះទៅមុខ ទុកចិត្តលើព្រះអម្ចាស់ ដោយមិនគិតពីអ្វីដែលពួកគេពុំយល់នោះឡើយ ។

- តើគ្រួសារម៉ាទិន ធ្វើជាគំរូមួយសម្រាប់អ្នក នៅពេលអ្នកមានចម្ងល់ដោយរបៀបណា ? ( យើងអាចតោងឲ្យជាប់ទៅនឹងអ្វីដែលអ្នកបានដឹងរួចហើយនោះ ហើយឈរឲ្យរឹងមាំរហូតដល់ទទួលបានចំណេះដឹងបន្ថែម )។

សូមពន្យល់ថា បន្ថែមពីលើគ្រួសារម៉ាទិន ពូជអំបូរអាហ្វ្រិករាប់ពាន់ទៀត នៅក្នុងជាតិសាសន៍ជាច្រើនប្រភេទបានមកស្គាល់នូវសេចក្ដីពិតពេញលេញនៃដំណឹងល្អដែលបានស្ដារឡើងវិញនៅក្នុងបណ្ដាទស្សវត្សរ៍មុននឹងមានវិវរណៈឆ្នាំ ១៩៧៨ ទៅទៀត ។ ថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងទីក្រុងសលត៍ លេក បានទទួលសំបុត្រជាច្រើនមកពីអ្នកប្រែចិត្តដែលមិនទាន់បានជ្រមុជទឹកនៅក្នុងប្រទេសនីហ្សេរីយ៉ា និងហ្គាណាស្នើសុំឲ្យមានអ្នកផ្សព្វផ្សាយសាសនាជាច្រើនបញ្ជូនទៅកាន់អាហ្វ្រិក ។ អស់រយៈពេលជាច្រើនឆ្នាំ ពួកអ្នកដឹកនាំសាសនាចក្របានពិចារណាប្រកបដោយការអធិស្ឋានអំពីរឿងនោះ ប៉ុន្តែពួកលោកបានមានអារម្មណ៍ថា ពេលវេលាពុំទាន់មកដល់នៅឡើយ ដើម្បីបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាទៅអាហ្វ្រិកជាកន្លែងដែលសមាជិកក្នុងមូលដ្ឋាននឹងពុំអាចធ្វើជាអធិបតី ឬធ្វើពិធីបរិសុទ្ធនៅឡើយនោះ ។



សូមប្រាប់សិស្សថាសេចក្ដីប្រកាសជាផ្លូវការទី ២មាននូវការប្រកាសជាផ្លូវការអំពីវិវរណៈមួយដែលប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល បានទទួលនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៨ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌទីមួយ នៅត្រង់ឃ្លា « បងប្អូនប្រុសជាទីស្រឡាញ់ » ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ដោយរកមើលអ្វីដែលថ្នាក់ដឹកនាំសាសនាចក្របានមានប្រសាសន៍ថាពួកលោកបានធ្វើជាសាក្សី ។

- តើថ្នាក់ដឹកនាំសាសនាចក្របានមើលឃើញទូទាំងផែនដីអំពីអ្វីខ្លះ ?

- តើថ្នាក់ដឹកនាំសាសនាចក្រត្រូវបានបំផុសគំនិតអ្វីខ្លះ នៅពេលពួកលោកបានធ្វើជាសាក្សីអំពីកិច្ចការរបស់ព្រះអម្ចាស់ ? ( បំណងប្រាថ្នាដើម្បីផ្ដល់ពរជ័យនៃដំណឹងល្អទាំងអស់ទៅដល់សមាជិកសក្ដិសមទាំងអស់ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាកណ្ឌបន្ទាប់ ( ដែលចាប់ផ្ដើមត្រង់ ( «សូមយល់ពីសេចក្ដីសន្យាទាំងឡាយ» ) ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្វែងរករបៀបដែលថ្នាក់ដឹកនាំសាសនាចក្របានធ្វើសកម្មភាពលើបំណងប្រាថ្នាដ៏បំផុសគំនិតរបស់ពួកលោក ។

- តើប្រធាន ស្ពែនសើរ ដបុលយូ ឃឹមប៊ល និងថ្នាក់ដឹកនាំសាសនាចក្រផ្សេងទៀតបានធ្វើសកម្មភាពលើបំណងប្រាថ្នាដ៏បំផុសគំនិតរបស់ពួកលោកដោយរបៀបណា ?

- តើរឿងនេះបង្រៀនយើងអំពីពួកព្យាការីយ៉ាងណាខ្លះ ? ( បន្ទាប់ពីសិស្សឆ្លើយតប អ្នកអាចនឹងចង់សរសេរសេចក្ដីពិតដូចតទៅនេះ នៅលើក្ដារខៀន ៖ **ពួកព្យាការីបានស្វែងរកការដឹកនាំរបស់ព្រះអម្ចាស់នៅក្នុងការដឹកនាំសាសនាចក្រ**) ។

សូមចង្អុលបង្ហាញថា ឃ្លា « ដោយយល់ពីសេចក្ដីសន្យាទាំងឡាយ ដែលបានធ្វើដោយពួកព្យាការី » ។

- តើឃ្លា និងប្រយោគនេះបង្រៀនយើងអំពីអ្វី ដែលពួកអ្នកដឹកនាំសាសនាចក្របានដឹងអំពីការដាក់ កំហិតបព្វជិតភាពយ៉ាងណាខ្លះ ? ( ពួកលោកបានដឹងថា នៅពេលខ្លះ បុរសសក្ដិសមទាំងឡាយនឹងមានឱកាសដើម្បីទទួលបានបព្វជិតភាព ) ។

សូមពន្យល់ថា អស់ជាច្រើនឆ្នាំពីមុនឆ្នាំ ១៩៧៨ គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពិភាក្សា ហើយអធិស្ឋានអំពីការដាក់កំហិតបព្វជិតភាពនេះ ។ ពួកអ្នកដឹកនាំមានអារម្មណ៍ថា វិវរណៈ គឺចាំបាច់ត្រូវមានដើម្បីមានការផ្លាស់ប្ដូរនូវការដាក់កំហិតនេះ ដែលបានស្ថាបនាឡើងជាយូរមកអស់មួយសតវត្សន៍ហើយនោះ ។ ពេលខ្លះ សំណួរនេះបានជិតជាប់យ៉ាងខ្លាំងក្នុងចិត្តរបស់ប្រធាន ឃឹមប៊ល ហើយជាញឹកញាប់ លោកបានចេញទៅព្រះវិហារបរិសុទ្ធតែម្នាក់ឯងដើម្បីអធិស្ឋានអំពីរឿងនោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវកថាកណ្ឌពីរបន្ទាប់ទៀត ដោយចាប់ផ្ដើមត្រង់ « ទ្រង់បានឮពាក្យអធិស្ឋានទាំងឡាយរបស់យើង » ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្វែងរកចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់ប្រធាន ឃឹមប៊ល ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ និងសមាជិកដប់រូបនៃកូរ៉ុមនៃពួកសាវកដប់ពីរ ។

- តើអ្វីជាចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់ព្យាការីរបស់ទ្រង់ ?

- តើរឿងនេះបង្រៀនយើងអ្វីខ្លះ អំពីរបៀបដែលព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់ ? ( បន្ទាប់ពីសិស្សបានឆ្លើយតប សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖ **ព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់ តាមរយៈពួកព្យាការីរបស់ទ្រង់ ) ។**

សូមពន្យល់ថា វិវរណៈនេះមានឥទ្ធិពលយ៉ាងខ្លាំងលើមនុស្សនៅទូទាំងពិភពលោក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានអំពីរបៀបដែល ហេលវេសឺអូ ម៉ាទិន និងភរិយារបស់គាត់ រូដា បានឆ្លើយតប នៅពេលពួកគេបានដឹងអំពីវានោះ ៖

« ខ្ញុំពុំអាចទប់អារម្មណ៍បានទេ ។ រូដា និងខ្ញុំបានចូលទៅបន្ទប់ដេករបស់យើង លុតជង្គង់ចុះ ហើយបានអធិស្ឋាន ។ យើងបានយំ ខណៈពេលដែលយើងអរគុណដល់ព្រះវរបិតាសួគ៌ ចំពោះព្រឹត្តិការណ៍មួយ ដែលយើងបានគ្រាន់តែសុបិន្តចង់បានប៉ុណ្ណោះ ។ ថ្ងៃនោះបានមកដល់យ៉ាងពិត ហើយវានៅក្នុងជីវិតមែងស្លាប់ *របស់យើង*» (*Autobiography* ទំព័រ ៦៩–៧០ ) ។ គ្រួសារម៉ាទិន បានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ កូនប្រុសរបស់ពួកគាត់ ម៉ាគឺស គឺជាសមាជិកសាសនាចក្រជនជាតិអាហ្វ្រិកដំបូងគេបំផុត ដែលបម្រើបេសកកម្មបន្ទាប់ពីទទួលវិវរណៈ ដើម្បីបញ្ចប់នូវការដាក់កំហិតចំពោះបព្វជិតភាព ។ ហេលវេសឺអូ ម៉ាទិន បានក្លាយជាអ្នកកាន់បព្វជិតភាពក្នុងមូលដ្ឋាន ហើយទីបំផុត ត្រូវបានហៅឲ្យបម្រើជាសមាជិកម្នាក់នៃកូរ៉ុមទីពីរនៃពួកចិតសិបនាក់ ។

សូមពន្យល់ថា ក្នុងអំឡុងពេលយ៉ាងខ្លីក្រោយពីវិវរណៈដែលបានបញ្ចប់ការដាក់កំហិតបព្វជិតភាពត្រូវបានទទួល នោះពួកអ្នកផ្សព្វផ្សាយសាសនាជាច្រើនត្រូវបានបញ្ជូនទៅកាន់ទ្វីបអាហ្វ្រិក ។ ព្រះវិហារបរិសុទ្ធជាច្រើនត្រូវបានសាងសង់នៅលើទ្វីបនោះ ហើយមនុស្សរាប់រយរាប់ពាន់នាក់បានទទួលពិធីបរិសុទ្ធនៃដំណឹងល្អសម្រាប់ខ្លួនគេ និងសម្រាប់ដូនតាដែលចែកឋានទៅរបស់ពួកគេ ។

សូមចង្អុលបង្ហាញថា សិស្សប្រហែលជានឹងសួរថា ហេតុអ្វីសាសនាចក្រពុំតែងតាំងបុរសជនជាតិអាហ្វ្រិក មានបព្វជិតភាពក្នុងមួយរយៈពេលនោះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេនឹងឆ្លើយសំណួរនេះ ។

សូមបញ្ជាក់ថា វាសមរម្យដើម្បីពន្យល់ដល់អ្នកដទៃថា យើងពុំដឹងថាហេតុអ្វីបានជាចាប់ផ្ដើមមានការដាក់កំហិតបព្វជិតភាពដូច្នោះទេ ។ បន្ថែមពីលើនោះ យើងអាចចែកចាយ និងថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ដែលយើងដឹង ។ ( អ្នកអាចនឹងចង់យោងទៅលើសេចក្ដីពិតដែលបានសរសេរនៅលើក្ដារខៀន ) ។ សូមបញ្ចប់ដោយការអញ្ជើញសិស្សឲ្យចែកចាយអារម្មណ៍ និងទីបន្ទាល់របស់ពួកគេ ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកផងដែរ ។

មេរៀនទី ១៥៨

# ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ

## បុព្វកថា

តាំងពីការចាប់ផ្ដើមនៃការស្ដារឡើងវិញ កិច្ចការនៃព្រះអម្ចាស់បានពង្រីកទៅទូទាំងពិភពលោក ។ យើងរស់នៅក្នុងជំនាន់មួយ ដែលព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ ។ យុវវ័យនៃសាសនាចក្រមានធនធាន និងឱកាសជាច្រើនដើម្បីរួមចំណែកចំពោះការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។

## យោបល់សម្រាប់ការបង្រៀន

### ព្រះអម្ចាស់ កំពុងពន្លឿនកិច្ចការរបស់ទ្រង់

សូមអញ្ជើញសិស្សឲ្យដើរពីជ្រុងម្ខាងទៅជ្រុងម្ខាងទៀតនៃបន្ទប់ថ្នាក់រៀនដោយល្បឿនធម្មតា ។ បន្ទាប់មកសុំសិស្សឲ្យដើរឆ្លងកាត់បន្ទប់ម្ដងទៀត ហើយដើរក្នុងដំណើរលឿន ឬបង្កើនល្បឿន ។ ខណៈដែលសិស្សកំពុងដើរឆ្លងកាត់បន្ទប់ជាលើកទីពីរ សូមសួរដល់សិស្សក្នុងថ្នាក់នូវសំណួរដូចខាងក្រោម ៖

- តើការពន្លឿនអ្វីមួយមានន័យយ៉ាងណា ? ( បង្កើនល្បឿនវា ) ។ តើមានមូលហេតុបែបណាខ្លះដែលមនុស្សអាចនឹងពន្លឿន ឬបង្កើនល្បឿនការងារនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្វែងរកអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា ទ្រង់នឹងពន្លឿន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថាការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ មានន័យយ៉ាងណាចំពោះទ្រង់ ?

យោងទៅលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៣ អែលឌើរ រ័សុល អិម ណិលសុន បានមានប្រសាសន៍ថា « ពេលវេលានៃការពន្លឿននោះ គឺជាពេលឥឡូវនេះហើយ » («Thus Shall My Church Be Called» *Ensign* ខែ ឧសភា ឆ្នាំ ១៩៩០ ទំព័រ ១៧ ) ។ សូមសរសេរនូវគោលលទ្ធិដូចខាងក្រោមនៅលើក្ដារខៀន ៖**យើងរស់នៅក្នុងគ្រាមួយដែលព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ ។**

- តើអ្នកបានធ្វើជាសាក្សីថា ព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ តាមរបៀបណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្វែងរកនូវអ្វីដែលខគម្ពីរនេះ ផ្ដល់យោបល់អំពីមូលហេតុដែលព្រះអម្ចាស់នឹងពន្លឿនកិច្ចការរបស់ទ្រង់ ។

- តើខគម្ពីរនេះផ្ដល់យោបល់ដូចម្ដេចខ្លះ អំពីមូលហេតុដែលព្រះអម្ចាស់នឹងពន្លឿនកិច្ចការរបស់ទ្រង់ ? ( ដើម្បីជួយមនុស្សត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ) ។

សូមដាក់បង្ហាញរូបភាព ប្រធាន ស្ពែនស៊ើរ ដបុលយូ឴ ឃីមបឹល (*សៀវភៅសិល្បៈដំណឹងល្អ* [ឆ្នាំ ២០០៩ ] ទំព័រ ១៣៣, សូមមើលផងដែរ LDS.org) ។ សូមពន្យល់ថា អំឡុងពេលការបម្រើរបស់ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ក្នុងនាមជាប្រធានសាសនាចក្រ ព្រះអម្ចាស់បានពន្លឿនកិច្ចការរបស់ទ្រង់ ។ ឧទាហរណ៍ កិច្ចការផ្សព្វផ្សាយសាសនាបានពង្រីក ហើយសាសនាចក្របានបោះពុម្ពកំណែថ្មីនៃព្រះគម្ពីរ ។ នៅពេលលោកលើកទឹកចិត្តដល់សមាជិកសាសនាចក្រឲ្យបោះជំហានឆ្ពោះទៅមុខ នោះប្រធាន ឃីមបឹលបានមានប្រសាសន៍ថា សាសនាចក្រ « បានបញ្ឈប់ជំហាននៅត្រង់កន្លែងខ្លះ យូរល្មមគ្រប់គ្រាន់ហើយ » ( «Let Us Move Forward and Upward» *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៩ ទំព័រ ៨២ ) ។ លោកក៏បានបង្រៀនផងដែរថា « យើងត្រូវតែពង្រីកការបោះជំហានរបស់យើង ហើយត្រូវតែធ្វើវាឥឡូវនេះ » (Always a Convert Church: Some Lessons to Learn and Apply This Year » *Ensign* ខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៣ ) ។

- តើអ្នកគិតថាប្រធាន ឃឹមបឹល ចង់មានន័យយ៉ាងណា នៅពេលលោកមានប្រសាសន៍ថា យើងត្រូវតែ « ពង្រីកការបោះជំហានរបស់យើង » ?



ដើម្បីជួយសិស្សយល់អំពីរបៀបមួយចំនួន ដែលព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់បច្ចុប្បន្ននេះ និងរបៀបមួយចំនួនដែលពួកគេអាចចូលរួមនៅក្នុងកិច្ចការរបស់ទ្រង់ សូមធ្វើសកម្មភាពដូចខាងក្រោម ៖

សូមបំបែកសិស្សជាបីក្រុម ហើយផ្ដល់ដល់សិស្សក្នុងក្រុមនិមួយៗនូវ ច្បាប់ចម្លងនៃកិច្ចការបង្រៀនមួយដូចខាងក្រោម។ សូមផ្ដល់ដល់សិស្សនូវរយៈពេលពីរបីនាទីដើម្បីសិក្សា និងត្រៀមខ្លួនដើម្បីបង្រៀនតាមកិច្ចការរបស់ពួកគេដល់មិត្តរួមថ្នាក់ ។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយនោះ សូមរៀបចំសិស្សជាក្រុមៗដែលមានបីនាក់ ដោយមានសិស្សម្នាក់ពីក្រុមដើមនិមួយៗ ។ សូមអញ្ជើញសិស្សឲ្យផ្លាស់វេនគ្នាបង្រៀនក្រុមរបស់ពួកគេ អំពីរបៀបដែលព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ និងរបៀបដែលពួកគេអាចចូលរួមក្នុងកិច្ចការនោះ ។

## កិច្ចការបង្រៀនទី ១ ៖ ការពន្លឿនកិច្ចការផ្សព្វផ្សាយសាសនា

ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល បានប្រាប់ពួកបរិសុទ្ធថា ព្រះអម្ចាស់បានរៀបចំ ដើម្បីបើកទ្វាសម្រាប់ពួកគេឲ្យចែកចាយដំណឹងល្អ រួមទាំងនៅក្នុងជាតិសាសន៍ដែលពុំអនុញ្ញាតឲ្យមានកិច្ចការផ្សព្វផ្សាយសាសនាផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ លោកក៏បានមានប្រសាសន៍ថា ពួកបរិសុទ្ធចាំបាច់ត្រូវត្រៀមខ្លួនឯងដើម្បីទទួលយកឱកាសនោះផងដែរ ។ ប្រធាន ឃឹមបឹល ក៏បានថ្លែងទីបន្ទាល់ថា បើយុវជនគ្រប់រូបត្រៀមខ្លួនបម្រើបេសកកម្មពេញម៉ោង នោះព្រះអម្ចាស់នឹងបើកទ្វា ហើយផ្ដល់មធ្យោបាយមួយសម្រាប់កិច្ចការផ្សព្វផ្សាយសាសនា ដើម្បីចេញទៅពេញពិភពលោកទាំងមូល ។ លោកបានប្រកាសថា ៖



« ខ្ញុំដឹងថា ពួកគេមានរាំងនន ដូចជារាំងននដែក និងរាំងននឫស្សី ។ ខ្ញុំដឹងថាវាលំបាកខ្លាំងដោយសារយើងបានខិតខំបញ្ចេញសមត្ថភាពខ្លះហើយ ។. . . « ប៉ុន្តែខ្ញុំអាចមើលឃើញថា វាគ្មានហេតុផលល្អទេ ដែលព្រះអម្ចាស់នឹងបើកទ្វារ ដែលយើងពុំបានត្រៀមខ្លួនដើរចូលទៅនោះ ។ ហេតុអ្វីក៏ទ្រង់គប្បីបំបាក់រាំងននដែក ឬរាំងននឫស្សី ឬរាំងននផ្សេងទៀត បើយើងពុំត្រៀមខ្លួនដើម្បីដើរចូលផងនោះ ? «When the World Will Be Converted,» *Ensign* ខែ តុលា ឆ្នាំ ១៩៧៤ ទំព័រ ៥, ៧ ) ។

សមាជិកនៃសាសនាចក្របានធ្វើតាមការទូន្មានរបស់ប្រធាន ឃឹមបឹល ហើយបានត្រៀមខ្លួនដើម្បីចែកចាយដំណឹងល្អ ។ អំឡុងការដឹកនាំរបស់ប្រធាន ឃឹមបឹល នោះចំនួនអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង បានកើនឡើងច្រើនជាង ៥០ ភាគរយ ។ នៅចុងឆ្នាំ ១៩៨០ និងដើមឆ្នាំ ១៩៩០ រដ្ឋាភិបាលអាល្លឺម៉ង់ខាងកើត ប្រទេសជាតិទាំងឡាយនៅក្នុងសហភាពសូវៀតពីដើម និងប្រទេសជាតិនានាឯទៀត ជាទីកន្លែងដែលកិច្ចការផ្សព្វផ្សាយសាសនាត្រូវបានដាក់កំហិតពីមុននោះ បានចាប់ផ្ដើមអនុញ្ញាតឲ្យអ្នកផ្សព្វផ្សាយសាសនាចូលទៅចែកចាយដំណឹងល្អនៅក្នុងប្រទេសទាំងនេះ ។ ការព្យាករណ៍របស់ប្រធាន ឃឹមបឹល ត្រូវបានបំពេញ ។

នៅក្នុងខែតុលា ឆ្នាំ ២០០៨ ប្រធាន ថូម៉ាស អេស ម៉នសុន បានថ្លែងបញ្ជាក់ឡើងវិញនូវដំបូន្មានដែលប្រធាន ឃឹមបឹល បានផ្ដល់ឲ្យថា ៖



« នៅមាន . . .តំបន់ជាច្រើននៅក្នុងពិភពលោកដែលឥទ្ធិពលរបស់យើងនៅមានកម្រិត ហើយជាកន្លែងដែលយើងពុំត្រូវបានអនុញ្ញាតឲ្យចែកចាយដំណឹងល្អដោយសេរី ។ ក៏ដូចជាប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល កាលពី ៣២ ឆ្នាំមុន ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យអធិស្ឋានសុំការបើកតំបន់ទាំងនោះ ដើម្បីយើងអាចចែកចាយជាមួយពួកគេនូវសេចក្ដីអំណរនៃដំណឹងល្អ ។ នៅពេលយើងបានអធិស្ឋានក្នុងការឆ្លើយតបចំពោះការអង្វររបស់ប្រធាន ឃឹមបឹល នោះ យើងបានឃើញអព្ភូតហេតុបើកសម្ដែងពីប្រទេសមួយទៅប្រទេសមួយ ដែលកាលពីមុនបានបិទទ្វារចំពោះសាសនាចក្រ ត្រូវបានបើកទ្វារឲ្យសាសនាចក្រចូលវិញ ។ ការណ៍ដូច្នេះ នឹងកើតឡើងម្ដងទៀត

នៅពេលយើងអធិស្ឋានដោយសេចក្ដីជំនឿ (« Welcome to Conference» *Ensign* ឬ *លីអាហូណា* ខែវិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៦ ) ។

សូមចង្អុលបង្ហាញថា នៅពេលប្រធាន឴ ឃឹមបឹល បានលើកទឹកចិត្តដល់សមាជិកសាសនាចក្រឲ្យពង្រីកជំហានរបស់ពួកគេ នោះលោកបានបញ្ជាក់អំពីទំនួលខុសត្រូវមួយរបស់យុវជនគ្រប់រូបក្នុងសាសនាចក្រ ។ សូមអញ្ជើញសមាជិកម្នាក់ពីក្រុមរបស់អ្នកឲ្យអាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមឲ្យឮៗ ៖



« សំណួរត្រូវបានសួរជារឿយៗថា ៖ តើយុវជនគ្រប់រូបគួរតែបំពេញបេសកកម្មដែរឬទេ ? ហើយចម្លើយត្រូវបានប្រទានឲ្យដោយព្រះអម្ចាស់ ។ គឺ ‹ពិតមែនហើយ› ។ យុវជនគ្រប់រូបគប្បីបំពេញបេសកកម្ម » («When the World Will Be Converted» ទំព័រ ៨ )។

សូមរំឭកសមាជិកនៃក្រុមរបស់អ្នកថា ពួកព្យាការីបានបន្តលើកទឹកចិត្តយុវជនដែលសក្ដិសម និងមានសមត្ថភាពគ្រប់រូប បម្រើបេសកកម្មពេញម៉ោង ។ ពួកព្យាការីក៏ស្វាគមន៍ដល់យុវនារីឲ្យបម្រើបេសកកម្មពេញម៉ោងផងដែរ បើពួកគេមានបំណងចង់ធ្វើ ។ នៅខែតុលា ឆ្នាំ ២០១២ ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសអំពីការផ្លាស់ប្ដូរអាយុដែលតម្រូវឲ្យចេញផ្សព្វផ្សាយសាសនា ដោយអនុញ្ញាតឲ្យយុវជនចាប់ផ្ដើមការបម្រើនៅវ័យ ១៨ ឆ្នាំ ហើយយុវនារីនៅវ័យ ១៩ ឆ្នាំ ។

សូមពិភាក្សាសំណួរខាងក្រោមនេះជាក្រុម ៖

- ស្របតាមពួកព្យាការីថ្ងៃចុងក្រោយ តើការរំពឹងទុកអ្វីខ្លះដែលព្រះអម្ចាស់មានចំពោះយុវជន ទាក់ទងនឹងកិច្ចការផ្សព្វផ្សាយសាសនាពេញម៉ោង ? ( ទោះសមាជិកក្រុមអាចប្រើពាក្យផ្សេងក្ដី ក៏ចម្លើយរបស់ពួកគេគប្បីឆ្លុះបញ្ចាំងនូវគោលការណ៍ដូចខាងក្រោម **៖យុវជនគ្រប់រូបគប្បីត្រៀមខ្លួនបម្រើបេសកកម្មពេញម៉ោង ហើយរក្សាខ្លួនឲ្យបានសក្ដិសមដើម្បីបម្រើ )**។
- ហេតុអ្វីក៏យុវជនគ្រប់រូបគប្បីត្រៀមខ្លួនបម្រើបេសកកម្មពេញម៉ោងយ៉ាងដូច្នេះ ?
- តើការត្រៀមខ្លួនសម្រាប់បេសកកម្មនាពេលឥឡូវនេះ អាចជួយអ្នករួមចំណែកចំពោះកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?
- តើអ្នកគិតថា ការផ្លាស់ប្ដូរចំពោះតម្រូវការអាយុសម្រាប់ការចេញផ្សព្វផ្សាយសាសនាពេញម៉ោងដ៏បំផុសគំនិត បានរួចចំណែកចំពោះការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

## កិច្ចការបង្រៀនទី ២ ៖ កំណែថ្មីនៃព្រះគម្ពីរ

សូមឲ្យសមាជិកក្រុមរបស់អ្នកពិចារណាអំពីអ្វីដែលពួកគេនឹងធ្វើ បើមានមិត្តជិតស្និតម្នាក់សួរដល់ពួកគេថា « ខ្ញុំចង់ខិតទៅកាន់តែជិតព្រះ ។ តើខ្ញុំគួរតែធ្វើយ៉ាងដូចម្ដេច ? » បន្ទាប់មកសូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកនឹងនិយាយទៅកាន់មិត្តភក្ដិរបស់អ្នកយ៉ាងដូចម្ដេច ?

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយ ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល ៖



«ខ្ញុំរកឃើញថា ពេលខ្ញុំបង្ហាញនូវទំនាក់ទំនងមិនសូវហ្មត់ចត់ជាមួយនឹងព្រះអាទិទេព ហើយកាលវាហាក់ដូចជាគ្មានព្រះ កំពុងស្ដាប់ ហើយមានបន្ទូលមកកាន់ខ្ញុំ នោះខ្ញុំឃ្លាតពីទ្រង់កាន់តែឆ្ងាយហើយ។ បើសិនខ្ញុំផ្ដោតយកចិត្តទុកដាក់ទាំងស្រុងលើព្រះគម្ពីរ ចន្លោះរវាងខ្ញុំនឹងព្រះត្រូវបានបង្រួមឲ្យតូច ជីវភាពខាងវិញ្ញាណមានត្រឡប់មកវិញ » (*Teachings of Spencer W. Kimball* បានបោះពុម្ពដោយ អែតវើត អិល ឃឹមបឹល [ឆ្នាំ ១៩៨២ ] ទំព័រ ១៣៥ ) ។

សូមជូនដំណឹងល្អដល់សមាជិកក្រុមរបស់អ្នកថា សេចក្ដីថ្លែងការណ៍របស់ប្រធាន ឃឹមបឹល ពន្យល់អំពីតម្រូវការដ៏ខ្លាំងចំពោះយើងដើម្បីមានព្រះគម្ពីរ ។ សូមអញ្ជើញសមាជិកក្រុមរបស់អ្នកម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៥៨–៥៩ ឲ្យឮៗ ។ សូមឲ្យក្រុមផ្ទៀងតាម ហើយប្រាប់ថាហេតុអ្វីព្រះអម្ចាស់ចង់ឲ្យអ្នកដឹកនាំសាសនាចក្របោះពុម្ពវិវរណៈទាំងឡាយ ។

- តើការសិក្សាព្រះគម្ពីរអាចជួយយើងពង្រីកជំហានរបស់យើង ហើយរួមចំណែកក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

សូមពន្យល់ថា នៅដើមឆ្នាំ ១៩៧០ អ្នកដឹកនាំសាសនាចក្រទទួលស្គាល់ពីតម្រូវការ ដែលសមាជិកសាសនាចក្រត្រូវចេះបទគម្ពីរឲ្យបានកាន់តែស្ទាត់ជំនាញ ហើយឲ្យមានកំណែថ្មីនៃព្រះគម្ពីរប៊ីបជាបទដ្ឋានមួយដើម្បីសិក្សា និងបង្រៀន ។ នៅឆ្នាំ ១៩៧៩ បន្ទាប់ពីរយៈពេលជាច្រើនឆ្នាំនៃកិច្ចខិតខំ ដ៏បំផុសគំនិត និងឧស្សាហ៍ព្យាយាម នោះសាសនាចក្រ បានបោះពុម្ពកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ អិល.ឌី.អេស ជាផ្លូវការជាភាសាអង់គ្លេស ។ គម្ពីរប៊ីបនេះ មាននូវជំនួយការសិក្សាដ៏ច្រើន ដែលពុំធ្លាប់មានពីមុន

រួមមានទាំងលេខយោងជាមួយនឹងសេចក្ដីយោងបទគម្ពីរ និងជំនួយដទៃៗទៀតត្រូវបានពង្រីកកាន់តែច្រើន ហើយបានកែលម្អជើមជំពូក ដកស្រង់ចេញមកពីការបកប្រែរបស់យ៉ូសែប ស្ម៊ីធ Topical Guide និង Bible Dictionary ។ នៅឆ្នាំ ១៩៨១ សាសនាចក្របានបោះពុម្ពកំណែថ្មី នៃបណ្ដុំព្រះគម្ពីរទាំងបីជាភាសាអង់គ្លេស ដែលរួមមានទាំងការកែលម្អលេខយោង ជើមជំពូក ផែនទី និងមាតិកា ។ នៅឆ្នាំ ២០០៩ សាសនាចក្របានបោះពុម្ពកំណែថ្មីនៃព្រះគម្ពីរប៊ីបនៃ រីណា វ៉ាឡេរ៉ា អិល.ឌី.អេស ជាភាសាអេស្ប៉ាញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ប៊យដ៍ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដែលបានធ្វើឡើង នៅរយៈពេលមួយឆ្នាំ បន្ទាប់ពីបានចេញបណ្ដុំព្រះគម្ពីរទាំងបីជាភាសាអង់គ្លេសនៅឆ្នាំ ១៩៨១ ។ សូមឲ្យសិស្សស្ដាប់អំពីរបៀបដែលលោកបានមើលឃើញជាមុនថា កំណែថ្មីនៃព្រះគម្ពីរទាំងនេះ នឹងប្រទានពរដល់ជីវិតជាច្រើន ហើយគាំរកិច្ចការរបស់ព្រះឆ្ពោះទៅមុខ ។



« រយៈពេលជាច្រើនឆ្នាំបានកន្លងផុតទៅ ព្រះគម្ពីរទាំងនេះនឹងបង្កើតផលជាជំនាន់នៃពួកគ្រីស្ទានស្មោះត្រង់ជាបន្តបន្ទាប់ ដែលស្គាល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយដែលចង់គោរពតាមព្រះទ័យទ្រង់ ។

« . . . ពួកគេនឹងអភិវឌ្ឍចំណេះវិជ្ជាដំណឹងល្អ លើសហួសជីដូនជីតារបស់ពួកគេអាចសម្រេច ។ ពួកគេនឹងមានទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយអាចប្រកាសអំពីទ្រង់ និងការពារទ្រង់ » ( Scriptures » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨២ ទំព័រ ៥៣ ) ។

សូមចែកចាយទីបន្ទាល់របស់អ្នកថា **បទគម្ពីរថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ** ។ ការសិក្សាបទគម្ពីរអាចជួយយើងទទួលបានទីបន្ទាល់អំពី ព្រះយេស៊ូវគ្រីស្ទ ហើយជួយបំពេញជីវិតរបស់យើងដោយព្រះវិញ្ញាណបរិសុទ្ធ ។

សូមពន្យល់ថា កិច្ចខិតខំដ៏អស្ចារ្យ បានមាន និងបន្តធ្វើឡើងដើម្បីផ្ដល់ឲ្យសមាជិកសាសនាចក្រនូវព្រះគម្ពីរ ហើយជំនួយសម្រាប់ការសិក្សាជាភាសារបស់ពួកគេ ។

សូមពិភាក្សាសំណួរខាងក្រោមនេះជាក្រុម ៖

- ហេតុអ្វីក៏ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃសំខាន់ ?
- តើការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់អ្នក បានជួយអ្នក ឲ្យជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

## កិច្ចការបង្រៀនទី ៣ ៖ ការពន្លឿនកិច្ចការព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ

សូមក្រុមរបស់អ្នកឲ្យប៉ាន់ស្មានថាមានព្រះវិហារបរិសុទ្ធចំនួនប៉ុន្មាន ត្រូវបានសាងសង់ក្នុងរយៈពេល ១៤៣ ឆ្នាំ ចន្លោះការរៀបចំសាសនាចក្រនៅក្នុងឆ្នាំ ១៨៣០ និងការហៅរបស់ប្រធាន ស្ពែនស៊ើរ ដបុលយូ឴ ឃីមបឹល នៅឆ្នាំ ១៩៧៣ ( ១៧ ព្រះវិហារបរិសុទ្ធ ) ។ បន្ទាប់មកសូមក្រុមឲ្យស្មានថាមានព្រះវិហារបរិសុទ្ធចំនួនប៉ុន្មានដែលត្រូវបានប្រកាស ឬបានសាងសង់នៅក្នុង ៤០ ឆ្នាំ ចន្លោះឆ្នាំ ១៩៧៣ និង ឆ្នាំ ២០១៣ ( ១៥៣ ព្រះវិហារបរិសុទ្ធ ) ។

សូមពន្យល់ថាការសាងសង់សង់ព្រះវិហារបរិសុទ្ធបានកើនឡើងយ៉ាងច្រើនក្រៃលែង នៅក្រោមការដឹកនាំរបស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមអញ្ជើញនរណាម្នាក់ពីក្នុងក្រុមរបស់អ្នកឲ្យអាននូវសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ៖



« ខ្ញុំមានបំណងប្រាថ្នាដ៏ឆេះឆួលឡើងមួយថា ព្រះវិហារបរិសុទ្ធមួយ ត្រូវស្ថាបនានៅក្នុងកន្លែងដែលស្ថិតនៅក្បែរពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅទូទាំងពិភពលោក ។. . . កិច្ចការកំពុងឆ្ពោះទៅមុខយ៉ាងលឿនតាមដែលយើងអាចធ្វើទៅបាន ។ វាគឺជាការអធិស្ឋានដ៏ខ្ជាប់ខ្ជួនរបស់ខ្ញុំសុំឲ្យវាអាចត្រូវបានពន្លឿនល្បឿនឡើង ដើម្បីឲ្យប្រជាជនរបស់យើងកាន់តែច្រើននាក់អាចចូលទៅក្នុងដំណាក់ដ៏ពិសិដ្ឋរបស់ព្រះអម្ចាស់បានកាន់តែងាយស្រួល » (Of Missions, Temples, and Stewardship» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៥២, ៥៣ ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៥, ១៧ ឲ្យឮៗ ។ សូមឲ្យក្រុមផ្ទៀងតាម រកមើលទំនួលខុសត្រូវដែលយើងមានចំពោះជីដូនជីតារបស់យើង ។ បន្ទាប់មក សូមអានឮៗនូវសេចក្ដីថ្លែងការណ៍នៃគោលលទ្ធិដូចខាងក្រោមដែលបានផ្ដល់ឲ្យដោយ អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ **យើងមានទំនួលខុសត្រូវក្នុងសេចក្ដីសញ្ញា ដើម្បីស្រាវជ្រាវរកជីដូនជីតារបស់យើង ហើយផ្ដល់ដល់ពួកគេនូវពិធីបរិសុទ្ធនៃដំណឹងល្អសម្រាប់ការសង្គ្រោះ**» The Hearts of the Children Shall Turn,» *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៥ ) ។

សូមចង្អុលបង្ហាញថា សំណង់ព្រះវិហារបរិសុទ្ធ និងការរីកចម្រើននៃកិច្ចការពង្សប្រវត្តិ គឺជាភស្ដុតាងដែលព្រះកំពុងពន្លឿនកិច្ចការរបស់ទ្រង់ នៅផ្នែកម្ខាងទៀតនៃវាំងនន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ បែដណា ។ សូមឲ្យក្រុមស្ដាប់មើលរបៀបដែលពួកគេអាចរួមចំណែកចំពោះកិច្ចការរបស់ព្រះអម្ចាស់ ។



« វាពុំមែនជាព្រឹត្តិការណ៍ចៃដន្យដែល កម្មវិធី FamilySearch និងឧបករណ៍ដទៃទៀត បានចេញមកនៅគ្រាមួយដែលយុវវ័យ ចេះយ៉ាងស្ទាត់ជំនាញជាមួយនឹងបច្ចេកវិទ្យាព័ត៌មានដ៏ទូលំទូលាយ និងទំនាក់ទំនងនោះទេ ។ ម្រាមដៃរបស់អ្នកត្រូវបានបង្រៀនឲ្យវាយសារ និងធ្វីតដើម្បីបង្កើនល្បឿន និងចម្រើនកិច្ចការរបស់ព្រះអម្ចាស់–ពុំគ្រាន់តែទំនាក់ទំនងបានឆាប់ជាមួយមិត្តរបស់អ្នកប៉ុណ្ណោះទេ ។ ជំនាញ និងសមត្ថភាព ដែលជាភស្តុតាងនៅក្នុងចំណោមមនុស្សវ័យក្មេងជាច្រើនសព្វថ្ងៃនេះ គឺជាការរៀបចំមួយដើម្បីរួមចំណែកចំពោះកិច្ចការនៃសេចក្តីសង្គ្រោះ » (« The Hearts of the Children Shall Turn » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៦ ) ។

សូមពិភាក្សាសំណួរខាងក្រោមនេះជាមួយក្រុមរបស់អ្នក ៖

- តើបទពិសោធន៏វិជ្ជមានអ្វីខ្លះដែលអ្នកមាន នៅក្នុងការធ្វើកិច្ចការពង្សប្រវត្តិរបស់អ្នក ឬការទៅព្រះវិហារបរិសុទ្ធដើម្បីចូលរួមក្នុងពិធីបរិសុទ្ធសម្រាប់មរណជន ?

## ទំនួលខុសត្រូវរបស់យើងនៅក្នុងការជម្រុញកិច្ចការឲ្យឆ្ពោះទៅមុខ

បន្ទាប់ពីសិស្សបានបញ្ចប់ការបង្រៀនរបស់ពួកគេនៅក្នុងក្រុមតូច ៗហើយ អញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិត និងអារម្មណ៍របស់ពួកគេ អំពីការពន្លឿនកិច្ចការនៃព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ. ហេត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់ ហើយស្វែងរកនូវអ្វីដែលអាចកើតមានឡើង នៅពេលយើងមានចំណែកនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។



« បងប្អូនប្រុសស្រី ព្រះអម្ចាស់កំពុងបើកផ្លូវ ហើយធ្វើឲ្យមានលទ្ធភាពដើម្បីពង្រីកកិច្ចការរបស់ទ្រង់នៅទូទាំងពិភពលោក ហើយនោះជាពរជ័យមួយសម្រាប់យើងទាំងអស់គ្នា– ដែលបុគ្គលម្នាក់ៗត្រូវចូលរួមចំណែក–តាមរបៀបផ្ទាល់ខ្លួន ។. . .

« តើមាននរណាក្រៅពីពួកព្យាការីនៃព្រះ អាចមើលឃើញជាមុនអំពីអព្ភូតហេតុនៃការរីកចម្រើនយ៉ាងលឿននៃកិច្ចការរបស់ព្រះអម្ចាស់ ? ពិតណាស់ ដូចដែលព្រះអម្ចាស់បានប្រាប់ជាមុននៅក្នុងកណ្ឌ ៨៨ អំពី គោលលទ្ធិ និង សេចក្តីសញ្ញា នោះទ្រង់កំពុងពន្លឿនកិច្ចការរបស់ទ្រង់តាមពេលវា ( សូមមើល គ. និង ស. ៨៨:៧៣ Missionary Work—Our Responsibility,» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, ទំព័រ ៦១, ៦២ ) ។

- ស្របតាមអែលឌើរ ហេត តើមានអ្វីខ្លះអាចកើតឡើង នៅពេលយើងមានចំណែកនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ? ( នៅពេលសិស្សឆ្លើយ សូមសរសេរសេចក្តីពិតដូចខាងក្រោមនៅលើក្តារខៀន ៖**យើងអាចត្រូវបានប្រទានពរដោយការចូលរួមចំណែកនៅក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ) ។**

- តើពរជ័យអ្វីខ្លះដែលអ្នកបានទទួលពិសោធន៍ នៅពេលអ្នកបានចូលរួមក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីឱកាសទាំងឡាយ ដែលពួកគេត្រូវរួមចំណែកដើម្បីពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោម នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

- តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកអាចរួមចំណែកដើម្បីពន្លឿនដល់កិច្ចការរបស់ព្រះអម្ចាស់ ?

បន្ទាប់ពីផ្តល់ពេលវេលាគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយដើម្បីធ្វើតាមអ្វីដែលពួកគេបានសរសេរ ។ សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ និងទំនួលខុសត្រូវ និងឱកាសរបស់យើងដើម្បីចូលរួមនៅក្នុងកិច្ចការរបស់ទ្រង់ ។

មេរៀនទី ១៥៩

# ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក

### បុព្វកថា

នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៥ នៅក្នុងការប្រជុំសមាគមសង្គ្រោះទូទៅមួយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានណែនាំអំពី « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។ សេចក្ដីប្រកាសនេះ ចេញមកពីគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ប្រកាសទៅកាន់ពិភពលោកអំពីបទដ្ឋាន និងគោលលទ្ធិរបស់ព្រះអម្ចាស់អំពីក្រុមគ្រួសារ ។ សេចក្ដីប្រកាសក៏ផ្ដល់នូវការទូន្មានផងដែរ សម្រាប់ជាការពង្រឹងដល់ក្រុមគ្រួសារ និងការព្រមានអំពីលទ្ធផលនៃការបែកបាក់ក្រុមគ្រួសារ ។

*កំណត់ចំណាំ ៖* សូមប្រាកដថាសិស្សម្នាក់ៗមានអត្ថបទ «ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក »មួយច្បាប់ ។ ឯកសារនេះ អាចរកបាននៅទំព័រ ១២៩ នៃទស្សនាវដ្ដី *Ensign* ឬ *លីអាហូណា* ខែវិច្ឆិកា ឆ្នាំ ២០១០, នៅក្នុងកូនសៀវភៅ *កាតព្វកិច្ចចំពោះព្រះ* និង *ការអភិវឌ្ឍខ្លួន* និងនៅក្នុងកូនសៀវភៅ *ពិតចំពោះសេចក្ដីជំនឿ*ក្រោមពាក្យ «គ្រួសារ » និងនៅ LDS.org។ អ្នកក៏អាចរកឃើញសំណៅនៃសេចក្ដីប្រកាសអំពីគ្រួសារនៅក្នុងសេចក្ដីបន្ថែមនៃសៀវភៅសិក្សានេះផងដែរ ។

## យោបល់សម្រាប់ការបង្រៀន

### គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានចេញសេចក្ដីប្រកាសមួយទៅកាន់ពិភពលោកអំពីក្រុមគ្រួសារ ។

ពីមុនថ្នាក់ចាប់ផ្ដើម សូមសរសេរ ពាក្យ និងឃ្លាទាំងឡាយ ដូចខាងក្រោម នៅលើក្ដារខៀន ៖

> *សារៈសំខាន់នៃអាពាហ៍ពិពាហ៍ និងគ្រួសារ*
>
> *ការលែងលះគ្នា*
>
> *អាពាហ៍ពិពាហ៍ភេទដូចគ្នា*
>
> *ភេទ*
>
> *ការមានកូន*
>
> *ទំនាក់ទំនងផ្លូវភេទក្រៅចំណងអាពាហ៍ពិពាហ៍*
>
> *តួនាទីរបស់ម្ដាយ*
>
> *តួនាទីរបស់ឪពុក*
>
> *ការពន្លូតកូន*

សូមចាប់ផ្ដើមបង្រៀនដោយសួរសំណួរដូចខាងក្រោមនេះ ៖

- តើមានអ្នករាល់គ្នាប៉ុន្មាននាក់ដែលមានសំណួរ ឬបានដឹងថានរណាម្នាក់មានសំណួរទាក់ទងនឹងវិបត្តិមួយ ឬច្រើននៅខាងលើក្ដារខៀននេះ សូមលើកដៃ ?
- តើយើងអាចរកឃើញការណែនាំរបស់ព្រះអម្ចាស់ អំពីប្រធានបទទាំងនេះនៅឯណា ?

សូមចែកចាយសំណៅ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ដល់សិស្ស ។ ( អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យដាក់លេខត្រង់កថាកណ្ឌក្នុងសេចក្ដីប្រកាស ដើម្បីពួកគេអាចផ្ទៀងតាមដោយងាយស្រួល នៅពេលអ្នកយោងទៅលើកថាកណ្ឌផ្សេងៗ ) ។ សូមពន្យល់ថា ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានប្រកាសអំពីសេចក្ដីប្រកាសនេះនៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៥ នៅក្នុងការប្រជុំសមាគមសង្គ្រោះទូទៅមួយ ។ មុនពេលប្រធាន ហ៊ិងគ្លី អានសេចក្ដីប្រកាសនេះ លោកបានថ្លែងអំពីមូលហេតុមួយចំនួនថាហេតុអ្វីក៏ពិភពលោកត្រូវការនូវសេចក្ដីពិតទាំងឡាយក្នុងសេចក្ដីប្រកាសនេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហ៊ិងគ្លី ឲ្យឮៗ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់មើលមូលហេតុដែលពិភពលោកត្រូវការចាំបាច់នូវសេចក្ដីប្រកាសនេះ ។



« មានសេចក្ដីពុំទៀងត្រង់ជាច្រើនត្រូវបានបង្ហាញថាជាសេចក្ដីពិត ដោយមាននូវការបោកបញ្ឆោតដ៏ច្រើនអំពីបទដ្ឋាន និងគុណតម្លៃ ហើយមាននូវការទាក់ទញចិត្ត និងការល្បួងយ៉ាងច្រើនដែលបានដុះស្នឹមក្នុងពិភពលោកបន្តិចម្ដង ៗ ដែលយើងបានមានអារម្មណ៍ថាត្រូវធ្វើការព្រមាន ហើយព្រមានទុកជាមុន ។ បន្ថែមពីលើនេះ យើងជាគណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ ឥឡូវនេះបានចេញនូវសេចក្ដីប្រកាសមួយចំពោះសាសនាចក្រ និងពិភពលោក ជាសេចក្ដីប្រកាស និងការបញ្ជាក់ជាថ្មីអំពីបទដ្ឋាន គោលលទ្ធិ និងការអនុវត្តទាំងឡាយ ដែលទាក់ទងទៅនឹងក្រុមគ្រួសារដែលពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈនៃសាសនាចក្រ បានថ្លែងដដែលៗនៅពេញប្រវត្តិសាសនាចក្រ » («Stand Strong against the Wiles of the World,» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ១០០ ) ។

- ហេតុអ្វីក៏សេចក្ដីប្រកាសនេះត្រូវបានចេញឲ្យដល់សាសនាចក្រផង និងពិភពលោកផងដូច្នេះ ?

សូមពន្យល់ថា នៅពេលយើងសិក្សា « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » យើងអាចទទួលបានចម្លើយចំពោះសំណួរជាច្រើនស្ដីអំពីគ្រួសារ ។ ដើម្បីជួយសិស្សស្គាល់ពីគោលលទ្ធិ ដែលនឹងជួយពួកគេឲ្យយល់កាន់តែច្បាស់បន្ថែមទៀតអំពីប្រធានបទដែលបានរៀបរាប់នៅលើក្ដារខៀន សូមអញ្ជើញសិស្សប្រាំនាក់ឲ្យផ្លាស់វេនគ្នាអានឲ្យឮៗចេញមកពីកថាកណ្ឌ ១–៥ នៃសេចក្ដីប្រកាស ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយស្វែងរកគោលលទ្ធិដែលទាក់ទងនឹងប្រធានបទនៅលើក្ដារខៀន ។ សូមឈប់បន្ទាប់ពីអានមួយកថាកណ្ឌម្ដង ដើម្បីអនុញ្ញាតឲ្យសិស្សរាយការណ៍នូវអ្វីដែលពួកគេបានរកឃើញ ។ សូមអញ្ជើញសិស្សឲ្យគូសចំណាំគោលលទ្ធិ ដែលពួកគេរកឃើញនៅលើសេចក្ដីប្រកាសអំពីក្រុមគ្រួសាររបស់ពួកគេ ។

**សម្របមេរៀននេះដើម្បីបំពេញតាមតម្រូវការរបស់សិស្ស**

មេរៀនភាគច្រើនរួមមានសេចក្ដីពិតជាច្រើននៃព្រះគម្ពីរជាងអ្វីដែលអ្នកអាចបង្រៀនក្នុងពេលដែលអ្នកមាន ។ នៅពេលអ្នកសិក្សាព្រះគម្ពីរ និង កម្មវិធី សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធដើម្បីដឹងថាតើគោលលទ្ធិ និងគោលការណ៍មួយណាដែលសំខាន់បំផុត សម្រាប់សិស្សរបស់អ្នក ដើម្បីរៀន និង ពិភាក្សានៅក្នុងមេរៀននេះ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងជួយអ្នកឲ្យសម្របមេរៀននីមួយៗទៅតាមតម្រូវការរបស់សិស្ស ។

នៅពេលសិស្សរាយការណ៍ សូមអញ្ជើញពួកគេឲ្យសរសេរនៅលើក្ដារខៀនអំពី គោលលទ្ធិដែលពួកគេស្គាល់។ សិស្សអាចប្រាប់ ហើយសរសេរនូវគោលលទ្ធិដូចខាងក្រោម ៖

**អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រីគឺតែងតាំងឡើងដោយព្រះ** កថាកណ្ឌទី ១] ។

**គ្រួសារ គឺជាផ្នែកសំខាន់នៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌**កថាកណ្ឌទី ១]។

**ភេទប្រុសស្រី គឺជាលក្ខណៈពិសេសនៃអត្តសញ្ញាណនិង គោលបំណងសំខាន់មួយនៃបុគ្គលម្នាក់ៗ ចាប់តាំងពីមុនកើតមកជីវិតនេះ ជីវិតរមែងស្លាប់ និង នៅអស់កល្បជានិច្ច** កថាកណ្ឌទី ២]។

**ផែនការនៃសុភមង្គល ធ្វើឲ្យទំនាក់ទំនងក្រុមគ្រួសារចេះតែបន្តរហូតហួសពីសេចក្ដីស្លាប់**កថាកណ្ឌទី ៣]។

**បទបញ្ញត្តិរបស់ព្រះសម្រាប់ប្ដី និង ប្រពន្ធ ដើម្បីបង្កើតកូនចៅឲ្យចម្រើនជាច្រើនឡើងឲ្យមានពាសពេញលើផែនដី នោះនៅតែឲ្យប្រតិបត្តិនៅឡើយ**កថាកណ្ឌទី ៤] ។

**ព្រះបានបញ្ជាឲ្យរក្សា អំណាចដ៏ពិសិដ្ឋនៃការបង្កើតកូនចៅ ប្រើបានសម្រាប់តែរវាងតែបុរសម្នាក់ និងស្ត្រីម្នាក់ ដែលបានរៀបអាពាហ៍ពិពាហ៍យ៉ាងពេញច្បាប់ជាប្ដី និងប្រពន្ធប៉ុណ្ណោះ** [ កថាកណ្ឌទី ៤] ។

**ការបង្កបង្កើតជីវិតរមែងស្លាប់ គឺជាផ្នែកមួយដ៏ពិសិដ្ឋ និងសំខាន់នៃផែនការរបស់ព្រះវរបិតាសួគ៌** [ កថាកណ្ឌទី ៣ និង ៥ ] ។

នៅពេលសិស្សរាយការណ៍គោលលទ្ធិនិមួយៗដែលពួកគេបានស្គាល់ សូមប្រើសំណួរមួយ ឬច្រើនដូចខាងក្រោមដើម្បីសួរតាមដាន ដើម្បីជួយដល់ពួកគេយល់គោលលទ្ធិកាន់តែច្បាស់ ។

- តើគោលលទ្ធិនេះ ទាក់ទងនឹងប្រធានបទដែលបានសរសេរនៅលើក្ដារខៀនយ៉ាងដូចម្ដេច ?
- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីយល់អំពីគោលលទ្ធិនេះ ?
- តើការយល់ដឹង និងការជឿទៅលើគោលលទ្ធិនេះ អាចមានឥទ្ធិពលទៅលើការសម្រេចចិត្តដែលអ្នកធ្វើយ៉ាងដូចម្ដេច ?

បើសិស្សពុំប្រាប់អំពីគោលលទ្ធិណាមួយដែលបានរៀបរាប់ខាងលើទេ សូមជួយពួកគេរកកន្លែងនោះ ហើយពិភាក្សាវា ។

## សេចក្ដីប្រកាសអំពីក្រុមគ្រួសារ ជួយយើងស្ថាបនាក្រុមគ្រួសារដោយជោគជ័យ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីដែលពួកគេចង់ឲ្យក្រុមគ្រួសារនាពេលអនាគតរបស់ពួកគេប្រែក្លាយ ។

- តើសកម្មភាព ចរិតលក្ខណៈ អាកប្បកិរិយា និងជំនឿប្រភេទណា ដែលអ្នកគិតថានឹងនាំសុភមង្គលកើតមានដល់ក្រុមគ្រួសារនាពេលអនាគតរបស់អ្នក ?

សូមបែងចែកសិស្សឲ្យធ្វើការជាក្រុមតូចៗ ។ សូមអញ្ជើញក្រុមនិមួយៗអានកថាកណ្ឌទី ៦–៧ ក្នុងសេចក្ដីប្រកាសអំពីក្រុមគ្រួសារឲ្យឮៗជាមួយគ្នា ។ សូមអញ្ជើញពួកគេឲ្យស្វែងរកអ្វីដែលអាចជួយពួកគេសម្រេចបានសុភមង្គលនៅក្នុងក្រុមគ្រួសាររបស់ពួកគេ ។ បន្ទាប់ពីផ្ដល់ពេលគ្រប់គ្រាន់ហើយ សូមសួរសំណួរដូចខាងក្រោមទៅដល់សិស្សក្នុងថ្នាក់ទាំងមូល ៖

- តើសុភមង្គលនៅក្នុងក្រុមគ្រួសារអាចសម្រេចទៅបានល្អបំផុតយ៉ាងដូចម្ដេច ? (សិស្សគប្បីប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **សុភមង្គលនៅក្នុងជីវិតគ្រួសារអាចសម្រេចទៅបានល្អបំផុត នៅពេលផ្ដោតទៅលើការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ** ។ អ្នកអាចនឹងចង់ផ្ដល់យោបល់ដល់សិស្សឲ្យគូសចំណាំគោលកាណ៍នេះ នៅក្នុងច្បាប់នៃសេចក្ដីប្រកាសអំពីក្រុមគ្រួសាររបស់ពួកគេ ) ។

- ស្របតាមកថាកណ្ឌទី ៦ និង ៧ តើគោលការណ៍មួយចំនួនណាខ្លះ ដែលជួយក្រុមគ្រួសាររកបានសុភមង្គល ? ( សូមពិចារណាធ្វើការអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន ) ។

សូមអញ្ជើញសិស្សឲ្យពិភាក្សាអំពីសំណួរដូចខាងក្រោមជាមួយគ្នានៅក្នុងក្រុមតូច ៗរបស់ពួកគេ ។ សូមផ្ដល់ដល់ក្រុមនីមួយ ៗនូវច្បាប់ចម្លងនៃសំណួរ ឬសរសេរសំណួរនៅលើក្ដារខៀន ។

> *តើគំរូអ្វីខ្លះដែលអ្នកបានមើលឃើញក្រុមគ្រួសារបានធ្វើតាមការបង្រៀនដែលបានសរសេរនៅលើក្ដារខៀន ?*
>
> *ហេតុអ្វីអ្នកគិតថាក្រុមគ្រួសារដែលធ្វើតាមការបង្រៀនទាំងនេះគឺទំនងជាមានភាពសប្បាយរីករាយច្រើនដូច្នេះ ?*

*កំណត់ចំណាំ ៖* ដោយសារតែភាពរំញោច និងលក្ខណៈនៃទំនាក់ទំនងក្រុម គ្រួសារមានភាពផ្សេងគ្នា សូមកុំអញ្ជើញសិស្សដែលពិភាក្សាអំពីសកម្មភាពដូចខាងក្រោមព្ ៗឡើយ ។ តែផ្ទុយទៅវិញ សូមលើកទឹកចិត្តសិស្សឲ្យនឹកគិតទៅលើការបង្រៀនទាំងនេះដោយខ្លួនគេម្នាក់ៗ ហើយពិចារណាអំពីរបៀបដែលពួកគេអាចកែលម្អ ។

បន្ទាប់ពីក្រុមមានពេលពិភាក្សាគ្នាអំពីសំណួរទាំងឡាយហើយ សូមឲ្យសិស្សពិចារណាអំពីការបង្រៀនណាមួយ នៃការបង្រៀនទាំងនេះ ដែលពួកគេរស់នៅតាម ក្នុងក្រុមគ្រួសាររបស់ពួកគេ និងពីរបៀបដែលអាចបន្ថែមសុភមង្គលដល់ក្រុមគ្រួសាររបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យគិតពិចារណាថាតើការបង្រៀនណាមួយ នៅក្នុងសេចក្ដីប្រកាសនេះ ដែល ពួកគេអាចរស់នៅតាមបានល្អប្រសើរ ក្នុងការខិតខំដើម្បីនាំឲ្យមានសុភមង្គលចំពោះពួកគេ និងក្រុមគ្រួសារពួកគេកាន់តែខ្លាំងឡើង ។ អ្នកអាចអញ្ជើញសិស្សឲ្យសរសេរនូវគោលដៅមួយ អំពីរបៀបដែលពួកគេដាក់ផែនការរស់នៅតាមការបង្រៀនទាំងនេះនៅក្នុងក្រុមគ្រួសាររបស់ពួកគេកាន់តែល្អប្រសើរ ។

បើមានពេល សូមជ្រើសរើសសំណួរមួយ ឬច្រើនដូចខាងក្រោម ដើម្បីពិភាក្សាជារួម ៖

- នៅពាក់កណ្ដាលចុងក្រោយនៃកថាកណ្ឌទី ៧ តើការទទួលខុសត្រូវរបស់ឪពុកមានអ្វីខ្លះ ? តើអ្នកបានមើលឃើញឪពុកអ្នក ឬឪពុកដទៃទៀត បានបំពេញតាមការទទួលខុសត្រូវទាំងនេះតាមវិធីណាខ្លះ ?

- នៅពាក់កណ្ដាលចុងក្រោយនៃកថាកណ្ឌ ទី ៧ តើការទទួលខុសត្រូវចម្បងរបស់ម្ដាយមានអ្វីខ្លះ ? តើអ្នកបានមើលឃើញម្ដាយអ្នក ឬម្ដាយដទៃទៀត បានបំពេញតាមតួនាទីនេះតាមវិធីណាខ្លះ ?

- តើទំនួលខុសត្រូវទាំងនេះត្រូវបានផ្ដល់ឲ្យដោយ « បានតែងតាំងឡើងដោយព្រះ » មានន័យយ៉ាងណា ? ( វាត្រូវបានបង្កើតឡើងដោយព្រះវរបិតាសួគ៌របស់យើង ) ។ ហេតុអ្វីក៏អ្នកគិតថា កិច្ចការនេះសំខាន់ដើម្បីយល់ដឹង ?

- តើឃ្លាណាមួយនៅក្នុងកថាកណ្ឌទី ៧ ដែលជួយយើងឲ្យយល់អំពីរបៀបដែលឪពុក និងម្ដាយ គឺត្រូវជួយគ្នាទៅវិញទៅមក ? ( សិស្សគប្បីប្រាប់នូវគោលការណ៍ដូចខាងក្រោម ៖ **ឪពុក និងម្ដាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមក ជាដៃគូស្មើភាពគ្នានៅក្នុងការទទួលខុសត្រូវក្នុងគ្រួសាររបស់ពួកគេ** )។

- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់អ្វីម្ល៉េះ សម្រាប់ម្ដាយ និងឪពុកដើម្បីយល់ថា ពួកគេជាដៃគូស្មើភាពគ្នាដូច្នេះ ?

សូមអញ្ជើញសិស្សឲ្យចែកចាយនូវរបៀបដែលពួកគេបានមើលឃើញម្ដាយ និងឪពុកធ្វើការជាមួយគ្នា ជាដៃគូស្មើភាព ។

នៅពេលសិស្សពិភាក្សាអំពីតម្រូវការចំពោះឪពុក និងម្ដាយដើម្បីគាំទ្រដល់គ្នាទៅវិញទៅមក នោះអ្នកអាចនឹងចង់បង្វែរចំណាប់អារម្មណ៍របស់ពួកគេ ទៅយកចិត្តទុកដាក់លើប្រយោគដូចខាងក្រោមនៅជិតចុងបញ្ចប់កថាកណ្ឌទី ៧ ៖ « អសមត្ថភាព មរណភាព ឬកាលៈទេសៈផ្សេង ៗទៀត អាចនឹងត្រូវសម្របទៅតាមស្ថានភាពចាំបាច់របស់បុគ្គលម្នាក់ៗ » ។ សូមអះអាងនឹងសិស្សថា ព្រះអម្ចាស់បានញាណដឹងអំពីស្ថានភាពទាំងនេះ ហើយថាទ្រង់ប្រទានពរដល់ឪពុកម្ដាយ និងក្រុមគ្រួសារ នៅពេលពួកគេខិតខំបំពេញតាមកាតព្វកិច្ចរបស់ពួកគេ ។

- ស្របតាមប្រយោគចុងក្រោយនៃកថាកណ្ឌទី ៧ តើមាននរណាផ្សេងទៀត អាចជួយដល់ម្ដាយ និងឪពុកនៅក្នុងទំនួលខុសត្រូវរបស់ពួកគេ ? ( សាច់ញាតិក្រុមគ្រួសារ។ អ្នកអាចចង្អុលបង្ហាញថា កូន ៗក៏អាចជួយឪពុកម្ដាយរបស់ពួកគេផងដែរ ។)

សូមពន្យល់ថាគ្រប់គ្រួសារ មានភាពលំបាករៀង ៗខ្លួន ប៉ុន្ដែគ្រួសារទាំងនោះ អាចរស់នៅតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយស្វែងរកសុភមង្គលបាន ។

សូមអញ្ជើញសិស្សម្នាក់អានកថាខណ្ឌទី ៨ និង ៩ អំពីសេចក្តីប្រកាសក្រុមគ្រួសារឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្វែងរកនូវអ្វីដែលនឹងកើតឡើង បើសិនជាយើងពុំបំពេញតាមទំនួលខុសត្រូវរបស់យើងនៅក្នុងក្រុមគ្រួសារយើងនោះ ។

- តើអ្វីខ្លះនឹងកើតឡើង បើយើងបដិសេធទំនួលខុសត្រូវក្នុងគ្រួសាររបស់យើង ? (សិស្សគប្បីបង្ហាញអារម្មណ៍ថា **ព្រះអម្ចាស់នឹងធ្វើឲ្យយើងទទួលខុសត្រូវ បើយើងពុំបំពេញតាមទំនួលខុសត្រូវរបស់យើងនៅក្នុងក្រុមគ្រួសារនោះទេ ។** ពួកគេអាចចង្អុលបង្ហាញផងដែរថា ការបែកបាក់ក្រុមគ្រួសារ នឹងនាំទៅរកគ្រោះមហន្តរាយ ) ។
- តើទំនួលខុសត្រូវអ្វីខ្លះ ដែលអ្នកគិតថា កូនចៅមាននៅក្នុងគ្រួសារ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេបំពេញទំនួលខុសត្រូវរបស់ពួកគេ នៅក្នុងក្រុមគ្រួសារ ។ បើអ្នកអញ្ជើញពួកគេឲ្យកត់ត្រាគោលដៅមួយ ដើម្បីរស់នៅឲ្យកាន់តែល្អប្រសើរ តាមការបង្រៀនមកពីសេចក្តីប្រកាសអំពីក្រុមគ្រួសារ នៅក្នុងក្រុមគ្រួសាររបស់ពួកគេ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកជំនួយរបស់ព្រះអម្ចាស់ នៅពេលពួកគេព្យាយាមដើម្បីសម្រេចគោលដៅរបស់ពួកគេ ។

សូមបញ្ចប់ដោយការសុំឲ្យសិស្សពីរបីនាក់ចែកចាយទីបន្ទាល់របស់ពួកគេ អំពីសេចក្តីពិតណាក៏ដោយ ដែលត្រូវបានបង្រៀននៅក្នុងមេរៀននេះ ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកផងដែរអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅក្នុងសេចក្តីប្រកាសអំពីក្រុមគ្រួសារ ។

មេរៀនទី ១៦០

# ព្យាការីនៅរស់

## បុព្វកថា

សមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានប្រទានពរដែលត្រូវបានដឹកនាំដោយព្យាការីនៅរស់ ជាអ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។ នៅជំនាន់បុរាណ ពួកព្យាការី ត្រូវបានជ្រើសរើសដោយព្រះអម្ចាស់ និងបានអនុញ្ញាតឲ្យនិយាយជំនួសទ្រង់ ។ ដូចគ្នានេះដែរ នៅជំនាន់របស់យើង ពាក្យសម្ដីរបស់ព្យាការីនៅរស់ តំណាងឲ្យសំឡេងរបស់ព្រះអម្ចាស់មកកាន់យើង និងទៅកាន់ពិភពលោក ( សូមមើល គ. និង ស. ១:៣៧–៣៨) ។ នៅក្នុងមេរៀននេះ សិស្សនឹងសិក្សាពីដំបូន្មានថ្មីៗមកពីប្រធានសាសនាចក្រ ជាព្យាការីដ៏ជ្រើសរើសរបស់ព្រះអម្ចាស់ ។

## យោបល់សម្រាប់ការបង្រៀន

### ការបន្តមានវិវរណៈតាមរយៈព្យាការីនៅរស់

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្ដារខៀន ៖ *តើនរណាជាព្យាការីសំខាន់បំផុតចំពោះអ្នក ?*

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យពិចារណាសំណួរនេះ ហើយស្ដាប់មើលចម្លើយ នៅពេលពួកគេអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន ។



« ព្យាការីសំខាន់បំផុតចំពោះយើងរាល់គ្នាក្នុងពេលនេះនោះគឺជាព្យាការីម្នាក់ដែលកំពុងតែនៅរស់ក្នុងសម័យ និង ជំនាន់របស់យើងនេះឯង » (Jesus Christ—Gifts and Expectations » *New Era*, ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១៧ ) ។

- ហេតុអ្វីអ្នកគិតថាព្យាការីនៅរស់ គឺជាព្យាការីសំខាន់បំផុតសម្រាប់យើង ?

បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមបន្តអានសេចក្ដីថ្លែងការណ៍របស់ប្រធានបែនសឹន ៖



« នេះគឺជាព្យាការីដែលមាននូវសេចក្ដីណែនាំនាសម័យនេះ ពីព្រះសម្រាប់យើង ។. . . គ្រប់ជំនាន់មានតម្រូវការចាំបាច់នូវបទគម្ពីរពីបុរាណ បូករួមទាំងគម្ពីរបច្ចុប្បន្នកាលមកពីព្យាការីនៅរស់ ។ ហេតុដូច្នោះហើយ ការអាន និងការពិចារណាដ៏សំខាន់បំផុតដែលអ្នកគប្បីធ្វើ នោះគឺពាក្យពេចន៍ដ៏បំផុសគំនិតថ្មីៗបំផុតមកពីមាត់នៃអ្នកនាំពាក្យរបស់ព្រះអម្ចាស់ ។ នោះហើយជាមូលហេតុចាំបាច់ដែលអ្នកមានសិទ្ធិ និង អានដោយយកចិត្តទុកដាក់នូវពាក្យរបស់លោក នៅក្នុងទស្សនាវដ្ដីប្រចាំខែរបស់សាសនាចក្រ » (Jesus Christ—Gifts and Expectations » ទំព័រ ១៧ ) ។

សូមពន្យល់ថា យើងគាំទ្រសមាជិកទាំងអស់នៃគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ ប៉ុន្តែ ប្រធានសាសនាចក្រគឺជាបុគ្គលតែម្នាក់គត់ដែលមានសិទ្ធិអំណាច ដើម្បីអនុវត្តកូនសោបព្វជិតភាពទាំងអស់នៅលើផែនដីនេះ ហើយជាបុគ្គលតែម្នាក់គត់ដែលមានសិទ្ធិអំណាចដើម្បីទទួល និង ប្រកាសវិវរណៈសម្រាប់សាសនាចក្រទាំងមូល ។

- យោងតាមអ្វីដែលបានរៀននៅក្នុងមេរៀនថ្មីៗនេះ តើពេលណាដែលប្រធានសាសនាចក្របានប្រកាសវិវរណៈសម្រាប់សាសនាចក្រទាំងមូល ឬ ប្រកាសពីការផ្លាស់ប្ដូរពិសេសៗនៅក្នុងដំណើរការនានានៃសាសនាចក្រ ? ( ចម្លើយអាចរួមមាន ប្រធាន វិលហ្វូឌ វ៉ូឌ្រុព្វ បានចេញនូវគោលនយោបាយស្ដីអំពីអាពាហ៍ពិពាហ៍ពហុពន្ធភាព [ សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ១]  នៅពេលប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានប្រកាសកាលពីមុនអំពីសេចក្ដីពិតដែលពុំបានដឹងពីមុនមកអំពីពិភពវិញ្ញាណក្រោយជីវិតរមែងស្លាប់ [សូមមើល គ. និង ស. ១៣៨]  និងនៅពេលដែលប្រធាន ស្ពេនស៊ើរ ដបុលយូ឵ យីមប៊ឹល បានប្រកាសថា ពរជ័យនៃបព្វជិតភាព ត្រូវបានធ្វើឡើងឲ្យមានសម្រាប់សមាជិកសក្តិសមទាំងអស់នៃសាសនាចក្រ [សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ២]) ។

សូមអញ្ជើញសិស្សម្នាក់អានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្ដាប់មើលសេចក្ដីពិតមួយ ស្ដីអំពីវិវរណៈនៅក្នុងជំនាន់របស់យើង ។



« សារដំណឹងដ៏រុងរឿងមួយនៃការស្ដារឡើងវិញនូវសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺថា ព្រះទ្រង់បន្តមានបន្ទូលមកកាន់កូនចៅរបស់ទ្រង់ ! ទ្រង់មិនលាក់ទុកនៅក្នុងស្ថានសួគ៌ឡើយ ប៉ុន្តែមានព្រះបន្ទូលនៅសម័យនេះដូចដែលទ្រង់បានធ្វើនៅក្នុងសម័យបុរាណដែរ ។

« ដំបូន្មានដែលមិនអាចកាត់ថ្លៃបានរបស់ព្រះចំពោះមនុស្សលោកគឺ ត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមនគោលលទ្ធិ និង សេចក្ដីសញ្ញា និង មុក្ដាដ៏មានតម្លៃមហិមា ។ ជាងនោះទៀត ព្រះអម្ចាស់មានបន្ទូលតាមរយៈអ្នកបម្រើទាំងឡាយរបស់ទ្រង់ ដូចដែលទ្រង់នឹងធ្វើម្ដងទៀតនៅឯ. . . សន្និសីទទូទៅ » (« Why Do We Need Prophets ? » *Ensign*, ខែ មិនា ឆ្នាំ ២០១២ ទំព័រ ៤ ) ។

- តើគោលលទ្ធិអ្វីខ្លះ ស្ដីអំពីវិវរណៈដែលប្រធាន អុជដូហ្វ បង្រៀនដល់យើង ? ( សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរប្រាប់អ្វីស្រដៀងគ្នាទៅនឹងសេចក្ដីថ្លែងការណ៍ខាងគោលលទ្ធិដូចខាងក្រោម ៖ **ព្រះអម្ចាស់បន្តមានបន្ទូលមកកាន់យើងនៅសព្វថ្ងៃនេះ តាមរយៈព្យាការីនៅរស់របស់ទ្រង់ ។** អ្នកអាចនឹងចង់សរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។
- តើយើងអាចស្វែងរកពាក្យសម្ដីរបស់ពួកព្យាការីនៅរស់នៅទីណា ? ( ចម្លើយអាចរួមមានសន្និសីទទូទៅ ទស្សនាវដ្ដីនៃសាសនាចក្រ គេហទំព័រ LDS.org និង mormonchannel.org) ។

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់ ដែលព្រះអម្ចាស់បន្តមានបន្ទូលមកកាន់ព្យាការីនៅរស់របស់ទ្រង់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន យ៉ូហាន ថេលើរ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមូលហេតុដែលវិវរណៈបន្តមានតាមរយៈព្យាការីនោះសំខាន់អ្វីម្ល៉េះ ។



« យើងតម្រូវឲ្យមានដើមឈើដែលមានជីវិត—ប្រភពទឹករស់—បញ្ញាដែលរស់រវើក ដែលចេញមកពីបព្វជិតភាពដែលកំពុងមានជីវិតនៅឋានសួគ៌ តាមរយៈបព្វជិតភាពដែលកំពុងនៅរស់នៅលើផែនដីនេះ ។. . . ហើយចាប់តាំងពីពេលដែលអ័ដាមបានទទួលទំនាក់ទំនងដំបូងជាមួយព្រះ . . . វាត្រូវបានតម្រូវឲ្យមានវិវរណៈថ្មីៗ សមស្របទៅនឹងកាលៈទេសៈពិសេសៗនេះដែលសាសនាចក្រ ឬ បុគ្គលម្នាក់ៗត្រូវបានដាក់ឲ្យរស់នៅនោះ ។ វិវរណៈរបស់អ័ដាមពុំបានណែនាំណូអេឲ្យសង់សំពៅទេ ហើយវិវរណៈរបស់ណូអេ ពុំបានប្រាប់ឡុតឲ្យបោះបង់ចោលទីក្រុងសូដុំមដែរ ហើយវិវរណៈទាំងនេះក៏ពុំបាននិយាយអំពីការធ្វើដំណើររបស់កូនចៅអ៊ីស្រាអែលឲ្យចាកចេញពីអេស៊ីព្ទដែរ » ( នៅក្នុង *The Gospel Kingdom* ជ្រើសរើសចេញដោយ G. Homer Durham [ ឆ្នាំ ១៩៨៧ ] ទំព័រ ៣៤ ) ។

- យោងតាមប្រធានថេលើរហេតុអ្វីយើងត្រូវការព្យាការីនៅរស់ ? ( តាមរយៈព្យាការីនៅរស់ នោះព្រះបានប្រទានការណែនាំជាក់លាក់ចំពោះសេចក្ដីត្រូវការ និង កាលៈទេសៈតាមកាលវេលា ) ។
- តើការយល់ដឹងពីភាពចាំបាច់នៃការបន្តមានវិវរណៈ អាចជះឥទ្ធិពលលើរបៀបដែលអ្នកស្ដាប់ ឬ អានប្រសាសន៍របស់ព្យាការីនៅរស់យ៉ាងដូចម្ដេច ?

## ធ្វើតាមការទូន្មានរបស់ព្យាការីនៅរស់

ដើម្បីជួយសិស្សឲ្យពិភាក្សាគ្នាពីការទូន្មានរបស់ព្យាការីនៅរស់ សូមជ្រើសរើសយកសុន្ទរកថាសន្និសីទទូទៅមួយ ឬ ច្រើនជាងនេះដែលបានផ្ដល់ឲ្យដោយប្រធានសាសនាចក្រកាលពីឆ្នាំមុន ។ សូមផ្ដល់ច្បាប់ចម្លងនៃសុន្ទរកថានោះទៅសិស្សម្នាក់មួយច្បាប់ ។ សូមទុកពេលឲ្យសិស្សស្វែងរកគោលលទ្ធិ និង គោលការណ៍ដែលព្យាការីនៅរស់កំពុងបង្រៀនបច្ចុប្បន្ននេះ ។

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីអានហើយ សូមឲ្យពួកគេធ្វើជាបញ្ជីគោលលទ្ធិ និង គោលការណ៍ដែលប្រធានសាសនាចក្រកំពុងបង្រៀន ។ សូមគិតពីការអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។

ដើម្បីជួយសិស្សយល់ និង ដឹងពីសារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍ទាំងនេះដែលពួកគេបានរកឃើញ សូមសួរសំណួរមួយចំនួន ឬ ទាំងអស់ដូចខាងក្រោម ៖

- តើគោលការណ៍ ឬ គោលលទ្ធិណាមួយដែលអ្នកទទួលអារម្មណ៍ថាវាទាក់ទងយ៉ាងពិសេសជាមួយនឹងអ្នក ? ហេតុអ្វី ?
- តើអ្នក និង គ្រួសាររបស់អ្នកកំពុងព្យាយាមធ្វើតាមការទូន្មានរបស់ព្យាការីតាមរបៀបណាខ្លះ ?
- ហេតុអ្វីអ្នកគិតថាវាសំខាន់ ដែលយើងត្រូវសិក្សា ហើយអនុវត្តនូវអ្វីដែលប្រធានសាសនាចក្របច្ចុប្បន្ននេះកំពុងបង្រៀន ?

សូមសរសេរ សំណួរខាងក្រោម នៅលើក្ដារខៀន ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬ កំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

> *ចេញពីប្រសាសន៍របស់ព្យាការីនៅរស់ដែលអ្នកទើបតែបានសិក្សា តើសារលិខិតអ្វីដែលអ្នកទទួលអារម្មណ៍ថាព្រះអម្ចាស់ចង់ឲ្យអ្នកទទួលនោះ ?*
>
> *តើអ្នកនឹងធ្វើអ្វីខ្លះតាមរយៈការទូន្មានថ្មីៗនេះរបស់ព្យាការី ?*

សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។ សូមថ្លែងទីបន្ទាល់ថានៅពេលពួកគេធ្វើដូច្នេះ នោះពួកគេអាចមានទំនុកចិត្តថាព្រះវរបិតាសួគ៌នឹងប្រទានពរដល់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យបន្តសិក្សា និង អនុវត្តការបង្រៀននានារបស់ព្យាការីនៅរស់ឲ្យបានជាប់លាប់ ។

សូមអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្យាការីនៅរស់ ។

នៅពេលបញ្ចប់ថ្នាក់សិក្ខាសាលាឆ្នាំសិក្សានេះ សូមលើកទឹកចិត្តសិស្សឲ្យបន្តសិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ ។ បើពួកគេនឹងចូលរៀនថ្នាក់សិក្ខាសាលាវគ្គក្រោយទៀត អ្នកអាចនឹងផ្ដល់យោបល់ថា ពួកគេចាប់ផ្ដើមការសិក្សាព្រះគម្ពីរសញ្ញាចាស់ ។ អ្នកអាចនឹងអញ្ជើញសិស្សម្នាក់ឲ្យថ្លែងទីបន្ទាល់អំពីពរជ័យដែលគាត់បានទទួលដោយ  បន្តការអានព្រះគម្ពីរប្រចាំថ្ងៃ ទោះជាពេលដែលថ្នាក់សិក្ខាសាលាពុំមានក្នុងរដូវកាលនោះក្ដី ។

### *ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ*

មានកិច្ចការមួយចំនួន ដែលគ្រូបង្រៀនអាចធ្វើ ដែលនឹងកាន់តែមានអំណាចនិងឥទ្ធិពលដ៏យូរអង្វែងបន្ថែមទៀតសម្រាប់ជាសេចក្ដីល្អនៅក្នុងជីវិតសិស្សទាំងឡាយរបស់ពួកគាត់ជាងនោះ គឺការជួយពួកគេឲ្យរៀនស្រឡាញ់ព្រះគម្ពីរ ហើយសិក្សាពីវាជារៀងរាល់ថ្ងៃ ។ អ្នកអាចលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃតាមរយៈការអញ្ជើញសិស្សឲ្យអានគម្ពីរដោយខ្ជាប់ខ្ជួន របស់ពួកគេ ទោះជាពេលដែលគ្មានថ្នាក់សិក្ខាសាលាក្ដី ។

មេរៀនសិក្សានៅផ្ទះ

# កម្មវិធី និង អង្គការសាសនាចក្រ សេចក្ដីប្រកាសជាផ្លូវការទី ២, ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ, ការប្រកាសអំពីក្រុមគ្រួសារ និង ព្យាការីនៅរស់ ( មេរៀនទី ៣២ )

## ការរៀបចំមេរៀនសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

*សេចក្ដីសង្ខេបមេរៀនសម្រាប់សិស្សសិក្សានៅផ្ទះប្រចាំថ្ងៃ*

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃគោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សាមេរៀនទី ៣២ ។ សេចក្ដីសង្ខេបនេះមិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនសម្រាប់មេរៀនទី ៣២ផ្ដោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

### ថ្ងៃទី ១ ( កម្មវិធី និង អង្គការសាសនាចក្រ )

នៅក្នុងមេរៀននេះ សិស្សបានរៀនថាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជួយព្រះវរបិតាសួគ៌ដើម្បីនាំឲ្យមានជីវិតដ៏នៅអស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់ ។ ពួកគេក៏បានរៀនផងដែរថា កម្មវិធី និង អង្គការសាសនាចក្រទាំងអស់ដំណើរការក្រោមការដឹកនាំនៃថ្នាក់ដឹកនាំបព្វជិតភាព ដែលកាន់កូនសោដើម្បីធ្វើជាអធិបតី ។ សិស្សបានរកឃើញថានៅពេលយើងចូលរួមនៅក្នុងកម្មវិធី និង អង្គការសាសនាចក្រ នោះយើងទទួលពរជ័យទាំងឡាយដែលមានតាមរយៈពួកលោក ។ បន្ទាប់មកពួកគេដាក់គោលដៅ ដើម្បីកែលម្អការចូលរួមនៅក្នុងអង្គការជំនួយ និង កម្មវិធីនានានៃសាសនាចក្រ ។

### ថ្ងៃទី ២ (សេចក្ដីប្រកាសជាផ្លូវការទី ២)

នៅពេលសិស្សបានរៀនអំពីវិវរណៈឆ្នាំ ១៩៨៧ដែលបានផ្ដល់បព្វជិតភាព និង ពរជ័យនៃព្រះវិហារបរិសុទ្ធដល់សមាជិកសក្ដិសមគ្រប់រូបនៃសាសចក្រ នោះពួកគេបានរៀនថាព្យាការីស្វែងរកការដឹកនាំរបស់ព្រះអម្ចាស់ក្នុងការដឹកនាំសាសនាចក្រ ហើយថាព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់តាមរយៈវិវរណៈទៅកាន់ព្យាការីរបស់ទ្រង់នៅក្នុងពេលកំណត់របស់ទ្រង់ ។

### ថ្ងៃទី ៣ ( ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ )

ចេញពីមេរៀននេះ សិស្សបានរៀនថាព្រះអម្ចាស់កំពុងពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ ។ ពួកគេក៏បានរៀនផងដែរថា ពួកគេអាចចូលរួមនៅក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ តាមរយៈការចែកចាយដំណឹងល្អ ការសិក្សាព្រះគម្ពីរ និង ការធ្វើកិច្ចការព្រះវិហារបរិសុទ្ធ និង កិច្ចការពង្សប្រវត្តិ ។

### ថ្ងៃទី ៤ ( ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក )

នៅក្នុងមេរៀននេះសិស្សបានរកឃើញគោលលទ្ធិ និង គោលការណ៍នានាដែលទាក់ទងនឹងគ្រួសារ ដូចខាងក្រោមនេះ ៖
អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រីត្រូវបានតែងតាំងដោយព្រះ ការបង្កបង្កើតនៃជីវិតរមែងស្លាប់គឺពិសិដ្ឋ ហើយជាផ្នែកសំខាន់នៃផែនការរបស់ព្រះវរបិតាសួគ៌ ហើយឪពុក និង ម្ដាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូស្មើគ្នានៅក្នុងទំនួលខុសត្រូវនៃក្រុមគ្រួសាររបស់ពួកគេ ។ សិស្សក៏បានរៀនផងដែរថា ព្រះអម្ចាស់នឹងឲ្យយើងទទួលខុសត្រូវប្រសិនបើយើងពុំបំពេញទំនួលខុសត្រូវរបស់យើងនៅក្នុងគ្រួសារយើងនោះទេ ។

## សេចក្ដីផ្ដើម

មេរៀននេះអាចជួយសិស្សឲ្យយល់ពីពរជ័យនៃការត្រូវបានដឹកនាំដោយព្យាការីអ្នកមើលឆុត និង អ្នកទទួលវិវរណៈដែលនៅរស់ ។ សិស្សនឹងសិក្សាការទូន្មានថ្មីៗពីប្រធានសាសនាចក្រ ដែលជាព្យាការីជម្រើសរបស់ព្រះអម្ចាស់ ។

## យោបល់សម្រាប់ការបង្រៀន

### វិវរណៈមានមកជាបន្ដបន្ទាប់តាមរយៈព្យាការីនៅរស់

សូមសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន ៖ *តើនរណាគឺជាព្យាការីសំខាន់បំផុតសម្រាប់អ្នក?*

សូមឲ្យសិស្សពិចារណាពីសំណួរនេះ ហើយស្ដាប់រកចម្លើយនៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន ៖



« ព្យាការីសំខាន់បំផុតចំពោះយើងរាល់គ្នាក្នុងពេលនេះនោះគឺជាព្យាការីម្នាក់ដែលកំពុងតែនៅរស់ក្នុងសម័យ និង ជំនាន់របស់យើងនេះឯង » (« Jesus Christ—Gifts and Expectations » *New Era*, ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១៧ ) ។

- ហេតុអ្វីអ្នកគិតថាព្យាការីនៅរស់ គឺជាព្យាការីសំខាន់បំផុតសម្រាប់យើង ?

បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមបន្ដអានសេចក្ដីថ្លែងការណ៍របស់ប្រធានបែនសឹន ៖



« នេះគឺជាព្យាការីដែលមាននូវសេចក្ដីណែនាំនាសម័យនេះ ពីព្រះសម្រាប់យើង ។. . . គ្រប់ជំនាន់មានតម្រូវការចាំបាច់នូវបទគម្ពីរពីបុរាណ បូករួមទាំងគម្ពីរបច្ចុប្បន្នកាលមកពីព្យាការីនៅរស់ ។ ហេតុដូច្នោះហើយ ការអាន និងការពិចារណាដ៏សំខាន់បំផុតដែលអ្នកគប្បីធ្វើ នោះគឺពាក្យពេចន៍ដ៏បំផុសគំនិតថ្មីៗបំផុតមកពីមាត់នៃអ្នកនាំពាក្យរបស់ព្រះអម្ចាស់ ។ នោះហើយជាមូលហេតុចាំបាច់ដែលអ្នកមានសិទ្ធិ និង អានដោយយកចិត្តទុកដាក់នូវពាក្យរបស់លោក នៅក្នុងទស្សនាវដ្ដីប្រចាំខែរបស់សាសនាចក្រ » (« Jesus Christ—Gifts and Expectations » ទំព័រ ១៧ ) ។

សូមពន្យល់ថា យើងគាំទ្រសមាជិកទាំងអស់នៃគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ ប៉ុន្តែ ប្រធានសាសនាចក្រគឺជាបុគ្គលតែម្នាក់គត់ដែលមានសិទ្ធិអំណាច ដើម្បីអនុវត្តកូនសោបព្វជិតភាពទាំងអស់នៅលើផែនដីនេះ ហើយជាបុគ្គលតែម្នាក់គត់ដែលមានសិទ្ធិអំណាចដើម្បីទទួល និង ប្រកាសវិវរណៈសម្រាប់សាសនាចក្រទាំងមូល ។

- យោងតាមអ្វីដែលបានរៀននៅក្នុងមេរៀនថ្មីៗនេះ តើពេលណាដែលប្រធានសាសនាចក្របានប្រកាសវិវរណៈសម្រាប់សាសនាចក្រទាំងមូល ឬ ប្រកាសពីការផ្លាស់ប្ដូរពិសេសៗនៅក្នុងដំណើរការនានានៃសាសនាចក្រ ? ( ចម្លើយអាចរួមមាននៅពេលប្រធាន វិលហ្វឺដ វូឌ្រុហ្វ បានចេញសេចក្ដីប្រកាសទាក់ទងនឹងអាពាហ៍ពិពាហ៍ពហុពន្ធភាព [ សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ១] នៅពេលប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានប្រកាសពីសេចក្ដីពិតដែលពុំដឹងពីមុនអំពីស្ថានភាពជីវិតពិភពវិញ្ញាណ [ សូមមើល គ. និង ស. ១៣៨] ហើយនៅពេលប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល បានប្រកាសថាពរជ័យនៃបព្វជិតភាពមានដល់សមាជិកសក្ដិសមគ្រប់រូបនៃសាសនាចក្រ [ សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ២] ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្ដាប់ រកមើលសេចក្ដីពិតទាក់ទងនឹងវិវរណៈនៅក្នុងសម័យបច្ចុប្បន្នរបស់យើង ។



« សារដំណឹងដ៏រុងរឿងមួយនៃការស្ដារឡើងវិញនូវសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺថា ព្រះទ្រង់បន្តមានបន្ទូលមកកាន់កូនចៅរបស់ទ្រង់ ! ទ្រង់មិនលាក់ទុកនៅក្នុងស្ថានសួគ៌ឡើយ ប៉ុន្តែមានព្រះបន្ទូលនៅសម័យនេះដូចដែលទ្រង់បានធ្វើនៅក្នុងសម័យបុរាណដែរ ។. . .

« ដំបូន្មានដែលមិនអាចកាត់ថ្លៃបានរបស់ព្រះចំពោះមនុស្សលោកគឺ ត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមនគោលលទ្ធិ និង សេចក្ដីសញ្ញា និង មុក្ដាដ៏មានតម្លៃមហិមា ។ ជាងនោះទៀត ព្រះអម្ចាស់មានបន្ទូលតាមរយៈអ្នកបម្រើទាំងឡាយរបស់ទ្រង់ ដូចដែលទ្រង់នឹងធ្វើម្ដងទៀតនៅឯ. . . សន្និសីទទូទៅ » (« Why Do We Need Prophets ? » *Ensign,* ខែ មិនា ឆ្នាំ ២០១២ ទំព័រ ៤ ) ។

- តើគោលលទ្ធិអ្វីខ្លះទាក់ទងនឹងវិវរណៈដែលប្រធាន អុជដូហ្វបានបង្រៀន ? ( សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែរកឃើញគោលលទ្ធិដូចខាងក្រោមនេះ ៖ **ព្រះអម្ចាស់បន្តមានបន្ទូលមកកាន់ពួកយើងសព្វថ្ងៃនេះ តាមរយៈព្យាការីនៅរស់របស់ទ្រង់ ។** អ្នកអាចសរសេរគោលលទ្ធិនេះនៅលើក្ដារខៀន ) ។
- តើយើងអាចស្វែងរកពាក្យសម្ដីរបស់ពួកព្យាការីនៅរស់នៅទីណា ? ( ចម្លើយអាចរួមមានសន្និសីទទូទៅ ទស្សនាវដ្ដីនៃសាសនាចក្រ គេហទំព័រ, LDS.org និង mormonchannel.org) ។

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់ ដែលព្រះអម្ចាស់បន្តមានបន្ទូលមកកាន់ព្យាការីនៅរស់របស់ទ្រង់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន យ៉ូហាន ថេលើរ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្ដាប់រកមូលហេតុដែលវិវរណៈបន្តមានតាមរយៈព្យាការីនោះសំខាន់អ្វីម្ល៉េះ ។



« យើងតម្រូវឲ្យមានដើមឈើដែលមានជីវិត—ប្រភពទឹករស់—បញ្ញាដែលរស់រវើក ដែលចេញមកពីបព្វជិតភាពដែលកំពុងមានជីវិតនៅឋានសួគ៌ តាមរយៈបព្វជិតភាពដែលកំពុងនៅរស់នៅលើផែនដីនេះ ។. . . ហើយចាប់តាំងពីពេលដែលអ័ដាមបានទទួលទំនាក់ទំនងដំបូងជាមួយព្រះ . . . វាត្រូវបានតម្រូវឲ្យមានវិវរណៈថ្មីៗ សមស្របទៅនឹងកាលៈទេសៈពិសេសៗនេះដែលសាសនាចក្រ ឬ បុគ្គលម្នាក់ៗត្រូវបានដាក់ឲ្យរស់នៅនោះ ។ វិវរណៈរបស់អ័ដាមពុំបានបង្គាប់ឲ្យ ណូអេសង់ទូករបស់គាត់ឡើយ ហើយវិវរណៈរបស់ណូអេក៏ពុំបានប្រាប់ឲ្យឡុតបោះបង់ចោលក្រុងសូដុំមឡើយ រីឯពាក្យសម្ដីទាំងនេះក៏ពុំបាននិយាយអំពីការចាកចេញរបស់កូនចៅអ៊ីស្រាអែលពីស្រុងអេស៊ីពដែរ » ( នៅក្នុង *The Gospel Kingdom,* sel. G. Homer Durham [ ឆ្នាំ ១៩៨៧ ] ទំព័រ ៣៤ សូមមើលផងដែរ គ. និង ស. ១:៣០) ។

- យោងតាមប្រធានថេលើរហេតុអ្វីយើងត្រូវការព្យាការីនៅរស់ ? ( តាមរយៈព្យាការីនៅរស់ នោះព្រះបានប្រទានការណែនាំជាក់លាក់ចំពោះសេចក្ដីត្រូវការ និង កាលៈទេសៈតាមកាលវេលា ) ។
- តើការយល់ដឹងពីភាពចាំបាច់នៃការបន្តមានវិវរណៈ អាចជះឥទ្ធិពលលើរបៀបដែលអ្នកស្ដាប់ ឬ អានប្រសាសន៍របស់ព្យាការីនៅរស់យ៉ាងដូចម្ដេច ?

## ធ្វើតាមការទូន្មានរបស់ព្យាការីនៅរស់

ដើម្បីជួយសិស្សឲ្យពិភាក្សាគ្នាពីការទូន្មានរបស់ព្យាការីនៅរស់ សូមជ្រើសរើសយកសុន្ទរកថាសន្និសីទទូទៅមួយ ឬ ច្រើនជាងនេះដែលបានផ្ដល់ឲ្យដោយប្រធានសាសនាចក្រកាលពីឆ្នាំមុន ។ សូមផ្ដល់ច្បាប់ចម្លងនៃសុន្ទរកថានោះទៅសិស្សម្នាក់មួយច្បាប់ ។ សូមទុកពេលឲ្យសិស្សស្វែងរកគោលលទ្ធិ និង គោលការណ៍ដែលព្យាការីនៅរស់កំពុងបង្រៀនបច្ចុប្បន្ននេះ ។

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីអានហើយ សូមឲ្យពួកគេធ្វើជាបញ្ជីគោលលទ្ធិ និង គោលការណ៍ដែលប្រធានសាសនាចក្រកំពុងបង្រៀន ។ សូមគិតពីការអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន ។

ដើម្បីជួយសិស្សយល់ និង ដឹងពីសារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍ទាំងនេះដែលពួកគេបានរកឃើញ សូមសួរសំណួរមួយចំនួន ឬ ទាំងអស់ដូចខាងក្រោម ៖

- តើគោលការណ៍ ឬ គោលលទ្ធិណាមួយដែលអ្នកទទួលអារម្មណ៍ថាវាទាក់ទងយ៉ាងពិសេសជាមួយនឹងអ្នក ? ហេតុអ្វី ?
- តើអ្នក និង គ្រួសាររបស់អ្នកកំពុងព្យាយាមធ្វើតាមការទូន្មានរបស់ព្យាការីតាមរបៀបណាខ្លះ ?
- ហេតុអ្វីអ្នកគិតថាវាសំខាន់ ដែលយើងត្រូវសិក្សា ហើយអនុវត្តនូវអ្វីដែលប្រធានសាសនាចក្របច្ចុប្បន្ននេះកំពុងបង្រៀន ?

សូមសរសេរ សំណួរខាងក្រោម នៅលើក្ដារខៀន ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬ កំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

> *ចេញពីប្រសាសន៍របស់ព្យាការីនៅរស់ដែលអ្នកទើបតែបានសិក្សា តើសារលិខិតអ្វីដែលអ្នកទទួលអារម្មណ៍ថាព្រះអម្ចាស់ចង់ឲ្យអ្នកទទួលនោះ ?*
> *តើអ្នកនឹងធ្វើអ្វីខ្លះតាមរយៈការទូន្មានថ្មីៗនេះរបស់ព្យាការី ?*

សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។ សូមថ្លែងទីបន្ទាល់ថានៅពេលពួកគេធ្វើដូច្នេះ នោះពួកគេអាចមានទំនុកចិត្តថាព្រះវរបិតាសួគ៌នឹងប្រទានពរដល់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យបន្តសិក្សា និង អនុវត្តការបង្រៀននានារបស់ព្យាការីនៅរស់ឲ្យបានជាប់លាប់ ។

សូមអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្យាការីនៅរស់ ។

នៅពេលបញ្ចប់ថ្នាក់សិក្ខាសាលាឆ្នាំសិក្សានេះ សូមលើកទឹកចិត្តសិស្សឲ្យបន្តសិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ ។ ប្រសិនបើពួកគេនឹងរៀនវគ្គសិក្សាថ្នាក់សិក្ខាសាលាឆ្នាំក្រោយទៀត អ្នកអាចផ្ដល់យោបល់ឲ្យពួកគេចាប់ផ្ដើមសិក្សាព្រះគម្ពីរសញ្ញាចាស់ ។ អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យថ្លែងទីបន្ទាល់អំពីពរជ័យដែលគាត់បានទទួល តាមរយៈការបន្តអានព្រះគម្ពីររៀងរាល់ថ្ងៃ ទោះបីជាគ្មានថ្នាក់សិក្ខាសាលានៅក្នុងវគ្គសិក្សាក៏ដោយ ។

# ឧបសម្ព័ន្ធ

# តារាងអានព្រះគម្ពីរ

យើងជួយបំពេញគោលបំណងនៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា នៅពេលយើងលើកទឹកចិត្តសិស្សឲ្យ (១) អាន និង សិក្សាព្រះគម្ពីររាល់ថ្ងៃ និង (២) អានព្រះគម្ពីរសម្រាប់វគ្គសិក្សា ។ អ្នកអាចឲ្យតារាងដូចខាងក្រោមនេះដល់សិស្ស ដើម្បីជួយពួកគេឲ្យតាមដានការរីកចម្រើនរបស់ខ្លួន ។ ប្រសិនបើអ្នកចង់រាយការណ៍ពីការអានព្រះគម្ពីរប្រចាំថ្ងៃរបស់សិស្ស សូមធ្វើតាមការណែនាំនៅក្នុងសេចក្ដីណែនាំអំពីការរាយការណ៍នៃការអានព្រះគម្ពីរ ។ សូមរកមើលសេចក្ដីណែនាំទាំងនេះនៅក្នុងគេហទំព័រ si.lds.org ដោយប្រើឃ្លា « scripture reading reporting instructions » ។

## តារាងអានគោលលទ្ធិ និងសេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ

| ទីបន្ទាល់របស់សាវកដប់ពីរនាក់អំពីសេចក្ដីពិតនៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា | | | | | | |
|---|---|---|---|---|---|---|
| យ៉ូសែប ស្ម៊ីធ—ប្រវត្តិ | ១ | | | | | |
| គោលលទ្ធិ និង សេចក្ដីសញ្ញា | ១ | ២ | ៣ | ៤ | ៥ | ៦ |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ |
| | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ |
| | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ |
| | ៣១ | ៣២ | ៣៣ | ៣៤ | ៣៥ | ៣៦ |
| | ៣៧ | ៣៨ | ៣៩ | ៤០ | ៤១ | ៤២ |
| | ៤៣ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ |
| | ៤៩ | ៥០ | ៥១ | ៥២ | ៥៣ | ៥៤ |
| | ៥៥ | ៥៦ | ៥៧ | ៥៨ | ៥៩ | ៦០ |
| | ៦១ | ៦២ | ៦៣ | ៦៤ | ៦៥ | ៦៦ |
| | ៦៧ | ៦៨ | ៦៩ | ៧០ | ៧១ | ៧២ |
| | ៧៣ | ៧៤ | ៧៥ | ៧៦ | ៧៧ | ៧៨ |
| | ៧៩ | ៨០ | ៨១ | ៨២ | ៨៣ | ៨៤ |
| | ៨៥ | ៨៦ | ៨៧ | ៨៨ | ៨៩ | ៩០ |
| | ៩១ | ៩២ | ៩៣ | ៩៤ | ៩៥ | ៩៦ |
| | ៩៧ | ៩៨ | ៩៩ | ១០០ | ១០១ | ១០២ |
| | ១០៣ | ១០៤ | ១០៥ | ១០៦ | ១០៧ | ១០៨ |
| | ១០៩ | ១១០ | ១១១ | ១១២ | ១១៣ | ១១៤ |
| | ១១៥ | ១១៦ | ១១៧ | ១១៨ | ១១៩ | ១២០ |
| | ១២១ | ១២២ | ១២៣ | ១២៤ | ១២៥ | ១២៦ |
| | ១២៧ | ១២៨ | ១២៩ | ១៣០ | ១៣១ | ១៣២ |
| | ១៣៣ | ១៣៤ | ១៣៥ | ១៣៦ | ១៣៧ | ១៣៨ |
| | សេចក្ដីប្រកាសជាផ្លូវការទី ១ | | | សេចក្ដីប្រកាសជាផ្លូវការទី ២ | | |
| មាត្រានៃសេចក្ដីជំនឿ | ១ | | | | | |

## តារាងអានព្រះគម្ពីរប្រចាំថ្ងៃ

| មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ |
| ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ |
| ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ |
| ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ |
| ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ |
| ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ |
| ១០ | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| ១២ | ១២ | ១២ | ១២ | ១២ | ១២ | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| ១៣ | ១៣ | ១៣ | ១៣ | ១៣ | ១៣ | ១៣ | ១៣ | ១៣ | ១៣ | ១៣ | ១៣ |
| ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ |
| ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៦ |
| ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ |
| ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ | ១៨ |
| ១៩ | ១៩ | ១៩ | ១៩ | ១៩ | ១៩ | ១៩ | ១៩ | ១៩ | ១៩ | ១៩ | ១៩ |
| ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| ២១ | ២១ | ២១ | ២១ | ២១ | ២១ | ២១ | ២១ | ២១ | ២១ | ២១ | ២១ |
| ២២ | ២២ | ២២ | ២២ | ២២ | ២២ | ២២ | ២២ | ២២ | ២២ | ២២ | ២២ |
| ២៣ | ២៣ | ២៣ | ២៣ | ២៣ | ២៣ | ២៣ | ២៣ | ២៣ | ២៣ | ២៣ | ២៣ |
| ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៤ |
| ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ |
| ២៦ | ២៦ | ២៦ | ២៦ | ២៦ | ២៦ | ២៦ | ២៦ | ២៦ | ២៦ | ២៦ | ២៦ |
| ២៧ | ២៧ | ២៧ | ២៧ | ២៧ | ២៧ | ២៧ | ២៧ | ២៧ | ២៧ | ២៧ | ២៧ |
| ២៨ | ២៨ | ២៨ | ២៨ | ២៨ | ២៨ | ២៨ | ២៨ | ២៨ | ២៨ | ២៨ | ២៨ |
| ២៩ | (២៩) | ២៩ | ២៩ | ២៩ | ២៩ | ២៩ | ២៩ | ២៩ | ២៩ | ២៩ | ២៩ |
| ៣០ | | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |
| ៣១ | | ៣១ | | ៣១ | | ៣១ | ៣១ | | ៣១ | | ៣១ |

# ការណែនាំពីល្បឿនបង្រៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀន

## *កាលវិភាគដែលបានណែនាំសម្រាប់ ៣៦ សប្ដាហ៍នៃឆ្នាំសិក្សា*

| សប្ដាហ៍ | បណ្ដុំបទគម្ពីរដែលត្រូវបង្រៀន | វគ្គត្រូវអាន |
|---|---|---|
| ១ | ថ្ងៃទី ១ ៖ មេរៀនទី ១ ផែនការនៃសេចក្ដីសង្គ្រោះ<br>ថ្ងៃទី ២ ៖ មេរៀនទី ២ បុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា<br>ថ្ងៃទី ៣ ៖ មេរៀនទី ៣ ការក្បត់សាសនាដ៏ធំ<br>ថ្ងៃទី ៤ ៖ មេរៀនទី ៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១<br>ថ្ងៃទី ៥ ៖ មេរៀនទី ៥ ការសិក្សាព្រះគម្ពីរ | បុព្វកថានៃព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា គោលលទ្ធិ និង សេចក្ដីសញ្ញា ១ |
| ២ | ថ្ងៃទី ១ ៖ មេរៀនទី ៦ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២០<br>ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៣ ៖ មេរៀនទី ៧ តួនាទីរបស់សិស្ស<br>ថ្ងៃទី ៤ ៖ មេរៀនទី ៨ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២១–២៦<br>ថ្ងៃទី ៥ ៖ មេរៀនទី ៩ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–៥៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ២ | យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–៥៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ២ |
| ៣ | ថ្ងៃទី ១ ៖ មេរៀនទី ១០ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៦៥<br>ថ្ងៃទី ២ ៖ មេរៀនទី ១១ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣<br>ថ្ងៃទី ៣ ៖ មេរៀនទី ១២ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៣–៥; ១០; យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៦៥ |
| ៤ | ថ្ងៃទី ១ ៖ មេរៀនទី ១៥ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧<br>ថ្ងៃទី ២ ៖ មេរៀនទី ១៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១–១២<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៩ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨–៧៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣ | យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៧៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៩; ១១–១៣ |
| ៥ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ២០ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦<br>ថ្ងៃទី ៣ ៖ មេរៀនទី ២១ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧<br>ថ្ងៃទី ៤ ៖ មេរៀនទី ២២ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១–១៦<br>ថ្ងៃទី ៥ ៖ មេរៀនទី ២៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៧–៤៧ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៨ |

| សប្ដាហ៍ | បណ្ដុំបទគម្ពីរដែលត្រូវបង្រៀន | វគ្គត្រូវអាន |
|---|---|---|
| ៦ | ថ្ងៃទី ១ ៖ មេរៀនទី ២៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២<br>ថ្ងៃទី ២ ៖ មេរៀនទី ២៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៤១<br>ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៤ ៖ មេរៀនទី ២៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦<br>ថ្ងៃទី ៥ ៖ មេរៀនទី ២៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២០:៦៧ |
| ៧ | ថ្ងៃទី ១ ៖ មេរៀនទី ២៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៨៤<br>ថ្ងៃទី ២ ៖ មេរៀនទី ២៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ២១<br>ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៤ ៖ មេរៀនទី ៣០ គោលលទ្ធិ និង សេចក្ដីសញ្ញា ២២–២៣<br>ថ្ងៃទី ៥ ៖ មេរៀនទី ៣១ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤ និង ២៦ | គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៨៤; ២១–២៤; ២៦ |
| ៨ | ថ្ងៃទី ១ ៖ មេរៀនទី ៣២ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥<br>ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៣ ៖ មេរៀនទី ៣៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧<br>ថ្ងៃទី ៤ ៖ មេរៀនទី ៣៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨<br>ថ្ងៃទី ៥ ៖ មេរៀនទី ៣៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–២៩ | គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥; ២៧–២៨; ២៩:១–២៩ |
| ៩ | ថ្ងៃទី ១ ៖ មេរៀនទី ៣៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣០–៥០<br>ថ្ងៃទី ២ ៖ មេរៀនទី ៣៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០<br>ថ្ងៃទី ៣ ៖ មេរៀនទី ៣៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១–៣២<br>ថ្ងៃទី ៤ ៖ មេរៀនទី ៣៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣–៣៤<br>ថ្ងៃទី ៥ ៖ មេរៀនទី ៤០ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ | គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣០–៥០; ៣០–៣៥ |
| ១០ | ថ្ងៃទី ១ ៖ មេរៀនទី ៤១ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៧<br>ថ្ងៃទី ២ ៖ មេរៀនទី ៤២ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១–១៦<br>ថ្ងៃទី ៣ ៖ មេរៀនទី ៤៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៧–៤២<br>ថ្ងៃទី ៤ ៖ មេរៀនទី ៤៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០<br>ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ) | គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៤០ |
| ១១ | ថ្ងៃទី ១ ៖ មេរៀនទី ៤៥ នៅរដ្ឋអូហៃអូ<br>ថ្ងៃទី ២ ៖ មេរៀនទី ៤៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១<br>ថ្ងៃទី ៣ ៖ មេរៀនទី ៤៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–២៩<br>ថ្ងៃទី ៤ ៖ មេរៀនទី ៤៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៤២<br>ថ្ងៃទី ៥ ៖ មេរៀនទី ៤៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៣–៩៣ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១–៤២ |

| សប្ដាហ៍ | បណ្ដុំបទគម្ពីរដែលត្រូវបង្រៀន | វគ្គត្រូវអាន |
|---|---|---|
| ១២ | ថ្ងៃទី ១ ៖ មេរៀនទី ៥០ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៤<br>ថ្ងៃទី ២ ៖ មេរៀនទី ៥១ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៥<br>ថ្ងៃទី ៣ ៖ មេរៀនទី ៥២ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៥៩<br>ថ្ងៃទី ៤ ៖ មេរៀនទី ៥៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦០–៧៥<br>ថ្ងៃទី ៥ ៖ មេរៀនទី ៥៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៦ |
| ១៣ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ៥៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨<br>ថ្ងៃទី ៣ ៖ មេរៀនទី ៥៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩<br>ថ្ងៃទី ៤ ៖ មេរៀនទី ៥៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០<br>ថ្ងៃទី ៥ ៖ មេរៀនទី ៥៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១–៥២ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៥២ |
| ១៤ | ថ្ងៃទី ១ ៖ មេរៀនទី ៥៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៥<br>ថ្ងៃទី ២ ៖ មេរៀនទី ៦០ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦<br>ថ្ងៃទី ៣ ៖ មេរៀនទី ៦១ កន្លែងកណ្ដាលនៃស៊ីយ៉ូន<br>ថ្ងៃទី ៤ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៥ ៖ មេរៀនទី ៦២ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៧ |
| ១៥ | ថ្ងៃទី ១ ៖ មេរៀនទី ៦៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–៣៣<br>ថ្ងៃទី ២ ៖ មេរៀនទី ៦៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៤–៦៥<br>ថ្ងៃទី ៣ ៖ មេរៀនទី ៦៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩<br>ថ្ងៃទី ៤ ៖ មេរៀនទី ៦៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២<br>ថ្ងៃទី ៥ ៖ មេរៀនទី ៦៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១–២១ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–៦៣:២១ |
| ១៦ | ថ្ងៃទី ១ ៖ មេរៀនទី ៦៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២២–៦៦<br>ថ្ងៃទី ២ ៖ មេរៀនទី ៦៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩<br>ថ្ងៃទី ៣ ៖ មេរៀនទី ៧០ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣<br>ថ្ងៃទី ៤ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៥ ៖ មេរៀនទី ៧១ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២២–៦៥:៦ |
| ១៧ | ថ្ងៃទី ១ ៖ មេរៀនទី ៧២ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦<br>ថ្ងៃទី ២ ៖ មេរៀនទី ៧៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧<br>ថ្ងៃទី ៣ ៖ មេរៀនទី ៧៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨<br>ថ្ងៃទី ៤ ៖ មេរៀនទី ៧៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១<br>ថ្ងៃទី ៥ ៖ មេរៀនទី ៧៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៤ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦–៧៤ |
| ១៨ | ថ្ងៃទី ១ ៖ មេរៀនទី ៧៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥<br>ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៣ ៖ មេរៀនទី ៧៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–១៩<br>ថ្ងៃទី ៤ ៖ មេរៀនទី ៧៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–៤៩<br>ថ្ងៃទី ៥ ៖ មេរៀនទី ៨០ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១–៧៦:៨០ |

| សប្ដាហ៍ | បណ្ដុំបទគម្ពីរដែលត្រូវបង្រៀន | វគ្គត្រូវអាន |
|---|---|---|
| ១៩ | ថ្ងៃទី ១ ៖ មេរៀនទី ៨១ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩<br>ថ្ងៃទី ២ ៖ មេរៀនទី ៨២ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧<br>ថ្ងៃទី ៣ ៖ មេរៀនទី ៨៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨–៨០<br>ថ្ងៃទី ៤ ៖ មេរៀនទី ៨៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១<br>ថ្ងៃទី ៥ ៖ មេរៀនទី ៨៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២–៨៣ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–៨៣:៦ |
| ២០ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ៨៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤៤<br>ថ្ងៃទី ៣ ៖ មេរៀនទី ៨៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–៦១<br>ថ្ងៃទី ៤ ៖ មេរៀនទី ៨៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦២–១២០<br>ថ្ងៃទី ៥ ៖ មេរៀនទី ៨៩គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤–៨៦ |
| ២១ | ថ្ងៃទី ១ ៖ មេរៀនទី ៩០ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧<br>ថ្ងៃទី ២ ៖ មេរៀនទី ៩១ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–៤០<br>ថ្ងៃទី ៣ ៖ មេរៀនទី ៩២ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៦៩<br>ថ្ងៃទី ៤ ៖ មេរៀនទី ៩៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១១៧<br>ថ្ងៃទី ៥ ៖ មេរៀនទី ៩៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១៤១ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧–៨៨ |
| ២២ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ៩៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩<br>ថ្ងៃទី ៣ ៖ មេរៀនទី ៩៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២<br>ថ្ងៃទី ៤ ៖ មេរៀនទី ៩៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–២០<br>ថ្ងៃទី ៥ ៖ មេរៀនទី ៩៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–៥៣ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩–៩៣ |
| ២៣ | ថ្ងៃទី ១ ៖ មេរៀនទី ៩៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦<br>ថ្ងៃទី ២ ៖ មេរៀនទី ១០០ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧<br>ថ្ងៃទី ៣ ៖ មេរៀនទី ១០១ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–២២<br>ថ្ងៃទី ៤ ៖ មេរៀនទី ១០២ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៣–៤៨<br>ថ្ងៃទី ៥ ៖ មេរៀនទី ១០៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០ | គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–១០០ |
| ២៤ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ១០៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦<br>ថ្ងៃទី ៣ ៖ មេរៀនទី ១០៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២<br>ថ្ងៃទី ៤ ៖ មេរៀនទី ១០៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១<br>ថ្ងៃទី ៥ ៖ មេរៀនទី ១០៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១–១០២ |

| សប្ដាហ៍ | បណ្ដុំបទគម្ពីរដែលត្រូវបង្រៀន | វគ្គត្រូវអាន |
|---|---|---|
| ២៥ | ថ្ងៃទី ១ ៖ មេរៀនទី ១០៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣<br>ថ្ងៃទី ២ ៖ មេរៀនទី ១០៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤<br>ថ្ងៃទី ៣ ៖ មេរៀនទី ១១០ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥<br>ថ្ងៃទី ៤ ៖ មេរៀនទី ១១១ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:១–១០៧:២០<br>ថ្ងៃទី ៥ ៖ មេរៀនទី ១១២ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:១–១០៧:៣៨ |
| ២៦ | ថ្ងៃទី ១ ៖ មេរៀនទី ១១៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០<br>ថ្ងៃទី ២ ៖ មេរៀនទី ១១៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨<br>ថ្ងៃទី ៣ ៖ មេរៀនទី ១១៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧<br>ថ្ងៃទី ៤ ៖ មេរៀនទី ១១៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១–៤៦<br>ថ្ងៃទី ៥ ៖ មេរៀនទី ១១៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៨០ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០៩:៨០; ១៣៧ |
| ២៧ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ១១៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០<br>ថ្ងៃទី ៣ ៖ មេរៀនទី ១១៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១<br>ថ្ងៃទី ៤ ៖ មេរៀនទី ១២០ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២<br>ថ្ងៃទី ៥ ៖ មេរៀនទី ១២១ សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង | គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០–១១២ |
| ២៨ | ថ្ងៃទី ១ ៖ មេរៀនទី ១២២ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១១៤<br>ថ្ងៃទី ២ ៖ មេរៀនទី ១២៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥–១១៦<br>ថ្ងៃទី ៣ ៖ មេរៀនទី ១២៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–១១៨<br>ថ្ងៃទី ៤ ៖ មេរៀនទី ១២៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩–១២០<br>ថ្ងៃទី ៥ ៖ មេរៀនទី ១២៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:១–១២១:១០; ១២២ |
| ២៩ | ថ្ងៃទី ១ ៖ មេរៀនទី ១២៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣<br>ថ្ងៃទី ២ ៖ មេរៀនទី ១២៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦<br>ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៤ ៖ មេរៀនទី ១២៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៣០ ការស្ថាបនាទីក្រុងណៅវូ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៤៦; ១២៣ |
| ៣០ | ថ្ងៃទី ១ ៖ មេរៀនទី ១៣១ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–២១<br>ថ្ងៃទី ២ ៖ មេរៀនទី ១៣២ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២២–៨៣<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៣៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–១២៦<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៣៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៣៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤–១២៨ |

| សប្ដាហ៍ | បណ្ដុំបទគម្ពីរដែលត្រូវបង្រៀន | វគ្គត្រូវអាន |
|---|---|---|
| ៣១ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ១៣៦ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៣៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៣៨ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៣៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣–៣៣ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩–១៣១; ១៣២:៣–៣៣ |
| ៣២ | ថ្ងៃទី ១ ៖ មេរៀនទី ១៤០ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–២, ៣៤–៦៦<br>ថ្ងៃទី ២ ៖ មេរៀនទី ១៤១ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៤២ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៧៤<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៤៣ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤<br>ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ) | គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–២, ៣៤–៦៦; ១៣៣–១៣៤ |
| ៣៣ | ថ្ងៃទី ១ ៖ មេរៀនទី ១៤៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥, ផ្នែកទី ១<br>ថ្ងៃទី ២ ៖ មេរៀនទី ១៤៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥, ផ្នែកទី ២<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៤៦ ការស្នងតំណែងនៅក្នុងគណៈប្រធាន<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៤៧ ការចាកចេញពីទីក្រុងណៅវូ<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៤៨ ការធ្វើដំណើរឆ្លងកាត់រដ្ឋអៃអូវ៉ា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:១–១៣៦:១៨ |
| ៣៤ | ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ២ ៖ មេរៀនទី ១៤៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៥០ ក្រុមអ្នកត្រួសត្រាយរទេះអូស ឆ្នាំ ១៨៥៦–១៨៦០<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៥១ សង្គ្រាមនៅរដ្ឋយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំមេដូ<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៥២ ការលេចចេញមកនៃព្រះគម្ពីរមុក្ដាដ៏មានតម្លៃមហិមា | គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២; បុព្វកថានៃព្រះគម្ពីរមុក្ដាដ៏មានតម្លៃមហិមា មាត្រានៃសេចក្ដីជំនឿ |
| ៣៥ | ថ្ងៃទី ១ ៖ មេរៀនទី ១៥៣ សេចក្ដីប្រកាសជាផ្លូវការទី ១ និង ការអភិវឌ្ឍកិច្ចការព្រះវិហារបរិសុទ្ធជាបន្តបន្ទាប់<br>ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន )<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៥៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–២៤, ៣៨–៥០<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៥៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៧–៦០<br>ថ្ងៃទី ៥ ៖ មេរៀនទី ១៥៦ កម្មវិធី និង អង្គការសាសនាចក្រ | សេចក្ដីប្រកាសជាផ្លូវការទី ១; គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ |

| សប្ដាហ៍ | បណ្ដុំបទគម្ពីរដែលត្រូវបង្រៀន | វគ្គត្រូវអាន |
|---|---|---|
| ៣៦ | ថ្ងៃទី ១ ៖ មេរៀនទី ១៥៧ សេចក្ដីប្រកាសជាផ្លូវការទី ២<br>ថ្ងៃទី ២ ៖ មេរៀនទី ១៥៨ ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ<br>ថ្ងៃទី ៣ ៖ មេរៀនទី ១៥៩ ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក<br>ថ្ងៃទី ៤ ៖ មេរៀនទី ១៦០ ព្យាការីនៅរស់<br>ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ( សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្ដូរបាន ) | សេចក្ដីប្រកាសជាផ្លូវការទី ២ ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក |

# យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន

ការណែនាំពីល្បឿនបង្រៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀន គឺផ្អែកទៅលើកាលវិភាគ ៣៦សប្តាហ៍ ឬ ១៨០ ថ្ងៃនៃឆ្នាំសិក្សា ។ សៀវភៅសិក្សានេះមាន ១៦០ មេរៀនដែលជាមេរៀនប្រចាំថ្ងៃ ដោយទុក ២០ ថ្ងៃទៀតគ្មានសម្ភារមេរៀនឡើយ ។ « ថ្ងៃដែលអាចផ្លាស់ប្តូរបាន » ទាំង ២០ ថ្ងៃនោះ គួរតែប្រើដោយឆ្លាតវៃសម្រាប់គោលដៅ និង សកម្មភាពនានាដែលមានតម្លៃមមានដូចខាងក្រោមនេះ ៖

១. **ការវាយតម្លៃ ។** គោលបំណងនៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា គឺដើម្បី « ជួយដល់យុវវ័យ និងមជ្ឈឹមវ័យវ័យក្មេងឲ្យយល់ និងពឹងផ្អែកទៅលើការបង្រៀន និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មានលក្ខណៈសម្បត្តិនឹងទទួលពរជ័យនៃព្រះវិហារបរិសុទ្ធ ហើយរៀបចំខ្លួនពួកគេផ្ទាល់ ក្រុមគ្រួសាររបស់ពួកគេ និងអ្នកដទៃទៀត សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ជាមួយនឹងព្រះវរបិតាសួគ៌របស់ពួកគេ » ។ ដោយគិតពីគោលបំណងនេះ ស. & វ. បានរៀបចំការវាយតម្លៃការរៀនសូត្រ ។ ការវាយតម្លៃទាំងនេះមានបំណងដើម្បីជួយសិស្សឲ្យយល់ ពន្យល់ ជឿ ហើយរស់នៅតាមអ្វីដែលពួកគេកំពុងតែរៀននៅក្នុងថ្នាក់ ។

   ក្នុងឆ្នាំ ២០១៤ តម្រូវការសម្រាប់ការបញ្ចប់ថ្នាក់សិក្ខាសាលាបានកែតម្រូវ ដោយសិស្សត្រូវតែប្រឡងឲ្យជាប់សម្រាប់ការវាយតម្លៃការរៀនសូត្រសម្រាប់វគ្គសិក្សានីមួយៗ ដើម្បីអាចទទួលបានសញ្ញាបត្រ ។ អ្នកគួរធ្វើការវាយតម្លៃការរៀនសូត្រម្តង រៀងរាល់ពាក់កណ្តាលនៃឆ្នាំសិក្សា ។ ការវាយតម្លៃនីមួយៗមានពីរផ្នែក (១) ការមានការវាយតម្លៃដែលនឹងចំណាយពេលប្រមាណជា ៤០ នាទី ឬ ពេលសម្រាប់ថ្នាក់មួយថ្ងៃ និង (២) ការកែតម្រូវ និងការពិភាក្សាពីការវាយតម្លៃជាមួយនឹងសិស្សនៅម៉ោងសិក្សាលើកក្រោយ ។ ការពិនិត្យមើលនេះគឺជាផ្នែកមួយដ៏ចាំបាច់ ដើម្បីជួយសិស្សឲ្យរៀនពីបទពិសោធន៍នោះ ។ ប្រសិនបើថ្នាក់របស់អ្នកមានរយៈច្រើនជាង ៦០ នាទី អ្នកគួរតែចំណាយពេលតែម្តងគត់ក្នុងថ្នាក់ ដើម្បីចាត់ចែង និងពិនិត្យការវាយតម្លៃនេះ ។

   ការវាយតម្លៃត្រូវតែយកមកប្រើដើម្បីជួយសិស្ស ។ កាលប្រកាសពីការបន្ថែមនៃការវាយតម្លៃការរៀនសូត្រសម្រាប់តម្រូវការនៃការបញ្ចប់ថ្នាក់សិក្ខាសាលា អែលឌើរ ប៉ុល វី.ចនសុន នៃពួកចិតសិបនាក់បានថ្លែងថា « ឥរិយាបថរបស់គ្រូបង្រៀនម្នាក់នឹងធ្វើឲ្យមានការខុសប្លែកយ៉ាងខ្លាំង ។ ប្រសិនបើគ្រូបង្រៀនអាចមើលឃើញពីរបៀប ដែលការណ៍នេះផ្តល់ពរជ័យដល់ជីវិតរបស់សិស្ស នោះពួកគេនឹងមើលឃើញការវាយតម្លៃនេះថាជាវិធីមួយដើម្បីជួយដល់សិស្សរបស់ពួកគេ ។. . . ខ្ញុំគិតថា ប្រសិនបើមានការដាស់តឿនមួយ នោះវាអាចជាអ្វីដែលយើងពុំចង់ឲ្យគ្រូបង្រៀនចាត់ទុកច្បាប់នេះជាឧបករណ៍ ឬ ព្រនង់ដែលបានរៀបចំឡើងឡើយ—ប្រហែលជាព្រនង់ដែលមានន័យពីរយ៉ាងគឺ—ជាឧបករណ៍ទាលសម្រាប់វាយសំពងនរណាម្នាក់ ឬ ជាព្រនង់ដែលសំរិតសំរាំងគ្រាន់តែសម្រាប់សិស្សជាក់លាក់មួយចំនួននោះ ។ យើងចង់ឲ្យពួកគេមើលឃើញការវាយតម្លៃនេះជាអ្វីមួយ ដែលនឹងផ្តល់ពរជ័យដល់ជីវិតរបស់ពួកគេយ៉ាងប្រាកដ » ( Elevate Learning Announcement »Seminaries and Institutes of Religion global faculty meeting ខែ មិថុនា ឆ្នាំ២០១៤ | si.lds.org

២. **កែសម្រួលមេរៀនប្រចាំថ្ងៃ ។** អ្នកអាចចំណាយពេលបន្ថែមទៀតលើមេរៀនមួយ ដែលអាចប្រើពេលច្រើន ដើម្បីបង្រៀនឲ្យមានប្រសិទ្ធភាព ។ អ្នកក៏អាចប្រើគំនិតសម្រាប់ការបង្រៀនបន្ថែម ដែលមាននៅចុងបញ្ចប់នៃមេរៀនមួយចំនួន ឬ ចំណាយពេលឆ្លើយសំណួរសិស្សអំពីវគ្គបទគម្ពីរពិសេស ឬ ប្រធានបទនៃដំណឹងល្អ ។ បណ្តាថ្ងៃដែលអាចផ្លាស់ប្តូរបានធ្វើឲ្យអ្នកទទួលប្រយោជន៍នៃឱកាសទាំងនេះ ដោយការរក្សាល្បឿននៃកាលវិភាគរបស់អ្នក ហើយបំពេញការចាត់តាំងរបស់អ្នក ដើម្បីបង្រៀនខគម្ពីរជាបន្តបន្ទាប់ ។

៣. **ចេះស្ទាត់នូវវគ្គបទគម្ពីរសំខាន់ៗ និង គោលលទ្ធិគ្រឹះទាំងឡាយ ។** អ្នកអាចប្រើសកម្មភាពរំឭកសម្រាប់វគ្គចំណេះចំណានខគម្ពីរ ដែលមាននៅក្នុងសៀវភៅសិក្សា និង ក្នុងឧបសម្ព័ន្ធ ។ អ្នកអាចបង្កើតសកម្មភាពរំឭកចំណេះចំណានខគម្ពីរបន្ថែម ដែលបំពេញតាមសេចក្តីត្រូវការ និង ចំណាប់អារម្មណ៍ជាក់លាក់របស់សិស្សនៅក្នុងថ្នាក់របស់អ្នក ។ អ្នកក៏អាចប្រើម៉ោងនៃថ្ងៃដែលអាចផ្លាស់ប្តូរបានសម្រាប់សកម្មភាពនានា ដែលជួយសិស្សឲ្យរំឭក និង យល់កាន់តែជ្រៅជ្រះអំពីគោលលទ្ធិគ្រឹះនានា ។

៤. **រំឭកមេរៀនមុនៗ ។** វាមានប្រយោជន៍សម្រាប់សិស្សឲ្យរំឭកម្តងម្កាលអំពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនមុនៗ ឬ មកពីគម្ពីរជាក់លាក់មួយ ។ អ្នកអាចផ្តល់ឱកាសមួយដល់សិស្ស ឲ្យពន្យល់សេចក្តីពិតមួយពីមេរៀនមុនៗ ហើយចែកចាយពីរបៀបដែលសេចក្តីពិតនោះបានមានឥទ្ធិពលលើជីវិតរបស់ពួកគេ ។ អ្នកអាចបង្កើត ហើយធ្វើសំណួរ ឬ បង្កើតសកម្មភាពការរៀនសូត្រនានា ដែលរំឭកមេរៀនមុនៗ ។

៥. **អនុញ្ញាតឲ្យមានការរំខាននានាចំពោះកាលវិភាគ ។** សកម្មភាព ឬ ការប្រជុំនៅសាលារៀន ព្រឹត្តិការណ៍ក្នុងសហគមន៍ អាកាសធាតុ និង ការរំខានផ្សេងទៀត ដែលអាចតម្រូវឲ្យអ្នកលុបចោលការបង្រៀន ឬ បន្ថយម៉ោងបង្រៀនម្តងម្កាល ។ ថ្ងៃដែលអាចផ្លាស់ប្តូរបាន អាចត្រូវបានប្រើសម្រាប់ការរំខានបែបនោះ ។

# ការណែនាំពីល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនមេរៀននៅផ្ទះ

សៀវភៅសិក្សានេះមាន ៣២មេរៀនសម្រាប់ថ្នាក់សិក្សានៅផ្ទះ ដែលត្រូវគ្នានឹង ៣២មេរៀននៅក្នុង *សៀវភៅមគ្គុទេសន៍សិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រសម្រាប់សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ* ។ អ្នកអាចសម្របមេរៀននេះ និង ល្បឿននៃការបង្រៀនទៅតាមតម្រូវការនៃចំនួនសប្ដាហ៍ដែលអ្នកមានដើម្បីបង្រៀនសិស្សរបស់អ្នក ។

| មេរៀន | មេរៀនសិក្សានៅផ្ទះ |
|---|---|
| មេរៀនទី ១ | ថ្ងៃទី ១ ៖ ផែនការនៃសេចក្ដីសង្គ្រោះ<br>មេរៀនទី ២ ៖ ការក្បត់សាសនាដ៏ធំ<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១<br>ថ្ងៃទី ៤ ៖ ការសិក្សាព្រះគម្ពីរ<br>*មេរៀនរបស់គ្រូ ៖ ផែនការនៃសេចក្ដីសង្គ្រោះ–ការសិក្សាព្រះគម្ពីរ* |
| មេរៀនទី ២ | ថ្ងៃទី ១ ៖ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:១–២០<br>ថ្ងៃទី ២ ៖ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២១–២៦<br>ថ្ងៃទី ៣ ៖ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២៧–៥៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ២<br>ថ្ងៃទី ៤ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៥៥–៦៥<br>*មេរៀនរបស់គ្រូ ៖ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:១–៦៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ២* |
| មេរៀនទី ៣ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣; ១០<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥<br>ថ្ងៃទី ៤ ៖ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣–៧; ១០; យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៦–៦៧* |
| មេរៀនទី ៤ | ថ្ងៃទី ១ ៖គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩<br>ថ្ងៃទី ២ ៖គោលលទ្ធិ និង សេចក្ដីសញ្ញា ១១–១២<br>ថ្ងៃទី ៣ ៖យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៨–៧៥; គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣<br>ថ្ងៃទី ៤ ៖គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩; ១១–១៦; យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៨–៧៥* |
| មេរៀនទី ៥ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៤១<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧–១៩* |
| មេរៀនទី ៦ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៨៤<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២១–២៣<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០–២៣* |

| មេរៀន | មេរៀនសិក្សានៅផ្ទះ |
|---|---|
| មេរៀនទី ៧ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៦<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៣០<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៩: ៣០* |
| មេរៀនទី ៨ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០–៣២<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣–៣៤<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០; ៣០–៣៥* |
| មេរៀនទី ៩ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៧<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០<br>មេរៀនទី៤ ៖ នៅរដ្ឋអូហៃអូ<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៤០; នៅរដ្ឋអូហៃអូ* |
| មេរៀនទី ១០ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–២៩<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៩៣<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៤<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១–៤៤* |
| មេរៀនទី ១១ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៥<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៧៥<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥–៤៨* |
| មេរៀនទី ១២ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១–៥២<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៦<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩–៥៦* |
| មេរៀនទី ១៣ | ថ្ងៃទី ២ ៖ កន្លែងកណ្ដាលនៃស៊ីយ៉ូន<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩<br>*មេរៀនរបស់គ្រូ ៖ កន្លែងកណ្ដាលនៃស៊ីយ៉ូន; គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧–៥៩* |
| មេរៀនទី ១៤ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦៤* |

| មេរៀន | មេរៀនសិក្សានៅផ្ទះ |
| --- | --- |
| មេរៀនទី ១៥ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៦៦<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៧១* |
| មេរៀនទី ១៦ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៤<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–៤៩<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៦:៨០* |
| មេរៀនទី ១៧ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨–៨០<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២–៨៣<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧–៨៣* |
| មេរៀនទី ១៨ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤២<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–១២០<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤–៨៧* |
| មេរៀនទី ១៩ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–៤០<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៦៩<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១៤១<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨–៨៩* |
| មេរៀនទី ២០ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩៧* |
| មេរៀនទី ២១ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨–១០១:៤២* |
| មេរៀនទី ២២ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២–១០៥* |

| មេរៀន | មេរៀនសិក្សានៅផ្ទះ |
|---|---|
| មេរៀនទី ២៣ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦; ១០៧:១–២០<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០; ១០៨<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦–១០៨;១៣៧* |
| មេរៀនទី ២៤ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩–១១២* |
| មេរៀនទី ២៥ | ថ្ងៃទី ១ ៖ សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១១៤<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥–១១៦<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–១២០<br>*មេរៀនរបស់គ្រូ ៖* សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង; *គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១២០* |
| មេរៀនទី ២៦ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣; ការស្ថាបនាទីក្រុងណៅវូ<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣; ការស្ថាបនាទីក្រុងណៅវូ* |
| មេរៀនទី ២៧ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–៨៣<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–១២៦<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤–១២៨* |
| មេរៀនទី ២៨ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–៣៣<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩–១៣២* |
| មេរៀនទី ២៩ | ថ្ងៃទី ១ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥<br>ថ្ងៃទី ២ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៧៤<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥<br>*មេរៀនរបស់គ្រូ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣–១៣៥* |
| មេរៀនទី ៣០ | ថ្ងៃទី ១ ៖ ការស្នងតំណែងនៅក្នុងគណៈប្រធាន<br>ថ្ងៃទី ២ ៖ ការចាកចេញពីទីក្រុងណៅវូ ការធ្វើដំណើរឆ្លងកាត់រដ្ឋអៃអូវ៉ា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨<br>ថ្ងៃទី ៣ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២<br>ថ្ងៃទី ៤ ៖ ក្រុមអ្នកត្រួសត្រាយរទេះអូស ឆ្នាំ ១៨៥៦–៦០<br>*មេរៀនរបស់គ្រូ ៖ ការស្នងតំណែងនៅក្នុងគណៈប្រធាន ការចាកចេញពីទីក្រុងណៅវូ និង ការធ្វើដំណើរទៅទិសខាងលិច* |

| មេរៀន | មេរៀនសិក្សានៅផ្ទះ |
| --- | --- |
| មេរៀនទី ៣១ | ថ្ងៃទី ១ ៖ សង្គ្រាមនៅរដ្ឋយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ<br>ថ្ងៃទី ២ ៖ ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា<br>ថ្ងៃទី ៣ ៖ សេចក្តីប្រកាសជាផ្លូវការទី ១ និង ការអភិវឌ្ឍកិច្ចការព្រះវិហារបរិសុទ្ធជាបន្តបន្ទាប់<br>ថ្ងៃទី ៤ ៖ គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨<br>*មេរៀនរបស់គ្រូ ៖ សង្គ្រាមនៅរដ្ឋយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា សេចក្តីប្រកាសជាផ្លូវការទី ១ និង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨* |
| មេរៀនទី ៣២ | ថ្ងៃទី ១ ៖ កម្មវិធី និង អង្គការសាសនាចក្រ<br>ថ្ងៃទី ២ ៖ សេចក្តីប្រកាសជាផ្លូវការទី ២<br>ថ្ងៃទី ៣ ៖ ការពន្លឿនកិច្ចការនៃសេចក្តីសង្គ្រោះ<br>ថ្ងៃទី ៤ ៖ ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក<br>*មេរៀនរបស់គ្រូ ៖ កម្មវិធី និង អង្គការសាសនាចក្រ សេចក្តីប្រកាសជាផ្លូវការទី ២ ការពន្លឿនកិច្ចការនៃសេចក្តីសង្គ្រោះ, ការប្រកាសអំពីក្រុមគ្រួសារ និង ព្យាការីនៅរស់* |

# ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក

## ក្រុមគ្រួសារ

## ការប្រកាស ដល់ពិភពលោក

គណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ នៃសាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

យើងជាគណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ សូមប្រកាសជាឧឡារិកថា អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយថាគ្រួសារជាផ្នែកដ៏សំខាន់មួយ នៅក្នុងផែនការរបស់ព្រះដ៏បង្កបង្កើត សំរាប់គោលដៅដ៏នៅអស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់។

មនុស្សទាំងអស់—ទាំងប្រុសទាំងស្រី—ត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះ។ មនុស្សម្នាក់ៗសុទ្ធតែជាបុត្រា និងបុត្រីខាងវិញ្ញាណរបស់ព្រះមាតាបិតាសួគ៌ ដូច្នេះហើយមនុស្សម្នាក់ៗមានចរិត និងគោលដៅនៃព្រះ។ ភេទប្រុសស្រី គឺជាលក្ខណៈពិសេសនៃអត្តសញ្ញាណ និងគោលបំណងរបស់បុគ្គលម្នាក់ៗ នៅជីវិតមុនផែនដី ជីវិតរមែងស្លាប់ និងនៅអស់កល្បជានិច្ច។

នៅជីវិតមុនផែនដី បុត្រា និងបុត្រីខាងវិញ្ញាណទាំងឡាយបានស្គាល់ ហើយបានថ្វាយបង្គំព្រះជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ ហើយបានទទួលផែនការរបស់ទ្រង់ ដែលនាំឱ្យកូនចៅទាំងឡាយ អាចទទួលរូបកាយ ហើយនឹងទទួលបទពិសោធន៍នៅលើផែនដី ដើម្បីរីកចំរើនទៅរកភាពល្អឥតខ្ចោះ ហើយនៅទីបញ្ចប់ នឹងដឹងពីគោលបំណងដ៏ទេវភាពរបស់ពួកគេ ដោយទទួលជីវិតដ៏នៅអស់កល្បទុកជាមរតក។ ផែនការនៃសុភមង្គលដ៏ទេវភាពនេះ ផ្តល់លទ្ធភាពដល់ទំនាក់ទំនងក្រុមគ្រួសារចេះតែបន្តមានរហូតហួសពីសេចក្តីស្លាប់។ ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាពិសិដ្ឋនានា ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ អាចធ្វើឱ្យបុគ្គលម្នាក់ៗត្រឡប់ទៅកាន់វត្តមាននៃព្រះវិញ ហើយដើម្បីឱ្យក្រុមគ្រួសារអាចត្រូវបានរួបរួមគ្នាដ៏អស់កល្បជានិច្ច។

ព្រះបញ្ញត្តិ ទីមួយ ដែលព្រះបានប្រទានដល់លោកអ័ដាម និងនាងអេវ៉ា ទាក់ទងទៅនឹងសមត្ថភាពរបស់ពួកគេ សំរាប់ភាពជាឪពុកម្តាយ ក្នុងនាមជាស្វាមី និងភរិយា។ យើងសូមប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសំរាប់កូនចៅរបស់ទ្រង់ ដើម្បីបង្កើតកូនចៅឱ្យចំរើនជាច្រើនឡើងឱ្យមានពាសពេញលើផែនដី នោះនៅតែឱ្យប្រតិបត្តិនៅឡើយ។ យើងសូមប្រកាសថែមទៀតថា ព្រះបានបញ្ជាថា អំណាចពិសិដ្ឋនៃការបង្កើតកូន គឺត្រូវបានប្រើរវាងតែបុរស និងស្ត្រី ដែលបានរៀបអាពិហ៍ពិពាហ៍យ៉ាងស្របច្បាប់ជាប្តី និងប្រពន្ធប៉ុណ្ណោះ។

យើងសូមប្រកាសថា មធ្យោបាយដើម្បីបង្កើតជីវិតរមែងស្លាប់នេះ គឺត្រូវបានតែងតាំងឡើងដោយព្រះ។ យើងសូមបញ្ជាក់នូវការញែកចេញជាបរិសុទ្ធនៃជីវិត និងសារៈសំខាន់នៃជីវិតនៅក្នុងផែនការដ៏អស់កល្បជានិច្ចរបស់ព្រះ។

ស្វាមី និងភរិយា មានការទទួលខុសត្រូវដ៏ឧឡារិកដើម្បីស្រឡាញ់ និងថែរក្សាគ្នាទៅវិញទៅមកព្រមទាំងកូនចៅរបស់ខ្លួនផងដែរ។ “កូនចៅជាមរតកពីព្រះយេហូវ៉ា” (ទំនុកដំកើង 127:3)។ ឪពុកម្តាយមានកាតព្វកិច្ចដ៏ពិសិដ្ឋ ដើម្បីចិញ្ចឹមបីបាច់កូនចៅរបស់ខ្លួនដោយក្តីស្រឡាញ់ និងសេចក្តីសុចរិត ផ្គត់ផ្គង់សេចក្តីត្រូវការ ទាំងខាងរូបកាយនិងខាងវិញ្ញាណរបស់ពួកគេ និងបង្រៀនពួកគេឱ្យចេះស្រឡាញ់ និងបំរើគ្នាទៅវិញទៅមក ចេះគោរពព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយធ្វើជាពលរដ្ឋល្អ ចេះគោរពច្បាប់គ្រប់ទីកន្លែង ដែលពួកគេរស់នៅ។ ស្វាមី និងភរិយា—ម្តាយ និងឪពុក—នឹងទទួលខុសត្រូវនៅចំពោះព្រះភ័ក្ត្រព្រះ តាមការប្រតិបត្តិនៃភារកិច្ចទាំងឡាយនេះ។

ក្រុមគ្រួសារ ត្រូវបានតែងតាំងឡើងដោយព្រះ។ អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺជាផ្នែកមួយដ៏សំខាន់ក្នុងផែនការដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់។ កូនចៅមានសិទ្ធនឹងទទួលកំណើតមកក្នុងចំណងនៃអាពាហ៍ពិពាហ៍ ហើយនឹងត្រូវបានចិញ្ចឹមបីបាច់ដោយឪពុកម្តាយ ដែលគោរពប្រតិបត្តិតាមសច្ចានៃអាពាហ៍ពិពាហ៍ដោយស្មោះត្រង់ទាំងស្រុង។ សុភមង្គលនៅក្នុងជីវិតគ្រួសារអាចកើតមានឡើងបាន នៅពេលធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។ អាពាហ៍ពិពាហ៍ និងគ្រួសារដែលមានជោគជ័យ នោះគឺត្រូវស្ថាបនា និងថែរក្សានៅលើគោលការណ៍នៃសេចក្តីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស ការគោរពគ្នា សេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា ការងារ និងកម្មវិធីកំសាន្តល្អៗនានា។ តាមការរៀបចំដ៏ទេវភាពនេះ ឪពុកត្រូវបានចាត់ឱ្យធ្វើជាអ្នកដឹកនាំនៅក្នុងគ្រួសាររបស់ខ្លួន ដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត ហើយមានភារកិច្ចក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងជីវិត ព្រមទាំងការពារក្រុមគ្រួសារខ្លួនផង។ ម្តាយមានភារកិច្ចសំខាន់ដើម្បីថែរក្សាបីបាច់កូនចៅរបស់ខ្លួន។ នៅក្នុងការទទួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះ ឪពុក និងម្តាយ មានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូស្មើគ្នា។ ពិការភាព មរណភាព ឬកាលៈទេសៈផ្សេងៗទៀត អាចនឹងត្រូវសម្របទៅតាមស្ថានភាពចាំបាច់របស់បុគ្គលម្នាក់ៗ។ ញាតិសន្តានក្រុមគ្រួសារ គួរតែជួយគាំទ្រ នៅពេលមានសេចក្តីត្រូវការ។

យើងសូមព្រមានថា បុគ្គលណាដែលបំពានលើសេចក្តីសញ្ញានៃព្រហ្មចារីភាព ដោយបានធ្វើបាបភរិយា ឬកូនចៅ ឬមិនបានបំពេញការទទួលខុសត្រូវក្នុងគ្រួសារ គង់តែថ្ងៃណាមួយនឹងទទួលខុសត្រូវនៅចំពោះព្រះ។ លើសពីនេះទៅទៀត យើងសូមព្រមានថា ការបែកបាក់នៅក្នុងគ្រួសារនឹងនាំមកនូវមហន្តរាយដល់បុគ្គលនោះ សហគមន៍ និងជាតិសាសន៍ ដូចដែលបានទាយទុកជាមុនដោយពួកព្យាការីសម័យបុរាណ និងពួកព្យាការីសម័យទំនើប។

យើងសូមអំពាវនាវដល់ ប្រជាពលរដ្ឋ និងមន្ត្រីរាជការទាំងឡាយនៅក្នុងរដ្ឋាភិបាល ដែលទទួលខុសត្រូវនៅគ្រប់ទីកន្លែងទាំងអស់ សូមឱ្យគាំទ្រនូវអ្វីៗទាំងនេះ ដែលបានរៀបរាប់ឡើង ដើម្បីទ្រទ្រង់ និងធ្វើឱ្យក្រុមគ្រួសារមាំមួន ដូចជាអង្គភាពមួយដ៏សំខាន់នៃសង្គម។

*ការប្រកាសនេះត្រូវបានអាន ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ជាផ្នែកនៃសារលិខិតរបស់លោក នៅក្នុងការប្រជុំសមាគមសង្គ្រោះទូទៅ ដែលបានធ្វើឡើងនៅថ្ងៃទី 23 ខែ កញ្ញា ឆ្នាំ 1995 នៅក្នុងទីក្រុងសលត៍ លេក រដ្ឋយូថាហ៍។*

ថ្នាក់សិក្ខាសាលា និង
ថ្នាក់វិទ្យាស្ថានសាសនា

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02105 90258 4
10590 258